# លទ្ធិនៃគ្រីស្តសាសនា
# តាម
# ព្រះសហគមន៍កាតូលិក

# បញ្ជីអក្សរកាត់

| | |
|---|---|
| AA | Apostolicam actuositatem |
| AG | Ad gentes |
| Ben | De Benedictionibus |
| CA | Centesimus annus |
| CR | Catechismus Romanus |
| CCEO | Corpus Canonum Ecclesiarum Orientalium |
| CD | Christus Dominus |
| CDF | Congrégation pour la doctrine de la foi |
| CIC | Codex Iuris Canonici |
| CL | Christifideles laici |
| COD | Conciliorum oecumenicorum decreta |
| CT | Catechesi tradentae |
| DCG | Directorium Catecheticum Generale |
| DeV | Dominum et Vivificantem |
| DH | Dignitatis Humanae |
| DM | Dives in misericordia |
| DS | Denzinger |
| DV | Dei Verbum |
| EN | Evangelii Nuntiandi |
| FC | Familiaris consortio |
| GE | Gravissimum educationis |
| GS | Gaudium et spes |
| HV | Humanae vitae |
| IGLH | Introductio generalis LH |
| IGMR | Intitutio generalis MR |
| IM | Inter mirifica |
| LE | Laborem exercens |
| LG | Lumen gentium |
| LH | Liturgie des heures |
| MC | Marialis cultus |
| MD | Mulieris dignitatem |
| MF | Mysterium fidei |
| MM | Mater et magista |
| MR | Missel romain |
| NA | Nostra aetate |
| OBA | Ordo baptismi adultorum |
| OBP | Ordo baptismi parvulorum |
| OCf | Ordo confirmationis |
| OcM | Ordo celebrandi matrimonium |
| OCV | Ordo consecrationis virginum |
| OE | Orientalium ecclesiarum |
| OEx | Ordo exsequiarum |
| | off. lect. office des lectures |
| OICA | Ordo initiationis christinae adul torum |
| OP | Ordo poenitentiae |
| OT | Optatam totius |
| PC | Perfectae caritatis |
| PO | Presbyterorum ordinis |
| PP | Populorum progressio |
| PT | Pacem in terris |
| RH | Redemptor hominis |
| RM | Redemptoris mater |
| RP | Reconciliatio et poenitentia |
| SC | Sacrosanctum concilium |
| SPF | Credo du Peuple de Dieu: profession de foi solennelle |
| SRS | Sollicitudo rei socialis |
| UR | Unitatis redintegratio |

# មាតិកា


**បុព្វកថា** ... 17

១-ជីវិតរបស់មនុស្សគឺ ស្គាល់ និងស្រឡាញ់ព្រះជាម្ចាស់ ... 17

២-ការបញ្ជូនជំនឿ ៖ ការអប់រំជំនឿ ... 17

៣-គោលដៅរបស់សៀវភៅនេះ និងអ្នកទទួលសៀវភៅនេះ ... 19

៤-រចនាសម្ព័ន្ធនៃសៀវភៅនេះ ... 19

៥-ពាក្យណែនាំដើម្បីប្រើប្រាស់សៀវភៅនេះ ... 20

៦-ការកែសម្រួលជាចាំបាច់ ... 20

**វគ្គទីមួយ៖ ធម៌ប្រកាសជំនឿ** ... 22

**ភាគទីមួយ៖ "ខ្ញុំជឿ" "យើងជឿ"** ... 23

**ជំពូកទីមួយ៖ មនុស្សអាចស្គាល់ព្រះជាម្ចាស់បាន** ... 23

១-មនុស្សមានបំណងប្រាថ្នាចង់ស្គាល់ព្រះជាម្ចាស់ ... 23

២-ផ្លូវផ្សេង ៗដើម្បីស្គាល់ព្រះជាម្ចាស់ ... 24

៣-តាមព្រះសហគមន៍ មនុស្សអាចស្គាល់ព្រះជាម្ចាស់បាន ... 25

៤-តើត្រូវនិយាយយ៉ាងដូចម្ដេចអំពីព្រះជាម្ចាស់ ? ... 26

**ជំពូកទីពីរ៖ ព្រះជាម្ចាស់យាងមករកមនុស្ស** ... 27

**ប្រការទី១៖ ព្រះជាម្ចាស់សម្ដែងព្រះអង្គឲ្យមនុស្សលោកស្គាល់** ... 27

១-ព្រះជាម្ចាស់សម្ដែង "គម្រោងការដ៏សប្បុរស" របស់ព្រះអង្គ ... 27

២-ព្រះជាម្ចាស់សម្ដែងព្រះអង្គជាលំដាប់លំដោយ ... 28

៣-ព្រះគ្រីស្តយេស៊ូ "ជាស្ពានមេត្រី និងបំពេញសេចក្ដីទាំងអស់ដែលព្រះជាម្ចាស់សម្ដែងឲ្យពេញលក្ខណៈ" .30

**ប្រកាសទី២៖ ការបញ្ជូនសេចក្ដីដែលព្រះជាម្ចាស់សម្ដែងឲ្យមនុស្សលោកស្គាល់** ... 31

១-ការបញ្ជូនបន្តនៃក្រុមគ្រីស្តទូត ... 32

២-ទំនាក់ទំនងរវាងការបញ្ជូនបន្តនិងព្រះគម្ពីរដ៏វិសុទ្ធ ... 33

៣-ការបកស្រាយមរតកនៃជំនឿ ... 34

**ប្រការទី៣៖ ព្រះគម្ពីរដ៏វិសុទ្ធ** ... 36

១-ព្រះគ្រីស្តជាព្រះបន្ទូលតែមួយនៃព្រះគម្ពីរដ៏វិសុទ្ធ ... 36

២-ការបំភ្លឺ និងការបកស្រាយព្រះគម្ពីរដ៏វិសុទ្ធ ... 37

៣-ព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកបកស្រាយព្រះគម្ពីរ ... 37

៤-សាសនាបញ្ញត្តិនៃព្រះគម្ពីរ ... 39

៥-ព្រះគម្ពីរដ៏វិសុទ្ធក្នុងការរស់នៅរបស់ព្រះសហគមន៍ ... 42

**ជំពូកទីបី៖ មនុស្សឆ្លើយតបនឹងព្រះជាម្ចាស់** ... 43

**ប្រកាសទី១៖ ខ្ញុំជឿ** ... 43

១-ការស្ដាប់បង្គាប់នៃជំនឿ ... 43

២-"ខ្ញុំដឹងថា ខ្ញុំបានជឿលើព្រះអង្គណា" (២ធម ១,១២) ....... 44
៣-លក្ខណៈនៃជំនឿ ....... 45
**ប្រការទី២៖ យើងជឿ** ....... 48
១-"សូមព្រះអម្ចាស់ទតមើលជំនឿរបស់ព្រះសហគមន៍ព្រះអង្គ" ....... 49
២-ភាសានៃជំនឿ ....... 49
៣-ជំនឿតែមួយ ....... 49
**ភាគទីពីរ៖ ធម៌ប្រកាសជំនឿនៃគ្រីស្តសាសនា -សេចក្តីសង្ខេបនៃជំនឿ** ....... 53
**ជំពូកទីមួយ៖ ខ្ញុំជឿលើព្រះជាម្ចាស់ជាព្រះបិតា** ....... 55
**ប្រការទី១៖ "ខ្ញុំជឿលើព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ជាព្រះបង្កើតមេឃ និងដី"** ....... 55
**កថាខណ្ឌទី១៖ ខ្ញុំជឿលើព្រះជាម្ចាស់** ....... 55
១-"ខ្ញុំជឿលើព្រះជាម្ចាស់តែមួយព្រះអង្គ" ....... 55
២-ព្រះជាម្ចាស់សម្តែងព្រះនាមព្រះអង្គឲ្យយើងស្គាល់ ....... 56
៣-ព្រះជាម្ចាស់ដែល "មានជីវិតគង់នៅ" ជាសេចក្តីពិត និងសេចក្តីស្រឡាញ់ ....... 58
៤-តើជំនឿលើព្រះជាម្ចាស់តែមួយព្រះអង្គនាំឲ្យទទួលផលអ្វីខ្លះ? ....... 60
**កថាខណ្ឌទី២៖ ព្រះបិតា** ....... 61
១-"ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" ....... 61
២-ព្រះជាម្ចាស់សម្តែងព្រះអង្គជាព្រះត្រៃឯក ....... 62
៣-លទ្ធិនៃជំនឿអំពីព្រះត្រៃឯកដ៏វិសុទ្ធ ....... 64
៤-ព្រះរាជកិច្ច និងបេសកកម្មរបស់ព្រះត្រៃឯក ....... 66
**កថាខណ្ឌទី៣៖ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ** ....... 68
**កថាខណ្ឌទី៤៖ ព្រះបង្កើត** ....... 70
១-ការអប់រំជំនឿអំពីការបង្កើត ....... 70
២-ការបង្កើតជាស្នាព្រះហស្តរបស់ព្រះត្រៃឯក ....... 72
៣-"ព្រះជាម្ចាស់បានបង្កើតពិភពលោកសម្រាប់សិរីរុងរឿងរបស់ព្រះអង្គ" ....... 73
៤-គម្រោងការដ៏អស្ចារ្យរបស់ការបង្កើត ....... 74
៥-ព្រះជាម្ចាស់ធ្វើឲ្យគម្រោងការរបស់ព្រះអង្គបានសម្រេច៖ ឧបការគុណ ....... 76
**កថាខណ្ឌទី៥៖ មេឃ និងដី** ....... 80
១-ពួកទេវទូត ....... 80
២-ពិភពដែលមើលឃើញ ....... 82
**កថាខណ្ឌទី៦៖ មនុស្សលោក** ....... 84
១-"មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់" ....... 84
២-មនុស្សជាបុគ្គលតែមួយទាំងរូបកាយទាំងវិញ្ញាណ ....... 86
៣-"ព្រះជាម្ចាស់បង្កើតមនុស្សជាបុរសជាស្ត្រី" ....... 87
៤-មនុស្សនៅស្ថានបរមសុខ ....... 88

**កថាខណ្ឌទី៧៖ មនុស្សធ្លាក់ខ្លួនជាអ្នកបាប** ......89
១-ទីណាមានបាបកាន់តែច្រើន ទីនោះព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ក៏កាន់តែមានច្រើន លើសលប់ថែមទៀត ......89
២-ពួកទេវទូតធ្លាក់ខ្លួនជាអ្នកបាប ......90
៣-អំពើបាបដើមដំបូង ......91
៤-ព្រះជាម្ចាស់ "នៅតែមិនបណ្ដោយឲ្យមនុស្សស្ថិតក្រោមអំណាចនៃសេចក្ដីស្លាប់ឡើយ" ......94
**ជំពូកទីពីរ៖ ខ្ញុំជឿលើព្រះយេស៊ូគ្រីស្ដជាព្រះបុត្រាតែមួយនៃព្រះជាម្ចាស់** ......96
**ប្រការទី២៖ "ខ្ញុំជឿលើព្រះយេស៊ូគ្រីស្ដជាព្រះបុត្រាតែមួយនៃព្រះបិតា ហើយជាអម្ចាស់នៃយើងខ្ញុំ"** ......98
១-ព្រះយេស៊ូ ......98
២-ព្រះគ្រីស្ដ ......99
៣-ព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់ ......100
៤-ព្រះអម្ចាស់ ......102
**ប្រការទី៣៖ "ព្រះយេស៊ូគ្រីស្ដមានកំណើតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី"** ......103
**កថាខណ្ឌទី១៖ ព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស** ......103
១-ហេតុអ្វីបានជាព្រះបន្ទូលប្រសូតជាមនុស្ស? ......103
២-ព្រះជាម្ចាស់ប្រសូតជាមនុស្ស ......104
៣-ពិតជាព្រះជាម្ចាស់មែនពិតជាមនុស្សមែន ......105
៤-តើព្រះបុត្រារបស់ព្រះជាម្ចាស់ជាមនុស្សយ៉ាងដូចម្ដេច? ......107
**កថាខណ្ឌទី២៖ "...ដែលមានកំណើតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី"** ......109
១-ដែលមានកំណើតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ......109
២-...ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី ......110
**កថាខណ្ឌទី៣៖ ព្រឹត្តិការណ៍ដ៏អស្ចារ្យនៃជីវិតរបស់ព្រះគ្រីស្ដ** ......115
១-ជីវិតទាំងស្រុងរបស់ព្រះគ្រីស្ដជាព្រឹត្តការណ៍មួយដ៏អស្ចារ្យ ......115
២-ព្រឹត្តិការណ៍ដ៏អស្ចារ្យអំពីកុមារភាព និងជីវិតដ៏លាក់កំបាំងរបស់ព្រះយេស៊ូ ......117
៣-ព្រឹត្តិការណ៍ដ៏អស្ចារ្យនៃជីវិតជាសាធារណៈរបស់ព្រះយេស៊ូ ......120
**ប្រការទី៤៖ "ព្រះយេស៊ូគ្រីស្ដបានសោយទុក្ខលំបាកនៅជំនាន់លោកប៉ុនពីឡាតព្រះអង្គត្រូវគេឆ្កាងសោយទិវង្គត ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះក្នុងរូងថ្មមួយ"** ......127
**កថាខណ្ឌទី១៖ ព្រះយេស៊ូ និងជនជាតិអ៊ីស្រាអែល** ......128
១-ព្រះយេស៊ូ និងធម្មវិន័យ ......129
២-ព្រះយេស៊ូ និងព្រះវិហារ ......130
៣-ព្រះយេស៊ូ និងជំនឿរបស់ជនជាតិអ៊ីស្រាអែលលើព្រះជាម្ចាស់តែមួយជាព្រះសង្គ្រោះ ......131
**កថាខណ្ឌទី២៖ ព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាង** ......133

១-គេកាត់ក្តីព្រះយេស៊ូ ..... 133

២-ព្រះគ្រីស្តសោយទិវង្គត តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ..... 134

៣-ព្រះគ្រីស្តបានថ្វាយខ្លួនព្រះអង្គទៅព្រះបិតាដើម្បីលោះបាបរបស់យើង ..... 136

**កថាខណ្ឌទី៣៖ ព្រះសពព្រះយេស៊ូគ្រីស្តត្រូវគេបញ្ចុះក្នុងរូងថ្មមួយ** ..... 140

**ប្រការទី៥៖ "ព្រះយេស៊ូគ្រីស្តបានយាងចុះទៅស្ថានក្រោម លុះដល់ថ្ងៃទីបីព្រះអង្គមានព្រះជន្មថ្មី"** ..... 142

**កថាខណ្ឌទី១៖ ព្រះគ្រីស្តយាងចុះទៅស្ថានក្រោម** ..... 142

**កថាខណ្ឌទី២៖ លុះដល់ថ្ងៃទីបីព្រះអង្គមានព្រះជន្មថ្មី** ..... 143

១-ព្រះជន្មថ្មីជាហេតុការណ៍នៃប្រវត្តិសាស្ត្រផង និងហួសប្រវត្តិសាស្ត្រផង ..... 144

២-ព្រះជន្មថ្មីជាស្នាព្រះហស្តនៃព្រះត្រៃឯក ..... 146

៣-តើ "ព្រះជន្មថ្មី" មានអត្ថន័យ និងសង្គ្រោះមនុស្សលោកយ៉ាងដូចម្តេច ? ..... 147

**ប្រការទី៦៖ "ព្រះយេស៊ូយាងឡើងស្ថានបរមសុខ គង់ខាងស្តាំព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ"** ..... 148

**ប្រការទី៧៖ "ព្រះអង្គនឹងយាងមកវិញ ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ទាំងស្លាប់"** ..... 150

១-ព្រះអង្គនឹងយាងមកវិញពោរពេញដោយសិរីរុងរឿង ..... 150

២-ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ទាំងស្លាប់ ..... 152

**ជំពូកទីបី៖ ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ** ..... 153

**ប្រការទី៨៖ "ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ"** ..... 155

១-បេសកកម្មរួមគ្នារបស់ព្រះបុត្រា និងព្រះវិញ្ញាណ ..... 155

២-ព្រះនាមរបៀបហៅ និងនិមិត្តរូបរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ..... 156

៣-ព្រះវិញ្ញាណ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅពេលព្រះជាម្ចាស់មានព្រះបន្ទូលសន្យានៅឡើយ ..... 159

៤-ព្រះវិញ្ញាណរបស់ព្រះគ្រីស្តនៅពេលកំណត់ ..... 162

៥-ព្រះវិញ្ញាណ និងព្រះសហគមន៍ក្នុងពេលចុងក្រោយបំផុត ..... 165

**ប្រការទី៩៖ "ខ្ញុំជឿថា ព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ"** ..... 167

**កថាកណ្ឌទី១៖ ព្រះសហគមន៍តាមគម្រោងការរបស់ព្រះជាម្ចាស់** ..... 168

១-នាម និងរូបរបស់ព្រះសហគមន៍ ..... 168

២-ប្រភពមូលដ្ឋានគ្រឹះ និងបេសកកម្មរបស់ព្រះសហគមន៍ ..... 170

៣-អាថ៌កំបាំងរបស់ព្រះសហគមន៍ ..... 173

**កថាខណ្ឌទី២៖ ព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ជាព្រះកាយព្រះគ្រីស្ត និងជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ** ..... 175

១-ព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ..... 175

២-ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត ..... 177

៣-ព្រះសហគមន៍ជាព្រះវិហារនៃព្រះវិញ្ញាណដ៏វិសុទ្ធ ..... 180

**កថាខណ្ឌសញ្ញាសម្គាល់ទី៣៖ ព្រះសហគមន៍មានតែមួយដ៏វិសុទ្ធកាតូលិក និងបន្តជំនឿពីក្រុមគ្រីស្តទូត** ..... 182

១-ព្រះសហគមន៍មានតែមួយ ... 182
២-ព្រះសហគមន៍ដ៏វិសុទ្ធ ... 185
៣-ព្រះសហគមន៍កាតូលិក ... 187
៤-ព្រះសហគមន៍មានក្រុមគ្រីស្តទូតជាគ្រឹះ ... 193
**កថាខណ្ឌទី៤៖ អ្នកធ្វើជីវិតលើព្រះគ្រីស្ត ក្រុមលំដាប់លំដោយ គ្រីស្តបរិស័ទធម្មតា អ្នកថ្វាយខ្លួនទាំងស្រុង** ... 196
១-ព្រះសហគមន៍មានរចនាសម្ព័ន្ធតាមលំដាប់លំដោយ ... 197
២-គ្រីស្តបរិស័ទធម្មតា ... 201
៣-របៀបរស់នៅជាអ្នកថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ ... 204
**កថាខណ្ឌទី៥៖ សហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ** ... 209
១-សហភាពរវាងអំពើល្អខាងវិញ្ញាណ ... 210
២-ព្រះសហគមន៍នៅលើផែនដីរួមរស់ជាមួយព្រះសហគមន៍នៅស្ថានបរមសុខ ... 210
**កថាខណ្ឌទី៦៖ ព្រះនាងម៉ារីជាព្រះមាតារបស់ព្រះគ្រីស្ត និងជាព្រះមាតារបស់ព្រះសហគមន៍ផង** ... 212
១-ព្រះនាងម៉ារីជាព្រះមាតាព្រះសហគមន៍ ... 212
២-ការគោរពប្រណិប័តន៍ព្រះនាងព្រហ្មចារិនីដ៏វិសុទ្ធ ... 214
៣-ព្រះនាងម៉ារីជារូបតំណាងរបស់ព្រះសហគមន៍នៅពេលចុងក្រោយបំផុត ... 215
**ប្រការទី១០៖ "ខ្ញុំជឿថា មានការលើកលែងទោសឲ្យមនុស្សរួចពីបាប"** ... 215
១-ពិធីជ្រមុជទឹកតែមួយសម្រាប់ការលើកលែងទោសឲ្យរួចពីបាប ... 216
២-អំណាចនៃកូនសោ ... 216
**ប្រការទី១១៖ "ខ្ញុំជឿថា រូបកាយមនុស្សនឹងមានជីវិតថ្មី"** ... 218
១-ព្រះគ្រីស្តមានព្រះជន្មថ្មី យើងក៏នឹងមានជីវិតថ្មីដែរ ព្រះជាម្ចាស់សម្តែងបន្តិចម្តង ៗឲ្យមនុស្សដឹងថាគេនឹងមានជីវិតថ្មី ... 219
២-រួមស្លាប់ក្នុងអង្គព្រះគ្រីស្តយេស៊ូ ... 221
**ប្រការទី១២៖ "ខ្ញុំជឿថា មានជីវិតអស់កល្បជានិច្ច"** ... 224
១-ព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សម្នាក់ៗ ... 225
២-ស្ថានបរមសុខ ... 225
៣-ព្រះជាម្ចាស់ជម្រះមនុស្សឲ្យបានវិសុទ្ធ ... 226
៤-ស្ថាននរក ... 227
៥-ព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោកទាំងអស់នៅពេលចុងក្រោយបំផុត ... 228
៦-យើងសង្ឃឹមផ្ទៃមេឃថ្មី និងផែនដីថ្មី ... 229
**"អាម៉ែន"** ... 232
**វគ្គទីពីរ៖ ការលើកតម្កើងគម្រោងការដ៏អស្ចារ្យនៃគ្រីស្តសាសនា** ... 234
**ភាគទីមួយ៖ ការចាត់ចែងនៃអគ្គសញ្ញា** ... 237
**ជំពូកទីមួយ៖ ព្រឹត្តិការណ៍ដ៏អស្ចារ្យអំពីព្រះយេស៊ូគ្រីស្ត ដែលសោយទិវង្គត**

**និងមានព្រះជន្មថ្មី ក្នុងវេលានៃព្រះសហគមន៍** ........ 238
**ប្រការទី១៖ ពិធីបុណ្យជាព្រះរាជកិច្ចនៃព្រះត្រៃឯក** ........ 238
១-ព្រះបិតាជាប្រភព និងទីចុងក្រោយនៃពិធីបុណ្យ ........ 238
២-ព្រះរាជកិច្ចរបស់ព្រះគ្រីស្តក្នុងពិធីបុណ្យ ........ 239
៣-ព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះសហគមន៍ក្នុងពិធីបុណ្យ ........ 241
**ប្រការទី២៖ ព្រឹត្តិការណ៍ដ៏អស្ចារ្យអំពីព្រះយេស៊ូគ្រីស្ត ដែលសោយទិវង្គត**
**និងមានព្រះជន្មថ្មី ក្នុងអគ្គសញ្ញានៃព្រះសហគមន៍** ........ 246
១-អគ្គសញ្ញារបស់ព្រះគ្រីស្ត ........ 246
២-អគ្គសញ្ញារបស់ព្រះសហគមន៍ ........ 246
៣-អគ្គសញ្ញានៃជំនឿ ........ 247
៤-អគ្គសញ្ញានៃការសង្គ្រោះ ........ 248
៥-អគ្គសញ្ញានៃជីវិតអស់កល្បជានិច្ច ........ 249
**ជំពូកទីពីរ៖ ពិធីលើកតម្កើងបុណ្យចម្លងខាងអគ្គសញ្ញា** ........ 250
**ប្រការទី១៖ ការប្រារព្ធពិធីបុណ្យព្រះសហគមន៍** ........ 250
១-តើនរណាលើកតម្កើង ? ........ 250
២-តើត្រូវលើកតម្កើងយ៉ាងដូចម្តេច ? ........ 252
៣-តើត្រូវលើកតម្កើងនៅពេលណា ? ........ 256
៤-តើត្រូវលើកតម្កើងនៅឯណា ? ........ 260
**ប្រការទី២៖ ពិធីបុណ្យខុសប្លែកពីគ្នា គម្រោងការដ៏អស្ចារ្យតែមួយ** ........ 263
**ភាគទីពីរ៖ អគ្គសញ្ញាទាំងប្រាំពីរនៃព្រះសហគមន៍** ........ 265
**ជំពូកទីមួយ៖ អគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ** ........ 265
**ប្រការទី១៖ អគ្គសញ្ញាជ្រមុជទឹក** ........ 266
១-តើគេហៅអគ្គសញ្ញានេះយ៉ាងដូចម្តេច ? ........ 266
២-ពិធីជ្រមុជទឹកក្នុងការចាត់ចែងនៃការសង្គ្រោះ ........ 267
៣-តើព្រះសហគមន៍ប្រារព្ធអគ្គសញ្ញាជ្រមុជទឹកយ៉ាងដូចម្តេច ? ........ 269
៤-តើអ្នកណាអាចទទួលពិធីជ្រមុជទឹកបាន ? ........ 271
៥-តើអ្នកណាអាចផ្តល់ពិធីជ្រមុជទឹកបាន ? ........ 273
៦-ចាំបាច់ត្រូវតែទទួលពិធីជ្រមុជទឹក ........ 273
៧-ព្រះអំណោយទានរបស់ពិធីជ្រមុជទឹក ........ 274
**ប្រការទី២៖ អគ្គសញ្ញាលាបថ្វាស** ........ 278
១-ការលាបថ្វាសក្នុងការចាត់ចែងនៃការសង្គ្រោះ ........ 278
២-សញ្ញាសម្គាល់ និងពិធីនៃអគ្គសញ្ញាលាបថ្វាស ........ 280
៣-ផលនៃអគ្គសញ្ញាលាបថ្វាស ........ 282
៤-តើនរណាអាចទទួលអគ្គសញ្ញានេះបាន ? ........ 282
៥-អ្នកមានមុខងារផ្តល់អគ្គសញ្ញាលាបថ្វាស ........ 284

**ប្រការទី៣៖ អគ្គសញ្ញាអរព្រះគុណ** ........ 285
១-ពិធីអរព្រះគុណជាប្រភព និងជាកំពូលនៃការរស់នៅក្នុងព្រះសហគមន៍ ........ 286
២-តើគេហៅអគ្គសញ្ញានេះយ៉ាងដូចម្ដេច? ........ 286
៣-អគ្គសញ្ញាអរព្រះគុណក្នុងការចាត់ចែងនៃការសង្គ្រោះ ........ 287
៤-ពិធីបុណ្យនៃអគ្គសញ្ញាអរព្រះគុណ ........ 290
៥-សក្ការបូជាខាងអគ្គសញ្ញា៖ អរព្រះគុណ នឹករឭក វត្តមាន ........ 293
៦-ពិធីជប់លៀងនៃបុណ្យចម្លង ........ 299
៧-ពិធីអរព្រះគុណ "បញ្ចាំសិរីរុងរឿងដែលនឹងយាងមក" ........ 303
**ជំពូកទីពីរ៖ អគ្គសញ្ញានៃការព្យាបាល** ........ 306
**ប្រការទី៤៖ អគ្គសញ្ញាលើកលែងទោស និងសម្រុះសម្រួល** ........ 306
១-តើគេហៅអគ្គសញ្ញានេះយ៉ាងដូចម្ដេច? ........ 306
២-ហេតុអ្វីបានជាមានអគ្គសញ្ញាលើកលែងទោសក្រោយពីពិធីជ្រមុជទឹក? ........ 307
៣-ការកែប្រែចិត្តគំនិតរបស់អ្នកជ្រមុជទឹក ........ 307
៤-ការសោកស្ដាយយ៉ាងពិតប្រាកដ ........ 308
៥-របៀបផ្សេងៗនៃការសោកស្ដាយអំពើបាបក្នុងការរស់នៅជាគ្រីស្តបរិស័ទ ........ 309
៦-អគ្គសញ្ញាលើកលែងទោស និងសម្រុះសម្រួល ........ 310
៧-កិច្ចការរបស់អ្នកបាប ........ 313
៨-អ្នកមានមុខងារផ្ដល់អគ្គសញ្ញានេះ ........ 315
៩-ផលនៃអគ្គសញ្ញានេះ ........ 316
១០-បុណ្យកុសលសម្រាប់អនុគ្រោះ ........ 317
១១-ពិធីបុណ្យនៃអគ្គសញ្ញាលើកលែងទោស ........ 319
**ប្រការទី៥៖ អគ្គសញ្ញាលាបប្រេងឲ្យអ្នកជំងឺ** ........ 322
១-មូលដ្ឋានគ្រឹះនៃពិធីលាបប្រេងក្នុងការចាត់ចែងនៃការសង្គ្រោះ ........ 322
២-តើនរណាទទួល និងនរណាផ្ដល់អគ្គសញ្ញានេះ? ........ 325
៣-តើគេប្រារព្ធអគ្គសញ្ញានេះយ៉ាងដូចម្ដេច? ........ 325
៤-ផលនៃពិធីអគ្គសញ្ញានេះ ........ 326
៥-អគ្គសញ្ញាចុងក្រោយរបស់គ្រីស្តបរិស័ទ ........ 327
**ជំពូកទីបី៖ អគ្គសញ្ញាបម្រើគ្រីស្តបរិស័ទឲ្យរួបរួមគ្នា** ........ 328
**ប្រការទី៦៖ អគ្គសញ្ញាតែងតាំង** ........ 328
១-ហេតុអ្វីបានជាគេហៅអគ្គសញ្ញានេះថា អគ្គសញ្ញាតែងតាំង (Orders)? ........ 329
២-អគ្គសញ្ញាតែងតាំងក្នុងការចាត់ចែងនៃការសង្គ្រោះ ........ 329
៣-លំដាប់ថ្នាក់ទាំងបីនៃអគ្គសញ្ញាតែងតាំង ........ 333
៤-ពិធីប្រារព្ធអគ្គសញ្ញានេះ ........ 336
៥-តើអ្នកណាអាចប្រគល់អគ្គសញ្ញានេះ? ........ 337
៦-តើអ្នកណាអាចទទួលអគ្គសញ្ញានេះ? ........ 337

៧. ផលនៃអគ្គសញ្ញាតែងតាំង ........ 338
**ប្រការទី៧៖ អគ្គសញ្ញាអាពាហ៍ពិពាហ៍** ........ 342
១-អាពាហ៍ពិពាហ៍ក្នុងគម្រោងការរបស់ព្រះជាម្ចាស់ ........ 342
២-ការប្រារព្ធពិធីអាពាហ៍ពិពាហ៍ ........ 346
៣-ការយល់ព្រមឲ្យរៀបអាពាហ៍ពិពាហ៍ ........ 347
៤-ផលនៃអគ្គសញ្ញាអាពាហ៍ពិពាហ៍ ........ 349
៥-សិទ្ធិ និងភារកិច្ចនៃសេចក្ដីស្រឡាញ់ជាគូស្វាមីភរិយា ........ 350
៦-ក្រុមគ្រួសារជាព្រះសហគមន៍ដ៏តូចមួយ ........ 353
**ជំពូកទីបួន៖ ពិធីលើកតម្កើងផ្សេងទៀត** ........ 355
**ប្រការទី១៖ អនុសញ្ញា** ........ 355
**ប្រការទី២៖ ពិធីបញ្ចុះសព** ........ 357
១-បុណ្យចម្លងចុងក្រោយរបស់គ្រីស្ដបរិស័ទ ........ 358
២-ការប្រារព្ធពិធីបញ្ចុះសព ........ 358
**វគ្គទីបី៖ ការរស់នៅក្នុងអង្គព្រះគ្រីស្ដ** ........ 360
**ភាគទីមួយ៖ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សលោកឲ្យរស់នៅក្នុងអង្គព្រះវិញ្ញាណ** ........ 363
**ជំពូកទីមួយ៖ ឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស** ........ 363
**ប្រការទី១៖ មនុស្សលោកជារូបតំណាងរបស់ព្រះជាម្ចាស់** ........ 363
**ប្រការទី២៖ ព្រះជាម្ចាស់ត្រាស់ហៅយើងឆ្ពោះទៅរកសុភមង្គលយ៉ាងពិតប្រាកដ** ........ 365
១-សុភមង្គលយ៉ាងពិតប្រាកដ ........ 365
២-មនុស្សប្រាថ្នាចង់បានសុភមង្គល ........ 366
៣-សុភមង្គលយ៉ាងពិតប្រាកដតាមគ្រីស្ដសាសនា ........ 366
**ប្រការទី៣៖ សេរីភាពរបស់មនុស្ស** ........ 368
១-សេរីភាព និងការទទួលខុសត្រូវ ........ 368
២-សេរីភាពរបស់មនុស្សក្នុងការចាត់ចែងការសង្គ្រោះ ........ 369
**ប្រការទី៤៖ សីលធម៌នៃកិច្ចការរបស់មនុស្ស** ........ 371
១-ប្រភពនៃសីលធម៌ ........ 371
២-អំពើល្អ និងអំពើអាក្រក់ ........ 372
**ប្រការទី៥៖ សីលធម៌នៃតណ្ហា** ........ 373
១-តណ្ហា ........ 373
២-តណ្ហា និងជីវិតប្រកបដោយសីលធម៌ ........ 373
**ប្រការទី៦៖ មនសិការខាងសីលធម៌** ........ 374
១-ការវិនិច្ឆ័យនៃមនសិការ ........ 374
២-ការអប់រំមនសិការ ........ 376
៣-ត្រូវតែជ្រើសរើសតាមមនសិការរបស់ខ្លួន ........ 376
៤-ការវិនិច្ឆ័យខុស ........ 377

**ប្រការទី៧៖ គុណធម៌** ....................378
១-គុណធម៌របស់មនុស្ស....................378
២-គុណធម៌ដែលព្រះជាម្ចាស់ប្រទាន ....................380
៣-ព្រះអំណោយទាន និងផលនៃព្រះវិញ្ញាណដ៏វិសុទ្ធ....................384
**ប្រការទី៨៖ អំពើបាប** ....................386
១-ធម៌មេត្តាករុណា និងអំពើបាប....................386
២-អ្វីទៅជាអំពើបាប ?....................386
៣-អំពើបាបផ្សេងៗទៀត ....................387
៤-អំពើបាបធ្ងន់ (ដែលនាំឲ្យស្លាប់) និងអំពើបាបស្រាល ....................387
៥-អំពើបាបរាលដាល....................389
**ជំពូកទីពីរ៖ សហគមន៍មនុស្ស** ....................391
**ប្រការទី១៖ មនុស្ស និងសង្គម** ....................391
១-ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យរួមរស់ជាមួយគ្នា ....................391
២-ការកែប្រែចិត្តគំនិត និងសង្គម ....................392
**ប្រការទី២៖ ការរួមចំណែកក្នុងការរស់នៅក្នុងសង្គម** ....................394
១-អំណាច ....................394
២-ផលប្រយោជន៍រួម ....................395
៣-ការទទួលខុសត្រូវ និងការចូលរួមចំណែក....................396
**ប្រការទី៣៖ យុត្តិធម៌នៅក្នុងសង្គម** ....................398
១-ការគោរពមនុស្សទុកជាបុគ្គល....................398
២-មនុស្សស្មើគ្នាផង ខុសប្លែកគ្នាផង....................399
៣-សាមគ្គីភាពរបស់មនុស្ស....................400
**ជំពូកទីបី៖ ការសង្គ្រោះរបស់ព្រះជាម្ចាស់៖**
**ធម្មវិន័យ និងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ** ....................401
**ប្រការទី១៖ ធម្មវិន័យខាងសីលធម៌** ....................402
១-ធម្មវិន័យខាងសីលធម៌តាមធម្មជាតិ ....................402
២-ធម្មវិន័យចាស់ ....................404
៣-ធម្មវិន័យថ្មី ឬធម្មវិន័យនៃដំណឹងល្អ....................405
**ប្រការទី២៖ ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្ដោស**
**និងប្រោសមនុស្សលោកឲ្យបានសុចរិត**....................408
១-ព្រះជាម្ចាស់ប្រោសមនុស្សលោកឲ្យបានសុចរិត....................408
២-ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ....................410
៣-បុណ្យកុសល ....................413
៤-ភាពដ៏វិសុទ្ធរបស់គ្រីស្តសាសនា....................414
**ប្រការទី៣៖ ព្រះសហគមន៍ជាមាតាអប់រំយើង** ....................417

១-ការរស់នៅប្រកបដោយសីលធម៌ និងក្រុមមេដឹកនាំព្រះសហគមន៍ ..... 417
២-បទបញ្ញារបស់ព្រះសហគមន៍ ..... 419
៣-របៀបរស់នៅប្រកបដោយសីលធម៌ និងសក្ខីភាពសម្រាប់អ្នកដទៃ ..... 419
**ភាគទីពីរៈ វិន័យដប់ប្រការ** ..... 424
**ជំពូកទីមួយៈ "ត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា"** ..... 429
**ប្រការទី១ៈ វិន័យទីមួយ** ..... 429
១-"ចូរកោតខ្លាចព្រះអម្ចាស់ ជាព្រះរបស់អ្នក ហើយគោរពបម្រើព្រះអង្គ" ..... 430
២-"មិនត្រូវគោរពព្រះណាផ្សេងក្រៅពីព្រះជាម្ចាស់ឡើយ" ..... 432
៣-"អ្នកមិនត្រូវគោរពព្រះណាផ្សេងទៀតក្រៅពីយើងបានឡើយ" ..... 435
៤-"អ្នកមិនត្រូវឆ្លាក់រូបអ្វី" ..... 438
**ប្រការទី២ៈ វិន័យទីពីរ** ..... 440
១-ព្រះនាមរបស់ព្រះអម្ចាស់ដ៏វិសុទ្ធ ..... 440
២-ការយកព្រះនាមព្រះអម្ចាស់ប្រើដោយឥតបានការ ..... 441
៣-ឈ្មោះរបស់គ្រីស្តបរិស័ទ ..... 442
**ប្រការទី៣ៈ វិន័យទីបី** ..... 444
១-ថ្ងៃសប្ប័ទ ..... 444
២-ថ្ងៃរបស់ព្រះអម្ចាស់ ..... 445
**ជំពូកទីពីរៈ "ត្រូវស្រឡាញ់បងប្អូនឯទៀតឲ្យបានដូចស្រឡាញ់ខ្លួនឯង"** ..... 449
**ប្រការទី៤ៈ វិន័យទីបួន** ..... 449
១-ក្រុមគ្រួសារតាមគម្រោងការរបស់ព្រះជាម្ចាស់ ..... 450
២-ក្រុមគ្រួសារ និងសង្គម ..... 451
៣-ភារកិច្ចនៃសមាជិកក្រុមគ្រួសារ ..... 453
៤-ក្រុមគ្រួសារ និងព្រះរាជ្យ ..... 456
៥-អាជ្ញាធរក្នុងសង្គមស៊ីវិល ..... 456
**ប្រការទី៥ៈ វិន័យទីប្រាំ** ..... 460
១-ការគោរពជីវិតរបស់មនុស្ស ..... 460
២-ការគោរពឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស ..... 465
៣-ការរក្សាសន្តិភាព ..... 468
**ប្រការទី៦ៈ វិន័យទីប្រាំមួយ** ..... 472
១-"ព្រះជាម្ចាស់បង្កើតមនុស្សជាបុរស ជាស្ត្រី" ..... 472
២-ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យចេះទប់ខ្លួន ..... 474
៣-សេចក្តីស្រឡាញ់របស់គូស្វាមីភរិយា ..... 478
៤-អំពើបាបប្រឆាំងនឹងកិត្តិយសដ៏ថ្លៃថ្នូរជាគូស្វាមីភរិយា ..... 482
**ប្រការទី៧ៈ វិន័យទីប្រាំពីរ** ..... 485

១-ទីដៅសកល និងកម្មសិទ្ធិឯកជននៃទ្រព្យសម្បត្តិ......485
២-ការគោរពបុគ្គល និងទ្រព្យសម្បត្តិរបស់គេ......486
៣-លទ្ធិសង្គមនៃព្រះសហគមន៍......488
៤-សកម្មភាពខាងសេដ្ឋកិច្ច និងយុត្តិធម៌ក្នុងសង្គម......489
៥-យុត្តិធម៌ និងសាមគ្គីភាពរវាងប្រជាជាតិនានា......491
៦-សេចក្តីស្រឡាញ់ចំពោះជនក្រីក្រ......492
**ប្រការទី៨៖ វិន័យទីប្រាំបី**......495
១-ការរស់នៅក្នុងសេចក្តីពិត......496
២-"ផ្តល់សក្ខីភាពអំពីសេចក្តីពិត"......497
៣-"អំពើបាបប្រឆាំងនឹងសេចក្តីពិត"......498
៤-ការគោរពសេចក្តីពិត......500
៥-ការប្រើប្រាស់មធ្យោបាយទំនាក់ទំនងក្នុងសង្គម......500
៦-សេចក្តីពិត សោភណភាព និងសិល្បៈជាទីសក្ការៈ......501
**ប្រការទី៩៖ វិន័យទីប្រាំបួន**......504
១-ការជម្រះចិត្តគំនិតឲ្យបានបរិសុទ្ធ......504
២-ត្រូវតែតស៊ូដើម្បីមានចិត្តបរិសុទ្ធ......505
**ប្រការទី១០៖ វិន័យទីដប់**......507
១-ចិត្តលោភលន់របស់លោកីយ៍......507
២-បំណងនៃព្រះវិញ្ញាណ......509
៣-ការដាក់ខ្លួនជាអ្នកក្រ......509
៤-"ខ្ញុំចង់ឃើញព្រះជាម្ចាស់"......510
**វគ្គទីបួន៖ ការអធិដ្ឋានក្នុងការរស់នៅជាគ្រីស្តបរិស័ទ**......512
**ភាគទីមួយ៖ ការអធិដ្ឋានក្នុងការរស់នៅជាគ្រីស្តបរិស័ទ**......513
**ជំពូកទីមួយ៖ ព្រះជាម្ចាស់សម្តែងឲ្យមនុស្សលោកដឹងអំពីការអធិដ្ឋាន ព្រះអង្គត្រាស់ហៅមនុស្សលោកទាំងអស់ឲ្យអធិដ្ឋាន**......514
**ប្រការទី១៖ ក្នុងសម្ព័ន្ធមេត្រីចាស់**......515
**ប្រការទី២៖ នៅពេលកំណត់ដ៏ពេញលក្ខណៈ**......521
**ប្រការទី៣៖ ក្នុងព្រះសហគមន៍**......527
១-ការប្រទានពរ និងការថ្វាយបង្គំ......528
២-ការអធិដ្ឋានដោយទូលអង្វរព្រះជាម្ចាស់......528
៣-ការជួយអង្វរឲ្យអ្នកដទៃ......530
៤-ការអធិដ្ឋានដោយអរព្រះគុណព្រះជាម្ចាស់......530
៥-ការអធិដ្ឋានដោយសរសើរលើកតម្កើងព្រះជាម្ចាស់......530
**ជំពូកទីពីរ៖ ការបញ្ជូនបន្តនៃការអធិដ្ឋាន**......532
**ប្រការទី១៖ ប្រភពនៃការអធិដ្ឋាន**......532

**ប្រការទី២៖ ផ្លូវនៃការអធិដ្ឋាន** ........ 534
**ប្រការទី៣៖ អ្នកណែនាំអធិដ្ឋាន** ........ 539
**ជំពូកទីបី៖ ជីវិតនៃការអធិដ្ឋាន** ........ 542
**ប្រការទី១៖ របៀបអធិដ្ឋាន** ........ 542
១-ការអធិដ្ឋានតាមពាក្យសម្ដី ........ 542
២-ការស្មឹងស្មាធ៏ ........ 543
៣-ការធ្វើសមាធិ ........ 544
**ប្រការទី២៖ ត្រូវតែតស៊ូដើម្បីអធិដ្ឋាន** ........ 546
១-ការប្រឆាំងតបនឹងការអធិដ្ឋាន ........ 546
២-ត្រូវប្រុងស្មារតីដោយមានចិត្តសុភាពរាបសា ........ 547
៣-ជឿលើព្រះជាម្ចាស់ដូចជឿលើឪពុក ........ 548
៤-ត្រូវព្យាយាមស្រឡាញ់ ........ 550
**ភាគទីពីរ៖ សេចក្ដីអធិដ្ឋានរបស់ព្រះយេស៊ូជាព្រះអម្ចាស់៖ "ឱព្រះបិតានៃយើងខ្ញុំ!"** ........ 552
**ប្រការទី១៖ "សេចក្ដីសង្ខេបនៃដំណឹងល្អទាំងមូល"** ........ 553
១-ស្នូលនៃព្រះគម្ពីរ ........ 553
២-"សេចក្ដីអធិដ្ឋានរបស់ព្រះអម្ចាស់" ........ 554
៣-ការអធិដ្ឋានរបស់ព្រះសហគមន៍ ........ 554
**ប្រការទី២៖ "ឱព្រះបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខ"** ........ 556
១-"ត្រូវហ៊ានចូលនៅជិតព្រះជាម្ចាស់ពោរពេញដោយទំនុកចិត្ត" ........ 556
២-"ឱព្រះបិតាអើយ!" ........ 557
៣-ព្រះបិតា "យើងខ្ញុំ" ........ 559
៤-"ដែលគង់នៅស្ថានបរមសុខ" ........ 560
**ប្រការទី៣៖ សំណូមពរទាំងប្រាំពីរ** ........ 561
១-"សូមឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ" ........ 562
២-"សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់" ........ 564
៣-សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដីដូចនៅលើមេឃ" ........ 566
៤-សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ" ........ 567
៥-"សូមអត់ទោសឲ្យយើងខ្ញុំផង ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំដែរ" ... 569
៦-"សូមកុំបណ្ដោយឲ្យយើងខ្ញុំចាញ់ការល្បួងឡើយ" ........ 571
៧-"តែសូមរំដោះយើងខ្ញុំឲ្យរួចផុតពីមារកំណាចផង" ........ 572

# បុព្វកថា

"ឱព្រះបិតាអើយ! (...) ជីវិតអស់កល្បជានិច្ច គឺឲ្យគេស្គាល់ព្រះអង្គដែលជាព្រះជាម្ចាស់ដ៏ពិតតែមួយគត់ និងឲ្យគេស្គាល់ព្រះយេស៊ូគ្រីស្តដែលព្រះអង្គចាត់ឲ្យមក" (យហ ១៧,៣)។ "ព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់យើង (...) ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់បានទទួលការសង្គ្រោះ និងបានស្គាល់សេចក្តីពិតយ៉ាងច្បាស់" (១ធម ២,៣-៤)។ "ក្រៅពីព្រះយេស៊ូ គ្មាននរណាម្នាក់អាចសង្គ្រោះមនុស្សបានទាល់តែសោះ ដ្បិតនៅក្រោមមេឃនេះព្រះជាម្ចាស់ពុំបានប្រទាននាមណាមួយផ្សេងទៀត ដើម្បីសង្គ្រោះយើងនោះឡើយ" (កក ៤,១២)។

## ១-ជីវិតរបស់មនុស្សគឺស្គាល់ និងស្រឡាញ់ព្រះជាម្ចាស់

១-ព្រះជាម្ចាស់ប្រកបដោយភាពល្អឥតខ្ចោះដែលគ្មានព្រំដែន និងពោរពេញទៅដោយសុភមង្គលតាមគម្រោងការដ៏សប្បុរសបំផុត ទ្រង់បានបង្កើតមនុស្សដោយមានសេរីភាពពេញលេញ ដើម្បីឲ្យមនុស្សរួមចំណែកនៅក្នុងព្រះជន្មប្រកបដោយសុភមង្គលរបស់ព្រះអង្គ។ អាស្រ័យហេតុនេះហើយបានជានៅគ្រប់សម័យកាល និងគ្រប់ទិសទីព្រះអង្គយាងមកជិតមនុស្ស។ ព្រះអង្គត្រាស់ហៅមនុស្សជួយឲ្យគេស្វែងរកព្រះអង្គឲ្យគេស្គាល់ និងស្រឡាញ់ព្រះអង្គអស់ពីកម្លាំងកាយចិត្ត។ ព្រះអង្គកោះហៅមនុស្សទាំងអស់ដែលអំពើបាបបានខ្ចាត់ខ្ចាយឲ្យរួមរស់ជាមួយគ្នាក្នុងក្រុមគ្រួសារតែមួយរបស់ព្រះអង្គគឺព្រះសហគមន៍។ ដល់ពេលកំណត់ព្រះអង្គក៏បានចាត់ព្រះបុត្រាព្រះអង្គជាព្រះសង្គ្រោះ ដើម្បីបំពេញគម្រោងការនេះ។ នៅក្នុងអង្គព្រះបុត្រានេះ និងដោយសារព្រះអង្គ ហើយនៅក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យទៅជាបុត្រធីតារបស់ព្រះអង្គ និងទទួលមរតកនៃព្រះជន្មប្រកបដោយសុភមង្គលរបស់ព្រះអង្គ។

២-ដើម្បីឲ្យការត្រាស់ហៅនេះលាន់ឮនៅលើផែនដីទាំងមូល ព្រះគ្រីស្តបានចាត់ក្រុមគ្រីស្តទូតដែលព្រះអង្គបានជ្រើសរើសដោយផ្តែផ្តាំឲ្យទៅប្រកាសដំណឹងល្អ៖ "ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវបង្រៀនគេឲ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ ចូរដឹងថាខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃរហូតដល់អវសានកាលនៃពិភពលោក" (មថ ២៨,១៩-២០)។ ដោយបានទទួលបេសកកម្មនេះក្រុមគ្រីស្តទូតក៏ "នាំគ្នាចេញទៅប្រកាសដំណឹងល្អនៅគ្រប់ទីកន្លែង។ ព្រះអម្ចាស់ធ្វើការរួមជាមួយគេព្រមទាំងបញ្ជាក់ព្រះបន្ទូលដោយសម្តែងទីសម្គាល់ផ្សេងៗភ្ជាប់ជាមួយផង" (មក ១៦,២០)។

៣-ដោយមានជំនួយពីព្រះជាម្ចាស់ អស់អ្នកដែលបានទទួលការត្រាស់ហៅរបស់ព្រះគ្រីស្ត ហើយក៏ស្ម័គ្រចិត្តធ្វើតាមសេចក្តីស្រឡាញ់របស់ព្រះគ្រីស្តបានជំរុញឲ្យគេទៅប្រកាសដំណឹងល្អគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល។ អ្នកបន្តមុខងារពីក្រុមគ្រីស្តទូតបានរក្សាទុកកំណប់នេះ ដោយចិត្តស្មោះត្រង់ ហើយព្រះជាម្ចាស់បានត្រាស់ហៅអស់អ្នកដែលផ្ញើជីវិតទៅលើព្រះគ្រីស្តឲ្យបញ្ជូនកំណប់នេះពីជំនាន់មួយទៅជំនាន់មួយដោយប្រកាសជំនឿ ដោយប្រតិបត្តិតាមជំនឿនេះក្នុងការចែករំលែករវាងបងប្អូន និងដោយលើកតម្កើងជំនឿនេះក្នុងពិធីបុណ្យ និងការអធិដ្ឋាន (កក ២,៤២)។

## ២-ការបញ្ជូនជំនឿ៖ ការអប់រំជំនឿ

៤-តាំងពីដើមគេហៅការអប់រំជំនឿ គឺជាការខិតខំទាំងប៉ុន្មានដែលព្រះសហគមន៍បានធ្វើដើម្បីបង្កើនសាវ័ក ដើម្បីជួយមនុស្សលោកឲ្យជឿថាព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដើម្បីឲ្យគេមានជីវិតក្នុងព្រះនាមព្រះអង្គដោយ

សារជំនឿ ហើយដើម្បីជួយអប់រំ និងប្រៀនប្រដៅគេក្នុងជីវិតនេះ និងដើម្បីកសាងព្រះកាយព្រះគ្រីស្ត (CT ១;២)។

៥-"ពេលយើងអប់រំជំនឿ គឺយើងជួយណែនាំក្មេងៗយុវជន និងមនុស្សពេញវ័យឲ្យយល់ដឹងអំពីលទ្ធិនៃគ្រីស្តសាសនាតាមរបៀបរៀបរយ និងយ៉ាងច្បាស់លាស់ដើម្បីឲ្យគេចាប់ផ្តើមស្គាល់ការរស់នៅជាគ្រីស្តបរិស័ទឲ្យបានពេញលក្ខណៈ" (CT ១៨)។

៦-ការអប់រំជំនឿទាក់ទងនឹងគោលការណ៍ខ្លះៗនៃបេសកកម្មរបស់ព្រះសហគមន៍ក្នុងការប្រកាសដំណឹងល្អដែលមានលក្ខណៈដូចការអប់រំជំនឿដែលជាការត្រៀមអប់រំជំនឿ ឬដែលបែកចេញមកពីការអប់រំជំនឿ គឺជាការប្រកាសដំណឹងល្អជាលើកទីមួយ ឬជាការទេសនាប្រៀនប្រដៅដើម្បីជំរុញឲ្យគេជឿ។ ការស្វែងរកនូវគុណសម្បត្តិដើម្បីឲ្យគេជឿបទពិសោធន៍នៃការរស់នៅជាគ្រីស្តបរិស័ទ ការប្រារព្ធនៃអគ្គសញ្ញា ការចូលរួមក្នុងព្រះសហគមន៍ និងការផ្តល់សក្ខីភាពរបស់គ្រីស្តទូត និងសាសនទូត (CT ១៨)។

៧-"ការអប់រំជំនឿទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងជីវិតទាំងស្រុងរបស់ព្រះសហគមន៍។ ព្រះសហគមន៍រីកចម្រើននៅលើផែនដី ចំនួនមនុស្សក៏កើនឡើងនៅក្នុងព្រះសហគមន៍អាស្រ័យទៅលើការអប់រំជំនឿ។ លើសពីនេះទៅទៀត ព្រះសហគមន៍លូតលាស់ និងគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ក៏អាស្រ័យទៅលើការអប់រំជំនឿផងដែរ" (CT ១៣)។

៨-ក្នុងសម័យកាលដែលព្រះសហគមន៍បានផ្លាស់ប្តូរសាជាថ្មី ក៏ជាពេលត្រូវអប់រំជំនឿកែលំអយ៉ាងខ្លាំងក្លាផងដែរ។ ដូច្នេះហើយ នៅវេលាដ៏ថ្លៃថ្លានៃគ្រូបាធ្យាយ មានលោកអភិបាលដ៏វិសុទ្ធបានខិតខំចូលរួមចំណែកយ៉ាងខ្លាំងក្នុងកិច្ចបម្រើនេះ ដូចជា សន្តៈ ស៊ីរីល នៃយេរូសាឡឹម សន្តៈ យ៉ូហាន គ្រីសូស្តូម សន្តៈ អំប្រ័រ និងសន្តៈ អូគូស្តាំង និងគ្រូបាធ្យាយជាច្រើននាក់ទៀត ដែលបានទុកស្នាដៃគំរូយ៉ាងច្រើន រហូតដល់សព្វថ្ងៃនេះ។

៩-អ្នកណែនាំអប់ជំនឿដកស្រង់គំនិតថ្មីៗជានិច្ច ក្នុងមហាសន្និបាតសកល។ មហាសន្និបាតនៅទីក្រុងត្រង់ជាគំរូគួរឲ្យកត់សម្គាល់ បានទុកការអប់រំជំនឿជាអាទិភាព ក្នុងធម្មនុញ្ញ និងក្រិត្យក្រម ហើយជាប្រភពនៃសៀវភៅអប់រំជំនឿនៃទីក្រុងរ៉ូម ដែលជាស្នាដៃដ៏សំខាន់បំផុត ជាសេចក្តីសង្ខេបអំពីលទ្ធិនៃគ្រីស្តសាសនា។ មហាសន្និបាតនេះបានជំរុញឲ្យព្រះសហគមន៍ ចាត់ចែងការអប់រំជំនឿតាមរបៀបល្អត្រឹមត្រូវជាទីបំផុត ហើយបានបណ្តាលឲ្យមានសៀវភៅអប់រំជំនឿជាច្រើនត្រូវគេបោះពុម្ពផងដែរ ដោយសារលោកអភិបាលដ៏វិសុទ្ធ និងទេវវិទូជាច្រើនរូប ដូចជាសន្តៈ សិលា កានីស៊ីយុស សន្តៈ សាល ប្ប៉រមេ សន្តៈ តូរីប៊ីយ៉ូ ឌឹម៉ូគ្រូវេយ៉ូ ឬសន្តៈ រ៉ូប៊ែរ បែលឡាមីនជាដើម ។

១០-ដូច្នេះហើយបានជាមិនត្រូវឆ្ងល់ថា បន្ទាប់ពីមហាសន្និបាតវ៉ាទីកង់ទីពីរ ដែលសម្តេចប៉ាប ប៉ូលទីប្រាំមួយចាត់ទុកជាការអប់រំជំនឿដ៏សំខាន់នៃសម័យទំនើប គេបានចាប់អារម្មណ៍អំពីការអប់រំជំនឿនៃព្រះសហគមន៍ឡើងវិញ ដូច "ក្បួនច្បាប់ទូទៅនៃការអប់រំជំនឿ" នៅឆ្នាំ១៩៧១ សិក្ខាសាលានៃសន្និបាតរបស់អស់លោកអភិបាលអំពីការប្រកាសដំណឹងល្អ (១៩៧៤) និងអំពីការអប់រំជំនឿ (១៩៧៧) លិខិតដាស់តឿនគ្រីស្តបរិស័ទ ដែលមកពីសិក្ខាសាលានោះ ដូចជា "Evangeli nuntiandi" (១៩៧៥) និង "Catechesi tradentae" (១៩៧៩) ផ្តល់សក្ខីភាព។ សិក្ខាសាលាវិសាមញ្ញនៃសន្និបាតរបស់អស់លោកអភិបាលនៅឆ្នាំ១៩៨៥ បានសុំឲ្យមានសៀវភៅអំពីលទ្ធិកាតូលិកទាំងមូល លើវិស័យជំនឿ និងសីលធម៌ផង។ សម្តេចប៉ាប យ៉ូហាន ប៉ូល ទីពីរ ក៏មានសំណូមពរនេះដែរ ដោយទទួលស្គាល់ថា "បំណងនេះស្របនឹងតម្រូវការពិតប្រាកដរបស់ព្រះសហគមន៍សកល និងព្រះសហគមន៍ភូមិភាគ"។ សម្តេចក៏បានខិតខំអស់ពីសមត្ថភាពឲ្យបំណងនៃអស់លោកអភិបាលនោះបានសម្រេច។

## ៣-គោលដៅរបស់សៀវភៅនេះ និងអ្នកទទួលសៀវភៅនេះ

១១-សៀវភៅនេះមានគោលដៅបង្ហាញតាមរបៀបរៀបរយយ៉ាងច្បាស់លាស់នូវសេចក្ដីសំខាន់ៗ និងមូលដ្ឋានគ្រឹះនៃលទ្ធិរបស់គ្រីស្តសាសនាដែលសំដៅទៅលើជំនឿផង សីលធម៌ផង ដោយមានការជួយបំភ្លឺអំពីមហាសន្និបាតវ៉ាទីកង់ទី២ និងការបញ្ញូនបន្តទាំងស្រុងនៃព្រះសហគមន៍។ សៀវភៅនេះមានប្រភពសំខាន់ៗដូចជាព្រះគម្ពីរដ៏វិសុទ្ធ គ្រូបាធ្យាយដ៏វិសុទ្ធនៃព្រះសហគមន៍ពិធីបុណ្យ និងក្រុមណែនាំព្រះសហគន៍។ យើងអាចយកសៀវភៅនេះធ្វើជាគំរូសម្រាប់អប់រំជំនឿ ឬសេចក្ដីសង្ខេបនៃជំនឿនៅក្នុងប្រទេសផ្សេងៗ។

១២-សៀវភៅនេះសម្រាប់បម្រើដល់តម្រូវការរបស់អ្នកអប់រំជំនឿ ជាពិសេសលោកអភិបាលដែលជាគ្រូបាធ្យាយនៃជំនឿ និងជាគង្វាលរបស់ព្រះសហគមន៍។ យើងផ្ដល់សៀវភៅនេះជូនពួកលោកដើម្បីទុកជាឧបករណ៍ក្នុងការប្រៀនប្រដៅប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ តាមរយៈពួកលោកអភិបាលសៀវភៅនេះមានប្រយោជន៍ចំពោះអ្នកនិពន្ធសៀវភៅអប់រំជំនឿ លោកបូជាចារ្យ និងអ្នកណែនាំអប់រំជំនឿ ព្រមទាំងគ្រីស្តបរិស័ទឯទៀតៗផងដែរ។

## ៤-រចនាសម្ព័ន្ធនៃសៀវភៅនេះ

១៣-រចនាសម្ព័ន្ធនៃសៀវភៅនេះមានដូចទំនៀមទម្លាប់បុរាណដែលរៀបចំការអប់រំជំនឿតាមបួនវគ្គ៖ ធម៌ប្រកាសជំនឿ (ធម៌ជឿ) អគ្គសញ្ញានៃជំនឿរបៀបរស់នៅរបស់អ្នកជឿ (ធម្មវិន័យ) និងការអធិដ្ឋានរបស់អ្នកជឿ (ធម៌ឱព្រះបិតា)។

### វគ្គទីមួយ៖ ធម៌ប្រកាសជំនឿ

១៤-ដោយសារជំនឿ និងពិធីជ្រមុជទឹកអស់អ្នកដែលជាកម្មសិទ្ធិរបស់ព្រះគ្រីស្តត្រូវតែប្រកាសជំនឿរបស់គេចំពោះមនុស្សលោក (មថ ១០,៣២ ;រម ១០,៩)។ សៀវភៅនេះថ្លែងអំពីព្រះជាម្ចាស់មានព្រះបន្ទូល និងប្រោសប្រទានខ្លួនព្រះអង្គឲ្យមនុស្សលោក ហើយថ្លែងអំពីជំនឿដែលជាចម្លើយរបស់មនុស្សចំពោះព្រះជាម្ចាស់ (ភាគទីមួយ)។ ធម៌ប្រកាសជំនឿជាសេចក្ដីសង្ខេបនៃព្រះអំណោយទានដែលព្រះជាម្ចាស់ប្រោសប្រទានឲ្យមនុស្សលោក ព្រះអង្គទ្រង់ជាប្រភពនៃសេចក្ដីល្អគ្រប់យ៉ាង ជាព្រះសង្គ្រោះ និងជាព្រះដែលប្រោសឲ្យបានវិសុទ្ធ។ ធម៌ប្រកាសជំនឿនេះមានបី "ជំពូក" គឺផ្ញើជីវិតទៅលើព្រះជាម្ចាស់តែមួយ៖ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ជាព្រះបង្កើតព្រះយេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះអង្គ ជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះរបស់យើង ហើយនឹងព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងព្រះសហគមន៍ដ៏វិសុទ្ធ (ភាគទីពីរ)។

### វគ្គទីពីរ៖ អគ្គសញ្ញានៃជំនឿ

១៥-វគ្គទីពីរនៃសៀវភៅនេះបរិយាយអំពីរបៀបសង្គ្រោះរបស់ព្រះជាម្ចាស់ដែលព្រះយេស៊ូគ្រីស្ត និងព្រះវិញ្ញាណដ៏វិសុទ្ធបានសម្រេចតែម្ដង ក្នុងកិច្ចការដ៏សក្ការៈនៃពិធីបុណ្យរបស់ព្រះសហគមន៍ (ភាគទីមួយ) ជាពិសេសនៅក្នុងអគ្គសញ្ញាទាំងប្រាំពីរ (ភាគទីពីរ)។

### វគ្គទីបី៖ របៀបរស់នៅរបស់អ្នកជឿ

១៦-វគ្គទីបីនៃសៀវភៅនេះថ្លែងអំពីទីចុងក្រោយរបស់មនុស្សដែលមានលក្ខណៈដូចព្រះជាម្ចាស់៖ ដើម្បីទទួលបានសុភមង្គលដ៏ពិតប្រាកដ និងផ្លូវឆ្ពោះទៅកាន់សុភមង្គលនេះ គឺត្រូវប្រព្រឹត្តកិច្ចការដោយមានចិត្តស្មោះត្រង់ និង

សេរីភាពពេញលេញ ដោយមានធម្មវិន័យ និងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ជួយផង (ភាគទីមួយ) ហើយដោយប្រព្រឹត្តកិច្ចការដែលធ្វើតាមសេចក្ដីស្រឡាញ់តាមវិន័យដប់ប្រការរបស់ព្រះជាម្ចាស់ (ភាគទីពីរ)។

### វគ្គទីបួនៈ ការអធិដ្ឋានរបស់អ្នកជឿ

១៧-វគ្គចុងក្រោយនៃសៀវភៅនេះបរិយាយអំពីអត្ថន័យ និងសារៈសំខាន់នៃការអធិដ្ឋានក្នុងការរស់នៅរបស់អ្នកជឿ (ភាគទីមួយ) ហើយទីបញ្ចប់សៀវភៅនេះផ្ដល់សេចក្ដីអធិប្បាយដ៏ខ្លីអំពីពាក្យសុំទាំងប្រាំពីរនៃការអធិដ្ឋានរបស់ព្រះអម្ចាស់ (ភាគទីពីរ)។ នៅក្នុងពាក្យសុំនោះយើងទទួលអ្វីៗដ៏ល្អដែលយើងត្រូវតែសង្ឃឹម ហើយដែលព្រះបិតារបស់យើងដែលគង់នៅស្ថានបរមសុខសព្វព្រះហឫទ័យប្រោសប្រទានមកយើង។

## ៥-ពាក្យណែនាំដើម្បីប្រើប្រាស់សៀវភៅនេះ

១៨-សៀវភៅនេះជាសេចក្ដីរាយការណ៍នៃលទ្ធិទាំងស្រុងរបស់ព្រះសហគមន៍កាតូលិក។ ដូច្នេះហើយបានជាត្រូវតែអានដោយយកចិត្តទុកដាក់នឹងឯកភាពនៃសៀវភៅនេះ។

១៩-ក្នុងកំណ្ឌខ្លះមានអត្ថបទដកស្រង់ពីព្រះគម្ពីរដ៏វិសុទ្ធ។ ត្រូវតែអានអត្ថបទនោះទាំងស្រុង ដើម្បីឈ្វេងយល់យ៉ាងច្បាស់អំពីគំនិតនៃកំណ្ឌនោះ។

២០-ក្នុងកំណ្ឌខ្លះ យើងប្រើអក្សរតូចៗ ជាកំណត់សម្គាល់ខាងប្រវត្តិសាស្ត្រ ឬដែលជួយពង្រឹងជំនឿ ឬអំពីអត្ថាធិប្បាយបន្ថែម ដើម្បីឲ្យងាយយល់អំពីលទ្ធិនៃគ្រីស្តសាសនា។

២១-មានការដកស្រង់អត្ថបទផ្សេងៗដោយប្រើអក្សរតូចៗដែលមានប្រភពមកពីបុព្វបុរស ពិធីបុណ្យផ្សេងៗ ក្រុមអ្នកដឹកនាំ ឬជីវប្រវត្តិរបស់សន្តបុគ្គល ដើម្បីបំពេញបន្ថែមទៅលើសេចក្ដីអត្ថាធិប្បាយអំពីលទ្ធិនៃគ្រីស្តសាសនាឲ្យកាន់តែក្បោះក្បាយ។ ជារឿយៗ អត្ថបទទាំងនោះត្រូវបានដកស្រង់ដើម្បីប្រើប្រាស់ក្នុងការអប់រំជំនឿ។

២២-នៅចុងបញ្ចប់នៃប្រធានបទនីមួយៗ តែងតែមានអត្ថបទយ៉ាងខ្លីៗ ដែលសង្ខេបពីអត្ថន័យសំខាន់ៗនៃការប្រៀនប្រដៅ។ សេចក្ដីសង្ខេបនោះ អាចផ្ដល់គំនិតឲ្យព្រះសហគមន៍នីមួយៗប្រើប្រាស់ដើម្បីអប់រំជំនឿ។

## ៦-ការកែសម្រួលជាចាំបាច់

២៣-សៀវភៅនេះសំដៅទៅលើលទ្ធិនៃគ្រីស្តសាសនាមានគោលដៅជួយឲ្យយល់អំពីជំនឿកាន់តែជ្រៅទៅៗ ដើម្បីឲ្យជំនឿនេះកាន់តែរីកចម្រើនចាក់ឫសនៅក្នុងជីវិត និងផ្ដល់ពន្លឺនៃសក្ខីភាព (CT ២០-២២ ; ២៥)។

២៤-ត្រូវតែកែសម្រួលសៀវភៅនេះស្របតាមវប្បធម៌សម័យកាល កម្រិតខាងវិញ្ញាណ ស្ថានភាពក្នុងសង្គម និងក្នុងព្រះសហគមន៍ដើម្បីបង្រៀនការអប់រំជំនឿដល់អ្នកស្វែងយល់។ ការកែសម្រួលជាចាំបាច់ទាំងអស់នោះ អាស្រ័យទៅលើសៀវភៅអប់រំជំនឿនីមួយៗ ជាពិសេសរបស់អ្នកណែនាំគ្រីស្តបរិស័ទ។

អ្នកបង្រៀនត្រូវតែ "ធ្វើឲ្យដូចមនុស្សទាំងអស់ក្នុងគ្រប់កាលៈទេសៈ (...) តាមគ្រប់មធ្យោបាយទាំងអស់" (១ករ ៩,២២) ដើម្បីណែនាំគេឲ្យស្គាល់ព្រះយេស៊ូគ្រីស្ត (...)។ ជាពិសេសមិនត្រូវគិតថា អ្នកទាំងនោះមានព្រលឹងវិញ្ញាណដូចៗគ្នា ហើយយកវិធីសាស្ត្របែបតែមួយដដែលៗ មកអប់រំទេ! ត្រូវគិតថា អ្នកខ្លះរួមរស់ជាមួយព្រះយេស៊ូគ្រីស្តដូចកូនក្មេងទើបនឹងកើត អ្នកខ្លះទៀតដូចក្មេងជំទង់ ហើយមានអ្នកខ្លះទៀត ជឿដូចមនុស្សពេញវ័យ (...)។ ដោយបញ្ជូនការប្រៀនប្រដៅនៃគម្រោងការដ៏អស្ចារ្យអំពីជំនឿ និងសីលធម៌ អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យ

បង្រៀន ត្រូវតែប្រើពាក្យសម្តីសមស្របទៅតាមប្រាជ្ញាស្មារតីរបស់អ្នកស្តាប់។

### សេចក្តីស្រឡាញ់លើសអ្វីៗទាំងអស់

២៥-ដើម្បីបញ្ចប់បុព្វកថានេះ គួររំឭកគោលការណ៍សំខាន់នៃសៀវភៅអប់រំជំនឿនៅទីក្រុងរ៉ូមគឺ៖

លទ្ធិ និងការប្រៀនប្រដៅមានគោលដៅត្រូវតែចូលក្រោមសេចក្តីស្រឡាញ់ដែលគ្មានទីបញ្ចប់ ដ្បិតយើងអាចរាយការណ៍អំពីអ្វីដែលត្រូវតែជឿសង្ឃឹម ឬប្រព្រឹត្ត ប៉ុន្តែយើងតែងតែត្រូវធ្វើឲ្យសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់នៃយើងលេចចេញមកដើម្បីឲ្យមនុស្សគ្រប់គ្នាយល់ថាអំពើល្អនីមួយៗដែលគ្រប់លក្ខណៈតាមគ្រីស្តសាសនាមានប្រភព និងទីចុងក្រោយតែមួយគឺសេចក្តីស្រឡាញ់ (CR)។

# វគ្គទីមួយ៖

# ធម៌ប្រកាសជំនឿ

# ភាគទីមួយៈ

# "ខ្ញុំជឿ" "យើងជឿ"

២៦-ពេលយើងប្រកាសជំនឿ យើងចាប់ផ្តើមប្រកាសថា "ខ្ញុំជឿ" ឬក៏ "យើងជឿ"។ មុននឹងរាយការណ៍អំពីជំនឿរបស់ព្រះសហគមន៍ដែលយើងប្រកាសនៅក្នុងធម៌ប្រកាសជំនឿ ដែលយើងលើកតម្កើងនៅក្នុងពិធីបុណ្យ ដែលយើងអនុវត្តន៍នៅក្នុងធម្មវិន័យ និងក្នុងការអធិដ្ឋានយើងត្រូវតែសួរខ្លួនឯងថា តើ "ជំនឿ" មានអត្ថន័យយ៉ាងដូចម្តេច? ជំនឿជាចម្លើយរបស់មនុស្សចំពោះព្រះជាម្ចាស់ដែលសម្តែងព្រះអង្គឲ្យមនុស្សស្គាល់ ដែលប្រទានព្រះអង្គឲ្យមនុស្សព្រមទាំងបំភ្លឺអស់អ្នកដែលស្វែងរកអត្ថន័យនៃដំណើរជីវិតរបស់គេ។ មនុស្សស្វែងរកព្រះជាម្ចាស់ (ជំពូកទីមួយ) ព្រះជាម្ចាស់ក៏សម្តែងព្រះអង្គឲ្យមនុស្សស្គាល់ (ជំពូកទីពីរ) ហើយមនុស្សឆ្លើយតបនឹងព្រះអង្គដោយផ្ញើជីវិតទាំងស្រុងលើព្រះអង្គ (ជំពូកទីបី)។

# ជំពូកទីមួយៈ

# មនុស្សអាចស្គាល់ព្រះជាម្ចាស់បាន

## ១-មនុស្សមានបំណងប្រាថ្នាចង់ស្គាល់ព្រះជាម្ចាស់

២៧-ក្នុងជម្រៅចិត្តគេ មនុស្សមានបំណងប្រាថ្នាចង់ស្គាល់ព្រះជាម្ចាស់ ដ្បិតព្រះជាម្ចាស់បានបង្កើតមនុស្សសម្រាប់ព្រះអង្គ។ ព្រះជាម្ចាស់តែងតែទាក់ទាញមនុស្សទៅរកព្រះអង្គ ហើយមានតែព្រះជាម្ចាស់ទេ ដែលអាចផ្តល់សេចក្តីពិត និងសេចក្តីសុខសាន្តដែលមនុស្សតែងតែស្វែងរក។

មនុស្សមានកិត្តិយសដ៏ថ្លៃថ្នូរបំផុត មកពីព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យរួបរួមជាមួយព្រះអង្គ។ តាំងពីពេលមានមនុស្សនៅលើផែនដី ព្រះអង្គអញ្ជើញមនុស្សឲ្យនិយាយសន្ទនាជាមួយព្រះអង្គ។ មនុស្សកើតមកនៅលើផែនដីមកពីព្រះជាម្ចាស់បង្កើតដោយព្រះហឫទ័យស្រឡាញ់ ហើយព្រះអង្គក៏នៅតែប្រទានឲ្យមនុស្សមានជីវិតតទៅទៀត។ មនុស្សរស់យ៉ាងពេញលក្ខណៈតាមសេចក្តីពិត លុះត្រាតែខ្លួនស្ម័គ្រចិត្តទទួលព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ និងផ្ញើជីវិតទាំងស្រុងទៅលើព្រះបង្កើតរបស់ខ្លួន។ (GS ១៩,១)

២៨-នៅក្នុងប្រវត្តិសាស្ត្រមនុស្សលោករហូតដល់សព្វថ្ងៃតាមរបៀបផ្សេងៗ ជំនឿ និងសាសនាបង្ហាញអំពីការស្វែងរករបស់មនុស្សចំពោះព្រះជាម្ចាស់ (សូត្រធម៌យញ្ញបូជាពិធីបុណ្យភាវនា។ល។) ទោះបីពាក្យអង្វរទាំងនោះមិនគ្រប់លក្ខណៈយ៉ាងណាក៏ដោយ ក៏យើងអាចសន្និដ្ឋានថាមនុស្សជា "សាសនាបុគ្គល" គឺមនុស្សចង់មានទំនាក់ទំនងជាមួយព្រះជានិច្ច។

"ព្រះជាម្ចាស់ប្រទានឲ្យប្រជាជាតិនានាកើតចេញមកពីមនុស្សតែម្នាក់ ហើយឲ្យគេរស់នៅពាសពេញលើផែនដីទាំងមូល។ ព្រះអង្គបានកំណត់រដូវកាល និងកំណត់ព្រំដែនឲ្យមនុស្សរស់នៅ។ ព្រះជាម្ចាស់ធ្វើដូច្នេះដើម្បីឲ្យគេស្វែងរកព្រះអង្គ ហើយបើគេខ្នះខ្នែងរកព្រះអង្គមែននោះ ប្រហែលជាគេនឹងរកព្រះអង្គឃើញ។ តាមពិតព្រះជាម្ចាស់មិនគង់ឆ្ងាយពីយើងម្នាក់ៗទេ ដ្បិតយើងមានជីវិតរស់ មានចលនា និងមានជាតិជាមនុស្សដោយសារព្រះអង្គ" (កក ១៧,២៦-២៨)។

២៩-ក៏ប៉ុន្តែ មនុស្សអាច "មិនយល់អំពីចំណងដ៏ស្និទ្ធស្នាលយ៉ាងជ្រៅជាមួយព្រះជាម្ចាស់ ជាចំណងផ្តល់ជីវិតឲ្យគេនេះទេ" (GS ១៩,១)។ គេអាចបំភ្លេចមិនស្គាល់ ឬបោះបង់ចោលទំនាក់ទំនងដ៏ស្និទ្ធស្នាល និងជាចាំបាច់ដែលមានជាមួយនឹងព្រះជាម្ចាស់។ មានមូលហេតុជាច្រើន (GS ១៩-២១) ដូចជាគេបះបោរទាស់នឹងសេចក្តីអាក្រក់ក្នុងពិភពលោក គេមិនដឹងមិនអើពើអំពីរឿងសាសនា ខ្វល់ខ្វាយអំពីរឿងលោកីយ៍ និងទ្រព្យសម្បត្តិ (មថ ១៣,២២) គំរូអាក្រក់របស់អ្នកជឿ គំនិតទូទៅប្រឆាំង និងសាសនាដែលមាននៅក្នុងសង្គម ហើយទីបញ្ចប់អំពើបាបរបស់មនុស្សដែលនាំឲ្យគេភ័យខ្លាចព្រះជាម្ចាស់ (កណ ៣,៨-១០) និងធ្វើឲ្យគេឃ្លាតឆ្ងាយពីព្រះអង្គ (យណ ១,៣)។

៣០-"ចូរត្រេកអរសប្បាយ អស់អ្នកដែលស្វែងរកព្រះជាម្ចាស់" (ទន ១០៥,៣)។ ទោះបីមនុស្សអាចបំភ្លេច ឬបដិសេធមិនព្រមទទួលព្រះជាម្ចាស់យ៉ាងណាក៏ដោយ ឯព្រះអង្គវិញទ្រង់ក៏តែងតែត្រាស់ហៅមនុស្សគ្រប់ៗរូបឲ្យស្វែងរកព្រះអង្គ ដើម្បីឲ្យគេមានជីវិត និងសេចក្តីសុខសាន្ត។ ប៉ុន្តែ មនុស្សត្រូវតែខិតខំអស់ពីប្រាជ្ញាស្មារតីស្វែងរកព្រះជាម្ចាស់ដោយមានចិត្តស្មោះត្រង់ និងមានចិត្តទូលាយយល់ព្រមទទួលសក្ខីភាពរបស់អ្នកជឿ។

ឱព្រះអម្ចាស់អើយ! ព្រះអង្គខ្ពង់ខ្ពស់ណាស់ គួរឲ្យលើកតម្កើងយ៉ាងក្រៃលែង។ ព្រះអង្គប្រកបដោយព្រះតេជានុភាពយ៉ាងឧត្តុងឧត្តម នឹងព្រះប្រាជ្ញាញាណរកទីបំផុតគ្មាន។ រីឯមនុស្សវិញដែលជាចំណែកតូចមួយនៃការបង្កើតរបស់ព្រះអង្គ គេមានបំណងចង់លើកតម្កើងព្រះអង្គ មនុស្សនេះហើយដែលស្ថិតនៅក្រោមអំណាចនៃសេចក្តីស្លាប់ ដែលមានអំពើបាបជាប់ខ្លួន និងជាបន្ទាល់ថា ព្រះអង្គមិនកាន់ជើងអ្នកឆ្មើងឆ្មៃទេ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សដែលជាចំណែកដ៏តូចមួយនៃការបង្កើត មានបំណងចង់លើកតម្កើងព្រះអង្គ។ សូម្បីតែព្រះអង្គ ក៏ទ្រង់ជំរុញឲ្យគេលើកតម្កើងនេះ ដោយរកឃើញពីភាពសប្បាយរីករាយក្នុងការលើកតម្កើងនេះ ដ្បិតព្រះអង្គបានបង្កើតគេ ដើម្បីព្រះអង្គ ហើយទឹកចិត្តគេមិនបានស្ងប់ទេ ដរាបណាបានសម្រាកនៅក្នុងអង្គព្រះអង្គ។

## ២-ផ្លូវផ្សេងៗដើម្បីស្គាល់ព្រះជាម្ចាស់

៣១-ព្រះជាម្ចាស់បានបង្កើតមនុស្សជារូបតំណាងរបស់ព្រះអង្គ ដើម្បីឲ្យគេស្គាល់ និងស្រឡាញ់ព្រះអង្គ។ មនុស្សដែលស្វែងរកព្រះជាម្ចាស់មាន "ផ្លូវ" ខ្លះដើម្បីស្គាល់ព្រះអង្គបាន។ គេហៅផ្លូវនោះថា "ភស្តុតាងនៃព្រះជាម្ចាស់"។ តាមការពិតផ្លូវនោះមិនមែនជាភស្តុតាងតាមវិទ្យាសាស្ត្រទេ គ្រាន់តែជាទីសម្គាល់អាចនាំឲ្យមានជំនឿយ៉ាងជាក់ច្បាស់បាន។

"ផ្លូវ" ទៅរកព្រះជាម្ចាស់មានពីរ គឺពិភពលោក និងមនុស្ស។

៣២-ពិភពលោក៖ យើងអាចស្គាល់ព្រះជាម្ចាស់ជាប្រភព និងទីបញ្ចប់នៃសកលលោកដោយរិះគិតអំពីចលនាការប្រែប្រួលអនិមិត្តសណ្តាប់ធ្នាប់ និងសោភណភាពនៃពិភពលោក។

សន្ត: ប៉ូល មានប្រសាសន៍អំពីសាសន៍ដទៃថា៖ "អ្វីៗដែលមនុស្សលោកអាចស្គាល់អំពីព្រះជាម្ចាស់បាននោះមានជាក់ច្បាស់ក្នុងចំណោមពួកគេ ហើយព្រោះព្រះអង្គបានសម្តែងឲ្យគេឃើញ។ លក្ខណៈដ៏ប្រសើរបំផុតរបស់ព្រះអង្គដែលមនុស្សមើលពុំឃើញ គឺឫទ្ធានុភាពដែលស្ថិតស្ថេរអស់កល្បជានិច្ចក្តី ឬឋានៈរបស់ព្រះអង្គជាព្រះជាម្ចាស់ក្តី ព្រះអង្គបានសម្តែងឲ្យគេឃើញតាំងពីកំណើតពិភពលោកមកម្ល៉េះ នៅពេលដែលគេរិះគិតអំពីស្នាព្រះហស្តរបស់ព្រះអង្គ" (រម ១,១៩-២០) (កក ១៤,១៥.១៧; ១៧,២៧-២៨; ប្រាញ ១៣,១-៩)។

ចំណែកឯសន្ត: អូគូស្តាំង មានប្រសាសន៍ថា "ចូរអ្នកសួរទៅសោភណភាពនៃផែនដី សោភណភាពនៃសមុទ្រ សោភណភាពនៃអាកាស ដែលពង្រីកខ្លួន និងផ្សព្វផ្សាយ សួរទៅសោភណភាពនៃមេឃ (...) សួរទៅការទាំងអស់នោះទៅ ហើយពួកអ្នកនោះឆ្លើយថា៖ អ្នកឃើញទេ ពួកយើងពិតជាស្រស់ស្អាតណាស់។ សោភណរបស់ពួកគេ

គឺជាការប្រកាសមួយ (confessio)។ សោភណភាពនោះស្ថិតនៅក្រោមអំណាចនៃការផ្លាស់ប្តូរប្រែប្រួល តើនរណាបានធ្វើពួកគេ បើមិនព្រះជាម្ចាស់ជាប្រភពនៃសោភណភាព (Pulcher) ដែលមិនចេះប្រែប្រួលទេឬ?"។

៣៣-មនុស្ស៖ មនុស្សអាចទទួលស្គាល់សេចក្តីពិត និងសោភណភាព អាចស្គាល់អ្វីល្អមានសីលធម៌ សេរីភាព និងមនសិការ ហើយគេចង់បានជីវិតដែលគ្មានព្រំដែន និងសេចក្តីសុខសាន្ត ទើបគេសួរខ្លួនឯងអំពីព្រះជាម្ចាស់។ គេអាចយល់ឃើញថាអ្វីៗទាំងអស់នោះបង្ហាញបញ្ជាក់អំពីឋានៈនៃព្រលឹងវិញ្ញាណរបស់គេ។ មនុស្ស "មានពូជនៃជីវិតអស់កល្បជានិច្ចកប់ក្នុងខ្លួន ពូជនៃជីវិតនេះមិនគ្រាន់តែកើតតាមធម្មជាតិទេ" (GS ១៨,១; ១៤,២) មានតែព្រះជាម្ចាស់ទេជាប្រភពនៃព្រលឹងរបស់មនុស្ស។

៣៤-ពិភពលោក និងមនុស្សមិនមែនជាប្រភព និងទីបញ្ចប់នៃអ្វីៗទាំងអស់ទេ តែចូលរួមចំណែករួមនឹងសភាវៈដែលគ្មានដើមកំណើត និងគ្មានកំណត់ឡើយ។ ដូច្នេះហើយបានជាតាមរយៈ "ផ្លូវ" ផ្សេងៗនោះមនុស្សអាចស្គាល់នូវអ្វីដែលជាដើមហេតុ និងជាចុងក្រោយបំផុតនៃអ្វីៗទាំងអស់ "ហើយដែលគេទាំងអស់គ្នាហៅថាព្រះជាម្ចាស់" (សន្តៈ ថូម៉ាសនៃអាកាំង)។

៣៥-សមត្ថភាពរបស់មនុស្សនាំឲ្យគេអាចដឹងថា មានព្រះជាម្ចាស់។ ប៉ុន្តែ ដើម្បីឲ្យមនុស្សអាចស្គាល់ព្រះជាម្ចាស់យ៉ាងស្និទ្ធស្នាលបាន ព្រះអង្គក៏សព្វព្រះហឫទ័យសម្តែងព្រះអង្គឲ្យគេស្គាល់ព្រមទាំងប្រោសប្រណីឲ្យគេអាចទទួលការសម្តែងនេះដោយសារជំនឿ។ ក៏ប៉ុន្តែ "ភស្តុតាង" នៃព្រះជាម្ចាស់អាចរៀបចំចិត្តគំនិតមនុស្សឲ្យមានជំនឿ និងឲ្យយល់ថា ជំនឿមិនប្រឆាំងនឹងប្រាជ្ញារបស់មនុស្សឡើយ។

## ៣-តាមព្រះសហគមន៍ មនុស្សអាចស្គាល់ព្រះជាម្ចាស់បាន

៣៦-"ព្រះសហគមន៍ដ៏វិសុទ្ធដែលជាមាតារបស់យើងអះអាង និងបង្រៀនថា "ដោយសារពន្លឺនៃប្រាជ្ញារបស់ខ្លួនមនុស្សមានសមត្ថភាពអាចស្គាល់ព្រះជាម្ចាស់យ៉ាងជាក់ច្បាស់ ទ្រង់ដែលជាដើមកំណើត និងជាចុងបំផុតនៃអ្វីៗទាំងអស់តាមរយៈសត្វលោកដែលព្រះអង្គបានបង្កើតមក" (វ៉ាទីកង់ទី១ DS ៣០០៤; ៣០២៦; DV ៦)។ បើមនុស្សគ្មានសមត្ថភាពនេះទេ គេនឹងមិនអាចទទួលព្រះជាម្ចាស់ដែលសម្តែងព្រះអង្គបានឡើយ។ មនុស្សមានសមត្ថភាពអាចស្គាល់ព្រះជាម្ចាស់បាន ពីព្រោះគេមាន "លក្ខណៈដូចព្រះជាម្ចាស់"។

៣៧-ប៉ុន្តែដោយសារលក្ខណៈផ្សេងៗរបស់គេ មនុស្សមានការលំបាកស្គាល់ព្រះជាម្ចាស់ដោយប្រើប្រាស់តែពន្លឺនៃប្រាជ្ញារបស់ខ្លួន។

ទោះជាដោយសារកម្លាំង និងពន្លឺដែលមកពីធម្មជាតិ ប្រាជ្ញារបស់មនុស្សលោកអាចឈានទៅដល់ការស្គាល់ដ៏ពិតប្រាកដ និងច្បាស់ៗនៃព្រះមួយអង្គ ដែលការពារ និងគ្រប់គ្រងពិភពលោក ដោយឧបការគុណរបស់ព្រះអង្គ ហើយនឹងអាចស្គាល់ច្បាប់ធម្មជាតិ ដែលជាព្រះអំណោយទានរបស់ព្រះបង្កើតនៅក្នុងព្រលឹងរបស់យើងយ៉ាងណាក៏ដោយ ក៏ប៉ុន្តែមានឧបសគ្គជាច្រើន ដែលរារាំងប្រាជ្ញានេះ មិនអាចប្រើប្រាស់យ៉ាងស័ក្តិសិទ្ធ និងដោយបង្កើតផលអនុភាពនៃធម្មជាតិរបស់ខ្លួន ពីព្រោះសេចក្តីពិត ដែលទាក់ទងនឹងព្រះជាម្ចាស់ និងមនុស្សលោក ហួសធម្មជាតិ ហើយត្រូវផ្តល់ និងលះបង់ខ្លួន ដើម្បីយល់ពីសេចក្តីពិតនេះ និងប្រតិបត្តិតាម។ ដើម្បីបានទទួលសេចក្តីពិតទាំងនោះ ស្មារតីមនុស្សរងនូវទុក្ខលំបាកពីវិញ្ញាណទាំងអស់ ភាពស្រមើស្រមៃ និងពីបំណងអាក្រក់ ដែលមកពីអំពើបាបដើម។ ហេតុដូច្នេះហើយបានជាមនុស្សងាយយល់ដល់ភាពក្លែងក្លាយ ឬភាពមិនពិតប្រាកដនៃអ្វីៗដែលពួកគេមិនចង់ឲ្យទៅជាពិតប្រាកដ (សម្តេចប៉ាប ពីយូសទី១២ ; DS ៣៨៧៥)។

៣៨-អាស្រ័យហេតុនេះហើយបានជាព្រះជាម្ចាស់ត្រូវតែសម្ដែងព្រះអង្គ ដើម្បីបំភ្លឺមនុស្សមិនគ្រាន់តែអំពីអ្វីដែលហួសប្រាជ្ញារបស់គេប៉ុណ្ណោះទេ ថែមទាំងអំពី "សេចក្ដីពិតខាងសាសនា និងខាងសីលធម៌ដែលប្រាជ្ញាមនុស្សមិនអាចយល់បានទេ ដើម្បីឱ្យមនុស្សទាំងអស់អាចស្គាល់សេចក្ដីទាំងអស់នោះដោយគ្មានការលំបាកយ៉ាងច្បាស់លាស់ និងដោយគ្មានការភ័ន្តច្រឡំឡើយ" (DS ៣៨៧៦; វ៉ាទីកង់ទី១ DS ៣០០៥; DV ៦; សន្ដ: ថូម៉ាសនៃអាកាំង)។

## ៤-តើត្រូវនិយាយយ៉ាងដូចម្ដេចអំពីព្រះជាម្ចាស់?

៣៩-ព្រះសហគមន៍អះអាងថាប្រាជ្ញាមនុស្សអាចស្គាល់ព្រះជាម្ចាស់បាន ទើបព្រះសហគមន៍ជឿជាក់ថា អាចនិយាយអំពីព្រះជាម្ចាស់ដល់មនុស្សទាំងអស់។ ការជឿជាក់នេះនាំឱ្យព្រះសហគមន៍អាចមានទំនាក់ទំនងជាមួយនឹងសាសនាដទៃ ទស្សនវិជ្ជា និងវិទ្យាសាស្ត្រថែមទាំងជាមួយមនុស្សដែលគ្មានជំនឿផងដែរ។

៤០-ដោយសារយើងមិនអាចស្គាល់ព្រះជាម្ចាស់ទាំងស្រុងបានទេ ពាក្យសម្ដីរបស់យើងអំពីព្រះជាម្ចាស់ក៏មានព្រំដែនដែរ។ ដូច្នេះយើងអាចនិយាយអំពីព្រះជាម្ចាស់តាមរយៈសត្វលោក និងតាមការយល់ដឹង និងការគិតពិចារណារបស់យើងតែប៉ុណ្ណោះ។

៤១-សត្វលោកទាំងឡាយមានលក្ខណៈម្យ៉ាងដូចព្រះជាម្ចាស់ ជាពិសេសមនុស្សដែលជាតំណាង និងមានលក្ខណៈដូចព្រះអង្គ។ លក្ខណៈផ្សេងៗ និងល្អៗនៃសត្វលោក (សេចក្ដីពិតសប្បុរសធម៌ និងសោភណភាព) ឆ្លុះបញ្ចាំងអំពីលក្ខណៈដ៏ល្អឥតខ្ចោះ ឥតព្រំដែនរបស់ព្រះជាម្ចាស់។ ដូច្នេះហើយបានជាយើងអាចនិយាយអំពីព្រះជាម្ចាស់តាមលក្ខណៈល្អៗនៃសត្វលោក ដ្បិត "ភាពថ្កុំថ្កើង និងសម្រស់របស់សត្វលោកនាំមនុស្សសញ្ជឹងគិតដោយការប្រៀបធៀបអំពីព្រះអង្គដែលបានបង្កើតសត្វលោកទាំងអស់" (ប្រាញ ១៣,៥)។

៤២-ព្រះជាម្ចាស់ខុសប្លែក និងហួសសត្វលោកទាំងអស់។ ដូច្នេះត្រូវតែបន្សុទ្ធពាក្យសម្ដីរបស់យើងដែលមានព្រំដែន ដែលប្រើនិមិត្តរូប និងដែលមិនគ្រប់លក្ខណៈកុំឱ្យយើងច្រឡំនឹងព្រះដ៏វិសុទ្ធបំផុត "ដែលយើងមិនអាចយល់ ដែលយើងមិនអាចមើលឃើញ ហើយដែលយើងមិនអាចគ្រប់គ្រងបានឡើយ" (សន្ដ: យ៉ូហានគ្រីសូស្ដូម) ជាមួយនឹងការយល់ដឹងរបស់យើង។ ពាក្យសម្ដីយើងតែងតែស្ថិតនៅក្រោមអាថ៌កំបាំងរបស់ព្រះជាម្ចាស់។

៤៣-ទោះបីពាក្យសម្ដីយើងមានព្រំដែនក្ដី ក៏យើងអាចនិយាយអំពីព្រះជាម្ចាស់ម្យ៉ាងដែរ។ យើងអាចប្រៀបធៀបសត្វលោកនឹងព្រះជាម្ចាស់មែនតែត្រូវរំឭកថា ព្រះជាម្ចាស់មានលក្ខណៈខុសពីសត្វលោកឆ្ងាយណាស់ (ឡាត្រង់ទី៤) ហើយយើងមិនដែលអាចយល់អំពីព្រះជាម្ចាស់ទាំងស្រុងនោះបានទេ (សន្ដ: ថូម៉ាសនៃអាកាំង)។

## សង្ខេប

៤៤-មនុស្សមានលក្ខណៈ និងទីដៅជាសាសនាបុគ្គល។ គេអាចទៅជាមនុស្សដ៏ពេញលក្ខណៈបាន លុះត្រាតែគេស្ម័គ្រចិត្តមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដោយព្រះអង្គជាព្រះបង្កើតគេ ដូច្នេះគេត្រូវត្រឡប់ទៅរកព្រះអង្គវិញ។

៤៥-ព្រះជាម្ចាស់បានបង្កើតមនុស្ស ដើម្បីឱ្យគេរួបរួមជាមួយព្រះអង្គ ដែលជាសុភមង្គលរបស់គេ៖ "កាលណាខ្ញុំនឹងនៅក្នុងអង្គព្រះអង្គទាំងស្រុង ពេលនោះ ខ្ញុំនឹងលែងមានទុក្ខ និងឧបសគ្គជីវិតរបស់ខ្ញុំនឹងបានពោរពេញទៅដោយព្រះអង្គ ហើយជីវិតខ្ញុំនឹងបានពេញលក្ខណៈ" (សន្ដ: អូគូស្តាំង)។

៤៦-នៅពេលដែលគេស្ដាប់សាររបស់សត្វលោក និងសម្លេងនៃមនសិការរបស់ខ្លួន មនុស្សអាចដឹងច្បាស់ថាពិតជាមានព្រះជាម្ចាស់ ដែលជាដើមហេតុ និងគោលដៅនៃអ្វីៗទាំងអស់។

៤៧-ព្រះសហគមន៍ប្រៀនប្រដៅថា ដោយសារពន្លឺនៃប្រាជ្ញារបស់មនុស្ស សត្វលោកអាចស្គាល់យ៉ាងច្បាស់ថា ព្រះដ៏ពិតប្រាកដមានតែមួយ ដែលជាព្រះបង្កើត និងព្រះអម្ចាស់នៃយើង (មហាសន្និបាតវ៉ាទីកង់ទី១៖ DS ៣០២៦)។

៤៨-ទោះបីជាពាក្យសម្ដីដ៏មានកំណត់របស់យើងមិនអាចថ្លែងអាថ៌កំបាំងរបស់ព្រះអង្គបានឡើយ ក៏យើងពិតជាអាចហៅព្រះជាម្ចាស់ ចាប់តាំងពីលក្ខណៈល្អៗនៃសត្វលោក ដែលស្រដៀងនឹងព្រះដ៏ល្អឥតខ្ចោះគ្មានព្រំដែន។

៤៩-"ប្រសិនបើគ្មានអ្នកបង្កើតទេ ក៏គ្មានសត្វលោកទៀត" (GS ៣៦)។ ហេតុនេះហើយបានជាអ្នកជឿដឹងថា សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ដជំរុញពួកគេឲ្យនាំពន្លឺនៃព្រះដ៏មានព្រះជន្មគង់នៅ ឲ្យបំភ្លឺដល់អស់អ្នកដែលមិនស្គាល់ ឬអ្នកបដិសេធព្រះអង្គ។

## ជំពូកទីពីរ៖

## ព្រះជាម្ចាស់យាងមករកមនុស្ស

៥០-ដោយសារប្រាជ្ញារបស់គេ មនុស្សអាចស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់លាស់ ពេលនឹកសញ្ជឹងអំពីស្នាព្រះហស្ដរបស់ព្រះអង្គ។ ប៉ុន្តែមនុស្សមិនអាចស្គាល់ព្រះដ៏ពិតប្រាកដដោយខ្លួនឯងបានទេ គឺគេត្រូវការឲ្យព្រះជាម្ចាស់សម្ដែងព្រះអង្គ។ ព្រះជាម្ចាស់សម្ដែងព្រះអង្គឲ្យមនុស្សស្គាល់ដោយគ្មានអ្វី ឬគ្មាននរណាបង្ខិតបង្ខំ។ ព្រះជាម្ចាស់សម្ដែងអាថ៌កំបាំងរបស់ព្រះអង្គ និងគម្រោងការដ៏សប្បុរសដែលទ្រង់បានរៀបចំទុកជាមុនក្នុងអង្គព្រះគ្រីស្ដ ចំពោះមនុស្សលោកទាំងអស់។ ព្រះអង្គសម្ដែងគម្រោងការដោយចាត់ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គឲ្យយាងមក គឺព្រះអម្ចាស់យេស៊ូគ្រីស្ដ ហើយដោយចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមកផងដែរ។

## ប្រការទី១៖

## ព្រះជាម្ចាស់សម្ដែងព្រះអង្គឲ្យមនុស្សលោកស្គាល់

### ១-ព្រះជាម្ចាស់សម្ដែង "គម្រោងការដ៏សប្បុរស" របស់ព្រះអង្គ

៥១-"ព្រះជាម្ចាស់ប្រកបដោយព្រះប្រាជ្ញាញាណ និងដោយព្រះហឫទ័យសប្បុរស ទ្រង់សព្វព្រះហឫទ័យសម្ដែងព្រះអង្គផ្ទាល់ និងសម្ដែងគម្រោងការដ៏អស្ចារ្យនៃព្រះហឫទ័យរបស់ព្រះអង្គឲ្យមនុស្សលោកស្គាល់។ តាមគម្រោងការនេះ មនុស្សលោកអាចចូលទៅកាន់ព្រះបិតាបានដោយសារព្រះគ្រីស្ដជាព្រះបន្ទូលប្រសូតជាមនុស្ស និងដោយរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង មនុស្សក៏រួមចំណែកក្នុងសភាពរបស់ព្រះជាម្ចាស់ផ្ទាល់ដែរ" (DV ២)។

៥២-ព្រះជាម្ចាស់ "ដែលគង់នៅក្នុងពន្លឺដែលគ្មាននរណាអាចចូលជិតបានឡើយ" (១ធម ៦.១៦) ហើយដែលបានស្ម័គ្រចិត្តបង្កើតមនុស្ស ទ្រង់សព្វព្រះហឫទ័យឲ្យគេទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គ ដើម្បីឲ្យគេទៅជាបុត្រធីតារបស់ព្រះអង្គនៅក្នុងអង្គព្រះបុត្រាតែមួយរបស់ព្រះអង្គ។ ដោយសម្ដែងព្រះអង្គ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សអាចឆ្លើយតបនឹងព្រះអង្គ ស្គាល់ហើយស្រឡាញ់ព្រះអង្គលើសពីសមត្ថភាពរបស់គេថែមទៀតផង។

៥៣-ព្រះជាម្ចាស់ចាត់ចែងការសម្ដែងនេះ "ដោយសារព្រឹត្តិការណ៍ និងព្រះបន្ទូលដែលភ្ជាប់ជាមួយគ្នាយ៉ាងជិតស្និទ្ធដែលបំភ្លឺគ្នាទៅវិញទៅមក" (DV ២)។ ព្រះអង្គក៏ប្រើប្រាស់ "គរុកោសល្យ" ដ៏ពិសេស គឺព្រះជាម្ចាស់ប្រោសប្រទានព្រះអង្គឲ្យមនុស្សជាលំដាប់លំដោយ ព្រះអង្គក៏រៀបចំគេឲ្យទទួលព្រះអង្គដែលសម្ដែងព្រះអង្គផ្ទាល់តាមដំណាក់

កាលនីមួយៗរហូតដល់ព្រះយេស៊ូគ្រីស្តជាព្រះបន្ទូលប្រសូតជាមនុស្ស។

សន្តៈ អ៊ីរ៉េណេ នៃទីក្រុងលីយ៉ុង មានប្រសាសន៍ជាញឹកញាប់ថា គរុកោសល្យនៃព្រះជាម្ចាស់នេះស្ថិតនៅក្រោមរូបភាពជាទម្លាប់ស្និទ្ធស្នាលរវាងព្រះជាម្ចាស់ និងមនុស្ស៖ "ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានតាំងទីលំនៅនៅក្នុងខ្លួនមនុស្ស ហើយបានទៅជាបុត្រមនុស្ស ដើម្បីឲ្យមនុស្សធ្លាប់នឹងព្រះជាម្ចាស់ ហើយដើម្បីឲ្យព្រះជាម្ចាស់ធ្លាប់នឹងស្ថិតនៅក្នុងមនុស្ស តាមព្រះហឫទ័យរបស់ព្រះបិតា"។

## ២-ព្រះជាម្ចាស់សម្តែងព្រះអង្គជាលំដាប់លំដោយ

### ព្រះជាម្ចាស់សម្តែងព្រះអង្គតាំងពីដើមរៀងមក

៥៤-"ព្រះជាម្ចាស់ដែលបង្កើត និងថែរក្សាអ្វីៗទាំងអស់បានគង់វង្សដោយសារព្រះបន្ទូលព្រះអង្គប្រទានសក្ខីភាពមិនឈប់ឈរអំពីព្រះអង្គចំពោះសត្វលោកទាំងអស់ដែលព្រះអង្គបានបង្កើតមកនោះ។ ដោយព្រះអង្គសព្វព្រះហឫទ័យបើកមាគ៌ានៃការសង្គ្រោះដ៏មានកម្រិតខ្ពស់ ទើបទ្រង់បានសម្តែងព្រះអង្គផ្ទាល់តាំងពីដើមដំបូងបង្អស់ឲ្យឪពុកម្តាយដើមស្គាល់" (DV ៣)។ ព្រះអង្គបានអញ្ជើញគេឲ្យរួមជាមួយព្រះអង្គយ៉ាងស្និទ្ធស្នាល ដោយប្រោសប្រណីឲ្យគេបានសុចរិត។

៥៥-ទោះបីឪពុកម្តាយដើមបានប្រព្រឹត្តអំពើបាបយ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់នៅតែសម្តែងព្រះអង្គឲ្យគេស្គាល់។ "បន្ទាប់ពីឪពុកម្តាយដើមបានប្រព្រឹត្តអំពើបាប ព្រះអង្គប្រោសឲ្យគេងើបឡើងវិញ ដោយមានព្រះបន្ទូលសន្យាថានឹងរំដោះគេដើម្បីឲ្យគេមានសេចក្តីសង្ឃឹមថានឹងទទួលការសង្គ្រោះ។ ព្រះអង្គនៅតែថែទាំមនុស្សជាតិឥតឈប់ឈរ ដើម្បីប្រោសប្រទានជីវិតអស់កល្បជានិច្ចដល់អស់អ្នកដែលស្វែងរកការសង្គ្រោះនេះ ដោយព្យាយាមប្រព្រឹត្តអំពើល្អ" (DV ៣)។

"ទោះបីមនុស្សលោកបានផ្តាច់ចំណងមេត្រីភាពជាមួយព្រះអង្គ ដោយមិនព្រមគោរពតាមព្រះបញ្ញារបស់ព្រះអង្គក៏ដោយ ក៏ទ្រង់នៅតែមិនបណ្តោយឲ្យមនុស្សលោកស្ថិតនៅក្រោមអំណាចនៃសេចក្តីស្លាប់ឡើយ (...)។ ជាច្រើនលើកច្រើនគ្រាព្រះអង្គចងសម្ព័ន្ធមេត្រីជាមួយមនុស្សលោក" (MR ធម៌អរព្រះគុណទី៤)។

### ព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីជាមួយលោកណូអេ

៥៦-នៅពេលដែលអំពើបាបបានធ្វើឲ្យឯកភាពមនុស្សជាតិបាក់បែកគ្នារួចហើយ ព្រះជាម្ចាស់ព្យាយាមសង្គ្រោះមនុស្សលោកដោយសង្គ្រោះភាគីនីមួយៗ។ ក្រោយពីទឹកជំនន់ (កណ ៩,៩) ព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីជាមួយលោក ណូអេ ដើម្បីបង្ហាញថាព្រះជាម្ចាស់ចាត់ចែងការសម្តែងឲ្យ "សាសន៍ដទៃ" គឺមនុស្សទាំងអស់ "ដែលរស់នៅតាមតំបន់ឆ្នេរសមុទ្របែកចេញជាស្រុក តាមភាសា និងបែកចេញជាជាតិសាសន៍តាមពូជអំបូររៀងៗខ្លួន" (កណ ១០,៥) (កណ ១០,២០-៣១)។

៥៧-ព្រះជាម្ចាស់បានបំបែកមនុស្សលោកឲ្យចេញពីគ្នាតាមជាតិសាសន៍ និងសាសនានានាដែលព្រះអង្គបានប្រគល់ឲ្យទេវទូតរក្សាទុក (ទក ៤,១៩; ៣២,៨) កុំឲ្យមនុស្សលោកដែលរួមគ្នាក្នុងការប្រព្រឹត្តអំពើបាប (ប្រាញ ១០,៥) អួតបំប៉ោង និងប្រមូលផ្តុំគ្នាជាធ្លុងតែមួយដោយពឹងលើខ្លួនឯង ដូចនៅក្នុងរឿងប្រាសាទនៅទីក្រុងបាបិល (កណ ១១,៤-៦)។ ប៉ុន្តែ អំពើបាប (រម ១,១៨-២៥) តែងតែអាចនាំឲ្យមនុស្សលោកជឿលើព្រះក្លែងក្លាយ ឬភ្លើតភ្លើននឹងប្រទេសជាតិ និងអ្នកគ្រប់គ្រងនៃប្រទេសរបស់ខ្លួនផងដែរ។

៥៨-ព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីជាមួយលោក ណូអេ រហូតដល់ពេលកំណត់នៃជាតិសាសន៍នានា (លក ២១,២៤) គឺរហូតដល់ព្រះសហគមន៍ប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់។ ព្រះគម្ពីរគោរពជាតិសាសន៍ដទៃខ្លះផងដែរ ដូចជា "លោក អេបិល ជាមនុស្សសុចរិត" "ព្រះបាទ មែលគីសេដែក ជាបូជាចារ្យ" (កណ ១៤,១៨) ដែលជារូបដំណាងរបស់ព្រះគ្រីស្ត (ហប ៧.១៣) ឬមនុស្សសុចរិតដូចជា "លោក ណូអេ លោក ដានីអែល និងលោក យ៉ូប" (អគ ១៤,១៤)។ ដូច្នេះព្រះគម្ពីរបង្ហាញថាអ្នកដែលរស់នៅស្របតាមសម្ព័ន្ធមេត្រីរបស់លោក ណូអេ ហើយដែលកំពុងរង់ចាំឲ្យព្រះគ្រីស្ត "បង្រួបបង្រួមជាធ្លុងតែមួយ កូនចៅរបស់ព្រះជាម្ចាស់ដែលបែកខ្ញែកគ្នា" (យហ ១១,៥២) អាចទៅជាសន្តៈបុគ្គលដ៏ប្រសើរផងដែរ។

## ព្រះជាម្ចាស់ត្រាស់ហៅលោកអបាប្រាំ

៥៩-ដើម្បីបង្រួបបង្រួមជាធ្លុងតែមួយមនុស្សលោកដែលបែកខ្ញែកគ្នានេះ ព្រះជាម្ចាស់ត្រាស់ហៅលោក អបាប្រាំ ឲ្យ "ចាកចេញពីស្រុករបស់អ្នកចាកចេញពីញាតិសន្តាន និងចាកចេញពីក្រុមគ្រួសារឪពុករបស់លោក" (កណ ១២,១) ដើម្បីឲ្យលោក អបាប្រាំ ទៅជា "ឪពុកនៃប្រជាជាតិដ៏ច្រើន" (កណ ១៧,៥) គឺ "ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងទទួលពរដោយសារលោក" (កណ ១២,៣) (កាឡ ៣.៨)។

៦០-ប្រជារាស្ត្រដែលនឹងចេញមកពីលោក អប្រាហាំ នឹងទទួលព្រះបន្ទូលសន្យាដែលព្រះជាម្ចាស់បានប្រោសប្រទានឲ្យបុព្វបុរស ជាប្រជារាស្ត្រដែលព្រះអង្គបានជ្រើសរើស (រម ១១.២៨) ហើយដែលទ្រង់ត្រាស់ហៅកូនចៅរបស់ព្រះអង្គ ដើម្បីបង្រួបបង្រួមនៅថ្ងៃណាមួយក្នុងឯកភាពនៃព្រះសហគមន៍ (យហ ១១,៥២; ១០,១៦)។ ប្រជារាស្ត្រនេះនឹងទៅជាឫសគល់ដែលព្រះជាម្ចាស់នឹងផ្សាំសាសន៍ដទៃ ដែលនឹងបានក្លាយទៅជាអ្នកជឿ (រម ១១,១៧-១៨.២៤)។

៦១-ពិធីបុណ្យទាំងឡាយនៃព្រះសហគមន៍តែងតែគោរពបុព្វបុរសអស់លោកព្យាការី និងបុគ្គលផ្សេងៗទៀតនៃសម្ព័ន្ធមេត្រីចាស់ និងចាត់ទុកពួកលោកជាសន្តបុគ្គលផងដែរ។

## ព្រះជាម្ចាស់អប់រំប្រជារាស្ត្រអ៊ីស្រាអែល

៦២-បន្ទាប់ពីបុព្វបុរស ព្រះជាម្ចាស់អប់រំជនជាតិអ៊ីស្រាអែលឲ្យទៅជាប្រជារាស្ត្ររបស់ព្រះអង្គដោយសង្គ្រោះគេឲ្យរួចផុតពីភាពជាទាសករនៅប្រទេសអេស៊ីប។ ព្រះអង្គបានចងសម្ព័ន្ធមេត្រីជាមួយគេនៅលើភ្នំស៊ីណៃ ហើយតាមរយៈលោក ម៉ូសេ ទ្រង់ក៏បានប្រោសប្រទានធម្មវិន័យរបស់ព្រះអង្គ ដើម្បីឲ្យគេស្គាល់ និងបម្រើព្រះអង្គជាព្រះតែមួយយ៉ាងពិតប្រាកដ ដែលមានព្រះជន្មគង់នៅជាព្រះបិតាដ៏សប្បុរស និងជាចៅក្រមដ៏សុចរិត ហើយដើម្បីឲ្យគេរង់ចាំព្រះសង្គ្រោះដែលព្រះជាម្ចាស់បានសន្យានឹងប្រោសប្រទាន (DV ៣)។

៦៣-ជនជាតិអ៊ីស្រាអែលជាក្រុមបូជាចារ្យរបស់ព្រះជាម្ចាស់ (សរ ១៩,៦) ជា "ប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់" (ទក ២៨,១០) ហើយជាប្រជារាស្ត្រដែលព្រះជាម្ចាស់មានព្រះបន្ទូលមុនគេបង្អស់ និងជាប្រជារាស្ត្រនៃ "រៀមច្បង" ក្នុងជំនឿរបស់លោក អប្រាហាំ។

៦៤-តាមរយៈពួកព្យាការីព្រះជាម្ចាស់អប់រំប្រជារាស្ត្ររបស់ព្រះអង្គឲ្យគេសង្ឃឹមថានឹងទទួលការសង្គ្រោះ ហើយឲ្យគេរង់ចាំសម្ព័ន្ធមេត្រីថ្មី និងអស់កល្បជានិច្ចសម្រាប់មនុស្សលោកទាំងអស់ (អស ២,២-៤) ដែលព្រះអង្គនឹងឆ្លាក់នៅក្នុងចិត្ត (យរ ៣១,៣១-៣៤; ហប ១០,១៦)។ ពួកព្យាការីប្រកាសថាព្រះជាម្ចាស់នឹងសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គយ៉ាងដាច់ស្រឡះ បន្សុទ្ធគេអំពីអំពើផិតក្បត់ទាំងឡាយ (អគ ៣៦) ព្រមទាំងសង្គ្រោះគ្រប់ជាតិគ្រប់

សាសន៍ផងដែរ (អស ៤៩,៥-៦; ៥៣,១១)។ ជាពិសេសជនក្រីក្រ និងអ្នកតូចតាចរបស់ព្រះអម្ចាស់ជាអ្នកសង្ឃឹមលើការសង្គ្រោះនេះ (សផ ២,៣)។ ស្ត្រីដ៏វិសុទ្ធដូចជានាង សារ៉ា នាង រេបេកា នាង រ៉ាខែល នាង មីរីយ៉ាម នាងដេបូរ៉ា នាង ហណ្ណា នាង យូឌីត និងនាង អេសធែរ បានសង្ឃឹមជានិច្ចថាព្រះជាម្ចាស់នឹងសង្គ្រោះប្រជារាស្ត្រអ៊ីស្រាអែល។ នៅក្នុងចំណោមពួកនាងព្រះនាងម៉ារីជាស្ត្រីដ៏ល្អវិសុទ្ធបំផុត។

## ៣-ព្រះគ្រីស្តយេស៊ូ "ជាស្ពានមេត្រី និងបំពេញសេចក្តីទាំងអស់ដែលព្រះជាម្ចាស់សម្តែងឲ្យពេញលក្ខណៈ" (DV ២)

### ព្រះជាម្ចាស់មានព្រះបន្ទូលគ្រប់លក្ខណៈតាមរយៈព្រះបុត្រាព្រះអង្គ

៦៥-"នៅជំនាន់ដើមព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់បុព្វបុរសយើងជាច្រើនលើកច្រើនសា ដោយប្រើរបៀបផ្សេងៗជាច្រើនតាមរយៈពួកព្យាការី។ គ្រានេះជាគ្រាចុងក្រោយបំផុត ព្រះអង្គមានព្រះបន្ទូលមកយើងតាមរយៈព្រះបុត្រា" (ហប ១,១-២)។ ព្រះគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់កើតជាមនុស្សជាព្រះបន្ទូលតែមួយរបស់ព្រះបិតាល្អឥតខ្ចោះ និងដែលមិនអាចទៅហួសបានទេ។ នៅក្នុងអង្គព្រះគ្រីស្តព្រះជាម្ចាស់មានព្រះបន្ទូលគ្រប់លក្ខណៈ ហើយគ្មានព្រះបន្ទូលណាមួយផ្សេងទៀតក្រៅពីព្រះបន្ទូលនេះឡើយ។ ក្រោយពីសន្តបុគ្គលជាច្រើននាក់សន្តៈ យ៉ូហាន នៃព្រះឈើឆ្កាងបំភ្លឺយើងយ៉ាងច្បាស់ ដោយធ្វើអត្ថាធិប្បាយអំពី ហប ១,១-២៖

លុះដល់ព្រះជាម្ចាស់បានប្រោសប្រទានព្រះបុត្រារបស់ព្រះអង្គដែលជាព្រះបន្ទូលរបស់ព្រះអង្គ ទ្រង់ក៏គ្មានព្រះបន្ទូលណាមួយផ្សេងទៀតប្រទានឲ្យយើងឡើយ។ ដោយព្រះបន្ទូលតែមួយនោះ ព្រះអង្គមានព្រះបន្ទូលអំពីអ្វីៗទាំងអស់ និងតែម្តងជាការស្រេច (...) ដ្បិតតែព្រះអង្គមានព្រះបន្ទូលតាមរយៈពួកព្យាការីជាផ្នែកៗ ទ្រង់ក៏មានព្រះបន្ទូលសព្វគ្រប់ទាំងអស់ក្នុងអង្គព្រះបុត្រា ដោយប្រោសប្រទាននូវអ្វីៗទាំងអស់ដែលជាព្រះបុត្រារបស់ព្រះអង្គ។ ហេតុនេះហើយបានជាអ្នកណាដែលចង់ទូលសួរព្រះអង្គ ឬចង់និមិត្តឃើញព្រះអង្គ ឬចង់ឲ្យព្រះអង្គសម្តែងសេចក្តីណាម្តងទៀត អ្នកនោះមិនគ្រាន់តែធ្វើអំពើឆ្កួតលេលាទេ ថែមទាំងប្រមាថព្រះជាម្ចាស់ដោយមិនសម្លឹងមើលតែព្រះគ្រីស្ត និងដោយស្វែងរកអ្វីផ្សេងមួយទៀត ឬអ្វីថ្មីមួយទៀត។

### ព្រះជាម្ចាស់នឹងមិនសម្តែងព្រះអង្គសាជាថ្មីម្តងទៀតទេ

៦៦-"ការចាត់ចែងសម្ព័ន្ធមេត្រីដោយសារព្រះគ្រីស្តបែបនេះ ពិតជាសម្ព័ន្ធមេត្រីថ្មី និងជាស្ថាពរដែលមិនត្រូវកន្លងផុតទៅទេ។ មនុស្សយើងក៏មិនត្រូវរង់ចាំព្រះជាម្ចាស់សម្តែងព្រះអង្គសាជាថ្មីជាសាធារណៈទៀតដែរ ទម្រាំពេលព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើងនឹងសម្តែងព្រះអង្គយ៉ាងរុងរឿង" (DV ៤)។ ក៏ប៉ុន្តែទោះបីព្រះជាម្ចាស់បានសម្តែងព្រះអង្គសព្វគ្រប់អស់ហើយក្តី ព្រះអង្គមិនបានពន្យល់នូវអ្វីៗទាំងអស់នៃការសម្តែងនេះទេ ហេតុនេះគ្រីស្តសាសនាត្រូវតែយល់ និងពន្យល់អំពីការសម្តែងនេះបន្តិចម្តងៗជារៀងរហូតទៅ។

៦៧-ពីសតវត្សមួយទៅសតវត្សមួយ ព្រះសហគមន៍ប្រកបដោយអំណាចបានទទួលស្គាល់ថា មនុស្សផ្សេងៗបានទទួលសេចក្តីខ្លះដែលព្រះជាម្ចាស់សម្តែងឲ្យគេស្គាល់ តែព្រះសហគមន៍មិនបញ្ចូលសេចក្តីនោះក្នុងបញ្ញត្តិនៃជំនឿឡើយ។ សេចក្តីនោះគ្មានមុខងារ "កែសម្រួល" ឬ "បំពេញ" ការសម្តែងដ៏ពេញលក្ខណៈរបស់ព្រះគ្រីស្តទេ គឺគ្រាន់តែឲ្យយល់អំពីអត្ថន័យកាន់តែច្បាស់តាមសម័យកាលខ្លះៗប៉ុណ្ណោះ។ គ្រីស្តបរិស័ទដែលមានក្រុមណែនាំព្រះសហគមន៍ជួយណែនាំចេះរិះគិតពិចារណា និងទទួលក្នុងសេចក្តីទាំងអស់នោះអ្វីដែលជាការត្រាស់ហៅយ៉ាងពិតប្រាកដរបស់

ព្រះគ្រីស្ត ឬរបស់សន្តបុគ្គលរបស់ព្រះអង្គចំពោះព្រះសហគមន៍។

គ្រីស្តសាសនាមិនអាចទទួល "ការសម្ដែង" ផ្សេងទៀតដែលមកពីសាសនាផ្សេង ឬនិកាយថ្មីៗ ហើយដែលមានបំណងកែសម្រួលសេចក្ដីដែលព្រះគ្រីស្តសម្ដែងឲ្យមនុស្សលោកស្គាល់ ហើយដែលព្រះគ្រីស្តបង្គ្រប់សព្វគ្រប់អស់ហើយ។

## សង្ខេប

៦៨-ដោយសារសេចក្ដីស្រឡាញ់ ព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សស្គាល់ និងបានប្រគល់ព្រះអង្គឲ្យមនុស្សផងដែរ។ ដូច្នេះ ព្រះអង្គមានព្រះបន្ទូលឆ្លើយតបទៅនឹងសំណួរទាំងប៉ុន្មាន ដែលមនុស្សសួរខ្លួនឯងអំពីអត្ថន័យ និងគោលដៅនៃជីវិតរបស់ខ្លួន ដោយចម្លើយដែលមានន័យជាស្ថាពរ និងពេញបរិបូណ៌។

៦៩-ព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សស្គាល់ ដោយផ្ដល់ឲ្យគេបន្ដិចម្ដងៗនូវអាថ៌កំបាំងរបស់ព្រះអង្គផ្ទាល់ ដោយសារកិច្ចការផង និងដោយសារព្រះបន្ទូលផងដែរ។

៧០-ព្រះជាម្ចាស់ផ្ដល់ព្រះកាយព្រះអង្គ តាមរយៈសត្វលោក លើសពីនេះទៅទៀត ព្រះអង្គបានសម្ដែងព្រះអង្គឲ្យឪពុកម្ដាយដើមរបស់យើងដឹង។ ព្រះអង្គមានព្រះបន្ទូលទៅគាត់ ក្រោយពីគាត់បានធ្លាក់ខ្លួនជាអ្នកបាប ព្រះអង្គមានព្រះពន្ធូលសន្យានឹងប្រទានការសង្គ្រោះ (កណ ៣,១៥) និងបានចងសម្ព័ន្ធមេត្រីជាមួយ។

៧១-ព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីអស់កល្បជានិច្ចជាមួយលោក ណូអេ និងជាមួយសត្វលោកទាំងអស់ ដែលមានជីវិត (កណ ៩,១៦)។ សម្ព័ន្ធមេត្រីនេះមានរហូតដល់អវសានកាលនៃពិភពលោក។

៧២-ព្រះជាម្ចាស់បានជ្រើសតាំងលោក អប្រាហាំ និងបានចងសម្ព័ន្ធមេត្រីជាមួយលោក និងពូជពង្សរបស់លោក។ ព្រះអង្គបានអប់រំប្រជារាស្ត្ររបស់ព្រះអង្គ ហើយបានសម្ដែងធម្មវិន័យរបស់ព្រះអង្គឲ្យប្រជារាស្ត្រនេះតាមរយៈលោក ម៉ូសេ។ ដោយសារព្យាការី ព្រះអង្គបានរៀបចំប្រជារាស្ត្ររបស់ព្រះអង្គឲ្យទទួលការសង្គ្រោះ ដែលមានសម្រាប់មនុស្សលោកទាំងអស់។

៧៣-ព្រះជាម្ចាស់បានសម្ដែងឲ្យបានពេញលក្ខណៈ ដោយចាត់ព្រះបុត្រាផ្ទាល់របស់ព្រះអង្គ ដែលបានចងសម្ព័ន្ធមេត្រីរបស់ព្រះអង្គជាដរាបតរៀងទៅ។ ដោយហេតុថា ព្រះបុត្រានេះហើយជាព្រះបន្ទូលជាស្ថាពរនៃព្រះបិតា ទើបក្រោយពីព្រះអង្គ ព្រះជាម្ចាស់នឹងមិនសម្ដែងព្រះអង្គទៀតទេ។

# ប្រការទី២៖

## ការបញ្ជូនសេចក្ដីដែលព្រះជាម្ចាស់សម្ដែងឲ្យមនុស្សលោកស្គាល់

៧៤-ព្រះជាម្ចាស់ "សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់បានទទួលការសង្គ្រោះ និងបានស្គាល់សេចក្ដីពិតយ៉ាងច្បាស់" (១ធម ២,៤) គឺព្រះគ្រីស្តយេស៊ូ។ ដូច្នេះហើយបានជាត្រូវតែប្រកាសព្រះគ្រីស្តឲ្យប្រជាជាតិទាំងឡាយ និងមនុស្សទាំងអស់ ដើម្បីឲ្យសេចក្ដីដែលព្រះជាម្ចាស់សម្ដែងទៅដល់ទីដាច់ស្រយ៉ាលនៃផែនដី។

"ព្រះជាម្ចាស់បានសម្ដែងព្រះអង្គ ដើម្បីសង្គ្រោះមនុស្សគ្រប់ជាតិសាសន៍។ ដោយព្រះជាម្ចាស់នៅតែមានព្រះហឫទ័យសប្បុរសដដែល ព្រះអង្គក៏ចាត់ចែងឲ្យសេចក្ដីដែលព្រះអង្គបានសម្ដែងនោះ ស្ថិតនៅគង់វង្សឥតប្រែប្រួល និងត្រូវឲ្យគេបញ្ជូនបន្តទៅមនុស្សនៅគ្រប់ជំនាន់ក្រោយតទៅទៀត" (DV ៧)។

## ១-ការបញ្ជូនបន្តនៃក្រុមគ្រីស្តទូត

៧៥-"ព្រះគ្រីស្តជាអម្ចាស់ដែលបង្រួប់សេចក្តីគ្រប់បែបយ៉ាងដែលព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតសម្តែង ទ្រង់បានធ្វើឲ្យដំណឹងល្អកើតជារូបរាងឡើងដោយព្រះអង្គផ្ទាល់ ទ្រង់ក៏បានប្រកាសដំណឹងល្អនេះដោយផ្ទាល់ព្រះឱស្ឋដែរ ជាដំណឹងល្អដែលអស់ព្យាការីបានសន្យាទុកជាមុនមកនោះ។ បន្ទាប់មកព្រះគ្រីស្តបញ្ជាក្រុមគ្រីស្តទូតប្រកាសដំណឹងល្អនេះដល់មនុស្សទាំងអស់ទុកជាប្រភពនៃសេចក្តីពិតគ្រប់យ៉ាងដែលអាចសង្គ្រោះគេបាន និងទុកជាក្បួននៃសីលធម៌គ្រប់យ៉ាងដែរ ដោយប្រទានព្រះអំណោយទានទៀតផង" (DV ៧)។

### ក្រុមគ្រីស្តទូតប្រកាសដំណឹងល្អ...

៧៦-តាមព្រះបញ្ញារបស់ព្រះអម្ចាស់ ការបញ្ជូនដំណឹងល្អមានពីរបែបគឺ៖

ពីមាត់មួយទៅមាត់មួយ៖ "ក្រុមគ្រីស្តទូតប្រព្រឹត្តដូច្នេះដោយប្រកាសដំណឹងល្អដោយផ្តល់គំរូល្អ និងដោយបញ្ជូនការចាត់ចែងផ្សេងៗ។ អស់លោកប្រកាសសេចក្តីដែលគេបានស្តាប់ពីព្រះគ្រីស្តផ្ទាល់ នៅពេលរួមរស់ជាមួយព្រះអង្គ ដោយឃើញព្រះអង្គប្រព្រឹត្តកិច្ចការផ្សេងៗ។ អស់លោកក៏ប្រកាសសេចក្តីដែលព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺឲ្យគេដឹង"។

ជាលាយលក្ខណ៍អក្សរ៖ "ក្រុមគ្រីស្តទូត ឬអស់អ្នកដែលរស់នៅជាមួយពួកលោកបានកត់ត្រាទុកជាលាយលក្ខណ៍អក្សរនូវសេចក្តីស្តីអំពីការសង្គ្រោះដោយមានព្រះវិញ្ញាណដ៏វិសុទ្ធដដែលនេះបំភ្លឺចិត្តគំនិតគេឲ្យសរសេរផង" (DV ៧)។

### ...រហូតដល់អស់អ្នកដែលទទួលមុខតំណែងពីក្រុមគ្រីស្តទូតមក

៧៧-"ក្រុមគ្រីស្តទូតបានតែងតាំងលោកអភិបាលឲ្យបន្តមុខងារពីអស់លោក ដើម្បីរក្សាទុកដំណឹងល្អនេះឲ្យនៅគង់វង្សជានិច្ចមិនប្រែប្រួលឡើយ និងឲ្យមានជីវិតរស់រវើកក្នុងព្រះសហគមន៍។ ក្រុមគ្រីស្តទូតបានផ្ញើមុខងារបង្រៀនរបស់ខ្លួនឲ្យអភិបាលទាំងនោះ" (DV ៧) ដ្បិត "ត្រូវរក្សាទុកសេចក្តីដែលក្រុមគ្រីស្តទូតបានថ្លែងនោះឲ្យនៅគង់រហូតដល់អវសានកាលនៃពិភពលោក ដោយមិនរអាក់ខានពេលណាឡើយ" (DV ៨)។

៧៨-គេហៅការបញ្ជូនបន្តដ៏រស់រវើកដែលបានគ្រប់លក្ខណៈក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនេះថា ជាការបញ្ជូនបន្ត។ ការបញ្ជូនបន្តនេះខុសប្លែកពីព្រះគម្ពីរដ៏វិសុទ្ធ ទោះបីការបញ្ជូនបន្ត និងព្រះគម្ពីរដ៏វិសុទ្ធនោះជាប់ពាក់ព័ន្ធជាមួយគ្នាយ៉ាងស្និទ្ធស្នាលក៏ដោយ។ តាមរយៈការបញ្ជូនបន្តនេះ "ព្រះសហគមន៍បង្រៀនលទ្ធិដោយរស់នៅតាមជំនឿ និងដោយធ្វើពិធីគោរពបម្រើព្រះជាម្ចាស់ព្រះសហគមន៍បញ្ជូនបន្តលក្ខណៈសម្បត្តិទាំងប៉ុន្មានរបស់ខ្លួន និងអ្វីៗដែលខ្លួនជឿឲ្យមនុស្សជំនាន់ក្រោយតទៅទៀតផង" (DV ៨)។ "ការប្រៀនប្រដៅរបស់គ្រូបាធ្យាយផ្តល់សក្ខីភាពបញ្ជាក់ថាការបញ្ជូនបន្តនេះមានតម្លៃដ៏ថ្លៃថ្នូរ គឺមានឥទ្ធិពលក្នុងការប្រតិបត្តិ និងក្នុងការរស់នៅរបស់ព្រះសហគមន៍ដែលជឿ និងអធិដ្ឋាន" (DV ៨)។

៧៩-ហេតុដូច្នេះហើយបានជាទំនាក់ទំនងដែលព្រះជាម្ចាស់បានកសាងដោយព្រះអង្គផ្ទាល់ តាមរយៈព្រះបន្ទូលព្រះអង្គ នៅក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធនៅតែស្ថិតក្នុងព្រះសហគមន៍តាមរយៈការប្រព្រឹត្តកិច្ចការផ្សេងៗ៖ "ព្រះជាម្ចាស់ដែលមានព្រះបន្ទូលកាលពីដើមមកនៅតែសន្ទនាជាមួយព្រះមហេសីនៃព្រះបុត្រាដ៏ជាទីស្រឡាញ់ជានិច្ចនិរន្តរ៍។ ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើឲ្យព្រះសូរសៀងដំណឹងល្អលាន់ឮក្នុងព្រះសហគមន៍ ហើយក៏លាន់ឮក្នុងពិភពលោកទាំងមូល

ដោយសារព្រះសហគមន៍ដែរ ព្រះវិញ្ញាណក៏ណែនាំអ្នកជឿទាំងប៉ុន្មានឲ្យស្គាល់សេចក្ដីពិតគ្រប់ជំពូក និងប្រោសឲ្យតម្លៃដ៏ថ្លៃថ្នូរនៃព្រះបន្ទូលរបស់ព្រះគ្រីស្តស្ថិតនៅក្នុងខ្លួនគេយ៉ាងបរិបូរណ៍" (DV ៨)។

## ២-ទំនាក់ទំនងរវាងការបញ្ជូនបន្ត និងព្រះគម្ពីរដ៏វិសុទ្ធ

### ប្រភពតែមួយ...

៨០-"ការបញ្ជូនបន្ត និងព្រះគម្ពីរដ៏វិសុទ្ធជាប់ពាក់ព័ន្ធគ្នា និងមានទំនាក់ទំនងយ៉ាងស្និទ្ធស្នាលជាមួយគ្នា។ ការបញ្ជូនបន្ត និងព្រះគម្ពីរដ៏វិសុទ្ធផុសចេញមកពីប្រភពតែមួយ ពោលគឺព្រះជាម្ចាស់។ ព្រះគម្ពីរ និងការបញ្ជូនបន្តហាក់ដូចជារួមជាធ្លុងតែមួយ និងមានទីដៅតែមួយដែរ" (DV ៩)។ ព្រះគម្ពីរ និងការបញ្ជូនបន្តនាំឲ្យអាថ៌កំបាំងរបស់ព្រះគ្រីស្តស្ថិតនៅក្នុងព្រះសហគមន៍ព្រមទាំងបង្កើតផលដ៏ល្អ ទ្រង់ដែលមានព្រះបន្ទូលសន្យាថានឹងគង់នៅជាមួយសាវ័ក "ជារៀងរាល់ថ្ងៃរហូតដល់អវសានកាលនៃពិភពលោក" (មថ ២៨,២០)។

### ...បញ្ជូនតាមរបៀបពីរយ៉ាងខុសៗគ្នា

៨១-"ព្រះគម្ពីរដ៏វិសុទ្ធជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលគេកត់ត្រាទុកជាលាយលក្ខណ៍អក្សរក្រោមការបំភ្លឺនៃព្រះវិញ្ញាណរបស់ព្រះអង្គ"។

"រីឯការបញ្ជូនបន្តដ៏វិសុទ្ធក៏ពាំនាំព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលព្រះគ្រីស្តជាអម្ចាស់ និងព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ញើទុកឲ្យក្រុមគ្រីស្តទូត រួចបញ្ជូនសព្វគ្រប់ឲ្យអ្នកបន្តមុខងាររបស់អស់លោកដើម្បីឲ្យអ្នកបន្តទាំងនោះរក្សាទុក បកស្រាយ និងផ្សព្វផ្សាយព្រះបន្ទូលនោះក្រោមការបំភ្លឺរបស់ព្រះវិញ្ញាណនៃសេចក្ដីពិតនៅពេលគេប្រកាស"។

៨២-ហេតុដូច្នេះហើយបានជាព្រះសហគមន៍ដែលមានមុខងារបញ្ជូន និងបកស្រាយសេចក្ដីដែលព្រះជាម្ចាស់សម្ដែងយោងជំនឿដ៏មាំមួនទៅលើ "សេចក្ដីទាំងប៉ុន្មានដែលព្រះជាម្ចាស់បានសម្ដែងនោះ ពុំមែនដោយសំអាងតែលើព្រះគម្ពីរប៉ុណ្ណោះទេ។ ហេតុនេះត្រូវទទួលស្គាល់ និងលើកតម្កើងការបញ្ជូនបន្ត និងព្រះគម្ពីរដោយចិត្តស្រឡាញ់ និងគោរពស្មើគ្នា" (DV ៩)។

### ការបញ្ជូនបន្ត និងទំនៀមទម្លាប់របស់ព្រះសហគមន៍

៨៣-ការបញ្ជូនបន្តដែលមកពីក្រុមគ្រីស្តទូតបញ្ជូននូវអ្វីដែលគេបានទទួលអំពីការប្រៀនប្រដៅ និងកិច្ចការរបស់ព្រះយេស៊ូ និងអ្វីដែលគេបានរៀនពីព្រះវិញ្ញាណដ៏វិសុទ្ធដែរ។ ជំនាន់ដំបូងរបស់គ្រីស្តបរិស័ទពុំទាន់មានសម្ពន្ធមេត្រីថ្មីទុកជាលាយលក្ខណ៍អក្សរឡើយ ហើយសម្ពន្ធមេត្រីថ្មីផ្ទាល់ផ្ដល់សក្ខីភាពអំពីដំណើរការនៃការបញ្ជូនបន្តដ៏រស់រវើក។

"ទំនៀមទម្លាប់" ខាងទេវវិទ្យា ខាងវិន័យ ឬខាងពិធីបុណ្យដែលបានកើតឡើងបន្តិចម្ដងៗ នៅក្នុងព្រះសហគមន៍ភូមិភាគមិនមែនជាការបញ្ជូនបន្តឡើយ តែជួយសម្ដែងការបញ្ជូនបន្តនេះតាមសម័យកាល ឬកន្លែងផ្សេងៗ។ ក្រោមពន្លឺនៃការបញ្ជូនបន្តក្រុមណែនាំព្រះសហគមន៍អាចបន្តកែសម្រួល ឬលះបង់ទំនៀមទម្លាប់នោះបាន។

## ៣-ការបកស្រាយមរតកនៃជំនឿ

### ក្រុមគ្រីស្តទូតបានផ្ញើមរតកនៃជំនឿឲ្យព្រះសហគមន៍ទាំងមូល

៨៤-ក្រុមគ្រីស្តទូតបានផ្ញើ "មរតកដ៏សក្ការៈនៃជំនឿ" (**depositum fidei**) (១ធម ៦,២០) ដែលមាននៅក្នុងការបញ្ជូនបន្ត និងក្នុងព្រះគម្ពីរដ៏វិសុទ្ធឲ្យព្រះសហគមន៍ទាំងមូល។ "បើប្រជាជនដ៏វិសុទ្ធទាំងមូលរួមជាមួយអស់គង្វាលរបស់ខ្លួនភ្ជាប់ចិត្តទៅនឹងបញ្ញើនេះ គេមុខជានឹងនៅតែព្យាយាមយ៉ាងស្មោះ ស្ដាប់ការប្រៀនប្រដៅរបស់ក្រុមគ្រីស្តទូត រួបរួមគ្នាទុកជាបងប្អូន ធ្វើពិធីកាច់នំបុ័ង និងអធិដ្ឋាន។ ហេតុនេះហើយបានជាអស់គង្វាល និងអស់អ្នកជឿរួមគ្នាជាចិត្តគំនិតតែមួយយ៉ាងស្អិតល្មួតក្នុងកិច្ចរក្សាជំនឿ ក្នុងកិច្ចប្រតិបត្តិតាមជំនឿ និងក្នុងការប្រកាសជំនឿដែលគេទទួលតមក" (**DV ១០**)។

### ក្រុមណែនាំរបស់ព្រះសហគមន៍

៨៥-"ព្រះជាម្ចាស់បានផ្ញើមុខងារបកស្រាយព្រះបន្ទូលរបស់ព្រះអង្គយ៉ាងពិតបាក្រដ ទោះបីជាព្រះបន្ទូលត្រូវបានកត់ត្រាជាលាយលក្ខណ៍អក្សរក្ដី ឬបញ្ជូនបន្តមកក្ដីឲ្យក្រុមណែនាំដ៏រស់រវើក។ មានតែក្រុមអ្នកណែនាំនោះប៉ុណ្ណោះដែលមានអំណាចបកស្រាយក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត" (**DV ១០**) គឺលោកអភិបាលរួមជាមួយអ្នកបន្តមុខងាររបស់លោក សិលា គឺលោកអភិបាលព្រះសហគមន៍នៅទីក្រុងរ៉ូម។

៨៦-"ប៉ុន្តែក្រុមណែនាំនេះ គ្មានអំណាចលើសពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ តែត្រូវបម្រើព្រះបន្ទូលទៅវិញ។ ក្រុមណែនាំក៏បង្រៀនតែសេចក្ដីដែលគេបានទទួលតមក ហើយស្ដាប់ព្រះបន្ទូលនេះដោយចិត្តស្រឡាញ់ តាមបញ្ជារបស់ព្រះជាម្ចាស់ និងដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជួយឧបត្ថម្ភផង។ អស់លោកថែរក្សាព្រះបន្ទូលយ៉ាងល្អបំផុត និងពន្យល់ព្រះបន្ទូលយ៉ាងត្រឹមត្រូវ ហើយយោងពីបញ្ញើនៃជំនឿតែមួយនេះ នូវអ្វីៗទាំងប៉ុន្មានដែលក្រុមណែនាំជូនឲ្យគ្រីស្តបរិស័ទជឿទុកជាសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់" (**DV ១០**)។

៨៧-គ្រីស្តបរិស័ទដែលរំឭកអំពីព្រះបន្ទូលរបស់ព្រះគ្រីស្តចំពោះក្រុមគ្រីស្តទូតរបស់ព្រះអង្គគឺ "អ្នកណាស្ដាប់អ្នករាល់គ្នា ក៏ដូចជាស្ដាប់ខ្ញុំដែរ" (លក ១០,១៦) (**LG ២០**) ទទួលដោយមានចិត្តសុភាពរាបសាការប្រៀនប្រដៅ និងការណែនាំដែលគ្រូគង្វាលផ្ដល់ឲ្យគេតាមរបៀបផ្សេងៗ។

### គោលការណ៍នៃជំនឿ

៨៨-ក្រុមណែនាំព្រះសហគមន៍បានទទួលអំណាចរបស់ព្រះគ្រីស្តដ៏ពេញលក្ខណៈ នៅពេលដែលក្រុមណែនាំនេះកំណត់គោលការណ៍ គឺនៅពេលដែលក្រុមណែនាំស្នើសុំតាមរបៀបដែលបង្ខំប្រជាជននៃគ្រីស្តបរិស័ទឲ្យជឿជាដាច់ខាតសេចក្ដីពិតដែលព្រះជាម្ចាស់បានសម្ដែងមក ឬសេចក្ដីពិតដែលជាប់នឹងសេចក្ដីពិតដែលព្រះអង្គបានសម្ដែងមកហើយដែលមិនអាចបំបែកគ្នាបានទេ។

៨៩-ជីវិតខាងវិញ្ញាណរបស់យើង និងគោលការណ៍ជាប់ទាក់ទងនឹងគ្នាជាចាំបាច់។ គោលការណ៍ដូចជាពន្លឺនៅលើផ្លូវនៃជំនឿរបស់យើងបំភ្លឺ និងពង្រឹងផ្លូវនេះ។ ផ្ទុយទៅវិញបើយើងរស់នៅតាមរបៀបត្រឹមត្រូវប្រាជ្ញា និងចិត្តគំនិតរបស់យើងនឹងទូលាយដើម្បីទទួលពន្លឺនៃគោលការណ៍របស់ជំនឿ (យហ ៨,៣១-៣២)។

៩០-សេចក្ដីទាំងអស់ដែលព្រះជាម្ចាស់សម្ដែងអំពីអាថ៌កំបាំងរបស់ព្រះគ្រីស្តបង្ហាញថា គោលការណ៍ជាប់រួមជាមួយ

គ្នាយ៉ាងជិតស្និទ្ធ ដោយមានហេតុផលយ៉ាងច្បាស់លាស់ (វ៉ាទីកង់ទី១ DS ៣០១៦; LG ២៥)។ "គោលការណ៍ដែលទាក់ទងនឹងគ្នាតាមរបៀបផ្សេងៗ និងដែលរួមជាមួយគ្រឹះនៃគ្រីស្តសាសនាបង្ហាញថាសេចក្តីពិតនៃលទ្ធិកាតូលិកមានសណ្តាប់ធ្នាប់ ឬរួមគ្នាតាម "លំដាប់លំដោយ" (UR ១១)។

## ការយល់ឃើញហួសធម្មជាតិនៃជំនឿ

៩១-គ្រីស្តបរិស័ទទាំងអស់រួមចំណែកក្នុងការឈ្វេងយល់ និងការបញ្ជូននៃសេចក្តីពិតដែលព្រះជាម្ចាស់បានសម្តែងមក។ ពួកគេបានទទួលប្រេងអភិសេកនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលបង្រៀនគេ (១យហ ២,២០.២៧) និងណែនាំគេឆ្ពោះទៅសេចក្តីពិតគ្រប់ជំពូក (យហ ១៦,១៣)។

៩២-"គ្រីស្តបរិស័ទទាំងអស់មិនអាចវង្វេងជំនឿបានឡើយ និងបង្ហាញបញ្ជាក់អំពីព្រះអំណោយទានពិសេសនេះដោយប្រជារាស្ត្រទាំងមូលយល់ស្របគ្នាអំពីជំនឿនៅពេល "អស់លោកអភិបាលរហូតដល់គ្រីស្តបរិស័ទតូចជាងគេបំផុត" រួមគ្នាយល់ស្របទាំងអស់គ្នាអំពីសេចក្តីពិត ត្រង់ជំនឿ និងត្រង់សីលធម៌" (LG ១២)។

៩៣-"ដោយសារការឈ្វេងយល់នៃជំនឿនេះដែលមានព្រះវិញ្ញាណនៃសេចក្តីពិតដាស់តឿន និងជួយឧបត្ថម្ភ ហើយក្រោមក្រុមណែនាំដ៏សក្ការៈ (...) ប្រជាជនរបស់ព្រះជាម្ចាស់ជាប់ចិត្តជានិច្ចនឹងជំនឿដែលត្រូវបញ្ជូនទៅសន្តបុគ្គលម្តងជាការស្រេចចូលនៅក្នុងជំនឿស៊ីជម្រៅជាងមុន ដោយបកស្រាយជំនឿតាមរបៀបត្រឹមត្រូវ ហើយដោយប្រតិបត្តិតាមក្នុងការរស់នៅ" (LG ១២)។

## ការរីកចម្រើនក្នុងការឈ្វេងយល់នៃជំនឿ

៩៤-ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធជួយឧបត្ថម្ភយើងអាចឈ្វេងយល់ពីសម្បត្តិសួគ៌ និងពាក្យសម្តីរបស់មរតកនៃជំនឿកាន់តែចម្រើនឡើងៗក្នុងជីវិតព្រះសហគមន៍៖

-"ដោយអ្នកជឿស្មឹងស្មាធិ៍ និងសិក្សាព្រមទាំងនឹកសញ្ជឹងក្នុងចិត្ត" (DV ៨) ជាពិសេស "ការស្វែងរកខាងទេវវិទ្យារិះគិតឲ្យកាន់តែជ្រៅអំពីសេចក្តីពិត ដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់"(GS៦២,៧)"។

-"ដោយអ្នកជឿឈ្វេងយល់នៅក្នុងចិត្តពីសម្បត្តិសួគ៌កាន់តែច្បាស់ៗ (DV ៨)។ "ព្រះបន្ទូលរបស់ព្រះជាម្ចាស់និងអ្នកអានព្រះបន្ទូលនោះក៏រីកចម្រើនរួមជាមួយគ្នា" (សន្តៈ គ្រេគ័រ ដ៏ប្រសើរ)។

-"ដោយការប្រៀនប្រដៅរបស់អស់អ្នកដែលរួមជាមួយអ្នកបន្តមុខងារជាអភិបាលបានទទួលព្រះអំណោយទានយ៉ាងច្បាស់លាស់អំពីសេចក្តីពិត" (DV ៨)។

៩៥-"ដូច្នេះត្រូវឃើញជាក់ច្បាស់ថាការបញ្ជូនដ៏វិសុទ្ធ ព្រះគម្ពីរដ៏វិសុទ្ធ និងក្រុមណែនាំព្រះសហគមន៍ជាប់ទាក់ទិនគ្នា និងរួមគ្នាតាមព្រះជាម្ចាស់បានចាត់ចែងយ៉ាងឈ្លាសវៃ។ ក្នុងកត្តាទាំងបីនេះគ្មានអ្វីមួយណាដែលអាចស្ថិតស្ថេរដោយឯកឯងទេ គឺការទាំងបីនោះរួមគ្នាយ៉ាងសកម្ម ដើម្បីសង្គ្រោះមនុស្សលោកតាមរបៀបរៀងៗខ្លួន ក្រោមការឧបត្ថម្ភនៃព្រះវិញ្ញាណដ៏វិសុទ្ធតែមួយព្រះអង្គ" (DV ១០,៣)។

## សង្ខេប

៩៦-ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជួយបភ្លឺអ្វីៗដែលព្រះគ្រីស្តបានប្រគល់ឲ្យក្រុមគ្រីស្តទូត ពួកលោកបានបញ្ជូន

ដោយការទេសនា និងជាលាយលក្ខណ៍អក្សរ ឲ្យមនុស្សគ្រប់ជំនាន់ រហូតដល់ពេលព្រះគ្រីស្តយាងត្រឡប់មកវិញប្រកបដោយសិរីរុងរឿង។

៩៧-"ការបញ្ជូនបន្តដ៏វិសុទ្ធ និងព្រះគម្ពីរដ៏វិសុទ្ធជាបញ្ញត្តិជាទីសក្ការៈតែមួយនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់" (DV ៨)។ ការបញ្ជូនបន្តដ៏វិសុទ្ធ និងព្រះគម្ពីរដ៏វិសុទ្ធប្រៀបដូចជាកញ្ចក់។ ក្នុងកញ្ចក់នេះ ព្រះសហគមន៍ដែលកំពុងធ្វើដំណើរនៅនាលោកនេះ សញ្ជឹងមើលព្រះជាម្ចាស់ដែលជាប្រភពនៃលក្ខណៈសម្បត្តិទាំងអស់របស់ខ្លួន។

៩៨-"ព្រះសហគមន៍បញ្ជូនបន្តលក្ខណៈសម្បត្តិរបស់ខ្លួន និងអ្វីៗដែលខ្លួនជឿឲ្យមនុស្សគ្រប់ជំនាន់តៗទៅទៀត ដោយបង្រៀនលទ្ធិ ដោយរស់នៅតាមជំនឿ និងដោយធ្វើពិធីគោរពបម្រើព្រះជាម្ចាស់" (DV ៨)។

៩៩-ដោយសារការឈ្វេងយល់ហួសពីធម្មជាតិរបស់ខ្លួន ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូលនៅតែទទួលព្រះអំណោយទាននៃការសម្តែងរបស់ព្រះជាម្ចាស់ យល់អំពីព្រះអំណោយទាននេះកាន់តែស៊ីជម្រៅ និងមានរបៀបរស់នៅតាមព្រះអំណោយទាននេះផងដែរ។

១០០-ព្រះជាម្ចាស់បានប្រគល់បន្ទុកបកស្រាយព្រះបន្ទូលយ៉ាងពិតប្រាកដរបស់ព្រះអង្គ ឲ្យតែក្រុមមេដឹកនាំព្រះសហគមន៍ ឲ្យសម្តេចប៉ាប និងឲ្យពួកលោកអភិបាលដែលរួបរួមជាមួយសម្តេចប៉ាប។

# ប្រការទី៣៖

# ព្រះគម្ពីរដ៏វិសុទ្ធ

## ១-ព្រះគ្រីស្តជាព្រះបន្ទូលតែមួយនៃព្រះគម្ពីរដ៏វិសុទ្ធ

១០១-ព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរសពោរពេញដោយធម៌មេត្តាករុណា បានជាព្រះអង្គមានព្រះបន្ទូលដូចជាពាក្យសម្តីរបស់មនុស្ស ដើម្បីសម្តែងព្រះអង្គឲ្យមនុស្សលោកស្គាល់៖ "ព្រះជាម្ចាស់បានថ្លែងព្រះបន្ទូលតាមភាសារបស់មនុស្ស គឺព្រះបន្ទូលបានដូចជាពាក្យសម្តីមនុស្សយ៉ាងណា ក៏កាលពីដើមព្រះបន្ទូលរបស់ព្រះបិតាដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ចបានដូចមនុស្សយើង គឺយកភាពទន់ខ្សោយរបស់មនុស្សយើងយ៉ាងនោះដែរ" (DV ១៣)។

១០២-តាមរយៈពាក្យសម្តីទាំងអស់នៃព្រះគម្ពីរដ៏វិសុទ្ធ ព្រះជាម្ចាស់មានព្រះបន្ទូលតែមួយគឺ ព្រះបុត្រាតែមួយរបស់ព្រះអង្គ។ នៅក្នុងអង្គព្រះបុត្រានេះ ព្រះជាម្ចាស់សម្តែងព្រះអង្គទាំងស្រុង។

សូមរំឭកថា គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់តែមួយដែលលាតសន្ធឹងក្នុងព្រះគម្ពីរទាំងមូល គឺមានព្រះបុត្រាតែមួយដែលបន្លឺសម្លេងខ្ទរក្នុងមាត់របស់អ្នកនិពន្ធដ៏សក្ការៈ។ តាំងពីដើមដំបូងបង្អស់ទ្រង់ជាព្រះជាម្ចាស់រួមជាមួយព្រះជាម្ចាស់ មិនត្រូវការព្យាង្គ ដ្បិតព្រះអង្គមិនចុះក្រោមអំណាចនៃពេលវេលាឡើយ (សន្ត: អូគូស្តាំង)។

១០៣-ដោយសារហេតុនេះហើយព្រះសហគមន៍តែងតែគោរពព្រះគម្ពីរដ៏វិសុទ្ធជានិច្ច ដូចព្រះសហគមន៍ធ្លាប់គោរពព្រះកាយផ្ទាល់របស់ព្រះអម្ចាស់ផងដែរ ហើយព្រះសហគមន៍នៅតែផ្តល់នំប៉័ងនៃជីវិតយកពីលើតុនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងពីលើតុនៃព្រះកាយព្រះគ្រីស្តផងដែរ (DV ២១)។

១០៤-ព្រះសហគមន៍តែងតែយកពីព្រះគម្ពីរដ៏វិសុទ្ធ ចំណីអាហារ និងកម្លាំងរបស់ខ្លួន (DV ២៤) ដ្បិតនៅក្នុងព្រះគម្ពីរដ៏វិសុទ្ធនេះ ព្រះសហគមន៍មិនគ្រាន់តែទទួលយកពាក្យសម្តីរបស់មនុស្សទេ គឺទុកជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

តាមពិតជាព្រះបន្ទូលរបស់ព្រះអង្គមែន (១ថស ២,១៣)។ "ដោយសារព្រះគម្ពីរដ៏វិសុទ្ធ ព្រះបិតាដែលគង់នៅស្ថានបរមសុខ យាងមកទទួលបុត្រធីតារបស់ព្រះអង្គដោយព្រះហឫទ័យមេត្តាករុណា និងយាងមកសន្ទនាជាមួយគេ" (DV ២១)។

## ២-ការបំភ្លឺ និងការបកស្រាយព្រះគម្ពីរដ៏វិសុទ្ធ

១០៥-ព្រះជាម្ចាស់ជាអ្នកនិពន្ធព្រះគម្ពីរដ៏វិសុទ្ធ។ "ព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺឲ្យកត់ត្រាទុកជាលាយលក្ខណ៍អក្សរនូវសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែង ហើយដែលមានរៀបរាប់ក្នុងកណ្ឌព្រះគម្ពីរ"។

"ព្រះសហគមន៍កាតូលិកជាមាតាដ៏វិសុទ្ធរបស់យើង សំអាងទៅលើជំនឿរបស់ក្រុមគ្រីស្តទូតជាគ្រឹះ ហើយចាត់គ្រប់ផ្នែកនៃកណ្ឌទាំងប៉ុន្មានក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ក្ដី សម្ពន្ធមេត្រីថ្មីក្ដី ទុកជាសក្ការៈ និងទុកជាសាសនាបញ្ញត្តិរបស់ខ្លួន ព្រោះព្រះវិញ្ញាណបានបំភ្លឺចិត្តគំនិតអ្នកនិពន្ធឲ្យសរសេរ គឺព្រះជាម្ចាស់បាននិពន្ធកណ្ឌទាំងនោះ ហើយព្រះសហគមន៍ក៏បានទទួលកណ្ឌគម្ពីរទាំងនោះដោយយល់ដូច្នោះដែរ" (DV ១១)។

១០៦-ព្រះជាម្ចាស់បានបំភ្លឺអ្នកនិពន្ធព្រះគម្ពីរដ៏វិសុទ្ធ។ "ព្រះជាម្ចាស់បានជ្រើសរើសមនុស្សខ្លះ ដើម្បីនិពន្ធកណ្ឌគម្ពីរទាំងនោះ គឺព្រះអង្គឲ្យអ្នកទាំងនោះប្រើចំណេះប្រាជ្ញា ទេពកោសល្យ និងបច្ចេកទេសរបស់ខ្លួនយ៉ាងពិតប្រាកដ ហើយទ្រង់មានសកម្មភាពក្នុងអ្នកទាំងនោះ និងដោយសារអ្នកទាំងនោះ ព្រះអង្គឲ្យគេកត់ត្រាទុកជាលាយលក្ខណ៍អក្សរ នូវសេចក្ដីដែលព្រះអង្គសព្វព្រះហឫទ័យឲ្យគេនិពន្ធ គឺតែសេចក្ដីណាដែលព្រះអង្គសព្វព្រះហឫទ័យឲ្យគេសរសេរប៉ុណ្ណោះ" (DV ១១)។

១០៧-ព្រះគម្ពីរដែលព្រះជាម្ចាស់បានបំភ្លឺប្រៀនប្រដៅសេចក្ដីពិត។ "ហេតុនេះហើយបានជាត្រូវរាប់សេចក្ដីទាំងអស់ដែលអ្នកនិពន្ធ និងអ្នកតំណាលរឿងនិទានបានកត់ត្រានោះ ទុកជាសេចក្ដីដែលព្រះវិញ្ញាណបានបញ្ជាក់ ព្រោះព្រះវិញ្ញាណបានបំភ្លឺចិត្តគំនិតអ្នកនិពន្ធ។ យើងក៏ត្រូវតែប្រកាសថា ក្នុងកណ្ឌគម្ពីរមានបង្រៀនយ៉ាងប្រាកដម៉ឺងម៉ាត់យ៉ាងត្រឹមត្រូវ ដោយគ្មានកំហុសនូវសេចក្ដីពិតដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគេកត់ត្រាទុកជាលាយលក្ខណ៍អក្សរក្នុងព្រះគម្ពីរ ដើម្បីសង្គ្រោះយើង" (DV ១១)។

១០៨-ប៉ុន្តែគ្រីស្តសាសនាមិនមែនជា "សាសនានៃគម្ពីរ" ទេ។ គ្រីស្តសាសនាជាសាសនានៃ "ព្រះបន្ទូល" របស់ព្រះជាម្ចាស់ "មិនមែនព្រះបន្ទូលទុកជាលាយលក្ខណ៍អក្សរដូចជាមនុស្សគ តែព្រះបន្ទូលរស់រវើកដែលប្រសូតជាមនុស្ស" (សន្តៈ ប៊េរណា)។ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធព្រះគ្រីស្តដែលជាព្រះបន្ទូលអស់កល្បជានិច្ចរបស់ព្រះដ៏មានព្រះជន្មគង់នៅ ត្រូវតែ "បំភ្លឺចិត្តគំនិតយើងឲ្យយល់អត្ថន័យគម្ពីរ" (លក ២៤,៤៥) កុំឲ្យគម្ពីរគ្មានជីវិតនៅឡើយ។

## ៣-ព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកបកស្រាយព្រះគម្ពីរ

១០៩-នៅក្នុងព្រះគម្ពីរដ៏វិសុទ្ធព្រះជាម្ចាស់មានព្រះបន្ទូលមកមនុស្សតាមរបៀបរបស់មនុស្ស។ ដូច្នេះហើយបានជាត្រូវតែស្វែងរកសេចក្ដីដែលអ្នកនិពន្ធមានបំណងនិយាយប្រាប់ និងសេចក្ដីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យសម្ដែងតាមរយៈពាក្យសម្ដីរបស់គេ (DV ១២,១)។

១១០-ត្រូវតែស្វះស្វែងរកគោលដៅដែលអ្នកនិពន្ធមានបំណងចង់ប្រាប់តាមកាលៈទេសៈនៃសម័យកាល និងវប្បធម៌របស់គេតាម "របៀបនិពន្ធ" តាមរបៀបគិតនិយាយ និងនិទានរឿងដែលគេធ្លាប់ប្រើនៅជំនាន់នោះ។ "អស់លោកបង្ហាញសេចក្ដីពិតតាមរបៀបផ្សេងៗពីគ្នា ក្នុងអត្ថបទរៀបរាប់អំពីប្រវត្តិសាស្ត្រ ក្នុងសេចក្ដីប្រកាសរបស់

ព្យាការី ក្នុងពាក្យកាព្យ ឬក្នុងអត្ថបទនិពន្ធតាមរបៀបផ្សេងៗទៀត" (DV ១២,២)។

១១១-ប៉ុន្តែដោយសារព្រះវិញ្ញាណបំភ្លឺព្រះគម្ពីរដ៏វិសុទ្ធត្រូវតែបកស្រាយតាមគោលការណ៍ផ្សេងមួយទៀត និងសំខាន់ដូចគោលការណ៍ដើម ដើម្បីឲ្យព្រះគម្ពីររស់រវើកគឺ "ត្រូវតែអាន និងបកស្រាយព្រះគម្ពីរក្រោមពន្លឺនៃព្រះវិញ្ញាណដែលបានបំភ្លឺចិត្តគំនិតអ្នកនិពន្ធឲ្យចែងជាលាយលក្ខណ៍អក្សរនេះដែរ" (DV ១២,៣)។

មហាសន្និបាតវ៉ាទីកង់ទី២ បង្ហាញលក្ខណៈបីយ៉ាងដើម្បីបកស្រាយព្រះគម្ពីរតាមព្រះវិញ្ញាណដែលបានបំភ្លឺអ្នកនិពន្ធគឺ (DV ១២,៣)៖

១១២-១-ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះ "សេចក្តីទាំងអស់ដែលមានចែងក្នុងគម្ពីរ និងចំពោះឯកភាពនៃព្រះគម្ពីរទាំងមូល"។ ទោះបីកំណត់ទាំងប៉ុន្មានដែលមានចែងនៅក្នុងគម្ពីរខុសពីគ្នាយ៉ាងណាក៏ដោយ ក៏ព្រះគម្ពីរមានតែមួយ ព្រោះព្រះជាម្ចាស់មានគម្រោងការតែមួយដែរ ដែលមានព្រះយេស៊ូជាស្នូល និងជាបេះដូងបើកទទួលតាំងពីបុណ្យចម្លង (លក ២៤,២៥-២៧.៤៤-៤៦)។

បេះដូងរបស់ព្រះគ្រីស្តសំដៅលើព្រះគម្ពីរដ៏វិសុទ្ធដែលធ្វើឲ្យស្គាល់បេះដូងរបស់ព្រះគ្រីស្ត។ មុនព្រះអង្គរងទុក្ខលំបាកបេះដូងនេះបិទនៅឡើយ ដ្បិតព្រះគម្ពីរងងឹតនៅឡើយដែរ។ ប៉ុន្តែ ក្រោយពីព្រះអង្គបានរងទុក្ខលំបាកព្រះជាម្ចាស់បានបើកព្រះគម្ពីរ ពីព្រោះអស់អ្នកដែលយល់ព្រះគម្ពីរនេះរិះគិតពិចារណាអំពីរបៀបដែលត្រូវបកស្រាយព្យាករណ៍ទាំងអស់ (សន្តៈ ថូម៉ាសនៃអាកាំង)។

១១៣-២-ត្រូវចាប់អារម្មណ៍នឹង "ការបញ្ជូនយ៉ាងសកម្មនៃព្រះសហគមន៍ទាំងមូល"។ តាមពាក្យចាស់របស់គ្រូបាធ្យាយនៃព្រះសហគមន៍នៅក្នុងការបញ្ជូនរបស់ព្រះសហគមន៍ ព្រះសហគមន៍នឹករឭកព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងសកម្ម ហើយព្រះវិញ្ញាណដ៏វិសុទ្ធប្រទានការបកស្រាយខាងវិញ្ញាណរបស់ព្រះគម្ពីរឲ្យព្រះសហគមន៍ ("តាមអត្ថន័យខាងវិញ្ញាណដែលព្រះវិញ្ញាណបំភ្លឺព្រះសហគមន៍" (លោក អូរីសែន))។

១១៤-៣-ត្រូវចាប់អារម្មណ៍នឹង "លក្ខណៈប្រៀបធៀបនៃជំនឿផង" (រម ១២,៦) ពោលគឺសេចក្តីពិតនៃជំនឿសមហេតុសមផលរួមជាមួយគ្នានៅនឹងក្នុងគម្រោងការទាំងស្រុងអំពីសេចក្តីដែលព្រះជាម្ចាស់សម្តែងមក។

### អត្ថន័យនៃព្រះគម្ពីរ

១១៥-តាមប្រពៃណីពីបុរាណ យើងអាចយល់ឃើញថា ព្រះគម្ពីរមានអត្ថន័យពីរ គឺអត្ថន័យដើម និងអត្ថន័យខាងវិញ្ញាណ។ អត្ថន័យទីពីរនេះ ចែកចេញជាន័យតូចៗបីទៀត គឺន័យសំដៅទៅលើព្រះគ្រីស្ត ន័យតាមសីលធម៌ និងន័យដែលមានលក្ខណៈប្រៀបធៀប។ អត្ថន័យទាំងបួននេះ ផ្តល់លក្ខណៈសម្បត្តិយ៉ាងជ្រាលជ្រៅនៃព្រះគម្ពីរដល់អ្នកអានក្នុងព្រះសហគមន៍។

១១៦-អត្ថន័យដើម គឺន័យដែលបានមកអំពីពាក្យពេចន៍នៅក្នុងព្រះគម្ពីរ ហើយដែលអ្នកស្រាវជ្រាវបានរកឃើញដោយគោរពតាមវិន័យនៃការបកស្រាយព្រះគម្ពីរតាមរបៀបត្រឹមត្រូវ។ "អត្ថន័យទាំងអស់ក្នុងព្រះគម្ពីរដ៏វិសុទ្ធពឹងផ្អែកទៅលើអត្ថន័យដើម" (សន្តៈ ថូម៉ាសនៃអាកាំង)។

១១៧-អត្ថន័យខាងវិញ្ញាណ៖ ដោយសារឯកភាពនៃគម្រោងការរបស់ព្រះជាម្ចាស់ មិនគ្រាន់តែអត្ថបទនៃព្រះគម្ពីរទេ ប៉ុន្តែ សភាព និងហេតុការណ៍នានា ដែលមានចែកនៅក្នុងអត្ថបទនោះ ក៏អាចទៅជាសញ្ញាសម្គាល់ដែរ។

១-ន័យសំដៅទៅលើព្រះគ្រីស្ត៖ យើងអាចយល់យ៉ាងជ្រៅទៅក្នុងព្រឹត្តិការណ៍នានា ដែលកើតមានឡើង

ដោយតាមអត្ថន័យក្នុងអង្គព្រះគ្រីស្ត ដូចជាការឆ្លងសមុទ្រក្រហម ជាសញ្ញាសម្គាល់មួយនៃជ័យជម្នះរបស់ព្រះគ្រីស្ត ហើយអំពីពិធីបុណ្យជ្រមុជទឹក (១ករ ១០,២)។

២-ន័យខាងសីលធម៌៖ ព្រឹត្តិការណ៍ដែលមានចែកទុកក្នុងព្រះគម្ពីរ ត្រូវណែនាំយើងឲ្យប្រព្រឹត្តកិច្ចការតាមរបៀបសុចរិត។ គេបានសរសេរព្រឹត្តិការណ៍នោះ "ដើម្បីទូន្មានពួកយើង" (១ករ ១០,១១) (ហប ៣-៤,១១)។

៣-ន័យដែលមានលក្ខណៈប្រៀបធៀប៖ យើងអាចយល់សភាព និងព្រឹត្តិការណ៍ តាមអត្ថន័យអស់កល្បជានិច្ច ដែលនាំយើងឆ្ពោះទៅ (ជាភាសាក្រិក anagoge) មាតុប្រទេសរបស់យើង។ ឧ-ហេតុនេះ ព្រះសហគមន៍នៅលើផែនដី ជាសញ្ញាសម្គាល់នៃទីក្រុងយេរូសាឡឹមនៅស្ថានបរមសុខ។

១១៨-កំណាព្យនៅមជ្ឈិមសម័យមួយបានពន្យល់អត្ថន័យទាំងបួនថា៖

អត្ថន័យដើមឲ្យយើងដឹងអំពីហេតុការណ៍ដែលកើតមានឡើង។
អត្ថន័យសំដៅទៅលើព្រះគ្រីស្តឲ្យយើងដឹងថា អ្វីដែលត្រូវតែជឿ។
អត្ថន័យខាងសីលធម៌ឲ្យយើងដឹងថា អ្វីដែលត្រូវតែធ្វើតាម។
អត្ថន័យដែលមានលក្ខណៈប្រៀបធៀបឲ្យយើងដឹងអំពីគោលដៅ។

១១៩-"អ្នកវិភាគគម្ពីរមានភារកិច្ចខិតខំពិនិត្យពិច័យ និងបកស្រាយអត្ថន័យនៃព្រះគម្ពីរឲ្យកាន់តែជ្រៅទៅៗតាមគោលការណ៍ទាំងនោះ ដើម្បីឲ្យព្រះសហគមន៍មានយោបល់កាន់តែល្អប្រសើរឡើងៗ។ ដោយការសិក្សារបស់ខ្លួន អ្នកវិភាគទាំងនោះ ដូចជារៀបចំផ្លូវឲ្យព្រះសហគមន៍អាចវិនិច្ឆ័យបាន។ អ្វីៗទាំងអស់ដែលមានទាក់ទិននឹងរបៀបបកស្រាយព្រះគម្ពីរ គឺស្ថិតនៅលើព្រះសហគមន៍ដែលត្រូវរិះគិតពិចារណាដោះស្រាយ ព្រោះព្រះសហគមន៍ទទួលមុខងារបម្រើពីព្រះជាម្ចាស់មក និងក្នុងនាមព្រះអង្គ ពោលគឺរក្សាទុក និងបកស្រាយព្រះបន្ទូលរបស់ព្រះជាម្ចាស់" (DV ១២,៣)។

ប្រសិនបើអំណាចរបស់ព្រះសហគមន៍មិនជំរុញខ្ញុំទេ ខ្ញុំក៏ប្រហែលជាមិនជឿលើដំណឹងល្អឡើយ (សន្តៈ អូគូស្តាំង)។

## ៤-សាសនាបញ្ញត្តិនៃព្រះគម្ពីរ

១២០-ការបញ្ជូនបន្តដែលមកពីក្រុមគ្រីស្តទូតបានធ្វើឲ្យព្រះសហគមន៍ពិចារណាអំពីកណ្ឌណាដែលត្រូវតែរាប់បញ្ចូលក្នុងបញ្ជីកណ្ឌគម្ពីរដ៏វិសុទ្ធ (DV ៨,៣)។ គេហៅបញ្ជីទាំងអស់នេះថា "សាសនាបញ្ញត្តិ" នៃព្រះគម្ពីរ។ មាន ៤៦ កណ្ឌក្នុងសម្ពន្ធមេត្រីចាស់ និង ២៧ កណ្ឌក្នុងសម្ពន្ធមេត្រីថ្មី៖

កំណើតពិភពលោក សេរីភាព លេវីវិន័យ ជំរឿនប្រជាជន ទុតិយកថា យ៉ូស៊ូអា វិរបុរស នាងរូថ សាមូអែលទី១ និងទី២ ពង្សាវតារក្សត្រទី១ និងទី២ របាក្សត្រទី១ និងទី២ អែសរ៉ា នេហេមី តូប៊ីត យូឌីត អេសធែរ ម៉ាកាបាយទី១ និងទី២ យ៉ូប ទំនុកតម្កើង សុភាសិត សាស្ដា បទចម្រៀងរបស់ព្រះបាទសាឡូម៉ូន ព្រះប្រាជ្ញាញាណ បេនស៊ីរ៉ាក អេសាយ យេរេមី សំណោក បារូក អេសេគីអែល ដានីអែល ហូសេ យ៉ូអែល អម៉ូស អូបាឌី យ៉ូណាស មីកា ណាហ៊ូម ហាបាគូក សេផានី ហាកាយ សាការី ម៉ាឡាគី (សម្ពន្ធមេត្រីចាស់)។

ដំណឹងល្អតាមសន្តៈ ម៉ាថាយ សន្តៈ ម៉ាកុស សន្តៈ លូកា និងតាមសន្តៈ យ៉ូហាន កិច្ចការគ្រីស្តទូត លិខិតរបស់សន្តៈ ប៉ូល ផ្ញើជនគ្រីស្តបរិស័ទនៅទីក្រុងរ៉ូម កូរិនថូសទី១ និងទី២ កាឡាទី អេភេសូ ភីលីព

កូឡូស ថេស្សាឡូនិកទី១ និងទី២ធីម៉ូថេទី១ និងទី២ ទីតុស ភីលេម៉ូន និងហេប្រឺ លិខិតរបស់សន្តៈ យ៉ាកុប លិខិតទាំងពីររបស់សន្តៈ សិលា (ពេត្រុស) លិខិតទាំងបីរបស់សន្តៈ យ៉ូហាន លិខិតរបស់សន្តៈ យ៉ូដាស និង វិវរណៈ (សម្ព័ន្ធមេត្រីថ្មី)។

## សម្ព័ន្ធមេត្រីចាស់

១២១-សម្ព័ន្ធមេត្រីចាស់ជាវគ្គមួយនៃព្រះគម្ពីរដ៏វិសុទ្ធដែលមិនអាចកាត់ចោលបានជាដាច់ខាត។ ព្រះជាម្ចាស់បានបំភ្លឺអ្នកនិពន្ធកំណ្ឌសម្ព័ន្ធមេត្រីចាស់ដែលមានតម្លៃជានិច្ចតរៀងទៅ (DS ១៧៩; ១៣៣៤-១៣៣៦; ១៥០១-១៥០៤) ពីព្រោះព្រះអង្គមិនដែលដកហូតសម្ព័ន្ធមេត្រីចាស់នៅឡើយ។

១២២-"ព្រះជាម្ចាស់ចាត់ចែងសម្ព័ន្ធមេត្រីចាស់ ជាពិសេសសម្រាប់រៀបចំផ្លូវថ្វាយព្រះគ្រីស្ត ជាព្រះសង្គ្រោះនៃពិភពលោកយាងមក" (DV ១៥)។ ទោះបីកំណ្ឌគម្ពីរទាំងនោះ "មានចែងសេចក្តីមិនពេញលក្ខណៈដែលត្រូវបាត់បង់ក្តី" (DV ១៥) យ៉ាងណាក៏ដោយ ក៏កំណ្ឌទាំងនោះផ្តល់សក្ខីភាពអំពីគរុកោសល្យរបស់ព្រះជាម្ចាស់ដែលសង្គ្រោះមនុស្សលោកដោយក្តីស្រឡាញ់។ នៅក្នុងកំណ្ឌគម្ពីរទាំងនោះ "មានចែងគំនិតយ៉ាងច្បាស់អំពីព្រះអម្ចាស់ មានបង្រៀនសេចក្តីយ៉ាងជ្រាលជ្រៅអំពីព្រះអង្គ មានចែងអំពីប្រាជ្ញាញាណពោរពេញដោយសប្បុរសធម៌ចំពោះការរស់នៅរបស់មនុស្ស មានចែងសេចក្តីអធិដ្ឋានមួយចំនួនដ៏មានតម្លៃដ៏ប្រសើរបំផុត។ នៅទីបញ្ចប់ ក្នុងកំណ្ឌគម្ពីរទាំងនោះ មានបង្កប់ទុកនូវគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះរបស់យើងផង" (DV ១៥)។

១២៣-គ្រីស្តបរិស័ទគោរពសម្ព័ន្ធមេត្រីចាស់ដូចព្រះបន្ទូលយ៉ាងពិតប្រាកដរបស់ព្រះជាម្ចាស់។ ព្រះសហគមន៍តែងតែបដិសេធមិនព្រមឲ្យទាត់ចោលសម្ព័ន្ធមេត្រីចាស់ ដោយយកលេសថាសម្ព័ន្ធមេត្រីថ្មីជំនួសសម្ព័ន្ធមេត្រីចាស់ (Marcionism)។

## សម្ព័ន្ធមេត្រីថ្មី

១២៤-"ព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតជាឫទ្ធានុភាពរបស់ព្រះអង្គសម្រាប់សង្គ្រោះអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ។ ព្រះបន្ទូលនេះមានចែងទុកក្នុងកំណ្ឌគម្ពីរសម្ព័ន្ធមេត្រីថ្មី ហើយបង្ហាញឫទ្ធានុភាពយ៉ាងពិសេសក្នុងគម្ពីរនេះ" (DV ១៧)។ កំណ្ឌគម្ពីរទាំងនោះសម្តែងសេចក្តីពិតជាស្ថាពរនៃសេចក្តីដែលព្រះជាម្ចាស់សម្តែងឲ្យយើងស្គាល់។ ព្រះយេស៊ូគ្រីស្តដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស កិច្ចការ និងការប្រៀនប្រដៅរបស់ព្រះអង្គទុក្ខលំបាក និងសិរីរុងរឿងរបស់ព្រះអង្គ ហើយព្រះសហគមន៍ដើមដំបូងក្រោមកិច្ចការនៃព្រះវិញ្ញាណដ៏វិសុទ្ធជាស្នូលនៃកំណ្ឌទាំងអស់នោះ។

១២៥-ក្នុងព្រះគម្ពីរទាំងអស់ "ដំណឹងល្អដ៏ប្រសើរបំផុត ព្រោះកំណ្ឌគម្ពីរដំណឹងល្អផ្តល់សក្ខីភាពពិសេសស្តីអំពីជីវិត និងការប្រៀនប្រដៅរបស់ព្រះបន្ទូលប្រសូតជាមនុស្សដែលជាព្រះសង្គ្រោះរបស់យើង" (DV ១៨)។

១២៦-ប្រវត្តិកំណ្ឌដំណឹងល្អមានបីដំណាក់កាលគឺ៖

១-ជីវិត និងការប្រៀនប្រដៅរបស់ព្រះយេស៊ូ៖ "ព្រះសហគមន៍បានចាត់ទុក ហើយនៅតែចាត់ទុកយ៉ាងរឹងមាំដោយមិនដែលងាករេថា គម្ពីរដំណឹងល្អទាំងបួននោះ បញ្ជូនបន្តយ៉ាងពិតប្រាដនូវកិច្ចការទាំងប៉ុន្មានដែលព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់បានប្រព្រឹត្តយ៉ាងពិតប្រាកដ និងសេចក្តីទាំងប៉ុន្មានដែលព្រះអង្គបានបង្រៀននៅពេលព្រះអង្គរស់នៅក្នុងចំណោមមនុស្សលោក ដើម្បីសង្គ្រោះមនុស្សលោកអស់កល្បជានិច្ច

រហូតដល់ថ្ងៃដែលព្រះជាម្ចាស់បានលើកព្រះអង្គឡើងស្ថានបរមសុខ" (កក ១,១-២)។

២-ការបញ្ជូនបន្តពីមាត់មួយទៅមាត់មួយ៖ "ក្រោយពេលព្រះជាម្ចាស់បានលើកព្រះយេស៊ូឡើងស្ថានបរមសុខនោះ ក្រុមគ្រីស្តទូតក៏បានបញ្ជូនបន្តអំពីកិច្ចការទាំងប៉ុន្មានដែលព្រះអម្ចាស់យេស៊ូបានប្រព្រឹត្ត ព្រមទាំងសេចក្តីដែលព្រះអង្គមានព្រះបន្ទូលនោះ ឲ្យអ្នកដទៃស្តាប់ថែមទាំងនឹងយល់អត្ថន័យបានជ្រៅជាងពីមុន អំពីព្រឹត្តការណ៍ដ៏រុងរឿងរបស់ព្រះគ្រីស្តដែលបានសម្តែងឲ្យពួកគេយល់អត្ថន័យ ដោយមានពន្លឺនៃព្រះវិញ្ញាណ នៃសេចក្តីពិតបំភ្លឺចិត្តគំនិតរបស់គេដែរ"។

៣-កំណែដំណឹងល្អជាលាយលក្ខណ៍អក្សរ៖ "ហេតុនេះហើយអ្នកនិពន្ធដ៏សក្ការៈសរសេរកំណែគម្ពីរទាំងបួននោះ ដោយជ្រើសរើសឯកសារខ្លះ ក្នុងចំណោមឯកសារទាំងប៉ុន្មានដែលពួកគេបានស្តាប់តៗពីគេក្តី ឬជាឯកសារចែងជាលាយលក្ខណ៍អក្សររួចជាការស្រេចក្តី។ គេក៏សង្ខេបឯកសារខ្លះៗទៀត ឬពន្យល់ឯកសារខ្លះឲ្យសមស្របតាមសភាពការណ៍នៃព្រះសហគមន៍នានា។ គេចែងគម្ពីរដូចជាធម្មទេសនាម៉្យាង ដើម្បីបញ្ជូនសេចក្តីដ៏ពិតប្រាកដ និងត្រឹមត្រូវអំពីព្រះយេស៊ូជានិច្ច" (DV ១៩)។

១២៧-ដំណឹងល្អទាំងបួនកំណែមានសារៈសំខាន់ណាស់សម្រាប់ព្រះសហគមន៍។ ពិធីបុណ្យគោរពដំណឹងល្អយ៉ាងពិសេស ហើយដំណឹងល្អនោះបានទាក់ទាញសន្តបុគ្គលតាំងពីដើមរៀងមកយ៉ាងអស្ចារ្យ។

គ្មានលទ្ធិណាមួយល្អប្រសើរជាងមានតម្លៃដ៏ថ្លៃថ្នូរជាង និងល្អឥតខ្ចោះជាងអត្ថបទដំណឹងល្អទេ។ សូមមើល និងចងចាំអ្វីដែលព្រះអម្ចាស់ និងលោកគ្រូរបស់យើងជាព្រះគ្រីស្តបានបង្រៀនតាមព្រះបន្ទូល និងបានប្រព្រឹត្តតាមកិច្ចការរបស់ព្រះអង្គ (សន្តី សេសារ៉េ ក្មេង)។

នៅពេលស៊ឹងស្មាធិ៍ ខ្ញុំនឹកគិតដល់ដំណឹងល្អលើសពីអ្វីៗទាំងអស់។ ក្នុងដំណឹងល្អនេះ ខ្ញុំរកឃើញអ្វីដែលជាចាំបាច់សម្រាប់ព្រលឹងដ៏កម្សត់របស់ខ្ញុំ។ ខ្ញុំតែងតែរកឃើញពន្លឺថ្មីៗ អត្ថន័យលាក់កំបាំង និងអាថ៌កំបាំងផង (សន្តីថេរេសា នៃព្រះកុមារយេស៊ូ)។

## សម្ព័ន្ធមេត្រីចាស់ និងសម្ព័ន្ធមេត្រីថ្មីរួមគ្នាជាធ្លុងតែមួយ

១២៨-តាំងពីសម័យក្រុមគ្រីស្តទូតមកហើយ ក្នុងការបញ្ជូនបន្តជាបន្តបន្ទាប់ព្រះសហគមន៍តែងតែបំភ្លឺឯកភាពនៃគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីទាំងពីរ ដោយប្រៀបធៀបព្រះរាជកិច្ចរបស់ព្រះជាម្ចាស់ក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ជាមួយនឹងអ្វីដែលព្រះអង្គបានបំពេញនៅពេលកំណត់បានគ្រប់លក្ខណៈនៅក្នុងអង្គព្រះបុត្រារបស់ព្រះអង្គប្រសូតជាមនុស្ស។

១២៩-ដូច្នេះហើយបានជាគ្រីស្តបរិស័ទអានគម្ពីរសម្ព័ន្ធមេត្រីចាស់ក្រោមពន្លឺនៃព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មី។ របៀបអានបែបនេះសម្តែងនូវសេចក្តីដែលមិនចេះអស់មិនចេះហើយនៃគម្ពីរសម្ព័ន្ធមេត្រីចាស់។ យើងមិនត្រូវភ្លេចតម្លៃនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ផ្ទាល់ដូចព្រះអម្ចាស់នៃយើងបានបញ្ជាក់ដែរ (មក ១២,២៩-៣១)។ ម៉្យាងទៀត ត្រូវតែអានគម្ពីរសម្ព័ន្ធមេត្រីថ្មីក្រោមពន្លឺនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ដូចអ្នកបង្រៀនគ្រីស្តបរិស័ទដើមដំបូងតែងតែធ្វើដូច្នេះដែរ (១ករ ៥,៦-៨; ១០,១-១១)។ តាមពាក្យបុរាណ "ព្រះជាម្ចាស់បង្កប់ទុកគម្ពីរសម្ព័ន្ធមេត្រីថ្មីក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ ហើយគម្ពីរសម្ព័ន្ធមេត្រីចាស់ក៏ទទួលអត្ថន័យយ៉ាងពេញលេញដោយសារគម្ពីរសម្ព័ន្ធមេត្រីថ្មីដែរ" (សន្តៈ អូគូស្តាំង)។

១៣០-របៀបអានព្រះគម្ពីរបែបនេះសម្ដែងនូវចលនានៃគម្រោងការរបស់ព្រះជាម្ចាស់នៅពេល "ព្រះអង្គបានគ្រងរាជ្យលើអ្វីៗទាំងអស់គ្រប់ប្រការ" (១ករ ១៥,២៨)។ ហេតុនេះហើយបានជាការត្រាស់ហៅរបស់បុព្វបុរស និងដំណើរឆ្លងទៅកាន់សេរីភាព (ឧទាហរណ៍) នៅតែមានតម្លៃក្នុងគម្រោងការរបស់ព្រះជាម្ចាស់ ដ្បិតកំណែនោះជាដំណាក់កាលនៃគម្រោងការនេះដែរ។

## ៥-ព្រះគម្ពីរដ៏វិសុទ្ធក្នុងការរស់នៅរបស់ព្រះសហគមន៍

១៣១-"ឫទ្ធានុភាព និងព្រះចេស្ដាបង្កប់ទុកក្នុងព្រះគម្ពីរយ៉ាងជ្រាលជ្រៅបំផុត បានជាព្រះសហគមន៍អាចយកព្រះគម្ពីរធ្វើជាទីពំនឹងដ៏រឹងមាំ និងធ្វើជាកម្លាំងផង។ បុត្រធីតានៃព្រះសហគមន៍ក៏អាចយកគម្ពីរធ្វើជាកម្លាំងនៃជំនឿ ជាអាហាររបស់គេ និងធ្វើជាប្រភពដ៏ថ្លៃថ្លាដែលមិនចេះរីងស្ងួតនៃជីវិតខាងវិញ្ញាណរបស់គេទៀតដែរ" (DV ២១)។ ហេតុនេះហើយបានជា "ត្រូវឲ្យគ្រីស្តបរិស័ទអាចឈានទៅកាន់ព្រះគម្ពីរយ៉ាងស្រួលបំផុត" (DV ២២)។

១៣២-"សូមចាត់ការសិក្សាព្រះគម្ពីរដ៏វិសុទ្ធទុកជាព្រលឹងនៃទេវវិទ្យា។ សូមឲ្យអស់អ្នកបម្រើព្រះបន្ទូល គឺអ្នកសម្ដែងធម្មទេសនា អ្នកបង្រៀនក្មេងៗ និងអ្នកចំណូលថ្មី អ្នកបង្រៀនគ្រីស្តបរិស័ទគ្រប់យ៉ាង អ្នកធ្វើអត្ថាធិប្បាយក្នុងពិធីបុណ្យនានា រកឃើញអាហារដ៏ឆ្ងាញ់ពិសា និងមានកម្លាំងដ៏វិសុទ្ធ យោងពីព្រះបន្ទូលដែលមានកត់ត្រាទុកក្នុងព្រះគម្ពីរផង" (DV ២៤)។

១៣៣-ព្រះសហគមន៍ "ដាស់តឿនគ្រីស្តបរិស័ទយ៉ាងខ្លាំងជាទីបំផុត (...) ឲ្យរៀន "ចំណេះដ៏វិសេសវិសាលដែលនៅក្នុងព្រះគម្ពីរ (ភីល ៣.៨) ដោយអានព្រះគម្ពីរជារឿយៗ ដ្បិត "អ្នកដែលមិនស្គាល់ព្រះគម្ពីរក៏មិនស្គាល់ព្រះគ្រីស្តដែរ" (សន្ត: យេរ៉ូម) (DV ២៥)។

## សង្ខេប

១៣៤-"ព្រះគម្ពីរទាំងមូលជាសៀវភៅតែមួយ ហើយសៀវភៅនេះ គឺជាព្រះគ្រីស្ត ដ្បិតព្រះគម្ពីរទាំងមូលស្ដីអំពីព្រះគ្រីស្ត ហើយព្រះគ្រីស្តបំពេញព្រះគម្ពីរទាំងមូល (លោក អូក នៃសន្ត: វិកតូរ)។

១៣៥-"ក្នុងព្រះគម្ពីរមានកត់ត្រាទុកព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដោយព្រះអង្គបានបំភ្លឺចិត្តគំនិតអ្នកនិពន្ធព្រះគម្ពីរ ដូច្នេះព្រះគម្ពីរពិតជាព្រះបន្ទូលរបស់ព្រះអង្គមែន" (DV ២៤)។

១៣៦-ព្រះជាម្ចាស់ជាអ្នកនិពន្ធព្រះគម្ពីរដ៏វិសុទ្ធ ដោយបំភ្លឺមនុស្សឲ្យនិពន្ធព្រះគម្ពីរ។ ព្រះអង្គប្រព្រឹត្តនៅក្នុងពួកគេ និងតាមរយៈពួកគេ។ ដូច្នេះព្រះអង្គធានាថា ព្រះគម្ពីរប្រៀនប្រដៅសេចក្ដីពិតអំពីការសង្គ្រោះ ដោយគ្មានកំហុសឡើយ (DV ១១)។

១៣៧-ដើម្បីបកស្រាយព្រះគម្ពីរដែលព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺ ត្រូវតែយកចិត្តទុកដាក់នឹងអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យសម្ដែងឲ្យដឹង ដើម្បីសង្គ្រោះយើងតាមរយៈអ្នកនិពន្ធដ៏សក្ការៈ។ "យើងអាចយល់អ្វីៗដែលមកពីព្រះវិញ្ញាណ ដោយសារការណែនាំរបស់ព្រះវិញ្ញាណតែប៉ុណ្ណោះ" (លោក អូរីសែន)។

១៣៨-ព្រះសហគមន៍ទទួល និងគោរពប្រណិប័តន៍ ៤៦ កណ្ឌនៃសម្ពន្ធមេត្រីចាស់ និង ២៧ កណ្ឌនៃសម្ពន្ធមេត្រីថ្មី ដោយចាត់ទុកថា ព្រះវិញ្ញាណដ៏វិសុទ្ធបានជួយបំភ្លឺអ្នកនិពន្ធ។

១៣៩-គម្ពីរដំណឹងល្អទាំងបួនកណ្ឌមានសារៈសំខាន់ណាស់ ដ្បិតព្រះយេស៊ូជាស្នូលនៃកណ្ឌទាំងអស់នោះ។

១៤០-ឯកភាពនៃសម្ព័ន្ធមេត្រីទាំងពីរមកពីឯកភាពនៃគម្រោងការរបស់ព្រះជាម្ចាស់ និងការសម្តែងរបស់ព្រះអង្គផងដែរ។ សម្ព័ន្ធមេត្រីចាស់រៀបចំសម្ព័ន្ធមេត្រីថ្មី ឯសម្ព័ន្ធមេត្រីថ្មីបំពេញសម្ព័ន្ធមេត្រីចាស់វិញ។ សម្ព័ន្ធមេត្រីទាំងពីរបំភ្លឺគ្នាទៅវិញទៅមក សម្ព័ន្ធមេត្រីទាំងពីរពិតជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

១៤១-"តាំងពីដើមរៀងមក ព្រះសហគមន៍តែងតែគោរពប្រណិប័តន៍ព្រះគម្ពីរជានិច្ច ដូចព្រះសហគមន៍ធ្លាប់គោរពប្រណិប័តន៍ព្រះកាយផ្ទាល់របស់ព្រះអម្ចាស់ដែរ" (DV ២១)។ ព្រះគម្ពីរ និងព្រះកាយបំប៉ន និងណែនាំការរស់នៅទាំងស្រុងរបស់គ្រីស្តបរិស័ទ។ "ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាចង្កៀងបំភ្លឺជំហានទូលបង្គំ និងជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ" (ទន ១១៩,១០៥) (អស ៥០,៤)។

# ជំពូកទីបី៖

# មនុស្សឆ្លើយតបនឹងព្រះជាម្ចាស់

១៤២-"ព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យមនុស្សមើលឃើញ ដោយសារព្រះអង្គប្រកបដោយព្រះហឫទ័យស្រឡាញ់ដ៏ទូលំទូលាយ ទ្រង់មានព្រះបន្ទូលមករកមនុស្សដូចជាមករកមិត្តសម្លាញ់របស់ព្រះអង្គ ព្រះអង្គសន្ទនាជាមួយពួកគេដើម្បីអញ្ជើញគេ និងទទួលគេឲ្យរួមចំណែកក្នុងព្រះជន្មផ្ទាល់របស់ព្រះអង្គ" (DV ២)។ មនុស្សឆ្លើយតបនឹងព្រះជាម្ចាស់យ៉ាងត្រឹមត្រូវនៅពេលគេផ្ញើជីវិតលើព្រះអង្គ។

១៤៣-ដោយសារជំនឿមនុស្សសុខចិត្តផ្ញើប្រាជ្ញា និងបំណងទាំងស្រុងរបស់ខ្លួនទៅលើព្រះជាម្ចាស់។ អស់ពីកម្លាំងកាយចិត្តមនុស្សផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ដែលសម្តែងព្រះអង្គឲ្យគេស្គាល់ (DV ៥)។ ព្រះគម្ពីរហៅចម្លើយរបស់មនុស្សទៅលើព្រះជាម្ចាស់ដែលសម្តែងព្រះអង្គនោះថា "ការស្តាប់បង្គាប់នៃជំនឿ"។

# ប្រការទី១៖

# ខ្ញុំជឿ

## ១-ការស្តាប់បង្គាប់នៃជំនឿ

១៤៤-តាមជំនឿយើងស្តាប់បង្គាប់ព្រះជាម្ចាស់ ដោយផ្ញើជីវិតទាំងស្រុងទៅលើព្រះបន្ទូលដែលយើងស្តាប់ ដ្បិតព្រះជាម្ចាស់ដែលខ្លួនព្រះអង្គជាសេចក្តីពិតធានាសេចក្តីពិតនៃព្រះបន្ទូលនេះ។ លោក អប្រាហាំ ជាគំរូនៃការស្តាប់បង្គាប់នេះដែលព្រះគម្ពីរស្នើសុំឲ្យយើងយកតម្រាប់តាម។ ព្រះនាងម៉ារីធ្វើឲ្យការស្តាប់បង្គាប់នេះបានពេញលក្ខណៈ។

### លោក អប្រាហាំ៖ "លោកឪពុករបស់អ្នកជឿទាំងឡាយ"

១៤៥-លិខិតផ្ញើជូនគ្រីស្តបរិស័ទជាតិហេប្រឺបានសរសើរជំនឿរបស់បុព្វបុរស ជាពិសេសជំនឿរបស់លោក អប្រាហាំ៖ "ដោយសារជំនឿលោក អប្រាហាំ ស្តាប់បង្គាប់ព្រះជាម្ចាស់ ដែលបានត្រាស់ហៅលោក ហើយចេញដំណើរទៅកាន់ស្រុកមួយដែលលោកនឹងទទួលទុកជាមរតក។ លោកចេញដំណើរទៅដោយពុំដឹងថាត្រូវទៅទីណាផង" (ហប ១១,៨) (កណ ១២,១-៤)។ ដោយសារជំនឿលោកបានរស់នៅដូចជាជនបរទេស និងដូចជាបូជនីយេសក៍ម្នាក់នៅក្នុងទឹកដីសន្យា (កណ ២៣,៤)។ ដោយសារជំនឿនាង សារ៉ា ទទួលបុត្រនៃព្រះបន្ទូលសន្យា។ ទីបញ្ចប់ដោយសារជំនឿ

លោក អប្រាហាំ យកបុត្រតែមួយរបស់លោកធ្វើយញ្ញបូជា (ហប ១១,១៧)។

១៤៦-ហេតុនេះលោក អប្រាហាំ ជារូបតំណាងនៃជំនឿ ដូចមានចែងក្នុងលិខិតផ្ញើជូនគ្រីស្តបរិស័ទជាតិហេប្រឺថា៖ "ជំនឿធ្វើឲ្យយើងមានអ្វីៗដែលយើងសង្ឃឹមថានឹងបាន និងធ្វើឲ្យស្គាល់ជាក់ច្បាស់នូវអ្វីៗដែលយើងមើលពុំឃើញ" (ហប ១១,១)។ ដោយសារ "ជំនឿដ៏មាំមួន" នេះ (រម ៤,២០) (កណ ១៥,៦) លោក អប្រាហាំ បានទៅជា "ឪពុករបស់អស់អ្នកដែលនឹងមានជំនឿ" (រម ៤,១១.១៨) (កណ ១៥,៥)។

១៤៧-គម្ពីរសម្ពន្ធមេត្រីចាស់ផ្តល់សក្ខីភាពជាច្រើនអំពីជំនឿនេះ។ លិខិតផ្ញើជូនគ្រីស្តបរិស័ទជាតិហេប្រឺប្រកាស និងសរសើរជំនឿដ៏គួរឲ្យយកតម្រាប់តាមនៃបុព្វបុរស "ដែលបានទទួលសក្ខីភាពល្អ" (ហប ១១,២.៣៩)។ ប៉ុន្តែ "ព្រះជាម្ចាស់គ្រោងទុកជាមុនថានឹងប្រទានអ្វីៗដ៏ល្អប្រសើរមកយើង"៖ ព្រះអង្គប្រោសប្រណីយើងឲ្យអាចមានជំនឿលើព្រះបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូ "ដែលជាដើមកំណើតនៃជំនឿ ហើយធ្វើឲ្យជំនឿបានគ្រប់លក្ខណៈ" (ហប ១១,៤០; ១២,២)។

### ព្រះនាងម៉ារី៖ "អ្នកដែលបានជឿមានសុភមង្គលហើយ"

១៤៨-ស្រ្តីព្រហ្មចារិនីម៉ារីបំពេញការស្តាប់បង្គាប់នៃជំនឿឲ្យបានគ្រប់លក្ខណៈ។ ដោយសារជំនឿ នាងម៉ារីបានទទួលសេចក្តីប្រកាស និងព្រះបន្ទូលសន្យាជូនដោយទេវទូតកាព្រីអែលថែមទាំងជឿថា "គ្មានអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើត" (លក ១,៣៧) (កណ ១៨,១៤) និងសុខចិត្តធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់៖ "នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់សូមឲ្យបានសម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គ" (លក ១,៣៨)។ នាង អេលីសាបិតបានជម្រាបនាងម៉ារីថា៖ "នាងពិតជាមានសុភមង្គលមែន ព្រោះនាងបានជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់" (លក ១,៤៥)។ ដោយសារជំនឿនេះគ្រប់ជំនាន់នឹងពោលថានាងពិតជាមានសុភមង្គលមែន (លក ១,៤៨)។

១៤៩-អស់មួយជីវិតរហូតដល់ទុក្ខលំបាកចុងក្រោយបំផុត (លក ២,៣៥) គឺនៅពេលព្រះយេស៊ូជាបុត្ររបស់នាងបានសោយទិវង្គតនៅលើឈើឆ្កាង នាងម៉ារីនៅតែមានជំនឿរឹងមាំ។ នាងម៉ារីមិនដែលឈប់ជឿថាព្រះបន្ទូលរបស់ព្រះជាម្ចាស់នឹង "កើតជារូបរាង"។ ហេតុនេះហើយបានជាព្រះសហគមន៍គោរពនាងម៉ារី ដ្បិតនាងធ្វើឲ្យជំនឿបានគ្រប់លក្ខណៈជាទីបំផុត។

## ២-"ខ្ញុំដឹងថា ខ្ញុំបានជឿលើព្រះអង្គណា" (២ធម ១,១២)

### ជឿលើព្រះជាម្ចាស់តែមួយព្រះអង្គគត់

១៥០-អ្នកជឿរៀងៗខ្លួនភ្ជាប់ចិត្តទាំងស្រុងទៅលើព្រះជាម្ចាស់ ហើយនៅពេលជាមួយគ្នា យល់ស្របនឹងសេចក្តីពិតគ្រប់ប្រការដែលព្រះជាម្ចាស់បានសម្តែងមក។ ដោយសារអ្នកជឿរៀងៗខ្លួនភ្ជាប់ចិត្តទាំងស្រុងទៅលើព្រះជាម្ចាស់ និងយល់ស្របនឹងសេចក្តីពិតដែលព្រះជាម្ចាស់បានសម្តែងមកជំនឿរបស់គ្រីស្តបរិស័ទខុសប្លែកពីជំនឿទៅលើបុគ្គលម្នាក់ គឺអ្នកណាផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ និងជឿជាក់លើព្រះបន្ទូលរបស់ព្រះអង្គ អ្នកនោះធ្វើការល្អត្រឹមត្រូវ ឯនរណាមានជំនឿបែបនេះទៅលើសត្វលោកណាមួយ អ្នកនោះពិតជាធ្វើខុស និងឥតបានការ (យរ ១៧,៥-៦; ទន ៤០,៥; ១៤៦,៣-៤)។

### ជឿលើព្រះយេស៊ូគ្រីស្ដជាព្រះបុត្រារបស់ព្រះជាម្ចាស់

១៥១-ចំពោះគ្រីស្ដបរិស័ទពេលយើងជឿលើព្រះជាម្ចាស់ យើងក៏ជឿលើអ្នកដែលព្រះអង្គបានចាត់ឲ្យមកគឺ "បុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ" ជាទីគាប់ព្រះហឫទ័យរបស់ព្រះអង្គ (មក ១,១១) ព្រះជាម្ចាស់មានព្រះបន្ទូលមកយើងថាត្រូវតែស្ដាប់ព្រះបុត្រារបស់ព្រះអង្គ (មក ៩,៧)។ ព្រះអម្ចាស់ផ្ទាល់មានព្រះបន្ទូលទៅក្រុមសាវ័កថា "អ្នករាល់គ្នាជឿលើព្រះជាម្ចាស់ ហើយចូរជឿលើខ្ញុំផង" (យហ ១៤,១)។ យើងអាចជឿលើព្រះយេស៊ូគ្រីស្ដ ព្រោះព្រះអង្គផ្ទាល់ជាព្រះជាម្ចាស់ ជាព្រះបន្ទូលប្រសូតជាមនុស្ស៖ "ពុំដែលមាននរណាម្នាក់បានឃើញព្រះជាម្ចាស់ឡើយ មានតែបុត្រាមួយព្រះអង្គប៉ុណ្ណោះ ដែលបាននាំយើងឲ្យស្គាល់ព្រះអង្គ ដ្បិតព្រះបុត្រាមានព្រះជន្មរួមជាមួយព្រះបិតា" (យហ ១,១៨)។ ដោយសារព្រះអង្គបាន "ឃើញព្រះបិតា" (យហ ៦,៤៦) មានតែព្រះអង្គប៉ុណ្ណោះដែលស្គាល់ និងអាចសម្ដែងព្រះបិតាបាន (មថ ១១,២៧)។

### ជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ

១៥២-យើងមិនអាចជឿលើព្រះយេស៊ូគ្រីស្ដបានឡើយ បើយើងមិនរួមចំណែកក្នុងព្រះវិញ្ញាណរបស់ព្រះអង្គទេ គឺព្រះវិញ្ញាណដ៏វិសុទ្ធដែលសម្ដែងឲ្យមនុស្សលោកដឹងថាព្រះយេស៊ូគ្រីស្ដជានរណា ដ្បិត "បើគ្មានព្រះវិញ្ញាណណែនាំទេ ក៏គ្មាននរណាម្នាក់អាចពោលថា "ព្រះយេស៊ូជាព្រះអម្ចាស់" បានឡើយ" (១ករ ១២,៣)។ "ព្រះវិញ្ញាណឈ្វេងយល់អ្វីៗទាំងអស់ សូម្បីតែជម្រៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ក៏ទ្រង់ឈ្វេងយល់ដែរ (...) គ្មាននរណាម្នាក់យល់អំពីព្រះជាម្ចាស់បានក្រៅពីព្រះវិញ្ញាណរបស់ព្រះអង្គនោះឡើយ" (១ករ ២,១០-១១)។ មានតែព្រះជាម្ចាស់ទេដែលស្គាល់ព្រះជាម្ចាស់ទាំងស្រុង។ យើងជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ពីព្រោះព្រះអង្គជាព្រះជាម្ចាស់។

ព្រះសហគមន៍នៅតែប្រកាសជំនឿរបស់ខ្លួនលើព្រះជាម្ចាស់តែមួយ គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាញដ៏វិសុទ្ធ។

## ៣-លក្ខណៈនៃជំនឿ

### ជំនឿមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់

១៥៣-នៅពេលសន្ដៈ សិលា ប្រកាសថាព្រះយេស៊ូជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ព្រះយេស៊ូមានព្រះបន្ទូលប្រកាសប្រាប់លោកថា "អ្នកដឹងសេចក្ដីនេះមិនមែនដោយខ្លួនឯងទេ គឺព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខបានសម្ដែងឲ្យអ្នកដឹង" (មថ ១៦,១៧) (កាឡ ១,១៥; មថ ១១,២៥)។ ជំនឿជាព្រះអំណោយទានរបស់ព្រះជាម្ចាស់គុណធម៌ហួសធម្មជាតិ ដែលព្រះអង្គប្រោសប្រទាន។ "ព្រះជាម្ចាស់ត្រូវតែជួយបំភ្លឺជាមុន ទើបមនុស្សមានជំនឿបាន ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវតែជួយគេនៅខាងក្នុង គឺព្រះវិញ្ញាណប្រែចិត្តទៅរកព្រះជាម្ចាស់ បើកភ្នែកនៃវិញ្ញាណ និងប្រោសប្រទានឲ្យអស់អ្នកជឿសប្បាយដោយសុខចិត្តជឿសេចក្ដីពិត។ ព្រះវិញ្ញាណដ៏វិសុទ្ធនៅតែប្រទានព្រះអំណោយទានសម្រាប់ឲ្យជំនឿនេះកាន់តែប្រសើរឡើងៗ ដើម្បីឲ្យគេយល់កាន់តែច្បាស់នូវសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងមកនោះ" (DV ៥)។

### ជំនឿជាកិច្ចការរបស់មនុស្ស

១៥៤-ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវតែប្រោសប្រណី និងជួយនៅខាងក្នុង ទើបមនុស្សអាចជឿបាន ប៉ុន្តែជំនឿជាកិច្ចការដ៏ពិតប្រាកដរបស់មនុស្សដែរ។ អ្នកដែលជឿទុកចិត្តលើព្រះជាម្ចាស់ យល់ស្របនឹងសេចក្ដីពិតដែលព្រះអង្គបាន

សម្តែង ហើយក៏មិនប្រឆាំងនឹងសេរីភាព និងប្រាជ្ញារបស់ខ្លួនទេ។ នៅក្នុងទំនាក់ទំនងរវាងមនុស្សយើងក៏មិនប្រឆាំងនឹងឋានៈដ៏ថ្លៃថ្នូររបស់ខ្លួន ដោយជឿនូវអ្វីៗដែលអ្នកផ្សេងនិយាយប្រាប់យើងអំពីខ្លួនគេ និងបំណងរបស់គេដោយជឿទុកចិត្តនឹងពាក្យសន្យារបស់គេ (ឧ. នៅពេលដែលបុរស និងស្ត្រីម្នាក់រៀបការ) ដើម្បីអាចរួមជាមួយគ្នាបាន។ ដូច្នេះហើយបានជាយើងក៏មិនប្រឆាំងនឹងឋានៈដ៏ថ្លៃថ្នូររបស់យើងនៅពេលដែល "ដោយសារជំនឿ យើងធ្វើប្រាជ្ញា និងបំណងទាំងស្រុងរបស់ខ្លួនទៅលើព្រះជាម្ចាស់ដែលសម្តែងព្រះអង្គ" (DS ៣០០៨) ដើម្បីអាចរួមជាមួយព្រះអង្គយ៉ាងស្និទ្ធស្នាលបានដែរ។

១៥៥-នៅក្នុងជំនឿប្រាជ្ញា និងបំណងរបស់មនុស្ស រួមជាមួយព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់៖ "អ្នកជឿប្រព្រឹត្តកិច្ចការមួយ ដែលប្រាជ្ញារបស់ខ្លួនយល់ស្របនឹងសេចក្តីពិតរបស់ព្រះជាម្ចាស់ក្រោមបញ្ជានៃបំណងរបស់ខ្លួន ដែលព្រះជាម្ចាស់ជំរុញដោយព្រះហឫទ័យប្រោសប្រណី" (សន្តៈ ថូម៉ាសនៃអាកាំង)។

## ជំនឿ និងប្រាជ្ញា

១៥៦-យើងជឿមិនមែនមកពីមូលហេតុថា ប្រាជ្ញារបស់យើងយល់ឃើញថាសេចក្តីពិតដែលព្រះជាម្ចាស់សម្តែងមកដូចជាពិតប្រាកដ និងអាចយល់បានទេ គឺយើងជឿដោយសារ "អំណាចរបស់ព្រះជាម្ចាស់ផ្ទាល់ដែលសម្តែងមិនអាចភ័ន្តច្រឡំ ហើយដែលគ្មានព្រះហឫទ័យបោកបញ្ឆោតយើងទេ"។ "ប៉ុន្តែដើម្បីឲ្យជំនឿស្របនឹងប្រាជ្ញា ព្រះជាម្ចាស់សព្វព្រះហឫទ័យថាភស្តុតាងខាងក្រៅនៃសេចក្តីដែលព្រះជាម្ចាស់សម្តែង ជួយកំដរព្រះវិញ្ញាណដ៏វិសុទ្ធដែលជួយមនុស្សខាងក្នុងដែរ" (DS ៣០០៩)។ ហេតុនេះហើយបានជាការអស្ចារ្យរបស់ព្រះគ្រីស្ត និងរបស់សន្តបុគ្គល (មក ១៦,២០; ហប ២,៤) ព្យាករណ៍ការរីកចម្រើន ភាពដ៏វិសុទ្ធ ផលផ្លែ និងស្ថិរភាពនៃព្រះសហគមន៍ជា "សញ្ញាសម្គាល់យ៉ាងច្បាស់លាស់នៃសេចក្តីដែលព្រះជាម្ចាស់សម្តែងស្របនឹងប្រាជ្ញារបស់មនុស្សទាំងអស់" និងជា "មូលហេតុដែលនាំឲ្យជឿ" ដែលបង្ហាញថាជំនឿមិន "ប្រឆាំងនឹងវិញ្ញាណ" ទេ (DS ៣០០៨-៣០១០)។

១៥៧-ជំនឿជាសេចក្តីពិតប្រាកដមែន ប្រាកដជាងចំណេះដឹងណាមួយរបស់មនុស្ស ដ្បិតជំនឿចាក់គ្រឹះលើព្រះបន្ទូលផ្ទាល់របស់ព្រះជាម្ចាស់ដែលមិនអាចបោកបញ្ឆោតបានឡើយ។ សេចក្តីពិតដែលព្រះជាម្ចាស់សម្តែងអាចដូចជាមិនសូវច្បាស់លាស់ចំពោះប្រាជ្ញា និងពិសោធន៍មនុស្សលោក ប៉ុន្តែ "ពន្លឺរបស់ព្រះជាម្ចាស់បំភ្លឺមនុស្សយ៉ាងច្បាស់ និងខ្លាំងជាងពន្លឺរបស់ប្រាជ្ញា" (សន្តៈ ថូម៉ាសនៃអាកាំង)។

១៥៨-"អ្នកជឿចង់ស្វែងយល់" (សន្តៈ អង់សេលម៍)។ ដោយសារជំនឿ អ្នកជឿចង់ស្គាល់កាន់តែច្បស់លាស់ព្រះអង្គណាដែលខ្លួនបានជឿ ហើយចង់ឈ្វេងយល់ឲ្យរឹតតែច្បាស់លាស់ថែមទៀតនូវសេចក្តីដែលព្រះអង្គបានសម្តែងមក។ ពេលយើងស្គាល់ព្រះអង្គកាន់តែស៊ីជម្រៅ ជំនឿរបស់យើងក៏រីកចម្រើនឡើងៗពោរពេញដោយសេចក្តីស្រឡាញ់កាន់តែខ្លាំងទៅៗ។ ជំនឿ "បំភ្លឺចិត្តគំនិត" (អភ ១,១៨) ដើម្បីឲ្យយើងយល់ច្បាស់ និងយ៉ាងសកម្មអំពីសេចក្តីដែលព្រះជាម្ចាស់សម្តែង គឺគម្រោងការទាំងស្រុងនៃព្រះជាម្ចាស់ និងអាថ៌កំបាំងផ្សេងៗនៃជំនឿ ហើយអំពីទំនាក់ទំនងរវាងគម្រោងការនៃព្រះអង្គ អាថ៌កំបាំងនៃជំនឿនោះ ជាមួយនឹងព្រះគ្រីស្តដែលជាស្នូលនៃអាថ៌កំបាំងដែលព្រះជាម្ចាស់សម្តែង។ "ព្រះវិញ្ញាណដ៏វិសុទ្ធនៅតែផ្តល់ព្រះអំណោយទានសម្រាប់ឲ្យជំនឿនេះកាន់តែប្រសើរឡើងៗ ដើម្បីឲ្យគេយល់កាន់តែច្បាស់នូវសេចក្តីដែលព្រះជាម្ចាស់បានសម្តែងមកនោះ" (DV ៥)។ ហេតុនេះតាមពាក្យចាស់របស់សន្តៈ អូគូស្តាំង ឲ្យថា "ខ្ញុំជឿដើម្បីយល់ ហើយខ្ញុំយល់ដើម្បីជឿកាន់តែប្រសើរឡើងៗ"។

១៥៩-ជំនឿ និងវិទ្យាសាស្ត្រ។ "ទោះបីជំនឿលើសប្រាជ្ញាយ៉ាងណាក៏ដោយ ក៏ជំនឿ និងប្រាជ្ញាមិនអាចប្រឆាំង

នឹងគ្នាបានទេ។ ដោយសារមានព្រះជាម្ចាស់តែមួយដែលបានសម្ដែងគម្រោងការផ្សេងៗ និងប្រោសប្រទានជំនឿ ហើយដែលបានបញ្ចុះពន្លឺនៃប្រាជ្ញានៅក្នុងវិញ្ញាណរបស់មនុស្ស ព្រះជាម្ចាស់មិនអាចបដិសេធខ្លួនព្រះអង្គបានទេ ដូចការពិតមិនអាចប្រឆាំងនឹងការពិតដែរ"។ "ហេតុនេះហើយបានជាការស្វែងរកតាមក្បួនវិធីក្នុងគ្រប់វិស័យនៃចំណេះដឹងមិនដែលជំទាស់នឹងជំនឿទេ លុះត្រាតែគេស្វែងរកតាមរបៀបបច្ចេកទេសយ៉ាងពិតប្រាកដ និងត្រូវតាមវិន័យនៃសីលធម៌។ អ្វីៗដែលស្ថិតនៅក្នុងលោកនេះ និងជំនឿហូរចេញមកពីព្រះជាម្ចាស់តែមួយព្រះអង្គ ជាប្រភពតែមួយ។ លើសពីនេះទៅទៀត អ្នកខិតខំស្វែងរកទីស្ងាត់កំបាំងនៃវត្ថុទាំងអស់ដោយចិត្តព្យាយាម និងដោយចេះបន្ទាបខ្លួន ទោះបីអ្នកនោះមិនដឹងខ្លួនក្ដី ក៏ព្រះជាម្ចាស់ណែនាំគេដែរ គឺព្រះអង្គដែលទ្រទ្រង់សត្វលោកទាំងអស់ និងប្រោសឲ្យសត្វលោកទាំងអស់មានលក្ខណៈផ្ទាល់របស់ខ្លួន" (GS ៣៦,២)។

### សេរីភាពខាងជំនឿ

១៦០-"មនុស្សត្រូវតែស្ម័គ្រចិត្តឆ្លើយតបនឹងព្រះជាម្ចាស់។ ដូច្នេះហើយបានជាគ្មាននរណាម្នាក់អាចបង្ខិតបង្ខំម្នាក់ផ្សេងឲ្យជឿ បើអ្នកនោះមិនព្រមជឿឡើយ" (DH ១០; CIC ៧៤៨,២) "ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យបម្រើព្រះអង្គខាងវិញ្ញាណ និងសេចក្ដីពិត បើព្រះជាម្ចាស់ត្រាស់ហៅមនុស្សនៅក្នុងស៊ីជម្រៅចិត្តគំនិត ព្រះអង្គមិនបង្ខំគេទេ (...) ដូចយើងអាចមើលឃើញនៅក្នុងអង្គព្រះគ្រីស្ដយេស៊ូ" (DH ១១)។ ព្រះគ្រីស្ដបានអញ្ជើញឲ្យជឿ និងឲ្យកែប្រែចិត្តគំនិត តែព្រះអង្គមិនដែលបង្ខំនរណាម្នាក់ឡើយ។ "ព្រះគ្រីស្ដបានផ្ដល់សក្ខីភាពចំពោះសេចក្ដីពិត តែព្រះអង្គគ្មានព្រះហឫទ័យបង្ខំអ្នកប្រឆាំងនឹងព្រះអង្គឡើយ។ ព្រះរាជ្យរបស់ព្រះអង្គ (...) រីកចម្រើនដោយសារសេចក្ដីស្រឡាញ់ដែលព្រះគ្រីស្ដនៅលើឈើឆ្កាងសម្ដែងដើម្បីទាក់ទាញមនុស្សទាំងអស់ទៅរកព្រះអង្គ" (DH ១១)។

### ត្រូវតែជឿជាចាំបាច់

១៦១-ត្រូវតែជឿជាចាំបាច់លើព្រះយេស៊ូគ្រីស្ដ និងលើព្រះអង្គណាដែលបានចាត់ព្រះអង្គឲ្យមកសង្គ្រោះយើង ដើម្បីទទួលការសង្គ្រោះនោះ ដ្បិត "បើគ្មានជំនឿ គ្មាននរណាអាចគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់" (ហប ១១,៦) អាចទៅជាបុត្រធីតារបស់ព្រះអង្គ និងអាចទៅជាមនុស្សសុចរិតបានឡើយ ហើយគ្មាននរណានឹងទទួលជីវិតអស់កល្បជានិច្ច លុះត្រាតែគេបាន "ស៊ូទ្រាំរហូតដល់ទីបំផុត" (មថ ១០,២២; ២៤,១៣) (DS ៣០១២; DS ១៥៣២)។

### ត្រូវតែមានចិត្តព្យាយាម

១៦២-ជំនឿជាព្រះអំណោយទានឥតគិតថ្លៃដែលព្រះជាម្ចាស់ប្រទានឲ្យមនុស្សលោក តែយើងអាចបាត់បង់ព្រះអំណោយទានដ៏មានតម្លៃបំផុតនោះបាន។ សន្ដៈ ប៉ូល ព្រមានលោក ធីម៉ូថេ ថា៖ "ចូរពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីពុះពារប្រយុទ្ធឲ្យបានល្អប្រសើរដោយមានជំនឿ និងមានមនសិការល្អ។ អ្នកខ្លះលែងមានមនសិការល្អនេះបណ្ដាលឲ្យជំនឿរបស់គេលិចលង់" (១ធម ១,១៨-១៩)។ ដើម្បីរស់រីកចម្រើន និងព្យាយាមតស៊ូរហូតដល់ទីបំផុតស្របតាមជំនឿ យើងត្រូវតែផ្ដត់ផ្គង់ជំនឿដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងត្រូវតែទូលអង្វរព្រះអម្ចាស់ឲ្យព្រះអង្គពង្រឹងជំនឿ (មក ៩,២៤; លក ១៧,៥; ២២,៣២) ឯជំនឿក៏ត្រូវតែ "នាំឲ្យប្រព្រឹត្តអំពើផ្សេងៗដោយចិត្តស្រឡាញ់" (កឡ ៥,៦) (យហ ២,១៤-២៦) សំអាងលើសេចក្ដីសង្ឃឹម (រម ១៥,១៣) និងចាក់ឫសក្នុងជំនឿនៃព្រះសហគមន៍។

### ជំនឿជាផលផ្លែដំបូងនៃជីវិតអស់កល្បជានិច្ច

១៦៣-ជំនឿផ្ដល់រសជាតិទុកជាមុននឹងអំណរ និងពន្លឺនៃការមើលឃើញព្រះភ័ក្ត្រព្រះជាម្ចាស់ដែលជាគោលដៅនៃការធ្វើដំណើរនៅក្នុងលោកនេះ។ យើងនឹងឃើញព្រះជាម្ចាស់ "ទល់មុខគ្នា" (១ករ ១៣,១២) យើងនឹងឃើញព្រះអង្គ "មានសភាពយ៉ាងណា" (១យហ ៣,២) ដែរ។ ដូច្នេះហើយបានជាជំនឿជាផ្លែដំបូងនៃជីវិតអស់កល្បជានិច្ច។

ចាប់ពីឥឡូវនេះទៅយើងមើលឃើញព្រះពរនៃជំនឿដូចពន្លឺឆ្លុះក្នុងកញ្ចក់ដែរ ហាក់ដូចជាយើងបានទទួលផលដ៏អស្ចារ្យ ហើយដែលជំនឿយើងធានាថាយើងនឹងទទួលផលនោះនៅថ្ងៃណាមួយមែន (សន្ដ: បាស៊ីល)។

១៦៤-ប៉ុន្តែឥឡូវនេះ "យើងដើរដោយមានជំនឿ មិនមែនដោយមើលឃើញច្បាស់នឹងភ្នែកទេ" (២ករ ៥,៧) ហើយយើងស្គាល់ព្រះជាម្ចាស់ "ព្រាលៗដូចជាមើលក្នុងកញ្ចក់" (១ករ ១៣,១២)។ អ្នកជឿមានពន្លឺមកពីព្រះអង្គណាដែលគេបានជឿ ប៉ុន្តែជារឿយៗ អ្នកជឿស្ថិតនៅក្នុងភាពងងឹត។ អ្នកជឿអាចប្រឈមមុខនឹងការល្បួងដែរ។ ពិភពលោកដែលយើងរស់នៅហាក់ដូចជានៅឆ្ងាយពីអ្វីដែលជំនឿសន្យាមកយើង គឺពិសោធន៍នៃសេចក្ដីអាក្រក់ ទុក្ខលំបាក អំពើអយុត្តិធម៌ និងសេចក្ដីស្លាប់ហាក់ដូចជាផ្ទុយប្រឆាំងនឹងដំណឹងល្អ ហើយអាចល្បួងអ្នកជឿឲ្យបោះបង់ជំនឿចោលបានដែរ។

១៦៥-នៅពេលនោះយើងក៏ត្រូវតែបែរមុខទៅរកសាក្សីនៃជំនឿ គឺលោក អប្រាហាំ ដែលបានជឿ និង "នៅតែមានសង្ឃឹម ទោះបីជាគ្មានទីសង្ឃឹមក៏ដោយ" (រម ៤,១៨) ព្រះនាងព្រហ្មចារិនីម៉ារីដែល "នៅក្នុងបូជនីយសចរណ៍នៃជំនឿ" (LG ៥៨) បានទៅដល់ "ភាពងងឹតនៃជំនឿ" (RM ១៨) ដោយរួមជាមួយព្រះបុត្រាព្រះនាង ដែលបានរងទុក្ខលំបាក និងបានចូលក្នុងភាពងងឹតនៃផ្នូររបស់ព្រះអង្គ៖ "ដោយមានមនុស្សជាច្រើនឥតគណនាធ្វើជាបន្ទាល់ទុកឲ្យយើងយ៉ាងនេះទៅហើយ យើងត្រូវលះបង់ចោលអ្វីៗទាំងអស់ដែលជាបន្ទុកពីលើយើង និងលះបង់អំពើបាបដែលរឹបរួតយើងនេះចោលទៅ ហើយព្យាយាមតម្រង់ទៅមុខតាមព្រះអម្ចាស់ដាក់ឲ្យយើងរត់។ ត្រូវសម្លឹងមើលទៅព្រះយេស៊ូដែលជាដើមកំណើតនៃជំនឿ ហើយធ្វើឲ្យជំនឿនេះបានគ្រប់លក្ខណៈ" (ហប ១២,១-២)។

## ប្រការទី២៖

## យើងជឿ

១៦៦-ជំនឿជាកិច្ចការរបស់យើងរៀងៗខ្លួន គឺយើងឆ្លើយតបនឹងព្រះជាម្ចាស់ដែលសម្ដែងព្រះអង្គទុកជាមុនដោយមានសេរីភាព។ ប៉ុន្តែជំនឿមិនមែនជាកិច្ចការរបស់យើងតែម្នាក់ឯងទេ។ គ្មាននរណាម្នាក់អាចជឿតែម្នាក់ឯងបានទេ ដូចគ្មាននរណាម្នាក់អាចរស់នៅតែម្នាក់ឯងបានឡើយ។ គ្មាននរណាបានផ្ដល់ជំនឿដល់ខ្លួនឯងទេ ដូចគ្មាននរណាបានផ្ដល់ជីវិតដល់ខ្លួនឯងដែរ។ អ្នកជឿបានទទួលជំនឿពីអ្នកដទៃ គេក៏ត្រូវតែបញ្ជូនជំនឿនេះដល់អ្នកដទៃដែរ។ សេចក្ដីស្រឡាញ់របស់យើងចំពោះព្រះយេស៊ូ និងចំពោះមនុស្សជំរុញឲ្យយើងនិយាយប្រាប់អ្នកដទៃអំពីជំនឿរបស់យើង។ អ្នកជឿម្នាក់ៗប្រៀបធៀបដូចជាក្រឡាមួយនៅក្នុងច្រវាក់ដ៏ធំរបស់អ្នកជឿ។ ខ្ញុំមិនអាចជឿបានទេដោយគ្មានជំនឿរបស់អ្នកដទៃមកជួយគាំទ្រខ្ញុំ ហើយដោយសារជំនឿរបស់ខ្ញុំ ខ្ញុំក៏ជួយគាំទ្រជំនឿរបស់អ្នកដទៃផងដែរ។

១៦៧-"ខ្ញុំជឿ" (ធម៌ប្រកាសជំនឿដែលមកពីក្រុមគ្រីស្តទូត) សំដៅទៅលើជំនឿរបស់ព្រះសហគមន៍ដែលអ្នកជឿម្នាក់ៗប្រកាស ជាពិសេសនៅពេលបុណ្យជ្រមុជទឹក។ "យើងជឿ" (ធម៌ប្រកាសជំនឿរបស់មហាសន្និបាតសកលនៅនិសេ/កុងស្តង់ទីណូប) សំដៅទៅលើជំនឿរបស់ព្រះសហគមន៍ដែលលោកអភិបាលប្រកាសនៅពេល

រួមគ្នាក្នុងមហាសន្និបាត ឬដែលអង្គប្រជុំគ្រីស្តបរិស័ទប្រកាសក្នុងពិធីបុណ្យ។ "ខ្ញុំជឿ" គឺជាព្រះសហគមន៍ជាមាតារបស់យើងដែលឆ្លើយតបនឹងព្រះជាម្ចាស់ ដោយសារជំនឿហើយដែលបង្រៀនឲ្យយើងចេះពោល៖ "ខ្ញុំជឿ" "យើងជឿ"។

## ១-"សូមព្រះអម្ចាស់ទតមើលជំនឿរបស់ព្រះសហគមន៍ព្រះអង្គ"

១៦៨-មុនដំបូងព្រះសហគមន៍ជឿ ទើបគាំទ្រពង្រឹង និងទ្រទ្រង់ជំនឿរបស់ខ្ញុំ។ មុនដំបូងព្រះសហគមន៍ប្រកាសព្រះអម្ចាស់គ្រប់កន្លែង (យើងច្រៀង "គឺអំពីព្រះអង្គទេតើដែលព្រះសហគមន៍ប្រកាសព្រះអម្ចាស់របស់ខ្លួនក្នុងសកលលោកទាំងមូល") ហើយជាមួយព្រះសហគមន៍ និងនៅក្នុងព្រះសហគមន៍យើងនាំគ្នាប្រកាសថា៖ "ខ្ញុំជឿ" "យើងជឿ"។ ដោយសារព្រះសហគមន៍យើងទទួលជំនឿ និងជីវិតថ្មីក្នុងអង្គព្រះគ្រីស្តនៅពេលជ្រមុជទឹក។ ក្នុងក្បួនពិធីបុណ្យនៃព្រះសហគមន៍នៅទីក្រុងរ៉ូម អ្នកជ្រមុជទឹកសួរទៅអ្នកស្វែងយល់ថា៖ "តើអ្នកសុំអ្វីពីព្រះសហគមន៍?" អ្នកស្វែងយល់ឆ្លើយតបថា៖ "ជំនឿ" "តើជំនឿផ្តល់អ្វីដល់អ្នក?" "ជីវិតអស់កល្បជានិច្ច" (OBA)។

១៦៩-មានតែព្រះជាម្ចាស់ដែលជួយសង្គ្រោះ ប៉ុន្តែដោយសារយើងទទួលជីវិតនៃជំនឿតាមរយៈព្រះសហគមន៍ ព្រះសហគមន៍ក៏ជាមាតារបស់យើង៖ "យើងជឿព្រះសហគមន៍ដូចជាមាតានៃកំណើតថ្មីរបស់យើង តែយើងមិនជឿព្រះសហគមន៍ដូចជាអ្នកសង្គ្រោះយើងទេ" (ហ្វូសទូសនៃរីអេស៍)។ ដោយសារព្រះសហគមន៍ជាមាតារបស់យើង ព្រះសហគមន៍ក៏ជាអ្នកអប់រំជំនឿយើងដែរ។

## ២-ភាសានៃជំនឿ

១៧០-យើងមិនជឿលើរូបមន្ត ប៉ុន្តែយើងជឿលើសេចក្តីដែលរូបមន្តនោះបញ្ជាក់ ហើយដែលជំនឿធ្វើឲ្យយើងអាច "ស្ទាបមើល" បាន។ "កិច្ចការ (នៃជំនឿ) របស់អ្នកជឿមិនឈប់នៅក្នុងវិញ្ញាប័នទេ តែនៅក្នុងសេចក្តីដែលវិញ្ញាប័ននោះសំដៅទៅលើ" (សន្តៈ ថូម៉ាសនៃអាកាំង)។ ប៉ុន្តែយើងចូលមកជិតសេចក្តីនោះដោយសាររូបមន្តនៃជំនឿដែលអាចសម្តែងបញ្ជូន និងលើកតម្កើងជំនឿនៅក្នុងសហគមន៍ ហើយដែលធ្វើឲ្យជំនឿនេះជ្រាបចូលក្នុងការរស់នៅរបស់យើងដែរ។

១៧១-ព្រះសហគមន៍ដែលជា "សសរ និងជាគ្រឹះទ្រទ្រង់សេចក្តីពិត" (១ធម ៣,១៥) រក្សាទុកដោយមានចិត្តស្មោះត្រង់ "ជំនឿដែលព្រះជាម្ចាស់បានប្រទានដល់ជនដ៏វិសុទ្ធម្តងជាការស្រេច" (យដ ៣)។ គឺព្រះសហគមន៍នេះហើយដែលនឹករឭកដល់ព្រះបន្ទូលរបស់ព្រះគ្រីស្ត ដែលបញ្ជូនធម៌ប្រកាសជំនឿនៃក្រុមគ្រីស្តទូតពីជំនាន់មួយទៅជំនាន់មួយ។ ដូចម្តាយបង្រៀនកូនៗរបស់ខ្លួនឲ្យចេះនិយាយ ទើបចេះយល់ និងទាក់ទងនឹងគ្នាយ៉ាងណា ព្រះសហគមន៍ដែលជាមាតារបស់យើងក៏បង្រៀនយើងភាសានៃជំនឿ ដើម្បីឲ្យយើងអាចឈានចូលក្នុងការឈ្វេងយល់ និងជីវិតនៃជំនឿយ៉ាងនោះដែរ។

## ៣-ជំនឿតែមួយ

១៧២-តាំងពីច្រើនសតវត្សមកហើយ តាមរយៈភាសាវប្បធម៌ និងប្រជាជាតិទាំងប៉ុន្មាន ព្រះសហគមន៍នៅតែប្រកាសជំនឿតែមួយរបស់ខ្លួន ដែលព្រះសហគមន៍បានទទួលពីព្រះអម្ចាស់តែមួយ ដែលពិធីជ្រមុជទឹកតែមួយបានបញ្ជូនបន្ត និងដែលបានចាក់ឫសក្នុងការជឿជាក់ថាមនុស្សទាំងអស់មានព្រះជាម្ចាស់ និងព្រះបិតាតែមួយ (អភ ៤,៤-៦)។ សន្តៈ អ៊ីរ៉េណេនៃលីយ៉ុង ដែលជាសាក្សីនៃជំនឿនេះមានប្រសាសន៍ថា៖

១៧៣-"ទោះបីព្រះសហគមន៍ខ្ចាត់ខ្ចាយក្នុងពិភពលោកទាំងមូលរហូតដល់ទីដាច់ស្រយាលនៃផែនដី

យ៉ាងណាក៏ដោយ ហើយដែលបានទទួលជំនឿពីក្រុមគ្រីស្តទូត និងសាវ័ករបស់ពួកលោក (...) ព្រះសហគមន៍រក្សាធម៌ទេសនា និងជំនឿនេះដោយយកចិត្តទុកដាក់ដូចជារស់នៅក្នុងផ្ទះតែមួយដែរ។ ព្រះសហគមន៍ក៏ជឿតាមរបៀបតែមួយ ដូចជាមានព្រលឹង និងចិត្តគំនិតតែមួយ ហើយព្រះសហគមន៍ប្រកាសប្រៀនប្រដៅ និងបញ្ជូនសេចក្តីនោះដោយមានសម្លេងតែមួយដូចជាមានមាត់តែមួយដែរ"។

១៧៤-"ទោះបីមានភាសាខុសប្លែកពីគ្នានៅក្នុងពិភពលោកយ៉ាងណាក៏ដោយ ក៏សេចក្តីនៃការបញ្ជូនបន្តមានតែមួយ និងដូចគ្នាគ្រប់កន្លែង។ ព្រះសហគមន៍ដែលស្ថិតនៅប្រទេសអាឡឺម៉ង់ នៅជាតិអីបេរ ជាតិសេល្ត នៅទិសខាងកើត នៅប្រទេសអេស៊ីប ប្រទេសលីប៊ី ឬព្រះសហគមន៍ដែលស្ថិតនៅកណ្តាលពិភពលោកពុំមានជំនឿផ្សេង ឬការបញ្ជូនបន្តផ្សេងពីគ្នាឡើយ"។ "ដូច្នេះហើយបានជាសារនៃព្រះសហគមន៍ពិតប្រាកដ និងរឹងមាំ ដ្បិតគឺនៅក្នុងព្រះសហគមន៍នោះហើយដែលមានផ្លូវនៃការសង្គ្រោះតែមួយ ដែលលេចឡើងនៅក្នុងពិភពលោកទាំងមូល"។

១៧៥-"យើងបានទទួលជំនឿពីព្រះសហគមន៍ យើងក៏រក្សាទុកជំនឿនេះដោយយកចិត្តទុកដាក់ ដ្បិតក្រោមកិច្ចការនៃព្រះវិញ្ញាណដ៏វិសុទ្ធ ជំនឿនៅតែធ្វើឲ្យយើងកាន់តែក្មេងទៅៗដូចជាបញ្ញើដ៏មានតម្លៃធ្វើឲ្យថូកាន់តែល្អប្រសើរ"។

## សង្ខេប

១៧៦-ដោយសារជំនឿ មនុស្សផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ ដែលសម្តែងព្រះអង្គ។ ដោយសារជំនឿប្រាជ្ញា និងឆន្ទះមនុស្សផ្សារភ្ជាប់នឹងព្រះជាម្ចាស់ ដែលបានសម្តែងព្រះអង្គ តាមរយៈកិច្ចការ និងព្រះបន្ទូលរបស់ព្រះអង្គ។

១៧៧-"ជំនឿ" ទាក់ទងនឹងគោលការណ៍ពីរ គឺមនុស្ស និងសេចក្តីពិត ពោលគឺអ្នកជឿលើសេចក្តីពិត ដោយទុកចិត្តលើអ្នក ដែលបញ្ជាក់អំពីសេចក្តីពិតនេះ។

១៧៨-យើងមិនត្រូវជឿលើព្រះណាផ្សេងទៀត ក្រៅពីព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

១៧៩-ជំនឿជាព្រះអំណោយទានហួសពីធម្មជាតិដែលមកពីព្រះជាម្ចាស់។ ដើម្បីជឿ មនុស្សត្រូវការឲ្យព្រះវិញ្ញាណដ៏វិសុទ្ធជួយសង្គ្រោះផ្នែកខាងក្នុង។

១៨០-"ជំនឿ" ជាកិច្ចការរបស់មនុស្ស ដែលដឹងខ្លួន និងដែលមានសេរីភាព ដែលទាក់ទងនឹងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស។

១៨១-"ជំនឿ" ជាកិច្ចការរបស់ព្រះសហគមន៍។ ជំនឿរបស់ព្រះសហគមន៍ដើរទៅមុខ បង្កើត ជួយ និងបំប៉នជំនឿរបស់យើង។ ព្រះសហគមន៍ជាមាតារបស់អស់អ្នកជឿ។ "គ្មាននរណាម្នាក់អាចមានព្រះជាម្ចាស់ជាព្រះបិតា បើគេពុំមានព្រះសហគមន៍ជាមាតាឡើយ" (សន្តៈ ស៊ីព្រីយ៉ាំង)។

១៨២-"យើងជឿលើអ្វីៗដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទោះជាសរសេរជាលាយលក្ខណ៍អក្សរ ឬត្រូវគេបញ្ជូន ហើយដែលព្រះសហគមន៍ស្នើសុំឲ្យជឿថា មកពីព្រះជាម្ចាស់ក៏ដោយ" (SPF ២០)។

១៨៣-ត្រូវតែជឿ ដើម្បីទទួលការសង្គ្រោះ។ ព្រះអម្ចាស់ផ្ទាល់អះអាងថា៖ "អ្នកណាជឿ ហើយទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់សង្គ្រោះអ្នកនោះ រីឯអ្នកដែលមិនជឿនឹងត្រូវទទួលទោស" (មក ១៦,១៦)។

១៨៤-"ជំនឿជាការដឹងរសជាតិមុននឹងស្គាល់ព្រះជាម្ចាស់ ដែលនឹងប្រោសឲ្យបានពោរពេញដោយសុភមង្គលក្នុងជីវិតខាងបរមលោក" (សន្តៈ ថូម៉ាសនៃអាកាំង)។

# ធម៌ប្រកាសជំនឿ

| ធម៌ប្រកាសជំនឿរបស់គ្រីស្តទូតទាំងឡាយ | ធម៌ប្រកាសជំនឿរបស់មហាសន្និបាតសកល នៅនិសេ/កុងស្តង់ទីណូបឆ្នាំ៣២៥ និង ៣៨១ |
|---|---|
| ខ្ញុំជឿលើព្រះជាម្ចាស់ | ខ្ញុំជឿលើព្រះជាម្ចាស់តែមួយព្រះអង្គ |
| ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ | ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ |
| ជាព្រះបង្កើតមេឃ និងដី | ជាព្រះបង្កើតមេឃ និងដី |
| | ទាំងអ្វីៗដែលមើលឃើញ និងមើលមិនឃើញ |
| ខ្ញុំជឿលើព្រះយេស៊ូគ្រីស្តជាព្រះបុត្រាតែមួយនៃព្រះបិតា | ខ្ញុំជឿលើព្រះអម្ចាស់យេស៊ូគ្រីស្តតែមួយ |
| ជាព្រះអម្ចាស់យើងខ្ញុំ | ជាព្រះបុត្រាតែមួយនៃព្រះបិតា |
| | ហើយមានប្រភពពីព្រះបិតាមុនកាលសម័យទាំងអស់ |
| | ព្រះអង្គជាព្រះជាម្ចាស់ចេញពីព្រះជាម្ចាស់ |
| | ជាពន្លឺចេញពីពន្លឺ |
| | ជាព្រះជាម្ចាស់ដ៏ពិតប្រាកដចេញពីព្រះជាម្ចាស់ |
| | ដ៏ពិតប្រាកដដែរ |
| | ព្រះអង្គទទួលព្រះជន្មពីព្រះបិតា ហើយមិនកើតដូចសត្វ |
| | លោកឡើយ |
| | ព្រះអង្គរួមសភាពជាមួយព្រះបិតា |
| | ហើយអ្វីៗសព្វសារពើក៏កើតមក |
| | ដោយសារព្រះអង្គដែរ |
| | ព្រះអង្គយាងមកពីស្ថានបរមសុខ ដើម្បីមនុស្សយើង និង |
| | សង្គ្រោះយើង |
| ព្រះអង្គមានកំណើតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ | ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ |
| ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី | ព្រះអង្គបានទទួលរូបកាយ |
| | ពីព្រះនាងព្រហ្មចារិនីម៉ារី |
| | ហើយព្រះអង្គទៅជាមនុស្ស |
| ព្រះអង្គសោយទុក្ខលំបាកនៅជំនាន់ប៉ុនពីឡាត | ព្រះអង្គត្រូវគេឆ្កាងនៅជំនាន់ប៉ុនពីឡាត |
| | ដើម្បីជាប្រយោជន៍ដល់យើង |
| ព្រះអង្គត្រូវគេឆ្កាងសោយទិវង្គត | ព្រះអង្គសោយទុក្ខលំបាក |
| ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះក្នុងរូងថ្មមួយ | ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះ |
| ព្រះអង្គបានយាងចុះទៅស្ថានក្រោម | |
| លុះដល់ថ្ងៃទីបីព្រះអង្គមានព្រះជន្មថ្មី | លុះដល់ថ្ងៃទីបីព្រះអង្គមានព្រះជន្មថ្មី |

| | |
|---|---|
| | ស្របតាមគម្ពីរ |
| ព្រះអង្គយាងឡើងស្ថានបរមសុខ | ព្រះអង្គយាងឡើងស្ថានបរមសុខ |
| គង់ខាងស្តាំព្រះបិតា | គង់ខាងស្តាំព្រះបិតា |
| ដ៏មានឫទ្ធានុភាពសព្វប្រការ | |
| ព្រះអង្គនឹងយាងមកវិញ ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ | ព្រះអង្គនឹងយាងមកវិញយ៉ាងរុងរឿង |
| ទាំងស្លាប់ | ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ទាំងស្លាប់ |
| | ហើយព្រះរាជ្យព្រះអង្គនឹងនៅស្ថិតស្ថេរ |
| | ឥតទីបញ្ចប់ឡើយ |
| ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ | ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ |
| | ដែលប្រទានជីវិត និងជាអម្ចាស់ |
| | ព្រះអង្គហូរចេញពីព្រះបិតា និងព្រះបុត្រា |
| | ព្រះអង្គទទួលការក្រាបថ្វាយបង្គំ និងសិរីរុងរឿង |
| | ស្មើនឹងព្រះបិតា និងព្រះបុត្រា |
| | ព្រះអង្គបានថ្លែងព្រះបន្ទូល |
| | តាមរយៈអស់លោកព្យាការី |
| ខ្ញុំជឿថា ព្រះសហគមន៍កាតូលិក | ខ្ញុំជឿលើព្រះសហគមន៍ |
| និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ | តែមួយដ៏វិសុទ្ធ និងកាតូលិក |
| | ដែលបន្តជំនឿពីក្រុមគ្រីស្តទូត |
| | ខ្ញុំប្រកាសថាមានអគ្គសញ្ញាជ្រមុជទឹកតែមួយ |
| ខ្ញុំជឿថាមានការលើកលែងទោស | ដែលលើកលែងទោសឲ្យរួចពីបាប |
| ឲ្យមនុស្សរួចពីបាប | |
| ហើយរូបកាយមនុស្សនឹងមានជីវិតថ្មី | ខ្ញុំរង់ចាំពេលដែលមនុស្សស្លាប់នឹងមានជីវិតថ្មី |
| ព្រមទាំងមានជីវិតរស់នៅអស់កល្បជានិច្ច | និងជីវិតលោកខាងមុខផង |
| អាម៉ែន | អាម៉ែន |

## ភាគទីពីរៈ

## ធម៌ប្រកាសជំនឿនៃគ្រីស្តសាសនា - សេចក្តីសង្ខេបនៃជំនឿ

១៨៥-អ្នកណាប្រកាសថា "ខ្ញុំជឿ" អ្នកនោះប្រកាសថា "ខ្ញុំយល់ស្របនឹងអ្វីដែលយើងជឿ"។ ពេលយើងរួមជាមួយគ្នាក្នុងជំនឿ យើងក៏ត្រូវការភាសារួមដើម្បីសម្តែងជំនឿនេះដែលជាក្បួនច្បាប់សម្រាប់អ្នកជឿទាំងអស់ និងធ្វើឲ្យគេរួមជាមួយគ្នាក្នុងធម៌ប្រកាសជំនឿតែមួយ។

១៨៦-តាំងពីដើមព្រះសហគមន៍ដែលមកពីក្រុមគ្រីស្តទូតបានថ្លែង និងបញ្ជូនជំនឿផ្ទាល់ខ្លួនដោយប្រើរូបមន្តខ្លីៗ និងជាក្បួនច្បាប់សម្រាប់មនុស្សទាំងអស់ (រម ១០,៩; ១ករ ១៥,៣-៥)។ ព្រះសហគមន៍មានបំណងចង់ប្រមូលសេចក្តីសំខាន់ៗនៃជំនឿក្នុងសេចក្តីសង្ខេបដែលមានរចនាសម្ព័ន្ធដ៏ត្រឹមត្រូវ ជាពិសេសសម្រាប់បេក្ខជនត្រៀមខ្លួនជ្រមុជទឹក។

យើងមិនបានរៀបចំសេចក្តីសង្ខេបនៃជំនឿតាមយោបល់របស់មនុស្ស តែយើងបានប្រមូលអ្វីៗដ៏សំខាន់ក្នុងព្រះគម្ពីរទាំងមូល ដើម្បីផ្តល់ការប្រៀនប្រដៅតែមួយអំពីជំនឿទាំងស្រុងតែម្តង ហើយដូចក្នុងគ្រាប់ពូជដ៏តូចល្អិតមានមែកជាច្រើនយ៉ាងណា យើងអាចស្គាល់សេចក្តីទាំងអស់ដែលព្រះជាម្ចាស់សម្តែងក្នុងសម្ពន្ធមេត្រីចាស់ និងសម្ពន្ធមេត្រីថ្មី សេចក្តីសង្ខេបខ្លីៗនៃជំនឿនេះក៏យ៉ាងនោះដែរ (សន្តៈ ស៊ីរីលនៃទីក្រុងយេរូសាឡឹម)។

១៨៧-គេហៅសេចក្តីសង្ខេបនៃជំនឿនោះថា "ធម៌ប្រកាសជំនឿ" ព្រោះសេចក្តីនោះសង្ខេបជំនឿដែលគ្រីស្តបរិស័ទប្រកាស។ គេហៅសេចក្តីនោះថា "Credo" (ខ្ញុំជឿ) ដោយសារពាក្យដំបូងនៃធម៌ប្រកាសជំនឿ៖ "ខ្ញុំជឿ"។ សេចក្តីនោះមកពីពាក្យ "symbolon"។

១៨៨-ត្រូវតែគោរពតាមពាក្យ symbolon ដែលជាភាសាក្រិកមានន័យថា បំណែកមួយចំហៀងនៃវត្ថុមួយដែលបែកជាពីរ (ឧ-ត្រាមួយ) សម្រាប់គ្រឿងសម្គាល់។ បំណែកទាំងពីរ បើកាលណាគេយកមកដាក់បញ្ចូលគ្នាវិញ គេអាចស្គាល់អត្តសញ្ញាណនៃអ្នកដែលមានបំណែកនោះ។ ហេតុនេះហើយ សេចក្តីសង្ខេបនៃជំនឿក៏ជាសញ្ញាសម្គាល់ និងការរួបរួមជាផ្លូងមួយរវាងពួកអ្នកជឿ។ Symbolon ក៏សម្រាប់សម្គាល់សេចក្តីដកស្រង់អត្ថបទមួយ ឬការប្រមូលផ្តុំមួយ ឬក៏ជាសេចក្តីសង្ខេបត្រួសៗមួយដែរ។ សេចក្តីសង្ខេបនៃជំនឿ គឺជាការដកស្រង់សេចក្តីពិតសំខាន់ៗនៃជំនឿ។ ដូច្នេះសេចក្តីសង្ខេបនៃជំនឿ គឺជាចំណុចយោងទីមួយ និងជាគ្រឹះសំខាន់ក្នុងការអប់រំជំនឿ។

១៨៩-យើងប្រកាសជំនឿលើកទីមួយនៅពេលយើងទទួលបុណ្យជ្រមុជទឹក។ "ធម៌ប្រកាសជំនឿ" ជាធម៌នៃពិធីជ្រមុជទឹក។ ដោយសារយើងផ្តល់ពិធីជ្រមុជទឹក "ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" (មថ ២៨,១៩) សេចក្តីពិតនៃជំនឿដែលយើងប្រកាសពេលទទួលបុណ្យជ្រមុជទឹកចែកជាបីវគ្គ យោងតាមអង្គទាំងបីនៃព្រះត្រៃឯកដ៏វិសុទ្ធ។

១៩០-ហេតុនេះហើយបានជាធម៌ប្រកាសជំនឿចែកជាបីវគ្គ៖ "ដំបូងព្រះជាម្ចាស់ជាព្រះបិតា និងការបង្កើតដ៏អស្ចារ្យនៃពិភពលោក បន្ទាប់មកព្រះជាម្ចាស់ជាព្រះបុត្រា និងគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះរបស់មនុស្សលោក ទីបញ្ចប់ព្រះជាម្ចាស់ជាព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាប្រភព និងជាគ្រឹះនៃភាពដ៏វិសុទ្ធរបស់យើង" (CR)។ នេះគឺជា "ជំពូកទាំងបីនៃពិធីជ្រមុជទឹករបស់យើង" (សន្តៈ អ៊ីរ៉េណេនៃលីយ៉ុង)

១៩១-"វគ្គទាំងបីនោះខុសប្លែកពីគ្នា តែទាក់ទិននឹងគ្នាផងដែរ។ គ្រូបាធ្យាយនៃព្រះសហគមន៍ធ្លាប់ប្រៀបធៀប

វគ្គនោះដូចជាសន្លាក់។ អវយវៈរបស់យើងមានសន្លាក់ដែលបែងចែកអវយវៈ នោះយ៉ាងណាមិញនៅក្នុងធម៌ប្រកាសជំនឿនេះ យើងហៅប្រការសេចក្តីពិតទាំងប៉ុន្មានដែលយើងត្រូវតែជឿតាមរបៀបខុសៗពីគ្នា (CR)។ តាមទំនៀមទម្លាប់បុរាណដែលសន្តៈ អំប្រ័រ បានបញ្ជាក់ធម៌ប្រកាសជំនឿមានដប់ពីរប្រការជានិមិត្តរូបនៃជំនឿដែលមកពីក្រុមគ្រីស្តទូតដប់ពីររូប។

១៩២-តាំងពីច្រើនសតវត្សមកហើយ ដោយសារតម្រូវការនៃជំនាន់នីមួយៗមានធម៌ប្រកាសជំនឿជាច្រើន៖ ធម៌ជឿនៃព្រះសហគមន៍បុរាណ ដែលបានមកពីក្រុមគ្រីស្តទូត (DS ១-៦៤) ធម៌ជឿនៃ "Quicumque" ឬរបស់សន្តៈ អាថាណាស (DS ៧៥-៧៦) ធម៌ជឿនៃសន្និបាតខ្លះៗ (តូលេឌ (DS ៥២៥-៥៤១), ឡាត្រង់ (DS ៨០០-៨០២), លីយ៉ុង (DS ៨៥១-៨៦១), ត្រង់ (DS ១៨៦២-១៨៧០) ឬរបស់សម្តេចប៉ាបខ្លះដូចជា "Fides Damasi" (DS ៧១-៧២) ឬ "ធម៌ជឿនៃប្រជាជនរបស់ព្រះជាម្ចាស់" របស់សម្តេចប៉ាបប៉ូលទី៦ (១៩៦៨)។

១៩៣-យើងមិនអាចចាត់ទុកថា ធម៌ប្រកាសជំនឿណាមួយដែលមកពីតំណាក់កាលផ្សេងៗនៃជីវិតរបស់ព្រះសហគមន៍គ្មានប្រយោជន៍ទៀតទេ។ ធម៌ប្រកាសជំនឿទាំងអស់នោះជួយឲ្យយើងយោងតាមជំនឿដែលមានតាំងពីដើម និងមិនដែលប្រែប្រួលតាមរយៈសេចក្តីសង្ខេបផ្សេងៗ ហើយជួយឲ្យយើងយល់អំពីជំនឿនេះកាន់តែជ្រៅទៅៗ។

នៅក្នុងចំណោមធម៌ប្រកាសជំនឿទាំងប៉ុន្មានមានពីរសំខាន់ជាងគេគឺ៖

១៩៤-ធម៌ប្រកាសជំនឿដែលបានមកពីគ្រីស្តទូតទាំងឡាយ ជាសេចក្តីសង្ខេបនៃជំនឿដ៏ត្រឹមត្រូវរបស់ក្រុមគ្រីស្តទូត។ ធម៌ប្រកាសជំនឿនេះជាធម៌ប្រកាសជំនឿបុរាណនៃពិធីជ្រមុជទឹករបស់ព្រះសហគន៍នៅទីក្រុងរ៉ូម។ ត្រូវតែគោរពធម៌ប្រកាសជំនឿនេះ "ជាធម៌ប្រកាសជំនឿរបស់ព្រះសហគមន៍នៅទីក្រុងរ៉ូមដែលលោកសិលាជាប្រធានក្រុមគ្រីស្តទូតបានស្នាក់នៅ និងបាននាំជំនឿតែមួយ" (សន្តៈ អំប្រ័រ)។

១៩៥-ត្រូវតែគោរពធម៌ប្រកាសជំនឿនៃមហាសន្និបាតសកលនីសេ/កុងស្តង់ទីណូប ដ្បិតធម៌ប្រកាសជំនឿនេះមកពីមហាសន្និបាតសកលដើមដំបូង (ឆ្នាំ ៣២៥ និង ៣៨១)។ ធម៌ប្រកាសជំនឿនេះនៅតែជាធម៌រួមជាមួយព្រះសហគមន៍ធំៗនៃបូព៌ា និងបស្ចិមប្រទេស។

១៩៦-សេចក្តីរាយការណ៍របស់យើងអំពីជំនឿនឹងដើរតាមធម៌ប្រកាសជំនឿដែលមកពីគ្រីស្តទូតទាំងឡាយជាសេចក្តីសង្ខេបបុរាណជាងគេនៃទីក្រុងរ៉ូម។ ប៉ុន្តែយើងនឹងបំពេញសេចក្តីរាយការណ៍នោះយោងតាមធម៌ប្រកាសជំនឿនៃមហាសន្និបាតសកលនីសេ/កុងស្តង់ទីណូប ដែលពន្យល់ពីជំនឿយ៉ាងល្អិតល្អន់។

១៩៧-កាលបើយើងបានផ្ញើជីវិតទាំងស្រុងទៅលើ "គោលការណ៍នៃសេចក្តីបង្រៀន" (រម ៦,១៧) នៅពេលបានទទួលបុណ្យជ្រមុជទឹក សូមទទួលធម៌ប្រកាសនៃជំនឿរបស់យើងដែលផ្តល់ជីវិត។ ពេលយើងសូត្រធម៌ប្រកាសជំនឿ ដោយមានជំនឿ យើងរួមរស់ជាមួយព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយយើងក៏រួមរស់ជាមួយព្រះសហគមន៍ទាំងមូលដែរ។ ព្រះសហគមន៍នេះហើយដែលបញ្ជូនបន្តជំនឿ ហើយគឺក្នុងព្រះសហគមន៍នេះហើយដែលយើងជឿផងដែរ៖

ធម៌ប្រកាសជំនឿជាត្រាខាងវិញ្ញាណ យើងសញ្ជឹងគិតក្នុងដួងចិត្តយើង និងរក្សាទុកធម៌ប្រកាសជំនឿនេះជានិច្ច។ ធម៌ប្រកាសជំនឿពិតជាកំណាប់នៃព្រលឹងរបស់យើងមែន (សន្តៈ អំប្រ័រ)។

# ជំពូកទីមួយៈ

# ខ្ញុំជឿលើព្រះជាម្ចាស់ជាព្រះបិតា

១៩៨-ធម៌ប្រកាសជំនឿរបស់យើងចាប់ផ្តើមដោយព្រះជាម្ចាស់ ដ្បិតព្រះជាម្ចាស់ជា "ព្រះនៅមុនគេ និងនៅក្រោយគេបំផុត" (អស ៤៤,៦) ជាប្រភព និងទីចុងក្រោយនៃអ្វីៗទាំងអស់។ ធម៌ប្រកាសជំនឿចាប់ផ្តើមដោយព្រះជាម្ចាស់ជាព្រះបិតា ពីព្រោះព្រះបិតាជាព្រះអង្គទីមួយនៃព្រះត្រៃឯកដ៏វិសុទ្ធបំផុត។ ធម៌ប្រកាសជំនឿចាប់ផ្តើមដោយការបង្កើតមេឃ និងដី ពីព្រោះការបង្កើតជាដើមកំណើត និងជាមូលដ្ឋានគ្រឹះនៃស្នាព្រះហស្តទាំងឡាយរបស់ព្រះជាម្ចាស់។

## ប្រការទី១ៈ

## "ខ្ញុំជឿលើព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ជាព្រះបង្កើតមេឃ និងដី"

### កថាខណ្ឌទី១ៈ ខ្ញុំជឿលើព្រះជាម្ចាស់

១៩៩-"ខ្ញុំជឿលើព្រះជាម្ចាស់"៖ ប្រការដំបូងនៃធម៌ប្រកាសជំនឿជាមូលដ្ឋានគ្រឹះនៃប្រការឯទៀតៗ។ ធម៌ប្រកាសជំនឿទាំងមូលថ្លែងអំពីព្រះជាម្ចាស់ ហើយថ្លែងអំពីមនុស្សលោក និងពិភពលោកយោងតាមព្រះជាម្ចាស់។ ប្រការឯទៀតៗនៃធម៌ប្រកាសជំនឿទាំងអស់ពឹងផ្អែកលើប្រការទីមួយ ដូចវិន័យទាំងអស់ពន្យល់វិន័យទីមួយដែរ។ ប្រការឯទៀតៗធ្វើឲ្យយើងស្គាល់ព្រះជាម្ចាស់កាន់តែច្បាស់ ដូចទ្រង់បានសម្តែងព្រះអង្គឲ្យមនុស្សលោកស្គាល់បន្តិចម្តងៗដែរ។ "គ្រីស្តបរិស័ទចាប់ផ្តើមប្រកាសថា គេជឿលើព្រះជាម្ចាស់" (CR)។

#### ១-"ខ្ញុំជឿលើព្រះជាម្ចាស់តែមួយព្រះអង្គ"

២០០-ពាក្យនោះចាប់ផ្តើមធម៌ប្រកាសជំនឿរបស់មហាសន្និបាតសកលនីសេ/កុងស្តង់ទីណូប។ ពេលយើងប្រកាសថាមានព្រះជាម្ចាស់តែមួយព្រះអង្គយោងតាមសម្ពន្ធមេត្រីចាស់ យើងក៏ជឿថា មានព្រះជាម្ចាស់មែន។ ធម៌ប្រកាសជាចាំបាច់ទាំងពីរនោះមិនអាចបំបែកពីគ្នាបានឡើយ។ ព្រះជាម្ចាស់មានតែមួយព្រះអង្គ មានព្រះតែមួយគត់៖ "គ្រីស្តសាសនាប្រកាសថា សភាពសារជាតុ និងសភាវៈរបស់ព្រះជាម្ចាស់មានតែមួយ" (CR)។

២០១-ព្រះជាម្ចាស់បានសម្តែងឲ្យជនជាតិអ៊ីស្រាអែលជាអ្នកដែលព្រះអង្គបានជ្រើសរើសដឹងថា ព្រះអង្គមានតែមួយគត់៖ "អ៊ីស្រាអែលអើយចូរស្តាប់! មានតែព្រះអម្ចាស់ជាព្រះរបស់យើងមួយព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់។ អ្នកត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីកម្លាំងកាយ" (ទក ៦,៤-៥)។ តាមរយៈអស់លោកព្យាការី ព្រះជាម្ចាស់ត្រាស់ហៅជនជាតិអ៊ីស្រាអែល និងប្រជាជាតិទាំងអស់ឲ្យបែរទៅរកព្រះអង្គជាព្រះតែមួយគត់៖ "អស់អ្នកដែលនៅទីដាច់ស្រយាលនៃផែនដីអើយ! ចូរនាំគ្នាបែរមករកយើង យើងនឹងសង្គ្រោះអ្នករាល់គ្នា ដ្បិតយើងជាព្រះជាម្ចាស់ក្រៅពីយើងគ្មានព្រះជាម្ចាស់ណាទៀតទេ (...) មនុស្សលោកទាំងអស់នឹងក្រាបថ្វាយបង្គំយើង ហើយមនុស្សគ្រប់ភាសានាំគ្នាសច្ចាថានឹងគោរពបម្រើយើងដោយស្មោះ" (អស ៤៥,២២-២៤) (ភីល ២,១០-១១)។

២០២-ព្រះយេស៊ូផ្ទាល់បញ្ជាក់ថា ព្រះជាម្ចាស់ជា "ព្រះអម្ចាស់តែមួយ" ហើយត្រូវស្រឡាញ់ព្រះអង្គ "ឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីប្រាជ្ញា និងអស់ពីកម្លាំងកាយ" (មក ១២,២៩-៣០)។ ព្រះយេស៊ូក៏ធ្វើឲ្យយើងអាចយល់ថាព្រះអង្គផ្ទាល់ជា "ព្រះអម្ចាស់" (មក ១២,៣៥-៣៧)។ យោងតាមលក្ខណៈពិសេសនៃគ្រីស្តសាសនា ពេលយើងប្រកាសថា "ព្រះយេស៊ូជាព្រះអម្ចាស់" យើងមិនប្រឆាំងនឹងជំនឿលើព្រះជាម្ចាស់តែមួយគត់ទេ។ ពេលយើងជឿលើព្រះវិញ្ញាណដ៏វិសុទ្ធជា "ព្រះអម្ចាស់ និងផ្តល់ជីវិត" យើងក៏មិនបំបែកព្រះជាម្ចាស់តែមួយព្រះអង្គដែរ។

យើងជឿជាក់យ៉ាងម៉ឺតមត់ និងអះអាងតែម្តងថាមានព្រះជាម្ចាស់ពិតប្រាកដតែមួយធំមហិមា ដែលមិនប្រែប្រួល និងដែលមិនអាចយល់បានប្រកបដោយឫទ្ធានុភាពសព្វប្រការ ដែលមិនអាចរៀបរាប់បានព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណ គឺព្រះបីអង្គ ប៉ុន្តែសភាវៈសារធាតុ និងសភាពយ៉ាងបរិសុទ្ធជាទីបំផុត (DS ៨០០)។

## ២-ព្រះជាម្ចាស់សម្តែងព្រះនាមព្រះអង្គឲ្យយើងស្គាល់

២០៣-ព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យប្រជាជនអ៊ីស្រាអែលស្គាល់ព្រះនាមព្រះអង្គ។ នាមសំដៅទៅលើសភាវៈ និងអត្តសញ្ញាណនៃបុគ្គលម្នាក់ ហើយអត្ថន័យនៃដំណើរជីវិតរបស់គេ។ ព្រះជាម្ចាស់មានព្រះនាមដែរ។ ព្រះអង្គក៏មិនមែនជាកម្លាំងអនាមិកទេ។ នៅពេលយើងប្រគល់ឈ្មោះរបស់យើង យើងធ្វើឲ្យគេស្គាល់យើង ហាក់ដូចជាយើងប្រគល់ខ្លួនឯង ម្យ៉ាងទៀតគេអាចមកជិតយើង ស្គាល់យើងយ៉ាងស្និទ្ធស្នាល និងហៅយើងរៀងៗខ្លួនដែរ។

២០៤-ព្រះជាម្ចាស់បានសម្តែងព្រះអង្គឲ្យប្រជាជនរបស់ព្រះអង្គស្គាល់បន្តិចម្តងៗតាមរយៈនាមផ្សេងៗ ប៉ុន្តែនៅពេលដែលព្រះជាម្ចាស់បានសម្តែងព្រះនាមព្រះអង្គឲ្យលោកម៉ូសេស្គាល់នៅក្នុងគុម្ពបន្លា មុននឹងធ្វើដំណើរទៅកាន់សេរីភាព និងចងសម្ព័ន្ធមេត្រីនៅលើភ្នំស៊ីណៃ នៅពេលនោះព្រះជាម្ចាស់បានសម្តែងលក្ខណៈចាំបាច់របស់ព្រះអង្គនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ និងគម្ពីរសម្ព័ន្ធមេត្រីថ្មីផង។

### ព្រះដែលមានព្រះជន្មគង់នៅ

២០៥-ព្រះជាម្ចាស់ត្រាស់ហៅលោកម៉ូសេពីនៅក្នុងគុម្ពបន្លាដែលដុតតែមិនឆេះ ព្រះអង្គមានព្រះបន្ទូលទៅកាន់លោកម៉ូសេថា៖ "យើងជាព្រះដែលឪពុកអ្នកតែងគោរពបម្រើ គឺព្រះរបស់អប្រាហាំ អ៊ីសាក និងយ៉ាកុប" (សរ ៣,៦)។ ព្រះជាម្ចាស់ជាព្រះរបស់ពួកឪពុកព្រះដែលបានត្រាស់ហៅ និងណែនាំបុព្វបុរសក្នុងការធ្វើដំណើររបស់ពួកលោក។ ព្រះជាម្ចាស់ជាព្រះដ៏ស្មោះត្រង់ដែលមានព្រះហឫទ័យអាណិតអាសូរ ហើយដែលនឹករឭកដល់ពួកលោក និងព្រះបន្ទូលសន្យារបស់ព្រះអង្គ។ ព្រះអង្គក៏យាងមកដើម្បីរំដោះកូនចៅរបស់បុព្វបុរសនោះ ឲ្យរួចពីភាពជាទាសករ។ ព្រះជាម្ចាស់ជាព្រះដែលហួសពីអាកាស និងហួសពេលវេលាអាចសង្គ្រោះគេ និងសព្វព្រះហឫទ័យសង្គ្រោះគេ ហើយដែលនឹងប្រើឫទ្ធានុភាពសព្វប្រការរបស់ព្រះអង្គ ដើម្បីឲ្យគម្រោងការនេះបានសម្រេច។

### "យើងជាព្រះអម្ចាស់ដែលមានជីវិតគង់នៅ"

លោកម៉ូសេទូលព្រះអម្ចាស់ថា៖ "បពិត្រព្រះជាម្ចាស់! ទូលបង្គំនឹងទៅជួបជនជាតិអ៊ីស្រាអែល ហើយប្រាប់ពួកគេថាព្រះរបស់បុព្វបុរសអ្នករាល់គ្នាបានចាត់ខ្ញុំឲ្យមកជួបអ្នករាល់គ្នា។ ប្រសិនបើពួកគេសួរថា៖ "ព្រះអង្គព្រះនាមអ្វីនោះ? "តើទូលបង្គំប្រាប់ពួកគេដូចម្តេច?"។ ព្រះជាម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖ "យើងជាព្រះអម្ចាស់ដែលមានជីវិតគង់នៅ។ អ្នកត្រូវប្រាប់ជនជាតិអ៊ីស្រាអែលថា៖ "ព្រះអម្ចាស់ដែលមានជីវិតគង់នៅ" ចាត់ខ្ញុំឲ្យជួបអ្នករាល់គ្នា (...)។ នេះជានាមរបស់យើងដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច សម្រាប់ឲ្យមនុស្សលោកនឹកដល់យើង

អស់កល្បជាអង្វែងតរៀងទៅ"។ (សរ ៣,១៣-១៥)

២០៦-ដោយសម្តែងព្រះនាមដ៏អាថ៌កំបាំងរបស់ព្រះអង្គ YHWH (យ៉ាវេ) "យើង គឺជាយើង" ឬ "យើងជាព្រះដែលមានជីវិតគង់នៅ" ឬ "យើងជាព្រះដែលមានជីវិតគង់នៅរហូតគ្មានកំណើត គ្មានចុងបញ្ចប់" ព្រះអង្គសម្តែងថាព្រះអង្គជានរណា ហើយត្រូវហៅព្រះអង្គយ៉ាងដូចម្តេច។ ព្រះនាមរបស់ព្រះជាម្ចាស់ជាអាថ៌កំបាំងដូចព្រះអង្គផ្ទាល់ជាអាថ៌កំបាំងដែរ។ ព្រះជាម្ចាស់សម្តែងព្រះនាមព្រះអង្គផង មិនព្រមសម្តែងព្រះនាមព្រះអង្គផង គឺព្រះនាមព្រះអង្គសម្តែងព្រះអង្គជាព្រះលើសពីអ្វីៗ ដែលយើងអាចយល់ ឬនិយាយប្រាប់គេ៖ ព្រះជាម្ចាស់ជាព្រះដែល "មនុស្សលោកពិបាករកឃើញណាស់" (អស ៤៥,៥) ព្រះនាមព្រះអង្គប្លែកអស្ចារ្យណាស់ (វប ១៣,១៨) ហើយព្រះអង្គជាព្រះដែលយាងមកជិតមនុស្សលោក។

២០៧-ដោយសម្តែងព្រះនាមព្រះអង្គ ព្រះអង្គសម្តែងភាពស្មោះត្រង់របស់ព្រះអង្គដែលមានតាំងពីដើមរៀងមក និងជាដរាបតរៀងទៅ ដែលមានតាំងពីអតីតកាល ("យើងជាព្រះដែលឪពុកអ្នកតែងគោរពបម្រើ" សរ ៣,៦) រហូតដល់អនាគតកាល ("យើងនឹងនៅជាមួយអ្នក" សរ ៣,១២)។ ព្រះជាម្ចាស់ដែលសម្តែងព្រះនាមរបស់ព្រះអង្គថា "យើងមានជីវិតគង់នៅ" សម្តែងព្រះអង្គជាព្រះដែលគង់នៅជាមួយប្រជាជនរបស់ព្រះអង្គជារៀងរហូត ដើម្បីសង្គ្រោះគេ។

២០៨-ពីមុខវត្តមានដ៏អាថ៌កំបាំងរបស់ព្រះជាម្ចាស់ដែលទាក់ទាញចិត្តគំនិតផង មនុស្សយល់ឃើញថាខ្លួនជាអ្នកតូចទាប។ ពីមុខគុម្ពបន្លា លោកម៉ូសេដោះស្បែកជើង និងខ្ទប់មុខទល់មុខនឹងភាពដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។ ពីមុខសិរីរុងរឿងរបស់ព្រះដ៏វិសុទ្ធបំផុត លោកអេសាយលាន់មាត់ថា៖ "ស្លាប់ខ្ញុំអើយ! ខ្ញុំពិតជាត្រូវវេទនា ព្រោះខ្ញុំជាមនុស្សមានបបូរមាត់មិនបរិសុទ្ធ" (អស ៦,៥)។ ពេលឃើញទីសម្គាល់ដ៏អស្ចារ្យដែលព្រះយេស៊ូប្រព្រឹត្ត លោកសិលាទូលថា៖ "ព្រះអម្ចាស់អើយ សូមយាងឲ្យឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សបាប" (លក ៥,៨)។ ប៉ុន្តែព្រះជាម្ចាស់អាចលើកលែងទោសឲ្យអ្នកដែលដឹងខ្លួនថាជាមនុស្សបាប ដ្បិតព្រះអង្គជាព្រះដ៏វិសុទ្ធ៖ "យើងមិនប្រព្រឹត្តតាមកំហឹងដ៏ខ្លាំងក្លារបស់យើង (...) ព្រោះយើងជាព្រះជាម្ចាស់មិនមែនជាមនុស្សទេ! យើងជាព្រះដ៏វិសុទ្ធដែលស្ថិតនៅជាមួយអ្នក" (ហស ១១,៩)។ គ្រីស្តទូតយ៉ូហាននឹងមានប្រសាសន៍ដដែលថា៖ "ចិត្តយើងមិនភ័យខ្លាចនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ទេ។ ហេតុនេះប្រសិនបើចិត្តគំនិតយើងដាក់ទោសយើងនោះ ព្រះជាម្ចាស់ដែលខ្ពង់ខ្ពស់ជាងចិត្តយើងទ្រង់ច្បាស់ជាឈ្វេងយល់ទាំងអស់ពុំខាន" (១យហ ៣,១៩-២០)។

២០៩-ប្រជាជនអ៊ីស្រាអែលមិនហ៊ានពោលព្រះនាមព្រះជាម្ចាស់ចំៗទេ ដើម្បីគោរពភាពដ៏វិសុទ្ធនៃព្រះនាមព្រះអង្គ។ ពេលអានព្រះគម្ពីរ គេប្រើពាក្យ "ព្រះអម្ចាស់" (អដូណៃ ឬ Kyrios ជាភាសាក្រិក) ជំនួសព្រះនាមព្រះជាម្ចាស់វិញ។ គ្រីស្តបរិស័ទប្រើពាក្យនេះចំពោះព្រះយេស៊ូ ដើម្បីសម្តែងថាព្រះអង្គជាព្រះជាម្ចាស់៖ "ព្រះយេស៊ូជាព្រះអម្ចាស់"។

### "ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យអាណិតអាសូរ និងសន្តោសប្រោសប្រណី"

២១០-ក្រោយពីជនជាតិអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាបឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ដើម្បីគោរពរូបគោមាស (សរ ៣២) ព្រះអង្គសណ្តាប់ពាក្យអង្វររបស់លោកម៉ូសេ និងសព្វព្រះហឫទ័យបន្តការធ្វើដំណើរក្នុងចំណោមប្រជាជនមិនស្មោះត្រង់នេះ ទើបព្រះអង្គសម្តែងសេចក្តីស្រឡាញ់របស់ព្រះអង្គ (សរ ៣៣,១២-១៧)។ ពេលលោកម៉ូសេទូលអង្វរសូមឲ្យព្រះជាម្ចាស់សម្តែងសិរីរុងរឿងរបស់ព្រះអង្គឲ្យលោកឃើញ ព្រះអង្គក៏មានព្រះបន្ទូលថា៖ "យើងនឹងសម្តែងសេចក្តីសប្បុរស (សោភណភាព) របស់យើង ហើយយើងប្រកាសឈ្មោះយើងជាព្រះអម្ចាស់នៅចំពោះ

មុខអ្នក" (សរ ៣៣,១៨-១៩)។ ព្រះអម្ចាស់ឆ្លងកាត់ពីមុខលោកម៉ូសេដែលប្រកាសថា៖ "ព្រះអម្ចាស់ៗជាព្រះប្រកបដោយព្រះហឫទ័យអាណិតអាសូរ និងប្រណីសន្តោស ព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ ហើយពោរពេញដោយធម៌មេត្តាករុណា និងស្មោះស្ម័គ្រជានិច្ច" (សរ ៣៤,៥-៦)។ ពេលនោះ លោកម៉ូសេប្រកាសថាព្រះអម្ចាស់ជាព្រះដែលលើកលែងទោស (សរ ៣៤,៩)។

២១១-ព្រះនាមរបស់ព្រះជាម្ចាស់ "យើងមានជីវិតគង់នៅ" ឬ "ព្រះអង្គគង់នៅ" សម្តែងថាទោះបីមនុស្សមិនស្មោះត្រង់ប្រព្រឹត្តអំពើបាប និងសក្តិសមនឹងទទួលទោសយ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះស្ម័គ្រ និង "សម្តែងព្រះហឫទ័យមេត្តាករុណារហូតដល់រាប់ពាន់ជំណា" (សរ ៣៤,៧)។ ព្រះជាម្ចាស់សម្តែងថាព្រះអង្គតែងតែមានព្រះហឫទ័យអាណិតអាសូរ" (អភ ២,៤) រហូតដល់ប្រគល់ព្រះបុត្រារបស់ព្រះអង្គផ្ទាល់។ នៅពេលព្រះយេស៊ូបូជាព្រះជន្មរបស់ព្រះអង្គ ដើម្បីឲ្យយើងរួចពីបាប ព្រះអង្គនឹងសម្តែងថាទ្រង់ផ្ទាល់មានព្រះនាមរបស់ព្រះជាម្ចាស់៖ "កាលណាអ្នករាល់គ្នាលើកបុត្រមនុស្សឡើង អ្នករាល់គ្នាមុខជានឹងស្គាល់ឋានៈរបស់ខ្ញុំ" (យហ ៨,២៨)។

### មានតែព្រះជាម្ចាស់ដែលមានជីវិតគង់នៅ

២១២-ពីសតវត្សមួយទៅសតវត្សមួយ ជំនឿរបស់ជនជាតិអ៊ីស្រាអែលបានរីកចម្រើន និងបានយល់កាន់តែស៊ីជម្រៅទៅៗ ពីលក្ខណៈសម្បត្តិដែលមាននៅក្នុងព្រះនាមព្រះជាម្ចាស់។ ព្រះជាម្ចាស់មានតែមួយព្រះអង្គ ក្រៅពីព្រះអង្គគ្មានព្រះណាផ្សេងទៀតទេ (អស ៤៤,៦)។ ពិភពលោក និងប្រវត្តិសាស្ត្រមិនអាចផ្ទឹមនឹងព្រះអង្គបានទេ។ គឺព្រះអង្គនេះហើយដែលបានបង្កើតមេឃ និងដី៖ "ផ្ទៃមេឃ និងផែនដីនឹងវិនាសសូន្យ ហើយរិចរឹលទៅដូចសម្លៀកបំពាក់ រីឯព្រះអង្គវិញ ព្រះអង្គនៅស្ថិតស្ថេរហូតតទៅ ព្រះអង្គនៅតែដដែល ព្រះជន្មាយុរបស់ព្រះអង្គគ្មានទីបញ្ចប់ទេ" (ទន ១០២,២៧-២៨)។ "ព្រះអង្គមិនចេះប្រែក្រឡាស់ទេ ហើយនៅក្នុងអង្គព្រះអង្គ សូម្បីតែស្រមោលនៃការប្រែប្រួលក៏គ្មានផង" (យក ១,១៧)។ ព្រះជាម្ចាស់ជា "ព្រះដែលមានជីវិតគង់នៅ" តាំងពីដើមរៀងមក ហើយជាដរាបតរៀងទៅ ហេតុនេះព្រះអង្គនៅតែស្មោះស្ម័គ្រនឹងខ្លួនព្រះអង្គ និងព្រះបន្ទូលសន្យារបស់ព្រះអង្គជានិច្ច។

២១៣-ពេលព្រះជាម្ចាស់សម្តែងព្រះនាមចម្លែកប្លែកអស្ចារ្យណាស់របស់ព្រះអង្គ "យើងមានជីវិតគង់នៅ" ព្រះអង្គក៏សម្តែងសេចក្តីពិតថាមានតែព្រះជាម្ចាស់ទេ ដែលមានជីវិតគង់នៅ។ ព្រះគម្ពីរ ៧០គម្ពីរ (ព្រះគម្ពីរបកប្រែជាភាសាក្រិក) និងការបញ្ជូនបន្តរបស់ព្រះសហគមន៍បានយល់ថា ព្រះនាមព្រះជាម្ចាស់សម្តែងថាព្រះជាម្ចាស់ជាកំពូលរបស់សភាវៈ និងភាពល្អឥតខ្ចោះទាំងអស់ដែលគ្មានដើមកំណើត និងគ្មានទីបញ្ចប់ឡើយ។ សត្វលោកទាំងអស់បានទទួលពីព្រះជាម្ចាស់ អ្វីៗទាំងអស់មានតែព្រះអង្គទេដែលជាសភាវៈផ្ទាល់របស់ព្រះអង្គ និងបានទទួលលក្ខណៈជាព្រះជាម្ចាស់ពីព្រះអង្គផ្ទាល់។

### ៣-ព្រះជាម្ចាស់ដែល "មានជីវិតគង់នៅ" ជាសេចក្តីពិត និងសេចក្តីស្រឡាញ់

២១៤-ព្រះជាម្ចាស់ដែល "មានជីវិតគង់នៅ" បានសម្តែងឲ្យជនជាតិអ៊ីស្រាអែលដឹងថាព្រះអង្គមាន "ព្រះហឫទ័យពោរពេញដោយអាណិតអាសូរ និងសន្តោសប្រោសប្រណី" (សរ ៣៤,៦)។ ពាក្យទាំងពីរនោះបញ្ជាក់អំពីលក្ខណៈសម្បត្តិរបស់ព្រះនាមព្រះជាម្ចាស់។ នៅក្នុងស្នាព្រះហស្តទាំងអស់របស់ព្រះអង្គ ព្រះអង្គសម្តែងថា ព្រះអង្គប្រកបដោយសប្បុរសធម៌ ព្រះហឫទ័យប្រោសប្រណី និងសេចក្តីស្រឡាញ់ ព្រះអង្គក៏សម្តែងទៀតថា យើងអាចជឿទុកចិត្តលើព្រះអង្គៗមិនប្រែប្រួលទេ ស្មោះស្ម័គ្រជានិច្ច និងជាសេចក្តីពិត។ "ទូលបង្គំសូមអរព្រះគុណព្រះអង្គ ព្រោះព្រះអង្គប្រកបដោយព្រះហឫទ័យមេត្តាករុណាយ៉ាងស្មោះស្ម័គ្រ" (ទន ១៣៨,២) (ទន ៨៥,១១)។ ព្រះអង្គជាសេចក្តីពិត

ដ្បិត "ព្រះជាម្ចាស់ជាពន្លឺ គ្មានសេចក្ដីងងឹតក្នុងអង្គព្រះអង្គទាល់តែសោះ" (១យហ ១,៥)។ ព្រះអង្គជា "សេចក្ដីស្រឡាញ់" ដូចគ្រីស្ដទូតយ៉ូហានប្រៀនប្រដៅ (១យហ ៤,៨)។

## ព្រះជាម្ចាស់ជាសេចក្ដីពិត

២១៥-"គោលការណ៍នៃព្រះបន្ទូលរបស់ព្រះអង្គជាសេចក្ដីពិត ហើយការអ្វីៗទាំងប៉ុន្មានដែលព្រះអង្គសម្រេចដោយសុចរិតនៅស្ថិតស្ថេររហូតតទៅ" (ទន ១១៩,១៦០)។ "បពិត្រព្រះជាម្ចាស់! ព្រះអង្គពិតជាព្រះជាម្ចាស់មែន ព្រះបន្ទូលទាំងប៉ុន្មានសុទ្ធតែជាការពិត" (២សម ៧,២៨) ហេតុនេះព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់តែងតែសម្រេចជានិច្ច (ទក ៧,៩)។ ព្រះជាម្ចាស់ជាសេចក្ដីពិតផ្ទាល់ ព្រះបន្ទូលរបស់ព្រះអង្គមិនអាចបោកបញ្ឆោតបានទេ។ ហេតុនេះយើងអាចប្រគល់ខ្លួនទៅលើសេចក្ដីពិត និងភាពស្មោះស្ម័គ្រនៃព្រះបន្ទូលគ្រប់ប្រការរបស់ព្រះអង្គ ដោយជឿទុកចិត្តទាំងស្រុងទៅលើព្រះអង្គ។ អំពើបាបដើមដំបូងបានធ្វើឲ្យមនុស្សវិនាសបាន មកពីមេល្បួងដែលនាំឲ្យមនុស្សសង្ស័យពីព្រះបន្ទូលព្រះហឫទ័យសប្បុរស និងភាពស្មោះស្ម័គ្ររបស់ព្រះជាម្ចាស់។

២១៦-សេចក្ដីពិតរបស់ព្រះជាម្ចាស់បានមកពីព្រះប្រាជ្ញាញាណរបស់ព្រះអង្គដែលគ្រប់គ្រងសណ្ដាប់ធ្នាប់របស់សត្វលោក និងពិភពលោក (ប្រាញ ១៣,១-៩)។ មានតែព្រះជាម្ចាស់ដែលបានបង្កើតមេឃ និងដី (ទន ១១៥,៥) ដូច្នេះហើយមានតែព្រះអង្គទេ ដែលអាចប្រទានឲ្យយើងស្គាល់ច្បាស់នូវអ្វីៗដែលមានក្នុងលោកនេះ ដោយមានទំនាក់ទំនងជាមួយព្រះអង្គ (ប្រាញ ៧,១៧-២១)។

២១៧-ព្រះជាម្ចាស់ជាសេចក្ដីពិត នៅពេលព្រះអង្គសម្ដែងព្រះអង្គដែរ៖ ការប្រៀនប្រដៅដែលមកពីព្រះជាម្ចាស់ជា "លទ្ធិនៃសេចក្ដីពិត" (មគ ២,៦)។ ព្រះជាម្ចាស់នឹងចាត់ព្រះបុត្រាព្រះអង្គឲ្យយាងមកក្នុងលោកនេះ ដើម្បី "ផ្ដល់សក្ខីភាពអំពីសេចក្ដីពិត" (យហ ១៨,៣៧)។ "យើងដឹងថា ព្រះបុត្រារបស់ព្រះជាម្ចាស់យាងមក ទ្រង់ប្រទានប្រាជ្ញាឲ្យយើងស្គាល់ព្រះដ៏ពិតប្រាកដ" (១យហ ៥,២០) (យហ ១៧,៣)។

## ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់

២១៨-ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ជនជាតិអ៊ីស្រាអែលបានយល់ឃើញថាព្រះជាម្ចាស់បានសម្ដែងព្រះអង្គឲ្យគេស្គាល់ និងបានជ្រើសរើសគេក្នុងចំណោមប្រជាជាតិទាំងឡាយ ដើម្បីធ្វើជាកម្មសិទ្ធរបស់ព្រះអង្គដោយសារមូលហេតុតែមួយ គឺសេចក្ដីស្រឡាញ់របស់ព្រះអង្គ (ទក ៤,៣៧; ៧,៨; ១០,១៥)។ ដោយសារអស់លោកព្យាការីជនជាតិអ៊ីស្រាអែលបានយល់ថាព្រះជាម្ចាស់តែងតែសង្គ្រោះគេ (អស ៤៣,១-៧) និងលើកលែងទោសអំពើផិតក្បត់របស់គេ និងអំពើបាបរបស់គេផង (ហស ២) ព្រោះតែសេចក្ដីស្រឡាញ់។

២១៩-សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះជនជាតិអ៊ីស្រាអែល ប្រៀបបាននឹងសេចក្ដីស្រឡាញ់របស់ឪពុកចំពោះកូន (ហស ១១,១)។ សេចក្ដីស្រឡាញ់នេះខ្លាំងជាងសេចក្ដីស្រឡាញ់របស់ម្ដាយចំពោះកូនៗ។ ព្រះជាម្ចាស់ស្រឡាញ់ប្រជាជនរបស់ខ្លួនខ្លាំងជាងស្វាមីចំពោះភរិយាទៅទៀត (អស ៦២,៤-៥)។ សេចក្ដីស្រឡាញ់នេះនឹងឈ្នះអំពើផិតក្បត់អាក្រក់ៗរហូតដល់ប្រទានអំណោយដែលមានតម្លៃជាងគេ៖ "ព្រះជាម្ចាស់បានស្រឡាញ់មនុស្សលោកខ្លាំងណាស់ បានជាព្រះអង្គបានប្រោសប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គ" (យហ ៣,១៦)។

២២០-សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ "អស់កល្បជានិច្ច" (អស ៥៤,៨)៖ "ទោះបីភ្នំធំកក្រើករំពើកក្ដីសេចក្ដីស្រឡាញ់របស់យើងមិនឃ្លាតចេញពីអ្នកឡើយ" (អស ៥៤,១០)។ "យើងស្រឡាញ់អ្នកដោយចិត្តស្រឡាញ់

ដែលស្ថិតស្ថេរនៅអស់កល្បជានិច្ច។ ហេតុនេះហើយបានជាយើងទាក់ទាញចិត្តអ្នក ព្រោះយើងជំពាក់ចិត្តនឹងអ្នកយ៉ាងខ្លាំង" (យរ ៣១,៣)។

២២១-សន្ត: យ៉ូហាន នឹងបញ្ជាក់ថែមទៀតថា៖ "ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់" (១យហ ៤,៨.១៦) គឺសភាវៈផ្ទាល់របស់ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ ដោយចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គ និងព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់ នៅពេលកំណត់ដ៏ពេញលក្ខណៈ ព្រះជាម្ចាស់សម្តែងទីស្ងាត់កំបាំងដ៏ស្និទ្ធស្នាលរបស់ព្រះអង្គ គឺព្រះអង្គផ្ទាល់ ជាសេចក្តីស្រឡាញ់អស់កល្បជានិច្ចរវាងព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយព្រះអង្គសព្វព្រះហឫទ័យឲ្យយើងរួមចំណែកក្នុងសេចក្តីស្រឡាញ់នេះដែរ។

### ៤-តើជំនឿលើព្រះជាម្ចាស់តែមួយព្រះអង្គនាំឲ្យទទួលផលអ្វីខ្លះ?

២២២-ពេលយើងជឿលើព្រះជាម្ចាស់តែមួយព្រះអង្គគត់ និងស្រឡាញ់ព្រះអង្គអស់ពីចិត្តគំនិត យើងអាចទទួលផលដ៏អស្ចារ្យអស់មួយជីវិតគឺ៖

២២៣-យើងស្គាល់ឋានៈដ៏ខ្ពង់ខ្ពស់បំផុត និងឧត្តមភាពរបស់ព្រះជាម្ចាស់៖ "ព្រះជាម្ចាស់ជាព្រះដ៏ឧត្តម ដែលយើងពុំអាចស្វែងយល់បានឡើយ" (យប ៣៦,២៦)។ ហេតុនេះហើយបានជា "ត្រូវតែបម្រើព្រះជាម្ចាស់មុនគេបង្អស់" (សន្ត: យ៉ូហាននៃអាក)។

២២៤-យើងរស់នៅដោយអរព្រះគុណព្រះជាម្ចាស់៖ បើមានព្រះជាម្ចាស់តែមួយ លក្ខណៈទាំងអស់របស់យើង និងអ្វីៗទាំងអស់ដែលយើងមានមកពីព្រះអង្គ៖ "អ្វីៗដែលអ្នកមាន គឺសុទ្ធតែបានទទួលពីព្រះជាម្ចាស់ទេតើ!" (១ករ ៤,៧)។ "តើខ្ញុំអាចយកអ្វីមកតបស្នងនឹងព្រះគុណទាំងប៉ុន្មានដែលព្រះអម្ចាស់បានសម្តែងមកលើរូបខ្ញុំ?" (ទំន ១១៦,១២)។

២២៥-យើងស្គាល់ឋានៈដ៏ថ្លៃថ្នូរពិតប្រាកដរបស់មនុស្សដែលរស់នៅជាមួយគ្នាជាផ្លូងតែមួយ៖ ព្រះជាម្ចាស់បានបង្កើតមនុស្សទាំងអស់ "ជារូបតំណាងរបស់ព្រះជាម្ចាស់ និងមានលក្ខណៈដូចព្រះអង្គដែរ" (កណ ១,២៦)។

២២៦-យើងអាចប្រើប្រាស់អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតតាមរបៀបល្អត្រឹមត្រូវ៖ ពេលយើងជឿលើព្រះជាម្ចាស់តែមួយ យើងប្រើប្រាស់អ្វីៗទាំងអស់ដើម្បីទៅរកព្រះអង្គ ហើយយើងលះបង់អ្វីៗទាំងអស់ដែលនាំឲ្យយើងឃ្លាតឆ្ងាយពីព្រះអង្គ (មថ ៥,២៩-៣០; ១៦,២៤; ១៩,២៣-២៤)។

ឱព្រះអម្ចាស់ និងព្រះជាម្ចាស់នៃខ្ញុំអើយ! សូមយកអ្វីៗដែលធ្វើឲ្យខ្ញុំឃ្លាតឆ្ងាយពីព្រះអង្គចេញទៅ។ ឱព្រះអម្ចាស់ និងព្រះជាម្ចាស់នៃខ្ញុំអើយ! សូមប្រទានឲ្យខ្ញុំនូវអ្វីៗដែលធ្វើឲ្យខ្ញុំមកជិតព្រះអង្គ។ ឱព្រះអម្ចាស់ និងព្រះជាម្ចាស់នៃខ្ញុំអើយ! សូមឲ្យខ្ញុំលះបង់ខ្លួនឯង ដើម្បីថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គ (សន្ត: នីកូឡាសនៃហ្វ្លួ)។

២២៧-យើងជឿទុកចិត្តលើព្រះជាម្ចាស់គ្រប់កាលៈទេសៈ សូម្បីតែពេលមានឧបសគ្គ៖ ពាក្យកំណាព្យរបស់សន្តី ថេរេសានៃព្រះយេស៊ូ (ថេរេសានៃអាវីឡា) សម្តែងសេចក្តីនេះយ៉ាងច្បាស់៖

"កុំឲ្យរន្ធត់ចិត្ត កុំឲ្យភ័យខ្លាច។ អ្វីៗទាំងអស់បាត់បង់ទៅហើយ តែព្រះជាម្ចាស់គង់នៅជានិច្ច។ អ្នកណាចេះអត់ធ្មត់ អ្នកនោះអាចឈ្នះអ្វីៗទាំងអស់។ អ្នកណាមានព្រះជាម្ចាស់ អ្នកនោះមានអ្វីៗទាំងអស់។ មានព្រះជាម្ចាស់ គឺគ្រប់គ្រាន់ហើយ។"

# សង្ខេប

២២៨-"អ៊ីស្រាអែលអើយ ចូរស្តាប់! មានតែព្រះអម្ចាស់ ជាព្រះរបស់យើងមួយព្រះអង្គគត់..." (ទក ៦,៤; មក ១២,២៩)។ "ចាំបាច់ត្រូវតែជាសភាវៈដ៏ខ្ពង់ខ្ពស់បំផុតតែមួយ ពោលគឺប្រៀបផ្ទឹមពុំបាន (...)។ បើមានព្រះជាម្ចាស់ច្រើន ព្រះអង្គមិនមែនជាព្រះជាម្ចាស់ទេ" (លោក ទែរទូលីយ៉ាំង)។

២២៩-ជំនឿលើព្រះជាម្ចាស់នាំយើងឲ្យបែរទៅរកព្រះអង្គ។ មានតែព្រះអង្គទេ ដែលជាប្រភពដើមដំបូង និងទីចុងក្រោយបំផុតរបស់យើង ហើយនាំអោយយើងមិនឲ្យស្រឡាញ់អ្វី ឬនរណាផ្សេងទៀត ក្រៅពីព្រះអង្គឡើយ។

២៣០-ដោយព្រះជាម្ចាស់សម្តែងព្រះអង្គ ព្រះអង្គនៅតែជាអាថ៌កំបាំងដែលមិនអាចថ្លែងបាន៖ "បើអ្នកយល់អំពីព្រះអង្គ ៗមិនមែនជាព្រះជាម្ចាស់ទេ" (សន្ត: អូគូស្តាំង)។

២៣១-ព្រះនៃជំនឿរបស់យើងបានសម្តែងព្រះអង្គដូចជា ព្រះដែលមានព្រះជន្មគង់នៅ ព្រះអង្គបានសម្តែងឲ្យយើងស្គាល់ "ជាព្រះប្រកបដោយព្រះហឫទ័យអាណិតអាសូរ និងប្រណីសន្តោស" (ទក ៣៤,៦)។ សភាពផ្ទាល់របស់ព្រះជាម្ចាស់ ជាសេចក្តីពិត និងសេចក្តីស្រឡាញ់។

## កថាខណ្ឌទី២៖ ព្រះបិតា

### ១-"ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"

២៣២-គ្រីស្តបរិស័ទទទួលពិធីជ្រមុជទឹក "ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" (មថ ២៨,១៩)។ មុនដំបូងពេលយើងសូមឲ្យគេប្រកាសជំនឿរបស់គេលើព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ គេឆ្លើយតបថា "ខ្ញុំជឿ"៖ "ជំនឿរបស់គ្រីស្តបរិស័ទទាំងអស់សំអាងលើព្រះត្រៃឯក" (សន្ត: សេសារ៉េនៃអារល៍)។

២៣៣-គ្រីស្តបរិស័ទទទួលពិធីជ្រមុជទឹក "ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" តែមិនជ្រមុជទឹកក្នុងព្រះនាមរបស់ព្រះបិតាផង ព្រះបុត្រាផង និងព្រះវិញ្ញាណដ៏វិសុទ្ធផងទេ (DS ៤១៥) ព្រោះមានព្រះជាម្ចាស់តែមួយជាព្រះបិតាប្រកបដោយឫទ្ធានុភាព ព្រះបុត្រាតែមួយរបស់ព្រះអង្គ និងព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះត្រៃឯកដ៏វិសុទ្ធបំផុត។

២៣៤-អាថ៌កំបាំងនៃព្រះត្រៃឯកដ៏វិសុទ្ធបំផុត ជាអាថ៌កំបាំងដ៏សំខាន់បំផុតនៃជំនឿ និងការរស់នៅរបស់គ្រីស្តបរិស័ទ គឺអាថ៌កំបាំងរបស់ព្រះជាម្ចាស់នៅក្នុងខ្លួនព្រះអង្គផ្ទាល់។ អាថ៌កំបាំងនៃព្រះត្រៃឯកជាប្រភព និងបំភ្លឺអាថ៌កំបាំងផ្សេង ៗនៃជំនឿ ហើយជាការប្រៀនប្រដៅដ៏សំខាន់បំផុត និងជាមូលដ្ឋានគ្រឹះនៃ "សេចក្តីពិតទាំងឡាយនៃជំនឿ" (DCG ៤៣)។ "ប្រវិត្តិសាស្រ្តទាំងអស់នៃការសង្គ្រោះ ជាប្រវិត្តិសាស្រ្តនៃមាគ៌ា និងមធ្យោបាយដែលព្រះជាម្ចាស់ជាព្រះដ៏ពិតប្រាកដតែមួយដែលជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធសម្រុះសម្រួល និងរួបរួមជាមួយមនុស្សដែលលែងប្រព្រឹត្តអំពើបាប" (DCG ៤៧)។

២៣៥-ក្នុងកថាខ័ណ្ឌនេះ យើងនឹងរាយការណ៍ខ្លី ៗអំពីរបៀបដែលព្រះជាម្ចាស់បានសម្តែងអាថ៌កាំបាំងនៃព្រះត្រៃឯកដ៏ពោរពេញដោយសុភមង្គល (២.) របៀបដែលព្រះសហគមន៍បានថ្លែងលទ្ធិនៃជំនឿអំពីអាថ៌កំបាំងនេះ (៣.) ហើយទីបញ្ចប់របៀបដែលព្រះជាម្ចាស់ជាព្រះបិតាបំពេញ "គម្រោងការដ៏សប្បុរសរបស់ព្រះអង្គ" គឺរបៀបដែលព្រះជាម្ចាស់បង្កើតសង្គ្រោះ និងធ្វើឲ្យមនុស្សបានដ៏វិសុទ្ធតាមរយៈបេសកកម្មរបស់ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ (៤.)។

២៣៦-គ្រូបាធ្យាយនៃព្រះសហគមន៍និយាយអំពី Theologia សំដៅទៅលើព្រះជន្មផ្ទាល់ដ៏លាក់កំបាំងនៃព្រះជាម្ចាស់ជាព្រះត្រៃឯក និង Oikonomia សំដៅទៅលើព្រះរាជកិច្ចរបស់ព្រះអង្គ ដែលសម្តែងព្រះអង្គ និងប្រទានព្រះជន្មរបស់ព្រះអង្គ។ Oikonomia សម្តែងឲ្យយើងស្គាល់នូវ Theologia ផ្ទុយទៅវិញ Theologia បំភ្លឺ Oikonomia។ ព្រះរាជកិច្ចរបស់ព្រះជាម្ចាស់សម្តែងឲ្យយើងដឹងថា តើព្រះអង្គជានរណា ផ្ទុយទៅវិញ សភាវៈដ៏លាក់កំបាំងរបស់ព្រះអង្គបំភ្លឺយើងឲ្យយល់អំពីព្រះរាជកិច្ចរបស់ព្រះអង្គ។ បើប្រៀបធៀបព្រះជាម្ចាស់ និងមនុស្សជារឿងដដែល គឺមនុស្សបង្ហាញខ្លួនតាមកិច្ចការដែលខ្លួនប្រព្រឹត្ត ហើយកាលណាយើងស្គាល់ម្នាក់កាន់តែច្បាស់ យើងយល់អំពីកិច្ចការរបស់គេកាន់តែច្បាស់ដែរ។

២៣៧-ព្រះត្រៃឯកជាអាថ៌កំបាំងដ៏ពិតប្រាកដនៃជំនឿគឺ "អាថ៌កំបាំងមួយនៅក្នុងចំណោមអាថ៌កំបាំងដែលព្រះជាម្ចាស់លាក់លៀម ហើយដែលយើងអាចស្គាល់ លុះត្រាតែព្រះអង្គសម្តែងឲ្យយើងស្គាល់" (SPF ១៦)។ ព្រះជាម្ចាស់បានសម្តែងទីសម្គាល់នៃព្រះត្រៃឯកនៅពេលព្រះអង្គបង្កើតពិភពលោក ហើយនៅពេលព្រះអង្គសម្តែងព្រះអង្គ នៅក្នុងសម្ពន្ធមេត្រីចាស់។ ប៉ុន្តែព្រះជាម្ចាស់ជាព្រះត្រៃឯកដ៏វិសុទ្ធជាអាថ៌កំបាំង ដែលប្រាជ្ញាសូម្បីតែជំនឿរបស់ប្រជាជនអ៊ីស្រាអែលមុនពេលព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស និងមុនបេសកកម្មរបស់ព្រះវិញ្ញាណដ៏វិសុទ្ធមិនអាចយល់បានឡើយ។

## ២-ព្រះជាម្ចាស់សម្តែងព្រះអង្គជាព្រះត្រៃឯក

### ព្រះបុត្រាសម្តែងព្រះបិតា

២៣៨-សាសនាជាច្រើនអង្វរព្រះជាម្ចាស់ជា "ព្រះបិតា"។ គេចាត់ទុកព្រះដូចជា "បិតារបស់ព្រះផ្សេងៗ និងរបស់មនុស្សលោកផង"។ នៅប្រទេសអ៊ីស្រាអែលគេហៅព្រះជាម្ចាស់ជាព្រះបិតា ព្រោះព្រះអង្គបានបង្កើតពិភពលោក (ទក ៣២,៦; មគ ២,១០) លើសពីនេះទៅទៀត ព្រោះព្រះអង្គចងសម្ពន្ធមេត្រី និងប្រទានធម៌វិន័យឲ្យជនជាតិអ៊ីស្រាអែលជា "កូនច្បង" របស់ព្រះអង្គ (សរ ៤,២២)។ គេហៅព្រះជាម្ចាស់ជាព្រះបិតារបស់ព្រះមហាក្សត្រអ៊ីស្រាអែលដែរ (២សម ៧,១៤) ជាពិសេសព្រះជាម្ចាស់ជា "ឪពុករបស់អ្នកក្រីក្រ" ក្មេងកំព្រា និងស្ត្រីមេម៉ាយដែលព្រះអង្គជួយការពារដោយក្តីស្រឡាញ់ (ទន ៦៨,៦)។

២៣៩-ភាសានិយាយនៃជំនឿសន្មតហៅព្រះជាម្ចាស់ថា "ព្រះបិតា" គឺសំដៅលើសភាពពីរ៖ ព្រះជាម្ចាស់ជាប្រភពដំបូងនៃអ្វីៗទាំងអស់ ដែលមានតេជានុភាពដ៏ខ្ពង់ខ្ពស់បំផុត ហើយជាមួយគ្នានេះ ព្រះអង្គប្រកបដោយព្រះហឫទ័យសប្បុរស និងយកចិត្តទុកដាក់នឹងបុត្រធីតារបស់ព្រះអង្គដោយក្តីស្រឡាញ់។ យើងអាចប្រដូចព្រះជាម្ចាស់ដែលស្រឡាញ់ថ្នាក់ថ្នមបុត្រធីតារបស់ព្រះអង្គ ដូចជាម្តាយម្នាក់ចំពោះកូន (អស ៦៦,១៣; ទន ១៣១,១២) ដែលសម្តែងថា ព្រះជាម្ចាស់យាងមកជិតមនុស្ស និងស្រឡាញ់គេយ៉ាងស្និទ្ធស្នាល។ ភាសានៃជំនឿដកស្រង់ពីបទពិសោធន៍របស់ឪពុកម្តាយ ដែលជារូបដំណាងដំបូងរបស់ព្រះជាម្ចាស់ចំពោះមនុស្សម្យ៉ាង។ ប៉ុន្តែ បទពិសោធន៍នេះបញ្ជាក់ថា ឪពុកម្តាយជាមនុស្សទន់ខ្សោយអាចប្រព្រឹត្តខុសពីតួនាទីជាឪពុកម្តាយពិតប្រាកដបាន។ ហេតុនេះគួររំឭកថា ព្រះជាម្ចាស់ខ្ពង់ខ្ពស់បំផុតខុសប្លែកពីមនុស្ស។ ព្រះអង្គមិនមែនជាបុរស មិនមែនជាស្ត្រីដែរ ព្រះអង្គជាព្រះជាម្ចាស់។ ព្រះអង្គខ្ពង់ខ្ពស់បំផុតខុសប្លែកពីឪពុកម្តាយ (ទន ២៧,១០) ប៉ុន្តែ ព្រះអង្គជាប្រភព និងគំរូ (អភ ៣,១៤; អស ៤៩,១៥) របស់ឪពុកម្តាយទាំងឡាយ គឺគ្មាននរណាជាឪពុកដូចព្រះជាម្ចាស់ឡើយ។

២៤០-ព្រះយេស៊ូបានសម្តែងថា ព្រះជាម្ចាស់ជាព្រះបិតាដែលមានអត្ថន័យដ៏អស្ចារ្យបំផុត៖ ព្រះជាម្ចាស់ជា

ព្រះបិតាមិនគ្រាន់តែជាព្រះបង្កើតពិភពលោកទេ ព្រះអង្គជាព្រះបិតាអស់កល្បជានិច្ច ដោយសារទំនាក់ទំនងជាមួយព្រះបុត្រាតែមួយរបស់ព្រះអង្គដែលជាព្រះបុត្រា ដោយសារតែទំនាក់ទំនងជាមួយព្រះបិតារបស់ព្រះអង្គដែរ៖ "ក្រៅពីព្រះបិតាគ្មាននរណាស្គាល់ព្រះបុត្រាទេ ហើយក្រៅពីព្រះបុត្រា និងអ្នកដែលព្រះបុត្រាសព្វព្រះហឫទ័យសម្តែងឲ្យស្គាល់នោះ ក៏គ្មាននរណាអាចស្គាល់ព្រះបិតាបានដែរ" (មថ ១១,២៧)។

២៤១-ហេតុនេះហើយបានជាក្រុមគ្រីស្តទូតប្រកាសព្រះយេស៊ូជា "ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ ហើយព្រះបន្ទូលជាព្រះជាម្ចាស់។ ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់កាលពីដើមបង្អស់" (យហ ១,១) "ព្រះគ្រីស្តជាតំណាងរបស់ព្រះជាម្ចាស់ដែលយើងមើលពុំឃើញ" (កូឡ ១,១៥) "ជារស្មីនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងមានលក្ខណៈដូចព្រះអង្គបេះបិទ" (ហប ១,៣)។

២៤២-យោងតាមការបញ្ជូនបន្តដែលមកពីក្រុមគ្រីស្តទូត ព្រះសហគមន៍បានប្រកាសនៅឆ្នាំ៣២៥ នៅមហាសន្និបាតសកលដំបូងនៃទីក្រុងនិសេថាព្រះបុត្រា "រួមសភាព" ជាមួយព្រះបិតា គឺជាព្រះជាម្ចាស់តែមួយជាមួយព្រះអង្គ។ មហាសន្និបាតសកលទីពីរនៅទីក្រុងកុងស្តង់ទីណូបនៅឆ្នាំ៣៨១ បានរក្សាទុកពាក្យសម្តីនេះនៅក្នុងធម៌ប្រកាសជំនឿនៃនិសេ ហើយបានប្រកាសថា "ព្រះបុត្រាតែមួយនៃព្រះបិតា ហើយមានប្រភពពីព្រះបិតាមុនកាលសម័យទាំងអស់ជាពន្លឺចេញពីពន្លឺជាព្រះជាម្ចាស់ដ៏ពិតប្រាកដ ចេញពីព្រះជាម្ចាស់ដ៏ពិតប្រាកដដែល ព្រះអង្គទទួលព្រះជន្មពីព្រះបិតា ហើយមិនកើតដូចសត្វលោកឡើយ ព្រះអង្គរួមសភាពជាមួយព្រះបិតា" (DS ១៥០)។

### ព្រះវិញ្ញាណដ៏វិសុទ្ធសម្តែងព្រះបិតា និងព្រះបុត្រា

២៤៣-មុនបុណ្យចម្លងរបស់ព្រះអង្គព្រះយេស៊ូមានព្រះបន្ទូលទុកជាមុនថានឹងចាត់ "ព្រះដ៏ជួយការពារ (ប៉ារ៉ាក្លេតូស-មេធាវី) គឺព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការតាំងពីកំណើតពិភពលោក (កណ ១,២) ទ្រង់មានព្រះបន្ទូល "តាមរយៈអស់លោកព្យាការី" (ធម៌ប្រកាសជំនឿនៃនីសេ/កុងស្តង់ទីណូប) គង់នៅជាមួយពួកសាវ័កនិងនៅក្នុងពួកគេ (យហ ១៤,១៧) ដើម្បីប្រៀនប្រដៅ (យហ ១៤,២៦) និងណែនាំគេឆ្ពោះទៅ "សេចក្តីពិតគ្រប់ជំពូក" (យហ ១៦,១៣)។ ដូច្នេះហើយបានជាព្រះជាម្ចាស់សម្តែងព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះមួយអង្គទៀតដូចព្រះយេស៊ូ និងព្រះបិតាផងដែរ។

២៤៤-បេសកកម្មនៅលើផែនដីរបស់ព្រះវិញ្ញាណដ៏វិសុទ្ធសម្តែងប្រភពអស់កល្បជានិច្ចរបស់ព្រះអង្គ។ ទាំងព្រះបិតាក្នុងព្រះនាមព្រះបុត្រា ទាំងព្រះបុត្រាផ្ទាល់នៅពេលឡើងទៅឯព្រះបិតាវិញរួចហើយចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមករកក្រុមគ្រីស្តទូត និងព្រះសហគមន៍ផង (យហ ១៤,២៦; ១៥,២៦; ១៦,១៤)។ ពេលព្រះជាម្ចាស់ចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមកក្រោយពីព្រះយេស៊ូបានទទួលសិរីរុងរឿង (យហ ៧,៣៩) ព្រះអង្គក៏សម្តែងគម្រោងការដ៏លាក់កំបាំងនៃព្រះត្រៃឯកដ៏វិសុទ្ធបានគ្រប់លក្ខណៈ។

២៤៥-មហាសន្និបាតសកលទីពីរបានប្រកាសជំនឿដែលមកពីក្រុមគ្រីស្តទូត លើព្រះវិញ្ញាណនៅទីក្រុងកុងស្តង់ទីណូបនៅឆ្នាំ៣៨១៖ "យើងជឿលើព្រះវិញ្ញាណដ៏វិសុទ្ធដែលប្រទានជីវិត និងជាអម្ចាស់ដែលហូរចេញពីព្រះបិតា" (DS ១៥០)។ ព្រះសហគមន៍ទទួលស្គាល់ថាព្រះបិតាជា "ប្រភព និងដើមកំណើតនៃព្រះជាម្ចាស់ទាំងស្រុង" (DS ៤៩០)។ ក៏ប៉ុន្តែព្រះវិញ្ញាណដ៏វិសុទ្ធមានប្រភពអស់កល្បជានិច្ច ដែលទាក់ទងនឹងប្រភពអស់កល្បជានិច្ចរបស់ព្រះបុត្រាដែរ៖ "ព្រះវិញ្ញាណដ៏វិសុទ្ធដែលជាព្រះអង្គទីបីនៃព្រះត្រៃឯកជាព្រះជាម្ចាស់តែមួយព្រះអង្គដែលមានឋានៈស្មើនឹងព្រះបិតា និងព្រះបុត្រាដែលមានសារធាតុ និងសភាពដូចគ្នា (...) ប៉ុន្តែ យើងមិននិយាយថាព្រះវិញ្ញាណ

ជាព្រះវិញ្ញាណរបស់ព្រះបិតាតែប៉ុណ្ណោះ ថែមទាំងជាព្រះវិញ្ញាណរបស់ព្រះបិតាផង និងរបស់ព្រះបុត្រាផងដែរ" (DS ៥២៧)។ ធម៌ប្រកាសជំនឿរបស់មហាសន្និបាតកុងស្តង់ទីណូបប្រកាសថា៖ "ព្រះវិញ្ញាណដ៏វិសុទ្ធទទួលការក្រាបថ្វាយបង្គំ និងសិរីរុងរឿងស្មើនឹងព្រះបិតា និងព្រះបុត្រា" (DS ១៥០)។

២៤៦-ការបញ្ជូនបន្តនៃធម៌ប្រកាសជំនឿនៅបស្ចិមប្រទេសប្រកាសថាព្រះវិញ្ញាណ "ហូរចេញពីព្រះបិតា និងព្រះបុត្រាផង (filioque)"។ មហាសន្និបាតនៃទីក្រុងហ្វ្លរង់នៅឆ្នាំ១៤៣៨ ពន្យល់លម្អិតថា៖ "ព្រះវិញ្ញាណដ៏វិសុទ្ធមានសភាវៈពីព្រះបិតាផង ពីព្រះបុត្រាផង ហើយហូរចេញអស់កល្បជានិច្ចពីព្រះបិតាដូចពីព្រះបុត្រាដែរ...ដោយសារព្រះបិតាបានប្រគល់អ្វីៗទាំងអស់ឲ្យព្រះបុត្រាតែមួយរបស់ព្រះអង្គ លើកលែងតែលក្ខណៈពិសេសរបស់ព្រះបិតា ព្រះបុត្រាក៏បានទទួលការហូរចេញរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនោះ ពីព្រះបិតាព្រះអង្គដែរ" (DS ១៣០០-១៣០១)។

២៤៧-ការប្រការថា ព្រះវិញ្ញាណ "ហូរចេញពីព្រះបិតា និងព្រះបុត្រាផង (filioque) មិនស្ថិតនៅក្នុងធម៌ប្រកាសជំនឿនៃទីក្រុងកុងស្តង់ទីណូបនៅឆ្នាំ៣៨១ ប៉ុន្តែ តាមប្រពៃណីបុរាណ ដែលមកពីពួកឡាតាំង និងពួកអាឡិចសង់ឌ្រី សម្តេចប៉ាប សន្តៈ ឡេអុង បានប្រកាសថា ជាគោលការណ៍នៅឆ្នាំ៤៤៧ មុនទីក្រុងរ៉ូមស្គាល់ និងទទួលនៅមហាសន្និបាតកាលសេដូន នៅឆ្នាំ៤៥១ ធម៌ប្រកាសជំនឿនៃឆ្នាំ៣៨១។ បន្តិចម្តងៗ គេធ្លាប់ប្រើប្រាស់ប្រការនេះនៃធម៌ប្រកាសជំនឿ ក្នុងពិធីបុណ្យខាងបស្ចិមប្រទេស (រវាងសតវត្សទី៨ និងទី១១) ប៉ុន្តែ ដោយសារពិធីបុណ្យខាងបស្ចិមប្រទេសបានបញ្ចូល filioque នេះ ក្នុងធម៌ប្រកាសជំនឿនៃនិសេ/កុងស្តង់ទីណូប ព្រះសហគមន៍អ័រតូដុក និងព្រះសហគមន៍កាតូលិកមិនទាន់បានឯកភាពនៅឡើយ។

២៤៨-ការបញ្ជូនបន្តខាងបូព៌ាប្រទេសសម្តែងជាមុនថា ព្រះបិតាមានប្រភពមុនព្រះវិញ្ញាណដ៏វិសុទ្ធ។ ដោយប្រកាសថា ព្រះវិញ្ញាណ "ហូរចេញពីព្រះបិតា" (យហ ១៥,២៦) គេអះអាងថា ព្រះវិញ្ញាណហូរចេញពីព្រះបិតាដោយព្រះបុត្រា (AG ២)។ ការបញ្ជូនបន្តខាងបស្ចិមប្រទេសសម្តែងជាមុនថា ព្រះបិតា និងព្រះបុត្ររួមសភាពដោយប្រកាសថា ព្រះវិញ្ញាណហូរចេញពីព្រះបិតាផង ពីព្រះបុត្រាផង (filioque)។ គេនិយាយ "បែបនេះ ត្រឹមត្រូវ" (DS ១៣០២) ដ្បិតដោយសារព្រះអង្គនីមួយៗរួមសភាពអស់កល្បជានិច្ច ព្រះបិតាត្រូវតែជាប្រភពដំបូងនៃព្រះវិញ្ញាណ ព្រោះព្រះអង្គជា "គោលដំបូង ដែលគ្មានគោលដំបូងទេ" (DS ១៣៣១) ដោយសារព្រះអង្គជាព្រះបិតានៃព្រះបុត្រាតែមួយ ព្រះអង្គត្រូវតែរួមជាមួយព្រះបុត្រាធ្វើជា "គោលតែមួយ ដែលហូរចេញព្រះវិញ្ញាណដ៏វិសុទ្ធ" (DS 850)។ លុះត្រាតែព្រះសហគមន៍ខាងបស្ចិមប្រទេស និងខាងបូព៌ាប្រទេស មិនរឹតគោលការណ៍របស់ខ្លួនឲ្យតឹងពេកទេ ព្រះសហគមន៍ទាំងពីរនោះក៏បំពេញគ្នាទៅវិញទៅមក។

## ៣-លទ្ធិនៃជំនឿអំពីព្រះត្រៃឯកដ៏វិសុទ្ធ

### ការបង្កបង្កើតគោលការណ៍អំពីព្រះត្រៃឯក

២៤៩-សេចក្តីពិតដែលព្រះជាម្ចាស់បានសម្តែងអំពីព្រះត្រៃឯកដ៏វិសុទ្ធ ជាគ្រឹះនៃជំនឿដ៏រស់រវើករបស់ព្រះសហគមន៍តាំងពីដើមដំបូង ជាពិសេសដោយសារបុណ្យជ្រមុជទឹក។ គោលការណ៍អំពីព្រះត្រៃឯកមាននៅក្នុងក្បួនច្បាប់នៃពិធីជ្រមុជទឹកក្នុងធម៌ទេសនាការអប់រំជំនឿ និងការអធិដ្ឋានរបស់ព្រះសហគមន៍ ហើយនៅក្នុងលិខិតទាំងប៉ុន្មានដែលមកពីក្រុមគ្រីស្តទូតដូចពាក្យជម្រាបសួរនេះ ដែលពិធីអរព្រះគុណព្រះជាម្ចាស់ផ្តល់សក្ខីភាពថា៖ "សូមឲ្យបងប្អូនទាំងអស់គ្នាប្រកបដោយព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត សូមឲ្យបងប្អូនបានប្រកបដោយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងសូមឲ្យបងប្អូនបានរួមរស់ជាមួយគ្នាដោយព្រះវិញ្ញាណដ៏វិសុទ្ធផង"

(២ករ ១៣,១៣) (១ករ ១២,៤-៦; អភ ៤,៤-៦)។

២៥០-ពីសតវត្សមួយទៅសតវត្សមួយ តាមរយៈមហាសន្និបាតបុរាណដោយមានទេវវិទ្យារបស់គ្រូបាធ្យាយ និងជំនឿរបស់គ្រីស្តបរិស័ទជួយគាំទ្រព្រះសហគមន៍បានព្យាយាមពន្យល់អំពីជំនឿលើព្រះត្រៃឯកកាន់តែច្បាស់ឡើងៗ ដើម្បីឈ្វេងយល់អំពីជំនឿកាន់តែស៊ីជម្រៅ និងដើម្បីការពារជំនឿនោះពីកំហុសផ្សេងៗផង។

២៥១-ដើម្បីបង្កើតគោលការណ៍នៃព្រះត្រៃឯក ព្រះសហគមន៍បានបង្កើតពាក្យថ្មី ដោយប្រើគំនិតខាងទស្សនវិទ្យា៖ "សារធាតុ" "បុគ្គល" "អង្គ" "ទំនាក់ទំនង" ជាដើម។ ធ្វើដូច្នោះ ព្រះសហគមន៍មិនបានបញ្ចុះជំនឿក្រោមប្រាជ្ញារបស់មនុស្សទេ ប៉ុន្តែបានផ្តល់អត្ថន័យថ្មី និងយ៉ាងអស្ចារ្យដល់ពាក្យទាំងអស់នោះ ដែលសំដៅទៅលើអាថ៌កំបាំងដ៏ប្លែកអស្ចារ្យ "លើសពីអ្វីៗទាំងអស់ ដែលប្រាជ្ញាមនុស្សយើងអាចនឹកគិតដល់ទៅទៀត" (SPF ២)។

២៥២-ព្រះសហគមន៍ប្រើពាក្យ"សារធាតុ" (ឬ"សភាវៈ"ឬ"សភាព") សំដៅទៅលើព្រះជាម្ចាស់ជាព្រះតែមួយព្រះអង្គ ប្រើពាក្យ "បុគ្គល" ឬ "អង្គ" សម្តែងថា ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធជាអង្គខុសប្លែកពីគ្នា ហើយពាក្យ "ទំនាក់ទំនង" សម្តែងថាព្រះអង្គទាំងបីអង្គខុសពីគ្នា ព្រោះតែទំនាក់ទំនងរវាងគ្នា និងគ្នា។

### គោលការណ៍នៃព្រះត្រៃឯក

២៥៣-ព្រះត្រៃឯកមានតែមួយព្រះអង្គ។ យើងមិនប្រកាសថាមានព្រះជាម្ចាស់បីអង្គទេ តែព្រះជាម្ចាស់តែមួយដែលមានព្រះបីអង្គគឺ "ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធរួមសភាពជាមួយគ្នា" (DS ៤២១)។ ព្រះទាំងបីអង្គមិនបែងចែកពីលក្ខណៈជាព្រះជាម្ចាស់រវាងគ្នា និងគ្នាទេ តែព្រះអង្គនីមួយៗជាព្រះជាម្ចាស់ទាំងស្រុង៖ "ព្រះបិតាជាសភាពរបស់ព្រះបុត្រា ព្រះបុត្រាជាសភាពរបស់ព្រះបិតា ហើយព្រះបិតា និងព្រះបុត្រាជាសភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះជាម្ចាស់តែមួយព្រះអង្គ" (DS ៥៣០)។ ព្រះអង្គនីមួយៗមានសារធាតុសភាវៈ ឬសភាពរបស់ព្រះជាម្ចាស់" (DS ៨០៤)។

២៥៤-ព្រះអង្គនីមួយៗខុសប្លែកពីគ្នាទៅវិញទៅមកយ៉ាងពិតប្រាកដ។ "ព្រះជាម្ចាស់មានតែមួយ ប៉ុន្តែព្រះអង្គមិនមែនតែម្នាក់ឯងទេ" (DS ៧១)។ "ព្រះបិតា" "ព្រះបុត្រា" "ព្រះវិញ្ញាណដ៏វិសុទ្ធ" មិនគ្រាន់តែជានាមសម្តែងលក្ខណៈផ្សេងៗពីព្រះជាម្ចាស់ទេ ដ្បិតព្រះអង្គនីមួយៗខុសប្លែកពីគ្នាយ៉ាងពិតប្រាកដ៖ "ព្រះអង្គដែលជាព្រះបុត្រាមិនមែនជាព្រះបិតា ព្រះអង្គដែលជាព្រះបិតាមិនមែនជាព្រះបុត្រា ហើយព្រះវិញ្ញាណដ៏វិសុទ្ធមិនមែនជាព្រះបិតា ឬព្រះបុត្រាឡើយ" (DS ៥៣០)។ ព្រះអង្គខុសប្លែកពីគ្នាមកពីទំនាក់ទំនងដើមដំបូងរវាងគ្នា និងគ្នា៖ "ព្រះបិតាផ្តល់ព្រះជន្ម ព្រះបុត្រាទទួលព្រះជន្ម ហើយព្រះវិញ្ញាណដ៏វិសុទ្ធហូរចេញ" (DS ៨០៤)។ ឯកភាពនៃព្រះជាម្ចាស់មានបីដង។

២៥៥-ព្រះអង្គនីមួយៗពឹងផ្អែកលើគ្នាទៅវិញទៅមក។ ភាពខុសគ្នាយ៉ាងពិតប្រាកដរវាងព្រះអង្គនីមួយៗស្ថិតតែនៅក្នុងទំនាក់ទំនងដែលមានរវាងព្រះអង្គនីមួយៗ ហើយមិនបំបែកព្រះជាម្ចាស់ឡើយ៖ "ព្រះនាមព្រះបិតាយោងតាមព្រះបុត្រា ព្រះនាមព្រះបុត្រាយោងតាមព្រះបិតា ហើយព្រះវិញ្ញាណដ៏វិសុទ្ធយោងតាមព្រះអង្គទាំងពីរនោះ។ ទោះបីយើងនិយាយអំពីទំនាក់ទំនងរវាងព្រះទាំងបីអង្គយ៉ាងណាក៏ដោយ ក៏យើងជឿថាមានសភាព ឬសារធាតុតែមួយដែរ" (DS ៥២៨)។ "នៅក្នុងអង្គព្រះអង្គនីមួយៗមានសភាពតែមួយ លើកលែងតែនៅពេលទំនាក់ទំនងរវាងព្រះអង្គនីមួយៗផ្សេងៗពីគ្នា" (DS ១៣៣០)។ "ដោយសារឯកភាពនោះ ព្រះបិតាស្ថិតទាំងស្រុងក្នុងព្រះបុត្រា និងស្ថិតទាំងស្រុងក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដែរ ព្រះបុត្រាស្ថិតទាំងស្រុងក្នុងព្រះបិតា និងស្ថិតទាំងស្រុងក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដែរ ហើយព្រះវិញ្ញាណដ៏វិសុទ្ធស្ថិតទាំងស្រុងក្នុងព្រះបិតា ទាំងស្រុងក្នុងព្រះបុត្រាផងដែរ" (DS ១៣៣១)។

២៥៦-សន្ត: គ្រេគ័រ នៃណាស៊ីអង់ ដែលគេហៅថា "ទេវវិទូ" ដែរប្រគល់សេចក្ដីសង្ខេបនៃជំនឿអំពីព្រះត្រៃឯក ឲ្យអ្នកស្វែងយល់ នៅទៅក្រុងកុងស្តង់ទីណូប៖

> មុនអ្វីៗទាំងអស់ សូមអ្នករាល់គ្នាជួយថែរក្សាបញ្ញត្តិដ៏ល្អប្រសើរនេះ។ ខ្ញុំរស់តស៊ូ និងចង់ស្លាប់ចំពោះបញ្ញត្តិនេះ ដែលធ្វើឲ្យខ្ញុំរងទុក្ខលំបាកទាំងអស់ និងប្រមាថមើលងាយភាពសប្បាយភ្លើតភ្លើនសព្វគ្រប់៖ ខ្ញុំចង់និយាយអំពីធម៌ប្រកាសជំនឿលើព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ខ្ញុំប្រគល់ធម៌ប្រកាសនេះឲ្យអ្នករាល់គ្នានៅថ្ងៃនេះ។ ដោយសារធម៌ប្រកាសជំនឿនេះ បន្តិចទៀតនេះ ខ្ញុំនឹងជ្រមុជអ្នករាល់គ្នាក្នុងទឹក ហើយលើកអ្នករាល់គ្នាចេញមកវិញ។ ខ្ញុំសូមជូនធម៌ប្រកាសនេះទៅអ្នករាល់គ្នា ធ្វើជាមិត្តសម្លាញ់ និងគំរូពេញមួយជីវិតរបស់អ្នករាល់គ្នា។ ខ្ញុំសូមជូនព្រះមួយព្រះអង្គប្រកបដោយតេជានុភាព ដែលមានព្រះជន្មគង់នៅតែមួយក្នុងអង្គទាំងបី ហើយដែលមានទាំងបីអង្គខុសប្លែកពីគ្នា គឺជាព្រះដោយគ្មានសារធាតុ ឬសភាវៈខុសប្លែកពីគ្នា (...) ជាព្រះជាម្ចាស់ទាំងស្រុងក្នុងព្រះទាំងបីអង្គ (...) ហើយទាំងបីអង្គរួមគ្នាជាព្រះជាម្ចាស់ (...)។ ខ្ញុំមិនទាន់បានចាប់ផ្ដើមគិតទៅដល់ឯកភាព បានជាព្រះត្រៃឯកជ្រមុជខ្លួនខ្ញុំក្នុងសោភណភាពត្រចះត្រចង់របស់ព្រះអង្គ។ ខ្ញុំមិនទាន់បានចាប់ផ្ដើមគិតដល់ព្រះត្រៃឯក បានជាឯកភាពឱបក្រសោបខ្លួនខ្ញុំរួចស្រេចទៅហើយដែរ។

## ៤-ព្រះរាជកិច្ចនិងបេសកកម្មរបស់ព្រះត្រៃឯក

២៥៧-"ឱ! ព្រះត្រៃឯកជាពន្លឺពោរពេញដោយសុភមង្គល ឱ! ព្រះត្រៃឯកជាឯកភាពដ៏សំខាន់បំផុត!" (LH)។ ព្រះជាម្ចាស់ជាសុភមង្គលអស់កល្បជានិច្ច ជីវិតអមតៈ និងពន្លឺដែលមិនចេះឱនថយ។ ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ដោយមានសេរីភាពព្រះជាម្ចាស់សព្វព្រះហឫទ័យប្រទានសិរីរុងរឿងនៃព្រះជន្មពោរពេញដោយសុភមង្គលរបស់ព្រះអង្គ។ នេះគឺជា "គម្រោងការដ៏សប្បុរស" (អភ ១,៩) ដែលព្រះអង្គបានទុកមុនកំណើតពិភពលោកនៅក្នុងព្រះបុត្រាជាទីស្រឡាញ់របស់ព្រះអង្គដោយ "តម្រូវទុកជាមុនឲ្យយើងធ្វើជាបុត្រធីតារបស់ព្រះអង្គ" (អភ ១,៤-៥) គឺ "ឲ្យមានលក្ខណៈដូចព្រះបុត្រារបស់ព្រះអង្គ" (រម ៨,១៥)។ គម្រោងការនេះ "មិនមែនមកពីអំពើដែលយើងបានប្រព្រឹត្តនោះទេ គឺ (...) ស្របតាមព្រះហឫទ័យប្រណីសន្ដោស (...) តាំងពីមុនកាលសម័យទាំងអស់មកម្ល៉េះ" (២ធម ១,៩-១០) ដែលមកពីសេចក្ដីស្រឡាញ់របស់ព្រះត្រៃឯកតែម្ដង។ គម្រោងការលាតត្រដាងនៅក្នុងស្នាព្រះហស្ដនៃកំណើតពិភពលោកនៅក្នុងប្រវត្តិនៃការសង្គ្រោះទាំងអស់ក្រោយពីមនុស្សបានប្រព្រឹត្តអំពើបាប និងនៅក្នុងបេសកកម្មរបស់ព្រះបុត្រា និងព្រះវិញ្ញាណដែលបេសកកម្មរបស់ព្រះសហគមន៍បន្តតទៅទៀត (AG ២-៩)។

២៥៨-ការចាត់ចែងនៃការសង្គ្រោះនេះជាព្រះរាជកិច្ចរបស់ព្រះទាំងបីអង្គ ដ្បិតព្រះត្រៃឯកមានសភាពតែមួយយ៉ាងណា ក៏ព្រះអង្គមានប្រតិបត្តិការតែមួយយ៉ាងនោះដែរ (DS ៤២១)។ "ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធមិនមែនជាគោលបីនៃសត្វលោក ប៉ុន្តែជាគោលតែមួយ" (DS ១៣៣១)។ ប៉ុន្តែព្រះអង្គនីមួយៗធ្វើការក្នុងព្រះរាជកិច្ចតែមួយតាមលក្ខណៈរៀងៗខ្លួន។ ដូច្នេះហើយបានជាព្រះសហគមន៍ប្រកាសតាមសម្ព័ន្ធមេត្រីថ្មីថា "អ្វីៗទាំងអស់មានប្រភពមកពីព្រះជាម្ចាស់ជាព្រះបិតា អ្វីៗទាំងអស់មានសម្រាប់ព្រះអម្ចាស់យេស៊ូគ្រីស្ត ហើយអ្វីៗទាំងអស់ស្ថិតនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ" (DS ៤២១)។ លក្ខណៈរៀងៗខ្លួនរបស់ព្រះអង្គនីមួយៗមកពីបេសកកម្មរបស់ព្រះបុត្រាដែលប្រសូតជាមនុស្ស និងពីព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

២៥៩-ការចាត់ចែងនៃការសង្គ្រោះនេះ ជាព្រះរាជកិច្ចរួមផង និងជាព្រះរាជកិច្ចរបស់ព្រះមួយអង្គៗផង ហើយ

ធ្វើឲ្យមនុស្សស្គាល់លក្ខណៈរបស់ព្រះទាំងបីអង្គ និងសភាពតែមួយរបស់ព្រះអង្គទាំងនោះដែរ។ ដូច្នេះហើយបាន ជាគ្រីស្តបរិស័ទរួបរួមជាមួយព្រះមួយអង្គៗ ដោយមិនបំបែកព្រះអង្គឡើយ។ អ្នកលើកតម្កើងព្រះបិតា លើកតម្កើង ព្រះអង្គ តាមរយៈព្រះគ្រីស្ត និងក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ អ្នកដើរតាមព្រះគ្រីស្ត ដើរតាមព្រះអង្គ ព្រោះព្រះបិតា ទាក់ទាញចិត្តគេ (យហ ៦,៤៤) ដោយសារព្រះវិញ្ញាណជំរុញគេផងដែរ (រម ៨,១៤)។

២៦០-ព្រះជាម្ចាស់បានតម្រូវទីបញ្ចប់បំផុតនៃការចាត់ចែងនៃការសង្គ្រោះ គឺឲ្យសត្វលោកចូលរួមចំណែកក្នុង ឯកភាពល្អឥតខ្ចោះនៃព្រះត្រៃឯកពោរពេញដោយសុភមង្គល (យហ ១៧,២១-២៣)។ ប៉ុន្តែចាប់តាំងពីឥឡូវ នេះទៅព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យទទួលព្រះត្រៃឯកដ៏វិសុទ្ធបំផុត៖ "អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងប្រតិបត្តិ តាមពាក្យខ្ញុំ។ ព្រះបិតាខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយព្រះបិតា និងខ្ញុំក៏នឹងមកតាំងទីលំនៅនៅក្នុងអ្នកនោះដែរ" (យហ ១៤,២៣)។

ឱ! ព្រះជាម្ចាស់អើយ! ព្រះត្រៃឯកដែលខ្ញុំគោរពក្រាបថ្វាយបង្គំ! សូមព្រះអង្គជួយឲ្យខ្ញុំម្ចាស់បំភ្លេចខ្លួនខ្ញុំម្ចាស់ ផ្ទាល់ទាំងស្រុងទៅ ដើម្បីឲ្យខ្ញុំម្ចាស់បានតាំងនៅស្ងៀមយ៉ាងស្ងប់ស្ងាត់ជាមួយព្រះអង្គ ហាក់ដូចជាព្រលឹងរបស់ខ្ញុំ ម្ចាស់បានទៅដល់ស្ថានបរមសុខរួចហើយ។ ឱព្រះអង្គដែលមិនប្រែប្រួលអើយ! សូមកុំឲ្យគ្មានអ្វីមួយរំខានសេចក្តី សុខសាន្តរបស់ខ្ញុំម្ចាស់ និងធ្វើឲ្យខ្ញុំម្ចាស់ឃ្លាតឆ្ងាយពីព្រះអង្គឡើយ ប៉ុន្តែ សូមឲ្យគ្រប់នាទីទាំងអស់នាំឲ្យខ្ញុំម្ចាស់ចូល ក្នុងអាថ៌កំបាំងដ៏អស្ចារ្យរបស់ព្រះអង្គយ៉ាងជ្រាលជ្រៅ! សូមប្រោសប្រទានឲ្យព្រលឹងខ្ញុំម្ចាស់បានសេចក្តីស្ងប់ផង។ សូមព្រះអង្គទុកឲ្យព្រលឹងខ្ញុំម្ចាស់ទៅជាស្ថានបរមសុខ ជាព្រះដំណាក់ដ៏ជាទីស្រឡាញ់ និងជាទីកន្លែងសម្រាករបស់ ព្រះអង្គផង។ សូមកុំឲ្យខ្ញុំម្ចាស់មិនដែលបោះបង់ព្រះអង្គចោលទេ ប៉ុន្តែសូមឲ្យខ្ញុំម្ចាស់បាននៅទីនោះទាំងស្រុង ដោយ មានជំនឿមាំមួន ដោយក្រាបថ្វាយបង្គំព្រះអង្គ និងដោយថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គ ដែលកំពុងបង្កើតខ្ញុំម្ចាស់ (សន្តី អេលីសាបិត នៃព្រះត្រៃឯក)។

## សង្ខេប

២៦១-អាថ៌កំបាំងនៃព្រះត្រៃឯកជាអាថ៌កំបាំងដ៏សំខាន់ៗនៃជំនឿ និងការរស់នៅជាគ្រីស្តបរិស័ទ។ មានតែ ព្រះជាម្ចាស់ទេ ដែលអាចនាំឲ្យយើងស្គាល់ ដោយសម្តែងព្រះអង្គជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

២៦២-ព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្សសម្តែងឲ្យយើងដឹងថា ព្រះជាម្ចាស់ជាព្រះបិតាអស់កល្បជានិច្ច ហើយព្រះបុត្រារួមសភាពជាមួយព្រះបិតា ពោលគឺព្រះបុត្រារួមជាមួយព្រះបិតា និងនៅក្នុងអង្គព្រះអង្គ ជាព្រះជាម្ចាស់ ដដែលតែមួយព្រះអង្គគត់។

២៦៣-បេសកកម្មរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះបិតាបានចាត់ឲ្យយាងមកក្នុងព្រះនាមនៃព្រះបុត្រា (យហ ១៤,២៦) ហើយដែលព្រះបុត្រាបានចាត់ "ពីព្រះបិតា" (យហ ១៤,២៦) សម្តែងថា ព្រះវិញ្ញាណរួមជាមួយព្រះបិតា និងព្រះបុត្រា ជាព្រះជាម្ចាស់តែមួយព្រះអង្គគត់។ "ព្រះវិញ្ញាណទទួលការក្រាបថ្វាយបង្គំ និងសិរីរុងរឿងស្មើនឹង ព្រះបិតា និងព្រះបុត្រា"។

២៦៤-ព្រះវិញ្ញាដ៏វិសុទ្ធហូរចេញមកពីព្រះបិតា ដែលជាប្រភពដើម ដោយសារព្រះបិតាប្រទានព្រះវិញ្ញាណឲ្យ ព្រះបុត្រាតាំងពីដើមរៀងមក ហើយជាដរាបតរៀងទៅ ព្រះវិញ្ញាណក៏ហូរចេញមកពីព្រះបិតា និងព្រះបុត្រាដែល រួមជាមួយគ្នាជាធ្លុងតែមួយ" (សន្តៈ អូគូស្តាំង)។

២៦៥-ដោយសារពិធីជ្រមុជទឹក "ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" ព្រះជាម្ចាស់ត្រាស់

ហៅយើងឲ្យរួមរស់ជាមួយព្រះត្រៃឯកពោរពេញទៅដោយសុភមង្គល នៅលើផែនដីនេះក្នុងភាពងងឹតនៃជំនឿ និងក្នុងពន្លឺអស់កល្បជានិច្ច ក្រោយពេលស្លាប់ (SPF ៩)។

២៦៦-"ជំនឿកាតូលិកមានដូចតទៅ៖ គឺគោរពក្រាបថ្វាយបង្គំព្រះជាម្ចាស់តែមួយក្នុងអង្គព្រះត្រៃឯក ហើយព្រះត្រៃឯកក្នុងឯកភាព ដោយមិនភ័ន្តច្រឡំអង្គនីមួយៗ ដោយមិនបែងចែកសារធាតុឡើយ ដ្បិតព្រះបិតាខុសប្លែកពីព្រះបុត្រា និងព្រះវិញ្ញាណ ព្រះបុត្រាខុសប្លែកពីព្រះបិតា និងព្រះវិញ្ញាណ ព្រះវិញ្ញាណដ៏វិសុទ្ធខុសប្លែកពីព្រះបិតា និងព្រះបុត្រា ប៉ុន្តែព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះជាម្ចាស់តែមួយ ដែលមានសិរីរុងរឿងស្មើគ្នាពោរពេញទៅដោយភាពថ្កុំថ្កើងអស់កល្បជានិច្ច" (Quicumque)។

២៦៧-ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធមិនអាចបែងចែកផ្ដាច់ពីគ្នាបានឡើយ។ ប៉ុន្តែ ក្នុងការប្រតិបត្តិតែមួយរបស់ព្រះជាម្ចាស់ ព្រះអង្គនីមួយៗសម្ដែងលក្ខណៈផ្ទាល់នៅក្នុងអង្គព្រះត្រៃឯក ជាពិសេសក្នុងបេសកកម្មរបស់ព្រះបុត្រាប្រសូតជាមនុស្ស និងក្នុងការប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ។

## កថាខណ្ឌទី៣៖ ព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ

២៦៨-ក្នុងចំណោមលក្ខណៈទាំងប៉ុន្មានរបស់ព្រះជាម្ចាស់មានតែឫទ្ធានុភាពរបស់ព្រះអង្គដែលមានថ្លែងក្នុងធម៌ប្រកាសជំនឿ។ យើងជឿថា ឫទ្ធានុភាពសព្វប្រការរបស់ព្រះជាម្ចាស់ស្ថិតនៅក្នុងសកលលោកទាំងមូល គឺព្រះជាម្ចាស់ដែលបានបង្កើតអ្វីៗទាំងអស់ (កណ ១,១; យហ ១,៣) គ្រប់គ្រងលើអ្វីៗទាំងអស់ និងអាចធ្វើអ្វីៗទាំងអស់ផងដែរ។ ឫទ្ធានុភាពសព្វប្រការរបស់ព្រះអង្គប្រកបដោយសេចក្ដីស្រឡាញ់ ព្រោះព្រះជាម្ចាស់ជាព្រះបិតារបស់យើង (មថ ៦,៩) ហើយឫទ្ធានុភាពសព្វប្រការរបស់ព្រះអង្គជាអាថ៌កំបាំង ដ្បិតមានតែជំនឿទេ ដែលអាចយល់ឃើញឫទ្ធានុភាពសព្វប្រការនេះបាននៅពេលដែល "ឫទ្ធានុភាពសព្វរបស់ព្រះជាម្ចាស់លេចចេញមកយ៉ាងខ្លាំងបំផុតក្នុងមនុស្សទន់ខ្សោយ" (២ករ ១២,៩) (១ករ ១,១៨)។

### "ព្រះអង្គធ្វើអ្វីក៏បានតាមតែព្រះហឫទ័យរបស់ព្រះអង្គ" (ទន ១១៥,៣)

២៦៩-ព្រះគម្ពីរដ៏វិសុទ្ធប្រកាសជាច្រើនលើកច្រើនសាថា ព្រះជាម្ចាស់មានឫទ្ធានុភាពសព្វប្រការក្នុងសកលលោកទាំងមូល។ ព្រះគម្ពីរហៅព្រះជាម្ចាស់ជា "ព្រះរបស់លោកយ៉ាកុប" (កណ ៤៩,២៤; អស ១,២៤) "ដ៏ខ្លាំងពូកែជានិច្ច" "គ្មាននរណាអាចយកជ័យជម្នះបាន" ជា "ព្រះមហាក្សត្រប្រកបដោយសិរីរុងរឿង" "ប្រកបដោយព្រះចេស្ដាបារមី" "ជាអ្នកចំបាំងដ៏ជំនាញ" (ទន ២៤,៨-១០)។ ដោយសារព្រះជាម្ចាស់ជាព្រះបង្កើត ព្រះជាម្ចាស់មានឫទ្ធានុភាពសព្វប្រការ "នៅលើផ្ទៃមេឃ និងនៅលើផែនដី" (ទន ១៣៥៦)។ គ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតទេ (យរ ៣២,១៧; លក ១,៣៧) ហើយទ្រង់ក៏ប្រគល់ស្នាព្រះហស្តរបស់ព្រះអង្គឲ្យនរណាក៏បានស្រេចតែតាមព្រះហឫទ័យព្រះអង្គ (យរ ២៧,៥)។ ព្រះអង្គជាព្រះអម្ចាស់នៃសកលលោកទាំងមូល ដែលធ្វើតែតាមព្រះហឫទ័យរបស់ព្រះអង្គជានិច្ច។ ព្រះអង្គជាម្ចាស់នៃប្រវត្តិសាស្ត្រគ្រប់គ្រងលើចិត្តគំនិត និងកាលៈទេសៈនានាតាមព្រះហឫទ័យព្រះអង្គ (អធ ៤,១៧ខ; សភ ២១,១)៖ "ព្រះអង្គអាចប្រើព្រះចេស្ដាដ៏ឧត្តុងឧត្តមរបស់ព្រះអង្គនៅពេលណាក៏បាន។ គ្មាននរណាអាចតទល់នឹងព្រះបារមីដ៏ខ្លាំងក្លារបស់ព្រះអង្គបានទេ" (ប្រាញ ១១,២៣)។

"ព្រះជាម្ចាស់អាណិតអាសូរមនុស្សទាំងអស់ ព្រោះព្រះអង្គមានឫទ្ធានុភាពអាចសម្រេចកិច្ចការទាំងអស់" (ប្រាញ ១១,២៣)

២៧០-ព្រះជាម្ចាស់ជាព្រះបិតាប្រកបដោយឫទ្ធានុភាពសព្វប្រការ។ លក្ខណៈទាំងពីររបស់ព្រះជាម្ចាស់នោះបំភ្លឺគ្នាទៅវិញទៅមក។ ព្រះជាម្ចាស់សម្ដែងថា ជាព្រះបិតាប្រកបដោយឫទ្ធានុភាពដោយយកចិត្តទុកដាក់នឹងអ្វីៗដែលយើងត្រូវការ (មថ ៦,៣២) ដោយប្រោសយើងឲ្យទៅជាបុត្រធីតារបស់ព្រះអង្គ ("យើងនឹងធ្វើជាឪពុករបស់អ្នករាល់គ្នា ហើយអ្នករាល់គ្នាក៏ធ្វើជាកូនប្រុសកូនស្រីរបស់យើងដែរ។ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏មានព្រះចេស្ដាលើសអ្វីៗទាំងអស់" (២ករ ៦,១៨) ហើយដោយធម៌មេត្តាករុណាឥតព្រំដែនរបស់ព្រះអង្គ ដ្បិតព្រះអង្គសម្ដែងនូវឫទ្ធានុភាពដ៏ខ្លាំងក្លាជាទីបំផុត នៅពេលព្រះអង្គស្ម័គ្រចិត្តលើកលែងទោសឲ្យរួចពីបាប។

២៧១-ព្រះជាម្ចាស់ប្រើឫទ្ធានុភាពសព្វប្រការរបស់ព្រះអង្គដោយគ្មានចិត្តលម្អៀងទេ៖ "នៅក្នុងអង្គព្រះអង្គឫទ្ធានុភាព និងសភាវៈព្រះហឫទ័យ និងប្រាជ្ញាឆ្លាតឈ្លាសវៃព្រះប្រាជ្ញាញាណ និងយុត្តិធម៌រួមជាមួយគ្នាក្នុងធ្លុងតែមួយ ទើបគ្មានអ្វីដែលស្ថិតក្នុងឫទ្ធានុភាពរបស់ព្រះអង្គដែលមិនស្ថិតក្នុងព្រះហឫទ័យដ៏សុចរិតរបស់ព្រះអង្គ ឬប្រាជ្ញាឆ្លាតឈ្លាសវៃប្រកបដោយព្រះប្រាជ្ញាញាណរបស់ព្រះអង្គ" (សន្តៈ ថូម៉ាសនៃអាកាំង)។

## ព្រះជាម្ចាស់ហាក់ដូចជាគ្មានឫទ្ធានុភាពសោះ

២៧២-ពេលយើងដកពិសោធន៍អំពីអំពើអាក្រក់ និងទុក្ខលំបាកពិបាកជឿថាព្រះជាម្ចាស់មានឫទ្ធានុភាពសព្វប្រការ។ ជួនកាលព្រះជាម្ចាស់ហាក់ដូចជានៅឆ្ងាយមិនអាចឃាត់អំពើអាក្រក់ឲ្យកើតឡើងបានទេ។ ប៉ុន្តែ ព្រះជាម្ចាស់បានសម្ដែងឫទ្ធានុភាពសព្វប្រការរបស់ព្រះអង្គ នៅពេលព្រះបុត្រារបស់ព្រះអង្គបានបន្ទាបខ្លួនមានព្រះជន្ម មានជីវិតថ្មី និងបានឈ្នះអំពើអាក្រក់។ ហេតុនេះព្រះគ្រីស្ដដែលត្រូវគេឆ្កាងជា "ឫទ្ធានុភាព និងព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។ អ្វីៗដែលមនុស្សលោកយល់ថាជាគំនិតលេលារបស់ព្រះជាម្ចាស់នោះ ប្រសើរលើសប្រាជ្ញារបស់មនុស្សទៅទៀត ហើយអ្វីៗដែលមនុស្សលោកយល់ថាជាការទន់ខ្សោយរបស់ព្រះជាម្ចាស់ ក៏ប្រសើរលើសកម្លាំងរបស់មនុស្សដែរ" (១ករ ១,២៤-២៥)។ ពេលព្រះជាម្ចាស់ប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញ និងឲ្យគង់នៅខាងស្ដាំព្រះអង្គនៅស្ថានបរមសុខដែលខ្ពស់ជាងអ្វីៗគ្រប់យ៉ាង ព្រះបិតាក៏ "សម្ដែងមហិទ្ធិឫទ្ធិនៃព្រះចេស្ដាដ៏ខ្លាំងក្លារបស់ព្រះអង្គ" "ជាប្រយោជន៍ដល់យើងជាអ្នកជឿ" (អភ ១,១៩-២២)។

២៧៣-មានតែអ្នកជឿប៉ុណ្ណោះ ដែលអាចយល់អំពីអាថ៌កំបាំងនៃឫទ្ធានុភាពសព្វប្រការរបស់ព្រះជាម្ចាស់។ អ្នកជឿសរសើរភាពទន់ខ្សោយរបស់ខ្លួនឯង ដើម្បីឲ្យឫទ្ធានុភាពរបស់ព្រះគ្រីស្ដគង់សណ្ឋិតលើពួកគេ (២ករ ១២,៩; ភីល ៤,១៣)។ ព្រះនាងព្រហ្មចារិនីម៉ារីជាគំរូដ៏ល្អប្រសើរ ដ្បិតព្រះនាងបានជឿថា "គ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតឡើយ" (លក ១,៣៧) ហើយព្រះនាងបានលើកតម្កើងសរសើរព្រះអម្ចាស់ថា៖ "ព្រះដ៏មានឫទ្ធានុភាពបានសម្ដែងការប្រសើរអស្ចារ្យចំពោះរូបខ្ញុំ ព្រះនាមព្រះអង្គពិតជាវិសុទ្ធមែន!" (លក ១,៤៩)។

២៧៤-"ដូច្នេះហើយបានជាគ្មានអ្វីប្រសើរជាងការជឿជាក់ដែលបានឆ្លាក់យ៉ាងជ្រាលជ្រៅនៅក្នុងចិត្តគំនិតយើងថា "គ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតឡើយ" ដើម្បីពង្រឹងជំនឿ និងសេចក្ដីសង្ឃឹមរបស់យើងទេ ដ្បិតអ្វីៗទាំងអស់ដែលធម៌ប្រកាសជំនឿនឹងសុំឲ្យយើងជឿ ដូចជាការអស្ចារ្យទាំងប៉ុន្មាន ទោះជាធំយ៉ាងណាក្ដី មិនអាចយល់បានក្ដី លើសពីច្បាប់ធម្មជាតិក្ដី ក៏ប្រាជ្ញាយើងនឹងងាយសុខចិត្តទទួលដោយមិនរួញរាឡើយ ឲ្យតែប្រាជ្ញានេះរិះគិតបន្តិចបន្តួចអំពីឫទ្ធានុភាពសព្វប្រការរបស់ព្រះជាម្ចាស់" (CR)។

## សង្ខេប

២៧៥-រួមជាមួយលោកយ៉ូប យើងប្រកាសថា៖ "ទូលបង្គំទទួលស្គាល់ថា ព្រះអង្គអាចធ្វើគ្រប់កិច្ចការទាំងអស់បាន ហើយគ្មានការអ្វីមួយ ដែលធ្វើឲ្យព្រះអង្គទាល់ព្រះតម្រិះឡើយ" (យប ៤២,២)។

២៧៦-ដោយស្មោះនឹងសក្ខីភាពនៃព្រះគម្ពីរ ព្រះសហគមន៍ឧស្សាហ៍អធិដ្ឋានទៅ "ព្រះប្រកបដោយឫទ្ធានុភាពសព្វប្រការ និងអស់កល្បជានិច្ច" ("omnipotens sempiterne Deus...") ដោយជឿជាក់ថា "គ្មានកិច្ចការណាដែលព្រះជាម្ចាស់ធ្វើមិនកើតទេ" (កណ ១៨,១៤; លក ១,៣៧; មថ ១៩,២៦)។

២៧៧-ព្រះជាម្ចាស់សម្តែងឫទ្ធានុភាពសព្វប្រការរបស់ព្រះអង្គ ដោយប្រោសយើងឲ្យកែប្រែចិត្តគំនិត និងដោយប្រោសប្រណីយើងឲ្យរួមមេត្រីភាពជាមួយព្រះអង្គឡើងវិញ៖ "ព្រះអង្គសម្តែងឫទ្ធានុភាពដ៏ខ្លាំងខ្លារបស់ព្រះអង្គដោយអត់ធ្មត់ខន្តីចំពោះអ្នកបាប និងអាណិតអាសូរគេជានិច្ច..." (MR ពាក្យអធិដ្ឋានចូលថ្ងៃអាទិត្យទី២៦)។

២៧៨-បើយើងមិនជឿថា សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការ តើយើងអាចជឿថា ព្រះបិតាបានបង្កើតយើង ព្រះបុត្រាបានសង្គ្រោះយើង ហើយព្រះវិញ្ញាណដ៏វិសុទ្ធបានប្រោសយើងឲ្យបានវិសុទ្ធយ៉ាងដូចម្តេចកើត?

## កថាខណ្ឌទី៤៖ ព្រះបង្កើត

២៧៩-"កាលពីដើមដំបូងបង្អស់ព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី" (កណ ១,១)។ ព្រះគម្ពីរដ៏វិសុទ្ធចាប់ផ្តើមជាមួយសេចក្តីយ៉ាងឧឡារិកនោះ។ ធម៌ប្រកាសជំនឿទទួលយកសេចក្តីនោះដែរ ដោយប្រកាសថា ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ជា "ព្រះបង្កើតផ្ទៃមេឃ និងផែនដី" "ទាំងអ្វីៗដែលមើលឃើញ និងមើលមិនឃើញ"។ ជាដំបូងយើងនឹងនិយាយអំពីព្រះបង្កើត បន្ទាប់មកអំពីការបង្កើតទីបញ្ចប់ពីអំពើបាបដែលព្រះយេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់បានស្រោចស្រង់យើង។

២៨០-ការបង្កើតជាមូលដ្ឋានគ្រឹះរបស់ "គម្រោងការទាំងអស់ក្នុងការសង្គ្រោះរបស់ព្រះជាម្ចាស់" ជា "ការចាប់ផ្តើមនៃប្រវត្តិសាស្ត្រនៃការសង្គ្រោះ" (DCG ៥១) ដែលព្រះយេស៊ូគ្រីស្តជាកំពូល។ ផ្ទុយទៅវិញ គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្តបំភ្លឺជាស្ថាពរ គម្រោងការដ៏អស្ចារ្យនៃការបង្កើត ហើយសម្តែងទីចុងក្រោយដែលព្រះជាម្ចាស់បានរៀបចំទុកជាមុននៅពេល "កាលពីដើមដំបូងបង្អស់ព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី" (កណ ១,១) គឺកាលពីដើមដំបូងបង្អស់ព្រះជាម្ចាស់តម្រូវទុកជាមុននូវសិរីរុងរឿងនៃការបង្កើតថ្មីក្នុងអង្គព្រះគ្រីស្ត (រម ៨,១៨-២៣)។

២៨១-ហេតុដូច្នេះហើយបានជាអត្ថបទនៃរាត្រីបុណ្យចម្លង ដែលប្រារព្ធព្រះគ្រីស្តដែលបង្កើតអ្វីៗទាំងអស់សាជាថ្មី ចាប់ផ្តើមដោយអានកំណើតពិភពលោក។ ក្នុងពិធីបុណ្យខាងបូព៌ាប្រទេស អត្ថបទនេះជាអត្ថបទទីមួយនៃដើមបុណ្យធំៗរបស់ព្រះអម្ចាស់។ តាមសក្ខីភាពរបស់ចាស់ៗ គេបង្រៀនអ្នកស្វែងយល់ ដើម្បីពិធីបុណ្យជ្រមុជទឹកតាមផ្លូវដដែល (អេថេរី; សន្តៈ អូគូស្តាំង)

### ១-ការអប់រំជំនឿអំពីការបង្កើត

២៨២-ការអប់រំជំនឿអំពីការបង្កើតមានសារៈសំខាន់ណាស់ជាមូលដ្ឋានគ្រឹះនៃជីវិតរបស់មនុស្ស និងរបស់គ្រីស្តបរិស័ទ ដ្បិតជាចម្លើយនៃគ្រីស្តសាសនាអំពីសំណួរសំខាន់ៗដែលមនុស្សគ្រប់សម័យកាលបានចោទសួរខ្លួនឯងថា៖

"តើមនុស្សយើងមកពីណា? តើមនុស្សយើងទៅណា? តើជីវិតមនុស្សមានប្រភពមកពីណា? តើជីវិតមនុស្សមានគោលដៅអ្វីខ្លះ? តើអ្វីៗទាំងអស់ដែលមាននៅក្នុងសកលលោកទាំងមូលបានមកពីណា និងទៅឯណា?"។ សំណួរទាំងពីរនោះដែលទាក់ទងនឹងប្រភព និងទីបញ្ចប់នៃជីវិតមិនអាចបំបែកគ្នាបានឡើយ។ សំណួរទាំងពីរនោះមានសារៈសំខាន់ណាស់ចំពោះអត្ថន័យ និងគោលដៅនៃជីវិត ហើយដើម្បីបំពេញកិច្ចការរបស់យើងផងដែរ។

២៨៣-អ្នកខាងវិទ្យាសាស្រ្តបានស្រាវជ្រាវយ៉ាងច្រើនអំពីសំណួរចង់ដឹងអំពីកំណើតពិភពលោក និងមនុស្សដែលនាំឲ្យយើងដឹងអំពីអាយុកាល និងទំហំនៃសកលលោក ការប្រែប្រួលនៃរូបដែលមានជីវិត និងការកើតមកជាមនុស្ស។ ការរកឃើញនេះ នាំឲ្យយើងកាន់តែស្ងើចសរសើរព្រះជាម្ចាស់ជាព្រះបង្កើតដ៏ថ្កុំថ្កើង និងអរព្រះគុណព្រះអង្គចំពោះស្នាព្រះហស្ដរបស់ព្រះអង្គ ហើយចំពោះប្រាជ្ញា និងប្រាជ្ញាញាណដែលព្រះអង្គប្រទានដល់អ្នកប្រាជ្ញ និងអ្នកស្រាវជ្រាវ។ ពួកគេអាចនិយាយជាមួយព្រះបាទសាឡូម៉ូនថា៖ "ព្រះអង្គប្រោសប្រទានឲ្យខ្ញុំស្គាល់ច្បាស់នូវអ្វីៗដែលមានក្នុងលោកនេះ គឺឲ្យខ្ញុំស្គាល់រចនាសម្ព័ន្ធនៃពិភពលោក និងសកម្មភាពរបស់ធាតុទាំងប្រាំ (...) ដ្បិតព្រះប្រាជ្ញាញាណដែលបានបង្កើតអ្វីៗទាំងអស់បានបង្រៀនខ្ញុំ" (ប្រាញ ៧,១៧-២១)។

២៨៤-ការស្រាវជ្រាវនេះមានផលប្រយោជន៍ដ៏សំខាន់ ដោយមានសំណួរមួយបែបផ្សេងទៀត ដែលមានលក្ខណៈហួសវិស័យវិទ្យាសាស្រ្តខាងធម្មជាតិ គឺគេមិនត្រឹមតែចង់ដឹងថា តើសកលលោកបានលេចចេញជារូបរាងនៅពេលណា ឬយ៉ាងដូចម្ដេច ឬតើមនុស្សមានកំណើតនៅពេលណាតែប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវតែរកឃើញអំពីអត្ថន័យនៃដើមកំណើតនេះ៖ តើកំណើតនេះ កើតឡើងដោយភាពចៃដន្យ ឬដោយសារព្រហ្មលិខិតងងឹតងងល់ ឬដោយសារតម្រូវការអនាមិក ឬក៏ដោយអ្នកដ៏ខ្ពង់ខ្ពស់បំផុត ប្រកបដោយប្រាជ្ញាវៀងវៃ និងសប្បុរសធម៌ ដែលគេហៅថាព្រះជាម្ចាស់។ ប៉ុន្តែ ប្រសិនបើពិភពលោកមកពីព្រះប្រាជ្ញាញាណ និងសប្បុរសធម៌របស់ព្រះជាម្ចាស់មែន ហេតុអ្វីបានជាមានអំពើអាក្រក់? តើអំពើអាក្រក់មកពីណា? តើនរណាជាអ្នកទទួលខុសត្រូវលើអំពើអាក្រក់នេះ? ហើយតើយើងអាចរួចផុតពីអំពើអាក្រក់នេះបានឬទេ?

២៨៥-តាំងពីដើម គ្រីស្ដសាសនាបានជួបប្រទះនឹងចម្លើយប្លែកៗពីគ្នាទាក់ទងនឹងសំណួរអំពីកំណើតដំបូងនេះ។ ហេតុនេះ ក្នុងសាសនា និងវប្បធម៌បុរាណ រឿងប្រឌិតជាច្រើនទាក់ទងនឹងដើមកំណើតដំបូង។ ទស្សនវិទូខ្លះបានពោលថា អ្វីៗទាំងអស់ជាព្រះជាម្ចាស់ ពិភពលោកជាព្រះជាម្ចាស់ ឬការប្រែក្លាយនៃពិភពលោកជាការប្រែក្លាយនៃព្រះជាម្ចាស់ដែរ (**pantheism**)។ ទស្សនវិទូខ្លះទៀតបានពោលថា ពិភពលោកជាការហូរចេញជាចំបាច់របស់ព្រះជាម្ចាស់ ដែលចេញមកពីប្រភពនេះ និងវិលត្រឡប់ទៅឯប្រភពនេះវិញ។ ទស្សនវិទូខ្លះផ្សេងទៀតបានអះអាងថា មានគោលអស់កល្បជានិច្ចពីរ គឺសេចក្តីល្អ និងសេចក្តីអាក្រក់ ពន្លឺ និងភាពងងឹត ដែលប្រគួតប្រជាំងគ្នាជាអាចិន្ត្រៃយ៍ (**dualism, manicheism**)។ បើគិតទៅតាមយោបល់ខ្លះនោះ ពិភពលោក (យ៉ាងហោចណាស់ក៏រូបធាតុ) អាក្រក់ដោយសារភាពអាប់ឱនមួយ ហើយត្រូវបោះបង់ចោល ឬត្រូវរំលងពិភពលោកនេះ (**gnosticism**)។ ទស្សនវិទូខ្លះទៀតយល់ស្របថា ព្រះជាម្ចាស់បានបង្កើតពិភពលោក ប៉ុន្តែ ព្រះជាម្ចាស់បានបង្កើតពិភពលោកដូចជាជាងនាឡិកា គឺបង្កើតរួចហើយលែងចោល (**deism**)។ ទីបញ្ចប់ ទស្សនវិទូខ្លះទៀតមិនទទួលស្គាល់ដើមកំណើតដ៏ខ្ពង់ខ្ពស់បំផុតនៃពិភពលោកទេ ប៉ុន្តែ គេយល់ថា ជាការប្រមូលផ្តុំនៃវត្ថុធាតុដូចៗគ្នា ដែលមានតាំងពីដើមរៀងមក ហើយនៅជាដរាបតរៀងទៅ (**materialism**)។ ការខិតខំទាំងប៉ុន្មាននោះ ផ្តល់សក្ខីភាពថា មនុស្សគ្រប់សម័យកាល និងគ្រប់ទិសទីតែងតែចង់ដឹងចង់ស្គាល់អំពីកំណើតនៃពិភពលោក។ មានតែមនុស្សទេ ដែលស្វែងរកអំពីសំណួរនេះ។

២៨៦-ប្រាជ្ញារបស់មនុស្សមានសមត្ថភាពអាចឆ្លើយនឹងសំណួរទាក់ទងនឹងប្រភពនៃជីវិតបាន ព្រោះពន្លឺនៃប្រាជ្ញា មនុស្សអាចស្គាល់ព្រះជាម្ចាស់ជាព្រះបង្កើតយ៉ាងច្បាស់តាមរយៈស្នាព្រះហស្ដរបស់ព្រះអង្គ (DS ៣០២៦) ទោះបី ចំណេះដឹងនេះអាចភ័ន្ដច្រឡំបានដែរ។ ហេតុនេះហើយបានជាជំនឿបញ្ជាក់ និងបំភ្លឺប្រាជ្ញាក្នុងការឈ្វេងយល់ដ៏ត្រឹមត្រូវនៃសេចក្ដីពិតនេះ៖ "ដោយសារជំនឿយើងយល់ថាព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្កើតពិភពលោកមក។ ដូច្នេះអ្វីៗដែលយើងមើលឃើញមិនមែនកើតចេញមកពីអ្វីៗដែលមានរូបរាងនោះឡើយ" (ហប ១១,៣)។

២៨៧-សេចក្ដីពិតអំពីការបង្កើត ដែលសំខាន់បំផុតសម្រាប់ជីវិតមនុស្សលោកបានជាព្រះជាម្ចាស់សព្វព្រះហឫទ័យប្រកបដោយសប្បុរសធម៌សម្ដែងឲ្យប្រជារាស្ដ្ររបស់ព្រះអង្គនូវអ្វីដែលត្រូវស្គាល់អំពីការបង្កើតនេះ ដើម្បីទទួលការសង្គ្រោះ។ លើសពីចំណេះដឹងតាមធម្មជាតិដែលមនុស្សអាចមានអំពីព្រះបង្កើត (កក ១៧,២៤-២៩; រម ១,១៩-២០) ព្រះជាម្ចាស់បានសម្ដែងបន្ដិចម្ដងៗឲ្យជនជាតិអ៊ីស្រាអែលស្គាល់គម្រោងការដ៏អស្ចារ្យនៃការបង្កើត។ ព្រះជាម្ចាស់បានជ្រើសរើសបុព្វបុរសដែលបានធ្វើឲ្យជនជាតិអ៊ីស្រាអែលចាកចេញពីប្រទេសអេស៊ីប ហើយបានជ្រើសរើសបង្កើត និងអប់រំជនជាតិអ៊ីស្រាអែល ព្រះអង្គក៏សម្ដែងព្រះអង្គជាព្រះដែលប្រជាជាតិទាំងឡាយ និងផែនដីទាំងមូលជាកម្មសិទ្ធិ ហើយជាព្រះតែមួយដែល "បានបង្កើតមេឃ និងដី" (ទន ១១៥,១៥; ១២៤,៨; ១៣៤,៣)។

២៨៨-ហេតុនេះហើយបានជាយើងមិនអាចបំបែកសេចក្ដីដែលព្រះជាម្ចាស់សម្ដែងអំពីការបង្កើត ពីសេចក្ដីដែលព្រះអង្គសម្ដែង ពេលទ្រង់ជាព្រះតែមួយចងសម្ពន្ធមេត្រីជាមួយនឹងប្រជាជនរបស់ព្រះអង្គបានឡើយ។ ព្រះជាម្ចាស់សម្ដែងថាការបង្កើតជាជំហ៊ានទីមួយឆ្ពោះទៅសម្ពន្ធមេត្រីនេះ ជាសក្ខីភាពដំបូងបង្អស់ និងសម្រាប់មនុស្សទាំងអស់អំពីសេចក្ដីស្រឡាញ់ដ៏មានឫទ្ធានុភាពសព្វប្រការរបស់ព្រះអង្គ (កណ ១៥,៥; យរ ៣៣,១៩-២៦)។ ហេតុនេះសាររបស់អស់លោកព្យាការី (អស ៤៤,២៤) ពាក្យអធិដ្ឋាននៃទំនុកតម្កើង (ទន ១០៤) ពិធីបុណ្យ និងការពិចារណានៃព្រះប្រាជ្ញាញាណរបស់ប្រជាជនអ៊ីស្រាអែល (សភ ៨,២២-៣១) សម្ដែងយ៉ាងច្បាស់នូវសេចក្ដីពិតនៃការបង្កើត។

២៨៩-ជំពូកទាំងបីដំបូងនៃកំណើតពិភពលោកមានសារៈសំខាន់ណាស់ក្នុងចំណោមសេចក្ដីទាំងអស់ដែលមានក្នុងព្រះគម្ពីរដ៏វិសុទ្ធ។ អត្ថបទនោះអាចមានប្រភពផ្សេងៗខាងអក្សរសាស្ត្រ។ អ្នកនិពន្ធដែលមានព្រះជាម្ចាស់ជួយបំភ្លឺបានដាក់អត្ថបទនោះនៅខាងមុខព្រះគម្ពីរ ទើបអត្ថបទនោះសម្ដែងយ៉ាងឧឡារិកអំពីសេចក្ដីពិត អំពីប្រភព និងទីបញ្ចប់នៃការបង្កើតដែលមានក្នុងព្រះជាម្ចាស់ អំពីសណ្ដាប់ធ្នាប់ និងសប្បុរសធម៌នៃការបង្កើតនេះ អំពីការត្រាស់ហៅរបស់មនុស្ស អំពីអំពើបាប និងសេចក្ដីសង្ឃឹមនៃការសង្គ្រោះ។ ពេលយើងអានអត្ថបទនោះក្រោមពន្លឺរបស់ព្រះគ្រីស្ដនៅក្នុងឯកភាពនៃព្រះគម្ពីរដ៏វិសុទ្ធ និងក្នុងការបញ្ជូនបន្ដដ៏រស់រវើកនៃព្រះសហគមន៍ សេចក្ដីទាំងអស់នោះជាប្រភពដ៏សំខាន់ដើម្បីបង្រៀនអំពីគម្រោងការដើមដំបូង គឺការបង្កើតអំពើបាប និងព្រះបន្ទូលសន្យាអំពីការសង្គ្រោះ។

### ២-ការបង្កើតជាស្នាព្រះហស្ដរបស់ព្រះត្រៃឯក

២៩០-"កាលពីដើមដំបូងបង្អស់ព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី"៖ ព្រះបន្ទូលនេះអះអាងនូវសេចក្ដីបីយ៉ាង គឺព្រះជាម្ចាស់អស់កល្បជានិច្ចបានបង្កើតអ្វីៗទាំងអស់ដែលមានក្រៅពីព្រះអង្គ។ មានតែព្រះជាម្ចាស់ជាព្រះបង្កើត (កិរិយាសព្ទ "បង្កើត" ជាភាសាហេប្រឺបារ៉ា តែងតែមានប្រធានតែមួយ គឺព្រះជាម្ចាស់)។ អ្វីៗទាំងអស់ដែលនៅ (ដែលពាក្យ "មេឃ និងដី" សំដៅ) ពឹងផ្អែកទៅលើព្រះជាម្ចាស់ ដែលប្រទានជីវិត។

២៩១-"កាលពីដើមដំបូងបង្អស់ព្រះបន្ទូលមានព្រះជន្មគង់នៅ (...) ហើយព្រះបន្ទូលជាព្រះជាម្ចាស់ (...) អ្វីៗសព្វសារពើសុទ្ធតែកើតឡើងដោយសារព្រះបន្ទូល គឺក្នុងបណ្ដាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមកក្រៅពីព្រះអង្គ

បង្កើតនោះឡើយ" (យហ ១,១-៣)។ សម្ពន្ធមេត្រីថ្មីសម្ដែងថាព្រះជាម្ចាស់បានបង្កើតអ្វីៗសព្វសារពើដោយសារព្រះបន្ទូលអស់កល្បជានិច្ច គឺព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។ គឺនៅក្នុងអង្គព្រះបុត្រានេះបានជា "ព្រះជាម្ចាស់បានបង្កើតអ្វីៗសព្វសារពើទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី (...) ព្រះជាម្ចាស់បានបង្កើតទាំងអស់មកដោយសារព្រះគ្រីស្ដ និងសម្រាប់ព្រះគ្រីស្ដ។ ព្រះគ្រីស្ដមានព្រះជន្មមុនអ្វីៗទាំងអស់ ហើយអ្វីៗទាំងអស់ក៏នៅស្ថិតស្ថេររួមគ្នា ដោយសារព្រះអង្គដែរ" (កូឡ ១,១៦-១៧)។ ម្យ៉ាងទៀត ព្រះសហគមន៍ជឿថាព្រះវិញ្ញាណដ៏វិសុទ្ធក៏ជាព្រះបង្កើតដែរ ព្រះអង្គ "ប្រទានជីវិត" (ធម៌ប្រកាសជំនឿនៅនិសេ/កុងស្តង់ទីណូប) ជា "ព្រះវិញ្ញាណជាព្រះបង្កើត" និងជា "ប្រភពនៃអំពើល្អគ្រប់យ៉ាង"។

២៩២-ក្បួនជំនឿរបស់ព្រះសហគមន៍អះអាងយ៉ាងច្បាស់ថា ព្រះបុត្រា និងព្រះវិញ្ញាណបង្កើតពិភពលោករួមជាមួយព្រះបិតាដូចសម្ពន្ធមេត្រីចាស់សម្ដែងដោយលាក់លៀម (ទន ៣៣,៦; ១០៤,៣០; កណ ១,២-៣) និងសម្ពន្ធមេត្រីថ្មីលាតត្រដាង៖ "មានព្រះជាម្ចាស់តែមួយព្រះអង្គ (...) ព្រះអង្គជាព្រះបិតា ជាព្រះជាម្ចាស់ ជាព្រះបង្កើតជាព្រះនៃដើមកំណើត ជាព្រះដែលរៀបចំនូវអ្វីៗទាំងអស់។ ព្រះអង្គបានធ្វើអ្វីៗទាំងអស់សព្វសារពើដោយព្រះអង្គផ្ទាល់ គឺដោយព្រះបន្ទូលរបស់ព្រះអង្គ និងព្រះប្រាជ្ញាញាណរបស់ព្រះអង្គ" "ដោយព្រះបុត្រា និងព្រះវិញ្ញាណ" ដែលប្រៀបធៀបដូចជា "ព្រះហស្ដរបស់ព្រះអង្គ" (សន្តៈ អ៊ីរ៉េណេ)។ ការបង្កើតជាស្នាព្រះហស្ដរួមនៃព្រះត្រៃឯក។

### ៣-"ព្រះជាម្ចាស់បានបង្កើតពិភពលោកសម្រាប់សិរីរុងរឿងរបស់ព្រះអង្គ"

២៩៣-ព្រះគម្ពីរ និងការបញ្ជូនបន្តនៅតែប្រៀនប្រដៅ និងលើកតម្កើងសេចក្ដីពិតដ៏សំខាន់នេះ៖ "ព្រះជាម្ចាស់បានបង្កើតពិភពលោកសម្រាប់សិរីរុងរឿងរបស់ព្រះអង្គ" (DS ៣០២៥)។ សន្តៈ ប៊ូណាវង់ទឿ ពន្យល់ថាព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ "មិនមែនដើម្បីបន្ថែមសិរីរុងរឿង ប៉ុន្តែដើម្បីសម្ដែង និងប្រទានសិរីរុងរឿងនេះ" ដ្បិតពេលព្រះជាម្ចាស់បង្កើតព្រះអង្គ គ្មានមូលហេតុផ្សេងក្រៅពីសេចក្ដីស្រឡាញ់ និងសប្បុរសធម៌របស់ព្រះអង្គ៖ "គន្លឹះនៃសេចក្ដីស្រឡាញ់បានបើកព្រះហស្ដរបស់ព្រះអង្គ ដើម្បីផលិតសត្វលោក" (សន្តៈ ថូម៉ាសនៃអាកាំង)។ មហាសន្និបាតវ៉ាទីកង់ទីមួយពន្យល់ថា៖

> ដោយសារសប្បុរសធម៌ និងអំណាចពោរពេញទៅដោយឫទ្ធានុភាពសព្វប្រការ ព្រះជាម្ចាស់តែមួយពិតប្រាកដនេះ បានបង្កើតតាំងពីកំណើតនៃពេលវេលា ដោយមិនប្រើអ្វីសោះ សត្វលោកទាំងពីរនេះ គឺសត្វលោកខាងវិញ្ញាណ និងសត្វលោកខាងរូបកាយ តាមគម្រោងការដ៏សេរី។ ព្រះអង្គបានធ្វើដូច្នោះ មិនមែនដើម្បីពង្រឹងសុភមង្គលរបស់ព្រះអង្គ ឬដើម្បីឲ្យព្រះអង្គបានគ្រប់លក្ខណៈទេ ប៉ុន្តែ ព្រះអង្គមានព្រះហឫទ័យសម្ដែងសប្បុរសធម៌ និងអំណាចពោរពេញទៅដោយឫទ្ធានុភាពសព្វប្រការរបស់ព្រះអង្គនេះ ឲ្យសត្វលោករបស់ព្រះអង្គស្គាល់ (DS ៣០០២)។

២៩៤-ព្រះជាម្ចាស់សព្វព្រះហឫទ័យសម្ដែង និងប្រទានសប្បុរសធម៌របស់ព្រះអង្គឲ្យសត្វលោកដែលព្រះអង្គបានបង្កើតមកជាសិរីរុងរឿងរបស់ព្រះអង្គ។ ព្រះជាម្ចាស់មានគម្រោងការទុកជាមុន "ធ្វើឲ្យយើងទៅជាបុត្រធីតារបស់ព្រះអង្គដោយសារព្រះយេស៊ូគ្រីស្ដ ស្របនឹងព្រះបំណងដ៏សប្បុរសរបស់ព្រះអង្គ ដើម្បីឲ្យយើងលើកតម្កើងសិរីរុងរឿងនៃព្រះហឫទ័យប្រណីសន្ដោសដែលទ្រង់បានប្រោសប្រទានមកយើង" (អភ ១,៥-៦) ដ្បិត "សិរីរុងរឿងរបស់ព្រះជាម្ចាស់ គឺដើម្បីឲ្យមនុស្សមានជីវិតដ៏រស់រវើក ហើយជីវិតរបស់មនុស្ស គឺឲ្យមើលឃើញព្រះអង្គ៖ ដោយសារព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ ព្រះអង្គសម្ដែងព្រះអង្គ ទើបផ្ដល់ជីវិតដល់សត្វលោកទាំងឡាយនៅលើផែនដីយ៉ាងណា លើសពីនេះទៅទៀតដោយសារព្រះបន្ទូលព្រះជាម្ចាស់ក៏សម្ដែងព្រះអង្គ ទើបប្រទានជីវិតដល់

អស់អ្នកដែលមើលឃើញព្រះអង្គយ៉ាងនោះដែរ" (សន្តៈ អ៊ីរ៉េណេ)។ គោលដៅចុងក្រោយរបស់ព្រះជាម្ចាស់ដែលបានបង្កើតអ្វីៗទាំងអស់ គឺឲ្យព្រះអង្គ "ដែលជាព្រះបង្កើតសត្វលោកទាំងអស់" "បានគ្រងរាជ្យលើអ្វីៗទាំងអស់គ្រប់ប្រការទាំងអស់" (១ករ ១៥,២៨) ដោយប្រទានសិរីរុងរឿងរបស់ព្រះអង្គ និងសុភមង្គលរបស់យើង" (AG ២)។

## ៤-គម្រោងការដ៏អស្ចារ្យរបស់ការបង្កើត

### ព្រះជាម្ចាស់បង្កើតប្រកបដោយព្រះប្រាជ្ញាញាណ និងសេចក្ដីស្រឡាញ់

២៩៥-យើងជឿថាព្រះជាម្ចាស់បានបង្កើតពិភពលោកប្រកបដោយព្រះប្រាជ្ញាញាណ (ប្រាញ ៩,៩)។ ពិភពលោកមិនមែនជាផលិតផលនៃតម្រូវការណាមួយព្រហ្មលិខិត ឬចៃដន្យទេ។ យើងជឿថាពិភពលោកមកពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលមានសេរីភាពពេញលេញ និងដែលសព្វព្រះហឫទ័យឲ្យសត្វលោករួមរស់ជាមួយព្រះអង្គ ដោយទទួលព្រះជន្មព្រះប្រាជ្ញាញាណ និងសប្បុរសធម៌របស់ព្រះអង្គ៖ "ព្រះជាម្ចាស់សមនឹងទទួលសិរីរុងរឿងព្រះកិត្តិនាម និងឫទ្ធានុភាព ដ្បិតព្រះអង្គបានបង្កើតរបស់សព្វសារពើមកអ្វីៗទាំងអស់ សុទ្ធតែកើតមានឡើងហើយស្ថិតស្ថេរនៅដោយសារព្រះហឫទ័យរបស់ព្រះអង្គ" (វវ ៤,១១)។ "ឱព្រះអម្ចាស់អើយ! ស្នាព្រះហស្តរបស់ព្រះអង្គមានច្រើនឥតគណនា ព្រះអង្គធ្វើការទាំងអស់នោះប្រកបដោយព្រះប្រាជ្ញាញាណ" (ទន ១០៤,២៤)។ "ព្រះអម្ចាស់មានព្រះហឫទ័យសប្បុរសចំពោះមនុស្សទាំងអស់ ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរដល់សត្វលោកទាំងអស់ ដែលព្រះអង្គបានបង្កើតមក" (ទន ១៤៥,៩)។

### ព្រះជាម្ចាស់បង្កើត "ដោយមិនប្រើអ្វីសោះ"

២៩៦-យើងជឿថា ព្រះជាម្ចាស់មិនត្រូវការអ្វីមួយ ឬជំនួយណាមួយដើម្បីបង្កើតឡើយ (DS ៣០២២)។ ម៉្យាងទៀតព្រះអង្គមិនត្រូវការបង្កើតពិភពលោកជាចាំបាច់ដែរ (DS ៣០២៣-៣០២៤)។ ព្រះអង្គបង្កើត "ដោយមិនប្រើអ្វី" (DS ៨០០; ៣០២៥) ដោយមានសេរីភាពពេញលេញ។

តើមានអ្វីអស្ចារ្យ បើព្រះជាម្ចាស់បានបង្កើតពិភពលោកមកពីវត្ថុធាតុមួយ ដែលមានពីមុនរួចមកហើយនោះ? កាលណាគេមានសម្ភារៈ ជាងសិប្បករអាចធ្វើអ្វីក៏បានតាមបំណងរបស់គេ។ រីឯព្រះជាម្ចាស់សម្ដែងឫទ្ធានុភាពពេលព្រះអង្គធ្វើអ្វីក៏បាន ដោយមិនប្រើអ្វីសោះ (សន្តៈ ថេអូភីល នៃអង់ទីអូស)។

២៩៧-ព្រះគម្ពីរបញ្ជាក់ថាព្រះជាម្ចាស់បានបង្កើត "ដោយមិនប្រើអ្វីសោះ" ជាសេចក្ដីពិតដែលជំរុញយើងឲ្យសង្ឃឹមជានិច្ច។ ហេតុដូច្នេះហើយបានជាមាតារបស់កូនទាំងប្រាំពីរលើកទឹកចិត្តគេឲ្យក្លាយទៅជាមរណៈសាក្សី៖

> "ម៉ែមិនដឹងថាកូនបានមកចាប់ផ្ទៃដូចម្ដេចទេ ពុំមែនម៉ែទេ ដែលផ្ដល់វិញ្ញាណ និងជីវិតឲ្យកូន! ដូចព្រះជាម្ចាស់បានបង្កើតពិភពលោក ព្រះអង្គបានសូនរូបមនុស្សក្នុងផ្ទៃព្រះអង្គជាប្រភពនៃអ្វីៗទាំងអស់។ ព្រះអង្គនឹងប្រទានវិញ្ញាណព្រមទាំងជីវិតឲ្យកូនតាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ព្រោះឥឡូវនេះកូនសុខចិត្តបូជាជីវិតដោយស្រឡាញ់វិន័យរបស់ព្រះអង្គ (...) ម៉ែអង្វរកូន ចូរសម្លឹងមើលផ្ទៃមេឃ និងផែនដី ចូររំពៃមើលអ្វីៗដែលមាននៅលើផែនដី និងផ្ទៃមេឃ! ចូរទទួលស្គាល់ថា ព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងនោះ ដោយមិនប្រើអ្វីសោះ រីឯមនុស្សវិញ ព្រះអង្គក៏បានបង្កើតតាមរបៀបដូច្នោះដែរ" (២មបា ៧,២២-២៣.២៨)។

២៩៨-ព្រះជាម្ចាស់អាចបង្កើតដោយមិនប្រើអ្វីយ៉ាងណា ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះអង្គក៏អាចប្រទានជីវិតឲ្យអ្នកបាបដោយផ្ដល់ចិត្តបរិសុទ្ធឲ្យគេ (ទន ៥១,២) ហើយព្រះអង្គអាចធ្វើឲ្យរូបកាយរបស់មនុស្សស្លាប់បាន

រស់ឡើងវិញយ៉ាងនោះដែរ "គឺព្រះអង្គដែលប្រោសមនុស្សស្លាប់ឲ្យមានជីវិតថ្មី ហើយបានត្រាស់ហៅអ្វីៗដែលគ្មានរូបរាងឲ្យកើតមានឡើង" (រម ៤,១៧) ហើយព្រះបន្ទូលរបស់ព្រះអង្គអាចធ្វើឲ្យពន្លឺចេញពីភាពងងឹតយ៉ាងណា (កណ ១,៣) ព្រះអង្គក៏អាចផ្តល់ពន្លឺនៃជំនឿឲ្យអស់អ្នកដែលមិនស្គាល់ព្រះអង្គយ៉ាងនោះដែរ (២ករ ៤,៦)។

## ព្រះជាម្ចាស់បង្កើតពិភពមួយប្រកបដោយសណ្តាប់ធ្នាប់ និងល្អប្រសើរ

២៩៩-ព្រះជាម្ចាស់បង្កើតប្រកបដោយព្រះប្រាជ្ញាញាណ ទើបការបង្កើតមានសណ្តាប់ធ្នាប់៖ "ព្រះអង្គចាត់ចែងអ្វីៗទាំងអស់ដោយមានកម្រិត និងរបៀបរៀបរយ" (ប្រាញ ១១,២០)។ ព្រះជាម្ចាស់បានបង្កើតនៅក្នុងអង្គ និងដោយសារព្រះបន្ទូលអស់កល្បជានិច្ចដែល "ជារូបតំណាងរបស់ព្រះជាម្ចាស់ដែលយើងមើលពុំឃើញ" (កូឡ ១,១៥) សម្រាប់មនុស្សលោកដែលជារូបតំណាងរបស់ព្រះជាម្ចាស់ (កណ ១,២៦) ហើយដែលព្រះអង្គត្រាស់ហៅឲ្យរៀងៗខ្លួនមានទំនាក់ទំនងជាមួយព្រះអង្គ។ ដោយចិត្តព្យាយាម និងសុភាពរាបសាដោយគោរពកោតខ្លាចព្រះជាម្ចាស់ និងដោយប្រាជ្ញា យើងរួមចំណែកជាមួយនឹងមានពន្លឺរបស់ព្រះជាម្ចាស់ (យប ៤២,៣) មនុស្សយើងអាចឈ្វេងយល់នូវអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលមកយើងតាមរយៈការបង្កើត (ទន ១៩,២-៥)។ ការបង្កើតដែលមកពីព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់រួមចំណែកក្នុងសប្បុរសធម៌នោះ ("ព្រះជាម្ចាស់ទតឃើញអ្វីៗទាំងអស់ដែលព្រះអង្គបានបង្កើតមកទ្រង់ឈ្វេងយល់ថាល្អប្រសើរ (...) ល្អប្រសើរបំផុត" (កណ ១,៤.១០.១២.១៨.២១.៣១)។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យការបង្កើតធ្វើជាអំណោយ និងមរតកដែលមនុស្សលោកត្រូវតែថែរក្សា។ ជាច្រើនលើកច្រើនសា ព្រះសហគមន៍បានជួយការពារអះអាងថាអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បង្កើតសុទ្ធតែល្អប្រសើរ។

## ព្រះជាម្ចាស់ខ្ពង់ខ្ពស់ហួស និងលើសអ្វីដែលព្រះអង្គបង្កើត ហើយគង់នៅជាមួយ

៣០០-ព្រះជាម្ចាស់ប្រសើរឧត្តុង្គឧត្តមលើសស្នាព្រះហស្តទាំងអស់របស់ព្រះអង្គ (បសរ ៤៣,២៨)៖ "ព្រះអង្គថ្កុំថ្កើងរុងរឿងលើសផ្ទៃមេឃទៅទៀត" (ទន ៨,២) "ព្រះអង្គឧត្តុង្គឧត្តមរកអ្វីប្រៀបផ្ទឹមស្មើពុំបាន" (ទន ១៤៥,៣)។ ប៉ុន្តែដោយសារព្រះអង្គជាព្រះបង្កើតដ៏ប្រសើរបំផុត ដែលមានសេរីភាពពេញលេញ ហើយជាដើមកំណើតនៃអ្វីៗទាំងអស់សព្វសារពើ ព្រះអង្គគង់នៅក្នុងសត្វលោករបស់ព្រះអង្គយ៉ាងស្និទ្ធស្នាល៖ "ដ្បិតយើងមានជីវិតរស់ចលនា និងមានជាតិជាមនុស្សដោយសារព្រះអង្គ" (កក ១៧,២៨)។ តាមពាក្យសម្តីរបស់សន្តៈ អូគូស្តាំង "ព្រះអង្គខ្ពស់ជាងទីខ្ពស់របស់ខ្ញុំ ស្និទ្ធស្នាលជាងទីស្និទ្ធស្នាលរបស់ខ្ញុំ"។

## ព្រះជាម្ចាស់រក្សាទុក និងទ្រទ្រង់អ្វីដែលព្រះអង្គបង្កើត

៣០១-ពេលព្រះជាម្ចាស់បង្កើតព្រះអង្គមិនលះបង់សត្វលោកចោលទេ។ ព្រះអង្គមិនគ្រាន់តែផ្តល់កំណើត និងជីវិតឲ្យសត្វលោកទេ ថែមទាំងរក្សាទុកគេនៅក្នុងអង្គព្រះអង្គគ្រប់ពេលវេលា ធ្វើឲ្យគេអាចប្រព្រឹត្តកិច្ចការបាន និងទ្រទ្រង់គេរហូតដល់ទីបញ្ចប់។ ពេលយើងទទួលស្គាល់ថាយើងពឹងផ្អែកទាំងស្រុងលើព្រះបង្កើត យើងពោរពេញដោយប្រាជ្ញាញាណសេរីភាព អំណរសប្បាយ និងទំនុកចិត្ត។

ព្រះអង្គស្រឡាញ់សត្វលោកទាំងអស់មិនស្អប់ខ្ពើមសត្វលោកណាមួយដែលព្រះអង្គបានបង្កើតសោះឡើយ។ ប្រសិនបើព្រះអង្គស្អប់សត្វលោកណាមួយព្រះអង្គមិនបង្កើតសត្វនោះទេ! ប្រសិនបើព្រះអង្គមិនសព្វព្រះហឫទ័យបង្កើតទេនោះ តើមានសត្វលោកណាអាចរស់នៅបាន? ប្រសិនបើព្រះអង្គមិនហៅឲ្យកើតមកទេ តើសត្វលោកនោះអាចស្ថិតស្ថេរដូចម្តេចបាន? បពិត្រព្រះអម្ចាស់ដែលស្រឡាញ់ជីវិត ព្រះអង្គសម្តែងព្រះហឫទ័យសប្បុរសចំពោះ

សត្វលោកទាំងអស់ ដ្បិតសត្វលោកសុទ្ធតែជាកម្មសិទ្ធិរបស់ព្រះអង្គ (ប្រាញ ១១,២៤-២៦)។

### ៥-ព្រះជាម្ចាស់ធ្វើឲ្យគម្រោងការរបស់ព្រះអង្គបានសម្រេច៖ ឧបការគុណ

៣០២-ព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ប្រកបដោយសប្បុរសធម៌ និងភាពល្អឥតខ្ចោះ ប៉ុន្តែ ព្រះអង្គមិនបានបង្ហើយស្នាព្រះហស្ដរបស់ព្រះអង្គទេ។ ដោយសារឧបការគុណរបស់ព្រះជាម្ចាស់ព្រះអង្គកំពុង ("in statu viae") បង្កើតអ្វីៗទាំងអស់ និងត្រាស់ហៅអ្វីៗទាំងអស់ ឆ្ពោះទៅរកភាពល្អឥតខ្ចោះជាទីបំផុត។

ដោយឧបការគុណព្រះជាម្ចាស់រក្សាទុក និងគ្រប់គ្រងអ្វីៗដែលព្រះអង្គបានបង្កើតមក "ព្រះប្រាជ្ញាញាណលាតត្រដាងឫទ្ធានុភាពពីជើងមេឃម្ខាងទៅជើងមេឃម្ខាង ហើយត្រួតត្រាអ្វីៗទាំងអស់ដោយព្រះហឫទ័យសប្បុរស" (ប្រាញ ៨,១) ដ្បិត "គ្មានសត្វលោកណាមួយដែលព្រះបន្ទូលមើលមិនឃើញឡើយ ចំពោះព្រះនេត្ររបស់ព្រះអង្គ អ្វីៗទាំងអស់នៅទទេឥតបិទបាំងទាល់តែសោះ" (ហប ៤,១៣) សូម្បីតែកិច្ចការដែលសត្វលោកនឹងប្រព្រឹត្តដោយសេរី។

៣០៣-ព្រះគម្ពីរផ្ដល់សក្ខីភាពតែមួយ៖ ព្រះជាម្ចាស់ថែរក្សាអ្វីៗទាំងអស់ភ្លាមៗ និងយ៉ាងច្បាស់លាស់ព្រះអង្គថែទាំអ្វីៗទាំងអស់តាំងពីរឿងតូចតាចបំផុតរហូតដល់ហេតុការដ៏ធំៗនៃពិភពលោក និងប្រវត្តិសាស្ត្ររបស់មនុស្សលោក។ ព្រះគម្ពីរដ៏វិសុទ្ធអះអាងយ៉ាងច្បាស់លាស់ថាព្រះជាម្ចាស់ប្រកបដោយភាពថ្កុំថ្កើងណែនាំអ្វីៗទាំងអស់គ្រប់កាលៈទេសៈ៖ "ព្រះរបស់យើងគង់នៅស្ថានបរមសុខព្រះអង្គធ្វើអ្វីៗក៏បានតាមតែព្រះហឫទ័យរបស់ព្រះអង្គ" (ទន ១១៥,៣) ហើយមានថ្លែងអំពីព្រះគ្រីស្ដថា៖ "បើព្រះអង្គបើកគ្មាននរណាបិទបាន បើព្រះអង្គបិទគ្មាននរណាបើកបាន" (វវ ៣,៧)។ "មនុស្សគិតគូរគម្រោងការជាច្រើន ក៏ប៉ុន្តែមានតែគម្រោងការរបស់ព្រះអម្ចាស់ប៉ុណ្ណោះដែលសម្រេចជារូបរាង" (សភ ១៩,២១)។

៣០៤-ហេតុនេះហើយបានជាយើងអាចយល់ឃើញថា ព្រះវិញ្ញាណដ៏វិសុទ្ធ ជាអ្នកនិពន្ធសំខាន់ជាងគេនៃព្រះគម្ពីរដ៏វិសុទ្ធថ្វាយកិច្ចការនានាទៅព្រះជាម្ចាស់ ដោយមិនបាច់និយាយអំពីហេតុជាបន្តបន្ទាប់ឡើយ គឺមិនមែនជា "របៀបនិយាយ" ដើមទេ ប៉ុន្តែជារបៀបរំឭកថា ព្រះជាម្ចាស់មានអាទិភាពលើសអ្វីៗទាំងអស់ និងគ្រប់គ្រងនឹងប្រវត្តិសាស្ត្រ និងពិភពលោក (អស ១០,៥-១៥; ៤៧,៥-៧; ទក ៣២,៣៩; បសរ ១១,១៤) ដោយមិនអាក់ខានឡើយ ហើយជារបៀបអប់រំឲ្យជឿទុកចិត្តលើព្រះអង្គផង។ ការអធិដ្ឋានតាមទំនុកតម្កើងដូចជាសាលាដ៏ខ្ពង់ខ្ពស់នៃទំនុកចិត្តនេះ (ទន ២២; ៣២; ៣៥; ១០៣; ១៣៨)។

៣០៥-ព្រះយេស៊ូសូមឲ្យយើងលះបង់អ្វីៗទាំងអស់ទៅព្រះបិតាដែលគង់នៅស្ថានបរមសុខ ហើយដែលថែរក្សានូវតម្រូវការទាំងអស់នៃបុត្រធីតារបស់ព្រះអង្គ៖ "កុំខ្វល់ខ្វាយដោយពោលថា "យើងនឹងមានអ្វីបរិភោគ មានអ្វីស្លៀកពាក់? នោះឡើយ (...) ព្រះបិតាដែលគង់នៅស្ថានបរមសុខទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ។ ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសេចក្ដីសុចរិតរបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀត" (មត ៦,៣១-៣៣)។

### ឧបការគុណ និងហេតុជាបន្តបន្ទាប់

៣០៦-ព្រះជាម្ចាស់គ្រប់គ្រងយ៉ាងច្បាស់លាស់លើគម្រោងការរបស់ព្រះអង្គ។ ប៉ុន្តែព្រះអង្គប្រើប្រាស់សត្វលោកដើម្បីឲ្យគម្រោការនេះបានសម្រេចដែរ មិនមែនដោយសារព្រះអង្គទន់ខ្សោយទេ គឺមកពីភាពថ្កុំថ្កើង និងសប្បុរសធម៌របស់ព្រះអង្គប្រកបដោយឫទ្ធានុភាពសព្វប្រការ ដ្បិតព្រះអង្គមិនគ្រាន់តែឲ្យសត្វលោកមានជីវិតរស់នៅទេ ថែម

ទាំងឲ្យគេអាចប្រព្រឹត្តកិច្ចការដោយខ្លួនឯង និងធ្វើជាហេតុ និងគោលវាំងគ្នានឹងគ្នា ទើបអាចធ្វើសហប្រតិបត្តិការជាមួយព្រះអង្គ ដើម្បីឲ្យគម្រោងការរបស់ព្រះអង្គបានសម្រេច។

៣០៧-ព្រះជាម្ចាស់ប្រទានឲ្យមនុស្សលោកអាចធ្វើការរួមជាមួយឧបការគុណរបស់ព្រះអង្គដោយប្រោសគេឲ្យទទួលខុសត្រូវ "ត្រួតត្រា" និងមានអំណាចលើផែនដី (កណ ១,២៦-២៨)។ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់ប្រោសប្រទានមនុស្សលោកឲ្យទៅជាហេតុដែលមានប្រាជ្ញា និងសេរីភាពដើម្បីបំពេញស្នាព្រះហស្តនៃការបង្កើតឲ្យបានគ្រប់លក្ខណៈដើម្បីខ្លួនគេ និងបងប្អូនរបស់គេផងដែរ។ ជារឿយៗមនុស្សលោករួមសហប្រតិបត្តិការជាមួយព្រះបំណងរបស់ព្រះជាម្ចាស់ដោយមិនដឹងខ្លួន ប៉ុន្តែពួកគេអាចសុខចិត្តចូលរួមក្នុងគម្រោងការរបស់ព្រះអង្គតាមកិច្ចការ ការអធិដ្ឋាន និងទុក្ខលំបាករបស់គេផងដែរ (កូឡ ១,២៤)។ ពេលនោះគេក៏ក្លាយទៅជា "សហការីរបស់ព្រះជាម្ចាស់" (១ករ ៣,៩; ១ថស ៣,២) និងរបស់ព្រះរាជ្យនៃព្រះអង្គ (កូឡ ៤,១១)។

៣០៨-ពេលយើងជឿថាព្រះជាម្ចាស់ជាព្រះបង្កើតយើង ក៏ត្រូវតែជឿលើសេចក្តីពិតនេះផងដែរ គឺព្រះជាម្ចាស់ប្រព្រឹត្តតាមកិច្ចការទាំងអស់នៃសត្វលោករបស់ព្រះអង្គ។ ព្រះជាម្ចាស់ជាដើមហេតុដែលប្រតិបត្តិការនៅក្នុង និងតាមរយៈហេតុបន្តបន្ទាប់៖ "ដ្បិតព្រះជាម្ចាស់ទេតើដែលធ្វើឲ្យបងប្អូនមានទាំងបំណង មានទាំងសមត្ថភាពអាចនឹងប្រព្រឹត្តតាមព្រះបំណងដ៏សប្បុរសរបស់ព្រះអង្គ" (ភីល ២,១៣) (១ករ ១២,៧)។ សេចក្តីពិតនេះមិនបង្អាប់បង្អោន ប៉ុន្តែជាការលើកតម្កើងសេចក្តីដ៏ថ្លៃថ្នូររបស់សត្វលោកទៅវិញ។ ព្រះជាម្ចាស់បានបង្កើតសត្វលោកពីគ្មានអ្វីទាំងអស់ដោយសារឫទ្ធានុភាពព្រះប្រាជ្ញាញាណ និងសប្បុរសធម៌ ទើបសត្វលោកធ្វើអ្វីពុំកើតបើដាច់ពីប្រភពរបស់ខ្លួន ដ្បិត "ប្រសិនបើគ្មានព្រះបង្កើតទេ ក៏គ្មានសត្វលោកដែរ" (GS ៣៦,៣) ហើយសត្វលោកនោះមិនអាចទៅដល់គោលដៅរបស់ខ្លួនឡើយ បើព្រះជាម្ចាស់មិនប្រណីសន្តោសឡើយ (មថ ១៩,២៦; យហ ១៥,៥; ភីល ៤,១៣)។

## ឧបការគុណ និងអំពើអាក្រក់

៣០៩-បើព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ជាព្រះបង្កើតពិភពមួយប្រកបដោយសណ្តាប់ធ្នាប់ និងដ៏ល្អប្រសើរទ្រង់ថែរក្សាសត្វលោកទាំងអស់របស់ព្រះអង្គ ហេតុអ្វីបានជាមានអំពើអាក្រក់ដូច្នោះ? យើងមិនអាចឆ្លើយតបភ្លាមៗនឹងសំណួរដ៏សំខាន់គួរឲ្យឈឺចាប់ដែលយើងមិនអាចជៀសវាងបាន ហើយដែលយើងមិនអាចឈ្វេងយល់ទាំងស្រុងបានទេ។ មានតែគ្រីស្តសាសនាទាំងមូលទេដែលឆ្លើយតបនឹងសំណួរនេះបាន៖ សប្បុរសធម៌នៃការបង្កើតវិនាដកម្មនៃអំពើបាប សេចក្តីស្រឡាញ់ដ៏អត់ធ្មត់របស់ព្រះជាម្ចាស់ដែលយាងមករកមនុស្សដោយចងសម្ព័ន្ធមេត្រីជាមួយគេដោយព្រះបុត្រារបស់ព្រះអង្គប្រសូតជាមនុស្ស ដោយប្រោសប្រទានព្រះវិញ្ញាណ ដោយបង្រួបបង្រួមព្រះសហគមន៍ ដោយកម្លាំងនៃអគ្គសញ្ញា ដោយត្រាស់ហៅសត្វលោកឲ្យមានសុភមង្គលដែលគេអាចសុខចិត្តទទួល ឬបដិសេធមិនព្រមទទួល។ សេចក្តីនីមួយៗនៃគ្រីស្តសាសនាអាចឆ្លើយតបនឹងសំណួរស្តីអំពីអំពើអាក្រក់នេះបាន ។

៣១០-ហេតុអ្វីបានជាព្រះជាម្ចាស់មិនបានបង្កើតពិភពមួយដ៏ល្អឥតខ្ចោះដែលគ្មានអំពើអាក្រក់អាចមកបៀតបៀន? ដោយសារឫទ្ធានុភាពសព្វប្រការរបស់ព្រះជាម្ចាស់ ព្រះអង្គអាចបង្កើតអ្វីមួយដ៏ល្អប្រសើរបំផុត (សន្តះថូម៉ាសនៃអាកាំង)។ ក៏ប៉ុន្តែព្រះជាម្ចាស់ប្រកបដោយព្រះប្រាជ្ញាញាណ និងសប្បុរសធម៌ដែលគ្មានព្រំដែនទ្រង់សព្វព្រះហឫទ័យបង្កើតពិភពមួយដែលកំពុង "ធ្វើដំណើរ" ឆ្ពោះទៅភាពល្អឥតខ្ចោះជាទីបំផុត។ ក្នុងការធ្វើដំណើរនេះតាមគម្រោងការរបស់ព្រះជាម្ចាស់សត្វលោកខ្លះត្រូវតែលេចឡើង សត្វលោកខ្លះផ្សេងទៀតត្រូវតែវិនាសមានទាំងភាពល្អឥតខ្ចោះ មានទាំងភាពមិនល្អឥតខ្ចោះ មានទាំងការសាងសង់ មានទាំងការបំផ្លាញនៃធម្មជាតិផងដែរ។

ហេតុនេះហើយបានជាកើតមានអំពើអាក្រក់រហូតដល់ព្រះជាម្ចាស់ណែនាំការបង្កើតឲ្យបានល្អគ្រប់លក្ខណៈ (សន្តៈថូម៉ាសនៃអាកាំង)។

៣១១-ពួកទេវទូត និងមនុស្សលោកជាសត្វលោកដែលមានប្រាជ្ញា និងសិរីភាពត្រូវតែធ្វើដំណើរឆ្ពោះទៅគោលដៅចុងក្រោយបំផុតរបស់ខ្លួន ដោយមានសេរីភាពក្នុងការជ្រើសរើស ព្រមទាំងសេចក្ដីស្រឡាញ់ផង។ ដូច្នេះពួកគេអាចវង្វេងផ្លូវបាន។ តាមការពិតពួកគេបានប្រព្រឹត្តអំពើបាបរួចទៅហើយ ជាហេតុនាំឲ្យអំពើបាបចូលក្នុងពិភពលោក។ អំពើបាបនេះធ្ងន់ធ្ងរខ្លាំងជាងអំពើអាក្រក់ទៅទៀត មិនអាចកម្រិតបានទេ។ ព្រះជាម្ចាស់មិនមែនជាដើមហេតុនៃអំពើបាបទាល់តែសោះ (សន្តៈ អំប្រ័រ) ប៉ុន្តែព្រះអង្គបណ្ដោយឲ្យមានអំពើបាបដោយបំប្រែឲ្យមានអំពើល្អចេញពីអំពើបាបនោះ ដោយគោរពសេរីភាពនៃសត្វលោករបស់ព្រះអង្គ។

ដ្បិតព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ (...) ប្រកបដោយព្រះហឫទ័យសប្បុរសដ៏ខ្ពង់ខ្ពស់បំផុត មិនដែលឲ្យមានអំពើអាក្រក់ណាមួយស្ថិតនៅក្នុងសត្វលោករបស់ព្រះអង្គ បើព្រះអង្គមិនអាចធ្វើឲ្យអំពើល្អចេញពីអំពើអាក្រក់នោះបានឡើយ (សន្តៈ អូគូស្តាំង)។

៣១២-ដូច្នេះហើយបានជាបន្តិចម្ដងៗយើងអាចយល់ឃើញថា ព្រះជាម្ចាស់ដែលមានឧបការគុណប្រកបដោយឫទ្ធានុភាពសព្វប្រការអាចបំប្រែឲ្យអំពើល្អចេញមកពីអំពើអាក្រក់ ទោះជាអំពើបាបដែលសត្វលោកបានប្រព្រឹត្តក៏ដោយ។ លោកយ៉ូសែបមានប្រសាសន៍ទៅកាន់បងៗរបស់គាត់ថា៖ "ពុំមែនពួកបងទេ គឺព្រះជាម្ចាស់វិញទេតើដែលចាត់ប្អូនឲ្យមកទីនេះ (...) ពួកបងបានឃុបឃិតគ្នាធ្វើបាបខ្ញុំ តែព្រះជាម្ចាស់បានធ្វើឲ្យការនោះប្រែក្លាយទៅជាល្អ (...) គឺព្រះអង្គសង្គ្រោះជីវិតប្រជាជនមួយចំនួនធំ" (កណ ៤៥,៨; ៥០,២០) (តប ២,១២-១៨)។ ម្យ៉ាងទៀតព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យប្រណីសន្ដោសដ៏លើសលប់ (រម ៥,២០) ទ្រង់បានបំប្រែឲ្យមានផលល្អជាទីបំផុតចេញពីអំពើបាបអាក្រក់ជាងគេជាទីបំផុត គឺព្រះជាម្ចាស់បានប្រោសព្រះបុត្រារបស់ព្រះអង្គឲ្យមានព្រះជន្មថ្មីដ៏រុងរឿង និងបានសង្គ្រោះយើង ចាប់ពីការមិនទទួលស្គាល់ និងការសម្លាប់ព្រះបុត្រាព្រះអង្គនេះដោយអំពើបាបរបស់មនុស្សទាំងឡាយ។ ក៏ប៉ុន្តែអំពើអាក្រក់មិនមែនជាអំពើល្អទេ។

៣១៣-"អ្វីៗទាំងអស់ផ្សុំគ្នាឡើងដើម្បីឲ្យអស់អ្នកស្រឡាញ់ព្រះជាម្ចាស់បានទទួលផលល្អ" (រម ៨,២៨)។ សក្ខីភាពរបស់សន្តបុគ្គលនៅតែបញ្ជាក់សេចក្ដីពិតនេះ៖

> ហេតុនេះហើយទើបសន្តី កាតឺរីន នៅស៊ីយ៉ែនពោលថា ចំពោះ "អស់អ្នកដែលទាស់ចិត្ត និងបះបោរប្រឆាំងនឹងអ្វីៗដែលកើតមានដល់ពួកគេ"៖ "អ្វីៗទាំងអស់កើតចេញមកពីសេចក្ដីស្រឡាញ់ អ្វីៗទាំងអស់កើតឡើងដើម្បីសង្គ្រោះរបស់មនុស្សលោក ព្រះជាម្ចាស់មានព្រះហឫទ័យនេះតែមួយគត់"។
>
> ចំណែក សន្តៈ ថូម៉ាស ម័រ មុនពេលលោកក្លាយទៅជាមរណៈសាក្សី បានលួងលោមកូនស្រីលោកថា៖ "បើមិនមែនជាព្រះហឫទ័យព្រះជាម្ចាស់ទេ អ្វីក៏មិនអាចកើតមានដែរ។ ទោះបីយើងយល់ថា អាក្រក់ក៏ដោយ បើជាព្រះហឫទ័យរបស់ព្រះអង្គនោះ ជាការល្អប្រសើរបំផុតសម្រាប់យើងហើយ"។
>
> ឯលោកស្រី ជូលាន នៃន័រវិច៖ "ដោយសារព្រះជាម្ចាស់បានប្រោសប្រណីមកខ្ញុំ ខ្ញុំបានយល់ថា ត្រូវតែមានជំនឿមាំមួន ហើយជឿជាក់ថា អ្វីៗទាំងអស់សុទ្ធតែល្អ... ហើយអ្នកនឹងឃើញថា អ្វីៗទាំងអស់សុទ្ធតែល្អមែន" (**"Thou shall see thyself that all MANNER of thing shall be well"**)។

៣១៤-យើងជឿជាក់ថា ព្រះជាម្ចាស់ណែនាំពិភពលោក និងប្រវត្តិសាស្ត្រមនុស្សលោក។ ប៉ុន្តែយើងមិនសូវ

ស្គាល់ផ្លូវនៃឧបការគុណរបស់ព្រះអង្គឡើយ។ មានតែនៅពេលចុងក្រោយបំផុតនៅពេលយើងនឹងឃើញព្រះអង្គ "ទល់មុខគ្នា" (១ករ ១៣,១២) ទើបយើងនឹងលែងស្គាល់ព្រះអង្គព្រាលៗ ហើយយើងនឹងស្គាល់យ៉ាងច្បាស់ៗផ្លូវ ដែលព្រះជាម្ចាស់ប្រើប្រាស់ដើម្បីណែនាំសត្វលោករបស់ព្រះអង្គ តាមរយៈវិនាដកម្មនៃអំពើអាក្រក់ និងអំពើបាប រហូតដល់ថ្ងៃសប្ប័ទ (កណ ២,២) ជាថ្ងៃសម្រាកចុងក្រោយបំផុត ជាគោលដៅរបស់ព្រះជាម្ចាស់ដែលបានបង្កើត មេឃ និងដី។

## សង្ខេប

៣១៥-ក្នុងការបង្កើតពិភពលោក និងមនុស្ស ព្រះជាម្ចាស់បានផ្ដល់សក្ខីភាពមុនគេបង្អស់អំពីសេចក្ដីស្រឡាញ់ ប្រកបដោយឫទ្ធានុភាព និងព្រះប្រាជ្ញាញាណរបស់ព្រះអង្គ និងមានព្រះបន្ទូលប្រកាសមុនគេបង្អស់នូវ "គម្រោងការដ៏សប្បុរស" របស់ព្រះអង្គ ដែលមានទីបញ្ចប់ក្នុងការបង្កើតថ្មីនៅក្នុងអង្គព្រះគ្រីស្ត។

៣១៦-ទោះបីយើងចាត់ទុកថា ព្រះបិតាជាអ្នកបង្កើតក៏ដោយ ក៏ត្រូវតែជឿថា ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ ជាគោលការណ៍តែមួយ ដែលមិនអាចបំបែកពីគ្នាបាននៃការបង្កើតដែរ។

៣១៧-មានតែព្រះជាម្ចាស់ទេ ដែលបានបង្កើតសកលលោក ដោយគ្មានការបង្ខំ គ្មានអ្នកណែនាំ និងដោយគ្មានជំនួយអ្វីណាមួយឡើយ។

៣១៨-គ្មានសត្វលោកណាមួយមានអំណាចក្រៃលែង ដែលចាំបាច់ដើម្បី "បង្កើត" តាមន័យចំនៃពាក្យនេះ គឺផលិត និងផ្ដល់សភាវៈដល់អ្នកណា ដែលគ្មានសភាវៈសោះឡើយ (ត្រាស់ហៅពី "ភាពសាបសូន្យ" ឲ្យមានជីវិត) (DS៖ ៣៦២៤)

៣១៩-ព្រះជាម្ចាស់បានបង្កើតពិភពលោក ដើម្បីសម្ដែង និងប្រទានសិរីរុងរឿងរបស់ព្រះអង្គ ដើម្បីនាំសត្វលោកឲ្យរួមចំណែកក្នុងសេចក្ដីពិត សប្បុរសធម៌ និងសោភណភាពរបស់ព្រះអង្គ។

៣២០-ព្រះជាម្ចាស់ ដែលបានបង្កើតសកលលោក ហើយទ្រទ្រង់សកលោកនេះ ឲ្យស្ថិតនៅ ដោយសារព្រះបន្ទូលរបស់ព្រះអង្គ "ព្រះបុត្រាទ្រទ្រង់អ្វីៗទាំងអស់ ដោយសារព្រះបន្ទូលប្រកបដោយឫទ្ធានុភាព" (ហប ១,៣) និងដោយព្រះវិញ្ញាណរបស់ព្រះអង្គជាអ្នកបង្កើតដែលប្រទានជីវិត។

៣២១-ឧបការគុណរបស់ព្រះជាម្ចាស់ គឺជាការណែនាំសត្វលោកទាំងអស់ ដោយព្រះប្រាជ្ញាញាណ និងសេចក្ដីស្រឡាញ់រហូតដល់ទីចុងក្រោយបំផុតរបស់ពួកគេ។

៣២២-ព្រះគ្រីស្តណែនាំយើងឲ្យលះបង់ខ្លួនឯងចំពោះឧបការគុណនៃព្រះបិតារបស់យើង ដែលគង់នៅស្ថានបរមសុខ (មថ ៦,២៦-៣៤) ហើយគ្រីស្តទូតសិលាមានប្រសាសន៍ថែមទៀតថា៖ "ចូរផ្ទេរទុក្ខកង្វល់ទាំងប៉ុន្មានរបស់បងប្អូនថ្វាយព្រះអង្គទៅ ដ្បិតទ្រង់យកព្រះហឫទ័យទុកដាក់នឹងបងប្អូន" (១ពត្រ ៥,៧) (ទន ៥៥, ២៣)។

៣២៣-ឧបការគុណរបស់ព្រះជាម្ចាស់ប្រតិបត្តិតាមកិច្ចការរបស់សត្វលោកដែរ។ ព្រះជាម្ចាស់ប្រោសប្រទានឲ្យមនុស្សស្ម័គ្រចិត្តរួមសហការក្នុងគម្រោងការរបស់ព្រះអង្គ។

៣២៤-ព្រះជាម្ចាស់អនុញ្ញាតឲ្យមានអំពើអាក្រក់ និងអំពើបាប ជាអាថ៌កំបាំងដែលព្រះអង្គបំភ្លឺដោយព្រះបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត ដែលបានសោយទិវង្គត និងមានព្រះជន្មថ្មី ដើម្បីឈ្នះអំពើអាក្រក់។ ជំនឿធ្វើឲ្យយើងជឿជាក់ថា ព្រះជាម្ចាស់មិនអនុញ្ញាតឲ្យមានអំពើអាក្រក់ទេ បើព្រះអង្គមិនដកយកអំពើល្អ ចេញពីអំពើអាក្រក់

តាមផ្លូវដែលយើងនឹងស្គាល់ឲ្យបានច្បាស់នៅក្នុងជីវិតអស់កល្បជានិច្ចនោះ។

## កថាខណ្ឌទី៥៖ មេឃ និងដី

៣២៥-ធម៌ប្រកាសជំនឿដែលមកពីក្រុមគ្រីស្តទូតប្រកាសថាព្រះជាម្ចាស់ជា "ព្រះបង្កើតមេឃ និងដី" ហើយធម៌ប្រកាសជំនឿរបស់មហាសន្និបាតសកលនៅនិសេ/កុងស្តង់ទីណូបថែងយ៉ាងច្បាស់លាស់ថា៖ "ទាំងអ្វីៗដែលមើលឃើញ និងមើលមិនឃើញ"។

៣២៦-ក្នុងព្រះគម្ពីរដ៏វិសុទ្ធពាក្យ "មេឃ និងដី" មានន័យថាអ្វីៗទាំងអស់សព្វសារពើសត្វលោកទាំងអស់ ហើយសម្តែងនូវទំនាក់ទំនងរវាងមេឃ និងដី គឺ "ដី" សំដៅលើពិភពរបស់មនុស្ស (ទន ១១៥,៦) ឯ "មេឃ" សំដៅលើអាកាសវេហាស៍ (ទន ១៩,២) ឬស្ថានរបស់ព្រះជាម្ចាស់៖ "ឱព្រះបិតាយើងខ្ញុំដែលគង់នៅស្ថានបរមសុខ" (មថ ៥,១៦) (ទន ១១៥,៦) ហើយ "មេឃ" ជាសិរីរុងរឿងនៅពេលអវសានកាលនៃពិភពលោកដែរ។ ទីបញ្ចប់ "មេឃ" សំដៅទៅលើ "កន្លែង" របស់សត្វលោកខាងវិញ្ញាណ គឺទេវទូតដែលនៅជាមួយព្រះជាម្ចាស់។

៣២៧-ធម៌ប្រកាសជំនឿនៃមហាសន្និបាតទី៤នៅទីក្រុងឡាត្រង់អះអាងថា "កាលពីដើមដំបូងបង្អស់ព្រះជាម្ចាស់បានបង្កើតដោយមិនប្រើអ្វីទាំងសត្វលោកខាងរូបកាយ និងសត្វលោកខាងវិញ្ញាណ ពោលគឺពួកទេវទូត និងផែនដី ហើយព្រះអង្គបានបង្កើតមនុស្សលោកដែលមានទាំងរូបកាយ ទាំងវិញ្ញាណផង" (DS ៨០០)។

### ១-ពួកទេវទូត

#### ត្រូវតែជឿថា មានទេវទូតមែន

៣២៨-ត្រូវតែជឿថាមានសត្វលោកខាងវិញ្ញាណដែលគ្មានរូបកាយ ហើយដែលព្រះគម្ពីរដ៏វិសុទ្ធហៅថា ទេវទូត។ សក្ខីភាពរបស់ព្រះគម្ពីរដ៏វិសុទ្ធច្បាស់ដូចសក្ខីភាពនៃការបញ្ជូនបន្តផងដែរ។

#### តើពួកទេវទូតជានរណា?

៣២៩-តាមសន្តៈ អូគូស្តាំង "ទេវទូត" សំដៅលើមុខងារមិនមែនសំដៅលើសភាព។ "អ្នកសួរថាអ្វីទៅជាសភាពនេះ? -វិញ្ញាណ។ អ្វីទៅជាមុខងារនេះ? -ទេវទូត។ តាមសភាពសត្វលោកនេះជាវិញ្ញាណ តាមមុខងារសត្វលោកនេះជាទេវទូត"។ ទេវទូតមានសភាពជាអ្នកបម្រើ និងអ្នកនាំសាររបស់ព្រះជាម្ចាស់។ ដោយសារពួកលោក "ឃើញព្រះភ័ក្ត្ររបស់ព្រះបិតាដែលគង់នៅស្ថានបរមសុខគ្រប់ពេលវេលា" (មថ ១៨,១០) ពួកលោក "តែងតែអនុវត្តតាមព្រះបន្ទូលរបស់ព្រះអង្គ ហើយស្តាប់តាមបញ្ជារបស់ព្រះអង្គជានិច្ច" (ទន ១០៣,២០)។

៣៣០-ទេវទូតជាសត្វលោកខាងវិញ្ញាណសុទ្ធសាធ ទើបពួកលោកមានប្រាជ្ញា និងបំណង។ ពួកលោកជាសត្វលោកដែលមានលក្ខណៈរៀងៗខ្លួន (DS ៣៨៩១) ហើយមានជីវិតអមតៈ (លក ២០,៣៦)។ សិរីរុងរឿងដ៏ត្រចះត្រចង់របស់ពួកលោកបញ្ជាក់ពីភាពល្អឥតខ្ចោះរបស់ពួកលោក លើសសត្វលោកទាំងអស់ដែលអាចមើលឃើញ (ដន ១០,៩-១២)។

#### ព្រះគ្រីស្ត "ជាមួយពួកទេវទូតទាំងអស់របស់ព្រះអង្គ"

៣៣១-ព្រះគ្រីស្តជាព្រះមហាក្សត្រនៃទេវទូតទាំងឡាយដែលជាកម្មសិទ្ធិរបស់ព្រះអង្គ៖ "នៅពេលបុត្រមនុស្ស

យាងមកជាមួយពួកទេវទូតប្រកបដោយសិរីរុងរឿង..." (មថ ២៥,៣១)។ ពួកទេវទូតជាកម្មសិទ្ធិរបស់ព្រះអង្គ ព្រោះព្រះជាម្ចាស់បានបង្កើតពួកលោកដោយសារព្រះគ្រីស្ត និងសម្រាប់ព្រះគ្រីស្ត៖ "ដ្បិតព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់សព្វសារពើក្នុងអង្គព្រះគ្រីស្តទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ទាំងអ្វីៗដែលមើលឃើញ ទាំងអ្វីៗដែលមើលមិនឃើញ ទាំងទេវរាជ្យ ទាំងអ្វីៗដែលមានបារមីគ្រប់គ្រង ទាំងវត្ថុសក្តិសិទ្ធិ និងអំណាចនានាព្រះជាម្ចាស់បានបង្កើតដោយសារព្រះគ្រីស្ត និងសម្រាប់ព្រះគ្រីស្ត" (កូឡ ១,១៦)។ ពួកលោកជាកម្មសិទ្ធិរបស់ព្រះអង្គ ព្រោះព្រះអង្គបានប្រោសពួកលោកឲ្យទៅជាអ្នកនាំសារនៃគម្រោងការរបស់ព្រះអង្គអំពីការសង្គ្រោះ៖ "ទេវទូតទាំងនោះសុទ្ធតែជាវិញ្ញាណដែលនៅបម្រើព្រះជាម្ចាស់។ ព្រះអង្គចាត់ពួកលោកឲ្យមកបំពេញមុខងារជាប្រយោជន៍ដល់អស់អ្នកដែលត្រូវទទួលការសង្គ្រោះទុកជាមរតក!" (ហប ១,១៤)។

៣៣២-ពួកទេវទូតនៅជាមួយយើង ពេលព្រះជាម្ចាស់បង្កើតពិភពលោក (យប ៣៨,៧) ហើយនៅក្នុងប្រវត្តិសាស្ត្រនៃការសង្គ្រោះ ដោយប្រកាសអំពីការសង្គ្រោះ និងជួយបម្រើព្រះជាម្ចាស់ឲ្យគម្រោងការនេះបានសម្រេច។ ពួកលោកបិទទ្វារនៃសួនឧទ្យានអេដែន (កណ ៣,២៤) ជួយការពារលោកឡុត (កណ ១៩) សង្គ្រោះនាងហាការ និងកូន (កណ ២១,១៧) ឃាត់លោកអប្រាហាំកុំឲ្យសម្លាប់កូន (កណ ២២,១១) បញ្ជូនធម្មវិន័យ (កក ៧,៥៣) ណែនាំប្រជាជនរបស់ព្រះជាម្ចាស់ (សរ ២៣,២០-២៣) ប្រកាសទុកជាមុនថា ស្ត្រីៗនឹងមានកូន (វប ១៣) និងពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ (វប ៦,១១-២៤) ជួយគាំទ្រអស់លោកព្យាការី (១ពង្ស ១៩,៥) ល។ល។ ទីបញ្ចប់ទេវទូតកាព្រីអែលប្រកាសទុកជាមុនថា លោកយ៉ូហានបាទីស្តនឹងកើតមក ហើយព្រះយេស៊ូនឹងប្រសូត (លក ១,១១.២៦)។

៣៣៣-តាំងពីព្រះយេស៊ូប្រសូតរហូតដល់ព្រះអង្គឡើងស្ថានបរមសុខ ពួកទេវទូតតែងតែគោរពក្រាបថ្វាយបង្គំ និងបម្រើព្រះអង្គជានិច្ច។ នៅពេលព្រះជាម្ចាស់ចាត់ "បុត្រច្បងឲ្យមកផែនដីនេះ" ព្រះអង្គមានព្រះបន្ទូលថា៖ "ទេវទូតទាំងអស់របស់ព្រះជាម្ចាស់ត្រូវក្រាបថ្វាយបង្គំព្រះបុត្រា" (ហប ១,១៦)។ ពេលព្រះយេស៊ូប្រសូតមក ពួកលោកច្រៀងកោតសរសើរព្រះអង្គរហូតដល់សព្វថ្ងៃ នៅក្នុងព្រះសហគមន៍៖ "សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់..." (លក ២,១៤)។ ពួកលោកការពារព្រះកុមារយេស៊ូ (មថ ១,២០; ២,១៣.១៩) បម្រើព្រះអង្គនៅវាលរហោស្ថាន (មក ១,១២; មថ ៤,១១) លើកទឹកចិត្តព្រះអង្គនៅពេលព្រះអង្គរងទុក្ខលំបាក (លក ២២,៤៣) និងអាចជួយសង្គ្រោះព្រះអង្គពីដៃរបស់ខ្មាំងសត្រូវ (មថ ២៦,៥៣) ដូចជនជាតិអ៊ីស្រាអែលកាលពីមុន (២មបា ១០,២៩-៣០; ១១,៨)។ ម្យ៉ាងទៀតពួកទេវទូត "ប្រកាសដំណឹងល្អ" (លក ២,១០) នៅពេលព្រះយេស៊ូប្រសូត (លក ២,៨-១៤) និងមានព្រះជន្មថ្មី (មក ១៦,៥-៧)។ ពួកលោកនឹងនៅជាមួយព្រះគ្រីស្ត នៅពេលព្រះអង្គនឹងយាងមកវិញ (កក ១,១០-១១) ដោយបម្រើព្រះអង្គ (មថ ១៣,៤១; ២៤,៣១)។

## ទេវទូតក្នុងព្រះសហគមន៍

៣៣៤-ព្រះសហគមន៍ទទួលផលប្រយោជន៍ពីពួកទេវទូតដែលជួយព្រះសហគមន៍ រហូតដល់ព្រះយេស៊ូយាងមកវិញ តាមរបៀបលាក់កំបាំង និងប្រកបដោយឫទ្ធានុភាព (កក ៥,១៨-២០; ៨,២៦-២៩; ១០,៣-៨; ១២,៦-១១; ២៧,២៣-២៥)។

៣៣៥-នៅក្នុងពិធីបុណ្យព្រះសហគមន៍រួមជាមួយពួកទេវទូត ដើម្បីក្រាបថ្វាយបង្គំព្រះដ៏វិសុទ្ធបំផុត (MR) សូមឲ្យពួកលោកមកជួយ ហើយរំឭកពីទេវទូតខ្លះដូចជាសន្តៈ មីកាអែល សន្តៈ កាព្រីអែល សន្តៈ រ៉ាផាអែល និងទេវទូតទាំងឡាយដែលជួយការពារ។

៣៣៦-ពួកទេវទូតជួយការពារ (ទន ៣៤,៨; ៩១,១០-១៣) មនុស្សលោកពីកំណើត (មថ ១៨,១០) រហូតដល់ស្លាប់ (លក ១៦,២២) និងជួយអង្វរព្រះជាម្ចាស់សម្រាប់យើង (យប ៣៣,២៣-២៤)។ "មានទេវទូតមួយរូបនៅក្បែរគ្រីស្តបរិស័ទម្នាក់ៗ ដើម្បីជួយការពារថែរក្សា និងណែនាំគេទៅដល់ជីវិត" (សន្តៈ បាស៊ីល)។ នៅក្នុងលោកនេះដោយសារជំនឿគ្រីស្តបរិស័ទរួមជាមួយពួកទេវទូតផង មនុស្សលោកផង និងព្រះជាម្ចាស់ផងពោរពេញទៅដោយសុភមង្គល។

## ២-ពិភពដែលមើលឃើញ

៣៣៧-ព្រះជាម្ចាស់ផ្ទាល់បានបង្កើតពិភពដែលមើលឃើញប្រកបដោយភាពសម្បូណ៌ផ្សេងៗពីគ្នា និងមានរបៀបរៀបរយ។ ក្នុងពាក្យកំណាព្យដែលប្រើនិមិត្តរូបជាច្រើន ព្រះគម្ពីរបង្ហាញថាព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ដោយ "ធ្វើការ" អស់រយៈពេលប្រាំមួយថ្ងៃ និង "សម្រាក" ថ្ងៃទីប្រាំពីរ (កណ ១,១-២,៤)។ អត្ថបទដ៏វិសុទ្ធប្រៀនប្រដៅសេចក្តីពិតដែលព្រះជាម្ចាស់បានសម្តែងអំពីការបង្កើត ដើម្បីសង្គ្រោះយើង (DV ១១) ហើយដែលអាចជួយយើងឲ្យ "ទទួលស្គាល់លក្ខណៈដ៏ជ្រៅបំផុតនៃសត្វលោកទាំងអស់ តម្លៃដ៏ថ្លៃថ្នូរ និងទីដៅនៃសត្វលោកទាំងនោះ គឺទទួលសិរីរុងរឿងរបស់ព្រះជាម្ចាស់" (LG ៣៦)។

៣៣៨-អ្វីៗសព្វសារពើជំពាក់ជីវិតរបស់ខ្លួនទៅព្រះជាម្ចាស់ជាព្រះបង្កើត។ ពិភពលោកបានចាប់ផ្តើមនៅពេលព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់អំពីសូន្យ។ សត្វលោកទាំងឡាយធម្មជាតិទាំងអស់ និងប្រវត្តិសាស្ត្រទាំងមូលរបស់មនុស្សចាក់ឫសក្នុងហេតុការណ៍ដ៏សំខាន់នេះ គឺលោកុប្បត្តិនៃពិភពលោក និងពេលវេលា (សន្តៈ អូគូស្តាំង)។

៣៣៩-សត្វលោកនីមួយៗមានសប្បុរសធម៌ និងភាពល្អឥតខ្ចោះរបស់ខ្លួនផ្ទាល់។ អស់រយៈពេលប្រាំមួយថ្ងៃដែលព្រះជាម្ចាស់បង្កើតស្នាព្រះហស្តនីមួយៗមានថ្លែងថា៖ "ព្រះជាម្ចាស់ទតឃើញអ្វីៗទាំងអស់ល្អប្រសើរបំផុតហើយ!"។ "ដោយព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ អ្វីៗទាំងអស់នោះត្រូវតែងតាំងឲ្យនៅជាប់ស្ថិតស្ថេរតាមសេចក្តីពិតរបស់គេ និងតាមតម្លៃដ៏ថ្លៃថ្នូររបស់គេផ្ទាល់ តាមការចាត់ចែង និងតាមក្បួនច្បាប់ពិសេសរបស់គេ" (GS ៣៦,២)។ សត្វលោកនីមួយៗដែលព្រះជាម្ចាស់សព្វព្រះហឫទ័យបង្កើតមក ដើម្បីខ្លួនគេឆ្លុះរស្មីនៃព្រះប្រាជ្ញាញាណ និងសប្បុរសធម៌ឥតព្រំដែនរបស់ព្រះជាម្ចាស់។ ហេតុនេះហើយបានជាមនុស្សលោកត្រូវតែគោរពសប្បុរសធម៌ផ្ទាល់របស់សត្វលោកនីមួយៗកុំឲ្យប្រើប្រាស់គេតាមរបៀបមិនត្រឹមត្រូវ ដែលប្រមាថមើលងាយព្រះបង្កើត និងនាំឲ្យមានផលអាក្រក់ដល់មនុស្សលោក និងបរិស្ថានរបស់គេ។

៣៤០-ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យសត្វលោកនីមួយៗពឹងផ្អែកលើគ្នាទៅវិញទៅមក។ ព្រះអាទិត្យ និងព្រះច័ន្ទដើមតាត្រៅផ្កាតូចៗ សត្វឥន្ទ្រី និងសត្វចាប... សត្វលោកទាំងអស់ផ្សេងៗពីគ្នា និងមិនស្មើគ្នា។ គ្មានសត្វលោកណាមួយមិនពឹងពាក់ទេ។ សត្វលោកនីមួយៗពឹងពាក់គ្នាទៅវិញទៅមក និងបំពេញគ្នាទៅវិញទៅមក ដោយបម្រើគ្នាទៅវិញទៅមក។

៣៤១-សោភណភាពនៃសកលលោក៖ ព្រះជាម្ចាស់បានបង្កើតពិភពលោកប្រកបដោយសណ្តាប់ធ្នាប់ និងភាពសុខដុមរមនាដែលមកពីសត្វលោកទាំងឡាយផ្សេងៗពីគ្នា និងពីទំនាក់ទំនងរវាងគ្នានឹងគ្នា។ មនុស្សយល់ឃើញបន្តិចម្តងៗថាទំនាក់ទំនាងនោះជាច្បាប់នៃធម្មជាតិដែលអ្នកប្រាជ្ញកោតសរសើរ។ សោភណភាពនៃសត្វលោកឆ្លុះសោភណភាពដែលគ្មានព្រំដែនរបស់ព្រះបង្កើត។ ប្រាជ្ញា និងបំណងរបស់មនុស្សលោកត្រូវតែគោរពសោភណភាពនោះ។

៣៤២-សត្វលោករួមគ្នាជាលំដាប់លំដោយដូចពាក្យកំណាព្យនៃកំណើតពិភពលោកបង្ហាញឲ្យដឹង គឺព្រះជាម្ចាស់បង្កើតពិភពលោកក្នុង "ប្រាំមួយថ្ងៃ" ពីសត្វលោកមិនពេញលក្ខណៈដល់សត្វលោកគ្រប់លក្ខណៈ។ ព្រះជាម្ចាស់ស្រឡាញ់ (ទន ១៤៥,៩) និងថែរក្សាគ្រប់សត្វលោករបស់ព្រះអង្គ សូម្បីតែសត្វចាបដ៏តូចៗ។ ក៏ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលថា៖ "អ្នករាល់គ្នាមានតម្លៃលើសចាបជាច្រើនទៅទៀត" (លក ១២,៦-៧) ឬ "មនុស្សមានតម្លៃលើសចៀមឆ្ងាយណាស់!" (មថ ១២,១២)។

៣៤៣-មនុស្សជាកំពូលនៃស្នាព្រះហស្ដរបស់ព្រះជាម្ចាស់។ ព្រះគម្ពីរសម្ដែងសេចក្ដីនេះដោយបំបែកការបង្កើតរបស់មនុស្សពីការបង្កើតរបស់សត្វលោកផ្សេង (កណ ១,២៦)។

៣៤៤-សត្វលោករួមសាមគ្គីគ្នា ដ្បិតពួកគេមានព្រះបង្កើតតែមួយដែលត្រាស់ហៅគេឲ្យទទួលសិរីរុងរឿងរបស់ព្រះអង្គ។

សូមលើកតម្កើងព្រះអម្ចាស់ក្នុងគ្រប់សត្វលោកទាំងអស់របស់ព្រះអង្គ ជាពិសេសព្រះអាទិត្យជាបងប្រុសដែលព្រះអង្គចាត់ឲ្យបំភ្លឺយើងគ្រប់គ្នា ប្រកបដោយសោភណភាពរស្មីភ្លឺផ្លេកចែងចាំង ជានិមិត្តរូបនៃព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់បំផុត...

សូមលើកតម្កើងព្រះអម្ចាស់នៃខ្ញុំ ចំពោះបងស្រីទឹក ដែលមានប្រយោជន៍លើសលប់ សុភាពរាបសា មានតម្លៃថ្លៃថ្លា និងបរិសុទ្ធ...

សូមលើកតម្កើងព្រះអម្ចាស់នៃខ្ញុំ ចំពោះបងស្រីផែនដី ជាមាតារបស់យើង ដែលបីបមថ្នមបំពេ និងចិញ្ចឹមយើង និងផ្ដល់ផលិតផលផ្លែគ្រប់បែបយ៉ាង មានទាំងបុប្ផាចំរុះព័ណ ស្មៅព្រៃព្រឹក្សា...

សូមលើកតម្កើង និងប្រទានពរថ្វាយព្រះអម្ចាស់នៃខ្ញុំ សូមអរព្រះគុណព្រះអង្គ និងបម្រើព្រះអង្គ ដោយមានចិត្តសុភាពរាបសាជាទីបំផុត (សន្ដៈ ហ្វ្រង់ស័រ នៃអាស៊ីស៊ី)។

៣៤៥-ថ្ងៃសប្ប័ទជាថ្ងៃចុងក្រោយនៃស្នាព្រះហស្ដរបស់ព្រះជាម្ចាស់។ តាមអត្ថបទដ៏វិសុទ្ធ "ព្រះជាម្ចាស់បង្ហើយកិច្ចការដែលព្រះអង្គបានធ្វើ" "មេឃ និងដីចប់សព្វគ្រប់ហើយ" ហើយនៅថ្ងៃទីប្រាំពីរព្រះជាម្ចាស់ "ឈប់សម្រាក" ប្រទានពរឲ្យថ្ងៃទីប្រាំពីរ និងញែកថ្ងៃនេះឲ្យបានវិសុទ្ធ (កណ ២,១-៣)។ ព្រះបន្ទូលនេះមានការប្រៀនប្រដៅជាច្រើនដើម្បីការសង្គ្រោះរបស់យើងដូចជា៖

> ៣៤៦-ពេលព្រះជាម្ចាស់បង្កើតពិភពលោកព្រះអង្គក៏បានដាក់គ្រឹះ និងវិន័យដែលនៅស្ថិតស្ថេរជានិច្ច (ហប ៤,៣-៤)។ គ្រីស្ដបរិស័ទអាចពឹងផ្អែកលើគ្រឹះ និងវិន័យនោះបានដែលជាទីសម្គាល់ និងបញ្ចាំនៃព្រះហឫទ័យដែលគ្មានអ្វីអាចប្រែប្រួលបាននៃសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់ (យរ ៣១,៣៥-៣៧; ៣៣,១៩-២៦)។ រីឯមនុស្សវិញគេត្រូវតែនៅស្មោះត្រង់នឹងគ្រឹះនោះ និងគោរពវិន័យដែលព្រះជាម្ចាស់បានឆ្លាក់ចារទុកហើយ។
>
> ៣៤៧-ព្រះជាម្ចាស់បានបង្កើតសត្វលោកដើម្បីថ្ងៃសប្ប័ទ គឺដើម្បីឲ្យសត្វលោកលើកដម្កើង និងក្រាបថ្វាយបង្គំព្រះអង្គ។ ការលើកតម្កើងព្រះជាម្ចាស់ជាលក្ខណៈចាំបាច់នៃសត្វលោក (កណ ១,១៤)។ តាមក្បួនច្បាប់របស់សន្ដៈ បេណេឌីក "គ្មានអ្វីប្រសើរជាងលើកតម្កើងព្រះជាម្ចាស់" ដែលជាកិច្ចការសំខាន់ជាទីបំផុតរបស់មនុស្សលោក។
>
> ៣៤៨-ក្នុងធម្មវិន័យរបស់ជនជាតិអ៊ីស្រាអែលថ្ងៃសប្ប័ទសំខាន់ជាងគេ។ ពេលយើងគោរពធម្មវិន័យយើងក៏គាប់ព្រះប្រាជ្ញាញាណ និងព្រះបំណងរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានសម្ដែងនៅពេលព្រះអង្គបានបង្កើតពិភពលោក។

៣៤៩-ថ្ងៃទីប្រាំបី៖ សម្រាប់យើងថ្ងៃថ្មីមួយទៀតបានរះឡើង គឺថ្ងៃដែលព្រះយេស៊ូមានជីវិតថ្មី។ ថ្ងៃទីប្រាំពីរ ព្រះជាម្ចាស់បង្ហើយបង្កើតពិភពលោកទីមួយ ហើយថ្ងៃទីប្រាំបីព្រះអង្គចាប់ផ្ដើមបង្កើតសាជាថ្មីម្ដងទៀត។ ហេតុនេះ ពេលព្រះជាម្ចាស់សង្គ្រោះមនុស្សលោកក្នុងអង្គព្រះគ្រីស្ដដែលមានព្រះជន្មរស់ឡើងវិញ ព្រះអង្គក៏បំពេញស្នាព្រះហស្ដដំបូងរបស់ព្រះអង្គ។ ព្រះជាម្ចាស់បង្កើតពិភពលោកថ្មីនៅក្នុងអង្គព្រះគ្រីស្ដ គឺទ្រង់បង្គ្រប់អត្ថន័យជាកំពូល និងប្រទានសិរីរុងរឿងដល់ពិភពលោកដំបូង (MR)។

## សង្ខេប

៣៥០-ពួកទេវទូតជាសត្វលោកខាងវិញ្ញាណ ដែលតែងតែលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ហើយដែលជួយបម្រើព្រះអង្គក្នុងគម្រោងការសង្គ្រោះសត្វលោកឯទៀតៗ៖ "ពួកទេវទូតរួមសហការជាមួយអ្វីដែលល្អសម្រាប់យើង" (សន្ដ: ថូម៉ាស នៃអាកាំង)។

៣៥១-ពួកទេវទូតស្ថិតនៅជាមួយព្រះគ្រីស្ដ ជាព្រះអម្ចាស់របស់ពួកលោក។ ពួកលោកបម្រើព្រះអង្គជាពិសេសដោយជួយបំពេញបេសកកម្មរបស់ព្រះអង្គក្នុងការសង្គ្រោះមនុស្សលោក។

៣៥២-ព្រះសហគមន៍គោរពប្រណិប័តន៍ពួកទេវទូត ដែលជួយព្រះសហគមន៍នេះ ឲ្យធ្វើបូជនីយេសចរណ៍ក្នុងលោកនេះ ហើយដែលថែរក្សាគាំពារមនុស្សគ្រប់រូប។

៣៥៣-ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យសត្វលោកមានពូជសាសន៍ប្លែកៗពីគ្នា ឲ្យមានសប្បុរសធម៌ពឹងពាក់លើគ្នាទៅវិញទៅមក និងឲ្យពួកគេមានរបៀបរៀបរយ។ ព្រះអង្គបានតម្រូវទុកជាមុននូវអ្វីៗទាំងអស់ ដើម្បីជាប្រយោជន៍ដល់មនុស្សលោក។ ព្រះអង្គតម្រូវឲ្យមនុស្ស និងអ្វីៗទាំងអស់តាមរយៈមនុស្សឲ្យទទួលសិរីរុងរឿងរបស់ព្រះអង្គ។

៣៥៤-គោលការណ៍នៃព្រះប្រាជ្ញាញាណ និងគ្រឹះមួយនៃសីលធម៌ គឺការគោរពច្បាប់ដែលមានក្នុងការបង្កើត និងទំនាក់ទំនងដែលហូរចេញមកពីលក្ខណៈធម្មជាតិនៃអ្វីៗទាំងអស់។

## កថាខណ្ឌទី៦៖ មនុស្សលោក

៣៥៥-"ព្រះជាម្ចាស់បានបង្កើតមនុស្សជារូបតំណាងរបស់ព្រះអង្គ ព្រះអង្គបានបង្កើតគេឲ្យមានលក្ខណៈដូចព្រះអង្គ ទ្រង់បានបង្កើតគេជាបុរសជាស្ត្រី" (កណ ១,២៧)។ មនុស្សមានលក្ខណៈពិសេសក្នុងចំណោមសត្វលោកទាំងអស់គឺ "មនុស្សជាតំណាងរបស់ព្រះជាម្ចាស់" (១.) នៅក្នុងខ្លួនគេ គេធ្វើឲ្យពិភពខាងវិញ្ញាណ និងពិភពខាងរូបកាយរួមជាមួយគ្នា (២.) ហើយមនុស្ស "ជាបុរសជាស្ត្រី" (៣.)។ ព្រះជាម្ចាស់បានតែងតាំងមនុស្សជាមិត្តសម្លាញ់របស់ព្រះអង្គ (៤.)។

### ១-"មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់"

៣៥៦-ក្នុងចំណោមសត្វលោកដែលមើលឃើញមានតែមនុស្សដែល "អាចស្គាល់ និងស្រឡាញ់ព្រះបង្កើតរបស់គេ" (GS ១២,៣)។ "នៅលើផែនដីមនុស្សជាសត្វលោកតែមួយគត់ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យបង្កើតដើម្បីខ្លួនឯង" (GS ២៤,៣)។ មានតែមនុស្សទេ ដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យទទួលព្រះជន្មរបស់ព្រះអង្គដោយស្គាល់ និងស្រឡាញ់ព្រះអង្គជាមូលដ្ឋានគ្រឹះនៃឋានៈដ៏ថ្លៃថ្នូររបស់គេ។

ហេតុអ្វីក៏ព្រះអង្គបង្កើតមនុស្សលោកឲ្យមានឋានៈដ៏ថ្លៃថ្នូរខ្ពង់ខ្ពស់ម្ល៉េះ? ព្រះអង្គបានមើលឃើញព្រះអង្គផ្ទាល់ក្នុងសត្វលោករបស់ព្រះអង្គដោយសេចក្ដីស្រឡាញ់ដែលមិនអាចប្រៀបផ្ទឹមបាន ហើយព្រះអង្គបានជាប់ព្រះហឫទ័យនឹងសត្វលោកនេះ ដ្បិតព្រះអង្គបានបង្កើតគេដោយសារសេចក្ដីស្រឡាញ់។ ដោយសារសេចក្ដីស្រឡាញ់ ព្រះអង្គបានប្រទានឲ្យគេអាចភ្លក់រសជាតិនៃសម្បត្តិអស់កល្បជានិច្ចរបស់ព្រះអង្គ (សន្តី កាតឺរីន នៅស៊ីយ៉ែន)។

៣៥៧-ដោយសារគេជាតំណាងរបស់ព្រះជាម្ចាស់សត្វលោកនេះមានឋានៈជាមនុស្ស។ គេមិនគ្រាន់តែជាវត្ថុមួយថែមទាំងជាមនុស្សម្នាក់ដែរ។ មនុស្សអាចស្គាល់ខ្លួនឯងធ្វើជាម្ចាស់ការលើខ្លួនឯង ផ្ដល់ខ្លួនឯង និងរួមជាមួយអ្នកដទៃបាន ហើយព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យចងសម្ព័ន្ធមេត្រីជាមួយព្រះបង្កើតរបស់គេដោយថ្វាយខ្លួន និងធ្វើជីវិតទាំងស្រុងទៅលើព្រះអង្គ ដោយក្ដីស្រឡាញ់ដែលគ្មាននរណាម្នាក់ផ្សេងទៀតអាចធ្វើបាន។

៣៥៨-ព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់សម្រាប់មនុស្ស ហើយបានបង្កើតមនុស្សដើម្បីបម្រើ និងស្រឡាញ់ព្រះអង្គ ហើយថ្វាយសត្វលោកទាំងអស់ទៅព្រះអង្គវិញ។

តើសត្វលោកណាទៅ ដែលនឹងកើតមកដោយមានព្រះហឫទ័យប្រណីសន្ដោសបែបនេះ? គឺជាមនុស្ស ជារូបដ៏ខ្ពង់ខ្ពស់ និងគួរឲ្យសរសើរ ដែលមានតម្លៃជាងសត្វលោកឯទៀតៗទាំងអស់ ចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់៖ ព្រះអង្គបានបង្កើតមេឃ ដី សមុទ្រ និងអ្វីៗទាំងអស់សព្វសារពើសម្រាប់មនុស្ស ហើយដើម្បីសង្គ្រោះគេ ទ្រង់បានគិតគូរយ៉ាងល្អិតល្អន់ជាទីបំផុតរហូតដល់មិនប្រោសប្រណីព្រះបុត្រាតែមួយព្រះអង្គគត់។ ព្រះជាម្ចាស់បានខិតខំឥតឈប់ឈរ ដើម្បីឲ្យមនុស្សឡើងដល់ព្រះអង្គ និងអង្គុយខាងស្ដាំព្រះអង្គ (សន្តៈ យ៉ូហាន គ្រីសូស្តូម)។

៣៥៩-"តាមពិត ប្រសិនបើយើងចង់យល់ខ្លះៗអំពីអាថ៌កំបាំងរបស់មនុស្ស យើងត្រូវតែរិះគិតក្នុងពន្លឺនៃគម្រោងការដ៏អស្ចារ្យរបស់ព្រះបន្ទូលដែលប្រសូតជាមនុស្ស គ្មានផ្លូវផ្សេងទៀតទេ" (GS ២២,១)។

សន្តៈ ប៉ូល ប្រាប់ឲ្យយើងដឹងថា មនុស្សពីរនាក់ជាប្រភពនៃមនុស្សជាតិ គឺលោក អដាំ និងព្រះគ្រីស្ត... អដាំទីមួយត្រូវបានបង្កើតឡើង ជាមនុស្សម្នាក់ ដែលបានទទួលជីវិត អដាំទីពីរ គឺជាមនុស្សម្នាក់ខាងវិញ្ញាណ ដែលផ្ដល់ជីវិត។ មនុស្សទីពីរបានបង្កើតមនុស្សទីមួយ ដោយផ្ដល់ព្រលឹងឲ្យគេមានជីវិត... អដាំទីពីរបានសូនអដាំទីមួយធ្វើជារូបតំណាងរបស់គេ។ ចាប់តាំងពីពេលនោះមក គេបានទទួលមុខងារ និងទទួលឈ្មោះដើម្បីកុំឲ្យបាត់បង់រូបតំណាងនេះ។ អដាំទីមួយបានចាប់ផ្ដើម អដាំទីពីរនឹងមិនអាចបញ្ចប់បាន ដ្បិតអដាំទីពីរ គឺពិតជាអដាំទីមួយ ដូចខ្លួនគេពោលថា៖ "ខ្ញុំជាអ្នកទីមួយ និងជាអ្នកចុងក្រោយ" (សន្តៈ សិលា គ្រីសូឡូង)។

៣៦០-ដោយសារមានប្រភពតែមួយ មនុស្សជាតិឯកភាពរួមគ្នាដ្បិតព្រះជាម្ចាស់ "ប្រទានឲ្យប្រជាជាតិនានាកើតចេញមកពីមនុស្សតែម្នាក់ ហើយឲ្យគេរស់នៅពាសពេញលើផែនដីទាំងមូល" (កក ១៧,២៦)។

គឺជាទស្សនៈដ៏អស្ចារ្យមួយ ដែលនាំឲ្យយើងមើលឃើញមនុស្សជាតិ ក្នុងឯកភាព ដែលមានប្រភពក្នុងអង្គព្រះជាម្ចាស់ (...) ក្នុងឯកភាពនៃធម្មជាតិដូចៗគ្នា ដែលផ្សំជារូបរាងកាយ និងព្រលឹងវិញ្ញាណ ក្នុងឯកភាពនៃទីបញ្ចប់ភ្លាមៗ និងបេសកកម្មរបស់គេក្នុងពិភពលោក ក្នុងឯកភាពនៃទីលំនៅរបស់គេ៖ ផែនដី សម្បត្តិទ្រព្យដែលមនុស្សលោកមានសិទ្ធប្រើប្រាស់ ដើម្បីទ្រទ្រង់ និងអភិវឌ្ឍជីវិត តាមច្បាប់ធម្មជាតិ ក្នុងឯកភាពនៃទីបញ្ចប់លើសពីច្បាប់ធម្មជាតិ គឺព្រះជាម្ចាស់ផ្ទាល់ ដែលមនុស្សគ្រប់រូបត្រូវតែឈានទៅដល់ ក្នុងឯកភាពនៃមធ្យោបាយជាច្រើន ដើម្បីឈានទៅរកទីបញ្ចប់នេះ (...) ក្នុងឯកភាពនៃការលោះដែលព្រះគ្រីស្តបានធ្វើដើម្បីមនុស្សទាំងអស់ (សម្ដេចប៉ាបពីយូសទី១២; NA ១)។

៣៦១-"វិន័យនោះចែងថាមនុស្សរួមសាមគ្គីដោយក្ដីស្រឡាញ់" (NA ១) ធានាឲ្យយើងដឹងថាទោះបីមនុស្សខុសប្លែកពីគ្នាទៅវិញទៅមកមានវប្បធម៌ផ្សេងៗពីគ្នា និងមានពូជសាសន៍ផ្សេងពីគ្នាយ៉ាងណាក៏ដោយ ក៏មនុស្សទាំងអស់ពិតជាបងប្អូនមែន។

## ២-មនុស្សជាបុគ្គលតែមួយទាំងរូបកាយទាំងវិញ្ញាណ

៣៦២-មនុស្សដែលមានលក្ខណៈដូចព្រះជាម្ចាស់ជាបុគ្គលដែលមានទាំងរូបកាយ ទាំងវិញ្ញាណផង។ អត្ថបទគម្ពីរសម្ដែងលក្ខណៈនេះដោយប្រើនិមិត្តរូបខ្លះៗដូចជា "ព្រះអម្ចាស់បានយកធូលីដីមកសូនធ្វើជាមនុស្ស រួចព្រះអង្គផ្លុំដង្ហើមជីវិតតាមរន្ធច្រមុះគេ មនុស្សក៏មានជីវិតរស់ឡើង" (កណ ២,៧)។ ដូច្នេះព្រះជាម្ចាស់មានព្រះបំណងបង្កើតមនុស្សទាំងមូល។

៣៦៣-នៅក្នុងព្រះគម្ពីរដ៏វិសុទ្ធពាក្យព្រលឹងសំដៅលើដំណើរជីវិតរបស់មនុស្ស (មថ ១៦,២៥-២៦) ឬមនុស្សទាំងស្រុង (កក ២,៤១)។ ប៉ុន្តែពាក្យនេះសំដៅលើអ្វីដែលស្ថិតនៅក្នុងមនុស្សយ៉ាងជិតស្និទ្ធ (មថ ២៦,៣៨; យហ ១២,២៧) ដែលមានតម្លៃបំផុត (មថ ១០,២៨; ២មបា ៦,៣០) និងមានលក្ខណៈពិសេសរបស់គេ គឺរូបតំណាងរបស់ព្រះជាម្ចាស់៖ ពាក្យ "ព្រលឹង" បានសេចក្ដីថាគោលខាងវិញ្ញាណរបស់មនុស្ស។

៣៦៤-រូបកាយរួមចំណែកក្នុងលក្ខណៈដ៏ថ្លៃថ្នូររបស់មនុស្សដែលជា "តំណាងរបស់ព្រះជាម្ចាស់"។ មនុស្សជារូបកាយ ដ្បិតព្រលឹងវិញ្ញាណធ្វើឲ្យរូបកាយនោះមានចលនា គឺព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងមូលឲ្យទៅជាព្រះដំណាក់របស់ព្រះវិញ្ញាណនៅក្នុងអង្គព្រះគ្រីស្ដ (១ករ ៦,១៩-២០; ១៥,៤៤-៤៥)។

"ទោះបីមនុស្សមានរូបកាយ និងវិញ្ញាណ តែក៏ជាអង្គតែមួយដែរ។ ក្នុងឋានៈខ្លួនមានរូបកាយ មនុស្សយើងសរុបធាតុ និងអ្វីៗទាំងអស់ដែលមានក្នុងពិភពលោក ដូច្នេះអ្វីៗទាំងនោះអាចលើកតម្កើងសិរីរុងរឿងព្រះបង្កើតរបស់ខ្លួនដោយសេរី តាមរយៈមនុស្សជាកំពូលនៃពិភពលោក។ ហេតុនេះ ហាមផ្ដាច់មនុស្សយើងមិនត្រូវមាក់ងាយជីវិតរូបកាយជាដាច់ខាត ផ្ទុយទៅវិញ មនុស្សយើងត្រូវតែលើកតម្លៃនៃរូបកាយ និងគោរពរូបកាយដែលព្រះជាម្ចាស់បង្កើតមក ហើយដែលត្រូវទទួលជីវិតថ្មីដ៏រុងរឿងនៅពេលចុងក្រោយបំផុត" (GS ១៤,១)។

៣៦៥-ព្រលឹង និងរូបកាយរួមរស់ជាមួយគ្នាយ៉ាងជ្រាលជ្រៅជាទីបំផុត បានជាយើងត្រូវចាត់ទុកព្រលឹងដូចជា "រូបរាង" របស់រូបកាយ (DS ៩០២) គឺដោយសារព្រលឹងវិញ្ញាណរូបកាយដែលជារូបធាតុ ជារូបកាយដ៏រស់រវើករបស់មនុស្ស។ នៅក្នុងមនុស្សវិញ្ញាណ និងរូបធាតុមិនមែនជាសភាពពីរទេ តែវិញ្ញាណ និងរូបកាយរួមគ្នាជាសភាពតែមួយ។

៣៦៦-ព្រះសហគមន៍ប្រៀនប្រដៅថាព្រះជាម្ចាស់បង្កើតព្រលឹងវិញ្ញាណនីមួយៗភ្លាមៗ (DS ៣៨៩៦; SPF ៨) មិនមែនឪពុកម្ដាយទេដែលបាន "ផលិត" ព្រលឹងវិញ្ញាណ។ ព្រះសហគមន៍បង្រៀនឲ្យយើងដឹងទៀតថា ព្រលឹងវិញ្ញាណមានជីវិតអមតៈមិនស្លាប់នៅពេលបែកចេញពីរូបកាយ ពេលមនុស្សស្លាប់ហើយនឹងរួមរស់ជាមួយរូបកាយម្ដងទៀតនៅពេលមនុស្សទាំងឡាយនឹងមានជីវិតថ្មី។

៣៦៧-ជួនកាលព្រលឹង និងវិញ្ញាណទទួលអត្ថន័យផ្សេងពីគ្នា។ សន្តៈ ប៉ូល ទូលអង្វរព្រះជាម្ចាស់ឲ្យ "ព្រះអង្គថែរក្សាខ្លួនបងប្អូនទាំងមូល ទាំងវិញ្ញាណ ទាំងព្រលឹង ទាំងរូបកាយឲ្យបានស្អាតឥតសៅហ្មងនៅថ្ងៃព្រះយេស៊ូគ្រីស្ដជាអម្ចាស់នៃយើងយាងមក" (១ថស ៥,២៣)។ ព្រះសហគមន៍ប្រៀនប្រដៅថាការបែងចែកនេះមិននាំឲ្យព្រលឹងចែកជាពីរទេ (DS ៦៥៧) គឺ "វិញ្ញាណ" មានន័យថាព្រះជាម្ចាស់មានគោលដៅឲ្យមនុស្សមានជីវិតអមតៈតាំងពីកំណើតមក (DS ៣០០៥; GS ២២,៥) ហើយព្រលឹងរបស់គេអាចឡើងទៅរួមជាមួយព្រះជាម្ចាស់បានដែរ (DS ៣៨៩១)។

៣៦៨-ការបញ្ជូនបន្តខាងវិញ្ញាណរបស់ព្រះសហគមន៍សង្កត់ធ្ងន់ពីលើចិត្តគំនិតដែរ គឺតាមព្រះគម្ពីរ "ទីជម្រៅចិត្តគំនិត" (យរ ៣១,៣៣) ជាទីលំនៅដែលមនុស្សសម្រេចធ្វើជីវិតលើព្រះជាម្ចាស់ឬទេ (ទក ៦,៥; ២៩,៣; អគ ៣៦,២៦; មថ ៦,២១; លក ៨,១៥; រម ៥,៥)។

### ៣-"ព្រះជាម្ចាស់បង្កើតមនុស្សជាបុរសជាស្ត្រី"

#### ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សប្រុស និងមនុស្សស្រីស្មើគ្នាផង ខុសប្លែកពីគ្នាផង

៣៦៩-ព្រះជាម្ចាស់បានបង្កើតបុរស និងស្ត្រី គឺព្រះអង្គមានព្រះបំណងឲ្យគេមានឋានៈស្មើគ្នា ដ្បិតអ្នកទាំងពីរជាមនុស្សទោះបីខុសប្លែកពីគ្នាក្តី សភាពមនុស្សមានបុរស និងស្ត្រី។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សជាបុរសជាស្ត្រី។ សភាពការណ៍នេះល្អប្រសើរហើយ។ មនុស្សប្រុស និងមនុស្សស្រីមានឋានៈថ្លៃថ្នូរបំផុតដែលមិនអាចរលាយបាត់ទេ ហើយដែលមកពីព្រះជាម្ចាស់ជាព្រះបង្កើតពួកគេតែម្តង (កណ ២,៧.២២)។ មនុស្សប្រុស និងមនុស្សស្រីជា "រូបតំណាងរបស់ព្រះជាម្ចាស់" ដោយមានឋានៈស្មើគ្នា។ អ្នកទាំងពីរឆ្លុះបញ្ចាំងនូវព្រះប្រាជ្ញាញាណ និងសប្បុរសធម៌របស់ព្រះជាម្ចាស់។

៣៧០-ព្រះជាម្ចាស់មិនមែនជាតំណាងរបស់មនុស្សទាល់តែសោះ។ ព្រះអង្គគ្មានលក្ខណៈជាបុរសជាស្ត្រីទេ ទ្រង់ជាវិញ្ញាណសុទ្ធសាធដែលគ្មានភេទឡើយ។ ប៉ុន្តែ "លក្ខណៈសម្បត្តិ" របស់មនុស្សប្រុស និងមនុស្សស្រីឆ្លុះបញ្ចាំងនូវភាពល្អឥតខ្ចោះឥតព្រំដែនរបស់ព្រះជាម្ចាស់ គឺលក្ខណៈជាមាតា (អស ៤៩,១៤-១៥; ៦៦,១៣; ទន ១៣១,២-៣) ជាបិតា និងជាគូស្វាមីភរិយា (ហស ១១,១-៤; យរ ៣,៤-១៩)។

#### ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងមនុស្សស្រី "ចំពោះគ្នាទៅវិញទៅមក អ្នកទាំងពីររួមឯកភាពជាមួយគ្នា"

៣៧១-ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងមនុស្សស្រីនៅពេលជាមួយគ្នា ហើយដើម្បីគ្នាទៅវិញទៅមក។ តាមអត្ថបទខ្លះនៃព្រះគម្ពីរដ៏វិសុទ្ធព្រះបន្ទូលរបស់ព្រះជាម្ចាស់បញ្ជាក់សេចក្តីនោះ៖ "បើមនុស្សប្រុសនៅតែឯង ដូច្នេះមិនស្រួលទេ។ យើងនឹងបង្កើតម្នាក់ទៀតឲ្យជួយ និងបានជាគ្នា" (កណ ២,១៨)។ គ្មានសត្វណាមួយអាចធ្វើ "ជាគ្នា" នឹងមនុស្សទេ (កណ ២,១៩-២០)។ ពេលព្រះជាម្ចាស់ "សូន" មនុស្សស្រីចេញពីឆ្អឹងជំនីររបស់មនុស្សប្រុសធ្វើឲ្យគេស្ងើចសរសើរដោយក្តីស្រឡាញ់ និងរួមជាមួយស្ត្រីនោះថា៖ "លើកនេះពិតជាឆ្អឹងដែលកើតចេញពីឆ្អឹងអញជាសាច់ដែលកើតចេញពីសាច់អញ" (កណ ២,២៣)។ មនុស្សប្រុសយល់ឃើញថាមនុស្សស្រីជា "ខ្លួនឯង" មួយផ្សេងទៀត ហើយទាំងពីរអ្នករួមរស់ជាមួយគ្នាក្នុងសភាពជាមនុស្សតែមួយ។

៣៧២-ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងមនុស្សស្រី "ដើម្បីគ្នាទៅវិញទៅមក"។ ព្រះជាម្ចាស់មិនបានបង្កើតគេ "មិនគ្រប់លក្ខណៈ" ឬ "តែពាក់កណ្តាល" ទេ ព្រះអង្គបានបង្កើតគេឲ្យរួមរស់ជាមួយគ្នាជាជំនួយសម្រាប់គ្នាទៅវិញទៅមក ដ្បិតពួកគេស្មើគ្នាក្នុងសភាពជាមនុស្សផង ("ពិតជាឆ្អឹងដែលកើតចេញពីឆ្អឹងអញ") និងបំពេញគ្នាទៅវិញទៅមកក្នុងសភាពជាបុរសជាស្ត្រី។ ក្នុងអាពាហ៍ពិពាហ៍ព្រះជាម្ចាស់ផ្សំផ្គុំគេដើម្បីឲ្យគេអាចបន្តជីវិត ដោយ "ធ្វើជារូបកាយតែមួយ" (កណ ២,២៤)៖ "ចូរបង្កើតកូនចៅឲ្យបានកើនឡើងច្រើនពាសពេញលើផែនដី" (កណ ១,២៨)។ មនុស្សប្រុស និងមនុស្សស្រីដែលជាស្វាមីភរិយា និងមាតាបិតារួមសហការយ៉ាងពិសេសជាមួយព្រះជាម្ចាស់ដោយបន្តជីវិតដល់កូនចៅរបស់គេ (ហស ១១,១-៤; យរ ៣,៤-១៩)។

៣៧៣-តាមគម្រោងការរបស់ព្រះជាម្ចាស់ ព្រះអង្គក៏ត្រាស់ហៅមនុស្សប្រុស និងមនុស្សស្រីឲ្យ "ត្រួតត្រា" ផែនដី (កណ ១,២៨) ដូចជា "អ្នកបម្រើ" របស់ព្រះអង្គ។ មនុស្សមិនត្រូវត្រួតត្រាផែនដីនេះ ដូចជាអ្នកប្រើអំណាចផ្ដាច់ការ ដែលបំផ្លាញអ្វីៗទាំងអស់ទេ។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សប្រុស និងមនុស្សស្រីឲ្យចូលរួមជាមួយព្រះជាម្ចាស់ ថែរក្សាសត្វលោកផ្សេងទៀត ហើយដែល "ស្រឡាញ់សត្វលោកទាំងអស់" (ប្រាញ ១១,២៤) ទើបគេទទួលខុសត្រូវលើពិភពលោកដែលព្រះជាម្ចាស់ប្រទានឲ្យមក។

### ៤-មនុស្សនៅស្ថានបរមសុខ

៣៧៤-ព្រះជាម្ចាស់មិនគ្រាន់តែបង្កើតមនុស្សដើមដំបូងឲ្យមានលក្ខណៈល្អប្រសើរទេ ទ្រង់ក៏បានតែងតាំងគេធ្វើជាមិត្តសម្លាញ់របស់ព្រះអង្គដោយរួមយ៉ាងសុខសាន្តជាមួយខ្លួនឯង និងជាមួយសត្វលោកទាំងអស់ដែរ។ មានតែសិរីរុងរឿងនៃការបង្កើតថ្មីនៅក្នុងអង្គព្រះគ្រិស្តទេ ដែលប្រសើរជាងសេចក្ដីសុខសាន្តនេះ។

៣៧៥-ដោយបកស្រាយត្រឹមត្រូវអត្ថបទនៃព្រះគម្ពីរដែលប្រើនិមិត្តរូបជាច្រើនក្រោមពន្លឺនៃសម្ព័ន្ធមេត្រីថ្មី និងការបញ្ជូនបន្តដែលជួយបំភ្លឺព្រះសហគមន៍ប្រៀនប្រដៅថាឪពុកម្ដាយដើមរបស់យើង គឺលោកអដាំ និងនាងអេវ៉ា បានកើតមកដោយជាមនុស្ស "ដ៏វិសុទ្ធ និងសុចរិតតាំងពីដើម" (DS ១៥១១)។ ព្រះជាម្ចាស់ប្រោសប្រណីភាពដ៏វិសុទ្ធដើមឲ្យទាំងពីរនាក់ ដើម្បីឲ្យគេ "ទទួលព្រះជន្មរបស់ព្រះអង្គ" (LG ២)។

៣៧៦-ព្រះជាម្ចាស់ប្រោសប្រណីមនុស្សបែបនេះ ដើម្បីជួយសម្រួលលក្ខណៈទាំងអស់នៃជីវិតរបស់មនុស្សលោក។ មនុស្សមិនត្រូវស្លាប់ (កណ ២,១៧; ៣,១៩) ឬមិនត្រូវរងទុក្ខលំបាក (កណ ៣,១៩) ទាល់តែគេរួមរស់ជាមួយព្រះជាម្ចាស់យ៉ាងស្និទ្ធស្នាល។ តាមសភាពការណ៍ដើមនេះមនុស្សទទួលសេចក្ដីសុខសាន្តជាមួយនឹងខ្លួនឯង សេចក្ដីសុខសាន្តរវាងមនុស្សប្រុស និងមនុស្សស្រី (កណ ២,២៥) និងសេចក្ដីសុខសាន្តរវាងប្ដីប្រពន្ធដើម និងសត្វលោកទាំងអស់។

៣៧៧-តាំងពីដើមព្រះជាម្ចាស់ឲ្យមនុស្ស "ត្រួតត្រា" ផែនដីបានសេចក្ដីថាមនុស្សត្រូវតែត្រួតត្រាលើខ្លួនឯងសិន។ មនុស្សបានគ្រប់លក្ខណៈ ព្រោះមិនជាប់ជំពាក់នឹងកិលេសតណ្ហា (១យហ ២,១៦) ដែលបង្ក្រាបគេឲ្យមានចិត្តវក់វីនឹងគ្រឿងសប្បាយ មានចិត្តលោភលន់នឹងទ្រព្យសម្បត្តិលោកីយ៍ និងលើកតម្កើងអួតបំប៉ោងខ្លួនឯងដោយគ្មានហេតុផលឡើយ។

៣៧៨-ព្រះជាម្ចាស់បានយកមនុស្សទៅដាក់ក្នុងសួនឧទ្យាន (កណ ២,៨) ជាសញ្ញាសម្គាល់ថាមនុស្សជាមិត្តសម្លាញ់របស់ព្រះអង្គ។ មនុស្សនៅក្នុងសួនដើម្បីឲ្យគេ "ភ្ជួររាស់ និងថែរក្សា" សួននោះ (កណ ២,១៥) គឺព្រះជាម្ចាស់ប្រគល់ការងារឲ្យមនុស្ស ដើម្បីឲ្យមនុស្សប្រុស និងមនុស្សស្រីសហការជាមួយព្រះអង្គក្នុងការកែសម្រួលការបង្កើតដែលមើលឃើញ។ ដោយប្រគល់ការងារឲ្យមនុស្សធ្វើតាមព្រះជាម្ចាស់ មិនដាក់ទោសពួកគេទេ (កណ ៣,១៧-១៩)។

៣៧៩-នៅពេលដែលឪពុកម្ដាយដើមនឹងប្រព្រឹត្តអំពើបាប ភាពសុខដុមរមនាដែលព្រះជាម្ចាស់បានគ្រោងទុកជាមុនសម្រាប់មនុស្សនឹងរលាយឲ្យបាត់បង់អស់ទៅ។

## សង្ខេប

៣៨០-"បពិត្រព្រះជាម្ចាស់! ព្រះអង្គបានបង្កើតមនុស្សលោកឲ្យមានលក្ខណៈដូចព្រះអង្គ ហើយបានប្រគល់សកលលោក ដើម្បីឲ្យគេគ្រប់គ្រងលើអ្វីៗទាំងអស់ ដោយបម្រើព្រះអង្គជាអ្នកបង្កើតគេ" (MR ធម៌ប្រសិទ្ធិព្រះកាយទី៤)។

៣៨១-ព្រះជាម្ចាស់តម្រូវមនុស្សទុកជាមុនឲ្យទៅជារូបតំណាងរបស់ព្រះបុត្រាប្រសូតជាមនុស្ស "ជាតំណាងរបស់ព្រះដែលមើលមិនឃើញ" (កូឡ ១,១៥) ដើម្បីឲ្យព្រះគ្រីស្តទៅជារៀមច្បងក្នុងបណ្តាបងប្អូនជាច្រើន (អភ ១,៣-៦) (រម ៨,២៩)។

៣៨២-មនុស្ស "មានរូបកាយ និងវិញ្ញាណ តែជាអង្គតែមួយ" (GS ១៤,១)។ លទ្ធិនៃជំនឿអះអាងថា ព្រះជាម្ចាស់ផ្ទាល់បានបង្កើតព្រលឹងវិញ្ញាណ ដែលមិនចេះស្លាប់។

៣៨៣-"ព្រះជាម្ចាស់មិនបានបង្កើតមនុស្សឲ្យនៅឯកឯងទេ តាំងពីដើមរៀងមក "ព្រះអង្គបង្កើតមនុស្សជាបុរសជាស្ត្រី" (កណ ១,២៧)។ សង្គមរបស់បុរស និងស្ត្រីជារបៀបដើមដំបូងបញ្ជាក់ថា បុគ្គលត្រូវតែរួបរួមគ្នា" (GS ១២,៤)។

៣៨៤-ព្រះជាម្ចាស់សម្តែងឲ្យយើងដឹងថា មុនធ្លាក់ខ្លួនជាអ្នកបាប បុរស និងស្ត្រីជាបុគ្គលដ៏វិសុទ្ធ និងសុចរិត។ ដោយសារពួកគេរួមមេត្រីភាពជាមួយព្រះជាម្ចាស់ ពួកគេរស់នៅពោរពេញដោយសុភមង្គលនៅស្ថានបរមសុខ។

## កថាខណ្ឌទី៧៖ មនុស្សធ្លាក់ខ្លួនជាអ្នកបាប

៣៨៥-ព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរសឥតព្រំដែន ហើយស្នាព្រះហស្តរបស់ព្រះអង្គក៏ល្អប្រសើរបំផុត។ ប៉ុន្តែគ្មាននរណាម្នាក់អាចគេចផុតពីបទពិសោធន៍នៃទុក្ខលំបាកអំពើអាក្រក់ទាំងប៉ុន្មាន ដែលមានក្នុងធម្មជាតិ ដែលមកពីលក្ខណៈរបស់សត្វលោកដែលមានកំណត់ព្រំដែន ហើយជាពិសេសអំពីបញ្ហានៃអំពើបាប។ តើសេចក្តីអាក្រក់ចេញមកពីណា? សន្តៈ អូគូស្តាំង ធ្លាប់ចោទសួរខ្លួនឯងថា៖ "ខ្ញុំស្វែងរកថា តើសេចក្តីអាក្រក់ចេញមកពីណា ប៉ុន្តែខ្ញុំមិនអាចឆ្លើយតបបានទេ" ហើយការស្វែងរកដ៏លំបាករបស់លោកនឹងមានផ្លូវចេញតែមួយ គឺនៅពេលលោកកែប្រែចិត្តគំនិតទៅរកព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ដ្បិតមានតែ "គម្រោងការដ៏លាក់កំបាំងនៃការគោរពប្រណិប័តន៍ព្រះជាម្ចាស់" (១ធម ៣,១៦) ដែលអាចជួយបំភ្លឺ "គម្រោងការដ៏លាក់កំបាំងរបស់មេប្រឆាំងព្រះជាម្ចាស់" (២ថស ២,៧)។ ពេលព្រះគ្រីស្តបានសម្តែងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ព្រះអង្គក៏បានសម្តែងការលាតត្រដាងនៃសេចក្តីអាក្រក់ផង និងព្រះហឫទ័យប្រណីសន្តោសដ៏លើសលប់យ៉ាងក្រៃលែងរបស់ព្រះជាម្ចាស់ផង (រម ៥,២០)។ ហេតុដូច្នេះហើយបានជាយើងត្រូវចាត់ទុកបញ្ហាអំពីប្រភពនៃសេចក្តីអាក្រក់ ដោយសម្លឹងមើលទៅរកមនុស្សម្នាក់ដែលបានទទួលជោគជ័យរួចហើយ គឺព្រះយេស៊ូគ្រីស្ត (លក ១១,២១-២២; យហ ១៦,១១; ១យហ ៣,៨)។

### ១-ទីណាមានបាបកាន់តែច្រើន ទីនោះព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ក៏កាន់តែមានច្រើនលើសលប់ថែមទៀត

#### អំពើបាបបានកើតជារូបរាង

៣៨៦-អំពើបាបមានវត្តមានក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោក។ បើយើងព្យាយាមធ្វើមិនដឹងមិនឮ ឬដាក់ឈ្មោះផ្សេងទៀតដល់អំពើដ៏ងងឹតនេះ គ្មានប្រយោជន៍ទាល់តែសោះ។ ដើម្បីយល់ច្បាស់អំពីអ្វីដែលជាអំពើបាបមុនដំបូងត្រូវតែទទួលស្គាល់ចំណងដ៏ជ្រាលជ្រៅបំផុតរវាងមនុស្ស និងព្រះជាម្ចាស់ ដ្បិតក្រៅពីទំនាក់ទំនងនេះ យើងមិនអាចយល់ច្បាស់អំពីសេចក្តីអាក្រក់នៃអំពើបាបដែលជំទាស់ និងប្រឆាំងព្រះជាម្ចាស់ថែមទាំងមានឥទ្ធិពលលើជីវិត និងប្រវត្តិសាស្ត្ររបស់មនុស្សលោកផងដែរ។

៣៨៧-មានតែពន្លឺរបស់ព្រះជាម្ចាស់ដែលសម្តែងព្រះអង្គ ទើបអាចជួយបំភ្លឺយ៉ាងពិតប្រាកដអំពើបាប ជាពិសេស

អំពើបាបដើម។ ប្រសិនបើព្រះជាម្ចាស់មិនសម្តែងព្រះអង្គឲ្យយើងស្គាល់ទេ យើងមិនអាចយល់យ៉ាងច្បាស់អំពើបាប ហើយយើងអាចចាត់ទុកថាអ្នកប្រព្រឹត្តអំពើបាបនេះ មកពីគេមិនបានលូតលាស់បានគ្រប់លក្ខណៈ ឬមកពីភាពទន់ខ្សោយខាងផ្លូវចិត្តរបស់គេ ឬគេភ័ន្តច្រឡំបានជាប្រព្រឹត្តិកំហុស ឬមកពីផលវិបាកដែលមិនអាចជៀសវាងបាននៃរចនាសម្ព័ន្ធមិនត្រឹមត្រូវនៅក្នុងសង្គម។ល។ មានតែពេលយើងស្គាល់គម្រោងការរបស់ព្រះជាម្ចាស់សម្រាប់មនុស្សលោក ទើបយើងយល់ថាអ្នកប្រព្រឹត្តអំពើបាបមកពីគេបំពានសេរីភាពដែលព្រះអង្គប្រទានឲ្យសត្វលោកដើម្បីឲ្យគេអាចស្រឡាញ់ព្រះអង្គ និងស្រឡាញ់គ្នាទៅវិញទៅមក។

### អំពើបាបដើមជាសេចក្តីពិតនៃជំនឿដែលត្រូវតែជឿ

៣៨៨-ពេលព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យគេស្គាល់បន្តិចម្តងៗ ព្រះអង្គក៏បំភ្លឺទង្វើនៃអំពើបាបផងដែរ។ ទោះបីប្រជាជនរបស់ព្រះជាម្ចាស់នៃសម្ព័ន្ធមេត្រីចាស់បានលើកបញ្ហានៃលក្ខណៈដ៏លំបាករបស់មនុស្សនៅក្នុងរឿងនិទានអំពីមនុស្សធ្លាក់ខ្លួនជាអ្នកបាប ដែលមានក្នុងកណ្ឌកំណើតពិភពលោកយ៉ាងណាក៏ដោយ ក៏ពួកគេមិនអាចយល់រឿងនេះបានច្បាស់ឡើយ ដ្បិតមានតែពន្លឺរបស់ព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មថ្មីដែលបំភ្លឺអត្ថន័យដ៏ពេញលេញរបស់រឿងនេះបាន (រម ៥,១២-២១)។ ត្រូវតែស្គាល់ព្រះគ្រីស្តជាប្រភពនៃការប្រណីសន្តោស ដើម្បីអាចយល់ថា លោក អដាំ ជាប្រភពនៃអំពើបាប។ ព្រះគ្រីស្តដែលមានព្រះជន្មមានជីវិតថ្មីចាត់ព្រះវិញ្ញាណជាព្រះជួយការពារ ឲ្យយាងមកដើម្បី "ចោទប្រកាន់មនុស្សលោកថាគេយល់ខុសអំពីបាប" (យហ ១៦,៨) ដោយទ្រង់សម្តែងព្រះសង្គ្រោះ។

៣៨៩-លទ្ធិនៃអំពើបាបដើមឆ្លុះបញ្ចាំង "ខាងក្រោយ" នូវដំណឹងល្អ គឺព្រះយេស៊ូជាព្រះសង្គ្រោះរបស់មនុស្សទាំងអស់ដែលគេទាំងអស់គ្នាត្រូវការ។ ដោយសារព្រះគ្រីស្តនេះ ព្រះជាម្ចាស់ប្រទានឲ្យមនុស្សលោកទាំងអស់អាចទទួលការសង្គ្រោះបាន។ ព្រះសហគមន៍ដែលឈ្វេងយល់អំពីព្រះគ្រីស្ត (១ករ ២,១៦) ដឹងច្បាស់ថាយើងមិនអាចផ្លាស់ប្តូរសេចក្តីដែលព្រះជាម្ចាស់សម្តែងអំពីអំពើបាប ដោយមិនប៉ះពាល់ដល់គម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្តបានទេ។

### ធ្វើយ៉ាងដូចម្តេច ដើម្បីអានរឿងនិទានអំពីអំពើបាបដើម?

៣៩០-ទោះបីជារឿងនិទានដែលថ្លែងអំពីអំពើបាបដើម (កណ ៣) ប្រើនិមិត្តរូបយ៉ាងណាក៏ដោយ ក៏រឿងនេះអះអាងថាមានហេតុការណ៍មួយដែលកើតឡើងនៅពេលដើមដំបូង គឺនៅពេលប្រវត្តិសាស្ត្ររបស់មនុស្សលោកចាប់ផ្តើម (GS ១៣,១)។ ព្រះជាម្ចាស់សម្តែងឲ្យយើងជឿជាក់យ៉ាងច្បាស់ថាប្រវត្តិសាស្ត្រមនុស្សលោកបានទទួលផលវិបាកនៃអំពើបាបដើមដែលឪពុកម្តាយដើមយើងបានប្រព្រឹត្ត ដោយខ្លួនឯងផ្ទាល់ (DS ១៥១៣; DS ៣៨៩៧)។

## ២-ពួកទេវទូតធ្លាក់ខ្លួនជាអ្នកបាប

៣៩១-មានសម្លេងរបស់ម្នាក់ប្រឆាំងនឹងព្រះជាម្ចាស់ (កណ ៣,១-៥) បានបោកបញ្ឆោតដោយមានចិត្តច្រណែនឪពុកម្តាយដើម ធ្វើឲ្យគេធ្លាក់ក្នុងសេចក្តីស្លាប់ (ប្រាញ ២,២៤)។ ព្រះគម្ពីរ និងការបញ្ជូនបន្តព្រះសហគមន៍យល់ឃើញថា អ្នកនោះជាទេវទូតមួយរូបដែលគេហៅថាសាតាំង ឬមារ (យហ ៨,៤៤; វវ ១២,៩)។ ព្រះសហគមន៍បង្រៀនថាមុនដំបូងព្រះជាម្ចាស់បានបង្កើតទេវទូតនេះជាទេវទូតល្អ។ "ព្រះជាម្ចាស់បានបង្កើតមារ និងអារក្សផ្សេងទៀតជាសត្វលោកល្អ ប៉ុន្តែពួកវាបានបណ្តោយឲ្យខ្លួនឯងទៅជាសត្វលោកអាក្រក់វិញ" (DS ៨០០)។

៣៩២-ព្រះគម្ពីរថ្លែងថាពួកទេវទូតនោះបានប្រព្រឹត្តអំពើបាប (២ពត្រ ២,៤) គឺពួកវិញ្ញាណនោះដែលព្រះជាម្ចាស់បានបង្កើតនោះហើយ ដែលបានបដិសេធជាដាច់ខាត មិនព្រមទទួលស្គាល់ព្រះអង្គ និងព្រះរាជ្យរបស់ព្រះអង្គតរៀងទៅ ដោយមានសេរីភាពពេញលេញ។ ពាក្យសម្ដីរបស់មេល្បួងទៅកាន់ឪពុកម្ដាយដើមរបស់យើងបញ្ជាក់សេចក្តីនេះថា៖ "អ្នកនឹងបានដូចព្រះដែលស្គាល់ល្អស្គាល់អាក្រក់ជាមិនខាន" (កណ ៣,៥)។ "មារបានប្រព្រឹត្តអំពើបាបតាំងពីដើមដំបូង" (១យហ ៣,៨)។ មារ "ជាឪពុកនៃអ្នកកុហក" (យហ ៨,៤៤)។

៣៩៣-ព្រះជាម្ចាស់មិនអាចលើកលែងទោសឲ្យពួកវា មិនមែនមកពីព្រះជាម្ចាស់គ្មានធម៌មេត្តាករុណាទេ ប៉ុន្តែមកពីពួកទេវទូតបានបដិសេធព្រះជាម្ចាស់ជាដាច់ខាត និងជារៀងរហូត។ "ក្រោយពីពួកវាបានប្រព្រឹត្តអំពើបាប ព្រះជាម្ចាស់មិនអាចលើកលែងទោសឲ្យពួកវាបានទេ ដូចព្រះអង្គមិនអាចលើកលែងទោសឲ្យមនុស្សនៅពេលស្លាប់ហើយ" (សន្តៈ យ៉ូហានដាម៉ាសែន)។

៣៩៤-ព្រះគម្ពីរបញ្ជាក់អំពីឥទ្ធិពលដ៏អាក្រក់របស់មារដែលព្រះយេស៊ូហៅថា "អ្នកសម្លាប់មនុស្ស" (យហ ៨,៤៤) ហើយដែលបានព្យាយាមបំបែរព្រះយេស៊ូចេញពីបេសកកម្មដែលព្រះអង្គបានទទួលពីព្រះបិតា (មថ ៤,១-១១)។ "ព្រះបុត្រារបស់ព្រះជាម្ចាស់បានយាងមក ដើម្បីរំលាយកិច្ចការរបស់មារ" (១យហ ៣,៨)។ មារបានបង្កើតផលវិបាកអាក្រក់ជាងគេជាទីបំផុត នៅពេលវាបានបោកបញ្ឆោតមនុស្សមិនឲ្យធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

៣៩៥-ប៉ុន្តែអំណាចរបស់មារសាតាំងមានព្រំដែន។ ទោះបីមារមានអំណាច ព្រោះវាជាវិញ្ញាណសុទ្ធសាធក៏ដោយ ក៏វាគ្រាន់តែជាសត្វលោកប៉ុណ្ណោះ។ វាមិនអាចឃាត់ព្រះជាម្ចាស់មិនឲ្យកសាងព្រះរាជ្យព្រះអង្គបានឡើយ។ ក្នុងពិភពលោកទោះបីសាតាំងប្រព្រឹត្តកិច្ចការប្រឆាំងនឹងព្រះជាម្ចាស់ និងព្រះរាជ្យរបស់ព្រះអង្គនៅក្នុងអង្គព្រះគ្រីស្តក្តី ទោះបីកិច្ចការរបស់វាបង្កើតផលវិបាកដ៏អាក្រក់ខាងផ្លូវវិញ្ញាណ ខាងផ្លូវកាយក្តី ចំពោះមនុស្ស និងសង្គមក្តី ក៏ព្រះជាម្ចាស់បណ្ដោយឲ្យមារប្រព្រឹត្តដូច្នោះ ដោយណែនាំប្រវត្តិសាស្ត្ររបស់ពិភពលោក និងមនុស្សលោកប្រកបដោយព្រះចេស្ដា និងភាពថ្នាក់ថ្នម។ យើងមិនអាចយល់មូលហេតុដែលនាំឲ្យព្រះជាម្ចាស់ឲ្យមារមានសកម្មភាពបានទេ តែ "យើងដឹងថាព្រះជាម្ចាស់ផ្សំអ្វីៗទាំងអស់ឡើង ដើម្បីឲ្យអស់អ្នកស្រឡាញ់ព្រះអង្គបានទទួលផលល្អ" (រម ៨,២៨)។

## ៣-អំពើបាបដើមដំបូង

### មារល្បងសេរីភាពមនុស្សលោក

៣៩៦-ព្រះជាម្ចាស់បានបង្កើតមនុស្សលោកឲ្យមានលក្ខណៈដូចព្រះអង្គ ហើយបានតែងតាំងគេធ្វើជាមិត្តសម្លាញ់របស់ព្រះអង្គ។ ក្នុងឋានៈជាសត្វលោកខាងវិញ្ញាណ មនុស្សលោកគ្រាន់តែអាចស្ម័គ្រចិត្តគោរពប្រណិប័តន៍ព្រះជាម្ចាស់។ សេចក្តីនេះជាហេតុនាំឲ្យព្រះជាម្ចាស់ហាមមនុស្សលោកកុំឲ្យបរិភោគផ្លែឈើពីដើមដែលនាំឲ្យស្គាល់ល្អ ស្គាល់អាក្រក់ ដ្បិត "ថ្ងៃណាអ្នកបរិភោគផ្លែនោះ អ្នកមុខជាស្លាប់មិនខាន" (កណ ២,១៧)។ ព្រះបញ្ញានេះរៀបរាប់ដោយប្រើនិមិត្តរូបកំណត់ព្រំដែនដែលមនុស្សមិនអាចឆ្លងកាត់បាន ហើយដែលក្នុងឋានៈជាសត្វលោកមនុស្សត្រូវទទួលស្គាល់ដោយសេរី និងដោយគោរពជឿទុកចិត្តលើព្រះជាម្ចាស់។ មនុស្សលោកពឹងផ្អែកលើព្រះជាម្ចាស់ជាព្រះបង្កើតគេត្រូវប្រតិបត្តិតាមវិន័យរបស់ពិភពលោក និងក្បួនច្បាប់ខាងសីលធម៌នៃសេរីភាព។

### អំពើបាបដំបូងរបស់មនុស្សលោក

៣៩៧-មនុស្សលោកដែលមានមារល្បួងចិត្តគំនិតលែងជឿទុកចិត្តលើព្រះបង្កើតរបស់គេ (កណ ៣,១-១១)

ហើយបំពានសេរីភាពរបស់ខ្លួនមិនប្រតិបត្តិតាមព្រះបញ្ញារបស់ព្រះជាម្ចាស់ឡើយ។ នេះគឺជាអំពើបាបដំបូងរបស់មនុស្សលោក (រម ៥,១៩)។ ក្រោយមករាល់ពេលដែលមនុស្សលោកប្រព្រឹត្តអំពើបាប គេមិនប្រតិបត្តិតាមព្រះជាម្ចាស់ និងមិនជឿទុកចិត្តលើព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ។

៣៩៨-នៅពេលមនុស្សបានប្រព្រឹត្តអំពើបាប ដំបូងគេស្រឡាញ់ខ្លួនឯងច្រើនជាងព្រះជាម្ចាស់ ហេតុដូច្នេះហើយបានជាគេប្រមាថមើលងាយព្រះជាម្ចាស់។ មនុស្សបានជ្រើសរើសខ្លួនឯងប្រឆាំងនឹងព្រះជាម្ចាស់ ប្រឆាំងនឹងលក្ខណៈរបស់ខ្លួនជាសត្វលោកទើបប្រឆាំងនឹងប្រយោជន៍របស់ខ្លួនដែរ។ ព្រះជាម្ចាស់បានបង្កើតមនុស្សដ៏វិសុទ្ធ ក្នុងគោលបំណងឲ្យមនុស្សទៅជា "ព្រះ" ក្នុងសិរីរុងរឿងរបស់ព្រះអង្គដែរ។ ដោយសារមារបានបោកបញ្ឆោតគេ មនុស្សលើកខ្លួនជា "ព្រះដែលស្គាល់ល្អ ស្គាល់អាក្រក់" (កណ ៣,៥) ដោយ "មិនចាំបាច់ឲ្យមានព្រះជាម្ចាស់ មុនព្រះអង្គសព្វព្រះហឫទ័យ ហើយដោយមិនធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គផងដែរ" (សន្ដ: ម៉ាកស៊ីម)។

៣៩៩-ព្រះគម្ពីរបង្ហាញពីផលវិបាកដ៏អាក្រក់ នៅពេលមនុស្សដើមមិនបានប្រតិបត្តិតាមព្រះជាម្ចាស់ គឺលោកអដាំ និងនាងអេវ៉ាបានលែងជាមនុស្សដ៏វិសុទ្ធទៀតទេ (រម ៣,២៣)។ ពួកគេភ័យខ្លាចព្រះជាម្ចាស់ (កណ ៣,៩-១០) ដែលគេបានយល់ច្រឡំថាជាព្រះដែលចង់រក្សាទុកលក្ខណៈសម្បត្តិរបស់ព្រះអង្គ (កណ ៣,៥)។

៤០០-ដោយសារអំពើបាបមនុស្សដើមលែងរស់នៅក្នុងស្ថានភាពប្រកបដោយសេចក្ដីសុខសាន្ដដែលមកពីភាពដ៏វិសុទ្ធដើមដំបូង។ វិញ្ញាណរបស់គេលែងគ្រប់គ្រងលើរូបកាយ (កណ ៣,៦) មនុស្សប្រុស និងមនុស្សស្រីលែងត្រូវគ្នាទៀតទេ (កណ ៣,១១-១៣) គេមានចិត្តលោភលន់ចំពោះគ្នាទៅវិញទៅមក ចង់ធ្វើជាម្ចាស់លើគ្នាទៅវិញទៅមក (កណ ៣,១៦)។ គេលែងរស់នៅក្នុងពិភពនេះប្រកបដោយសេចក្ដីសុខសាន្ដទៀតហើយ សត្វលោកដែលមើលឃើញចាកចេញពីគេ និងស្អប់គេវិញ (កណ ៣,១៧-១៩)។ ដោយសារមនុស្ស "អ្វីៗទាំងអស់បែរទៅជាឥតន័យ" (រម ៨,២០)។ ទីបញ្ចប់មនុស្សនឹង "ត្រឡប់ទៅជាដីវិញ ដ្បិត (មនុស្ស) មានកំណើតមកពីដី" (កណ ៣,១៩)។ សេចក្ដីស្លាប់បានចូលមកក្នុងពិភពលោក (រម ៥,១២)។

៤០១-តាំងពីពេលដែលមនុស្សបានប្រព្រឹត្តអំពើបាបដំបូងនេះ បាបបាន "រាលដាល" ក្នុងពិភពលោកទាំងមូល៖ លោក កាអ៊ីន សម្លាប់លោក អេបិល ជាប្អូនរបស់គេ (កណ ៣,៤-១៥) មនុស្សលោកប្រព្រឹត្តអំពើអាក្រក់កាន់តែច្រើនឡើងៗ (កណ ៦,៥.១២; រម ១,១៨-៣២)។ យ៉ាងណាមិញក្នុងប្រវត្តិសាស្ត្រជនជាតិអ៊ីស្រាអែល ពួកគេមិនគោរពសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់ និងបំពានវិន័យរបស់លោក ម៉ូសេ។ សូម្បីតែក្រោយពីព្រះគ្រីស្ដបានសង្គ្រោះមនុស្សលោក គ្រីស្ដបរិស័ទនៅតែប្រព្រឹត្តអំពើបាបតាមរបៀបផ្សេងៗជាច្រើន (១ករ ១-៦; វវ ២-៣)។ ព្រះគម្ពីរ និងការបញ្ជូនបន្ដព្រះសហគមន៍នៅតែរំឭកពីវត្តមានគ្រប់សម័យ គ្រប់ទិសទីនៃអំពើបាបក្នុងប្រវត្តិសាស្ត្រមនុស្សលោក។

ដូច្នេះ ព្រះជាម្ចាស់សម្ដែងឲ្យយើងដឹងនូវអ្វីដែលបទពិសោធន៍របស់យើងបញ្ជាក់ស្រាប់ គឺថាប្រសិនបើមនុស្សយើងពិនិត្យមើលចិត្តគំនិតរបស់ខ្លួន យើងមុខជានឹងឈ្វេងយល់ថា ខ្លួនលម្អៀងទៅប្រព្រឹត្តអំពើបាប មានតណ្ហាជាច្រើនចង់ពន្លិចស្មារតីរបស់យើង។ តណ្ហាទាំងប៉ុន្មាននេះមិនមែនបណ្ដាលមកពីព្រះបង្កើតរបស់យើងដែលមានព្រះហឫទ័យសប្បុរសទេ។ ជាញឹកញាប់ មនុស្សលោកមិនព្រមទទួលស្គាល់ព្រះជាម្ចាស់ទុកជាដើមកំណើតរបស់ខ្លួនទេ។ ធ្វើដូច្នេះគេបាក់បែកសណ្ដាប់ធ្នាប់ដែលតម្រង់ខ្លួនទៅរកទីដៅបំផុតនៃជីវិតរបស់គេ។ ជាមួយគ្នានេះ មនុស្សបំបាត់ភាពសុខសាន្ដជាមួយខ្លួនឯងផ្ទាល់ ជាមួយមនុស្សឯទៀតៗ និងជាមួយសត្វលោកទាំងឡាយ (GS ១៣,១)។

## ផលវិបាកនៃអំពើបាបរបស់លោកអដាំសម្រាប់មនុស្សលោកទាំងអស់

៤០២-មនុស្សទាំងឡាយជាប់បាបរបស់លោកអដាំ។ សន្តៈ ប៉ូល មានប្រសាសន៍ថា៖ "មនុស្សទាំងអស់ជាប់បាបដោយសារមនុស្សតែម្នាក់មិនស្តាប់បង្គាប់" (រម ៥,១៩)។ "តាមរយៈមនុស្សតែម្នាក់បាបបានចូលមកក្នុងពិភពលោក ហើយតាមរយៈបាប សេចក្តីស្លាប់ក៏ចូលមកដែរ។ ហេតុនេះហើយបានជាសេចក្តីស្លាប់រាលដាលដល់មនុស្សគ្រប់ៗរូប ព្រោះគ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប" (រម ៥,១២)។ តាមគ្រីស្តទូតប៉ូល ទោះបីមនុស្សទាំងអស់រួមគ្នាក្នុងអំពើបាប និងសេចក្តីស្លាប់ក៏ដោយ ក៏មនុស្សទាំងអស់រួមគ្នាក្នុងការសង្គ្រោះនៅក្នុងអង្គព្រះគ្រីស្តដែរ៖ "ដោយសារកំហុសរបស់មនុស្សតែម្នាក់ មនុស្សទាំងអស់ត្រូវជាប់ទោសយ៉ាងណា ដោយសារអំពើសុចរិតរបស់មនុស្សតែម្នាក់ មនុស្សទាំងអស់ក៏បានសុចរិត និងទទួលជីវិតយ៉ាងនោះដែរ" (រម ៥,១៨)។

៤០៣-ព្រះសហគមន៍តែងតែបង្រៀនតាមសន្តៈ ប៉ូល ថាបើយើងមិននឹកគិតដល់អំពើបាបរបស់លោក អដាំ ដែលបានបញ្ជូនបាបមកយើងតាំងពីកំណើតមក ហើយដែលនាំឲ្យព្រលឹងបានស្លាប់ យើងក៏មិនអាចយល់ទុក្ខលំបាកដ៏សែនវេទនាដែលជិះជាន់មនុស្សលោក និងចិត្តលម្អៀងរបស់គេឲ្យប្រព្រឹត្តអំពើបាប ដែលទាក់ទាញគេទៅរកសេចក្តីស្លាប់ (DS ១៥១២)។ ដោយសារសេចក្តីនៃជំនឿនេះ ព្រះសហគមន៍ក៏ផ្តល់អគ្គសញ្ញាជ្រមុជទឹកឲ្យរួចពីបាប សូម្បីតែឲ្យក្មេងតូចៗដែលមិនបានប្រព្រឹត្តអំពើបាបផ្ទាល់ខ្លួនដែរ (DS ១៥១៤)។

៤០៤-តើបាបរបស់លោក អដាំ ក្លាយទៅជាបាបនៃកូនចៅរបស់លោកយ៉ាងដូចម្តេច? នៅក្នុងលោក អដាំ មនុស្សជាតិទាំងអស់ដូចជា "រូបកាយតែមួយរបស់មនុស្សតែម្នាក់" (សន្តៈ ថូម៉ាសនៃអាកាំង)។ ដោយសារ "ឯកភាពរបស់មនុស្សជាតិ" មនុស្សទាំងអស់ចូលរួមក្នុងបាបរបស់លោក អដាំ ដូចពួកគេចូលរួមក្នុងសេចក្តីសុចរិតរបស់ព្រះគ្រីស្តដែរ។ ក៏ប៉ុន្តែយើងមិនអាចយល់ដឹងច្បាស់អំពីការបញ្ជូនអំពើបាបដើមដូចម្តេចទេ ដែលជារឿងលាក់កំបាំង។ ព្រះជាម្ចាស់សម្តែងឲ្យយើងដឹងថាលោក អដាំ បានទទួលភាពដ៏វិសុទ្ធ និងបានសុចរិតដើមដំបូង មិនគ្រាន់តែសម្រាប់ខ្លួនគេតែម្នាក់ឯងទេ គឺសម្រាប់មនុស្សលោកទាំងអស់៖ នៅពេលពួកគេចាញ់មេល្បួងលោក អដាំ និងនាងអេវ៉ាប្រព្រឹត្តអំពើបាបរៀងៗខ្លួន ប៉ុន្តែអំពើបាបនេះប៉ះពាល់នឹងសភាពជាមនុស្សដែលគេនឹងបញ្ជូនក្នុងលក្ខណៈជាអ្នកបាប (DS ១៥១១-១៥១២)។ បាបនេះនឹងរាលដាលដល់មនុស្សលោកទាំងអស់ គឺគេនឹងបញ្ជូនសភាពជាមនុស្សដែលលែងមានភាពដ៏វិសុទ្ធ និងសេចក្តីសុចរិតទៀតហើយ។ ហេតុដូច្នេះហើយបានជាគេហៅ "បាប" អំពើបាបដើមដំបូងមិនមែនមកពីមនុស្សទាំងអស់បាន "ប្រព្រឹត្ត" អំពើបាបតែគេបាន "ទទួល" អំពើបាបដើមដំបូង បានសេចក្តីថាបាបដើមដំបូងមានលក្ខណៈជាសភាពការណ៍តែមិនមែនជាកិច្ចការឡើយ។

៤០៥-ទោះបីកូនចៅលោក អដាំ បានទទួលបាបដើមដំបូងតាមលក្ខណៈរៀងៗខ្លួនក៏ដោយ (DS ១៥១៣) ក៏គេមិនបានប្រព្រឹត្តកំហុសដោយខ្លួនគេផ្ទាល់ដែរ។ មនុស្សលោកបានបាត់បង់ភាពដ៏វិសុទ្ធ និងសេចក្តីសុចរិតដើមដំបូង ប៉ុន្តែសភាពជាមនុស្សមិនខូចទាំងស្រុងទេ គឺមនុស្សលោករងអវិជ្ជា រងទុក្ខលំបាកស្ថិតនៅក្រោមអំណាចនៃសេចក្តីស្លាប់ និងមានចិត្តលម្អៀងប្រព្រឹត្តអំពើបាប (ដែលគេហៅថា "តណ្ហា")។ បុណ្យជ្រមុជទឹកដែលផ្តល់ព្រះជន្មរបស់ព្រះគ្រីស្តលប់បំបាត់អំពើបាបដើមដំបូង និងធ្វើឲ្យមនុស្សវិលទៅរកព្រះជាម្ចាស់វិញ ប៉ុន្តែផលវិបាកនៅតែស្ថិតក្នុងសភាពជាមនុស្ស និងបណ្តាលឲ្យគេទន់ខ្សោយ និងលម្អៀងប្រព្រឹត្តអំពើបាប ហើយត្រាស់ហៅគេឲ្យប្រយុទ្ធប្រឆាំងខាងផ្លូវវិញ្ញាណ។

៤០៦-ព្រះសហគមន៍បានលម្អិតគោលការណ៍អំពីការបញ្ជូនបាបដើមនៅសតវត្សទីប្រាំ ក្រោយពីសន្តៈ អូគូស្តាំង បានរិះគិតពិចារណាប្រឆាំងនឹងលោកពេឡា ហើយនៅសតវត្សទីដប់ប្រាំមួយ ដើម្បីប្រយុទ្ធប្រឆាំងនឹងការកែតម្រង់

របស់ពួកប្រូតេស្តង់។ លោក ពេឡា អះអាងថាមនុស្សអាចមានរបៀបរស់នៅល្អត្រឹមត្រូវតាមសីលធម៌ ដោយពឹងលើកម្លាំងរបស់ខ្លួនឯង និងដោយមិនត្រូវការឲ្យព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់មកជួយគេឡើយ។ គិតដូច្នោះលោក អដាំ លែងជាអ្នកបាបគ្រាន់តែជាគំរូមិនល្អប៉ុណ្ណោះ។ ផ្ទុយទៅវិញ ពួកប្រូតេស្តង់បង្រៀនថា ដោយសារអំពើបាបដើមមនុស្សជាប់បាបជាដាច់ខាត យ៉ាងស៊ីជម្រៅជាទីបំផុត បណ្ដាលឲ្យគេគ្មានសេរីភាពទាល់តែសោះ។ ពួកគេច្រឡំបាបដើមដែលមនុស្សបានទទួលតាំងពីលោក អដាំ និងកិលេសតណ្ហា (concupiscentia) ដែលមនុស្សអាចពុះពារបាន។ ព្រះសហគមន៍បានពន្យល់យ៉ាងច្បាស់អំពីអត្ថន័យនៃអំពើបាបដើមដំបូងនៅមហាសន្និបាតទីពីរនៅទីក្រុងអូរ៉ង់ នៅឆ្នាំ៥២៩ និងនៅមហាសន្និបាតនៅទីក្រុងត្រង់ នៅឆ្នាំ១៥៤៦។

### មនុស្សត្រូវតែប្រយុទ្ធប្រឆាំងនឹងអំពើបាប

៤០៧-លទ្ធិអំពីអំពើបាបដើមដំបូងដែលទាក់ទងនឹងលទ្ធិអំពីការសង្គ្រោះ ជួយឲ្យយើងចេះរិះគិតពិចារណាយ៉ាងច្បាស់ និងយ៉ាងត្រឹមត្រូវអំពីស្ថានភាព និងសកម្មភាពរបស់មនុស្សលោកនៅក្នុងពិភពលោក។ ដោយសារបាបរបស់ឪពុកម្ដាយដើមទោះបីមនុស្សនៅតែមានសេរីភាពយ៉ាងណាក៏ដោយ ក៏មារគ្រប់គ្រងលើគេម្យ៉ាងដែរ។ បាបដើមដំបូងបណ្ដាលឲ្យ "មនុស្សលោកក្លាយជាខ្ញុំបម្រើរបស់អ្នកដែលជាម្ចាស់នៃព្រះរាជ្យរបស់សេចក្ដីស្លាប់ គឺមារ" (DS ១៥១១; ហប ២,១៤)។ ប្រសិនបើយើងមិនដឹងថាសភាពជាមនុស្សត្រូវរបួស ហើយមនុស្សលោកមានចិត្តលម្អៀងទៅរកអំពើបាបយើងអាចប្រព្រឹត្តកំហុសជាច្រើនក្នុងវិស័យអប់រំនយោបាយសង្គមកិច្ច (CA ២៥) និងសីលធម៌ផង។

៤០៨-ផលវិបាកនៃអំពើបាបដើមដំបូង និងអំពើបាបរបស់មនុស្សម្នាក់ៗរៀងៗខ្លួនបណ្ដាលឲ្យពិភពលោកទាំងមូលមានលក្ខណៈជាអ្នកបាប ដូចសន្ដ: យ៉ូហាន បញ្ជាក់ស្រាប់ជា "បាបរបស់មនុស្សលោក" (យហ ១,២៩) បានសេចក្ដីថាសហគមន៍របស់មនុស្ស និងរចនាសម្ព័ន្ធនៅក្នុងសង្គមមានឥទ្ធិពលអាក្រក់ដែលជាផលផ្លែនៃអំពើបាបរបស់មនុស្សលោកលើមនុស្សម្នាក់ៗ (RP ១៦)។

៤០៩-ស្ថានភាពដ៏សែនវេទនារបស់ពិភពលោកដែល "ស្ថិតនៅក្រោមអំណាចរបស់មារកំណាច" (១យហ ៥,១៩) (១ភត្រ ៥,៨) ធ្វើឲ្យមនុស្សត្រូវតែប្រយុទ្ធប្រឆាំងនឹងអំពើបាបអស់មួយជីវិត៖

> ប្រវត្តិសាស្ត្រមនុស្សលោកតាំងពីដើមរៀងមក សុទ្ធតែជាការប្រយុទ្ធដ៏សាហាវប្រឆាំងនឹងអំណាចនានានៃសេចក្ដីងងឹត។ ព្រះអម្ចាស់មានព្រះបន្ទូលមកយើងថា ការប្រយុទ្ធនេះចាប់ផ្ដើមតាំងពីដើមកំណើតពិភពលោករៀងមក នឹងនៅតែបន្តរហូតដល់ថ្ងៃចុងក្រោយបំផុត។ មនុស្សចូលក្នុងចម្បាំងនេះ ត្រូវតែប្រយុទ្ធ ដើម្បីភ្ជាប់ចិត្តនឹងសេចក្ដីល្អ។ មនុស្សអាចស្ងប់ក្នុងចិត្តបាន ក្រោយពីបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង និងដោយព្រះជាម្ចាស់ប្រោសប្រណីទៀតផង (GS ៣៧,២)។

### ៤-ព្រះជាម្ចាស់ "នៅតែមិនបណ្ដោយឲ្យមនុស្សស្ថិតក្រោមអំណាចនៃសេចក្ដីស្លាប់ឡើយ"

៤១០-ក្រោយពីបានធ្លាក់ខ្លួនជាអ្នកបាបព្រះជាម្ចាស់មិនបោះបង់មនុស្សលោកចោលទេ។ ផ្ទុយទៅវិញ ព្រះអង្គត្រាស់ហៅគេ (កណ ៣,៩) និងមានព្រះបន្ទូលទុកជាមុនតាមរបៀបលាក់កំបាំងថាព្រះអង្គនឹងឈ្នះអំពើអាក្រក់ និងលើកមនុស្សឲ្យងើបឡើងវិញ (កណ ៣,១៥)។ អត្ថបទនេះដកស្រង់ពីកណ្ឌកំណើតពិភពលោកដូចជា "ដំណឹងល្អមុនគេ" ដែលប្រកាសប្រាប់ជាមុនថានឹងមានព្រះមេស្ស៊ីជាព្រះសង្គ្រោះ នឹងមានប្រយុទ្ធប្រឆាំងរវាងសត្វពស់ និងស្ត្រី ហើយកូនចៅរបស់នាងនឹងឈ្នះវា នៅពេលចុងក្រោយបំផុត។

៤១១-ការបញ្ជូនបន្តគ្រីស្តសាសនាយល់ថា អត្ថបទនេះប្រកាសអំពី "លោកអដាំថ្មី" (១ករ ១៥,២១-២២.៤៥) ដែលទូទាត់យ៉ាងបរិបូណ៌ចំពោះអំពើឆ្គាំឆ្គងរបស់លោកអដាំ (រម ៥,១៩-២០) ដោយ "ព្រះអង្គបានដាក់ខ្លួនធ្វើតាមព្រះបញ្ជារហូតដល់សោយទិវង្គតលើឈើឆ្កាង" (ភីល ២,៨)។ ម្យ៉ាងទៀតគ្រូបាធ្យាយ និងបណ្ឌិតព្រះសហគមន៍ជាច្រើនទទួលស្គាល់ថាមាតារបស់ព្រះគ្រីស្ត នាងម៉ារីជាស្ត្រីម្នាក់ដែលមានចែងនៅក្នុង "ដំណឹងល្អមុនគេ" ជា "នាងអេវ៉ាថ្មី"។ នាងបានទៅជាស្ត្រីមុនគេ ហើយតាមរបៀបតែមួយដែលបានទទួលផលពីជ័យជម្នះរបស់ព្រះគ្រីស្តលើអំពើបាប៖ អស់មួយជីវិតដោយសារព្រះហឫទ័យប្រណីសន្ដោស ពិសេសរបស់ព្រះជាម្ចាស់ នាងបានរួចផុតពីអំពើបាបដើមដំបូង (DS ២៨០៣) នាងមិនដែលប្រព្រឹត្តអំពើបាបណាមួយសោះ (DS ១៥៧៣)។

៤១២-ហេតុអ្វីបានជាព្រះជាម្ចាស់មិនហាមឃាត់មនុស្សដើមដំបូងកុំឲ្យប្រព្រឹត្តអំពើបាបដូច្នេះ? សន្តៈ ឡេអុងដ៏ប្រសើរឆ្លើយតបថា៖ "ព្រះហឫទ័យប្រណីសន្ដោសដ៏ប្លែកអស្ចារ្យណាស់របស់ព្រះគ្រីស្តបានប្រទានមកយើងនូវព្រះអំណោយដ៏ល្អប្រសើរជាងព្រះអំណោយដែលចិត្តច្រណែនរបស់មារបានដកហូតចេញពីយើង"។ សន្តៈ ថូម៉ាសនៃអាកាំងបញ្ជាក់ថា៖ "គ្មានអ្វីប្រឆាំងនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលទ្រង់ត្រាស់ហៅមនុស្សលោកឲ្យមានឋានៈប្រសើរជាងមុន ក្រោយពីបានប្រព្រឹត្តបាប។ ព្រះជាម្ចាស់បណ្តោយឲ្យមានអំពើអាក្រក់ ដើម្បីឲ្យមានអំពើល្អច្រើនជាងពីមុនចេញមកពីអំពើអាក្រក់នោះ"។ ហេតុនេះសន្តៈ ប៉ូល បន្ថែមថា៖ "នៅទីណាមានអំពើបាបកាន់តែច្រើន នៅទីនោះព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ក៏រឹតតែមានច្រើនលើសលប់ថែមទៀត" (រម ៥,២០)។ ដូចបទចម្រៀងពេលបុណ្យចម្លងថ្លែងថា៖ "អំពើបាបជាកំហុសដ៏ល្អ ដ្បិតដោយសារកំហុសនោះយើងបានទទួលព្រះសង្គ្រោះដ៏ប្រសើរបំផុត"។

## សង្ខេប

៤១៣-"ព្រះជាម្ចាស់មិនបានបង្កើតសេចក្តីស្លាប់ទេ ព្រះអង្គក៏មិនសព្វព្រះហឫទ័យឲ្យសត្វលោកបាត់បង់ដែរ (...)។ សេចក្តីស្លាប់ចូលមកក្នុងពិភពលោក ព្រោះតែការច្រណែនឈ្នានីសរបស់មារ" (ប្រាញ ១,១៣; ២,២៤)។

៤១៤-សាតាំង ឬមារ និងអារក្សឯទៀតៗជាទេវទូត ដែលធ្លាក់ខ្លួនជាអ្នកបាប ព្រោះពួកវាបានស្ម័គ្រចិត្តបដិសេធមិនព្រមបម្រើព្រះជាម្ចាស់ និងគម្រោងការរបស់ព្រះអង្គ។ ពួកវាបានជ្រើសយកការប្រឆាំងនឹងព្រះជាម្ចាស់ជាស្ថាពរ។ ពួកវាព្យាយាមធ្វើឲ្យមនុស្សរួមសហការបះបោរប្រឆាំងនឹងព្រះជាម្ចាស់ជាមួយពួកវា។

៤១៥-"ព្រះជាម្ចាស់តែងតាំងឲ្យមនុស្សមានភាពសុចរិត។ ប៉ុន្តែ មារដ៏មានកលល្បិចបញ្ឆោតមនុស្ស បណ្តាលឲ្យគេប្រើសេរីភាពរបស់ខ្លួនហួសហេតុ លើកខ្លួនប្រឆាំងជំទាស់នឹងព្រះជាម្ចាស់ និងមានបំណងចង់បានសេចក្តីសុខដោយមិនត្រូវការព្រះអង្គសោះឡើយ" (GS ១៣,១)។

៤១៦-ដោយសារអំពើបាបរបស់ខ្លួន លោក អដាំ ក្នុងឋានៈជាមនុស្សដើមដំបូង បានបាត់បង់ភាពដ៏វិសុទ្ធ និងសេចក្តីសុចរិត ដែលគាត់បានទទួលពីព្រះជាម្ចាស់ មិនគ្រាន់តែសម្រាប់ខ្លួនគាត់ផ្ទាល់ទេ ថែមទាំងសម្រាប់មនុស្សទាំងអស់។

៤១៧-លោក អដាំ និងនាង អេវ៉ា បានបញ្ជូនសភាពជាមនុស្ស ដែលត្រូវរបួសដោយសារអំពើបាបដំបូងនេះទៅពូជពង្សរបស់ពួកគាត់ ទើបមនុស្សលែងជាមនុស្សដ៏វិសុទ្ធ និងសុចរិតទៀតទៅ។ គេហៅស្ថានភាពនេះថា "អំពើបាបដើមដំបូង"។

៤១៨-ដោយសារអំពើបាបដើមដំបូង សភាពជាមនុស្សចុះថយកម្លាំង រងអវិជ្ជា រងទុក្ខលំបាក ស្ថិតក្រោម

អំណាចនៃសេចក្តីស្លាប់ និងលម្អៀងទៅរកអំពើបាប (ដែលគេហៅថា "កិលេសតណ្ហា)។

៤១៩-"ដូច្នេះហើយបានជានៅក្នុងមហាសន្និបាតនៅទីក្រុងត្រង់ យើងអះអាងថា អំពើបាបដើមដំបូង ដែលបញ្ជូលបន្តជាមួយលក្ខណៈធម្មជាតិរបស់មនុស្ស "មិនមែនដោយយកតម្រាប់តាម ប៉ុន្តែដោយរាលដាល" ទើបបាបនេះជាបាប "មនុស្សគ្រប់រូប"" (SPF ១៦)។

៤២០-ព្រះគ្រីស្ត ដែលបានឈ្នះអំពើបាប បានប្រោសប្រទានឲ្យយើងនូវផលដ៏ល្អជាងអ្វី ដែលអំពើបាបបានយកចេញពីយើង៖ "នៅទីណាដែលមានបាបកាន់តែច្រើន នៅទីនោះព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ក៏រឹតតែមានច្រើនលើសលប់ថែមទៀត" (រម ៥,២០)។

៤២១-"តាមជំនឿរបស់គ្រីស្តបរិស័ទ ព្រះបង្កើតបានតែងតាំង និងនៅតែថែរក្សាពិភពលោកនេះដោយព្រះហឫទ័យស្រឡាញ់។ ពិភពលោកពិតជាធ្លាក់ក្រោមអំណាចនៃបាបកម្មរបស់មារកំណាចរួចហើយមែន ក៏ប៉ុន្តែព្រះគ្រីស្តបានកម្ទេចអំណាចនោះ ដោយព្រះអង្គបូជាព្រះជន្មនៅលើឈើឆ្កាងមានព្រះជន្មថ្មី ព្រះអង្គក៏បានរំដោះពិភពលោក..." (GS ២,២)។

# ជំពូកទីពីរ៖

# ខ្ញុំជឿលើព្រះយេស៊ូគ្រីស្តជាព្រះបុត្រាតែមួយនៃព្រះជាម្ចាស់

## ដំណឹងល្អ៖ ព្រះជាម្ចាស់បានចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យយាងមក

៤២២-"លុះដល់ពេលកំណត់ហើយ ព្រះជាម្ចាស់ក៏ចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យមកប្រសូតចេញពីស្ត្រី ហើយប្រសូតក្រោមអំណាចរបស់វិន័យផង ដើម្បីលោះអស់អ្នកដែលស្ថិតនៅក្រោមអំណាចវិន័យ និងឲ្យយើងទទួលឋានៈជាបុត្រធីតារបស់ព្រះអង្គ" (កាឡ ៤,៤-៥)។ នេះគឺជា "ដំណឹងល្អអំពីព្រះយេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់" (មក ១,១) ពេលគឺព្រះជាម្ចាស់យាងមកសួរសុខទុក្ខប្រជារាស្ត្ររបស់ព្រះអង្គ (លក ១,៦៨)។ ព្រះអង្គបានបំពេញព្រះបន្ទូលដែលទ្រង់បានសន្យាឲ្យលោក អប្រាហាំ និងកូនចៅរបស់លោក (លក ១,៥៥)។ ព្រះអង្គបានធ្វើបែបនេះលើសពីការរង់ចាំរបស់មនុស្សលោក គឺព្រះអង្គចាត់ "ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ" (មក ១,១១) ឲ្យយាងមក។

៤២៣-យើងជឿ និងប្រកាសថាលោក យេស៊ូ ពីភូមិណាសារ៉ែតជាជនជាតិយូដា កើតមកពីស្ត្រីជនជាតិអ៊ីស្រាអែលម្នាក់នៅភូមិបេថ្លេហិម នៅសម័យព្រះបាទហេរ៉ូដ និងព្រះចៅអធិរាជរ៉ូម៉ាំងព្រះនាមអូគូស្ត។ លោកប្រកបអាជីវកម្មជាជាងឈើ ត្រូវបានគេឆ្កាងនៅជំនាន់លោកទេសាភិបាល ប៉ុនពីឡាត នៅជំនាន់ព្រះចៅអធិរាជទីបេរសោយរាជ្យ។ លោកនេះហើយជាព្រះបុត្រាអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ប្រសូតជាមនុស្សដែល "យាងមកពីព្រះជាម្ចាស់" (យហ ១៣,៣) "យាងចុះពីស្ថានបរមសុខ" (យហ ៣,១៣; ៦,៣៣) "យាងមកកើតជាមនុស្ស" (១យហ ៤,២) ដ្បិត "ព្រះបន្ទូលកើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា យើងបានឃើញសិរីរុងរឿងរបស់ព្រះអង្គជាសិរីរុងរឿងនៃព្រះបុត្រាតែមួយគត់ដែលមកពីព្រះបិតា។ ព្រះអង្គពោរពេញទៅដោយព្រះហឫទ័យប្រណីសន្តោស និងសេចក្តីពិត (...) យើងទាំងអស់គ្នាបានទទួលពីព្រះហឫទ័យប្រណីសន្តោសមិនចេះអស់ មិនចេះហើយពីគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ" (យហ ១,១៤.១៦)។

៤២៤-ដោយមានព្រះហឫទ័យប្រណីសន្តោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធជំរុញ ហើយមានព្រះបិតាទាក់ទាញយើងជឿ និងប្រកាសអំពីព្រះយេស៊ូថា៖ "លោកជាព្រះគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ" (មថ ១៦,១៦)។ ព្រះគ្រីស្តបានសាងសង់ព្រះសហគមន៍របស់ព្រះអង្គលើថ្មដានៃជំនឿនេះ ដែលសន្តៈ សិលាបានប្រកាស (មថ ១៦,១៨; សន្តៈ ឡេអុងដ៏ប្រសើរ)។

### "នាំដំណឹងល្អអំពីព្រះជន្មដ៏បរិបូណ៌បំផុតរបស់ព្រះគ្រីស្តទៅប្រាប់សាសន៍ដទៃ" (អភ ៣,៨)

៤២៥-ពេលយើងបញ្ជូនគ្រីស្តសាសនាមុនដំបូង យើងប្រកាសអំពីព្រះយេស៊ូគ្រីស្ត ដើម្បីឱ្យគេផ្ញើជីវិតទៅលើព្រះអង្គ។ តាំងពីដើមក្រុមគ្រីស្តទូតមានបំណងប្រាថ្នាយ៉ាងខ្លាំងជាទីបំផុតនឹងប្រកាសព្រះគ្រីស្ត៖ "យើងខ្ញុំឈប់និយាយអំពីហេតុការណ៍ដែលយើងខ្ញុំបានឃើញបានឮនោះពុំកើតទេ" (កក ៤,២០) ហើយពួកលោកអញ្ជើញមនុស្សគ្រប់សម័យឱ្យចូលរួមជាមួយពួកលោក ដែលរួមរស់ជាមួយព្រះគ្រីស្តដោយចិត្តរីករាយ៖

> ព្រះបន្ទូលដែលផ្តល់ជីវិតគង់នៅកាលពីដើមដំបូងបង្អស់ យើងបានឮព្រះបន្ទូលនេះបានឃើញផ្ទាល់នឹងភ្នែកបានរំពឹងគិត និងបានប៉ះពាល់ដោយដៃយើងផ្ទាល់ (ដ្បិតជីវិតនេះបានលេចមកឱ្យយើងឃើញហើយយើងសូមផ្តល់សក្ខីភាព និងសូមជូនដំណឹងមកបងប្អូនអំពីជីវិតអស់កល្បជានិច្ច ដែលបែរទៅរកព្រះបិតា និងលេចមកឱ្យយើងឃើញ)។ យើងសូមជូនដំណឹងអំពីព្រះបន្ទូលដែលយើងបានឃើញ និងបានឮនោះដល់បងប្អូន ដើម្បីឱ្យបងប្អូនបានចូលរួមរស់ជាមួយយើង រីឯយើងវិញ យើងក៏រួមរស់ជាមួយព្រះបិតា និងជាមួយព្រះយេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះអង្គ។ យើងសរសេរសេចក្តីទាំងនេះមកជូនបងប្អូន ដើម្បីឱ្យយើងមានអំណរពេញលក្ខណៈ (១យហ ១,១-៤)។

## ព្រះគ្រីស្តជាស្នូលនៃការអប់រំជំនឿ

៤២៦-"ចំណុចសំខាន់ៗនៃការអប់រំជំនឿ គឺមនុស្សម្នាក់ ព្រះយេស៊ូពីភូមិណាសារ៉ែតព្រះបុត្រាតែមួយរបស់ព្រះបិតា (...) ដែលបានរងទុក្ខលំបាក និងសោយទិវង្គតសម្រាប់យើង ហើយដែលមានព្រះជន្មថ្មី និងគង់នៅជាមួយយើងឥឡូវនេះ និងតរៀងទៅ (...)។ ពេលយើងអប់រំជំនឿ (...) យើងសម្តែងគម្រោងការអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់នៅក្នុងអង្គព្រះគ្រីស្ត។ យើងស្វែងយល់នូវអត្ថន័យនៃកិច្ចការព្រះបន្ទូល និងទីសម្គាល់របស់ព្រះគ្រីស្ត"។ ពេលយើងអប់រំជំនឿយើងមានគោលដៅតែមួយគឺ៖ "នាំឱ្យអ្នកស្វែងរករួមរស់ជាមួយព្រះយេស៊ូគ្រីស្ត ដ្បិតមានតែព្រះអង្គទេ ដែលអាចណែនាំយើងទៅកាន់សេចក្តីស្រឡាញ់របស់ព្រះបិតា នៅក្នុងអង្គព្រះវិញ្ញាណ ហើយនាំឱ្យយើងចូលរួមចំណែកនៅក្នុងជីវិតនៃព្រះត្រៃឯកដ៏វិសុទ្ធ"។

៤២៧-"ពេលយើងអប់រំជំនឿ យើងបង្រៀនអំពីព្រះគ្រីស្តជាព្រះបន្ទូលប្រសូតជាមនុស្ស និងជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយអ្វីៗផ្សេងទៀតដែលយើងបង្រៀនទាក់ទងនឹងព្រះអង្គ។ ម្យ៉ាងទៀតមានតែព្រះគ្រីស្តទេ ដែលជាគ្រូបង្រៀន អ្នកណែនាំប្រៀបធៀបដូចជាអ្នកនាំព្រះបន្ទូលរបស់ព្រះអង្គតែប៉ុណ្ណោះ ដែលបណ្តាលឱ្យព្រះគ្រីស្តបង្រៀនតាមរយៈមាត់គេ (...)។ អ្នកណែនាំគ្រប់ៗរូបត្រូវតែប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះយេស៊ូ៖ "សេចក្តីដែលខ្ញុំបង្រៀនមិនមែនចេញពីខ្ញុំទេ គឺចេញពីព្រះជាម្ចាស់ដែលបានចាត់ខ្ញុំឱ្យមក" (យហ ៧,១៦)" (CT ៥)។

៤២៨-អ្នកណាដែលព្រះជាម្ចាស់ត្រាស់ហៅឱ្យ "បង្រៀនព្រះគ្រីស្ត" ត្រូវតែស្វែងរក "ការមួយដ៏ប្រសើរវិសេសវិសាលបំផុត" គឺ "ស្គាល់ព្រះគ្រីស្ត"។ ត្រូវតែ "សុខចិត្តខាតបង់អ្វីៗទាំងអស់ (...) ឱ្យតែបានព្រះគ្រីស្ត និងឱ្យតែបានរួមជាមួយព្រះអង្គ" គឺ "ស្គាល់ព្រះគ្រីស្ត និងស្គាល់ឫទ្ធានុភាពដែលបានប្រោសព្រះអង្គឱ្យមានព្រះជន្មថ្មី ព្រម

ទាំងចូលរួមជាមួយព្រះអង្គដែលរងទុក្ខលំបាក ហើយឲ្យបានដូចព្រះអង្គដែលសោយទិវង្គត ដើម្បីឲ្យខ្ញុំមានជីវិតថ្មី ប្រសិនបើអាចមានជីវិតថ្មីបាន" (ភីល ៣,៨-១១)។

៤២៩-ពេលយើងស្គាល់ព្រះគ្រីស្តដោយជាប់ចិត្តនឹងព្រះអង្គ យើងមានបំណងប្រាថ្នាចង់ប្រកាសព្រះអង្គ និងនាំឲ្យអ្នកដទៃសុខចិត្តផ្ញើជីវិតលើព្រះអង្គផងដែរ។ ប៉ុន្តែនៅពេលជាមួយគ្នានេះ យើងត្រូវការស្គាល់ជំនឿនេះកាន់តែច្បាស់ឡើងៗ។ ហេតុនេះហើយយោងតាមធម៌ប្រកាសជំនឿ យើងនឹងរាយការណ៍អំពីងាររបស់ព្រះយេស៊ូ គឺព្រះគ្រីស្តព្រះបុត្រារបស់ព្រះជាម្ចាស់ និងព្រះអម្ចាស់ (ប្រការទី២)។ បន្ទាប់មកធម៌ជឿប្រកាសអំពីព្រឹត្តិការណ៍ដ៏លាក់កំបាំងនៃជីវិតរបស់ព្រះគ្រីស្ត គឺព្រះអង្គប្រសូតជាមនុស្ស (ប្រការទី៣ ) ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ (ប្រការទី៤ និងទី៥ ) ហើយព្រះអង្គទទួលសិរីរុងរឿង (ប្រការទី៦ និងទី៧ )។

## ប្រការទី២៖

## "ខ្ញុំជឿលើព្រះយេស៊ូគ្រីស្តជាព្រះបុត្រាតែមួយនៃព្រះបិតា ហើយជាអម្ចាស់នៃយើងខ្ញុំ"

### ១-ព្រះយេស៊ូ

៤៣០-ជាភាសាហេប្រឺ យេស៊ូ មានន័យថា "ព្រះជាម្ចាស់សង្គ្រោះ"។ នៅពេលទេវទូតកាព្រីអែលជូនដំណឹងអំពីកំណើតព្រះយេស៊ូ លោកថ្វាយព្រះនាមថា យេស៊ូ ដែលសម្ដែងអត្តសញ្ញាណផង និងបេសកកម្មរបស់ព្រះអង្គផង (លក ១,៣១)។ "ក្រៅពីព្រះជាម្ចាស់តែមួយព្រះអង្គ គ្មាននរណាអាចអត់ទោសឲ្យមនុស្សរួចពីបាបបាន" (មក ២,៧) ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់ "នឹងសង្គ្រោះប្រជារាស្ត្រព្រះអង្គឲ្យរួចពីបាបរបស់គេ" (មថ ១,២១) នៅក្នុងអង្គព្រះយេស៊ូជាព្រះបុត្រាព្រះអង្គអស់កល្បជានិច្ចប្រសូតជាមនុស្ស។ នៅក្នុងអង្គព្រះយេស៊ូ ព្រះជាម្ចាស់សរុបប្រវត្តិសាស្ត្រនៃការសង្គ្រោះរបស់ព្រះអង្គចំពោះមនុស្សលោក។

៤៣១-ក្នុងប្រវត្តិសាស្ត្រនៃការសង្គ្រោះ ព្រះជាម្ចាស់មិនគ្រាន់តែបានរំដោះជនជាតិអ៊ីស្រាអែលឲ្យចាកចេញពីប្រទេសអេស៊ីបជា "ស្រុកដែលអ្នកធ្វើជាទាសករ" (ទក ៥,៦) ប៉ុណ្ណោះទេ ថែមទាំងជួយសង្គ្រោះគេឲ្យរួចពីបាបទៀតផង។ ដោយសារអ្នកបាបតែងតែប្រព្រឹត្តខុសនឹងព្រះជាម្ចាស់ (ទន ៥១,៦) មានតែព្រះអង្គទេ ដែលអាចលើកលែងទោសឲ្យពួកគេរួចពីបាបបាន (ទន ៥១,២)។ ហេតុនេះដោយយល់កាន់តែច្បាស់អំពីអំពើបាបដែលរាលដាលក្នុងសកលលោកទាំងមូល និងគ្រប់សម័យកាលជនជាតិអ៊ីស្រាអែលត្រូវតែរកការសង្គ្រោះ ក្នុងព្រះនាមព្រះជាម្ចាស់ជាព្រះសង្គ្រោះ (ទន ៧៩,៩)។

៤៣២-ព្រះនាមរបស់យេស៊ូមានន័យថា ព្រះនាមរបស់ព្រះជាម្ចាស់ផ្ទាល់ស្ថិតនៅក្នុងអង្គព្រះបុត្រា ព្រះអង្គប្រសូតជាមនុស្ស (កក ៥,៤១; ៣យហ ៧) ដើម្បីរំដោះពិភពលោកទាំងមូលឲ្យរួចពីបាបជាស្ថាពរ។ មានតែព្រះនាមរបស់ព្រះជាម្ចាស់ទេ ដែលអាចនាំការសង្គ្រោះបាន (យហ ៣,៥; កក ២,២១) ហើយដែលមនុស្សទាំងអស់អាចទូលអង្វរបាន ដ្បិតព្រះយេស៊ូប្រសូតជាមនុស្ស ព្រះអង្គក៏រួមរស់ជាមួយមនុស្សទាំងអស់ (រម ១០,៦-១៣)។ "ក្រៅពីព្រះយេស៊ូ គ្មាននរណាម្នាក់អាចសង្គ្រោះមនុស្សទាល់តែសោះ" (កក ៤,១២) (កក ៩,១៤; យហ ២,៧)។

៤៣៣-មួយឆ្នាំម្តង ពេលមហាបូជាចារ្យប្រោះឈាមនៃយញ្ញបូជានៅលើគម្របហិប លោកទូលអង្វរក្នុងព្រះនាមរបស់ព្រះជាម្ចាស់ ជាព្រះសង្គ្រោះ ដើម្បីឲ្យជនជាតិអ៊ីស្រាអែលរួចពីបាប (លវ ១៦,១៥-១៦; បសរ ៥០,២០;

ហប ៩,៧)។ គម្របហិបជាកន្លែងនៃវត្តមានរបស់ព្រះជាម្ចាស់ (សរ ២៥,២២; លវ ១៦,២; ជរ ៧,៨៩; ហប ៩,៥)។ ពេលសន្តៈ ប៉ូល មានប្រសាសន៍អំពីព្រះយេស៊ូថា៖ "ព្រះជាម្ចាស់បានតម្រូវឲ្យព្រះយេស៊ូធ្វើជាយញ្ញបូជាសម្រាប់លោះអស់អ្នកដែលមានជំនឿឲ្យរួចពីបាប ដោយសារព្រះលោហិតរបស់ព្រះអង្គ" (រម ៣,២៥) បានសេចក្តីថាក្នុងសភាពជាមនុស្សរបស់ព្រះគ្រីស្ត "ព្រះជាម្ចាស់បានសម្រុះសម្រួលមនុស្សលោកឲ្យជានានឹងព្រះអង្គ" (២ករ ៥,១៩)។

៤៣៤-ពេលព្រះយេស៊ូមានព្រះជន្មថ្មី ព្រះអង្គក៏លើកតម្កើងសិរីរុងរឿងនៃព្រះនាមរបស់ព្រះជាម្ចាស់ ជាព្រះសង្គ្រោះ (យហ ១២,២៨) ដ្បិតចាប់ពីឥឡូវនេះតទៅ ព្រះនាមរបស់ព្រះយេស៊ូសម្តែងឫទ្ធានុភាពសព្វប្រការរបស់ "ព្រះនាមដ៏ប្រសើរលើសអ្វីៗទាំងអស់" (ភីល ២,៩-១០) ឲ្យបានពេញលក្ខណៈ។ អារក្សដ៏អាក្រក់ខ្លាចព្រះនាមព្រះអង្គ (កក ១៦,១៦-១៨) ហើយក្នុងព្រះនាមព្រះអង្គក្រុមសាវ័កសម្តែងហេតុអស្ចារ្យ (មក ១៦,១៧) ដ្បិតអ្វីៗដែលពួកលោកទូលសូមពីព្រះបិតាក្នុងព្រះនាមព្រះយេស៊ូ ព្រះអង្គក៏ប្រោសប្រទានឲ្យពួកលោក (យហ ១៥,១៦)។

៤៣៥-ព្រះនាមរបស់ព្រះយេស៊ូជាស្នូលនៃការអធិដ្ឋានតាមគ្រីស្តសាសនា។ ក្នុងពិធីបុណ្យ ពាក្យអធិដ្ឋានទាំងអស់បញ្ចប់ដោយប្រើពាក្យ "ដោយព្រះអម្ចាស់យេស៊ូគ្រីស្ត"។ "ហើយទ្រង់ (ព្រះជាម្ចាស់) ក៏ប្រទានពរដល់បុត្រ (ព្រះយេស៊ូ) ព្រះនាងម៉ារី" ជាកំពូលនៃពាក្យអង្វរ "បពិត្រព្រះនាងម៉ារី"។ ពាក្យអធិដ្ឋានខាងបូព៌ាប្រទេសដែលគេហៅថា "ពាក្យទូលអង្វរព្រះយេស៊ូ" ពោលថា៖ "ព្រះយេស៊ូគ្រីស្តព្រះបុត្រារបស់ព្រះជាម្ចាស់ ឱព្រះអម្ចាស់អើយ! សូមអាណិតអាសូរខ្ញុំជាអ្នកបាបផង"។ គ្រីស្តបរិស័ទជាច្រើននាក់ទទួលមរណភាពដោយពោលពាក្យ "ព្រះយេស៊ូ" ដូចសន្តី យ៉ូហាននៃអាកដែរ។

## ២-ព្រះគ្រីស្ត

៤៣៦-ព្រះគ្រីស្តជាពាក្យក្រិកដែលមកពីពាក្យ "ព្រះមេស្ស៊ី" ជាភាសាហេប្រឺដែលមានន័យថា "អ្នកដែលព្រះជាម្ចាស់ចាក់ប្រេងអភិសេក"។ ព្រះគ្រីស្តទៅជាព្រះនាមរបស់ព្រះយេស៊ូ ព្រោះតែព្រះអង្គបំពេញបេសកកម្មរបស់ព្រះជាម្ចាស់ឲ្យបានគ្រប់លក្ខណៈ។ នៅប្រទេសអ៊ីស្រាអែលព្រះជាម្ចាស់ចាក់ប្រេងអភិសេកអស់អ្នកដែលបានទទួលបេសកកម្មពីព្រះអង្គដូចជាស្តេច (១ពង្ស ១,៣៩) ពួកបូជាចារ្យ (សរ ២,៩; លវ ៨,១២) ហើយព្យាការីខ្លះៗផងដែរ (១ពង្ស ១៩,១៦) ជាពិសេសព្រះមេស្ស៊ីដែលព្រះជាម្ចាស់នឹងចាត់ឲ្យមកដើម្បីតាំងព្រះរាជ្យព្រះអង្គ (ទន ២,២; កក ៤,២៦-២៧)។ ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវតែចាក់ប្រេងអភិសេកព្រះមេស្ស៊ី (អស ១១,១២) តាំងព្រះអង្គជាស្តេចបូជាចារ្យ (សក ៤,១៤; ៦,១៣) និងព្យាការីផង (អស ៦១,១; លក ៤,១៦-២១)។ ដោយមានមុខងារជាបូជាចារ្យ ព្យាការី និងព្រះមហាក្សត្រ ព្រះយេស៊ូបានបំពេញសេចក្តីសង្ឃឹមរបស់ជនជាតិអ៊ីស្រាអែលអំពីព្រះមេស្ស៊ី។

៤៣៧-ទេវទូតបានជូនដំណឹងដល់ពួកគង្វាលអំពីកំណើតរបស់ព្រះយេស៊ូ ដូចជាកំណើតរបស់ព្រះមេស្ស៊ីដែលព្រះជាម្ចាស់បានសន្យាប្រទានឲ្យជនជាតិអ៊ីស្រាអែល៖ "យប់នេះនៅក្នុងភូមិកំណើតរបស់ព្រះបាទដាវីឌ ព្រះសង្គ្រោះរបស់អ្នករាល់គ្នាប្រសូតហើយ គឺព្រះគ្រីស្តជាអម្ចាស់" (លក ២,១១)។ តាំងពីដើមព្រះអង្គជា "អ្នកដែលព្រះបិតាបានប្រោសឲ្យបានវិសុទ្ធ និងចាត់ឲ្យមកក្នុងពិភពលោកនេះទៀតផង" (យហ ១០,៣៦) ព្រះវិញ្ញាណបានប្រោសឲ្យព្រះអង្គបាន "ដ៏វិសុទ្ធ" (លក ១,៣៥) នៅក្នុងផ្ទៃនាងព្រហ្មចារិនីម៉ារី។ ព្រះជាម្ចាស់បានត្រាស់ហៅលោកយ៉ូសែបឲ្យ "ទទួលនាងម៉ារីធ្វើជាភរិយា" នាងម៉ារីដែលមានគភ៌ដោយសារ "ព្រះវិញ្ញាណដ៏វិសុទ្ធ" (មថ ១,២០) ដើម្បីឲ្យព្រះយេស៊ូ "ហៅថាព្រះគ្រីស្ត" ប្រសូតពីភរិយារបស់លោក យ៉ូសែប ជាព្រះរាជវង្សរបស់ព្រះបាទដាវីឌ (មថ ១,១៦) (រម ១,៣; ២ធម ២,៨; វវ ២២,១៦)។

៤៣៨-ពេលព្រះជាម្ចាស់អភិសេកព្រះយេស៊ូធ្វើជាព្រះមេស្ស៊ី ទ្រង់សម្ដែងបេសកកម្មរបស់ព្រះគ្រីស្ត។ "តាមពិតព្រះនាមរបស់ព្រះយេស៊ូផ្ទាល់សម្ដែងបេសកកម្មរបស់ព្រះជាម្ចាស់នោះ ព្រោះក្នុងព្រះនាមព្រះអង្គមានចែងថា អ្នកចាក់ប្រេងអភិសេក អ្នកទទួលប្រេងអភិសេក និងប្រេងអភិសេកផ្ទាល់៖ អ្នកចាក់ប្រេងអភិសេក គឺព្រះបិតា អ្នកទទួលប្រេងអភិសេក គឺព្រះបុត្រា ហើយប្រេងអភិសេក គឺព្រះវិញ្ញាណ" (សន្ដ: អ៊ីរ៉េណេ)។ នៅលើផែនដី ព្រះជាម្ចាស់សម្ដែងថា ព្រះយេស៊ូជាព្រះគ្រីស្តអស់កល្បជានិច្ច នៅពេលលោក យ៉ូហានបាទីស្ត ជ្រមុជព្រះអង្គក្នុងទឹក។ ពេលនោះ "ព្រះជាម្ចាស់បានចាក់ព្រះវិញ្ញាណដ៏វិសុទ្ធ និងឫទ្ធានុភាពអភិសេកព្រះយេស៊ូ" (កក ១០,៣៨) ដើម្បីឱ្យ "លោកបង្ហាញខ្លួនឱ្យប្រជារាស្ត្រអ៊ីស្រាអែលស្គាល់" (យហ ១,៣១) ថាជាព្រះមេស្ស៊ីរបស់គេ។ ដោយសារកិច្ចការ និងព្រះបន្ទូលរបស់ព្រះអង្គគេនឹងស្គាល់ព្រះអង្គជា "ព្រះដ៏វិសុទ្ធដែលព្រះជាម្ចាស់ចាត់ឱ្យមក" (មក ១,២៤; យហ ៦,៦៩; កក ៣,១៤)។

៤៣៩-ជនជាតិយូដាជាច្រើន សូម្បីតែសាសន៍ដទៃខ្លះដែលជឿ និងសង្ឃឹមលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដូចគ្នាដែរ បានទទួលស្គាល់ថាព្រះយេស៊ូមានលក្ខណៈសម្បត្តិរបស់ "បុត្រារបស់ព្រះបាទដាវីឌ" ជាព្រះមេស្ស៊ីដែលព្រះជាម្ចាស់បានសន្យាប្រទានឱ្យជនជាតិអ៊ីស្រាអែល (មថ ៩,២៧)។ ព្រះយេស៊ូសុខចិត្តទទួលងារជាព្រះមេស្ស៊ី (យហ ៤,២៥-២៦) ដូចព្រះអង្គមានសិទ្ធិទទួលព្រះបរមងារនេះមែន ប៉ុន្តែព្រះអង្គប្រុងប្រយ័ត្នជានិច្ច ព្រោះជនជាតិអ៊ីស្រាអែលភាគច្រើនគិតថា ព្រះមេស្ស៊ីដូចជាស្ដេចលោកីយ៍ (មថ ២២,៤១-៤៦; យហ ៦,១៥; លក ២៤,២១)។

៤៤០-ព្រះយេស៊ូបានទទួលការប្រកាសជំនឿរបស់លោក សិលា ដែលទទួលស្គាល់ព្រះអង្គជាព្រះមេស្ស៊ី នៅពេលព្រះអង្គមានព្រះបន្ទូលទុកជាមុនថា បុត្រមនុស្សនឹងរងទុក្ខលំបាក (មថ ១៦,១៦-២៣)។ ព្រះអង្គបានសម្ដែងយ៉ាងច្បាស់ថាព្រះអង្គជាព្រះមេស្ស៊ី និងព្រះមហាក្សត្របែបណានៅក្នុងអត្តសញ្ញាណដ៏ខ្ពង់ខ្ពស់បំផុតនៃបុត្រមនុស្សដែល "យាងចុះពីស្ថានបរមសុខ" (យហ ៣,១៣) និងនៅក្នុងបេសកកម្មសង្គ្រោះមនុស្សលោកដូចជាអ្នកបម្រើដែលត្រូវរងទុក្ខលំបាក៖ "បុត្រមនុស្សមកក្នុងពិភពលោកនេះ មិនមែនដើម្បីឱ្យគេបម្រើលោកទេ គឺលោកបម្រើគេវិញ ព្រមទាំងបូជាជីវិត ដើម្បីលោះមនុស្សទាំងអស់" (មថ ២០,២៨) (អស ៥៣,១០-១២)។ ហេតុដូច្នេះហើយប្រសិនបើគ្មានព្រះឈើឆ្កាងជួយបំភ្លឺទេ យើងមិនអាចយល់ថា ព្រះយេស៊ូជាព្រះមហាក្សត្រយ៉ាងដូចម្ដេចបានទេ (យហ ១៩,១៩-២២; លក ២៣,៣៩-៤៣)។ លោកសិលាអាចប្រកាសពីមុខប្រជាជនរបស់ព្រះជាម្ចាស់ថាព្រះយេស៊ូជាព្រះមហាក្សត្រ នៅពេលព្រះយេស៊ូមានព្រះជន្មថ្មីតែប៉ុណ្ណោះ៖ "សូមឱ្យជនជាតិអ៊ីស្រាអែលទាំងមូលដឹងជាក់ច្បាស់ថាលោកយេស៊ូនេះដែលបងប្អូនបានឆ្កាង ព្រះជាម្ចាស់បានតែងតាំងលោកឡើងជាព្រះអម្ចាស់ និងជាព្រះគ្រីស្តហើយ" (កក ២,៣៦)។

## ៣-ព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់

៤៤១-នៅក្នុងសម្ពន្ធមេត្រីចាស់ ព្រះបុត្រារបស់ព្រះជាម្ចាស់ជាងារដែលព្រះជាម្ចាស់ប្រទានឱ្យពួកទេវទូត (ទក ៣២,៨; យប ១,៦) ប្រជាជនដែលព្រះជាម្ចាស់បានជ្រើសរើស (សរ ៤,២២) កូនចៅជនជាតិអ៊ីស្រាអែល (ហស ២,១) និងព្រះមហាក្សត្ររបស់គេ (២សម ៧,១៤)។ ព្រះបុត្រារបស់ព្រះជាម្ចាស់មានន័យថា ព្រះជាម្ចាស់ប្រោសមនុស្សម្នាក់ឱ្យទៅជាបុត្រចិញ្ចឹមរបស់ព្រះអង្គដោយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ។ កាលដែលមានចែងថាព្រះជាម្ចាស់បានសន្យាប្រទានព្រះមហាក្សត្រ ព្រះមេស្ស៊ីជា "ព្រះបុត្រារបស់ព្រះជាម្ចាស់" (១របា ១៧,១៣; ទន ២,៧) យើងមិនត្រូវសន្និដ្ឋានភ្លាមៗតាមអត្ថន័យចំៗនៃអត្ថបទនោះថា ព្រះអង្គមានឋានៈខ្ពស់ជាងមនុស្សលោកទេ។ ប្រហែលជាអស់អ្នកដែលបានហៅព្រះយេស៊ូថាជាព្រះមេស្ស៊ីនៃជនជាតិអ៊ីស្រាអែល (មថ ២៧,៥៤)

គ្មានបំណងចង់ផ្តល់អត្ថន័យផ្សេងពីអត្ថន័យនោះឡើយ (លក ២៣,៤៧)។

៤៤២-រីឯលោក សិលា វិញពេលលោកប្រកាសថាព្រះយេស៊ូជា "ព្រះគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ" (មថ ១៦,១៧) ព្រះអង្គឆ្លើយតបយ៉ាងឧឡារិកថា "អ្នកដឹងសេចក្តីនេះមិនមែនដោយខ្លួនឯងទេ គឺព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខបានសម្តែងឲ្យអ្នកដឹង" (មថ ១៦,១៧)។ ក្រោយពីសន្តះ ប៉ូល បានប្រែចិត្តគំនិតនៅតាមផ្លូវទៅកាន់ទីក្រុងដាម៉ាសលោកថ្លែងថា៖ "ព្រះជាម្ចាស់បានជ្រើសរើសខ្ញុំទុកដោយឡែកតាំងពីក្នុងផ្ទៃម្តាយមកម្ល៉េះ ហើយព្រះអង្គបានត្រាស់ហៅខ្ញុំដោយព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ។ នៅពេលព្រះអង្គសព្វព្រះហឫទ័យសម្តែងឲ្យខ្ញុំស្គាល់ព្រះបុត្រារបស់ព្រះអង្គ ដើម្បីឲ្យខ្ញុំនាំដំណឹងល្អអំពីព្រះបុត្រាទៅជូនសាសន៍ដទៃ" (កាឡ ១,១៥-១៦)។ "លោកចាប់ផ្តើមប្រកាសនៅក្នុងសាលាប្រជុំនានាភ្លាមថា ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់" (កក ៩,២០)។ តាំងពីដំបូងបង្អស់ (១ថស ១,១០) "ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់" ជាស្នូលនៃជំនឿរបស់ក្រុមគ្រីស្តទូត (យហ ២០,៣១) ដែលលោក សិលា បានប្រកាសមុនគេ និងដែលជាគ្រឹះរបស់ព្រះសហគមន៍ (មថ ១៦,១៨)។

៤៤៣-តាមពិតលោក សិលា បានទទួលស្គាល់ថា ព្រះយេស៊ូជាព្រះមេស្ស៊ី ជាព្រះបុត្រាដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះជាម្ចាស់ ដ្បិតព្រះយេស៊ូបានជួយឲ្យគេយល់បាន។ ចំពោះក្រុមប្រឹក្សាជាន់ខ្ពស់ ពេលគេចោទសួរព្រះយេស៊ូថា៖ "បើដូច្នេះ អ្នកជាព្រះបុត្រារបស់ព្រះជាម្ចាស់ឬ?" ព្រះអង្គឆ្លើយតបនឹងគេថា៖ "អស់លោកមានប្រសាសន៍ត្រូវមែន គឺខ្ញុំនេះហើយ" (លក ២២,៧០) (មថ ២៦,៦៤; មក ១៤,៦១)។ តាំងពីដើមមកម្ល៉េះ ព្រះអង្គបានណែនាំខ្លួនឯងជា "ព្រះបុត្រា" ដែលស្គាល់ព្រះបិតា (មថ ១១,២៧) ខុសប្លែកពី "អ្នកបម្រើ" ដែលព្រះជាម្ចាស់បានចាត់ឲ្យមកពីមុនៗឲ្យប្រជាជនរបស់ព្រះអង្គ (មថ ២១,៣៤-៣៦) ហើយដែលមានឋានៈលើសពីពួកទេវទូតទៅទៀត (មថ ២៤,៣៦)។ ព្រះអង្គបានញែកខ្លួនឯងពីសាវ័ករបស់ព្រះអង្គដោយមិនដែលមានព្រះបន្ទូលថា "ព្រះបិតារបស់យើង" ទេ (មថ ៥,៤៨) លើកលែងតែ ដើម្បីបង្គាប់ឲ្យគេថា៖ "អ្នករាល់គ្នាត្រូវទូលព្រះអង្គដូចតទៅ៖ ឱព្រះបិតានៃយើងខ្ញុំ" (មថ ៦,៩) ហើយព្រះអង្គបានបញ្ជាក់ពីការញែកនេះ៖ "ព្រះបិតាខ្ញុំ និងព្រះបិតារបស់អ្នករាល់គ្នា" (យហ ២០,១៧)។

៤៤៤-តាមដំណឹងល្អព្រះសូរសៀងរបស់ព្រះបិតាបង្ហាញព្រះយេស៊ូថាជា "បុត្រដ៏ជាទីស្រឡាញ់" (មថ ៣,១៧ ; ១៧,៥) របស់ព្រះអង្គនៅពេលព្រះយេស៊ូជ្រមុជទឹក និងនៅពេលព្រះអង្គប្រែទ្រង់ទ្រាយឲ្យសាវ័កឃើញ។ ព្រះយេស៊ូណែនាំខ្លួនជា "ព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់" (យហ ៣,១៦) និងបញ្ជាក់ថាព្រះអង្គមានព្រះជន្មគង់នៅអស់កល្បជានិច្ច មុនសម័យកាលទាំងអស់ (យហ ១០,៣៦)។ ព្រះអង្គសូមឲ្យគេជឿ "លើព្រះនាមព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់" (យហ ៣,១៨)។ ធម៌ប្រកាសជំនឿរបស់គ្រីស្តសាសនានេះ លេចចេញមករួចហើយកាលដែលនាយទាហានភ្លាត់មាត់ពីមុខព្រះយេស៊ូនៅលើឈើឆ្កាងថា៖ "បុរសនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន" (មក ១៥,៣៩)។ មានតែពេលព្រះយេស៊ូសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញទេ ទើបអ្នកជឿអាចផ្តល់អត្ថន័យពេញលេញដល់ព្រះបរមងារ "ព្រះបុត្រារបស់ព្រះជាម្ចាស់"។

៤៤៥-យើងអាចយល់ថា ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ពោរពេញដោយសិរីរុងរឿង និងឫទ្ធានុភាពពេលព្រះអង្គមានព្រះជន្មថ្មី៖ "ព្រះជាម្ចាស់បានតែងតាំងព្រះអង្គជាព្រះបុត្រាប្រកបដោយឫទ្ធានុភាព ដោយប្រោសព្រះអង្គឲ្យមានព្រះជន្មថ្មី" (រម ១,៤) (កក ១៣,៣៣)។ ក្រុមគ្រីស្តទូតនឹងប្រកាសថា៖ "យើងបានឃើញសិរីរុងរឿងរបស់ព្រះអង្គ ជាសិរីរុងរឿងនៃព្រះបុត្រាតែមួយគត់ដែលមកពីព្រះបិតា ព្រះអង្គពោរពេញទៅដោយព្រះហឫទ័យប្រណីសន្តោស និងសេចក្តីពិត" (យហ ១,១៤)។

## ៤-ព្រះអម្ចាស់

៤៤៦-ពេលគេបកប្រែគម្ពីរសម្ព័ន្ធមេត្រីចាស់ជាភាសាក្រិក គេប្រើពាក្យ **Kyrios** ("ព្រះអម្ចាស់") ដើម្បីបកប្រែព្រះនាមដ៏ប្លែកអស្ចារ្យរបស់ព្រះជាម្ចាស់ដែលទ្រង់បានសម្តែងឲ្យលោក ម៉ូសេ ស្គាល់ **YHWH** (សរ ៣,១៤)។ ដូច្នេះគេធ្លាប់ប្រើព្រះអម្ចាស់ ដើម្បីសម្តែងថាព្រះរបស់ជនជាតិអ៊ីស្រាអែលជាព្រះជាម្ចាស់។ ក្នុងសម្ព័ន្ធមេត្រីថ្មី គេប្រើងារ "ព្រះអម្ចាស់" សំដៅលើព្រះបិតាផង ព្រះយេស៊ូផង។ ហេតុដូច្នេះហើយបានជាគេទទួលស្គាល់ថា ព្រះយេស៊ូជាព្រះជាម្ចាស់ផ្ទាល់ (១ករ ២,៨)។

៤៤៧-ពេលព្រះយេស៊ូពិភាក្សាជាមួយពួកគណៈផារីស៊ីអំពីអត្ថន័យនៃទំនុកតម្កើងលេខ១១០ (មថ ២២,៤១-៤៦) ព្រះយេស៊ូដូចជាទទួលស្គាល់យ៉ាងលាក់លៀមថា ខ្លួនជាព្រះអម្ចាស់ ប៉ុន្តែពេលព្រះអង្គមានព្រះបន្ទូលជាមួយក្រុមគ្រីស្តទូត ព្រះអង្គសម្តែងឲ្យគេដឹងច្បាស់ថា ព្រះអង្គជាព្រះអម្ចាស់ (យហ ១៣,១៣)។ អស់មួយជីវិតព្រះយេស៊ូបង្ហាញថាព្រះអង្គជាព្រះជាម្ចាស់ ដោយធ្វើកាយវិការគ្រប់គ្រងធម្មជាតិ ជំងឺ អារក្ខ សេចក្តីស្លាប់ និងអំពើបាប។

៤៤៨-ជារឿយៗក្នុងដំណឹងល្អមនុស្សជាច្រើនហៅព្រះយេស៊ូជា "ព្រះអម្ចាស់"។ ងារនេះផ្តល់សក្ខីភាពថាអ្នកដែលមករកព្រះយេស៊ូ គោរព និងជឿទុកចិត្តលើព្រះអង្គ ហើយសូមឲ្យព្រះអង្គជួយសង្គ្រោះ និងព្យាបាល (មថ ៨,២; ១៤,៣០)។ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជំរុញផង អ្នកនោះទទួលស្គាល់ថា ព្រះយេស៊ូជាព្រះជាម្ចាស់ (លក ១,៤៣; ២,១១)។ ពេលគេជួបព្រះយេស៊ូដែលមានព្រះជន្មថ្មី គេក្រាបថ្វាយបង្គំព្រះអង្គ៖ "ព្រះអង្គពិតជាព្រះអម្ចាស់ និងជាព្រះរបស់ទូលបង្គំមែន!" (យហ ២០,២៨)។ ពេលនោះ "ព្រះអម្ចាស់" ទទួលអត្ថន័យពិសេសតាមគ្រីស្តសាសនា គឺសម្តែងថា គេស្រឡាញ់ព្រះអង្គយ៉ាងជិតស្និទ្ធ៖ "ព្រះអម្ចាស់ទេតើ!" (យហ ២១,៧)។

៤៤៩-ដោយប្រគល់ងារព្រះអម្ចាស់ឲ្យព្រះយេស៊ូ ធម៌ប្រកាសជំនឿដំបូងនៃព្រះសហគមន៍អះអាងតាំងពីដើមថា (កក ២,៣៤-៣៦) ត្រូវតែថ្វាយទៅព្រះយេស៊ូ អំណាច ព្រះកិត្តិនាម និងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជាព្រះបិតា (រម ៩,៥; ទត ២,១៣; វវ ៥,១៣) ដ្បិតព្រះអង្គ "មានឋានៈជាព្រះជាម្ចាស់" (ភីល ២,៦) ហើយពីព្រោះព្រះបិតាបានសម្តែងថាព្រះយេស៊ូជាព្រះជាម្ចាស់ ដោយប្រោសព្រះអង្គឲ្យក្រោកឡើងពីចំណោមមនុស្សស្លាប់ និងឲ្យទទួលសិរីរុងរឿងរបស់ព្រះអង្គ (រម ១០,៩; ១ករ ១២,៣; ភីល ២,៩; ១១)។

៤៥០-តាំងពីការចាប់ផ្តើមដំបូងនៃគ្រីស្តសាសនាព្រះសហគមន៍អះអាងថា ព្រះយេស៊ូជាព្រះអម្ចាស់លើពិភពលោក និងប្រវត្តិសាស្ត្រ (វវ ១១,១៥) ដើម្បីសម្តែងថាមនុស្សលោកមិនត្រូវលះបង់សេរីភាពផ្ទាល់ខ្លួន ក្រោមអំណាចលោកីយ៍ណាមួយ ក្រៅពីព្រះជាម្ចាស់ជាព្រះបិតា និងព្រះអម្ចាស់យេស៊ូគ្រីស្តជាដាច់ខាត៖ ព្រះចៅអធិរាជមិនមែនជា "ព្រះអម្ចាស់" ទេ (មក ១២,១៧; កក ៥,២៩)។ "ព្រះសហគមន៍ជឿថា (...) អត្ថន័យដ៏សំខាន់ និងទីដៅនៃប្រវត្តិសាស្ត្រទាំងមូលរបស់មនុស្សលោកស្ថិតក្នុងអង្គព្រះអម្ចាស់ និងក្នុងព្រះបរមគ្រូរបស់ខ្លួន" (GS ១០,២; ៤៥,២)។

៤៥១-ព្រះបរមងារជា "ព្រះអម្ចាស់" មានក្នុងការអធិដ្ឋាននៃគ្រីស្តសាសនាដូចជាពេលយើងអញ្ជើញគេឲ្យអធិដ្ឋាន "សូមព្រះអម្ចាស់គង់ជាមួយបងប្អូន" ឬពេលអធិដ្ឋានចប់ "ដោយព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើង" ឬពេលយើងអង្វរព្រះអង្គឲ្យយាងមកវិញពោរពេញដោយទំនុកចិត្ត និងក្តីសង្ឃឹម៖ "ម៉ារ៉ាណាថា" ("ព្រះអម្ចាស់យាងមក!") ឬ "ម៉ារ៉ាណាថា" (ឱព្រះអម្ចាស់សូមយាងមក!") (១ករ ១៦,២២) "អាម៉ែន ព្រះអម្ចាស់យេស៊ូអើយ សូមយាងមក!" (វវ ២២,២០)។

## សង្ខេប

៤៥២-ព្រះនាមរបស់ព្រះយេស៊ូមានន័យថា "ព្រះជាម្ចាស់សង្គ្រោះ"។ គេហៅបុត្រដែលប្រសូតពីព្រហ្មចារិនីម៉ារីថា "យេស៊ូ" "ដ្បិតបុត្រនោះនឹងសង្គ្រោះប្រជារាស្ត្រព្រះអង្គឲ្យរួចពីបាបរបស់គេ" (មថ ១,២១)៖ "នៅក្រោមមេឃនេះ ក្រៅពីព្រះយេស៊ូ គ្មាននរណាម្នាក់អាចសង្គ្រោះមនុស្សបានទាល់តែសោះ" (កក ៤,១២)។

៤៥៣-ព្រះនាមរបស់ព្រះគ្រីស្តមានន័យថា "អ្នកទទួលអភិសេក" "ព្រះមេស្ស៊ី"។ ព្រះយេស៊ូជាព្រះគ្រីស្ត ដ្បិត "ព្រះជាម្ចាស់បានចាក់ព្រះវិញ្ញាណដ៏វិសុទ្ធ និងឫទ្ធានុភាពអភិសេកព្រះយេស៊ូ" (កក ១០,៣៨)។ ព្រះអង្គជា "អ្នកដែលត្រូវយាងមក"(លក ៧,១៩) ជា "សេចក្តីសង្ឃឹមរបស់ជនជាតិអ៊ីស្រាអែល" (កក ២៨,២០)។

៤៥៤-ព្រះនាមនៃព្រះបុត្រារបស់ព្រះជាម្ចាស់មានន័យថា ទំនាក់ទំនងតែមួយ និងអស់កល្បជានិច្ចរវាងព្រះយេស៊ូ និងព្រះបិតារបស់ព្រះអង្គ គឺព្រះអង្គជាព្រះបុត្រាតែមួយរបស់ព្រះបិតា (យហ ១,១៤.១៨; ៣,១៦.១៨) និងជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ (យហ ១,១)។ ដើម្បីក្លាយទៅជាគ្រីស្តបរិស័ទ ត្រូវតែជឿថា ព្រះយេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់ (កក ៨,៣៧; ១យហ ២,២៣)។

៤៥៥-ព្រះនាមរបស់ព្រះអម្ចាស់មានន័យថា ព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់បំផុត។ ពេលយើងប្រកាស ឬទូលអង្វរព្រះយេស៊ូជាព្រះអម្ចាស់ យើងជឿថា ព្រះអង្គជាព្រះជាម្ចាស់។ "បើគ្មានព្រះវិញ្ញាណដ៏វិសុទ្ធណែនាំទេ នោះក៏គ្មាននរណាម្នាក់អាចពោលថា "ព្រះយេស៊ូជាព្រះអម្ចាស់" បានឡើយ" (១ករ ១២,៣)។

## ប្រការទី៣៖

## "ព្រះយេស៊ូគ្រីស្តមានកំណើតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី"

### កថាខណ្ឌទី១៖ ព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស

#### ១-ហេតុអ្វីបានជាព្រះបន្ទូលប្រសូតជាមនុស្ស?

៤៥៦-យើងឆ្លើយតបនឹងសំណួរនេះតាមធម៌ប្រកាសជំនឿនៃមហាសន្និបាតសកលនីសេ/កុងស្តង់ទីណូប ដែលប្រកាសថា "ព្រះអង្គយាងមកពីស្ថានបរមសុខ ដើម្បីមនុស្សយើង និងសង្គ្រោះយើងដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះអង្គបានទទួលរូបកាយពីព្រះនាងព្រហ្មចារិនីម៉ារី ហើយព្រះអង្គកើតជាមនុស្ស"។

៤៥៧-ព្រះបន្ទូលប្រសូតជាមនុស្សដើម្បីសង្គ្រោះយើង ដោយសម្រុះសម្រួលយើងឲ្យជានានឹងព្រះជាម្ចាស់៖ "គឺព្រះជាម្ចាស់ទេតើដែលបានស្រឡាញ់យើង និងបានចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យយាងមកបូជាព្រះជន្មលោះយើងឲ្យរួចពីបាបទាំងពួង" (១យហ ៤,១០)។ "ព្រះបិតាបានចាត់ព្រះបុត្រាឲ្យយាងមកសង្គ្រោះមនុស្សលោក" (១យហ ៤,១៤)។ "ព្រះយេស៊ូយាងមកដើម្បីដកបាបចេញពីមនុស្សលោក" (១យហ ៣,៥)។

ពេលយើងមានជំងឺ សភាពរបស់យើងទាមទារឲ្យយើងបានជាសះស្បើយ ពេលយើងធ្លាក់ខ្លួនជាអ្នកបាប សភាពនេះទាមទារឲ្យយើងងើបឡើងវិញ ពេលយើងស្លាប់ សភាពយើងទាមទារឲ្យយើងរស់ឡើងវិញ។ យើងលែងជាម្ចាស់នៃអំពើល្អ ត្រូវតែសងមកយើងវិញ។ ពេលយើងជាឈ្លើយនៃភាពងងឹត ត្រូវតែយកពន្លឺមកបំភ្លឺយើង ត្រូវនាំអ្នក

ជួយសង្គ្រោះមករំដោះ ពេលយើងត្រូវជាប់ឃុំឃាំង ជាប់គុកច្រវាក់ ពេលយើងធ្លាក់ខ្លួនជាទាសករ ត្រូវមានអ្នកមកជួយរំដោះ។ តើមូលហេតុទាំងអស់នោះមិនសំខាន់ទេឬ? តើមូលហេតុនោះ មិនអាចនាំឲ្យព្រះជាម្ចាស់រំជួលព្រះហឫទ័យរហូតដល់យាងចុះមកកើតជាមនុស្ស ដ្បិតជាតិជាមនុស្សស្ថិតក្នុងសភាពដ៏លំបាកវេទនាបែបនេះឬទេ? (សន្ត: គ្រេគ័រនៃនីស)។

៤៥៨-ព្រះបន្ទូលប្រសូតជាមនុស្ស ដើម្បីឲ្យយើងស្គាល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់៖ "ព្រះជាម្ចាស់បានសម្តែងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គចំពោះយើង គឺព្រះអង្គបានចាត់ព្រះបុត្រាតែមួយគត់របស់ព្រះអង្គឲ្យយាងមកក្នុងលោកនេះ ដើម្បីឲ្យយើងមានជីវិតដោយសារព្រះបុត្រា" (១យហ ៤,៩)។ "ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមកដើម្បីឲ្យអស់អ្នកដែលជឿលើព្រះបុត្រាមានជីវិតអស់កល្បជានិច្ច មិនឲ្យគេវិនាសឡើយ" (យហ ៣,១៦)។

៤៥៩-ព្រះបន្ទូលប្រសូតជាមនុស្ស ដើម្បីធ្វើជាគំរូឲ្យយើងបានវិសុទ្ធ៖ "ចូរយកនឹមរបស់ខ្ញុំដាក់លើអ្នករាល់គ្នាហើយរៀនពីខ្ញុំ..." (មថ ១១,២៩)។ "ខ្ញុំហ្នឹងហើយជាផ្លូវជាសេចក្តីពិត និងជាជីវិត។ គ្មាននរណាម្នាក់អាចទៅកាន់ព្រះបិតាបានទេ លើកលែងតែទៅតាមរយៈខ្ញុំ" (យហ ១៤,៦)។ នៅលើភ្នំដែលព្រះយេស៊ូបានប្រែទ្រង់ទ្រាយព្រះបិតាបញ្ជាថា៖ "ចូរស្តាប់ព្រះអង្គចុះ!" (មក ៩,៧) (ទក ៦,៤-៥)។ ព្រះអង្គពិតជាគំរូឲ្យយើងទទួលសុភមង្គលដ៏ពិតប្រាកដ និងជាក្បួននៃធម្មវិន័យថ្មី៖ "ចូរស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" (យហ ១៥,១២)។ តាមសេចក្តីស្រឡាញ់នេះយើងក៏ត្រូវតែបូជាខ្លួនឯងដោយដើរតាមព្រះអង្គ (មក ៨,៣៤)។

៤៦០-ព្រះបន្ទូលប្រសូតជាមនុស្ស ដើម្បីឲ្យ "យើងចូលរួមចំណែកក្នុងព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់" (២ពត្រ ១,៤)៖ "ព្រះបន្ទូលប្រសូតជាមនុស្ស ហើយព្រះបុត្រារបស់ព្រះជាម្ចាស់កើតជាបុត្រមនុស្ស ដើម្បីឲ្យមនុស្សទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដោយរួមជាមួយព្រះបន្ទូល និងទទួលព្រះជន្មរបស់ព្រះអង្គ" (សន្ត: អ៊ីរ៉េណេ)។ "ដ្បិតព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស ដើម្បីឲ្យយើងទៅជាព្រះជាម្ចាស់" (សន្ត: អាថាណាស)។ "ព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់ ដែលសព្វព្រះហឫទ័យឲ្យយើងរួមជាមួយព្រះជាម្ចាស់យកសភាពរបស់យើង ដើម្បីឲ្យព្រះអង្គទៅជាមនុស្ស និងមនុស្សទៅជាព្រះ" (សន្ត: ថូម៉ាសនៃអាកាំង)។

### ២-ព្រះជាម្ចាស់ប្រសូតជាមនុស្ស

៤៦១-តាមប្រសាសន៍របស់សន្ត: យ៉ូហាន ("ព្រះបន្ទូលបានកើតមកជាមនុស្ស" (យហ ១,១៤) ព្រះសហគមន៍ជឿថា ព្រះបុត្រារបស់ព្រះជាម្ចាស់បានទទួលយកសភាពជាមនុស្ស ដើម្បីជួយសង្គ្រោះយើង។ ព្រះសហគមន៍ច្រៀងគម្រោងការដ៏អស្ចារ្យនេះដែលលិខិតរបស់សន្ត: ប៉ូល ជូនគ្រីស្តបរិស័ទនៅទីក្រុងភីលីពបញ្ជាក់៖

> ព្រះគ្រីស្តយេស៊ូមានចិត្តគំនិតយ៉ាងណា បងប្អូនត្រូវមានចិត្តគំនិតយ៉ាងនោះដែរ។ ទោះបីព្រះអង្គមានឋានៈជាព្រះជាម្ចាស់ក៏ដោយ ក៏ព្រះអង្គពុំបានក្តោបក្តាប់ឋានៈដែលស្មើនឹងព្រះជាម្ចាស់នេះទុកជាកម្មសិទ្ធិផ្តាច់មុខរបស់ព្រះអង្គឡើយ។ ផ្ទុយទៅវិញ ព្រះអង្គបានលះបង់អ្វីៗទាំងអស់មកយកឋានៈជាទាសករ ព្រះអង្គបានក្លាយទៅជាមនុស្សដូចមនុស្សឯទៀតៗ ហើយក៏រស់នៅក្នុងភាពជាមនុស្សសាមញ្ញដែរ។ ព្រះអង្គបានបន្ទាបខ្លួនធ្វើតាមព្រះបញ្ជារហូតដល់សោយទិវង្គត គឺសោយទិវង្គតលើឈើឆ្កាងថែមទៀតផង! (ភីល ២,៥-៨) (LH)។

៤៦២-លិខិតផ្ញើជូនគ្រីស្តបរិស័ទជាតិហេប្រឺថ្លែងអំពីគម្រោងការដ៏អស្ចារ្យនេះដូចតទៅ៖

> ហេតុនេះនៅពេលព្រះគ្រីស្តយាងចូលមកក្នុងពិភពលោក ព្រះអង្គមានព្រះបន្ទូលទៅកាន់ព្រះជាម្ចាស់

ថាព្រះអង្គមិនចង់បានយញ្ញបូជា ឬតង្វាយអ្វីទេ តែព្រះអង្គបានធ្វើរូបកាយមួយឲ្យទូលបង្គំ ព្រះអង្គមិនសព្វព្រះហឫទ័យនឹងតង្វាយដុត ឬយញ្ញបូជាសុំឲ្យរួចពីបាបឡើយ។ ដូច្នេះទូលបង្គំពោលថា បពិត្រព្រះជាម្ចាស់ ឥឡូវនេះ ទូលបង្គំសូមមកធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ (ហប ១០,៥-៧ យោងតាម ទន ៤០,៧-៩)។

៤៦៣-ពេលយើងជឿថាព្រះបុត្រារបស់ព្រះជាម្ចាស់ពិតជាកើតជាមនុស្ស យើងសម្តែងលក្ខណៈពិសេសនៃគ្រីស្តសាសនា៖ "បងប្អូនអាចស្គាល់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានត្រង់នេះ គឺអ្នកណាប្រកាសជំនឿថា ព្រះយេស៊ូគ្រីស្តបានយាងមកកើតជាមនុស្ស អ្នកនោះមានព្រះវិញ្ញាណមកពីព្រះជាម្ចាស់មែន" (១យហ ៤,២)។ តាំងពីដើមព្រះសហគមន៍ជឿជាក់ "គម្រោងការដ៏លាក់កំបាំងនៃការគោរពប្រណិប័តន៍ព្រះជាម្ចាស់" គឺថា "ព្រះគ្រីស្តយាងមកមានឋានៈជាមនុស្ស" (១ធម ៣,១៦)។

### ៣-ពិតជាព្រះជាម្ចាស់មែន ពិតជាមនុស្សមែន

៤៦៤-ព្រះបុត្រារបស់ព្រះជាម្ចាស់កើតជាមនុស្ស ជាហេតុការណ៍តែមួយ និងយ៉ាងពិសេស។ ព្រះបុត្រាប្រសូតជាមនុស្សមិនមែនមានន័យថា ព្រះយេស៊ូគ្រីស្តពាក់កណ្តាលព្រះជាម្ចាស់ផង ពាក់កណ្តាលមនុស្សផង ឬព្រះអង្គដូចជាលទ្ធផលនៃការលាយឡំមិនច្បាស់លាស់រវាងព្រះជាម្ចាស់ និងមនុស្សឡើយ។ ដោយនៅតែមានឋានៈជាព្រះជាម្ចាស់ ព្រះអង្គបានកើជាមនុស្សមែន។ ព្រះអង្គពិតជាព្រះជាម្ចាស់ផង ពិតជាមនុស្សផង។ នៅសតវត្សដើមព្រះសហគមន៍បានការពារ និងបំភ្លឺសេចក្តីពិតនៃជំនឿនេះប្រឆាំងនឹងជំនឿក្លែងក្លាយ។

៤៦៥-មុនដំបូងអ្នកជឿជំនឿក្លែងក្លាយមិនព្រមទទួលស្គាល់ថា ព្រះយេស៊ូពិតជាមនុស្សជាជាងព្រះយេស៊ូ ជាព្រះជាម្ចាស់ (gnostic docetism)។ តាំងពីសម័យក្រុមគ្រីស្តទូត ព្រះសហគមន៍តែងតែសង្កត់ធ្ងន់ថា ព្រះបុត្រារបស់ព្រះជាម្ចាស់បានកើតជាមនុស្សពិតប្រាកដមែន (១យហ ៤,២-៣; ២យហ ៧)។ ប៉ុន្តែតាំងពីសតវត្សទីបីនៅមហាសន្និបាតនៃទីក្រុងអន់ទីយ៉ូក ព្រះសហគមន៍ត្រូវតែអះអាងប្រឆាំងនឹងលោក ប៉ូល នៃសាមូសាតាថា ព្រះយេស៊ូគ្រីស្តមានសភាវៈជាព្រះបុត្រារបស់ព្រះជាម្ចាស់ គឺព្រះជាម្ចាស់មិនបានយកព្រះគ្រីស្តធ្វើជាព្រះបុត្រាចិញ្ចឹមទេ។ នៅឆ្នាំ៣២៥ មហាសន្និបាតសកលទីមួយនៃទីក្រុងនិសេប្រកាសថា ព្រះបុត្រារបស់ព្រះជាម្ចាស់ "ចេញមកពីព្រះជាម្ចាស់មិនកើតដូចសត្វលោកទេ ហើយរួមសភាព (homousios) ជាមួយព្រះបិតា"។ សេចក្តីនេះ ប្រឆាំងនឹងលោក អារីយូស ដែលអះអាងថា "ព្រះបុត្រារបស់ព្រះជាម្ចាស់ចេញមកពីសូន្យ" (DS ១៣០) និង "មានសភាវៈផ្សេងពីព្រះបិតា" (DS ១២៦)។

៤៦៦-ជំនឿក្លែងក្លាយរបស់លោក ណេស្តូរីយូស អះអាងថាព្រះគ្រីស្តជាមនុស្សម្នាក់ភ្ជាប់នឹងព្រះបុត្រារបស់ព្រះជាម្ចាស់។ ផ្ទុយទៅវិញ សន្តៈ ស៊ីរីល នៃទីក្រុងអឡិសង់ឌ្រី និងមហាសន្និបាតសកលទីបីនៅទីក្រុងអេភេសូនៅឆ្នាំ៤៣១ បានប្រកាសថា "ព្រះបន្ទូលកើតជាមនុស្សដោយផ្សំផ្គុំរូបកាយ និងព្រលឹងមួយឲ្យរួបរួមជាមួយគ្នានៅក្នុងអង្គព្រះអង្គ" (DS ២៥០)។ ជាតិជាមនុស្សរបស់ព្រះគ្រីស្តមានប្រធានបទតែមួយ គឺព្រះបុត្រារបស់ព្រះជាម្ចាស់ទ្រង់បានទទួលយកសភាពជាមនុស្សតាំងពីពេលផ្ទៃដំបូងមក។ ហេតុនេះហើយបានជានៅឆ្នាំ៤៣១ មហាសន្និបាតនៅទីក្រុងអេភេសូបានប្រកាសថា នាងម៉ារីពិតជាព្រះមាតារបស់ព្រះជាម្ចាស់ ដ្បិតព្រះបុត្រារបស់ព្រះជាម្ចាស់កើតជាមនុស្សនៅក្នុងខ្លួននាង៖ "ព្រះនាងម៉ារីជាព្រះមាតារបស់ព្រះជាម្ចាស់មិនមែនមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់បានយកសភាពរបស់ព្រះអង្គចេញពីព្រះនាងទេ។ ព្រះនាងជាព្រះមាតារបស់ព្រះជាម្ចាស់ ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់មានរូបកាយដ៏សក្ការៈ និងព្រលឹងរួមជាមួយគ្នានៅក្នុងអង្គព្រះអង្គដោយសារព្រះនាង" (DS ២៥១)។

៤៦៧-ពួកមូនូភីស៊ីតអះអាងថា នៅក្នុងអង្គព្រះគ្រីស្តសភាពជាព្រះបុត្រារបស់ព្រះជាម្ចាស់បានស្រូបសភាពជាមនុស្ស។ នៅឆ្នាំ៤៥១ មហាសន្និបាតសកលទីបួន នៅទីក្រុងកាលសេដូនបានប្រកាសថា៖

តាមគ្រូបាធ្យាយដ៏វិសុទ្ធ យើងប្រកាសដោយរួមជាមួយគ្នាជាធ្លុងតែមួយថា មានព្រះបុត្រាតែមួយ គឺព្រះអម្ចាស់នៃយើងយេស៊ូគ្រីស្ត អង្គតែមួយគ្រប់លក្ខណៈក្នុងឋានៈជាព្រះជាម្ចាស់គ្រប់លក្ខណៈក្នុងឋានៈជាមនុស្សអង្គតែមួយពិតប្រាកដ ជាព្រះជាម្ចាស់ផង ពិតប្រាកដជាមនុស្សផង ដែលមានព្រលឹង និងរូបកាយមួយរួមសភាពជាមួយព្រះបិតាក្នុងឋានៈជាព្រះជាម្ចាស់ រួមសភាពជាមួយយើងក្នុងឋានៈជាមនុស្ស "គ្រប់ជំពូកដូចយើងដែរ តែទ្រង់មិនបានប្រព្រឹត្តអំពើបាបសោះឡើយ" (ហប ៤,១៥)។ ព្រះអង្គចេញមកពីព្រះបិតាមុនសម័យកាលទាំងអស់ ក្នុងឋានៈជាព្រះជាម្ចាស់ ហើយនៅគ្រាចុងក្រោយនេះកើតពីព្រហ្មចារិនីម៉ារីជាព្រះមាតារបស់ព្រះជាម្ចាស់ក្នុងឋានៈជាមនុស្ស ដើម្បីយើង និងដើម្បីសង្គ្រោះយើង។

មានព្រះគ្រីស្តតែមួយព្រះអង្គដដែល ជាព្រះអម្ចាស់ ជាព្រះបុត្រាតែមួយដែលយើងត្រូវស្គាល់ថា មានសភាពពីរដែលយើងមិនអាចច្រឡំបានទេ ដែលគ្មានការប្រែប្រួលសោះ ដែលមិនអាចបែងចែកបានទេ និងដែលមិនអាចវែកញែកបានទេ។ ទោះបីសភាពទាំងពីររួមជាមួយគ្នាយ៉ាងណាក៏ដោយ ក៏សភាពទាំងពីរខុសប្លែកពីគ្នាតែមានលក្ខណៈរៀងៗខ្លួន ដោយរួមជាមួយគ្នាជាបុគ្គល និងអង្គតែមួយ (DS ៣០១-៣០២)។

៤៦៨-បន្ទាប់ពីមហាសន្និបាតកាលសេដូន អ្នកខ្លះជឿថាសភាពជាមនុស្សរបស់ព្រះគ្រីស្តដូចជាបុគ្គលមួយ។ នៅឆ្នាំ៥៥៣ មហាសន្និបាតសកលទីប្រាំនៅទីក្រុងកុងស្តង់ទីណូបបានប្រកាសប្រឆាំងអ្នកនោះថា៖ "មានអង្គតែមួយ (ឬបុគ្គល) ជាព្រះអម្ចាស់នៃយើងយេស៊ូគ្រីស្តជាព្រះមួយអង្គនៃព្រះត្រៃឯក " (DS ៤២៤)។ អ្វីៗទាំងអស់ក្នុងសភាពជាមនុស្សរបស់ព្រះគ្រីស្តដូចជាការអស្ចារ្យទុក្ខលំបាក (DS ៤២៤) សូម្បីតែសេចក្ដីស្លាប់ក៏មានប្រធានបទផ្ទាល់ (DS ២៥៥) ដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់។ "អ្នកដែលត្រូវគេឆ្កាងនៅក្នុងរូបកាយព្រះយេស៊ូគ្រីស្តដែលជាព្រះអម្ចាស់នៃយើង ជាព្រះជាម្ចាស់ពិតប្រាកដ ជាព្រះអម្ចាស់នៃសិរីរុងរឿង និងព្រះមួយអង្គនៃព្រះត្រៃឯក" (DS ៤៣២)។

៤៦៩-ព្រះសហគមន៍ប្រកាសថាព្រះយេស៊ូពិតជាព្រះជាម្ចាស់ផង ពិតជាមនុស្សផង ដោយមិនអាចបំបែកបានទេ។ ព្រះអង្គពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែលកើតជាមនុស្ស ជាបងរបស់យើងដោយនៅតែមានឋានៈជាព្រះជាម្ចាស់ គឺព្រះអម្ចាស់នៃយើង។

ពិធីបុណ្យនៃទីក្រុងរ៉ូម (LH; សន្ធ: ឡេអុង់ដ៏ប្រសើរ) ច្រៀងថា៖ "ព្រះអង្គនៅតែជាព្រះជាម្ចាស់ ព្រះអង្គទទួលយកសភាពជាមនុស្ស"។ ចំណែកពិធីបុណ្យនៃសន្ធ: យ៉ូហាន គ្រីសូស្តូម ប្រកាស និងច្រៀងថា៖ "ឱព្រះបុត្រាតែមួយ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់! ដោយសារព្រះអង្គមានព្រះជន្មអមតៈ ដើម្បីសង្គ្រោះយើង ព្រះអង្គបានប្រោសប្រណីមកចាប់កំណើតជាមនុស្សពីព្រះមាតាដ៏វិសុទ្ធនៃព្រះជាម្ចាស់ ហើយនៅតែព្រហ្មចារិនីម៉ារី ព្រះអង្គមិនប្រែប្រួលទេ បានក្លាយទៅជាមនុស្ស ហើយត្រូវគេឆ្កាង។ ឱព្រះគ្រីស្តជាព្រះជាម្ចាស់អើយ! ព្រះអង្គសោយទិវង្គត ដើម្បីកម្ទេចសេចក្តីស្លាប់ ព្រះអង្គជាព្រះមួយអង្គនៃព្រះត្រៃឯកដ៏វិសុទ្ធ ដែលទទួលសិរីរុងរឿងរួមជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធ ឱព្រះអង្គអើយ! សូមយាងមកសង្គ្រោះយើងខ្ញុំផង!"។

## ៤-តើព្រះបុត្រារបស់ព្រះជាម្ចាស់ជាមនុស្សយ៉ាងដូចម្ដេច?

៤៧០-ពីសតវត្សមួយទៅសតវត្សមួយព្រះសហគមន៍បានប្រកាសថា ព្រះគ្រីស្តពិតជាមានព្រលឹងរួមជាមួយប្រាជ្ញាបំណង និងរូបកាយ ដ្បិតនៅក្នុងព្រះជាម្ចាស់កើតជាមនុស្ស "សភាពជាព្រះជាម្ចាស់បានទទួលយកតែមិនបានស្រូបនឹងសភាពជាមនុស្ស" (GS ២២,២)។ ប៉ុន្តែនៅពេលជាមួយគ្នាព្រះសហគមន៍ត្រូវរំឭកថាសភាពជាមនុស្សរបស់ព្រះគ្រីស្តជាកម្មសិទ្ធិផ្ទាល់របស់ព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលបានទទួលយកសភាពជាមនុស្សនេះ។ អ្វីៗទាំងអស់ដែលព្រះអង្គមាន ឬប្រព្រឹត្តមកពី "ព្រះមួយអង្គនៃព្រះត្រៃឯក"។ ព្រះបុត្រារបស់ព្រះជាម្ចាស់ប្រទានឲ្យសភាពជាមនុស្សរបស់ព្រះអង្គ របៀបរស់នៅផ្ទាល់នៅក្នុងព្រះត្រៃឯក។ ហេតុនេះហើយបានជាក្នុងព្រលឹងដូចក្នុងរូបកាយរបស់ព្រះអង្គ ព្រះគ្រីស្តសម្តែងព្រះត្រៃឯកតាមរបៀបជាមនុស្ស (យហ ១៤,៩-១០)៖

> ព្រះបុត្រារបស់ព្រះជាម្ចាស់បានធ្វើការជាមួយដៃរបស់មនុស្ស បានគិតជាមួយប្រាជ្ញារបស់មនុស្ស បានប្រព្រឹត្តជាមួយបំណងរបស់មនុស្ស បានស្រឡាញ់ជាមួយបេះដូងរបស់មនុស្ស។ ព្រះអង្គបានប្រសូតពីព្រហ្មចារិនីម៉ារី ទ្រង់បានទៅជាមនុស្សដូចយើងដែរ មនុស្សដូចយើងបេះបិទលើកលែងតែអំពើបាប (GS ២២,២)។

### ព្រលឹង និងចំណេះដឹងរបស់ព្រះគ្រីស្តក្នុងឋានៈជាមនុស្ស

៤៧១-លោក អាពូលីនែរ នៃឡៅឌីសេអះអាងថា ក្នុងអង្គព្រះគ្រីស្តព្រះបន្ទូលបានជំនួសព្រលឹង ឬវិញ្ញាណ។ ព្រះសហគមន៍បានប្រកាសប្រឆាំងនឹងកំហុសនេះថាព្រះបុត្រាអស់កល្បជានិច្ចបានទទួលយកព្រលឹងប្រាជ្ញារបស់មនុស្ស (DS ១៤៩)។

៤៧២-ព្រលឹងនេះដែលព្រះបុត្រារបស់ព្រះជាម្ចាស់បានទទួលយកមានចំណេះដឹងខាងមនុស្សយ៉ាងពិតប្រាកដ។ ដោយសារព្រលឹងរបស់ព្រះគ្រីស្តមកពីសភាពជាមនុស្ស ព្រលឹងនេះមានកំណត់ព្រំដែនក្នុងពេលវេលា និងអាកាសផង។ ហេតុនេះហើយដោយកើតមកជាមនុស្ស ព្រះបុត្រារបស់ព្រះជាម្ចាស់បានសុខចិត្ត "មានចម្រើនវ័យឡើង ហើយមានប្រាជ្ញាកាន់តែវាងវៃ" (លក ២,៥២) ព្រមទាំងសុខចិត្តរៀនបន្តិចម្តងៗអំពីលក្ខណៈជាមនុស្សដែលយើងត្រូវរៀនតាមបទពិសោធន៍ (មក ៦,៣៨; មក ៨,២៧; យហ ១១,៣៤)។ ព្រះអង្គសុខចិត្តបន្ទាបខ្លួនយក "ឋានៈជាទាសករ" (ភីល ២,៧)។

៤៧៣-ក៏ប៉ុន្តែនៅពេលជាមួយគ្នានេះចំណេះដឹងក្នុងឋានៈជាមនុស្សនៃព្រះបុត្រារបស់ព្រះជាម្ចាស់សម្តែងនូវឋានៈជាព្រះជាម្ចាស់របស់ព្រះអង្គដែរ (សន្តៈ គ្រេគ័រ ដ៏ប្រសើរ; DS ៤៧៥)។ "សភាពជាមនុស្សនៃព្រះបុត្រារបស់ព្រះជាម្ចាស់មិនមែនដោយខ្លួនឯង ប៉ុន្តែដោយរួមជាមួយព្រះបន្ទូលស្គាល់ និងសម្តែងនៅក្នុងខ្លួនអ្វីៗដែលព្រះអង្គត្រូវការដឹងអំពីព្រះជាម្ចាស់" (សន្តៈ ម៉ាកស៊ីម)។ ហេតុនេះព្រះបុត្រារបស់ព្រះជាម្ចាស់កើតជាមនុស្ស ស្គាល់ព្រះបិតារបស់ព្រះអង្គភ្លាមៗ និងយ៉ាងជិតស្និទ្ធ (មក ១៤,៣៦; មថ ១១,២៧; យហ ១,១៨)។ ចំណេះដឹងក្នុងឋានៈជាមនុស្សរបស់ព្រះបុត្រាបង្ហាញទៀតថា ព្រះអង្គអាចឈ្វេងយល់ចិត្តគំនិតដ៏លាក់កំបាំងរបស់មនុស្សបាន (មក ២,៨; យហ ២,២៥; ៦,៦១)។

៤៧៤-ដោយរួមជាមួយព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ នៅក្នុងអង្គព្រះបន្ទូលកើតជាមនុស្ស ចំណេះដឹងក្នុងឋានៈជាមនុស្សរបស់ព្រះគ្រីស្ត ស្គាល់ឲ្យបានពេញលក្ខណៈនូវគម្រោងការដ៏អស់កល្បជានិច្ចដែលព្រះអង្គយាងមកសម្តែង (មក ៨,៣១; ៩,៣១)។ ព្រះអង្គទទួលស្គាល់ថាមិនដឹងអំពីអ្វីៗទាំងអស់ (មក ១៣,៣២) ដ្បិតព្រះអង្គ

មិនបានទទួលបេសកកម្មឲ្យសម្ដែងការទាំងនោះ (កក ១,៧)។

### បំណងរបស់ព្រះគ្រីស្ដក្នុងឋានៈជាមនុស្ស

៤៧៥-តាមរបៀបដដែលនៅមហាសន្និបាតសកលទីប្រាំមួយ (កុងស្តង់ទីណូបទី៣នៅឆ្នាំ៦៨១) ព្រះសហគមន៍បានប្រកាសថា ព្រះគ្រីស្ដមានបំណងពីរ និងការប្រតិបត្តិពីរដែលមកពីសភាពជាព្រះជាម្ចាស់ផង មកពីសភាពជាមនុស្សផង ហើយដែលមិនប្រឆាំងនឹងគ្នា តែរួមសហការជាមួយគ្នា។ ហេតុនេះក្នុងឋានៈជាមនុស្ស ព្រះបន្ទូលកើតជាមនុស្សមានបំណងស្ដាប់បង្គាប់ព្រះបិតារបស់ព្រះអង្គ អំពីអ្វីដែលព្រះអង្គក្នុងឋានៈជាព្រះជាម្ចាស់បានសម្រេចរួមជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីសង្គ្រោះយើង (DS ៥៥៦-៥៥៩)។ បំណងរបស់ព្រះគ្រីស្ដក្នុងឋានៈជាមនុស្ស "តាមព្រះបំណងរបស់ព្រះអង្គក្នុងឋានៈជាព្រះជាម្ចាស់មិនប្រឆាំងនឹងព្រះបំណងនេះទេ ប៉ុន្ដែចុះចូលក្រោមព្រះបំណងដ៏មានឫទ្ធានុភាពសព្វប្រការនេះ" (DS ៥៥៦)។

### រូបកាយពិតប្រាកដរបស់ព្រះគ្រីស្ដ

៤៧៦-ដោយសារព្រះបន្ទូលកើតជាមនុស្ស ដោយទទួលយកសភាពជាមនុស្សយ៉ាងពិតប្រាកដ រូបកាយព្រះគ្រីស្ដក៏មានកំណត់ដែរ (DS ៥០៤)។ ហេតុនេះយើងអាច "គូរ" (កាឡ ៣,២) ព្រះភ័ក្ត្ររបស់ព្រះយេស៊ូក្នុងឋានៈជាមនុស្សបាន។ នៅមហាសន្និបាតសកលទីប្រាំមួយ (នីសេទី២ នៅឆ្នាំ៧៨៧; DS ៦០០-៦០៣) ព្រះសហគមន៍ទទួលស្គាល់ថាយើងអាចគូរព្រះយេស៊ូធ្វើជារូបដ៏វិសុទ្ធបាន។

៤៧៧-ជាមួយគ្នានេះដែរព្រះសហគមន៍តែងតែទទួលស្គាល់ថា ក្នុងព្រះកាយរបស់ព្រះយេស៊ូ "យើងអាចមើលឃើញព្រះជាម្ចាស់ដែលមើលមិនឃើញ"។ តាមពិតលក្ខណៈពិសេសនៃព្រះកាយរបស់ព្រះគ្រីស្ដសម្ដែងនូវអង្គនៃព្រះបុត្រារបស់ព្រះជាម្ចាស់ដែលបានទទួលយករូបរាងនៃរូបកាយរបស់ព្រះអង្គក្នុងឋានៈជាមនុស្ស។ ដូច្នេះហើយបានជាយើងអាចគោរពគំនូររបស់ព្រះយេស៊ូ ដ្បិតអ្នកជឿដែលគោរពរូបព្រះអង្គ "គោរពព្រះយេស៊ូដែលគេបានគូរ" (DS ៦០១)។

### បេះដូងនៃព្រះបន្ទូលកើតជាមនុស្ស

៤៧៨-ព្រះយេស៊ូបានស្គាល់ និងស្រឡាញ់យើងទាំងអស់គ្នា និងយើងម្នាក់ៗអស់មួយជីវិត និងនៅពេលរងទុក្ខលំបាក ព្រះអង្គបានប្រគល់ខ្លួនព្រះអង្គសម្រាប់យើងរាល់គ្នាដែរ៖ "ព្រះបុត្រារបស់ព្រះជាម្ចាស់បានស្រឡាញ់ខ្ញុំ និងបានបូជាព្រះជន្មសម្រាប់ខ្ញុំ" (កាឡ ២,២០)។ ព្រះអង្គបានស្រឡាញ់យើងទាំងអស់គ្នាដោយមានបេះដូងក្នុងឋានៈជាមនុស្ស។ ហេតុនេះព្រះសហគមន៍ "ចាត់ទុកថា" ដើម្បីសង្គ្រោះយើងបេះដូងដ៏សក្ការៈរបស់ព្រះយេស៊ូដែលត្រូវធ្លុះធ្លាយដោយអំពើបាបរបស់យើង (យហ ១៩,៣៤) "ជាទីសម្គាល់ និងនិមិត្តរូបដ៏អស្ចារ្យ... ដែលព្រះសង្គ្រោះតែងតែសម្ដែងសេចក្ដីស្រឡាញ់នេះចំពោះព្រះបិតា និងមនុស្សទាំងអស់ ដោយគ្មានខានឡើយ" (DS ៣៩២៤; DS ៣៨១២)។

## សង្ខេប

៤៧៩-នៅពេលកំណត់របស់ព្រះជាម្ចាស់ ព្រះបុត្រាតែមួយរបស់ព្រះបិតា ព្រះបន្ទូលអស់កល្បជានិច្ច ពោលគឺព្រះបន្ទូល និងតំណាងពិតប្រាកដរបស់ព្រះបិតា បានប្រសូតជាមនុស្ស៖ ដោយមិនបានបាត់បង់សភាពជាព្រះជាម្ចាស់

ព្រះអង្គបានទទួលយកសភាពជាមនុស្ស។

៤៨០-ព្រះយេស៊ូគ្រីស្តពិតជាព្រះជាម្ចាស់ផង ពិតជាមនុស្សផង ហេតុនេះហើយបានជាព្រះអង្គជាស្ពានតែមួយរវាងព្រះជាម្ចាស់ និងមនុស្ស។

៤៨១-ព្រះយេស៊ូគ្រីស្តមានសភាពពីរ គឺសភាពជាព្រះជាម្ចាស់ផង សភាពជាមនុស្សផង ដែលមិនលាយឡំទេ ប៉ុន្តែដែលរួមគ្នាក្នុងអង្គតែមួយនៃព្រះបុត្រារបស់ព្រះជាម្ចាស់។

៤៨២-ដោយព្រះគ្រីស្តពិតជាព្រះជាម្ចាស់ផង ពិតជាមនុស្សផង ព្រះអង្គមានប្រាជ្ញា និងឆន្ទះរបស់មនុស្ស ដែលរួមជាមួយប្រាជ្ញា និងឆន្ទះរបស់ព្រះជាម្ចាស់ ឲ្យបានពេញលក្ខណៈ ហើយដែលរួមជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ។

៤៨៣-ការប្រសូតជាមនុស្សរបស់ព្រះជាម្ចាស់ គឺជាអាថ៌កំបាំងដ៏អស្ចារ្យនៃសភាពជាព្រះជាម្ចាស់ និងសភាពជាមនុស្ស ដែលរួមជាមួយគ្នា ក្នុងអង្គតែមួយនៃព្រះបន្ទូល។

## កថាខណ្ឌទី២៖"...ដែលមានកំណើតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី"

### ១-ដែលមានកំណើតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ...

៤៨៤-ពេលទេវទូតជូនដំណឹងអំពីកំណើតព្រះយេស៊ូដល់នាងម៉ារី "ពេលកំណត់ដល់ហើយ" (កាឡ ៤,៤) គឺព្រះជាម្ចាស់បំពេញតាមព្រះបន្ទូលសន្យាដែលទ្រង់បានរៀបចំទុកជាមុន។ ព្រះអង្គអញ្ជើញនាងម៉ារីឲ្យប្រសូតព្រះគ្រីស្ត ដែលមាន "គ្រប់លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់" "នៅក្នុងរូបកាយ" របស់ព្រះអង្គ (កូឡ ២,៩)។ ព្រះវិញ្ញាណប្រកបដោយឫទ្ធានុភាពឆ្លើយតបនឹងសំណួររបស់នាងម៉ារីថា៖ "តើធ្វើដូចម្ដេចនឹងឲ្យការនេះកើតឡើងបាន បើនាងខ្ញុំមិនរួមរស់ជាមួយបុរសណាផង?" (លក ១,៣៤) គឺ "ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកសណ្ឋិតលើនាង" (លក ១,៣៥)។

៤៨៥-បេសកកម្មរបស់ព្រះវិញ្ញាណដ៏វិសុទ្ធតែងតែរួមជាមួយ និងក្រោមបេសកកម្មរបស់ព្រះបុត្រា (យហ ១៦,១៤-១៥)។ ព្រះជាម្ចាស់ចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមក ដើម្បីឲ្យនាងម៉ារីបានវិសុទ្ធ និងប្រោសនាងឲ្យមានគភ៌។ ព្រះវិញ្ញាណជា "ព្រះអម្ចាស់ដែលប្រទានជីវិត" ទ្រង់ក៏ប្រោសនាងម៉ារីជាមនុស្សម្នាក់ឲ្យប្រសូតព្រះបុត្រាអស់កល្បជានិច្ចរបស់ព្រះបិតា។

៤៨៦-ព្រះបុត្រាតែមួយរបស់ព្រះបិតាដែលចាប់កំណើតដូចមនុស្សម្នាក់ក្នុងផ្ទៃរបស់ព្រហ្មចារិនីម៉ារីជា "ព្រះគ្រីស្ត" គឺព្រះវិញ្ញាណដ៏វិសុទ្ធបានអភិសេកព្រះអង្គ (មថ ១,២០; លក ១,៣៥)។ ទោះបីព្រះអង្គបានសម្ដែងការនេះបន្តិចម្ដងៗឲ្យពួកគង្វាល (លក ២,៨-២០) ពួកហោរាចារ្យ (មថ ២,១-១២) លោកយ៉ូហានបាទីស្ត (យហ ១,៣១-៣៤) និងពួកសាវ័ក (យហ ២,១១) ឃើញយ៉ាងណាក៏ដោយ ក៏ព្រះអង្គបានទទួលអភិសេកតាំងពីកំណើតមក។ ជីវិតទាំងស្រុងរបស់ព្រះយេស៊ូគ្រីស្តនឹងសម្ដែងឲ្យដឹងថាតើ "ព្រះជាម្ចាស់បានចាក់ព្រះវិញ្ញាណដ៏វិសុទ្ធ និងឫទ្ធានុភាពអភិសេកព្រះយេស៊ូ" (កក ១០,៣៨) យ៉ាងដូចម្ដេច។

### ២-...ហើយទ្រង់ប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី

៤៨៧-អ្វីដែលព្រះសហគមន៍កាតូលិកជឿអំពីនាងម៉ារី ចាក់គ្រឹះលើអ្វីដែលព្រះសហគមន៍ជឿលើអំពីព្រះគ្រីស្ត ប៉ុន្តែអ្វីដែលព្រះសហគមន៍បង្រៀនអំពីនាងម៉ារី បំភ្លឺជំនឿរបស់ព្រះសហគមន៍លើព្រះគ្រីស្តទៅវិញ។

### ព្រះជាម្ចាស់តម្រូវនាងម៉ារីទុកជាមុន

៤៨៨-"ព្រះជាម្ចាស់បានចាត់ព្រះបុត្រារបស់ព្រះអង្គ" (កាឡ ៤,៤) ប៉ុន្តែព្រះអង្គសព្វព្រះហឫទ័យឲ្យសត្វលោកមួយរួមសហការជាមួយព្រះអង្គដោយគ្មានបង្ខិតបង្ខំ ដើម្បី "ធ្វើរូបកាយមួយ" (ហប ១០,៥) ឲ្យព្រះអង្គ។ ហេតុនេះហើយបានជាតាំងពីមុនសម័យកាលទាំងអស់ ព្រះជាម្ចាស់បានជ្រើសរើសស្ត្រីជនជាតិអ៊ីស្រាអែលម្នាក់ គឺយុវនារីជនជាតិយូដាពីភូមិណាសារ៉ែត នៅស្រុកកាលីឡេ "ស្ត្រីក្រមុំព្រហ្មចារីម្នាក់ឈ្មោះ ម៉ារី ជាគូដណ្ដឹងរបស់កំលោះយ៉ូសែប ដែលត្រូវជាញាតិវង្សព្រះបាទដាវីឌ" (លក ១,២៦-២៧)។

ព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណាយ៉ាងក្រៃលែង ទ្រង់សព្វព្រះហឫទ័យឲ្យមាតាដែលព្រះអង្គតម្រូវទុកជាមុន សុខចិត្តធ្វើតាមព្រះបន្ទូលព្រះអង្គ មុនព្រះបុត្រាប្រសូតជាមនុស្ស។ ដូចស្ត្រីម្នាក់រួមសហការក្នុងកិច្ចនាំមនុស្សលោកស្លាប់យ៉ាងណា ក៏ស្ត្រីម្នាក់ទៀត រួមសហការនាំឲ្យមនុស្សលោកមានជីវិតយ៉ាងនោះដែរ (LG ៥៦)។

៤៨៩-អស់រយៈពេលសម្ព័ន្ធមេត្រីចាស់ ស្ត្រីបរិសុទ្ធជាច្រើននាក់បានរៀបចំបេសកកម្មរបស់នាងម៉ារី។ ពីដំបូងបង្អស់មាននាង អេវ៉ា គឺទោះបីនាងមិនបានស្ដាប់បង្គាប់ព្រះជាម្ចាស់ក៏ដោយ ក៏ព្រះអង្គមានព្រះបន្ទូលសន្យាថានឹងប្រទានកូនចៅដែលនឹងឈ្នះមារ (កណ ៣,១៥) ហើយនាងនឹងទៅជាមាតារបស់មនុស្សទាំងអស់ដែលមានជីវិត (កណ ៣,២០)។ ដោយសារព្រះបន្ទូលសន្យានេះ ទោះបីនាង សារ៉ា អាយុចាស់ជរាយ៉ាងណាក៏ដោយ ក៏នាងមានកូនមួយ (កណ ១៨,១០-១៤)។ លើសសេចក្ដីរង់ចាំរបស់មនុស្ស ព្រះជាម្ចាស់ជ្រើសរើសអ្វីដែលមនុស្សលោកចាត់ទុកថាថោកទាប និងទន់ខ្សោយ (១ករ ១,២៧) ដើម្បីបង្ហាញថាព្រះអង្គគោរពព្រះបន្ទូលសន្យារបស់ព្រះអង្គ គឺមាននាង ហាណ្ណា ជាមាតារបស់លោក សាមូអែល (១សម ១) នាង ដេបូរាស នាង រូថ នាង យូឌីត នាង អេសធែរ និងស្ត្រីជាច្រើនផ្សេងទៀត។ "នាង ម៉ារី ពិតជាអ្នកតូចតាច និងអ្នកសុភាពរាបសាររបស់ព្រះអម្ចាស់ ដែលមានចិត្តសង្ឃឹមថា និងទទួលការសង្គ្រោះដោយផ្ញើជីវិតលើព្រះអង្គ លើសអ្នកឯទៀត។ នៅទីបញ្ចប់ នាងជាបុត្រីក្រុងស៊ីយ៉ូនដ៏ប្រសើរជាងគេ។ ក្រោយពីប្រជារាស្ត្រទន្ទឹងរង់ចាំព្រះបន្ទូលសន្យាយ៉ាងយូរអង្វែង ពេលកំណត់មកដល់ហើយ" (LG ៥៥)។

### តាំងពីកើតនាងម៉ារីគ្មានជំពាក់បាបកម្មអ្វី

៤៩០-"ព្រះជាម្ចាស់បានផ្ដត់ផ្ដង់នាងដោយព្រះអំណោយទាន តម្រូវតាមករណីកិច្ចដ៏ប្រសើរដែលនាងត្រូវបំពេញនោះ" (LG ៥៦) គឺឲ្យនាងម៉ារីធ្វើជាមាតានៃព្រះសង្គ្រោះ។ នៅពេលជូនដំណឹងអំពីកំណើតព្រះយេស៊ូ ទេវទូតជម្រាបនាងថា "ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងនាងហើយ" (លក ១,២៨) ដ្បិតព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ត្រូវតែជួយគាំទ្រនាងម៉ារី ដើម្បីឲ្យនាងអាចស្ម័គ្រចិត្តផ្ញើជីវិតទាំងស្រុងចំពោះការត្រាស់ហៅរបស់ព្រះអង្គ។

៤៩១-ពីសតវត្សមួយទៅសតវត្សមួយព្រះសហគមន៍បានឈ្វេងយល់បន្តិចម្ដងៗថា នាងម៉ារី ដែល "ព្រះអម្ចាស់គាប់ព្រះហឫទ័យ" (លក ១,២៨) ទ្រង់បានលោះនាងម៉ារីចាប់ពីផ្ទៃម្ដាយ។ នៅឆ្នាំ១៨៥៤ សម្ដេចប៉ាប ពីយូទី៩

ប្រកាសគោលការណ៍អំពីព្រះនាងម៉ារីមិនជំពាក់បាបតាំងពីផ្ទៃនេះ ៖

ដោយសារព្រះហឫទ័យប្រោសប្រណីសន្ដោសយ៉ាងពិសេសរបស់ព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការព្រហ្មចារិនីម៉ារីដ៏មានសុភមង្គល ជាស្ដ្រីនិមលមិនដែលជំពាក់បាបកម្មអ្វីឡើយចាប់តាំងពីផ្ទៃម្ដាយមកម្ល៉េះ។ ព្រះអង្គសព្វព្រះហឫទ័យធ្វើដូច្នេះដោយសារកុសលផលបុណ្យរបស់ព្រះយេស៊ូគ្រីស្ដ ជាព្រះសង្គ្រោះមនុស្សលោក (DS ២៨០៣)។

៤៩២-"ចាប់តាំងពីពេលនាងចាប់ផ្ទៃដំបូង ព្រះជាម្ចាស់បានប្រោសឲ្យនាងបានវិសុទ្ធភ្លឺស្វាងអស្ចារ្យជាច់គេ" (LG ៥៦) ព្រោះតែព្រះគ្រីស្ដ៖ "ព្រះជាម្ចាស់បានរំដោះនាងយ៉ាងអស្ចារ្យ ដោយឈ្វេងយល់ដល់កុសលផលបុណ្យរបស់ព្រះបុត្រាព្រះអង្គ" (LG ៥៣)។ ព្រះបិតា "បានប្រោសប្រទានព្រះពរគ្រប់យ៉ាង ផ្នែកខាងវិញ្ញាណពីស្ថានបរមសុខមក (នាងម៉ារី) ក្នុងអង្គព្រះគ្រីស្ដ" (អភ ១,៣) លើសពីសត្វលោកនានា។ "ព្រះអង្គបានជ្រើសរើស (នាងម៉ារី) ក្នុងអង្គព្រះគ្រីស្ដតាំងពីកំណើតពិភពលោកមកម្ល៉េះ ដើម្បីឲ្យ (នាង) បានវិសុទ្ធ និងឥតសៅហ្មងនៅចំពោះព្រះភ័ក្ត្រព្រះអង្គ" (អភ ១,៤)។

៤៩៣-គ្រូបាធ្យាយខាងបូព៌ាប្រទេសហៅព្រះមាតារបស់ព្រះជាម្ចាស់ជា "ស្ត្រីដ៏វិសុទ្ធបំផុត" (Panaghia) ពួកលោកលើកតម្កើងព្រះនាង "ជាស្ត្រីនិមលមិនដែលជាប់ជំពាក់បាប ជាស្ត្រីព្រះវិញ្ញាណដ៏វិសុទ្ធបានសូន និងជាស្ត្រីដែលព្រះអង្គបានបង្កើតជាថ្មី" (LG ៥៦)។ ដោយសារព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ នាងម៉ារីមិនដែលប្រព្រឹត្តអំពើបាបណាមួយអស់មួយជីវិត។

### "សូមឲ្យបានសម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គចុះ..."

៤៩៤-នៅពេលទេវទូតជូនដំណឹងថា នាងនឹងសម្រាល "ព្រះបុត្រានៃព្រះដ៏ខ្ពង់ខ្ពស់បំផុត" ដោយមិនរួមរស់ជាមួយបុរសណាមួយ ដោយសារគុណធម៌នៃព្រះវិញ្ញាណដ៏វិសុទ្ធ (លក ១,២៨-៣៧) នាងម៉ារីបាន "ប្រតិបត្តិតាមជំនឿ" (រម ១,៥) ដោយជឿជាក់ថា "គ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើត" (លក ១,៣៧-៣៨)។ "នាងយល់ស្របនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយក្លាយទៅជាមាតារបស់ព្រះយេស៊ូ។ នាងសុខចិត្តយ៉ាងស្មោះស្ម័គ្របំផុតធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលចង់សង្គ្រោះមនុស្សលោក ដោយគ្មានអំពើបាបណាមករារាំងនាងឡើយ។ នាងក៏ប្រគល់ខ្លួនទាំងស្រុង ក្នុងឋានៈជាអ្នកបម្រើរបស់ព្រះអម្ចាស់ សុខចិត្តថ្វាយខ្លួនទៅព្រះបុត្រាផ្ទាល់ និងព្រះរាជកិច្ចនៃព្រះបុត្រារបស់នាង ដើម្បីបម្រើគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ រួមជាមួយព្រះបុត្រានិងក្រោមអំណាចរបស់ព្រះបុត្រា ដោយព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការប្រោសប្រណីផងដែរ" (LG ៥៦)។

សន្ដៈ អ៊ីរ៉េណេ មានប្រសាសន៍ថា «ដោយនាងម៉ារីសុខចិត្តធ្វើតាមព្រះបញ្ជារបស់ព្រះជាម្ចាស់ នាងក្លាយទៅជាអ្នកនាំការសង្គ្រោះមកឲ្យនាងផ្ទាល់ខ្លួន និងមកឲ្យមនុស្សលោកទាំងមូលផងដែរ»។ ហេតុនេះហើយបានជាគ្រូបាធ្យាយពីបុរាណជាច្រើន ចូលចិត្តនិយាយនៅពេលទេសនាថា "ដោយនាងម៉ារីសុខចិត្តធ្វើតាមព្រះបញ្ជារបស់ព្រះជាម្ចាស់ នាងស្រាយចំណងដែលនាង អេវ៉ា បានចងដោយមិនព្រមធ្វើតាមព្រះបញ្ជារបស់ព្រះអង្គកាលពីពេលមុននោះ។ អ្វីដែលព្រហ្មចារិនីអេវ៉ាបានចងដោយមិនព្រមជឿ ព្រហ្មចារិនីម៉ារីបានស្រាយដោយសារជំនឿ"។ អស់លោកតែងប្រៀបប្រដូចនាងម៉ារីនឹងនាងអេវ៉ា ហើយធ្លាប់ហៅនាងម៉ារីថា "មាតារបស់មនុស្សដែលមានជីវិត" និងប្រកាសជាញឹកញាប់ថា "ដោយសារនាងអេវ៉ា សេចក្ដីស្លាប់ចូលមកក្នុងពិភពលោក ដោយសារនាងម៉ារី ជីវិតចូលមកវិញ" (LG ៥៦)។

## នាងម៉ារីជាព្រះមាតារបស់ព្រះជាម្ចាស់

៤៩៥-ក្នុងដំណឹងល្អគេហៅនាងម៉ារីថា "មាតារបស់ព្រះយេស៊ូ" (យហ ២,១; ១៩,២៥) (មថ ១៣,៥៥) ហើយមុនបុត្រនាងកើតមកដោយមានព្រះវិញ្ញាណជំរុញ គេលើកតម្កើងនាងជា "មាតាព្រះអម្ចាស់របស់ខ្ញុំ" (លក ១,៤៣)។ នាងម៉ារីបានប្រសូតមនុស្សម្នាក់ពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលពិតជាបានទៅជាបុត្ររបស់នាងក្នុងឋានៈជាមនុស្ស បុត្រនេះក៏ជាព្រះបុត្រាអស់កល្បជានិច្ចរបស់ព្រះបិតាអង្គទីពីរនៃព្រះត្រៃឯក។ ដូច្នេះព្រះសហគមន៍ប្រកាសថា នាងម៉ារីពិតជាព្រះមាតារបស់ព្រះជាម្ចាស់ (Theotokos) (DS ២៥១)។

## នាងម៉ារីជាស្ត្រីព្រហ្មចារី

៤៩៦-ក្នុងធម៌ប្រកាសជំនឿដំបូង (DS ១០-៦៤) ព្រះសហគមន៍ប្រកាសថា ព្រះយេស៊ូបានចាប់ផ្ទៃកំណើតពីនាងម៉ារីដោយសារតែឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះសហគមន៍បានលម្អិតទៀតថាព្រះយេស៊ូបានចាប់ផ្ទៃ "ពីព្រះវិញ្ញាណដ៏វិសុទ្ធដោយគ្មានពូជនៃបុរសម្នាក់ឡើយ" (DS ៥០៣)។ គ្រូបាធ្យាយយល់ឃើញថា ព្រះយេស៊ូប្រសូតពីស្ត្រីព្រហ្មចារិយម្នាក់ជាទីសម្គាល់ថា គឺពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែលយាងមកយកសភាពជាមនុស្សដូចយើងដែរ។

> ហេតុនេះសន្តៈ អ៊ីញ៉ាស នៃអង់ទីអូស (ដើមសតវត្សទីពីរ)៖ "បងប្អូនជឿជាក់យ៉ាងច្បាស់ថាព្រះអម្ចាស់នៃយើងដែលពិតជាព្រះញាតិវង្សព្រះបាទដាវីឌក្នុងឋានៈជាមនុស្ស (រម ១,៣) ព្រះបុត្រារបស់ព្រះជាម្ចាស់តាមព្រះហឫទ័យ និងឫទ្ធានុភាពរបស់ព្រះជាម្ចាស់ (យហ ១,១៣) ពិតជាបានប្រសូតពីស្ត្រីព្រហ្មចារី (...) ព្រះអង្គពិតជាបានត្រូវគេបោះដែកគោលទម្លុះសាច់ ហើយឆ្កាងដើម្បីយើងមែននៅជំនាន់លោក ប៉ុនពីឡាត (...) ព្រះអង្គពិតជាបានរងទុក្ខលំបាក ហើយទ្រង់ពិតជាមានព្រះជន្មមានជីវិតថ្មី"។

៤៩៧-អ្នកនិពន្ធកំណត់គម្ពីរដំណឹងល្អ (មថ ១,១៨-២៥; លក ១,២៦-៣៨) យល់ឃើញថាព្រះយេស៊ូប្រសូតពីស្ត្រីព្រហ្មចារីម្នាក់មកពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដែលយើងមិនអាចយល់បានហួសពីសមត្ថភាពមនុស្ស (លក ១,៣៤)។ ពេលនិយាយអំពីនាង ម៉ារី ជាគូដណ្តឹងរបស់លោក យ៉ូសែប ទេវទូតមានប្រសាសន៍ទៅកាន់លោកថា៖ "បុត្រដែលនៅក្នុងផ្ទៃនាងកើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធ" (មថ ១,២០)។ ព្រះសហគមន៍យល់ឃើញថា ព្រះជាម្ចាស់បំពេញព្រះបន្ទូលសន្យារបស់ព្រះអង្គដែលព្យាការីអេសាយបានថ្លែងជាមុន៖ "មើល៍! ស្ត្រីក្រមុំព្រហ្មចារិយនឹងមានផ្ទៃពោះ នាងនឹងសម្រាលបានបុត្រមួយ" (អស ៧,១៤) តាមការបកប្រែជាភាសាក្រិកនៃ មថ ១,២៣។

៤៩៨-មានគេខ្វល់ខ្វាយដោយសារដំណឹងល្អរបស់សន្តៈ ម៉ាកុស និងលិខិតផ្សេងៗនៃសម្ពន្ធមេត្រីថ្មី គ្មានរៀបរាប់ឲ្យដឹងទាល់តែសោះអំពីភាពជាស្ត្រីព្រហ្មចារីរបស់នាងម៉ារី។ មានគេបានចោទសួរផងដែរថា តើគ្រាន់តែជារឿងព្រេងនិទាន ឬគ្រាន់តែជាសំណេរក្នុងទេវកថា ដែលមិនគិតដល់ប្រវត្តិសាស្ត្រប៉ុណ្ណោះ។ ត្រូវតែឆ្លើយថា អ្នកមិនព្រមជឿទាំងជនជាតិយូដា ទាំងសាសន៍ដទៃ (សន្តៈ យ៉ូស្តាំង; លោកអូរីសែន) បានជំទាស់ប្រឆាំងចំអកឡកឡឺយយ៉ាងខ្លាំង មិនយល់ស្រុបនឹងអ្នកជឿថា ព្រះយេស៊ូបានប្រសូតពីស្ត្រីព្រហ្មចារីយ៍ ដូច្នេះគេជឿសេចក្តីនេះ មិនមែនដើម្បីធ្វើតាមទេវកថានៃសាសនាដទៃ ឬដើម្បីស្របនឹងសំណេរផ្សេងៗទៀតក្នុងសម័យនោះឡើយ។ មានតែអ្នកជឿប៉ុណ្ណោះ ដែលអាចយល់អំពីអត្ថន័យនៃហេតុការណ៍នេះ "ជាចំណងដែលចងគម្រោងការទាំងអស់រវាងគ្នានិងគ្នា" (DS ៣០០៦) ក្នុងគម្រោងការទាំងស្រុងរបស់ព្រះគ្រីស្ត ពីពេលព្រះអង្គចាប់កំណើតជាមនុស្សរហូតដល់ព្រះអង្គសោយទិវង្គត និងមានព្រះជន្មថ្មី។ សន្តៈ អ៊ីញ៉ាស់ នៃអង់ទីអូស ផ្តល់សក្ខីភាពនៃចំណងនេះថា "ម្ចាស់

នៃលោកនេះ បានធ្វើមិនដឹងថា នាងម៉ារីជាស្ត្រីព្រហ្មចារីយ៍ ហើយព្រះយេស៊ូបានប្រសូត និងបានសោយទិវង្គត ឡើយ គឺជាគម្រោងការដ៏អស្ចារ្យបី ដែលលាន់ឮក្នុងភាពស្ងៀមស្ងាត់របស់ព្រះជាម្ចាស់" (អភ ១៩,១) (១ករ ២,៨)។

## នាងម៉ារីនៅតែជាស្ត្រីព្រហ្មចារី

៤៩៩-ដោយសិក្សាកាន់តែជ្រៅៗនៅនាងម៉ារីជាមាតាផង ព្រហ្មចារីផង ព្រះសហគមន៍បានប្រកាសថា នាងម៉ារី នៅតែពិតជាព្រហ្មចារីជាដរាបតរៀងទៅ (DS ៤២៧) សូម្បីតែនៅពេលព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស (DS ២៩១; ២៩៤; ៤៤២; ៥០៣; ៥៧១; ១៨៨០)។ កំណើតរបស់ព្រះគ្រីស្ត "មិនបន្ថយតែលើកព្រហ្មចារិយធម៌" របស់ព្រះមាតារបស់ព្រះអង្គវិញ (LG ៥៧)។ ពិធីបុណ្យព្រះសហគមន៍សរសើរនាងម៉ារីជា "ស្ត្រីព្រហ្មចារិយជាដរាប" (Aeiparthenos) (LG ៥២)។

៥០០-មានគេប្រកែកប្រឆាំងសេចក្តីនេះថាតាមព្រះគម្ពីរព្រះយេស៊ូមានបងប្អូន (មក ៣,៣១-៣៥; ៦,៣; ១ករ ៩,៥; កាឡ ១,១៩) ប៉ុន្តែព្រះសហគមន៍យល់ថាអត្ថបទទាំងនោះមិនសំដៅលើបុត្រផ្សេងរបស់ព្រហ្មចារិនី ម៉ារីឡើយ ដ្បិតលោក យ៉ាកុប និងលោក យ៉ូសែប "បងប្អូន" របស់ព្រះយេស៊ូ (មថ ១៣,៥៥) ជាកូនរបស់នាងម៉ារី ដែលជាសាវ័ករបស់ព្រះគ្រីស្ត (មថ ២៧,៥៦) ដែលគេហៅថា "នាងម៉ារីម្នាក់ទៀត" (មថ ២៨,១)។ ពួកគេជា បងប្អូនជីដូនមួយរបស់ព្រះយេស៊ូ បើតាមពាក្យសម្តីនៃសម្ពន្ធមេត្រីចាស់ (កណ ១៣,៨; ១៤,១៦; ២៩,១៥)។

៥០១-ព្រះយេស៊ូជាបុត្រតែមួយរបស់នាងម៉ារី។ ប៉ុន្តែនាងម៉ារីជាមាតាខាងវិញ្ញាណរបស់មនុស្សទាំងអស់ (យហ ១៩,២៦-២៧; វវ ១២,១៧) ដែលព្រះអង្គយាងមកសង្គ្រោះ៖ "នាងប្រសូតបុត្ររបស់នាង ហើយព្រះជាម្ចាស់ តែងតាំងបុត្រនោះឲ្យទៅជារៀមច្បងក្នុងបណ្តាបងប្អូនជាច្រើន (រម ៨,២៩) ក្នុងចំណោមអ្នកជឿទាំងប៉ុន្មាន។ ដូច្នេះនាងជួយសហការឲ្យអ្នកជឿទាំងនោះកើនឡើង និងជួយអប់រំគេដោយស្រឡាញ់គេក្នុងឋានៈជាម្តាយ" (LG ៦៣)។

## នាងម៉ារីជាមាតាព្រហ្មចារិយតាមគម្រោងការរបស់ព្រះជាម្ចាស់

៥០២-ពេលយើងមានជំនឿ យើងអាចយល់ឃើញអំពីមូលហេតុដ៏លាក់កំបាំងដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ ឲ្យព្រះបុត្រាកើតពីស្ត្រីព្រហ្មចារិយម្នាក់ ដើម្បីជួយសង្គ្រោះមនុស្សលោក។ មូលហេតុនោះទាក់ទងនឹងព្រះគ្រីស្ត បេសកកម្មរបស់ព្រះអង្គ និងការទទួលបេសកកម្មនេះ ដោយនាងម៉ារីសម្រាប់មនុស្សទាំងអស់៖

> ៥០៣-នាងម៉ារីជាស្ត្រីព្រហ្មចារិនីបង្ហាញថា ព្រះជាម្ចាស់ជាអ្នកផ្តើមគំនិតក្នុងការប្រសូតជាមនុស្ស។ ព្រះយេស៊ូ មានព្រះបិតាតែមួយ គឺព្រះជាម្ចាស់ (លក ២,៤៨-៤៩)។ "សភាពជាមនុស្សមិនធ្វើឲ្យព្រះអង្គឃ្លាតឆ្ងាយ ពីព្រះបិតាទេ (...) ព្រះអង្គជាព្រះបុត្រារបស់ព្រះបិតាក្នុងឋានៈជាព្រះជាម្ចាស់ ព្រះអង្គជាបុត្រារបស់មាតា ក្នុងឋានៈជាមនុស្ស ដូច្នេះព្រះអង្គក៏ជាព្រះបុត្រារបស់ព្រះជាម្ចាស់ផងដោយសភាពទាំងពីរ" (DS ៦១៩)។
>
> ៥០៤-ព្រះយេស៊ូមានកំណើតពីព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងផ្ទៃព្រហ្មចារិនីម៉ារី ពីព្រោះព្រះអង្គជាលោក អដាំថ្មី (១ករ ១៥,៤៥) ដែលចាប់ផ្តើមពិភពលោកថ្មី៖ "មនុស្សទីមួយកើតចេញពីដីមកមានលក្ខណៈជា ដី។ រីឯមនុស្សទីពីរវិញ កើតមកពីស្ថានបរមសុខ" (១ករ ១៥,៤៧)។ ចាប់តាំងពីក្នុងផ្ទៃម្តាយមកម្ល៉េះ សភាពជាមនុស្សរបស់ព្រះគ្រីស្តពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដ្បិតព្រះជាម្ចាស់ "ប្រទានព្រះវិញ្ញាណ មកព្រះអង្គយ៉ាងបរិបូណ៌" (យហ ៣,៣៤)។ "យើងបានទទួលព្រះហឫទ័យប្រណីសន្តោសមិនចេះអស់ មិនចេះហើយ (យហ ១,១៦) ពីគ្រប់លក្ខណៈសម្បត្តិរបស់ព្រះអង្គ" ដែលទ្រង់ជាសិរសានៃមនុស្សលោក

ដែលព្រះអង្គបានលោះ (កូឡ ១,១៨)។

៥០៥-ដោយប្រសូតពីស្ត្រីព្រហ្មចារិយព្រះយេស៊ូជាលោកអដាំថ្មី ដែលចាប់ផ្តើមកំណើតថ្មីនៃបុត្រធីតារបស់ព្រះជាម្ចាស់នៅក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធដោយសារជំនឿ។ "តើធ្វើដូចម្តេចឲ្យការនេះកើតឡើងបាន?" (លក ១,៣៤) (យហ ៣,៩)។ "អ្នកទាំងអស់នោះ (ដែលទៅជាបុត្រធីតារបស់ព្រះជាម្ចាស់) ពុំមែនកើតពីលោហិត ពីចំណង់តណ្ហា ឬពីការប៉ងប្រាថ្នារបស់មនុស្សឡើយ គឺកើតពីព្រះជាម្ចាស់ទៅវិញ" (យហ ១,១៣)។ ព្រះវិញ្ញាណប្រទានជីវិតនេះទាំងស្រុងទៅដល់មនុស្សដែលប្រៀបធៀបដូចជាព្រហ្មចារិនីម្នាក់។ នាងម៉ារីជាមាតាផង ជាស្ត្រីព្រហ្មចារិយផង បំពេញការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះមនុស្សឲ្យបានពេញលក្ខណៈ (២ករ ១១,២)។

៥០៦-នាងម៉ារីជាស្ត្រីព្រហ្មចារិយជាទីសម្គាល់នៃជំនឿរបស់នាង "ដែលមិនគួរឲ្យសង្ស័យអ្វីឡើយ" (LG ៦៣) ហើយជាទីសម្គាល់បង្ហាញថានាងម៉ារីថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ (១ករ ៧,៣៤-៣៥)។ គឺដោយសារជំនឿនាងទៅជាព្រះមាតានៃព្រះសង្គ្រោះ។ "នាងម៉ារីមានសុភមង្គលមិនគ្រាន់តែដោយសារនាងជាមាតារបស់ព្រះគ្រីស្តប៉ុណ្ណោះទេ ថែមទាំងនាងបានទទួលជំនឿពីព្រះគ្រីស្តផងដែរ" (សន្តៈ អូគូស្តាំង)។

៥០៧-នាងម៉ារីជាមាតាផង ព្រហ្មចារីផង ព្រោះនាងជារូបតំណាងដ៏ល្អឥតខ្ចោះរបស់ព្រះសហគមន៍ (LG ៦៣)៖ "ព្រះសហគមន៍ក្លាយទៅជាមាតាដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលព្រះសហគមន៍បានទទួលនៅក្នុងជំនឿ។ ដោយសារព្រះសហគមន៍ប្រៀនប្រដៅផង និងជ្រមុជទឹកផង ព្រះសហគមន៍ផ្តល់ជីវិតថ្មី និងអមតៈដល់បុត្រធីតាកើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធ និងពីព្រះជាម្ចាស់។ ព្រះសហគមន៍ព្រហ្មចារីព្រោះបានថ្វាយជំនឿដ៏វិសុទ្ធឥតសៅហ្មងដល់ស្វាមីរបស់ខ្លួន" (LG ៦៤)។

## សង្ខេប

៥០៨-ក្នុងចំណោមពូជពង្សរបស់នាងអេវ៉ា ព្រះជាម្ចាស់បានជ្រើសរើសព្រហ្មចារិណីម៉ារី ដើម្បីឲ្យទៅជាព្រះមាតានៃព្រះបុត្រាព្រះអង្គ។ "ពោរពេញដោយព្រះហឫទ័យប្រោសប្រណី" ព្រះនាងជា "ផលដ៏ល្អជាងគេនៃការសង្គ្រោះ" (SC ១០៣)៖ តាំងពីក្នុងផ្ទៃម្តាយមកម្ល៉េះ ព្រះនាងរួចពីអំពើបាបដើមដំបូង ហើយនៅតែរួចពីអំពើបាបណាមួយអស់មួយជីវិតរបស់ព្រះនាង។

៥០៩-ព្រះនាងម៉ារីពិតជា "ព្រះមាតារបស់ព្រះជាម្ចាស់" ដ្បិតព្រះនាងជាមាតានៃព្រះបុត្រាអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស ដែលជាព្រះជាម្ចាស់ផ្ទាល់។

៥១០-ព្រះនាងម៉ារី "នៅតែព្រហ្មចារិនីដោយមានគភ៌ ព្រហ្មចារិនីដោយសម្រាលបុត្រ ព្រហ្មចារិនីដោយចិញ្ចឹមបុត្រនេះ ព្រហ្មចារិនីរហូត" (សន្តៈ អូគូស្តាំង)៖ ព្រះនាងជា "អ្នកបម្រើរបស់ព្រះអម្ចាស់" (លក ១,៣៨) អស់ពីកម្លាំងកាយចិត្ត។

៥១១-ព្រហ្មចារិនីម៉ារី "បានរួមសហការក្នុងការសង្គ្រោះមនុស្សលោក នាងមានសេរីភាពដោយនាងផ្ញើជីវិតលើព្រះជាម្ចាស់ និងសុខចិត្តធ្វើតាមព្រះបញ្ញាព្រះអង្គ" (LG ៥៦)។ ព្រះនាងយល់ព្រម "ក្នុងនាមមនុស្សជាតិទាំងមូល" (សន្តៈ ថូម៉ាស នៃអាកាំង)៖ ដោយសារព្រះនាងបានស្តាប់បង្គាប់ ព្រះនាងបានទៅជានាងអេវ៉ាថ្មី ជាមាតារបស់អស់អ្នកដែលមានជីវិត។

## កថាខណ្ឌទី៣៖ ព្រឹត្តការណ៍ដ៏អស្ចារ្យនៃជីវិតរបស់ព្រះគ្រីស្ត

៥១២-ក្នុងចំណោមព្រឹត្តការណ៍ដ៏អស្ចារ្យនៃជីវិតរបស់ព្រះគ្រីស្ត ធម៌ប្រកាសជំនឿថ្លែងតែអំពីព្រឹត្តការណ៍ដ៏អស្ចារ្យនៅពេលព្រះគ្រីស្តកើតជាមនុស្ស (ព្រះយេស៊ូចាប់កំណើត និងប្រសូត) និងពេលព្រះអង្គសោយទិវង្គត និងមានព្រះជន្មមានជីវិតថ្មី (ព្រះយេស៊ូរងទុក្ខលំបាក ត្រូវគេឆ្កាងសោយទិវង្គត គេបញ្ចុះព្រះសពព្រះអង្គក្នុងរូងថ្មមួយ ព្រះអង្គយាងចុះទៅស្ថានក្រោម មានព្រះជន្មថ្មី និងយាងឡើងទៅស្ថានបរមសុខ)។ គ្មានប្រការណាមួយចែងអំពីព្រឹត្តិការណ៍ដ៏អស្ចារ្យនៃជីវិតដ៏លាក់កំបាំង និងជាសាធារណៈរបស់ព្រះយេស៊ូ ប៉ុន្តែប្រការទាំងប៉ុន្មានដែលទាក់ទងនឹងការប្រសូត ការសោយទិវង្គត និងការមានព្រះជន្មមានជីវិតថ្មីរបស់ព្រះយេស៊ូបំភ្លឺជីវិតទាំងស្រុងរបស់ព្រះអង្គនៅលើផែនដីនេះ គឺ "កិច្ចការទាំងប៉ុន្មានដែលព្រះយេស៊ូបានប្រព្រឹត្ត និង (...) សេចក្តីទាំងប៉ុន្មានដែលព្រះអង្គបានបង្រៀនតាំងពីដើមរៀងមករហូតដល់ថ្ងៃដែលព្រះជាម្ចាស់លើកព្រះអង្គឡើងទៅស្ថានបរមសុខ" (កក ១,១-២)។

៥១៣-តាមកាលៈទេសៈការអប់រំជំនឿត្រូវសម្តែងនូវលក្ខណៈសម្បត្តិនៃព្រឹត្តការណ៍ដ៏អស្ចារ្យទាំងអស់នៃជីវិតរបស់ព្រះយេស៊ូ។ ក្នុងសៀវភៅនេះយើងគ្រាន់តែណែនាំអំពីកត្តារួមនឹងព្រឹត្តការណ៍ដ៏អស្ចារ្យទាំងអស់នៃជីវិតរបស់ព្រះគ្រីស្ត (១.) ហើយអំពីព្រឹត្តការណ៍នៃជីវិតដ៏លាក់កំបាំង (២.) និងជីវិតជាសាធារណៈ (៣.) របស់ព្រះអង្គ។

### ១-ជីវិតទាំងស្រុងរបស់ព្រះគ្រីស្តជាព្រឹត្តការណ៍មួយដ៏អស្ចារ្យ

៥១៤-មានរឿងជាច្រើនដែលមនុស្សចង់ដឹងអំពីព្រះយេស៊ូ ប៉ុន្តែគ្មានកត់ត្រានៅក្នុងដំណឹងល្អទេ។ គ្មានអ្វីបញ្ជាក់អំពីការរស់នៅរបស់ព្រះយេស៊ូនៅភូមិណាសារ៉ែត សូម្បីតែអំពីការរស់នៅជាសាធារណៈរបស់ព្រះអង្គក៏មិនសូវមានផងដែរ (យហ ២០,៣០)។ សេចក្តីដែលមានកត់ត្រានៅក្នុងដំណឹងល្អ គឺ "ក្នុងបំណងឲ្យអ្នករាល់គ្នាជឿថាព្រះយេស៊ូពិតជាព្រះគ្រីស្ត និងពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយឲ្យអ្នករាល់គ្នាដែលជឿមានជីវិតដោយរួមជាមួយព្រះអង្គ" (យហ ២០,៣១)។

៥១៥-គម្ពីរដំណឹងល្អត្រូវបានសរសេរដោយសារអ្នកខ្លះក្នុងចំណោមមនុស្សដែលមានជំនឿមុនគេ (មក ១,១; យហ ២១,២៤) ចង់ចែករំលែកជំនឿនេះដល់អ្នកដទៃ។ ដោយសារជំនឿ គេបានស្គាល់ព្រះយេស៊ូ ហើយគេបានផ្តល់ស្លាកស្នាមនៃអាថ៌កំបាំងរបស់ព្រះអង្គក្នុងជីវិតរបស់ព្រះអង្គនៅលើផែនដីនេះ។ បន្ទាប់ពីព្រះអង្គទើបនឹងកើត (លក ២,៧) រហូតដល់ទឹកខ្មេះ ពេលព្រះអង្គរងទុក្ខលំបាក (មថ ២៧,៤៨) និងសំពត់ស្នបពេលព្រះអង្គមានព្រះជន្មមានជីវិតថ្មី (យហ ២០,៧) អ្វីៗទាំងអស់ក្នុងជីវិតព្រះយេស៊ូជាសញ្ញាសម្គាល់នៃអាថ៌កំបាំងរបស់ព្រះអង្គ។ តាមរយៈកិច្ចការការអស្ចារ្យ និងព្រះបន្ទូលរបស់ព្រះយេស៊ូ ព្រះជាម្ចាស់សម្តែងថា "គ្រប់លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់ស្ថិតនៅយ៉ាងពោរពេញក្នុងព្រះកាយព្រះគ្រីស្ត" (កូឡ ២,៩)។ សភាពជាមនុស្សរបស់ព្រះយេស៊ូដូចជា "អគ្គសញ្ញា" គឺទីសម្គាល់ និងឧបករណ៍បង្ហាញថាព្រះអង្គជាព្រះជាម្ចាស់ដែលនាំការសង្គ្រោះមក។ អ្វីដែលមើលឃើញក្នុងជីវិតរបស់ព្រះយេស៊ូលើផែនដីនេះ ឆ្លុះបញ្ចាំងអំពីអាថ៌កំបាំងដែលមើលមិនឃើញ គឺព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលមានបេសកកម្មសង្គ្រោះមនុស្សលោក។

#### កត្តារួមនៃព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះយេស៊ូ

៥១៦-ជីវិតទាំងស្រុងរបស់ព្រះគ្រីស្តសម្តែងព្រះបិតា គឺព្រះបន្ទូល និងកិច្ចការរបស់ព្រះអង្គពេលព្រះអង្គនៅស្ងៀមស្ងាត់ ឬរងទុក្ខលំបាក របៀបរស់នៅ និងរបៀបនិយាយស្តីរបស់ព្រះអង្គ។ ព្រះយេស៊ូអាចមានព្រះបន្ទូលថា៖

"អ្នកណាបានឃើញខ្ញុំ អ្នកនោះក៏បានឃើញព្រះបិតាដែរ" (យហ ១៤,៩) ហើយព្រះបិតា៖ "ព្រះអង្គនេះជាបុត្រដែលយើងបានជ្រើសរើស ចូរស្ដាប់ព្រះអង្គចុះ!" (លក ៩,៣៥)។ ព្រះអម្ចាស់នៃយើងបានកើតជាមនុស្ស ដើម្បីគាប់ព្រះហឫទ័យព្រះបិតា (ហប ១០,៥-៧) ព្រឹត្តិការណ៍ដ៏តូចតាចជាងគេរបស់ព្រះអង្គសម្ដែង "សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង" (១យហ ៤,៩)។

៥១៧-ជីវិតទាំងស្រុងរបស់ព្រះគ្រីស្ដជាព្រឹត្តិការណ៍ដ៏អស្ចារ្យនៃការសង្គ្រោះ។ យើងបានទទួលការសង្គ្រោះដោយសារព្រះលោហិតនៃព្រះឈើឆ្កាង (អភ ១,៧...) ប៉ុន្តែព្រឹត្តិការណ៍ដ៏អស្ចារ្យនៃការសង្គ្រោះនេះ ស្ថិតនៅក្នុងជីវិតរបស់ព្រះគ្រីស្ដជាស្រេច គឺពេលព្រះយេស៊ូប្រសូត ព្រះអង្គបានដាក់ខ្លួនជាអ្នកក្រ ដើម្បីឲ្យយើងទៅជាអ្នកមាន (២ករ ៨,៩) នៅភូមិណាសារ៉ែតពេលព្រះអង្គស្ដាប់បង្គាប់ ទ្រង់ក៏ព្យាបាលយើងដែលមិនចេះស្ដាប់បង្គាប់។ ព្រះបន្ទូលព្រះអង្គធ្វើឲ្យអ្នកស្ដាប់បានវិសុទ្ធ (យហ ១៥,៣) ពេលព្រះអង្គប្រោសអ្នកជំងឺឲ្យបានជា និងដេញខ្មោចចេញពីមនុស្ស ទ្រង់ "បានទទួលយកភាពពិការរបស់យើង ហើយព្រះអង្គក៏ទទួលយកជំងឺរបស់យើងដែរ" (មថ ៨,១៧) (អស ៥៣,៤) នៅពេលព្រះអង្គមានព្រះជន្មថ្មី ព្រះអង្គប្រោសយើងឲ្យបានសុចរិត (រម ៤,២៥)។

៥១៨-ជីវិតទាំងស្រុងរបស់ព្រះគ្រីស្ដសរុបនូវអ្វីៗទាំងអស់។ អ្វីៗទាំងអស់ដែលព្រះយេស៊ូបានប្រព្រឹត្តសេចក្ដីទាំងអស់ដែលព្រះអង្គបានប្រៀនប្រដៅ និងទុក្ខលំបាកទាំងអស់របស់ព្រះអង្គមានគោលដៅប្រោសមនុស្សបាបឲ្យបានសុចរិតវិញ៖

> ពេលព្រះយេស៊ូប្រសូត និងកើតជាមនុស្ស ព្រះអង្គបានសរុបនៅក្នុងខ្លួនព្រះអង្គប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់មនុស្សលោក និងបានប្រទានឲ្យយើងបានទទួលការសង្គ្រោះ។ អ្វីដែលយើងបានបាត់បង់ដោយសារលោកអដាំ គឺមនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់ និងមានលក្ខណៈរបស់ព្រះអង្គ យើងក៏បានទទួលវិញនៅក្នុងអង្គព្រះគ្រីស្ដយេស៊ូ។ ហេតុនេះហើយបានជាព្រះយេស៊ូបានឆ្លងកាត់គ្រប់អាយុកាលនៃដំណើរជីវិតដើម្បីប្រោសមនុស្សទាំងអស់ឲ្យរួមរស់ជាមួយព្រះជាម្ចាស់បាន (សន្ត: អ៊ីរ៉េណេ)។

## យើងរួមរស់ក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះយេស៊ូ

៥១៩-លក្ខណៈសម្បត្តិទាំងអស់របស់ព្រះគ្រីស្ដ "សម្រាប់មនុស្សទាំងអស់ ហើយជាប្រយោជន៍ដល់មនុស្សម្នាក់ៗ" (RH ១១)។ ព្រះគ្រីស្ដមិនបានរស់នៅសម្រាប់ខ្លួនឯង តែសម្រាប់យើងចាប់តាំងពីពេលព្រះអង្គប្រសូត "ដើម្បីមនុស្សយើង និងដើម្បីសង្គ្រោះយើង" រហូតដល់ពេលព្រះអង្គ "សោយទិវង្គតដើម្បីរំដោះបាបយើង" (១ករ ១៥,៣) និងមានព្រះជន្មថ្មី "ដើម្បីឲ្យយើងបានសុចរិត" (រម ៤,២៥)។ សព្វថ្ងៃនេះដែរ ព្រះអង្គក៏ "ជួយការពារ (យើង) ទល់មុខព្រះបិតា" (១យហ ២,១) "ដ្បិតព្រះអង្គមានព្រះជន្មរស់នៅរហូត ដើម្បីទូលអង្វរព្រះជាម្ចាស់" សម្រាប់យើង (ហប ៧,២៥)។ ដោយសារព្រះអង្គបានរស់ និងរងទុក្ខលំបាកសម្រាប់យើងតែម្ដងជាការស្រេច ទ្រង់ក៏ "ស្ថិតនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍ដល់យើង" (ហប ៩,២៤)។

៥២០-អស់មួយជីវិតព្រះយេស៊ូជាគំរូសម្រាប់យើង (រម ១៥,៥; ភីល ២,៥)។ ព្រះអង្គជា "មនុស្សដ៏ពេញលក្ខណៈ" (GS ៣៨) ព្រះអង្គក៏អញ្ជើញយើងឲ្យទៅជាសាវ័ករបស់ព្រះអង្គ និងឲ្យយើងដើរតាមព្រះអង្គ។ ដោយសារព្រះអង្គបានបន្ទាបខ្លួន យើងក៏ត្រូវតែយកតម្រាប់តាមព្រះអង្គ (យហ ១៣,១៥)។ ដោយសារព្រះអង្គអធិដ្ឋានទ្រង់ក៏ទាក់ទាញយើងឲ្យអធិដ្ឋានដែរ (យហ ១៣,១៥)។ ដោយសារព្រះអង្គជាអ្នកក្រទ្រង់ក៏ត្រាស់ហៅយើងឲ្យសុខចិត្តដាក់ខ្លួនជាអ្នកក្រ ហើយឲ្យយើងស្ម័គ្រចិត្តទទួលការបៀតបៀនដែរ (មថ ៥,១១-១២)។

៥២១-អ្វីៗដែលព្រះគ្រីស្តបានពិសោធន៍ ទ្រង់ក៏បានធ្វើដើម្បីឲ្យយើងអាចរួមរស់នៅក្នុងអង្គព្រះអង្គ ហើយដើម្បីឲ្យព្រះអង្គអាចរួមរស់នៅក្នុងខ្លួនយើងដែរ។ "ដោយព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្សសុទ្ធសាធ ទ្រង់ដូចជាភ្ជាប់ព្រះអង្គជាមួយមនុស្សគ្រប់ៗរូប" (GS ២២,២)។ ព្រះអង្គត្រាស់ហៅយើងឲ្យធ្វើជារូបកាយតែមួយនៅក្នុងអង្គព្រះអង្គ។ អ្វីដែលព្រះអង្គបានពិសោធន៍នៅក្នុងរូបកាយព្រះអង្គសម្រាប់យើង និងដើម្បីឲ្យយើងយកតម្រាប់តាម ទ្រង់ក៏បានប្រោសឲ្យយើងអាចរួមរស់ជាមួយព្រះអង្គដូចអវយវៈនៃព្រះកាយព្រះអង្គ។

យើងត្រូវតែបំពេញព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះយេស៊ូបន្តទៅមុខទៀត និងទូលអង្វរព្រះអង្គជារឿយៗ សូមព្រះអង្គបង្ហើយ និងបំពេញព្រឹត្តិការណ៍នោះ ក្នុងខ្លួនយើង និងក្នុងព្រះសហគមន៍ផង (...) ដ្បិតព្រះបុត្រារបស់ព្រះជាម្ចាស់មានគម្រោងការឲ្យយើង និងព្រះសហគមន៍ចូលរួមចំណែកក្នុងព្រឹត្តិការណ៍នោះបន្តទៅមុខទៀត ដោយសារព្រះអង្គមានព្រះហឫទ័យប្រណីសន្ដោសមកយើង ហើយឲ្យយើងបង្កើតផលតាមរយៈព្រឹត្តិការណ៍នោះ។ ហេតុនេះព្រះអង្គមានព្រះហឫទ័យឲ្យព្រឹត្តិការណ៍នោះបានសម្រេចនៅក្នុងខ្លួនយើង (សន្ដ: យ៉ូហាន អើដ)។

## ២-ព្រឹត្តិការណ៍ដ៏អស្ចារ្យអំពីកុមារភាព និងជីវិតដ៏លាក់កំបាំងរបស់ព្រះយេស៊ូ

### ការរៀបចំ

៥២២-ព្រះបុត្រាយាងមកនៅលើផែនដី ជាហេតុការណ៍ដ៏អស្ចារ្យបំផុត បានជាព្រះជាម្ចាស់សព្វព្រះហឫទ័យរៀបចំហេតុការណ៍នេះអស់រយៈពេលជាច្រើនសតវត្ស។ ព្រះជាម្ចាស់តម្រូវឲ្យមានពិធីយញ្ញបូជារូបតំណាង និងនិមិត្តរូបនៃ "សម្ពន្ធមេត្រីទីមួយ" (ហប ៩,១៥) ដើម្បីបានដល់ព្រះគ្រីស្ត។ ព្រះអង្គប្រកាសព្រះគ្រីស្តតាមរយៈពួកព្យាការីដែលនិយាយតៗគ្នានៅប្រទេសអ៊ីស្រាអែល ហើយទ្រង់ប្រោសឲ្យសាសន៍ដទៃរង់ចាំព្រះគ្រីស្តយាងមកដែរ។

៥២៣-មុននឹងព្រះគ្រីស្តយាងមក (កក ១៣,២៤) ព្រះជាម្ចាស់ចាត់សន្ដ: យ៉ូហានបាទីស្ត ឲ្យមករៀបចំផ្លូវថ្វាយព្រះអង្គ (មថ ៣,៣)។ លោកជា "ព្យាការីនៃព្រះដ៏ខ្ពង់ខ្ពស់បំផុត" (លក ១,៧៦) ប្រសើរជាងព្យាការីឯទៀតៗ (លក ៧,២៦) ជាព្យាការីចុងក្រោយបំផុត (មថ ១១,១៣)។ លោកចាប់ផ្ដើមដំណឹងល្អ (កក ១,២២; លក ១៦,១៦) ជម្រាបព្រះគ្រីស្តនៅក្នុងផ្ទៃម្ដាយមកម្ល៉េះ (លក ១,៤១) ហើយលោកត្រេកអរធ្វើជា "មិត្តសម្លាញ់របស់ស្វាមី" (យហ ៣,២៩) ដែលលោកសម្ដែងជា "កូនចៀមរបស់ព្រះជាម្ចាស់ដែលដកបាបចេញពីមនុស្សលោក" (យហ ១,២៩)។ លោកមកមុនព្រះយេស៊ូ "មានវិញ្ញាណប្រកបដោយឫទ្ធានុភាពដូចលោក អេលី" (លក ១,១៧) ហើយផ្ដល់សក្ខីភាពអំពីព្រះអង្គដោយទេសនាជ្រមុជមនុស្សក្នុងទឹកឲ្យគេប្រែចិត្តគំនិត និងដោយបូជាជីវិត (មក ៦,១៧-២៩)។

៥២៤-ដោយប្រារព្ធជារៀងរាល់ឆ្នាំក្នុងពិធីបុណ្យរដូវរង់ចាំ ព្រះសហគមន៍រំឭកអំពីការរង់ចាំព្រះមេស្ស៊ីនោះ។ ដោយរួមជាមួយអស់អ្នកដែលបានរង់ចាំអស់ពេលយ៉ាងយូរ ព្រះសង្គ្រោះយាងមកជាលើកទីមួយ អ្នកជឿក៏ជាស់តឿនរង់ចាំព្រះអង្គយាងមកវិញជាលើកទីពីរ។ ដោយប្រារព្ធកំណើត និងសេចក្ដីស្លាប់របស់លោក យ៉ូហានបាទីស្ត ដែលជាមរណៈសាក្សី ព្រះសហគមន៍ក៏រួមជាមួយលោកដែលមានបំណងប្រាថ្នាតែមួយគឺ "ព្រះអង្គត្រូវតែចម្រើនឡើង រីឯខ្ញុំវិញខ្ញុំត្រូវតែអន់ថយ" (យហ ៣,៣០)។

### ព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យព្រះយេស៊ូប្រសូត

៥២៥-ព្រះយេស៊ូប្រសូតនៅក្នុងក្រោលសត្វពីក្រុមគ្រួសារក្រីក្រ (លក ១,៤១)។ ពួកគង្វាលដ៏សាមញ្ញជាសាក្សី

ដំបូងនៃហេតុការណ៍នេះ។ នៅក្នុងភាពក្រីក្រនេះព្រះជាម្ចាស់សម្ដែងសិរីរុងរឿងនៃស្ថានបរមសុខ (លក ២,៨-២០)។ ព្រះសហគមន៍នៅតែច្រៀងសិរីរុងរឿងនៃយប់នោះ។

ថ្ងៃនេះ ព្រហ្មចារិនីប្រសូតបានអ្នកដែលស្ថិតនៅអស់កល្បជានិច្ច ហើយផែនដីថ្វាយគុហាមួយដល់អ្នក ដែលគ្មាននរណាអាចឈានទៅដល់បាន។ ពួកទេវទូត និងពួកគង្វាលលើកតម្កើងព្រះអង្គ ហើយពួកហោរាចារ្យមកជិតជាមួយផ្កាយ ដ្បិតព្រះអង្គប្រសូតដើម្បីយើង ព្រះកុមារតូចជាព្រះជាម្ចាស់ ដែលស្ថិតស្ថេរអស់កល្បជានិច្ច! (កង់តាគីយង់ ឌី រ៉ូម៉ាណូស៍ លី មេលូដ)។

៥២៦-យើងត្រូវតែ "ដូរចិត្តគំនិតឲ្យបានដូចក្មេងតូចៗ" ដើម្បីអាចចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បាន (មថ ១៨,៣-៤) គឺយើងត្រូវបន្ទាបខ្លួន (មថ ២៣,១២) ដាក់ខ្លួនជាអ្នកតូច។ លើសពីនេះទៅទៀត យើងត្រូវ "កើតជាថ្មី" (យហ ៣,៧) "កើតពីព្រះជាម្ចាស់" (យហ ១,១៣) ដើម្បី "អាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់" (យហ ១,១២)។ ព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យព្រះយេស៊ូប្រសូតកើតក្នុងយើង ពេលព្រះយេស៊ូ "កើតជារូបរាង" ក្នុងយើង (កាឡ ៤,១៩)។ បុណ្យព្រះយេស៊ូប្រសូតជាព្រឹត្តិការណ៍នៃ "ការប្ដូរដ៏អស្ចារ្យនេះ"៖

> "ឱការប្ដូរដ៏អស្ចារ្យ! ព្រះជាម្ចាស់ជាព្រះបង្កើតមនុស្សលោកដែលបានទទួលយករូបកាយ និងព្រលឹងបានសុខចិត្តកើតមកពីព្រហ្មចារិនីម្នាក់ ហើយបានទៅជាមនុស្សដោយគ្មានមនុស្សណាម្នាក់ចូលរួមចំណែកព្រះអង្គក៏បានប្រោសប្រទានឲ្យយើងទៅជាព្រះ" (**LH**)។

## ព្រឹត្តិការណ៍ដ៏អស្ចារ្យនៃកុមារភាពរបស់ព្រះយេស៊ូ

៥២៧-ប្រាំបីថ្ងៃក្រោយពីព្រះយេស៊ូបានប្រសូត ពិធីកាត់ស្បែករបស់ព្រះអង្គ (លក ២,២១) ជាសញ្ញាសម្គាល់បង្ហាញថា ព្រះអង្គជាកូនចៅរបស់លោក អប្រាហាំ និងបានចូលក្នុងប្រជាជននៃសម្ពន្ធមេត្រី។ ព្រះអង្គនឹងប្រតិបត្តិតាមធម្មវិន័យ (កាឡ ៤,៤) និងចូលរួមក្នុងពិធីបុណ្យនៃជនជាតិអ៊ីស្រាអែលអស់មួយជីវិត។ សញ្ញាសម្គាល់នេះបង្ហាញទុកជាមុននូវ "ពិធីកាត់ស្បែកក្នុងអង្គព្រះគ្រីស្ត" គឺពិធីជ្រមុជទឹក (កូឡ ២,១១-១៣)។

៥២៨-បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គឲ្យសាសន៍ដទៃស្គាល់ បង្ហាញថាព្រះយេស៊ូជាព្រះមេស្ស៊ីនៃជនជាតិអ៊ីស្រាអែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងជាព្រះសង្គ្រោះនៃពិភពលោក។ ដោយរួមជាមួយពិធីជ្រមុជទឹករបស់ព្រះយេស៊ូនៅទន្លេយ័រដាន់ និងពិធីមង្គលការនៅភូមិកាណា (**LH**) បុណ្យនេះលើកតម្កើងព្រះអង្គដែល "ពួកហោរាចារ្យ" មកពីបូព៌ាប្រទេសបានក្រាបថ្វាយបង្គំ (មថ ២,១)។ "ពួកហោរាចារ្យ" ជាតំណាងរបស់អ្នកកាន់សាសនាដទៃក្នុងតំបន់ជិតៗ ហើយព្រះសហគមន៍យល់ឃើញថា ពួកលោកជាផលផ្លែដំបូងនៃជាតិសាសន៍ដទៃដែលបានទទួលដំណឹងល្អអំពីព្រះសង្គ្រោះប្រសូតជាមនុស្ស។ ពួកហោរាចារ្យដែលមកដល់ទីក្រុងយេរូសាឡឹម ដើម្បី "ថ្វាយបង្គំ" "ព្រះមហាក្សត្ររបស់ជនជាតិយូដា" (មថ ២,២) បានប្រាប់ឲ្យដឹងថានៅប្រទេសអ៊ីស្រាអែលនេះ ដោយមានផ្កាយរបស់ព្រះបាទដាវីឌជួយបំភ្លឺ (ជរ ២៤,៧; វវ ២២,១៦) ពួកលោកមករកព្រះអង្គ ដែលនឹងទៅជាព្រះមហាក្សត្ររបស់សាសន៍ដទៃ (ជរ ២៤,១៧-១៩)។ ពួកលោកបង្ហាញថាសាសន៍ដទៃអាចរកព្រះយេស៊ូឃើញ និងអាចក្រាបថ្វាយបង្គំព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងព្រះសង្គ្រោះនៃពិភពលោក លុះត្រាតែគេបែរមុខទៅរកជនជាតិយូដា (យហ ៤,២២) និងទទួលព្រះបន្ទូលសន្យាអំពីព្រះមេស្ស៊ីពីគេ ដែលមានក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ (មថ ២,៤-៦)។ បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គឲ្យសាសន៍ដទៃស្គាល់សម្ដែងថា "គ្រប់ជាតិសាសន៍ដទៃចូលក្នុងក្រុមគ្រួសាររបស់បុព្វបុរស" ហើយទទួលឋានៈនៃជនជាតិអ៊ីស្រាអែល (**Israelitica dignitas-MR**)។

៥២៩-ពិធីថ្វាយព្រះឱរសយេស៊ូក្នុងព្រះវិហារ (លក ២,២២-៣៩) បង្ហាញថាព្រះអង្គជារៀមច្បង ដែលជាកម្មសិទ្ធិរបស់ព្រះអម្ចាស់ (សរ ១៣,១២-១៣)។ ដោយរួមជាមួយលោកតាស៊ីម៉ូន និងលោកយាយហាណ្ណាជនជាតិអ៊ីស្រាអែលទាំងអស់មកជួបព្រះសង្គ្រោះរបស់គេ។ គេទទួលស្គាល់ថាព្រះយេស៊ូជាព្រះមេស្ស៊ីដែលគេទន្ទឹងរង់ចាំជា "ពន្លឺដែលនាំឲ្យមនុស្សគ្រប់ជាតិសាសន៍ស្គាល់ព្រះអង្គ" ជា "សិរីរុងរឿងរបស់អ៊ីស្រាអែល" តែ "មានមនុស្សជាច្រើននឹងជំទាស់ប្រឆាំង"។ វេលាដែលលោកតាស៊ីម៉ូនមានប្រសាសន៍អំពីដាវដែលនឹងធ្វើឲ្យនាងម៉ារីឈឺចុកចាប់យ៉ាងខ្លាំង លោកប្រកាសទុកជាមុនថាព្រះយេស៊ូនឹងបូជាព្រះជន្មនៅលើឈើឆ្កាង និងផ្តល់ការសង្គ្រោះដែលព្រះជាម្ចាស់ "បានប្រទានមកឲ្យប្រជាជាតិទាំងអស់"។

៥៣០-រឿងព្រះយេស៊ូភៀសខ្លួនទៅស្រុកអេស៊ីប និងស្តេចហេរ៉ូដចេញបញ្ជាឲ្យគេសម្លាប់ក្មេងៗ (មថ ២,១៣-១៨) សម្តែងថាភាពងងឹតប្រឆាំង និងពន្លឺ៖ "ព្រះបន្ទូលបានយាងមកគង់ជាមួយប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ តែប្រជារាស្ត្រនោះពុំបានទទួលព្រះអង្គឡើយ" (យហ ១,១១)។ អស់មួយជីវិតព្រះយេស៊ូនឹងត្រូវគេបៀតបៀន ហើយសាវ័ករបស់ព្រះអង្គក៏ទទួលការបៀតបៀននោះជាមួយព្រះអង្គដែរ (យហ ១៥,២០)។ ព្រះអង្គត្រឡប់មកពីស្រុកអេស៊ីបវិញ (មថ ២,១៥) រំឭកឡើងវិញអំពីដំណើរឆ្ពោះទៅកាន់សេរីភាពរបស់ជនជាតិយូដា (ហស ១១,១) និងណែនាំព្រះយេស៊ូថា ជាអ្នករំដោះជាស្ថាពរ។

## ព្រឹត្តិការណ៍ដ៏អស្ចារ្យនៃជីវិតដ៏លាក់កំបាំងរបស់ព្រះយេស៊ូ

៥៣១-អស់រយៈពេលជាច្រើនឆ្នាំព្រះយេស៊ូមានរបៀបរស់នៅដូចមនុស្សឯទៀតៗភាគច្រើន គឺព្រះអង្គរស់នៅក្នុងជីវិតប្រចាំថ្ងៃតាមរបៀបសាមញ្ញ ដោយធ្វើការផ្ទាល់ដៃដោយកាន់សាសនាយូដា និងប្រតិបត្តិតាមធម៌វិន័យរបស់ព្រះជាម្ចាស់ (កាឡ ៤,៤) ហើយដោយរស់នៅក្នុងសហគមន៍។ ដំណឹងល្អសម្តែងឲ្យយើងដឹងអំពីការរស់នៅនេះថាព្រះអង្គ "ធ្វើតាមឱវាទ" របស់មាតាបិតាព្រះអង្គ "មានវ័យចម្រើនឡើង ហើយមានប្រាជ្ញាកាន់តែរៀងរៃជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងជាទីគាប់ចិត្តនឹងមនុស្សផងទាំងពួង" (លក ២,៥១-៥២)។

៥៣២-ពេលព្រះយេស៊ូធ្វើតាមមាតាបិតាព្រះអង្គបំពេញវិន័យទីបួនបានគ្រប់លក្ខណៈ និងសម្តែងថា ព្រះអង្គប្រតិបត្តិតាមព្រះបិតារបស់ព្រះអង្គដែលគង់នៅស្ថានបរមសុខ។ ជារៀងរាល់ថ្ងៃព្រះយេស៊ូធ្វើតាមលោក យ៉ូសែប និងនាង ម៉ារី យ៉ាងណា ព្រះអង្គក៏នឹងធ្វើតាមព្រះបិតានៅថ្ងៃព្រហស្បត្តិ៍ពិសិដ្ឋយ៉ាងនោះដែរ៖ "សូមកុំឲ្យសម្រេចតាមចិត្តទូលបង្គំឡើយ..." (លក ២២,៤២)។ ដោយព្រះយេស៊ូស្តាប់បង្គាប់ព្រះជាម្ចាស់នៅក្នុងជីវិតប្រចាំថ្ងៃព្រះអង្គក៏ចាប់ផ្តើមទូទាត់ការមិនស្តាប់បង្គាប់របស់លោកអដាំ។

៥៣៣-ដោយសារជីវិតដ៏លាក់កំបាំងនៅភូមិណាសារ៉ែត មនុស្សគ្រប់ៗរូបអាចរួមរស់ជាមួយព្រះយេស៊ូនៅក្នុងជីវិតប្រចាំថ្ងៃដែរ៖

> ណាសារ៉ែតជាសាលារៀនដែលយើងចាប់ផ្តើមយល់អំពីជីវិតរបស់ព្រះយេស៊ូ ជាសាលារៀននៃដំណឹងល្អ (...)។ ដំបូងយើងរៀនអំពីភាពស្ងៀមស្ងាត់។ សូមឲ្យយើងចូលចិត្តភាពស្ងៀមស្ងាត់ដែលជាលក្ខណៈដ៏អស្ចារ្យ និងជាចាំបាច់នៃចិត្តគំនិត (...)។ យើងរៀនអំពីជីវិតក្នុងក្រុមគ្រួសារដែរ។ សូមឲ្យណាសារ៉ែតបង្រៀនឲ្យយើងយល់អំពីក្រុមគ្រួសារ អំពីការរួមរស់ជាមួយគ្នាដោយចិត្តស្រឡាញ់ពីសោភណភាពដ៏សាមញ្ញរបស់ក្រុមគ្រួសារដែលជាទីសក្ការៈដែលមិនអាចរំលោភបាន (...)។ យើងរៀនអំពីការងារដែរ។ ណាសារ៉ែត! ឱផ្ទះរបស់ "បុត្រនៃជាងឈើ"! នៅទីនេះយើងចង់យល់ និងលើកតម្កើងវិន័យដ៏តឹងរបស់ការងារមនុស្ស

លោកដែលជួយសង្គ្រោះយើង (...)។ នៅទីនេះយើងចង់សម្តែងការគោរពចំពោះកម្មករនៃពិភពលោកទាំងមូល និងសម្តែងឲ្យគេស្គាល់គំរូដ៏អស្ចារ្យរបស់គេជាបងរបស់គេដែលមកពីព្រះជាម្ចាស់" (សម្តេចប៉ាប ប៉ូលទី៦ សុន្ទរកថានៅភូមិណាសារ៉ែត ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៦៤)។

៥៣៤-ដំណឹងល្អថ្លែងអំពីហេតុការណ៍តែមួយក្នុងជីវិតដ៏លាក់កំបាំងរបស់ព្រះយេស៊ូ គឺនៅពេលព្រះអង្គដែលមានព្រះជន្មដប់ពីរព្រះវស្សាចូលក្នុងព្រះវិហារ (លក ២,៤១-៥២)។ នៅទីនោះព្រះយេស៊ូសម្តែងថាព្រះអង្គថ្វាយខ្លួនទាំងស្រុងចំពោះបេសកកម្មដែលមកពីព្រះអង្គជាបុត្ររបស់ព្រះជាម្ចាស់៖ "តើលោកឪពុកអ្នកម្តាយមិនជ្រាបថាកូនត្រូវនៅក្នុងដំណាក់ព្រះបិតារបស់កូនទេឬ?"។ នាងម៉ារី និងលោក យ៉ូសែប "ពុំបានយល់អត្ថន័យនៃព្រះបន្ទូល" នេះទេ តែពួកគាត់បានជឿព្រះបន្ទូលនេះ ហើយនាងម៉ារី "ចងចាំហេតុការណ៍ទាំងនោះទុកនៅក្នុងចិត្ត" អស់រយៈពេលព្រះយេស៊ូមានជីវិតរស់នៅតាមរបៀបធម្មតា។

## ៣-ព្រឹត្តិការណ៍ដ៏អស្ចារ្យនៃជីវិតជាសាធារណៈរបស់ព្រះយេស៊ូ

### ពិធីជ្រមុជទឹករបស់ព្រះយេស៊ូ

៥៣៥-ព្រះយេស៊ូចាប់ផ្តើមជីវិតជាសាធារណៈ (លក ៣,២៣) ពេលព្រះអង្គទទួលពិធីជ្រមុជទឹកពីលោក យ៉ូហាន នៅក្នុងទន្លេយ័រដាន់ (កក ១,២២)។ លោក យ៉ូហាន ប្រកាស "ឲ្យមនុស្សកែប្រែចិត្តគំនិតដោយទទួលពិធីជ្រមុជទឹក" (លក ៣,៣)។ មនុស្សជាច្រើនដូចជាអ្នកបាប អ្នកទារពន្ធ ទាហាន (លក ៣,១០-១៤) ពួកផារីស៊ី ពួកសាឌូស៊ី (មថ ៣,៧) និងស្ត្រីពេស្យា (មថ ២១,៣២) មករកលោកដើម្បីទទួលពិធីជ្រមុជទឹក។ "ពេលនោះព្រះយេស៊ូយាងមក"។ លោកយ៉ូហានរួញរាតែព្រះយេស៊ូទទូចសុំលោក ព្រះអង្គក៏ទទួលពិធីជ្រមុជទឹក។ ពេលនោះព្រះវិញ្ញាណដ៏វិសុទ្ធដូចសត្វព្រាបយាងមកសណ្ឋិតលើព្រះអង្គ ហើយមានព្រះសូរសៀងពីលើមេឃថា៖ "នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង" (មង ៣,១៣-១៧)។ ពិធីជ្រមុជទឹកនេះសម្តែងថាព្រះយេស៊ូជាព្រះមេស្ស៊ីនៃជនជាតិអ៊ីស្រាអែល និងជាព្រះបុត្រារបស់ព្រះជាម្ចាស់។

៥៣៦-ពិធីជ្រមុជទឹករបស់ព្រះយេស៊ូសម្តែងថាព្រះអង្គសុខចិត្តទទួល និងចាប់ផ្តើមបេសកកម្មរបស់ព្រះអង្គជាអ្នកបម្រើដែលរងទុក្ខលំបាក។ ព្រះអង្គសុខចិត្តឲ្យគេរាប់ព្រះអង្គក្នុងចំណោមអ្នកបាប (អស ៥៣,២) ទ្រង់ជា "កូនចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបចេញពីមនុស្សលោក" (យហ ១,២៩)។ ពិធីជ្រមុជទឹកសម្តែងទុកជាមុនថាព្រះយេស៊ូនឹងទទួល "ពិធីជ្រមុជ" នៅពេលសោយទិវង្គត (មក ១០,៣៨)។ ព្រះអង្គយាងមក "ស្របតាមគ្រប់សេចក្តីដែលព្រះជាម្ចាស់បានបង្គាប់ទុកមក" (មថ ៣,១៥) គឺព្រះអង្គសម្រេចព្រះកាយទាំងស្រុងតាមព្រះហឫទ័យនៃព្រះបិតា។ ដោយសារសេចក្តីស្រឡាញ់ ព្រះអង្គសុខចិត្តទទួលពិធីជ្រមុជក្នុងសេចក្តីស្លាប់ ដើម្បីឲ្យយើងរួចពីបាប (មថ ២៦,៣៩) ទើបព្រះបិតាគាប់ព្រះហឫទ័យនឹងព្រះបុត្រារបស់ព្រះអង្គណាស់ (លក ៣,២២)។ ព្រះវិញ្ញាណដែលព្រះយេស៊ូមានគ្រប់លក្ខណៈតាំងពីផ្ទៃម្តាយយាងមក "សណ្ឋិត" លើព្រះអង្គ (យហ ១,៣២-៣៣) (អស ១១,២) ហើយនឹងទៅជាប្រភពសម្រាប់មនុស្សលោកទាំងអស់។ ពេលព្រះយេស៊ូជ្រមុជទឹក "ផ្ទៃមេឃ" ដែលបាបរបស់លោកអដាំបានបិទ ក៏ "បើកចំហ" (មថ ៣,១៦) ហើយដោយសារព្រះយេស៊ូ និងព្រះវិញ្ញាយាងចុះមកទឹកបានវិសុទ្ធ ទើបព្រះជាម្ចាស់ចាប់ផ្តើមបង្កើតពិភពលោកសាជាថ្មីម្តងទៀត។

៥៣៧-ពេលទទួលអគ្គសញ្ញាជ្រមុជទឹក គ្រីស្តបរិស័ទរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មមានជីវិតថ្មី។ គេត្រូវតែបន្ទាបខ្លួនដោយទទួលស្គាល់បាបរបស់ខ្លួនចុះក្នុងទឹករួមជាមួយព្រះយេស៊ូ ដើម្បី

ងើបឡើងជាមួយព្រះអង្គវិញ និងកើតចេញពីទឹក និងពីព្រះវិញ្ញាណសាជាថ្មី ហើយដើម្បីបានទៅជាបុត្រធីតាជាទីស្រឡាញ់របស់ព្រះបិតានៅក្នុងអង្គព្រះបុត្រា និងដើម្បី "រស់នៅតាមរបៀបថ្មី" (រម ៤,៦)។

ដោយសារពិធីបុណ្យជ្រមុជទឹក ចូរចូលក្នុងផ្នូររួមជាមួយព្រះគ្រីស្ត ដើម្បីបានមានជីវិតថ្មីរួមជាមួយព្រះអង្គដែរ ចូរចុះជាមួយព្រះអង្គ ដើម្បីឲ្យព្រះជាម្ចាស់លើកយើងរួមជាមួយព្រះអង្គ ចូរឡើងជាមួយព្រះអង្គវិញ ដើម្បីឲ្យព្រះជាម្ចាស់លើកតម្កើងយើងក្នុងអង្គព្រះគ្រីស្ត (សន្តៈ គ្រេគ័រ នៃណាស៊ីអង់)។

អ្វីៗទាំងអស់ដែលបានកើតឡើងនៅក្នុងអង្គព្រះគ្រីស្ត ធ្វើឲ្យយើងដឹងថា ក្រោយពីជ្រមុជទឹក ព្រះវិញ្ញាណដ៏វិសុទ្ធហោះសណ្ឋិតលើយើងពីលើមេឃ ហើយព្រះសូរសៀងរបស់ព្រះបិតាបានប្រោសយើងឲ្យទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ (សន្តៈ អ៊ីលែរ)។

### មារល្បួងព្រះយេស៊ូ

៥៣៨-តាមដំណឹងល្អលុះដល់ព្រះយេស៊ូបានជ្រមុជទឹករួចហើយ ព្រះអង្គយាងទៅវាលរហោស្ថានតែម្នាក់ឯង៖ "ព្រះវិញ្ញាណនាំព្រះអង្គទៅវាលរហោស្ថាន" ព្រះអង្គស្នាក់នៅទីនោះអស់រយៈពេលសែសិបថ្ងៃ ដោយមិនសោយអ្វីឡើយ។ ព្រះអង្គរស់នៅជាមួយសត្វព្រៃ ហើយពួកទេវទូតបម្រើព្រះអង្គ (មក ១,១២-១៣)។ លុះផុតពីពេលនោះទៅមារសាតាំងល្បួងព្រះអង្គបីដង ដោយព្យាយាមបំបែកព្រះអង្គចេញពីព្រះបិតា។ ព្រះយេស៊ូឈ្នះការល្បួងនោះដែលសរុបការល្បួងរបស់លោកអដាំនៅសួនអេដែន និងការល្បួងរបស់ជនជាតិអ៊ីស្រាអែលនៅវាលរហោស្ថាន ហើយមារថយចេញឆ្ងាយពីព្រះអង្គ "រហូតដល់ពេលកំណត់" (លក ៤,១៣)។

៥៣៩-អ្នកនិពន្ធដំណឹងល្អផ្តល់អត្ថន័យដល់ព្រឹត្តិការណ៍ដ៏លាក់កំបាំងនេះ គឺព្រះយេស៊ូជាលោកអដាំថ្មីដែលនៅស្មោះត្រង់ជានិច្ច មិនបានចាញ់ការល្បួងដូចលោកអដាំពីមុនទេ។ ព្រះយេស៊ូបំពេញការត្រាស់ហៅរបស់ជនជាតិអ៊ីស្រាអែលឲ្យបានពេញលក្ខណៈ គឺព្រះយេស៊ូសម្តែងព្រះអង្គដូចជាអ្នកបម្រើរបស់ព្រះជាម្ចាស់ដែលប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះអង្គ ផ្ទុយពីមនុស្សជំនាន់មុនដែលបានរករឿងព្រះជាម្ចាស់អស់រយៈពេលសែសិបឆ្នាំ នៅវាលរហោស្ថាន (ទន ៩៥,១០)។ ហេតុនេះព្រះយេស៊ូឈ្នះមារសាតាំង ព្រះអង្គបាន "ចងមនុស្សខ្លាំងពូកែ" ដើម្បីយកទ្រព្យសម្បត្តិរបស់វា (មក ៣,២៧)។ ជ័យជម្នះរបស់ព្រះយេស៊ូលើមេល្បួងនៅវាលរហោស្ថាន សម្តែងទុកជាមុនអំពីជ័យរបស់ព្រះយេស៊ូនៅពេលព្រះអង្គនឹងរងទុក្ខលំបាក ហើយដែលមកពីព្រះអង្គបានប្រតិបត្តិតាមព្រះបិតាដោយសារសេចក្តីស្រឡាញ់។

៥៤០-ការល្បួងរបស់ព្រះយេស៊ូសម្តែងនូវរបៀបដែលព្រះយេស៊ូជាព្រះមេស្ស៊ី គឺផ្ទុយស្រឡះនឹងអ្វីដែលមារសាតាំងស្នើសុំឲ្យព្រះអង្គ ហើយដែលមនុស្សទាំងអស់ចង់ឲ្យព្រះអង្គប្រព្រឹត្តតាម (មថ ១៦,២១-២៣)។ ហេតុនេះហើយបានជាព្រះគ្រីស្តបានឈ្នះមេល្បួងដើម្បីយើង៖ "ព្រះអង្គក៏រងការល្បួងគ្រប់ជំពូកដូចយើងដែរ តែទ្រង់មិនបានប្រព្រឹត្តអំពើបាបសោះឡើយ" (ហប ៤,១៥)។ ជារៀងរាល់ឆ្នាំនៅពេលរដូវអប់រំពិសេសអស់រយៈពេលសែសិបថ្ងៃ ព្រះសហគមន៍រួមជាមួយព្រះយេស៊ូនៅឯវាលរហោស្ថាន។

### "ព្រះរាជ្យរបស់ព្រះជាម្ចាស់ជិតបង្កើយ"

៥៤១-"ក្រោយពីគេបានចាប់លោក យ៉ូហាន យកទៅឃុំឃាំង ព្រះយេស៊ូយាងទៅស្រុកកាលីឡេ ហើយប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់។ ព្រះអង្គមានព្រះបន្ទូលថា៖ ពេលកំណត់មកដល់ហើយ រីឯព្រះរាជ្យរបស់ព្រះជាម្ចាស់

ក៏មកជិតបង្កើយដែរ។ ចូរនាំគ្នាកែប្រែចិត្តគំនិត ហើយជឿដំណឹងល្អចុះ!" (មក ១,១៤-១៥)។ "ព្រះគ្រីស្តចាប់ផ្តើមធ្វើឲ្យព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតគ្រងរាជ្យនៅលើផែនដី ដើម្បីធ្វើឲ្យព្រះហឫទ័យរបស់ព្រះបិតាកើតជារូបរាង" (LG ៣)។ ព្រះហឫទ័យរបស់ព្រះបិតា គឺ "លើកមនុស្សលោកឲ្យមានជីវិតរួមរស់ជាមួយព្រះអង្គ" (LG ២)។ ព្រះអង្គធ្វើដូច្នេះដោយប្រមែប្រមូលមនុស្សលោកនៅក្នុងអង្គព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត។ ព្រះជាម្ចាស់ប្រមែប្រមូលមនុស្សលោកនៅក្នុងព្រះសហគមន៍ដែល "ជាពន្លក និងជាដើមកំណើតនៃព្រះរាជ្យរបស់ព្រះអង្គនៅលើផែនដី" (LG ៥)។

៥៤២-ព្រះគ្រីស្តជាកំពូលនៃការប្រមែប្រមូលនេះនៅក្នុង "ក្រុមគ្រួសាររបស់ព្រះជាម្ចាស់"។ ព្រះអង្គកោះហៅមនុស្សដោយសារព្រះបន្ទូល និងទីសម្គាល់ដែលសម្តែងថាព្រះជាម្ចាស់គ្រងរាជ្យ ហើយដោយចាត់ក្រុមសាវ័កឲ្យទៅ។ ព្រះអង្គនឹងធ្វើឲ្យព្រះរាជ្យរបស់ព្រះអង្គកើតជារូបរាង ជាពិសេសនៅពេលដែលព្រះអង្គនឹងសោយទិវង្គត និងមានព្រះជន្មថ្មី។ "រីឯខ្ញុំវិញកាលណាគេលើកខ្ញុំឡើងពីដី ខ្ញុំនឹងទាក់ទាញមនុស្សទាំងអស់មកខ្ញុំ" (យហ ១២,៣២)។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យរួមរស់ជាមួយព្រះគ្រីស្ត (LG ៣)។

## ការប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់

៥៤៣-ព្រះជាម្ចាស់ត្រាស់ហៅមនុស្សលោកទាំងអស់ឲ្យចូលក្នុងព្រះរាជ្យព្រះអង្គ។ ដំបូងព្រះអង្គប្រកាសព្រះរាជ្យនេះឲ្យជនជាតិអ៊ីស្រាអែលដឹង (មថ ១០,៥-៧) ក្រោយមកព្រះរាជ្យព្រះអង្គនឹងទទួលមនុស្សគ្រប់ជាតិសាសន៍ (មថ ៨,១១)។ ដើម្បីចូលក្នុងព្រះរាជ្យព្រះអង្គត្រូវតែទទួលព្រះបន្ទូលរបស់ព្រះយេស៊ូ៖

> ព្រះបន្ទូលរបស់ព្រះជាម្ចាស់ប្រៀបដូចជាគ្រាប់ពូជម៉្យាងព្រោះក្នុងចម្ការមួយ។ អស់អ្នកស្តាប់ព្រះបន្ទូលនេះ ដោយផ្ញើជីវិតលើព្រះអង្គ ចូលរួមក្នុងក្រុមតូចរបស់ព្រះគ្រីស្ត។ បន្ទាប់មក គ្រាប់ពូជនោះដុះពន្លកឡើង និងចម្រើនឡើងរហូតដល់ពេលចម្រូត (LG ៥)។

៥៤៤-ព្រះរាជ្យជាកម្មសិទ្ធិរបស់អ្នកក្រីក្រ និងអ្នកតូចតាច គឺអស់អ្នកដែលបានទទួលព្រះរាជ្យនេះដោយមានចិត្តសុភាពរាបសា។ ព្រះជាម្ចាស់ចាត់ព្រះយេស៊ូឲ្យយាង "ទៅប្រាប់ជនក្រីក្រ" (លក ៤,១៨) (លក ៧,២២)។ អ្នកនោះមានសុភមង្គល ដ្បិត "ពួកគេបានទទួលព្រះរាជ្យនៃស្ថានបរមសុខ" (មថ ៥,៣)។ ព្រះបិតាបានសម្តែងការទាំងនោះឲ្យមនុស្ស "តូចតាច" យល់ តែទ្រង់បានលាក់មិនឲ្យអ្នកប្រាជ្ញ និងអ្នកចេះដឹងយល់ទេ (មថ ១១,២៥)។ ព្រះយេស៊ូមានរបៀបរស់នៅដូចអ្នកក្រីក្រ ពីពេលព្រះអង្គប្រសូតក្នុងក្រោលសត្វរហូតដល់ពេលព្រះអង្គសោយទិវង្គតនៅលើឈើឆ្កាង។ ព្រះអង្គក៏ស្គាល់ការអត់ឃ្លាន (មថ ១១,១៨) ការស្រេកទឹក (យហ ៤,៦-៧) និងភាពក្រីក្រ (លក ៩,៥៨)។ លើសពីនេះទៅទៀតព្រះអង្គក៏យកអ្នកក្រីក្រគ្រប់យ៉ាងធ្វើជាតំណាងព្រះអង្គ ហើយមានព្រះបន្ទូលថាអ្នកណាប្រព្រឹត្តអំពើល្អចំពោះអ្នកតូចតាចនោះ អ្នកនោះអាចចូលក្នុងព្រះរាជ្យព្រះអង្គបាន (មថ ២៥,៣១-៤៦)។

៥៤៥-ព្រះយេស៊ូអញ្ជើញអ្នកបាប ឲ្យចូលរួមក្នុងព្រះរាជ្យព្រះអង្គ៖ "ខ្ញុំមិនមែនមករកមនុស្សសុចរិតទេ គឺខ្ញុំមករកមនុស្សបាប" (មក ២,១៧)។ ព្រះអង្គសូមឲ្យគេប្រែចិត្តគំនិត ដើម្បីឲ្យគេអាចចូលក្នុងព្រះរាជ្យបាន ប៉ុន្តែដោយមានព្រះបន្ទូល និងដោយប្រព្រឹត្តកិច្ចការព្រះអង្គសម្តែងនូវធម៌មេត្តាករុណាឥតព្រំដែនរបស់ព្រះបិតាចំពោះគេ (លក ១៥,១១-៣២) ដែលទ្រង់ "មានអំណរសប្បាយដោយមានមនុស្សបាបតែម្នាក់កែប្រែចិត្តគំនិត" (លក ១៥,៧)។ ព្រះអង្គនឹងបង្ហាញភស្តុតាងអំពីសេចក្តីស្រឡាញ់នេះ ពេលព្រះអង្គនឹងបូជាព្រះជន្មព្រះអង្គផ្ទាល់ដើម្បី "លើកលែងទោសមនុស្សទាំងអស់ឲ្យរួចពីបាប" (មថ ២៦,២៨)។

៥៤៦-ព្រះយេស៊ូត្រាស់ហៅមនុស្សលោកឲ្យចូលក្នុងព្រះរាជ្យដោយប្រើពាក្យប្រស្នាជាលក្ខណៈពិសេសនៃការ

ប្រៀនប្រដៅរបស់ព្រះអង្គ (មក ៤,៣៣-៣៤)។ តាមរយៈពាក្យប្រស្នានោះ ព្រះអង្គអញ្ជើញឲ្យចូលរួមក្នុងពិធីជប់លៀងនៃព្រះរាជ្យ (មថ ២២,១-១៤) ប៉ុន្តែទ្រង់សូមឲ្យយើងសម្រេចចិត្តជាដាច់ខាត គឺដើម្បីចូលក្នុងព្រះរាជ្យត្រូវថ្វាយអ្វីៗទាំងអស់ (មថ ១៣,៤៤-៤៥) ហើយយើងមិនគ្រាន់តែត្រូវនិយាយតែមាត់ទេ ត្រូវផ្ដល់សក្ខីភាពផង (មថ ២១,២៨-៣២)។ ពាក្យប្រស្នាប្រៀបធៀបដូចជាកញ្ចក់ចំពោះមនុស្ស គឺតើគេទទួលព្រះបន្ទូលដូចជាដីមានថ្ម ឬដូចជាដីមានជីជាតិល្អ (មថ ១៣,៣-៩)? តើគេធ្វើអ្វីខ្លះនឹងអំណោយទានដែលគេបានទទួល (មថ ២៥,១៤-៣០)? ពាក្យប្រស្នាសម្ដែងដ៏លាក់កំបាំងព្រះយេស៊ូ និងវត្តមាននៃព្រះរាជ្យនៅលើពិភពលោកនេះ។ ត្រូវចូលក្នុងព្រះរាជ្យ គឺត្រូវធ្វើជាសាវ័ករបស់ព្រះគ្រីស្តដើម្បី "យល់គម្រោងការដ៏លាក់កំបាំងរបស់ព្រះរាជ្យនៃស្ថានបរមសុខ" (មថ ១៣,១១)។ រីឯចំពោះអ្នកដែល "នៅខាងក្រៅ" (មក ៤,១១) វិញ គេមិនអាចយល់សេចក្ដីនៃពាក្យប្រស្នាទាល់តែសោះ (លក ៧,១៨-២៣)។

## ទីសម្គាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់

៥៤៧-ព្រះយេស៊ូមានព្រះបន្ទូលប្រកបដោយ "ភាពអស្ចារ្យឫទ្ធិបាដិហារិយ៍ និងទីសម្គាល់ផ្សេងៗ" (កក ២,២២) ដែលបង្ហាញថាព្រះរាជ្យស្ថិតនៅក្នុងអង្គព្រះអង្គ ហើយដែលបញ្ជាក់ថាព្រះយេស៊ូជាព្រះមេស្ស៊ីតាមព្រះបន្ទូលសន្យាទុកជាមុន (លក ៧,១៨-២៣)។

៥៤៨-ព្រះយេស៊ូប្រព្រឹត្តទីសម្គាល់ដែលផ្ដល់សក្ខីភាពថាព្រះបិតាបានចាត់ព្រះអង្គឲ្យយាងមក (យហ ៥,៣៦)។ ដោយសារទីសម្គាល់នោះ ព្រះយេស៊ូសូមឲ្យយើងផ្ញើជីវិតលើព្រះអង្គ (យហ ១០,៣៨)។ ព្រះអង្គប្រទានឲ្យអស់អ្នកដែលអង្វរព្រះអង្គដោយមានចិត្តជឿលើព្រះអង្គនូវអ្វីដែលគេត្រូវការ (មក ៥, ២៥-៣៤)។ ដូច្នេះការអស្ចារ្យពង្រឹងជំនឿលើព្រះយេស៊ូដែលបំពេញកិច្ចការនៃព្រះបិតា គឺការអស្ចារ្យផ្ដល់សក្ខីភាពថា ព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ (យហ ១០,៣១-៣៨)។ ប៉ុន្តែដោយសារការអស្ចារ្យនោះ មានមនុស្សខ្លះអាច "រវាតចិត្តចេញពីជំនឿ" បានដែរ (មថ ១១,៦) គឺព្រះអង្គគ្មានព្រះហឫទ័យបំពេញចិត្តមនុស្សដែលចង់ដឹង ឬចង់បានមន្តអាគមទេ។ ទោះបីព្រះយេស៊ូប្រព្រឹត្តការអស្ចារ្យល្អប្រសើរយ៉ាងណាក៏ដោយ ក៏អ្នកខ្លះបោះបង់ព្រះអង្គចោល (យហ ១១,៤៧-៤៨) អ្នកខ្លះទៀតចោទព្រះអង្គថា ព្រះអង្គប្រព្រឹត្តការអស្ចារ្យ ព្រោះស្ដេចខ្មោចបានប្រគល់អំណាចឲ្យព្រះអង្គ (មក ៣,២២)។

៥៤៩-ដោយរំដោះមនុស្សខ្លះឲ្យរួចពីការអត់ឃ្លាន (យហ ៦,៥-១៥) អំពើអយុត្តិធម៌ (លក ១៩,៨) ជំងឺ និងសេចក្ដីស្លាប់ (មថ ១១,៥) ព្រះយេស៊ូបានប្រទានទីសម្គាល់នៃការសង្គ្រោះ។ ព្រះអង្គមិនមែនយាងមក ដើម្បីរំដោះយើងឲ្យរួចពីអំពើអាក្រក់ទាំងឡាយ (លក ១២,១៣.១៤) ប៉ុន្តែព្រះអង្គយាងមក ដើម្បីរំដោះមនុស្សលោកឲ្យរួចពីអំពើអាក្រក់ធ្ងន់ជាងគេ គឺអំពើបាប (យហ ៨,៣៤-៣៦) ដែលនាំឲ្យមនុស្សលោកធ្វើជាទាសករមិនអាចធ្វើជាបុត្រធីតារបស់ព្រះជាម្ចាស់បាន ហើយដែលជាដើមហេតុនៃទុក្ខលំបាកទាំងអស់របស់មនុស្សលោក។

៥៥០-ព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមកបានសេចក្ដីថា ព្រះរាជ្យរបស់មារសាតាំងបរាជ័យដែរ (មថ ១២,២៦)៖ "បើខ្ញុំដេញខ្មោចដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ បានសេចក្ដីថាព្រះរាជ្យរបស់ព្រះអង្គមកដល់អ្នករាល់គ្នាហើយ" (មថ ១២,២៨)។ ពេលព្រះយេស៊ូដេញខ្មោច ព្រះអង្គរំដោះមនុស្សឲ្យរួចពីខ្មោចដែលគ្រប់គ្រងលើពួកគេដែរ (លក ៨,២៦-៣៩) និងជាទីសម្គាល់ទុកជាមុនថាព្រះអង្គនឹងទទួលជោគជ័យលើ "ចៅហ្វាយរបស់មនុស្សលោក" (យហ ១២,៣១)។ ពេលព្រះគ្រីស្តនឹងសោយទិវង្គតលើឈើឆ្កាង ព្រះជាម្ចាស់នឹងសោយរាជ្យផងដែរ៖ "ព្រះជាម្ចាស់គ្រងរាជ្យលើឈើឆ្កាង"។

"កូនសោនៃព្រះរាជ្យរបស់ព្រះជាម្ចាស់"

៥៥១-ពេលចាប់ផ្ដើមជីវិតជាសាធារណៈ ព្រះយេស៊ូជ្រើសរើសមនុស្សដប់ពីរនាក់ដើម្បីឲ្យគេនៅជាមួយព្រះអង្គ និងចូលរួមក្នុងបេសកកម្មរបស់ព្រះអង្គ (មក ៣,១៣-១៩)។ ព្រះអង្គចែកអំណាចរបស់ព្រះអង្គឲ្យគេហើយ "ចាត់គេឲ្យចេញទៅប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ព្រមទាំងមើលអ្នកជំងឺឲ្យបានជាផង" (លក ៩,២)។ ពួកគេរួមនៅក្នុងព្រះរាជ្យព្រះគ្រីស្ដជានិច្ច ដ្បិតព្រះអង្គណែនាំព្រះសហគមន៍តាមរយៈពួកគេ៖

> ខ្ញុំប្រគល់ព្រះរាជ្យឲ្យអ្នករាល់គ្នាដូចព្រះបិតាបានប្រគល់មកឲ្យខ្ញុំដែរ។ ក្នុងព្រះរាជ្យរបស់ខ្ញុំអ្នករាល់គ្នានឹងបរិភោគរួមតុជាមួយខ្ញុំ ហើយអ្នករាល់គ្នានឹងអង្គុយលើបល្ល័ង្កដើម្បីគ្រប់គ្រងលើកុលសម្ព័ន្ធទាំងដប់ពីរនៃជនជាតិអ៊ីស្រាអែល (លក ២២,២៩-៣០)។

៥៥២-លោកស៊ីម៉ូនសិលាជាប្រធានក្រុមទាំងដប់ពីរនាក់ (មក ៣,១៦)។ ព្រះយេស៊ូបានប្រគល់ឲ្យលោកមានបេសកកម្មដ៏សំខាន់បំផុត។ ដោយសារព្រះជាម្ចាស់បានសម្ដែងឲ្យលោកដឹង លោកបានប្រកាសថា៖ "លោកជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ"។ ព្រះអម្ចាស់នៃយើងបានឆ្លើយតបថា៖ "អ្នកឈ្មោះសិលា ហើយនៅលើផ្ទាំងសិលានេះខ្ញុំនឹងសង់ព្រះសហគមន៍របស់ខ្ញុំ។ សេចក្ដីស្លាប់ពុំមានអំណាចលើព្រះសហគមន៍នេះបានឡើយ" (មថ ១៦,១៨)។ ព្រះគ្រីស្ដ "ជាសិលាដ៏មានជីវិត" (១ពត្រ ២,៤) ធានាថា ព្រះសហគមន៍ដែលមានលោកសិលាជាគ្រឹះនឹងទទួលជោគជ័យលើអំណាចនៃសេចក្ដីស្លាប់។ ដោយសារលោកសិលាបានប្រកាសជំនឿ លោកនឹងទៅជាផ្ទាំងថ្មដ៏រឹងមាំនៃព្រះសហគមន៍។ លោកមានបេសកកម្មការពារជំនឿនេះអំពីកំហុសទាំងអស់ព្រមទាំងពង្រឹងជំនឿរបស់បងប្អូនលោកផងដែរ (លក ២២,៣២)។

៥៥៣-ព្រះយេស៊ូបានប្រគល់ឲ្យលោកសិលានូវអំណាចដ៏ពិសេស៖ "ខ្ញុំនឹងប្រគល់កូនសោព្រះរាជ្យនៃស្ថានបរមសុខឲ្យអ្នក។ អ្វីៗដែលអ្នកចងនៅលើផែនដីនេះ ព្រះជាម្ចាស់នឹងចងនៅស្ថានបរមសុខ ហើយអ្វីៗដែលអ្នកស្រាយនៅលើផែនដី ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថានបរមសុខដែរ" (មថ ១៦,១៩)។ "អំណាចនៃកូនសោ" សំដៅទៅលើអ្នកដែលមានអំណាចគ្រប់គ្រងលើព្រះដំណាក់របស់ព្រះជាម្ចាស់ គឺព្រះសហគមន៍។ ព្រះយេស៊ូដែលជា "គង្វាលដ៏ល្អ" (យហ ១០,១១) បានបញ្ជាក់បន្ទុកនេះ ក្រោយពីព្រះអង្គមានព្រះជន្មថ្មី៖ "សូមថែរក្សាកូនចៀមរបស់ខ្ញុំផង" (យហ ២១,១៥-១៧)។ អ្នកណាមានអំណាច "ចង និងស្រាយ" គឺមានអំណាចលើកលែងទោសឲ្យរួចពីបាប កាត់ក្ដីតាមលទ្ធិនៃសាសនា និងធ្វើការសម្រេចចិត្តខាងវិន័យក្នុងព្រះសហគមន៍។ ព្រះយេស៊ូបានប្រគល់អំណាចនេះឲ្យព្រះសហគមន៍តាមរយៈក្រុមគ្រីស្ដទូត (មថ ១៨,១៨) ជាពិសេសតាមរយៈលោកសិលាជាតែម្នាក់គត់ដែលបានទទួលកូនសោនៃព្រះរាជ្យពីព្រះអង្គយ៉ាងច្បាស់លាស់។

## ព្រះយេស៊ូប្រែទ្រង់ទ្រាយសម្ដែងអំពីព្រះរាជ្យទុកជាមុន

៥៥៤-ចាប់ពីថ្ងៃដែលលោកសិលាបានប្រកាសថា ព្រះយេស៊ូជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ លោកគ្រូយេស៊ូ "ចាប់ផ្ដើមប្រាប់ឲ្យពួកសាវ័កដឹងថាព្រះអង្គត្រូវតែយាងទៅក្រុងយេរូសាឡឹមរងទុក្ខលំបាកយ៉ាងខ្លាំង (...) សោយទិវង្គត តែបីថ្ងៃក្រោយព្រះអង្គនឹងមានព្រះជន្មថ្មី" (មថ ១៦,២១)។ លោកសិលាបដិសេធមិនព្រមទទួលព្រះបន្ទូលនេះ (មថ ១៦,២២-២៣) ឯសាវ័កឯទៀត ពួកគេមិនយល់ព្រះបន្ទូលនេះផងដែរ (មថ ១៧,២៣)។ ក្នុងកាលៈទេសៈនេះ ព្រះយេស៊ូប្រែទ្រង់ទ្រាយ (មថ ១៧,១-៨; ២ពត្រ ១,១៦-១៨) នៅលើភ្នំខ្ពស់ចំពោះមុខសាក្សីបីនាក់ដែលព្រះអង្គបានជ្រើសរើស គឺលោកសិលា លោកយ៉ាកុប និងលោកយ៉ូហាន។ ព្រះភ័ក្ត្រ និងព្រះពស្ត្ររបស់ព្រះយេស៊ូពោរពេញដោយពន្លឺត្រចះត្រចង់ លោក ម៉ូសេ និងលោក អេលី លេចមក

ហើយ "មានប្រសាសន៍អំពីដំណើរដែលព្រះអង្គត្រូវសោយទិវង្គតនៅក្រុងយេរូសាឡឹម" (លក ៩,៣១)។ មានពពកមកគ្របបាំងគេទាំងអស់គ្នា ហើយមានព្រះសូរសៀងបន្លឺពីលើមេឃថា៖ "ព្រះអង្គនេះជាបុត្រដែលយើងបានជ្រើសរើស ចូរស្តាប់ព្រះអង្គចុះ" (លក ៩,៣៥)។

៥៥៥-ក្នុងពេលតែមួយព្រះយេស៊ូសម្តែងសិរីរុងរឿងរបស់ព្រះអង្គ ទើបបញ្ជាក់ការប្រកាសរបស់លោកសិលា។ ម៉្យាងទៀតព្រះអង្គបង្ហាញថាដើម្បី "ចូលក្នុងសិរីរុងរឿងរបស់ព្រះអង្គ" (លក ២៤,២៦) ព្រះអង្គត្រូវតែសោយទិវង្គតនៅលើឈើឆ្កាងនៅទីក្រុងយេរូសាឡឹម។ លោក ម៉ូសេ និងលោក អេលី បានឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅលើភ្នំ ឯធម្មវិន័យ និងព្យាការីបានប្រកាសទុកជាមុនថាព្រះមេស្ស៊ីត្រូវតែរងទុក្ខលំបាក (លក ២៤,២៧)។ ព្រះបិតាសព្វព្រះហឫទ័យឲ្យព្រះយេស៊ូរងទុក្ខលំបាកមែន គឺព្រះបុត្រាប្រព្រឹត្តដូចអ្នកបម្រើរបស់ព្រះជាម្ចាស់ (អស ៤២,១)។ ពពកសម្តែងនូវវត្តមានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ៖ "ព្រះត្រៃឯកទាំងអស់លេចមក គឺព្រះបិតានៅក្នុងព្រះសូរសៀង ព្រះបុត្រានៅក្នុងមនុស្ស ព្រះវិញ្ញាណនៅក្នុងពពក" (សន្ត: ថូម៉ាសនៃអាកាំង)។

> ព្រះអង្គបានប្រែទ្រង់ទ្រាយនៅលើភ្នំ ហើយតាមតែគេអាចធ្វើបាន ពួកសាវ័ករបស់ព្រះអង្គបានឃើញសិរីរុងរឿងរបស់ព្រះអង្គ ព្រះគ្រីស្តជាព្រះជាម្ចាស់ ដើម្បីឲ្យនៅពេលគេនឹងឃើញព្រះអង្គត្រូវគេឆ្កាង គេយល់ថា ព្រះអង្គស្ម័គ្រចិត្តរងទុក្ខលំបាក ហើយដើម្បីឲ្យគេទៅប្រកាសប្រាប់ពិភពលោកថា ព្រះអង្គពិតជារស្មីរបស់ព្រះបិតា (ពិធីបុណ្យខាងបូព៌ាប្រទេស)។

៥៥៦-មុនចាប់ផ្តើមជីវិតជាសាធារណៈ ព្រះយេស៊ូជ្រមុជទឹក ហើយមុនសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ព្រះអង្គក៏ប្រែទ្រង់ទ្រាយ។ ដោយសារព្រះយេស៊ូជ្រមុជទឹក ព្រះអង្គសម្តែងឲ្យយើងដឹងអំពី "កំណើតថ្មីលើកទីមួយរបស់យើង "គឺបុណ្យជ្រមុជទឹករបស់យើង ឯពេលព្រះអង្គប្រែទ្រង់ទ្រាយទ្រង់សម្តែងនូវ "អគ្គសញ្ញានៃកំណើតទីពីរ" គឺយើងនឹងមានជីវិតថ្មី។ ពីពេលនេះទៅយើងចូលរួមចំណែកក្នុងព្រះអម្ចាស់ ដែលមានព្រះជន្មថ្មីដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រព្រឹត្តកិច្ចការក្នុងអគ្គសញ្ញានានានៃព្រះកាយព្រះគ្រីស្ត។ ការប្រែទ្រង់ទ្រាយរបស់ព្រះយេស៊ូសម្តែងថា ព្រះអង្គនឹងយាងមកវិញប្រកបដោយសិរីរុងរឿង ហើយទ្រង់នឹង "ផ្លាស់ប្តូររូបកាយដ៏ថោកទាបរបស់យើងនេះឲ្យបានដូចព្រះកាយប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ" (ភីល ៣,២១)។ ប៉ុន្តែការប្រែទ្រង់ទ្រាយរបស់ព្រះយេស៊ូរំឭកឲ្យយើងដឹងថា "យើងត្រូវឆ្លងកាត់ទុក្ខវេទនាជាច្រើន ដើម្បីឲ្យបានចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់" (កក ១៤,២២)។

> លោកសិលាមិនទាន់បានយល់សេចក្តីនេះ នៅពេលលោកមានបំណងចង់ស្នាក់នៅជាមួយព្រះគ្រីស្តនៅលើភ្នំ (លក ៩,៣៣)។ លោកសិលាអើយ! ព្រះអង្គបានបម្រុងទុកបំណងនេះ នៅពេលលោកនឹងស្លាប់។ ប៉ុន្តែ ឥឡូវនេះ ព្រះអង្គមានព្រះបន្ទូលថា៖ ចូរចុះដើម្បីរងទុក្ខលំបាកនៅលើផែនដី ដើម្បីបម្រើនៅលើផែនដី ដើម្បីត្រូវគេប្រមាថមើលងាយ ត្រូវគេឆ្កាងនៅលើផែនដី។ ជីវិតចុះដើម្បីត្រូវគេសម្លាប់ នំប៉័ងចុះដើម្បីឃ្លាន ផ្លូវចុះដើម្បីអស់កម្លាំងក្នុងការធ្វើដំណើរ ប្រភពចុះដើម្បីស្រេកទឹក ហើយអ្នកបដិសេធមិនព្រមរងទុក្ខលំបាក? (សន្ត: អូគូស្តាំង)។

### ព្រះយេស៊ូឡើងទៅទីក្រុងយេរូសាឡឹម

៥៥៧-"លុះជិតដល់ថ្ងៃកំណត់ដែលព្រះយេស៊ូត្រូវយាងចាកចេញពីលោកនេះទៅ ព្រះអង្គសម្រេចព្រះហឫទ័យយាងទៅក្រុងយេរូសាឡឹម" (លក ៩,៥១) (យហ ១៣,១) គឺព្រះអង្គបង្ហាញថាព្រះអង្គយាងទៅទីក្រុងយេរូសាឡឹម

ដើម្បីត្រៀមខ្លួនសោយទិវង្គត។ អស់បីដងហើយព្រះអង្គបានប្រកាសថានឹងរងទុក្ខលំបាក និងមានព្រះជន្មរស់ឡើងវិញ (មក ៨,៣១-៣៣; ៩,៣១-៣២; ១០,៣២-៣៤)។ ពេលធ្វើដំណើរទៅទីក្រុងយេរូសាឡឹម ព្រះអង្គមានព្រះបន្ទូលថា៖ "មិនគួរឲ្យព្យាការីស្លាប់នៅខាងក្រៅក្រុងយេរូសាឡឹមឡើយ" (លក ១៣,៣៣)។

៥៥៨-ព្រះយេស៊ូរំឭកអំពីព្យាការីទាំងប៉ុន្មានដែលត្រូវគេសម្លាប់នៅទីក្រុងយេរូសាឡឹម (មថ ២៣,៣៧ក)។ ប៉ុន្តែព្រះអង្គនៅតែត្រាស់ហៅអ្នកទីក្រុងយេរូសាឡឹមឲ្យមកប្រមូលផ្តុំគ្នារួមជាមួយព្រះអង្គ៖ "ច្រើនលើក ច្រើនសាមកហើយដែលខ្ញុំចង់ប្រមូលផ្តុំអ្នករាល់គ្នាដូចមេមាន់ក្រុងកូនវានៅក្រោមស្លាប តែអ្នករាល់គ្នាពុំព្រមសោះ" (មថ ២៣,៣៧ខ)។ ពេលព្រះអង្គទតឃើញទីក្រុងយេរូសាឡឹម ទ្រង់ព្រះកន្សែង និងសម្តែងបំណងប្រាថ្នារបស់ព្រះអង្គថា៖ "នៅថ្ងៃនេះអ្នកពុំបានយល់ហេតុការណ៍ដែលផ្តល់សេចក្តីសុខសាន្តមកអ្នកសោះ ដោយអត្ថន័យនៅលាក់កំបាំងនៅឡើយ អ្នកពុំបានឃើញទេ" (លក ១៩,៤២)។

### ព្រះយេស៊ូយាងចូលទីក្រុងយេរូសាឡឹម

៥៥៩-តើអ្នកក្រុងយេរូសាឡឹមនឹងទទួលព្រះមេស្ស៊ីរបស់ពួកគេយ៉ាងដូចម្តេច? ព្រះយេស៊ូតែងតែបានគេចផុតពីអស់អ្នកដែលចង់តែងតាំងព្រះអង្គធ្វើជាស្តេច (យហ ៦,១៥) ប៉ុន្តែព្រះអង្គជ្រើសរើសពេលវេលា និងរៀបចំយ៉ាងល្អិតល្អន់អំពីពេលព្រះអង្គនឹងចូលក្នុងទីក្រុងរបស់ "ព្រះបាទដាវីឌជាព្រះអយ្យកោរបស់ព្រះអង្គ" (លក ១,៣២) (មថ ២១,១-១១)។ គេលើកតម្កើងព្រះអង្គជាបុត្ររបស់ព្រះបាទដាវីឌ ជាព្រះអង្គដែលនាំការសង្គ្រោះមក (Hosanna មានន័យថា "ចូរសង្គ្រោះយើងទៅ!" "ចូរនាំការសង្គ្រោះមក!")។ ប៉ុន្តែ "ព្រះមហាក្សត្រប្រកបដោយសិរីរុងរឿង" (ទន ២៤,៧-១០) យាងចូលក្នុងទីក្រុងរបស់ព្រះអង្គដោយ "គង់នៅលើខ្នងលា" (សក ៩,៩) គឺព្រះអង្គមិនយកដណ្តើមកូនស្រីនៃទីក្រុងស៊ីយ៉ូន ជាតំណាងព្រះសហគមន៍ ព្រះអង្គដោយប្រើកលល្បិច ឬអំពើហិង្សាឡើយ តែដោយមានចិត្តសុភាពរាបសាដែលផ្តល់សក្ខីភាពនៃសេចក្តីពិត (យហ ១៨,៣៧)។ ហេតុនេះនៅថ្ងៃនោះ ក្មេងៗ (មថ ២១,១៥-១៦; ទន ៨,៣) និង "អ្នកដែលពឹងផ្អែកលើព្រះជាម្ចាស់" លើកតម្កើងព្រះអង្គដូចពួកទេវទូតបានប្រកាសទៅពួកគង្វាល (លក ១៩,៣៨; ២,១៤)។ ពេលថ្វាយអភិបូជាព្រះសហគមន៍ច្រៀងពាក្យសរសើររបស់គេ "សូមលើកតម្កើងសិរីរុងរឿងព្រះអង្គដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់" (ទន ១១៨,២៦) ក្នុងធម៌ "ព្រះដ៏វិសុទ្ធ" មុនរំឭកថាព្រះអម្ចាស់បានសោយទិវង្គត និងមានព្រះជន្មថ្មី។

៥៦០-ព្រះយេស៊ូដែលយាងចូលទីក្រុងយេរូសាឡឹមបង្ហាញថាព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលព្រះមហាក្សត្រ-ព្រះមេស្ស៊ីនឹងសម្រេចដោយសោយទិវង្គត និងមានព្រះជន្មថ្មីយាងមកដល់ហើយ។ ព្រះសហគមន៍ចូលក្នុងអាទិត្យពិសិដ្ឋ ដោយប្រារព្ធបុណ្យហែស្លឹកជាបុណ្យរំឭកព្រះយេស៊ូយាងចូលទីក្រុងយេរូសាឡឹម។

## សង្ខេប

៥៦១-"ជីវិតទាំងស្រុងរបស់ព្រះគ្រីស្តដូចជាមេរៀន គឺពេលព្រះអង្គនៅស្ងៀម ការអស្ចារ្យ កាយវិការ ការអធិដ្ឋានរបស់ព្រះអង្គ សេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះមនុស្ស ធម៌ទេសនារបស់ព្រះអង្គចំពោះអ្នកតូចតាច និងអ្នកក្រីក្រ ការបូជាព្រះជន្មរបស់ព្រះអង្គនៅលើឈើឆ្កាងដើម្បីសង្គ្រោះពិភពលោក ការមានព្រះជន្មថ្មីរបស់ព្រះអង្គ អ្វីៗទាំងអស់នោះធ្វើឲ្យព្រះបន្ទូលរបស់ព្រះអង្គកើតជារូបរាង និងសម្តែងព្រះអង្គឲ្យបានពេញលក្ខណៈ" (CT ៩)។

៥៦២-សាវ័ករបស់ព្រះគ្រីស្តត្រូវតែសម្របខ្លួនឲ្យដូចព្រះអង្គ រហូតដល់ព្រះអង្គសណ្ឋិតនៅក្នុងខ្លួនគេ (កាឡ

៤,១៩)។ "ហេតុនេះហើយបានជាព្រះជាម្ចាស់បានលើកយើងឲ្យចូលក្នុងគម្រោងការដ៏អស្ចារ្យនៃព្រះជន្មរបស់ព្រះគ្រីស្ត យើងធ្វើឲ្យបានដូចព្រះគ្រីស្ត រួមជាមួយព្រះអង្គដែលសោយទិវង្គត ហើយក៏រួមជាមួយព្រះអង្គដែលមានព្រះជន្មថ្មី ដោយរង់ចាំឲ្យបានរួបរួមជាមួយព្រះអង្គដែលសោយរាជ្យ" (LG ៧)។

៥៦៣-ទោះជាគង្វាល ឬហោរាចារ្យក្តី យើងអាចឈានទៅដល់ព្រះជាម្ចាស់ លុះត្រាតែយើងលិតជង្គង់ពីមុខស្នូកសត្វនៃភូមិបេថ្លេហិម ដោយក្រាបថ្វាយបង្គំព្រះអង្គ ដែលលាក់ខ្លួនក្នុងកូនក្មេងដ៏ទន់ខ្សោយម្នាក់។

៥៦៤-ដោយចុះចូលក្រោមនាងម៉ារី និងលោកយ៉ូសែប ហើយដាក់ខ្លួនធ្វើការអស់រយៈពេលជាច្រើនឆ្នាំ នៅភូមិណាសារ៉ែត ព្រះយេស៊ូផ្តល់គំរូឲ្យយើងយល់ថា យើងអាចធ្វើជាសន្តៈ ឬសន្តីបុគ្គលម្នាក់ក្នុងការរស់នៅប្រចាំថ្ងៃនៃក្រុមគ្រួសារ និងក្នុងការងារ។

៥៦៥-តាំងពីដំបូងនៃជីវិតជាសាធារណៈរបស់ព្រះអង្គ នៅពេលដែលព្រះអង្គជ្រមុជទឹក ព្រះយេស៊ូជា "អ្នកបម្រើ" ដែលថ្វាយខ្លួនទាំងស្រុងចំពោះព្រះរាជកិច្ចនៃការសង្គ្រោះ ដែលនឹងកើតឡើង ដោយ "ពិធីជ្រមុជ" នៃទុក្ខលំបាករបស់ព្រះអង្គ។

៥៦៦-ការល្បួងនៅវាលរហោស្ថានបង្ហាញថា ព្រះយេស៊ូជាព្រះមេស្ស៊ីដ៏សុភាពរាបសា ដែលឈ្នះសាតាំង ដោយភ្ជាប់ព្រះហឫទ័យទាំងស្រុងទៅនឹងគម្រោងការនៃការសង្គ្រោះរបស់ព្រះបិតា។

៥៦៧-ព្រះគ្រីស្តបានចាប់ផ្តើមព្រះរាជ្យនៃស្ថានបរមសុខនៅលើផែនដីនេះ។ "ព្រះគ្រីស្តបញ្ចាំងពន្លឺនៃព្រះរាជ្យនោះដោយព្រះបន្ទូល ដោយស្នាព្រះហស្តផ្សេងៗ និងដោយគង់នៅជាមួយមនុស្សលោកផង" (LG ៥)។ ព្រះសហគមន៍ជាពូជ និងជាការចាប់ផ្តើមនៃព្រះរាជ្យនេះ។ ព្រះអង្គបានប្រគល់កូនសោនៃព្រះសហគមន៍ឲ្យលោកសិលា។

៥៦៨-ព្រះគ្រីស្តប្រែទ្រង់ទ្រាយ ដើម្បីពង្រឹងជំនឿរបស់ក្រុមគ្រីស្តទូត មុនព្រះអង្គរងទុក្ខលំបាក។ ការឡើងនៅលើ "ភ្នំដ៏ខ្ពស់" រៀបចំការឡើងនៅលើភ្នំនៃទុក្ខលំបាក។ ព្រះគ្រីស្តដែលជាព្រះសិរសានៃព្រះសហគមន៍ សម្តែងឲ្យយើងឃើញនូវអ្វីដែលព្រះកាយរបស់ព្រះអង្គមាន និងដែលភ្លឺចិញ្ចាចចិញ្ចែងនៅក្នុងអគ្គសញ្ញា គឺ "ឲ្យយើងសង្ឃឹមថានឹងទទួលសិរីរុងរឿង" (កូឡ ១,២៧) (សន្តៈ ឡេអុងដ៏ប្រសើរ)។

៥៦៩-ព្រះគ្រីស្តស្ម័គ្រចិត្តឡើងនៅទីក្រុងយេរូសាឡឹម ដោយដឹងថា ព្រះអង្គនឹងសោយទិវង្គតយ៉ាងសាហាវដោយសារអ្នកបាបប្រឆាំងនឹងព្រះអង្គ (ហប ១២,៣)។

៥៧០-នៅពេលដែលព្រះយេស៊ូយាងចូលទីក្រុងយេរូសាឡឹម ព្រះអង្គបង្ហាញថា ព្រះរាជ្យយាងមកដល់ហើយ។ ព្រះមហាក្សត្រ-ព្រះមេស្ស៊ី ដែលកូនក្មេង និងអ្នកសុភាពរាបសាទទួលស្វាគមន៍នៅក្នុងទីក្រុងរបស់ព្រះអង្គនឹងសម្រេចព្រះរាជ្យនេះ ដោយសោយទិវង្គត និងមានព្រះជន្មថ្មី។

## ប្រការទី៤៖

## "ព្រះយេស៊ូគ្រីស្តបានសោយទុក្ខលំបាកនៅជំនាន់លោកប៉ុនពីឡាត ព្រះអង្គត្រូវគេឆ្កាងសោយទិវង្គត ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះក្នុងរូងថ្មមួយ"

៥៧១-គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មីជាស្នូលនៃដំណឹងល្អដែលក្រុមគ្រីស្តទូត និងព្រះសហគមន៍ត្រូវតែប្រកាសដល់ពិភពលោកទាំងមូល។ ព្រះជាម្ចាស់បានបំពេញគម្រោងការ

នៃការសង្គ្រោះ "តែម្តងគត់" (ហប ៩,២៦) ដោយមានព្រះបុត្រារបស់ព្រះអង្គជាព្រះយេស៊ូគ្រីស្តបានសោយទិវង្គត ដើម្បីសង្គ្រោះមនុស្សលោក។

៥៧២-ព្រះសហគមន៍នៅតែស្មោះត្រង់នឹង "ការបកស្រាយនៃសេចក្តីដែលមានចែងក្នុងគម្ពីរទាំងមូល" ដែលព្រះយេស៊ូផ្ទាល់ព្រះអង្គបានប្រទានមុន និងក្រោយពេលព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ៖ "ព្រះគ្រីស្តត្រូវតែរងទុក្ខលំបាកបែបនេះសិន មុននឹងចូលទៅទទួលសិរីរុងរឿងរបស់ព្រះអង្គ" (លក ២៤,២៦-២៧.៤៤-៤៥)។ ទុក្ខលំបាករបស់ព្រះយេស៊ូបានកើតជារូបរាងក្នុងប្រវត្តិសាស្ត្រមនុស្សលោក ដ្បិត "ពួកព្រឹទ្ធាចារ្យ ពួកនាយកបូជាចារ្យ និងពួកបណ្ឌិតខាងវិន័យនឹងបោះបង់ព្រះអង្គចោល" (មក ៨, ៣១) ហើយ "គេនឹងបញ្ជូនលោកទៅក្នុងកណ្តាប់ដៃរបស់សាសន៍ដទៃ ដើម្បីឲ្យពួកនោះចំអកដាក់លោក យករំពាត់វាយលោក ព្រមទាំងឆ្កាងសម្លាប់លោកទៀតផង" (មថ ២០,១៩)។

៥៧៣-ដូច្នេះអ្នកជឿអាចស្វែងយល់អំពីកាលៈទេសៈនៃសេចក្តីស្លាប់របស់ព្រះយេស៊ូ ដែលដំណឹងល្អបានបញ្ជូនយ៉ាងត្រឹមត្រូវ (DV ១៩) ហើយដែលមានឯកសារខាងប្រវត្តិសាស្ត្រជួយបំភ្លឺ ដើម្បីយល់កាន់តែច្បាស់អំពីអត្ថន័យនៃការសង្គ្រោះ។

## កថាខណ្ឌទី១៖ ព្រះយេស៊ូ និងជនជាតិអ៊ីស្រាអែល

៥៧៤-លុះព្រះយេស៊ូចាប់ផ្តើមប្រកាសដំណឹងល្អជាសាធារណៈ ពួកខាងគណៈផារីស៊ី និងពួកស្តេចហេរ៉ូដរួមជាមួយពួកបូជាចារ្យ និងពួកបណ្ឌិតខាងវិន័យខ្លះឃុបឃិតគ្នា ដើម្បីធ្វើគុតព្រះអង្គ (មក ៣,៦)។ ដោយសារកិច្ចការខ្លះរបស់ព្រះអង្គ (ដូចជាពេលព្រះអង្គដេញខ្មោចចេញពីមនុស្ស (មថ ១២,២៤) លើកលែងទោសឲ្យគេរួចពីបាប (មក ២,៧) ប្រោសអ្នកជំងឺឲ្យបានជានៅថ្ងៃសប្ប័ទ (មក ៣,១-៦) បកស្រាយធម៌វិន័យតាមរបៀបផ្សេងពីគេ (មក ៧,១៤-២៣) ស្រឡាញ់រាប់អានអ្នកទារពន្ធ និងអ្នកបាប (មក ២,១៤-១៧)) អ្នកខ្លះដែលមានបំណងមិនល្អបានសង្ស័យថាព្រះអង្គមានខ្មោចចូល (មក ៣,២២; យហ ៨,៤៨; ១០,២០)។ គេចោទព្រះអង្គថាព្រះអង្គប្រមាថព្រះជាម្ចាស់ (មក ២,៧) ព្រះអង្គបញ្ឆោតប្រជាជន (យហ ៧,១២) ជាអំពើឧក្រិដ្ឋដែលធម្មវិន័យដាក់ទោសដោយគប់នឹងដុំថ្មរហូតដល់ស្លាប់ (យហ ៨,៥៩)។

៥៧៥-ព្រះយេស៊ូបានប្រព្រឹត្តកិច្ចការ និងមានព្រះបន្ទូលជាច្រើនធ្វើឲ្យមនុស្សខ្លះបាន "ជំទាស់ប្រឆាំង" (លក ២,៣៤) នឹងព្រះអង្គ។ មនុស្សទាំងអស់នោះជាមេដឹកនាំសាសនា ឬតាមដំណឹងល្អរបស់សន្តៈ យ៉ូហាន "ជនជាតិយូដា" ច្រើនជាងប្រជាជនធម្មតា។ ប៉ុន្តែព្រះយេស៊ូមានទំនាក់ទំនងល្អជាមួយនឹងពួកខាងគណៈផារីស៊ីដែរ គឺពួកគេប្រាប់ព្រះអង្គទុកជាមុនថា មានគេចង់សម្លាប់ព្រះអង្គ ព្រះយេស៊ូសរសើរពួកខាងគណៈផារីស៊ីខ្លះដូចជាគ្រូបណ្ឌិតខាងវិន័យក្នុង មក ១២,៣៤ ហើយទ្រង់ក៏សោយព្រះស្ងោយរួមជាមួយពួកផារីស៊ីជាច្រើនដងដែរ។ ព្រះយេស៊ូបញ្ជាក់សេចក្តីខ្លះរបស់មេដឹកនាំខាងសាសនានោះ ដូចជាមនុស្សស្លាប់នឹងមានជីវិតថ្មីរបៀបធ្វើទានតមអាហារ និងការអធិដ្ឋានទំនៀមទម្លាប់នឹងសន្ទនាជាមួយព្រះជាម្ចាស់ដូចជាព្រះបិតា ហើយវិន័យសំខាន់ជាងគេអំពីសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងបងប្អូនឯទៀតៗ។

៥៧៦-ចំពោះមនុស្សជាច្រើននៅប្រទេសអ៊ីស្រាអែល ព្រះយេស៊ូហាក់ដូចជាប្រព្រឹត្តប្រឆាំងនឹងរចនាសម្ព័ន្ធដ៏សំខាន់ៗនៃប្រជាជនអ៊ីស្រាអែល៖

-ត្រូវតែប្រតិបត្តិតាមធម្មវិន័យក្នុងគ្រប់ប្រការជាលាយលក្ខណ៍អក្សរ ហើយចំពោះពួកខាងគណៈផារីស៊ី

ក្នុងការបកស្រាយធម្មវិន័យនេះផងដែរ។

-ព្រះវិហារនៅទីក្រុងយេរូសាឡឹមជាកន្លែងដ៏សំខាន់ និងដ៏វិសុទ្ធបំផុតដែលមានព្រះជាម្ចាស់គង់នៅតាមរបៀបពិសេស។

-ត្រូវតែជឿលើព្រះជាម្ចាស់តែមួយគត់ ដែលគ្មាននរណាម្នាក់អាចរួមចំណែកក្នុងសិរីរុងរឿងបានឡើយ។

## ១-ព្រះយេស៊ូ និងធម្មវិន័យ

៥៧៧-ពេលព្រះយេស៊ូចាប់ផ្ដើមមានព្រះបន្ទូលអំពីសុភមង្គលដ៏ពិតប្រាកដនៅលើភ្នំដែលព្រះអង្គបានជួយបំភ្លឺដោយមានការប្រណីសន្ដោសនៃសម្ពន្ធមេត្រីថ្មី ធម្មវិន័យដែលព្រះជាម្ចាស់ប្រោសប្រទាននៅលើភ្នំស៊ីណៃ នៅក្នុងសម្ពន្ធមេត្រីទីមួយ ព្រះអង្គក៏ព្រមានយ៉ាងឱឡារិកថា៖

> សូមកុំនឹកស្មានថាខ្ញុំមកលុបបំបាត់ធម្មវិន័យ ឬគម្ពីរព្យាការីចោលឡើយ។ ខ្ញុំមិនមែនមកលុបបំបាត់ទេ គឺខ្ញុំមកធ្វើឲ្យគម្ពីរមានអត្ថន័យពេញលក្ខណៈទៅវិញ។ ខ្ញុំសូមប្រាប់ឲ្យអ្នករាល់គ្នាបានដឹងច្បាស់ថាដរាបណាផ្ទៃមេឃ និងផែនដីនៅស្ថិតស្ថេរ ដរាបនោះគ្មានក្បៀស ឬបន្តក់ណាមួយក្នុងគម្ពីរវិន័យត្រូវលុបបំបាត់ឡើយ គឺគម្ពីរទាំងមូលនឹងនៅស្ថិតស្ថេររហូតដល់ទីបំផុត។ អ្នកណាល្មើសបញ្ញត្តិតូចមួយនេះ ហើយបង្រៀនអ្នកផ្សេងឲ្យធ្វើតាម អ្នកនោះនឹងមានឋានៈតូចជាងគេក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ ផ្ទុយទៅវិញ អ្នកណាប្រតិបត្តិតាមវិន័យ ហើយបង្រៀនអ្នកផ្សេងឲ្យប្រតិបត្តិតាម អ្នកនោះនឹងមានឋានៈធំក្នុងព្រះរាជ្យនៃស្ថានបរមសុខ (មថ ៥,១៧-១៩)។

៥៧៨-តាមព្រះបន្ទូលរបស់ព្រះយេស៊ូផ្ទាល់ ព្រះអង្គដែលជាព្រះមេស្ស៊ីនៃជនជាតិអ៊ីស្រាអែល អ្នកធំជាងគេក្នុងព្រះរាជ្យនៃស្ថានបរមសុខ ត្រូវតែបំពេញធម្មវិន័យដោយប្រតិបត្តិតាមក្នុងគ្រប់ប្រការរហូតដល់វិន័យតូចជាងគេ។ មានតែព្រះអង្គនេះហើយដែលបានប្រព្រឹត្តតាមគ្រប់លក្ខណៈ។ ជនជាតិយូដាបានសារភាពថាពួកគេមិនអាចប្រតិបត្តិតាមធម្មវិន័យឲ្យបានគ្រប់លក្ខណៈ ដោយមិនបំពានច្បាប់ណាមួយឡើយ។ ហេតុនេះហើយជារៀងរាល់ឆ្នាំ នៅពេលគេធ្វើបុណ្យឲ្យរួចពីបាប គេអង្វរព្រះជាម្ចាស់ឲ្យព្រះអង្គលើកលែងទោសឲ្យគេដែលបានបំពានធម្មវិន័យ។ ធម្មវិន័យ និងប្រការនីមួយៗជាបញ្ញត្តិតែមួយ ហើយដូចសន្តៈ យ៉ាកុប រំឭកយើង៖ "អ្នកណាប្រតិបត្តិតាមវិន័យទាំងមូល តែបំពានលើបញ្ញត្តិណាមួយ អ្នកនោះក៏ដូចជាខុសនឹងវិន័យទាំងមូលដែរ" (យក ២,១០)។

៥៧៩-ពួកផារីស៊ីចូលចិត្តប្រតិបត្តិតាមធម្មវិន័យទាំងស្រុង មិនគ្រាន់តែតាមចំអក្សរទេ ថែមទាំងតាមវិញ្ញាណផងដែរ។ ហេតុនេះនៅសម័យព្រះយេស៊ូ គេបាននាំជនជាតិយូដាជាច្រើនឲ្យប្រតិបត្តិតាមធម្មវិន័យយ៉ាងតឹងរឹង និងដាច់ខាត។ បើព្រះអង្គមិនព្រមជួយដោះស្រាយបញ្ហានីមួយៗដោយលម្អិតលម្អន់ ធម្មវិន័យជ្រុលពេកដូច "ពួកអ្នកមានពុត" ព្រះអង្គក៏ត្រូវតែរៀបចំចិត្តគំនិតរបស់ប្រជាជនឲ្យយល់ថា ព្រះជាម្ចាស់នឹងធ្វើអន្តរាគមន៍យ៉ាងអស្ចារ្យដោយសារមនុស្សសុចរិតតែម្នាក់នឹងបំពេញធម្មវិន័យឲ្យបានគ្រប់លក្ខណៈជំនួសមនុស្សបាបទាំងឡាយ។

៥៨០-មានតែព្រះជាម្ចាស់ជាអ្នកតែងច្បាប់ដែលកើតជាមនុស្សនៅក្នុងអង្គព្រះបុត្រា ព្រះអង្គក្រោមអំណាចនៃធម្មវិន័យដែលអាចបំពេញធម្មវិន័យបានពេញលក្ខណៈ (កាឡ ៤,៤)។ នៅក្នុងអង្គព្រះយេស៊ូធម៌វិន័យមិនមែនឆ្លាក់នៅលើផ្ទាំងថ្មទេ តែ "នៅក្នុងជម្រៅចិត្ត" (យរ ៣១,៣៣) របស់អ្នកបម្រើដែលបានទៅជា "សម្ពន្ធមេត្រីជាមួយប្រជាជន" (អស ៤២,៦) ដ្បិតព្រះអង្គ "នាំមកនូវការវិនិច្ឆ័យពិតមែន" (អស ៤២,៣)។ ព្រះយេស៊ូបំពេញធម្មវិន័យរហូតដល់ទទួលយក "បណ្ដាសាដែលមកពីវិន័យ" (កាឡ ៣,១៣) ដែល "អស់អ្នកដែលមិនប្រតិបត្តិតាមធម្មវិន័យ

ត្រូវបណ្តាសា" (កាឡ ៣,១០) ដ្បិត "ព្រះគ្រីស្តបានសោយទិវង្គត ដើម្បីលោះមនុស្សលោកឲ្យរួចផុតពីទោសដែលគេបានប្រព្រឹត្តល្មើសកាលនៅក្រោមសម្ព័ន្ធមេត្រីទីមួយ" (ហប ៩,១៥)។

៥៨១-ជនជាតិយូដា និងមេដឹកនាំសាសនាបានចាត់ទុកព្រះយេស៊ូជា "លោកគ្រូ" (យហ ១១,២៨; ៣,២; មថ ២២,២៣-២៤.៣៤-៣៦)។ ព្រះអង្គបានឧស្សាហ៍បកស្រាយធម្មវិន័យតាមក្បួនច្បាប់របស់មេដឹកនាំ (មថ ១២,៥ ;៩,១២; មក ២,២៣-២៧; លក ៦,៦-៩; យហ ៧,២២-២៣)។ ប៉ុន្តែនៅពេលជាមួយគ្នានេះ ព្រះអង្គធ្វើឲ្យគ្រូបណ្ឌិតខាងវិន័យទាស់ចិត្ត ពីព្រោះព្រះអង្គមិនគ្រាន់តែបញ្ចេញយោបល់ដូចពួកគេតែប៉ុណ្ណោះទេ ព្រះអង្គ "មានព្រះបន្ទូលប្រកបដោយអំណាច ខុសប្លែកពីពួកបណ្ឌិតខាងវិន័យរបស់គេ" (មថ ៧,២៨-២៩)។ ក្នុងអង្គព្រះអង្គគឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ដដែលបានលាន់ឮលើភ្នំស៊ីណៃ ដើម្បីប្រទានឲ្យលោក ម៉ូសេ នូវធម្មវិន័យជាលាយល័ក្ខណ៍អក្សរ ហើយដែលលាន់ឮម្តងទៀតលើភ្នំនៃធម៌វិន័យថ្មី អំពីសុភមង្គលយ៉ាងពិតប្រាកដ (មថ ៥,១)។ ព្រះបន្ទូលនេះ មិនលុបបំបាត់ធម្មវិន័យទេ ប៉ុន្តែបំពេញធម្មវិន័យ ដោយព្រះជាម្ចាស់បកស្រាយធម្មវិន័យជាលើកចុងក្រោយ៖ "អ្នករាល់គ្នាធ្លាប់បានឮសេចក្តីដែលមានចែងប្រាប់បុព្វបុរសថា (...) រីឯខ្ញុំវិញ ខ្ញុំសូមបញ្ជាក់ប្រាប់អ្នករាល់គ្នាថា" (មថ ៥,៣៣-៣៤)។ ដោយមានព្រះបន្ទូលប្រកបដោយអំណាចដដែលនេះ ព្រះអង្គមិនព្រមនឹង "ទំនៀមទម្លាប់របស់មនុស្ស" (មក ៧,៨) នៃពួកផារីស៊ីដែល "បំបាត់តម្លៃព្រះបន្ទូលរបស់ព្រះជាម្ចាស់" (មក ៧,១៣)។

៥៨២-មិនតែប៉ុណ្ណោះទេ ព្រះយេស៊ូបំពេញធម្មវិន័យអំពីភាពបរិសុទ្ធនៃចំណីអាហារ ដែលមានសារៈសំខាន់យ៉ាងខ្លាំងក្នុងជីវភាពប្រចាំថ្ងៃរបស់ជនជាតិយូដា ទ្រង់សម្តែងនូវ "គរុកោសល្យ" របស់វិន័យនេះ ដោយបកស្រាយថា៖ "អ្វីៗពីខាងក្រៅចូលទៅក្នុងមនុស្ស ពុំអាចធ្វើឲ្យគេក្លាយទៅជាមិនបរិសុទ្ធបានឡើយ (...)។ ព្រះអង្គបញ្ជាក់ថា គ្រប់អាហារសុទ្ធតែបរិសុទ្ធទាំងអស់។ មានតែអ្វីៗចេញពីមនុស្សប៉ុណ្ណោះ ដែលធ្វើឲ្យគេមិនបរិសុទ្ធ ដ្បិតគំនិតអាក្រក់ទាំងប៉ុន្មានសុទ្ធតែចេញមកពីខាងក្នុងចិត្តរបស់មនុស្ស" (មក ៧,១៨-២១)។ ព្រះអង្គបានបកស្រាយធម៌វិន័យជាលើកចុងក្រោយប្រកបដោយអំណាច ប៉ុន្តែគ្រូបណ្ឌិតខាងវិន័យខ្លះបានប្រឆាំងមិនព្រមទទួលយកការបកស្រាយរបស់ព្រះអង្គ ទោះបីព្រះជាម្ចាស់បញ្ជាក់អំពីការបកស្រាយរបស់ព្រះយេស៊ូ ដោយប្រទានទីសម្គាល់ដ៏អស្ចារ្យក៏ដោយ (យហ ៥,៣៦; ១០,២៥.៣៧-៣៨; ១២,៣៧) ជាពិសេសអំពីថ្ងៃសប្ប័ទ៖ ដោយឧស្សាហ៍ប្រើអំណះអំណាងរបស់មេដឹកនាំសាសនា (មក ២,២៥-២៥; យហ ៧,២២-២៤) ព្រះយេស៊ូរំឭកថា ពេលព្រះអង្គប្រោសមនុស្សឲ្យបានជាសះស្បើយ ដើម្បីបម្រើព្រះជាម្ចាស់ (មថ ១២,៥; ជរ ២៨,៩) ឬអ្នកដទៃ (លក ១៣,១៥-១៦; ១៤,៣-៤) ទ្រង់មិនប៉ះពាល់ដល់ថ្ងៃសប្ប័ទឡើយ។

## ២-ព្រះយេស៊ូនិងព្រះវិហារ

៥៨៣-ដូចពួកព្យាការីមុនព្រះយេស៊ូ ព្រះអង្គក៏បានគោរពយ៉ាងខ្ជាប់ខ្ជួនព្រះវិហារនៃទីក្រុងយេរូសាឡឹម។ លោកយ៉ូសែប និងនាង ម៉ារី បានថ្វាយព្រះអង្គសែសិបថ្ងៃ ក្រោយពីព្រះអង្គបានប្រសូត (លក ២,២២-៣៩)។ លុះដល់ពេលមានព្រះជន្មាយុដប់ពីរព្រះវស្សា ព្រះអង្គសម្រេចចិត្តស្នាក់នៅក្នុងព្រះវិហារ ដើម្បីរំឭកមាតាបិតាថាព្រះអង្គត្រូវតែយកចិត្តទុកដាក់នឹងកិច្ចការរបស់ព្រះបិតាព្រះអង្គ(លក ២,៤៦-៤៩)។ យ៉ាងហោចណាស់មួយឆ្នាំម្តងនៅពេលព្រះអង្គមានជីវិតដ៏លាក់កំបាំងនៅឡើយ ព្រះអង្គយាងឡើងទៅព្រះវិហារ ដើម្បីប្រារព្ធបុណ្យចម្លង (លក ២,៤១) ហើយលុះពេលព្រះអង្គមានជីវិតជាសាធារណៈ ហើយទ្រង់ក៏ធ្វើបូជនីយេសចរណ៍ទៅទីក្រុងយេរូសាឡឹមសម្រាប់បុណ្យធំៗនៃជនជាតិយូដា (យហ ២,១៣-១៥; ៥,១.១៤; ៧,១.១០.១៤; ៨,២; ១០,២២-២៣)។

៥៨៤-ព្រះយេស៊ូយាងឡើងទៅព្រះវិហារជាកន្លែងដ៏ពិសេស ដើម្បីជួបព្រះជាម្ចាស់។ សម្រាប់ព្រះអង្គព្រះវិហារ

ជាព្រះដំណាក់នៃព្រះបិតារបស់ព្រះអង្គ ជាផ្ទះសម្រាប់អធិដ្ឋាន ហើយព្រះអង្គក៏ទាស់ចិត្តថាទីធ្លាព្រះវិហារបានទៅជាសំបុកចោរទៅវិញ (មថ ២១,១៣)។ ព្រះអង្គដេញអ្នកលក់ចេញពីព្រះវិហារ ដ្បិតព្រះអង្គស្រឡាញ់ព្រះបិតាខ្លាំងពេក៖ "កុំយកដំណាក់ព្រះបិតាខ្ញុំធ្វើជាកន្លែងលក់ដូរដូច្នេះ។ ពួកសាវ័កនឹកឃើញសេចក្តីដែលមានចែងទុកក្នុងគម្ពីរថា៖ "មកពីទូលបង្គំស្រឡាញ់ព្រះដំណាក់របស់ព្រះអង្គ បានគេប្រហារជីវិតទូលបង្គំ" (ទន ៦៩,១០)" (យហ ២,១៦-១៧)។ ក្រោយពីព្រះអង្គមានព្រះជន្មថ្មី ក្រុមគ្រីស្តទូតនៅតែគោរពព្រះវិហារជានិច្ច (កក ២,៤៦; ៣,១; ៥,២០.២១)។

៥៨៥-ក៏ប៉ុន្តែមុននឹងរងទុក្ខលំបាកព្រះយេស៊ូបានប្រកាសថា ព្រះវិហារដ៏ល្អឆើតឆាយនេះនឹងត្រូវរលំបាក់បែកអស់លែងមានថ្មត្រួតពីលើថ្មទៀតហើយ (មថ ២៤,១-២)។ ព្រះយេស៊ូប្រកាសថាព្រះវិហារនឹងធ្វើជាសញ្ញាសម្គាល់មួយនៃពេលចុងក្រោយបំផុតដែលនឹងចាប់ផ្តើមពេលព្រះអង្គនឹងសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ (មថ ២៤,៣)។ ប៉ុន្តែមានអ្នកខ្លះបានពោលរឿងក្លែងក្លាយអំពីព្រះបន្ទូលនេះ នៅពេលមហាបូជាចារ្យសួរចម្លើយព្រះអង្គ (មក ១៤,៥៧-៥៨) ហើយបានជេរប្រមាថព្រះអង្គនៅពេលទ្រង់ត្រូវគេឆ្កាង (មថ ២៧,៣៩-៤០)។

៥៨៦-ព្រះយេស៊ូមិនប្រកាន់ព្រះវិហារទេ (មថ ៨,៤) គឺព្រះអង្គបានប្រៀនប្រដៅក្នុងព្រះវិហារ (យហ ១៨,២០) មានព្រះហឫទ័យចង់បង់ពន្ធព្រះវិហាររួមជាមួយលោកសិលា (មថ ១៧,២៤-២៧) ដែលទ្រង់ទើបតែងតាំងធ្វើជាគ្រឹះនៃព្រះសហគមន៍ព្រះអង្គ (មថ ១៦,១៨)។ ម្យ៉ាងទៀតព្រះអង្គបានយកព្រះវិហារធ្វើជាតំណាងដោយណែនាំខ្លួនថា ព្រះអង្គជាព្រះដំណាក់ជាស្ថាពររបស់ព្រះជាម្ចាស់ក្នុងចំណោមមនុស្សលោក (យហ ២,២១)។ ហេតុនេះព្រះយេស៊ូសោយទិវង្គត (យហ ២,១៨-២២) ជាទីសម្គាល់ទុកជាមុនថា ព្រះវិហារនឹងត្រូវបាក់បែកខ្ទេចហើយសម្តែងសម័យថ្មីក្នុងប្រវត្តិសាស្ត្រនៃការសង្គ្រោះ៖ "ដល់ពេលកំណត់មិនមែននៅលើភ្នំនេះ ឬនៅក្រុងយេរូសាឡឹមទៀតទេ ដែលអ្នករាល់គ្នានឹងថ្វាយបង្គំព្រះបិតា" (យហ ៤,២១)។

### ៣-ព្រះយេស៊ូនិងជំនឿរបស់ជនជាតិអ៊ីស្រាអែលលើព្រះជាម្ចាស់តែមួយជាព្រះសង្គ្រោះ

៥៨៧-ដោយសារព្រះយេស៊ូ ធម្មវិន័យ និងព្រះវិហារបានធ្វើឲ្យមេដឹកនាំសាសនាជនជាតិអ៊ីស្រាអែលខ្លះ បាន "ជំទាស់ប្រឆាំង" (លក ២,៣៤) តែពួកគេបាន "ដួលលើថ្ម" (លក ២០,១៧-១៨) នៃតួនាទីរបស់ព្រះអង្គក្នុងការសង្គ្រោះឲ្យរួចពីបាបជាព្រះរាជកិច្ចរបស់ព្រះជាម្ចាស់ផ្ទាល់តែម្តង។

៥៨៨-ព្រះយេស៊ូបានធ្វើឲ្យពួកខាងគណៈផារីស៊ីទាស់ចិត្ត ដោយសោយព្រះស្ងោយជាមួយអ្នកបាបយ៉ាងជិតស្និត (លក ៥,៣០) ដូចពេលព្រះអង្គសោយព្រះស្ងោយជាមួយពួកគេដែរ (លក ៧,៣៦)។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំមិនមែនមករកមនុស្សសុចរិតទេ គឺមករកមនុស្សបាប ដើម្បីឲ្យគេកែប្រែចិត្តគំនិត" (លក ៥,៣២) ប្រឆាំងនឹងពួកខាងគណៈផារីស៊ីដែល "នឹកស្មានថាខ្លួនជាមនុស្សសុចរិត ហើយបែរជាមើលងាយអ្នកដទៃ" (លក ១៨,៩)។ លើសពីនេះទៅទៀត ព្រះអង្គបានប្រកាសប្រាប់ពួកផារីស៊ីថា ដោយសារមនុស្សលោកទាំងអស់ជាប់នឹងអំពើបាប (យហ ៨,៣៣-៣៦) នរណាអះអាងថាខ្លួនមិនត្រូវការការសង្គ្រោះ អ្នកនោះប្រៀបដូចជាមនុស្សខ្វាក់ (យហ ១៩,៤០-៤១)។

៥៨៩-ជាពិសេសមនុស្សជាច្រើនបានទាស់ចិត្តនឹងព្រះអង្គ ព្រោះព្រះអង្គបានធ្វើឲ្យគេយល់ថាធម៌មេត្តាករុណារបស់ព្រះអង្គចំពោះអ្នកបាប ក៏ដូចជាធម៌មេត្តាករុណារបស់ព្រះអង្គចំពោះគេដែរ (មថ ៩,១៣)។ ព្រះអង្គបានធ្វើឲ្យគេយល់ថាដោយរួមតុជាមួយអ្នកបាប (លក ១៥,១-២) ព្រះអង្គក៏ទទួលគេក្នុងពិធីជប់លៀងចុងក្រោយ (លក

១៥,២៣-៣២)។ ប៉ុន្តែពេលព្រះអង្គលើកលែងទោសឲ្យអ្នកបាប មេដឹកនាំសាសនាបានបែកជាពីរ។ ដោយភ័យខ្លាច ពួកគេនិយាយពាក្យពិតថា៖ "ក្រៅពីព្រះជាម្ចាស់មួយព្រះអង្គ តើនរណាអាចអត់ទោសមនុស្សឲ្យរួចពីបាបបាន?" (មក ២,៧)។ ដោយលើកលែងទោសឲ្យអ្នកបាប លោកយេស៊ូប្រមាថព្រះជាម្ចាស់ ព្រោះលោកជាមនុស្សដែលតាំងខ្លួនជាព្រះជាម្ចាស់ (យហ ៥,១៨; ១០,៣៣) ឬមួយលោកនិយាយការពិត ហើយលោកសម្តែងព្រះនាមរបស់ព្រះជាម្ចាស់ (យហ ១៧,៦.២៦) ដែលមានវត្តមានក្នុងចំណោមមនុស្សលោក។

៥៩០-ដោយសារព្រះយេស៊ូជាព្រះជាម្ចាស់ មានតែព្រះអង្គទេ ដែលអាចមានព្រះបន្ទូលដូចតទៅ៖ "អ្នកណាមិនរួមជាមួយខ្ញុំ អ្នកនោះប្រឆាំងនឹងខ្ញុំ" (មថ ១២,៣០) យ៉ាងណាមិញនៅពេលព្រះយេស៊ូមានព្រះបន្ទូលអំពីខ្លួនព្រះអង្គថា៖ "មានម្នាក់ប្រសើរជាងលោក យ៉ូណាស ទៅទៀត (...) ប្រសើរជាងព្រះបាទ សាឡូម៉ូន ទៅទៀត" (មថ ១២,៤១-៤២) ប្រសើរជាងព្រះវិហារទៅទៀត (មថ ១២,៦) ឬពេលព្រះអង្គរំឭកអំពីខ្លួនព្រះអង្គថា ព្រះបាទដាវីឌ បានហៅព្រះមេស្ស៊ីជាព្រះអម្ចាស់របស់ព្រះអង្គ (មក ១២,៣៦-៣៧) ឬពេលព្រះអង្គមានព្រះបន្ទូលថា៖ "មុនលោក អប្រាហាំ កើតមក ខ្ញុំមានជីវិតរួចស្រេចទៅហើយ" (យហ ៨,៥៨) ឬ៖ "ខ្ញុំ និងព្រះបិតាជាអង្គតែមួយ" (យហ ១០,៣០)។

៥៩១-ព្រះយេស៊ូបានសុំឲ្យមេដឹកនាំសាសនានៅទីក្រុងយេរូសាឡឹមឲ្យផ្ញើជីវិតលើព្រះអង្គ ដោយសារកិច្ចការដែលព្រះអង្គប្រព្រឹត្ត (យហ ១០,៣៦-៣៨) ប៉ុន្តែត្រូវតែ "កើតជាថ្មី" (យហ ៣,៧) ដោយមានព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ទាក់ទាញចិត្តគំនិត (យហ ៦,១០) ដើម្បីផ្ញើជីវិតលើព្រះអង្គ។ ដោយសារព្រះយេស៊ូទាមទារឲ្យគេប្រែចិត្តគំនិតខ្លាំងពេក និងបំពេញព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់បែបនេះ យើងអាចយល់ថាក្រុមប្រឹក្សាជាន់ខ្ពស់បានភ័ន្តច្រឡំដោយសម្រេចចិត្តនឹងប្រហារជីវិតព្រះយេស៊ូជាអ្នកប្រមាថព្រះជាម្ចាស់ (មក ៣,៦)។ សមាជិកក្រុមប្រឹក្សាប្រព្រឹត្តដូច្នេះមកពីគេ "មិនដឹង" (លក ២៣,៣៤) គេមាន "ចិត្តរឹងរូស" (មក ៣,៥; រម ១១,២៥) ហើយគេ "គ្មានជំនឿ" (រម ១១,២០)។

## សង្ខេប

៥៩២-ព្រះយេស៊ូមិនបានលុបបំបាត់វិន័យនៃភ្នំស៊ីណៃចោលទេ ប៉ុន្តែព្រះអង្គបានបំពេញ (មថ ៥,១៧-១៩) វិន័យបានពេញលក្ខណៈ (យហ ៨,៤៦) បានជាព្រះអង្គសម្តែងអត្ថន័យចុងក្រោយ (មថ ៥,៣៣) នៃវិន័យនេះ ហើយព្រះអង្គក៏លោះការបំពានទាំងប៉ុន្មាន ដែលប្រឆាំងនឹងវិន័យនេះ (ហប ៩,១៥)។

៥៩៣-ព្រះយេស៊ូបានគោរពព្រះវិហារ ដោយយាងឡើងទៅធ្វើបូជនីយេចរណ៍នៃបុណ្យទាំងប៉ុន្មានៃសាសនាយូដា ហើយព្រះអង្គបានស្រឡាញ់ព្រះដំណាក់នៃព្រះជាម្ចាស់នេះ ដែលស្ថិតនៅក្នុងចំណោមមនុស្សលោក។ ព្រះវិហារតំណាងអាថ៌កំបាំងរបស់ព្រះអង្គ។ ពេលព្រះអង្គប្រកាសទុកជាមុនថា ព្រះវិហារនឹងត្រូវគេបំផ្លាញ ព្រះអង្គមានព្រះបន្ទូលអំពីការស្លាប់របស់ព្រះអង្គផ្ទាល់ ដែលជាការចូលក្នុងយុគថ្មីនៃប្រវត្តសាស្ត្រនៃការសង្គ្រោះ ដែលព្រះកាយព្រះអង្គនឹងទៅជាព្រះវិហារចុងក្រោយបំផុត។

៥៩៤-ព្រះយេស៊ូបានបំពេញសកម្មភាពជាច្រើន ដូចជាការលើងលែងទោសឲ្យរួចពីបាប ដែលបានសម្តែងព្រះអង្គជាព្រះជាម្ចាស់ ជាព្រះសង្គ្រោះផ្ទាល់ (យហ ៥,១៦-១៨)។ ជនជាតិយូដាខ្លះ ដែលមិនទទួលស្គាល់ព្រះជាម្ចាស់ប្រសូតជាមនុស្ស (យហ ១,១៤) ចាត់ទុកថាព្រះអង្គជា "មនុស្សដែលតាំងខ្លួនជាព្រះជាម្ចាស់" (យហ ១០,៣៣) និងបានកាត់ក្តីព្រះអង្គថា ជាអ្នកប្រមាថព្រះជាម្ចាស់។

## កថាខណ្ឌទី២៖ ព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាង

### ១-គេកាត់ក្ដីព្រះយេស៊ូ

#### មេដឹកនាំជនជាតិយូដាបាក់បែកគ្នាដោយសារព្រះយេស៊ូ

៥៩៥-ក្នុងចំណោមមេដឹកនាំសាសនានៅទីក្រុងយេរូសាឡឹមមានលោក នីកូដេម (យហ ៧,៥០) ជាអ្នកខាងគណៈផារីស៊ី ឬលោក យ៉ូសែប ជាអ្នកស្រុកអារីម៉ាថេជាសាវ័កសម្ងាត់របស់ព្រះយេស៊ូ (យហ ១៩,៣៨-៣៩)។ ប៉ុន្តែមេដឹកនាំសាសនាបានបាក់បែកគ្នា ដោយសារព្រះអង្គ (យហ ១៩,១៦-១៧; ១០,១៩-២១) គឺនៅពេលព្រះអង្គហៀបនឹងរងទុក្ខលំបាក "មានអ្នកជាច្រើននាក់ជឿលើព្រះអង្គ" ទោះបីជំនឿនេះមិនគ្រប់លក្ខណៈយ៉ាងណាក៏ដោយ (យហ ១២,៤២)។ ដូច្នេះយើងមិនត្រូវឆ្ងល់ថា ក្រោយពីបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក "មានពួកបូជាចារ្យដ៏ច្រើនលើសលប់ សុខចិត្តប្រតិបត្តិតាមជំនឿ" (កក ៦,៧) ហើយ "មានបងប្អូនខ្លះខាងគណៈផារីស៊ីដែលជឿព្រះអម្ចាស់" (កក ១៥,៥)។ ហេតុនេះហើយបានជាសន្តៈ យ៉ាកុប អាចមានប្រសាសន៍ទៅកាន់សន្តៈ ប៉ូល ថា៖ "មានជនជាតិយូដារាប់ម៉ឺននាក់បានជឿ ហើយបងប្អូនទាំងនោះជាប់ចិត្តនឹងធម្មវិន័យខ្លាំងណាស់" (កក ២០,២១)។

៥៩៦-មេដឹកនាំសាសនានៅទីក្រុងយេរូសាឡឹម មិនបានរួបរួមគ្នាជាផ្លុងតែមួយចំពោះព្រះយេស៊ូទេ (យហ ៩,១៦; ១០,១៩)។ ពួកខាងគណៈផារីស៊ីគំរាមថានឹងបណ្ដេញអស់អ្នកដែលដើរតាមព្រះអង្គ (យហ ៩,២២)។ ចំពោះអស់អ្នកដែលខ្លាចថា "ប្រជាជនមុខតែជឿទៅលើ (ព្រះយេស៊ូ) ទាំងអស់គ្នា ហើយជនជាតិរ៉ូម៉ាំងនឹងមកបំផ្លាញព្រះវិហារ និងបំបាត់ជាតិសាសន៍របស់យើងជាមិនខាន" (យហ ១១,៤៨) លោកមហាបូជាចារ្យកៃផាសមានប្រសាសន៍ទាយថា៖ "បើមនុស្សតែម្នាក់ស្លាប់ជាប្រយោជន៍ដល់ប្រជារាស្ត្រនោះ ប្រសើរជាងទុកឲ្យជាតិទាំងមូលត្រូវវិនាស" (យហ ១១,៤៩-៥០)។ ក្រុមប្រឹក្សាជាន់ខ្ពស់បានប្រកាសថា ព្រះយេស៊ូជាអ្នកប្រមាថព្រះជាម្ចាស់ "ត្រូវមានទោសដល់ជីវិត" (មថ ២៦,៦៦) ប៉ុន្តែដោយសារពួកគេគ្មានច្បាប់នឹងប្រហារជីវិតមនុស្ស (យហ ១៨,៣១) ពួកគេប្រគល់ព្រះយេស៊ូឲ្យជនជាតិរ៉ូម៉ាំង ដោយចោទប្រកាន់ព្រះអង្គថាព្រះអង្គបំបះបំបោរប្រជារាស្ត្រ (លក ២៣,២)។ ហេតុនេះគេនឹងកាត់ក្តីព្រះអង្គរួមជាមួយលោកបារ៉ាបាស ដែលជាប់ឃុំឃាំង ព្រោះលោកបាន "បង្កចលាចល ព្រមទាំងបានសម្លាប់មនុស្សផង" (លក ២៣,១៩)។ ពួកមហាបូជាចារ្យគំរាមលោកពីឡាតឲ្យបង្កើតរឿងនយោបាយ បើលោកមិនព្រមដាក់ទោសប្រហារជីវិតព្រះយេស៊ូដែរ (យហ ១៩,១២.១៥.២១)។

#### ជនជាតិយូដាទាំងមូលមិនទទួលខុសត្រូវក្នុងការប្រហារជីវិតព្រះយេស៊ូឡើយ

៥៩៧-ពេលយើងចាប់អារម្មណ៍ពីកាលៈទេសៈដ៏ស្មុគស្មាញ ដែលកំណត់ដំណឹងល្អសម្ដែងឲ្យយើងដឹងនូវការកាត់ក្តីរបស់ព្រះយេស៊ូ ហើយទោះបីជាតួអង្គម្នាក់ៗ (លោកយូដាសក្រុមប្រឹក្សាជាន់ខ្ពស់លោកពីឡាត) បានប្រព្រឹត្តអំពើបាបតូច ឬធំដែលមានតែព្រះជាម្ចាស់ស្គាល់យ៉ាងណាក៏ដោយ ក៏យើងគ្មានសិទ្ធិចោទប្រកាន់ថាជនជាតិយូដាទាំងមូលនៅទីក្រុងយេរូសាឡឹម ជាអ្នកទទួលខុសត្រូវក្នុងការកាត់ក្តីនេះឡើយ ទោះបីបណ្ដាជនដែលត្រូវគេបញ្ចុះបញ្ចូល (មក ១៥,១១) បានស្រែកឡើងថា៖ "ឆ្កាងទៅ!" ហើយទោះបីក្រុមគ្រីស្តទូតបានស្ដីបន្ទោសបណ្ដាជននេះ នៅពេលពួកលោកសុំឲ្យគេកែប្រែចិត្តគំនិតពេលបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក (កក ២,២៣.៣៦; ៣,១៣-១៤; ៤,១០; ៥,៣០; ៧,៥២; ១០,៣៩; ១៣,២៧-២៨; ១ថស ២,១៤-១៥) យ៉ាងណាក៏ដោយ។ ព្រះយេស៊ូផ្ទាល់បានលើកលែងទោសឲ្យគេនៅលើឈើឆ្កាង ហើយលោកសិលាបានទទួលស្គាល់ថាជនជាតិយូដានៅទីក្រុង

យេរូសាឡឹម និងពួកមេរបស់គេបានប្រព្រឹត្តដូច្នោះ "ទាំងមិនដឹងខ្លួន" (កក ៣,១៧)។ ទោះបីប្រជាជនបានស្រែកឡើងថា៖ "យើងខ្ញុំ និងកូនចៅរបស់យើងខ្ញុំទទួលខុសត្រូវក្នុងការប្រហារជីវិតជននេះ!" (មថ ២៧,២៥) យ៉ាងណាក៏ដោយ ក៏យើងមិនអាចចោទប្រកាន់ជនជាតិយូដាដទៃគ្រប់សម័យ និងគ្រប់កន្លែងបានដែរ។

ហេតុនេះហើយបានជាព្រះសហគមន៍បានប្រកាសនៅមហាសន្និបាតវ៉ាទីកង់ទីពីរថា "យើងគ្មានសិទ្ធិចោទប្រកាន់ប្រជាជនយូដាទាំងមូលដែលរស់នៅសម័យព្រះយេស៊ូ ឬជនជាតិយូដាសព្វថ្ងៃនេះថាគេបានធ្វើគុតព្រះអង្គទេ (...) មិនត្រូវសំអាងលើគម្ពីរ ដើម្បីប្រកាន់ថាព្រះអង្គបានដាក់ទោសប្រជាជនយូដា ឬដាក់បណ្ដាសាគេដែរ" (NA ៤)។

## មនុស្សបាបទាំងអស់ជាអ្នកទទួលខុសត្រូវនៃទុក្ខលំបាករបស់ព្រះគ្រីស្ដ

៥៩៨-ដោយរួមជាមួយក្រុមមេដឹកនាំ និងសក្ខីភាពរបស់សន្តបុគ្គល ព្រះសហគមន៍មិនដែលភ្លេចថា "មនុស្សបាបផ្ទាល់ខ្លួនជាអ្នកទទួលខុសត្រូវ និងដូចជាឧបករណ៍នៃទុក្ខលំបាកទាំងប៉ុន្មានរបស់ព្រះសង្គ្រោះ" (CR)។ ដោយចាត់ទុកថាអំពើបាបរបស់យើងប៉ះពាល់នឹងព្រះគ្រីស្ដផ្ទាល់ (មថ ២៥,៤៥; កក ៩,៤-៥) ព្រះសហគមន៍មិនរួញរាចោទប្រកាន់ថា គឺគ្រីស្ដបរិស័ទដែលធ្លាប់ចោទជនជាតិយូដាច្រើនពេក ជាអ្នកទទួលខុសត្រូវធ្ងន់ជាងគេក្នុងការធ្វើគុតព្រះយេស៊ូ។

យើងត្រូវតែចាត់ទុកថា អស់អ្នកដែលនៅតែប្រព្រឹត្តអំពើបាបដដែល ជាអ្នកទទួលខុសត្រូវចំពោះកំហុសដ៏ធ្ងន់ធ្ងរនេះ។ ដោយសារអំពើឧក្រិដ្ឋទាំងប៉ុន្មានរបស់យើងបានធ្វើឲ្យព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់នៃយើងបានរងទុក្ខលំបាកនៅលើឈើឆ្កាង ប្រាកដជាអស់អ្នកដែលប្រព្រឹត្តអំពើបាបនានា "ឆ្កាងព្រះបុត្រារបស់ព្រះជាម្ចាស់សាជាថ្មី ព្រមទាំងបន្ថោកកិត្តិយសព្រះអង្គជាសាធារណៈផង" (ហប ៦,៦)។ យើងត្រូវតែទទួលស្គាល់ថា បទឧក្រិដ្ឋរបស់យើងធ្ងន់ជាងបទឧក្រិដ្ឋរបស់ជនជាតិយូដាទៅទៀត ដ្បិតតាមសក្ខីភាពរបស់គ្រីស្ដទូតប៉ូល "ប្រសិនបើគេពិតជាបានស្គាល់មែន គេមិនបានឆ្កាងព្រះអម្ចាស់ប្រកបដោយសិរីរុងរឿងនេះឡើយ" (១ករ ២,៨)។ ផ្ទុយទៅវិញ ចំពោះយើងវិញ យើងប្រកាសថាស្គាល់ព្រះអង្គ ហើយនៅពេលយើងបដិសេធមិនព្រមស្គាល់ព្រះអង្គ ដោយកិច្ចការរបស់យើង ហាក់ដូចជាយើងធ្វើគត់ព្រះអង្គដោយដៃរបស់យើងផ្ទាល់ (CR)។

ពួកបិសាចមិនបានឆ្កាងព្រះអង្គទេ គឺអ្នករួមជាមួយនឹងពួកវាបានឆ្កាងព្រះអង្គ និងនៅតែឆ្កាងព្រះអង្គម្ដងទៀត ដោយត្រេកត្រអាលក្នុងអបាយមុខ និងអំពើបាប (សន្តៈ ហ្វ្រង់ស័រ នៃអាសុីសុី)។

## ២-ព្រះគ្រីស្ដសោយទិវង្គតតាមគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់

### "បងប្អូនបានចាប់បញ្ជូនលោកយេស៊ូ (...) ដូចព្រះជាម្ចាស់បានកំណត់ទុក"

៥៩៩-ព្រះយេស៊ូសោយទិវង្គតយ៉ាងសាហាវ មិនមែនមកពីចៃដន្យ ឬកាលៈទេសៈដ៏អាក្រក់ទេ តែមកពីគម្រោងការដ៏លាក់កំបាំងរបស់ព្រះជាម្ចាស់ដូចសន្តៈ សិលា ពន្យល់ឲ្យជនជាតិយូដានៅទីក្រុងយេរូសាឡឹមនៅបុណ្យព្រះវិញ្ញាណយាងមក៖ "បងប្អូនបានចាប់បញ្ជូនលោកយេស៊ូ (...) ដូចព្រះជាម្ចាស់បានកំណត់ទុកដោយព្រះអង្គទ្រង់ញាណជាមុន" (កក ២,២៣)។ ប៉ុន្តែព្រះគម្ពីរមិនចែងថា អ្នកដែលបាន "ចាប់បញ្ជូនព្រះយេស៊ូ" (កក ៣,១៣) ដូចជាអាយ៉ងនៃគម្រោងការទុកជាមុនរបស់ព្រះជាម្ចាស់ឡើយ។

៦០០-ចំពោះព្រះជាម្ចាស់គ្រប់សម័យកាលស្ថិតក្នុងពេលតែមួយ។ ដូច្នេះព្រះអង្គកំណត់ទុកជាមុនគម្រោងការអស់កល្បជានិច្ចរបស់ព្រះអង្គ ដោយនឹកគិតដល់ចម្លើយដ៏សេរីរបស់មនុស្សចំពោះព្រះហឫទ័យប្រណីសន្ដោសរបស់

ព្រះអង្គ៖ "ប្រាកដមែន! នៅក្នុងក្រុងនេះស្តេច ហេរ៉ូដ និងលោក ប៉ុនពីឡាត បានរួមគ្នាប្រឆាំងនឹងព្រះយេស៊ូជាអ្នកបម្រើដ៏វិសុទ្ធរបស់ព្រះអង្គដែលទ្រង់បានចាក់ប្រេងអភិសេក មានទាំងសាសន៍ដទៃ និងប្រជារាស្ត្រអ៊ីស្រាអែលសមគំនិតផង។ គេនាំគ្នាប្រព្រឹត្តដូចព្រះអង្គបានកំណត់ទុកជាមុនតាមឫទ្ធានុភាព និងព្រះប្រាជ្ញាញាណរបស់ព្រះអង្គ" (កក ៤,២៧-២៨)។ ព្រះជាម្ចាស់បានឲ្យគេប្រព្រឹត្តកិច្ចការដោយងងឹតងងល ដើម្បីគម្រោងការរបស់ព្រះអង្គអំពីការសង្គ្រោះមនុស្សលោកបានសម្រេច។

## "ព្រះគ្រីស្តបានសោយទិវង្គតដើម្បីរំដោះបាបយើងស្របតាមគម្ពីរ"

៦០១-ព្រះគម្ពីរបានចែងទុកជាមុនអំពីគម្រោងការរបស់ព្រះជាម្ចាស់សង្គ្រោះមនុស្សលោក ដោយសារ "អ្នកបម្រើដ៏សុចរិត" (អស ៥៣,១១)។ តាមគម្រោងការដ៏លាក់កំបាំងនេះ ព្រះអង្គនឹងលោះមនុស្សលោកឲ្យរួចពីភាពជាទាសករនៃអំពើបាប។ នៅក្នុងធម៌ប្រកាសជំនឿមួយដែលសន្តៈ ប៉ូល បាន "ទទួល" លោកប្រកាសថា "ព្រះគ្រីស្តបានសោយទិវង្គតដើម្បីរំដោះបាបយើងស្របតាមគម្ពីរ" (១ករ ១៥,៣)។ សេចក្តីស្លាប់របស់ព្រះយេស៊ូដែលសង្គ្រោះមនុស្សលោកបំពេញអត្ថន័យនៃពាក្យប្រកាសអំពីអ្នកបម្រើដែលរងទុក្ខលំបាក (អស ៥៣,៧-៨)។ ព្រះយេស៊ូផ្ទាល់បានពន្យល់អត្ថន័យនៃជីវិត និងសេចក្តីស្លាប់របស់ព្រះអង្គក្រោមពន្លឺនៃអ្នកបម្រើដែលរងទុក្ខលំបាក (មត ២០,២៨)។ ក្រោយពីព្រះអង្គបានមានជីវិតថ្មី ទ្រង់ក៏បកស្រាយព្រះគម្ពីរតាមអត្ថន័យនោះចំពោះសាវ័កដែលធ្វើដំណើរទៅភូមិអេម៉ាអ៊ូស (លក ២៤,២៥-២៧) និងចំពោះក្រុមគ្រីស្តទូតផ្ទាល់ (លក ២៤,៤៤-៤៥)។

## "ព្រះជាម្ចាស់បានធ្វើឲ្យព្រះគ្រីស្តទៅជាតួបាបសម្រាប់យើង"

៦០២-ហេតុនេះហើយបានជាសន្តៈ សិលា អាចសម្តែងនូវជំនឿដែលមកពីក្រុមគ្រីស្តទូតតាមគម្រោងការរបស់ព្រះជាម្ចាស់អំពីការសង្គ្រោះ៖ "បងប្អូនជ្រាបស្រាប់ហើយថា ព្រះជាម្ចាស់បានលោះបងប្អូនឲ្យរួចពីរបៀបរស់នៅឥតន័យ ដែលជាដំណែលតពីបុព្វបុរសរបស់បងប្អូន មិនមែនដោយសារអ្វីៗដែលតែងតែរលាយសាបសូន្យទៅ ដូចជាមាស ឬប្រាក់ទេ គឺដោយសារព្រះលោហិតដ៏ថ្លៃវិសេសរបស់ព្រះគ្រីស្ត ដែលប្រៀបបាននឹងកូនចៀមដ៏ល្អឥតខ្ចោះ ឥតស្លាកស្នាម។ ព្រះជាម្ចាស់បានជ្រើសតាំងព្រះគ្រីស្តមុនកំណើតពិភពលោកទៅទៀត ហើយបានបង្ហាញព្រះអង្គឲ្យមនុស្សលោកឃើញនៅគ្រាចុងក្រោយនេះ ព្រោះតែបងប្អូន" (១ពត្រ ១,១៨-២០)។ អំពើបាបរបស់មនុស្សលោកដែលមកពីអំពើបាបដើមត្រូវតែស្លាប់ (រម ៥,១២)។ ដោយចាត់ព្រះបុត្រាព្រះអង្គឲ្យយាងមកក្នុងឋានៈជាទាសករ (ភីល ២,៧) គឺដូចមនុស្សជាតិដែលបានធ្លាក់ខ្លួនជាអ្នកបាប និងត្រូវតែស្លាប់ (រម ៨,៣) "ព្រះជាម្ចាស់បានធ្វើឲ្យព្រះគ្រីស្ត (ដែលគ្មានបាបទាល់តែសោះ) ទៅជាតួបាបសម្រាប់យើង ដើម្បីប្រោសយើងឲ្យបានសុចរិតរួមជាមួយព្រះគ្រីស្តដែរ" (២ករ ៥,២១)។

៦០៣-ព្រះជាម្ចាស់មិនបានដាក់ទោសព្រះយេស៊ូ ដូចជាព្រះអង្គផ្ទាល់បានប្រព្រឹត្តបាបទេ (យហ ៨,៤៦) ប៉ុន្តែដោយរួមជាមួយព្រះបិតាក្នុងសេចក្តីស្រឡាញ់ដែលសង្គ្រោះមនុស្សលោក (យហ ៨,២៩) ព្រះអង្គក៏បានទទួលយកយើងជាអ្នកឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ដោយសារអំពើបាបរបស់យើងរហូតដល់ព្រះអង្គអាចមានព្រះបន្ទូលក្នុងនាមយើងនៅលើឈើឆ្កាងថា៖ "ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ! ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ?" (មក ១៥,៣៤; ទន ២២,១)។ ដោយប្រោសព្រះអង្គឲ្យបានរួមសាមគ្គីជាមួយយើងជាអ្នកបាប "ព្រះជាម្ចាស់ពុំបានទុកព្រះបុត្រារបស់ព្រះអង្គផ្ទាល់ទេ គឺព្រះអង្គបានបញ្ជូនព្រះបុត្រានោះមកសម្រាប់យើងទាំងអស់គ្នា" (រម ៨,៣២) ដើម្បីសម្រុះសម្រួលយើងឲ្យជានានឹងព្រះអង្គវិញ ដោយព្រះបុត្រារបស់ព្រះអង្គបានសោយ

ទិវង្គត" (រម ៥,១០)។

## ព្រះជាម្ចាស់ជាអ្នកផ្តើមស្រឡាញ់ និងសង្គ្រោះមនុស្សលោកទាំងអស់

៦០៤-ដោយប្រគល់ព្រះបុត្រាព្រះអង្គដើម្បីលោះបាបយើង ព្រះជាម្ចាស់សម្តែងថាគម្រោងការរបស់ព្រះអង្គចំពោះយើងជាគម្រោងការដ៏សប្បុរសហួសពីគុណណាមួយរបស់យើង៖ "សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មានដូចតទៅនេះមិនមែនយើងទេដែលបានស្រឡាញ់ព្រះអង្គ គឺព្រះអង្គទេតើដែលបានស្រឡាញ់យើង និងបានចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យយាងមកបូជាព្រះជន្មលោះយើងឲ្យរួចពីបាប" (១យហ ៤,១០) (១យហ ៤,១៩)។ "ព្រះជាម្ចាស់បានបង្ហាញព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គចំពោះយើង គឺព្រះគ្រីស្តបានសោយទិវង្គតសម្រាប់យើងក្នុងពេលដែលយើងនៅជាមនុស្សជាប់បាបនៅឡើយ" (រម ៥,៨)។

៦០៥-ព្រះយេស៊ូបានរំឭកសេចក្តីស្រឡាញ់នេះដែលមិនប្រកាន់អ្នកណាម្នាក់ឡើយ នៅចុងក្រោយនៃពាក្យប្រស្នាអំពីចៀមដែលវង្វេងបាត់៖ "រីឯព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខ ក៏ដូច្នេះដែរ ទ្រង់មិនសព្វព្រះហឫទ័យឲ្យអ្នកណាម្នាក់ក្នុងចំណោមអ្នកតូចតាចទាំងនេះ វិនាសបាត់បង់ឡើយ" (មថ ១៨,១៤)។ ព្រះអង្គមានព្រះបន្ទូលថាព្រះអង្គ "បូជាជីវិតដើម្បីលោះមនុស្សទាំងអស់ផង" (មថ ២០,២៨) គឺមានតែព្រះសង្គ្រោះទេដែលប្រគល់ខ្លួនដើម្បីសង្គ្រោះមនុស្សជាតិទាំងមូល (រម ៥,១៨-១៩)។ តាមក្រុមគ្រីស្តទូត (២ករ ៥,១៥; ១យហ ២,២) ព្រះសហគមន៍ប្រៀនប្រដៅថា ព្រះគ្រីស្តបានសោយទិវង្គតសម្រាប់មនុស្សលោកទាំងអស់ដោយគ្មានការលើកលែងទេ។ "ព្រះគ្រីស្តបានរងទុក្ខលំបាកសម្រាប់មនុស្សគ្រប់ៗរូប តាំងពីអតីតកាលក្តី សម័យឥឡូវក្តី ឬអនាគតកាលក្តី" (DS ៦២៤)។

## ៣-ព្រះគ្រីស្តបានថ្វាយខ្លួនព្រះអង្គទៅព្រះបិតាដើម្បីលោះបាបរបស់យើង

### ជីវិតទាំងស្រុងរបស់ព្រះគ្រីស្តជាតង្វាយថ្វាយទៅព្រះបិតា

៦០៦-ព្រះបុត្រារបស់ព្រះជាម្ចាស់ "ចុះពីស្ថានបរមសុខមកដើម្បីធ្វើតាមព្រះហឫទ័យរបស់ (ព្រះបិតា) ដែលបានចាត់ (ព្រះបុត្រា) ឲ្យមក គឺពុំមែនធ្វើតាមបំណងចិត្តរបស់ (ព្រះបុត្រា) ទេ" (យហ ៦,៣៨) "នៅពេលដែលព្រះគ្រីស្តយាងចូលក្នុងពិភពលោក ព្រះអង្គមានព្រះបន្ទូល (...) ថា៖ ទូលបង្គំមកធ្វើតាមព្រះហឫទ័យរបស់ (ព្រះជាម្ចាស់)។ ព្រះយេស៊ូគ្រីស្តថ្វាយព្រះកាយរបស់ព្រះអង្គតែម្តងជាការស្រេច តាមព្រះហឫទ័យព្រះជាម្ចាស់ ហេតុនេះហើយបានជាព្រះអង្គប្រោសយើងឲ្យបានវិសុទ្ធ" (ហប ១០,៥-១០)។ លុះដល់ពេលព្រះបុត្រាប្រសូតជាមនុស្សភ្លាមៗ ព្រះអង្គរួមជាមួយព្រះជាម្ចាស់ក្នុងការសង្គ្រោះមនុស្សលោក៖ "អាហាររបស់ខ្ញុំ គឺធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គដែលបានចាត់ខ្ញុំឲ្យមក ព្រមទាំងបង្ហើយកិច្ចការរបស់ព្រះអង្គឲ្យបានសម្រេច" (យហ ៤,៣៤)។ ព្រះយេស៊ូបូជាព្រះជន្ម "ដើម្បីលោះមនុស្សលោកទាំងមូល" ឲ្យរួចពីបាប (១យហ ២,២) សម្តែងថាព្រះអង្គរួមជាមួយព្រះបិតាដោយក្តីស្រឡាញ់៖ "ព្រះបិតាស្រឡាញ់ខ្ញុំ ព្រោះខ្ញុំសុខចិត្តស៊ូប្តូរជីវិត" (យហ ១០,១៧)។ "ឲ្យមនុស្សលោកដឹងថាខ្ញុំស្រឡាញ់ព្រះបិតា ហើយខ្ញុំសុខចិត្តធ្វើតាមបង្គាប់របស់ព្រះអង្គ" (យហ ១៤,៣១)។

៦០៧-អស់មួយជីវិត ព្រះយេស៊ូមានបំណងប្រាថ្នារួមជាមួយព្រះបិតាក្នុងគម្រោងការសង្គ្រោះមនុស្សលោក (លក ១២,៥០; ២២,១៥) ព្រោះព្រះយេស៊ូប្រសូតដើម្បីរងទុក្ខលំបាក និងសង្គ្រោះមនុស្សលោក៖ "ឱព្រះបិតាអើយ! សូមសង្គ្រោះទូលបង្គំឲ្យរួចផុតពីទុក្ខលំបាកនៅពេលកំណត់នេះផង។ ប៉ុន្តែទូលបង្គំមកដើម្បីរងទុក្ខលំបាក

ក្នុងពេលកំណត់នេះហើយ" (យហ ១២,២៧)។ "តើអ្នកមិនចង់ឲ្យខ្ញុំផឹកពីពែងនៃទុក្ខលំបាកដែលព្រះបិតាប្រទានមកខ្ញុំទេឬ?" (យហ ១៨,១១) ហើយនៅលើឈើឆ្កាងមុនព្រះអង្គ "បានសម្រេចសព្វគ្រប់អស់ហើយ" (យហ ១៩,៣០) ព្រះអង្គមានព្រះបន្ទូលថា៖ "ខ្ញុំស្រេចទឹក" (យហ ១៩,២៨)។

## "កូនចៀមរបស់ព្រះជាម្ចាស់ដែលដកបាបចេញពីមនុស្សលោក"

៦០៨-ក្រោយពីបានសុខចិត្តជ្រមុជទឹក ព្រះយេស៊ូដូចអ្នកបាបឯទៀតៗ (លក ៣,២១; មថ ៣,១៤-១៥) លោក យ៉ូហានបាទីស្ត បានឃើញ និងបានណែនាំព្រះអង្គជា "កូនចៀមរបស់ព្រះជាម្ចាស់ដែលដកបាបចេញពីមនុស្សលោក" (យហ ១,២៩) (យហ ១,៣៦)។ លោកសម្តែងថាព្រះយេស៊ូជាអ្នកបម្រើដែលរងទុក្ខលំបាកដែលគេដឹកទៅទីពិឃាត (អស ៥៣,៧) (យរ ១១,១៩) និងដែលទទួលយកបាបរបស់មនុស្សទាំងអស់ (អស ៥៣,១២) ហើយជាកូនចៀមនៃបុណ្យចម្លងដែលជានិមិត្តរូបនៃការសង្គ្រោះរបស់ជនជាតិអ៊ីស្រាអែលនៅបុណ្យចម្លងទីមួយ (សរ ១២,៣-១៤) (យហ ១៩,៣៦; ១ករ ៥,៧)។ ជីវិតទាំងស្រុងរបស់ព្រះគ្រីស្តសម្តែងនូវបេសកកម្មរបស់ព្រះអង្គគឺ "បម្រើ និងបូជាជីវិតដើម្បីលោះមនុស្សទាំងអស់ផង" (មក ១០,៤៥)។

## ព្រះយេស៊ូរួមជាមួយព្រះបិតាដែលស្រឡាញ់ និងសង្គ្រោះមនុស្សលោក

៦០៩-ដោយរួមចិត្តគំនិតជាមួយព្រះបិតាដែលស្រឡាញ់មនុស្សលោក ព្រះយេស៊ូបាន "ស្រឡាញ់គេរហូតដល់ទីបំផុត" (យហ ១៣,១) ដ្បិត "គ្មាននរណាមានសេចក្តីស្រឡាញ់ខ្លាំងជាងអ្នកដែលស៊ូប្តូរជីវិតដើម្បីមិត្តសម្លាញ់របស់ខ្លួននោះឡើយ" (យហ ១៥,១៣)។ ហេតុនេះក្នុងទុក្ខលំបាក និងសេចក្តីស្លាប់ជាតិជាមនុស្សរបស់ព្រះអង្គបានទៅជាឧបករណ៍ដ៏សេរី និងដ៏ល្អឥតខ្ចោះនៃសេចក្តីស្រឡាញ់របស់ព្រះអង្គក្នុងឋានៈជាព្រះជាម្ចាស់ដែលមានព្រះហឫទ័យសង្គ្រោះមនុស្សលោកទាំងអស់ (ហប ២,១០.១៧-១៨; ៤,១៥; ៥,៧-៩)។ ព្រះអង្គស្ម័គ្រចិត្តសុខចិត្តរងទុក្ខលំបាក និងសេចក្តីស្លាប់ដោយសារសេចក្តីស្រឡាញ់ចំពោះព្រះបិតា និងមនុស្សលោកដែលព្រះបិតាមានព្រះហឫទ័យសង្គ្រោះ៖ "គ្មាននរណាដកហូតជីវិតរបស់ខ្ញុំបានឡើយ គឺខ្ញុំស៊ូប្តូរជីវិតដោយខ្លួនខ្ញុំផ្ទាល់តែម្តង" (យហ ១០,១៨)។ ហេតុនេះព្រះបុត្រារបស់ព្រះជាម្ចាស់មានសេរីភាពពេញលេញ នៅពេលព្រះអង្គតម្រង់ទៅសេចក្តីស្លាប់ (យហ ១៨,៤-៦; មថ ២៦,៥៣)។

## នៅពិធីជប់លៀងចុងក្រោយព្រះយេស៊ូស្ម័គ្រចិត្តថ្វាយព្រះជន្មទុកជាមុន

៦១០-នៅពេលរួមតុជាមួយគ្រីស្តទូតដប់ពីររូប (មថ ២៦,២០) គឺ "នៅយប់ដែលព្រះអម្ចាស់យេស៊ូត្រូវគេចាប់បញ្ជូន" (១ករ ១១,២៣) ព្រះយេស៊ូបានសម្តែងយ៉ាងច្បាស់ថា ព្រះអង្គស្ម័គ្រចិត្តថ្វាយព្រះជន្មរបស់ព្រះអង្គផ្ទាល់។ ថ្ងៃមុនរងទុក្ខលំបាកនៅពេលព្រះយេស៊ូមានសេរីភាពនៅឡើយ ព្រះអង្គបានធ្វើឲ្យពិធីជប់លៀងចុងក្រោយជាមួយក្រុមគ្រីស្តទូតបានទៅជាពិធីរំឭកសក្ការៈបូជារបស់ព្រះអង្គចំពោះព្រះបិតា (១ករ ៥,៧) ដើម្បីសង្គ្រោះមនុស្សលោក៖ "នេះជារូបកាយរបស់ខ្ញុំដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា" (លក ២២,១៩) ហើយ "នេះជាលោហិតរបស់ខ្ញុំគឺលោហិតនៃសម្ពន្ធមេត្រីដែលត្រូវបង្ហូរ ដើម្បីលើកលែងទោសមនុស្សទាំងអស់ឲ្យរួចពីបាប" (មថ ២៦,២៨)។

៦១១-នៅពេលនោះព្រះយេស៊ូបង្កើតពិធីអភិបូជាដែលនឹងទៅជា "ពិធីនឹករឭក" (១ករ ១១,២៥) នៃយញ្ញបូជារបស់ព្រះអង្គ។ ព្រះយេស៊ូបញ្ចូលក្រុមគ្រីស្តទូតទៅក្នុងតង្វាយរបស់ព្រះអង្គផ្ទាល់ ហើយសុំឲ្យគេបន្តតង្វាយនេះតទៅទៀត (លក ២២,១៩)។ ហេតុនេះព្រះយេស៊ូតែងតាំងក្រុមគ្រីស្តទូតឲ្យទៅជាបូជាចារ្យនៃសម្ពន្ធមេត្រីថ្មី៖

"ទូលបង្គំបូជាជីវិតថ្វាយព្រះអង្គជាប្រយោជន៍ដល់គេ ដើម្បីឲ្យគេបានវិសុទ្ធដោយសារសេចក្តីពិត" (យហ ១៧,១៩) (DS ១៧៥២; ១៧៦៤)។

## ព្រះយេស៊ូរងទុក្ខលំបាកនៅសួនកេតសេម៉ានី

៦១២-នៅសួនកេតសេម៉ានី (មថ ២៦,៤២) ដោយ "ធ្វើតាមព្រះបញ្ជារហូតដល់សោយទិវង្គត" (ភីល ២,៨; ហប ៥,៧-៨) ព្រះយេស៊ូក៏សុខចិត្តទទួលពីព្រះហស្តរបស់ព្រះបិតាពែងនៃសម្ព័ន្ធមេត្រីថ្មី ដែលព្រះអង្គបានទុកជាមុនដោយថ្វាយខ្លួន (លក ២២,២០) នៅពិធីជប់លៀងចុងក្រោយ។ ព្រះយេស៊ូអធិដ្ឋាន៖ "ឱព្រះបិតាអើយ! ប្រសិនបើបានសូមឲ្យពែងនៃទុក្ខលំបាកនេះចេញឆ្ងាយពីទូលបង្គំទៅ..." (មថ ២៦,៣៩)។ ព្រះយេស៊ូសម្តែងថាក្នុងឋានៈជាមនុស្ស ព្រះអង្គរន្ធត់ចិត្តយ៉ាងខ្លាំងចំពោះសេចក្តីស្លាប់ ដ្បិតព្រះជាម្ចាស់តម្រូវសភាពជាមនុស្សរបស់ព្រះយេស៊ូឲ្យមានជីវិតអស់កល្បជានិច្ចដូចមនុស្សយើងដែរ។ ម្យ៉ាងទៀតសភាពជាមនុស្សរបស់ព្រះយេស៊ូខុសប្លែកពីយើង ដ្បិតព្រះអង្គមិនជាប់បាបអ្វីឡើយ (ហប ៤,១៥) ដែលរមែងតែងតែនាំឲ្យស្លាប់ (រម ៥,១២)។ លើសពីនេះទៅទៀត "ម្ចាស់នៃជីវិត" (កក ៣,១៥) "អស់កល្បជានិច្ច" (វវ ១,១៧) (យហ ១,៤; ៥,២៦) បានទទួលយកសភាពជាមនុស្ស។ ដោយសុខចិត្តធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាក្នុងឋានៈជាមនុស្ស (មថ ២៦,៤២) ព្រះយេស៊ូសុខចិត្តឲ្យសេចក្តីស្លាប់របស់ព្រះអង្គនាំការសង្គ្រោះដោយ "ផ្ទុកបាបរបស់យើងក្នុងព្រះកាយរបស់ព្រះអង្គដែលជាប់លើឈើឆ្កាង" (១ពត្រ ២,២៤)។

## សេចក្តីស្លាប់របស់ព្រះគ្រីស្តជាយញ្ញបូជាតែមួយ និងជាស្ថាពរ

៦១៣-សេចក្តីស្លាប់របស់ព្រះគ្រីស្តជាយញ្ញបូជានៃបុណ្យចម្លងដែលសម្រេចការសង្គ្រោះរបស់មនុស្សលោកជាស្ថាពរ (១ករ ៥,៧; យហ ៨,៣៤-៣៦) ដោយសារ "កូនចៀមដែលដកបាបចេញពីមនុស្សលោក" (យហ ១,២៩) (១ពត្រ ១,១៩) ហើយជាយញ្ញបូជានៃសម្ព័ន្ធមេត្រីថ្មី (១ករ ១១,២៥) ដែលធ្វើឲ្យមនុស្សលោករួមរស់ជាមួយនឹងព្រះជាម្ចាស់ឡើងវិញ (សរ ២៤,៨) ដោយសម្រុះសម្រួលគេឲ្យជានានឹងព្រះអង្គតាម "លោហិត (...) ដែលត្រូវបង្ហូរដើម្បីលើកលែងទោសមនុស្សទាំងអស់ឲ្យរួចពីបាប" (មថ ២៦,២៨) (លវ ១៦,១៥-១៦)។

៦១៤-ព្រះគ្រីស្តបានថ្វាយយញ្ញបូជាតែមួយចុងក្រោយ និងលើសពីយញ្ញបូជាទាំងឡាយ (ហប ១០,១០)។ យញ្ញបូជានេះជាព្រះអំណោយទានដែលមកពីព្រះបិតាផ្ទាល់ព្រះអង្គ គឺព្រះបិតាប្រគល់ព្រះបុត្រារបស់ព្រះអង្គ ដើម្បីសម្រុះសម្រួលយើងឲ្យជានានឹងព្រះអង្គ (១យហ ៤,១០) ហើយជាយញ្ញបូជានៃព្រះបុត្រារបស់ព្រះជាម្ចាស់កើតជាមនុស្សដែលថ្វាយព្រះជន្មរបស់ព្រះអង្គ (យហ ១០,១៧-១៨) ចំពោះព្រះបិតា នៅក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ (ហប ៩,១៤) ដោយស្ម័គ្រចិត្ត និងដោយសេចក្តីស្រឡាញ់ (យហ ១៥,១៣) ដើម្បីឲ្យយើងចេះស្តាប់បង្គាប់ព្រះអង្គឡើងវិញ។

## ព្រះយេស៊ូស្តាប់បង្គាប់ព្រះជាម្ចាស់ជំនួសយើង

៦១៥-"មនុស្សទាំងអស់ជាប់បាបដោយសារមនុស្សតែម្នាក់ មិនបានស្តាប់បង្គាប់យ៉ាងណា ព្រះជាម្ចាស់ក៏នឹងប្រោសមនុស្សទាំងអស់ឲ្យបានសុចរិតដោយសារមនុស្សតែម្នាក់បានស្តាប់បង្គាប់យ៉ាងនោះដែរ" (រម ៥,១៩)។ ដោយស្តាប់បង្គាប់រហូតដល់សោយទិវង្គត ព្រះយេស៊ូជាអ្នកបម្រើដែលរងទុក្ខលំបាក និងដែល "បូជាជីវិតធ្វើជាយញ្ញបូជាលោះបាបសម្រាប់អ្នកដទៃ"។ "ព្រះអង្គប្រោសមហាជនឲ្យបានសុចរិតដោយទទួលយកកំហុសរបស់ពួក

គេ" (អស ៥៣,១០-១២)។ ព្រះអង្គបានលោះកំហុសរបស់យើង និងគាប់ព្រះហឫទ័យព្រះបិតាដោយប្រោសយើងឲ្យរួចពីបាប (DS ១៥២៩)។

## នៅលើឈើឆ្កាងព្រះយេស៊ូធ្វើជាយញ្ញបូជា

៦១៦-ដោយសារព្រះគ្រីស្តបាន "ស្រឡាញ់ (...) រហូតដល់ទីបំផុត" (យហ ១៣,១) ព្រះអង្គក៏អាចធ្វើជាយញ្ញបូជា ដើម្បីសង្គ្រោះ និងលោះបាបសម្រាប់មនុស្សលោកហើយ ដែលគាប់ព្រះហឫទ័យរបស់ព្រះបិតា។ ពេលព្រះអង្គបូជាព្រះជន្មទ្រង់បានស្គាល់ និងស្រឡាញ់យើងម្នាក់ៗ (កាឡ ២,២០)។ "ព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្តបានជំរុញយើងឲ្យយល់ឃើញថា បើមនុស្សម្នាក់ស្លាប់សម្រាប់មនុស្សទាំងអស់នោះ មនុស្សទាំងអស់ក៏ដូចជាបានស្លាប់ដែរ" (២ករ ៥,១៤)។ គ្មាននរណាម្នាក់ទោះជាដ៏វិសុទ្ធបំផុតក្តី អាចទទួលយកបាបរបស់មនុស្សលោកទាំងអស់ ហើយបូជាជីវិតសម្រាប់ពួកគេទាំងអស់គ្នាបានឡើយ។ ដោយសារព្រះបុត្រារបស់ព្រះជាម្ចាស់ដែលហួសមនុស្សទាំងអស់ និងបង្គ្រប់គេស្ថិតនៅក្នុងអង្គព្រះគ្រីស្ត ហើយធ្វើឲ្យព្រះអង្គទៅជាព្រះសិរសារបស់មនុស្សលោកទាំងអស់ព្រះអង្គអាចសង្គ្រោះពួកគេទាំងអស់គ្នាបាន។

៦១៧-មហាសន្និបាតនៅទីក្រុងត្រង់បង្រៀនយើងថា៖ "ដោយសារព្រះអង្គបានរងទុក្ខលំបាកយ៉ាងវិសុទ្ធនៅលើឈើឆ្កាង ទ្រង់ក៏ប្រោសយើងឲ្យបានសុចរិត" (DS ១៥២៩) គឺដោយសារយញ្ញបូជារបស់ព្រះគ្រីស្តមានតែមួយព្រះអង្គបានទៅជា "ប្រភពនៃការសង្គ្រោះដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច" (ហប ៥,៩)។ ព្រះសហគមន៍គោរពព្រះឈើឆ្កាងដោយច្រៀងថា៖ "ឱព្រះឈើឆ្កាងអើយ! ជាសេចក្តីសង្ឃឹមតែមួយរបស់យើង!"។

## យើងរួមចំណែកជាមួយព្រះគ្រីស្តដែលបូជាព្រះជន្ម

៦១៨-ព្រះគ្រីស្តដែលជា "ស្ពានមេត្រីតែមួយរវាងព្រះជាម្ចាស់ និងមនុស្សលោក" (១ធម ២,៥) បូជាព្រះជន្មតែមួយដងនៅលើឈើឆ្កាង។ ប៉ុន្តែដោយព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្សសុទ្ធសាធ "ព្រះអង្គដូចជាភ្ជាប់ព្រះអង្គជាមួយមនុស្សគ្រប់ៗរូប" (GS ២២,២) ទ្រង់ក៏ "ប្រោសឲ្យមនុស្សទាំងអស់អាចរួមជាមួយព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មី តាមរបៀបដែលព្រះជាម្ចាស់ស្គាល់" (GS ២២,៥)។ ព្រះអង្គត្រាស់ហៅសាវ័ករបស់ព្រះអង្គឲ្យ "លីឈើឆ្កាងរបស់ខ្លួនហើយមកតាម" ព្រះអង្គ (មថ ១៦,២៤) ដ្បិត "ព្រះគ្រីស្តក៏បានរងទុក្ខលំបាកសម្រាប់យើងទុកជាគំរូឲ្យយើងដើរតាមកន្លងរបស់ព្រះអង្គដែរ" (១ពត្រ ២,២១)។ ព្រះអង្គមានព្រះហឫទ័យឲ្យអ្នកទទួលការសង្គ្រោះរបស់ព្រះអង្គរួមចំណែកជាមួយព្រះអង្គដែលបូជាព្រះជន្ម ដើម្បីឲ្យរួចពីបាប (មក ១០,៣៩; យហ ២១,១៨-១៩; កូឡ ១,២៤)។ ព្រះមាតារបស់ព្រះអង្គដែលរួមជាមួយព្រះអង្គយ៉ាងស្និទ្ធស្នាលក្នុងគម្រោងការដ៏លាក់កំបាំងនៃទុក្ខលំបាករបស់ព្រះអង្គដែលសង្គ្រោះមនុស្សលោក បំពេញគម្រោងការនេះឲ្យបានគ្រប់លក្ខណៈ (លក ២,៣៥)។

ក្រៅពីឈើឆ្កាងគ្មានជណ្តើរណាដើម្បីឡើងស្ថានបរមសុខឡើយ (សន្តី រ៉ូសានៃទីក្រុងលីម៉ា)។

## សង្ខេប

៦១៩-"ព្រះគ្រីស្តបានសោយទិវង្គត ដើម្បីរំដោះបាបយើង ស្របតាមគម្ពីរ" (១ករ ១៥,៣)។

៦២០-ការសង្គ្រោះរបស់យើងហូរចេញមកពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង ដ្បិត "គឺព្រះអង្គទេតើ

ដែលបានស្រឡាញ់យើង និងបានចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យយាងមកបូជាព្រះជន្មលោះយើងឲ្យរួចពីបាប" (១យហ ៤,១០)។ "នៅក្នុងអង្គព្រះគ្រីស្ត ព្រះជាម្ចាស់បានសម្រុះសម្រួលមនុស្សលោក ឲ្យបានជានានឹងព្រះអង្គវិញ" (២ករ ៥,១៩)។

៦២១-ព្រះយេស៊ូស្ម័គ្រចិត្តបូជាព្រះជន្ម ដើម្បីសង្គ្រោះយើង។ ព្រះអង្គសម្តែង និងសម្រេចព្រះអំណោយទាននេះនៅពិធីជប់លៀងចុងក្រោយ៖ "នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា" (លក ២២,១៩)។

៦២២-ការសង្គ្រោះដែលមកពីព្រះគ្រីស្តមានដូចតទៅ៖ ព្រះអង្គ "យាងមកបូជាជីវិត ដើម្បីលោះមនុស្សទាំងអស់" (មថ ២០,២៨) ពោលគឺ "ស្រឡាញ់សាវ័ករបស់ព្រះអង្គរហូតដល់ទីបំផុត" (យហ ១៣,១) ដើម្បីឲ្យពួកគេ "រួចពីរបៀបរស់នៅដ៏ឥតន័យ ដែលជាដំណែលតពីបុព្វបុរស" (១ពត្រ ១,១៨) របស់ពួកគេ។

៦២៣-ដោយស្តាប់បង្គាប់ព្រះបិតាប្រកបដោយក្តីស្រឡាញ់ "រហូតដល់សោយទិវង្គតលើឈើឆ្កាង" (ភីល ២,៨) ព្រះយេស៊ូបំពេញបេសកកម្ម (អស ៥៣,១០) របស់អ្នកបម្រើដ៏កម្សត់ ដែល "ប្រោសមហាជនឲ្យបានសុចរិតដោយទទួលយកកំហុសរបស់ពួកគេ" (អស ៥៣,១១) (រម ៥,១៩)។

## កថាខណ្ឌទី៣៖ ព្រះសពព្រះយេស៊ូគ្រីស្តត្រូវគេបញ្ចុះក្នុងរូងថ្មមួយ

៦២៤-"ដោយសារព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ព្រះគ្រីស្តបានសោយទិវង្គតសម្រាប់មនុស្សគ្រប់ៗរូប" (ហប ២,៩)។ ក្នុងគម្រោងការសង្គ្រោះមនុស្សលោកព្រះជាម្ចាស់បានសម្រេចឲ្យព្រះបុត្រារបស់ព្រះអង្គមិនគ្រាន់តែនឹង "សោយទិវង្គតដើម្បីរំដោះបាបយើង" (១ករ ១៥,៣) ថែមទាំងនឹង "ស្គាល់ឱជារសនៃសេចក្តីស្លាប់" ដែរ គឺព្រះអង្គនឹងស្គាល់សភាពជាមនុស្សស្លាប់។ ព្រលឹង និងព្រះកាយរបស់ព្រះអង្គបំបែកគ្នានៅពេលដែលព្រះអង្គសោយទិវង្គតនៅលើឈើឆ្កាងរហូតដល់ពេលព្រះអង្គមានព្រះជន្មថ្មី គឺព្រះគ្រីស្តស្គាល់សភាពជាមនុស្សស្លាប់នេះពេលព្រះអង្គនៅក្នុងផ្នូរ និងចុះទៅស្ថានក្រោម។ ព្រះគ្រីស្តត្រូវគេបញ្ចុះនៅថ្ងៃសៅរ៍ពិសិដ្ឋ (យហ ១៩,៤២) សម្តែងថាព្រះជាម្ចាស់ឈប់សម្រាក (ហប ៤,៤-៩) ក្រោយពីបានសង្គ្រោះមនុស្សលោក (យហ ១៩,៣០) ធ្វើឲ្យសកលលោកទាំងមូលបានសន្តិភាព (កូឡ ១,១៨-២០)។

### ព្រះសពព្រះគ្រីស្តនៅក្នុងផ្នូរ

៦២៥-មុនបុណ្យចម្លងរហូតដល់ព្រះគ្រីស្តមានព្រះជន្មថ្មីពោរពេញដោយសិរីរុងរឿង ព្រះអង្គក៏គង់នៅក្នុងផ្នូរ។ ព្រះអង្គដែលមាន "ជីវិត" អាចមានព្រះបន្ទូលថា៖ "យើងបានស្លាប់ តែឥឡូវនេះយើងមានជីវិតរស់អស់កល្បជានិច្ចតរៀងទៅ" (វវ ១,១៨)៖

> ព្រះជាម្ចាស់ (ជាព្រះបុត្រា) មិនបានឃាត់សេចក្តីស្លាប់មិនឲ្យបំបែកព្រលឹងពីព្រះកាយតាមតម្រូវការនៃធម្មជាតិទេ ប៉ុន្តែព្រះអង្គបានផ្គុំព្រលឹង និងព្រះកាយដោយមានព្រះជន្មថ្មី ដើម្បីឲ្យទៅជាគំនូចរវាងសេចក្តីស្លាប់ និងជីវិតនៅក្នុងអង្គព្រះអង្គផ្ទាល់។ ព្រះអង្គបានបញ្ឈប់ភាពស្អុយរលួយនៃព្រះសពព្រះអង្គដែលមកពីសេចក្តីស្លាប់ ដោយបានប្រមូលផ្តុំផ្នែកទាំងពីរដែលត្រូវបានគេបំបែក (សន្តៈ គ្រេគ័រនៃនីស)។

៦២៦-ដោយសារ "ម្ចាស់នៃជីវិត" (កក ៣,១៥) ដែលយើងបានសម្លាប់ និង "ព្រះអង្គដែលមានព្រះជន្មរស់ហើយដែលព្រះជាម្ចាស់បានប្រោស (...) ឲ្យមានព្រះជន្មថ្មី" ជាអង្គតែមួយព្រះបុត្រារបស់ព្រះជាម្ចាស់បានបន្តទទួលយកព្រលឹង និងព្រះកាយរបស់ព្រះអង្គដែលសេចក្តីស្លាប់បានបំបែក៖

ដោយសារព្រះគ្រីស្តបានសោយទិវង្គតព្រលឹងបានបែកចេញពីព្រះកាយព្រះអង្គ ប៉ុន្តែទ្រង់ដែលជាអង្គតែមួយមិនបានបំបែកជាពីរអង្គទេ ដ្បិតព្រលឹង និងព្រះកាយព្រះគ្រីស្តគង់នៅតាំងពីដើមនៅក្នុងអង្គព្រះបន្ទូល ហើយពេលព្រះអង្គបានសោយទិវង្គតទោះបីព្រលឹង និងព្រះកាយបានបំបែកពីគ្នាយ៉ាងណាក៏ដោយ ក៏ព្រលឹង និងព្រះកាយនោះនៅតែជាមួយព្រះបន្ទូលតែមួយព្រះអង្គ (សន្តៈ យ៉ូហានដាម៉ាសែន)។

### "ព្រះជាម្ចាស់ក៏មិនបណ្តោយឲ្យសពអ្នកបម្រើរបស់ព្រះអង្គត្រូវរលួយដែរ"

៦២៧-សេចក្តីស្លាប់របស់ព្រះគ្រីស្តពិតជាសេចក្តីស្លាប់មែន ដ្បិតព្រះអង្គបានបញ្ចប់ការរស់នៅលើផែនដីនេះ។ ប៉ុន្តែដោយសារព្រះកាយព្រះបុត្រានៅតែរួមជាមួយព្រះអង្គ ព្រះសពព្រះអង្គមិនបានទៅដូចសពឯទៀតៗ ដ្បិត "ព្រះជាម្ចាស់សព្វព្រះហឫទ័យរក្សាការពារព្រះសពព្រះគ្រីស្តកុំឲ្យរលួយ" (សន្តៈ ថូម៉ាសនៃអាកាំង)។ យើងអាចថ្លែងអំពីព្រះគ្រីស្តថា៖ "គេបានដកលោកចេញពីចំណោមមនុស្សដែលរស់នៅលើផែនដីនេះ" (អស ៥៣,៨) ហើយនៅពេលជាមួយគ្នានេះថា៖ "រូបកាយរបស់ទូលបង្គំក៏នឹងសម្រាកដោយសេចក្តីសង្ឃឹម (...) ដ្បិតព្រះអង្គនឹងមិនបោះបង់ព្រលឹងទូលបង្គំចោលនៅក្នុងស្ថានមនុស្សស្លាប់ឡើយ ហើយព្រះអង្គក៏មិនបណ្តោយឲ្យសពអ្នកបម្រើរបស់ព្រះអង្គរលួយដែរ" (កក ២,២៦-២៧) (ទន ១៦,៩-១០)។ ការមានព្រះជន្មរស់ឡើងវិញ "នៅថ្ងៃទីបី" (១ករ ១៥,៤; លក ២៤,៤៦) (មថ ១២,៤០; យណ ២,១; ហស ៦,២) បង្ហាញភស្តុតាងថាព្រះសពព្រះអង្គមិនបានរលួយទេ ដ្បិតតាមធម្មតាសពចាប់ផ្តើមរលួយចាប់ពីថ្ងៃទីបួនទៅ (យហ ១១,៣៩)។

### "យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះគ្រីស្តដែរ"

៦២៨-ពេលគ្រីស្តបរិស័ទទទួលពិធីជ្រមុជក្នុងទឹក គេចុះក្នុងផ្នូររួមស្លាប់នឹងអំពើបាបរួមរស់ជាមួយព្រះគ្រីស្តដើម្បីបានជីវិតថ្មី៖ "ដោយពិធីជ្រមុជទឹកដើម្បីរួមស្លាប់ជាមួយព្រះគ្រីស្ត យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ។ ដូច្នេះព្រះគ្រីស្តមានព្រះជន្មថ្មីដោយសារសិរីរុងរឿងរបស់ព្រះបិតាយ៉ាងណា យើងក៏រស់តាមរបៀបថ្មីយ៉ាងនោះដែរ" (រម ៦,៤)។

## សង្ខេប

៦២៩-ព្រះយេស៊ូបានសោយទិវង្គតដើម្បីមនុស្សគ្រប់រូប (ហប ២,៩)។ គឺពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស ដែលបានសោយទិវង្គត និងបានត្រូវគេបញ្ចុះ។

៦៣០-នៅក្នុងផ្នូរ ព្រះគ្រីស្តនៅតែទទួលយកព្រលឹង និងព្រះកាយព្រះអង្គជានិច្ច ទោះជាសេចក្តីស្លាប់បានបំបែកព្រលឹង និងព្រះកាយនេះចេញពីគ្នាក៏ដោយ។ ហេតុនេះហើយបានជាព្រះសពព្រះគ្រីស្តដែលសោយទិវង្គត "ពុំបានរលួយទេ" (កក ១៣,៣៧)។

# ប្រការទី៥៖

## "ព្រះយេស៊ូគ្រីស្តបានយាងចុះទៅស្ថានក្រោម លុះដល់ថ្ងៃទីបីព្រះអង្គមានព្រះជន្មថ្មី"

៦៣១-"ព្រះយេស៊ូបានយាងចុះមកផែនដីដ៏ទាបនេះជាមុនសិន។ ព្រះអង្គដែលបានយាងចុះមកនោះជាព្រះអង្គដែលបានយាងឡើងទៅទីដ៏ខ្ពស់បំផុតនៃស្ថានបរមសុខ" (អភ ៤,៩-១០)។ ធម៌ប្រកាសជំនឿនៃក្រុមគ្រីស្តទូតប្រកាសក្នុងប្រការតែមួយថា ព្រះគ្រីស្តបានយាងចុះទៅស្ថានក្រោម ហើយមានព្រះជន្មថ្មីនៅថ្ងៃទីបី ដ្បិតក្នុងបុណ្យចម្លងទ្រង់ក៏ធ្វើឲ្យជីវិតផុសចេញពីសេចក្តីស្លាប់។

ព្រះគ្រីស្តជាព្រះបុត្រារបស់ព្រះអង្គ ព្រះអង្គឡើងពីស្ថានក្រោមវិញ ទ្រង់បានចាក់បង្ហូរពន្លឺដ៏សុខសាន្តរបស់ព្រះអង្គលើមនុស្សទាំងឡាយ ហើយទ្រង់មានព្រះជន្មរស់ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន (MR)។

## កថាខណ្ឌទី១៖ ព្រះគ្រីស្តយាងចុះទៅស្ថានក្រោម

៦៣២-ជារឿយៗ តាមគម្ពីរសម្ពន្ធមេត្រីថ្មីព្រះយេស៊ូ "មានព្រះជន្មថ្មី" (កក ៣,១៥; រម ៨,១១; ១ករ ១៥,២០) បានសេចក្តីថាមុនព្រះអង្គមានព្រះជន្មថ្មី ទ្រង់ក៏បានស្នាក់នៅស្ថានមនុស្សស្លាប់ (ហប ១៣,២០)។ ក្រុមគ្រីស្តទូតបានផ្តល់អត្ថន័យដំបូងអំពី "ព្រះយេស៊ូយាងចុះទៅស្ថានក្រោម" គឺព្រះយេស៊ូបានសោយទិវង្គតដូចមនុស្សទាំងអស់ ហើយព្រលឹងព្រះអង្គបានចុះទៅជាមួយគេនៅស្ថានមនុស្សស្លាប់។ ប៉ុន្តែព្រះអង្គយាងចុះក្នុងឋានៈជាព្រះសង្គ្រោះដោយប្រកាសដំណឹងល្អដល់វិញ្ញាណក្ខ័ន្ធដែលជាប់ឃុំឃាំង (១ពត្រ ៣,១៨-១៩)។

៦៣៣-ព្រះគម្ពីរហៅស្ថានមនុស្សស្លាប់ដែលព្រះគ្រីស្តបានយាងចុះក្នុងឋានៈជាមនុស្សស្លាប់ថា ស្ថានមច្ចុរាជនរក ឬស្ថានក្រោម (ភីល ២,១០; កក ២,២៤; វវ ១,១៨; អភ ៤,៩) ដ្បិតអស់អ្នកដែលនៅទីនោះ គឺមនុស្សស្លាប់ទាំងអស់ ទាំងទុច្ចរិត ទាំងសុចរិត (ទន ៨៩,៤៩; ១សម ២៨,១៩; អគ ៣២,១៧-៣២) មិនអាចមើលឃើញព្រះជាម្ចាស់បានឡើយ (ទន ៦,៦; ៨៨,១១-១៣) រហូតដល់ព្រះសង្គ្រោះយាងមក។ ប៉ុន្តែមនុស្សទុច្ចរិត និងមនុស្សសុចរិតនោះមានវាសនាផ្សេងពីគ្នា ដូចព្រះយេស៊ូសម្តែងក្នុងពាក្យប្រស្នាអំពីលោកឡាសារដែល "នៅក្បែរលោកអប្រាហាំ" (លក ១៦,២២-២៦) គឺ "ពេលព្រះយេស៊ូគ្រីស្តបានយាងចុះទៅស្ថានក្រោម ព្រះអង្គក៏រំដោះព្រលឹងដ៏វិសុទ្ធនោះដែលកំពុងរង់ចាំព្រះសង្គ្រោះរបស់គេនៅក្បែរលោកអប្រាហាំ" (CR)។ ព្រះយេស៊ូមិនមែនយាងចុះទៅស្ថានក្រោមដើម្បីរំដោះមនុស្សធ្លាក់នរក ឬដើម្បីបំផ្លាញស្ថាននរកឡើយ (DS ១០១១; ១០៧៧) តែដើម្បីរំដោះមនុស្សសុចរិតដែលបានស្លាប់មុនព្រះអង្គ (DS ៤៨៥; មថ ២៧,៥២-៥៣)។

៦៣៤-"សូម្បីតែមនុស្សស្លាប់ក៏ព្រះអង្គបាននាំដំណឹងល្អទៅឲ្យគេឮដែរ" (១ពត្រ ៤,៦)។ ពេលព្រះយេស៊ូយាងចុះទៅស្ថានមច្ចុរាជ ព្រះអង្គបំពេញការប្រកាសដំណឹងល្អឲ្យបានគ្រប់លក្ខណៈ ហើយទ្រង់បង្ហើយដំណាក់កាលចុងក្រោយបំផុតនៃបេសកកម្មរបស់ព្រះអង្គជាព្រះសង្គ្រោះ។ ដោយសារដំណាក់កាលដ៏ខ្លីនេះ ព្រះអង្គសង្គ្រោះមនុស្សលោកទាំងអស់គ្រប់សម័យ គ្រប់កន្លែង ដ្បិតអស់អ្នកដែលព្រះអង្គបានសង្គ្រោះ ទ្រង់ក៏ប្រោសគេឲ្យរួមចំណែកក្នុងការសង្គ្រោះដែរ។

៦៣៥-ហេតុនេះហើយបានជាព្រះគ្រីស្តបានយាងចុះក្នុងទីជម្រៅនៃសេចក្តីស្លាប់ (មថ ១២,៤០; រម ១០,៧; អភ ៤,៩) ដើម្បីឲ្យ "មនុស្សស្លាប់អាចឮព្រះសូរសៀងព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយអស់អ្នកដែលឮព្រះសូរសៀង

នោះនឹងមានជីវិតរស់នៅ" (យហ ៥,២៥)។ ព្រះយេស៊ូជា "ម្ចាស់នៃជីវិត" (កក ៣,១៥) "ព្រះអង្គសោយទិវង្គត ដើម្បីកម្ទេចមារដែលមានអំណាចលើសេចក្ដីស្លាប់ និងដើម្បីរំដោះអស់អ្នកដែលជាប់ជាទាសករមួយជីវិត ព្រោះតែខ្លាចស្លាប់" (ហប ២,១៤-១៥)។ ឥឡូវនេះព្រះគ្រីស្ដដែលមានព្រះជន្មថ្មី "មានអំណាច (...) លើស្ថានមច្ចុរាជ" (វវ ១,១៨) ហើយ "នៅពេលឮព្រះនាមព្រះយេស៊ូ" "អ្វីៗទាំងអស់ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ទាំងនៅស្ថានក្រោមនាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ" (ភីល ២,១០)។

នៅថ្ងៃនេះ នៅលើផែនដី មានសភាពស្ងាត់ស្ងៀមណាស់ ជាសភាពដ៏ធំមហិមា និងសភាពឯកោយ៉ាងធំធេង។ មានសភាពស្ងាត់ស្ងៀមយ៉ាងខ្លាំង ដ្បិតព្រះមហាក្សត្រផ្ទុំលក់។ ផែនដីបានរញ្ជួយ ហើយបានស្ងប់ទៅវិញ ពីព្រោះព្រះជាម្ចាស់ ទ្រង់បានផ្ទុំលក់ក្នុងសាច់ ហើយព្រះអង្គបានយាងទៅដាស់អស់អ្នកដែលសម្រាន្តលង់លក់ តាំងពីយូរយារណាស់មកហើយ (...)។ ព្រះអង្គយាងទៅរកលោក អដាំ ជាបិតាដំបូងរបស់យើង ជាចៀមដែលវង្វេង។ ព្រះអង្គចង់យាងទៅសួរសុខទុក្ខអស់អ្នកដែលស្ថិតក្នុងភាពងងឹត ក្រោមម្លប់នៃសេចក្ដីស្លាប់។ ព្រះអង្គយាងទៅរំដោះលោក អដាំ និងនាង អេវ៉ា ដែលជាប់ជាឈ្លើយជាមួយលោក ឲ្យរួចផុតពីការឈឺចាប់ ក្នុងទីឃុំឃាំង។ ព្រះអង្គដែលជាព្រះជាម្ចាស់របស់គេផង ព្រះបុត្រារបស់គេផង (...)។ "យើងជាព្រះជាម្ចាស់របស់អ្នក ដោយសារអ្នក យើងបានក្លាយទៅជាបុត្ររបស់អ្នក។ សូមអ្នកក្រោកឡើង អ្នកបានសម្រាន្តលក់យូរណាស់មកហើយ ពីព្រោះយើងមិនបានបង្កើតអ្នកមក ឲ្យអ្នកជាប់ច្រវាក់នៅស្ថាននរកនេះទេ។ ចូរក្រោកឡើងពីចំណោមមនុស្សស្លាប់ទៅ យើងជាព្រះជន្មរបស់អ្នកស្លាប់"។

## សង្ខេប

៦៣៦-ធម៌ជឿប្រកាសថា "ព្រះយេស៊ូយាងចុះទៅស្ថានក្រោម" មានន័យថា ព្រះយេស៊ូពិតជាបានសោយទិវង្គតមែន ហើយដោយសារព្រះអង្គបានសោយទិវង្គតដើម្បីយើង ព្រះអង្គក៏បានឈ្នះសេចក្ដីស្លាប់ និងមារដែល "មានអំណាចនៃសេចក្ដីស្លាប់" (ហប ២,១៤)។

៦៣៧-ពេលព្រះគ្រីស្ដសោយទិវង្គត ព្រលឹងព្រះអង្គនៅរួបរួមជាមួយព្រះអង្គក្នុងឋានៈជាព្រះជាម្ចាស់ បានយាងចុះទៅដល់ស្ថានមនុស្សស្លាប់។ព្រះអង្គបានបើកទ្វារនៃស្ថានបរមសុខឲ្យអស់មនុស្សសុចរិតដែលបានចុះមុនព្រះអង្គ។

## កថាខណ្ឌទី២៖ លុះដល់ថ្ងៃទីបីព្រះអង្គមានព្រះជន្មថ្មី

៦៣៨-"យើងខ្ញុំសូមជូនដំណឹងល្អនេះប្រាប់បងប្អូនថា ព្រះបន្ទូលដែលព្រះជាម្ចាស់បានសន្យាជាមួយបុព្វបុរសរបស់យើង ព្រះអង្គបានធ្វើតាមដើម្បីជាប្រយោជន៍ដល់យើងដែលជាពូជពង្សរបស់លោកទាំងនោះ ហើយគឺព្រះអង្គបានប្រោសព្រះយេស៊ូឲ្យមានព្រះជន្មថ្មី" (កក ១៣,៣២-៣៣)។ ព្រះជន្មថ្មីរបស់ព្រះយេស៊ូជាសេចក្ដីពិតដ៏ខ្ពង់ខ្ពស់បំផុតនៃជំនឿយើងនៅក្នុងអង្គព្រះគ្រីស្ដ ដែលសហគមន៍គ្រីស្ដបរិស័ទដើមបានជឿ និងបានប្រតិបត្តិតាមដែលការបញ្ជូនបន្តបានបញ្ជូនដែលក៏ណ្ដដំណឹងល្អបានបញ្ជាក់ហើយ ដែលព្រះសហគមន៍បានប្រកាសជាផ្នែកដ៏សំខាន់បំផុតរបស់គម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង និងព្រះឈើឆ្កាងផងដែរ។

ព្រះគ្រីស្ដមានព្រះជន្មថ្មីដោយសារព្រះអង្គបានសោយទិវង្គត ទ្រង់ក៏បានឈ្នះសេចក្ដីស្លាប់ ហើយបានប្រទានជីវិតដល់មនុស្សស្លាប់ផងដែរ។

## ១-ព្រះជន្មថ្មីជាហេតុការណ៍នៃប្រវត្តិសាស្ត្រផង និងហួសប្រវត្តិសាស្ត្រផង

៦៣៩-គម្រោងការដ៏អស្ចារ្យនៃព្រះជន្មថ្មី ជាហេតុការណ៍ដ៏ពិតប្រាកដដែលកើតឡើងនៅក្នុងប្រវត្តិសាស្ត្រមនុស្សលោក ដូចមានចែងទុកនៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី។ នៅឆ្នាំ៥៦ សន្តៈ ប៉ូល សរសេរទៅជនកូរិនថូសថា៖ "ខ្ញុំជម្រាបបងប្អូននូវសេចក្តីដែលខ្ញុំបានទទួល គឺថាព្រះគ្រីស្តបានសោយទិវង្គតដើម្បីរំដោះបាបយើងស្របតាមគម្ពីរ។ គេបានបញ្ចុះសពព្រះអង្គនៅក្នុងផ្នូរ ហើយព្រះអង្គមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបីស្របតាមគម្ពីរ។ ព្រះអង្គបានបង្ហាញខ្លួនឲ្យលោកកេផាសឃើញ រួចឲ្យក្រុមគ្រីស្តទូតដប់ពីររូបឃើញដែរ" (១ករ ១៥,៣-៤)។ គ្រីស្តទូតប៉ូលនិយាយអំពីការបញ្ជូនបន្តដ៏រស់រវើកនៃជីវិតថ្មី ដែលលោកបានទទួលក្រោយពីបានកែប្រែចិត្តគំនិតនៅទីក្រុងដាម៉ាស (កក ៩,៣-១៨)។

### ផ្នូរទទេ

៦៤០-"ហេតុអ្វីបានជានាងនាំគ្នាមករកព្រះអង្គដែលមានព្រះជន្មរស់ក្នុងចំណោមមនុស្សស្លាប់ដូច្នេះ? ទ្រង់មិនគង់នៅទីនេះទេ ព្រះជាម្ចាស់បានប្រោសព្រះអង្គឲ្យមានព្រះជន្មថ្មីហើយ" (លក ២៤,៥-៦)។ ក្នុងចំណោមហេតុការណ៍ទាំងឡាយនៃបុណ្យចម្លង ផ្នូរទទេជាទីសម្គាល់ដំបូង។ ផ្នូរទទេនេះមិនបង្ហាញភស្តុតាងថាព្រះគ្រីស្តមានព្រះជន្មថ្មីទេ ដ្បិតយើងអាចពន្យល់ថាព្រះសពព្រះអង្គមិននៅក្នុងផ្នូរដោយសារមូលហេតុផ្សេងៗ (យហ ២០,១៣; មថ ១៨,១១-១៥) ក៏ប៉ុន្តែផ្នូរទទេនោះជាសញ្ញាសម្គាល់ដ៏សំខាន់បំផុតសម្រាប់យើងទាំងអស់គ្នា។ ពេលក្រុមសាវ័កបានឃើញផ្នូរទទេដូចជាស្ត្រីបរិសុទ្ធ (លក ២៤,៣.២២-២៣)និងលោក សិលា (លក ២៤,១២) ពួកគេចាប់ផ្តើមទទួលស្គាល់ថាព្រះគ្រីស្តមានព្រះជន្មថ្មី។ "សាវ័កដែលព្រះយេស៊ូស្រឡាញ់" (យហ ២០,២) អះអាងថា នៅពេលចូលក្នុងផ្នូរទទេ និងឃើញ "សំពត់ស្នបនៅទីនោះ" (យហ ២០,៦) លោក "ឃើញហើយជឿ" (យហ ២០,៨) បានសេចក្តីថាលោកបានយល់ឃើញថា អវត្តមានរបស់ព្រះសពព្រះយេស៊ូមិនមែនមកពីកិច្ចការណាមួយរបស់មនុស្សទេ ហើយព្រះអង្គក៏មិនគ្រាន់តែរស់ឡើងវិញដូចលោកឡាសារឡើយ (យហ ១១,៤៤)។

### ព្រះយេស៊ូដែលមានព្រះជន្មថ្មីបង្ហាញខ្លួនឲ្យគេឃើញ

៦៤១-ក្រោយពីគេបានបញ្ចុះព្រះសពព្រះយេស៊ូ (មក ១៦,១; លក ២៤,១) យ៉ាងរហ័សនៅថ្ងៃសុក្រពិសិដ្ឋមុនថ្ងៃសប្ប័ទ (យហ ១៩,៣១.៤២) នាងម៉ារីជាអ្នកស្រុកម៉ាដាឡា និងស្ត្រីបរិសុទ្ធដែលទើបទិញគ្រឿងក្រអូបយកទៅអប់ព្រះសពព្រះអង្គ ពួកនាងបានជួបព្រះយេស៊ូដែលមានព្រះជន្មថ្មីមុនគេបង្អស់ (មថ ២៨,៩-១០; យហ ២០,១១-១៨)។ ហេតុនេះហើយបានជាស្ត្រីៗជាអ្នកនាំសារដើមដំបូងអំពីព្រះគ្រីស្តដែលមានព្រះជន្មថ្មីសម្រាប់ក្រុមគ្រីស្តទូតផ្ទាល់ (លក ២៤,៩-១០)។ ក្រោយមកព្រះយេស៊ូបង្ហាញខ្លួនឲ្យលោក សិលា និងគ្រីស្តទូតដប់ពីររូបឃើញ (១ករ ១៥,៥)។ លោក សិលា ដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យពង្រឹងជំនឿរបស់បងប្អូន លោក (លក ២២,៣១-៣២) ឃើញព្រះគ្រីស្តមានព្រះជន្មថ្មី មុនគេដោយសារលោកផ្តល់សក្ខីភាពសហគមន៍ពោលថា៖ "ព្រះអម្ចាស់មានព្រះជន្មថ្មីពិតប្រាកដមែន ហើយទ្រង់បានបង្ហាញខ្លួនឲ្យស៊ីម៉ូនឃើញ!" (លក ២៤,៣៤)។

៦៤២-អ្វីៗដែលបានកើតឡើងនៅថ្ងៃនីមួយៗនៃបុណ្យចម្លងនាំឲ្យគ្រីស្តទូតម្នាក់ៗ ជាពិសេសលោក សិលា ឲ្យកសាងសម័យកាលថ្មីដែលបានចាប់ផ្តើមនៅព្រឹកបុណ្យចម្លង។ ដោយសារគេជាបន្ទាល់បញ្ជាក់ថាព្រះគ្រីស្តមានព្រះជន្មថ្មីមែន គេទៅជាថ្មដាដែលជាគ្រឹះនៃព្រះសហគមន៍ព្រះអង្គ។ ជំនឿរបស់សហគមន៍អ្នកជឿដើមដំបូងបានចាក់ឫសលើសក្ខីភាពរបស់មនុស្សដែលគ្រីស្តបរិស័ទស្គាល់ ហើយដែលភាគច្រើននៅតែរស់ក្នុងចំណោមពួកគេ។

ក្នុងចំណោម "បន្ទាល់នៃព្រះគ្រីស្តដែលមានព្រះជន្មថ្មី" (កក ១,២២) មានលោក សិលា និងគ្រីស្តទូតដប់ពីររូបថែម ទាំងតាមលោក ប៉ូល បងប្អូនជាងប្រាំរយនាក់ក្នុងពេលជាមួយគ្នា លោក យ៉ាកុប និងគ្រីស្តទូតទាំងអស់ផងដែរ (១ករ ១៥,៤-៨)។

៦៤៣-នៅពីមុខសក្ខីភាពទាំងនោះ យើងមិនអាចបកស្រាយអំពីព្រះជន្មថ្មីរបស់ព្រះគ្រីស្ត ក្រៅពីបែបផែនអង្គធាតុបានទេ ហើយក៏មិនរាប់បញ្ចូលថា ជាហេតុការណ៍ប្រវត្តិសាស្ត្របានដែរ។ តាមហេតុការណ៍នានា ក្រុមសាវ័កបានរវាតនឹងជំនឿ ដោយសារលោកគ្រូរបស់គេបានរងទុក្ខលំបាក និងសោយទិវង្គតនៅលើឈើឆ្កាង ដែលព្រះអង្គបានប្រកាសទុកជាមុន (លក ២២,៣១-៣២)។ ដោយសារគេបានរំជើបរំជួលយ៉ាងខ្លាំង ពួកសាវ័ក (យ៉ាងហោចណាក៏មានខ្លះដែរ) មិនបានជឿថា ព្រះយេស៊ូបានមានជីវិតថ្មីភ្លាមៗទេ។ ដំណឹងល្អមិនបានប្រកាសឲ្យយើងដឹងថា សហគមន៍សាវ័កសប្បាយរីករាយទេ ប៉ុន្តែពណ៌នាថា ពួកសាវ័កអស់សង្ឃឹម ("ទឹកមុខស្រងូត"៖ លក ២៤,១៧) និងភិតភ័យ (យហ ២០,១៩) ទៅវិញ។ ដូច្នេះហើយ គេមិនបានជឿស្ត្រីៗដ៏វិសុទ្ធ ដែលត្រឡប់មកពីផ្នូរវិញ ហើយសម្ដីនាងទាំងអស់នោះ ដូចជា "រឿងផ្ដេសផ្ដាស" (លក ២៤,១១)។ ពេលព្រះយេស៊ូបង្ហាញព្រះអង្គឲ្យគ្រីស្តទូតដប់មួយរូបបានឃើញ នៅល្ងាចបុណ្យចម្លង "ព្រះអង្គបន្ទោសគេ ព្រោះគេគ្មានជំនឿ ហើយមានចិត្តរឹងរូសពុំព្រមជឿអស់អ្នកដែលបានឃើញព្រះអង្គដែលមានព្រះជន្មថ្មី" (មក ១៦,១៤)។

៦៤៤-ទោះជាស្ថិតនៅចំពោះព្រះយេស៊ូដែលមានព្រះជន្មថ្មីក៏ដោយ ក៏ពួកសាវ័កនៅតែមន្ទិលសង្ស័យថា ហេតុការណ៍នេះមិនបានកើតឡើងទេ ពួកគេជឿថា ឃើញខ្មោចមួយ (លក ២៤,៣៩)។ "សាវ័កពុំទាន់ជឿនៅឡើយទេ ព្រោះគេអរផង ហើយងឿងឆ្ងល់ផង" (លក ២៤,៤១)។ លោកថូម៉ាសនឹងកើតមន្ទិលសង្ស័យដែរ (យហ ២០,២៤-២៧) ហើយតាមលោក ម៉ាថាយ ពេលព្រះយេស៊ូបង្ហាញព្រះអង្គជាលើកចុងក្រោយនៅស្រុកកាលីឡេ "មានអ្នកខ្លះនៅសង្ស័យ" (មថ ២៨,១៧)។ ដូច្នេះហើយ ការអះអាងថា ព្រះជន្មថ្មីជា "លទ្ធផល" នៃជំនឿ (ឬការជឿជាក់) របស់ក្រុមគ្រីស្តទូតគ្មានហេតុផលទេ។ ផ្ទុយទៅវិញ អស់លោកបានជឿថាព្រះយេស៊ូមានព្រះជន្មថ្មីមែន មកពីពួកលោកបានជួបនឹងព្រះយេស៊ូដែលមានព្រះជន្មថ្មី ដោយមានព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់មកជួយដែរ។

### ជាតិជាមនុស្សរបស់ព្រះយេស៊ូដែលមានព្រះជន្មថ្មី

៦៤៥-ព្រះយេស៊ូដែលមានព្រះជន្មថ្មីមានទំនាក់ទំនងផ្ទាល់ជាមួយក្រុមសាវ័ក គឺគេអាច "ស្ទាប" (លក ២៤,៣៩) និង "រួមតុ" (លក ២៤,៣០) ជាមួយព្រះអង្គបាន។ ព្រះអង្គអញ្ជើញគេឲ្យទទួលស្គាល់ថា ព្រះអង្គមិនមែនជាខ្មោចទេ (លក ២៤,៣៩) ហើយឲ្យគេយល់ឃើញថាព្រះកាយព្រះអង្គដែលមានព្រះជន្មរស់ឡើងវិញ ជាព្រះកាយដដែល ដែលបានរងទុក្ខលំបាក និងត្រូវគេឆ្កាង ដ្បិតព្រះកាយនេះមានស្នាមរបួស (លក ២០,៤០; យហ ២០,២០.២៧)។ ព្រះកាយនេះដ៏ពិតប្រាកដ ដែលមានលក្ខណៈថ្មីផងដែរ គឺលក្ខណៈនៃព្រះកាយពោរពេញដោយសិរីរុងរឿង។ ព្រះអង្គអាចទៅទីណា និងនៅពេលណាក៏បាន គ្មានព្រំដែនក្នុងទីអាកាស ឬក្នុងពេលវេលាឡើយ (មថ ២៨,៩.១៦-១៧) ដ្បិតជាតិជាមនុស្សរបស់ព្រះអង្គមិនស្ថិតនៅលើផែនដីនេះទៀតទេ តែស្ថិតនៅឯព្រះបិតា (យហ ២០,១៧)។ ហេតុនេះហើយបានជាព្រះយេស៊ូដែលមានព្រះជន្មថ្មីស្ម័គ្រចិត្តបង្ហាញខ្លួនតាមរបៀបណាក៏បាន គឺដូចជាអ្នកថែរក្សាសួនច្បារ (យហ ២០,១៤-១៥) ឬ "តាមទ្រង់ទ្រាយផ្សេងទៀត" (មក ១៦,១២) ដែលសាវ័កធ្លាប់ស្គាល់ដើម្បីតាមមើលជំនឿរបស់គេ (យហ ២០,១៤.១៦; ២១,៤.៧)។

៦៤៦-ព្រះគ្រីស្តដែលមានព្រះជន្មថ្មីមិនត្រឡប់មករស់នៅលើផែនដីនេះដូចកាលពីមុនទេ ដូចពេលព្រះអង្គបាន

ប្រោសកូនស្រីរបស់លោក យ៉ៃរ៉ូស កំលោះម្នាក់នៅភូមិណាអ៊ីន និងលោក ឡាសារ ឲ្យមានជីវិតរស់ឡើងវិញមុនបុណ្យចម្លង។ ព្រះអង្គបានប្រព្រឹត្តការអស្ចារ្យ គឺដោយសារអំណាចរបស់ព្រះអង្គ មនុស្សទាំងអស់នោះមានជីវិតនៅលើផែនដីនេះដូច "ធម្មតា" ប៉ុន្តែពួកគេនឹងត្រូវស្លាប់ម្ដងទៀត។ ព្រះគ្រីស្តមានព្រះជន្មថ្មីខុសប្លែកពីគេ គឺក្នុងព្រះកាយព្រះអង្គដែលមានព្រះជន្មថ្មី ទ្រង់ក៏ឆ្លងពីសេចក្ដីស្លាប់ទៅជីវិតហួសពីអាកាស និងពេលវេលា។ ព្រះកាយព្រះគ្រីស្តដែលមានព្រះជន្មថ្មីពោរពេញដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះអង្គរួមជាមួយព្រះជាម្ចាស់ក្នុងសិរីរុងរឿងរបស់ព្រះអង្គ។ ហេតុនេះសន្តៈ ប៉ូល អាចមានប្រសាសន៍អំពីព្រះគ្រីស្តថា ព្រះអង្គ "គង់នៅស្ថានបរមសុខ" (១ករ ១៥,៣៥-៥០)។

### ការមានព្រះជន្មថ្មីជាហេតុការណ៍ហួស និងលើសអ្វីៗទាំងអស់

៦៤៧-"ឱយប់នៃបុណ្យចម្លង! ចូរច្រៀងកោតសរសើរ! មានតែឯងទេតើដែលស្គាល់ពេលព្រះគ្រីស្តបានចេញពីចំណោមមនុស្សស្លាប់"។ គ្មាននរណាម្នាក់បានឃើញផ្ទាល់នឹងភ្នែក ពេលព្រះគ្រីស្តមានជីវិតថ្មី ហើយគ្មានអ្នកនិពន្ធដំណឹងល្អរៀបរាប់ហេតុការណ៍នេះឡើយ។ គ្មាននរណាម្នាក់អាចនិយាយប្រាប់ថា តើព្រះគ្រីស្តបានរស់ឡើងវិញយ៉ាងដូចម្ដេច ឬតើព្រះអង្គបានឆ្លងទៅជីវិតថ្មីយ៉ាងដូចម្ដេចបានឡើយ។ ទោះបីការរស់ឡើងវិញ ជាហេតុការណ៍នៃប្រវត្តិសាស្ត្រ ដែលយើងអាចយល់ឃើញដោយសារផ្នូរទទេ និងដោយសារក្រុមគ្រីស្តទូតបានជួបព្រះអង្គយ៉ាងណាក៏ដោយ ក៏ព្រះជន្មថ្មីជាហេតុការណ៍ហួស និងលើសប្រវត្តិសាស្ត្រដែលជាគ្រឹះដ៏សំខាន់ៗនៃជំនឿ។ ហេតុនេះហើយបានជាព្រះគ្រីស្តដែលមានព្រះជន្មថ្មី មិនបង្ហាញខ្លួនឲ្យមនុស្សលោកឃើញ (យហ ១៤,២២) គ្រាន់តែឲ្យសាវ័ករបស់ព្រះអង្គ គឺ "អស់អ្នកដែលបានរួមដំណើរជាមួយព្រះអង្គពីស្រុកកាលីឡេទៅក្រុងយេរូសាឡឹម ឃើញអស់រយៈពេលជាច្រើនថ្ងៃ។ ឥឡូវនេះអ្នកទាំងនោះធ្វើជាបន្ទាល់របស់ព្រះអង្គ នៅចំពោះមុខប្រជាជនទៀតផង" (កក ១៣,៣១)។

### ២-ព្រះជន្មថ្មីជាស្នាព្រះហស្តនៃព្រះត្រៃឯក

៦៤៨-ដោយសារព្រះជាម្ចាស់ផ្ទាល់បានធ្វើអន្តរាគមន៍ក្នុងការបង្កើត និងក្នុងប្រវត្តិសាស្ត្រមនុស្សលោកត្រូវតែជឿថាព្រះគ្រីស្តមានព្រះជន្មថ្មី។ ក្នុងព្រះគ្រីស្តដែលមានព្រះជន្មថ្មី ព្រះទាំងបីអង្គប្រត្តិបត្តិតាមរួមជាមួយគ្នា និងសម្ដែងលក្ខណៈពិសេសរៀងៗខ្លួន។ ឫទ្ធានុភាពរបស់ព្រះបិតា "បានប្រោសឲ្យព្រះគ្រីស្ត (ជាព្រះបុត្រាព្រះអង្គ) ឲ្យមានជីវិតថ្មី" (កក ២,២៤) ទើបបានបញ្ចូលជាតិជាមនុស្ស ព្រមទាំងព្រះកាយព្រះអង្គក្នុងព្រះត្រៃឯក។ ព្រះជាម្ចាស់បានតែងតាំងព្រះយេស៊ូ "ជាព្រះបុត្រាប្រកបដោយឫទ្ធានុភាព (ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ) ដោយប្រោសព្រះអង្គឲ្យមានព្រះជន្មថ្មី" (រម ១,៣-៤)។ តាមសន្តៈ ប៉ូល ព្រះជាម្ចាស់សម្ដែងឫទ្ធានុភាពរបស់ព្រះអង្គ (រម ៦,៤; ២ករ ១៣,៤; ភីល ៣,១០; អភ ១,១៩-២២; ហប ៧,១៦) ដោយសារកិច្ចការរបស់ព្រះវិញ្ញាណ ដែលបានប្រោសជាតិជាមនុស្សរបស់ព្រះយេស៊ូឲ្យរស់ និងឲ្យបានទទួលសិរីរុងរឿងរបស់ព្រះអម្ចាស់។

៦៤៩-រីឯចំពោះព្រះបុត្រាវិញ ព្រះអង្គប្រោសខ្លួនព្រះអង្គឲ្យមានជីវិតថ្មីដោយសារឫទ្ធានុភាពរបស់ព្រះអង្គផ្ទាល់។ ព្រះយេស៊ូប្រកាសថាបុត្រមនុស្សត្រូវរងទុក្ខលំបាកយ៉ាងខ្លាំងសោយទិវង្គត ហើយនឹងមានព្រះជន្មមានជីវិតថ្មី (មក ៨,៣១)។ ព្រះអង្គមានព្រះបន្ទូលទៀតថា៖ "ខ្ញុំសុខចិត្តស៊ូប្ដូរជីវិត ដើម្បីឲ្យបានជីវិតនោះមកវិញ (...)។ ខ្ញុំមានអំណាចនឹងស៊ូប្ដូរជីវិតរបស់ខ្ញុំ ហើយខ្ញុំក៏មានអំណាចនឹងយកជីវិតនោះមកវិញ" (យហ ១០,១៧-១៨)។ "យើងជឿថាព្រះយេស៊ូពិតជាបានសោយទិវង្គត ហើយមានព្រះជន្មថ្មីមែន" (១ថស ៤,១៤)។

៦៥០-គ្រូបាធ្យាយរិះគិតអំពីព្រះជន្មថ្មីដោយយល់ឃើញថា ព្រលឹង និងព្រះកាយព្រះគ្រីស្តដែលសេចក្តីស្លាប់បានបំបែកនៅតែរួមជាមួយព្រះគ្រីស្តក្នុងឋានៈជាព្រះជាម្ចាស់៖ "ដោយសារសភាពជាព្រះជាម្ចាស់មានតែមួយ និងនៅស្ថិតស្ថេរក្នុងផ្នែកទាំងពីររបស់មនុស្ស ផ្នែកទាំងពីរនោះរួមជាមួយគ្នាម្តងទៀត។ ហេតុនេះសេចក្តីស្លាប់កើតឡើងដោយសារផ្នែកទាំងពីររបស់មនុស្សត្រូវបំបែក ហើយមនុស្សមានជីវិតថ្មីដោយសារផ្នែកទាំងពីរនោះរួមជាមួយគ្នាម្តងទៀត" (សន្តៈ គ្រេគ័រនៃនីស; DS ៣២៥; ៣៥៩; ៣៦៩; ៥៣៩)។

## ៣-តើ "ព្រះជន្មថ្មី" មានអត្ថន័យ និងសង្គ្រោះមនុស្សលោកយ៉ាងដូចម្តេច?

៦៥១-"បើព្រះគ្រីស្តមិនបានមានជីវិតថ្មីទេ សេចក្តីដែលយើងប្រកាសមុខជាគ្មានន័យអ្វីសោះឡើយ" (១ករ ១៥,១៤)។ ព្រះជន្មថ្មីបញ្ជាក់នូវអ្វីៗទាំងអស់ដែលព្រះអង្គបានប្រព្រឹត្ត និងបង្រៀន។ បើព្រះគ្រីស្តមានព្រះជន្មថ្មីព្រះអង្គបញ្ជាក់អំពីសេចក្តីពិតទាំងអស់ សូម្បីតែសេចក្តីពិតលើសប្រាជ្ញារបស់មនុស្ស ហើយបង្ហាញភស្តុតាងជាដាច់ខាតអំពីអំណាចរបស់ព្រះអង្គជាព្រះជាម្ចាស់ដែលទ្រង់បានសន្យាទុកជាមុន។

៦៥២-ព្រះជន្មថ្មីរបស់ព្រះគ្រីស្តបំពេញព្រះបន្ទូលសន្យានៃសម្ព័ន្ធមេត្រីចាស់ (លក ២៤,២៦-២៧) និងរបស់ព្រះយេស៊ូផ្ទាល់នៅលើផែនដីនេះ (មថ ២៨,៦)។ ពាក្យសម្តី "ស្របតាមគម្ពីរ" (១ករ ១៥,៣-៤) បង្ហាញថាព្រះជន្មថ្មីរបស់ព្រះគ្រីស្តបំពេញសេចក្តីប្រកាសទុកជាមុនទាំងអស់នោះ។

៦៥៣-ព្រះជន្មថ្មីរបស់ព្រះយេស៊ូបញ្ជាក់ថា ព្រះអង្គជាព្រះជាម្ចាស់។ ព្រះយេស៊ូមានព្រះបន្ទូលទុកជាមុនថា៖ "កាលណាអ្នករាល់គ្នាលើកបុត្រមនុស្សឡើង អ្នករាល់គ្នាមុខជានឹងស្គាល់ឋានៈរបស់ខ្ញុំ" (យហ ៨,២៨)។ ព្រះជន្មថ្មីរបស់ព្រះគ្រីស្តដែលត្រូវគេឆ្កាងបញ្ជាក់ថាព្រះអង្គមាន "ជីវិតគង់នៅ" គឺជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងព្រះជាម្ចាស់ផ្ទាល់។ សន្តៈ ប៉ូល បានប្រកាសទៅកាន់ជនជាតិយូដាថា៖ "ព្រះបន្ទូលដែលព្រះជាម្ចាស់បានសន្យាជាមួយបុព្វបុរសរបស់យើង ព្រះអង្គបានធ្វើតាមដើម្បីជាប្រយោជន៍ដល់យើង (...) គឺព្រះអង្គបានប្រោសព្រះយេស៊ូឲ្យមានព្រះជន្មថ្មីដូចមានចែងទុកក្នុងទំនុកតម្កើងទីពីរថា៖ "ព្រះអង្គជាបុត្ររបស់យើង គឺយើងដែលបានបង្កើតព្រះអង្គមកនៅថ្ងៃនេះ" (កក ១៣,៣២-៣៣) (ទន ២,៧)។ តាមគម្រោងការអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ ព្រះអង្គប្រោសព្រះគ្រីស្តឲ្យមានជីវិតថ្មី ដើម្បីឲ្យគម្រោងការដ៏អស្ចារ្យនៃព្រះយេស៊ូប្រសូតបានគ្រប់លក្ខណៈ។

៦៥៤-បុណ្យចម្លងមានទិដ្ឋភាពពីរ គឺដោយសារព្រះយេស៊ូសោយទិវង្គត ព្រះអង្គរំដោះយើងឲ្យរួចពីបាប ដោយសារព្រះអង្គមានព្រះជន្មថ្មី ព្រះអង្គក៏បើកផ្លូវឲ្យយើងទទួលជីវិតថ្មី។ ព្រះអង្គប្រោសយើងឲ្យទៅជាមនុស្សសុចរិតក្នុងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ (រម ៤,២៥)។ "ដូច្នេះព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ (...) យ៉ាងណា យើងក៏រស់នៅតាមរបៀបថ្មីយ៉ាងនោះដែរ" (រម ៦,៤)។ ព្រះគ្រីស្តដែលមានព្រះជន្មថ្មីទទួលជោគជ័យលើអំពើបាប និងលើសេចក្តីស្លាប់ ហើយប្រោសយើងឲ្យរួមចំណែកក្នុងព្រះហឫទ័យប្រណីសន្តោសសាជាថ្មីម្តងទៀត (អភ ២,៤-៥; ១ពត្រ ១,៣)។ ព្រះគ្រីស្តដែលមានព្រះជន្មមានជីវិតថ្មីប្រោសយើងឲ្យទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដ្បិតមនុស្សលោកទៅជាបងប្អូនរបស់ព្រះគ្រីស្ត ដូចព្រះអង្គផ្ទាល់ហៅសាវ័ករបស់ព្រះអង្គក្រោយពីព្រះអង្គបានមានជីវិតថ្មីថា៖ "សូមទៅប្រាប់បងប្អូនខ្ញុំ" (មថ ២៨,១០; យហ ២០,១៧)។ យើងជាបងប្អូនមិនមែនមកពីធម្មជាតិទេ តែមកពីព្រះអំណោយទាននៃព្រះហឫទ័យប្រណីសន្តោស ដ្បិតយើងទៅជាបុត្រធីតារបស់ព្រះអង្គដោយរួមរស់ជាមួយព្រះបុត្រាតែមួយដែលបានសម្តែងព្រះអង្គឲ្យបានពេញលក្ខណៈ ពេលព្រះអង្គបានមានជីវិតថ្មី។

៦៥៥-ទីបញ្ចប់ព្រះជន្មថ្មីរបស់ព្រះគ្រីស្ត ហើយព្រះគ្រីស្តដែលមានព្រះជន្មថ្មីផ្ទាល់ជាគោល និងប្រភពនៃជីវិតថ្មី

របស់យើង៖ "ព្រះគ្រីស្តពិតជាមានព្រះជន្មថ្មីមែន។ ក្នុងចំណោមមនុស្សស្លាប់ ព្រះអង្គមានព្រះជន្មថ្មីមុនគេបង្អស់។ មនុស្សទាំងអស់បានស្លាប់រួមជាមួយលោក អដាំ យ៉ាងណា គេក៏នឹងមានជីវិតថ្មីរួមជាមួយព្រះគ្រីស្តយ៉ាងនោះដែរ" (១ករ ១៥,២០-២២)។ ដោយរង់ចាំឲ្យព្រះបន្ទូលសន្យានេះបានសម្រេចព្រះគ្រីស្តដែលមានព្រះជន្មថ្មីរស់នៅក្នុងចិត្តគំនិតរបស់អ្នកជឿ។ នៅក្នុងអង្គព្រះអង្គគ្រីស្តបរិស័ទ "ស្គាល់ឱជារសឫទ្ធានុភាពទាំងឡាយនៃបរមលោក" (ហប ៦,៥) ហើយព្រះគ្រីស្តនាំជីវិតគេឆ្ពោះទៅឯព្រះជាម្ចាស់ (កូឡ ៣,១-៣) ដើម្បីឲ្យគេ "លែងរស់សម្រាប់ខ្លួនឯងទៀតហើយ គឺរស់សម្រាប់ព្រះអង្គដែលបានសោយទិវង្គត និងមានព្រះជន្មថ្មីសម្រាប់គេ" (២ករ ៥,១៥)។

## សង្ខេប

៦៥៦-ជំនឿលើការមានជីវិតថ្មីមានស្នូលថា ព្រឹត្តិការណ៍នៃប្រវិត្តសាស្ត្រ ដែលក្រុមសាវ័កបានបញ្ជាក់ថា ពួកគាត់ពិតជាបានជួបព្រះយេស៊ូដែលមានព្រះជន្មថ្មីមែន និងជាព្រឹត្តិការណ៍ដ៏អាថ៌កំបាំងខ្ពង់ខ្ពស់បំផុត គឺសភាពជាមនុស្សរបស់ព្រះគ្រីស្តចូលក្នុងសិរីរុងរឿងនៃព្រះជាម្ចាស់។

៦៥៧-ផ្នូរទទេរ និងសំពត់ស្នបបង្ហាញថា ព្រះសពព្រះគ្រីស្តបានរួចចាកផុតអំពីចំណងនៃសេចក្តីស្លាប់ និងភាពរលួយស្អុយ ដោយឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ សញ្ញាសម្គាល់នោះ រៀបចំក្រុមសាវ័កឲ្យជួបព្រះគ្រីស្ត ដែលមានព្រះជន្មថ្មី។

៦៥៨-ព្រះគ្រីស្តជា "ដើមកំណើតនៃអ្វីៗទាំងអស់ក្នុងចំណោមមនុស្សស្លាប់" (កូឡ ១,១៨) ជាគោលការណ៍នៃការមានជីវិតថ្មីរបស់យើង ចាប់តាំងពីពេលនេះទៅ ដោយប្រោសព្រលឹងយើងឲ្យបានសុចរិត (រម ៦,៤) បន្ទាប់មកទៀត ដោយប្រោសរូបកាយយើងឲ្យមានជីវិត (រម ៨,១១)។

## ប្រការទី៦៖

## "ព្រះយេស៊ូយាងឡើងស្ថានបរមសុខ គង់ខាងស្តាំព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ"

៦៥៩-"កាលព្រះអម្ចាស់យេស៊ូមានព្រះបន្ទូលរួចហើយ ព្រះជាម្ចាស់លើកព្រះអង្គឡើងទៅស្ថានបរមសុខ" (មក ១៦,១៩)។ ដោយសារព្រះកាយព្រះគ្រីស្តមានលក្ខណៈថ្មី និងហួសធម្មជាតិជារៀងរហូត (លក ២៤,៣១) ព្រះកាយព្រះអង្គបានទទួលសិរីរុងរឿងនៅពេលព្រះអង្គមានព្រះជន្មថ្មី។ ប៉ុន្តែអស់រយៈពេលសែសិបថ្ងៃ ដែលព្រះអង្គបានបរិភោគជាមួយសាវ័ករបស់ព្រះអង្គ (កក ១០,៤១) ព្រមទាំងបង្រៀនគេអំពីព្រះរាជ្យព្រះអង្គ (កក ១,៣) សិរីរុងរឿងរបស់ព្រះអង្គនៅតែលាក់លៀមក្រោមជាតិជាមនុស្សធម្មតា (មក ១៦,១២)។ ពេលព្រះយេស៊ូបង្ហាញខ្លួនជាលើកចុងក្រោយ ជាតិជាមនុស្សរបស់ព្រះអង្គចូលជាស្ថាពរក្នុងសិរីរុងរឿងរបស់ព្រះជាម្ចាស់ដែលពពក (កក ១,៩) និងមេឃ (លក ២៤,៥១) ជានិមិត្តរូប។ ចាប់ពីឥឡូវនេះទៅ ព្រះអង្គគង់នៅខាងស្តាំព្រះជាម្ចាស់ (មក ១៦,១៩)។ ព្រះអង្គនឹងបង្ហាញខ្លួនតាមរបៀបពិសេសតែមួយ និងជាលើកចុងក្រោយឲ្យលោក ប៉ូល ឃើញដែលប្រៀបបីខ្លួនដូចជា "កូនកើតមិនគ្រប់ខែ" (១ករ ១៥,៨) និងធ្វើឲ្យលោកទៅជាគ្រីស្តទូត (១ករ ៩,១; កាឡ ១,៦)។

៦៦០-អស់រយៈពេលនោះព្រះគ្រីស្តដែលមានព្រះជន្មថ្មីលាក់លៀមសិរីរុងរឿងរបស់ព្រះអង្គ ដូចព្រះអង្គមានព្រះបន្ទូលដ៏លាក់កំបាំងទៅនាងម៉ារីម៉ាដាឡាថា៖ "ខ្ញុំមិនទាន់បានឡើងទៅឯព្រះបិតាខ្ញុំនៅឡើយ។ សូមទៅប្រាប់ពួកបងប្អូនខ្ញុំផងថា ខ្ញុំឡើងទៅឯព្រះបិតាខ្ញុំដែលជាព្រះបិតារបស់អ្នករាល់គ្នា ខ្ញុំឡើងទៅឯព្រះរបស់ខ្ញុំដែលជាព្រះ

របស់អ្នករាល់គ្នាដែរ" (យហ ២០,១៧)។ ព្រះបន្ទូលនេះបង្ហាញថាសិរីរុងរឿងរបស់ព្រះគ្រីស្តដែលមានព្រះជន្មមានជីវិតថ្មីខុសប្លែកពីសិរីរុងរឿងរបស់ព្រះគ្រីស្តដែលគង់ខាងស្តាំព្រះបិតា។ ពេលព្រះអង្គយាងឡើងទៅស្ថានបរមសុខជាហេតុការណ៍នៃប្រវត្តិសាស្ត្រ និងហួសប្រវត្តិសាស្ត្រ ព្រះអង្គនឹងឆ្លងពីសិរីរុងរឿងមួយទៅសិរីរុងរឿងមួយទៀត។

៦៦១-ដំណាក់កាលចុងក្រោយរួមនឹងដំណាក់កាលទីមួយ គឺពេលដែលព្រះអង្គយាងចុះពីលើមេឃ និងប្រសូតជាមនុស្ស។ មានតែអ្នកដែល "ចេញពីព្រះបិតា" ទេដែលអាច "ទៅឯព្រះបិតាវិញ" គឺព្រះគ្រីស្ត (យហ ១៦,២៨)។ "ពុំដែលមាននរណាបានឡើងស្ថានបរមសុខឡើយ គឺមានតែបុត្រមនុស្សប៉ុណ្ណោះ ដែលយាងចុះពីស្ថានបរមសុខមក" (យហ ៣,១៣) (អភ ៤,៨-១០)។ ដោយពឹងតែលើកម្លាំងខ្លួន មនុស្សជាតិមិនអាចចូលក្នុង "ព្រះដំណាក់" (យហ ១៤,២) ព្រះជន្ម និងស្ថានបរមសុខរបស់ព្រះបិតាបានឡើយ។ មានតែព្រះគ្រីស្តទេ ដែលអាចបើកទ្វារស្ថានបរមសុខនេះឲ្យមនុស្សលោកទើប "យើងដែលជាអវយវៈរបស់ព្រះអង្គមានសេចក្តីសង្ឃឹមថានឹងទៅឯព្រះអង្គដែលជាព្រះសិរសា និងគោលរបស់យើង" (MR)។

៦៦២-"រីឯខ្ញុំវិញ កាលណាគេលើកខ្ញុំឡើងពីលើដី ខ្ញុំនឹងទាក់ទាញមនុស្សទាំងអស់មកឯខ្ញុំ" (យហ ១២,៣២)។ ការលើកនៅលើឈើឆ្កាងមានន័យថា និងប្រកាសទុកជាមុនថាព្រះយេស៊ូនឹងយាងឡើងទៅស្ថានបរមសុខ។ ព្រះយេស៊ូគ្រីស្តជាបូជាចារ្យតែមួយនៃសម្ពន្ធមេត្រីថ្មី និងអស់កល្បជានិច្ច "មិនបានយាងចូលក្នុងទីសក្ការៈសង់ឡើងដោយស្នាដៃមនុស្ស (...) គឺព្រះអង្គបានយាងចូលក្នុងស្ថានបរមសុខតែម្តង។ ឥឡូវនេះព្រះអង្គស្ថិតនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍ដល់យើង" (ហប ៩,២៤)។ នៅស្ថានបរមសុខព្រះគ្រីស្តធ្វើជាបូជាចារ្យជារៀងរហូត "ដ្បិតព្រះអង្គមានព្រះជន្មរស់រហូត ដើម្បីទូលអង្វរព្រះជាម្ចាស់ឲ្យពួកអ្នកដែលចូលមកជិតព្រះជាម្ចាស់" (ហប ៧,២៥)។ ដោយសារព្រះគ្រីស្តជា "មហាបូជាចារ្យដែលនាំទៅកាន់សម្បត្តិបរលោក" (ហប ៩,១១) ព្រះអង្គជាស្នូល និងតួដ៏សំខាន់ជាងគេនៃពិធីបុណ្យដែលលើកតម្កើងព្រះបិតានៅឯស្ថានបរមសុខ (វវ ៤,៦-១១)។

៦៦៣-ចាប់ពីឥឡូវនេះទៅ ព្រះគ្រីស្តគង់នៅខាងស្តាំព្រះបិតា៖ "ពាក្យថា "ខាងស្តាំព្រះបិតា" ត្រូវតែគិតដល់សិរីរុងរឿង និងកិត្តិយសរបស់ព្រះជាម្ចាស់ដែលព្រះបុត្រារបស់ព្រះអង្គជាព្រះជាម្ចាស់ និងរួមសភាពជាមួយព្រះបិតាមុនគ្រប់សម័យកាលទាំងអស់បានទទួលក្រោយពីព្រះអង្គបានកើតជាមនុស្ស និងក្រោយពីជាតិជាមនុស្សរបស់ព្រះអង្គបានទទួលសិរីរុងរឿង"(សន្តៈ យ៉ូហានដាម៉ាសែន)។

៦៦៤-ព្រះគ្រីស្តគង់ខាងស្តាំព្រះបិតាមានន័យថា ព្រះមេស្ស៊ីចាប់ផ្តើមសោយរាជ្យ និងបំពេញសុបិន្តនិមិត្តរបស់ព្យាការីដានីអែលអំពីបុត្រមនុស្ស៖ "លោកបានទទួលអំណាចគ្រប់គ្រងព្រះកិត្តិនាម ព្រមទាំងរាជ្យសម្បត្តិផង។ ប្រជាជនទាំងអស់ ប្រជាជាតិទាំងអស់ និងមនុស្សគ្រប់ភាសានាំគ្នាគោរពបម្រើលោក អំណាចគ្រប់គ្រងរបស់លោកនៅស្ថិតស្ថេរអស់កល្បជានិច្ចឥតសាបសូន្យឡើយ។ រាជ្យសម្បត្តិរបស់លោកក៏មិនត្រូវរលាយដែរ" (ដន ៧,១៤)។ ចាប់ពីពេលនោះទៅក្រុមគ្រីស្តទូតទៅជាសាក្សីនៃ "ព្រះរាជ្យដែលគ្មានទីបញ្ចប់ឡើយ" (ធម៌ប្រកាសជំនឿនៃនិសេ/កុងស្តង់ទីណូប)។

## សង្ខេប

៦៦៥-ការយាងឡើងរបស់ព្រះគ្រីស្តបង្ហាញថា សភាពជាមនុស្សរបស់ព្រះយេស៊ូចូលទៅក្នុងព្រះដំណាក់នៃស្ថានបរមសុខរបស់ព្រះជាម្ចាស់ជារៀងរហូត ហើយជាទីដែលព្រះអង្គនឹងយាងមកវិញ (កក ១,១១) ប៉ុន្តែជាកន្លែងលាក់បំបាំងព្រះអង្គអំពីភ្នែកមនុស្សលោករហូតដល់ពេលព្រះអង្គនឹងយាងមកវិញ (កូឡ ៣,៣)។

៦៦៦-ព្រះយេស៊ូគ្រីស្តដែលជាព្រះសិរសារបស់ព្រះសហគមន៍ យាងចូលក្នុងព្រះរាជ្យដែលពោរពេញដោយសិរីរុងរឿងរបស់ព្រះបិតាមុនយើង ដើម្បីឲ្យពួកយើងដែលជាសិរីរាង្គនៃព្រះកាយព្រះអង្គ រស់នៅដោយសង្ឃឹមថាក្នុងថ្ងៃណាមួយ នឹងនៅក្នុងអង្គព្រះអង្គអស់កល្បជានិច្ច។

៦៦៧-ដោយសារព្រះយេស៊ូគ្រីស្តបានយាងឡើងទៅកាន់ស្ថានលើជាការស្រេច ព្រះអង្គតែងតែជួយអង្វរព្រះជាម្ចាស់ ដើម្បីពួកយើង ដូចជាស្ពានមេត្រីដែលធានាថា ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកជារៀងរហូត។

# ប្រការទី៧៖

## "ព្រះអង្គនឹងយាងមកវិញដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ទាំងស្លាប់"

### ១-ព្រះអង្គនឹងយាងមកវិញពោរពេញដោយសិរីរុងរឿង

#### តាមរយៈព្រះសហគមន៍ព្រះគ្រីស្តសោយរាជ្យហើយ

៦៦៨-"ព្រះគ្រីស្តបានសោយទិវង្គត និងមានព្រះជន្មថ្មីដើម្បីធ្វើជាព្រះអម្ចាស់ទាំងលើមនុស្សស្លាប់ ទាំងលើមនុស្សរស់" (រម ១៤,៩)។ ក្នុងជាតិជាមនុស្សព្រះគ្រីស្តយាងឡើងស្ថានបរមសុខរួមចំណែកជាមួយនឹងឫទ្ធានុភាព និងអំណាចរបស់ព្រះជាម្ចាស់ផ្ទាល់។ ព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ គឺព្រះអង្គមានអំណាចលើផែនដី និងនៅលើមេឃ។ ព្រះអង្គ "ខ្ពស់ជាងវត្ថុសក្តិសិទ្ធិគ្រប់យ៉ាង ខ្ពស់ជាងអ្វីៗដែលមានអំណាច មានឫទ្ធិ មានបារមីគ្រប់គ្រង" ដ្បិតព្រះបិតា "បានបង្ក្រាបអ្វីៗទាំងអស់ឲ្យនៅក្រោមព្រះបាទារបស់ព្រះគ្រីស្ត" (អភ ១,២០-២១)។ ព្រះគ្រីស្តជាព្រះអម្ចាស់លើសកលលោក (អភ ៤,១០; ១ករ ១៥,២៤.២៧-២៨) និងលើប្រវត្តិសាស្ត្រ។ ព្រះជាម្ចាស់ចាត់ចែងឲ្យប្រវត្តិសាស្ត្រមនុស្សលោក និងសត្វលោកទាំងអស់ឲ្យ "រួមគ្នានៅក្នុងអង្គព្រះគ្រីស្ត" (អភ ១,១០) ដែលបំពេញអ្វីៗទាំងអស់។

៦៦៩-ដោយសារព្រះគ្រីស្តជាព្រះអម្ចាស់ ព្រះអង្គក៏ជាព្រះសិរសានៃព្រះសហគមន៍ដែលជាព្រះកាយព្រះអង្គដែរ (អភ ១,២២)។ ព្រះអង្គបានយាងឡើងស្ថានបរមសុខ និងបានទទួលសិរីរុងរឿងព្រះអង្គបានបំពេញបេសកកម្មរបស់ព្រះអង្គឲ្យបានគ្រប់លក្ខណៈ ទ្រង់ក៏ស្ថិតនៅលើផែនដីក្នុងព្រះសហគមន៍។ ដោយសារព្រះគ្រីស្តបានសង្គ្រោះមនុស្សលោក ព្រះអង្គមានអំណាចលើព្រះសហគមន៍ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ (អភ ៤,១១-១៣)។ "ព្រះសហគមន៍បង្ហាញអំពីព្រះគ្រីស្តគ្រងរាជ្យយ៉ាងអាថ៌កំបាំងក្នុងលោកនេះរួចហើយ" ដែល "ជាពន្លក និងជាដើមកំណើតនៃព្រះរាជ្យនេះនៅលើផែនដី" (LG ៣; ៥)។

៦៧០-ចាប់តាំងពីព្រះគ្រីស្តបានយាងឡើងស្ថានបរមសុខ ព្រះជាម្ចាស់បានសម្រេចគម្រោងការរបស់ព្រះអង្គរួចហើយ។ យើងមកដល់ "ពេលចុងក្រោយបំផុត" ហើយ (១យហ ២,១៨) (១ពត្រ ៤,៧)។ "ដូច្នេះជំនាន់ចុងក្រោយបង្អស់មកដល់យើងហើយ។ ពិភពលោកពិតជាបានប្រែជាថ្មីដោយសារព្រះគ្រីស្តរួចទៅហើយៗ ក៏ចាប់ផ្តើមមានរូបរាងជាមុនយ៉ាងពិតប្រាកដ នៅពេលឥឡូវនេះ គឺថាព្រះសហគមន៍តែងខ្លួនដោយភាពវិសុទ្ធយ៉ាងពិតប្រាកដនៅលើផែនដីនេះ ទោះបីភាពវិសុទ្ធនេះមិនទាន់ពេញលក្ខណៈនៅឡើយក្តី" (LG ៤៨)។ ព្រះរាជ្យព្រះគ្រីស្តសម្តែងនូវវត្តមានព្រះអង្គ ដែលព្រះសហគមន៍ប្រកាស (មក ១៦,២០) ដោយសារសញ្ញាសម្គាល់ដ៏អស្ចារ្យ (មថ ១៦,១៧-១៨)។

### ...លុះដល់ពេលអ្វីៗទាំងអស់ស្ថិតនៅក្រោមអំណាចរបស់ព្រះគ្រីស្ត

៦៧១-ទោះបីព្រះគ្រីស្តស្ថិតនៅក្នុងព្រះសហគមន៍រួចហើយក្តី ក៏ព្រះអង្គមិនទាន់យាងមកបំពេញព្រះរាជ្យព្រះអង្គដោយគ្រងរាជ្យនៅលើផែនដី "ប្រកបដោយឫទ្ធានុភាព និងសិរីរុងរឿងពន់ពេកក្រៃ" នៅឡើយ (លក ២១,២៧) (មថ ២៥,៣១)។ ទោះបីព្រះគ្រីស្តសោយទិវង្គត និងមានព្រះជន្មថ្មី ទ្រង់បានឈ្នះមេប្រឆាំងយ៉ាងណាក៏ដោយ ក៏វានៅតែវាយលុកព្រះរាជ្យព្រះអង្គដែរ (២ថស ២,៧)។ លុះដល់ពេលអ្វីៗទាំងអស់ស្ថិតនៅក្រោមអំណាចរបស់ព្រះគ្រីស្តហើយ (១ករ ១៥,២៨) "ព្រះសហគមន៍កំពុងធ្វើបូជានីយេសចរណ៍ ទម្រាំដល់ពេលព្រះជាម្ចាស់នឹងបង្កើតមេឃថ្មី និងផែនដីថ្មីប្រកបដោយសេចក្តីសុចរិត។ ហេតុនេះ ទាំងអគ្គសញ្ញារបស់ព្រះសហគមន៍ក្តី ទាំងរចនាសម្ព័ន្ធរបស់ខ្លួនក្តី ក៏មានលក្ខណៈរបស់លោកីយ៍មិនទៀងទាត់ដែលចេះតែកន្លងផុតទៅដែរ។ ព្រះសហគមន៍រស់នៅក្នុងចំណោមសត្វលោកដែលកំពុងតែស្រែកថ្ងូរ និងឈឺចុកចាប់ ដូចជាស្ត្រីដែលហៀបនឹងសម្រាលកូនដោយទន្ទឹងរង់ចាំសិរីរុងរឿងនៃបុត្រធីតារបស់ព្រះជាម្ចាស់" (LG ៤៨)។ ហេតុនេះហើយទើបបានជាគ្រីស្តបរិស័ទអធិដ្ឋានជាពិសេសក្នុងអភិបូជា (១ករ ១១,២៦) ឲ្យព្រះគ្រីស្តយាងមកវិញ (២ពត្រ ៣,១១-១២) ដោយទូលអង្វរព្រះអង្គថា៖ "ឱព្រះអម្ចាស់អើយ! សូមយាងមក!" (១ករ ១៦,២២; វវ ២២,១៧.២០)។

៦៧២-មុនព្រះគ្រីស្តយាងឡើងទៅស្ថានបរមសុខ ព្រះអង្គមានព្រះបន្ទូលថាមិនទាន់ដល់ពេលកំណត់នៅឡើយ ដែលព្រះអង្គនឹងតាំងរាជាណាចក្រប្រកបដោយសិរីរុងរឿងដែលជនជាតិអ៊ីស្រាអែលរង់ចាំ (កក ១,៦-៧) ហើយបើតាមព្យាការីបានថ្លែងទុកជាមុន (អស ១១,១-៩) ត្រូវនាំឲ្យមនុស្សលោកទាំងអស់បានយុត្តិធម៌ សេចក្តីស្រឡាញ់ និងសន្តិភាព។ បើតាមព្រះអម្ចាស់ បច្ចុប្បន្នកាលនេះជាពេលរបស់ព្រះវិញ្ញាណ និងសក្ខីភាព (កក ១,៨) ប៉ុន្តែជាពេលប្រកបដោយ "ភាពតានតឹង" (១ករ ៧,២៦) និងសេចក្តីអាក្រក់ (អភ ៥,១៦) ដែលមិនត្រាប្រណីព្រះសហគមន៍ (១ពត្រ ៤,១៧) ហើយដែលចាប់ផ្តើមការប្រយុទ្ធប្រឆាំងនៃថ្ងៃចុងក្រោយ (១យហ ២,១៨; ៤,៣; ១ធម ៤,១)។ ពេលវេលាបច្ចុប្បន្នកាលនេះជាពេលដែលយើងត្រូវតែរង់ចាំព្រមទាំងប្រុងស្មារតីជានិច្ច (មថ ២៥,១-១៣; មក ១៣,៣៣-៣៧)។

### ជនជាតិអ៊ីស្រាអែលសង្ឃឹមថាព្រះគ្រីស្តនឹងយាងមកវិញប្រកបដោយសិរីរុងរឿង

៦៧៣-តាំងពីពេលព្រះគ្រីស្តយាងឡើងស្ថានបរមសុខ ព្រះអង្គនឹងយាងមកវិញក្នុងពេលចាប់ៗ (វវ ២២,២០) ទោះបី "ត្រង់ឯណាវេលាដែលព្រះបិតាបានកំណត់ទុកដោយអំណាចព្រះអង្គផ្ទាល់នោះ អ្នករាល់គ្នាមិនបាច់ដឹងទេ" (កក ១,៧) (មក ១៣,៣២) គឺព្រះអង្គអាចយាងមកវិញនៅពេលណាក៏បាន (មថ ២៤,៤៤; ១ថស ៥,២) ទោះបីព្រះជាម្ចាស់ "ឃាត់" ព្រះគ្រីស្ត និងទុក្ខលំបាកទាំងប៉ុន្មានដែលនឹងមកមុនព្រះអង្គនៅឡើយ (២ថស ២,៣-១២)។

៦៧៤-ព្រះមេស្ស៊ីប្រកបដោយសិរីរុងរឿងអាចយាងមកវិញនៅពេលណាក៏បានក្នុងប្រវត្តិសាស្ត្រ (រម ១១,៣១) គឺរហូតដល់ "ជនជាតិអ៊ីស្រាអែលទាំងមូល" (រម ១១,២៦; មថ ២៣,៣៩) ដែលមាន "មួយចំនួនមានចិត្តរឹងរូស" (រម ១១,២៥) ដោយ "គ្មានជំនឿ" (រម ១១,២០) ចំពោះព្រះយេស៊ូនឹងទទួលស្គាល់ព្រះអង្គ។ សន្តៈ សិលា មានប្រសាសន៍ទៅកាន់ជនជាតិយូដានៅទីក្រុងយេរូសាឡឹមនៅពេលបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមកថា៖ "សូមកែប្រែចិត្តគំនិត ហើយវិលមករកព្រះជាម្ចាស់វិញ ដើម្បីឲ្យព្រះអង្គលុបបំបាត់បាបរបស់បងប្អូន។ ព្រះអម្ចាស់នឹងប្រទានឲ្យបងប្អូនបានស្គាល់ពេលសម្រាក ព្រមទាំងប្រទានព្រះគ្រីស្តយេស៊ូមកបងប្អូនដូចព្រះអង្គគ្រោងទុកជាមុន។ ឥឡូវនេះព្រះយេស៊ូគ្រីស្តគង់នៅស្ថានបរមសុខរហូតដល់ព្រះជាម្ចាស់រៀបចំអ្វីៗទាំងអស់ឡើងវិញ ដូចទ្រង់មានព្រះបន្ទូលទុកតាមរយៈព្យាការីដ៏វិសុទ្ធរបស់ព្រះអង្គនៅជំនាន់ដើមស្រាប់" (កក ៣,១៩-២១)។ សន្តៈ ប៉ូល បន្ថែមទៀតថា៖

"ដោយសាសន៍អ៊ីស្រាអែលដាច់ចេញពីព្រះអង្គ ទៅធ្វើឲ្យមនុស្សលោកបានជានានឹងព្រះអង្គវិញ យ៉ាងនេះទៅហើយ ចុះចំណង់បើព្រះអង្គទទួលគេសាជាថ្មី តើនឹងកើតមានយ៉ាងណាទៅទៀត? គឺប្រាកដជាមនុស្សស្លាប់នឹងមានជីវិតថ្មីពុំខាន!" (រម ១១,១៥)។ ពេលជនជាតិអ៊ីស្រាអែលទាំងអស់ (រម ១១,១២) នឹងចូលក្នុងការសង្គ្រោះក្រោយ "សាសន៍ដទៃទាំងអស់" (រម ១១,២៥) (លក ២១,២៤) ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ "ឡើងដល់កំពស់របស់ព្រះគ្រីស្តដែលបំពេញអ្វីទាំងអស់" (អភ ៤,១៣) រហូតដល់ "ព្រះជាម្ចាស់បានគ្រងរាជ្យលើអ្វីៗទាំងអស់គ្រប់ប្រការ" (១ករ ១៥,២៨)។

### ព្រះសហគមន៍ប្រឈមមុខនឹងទុក្ខលំបាកចុងក្រោយ

៦៧៥-មុនព្រះគ្រីស្តនឹងយាងមកវិញ ព្រះសហគមន៍ត្រូវប្រឈមមុខនឹងទុក្ខលំបាកចុងក្រោយដែលនឹងធ្វើឲ្យអ្នកជឿមួយចំនួនធំធ្លាក់ចុះអន់ថយ (លក ១៨,១៨; មថ ២៤,១២)។ ព្រះសហគមន៍ដែលកំពុងធ្វើបូជនីយេសចរណ៍នៅលើផែនដីត្រូវគេបៀតបៀន (លក ២១,១២; យហ ១៥,១៩-២០)។ ការបៀតបៀននេះនឹងសម្តែងអំពើអាក្រក់ជាទីបំផុត ដូចជាសាសនាក្លែងក្លាយដែលនឹងនាំឲ្យមនុស្សលោកជឿថាគេអាចដោះស្រាយបញ្ហាទាំងឡាយដោយក្បត់សេចក្តីពិត។ សាសនាក្លែងក្លាយធំជាងគេបំផុត គឺសាសនាក្លែងក្លាយរបស់មេប្រឆាំងព្រះគ្រីស្ត បានសេចក្តីថាមនុស្សលោកលើកតម្កើងខ្លួនឯងជំនួសព្រះជាម្ចាស់ និងព្រះមេស្ស៊ីរបស់ព្រះអង្គដែលបានកើតជាមនុស្ស (២ថស ២,៤-១២)។

៦៧៦-ជំនឿក្លែងក្លាយប្រឆាំងនឹងព្រះគ្រីស្តនេះ មានរាល់ពេលគេចង់បំពេញសេចក្តីសង្ឃឹមលើព្រះមេស្ស៊ី ក្នុងប្រវត្តិសាស្ត្រមនុស្សលោក ដែលមានតែពេលព្រះជាម្ចាស់នឹងវិនិច្ឆ័យមនុស្សលោក នឹងបង្ហើយសេចក្តីសង្ឃឹមនេះ។ ព្រះសហគមន៍បានបដិសេធមិនព្រមទទួលជំនឿនេះ ដែលគេហៅថា "សហស្សវត្សរ៍និយម" (DS ៣៨៣៩) ជាពិសេសខាងផ្នែកនយោបាយ ដែល "ខូចពីខាងក្នុង" (សម្តេចប៉ាប ពីយូសទី១១; GS ២០-២១)។

៦៧៧-ព្រះសហគមន៍នឹងចូលក្នុងសិរីរុងរឿងនៃព្រះរាជ្យព្រះអង្គ លុះត្រាតែព្រះសហគមន៍រួមស្លាប់រួមរស់ជាមួយព្រះអម្ចាស់របស់ខ្លួន (វវ ១៩,១-៩)។ ព្រះជាម្ចាស់នឹងសម្រេចព្រះរាជ្យព្រះអង្គឲ្យបានគ្រប់លក្ខណៈ មិនមែនមកពីព្រះសហគមន៍នឹងឈ្នះអំពើអាក្រក់ (វវ ១៣,៨) ជាលំដាប់លំដោយទេ តែមកពីព្រះអង្គនឹងទទួលជោគជ័យលើអំពើអាក្រក់នេះ (វវ ២០,៧-១០)។ ពេលនោះព្រះមហេសីរបស់ព្រះអង្គនឹងយាងចុះពីលើមេឃ (វវ ២១,២-៤)។ ព្រះជាម្ចាស់នឹងទទួលជោគជ័យលើការបះបោរនៃអំពើអាក្រក់ ដោយវិនិច្ឆ័យមនុស្សលោក (វវ ២០,១២) ក្រោយពីផែនដីនេះដែលចេះតែប្រែប្រួលនឹងបានវិនាសអន្តរាយ (២ពត្រ ៣,១២-១៣)។

## ២-ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ទាំងស្លាប់

៦៧៨-ដូចពួកព្យាការី (ដន ៧,១០) និងលោកយ៉ូហានបាទីស្ត (មថ ៣,៧-១២) ព្រះយេស៊ូបានប្រកាសទុកជាមុនថា ព្រះជាម្ចាស់នឹងវិនិច្ឆ័យមនុស្សលោកនៅថ្ងៃចុងក្រោយ។ ពេលនោះព្រះជាម្ចាស់នឹងបំភ្លឺកិច្ចការ (មក ១២,៣៨-៤០) និងចិត្តគំនិតដ៏លាក់កំបាំង (លក ១២,១-៣) របស់មនុស្សម្នាក់ៗ ហើយព្រះអង្គនឹងដាក់ទោសដល់អស់អ្នកដែលមិនព្រមជឿ និងមិនព្រមទទួលព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ (មថ ១១,២០-២៤)។ កិច្ចការរបស់យើងចំពោះអ្នកដទៃនឹងសម្តែងថា យើងព្រម ឬមិនព្រមទទួលព្រះហឫទ័យប្រណីសន្តោស និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ (មថ ៥,២២)។ នៅថ្ងៃចុងក្រោយ ព្រះយេស៊ូនឹងមានព្រះបន្ទូលថា៖ "គ្រប់ពេលដែលអ្នករាល់គ្នាប្រព្រឹត្តអំពើទាំងនោះចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ដែលជាបងប្អូនរបស់យើងនេះ អ្នករាល់គ្នាក៏

ដូចជាបានប្រព្រឹត្តចំពោះយើងដែរ" (មថ ២៥,៤០)។

៦៧៩-ព្រះគ្រីស្តជាព្រះអម្ចាស់នៃជីវិតអស់កល្បជានិច្ច។ ដោយសារព្រះអង្គជាព្រះសង្គ្រោះមនុស្សលោក ទ្រង់ក៏មានសិទ្ធិពេញទីនឹងវិនិច្ឆ័យកិច្ចការ និងចិត្តគំនិតរបស់មនុស្សលោក។ ព្រះអង្គបាន "ទទួល" សិទ្ធិនេះដោយសារព្រះឈើឆ្កាងរបស់ព្រះអង្គ។ ហេតុនេះហើយបានជាព្រះបិតាបានប្រគល់ "អំណាចដាក់ទោសទាំងអស់ឲ្យព្រះបុត្រាវិញ" (យហ ៥,២២) (យហ ៥,២៧; មថ ២៥,៣១; កក ១០,៤២; ១៧,៣១; ២ធម ៤,១)។ ក៏ប៉ុន្តែព្រះបុត្រាមិនមែនយាងមកដើម្បីដាក់ទោសទេ គឺព្រះអង្គយាងមកដើម្បីសង្គ្រោះ (យហ ៣,១៧) និងប្រទានជីវិតដែលស្ថិតនៅក្នុងអង្គព្រះអង្គ (យហ ៥,២៦)។ ពេលយើងម្នាក់ៗមិនព្រមទទួលព្រះហឫទ័យប្រណីសន្តោស យើងក៏ដាក់ទោសលើខ្លួនឯងនៅក្នុងជីវិតនេះរួចហើយ (យហ ៣,១៨) យើងក៏ទទួលទោសតាមកិច្ចការរៀងៗខ្លួន (១ករ ៣,១២-១៥) ហើយយើងអាចធ្លាក់ស្ថាននរកជារៀងរហូតដោយមិនព្រមទទួលព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់ (មថ ១២,៣២)។

## សង្ខេប

៦៨០-ព្រះគ្រីស្តជាអម្ចាស់សោយរាជ្យរួចស្រេចទៅហើយតាមរយៈព្រះសហគមន៍ ប៉ុន្តែអ្វីៗទាំងអស់ក្នុងលោកនេះមិនទាន់ចុះចូលក្រោមអំណាចព្រះអង្គឡើយ។ ជ័យជម្នះនៃព្រះរាជ្យនេះនឹងត្រូវរងនូវការវាយលុកចុងក្រោយ អំពីឫទ្ធិអំណាចនៃអំពើអាក្រក់ជាមិនខាន។

៦៨១-ព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក នៅអវសានកាលនៃពិភពលោក គឺជាពេលដែលព្រះគ្រីស្តនឹងយាងមកពោរពេញដោយសិរីរុងរឿង ដើម្បីសម្រេចជ័យជម្នះជាស្ថាពរនៃអំពើល្អលើអំពើអាក្រក់ ដែលដូចគ្រាប់ពូជស្រូវល្អ និងស្រងែដែលរីកចម្រើនឡើងជាមួយគ្នាក្នុងអំឡុងប្រវត្តសាស្ត្រ។

៦៨២-ដោយយាងមកក្នុងអវសានកាលនៃពិភពលោក ដើម្បីវិនិច្ឆ័យទោសមនុស្សទាំងរស់ទាំងស្លាប់ ព្រះគ្រីស្តពោរពេញដោយសិរីរុងរឿងនឹងសម្តែងឲ្យយើងដឹងអំពីអាថ៌កំបាំងនៃចិត្តគំនិត និងប្រោសប្រទានឲ្យមនុស្សម្នាក់ៗទៅតាមអំពើរបស់គេ និងតាមការទទួល ឬការមិនព្រមទទួលការប្រោសប្រណី។

# ជំពូកទីបី៖

# ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ

៦៨៣-"បើគ្មានព្រះវិញ្ញាណដ៏វិសុទ្ធណែនាំទេ នោះគ្មាននរណាម្នាក់អាចពោលថា "ព្រះយេស៊ូជាព្រះអម្ចាស់បានទេ" (១ករ ១២,៣)។ "ព្រះជាម្ចាស់បានចាត់ព្រះវិញ្ញាណនៃព្រះបុត្រារបស់ព្រះអង្គឲ្យមកសណ្ឋិតក្នុងចិត្តយើង គឺព្រះវិញ្ញាណនេះហើយដែលបន្លឺព្រះសូរសៀងឡើងថា "អប្បា! ឱព្រះបិតាអើយ!" (កាឡ ៤,៦)។ មានតែនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធទេតើ ទើបយើងអាចមានជំនឿបាន។ ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវតែមកសណ្ឋិតក្នុងចិត្តយើង ដើម្បីឲ្យយើងអាចមានទំនាក់ទំនងជាមួយព្រះគ្រីស្តបាន។ គឺព្រះវិញ្ញាណនេះហើយដែលយាងមករកយើង និងប្រោសយើងឲ្យមានជំនឿ។ ដោយសារបុណ្យជ្រមុជទឹកដែលជាអគ្គសញ្ញាដំបូងនៃជំនឿ ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានជីវិតដែលមានប្រភពក្នុងអង្គព្រះបិតា និងដែលព្រះអង្គប្រោសប្រទានក្នុងអង្គព្រះគ្រីស្តមកយើងរៀងៗខ្លួន និងយ៉ាងស្និទស្នាលនៅក្នុងព្រះសហគមន៍៖

ដោយសារពិធីជ្រមុជទឹក យើងកើតសាជាថ្មីនៅក្នុងអង្គព្រះជាម្ចាស់ជាព្រះបិតាតាមរយៈព្រះបុត្រាព្រះអង្គ នៅក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ។ អស់អ្នកដែលមានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ព្រះវិញ្ញាណក៏ណែនាំគេទៅកាន់ព្រះបន្ទូល គឺព្រះបុត្រា។ ព្រះបុត្រាណែនាំគេទៅព្រះបិតា ហើយព្រះបិតាប្រទានឲ្យគេមានជីវិតអស់កល្បជានិច្ច។ ហេតុនេះហើយបើសិនជាគ្មានព្រះវិញ្ញាណទេ យើងមិនអាចមើលឃើញព្រះបុត្រារបស់ព្រះជាម្ចាស់បានទេ ហើយបើគ្មានព្រះបុត្រាទេ គ្មាននរណាម្នាក់អាចទៅកាន់ព្រះបិតាបានដែរ ដ្បិតអ្នកណាចង់ស្គាល់ព្រះបិតា ត្រូវតែស្គាល់ព្រះបុត្រា ហើយយើងអាចស្គាល់ព្រះបុត្រារបស់ព្រះជាម្ចាស់ តែតាមព្រះវិញ្ញាណដ៏វិសុទ្ធប៉ុណ្ណោះ (សន្តៈ អ៊ីរ៉េណេ)។

៦៨៤-ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រណី ព្រះអង្គជាអង្គដំបូងដែលនាំឲ្យយើងមានជំនឿ និងមានជីវិតថ្មីគឺ "ឲ្យស្គាល់ព្រះបិតា និងព្រះយេស៊ូគ្រីស្តដែលព្រះអង្គចាត់ឲ្យមក" (យហ ១៧,៣)។ ប៉ុន្តែព្រះវិញ្ញាណដ៏វិសុទ្ធជាអង្គចុងក្រោយក្នុងការសម្តែងអង្គនីមួយៗនៃព្រះត្រៃឯក។ សន្តៈ គ្រេគ័រនៃណាស៊ីអង់ជា "ទេវវិទូ" ពន្យល់ថា យើងស្គាល់ព្រះត្រៃឯកជាលំដាប់លំដោយបែបនេះ មកពីព្រះជាម្ចាស់មានគរុកោសល្យពោរពេញដោយធម៌មេត្តាករុណា។

សម្ពន្ធមេត្រីចាស់ប្រកាសយ៉ាងច្បាស់លាស់អំពីព្រះបិតាច្រើនជាងព្រះបុត្រា។ ចំណែកឯសម្ពន្ធមេត្រីថ្មីវិញបង្ហាញឲ្យដឹងអំពីព្រះបុត្រា និងឲ្យយល់ខ្លះៗអំពីសភាពជាព្រះជាម្ចាស់នៃព្រះវិញ្ញាណ។ បច្ចុប្បន្ននេះព្រះវិញ្ញាណត្រូវបានលើកយកមកបង្ហាញឲ្យយើងដឹង និងធ្វើឲ្យយើងស្គាល់ព្រះអង្គច្បាស់ជាងមុន។ តាមពិតទៅ កាលដែលយើងមិនទាន់ទទួលស្គាល់ថា ព្រះបិតាជាព្រះជាម្ចាស់ មិនគួរប្រកាសអំពីព្រះបុត្រាឲ្យបើកចំហរ ហើយកាលដែលយើងមិនទាន់ជឿថា ព្រះបុត្រាជាព្រះជាម្ចាស់ មិនគួរបន្ថែមព្រះវិញ្ញាណដ៏វិសុទ្ធដូចជានឹមម្យ៉ាងទៅទៀត បើនិយាយជ្រុលបន្តិច... គឺពន្លឺនៃព្រះត្រៃឯកនឹងភ្លឺត្រចះត្រចង់កាន់តែខ្លាំងឡើងៗតទៅមុខបន្តិចម្តងៗ "ពីសិរីរុងរឿងមួយទៅសិរីរុងរឿងមួយទៀត" (សន្តៈ គ្រេគ័រ នៃណាស៊ីអង់)។

៦៨៥-ពេលយើងជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ យើងក៏ប្រកាសថាព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះមួយអង្គនៃព្រះត្រៃឯកដ៏វិសុទ្ធដែលរួមសភាពជាមួយព្រះបិតា និងព្រះបុត្រាទ្រង់ "ទទួលការក្រាបថ្វាយបង្គំ និងសិរីរុងរឿងស្មើនឹងព្រះបិតា និងព្រះបុត្រា" (ធម៌ប្រកាសជំនឿនិសេ/កុងស្តង់ទីណូប)។ ហេតុនេះហើយបានជាយើងបាននិយាយអំពីអាថ៌កំបាំងនៃព្រះវិញ្ញាណដ៏វិសុទ្ធ ក្នុងវគ្គទាក់ទងនឹង "ទេវវិទ្យា" នៃព្រះត្រៃឯក។ ឥឡូវនេះយើងនិយាយអំពី "តួនាទី" នៃព្រះវិញ្ញាណដ៏វិសុទ្ធ។

៦៨៦-ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការរួមជាមួយព្រះបិតា និងព្រះបុត្រាអំពីកំណើតនៃអ្វីៗទាំងអស់រហូតដល់ទីបញ្ចប់នៃគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះរបស់យើង។ ប៉ុន្តែព្រះជាម្ចាស់សម្តែង និងប្រទានព្រះវិញ្ញាណមកយើង ដែលយើងអាចស្គាល់ និងទទួលដូចព្រះមួយអង្គ "នៅពេលចុងក្រោយបំផុត" ដែលព្រះបុត្រាប្រសូតជាមនុស្ស ដើម្បីសង្គ្រោះមនុស្សលោកបានចាប់ផ្តើមហើយ។ ហេតុនេះគម្រោងការដ៏អស្ចារ្យនេះរបស់ព្រះជាម្ចាស់ដែលព្រះគ្រីស្តជា "រៀមច្បង" និងជាព្រះសិរសានៃការបង្កើតពិភពលោកថ្មីនឹងអាចកើតជារូបរាងនៅក្នុងមនុស្សជាតិ ដោយសារព្រះជាម្ចាស់ចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះសហគមន៍សហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ការលើកលែងទោសឲ្យមនុស្សរួចពីបាបរូបកាយមនុស្សនឹងមានជីវិតថ្មី ជីវិតរស់នៅអស់កល្បជានិច្ច។

# ប្រការទី៨៖

## "ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ"

៦៨៧-"គ្មាននរណាម្នាក់យល់អំពីព្រះជាម្ចាស់បានក្រៅពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នោះឡើយ" (១ករ ២,១១)។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលសម្តែងព្រះអង្គ ប្រោសយើងឲ្យស្គាល់ព្រះគ្រីស្តជាព្រះបន្ទូលដ៏រស់រវើករបស់ព្រះអង្គ ប៉ុន្តែមិនសម្តែងខ្លួនព្រះអង្គនោះទេ។ ព្រះអង្គដែល "បានថ្លែងព្រះបន្ទូលតាមរយៈអស់លោកព្យាការី" ណែនាំយើងឲ្យស្តាប់ព្រះបន្ទូលរបស់ព្រះបិតា ប៉ុន្តែយើងមិនឮព្រះអង្គផ្ទាល់ទេ។ យើងគ្រាន់តែស្គាល់ព្រះអង្គនៅពេលព្រះអង្គសម្តែងឲ្យយើងស្គាល់ព្រះគ្រីស្ត និងប្រោសយើងឲ្យទទួលព្រះអង្គនៅក្នុងជំនឿ។ ព្រះវិញ្ញាណនៃសេចក្តីពិត "សម្តែង" ព្រះគ្រីស្តឲ្យយើងស្គាល់ ប៉ុន្តែមិនថ្លែងអំពីព្រះអង្គផ្ទាល់ (យហ ១៦,១៣)។ ហេតុនេះដោយសារព្រះវិញ្ញាណលុបលាងខ្លួនព្រះអង្គចោល "មនុស្សលោកពុំអាចទទួលព្រះអង្គបានទេ ព្រោះគេមើលព្រះអង្គមិនឃើញ ហើយក៏មិនស្គាល់ព្រះអង្គផង" រីឯអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ក៏ស្គាល់ព្រះវិញ្ញាណ ដ្បិតព្រះអង្គស្ថិតនៅជាប់នឹងគេ (យហ ១៤,១៧)។

៦៨៨-យើងអាចស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធ ដោយសារព្រះសហគមន៍ដែលបានទទួល និងបញ្ជូនបន្តជំនឿរបស់ក្រុមគ្រីស្តទូតមក៖

-ក្នុងព្រះគម្ពីរដែលព្រះអង្គបានបំភ្លឺអ្នកនិពន្ធ

-ក្នុងការបញ្ជូនបន្តដែលគ្រូបាធ្យាយធ្វើជាសាក្សីរហូតដល់សព្វថ្ងៃ

-ក្នុងក្រុមមេដឹកនាំព្រះសហគមន៍ដែលព្រះអង្គជួយឧបត្ថម្ភ

- ក្នុងពិធីបុណ្យនៃអគ្គសញ្ញាតាមរយៈពាក្យសម្តី និងនិមិត្តរូបទាំងប៉ុន្មានដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រោសយើងឲ្យរួមជាមួយព្រះគ្រីស្ត

- ក្នុងការអធិដ្ឋានដែលព្រះអង្គជួយអង្វរព្រះជាម្ចាស់សម្រាប់យើង

-ក្នុងព្រះអំណោយទាន និងមុខងារដែលព្រះសហគមន៍សំអាងទៅលើ

-ក្នុងទីសម្គាល់នៃការប្រកាសដំណឹងល្អ

-ក្នុងសក្ខីភាពនៃសន្តបុគ្គលដែលព្រះអង្គសម្តែងភាពបរិសុទ្ធរបស់ព្រះអង្គ និងបន្តព្រះរាជកិច្ចនៃការសង្គ្រោះ។

### ១-បេសកកម្មរួមគ្នារបស់ព្រះបុត្រា និងព្រះវិញ្ញាណ

៦៨៩-ព្រះវិញ្ញាណនៃព្រះបុត្រារបស់ព្រះបិតា (កាឡ ៤,៦) ដែលព្រះបិតាបានចាត់ឲ្យមកក្នុងចិត្តយើងពិតជាព្រះជាម្ចាស់។ ព្រះវិញ្ញាណរួមសុភាពជាមួយព្រះបិតា និងព្រះបុត្រា ហើយក៏មិនអាចបំបែកចេញពីព្រះបិតា និងព្រះបុត្រាបានទេ នៅក្នុងព្រះជន្មយ៉ាងស្និទ្ធស្នាលនៃព្រះត្រៃឯកផង នៅក្នុងព្រះអំណោយទានពោរពេញដោយសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះមនុស្សលោកផង។ ដោយក្រាបថ្វាយបង្គំព្រះត្រៃឯកដ៏វិសុទ្ធដែលផ្តល់ជីវិតដែលរួមសុភាពជាមួយគ្នា និងដែលមិនអាចបំបែកបានជំនឿរបស់ព្រះសហគមន៍ប្រកាសថាអង្គនីមួយៗខុសប្លែកពីគ្នាផងដែរ។ ពេលព្រះបិតាចាត់ព្រះបន្ទូលឲ្យយាងមក ព្រះអង្គក៏ចាត់ឲ្យខ្យល់ដង្ហើមរបស់ព្រះអង្គឲ្យយាងមកផងដែរ គឺបេសកកម្មរបស់ព្រះបុត្រា និងព្រះវិញ្ញាណដែលទ្រង់ខុសប្លែកពីគ្នា តែមិនអាចបំបែកចេញពីគ្នាបានទេ។ ព្រះគ្រីស្តដែលជារូបតំណាង ដែលមើលឃើញរបស់ព្រះជាម្ចាស់ ដែលមើលមិនឃើញ ជាអ្នកលេចឡើងតែព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកសម្តែងឲ្យគេស្គាល់ព្រះអង្គ។

៦៩០-ព្រះយេស៊ូជាព្រះគ្រីស្តដែលបានទទួល "ប្រេងអភិសេក" ដ្បិតព្រះវិញ្ញាណជាប្រេងអភិសេក ហើយអ្វីៗដែលកើតឡើងចាប់ពីព្រះបុត្រាប្រសូតជាមនុស្សមក ពីព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណយ៉ាងបរិបូណ៌ (យហ ៣,៣៤)។ ពេលព្រះគ្រីស្តទទួលសិរីរុងរឿងរួចហើយ (យហ ៧,៣៩) ព្រះអង្គដែលគង់ខាងស្តាំព្រះបិតាអាចចាត់ព្រះវិញ្ញាណដល់អស់អ្នកដែលជឿលើព្រះអង្គ៖ ព្រះអង្គប្រទានសិរីរុងរឿងរបស់ព្រះអង្គឲ្យគេ (យហ ១៧,២២) គឺព្រះវិញ្ញាណដ៏វិសុទ្ធដែលសម្តែងសិរីរុងរឿងរបស់ព្រះអង្គ (យហ ១៦,១៤)។ បេសកកម្មរួមគ្នានឹងលាតត្រដាងដល់បុត្រធីតាទាំងអស់ដែលព្រះបិតាបានយកមកចិញ្ចឹមក្នុងព្រះកាយព្រះគ្រីស្ត ហើយព្រះវិញ្ញាណនឹងមានបេសកកម្មប្រោសឲ្យគេរួមជាមួយព្រះគ្រីស្ត និងមានជីវិតក្នុងអង្គព្រះអង្គដែរ។

សញ្ញានៃប្រេងអភិសេកនាំឲ្យគិតថា (...) ព្រះបុត្រា និងព្រះវិញ្ញាណមិនស្ថិតនៅឆ្ងាយពីគ្នាទេ។ តាមពិតទៅ ចន្លោះផ្ទៃរាងកាយ និងប្រេង ទោះជាវិចារណញ្ញាណ ឬក៏ការរំភើបដោយវិញ្ញាណក៏ដោយ មិនស្គាល់អ្នកនៅចន្លោះកណ្តាលណាមួយយ៉ាងណា ទំនាក់ទំនងរវាងព្រះបុត្រា និងព្រះវិញ្ញាណកើតឡើងភ្លាមៗយ៉ាងនោះដែរ ទើបចំពោះអ្នកដែលនឹងជួបជាមួយព្រះបុត្រាដោយសារជំនឿមុនដំបូងបង្អស់ គេត្រូវជួបជាមួយប្រេងអភិសេកជាមុនសិន។ តាមការពិត គ្មានផ្ទៃកណាមួយដែលគ្មានវត្តមាននៃព្រះវិញ្ញាណដ៏វិសុទ្ធទេ។ ហេតុនេះអស់អ្នកទទួលជំនឿ ត្រូវប្រកាសជំនឿរបស់ខ្លួនចំពោះព្រះអម្ចាស់ជាព្រះបុត្រា នៅក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះវិញ្ញាណនឹងយាងមកពីគ្រប់ទិសទីនៅពីខាងមុខអស់អ្នកដែលចូលទៅជិតព្រះអង្គដោយសារជំនឿ (សន្តៈ គ្រេគ័រ នៃនីស)។

## ២-ព្រះនាមរបៀបហៅ និងនិមិត្តរូបរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

### ព្រះនាមរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

៦៩១-"ព្រះវិញ្ញាណដ៏វិសុទ្ធ" ជាព្រះនាមរបស់អ្នកដែលយើងក្រាបថ្វាយបង្គំ និងលើកតម្កើងសិរីរុងរឿងរួមជាមួយព្រះបិតា និងព្រះបុត្រាផង។ ព្រះសហគមន៍បានទទួលព្រះនាមនេះពីព្រះអម្ចាស់ ហើយប្រកាសព្រះនាមនេះក្នុងពិធីជ្រមុជទឹកនៃបុត្រធីតាថ្មីរបស់ព្រះអង្គ (មថ ២៨,១៩)។

ពាក្យ "ព្រះវិញ្ញាណ" មកពីពាក្យ "Ruah" ជាភាសាហេប្រឺដែលមានន័យថា ការដកដង្ហើមអាកាសខ្យល់។ ព្រះយេស៊ូប្រើពាក្យខ្យល់ ដើម្បីឲ្យលោក នីកូដេម យល់ថា ខ្យល់របស់ព្រះជាម្ចាស់ គឺព្រះវិញ្ញាណរបស់ព្រះអង្គសុទ្ធតែថ្មីៗខុសប្លែកពីអ្វីៗទាំងអស់ (យហ ៣,៥-៨)។ ម្យ៉ាងទៀតព្រះវិញ្ញាណ និងដ៏វិសុទ្ធជាលក្ខណៈរួមនឹងព្រះទាំងបីអង្គ ប៉ុន្តែដោយភ្ជាប់ពាក្យទាំងពីររួមជាមួយគ្នា ព្រះគម្ពីរ ពិធីបុណ្យ និងទេវវិទ្យាសំដៅលើព្រះវិញ្ញាណដ៏វិសុទ្ធតែប៉ុណ្ណោះ។

### របៀបហៅព្រះវិញ្ញាណដ៏វិសុទ្ធ

៦៩២-ពេលព្រះយេស៊ូប្រកាស និងសន្យាថាព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកព្រះអង្គហៅព្រះវិញ្ញាណថា "ប៉ារ៉ាក្លេតូស" គឺ "អ្នកដែលគេកោះហៅ" មេធាវី (យហ ១៤,១៦.២៦; ១៥,២៦; ១៦,៧)។ ជាធម្មតាគេបកប្រែ "ប៉ារ៉ាក្លេតូស" ដោយ "អ្នកលួងលោម" ដោយដឹងថាព្រះយេស៊ូជាអ្នកលួងលោមដំបូង (១យហ ២,១)។ ព្រះអម្ចាស់ផ្ទាល់ហៅព្រះវិញ្ញាណដ៏វិសុទ្ធ "ព្រះវិញ្ញាណនៃសេចក្តីពិត" (យហ ១៦,១៣)។

៦៩៣-កិច្ចការគ្រីស្តទូត និងលិខិតផ្សេងៗប្រើព្រះនាមព្រះវិញ្ញាណដ៏វិសុទ្ធ តែសន្តៈ ប៉ូល ហៅព្រះអង្គថា៖

ព្រះវិញ្ញាណនៃព្រះបន្ទូលសន្យា (កាឡ ៣,១៤; អភ ១,១៣) ព្រះវិញ្ញាណដែលធ្វើឲ្យបងប្អូនទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ (រម ៨,១៥; កាឡ ៤,៦) ព្រះវិញ្ញាណរបស់ព្រះគ្រីស្ត (រម ៨,១១) ព្រះវិញ្ញាណរបស់ព្រះអម្ចាស់ (២ករ ៣,១៧) ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ (រម ៨,៩.១៤; ១៥,១៩; ១ករ ៦,១១; ៧,៤០) ហើយសន្តៈ សិលាហៅព្រះអង្គថាព្រះវិញ្ញាណប្រកបដោយសិរីរុងរឿង (១ពត្រ ៤,១៤)។

## និមិត្តរូបនៃព្រះវិញ្ញាណដ៏វិសុទ្ធ

៦៩៤-ទឹក៖ ទឹកជានិមិត្តរូបនៃកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធក្នុងពិធីជ្រមុជទឹក ពីព្រោះក្រោយពីបានអង្វរព្រះវិញ្ញាណឲ្យយាងមក ទឹកទៅជាសញ្ញារបស់អគ្គសញ្ញាដ៏មានប្រសិទ្ធិភាពនៃកំណើតថ្មី។ កំណើតដំបូងរបស់យើងបានកើតក្នុងទឹកយ៉ាងណា ទឹកនៃពិធីជ្រមុជពិតជាមានន័យថា ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសយើងឲ្យកើតសាជាថ្មីក្នុងព្រះជាម្ចាស់យ៉ាងនោះដែរ។ "យើងបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណតែមួយ (...) យើងក៏បានទទួលព្រះវិញ្ញាណតែមួយដែរ" (១ករ ១២,៣)៖ ដូច្នេះព្រះវិញ្ញាណផ្ទាល់ជាទឹកដ៏រស់រវើកដែលផុសចេញពីព្រះគ្រីស្តដែលត្រូវគេឆ្កាង (យហ ១៩,៣៤; ១យហ ៥,៨) ដូចជាប្រភពរបស់ព្រះអង្គ ហើយផុសចូលនៅក្នុងខ្លួនដូចជាជីវិតអស់កល្បជានិច្ច (យហ ៤,១០-១៤; ៧,៣៨; សរ ១៧,១-៦; អស ៥៥,១; សក ១៤,៨; ១ករ ១០,៤; វវ ២១,៦; ២២,១៧)។

៦៩៥-ប្រេង៖ ប្រេងជានិមិត្តរូបនៃកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែរ (១យហ ២២០,២៧; ២ករ ១,២១)។ ក្នុងការអប់រំជំនឿ ប្រេងជាសញ្ញានៃអគ្គសញ្ញាលាបថ្ងាស ប៉ុន្តែដើម្បីយល់យ៉ាងច្បាស់អំពីអត្ថន័យពេញលេញនៃនិមិត្តរូបនេះត្រូវតែរំឭកអំពីប្រេងអភិសេកដំបូងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធលើព្រះយេស៊ូ។ ព្រះគ្រីស្ត (ជាភាសាហេប្រឺ "ព្រះមេស្ស៊ី") មានន័យថា "បានទទួលប្រេងអភិសេក" ពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ ក្នុងសម្ពន្ធមេត្រីចាស់ (សរ ៣០,២២-៣២) មានអ្នកខ្លះបានទទួលប្រេងអភិសេកពីព្រះអម្ចាស់ ជាពិសេសព្រះបាទដាវីឌ (១សម ១៦,១៣)។ ប៉ុន្តែព្រះយេស៊ូបានទទួលប្រេងអភិសេកតាមរបៀបតែមួយ គឺជាតិជាមនុស្សដែលព្រះបុត្រាទទួលយក បានទទួលប្រេងនៃព្រះវិញ្ញាណដ៏វិសុទ្ធឲ្យបានពេញលេញ។ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធព្រះជាម្ចាស់តែងតាំងព្រះយេស៊ូជាព្រះគ្រីស្ត (លក ៤,១៨-១៩; អស ៦១,១)។ ព្រះនាងព្រហ្មចារិនីម៉ារីប្រសូតព្រះគ្រីស្តពីព្រះវិញ្ញាណដ៏វិសុទ្ធ។ តាមរយៈទេវទូតព្រះវិញ្ញាណដ៏វិសុទ្ធប្រកាសថាព្រះអង្គជាព្រះគ្រីស្តនៅពេលព្រះអង្គប្រសូត (លក ២១១) ហើយជំរុញឲ្យលោក ស៊ីម្ម៉ូន ចូលមកព្រះវិហារទៅជួបព្រះគ្រីស្តនៃព្រះអម្ចាស់ (លក ២២៦-២៧)។ ព្រះវិញ្ញាណប្រោសព្រះគ្រីស្តឲ្យពោរពេញទៅដោយព្រះអង្គ (លក ៤,១) និងប្រកបដោយឫទ្ធានុភាពនៅពេលព្រះអង្គប្រោសអ្នកជំងឺឲ្យបានជា និងជួយសង្គ្រោះមនុស្ស (លក ៦,១៩; ៨,៤៦)។ ព្រះវិញ្ញាណប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញពីចំណោមមនុស្សស្លាប់ (រម ១,៤; ៨,១១)។ ហេតុនេះព្រះយេស៊ូដែលជា "ព្រះគ្រីស្ត" យ៉ាងពេញលក្ខណៈដោយសារជាតិជាមនុស្សរបស់ព្រះអង្គបានឈ្នះសេចក្តីស្លាប់ (កក ២,៣៦) ចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងបរិបូណ៌រហូតដល់ "សន្តបុគ្គល" ដោយរួមជាមួយជាតិជាមនុស្សនៃព្រះបុត្រារបស់ព្រះជាម្ចាស់នឹងទៅជា "មនុស្សពេញវ័យឡើងដល់កំពស់របស់ព្រះគ្រីស្តដែលបំពេញអ្វីៗទាំងអស់" (អភ ៤,១៣) គឺ "ព្រះគ្រីស្តដ៏ពេញលេញ" តាមពាក្យរបស់សន្តៈ អូគូស្តាំង។

៦៩៦-ភ្លើង៖ ទឹកបង្ហាញអំពីកំណើតថ្មី និងពហុផលនៃជីវិតដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រទាន ឯភ្លើងវិញជានិមិត្តរូបនៃថាមពលរបស់កិច្ចការនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រែអ្វីៗទាំងអស់។ ដោយសារលោកអធិដ្ឋានព្យាការីអេលីដែល "ងើបឡើងដូចភ្លើង ពាក្យសម្តីរបស់លោកភ្លឺដូចចន្លុះក្នុងពេលយប់" (បសរ ៤៨,១) ទាក់ទាញភ្លើងរបស់មេឃលើយញ្ញបូជានៃភ្នំការម៉ែល (១ពង្ស ១៨,៣៨-៣៩) ជាតំណាងនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលប្រែ

អ្វីៗដែលព្រះអង្គប៉ះពាល់។ លោក យ៉ូហានបាទីស្ដ ដែល "មកមុនព្រះអង្គ ហើយមានព្រះវិញ្ញាណប្រកបដោយឫទ្ធានុភាពដូចលោក អេលី" (លក ១,១៧) ប្រកាសថា ព្រះគ្រីស្ដជាអ្នកនឹង "ជ្រមុជ (...) ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងដោយភ្លើង" (លក ៣,១៦)។ ព្រះយេស៊ូនឹងមានព្រះបន្ទូលអំពីព្រះវិញ្ញាណនេះថា៖ "ខ្ញុំមកដើម្បីនាំភ្លើងមកផែនដី ប្រសិនបើភ្លើងនោះឆេះខ្ញុំស្ងប់ចិត្តហើយ" (លក ១២,៤៩)។ នៅពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកព្រះអង្គសណ្ឋិតលើក្រុមសាវ័ក "ហាក់ដូចជាអណ្ដាតភ្លើង" (កក ២,៣-៤) និងប្រោសពួកគេឲ្យពោរពេញដោយព្រះអង្គ។ ការបញ្ជូនបន្តខាងវិញ្ញាណរំឭកថាភ្លើងជានិមិត្តរូបយ៉ាងច្បាស់នៃកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (សន្តៈយ៉ូហាននៃព្រះឈើឆ្កាង)៖ "កុំរារាំងសកម្មភាពរបស់ព្រះវិញ្ញាណឡើយ" (១ថស ៥,១៩)។

៦៩៧-ពពក និងពន្លឺ៖ និមិត្តរូបទាំងពីរនេះមិនអាចបែកញែកបានទេ នៅពេលព្រះវិញ្ញាណដ៏វិសុទ្ធសម្ដែងព្រះអង្គ។ ក្នុងសម្ពន្ធមេត្រីចាស់ពពកដែលងងឹតផង ភ្លឺផង សម្ដែងព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ ហើយដែលជាព្រះសង្គ្រោះដោយគ្របបាំងសិរីរុងរឿងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះអង្គ៖ ជាមួយលោក ម៉ូសេ លើភ្នំស៊ីណៃ (សរ ២៤,១៥-១៨) ក្នុងពន្លាជួបព្រះអង្គ (សរ ៣៣,៩-១០) ពេលជនជាតិអ៊ីស្រាអែលធ្វើដំណើរក្នុងវាលរហោស្ថាន (សរ ៤០,៣៦-៣៨) ហើយជាមួយព្រះបាទសាឡូម៉ូនក្នុងពិធីឆ្លងព្រះវិហារ (១ពង្ស ៨,១០-១២)។ ព្រះគ្រីស្ដបំពេញរូបនោះក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះអង្គនេះហើយដែលយាងមកសណ្ឋិតលើព្រះនាងព្រហ្មចារិនីម៉ារី និង "គ្របបាំង" នាងដើម្បីឲ្យនាងសម្រាលព្រះយេស៊ូ (លក ១,៣៥)។ នៅលើភ្នំពេលព្រះយេស៊ូប្រែទ្រង់ទ្រាយ ព្រះវិញ្ញាណចេញពីពពក និងយាងមក "គ្របបាំង" ព្រះយេស៊ូ លោក ម៉ូសេ និងលោក អេលី លោក សិលា លោក យ៉ាកុប និងលោកយ៉ូហាន ហើយ "មានព្រះសូរសៀងបន្លឺពីក្នុងពពកមកថា៖ "ព្រះអង្គនេះជាបុត្រដែលយើងបានជ្រើសរើស ចូរស្ដាប់ព្រះអង្គចុះ!" (លក ៩,៣៤-៣៥)។ គឺពពកដដែលនេះហើយដែល "មកបាំងព្រះយេស៊ូបាត់ពីភ្នែក" របស់ក្រុមសាវ័ក នៅពេលព្រះជាម្ចាស់លើកព្រះអង្គឡើងស្ថានបរមសុខ (កក ១,៩) ហើយដែលនឹងសម្ដែងថា ព្រះអង្គជាបុត្រមនុស្សពោរពេញដោយសិរីរុងរឿង នៅពេលព្រះអង្គនឹងយាងមកវិញ (លក ២១,២៧)។

៦៩៨-ត្រា {សញ្ញាសម្គាល់} ជានិមិត្តរូបស្រដៀងនឹងប្រេងដែរ "ដ្បិតបុត្រមនុស្សនេះហើយដែលព្រះជាម្ចាស់ជាព្រះបិតាបានដៅសញ្ញាសម្គាល់" (យហ ៦,២៧) ហើយ គឺនៅក្នុងអង្គព្រះអង្គដែលព្រះជាម្ចាស់ដៅសញ្ញាសម្គាល់លើយើង (២ករ ១,២២; អភ ១,១៣; ៤,៣០)។ ទេវវិទ្យាខ្លះបានប្រើនិមិត្តរូបនៃត្រា (sphragis) ដើម្បីសម្ដែងថាប្រេងនៃព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងអគ្គសញ្ញាជ្រមុជទឹក លាបថ្ងាស និងតែងតាំងមិនអាចយកចេញបានទេ ហើយអគ្គសញ្ញាទាំងបីនោះមិនអាចទទួលម្ដងទៀតទេ។

៦៩៩-ដៃ-ព្រះហស្ដ៖ ព្រះយេស៊ូប្រោសអ្នកជំងឺឲ្យបានជា និងប្រទានពរដល់ក្មេងៗ (មក ១០,១៦) ដោយដាក់ព្រះហស្ដលើពួកគេ (មក ៦,៥)។ ក្នុងព្រះនាមព្រះអង្គក្រុមគ្រីស្ដទូតក៏នឹងធ្វើដូច្នោះដែរ (មក ១៦,១៨)។ លើសពីនេះទៅទៀត ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ពេលក្រុមគ្រីស្ដទូតធ្វើពិធីដាក់ដៃ (កក ៨,១៧-១៩)។ តាមលិខិតផ្ញើជនគ្រីស្ដបរិស័ទហេប្រឺ ពិធីដាក់ដៃស្ថិតនៅក្នុង "សេចក្ដីណាដែលមានខ្លឹមសារគ្រប់លក្ខណៈ" (ហប ៦,២)។ ពេលផ្ដល់អគ្គសញ្ញាព្រះសហគមន៍បានទុកសញ្ញានេះនៃព្រះវិញ្ញាណដ៏វិសុទ្ធប្រកបដោយឫទ្ធានុភាពសព្វប្រការក្នុងធម៌អង្វរព្រះវិញ្ញាណ។

៧០០-ម្រាមដៃ-ព្រះអង្គុលី៖ "(ព្រះយេស៊ូ) ដេញខ្មោចដោយឫទ្ធានុភាព (ព្រះអង្គុលី) របស់ព្រះជាម្ចាស់" (លក ១១,២០)។ ព្រះជាម្ចាស់បានសរសេរធម្មវិន័យរបស់ព្រះអង្គលើបន្ទះថ្ម "ដោយព្រះអង្គុលីរបស់ព្រះអង្គ" (សរ ៣១,១៨) "លិខិតរបស់ព្រះគ្រីស្ដ" ជាលិខិតដែលព្រះជាម្ចាស់បានផ្ញើមកក្រុមគ្រីស្ដទូត "លិខិតនេះមិនមែន

សរសេរដោយទឹកខ្មៅទេ គឺសរសេរឡើងដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ មិនមែនជាលិខិតសរសេរនៅលើផ្ទាំងថ្មទេ គឺសរសេរក្នុងសាច់ក្នុងដួងចិត្តរបស់បងប្អូន" (២ករ ៣,៣)។ បទចម្រៀង "ឱព្រះវិញ្ញាណសូមយាងមក" អង្វរព្រះវិញ្ញាណដ៏វិសុទ្ធដូចជា "ព្រះអង្គុលីនៃព្រះហស្តស្តាំរបស់ព្រះបិតា"។

៧០១-សត្វព្រាប៖ ពេលទឹកជំនន់ស្រកហើយ (ជានិមិត្តរូបនៃពិធីជ្រមុជទឹក) សត្វព្រាបដែលលោក ណូអេបានលែងត្រឡប់មកវិញ ដោយមានត្រួយអូលីវដ៏ស្រស់ក្នុងចំពុះជាសញ្ញាថា មនុស្សអាចរស់នៅលើផែនដី ហើយ (កណ ៨,៨-១២)។ ពេលព្រះគ្រីស្តងើបឡើងពីទឹកនៃពិធីជ្រមុជទឹករបស់ព្រះអង្គ ព្រះវិញ្ញាណដ៏វិសុទ្ធដូចជាសត្វព្រាបយាងចុះមកសណ្ឋិតលើព្រះអង្គ (មថ ៣,១៦)។ ព្រះវិញ្ញាណយាងចុះ និងសណ្ឋិតលើដួងចិត្តដ៏បរិសុទ្ធរបស់អស់អ្នកដែលបានជ្រមុជទឹក។ នៅក្នុងព្រះវិហារខ្លះ ព្រះពន្លាដែលមានព្រះកាយព្រះគ្រីស្តមានរូបរាងដូចជាសត្វព្រាបព្យួរលើអាសនៈ។ ជាងគំនូរធ្លាប់យកសត្វព្រាបធ្វើជានិមិត្តរូបនៃព្រះវិញ្ញាណដ៏វិសុទ្ធ។

## ៣-ព្រះវិញ្ញាណ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅពេលព្រះជាម្ចាស់មានព្រះបន្ទូលសន្យានៅឡើយ

៧០២-ចាប់តាំងពីកំណើតនៃអ្វីៗទាំងអស់រហូតដល់ "ពេលកំណត់" (កាឡ ៤,៤) ព្រះបន្ទូល និងព្រះវិញ្ញាណរបស់ព្រះបិតាមានបេសកកម្មរួមគ្នាដែលនៅតែលាក់លៀម ប៉ុន្តែព្រះអង្គកំពុងធ្វើការ។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់រៀបចំពេលកំណត់របស់ព្រះមេស្ស៊ី ហើយព្រះជាម្ចាស់បានសន្យារួចហើយថា នឹងប្រទានទាំងពីរអង្គដែលមិនទាន់បានសម្តែងឲ្យពេញលេញ ដើម្បីឲ្យយើងអាចរង់ចាំ និងទទួលព្រះទាំងពីរអង្គនៅពេលព្រះជាម្ចាស់នឹងសម្តែងព្រះទាំងពីរអង្គ។ ហេតុនេះហើយបានជាពេលព្រះសហគមន៍អានគម្ពីរសម្ពន្ធមេត្រីចាស់ (២ករ ៣,១៤) ព្រះសហគមន៍ក៏ពិនិត្យពិច័យ (យហ ៥,៣៩.៤៦) អ្វីដែលព្រះវិញ្ញាណ "មានព្រះបន្ទូលតាមរយៈអស់លោកព្យាការី" សម្តែងឲ្យយើងដឹងអំពីព្រះគ្រីស្ត។

> តាមជំនឿព្រះសហគមន៍ពាក្យ "ព្យាការី" សំដៅទៅលើអស់អ្នកដែលព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺក្នុងការថ្លែងព្រះគម្ពីរដ៏វិសុទ្ធ ទាំងសម្ពន្ធមេត្រីចាស់ ទាំងសម្ពន្ធមេត្រីថ្មីផង។ តាមប្រពៃណីនៃសាសនាយូដាយើងត្រូវបែងចែកធម្មវិន័យ (កណ្ឌទាំងប្រាំដំបូង ឬបញ្ចកណ្ឌ) គម្ពីរព្យាការី (គម្ពីរប្រវត្តិសាស្ត្រ និងគម្ពីរព្យាការី) និងកណ្ឌផ្សេងៗ (ជាពិសេសព្រះប្រាជ្ញាញាណ និងទំនុកតម្កើង) (លក ២៤,៤៤)។

### ក្នុងការបង្កើត

៧០៣-ព្រះបន្ទូល និងដកដង្ហើមរបស់ព្រះជាម្ចាស់ជាប្រភពនៃការរស់នៅ និងជីវិតរបស់សត្វលោកនីមួយៗ (ទន ៣៣,៦; ១០៤,៣០; កណ ១,២; ២,៧; បសរ ៣,២០-២១; អគ ៣៧,១០)៖

> ព្រះវិញ្ញាណដ៏វិសុទ្ធសោយរាជ្យប្រោសឲ្យបានវិសុទ្ធ និងណែនាំសត្វលោក ដ្បិតព្រះអង្គរួមសភាពជាមួយព្រះបិតា និងព្រះបុត្រា (...)។ ដោយសារព្រះអង្គជាព្រះជាម្ចាស់ ព្រះអង្គក៏មានអំណាចលើជីវិត និងរក្សាទុកសត្វលោកក្នុងអង្គព្រះបិតាតាមព្រះបុត្រា។

៧០៤-"រីឯមនុស្សវិញ ព្រះជាម្ចាស់បានសូនរូបគេដោយព្រះហស្តព្រះអង្គផ្ទាល់ (គឺព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ) ហើយព្រះអង្គក៏គូររូបរាងរបស់ព្រះអង្គផ្ទាល់លើសាច់មនុស្ស ទើបសូម្បីតែអ្វីដែលមើលឃើញក៏មានរូបរាងរបស់ព្រះជាម្ចាស់ដែរ" (សន្តៈ អ៊ីរ៉េណេ)។

## ព្រះវិញ្ញាណនៃព្រះបន្ទូលសន្យា

៧០៥-ទោះបីមនុស្សលោកត្រូវរបួសដោយសារបាប និងសេចក្តីស្លាប់យ៉ាងណាក៏ដោយ ក៏គេនៅតែជា "រូបតំណាងរបស់ព្រះជាម្ចាស់" ជារូបតំណាងរបស់ព្រះបុត្រា ប៉ុន្តែ "គ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ" (រម ៣,២៣) គេលែងមានលក្ខណៈដូចព្រះអង្គទៀតទេ។ ពេលព្រះជាម្ចាស់មានព្រះបន្ទូលសន្យាមកលោក អប្រាហាំ ព្រះអង្គក៏ចាប់ផ្តើមសង្គ្រោះមនុស្សលោកដែលមានព្រះបុត្រានឹងទៅជាមនុស្ស (១យហ ១,៤; ភីល ២,៧) ដើម្បីឲ្យគេទៅជា "រូបតំណាង" របស់ព្រះបិតាវិញ ដោយប្រទានឲ្យគេសិរីរុងរឿង និងព្រះវិញ្ញាណដែល "ផ្តល់ជីវិត"។

៧០៦-ទោះបីគ្មានអ្វីជាទីសង្ឃឹមក៏ដោយ ក៏ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាមកលោក អប្រាហាំ ថានឹងប្រទានពូជពង្សមកលោកដែលជាផលផ្លែនៃជំនឿ និងឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (កណ ១៨,១-១៥; លក ១,២៦-៣៨.៥៤-៥៥; យហ ១,១២-១៣; រម ៤,១៦-២១)។ ព្រះជាម្ចាស់នឹងឲ្យពរដល់ជនទាំងឡាយដោយសារពូជពង្សរបស់លោក (កណ ១២,៣)។ ពូជពង្សនេះ គឺព្រះគ្រីស្ត (កាឡ ៣,១៦) ពោរពេញដោយព្រះវិញ្ញាណដែលនឹងធ្វើឲ្យ "កូនចៅរបស់ព្រះជាម្ចាស់ដែលបែកខ្ញែកគ្នាមកប្រមូលជាប្រជាជនតែមួយ" (យហ ១១,៥២)។ ដោយមានព្រះបន្ទូលសន្យាយ៉ាងមឺងម៉ាត់ (លក ១,៧៣) ព្រះជាម្ចាស់ក៏សុខចិត្តប្រទានព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គរួចហើយ (កណ ២២,១៧-១៩; រម ៨,៣២; យហ ៣,១៦) និងប្រទានព្រះវិញ្ញាណនៃព្រះបន្ទូលសន្យាដែល "បញ្ចាំចិត្តយើងឲ្យដឹងថាយើងនឹងទទួលមរតកនៅពេលព្រះអង្គលោះប្រជារាស្ត្ររបស់ព្រះអង្គ" (អភ ១,១៣-១៤) (កាឡ ៣,១៤)។

## ពេលព្រះជាម្ចាស់សម្តែងព្រះអង្គ និងក្នុងធម្មវិន័យ

៧០៧-ពេលព្រះជាម្ចាស់សម្តែងព្រះអង្គ ព្រះអង្គបំភ្លឺផ្លូវនៃព្រះបន្ទូលសន្យាពីពួកបុព្វបុរសរហូតដល់លោក ម៉ូសេ ហើយពីលោក យ៉ូស៊ូអា រហូតដល់ព្យាការីធំៗដែលសុបិននិមិត្តឃើញព្រះអង្គ។ ការបញ្ជូនបន្តនៃគ្រីស្តសាសនាតែងតែយល់ឃើញថា ពេលព្រះជាម្ចាស់សម្តែងព្រះអង្គតាមបែបនោះ យើងអាចមើលឃើញ និងស្តាប់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលពពកនៃព្រះវិញ្ញាណដ៏វិសុទ្ធសម្តែងផង និង "គ្របបាំង" ផង។

៧០៨-យើងអាចយល់ឃើញអំពីគរុកោសល្យរបស់ព្រះជាម្ចាស់នេះពេលព្រះអង្គប្រទានធម្មវិន័យ (សរ ១៩-២០; ទក ១-១១; ២៩-៣០)។ ព្រះជាម្ចាស់ប្រទានធម្មវិន័យដែលមាន "នាទីណែនាំ" ប្រជារាស្ត្រទៅកាន់ព្រះគ្រីស្ត (កាឡ ៣,២៤)។ ប៉ុន្តែដោយសារធម្មវិន័យមិនអាចសង្គ្រោះមនុស្សលោកដែលលែង "មានលក្ខណៈដូចព្រះជាម្ចាស់" និងលែងស្គាល់អំពីអំពើបាប (រម ៣,២០) មនុស្សលោកក៏ប្រាថ្នាចង់បានព្រះវិញ្ញាណដ៏វិសុទ្ធ ដូចទំនុកតម្កើងផ្តល់សក្ខីភាពដែរ។

## នៅក្នុងព្រះរាជាណាចក្រ និងនៅពេលជនជាតិអ៊ីស្រាអែលនិរទេស

៧០៩-ធម្មវិន័យដែលជាសញ្ញានៃព្រះបន្ទូលសន្យា និងសម្ព័ន្ធមេត្រីត្រូវតែណែនាំចិត្តគំនិត និងរចនាសម្ព័ន្ធនៃប្រជាជនដែលចេញមកពីជំនឿរបស់លោក អប្រាហាំ។ "ប្រសិនបើអ្នករាល់គ្នាស្តាប់តាមពាក្យរបស់យើង ប្រសិនបើអ្នករាល់គ្នាគោរពសម្ព័ន្ធមេត្រីរបស់យើងនោះ (...) យើងចាត់ទុកអ្នករាល់គ្នាជាអាណាចក្របូជាចារ្យ ហើយអ្នករាល់គ្នាជាប្រជាជាតិដ៏វិសុទ្ធ" (សរ ១៩,៥-៦) (១ពត្រ ២,៩)។ ប៉ុន្តែក្រោយពីព្រះបាទដាវីឌ ជនជាតិអ៊ីស្រាអែលចាញ់ការល្បួងចង់ទៅជាព្រះរាជាណាចក្រដូចសាសន៍ដទៃផងដែរ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងតែងតាំងព្រះរាជាណាចក្រ

នេះដែលព្រះជាម្ចាស់មានព្រះបន្ទូលសន្យាមកព្រះបាទដាវីឌ (២សម ៧; ទន ៨៩; លក ១,៣២-៣៣) ហើយដែលនឹងទៅជាកម្មសិទ្ធិរបស់អស់អ្នកដែលពឹងលើព្រះអង្គ។

៧១០-ដោយសារជនជាតិអ៊ីស្រាអែលបានបំភ្លេចធម្មវិន័យ ហើយបានក្បត់សម្ព័ន្ធមេត្រី ទើបគេត្រូវតែស្លាប់ គឺគេត្រូវនិរទេសហាក់ដូចជាព្រះជាម្ចាស់មិនបានសម្រេចព្រះបន្ទូលសន្យារបស់ព្រះអង្គ។ តាមពិតព្រះជាម្ចាស់ជាព្រះសង្គ្រោះនៅតែស្មោះត្រង់នឹងជនជាតិអ៊ីស្រាអែលតាមរបៀបដ៏អាថ៌កំបាំង ហើយព្រះអង្គបានចាប់ផ្តើមកែសម្រួលគេឡើងវិញ ដូចព្រះអង្គមានព្រះបន្ទូលសន្យាទុកជាមុន។ ប៉ុន្តែព្រះជាម្ចាស់នឹងកែសម្រួលគេនោះ តាមព្រះវិញ្ញាណ។ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ត្រូវតែរងទុក្ខលំបាកបែបនេះ (លក ២៤,២៦) គឺគេត្រូវនិរទេស។ ការនិរទេសនេះដូចជាតំណាងទុកជាមុននៃព្រះឈើឆ្កាង តាមគម្រោងការរបស់ព្រះអង្គ ហើយអ្នកក្រីក្រដែលនៅសេសសល់ និងដែលវិលត្រឡប់មកវិញជាតំណាងរបស់ព្រះសហគមន៍។

## ការរង់ចាំព្រះមេស្ស៊ី និងព្រះវិញ្ញាណរបស់ព្រះអង្គ

៧១១-"បន្តិចទៀតយើងនឹងធ្វើឲ្យព្រឹត្តិការណ៍ថ្មីកើតឡើង" (អស ៤៣,១៩)៖ ពួកព្យាការីនឹងធ្វើឲ្យប្រជារាស្ត្រអ៊ីស្រាអែលរង់ចាំព្រះមេស្ស៊ីផង ព្រមទាំងប្រកាសអំពីព្រះវិញ្ញាណថ្មីផង។ ព្រះជាម្ចាស់នឹងបំពេញពព្យាការពីរនោះក្នុងជនជាតិអ៊ីស្រាអែលមួយចំនួនតូចដែលនៅសេសសល់ជាប្រជាជនរបស់អ្នកដែលគ្មានទីពឹង (សផ ២,៣) ដែលទន្ទឹងរង់ចាំពេលព្រះអង្គយាងមក "សម្រាលទុក្ខប្រជារាស្ត្រអ៊ីស្រាអែល" និង "លោះក្រុងយេរូសាឡឹម" (លក ២,២៥.៣៨)។

យើងបានឃើញរួចហើយថា តើព្រះយេស៊ូបំពេញព្យាការទាំងប៉ុន្មានដែលទាក់ទងនឹងព្រះអង្គ។ នៅទីនេះយើងគ្រាន់តែនិយាយអំពីព្យាការដែលទាក់ទងនឹងទំនាក់ទំនងរវាងព្រះមេស្ស៊ី និងព្រះវិញ្ញាណព្រះអង្គ។

៧១២-យើងអាចចាប់ផ្តើមយល់អំពីលក្ខណៈរបស់ព្រះមេស្ស៊ី ដែលជនជាតិអ៊ីស្រាអែលរង់ចាំនៅក្នុងកណ្ឌ "អេម៉ានូអែល" (អស ៦-១២) (ពេល "លោក អេសាយ បានឃើញសិរីរុងរឿង" របស់ព្រះគ្រីស្ត (យហ ១២,៤១)) ជាពិសេសនៅ អស ១១,១-២៖

> មានខ្នែងមួយដុះចេញពីគល់របស់លោក យេសាយ មានដើមថ្មីមួយដុះចេញពីឫសរបស់លោក។ ព្រះវិញ្ញាណរបស់ព្រះអម្ចាស់នឹងសណ្ឋិតនៅលើព្រះបុត្រានោះ គឺជាព្រះវិញ្ញាណដែលផ្តល់ប្រាជ្ញាឲ្យចេះពិចារណាដឹងខុសត្រូវ ព្រះវិញ្ញាណដែលផ្តល់ការឈ្លាសវៃ និងចិត្តអង់អាច ព្រះវិញ្ញាណដែលបំភ្លឺឲ្យស្គាល់ និងគោរពកោតខ្លាចព្រះអម្ចាស់។

៧១៣-បទចម្រៀងរបស់អ្នកបម្រើសម្តែងលក្ខណៈរបស់ព្រះមេស្ស៊ីយ៉ាងច្បាស់ (អស ៤២,១-៩; មថ ១២,១៨-២១; យហ ១,៣២-៣៤ ហើយ អស ៤៩,១-៦; មថ ៣,១៧; លក ២,៣២ ទីបញ្ចប់ អស ៥០, ៤-១០ និង អស ៥២,១៣-៥៣,១២)។ បទចម្រៀងនោះពន្យល់នូវអត្ថន័យនៃទុក្ខលំបាករបស់ព្រះយេស៊ូ និងសម្តែងនូវរបៀបដែលព្រះអង្គនឹងបង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យប្រជាជាតិទាំងឡាយមានជីវិត គឺមិនមែនពីខាងក្រៅ តែដោយយាងមកយក "ឋានៈជាទាសករ" (ភីល ២,៧)។ ដោយសោយទិវង្គតជំនួសយើង ព្រះអង្គក៏អាចផ្តល់ព្រះវិញ្ញាណរបស់ព្រះអង្គផ្ទាល់ជាព្រះវិញ្ញាណនៃជីវិត។

៧១៤-ហេតុនេះហើយបានជាព្រះគ្រីស្តចាប់ផ្តើមប្រកាសដំណឹងល្អតាមអត្ថបទរបស់លោក អេសាយ នេះថា (លក ៤,១៨-១៩) (អស ៦១,១-២)៖

ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ។ ព្រះអង្គបានចាក់ប្រេងអភិសេកឲ្យខ្ញុំនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ព្រះអង្គបានចាត់ខ្ញុំឲ្យមកប្រកាសប្រាប់ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាព ហើយប្រាប់មនុស្សខ្វាក់ថា គេនឹងមើលឃើញវិញ។ ព្រះអង្គបានចាត់ខ្ញុំឲ្យមករំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិន ព្រមទាំងប្រកាសអំពីឆ្នាំដែលព្រះអម្ចាស់សម្តែងព្រហ្មទ័យមេត្តាករុណា។

៧១៥-អត្ថបទរបស់ព្យាការីដែលទាក់ទងនឹងព្រះជាម្ចាស់ចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមក ជាសេចក្តីប្រកាសដែលព្រះជាម្ចាស់មានព្រះបន្ទូលសន្យាក្នុងដួងចិត្តប្រជារាស្ត្ររបស់ព្រះអង្គ "ដោយចិត្តស្រឡាញ់ និងចិត្តស្មោះត្រង់" (អគ ១១,១៩; ៣៦,២៥-២៨; ៣៧,១-១៤; យរ ៣១,៣១-៣៤; និង យអ ៣,១-៥) ហើយដែលសន្តះ សិលា នឹងប្រកាសថាព្រះអង្គបានបំពេញព្រះបន្ទូលសន្យានេះពេលបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក (កក ២,១៧-២១)។ តាមព្រះបន្ទូលសន្យានោះ "ក្នុងពេលចុងក្រោយ" ព្រះវិញ្ញាណរបស់ព្រះអម្ចាស់នឹងឲ្យចិត្តមនុស្សកើតសាជាថ្មីឡើងវិញ ដោយឆ្លាក់វិន័យថ្មីនៅក្នុងគេ ព្រះអង្គនឹងប្រមូល និងសម្រុះសម្រួលប្រជាជាតិដែលបែកខ្ញែក និងបាក់បែកគ្នា ទ្រង់ក៏នឹងកែប្រែការបង្កើតដំបូង ហើយព្រះជាម្ចាស់នឹងរស់នៅជាមួយមនុស្សលោកក្នុងសេចក្តីសុខសាន្ត។

៧១៦-ប្រជារាស្ត្ររបស់ "ជនក្រីក្រ" (សផ ២,៣; ទន ២២,២៧; ៣៤,៣; អស ៤៩,១៣; ៦១,១) អ្នកសុភាពរាបសា និងអ្នកមានចិត្តស្លូតបូតដែលផ្ញើជីវិតទាំងស្រុងក្នុងគម្រោងការដ៏លាក់កំបាំងនៃព្រះជាម្ចាស់របស់គេ អស់អ្នកដែលរង់ចាំយុត្តិធម៌ដែលមិនមែនមកពីមនុស្សទេ តែដែលមកពីព្រះមេស្ស៊ីវិញ ជាស្នាព្រះហស្តដ៏អស្ចារ្យរបស់បេសកកម្មដ៏លាក់លៀមនៃព្រះវិញ្ញាណដ៏វិសុទ្ធក្នុងពេលព្រះជាម្ចាស់មានព្រះបន្ទូលសន្យានៅឡើយ ដើម្បីរៀបចំផ្លូវឲ្យព្រះគ្រីស្តយាងមក។ ទំនុកតម្កើងសម្តែងនូវលក្ខណៈនៃចិត្តគំនិតរបស់គេដែលព្រះវិញ្ញាណបានបន្សុទ្ធ និងបានបំភ្លឺ។ ក្នុងជនក្រីក្រនោះព្រះវិញ្ញាណរៀបចំ "ប្រជារាស្ត្រមួយជាស្រេចទុកសម្រាប់ទទួលព្រះអម្ចាស់" (លក ១,១៧)។

## ៤-ព្រះវិញ្ញាណរបស់ព្រះគ្រីស្តនៅពេលកំណត់

### លោក យ៉ូហានបាទីស្ត ជាអ្នករៀបចំផ្លូវថ្វាយព្រះអម្ចាស់ ជាព្យាការី និងជាអ្នកផ្តល់ពិធីជ្រមុជទឹក

៧១៧-"ព្រះជាម្ចាស់បានចាត់បុរសម្នាក់ឈ្មោះ យ៉ូហាន ឲ្យមក" (យហ ១,៦)។ លោក យ៉ូហាន "ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធតាំងពីក្នុងផ្ទៃម្តាយមក" (លក ១,១៥.៤១) ដោយសារព្រះគ្រីស្តផ្ទាល់ដែលព្រះនាងព្រហ្មចារិនីម៉ារី ទើបប្រសូតពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ពេលនាង ម៉ារី ទៅសួរសុខទុក្ខនាង អេលីសាបិត ហាក់ដូចជាព្រះជាម្ចាស់យាងមកសួរសុខទុក្ខប្រជារាស្ត្ររបស់ព្រះអង្គដែរ (លក ១,៦៨)។

៧១៨-លោក យ៉ូហាន ជាលោក អេលី ដែល "ត្រូវអញ្ជើញមកមុន" (មថ ១៧,១០-១៣)៖ ភ្លើងនៃព្រះវិញ្ញាណគង់នៅក្នុងលោក ហើយធ្វើឲ្យលោក "រត់ខាងមុខ" ព្រះអម្ចាស់ដែលយាងមក។ ក្នុងលោក យ៉ូហាន ជាអ្នករៀបចំផ្លូវថ្វាយព្រះអម្ចាស់ ព្រះវិញ្ញាណដ៏វិសុទ្ធរៀបចំ "ប្រជារាស្ត្រមួយជាស្រេចទុកសម្រាប់ទទួលព្រះអម្ចាស់" (លក ១,១៧)។

៧១៩-លោក យ៉ូហាន "ប្រសើរជាងព្យាការីទៅទៀត" (លក ៧,២៦)។ ក្នុងលោកព្រះវិញ្ញាណបំពេញ "ព្រះបន្ទូលតាមរយៈអស់លោកព្យាការី"។ លោក យ៉ូហាន បញ្ចប់វគ្គនៃពួកព្យាការីដែលលោក អេលី បានចាប់ផ្តើម (មថ ១១,១៣-១៤)។ លោកប្រកាសថាព្រះជាម្ចាស់ហៀបនឹងសម្រាលទុក្ខជនជាតិអ៊ីស្រាអែល លោកជា "សម្លេង" នៃព្រះដ៏លួងលោមដែលយាងមក (យហ ១,២៣) (អស ៤០,១-៣)។ ដូចព្រះវិញ្ញាណនៃសេចក្តីពិត "លោកបានមកធ្វើជាបន្ទាល់ផ្តល់សក្ខីភាពអំពីពន្លឺ" (យហ ១,៧) (យហ ១៥,២៦; ៥,៣៣)។ ចំពោះលោក យ៉ូហាន

ព្រះវិញ្ញាណបំពេញការ "ស្រាវជ្រាវ" របស់អស់លោកព្យាការី និង "ប្រាថ្នាចង់បាន" របស់ពួកទេវទូត (១ពត្រ ១,១០-១២)៖ "អ្នកឃើញព្រះវិញ្ញាណយាងចុះមកសណ្ឋិតលើអ្នកណា គឺអ្នកនោះហើយដែលធ្វើពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ខ្ញុំបានឃើញហើយ ខ្ញុំសូមបញ្ជាក់ថាលោកនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន (...) លោកនេះហើយជាកូនចៀមរបស់ព្រះជាម្ចាស់" (យហ ១,៣៣-៣៦)។

៧២០-ទីបញ្ចប់ជាមួយលោក យ៉ូហានបាទីស្ដ ព្រះវិញ្ញាណដ៏វិសុទ្ធចាប់ផ្ដើមទុកជាមុននូវអ្វីៗដែលព្រះអង្គនឹងធ្វើជាមួយព្រះគ្រីស្ដ និងក្នុងអង្គព្រះអង្គ គឺផ្ដល់ឲ្យមនុស្សមាន "លក្ខណៈដូចព្រះជាម្ចាស់" ឡើងវិញ។ លោក យ៉ូហានធ្វើពិធីជ្រមុជឲ្យគេកែប្រែចិត្តគំនិត ឯព្រះអង្គនឹងធ្វើពិធីជ្រមុជក្នុងទឹក និងព្រះវិញ្ញាណដើម្បីឲ្យគេកើតសាជាថ្មី (យហ ៣,៥)។

### "ចូរមានអំណរសប្បាយឡើង! ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងនាងហើយ!"

៧២១-នាងម៉ារីជាព្រះមាតាដ៏វិសុទ្ធបំផុតរបស់ព្រះជាម្ចាស់ នៅតែព្រហ្មចារីជាស្នាព្រះហស្ដរបស់បេសកកម្មរួមនៃព្រះបុត្រា និងព្រះវិញ្ញាណក្នុងពេលកំណត់។ ជាលើកទីមួយក្នុងគម្រោងការនៃការសង្គ្រោះ ដោយសារព្រះវិញ្ញាណបានរៀបចំនាង ហើយព្រះបិតារកឃើញព្រះដំណាក់ដែលព្រះបុត្រា និងព្រះវិញ្ញាណរបស់ព្រះអង្គអាចរស់នៅក្នុងចំណោមមនុស្សលោកបាន។ ហេតុនេះហើយបានជាការបញ្ចូនបន្ដព្រះសហគមន៍បានអានអត្ថបទពិរោះជាងគេនៃព្រះប្រាជ្ញាញាណ (សុភ ៨,១-៩,៦; បសរ ២៤) ដោយសំដៅលើព្រះនាងម៉ារី គឺក្នុងពិធីបុណ្យព្រះសហគមន៍ច្រៀង និងយកព្រះនាងម៉ារីជារូបតំណាងនៃ "បល្ល័ង្ករបស់ព្រះប្រាជ្ញាញាណ"។ ក្នុងនាងម៉ារីព្រះវិញ្ញាណចាប់ផ្ដើមសម្ដែង "កិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់" ដែលព្រះអង្គនឹងបំពេញក្នុងព្រះគ្រីស្ដ និងក្នុងព្រះសហគមន៍។

៧២២-ព្រះហឫទ័យប្រណីសន្ដោសនៃព្រះវិញ្ញាណដ៏វិសុទ្ធបានរៀបចំនាងម៉ារី។ ព្រះមាតារបស់ព្រះគ្រីស្ដដែលមាន "គ្រប់លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់" "នៅក្នុងព្រះកាយព្រះអង្គ" (កូឡ ២,៩) ត្រូវតែពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ ដោយសារព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ នាងម៉ារីមិនជំពាក់បាបតាំងពីកំណើតមកជាសត្វលោកតូចតាចជាងគេដែលអាចទទួលព្រះអំណោយទានដ៏លើសលប់របស់ព្រះដ៏មានឫទ្ធានុភាពសព្វប្រការ។ ហេតុនេះទេវទូតកាព្រីអែលជម្រាបសួរនាងជា "បុត្រីរបស់ក្រុងស៊ីយ៉ូន"៖ "ចូរមានអំណរសប្បាយឡើង!" (សផ ៣,១៤; សក ២,១៤)។ ពេលនាងមាននៅក្នុងខ្លួនព្រះបុត្រាអស់កល្បជានិច្ច បទចម្រៀងរបស់នាង (លក ១,៤៦-៥៥) លើកពាក្យអរព្រះគុណរបស់ប្រជាជនព្រះជាម្ចាស់ និងរបស់ព្រះសហគមន៍ឡើងទៅកាន់ព្រះបិតាក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ។

៧២៣-ក្នុងនាងម៉ារីព្រះវិញ្ញាណដ៏វិសុទ្ធសម្រេចគម្រោងការដ៏សប្បុរសរបស់ព្រះបិតា។ នាងព្រហ្មចារីប្រសូត និងសម្រាលព្រះបុត្រារបស់ព្រះជាម្ចាស់ជាមួយ និងដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ។ ដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណ និងជំនឿ (លក ១,២៦-២៨; រម ៤,១៨-២១; កាឡ ៤,២៦-២៨) នាងម៉ារីជាស្ដ្រីព្រហ្មចារីបង្កើតផលតាមរបៀបតែមួយគត់។

៧២៤-ក្នុងនាងម៉ារីព្រះវិញ្ញាណដ៏វិសុទ្ធសម្ដែងព្រះបុត្រារបស់ព្រះបិតា ដែលបានទៅជាបុត្រារបស់ព្រហ្មចារិនី។ នាងជាគុម្ពោតដែលដុតមិនឆេះ ដែលព្រះជាម្ចាស់សម្ដែងព្រះអង្គជាលើកចុងក្រោយ៖ ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ នាងបង្ហាញព្រះបន្ទូលក្នុងសាច់នាង ហើយសម្ដែងព្រះអង្គឲ្យអ្នកដែលគ្មានទីពឹង (លក ១,១៥-១៩) និងផលផ្លែដំបូងនៃជាតិសាសន៍ដទៃស្គាល់ (មថ ២,១១)។

៧២៥-ទីបញ្ចប់តាមរយៈនាងម៉ារីព្រះវិញ្ញាណដ៏វិសុទ្ធធ្វើឲ្យមនុស្សលោក "ដ៏ជាទីស្រឡាញ់" របស់ព្រះជាម្ចាស់ (លក ២,១៤) រួមរស់ជាមួយព្រះគ្រីស្ត ហើយអ្នកតូចតាចជាអ្នកទទួលព្រះអង្គមុនគេ គឺពួកគង្វាល ពួកហោរាចារ្យ លោកតា ស៊ីម៉ូន នាង ហណ្ណាប្តីប្រពន្ធនៅស្រុកកាណា និងសាវ័កដំបូង។

៧២៦-នៅទីបញ្ចប់នៃបេសកកម្មរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ នាងម៉ារីទៅជា "មនុស្សស្រី" ជានាង អេវ៉ា ថ្មី "មាតារបស់មនុស្សទាំងអស់ដែលមានជីវិត" មាតារបស់ "ព្រះគ្រីស្តដែលមានគ្រប់លក្ខណៈសម្បត្តិ" ហើយក្នុងឋានៈនោះ នាងនៅជាមួយគ្រីស្តទូតដប់ពីររូប "រួមចិត្តគំនិតគ្នាព្យាយាមអធិដ្ឋាន" (កក ១,១៤) នៅ "ពេលចុងក្រោយបំផុត" ដែលព្រះវិញ្ញាណនឹងចាប់ផ្តើមពេលព្រះអង្គនឹងយាងមកដោយសម្តែងព្រះសហគមន៍។

## ព្រះគ្រីស្តយេស៊ូ

៧២៧-បេសកកម្មទាំងអស់របស់ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធនៅពេលកំណត់ គឺព្រះបុត្រាបានទទួលប្រេងអភិសេកនៃព្រះវិញ្ញាណរបស់ព្រះបិតាតាំងពីព្រះអង្គបានកើតជាមនុស្សមក៖ ព្រះយេស៊ូជាព្រះគ្រីស្ត ជាព្រះមេស្ស៊ី។ ត្រូវតែអានជំពូកទីពីរទាំងអស់នៃធម៌ប្រកាសជំនឿក្រោមពន្លឺនេះ។ ព្រះរាជកិច្ចទាំងអស់របស់ព្រះគ្រីស្តជាបេសកកម្មរួមរបស់ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅទីនេះយើងនឹងនិយាយតែអំពីអ្វីដែលទាក់ទងនឹងព្រះបន្ទូលសន្យារបស់ព្រះយេស៊ូ អំពីព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះអំណោយទានរបស់ព្រះវិញ្ញាណដែលព្រះអម្ចាស់ពោរពេញដោយសិរីរុងរឿងបានប្រោសប្រទាន។

៧២៨-ព្រះយេស៊ូមិនសម្តែងព្រះវិញ្ញាណដ៏វិសុទ្ធឲ្យបានពេញលេញ ទាល់តែព្រះអង្គបានទទួលសិរីរុងរឿងដោយសោយទិវង្គត និងមានព្រះជន្មថ្មី។ ក៏ប៉ុន្តែព្រះអង្គមានព្រះបន្ទូលជាសម្ងាត់អំពីព្រះវិញ្ញាណបន្តិចម្តងៗ ពេលព្រះអង្គបង្រៀនបណ្តាជន ពេលព្រះអង្គសម្តែងថាសាច់របស់ព្រះអង្គជាអាហារដែលផ្តល់ជីវិតសម្រាប់មនុស្សលោក (យហ ៦,២៧.៥១.៦២-៦៣)។ ព្រះអង្គមានព្រះបន្ទូលជាសម្ងាត់អំពីព្រះវិញ្ញាណជាមួយលោក នីកូដេម (យហ ៣,៥-៨) ស្ត្រីសាសន៍សាម៉ារី (យហ ៤,១០.១៤.២៣-២៤) និងជាមួយអស់អ្នកដែលចូលរួមក្នុងបុណ្យបារាំ (យហ ៧,៣៧-៣៩)។ ព្រះអង្គមានព្រះបន្ទូលយ៉ាងច្បាស់លាស់អំពីព្រះវិញ្ញាណជាមួយក្រុមសាវ័ក ពេលព្រះអង្គប្រៀនប្រដៅគេអំពីការអធិដ្ឋាន (លក ១១,១៣) និងអំពីសក្ខីភាពដែលគេនឹងត្រូវផ្តល់ (មថ ១០,១៩-២០)។

៧២៩-មានតែពេលកំណត់មកដល់ ទើបជាពេលដែលព្រះយេស៊ូនឹងទទួលសិរីរុងរឿងដែលព្រះអង្គមានព្រះបន្ទូលសន្យាថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមក ដ្បិតពេលព្រះអង្គនឹងសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ព្រះជាម្ចាស់នឹងបំពេញព្រះបន្ទូលសន្យារបស់ព្រះអង្គចំពោះបុព្វបុរស (យហ ១៤,១៦-១៧.២៦)៖ ដោយសារព្រះយេស៊ូទូលអង្វរព្រះបិតា ព្រះអង្គនឹងប្រទានវិញ្ញាណនៃសេចក្តីពិតជាព្រះជួយការពារ។ ព្រះបិតានឹងចាត់ព្រះវិញ្ញាណឲ្យមកក្នុងនាមព្រះយេស៊ូ។ ព្រះយេស៊ូនឹងចាត់ព្រះវិញ្ញាណពីព្រះបិតាមក ដ្បិតព្រះវិញ្ញាណចេញមកពីព្រះបិតា។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមក យើងក៏នឹងស្គាល់ព្រះអង្គ ព្រះអង្គនឹងគង់នៅជាមួយយើងជារៀងរហូត ទ្រង់ក៏នឹងស្ថិតនៅជាមួយយើង។ ព្រះវិញ្ញាណនឹងប្រៀនប្រដៅយើងអំពីអ្វីៗទាំងអស់ និងរំឭកយើងនូវអ្វីៗដែលព្រះគ្រីស្តមានព្រះបន្ទូលមកយើង ហើយព្រះអង្គនឹងផ្តល់សក្ខីភាពអំពីព្រះគ្រីស្ត។ ព្រះវិញ្ញាណនឹងនាំយើងឆ្ពោះទៅសេរីភាពគ្រប់ជំពូក និងផ្តល់សិរីរុងរឿងដល់ព្រះគ្រីស្តផងដែរ។ រីឯចំពោះលោកីយ៍វិញ ព្រះវិញ្ញាណនឹងបញ្ជាក់ឲ្យមនុស្សលោកដឹងថា គេយល់ខុសអំពីបាប អំពីសេចក្តីសុចរិត និងអំពីការកាត់ទោស។

៧៣០-ទីបំផុត ពេលកំណត់របស់ព្រះយេស៊ូមកដល់ (យហ ១៣,១; ១៧,១)៖ ព្រះយេស៊ូប្រគល់វិញ្ញាណ

របស់ព្រះអង្គក្នុងព្រះហស្តព្រះបិតា (លក ២៣,៤៦; យហ ១៩,៣០) ពេលព្រះអង្គសោយទិវង្គត។ ដោយសារព្រះអង្គសោយទិវង្គត ទ្រង់ក៏ឈ្នះសេចក្តីស្លាប់ទើប "ព្រះគ្រីស្តមានព្រះជន្មថ្មីដោយសារសិរីរុងរឿងរបស់ព្រះបិតា" (រម ៦,៤) ទ្រង់ក៏ប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធភ្លាមដោយ "ផ្លុំ" លើក្រុមសាវ័ក (យហ ២០,២២)។ ចាប់ពីពេលកំណត់នោះមក បេសកកម្មរបស់ព្រះគ្រីស្ត និងព្រះវិញ្ញាណទៅជាបេសកកម្មរបស់ព្រះសហគមន៍៖ "ដូចព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅយ៉ាងនោះដែរ" (យហ ២០,២១) (មថ ២៨,១៩; លក ២៤,៤៧-៤៨; កក ១,៨)។

## ៥-ព្រះវិញ្ញាណ និងព្រះសហគមន៍ក្នុងពេលចុងក្រោយបំផុត

### បុណ្យព្រះវិញ្ញាណយាងមក

៧៣១-ថ្ងៃបុណ្យព្រះវិញ្ញាណយាងមក (ប្រាំពីរសប្តាហ៍ក្រោយពីបុណ្យចម្លង) ព្រះជាម្ចាស់សម្តែងផ្តល់ និងប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះមួយអង្គដែលបំពេញបុណ្យចម្លងរបស់ព្រះគ្រីស្ត គឺព្រះគ្រីស្តជាព្រះអម្ចាស់ដ៏មានគ្រប់លក្ខណៈសម្បត្តិ ចាក់បង្ហូរព្រះវិញ្ញាណឲ្យបានពេញបរិបូណ៌ (កក ២,៣៦)។

៧៣២-នៅថ្ងៃនោះព្រះជាម្ចាស់សម្តែងព្រះត្រៃឯកដ៏វិសុទ្ធឲ្យបានពេញលេញ។ តាំងពីថ្ងៃនោះមក ព្រះជាម្ចាស់បើកព្រះរាជ្យដែលព្រះគ្រីស្តបានប្រកាសឲ្យអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ គឺទោះបីពួកគេទន់ខ្សោយនៅឡើយក៏ពួកគេរួមរស់ជាមួយព្រះត្រៃឯកដ៏វិសុទ្ធដោយសារជំនឿ។ ដោយសារព្រះវិញ្ញាណបានយាងមក និងនៅតែយាងមកព្រះអង្គបញ្ចូលមនុស្សលោកក្នុង "ពេលចុងក្រោយបំផុត" ជាពេលនៃព្រះសហគមន៍ ជាព្រះរាជ្យទទួលទុកជាមរតកតែមិនទាន់ចែកឲ្យនៅឡើយ។

> យើងបានឃើញពន្លឺយ៉ាងពិតប្រាកដ យើងបានទទួលព្រះវិញ្ញាណនៃស្ថានបរមសុខ យើងបានរកឃើញជំនឿដ៏ពិតប្រាកដ៖ យើងក្រាបថ្វាយបង្គំព្រះត្រៃឯកដែលមើលមិនឃើញ ដ្បិតគឺព្រះត្រៃឯកនេះហើយដែលបានសង្គ្រោះយើង។

### ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះអំណោយទានរបស់ព្រះជាម្ចាស់

៧៣៣-"ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់" (១យហ ៤,៨.១៦) ហើយសេចក្តីស្រឡាញ់ជាព្រះអំណោយទានដំបូងដែលមានអំណោយទានផ្សេងៗទាំងអស់។ "ព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គមកក្នុងដួងចិត្តយើងដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង" (រម ៥,៥)។

៧៣៤-ដោយសារបាបយើងស្លាប់ ឬយ៉ាងហោចណាស់យើងត្រូវរបួសផលដំបូងនៃព្រះអំណោយទានរបស់សេចក្តីស្រឡាញ់រំដោះយើងឲ្យរួចចាកពីអំពើបាប។ ពេលអស់អ្នកដែលបានជ្រមុជទឹករួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ (២ករ ១៣,១៣) នៅក្នុងព្រះសហគមន៍ព្រះជាម្ចាស់ក៏ប្រទានដល់អ្នកទាំងអស់នោះឲ្យមានលក្ខណៈរបស់ព្រះអង្គឡើងវិញដែលគេបានបាត់បង់ដោយសារបាប។

៧៣៥-សេចក្តីស្រឡាញ់ផ្តល់ផលផ្លែដំបូងនៃមរតកយើង (រម ៨,២៣; ២ករ ១,២១) គឺព្រះជន្មផ្ទាល់របស់ព្រះត្រៃឯកដ៏វិសុទ្ធបានសេចក្តីថាស្រឡាញ់ "ដូចព្រះអង្គបានស្រឡាញ់យើង" (១យហ ៤,១១-១២)។ សេចក្តីស្រឡាញ់នេះ (សេចក្តីស្រឡាញ់របស់ ១ករ ១៣) ជាគោលនៃជីវិតថ្មីក្នុងអង្គព្រះគ្រីស្តដែលយើងអាចទទួលបានដ្បិតយើងបាន "ទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ" (កក ១,៨)។

៧៣៦-ដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណបុត្រធីតារបស់ព្រះជាម្ចាស់អាចបង្កើតផលបាន។ អ្នកដែលបានបំប៉ៅយើងនៅលើដើមទំពាំងបាយជូរដ៏ពិតប្រាកដនឹងធ្វើឲ្យយើងបង្កើតផលនៃព្រះវិញ្ញាណ ពោលគឺ "សេចក្ដីស្រឡាញ់ អំណរ សេចក្ដីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្ដោសមេត្តាជំនឿ ចិត្តស្លូតបូត ចេះទប់ចិត្តខ្លួនឯង" (កាឡ ៥,២២-២៣)។ "យើងមានជីវិតដោយសារព្រះវិញ្ញាណ" ពេលយើងលះបង់ខ្លួនឯងចោលកាន់តែច្រើនទៅៗ (មថ ១៦,២៤-២៦) "យើងក៏ត្រូវប្រតិបត្តិតាមព្រះវិញ្ញាណ" (កាឡ ៥,២៥) កាន់តែច្រើនទៅៗដែរ។

> ដោយរួមរស់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះអង្គប្រោសយើងឲ្យទៅជាសត្វលោកខាងវិញ្ញាណឲ្យឡើងទៅស្ថានបរមសុខ ចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ និងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។ ព្រះអង្គប្រោសយើងឲ្យហ៊ានហៅព្រះជាម្ចាស់ថា ព្រះបិតាឲ្យចូលរួមក្នុងសិរីរុងរឿងរបស់ព្រះគ្រីស្តទៅជាបុត្រធីតានៃពន្លឺ និងទទួលសិរីរុងរឿងអស់កល្បជានិច្ច (សន្ត: បាស៊ីល)។

## ព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះសហគមន៍

៧៣៧-បេសកកម្មរបស់ព្រះគ្រីស្ត និងព្រះវិញ្ញាណដ៏វិសុទ្ធសម្រេចក្នុងព្រះសហគមន៍ ជាព្រះកាយព្រះគ្រីស្ត និងជាព្រះដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ បេសកកម្មរួមនេះធ្វើឲ្យគ្រីស្តបរិស័ទចូលរួមជាមួយព្រះគ្រីស្តដែលរួមរស់ជាមួយព្រះបិតាក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះវិញ្ញាណរៀបចំមនុស្សលោកដោយព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ ដើម្បីទាក់ទាញគេទៅរកព្រះគ្រីស្ត។ ព្រះវិញ្ញាណសម្ដែងព្រះអម្ចាស់ដែលមានព្រះជន្មថ្មីទ្រង់រំឭកឲ្យគេព្រះបន្ទូលរបស់ព្រះអង្គ និងធ្វើឲ្យគេយល់ពីអាថ៌កំបាំងរបស់ព្រះគ្រីស្តដែលបានសោយទិវង្គត និងមានព្រះជន្មថ្មី។ ព្រះវិញ្ញាណក៏ប្រោសឲ្យព្រះគ្រីស្តគង់នៅ ជាពិសេសក្នុងអភិបូជាដើម្បីឲ្យមនុស្សលោកសម្រុះសម្រួលជាមួយព្រះជាម្ចាស់ និងឲ្យគេរួមរស់ជាមួយព្រះអង្គទើបគេនឹង "បង្កើតផលបានច្រើន" (យហ ១៥,៥.៨.១៦)។

៧៣៨-ហេតុដូច្នេះហើយបានជាបេសកកម្មរបស់ព្រះសហគមន៍មិនបន្ថែមបេសកកម្មរបស់ព្រះគ្រីស្ត និងព្រះវិញ្ញាណដ៏វិសុទ្ធតែជាអគ្គសញ្ញានៃបេសកកម្មនោះ៖ ព្រះជាម្ចាស់ចាត់ព្រះសហគមន៍ទាំងមូល ឲ្យទៅប្រកាស និងផ្ដល់សក្ខីភាពអំពីព្រះត្រៃឯក (ប្រធានបទនៃប្រការបន្ទាប់)។

> យើងទាំងអស់គ្នា ដែលបានទទួលព្រះវិញ្ញាណតែមួយដូចៗគ្នា ពោលគឺព្រះវិញ្ញាណដ៏វិសុទ្ធ យើងបានរួបរួមជាមួយគ្នា និងជាមួយព្រះជាម្ចាស់ ដ្បិតទោះជាយើងមានគ្នាច្រើន ដោយឡែកពីគ្នា ហើយទោះបីព្រះគ្រីស្តធ្វើឲ្យព្រះវិញ្ញាណនៃព្រះបិតា និងព្រះវិញ្ញាណរបស់ព្រះអង្គ គង់នៅក្នុងយើងគ្រប់ៗរូបយ៉ាងណាក៏ដោយ ក៏ព្រះវិញ្ញាណតែមួយនេះ ដែលមិនអាចបែងចែកបានបង្រួបបង្រួមអស់អ្នកដែលខុសប្លែកពីគ្នា ដោយផ្ទាល់ (...) និងធ្វើឲ្យគេទាំងអស់គ្នាទៅជាធ្លុងតែមួយ ក្នុងអង្គព្រះអង្គ។ ជាមួយគ្នានេះដែរ ឫទ្ធានុភាពនៃជាតិជាមនុស្សដ៏វិសុទ្ធរបស់ព្រះគ្រីស្ត ធ្វើឲ្យអស់អ្នកដែលរួមរស់ជាមួយព្រះអង្គឲ្យទៅជារូបកាយតែមួយយ៉ាងណា ខ្ញុំគិតថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលគង់នៅក្នុងមនុស្សទាំងអស់ ជាព្រះវិញ្ញាណតែមួយ ដែលមិនអាចបែងចែក បានបង្រួបបង្រួមគេទាំងអស់គ្នាឲ្យរួមជាមួយគ្នាជាធ្លុងខាងវិញ្ញាណតែមួយ (សន្ត: ស៊ីរីល នៃអាឡិចសង់ឌ្រី)។

៧៣៩-ដោយសារព្រះវិញ្ញាណជាប្រេងអភិសេករបស់ព្រះគ្រីស្ត ព្រះគ្រីស្តជាព្រះសិរសានៃព្រះកាយ ចាក់បង្ហូរព្រះវិញ្ញាណក្នុងអវយវៈរបស់ព្រះអង្គ ដើម្បីចិញ្ចឹមព្យាបាល និងចាត់ចែងគេតាមមុខងាររៀងៗខ្លួនផ្ដល់ជីវិតឲ្យគេចាត់ឲ្យគេទៅផ្ដល់សក្ខីភាព ប្រោសគេឲ្យចូលរួមក្នុងតង្វាយរបស់ព្រះអង្គចំពោះព្រះបិតា និងក្នុងការជួយអង្វរព្រះ

អង្គចំពោះពិភពលោកទាំងមូល។ ព្រះគ្រីស្តប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គដែលប្រោសឲ្យបានវិសុទ្ធដល់អវយវៈនៃព្រះកាយព្រះអង្គតាមរយៈអគ្គសញ្ញា (វគ្គទីពីរនៃសៀវភៅនេះ)។

៧៤០-"ការអស្ចារ្យទាំងប៉ុន្មានរបស់ព្រះជាម្ចាស់" ដែលព្រះអង្គប្រោសប្រទានឲ្យអ្នកជឿក្នុងអគ្គសញ្ញាព្រះសហគមន៍បង្កើតផលក្នុងជីវិតថ្មីក្នុងអង្គព្រះគ្រីស្តតាមព្រះវិញ្ញាណ (វគ្គទីបីនៃសៀវភៅនេះ)។

៧៤១-"ព្រះវិញ្ញាណក៏យាងមកជួយយើងដែលទន់ខ្សោយនេះដែរ ដ្បិតយើងពុំដឹងអធិដ្ឋានដូចម្ដេច ដើម្បីឲ្យបានសមនោះឡើយ តែព្រះវិញ្ញាណផ្ទាល់ ទ្រង់ទូលអង្វរយើងដោយព្រះសូរសៀងដែលគ្មាននរណាអាចថ្លែងបាន" (រម ៨,២៦)។ ព្រះវិញ្ញាណដ៏វិសុទ្ធជាសិប្បករនៃស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ជាម្ចាស់នៃការអធិដ្ឋាន (វគ្គទីបួននៃសៀវភៅនេះ)។

## សង្ខេប

៧៤២-"បងប្អូនពិតជាបុត្រធីតារបស់ព្រះជាម្ចាស់មែន ព្រោះព្រះអង្គបានចាត់ព្រះវិញ្ញាណនៃព្រះបុត្រារបស់ព្រះអង្គឲ្យមកសណ្ឋិតក្នុងចិត្តយើង គឺព្រះវិញ្ញាណនេះហើយ ដែលបន្លឺព្រះសូរសៀងឡើងថា "អប្បា! ឱព្រះបិតា!" (កាឡ ៤,៦)។

៧៤៣-តាំងពីដើមដំបូងរហូតដល់ទីចុងក្រោយបំផុត នៅពេលដែលព្រះជាម្ចាស់ចាត់ព្រះបុត្រារបស់ព្រះអង្គ ឲ្យយាងមក ព្រះអង្គក៏តែងតែចាត់ព្រះវិញ្ញាណរបស់ព្រះអង្គឲ្យយាងមកដែរ គឺយើងមិនអាចបំបែក បេសកកម្មរបស់ព្រះបុត្រា និងព្រះវិញ្ញាណដែលរួបរួមជាមួយគ្នាបានទេ។

៧៤៤-នៅពេលកំណត់ ព្រះវិញ្ញាណដ៏វិសុទ្ធបំពេញក្នុងព្រះនាងម៉ារី ការរៀបចំទុកជាមុនទាំងអស់ឲ្យព្រះគ្រីស្តយាងមកក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ ដោយសារកិច្ចការនៃព្រះវិញ្ញាណដ៏វិសុទ្ធក្នុងខ្លួនព្រះនាង ព្រះបិតាប្រទានអេម៉ានូអែល "ព្រះជាម្ចាស់គង់ជាមួយយើង" (មថ ១,២៣) ឲ្យពិភពលោក។

៧៤៥-ព្រះវិញ្ញាណដ៏វិសុទ្ធអភិសេកតែងតាំងព្រះបុត្រារបស់ព្រះជាម្ចាស់ឲ្យទៅជាព្រះគ្រីស្ត (ព្រះមេស្ស៊ី) នៅពេលព្រះអង្គប្រសូតជាមនុស្ស (ទន ២,៦-៧)។

៧៤៦-ព្រះជាម្ចាស់តែងតាំងព្រះយេស៊ូដោយការសោយទិវង្គត និងមានព្រះជន្មថ្មី ឲ្យទៅជាព្រះអម្ចាស់ និងព្រះគ្រីស្តពោរពេញដោយសិរីរុងរឿង (កក ២,៣៦)។ ដោយសារព្រះអង្គគ្រប់លក្ខណៈ ព្រះអង្គក៏ចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធទៅលើក្រុមគ្រីស្តទូត និងលើព្រះសហគមន៍ផងដែរ។

៧៤៧-ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះគ្រីស្តជាព្រះសិរសាចាក់បង្ហូរលើសិរីរាង្គរបស់ព្រះអង្គ កសាង ណែនាំ និងប្រោសព្រះសហគមន៍ឲ្យបានវិសុទ្ធ។ ព្រះសហគមន៍ជាអគ្គសញ្ញានៃការរួបរួមរវាងព្រះត្រៃឯក និងមនុស្សលោក។

# ប្រការទី៩៖

## "ខ្ញុំជឿថា ព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ"

៧៤៨-ធម្មនុញ្ញគោលលទ្ធិរបស់មហាសន្និបាតវ៉ាទីកង់ទីពីរអំពីព្រះសហគមន៍ចាប់ផ្ដើមប្រកាសថា៖ "ព្រះគ្រីស្តជាពន្លឺបំភ្លឺប្រជាជាតិនានា។ អស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ សង្វាតចង់ផ្សព្វផ្សាយ

ពន្លឺរបស់ព្រះគ្រីស្ត ដែលចែងលើមុខព្រះសហគមន៍ ដោយប្រកាសដំណឹងល្អឲ្យសត្វលោកទាំងឡាយបានដឹង"។ មហាសន្និបាតបង្ហាញថាប្រការនៃធម៌ប្រកាសជំនឿអំពីព្រះសហគមន៍ពឹងផ្អែកទាំងស្រុងលើប្រការទាំងប៉ុន្មានដែលទាក់ទងនឹងព្រះគ្រីស្តយេស៊ូ។ ព្រះសហគមន៍គ្មានពន្លឺផ្សេងក្រៅពីព្រះគ្រីស្ត គឺតាមពាក្យបុរាណរបស់គ្រូបាធ្យាយព្រះសហគមន៍ប្រៀបធៀបដូចជាព្រះច័ន្ទដែលពន្លឺទាំងស្រុងមកពីព្រះអាទិត្យ។

៧៤៩-ប្រការអំពីព្រះសហគមន៍ពឹងផ្អែកទាំងស្រុងលើប្រការអំពីព្រះវិញ្ញាណដ៏វិសុទ្ធដែលមានចែងទុកជាមុន។ "ក្រោយពីបានបង្ហាញថាព្រះវិញ្ញាណដ៏វិសុទ្ធជាប្រភព និងជាអ្នកប្រទានភាពដ៏វិសុទ្ធនានា យើងក៏ប្រកាសថា ព្រះអង្គបានប្រទានភាពដ៏វិសុទ្ធឲ្យព្រះសហគមន៍" (CR)។ តាមគ្រូបាធ្យាយព្រះសហគមន៍ជាកន្លែង "ដែលព្រះវិញ្ញាណរីកចម្រើន" (សន្ត: អ៊ីប៉ូលីត)។

៧៥០-ពេលយើងជឿលើព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ យើងក៏ត្រូវតែជឿថា ព្រះសហគមន៍ "ដ៏វិសុទ្ធ" "កាតូលិក" "តែមួយ" និង "ដែលបន្តជំនឿពីក្រុមគ្រីស្តទូត" (ធម៌ប្រកាសជំនឿមហាសន្និបាតនិសេ/កុងស្តង់ទីណូប)។ ក្នុងធម៌ប្រកាសជំនឿដែលមកពីគ្រីស្តទូតទាំងឡាយ យើងប្រកាសថា យើងជឿថា ព្រះសហគមន៍ដ៏វិសុទ្ធ ("Credo [...] Ecclesiam") ប៉ុន្តែយើងមិនជឿលើព្រះសហគមន៍កុំឲ្យច្រឡំព្រះជាម្ចាស់ និងស្នាព្រះហស្តរបស់ព្រះអង្គ ហើយដើម្បីយល់យ៉ាងច្បាស់ថា ព្រះអំណោយទានទាំងអស់ដែលព្រះជាម្ចាស់បានប្រទានឲ្យព្រះសហគមន៍មកពីសប្បុរសធម៌របស់ព្រះអង្គ (CR)។

## កថាខណ្ឌទី១៖ ព្រះសហគមន៍តាមគម្រោងការរបស់ព្រះជាម្ចាស់

### ១-នាម និងរូបរបស់ព្រះសហគមន៍

៧៥១-ពាក្យ "ព្រះសហគមន៍" [ekklesia, ជាភាសាក្រិក ek-kalein "ហៅខាងក្រៅ"] មានន័យថា៖ "ការត្រាស់ហៅ"។ ពាក្យនេះសំដៅទៅលើអង្គប្រជុំនៃប្រជាជន (កក ១៩,៣៩) ដែលជាធម្មតាទាក់ទងនឹងសាសនា។ ព្រះគម្ពីរសម្ពន្ធមេត្រីចាស់ជាភាសាក្រិកឧស្សាហ៍ប្រើពាក្យនេះ ដើម្បីសំដៅទៅលើអង្គប្រជុំរបស់ប្រជាជនដែលព្រះជាម្ចាស់បានជ្រើសរើស ជាពិសេសអង្គប្រជុំនៅលើភ្នំស៊ីណៃ ដែលប្រជាជនអ៊ីស្រាអែលបានទទួលធម្មវិន័យ និងបានទៅជាប្រជាជនដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ (សរ ១៩)។ ដោយដាក់ឈ្មោះខ្លួនឯងថា "ព្រះសហគមន៍" សហគមន៍ដំបូងរបស់អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្តទទួលស្គាល់ថា ជាអ្នកបន្តអង្គប្រជុំនេះ។ នៅក្នុងព្រះសហគមន៍ព្រះជាម្ចាស់ "ត្រាស់ហៅ" ប្រជាជនរបស់ព្រះអង្គពីគ្រាប់ទិសទីនៃផែនដី។ ពាក្យ Church,Kirche ដែលមកពី Kyriake មានន័យថា "អ្នកដែលជាកម្មសិទ្ធិរបស់ព្រះអម្ចាស់"។

៧៥២-ក្នុងភាសារបស់គ្រីស្តបរិស័ទពាក្យ "ព្រះសហគមន៍" សំដៅទៅលើអង្គប្រជុំនៃពិធីបុណ្យផង (១ករ ១១,១៨) សហគមន៍នៅភូមិមួយផង (១ករ ១,២) ឬសហគមន៍ទាំងមូលរបស់អ្នកជឿ (១ករ ១៥,៩) ហើយយើងមិនអាចបំបែកអត្ថន័យទាំងបីនោះចេញពីគ្នាបានឡើយ។ "ព្រះសហគមន៍" គឺប្រជាជនដែលព្រះជាម្ចាស់ប្រមូលក្នុងពិភពលោកទាំងមូល។ ព្រះសហគមន៍រស់នៅក្នុងសហគមន៍ភូមិនីមួយៗ ហើយទៅជាព្រះសហគមន៍យ៉ាងពេញលេញក្នុងអង្គប្រជុំខាងពិធីបុណ្យ ជាពិសេសពេលថ្វាយអភិបូជា។ ព្រះសហគមន៍រស់ដោយសារព្រះបន្ទូល និងព្រះកាយព្រះគ្រីស្ត ទើបទៅជាព្រះកាយព្រះគ្រីស្តផ្ទាល់។

## និមិត្តរូបនៃព្រះសហគមន៍

៧៥៣-ក្នុងព្រះគម្ពីរដ៏វិសុទ្ធព្រះជាម្ចាស់សម្ដែងនូវគម្រោងការដ៏លាក់កំបាំងនៃព្រះសហគមន៍ដោយប្រើរូប និង និមិត្តសញ្ញាជាច្រើនដែលជាប់ទាក់ទិននឹងគ្នា។ ទោះបីរូបទាំងប៉ុន្មានដែលមានក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ខុសប្លែកពីគ្នាយ៉ាងណាក៏ដោយ ក៏រូបទាំងអស់នោះសំដៅទៅលើគំនិតតែមួយគឺ "ប្រជាជនរបស់ព្រះជាម្ចាស់"។ ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី (អភ ១,២២) រូបទាំងអស់នោះបានទទួលទិសដៅថ្មី ដ្បិតព្រះគ្រីស្ដទៅជា "ព្រះសិរសា" របស់ប្រជាជននេះ (LG ៩) ដែលបានទៅជាព្រះកាយព្រះអង្គវិញ។ និមិត្តសញ្ញាអំពីព្រះសហគមន៍ "ដកស្រង់ពីការរស់នៅរបស់អ្នកឃ្វាលសត្វ ឬអំពីការរស់នៅរបស់កសិករ ឬអំពីការសាងសង់សំណង់ ឬអំពីការរស់នៅក្នុងក្រុមគ្រួសារ និងអំពីអាពាហ៍ពិពាហ៍" (LG ៦)

៧៥៤-"ព្រះសហគមន៍ប្រៀបដូចជាក្រោលសត្វ រីឯព្រះគ្រីស្ដវិញ ព្រះអង្គប្រៀបដូចជាទ្វារចេញចូលតែមួយដែលត្រូវការជាចំបាច់ (យហ ១០,១-១០)។ ព្រះសហគមន៍ជាហ្វូងសត្វដែលព្រះជាម្ចាស់បានប្រកាសជាមុនថា ព្រះអង្គនឹងទៅជាគង្វាល (អស ៤០,១១; អគ ៣៤,១១-៣១) ហើយទោះបីចៀមមានមនុស្សជាគង្វាលណែនាំក្ដី ក៏ព្រះគ្រីស្ដផ្ទាល់ណែនាំ និងចិញ្ចឹមចៀមទាំងនោះជានិច្ច ព្រះអង្គជាគង្វាលដ៏ល្អ ជាម្ចាស់លើគង្វាលទាំងប៉ុន្មាន (យហ ១០,១១; ១សល ៥,៤) ព្រះអង្គបានប្ដូរជីវិត ដើម្បីចៀមរបស់ខ្លួន (យហ ១៩,១១-១៥)។

៧៥៥-ព្រះសហគមន៍ប្រៀបដូចស្រែចម្ការ គឺជាស្រែចម្ការរបស់ព្រះជាម្ចាស់ (១ករ ៣,៩)។ ក្នុងចម្ការនោះមានដើមអូលីវដុះឡើងតាំងពីដើមមក គឺដើមអូលីវដែលមានអស់លោកបុព្វបុរសជាឫសដ៏វិសុទ្ធ។ នៅដើមអូលីវនោះជនជាតិយូដា និងសាសន៍ដទៃកំពុងសម្រុះសម្រួលគ្នា និងគង់តែនឹងស្រុះស្រួលគ្នាជាស្ថាពរនៅថ្ងៃណាមួយមិនខាន (រម ១១, ១៣-២៦)។ ព្រះជាម្ចាស់ប្រៀបដូចជាអ្នកថែរក្សាចម្ការនៃស្ថានបរមសុខ ព្រះអង្គបានដាំដើមទំពាំងបាយជូរដែលទ្រង់បានជ្រើសរើសនោះ (មថ ២១,៣៣-៤៣; អស ៥,១ក)។ ដើមទំពាំងបាយជូរដ៏ពិតប្រាកដ គឺព្រះគ្រីស្ដ ព្រះអង្គប្រទានឲ្យយើងជាមែកមានជីវិត និងអាចបង្កើតផលផ្លែបាន។ ដោយសារព្រះសហគមន៍ យើងស្ថិតនៅក្នុងព្រះគ្រីស្ដ បើដាច់ពីព្រះអង្គ យើងពុំអាចធ្វើអ្វីបានឡើយ (យហ ១៥,១-៥)។

៧៥៦-គម្ពីរបានចែងជារឿយៗថា ព្រះសហគមន៍ជាសំណង់របស់ព្រះជាម្ចាស់ (១ករ ៣,៩)។ ព្រះយេស៊ូជាអម្ចាស់បានប្រៀបព្រះអង្គផ្ទាល់ទុកជាថ្មដែលជាងសំណង់បានបោះបង់ចោល ហើយដែលត្រឡប់ទៅជាថ្មគ្រឹះដ៏សំខាន់វិញ (មថ ២១,៤២; កក ៤,១១; ១សល ២,៧; ទន ១១៧,២២)។ ក្រុមគ្រីស្ដទូតបានសង់ព្រះសហគមន៍លើគ្រឹះនោះ (១ករ ៣,១១) ព្រះសហគមន៍ក៏រឹងប៉ឹង និងតភ្ជាប់គ្នាយ៉ាងមាំមួនដោយសារគ្រឹះនោះដែរ។ សំណង់នេះមានឈ្មោះផ្សេងៗពីគ្នា គឺជាព្រះដំណាក់របស់ព្រះជាម្ចាស់ (១ធម ៣,១៥) មានក្រុមគ្រួសាររបស់ព្រះអង្គរស់នៅក្នុងដំណាក់នោះ ជាព្រះដំណាក់របស់ព្រះជាម្ចាស់ក្នុងព្រះវិញ្ញាណ (អភ ២,១៩-២២) ជាព្រះពន្លារបស់ព្រះជាម្ចាស់ ស្ថិតនៅជាមួយមនុស្សលោក (វវ ២១,៣) ជាពិសេសជាព្រះវិហារដ៏វិសុទ្ធ ដែលមានកន្លែងគោរពបូជាសាងសង់អំពីថ្មជានិមិត្តរូប។ អស់គ្រូបាធ្យាយតែងតែលើកតម្កើងព្រះវិហារនេះ។ ក្បួនពិធីបុណ្យនានាក៏តែងប្រៀបធៀបយ៉ាងត្រឹមត្រូវ អំពីព្រះវិហារនោះទៅនឹងក្រុងដ៏វិសុទ្ធ គឺក្រុងយេរូសាឡឹមថ្មី។ យើងកំពុងតែរស់នៅលើផែនដីនេះ ប្រៀបដូចជាថ្មដែលមានជីវិត ផ្គុំគ្នាកសាងសំណង់ (១ សល ២,៥០)។ គ្រីស្ដទូតយ៉ូហាននឹកសញ្ជឹងគិតអំពីទីក្រុងដ៏វិសុទ្ធដែលចុះពីស្ថានបរមសុខមក ទុកជាគូដណ្ដឹងដែលតុបតែងខ្លួនត្រៀមទទួលស្វាមី នៅពេលព្រះជាម្ចាស់ប្រែពិភពលោកឲ្យទៅជាថ្មី (វវ ២១,១ត)។

៧៥៧-ព្រះសហគមន៍ក៏មានឈ្មោះទៀតថា "ទីក្រុងយេរូសាឡឹមនៃស្ថានលើ" និង "មាតារបស់យើង" (កាឡ

៤,២៦; វវ ១២,១៧)។ គេទុកព្រះសហគមន៍ដូចជាភរិយាដ៏និមលនៃកូនចៀម ដែលត្រូវគេបូជា (វវ ១៩,៧; ២១,២ និង ៩;២២,១៧) ជាភរិយាដែលព្រះគ្រីស្ត "បានស្រឡាញ់ និងបូជាព្រះជន្ម ដើម្បីប្រោសឲ្យបានទៅជាវិសុទ្ធ" (អភ ៥, ២៦) ព្រះអង្គតភ្ជាប់នឹងព្រះសហគមន៍ដោយសន្ធិសញ្ញាដែលមិនអាចបែកខ្ញែកពីគ្នាបាន ព្រះអង្គនៅតែ "ចិញ្ចឹមបីបាច់ថែរក្សា" ព្រះសហគមន៍ (អភ ៥,២៩)" (LG ៦)។

### ២-ប្រភពមូលដ្ឋានគ្រឹះ និងបេសកកម្មរបស់ព្រះសហគមន៍

៧៥៨-ដើម្បីពិនិត្យពិច័យអាថ៌កំបាំងនៃព្រះសហគមន៍ ត្រូវតែរិះគិតពិចារណាអំពីប្រភពរបស់ព្រះសហគមន៍នៅក្នុងគម្រោងការនៃព្រះត្រៃឯកដ៏វិសុទ្ធបំផុត និងអំពីការសម្រេចគម្រោងការនេះក្នុងប្រវត្តិសាស្ត្រមនុស្សលោកបន្តិចម្តងៗ។

### ព្រះបិតាសព្វព្រះហឫទ័យបង្កើតព្រះសហគមន៍

៧៥៩-"ព្រះបិតាដែលមានព្រះជន្មមុនកាលសម័យទាំងអស់ ព្រះអង្គស្ម័គ្រចិត្តសម្រេចគម្រោងការដ៏អស្ចារ្យ និងដ៏អាថ៌កំបាំង គឺបង្កើតពិភពលោកដោយព្រះប្រាជ្ញាញាណ និងដោយព្រះហឫទ័យសប្បុរស។ ព្រះអង្គក៏សម្រេចព្រះហឫទ័យលើកមនុស្សលោកឲ្យមានជីវិតរួមរស់ជាមួយព្រះអង្គថែមទៀត" ហើយព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យរួមរស់ជាមួយព្រះអង្គ នៅក្នុងអង្គព្រះបុត្រាព្រះអង្គ៖ "ចំពោះអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្តវិញ ព្រះបិតាសព្វព្រះហឫទ័យត្រាស់ហៅគេឲ្យទៅជាព្រះសហគមន៍ដ៏វិសុទ្ធ"។ ព្រះបិតាសព្វព្រះហឫទ័យសម្រេច "ក្រុមគ្រួសាររបស់ព្រះជាម្ចាស់នេះ" បន្តិចម្តងៗតាមដំណាក់កាលនៃប្រវត្តិសាស្ត្រមនុស្សលោក។ "ព្រះអង្គប្រទានដំណឹងអំពីព្រះសហគមន៍នេះ តាមនិមិត្តសញ្ញាជាច្រើន តាំងពីកំណើតពិភពលោកមក ទ្រង់ក៏បានរៀបចំព្រះសហគមន៍នេះយ៉ាងអស្ចារ្យតាមប្រវត្តិសាស្ត្រប្រជាជនអ៊ីស្រាអែល និងតាមសម្ពន្ធមេត្រីចាស់។ នៅទីបញ្ចប់ ព្រះអង្គក៏បានតែងតាំងព្រះសហគមន៍សម័យឥឡូវជាជំនាន់ចុងក្រោយបំផុត។ ព្រះសហគមន៍សម្តែងខ្លួនដោយព្រះបិតាបង្ហូរព្រះវិញ្ញាណ និងបានទៅជាពេញលក្ខណៈជាស្ថាពរក្នុងសិរីរុងរឿងនៅពេលចុងក្រោយបំផុត" (LG ២)។

### ព្រះជាម្ចាស់ប្រទានដំណឹងអំពីព្រះសហគមន៍តាមនិមិត្តសញ្ញាជាច្រើនតាំងពីកំណើតពិភពលោកមក

៧៦០-តាមគ្រីស្តបរិស័ទដើមដំបូង "ព្រះជាម្ចាស់បានបង្កើតពិភពលោកដើម្បីព្រះសហគមន៍" (គង្វាលអាឡិចសង់ឌ្រីហែរម៉ាស់; អារីស្ទីដ; សន្តៈ យូស្តាំង)។ ព្រះជាម្ចាស់បានបង្កើតពិភពលោកដើម្បីឲ្យមនុស្សលោករួមរស់ជាមួយព្រះអង្គដោយ "ត្រាស់ហៅ" មនុស្សក្នុងអង្គព្រះគ្រីស្តហើយ "ការត្រាស់ហៅ" នេះគឺជាព្រះសហគមន៍។ ព្រះសហគមន៍ជាទីចុងក្រោយនៃអ្វីៗទាំងអស់ (សន្តៈ អេពីផាន) ហើយព្រះជាម្ចាស់បណ្តោយឲ្យមានទុក្ខលំបាកដូចជាអំពើបាបរបស់ទេវទូត និងរបស់មនុស្សលោក ដើម្បីទៅជាឱកាស និងមធ្យោបាយឲ្យព្រះអង្គសម្តែងឫទ្ធានុភាពរបស់ព្រះអង្គ និងសេចក្តីស្រឡាញ់ដែលព្រះអង្គសព្វព្រះហឫទ័យប្រទានឲ្យមនុស្សលោក។

> ព្រះបំណងរបស់ព្រះជាម្ចាស់ជាកិច្ចការមួយ គឺពិភពលោកយ៉ាងណា ព្រះអង្គក៏មានគោលដៅសង្គ្រោះមនុស្សលោក គឺព្រះសហគមន៍យ៉ាងនោះដែរ (សន្តៈ ក្លេម៉ង់នៃអាឡិចសង់ឌ្រី)។

## ព្រះជាម្ចាស់បានរៀបចំព្រះសហគមន៍ក្នុងសម្ព័ន្ធមេត្រីចាស់

៧៦១-ព្រះជាម្ចាស់ចាប់ផ្តើមប្រមូលប្រជាជនរបស់ព្រះអង្គ កាលណាអំពើបាបបំបែកមនុស្សឲ្យឃ្លាតឆ្ងាយពីព្រះអង្គ និងបាក់បែកគ្នា។ ព្រះជាម្ចាស់ប្រមូលព្រះសហគមន៍ដើម្បីទប់ស្កាត់នឹងភាពច្របូកច្របល់ដែលមកពីអំពើបាប។ ព្រះជាម្ចាស់ប្រមូលព្រះសហគមន៍ជាសម្ងាត់ក្នុងចំណោមប្រជាជាតិទាំងឡាយ៖ "ក្នុងចំណោមជាតិសាសន៍ទាំងប៉ុន្មាន អ្នកណាក៏ដោយឲ្យតែគោរពកោតខ្លាចព្រះជាម្ចាស់ហើយប្រព្រឹត្តអំពើសុចរិត ព្រះអង្គមុខជាគាប់ព្រះហឫទ័យនឹងអ្នកនោះមិនខាន" (កក ១០,៣៥) (LG ៩;១៣;១៦)។

៧៦២-ព្រះជាម្ចាស់ចាប់ផ្តើមរៀបចំប្រមូលប្រជាជនរបស់ព្រះអង្គដោយត្រាស់ហៅលោក អប្រាហាំ ដែលព្រះអង្គមានព្រះបន្ទូលសន្យាថានឹងទៅជាឪពុកនៃប្រជាជាតិមួយដ៏ធំ (កណ ១២,២; ១៥,៥-៦) រួចព្រះអង្គជ្រើសរើសជនជាតិអ៊ីស្រាអែលឲ្យទៅជាប្រជាជនរបស់ព្រះអង្គ (សរ ១៩,៥-៦; ទក ៧,៦)។ ដោយសារព្រះជាម្ចាស់បានជ្រើសរើសគេ ជនជាតិអ៊ីស្រាអែលក៏ត្រូវតែទៅជាសញ្ញាសម្គាល់ថាព្រះជាម្ចាស់សព្វព្រះហឫទ័យប្រមូលផ្តុំជាតិសាសន៍ទាំងឡាយ (អស ២,២-៥)។ ប៉ុន្តែពួកព្យាការីចោទប្រកាន់ជនជាតិអ៊ីស្រាអែលថាបានផ្តាច់សម្ព័ន្ធមេត្រី និងប្រកាន់យកឥរិយាបទដូចជាស្ត្រីពេស្យាម្នាក់ (ហស ១; អស ១,២-៤; យរ ២; ល។ល)។ ពួកគេប្រកាសថាព្រះជាម្ចាស់នឹងចងសម្ព័ន្ធមេត្រីថ្មីអស់កល្បជានិច្ច (យរ ៣១,៣១-៣៤; អស ៥៥,៣)។ "ព្រះគ្រីស្តបានចងសម្ពន្ធមេត្រីថ្មីនេះហើយ" (LG ៩)។

## ព្រះគ្រីស្តបានតែងតាំងព្រះសហគមន៍

៧៦៣-នៅពេលចុងក្រោយបំផុត ព្រះបុត្រាមានតួនាទីចាត់ចែងគម្រោងការនៃព្រះបិតាព្រះអង្គអំពីការសង្គ្រោះ៖ នេះគឺជាមូលហេតុនៃ "បេសកកម្ម" របស់ព្រះអង្គ (LG ៣; AG ៣)។ "ព្រះអម្ចាស់យេស៊ូបង្កើតព្រះសហគមន៍ដោយប្រកាសដំណឹង ដែលផ្តល់អំណរសប្បាយថាព្រះជាម្ចាស់យាងមកគ្រងរាជ្យហើយ តាមព្រះបន្ទូលសន្យាជាច្រើនសតវត្សមក" (LG ៥)។ ព្រះគ្រីស្តចាប់ផ្តើមព្រះរាជ្យនៃស្ថានបរមសុខនៅលើផែនដីដើម្បីគាប់ព្រះហឫទ័យរបស់ព្រះបិតា។ "ព្រះសហគមន៍បង្ហាញអំពីព្រះជាម្ចាស់គ្រងរាជ្យយ៉ាងអាថ៌កំបាំងម៉្យាងក្នុងលោកនេះរួចហើយ" (LG ៣)។

៧៦៤-"ព្រះគ្រីស្តបញ្ចាំងពន្លឺនៃព្រះរាជ្យនោះ ដោយព្រះអង្គមានព្រះបន្ទូលបង្រៀនមនុស្សលោក ដោយប្រព្រឹត្តព្រះរាជកិច្ចផ្សេងៗ និងដោយគង់នៅជាមួយមនុស្សលោកផង" (LG ៥)។ ពេលយើងទទួលព្រះបន្ទូលរបស់ព្រះយេស៊ូយើងក៏ទទួលព្រះរាជ្យផ្ទាល់ (LG ៥)។ ព្រះរាជ្យដែលទើបចាប់ផ្តើម និងប្រៀបធៀបដូចជាគ្រាប់ពូជជា "ក្រុមដ៏តូច" (លក ១២,៣២) នៃអស់អ្នកដែលព្រះយេស៊ូត្រាស់ហៅឲ្យមកជាមួយ ហើយដែលព្រះអង្គផ្ទាល់ជាគង្វាល (មថ ១០,១៦)។ ពួកគេជាក្រុមគ្រួសារយ៉ាងពិតប្រាកដរបស់ព្រះយេស៊ូ (មថ ១២,៤៩)។ ព្រះអង្គបានប្រៀនប្រដៅអស់អ្នកដែលនៅជាមួយព្រះអង្គឲ្យមាន "របៀបរស់នៅ" ថ្មី និងឲ្យគេអធិដ្ឋានតាមរបៀបផ្សេង (មថ ៥,៦)។

៧៦៥-ព្រះអម្ចាស់យេស៊ូបានចាត់ចែងសហគមន៍របស់ព្រះអង្គនូវរចនាសម្ព័ន្ធដែលនឹងស្ថិតស្ថេររហូតដល់ទីបញ្ចប់។ ព្រះអង្គបានជ្រើសរើសគ្រីស្តទូតដប់ពីររូបដែលមានលោក សិលា ជាប្រធាន (មក ៣,១៤-១៥)។ ពួកគេជាតំណាងរបស់កុលសម្ព័ន្ធទាំងដប់ពីរនៃជនជាតិអ៊ីស្រាអែល (មថ ១៩,២៨; លក ២២,៣០) និងជាគ្រឹះនៃទីក្រុងយេរូសាឡឹមថ្មី (វវ ២១,១២-១៤)។ គ្រីស្តទូតដប់ពីររូប (មក ៦,៧) និងសាវ័កឯទៀតៗ (លក ១០,១-២) ចូលរួមក្នុងបេសកកម្មអំណាច និងវាសនា (មថ ១០,២៥) របស់ព្រះគ្រីស្ត។ តាមកិច្ចការទាំងអស់នោះ ព្រះគ្រីស្ត

រៀបចំ និងសាងសង់ព្រះសហគមន៍របស់ព្រះអង្គ។

៧៦៦-ប៉ុន្តែព្រះសហគមន៍កើតមកពីព្រះគ្រីស្តបានបូជាព្រះជន្មទាំងស្រុងដើម្បីសង្គ្រោះយើង ដែលព្រះអង្គបានទុកជាមុនក្នុងអភិបូជា និងបានសម្រេចនៅលើឈើឆ្កាង។ "ដើមកំណើត និងការអភិវឌ្ឍន៍នៃព្រះរាជ្យនេះ មកពីព្រះលោហិត និងពីទឹក ដែលហូរចេញពីរបួសត្រង់ឆ្អឹងជំនីរបស់ព្រះយេស៊ូដែលត្រូវគេឆ្កាង" (LG ៣)។ "ដ្បិតអគ្គសញ្ញាដ៏អស្ចារ្យរបស់ព្រះសហគមន៍ទាំងមូលបានកើតមកពីឆ្អឹងជំនីរបស់ព្រះគ្រីស្ត ដែលផ្ទំនៅលើឈើឆ្កាង" (SC ៥)។ នាង អេវ៉ា បានកើតមកពីឆ្អឹងជំនីរបស់លោក អដាំ ដែលដេកលង់លក់យ៉ាងណា ព្រះសហគមន៍ក៏កើតមកពីឆ្អឹងជំនីរបស់ព្រះគ្រីស្តដែលសោយទិវង្គតនៅលើឈើឆ្កាងយ៉ាងនោះដែរ (សន្តៈ អំប្រ៊ូស)។

## ព្រះវិញ្ញាណដ៏វិសុទ្ធសម្តែងព្រះសហគមន៍

៧៦៧-"ក្រោយពីព្រះបុត្រាបានបង្ហើយព្រះរាជកិច្ច ដែលព្រះបិតាផ្តាំឲ្យព្រះអង្គបំពេញនៅលើផែនដីសព្វគ្រប់ទៅហើយ នៅថ្ងៃបុណ្យព្រះវិញ្ញាណយាងមក ព្រះបិតាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីប្រោសឲ្យព្រះសហគមន៍បានវិសុទ្ធជានិច្ច" (LG ៤)។ "ពេលនោះព្រះសហគមន៍បង្ហាញខ្លួនចំពោះមនុស្សទាំងអស់ជាសាធារណៈ ហើយក្រុមសាវ័កចាប់ផ្តើមប្រកាសដំណឹងល្អ" (AG ៤)។ ដោយសារព្រះសហគមន៍ "ត្រាស់ហៅ" មនុស្សទាំងអស់ឲ្យទទួលការសង្គ្រោះព្រះសហហគមន៍មានលក្ខណៈជាសាសនទូតដែលព្រះគ្រីស្តចាត់ឲ្យទៅប្រកាសដំណឹងល្អ ដល់ជាតិសាសន៍ទាំងអស់ឲ្យធ្វើជាសាវ័ក (មថ ២៨,១៩-២០)។

៧៦៨-ដើម្បីបំពេញបេសកកម្មរបស់ខ្លួនព្រះវិញ្ញាណដ៏វិសុទ្ធ "ណែនាំព្រះសហគមន៍ដោយប្រទានព្រះអំណោយទានផ្សេងៗដែលចាត់ចែងឲ្យព្រះសហគមន៍មានរចនាសម្ព័ន្ធតាមលំដាប់លំដោយ" (LG ៤)។ "ដូច្នេះ ព្រះសហគមន៍បានទទួលព្រះអំណោយទានផ្សេងៗពីព្រះគ្រីស្តដែលបានបង្កើតព្រះសហគមន៍។ ព្រះសហគមន៍ក៏យកចិត្តទុកដាក់ គោរពតាមបទបញ្ជារបស់ព្រះអង្គ ដោយចិត្តស្មោះ ពោលគឺឲ្យមានចិត្តស្រឡាញ់ ឲ្យមានចិត្តសុភាពរាបសាឲ្យមានចិត្តលះបង់។ ព្រះសហគមន៍ក៏ទទួលបេសកកម្មប្រកាសថា ព្រះគ្រីស្ត និងព្រះជាម្ចាស់គ្រងរាជ្យ និងមានមុខងារចាត់ចែងព្រះរាជ្យក្នុងប្រជាជាតិនានា។ ព្រះសហគមន៍ជាពន្លក និងជាដើមកំណើតនៃព្រះរាជ្យនេះនៅលើផែនដី" (LG ៥)។

## ព្រះជាម្ចាស់នឹងប្រោសព្រះសហគមន៍ឲ្យពេញលក្ខណៈជាស្ថាពរក្នុងសិរីរុងរឿង

៧៦៩-"ព្រះសហគមន៍ (...) នឹងបានពេញលក្ខណៈជាស្ថាពរនៅក្នុងសិរីរុងរឿងនៃលោកខាងមុខ" (LG ៤៨) នៅពេលព្រះគ្រីស្តនឹងយាងមកវិញពោរពេញដោយសិរីរុងរឿង។ រហូតដល់ពេលនោះ "ព្រះសហគមន៍ធ្វើបូជនីយសចរណ៍តទៅទៀតតាមរយៈការបៀតបៀនខាងលោកីយ៍ និងការលួងលោមរបស់ព្រះជាម្ចាស់" (សន្តៈ អូគូស្តាំង; LG ១៨)។ នៅក្នុងលោកនេះព្រះសហគមន៍ក៏ដឹងថាខ្លួនត្រូវនិរទេស និងឃ្លាតឆ្ងាយពីព្រះអម្ចាស់ (២ករ ៥,៦) ហើយសង្ឃឹមថាព្រះជាម្ចាស់នឹងគ្រងរាជ្យឲ្យពេញលក្ខណៈជា "ពេលកំណត់ដែលព្រះសហគមន៍នឹងរួបរួមជាមួយព្រះមហាក្សត្ររបស់ខ្លួនក្នុងសិរីរុងរឿង" (LG ៥)។ ប៉ុន្តែព្រះសហគមន៍ និងតាមរយៈព្រះសហគមន៍អស់មនុស្សលោកត្រូវរងទុក្ខលំបាកជាច្រើនមុននឹងបានពេញលក្ខណៈជាស្ថាពរនៅក្នុងសិរីរុងរឿង។ ពេលនោះ "អស់មនុស្សសុចរិតតាំងពីជំនាន់លោក អដាំ មក គឺ "តាំងពីលោក អេបិល ជាមនុស្សសុចរិតរហូតដល់អស់អ្នកដែលព្រះបិតាជ្រើសរើសនៅពេលចុងក្រោយគេបង្អស់" ក៏នឹងរួបរួមគ្នានៅក្បែរព្រះបិតាក្នុងព្រះសហគមន៍ ស្របតាមសេចក្តីដែលអស់គ្រូបាធ្យាយបានចែងទុកមក" (LG ២)។

## ៣-អាថ៌កំបាំងរបស់ព្រះសហគមន៍

៧៧០-ព្រះសហគមន៍នៅក្នុងប្រវត្តិសាស្ត្រផង ហួសប្រវត្តិសាស្ត្រផង។ មានតែអ្នកជឿប៉ុណ្ណោះទេ (CR) ដែលអាចយល់ឃើញថា ព្រះសហគមន៍នៅលើផែនដីនេះដែលមើលឃើញមានលក្ខណៈជាវិញ្ញាណផង ដែលនាំជីវិតរបស់ព្រះជាម្ចាស់។

### ព្រះសហគមន៍មានមុខដែលមើលឃើញ និងមានលក្ខណៈជាវិញ្ញាណ

៧៧១-"ព្រះគ្រីស្តជាស្ពានមេត្រីតែមួយព្រះអង្គគត់ ព្រះអង្គនៅតែបង្កើត និងទ្រទ្រង់ព្រះសហគមន៍ដ៏វិសុទ្ធរបស់ព្រះអង្គនៅលើផែនដី ជាអង្គភាពដែលមនុស្សលោកមើលឃើញបាន។ ព្រះសហគមន៍ជាសហគមន៍របស់មនុស្សដែលមានជំនឿ មានសេចក្តីសង្ឃឹម និងមានសេចក្តីស្រឡាញ់។ ព្រះគ្រីស្តផ្សព្វផ្សាយសេចក្តីពិត និងព្រះហឫទ័យប្រោសប្រណីរបស់ព្រះអង្គ ដើម្បីជាប្រយោជន៍ដល់មនុស្សទាំងអស់ដោយសារព្រះសហគមន៍"។ ព្រះសហគមន៍៖

-"ជាសង្គមមួយដែលមានរបៀបរៀបរយ ដោយមានរចនាសម្ព័ន្ធតាមលំដាប់លំដោយ និងជាព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តផងដែរ

-ជាសហគមន៍ដែលអាចមើលឃើញបានផង និងជាសហគមន៍ខាងវិញ្ញាណដែលមើលមិនឃើញផងដែរ

-ជាព្រះសហគមន៍នៅលើផែនដីនេះ និងជាព្រះសហគមន៍ប្រកបដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានបរមសុខ"។

លក្ខណៈទាំងអស់នោះធ្វើឲ្យ "ព្រះសហគមន៍តែមួយរួមគ្នាជាអង្គភាពតែមួយដែលមានផ្នែកជាច្រើន គឺមានសភាពជាមនុស្សផង និងមានសភាពជាព្រះជាម្ចាស់ផង" (LG ៨)។

> ព្រះសហគមន៍មានលក្ខណៈផ្ទាល់ជាមនុស្សផង ជាព្រះជាម្ចាស់ផង ដែលមើលឃើញផង និងបរិបូណ៌នៃភាពដែលមើលមិនឃើញផង ពុះពារទៅដោយសកម្មភាព និងជាប់រវល់ក្នុងការស្ញឹងស្មាធិ៍ស្ថិតនៅក្នុងលោកនេះ ប៉ុន្តែស្ថិតនៅខាងក្រៅលោកនេះដែរ។ ក៏ប៉ុន្តែអ្វីៗដែលមានលក្ខណៈជាមនុស្សក្នុងព្រះសហគមន៍ស្ថិតនៅក្រោមការចាត់ចែងរបស់ព្រះជាម្ចាស់ គឺអ្វីដែលមើលឃើញ ស្ថិតនៅក្រោមអ្វីដែលមើលមិនឃើញ អ្វីដែលមកពីសកម្មភាព ស្ថិតនៅក្រោមអ្វីដែលមកពីការស្ញឹងស្មាធិ៍ ហើយអ្វីដែលនៅក្នុងពិភពនេះ ស្ថិតនៅក្រោមបូរីនៃអនាគតដែលយើងស្វែងរក (SC ២)។
>
> សុភាពរាបសា! ភាពខ្ពង់ខ្ពស់ថ្លៃថ្នូរ! ជំរំនៃដើមឈើធំៗ ព្រះពន្លារបស់ព្រះជាម្ចាស់ លំនៅស្ថានលើផែនដី និងវិមាននៃស្ថានបរមសុខ ផ្ទះដីអិដ្ឋ និងទីធ្លានៃវាំងហ្លួង រូបកាយដែលត្រូវស្លាប់ និងព្រះវិហារនៃពន្លឺព្រោងព្រាយ ពួកអ្នកមានឫកឆ្មើងឆ្មៃប្រមាថនាង ព្រះមហេសីរបស់ព្រះគ្រីស្ត! ឱបុត្រីនៃទីក្រុងយេរូសាឡឹម នាងសម្បុរខ្មៅ ប៉ុន្តែស្រស់ស្អាត នាងមានទឹកមុខស្លេកស្លាំង ដោយនឿយហត់បានទទួលរងទុក្ខលំបាកក្នុងការនិរទេសខ្លួនយ៉ាងយូរ ប៉ុន្តែ នាងបានទទួលមកុដនៃស្ថានបរមសុខ (សន្តៈ បែរណា)។

### ព្រះសហគមន៍ជាអាថ៌កំបាំងដែលមនុស្សលោករួមរស់ជាមួយព្រះជាម្ចាស់

៧៧២-ក្នុងព្រះសហគមន៍ព្រះគ្រីស្តបំពេញ និងសម្តែងអាថ៌កំបាំងរបស់ព្រះអង្គផ្ទាល់ដែលជាគោលដៅនៃគម្រោងការរបស់ព្រះជាម្ចាស់ គឺ "ប្រមូលអ្វីៗទាំងអស់ (...) ឲ្យរួមគ្នាក្នុងអង្គព្រះគ្រីស្ត" (អភ១,១០)។ សន្តៈ ប៉ូល មាន

ប្រសាសន៍ថា "គម្រោងការដ៏លាក់កំបាំងនេះមានអត្ថន័យជ្រៅណាស់" (អភ ៥,៣២) គឺព្រះគ្រីស្ត និងព្រះសហគមន៍រួមអាពិហ៍ពិពាហ៍ជាមួយគ្នា។ ដោយសារព្រះសហគមន៍រួមជាមួយព្រះគ្រីស្តដូចស្វាមីភរិយារួមជាមួយគ្នា (អភ ៥,២៥-២៧) ព្រះសហគមន៍ក៏ក្លាយទៅជាអាថ៌កំបាំងផងដែរ (អភ ៣,៩-១១)។ ដោយយល់ឃើញថាព្រះសហគមន៍ជាអាថ៌កំបាំងសន្តៈ ប៉ូល បន្លឺសម្លេងឡើងថា៖ "ព្រះគ្រីស្តគង់នៅក្នុងបងប្អូន ព្រះអង្គប្រទានឲ្យបងប្អូនមានសង្ឃឹម" (កូឡ ១,២៧)។

៧៧៣-ក្នុងព្រះសហគមន៍មនុស្សលោករួមរស់ជាមួយព្រះជាម្ចាស់ដោយសារ "សេចក្តីស្រឡាញ់ (ដែល) មិនសាបសូន្យឡើយ" (១ករ ១៣,៨) ជាគោលដៅដែលបញ្ជាអ្វីៗដែលជាមធ្យោបាយខាងអគ្គសញ្ញាដែលមានលក្ខណៈរបស់លោកីយ៍ដែលចេះតែកន្លងផុតទៅ។ "រចនាសម្ព័ន្ធរបស់ព្រះសហគមន៍ស្ថិតក្រោមភាពដ៏វិសុទ្ធរបស់អវយវៈព្រះគ្រីស្ត ហើយយើងវិនិច្ឆ័យភាពដ៏វិសុទ្ធតាមសេចក្តីស្រឡាញ់ដែលភរិយាឆ្លើយតបនឹងអំណោយទានរបស់ស្វាមី" (MD ២៧)។ នាងម៉ារីដើរខាងមុខយើងទាំងអស់គ្នាក្នុងភាពដ៏វិសុទ្ធដែលជាអាថ៌កំបាំងនៃព្រះសហគមន៍ ជាភរិយា "ឥតស្លាកស្នាម ឥតជ្រីវជ្រួញ" (អភ ៥,២៧)។ ហេតុនេះហើយបានជា "ក្នុងព្រះសហគមន៍អ្វីដែលមានលក្ខណៈរបស់នាងម៉ារីដើរទៅមុខ អ្វីដែលមានលក្ខណៈរបស់លោក សិលា"។

## ព្រះសហគមន៍ជាអគ្គសញ្ញាសកលនៃការសង្គ្រោះ

៧៧៤-ពាក្យក្រិក mysterion (អាថ៌កំបាំង) បកប្រែជាភាសាឡាតាំងថា mysterium (អាថ៌កំបាំង) និង sacramentum (អគ្គសញ្ញា)។ ក្រោយមកយើងបានបកស្រាយពាក្យ sacramentum សំដៅទៅលើសញ្ញាដែលមើលឃើញនៃអង្គភាពដ៏លាក់លៀមនៃការសង្គ្រោះដែលពាក្យ mysterium ឆ្លុះបង្ហាញ។ តាមអត្ថន័យនេះព្រះគ្រីស្តផ្ទាល់ជាអាថ៌កំបាំងនៃការសង្គ្រោះ គឺគ្មានអាថ៌កំបាំងផ្សេងក្រៅពីព្រះគ្រីស្ត (សន្តៈ អូគូស្តាំង)។ ព្រះរាជកិច្ចនៃការសង្គ្រោះរបស់សភាពជាមនុស្សដ៏វិសុទ្ធ និងដែលប្រោសឲ្យបានវិសុទ្ធរបស់ព្រះអង្គជាអគ្គសញ្ញានៃការសង្គ្រោះដែលសម្តែងខ្លួន និងប្រតិបត្តិតាមអគ្គសញ្ញារបស់ព្រះសហគមន៍ (ដែលព្រះសហគមន៍ខាងបូព៌ាប្រទេសហៅថា "អាថ៌កំបាំងដ៏វិសុទ្ធ")។ អគ្គសញ្ញាទាំងប្រាំពីរជាសញ្ញា និងជាឧបករណ៍ដែលព្រះវិញ្ញាណដ៏វិសុទ្ធចាក់បង្ហូរព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្ត ដែលជាព្រះសិរសានៅក្នុងព្រះសហគមន៍ ដែលជាព្រះកាយព្រះអង្គ។ ដូច្នេះព្រះសហគមន៍មាន និងផ្តល់ការប្រណីសន្តោសដែលមើលមិនឃើញដែលខ្លួនសម្តែង។ ក្នុងអត្ថន័យប្រៀបធៀបនេះយើងហៅព្រះសហគមន៍ថា "អគ្គសញ្ញា"។

៧៧៥-"ព្រះសហគមន៍រួមក្នុងអង្គព្រះគ្រីស្ត ហាក់ដូចជាអគ្គសញ្ញារបស់ព្រះគ្រីស្ត គឺជាសញ្ញាសម្គាល់បង្ហាញព្រះគ្រីស្តផង និងជាមធ្យោបាយឲ្យមនុស្សរួមរស់ជាមួយព្រះជាម្ចាស់យ៉ាងជិតស្និទ្ធផង។ ព្រះសហគមន៍ក៏ជាមធ្យោបាយប្រមែប្រមូលមនុស្សលោកឲ្យរួមគ្នាជាធ្លុងតែមួយដែរ" (LG ១)៖ ព្រះសហគមន៍មានគោលដៅដំបូងធ្វើជាអគ្គសញ្ញាឲ្យមនុស្សរួមរស់ជាមួយព្រះជាម្ចាស់យ៉ាងជិតស្និទ្ធ។ មនុស្សអាចរួមរស់ជាមួយគ្នា ដ្បិតពួកគេរួមរស់ជាមួយព្រះជាម្ចាស់ ហេតុនេះព្រះសហគមន៍ជាអគ្គសញ្ញាឲ្យមនុស្សរួមគ្នាជាធ្លុងតែមួយ។ ក្នុងព្រះសហគមន៍មនុស្សបានចាប់ផ្តើមរួមគ្នាជាធ្លុងតែមួយ ដ្បិតព្រះសហគមន៍ប្រមូលមនុស្ស "គ្រប់ជាតិសាសន៍ គ្រប់កុលសម្ព័ន្ធ គ្រប់ប្រជាជន និងគ្រប់ភាសា" (វវ ៧,៩) ជាមួយគ្នានេះដែរ ព្រះសហគមន៍ជា "សញ្ញា និងឧបករណ៍" នៃឯកភាពគ្រប់លក្ខណៈនេះ ដែលត្រូវមានតទៅទៀត។

៧៧៦-ដោយសារព្រះសហគមន៍ជាអគ្គសញ្ញា ព្រះសហគមន៍ក៏ជាឧបករណ៍របស់ព្រះគ្រីស្ត។ ក្នុងព្រះហស្តរបស់ព្រះគ្រីស្តព្រះសហគមន៍ជាឧបករណ៍ "សម្រាប់ឲ្យព្រះគ្រីស្តលោះមនុស្សទាំងអស់" (LG ៩) ជា "អគ្គសញ្ញា

សកលនៃការសង្គ្រោះ" (LG ៤៨) ដែលព្រះគ្រីស្ត "បង្ហាញឲ្យមនុស្សលោកស្គាល់គម្រោងការដ៏អស្ចារ្យនៃព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្ស និងនាំព្រះហឫទ័យស្រឡាញ់នោះមកដល់គេនាសម័យឥឡូវ" (GS ៤៥,១)។ ព្រះសហគមន៍ "ជាគម្រោងការដែលមើលឃើញនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក" (សម្តេចប៉ាបប៉ូលទី៦) ដែលសព្វព្រះហឫទ័យឲ្យមនុស្សលោកទាំងមូលរួមគ្នាជាប្រជារាស្ត្រតែមួយរបស់ព្រះជាម្ចាស់រួមក្នុងព្រះកាយតែមួយរបស់ព្រះគ្រីស្ត កសាងជាព្រះវិហារតែមួយរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ" (AG ៧)។

## សង្ខេប

៧៧៧-ពាក្យ "ព្រះសហគមន៍" មានន័យថា "ការត្រាស់ហៅ"។ ពាក្យនេះ សំដៅទៅលើអស់អ្នកដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រាស់ហៅ ដើម្បីបង្កើតប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយដែលក្លាយទៅជាព្រះកាយព្រះគ្រីស្តផ្ទាល់ ដោយទទួលព្រះកាយព្រះគ្រីស្ត។

៧៧៨-ព្រះសហគមន៍ជាមាគ៌ា និងជាគោលដៅនៃគម្រោងការរបស់ព្រះជាម្ចាស់៖ ការបង្កើតរៀបចំព្រះសហគមន៍ទុកជាមុន សម្ព័ន្ធមេត្រីចាស់រៀបចំព្រះសហគមន៍ ព្រះបន្ទូល និងកាយវិការរបស់ព្រះយេស៊ូគ្រីស្តជាគ្រឹះនៃព្រះសហគមន៍ ព្រះឈើឆ្កាង និងការមានព្រះជន្មថ្មីរបស់ព្រះអង្គសម្រេចព្រះសហគមន៍ ការចាក់បង្ហូរនៃព្រះវិញ្ញាណដ៏វិសុទ្ធសម្តែងថា ព្រះសហគមន៍ជាព្រឹត្តិការណ៍ដ៏អាថ៌កំបាំងនៃការសង្គ្រោះ។ ព្រះជាម្ចាស់នឹងសម្រេចព្រះសហគមន៍នៅក្នុងសិរីរុងរឿងនៃស្ថានបរមសុខ ជាអង្គប្រជុំរបស់អស់អ្នកដែលព្រះអង្គបានលោះឲ្យរួចពីបាប (វវ ១៤,៤)។

៧៧៩-ព្រះសហគមន៍ជាអង្គភាពដែលអាចមើលឃើញ និងខាងវិញ្ញាណ ជាសង្គមដែលបានរៀបចំតាមលំដាប់លំដោយ និងជាព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត។ ព្រះសហគមន៍មានតែមួយ ប្រកបដោយភាពជាមនុស្សផង ភាពជាព្រះជាម្ចាស់ផង។ នេះគឺជាអាថ៌កំបាំងរបស់ព្រះសហគមន៍ ដែលមានតែជំនឿទេ ដែលអាចទទួលស្គាល់បាន។

៧៨០-នៅក្នុងលោកនេះ ព្រះសហគមន៍ជាអគ្គសញ្ញានៃការសង្គ្រោះ សញ្ញាសម្គាល់ និងឧបករនៃការរួបរួមរវាងព្រះជាម្ចាស់ និងមនុស្ស។

## កថាខណ្ឌទី២៖ ព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់

### ជាព្រះកាយព្រះគ្រីស្ត និងជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

#### ១-ព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់

៧៨១-"នៅគ្រប់សម័យ ក្នុងចំណោមជាតិសាសន៍ទាំងប៉ុន្មាន អ្នកណាក៏ដោយ ឲ្យតែគោរពកោតខ្លាចព្រះជាម្ចាស់ហើយប្រព្រឹត្តអំពើសុចរិត ព្រះអង្គបានគាប់ព្រះហឫទ័យនឹងអ្នកនោះហើយ។ ក៏ប៉ុន្តែព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សបានវិសុទ្ធ និងទទួលការសង្គ្រោះ មិនមែនដោយដាច់ឡែកពីគ្នា ឬដោយគ្មានទំនាក់ទំនងទៅវិញទៅមកនោះទេ តែព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សទៅជាប្រជាជនមួយ ដែលនឹងស្គាល់ព្រះអង្គ តាមសេចក្តីពិត និងបម្រើព្រះអង្គយ៉ាងវិសុទ្ធ។ ហេតុនេះហើយបានជាព្រះអង្គបានជ្រើសរើសប្រជាជនអ៊ីស្រាអែល និងចងសម្ព័ន្ធមេត្រីជាមួយគេ ឲ្យទៅជាប្រជារាស្ត្រផ្ទាល់របស់ព្រះអង្គ។ ព្រះអង្គបានបង្រៀនគេបន្តិចម្តងៗ (...) ហេតុការណ៍ទាំងប៉ុន្មាននោះ គ្រាន់តែរៀបចំផ្លូវជូនសម្ព័ន្ធមេត្រីថ្មី និងជាប្រផ្នូលនៃសម្ព័ន្ធមេត្រីថ្មីនោះ ដែលជាសម្ព័ន្ធមេត្រីដ៏ពេញ

លក្ខណៈចងក្នុងអង្គព្រះគ្រីស្ត។ ព្រះគ្រីស្តបានចងសម្ព័ន្ធមេត្រីថ្មីនេះហើយ គឺជាសម្ព័ន្ធមេត្រីថ្មីចងឡើងដោយព្រះលោហិតព្រះអង្គ។ ព្រះអង្គត្រាស់ហៅមនុស្សទាំងអស់ពីក្នុងចំណោមសាសន៍យូដាផង និងពីក្នុងចំណោមសាសន៍ដទៃផង ឲ្យរួមគ្នាជាប្រជារាស្ត្រថ្មីរបស់ព្រះជាម្ចាស់ មិនមែនជាប្រជារាស្ត្រតាមសាច់ឈាមទេ តែក្នុងព្រះវិញ្ញាណវិញ" (LG ៩)។

## លក្ខណៈនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់

៧៨២-ប្រជារាស្ត្ររបស់ព្រះជាម្ចាស់មានលក្ខណៈខុសប្លែកពីក្រុមសាសនា ក្រុមជាតិសាសន៍ ក្រុមនយោបាយ ឬក្រុមវប្បធម៌ទាំងអស់នៃប្រវត្តិសាស្ត្រ។ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់៖

-ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់៖ ព្រះជាម្ចាស់មិនមែនជាកម្មសិទ្ធិរបស់ប្រជារាស្ត្រណាមួយទេ ប៉ុន្តែព្រះអង្គបានយកប្រជារាស្ត្រមួយពីអស់អ្នកដែលមិនធ្លាប់ធ្វើជាប្រជារាស្ត្រមួយមកធ្វើជាកម្មសិទ្ធិ គឺ «ពូជសាសន៍ដែលព្រះអង្គបានជ្រើសរើសជាក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ ជាជាតិសាសន៍ដ៏វិសុទ្ធ" (១ពត្រ ២,៩)។

-យើងក្លាយទៅជាសមាជិករបស់ប្រជារាស្ត្រនេះ មិនមែនដោយកំណើតនៃរូបកាយទេ តែដោយកំណើតពីស្ថានលើ "ពីទឹក និងព្រះវិញ្ញាណ" (យហ ៣,៣-៥) គឺដោយផ្ញើជីវិតទាំងស្រុងលើព្រះគ្រីស្ត និងដោយទទួលពិធីជ្រមុជទឹក។

-ប្រជារាស្ត្រនោះមានអ្នកដឹកនាំ (ព្រះសិរសា) ព្រះយេស៊ូគ្រីស្ត (ជាអ្នកទទួលប្រេងអភិសេក-ព្រះមេស្ស៊ី)៖ ដោយសារប្រេងអភិសេកដដែល គឺព្រះវិញ្ញាណដ៏វិសុទ្ធហូរចេញពីព្រះសិរសាចូលក្នុងព្រះកាយប្រជារាស្ត្រនេះជា "ប្រជារាស្ត្ររបស់ព្រះមេស្ស៊ី"។

-"ប្រជារាស្ត្រនោះមានលក្ខណៈពិសេស គឺមានកិត្តិយសដ៏ថ្លៃថ្នូរ និងសេរីភាពនៃបុត្រធីតារបស់ព្រះជាម្ចាស់ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងចិត្តគេ ដូចជាគង់នៅក្នុងព្រះវិហារមួយដែរ"។

-"ច្បាប់នៃប្រជារាស្ត្រនោះ គឺវិន័យថ្មីរបស់ព្រះយេស៊ូ ពោលគឺត្រូវស្រឡាញ់ដូចព្រះគ្រីស្តបានស្រឡាញ់យើងដែរ" (យហ ១៣,៣៤)។ វិន័យនេះ ជាវិន័យ "ថ្មី" នៃព្រះវិញ្ញាណដ៏វិសុទ្ធ (រម ៨,២; កាឡ ៥,២៥)។

-បេសកកម្មនៃប្រជារាស្ត្រនោះ គឺឲ្យទៅជាអំបិលសម្រាប់មនុស្សលោក និងពន្លឺសម្រាប់បំភ្លឺមនុស្សលោក (មថ ៥,១៣-១៦)។ ប្រជារាស្ត្រនោះ "ជាពូជដ៏មានកម្លាំងខ្លាំងជាងគេ អាចធ្វើឲ្យមនុស្សរួបរួមគ្នា មានសេចក្តីសង្ឃឹម និងអាចទទួលការសង្គ្រោះបានផងដែរ"។

-"ប្រជាជននោះមានទីដៅតែមួយ គឺឲ្យព្រះជាម្ចាស់គ្រង់រាជ្យលើគេ ដូចព្រះអង្គផ្ទាល់ចាប់ផ្តើមគ្រងរាជ្យនៅលើផែនដីនេះ ហើយដែលនឹងត្រូវលាតត្រដាងឲ្យបានឆ្ងាយច្រើនជាង រហូតដល់អវសានកាលនៃពិភពលោក" (LG ៩)។

## ប្រជារាស្ត្ររបស់បូជាចារ្យព្យាការី និងព្រះមហាក្សត្រ

៧៨៣-ព្រះយេស៊ូគ្រីស្តជាអ្នកដែលព្រះបិតាបានចាក់បញ្ចូលព្រះវិញ្ញាណដ៏វិសុទ្ធ និងបានតែងតាំងជា "បូជាចារ្យព្យាការី និងព្រះមហាក្សត្រ"។ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូលចូលរួមចំណែកក្នុងមុខងារទាំងបីនោះរបស់ព្រះគ្រីស្ត ទទួលការខុសត្រូវប្រកាសដំណឹងល្អ និងបម្រើអ្នកដទៃទៅតាមមុខងាររបស់ខ្លួន (RH ១៨-២១)។

៧៨៤-យើងចូលក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដោយធ្វើជីវិតទាំងស្រុងលើព្រះគ្រីស្ត និងដោយទទួលពិធីជ្រមុជទឹក ទើបយើងចូលរួមក្នុងការត្រាស់ហៅតែមួយនៃប្រជារាស្ត្រនោះ គឺឲ្យទៅជាបូជាចារ្យ៖ "ព្រះគ្រីស្តជាអម្ចាស់ ជាមហាបូជាចារ្យជ្រើសរើសពីក្នុងចំណោមមនុស្ស បានលើកប្រជារាស្ត្រថ្មីធ្វើជា «ព្រះរាជាណាចក្រមួយជាក្រុមបូជាចារ្យបម្រើព្រះជាម្ចាស់ជាព្រះបិតារបស់ព្រះអង្គ»។ អស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក បានកើតជាថ្មី និងទទួលពិធីអភិសេកពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ទាំងអស់គ្នាបានវិសុទ្ធដើម្បីឲ្យទៅជាព្រះដំណាក់ខាងព្រះវិញ្ញាណ និងទៅជាក្រុមបូជាចារ្យដ៏វិសុទ្ធ" (LG ១០)។

៧៨៥-"ប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់មានចំណែកបំពេញមុខងាររបស់ព្រះគ្រីស្តជាព្យាការី"។ ប្រជារាស្ត្រជាព្យាការីដោយសារជំនឿដ៏ហួសធម្មជាតិជារបស់ប្រជារាស្ត្រទាំងមូល គ្រីស្តបរិស័ទធម្មតាផង ក្រុមអ្នកដឹកនាំផង ពេលគេ "ភ្ជាប់ចិត្តនឹងជំនឿដែលព្រះជាម្ចាស់បានប្រទានមកប្រជាជនដ៏វិសុទ្ធតែម្តងជាការស្រេច" (LG ១២) ហើយពេលគេឈ្វេងយល់ឲ្យកាន់តែស៊ីជម្រៅពីជំនឿនេះ និងទៅជាសាក្សីនៃព្រះគ្រីស្តក្នុងចំណោមមនុស្សលោក។

៧៨៦-ប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់មានចំណែកបំពេញមុខងាររបស់ព្រះគ្រីស្តជាព្រះមហាក្សត្រ។ ព្រះគ្រីស្តជាព្រះមហាក្សត្រដោយទាក់ទាញមនុស្សទាំងអស់មករកព្រះអង្គដោយសោយទិវង្គត និងមានព្រះជន្មថ្មី (យហ ១២,៣២)។ ព្រះគ្រីស្តជាព្រះមហាក្សត្រ និងជាព្រះអម្ចាស់នៃសកលលោកបានដាក់ខ្លួនជាអ្នកបម្រើរបស់មនុស្សទាំងអស់ ដ្បិតព្រះអង្គយាងមក "មិនមែនឲ្យគេបម្រើលោកទេ គឺលោកមកបម្រើគេវិញ ព្រមទាំងបូជាជីវិតដើម្បីលោះមនុស្សទាំងអស់ផង" (មថ ២០,២៨)។ ចំពោះគ្រីស្តបរិស័ទ "គ្រងរាជ្យ គឺបម្រើព្រះអង្គ" ជាពិសេស "អ្នកក្រីក្រ និងអ្នកកើតទុក្ខ (ដែល) ព្រះសហគមន៍ក៏ប្រដូចទៅនឹងព្រះភ័ក្ត្ររបស់ព្រះយេស៊ូជាអ្នកក្រីក្រ និងជាអ្នករងទុក្ខលំបាកដែលបានបង្កើតព្រះសហគមន៍" (LG ៥)។ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់បំពេញ "ឋានៈរបស់ខ្លួនជាស្តេច" ដោយរស់នៅស្របតាមព្រះគ្រីស្តដែលត្រាស់ហៅគេឲ្យបម្រើជាមួយព្រះអង្គផងដែរ។

> សញ្ញាព្រះឈើឆ្កាងធ្វើឲ្យអស់អ្នកដែលបានទទួលជីវិតថ្មីក្នុងអង្គព្រះគ្រីស្តទៅជាស្តេច ប្រេងអភិសេកនៃព្រះវិញ្ញាណដ៏វិសុទ្ធធ្វើឲ្យពួកគេទៅជាបូជាចារ្យ ដើម្បីឲ្យគ្រីស្តបរិស័ទខាងវិញ្ញាណទាំងឡាយ ដោយប្រើប្រាជ្ញាទទួលស្គាល់ខ្លួនឯងថា ជាសមាជិកនៃពូជស្តេចនោះ និងចូលរួមចំណែកក្នុងមុខងារជាបូជាចារ្យ លើកលែងតែកិច្ចបម្រើពិសេសនៃមុខងាររបស់យើងទេ។ សម្រាប់ព្រលឹងមួយ តើមានអ្វីដែលមានលក្ខណៈជាស្តេចប្រសើរជាងការគ្រប់គ្រងរូបកាយរបស់ខ្លួនក្នុងការគោរពប្រណិប័តន៍ព្រះជាម្ចាស់? តើមានអ្វីដែលមានលក្ខណៈជាបូជាចារ្យប្រសើរជាងការថ្វាយខ្លួនទាំងស្រុងចំពោះព្រះអម្ចាស់? (សន្តៈ ឡេអុងដ៏ប្រសើរ)។

## ២-ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត

### ព្រះសហគមន៍រួមរស់ជាមួយព្រះយេស៊ូ

៧៨៧-តាំងពីដំបូងបង្អស់ ព្រះយេស៊ូបានឲ្យសាវ័កព្រះអង្គចូលរួមចំណែកជាមួយព្រះអង្គក្នុងសកម្មភាពនៃជីវិតព្រះអង្គ (មក ១,១៦-២០)។ ព្រះអង្គបានសម្តែងឲ្យគេស្គាល់នូវគម្រោងការដ៏លាក់កំបាំងនៃព្រះរាជ្យ (មថ ១៣,១០-១៧) ព្រះអង្គបានឲ្យគេចូលរួមក្នុងបេសកកម្មអំណរសប្បាយ (លក ១០,១៧-២០) និងទុក្ខលំបាករបស់ព្រះអង្គ (លក ២២,២៨-៣០)។ ព្រះយេស៊ូមានព្រះបន្ទូលថា អស់អ្នកដែលនឹងដើរតាមព្រះអង្គនឹងរួមរស់ជាមួយព្រះអង្គដោយកាន់តែស្និទ្ធស្នាលទៅទៀត៖ "ចូរស្ថិតនៅជាប់នឹងខ្ញុំ ដូចខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នាដែរ (...)។ ខ្ញុំនេះហើយជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក" (យហ ១៥,៤-៥) ហើយព្រះអង្គប្រកាសថា

ព្រះកាយរបស់ព្រះអង្គផ្ទាល់ និងរូបកាយរបស់យើងនឹងរួមរស់ជាមួយគ្នាយ៉ាងអាថ៌កំបាំង និងយ៉ាងពិតប្រាកដផង ដែរ៖ "អ្នកណាពិសាសាច់ និងលោហិតរបស់ខ្ញុំ អ្នកនោះស្ថិតនៅក្នុងខ្ញុំ ហើយខ្ញុំក៏ស្ថិតនៅក្នុងអ្នកនោះដែរ" (យហ ៦,៥៦)។

៧៨៨-ពេលសាវ័កលែងមើលឃើញវត្តមានរបស់ព្រះយេស៊ូ ព្រះអង្គមិនបានទុកគេចោលឲ្យនៅកំព្រាឡើយ (យហ ១៤,១៨)។ ព្រះអង្គមានព្រះបន្ទូលសន្យាគង់នៅជាមួយគេរហូតដល់អវសានកាលនៃពិភពលោក (មថ ២៨,២០) ទ្រង់ក៏ចាត់ព្រះវិញ្ញាណរបស់ព្រះអង្គឲ្យយាងមកលើគេ (យហ ២០,២២)។ ដូច្នេះគេបានរួមរស់ជាមួយព្រះយេស៊ូខ្លាំងជាងមុនទៅទៀត៖ "ដោយព្រះអង្គចែករំលែកព្រះវិញ្ញាណរបស់ព្រះអង្គឲ្យបងប្អូនដែលទ្រង់ប្រមែប្រមូលពីជាតិទាំងឡាយ ព្រះអង្គបានប្រោសឲ្យគេហាក់ដូចជាព្រះកាយព្រះអង្គតាមរបៀបមួយដ៏អាថ៌កំបាំង" (LG ៧)។

៧៨៩-ពេលយើងប្រៀបធៀបព្រះសហគមន៍នឹងព្រះកាយ យើងក៏បំភ្លឺនូវចំណងយ៉ាងស្និទ្ធស្នាលរវាងព្រះសហគមន៍ និងព្រះគ្រីស្ត។ ព្រះសហគមន៍មិនគ្រាន់តែប្រមូលនៅជុំវិញព្រះអង្គទេ គឺព្រះសហគមន៍រួមឯកភាពនៅក្នុងអង្គព្រះអង្គ ក្នុងព្រះកាយព្រះអង្គ។ ត្រូវតែសង្កត់ធ្ងន់នូវលក្ខណៈទាំងបីរបស់ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត ពោលគឺសរីរាង្គរួមឯកភាពជាមួយគ្នាដោយរួមរស់ជាមួយព្រះគ្រីស្ត ព្រះគ្រីស្តជាព្រះសិរសារបស់ព្រះកាយ ហើយព្រះសហគមន៍ក៏ជាភរិយារបស់ព្រះគ្រីស្ត។

### "រូបកាយតែមួយ"

៧៩០-អ្នកជឿដែលផ្ញើជីវិតលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយដែលទៅជាសរីរាង្គរបស់ព្រះកាយព្រះគ្រីស្ត រួមរស់ជាមួយព្រះគ្រីស្តយ៉ាងជិតស្និទ្ធ៖ "ព្រះគ្រីស្តផ្សព្វផ្សាយព្រះជន្មរបស់ព្រះអង្គក្នុងរូបកាយនេះ គឺក្នុងអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ។ អគ្គសញ្ញានានាបង្រួបបង្រួមគ្រីស្តបរិស័ទជាមួយនឹងព្រះគ្រីស្ត ដែលរងទុក្ខ និងដែលមានព្រះជន្មមានជីវិតថ្មី តាមរបៀបដ៏អាថ៌កំបាំងម៉្យាង ក៏ប៉ុន្តែយ៉ាងពិតប្រាកដ" (LG ៧)។ ពេលយើងទទួលពិធីជ្រមុជទឹក យើងក៏រួមរស់យ៉ាងពិតប្រាកដជាមួយព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មី ហើយជាពិសេសពេលយើងចូលរួមក្នុងពិធីអភិបូជា យើងក៏ចូលរួមក្នុងព្រះកាយព្រះគ្រីស្តយ៉ាងពិតប្រាកដដែរ គឺព្រះអង្គលើកយើងឲ្យរួបរួមជាមួយព្រះអង្គ និងឲ្យរួបរួមជាមួយគ្នាដែរ" (LG ៧)។

៧៩១-ទោះបីរូបកាយរួមឯកភាពយ៉ាងណាក៏ដោយ ក៏សរីរាង្គខុសប្លែកពីគ្នាដែរ៖ "ទោះបីមានសរីរាង្គ និងអវយវៈដែលជាមុខងារផ្សេងៗជាច្រើនក្តី ក៏គេផ្គុំគ្នាកសាងព្រះកាយព្រះគ្រីស្តតែមួយដែរ។ មានព្រះវិញ្ញាណតែមួយព្រះអង្គដែលចែកអំណោយទានផ្សេងៗពីគ្នា ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ តាមព្រះហឫទ័យទូលំទូលាយរបស់ព្រះអង្គ និងតាមតម្រូវការក្នុងកិច្ចបម្រើ"។ ព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តបង្កើត និងពង្រឹងសេចក្តីស្រឡាញ់រវាងគ្រីស្តបរិស័ទគ្នាឯង៖ "ដូច្នេះប្រសិនបើមានសរីរាង្គណាមួយរងទុក្ខលំបាក សរីរាង្គទាំងអស់ក៏រងទុក្ខលំបាកជាមួយដែរ ប្រសិនបើមានសរីរាង្គណាមួយបានសិរីរុងរឿង សរីរាង្គទាំងអស់ក៏ត្រេកអរសប្បាយជាមួយដែរ" (LG ៧)។ ទីបំផុតឯកភាពនៃព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តឈ្នះការបាក់បែកទាំងអស់របស់មនុស្ស៖ "បងប្អូនទាំងអស់គ្នាដែលបានទទួលពិធីជ្រមុជទឹក ដើម្បីបានរួមជាមួយព្រះគ្រីស្ត បងប្អូនក៏មានព្រះគ្រីស្តនៅជាប់ជាមួយដែរ។ ដូច្នេះគ្មានសាសន៍យូដា គ្មានសាសន៍ក្រិកទៀតទេ ហើយក៏គ្មានអ្នកងារ គ្មានអ្នកជា គ្មានបុរស គ្មានស្ត្រីទៀតទេ គឺបងប្អូនទាំងអស់បានរួមគ្នាមកជាអង្គតែមួយ" (កាឡ ៣,២៧-២៨)។

### "ព្រះគ្រីស្ដជាព្រះសិរសានៃព្រះកាយនេះ"

៧៩២-ព្រះគ្រីស្ដជា "ព្រះសិរសានៃព្រះសហគមន៍ដែលជាព្រះកាយព្រះអង្គ" (កូឡ ១,១៨)។ ព្រះអង្គជាគោលការណ៍នៃការបង្កើត និងការសង្គ្រោះ។ ព្រះអង្គដែលព្រះជាម្ចាស់បានលើកក្នុងសិរីរុងរឿងនៃព្រះបិតា "ជាដើមកំណើតនៃអ្វីៗទាំងអស់" (កូឡ ១,១៨) ជាពិសេសជាដើមកំណើតនៃព្រះសហគមន៍ដែលព្រះអង្គលាតសន្ធឹងព្រះរាជ្យព្រះអង្គលើសអ្វីៗទាំងអស់៖

៧៩៣-ព្រះអង្គប្រោសយើងឲ្យរួមស្លាប់រួមរស់ជាមួយព្រះអង្គ៖ សរីរាង្គទាំងអស់ត្រូវខិតខំឲ្យបានដូចព្រះអង្គ "រហូតទាល់តែព្រះគ្រីស្ដបានកើតជារូបរាង" ក្នុងគេ (កាឡ ៤,១៩)។ "ហេតុនេះហើយបានជាព្រះជាម្ចាស់បានលើកយើងឲ្យចូលក្នុងគម្រោងការដ៏អស្ចារ្យនៃព្រះជន្មរបស់ព្រះអង្គ (...) ពេលយើងត្រូវរងទុក្ខលំបាក និងត្រូវគេបៀតបៀន យើងរួមជាមួយព្រះអង្គដែលរងទុក្ខលំបាកដូចដងខ្លួនរួមជាមួយក្បាល គឺយើងរួមជាមួយព្រះអង្គដែលរងទុក្ខលំបាក ដើម្បីឲ្យបានរួមជាមួយព្រះអង្គប្រកបដោយសិរីរុងរឿងដែរ" (LG ៧)។

៧៩៤-ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងរីកចម្រើន (កូឡ ២,១៩)៖ ដើម្បីឲ្យយើងរីកចម្រើនឡើងឆ្ពោះទៅព្រះអង្គដែលជាព្រះសិរសារបស់យើង (អភ ៤,១១-១៦) ព្រះគ្រីស្ដប្រទាននៅក្នុងព្រះកាយព្រះអង្គដែលជាព្រះសហគមន៍ ព្រះអំណោយទាន និងកិច្ចបម្រើដើម្បីឲ្យយើងជួយគ្នាទៅវិញទៅមកនៅតាមផ្លូវនៃការសង្គ្រោះ។

៧៩៥-ព្រះគ្រីស្ដ និងព្រះសហគមន៍ជា "ព្រះគ្រីស្ដគ្រប់លក្ខណៈ" (**Christus totus**)។ ព្រះសហគមន៍រួមជាមួយព្រះគ្រីស្ដជាអង្គតែមួយ។ សន្តបុគ្គលដឹងខ្លួនយ៉ាងច្បាស់អំពីឯកភាពនេះ៖

សូមលើកតម្កើង និងអរព្រះគុណព្រះអង្គ ដ្បិតយើងមិនគ្រាន់តែបានជាគ្រីស្ដបរិស័ទប៉ុណ្ណោះទេ ថែមទាំងជាព្រះគ្រីស្ដផងដែរ។ តើបងប្អូនយល់នូវព្រះអំណោយទានដែលព្រះជាម្ចាស់បានប្រោសប្រទាន គឺព្រះគ្រីស្ដជាព្រះសិរសាមកយើងទេ? សូមកោតសរសើរ និងត្រេកអរសប្បាយយើងបានទៅជាព្រះគ្រីស្ដ។ មែនហើយ! ដោយសារព្រះអង្គជាព្រះសិរសា ហើយយើងជាសរីរាង្គមនុស្សទាំងមូល គឺព្រះអង្គ និងយើង (...)។ ព្រះគ្រីស្ដបានពេញលក្ខណៈ គឺព្រះសិរសា និងសរីរាង្គ។ អ្វីខ្លះជាព្រះសិរសា និងសរីរាង្គ? ព្រះគ្រីស្ដ និងព្រះសហគមន៍ (សន្តៈ អូគូស្តាំង)។

ព្រះសង្គ្រោះយើងបានសម្ដែងថា ព្រះអង្គជាអង្គតែមួយជាមួយព្រះសហគមន៍ដែលព្រះអង្គបានទទួលយក (សន្តៈ គ្រេគ័រដ៏ប្រសើរ)។

ព្រះសិរសា និងសរីរាង្គ គឺអង្គដ៏អាថ៌កំបាំងតែមួយ (សន្តៈ ថូម៉ាសនៃអាកាំង)។

សន្តី យ៉ូហាន នៃអាកសង្ខេបជំនឿនៃគ្រូបាធ្យាយដ៏វិសុទ្ធចំពោះអ្នកកាត់ក្ដីនាងថា៖ "មិនបាច់គិតច្រើនពេកទេ ខ្ញុំគិតថាព្រះយេស៊ូ និងព្រះសហគមន៍ គឺអង្គតែមួយ"។

### ព្រះសហគមន៍ជាព្រះមហេសីព្រះគ្រីស្ដ

៧៩៦-ទោះបីព្រះគ្រីស្ដ និងព្រះសហគមន៍ជាព្រះសិរសា និងសរីរាង្គនៃព្រះកាយរួមឯកភាពជាមួយគ្នាយ៉ាងណាក៏ដោយ ក៏ព្រះគ្រីស្ដ និងព្រះសហគមន៍ខុសប្លែកពីគ្នាក្នុងទំនាក់ទំនងរៀងៗខ្លួន ដូចនិមិត្តសញ្ញាស្វាមីភរិយាសម្ដែងឲ្យយើងយល់។ ពួកព្យាការីបានរៀបចំ និងលោកយ៉ូហានបាទីស្ដ (យហ ៣,២៩) បានប្រកាសទុកជាមុនថា

ព្រះគ្រីស្តជាព្រះស្វាមីរបស់ព្រះសហគមន៍។ ព្រះអម្ចាស់ផ្ទាល់បានបង្ហាញខ្លួនជា "កូនកំលោះ" (មក ២,១៩)។ គ្រីស្តទូតប៉ូលណែនាំព្រះសហគមន៍ និងអ្នកជឿម្នាក់ៗដែលជាសរីរាង្គនៃព្រះកាយព្រះអង្គ ជាព្រះមហេសីរបស់ព្រះគ្រីស្ត ជាព្រះអម្ចាស់ដើម្បីឲ្យទៅជាវិញ្ញាណតែមួយជាមួយព្រះអង្គ (១ករ ៦,១៥-១៧)។ ព្រះសហគមន៍ជាព្រះមហេសីនិមលរបស់កូនចៀមនិមល (វវ ២២,១៧) ដែលព្រះគ្រីស្តបានស្រឡាញ់ ព្រះអង្គក៏បានបូជាព្រះអង្គសម្រាប់ព្រះសហគមន៍ "ដើម្បីប្រោសព្រះសហគមន៍បានទៅជាវិសុទ្ធ" (អភ ៥,២៦) ព្រះអង្គបានចងសម្ព័ន្ធមេត្រីអស់កល្បជានិច្ចជាមួយព្រះសហគមន៍ ដែលទ្រង់តែងតែថែរក្សាបីបាច់ដូចព្រះកាយព្រះអង្គផ្ទាល់ផងដែរ (អភ ៥,២៩)៖

> នេះហើយជាព្រះគ្រីស្តគ្រប់លក្ខណៈ ព្រះសិរសា និងព្រះកាយជាអង្គតែមួយដែលមានផ្នែកជាច្រើន (...)។ ទោះបី គឺជាព្រះសិរសា ឬសរីរាង្គដែលមានប្រសាសន៍ក្តី ក៏ព្រះគ្រីស្តមានព្រះបន្ទូលដែរ។ ព្រះអង្គមានព្រះបន្ទូលក្នុងឋានៈជាព្រះសិរសា (**ex persona capitis**) ឬក្នុងឋានៈជាព្រះកាយ (**ex persona corporis**) ផងដែរ។ តាមអ្វីដែលមានចែង៖ "អ្នកទាំងពីរនឹងបានទៅជារូបកាយតែមួយ។ គម្រោងការដ៏លាក់កំបាំងនេះមានអត្ថន័យជ្រៅណាស់ ខ្ញុំនិយាយសេចក្តីនេះសំដៅលើព្រះគ្រីស្ត និងព្រះសហគមន៍តែប៉ុណ្ណោះ" (អភ ៥,៣១-៣២)។ ហើយព្រះអម្ចាស់ផ្ទាល់តាមដំណឹងល្អរបស់ព្រះអង្គ៖ "គេមិនមែនជាបុគ្គលពីរនាក់ទៀតទេ គឺជារូបកាយតែមួយវិញ" (មថ ១៩,៦)។ ដូចបងប្អូនបានឃើញហើយ មានបុគ្គលពីរនាក់ខុសប្លែកពីគ្នា ក៏ប៉ុន្តែគេធ្វើជារូបកាយតែមួយពេលរួមរ័កជាប្តីប្រពន្ធ (...)។ ក្នុងឋានៈជាព្រះសិរសា ព្រះអង្គជាព្រះស្វាមីក្នុងឋានៈជាព្រះកាយ ព្រះអង្គជាព្រះមហេសី"។

### ៣-ព្រះសហគមន៍ជាព្រះវិហារនៃព្រះវិញ្ញាណដ៏វិសុទ្ធ

៧៩៧-"វិញ្ញាណយើង ពោលគឺព្រលឹងយើងមានមុខងារសម្រាប់សរីរាង្គយើងយ៉ាងណា ព្រះវិញ្ញាណដ៏វិសុទ្ធក៏មានមុខងារសម្រាប់សរីរាង្គព្រះគ្រីស្ត និងព្រះកាយព្រះគ្រីស្ត ពោលគឺព្រះសហគមន៍យ៉ាងនោះដែរ" (សន្តៈ អូគូស្តាំង)។ "ដោយសារព្រះវិញ្ញាណ ព្រះគ្រីស្តដូចជាដើមកំណើតដ៏សម្ងាត់ម្យ៉ាងផ្នែកនីមួយៗនៃព្រះកាយភ្ជាប់ជាមួយគ្នារួមជាមួយគ្នាផង រួមជាមួយព្រះសិរសារបស់ខ្លួនផង ពីព្រោះព្រះអង្គស្ថិតទាំងមូលក្នុងព្រះសិរសាទាំងមូលក្នុងព្រះកាយទាំងមូលក្នុងសរីរាង្គនីមួយៗ" (**DS** ៣៨០៨)។ ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសព្រះសហគមន៍ឲ្យទៅជា "ព្រះវិហាររបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់" (២ករ ៦,១៦) (១ករ ៣,១៦-១៧; អភ ២,២១)។

ព្រះជាម្ចាស់បានប្រទានព្រះអំណោយទានរបស់ព្រះអង្គឲ្យព្រះសហគមន៍ផ្ទាល់ (...)។ គឺនៅក្នុងព្រះសហគមន៍ដែលព្រះអង្គបានដាក់ការរួមរស់ជាមួយព្រះគ្រីស្ត ពោលគឺព្រះវិញ្ញាណដ៏វិសុទ្ធជាប្រាក់កក់នៃភាពមិនអាចពុករលួយ បានជាការបញ្ជាក់អំពីជំនឿយើង និងជណ្តើរនៃការឡើងរបស់យើងឆ្ពោះទៅព្រះជាម្ចាស់ (...) ដ្បិតនៅទីណាមានព្រះសហគមន៍ នៅទីនោះមានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែរ ហើយនៅទីណាមានព្រះវិញ្ញាណដ៏វិសុទ្ធ នៅទីនោះក៏មានព្រះសហគមន៍ និងព្រះអំណោយទានណាមួយផងដែរ (សន្តៈ អ៊ីរ៉េណេ)។

៧៩៨-ព្រះវិញ្ញាណដ៏វិសុទ្ធជា "គោលការណ៍នៃកិច្ចការដ៏សំខាន់បំផុត និងដែលនាំការសង្គ្រោះក្នុងផ្នែកនីមួយៗនៃព្រះកាយ" (**DS** ៣៨០៨)។ ព្រះអង្គប្រតិបត្តិតាមរបៀបផ្សេងក្នុងការកសាងព្រះកាយទាំងមូល ដោយសេចក្តីស្រឡាញ់ (អភ ៤,៦)៖ តាមព្រះបន្ទូលព្រះជាម្ចាស់ "ដែលអាចកសាងបងប្អូនឡើងជាព្រះសហគមន៍" តាមបុណ្យជ្រមុជទឹក ព្រះអង្គក៏កសាងព្រះកាយព្រះគ្រីស្ត (១ករ ១២,១៣) តាមអគ្គសញ្ញាដែលធ្វើឲ្យសរីរាង្គព្រះគ្រីស្តរីកចម្រើន និងព្យាបាលគេ "តាមព្រះអំណោយទានដែលព្រះអង្គបានប្រទានឲ្យក្រុមគ្រីស្តទូតដែលលើសព្រះអំណោយទាន

ផ្សេងៗ" (LG ៧) តាមគុណធម៌ដែលធ្វើឲ្យប្រព្រឹត្តសេចក្តីល្អ ហើយតាមព្រះអំណោយទាន ពិសេសដែលព្រះអង្គប្រោសឲ្យអ្នកជឿឲ្យមាន "សមត្ថភាព (...) អាចបំពេញមុខងារ និងទទួលបន្ទុកដែលមានប្រយោជន៍សម្រាប់ឲ្យព្រះសហគមន៍នៅតែថ្មីជានិច្ច និងរីកចម្រើនទៀតផង" (LG ១២)។

### ព្រះអំណោយទាន

៧៩៩-ទោះជាអស្ចារ្យសាមញ្ញ ឬតូចទាបក្តី ផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ក៏ព្រះអំណោយទានមកពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធមានប្រយោជន៍ដល់ព្រះសហគមន៍ ហើយដែលព្រះជាម្ចាស់បានចាត់ចែងសម្រាប់កសាងព្រះសហគមន៍ ផលប្រយោជន៍មនុស្ស និងតម្រូវការពិភពលោក។

៨០០-អ្នកដែលទទួលព្រះអំណោយទានផង និងសមាជិកព្រះសហគមន៍ផង ត្រូវតែទទួលព្រះអំណោយទានដោយដឹងគុណ ដ្បិតព្រះអំណោយទានជាទ្រព្យសម្បត្តិដ៏អស្ចារ្យនៃព្រះហឫទ័យប្រណីសន្តោស ដើម្បីឲ្យព្រះសហគមន៍ប្រកាសដំណឹងល្អយ៉ាងសកម្ម និងដើម្បីឲ្យព្រះកាយព្រះគ្រីស្តទាំងមូលបានវិសុទ្ធឲ្យតែព្រះអំណោយទានពិតជាមកពីព្រះវិញ្ញាណដ៏វិសុទ្ធមែន ហើយអ្នកទទួលប្រតិបត្តិតាមព្រះអំណោយាទាននោះដ៏ពេញលេញតាមការជំរុញយ៉ាងពិតប្រាកដនៃព្រះវិញ្ញាណដដែលនេះ ពោលគឺតាមសេចក្តីស្រឡាញ់ជាអ្នកវិនិច្ឆ័យយ៉ាងពិតប្រាកដព្រះអំណោយទាន (១ករ ១៣)។

៨០១-ហេតុនេះត្រូវតែរិះគិតពិចារណាយ៉ាងច្បាស់អំពីព្រះអំណោយទាន។ គ្មានព្រះអំណោយទានណាមួយលើកលែងឲ្យអ្នកទទួលយោងតាម និងស្ថិតនៅក្រោមអំណាចនៃគង្វាលព្រះសហគមន៍ឡើយ គឺ "អស់លោកគ្មានមុខងាររារាំងសកម្មភាពរបស់ព្រះវិញ្ញាណឡើយ តែមានមុខងារពិចារណាមើលគ្រប់ការទាំងអស់ ហើយស្រង់យកការណាដែលល្អ" (LG ១២) ដើម្បីឲ្យព្រះអំណោយទានទាំងអស់ដែលផ្សេងៗពីគ្នា បំពេញគ្នាទៅវិញទៅមកនិងរួមសហការណ៍ "ដើម្បីជាប្រយោជន៍រួម" (១ករ ១២,៧)។

## សង្ខេប

៨០២-"ព្រះគ្រីស្តយេស៊ូបានបូជាព្រះជន្មរបស់ព្រះអង្គផ្ទាល់សម្រាប់យើង ដើម្បីលោះយើងឲ្យរួចផុតពីអំពើទុចរិតគ្រប់យ៉ាង និងជម្រះប្រជារាស្ត្រមួយទុកសម្រាប់ព្រះអង្គផ្ទាល់" (ទត ២,១៤)។

៨០៣-"បងប្អូនជាពូជសាសន៍ដែលព្រះអង្គបានជ្រើសរើស ជាក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ ជាជាតិសាសន៍ដ៏វិសុទ្ធ ជាប្រជារាស្ត្រដែលព្រះជាម្ចាស់បានយកមកធ្វើជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ" (១ពត្រ ២,៩)។

៨០៤-យើងចូលជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដោយផ្ញើជីវិតទៅលើព្រះអង្គ និងដោយទទួលបុណ្យជ្រមុជទឹក។ "ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យចូលក្នុងជាប្រជារាស្ត្ររបស់ព្រះអង្គ" (LG ១៣) ដើម្បីឲ្យ "មនុស្សទៅជាក្រុមគ្រួសារតែមួយ និងប្រជារាស្ត្ររបស់ព្រះជាម្ចាស់តែមួយ" (AG ១) ក្នុងអង្គព្រះគ្រីស្ត។

៨០៥-ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត។ ដោយសារព្រះវិញ្ញាណ និងកិច្ចការរបស់ព្រះអង្គនៅក្នុងអគ្គសញ្ញាជាពិសេសពិធីអរព្រះគុណ ព្រះគ្រីស្តដែលបានសោយទិវង្គត និងមានព្រះជន្មថ្មីកសាងសហគមន៍របស់អស់អ្នកជឿដូចជាព្រះកាយព្រះអង្គ។

៨០៦-ក្នុងឯកភាពនៃព្រះកាយនេះ មានសិរីរាង្គ និងមុខងារប្លែកពីគ្នា។ សិរីរាង្គទាំងអស់ជាប់ចំណងនឹងគ្នាទៅវិញទៅមក ជាពិសេសជាមួយអស់អ្នកដែលរងទុក្ខលំបាក ក្រីក្រ និងដែលត្រូវគេបៀតបៀន។

៨០៧-ព្រះសហគមន៍ជាព្រះកាយ ដែលមានព្រះគ្រីស្តជាព្រះសិរសា គឺព្រះសហគមន៍មានជីវិតពីព្រះអង្គ នៅក្នុងអង្គព្រះអង្គ និងដើម្បីព្រះអង្គ។ ព្រះអង្គក៏រួមរស់ជាមួយព្រះសហគមន៍ និងនៅក្នុងអង្គព្រះសហគមន៍ផង។

៨០៨-ព្រះសហគមន៍ជាព្រះមហេសីរបស់ព្រះគ្រីស្ត គឺព្រះអង្គបានស្រឡាញ់ព្រះសហគមន៍ និងបានបូជាព្រះជន្មសម្រាប់ព្រះសហគមន៍។ ព្រះអង្គបានប្រោសព្រះសហគមន៍ឲ្យបានវិសុទ្ធដោយសារព្រះលោហិតព្រះអង្គ។ ព្រះអង្គបានប្រោសព្រះសហគមន៍ឲ្យទៅជាព្រះមាតាដែលបង្កើតបុត្រធីតារបស់ព្រះជាម្ចាស់។

៨០៩-ព្រះសហគមន៍ជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដូចជាព្រលឹងនៃព្រះកាយដ៏អាថ៌កំបាំង ជាគោលការណ៍នៃជីវិតនៃព្រះសហគមន៍ ជាគោលការណ៍នៃឯកភាពនៃព្រះសហគមន៍ ដែលមានព្រះអំណោយទានដ៏ច្រើនលើសលប់ផ្សេងៗពីគ្នា។

៨១០-"ហេតុនេះហើយបានជាមនុស្សមើលឃើញថា ព្រះសហគមន៍ជា "ប្រជាជនមួយដែលរួបរួមគ្នាជាធ្លុងតែមួយមកពីព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធរួបរួមគ្នាជាធ្លុងតែមួយដែរ"" (LG ៤ សន្ត: ស៊ីព្រីយ៉ាំង)។

## កថាខណ្ឌសញ្ញាសម្គាល់ទី៣៖ ព្រះសហគមន៍មានតែមួយដ៏វិសុទ្ធ កាតូលិក និងបន្តជំនឿពីក្រុមគ្រីស្តទូត

៨១១-"នេះជាព្រះសហគមន៍តែមួយរបស់ព្រះគ្រីស្ត។ ក្នុងធម៌ប្រកាសជំនឿ យើងតែងតែប្រកាសថា ព្រះសហគមន៍មានតែមួយដ៏វិសុទ្ធ កាតូលិក និងមានជំនឿស្របតាមក្រុមគ្រីស្តទូត" (LG ៨)។ គុណសព្ទទាំងបួននោះដែលជាប់ទាក់ទិននឹងគ្នា ដោយមិនអាចបំបែកបាន (DS ២៨៨៨) បង្ហាញពីលក្ខណៈសំខាន់ៗនៃព្រះសហគមន៍ និងបេសកកម្មរបស់ព្រះសហគមន៍ផងដែរ។ ព្រះសហគមន៍មិនបានទទួលលក្ខណៈនោះពីខ្លួនឯងទេ តែព្រះគ្រីស្តតាមព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រទានឲ្យព្រះសហគមន៍របស់ព្រះអង្គបានតែមួយដ៏វិសុទ្ធ កាតូលិក និងឲ្យមានជំនឿស្របតាមក្រុមគ្រីស្តទូត ហើយព្រះអង្គក៏ត្រាស់ហៅព្រះសហគមន៍ឲ្យបំពេញលក្ខណៈនីមួយៗនោះទៀតផង។

៨១២-មានតែអ្នកជឿដែលអាចទទួលស្គាល់ថា លក្ខណៈព្រះសហគមន៍មានប្រភពចេញមកពីព្រះជាម្ចាស់។ ប៉ុន្តែលក្ខណៈនោះដែលព្រះជាម្ចាស់សម្តែងក្នុងប្រវត្តិសាស្ត្រ ជាសញ្ញាសម្គាល់ចំពោះប្រាជ្ញាមនុស្សផងដែរ។ ដូចមហាសន្និបាតវ៉ាទីកង់ទីមួយរំឭកយើង "ដោយសារភាពដ៏វិសុទ្ធឯកភាពកាតូលិក និងចិត្តព្យាយាមដែលមិនបានបរាជ័យ ព្រះសហគមន៍ផ្ទាល់ជាមូលហេតុដ៏ធំ និងជានិច្ចនិរន្តរ៍ដែលអាចនាំឲ្យជឿ ហើយដែលបង្ហាញភស្តុតាងដែលមិនអាចបដិសេធបានអំពីបេសកកម្មរបស់ខ្លួនដែលមកពីព្រះជាម្ចាស់" (DS ៣០១៣)។

### ១-ព្រះសហគមន៍មានតែមួយ

#### អាថ៌កំបាំងដ៏សក្ការៈនៃឯកភាពរបស់ព្រះសហគមន៍ (UR ២)

៨១៣-ព្រះសហគមន៍មានតែមួយ ដ្បិតចេញមកពីប្រភពតែមួយ៖ "ព្រះត្រៃឯក គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដែលរួមគ្នាជាអង្គតែមួយ ពិតជាគំរូដ៏ប្រសើរបំផុត និងគោលការណ៍ចំពោះឯកភាពរបស់ព្រះសហគមន៍" (UR ២)។ ព្រះសហគមន៍មានតែមួយ ដ្បិតអ្នកបង្កើតព្រះសហគមន៍ក៏មានតែមួយដែរ៖ "ព្រះបុត្រាផ្ទាល់ប្រសូតជាមនុស្ស ព្រះអង្គជាអង្គម្ចាស់នៃសន្តិភាព គឺព្រះអង្គបានសម្រុះសម្រួលមនុស្សទាំងអស់ឲ្យបានជានាជាមួយនឹងព្រះជាម្ចាស់ ដោយទ្រង់សោយទិវង្គតនៅលើឈើឆ្កាង ព្រះអង្គប្រមែប្រមូលមនុស្សទាំងអស់ឲ្យរួមគ្នាជាប្រជាជនតែមួយ និងជារូបកាយតែមួយដែរ" (GS ៧៨,៣)។ ព្រះសហគមន៍មានតែមួយ ដ្បិតមាន "ព្រលឹង" តែមួយ៖

"ព្រះវិញ្ញាណគង់សណ្ឋិតក្នុងអ្នកជឿ ទ្រង់ក៏បំពេញ និងគ្រប់គ្រងព្រះសហគមន៍ទាំងមូលដែរ។ ព្រះវិញ្ញាណធ្វើឲ្យអ្នកជឿទាំងប៉ុន្មានរួមចិត្តគំនិតជាមួយគ្នាយ៉ាងអស្ចារ្យ គឺធ្វើឲ្យពួកគេរួមគ្នាយ៉ាងស្និទ្ធស្នាលជាទីបំផុតក្នុងអង្គព្រះគ្រីស្ត ទើបព្រះវិញ្ញាណជាគោលការណ៍នៃឯកភាពរបស់ព្រះសហគមន៍" (UR ២)។ ដូច្នេះព្រះសហគមន៍ត្រូវតែរួមជាធ្លុងតែមួយ៖

> គម្រោងការដ៏អស្ចារ្យមែន! មានព្រះបិតានៃសកលលោកតែមួយ ព្រះបន្ទូលនៃសកលលោកតែមួយ និងព្រះវិញ្ញាណដ៏វិសុទ្ធតែមួយដដែលគ្រប់កន្លែង។ មានព្រហ្មចារិនីទៅជាមាតាតែម្នាក់ផងដែរ ហើយខ្ញុំចូលចិត្តហៅព្រះនាងថាព្រះសហគមន៍ (សន្ត: ក្លេម៉ង់នៃអាឡិចសង់ឌ្រី)។

៨១៤-តាំងពីដើមរៀងមក ក្នុងព្រះសហគមន៍ដែលមានតែមួយ មានភាពផ្សេងពីគ្នាជាច្រើនដែលមកពីព្រះអំណោយទានផ្សេងៗរបស់ព្រះជាម្ចាស់ និងពីមនុស្សផ្សេងៗពីគ្នាដែលទទួលព្រះអំណោយទាននោះ។ ប្រជាជាតិនិងវប្បធម៌ខុសប្លែកពីគ្នា ប្រមូលគ្នាក្នុងឯកភាពនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ សមាជិកព្រះសហគមន៍ក៏មានអំណោយទានមុខងារលក្ខណ្ឌ និងរបៀបរស់នៅផ្សេងពីគ្នា៖ "ក្នុងព្រះសហគមន៍សាកលមានព្រះសហគមន៍ដោយឡែក ដែលកាន់តាមប្រពៃណីរបស់ខ្លួនផ្ទាល់ត្រឹមត្រូវតាមច្បាប់" (LG ១៣)។ លក្ខណៈសម្បត្តិដ៏ប្រសើរនៃភាពផ្សេងពីគ្នានេះ មិនប្រឆាំងនឹងឯកភាពរបស់ព្រះសហគមន៍ឡើយ។ ក៏ប៉ុន្តែអំពើបាប និងផលវិបាករបស់អំពើបាបគម្រាមកំហែងអំណោយទាននៃឯកភាពឥតឈប់ឈរឡើយ។ ហេតុដូច្នេះហើយបានជាគ្រីស្តទូតប៉ូលត្រូវតែដាស់តឿនឲ្យ "រក្សាឯកភាពដែលមកពីព្រះវិញ្ញាណ ដោយយកសេចក្តីសុខសាន្តធ្វើជាចំណងប្រាស្រ័យទាក់ទងគ្នា" (អភ ៤,៣)។

៨១៥-អ្វីទៅជាចំណងនៃឯកភាព? "លើសពីនេះទៅទៀតត្រូវមានចិត្តស្រឡាញ់ ដ្បិតសេចក្តីស្រឡាញ់ធ្វើឲ្យបងប្អូនរួបរួមគ្នាពេញលក្ខណៈ" (កូឡ ៣,១៤)។ ប៉ុន្តែមានចំណងដែលមើលឃើញនៃការរួបរួមគ្នានេះ ដែលធានានូវឯកភាពរបស់ព្រះសហគមន៍ដែលកំពុងធ្វើបូជនីយេចរណ៍៖

-ព្រះសហគមន៍ប្រកាសជំនឿតែមួយដែលមកពីក្រុមគ្រីស្តទូត

-ព្រះសហគមន៍ធ្វើពិធីគោរពព្រះជាម្ចាស់ដោយរួបរួមគ្នាជាពិសេសក្នុងអគ្គសញ្ញា

-ព្រះសហគមន៍បានទទួលមុខងារមកពីក្រុមគ្រីស្តទូត ដោយអគ្គសញ្ញាតែងតាំងដែលរក្សាទុកនូវសេចក្តីសុខសាន្តរវាងបងប្អូនក្នុងមហាគ្រួសាររបស់ព្រះជាម្ចាស់ (UR ២; LG ១៤; CIC ២០៥)។

៨១៦-"នេះជាព្រះសហគមន៍តែមួយរបស់ព្រះគ្រីស្ត (...)។ ក្រោយពីព្រះយេស៊ូជាព្រះសង្គ្រោះមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានប្រគល់ព្រះសហគមន៍នេះឲ្យលោក សិលា ឃ្វាល ផ្ញើឲ្យលោក និងឲ្យគ្រីស្តទូតឯទៀតៗផ្សព្វផ្សាយ និងណែនាំ (...)។ ព្រះសហគមន៍ជាសង្គមម៉្យាង ចាត់ចែងឲ្យមានរបៀបរៀបរយក្នុងលោកបែបនេះ គឺស្ថិតនៅក្នុង (subsistit in) ព្រះសហគមន៍កាតូលិក ដែលមានអភិបាលព្រះសហគមន៍ក្រុងរ៉ូមបន្តមុខតំណែងពីគ្រីស្តទូតសិលាត្រួតត្រា និងដែលមានអស់លោកអភិបាលរួបរួមជាមួយលោកត្រួតត្រាដែរ" (LG ៨)។

ក្រិត្យក្រមអំពីការប្រមែប្រមូលគ្រីស្តបរិស័ទជាធ្លុងតែមួយនៃមហាសន្និបាតវ៉ាទីកង់ទីពីរចែងថា៖ «មានតែក្នុងព្រះសហគមន៍កាតូលិករបស់ព្រះគ្រីស្តទេ ដែលជា «មធ្យោបាយទូទៅនៃការសង្គ្រោះ» អាចផ្តល់មធ្យោបាយទាំងអស់យ៉ាងពេញលេញឲ្យមនុស្សលោកទទួលការសង្គ្រោះ។ តាមជំនឿរបស់យើង យើងជឿថា ព្រះគ្រីស្តបានផ្ញើព្រះអំណោយទានដ៏បរិបូណ៌លើសលប់ទៅក្រុមសាសនាទូតតែមួយនេះទេ ដើម្បីបង្កើតព្រះកាយព្រះគ្រីស្តតែមួយនៅលើផែនដីទាំងមូល។ អស់អ្នកដែលជាប់ទាក់ទងនឹងប្រជាជនរបស់ព្រះជាម្ចាស់តាមបែបណាក៏ដោយ ក៏យើងត្រូវរាប់ថាគេចូលរួមក្នុងព្រះកាយនេះយ៉ាងពេញលេញហើយ» (UR ៣)។

## មុខរបួសនៃឯកភាព

៨១៧-តាមពិត "តាំងពីដើមដំបូងមក នៅក្នុងព្រះសហគមន៍តែមួយគត់របស់ព្រះជាម្ចាស់នេះមានការបាក់បែកគ្នា។ គ្រីស្តទូតប៉ូលស្តីបន្ទោសអ្នកដែលធ្វើឲ្យព្រះសហគមន៍បែកបាក់ដូច្នេះ។ នៅសតវត្សក្រោយៗមកទៀត ការបែកបាក់កើតមានឡើងរឹតតែធ្ងន់ទៅទៀត មានសហគមន៍ជាច្រើនបានបែកចេញពីព្រះសហគមន៍កាតូលិកផ្ដាច់ការរួបរួមគ្នារហូត។ ជួនកាលកំហុសមកពីមនុស្សក្នុងព្រះសហគមន៍ទាំងសងខាង" (UR ៣)។ ការបែកបាក់ដែលធ្វើឲ្យឯកភាពនៃព្រះកាយព្រះគ្រីស្តរបួស (មានការឃ្លាតចាកពីសេចក្ដីពិត ការក្បត់ជំនឿ និងការផ្ដាច់ខ្លួនចេញពីព្រះសហគមន៍) មិនកើតឡើងដោយគ្មានបាបរបស់មនុស្សលោកទេ៖

> នៅទីណាមានបាប នៅទីនោះមានភាពជាច្រើនអនេក គឺមនុស្សបែកចេញពីព្រះសហគមន៍ផង ឃ្លាតចាកពីសេចក្ដីពិតផង ប៉ះទង្គិចគ្នាផង ប៉ុន្តែនៅទីណាមានគុណធម៌ នៅទីនោះមនុស្សរួមឯកភាពជាមួយគ្នាដែលធ្វើឲ្យអ្នកជឿមានរូបកាយ និងព្រលឹងតែមួយ (លោក អូរីសែន)។

៨១៨-"បងប្អូនដែលមានឪពុកម្ដាយកាន់តាមសហគមន៍ទាំងនោះ ហើយដែលខិតខំប្រតិបត្តិតាមជំនឿរបស់ខ្លួន មិនត្រូវចោទថាគេធ្វើឲ្យព្រះសហគមន៍បាក់បែកទេ! ព្រះសហគមន៍កាតូលិកគោរពហើយស្រឡាញ់ពួកគេក្នុងឋានៈជាបងប្អូន (...)។ ទោះជាយ៉ាងណាក៏ដោយ ក៏បងប្អូនទាំងនោះបានសុចរិតដោយសារជំនឿដែលពួកគេបានទទួលក្នុងពេលទទួលបុណ្យជ្រមុជទឹក ពួកគេបានចូលរួមក្នុងព្រះកាយព្រះគ្រីស្ត ពួកគេក៏ពិតជាមានឈ្មោះថាជាគ្រីស្តបរិស័ទដែរ។ ពិតជាត្រឹមត្រូវហើយ! សមាជិកនៃព្រះសហគមន៍កាតូលិកទទួលស្គាល់គេទុកជាបងប្អូនក្នុងព្រះអម្ចាស់ដូច្នេះ" (UR ៣)។

៨១៩-មិនតែប៉ុណ្ណោះសោត "ទោះបីនៅខាងក្រៅរចនាសម្ព័ន្ធនៃព្រះសហគមន៍កាតូលិក មានកត្តាជាច្រើនដែលអាចនាំឲ្យមនុស្សបានវិសុទ្ធ និងស្គាល់សេចក្ដីពិត" (LG ៨) គឺ "មានព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលចែងទុកជាលាយលក្ខណ៍អក្សរ មានជីវិតរស់នៅក្រោមព្រះហឫទ័យប្រោសប្រណីនៃព្រះជាម្ចាស់ មានជំនឿ មានសេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ មានព្រះអំណោយទានផ្សេងៗពីព្រះវិញ្ញាណដែលស្ថិតក្នុងចិត្តគេ ព្រមទាំងមានកត្តាជាច្រើនទៀតដែលមនុស្សអាចមើលឃើញផង" (UR ៣)។ ព្រះវិញ្ញាណព្រះគ្រីស្តយកព្រះសហគមន៍ និងសហគមន៍នោះទុកជាមធ្យោបាយនៃការសង្គ្រោះ ដែលមានកម្លាំងមកពីព្រះហឫទ័យប្រណីសន្តោស និងសេចក្ដីពិតដែលព្រះគ្រីស្តបានប្រគល់ឲ្យព្រះសហគមន៍កាតូលិក។ សេចក្ដីល្អទាំងអស់នោះមកពីព្រះគ្រីស្ត និងនាំទៅកាន់ព្រះអង្គ ហើយក៏មានលក្ខណៈដាស់តឿនមនុស្សលោកឲ្យរួមគ្នាជាធ្លុងតែមួយ ក្នុងព្រះសហគមន៍កាតូលិកផងដែរ (LG ៨)។

## ឆ្ពោះទៅឯកភាព

៨២០-"ព្រះគ្រីស្តបានប្រោសប្រទានឯកភាពនេះឲ្យព្រះសហគមន៍របស់ព្រះអង្គតាំងពីដើមរៀងមក។ យើងជឿថាឯកភាពនេះស្ថិតនៅក្នុងព្រះសហគមន៍កាតូលិកមិនអាចបាត់បង់ឡើយ។ យើងក៏សង្ឃឹមថាឯកភាពនេះនឹងចម្រើនឡើងជារៀងរាល់ថ្ងៃជាលំដាប់រហូតដល់អវសានកាលនៃពិភពលោក" (UR ៤)។ ព្រះគ្រីស្តនៅតែប្រោសប្រទានឯកភាពឲ្យព្រះសហគមន៍ ប៉ុន្តែព្រះសហគមន៍ត្រូវតែអធិដ្ឋានជានិច្ច និងធ្វើការដើម្បីរក្សាទុក និងពង្រឹងឯកភាពដើម្បីឲ្យឯកភាពដែលព្រះគ្រីស្តសព្វព្រះហឫទ័យចំពោះព្រះសហគមន៍បានគ្រប់លក្ខណៈ។ ហេតុនេះព្រះយេស៊ូផ្ទាល់បានអធិដ្ឋានមុននឹងរងទុក្ខលំបាក ហើយទ្រង់ក៏នៅតែទូលអង្វរព្រះបិតា ដើម្បីឲ្យសាវ័ករបស់ព្រះអង្គរួមជាមួយគ្នាជាធ្លុងតែមួយ៖ "សូមឲ្យគេទាំងអស់គ្នារួមជាអង្គតែមួយ។ ឱព្រះបិតាអើយ! ព្រះអង្គស្ថិតនៅជាប់

នឹងទូលបង្គំ ហើយទូលបង្គំស្ថិតនៅជាប់នឹងព្រះអង្គយ៉ាងណា សូមឲ្យគេរួមជាអង្គតែមួយនៅក្នុងយើងយ៉ាងនោះដែរ ដើម្បីឲ្យមនុស្សលោកជឿថាព្រះអង្គបានចាត់ទូលបង្គំឲ្យមកមែន" (យហ ១៧,២១)។ ព្រះគ្រីស្តប្រោសប្រទានឲ្យគ្រីស្តបរិស័ទប្រាថ្នាចង់បានឯកភាព ហើយព្រះវិញ្ញាណដ៏វិសុទ្ធត្រាស់ហៅគេឲ្យរួមគ្នាជាធ្លុងតែមួយផង (UR ១)។

៨២១-ដើម្បីឲ្យគ្រីស្តបរិស័ទរួមជាមួយគ្នាជាធ្លុងតែមួយ៖

-"ព្រះសហគមន៍ត្រូវតែប្រែឲ្យបានថ្មីឡើងវិញគ្រប់យ៉ាង ពោលគឺឲ្យបានស្មោះស្ម័គ្រកាន់តែខ្លាំងនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។ កម្លាំងនៃចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយច្បាស់ជាអាស្រ័យលើការប្រែព្រះសហគមន៍ឲ្យបានថ្មីឡើងវិញនោះ" (UR ៦)។

-ត្រូវតែកែប្រែចិត្តគំនិត "ដើម្បីរស់នៅឲ្យបានសមរម្យនឹងដំណឹងល្អ" (UR ៧) ប្រសើរជាងមុន ដ្បិតពេលណាសមាជិកមិនស្មោះត្រង់នឹងព្រះអំណោយទានរបស់ព្រះគ្រីស្ត ពេកនោះមានការបាក់បែកគ្នាជាពុំខាន។

-ត្រូវតែអធិដ្ឋានរួមជាមួយគ្នា ដ្បិត "ការប្រែចិត្តគំនិត និងការរស់នៅបែបវិសុទ្ធយ៉ាងនេះ រួមជាមួយពាក្យអធិដ្ឋានជាសាធារណៈ និងជាមួយពាក្យអធិដ្ឋានរបស់បុគ្គលម្នាក់ៗ ពិតជាដួងព្រលឹងនៃចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយមែន។ យើងក៏អាចហៅការអធិដ្ឋាននេះយ៉ាងត្រឹមត្រូវថា ជាចលនាបង្រួបបង្រួមគ្រីស្តបរិស័ទបែបព្រះវិញ្ញាណ" (UR ៨)។

-"គ្រីស្តបរិស័ទគ្រប់និកាយត្រូវតែស្គាល់គ្នាទៅវិញទៅមកក្នុងឋានៈជាបងប្អូន" (UR ៩)។

-គ្រីស្តបរិស័ទ ជាពិសេសលោកបូជាចារ្យ ត្រូវតែទទួល "ការអប់រំអំពីចលនាបង្រួបបង្រួមគ្រីស្តបរិស័ទ" (UR ១០)។

-ទេវវិទូតគ្រប់និកាយត្រូវតែសន្ទនាជាមួយគ្នា ហើយគ្រីស្តបរិស័ទនៃព្រះសហគមន៍ និងសហគមន៍នីមួយៗត្រូវតែជួបជុំគ្នាផងដែរ (UR ៤; ៩; ១១)។

-គ្រីស្តបរិស័ទត្រូវតែរួមសហការជាមួយគ្នា ក្នុងគ្រប់វិស័យ ដើម្បីជួយបម្រើមនុស្សទាំងអស់ (UR ១២)។

៨២២-"ព្រះសហគមន៍ទាំងមូល ទាំងគង្វាល ទាំងគ្រីស្តបរិស័ទធម្មតា ម្នាក់ៗតាមសមត្ថភាពរៀងៗខ្លួន ត្រូវតែយកចិត្តទុកដាក់នាំឲ្យគ្រីស្តបរិស័ទទាំងអស់រួបរួមគាជាធ្លុងតែមួយ" (UR ៥) ប៉ុន្តែ "ត្រូវតែដឹងខ្លួនថា គម្រោងការដ៏សក្ការៈនេះ គឺឲ្យគ្រីស្តបរិស័ទសម្រុះសម្រួលជាមួយគ្នា ក្នុងឯកភាពនៃព្រះសហគមន៍តែមួយរបស់ព្រះគ្រីស្តលើសពីកម្លាំង និងសមត្ថភាពរបស់មនុស្ស"។ ហេតុនេះ យើងសង្ឃឹមទាំងស្រុងទៅក្នុងពាក្យអង្វររបស់ព្រះគ្រីស្តចំពោះព្រះសហគមន៍ ក្នុងសេចក្តីស្រឡាញ់របស់ព្រះបិតាចំពោះយើង និងក្នុងឫទ្ធិនុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធផង" (UR ២៤)។

## ២-ព្រះសហគមន៍ដ៏វិសុទ្ធ

៨២៣-"តាមជំនឿកាតូលិកយើង ព្រះសហគមន៍ពិតជាវិសុទ្ធ ហើយក៏មិនអាចលែងទៅជាវិសុទ្ធថែមទៀតផង។ ក្នុងធម៌ "សូមលើកតម្កើងសិរីរុងរឿង" យើងធ្លាប់ប្រកាសថា ព្រះគ្រីស្តជាព្រះបុត្រា ពិតជា "ព្រះដ៏វិសុទ្ធតែមួយព្រះអង្គទេ" រួមជាមួយព្រះបិតា និងព្រះវិញ្ញាណ។ ព្រះអង្គបានស្រឡាញ់ព្រះសហគមន៍ទុកជាព្រះមហេសី និងបានបូជាព្រះជន្មសម្រាប់ព្រះសហគមន៍ ដើម្បីប្រោសព្រះសហគមន៍ឲ្យបានទៅជាវិសុទ្ធ ទ្រង់បានប្រោសព្រះសហគមន៍ឲ្យភ្ជាប់ជាមួយព្រះអង្គទុកជាព្រះកាយព្រះអង្គ និងបានប្រទានព្រះអំណោយទាននៃព្រះវិញ្ញាណយ៉ាងបរិបូរណ៍ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់" (LG ៣៩)។ ព្រះសហគមន៍ជា "ប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជា

ម្ចាស់" (LG ១២) ហើយសរីរាង្គព្រះសហគមន៍ជា "ជនដ៏វិសុទ្ធ" (កក ៩,១៣)។

៨២៤-ព្រះសហគមន៍រួមជាមួយព្រះគ្រីស្ត ទ្រង់ក៏ប្រោសព្រះសហគមន៍ឲ្យបានវិសុទ្ធតាមព្រះអង្គ និងក្នុងអង្គព្រះអង្គ ព្រះសហគមន៍ផ្ទាល់ប្រោសមនុស្សយើងឲ្យបានវិសុទ្ធ។ "ព្រះរាជកិច្ចទាំងអស់របស់ព្រះសហគមន៍មានគោលដៅប្រោសមនុស្សលោកឲ្យបានវិសុទ្ធក្នុងអង្គព្រះគ្រីស្ត និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់" (SC ១០)។ ព្រះជាម្ចាស់ក៏បានផ្តល់ "មធ្យោបាយទាំងអស់យ៉ាងពេញលេញឲ្យមនុស្សលោកទទួលការសង្គ្រោះ" (UR ៣) ក្នុងព្រះសហគមន៍នេះ។ "យើងក៏បានវិសុទ្ធ (...) ដោយព្រះជាម្ចាស់ប្រោសប្រណី" (LG ៤៨) ក្នុងព្រះសហគមន៍នេះផងដែរ។

៨២៥-"ព្រះសហគមន៍តែងខ្លួនដោយភាពវិសុទ្ធហើយ យ៉ាងពិតប្រាកដមែននៅលើផែនដីនេះ ទោះបីភាពវិសុទ្ធនេះមិនទាន់ពេញលក្ខណៈនៅឡើយក្តី" (LG ៤៨)។ សមាជិកព្រះសហគមន៍ត្រូវតែវិសុទ្ធបានគ្រប់លក្ខណៈ៖ "អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ទោះជាមានឋានៈ ឬមានរបៀបរស់នៅបែបណាក្តី ក៏ទទួលមធ្យោបាយយ៉ាងលើសលប់ និងដ៏ប្រសើរបំផុតដែលនាំការសង្គ្រោះដល់គេ។ ព្រះជាម្ចាស់ត្រាស់ហៅគេម្នាក់ៗ តាមមាគ៌ារបស់ខ្លួនឲ្យបានវិសុទ្ធយ៉ាងពេញលក្ខណៈ ដូចព្រះបិតាពេញលក្ខណៈដូច្នោះដែរ" (LG ១១)។

៨២៦-ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យបានវិសុទ្ធ។ សេចក្តីស្រឡាញ់ជាព្រលឹងនៃភាពដ៏វិសុទ្ធនេះ៖ "សេចក្តីស្រឡាញ់តម្រង់គ្រប់មធ្យោបាយ ដែលនាំឲ្យបានវិសុទ្ធ និងផ្តល់ឲ្យមធ្យោបាយទាំងនេះមានប្រសិទ្ធិភាព និងនាំទៅដល់ទីដៅ" (LG ៤២)៖

> បើព្រះសហគមន៍ជាអង្គភាពប្រមូលផ្តុំសរីរាង្គខុសៗគ្នា អ្នកដែលចាំបាច់ អ្នកដែលសមរម្យជាងគេមិនខ្វះទេ។ ព្រះសហគមន៍មានបេះដូងៗនេះកំពុងតែដុតរោលដោយសេចក្តីស្រឡាញ់។ ខ្ញុំយល់ថាមានតែសេចក្តីស្រឡាញ់ទេ ដែលធ្វើឲ្យសរីរាង្គព្រះសហគមន៍មានសកម្មភាព បើសេចក្តីស្រឡាញ់រលត់ គ្រីស្តទូតលែងប្រកាសដំណឹងល្អ មរណៈសាក្សីមិនព្រមបូជាជីវិតទៀតទេ... ខ្ញុំយល់ថាសេចក្តីស្រឡាញ់ផ្ទុកទៅដោយការត្រាស់ហៅទាំងអស់ សេចក្តីស្រឡាញ់ជាអ្វីៗទាំងអស់ ទាំងអស់ដែលគ្រប់ដណ្តប់គ្រប់ពេល និងគ្រប់ទីកន្លែង និយាយឲ្យខ្លីទៅ សេចក្តីស្រឡាញ់ស្ថិតនៅអស់កល្បជានិច្ច!" (សន្តី ថេរ៉េសនៃព្រះកុមារយេស៊ូ)។

៨២៧-"ព្រះគ្រីស្តជាអ្នកដ៏វិសុទ្ធ ឥតសៅហ្មង គ្មានទោសអ្វីឡើយ ព្រះអង្គមិនដែលប្រព្រឹត្តអំពើបាបទាល់តែសោះ ព្រះអង្គយាងមករំដោះប្រជាជនឲ្យបានរួចពីបាប ព្រះសហគមន៍ក៏ដូច្នេះដែរ ទោះបីមានអ្នកបាបនៅក្នុងផ្ទៃព្រះសហគមន៍ក្តី ក៏ព្រះសហគមន៍នៅតែវិសុទ្ធ និងត្រូវជម្រះខ្លួនជានិច្ច ហើយនៅតែបន្តខិតខំប្រែចិត្តគំនិតឲ្យបានថ្មីជានិច្ចដែរ" (LG ៨; UR ៣;៦)។ សរីរាង្គទាំងអស់របស់ព្រះសហគមន៍ ព្រមទាំងអ្នកទទួលបន្ទុកបម្រើព្រះសហគមន៍ត្រូវតែទទួលស្គាល់ថា ខ្លួនជាអ្នកបាប (១យហ ១,៨-១០)។ នៅក្នុងគេទាំងអស់គ្នាស្រងែបាបនៅតែលាយឡំនឹងស្រូវដំណើងល្អរហូតដល់អវសានកាលនៃពិភពលោក (មថ ១៣,២៤-៣០)។ ដូច្នេះព្រះសហគមន៍ប្រមែប្រមូលអ្នកបាបដែលព្រះគ្រីស្តបានសង្គ្រោះ ប៉ុន្តែអ្នកទាំងអស់នោះនៅតែដើរតាមផ្លូវនៃភាពដ៏វិសុទ្ធ៖

> ព្រះសហគមន៍ដ៏វិសុទ្ធទាំងមានអ្នកបាបនៅក្នុងខ្លួន ដ្បិតព្រះសហគមន៍គ្មានជីវិតក្រៅពីព្រះហឫទ័យប្រណីសន្តោសទេ គឺដោយទទួលជីវិតពីព្រះសហគមន៍ សរីរាង្គព្រះសហគមន៍បានវិសុទ្ធដោយមិនព្រមទទួលជីវិតនោះឡើយ ពួកគេធ្លាក់ខ្លួនជាអ្នកបាប និងក្នុងភាពច្របូកច្របល់ដែលរារាំងភាពដ៏វិសុទ្ធរបស់ព្រះសហគមន៍មិនអាចបំភ្លឺពួកគេបានឡើយ។ ហេតុនេះហើយបានជាព្រះសហគមន៍រងទុក្ខលំបាក និងសោកស្តាយនូវកំហុសទាំងនោះ។ ព្រះសហគមន៍ក៏មានអំណាចព្យាបាលកូនៗរបស់ខ្លួនដោយព្រះលោហិតព្រះគ្រីស្ត

និងព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ (SPF ១៩)។

៨២៨-ដោយប្រោសគ្រីស្តបរិស័ទឲ្យបានទៅជាសន្តបុគ្គល គឺដោយប្រកាសយ៉ាងឧឡារិកថាគ្រីស្តបរិស័ទនោះបានប្រតិបត្តិតាមគុណធម៌យ៉ាងអស្ចារ្យ និងបានរស់នៅក្នុងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដោយមានចិត្តភក្តី ព្រះសហគមន៍ទទួលស្គាល់នូវឫទ្ធានុភាពរបស់ព្រះវិញ្ញាណនៃភាពដ៏វិសុទ្ធដែលស្ថិតនៅក្នុងខ្លួន ហើយជួយគាំទ្រសេចក្តីសង្ឃឹមរបស់គ្រីស្តបរិស័ទ ដោយផ្តល់គំរូ និងអ្នកជួយទូលអង្វរព្រះជាម្ចាស់ឲ្យពួកគេ (LG ៤០; ៤៨-៥១)។ "សន្តៈ និងសន្តីបុគ្គលតែងតែជាប្រភព និងដើមហេតុឲ្យព្រះសហគមន៍កើតសាជាថ្មីម្តងទៀតក្នុងគ្រាដ៏លំបាកជាងគេនៃប្រវត្តិសាស្ត្រព្រះសហគមន៍ (CL ១៦,៣)។ "ភាពដ៏វិសុទ្ធជាប្រភពសម្ងាត់ និងជាប្រដាប់វាស់នៃសកម្មភាពរបស់ព្រះសហគមន៍ក្នុងការប្រកាសដំណឹងល្អដែលមិនអាចច្រឡំបានទេ"(CL ១៧,៣)។

៨២៩-"ព្រះសហគមន៍បានពេញលក្ខណៈហើយ គឺឥតស្លាកស្នាម ឥតជ្រីវជ្រួញ និងឥតខ្ចោះត្រង់ណាឡើយ ដោយព្រះនាងព្រហ្មចារីម៉ារីជាតំណាងបានពេញលក្ខណៈ។ ក៏ប៉ុន្តែ គ្រីស្តបរិស័ទនៅតែខិតខំប្រឹងប្រែងឲ្យកាន់តែវិសុទ្ធដើម្បីឈ្នះអំពើបាប។ ហេតុនេះហើយបានជាគ្រីស្តបរិស័ទតែងងើបភ្នែកសម្លឹងមើលនាងម៉ារីជាគំរូ" (LG ៦៥)៖ ដោយរួមជាមួយនាងម៉ារីព្រះសហគមន៍ជាអ្នកដ៏វិសុទ្ធបំផុត។

## ៣-ព្រះសហគមន៍កាតូលិក

### តើ "កាតូលិក" មានអត្ថន័យដូចម្តេចខ្លះ?

៨៣០-ពាក្យ "កាតូលិក" មានន័យថា "សាកល" ពោលគឺ "ទាំងស្រុង" ឬ "យ៉ាងបរិបូរណ៍"។ ព្រះសហគមន៍កាតូលិកមានអត្ថន័យពីរយ៉ាង៖

> ព្រះសហគមន៍កាតូលិក ដ្បិតមានវត្តមានរបស់ព្រះគ្រីស្តនៅក្នុងខ្លួន។ "ទីណាមានព្រះគ្រីស្តយេស៊ូ ទីនោះមានព្រះសហគមន៍កាតូលិក" (សន្តៈ អ៊ីញ៉ាសនៃអង់ទីអូស)។ ព្រះកាយព្រះគ្រីស្តដ៏គ្រប់លក្ខណៈដែលរួមជាមួយព្រះសិរសា (អភ ១,២២-២៣) ស្ថិតនៅក្នុងព្រះសហគមន៍បានសេចក្តីថាព្រះសហគមន៍ទទួលពីព្រះអង្គ "មធ្យោបាយទាំងអស់យ៉ាងពេញលេញឲ្យមនុស្សលោកទទួលការសង្គ្រោះ» (AG ៦) ដែលព្រះអង្គសព្វព្រះហឫទ័យ គឺការប្រកាសជំនឿដ៏ស្មោះ និងយ៉ាងពេញលេញជីវិតខាងអគ្គសញ្ញាយ៉ាងបរិបូរណ៍ និងអ្នកទទួលមុខតំណែងតពីក្រុមគ្រីស្តទូតមក។ ក្នុងអត្ថន័យមូលដ្ឋាននេះ ព្រះសហគមន៍បានទៅជាកាតូលិកនៅថ្ងៃបុណ្យព្រះវិញ្ញាណយាងមក ហើយនឹងនៅតែជាកាតូលិករហូតដល់អវសានកាលនៃពិភពលោក (AG ៤)។

៨៣១-ព្រះសហគមន៍កាតូលិក ដ្បិតព្រះគ្រីស្តចាត់ឲ្យព្រះសហគមន៍ទៅប្រកាសដំណឹងល្អដល់មនុស្សជាតិក្នុងសកលលោកទាំងមូល (មថ ២៨,១៩)៖

> ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យចូលរួមក្នុងប្រជារាស្ត្រព្រះអង្គ។ ទោះបីប្រជារាស្ត្រនេះរួមគ្នាជាធ្លុងតែមួយ និងមានតែមួយគត់ក្តី ក៏ប្រជារាស្ត្រនេះមានទីដៅឲ្យរីកសុះសាយរហូតដល់ចុងកាត់មាត់នៃពិភពលោកទាំងមូល និងនៅគ្រប់សម័យរហូតតរៀងទៅ ដើម្បីឲ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលបង្កើតមនុស្សជាតិ បានកើតជារូបរាង គឺប្រមែប្រមូលកូនចៅរបស់ព្រះអង្គដែលបែកខ្ញែកគ្នា មករួបរួមគ្នាជាប្រជាជនតែមួយជាស្ថាពរ (...)។ ព្រះអម្ចាស់ផ្ទាល់ប្រោសប្រទានឲ្យប្រជារាស្ត្ររបស់ព្រះអង្គមានលក្ខណៈសកល។ ដូច្នេះ ដោយព្រះអំណាយទាននោះ ព្រះសហគមន៍កាតូលិកយកចិត្តទុកដាក់យ៉ាងស័ក្តិសិទ្ធិ និងជានិច្ចនិរន្តរ៍

ដើម្បីប្រមែប្រមូលមនុស្សជាតិទាំងមូល និងអ្វីៗទាំងអស់ដ៏ល្អប្រសើរ ដែលស្ថិតនៅក្នុងមនុស្សជាតិនោះ ឲ្យរួមគ្នាជាធ្លុងតែមួយ ក្រោមអំណាចរបស់ព្រះគ្រីស្តជាអម្ចាស់ ដោយសារព្រះវិញ្ញាណព្រះអង្គ (LG ១៣)។

## ព្រះសហគមន៍ភូមិភាគនីមួយៗជាព្រះសហគមន៍កាតូលិក

៨៣២-"ព្រះសហគមន៍របស់ព្រះគ្រីស្តនេះ ពិតជាស្ថិតនៅក្នុងគ្រប់អង្គប្រជុំត្រឹមត្រូវតាមច្បាប់របស់គ្រីស្តបរិស័ទនៅតាមភូមិនានា បើគេរួមជាមួយគង្វាលរបស់គេ។ ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី អង្គប្រជុំទាំងនោះទទួលឈ្មោះថា "ព្រះសហគមន៍" (...)។ ការប្រកាសដំណឹងល្អរបស់ព្រះគ្រីស្តប្រមែប្រមូលគ្រីស្តបរិស័ទក្នុងព្រះសហគមន៍ទាំងនោះ គេធ្វើពិធីជប់លៀងរបស់ព្រះអម្ចាស់ (...)។ ទោះបីសហគមន៍ទាំងនេះតូច ឬក្រីក្រយ៉ាងណាក្តី ជួនកាលខ្ចាត់ខ្ចាយយ៉ាងណាក្តី ក៏ព្រះគ្រីស្តគង់នៅជាមួយដែរ គឺដោយសារឫទ្ធានុភាពរបស់ព្រះអង្គ ព្រះសហគមន៍តាំងឡើងជាអង្គតែមួយដ៏វិសុទ្ធ កាតូលិក និងមានជំនឿរបស់គ្រីស្តទូតជាគ្រឹះ" (LG ២៦)។

៨៣៣-ព្រះសហគមន៍ភូមិភាគ (ភូមិភាគ) ជាសហគមន៍របស់គ្រីស្តបរិស័ទដែលរួមរស់ខាងជំនឿ និងខាងអគ្គសញ្ញាជាមួយលោកអភិបាល ដែលបានទទួលតែងតាំងពីក្រុមគ្រីស្តទូតមក (CD ១១; CIC ៣៦៨-៣៦៩)។ "ព្រះសហគមន៍ភូមិភាគនោះក៏មានការចាត់ចែងជាព្រះសហគមន៍សាកល គឺមានព្រះសហគមន៍កាតូលិកសាកលតែមួយ ដោយមានព្រះសហគមន៍ភូមិភាគ" (LG ២៣)។

៨៣៤-ព្រះសហគមន៍ភូមិភាគ ជាព្រះសហគមន៍កាតូលិកមានលក្ខណៈពេញលេញដោយរួមរស់ជាមួយព្រះសហគមន៍ភូមិភាគមួយ គឺព្រះសហគមន៍នៅទីក្រុងរ៉ូមដែល "គ្រប់គ្រងដោយសេចក្តីស្រឡាញ់" (សន្ត: នៃអង់ទីអូស)។ "ដ្បិតដោយសារប្រភពដ៏ប្រសើរនៃព្រះសហគមន៍នេះ ព្រះសហគមន៍នីមួយៗ គឺគ្រីស្តបរិស័ទពីគ្រប់កន្លែងក៏ត្រូវតែរួមរស់ជាមួយព្រះសហគមន៍នេះ" (សន្ត: អ៊ីរ៉េណេ)។" ចាប់តាំងពីព្រះបន្ទូលកើតជាមនុស្សបានយាងចុះមករកយើង ព្រះសហគមន៍គ្រីស្តបរិស័ទពីគ្រប់ទិសទីបានចាត់ទុកថាព្រះសហគមន៍ដ៏ប្រសើរដែលនៅទីនេះ (ទីក្រុងរ៉ូម) ជាមូលដ្ឋានគ្រឹះតែមួយ ដ្បិតតាមព្រះបន្ទូលសន្យាផ្ទាល់របស់ព្រះអម្ចាស់ទ្វារនៃឋាននរកមិនដែលបានឈ្នះលើព្រះសហគមន៍នេះឡើយ" (សន្ត: ម៉ាកស៊ីម)។

៨៣៥-"មិនត្រូវចាត់ទុកថាព្រះសហគមន៍សាកលដូចជាចំនួនបូករួម ឬសហព័ន្ធរបស់ព្រះសហគមន៍ភូមិភាគទេ គឺព្រះសហគមន៍ដែលព្រះជាម្ចាស់ត្រាស់ហៅហើយប្រទានបេសកកម្មឲ្យទៅជាសាកល ចាក់ឫសក្នុងវប្បធម៌សង្គម និងមនុស្សខុសប្លែកពីគ្នា ដោយទទួលយករូបរាងផ្សេងៗក្នុងផ្នែកផ្សេងៗនៃពិភពលោក" (EN ៦២)។ វិន័យព្រះសហគមន៍ ពិធីបុណ្យ និងទ្រព្យសម្បត្តិខាងទេវវិទ្យា និងខាងវិញ្ញាណផ្សេងៗដែលជារបស់ព្រះសហគមន៍ភូមិភាគ "បង្ហាញឲ្យឃើញកាន់តែច្បាស់ថា ព្រះសហគមន៍មានលក្ខណៈជា «កាតូលិក» គឺបំបែកមិនបានឡើយ" (LG ២៣)។

## តើនរណាជាសមាជិកព្រះសហគមន៍កាតូលិក?

៨៣៦-"ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យរួបរួមគ្នាបែបសាកល ចូលក្នុងប្រជារាស្ត្ររបស់ព្រះអង្គ (...)។ ព្រះជាម្ចាស់ប្រោសប្រណីត្រាស់ហៅគ្រីស្តបរិស័ទកាតូលិកទាំងអស់ និងអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្តតាមរបៀបផ្សេងៗពីគ្នា និងមនុស្សទាំងអស់ ឥតមានចោលនរណាឡើយ ឲ្យមកទទួលការសង្គ្រោះ។ គេទាំងអស់គ្នាក៏តម្រង់ទៅរកការរួបរួមគ្នាក្នុងឯកភាពនេះតាមរបៀបផ្សេងៗពីគ្នា" (LG ១៣)។

៨៣៧-"អស់អ្នកដែលទទួលព្រះវិញ្ញាណរបស់ព្រះគ្រីស្ត ហើយសុខចិត្តទទួលស្គាល់ការចាត់ចែងទាំងស្រុងរបស់

ព្រះសហគមន៍ និងសុខចិត្តទទួលស្គាល់មធ្យោបាយទាំងប៉ុន្មានសម្រាប់ចែកការសង្គ្រោះ ដូចមានចាត់ចែងក្នុងព្រះសហគមន៍នោះ ពិតជាចូលរួមយ៉ាងពេញលេញក្នុងសង្គមនៃព្រះសហគមន៍មែន។ លើសពីនេះទៅទៀត គេជាប់ចំណងក្នុងព្រះសហគមន៍ជាអង្គប្រជុំដែលមើលឃើញដោយការប្រកាសជំនឿ ដោយការទទួលអគ្គសញ្ញានានា ដោយការត្រួតត្រារបស់អស់លោកអភិបាល និងដោយការរួបរួមគ្នា។ គេក៏រួបរួមជាមួយព្រះគ្រីស្ត ដែលណែនាំព្រះសហគមន៍ដោយសារអភិបាលព្រះសហគមន៍ក្រុងរ៉ូម និងដោយអភិបាលនានា។ ក៏ប៉ុន្តែ អ្នកចូលរួមក្នុងព្រះសហគមន៍ បើគេមិនទទួលការធានាថានឹងទទួលការសង្គ្រោះ មិនព្យាយាមក្នុងសេចក្តីស្រឡាញ់ទេ គេនៅជាសមាជិកនៃព្រះសហគមន៍ គឺខាងរូបកាយ តែមិនមែនខាងចិត្តទេ" (LG ១៤)។

៨៣៨-"ព្រះសហគមន៍ដឹងថា ខ្លួនមានចំណងជាច្រើនភ្ជាប់ជាមួយបងប្អូន ដែលមានឈ្មោះដ៏ប្រសើរថាជាគ្រីស្តបរិស័ទ ព្រោះគេបានទទួលអគ្គសញ្ញាជ្រមុជទឹក។ ទោះបីបងប្អូនទាំងនោះមិនប្រកាន់ជំនឿគ្រប់ប្រការក្តី ឬមិនរួបរួមក្នុងឯកភាពក្រោមការដឹកនាំអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបន្តមុខងារពីគ្រីស្តទូតសិលាមកក្តី ក៏គេជាគ្រីស្តបរិស័ទដែរ" (LG ១៥)។ "អស់អ្នកដែលជឿលើព្រះគ្រីស្ត ហើយដែលបានទទួលបុណ្យជ្រមុជទឹកយ៉ាងត្រឹមត្រូវ ក៏រួមរស់ជាមួយព្រះសហគមន៍កាតូលិកខ្លះដែរ ទោះបីគេមិនរួមយ៉ាងពេញលេញក៏ដោយ" (UR ៣)។ ព្រះសហគមន៍អ័រតូដុក្សរួមរស់ជាមួយគ្នានេះស៊ីជម្រៅបំផុត "មានខ្វះចំណុចតិចតួចតែប៉ុណ្ណោះ ឲ្យការរួមរស់បានគ្រប់លក្ខណៈ និងអាចថ្វាយអភិបូជារួមគ្នា" (សម្តេចប៉ាប ប៉ូលទី៦; UR ១៣-១៨)។

### ព្រះសហគមន៍ និងអស់អ្នកដែលមិនមែនជាគ្រីស្តបរិស័ទ

៨៣៩-"ចំពោះបងប្អូនដែលមិនទាន់ទទួលដំណឹងល្អ ជីវិតបងប្អូនក៏មានទីដៅតម្រង់ទៅកាន់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់តាមរបៀបផ្សេងៗដែរ" (LG ១៦)៖

> ទំនាក់ទំនងរវាងព្រះសហគមន៍ និងប្រជាជាតិយូដា។ ដោយពិចារណាអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ទៅលើព្រះសហគមន៍ ព្រះសហគមន៍ដែលជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ក្នុងសម្ព័ន្ធមេត្រីថ្មី យល់ឃើញថា ខ្លួនជាប់ចំណងជាមួយប្រជាជាតិយូដា (NA ៤) ដែល "ព្រះជាម្ចាស់មានព្រះបន្ទូលមុនគេបង្អស់" (MR)។ ជំនឿជនជាតិយូដាផ្សេងពីសាសនាដទៃ ក្រៅពីគ្រីស្តសាសនា ដ្បិតជាចម្លើយនឹងព្រះជាម្ចាស់ដែលសម្តែងព្រះអង្គក្នុងសម្ព័ន្ធមេត្រីចាស់ហើយ។ "ព្រះជាម្ចាស់បានរាប់ (ជនជាតិយូដា) ទុកជាបុត្រធីតារបស់ព្រះអង្គ ពួកគេមានសិរីរុងរឿងមានសម្ព័ន្ធមេត្រីនានា មានធម្មវិន័យ ស្គាល់របៀបគោរពបម្រើព្រះអង្គ ទទួលព្រះបន្ទូលសន្យាផ្សេងៗ មានបុព្វបុរស ហើយព្រះគ្រីស្តក៏កើតមកជាមនុស្សក្នុងពូជពង្សរបស់ពួកគេថែមទៀងផង" (រម ៩,៤-៥) ដ្បិត "កាលណាព្រះជាម្ចាស់ប្រទានព្រះអំណោយទានហើយ ព្រះអង្គមិនដកហូតវិញទេ ហើយកាលណាព្រះជាម្ចាស់ត្រាស់ហៅ ទ្រង់ក៏មិនប្រែប្រួលដែរ" (រម ១១,២៩)។

៨៤០-ដោយឡែកពេលគិតអំពីអនាគតប្រជារាស្ត្រនៃសម្ព័ន្ធមេត្រីចាស់ និងប្រជារាស្ត្រថ្មីឆ្ពោះទៅគោលដៅតែមួយ គឺគេរង់ចាំឲ្យព្រះមេស្ស៊ីយាងមក (វិញ)។ ប៉ុន្តែអ្នកម្ខាងរង់ចាំឲ្យព្រះមេស្ស៊ីដែលបានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញដែលគេទទួលស្គាល់ថា ជាព្រះអម្ចាស់ និងព្រះបុត្រារបស់ព្រះជាម្ចាស់ ទ្រង់នឹងយាងមកវិញ ឯអ្នកម្ខាងទៀតដោយមិនស្គាល់ ឬមិនព្រមទទួលស្គាល់ព្រះគ្រីស្តយេស៊ូ គេរង់ចាំឲ្យព្រះមេស្ស៊ីដែលគេមិនទាន់ស្គាល់ច្បាស់យាងមកពេលអវសានកាលនៃពិភពលោក។

៨៤១-ទំនាក់ទំនងរវាងព្រះសហគមន៍ និងអ្នកកាន់សាសនាអ៊ីស្លាម៖ "ព្រះជាម្ចាស់មានគម្រោងការសង្គ្រោះ

អស់មនុស្សណាដែលទទួលស្គាល់ព្រះអង្គ ទុកជាព្រះដែលបង្កើតអ្វីៗទាំងអស់ មានបងប្អូនអ៊ីស្លាមជាដើម ដែលប្រកាសជំនឿរបស់លោក អាប្រាហាំ គេក្រាបថ្វាយបង្គំព្រះជាម្ចាស់តែមួយព្រះអង្គគត់ដូចយើង ជាព្រះប្រកបដោយព្រះហឫទ័យមេត្តាករុណា ជាចៅក្រមដែលនឹងវិនិច្ឆ័យមនុស្សលោក នៅថ្ងៃចុងក្រោយបំផុត" (LG ១៦; NA ៣)។

៨៤២-ព្រះសហគមន៍ និងសាសនាដទៃជាប់ចំណងនឹងគ្នាអំពីប្រភព និងទីចុងក្រោយរបស់មនុស្សជាតិ៖

> ប្រជាជាតិទាំងអស់ចូលរួមជាសហគមន៍តែមួយ។ ប្រជាជាតិទាំងអស់មានប្រភពតែមួយ ព្រោះព្រះជាម្ចាស់បានប្រោសប្រទានឲ្យមនុស្សរស់នៅពាសពេញនៅលើផែនដី។ ជីវិតមនុស្សគ្រប់ៗរូបក៏មានទិសដៅតែមួយដែរ គឺរួមរស់ជាមួយព្រះជាម្ចាស់ដែលទ្រង់មានធម៌មេត្តាករុណាសប្បុរសថែរក្សាមនុស្សទាំងអស់ ព្រះអង្គក៏មានគម្រោងការចង់សង្គ្រោះមនុស្សទាំងអស់ដែរ រហូតដល់ពេលមនុស្សទាំងអស់ដែលទ្រង់បានជ្រើសរើសបានរួមគ្នានៅក្នុងបុរីដ៏វិសុទ្ធរបស់ព្រះអង្គ (NA ១)។

៨៤៣-ព្រះសហគមន៍ទទួលស្គាល់ថា សាសនាដទៃស្វែងរក "តាមស្រមោល និងតាមនិមិត្តរូប" ព្រះជាម្ចាស់ដែលគេមិនស្គាល់ព្រះអង្គក៏មិនស្ថិតនៅឆ្ងាយពីគេដែរ ព្រោះព្រះអង្គទេតើដែលបានប្រទានជីវិត ប្រទានដង្ហើម និងប្រទានអ្វីៗសព្វគ្រប់ទាំងអស់មកមនុស្ស។ ព្រះអង្គជាព្រះសង្គ្រោះ ទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ (...)។ ព្រះសហគមន៍យល់ឃើញថា អ្វីៗដ៏ល្អ និងដ៏ពិតប្រាកដនៅក្នុងចំណោមពួកគេសុទ្ធតែជាអ្វីដែលត្រៀមទទួលដំណឹងល្អ ឬទុកជាព្រះអំណោយទានរបស់ព្រះអង្គដែលបំភ្លឺចិត្តគំនិតមនុស្សគ្រប់ៗគ្នា ដើម្បីឲ្យគេមានជីវិត" (LG ១៦)។

៨៤៤-ក៏ប៉ុន្តែក្នុងការប្រតិបត្តិសាសនារបស់គេមនុស្សលោកបបង្ហាញថាគេមានកំណត់ និងប្រព្រឹត្តកំហុសបណ្ដាលឲ្យគេលែងធ្វើជារូបតំណាងរបស់ព្រះជាម្ចាស់៖

> មារកំណាចបានបញ្ឆោតមនុស្សជាច្រើន និងជាញឹកញាប់ឲ្យវង្វេងទៅតាមការរិះគិតរបស់ខ្លួន ហើយគេក៏បោះបង់សេចក្ដីពិតរបស់ព្រះជាម្ចាស់ចោល បែរទៅរកការភូតភរ ហើយនាំគ្នាគោរពបម្រើសត្វលោកជាជាងគោរពបម្រើព្រះដែលបានបង្កើតអ្វីៗទាំងអស់នោះវិញ។ គេរស់នៅ និងស្លាប់ក្នុងលោកនេះដោយមិនគោរពបម្រើព្រះណាមួយព្រះអង្គសោះ គេមុខជាអស់សង្ឃឹម (LG ១៦)។

៨៤៥-ព្រះបិតាសព្វព្រះហឫទ័យត្រាស់ហៅមនុស្សលោកទាំងអស់ក្នុងព្រះសហគមន៍នៃព្រះបុត្រារបស់ព្រះអង្គដើម្បីប្រមែប្រមូលសាជាថ្មីម្ដងទៀតកូនចៅទាំងអស់របស់ព្រះអង្គដែលអំពើបាបបានកម្ចាត់កម្ចាយ និងបានធ្វើឲ្យវង្វេង។ ព្រះសហគមន៍ជាកន្លែងដែលមនុស្សលោកទាំងមូលត្រូវរួបរួមជាមួយគ្នាឡើងវិញ និងទទួលការសង្គ្រោះ។ ព្រះសហគមន៍ជា "ពិភពលោកដែលព្រះជាម្ចាស់បានសម្រុះសម្រួលឲ្យជានានឹងព្រះអង្គ" (សន្តៈ អូគូស្តាំង)។ ព្រះសហគមន៍ជានាវាដែល "ធ្វើដំណើរក្នុងពិភពនេះក្រោមខ្យល់នៃព្រះវិញ្ញាណដ៏វិសុទ្ធដោយមានព្រះឈើឆ្កាងរបស់ព្រះអម្ចាស់ជាក្ដោង" (សន្តៈ អំប្រ័រ)។ តាមការប្រៀបធៀបដ៏ថ្លៃថ្លានៃគ្រូបាធ្យាយ ព្រះសហគមន៍ដូចជាសំពៅរបស់លោក ណូអេ ជាសំពៅតែមួយដែលស្រោចស្រង់ពីទឹកជំនន់ (១ពត្រ ៣,២០-២១)។

### "ក្រៅពីព្រះសហគមន៍គ្មានការសង្គ្រោះទេ"

៨៤៦-តើត្រូវយល់ការអះអាងនេះដែលគ្រូបាធ្យាយបានប្រើជាញឹកញាប់យ៉ាងដូចម្ដេច? បើនិយាយតាមរបៀបវិជ្ជមានទៅពាក្យសម្ដីនេះមានន័យថា ការសង្គ្រោះមកពីព្រះគ្រីស្តជាព្រះសិរសា តាមរយៈព្រះសហគមន៍ជាព្រះកាយព្រះអង្គ៖

> មហាសន្និបាតសំអាងលើព្រះគម្ពីរ និងលើការបញ្ជូនបន្តមកបង្រៀនថា ព្រះសហគមន៍ដែលកំពង់ធ្វើដំណើរនៅលើផែនដីនេះ មានសារៈសំខាន់ជាចាំបាច់ ដើម្បីឲ្យមនុស្សលោកទទួលការសង្គ្រោះ។ មានតែព្រះគ្រីស្តមួយព្រះអង្គគត់ជាស្ពានមេត្រី និងជាមាគ៌ាទៅកាន់ការសង្គ្រោះ។ ព្រះអង្គមានវត្តមានគង់នៅជាមួយយើងក្នុងព្រះកាយព្រះអង្គ គឺក្នុងព្រះសហគមន៍។ ព្រះអង្គបង្រៀនយើងយ៉ាងច្បាស់ថា មនុស្សត្រូវតែធ្វើជីវិតលើព្រះអង្គ និងទទួលអគ្គសញ្ញាជ្រមុជទឹកជាចំបាច់ ព្រះអង្គក៏បង្រៀនបញ្ជាក់យើងនៅពេលជាមួយគ្នាអំពីការចំបាច់នៃព្រះសហគមន៍ ព្រោះមនុស្សចូលក្នុងព្រះសហគមន៍ដោយអគ្គសញ្ញាជ្រមុជទឹកជាទ្វារ។ ហេតុនេះអស់អ្នកដែលបដិសេធមិនព្រមចូលព្រះសហគមន៍កាតូលិក ឬបដិសេធមិនព្រមព្យាយាមនៅជាប់នឹងព្រះសហគមន៍កាតូលិក ទោះបីគេដឹងច្បាស់ថា ព្រះជាម្ចាស់បានបង្កើតព្រះសហគមន៍នេះដោយសារព្រះយេស៊ូគ្រីស្តទុកជាការចំបាច់ក្តី អ្នកទាំងនោះពុំអាចទទួលការសង្គ្រោះបានទេ (LG ១៤)។

៨៤៧-ការអះអាងនេះមិនសំដៅលើអស់អ្នកដែលមិនស្គាល់ព្រះគ្រីស្ត និងព្រះសហគមន៍របស់ព្រះអង្គដោយគេមិនបានធ្វើកំហុសផ្ទាល់ខ្លួន៖

> អស់អ្នកដែលមិនស្គាល់ដំណឹងល្អរបស់ព្រះគ្រីស្ត និងរបស់ព្រះសហគមន៍ (ដោយគេមិនធ្វើកំហុសផ្ទាល់ខ្លួន) បើគេស្វែងរកព្រះជាម្ចាស់ដោយចិត្តស្មោះ និងខិតខំរស់នៅដោយប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គតាមមនសិការដែលបង្ហាញ និងបញ្ជាឲ្យប្រព្រឹត្តនោះ អ្នកទាំងនោះក៏អាចឈានទៅដល់ការសង្គ្រោះអស់កល្បជានិច្ចបានដែរ (LG ១៦; DS ៣៨៦៦-៣៨៧២)។

៨៤៨-"ទោះបីព្រះជាម្ចាស់អាចណែនាំមនុស្សដែលមិនទាន់ស្គាល់ដំណឹងល្អ (ដោយគេមិនធ្វើកំហុសផ្ទាល់ខ្លួន) ឲ្យជឿលើព្រះអង្គបានតាមផ្លូវដែលមានតែព្រះអង្គស្គាល់នោះ គឺឲ្យមានជំនឿ "ដែលធ្វើឲ្យមនុស្សអាចគាប់ព្រះហឫទ័យព្រះជាម្ចាស់បាន" (ហប ១១,៦) ក៏ព្រះសហគមន៍មានកាតព្វកិច្ចប្រកាសដំណឹងល្អ ហើយក៏មានសិទ្ធិនេះមកពីព្រះជាម្ចាស់ដែរ។ ហេតុនេះហើយបានជាព្រះសហគមន៍ត្រូវមានសកម្មភាពប្រកាសដំណឹងល្អទុកជាការចាំបាច់ និងប្រើកម្លាំងខ្លាំងក្លាគ្រប់ជំពូកនៅពេលនេះ ក៏ដូចជានៅគ្រប់សម័យ" (AG ៧)។

### ព្រះសហគមន៍កាតូលិកត្រូវតែប្រកាសដំណឹងល្អជាចាំបាច់

៨៤៩-ព្រះសហគមន៍បានទទួលបេសកកម្មទៅប្រកាសដំណឹងល្អ។ "ព្រះជាម្ចាស់ចាត់ព្រះសហគមន៍ទៅកាន់សាសន៍ដទៃដើម្បីទៅជា "អគ្គសញ្ញានៃការសង្គ្រោះសម្រាប់មនុស្សទាំងអស់"។ ហេតុនេះហើយបានជាព្រះសហគមន៍ខិតខំអស់ពីសមត្ថភាពប្រកាសដំណឹងល្អឲ្យមនុស្សទាំងអស់ស្របតាមលក្ខណៈដ៏ជ្រាលជ្រៅរបស់ខ្លួនផ្ទាល់ជាព្រះសហគមន៍សាកល និងស្របតាមព្រះបញ្ជារបស់ព្រះយេស៊ូដែលបានបង្កើតព្រះសហគមន៍នោះ (AG ៧)៖ "ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវបង្រៀនគេឲ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក"" (មថ ២៨,១៩-២០)។

៨៥០-ប្រភព និងគោលដៅនៃការប្រកាសដំណឹងល្អ។ បេសកកម្មទៅប្រកាសដំណឹងល្អរបស់ព្រះអម្ចាស់មានប្រភពចេញមកពីសេចក្តីស្រឡាញ់អស់កល្បជានិច្ចរបស់ព្រះត្រៃឯកដ៏វិសុទ្ធបំផុត៖ "ព្រះសហគមន៍តាមសភាពរបស់ខ្លួនជាព្រះសហគមន៍ នៅពេលធ្វើដំណើរក្នុងលោកនេះមានមុខងារប្រកាសដំណឹងល្អ ព្រោះព្រះសហគមន៍កើតឡើងដោយព្រះជាម្ចាស់ជាព្រះបិតាមានគម្រោងការចាត់ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" (AG ២)។ គោល

ដៅចុងក្រោយនៃការប្រកាសដំណឹងល្អមានតែមួយ គឺឲ្យមនុស្សលោកចូលរួមចំណែកក្នុងការរួមរស់រវាងព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណនៃសេចក្ដីស្រឡាញ់ (RM ២៣)។

៨៥១-មូលហេតុនៃការប្រកាសដំណឹងល្អ។ ព្រះសហគមន៍បានទទួលយកកាតព្វកិច្ច និងកម្លាំងទៅប្រកាសដំណឹងល្អពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងអស់៖ "ដ្បិតព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្ដជំរុញយើង" (២ករ ៥,១៤) (AA ៦; RM ១១) ដ្បិតព្រះជាម្ចាស់ "សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់បានទទួលការសង្គ្រោះ និងបានស្គាល់សេចក្ដីពិតយ៉ាងច្បាស់" (២ធម ២,៤)។ ព្រះជាម្ចាស់សព្វព្រះហឫទ័យសង្គ្រោះមនុស្សទាំងអស់ ដោយគេស្គាល់សេចក្ដីពិត។ ការសង្គ្រោះស្ថិតនៅក្នុងសេចក្ដីពិត។ អស់អ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះវិញ្ញាណនៃសេចក្ដីពិត គឺស្ថិតនៅតាមផ្លូវនៃការសង្គ្រោះរួចហើយ ប៉ុន្តែព្រះសហគមន៍ដែលព្រះជាម្ចាស់បានប្រគល់សេចក្ដីពិតនេះត្រូវតែទៅជួបប្រាថ្នារបស់គេ ដើម្បីនាំសេចក្ដីពិតនេះឲ្យគេទទួល។ ព្រះសហគមន៍ប្រកាសដំណឹងល្អ ពីព្រោះព្រះសហគមន៍ជឿថាព្រះជាម្ចាស់មានគម្រោងការសង្គ្រោះសាកលលោកទាំងមូល។

៨៥២-ផ្លូវនៃការប្រកាសដំណឹងល្អ។ "ព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកកំដរព្រះសហគមន៍ក្នុងគ្រប់កិច្ចប្រកាសដំណឹងល្អ" (RM ២១)។ គឺព្រះវិញ្ញាណនេះហើយដែលណែនាំព្រះសហគមន៍នៅតាមផ្លូវនៃការប្រកាសដំណឹងល្អ។ បេសកកម្មរបស់ព្រះសហគមន៍បន្ត និងពង្រីងបេសកកម្មរបស់ព្រះគ្រីស្ដផ្ទាល់តាមដំណើរនៃប្រវត្តិសាស្ត្រ។ ព្រះបិតាចាត់ព្រះគ្រីស្ដឲ្យមកប្រកាសដំណឹងល្អដល់ជនក្រីក្រ។ ព្រះវិញ្ញាណរបស់ព្រះគ្រីស្ដជំរុញព្រះសហគមន៍នោះឲ្យទៅតាមផ្លូវរបស់ព្រះគ្រីស្ដនោះ គឺព្រះសហគមន៍ក៏ត្រូវរស់នៅក្នុងឋានៈជាជនក្រីក្រធ្វើតាមបញ្ជា សុខចិត្តបម្រើគេ និងសុខចិត្តបូជាជីវិត។ ព្រះគ្រីស្ដមានជ័យជម្នះលើសេចក្ដីស្លាប់នេះ ដោយទ្រង់ទទួលព្រះជន្មរស់ឡើងវិញ" (AG៥)។ ហេតុនេះហើយបានជា "ឈាមរបស់មរណៈសាក្សីជាពូជរបស់គ្រីស្ដបរិស័ទ" (ទែរទូលីយ៉ាំង)។

៨៥៣-ក៏ប៉ុន្តែពេលកំពុងធ្វើបូជនិយេចរណ៍ព្រះសហគមន៍ក៏ដកពិសោធន៍អំពី "សារដ៏ថ្លៃថ្នូរដែលខ្លួនសម្ដែងនោះប្លែកដាច់យ៉ាងឆ្ងាយពីភាពទន់ខ្សោយក្នុងឋានៈជាមនុស្សរបស់អស់អ្នកដែលបានទទួលដំណឹងល្អនេះ ទុកជាបញ្ញើដែរ" (GS ៤៣,៦)។ មានតែពេលធ្វើដំណើរដោយ "សោកស្ដាយទោសរបស់ខ្លួន និងកើតសាជាថ្មីម្ដងទៀត" (AG ១) ហើយ "តាមទ្វារចង្អៀតនៃឈើឆ្កាង" (AG ១) ដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់អាចលាតសន្ធឹងព្រះរាជ្យព្រះគ្រីស្ដបាន (RM ១២-២០)។ "ព្រះគ្រីស្ដបានលោះមនុស្សលោកដោយព្រះអង្គរស់នៅជាជនក្រីក្រ និងដោយត្រូវគេបៀតបៀនយ៉ាងណា ព្រះជាម្ចាស់ក៏ត្រាស់ហៅព្រះសហគមន៍ឲ្យរស់នៅក្នុងឋានៈជាអ្នកក្រីក្រ និងត្រូវគេបៀតបៀនយ៉ាងនោះដែរ ដើម្បីចែករំលែកផលនៃការសង្គ្រោះឲ្យមនុស្សលោក" (LG ៨)។

៨៥៤-ដោយបេសកកម្មរបស់ខ្លួនផ្ទាល់ "ព្រះសហគមន៍រួមដំណើរជាមួយមនុស្សជាតិទាំងមូល និងចែងរំលែកជោគវាសនារបស់មនុស្សលោកនៅលើផែនដី។ ព្រះសហគមន៍ក៏ដូចជាមេក្នុងម្សៅ និងដូចជាវិញ្ញាណនៃសង្គមមនុស្សដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យប្រែជានិច្ចក្នុងអង្គព្រះគ្រីស្ដ និងឲ្យក្លាយទៅជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់" (GS ៤០,២)។ ដូច្នេះការខិតខំប្រកាសដំណឹងល្អទាមទារឲ្យមានចិត្តអត់ធ្មត់។ ត្រូវចាប់ផ្ដើមប្រកាសដំណឹងល្អដល់ប្រជាជាតិ និងក្រុមដែលមិនទាន់ជឿលើព្រះគ្រីស្ដ (RM ៤២-៤៧) ហើយត្រូវចាត់តាំងសហគមន៍គ្រីស្ដបរិស័ទដែលទៅជា "សញ្ញាសម្គាល់អំពីព្រះជាម្ចាស់ដែលគង់នៅក្នុងពិភពលោក" (AG ១៥) និងបង្កើតព្រះសហគមន៍ក្នុងភូមិ (RM ៤៨-៤៩)។ ត្រូវព្យាយាមឲ្យដំណឹងល្អកើតស្របតាមវប្បធម៌នៃប្រជាជាតិនានា ដោយដឹងថាយើងពិតជានឹងបរាជ័យមែន។ "ចំពោះមនុស្ស ក្រុមមនុស្ស និងប្រជាជនវិញ ព្រះសហគមន៍ទាក់ទងជាមួយគេ និងជ្រួតជ្រាបក្នុងក្រុមគេបន្តិចម្ដងៗ និងលើកពួកគេក្នុងសេចក្ដីពេញលក្ខណៈរបស់ព្រះសហគមន៍សាកល" (AG ៦)។

៨៥៥-ក្នុងការប្រកាសដំណឹងល្អ ព្រះសហគមន៍ត្រូវខិតខំបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួមគ្នាជាធ្លុងតែមួយ (RM ៥០)។ "តាមការពិត បើគ្រីស្តបរិស័ទបាក់បែកគ្នាគេមិនអាចធ្វើឲ្យព្រះសហគមន៍លក្ខណៈកាតូលិកបានពេញលេញឡើយ។ បងប្អូនទាំងនោះចូលរួមក្នុងព្រះសហគមន៍ដោយសារបុណ្យជ្រមុជទឹក តែគេបែកចេញពីការរួមរស់ដ៏ពេញលេញ។ ព្រះសហគមន៍ផ្ទាល់ក៏កាន់តែពិបាកបង្ហាញលក្ខណៈកាតូលិករបស់ខ្លួនឲ្យបានគ្រប់ជំពូកក្នុងការរស់នៅជាធម្មតាដែរ" (UR ៤)។

៨៥៦-ក្នុងការប្រកាសដំណឹងល្អ ព្រះសហគមន៍ត្រូវមានទំនាក់ទំនងជាមួយអស់អ្នកដែលមិនទាន់ទទួលដំណឹងល្អដោយគោរពពួកគេផង (RM ៥៥)។ ក្នុងទំនាក់ទំនងនោះអ្នកជឿអាចទទួលផលប្រយោជន៍សម្រាប់គេផ្ទាល់ដោយទទួលស្គាល់នូវ "អ្វីៗដែលជាការពិតប្រាកដ និងអ្វីៗដែលព្រះជាម្ចាស់បង្កប់ទុកអំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ (...) ជាវត្តមានដ៏លាក់កំបាំងរបស់ព្រះអង្គក្នុងប្រជារាស្ត្រនេះ" (AG ៩)។ បើគេប្រកាសដំណឹងល្អដល់អស់អ្នកដែលមិនទាន់ស្គាល់ដំណឹងល្អនោះ ដើម្បីពង្រឹងបំពេញ និងបង្ហាញសេចក្តីពិត ហើយនឹងសេចក្តីល្អដែលព្រះជាម្ចាស់បានលាតត្រដាងក្នុងចំណោមមនុស្សលោក និងប្រជាជាតិនានាដើម្បីបន្សុទ្ធគេពីកំហុស និងសេចក្តីអាក្រក់ហើយ "ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងដើម្បីឲ្យមារបាត់បង់អំណាចព្រមទាំងឲ្យមនុស្សលោកបានសេចក្តីសុខសាន្ត" (AG ៩)។

### ៤-ព្រះសហគមន៍មានក្រុមគ្រីស្តទូតជាគ្រឹះ

៨៥៧-ព្រះសហគមន៍មានក្រុមគ្រីស្តទូតជាគ្រឹះបានសេចក្តីថា៖

-ព្រះជាម្ចាស់បានកសាង និងនៅតែកសាងព្រះសហគមន៍ "ដោយមានក្រុមគ្រីស្តទូត (...) ជាគ្រឹះ" (អភ ២,២០; វវ ២១,១៤) ជាសាក្សីដែលព្រះគ្រីស្តផ្ទាល់បានជ្រើសរើស និងចាត់ឲ្យទៅប្រកាសដំណឹងល្អ (មថ ២៨,១៦-២០)។

-ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតនៅក្នុងខ្លួន ព្រះសហគមន៍រក្សាទុក និងបញ្ជូនការប្រៀនប្រដៅ (កក ២,៤២) អ្វីៗដ៏ល្អដែលព្រះអង្គផ្ញើទុក និងព្រះបន្ទូលដ៏ត្រឹមត្រូវដែលយើងបានទទួលពីក្រុមគ្រីស្តទូតមក (២ធម ១,១៣-១៤)។

-ក្រុមគ្រីស្តទូតនៅតែប្រៀនប្រដៅណែនាំ និងធ្វើឲ្យព្រះសហគមន៍បានវិសុទ្ធដោយសារអ្នកបន្តមុខងារពីក្រុមគ្រីស្តទូត ពោលគឺក្រុមលោកអភិបាល "ដោយមានក្រុមបូជាចារ្យជួយផង និងដោយរួមជាមួយលោកអភិបាលដែលបន្តមុខងារពីគ្រីស្តទូតសិលាមក ជាគង្វាលដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះសហគមន៍" (AG ៥)។

ឱព្រះបិតាដ៏មានជីវិតអស់កល្បជានិច្ច! ព្រះអង្គមិនលះបង់ហ្វូងចៀមរបស់ព្រះអង្គចោលទេ តែទ្រង់រក្សាទុកហ្វូងនេះដោយមានក្រុមគ្រីស្តទូតដ៏មានសុភមង្គល ក្រោមឫទ្ធានុភាពរបស់ព្រះអង្គ។ ព្រះអង្គក៏នៅតែណែនាំហ្វូងនេះ ដោយមានគង្វាលដដែលនោះ ដែលបន្តព្រះរាជកិច្ចរបស់ព្រះបុត្រាព្រះអង្គរហូតដល់សព្វថ្ងៃនេះ (MR)។

### បេសកកម្មរបស់ក្រុមគ្រីស្តទូត

៨៥៨-ព្រះបិតាបានចាត់ព្រះយេស៊ូឲ្យមក។ ចាប់ពីព្រះអង្គចាប់ផ្តើមប្រកាសដំណឹងល្អព្រះអង្គ "បានត្រាស់ហៅអស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យជ្រើសរើស ហើយអ្នកទាំងនោះក៏ចូលមកគាល់ព្រះអង្គ។ ព្រះអង្គតែងតាំងសាវ័កដប់ពីររូបឲ្យគេនៅជាមួយព្រះអង្គ និងដើម្បីចាត់គេឲ្យទៅប្រកាសដំណឹងល្អ" (មក ៣,១៣-១៤)។ ពីពេលនោះទៅ ពួកគេនឹងទៅជា "ទូត" របស់ព្រះអង្គ (ជាភាសាក្រិក apostoloi បានសេចក្តីថា "ចាត់ឲ្យទៅ")។

នៅក្នុងពួកគេ ព្រះអង្គបន្តបេសកកម្មរបស់ព្រះអង្គផ្ទាល់៖ "ដូចព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅយ៉ាងនោះដែរ" (យហ ២០,២១) (យហ ១៣,២០; ១៧,១៨)។ ដូច្នេះក្រុមគ្រីស្តទូតមានមុខងារបន្តបេសកកម្មរបស់ព្រះអង្គផ្ទាល់។ ព្រះយេស៊ូមានព្រះបន្ទូលទៅគ្រីស្តទូតដប់ពីររូបថា៖ "អ្នកណាទទួលអ្នករាល់គ្នាក៏ដូចជាទទួលខ្ញុំដែរ" (មថ ១០,៤០) (លក ១០,១៦)។

៨៥៩-ព្រះយេស៊ូប្រោសឲ្យគេរួមក្នុងបេសកកម្មរបស់ព្រះអង្គ ដែលទ្រង់បានទទួលពីព្រះបិតា៖ ដូច "ព្រះបុត្រាមិនអាចធ្វើអ្វីដោយព្រះអង្គផ្ទាល់បានឡើយ" (យហ ៥,១៩.៣០) តែទ្រង់បានទទួលអ្វីៗទាំងអស់ពីព្រះបិតាដែលចាត់ព្រះអង្គឲ្យទៅយ៉ាងណា អស់អ្នកដែលទទួលបេសកកម្ម និងអំណាចបំពេញបេសកកម្មនេះក៏មិនអាចធ្វើអ្វីដោយខ្លួនគេផ្ទាល់យ៉ាងនោះដែរ (យហ ១៥,៥)។ ដូច្នេះគ្រីស្តទូតរបស់ព្រះគ្រីស្តដឹងថាព្រះជាម្ចាស់បានប្រគល់ឲ្យគេទៅជា "អ្នកបម្រើសម្ពន្ធមេត្រីថ្មី" (២ករ ៣,៦) "អ្នកបម្រើរបស់ព្រះជាម្ចាស់" (២ករ ៦,៤) "ទូតរបស់ព្រះគ្រីស្ត" (២ករ ៥,២០) "អ្នកបម្រើរបស់ព្រះគ្រីស្ត និងអ្នកមើលខុសត្រូវលើគម្រោងការដ៏លាក់កំបាំងរបស់ព្រះជាម្ចាស់" (១ករ ៤,១)។

៨៦០-ក្នុងមុខងាររបស់ក្រុមគ្រីស្តទូតមានចំណុចមួយដែលមិនអាចបញ្ជូនបានទេ គឺទៅជាអ្នកដែលព្រះជាម្ចាស់បានជ្រើសរើស ដើម្បីធ្វើជាសាក្សីអំពីព្រះអម្ចាស់ដែលមានព្រះជន្មថ្មី និងអំពីមូលដ្ឋានគ្រឹះនៃព្រះសហគមន៍។ ប៉ុន្តែក្នុងមុខងារនេះមានចំណុចមិនប្រែប្រួលមួយ គឺព្រះគ្រីស្តមានព្រះបន្ទូលសន្យាថានឹងគង់នៅជាមួយពួកលោករហូតដល់អវសានកាលនៃពិភពលោក (មថ ២៨,២០)។ "ព្រះគ្រីស្តប្រទានបេសកកម្មឲ្យក្រុមគ្រីស្តទូត ជាបេសកកម្មដ៏វិសុទ្ធ ដែលនៅស្ថិតស្ថេរជារៀងរហូតដល់អវសានកាលនៃពិភពលោក ពីព្រោះអស់លោកត្រូវបញ្ជូនបន្តដំណឹងល្អឲ្យមនុស្សលោក។ ដំណឹងល្អនេះពិតជាគោលនៃការរស់នៅទាំងមូលរបស់ព្រះសហគមន៍ជារៀងរហូត។ ហេតុនេះហើយបានជាក្រុមគ្រីស្តទូតយកចិត្តទុកដាក់តែងតាំងអ្នកបន្តមុខងាររបស់អស់លោកក្នុងព្រះសហគមន៍" (LG ២០)។

## លោកអភិបាលជាអ្នកបន្តមុខងារក្រុមគ្រីស្តទូត

៨៦១-"អស់លោកក៏ធ្វើមុខងាររបស់អស់លោក ដូចជាផ្ដែផ្ដាំឲ្យសហការីយ៉ាងជិតស្និទ្ធ បង្ហើយកិច្ចការរបស់អស់លោក និងពង្រឹងកិច្ចការដែលអស់លោកចាប់ផ្ដើមធ្វើ ទាំងប្រៀនប្រដៅគេឲ្យថែរក្សាហ្វូងទាំងមូល ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ទុកផ្ដាក់លោកឲ្យឃ្វាលព្រះសហគមន៍របស់ព្រះជាម្ចាស់។ ហេតុនេះ អស់លោកតែងតាំងមនុស្សបែបនេះ និងផ្ដាំចាត់ចែងថា ក្រោយពីអស់លោកទទួលមរណភាពទៅ មានមនុស្សផ្សេងទៀតដែលគេបានល្បងលមើល រួចហើយទទួលមុខងារបម្រើព្រះសហគមន៍ បន្តពីអស់លោក" (LG ២០)។

៨៦២-"ព្រះអម្ចាស់បានផ្ញើមុខងារឲ្យគ្រីស្តទូតសិលាផ្ទាល់ ជាគ្រីស្តទូតទីមួយក្នុងចំណោមគ្រីស្តទូតឯទៀតៗ។ មុខងាររបស់គ្រីស្តទូតសិលា ដែលត្រូវបញ្ជូនបន្តឲ្យអ្នកបន្តមុខងាររបស់លោក នៅស្ថិតស្ថេររហូតយ៉ាងណា ក៏បន្ទុកព្រះគ្រីស្តផ្ញើឲ្យក្រុមគ្រីស្តទូតជាគង្វាលព្រះសហគមន៍ ក៏ជាបន្ទុកដែលស្ថិតស្ថេរនៅរហូតយ៉ាងនោះដែរ ដោយអស់លោកទទួលអគ្គសញ្ញាតែងតាំងជាអភិបាល"។ ហេតុនេះហើយបានជាព្រះសហគមន៍បង្រៀនថា "ព្រះជាម្ចាស់ចាត់ចែងក្រុមអភិបាលឲ្យបន្តមុខងារក្រុមគ្រីស្តទូតក្នុងឋានៈជាគង្វាលព្រះសហគមន៍។ អ្នកណាស្ដាប់អស់លោកក៏ស្ដាប់ព្រះគ្រីស្តដែរ។ អ្នកណាបដិសេធមិនទទួលអស់លោក ក៏បដិសេធមិនទទួលព្រះគ្រីស្តដែរ ហើយថែមទាំងមិនទទួលព្រះបិតាដែលចាត់ព្រះគ្រីស្តឲ្យមកនោះទៀតផង" (LG ២០)។

## ចាត់ឲ្យប្រកាសដំណឹងល្អ

៨៦៣-ព្រះសហគមន៍ទាំងមូលប្រកាសដំណឹងល្អ ទាល់តែព្រះសហគមន៍ និងអស់អ្នកបន្តមុខងារពីសន្ធៈ សិលា និងគ្រីស្តទូតឯទៀតៗ រួមរស់ជាមួយដើមកំណើតរបស់ព្រះសហគមន៍តាមជំនឿ និងតាមរបៀបរស់នៅ។ ព្រះសហគមន៍ទាំងមូលមានក្រុមគ្រីស្តទូតជាគ្រឹះ ព្រោះព្រះជាម្ចាស់ "ចាត់ព្រះសហគមន៍ឲ្យទៅ" ក្នុងពិភពលោកទាំងមូល ហើយព្រះអង្គក៏ចាត់សមាជិកម្នាក់ៗតាមលក្ខណៈរៀងៗខ្លួនឲ្យទៅដែរ។ "អ្នកណាជាគ្រីស្តបរិស័ទ អ្នកនោះក៏ព្រះជាម្ចាស់ចាត់ឲ្យទៅប្រកាសដំណឹងល្អដែរ"។ គេហៅ "ការប្រកាសដំណឹងល្អ" សកម្មភាពទាំងប៉ុន្មាននៃព្រះកាយដ៏អស្ចារ្យរបស់ព្រះគ្រីស្ត" ដែល "លាតសន្ធឹងព្រះរាជ្យព្រះគ្រីស្តនៅលើផែនដី" (AA ២)។

៨៦៤-"ព្រះគ្រីស្តដែលព្រះបិតាចាត់ឲ្យទៅជាប្រភព និងដើមកំណើតនៃការប្រកាសដំណឹងល្អទាំងអស់របស់ព្រះសហគមន៍"។ ហេតុនេះហើយបានជាក្រុមអ្នកបម្រើដែលទទួលអគ្គសញ្ញាតែងតាំងដូចគ្រីស្តបរិស័ទធម្មតាផង នឹងបង្កើតផលក្នុងការប្រកាសដំណឹងល្អ ទាល់តែគេរួមរស់យ៉ាងជិតស្និតជាមួយព្រះគ្រីស្តផងដែរ (យហ ១៥,៥; AA ៤)។ តាមការត្រាស់ហៅសម័យកាលនីមួយៗ និងព្រះអំណោយទានផ្សេងៗពីព្រះវិញ្ញាណដ៏វិសុទ្ធមានរបៀបជាច្រើនផ្សេងពីគ្នា ដើម្បីប្រកាសដំណឹងល្អ ប៉ុន្តែសេចក្តីស្រឡាញ់ដែលហូរចេញមកពីអភិបូជា "ដូចជាព្រលឹងនៃការប្រកាសដំណឹងល្អ" (AA ៣)។

៨៦៥-ក្នុងអគ្គសញ្ញាណដ៏ជ្រាលជ្រៅជាទីបំផុត ព្រះសហគមន៍មានតែមួយដ៏វិសុទ្ធកាតូលិក និងមានក្រុមគ្រីស្តទូតជាគ្រឹះ ដ្បិត "ព្រះរាជ្យនៃស្ថានបរមសុខ" "ព្រះរាជ្យរបស់ព្រះជាម្ចាស់" (វវ ១៩,៦) ដែលព្រះជាម្ចាស់នឹងសម្រេចពេលអវសានកាលនៃពិភពលោកស្ថិតនៅក្នុងព្រះសហគមន៍ហើយ។ ព្រះរាជ្យនោះបានកើតជារូបរាង ហើយក្នុងអង្គព្រះគ្រីស្ត និងចម្រើនឡើងតាមរបៀបដ៏អាថ៌កំបាំងនៅក្នុងចិត្តគំនិតរបស់អស់អ្នកដែលចូលក្នុងព្រះរាជ្យនោះរហូតដល់ព្រះជាម្ចាស់សម្តែងព្រះរាជ្យនោះ ឲ្យមនុស្សលោកទាំងអស់ស្គាល់នៅពេលអវសានកាលនៃពិភពលោក។ ពេលនោះ ព្រះជាម្ចាស់នឹងបង្រួបបង្រួមមនុស្សទាំងអស់ដែលព្រះអង្គបានលោះក្នុងអង្គព្រះអង្គ និងប្រោសគេ "ឲ្យបានវិសុទ្ធ និងឥតសៅហ្មងនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ព្រោះព្រះអង្គមានព្រះហឫទ័យស្រឡាញ់យើង" (អភ ១,៤) ជាប្រជាជនតែមួយរបស់ព្រះអង្គ "កូនក្រមុំជាភរិយារបស់កូនចៀម" (វវ ២១,៩) "ជាក្រុងដ៏វិសុទ្ធ (...) ដែលចុះពីស្ថានបរមសុខ គឺចុះមកពីព្រះជាម្ចាស់ (...) ប្រកបដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់" (វវ ២១,១០-១១) និង "កំពែងរបស់ក្រុងមានគ្រឹះដប់ពីរ ហើយគ្រឹះទាំងនោះមានចារឹកឈ្មោះគ្រីស្តទូតទាំងដប់ពីររបស់កូនចៀម"(វវ ២១,១៤)។

## សង្ខេប

៨៦៦-ព្រះសហគមន៍មានតែមួយ៖ ព្រះសហគមន៍មានព្រះអម្ចាស់តែមួយ ប្រកាសជំនឿតែមួយ កើតមកពីពិធីជ្រមុជទឹកតែមួយ ធ្វើជាព្រះកាយតែមួយ មានព្រះវិញ្ញាណតែមួយ ដែលប្រោសព្រះសហគមន៍ឲ្យមានជីវិតដោយមានសេចក្តីសង្ឃឹមតែមួយ (អភ ៤,៣-៥) ថានៅទីចុងក្រោយបំផុត គ្មានការបាក់បែកគ្នាទៀតទេ។

៨៦៧-ព្រះសហគមន៍ដ៏វិសុទ្ធ៖ ព្រះដ៏វិសុទ្ធបំផុតជាអ្នកបង្កើតព្រះសហគមន៍ ព្រះគ្រីស្ត ដែលជាព្រះស្វាមី បានបូជាព្រះជន្មរបស់ព្រះអង្គ ដើម្បីប្រោសព្រះសហគមន៍ឲ្យបានវិសុទ្ធ ព្រះវិញ្ញាណនៃភាពដ៏វិសុទ្ធ ប្រោសព្រះសហគមន៍ឲ្យមានជីវិត។ ទោះជាព្រះសហគមន៍មានអ្នកបាបក៏ដោយ ក៏ព្រះសហគមន៍ជា "អ្នកដែលគ្មានបាប ដោយមានអ្នកបាប" ដែរ។ ភាពដ៏វិសុទ្ធរបស់ព្រះសហគមន៍ភ្លឺចិញ្ចាចចិញ្ចែងក្នុងជនដ៏វិសុទ្ធ។ នៅក្នុងព្រះនាងម៉ារី ព្រះសហគមន៍ជាអ្នកពោរពេញភាពដ៏វិសុទ្ធរួចទៅហើយ។

៨៦៨-ព្រះសហគមន៍កាតូលិក៖ ព្រះសហគមន៍ប្រកាសជំនឿទាំងស្រុង មាននៅក្នុងខ្លួន និងចាត់ចែងមធ្យោបាយនៃការសង្គ្រោះឲ្យបានពេញលក្ខណៈ។ ព្រះជាម្ចាស់ចាត់ព្រះសហគមន៍ឲ្យជាតិសាសន៍នានា ប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ និងស្ថិតក្នុងគ្រប់សម័យកាលទាំងអស់។ "ព្រះសហគមន៍មានលក្ខណៈផ្ទាល់ជាសាសនទូត" (AG ២)។

៨៦៩-ព្រះសហគមន៍មានក្រុមគ្រីស្តទូតជាគ្រឹះ៖ ព្រះជាម្ចាស់បានកសាងព្រះសហគមន៍លើគ្រឹះដ៏រឹងមាំ គឺ "គ្រីស្តទូតទាំងដប់ពីររូបនៃកូនចៀម" (វវ ២១,១៤) ។ គ្មានអ្វី និងគ្មាននរណាអាចបំផ្លាញព្រះសហគមន៍បានឡើយ (មថ ១៦,១៨) ហើយស្ថិតក្នុងសេចក្តីពិត ដោយមិនអាចភ័ន្តច្រឡំបានឡើយ។ ព្រះគ្រីស្តដឹកនាំព្រះសហគមន៍ដោយលោក សិលា និងគ្រីស្តទូតឯទៀត ដែលនៅក្នុងអ្នកបន្តមុខងាររបស់ពួកលោក គឺសម្តេចប៉ាប និងក្រុមលោកអភិបាលផង។

៨៧០-"នេះជាព្រះសហគមន៍តែមួយរបស់ព្រះគ្រីស្ត។ ក្នុងធម៌ប្រកាសជំនឿ យើងតែងតែប្រកាសថា ព្រះសហគមន៍មានតែមួយដ៏វិសុទ្ធ កាតូលិក និងមានជំនឿស្របតាមក្រុមគ្រីស្តទូត (...) ព្រះសហគមន៍នេះជាសង្គមម៉្យាងក្នុងលោកនេះ ដែលចាត់ចែងឲ្យមានរបៀបរៀបរយ គឺស្ថិតនៅក្នុងព្រះសហគមន៍កាតូលិក ដែលមានសម្តេចប៉ាបបន្តមុខងារពីគ្រីស្តទូតសិលាមក និងដែលមានអស់លោកអភិបាលរួបរួមជាមួយលោកក្នុងការដឹកនាំ។ ទោះបីជានៅខាងក្រៅរចនាសម្ព័ន្ធនៃព្រះសហគមន៍ មានកត្តាជាច្រើនអាចនាំឲ្យមនុស្សបានវិសុទ្ធ និងស្គាល់សេចក្តីពិតក៏ដោយ" (LG ៨)។

## កថាខណ្ឌទី៤៖ អ្នកផ្ញើជីវិតលើព្រះគ្រីស្ត ក្រុមលំដាប់លំដោយ គ្រីស្តបរិស័ទធម្មតា អ្នកថ្វាយខ្លួនទាំងស្រុង

៨៧១-"អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត" ជាគ្រីស្តបរិស័ទដែល (...) ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដោយអគ្គសញ្ញាជ្រមុជទឹកប្រោសឲ្យគេរួមនៅក្នុងអង្គព្រះគ្រីស្ត។ ពេលនោះគេទទួលមុខងារជាបូជាចារ្យ ជាព្យាការី និងជាស្តេចរបស់ព្រះអង្គតាមរបៀបរបស់គេ។ គេបំពេញបេសកកម្មរបស់ប្រជាជនគ្រីស្តបរិស័ទទាំងមូល នៅក្នុងព្រះសហគមន៍ និងនៅក្នុងពិភពលោកតាមចំណែករៀងៗខ្លួន" (CIC ២០៤,១; LG ៣១)

៨៧២-"សមាជិកប្រជារាស្ត្រនេះមានកិត្តិយសថ្លៃថ្នូររួមគ្នា ព្រោះគេសុទ្ធតែកើតជាថ្មីក្នុងអង្គព្រះគ្រីស្ត គឺក្នុងសកម្មភាព និងកិត្តិយសគេស្មើគ្នាទាំងអស់យ៉ាងពិតប្រាកដ ដែលធ្វើឲ្យគេកសាងព្រះកាយព្រះគ្រីស្តតាមលក្ខណៈ និងមុខងាររៀងៗខ្លួន" (LG ៣២)។

៨៧៣-ព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យសរីរាង្គនៃព្រះកាយព្រះអង្គខុសប្លែកពីគ្នា ដើម្បីបម្រើឯកភាព និងបេសកកម្មរបស់ព្រះអង្គ ដ្បិត "មានមុខងារផ្សេងៗក្នុងព្រះសហគមន៍ ប៉ុន្តែមានបេសកកម្មតែមួយ។ ព្រះគ្រីស្តបានផ្ញើឲ្យក្រុមគ្រីស្តទូត និងអ្នកបន្តមុខងាររបស់គេទទួលបន្ទុកប្រៀនប្រដៅធ្វើឲ្យបានវិសុទ្ធ និងណែនាំក្នុងនាមព្រះអង្គ និងដោយអំណាចព្រះអង្គ។ ប៉ុន្តែគ្រីស្តបរិស័ទធម្មតាដែលចូលរួមចំណែកទទួលបន្ទុកជាបូជាចារ្យ ព្យាការី និងព្រះមហាក្សត្រក្នុងព្រះសហគមន៍ និងក្នុងពិភពលោកក្នុងបេសកកម្មនៃប្រជាជនរបស់ព្រះជាម្ចាស់ក្នុងពិភពលោកទាំងមូល" (AA ២)។ ទីបញ្ចប់មានគ្រីស្តបរិស័ទដែលជាមេដឹកនាំផង គ្រីស្តបរិស័ទធម្មតាផង ដែលដោយធ្វើសច្ចាប្រណិធាន (...) ថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ ហើយចូលរួមក្នុងបេសកកម្មរបស់ព្រះសហគមន៍តាមរបៀបរៀងៗខ្លួន (CIC ២០៧,២)។

## ១-ព្រះសហគមន៍មានរចនាសម្ព័ន្ធតាមលំដាប់លំដោយ

### ហេតុអ្វីបានជាមានមុខងារបម្រើព្រះសហគមន៍?

៨៧៤-ព្រះគ្រីស្តផ្ទាល់ជាប្រភពនៃមុខងារបម្រើក្នុងព្រះសហគមន៍។ ព្រះអង្គបានតែងតាំងអ្នកមានមុខងារបម្រើ បានប្រគល់អំណាច និងបេសកកម្មទិសដៅ និងគោលដៅឲ្យពួកគេ។

ព្រះគ្រីស្តជាអម្ចាស់តែងតាំងមុខងារបម្រើផ្សេងៗក្នុងព្រះសហគមន៍ ដើម្បីឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់មានគង្វាលណែនាំ និងមានមធ្យោបាយនាំឲ្យរីកចម្រើនឡើងបាន។ មុខងារទាំងនោះមានគោលដៅតែមួយ គឺរកប្រយោជន៍ដល់រូបកាយទាំងមូល។ អស់លោកដែលទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ មានអំណាចមកពីព្រះជាម្ចាស់ គឺអស់លោកបម្រើបងប្អូនដើម្បីណែនាំអស់សមាជិកនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ (...) អាចទៅកាន់ការសង្គ្រោះ (LG ១៨)។

៨៧៥-"ឲ្យគេជឿលើព្រះអង្គដូចម្តេចកើត បើគេមិនដែលឮព្រះអង្គមានព្រះបន្ទូល? ឲ្យគេឮដូចម្តេចកើតបើគ្មាននរណាប្រកាស? ឲ្យមានអ្នកប្រកាសដូចម្តេចកើត បើគ្មាននរណាចាត់ឲ្យទៅប្រកាសផងនោះ?" (រម ១០,១៤-១៥)។ គ្មាននរណាម្នាក់ គ្មានបុគ្គលណាម្នាក់ ហើយគ្មានសហគមន៍ណាមួយអាចប្រកាសដំណឹងល្អដល់ខ្លួនផ្ទាល់ឡើយ។ "ជំនឿមកពីសេចក្តីដែលយើងបានស្តាប់" (រម ១០,១៧)។ គ្មាននរណាម្នាក់អាចផ្តល់ដល់ខ្លួនឯងអាណត្តិ និងបេសកកម្មប្រកាសដំណឹងល្អបានទេ។ អ្នកដែលព្រះអម្ចាស់ចាត់ឲ្យទៅនិយាយ និងប្រព្រឹត្តមិនមែនមកពីអំណាចរបស់ខ្លួនឯងទេ តែដោយសំអាងទៅលើអំណាចរបស់ព្រះគ្រីស្តវិញ មិនមែនក្នុងឋានៈជាសមាជិកសហគមន៍ឡើយ តែដោយនិយាយទៅកាន់សហគមន៍នេះក្នុងនាមព្រះគ្រីស្តវិញ។ គ្មាននរណាម្នាក់អាចប្រគល់ដល់ខ្លួនឯងការប្រណីសន្តោសឡើយ គឺព្រះជាម្ចាស់ជាអ្នកប្រគល់ និងប្រទានការប្រណីសន្តោសនេះវិញ បានសេចក្តីថាព្រះគ្រីស្តត្រូវប្រគល់សិទ្ធិ និងអំណាចដល់អ្នកបម្រើនៃការប្រណីសន្តោស។ គេទទួលពីព្រះអង្គ បេសកកម្ម និងសមត្ថភាព ("អំណាចដ៏សក្ការៈ") ដើម្បីធ្វើសកម្មភាព **in persona Christi Capitis** (ក្នុងអង្គព្រះគ្រីស្តជាព្រះសិរសា)។ ការបញ្ជូនបន្តព្រះសហគមន៍ហៅមុខងារបម្រើនេះ "អគ្គសញ្ញា" គឺដោយសារព្រះអំណោយទានរបស់ព្រះជាម្ចាស់ អ្នកដែលព្រះគ្រីស្តចាត់ឲ្យទៅធ្វើ និងផ្តល់អ្វីដែលគេមិនអាចធ្វើ និងផ្តល់ដោយខ្លួនឯងបានឡើយ។ ព្រះជាម្ចាស់ប្រគល់មុខងារបម្រើព្រះសហគមន៍ដោយសារអគ្គសញ្ញាពិសេស។

៨៧៦-ដោយសារមុខងារបម្រើព្រះសហគមន៍មានសភាពជាអគ្គសញ្ញា អ្នកទទួលមុខងារនេះក៏បម្រើព្រះសហគមន៍។ ដោយសារគេពឹងផ្អែកទាំងស្រុងលើព្រះគ្រីស្តដែលប្រទានបេសកកម្ម និងអំណាចអ្នកទទួលមុខងារក្នុងព្រះសហគមន៍ជា "ខ្ញុំបម្រើរបស់ព្រះគ្រីស្ត" (រម ១,១) ដូចព្រះគ្រីស្តដែលសព្វព្រះហឫទ័យ "យកឋានៈជាទាសករ" (ភីល ២,៧)។ ដោយសារព្រះបន្ទូល និងការប្រណីសន្តោសមិនមែនមកពីគេ តែមកពីព្រះគ្រីស្តដែលបានប្រគល់ឲ្យគេសម្រាប់អ្នកដទៃ គេនឹងសុខចិត្តទៅជាខ្ញុំបម្រើរបស់មនុស្សទាំងអស់ (១ករ ៩,១៩)។

៨៧៧-យ៉ាងណាមិញដោយសារមុខងារបម្រើព្រះសហគមន៍មានសភាពជាអគ្គសញ្ញា អ្នកទទួលមុខងារនេះរួមជាមួយគ្នា។ ចាប់តាំងពីព្រះយេស៊ូប្រកាសដំណឹងល្អ ព្រះអម្ចាស់យេស៊ូតែងតាំងគ្រីស្តទូតដប់ពីររូប "ជាពូជនៃប្រជាជនអ៊ីស្រាអែលថ្មី និងជាដើមកំណើតនៃក្រុមអភិបាល" (AG ៥)។ ព្រះយេស៊ូបានជ្រើសរើសគេជាមួយគ្នា ព្រះអង្គក៏ចាត់ឲ្យគេទៅជាមួយគ្នាដែរ ដោយសារគេរួមជាមួយគ្នាដូចជាបងប្អូន គេនឹងជួយបម្រើគ្រីស្តបរិស័ទទាំងអស់ឲ្យរួមរស់ជាមួយគ្នាផងដែរ។ គេនឹងបង្ហាញបញ្ជាក់ និងផ្តល់សក្ខីភាពថាព្រះអង្គនីមួយៗរួមរស់ជាមួយគ្នា (យហ

១៧,២១-២៣)។ ហេតុនេះលោកអភិបាលម្នាក់ៗបម្រើព្រះសហគមន៍រួមជាមួយក្រុមលោកអភិបាល ដោយរួមរស់ជាមួយលោកអភិបាលនៅទីក្រុងរ៉ូមជាអ្នកបន្តមុខងារសន្ត: សិលា និងមេដឹកនាំក្រុមលោកអភិបាលផង។ ឯពួកលោកបូជាចារ្យវិញ គេបម្រើព្រះសហគមន៍រួមជាមួយក្រុមបូជាចារ្យនៃភូមិភាគក្រោមការណែនាំរបស់លោកអភិបាលរបស់គេ។

៨៧៨-ទីបំផុតដោយសារមុខងារបម្រើព្រះសហគមន៍មានសភាពជាអគ្គសញ្ញា អ្នកទទួលមុខងារនេះបម្រើព្រះសហគមន៍ដោយខ្លួនគេផ្ទាល់។ បើអ្នកបម្រើព្រះគ្រីស្តរួមរស់ជាមួយគ្នា គេក៏តែងតែប្រព្រឹត្តដោយខ្លួនគេផ្ទាល់ដែរ។ ព្រះគ្រីស្តត្រាស់ហៅគេម្នាក់ៗផ្ទាល់ខ្លួន៖ "អ្នកសុំអញ្ជើញមកតាមខ្ញុំ" (យហ ២១,២២) ដើម្បីទៅជាសាក្សីផ្ទាល់ខ្លួននៅក្នុងបេសកកម្មរួមដោយធ្វើជាអ្នកទទួលខុសត្រូវដោយខ្លួនឯងផ្ទាល់ ចំពោះអ្នកដែលផ្តល់បេសកកម្ម។ គេបម្រើព្រះសហគមន៍ "ក្នុងខ្លួនគេផ្ទាល់" និងចំពោះមនុស្ស៖ "ខ្ញុំជ្រមុជទឹកអ្នកក្នុងព្រះនាមព្រះបិតា..." "ខ្ញុំលើកលែងទោសឲ្យអ្នក..."។

៨៧៩-អ្នកដែលព្រះសហគមន៍ផ្តល់អគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ ត្រូវតែបម្រើព្រះសហគមន៍ក្នុងនាមព្រះគ្រីស្ត ដោយរួមជាមួយគ្នាផង និងដោយខ្លួនគេផ្ទាល់ផង ពោលគឺក្រុមអភិបាលរួមជាមួយមេដឹកនាំក្រុមអភិបាលជាអ្នកបន្តមុខងារសន្ត: សិលា លោកអភិបាលទទួលការខុសត្រូវចំពោះភូមិភាគរបស់លោក ហើយក្រុមអភិបាលរួមគ្នាក្នុងការយកចិត្តទុកដាក់ព្រះសហគមន៍សាកល។

## ក្រុមអភិបាល និងប្រធានក្រុមអភិបាលជាសម្តេចប៉ាប

៨៨០-ព្រះគ្រីស្តបានតែងតាំងគ្រីស្តទូតដប់ពីររូប "ជាក្រុមមួយដែលនៅស្ថិតស្ថេរ និងតែងតាំងលោកសិលាដែលព្រះអង្គបានជ្រើសរើសក្នុងចំណោមអស់លោកទាំងដប់ពីរនាក់ឲ្យនាំមុខគេ" (LG ១៩)។ "គ្រីស្តទូតសិលា និងគ្រីស្តទូតឯទៀតៗរួមគ្នាជាក្រុមគ្រីស្តទូតតែមួយ ដោយព្រះអម្ចាស់តែងតាំងយ៉ាងណា អភិបាលព្រះសហគមន៍ក្រុងរ៉ូមដែលបន្តមុខងារពីគ្រីស្តទូតសិលា និងអភិបាលទាំងប៉ុន្មានដែលបន្តមុខងារពីក្រុមគ្រីស្តទូត ក៏រួមគ្នាជាក្រុមតែមួយយ៉ាងនោះដែរ" (LG ២២)។

៨៨១-ព្រះអម្ចាស់បានប្រោសលោក ស៊ីម៉ូន ដែលព្រះអង្គដាក់ឈ្មោះថា សិលា ឲ្យទៅជាផ្ទាំងសិលានៃព្រះសហគមន៍របស់ព្រះអង្គ។ ព្រះអង្គបានប្រគល់កូនសោឲ្យលោក (មថ ១៦,១៨-១៩) ទ្រង់ក៏តែងតាំងលោកឲ្យទៅជាគង្វាលលើហ្វូងទាំងមូល (យហ ២១,១៥-១៧)។ "ក៏ប៉ុន្តែ ព្រះអង្គប្រទានឲ្យលោកសិលាមានបន្ទុកចង និងស្រាយ ព្រះអង្គក៏បានប្រទានបន្ទុកនេះយ៉ាងពិតប្រាកដឲ្យក្រុមគ្រីស្តទូត ដែលរួមជាមួយមេដឹកនាំរបស់គេដែរ" (LG ២២)។ បន្ទុករបស់លោកសិលានេះ និងគ្រីស្តទូតឯទៀតៗជាមូលដ្ឋានគ្រឹះនៃព្រះសហគមន៍។ លោកអភិបាលបន្តបន្ទុកនេះក្រោមអំណាចរបស់សម្តេចប៉ាប។

៨៨២-សម្តេចប៉ាបដែលជាអភិបាលទីក្រុងរ៉ូម និងអ្នកបន្តមុខងារពីសន្ត: សិលា "ជាគោលអចិន្ត្រៃដែលអាចមើលឃើញ ហើយជាគ្រឹះបណ្តោយឲ្យអស់អភិបាលរួមគ្នាទៅវិញទៅមក និងឲ្យគ្រីស្តបរិស័ទទាំងអស់រួមគ្នាជាធ្លុងតែមួយដែរ" (LG ២៣)។ "សម្តេចប៉ាបមានអំណាចពេញលេញលើព្រះសហគមន៍ គឺអំណាចដ៏ខ្ពង់ខ្ពស់បំផុត និងសកល ដែលលោកអាចបម្រើដោយសេរីជានិច្ច ព្រោះលោកទទួលបន្ទុកជាតំណាងព្រះគ្រីស្ត និងជាគង្វាលនៃព្រះសហគមន៍ទាំងមូល" (LG ២២)។

៨៨៣-ក្រុមលោកអភិបាល "មានអំណាច (...) លុះត្រាតែក្រុមអភិបាលនេះរួមជាមួយសម្តេចប៉ាបជាមេដឹក

នាំក្រុមអភិបាលនោះ"។ ក្រុមអភិបាលនេះ "ក៏មានអំណាចដ៏ខ្ពង់ខ្ពស់បំផុត និងមានអំណាចពេញលេញលើព្រះសហគមន៍ទាំងមូល លុះត្រាតែក្រុមអភិបាលនេះរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម" (LG ២២)។

៨៨៤-"ក្រុមអភិបាលមានអំណាចលើព្រះសហគមន៍ទាំងមូលយ៉ាងឱឡារិកក្នុងមហាសន្និបាតសាកល" (CIC ៣៣៧,១)។ "មានមហាសន្និបាតសាកល លុះត្រាតែអភិបាលដែលបន្តមុខងារពីលោក សិលា មកបញ្ជាក់ ឬយ៉ាងហោចណាស់ សុខចិត្តទទួលមហាសន្និបាតនោះ" (LG ២២)។

៨៨៥-"ដោយក្រុមអភិបាលនេះមានផ្នែកជាច្រើនផ្សេងៗពីគ្នាយ៉ាងណា ក្រុមនេះបង្ហាញបញ្ជាក់ថា ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ក៏មានផ្នែកជាច្រើនផ្សេងៗពីគ្នា និងជាប្រជារាស្ត្រសាកលយ៉ាងនោះដែរ។ ដោយក្រុមអភិបាលនោះរួមគ្នាក្រោមអំណាចមេដឹកនាំតែមួយយ៉ាងណា ក្រុមនេះក៏បង្ហាញបញ្ជាក់ថា ហ្វូងរបស់ព្រះគ្រីស្តរួមគ្នាជាផ្លូងតែមួយយ៉ាងនោះដែរ"(LG ២២)។

៨៨៦-"អភិបាលម្នាក់ៗតាមចំណែករៀងៗខ្លួន ក៏ជាគោល និងជាគ្រឹះធ្វើឲ្យព្រះសហគមន៍ភូមិភាគរបស់ខ្លួនរួបរួមគ្នាជាផ្លូងតែមួយដែរ" (LG ២៣)។ "អស់លោកប្រើអំណាចតាមចំណែករៀងៗខ្លួន ក្នុងឋានៈជាគង្វាលលើផ្នែកនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានផ្ញើមកអស់លោក" (LG ២៣) ដោយមានលោកបូជាចារ្យ និងលោកឧបដ្ឋាកជួយផង។ ប៉ុន្តែក្នុងឋានៈជាសមាជិកក្រុមអភិបាល ម្នាក់ៗចូលរួមចំណែកក្នុងការយកចិត្តទុកដាក់លើព្រះសហគមន៍ទាំងឡាយ (CD ៣) "ដោយ (...) ត្រួតត្រាព្រះសហគមន៍របស់ខ្លួនផ្ទាល់ ទុកជាចំណែកមួយនៃព្រះសហគមន៍សាកល អស់លោកសហការគ្នាយ៉ាងស័ក្តិសិទ្ធ ដើម្បីជាប្រយោជន៍របស់ព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តដែលជាព្រះកាយរបស់ព្រះសហគមន៍ទាំងឡាយដែរ" (LG ២៣)។ ជាពិសេសគេនឹងយកចិត្តទុកដាក់នឹងជនក្រីក្រ អ្នកដែលត្រូវគេបៀតបៀន ព្រោះតែជំនឿ និងសាសនទូតដែលប្រកាសដំណឹងល្អលើផែនដីទាំងមូល។

៨៨៧-ព្រះសហគមន៍ភូមិភាគដែលនៅជិតគ្នា និងដែលមានវប្បធម៌ស្រដៀងគ្នា ទៅជាខេត្តព្រះសហគមន៍ ឬក្រុមធំជាងដែលគេហៅថាតំបន់។ អភិបាលនៃក្រុមនោះអាចប្រជុំគ្នាជាសន្និបាតខាងខេត្តដែរ។ "ក្រុមអភិបាលតាមប្រទេសនីមួយៗអាចជួយសហការគ្នាតាមរបៀបផ្សេងៗដែលបង្កើតផល បានបញ្ជាក់ថាគោលបំណងនៃក្រុមអភិបាលណែនាំព្រះសហគមន៍រួម កើតជារូបរាងយ៉ាងជាក់ច្បាស់ហើយ" (LG ២៣)។

### ក្រុមអភិបាល និងសម្តេចប៉ាបមានបន្ទុកបង្រៀនគ្រីស្តបរិស័ទ

៨៨៨-លោកអភិបាលរួមជាមួយលោកបូជាចារ្យដែលជាសហការីរបស់លោក "មានភារកិច្ចសំខាន់ជាងគេប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងអស់" (PO ៤) តាមព្រះបញ្ជារបស់ព្រះអម្ចាស់ (មក ១៦,១៥)។ អស់លោក "ជាអ្នកប្រកាសជំនឿដែលនាំសាវ័កថ្មីមករកព្រះគ្រីស្ត គេក៏ជាគ្រូគួរឲ្យជឿទុកចិត្ត" នៃជំនឿដែលមកពីក្រុមគ្រីស្តទូត" គឺជាគ្រូដែលទទួលអំណាចរបស់ព្រះគ្រីស្ត" (LG ២៥)។

៨៨៩-ដើម្បីឲ្យព្រះសហគមន៍នៅតែរក្សាទុកជំនឿដ៏បរិសុទ្ធ ដែលក្រុមគ្រីស្តទូតបានបញ្ជូនព្រះគ្រីស្តសព្វព្រះហឫទ័យប្រគល់ឲ្យព្រះសហគមនន៍មិនអាចភ័ន្តច្រឡំបានទេ រួមជាមួយព្រះអង្គដែលទ្រង់ជាសេចក្តីពិត។ ដោយ "ជំនឿហួសធម្មជាតិ" ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ "ក៏ភ្ជាប់ចិត្តនឹងលទ្ធិនៃជំនឿផ្តាច់មិនបាន" ក្រោមក្រុមមេដឹកនាំដ៏រស់រវើករបស់ព្រះសហគមន៍ (LG ១២)។

៨៩០-បេសកកម្មរបស់ក្រុមមេដឹកនាំទាក់ទងនឹងលក្ខណៈជាស្ថាពររបស់សម្ពន្ធមេត្រី ដែលព្រះជាម្ចាស់បានចងក្នុងអង្គព្រះគ្រីស្តជាមួយប្រជារាស្ត្រព្រះអង្គ។ ក្រុមមេដឹកនាំក៏ត្រូវតែការពារប្រជារាស្ត្រនេះកុំឲ្យគេវង្វេង ឬកុំឲ្យមាន

ការខ្វះខាតអ្វីឡើយ ហើយដើម្បីធានាថាគេប្រកាសជំនឿដ៏ពិតប្រាកដដោយគ្មានកំហុសឡើយ។ ក្រុមមេដឹកនាំមានបន្ទុកប្រុងប្រយ័ត្នឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់ស្ថិតនៅក្នុងសេចក្តីពិតដែលនាំឲ្យមានសេរីភាពពេញទី។ ដើម្បីបំពេញកិច្ចបម្រើនេះ ព្រះគ្រីស្តបានប្រទានឲ្យពួកគង្វាលមានព្រះអំណោយទានមិនអាចភ័ន្តច្រឡំបានក្នុងវិស័យលទ្ធិជំនឿ និងសីលធម៌។ ពួកគេអាចប្រើព្រះអំណោយទាននេះតាមរបៀបពីរ៖

៨៩១-"សម្តេចប៉ាបមានឯកសិទ្ធិមិនអាចភ័ន្តច្រឡំបាន ក្នុងឋានៈលោកទទួលបន្ទុកជាមេដឹកនាំក្រុមអភិបាល និងក្នុងឋានៈជាគង្វាល និងជាគ្រូដ៏ខ្ពង់ខ្ពស់បំផុតរបស់គ្រីស្តបរិស័ទទាំងឡាយ។ លោកទទួលភារកិច្ចគាំទ្របងប្អូនក្នុងជំនឿ។ នៅពេលលោកប្រកាសអំពីប្រការមួយក្នុងវិស័យលទ្ធិនៃជំនឿ និងសីលធម៌ ទាំងបញ្ចេញឯកសារជាស្ថាពរ លោកមិនអាចភ័ន្តច្រឡំបានឡើយ" (...)។ ក្រុមអភិបាលក៏មិនអាចភ័ន្តច្រឡំបានដែរ តាមព្រះបន្ទូលសន្យាមកព្រះសហគមន៍ថាមិនអាចភ័ន្តច្រឡំបាន នៅពេលក្រុមអភិបាលបំពេញមុខងារបង្រៀនយ៉ាងខ្ពង់ខ្ពស់ រួមជាមួយសម្តេចប៉ាបដែលបន្តមុខងារពីគ្រីស្តទូតសិលាមក" ជាពិសេសក្នុងមហាសន្និបាតសាកល (LG ២៥; DS ៣០៧៤)។ នៅពេលដែលព្រះសហគមន៍តាមរយៈក្រុមមេដឹកនាំពន្យល់ "នូវអ្វីៗដែលត្រូវជឿទុកជាសេចក្តីដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់" (DV ១០) និងទុកជាសេចក្តីប្រៀនប្រដៅរបស់ព្រះគ្រីស្ត "គ្រីស្តបរិស័ទត្រូវតែភ្ជាប់ចិត្តនឹងសេចក្តីបញ្ជាក់គោលលទ្ធិ ដោយស្តាប់បង្គាប់ក្នុងឋានៈជាអ្នកផ្ញើជីវិតលើព្រះគ្រីស្ត" (LG ២៥)។ ព្រះសហគមន៍ក៏មិនអាចភ័ន្តច្រឡំបាន ក្នុងករណីថែរក្សា និងពន្យល់ដោយស្មោះនូវសេចក្តីដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់ដែរ (LG ២៥)។

៨៩២-ព្រះជាម្ចាស់ជួយឧបត្ថម្ភអ្នកបន្តមុខងារពីក្រុមគ្រីស្តទូត ដែលបង្រៀនរួមជាមួយអ្នកបន្តមុខងាររបស់លោក សិលា តាមរបៀបពិសេសរួមជាមួយលោកអភិបាលទីក្រុងរ៉ូមជាគង្វាលនៃព្រះសហគមន៍ទាំងមូលដែរ។ ព្រះជាម្ចាស់ជួយឧបត្ថម្ភពួកលោកក្នុងឋានៈជាក្រុមមេដឹកនាំធម្មតា នៅពេលដែលគេបង្រៀននូវលទ្ធិនៃជំនឿ និងសីលធម៌ដែលនាំឲ្យយល់កាន់តែច្បាស់ សេចក្តីដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់ ទោះបីគេមិនបានបញ្ជាក់គោលលទ្ធិដោយមិនអាចភ័ន្តច្រឡំបានទេ និង "ជាស្ថាពរ"។ គ្រីស្តបរិស័ទធម្មតាត្រូវតែ "យល់ស្របអស់ពីចិត្តគំនិត" (LG ២៥) នូវការប្រៀនប្រដៅធម្មតានេះ។ ទោះបីគ្រីស្តបរិស័ទមិនត្រូវភ្ជាប់ចិត្តនឹងសេចក្តីបញ្ជាក់គោលលទ្ធិយ៉ាងណាក៏ដោយ ក៏គ្រីស្តបរិស័តត្រូវយល់ស្របនឹងសេចក្តីនោះដែរ។

## ក្រុមអភិបាល និងសម្តេចប៉ាបមានបន្ទុកណែនាំគ្រីស្តបរិស័ទឲ្យបានវិសុទ្ធ

៨៩៣-លោកអភិបាល "ទទួលខុសត្រូវ និងចែកចាយព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់ ក្នុងឋានៈលោកជាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុត" (LG ២៦) ជាពិសេសក្នុងអភិបូជាដែលលោកថ្វាយដោយខ្លួនលោកផ្ទាល់ ឬដោយចាត់ចែងឲ្យលោកបូជាចារ្យជាសហការីរបស់លោកថ្វាយ ដ្បិតអភិបូជាជាស្នូលនៃព្រះសហគមន៍ភូមិភាគ។ លោកអភិបាល និងលោកបូជាចារ្យណែនាំព្រះសហគមន៍ឲ្យបានវិសុទ្ធដោយអធិដ្ឋាន និងធ្វើការដោយប្រកាសព្រះបន្ទូល និងផ្តល់អគ្គសញ្ញា។ ពួកលោកណែនាំព្រះសហគមន៍ឲ្យបានវិសុទ្ធដោយធ្វើជាគំរូ៖ "កុំប្រើអំណាចជិះជាន់អស់អ្នកដែលព្រះជាម្ចាស់ប្រទានមកឲ្យបងប្អូនថែរក្សានោះឡើយ គឺត្រូវធ្វើជាគំរូដល់ហ្វូងចៀមវិញ" (១ពត្រ ៥,៣)។ ហេតុនេះ "អស់លោកអាចឈានទៅដល់ព្រះជន្មរបស់ព្រះជាម្ចាស់ រួមជាមួយហ្វូងដែលព្រះអង្គបានផ្ញើលើអស់លោក" (LG ២៦)។

### ក្រុមអភិបាល និងសម្ដេចប៉ាបមានបន្ទុកដឹកនាំព្រះសហគមន៍

៨៩៤-"អស់លោកអភិបាលទទួលបន្ទុកលើព្រះសហគមន៍តាមភូមិភាគ ក្នុងឋានៈខ្លួនជាតំណាង និងជាទូត របស់ព្រះគ្រីស្ត។ ដូច្នេះអស់លោកណែនាំព្រះសហគមន៍ភូមិភាគដោយទូន្មាន ដោយលើកទឹកចិត្ត ដោយធ្វើជាគំរូដាក់គេ ហើយដោយប្រើអំណាចរបស់លោកក្នុងឋានៈអស់លោកជាអ្នកទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍" (LG ២៧)។ ប៉ុន្តែ អស់លោកមិនអាចប្រើអំណាចនេះតាមអំពើចិត្តបានទេ គឺលោកត្រូវប្រើអំណាចនេះ ដើម្បីសាងសង់គ្រីស្តបរិស័ទ ដោយបម្រើគេដូចម្ចាស់របស់អស់លោក (លក ២២,២៦-២៧)។

៨៩៥-"អស់លោកអភិបាលប្រើអំណាចនេះក្នុងនាមព្រះគ្រីស្ត ជាអំណាចរបស់លោកផ្ទាល់ ជាអំណាចធម្មតា និងជាអំណាចចំលើគេ។ ក៏ប៉ុន្តែ នៅពេលប្រើអំណាចនេះ អស់លោកត្រូវអនុវត្តតាមការគ្រប់គ្រងនៃអំណាចដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចប៉ាប" (LG ២៧)។ ប៉ុន្តែមិនត្រូវចាត់ទុកអស់លោកអភិបាលជាតំណាងរបស់សម្ដេចប៉ាប ប៉ុណ្ណោះទេ ដែលអំណាចធម្មតា និងលើព្រះសហគមន៍មិនលុបបំបាត់អំណាចរបស់ពួកលោក តែផ្ទុយទៅវិញពង្រឹង និងការពារអំណាចនេះ។ អស់លោកត្រូវប្រើអំណាចដោយរួមជាមួយព្រះសហគមន៍ទាំងមូល ដោយមានសម្ដេចប៉ាបណែនាំ។

៨៩៦-គង្វាលដ៏ល្អនឹងធ្វើជាគំរូ និងជា "រូបរាង" របស់លោកអភិបាលដែលមានបន្ទុកដឹកនាំព្រះសហគមន៍។ ដោយដឹងខ្លួនពីភាពទន់ខ្សោយរបស់ខ្លួន "លោកអភិបាលអាចអធ្យាស្រ័យដល់មនុស្សល្ងិតល្ងង់ និងមនុស្សវង្វេងបាន។ ហេតុនេះលោកត្រូវយកចិត្តទុកដាក់ស្ដាប់អ្នកដែលស្ថិតនៅក្រោមអំណាចរបស់លោក និងយកចិត្តទុកដាក់ស្រឡាញ់គេទុកជាកូនដ៏ពិតប្រាកដ" (...)។ "រីឯគ្រីស្តបរិស័ទវិញ គេត្រូវភ្ជង់ចិត្តស្រឡាញ់អភិបាលរបស់ខ្លួន ដូចព្រះសហគមន៍ភ្ជង់ចិត្តស្រឡាញ់ព្រះគ្រីស្ត និងដូចព្រះគ្រីស្តភ្ជង់ចិត្តស្រឡាញ់ព្រះបិតា" (LG ២៧)៖

> សូមទាំងអស់គ្នាដើរតាមលោកអភិបាលដូចព្រះយេស៊ូគ្រីស្ត {ដើរតាម} ព្រះបិតារបស់ព្រះអង្គ ហើយក្រុមលោកបូជាចារ្យដើរតាមក្រុមគ្រីស្តទូតផងដែរ។ ឯចំពោះពួកលោកឧបដ្ឋាកវិញ សូមគោរពពួកលោកដូចបងប្អូនគោរពធម្មវិន័យរបស់ព្រះជាម្ចាស់ដែរ។ សូមកុំឲ្យនរណាម្នាក់ធ្វើអ្វីមួយដែលទាក់ទងនឹងព្រះសហគមន៍ក្រៅពីលោកអភិបាលឲ្យសោះ (សន្តៈ អ៊ីញ៉ាសនៃអង់ទីអូស)។

## ២-គ្រីស្តបរិស័ទធម្មតា

៨៩៧-"ឈ្មោះ "គ្រីស្តបរិស័ទធម្មតា" ជាគ្រីស្តបរិស័ទដែលមិនបានទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ និងមិនមែនជាបព្វជិតបព្វជិតា ដែលព្រះសហគមន៍ទទួលស្គាល់ជាផ្លូវការទេ។ "គ្រីស្តបរិស័ទធម្មតា" ជាគ្រីស្តបរិស័ទដែលចូលក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដោយអគ្គសញ្ញាជ្រមុជទឹកប្រោសឲ្យគេរួមក្នុងអង្គព្រះគ្រីស្ត។ ពេលនោះគេទទួលមុខងារជាបូជាចារ្យ ជាព្យាការី និងជាស្តេចរបស់ព្រះអង្គតាមរបៀបរបស់គេ។ គេបំពេញបេសកកម្មរបស់ប្រជាជនគ្រីស្តបរិស័ទទាំងមូល នៅក្នុងព្រះសហគមន៍ និងនៅក្នុងពិភពលោក តាមចំណែករៀងៗខ្លួន" (LG ៣១)។

### ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទធម្មតា

៨៩៨-"ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទធម្មតាឲ្យស្វែងរកព្រះរាជ្យរបស់ព្រះអង្គដោយត្រួតត្រាកិច្ចការក្នុងលោកនេះ ដែលគេចាត់ចែងតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ (...)។ គ្រីស្តបរិស័ទធម្មតាទាំងនេះ មានភារកិច្ច

ផ្ទាល់យ៉ាងពិសេស គឺបំភ្លឺ និងតម្រង់អ្វីៗទាំងអស់ក្នុងលោកីយ៍ ដែលគេរស់ភ្ជាប់ជាមួយនោះ ដើម្បីឲ្យអ្វីៗទាំងនោះកើតឡើង និងចម្រើនតាមព្រះគ្រីស្តជានិច្ច និងសម្រាប់លើកតម្កើងសិរីរុងរឿងព្រះដែលបង្កើត និងសង្គ្រោះមនុស្សលោក" (LG ៣១)។

៨៩៩-គ្រីស្តបរិស័ទធម្មតាត្រូវតែមានគំនិតថ្មីជាចាំបាច់កាលបើត្រូវរកឲ្យឃើញ និងបង្កើតមធ្យោបាយដើម្បីឲ្យលទ្ធិនៃគ្រីស្តសាសនា និងរបៀបរស់នៅរបស់គ្រីស្តបរិស័ទជ្រាបចូលក្នុងសង្គមនយោបាយ និងសេដ្ឋកិច្ច ហើយដែលជាការធម្មតានៃជីវិតរបស់ព្រះសហគមន៍ៈ

> គ្រីស្តបរិស័ទធម្មតាស្ថិតនៅខាងមុខនៃជីវិតព្រះសហគមន៍។ ដោយសារពួកគេព្រះសហគមន៍ជាគោលដ៏សំខាន់ដល់ជីវិតនៃសង្គម។ ហេតុនេះពួកគេត្រូវតែដឹងខ្លួនកាន់តែច្បាស់ៗថា ពួកគេមិនគ្រាន់តែជាកម្មសិទ្ធិរបស់ព្រះសហគមន៍ប៉ុណ្ណោះទេ ថែមទាំងពួកគេជាព្រះសហគមន៍ គឺសហគមន៍នៃគ្រីស្តបរិស័ទនៅលើផែនដីនេះ ដោយសម្តេចប៉ាបជាប្រធានរួមជាមួយលោកអភិបាលជាអ្នកជួយណែនាំ។ ពួកគេជាព្រះសហគមន៍ (សម្តេចប៉ាប ពីយ៉ូសទី១២ CL ៩)។

៩០០-ដោយសារអគ្គសញ្ញាជ្រមុជទឹក និងលាបថ្វាសព្រះជាម្ចាស់ផ្ញើគ្រីស្តបរិស័ទធម្មតាឲ្យមានមុខងារប្រកាសដំណឹងល្អដូចគ្រីស្តបរិស័ទឯទៀតៗទាំងអស់គ្នាផងដែរ។ គ្រីស្តបរិស័ទធម្មតាមានកាតព្វកិច្ច និងមានសិទ្ធិដោយខ្លួនគេផ្ទាល់ ឬដោយរួមជាសហគមន៍ធ្វើការដើម្បីឲ្យមនុស្សទាំងអស់នៅលើផែនដីទាំងមូលស្គាល់ និងទទួលសាររបស់ព្រះជាម្ចាស់អំពីការសង្គ្រោះ។ ជាពិសេសពួកគេត្រូវតែប្រកាសសារនេះជាចាំបាច់នៅពេលដែលមនុស្សលោកអាចស្តាប់ឮអំពីដំណឹងល្អ និងស្គាល់ព្រះគ្រីស្តបានតាមរយៈពួកគេតែប៉ុណ្ណោះ។ ក្នុងព្រះសហគមន៍កិច្ចការរបស់ពួកគេពិតជាចាំបាច់ បើពួកគេមិនបំពេញកិច្ចការនេះ ពួកគង្វាលមិនអាចបង្កើតផលបានបរិបូរណ៍សោះឡើយ។

## គ្រីស្តបរិស័ទធម្មតាទទួលចំណែកក្នុងបន្ទុករបស់ព្រះគ្រីស្តជាបូជាចារ្យ

៩០១-"ដោយគ្រីស្តបរិស័ទធម្មតាថ្វាយខ្លួនទៅព្រះគ្រីស្ត និងដោយព្រះវិញ្ញាណដ៏វិសុទ្ធចាក់ប្រេងអភិសេកគេ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទធម្មតាឲ្យមានបេសកកម្មដ៏ល្អប្រសើរ និងមានគ្រប់មធ្យោបាយបណ្តោយឲ្យព្រះវិញ្ញាណបង្កើតផលកាន់តែច្រើនឡើងៗនៅក្នុងខ្លួនគេ។ កិច្ចការធម្មតាទាំងអស់ដែលគេប្រព្រឹត្តប្រចាំថ្ងៃ ពាក្យអធិដ្ឋាន និងកិច្ចការរបស់គេ ក្នុងឋានៈជាគ្រីស្តទូត ការរស់នៅជាគូស្វាមីភរិយា ការរស់នៅក្នុងក្រុមគ្រួសារ ការនឿយហត់ដើម្បីចិញ្ចឹមជីវិត ការសម្រាកទាំងរូបកាយក្តីទាំងចិត្តគំនិតក្តី (លុះត្រាតែគេប្រព្រឹត្តការទាំងនោះរួមជាមួយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់) សូម្បីតែទុក្ខលំបាកប្រចាំជីវិត (លុះត្រាតែគេស៊ូទ្រាំដោយអត់ធ្មត់ខន្តី) ក៏សុទ្ធតែត្រឡប់ទៅជា «យញ្ញបូជាខាងវិញ្ញាណជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដោយសារព្រះយេស៊ូគ្រីស្ត» (១សល ២,៥)។ ពេលគេថ្វាយអភិបូជា គេថ្វាយតង្វាយទាំងនោះទៅព្រះបិតា រួមជាមួយព្រះកាយព្រះអម្ចាស់ ដោយគោរពប្រណិប័តន៍។ ធ្វើដូច្នោះ គ្រីស្តបរិស័ទធម្មតា ប្រសិទ្ធិពិភពលោកទាំងមូលថ្វាយទៅព្រះបិតា និងគោរពក្រាបថ្វាយបង្គំព្រះបិតានៅគ្រប់ទីកន្លែងដោយរស់នៅបែបវិសុទ្ធ" (LG ៣៤; LG ១០)។

៩០២-តាមរបៀបពិសេសមាតាបិតារួមចំណែកទទួលបន្ទុកណែនាំឲ្យបានវិសុទ្ធ "នៅពេលដែលគាត់មានរបៀបរស់នៅជាស្វាមីភរិយារតាមលក្ខណៈជាគ្រីស្តបរិស័ទ ហើយអប់រំកូនៗតាមគ្រីស្តសាសនា (CIC ៨៣៥,៤)។

៩០៣-បើគេមានលក្ខណៈត្រឹមត្រូវ ព្រះសហគមន៍អាចទទួលគ្រីស្តបរិស័ទធម្មតាឲ្យធ្វើជាអ្នកបម្រើព្រះបន្ទូល និងអ្នកបម្រើអាសនៈដោយស្ថិតស្ថេរ (CIC ២៣០,១)។ "នៅពេលដែលព្រះសហគមន៍ត្រូវការ បើគ្មានអ្នកបាន

ទទួលមុខងារបម្រើព្រះសហគមន៍ ហើយទោះបីគេមិនមែនជាអ្នកបម្រើព្រះបន្ទូល និងអ្នកបម្រើអាសនៈក៏ដោយ ក៏គ្រីស្តបរិស័ទធម្មតាអាចបំពេញមុខងារខ្លះៗ ដូចជាប្រកាសព្រះបន្ទូលណែនាំការអធិដ្ឋានខាងពិធីបុណ្យ ផ្តល់បុណ្យជ្រមុជទឹក និងផ្តល់ព្រះកាយដ៏វិសុទ្ធរបស់ព្រះគ្រីស្តតាមច្បាប់ព្រះសហគមន៍" (CIC ២៣០,៣)។

## គ្រីស្តបរិស័ទធម្មតាទទួលចំណែកនៃបន្ទុករបស់ព្រះគ្រីស្តជាព្យាការី

៩០៤-"ព្រះគ្រីស្តបំពេញមុខងារជាព្យាការី (...) មិនគ្រាន់តែដោយសារអស់លោកអភិបាលដែលបង្រៀនក្នុងព្រះនាមព្រះអង្គ និងដែលប្រកបដោយអំណាចរបស់ព្រះអង្គប៉ុណ្ណោះទេ តែព្រះអង្គក៏បន្តបំពេញមុខងារនេះ ដោយសារគ្រីស្តបរិស័ទធម្មតាដែរ គឺព្រះអង្គប្រោសឲ្យគ្រីស្តបរិស័ទទាំងនោះទៅជាសាក្សីរបស់ព្រះអង្គ។ ព្រះអង្គប្រោសគេឲ្យមានជំនឿជ្រៅក្នុងចិត្តស្របគ្នា និងប្រោសឲ្យគេអាចថ្លែងព្រះបន្ទូលបានផង" (LG ៣៥)៖

> អ្នកប្រកាសដំណឹងល្អគ្រប់ៗរូប ហើយសូម្បីតែអ្នកជឿម្នាក់ៗមានភារកិច្ចបង្រៀនអ្នកដទៃ ដើម្បីនាំគេឲ្យជឿ (សន្ត: ថូម៉ាសនៃអាកាំង)។

៩០៥-គ្រីស្តបរិស័ទធម្មតាបំពេញមុខងារជាព្យាការីដោយប្រកាសដំណឹងល្អ គឺគេ "ប្រកាសដំណឹងល្អអំពីព្រះគ្រីស្ត ដោយការរស់នៅរបស់គេផ្តល់សក្ខីភាពផង និងដោយពោលពាក្យសម្តីផង"។ សម្រាប់គ្រីស្តបរិស័ទធម្មតា "ការប្រកាសដំណឹងល្អនេះ មានលក្ខណៈពិសេស និងមានប្រសិទ្ធិភាពយ៉ាងខ្លាំង ព្រោះគេប្រកាសដំណឹងល្អក្នុងសភាពការណ៍ធម្មតារបស់មនុស្សលោក" (LG ៣៥)។

> ការប្រកាសដំណឹងល្អនេះ មិនគ្រាន់តែស្ថិតនៅក្នុងការរស់នៅរបស់គ្រីស្តបរិស័ទប៉ុណ្ណោះទេ គឺគ្រីស្តទូតយ៉ាងពិតប្រាកដស្វែងរកឱកាសនីមួយៗ ដើម្បីប្រកាសព្រះគ្រីស្តដល់អស់អ្នកដែលមិនជឿផង (...) និងដល់គ្រីស្តបរិស័ទឯទៀតៗផង (AA ៦)។

៩០៦-ក្នុងចំណោមគ្រីស្តបរិស័ទធម្មតា អស់អ្នកដែលអាចធ្វើបាន ហើយដែលទទួលការអប់រំអាចជួយបង្រៀនអប់រំជំនឿ (CIC ៧៧៤; ៧៧៦; ៧៨០) ទេវវិទ្យាដ៏វិសុទ្ធ (CIC ២២៩) និងមធ្យោបាយទំនាក់ទំនងក្នុងសង្គម (CIC ៨២៣,១)។

៩០៧-ដោយសារកាតព្វកិច្ចបច្ចេកទេស និងកិត្តិយសដែលគេមានគេមានសិទ្ធិ ហើយជួនកាលគេមានភារកិច្ចបញ្ចេញយោបល់របស់គេដល់ពួកគង្វាលដ៏វិសុទ្ធ ដើម្បីជាផលប្រយោជន៍នៃព្រះសហគមន៍ ហើយផ្តល់យោបល់នេះឲ្យគ្រីស្តបរិស័ទឯទៀតៗស្គាល់ដោយមិនរាប់អំពីលទ្ធិនៃជំនឿដ៏ត្រឹមត្រូវ និងសីលធម៌ ហើយដោយគោរពពួកគង្វាល ទាំងយកចិត្តទុកដាក់នូវផលប្រយោជន៍រួម និងសេចក្តីថ្លៃថ្នូររបស់មនុស្ស (CIC ២១២,៣)។

## គ្រីស្តបរិស័ទធម្មតាទទួលចំណែកនៃបន្ទុករបស់ព្រះគ្រីស្តជាព្រះមហាក្សត្រ

៩០៨-"ព្រះគ្រីស្តធ្វើតាមព្រះបញ្ញារហូតដល់សោយទិវង្គត (ភីល ២,៨-៩) ព្រះអង្គបានប្រគល់អំណាចនេះឲ្យក្រុមសាវ័ក ទ្រង់ក៏តែងតាំងគេឲ្យមានសេរីភាព ក្នុងឋានៈជាព្រះមហាក្សត្រ ដើម្បីរំដោះគេឲ្យបានរួចពីអំណាចនៃបាបដែលសោយរាជ្យក្នុងខ្លួនគេផ្ទាល់។ គេត្រូវមានចិត្តលះបង់ និងរស់នៅយ៉ាងវិសុទ្ធ ទើបព្រះអង្គប្រោសគេឲ្យរួចបាន" (LG ៣៦)។

> អ្នកណាដែលគ្រប់គ្រងរូបកាយរបស់ខ្លួន និងណែនាំព្រលឹងរបស់ខ្លួនដោយមិនចុះក្រោមអំណាចនៃកិលេសតណ្ហាជាម្ចាស់ការលើខ្លួនឯង។ យើងអាចហៅគេថា ជាព្រះមហាក្សត្រ ព្រោះគេចេះណែនាំខ្លួនឯង។ គេមាន

សេរីភាព និងឯករាជ្យ ហើយគេមិនមែនជាឈ្លើយនៃតណ្ហាឡើយ (សន្ធ: អំប្រ័រ)។

៩០៩-"លើសពីនេះទៅទៀត ប្រសិនបើស្ថាប័ននានា និងសភាពនៃការរស់នៅក្នុងពិភពលោកបណ្តាលឲ្យប្រព្រឹត្ត អំពើបាប សូមឲ្យគ្រីស្តបរិស័ទធម្មតារួមកម្លាំងគ្នាជួយប្រែ និងព្យាបាលស្ថាប័ន និងស្ថានភាពទាំងនោះ ឲ្យបាន សមគួរ ដើម្បីឲ្យស្ថាប័ន និងស្ថានភាពទាំងនោះបានស្របតាមក្បួននៃយុត្តិធម៌ ហើយជួយមនុស្សឲ្យប្រព្រឹត្តតាម ព្រហ្មវិហារធម៌ លែងរារាំងយុត្តិធម៌ និងព្រហ្មវិហារធម៌ដូចពីមុនទៀតឡើយ។ ប្រសិនបើគេប្រព្រឹត្តដូច្នេះ គ្រីស្តបរិស័ទ នឹងនាំតម្លៃដ៏ថ្លៃថ្នូរនៃសីលធម៌ឲ្យជ្រាបចូលក្នុងវប្បធម៌ និងក្នុងគ្រប់កិច្ចការរបស់មនុស្ស" (LG ៣៦)។

៩១០-"គ្រីស្តបរិស័ទធម្មតាអាចយល់ឃើញថា ព្រះជាម្ចាស់ត្រាស់ហៅគេ ឬព្រះសហគមន៍អាចត្រាស់ហៅគេ ឲ្យរួមសហការជាមួយពួកគង្វាល និងបម្រើព្រះសហគមន៍ដើម្បីឲ្យព្រះសហគមន៍រីកចម្រើនឡើង និងមានជីវិត ដោយមានមុខងារផ្សេងៗពីគ្នាតាមការប្រណីសន្តោស និងព្រះអំណោយទានដែលព្រះអម្ចាស់សព្វព្រះហឫទ័យ ប្រោសប្រទានឲ្យគេ" (EN ៧៣)។

៩១១-ក្នុងព្រះសហគមន៍ "គ្រីស្តបរិស័ទធម្មតាអាចរួមសហការក្នុងការគ្រប់គ្រងព្រះសហគមន៍តាមក្បួនច្បាប់" (CIC ១២៩,២)។ ហេតុនេះគេនៅក្នុងក្រុមទីប្រឹក្សាតាមភូមិ (CIC ៤៤៣,៤) តាមភូមិភាគ (CIC ៤៦៣, ១.២) និងតាមសហគមន៍ (CIC ៥១១; ៥៣៦)។ គេអាចរួមចំណែកក្នុងការទទួលខុសត្រូវលើព្រះសហគមន៍ ណាមួយ (CIC ៥១៧,២) រួមសហការជាមួយទីប្រឹក្សាខាងសេដ្ឋកិច្ច (CIC ៤៩២,១) និងក្នុងតុលាការ ព្រះសហគមន៍ (CIC ១៤២១,២) ល។ល។

៩១២-គ្រីស្តបរិស័ទត្រូវតែ "បង្ហាត់ខ្លួនឲ្យចេះវែកញែកយ៉ាងច្បាស់នូវអ្វីៗជាសិទ្ធិ និងជាភារកិច្ចរបស់ខ្លួនក្នុង ឋានៈជាសមាជិកនៃព្រះសហគមន៍ និងអ្វីៗជាសិទ្ធិ និងជាភារកិច្ចរបស់ខ្លួនក្នុងឋានៈជាសមាជិកនៃសង្គមមនុស្ស។ សូមយកចិត្តទុកដាក់ខិតខំធ្វើឲ្យសិទ្ធិ និងភារកិច្ចទាំងពីរយ៉ាងនេះស៊ីសង្វាក់គ្នាទៅវិញទៅមកយ៉ាងស្រួល។ ត្រូវនឹក ជានិច្ចថា មនសិការជាគ្រីស្តបរិស័ទត្រូវណែនាំគេគ្រប់វិស័យខាងលោកីយ៍ ដ្បិតគ្មានកិច្ចការណាមួយរបស់មនុស្ស សូម្បីតែខាងលោកីយ៍ក្តី អាចជៀសផុតពីអំណាចរបស់ព្រះជាម្ចាស់បានសោះឡើយ" (LG ៣៦)។

៩១៣-"ដូច្នេះគ្រីស្តបរិស័ទម្នាក់ៗជាសាក្សីតាមព្រះអំណោយទានដែលខ្លួនបានទទួល។ នៅពេលជាមួយគ្នា នេះ គេបំពេញបេសកកម្មរបស់ព្រះសហគមន៍ផ្ទាល់ "តាមកម្រិតនៃព្រះអំណោយទាន ដែលព្រះគ្រីស្តប្រទានមក" (អភ ៤,៧) (LG ៣៣)។

### ៣-របៀបរស់នៅជាអ្នកថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់

៩១៤-"ទោះបីរបៀបរស់នៅជាបព្វជិតបព្វជិតា ដែលប្រកាសពាក្យសច្ចាប្រណិធានកាន់តាមដំបូន្មានចែងក្នុង គម្ពីរដំណឹងល្អ មិនចូលក្នុងរចនាសម្ព័ន្ធតាមលំដាប់លំដោយរបស់ព្រះសហគមន៍ក្តី ក៏របៀបរស់នៅបែបនេះជាប់ នឹងជីវិត និងលក្ខណៈដ៏វិសុទ្ធរបស់ព្រះសហគមន៍កាត់ផ្តាច់មិនបានដែរ" (LG ៤៤)។

### ដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ និងអ្នកថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់

៩១៥-ព្រះជាម្ចាស់ត្រាស់ហៅសាវ័កម្នាក់ៗរបស់ព្រះគ្រីស្តឲ្យប្រព្រឹត្តតាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ។ ដំបូន្មាន នោះមានច្រើនផ្សេងៗពីគ្នា។ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទទាំងអស់ឲ្យបានគ្រប់លក្ខណៈដោយសារសេចក្តី ស្រឡាញ់ គឺមានសម្រាប់អស់អ្នកដែលថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គដោយស្ម័គ្រចិត្ត ត្រូវរស់នៅជាព្រហ្មចារី

ថ្វាយព្រះជាម្ចាស់ ដោយរក្សាភាពនូវលើវចំពោះព្រះរាជ្យរស់នៅបែបអ្នកក្រីក្រ និងស្តាប់បង្គាប់អ្នកដឹកនាំ។ អ្នកណាប្រកាសពាក្យសច្ចាប្រណិធានកាន់តាមដំបូន្មាន ក៏ថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ (LG ៤២-៤៣; PC ១)។

៩១៦-ដូច្នេះការថ្វាយខ្លួនជាបព្វជិតបព្វជិតាជារបៀបរស់នៅ "យ៉ាងស្និតស្នាលបំផុត" ជាមួយព្រះជាម្ចាស់ ដែលចាក់ឫសក្នុងបុណ្យជ្រមុជទឹក និងនាំឲ្យយើងបូជាខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ (PC ៥)។ ពេលថ្វាយខ្លួន អ្នកផ្ញើជីវិតទាំងស្រុងលើព្រះគ្រីស្តមានបំណងចង់ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធណែនាំដើរតាមព្រះគ្រីស្តយ៉ាងជិតស្និទ្ធ ថ្វាយខ្លួនចំពោះព្រះជាម្ចាស់ ហើយលើសអ្វីៗទាំងអស់ចង់បង្ហាញ និងប្រកាសក្នុងព្រះសហគមន៍សិរីរុងរឿងនៃពិភពលោកថ្មីដោយធ្វើតាមសេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណៈក្នុងកិច្ចបម្រើព្រះរាជ្យ (CIC ៥៧៣)។

### ដើមឈើធំៗបែកមែកសាខាយ៉ាងច្រើន

៩១៧-"ដំបូន្មានក្នុងគម្ពីរដំណឹងល្អចែងថា មានរបៀបរស់នៅប្លែកៗពីគ្នាកាន់តែច្រើនឡើង ប្រៀបបីដូចគ្រាប់ពូជដែលព្រះជាម្ចាស់សាបព្រោះ កើតជាដើមឈើមួយបែកមែកសាខាយ៉ាងច្រើនអស្ចារ្យក្នុងចម្ការរបស់ព្រះអម្ចាស់ គឺមានអ្នកខ្លះជាឥសី រស់នៅម្នាក់ឯង អ្នកខ្លះនាំគ្នារស់នៅរួមជាមួយគ្នា អ្នកខ្លះបង្កើតក្រុមគ្រួសារផ្សេងៗប្រកបដោយធនធានខាងវិញ្ញាណយ៉ាងស្តុកស្តម្ភ ដែលមានប្រយោជន៍ដល់សមាជិកក្រុមគ្រួសារទាំងនោះផង និងដល់ព្រះកាយព្រះគ្រីស្តទាំងមូលផងដែរ" (LG ៤៣)។

៩១៨-"តាំងពីព្រះសហគមន៍ដើមដំបូងមានបុរស និងស្ត្រីដែលមានបំណងចង់ដើរតាមព្រះគ្រីស្តដោយធ្វើតាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ ដោយមានសេរីភាពច្រើនជាង និងយកតម្រាប់តាមព្រះអង្គយ៉ាងស្មោះ។ តាមរបៀបរៀងៗខ្លួន គេបានថ្វាយខ្លួនចំពោះព្រះជាម្ចាស់។ ក្នុងចំណោមពួកគេ មានមនុស្សជាច្រើនដោយមានព្រះវិញ្ញាណបានណែនាំរស់នៅតែម្នាក់ឯង ឬបង្កើតក្រុមគ្រួសារបព្វជិតបព្វជិតាដែលព្រះសហគមន៍ទទួលរាក់ទាក់ ហើយយល់ស្របនឹងរបៀបចាត់ចែងរបស់គេ" (PC ១)។

៩១៩-លោកអភិបាលនឹងខិតខំពិចារណាលើព្រះអំណោយទានថ្មី នៃរបៀបរស់នៅជាអ្នកថ្វាយខ្លួន ដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រទានឲ្យព្រះសហគមន៍របស់ព្រះអង្គ។ មានតែព្រះសហគមន៍នៅទីក្រុងរ៉ូមទេ ដែលអាចបញ្ជាក់អំពីរបៀបរស់នៅថ្មីជាអ្នកថ្វាយខ្លួនបាន។

### របៀបរស់នៅជាឥសី

៩២០-ឥសីមិនតែងតែប្រកាសពាក្យសច្ចាប្រណិធានជាសាធារណៈឡើយ។ ពួកគេរស់នៅ "ដាច់ដោយឡែកពីលោកកីយ៍តែម្នាក់ឯងយ៉ាងតឹងរឹង ក្នុងភាពស្ងៀមស្ងាត់ដោយអធិដ្ឋានជានិច្ច និងសោកស្តាយអំពើបាបរបស់ខ្លួនឯង និងរបស់អ្នកដទៃ។ ពួកគេបូជាជីវិតរបស់គេដើម្បីសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងការសង្គ្រោះនៃពិភពលោក" (CIC ៦០៣,១)

៩២១-ពួកគេបង្ហាញគេឯងរាល់គ្នាអំពីភាពខាងក្នុងនៃអាថ៌កំបាំងរបស់ព្រះសហគមន៍ គឺទំនាក់ទំនងយ៉ាងស្និតស្នាលជាមួយព្រះគ្រីស្ត។ ជីវិតរបស់ឥសីដែលជាទីសម្ងាត់កំបាំងពីភ្នែកមនុស្សលោក ដូចជាធម្មទេសនាដ៏ស្ងៀមស្ងាត់ចំពោះព្រះគ្រីស្តដែលពួកគេបានបូជាជីវិត ដ្បិតព្រះអង្គជាអ្វីៗទាំងអស់ចំពោះគេ។ ព្រះជាម្ចាស់ត្រាស់ហៅគេយ៉ាងពិសេស គឺឲ្យគេរកឃើញសិរីរុងរឿងរបស់ព្រះគ្រីស្តដែលត្រូវគេឆ្កាងក្នុងវាលរហោស្ថាន គឺក្នុងការច្បាំងប្រយុទ្ធខាងវិញ្ញាណ។

## ស្ត្រីព្រហ្មចារិនីដែលថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់

៩២២-ចាប់ពីដើមដំបូងព្រះអម្ចាស់ត្រាស់ហៅស្ត្រីប្រហ្មចារិនី គ្រីស្តបរិស័ទឲ្យជាប់ចិត្តនឹងព្រះអង្គដោយបូជាខ្លួនទាំងស្រុងថ្វាយព្រះអង្គ (១ករ ៧,៣៤-៣៦)។ ដោយមានការយល់ស្របពីព្រះសហគមន៍ ស្ត្រីនោះមានសេរីភាពទាំងចិត្តគំនិត ទាំងរូបកាយ ទាំងវិញ្ញាណបានប្តេជ្ញារស់នៅជាព្រហ្មចារិនី "ដោយសារព្រះរាជ្យនៃស្ថានបរមសុខ" (មថ ១៩,១២)។

៩២៣-"ស្ត្រីព្រហ្មចារិនីខ្លះពោលថា ចង់ដើរតាមព្រះគ្រីស្តយ៉ាងជិតស្និទ្ធ ដោយថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់។ ហេតុនេះលោកអភិបាលភូមិភាគទទួលពួកស្ត្រីនោះ ដោយធ្វើពិធីបុណ្យត្រឹមត្រូវ ព្រះគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់យកពួកគេធ្វើជាភរិយារតាមរបៀបយ៉ាងអស្ចារ្យ ដើម្បីឲ្យពួកគេបម្រើព្រះសហគមន៍" (CIC ៦០៤,១)។ ដោយសារពិធីយ៉ាងឧឡារិកនេះ (Consecratio virginum) "ព្រះជាម្ចាស់ប្រោសស្ត្រីព្រហ្មចារិនីឲ្យទៅជាបុគ្គលដ៏សក្ការៈ ជាសញ្ញាសម្គាល់ដ៏ខ្ពង់ខ្ពស់នៃសេចក្តីស្រឡាញ់របស់ព្រះសហគមន៍ចំពោះព្រះគ្រីស្ត និងជារូបតំណាងរបស់ព្រះសហគមន៍នៃពេលចុងក្រោយបំផុត ដែលជាព្រះមហេសីនៃស្ថានបរមសុខ និងជារូបតំណាងរបស់ជីវិតក្នុងអនាគត" (OCV)។

៩២៤-ក្រុមស្ត្រីព្រហ្មចារិនីដែលថ្វាយខ្លួនចំពោះព្រះជាម្ចាស់ "មានរបៀបរស់នៅស្រដៀងនឹងអស់អ្នកដែលថ្វាយខ្លួនចំពោះព្រះជាម្ចាស់" (CIC ៦០៤,១) ធ្វើឲ្យស្ត្រីនោះដែលរស់នៅក្នុងលោកកីយ៍ (ឬបព្វជិតាដែលរស់នៅក្នុងអារាម) រស់នៅដោយអធិដ្ឋានសោកស្តាយអំពើបាបរបស់ខ្លួនឯង និងរបស់អ្នកដទៃបម្រើបងប្អូនឯទៀតៗ និងប្រកាសដំណឹងល្អតាមលក្ខណៈ និងព្រះអំណោយទានដែលព្រះជាម្ចាស់បានប្រោសប្រទានឲ្យម្នាក់ៗ។ ស្ត្រីព្រហ្មចារិនីអាចប្រមូលផ្តុំគ្នាជាសហគមន៍ ដើម្បីជួយគ្នាក្នុងការរក្សាទុកព្រហ្មចារិយធម៌របស់គេយ៉ាងស្មោះស្ម័គ្រ។

## របៀបរស់នៅជាបព្វជិត បព្វជិតា

៩២៥-របៀបរស់នៅជាបព្វជិត បព្វជិតាបានកើតឡើងក្នុងព្រះសហគមន៍ដើមដំបូងនៅបូព៌ាប្រទេស (UR ១៥) ហើយបព្វជិត បព្វជិតាបានរស់នៅក្នុងក្រុមគ្រួសារដែលព្រះសហគមន៍បានតែងតាំងតាមក្បួនច្បាប់ព្រះសហគមន៍ (CIC ៥៧៣)។ របៀបរស់នៅជាបព្វជិត បព្វជិតាខុសប្លែកពីរបៀបរស់នៅរបស់អស់អ្នកដែលថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ដោយសារពិធីបុណ្យការប្រកាសពាក្យសច្ចាប្រណិធានជាសាធារណៈ ការរស់នៅជាមួយគ្នាដូចជាបងប្អូន និងដោយសារពួកគេផ្តល់សក្ខីភាពដល់ព្រះគ្រីស្តដែលរួមរស់ជាមួយព្រះសហគមន៍ (CIC ៦០៧)។

៩២៦-របៀបរស់នៅជាបព្វជិត បព្វជិតាមកពីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ចំពោះព្រះសហគមន៍ជាព្រះអំណោយទានដែលព្រះអម្ចាស់ប្រោសប្រទានដល់ព្រះសហគមន៍។ ព្រះសហគមន៍ផ្តល់ដល់គ្រីស្តបរិស័ទដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យប្រកាសពាក្យសច្ចាប្រណិធានឲ្យមានរបៀបរស់នៅដ៏ស្ថិតស្ថេរមួយ។ ហេតុនេះហើយបានជាព្រះសហគមន៍អាចសម្តែងព្រះគ្រីស្ត និងទទួលស្គាល់ថាខ្លួនឯងជាព្រះមហេសីរបស់ព្រះសង្គ្រោះផង។ របៀបរស់នៅជាបព្វជិត បព្វជិតាជាសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ផ្ទាល់ចំពោះមនុស្សលោកក្នុងបច្ចុប្បន្នកាល។

៩២៧-បព្វជិត បព្វជិតាទាំងអស់ទោះជាមានឯកសិទ្ធិពិសេស ឬគ្មាន (CIC ៥៩១) រួមជាមួយសហការីរបស់លោកអភិបាលក្នុងបន្ទុករបស់លោក។ ចាប់តាំងពីពេលប្រកាសដំណឹងល្អដើមដំបូង វត្តមានបព្វជិត បព្វជិតាគ្រប់យ៉ាងជាចាំបាច់ ដើម្បីតែងតាំងព្រះសហគមន៍ និងដើម្បីឲ្យព្រះសហគមន៍នោះរីកចម្រើន (AG ១៨; ៤០)។

"ប្រវត្តិសាស្ត្របញ្ជាក់នូវបុណ្យកុសលដ៏ខ្ពង់ខ្ពស់នៃក្រុមគ្រួសារបព្វជិត បព្វជិតាក្នុងការផ្សព្វផ្សាយដំណឹងល្អ និងការបង្កើតព្រះសហគមន៍ថ្មីតាំងពីវត្តអារាមសម័យបុរាណ និងក្រុមគ្រួសារនៃមធ្យមសម័យរហូតដល់ក្រុមគ្រួសារទាន់សម័យ" (RM ៦៩)។

## ក្រុមគ្រីស្តបរិស័ទដែលថ្វាយខ្លួន តែរស់នៅក្នុងសង្គម

៩២៨-"ក្រុមគ្រីស្តបរិស័ទដែលថ្វាយខ្លួន តែរស់នៅក្នុងសង្គមជាក្រុមដែលសមាជិកខិតខំរស់នៅដោយចិត្តស្រឡាញ់ឲ្យបានគ្រប់លក្ខណៈ ហើយដែលព្យាយាមធ្វើឲ្យពិភពលោកបានវិសុទ្ធពីខាងក្នុង" (CIC ៧១០)។

៩២៩-ដោយថ្វាយខ្លួនទាំងស្រុង និងឲ្យបានពេញលក្ខណៈ ដើម្បីឲ្យពិភពលោកបានវិសុទ្ធនោះ សមាជិកក្រុមគ្រីស្តបរិស័ទនោះ ចូលរួមចំណែកក្នុងបន្ទុកប្រកាសដំណឹងល្អរបស់ព្រះសហគមន៍ "ក្នុងលោកីយ៍ និងចាប់ពីលោកីយ៍" ដោយប្រព្រឹត្តដូចមេក្នុងម្សៅ" (PC ១១)។ ពួកគេ "ផ្តល់សក្ខីភាពអំពីរបៀបរស់នៅជាគ្រីស្តបរិស័ទដោយមានគោលដៅឲ្យកិច្ចការលោកីយ៍ស្របនឹងព្រះជាម្ចាស់ និងឲ្យកម្លាំងដំណឹងល្អចូលជ្រាបក្នុងពិភពលោក"។ ពួកគេធ្វើតាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អដោយចងចំណងដ៏សក្ការៈ និងរក្សាទុកការរួមរស់ជាមួយគ្នាដូចជាបងប្អូនដែលជាលក្ខណៈពិសេសនៃ "របៀបរស់នៅក្នុងសង្គម" របស់គេ (CIC ៧១៣,២)។

## សហគមន៍បំពេញមុខងារជាសាសនទូត

៩៣០-រួមជាមួយក្រុមអ្នកថ្វាយខ្លួន "មានសហគមន៍បំពេញមុខងារជាសាសនទូត។ សមាជិកសហគមន៍នោះមិនធ្វើសច្ចាប្រណិធាន តែធ្វើតាមគោលដៅនៃសហគមន៍របស់គេទេ។ ពួកគេរស់នៅជាមួយគ្នាដូចជាបងប្អូន ហើយនៅតាមរបៀបរស់នៅរបស់រៀងៗខ្លួន ពួកគេព្យាយាមស្រឡាញ់ឲ្យបានគ្រប់លក្ខណៈ ដោយធ្វើតាមគោលវិន័យក្រុមគ្រួសារ" (CIC ៧៣១,១)។

## អ្នកថ្វាយខ្លួនមានបេសកកម្មប្រកាសថាព្រះមហាក្សត្រកំពុងយាងមក

៩៣១-អ្នកដែលបានជ្រមុជទឹក បានថ្វាយខ្លួនចំពោះព្រះជាម្ចាស់រួចហើយតែដោយបូជាខ្លួនថ្វាយព្រះជាម្ចាស់ដែលគេស្រឡាញ់លើសអ្វីៗទាំងអស់ អ្នកនោះថ្វាយខ្លួនយ៉ាងស្និតស្នាលដើម្បីបម្រើព្រះជាម្ចាស់ និងដើម្បីផលប្រយោជន៍ព្រះសហគមន៍ផងដែរ។ ដោយថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ ព្រះសហគមន៍សម្តែងព្រះគ្រីស្ត និងបង្ហាញនូវកិច្ចការយ៉ាងអស្ចារ្យរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងខ្លួន។ អស់អ្នកដែលប្រកាសដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អមានបេសកកម្មដំបូងបង្អស់ គឺធ្វើតាមរបៀបរស់នៅជាអ្នកថ្វាយខ្លួន។ "ប៉ុន្តែដោយសារគេបានថ្វាយខ្លួន ទើបគេប្រគល់ខ្លួនបម្រើព្រះសហគមន៍ ដូច្នេះគេត្រូវតែធ្វើការតាមរបៀបពិសេសដោយប្រកាសដំណឹងល្អតាមលក្ខណៈពិសេសនៃក្រុមគ្រួសាររបស់គេ" (CIC ៧៨៣)។

៩៣២-ក្នុងព្រះសហគមន៍ដែលជាអគ្គសញ្ញា ជាសញ្ញាសម្គាល់ និងឧបករណ៍នៃព្រះជន្មរបស់ព្រះជាម្ចាស់ របៀបរស់នៅជាអ្នកថ្វាយខ្លួន ដូចជាសញ្ញាសម្គាល់ពិសេសរបស់គម្រោងការដ៏អស្ចារ្យអំពីការសង្គ្រោះ។ ពេលយើងដើរតាម និងយកតម្រាប់តាមព្រះយេស៊ូគ្រីស្ត "យ៉ាងស្និទ្ធស្នាលជាង" ពេលយើងសម្តែង "យ៉ាងច្បាស់ជាង" ថាព្រះអង្គបានបន្ទាបខ្លួនរហូតដល់សោយទិវង្គត ពេលនោះយើងរួមរស់យ៉ាងជ្រាលជ្រៅជាមួយបងប្អូនក្នុងសង្គមនៅក្នុងអង្គព្រះគ្រីស្ត ដ្បិតអស់អ្នកដែលដើរតាម "ផ្លូវដ៏ចង្អៀត" នេះជួយដាស់តឿនបងប្អូនគេ ដោយធ្វើជាគំរូសម្រាប់គេ ហើយផ្តល់សក្ខីភាពយ៉ាងអស្ចារ្យនោះថា "មនុស្សលោកមិនអាចផ្លាស់ប្រែបាន ហើយក៏មិនអាចយកទៅថ្វាយព្រះជាម្ចាស់

បាន ក្រៅពីការប្រៀនប្រដៅរបស់ព្រះយេស៊ូអំពីសុភមង្គលដ៏ពិតប្រាកដ" (LG ៣១)។

៩៣៣-ទោះជាសក្ខីភាពនេះលាតត្រដាងជាសាធារណៈ ដូចរបៀបរស់នៅជាបព្វជិត បព្វជិតាក្ដី ឬដោយមិនសូវបញ្ចេញឲ្យគេដឹងក្ដី ឬដោយសម្ងាត់ក្ដីក៏ព្រះគ្រីស្ត ដែលយាងមក នៅតែជាប្រភព និងទីចុងក្រោយនៃជីវិតរបស់អស់អ្នកដែលថ្វាយខ្លួនដែរ៖

> ប្រជារាស្ត្ររបស់ព្រះជាម្ចាស់គ្មានមាតុភូមិនៅស្ថិតស្ថេរក្នុងលោកនេះទេ (...)។ យ៉ាងណាមិញ របៀបរស់នៅជាបព្វជិត បព្វជិតាបង្ហាញបញ្ជាក់យ៉ាងច្បាស់ឲ្យគ្រីស្ដបរិស័ទទាំងអស់ ស្គាល់អំពីសម្បត្តិសួគ៌ ដែលស្ថិតនៅក្នុងលោកនេះរួចហើយ។ ពួកគេធ្វើសាក្សីបញ្ជាក់ថា មានជីវិតថ្មីម្យ៉ាងស្ថិតនៅអស់កល្បជានិច្ច ដែលព្រះគ្រីស្ដបានបង្កើតដោយព្រះអង្គបូជាព្រះជន្ម។ គេក៏ជូនដំណឹងអំពីជីវិតថ្មីដែលមនុស្សត្រូវទទួលនៅលោកខាងមុខ និងអំពីសិរីរុងរឿងនៃព្រះរាជ្យរបស់ព្រះអង្គដ៏ខ្ពង់ខ្ពស់បំផុត (LG ៤៤)។

## សង្ខេប

៩៣៤-"ព្រះជាម្ចាស់បានចាត់ចែងឲ្យមាននៅក្នុងព្រះសហគមន៍ នៅក្នុងចំណោមគ្រីស្ដបរិស័ទ អ្នកបម្រើដ៏សក្ការៈ ដែលគេហៅថា បូជាចារ្យ ឯអ្នកដទៃវិញ គេហៅថា គ្រីស្ដបរិស័ទធម្មតា"។ ទីបញ្ចប់ មានគ្រីស្ដបរិស័ទដែលជាបូជាចារ្យ ឬជាគ្រីស្ដបរិស័ទធម្មតា ដែលសច្ចារធ្វើតាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ ហើយដែលបានថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ និងបម្រើបេសកកម្មរបស់ព្រះសហគមន៍ (CIC ២០៧,១.២) ។

៩៣៥-ដើម្បីប្រកាសជំនឿ និងធ្វើឲ្យព្រះរាជ្យរបស់ព្រះអង្គយាងមក ព្រះគ្រីស្ដចាត់ក្រុមគ្រីស្ដទូត និងអ្នកបន្តមុខងាររបស់ពួកលោកឲ្យទៅ។ ព្រះអង្គប្រោសឲ្យពួកលោករួមចំណែកក្នុងបេសកកម្មរបស់ព្រះអង្គ។ ពួកលោកទទួលអំណាចពីព្រះអង្គឲ្យប្រព្រឹត្តកិច្ចការក្នុងអង្គព្រះអង្គ។

៩៣៦-ព្រះអម្ចាស់បានប្រោសឲ្យសន្តៈ សិលា ទៅជាគ្រឹះដែលអាចមើលឃើញនៃព្រះសហគមន៍ព្រះអង្គ។ ព្រះអង្គបានប្រគល់កូនសោឲ្យលោក។ លោកអភិបាលព្រះសហគមន៍នៅទីក្រុងរ៉ូម ជាអ្នកបន្តមុខងារលោក សិលា ជា "ប្រធានក្រុមលោកអភិបាល ជាតំណាងរបស់ព្រះគ្រីស្ដ គង្វាលរបស់ព្រះសហគមន៍ទាំងមូលនៅលើផែនដីនេះ" (CIC ៣៣១)។

៩៣៧-សម្ដេចប៉ាប "បានទទួលអំណាចដ៏ខ្ពង់ខ្ពស់បំផុតយ៉ាងពេញលក្ខណៈភ្លាម និងជាសកលពីព្រះជាម្ចាស់ដើម្បីដឹកនាំព្រលឹង" (CD ២)។

៩៣៨-ពួកលោកអភិបាល ដែលព្រះវិញ្ញាណដ៏វិសុទ្ធបានចាត់ចែងជាអ្នកបន្តមុខងារក្រុមគ្រីស្ដទូត។ "ពួកលោកអភិបាលម្នាក់ៗតាមចំណែករៀងៗខ្លួន ក៏ជាគោល និងជាគ្រឹះ ដែលធ្វើឲ្យព្រះសហគមន៍ភូមិភាគរបស់ខ្លួនរួបរួមគ្នាជាធ្លុងតែមួយដែរ" (LG ២៣)។

៩៣៩-ដោយមានពួកបូជាចារ្យជាសហការីរបស់ពួកលោក និងដោយមានពួកឧបដ្ឋាកផងដែរ ពួកអភិបាលមានបន្ទុកបង្រៀនជំនឿយ៉ាងត្រឹមត្រូវ ប្រារព្ធពិធីលើកតម្កើងព្រះជាម្ចាស់ ជាពិសេសពិធីអរព្រះគុណ និងណែនាំព្រះសហគមន៍របស់ខ្លួនដូចជាគង្វាលពិតប្រាកដ។ ពួកលោកមានបន្ទុកយកចិត្តទុកដាក់លើព្រះសហគមន៍ទាំងឡាយជាមួយ និងក្រោមបញ្ជាសម្ដេចប៉ាបដែរ។

៩៤០-"គ្រីស្ដបរិស័ទធម្មតាមានលក្ខណៈពិសេស គឺរស់នៅក្នុងលោកីយ៍។ ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យប្រកាស

ដំណឹងល្អក្នុងលោកនេះ ដូចជាមេដំបែ ដោយសារចិត្តគំនិតជាគ្រីស្តបរិស័ទដ៏រឹងមាំរបស់គេ "(AA ២)។

៩៤១-គ្រីស្តបរិស័ទធម្មតារួមចំណែកក្នុងអង្គព្រះគ្រីស្តក្នុងឋានៈជាបូជាចារ្យ៖ គេរួមរស់ជាមួយព្រះអង្គកាន់តែខ្លាំងឡើងៗ គេធ្វើឲ្យព្រះអំណោយទាននៃពិធីជ្រមុជទឹក និងពិធីលាបថ្ងាសចម្រើនឡើងគ្រប់វិស័យទាំងអស់ គឺជីវិតផ្ទាល់ខ្លួន ក្នុងក្រុមគ្រួសារ ក្នុងសង្គម និងក្នុងព្រះសហគមន៍ ដូច្នេះហើយបានជាគេសម្រេចបានតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលត្រាស់ហៅគ្រីស្តបរិស័ទទាំងអស់ឲ្យទៅជាសន្តបុគ្គល។

៩៤២-ដោយសារបេសកកម្មរបស់គេជាព្យាការី "ព្រះជាម្ចាស់ត្រាស់ហៅឲ្យគេធ្វើជាសាក្សីអំពីព្រះគ្រីស្តនៅកណ្តាលចំណោមសហគមន៍មនុស្សគ្រប់កាលៈទេសៈទាំងអស់" (GS ៤៣,៤)។

៩៤៣-ដោយសារបេសកកម្មរបស់គេជាព្រះមហាក្សត្រ គ្រីស្តបរិស័ទធម្មតាមានអំណាចដកអំពើបាបចេញពីខ្លួនគេផង ចេញពីពិភពលោកផង ដោយលះបង់ខ្លួនឯង និងរបៀបរស់ដ៏វិសុទ្ធផង (LG ៣៦)។

៩៤៤-អ្នកថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ មានលក្ខណៈជាអ្នកសច្ចាជាសាធារណៈ ដំបូន្មានដែលមានចែងក្នុងដំណឹងល្អ គឺដាក់ខ្លួនជាអ្នកក្រ ចេះទប់ចិត្តខ្លួនឯង និងស្តាប់បង្គាប់ ដោយមានរបៀបរស់នៅយ៉ាងស្ថិតស្ថេរដែលព្រះសហគមន៍ទទួលស្គាល់។

៩៤៥-ដោយសារពិធីជ្រមុជទឹក គ្រីស្តបរិស័ទជាកម្មសិទ្ធិរបស់ព្រះអង្គរួចទៅហើយ ប៉ុន្តែដោយការថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គ ដែលគេស្រឡាញ់លើសអ្វីៗទាំងអស់ គ្រីស្តបរិស័ទនោះបម្រើព្រះជាម្ចាស់ និងព្រះសហគមន៍កាន់តែជ្រាលជ្រៅថែមទៀត។

## កថាខណ្ឌទី៥៖ សហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ

៩៤៦-ក្រោយពីបានប្រកាសថា "ព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ" ធម៌ប្រកាសជំនឿដែលមកពីក្រុមគ្រីស្តទូតបន្ថែម "សហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ"។ ប្រការនេះដូចជាពន្យល់ប្រការដើមអំពី "ព្រះសហគមន៍ដ៏វិសុទ្ធ"៖ "អ្វីទៅជាព្រះសហគមន៍ ក្រៅពីសហគមន៍របស់ជនដ៏វិសុទ្ធទាំងឡាយ?" (នីសេតាស)។ សហភាពរវាងជនដ៏វិសុទ្ធជាព្រះសហគមន៍។

៩៤៧-"ដោយសារអ្នកជឿធ្វើជារូបកាយតែមួយ អំពើល្អរបស់អ្នកខ្លះឆ្លងទៅអ្នកដទៃ (...)។ ដូច្នេះត្រូវតែជឿថាមានសហភាពរវាងអំពើល្អក្នុងព្រះសហគមន៍។ ប៉ុន្តែសរីរាង្គសំខាន់ជាងគេ គឺព្រះគ្រីស្ត ដ្បិតព្រះអង្គជាព្រះសិរសា (...)។ ហេតុដូច្នេះហើយបានជាអំពើល្អរបស់ព្រះគ្រីស្តឆ្លងទៅសរីរាង្គទាំងអស់ ដោយសារអគ្គសញ្ញារបស់ព្រះសហគមន៍" (សន្តៈ ថូម៉ាសនៃអាកាំង)។ "ដោយសារមានព្រះវិញ្ញាណតែមួយដែលណែនាំព្រះសហគមន៍ អំពើល្អទាំងអស់ដែលព្រះសហគមន៍បានទទួលទៅជារបស់រួម" (CR)។

៩៤៨-ដូច្នេះហើយបានជាពាក្យ "សហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ" មានអត្ថន័យពីរដែលរួមជាមួយគ្នាយ៉ាងជិតស្និទ្ធគឺ "សហភាពជាមួយនឹងអ្វីដែលវិសុទ្ធ sancta" និង "សហភាពរវាងជនដ៏វិសុទ្ធ sancti"។

ក្នុងពិធីបុណ្យតាមបូព៌ាប្រទេសប្រធានអភិបូជាប្រកាស "Sancta santis! (អ្វីដែលដ៏វិសុទ្ធសម្រាប់ជនដ៏វិសុទ្ធ)" នៅពេលលើកតង្វាយមុនពិធីទទួលព្រះកាយ។ គ្រីស្តបរិស័ទ (sancti) ទទួលព្រះកាយព្រះលោហិតព្រះគ្រីស្ត (sancta) ដើម្បីបានរីកចម្រើនក្នុងការរួមរស់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ (Koinônia) និងផ្តល់ការរួមរស់នេះដល់មនុស្សលោក។

### ១-សហភាពខាងអំពើល្អខាងវិញ្ញាណ

៩៤៩-ក្នុងសហគមន៍ដើមដំបូងនៅទីក្រុងយេរូសាឡឹមក្រុមសាវ័ក "ព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូតរួមរស់ជាមួយគ្នាជាបងប្អូនធ្វើពីធីកាច់នំប៉័ង និងព្យាយាមអធិដ្ឋាន" (កក ២,៤២)។

សហភាពក្នុងជំនឿ៖ ជំនឿរបស់គ្រីស្តបរិស័ទជាជំនឿរបស់ព្រះសហគមន៍ដែលមកពីក្រុមគ្រីស្តទូតជាសម្បត្តិសួគ៌ដែលកើនឡើងពេលចែកឲ្យគេ។

៩៥០-សហភាពនៃអគ្គសញ្ញា៖ "ផលនៃអគ្គសញ្ញាជារបស់រួម ដ្បិតអគ្គសញ្ញា ជាពិសេសអគ្គសញ្ញាជ្រមុជទឹក (ជាទ្វារដែលមនុស្សចូលក្នុងព្រះសហគមន៍) ជាចំណងដ៏សក្ការៈដែលធ្វើឲ្យមនុស្សរួមជាមួយគ្នា និងធ្វើឲ្យគេភ្ជាប់នឹងព្រះយេស៊ូគ្រីស្ត។ សហភាពរវាងជនដ៏វិសុទ្ធ គឺជាសហភាពរវាងអគ្គសញ្ញា (...)។ យើងក៏អាចប្រើពាក្យសហភាពដល់អគ្គសញ្ញានានា ដ្បិតអគ្គសញ្ញានានាធ្វើឲ្យយើងភ្ជាប់នឹងព្រះជាម្ចាស់ (...)។ ប៉ុន្តែពាក្យនេះប្រើចំពោះអភិបូជាប្រសើរលើសអគ្គសញ្ញាឯទៀតៗ ដ្បិតក្នុងអភិបូជាមនុស្សរួមរស់ជាមួយគ្នាយ៉ាងស្និទ្ធស្នាលជាងគេ" (CR)។

៩៥១-សហភាពនៃព្រះអំណោយទាន៖ ក្នុងសហភាពព្រះសហគមន៍ព្រះវិញ្ញាណដ៏វិសុទ្ធ "ប្រោសប្រទានឲ្យគ្រីស្តបរិស័ទម្នាក់ៗគ្រប់ជាន់ថ្នាក់ (...) ព្រះអំណោយទានពិសេស" ដើម្បីកសាងព្រះសហគមន៍ (LG ១២) ហើយ "ព្រះវិញ្ញាណប្រោសប្រទានឲ្យម្នាក់ៗសម្តែងព្រះអង្គ ដើម្បីជាផលប្រយោជន៍រួម" (១ករ ១២,៧)។

៩៥២-"អ្នកជឿយកទ្រព្យសម្បត្តិដាក់ជាសម្បត្តិរួមទាំងអស់" (កក ៤,៣២)៖ "អ្វីដែលគ្រីស្តបរិស័ទពិតប្រាកដមានគេត្រូវចាត់ទុកថាជាសម្បត្តិរួម ហើយគេត្រូវត្រៀមខ្លួន និងប្រញាប់ប្រញាល់ជួយសង្គ្រោះជនក្រីក្រ និងបងប្អូនដែលរងទុក្ខវេទនាជានិច្ច"។ គ្រីស្តបរិស័ទជាអ្នកមើលខុសត្រូវលើទ្រព្យសម្បត្តិរបស់ព្រះអម្ចាស់ (លក ១៦,១.៣)។

៩៥៣-សហភាពក្នុងសេចក្តីស្រឡាញ់៖ ក្នុង sanctorum communio (សហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ) "គ្មាននរណាម្នាក់រស់ ឬស្លាប់សម្រាប់ខ្លួនឯងឡើយ" (រម ១៤,៧)។ "ប្រសិនបើមានសរីរាង្គណាមួយឈឺចុកចាប់សរីរាង្គទាំងអស់ក៏ឈឺចុកចាប់ជាមួយដែរ។ ប្រសិនបើមានសរីរាង្គណាមួយបានថ្លៃថ្នូរ សរីរាង្គទាំងអស់ក៏ត្រេកអរសប្បាយជាមួយដែរ។ បងប្អូនជាព្រះកាយរបស់ព្រះគ្រីស្ត ហើយម្នាក់ៗជាសរីរាង្គនៃព្រះកាយនេះតាមចំណែករៀងៗខ្លួន" (១ករ ១២,២៦-២៧)។ "អ្នកមានចិត្តស្រឡាញ់មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន" (១ករ ១៣,៥) (១ករ ១០,២៤)។ កិច្ចការដ៏តូចជាងគេដែលយើងប្រព្រឹត្តដោយមានចិត្តស្រឡាញ់ បង្កើតផលប្រយោជន៍រួម ហើយសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយចាក់ឫសក្នុងការរួមសាមគ្គីជាមួយមនុស្សលោកទាំងអស់នោះ។ អំពើបាបនីមួយៗព្យាបាទសហភាពនោះ។

### ២-ព្រះសហគមន៍នៅលើផែនដីរួមរស់ជាមួយព្រះសហគមន៍នៅស្ថានបរមសុខ

៩៥៤-សភាពការណ៍ទាំងបីនៃព្រះសហគមន៍៖ "ទម្រាំព្រះអម្ចាស់យាងមកប្រកបដោយសិរីរុងរឿង រួមជាមួយពួកទេវទូតរបស់ព្រះអង្គ និងទម្រាំសេចក្តីស្លាប់ត្រូវរំលាយចោល ព្រមទាំងព្រះអង្គបង្ក្រាបអ្វីៗទាំងអស់ សាវ័ករបស់ព្រះគ្រីស្តមួយចំនួននៅតែបន្តបូជានិយេសចរណ៍នៅលើផែនដីនេះតទៅទៀត។ មានសាវ័កមួយចំនួនទៀតផុតជីវិតនៅតែជម្រះខ្លួនមុននឹងជួបព្រះជាម្ចាស់។ មួយចំនួនផ្សេងទៀត ស្ថិតនៅក្នុងសិរីរុងរឿងរបស់ព្រះជាម្ចាស់ «នៅក្នុងពន្លឺដ៏ត្រចះត្រចង់យ៉ាងពេញលេញ ឃើញព្រះជាម្ចាស់តែមួយព្រះអង្គ និងជាព្រះត្រៃឯក»" (LG ៤៩)។

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏យើងទាំងអស់រួបរួមគ្នាក្នុងសេចក្តីស្រឡាញ់តែមួយចំពោះព្រះជាម្ចាស់

និងចំពោះអ្នកដទៃ តាមកម្រិត និងតាមរបៀបផ្សេងៗ នាំគ្នាច្រៀងលើកតម្កើងសិរីរុងរឿងថ្វាយព្រះជាម្ចាស់។ អស់អ្នកដែលរួបរួមជាមួយព្រះគ្រីស្ត និងដែលបានទទួលព្រះវិញ្ញាណរបស់ព្រះអង្គ ហើយរួមគ្នាជាព្រះសហគមន៍តែមួយ និងភ្ជាប់គ្នាទៅវិញទៅមកជាអង្គភាពតែមួយក្នុងអង្គព្រះគ្រីស្ត (LG ៤៩)។

៩៥៥-"ដូច្នេះអស់អ្នកដែលនៅតែធ្វើដំណើរក្នុងលោកនេះនៅឡើយ និងបងប្អូនដែលចែកឋានសម្រាន្តលក់ក្នុងសេចក្តីសុខសាន្តរបស់ព្រះគ្រីស្តទៅហើយ ក៏រួបរួមគ្នាមិនបែកចេញពីគ្នាទេ។ ផ្ទុយទៅវិញ តាមជំនឿរបស់ព្រះសហគមន៍តាំងពីដើមរៀងមក ក្រុមទាំងពីររឹតតែរួមគ្នា ដោយចែកចាយសម្បត្តិខាងវិញ្ញាណទៅវិញទៅមក" (LG ៤៩)។

៩៥៦-សន្តបុគ្គលជួយទូលអង្វរព្រះជាម្ចាស់៖ "អ្នកដែលនៅលោកខាងមុខ ភ្ជាប់ជាមួយព្រះគ្រីស្តយ៉ាងស្អិតល្មួតច្រើនជាងមុន និងជួយព្រះសហគមន៍ទាំងមូលឲ្យកាន់តែវិសុទ្ធ (...)។ បងប្អូនទាំងនោះ ដោយសារព្រះគ្រីស្តរួមជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត នៅតែជួយអង្វរព្រះបិតាឲ្យយើង ព្រមទាំងថ្វាយកុសលផលបុណ្យដែលគេបានសន្សំនៅលើផែនដីដោយសារព្រះគ្រីស្តយេស៊ូជាស្ពានមេត្រីតែមួយគត់រវាងព្រះជាម្ចាស់ និងមនុស្សលោក (...)។ ដោយបងប្អូនទាំងនោះយកចិត្តទុកដាក់ស្រឡាញ់យើងដូចបងប្អូន គាត់ជួយយើងជាមនុស្សទន់ខ្សោយយ៉ាងខ្លាំង" (LG ៤៩)។

> កុំយំអី! ពេលស្លាប់ទៅខ្ញុំនឹងជួយបងប្អូនបានផលប្រយោជន៍ច្រើនជាងមុន ហើយខ្ញុំនឹងជួយបងប្អូនយ៉ាងស័ក្តិសិទ្ធជាងពេលដែលខ្ញុំរស់នៅ (សន្តៈ ដូមីនីក)។
>
> នៅស្ថានបរមសុខខ្ញុំនឹងធ្វើអំពើល្អចំពោះផែនដីជានិច្ច (សន្តី ថេរេសានៃព្រះកុមារយេស៊ូ)។

៩៥៧-សហភាពជាមួយសន្តបុគ្គល៖ "ក៏ប៉ុន្តែ យើងនឹកដល់សន្តបុគ្គលដោយគោរព មិនគ្រាន់តែពីព្រោះពួកគាត់ជាគំរូល្អឲ្យយើងធ្វើតាមប៉ុណ្ណោះទេ តែយើងក៏ចង់ពង្រឹងការរួបរួមរបស់ព្រះសហគមន៍ទាំងមូលក្នុងព្រះវិញ្ញាណថែមទៀត ដោយប្រតិបត្តិតាមសេចក្តីស្រឡាញ់គ្នាទុកជាបងប្អូន។ បើយើងជាគ្រីស្តបរិស័ទនៅលើផែនដីរួបរួមគ្នាយើងឈានទៅកាន់ព្រះគ្រីស្តឲ្យកាន់តែជិតស្និទ្ធឡើងៗយ៉ាងណា ការរួមសហភាពជាមួយសន្តបុគ្គលក៏បង្រួបបង្រួមយើងជាមួយព្រះគ្រីស្តកាន់តែខ្លាំងឡើងយ៉ាងនោះដែរ ព្រោះព្រះហឫទ័យប្រោសប្រណីគ្រប់យ៉ាងរបស់ព្រះជាម្ចាស់ផ្ទាល់ និងជីវិតរបស់ប្រជារាស្ត្រព្រះអង្គ ហូរពីព្រះគ្រីស្តមកដូចជាហូរពីប្រភព និងពីព្រះសិរសាររបស់ខ្លួន" (LG ៥០)៖

> យើងក្រាបថ្វាយបង្គំព្រះគ្រីស្ត ពីព្រោះព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ ឯមរណៈសាក្សីវិញ យើងក៏ស្រឡាញ់ពួកគាត់ដូចជាសាវ័ក និងអ្នកដែលយកតម្រាប់តាមព្រះអម្ចាស់។ ពិតជាត្រឹមត្រូវមែន! ដោយសារពួកគាត់បានគោរពយ៉ាងអស្ចារ្យ ព្រះមហាក្សត្រ និងម្ចាស់របស់ពួកគាត់ ហេតុនេះសូមឲ្យយើងអាចធ្វើជាមិត្តសម្លាញ់ និងសាវ័ករបស់ពួកគាត់យ៉ាងនោះដែរ (សន្តៈ ប៉ូលីកាប)។

៩៥៨-សហភាពជាមួយអ្នកដែលចែកឋាន៖ "ព្រះសហគមន៍ទទួលស្គាល់ថា សមាជិកនៃព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះយេស៊ូគ្រីស្តទាំងមូល រួបរួមគ្នារួចហើយ។ តាំងពីដើមដំបូងនៃគ្រីស្តសាសនា សមាជិកនៃព្រះសហគមន៍កំពុងធ្វើដំណើរនៅនាលោកនេះ តែងតែនឹករឭកដល់អស់អ្នកចែកឋានទៅហើយ ដោយគោរពប្រណិប័តន៍យ៉ាងខ្លាំង គេធ្លាប់អង្វរព្រះជាម្ចាស់ឲ្យពួកគាត់ ដ្បិត «គំនិតអង្វរព្រះជាម្ចាស់សូមព្រះអង្គលើកលែងទោសឲ្យមនុស្សស្លាប់បានរួចពីបាប ពិតជាគំនិតដ៏វិសុទ្ធរបស់អស់អ្នក ដែលគោរពប្រណិប័តន៍ព្រះអង្គមែន» (២មរ ១២,៤៥)" (LG ៥០)។ ពាក្យអង្វររបស់យើងសម្រាប់ពួកគាត់ មិនគ្រាន់តែអាចជួយពួកគាត់ទេ ថែមទាំងធ្វើឲ្យការជួយអង្វររបស់ពួកគាត់សម្រាប់យើងឲ្យបានស័ក្តិសិទ្ធិដែរ។

៩៥៩-ក្នុងមហាគ្រួសារតែមួយរបស់ព្រះជាម្ចាស់៖ "ប្រសិនបើយើង និងសន្តបុគ្គលស្រឡាញ់គ្នាទៅវិញទៅមក ហើយនាំគ្នារួបរួមលើកតម្កើងព្រះត្រៃឯកដ៏វិសុទ្ធបំផុត ពេលនោះយើងមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក។ យើងទាំងអស់ជាបុត្រធីតារបស់ព្រះជាម្ចាស់ រួមជាក្រុមគ្រួសារតែមួយក្នុងអង្គព្រះគ្រីស្ត" (LG ៥១)។

## សង្ខេប

៩៦០-ព្រះសហគមន៍ជា "សហភាពរវាងជនដ៏វិសុទ្ធ"៖ ពាក្យសម្ដីនេះ សំដៅទៅលើ "អ្វីដែលដ៏វិសុទ្ធ" (sancta) ហើយជាពិសេសពិធីអរព្រះគុណដែលធ្វើឲ្យ "គ្រីស្តបរិស័ទរួបរួមគ្នាជាព្រះកាយតែមួយក្នុងអង្គព្រះគ្រីស្ត" (LG ៣)។

៩៦១-ពាក្យនេះសំដៅទៅលើសហភាពរវាង "ជនដ៏វិសុទ្ធ" (sancti) នៅក្នុងអង្គព្រះគ្រីស្តដែល "បានសោយទិវង្គត សម្រាប់មនុស្សទាំងអស់" ទើបអ្វីដែលម្នាក់ៗធ្វើ ឬរងទុក្ខលំបាកនៅក្នុងអង្គព្រះគ្រីស្ត និងសម្រាប់ព្រះអង្គ បង្កើតផលសម្រាប់គេទាំងអស់គ្នា។

៩៦២-"យើងជឿលើសហភាពរវាងគ្រីស្តបរិស័ទទាំងអស់ គឺអស់អ្នកដែលកំពុងធ្វើដំណើរនៅលើផែនដីនេះ អស់អ្នកស្លាប់ដែលកំពុងជម្រះចិត្តគំនិត អស់អ្នកដែលពោរពេញដោយសុភមង្គលនៅស្ថានបរមសុខ អ្នកទាំងអស់នោះរួបរួមគ្នាធ្វើជាព្រះសហគមន៍តែមួយ ហើយយើងជឿថា ក្នុងការរួបរួមបែបនេះ សេចក្ដីស្រឡាញ់ប្រកបដោយធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ និងរបស់ជនដ៏វិសុទ្ធទាំងអស់នោះ ចាំស្ដាប់ពាក្យអង្វររបស់យើងជានិច្ច" (SPF ៣០)។

## កថាខណ្ឌទី៦៖ ព្រះនាងម៉ារីជាព្រះមាតារបស់ព្រះគ្រីស្ត និងជាព្រះមាតារបស់ព្រះសហគមន៍ផង

៩៦៣-ក្រោយពីបានថ្លែងអំពីតួនាទីរបស់ព្រហ្មចារិនីម៉ារីតាមគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត និងរបស់ព្រះវិញ្ញាណ ត្រូវរិះគិតពិចារណាអំពីតួនាទីរបស់ព្រះនាងក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះសហគមន៍។ "គេទទួលស្គាល់ និងគោរពនាងព្រហ្មចារិនីម៉ារីទុកជាព្រះមាតាដ៏ពិតប្រាកដរបស់ព្រះអម្ចាស់ និងជាព្រះសង្គ្រោះផង (...)។ ប្រសើរជាងនេះទៅទៀត នាងពិតជា "មាតានៃសរីរាង្គរបស់ព្រះគ្រីស្ត ព្រោះនាងរួមសហការដោយចិត្តស្រឡាញ់ បង្កើតព្រះសហគមន៍របស់គ្រីស្តបរិស័ទដែលជាសរីរាង្គនៃព្រះអម្ចាស់ជាមេដឹកនាំ" (LG ៥៣)។ "នាងម៉ារីជាព្រះមាតារបស់ព្រះគ្រីស្តផង ជាព្រះមាតារបស់ព្រះសហគមន៍ផង" (សម្ដេចប៉ាប ប៉ូលទី៦ ឆ្នាំ១៩៦៤)។

### ១-ព្រះនាងម៉ារីជាព្រះមាតាព្រះសហគមន៍

#### ព្រះនាងម៉ារីរួបរួមទាំងស្រុងជាមួយព្រះបុត្រារបស់ព្រះនាង

៩៦៤-តួនាទីរបស់នាងម៉ារីចំពោះព្រះសហគមន៍ មកពីនាងរួបរួមជាមួយព្រះគ្រីស្តតែម្ដងដែលមិនអាចបំបែកពីគ្នាបានឡើយ។ "ព្រះនាងម៉ារី និងព្រះបុត្រាព្រះនាងរួមគ្នាក្នុងកិច្ចសង្គ្រោះយ៉ាងច្បាស់ជាក់ស្ដែង តាំងពីពេលព្រះគ្រីស្តចាប់ផ្ទៃនាងព្រហ្មចារីមក រហូតដល់ពេលព្រះអង្គសោយទិវង្គត" (LG ៥៧)។ ជាពិសេសយើងអាចយល់ថា អ្នកទាំងពីររួបរួមជាមួយគ្នាបែបនេះនៅពេលព្រះអង្គរងទុក្ខលំបាក។

> ពេលព្រះនាងព្រហ្មចារិនីកំពុងធ្វើបូជនិយេសចរណ៍តាមជំនឿតទៅមុខទៀត នាងរួបរួមជាមួយព្រះបុត្រាដោយចិត្តស្មោះរហូតដល់ឈើឆ្កាង គឺនាងនៅឈរក្បែរឈើឆ្កាង។ ការនេះពិតជាកើតឡើងតាមគម្រោងការរបស់ព្រះជាម្ចាស់មែន។ នាងឈឺចុកចាប់យ៉ាងសែនខ្លោចផ្សារួមជាមួយព្រះបុត្រាតែមួយរបស់នាង នាងក៏

សុខចិត្តរួមក្នុងសក្ការបូជារបស់ព្រះអង្គ តាមចិត្តគំនិតជាម្ដាយ គឺសុខចិត្តដោយសេចក្ដីស្រឡាញ់ឲ្យគេយកបុត្រដែលកើតពីសាច់ឈាមរបស់នាង ធ្វើយញ្ញនោះ។ នៅទីបញ្ចប់ ព្រះគ្រីស្ដយេស៊ូកំពុងសោយទិវង្គតនៅលើឈើឆ្កាង ប្រគល់នាងឲ្យសាវ័កទុកជាម្ដាយ ដោយមានព្រះបន្ទូលថា «អ្នកអើយ! នេះកូនរបស់អ្នក" (យហ ១៩,២៦-២៧; LG ៥៨)។

៩៦៥-ក្រោយពីព្រះជាម្ចាស់បានលើកព្រះយេស៊ូឡើងស្ថានបរមសុខ នាងម៉ារី "បានជួយអង្វរព្រះជាម្ចាស់ឲ្យព្រះសហគមន៍កំពុងកើតមក" (LG ៦៩)។ ដោយរួមជាមួយក្រុមគ្រីស្ដទូត និងស្ត្រីខ្លះ "យើងក៏ឃើញនាងម៉ារីអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានព្រះវិញ្ញាណដែលមកសណ្ឋិតលើនាង រួចទៅហើយនៅពេលទេវទូតនាំដំណឹងមកប្រាប់នាង" (LG ៥៩)។

## នាងម៉ារីរួបរួមជាមួយព្រះបុត្រារហូតដល់ព្រះជាម្ចាស់លើកនាងឡើងស្ថានបរមសុខ

៩៦៦-"នៅទីបញ្ចប់ នាងព្រហ្មចារីដ៏និមលដែលព្រះជាម្ចាស់បានការពារមិនឲ្យជំពាក់បាបខាងដើម ក្រោយពីបានបង្ហើយជីវិតនៅក្នុងលោកនេះ ត្រូវព្រះជាម្ចាស់លើកឡើងទាំងរូបកាយ ទាំងវិញ្ញាណ ឲ្យចូលក្នុងសិរីរុងរឿងនៃលោកខាងមុខ។ ព្រះអម្ចាស់បានលើកតម្កើងនាងទៅជាព្រះមហាក្សត្រីយានីនៃពិភពលោក ដើម្បីឲ្យនាងបានដូចព្រះបុត្រាយ៉ាងពេញលេញ គឺដូចព្រះបុត្រាដែលជា «ព្រះអម្ចាស់លើអម្ចាស់នានា» ដែលមានជ័យជម្នះលើបាបកម្ម និងលើសេចក្ដីស្លាប់" (LG ៥៩; DS ៣៩០៣)។ ព្រះជាម្ចាស់លើកព្រហ្មចារិនីម៉ារីដ៏វិសុទ្ធឲ្យឡើងស្ថានបរមសុខ នោះព្រះនាងចូលរួមយ៉ាងពិសេសរួមជាមួយព្រះបុត្រារបស់ព្រះនាង ដែលមានព្រះជន្មរស់ឡើងវិញ ហើយឲ្យព្រះនាងមានជីវិតថ្មីមុនគ្រីស្ដបរិស័ទឯទៀតៗ៖

> នៅពេលសម្រាលបុត្រ ព្រះនាងបានរក្សាព្រហ្មចារិយធម៌ទុកនៅពេលឡើងស្ថានបរមសុខ ព្រះនាងមិនបានចាកចេញពីលោកនេះទេ។ ឱព្រះមាតារបស់ព្រះជាម្ចាស់អើយ! ព្រះនាងបានទៅដល់ប្រភពនៃជីវិត ព្រះនាងដែលជាអ្នកបង្កើតព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ ហើយដែលរំដោះព្រលឹងរបស់យើងពីសេចក្ដីស្លាប់ ដោយសារពាក្យអង្វររបស់ព្រះនាង។

## ព្រះនាងម៉ារីជាព្រះមាតារបស់យើងតាមការប្រោសប្រណីរបស់ព្រះជាម្ចាស់

៩៦៧-ដោយរួមចិត្តគំនិតទាំងស្រុងជាមួយនឹងព្រះហឫទ័យរបស់ព្រះបិតា ព្រះរាជកិច្ចនៃការសង្គ្រោះរបស់ព្រះបុត្រា និងការណែនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ព្រហ្មចារិនីម៉ារីជាគំរូត្រង់ជំនឿ និងសេចក្ដីស្រឡាញ់ចំពោះព្រះសហគមន៍។ ហេតុនេះហើយបានជា "ព្រះសហគមន៍ធ្លាប់សរសើរនាងទុកជាសមាជិកដ៏ប្រសើរជាងគេបំផុតតែមួយគត់របស់ព្រះសហគមន៍" (LG ៥៣) ព្រះនាង "ពិតជាគំរូដ៏អស្ចារ្យ (typus) របស់ព្រះសហគមន៍" (LG ៦៣)។

៩៦៨-ក៏ប៉ុន្តែតួនាទីរបស់ព្រះនាងម៉ារីចំពោះព្រះសហគមន៍ និងមនុស្សលោកនៅតែបន្តទៅមុខជានិច្ច។ "នាងសហការក្នុងព្រះរាជកិច្ចនៃព្រះសង្គ្រោះ ដែលគ្មាននរណាអាចប្រៀបផ្ទឹម និងនាងបាន។ ដោយនាងស្ដាប់បង្គាប់ ដោយនាងផ្ញើជីវិតលើព្រះជាម្ចាស់ ដោយនាងមានសេចក្ដីសង្ឃឹម មានសេចក្ដីស្រឡាញ់យ៉ាងខ្លាំង នាងសហការឲ្យមនុស្សលោកទទួលព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់វិញ។ ហេតុនេះហើយបានជាប្រសិនបើយល់ដល់ព្រះជាម្ចាស់ប្រោសប្រណីមនុស្សលោក នាងម៉ារីពិតជាត្រឡប់ទៅជាមាតារបស់យើង" (LG ៦១)។

៩៦៩-"តាំងពីពេលនាងយល់ព្រមធ្វើតាមដំណឹងដែលទេវទូតជម្រាបមកនោះ នាងម៉ារីផ្ញើជីវិតលើព្រះជាម្ចាស់

ហើយនាងក៏នៅតែយល់ស្របតទៅទៀតដោយចិត្តរឹងប៉ឹង នៅពេលនាងឈរនៅក្បែរឈើឆ្កាង។ នាងម៉ារីមានតួនាទីជាមាតា ក្នុងការចាត់ចែងព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់ ហើយនៅតែបន្តតួនាទីនេះតទៅទៀតដោយគ្មានឈប់ឈរ រហូតដល់អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើសទទួលការសង្គ្រោះជាស្ថាពរ។ ក្រោយពីព្រះអង្គបានលើកនាងទៅស្ថានបរមសុខហើយ តួនាទីរបស់នាងក្នុងការសង្គ្រោះមិនអាក់ខានឡើយ គឺនាងនៅតែជួយអង្វរព្រះជាម្ចាស់ជារៀយៗ ធ្វើឲ្យយើងទទួលព្រះអំណោយទានពីព្រះអង្គតទៅទៀត ជាព្រះអំណោយទានដែលយើងត្រូវការសម្រាប់ទទួលការសង្គ្រោះអស់កល្បជានិច្ច (...)។ ហេតុនេះហើយបានជាព្រះសហគមន៍តែងតែអង្វរនាងព្រហ្មចារិនី ដោយយកនាមផ្សេងៗមកហៅដូចតទៅ "មេធាវី" "អ្នកជួយអង្វរ" "អ្នកប្រោសប្រណី" "ស្ពានមេត្រី" (LG ៦២)។

៩៧០-តួនាទីរបស់នាងម៉ារីជាមាតាចំពោះមនុស្សទាំងអស់ មិនជំទាស់ និងមិនបណ្ដាលឲ្យតួនាទីរបស់ព្រះគ្រីស្តជាស្ពានមេត្រីតែមួយគត់នោះអន់ខ្សោយទេ។ ផ្ទុយទៅវិញ តួនាទីនេះកាន់តែបង្ហាញអំពីឫទ្ធិទៅវិញ។ ឥទ្ធិពលរបស់ព្រះនាងព្រហ្មចារីនីម៉ារីសម្រាប់សង្គ្រោះមនុស្សលោក (...) ហូរចេញពីព្រះគ្រីស្ត ដោយកុសលផលបុណ្យជាច្រើនលើសលប់រាប់មិនអស់។ ឥទ្ធិពលរបស់ព្រះនាងសំអាងលើព្រះគ្រីស្តជាស្ពានមេត្រី គឺនាងទទួលអ្វីៗទាំងអស់ពីព្រះគ្រីស្ត និងបានអនុភាពទាំងអស់ពីព្រះអង្គ (LG ៦០)។ យើងមិនអាចលើកតម្កល់សត្វលោកណាមួយ ដែលព្រះជាម្ចាស់បង្កើតមក ឲ្យបានស្មើនឹងព្រះបន្ទូលប្រសូតជាមនុស្ស និងជាព្រះសង្គ្រោះសោះឡើយ។ ក៏ប៉ុន្តែ ប្រជាជនគ្រីស្តបរិស័ទទាំងមូលទទួលចំណែកមុខងាររបស់ព្រះគ្រីស្តជាមហាបូជាចារ្យតែមួយ អ្នកទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ និងប្រជាជនគ្រីស្តបរិស័ទទទួលចំណែកតាមរបៀបផ្សេងៗផងយ៉ាងណា ក៏តួនាទីជាស្ពានមេត្រីរបស់ព្រះគ្រីស្តមិនឃាត់ឲ្យសត្វលោកសហការជាមួយព្រះអង្គក្នុងការសង្គ្រោះយ៉ាងនោះដែរ។ ព្រះហឫទ័យមេត្តាករុណាគ្មានពីររបស់ព្រះជាម្ចាស់ ផ្សព្វផ្សាយដល់សត្វលោកទាំងអស់ តាមរបៀបផ្សេងៗយ៉ាងណា ក៏ព្រះអង្គចែកចំណែកនៃតួនាទីជាស្ពានមេត្រីតែមួយឲ្យសត្វលោកយ៉ាងនោះដែរ។ ផ្ទុយទៅវិញ ការរួមចំណែកក្នុងតួនាទីនោះដាស់តឿនគ្រីស្តបរិស័ទជាសត្វលោក ដែលព្រះជាម្ចាស់បង្កើតមកឲ្យសហការតាមរបៀបផ្សេងៗក្នុងការសង្គ្រោះដោយសត្វលោកទាំងនោះ ជាចំណុះរបស់ព្រះគ្រីស្ត ជាប្រភពតែមួយគត់នៃការសង្គ្រោះ (LG ៦២)។

## ២-ការគោរពប្រណិប័តន៍ព្រះនាងព្រហ្មចារិនីដ៏វិសុទ្ធ

៩៧១-"អំណើះតទៅមនុស្សគ្រប់ជំនាន់នឹងពោលថាខ្ញុំជាអ្នកមានសុភមង្គលពិតមែន" (លក ១,៤៨)៖ "ព្រះសហគមន៍គោរពព្រះនាងព្រហ្មចារិនីដ៏វិសុទ្ធ ជាការចំណែកនៃការគោរពប្រណិប័តន៍របស់គ្រីស្តសាសនា" (MC ៥៦)។ "ព្រះសហគមន៍គោរពប្រណិប័តន៍ព្រះនាងម៉ារីយ៉ាងពិសេស ពិតជាត្រឹមត្រូវហើយ។ ហេតុនេះហើយបានជាតាំងពីច្រើនសតវត្សមកហើយគ្រីស្តបរិស័ទតែងតែគោរពព្រះនាងព្រហ្មចារិនីម៉ារី ដោយថ្វាយព្រះនាមនាងថា "ព្រះមាតារបស់ព្រះអម្ចាស់"។ គ្រីស្តបរិស័ទតែងតែ (...) សូមឲ្យព្រះនាងជួយការពារ អង្វរព្រះនាងឲ្យជួយក្នុងពេលមានគ្រោះកាចនានា តាមតម្រូវការរបស់គេ។ ព្រះសហគមន៍តែងតែគោរពបម្រើព្រះនាងម៉ារី (...) តែការគោរពបម្រើនេះមានលក្ខណៈពិសេសអស្ចារ្យប្លែកពីការគោរពអ្នកដទៃទាំងស្រុង។ ក៏ប៉ុន្តែ ការគោរពប្រណីប័តន៍នាងម៉ារីមានលក្ខណៈប្លែកទាំងស្រុងពីការគោរពថ្វាយបង្គំក្រាបប្រណីប័តន៍ព្រះបន្ទូលដែលប្រសូតជាមនុស្ស និងពីការគោរពថ្វាយបង្គំក្រាបប្រណិប័តន៍ព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធផង។ ការគោរពនាងម៉ារីមានទីដៅគោរពថ្វាយបង្គំព្រះជាម្ចាស់" (LG ៦៦)។ ការគោរពប្រណិប័តន៍នេះលាតត្រដាងក្នុងពិធីបុណ្យផ្សេងៗ ដែលព្រះសហគមន៍ឧទ្ទិសដល់ព្រះនាងម៉ារី (SC ១០៣) ហើយនៅក្នុងពាក្យអង្វរចំពោះព្រះនាងម៉ារីដូចជាផ្កាំដ៏វិសុទ្ធដែលជា "សេចក្តី

សង្ខេបនៃដំណឹងល្អទាំងមូល" (MC ៤២)។

### ៣-ព្រះនាងម៉ារីជារូបតំណាងរបស់ព្រះសហគមន៍នៅពេលចុងក្រោយបំផុត

៩៧២-ក្រោយពីបានថ្លែងអំពីព្រះសហគមន៍ អំពីប្រភពបេសកកម្ម និងគោលដៅរបស់ព្រះសហគមន៍គួរបញ្ចប់ដោយបែរមុខទៅរកព្រះនាងម៉ារី ដើម្បីយល់ឃើញដោយស៊ឹងស្មាធ៏នូវសភាពរបស់ព្រះសហគមន៍តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៅពេលព្រះសហគមន៍ "ធ្វើបូជនិយេសចរណ៍តាមជំនឿ" ហើយនៅពេលព្រះសហគមន៍នឹងទៅជាយ៉ាងណាក្នុងមាតុភូមិ ពេលបញ្ចប់ដំណើរក្នុងលោកនេះដែលមានអ្នកដែលព្រះសហគមន៍គោរពដូចជាព្រះមាតានៃព្រះអម្ចាស់របស់ខ្លួន និងដូចជាព្រះមាតារបស់ខ្លួនផ្ទាល់ "ក្នុងសិរីរុងរឿងនៃព្រះត្រៃឯកដ៏វិសុទ្ធបំផុតដែលមិនអាចបំបែកបាន" និង "ក្នុងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ" ផង (LG ៦៩)។

> ទាំងរូបកាយ ទាំងវិញ្ញាណនៅស្ថានបរមសុខរួចហើយយ៉ាងណា ព្រះនាងក៏ជាតំណាងរបស់ព្រះសហគមន៍ និងធ្វើឲ្យព្រះសហគមន៍នៃលោកខាងមុខកើតជារូបរាង រួចហើយសូម្បីតែនៅលើផែដីនេះយ៉ាងនោះដែរ។ ទម្រាំថ្ងៃព្រះអម្ចាស់យាងមក នាងបញ្ចេញពន្លឺដូចជាបញ្ចាំងសញ្ញាសម្គាល់យ៉ាងនឹងនរ និងជាសញ្ញាលួងលោមនៅមុខប្រជារាស្ត្ររបស់ព្រះជាម្ចាស់កំពុងធ្វើបូជនីយេសចរណ៍នៅលើផែនដីនេះ (LG ៦៨)។

## សង្ខេប

៩៧៣-ដោយយល់ព្រមនឹងគម្រោងការដ៏អស្ចារ្យនៃព្រះជាម្ចាស់ប្រសូតជាមនុស្ស-នៅពេលដែលទេវទូតជូនដំណឹងដល់ព្រះនាង-ព្រះនាងម៉ារីរួមសហការជាមួយនឹងព្រះរាជកិច្ច ដែលបុត្រព្រះនាងត្រូវសម្រេច។ ព្រះនាងជាព្រះមាតាគ្រប់កន្លែង ដែលព្រះអង្គជាព្រះសង្គ្រោះ និងជាព្រះសិរសានៃព្រះកាយដ៏អាថ៌កំបាំង។

៩៧៤-នៅពេលដែលព្រះនាងបានធ្វើដំណើរនៅនាលោកនេះ ព្រះជាម្ចាស់បានលើកព្រហ្មចារិនីម៉ារីដ៏វិសុទ្ធបំផុតទាំងរូបកាយ ទាំងព្រលឹងឡើងទៅសិរីរុងរឿងនៃស្ថានបរមសុខ។ នៅទីនោះ ព្រះនាងចូលរួមក្នុងសិរីរុងរឿងនៃព្រះបុត្រាព្រះនាង សង្ឃឹមទុកជាមុនថា សិរីរាង្គទាំងអស់នៃព្រះកាយព្រះអង្គនឹងមានជីវិតថ្មី។

៩៧៥-"យើងជឿថា ព្រះមាតាដ៏វិសុទ្ធបំផុតរបស់ព្រះជាម្ចាស់ ជានាងអេវ៉ាថ្មី មាតារបស់ព្រះសហគមន៍បន្តតួនាទីជាមាតាចំពោះសិរីរាង្គរបស់ព្រះគ្រីស្តនៅស្ថានលើ" (SPF ១៥)។

## ប្រការទី១០៖

## "ខ្ញុំជឿថាមានការលើកលែងទោសឲ្យមនុស្សរួចពីបាប"

៩៧៦-ក្នុងធម៌ប្រកាសជំនឿដែលមកពីក្រុមគ្រីស្តទូតជំនឿលើការលើកលែងទោសឲ្យរួចពីបាបភ្ជាប់នឹងជំនឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ថែមទាំងជំនឿលើព្រះសហគមន៍ និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយផងដែរ។ ដោយប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យក្រុមគ្រីស្តទូតរបស់ព្រះអង្គ ព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញក៏បានប្រគល់អំណាចផ្ទាល់របស់ព្រះអង្គ គឺលើកលែងទោសឲ្យរួចពីបាប៖ "ចូរទទួលព្រះវិញ្ញាណ! បើអ្នករាល់គ្នាលើកលែងទោសអ្នកណាឲ្យរួចពីបាប ព្រះជាម្ចាស់ក៏លើកលែងទោសអ្នកនោះឲ្យរួចពីបាបដែរ។ ផ្ទុយទៅវិញ បើអ្នករាល់គ្នាប្រកាន់ទោសអ្នកណា អ្នកនោះមុខជាត្រូវជាប់ទោសមិនខាន" (យហ ២០,២២-២៣)។

វគ្គទីពីរនៃសៀវភៅនេះនឹងជម្រាបអំពីការលើកលែងទោសឲ្យរួចពីបាប ដោយបុណ្យជ្រមុជទឹក អគ្គសញ្ញាលើកលែងទោស និងអគ្គសញ្ញាឯទៀតៗ ជាពិសេសអគ្គសញ្ញាអរព្រះគុណ។ នៅទីនេះយើងទើបតែពន្យល់អំពីលទ្ធិមូលដ្ឋានប៉ុណ្ណោះ។

## ១-ពិធីជ្រមុជទឹកតែមួយសម្រាប់ការលើកលែងទោសឲ្យរួចពីបាប

៩៧៧-តាមព្រះអម្ចាស់របស់យើង យើងអាចរួចពីបាបដោយផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ និងទទួលពិធីជ្រមុជទឹក៖ "ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់ចុះ។ អ្នកណាជឿ ហើយទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ" (មក ១៦,១៥-១៦)។ បុណ្យជ្រមុជទឹកជាអគ្គសញ្ញាដំបូង និងសំខាន់ជាងគេនៃការលើកលែងទោសឲ្យរួចពីបាប ដ្បិតពេលយើងជ្រមុជទឹក យើងរួមរស់ជាមួយព្រះគ្រីស្ដ ដែលសោយទិវង្គត ដើម្បីលោះយើងឲ្យរួចពីបាប ហើយដែលមានព្រះជន្មថ្មី ដើម្បីឲ្យយើងបានសុចរិត (រម ៤,២៥) ដូច្នេះ "យើងក៏រស់នៅតាមរបៀបថ្មី" (រម ៦,៤)។

៩៧៨-"ពេលយើងប្រកាសជំនឿលើកទីមួយដោយទទួលបុណ្យជ្រមុជទឹកដ៏វិសុទ្ធ ដែលបន្សុទ្ធយើង យើងបានទទួលការលើកលែងទោសទាំងស្រុង និងពេញលក្ខណៈអំពីអំពើបាបដើមដំបូងផង និងអំពីទោសដែលយើងបានប្រព្រឹត្តដោយចេតនាផង ហើយយើងក៏មិនត្រូវទទួលទោសណាមួយដោយសារអំពើបាបទាំងនោះដែរ (...)។ ក៏ប៉ុន្តែបុណ្យជ្រមុជទឹកដែលមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ មិនរំដោះនរណាម្នាក់ឲ្យរួចផុតពីគុណវិបត្តិនៃធម្មជាតិទេ។ ផ្ទុយទៅវិញ យើងត្រូវតែប្រយុទ្ធប្រឆាំងនឹងកិលេសតណ្ហាដែលតែងតែញុះញង់យើងឲ្យប្រព្រឹត្តអំពើអាក្រក់" (CR ១,១១,៣)។

៩៧៩-ក្នុងការប្រយុទ្ធប្រឆាំងនឹងកិលេសតណ្ហានោះ តើនរណាអង់អាច និងប្រុងប្រយ័ត្នល្មមនឹងជៀសវាងអំពើបាបណាមួយ? "ព្រះសហគមន៍ចាំបាច់ត្រូវតែមានអំណាចអាចលើកលែងទោសឲ្យរួចពីបាប។ បុណ្យជ្រមុជទឹកមិនមែនជាមធ្យោបាយតែមួយឲ្យព្រះសហគមន៍ប្រើកូនសោនៃព្រះរាជ្យនៃស្ថានបរមសុខ ដែលមកពីព្រះយេស៊ូគ្រីស្ដទេ គឺព្រះសហគមន៍ត្រូវតែមានអំណាចអាចលើកលែងទោសឲ្យអ្នកបាបទាំងអស់ ទោះបីពួកគេប្រព្រឹត្តអំពើបាបរហូតដល់ស្លាប់យ៉ាងណាក៏ដោយ" (CR ១,១១,៤)។

៩៨០-អ្នកដែលជ្រមុជទឹកហើយអាចសម្រុះសម្រួលជាមួយព្រះជាម្ចាស់ និងព្រះសហគមន៍បានដោយសារអគ្គសញ្ញាលើកលែងទោស៖

> គ្រូបាធ្យាយយល់បានត្រឹមត្រូវដោយហៅការលើកលែងទោសជា "ពិធីជ្រមុជទឹកដ៏លំបាក" (សន្ដ: គ្រេគ័រនៃណាស៊ីអង់)។ ចំពោះអស់អ្នកដែលបានប្រព្រឹត្តអំពើបាបក្រោយពីបានជ្រមុជទឹក ហើយអគ្គសញ្ញាលើកលែងទោសនោះជាចាំបាច់ ដើម្បីទទួលការសង្គ្រោះដូចបុណ្យជ្រមុជទឹកជាចាំបាច់ ដើម្បីឲ្យអស់អ្នកដែលមិនទាន់កើតជាថ្មីអាចទទួលការសង្គ្រោះបានផងដែរ (DS ១៦៧២)។

## ២-អំណាចនៃកូនសោ

៩៨១-ក្រោយពីបានមានជីវិតថ្មី ព្រះគ្រីស្ដបានចាត់ឲ្យក្រុមគ្រីស្ដទូតទៅ "ប្រកាសក្នុងព្រះនាមព្រះអង្គឲ្យមនុស្សគ្រប់ជាតិសាសន៍កែប្រែចិត្តគំនិត ដើម្បីឲ្យបានរួចពីបាប" (លក ២៤,៤៧)។ ក្រុមគ្រីស្ដទូត និងអ្នកបន្តមុខងាររបស់ពួកលោកមិនគ្រាន់តែបំពេញ "មុខងារសម្រុះសម្រួល" (២ករ ៥,១៨) នេះដោយប្រកាសឲ្យមនុស្សលោក

ដឹងថា ព្រះជាម្ចាស់លើកលែងទោសឲ្យគេដោយសារគុណបុណ្យរបស់ព្រះគ្រីស្ត ដោយត្រាស់ហៅគេឲ្យកែប្រែចិត្តគំនិត និងឲ្យគេផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គតែប៉ុណ្ណោះទេ ថែមទាំងពួកលោកត្រូវធ្វើការលើកលែងទោសឲ្យរួចពីបាបដោយសារបុណ្យជ្រមុជទឹក និងសម្រុះសម្រួលមនុស្សលោកឲ្យជានានឹងព្រះជាម្ចាស់ និងព្រះសហគមន៍ ដោយសារអំណាចនៃកូនសោដែលពួកលោកបានទទួលពីព្រះគ្រីស្តដែរ៖

ព្រះសហគមន៍បានទទួលកូនសោនៃព្រះរាជ្យនៃស្ថានបរមសុខ ដើម្បីឲ្យការលើកលែងទោសរួចពីបាបកើតនៅក្នុងខ្លួន ព្រះសហគមន៍ដោយសារព្រះលោហិត ព្រះគ្រីស្ត និងកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រលឹងដែលបានស្លាប់ដោយសារអំពើបាបមានជីវិតថ្មី ក្នុងព្រះសហគមន៍នេះហើយដើម្បីរួមរស់ជាមួយព្រះគ្រីស្តដែលមានព្រះហឫទ័យប្រណីសន្តោសសង្គ្រោះយើង (សន្តៈ អូគូស្តាំង)។

៩៨២-គ្មានអំពើបាបណាមួយ ទោះជាធំយ៉ាងណាក្តីដែលព្រះសហគមន៍ដ៏វិសុទ្ធមិនអាចលើកលែងបានទេ។ "គ្មាននរណាម្នាក់ទោះជាកាច ឬបានធ្វើខុសយ៉ាងណាក្តី ដែលមិនអាចសង្ឃឹមដោយជឿទុកចិត្តថានឹងទទួលការលើកលែងទោសឲ្យតែគេសោកស្តាយកំហុសរបស់ខ្លួនដោយចិត្តស្មោះត្រង់" (CR ១,១១,៥)។ នៅក្នុងព្រះសហគមន៍ព្រះអង្គ ព្រះគ្រីស្តដែលបានសោយទិវង្គតសម្រាប់មនុស្សទាំងអស់ សព្វព្រះហឫទ័យឲ្យទ្វារនៃការលើកលែងទោសបើកចំហសម្រាប់អ្នកបាបណាម្នាក់ដែលកែប្រែចិត្តគំនិត (មថ ១៨,២១-២២)។

៩៨៣-ពេលអប់រំជំនឿត្រូវតែធ្វើឲ្យគ្រីស្តបរិស័ទដឹងខ្លួនជានិច្ចនូវព្រះអំណោយទានដ៏ធំធេងដែលគ្មានអ្វីអាចប្រដូចបាន ដែលព្រះគ្រីស្តដ៏មានព្រះជន្មថ្មីប្រោសប្រទានឲ្យព្រះសហគមន៍របស់ព្រះអង្គ គឺបេសកកម្ម និងអំណាចលើកលែងទោសឲ្យរួចពីបាបមែន ដោយមុខងាររបស់ក្រុមគ្រីស្តទូត និងអ្នកបន្តមុខងាររបស់ពួកលោក។

ព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យសាវ័ករបស់ព្រះអង្គមានអំណាចដ៏លើសលប់ គឺព្រះអង្គសព្វព្រះហឫទ័យឲ្យអ្នកបម្រើដ៏កម្សត់បំពេញក្នុងព្រះនាមព្រះអង្គនូវអ្វីៗទាំងអស់ដែលព្រះអង្គបានបំពេញ នៅពេលព្រះអង្គនៅលើផែនដីនៅឡើយ (សន្តៈ អំប្រ័រ)។

ពួកបូជាចារ្យបានទទួលអំណាចមួយដែលព្រះជាម្ចាស់មិនបានប្រទានឲ្យទេវទូត ឬអគ្គទេវទូតផង (...)។ នៅស្ថានលើព្រះជាម្ចាស់ក៏បញ្ជាក់នូវអ្វីដែលពួកបូជាចារ្យធ្វើនៅខាងលើផែនដីនេះ (សន្តៈ យ៉ូហាន គ្រីសូស្តូម)។

បើនៅក្នុងព្រះសហគមន៍គ្មានការលើកលែងទោសឲ្យរួចពីបាបទេ កុំសង្ឃឹមឡើយគ្មានសេចក្តីសង្ឃឹមលើជីវិតអស់កល្បជានិច្ច និងនៅលើការសង្គ្រោះអស់កល្បជានិច្ចផងដែរ។ សូមអរព្រះគុណព្រះជាម្ចាស់ដែលបានប្រោសប្រទានព្រះអំណោយទានដ៏ថ្លៃថ្លានេះឲ្យព្រះសហគមន៍ (សន្តៈ អូគូស្តាំង)។

## សង្ខេប

៩៨៤-ធម៌ប្រកាសជំនឿធ្វើឲ្យ "ការលើកលែងទោសឲ្យរួចពីបាប" ទាក់ទងនឹងការប្រកាសជំនឿអំពីព្រះវិញ្ញាណដ៏វិសុទ្ធ។ តាមការពិត ព្រះគ្រីស្តដែលមានព្រះជន្មថ្មីបានប្រគល់អំណាចឲ្យក្រុមគ្រីស្តទូតលើកលែងទោសរួចពីបាបនៅពេលដែលព្រះអង្គបានប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យពួកលោក។

៩៨៥-ពិធីជ្រមុជទឹកជាអគ្គសញ្ញាទីមួយ និងសំខាន់ជាងគេ ដើម្បីទទួលការលើកលែងទោសឲ្យរួចពីបាប គឺយើងរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្ត ដែលមានព្រះជន្មថ្មី ហើយដែលប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយើង។

៩៨៦-ដោយសារព្រះហឫទ័យរបស់ព្រះគ្រីស្ត ព្រះសហគមន៍មានអំណាចលើកលែងទោសគ្រីស្តបរិស័ទឲ្យរួច

ពីបាប ហើយជាធម្មតាព្រះសហគមន៍ប្រតិបត្តិតាមអំណាចនេះ ដោយលោកអភិបាល និងលោកបូជាចារ្យក្នុងអគ្គសញ្ញា លើកលែងទោស។

៩៨៧-"ក្នុងការលើកលែងទោសឲ្យរួចពីបាប ពួកបូជាចារ្យ និងអគ្គសញ្ញាទាំងប៉ុន្មានជាឧបករណ៍សុទ្ធសាធ ដែលព្រះអម្ចាស់របស់យើងព្រះយេស៊ូគ្រីស្ត ដែលជាព្រះសង្គ្រោះតែមួយគត់របស់យើង សព្វព្រះហឫទ័យប្រើប្រាស់ ដើម្បីលុបបំបាត់អំពើសៅហ្មងរបស់យើង និងប្រោសយើងឲ្យទៅជាមនុស្សសុចរិត" (CR ១,១១,៦)។

## ប្រការទី១១៖

## "ខ្ញុំជឿថា រូបកាយមនុស្សនឹងមានជីវិតថ្មី"

៩៨៨-ធម៌ប្រកាសជំនឿនៃគ្រីស្តសាសនា-យើងប្រកាសជំនឿទៅលើព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយយើងជឿនៅលើកិច្ចបង្កើត កិច្ចសង្គ្រោះ និងកិច្ចប្រោសឲ្យបានវិសុទ្ធរបស់ព្រះអង្គ-មានកំពូលក្នុងការប្រកាសថាមនុស្សនឹងមានជីវិតថ្មី នៅពេលអវសានកាលនៃពិភពលោក និងមានជីវិតអស់កល្បជានិច្ច។

៩៨៩-យើងជឿជាក់ ទើបយើងសង្ឃឹមថាព្រះគ្រីស្តពិតជាមានព្រះជន្មថ្មីពីចំណោមមនុស្សស្លាប់ ព្រះអង្គមានព្រះជន្មគង់នៅជាដរាបតរៀងទៅយ៉ាងណា ក្រោយពីបានស្លាប់ហើយមនុស្សសុចរិតនឹងរស់នៅជាដរាបតរៀងទៅរួមជាមួយព្រះគ្រីស្តដែលមានព្រះជន្មថ្មី ហើយព្រះអង្គក៏នឹងប្រោសគេឲ្យមានជីវិតថ្មីនៅថ្ងៃចុងក្រោយបំផុតយ៉ាងនោះដែរ (យហ ៦,៣៩-៤០)។ យើងនឹងមានជីវិតថ្មីដោយសារព្រះត្រៃឯកដ៏វិសុទ្ធបំផុត ដូចព្រះគ្រីស្តបានមានជីវិតថ្មីដោយសារព្រះត្រៃឯកនេះដែរ៖

> ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលបានប្រោសព្រះយេស៊ូឲ្យមានព្រះជន្មថ្មីសណ្ឋិតនៅក្នុងបងប្អូនមែននោះ ព្រះជាម្ចាស់ដែលបានប្រោសព្រះគ្រីស្តឲ្យមានព្រះជន្មថ្មីទ្រង់ក៏នឹងប្រទានឲ្យរូបកាយរបស់បងប្អូនដែលរមែងតែងតែស្លាប់នេះ មានជីវិតតាមរយៈព្រះវិញ្ញាណដែលសណ្ឋិតនៅក្នុងបងប្អូននោះដែរ (រម ៨,១១) (១ថស ៤,១៤; ១ករ ៦,១៤; ២ករ ៤,១៤; ភីល ៣,១០-១១)។

៩៩០-ពាក្យ "សាច់" សំដៅលើលក្ខណៈមនុស្សលោកដែលទន់ខ្សោយ និងដែលត្រូវតែស្លាប់ (កណ ៦,៣; ទន ៥៦,៥; អស ៤០,៦)។ "រូបកាយមនុស្សនឹងមានជីវិតថ្មី" បានសេចក្តីថាពេលស្លាប់ហើយព្រលឹងនឹងមានជីវិតអមតៈផង ថែមទាំង "រូបកាយដែលរមែងតែងតែស្លាប់" (រម ៨,១១) នឹងមានជីវិតថ្មីផងដែរ។

៩៩១-ត្រូវតែជឿជាចំបាច់ថា មនុស្សស្លាប់នឹងមានជីវិតថ្មី នេះជាចំណុចដ៏សំខាន់នៃគ្រីស្តសាសនា។ "គ្រីស្តបរិស័ទជឿជាក់ថាមនុស្សស្លាប់នឹងមានជីវិតថ្មី។ ការជឿជាក់នេះធ្វើឲ្យយើងមានជីវិត" (សន្តៈ ទែរទូលីយ៉ាំង)៖

> ហេតុអ្វីបានជាមានអ្នកខ្លះក្នុងចំណោមបងប្អូនបែរជាពោលថា មនុស្សស្លាប់មិនមានជីវិតថ្មីដូច្នេះ? ប្រសិនបើមនុស្សស្លាប់មិនមានជីវិតថ្មីទេ នោះព្រះគ្រីស្តក៏គ្មានព្រះជន្មថ្មីដែរ ហើយបើព្រះគ្រីស្តមិនបានរស់ឡើងវិញទេ សេចក្តីដែលយើងប្រកាសមុខជាគ្មានន័យអ្វីសោះឡើយ ហើយជំនឿរបស់បងប្អូនក៏គ្មានន័យអ្វីដែរ (...)។ ប៉ុន្តែព្រះគ្រីស្តពិតជាមានព្រះជន្មថ្មីមែន។ ក្នុងចំណោមមនុស្សស្លាប់ ព្រះអង្គមានព្រះជន្មរស់ឡើងវិញមុនគេបង្អស់ (១ករ ១៥,១២-១៤.២០)។

## ១-ព្រះគ្រីស្តមានព្រះជន្មថ្មីយើងក៏នឹងមានជីវិតថ្មីដែរ ព្រះជាម្ចាស់សម្តែងបន្តិចម្តងៗឲ្យមនុស្សដឹងថាគេនឹងមានជីវិតថ្មី

៩៩២-ព្រះជាម្ចាស់បានសម្តែងបន្តិចម្តងៗឲ្យប្រជារាស្ត្ររបស់ព្រះអង្គដឹងថានឹងមានជីវិតថ្មី។ ពេលយើងជឿថាព្រះជាម្ចាស់បានបង្កើតមនុស្សទាំងស្រុង ទាំងព្រលឹង ទាំងរូបកាយផង យើងក៏ត្រូវតែជឿថាព្រះអង្គប្រោសរូបកាយមនុស្សឲ្យមានជីវិតថ្មីដែរ។ ម្យ៉ាងទៀតព្រះជាម្ចាស់ជាព្រះបង្កើតមេឃ និងដីជាព្រះដែលកាន់សម្ព័ន្ធមេត្រីរបស់ព្រះអង្គជាមួយលោក អប្រាហាំ និងកូនចៅរបស់លោកដោយព្រះហឫទ័យស្មោះត្រង់ផងដែរ។ ហេតុនេះជនជាតិអ៊ីស្រាអែលចាប់ផ្តើមជឿថាមនុស្សនឹងមានជីវិតថ្មី។ ក្នុងទុក្ខលំបាករបស់គេមរណៈសាក្សីម៉ាកាបាយប្រកាសថា៖

> ព្រះមហាក្សត្រនៃពិភពលោកនឹងប្រោសយើងឲ្យមានជីវិតថ្មី មានជីវិតអស់កល្បជានិច្ច ព្រោះទូលបង្គំយើងខ្ញុំស៊ូស្លាប់ដើម្បីគោរពវិន័យរបស់ព្រះអង្គ (២មបា ៧,៩)។ ស៊ូស្លាប់ដោយសារដៃមនុស្សប្រសើរជាងនៅរស់តទៅទៀត ទូលបង្គំយើងខ្ញុំរង់ចាំព្រះជាម្ចាស់ប្រោសយើងឲ្យមានជីវិតថ្មី (២មបា ៧,១៤) (មបា ៧,២៩; ដន ១២,១-១៣)។

៩៩៣-ពួកខាងគណៈផារីស៊ី (កក ២៣,៦) និងអ្នកភាគច្រើននៅសម័យព្រះអម្ចាស់ (យហ ១១,២៤) ជឿ ហើយសង្ឃឹមថាមនុស្សនឹងមានជីវិតថ្មី។ ព្រះយេស៊ូប្រៀនប្រដៅយ៉ាងមឹងម៉ាត់ថាមនុស្សនឹងមានជីវិតថ្មី។ ចំពោះពួកខាងគណៈសាឌូស៊ីដែលមិនជឿថាមនុស្សស្លាប់នឹងមានជីវិតថ្មីទេ ព្រះអង្គឆ្លើយតបទៅគេថា៖ "អ្នករាល់គ្នាយល់ខុសហើយ ដ្បិតអ្នករាល់គ្នាមិនស្គាល់គម្ពីរ ហើយមិនស្គាល់ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ផង" (មក ១២,២៤)។ យើងជឿថាមនុស្សនឹងមានជីវិតថ្មី ដ្បិតយើងជឿថាព្រះជាម្ចាស់ "មិនមែនជាព្រះរបស់មនុស្សស្លាប់ទេ គឺជាព្រះរបស់មនុស្សដែលមានជីវិត" (មក ១២,២៧)។

៩៩៤-លើសពីនេះទៅទៀត ព្រះយេស៊ូធ្វើឲ្យជំនឿអំពីព្រះជន្មថ្មីសំអាងលើខ្លួនព្រះអង្គផ្ទាល់៖ "ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សឲ្យមានជីវិតថ្មី ខ្ញុំនឹងផ្តល់ជីវិតឲ្យគេ" (យហ ១១,២៥)។ នៅពេលថ្ងៃចុងក្រោយបំផុត គឺព្រះយេស៊ូផ្ទាល់ខ្លួនដែលនឹងប្រោសអស់អ្នកដែលបានផ្ញើជីវិតលើព្រះអង្គ (យហ ៥,២៤-២៥; ៦,៤០) និងដែលបានពិសាសាច់ និងលោហិតរបស់ព្រះអង្គ (យហ ៦,៥៤) ឲ្យមានជីវិតថ្មី។ ចាប់ពីឥឡូវនេះទៅ ព្រះអង្គក៏ប្រទានសញ្ញាសម្គាល់បញ្ជាក់អំពីព្រះបន្ទូលសន្យានេះដោយប្រោសមនុស្សខ្លះឲ្យមានជីវិតរស់ឡើងវិញ (មក ៥,២១-៤២; លក ៧,១១-១៧; យហ ១១)។ ធ្វើដូច្នេះព្រះអង្គប្រកាសទុកជាមុនថាទ្រង់នឹងមានព្រះជន្មថ្មីតាមរបៀបពិសេស។ ព្រះអង្គមានព្រះបន្ទូលអំពីព្រះជន្មថ្មីរបស់ព្រះអង្គ ដែលជាហេតុការណ៍តែមួយដូចជាទីសម្គាល់របស់ព្យាការីយ៉ូណាស" (មថ ១២,៣៩) និងទីសម្គាល់នៃព្រះវិហារ (យហ ២,១៩-២២)៖ ព្រះអង្គប្រកាសថាទ្រង់នឹងមានជីវិតថ្មីបីថ្ងៃក្រោយពីបានសោយទិវង្គត (មក ១០,៣៤)។

៩៩៥-យើងជាសាក្សីរបស់ព្រះគ្រីស្ត ពេលយើងជា "សាក្សីអំពីព្រះអង្គដែលមានព្រះជន្មថ្មី" (កក ១,២២) និងពេលយើង "បរិភោគជាមួយព្រះអង្គក្រោយពេលព្រះអង្គមានព្រះជន្មថ្មី" (កក ១០,៤១)។ យើងជឿ ហើយសង្ឃឹមថានឹងមានជីវិតថ្មីដោយសារយើងបានជួបព្រះគ្រីស្តដែលមានព្រះជន្មថ្មី។ យើងក៏នឹងមានជីវិតថ្មីដូចព្រះអង្គជាមួយព្រះអង្គ និងនៅក្នុងអង្គព្រះអង្គ។

៩៩៦-តាំងពីដើមដំបូង គ្រីស្តបរិស័ទដែលជឿថាមនុស្សនឹងមានជីវិតថ្មី បានជួបប្រទះមនុស្សជាច្រើន ដែលយល់ខុស និងជំទាស់ប្រឆាំង (កក ១៧,៣២; ១ករ ១៥,១២-១៣)។ "ក្នុងគ្រីស្តសាសនា គ្មានចំណុចណាមួយក្រៅពីជីវិតថ្មីនៃរូបកាយរបស់មនុស្សទេ ដែលជួបនឹងការជំទាស់ប្រឆាំងជាងគេ" (សន្តៈ អូគូស្តាំង)។ ធម្មតាមនុស្ស

យល់ស្របថាក្រោយពីស្លាប់ជីវិត មនុស្សខាងវិញ្ញាណរស់នៅឡើយ។ ប៉ុន្តែធ្វើដូចម្តេចឲ្យបានជឿថារូបកាយនេះ ដែលរមែងតែស្លាប់អាចមានជីវិតថ្មីបាន?

## តើមនុស្សស្លាប់អាចមានជីវិតថ្មីយ៉ាងដូចម្តេច?

៩៩៧-តើ "មានជីវិតថ្មី" មានអត្ថន័យយ៉ាងដូចម្តេច? ពេលស្លាប់ព្រលឹង និងរូបកាយបំបែកចេញពីគ្នា រូបកាយមនុស្សក៏រលួយ ឯព្រលឹងរបស់គេទៅជួបព្រះជាម្ចាស់ដោយរង់ចាំឲ្យព្រះអង្គភ្ជាប់វានឹងរូបកាយពោរពេញទៅដោយសិរីរុងរឿងឡើងវិញ។ ព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាពសព្វប្រការនឹងប្រោសឲ្យរូបកាយយើងមានជីវិតដែលមិនអាចរលួយបាន ដោយភ្ជាប់វានឹងព្រលឹងរបស់យើងដោយសារគុណធម៌របស់ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។

៩៩៨-តើនរណានឹងមានជីវិតថ្មី? គឺអស់មនុស្សស្លាប់៖ "អ្នកដែលប្រព្រឹត្តអំពើល្អនឹងមានជីវិតថ្មី ដើម្បីទទួលជីវិត រីឯអ្នកដែលបានប្រព្រឹត្តអំពើអាក្រក់នឹងមានជីវិតថ្មី ដើម្បីទទួលទោស" (យហ ៥,២៩)។

៩៩៩-តើមនុស្សនឹងមានជីវិតថ្មីយ៉ាងដូចម្តេច? ព្រះគ្រីស្តបានមានជីវិតថ្មីជាមួយព្រះកាយរបស់ព្រះអង្គផ្ទាល់៖ "ចូរមើលដៃជើងខ្ញុំ គឺពិតជាខ្ញុំមែន!" (លក ២៤,៣៩) ប៉ុន្តែព្រះអង្គមិនមែនមានជីវិតដូចកាលពីមុនឡើយ។ យ៉ាងណាមិញនៅក្នុងអង្គព្រះអង្គ "គេទាំងអស់គ្នានឹងមានជីវិតថ្មី ដោយរូបកាយរបស់គេដែលគេមានដូចឥឡូវនេះ" (DS ៨០១) ប៉ុន្តែព្រះជាម្ចាស់នឹងផ្លាស់ប្តូររូបកាយនេះឲ្យបានដូច "ព្រះកាយប្រកបដោយសិរីរុងរឿង" (ភីល ៣,២១) "ប្រកបដោយវិញ្ញាណ" (១ករ ១៥,៤៤)៖

> ប្រហែលជាមាននរណាម្នាក់ចង់សួរថា៖ «តើមនុស្សស្លាប់នឹងមានជីវិតថ្មីបែបដូចម្តេច? តើអ្នកមានជីវិតថ្មីនោះមានរូបកាយយ៉ាងណា?»។ មនុស្សឆោតល្ងង់អើយ! គ្រាប់ពូជដែលអ្នកសាបព្រោះទៅ វាមានជីវិតបានលុះត្រាតែវាងាប់សិន។ គ្រាប់ពូជដែលអ្នកសាបព្រោះទៅនោះ គ្មានរូបរាងដូចដើមដែលនឹងដុះតាមក្រោយឡើយ គឺគ្រាន់តែជាគ្រាប់មួយដូចជាគ្រាប់ស្រូវ ឬគ្រាប់អ្វីមួយផ្សេងទៀតប៉ុណ្ណោះ (...)។ ចំណែកមនុស្សស្លាប់ ដែលទទួលជីវិតថ្មី ក៏ដូច្នោះដែរ រូបកាយដែលគេកប់ក្នុងដីរមែងតែងតែរលួយ រីឯរូបកាយដែលទទួលជីវិតថ្មីមិនចេះរលួយទេ (...) ។ រូបកាយដែលរមែងតែងតែរលួយនេះត្រូវតែទទួលយកភាពដែលមិនចេះរលួយ ហើយរូបកាយដែលរមែងតែងតែស្លាប់នេះ ក៏ត្រូវទទួលភាពអមតៈ (១ករ ១៥,៣៥-៣៧. ៤២. ៤៣-៥៣)។

១000-យើងមិនអាចយល់ ឬនឹកគិតដល់ថាតើមនុស្សនឹងមានជីវិតថ្មី "យ៉ាងដូចម្តេច" បានទេ គឺយើងគ្រាន់តែជឿប៉ុណ្ណោះ។ ប៉ុន្តែពេលយើងចូលរួមថ្វាយអភិបូជា យើងក៏អាចយល់ទុកជាមុនថាព្រះគ្រីស្តនឹងផ្លាស់ប្តូរទ្រង់ទ្រាយរូបកាយរបស់យើងយ៉ាងដូចម្តេច៖

> ក្រោយពីបានទូលអង្វរព្រះជាម្ចាស់ នំបុ័ងដែលមកពីផែនដី លែងជានំបុ័ងធម្មតាទៀតទេ ប៉ុន្តែបានក្លាយជាអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត ដែលផ្សំនឹងធាតុពីរ គឺមួយដែលមកពីផែនដី មួយដែលមកពីស្ថានបរមសុខ យ៉ាងណា រូបកាយរបស់យើង ដែលចូលរួមចំណែកក្នុងអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត លែងរលួយទៀតទេ យ៉ាងនោះដែរ ដ្បិតរូបកាយនេះ សង្ឃឹមថានឹងមានជីវិតថ្មី (សន្ត: អ៊ីរ៉េណេ)។

១00១-នៅពេលណា? "នៅថ្ងៃចុងក្រោយបំផុត" (យហ ៦,៣៩-៤០.៤៤.៥៤; ១១,២៤) "នៅពេលអវសានកាលនៃពិភពលោក" (LG ៤៨) ដ្បិតជីវិតថ្មីរបស់មនុស្សស្លាប់ទាក់ទងយ៉ាងស្អិតស្អាលជាមួយនឹងពេល

ព្រះគ្រីស្តយាងមកវិញពោរពេញដោយសិរីរុងរឿង៖

ដ្បិតនៅពេលមានស្នូរជាសញ្ញាលាន់ឮឡើង ហើយនៅពេលឮសម្លេងមហាទេវទូត និងសម្លេងត្រែរបស់ព្រះជាម្ចាស់ ព្រះអម្ចាស់ផ្ទាល់ទ្រង់នឹងយាងចុះពីស្ថានបរមសុខមក។ មុនដំបូង អស់អ្នកជឿលើព្រះគ្រីស្តដែលបានស្លាប់ទៅនោះនឹងរស់ឡើងវិញ (១តស ៤,១៦)។

### មានជីវិតថ្មីរួមជាមួយព្រះគ្រីស្ត

១០០២-បើព្រះគ្រីស្តពិតជានឹងប្រោសយើងឲ្យមានជីវិតថ្មី "នៅថ្ងៃចុងក្រោយបំផុត" យើងក៏ពិតជាបានរស់ឡើងវិញរួមជាមួយព្រះគ្រីស្តរួចហើយ ដ្បិតឥឡូវនេះនៅលើផែនដីនេះដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ យើងជាគ្រីស្តបរិស័ទរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្តដែលបានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ៖

ពេលបងប្អូនទទួលពិធីជ្រមុជទឹក បងប្អូនត្រូវកប់ក្នុងផ្នូររួមជាមួយព្រះគ្រីស្ត ហើយដោយបងប្អូនរួមក្នុងអង្គព្រះគ្រីស្ត បងប្អូនក៏មានជីវិតថ្មីរួមជាមួយព្រះអង្គដែរ ព្រោះបងប្អូនមានជំនឿលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដែលបានប្រោសព្រះគ្រីស្តឲ្យមានព្រះជន្មថ្មី (...)។ ដូច្នេះប្រសិនបើបងប្អូនបានមានជីវិតថ្មីរួមជាមួយព្រះគ្រីស្តមែន ចូរស្វែងរកអ្វីៗនៅស្ថានលើ ជាស្ថានដែលព្រះគ្រីស្តគង់នៅខាងស្តាំព្រះជាម្ចាស់នោះវិញ" (កូឡ ២,១២; ៣,១)។

១០០៣-ដោយសារបុណ្យជ្រមុជទឹក អ្នកជឿពិតជារួមរស់ជាមួយព្រះគ្រីស្តដែលមានព្រះជន្មថ្មី (ភីល ៣.២០) ប៉ុន្តែជីវិតនេះ "កប់ទុកជាមួយព្រះគ្រីស្តក្នុងព្រះជាម្ចាស់ដែរ" (កូឡ ៣,៣)។ "ព្រះអង្គបានប្រោសយើងឲ្យមានជីវិតថ្មីរួមជាមួយព្រះគ្រីស្តយេស៊ូ និងឲ្យយើងអង្គុយលើបល្ល័ង្កនៅស្ថានបរមសុខរួមជាមួយព្រះអង្គដែរ" (អភ ២,៦)។ ដោយសារយើងបានទទួលព្រះកាយព្រះអង្គក្នុងអភិបូជា យើងជាកម្មសិទ្ធិរបស់ព្រះកាយព្រះគ្រីស្តរួចហើយ។ ពេលយើងនឹងរស់ឡើងវិញនៅថ្ងៃចុងក្រោយបំផុតយើង "នឹងលេចចេញមកជាមួយព្រះគ្រីស្តប្រកបដោយសិរីរុងរឿងដែរ" (កូឡ ៣,៤)។

១០០៤-ដោយរង់ចាំថ្ងៃនោះរូបកាយ និងព្រលឹងរបស់អ្នកជឿមានតម្លៃថ្លៃថ្នូរ "ជាកម្មសិទ្ធិរបស់ព្រះគ្រីស្ត" ទើបត្រូវតែគោរពរូបកាយរបស់ខ្លួន និងរូបកាយរបស់អ្នកដទៃផង ជាពិសេសពេលរងទុក្ខលំបាក៖

រីឯរូបកាយវិញ (...) គឺសម្រាប់ថ្វាយទៅព្រះជាម្ចាស់ ហើយព្រះអង្គក៏ជាម្ចាស់លើរូបកាយដែរ។ ព្រះជាម្ចាស់ដែលបានប្រោសព្រះយេស៊ូជាអម្ចាស់ឲ្យមានព្រះជន្មថ្មី ទ្រង់ក៏នឹងប្រោសយើងឲ្យមានជីវិតរស់ឡើងវិញ ដោយសារឫទ្ធានុភាពរបស់ព្រះអង្គដែរ។ បងប្អូនមិនជ្រាបទេ ឬថារូបកាយរបស់បងប្អូនជាសរីរាង្គនៃព្រះកាយព្រះគ្រីស្ត? (...) បងប្អូនមិនមែនជាម្ចាស់លើខ្លួនឯងទៀតទេ (...)។ ហេតុនេះចូរប្រើរូបកាយរបស់បងប្អូនដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់" (១ករ ៦,១៣-១៥.១៩-២០)។

### ២-រួមស្លាប់ក្នុងអង្គព្រះគ្រីស្តយេស៊ូ

១០០៥-ដើម្បីមានជីវិតថ្មីរួមជាមួយព្រះគ្រីស្តត្រូវតែរួមស្លាប់ជាមួយព្រះគ្រីស្ត គឺត្រូវ "ឃ្លាតឆ្ងាយពីរូបកាយនេះហើយទៅនៅជិតព្រះអម្ចាស់" (២ករ ៥,៨)។ ពេលយើង "លាចាកលោកនេះ" (ភីល ១,២៣) គឺពេលយើងស្លាប់ព្រលឹង និងរូបកាយបំបែកគ្នា ហើយនឹងរួបរួមគ្នាម្តងទៀតនៅពេលថ្ងៃមនុស្សស្លាប់នឹងមានជីវិតថ្មី (SPF ២៨)។

## មរណភាព

១០០៦-"ពេលមនុស្សប្រឈមមុខនឹងមរណភាព លក្ខណៈដ៏អាថ៌កំបាំងនៃជីវិតមនុស្សទៅដល់កម្រិតកំពូល" (GS ១៨)។ មរណភាពខាងរូបកាយមកពីធម្មជាតិម្យ៉ាង តែចំពោះអ្នកជឿសេចក្ដីស្លាប់ជា "លទ្ធផលនៃអំពើបាប" (រម ៦,២៣) (កណ ២,១៧) ឯចំពោះអស់អ្នកដែលស្លាប់ក្នុងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្ដ គេរួមចំណែកក្នុងអង្គព្រះគ្រីស្ដដែលបានសោយទិវង្គត ដើម្បីឲ្យអាចរួមជាមួយព្រះអង្គដែលមានព្រះជន្មរស់ឡើងវិញ (រម ៦,៣-៩; ភីល ៣,១០-១១)។

១០០៧-មរណភាពជាទីបញ្ចប់នៃជីវិតនៅលើផែនដី។ ពេលវេលាជាចង្វាក់នៃជីវិតរបស់យើង យើងផ្លាស់ប្ដូរទៅជាចាស់ ហើយដូចសត្វលោកទាំងអស់នៃផែនដី សេចក្ដីស្លាប់ជាទីបញ្ចប់ធម្មតានៃជីវិត។ លក្ខណៈនៃមរណភាពជំរុញយើងឲ្យនឹកគិតថាត្រូវតែស្លាប់ យើងក៏រំឭកខ្លួនឯងថា ជីវិតយើងមានពេលកំណត់ដើម្បីយើងបានសម្រេច៖

> ក្នុងពេលដែលអ្នកនៅក្មេងនៅឡើយ ត្រូវនឹកដល់ព្រះអាទិកររបស់អ្នក (...)។ ពេលនោះរូបកាយដែលជាធូលីដីនឹងវិលទៅជាដីដូចដើមវិញ រីឯវិញ្ញាណដែលព្រះជាម្ចាស់ប្រទានឲ្យក៏នឹងវិលទៅកាន់ព្រះអង្គវិញដែរ (សស ១២,១.៧)។

១០០៨-មរណភាពជាលទ្ធផលនៃអំពើបាប។ ដោយបកស្រាយយ៉ាងពិតប្រាកដព្រះគម្ពីរដ៏វិសុទ្ធ (កណ ២, ១៧; ៣,៣; ៣,១៩) ការបញ្ជូនបន្ដ និងក្រុមណែនាំព្រះសហគមន៍បង្រៀនថាមរណភាពចូលក្នុងពិភពលោកដោយសារអំពើបាបរបស់មនុស្ស។ ទោះបីមនុស្សមានលក្ខណៈត្រូវតែស្លាប់យ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យឲ្យគេស្លាប់ដែរ។ មរណភាពប្រឆាំងនឹងគម្រោងការរបស់ព្រះជាម្ចាស់ជាព្រះបង្កើត ហើយមរណភាពចូលក្នុងពិភពលោកដោយសារអំពើបាប (ប្រាញ ២,២៣-២៤)។ "មនុស្សរមែងតែងតែស្លាប់ខាងរូបកាយ ព្រោះតែអំពើបាប" ហើយសេចក្ដីស្លាប់នេះជា "សត្រូវចុងក្រោយបង្អស់" (១ករ ១៥.២៦) របស់មនុស្សដែលព្រះជាម្ចាស់ត្រូវតែឈ្នះជាពុំខាន។

១០០៩-ព្រះគ្រីស្ដផ្លាស់ប្ដូរមរណភាព។ ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់បានរងទុក្ខពីសេចក្ដីស្លាប់ ដែលជាលក្ខណៈរបស់មនុស្សដែរ។ ក៏ប៉ុន្តែទោះបីព្រះអង្គព្រួយព្រះហឫទ័យយ៉ាងខ្លាំងចំពោះមរណភាពក្ដី ក៏ទ្រង់សុខចិត្តទទួលយកសេចក្ដីស្លាប់ដោយគាប់ព្រះហឫទ័យទាំងស្រុងនឹងព្រះបិតារបស់ព្រះអង្គ និងដោយគ្មានការបង្ខិតបង្ខំ។ ដោយសារព្រះយេស៊ូបានស្ដាប់បង្គាប់ ព្រះអង្គក៏បានផ្លាស់ប្ដូរបណ្ដាសានៃមរណភាពឲ្យទៅជាការប្រសិទ្ធិពរទៅវិញ (រម ៥,១៩-២១)។

## អត្ថន័យនៃមរណភាពតាមគ្រីស្ដសាសនា

១០១០-ដោយសារព្រះគ្រីស្ដមរណភាពខាងគ្រីស្ដសាសនាមានអត្ថន័យវិជ្ជមាន។ "ចំពោះខ្ញុំបើរស់ ខ្ញុំរស់រួមជាមួយព្រះគ្រីស្ដ ហើយបើស្លាប់ ខ្ញុំក៏បានចំណេញដែរ" (ភីល ១,២១)។ "ពាក្យនេះគួរឲ្យជឿថា ប្រសិនបើយើងរួមស្លាប់ជាមួយព្រះអង្គ យើងក៏នឹងមានជីវិតរស់រួមជាមួយព្រះអង្គដែរ" (២ធម ២,១១)។ មរណភាពខាងគ្រីស្ដសាសនាមានលក្ខណៈថ្មី គឺដោយសារបុណ្យជ្រមុជទឹកគ្រីស្ដបរិស័ទបាន "ស្លាប់រួមជាមួយព្រះគ្រីស្ដ" (តាមរបៀបអគ្គសញ្ញា) រួចហើយដើម្បីមានជីវិតថ្មី ហើយបើយើងស្លាប់ក្នុងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្ដ មរណភាពខាងរូបកាយបញ្ចប់ការ "រួមស្លាប់ជាមួយព្រះគ្រីស្ដ" នេះហើយយើងក៏រួមចំណែកនៅក្នុងអង្គព្រះអង្គក្នុងកិច្ចសង្គ្រោះយើងជាស្ថាពរ។

ឲ្យខ្ញុំស្លាប់ក្នុងអង្គព្រះគ្រីស្ត ប្រសើរជាងគ្រងរាជ្យនៅកន្លែងដាក់ស្រយាលនៃផែនដី។ គឺព្រះអង្គនេះហើយ ដែលខ្ញុំស្វែងរកទ្រង់ក៏បានសោយទិវង្គតសម្រាប់យើង។ គឺព្រះអង្គនេះហើយដែលខ្ញុំចង់បាន ទ្រង់ក៏បានមាន ជីវិតថ្មីសម្រាប់យើង។ កំណើតថ្មីរបស់ខ្ញុំជិតមកដល់ហើយ (...) សូមទុកឲ្យខ្ញុំទទួលពន្លឺដ៏បរិសុទ្ធបំផុត ពេល ខ្ញុំនឹងដល់ទីនោះ ខ្ញុំក៏នឹងទៅជាមនុស្សដ៏ពេញលក្ខណៈ (សន្ត: អ៊ីញ៉ាសនៃអង់ទីអូស)។

១០១១-ក្នុងមរណភាពព្រះជាម្ចាស់ត្រាស់ហៅមនុស្សមករកព្រះអង្គ។ ហេតុនេះគ្រីស្តបរិស័ទអាចមានបំណង ប្រាថ្នាចំពោះមរណភាពដូចសន្ត: ប៉ូល ដែរ៖ "ខ្ញុំប្រាថ្នាចង់លាចាកលោកនេះទៅនៅជាមួយព្រះគ្រីស្ត" (ភីល ១,២៣) ហើយគេអាចផ្លាស់ប្តូរសេចក្តីស្លាប់របស់ខ្លួនទៅជាការស្តាប់បង្គាប់ និងការស្រឡាញ់ព្រះបិតាដូចព្រះគ្រីស្ត ផងដែរ (លក ២៣,៤៦)៖

បំណងប្រាថ្នាខាងលោកីយ៍បានត្រូវគេឆ្កាង (...)។ ក្នុងខ្លួនខ្ញុំមានទឹករស់រវើកដែលខ្សឹបនៅខាងក្នុងខ្ញុំ ថា "សូមមករកព្រះបិតា" (សន្ត: អ៊ីញ៉ាសនៃអង់ទីអូស)។

ខ្ញុំចង់ឃើញព្រះជាម្ចាស់ ហើយដើម្បីឃើញព្រះអង្គខ្ញុំត្រូវតែស្លាប់ (សន្តី ថេរេសានៃព្រះកុមារយេស៊ូ)។

ខ្ញុំមិនស្លាប់ទេ ខ្ញុំចូលក្នុងជីវិត (សន្តី ថេរេសានៃព្រះកុមារយេស៊ូ)។

១០១២-ពិធីបុណ្យនៃព្រះសហគមន៍សម្តែងយ៉ាងពិសេស នូវទស្សនៃមរណភាពខាងគ្រីស្តសាសនា (១ថស ៤,១៣-១៤)៖

ឱព្រះអម្ចាស់អើយ! សម្រាប់អស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ ជីវិតមិនត្រូវបំផ្លាញទេ គឺត្រូវផ្លាស់ប្តូរហើយ ពេលដំណើរនៅលើលោកនេះនឹងត្រូវបញ្ចប់ គេមានទីលំនៅអស់កល្បជានិច្ចនៅស្ថានបរមសុខហើយ (MR)។

១០១៣-មរណភាពជាទីចុងក្រោយនៃបូជនិយេសចរណ៍លោកីយ៍របស់មនុស្ស ជាទីបញ្ចប់នៃពេលវេលាប្រកប ដោយព្រះហឫទ័យប្រណីសន្តោស និងធម៌មេត្តាករុណាដែលព្រះជាម្ចាស់ប្រោសប្រទាន ដើម្បីឲ្យគេសម្រេចជីវិត លើផែនដីនេះតាមព្រះហឫទ័យរបស់ព្រះអង្គ និងសម្រេចវាសនាចុងក្រោយរបស់ខ្លួន។ "នៅពេលដំណើរជីវិតតែ មួយរបស់យើងនឹងចប់ទៅ" (LG ៤៨) យើងនឹងលែងកើតនៅក្នុងលោកនេះទៀតហើយ។ "មនុស្សលោកទាំងអស់ ត្រូវស្លាប់តែមួយដង" (ហប ៩,២៧)។ គ្មាន "ការចាប់ជាតិជាថ្មី" ក្រោយពេលស្លាប់ទេ។

១០១៤-ព្រះសហគមន៍លើទឹកចិត្តយើងឲ្យត្រៀមខ្លួនជានិច្ចទទួលមរណភាព ("សូមព្រះអង្គរំដោះយើងខ្ញុំឲ្យ រួចផុតពីមរណភាពយ៉ាងឆាប់រហ័សដែលមិនបានគ្រោងទុកជាមុន"៖ ពាក្យអង្វរសន្តបុគ្គលទាំងឡាយ) យើងសូម ព្រះមាតារបស់ព្រះជាម្ចាស់ជួយអង្វរដល់យើងផង "វេលាដែលយើងស្លាប់" (ពាក្យអង្វរ "បពិត្រព្រះនាងម៉ារី") និង ឲ្យយើងជ្រកក្រោមម្លប់សន្ត: យ៉ូសែប ជាឧបការីនៃមរណភាពដ៏ល្អ។

ក្នុងគ្រប់កិច្ចការ គ្រប់គំនិត អ្នកត្រូវប្រព្រឹត្តដូចជាត្រូវតែស្លាប់នៅថ្ងៃនេះ។ បើមនសិការរបស់អ្នកនៅល្អ អ្នកមិនត្រូវភ័យខ្លាចនឹងសេចក្តីស្លាប់ទេ។ គួររក្សាខ្លួនឲ្យចាកផុតពីអំពើបាប ប្រសើរជាងរួចផុតពីសេចក្តីស្លាប់។ បើអ្នកមិនទាន់ត្រៀមខ្លួននៅថ្ងៃនេះ តើថ្ងៃស្អែក អ្នកនឹងទៅជាយ៉ាងណា? ("យកតម្រាប់តាមព្រះគ្រីស្ត")។

សូមលើកតម្កើងព្រះអម្ចាស់នៃខ្ញុំ ដើម្បីបងស្រីមរណភាពដែលគ្មាននរណាម្នាក់អាចគេចផុតបានទេ។ អស់ អ្នកដែលស្លាប់ក្នុងអំពើបាបដ៏ធ្ងន់ត្រូវវេទនាហើយ! អស់អ្នកដែលស្លាប់ដោយគាប់ព្រះហឫទ័យដ៏វិសុទ្ធបំផុត របស់ព្រះអង្គពិតជាមានសុភមង្គលហើយ ដ្បិតមរណភាពទីពីរនឹងមិនប៉ះពាល់នឹងគេទេ (សន្ត: ហ្វ្រង់ស័រ នៃអាស៊ីស៊ី)។

# សង្ខេប

១០១៥-"សាច់ជាស្នូលនៃការសង្គ្រោះ" (លោកទែរទូលីយ៉ាំង)។ យើងជឿលើព្រះជាម្ចាស់ ជាអ្នកបង្កើតសាច់ យើងជឿលើព្រះបន្ទូលប្រសូតជាមនុស្ស ដើម្បីលោះសាច់ យើងជឿថាសាច់ (រូបកាយ) មនុស្សនឹងមានជីវិតថ្មី ដែលបង្ហើយការបង្កើត និងសង្គ្រោះសាច់។

១០១៦-ដោយសារសេចក្ដីស្លាប់ ព្រលឹងបែកចេញពីរូបកាយ ប៉ុន្តែ នៅពេលមានជីវិតថ្មី ព្រះជាម្ចាស់នឹងប្រទានជីវិត ដែលមិនចេះរលួយដល់រូបកាយយើង ដោយភ្ជាប់រូបកាយនេះជាមួយនឹងព្រលឹងយើង។ ព្រះគ្រីស្ត មានព្រះជន្មថ្មីអស់កល្បជានិច្ចយ៉ាងណា យើងទាំងអស់គ្នានឹងមានជីវិតថ្មីនៅថ្ងៃចុងក្រោយបំផុតយ៉ាងនោះដែរ។

១០១៧-"យើងជឿថា រូបកាយដែលជាកម្មសិទ្ធិរបស់យើង ឥឡូវនេះពិតជានឹងទទួលជីវិតថ្មី" (DS ៨៥៤)។ យើងសាបព្រោះនៅក្នុងផ្នូររូបកាយមួយដែលត្រូវរលួយ ប៉ុន្តែ រូបកាយដែលមិនចេះរលួយ (១ករ ១៥,៤២) "រូបកាយខាងវិញ្ញាណ" (១ករ ១៥,៤៤) ទទួលជីវិតថ្មី។

១០១៨-ដោយសារអំពើបាបដើមដំបូង មនុស្សត្រូវតែ "ទទួលមរណភាពខាងរូបកាយ ប៉ុន្តែ ប្រសិនបើមនុស្ស មិនបានប្រព្រឹត្តអំពើបាប គេនឹងមិនត្រូវស្លាប់ឡើយ" (GS ១៨)។

១០១៩-ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ ស្ម័គ្រចិត្តសោយទិវង្គត ដើម្បីយើង ដោយសុខចិត្តធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ជាព្រះបិតាព្រះអង្គគ្រប់ជំពូក។ ដោយសារព្រះយេស៊ូបានសោយទិវង្គត ព្រះអង្គបានឈ្នះសេចក្ដីស្លាប់ ទើបមនុស្សទាំងអស់អាចទទួលការសង្គ្រោះបាន។

# ប្រការទី១២៖

## "ខ្ញុំជឿថា មានជីវិតអស់កល្បជានិច្ច"

១០២០-គ្រីស្តបរិស័ទដែលរួមស្លាប់ជាមួយព្រះយេស៊ូយល់ឃើញថា មរណភាពមករកគេហើយ ជាការចូលក្នុងជីវិតអស់កល្បជានិច្ច។ ពេលព្រះសហគមន៍លើកលែងទោសគ្រីស្តបរិស័ទជាលើកចុងក្រោយ នៅពេលជិតស្លាប់ក្នុងព្រះនាមព្រះគ្រីស្ត ព្រះសហគមន៍ក៏បានចាក់ប្រេងពង្រឹងគេ និងបានផ្ដល់ព្រះកាយព្រះគ្រីស្តឲ្យគេធ្វើជាចំណីអាហារក្នុងការធ្វើដំណើរ ហើយលួងលោមចិត្តគេដោយសម្ដីទន់ភ្លន់ថា៖

> ឱព្រលឹងរបស់គ្រីស្តបរិស័ទអើយ! ចូរចាកចេញពីលោកនេះក្នុងព្រះនាមព្រះបិតាប្រកបដោយឫទ្ធានុភាពសព្វប្រការដែលទ្រង់បានបង្កើតអ្នកក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រានៃព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ ដែលបានរងទុក្ខលំបាកដើម្បីអ្នកក្នុងព្រះនាមព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានត្រូវគេចាក់បង្ហូរក្នុងអ្នក។ សូមអ្នកទៅរកកន្លែងសុខសាន្ត ហើយតាំងទីលំនៅជាមួយព្រះជាម្ចាស់ក្នុងទីក្រុងស៊ីយ៉ូនដ៏វិសុទ្ធជាមួយព្រហ្មចារិនីម៉ារី ជាព្រះមាតារបស់ព្រះជាម្ចាស់ជាមួយសន្តៈ យ៉ូសែប ពួកទេវទូត និងសន្តបុគ្គលទាំងឡាយទៅ (...)។ ចូរត្រឡប់ទៅព្រះជាម្ចាស់ជាព្រះបង្កើតអ្នកដែលបានសូនអ្នកពីធូលីដី។ នៅពេលកំណត់ព្រលឹងរបស់អ្នកនឹងចាកចេញពីរូបកាយរបស់អ្នក ព្រះនាងម៉ារី ពួកទេវទូត និងសន្តបុគ្គលទាំងឡាយប្រញាប់ប្រញាល់មកជួបអ្នក (...)។ សូមឲ្យអ្នកជួបទល់មុខនឹងព្រះសង្គ្រោះរបស់អ្នកទៅ... (OEx)។

## ១-ព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សម្នាក់ៗ

១០២១-មរណភាពជាទីបញ្ចប់នៃដំណើរជីវិតមនុស្ស ដែលបានទទួល ឬបានទាត់ចោលព្រះហឫទ័យប្រណីសន្តោសដែលព្រះជាម្ចាស់បានសម្តែងក្នុងអង្គព្រះគ្រីស្ត (២ធម ១,៩-១០)។ គម្ពីរសម្ពន្ធមេត្រីថ្មីថ្លែងថា ពេលព្រះគ្រីស្តនឹងយាងមកវិញ ព្រះអង្គនឹងវិនិច្ឆ័យទោសមនុស្សលោក។ ប៉ុន្តែសម្ពន្ធមេត្រីថ្មីប្រកាសជាច្រើនលើកច្រើនសាថា ព្រះជាម្ចាស់នឹងវិនិច្ឆ័យទោសមនុស្សម្នាក់ៗភ្លាមៗ ក្រោយពីបានស្លាប់តាមកិច្ចការ និងជំនឿរបស់គេ។ ពាក្យប្រាស្នាអំពីជនកម្សត់ឡាសារ (លក ១៦.២២) និងព្រះបន្ទូលរបស់ព្រះគ្រីស្តដែលត្រូវគេឆ្កាងចំពោះអ្នកទោស (លក ២៣,៤៣) ហើយអត្ថបទផ្សេងក្នុងសម្ពន្ធមេត្រីថ្មី (២ករ ៥,៨; ភីល ១,២៣; ហប ៩.២៧; ១២,២៣) ថ្លែងអំពីវាសនាចុងក្រោយបំផុតនៃព្រលឹង (មថ ១៦.២៦) ដែលអាចខុសប្លែកពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់។

១០២២-នៅពេលស្លាប់ហើយ ព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សម្នាក់ៗភ្លាមៗ និងអស់កល្បជានិច្ចយោងតាមព្រះគ្រីស្ត។ ព្រះអង្គបន្សុទ្ធព្រលឹងអមតៈរបស់មនុស្ស (DS ៨៥៧-៨៥៨; DS ១៣០៤-១៣០៦; DS ១៨២០) ឬបញ្ចូលព្រលឹងនេះនៅស្ថានបរមសុខភ្លាមៗ (DS ១០០០-១០០១) ឬព្រលឹងនេះធ្លាក់ស្ថាននរកភ្លាមៗជារៀងរហូត (DS ១០០២)។

នៅពេលស្លាប់ព្រះជាម្ចាស់នឹងវិនិច្ឆ័យយើងតាមសេចក្តីស្រឡាញ់ (សន្តៈ យ៉ូហាននៃព្រះឈើឆ្កាង)។

## ២-ស្ថានបរមសុខ

១០២៣-អស់អ្នកដែលស្លាប់ក្នុងព្រះហឫទ័យប្រណីសន្តោស និងមេត្រីភាពរបស់ព្រះជាម្ចាស់ ហើយដែលព្រះអង្គបានបន្សុទ្ធឲ្យពេញលក្ខណៈ រួចហើយរួមរស់ជាមួយព្រះគ្រីស្តជាដរាបតរៀងទៅ។ ពួកគេដូចព្រះជាម្ចាស់ជារៀងរហូត ដ្បិតពួកគេឃើញព្រះអង្គដែល "មានសភាពយ៉ាងណា" (១យហ ៣,២) ទល់មុខគ្នា (១ករ ១៣,១២ ; វវ ២២,៤)៖

> យើងប្រកបដោយអំណាចដែលមកពីក្រុមគ្រីស្តទូត សូមកំណត់ថាដោយគម្រោងការទូទៅរបស់ព្រះជាម្ចាស់ព្រលឹងនៃសន្តបុគ្គលទាំងឡាយ (...) និងរបស់គ្រីស្តបរិស័ទឯទៀតៗទាំងអស់ដែលបានទទួលមរណភាពក្រោយពីបានទទួលបុណ្យជ្រមុជទឹកដ៏វិសុទ្ធរបស់ព្រះគ្រីស្ត ដែលគ្មានអ្វីត្រូវបន្សុទ្ធទៀតទេ ក្រោយពីបានស្លាប់ហើយ (...) ឬប្រសិនបើត្រូវបន្សុទ្ធអ្វីមួយផ្សេងទៀត ព្រលឹងនោះនឹងបានបង្ហើយកិច្ចការនោះនៅក្រោយស្លាប់ (...) ហើយមុននឹងព្រលឹងនោះមានជីវិតថ្មីក្នុងរូបកាយ និងមុនព្រះជាម្ចាស់វិនិច្ឆ័យមនុស្សទាំងឡាយ តាំងពីព្រះអង្គបានប្រោសព្រះអម្ចាស់ និងព្រះសង្គ្រោះយេស៊ូគ្រីស្តឲ្យឡើងស្ថានបរមសុខ ព្រលឹងនោះនឹងឡើងទៅស្ថានបរមសុខនៅព្រះរាជ្យនៃស្ថានបរមសុខ និងនៅសួននៃស្ថានលើជាមួយព្រះគ្រីស្តរួមជាមួយសហគមន៍របស់ពួកទេវទូតដ៏វិសុទ្ធ។ តាំងពីព្រះអម្ចាស់យេស៊ូគ្រីស្តបានរងទុក្ខលំបាក និងសោយទិវង្គត ព្រលឹងនោះបានឃើញ និងកំពុងតែឃើញសភាពរបស់ព្រះជាម្ចាស់ដោយទល់នឹងមុខ និងដោយគ្មានសត្វលោកណាមួយធ្វើជាស្ពានមេត្រីឡើយ (DS ១០០០; LG ៤៩)។

១០២៤-គេហៅ "ស្ថានបរមសុខ" ជីវិតដ៏ពេញលក្ខណៈរួមជាមួយព្រះត្រៃឯកដ៏វិសុទ្ធបំផុត គឺមនុស្សរួមរស់ជាមួយព្រះត្រៃឯកនេះដោយក្តីស្រឡាញ់ដ៏រស់រវើករួមជាមួយព្រហ្មចារិនីម៉ារី ពួកទេវទូត និងអស់អ្នកដែលមានសុភមង្គល។ ស្ថានបរមសុខជាទីចុងក្រោយបំផុត និងបំពេញសេចក្តីរង់ចាំយ៉ាងជ្រាលជ្រៅរបស់មនុស្សឲ្យបានពេញលក្ខណៈ។ នៅស្ថានបរមសុខ មនុស្សក៏ស្គាល់សុភមង្គលដ៏ឧត្តុងឧត្តមបំផុត និងជាស្ថាពរ។

១០២៥-ពេលរស់នៅស្ថានបរមសុខយើងក៏ "រួមរស់ជាមួយព្រះគ្រីស្ត" (យហ ១៤,៣; ភីល ១,២៣; ១ថស ៤,១៧)។ អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យរស់នៅ "ក្នុងអង្គព្រះគ្រីស្ត" ហើយរក្សាទុកបានល្អលើស ពីនេះទៅទៀត ពួកគេរកឃើញអត្តសញ្ញាណរបស់ខ្លួន និងនាមរបស់ខ្លួនគេ៖

> ដ្បិតជីវិត គឺរួបរួមជាមួយព្រះគ្រីស្ត។ ទីណាព្រះគ្រីស្តគង់នៅ ទីនោះមានជីវិត ទីនោះមានព្រះរាជ្យ (សន្ត: អំប្រ័រ)។

១០២៦-ដោយព្រះយេស៊ូគ្រីស្តបានសោយទិវង្គត និងមានព្រះជន្មថ្មីព្រះអង្គបាន "បើក" ស្ថានបរមសុខឲ្យយើង។ អស់អ្នកដែលមានសុភមង្គល ទទួលផលដ៏ពេញលេញនៃការសង្គ្រោះ ដែលព្រះគ្រីស្តបានបំពេញ។ ព្រះអង្គបង្រួប បង្រួមក្នុងសិរីរុងរឿងនៃស្ថានបរមសុខរបស់ព្រះអង្គ អស់អ្នកដែលបានផ្ញើជីវិតទៅលើព្រះអង្គ និងដែលបានគាប់ ព្រះហឫទ័យព្រះអង្គដោយភក្តីភាព។ ស្ថានបរមសុខជាសហគមន៍ដ៏មានសុភមង្គលរបស់អស់អ្នកដែលរួមចំណែក ជាមួយព្រះអង្គយ៉ាងពេញលក្ខណៈ។

១០២៧-យើងមិនអាចនឹកគិតដល់ ឬស្រមើស្រមៃនូវអាថ៌កំបាំងដ៏អស្ចារ្យនៃការរួបរួមពេញលេញទៅដោយ សុភមង្គលរវាងព្រះជាម្ចាស់ និងអស់អ្នកដែលនៅក្នុងអង្គព្រះគ្រីស្តបានឡើយ។ ព្រះគម្ពីរប្រើនិមិត្តរូបដូចជាជីវិត ពន្លឺសេចក្តីសុខសាន្តពិធីមង្គលការ ស្រាទំពាំងបាយជូរនៃព្រះរាជ្យព្រះដំណាក់របស់ព្រះបិតាទីក្រុងយេរូសាឡឹម នៅលើមេឃស្ថានបរមសុខ៖ "អ្វីៗដែលភ្នែកមើលមិនឃើញ អ្វីៗដែលត្រចៀកស្តាប់មិនឮ និងអ្វីៗដែលចិត្តមនុស្ស នឹកមិនដល់នោះ ព្រះជាម្ចាស់បានរៀបចំទុកសម្រាប់អស់អ្នកដែលស្រឡាញ់ព្រះអង្គ" (២ករ ២.៩)។

១០២៨-ដោយសារព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតខុសប្លែកអំពីអ្វីៗទាំងអស់ យើងមិនអាចមើលឃើញព្រះអង្គបានទេ លុះត្រាតែព្រះអង្គផ្ទាល់សម្តែងអាថ៌កំបាំងរបស់ព្រះអង្គឲ្យមនុស្សលោកស្គាល់ និងប្រោសប្រទានឲ្យគេមានសមត្ថភាព អាចមើលឃើញអាថ៌កំបាំងនេះបាន។ ព្រះសហគមន៍ហៅ "ការមើលឃើញពោរពេញដោយសុភមង្គល" ការមើល ឃើញព្រះជាម្ចាស់ពោរពេញដោយសិរីរុងរឿងនៃស្ថានបរមសុខនេះ៖

> អ្នកនឹងពោរពេញដោយអំណរសប្បាយ និងសុភមង្គល គឺព្រះជាម្ចាស់ត្រាស់ហៅអ្នកឲ្យមើលឃើញព្រះ អង្គឲ្យមានកិត្តិយសចូលរួមក្នុងអំណរសប្បាយនៃការសង្គ្រោះ និងពន្លឺអស់កល្បជានិច្ចរួមជាមួយព្រះគ្រីស្ត ជាព្រះអម្ចាស់របស់អ្នក (...) ឲ្យត្រេកត្រអាលនឹងបានទទួលជីវិតអមតៈក្នុងព្រះរាជ្យនៃស្ថានបរមសុខរួម ជាមួយមនុស្សសុចរិត និងមិត្តសម្លាញ់របស់ព្រះអង្គ (សន្ត: ស៊ីព្រីយ៉ាំង)។

១០២៩-ក្នុងសិរីរុងរឿងនៃស្ថានបរមសុខ មនុស្សពោរពេញដោយសុភមង្គលនៅតែបន្តគាប់ព្រះហឫទ័យរបស់ ព្រះជាម្ចាស់ចំពោះមនុស្សឯទៀតៗ និងសត្វលោកទាំងអស់ដោយត្រេកអរសប្បាយ។ ពួកគេគ្រងរាជ្យជាមួយព្រះ គ្រីស្តហើយៗ ពួកគេរួមជាមួយព្រះអង្គ "គេនឹងគ្រងរាជ្យអស់កល្បជាអង្វែងតរៀងទៅ" (វវ ២២,៥) (មថ ២៥, ២១.២៣)។

### ៣-ព្រះជាម្ចាស់ជម្រះមនុស្សឲ្យបានវិសុទ្ធ

១០៣០-អស់អ្នកដែលស្លាប់ក្នុងព្រះហឫទ័យប្រណីសន្តោស និងមេត្រីភាពរបស់ព្រះជាម្ចាស់តែមិនមែនជា មនុស្សបរិសុទ្ធដ៏ពេញលក្ខណៈឡើយ ទោះបីគេដឹងថានឹងទទួលការសង្គ្រោះយ៉ាងណាក៏ដោយ ក៏នៅពេលស្លាប់ ហើយគេត្រូវតែស៊ូទ្រាំឲ្យព្រះជាម្ចាស់បន្សុទ្ធគេ ដើម្បីឲ្យគេចូលក្នុងអំណរសប្បាយនៃស្ថានបរមសុខដែរ។

១០៣១-ព្រះសហគមន៍ហៅស្ថានភាពនេះថា កិច្ចជម្រះមនុស្សបាប គឺព្រះជាម្ចាស់ប្រោសអស់អ្នកដែលព្រះ

អង្គបានជ្រើសរើសឲ្យបានវិសុទ្ធជាលើកចុងក្រោយ។ ការបន្សុទ្ធនេះខុសប្លែកទាំងស្រុងពីស្ថាននរក។ ព្រះសហគមន៍បានបង្កើតលទ្ធិអំពីកិច្ចជម្រះមនុស្សបាបនៅសន្និបាតនៃទីក្រុងហ្វ្លរង់ (DS ១៣០៤) និងទីក្រុងត្រង់ (DS ១៨២០; ១៥៨០)។ យោងតាមអត្ថបទខ្លះក្នុងព្រះគម្ពីរ (១ករ ៣,១៥; ១ពត្រ ១,៧) ព្រះសហគមន៍ថ្លែងអំពីភ្លើងដែលធ្វើឲ្យបានវិសុទ្ធ។

និយាយអំពីអំពើបាបស្រាលៗខ្លះត្រូវតែជឿថា មុនព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក មានភ្លើងធ្វើឲ្យបានវិសុទ្ធតាមព្រះបន្ទូលរបស់អ្នកដែលជាសេចក្ដីពិត គឺបើមនុស្សលោកប្រព្រឹត្តអំពើបាប និងពោលពាក្យប្រមាថព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះជាម្ចាស់នឹងមិនលើកលែងទោសឲ្យឡើយ (មថ ១២,៣១) ទោះជាក្នុងលោកនេះ ឬក្នុងបរមលោកយ៉ាងណាក៏ដោយ។ តាមព្រះបន្ទូលនេះយើងអាចសន្និដ្ឋានថាព្រះជាម្ចាស់អាចលើកលែងទោសអំពើបាបខ្លះក្នុងលោកនេះ ហើយខ្លះផ្សេងទៀតក្នុងបរមលោក (សន្ដ: គ្រេគ័រដ៏ប្រសើរ)។

១០៣២-ការប្រៀនប្រដៅនេះសំអាងទៅលើព្រះគម្ពីដ៏វិសុទ្ធ ដែលមានចែងថាជនជាតិអ៊ីស្រាអែលទូលអង្វរព្រះជាម្ចាស់សម្រាប់មនុស្សស្លាប់៖ "អាស្រ័យហេតុនេះហើយបានជាលោក (យូដាម៉ាកាបាយ) សូមឲ្យគេថ្វាយសក្ការបូជារំដោះបាប ដើម្បីសូមព្រះជាម្ចាស់លើកលែងទោសឲ្យពលទាហានដែលបាត់បង់ជីវិត" (១មបា ១២,៤៦)។ តាំងពីដើមដំបូងព្រះសហគមន៍បានគោរពអធិដ្ឋាន ជាពិសេសបានថ្វាយអភិបូជា (DS ៨៥៦) សម្រាប់វិញ្ញាណក្ខន្ធមនុស្សស្លាប់ ដើម្បីឲ្យគេបានវិសុទ្ធ និងអាចមើលឃើញព្រះជាម្ចាស់បាន។ ព្រះសហគមន៍ទូន្មានថាគួរចែកទានសម្រាប់អ្នកស្លាប់ និងសោកស្ដាយអំពើបាបរបស់គេផងដែរ។

សូមជួយសង្គ្រោះគេ និងរំឭកគេផង។ បើយញ្ញបូជារបស់លោក យ៉ូប បានបន្សុទ្ធកូនៗរបស់លោក (យ៉ូប ១.៥) ហេតុអ្វីត្រូវសង្ស័យថាតង្វាយរបស់យើងសម្រាប់អ្នកស្លាប់មិនអាចសម្រាលទុក្ខគេបានឡើយ? កុំរុញរាជួយសង្គ្រោះអស់អ្នកដែលបានលាចាកលោកនេះហើយៗ សូមទូលអង្វរព្រះជាម្ចាស់សម្រាប់គេផង (សន្ដ: យ៉ូហានគ្រីសូស្ដូម)។

## ៤-ស្ថាននរក

១០៣៣-យើងមិនអាចរួបរួមជាមួយព្រះជាម្ចាស់បាន បើយើងមិនស្រឡាញ់ព្រះអង្គទេ។ ប៉ុន្តែយើងមិនអាចស្រឡាញ់ព្រះជាម្ចាស់បានឡើយ បើយើងប្រព្រឹត្តអំពើបាបដ៏ធ្ងន់ប្រឆាំងនឹងព្រះអង្គ ប្រឆាំងនឹងបងប្អូន ឬប្រឆាំងនឹងខ្លួនឯង៖ "អ្នកណាស្អប់បងប្អូនរបស់ខ្លួន អ្នកនោះជាឃាតករ។ បងប្អូនដឹងស្រាប់ហើយថាឃាតករគ្មានជីវិតអស់កល្បជានិច្ចស្ថិតនៅក្នុងខ្លួនទេ" (១យហ ៣,១៥)។ ព្រះអម្ចាស់របស់យើងព្រមានយើងថា យើងនឹងបែកចេញពីព្រះអង្គ បើយើងមិនជួយបំពេញតម្រូវការជាចាំបាច់របស់អ្នកក្រីក្រ និងអ្នកតូចតាចដែលជាបងប្អូនរបស់យើង (មថ ២៥,៣១-៤៦)។ បើយើងស្លាប់ដោយបានប្រព្រឹត្តអំពើបាបដ៏ធ្ងន់ដោយមិនបានសោកស្ដាយបាបនោះសោះ និងដោយមិនបានទទួលសេចក្ដីស្រឡាញ់ប្រកបដោយធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ យើងអាចឃ្លាតចាកពីព្រះអង្គជារៀងរហូតដោយសារជម្រើសដ៏សេរីរបស់យើង។ គេហៅ "ស្ថាននរក" ស្ថានភាពរបស់មនុស្សដែលឃ្លាតចាកពីព្រះជាម្ចាស់ និងពីអស់អ្នកពោរពេញដោយសុភមង្គល។

១០៣៤-ព្រះយេស៊ូមានព្រះបន្ទូលជាញឹកញាប់អំពី "ភ្លើងនរកអវិចី" (មថ ៥,២២.២៩; ១៣,៤២.៥០; មក ៩,៤៣-៤៨) ដែលព្រះជាម្ចាស់បានបម្រុងទុកសម្រាប់អស់អ្នកដែលមិនព្រមធ្វើជីវិតទាំងស្រុងទៅលើព្រះអង្គ និងមិនព្រមកែប្រែចិត្តគំនិតឡើយរហូតដល់ទីចុងក្រោយ។ ពួកអ្នកនោះអាចបាត់បង់ទាំងព្រលឹង ទាំងរូបកាយផង

(មថ ១០,២៨)។ ព្រះយេស៊ូប្រកាសយ៉ាងហ្មត់ចត់ថាព្រះអង្គ "នឹងចាត់ទេវទូតរបស់ព្រះអង្គឲ្យមក។ ទេវទូតទាំងនោះនឹងប្រមូលពួកអ្នកដែលនាំគេឲ្យប្រព្រឹត្តអំពើបាប (...) និងយកចេញបោះទៅភ្លើងដែលឆេះសន្ធោសន្ធៅ" (មថ ១៣,៤១-៤២) ហើយទ្រង់នឹងផ្តន្ទាទោស "ពួកអ្នកត្រូវបណ្តាសាអើយ! ចូរថយចេញឲ្យឆ្ងាយពីយើង ហើយធ្លាក់ទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច" (មថ ២៥,៤១)។

១០៣៥-ព្រះសហគមន៍ប្រៀនប្រដៅថា មានស្ថាននរកអស់កល្បជានិច្ចមែន។ នៅពេលស្លាប់ហើយព្រលឹងរបស់អស់អ្នកដែលបានស្លាប់ដោយប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្លាក់ភ្លាមក្នុងស្ថាននរក និងរងទុក្ខនៃ "ភ្លើងអស់កល្បជានិច្ច" (DS ៧៦; ៤០៩; ៤១១; ៨០១; ៨៥៨; ១០០២; ១៣៥១; ១៥៧៥; SPF ១២)។ អ្នកធ្លាក់នរកទទួលទោសធ្ងន់ធំជាងគេជាទីបំផុត គឺគេឃ្លាតចាកពីព្រះជាម្ចាស់អស់កល្បជានិច្ច ដ្បិតព្រះអង្គបានបង្កើតមនុស្សលោកដើម្បីឲ្យគេមានជីវិត និងសុភមង្គល ហើយមានតែព្រះអង្គទេដែលជាជីវិត និងសុភមង្គលនោះដែលមនុស្សទន្ទឹងរង់ចាំ។

១០៣៦-តាមពិតព្រះគម្ពីរដ៏វិសុទ្ធ និងការប្រៀនប្រដៅរបស់ព្រះសហហគមន៍អំពីស្ថាននរកថា ជាការត្រាស់ហៅមនុស្សឲ្យទទួលខុសត្រូវអំពីការប្រើប្រាស់សេរីភាពរបស់គេ ដើម្បីវាសនាអស់កល្បជានិច្ចរបស់ខ្លួន។ នៅពេលជាមួយគ្នានេះព្រះគម្ពីរដ៏វិសុទ្ធ និងការប្រៀនប្រដៅព្រះសហហគមន៍ត្រាស់ហៅមនុស្សឲ្យកែប្រែចិត្តគំនិតជាប្រញាប់៖ "ចូរនាំគ្នាចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែលនាំទៅរកសេចក្តីវិនាសអន្តរាយធំទូលាយណាស់ ហើយផ្លូវទៅរកសេចក្តីវិនាសក៏ទូលាយណាស់ដែរ។ មានមនុស្សជាច្រើនចូលតាមទ្វារនោះ។ រីឯទ្វារចង្អៀតនាំទៅរកជីវិត ហើយពិបាកដើរផង។ មានមនុស្សតិចទេ ដែលរកផ្លូវនោះឃើញ" (មថ ៧,១៣-១៤)។

> យើងមិនដឹងថ្ងៃ និងពេលកំណត់ទេ ហេតុនេះ យើងត្រូវប្រុងស្មារតីជានិច្ច ដើម្បីឲ្យព្រះបិតាសព្វព្រះហឫទ័យរាប់បញ្ចូលយើងក្នុងចំណោមអស់អ្នកដែលព្រះអង្គបានប្រទានពរ ឲ្យនៅពេលដំណើរជីវិតតែមួយរបស់យើងនឹងចប់ទៅ មិនមែនត្រូវងាកថយចេញអំពីព្រះបញ្ជារបស់ព្រះជាម្ចាស់ ដូចអ្នកបម្រើខ្ជិលច្រអូស ហើយត្រូវធ្លាក់ទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច គឺត្រូវគេបោះបង់ចោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំសោកខឹងសង្កៀតធ្មេញនោះទេ (LG ៤៨)។

១០៣៧-ព្រះជាម្ចាស់មិនតម្រូវទុកជាមុនឲ្យនរណាម្នាក់ធ្លាក់នរកទេ (DS ៣៩៧; ១៥៦៧)។ ដើម្បីធ្លាក់នរកត្រូវស្អប់ព្រះជាម្ចាស់ជាទីបំផុតដោយចេតនា (អំពើបាបដ៏ធ្ងន់ធ្ងរ) ហើយនៅតែប្រព្រឹត្តអំពើបាបនេះរហូតដល់ទីចុងក្រោយ។ ក្នុងពិធីបុណ្យអភិបូជា និងការអធិដ្ឋានប្រចាំថ្ងៃរបស់គ្រីស្តបរិស័ទ ព្រះសហគមន៍ក៏ទូលអង្វរធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដែល "ទ្រង់មិនសព្វព្រះហឫទ័យឲ្យនរណាម្នាក់ត្រូវវិនាសទេ គឺទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សលោកគ្រប់ៗរូបកែប្រែចិត្តគំនិតវិញ" (២ពត្រ ៣,៩)។

> សូមព្រះអង្គសព្វព្រះហឫទ័យទទួលតង្វាយពីយើងខ្ញុំជាអ្នកបម្រើព្រះអង្គ រួមជាមួយក្រុមគ្រួសារទាំងមូលរបស់ព្រះអង្គ។ សូមទ្រង់ថែរក្សាយើងខ្ញុំឲ្យបានរស់នៅដោយសុខសាន្តក្នុងលោកនេះ និងប្រោសយើងខ្ញុំកុំឲ្យឃ្លាតចាកពីព្រះអង្គក្នុងបរមលោក ហើយសូមទទួលយើងខ្ញុំក្នុងចំណោមសន្តបុគ្គលទាំងឡាយផង (MR)។

## ៥-ព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោកទាំងអស់នៅពេលចុងក្រោយបំផុត

១០៣៨-មុននឹងព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោកទាំងអស់មនុស្សស្លាប់ទាំងអស់ "ទាំងមនុស្សសុចរិតទាំងមនុស្សទុច្ចរិត" (កក ២៤.១៥) នឹងមានជីវិតថ្មី។ ពេលនោះជា "ពេលកំណត់ដែលមនុស្សស្លាប់ទាំងប៉ុន្មាននឹងឮព្រះសូរសៀងរបស់បុត្រមនុស្សហើយចេញពីផ្នូរមក។ អ្នកដែលបានប្រព្រឹត្តអំពើល្អនឹងមានជីវិតថ្មីដើម្បីទទួល

ជីវិត រីឯអ្នកដែលបានប្រព្រឹត្តអំពើអាក្រក់នឹងមានជីវិតថ្មីដើម្បីទទួលទោស" (យហ ៥,២៨-២៩)។ ពេលនោះ ព្រះគ្រីស្តនឹង "យាងមកជាមួយពួកទេវទូត (...)។ មនុស្សគ្រប់ជាតិសាសន៍នឹងមកផ្តុំគ្នានៅមុខព្រះអង្គ ៗនឹងញែកគេចេញពីគ្នាដូចអ្នកគង្វាលញែកចៀមចេញពីពពែ គឺឲ្យចៀមនៅខាងស្តាំ ពពែនៅខាងឆ្វេង (...)។ អ្នកទុច្ចរិតនឹងត្រូវទទួលទោសអស់កល្បជានិច្ច រីឯអ្នកសុចរិតវិញនឹងទទួលជីវិតអស់កល្បជានិច្ច" (មថ ២៥,៣១.៣២.៤៦)។

១០៣៩-ព្រះគ្រីស្តដែលជាសេចក្តីពិតនឹងលាតត្រដាងយ៉ាងច្បាស់ ទំនាក់ទំនងយ៉ាងពិតប្រាកដរបស់មនុស្សម្នាក់ៗចំពោះព្រះជាម្ចាស់ (យហ ១២,៤៩)។ ដោយវិនិច្ឆ័យទោសមនុស្សលោក ព្រះជាម្ចាស់នឹងសម្តែងនូវអំពើល្អដែលមនុស្សម្នាក់ៗបានប្រព្រឹត្ត ឬអ្វីដែលគេមិនបានប្រព្រឹត្តក្នុងជីវិតនៅលើផែនដីនេះ។

> ព្រះជាម្ចាស់កត់ចំនួនអំពើអាក្រក់ទាំងអស់ដែលមនុស្សទុច្ចរិតប្រព្រឹត្ត ហើយពួកគេមិនដឹងទេ។ ថ្ងៃដែល "ព្រះអង្គមិនសំងំនៅស្ងៀមឡើយ" (ទន ៥០,៣) (...) ព្រះអង្គនឹងបែរព្រះភ័ក្ត្រទៅមនុស្សទុច្ចរិត៖ "យើងបានដាក់ជនក្រីក្រដ៏តូចរបស់យើងនៅលើផែនដីសម្រាប់អ្នករាល់គ្នា។ យើងដែលជាប្រធានរបស់គេអង្គុយលើបល្ល័ង្កខាងស្តាំព្រះបិតារបស់យើង ប៉ុន្តែនៅលើផែនដីសរីរាង្គយើងស្រេកឃ្លាន។ បើអ្នករាល់គ្នានឹងបានចែកឲ្យសរីរាង្គយើង អ្វីដែលអ្នករាល់គ្នាបានចែកនឹងឡើងដល់ព្រះសិរសា។ ពេលយើងដាក់ជនក្រីក្រដ៏តូចនៅលើផែនដី យើងបានតែងតាំងគេឲ្យទៅជាអ្នកជួយនាំអំពើល្អរបស់អ្នករាល់គ្នាក្នុងកំណប់យើង។ អ្នករាល់គ្នាមិនបានដាក់អ្វីក្នុងដៃគេ ហេតុនេះអ្នករាល់គ្នាគ្មានអ្វីពីយើងឡើយ (សន្តៈ អូគូស្តាំង)។

១០៤០-ព្រះជាម្ចាស់នឹងវិនិច្ឆ័យមនុស្សទាំងអស់ ពេលព្រះគ្រីស្តនឹងយាងមកវិញប្រកបដោយសិរីរុងរឿង។ មានតែព្រះបិតាដែលស្គាល់ពេលកំណត់ មានតែព្រះអង្គដែលសម្រេចពេលព្រះអង្គនឹងឡើងសោយរាជ្យ។ តាមរយៈព្រះបុត្រាព្រះអង្គ ព្រះយេស៊ូគ្រីស្ត ព្រះអង្គនឹងមានព្រះបន្ទូលសម្រេចលើប្រវត្តិសាស្ត្រទាំងមូលរបស់មនុស្សលោក។ យើងនឹងដឹងអំពីអត្ថន័យចុងក្រោយនៃព្រះរាជកិច្ចនៃការបង្កើត និងអំពីការចាត់ចែងនៃការសង្គ្រោះ ហើយយើងនឹងដឹងផ្លូវផ្សេងៗដ៏អស្ចារ្យដែលឧបការគុណរបស់ព្រះអង្គបានណែនាំសត្វលោកទាំងអស់ ឆ្ពោះទៅវាសនាចុងក្រោយរបស់ខ្លួន។ ដោយសារព្រះជាម្ចាស់វិនិច្ឆ័យមនុស្សលោកទាំងអស់ ព្រះអង្គក៏នឹងប្រកាន់យកភាពយុត្តិធម៌របស់ព្រះអង្គ យកជ័យជម្នះលើអំពើអយុត្តិធម៌ទាំងឡាយដែលសត្វលោករបស់ព្រះអង្គបានប្រព្រឹត្ត ហើយទ្រង់នឹងសម្តែងថាសេចក្តីស្រឡាញ់របស់ព្រះអង្គខ្លាំងជាងសេចក្តីស្លាប់ (បច ៨,៦)។

១០៤១-ព្រះជាម្ចាស់វិនិច្ឆ័យមនុស្សលោកទាំងអស់បានសេចក្តីថា ព្រះអង្គត្រាស់ហៅមនុស្សលោកឲ្យកែប្រែចិត្តគំនិតរហូតដល់ "គ្រាណាដែល (ព្រះអង្គ) គាប់ព្រះហឫទ័យ (...) ថ្ងៃណាដែល (ព្រះអង្គ) សង្គ្រោះមនុស្សលោក" (២ករ ៦.២)។ ព្រះអង្គក៏ត្រាស់ហៅមនុស្សឲ្យគោរពកោតខ្លាចព្រះអង្គ រកយុត្តិធម៌នៃព្រះរាជ្យព្រះអង្គ ហើយប្រកាស "សេចក្តីសង្ឃឹម" (ទត ២,១៣) នៅពេលដែលព្រះអម្ចាស់នឹងយាងមកវិញ។ វេលានោះ "ប្រជាជនដ៏វិសុទ្ធនឹងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ហើយអស់អ្នកដែលបានផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គក៏នឹងនាំគ្នាស្ញើចសរសើរព្រះអង្គដែរ" (២ថស ១,១០)។

## ៦-យើងសង្ឃឹមផ្ទៃមេឃថ្មី និងផែនដីថ្មី

១០៤២-នៅអវសានកាលនៃពិភពលោក ព្រះរាជ្យរបស់ព្រះជាម្ចាស់នឹងបានពេញលក្ខណៈ។ ក្រោយពីព្រះជាម្ចាស់នឹងបានវិនិច្ឆ័យទោសមនុស្សលោកទាំងអស់ មនុស្សសុចរិតនឹងគ្រងរាជ្យជាមួយព្រះគ្រីស្តជារៀងរហូត រូបកាយ និងព្រលឹងរបស់គេនឹងពោរពេញដោយសិរីរុងរឿង ហើយសាកលលោកផ្ទាល់នឹងកើតជាថ្មី៖

ពេលនោះព្រះសហគមន៍ "នឹងបានពេញលក្ខណៈជាស្ថាពរនៅក្នុងសិរីរុងរឿងនៃលោកខាងមុខ គឺនៅពេលព្រះជាម្ចាស់រៀបចំអ្វីៗទាំងអស់ជាថ្មី។ នៅពេលនោះ ពិភពលោកទាំងមូលនឹងផ្សាភ្ជាប់គ្នាយ៉ាងស្អិតល្មួតជាមួយមនុស្សជាតិនឹងទៅដល់ទីដៅរបស់ខ្លួន ហើយៗក៏បានពេញលក្ខណៈជាស្ថាពរក្នុងអង្គព្រះគ្រីស្តដែរ (LG ៤៨)។

១០៤៣-ព្រះគម្ពីរដ៏វិសុទ្ធហៅថា "ផ្ទៃមេឃថ្មី និងផែនដីថ្មី" (២ពត្រ ៣,១៣) (វវ ២១,១) គឺព្រះជាម្ចាស់នឹងផ្លាស់ប្តូរមនុស្សជាតិ និងពិភពលោកសាជាថ្មីម្តងទៀត តាមរបៀបដ៏អាថ៌កំបាំង។ ពេលនោះព្រះជាម្ចាស់នឹងសម្រេចគម្រោងការរបស់ព្រះអង្គជាស្ថាពរដោយ "ប្រមូលអ្វីៗទាំងអស់ដែលនៅស្ថានបរមសុខ និងនៅលើផែនដីឲ្យរួមគ្នានៅក្នុងអង្គព្រះគ្រីស្តជាម្ចាស់តែមួយ" (អភ ១,១០)។

១០៤៤-ក្នុងសាកលលោកថ្មីនេះ (វវ ២១,៥) ជាទីក្រុងយេរូសាឡឹមនៃលោកខាងមុខ ព្រះជាម្ចាស់នឹងតាំងព្រះដំណាក់របស់ព្រះអង្គក្នុងចំណោមមនុស្សលោក។ "ព្រះអង្គនឹងជូតទឹកភ្នែកចេញអស់ពីភ្នែករបស់គេ សេចក្តីស្លាប់លែងមានទៀតហើយ ការកាន់ទុក្ខ ការសោកសង្រេង និងទុក្ខលំបាកក៏លែងមានទៀតដែរ ដ្បិតអ្វីៗដែលកើតមានកាលពីមុននោះបាត់អស់ទៅហើយ" (វវ ២១,៤) (វវ ២១,២៧)។

១០៤៥-សម្រាប់មនុស្សដោយសារព្រះជាម្ចាស់នឹងសម្រេចគម្រោងការនេះ ព្រះអង្គក៏នឹងធ្វើឲ្យមនុស្សជាតិរួមគ្នាជាធ្លុងតែមួយ ដែលព្រះអង្គសព្វព្រះហឫទ័យតាំងពីកំណើតពិភពលោកមកម៉្លេះ ហើយដែលព្រះសហគមន៍កំពុងធ្វើដំណើរដូចជា "អគ្គសញ្ញា" (LG ១)។ អស់អ្នកដែលរួបរួមជាមួយព្រះគ្រីស្តនឹងទៅជាសហគមន៍របស់អ្នកដែលព្រះអង្គបានលោះ គឺទីក្រុងដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ (វវ ២១,២) "ជាកូនក្រមុំ ជាភរិយារបស់កូនចៀម" (វវ ២១,៩)។ អំពើបាប អំពើសៅហ្មង (វវ ២១,២៧) សេចក្តីក្រអឺតក្រអោងដែលបំផ្លាញ ឬធ្វើឲ្យសហគមន៍មនុស្សខូចខាតនឹងមិនធ្វើឲ្យភរិយានេះរបួសទៀតទេ។ ព្រះជាម្ចាស់នឹងប្រោសសន្តបុគ្គលទាំងឡាយឲ្យឃើញព្រះភ័ក្ត្ររបស់ព្រះអង្គដែលជាប្រភពដែលគ្មានទីបញ្ចប់នៃសុភមង្គល និងសេចក្តីសុខសាន្តរបស់មនុស្សដែលនឹងរួមរស់គ្នាជាធ្លុងតែមួយ។

១០៤៦-ឯសាកលលោកវិញ ព្រះជាម្ចាស់សម្តែងឲ្យយើងដឹងថាមនុស្សលោក និងពិភពលោកមានវាសនារួមគ្នា៖

> អ្វីៗសព្វសារពើដែលព្រះអង្គបង្កើតមក កំពុងតែអន្ទះអន្ទែងទន្ទឹងរង់ចាំពេលដែលព្រះជាម្ចាស់នឹងបង្ហាញបុត្រធីតារបស់ព្រះអង្គ (...)។ ពិភពលោកនៅតែមានសង្ឃឹមថា ព្រះអង្គនឹងលោះឲ្យរួចផុតពីវិនាសអន្តរាយដើម្បីឲ្យមានសេរីភាព (...)។ យើងដឹងហើយថាមកទល់ថ្ងៃនេះ ពិភពលោកទាំងមូលកំពុងតែស្រែកថ្ងូរ និងឈឺចុកចាប់ដូចជាស្ត្រីហៀបនឹងសម្រាលកូន។ មិនត្រឹមតែពិភពលោកប៉ុណ្ណោះទេ សូម្បីតែយើងដែលបានទទួលព្រះអំណោយទានដំបូងរបស់ព្រះវិញ្ញាណ ក៏ថ្ងូរក្នុងចិត្តទន្ទឹងរង់ចាំព្រះជាម្ចាស់ប្រោសយើងឲ្យទៅជាបុត្រធីតារបស់ព្រះអង្គ និងលោះរូបកាយយើងទាំងស្រុងដែរ (រម ៨,១៩-២៣)។

១០៤៧-ព្រះជាម្ចាស់មានគម្រោងការផ្លាស់ប្តូរសាកលលោកដែលមើលឃើញ "ដើម្បីឲ្យពិភពលោកផ្ទាល់ដែលព្រះជាម្ចាស់នឹងប្រោសឲ្យដូចក្នុងស្ថានភាពដើមដំបូង ទៅជាអ្នកបម្រើមនុស្សសុចរិតដោយគ្មានឧបសគ្គណាមួយមករារាំងទៀតឡើយ"។ ពិភពលោកនេះនឹងចូលរួមចំណែកសិរីរុងរឿងរបស់មនុស្សសុចរិតទាំងនោះ ក្នុងអង្គព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មថ្មី (សន្ត: អ៊ីរ៉េណេ)។

១០៤៨-"យើងមិនដឹងអំពីពេលវេលាដែលផែនដី និងមនុស្សត្រូវបញ្ចប់នៅពេលណាទេ យើងក៏មិនស្គាល់របៀបប្រែប្រួលនៃពិភពលោកដែរ។ សភាពការណ៍ពិភពលោកនេះដែលត្រូវបានអំណាចបាបបង្ខូច នៅតែប្រែប្រួល។ ក៏ប៉ុន្តែ យើងបានដឹងថា ព្រះជាម្ចាស់រៀបចំដំណាក់ថ្មី និងផែនដីថ្មីសម្រាប់យើង ជាផែនដីដែលយុត្តិធម៌គ្រងរាជ្យ។

បរមសុខនៅលើផែនដីថ្មីនោះ និងបំពេញនូវបំណងរបស់មនុស្សដែលចង់បានសេចក្ដីសុខសាន្តយ៉ាងលើសលប់ពន់ពេក" (GS ៣៩,១)។

១០៤៩-"ប៉ុន្តែ ការរង់ចាំផែនដីថ្មី មិនបណ្ដាលឲ្យយើងមិនសូវអើពើនឹងថែទាំផែនដីនេះទេ ផ្ទុយទៅវិញ យើងត្រូវតែភ្ញាក់ស្មារតីឡើង ព្រោះថា រូបកាយនៃគ្រួសារថ្មីរបស់មនុស្សចម្រើនធំឡើងនៅលើផែនដីនេះ ហើយបង្ហាញការព្រាងនៃលោកខាងមុខទៀតផង។ ហេតុនេះហើយត្រូវញែកឲ្យបានច្បាស់ការអភិវឌ្ឍន៍ខាងផែនដី និងការរីកចម្រើននៃព្រះរាជ្យព្រះជាម្ចាស់។ ក៏ប៉ុន្តែការអភិវឌ្ឍន៍ខាងផែនដីមានសារៈសំខាន់ជាខ្លាំង ដើម្បីព្រះជាម្ចាស់គ្រងរាជ្យ គឺការអភិវឌ្ឍន៍នោះអាចជួយឲ្យចាត់ចែងរចនាសម្ព័ន្ធនៃសង្គមមនុស្សឲ្យមានលក្ខណៈល្អប្រសើរ (GS ៣៩,២)។

១០៥០-"ផលដ៏ល្អបំផុតនៃធម្មជាតិយើង និងនៃការខិតខំរបស់យើងដែលយើងបានផ្សព្វផ្សាយនៅលើផែនដីតាមព្រះបញ្ញារបស់ព្រះអម្ចាស់ និងក្នុងព្រះវិញ្ញាណព្រះអង្គយើងនឹងទទួលផលល្អទាំងនោះនៅពេលក្រោយ ជាផលដែលបរិសុទ្ធផុតពីភាពសៅហ្មងនានា ភ្លឺត្រចះត្រចង់ និងផ្លាស់ទ្រង់ទ្រាយនៅពេលព្រះគ្រីស្តនឹងប្រគល់ថ្វាយព្រះបិតា "ព្រះរាជ្យដែលស្ថិតស្ថេរអស់កល្បជានិច្ច និងជាសកល" (GS ៣៩,៣)។ ក្នុងជីវិតអស់កល្បជានិច្ចនោះ ព្រះជាម្ចាស់នឹង "គ្រងរាជ្យលើអ្វីៗទាំងអស់គ្រប់ប្រការទាំងអស់" (១ករ ១៥,២៨)។

> ជីវិតដែលនៅស្ថិតស្ថេរ និងយ៉ាងពិតប្រាកដ គឺព្រះបិតាតាមរយៈព្រះបុត្រា និងក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធចាក់បង្ហូរព្រះអំណោយទានដែលមកពីស្ថានបរមសុខលើយើងទាំងអស់គ្នា ដោយគ្មានអាក់ខានទាល់តែសោះ។ ដោយសារធម៌មេត្តាករុណារបស់ព្រះអង្គ យើងក៏ជាមនុស្សបានទទួលព្រះបន្ទូលសន្យា ដែលមិនអាចសាបសូន្យទៅបាននៃជីវិតអស់កល្បជានិច្ច (សន្ត: ស៊ីរីលនៃទីក្រុងយេរូសាឡឹម)។

## សង្ខេប

១០៥១-មនុស្សម្នាក់ៗក្នុងព្រលឹងអមតៈរបស់ខ្លួនទទួលរង្វាន់ ឬទោសអស់កល្បជានិច្ច នៅពេលស្លាប់ហើយដោយមានព្រះគ្រីស្ត ជាអ្នកកាត់ក្ដីវិនិច្ឆ័យគេទាំងរស់ទាំងស្លាប់។

១០៥២-"យើងជឿថា ព្រលឹងរបស់អស់អ្នកដែលស្លាប់នៅក្នុងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្ត (...) ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់នៅឯស្ថានលើ។ ថ្ងៃនៃការមានជីវិតថ្មី ជាថ្ងៃដែលព្រលឹងទាំងអស់នោះនឹងរួមជាមួយរូបកាយរបស់ខ្លួនឡើងវិញ សេចក្ដីស្លាប់នឹងចុះចាញ់ជាស្ថាពរ" (SPF ២៨)។

១០៥៣-"យើងជឿថា អស់អ្នកដែលប្រមូលគ្នានៅជាមួយព្រះយេស៊ូ និងព្រះនាងម៉ារី នៅស្ថានបរមសុខ បង្កើតព្រះសហគមន៍នៃស្ថានលើ។ នៅទីនោះ ពួកគេពោរពេញដោយសុភមង្គល មើលឃើញព្រះជាម្ចាស់ក្នុងសភាពរបស់ព្រះអង្គ។ តាមថ្នាក់ប្លែកៗពីគ្នា ពួកគេរួមជាមួយពួកទេវទូតដ៏វិសុទ្ធ ក្នុងការគ្រប់គ្រងរបស់ព្រះគ្រីស្តប្រកបដោយសិរីរុងរឿង ដោយជួយអង្វរសម្រាប់យើង និងដោយជួយរំលែកភាពទន់ខ្សោយរបស់យើងដូចបងប្អូនបង្កើត" (SPF ២៩)។

១០៥៤-អស់អ្នកដែលទទួលមរណភាពក្នុងការប្រោសប្រណី និងមេត្រីភាពរបស់ព្រះជាម្ចាស់ ប៉ុន្តែ ដែលមិនបានជម្រះចិត្តគំនិតឲ្យបានពេញលក្ខណៈ ទោះជាពួកគេនឹងទទួលការសង្គ្រោះក៏ដោយ ក៏ក្រោយពីបានទទួលមរណភាពពួកគេត្រូវជម្រះចិត្តគំនិត ដើម្បីទទួលភាពដ៏វិសុទ្ធជាចាំបាច់ ដើម្បីចូលក្នុងអំណរសប្បាយរបស់ព្រះជាម្ចាស់។

១០៥៥-ដោយសារ "សហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ" ព្រះសហគមន៍ផ្ដាំផ្ញើអ្នកស្លាប់ចំពោះធម៌មេត្តាករុណា

របស់ព្រះជាម្ចាស់ ហើយថ្វាយពាក្យអង្វរសម្រាប់គេ ជាពិសេសអភិបូជាដ៏វិសុទ្ធ។

១០៥៦-ដោយយកតម្រាប់តាមព្រះគ្រីស្ត ព្រះសហគមន៍ព្រមានគ្រីស្តបរិស័ទអំពី "សេចក្ដីស្លាប់អស់កល្បជានិច្ចដ៏គួរឲ្យសោយសោក" (DCG ៦៩) ដែលគេហៅថា "នរក"។

១០៥៧-ទោសធ្ងន់ជាងគេនៃនរក គឺឲ្យមនុស្សបែកចេញពីព្រះជាម្ចាស់អស់កល្បជានិច្ច។ មនុស្សអាចមានជីវិត និងសុភមង្គលពីព្រះជាម្ចាស់តែប៉ុណ្ណោះ។ ព្រះជាម្ចាស់បង្កើតមនុស្ស ដើម្បីឲ្យគេមានជីវិត និងសុភមង្គលនេះ ហើយមនុស្សក៏រង់ចាំជីវិតនឹងសុភមង្គលនេះដែរ។

១០៥៨-ព្រះសហគមន៍ទូលអង្វរព្រះជាម្ចាស់កុំឲ្យនរណាម្នាក់ធ្លាក់នរក៖ "ឱព្រះអម្ចាស់អើយ! សូមកុំឲ្យទូលបង្គំឃ្លាតឆ្ងាយពីព្រះអង្គ"។ គ្មាននរណាអាចសង្គ្រោះខ្លួនឯងពិតមែន ប៉ុន្តែ "ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ"(១ធម ២,៤) ហើយចំពោះព្រះអង្គ "គ្មានអ្វីដែលព្រះអង្គធ្វើមិនកើតទេ" (មថ១៩,២៦)។

១០៥៩-"ព្រះសហគមន៍នៅទីក្រុងរ៉ូមដ៏វិសុទ្ធបំផុតជឿ និងប្រកាសយ៉ាងម៉ឺងម៉ាត់ថា នៅពេលដែលព្រះជាម្ចាស់វិនិច្ឆ័យទោស មនុស្សទាំងអស់ ព្រមទាំងរូបកាយផ្ទាល់របស់គេ នឹងឈរមុខតុលាការរបស់ព្រះគ្រីស្ត ដើម្បីឲ្យព្រះអង្គកាត់ក្ដី" (DS ៨៥៩; DS ១៥៤៩)។

១០៦០-នៅអវសានកាលនៃពិភពលោក ព្រះរាជ្យរបស់ព្រះជាម្ចាស់បានគ្រប់លក្ខណៈ។ នៅពេលនោះ មនុស្សសុចរិតនឹងសោយរាជ្យរួមជាមួយព្រះគ្រីស្តជាដរាបតរៀងទៅ ទាំងរូបកាយ ទាំងព្រលឹងប្រកបដោយសិរីរុងរឿង ហើយព្រះជាម្ចាស់នឹងប្រែសកលលោក។ នៅពេលនោះ ព្រះជាម្ចាស់នឹង "គ្រងរាជ្យលើអ្វីៗទាំងអស់គ្រប់ប្រការ" (១ករ ១៥,២៨) ក្នុងជីវិតអស់កល្បជានិច្ច។

## "អាម៉ែន"

១០៦១-ដូចកំណ្ឌចុងក្រោយនៃព្រះគម្ពីរដ៏វិសុទ្ធ (វវ ២២,២១) ពាក្យហេប្រឺ អាម៉ែន សម្រាប់បញ្ចប់ធម៌ប្រកាសជំនឿ។ ជាញឹកញយពាក្យនេះបញ្ចប់ពាក្យអង្វរនៃសម្ពន្ធមេត្រីថ្មីដែរ។ យ៉ាងណាមិញព្រះសហគមន៍បញ្ចប់ពាក្យអង្វរដោយប្រើពាក្យ "អាម៉ែន"។

១០៦២-ជាភាសាហេប្រឺ អាម៉ែន មានមូលសព្ទដូចពាក្យ "ជឿ"។ មូលសព្ទនេះសម្ដែងទៅលើភាពរឹងមាំ ភាពស្មោះត្រង់ និងភក្ដីភាព។ ហេតុនេះយើងអាចយល់ថា "អាម៉ែន" សំដៅលើភក្ដីភាពរបស់ព្រះជាម្ចាស់សម្រាប់យើង និងទំនុកចិត្តរបស់យើងចំពោះព្រះអង្គ។

១០៦៣-ក្នុងព្យាការីអេសាយមានចែងថា "ព្រះជាម្ចាស់នៃសេចក្ដីពិត" ឬតាមន័យចំ "ព្រះជាម្ចាស់នៃអាម៉ែន" ពោលគឺព្រះជាម្ចាស់ជាព្រះគោរពព្រះបន្ទូលសន្យារបស់ព្រះអង្គ៖ "នៅក្នុងស្រុកអ្នកណាចង់ជូនពរត្រូវជូនពរក្នុងនាមព្រះជាម្ចាស់នៃអាម៉ែន (ដ៏ពិតប្រាកដ)" (អស ៦៥,១៦)។ ព្រះអម្ចាស់របស់យើងឧស្សាហ៍ប្រើពាក្យ "អាមែន" (មថ ៦,២.៥.១៦) ពេលខ្លះជាពីរដង (យហ ៥,១៩) ដើម្បីបញ្ជាក់ថាការប្រៀនប្រដៅរបស់ព្រះអង្គមិនប្រែប្រួលឡើយ ហើយអំណាចរបស់ព្រះអង្គចាក់ឫសលើសេចក្ដីពិតរបស់ព្រះជាម្ចាស់។

១០៦៤-ដូច្នេះហើយបានជា "អាម៉ែន" ចុងក្រោយនៃធម៌ប្រកាសជំនឿលើកយកមកវិញ និងបញ្ជាក់ពាក្យខាងដើម "ខ្ញុំជឿ"។ ពេលយើងជឿយើងថា "អាម៉ែន" ចំពោះព្រះបន្ទូល ព្រះបន្ទូលសន្យា និងព្រះរាជបញ្ញារបស់ព្រះជាម្ចាស់ គឺយើងផ្ញើជីវិតទាំងស្រុងទៅលើព្រះដែលជា "អាម៉ែន" ប្រកបដោយសេចក្ដីស្រឡាញ់ឥតព្រំដែន និង

ភក្តីភាពដ៏ល្អឥតខ្ចោះ។ គ្រីស្តបរិស័ទនឹងរស់នៅជារៀងរាល់ថ្ងៃតាមជំនឿ ("អាម៉ែន") នៃធម៌ប្រកាសជំនឿនៃពិធីជ្រមុជទឹករបស់យើង៖

> សូមឲ្យធម៌ជឿរបស់អ្នកដូចជាកញ្ចក់។ ចូរឆ្លុះខ្លួនដើម្បីដឹងថា តើអ្នកជឿអ្វីដែលអ្នកប្រកាស ហើយចូរមានចិត្តសប្បាយរីករាយជារៀងរាល់ថ្ងៃ ព្រោះតែជំនឿរបស់អ្នក (សន្ត: អូគូស្តាំង)។

១០៦៥-ព្រះយេស៊ូគ្រីស្តផ្ទាល់ជា "ព្រះអាម៉ែន" (វវ ៣,១៤)។ ព្រះអង្គជា "អាម៉ែន" ជាស្ពានរនៃសេចក្តីស្រឡាញ់របស់ព្រះបិតាចំពោះយើង ព្រះអង្គក៏ទទួលយក និងបង្ហើយការ "អាម៉ែន" របស់យើងចំពោះព្រះបិតា៖ "ព្រះគ្រីស្តបានធ្វើឲ្យព្រះបន្ទូលសន្យាទាំងប៉ុន្មានរបស់ព្រះជាម្ចាស់បានសម្រេចសព្វគ្រប់ទាំងអស់។ ហេតុនេះហើយបានជាយើងពោលពាក្យ "អាម៉ែន" ទៅកាន់ព្រះជាម្ចាស់តាមរយៈព្រះគ្រីស្ត ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ" (២ករ ១,២០)។

ឱព្រះបិតាដ៏មានតេជានុភាពសព្វប្រការ គឺដោយព្រះគ្រីស្តជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្តរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង បានជាយើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គអស់កល្បជាអង្វែងតរៀងទៅ។

អាម៉ែន។

# វគ្គទីពីរ៖

# ការលើកតម្កើង

# គម្រោងការដ៏អស្ចារ្យ

# នៃគ្រីស្ទសាសនា

## ហេតុអ្វីបានជាមានពិធីបុណ្យ?

១០៦៦-ក្នុងធម៌ប្រកាសជំនឿ ព្រះសហគមន៍ប្រកាសអំពីគម្រោងការក៏លាក់កំបាំងនៃព្រះត្រៃឯក និង "ព្រះបំណងដ៏សប្បុរស" (អភ ១,៩) របស់ព្រះអង្គលើសត្វលោកទាំងអស់ គឺព្រះបិតាបំពេញ "គម្រោងការដ៏លាក់កំបាំងនៃព្រះហឫទ័យរបស់ព្រះអង្គ" ដោយប្រគល់ព្រះបុត្រាដ៏ជាទីស្រឡាញ់ និងព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ ដើម្បីសង្គ្រោះពិភពលោក និងដើម្បីសិរីរុងរឿងនៃព្រះនាមព្រះអង្គ។ នេះគឺជាគម្រោងការដ៏លាក់កំបាំងនៃព្រះគ្រីស្ត (អភ ៣,៤) ដែលព្រះជាម្ចាស់បានសម្តែង និងបានសម្រេចនៅក្នុងប្រវត្តិសាស្ត្រតាមផែនការណ៍ តាម "គម្រោងការ" ច្បាស់លាស់ ដែលសន្ទះ ប៉ូល ហៅថា "ការចាត់ចែងគម្រោងការដែលលាក់ទុក" (អភ ៣,៩) ហើយដែលប្រពៃណីនៃគ្រូបាធ្យាយនឹងហៅថា "ការចាត់ចែងនៃព្រះបន្ទូលប្រសូតជាមនុស្ស" ឬ "ការចាត់ចែងនៃការសង្គ្រោះ"។

១០៦៧-"ព្រះគ្រីស្តជាព្រះអម្ចាស់បានរំដោះមនុស្សលោកជាសូរេច និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់យ៉ាងពេញលក្ខណៈទៀតផង ដោយមានកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ នៅក្នុងប្រជាជននៃសម្ព័ន្ធមេត្រីចាស់បានរៀបចំទុកជាមុន។ ព្រះគ្រីស្តបានបំពេញព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ដោយគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លងគឺព្រះអង្គបានរងទុក្ខលំបាក មានព្រះជន្មថ្មីពីក្នុងចំនោមមនុស្សស្លាប់ និងបានយាងទៅស្ថានលើយ៉ាងរុងរឿង។ ដោយសារព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ព្រះអង្គ "បានកម្ទេចបំផ្លាញអំណាចនៃសេចក្តីស្លាប់របស់មនុស្សយើងដោយទ្រង់សោយទិវង្គត ហើយទ្រង់ក៏កែទម្រង់ជីវិតឲ្យបានជាថ្មីឡើងវិញ ដោយទ្រង់មានព្រះជន្មថ្មី"។ "ព្រះសហគមន៍ទាំងមូល ដែលជាអគ្គសញ្ញាដ៏ប្រសើរអស្ចារ្យយ៉ាងក្រៃលែង" ក៏កើតចេញមកពីរមុខរបួសត្រង់ចន្លោះឆ្អឹងជំនីររបស់ព្រះអង្គដែលផ្ទុំលក់លើឈើឆ្កាង។ ស្នាព្រះហស្តដ៏អស្ចារ្យដែលព្រះជាម្ចាស់បានប្រព្រឹត្តក្នុងចំណោមប្រជារាស្ត្រនៃសម្ពន្ធមេត្រីចាស់ ក៏សុទ្ធសឹងតែជាប្រផ្នូលអំពីព្រឹត្តិការណ៍ដ៏អស្ចារ្យនេះដែរ" (SC ៥)។ ហេតុនេះហើយបានជាក្នុងពិធីបុណ្យ ព្រះសហគមន៍លើកតម្កើងជាពិសេសគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ដែលបានបំពេញព្រះរាជកិច្ចនៃការសង្គ្រោះរបស់យើង ដោយសោយទិវង្គត និងមានព្រះជន្មថ្មី។

១០៦៨-ក្នុងពិធីបុណ្យ ព្រះសហគមន៍ប្រកាស និងលើកតម្កើងគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្តនេះ ដើម្បីឲ្យគ្រីស្តបរិស័ទរួមជាមួយព្រះអង្គ និងផ្តល់សក្ខីភាពអំពីព្រះអង្គក្នុងពិភពលោក៖

> ដោយសារពិធីបុណ្យនានា ជាពិសេសដោយសារសក្ការបូជាអរព្រះគុណ (ពោលគឺអភិបូជា) "ព្រះជាម្ចាស់រំដោះយើង"។ ពិធីបុណ្យទាំងនោះក៏ជួយយ៉ាងខ្ពង់ខ្ពស់បំផុតឲ្យគ្រីស្តបរិស័ទប្រកាសជំនឿតាមការរស់នៅរបស់គេ និងសម្តែងឲ្យអ្នកដទៃស្គាល់គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ព្រមទាំងស្គាល់លក្ខណៈដ៏ពិតប្រាកដរបស់ព្រះសហគមន៍ទៀតផង (SC ២)។

## តើពាក្យ "ពិធីបុណ្យ" មានអត្ថន័យយ៉ាងដូចម្តេច?

១០៦៩-តាមអត្ថន័យដើមពាក្យ "ពិធីបុណ្យ" មានន័យថា "កិច្ចការជាសាធារណៈ" "កិច្ចបម្រើពី ឬចំពោះប្រជាជន"។ តាមប្រពៃណីនៃគ្រីស្តសាសនា ពាក្យនេះ មានន័យថា ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ចូលរួមចំណែកក្នុង "កិច្ចការរបស់ព្រះជាម្ចាស់" (យហ ១៧,៤)។ តាមពិធីបុណ្យ ព្រះគ្រីស្តជាព្រះសង្គ្រោះ និងជាមហាបូជាចារ្យបន្តព្រះរាជកិច្ចសង្គ្រោះយើង ក្នុងព្រះសហគមន៍ ជាមួយព្រះសហគមន៍ និងតាមរយៈព្រះសហគមន៍៖

> ១០៧០-ក្នុងសម្ព័ន្ធមេត្រីថ្មី គេប្រើពាក្យ "ពិធីបុណ្យ" មិនគ្រាន់តែដើម្បីសំដៅលើពិធីលើកតម្កើងព្រះជាម្ចាស់ប៉ុណ្ណោះទេ (កក ១៣,២; លក ១,២៣) ថែមទាំងសំដៅលើការប្រកាសដំណឹងល្អ (រម ១៥,១៦; ភីល

២,១៤-១៧.៣០) និងកិច្ចការនៃសេចក្តីស្រឡាញ់ដែរ (រម ១៥,២៧; ២ករ ៩,១២ ភីល ២,២៥)។ ក្នុងស្ថានការណ៍ទាំងអស់នោះ ពិធីបុណ្យសំដៅទៅលើកិច្ចបម្រើរបស់ព្រះជាម្ចាស់ និងរបស់មនុស្សលោក។ ក្នុងពិធីបុណ្យ ព្រះសហគមន៍ជាអ្នកបម្រើដូចព្រះអម្ចាស់របស់ខ្លួន ដែលមានតែព្រះអង្គជាអ្នកប្រារព្ធ (ហប ៨,២.៦) ដោយរួមចំណែកជាមួយព្រះអង្គក្នុងមុខងារជាបូជាចារ្យ (ពិធី) ជាព្យាការី (ការប្រកាស) និងជាព្រះមហាក្សត្រ (កិច្ចបម្រើនៃធម៌មេត្តាករុណា)៖

ហេតុនេះហើយបានជាត្រូវចាត់ទុកយ៉ាងត្រឹមត្រូវថា ព្រះយេស៊ូគ្រីស្តពិតជាបំពេញមុខងារជាបូជាចារ្យដោយសារពិធីបុណ្យនានា។ ដោយព្រះយេស៊ូគ្រីស្តបំពេញមុខងារជាបូជាចារ្យនោះ ព្រះអង្គក៏សម្តែងថាព្រះអង្គប្រោសមនុស្សឲ្យបានវិសុទ្ធ តាមសញ្ញាសម្គាល់ដែលអាចមើលឃើញ ហើយព្រះអង្គប្រោសគេឲ្យបានវិសុទ្ធ តាមរបៀបប្លែកៗពីគ្នា ស្របតាមសញ្ញានីមួយៗទាំងនោះផង។ ដោយព្រះយេស៊ូគ្រីស្តបំពេញមុខងារជាបូជាចារ្យនោះ ព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះអង្គ គឺទាំងព្រះសិរសារ ទាំងសិរីរាង្គ នាំគ្នាគោរពបម្រើព្រះជាម្ចាស់យ៉ាងសាធារណៈ និងយ៉ាងពេញលេញ។ ហេតុនេះហើយបានជាគ្រប់ពិធីបុណ្យនានាជាព្រះរាជកិច្ចរបស់ព្រះគ្រីស្តជាបូជាចារ្យផង និងជាកិច្ចរបស់ព្រះកាយព្រះអង្គផង ពោលគឺរបស់ព្រះសហគមន៍ជាកិច្ចសក្ការៈដ៏ប្រសើរឧត្តុង្គបំផុត គ្មានកិច្ចដ៏សក្ការៈណាមួយផ្សេងទៀតរបស់ព្រះសហគមន៍ ស័ក្តិសិទ្ធិដូច ឬមានកម្រិតដូចបានឡើយ (SC ៧)។

## ពិធីបុណ្យដូចជាប្រភពនៃជីវិត

១០៧១-ពិធីបុណ្យជាព្រះរាជកិច្ចរបស់ព្រះគ្រីស្តផង ជាកិច្ចការនៃព្រះសហគមន៍របស់ព្រះអង្គផង។ ពិធីបុណ្យសម្រេច និងសម្តែងព្រះសហគមន៍ ដូចជាសញ្ញាសម្គាល់ដែលបង្ហាញអំពីការរួបរួមជាមួយព្រះជាម្ចាស់ និងមនុស្សលោក ដោយសារព្រះគ្រីស្ត។ ពិធីបុណ្យធ្វើឲ្យគ្រីស្តបរិស័ទចូលរួមក្នុងជីវិតថ្មីនៃសហគមន៍ បានសេចក្តីថា គ្រីស្តបរិស័ទទាំងអស់ត្រូវតែចូលរួមចំណែកក្នុងពិធីបុណ្យ "ដោយដឹងខ្លួន គឺយល់អត្ថន័យ ចូលរួមយ៉ាងសកម្ម និងតាមរបៀបអាចបង្កើតផលបានទៀតផង" (SC ១១)។

១០៧២-"ពិធីបុណ្យនានាពុំមែនជាសកម្មភាពទាំងមូលរបស់ព្រះសហគមន៍ទេ" (SC ៩)៖ ត្រូវតែប្រកាសដំណឹងល្អ ត្រូវជឿ និងកែប្រែចិត្តគំនិតជាមុនសិន ទើបពិធីបុណ្យអាចផ្តល់បានផលដ៏ល្អក្នុងជីវិតរបស់គ្រីស្តបរិស័ទ ពោលគឺឲ្យគេរស់នៅតាមរបៀបថ្មីក្នុងអង្គព្រះវិញ្ញាណ ឲ្យគេចូលរួមក្នុងបេសកកម្មរបស់ព្រះសហគមន៍ ហើយឲ្យគេជួយបម្រើព្រះសហគមន៍ឲ្យរួមគ្នាជាធ្លុងតែមួយ។

## ការអធិដ្ឋាន និងពិធីបុណ្យ

១០៧៣-ពេលប្រាព្ធពិធីបុណ្យ យើងចូលរួមចំណែកក្នុងការអធិដ្ឋានរបស់ព្រះគ្រីស្តចំពោះព្រះបិតា ក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ។ ពិធីបុណ្យជាប្រភព និងទីចុងក្រោយនៃការអធិដ្ឋាននីមួយៗនៃគ្រីស្តសាសនា។ ដោយសារពិធីបុណ្យ មនុស្សមានទឹកចិត្តចាក់ឫសយ៉ាងមាំមួន (អភ ៣,១៦-១៧) "ក្នុងសេចក្តីស្រឡាញ់ដែលព្រះបិតាបានស្រឡាញ់យើង" (អភ ២,៤) ក្នុងអង្គព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។ ការអធិដ្ឋាននីមួយៗប្រារព្ធ និងរំឭកឡើងវិញ "កិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់" ដដែលនេះ "គ្រប់ពេលវេលាតាមការណែនាំរបស់ព្រះវិញ្ញាណ" (អភ ៦,១៨)។

## ការអប់រំជំនឿ និងពិធីបុណ្យ

១០៧៤-"សកម្មភាពគ្រប់យ៉ាងរបស់ព្រះសហគមន៍ពិតជាតម្រង់ទៅកាន់ពិធីបុណ្យនានាទុកជាកំពូល និងជាប្រភពនៃឫទ្ធានុភាពទាំងស្រុងរបស់ព្រះសហគមន៍ដែរ" (SC ១០)។ ដូច្នេះហើយបានជាពិធីបុណ្យជាឱកាសដ៏ពិសេស ដើម្បីអប់រំជំនឿប្រជាជនរបស់ព្រះជាម្ចាស់។ "ការអប់រំជំនឿជាប់ទាក់ទិននឹងកិច្ចការខាងពិធីបុណ្យ និងខាងអគ្គសញ្ញា ដ្បិតក្នុងអគ្គសញ្ញា ជាពិសេសក្នុងអភិបូជា ព្រះគ្រីស្តយេស៊ូបញ្ចេញសកម្មភាពយ៉ាងពេញលេញដើម្បីផ្លាស់ប្តូរមនុស្សលោក" (សម្តេចប៉ាប យ៉ូហាន ប៉ូលទី២, CT ២៣)។

១០៧៥-ការអប់រំជំនឿខាងពិធីបុណ្យមានគោលដៅបញ្ចូលគ្រីស្តបរិស័ទក្នុងគម្រោងការដ៏លាក់បាំងរបស់ព្រះគ្រីស្ត ("mystagogie") ដោយចាប់ផ្តើមអំពីអ្វីដែលមើលឃើញ ដល់អ្វីដែលមើលមិនឃើញ អំពីអ្វីដែលជាសញ្ញាសម្គាល់ដល់គោលដៅនៃសញ្ញាសម្គាល់នេះ អំពី "អគ្គសញ្ញា" ដល់ "គម្រោងការដ៏លាក់កំបាំង"។ សៀវភៅអប់រំជំនឿតាមភូមិភាគ និងតាមតំបន់ ត្រូវតែយកចិត្តទុកដាក់នឹងការអប់រំជំនឿបែបនេះ។ សៀវភៅនេះចង់បម្រើព្រះសហគមន៍ទាំងមូល ក្នុងការប្រារព្ធពិធីទៅតាមវប្បធម៌ផ្សេងៗពីគ្នា (SC ៣-៤) នឹងណែនាំអំពីអ្វីដែលជាមូលដ្ឋានគ្រឹះ និងជាលក្ខណៈរួមនៃព្រះសហគមន៍ទាំងមូល ដែលទាក់ទងនឹងពិធីបុណ្យ ដូចជាគម្រោងការដ៏លាក់កំបាំង និងដូចជាពិធីលើកតម្កើង (ភាគទីមួយ) ហើយនឹងណែនាំអំពីអគ្គសញ្ញាទាំងប្រាំពីរ និងពិធីផ្សេងៗទៀត (ភាគទីពីរ )។

# ភាគទីមួយ៖

# ការចាត់ចែងនៃអគ្គសញ្ញា

១០៧៦-ថ្ងៃបុណ្យព្រះវិញ្ញាណយាងមក គឺជាថ្ងៃដែលព្រះជាម្ចាស់សម្តែងព្រះសហគមន៍ឲ្យពិភពលោកស្គាល់ដោយទ្រង់ចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ (SC ៦; LG ២)។ ព្រះអំណោយទានរបស់ព្រះវិញ្ញាណចាប់ផ្តើមវេលាថ្មីក្នុងការ "សម្តែងគម្រោងការដ៏លាក់កំបាំង" គឺវេលានៃព្រះសហគមន៍ដែលមានព្រះគ្រីស្តសម្តែង ប្រោសឲ្យស្ថិតនៅ និងផ្តល់ព្រះរាជកិច្ចនៃការសង្គ្រោះ តាមរយៈពិធីបុណ្យ "រហូតដល់ព្រះអង្គយាងមកវិញ" (១ករ ១១,២៦)។ ចាប់ពីវេលានៃព្រះសហគមន៍នេះទៅ ព្រះគ្រីស្តមានព្រះជន្មគង់នៅ និងបញ្ចេញសកម្មភាពក្នុងព្រះសហគមន៍ព្រះអង្គ និងជាមួយព្រះសហគមន៍នេះ តាមរបៀបថ្មី ដែលជាលក្ខណៈពិសេសនៃវេលានេះ។ ព្រះអង្គមានសកម្មភាពតាមរយៈអគ្គសញ្ញា ដែលការបញ្ចូនបន្តរួមនៃបស្ចិម និងបូព៌ាប្រទេស ហៅថា "ការចាត់ចែងនៃអគ្គសញ្ញា"។ ការចាត់ចែងនេះ គឺជាការផ្តល់ (ឬ "ការសម្តែង") ផលនៃគម្រោងការរបស់ព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មី ក្នុងពិធីបុណ្យ "ផ្នែកអគ្គសញ្ញា" នៃព្រះសហគមន៍។

ហេតុនេះហើយបានជាមុនដំបូងត្រូវតែបំភ្លឺ "ការសម្តែងនៃអគ្គសញ្ញា" នេះ (ជំពូកទីមួយ) ដើម្បីឲ្យសភាព និងលក្ខណៈចាំបាច់នៃពិធីបុណ្យលេចឡើងឲ្យកាន់តែច្បាស់ (ជំពូកទីពីរ)។

# ជំពូកទីមួយ៖

# ព្រឹត្តិការណ៍ដ៏អស្ចារ្យអំពីព្រះយេស៊ូគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មីក្នុងវេលានៃព្រះសហគមន៍

## ប្រការទី១៖

## ពិធីបុណ្យជាព្រះរាជកិច្ចនៃព្រះត្រៃឯក

### ១-ព្រះបិតាជាប្រភព និងទីចុងក្រោយនៃពិធីបុណ្យ

១០៧៧-"សូមលើកតម្កើងព្រះជាម្ចាស់ជាព្រះបិតារបស់ព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់នៃយើង ដែលបានប្រោសប្រទានព្រះពរគ្រប់យ៉ាងផ្នែកខាងវិញ្ញាណពីស្ថានបរមសុខមកយើង ក្នុងអង្គព្រះគ្រីស្ត។ ព្រះអង្គបានជ្រើសរើសយើងក្នុងអង្គព្រះគ្រីស្ត តាំងពីមុនកំណើតពិភពលោកមកម្ល៉េះ ដើម្បីឲ្យយើងបានវិសុទ្ធ និងឥតសៅហ្មងនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ព្រោះព្រះអង្គមានព្រះហឫទ័យស្រឡាញ់យើង។ ព្រះអង្គបានតម្រូវយើងទុកជាមុន ឲ្យធ្វើជាបុត្រធីតារបស់ព្រះអង្គ ដោយសារព្រះយេស៊ូគ្រីស្ត ស្របតាមព្រះបំណងដ៏សប្បុរសរបស់ព្រះអង្គ ដើម្បីឲ្យយើងលើកតម្កើងសិរីរុងរឿងនៃព្រះហឫទ័យប្រណីសន្ដោស ដែលទ្រង់បានប្រោសប្រទានមកយើង ក្នុងអង្គព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ" (អភ ១,៣-៦)។

១០៧៨-ការប្រទានពរជាកិច្ចការរបស់ព្រះជាម្ចាស់ ដែលផ្តល់ជីវិត ហើយដែលព្រះបិតាជាប្រភព។ ការប្រទានពររបស់ព្រះអង្គជាព្រះបន្ទូលផង ជាព្រះអំណោយទានផង (**bene-dictio, eu-logia**)។ បើនិយាយអំពីមនុស្សវិញ ពាក្យនេះសំដៅថា មនុស្សក្រាបថ្វាយបង្គំ និងផ្ញើជីវិតទាំងស្រុងចំពោះព្រះជាម្ចាស់ ជាអ្នកបង្កើតគេ ដោយអរព្រះគុណព្រះអង្គផង។

១០៧៩-ចាប់តាំងពីកំណើតរហូតដល់អវសានកាលនៃពិភពលោក ព្រះរាជកិច្ចទាំងមូលរបស់ព្រះជាម្ចាស់ជាព្រះពរមួយ។ ចាប់តាំងពីពាក្យកំណាព្យនៃកំណើតដំបូងនៃពិភពលោករហូតដល់បទចម្រៀងនៃទីក្រុងយេរូសាឡឹមនៅស្ថានបរមសុខ អ្នកនិពន្ធដែលព្រះវិញ្ញាណដ៏វិសុទ្ធបានជួយបំភ្លឺ ប្រកាសអំពីគម្រោងការនៃការសង្គ្រោះដូចជាព្រះពរមួយដ៏អស្ចារ្យយ៉ាងក្រៃលែងរបស់ព្រះជាម្ចាស់។

១០៨០-តាំងពីដើមដំបូងបង្អស់ ព្រះជាម្ចាស់ប្រទានពរដល់សត្វលោកទាំងអស់ ជាពិសេសដល់មនុស្សប្រុស និងមនុស្សស្រី។ សម្ព័ន្ធមេត្រីជាមួយលោកណូអេ និងជាមួយសត្វលោកទាំងអស់ធ្វើឲ្យព្រះពរដែលបង្កើតផលនេះបានកើតជាថ្មី ទោះបីអំពើបាបរបស់មនុស្សលោកបានបណ្តាលដីឲ្យ "ត្រូវបណ្តាសា" ក៏ដោយ។ ក៏ប៉ុន្តែ ចាប់តាំងពីលោក អប្រាហាំ ព្រះពររបស់ព្រះជាម្ចាស់ជ្រាបចូលក្នុងប្រវត្តិសាស្ត្រមនុស្សលោក ដែលតម្រង់ទៅរកសេចក្តីស្លាប់ ដើម្បីឲ្យប្រវត្តិសាស្ត្រនេះងើបឡើងទៅរកមាគ៌ានៃជីវិតវិញ ឡើងទៅឯប្រភពរបស់ខ្លួន៖ ប្រវត្តិសាស្ត្រនៃការសង្គ្រោះចាប់ផ្តើម ដោយសារជំនឿរបស់ "លោកឪពុករបស់អស់អ្នកជឿ" ដែលបានទទួលព្រះពរ។

១០៨១-ព្រះជាម្ចាស់សម្តែងព្រះពរទាំងប៉ុន្មានរបស់ព្រះអង្គតាមហេតុការណ៍ដ៏គួរឲ្យសរសើរ និងដែលជួយសង្គ្រោះផង៖ កំណើតរបស់លោកអ៊ីសាក ការចាកចេញពីប្រទេសអេស៊ីប (បុណ្យចម្លង និងដំណើរឆ្ពោះទៅកាន់សេរីភាព)

ព្រះអំណោយទាននៃទឹកដីសន្យា ការជ្រើសរើសព្រះបាទដាវីឌ វត្តមានរបស់ព្រះជាម្ចាស់ក្នុងព្រះវិហាររបស់ព្រះអង្គ ការនិរទេសដែលបន្សុទ្ធប្រជាជន និងការត្រឡប់មកវិញរបស់ប្រជាជន ដែល "នៅសេសសល់"។ ធម៌វិន័យព្យាការី និងទំនុកតម្កើង ដែលជាគ្រឹះនៃពិធីបុណ្យរបស់ប្រជាជនដែលព្រះជាម្ចាស់បានជ្រើសរើស រំឭកព្រះពររបស់ព្រះអង្គនោះ ហើយឆ្លើយតបនឹងព្រះពរទាំងអស់នោះ ដោយលើកតម្កើង និងអរព្រះគុណព្រះអង្គ។

១០៨២-ក្នុងពិធីបុណ្យព្រះសហគមន៍ ព្រះជាម្ចាស់សម្ដែង និងប្រោសប្រទានព្រះពររបស់ព្រះអង្គឲ្យបានពេញលក្ខណៈ៖ គ្រីស្តបរិស័ទទទួលស្គាល់ និងក្រាបថ្វាយបង្គំព្រះបិតាដូចជាប្រភព និងទីចុងក្រោយរបស់ព្រះពរទាំងឡាយនៃការបង្កើត និងការសង្គ្រោះ។ ក្នុងព្រះបន្ទូលប្រសូតជាមនុស្ស ដែលសោយទិវង្គត និងមានព្រះជន្មថ្មីដើម្បីយើង ព្រះអង្គប្រោសប្រទានព្រះពរគ្រប់បែបយ៉ាងឲ្យយើង ហើយនៅក្នុងអង្គព្រះគ្រីស្ត ព្រះអង្គចាក់បង្ហូរក្នុងចិត្តយើង ព្រះអំណោយទានដែលសរុបអំណោយទានឯទៀតៗ គឺព្រះវិញ្ញាណដ៏វិសុទ្ធ។

១០៨៣-ដូច្នេះហើយបានជាយើងអាចយល់អំពីលក្ខណៈពីរយ៉ាងនៃពិធីបុណ្យខាងគ្រីស្តសាសនា ដែលជាចម្លើយខាងជំនឿ និងខាងសេចក្ដីស្រឡាញ់ចំពោះ "ព្រះពរខាងវិញ្ញាណ" ដែលព្រះបិតាប្រោសប្រទានមកយើង។ ព្រះសហគមន៍ដែលរួមជាមួយព្រះអម្ចាស់របស់ខ្លួន និង "ក្រោមកិច្ចការនៃព្រះវិញ្ញាណដ៏វិសុទ្ធ" (លក ១០,២១) ប្រទានពរដល់ព្រះបិតា "ចំពោះព្រះអំណោយទានដ៏ប្រសើរបំផុតពុំអាចថ្លែងបានរបស់ព្រះអង្គ" (២ករ ៩,១៥) ដោយក្រាបថ្វាយបង្គំ សរសើរ និងអរព្រះគុណព្រះអង្គ។ ម្យ៉ាងទៀត ព្រះសហគមន៍នៅតែថ្វាយ "តង្វាយនៃអំណោយទានរបស់ខ្លួនផ្ទាល់" ចំពោះព្រះបិតា រហូតដល់ព្រះបំណងរបស់ព្រះជាម្ចាស់បានសម្រេច ហើយអង្វរព្រះអង្គចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមកសណ្ឋិតលើព្រះសហគមន៍ លើគ្រីស្តបរិស័ទ និងលើពិភពលោកទាំងមូល រួមជាមួយព្រះគ្រីស្តជាបូជាចារ្យ ដែលបានសោយទិវង្គត និងមានព្រះជន្មថ្មី និងដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណ ដើម្បីឲ្យព្រះពរទាំងអស់នោះ បង្កើតផលនៃជីវិត "ដើម្បីឲ្យយើងលើកតម្កើងសិរីរុងរឿងនៃព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ" (អភ ១,៦)។

## ២-ព្រះរាជកិច្ចរបស់ព្រះគ្រីស្តក្នុងពិធីបុណ្យ

### ព្រះគ្រីស្តដែលបានទទួលសិរីរុងរឿង...

១០៨៤-ចាប់ពីពេលនេះទៅ ដោយ "គង់នៅខាងស្ដាំព្រះបិតា" និងដោយចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ ក្នុងព្រះកាយព្រះអង្គ ដែលជាព្រះសហគមន៍ ព្រះគ្រីស្តមានសកម្មភាពតាមរយៈអគ្គសញ្ញា ដែលព្រះអង្គបានចាត់ចែងដើម្បីប្រោសប្រទានព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ។ អគ្គសញ្ញាជាសញ្ញា (ពាក្យសម្ដី និងកិច្ចការ) ដែលវិញ្ញាណមនុស្សយើងក្នុងបច្ចុប្បន្នកាលអាចដឹងបាន។ អគ្គសញ្ញាបំពេញព្រះហឫទ័យប្រណីសន្ដោស ដែលអគ្គសញ្ញានោះសំដៅទៅលើយ៉ាងស័ក្តិសិទ្ធិ ដោយសារកិច្ចការរបស់ព្រះគ្រីស្ត និងឫទ្ធានុភាពនៃព្រះវិញ្ញាដ៏វិសុទ្ធផង។

១០៨៥-ក្នុងពិធីបុណ្យព្រះសហគមន៍ ព្រះគ្រីស្តបង្ហាញ និងសម្រេចជាពិសេសបុណ្យចម្លងរបស់ព្រះអង្គ។ នៅលើផែនដី ព្រះយេស៊ូប្រកាសដោយសារការប្រៀនប្រដៅរបស់ព្រះអង្គ និងគ្រោងទុកជាមុនដោយសារកិច្ចការរបស់ព្រះអង្គថា ទ្រង់នឹងសោយទិវង្គត និងមានព្រះជន្មថ្មី។ ពេលកំណត់របស់ព្រះអង្គមកដល់ហើយ (យហ ១៣,១; ១៧,១) ទ្រង់ក៏ទទួលហេតុការណ៍តែមួយនៃប្រវត្តិសាស្ត្រ ដែលមិនចេះកន្លងផុតទៅ គឺព្រះយេស៊ូសោយទិវង្គតត្រូវគេបញ្ចុះ មានព្រះជន្មថ្មីពីចំណោមមនុស្សស្លាប់ ហើយគង់ខាងស្ដាំព្រះបិតា "ម្ដងជាការស្រេច" (រម ៦,១០; ហប ៧,២៧; ៩,១២)។ ហេតុការណ៍នេះ ជាហេតុការណ៍ដ៏ពិតប្រាកដ ដែលបានកើតឡើងក្នុងប្រវត្តិសាស្ត្រមនុស្ស

យើង ប៉ុន្តែជាហេតុកាណ៍តែមួយ៖ ហេតុការណ៍ផ្សេងៗទៀតនៃប្រវត្តិសាស្ត្រកើតឡើងតែម្តង ហើយចេះតែកន្លងផុតទៅក្នុងអតីតកាល។ ផ្ទុយទៅវិញ បុណ្យចម្លងរបស់ព្រះគ្រីស្តមិនអាចស្ថិតនៅក្នុងអតីតកាលតែប៉ុណ្ណោះទេ ដ្បិតដោយសោយទិវង្គត ព្រះអង្គបានបំផ្លាញសេចក្តីស្លាប់។ អ្វីៗទាំងអស់ដែលជាលក្ខណៈរបស់ព្រះគ្រីស្ត អ្វីៗទាំងអស់ដែលព្រះអង្គបានប្រព្រឹត្ត និងអ្វីៗទាំងអស់ដែលទ្រង់បានរងទុក្ខលំបាក ដើម្បីមនុស្សទាំងអស់ចូលរួមចំណែកក្នុងព្រះជន្មអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ ហើយស្ថិតលើគ្រប់សម័យកាលទាំងអស់ ដើម្បីឲ្យមានវត្តមានក្នុងបច្ចុប្បន្នកាលនេះ។ ហេតុការណ៍នៃព្រះឈើឆ្កាង និងការមានព្រះជន្មថ្មីស្ថិតនៅជានិច្ច ហើយទាក់ទាញអ្វីៗទាំងអស់ឆ្ពោះទៅជីវិត។

### ...ចាប់តាំងពីព្រះសហគមន៍របស់ក្រុមគ្រីស្តទូត...

១០៨៦-"ព្រះបិតាចាត់ព្រះគ្រីស្តឲ្យយាងមកយ៉ាងណា ព្រះគ្រីស្តផ្ទាល់ក៏ចាត់ក្រុមគ្រីស្តទូតរបស់ព្រះអង្គឲ្យទៅយ៉ាងនោះដែរ។ គ្រីស្តទូតទាំងនោះពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យប្រកាសដំណឹងល្អដល់សត្វលោកទាំងអស់ គឺជូនដំណឹងថា ដោយព្រះបុត្រារបស់ព្រះជាម្ចាស់សោយទិវង្គត និងមានព្រះជន្មថ្មី ព្រះអង្គបានរំដោះយើងឲ្យរួចពីអំណាចរបស់មារសាតាំង និងបានរំដោះយើងឲ្យរួចពីសេចក្តីស្លាប់ ព្រមទាំងចម្លងយើងចូលក្នុងព្រះរាជ្យនៃព្រះបិតារបស់ព្រះអង្គ។ មិនតែប៉ុណ្ណោះសោត គឺព្រះគ្រីស្តចាត់ក្រុមគ្រីស្តទូតឲ្យប្រព្រឹត្តតាមកិច្ចសង្គ្រោះដែលអស់លោកប្រកាសនោះទៀតផង ដោយអស់លោកថ្វាយសក្ការបូជាអរព្រះគុណ និងធ្វើអគ្គសញ្ញានានាដែលជាស្នូលនៃពិធីបុណ្យទាំងអស់" (SC ៦)។

១០៨៧-ហេតុនេះហើយបានជាព្រះគ្រីស្ត ដែលមានព្រះជន្មថ្មី ប្រគល់ឲ្យក្រុមគ្រីស្តទូតអំណាចរបស់ព្រះអង្គដែលអាចប្រោសឲ្យបានវិសុទ្ធ ដោយប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យពួកលោក (យហ ២០,២១-២៣) គឺពួកលោកក្លាយទៅជាសញ្ញាសម្គាល់ខាងផ្នែកអគ្គសញ្ញារបស់ព្រះគ្រីស្ត។ ដោយសារឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដដែលនេះ ពួកលោកប្រគល់អំណាចនេះឲ្យអ្នកបន្តមុខងាររបស់ពួកលោក។ "ការបន្តមុខងារពីក្រុមគ្រីស្តទូត" នេះជារចនាសម្ព័ន្ធនៃជីវិតខាងផ្នែកពិធីបុណ្យរបស់ព្រះសហគមន៍ទាំងមូល ហើយការបន្តមុខងារផ្ទាល់នេះជា "អគ្គសញ្ញា" ដែលយើងបញ្ជូនដោយអគ្គសញ្ញាតែងតាំង។

### ...មានវត្តមានស្ថិតនៅក្នុងពិធីបុណ្យនៃផែនដី...

១០៨៨-"ព្រះគ្រីស្តនៅតែមានវត្តមានក្នុងព្រះសហគមន៍ជានិច្ច ជាពិសេសនៅពេលព្រះសហគមន៍ធ្វើពិធីបុណ្យផ្សេងៗ ដើម្បីឲ្យព្រះអង្គបង្ហើយព្រះរាជកិច្ចដ៏ប្រសើរបំផុតនោះឲ្យបានជាស្ថាពរ។ ព្រះអង្គគង់នៅក្នុងសក្ការបូជានៃអភិបូជា គឺក្នុងរូបបូជាចារ្យជាអ្នកបំពេញមុខងារបម្រើ។ "ព្រះអង្គដែលថ្វាយខ្លួននៅពេលនេះដោយសារមុខងារបម្រើរបស់បូជាចារ្យ ក៏ជាព្រះអង្គដដែលបានបូជាព្រះជន្មនៅលើឈើឆ្កាងដែរ"។ ព្រះអង្គគង់នៅតាមកម្រិតដ៏ខ្ពង់ខ្ពស់បំផុតក្នុងរូបសញ្ញានំ និងស្រា ថ្វាយក្នុងអគ្គសញ្ញាអរព្រះគុណ។ ព្រះអង្គក៏គង់នៅតាមអគ្គសញ្ញានានា ដោយសារឫទ្ធានុភាពរបស់ព្រះអង្គ។ នៅពេលនរណាម្នាក់ធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ គឺព្រះគ្រីស្តហើយផ្ទាល់ជ្រមុជទឹកជូនគេហើយ។ ព្រះអង្គគង់នៅតាមព្រះបន្ទូលព្រះអង្គ ដ្បិតពេលណាគេអានព្រះគម្ពីរនៅក្នុងព្រះសហគមន៍ ពេលនោះគឺព្រះអង្គផ្ទាល់មានព្រះបន្ទូលហើយ។ ពេលព្រះសហគមន៍ទូលអង្វរ និងស្មូតទំនុកតម្កើង ព្រះអង្គក៏គង់នៅទីនោះដែរ ព្រោះព្រះអង្គមានព្រះបន្ទូលសន្យាថា៖ "នៅទីណាមានពីរ ឬបីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ ខ្ញុំក៏ស្ថិតនៅទីនោះជាមួយគេដែរ" (មថ ១៨,២០)" (SC ៧)។

១០៨៩-"ព្រះគ្រីស្តរួបរួមជាមួយនឹងព្រះសហគមន៍គ្រប់ពេលវេលា ដើម្បីបង្ហើយព្រះរាជកិច្ចដ៏ប្រសើរបំផុតនេះ គឺនាំមនុស្សឲ្យលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់យ៉ាងពេញលេញ ព្រមទាំងប្រោសមនុស្សឲ្យបានវិសុទ្ធផង។ ព្រះគ្រីស្តរួបរួមជាមួយនឹងព្រះសហគមន៍ ជាព្រះមហេសីដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ព្រះសហគមន៍អង្វរព្រះអម្ចាស់របស់ខ្លួន ហើយគោរពបម្រើថ្វាយបង្គំព្រះបិតាដែលមានព្រះជន្មគង់នៅជានិច្ចនិរន្ត ដោយសារព្រះអង្គ" (SC ៧)។

### ... ដែលចូលរួមចំណែកក្នុងពិធីបុណ្យនៃស្ថានបរមសុខ

១០៩០-"ពេលយើងចូលរួមធ្វើពិធីបុណ្យនានាក្នុងលោកនេះ យើងក្រេបជញ្ជក់ជាមុននូវរសជាតិនៃពិធីបុណ្យនានា នៅបុរីយេរូសាឡឹមដ៏វិសុទ្ធនៃលោកខាងមុខ។ យើងកំពុងតែយាត្រាធ្វើបូជនីយេសចរណ៍ក្នុងលោកនេះតម្រង់ទៅបូរីនោះ ជាបូរីព្រះគ្រីស្តគង់ខាងស្តាំព្រះបិតា ក្នុងឋានៈជាអ្នកបម្រើព្រះវិហារដ៏សក្ការៈ និងព្រះពន្លាដ៏ពិតប្រាកដ។ យើងក៏ច្រៀងបទលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់រួមជាមួយកងកម្លាំងនៃស្ថានបរមសុខដែរ។ ដោយនឹកគោរពសន្តបុគ្គលទាំងឡាយ យើងសង្ឃឹមថា នឹងបានចូលរួមជាមួយដែរ។ យើងក៏ទន្ទឹងរង់ចាំព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើងទុកជាព្រះសង្គ្រោះ រហូតដល់ពេលព្រះអង្គដែលជាជីវិតរបស់យើង សម្តែងព្រះអង្គមក។ នៅពេលនោះ យើងក៏នឹងលេចធ្លោឡើងមក រួមជាមួយព្រះអង្គប្រកបដោយសិរីរុងរឿងដែរ" (SC ៨)។

## ៣-ព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះសហគមន៍ក្នុងពិធីបុណ្យ

១០៩១-ក្នុងពិធីបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធជាគ្រូណែនាំប្រជាជនរបស់ព្រះជាម្ចាស់ឲ្យផ្ញើជីវិតទាំងស្រុងលើព្រះអង្គ និងជាសិប្បករនៃ "ស្នាព្រះហស្តរបស់ព្រះជាម្ចាស់" ដែលជាអគ្គសញ្ញានៃសម្ពន្ធមេត្រីថ្មី។ ព្រះវិញ្ញាណដែលគង់នៅក្នុងព្រះសហគមន៍មានព្រះហឫទ័យ និងព្រះរាជកិច្ចប្រោសយើងឲ្យរួមរស់ជាមួយព្រះគ្រីស្តដែលមានព្រះជន្មថ្មី។ នៅពេលដែលព្រះអង្គជួបក្នុងចិត្តយើងចម្លើយនៃជំនឿ ដែលព្រះអង្គបានជំរុញយើងក៏រួមសហការជាមួយព្រះអង្គយ៉ាងពិតប្រាកដ។ ដោយសារជំនឿ ពិធីបុណ្យក្លាយទៅជាកិច្ចការរួមរបស់ព្រះវិញ្ញាណដ៏វិសុទ្ធផង និងព្រះសហគមន៍ផងដែរ។

១០៩២-ព្រះវិញ្ញាណដ៏វិសុទ្ធមានសកម្មភាពតាមរបៀបដដែល ដូចនៅក្នុងវេលាផ្សេងទៀតនៃការចាត់ចែងអំពីការសង្គ្រោះ ក្នុងការសម្តែងអគ្គសញ្ញានៃគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត គឺព្រះអង្គរៀបចំព្រះសហគមន៍ឲ្យជួបព្រះអម្ចាស់របស់ខ្លួន ព្រះអង្គរំឭក និងសម្តែងព្រះគ្រីស្តឲ្យអង្គប្រជុំផ្ញើជីវិតលើព្រះអង្គ ដោយឫទ្ធានុភាពដែលប្រែអ្វីៗទាំងអស់ ព្រះអង្គប្រោសគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្តឲ្យស្ថិតនៅក្នុងព្រះសហគមន៍បច្ចុប្បន្នកាលនេះ ទីបំផុតព្រះវិញ្ញាណនៃឯកភាពបង្រួបបង្រួមព្រះសហគមន៍ជាមួយនឹងជីវិត និងបេសកកម្មរបស់ព្រះគ្រីស្ត។

### ព្រះវិញ្ញាណដ៏វិសុទ្ធរៀបចំយើងឲ្យទទួលព្រះគ្រីស្ត

១០៩៣-ព្រះវិញ្ញាណប្រោសនិមិត្តសញ្ញានៃសម្ពន្ធមេត្រីចាស់ ឲ្យកើតជារូបរាងក្នុងការចាត់ចែងខាងផ្នែកអគ្គសញ្ញា។ ដោយសារព្រះជាម្ចាស់ "បានរៀបចំព្រះសហគមន៍របស់ព្រះគ្រីស្តយ៉ាងអស្ចារ្យតាមប្រវត្តិសាស្ត្រប្រជាជនអ៊ីស្រាអែល និងតាមសម្ពន្ធមេត្រីចាស់" (LG ២) ពិធីបុណ្យព្រះសហគមន៍រក្សាទុកចំណុចខ្លះនៃពិធីរបស់សម្ពន្ធមេត្រីចាស់ ដោយចាត់ទុកថា ជាផ្នែកពេញសិទ្ធិ ដែលមិនអាចជំនួសបាននៃពិធីបុណ្យរបស់ខ្លួនផ្ទាល់៖

-ជាពិសេសការអានសម្ពន្ធមេត្រីចាស់

- ការសូត្រទំនុកតម្កើង

-ហើយជាពិសេសទៅទៀត ការរំឭកឡើងវិញនៃហេតុការណ៍ដែលជួយសង្គ្រោះ និងតថភាពដ៏មានន័យ ដែលគម្រោងការរបស់ព្រះគ្រីស្តបានបំពេញ (ព្រះបន្ទូលសន្យា និងសម្ព័ន្ធមេត្រីដំណើរឆ្ពោះទៅកាន់សេរីភាព និងបុណ្យចម្លង ព្រះរាជ្យ និងព្រះវិហារ ការនិរទេស និងការត្រឡប់មកវិញ)។

១០៩៤-ការអប់រំជំនឿនៃបុណ្យចម្លងរបស់ព្រះអម្ចាស់ (លក ២៤,១៣-៤៩) ការអប់រំជំនឿរបស់ក្រុមគ្រីស្តទូត និងរបស់គ្រូបាធ្យាយព្រះសហគមន៍សំអាងទៅលើភាពសុខដុមនៃសម្ព័ន្ធមេត្រីទាំងពីរនោះ (DV ១៤-១៦)។ ការអប់រំជំនឿនេះ សម្តែងអត្ថន័យចំដែលសម្ព័ន្ធមេត្រីចាស់លាក់ទុក គឺគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត។ ការអប់រំជំនឿនេះ សម្តែងភាពថ្មោងថ្មីនៃព្រះគ្រីស្តចាប់តាំងពីនិមិត្តសញ្ញា ដែលប្រកាសព្រះអង្គទុកជាមុនក្នុងហេតុការណ៍ព្រះបន្ទូល និងនិមិត្តរូបនៃសម្ព័ន្ធមេត្រីដំបូង។ ដោយការអានឡើងវិញ ក្នុងអង្គព្រះវិញ្ញាណនៃសេចក្តីពិតតាមរយៈព្រះគ្រីស្តនេះ ព្រះជាម្ចាស់សម្តែងនិមិត្តសញ្ញានោះឲ្យយើងស្គាល់ (២ករ ៣,១៤-១៦)។ ដូច្នេះ ទឹកជំនន់ និងសំពៅរបស់លោក ណូអេ ពពក និងការឆ្លងសមុទ្រក្រហម គ្រោងទុកជាមុនការសង្គ្រោះដោយពិធីបុណ្យជ្រមុជទឹក (១ពត្រ ៣,២១) ហើយទឹកនៃផ្ទាំងថ្មជានិមិត្តសញ្ញានៃព្រះអំណោយទានផ្នែកវិញ្ញាណរបស់ព្រះគ្រីស្ត (១ករ ១០,១-៦)។ ឯនំម៉ាណានៅវាលរហោស្ថានវិញ ជានិមិត្តរូបឲ្យដឹងជាមុនអំពីអភិបូជាដែលជា "អាហារដ៏ពិតប្រាកដចុះពីស្ថានបរមសុខមក" (យហ ៦,៣២)។

១០៩៥-ហេតុនេះហើយបានជាពិសេសពេលរដូវរង់ចាំ រដូវអប់រំពិសេស និងរាត្រីបុណ្យចម្លង ព្រះសហគមន៍អាន និងរួមជាមួយហេតុការណ៍ដ៏អស្ចារ្យរបស់ប្រវត្តិសាស្ត្រនៃការសង្គ្រោះឡើងវិញ ក្នុង "បច្ចុប្បន្នកាល" នៃពិធីបុណ្យរបស់ខ្លួន។ ប៉ុន្តែ ការអប់រំជំនឿត្រូវតែជួយគ្រីស្តបរិស័ទឲ្យយល់ច្បាស់ "ខាងវិញ្ញាណ" អំពីការចាត់ចែងនៃការសង្គ្រោះ ដូចពិធីបុណ្យព្រះសហគមន៍សម្តែងឲ្យយើងដឹង និងឲ្យយើងរួមជាមួយផង។

១០៩៦-ពិធីបុណ្យខាងសាសនាយូដា និងពិធីបុណ្យខាងគ្រីស្តសាសនា។ បើយើងស្គាល់កាន់តែច្បាស់អំពីជំនឿ និងសាសនារបស់ប្រជាជនយូដា ដែលគេនៅតែប្រកាស និងប្រតិបត្តិតាមរហូតមកដល់សព្វថ្ងៃនេះ យើងក៏អាចយល់អំពីលក្ខណៈខ្លះនៃពិធីបុណ្យរបស់គ្រីស្តសាសនាកាន់តែច្បាស់ជាងមុនដែរ។ សម្រាប់ជនជាតិយូដា និងគ្រីស្តបរិស័ទ ព្រះគម្ពីរដ៏វិសុទ្ធជាផ្នែកចាំបាច់នៃពិធីបុណ្យ គឺដើម្បីប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឆ្លើយតបនឹងព្រះបន្ទូលនេះ ការលើកតម្កើងសរសើរ និងការជួយអង្វរសម្រាប់មនុស្សទាំងរស់ ទាំងស្លាប់ ហើយដើម្បីឲ្យធម៌មេត្តាករុណារបស់ព្រះជាម្ចាស់យាងមកជួយ។ ក្នុងរចនាសម្ព័ន្ធរបស់ខ្លួនផ្ទាល់ ពិធីលើកតម្កើងព្រះបន្ទូលមានប្រភពចេញមកពីការអធិដ្ឋានរបស់ជនជាតិយូដា។ ការអធិដ្ឋានតាមពេលកំណត់ និងអត្ថបទផ្សេងៗទៀត ហើយមូលដ្ឋានគ្រឹះនៃការអធិដ្ឋានដ៏ប្រសើរខ្លះរបស់យើង ព្រមទាំង "ឱព្រះបិតានៃយើងខ្ញុំ" មានក្នុងការអធិដ្ឋានរបស់ជនជាតិយូដាដែរ។ គំរូខ្លះរបស់ប្រពៃណីខាងពិធីបុណ្យនៃជនជាតិយូដាបំភ្លឺធម៌អរព្រះគុណផងដែរ។ យើងអាចយល់កាន់តែច្បាស់អំពីទំនាក់ទំនង និងភាពផ្សេងពីគ្នានៃពិធីបុណ្យខាងសាសនាយូដា និងខាងគ្រីស្តសាសនា ក្នុងបុណ្យធំៗនៃពិធីបុណ្យប្រចាំឆ្នាំ ដូចជាបុណ្យចម្លង។ គ្រីស្តបរិស័ទ និងជនជាតិយូដាប្រារព្ធពិធីបុណ្យចម្លង គឺបុណ្យចម្លងនៃប្រវត្តិសាស្ត្រ សម្រាប់ជនជាតិយូដាដែលកំពុងរង់ចាំអនាគត បុណ្យចម្លងដែលបានកើតឡើងរួចហើយក្នុងព្រះគ្រីស្តដែលបានសោយទិវង្គត និងមានព្រះជន្មថ្មីសម្រាប់គ្រីស្តបរិស័ទ ទោះបីពួកគេនៅតែរង់ចាំឲ្យបុណ្យចម្លងនេះបានសម្រេចឲ្យបានគ្រប់លក្ខណៈយ៉ាងណាក៏ដោយ។

១០៩៧-ក្នុងពិធីបុណ្យនៃសម្ព័ន្ធមេត្រីថ្មី កិច្ចការខាងពិធីបុណ្យនីមួយៗ ជាពិសេសការប្រារព្ធពិធីអភិបូជា និងអគ្គសញ្ញានានា ដូចជាការជួបជុំគ្នានៃព្រះគ្រីស្ត និងព្រះសហគមន៍។ អង្គប្រជុំខាងពិធីបុណ្យរួមជាមួយគ្នាជាធ្លុងតែមួយមកពី "ការរួបរួមនៃព្រះវិញ្ញាណដ៏វិសុទ្ធ" ដែលបង្រួបបង្រួមបុត្រធីតារបស់ព្រះជាម្ចាស់ក្នុងព្រះកាយតែមួយ

របស់ព្រះគ្រីស្ត។ អង្គប្រជុំនេះ ជាអង្គប្រជុំដ៏ប្រសើរក្រៃលែងសម្រាប់មនុស្សជាតិ ទាំងផ្ទៃងពូជសាសន៍ វប្បធម៌ និង សង្គមផង។

១០៩៨-អង្គប្រជុំត្រូវតែរៀបចំខ្លួន ឲ្យជួបនឹងព្រះអម្ចាស់របស់ខ្លួន និងទៅជា "ប្រជាជនដែលបានត្រៀមខ្លួនទុកជាមុន"។ ការរៀបចំចិត្តគំនិតនេះ ជាកិច្ចការរួមរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ និងអង្គប្រជុំ ជាពិសេសរបស់អស់អ្នកដែលបានទទួលមុខងារបម្រើព្រះសហគមន៍។ ការប្រណីសន្ដោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះហឫទ័យជំរុញឲ្យជឿ កែប្រែចិត្តគំនិត និងឲ្យភ្ជាប់នឹងព្រះហឫទ័យរបស់ព្រះបិតា។ ត្រូវតែត្រៀមខ្លួនតាមបែបនេះ ដើម្បីនឹងអាចទទួលព្រះអំណោយទានផ្សេងៗទៀត ដែលពិធីផ្ទាល់ផ្តល់ឲ្យ និងដើម្បីអាចទទួលផលនៃជីវិតថ្មី ដែលពិធីនេះនឹងបង្កើតនៅពេលក្រោយ។

## ព្រះវិញ្ញាណរំឭកនូវគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត

១០៩៩-ក្នុងពិធីបុណ្យ ព្រះវិញ្ញាណ និងព្រះសហគមន៍រួមសហការជាមួយគ្នា ដើម្បីសម្ដែងព្រះគ្រីស្ត និងព្រះរាជកិច្ចរបស់ព្រះអង្គអំពីការសង្គ្រោះ។ ពិធីបុណ្យជាការនឹករឭក អំពីគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ ជាពិសេសក្នុងពិធីអភិបូជា និងតាមលក្ខណៈប្រៀបធៀបក្នុងអគ្គសញ្ញាផ្សេងទៀត។ ព្រះវិញ្ញាណដ៏វិសុទ្ធជាការចងចាំដ៏រស់រវើកនៃព្រះសហគមន៍ (យហ ១៤,២៦)។

១១០០-ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ជាដំបូង ព្រះវិញ្ញាណរំឭកឲ្យអង្គប្រជុំនូវអត្ថន័យនៃហេតុការណ៍ដ៏អស្ចារ្យនៃការសង្គ្រោះ ដោយផ្តល់ជីវិតដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលព្រះអង្គប្រកាស ដើម្បីឲ្យគ្រីស្តបរិស័ទទទួល និងប្រតិបត្តិតាម៖

> ព្រះគម្ពីរដ៏វិសុទ្ធមានមុខងារសំខាន់ណាស់ក្នុងការប្រារព្ធពិធីបុណ្យ។ គេដកស្រង់ពីព្រះគម្ពីរអត្ថបទដែលយើងអាន ហើយដែលធម្មទេសនាពន្យល់ ព្រមទាំងទំនុកតម្កើងដែលយើងសូត្រ។ ការអធិដ្ឋានផ្សេងៗ និងបទចម្រៀងបានផុសចេញក្រោមពន្លឺនៃព្រះគម្ពីរ ហើយកិច្ចការ និងនិមិត្តរូបក៏ទទួលអត្ថន័យពីព្រះគម្ពីរផងដែរ (SC ២៤)។

១១០១-ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រទានឲ្យអ្នកអាន និងអ្នកស្ដាប់ ចេះយល់អត្ថន័យខាងវិញ្ញាណនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមចិត្តគំនិតរៀងៗខ្លួន។ តាមរយៈពាក្យសម្ដី កិច្ចការ និងនិមិត្តរូប ដែលមាននៅក្នុងពិធីមួយ ព្រះអង្គប្រោសគ្រីស្តបរិស័ទ និងអ្នកទទួលមុខងារបម្រើព្រះសហគមន៍ ឲ្យមានទំនាក់ទំនងដ៏រស់រវើកជាមួយព្រះគ្រីស្ត ដែលជាព្រះបន្ទូល និងជារូបតំណាងរបស់ព្រះបិតា ដើម្បីឲ្យពួកគេអាចប្រតិបត្តិក្នុងការរស់នៅរបស់ពួកគេនូវអត្ថន័យដែលគេស្ដាប់ឮ មើលឃើញ និងប្រព្រឹត្តក្នុងពិធីនេះ។

១១០២-"ព្រះបន្ទូលនៃការសង្គ្រោះពង្រឹងជំនឿក្នុងចិត្តគ្រីស្តបរិស័ទ ព្រះបន្ទូលនេះផ្តល់កំណើត និងការលូតលាស់ឲ្យគ្រីស្តបរិស័ទរួបរួមជាមួយគ្នា" (PO ៤)។ ការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនគ្រាន់តែជាការប្រៀនប្រដៅប៉ុណ្ណោះទេ គឺត្រូវតែជឿ ដោយថ្វាយខ្លួន និងធ្វើជីវិតទាំងស្រុងទៅលើព្រះអង្គ ដើម្បីឲ្យសម្ពន្ធមេត្រីរវាងព្រះជាម្ចាស់ និងប្រជារាស្ត្ររបស់ព្រះអង្គកើតជារូបរាង។ ព្រះវិញ្ញាណដ៏វិសុទ្ធដដែលនោះ ប្រោសប្រទានឲ្យជឿ ពង្រឹងជំនឿនេះ និងធ្វើឲ្យជំនឿនេះរីកចម្រើននៅក្នុងសហគមន៍។ អង្គប្រជុំរួបរួមគ្នាជាធ្លុងតែមួយដោយសារជំនឿ។

១១០៣-ធម៌នឹករឭក។ ពិធីបុណ្យតែងតែសំអាងទៅលើកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ក្នុងប្រវត្តិសាស្ត្រ។ "ព្រះអង្គចាត់ចែងការសម្ដែងនេះ ដោយសារព្រឹត្តិការណ៍ និងព្រះបន្ទូលដែលភ្ជាប់ជាមួយគ្នាយ៉ាងជិតស្និទ្ធ (...) រីឯ

ព្រះបន្ទូលវិញ ប្រកាសអំពីស្ពាព្រះហស្តទាំងនោះ និងបកស្រាយគម្រោងការដ៏អស្ចារ្យដែលកប់ទុកក្នុងស្នាព្រះហស្ត ទាំងនោះដែរ" (DV ២)។ ក្នុងពិធីលើកតម្កើងព្រះបន្ទូល ព្រះវិញ្ញាណដ៏វិសុទ្ធ "រំឭក" អង្គប្រជុំនូវអ្វីៗទាំងអស់ដែល ព្រះគ្រីស្តបានប្រព្រឹត្តចំពោះយើង។ ពិធីលើកតម្កើង "នឹករំឭក" នូវកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ក្នុងធម៌នឹក រឭកវែង ឬខ្លីក្តី ទៅតាមលក្ខណៈនៃកិច្ចការខាងពិធីបុណ្យ និងប្រពៃណីរបស់ព្រះសហគមន៍នានា។ ព្រះវិញ្ញាណដ៏ វិសុទ្ធ ដែលដាស់តឿនការចងចាំរបស់ព្រះសហគមន៍ ជំរុញព្រះសហគមន៍ឲ្យអរព្រះគុណ និងសរសើរព្រះជាម្ចាស់ (សេចក្តីចុងក្រោយសរសើរលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់)។

## ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសគម្រោងការដ៏លាក់កំបាំង របស់ព្រះគ្រីស្តឲ្យមានវត្តមានសព្វថ្ងៃនេះ

១១០៤-ពិធីបុណ្យខាងគ្រីស្តសាសនាមិនគ្រាន់តែរំឭកនូវហេតុការណ៍ ដែលបានសង្គ្រោះយើងប៉ុណ្ណោះទេ ថែម ទាំងធ្វើឲ្យហេតុការណ៍ទាំងអស់នោះមានវត្តមានសព្វថ្ងៃផង។ យើងប្រារព្ធគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត ដែលសោយទិវង្គត និងមានព្រះជន្មថ្មី ប៉ុន្តែ យើងមិនធ្វើឲ្យគម្រោងការនេះកើតឡើងវិញទេ គឺយើងប្រារព្ធពិធីទាំង ប៉ុន្មាននោះឡើងវិញ ហើយក្នុងពិធីនីមួយៗព្រះជាម្ចាស់ចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធដែលប្រោសគម្រោងការតែមួយ នេះឲ្យមានវត្តមានសព្វថ្ងៃ។

១១០៥-ដោយសារពិធីអង្វរព្រះវិញ្ញាណ លោកបូជាចារ្យទូលអង្វរព្រះបិតាឲ្យព្រះអង្គចាត់ព្រះវិញ្ញាណ ដែល ប្រោសឲ្យបានវិសុទ្ធ ដើម្បីឲ្យតង្វាយក្លាយទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត ហើយដើម្បីឲ្យគ្រីស្តបរិស័ទ ផ្ទាល់ក្លាយទៅជាតង្វាយដ៏រស់រវើកថ្វាយព្រះជាម្ចាស់ នៅពេលដែលពួកគេទទួលព្រះកាយ និងព្រះលោហិតនោះ។

១១០៦-រួមជាមួយធម៌នឹករឭកពិធីអង្វរព្រះវិញ្ញាណជាស្នូលនៃពិធីខាងអគ្គសញ្ញានីមួយៗ ជាពិសេសពិធីថ្វាយ អភិបូជា៖

> អ្នកសួរថា តើនំប៉័ងក្លាយទៅជាព្រះកាយព្រះគ្រីស្ត ហើយស្រាក្លាយជា (...) ព្រះលោហិតព្រះគ្រីស្តយ៉ាង ដូចម្តេច? ខ្ញុំប្រាប់អ្នកថា៖ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមក និងបំពេញកិច្ចការនេះ ដែលលើសពីពាក្យសម្តី ឬគំនិតទាំងអស់ (...)។ គ្រាន់តែឮថា មកពីព្រះវិញ្ញាណដ៏វិសុទ្ធ ដូចព្រះអម្ចាស់ តាមរយៈព្រះអង្គ និងនៅ ក្នុងអង្គព្រះអង្គ ប្រសូតជាមនុស្សពីព្រហ្មចារីយ៍ដ៏វិសុទ្ធ និងពីព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ បានហើយ (សន្តៈ យ៉ូហាន ដាម៉ាសែន)។

១១០៧-ក្នុងពិធីបុណ្យ ឫទ្ធានុភាពដែលប្រែអ្វីៗទាំងអស់នៃព្រះវិញ្ញាណដ៏វិសុទ្ធ ប្រោសព្រះរាជ្យឲ្យយាងមក និងគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះបានសម្រេចយ៉ាងឆាប់រហ័ស។ ដោយរង់ចាំ និងសង្ឃឹម ព្រះអង្គប្រោស យើងទុកជាមុនឲ្យរួមជាមួយព្រះត្រៃឯកដ៏វិសុទ្ធបានពេញលក្ខណៈ។ ព្រះវិញ្ញាណដែលព្រះបិតាបានចាត់ឲ្យយាង មកស្របតាមពិធីអង្វររបស់ព្រះសហគមន៍ ព្រះអង្គប្រទានជីវិតដល់អស់អ្នកដែលទទួលព្រះអង្គ ហើយទ្រង់ក៏ "បញ្ចាំ ចិត្តយើងឲ្យដឹងថា យើងនឹងទទួលមត៌ក" (អភ ១,១៤; ២ករ ១,២២)។

## ព្រះវិញ្ញាណដ៏វិសុទ្ធដែលប្រោសឲ្យរួមជាមួយគ្នាជាធ្លុងតែមួយ

១១០៨-ក្នុងគ្រប់កិច្ចការខាងពិធីបុណ្យ បេសកកម្មរបស់ព្រះវិញ្ញាណដ៏វិសុទ្ធមានគោលដៅចុងក្រោយឲ្យយើង រួមរស់ជាមួយព្រះគ្រីស្ត ដើម្បីធ្វើជាព្រះកាយព្រះអង្គ។ ព្រះវិញ្ញាណដ៏វិសុទ្ធដូចជាជ័រនៃដើមទំពាំងបាយជូររបស់

ព្រះបិតា ដែលបង្កើតផលក្នុងមែកវា (យហ ១៥,១-១៧; កាឡ ៥,២២)។ ក្នុងពិធីបុណ្យ ព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះសហគមន៍រួមសហការជាមួយគ្នាយ៉ាងស្និទ្ធស្នាលជាទីបំផុត។ ព្រះវិញ្ញាណដែលប្រោសឲ្យរួមរស់ជាមួយគ្នាជាធ្លុងតែមួយ គង់នៅក្នុងព្រះសហគមន៍ផ្ដាច់មិនបាន ហេតុនេះ ព្រះសហគមន៍ជាអគ្គសញ្ញាដ៏ប្រសើររបស់ព្រះជាម្ចាស់ដែលបង្រួបបង្រួមបុត្រធីតារបស់ព្រះអង្គដែលខ្ចាត់ខ្ចាយ។ ក្នុងពិធីបុណ្យ ព្រះវិញ្ញាណបង្កើតផលផ្លែឲ្យយើងចេះរួមរស់ជាមួយព្រះត្រៃឯកដ៏វិសុទ្ធ និងរួមរស់ជាមួយគ្នាដូចជាបងប្អូន ដែលមិនអាចបំបែកពីគ្នាបានឡើយ (១យហ ១,៣-៧)។

១១០៩-ពិធីអង្វរព្រះវិញ្ញាណជាការទូលអង្វរឲ្យអង្គប្រជុំរួមរស់ជាមួយនឹងគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្តឲ្យបានពេញលក្ខណៈដែរ។ "ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ជាព្រះបិតា និងការរួមរស់ជាមួយគ្នាដោយព្រះវិញ្ញាណដ៏វិសុទ្ធផង" (២ករ ១៣,១៣) ត្រូវតែស្ថិតនៅជាមួយយើងជារៀងរហូត និងបង្កើតផលលើសពីពិធីបុណ្យអភិបូជាទៅទៀត។ ដូច្នេះ ព្រះសហគមន៍ទូលអង្វរព្រះបិតាឲ្យព្រះអង្គចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យទ្រង់ប្រោសការរស់នៅរបស់គ្រីស្តបរិស័ទឲ្យបានទៅជាតង្វាយដ៏រស់រវើកថ្វាយព្រះជាម្ចាស់ ដោយប្រែពួកគេឲ្យទៅជារូបតំណាងខាងវិញ្ញាណរបស់ព្រះគ្រីស្ត ដើម្បីឲ្យព្រះសហគមន៍រួមរស់ជាមួយគ្នាជាធ្លុងតែមួយ ហើយដើម្បីឲ្យយើងចូលរួមចំណែកក្នុងបេសកកម្មរបស់ព្រះអង្គ ដោយផ្ដល់សក្ខីភាព និងបម្រើដោយក្ដីស្រឡាញ់។

## សង្ខេប

១១១០-ក្នុងពិធីបុណ្យព្រះសហគមន៍ យើងប្រទានពរ និងក្រាបថ្វាយបង្គំព្រះជាម្ចាស់ ដែលជាប្រភពនៃព្រះអំណោយទានទាំងឡាយនៃការបង្កើត និងការសង្គ្រោះ ដែលបានប្រទានពរឲ្យយើងនៅក្នុងអង្គព្រះបុត្រាព្រះអង្គ ដើម្បីប្រទានព្រះវិញ្ញាណ ដែលប្រោសយើងឲ្យទៅជាបុត្រធីតា។

១១១១-ព្រះរាជកិច្ចរបស់ព្រះគ្រីស្តក្នុងពិធីបុណ្យជាព្រះរាជកិច្ចខាងអគ្គសញ្ញា ដ្បិតឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធប្រោសគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះឲ្យមានវត្តមាន ដ្បិតព្រះកាយព្រះអង្គ ដែលជាព្រះសហគមន៍ដូចជាអគ្គសញ្ញា (សញ្ញាសម្គាល់ និងឧបករណ៍) ដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រទានគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ ដ្បិតតាមរយៈកិច្ចការខាងពិធីបុណ្យ ព្រះសហគមន៍ដែលធ្វើដំណើរចូលរួមក្នុងពិធីបុណ្យនៃស្ថានបរមសុខរួចទៅហើយ។

១១១២-បេសកកម្មរបស់ព្រះវិញ្ញាណដ៏វិសុទ្ធក្នុងពិធីបុណ្យព្រះសហគមន៍ គឺរៀបចំអង្គប្រជុំឲ្យជួបព្រះគ្រីស្ត រំឭក និងសម្ដែងព្រះគ្រីស្តឲ្យអង្គប្រជុំជឿ ធ្វើឲ្យព្រះរាជកិច្ចនៃការសង្គ្រោះរបស់ព្រះគ្រីស្តមានវត្តមានសព្វថ្ងៃ ដោយសារឫទ្ធានុភាពរបស់ព្រះអង្គ ដែលប្រែអ្វីៗទាំងអស់ ហើយធ្វើឲ្យការរួបរួមក្នុងព្រះសហគមន៍បង្កើតផល។

## ប្រការទី២៖

# ព្រឹត្តិការណ៍ដ៏អស្ចារ្យអំពីព្រះយេស៊ូគ្រីស្ត ដែលសោយទិវង្គត និងមានព្រះជន្មថ្មីក្នុងអគ្គសញ្ញានៃព្រះសហគមន៍

១១១៣-ពិធីអភិបូជា និងអគ្គសញ្ញានានាជាស្នូលនៃការរស់នៅទាំងស្រុងរបស់ព្រះសហគមន៍ផ្នែកពិធីបុណ្យ។ ក្នុងព្រះសហគមន៍មានអគ្គសញ្ញាប្រាំពីរ គឺអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្វាស អគ្គសញ្ញាអរព្រះគុណ (អភិបូជា) អគ្គសញ្ញាលើកលែងទោស អគ្គសញ្ញាលាបប្រេងអ្នកជំងឺ អគ្គសញ្ញាតែងតាំង និងអគ្គសញ្ញាអាពាហ៍ពិពាហ៍ (DS ៨៦០; ១៣១០; ១៦០១)។ ក្នុងប្រការនេះ យើងនឹងថ្លែងអំពីលទ្ធិនៃលក្ខណៈរួមរបស់អគ្គសញ្ញាទាំងប្រាំពីរនៃព្រះសហគមន៍។ យើងនឹងថ្លែងអំពីលក្ខណៈរួមទាក់ទងនឹងពិធីបុណ្យនៅជំពូកទី២ ហើយអំពីលក្ខណៈរៀងៗខ្លួននៃអគ្គសញ្ញានីមួយៗនៅជំពូកទី៣។

## ១-អគ្គសញ្ញារបស់ព្រះគ្រីស្ត

១១១៤-"ដោយភ្ជាប់នឹងលទ្ធិនៃព្រះគម្ពីរដ៏វិសុទ្ធ ប្រពៃណីផ្សេងៗដែលមកពីក្រុមគ្រីស្តទូត (...) និងចិត្តគំនិតតែមួយរបស់ពួកលោកអភិបាល" យើងប្រកាសថា "ព្រះអម្ចាស់នៃយើង គឺព្រះយេស៊ូគ្រីស្តបានតែងតាំងអគ្គសញ្ញាទាំងអស់នៃធម៌វិន័យថ្មី" (DS ១៦០០-១៦០១)។

១១១៥-ព្រះបន្ទូល និងកិច្ចការរបស់ព្រះយេស៊ូ ក្នុងជីវិតដ៏លាក់កំបាំង និងជាសាធារណៈរបស់ព្រះអង្គបានជួយសង្គ្រោះរួចទៅហើយ។ ព្រះបន្ទូល និងកិច្ចការទាំងអស់នោះគ្រោងទុកជាមុននូវឫទ្ធានុភាពនៃបុណ្យចម្លងរបស់ព្រះអង្គ ប្រកាស និងរៀបចំនូវអ្វីៗដែលព្រះអង្គនឹងប្រោសប្រទានឲ្យព្រះសហគមន៍ នៅពេលដែលអ្វីៗទាំងអស់នឹងបានសម្រេច។ ព្រឹត្តិការណ៍ដ៏អស្ចារ្យនៃជីវិតរបស់ព្រះគ្រីស្តជាមូលដ្ឋានគ្រឹះនៃអ្វីដែលព្រះគ្រីស្តប្រោសប្រទានសព្វថ្ងៃ ក្នុងអគ្គសញ្ញា តាមរយៈអ្នកទទួលមុខងារបម្រើព្រះសហគមន៍ ដ្បិត "អ្វីដែលមើលឃើញនៅក្នុងអង្គព្រះសង្គ្រោះយើង ស្ថិតនៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ" (សន្តៈ ឡេអុងដ៏ប្រសើរ)។

១១១៦-អគ្គសញ្ញាជា "ឫទ្ធានុភាពចេញពី" (លក ៥,១៧; ៦,១៩; ៨,៤៦) ព្រះកាយព្រះគ្រីស្ត ដែលនៅតែមានព្រះជន្មគង់នៅ និងដែលប្រោសឲ្យមានជីវិត ជាកិច្ចការនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រតិបត្តិក្នុងព្រះកាយព្រះអង្គជាព្រះសហគមន៍ ហើយជា "ស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់" ក្នុងសម្ព័ន្ធមេត្រីថ្មី និងអស់កល្បជានិច្ច។

## ២-អគ្គសញ្ញារបស់ព្រះសហគមន៍

១១១៧-ដោយមានព្រះវិញ្ញាណណែនាំ "ក្នុងសេចក្តីពិតគ្រប់ជំពូក" (យហ ១៦,១៣) ព្រះសហគមន៍បានទទួលស្គាល់បន្តិចម្តងៗកំណប់នេះ ដែលព្រះគ្រីស្តបានប្រោសប្រទានឲ្យ ហើយព្រះសហគមន៍ដែលជាអ្នកបម្រើដ៏ស្មោះត្រង់នៃគម្រោងការដ៏លាក់កំបាំងរបស់ព្រះជាម្ចាស់ (មថ ១៣,៥២; ១ករ ៤,១) បានបញ្ជាក់អំពី "ការសម្តែង" នៃអគ្គសញ្ញានោះ ដូចព្រះសហគមន៍បានធ្វើអំពីបញ្ញត្តិនៃព្រះគម្ពីរដ៏វិសុទ្ធ និងលទ្ធិនៃជំនឿដែរ។ ហេតុនេះហើយបានជាពីសតវត្សមួយទៅសតវត្សមួយ ព្រះសហគមន៍បានយល់ឃើញថា ក្នុងចំណោមពិធីបុណ្យផ្សេងៗ មានពិធីបុណ្យប្រាំពីរ ដែលព្រះអម្ចាស់បានតែងតាំងជាអគ្គសញ្ញា។

១១១៨-អគ្គសញ្ញា "មកពី" ព្រះសហគមន៍បានសេចក្តីថា អគ្គសញ្ញាកើតមាន "តាមរយៈ" និង "សម្រាប់"

ព្រះសហគមន៍។ អគ្គសញ្ញាកើតមាន "តាមរយៈ" ព្រះសហគមន៍ ដ្បិតព្រះសហគមន៍ជាអគ្គសញ្ញានៃកិច្ចការរបស់ព្រះគ្រីស្ត ដែលមានសកម្មភាពក្នុងព្រះសហគមន៍ ដោយសារបេសកកម្មរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ អគ្គសញ្ញាកើតមាន "សម្រាប់" ព្រះសហគមន៍ជាអគ្គសញ្ញាដែល "បង្កើតព្រះសហគមន៍" (សន្តៈ អូគូស្តាំង; សន្តៈ ថូម៉ាស នៃអាកាំង) ដ្បិតអគ្គសញ្ញា ជាពិសេសអភិបូជា សម្តែង និងផ្តល់ឲ្យមនុស្សលោកនូវគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ជាសេចក្តីស្រឡាញ់ គឺមួយជាបីអង្គ។

១១១៩-ដោយទុកព្រះគ្រីស្តជាព្រះសិរសា "ដូចជាបុគ្គលដ៏អាថ៌កំបាំងតែមួយ" (សន្តៈ ពីយូស ទី១២) ព្រះសហគមន៍មានសកម្មភាពក្នុងអគ្គសញ្ញាដូចជា "សហគមន៍ដែលសុទ្ធតែជាបូជាចារ្យ" ដែលមាន "រចនាសម្ព័ន្ធដ៏មានរបៀបរៀបរយ" (LG ១១) គឺដោយអគ្គសញ្ញាជ្រមុជទឹក និងលាបថ្ងាស ប្រជាជនដែលសុទ្ធតែជាបូជាចារ្យមានសិទ្ធិអាចប្រារព្ធពិធីបុណ្យ។ ម្យ៉ាងទៀត គ្រីស្តបរិស័ទខ្លះ "ដែលមានកិត្តិយស ទទួលអគ្គសញ្ញាតែងតាំងជាទីសក្ការៈ គឺគេទទួលការតែងតាំងក្នុងនាមព្រះគ្រីស្ត ដើម្បីទៅជាគង្វាលរបស់ព្រះសហគមន៍ ដោយផ្សព្វផ្សាយព្រះបន្ទូល និងដោយព្រះជាម្ចាស់ប្រោសប្រណីផង" (LG ១១)។

១១២០-អ្នកទទួលមុខងារបម្រើព្រះសហគមន៍ ឬលោកបូជាចារ្យ "សម្រាប់បម្រើ" (LG ១០) ត្រូវបម្រើគ្រីស្តបរិស័ទឯទៀតៗ ដែលសុទ្ធតែជាបូជាចារ្យដោយសារអគ្គសញ្ញាជ្រមុជទឹក។ ហេតុនេះហើយ បានជាក្នុងអគ្គសញ្ញាពិតជាព្រះគ្រីស្តដែលមានសកម្មភាព តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់ព្រះសហគមន៍។ ព្រះជាម្ចាស់បានប្រគល់បេសកកម្មសង្គ្រោះមនុស្សលោក ដែលព្រះបិតាបានប្រទានឲ្យព្រះបុត្រារបស់ព្រះអង្គ ប្រសូតជាមនុស្សឲ្យក្រុមគ្រីស្តទូត និងអ្នកបន្តមុខងារពីអស់លោក គឺអស់លោកទទួលព្រះវិញ្ញាណរបស់ព្រះយេស៊ូ ដើម្បីមានសកម្មភាពក្នុងព្រះនាមព្រះអង្គ និងក្នុងអង្គព្រះអង្គផង (យហ ២០,២១-២៣ ; លក ២៤,៤៧ ; មថ ២៨,១៨-២០)។ ហេតុនេះ អ្នកទទួលមុខងារបម្រើព្រះសហគមន៍ ជាចំណងខាងអគ្គសញ្ញាដែលចងកិច្ចការនៃពិធីបុណ្យ ជាមួយនឹងពាក្យសម្ដី និងកិច្ចការរបស់ក្រុមគ្រីស្តទូត ហើយតាមរយៈពួកលោក ជាមួយព្រះបន្ទូល និងកិច្ចការរបស់ព្រះគ្រីស្ត ដែលជាប្រភព និងជាគ្រឹះនៃអគ្គសញ្ញា។

១១២១-ដោយមិនរាប់អំពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ អគ្គសញ្ញាទាំងបីនៃពិធីជ្រមុជទឹក លាបថ្ងាស និងតែងតាំង ផ្តល់លក្ខណៈ ខាងអគ្គសញ្ញា ឬ "ត្រា" ដែលធ្វើឲ្យគ្រីស្តបរិស័ទចូលរួមចំណែកក្នុងអង្គព្រះគ្រីស្តជាបូជាចារ្យ និងទៅជាសមាជិកព្រះសហគមន៍តាមលក្ខណៈ និងមុខងារផ្សេងៗ។ គឺព្រះវិញ្ញាណដែលប្រោសគ្រីស្តបរិស័ទឲ្យរួមជាមួយព្រះគ្រីស្ត និងព្រះសហគមន៍តាមបែបនេះ ដែលមិនអាចលុបបំបាត់បានទេ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦០៩) ហើយដែលស្ថិតនៅក្នុងពួកគេជារៀងរហូត ដូចជាលក្ខណៈវិជ្ជមានដែលនាំឲ្យព្រះជាម្ចាស់ប្រោសប្រណី ដូចជាព្រះបន្ទូលសន្យារបស់ព្រះអង្គ ដែលធានាការពារថែរក្សាពួកគេដែលទ្រង់ត្រាស់ហៅឲ្យលើកតម្កើងព្រះអង្គ និងបម្រើព្រះសហគមន៍ផង។ ដូច្នេះ យើងមិនអាចផ្តល់អគ្គសញ្ញានោះម្តងទៀតបានទេ។

## ៣-អគ្គសញ្ញានៃជំនឿ

១១២២-ព្រះគ្រីស្តបានចាត់ក្រុមគ្រីស្តទូតឲ្យទៅ "ប្រកាសក្នុងនាមព្រះអង្គ ឲ្យមនុស្សគ្រប់ជាតិសាសន៍កែប្រែចិត្តគំនិត ដើម្បីបានរួចពីបាប" (លក ២៤,៤៧)។ "ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ ឲ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" (មថ ២៨,១៩)។ បេសកកម្មជ្រមុជក្នុងទឹក ទើបបេសកកម្មខាងអគ្គសញ្ញា រួមជាមួយបេសកកម្មប្រកាសដំណឹងល្អ ដ្បិតអគ្គសញ្ញា

នេះ ត្រូវរៀបចំឡើងដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងជំនឿ៖

ជាដំបូង ព្រះបន្ទូលរបស់ព្រះដ៏មានព្រះជន្មគង់នៅប្រមូលប្រជាជនរបស់ព្រះអង្គ (...)។ អ្នកទទួលមុខងារបម្រើព្រះសហគមន៍ ខាងអគ្គសញ្ញាចាំបាច់ត្រូវតែប្រកាសព្រះបន្ទូល ដ្បិតអគ្គសញ្ញានោះ ជាអគ្គសញ្ញានៃជំនឿ ហើយជំនឿនេះត្រូវការព្រះបន្ទូលដើម្បីកើតមក និងរីកចម្រើន (PO ៤)។

១១២៣-"អគ្គសញ្ញាមានគោលដៅនាំឲ្យគ្រីស្តបរិស័ទបានវិសុទ្ធ កសាងព្រះកាយព្រះគ្រីស្ត និងគោរពបម្រើព្រះជាម្ចាស់ទៀតដែរ។ ប៉ុន្តែ ដោយអគ្គសញ្ញាមានលក្ខណៈជាសញ្ញាសម្គាល់ ក៏អគ្គសញ្ញានានាទាក់ទិននឹងការអប់រំជំនឿដែរ។ ដោយមានប្រើពាក្យ និងវត្ថុផ្សេងៗ អគ្គសញ្ញាមិនគ្រាន់តែបញ្ជាក់ជំនឿប៉ុណ្ណោះទេ ប៉ុន្តែ អគ្គសញ្ញាក៏បំប៉នជំនឿ ពង្រឹងជំនឿ និងបង្ហាញបញ្ជាក់ជំនឿអ្នកទទួលនោះថែមទៀតផង។ ហេតុនេះហើយ បានជាយើងធ្លាប់ហៅអគ្គសញ្ញាថា "អគ្គសញ្ញានៃជំនឿ" (SC ៥៩)។

១១២៤-ព្រះសហគមន៍មានជំនឿមុនគ្រីស្តបរិស័ទ និងអញ្ជើញពួកគេឲ្យជឿផងដែរ។ ពេលព្រះសហគមន៍ប្រារព្ធអគ្គសញ្ញា ព្រះសហគមន៍ប្រកាសជំនឿដែលមកពីក្រុមគ្រីស្តទូត។ ហេតុនេះ គេធ្លាប់និយាយតាមពាក្យបុរាណថា៖ "Lex orandi, Lex credendi" (ឬ "Legem credendi Lex statuat supplicandi" តាមលោកព្រ័សពែរ នៃ អគីទែណ [សតវត្សទី៥])។ វិន័យនៃការអធិដ្ឋានជាវិន័យនៃជំនឿ ព្រះសហគមន៍ ជឿដូចព្រះសហគមន៍អធិដ្ឋានដែរ។ ពិធីបុណ្យជាចំណុចសំខាន់ៗនៃការបញ្ជូនបន្តដ៏វិសុទ្ធ និងដ៏រស់រវើក (DV ៨)។

១១២៥-ហេតុនេះហើយ បានជាអ្នកទទួលមុខងារបម្រើព្រះសហគមន៍ ឬសហគមន៍មិនអាចផ្លាស់ប្តូរ ឬប្រើតាមរបៀបខុស ពិធីខាងអគ្គសញ្ញាណាមួយឡើយ។ សូម្បីតែអំណាចដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះសហគមន៍ ក៏មិនអាចផ្លាស់ប្តូរពិធីបុណ្យតាមអំពើចិត្តដែរ គ្រាន់តែដោយស្តាប់បង្គាប់ទៅតាមជំនឿ និងដោយគោរពប្រណិប័តន៍គម្រោងការដ៏អស្ចារ្យនៃពិធីបុណ្យប៉ុណ្ណោះ។

១១២៦-ដោយឡែក ដោយសារអគ្គសញ្ញាសម្តែង និងពង្រឹងព្រះសហគមន៍ឲ្យរួមរស់ជាធ្លុងតែមួយ ក្នុងជំនឿ Lex orandi ជាលក្ខណៈចាំបាច់មួយនៃក្រុមសន្ទនា ដែលមានគោលដៅបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួមជាមួយគ្នាជាធ្លុងតែមួយ (UR ២ ; ១៥)។

## ៤-អគ្គសញ្ញានៃការសង្គ្រោះ

១១២៧-ពេលប្រារព្ធអគ្គសញ្ញាតាមរបៀបសមរម្យ និងទៅតាមជំនឿ អគ្គសញ្ញាផ្តល់ការប្រោសប្រណី ទៅតាមគោលបំណង (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦០៥-១៦០៦)។ អគ្គសញ្ញាមានប្រសិទ្ធិភាព ពីព្រោះព្រះគ្រីស្តផ្ទាល់ចូលរួមក្នុងអគ្គសញ្ញានោះ៖ គឺព្រះអង្គនេះហើយ ដែលជ្រមុជទឹក គឺព្រះអង្គនេះ ដែលមានសកម្មភាពក្នុងអគ្គសញ្ញារបស់ព្រះអង្គ ដើម្បីប្រទានការប្រោសប្រណី ដែលអគ្គសញ្ញាសំដៅទៅលើ។ ព្រះបិតាតែងតែទទួលយកពាក្យអង្វរនៃព្រះសហគមន៍របស់ព្រះបុត្រាព្រះអង្គ ដែលសម្តែងនូវជំនឿរបស់ខ្លួនទៅលើឫទ្ធានុភាពរបស់ព្រះវិញ្ញាណ ក្នុងពាក្យអង្វរឲ្យព្រះវិញ្ញាណយាងមកនៃអគ្គសញ្ញានីមួយៗ។ ដូចភ្លើងប្រែអ្វីៗទាំងអស់យ៉ាងណា ព្រះវិញ្ញាណដ៏វិសុទ្ធ ក៏ប្រែអ្វីដែលនៅក្រោមឫទ្ធានុភាពរបស់ព្រះអង្គ ឲ្យទៅជាព្រះជន្មរបស់ព្រះជាម្ចាស់។

១១២៨-នេះគឺជាការអះអាងរបស់ព្រះសហគមន៍ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦០៨)៖ អគ្គសញ្ញាមានសកម្មភាព ex opere operato (តាមន័យចំ៖ "ដោយសារតែកិច្ចការដែលត្រូវគេបំពេញ") ពោលគឺ ដោយសារព្រះរាជកិច្ចនៃការសង្គ្រោះរបស់ព្រះគ្រីស្ត ដែលបានកើតឡើងម្តងជាការស្រេច បានសេចក្តីថា គឺជា "ឫទ្ធានុភាព

របស់ព្រះជាម្ចាស់ដែលសម្រេចអគ្គសញ្ញានានា មិនមែនសេចក្ដីសុចរិតរបស់មនុស្ស ដែលផ្ដល់ ឬទទួលអគ្គសញ្ញានោះទេ" (សន្ដ: ថូម៉ាស នៃអាកាំង)។ លុះដល់គេប្រារព្ធអគ្គសញ្ញាណាមួយ ស្របតាមបំណងរបស់ព្រះសហគមន៍ ឫទ្ធានុភាពរបស់ព្រះគ្រីស្ដ និងរបស់ព្រះវិញ្ញាណព្រះអង្គមានសកម្មភាពក្នុង និងតាមរយៈអគ្គសញ្ញានេះ ដោយមិនរាប់អំពីភាពដ៏វិសុទ្ធផ្ទាល់របស់អ្នកផ្ដល់អគ្គសញ្ញាឡើយ។ ក៏ប៉ុន្តែ ផលផ្លែនៃអគ្គសញ្ញាអាស្រ័យទៅលើចិត្តគំនិតរបស់អ្នកទទួលដែរ។

១១២៩-ព្រះសហគមន៍អះអាងថា សម្រាប់អ្នកជឿអគ្គសញ្ញានៃសម្ពន្ធមេត្រីថ្មី ជាការចាំបាច់ដើម្បីទទួលការសង្គ្រោះ (មហាសន្និបាតនៅទីក្រុងត្រង់)។ "ការប្រោសប្រណីខាងអគ្គសញ្ញា" ជាការប្រោសប្រណីរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះគ្រីស្ដប្រោសប្រទាន ហើយដែលមានលក្ខណៈពិសេសតាមអគ្គសញ្ញានីមួយៗ។ ព្រះវិញ្ញាណព្យាបាល និងប្រែអស់អ្នកដែលទទួលព្រះអង្គ ដោយប្រោសគេឲ្យរួមជាមួយព្រះបុត្រារបស់ព្រះជាម្ចាស់។ ផលផ្លែនៃជីវិតខាងអគ្គសញ្ញា គឺព្រះវិញ្ញាណប្រោសគ្រីស្ដបរិស័ទឲ្យទៅជាព្រះ (២ពត្រ ១,៤) ដោយប្រោសគេឲ្យរួមជាមួយព្រះបុត្រាតែមួយ ជាព្រះសង្គ្រោះ។

## ៥-អគ្គសញ្ញានៃជីវិតអស់កល្បជានិច្ច

១១៣០-ព្រះសហគមន៍លើកតម្កើងគម្រោងការដ៏អស្ចារ្យនៃព្រះអម្ចាស់របស់ខ្លួន "រហូតដល់ព្រះអង្គយាងមកវិញ" ហើយរហូតដល់ "ព្រះជាម្ចាស់បានគ្រងរាជ្យលើអ្វីៗទាំងអស់គ្រប់ប្រការ" (១ករ ១១,២៦ ; ១៥,២៨)។ ចាប់តាំងពីសម័យរបស់ក្រុមគ្រីស្ដទូត ដោយព្រះវិញ្ញាណស្រែកថ្ងូរក្នុងព្រះសហគមន៍ ព្រះអង្គទាក់ទាញពិធីបុណ្យទៅទីចុងក្រោយរបស់ខ្លួន៖ "ម៉ារ៉ាណាថា!" (១ករ ១៦,២២)។ ហេតុនេះ ពិធីបុណ្យចូលរួមចំណែកក្នុងបំណងប្រាថ្នារបស់ព្រះយេស៊ូ៖ "ខ្ញុំចង់បរិភោគម្ហូបអាហារក្នុងឱកាសបុណ្យចម្លងនេះជាមួយអ្នករាល់គ្នាណាស់! (...) លុះត្រាតែពិធីបុណ្យនេះបានសម្រេចសព្វគ្រប់នៅក្នុងព្រះរាជ្យព្រះជាម្ចាស់" (លក ២២,១៥-១៦)។ ក្នុងអគ្គសញ្ញារបស់ព្រះគ្រីស្ដ ព្រះសហគមន៍ទទួលប្រាកកក់នៃមរតករបស់ខ្លួនហើយ ព្រះសហគមន៍ក៏ចូលរួមចំណែកក្នុងជីវិតអស់កល្បជានិច្ច "ទាំងទន្ទឹងរង់ចាំសុភមង្គលតាមសេចក្ដីសង្ឃឹមរបស់យើង ហើយរង់ចាំព្រះយេស៊ូគ្រីស្ដជាព្រះជាម្ចាស់ដ៏ឧត្ដមបំផុត និងជាព្រះសង្គ្រោះនៃយើងយាងមកប្រកបដោយសិរីរុងរឿង" (ទត ២,១៣)។ "ព្រះវិញ្ញាណ និងភរិយាថ្មោងថ្មីពោលឡើងថា៖ សូមព្រះអង្គយាងមក! (...) ព្រះអម្ចាស់យេស៊ូអើយ សូមយាងមក!" (វវ ២២,១៧.២០)។

> សន្ដ: ថូម៉ាសសង្ខេបលក្ខណៈផ្សេងៗនៃសញ្ញាសម្គាល់របស់អគ្គសញ្ញា៖ "អគ្គសញ្ញាជាសញ្ញាសម្គាល់ដែលរំឭកឡើងវិញនូវអ្វីដែលបានកើតជាមុន គឺទុក្ខលំបាករបស់ព្រះគ្រីស្ដ ដែលសម្ដែងនូវអ្វីដែលកើតឡើងនៅក្នុងខ្លួនយើងដោយសារទុក្ខលំបាករបស់ព្រះគ្រីស្ដ គឺការប្រោសប្រណី ហើយដែលប្រកាសទុកជាមុនសិរីរុងរឿង ដែលនឹងយាងមកក្នុងអនាគត"។

## សង្ខេប

១១៣១-អគ្គសញ្ញាជាសញ្ញាដ៏មានប្រសិទ្ធិភាពនៃព្រះហឫទ័យប្រណីសន្ដោស ដែលព្រះគ្រីស្ដបានចាត់ចែង និងបានប្រគល់ឲ្យព្រះសហគមន៍ ហើយដែលផ្ដល់ព្រះជន្មរបស់ព្រះជាម្ចាស់ឲ្យយើង។ ពិធីដែលមើលឃើញ ដែលប្រារព្ធអគ្គសញ្ញា សំដៅ និងសម្រេចព្រះអំណោយទានផ្សេងៗនៃអគ្គសញ្ញានីមួយៗ។ អគ្គសញ្ញាបង្កើតផលចំពោះអស់អ្នកដែលទទួលអគ្គសញ្ញានោះ ដោយមានចិត្តគំនិតត្រឹមត្រូវ។

១១៣២-ព្រះសហគមន៍ប្រារព្ធអគ្គសញ្ញា ដូចជាសហគមន៍ដែលសុទ្ធតែជាបូជាចារ្យ ដែលមានគ្រីស្តបរិស័ទជាបូជាចារ្យ និងអស់អ្នកដែលមានមុខងារបម្រើព្រះសហគមន៍។

១១៣៣-ព្រះវិញ្ញាណដ៏វិសុទ្ធរៀបចំឲ្យទទួលអគ្គសញ្ញា ដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងជំនឿ ដែលទទួលព្រះបន្ទូលក្នុងចិត្តគំនិតត្រឹមត្រូវ។ នៅពេលនោះ អគ្គសញ្ញាពង្រឹង និងសម្តែងជំនឿ។

១១៣៤-ផលនៃជីវិតខាងអគ្គសញ្ញាជាផលរបស់រៀងៗខ្លួនផង របស់ព្រះសហគមន៍ផង។ សម្រាប់គ្រីស្តបរិស័ទគ្រប់រូប ផលនេះ ជាការរស់នៅដើម្បីព្រះជាម្ចាស់ក្នុងអង្គព្រះគ្រីស្តយេស៊ូ ម្យ៉ាងទៀត សម្រាប់ព្រះសហគមន៍ ផលនេះ ធ្វើឲ្យព្រះសហគមន៍រីកចម្រើនក្នុងសេចក្តីស្រឡាញ់ និងក្នុងបេសកកម្មផ្តល់សក្ខីភាព។

## ជំពូកទីពីរៈ

## ពិធីលើកតម្កើងបុណ្យចម្លងខាងអគ្គសញ្ញា

១១៣៥-ការអប់រំខាងពិធីបុណ្យតម្រូវយើងឲ្យយល់អំពីការចាត់ចែងខាងអគ្គសញ្ញា (ជំពូកទីមួយ)។ ពន្លឺនេះសម្តែងឲ្យយើងស្គាល់ភាពថ្មោងថ្មីនៃពិធីលើកតម្កើង នៃការចាត់ចែងនេះ ។ ដូច្នេះ ក្នុងជំពូកនេះ យើងនឹងថ្លែងអំពីពិធីលើកតម្កើងអគ្គសញ្ញានៃព្រះសហគមន៍។ យើងនឹងរិះគិតអំពីអ្វីដែលមានលក្ខណៈរួមរបស់ពិធីនៃអគ្គសញ្ញាទាំងប្រាំពីរ តាមភាពផ្សេងពីគ្នានៃប្រពៃណីខាងពិធីបុណ្យ ហើយបន្ទាប់មក យើងនឹងថ្លែងអំពីអ្វីដែលមានលក្ខណៈរៀងៗខ្លួន។ ការអប់រំមូលដ្ឋានគ្រឹះនៃពិធីលើកតម្កើងខាងអគ្គសញ្ញានឹងឆ្លើយតបទៅនឹងសំណួរដើមដំបូង ដែលគ្រីស្តបរិស័ទធ្លាប់សួរៈ

- តើនរណាលើកតម្កើង?
- តើត្រូវលើកតម្កើងយ៉ាងដូចម្តេច?
- តើត្រូវលើកតម្កើងនៅពេលណា?
- តើត្រូវលើកតម្កើងនៅឯណា?

## ប្រការទី១ៈ

## ការប្រារព្ធពិធីបុណ្យព្រះសហគមន៍

### ១-តើនរណាលើកតម្កើង?

១១៣៦-ពិធីបុណ្យជា "កិច្ចការ" របស់ "ព្រះគ្រីស្តទាំងស្រុង" (Christus totus)។ ចាប់ពីឥឡូវនេះទៅ អស់អ្នកដែលប្រារព្ធពិធីបុណ្យ ហួសពីសញ្ញាសម្គាល់ផ្សេងៗ ស្ថិតនៅក្នុងពិធីបុណ្យនៃស្ថានបរមសុខរួចទៅហើយ។ នៅទីនោះ គេរួបរួមធ្វើបុណ្យជាមួយគ្នាយ៉ាងសប្បាយរីករាយ។

### អ្នកដែលនាំពិធីបុណ្យនៃស្ថានបរមសុខ

១១៣៧-វិវរណៈរបស់សន្តៈយ៉ូហាន ដែលយើងអានក្នុងពិធីបុណ្យព្រះសហគមន៍ សម្តែងឲ្យយើងដឹងថា "នៅ

ស្ថានបរមសុខ មានបល្ល័ង្កមួយ ហើយមានព្រះមួយអង្គគង់នៅលើបល្លង្កនេះ" (វវ ៤,២) គឺ "ព្រះជាម្ចាស់" (អស ៦,១) (អគ ១,២៦-២៨) ហើយកូនចៀម "ឈរ ដូចជាយញ្ញបូជា" (វវ ៥,៦) (យហ ១,២៩) គឺព្រះគ្រីស្ត ដែលត្រូវគេឆ្កាង និងដែលមានព្រះជន្មថ្មី ជាមហាបូជាចារ្យតែមួយរបស់ទីសក្ការៈដ៏ពិតប្រាកដ (ហប ៤,១៤-១៥; ១០,១៩-២១ ល។ល) ព្រះដដែល "ដែលប្រោសប្រទាន និងដែលថ្វាយខ្លួន" (សន្ធ: យ៉ូហាន គ្រីសូស្តូម) ទីបំផុត ទន្លេដែលមានទឹកផ្ដល់ជីវិតថ្លាដូចកែវចរណៃ ហូរចេញមកពីបល្ល័ង្ករបស់ព្រះជាម្ចាស់" (វវ ២២,១) ជានិមិត្តរូបដ៏ប្រសើរឧត្តមបំផុតនៃព្រះវិញ្ញាណដ៏វិសុទ្ធ (យហ ៤,១០-១៤ ; វវ ២១,៦)។

១១៣៨-ឫទ្ធិអំណាចនៃស្ថានបរមសុខ (វវ ៤-៥ ; អស ៦,២-៣) សត្វលោកទាំងអស់ (សត្វមានជីវិតបួន) អ្នកបម្រើនៃសម្ពន្ធមេត្រីចាស់ និងថ្មី (ព្រឹទ្ធាចារ្យទាំងម្ភៃបួននាក់) ប្រជារាស្ត្រថ្មីរបស់ព្រះជាម្ចាស់ (មនុស្សមួយសែនបួនម៉ឺនបួនពាន់នាក់) (វវ ៧,១-៨ ; ១៤,១) ជាពិសេសមរណសាក្សី "ដែលគេបានប្រហារជីវិត ព្រោះតែព្រះបន្ទូលរបស់ព្រះជាម្ចាស់" (វវ ៦,៩-១១) ហើយព្រះមាតាដ៏វិសុទ្ធបំផុតរបស់ព្រះជាម្ចាស់ (ស្ត្រី (វវ ១២) ភរិយារបស់កូនចៀម (វវ ២១,៩)) ទីបំផុត "មហាជនដ៏ច្រើនកុះករ គ្មាននរណាអាចរាប់ចំនួនបានឡើយ ដែលមកពីគ្រប់ជាតិសាសន៍ គ្រប់កុលសម្ព័ន្ធ គ្រប់ប្រជាជន និងពីគ្រប់ភាសា" (វវ ៧,៩) អ្នកទាំងអស់នោះ ដែលព្រះគ្រីស្តបាន "បង្រួបបង្រួម" ចូលរួមចំណែកក្នុងការបម្រើពិធីលើកតម្កើងព្រះជាម្ចាស់ និងដើម្បីឲ្យគម្រោងការរបស់ព្រះអង្គបានសម្រេច។

១១៣៩-ព្រះវិញ្ញាណ និងព្រះសហគមន៍ធ្វើឲ្យយើងចូលរួមចំណែកក្នុងពិធីបុណ្យនៃស្ថានបរមសុខនេះ នៅពេលដែលយើងលើកតម្កើងគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ ក្នុងអគ្គសញ្ញានានា។

## អ្នកណែនាំពិធីបុណ្យខាងអគ្គសញ្ញា

១១៤០-សហគមន៍ទាំងមូល ដែលជាព្រះកាយព្រះគ្រីស្ត រួបរួមជាមួយប្រធានរបស់ខ្លួន លើកតម្កើងព្រះជាម្ចាស់។ "កិច្ចតាមពិធីបុណ្យនានា មិនមែនជាកិច្ចឯកជនរបស់គ្រីស្តបរិស័ទម្នាក់ៗទេ ប៉ុន្តែ ពិតជាពិធីលើកតម្កើងរួមរបស់ព្រះសហគមន៍ ដែលជា "អគ្គសញ្ញាសម្ដែងអំពីការរួបរួមគ្នាជាធ្លុងតែមួយ" ពោលគឺជាប្រជារាស្ត្រដ៏វិសុទ្ធដែលជួបជុំគ្នា និងដែលមានរបៀបរៀបរយតាមលំដាប់លំដោយ ក្រោមការណែនាំរបស់ក្រុមអភិបាល។ ហេតុនេះហើយ បានជាពិធីបុណ្យនានាទាក់ទិននឹងព្រះកាយនៃព្រះសហគមន៍ទាំងមូល សម្ដែងព្រះកាយនេះឲ្យគេឃើញ ហើយក៏មានឥទ្ធិពលលើព្រះកាយនោះទៀតផងដែរ។ ប៉ុន្តែ ពិធីបុណ្យទាំងនោះមានទំនាក់ទំនងនឹងសិរីរាង្គនីមួយៗ តាមរបៀបផ្សេងៗពីគ្នា គឺតាមការតែងតាំងផ្សេងៗ តាមមុខងារផ្សេងៗ និងតាមរបៀបគេចូលរួមក្នុងពិធីទាំងនោះទៀតផង" (SC ២៦)។ ហេតុនេះហើយ បានជា "តាមលក្ខណៈពិសេសនៃពិធីនីមួយៗ ពេលណាពិធីនានាអាចប្រព្រឹត្តទៅដោយរួបរួមគ្នាបាន ដោយមានគ្រីស្តបរិស័ទចូលរួមជារឿយៗ និងយ៉ាងសកម្មផងនោះ ប្រសិនបើអាចធ្វើបាន ត្រូវគូសបញ្ជាក់ថា ត្រូវចូលចិត្តប្រព្រឹត្តពិធីរួមនោះ ជាងធ្វើពិធីម្នាក់ឯងជាឯកជនទៅទៀត ដែលហាក់ដូចជាពិធីផ្ទាល់ខ្លួនតែម្ដង" (SC ២៧)។

១១៤១-អង្គប្រជុំ ដែលលើកតម្កើងព្រះជាម្ចាស់ ជាសហគមន៍របស់អស់អ្នក ដែលទទួលអគ្គសញ្ញាជ្រមុជទឹក "ដែលបានកើតជាថ្មី និងបានទទួលពិធីអភិសេកពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ទាំងអស់គ្នាបានវិសុទ្ធ ដើម្បីឲ្យទៅជាព្រះដំណាក់ខាងព្រះវិញ្ញាណ និងទៅជាក្រុមបូជាចារ្យដ៏វិសុទ្ធ ដើម្បីថ្វាយនូវកិច្ចការទាំងប៉ុន្មាន ដែលគេធ្វើជារៀងរាល់ថ្ងៃទៅព្រះជាម្ចាស់ ទុកជាសក្ការបូជាខាងព្រះវិញ្ញាណ" (LG ១០)។ ពួកគេជា "ក្រុមបូជាចារ្យ" ដោយទទួលចំណែករួមជាមួយព្រះគ្រីស្ត ដែលជាមហាបូជាចារ្យតែមួយព្រះអង្គគត់ (LG ១០ ; ៣៤ ; PO ២)៖

"ព្រះសហគមន៍ ជាមាតា មានបំណងប្រាថ្នា ចង់ណែនាំគ្រីស្តបរិស័ទទាំងអស់ ឲ្យចូលរួមក្នុងពិធីបុណ្យនានាយ៉ាងពេញលេញ ដោយដឹងខ្លួនយល់អត្ថន័យ និងយ៉ាងសកម្មទៀតផង។ របៀបចូលពីធីបុណ្យបែបនោះ ពិតជាស្របតាមលក្ខណៈផ្ទាល់នៃពិធីបុណ្យទាំងនោះ។ ដោយគ្រីស្តបរិស័ទទទួលអគ្គសញ្ញាជ្រមុជទឹកគេទៅជា "ពូជសាសន៍មួយដែលព្រះអង្គបានជ្រើសរើស ជាក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ ជាជាតិសាសន៍ដ៏វិសុទ្ធ ជាប្រជារាស្ត្រ ដែលព្រះជាម្ចាស់បានយកមកធ្វើជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ" (១ពត្រ ២,៩)" (SC ១៤)។

១១៤២- ប៉ុន្តែ "សិរីរាង្គនីមួយៗមានមុខងារខុសៗគ្នា" (រម ១២,៤)។ ព្រះជាម្ចាស់ត្រាស់ហៅសមាជិកខ្លះក្នុងនិងតាមរយៈព្រះសហគមន៍ ឲ្យបម្រើសហគមន៍តាមរបៀបពិសេស។ អគ្គសញ្ញាតែងតាំងជ្រើសរើស និងញែកអ្នកបម្រើនោះ ដែលមានព្រះវិញ្ញាណដ៏វិសុទ្ធប្រោសគេឲ្យមានសិទ្ធិប្រតិបត្តិក្នុងអង្គព្រះគ្រីស្តជាព្រះសិរសា ដើម្បីបម្រើសមាជិកទាំងអស់របស់ព្រះសហគមន៍ (PO ២ ; ១៥)។ អ្នកដែលទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើដូចជា "រូបតំណាង" របស់ព្រះគ្រីស្តជាបូជាចារ្យ។ ដោយសារអគ្គសញ្ញារបស់ព្រះសហគមន៍សម្តែងខ្លួនឲ្យពេញលក្ខណៈក្នុងពិធីអភិបូជា អ្នកទទួលមុខងារជាលោកអភិបាលលេចឡើងពេលលោកធ្វើអធិបតីក្នុងអភិបូជា ហើយរួមជាមួយលោក អស់លោកបូជាចារ្យ និងអស់លោកឧបដ្ឋាកផងដែរ។

១១៤៣- ដើម្បីបម្រើមុខងាររបស់គ្រីស្តបរិស័ទដែលសុទ្ធតែជាបូជាចារ្យ មានអ្នកទទួលមុខងារពិសេស ផ្សេងទៀត ដែលមិនបានទទួលអគ្គសញ្ញាតែងតាំង ហើយដែលលោកអភិបាលសម្រេចមុខងាររបស់គេនោះ តាមប្រពៃណីខាងពិធីបុណ្យ និងតាមតម្រូវការរបស់ព្រះសហគមន៍ផង។ "អ្នកបម្រើអាសនៈ អ្នកប្រកាសអត្ថបទគម្ពីរ អ្នកអត្ថាធិប្បាយពិធី និងអស់សមាជិកក្រុមច្រៀង គឺសុទ្ធតែបំពេញមុខងារបម្រើពិធីបុណ្យយ៉ាងពិតប្រាកដក មែន" (SC ២៩)។

១១៤៤- ហេតុនេះហើយ បានជាក្នុងពិធីលើកតម្កើងខាងអគ្គសញ្ញា អង្គប្រជុំទាំងមូលជា "អ្នកប្រារព្ធ" ម្នាក់ៗតាមមុខងាររៀងៗខ្លួន ប៉ុន្តែ ក្នុង "ឯកភាពនៃព្រះវិញ្ញាណ" ដែលមានសកម្មភាពក្នុងមនុស្សគ្រប់ៗរូប។ "ពេលធ្វើពិធីបុណ្យផ្សេងៗ ទោះលោកដែលមានមុខងារបម្រើក្តី ទោះគ្រីស្តបរិស័ទក្តី ក៏ម្នាក់ៗត្រូវតែប្រព្រឹត្តតាមតួនាទីរបស់ខ្លួនផ្ទាល់ គឺត្រូវបំពេញភារកិច្ចទាំងមូលរបស់ខ្លួន ប៉ុន្តែត្រូវបំពេញតែភារកិច្ចរបស់ខ្លួនប៉ុណ្ណោះ ស្របតាមលក្ខណៈពិធីនោះ និងតាមសេចក្តីណែនាំពិធីបុណ្យទៀតផងដែរ" (SC ២៨)។

## ២-តើត្រូវលើកតម្កើងយ៉ាងដូចម្តេច?

## សញ្ញាសម្គាល់ និងនិមិត្តរូប

១១៤៥- ពិធីបុណ្យខាងអគ្គសញ្ញាមានសញ្ញាសម្គាល់ និងនិមិត្តរូបជាច្រើន។ តាមគរុកោសល្យរបស់ព្រះជាម្ចាស់ជាព្រះសង្គ្រោះ អត្ថន័យនៃសញ្ញាសម្គាល់ និងនិមិត្តរូបទាំងអស់នោះ ចាក់ឫសក្នុងស្នាព្រះហស្តនៃការបង្កើត និងក្នុងវប្បធម៌របស់មនុស្សលោក បញ្ជាក់ក្នុងហេតុការណ៍នៃសម្ពន្ធមេត្រីចាស់ និងលាតត្រដាងឲ្យបានពេញលក្ខណៈក្នុងព្រះរាជកិច្ច និងក្នុងអង្គព្រះគ្រីស្ត។

១១៤៦- សញ្ញាសម្គាល់នៃពិភពលោករបស់មនុស្ស។ ក្នុងជីវិតរបស់មនុស្ស សញ្ញាសម្គាល់ និងនិមិត្តរូបមានសារៈសំខាន់។ ដោយសារមនុស្សជាបុគ្គលខាងរូបកាយផង ខាងវិញ្ញាណផង គេសម្តែង និងទទួលតថភាពខាងវិញ្ញាណ តាមរយៈសញ្ញាសម្គាល់ និងនិមិត្តរូបដែលមានរូបរាង។ ដោយសារមនុស្សរស់នៅក្នុងសង្គម គេត្រូវការ

សញ្ញាសម្គាល់និងនិមិត្តរូប ដើម្បីទាក់ទងជាមួយអ្នកដទៃ ដូចជាមួយព្រះជាម្ចាស់ផងដែរ តាមភាសា កាយវិការ និងកិច្ចការ។

១១៤៧- ព្រះជាម្ចាស់មានព្រះបន្ទូលមកមនុស្ស តាមរយៈការបង្កើតដែលអាចមើលឃើញ។ ព្រះជាម្ចាស់សម្ដែងសកលលោកឲ្យប្រាជ្ញាមនុស្សយល់នូវស្នាកស្នាមនៃព្រះអង្គជាព្រះបង្កើតគេ (ប្រាញ ១៣,១ ; រម ១,១៩-២០;កក១៤,១៧)។ពន្លឺនិងភាពងងឹត ខ្យល់និងភ្លើង ទឹកនិងដី ដើមឈើនិងផ្លែផ្កា សំដៅទៅលើព្រះជាម្ចាស់ជានិមិត្តរូបនៃភាពថ្កុំថ្កើងរបស់ព្រះអង្គផង ដែលទ្រង់ជិតដិតនឹងមនុស្សផង។

១១៤៨- ដោយសារតថភាព ដែលវិញ្ញាណអាចដឹងបាន ជាសត្វលោក តថភាពនោះអាចសម្ដែងនូវកិច្ចការរបស់ព្រះជាម្ចាស់ដែលប្រោសមនុស្សឲ្យបានវិសុទ្ធ និងសម្ដែងនូវកិច្ចការរបស់មនុស្សដែលថ្វាយបង្គំព្រះជាម្ចាស់។ យ៉ាងណាមិញ សញ្ញាសម្គាល់ និងនិមិត្តរូបនៃការរស់នៅក្នុងសង្គមរបស់មនុស្ស៖ លាងនិងលាប កាច់នំប៉័ង និងប្រទានពែង អាចសម្ដែងនូវវត្តមានរបស់ព្រះជាម្ចាស់ដែលប្រោសឲ្យបានវិសុទ្ធ និងការដឹងគុណរបស់មនុស្សលោកចំពោះព្រះជាម្ចាស់ជាព្រះបង្កើតពួកគេ។

១១៤៩- សាសនាសំខាន់ៗនៃមនុស្សជាតិផ្ដល់សក្ខីភាពថា ពិធីខាងសាសនា ដែលប្រើនិមិត្តរូបជាច្រើន មានអត្ថន័យទាក់ទងនឹងសកលលោកទាំងមូល។ ពិធីបុណ្យព្រះសហគមន៍បានកំណត់ទុកជាមុន បញ្ចូល និងធ្វើឲ្យចំណុចខ្លះៗនៃសកលលោក និងវប្បធម៌របស់មនុស្សបានវិសុទ្ធ ដោយផ្ដល់ឲ្យចំណុចនោះមានសេចក្ដីថ្លៃថ្នូរ ព្រោះបានទៅជាសញ្ញាសម្គាល់នៃការប្រណីសន្ដោស និងរបស់ពិភពលោកថ្មីក្នុងអង្គព្រះយេស៊ូគ្រីស្ដ។

១១៥០- សញ្ញាសម្គាល់នៃសម្ពន្ធមេត្រី។ ប្រជារាស្ដ្រដែលព្រះជាម្ចាស់បានជ្រើសរើសទទួលពីព្រះអង្គ សញ្ញាសម្គាល់ និងនិមិត្តរូបផ្សេងៗពីគ្នាដើម្បីប្រារព្ធពិធីបុណ្យរបស់គេ គឺគេមិនគ្រាន់តែប្រារព្ធសកលលោក និងកាយវិការនៃសង្គមប៉ុណ្ណោះទេ ប៉ុន្ដែ គេប្រារព្ធសញ្ញាសម្គាល់នៃសម្ព័ន្ធមេត្រី និងនិមិត្តរូបនៃកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ចំពោះគេ។ ក្នុងចំណោមសញ្ញាសម្គាល់ខាងពិធីបុណ្យនៃសម្ព័ន្ធមេត្រីចាស់នោះ យើងអាចថ្លែងអំពីពិធីកាត់ស្បែក ការចាក់ប្រេងអភិសេកស្ដេច និងបូជាចារ្យ ពិធីដាក់ដៃ យញ្ញបូជា ហើយជាពិសេសបុណ្យចម្លង។ ព្រះសហគមន៍ចាត់ទុកថា សញ្ញាសម្គាល់ទាំងអស់នោះសម្ដែងទុកជាមុននូវអគ្គសញ្ញានៃសម្ព័ន្ធមេត្រីថ្មី។

១១៥១- ព្រះគ្រីស្ដបានទទួលយកសញ្ញាសម្គាល់នោះ។ ពេលទេសនា ព្រះអម្ចាស់យេស៊ូឧស្សាហ៍ប្រើ សញ្ញាសម្គាល់នៃការបង្កើត ដើម្បីឲ្យគេស្គាល់គម្រោងការដ៏អស្ចារ្យនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ (លក ៨,១០)។ ព្រះអង្គប្រោសឲ្យបានជាសះស្បើយ ឬបញ្ជាក់អំពីធម្មទេសនារបស់ព្រះអង្គ ដោយប្រើសញ្ញាសម្គាល់ ដែលមានរូបរាង ឬកាយវិការជានិមិត្តរូប (យហ ៩,៦ ; មក ៧,៣៣-៣៥ ; ៨,២២-២៥)។ ព្រះអង្គផ្ដល់អត្ថន័យថ្មីដល់ហេតុការណ៍ និងសញ្ញាសម្គាល់នៃសម្ព័ន្ធមេត្រីចាស់ ជាពិសេសអំពីដំណើរឆ្លងទៅកាន់សេរីភាព និងបុណ្យចម្លង (លក ៩,៣១ ; ២២,៧-២០) ដ្បិតព្រះអង្គផ្ទាល់ជាអត្ថន័យនៃសញ្ញាសម្គាល់ទាំងអស់នោះ។

១១៥២- សញ្ញាសម្គាល់ខាងអគ្គសញ្ញា។ ចាប់តាំងពីបុណ្យព្រះវិញ្ញាណយាងមក ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសឲ្យបានវិសុទ្ធ តាមរយៈសញ្ញាសម្គាល់ខាងអគ្គសញ្ញារបស់ព្រះសហគមន៍ព្រះអង្គ។ អគ្គសញ្ញារបស់ព្រះសហគមន៍មិនលុបបំបាត់ទេ ប៉ុន្ដែបន្សុទ្ធ និងទទួលយកលក្ខណៈសម្បត្តិនៃសញ្ញាសម្គាល់ និងនិមិត្តរូបរបស់សកលលោក និងរបស់ការរស់នៅក្នុងសង្គម។ ម្យ៉ាងទៀត អគ្គសញ្ញានោះ បំពេញនិមិត្តសញ្ញានៃសម្ព័ន្ធមេត្រីចាស់ ហើយសំដៅ និងបំពេញការសង្គ្រោះដែលព្រះគ្រីស្ដបានសម្រេច ព្រមទាំងសម្ដែងទុកជាមុនសិរីរុងរឿងនៃស្ថានបរមសុខ។

## ពាក្យសម្ដី និងកិច្ចការ

១១៥៣- ក្នុងពិធីបុណ្យខាងអគ្គសញ្ញា បុត្រធីតារបស់ព្រះជាម្ចាស់ដូចជាជួបជុំជាមួយនឹងព្រះបិតារបស់គេក្នុងអង្គព្រះគ្រីស្ដ និងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទាំងអស់គ្នាដូចជាសន្ទនាជាមួយគ្នា តាមរយៈកិច្ចការ និងពាក្យសម្ដី។ ទោះបីកិច្ចការដែលជានិមិត្តរូប ដូចជាភាសាមួយរួចស្រេចទៅហើយក្ដី ក៏ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងចម្លើយនៃជំនឿ ត្រូវតែកំដរ និងធ្វើឲ្យកិច្ចការនោះមានជីវិត ដើម្បីឲ្យពូជនៃព្រះរាជ្យបង្កើតផលក្នុងដីដ៏មានជីជាតិល្អ។ កិច្ចការខាងពិធីបុណ្យសំដៅនូវអ្វីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្ដែង គឺព្រះជាម្ចាស់យាងមករកមនុស្សដោយមិនគិតអំពីផលប្រយោជន៍ផ្ទាល់ ហើយប្រជារាស្ត្ររបស់ព្រះអង្គឆ្លើយតបនឹងព្រះអង្គ។

១១៥៤- ពិធីលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាផ្នែកដ៏សំខាន់បំផុតនៃពិធីបុណ្យខាងអគ្គសញ្ញា។ ដើម្បីចិញ្ចឹមជំនឿរបស់គ្រីស្ដបរិស័ទ ត្រូវតែលើកតម្កើងសញ្ញាសម្គាល់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់៖ សៀវភៅនៃព្រះបន្ទូល (សៀវភៅអត្ថបទគម្ពីរ ឬសៀវភៅដំណឹងល្អ) ការគោរពសៀវភៅនេះ (ក្បួនហែ កំញាន ពន្លឺ) កន្លែងប្រកាស (តុព្រះបន្ទូល) ត្រូវតែអានឲ្យគេស្ដាប់ឮ និងអាចយល់បាន ធម្មទេសនារបស់អ្នកទទួលមុខងារបម្រើព្រះសហគមន៍ ដែលបន្តការប្រកាសនៃព្រះបន្ទូលនេះ ហើយចម្លើយរបស់អង្គប្រជុំ (សេចក្ដីអបអរសាទរ ទំនុកតម្កើងដើម្បីស្នឹងស្មាធិ៍ ពាក្យសូត្រធម៌ ធម៌ប្រកាសជំនឿ)។

១១៥៥- ពាក្យសម្ដីនិងកិច្ចការខាងពិធីបុណ្យ ដែលជាសញ្ញាសម្គាល់ និងការប្រៀនប្រដៅ មិនអាចបំបែកពីគ្នាបានឡើយ ពីព្រោះពាក្យសម្ដីនិងកិច្ចការនោះ បំពេញអ្វីដែលពាក្យសម្ដីនិងកិច្ចការនោះសំដៅទៅលើ។ ព្រះវិញ្ញាណដ៏វិសុទ្ធ មិនគ្រាន់តែប្រោសប្រទានឲ្យឈ្វេងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយជំរុញឲ្យជឿទេ តាមរយៈអគ្គសញ្ញា ព្រះអង្គក៏សម្រេច "កិច្ចការដ៏អស្ចារ្យ" របស់ព្រះជាម្ចាស់ ដែលព្រះបន្ទូលបានប្រកាសទុកជាមុន គឺព្រះវិញ្ញាណប្រទានព្រះរាជកិច្ចរបស់ព្រះបិតា ដែលព្រះបុត្រាដ៏ជាទីស្រឡាញ់បានសម្រេច ហើយប្រោសព្រះរាជកិច្ចនេះឲ្យមានវត្តមានសព្វថ្ងៃ។

## បទចម្រៀង និងតន្ត្រី

១១៥៦- "ព្រះសហគមន៍សកលមានប្រពៃណីដ៏យូរអង្វែងអំពីភ្លេងដ៏សក្ការៈ ហើយបានប្រមូលបទភ្លេងជាច្រើន ទុកជាកំណប់ដ៏មានតម្លៃខ្ពង់ខ្ពស់បំផុត រកអ្វីមកប្រៀបផ្ទឹមពុំបាន ជាកំណប់ប្រសើរជាងសិល្បៈឯទៀតៗទាំងអស់។ ការណ៍នេះជាពិសេសមកពីភ្លេងដ៏សក្ការៈភ្ជាប់នឹងពាក្យសម្ដី គឺជាផ្នែកដែលត្រូវការជាចាំបាច់នៃពិធីបុណ្យនានាដ៏ឧឡារិក ហើយក៏ពិតជាផ្នែកមួយក្នុងពិធីបុណ្យទាំងនោះទៀតផង" (SC ១១២)។ ការតែងបទចម្រៀង និងការច្រៀងទំនុកតម្កើងដែលព្រះវិញ្ញាណបានបំភ្លឺ ដោយឧស្សាហ៍មានឧបករណ៍ភ្លេងជួយកំដរ ជាប់ទាក់ទិនយ៉ាងស្អិតស្អាលនឹងពិធីបុណ្យនៃសម្ពន្ធមេត្រីចាស់។ ព្រះសហគមន៍បន្ត និងអភិវឌ្ឍប្រពៃណីនេះ៖ "ចូរនិយាយគ្នាទៅវិញទៅមកដោយប្រើទំនុកតម្កើង បទសរសើរព្រះជាម្ចាស់ និងបទចម្រៀងមកពីព្រះវិញ្ញាណ។ ចូរច្រៀង និងលើកតម្កើងព្រះអម្ចាស់ឲ្យអស់ពីចិត្ត" (អភ ៥,១៩) (កូឡ ៣,១៦-១៧)។ "អ្នកណាច្រៀង អ្នកនោះអធិដ្ឋានពីរដង" (សន្តៈ អូគូស្តាំង)។

១១៥៧- បទចម្រៀងនិងតន្ត្រីបំពេញមុខងាររបស់ខ្លួនជាសញ្ញាសម្គាល់ តាមរបៀបកាន់តែប្រសើរ នៅពេលដែល "ជាប់ទាក់ទិននឹងកិច្ចការខាងពិធីបុណ្យយ៉ាងស្អិតស្អាល" (SC ១១២) តាមលក្ខណៈសំខាន់ៗបីយ៉ាង៖ សោភណភាពនៃការអធិដ្ឋាន ការចូលរួមចំណែករបស់អង្គប្រជុំ ដោយមានចិត្តគំនិតតែមួយ និងតាមពេលកំណត់

ហើយលក្ខណៈយ៉ាងឧឡារិកនៃពិធីបុណ្យ។ បទចម្រៀងនិងតន្ត្រីនោះ ចូលរួមចំណែកក្នុងគោលដៅចុងក្រោយនៃពាក្យសម្ដី និងកិច្ចការខាងពិធីបុណ្យ គឺឲ្យព្រះជាម្ចាស់ប្រកបដោយសិរីរុងរឿង និងឲ្យគ្រីស្តបរិស័ទបានវិសុទ្ធ (SC ១១២)៖

ខ្ញុំស្រក់ទឹកភ្នែក វេលាដែលបានឮបទចម្រៀងដ៏ពិរោះស្រទន់ដែលលេចចេញពីក្នុងព្រះសហគមន៍របស់បងប្អូន! គួរឲ្យរំភើបអ្វីម្ល៉េះទេ! បទចម្រៀងនោះ ហូរចូលក្នុងត្រចៀកខ្ញុំ ហើយបញ្ជូនសេចក្ដីពិតទៅក្នុងចិត្តខ្ញុំ។ ពេលនោះ សេចក្ដីអាណិតអាសូរយ៉ាងធំធេងមួយបានផុសចេញនាំយកទឹកភ្នែកមកស្រោចស្រប់ផែនថ្ពាល់ខ្ញុំ ប៉ុន្តែទឹកភ្នែកនោះធ្វើឲ្យខ្ញុំពេញចិត្តណាស់! (សន្តៈ អូគូស្តាំង)។

១១៥៨- បើសញ្ញាសម្គាល់ផ្សេងៗ (បទចម្រៀង តន្ត្រី ពាក្យសន្តិ និងកិច្ចការ) ចេញមកពីទ្រព្យសម្បត្តិខាងវប្បធម៌ ពិសេសនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលលើកតម្កើងព្រះអង្គ សញ្ញាសម្គាល់ទាំងអស់នោះពិតជាបង្ហាញអំពីព្រះជាម្ចាស់ និងបង្កើតផលបានច្រើន (SC ១១៩)។ ហេតុនេះហើយ បានជា "គួរគាំទ្របទភ្លេងសាសនាជាប្រជាប្រិយ ក្នុងពិធីគោរពប្រណិប័តន៍តាមប្រជាប្រិយ និងពិធីដ៏សក្ការៈ ហើយក្នុងពិធីបុណ្យនានាទៀតស្របតាមសេចក្ដីណែនាំ និងបទបញ្ជាព្រះសហគមន៍។ ធ្វើដូច្នេះ ទើបគ្រីស្តបរិស័ទអាចបន្លឺសម្លេងឡើងបាន" (SC ១១៨)។ ក៏ប៉ុន្តែ "អត្ថបទដែលត្រូវភ្ជាប់នឹងសាច់ភ្លេង ត្រូវស្របតាមលទ្ធិកាតូលិក មិនតែប៉ុណ្ណោះសោត គឺត្រូវជ្រើសរើសអត្ថបទយោងចេញពីព្រះគម្ពីរ ឬពីប្រភពនៃពិធីបុណ្យឯទៀតៗផង" (SC ១២១)។

## រូបភាពដ៏វិសុទ្ធ

១១៥៩- ជាធម្មតា រូបជាទីសក្ការៈ ជារូបនៃពិធីបុណ្យ តំណាងព្រះគ្រីស្ត។ រូបនេះមិនអាចតំណាងព្រះ ជាម្ចាស់ដែលមើលមិនឃើញ និងដែលមិនអាចយល់បានទេ។ ដោយសារព្រះបុត្រារបស់ព្រះជាម្ចាស់បានប្រសូតជាមនុស្ស ការ "ចាត់ចែង" ថ្មីនៃរូបភាពនោះបានចាប់ផ្ដើម៖

កាលពីមុន យើងមិនអាចយករូបភាពមួយតំណាងឲ្យព្រះជាម្ចាស់ដែលគ្មានព្រះកាយ ឬព្រះភ័ក្ត្របានទេ។ ប៉ុន្តែ ដោយសារព្រះអង្គបានសម្ដែងព្រះអង្គឲ្យយើងមើលឃើញក្នុងសាច់ ហើយដោយសារព្រះអង្គបានរស់នៅជាមួយមនុស្សលោក ខ្ញុំអាចធ្វើរូបមួយនឹងអ្វីដែលខ្ញុំបានឃើញពីព្រះជាម្ចាស់ (...)។ ដោយគ្មានអ្វីមកបាំងមុខខ្ញុំឡើយ ព្រះអង្គបើកព្រះភ័ក្ត្រឲ្យយើងមើលឃើញសិរីរុងរឿងរបស់ព្រះអម្ចាស់ (សន្តៈ យ៉ូហាន ដាម៉ាសែន)។

១១៦០- សិប្បករគ្រីស្តបរិស័ទបញ្ជូនតាមរូបភាពសារនៃដំណឹងល្អ ដែលព្រះគម្ពីរដ៏វិសុទ្ធបញ្ជូនដោយពាក្យសម្ដី។ រូបភាព និងពាក្យសម្ដីបំភ្លឺគ្នាទៅវិញទៅមក៖

និយាយឲ្យខ្លីអំពីធម៌ប្រកាសជំនឿរបស់យើង យើងរក្សាទុកប្រពៃណីទាំងអស់របស់ព្រះសហគមន៍ដែលជាលាយលក្ខណ៍អក្សរ ឬមិនមែនជាលាយលក្ខណ៍អក្សរ ហើយដែលត្រូវគេបញ្ជូនដោយគ្មានការផ្លាស់ប្ដូរ។ ក្នុងចំណោមប្រពៃណីទាំងអស់នោះ ប្រពៃណីមួយតំណាងដោយរូបភាព ដែលស្របនឹងធម្មទេសនានៃប្រវត្តិរបស់ដំណឹងល្អ ដោយជឿថា ព្រះជាម្ចាស់ជាព្រះបន្ទូលប្រសូតជាមនុស្សពិតប្រាកដមែន មិនមែនតាមលក្ខណៈខាងក្រៅទេ។ ប្រពៃណីនេះ មានប្រយោជន៍ ដ្បិតអ្វីដែលបំភ្លឺគ្នាទៅវិញទៅមក មានអត្ថន័យមួយជាពីរ (មហាសន្និបាតនៅទីក្រុងនិសេ ឆ្នាំ៧៨៧)។

១១៦១-សញ្ញាសម្គាល់ទាំងអស់នៃពិធីបុណ្យសំអាងទៅលើព្រះគ្រីស្ត ដូចរូបភាពដ៏វិសុទ្ធរបស់ព្រះមាតា

ដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ និងរូបរបស់សន្តៈបុគ្គលផងដែរ។ តាមការពិត រូបភាពទាំងអស់នោះ មានន័យថា ព្រះគ្រីស្តទទួលសិរីរុងរឿងនៅក្នុងពួកគាត់។ រូបភាពនោះបង្ហាញ "មនុស្សជាច្រើនឥតគណនាជាបន្ទាល់" (ហប ១២,១) ដែលនៅតែចូលរួមចំណែកក្នុងការសង្គ្រោះនៃពិភពលោក ហើយដែលយើងរួបរួមជាមួយ ជាពិសេសក្នុងពិធីបុណ្យខាងអគ្គសញ្ញា។ តាមរយៈរូបភាពរបស់ពួកគាត់ មនុស្សដែល "ជាតំណាងព្រះជាម្ចាស់" ដែលព្រះអង្គបានប្រែឲ្យមាន "លក្ខណៈដូចព្រះអង្គ" (រម ៨,២៩ ; ១យហ ៣,២) សម្តែងខ្លួនឲ្យយើងជឿ សូម្បីតែពួកទេវទូតក៏ព្រះគ្រីស្តបានបង្រួបបង្រួមដែរ៖

> តាមលទ្ធិរបស់បុព្វបុរសដ៏វិសុទ្ធរបស់យើង ដែលព្រះជាម្ចាស់បានបំភ្លឺ ហើយតាមការបញ្ជូនបន្តនៃព្រះសហគមន៍កាតូលិក ដែលយើងដឹងថា ជាការបញ្ជូនបន្តរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែលតាំងទីលំនៅក្នុងព្រះសហគមន៍នេះ យើងកំណត់ឲ្យច្បាស់លាស់ និងយ៉ាងត្រឹមត្រូវថា រូបភាពដ៏វិសុទ្ធដ៏គួរឲ្យគោរពដូចជាតំណាងទាំងប៉ុន្មាននៃព្រះឈើឆ្កាងដ៏មានតម្លៃ និងដែលផ្តល់ជីវិត ទោះជាត្រូវលាប ឬជារំលេចពណ៌ក្តី ក៏ត្រូវដាក់ ក្នុងព្រះវិហារដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ លើប្រដាប់ប្រដានិងសំលៀកបំពាក់ដ៏សក្ការៈ លើជញ្ជាំង និងលើផ្ទាំងគំនូរ នៅក្នុងផ្ទះក្តី និងនៅតាមផ្លូវក្តី ហើយទោះបីជារូបនៃព្រះអម្ចាស់របស់យើង ព្រះជាម្ចាស់ជាព្រះសង្គ្រោះ គឺព្រះយេស៊ូគ្រីស្ត ឬរូបនៃស្ត្រីរបស់យើង គឺព្រះមាតាដ៏វិសុទ្ធ និងដ៏បរិសុទ្ធបំផុតរបស់ព្រះជាម្ចាស់ រូបរបស់ពួកទេវទូតដ៏វិសុទ្ធ ហើយរបស់សន្តៈបុគ្គល និងមនុស្សសុចរិតទាំងអស់ (មហាសន្និបាតនៅទៅក្រុងនិសេ៖ DS ៦០០)។

១១៦២-"សោភណភាព និងពណ៌នៃរូបភាពជំរុញខ្ញុំឲ្យអធិដ្ឋាន ដូចជាបុណ្យនាំឲ្យសប្បាយភ្នែក ដូចទស្សនីយភាពនៃជនបទជំរុញចិត្តគំនិតខ្ញុំ ឲ្យលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់" (សន្តៈ យ៉ូហាន ដាម៉ាសែន)។ ការមើលឃើញរូបដ៏វិសុទ្ធ រួបរួមជាមួយនឹងការស្ទឹងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងបទចម្រៀងក្នុងពិធីបុណ្យចូលក្នុងភាពសុខដុមនៃសញ្ញាសម្គាល់របស់ពិធីលើកតម្កើង ដើម្បីឲ្យគម្រោងការ ដែលយើងប្រារព្ធជ្រាបចូលក្នុងចិត្តគំនិត និងបញ្ចេញក្នុងជីវិតថ្មីរបស់គ្រីស្តបរិស័ទ។

## ៣-តើត្រូវលើកតម្កើងនៅពេលណា?

### ពេលានៃពិធីបុណ្យ

១១៦៣- "ព្រះសហគមន៍ជាព្រះមាតាដ៏វិសុទ្ធរបស់យើងយល់ឃើញថា មានភារកិច្ចលើកតម្កើងកិច្ចសង្គ្រោះដែលព្រះគ្រីស្តជាព្រះស្វាមីបានសម្រេច ដោយចាត់ចែងពិធីនឹករឭក តាមថ្ងៃកំណត់ក្នុងអំឡុងពេលអស់មួយឆ្នាំតៗគ្នាមក។ រៀងរាល់ថ្ងៃអាទិត្យ នៅថ្ងៃដែលព្រះសហគមន៍ហៅថា "ថ្ងៃរបស់ព្រះអម្ចាស់" ព្រះសហគមន៍នឹករឭកដល់ព្រះអម្ចាស់មានព្រះជន្មថ្មី ដូចព្រះសហគមន៍ធ្លាប់លើកតម្កើងមួយឆ្នាំម្តងៗ ទាំងនឹករឭកដល់ព្រះអង្គរងទុក្ខលំបាកដ៏ប្រសើរនៅពេលជាមួយគ្នាផង ក្នុងឱកាសបុណ្យចម្លង ជាពិធីយ៉ាងឧឡារិកជាងគេបំផុត។ ក្នុងអម្លុងពេលអស់មួយឆ្នាំ ព្រះសហគមន៍លាតព្រឹត្តិការណ៍ដ៏អស្ចារ្យដែលព្រះគ្រីស្តបានសម្រេច (...)។ ដោយលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះគ្រីស្តដែលលោះរំដោះយើងដូច្នេះ ព្រះសហគមន៍ក៏បើកឲ្យគ្រីស្តបរិស័ទនូវកំណប់ដ៏ថ្លៃថ្នូរនៃអនុភាព និងនៃកុសលផលបុណ្យនៃព្រះអម្ចាស់របស់ខ្លួន។ ធ្វើដូច្នេះ ព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងនោះហាក់ដូចជាមានវត្តមានតាមពេលវេលាតៗទៅ ហើយគ្រីស្តបរិស័ទអាចភ្ជាប់នឹងព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងនោះ និងបានពោរពេញដោយព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ដែលសង្គ្រោះគេ" (SC ១០២)។

១១៦៤- ចាប់តាំងពីធម៌វិន័យរបស់លោកម៉ូសេ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់បានប្រារព្ធបុណ្យផ្សេងៗតាមពេលកំណត់ពីបុណ្យចម្លងមក ដើម្បីរំឭកនូវកិច្ចការដ៏គួរឲ្យស្ងើចសរសើររបស់ព្រះជាម្ចាស់ជាព្រះសង្គ្រោះ ដើម្បីអរព្រះគុណព្រះអង្គ ដើម្បីចងចាំកិច្ចការនោះ និងដើម្បីបង្រៀនឲ្យអ្នកជំនាន់ថ្មីប្រតិបត្តិតាម។ ក្នុងវេលានៃព្រះសហគមន៍ ដែលមានក្នុងចន្លោះបុណ្យចម្លងរបស់ព្រះគ្រីស្ត ដែលបានកើតឡើងម្តងជាការស្រេច និងរហូតដល់បុណ្យចម្លងនេះបានសម្រេចក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ពិធីបុណ្យ ដែលយើងប្រារព្ធនៅថ្ងៃកំណត់ ទទួលភាពថ្មោងថ្មីនៃគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត។

១១៦៥- នៅពេលដែលព្រះសហគមន៍លើកតម្កើងគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត មានពាក្យមួយបន្ទរទៅនឹងការអធិដ្ឋានរបស់ព្រះសហគមន៍ គឺ "នៅថ្ងៃនេះ! " ជាសម្លេងខ្ទរនៃការអធិដ្ឋានដែលព្រះអម្ចាស់បានបង្រៀនឲ្យចេះ (មថ ៦,១១) នឹងការត្រាស់ហៅនៃព្រះវិញ្ញាណដ៏វិសុទ្ធ (ហប ៣,៧-៤,១១)។ "ថ្ងៃនេះ" របស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ហើយដែលត្រាស់ហៅមនុស្សលោក ឲ្យចូលរួមជាមួយព្រះអង្គ ជា "ពេលកំណត់" នៃបុណ្យចម្លងរបស់ព្រះយេស៊ូដែលឆ្លងកាត់ និងទទួលយកប្រវត្តិសាស្ត្រទាំងមូល៖

> ជីវិតបានលាតសន្ធឹងលើសត្វលោកទាំងអស់ ហើយពួកគេពោរពេញដោយពន្លឺដ៏ធំល្វឹងល្វើយ បូព៌ានៃបូព៌ា ឈានចូលពាសពេញសកលលោក ហើយអ្នកដែល "គង់នៅមុនផ្កាយព្រឹក" និងមុនផ្កាយទាំងអស់ ដែលមានជីវិតអមតៈដ៏ខ្ពង់ខ្ពស់បំផុត គឺព្រះគ្រីស្តដ៏ប្រសើរភ្លឺចាំងលើសត្វលោកទាំងអស់ច្រើនជាងព្រះអាទិត្យ។ ហេតុនេះហើយ បានជាសម្រាប់យើង ដែលផ្ញើជីវិតទៅលើព្រះអង្គ មានថ្ងៃនៃពន្លឺដ៏យូរអង្វែង និងអស់កល្បជានិច្ច ដែលមិនចេះរលត់ គឺបុណ្យចម្លងដ៏អាថ៌កំបាំង (សន្តៈ អ៊ីប៉ូលីត)។

## ថ្ងៃរបស់ព្រះអម្ចាស់

១១៦៦- "ព្រះសហគមន៍លើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង រៀងរាល់ថ្ងៃទីប្រាំបី ដែលយើងតែងហៅយ៉ាងត្រឹមត្រូវថា "ថ្ងៃរបស់ព្រះអម្ចាស់" ព្រោះជាថ្ងៃព្រះគ្រីស្តមានព្រះជន្មថ្មី តាមក្រុមគ្រីស្តទូតបានបញ្ជូនបន្តមក" (SC ១០៦)។ ថ្ងៃដែលព្រះគ្រីស្តមានព្រះជន្មថ្មីជា "ថ្ងៃទីមួយនៃសប្តាហ៍" ដែលរំឭកថ្ងៃទីមួយនៃការបង្កើត ហើយជា "ថ្ងៃទីប្រាំបី" ដែលព្រះគ្រីស្ត ក្រោយពីបាន "ផ្ទំសម្រាក" នៃថ្ងៃសប្ប័ទដ៏ប្រសើរ ចាប់ផ្តើមថ្ងៃ "ដែលព្រះអម្ចាស់បង្កើត" "ថ្ងៃដែលគ្មានពេលល្ងាច" (ពិធីបុណ្យខាងបូព៌ាប្រទេស)។ "ពិធីជប់លៀងរបស់ព្រះអម្ចាស់" ជាស្នូលនៃថ្ងៃនេះ ដ្បិតនៅពេលនោះ សហគមន៍ទាំងមូលរបស់គ្រីស្តបរិស័ទជួបព្រះអម្ចាស់ដែលមានព្រះជន្មថ្មី ហើយដែលអញ្ជើញគេឲ្យរួមតុបរិភោគអាហារជាមួយព្រះអង្គ (យហ ២១,១២ ; លក ២៤,៣០)៖

> ថ្ងៃរបស់ព្រះអម្ចាស់ជាថ្ងៃនៃជីវិតថ្មី និងថ្ងៃរបស់គ្រីស្តបរិស័ទ ជាថ្ងៃរបស់យើង។ ហេតុនេះ គេហៅថ្ងៃនោះថា ថ្ងៃរបស់ព្រះអម្ចាស់ ដ្បិតថ្ងៃនោះ ព្រះអម្ចាស់ដែលបានជោគជ័យ បានឡើងទៅឯព្រះបិតា។ បើសាសន៍ដទៃហៅថ្ងៃនោះថា ថ្ងៃនៃព្រះអាទិត្យ យើងក៏ប្រកាសថា ថ្ងៃនោះជាថ្ងៃនៃព្រះអាទិត្យដែរ ពីព្រោះថ្ងៃនេះ ពន្លឺនៃពិភពលោកបានរះឡើង ថ្ងៃនេះព្រះអាទិត្យនៃសេចក្តីសុចរិត ដែលរស្មីផ្តល់ការសង្គ្រោះ បានលេចឡើង (សន្តៈ យេរ៉ូម)។

១១៦៧- ថ្ងៃអាទិត្យជាថ្ងៃដ៏ប្រសើររបស់អង្គប្រជុំ ដែលគ្រីស្តបរិស័ទប្រមូលផ្តុំគ្នា។ "នៅថ្ងៃអាទិត្យនោះ គ្រីស្តបរិស័ទត្រូវតែជួបជុំគ្នាជាធ្លុងតែមួយ។ ដោយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងចូលរួមថ្វាយអភិបូជា គ្រីស្តបរិស័ទនាំគ្នានឹករឭកដល់ព្រះអម្ចាស់យេស៊ូរងទុក្ខលំបាកមានជីវិតថ្មី។ គ្រីស្តបរិស័ទក៏អរព្រះគុណព្រះបិតា ដែល

"បានប្រោសគេឲ្យកើតជាថ្មី ដោយប្រោសព្រះយេស៊ូគ្រីស្តឲ្យមានព្រះជន្មថ្មី។ ដូច្នេះ យើងមានសេចក្តីសង្ឃឹមដែលមិនចេះសាបសូន្យឡើយ" (SC ១០៦)។

> "ឱព្រះគ្រីស្តអើយ! នៅពេលដែលយើងស្ញើងស្ញាធ៍អំពីព្រឹត្តិការណ៍ដ៏អស្ចារ្យ ដែលព្រះជាម្ចាស់បានបំពេញនៅថ្ងៃអាទិត្យនៃជីវិតថ្មីដ៏វិសុទ្ធរបស់ព្រះអង្គ យើងថ្លែងថា៖ សូមលើកតម្កើងថ្ងៃអាទិត្យ ដ្បិតនៅថ្ងៃនោះ ព្រះជាម្ចាស់បានចាប់ផ្តើមបង្កើត (...) បានសង្គ្រោះពិភពលោក (...) និងបានប្រោសមនុស្សជាតិឲ្យកើតសាជាថ្មី (...)។ នៅថ្ងៃនោះ មេឃនិងដីបានអបអរសាទរ ហើយសកលលោកទាំងមូលពោរពេញទៅដោយពន្លឺ ។ សូមលើកតម្កើងថ្ងៃអាទិត្យ ដ្បិតនៅថ្ងៃនោះ ទ្វារនៃស្ថានបរមសុខបានបើកចំពោះលោកអដាំ ហើយអស់អ្នកដែលត្រូវនិរទេសឲ្យចូលទៅក្នុងវិញ ដោយគ្មានការភិតភ័យ (ពិធីបុណ្យនៅអង់ទីអូស)។

## ឆ្នាំពិធីបុណ្យ

១១៦៨- ចាប់តាំងពីត្រៃទិវានៃបុណ្យចម្លង ដូចជាប្រភពនៃពន្លឺ វេលាថ្មីនៃជីវិតថ្មីបំភ្លឺឆ្នាំពិធីបុណ្យទាំងមូល។ បន្តិចម្តងៗ ពីម្នាងមួយទៅម្នាងមួយទៀត នៃប្រភពនេះ ពិធីបុណ្យផ្លាស់ប្តូរឆ្នាំទាំងមូល ដែលពិតជា "ឆ្នាំដែលព្រះអម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា" (លក ៤,១៩)។ ព្រះជាម្ចាស់មានព្រះរាជកិច្ចសង្គ្រោះមនុស្សលោកតាមពេលវេលា ប៉ុន្តែ ចាប់តាំងពីពេលដែលព្រះជាម្ចាស់បានសម្រេចការសង្គ្រោះនេះ ក្នុងបុណ្យចម្លងរបស់ព្រះយេស៊ូ ហើយបានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ ទីចុងក្រោយនៃប្រវត្តិសាស្ត្រ ដូចជាបានមកដល់ហើយ ហើយព្រះរាជ្យរបស់ព្រះជាម្ចាស់ចូលក្នុងពេលវេលានៃយើង។

១១៦៩- ហេតុនេះហើយ បានជាបុណ្យចម្លង មិនគ្រាន់តែជាបុណ្យមួយក្នុងចំណោមបុណ្យឯទៀតៗទេ គឺជា "បុណ្យនៃបុណ្យទាំងឡាយ" "ពិធីយ៉ាងឧឡារិកជាទីបំផុត" ដូចអភិបូជាជាអគ្គសញ្ញានៃអគ្គសញ្ញា (អគ្គ សញ្ញាដ៏ប្រសើរ)។ សន្ត: អាថាណាស ហៅបុណ្យចម្លងជា "ថ្ងៃអាទិត្យដ៏ប្រសើរ" ដូចបូព៌ាប្រទេសហៅសប្តាហ៍ពិសិដ្ឋថា "សប្តាហ៍ដ៏ប្រសើរ"។ គម្រោងការដ៏អស្ចារ្យនៃជីវិតថ្មី ដែលព្រះគ្រីស្តបានបំផ្លាញសេចក្តីស្លាប់ ជ្រាបចូលក្នុងពេលវេលាដ៏ចាស់ជរារបស់យើងជាមួយនឹងថាមពលដ៏ខ្លាំងខ្លា រហូតដល់អ្វីៗទាំងអស់ស្ថិតក្រោមអំណាចរបស់ព្រះអង្គ។

១១៧០- នៅមហាសន្និបាតនៅនីសេ (ឆ្នាំ ៣២៥) ព្រះសហគមន៍ទាំងអស់បានព្រមព្រៀងគ្នា ដើម្បីឲ្យបុណ្យចម្លងរបស់គ្រីស្តសាសនាត្រូវប្រារព្ធនៅថ្ងៃអាទិត្យក្រោយថ្ងៃចន្ទពេញបូណ៌មី (១៤ នីសាន់) នៃនិទាឃរដូវ។ សម្តេច ប៉ាបគ្រេគ័រទី១៣ ក្នុងឆ្នាំ១៥៨២ បានកែប្រតិទិននៅបស្ចិមប្រទេស ដែលនាំឲ្យមានការខុសគ្នាជាច្រើនថ្ងៃ បើប្រៀបធៀបនឹងប្រតិទិននៃបូព៌ាប្រទេស។ ឥឡូវនេះ ព្រះសហគមន៍ខាងបស្ចិម និងបូព៌ាប្រទេស ខិតខំឲ្យមានការព្រមព្រៀងគ្នា ដើម្បីប្រារព្ធពិធីបុណ្យព្រះយេស៊ូមានព្រះជន្មថ្មី ក្នុងថ្ងៃជាមួយគ្នាតែមួយ។

១១៧១- លក្ខណៈផ្សេងៗនៃព្រឹត្តិការណ៍តែមួយរបស់ព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ លាតសន្ធឹងក្នុងឆ្នាំពិធីបុណ្យ ជាពិសេសសម្រាប់បុណ្យៗ ដែលទាក់ទងនឹងព្រឹត្តិការណ៍ដ៏អស្ចារ្យ អំពីព្រះជាម្ចាស់ចាប់កំណើតជាមនុស្ស (បុណ្យទេវទូតជូនដំណឹងទៅព្រះនាងម៉ារី បុណ្យព្រះយេស៊ូប្រសូត និងបុណ្យព្រះយេស៊ូសម្តែងព្រះអង្គឲ្យសាសន៍ដទៃស្គាល់) ដែលរំឭកថា ព្រះជាម្ចាស់បានចាប់ផ្តើមសង្គ្រោះយើង ហើយដែលផ្តល់ផលផ្លែដំបូងនៃព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មរស់ថ្មី។

## ពិធីបុណ្យគោរពសន្តៈបុគ្គលប្រចាំឆ្នាំ

១១៧២- "ដោយព្រះសហគមន៍លើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងប៉ុន្មានរបស់ព្រះគ្រីស្ត ក្នុងអម្លុងពេលអស់មួយឆ្នាំ ដូច្នេះ ព្រះសហគមន៍ក៏គោរពព្រះនាងម៉ារីជាព្រះមាតារបស់ព្រះជាម្ចាស់ ដោយមានសេចក្ដីស្រឡាញ់យ៉ាងពិសេសចំពោះព្រះនាង ព្រោះព្រះនាងភ្ជាប់ជាមួយបុត្ររបស់ព្រះនាងក្នុងកិច្ចសង្គ្រោះរបស់បុត្រនោះ ដោយចំណងដែលមិនអាចស្រាយបាន។ ពេលព្រះសហគមន៍សម្លឹងមើលព្រះនាងម៉ារី ព្រះសហគមន៍សរសើរ និងលើកតម្កើងផលដ៏ប្រសើរជាងគេបំផុតរបស់ព្រះគ្រីស្ត ដែលលោះរំដោះមនុស្សលោក។ ម្យ៉ាងទៀត ពេលព្រះសហគមន៍សម្លឹងមើលព្រះនាង ព្រះសហគមន៍ក៏នឹករំពឹងគិតដោយអំណរ ហាក់ដូចជាសម្លឹងមើលក្នុងរូបដ៏និមលបំផុតនោះនូវអ្វីៗដែលខ្លួនប្រាថ្នាចង់បាន ហើយសង្ឃឹមថា នឹងបានទាំងអស់ដូចព្រះនាងដែរ" (SC ១០៣)។

១១៧៣- ពេលព្រះសហគមន៍ធ្វើពិធីនឹកថ្ងៃខួបនៃមរណសាក្សី និងរបស់សន្តៈបុគ្គលឯទៀតៗ ក្នុងពិធីបុណ្យប្រចាំឆ្នាំ "ព្រះសហគមន៍ក៏ប្រកាសនូវព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង ដោយសន្តៈបុគ្គលទាំងនោះរងទុក្ខរួមជាមួយព្រះគ្រីស្ត គេក៏បានទទួលសិរីរុងរឿងរួមជាមួយព្រះគ្រីស្តដែរ។ ព្រះសហគមន៍ក៏បង្ហាញសន្តៈបុគ្គល ទុកជាគំរូឲ្យគ្រីស្តបរិស័ទយកតម្រាប់ធ្វើតាម គឺគំរូដែលទាក់ទាញមនុស្សទាំងអស់ទៅរកព្រះបិតាដោយសារព្រះគ្រីស្ត។ កុសលផលបុណ្យរបស់សន្តៈបុគ្គលទាំងនោះ ក៏ធ្វើឲ្យព្រះជាម្ចាស់នឹងប្រទានពរដល់ព្រះសហគមន៍ទៀតផង" (SC ១០៤)។

## ពិធីបុណ្យតាមពេលកំណត់

១១៧៤- គម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត ដែលប្រសូតជាមនុស្ស សោយទិវង្គត និងមានព្រះជន្មថ្មី ដែលយើងលើកតម្កើងក្នុងពិធីអភិបូជា ជាពិសេសក្នុងអង្គប្រជុំនៃថ្ងៃអាទិត្យ ជ្រាបចូល និងប្រែពេល វេលាប្រចាំថ្ងៃ ដោយប្រារព្ធពិធីពេលកំណត់ "ពិធីរបស់ព្រះជាម្ចាស់" (SC IV)។ ព្រះសហគមន៍បានចាត់ចែងពិធីនេះ "ដើម្បីឲ្យមនុស្សលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គទាំងយប់ទាំងថ្ងៃ" (SC ៨៤) ស្របតាមពាក្យបណ្ដាំដែលមកពីក្រុមគ្រីស្តទូតថា "ត្រូវតែអធិដ្ឋានជានិច្ច" (១ថស ៥,១៧ ; អភ ៦,១៨)។ ពិធីនេះជា "ពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ជាសាធារណៈរបស់ព្រះសហគមន៍" (SC ៩៨) ដោយមានគ្រីស្តបរិស័ទ (អ្នកទទួលតែងតាំងបព្វជិត និងគ្រីស្តបរិស័ទធម្មតា) បំពេញមុខងារជាបូជាចារ្យរបស់អស់អ្នកដែលបានជ្រមុជទឹក។ នៅពេលនោះ "ពិតជាព្រះសហគមន៍ជាភរិយា បន្លឺព្រះសូរសំឡេងឡើងនិយាយសន្ទនាជាមួយព្រះគ្រីស្តជាព្រះស្វាមីមែន ឬបើពោលឲ្យបានល្អជាងនេះទៅទៀត គឺព្រះគ្រីស្តរួមជាមួយព្រះកាយព្រះអង្គមានព្រះបន្ទូលទៅកាន់ព្រះបិតា" (SC ៨៤)។

១១៧៥- ពិធីបុណ្យតាមពេលកំណត់មានគោលដៅ ឲ្យទៅជាការអធិដ្ឋាននៃប្រជាជនទាំងអស់របស់ព្រះជាម្ចាស់។ ក្នុងពិធីបុណ្យនេះ "ព្រះគ្រីស្តយេស៊ូនៅតែបន្តបំពេញមុខងារជាមហាបូជាចារ្យនេះ ដោយសារព្រះសហគមន៍" (SC ៨៣)។ ម្នាក់ៗចូលរួមចំណែកក្នុងពិធីនេះ តាមមុខងាររៀងៗខ្លួនក្នុងព្រះសហគមន៍ និងតាមកាលៈទេសៈប្រចាំជីវិត គឺលោកបូជាចារ្យ ដែលមានមុខងារប្រកាសដំណឹងល្អ ហើយពីព្រោះព្រះជាម្ចាស់ត្រាស់ហៅពួកលោកឲ្យអធិដ្ឋានដោយមិនរសាយចិត្ត និងបម្រើព្រះបន្ទូល (SC ៨៦ ; ៩៦ ; PO ៥) បព្វជិតបព្វជិតា ដែលបានទទួលព្រះអំណោយទានថ្វាយខ្លួនទាំងស្រុង (SC ៩៨) ហើយនឹងគ្រីស្តបរិស័ទទាំងអស់ទៅតាមលទ្ធភាពរបស់ខ្លួន៖ "អស់លោកគង្វាលត្រូវយកចិត្តទុកដាក់ ចាត់ចែងពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់រួបរួមគ្នាក្នុងព្រះវិហារ គឺពិធីនៅម៉ោងសំខាន់ៗ ជាពិសេសពិធីលើកតម្កើងពេលល្ងាច នៅថ្ងៃអាទិត្យ និងនៅថ្ងៃបុណ្យឧឡារិក។ យើងផ្ដែផ្ដាំ

ឲ្យគ្រីស្តបរិស័ទធម្មតា សូត្រធម៌ពិធីបុណ្យតាមពេលកំណត់ រួបរួមជាមួយបូជាចារ្យក៏បាន ឬរួបរួមជាមួយគ្នាក៏បាន ឬម្នាក់ឯងក៏បានដែរ" (SC ១០០)។

១១៧៦- ការប្រារព្ធពិធីបុណ្យ តាមពេលកំណត់ មិនគ្រាន់តែទាមទារឲ្យសម្លេងស្របនឹងចិត្តគំនិត ប៉ុណ្ណោះទេ ថែមទាំងឲ្យ "ខិតខំរៀនឲ្យមានចំណេះកាន់តែជ្រៅៗ អំពីពិធីបុណ្យនានា និងអំពីព្រះគម្ពីរ ជាពិសេសស្គាល់អត្ថន័យទំនុកតម្កើង"(SC ៩០)។

១១៧៧- បទចម្រៀង និងពាក្យសូត្រធម៌នៃពិធីបុណ្យតាមពេលកំណត់ បញ្ចូលទំនុកតម្កើងក្នុងវេលានៃព្រះសហគមន៍ ដោយសម្តែងជានិមិត្តរូបវេលានៃថ្ងៃ វេលានៃពិធីបុណ្យ ឬបុណ្យដែលគេលើកតម្កើង។ ម្យ៉ាងទៀត ការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ជារៀងរាល់ពេលកំណត់ (ជាមួយនឹងចម្លើយដែលមានបន្តបន្ទាប់ព្រះបន្ទូលនេះ) ហើយនៅពេលកំណត់ខ្លះ ការអានគ្រូបាធ្យាយ និងគ្រូខាងវិញ្ញាណ សម្តែងយ៉ាងជ្រាលជ្រៅនូវអត្ថន័យនៃព្រឹត្តិការណ៍ដែលគេប្រារព្ធ ជួយឲ្យឈ្វេងយល់ទំនុកតម្កើង និងរៀបចំចិត្តគំនិតឲ្យធ្វើសមាធិយ៉ាងស្ងៀមស្ងាត់។ ដូច្នេះ Lectio divina ដែលយើងអាន និងស្ញឹងស្មាធ៏ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីឲ្យព្រះបន្ទូលនេះទៅជាសេចក្តីអធិដ្ឋាន ចាក់ឫសក្នុងពិធីបុណ្យ។

១១៧៨- ពិធីបុណ្យតាមពេលកំណត់ ដែលបន្តពិធីអភិបូជាម្យ៉ាង មិនលុបចោលពិធីផ្សេងៗទៀតនៃប្រជាជនរបស់ព្រះជាម្ចាស់ ជាពិសេសការក្រាបថ្វាយបង្គំ និងការគោរពព្រះកាយព្រះគ្រីស្តទេ ផ្ទុយទៅវិញ ពិធីបុណ្យតាមពេលកំណត់បំពេញពិធីផ្សេងៗទាំងអស់នោះ។

## ៤-តើត្រូវលើកតម្កើងនៅឯណា?

១១៧៩- ការគោរព "ដោយវិញ្ញាណ និងសេចក្តីពិត" (យហ ៤,២៤) នៃសម្ពន្ធមេត្រីថ្មីមិនជាប់ទាក់ទិននឹងកន្លែងតែមួយទេ។ ព្រះជាម្ចាស់បានប្រគល់ផែនដីដ៏វិសុទ្ធទាំងមូលឲ្យបុត្រធីតារបស់មនុស្សលោក។ អ្វីដែលសំខាន់ នៅពេលដែលគ្រីស្តបរិស័ទប្រមូលផ្តុំគ្នាក្នុងកន្លែងតែមួយ គឺ "ថ្មដ៏មានជីវិត" ដែលផ្តុំគ្នាឡើង ដើម្បី "កសាងព្រះដំណាក់របស់ព្រះវិញ្ញាណ" (១ពត្រ ២,៤-៥)។ ព្រះកាយព្រះគ្រីស្តដែលមានព្រះជន្មថ្មី ជាព្រះដំណាក់ខាងវិញ្ញាណដែលទឹកដ៏មានជីវិតផុសឡើង។ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធបានបង្រួបបង្រួមយើងជាមួយព្រះគ្រីស្ត "យើងទាំងអស់គ្នាជាព្រះវិហាររបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ" (២ករ ៦,១៦)។

១១៨០- ពេលមានសេរីភាពខាងសាសនាយ៉ាងពេញលេញ (DH ៤) គ្រីស្តបរិស័ទកសាងអាគារ ដើម្បីលើកតម្កើងព្រះជាម្ចាស់។ ព្រះវិហារដែលមើលឃើញមិនគ្រាន់តែជាកន្លែងប្រជុំប៉ុណ្ណោះទេ ប៉ុន្តែ ព្រះវិហារនោះសម្តែងនូវព្រះសហគមន៍ដ៏មានជីវិតនៅកន្លែងនេះ ជាព្រះដំណាក់របស់ព្រះជាម្ចាស់ ដែលបានសម្រុះសម្រួលមនុស្សលោករួមជាមួយព្រះគ្រីស្ត។

១១៨១- "យើងគោរពព្រះដំណាក់នៃការអធិដ្ឋាន ដើម្បីជួយគាំទ្រ និងលើកទឹកចិត្តគ្រីស្តបរិស័ទ។ នៅក្នុងព្រះដំណាក់នេះ យើងប្រារព្ធពិធីអភិបូជា និងរក្សាទុកនូវព្រះកាយព្រះគ្រីស្ត គ្រីស្តបរិស័ទជួបជុំគ្នា យើងគោរពវត្តមាននៃព្រះបុត្រារបស់ព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់យើង ដែលត្រូវបូជាសម្រាប់យើងលើអាសនៈនៃសក្ការៈបូជា។ ដំណាក់នៃការអធិដ្ឋាននេះ ត្រូវតែស្អាត សមស្របនឹងការអធិដ្ឋាន និងពិធីអភិបូជា" (PO ៥ ; SC ១២២-១២៧)។ ក្នុង "ព្រះដំណាក់របស់ព្រះជាម្ចាស់" នេះ សេចក្តីពិត និងភាពសុខដុមនៃសញ្ញាសម្គាល់ត្រូវសម្តែងព្រះគ្រីស្ត ដែលមានវត្តមានគង់នៅ និងមានសកម្មភាពក្នុងកន្លែងនេះ" (SC ៧)៖

១១៨២- អាសនៈ នៃសម្ព័ន្ធមេត្រីថ្មីជាព្រះឈើឆ្កាងនៃព្រះអម្ចាស់ ( ហប ១៣,១០ ) ។ អគ្គសញ្ញានៃព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មថ្មីហូរចេញពីព្រះឈើឆ្កាងនោះ។ លើអាសនៈ ដែលជាស្នូលនៃព្រះវិហារ ព្រះជាម្ចាស់ប្រោសឲ្យសក្ការបូជានៃព្រះឈើឆ្កាងមានវត្តមានខាងអគ្គសញ្ញា។ អាសនៈនេះជាតុរបស់ព្រះអម្ចាស់ដែរ ដែលព្រះអង្គអញ្ជើញប្រជាជនរបស់ព្រះអង្គឲ្យចូលរួម ( **IGMR** ២៥៩ ) ។ ក្នុងពិធីបុណ្យខាងបូព៌ាប្រទេសខ្លះ អាសនៈជានិមិត្តរូបនៃផ្នូរ (ព្រះគ្រីស្តពិតជាបានសោយទិវង្គត ហើយពិតជាមានព្រះជន្មថ្មីមែន ) ។

១១៨៣- ត្រូវដាក់ព្រះពន្លា "ក្នុងកន្លែងដ៏សមរម្យបំផុតនៃព្រះវិហារ ដោយគោរពយ៉ាងជ្រាលជ្រៅ" ( **MF** ) ។ សភាពសមរម្យ កន្លែង និងសុវត្ថិភាពរបស់ព្រះពន្លា ( **SC** ១២៨ ) ត្រូវជំរុញយើងឲ្យក្រាបថ្វាយបង្គំព្រះអម្ចាស់ដែលមានវត្តមានដ៏ពិតប្រាកដក្នុងអគ្គសញ្ញាដ៏វិសុទ្ធនៃអាសនៈ។

ជាធម្មតា យើងរក្សាទុក និងគោរពប្រេងគ្រីស្មា (មីរ៉ូន) ដែលជាប្រេងអភិសេកសញ្ញាសម្គាល់ខាងអគ្គសញ្ញានៃព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ក្នុងកន្លែងដ៏មានសុវត្ថិភាពនៃទីសក្ការៈ។ យើងអាចបន្ថែមប្រេងលាបអ្នកត្រៀមខ្លួនជ្រមុជទឹក និងប្រេងលាបអ្នកជម្ងឺដែរ។

១១៨៤- កៅអី (ទីតាំង) របស់លោកអភិបាល ឬលោកបូជាចារ្យ "ត្រូវសម្តែងនូវមុខងាររបស់អ្នកអធិបតីអង្គប្រជុំ ដែលដឹកនាំការអធិដ្ឋាន" ( **IGMR** ២៧១ ) ។

តុព្រះបន្ទូល ៖ "សេចក្តីថ្លៃថ្នូរនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទាមទារឲ្យមានកន្លែងមួយ ក្នុងព្រះវិហារដែលជួយប្រកាសព្រះបន្ទូលនេះ ហើយដែលគ្រីស្តបរិស័ទងាយចាប់អារម្មណ៍ ពេលពិធីលើកតម្កើងព្រះបន្ទូល" ( **IGMR** ២៧២ ) ។

១១៨៥- ប្រជាជនរបស់ព្រះជាម្ចាស់ចាប់ផ្តើមជួបជុំគ្នាដោយអគ្គសញ្ញាជ្រមុជទឹក។ ដូច្នេះ ព្រះវិហារត្រូវតែមានកន្លែងមួយសម្រាប់ពិធីបុណ្យជ្រមុជទឹក ហើយជួយរំឭកពាក្យសន្យានៃពិធីនេះ ( ទឹកព្រះពរ ) ។

ការរស់នៅសាជាថ្មីរបស់គ្រីស្តបរិស័ទទាមទារឲ្យគេកែប្រែចិត្តគំនិត ។ ដូច្នេះ ត្រូវតែមានកន្លែងសមរម្យដើម្បីទទួលអ្នកបាប ដែលចង់ទទួលអគ្គសញ្ញាលើកលែងទោស។

ព្រះវិហារត្រូវតែជាកន្លែងដែលជំរុញឲ្យស្ងឹងស្មាធិ៍ និងអធិដ្ឋានដោយស្ងៀមស្ងាត់ ដែលបន្តការអធិដ្ឋានដ៏ប្រសើរនៃអភិបូជា ហើយដែលធ្វើការអធិដ្ឋាននេះជ្រាបចូលក្នុងចិត្តគំនិតផង។

១១៨៦- ទីបំផុត ព្រះវិហារមានអត្ថន័យសំដៅទៅលើគ្រាចុងក្រោយបំផុត។ ដើម្បីចូលក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់ ត្រូវតែឈានចូលតាមមាត់ទ្វារមួយ ជានិមិត្តរូបបង្ហាញថា ព្រះជាម្ចាស់ត្រាស់ហៅមនុស្សលោក ដែលត្រូវរបួសដោយសារអំពើបាប ឲ្យចូលក្នុងពិភពលោកនៃជីវិតថ្មី។ ព្រះវិហារដែលមើលឃើញជានិមិត្តរូបនៃព្រះដំណាក់របស់ព្រះបិតា។ ប្រជាជនរបស់ព្រះជាម្ចាស់កំពុងដើរឆ្ពោះទៅព្រះដំណាក់នេះ ដែលព្រះបិតា "នឹងជូតទឹកភ្នែកចេញអស់ពីភ្នែករបស់គេ" (វវ ២១,៤)។ ហេតុនេះហើយ បានជាព្រះវិហារជាដំណាក់របស់បុត្រធីតាទាំងអស់របស់ព្រះជាម្ចាស់ ដែលបើកទូលាយ និងទទួលគេយ៉ាងរាក់ទាក់។

## សង្ខេប

១១៨៧- ពិធីបុណ្យជាព្រះរាជកិច្ចរបស់ព្រះគ្រីស្តទាំងស្រុង ទាំងព្រះសិរសា ទាំងព្រះកាយ។ មហាបូជាចារ្យ

យើងតែងតែប្រារព្ធពិធីបុណ្យនេះក្នុងពិធីបុណ្យនៃស្ថានបរមសុខ រួមជាមួយព្រះមាតាដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ក្រុមគ្រីស្តទូត សន្តៈបុគ្គលទាំងឡាយ និងមហាជនដែលបានចូលក្នុងព្រះរាជ្យហើយ។

១១៨៨- ក្នុងពិធីបុណ្យ អង្គប្រជុំទាំងមូលជា "អ្នកប្រារព្ធ" ទៅតាមមុខងាររបស់ខ្លួន។ គ្រីស្តបរិស័ទសុទ្ធតែជាបូជាចារ្យមកពីគេជាព្រះកាយព្រះគ្រីស្ត។ ប៉ុន្តែ គ្រីស្តបរិស័ទខ្លះ ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ដើម្បី ធ្វើជាតំណាងរបស់ព្រះគ្រីស្តជាព្រះសិរសានៃព្រះកាយ។

១១៨៩- ក្នុងពិធីបុណ្យ មានសញ្ញាសម្គាល់ និងនិមិត្តរូបផ្សេងៗ ដែលដកស្រង់ពីការបង្កើត (ពន្លឺ ទឹក ភ្លើង) ជីវិតរបស់មនុស្ស (លាង ចាក់ប្រេង កាច់នំប៉័ង) និងប្រវត្តនៃការសង្គ្រោះ (ពិធីនៃបុណ្យចម្លង)។ ធាតុនៃសកលលោក ពិធីរបស់មនុស្ស និងកាយវិការដែលរំឭកអំពីព្រះជាម្ចាស់ទាំងអស់នោះ ត្រូវបញ្ចូលក្នុងពិភពនៃជំនឿ ហើយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធទទួលយកធាតុ ពិធី និងកាយវិការទាំងអស់នោះ ដែលក្លាយទៅជាសកម្មភាពសង្គ្រោះ និងប្រោសឲ្យបានវិសុទ្ធរបស់ព្រះគ្រីស្ត។

១១៩០- ពិធីបុណ្យលើកតម្កើងព្រះបន្ទូលជាផ្នែកដ៏សំខាន់នៃពិធីបុណ្យ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលគេប្រកាស និងជំនឿដែលឆ្លើយតបនឹងព្រះបន្ទូលនេះ សម្តែងអត្ថន័យនៃពិធីបុណ្យនេះ។

១១៩១- ចម្រៀង និងតន្ត្រីទាក់ទងយ៉ាងជិតស្និទនឹងកិច្ចការខាងពិធីបុណ្យ។ លក្ខណៈផ្សេងៗ ដើម្បី ប្រើប្រាស់ចម្រៀង និងតន្ត្រីយ៉ាងត្រឹមត្រូវមានដូចតទៅ៖ សោភណភាពនៃការអធិដ្ឋាន ការចូលរួមនៃអង្គប្រជុំ ដោយមានចិត្តថ្លើមតែមួយ និងលក្ខណៈដ៏សក្ការៈនៃពិធីបុណ្យ។

១១៩២- រូបភាពដ៏វិសុទ្ធ ដែលមានក្នុងព្រះវិហារយើង និងនៅក្នុងផ្ទះយើង មានគោលដៅដាស់តឿន និងបំប៉នជំនឿរបស់យើងក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត។ តាមរយៈរូបរបស់ព្រះគ្រីស្តនិងរបស់កិច្ចការព្រះអង្គអំពីការសង្គ្រោះ គឺព្រះអង្គនេះហើយ ដែលយើងក្រាបថ្វាយបង្គំ។ តាមរយៈរូបដ៏វិសុទ្ធនៃព្រះមាតាដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ពួកទេវទូត និងជនដ៏វិសុទ្ធ យើងគោរពប្រណិប័តន៍មនុស្ស ដែលគំនូរនោះជាតំណាង។

១១៩៣- ថ្ងៃអាទិត្យ "ថ្ងៃរបស់ព្រះអម្ចាស់" ជាថ្ងៃសំខាន់ជាងគេ ដើម្បីប្រារព្ធពិធីអរព្រះគុណ ដ្បិតថ្ងៃនេះ ជាថ្ងៃនៃការមានព្រះជន្មថ្មី។ ថ្ងៃនេះ ជាថ្ងៃនៃអង្គប្រជុំ ដែលលើកតម្កើងព្រះជាម្ចាស់ ជាថ្ងៃនៃក្រុមគ្រួសារ ជាថ្ងៃនៃអំណរសប្បាយ ថ្ងៃសម្រាកពីការងារ។ ថ្ងៃនេះ ជាថ្ងៃ "គ្រឹះ និងស្នូលនៃឆ្នាំពិធីបុណ្យ" (SC ១០៦)។

១១៩៤- ព្រះសហគមន៍ "លាតសន្ធឹងគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្តអស់មួយឆ្នាំ ចាប់តាំងពីព្រះយេស៊ូប្រសូតជាមនុស្ស រហូតដល់ព្រះអង្គយាងឡើងស្ថានបរមសុខ ថ្ងៃព្រះវិញ្ញាណយាងមក និងថ្ងៃដែលយើងរង់ចាំពោរពេញដោយសេចក្តីសង្ឃឹមឲ្យព្រះអម្ចាស់យាងសោយរាជ្យ" (SC ១០២)។

១១៩៥- ដោយនឹករឭកដល់ជនដ៏វិសុទ្ធ ជាពិសេសព្រះមាតាដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ បន្ទាប់មកក្រុមគ្រីស្តទូត មរណសាក្សី និងសន្តៈបុគ្គលឯទៀត នៅថ្ងៃកំណត់នៃឆ្នាំពិធីបុណ្យ ព្រះសហគមន៍នៅលើផែនដីបង្ហាញ ថាព្រះសហគមន៍រួមជាមួយនឹងពិធីបុណ្យនៃស្ថានបរមសុខ លើកតម្កើងព្រះគ្រីស្ត ដែលបានសម្រេចការសង្គ្រោះក្នុងសិរីរាង្គប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ ហើយគំរូរបស់ពួកលោកដាស់តឿនព្រះសហគមន៍ឲ្យធ្វើ ដំណើរទៅកាន់ព្រះបិតា។

១១៩៦- គ្រីស្តបរិស័ទដែលប្រារព្ធពិធីពេលកំណត់រួមជាមួយព្រះគ្រីស្ត ជាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុតរបស់យើង ដោយសូត្រធម៌ទំនុកតម្កើង រិះគិតអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ច្រៀង និងប្រទានពរ ដើម្បីបញ្ចូលទៅក្នុង

ការអធិដ្ឋានជានិច្ច និងជាសកលរបស់ព្រះអង្គ ដែលលើកតម្កើងព្រះបិតា និងទូលអង្វរឲ្យ ព្រះអង្គចាត់ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកលើពិភពលោកទាំងមូល។

១១៩៧- ព្រះគ្រីស្តជាព្រះវិហារពិតប្រាកដរបស់ព្រះជាម្ចាស់ "ព្រះដំណាក់ដែលសិរីរុងរឿងរបស់ព្រះអង្គគង់នៅ" ដោយសារព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ គ្រីស្តបរិស័ទក្លាយទៅជាព្រះវិហារនៃព្រះវិញ្ញាណដ៏វិសុទ្ធ ថ្មដ៏មានជីវិត ដែលកសាងព្រះសហគមន៍។

១១៩៨- ក្នុងការរស់នៅលើផែនដី ព្រះសហគមន៍ត្រូវការកន្លែង ដែលសហគមន៍អាចជួបជុំគ្នាបាន គឺព្រះវិហារយើង ដែលអាចមើលឃើញ កន្លែងដ៏វិសុទ្ធ ដែលតំណាងទីក្រុងដ៏វិសុទ្ធ ទីក្រុងយេរូសាឡឹមនៃស្ថានបរមសុខ ដែលយើងកំពុងធ្វើដំណើរដូចបូជនីយេសក៍។

១១៩៩- ក្នុងព្រះវិហារនោះ ព្រះសហគមន៍លើកតម្កើងជាសាធារណៈនូវសិរីរុងរឿងនៃព្រះត្រៃឯកដ៏វិសុទ្ធ ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងច្រៀងសរសើរព្រះអង្គ អធិដ្ឋាន និងថ្វាយពិធីសក្ការៈរបស់ព្រះគ្រីស្ត ដែលគង់នៅក្នុងចំណោមអង្គប្រជុំខាងអគ្គសញ្ញា។ព្រះវិហារនោះជាកន្លែងដើម្បីស្ងឹងស្ងាធ និងអធិដ្ឋានតែម្នាក់ឯងផងដែរ។

# ប្រការទី២៖

## ពិធីបុណ្យខុសប្លែកពីគ្នា គម្រោងការដ៏អស្ចារ្យតែមួយ

### ប្រពៃណីខាងពិធីបុណ្យក្នុងព្រះសហគមន៍កាតូលិក

១២០០- ពីសហគមន៍ដំបូងនៅទីក្រុងយេរូសាឡឹមរហូតដល់អវសានកាលនៃពិភពលោក ព្រះសហគមន៍របស់ព្រះជាម្ចាស់ ដែលនៅស្មោះត្រង់នឹងជំនឿដែលមកពីក្រុមគ្រីស្តទូត លើកតម្កើងគម្រោងការដ៏អស្ចារ្យតែមួយ អំពីព្រះយេស៊ូដែលសោយទិវង្គតនិងមានព្រះជន្មថ្មី។ គេលើកតមកើងគម្រោងការដ៏អស្ចារ្យមានតែមួយនេះ ប៉ុន្តែគេប្រារព្ធពិធីបុណ្យតាមរបៀបខុសប្លែកពីគ្នា។

១២០១- លក្ខណៈសម្បត្តិប្រសើរខ្ពង់ខ្ពស់ ដែលស្ទង់មិនបាន របស់គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត បានជាគ្មានប្រពៃណីខាងពិធីបុណ្យណាមួយ អាចសម្តែងគម្រោងការនេះឲ្យបានពេញលក្ខណៈឡើយ។ ប្រវត្តិនៃកំណើត និងការអភិវឌ្ឍរបស់ពិធីទាំងអស់នោះ ផ្តល់សក្ខីភាពថា ព្រះសហគមន៍ទាំងអស់បំពេញគ្នាទៅវិញទៅមក។ នៅពេលដែលព្រះសហគមន៍នោះបានប្រារព្ធប្រពៃណីខាងពិធីបុណ្យនោះ ដោយរួបរួមជាមួយគ្នាត្រង់ជំនឿ និងត្រង់អគ្គសញ្ញានៃជំនឿ ព្រះសហគមន៍នោះ បានទទួលពីគ្នាទៅវិញទៅមក ហើយរីកចម្រើនដោយគោរពការបញ្ជូនបន្ត និងបេសកកម្មរួមនៃព្រះសហគមន៍ទាំងមូល (EN ៦៣-៦៤)។

១២០២- ប្រពៃណីផ្សេងៗខាងពិធីបុណ្យបានកើតមក ដោយសារបេសកកម្មរបស់ព្រះសហគមន៍តែម្តង។ ព្រះសហគមន៍នៅក្នុងតំបន់ និងដែលមានវប្បធម៌តែមួយ បានចាប់ផ្តើមលើកតម្កើងគម្រោងការរបស់ព្រះគ្រីស្តតាមលក្ខណៈពិសេស និងវប្បធម៌ផ្ទាល់ខ្លួន៖ ក្នុងការបញ្ជូនបន្តរបស់ "បញ្ញត្តិនៃជំនឿ" (២ធម ១,១៤) ក្នុងនិមិត្តរូបផ្សេងៗនៃពិធីបុណ្យ ក្នុងការចាត់ចែងឲ្យរួបរួមគ្នាដូចជាបងប្អូន ក្នុងការយល់ខាងទេវវិទ្យានៃគម្រោងការដ៏លាក់កំបាំងទាំងអស់ ហើយក្នុងលក្ខណៈផ្សេងៗរបស់សន្តៈបុគ្គល។ ហេតុនេះ ជីវិតខាងពិធីបុណ្យរបស់ព្រះសហគមន៍មួយ សម្តែងនូវព្រះគ្រីស្ត ដែលជាពន្លឺ និងជាការសង្គ្រោះរបស់ប្រជាជាតិទាំងអស់ ឲ្យប្រជាជន

និងវប្បធម៌មួយ ដែលព្រះជាម្ចាស់បានចាត់ព្រះសហគមន៍នេះឲ្យទៅ ហើយដែលព្រះសហគមន៍នេះចាក់ឫស។ ព្រះសហគមន៍កាតូលិក គឺព្រះសហគមន៍អាចរាប់បញ្ចូលក្នុងឯកភាពរបស់ខ្លួន លក្ខណៈសម្បត្តិពិតប្រាកដនៃវប្បធម៌ទាំងអស់ ដោយបន្សុទ្ធវប្បធម៌ទាំងអស់នោះ (LG ២៣ ; UR ៤)។

១២០៣- ប្រពៃណីខាងពិធីបុណ្យ ឬពិធីដែលព្រះសហគមន៍ប្រើប្រាស់សព្វថ្ងៃ បានមកពីក្បួនឡាតាំង (ជាពិសេសក្បួនរ៉ូម៉ាំង ជាមួយនឹងពិធីផ្សេងៗទៀតរបស់ព្រះសហគមន៍តាមស្រុកនានា ដូចជាពិធីរបស់សន្ដៈអំប្រ័រ ឬរបស់ក្រុមគ្រួសារបព្វជិតខ្លះទៀត) ហើយនឹងពិធីខាងប៊ីសង់ អាឡិចសង់ឌ្រី ឬកុប ខាងស៊ីរី អារមេនី ម៉ារូនីត និងកាល់ដេ។ "មហាសន្និបាតដ៏វិសុទ្ធសូមប្រកាសថា របបពិធីបុណ្យផ្សេងៗដែលព្រះសហគមន៍ជាព្រះមាតាដ៏វិសុទ្ធរបស់យើងតែងតែទទួលស្គាល់យ៉ាងត្រឹមត្រូវតាមច្បាប់រួចហើយ សុទ្ធតែមានសិទ្ធិ និងមានតម្លៃដ៏ថ្លៃថ្នូរស្មើគ្នា។ នៅពេលអនាគត ព្រះសហគមន៍ក៏មានបំណងចង់រក្សាទុក និងជួយលើកស្ទួយរបបពិធីបុណ្យទាំងនោះ ឲ្យរីកចម្រើនគ្រប់បែបយ៉ាងទៀតផង" (SC ៤)។

## ពិធីបុណ្យ និងវប្បធម៌

១២០៤- ការប្រារព្ធពិធីបុណ្យត្រូវស្របនឹងទេពកោសល្យ និងវប្បធម៌របស់ប្រជាជាតិនានា (SC ៣៧-៤០)។ "ដើម្បីឲ្យជាតិសាសន៍ទាំងអស់ បានស្គាល់គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ហើយឲ្យគេជឿ និងស្ដាប់តាម" (រម ១៦,២៦) ត្រូវតែប្រកាសលើកតម្កើង និងទទួលគម្រោងការនេះ ក្នុងវប្បធម៌ទាំងអស់ ទើបវប្បធម៌នោះមិនត្រូវលុបបំបាត់ទេ ប៉ុន្តែឲ្យព្រះអង្គលោះ និងបំពេញវប្បធម៌នោះវិញ (CT ៥៣)។ បុត្រធីតាដ៏រាប់មិនអស់អាចចូលទៅឯព្រះបិតារបស់គេបាន ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ នៅក្នុងព្រះវិញ្ញាណតែមួយ ដោយសារ និងតាមវប្បធម៌របស់គេផ្ទាល់ ដែលព្រះគ្រីស្តបានទទួលយក និងបានកែប្រែ។

១២០៥- "ក្នុងពិធីបុណ្យ ជាពិសេសក្នុងអគ្គសញ្ញា មានផ្នែកមួយដែលមិនអាចផ្លាស់ប្ដូរបាន -ដ្បិតមកពីព្រះជាម្ចាស់- ដែលព្រះសហគមន៍ត្រូវរក្សាទុក ហើយមានផ្នែកខ្លះៗ ដែលយើងអាចផ្លាស់ប្ដូរបាន ដែលព្រះសហគមន៍មានអំណាច ហើយពេលខ្លះមានភារកិច្ច សម្របផ្នែកនោះតាមវប្បធម៌របស់ជាតិសាសន៍ ដែលទើបនឹងទទួលដំណឹងល្អ" (សម្ដេចប៉ាប យ៉ូហាន ប៉ូល ទី២ ; SC ២១)។

១២០៦- "ពិធីបុណ្យផ្សេងៗពីគ្នាអាចធ្វើឲ្យព្រះសហគមន៍រីកចម្រើន ប៉ុន្តែអាចបង្កើតភាពតានតឹង ធ្វើឲ្យគ្រីស្តបរិស័ទមិនយល់ចិត្តគ្នា សូម្បីតែព្រះសហគមន៍អាចបាក់បែកគ្នាដែរ។ ក្នុងវិស័យនេះ ត្រូវតែយល់ឲ្យច្បាស់ថា ភាពផ្សេងពីគ្នាមិនអាចបង្ខូចឯកភាពបានឡើយ។ ព្រះសហគមន៍អាចមានពិធីបុណ្យផ្សេងៗពីគ្នា លុះត្រាតែពិធីទាំងអស់នោះស្របតាមជំនឿរួម អគ្គសញ្ញាដែលព្រះសហគមន៍បានទទួលពីព្រះគ្រីស្ត និងរួបរួមជាមួយនឹងក្រុមលំដាប់លំដោយ។ ត្រូវតែប្រែចិត្តគំនិត និងលះបង់ទំនៀមទម្លាប់ ដែលខុសពីជំនឿកាតូលិក ដើម្បីស្របតាមវប្បធម៌"(សម្ដេចប៉ាប យ៉ូហាន ប៉ូល ទី២ ; SC ២១)។

### សង្ខេប

១២០៧- គួរប្រារព្ធពិធីបុណ្យក្នុងវប្បធម៌នៃប្រជាជាតិ ដែលព្រះសហគមន៍ស្ថិតនៅ ដោយមិនចុះចូលនឹងវប្បធម៌នេះ។ ម្យ៉ាងទៀត ពិធីបុណ្យផ្ទាល់បង្កើត និងអប់រំវប្បធម៌។

១២០៨- ប្រពៃណីផ្សេងៗខាងពិធីបុណ្យ ឬពិធី ដែលព្រះសហគមន៍ទទួលស្គាល់ត្រឹមត្រូវ ព្រោះពិធីនោះ

សំដៅ និងបញ្ចូនគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត សម្តែងអំពីព្រះសហគមន៍សកល។

១២០៩- លក្ខណៈដែលធានាឯកភាពក្នុងប្រពៃណីផ្សេងៗនៃពិធីបុណ្យ គឺធ្វើតាមការបញ្ចូនបន្ត ដែលមកពីក្រុមគ្រីស្តទូត ពោលគឺការរួបរួមក្នុងជំនឿ និងអគ្គសញ្ញាដែលយើងបានទទួលពីក្រុមគ្រីស្តទូត។ អ្នកបន្តមុខងាររបស់ក្រុមគ្រីស្តទូតបង្ហាញ និងធានាការរួបរួមនេះ។

## ភាគទីពីរៈ

## អគ្គសញ្ញាទាំងប្រាំពីរនៃព្រះសហគមន៍

១២១០- ព្រះគ្រីស្តបានតែងតាំងអគ្គសញ្ញានៃធម៌វិន័យថ្មី។ អគ្គសញ្ញានោះមានប្រាំពីរ គឺអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្ងាស អគ្គសញ្ញាអរព្រះគុណ (អភិបូជា) អគ្គសញ្ញាលើកលែងទោស អគ្គសញ្ញាលាបប្រេងអ្នកជម្ងឺ អគ្គសញ្ញាតែងតាំង និងអគ្គសញ្ញាអាពាហ៍ពិពាហ៍។ អគ្គសញ្ញាទាំងប្រាំពីរប៉ះពាល់នឹងដំណាក់កាល និងវេលាសំខាន់ៗនៃជីវិតរបស់គ្រីស្តបរិស័ទ៖ អគ្គសញ្ញានោះ ផ្តល់កំណើត និងធ្វើឲ្យលូតលាស់ ជួយព្យាបាល និងផ្តល់បេសកកម្មដល់ជីវិតខាងជំនឿរបស់គ្រីស្តបរិស័ទ។ ហេតុនេះ ដំណាក់កាលនៃជីវិតខាងធម្មជាតិ និងដំណាក់កាលនៃជីវិតខាងវិញ្ញាណស្រដៀងគ្នា (សន្តៈ ថូម៉ាស នៃអាកាំង)។

១២១១- យោងតាមលក្ខណៈប្រៀបធៀបនេះ យើងនឹងបរិយាយអំពីអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ (ជំពូកទីមួយ ) បន្ទាប់មកអំពីអគ្គសញ្ញាជួយព្យាបាល (ជំពូកទីពីរ ) ទីបំផុតអំពីអគ្គសញ្ញា ដែលជួយគ្រីស្តបរិស័ទឲ្យរួបរួមគ្នា និងជួយគេក្នុងបេសកកម្មរបស់ខ្លួន (ជំពូកទីបី )។ ការរៀបចំនេះ មានរបៀបផ្សេងទៀត ប៉ុន្តែ ដោយរៀបចំអគ្គសញ្ញាបែបនេះ យើងអាចយល់ឃើញថា អគ្គសញ្ញាដូចជាសពាង្គកាយ ដែលអគ្គសញ្ញានីមួយៗមានតួនាទីដ៏សំខាន់។ ក្នុងសពាង្គកាយនេះ ពិធីអរព្រះគុណជាអគ្គសញ្ញាសំខាន់បំផុត ដ្បិតពិធីនេះជា "អគ្គសញ្ញានៃអគ្គសញ្ញា" គឺ "អគ្គសញ្ញាឯទៀតៗទាំងអស់ស្ថិតនៅក្រោមអភិបូជាដូចជាទីចុងក្រោយរបស់អគ្គសញ្ញានោះ" (សន្តៈ ថូម៉ាស នៃអាកាំង)។

## ជំពូកទីមួយៈ

## អគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ

១២១២- ការរស់នៅជាគ្រីស្តបរិស័ទចាក់ឫស លើអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ គឺមានអគ្គសញ្ញាជ្រមុជទឹក លាបថ្ងាស និងអរព្រះគុណ (អភិបូជា)។ "យើងអាចប្រៀបធៀបម្យ៉ាង ការចូលរួមចំណែកក្នុងសភាពជាព្រះជាម្ចាស់ ដែលព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្តបានប្រោសប្រទានឲ្យមនុស្សលោកជាមួយនឹងប្រភព ការលូតលាស់ និងការទ្រទ្រង់នៃជីវិតខាងធម្មជាតិ។ គ្រីស្តបរិស័ទ ដែលបានកើតជាថ្មីដោយសារអគ្គសញ្ញាជ្រមុជទឹក ទទួលកម្លាំងពីអគ្គសញ្ញាលាបថ្ងាស និងទទួលនំប៉័ងនៃជីវិតអស់កល្បជានិច្ចក្នុងអគ្គសញ្ញាអរព្រះគុណ។ ហេតុនេះ ហើយបានជាដោយសារអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ គ្រីស្តបរិស័ទតែងតែទទួលលក្ខណៈសម្បត្តិនៃព្រះជន្មរបស់ព្រះជាម្ចាស់កាន់តែច្រើនឡើងៗ ហើយដើរឆ្ពោះទៅភាពល្អឥតខ្ចោះនៃសេចក្តីស្រឡាញ់" (សម្តេចប៉ាប ប៉ូលទី៦)។

# ប្រការទី១៖

# អគ្គសញ្ញាជ្រមុជទឹក

១២១៣- អគ្គសញ្ញាជ្រមុជទឹកដ៏វិសុទ្ធជាមូលដ្ឋានគ្រឹះនៃការរស់នៅទាំងស្រុងរបស់គ្រីស្តបរិស័ទ ជាខ្លោងទ្វារនៃជីវិតក្នុងអង្គព្រះវិញ្ញាណ (vitae spiritualis ianua) និងជាទ្វារដែលបើកឲ្យទទួលអគ្គសញ្ញាឯទៀតៗ។ ដោយសារអគ្គសញ្ញាជ្រមុជទឹកយើងរួចពីបាប និងជាបុត្រធីតារបស់ព្រះជាម្ចាស់ យើងក្លាយទៅជាសិរីរាង្គរបស់ព្រះគ្រីស្ត និងចូលក្នុងព្រះសហគមន៍ដោយរួមចំណែកក្នុងបេសកកម្មរបស់ព្រះសហគមន៍(មហាសន្និបាតនៅទីក្រុងហ្លរង់៖ DS ១៣១៤ ; CIC ២០៤,១ ; ៨៤៩ ; CCEO ៦៧៥,១)៖ "អគ្គសញ្ញាជ្រមុជទឹកជាអគ្គសញ្ញានៃកំណើតថ្មីដោយសារទឹក និងក្នុងព្រះបន្ទូល" (CR ២,២,៥)។

## ១. តើគេហៅអគ្គសញ្ញានេះយ៉ាងដូចម្តេច?

១២១៤- គេហៅអគ្គសញ្ញានេះថា អគ្គសញ្ញាជ្រមុជទឹក ដ្បិតពិធីជ្រមុជក្នុងទឹក (baptizein ជាភាសាក្រិក) ដែលជាពិធីសំខាន់បំផុតនៃអគ្គសញ្ញានេះ ជានិមិត្តរូបថា អ្នកស្វែងយល់ត្រូវបញ្ចុះក្នុងសេចក្តីស្លាប់របស់ព្រះគ្រីស្ត ហើយមានជីវិតថ្មីរួមជាមួយព្រះអង្គ (រម ៦,៣-៤ ; កូឡ ២,១២)។ គេបាន "កើតសាជាថ្មី" (២ករ ៥,១៧ ; កាឡ ៦,១៥)។

១២១៥- គេហៅអគ្គសញ្ញានេះថា "ការលាងជំរះឲ្យបានកើតជាថ្មី និងការប្រទានឲ្យមានជីវិតថ្មី ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ" (ទត ៣,៥) ដ្បិតអគ្គសញ្ញានេះ សំដៅ និងសម្រេចកំណើតពីទឹក និងពីព្រះវិញ្ញាណនេះ ដែលជាចាំបាច់ដើម្បីចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ (យហ ៣,៥)។

១២១៦- "គេហៅការមុជទឹកនេះ ថា ការបំភ្លឺចិត្តគំនិត ដ្បិតព្រះជាម្ចាស់បំភ្លឺអស់អ្នកដែលទទួលការអប់រំ (ជំនឿ) នេះ..." (សន្តៈ យូស្តាំង)។ ដោយបានទទួលក្នុងអគ្គសញ្ញាជ្រមុជទឹកព្រះបន្ទូល "ជាពន្លឺដ៏ពិតប្រាកដដែលបំភ្លឺមនុស្សគ្រប់ៗរូប" (យហ ១,៩) អ្នកដែលបានជ្រមុជទឹក "ដែលទើបនឹងទទួលពន្លឺពីព្រះជាម្ចាស់" (ហប ១០,៣២) បានក្លាយទៅជា "បុត្រធីតានៃពន្លឺ" (១ថស ៥,៥) ហើយបានទៅជា "ពន្លឺ" ផ្ទាល់ខ្លួន (អភ ៥,៨)៖

អគ្គសញ្ញាជ្រមុជទឹកជាព្រះអំណោយទាន ដ៏ប្រសើរជាទីបំផុតនៃព្រះអំណោយទានផ្សេងទៀត របស់ព្រះជាម្ចាស់ (...)។ យើងហៅអគ្គសញ្ញានេះថា អំណោយ ការប្រោសប្រណី អភិសេក ការបំភ្លឺចិត្តគំនិត សម្លៀកបំពាក់ដែលមិនអាចរលួយបាន កំណើតថ្មី ត្រា និងអ្វីៗទាំងអស់ដែលមានតម្លៃដ៏ខ្ពង់ខ្ពស់បំផុត។ អំណោយ ដ្បិតយើងផ្តល់អគ្គសញ្ញានេះដល់អស់អ្នកដែលគ្មានយកអ្វីមកសោះ ការប្រោសប្រណី ដ្បិតយើងផ្តល់អគ្គសញ្ញានេះដល់មនុស្សគ្រប់រូប ទោះជាមានទោសក៏ដោយ ជ្រមុជទឹក ដ្បិតអំពើបាបត្រូវបញ្ចុះក្នុងទឹក អភិសេក ដ្បិតអគ្គសញ្ញាដ៏សក្ការៈនេះធ្វើឲ្យគេទៅជាស្តេច ការបំភ្លឺចិត្តគំនិត ដ្បិតអគ្គសញ្ញានេះជាពន្លឺដ៏ចិញ្ចចចិញ្ចែង សម្លៀកបំពាក់ ដ្បិតអគ្គសញ្ញានេះបាំងការអៀនខ្មាស់របស់យើង ការមុជទឹក ដ្បិតអគ្គសញ្ញានេះលាងត្រា ដ្បិតអគ្គសញ្ញានេះការពារយើង និងជាសញ្ញាថា ព្រះជាម្ចាស់ជាព្រះអម្ចាស់ (សន្តៈ គ្រេគ័រ នៃណាស៊ីអង់)។

## ២. ពិធីជ្រមុជទឹកក្នុងការចាត់ចែងនៃការសង្គ្រោះ

### និមិត្តរូបទុកជាមុននៃអគ្គសញ្ញាជ្រមុជទឹកក្នុងសម្ព័ន្ធមេត្រីចាស់

១២១៧- ក្នុងពិធីបុណ្យនៃរាត្រីបុណ្យចម្លង នៅពេលពិធីប្រសិទ្ធពរលើទឹក ព្រះសហគមន៍រំឭកយ៉ាងឧឡារិកនូវហេតុការណ៍ដ៏អស្ចារ្យនៃប្រវត្តិសាស្ត្រអំពីការសង្គ្រោះ ដែលរៀបចំទុកជាមុនគម្រោងការដ៏អស្ចារ្យនៃអគ្គសញ្ញាជ្រមុជទឹក៖

> បពិត្រព្រះអម្ចាស់! ដោយសារឫទ្ធានុភាពរបស់ព្រះអង្គៗតែងតែប្រព្រឹត្តការអស្ចារ្យ ដោយសារអគ្គសញ្ញាផ្សេងៗ ហើយតាំងពីដើមរៀងមក ព្រះអង្គសព្វព្រះហឫទ័យប្រើទឹកដែលព្រះអង្គបានបង្កើតមកដើម្បីសម្ដែងជាមុន អំពីព្រះហឫទ័យប្រោសប្រណីរបស់ព្រះអង្គតាមអគ្គសញ្ញាជ្រមុជទឹក (MR)។

១២១៨- តាំងពីកំណើតពីភពលោកមកម្ល៉េះ ទឹកដែលព្រះជាម្ចាស់បង្កើតដូចជាសត្វលោកដ៏សុភាពរាបសា និងគួរឲ្យសរសើរ ជាប្រភពនៃជីវិត ដែលបង្កើតជីវិត។ ក្នុងព្រះគម្ពីរដ៏វិសុទ្ធ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ "នៅរេរាពីលើផ្ទៃទឹក" (កណ ១,២)៖

> កាលពីដើមដំបូងបង្អស់ ព្រះវិញ្ញាណព្រះអង្គរេរាលើទឹក ដើម្បីឲ្យទឹកបានទទួលឫទ្ធានុភាព ដែលប្រោសឲ្យបានវិសុទ្ធ (MR)។

១២១៩- ព្រះសហគមន៍បានយល់ឃើញថា សំពៅរបស់លោកណូអេជានិមិត្តរូបអំពីការសង្គ្រោះ ដោយសារអគ្គសញ្ញាជ្រមុជទឹក។ តាមការពិត "មាននមនុស្សមួយចំនួនតូច ប្រាំបីនាក់តែប៉ុណ្ណោះ ដែលបានរួចជីវិតដោយសារទឹក" (១ពត្រ ៣,២០)៖

> ដោយទឹកជំនន់លិចផែនដី ព្រះអង្គបង្ហាញសញ្ញាសម្គាល់អំពីអគ្គសញ្ញាជ្រមុជទឹក ដែលផ្ដល់ឲ្យមនុស្សកើតជាថ្មី ព្រោះទឹកបានបំផ្លាញអំពើអាក្រក់គ្រប់យ៉ាង និងចាប់ផ្ដើមប្រោសឲ្យបានសុចរិត (MR)។

១២២០- បើទឹកទន្លេជានិមិត្តរូបនៃជីវិត ទឹកសមុទ្រជានិមិត្តរូបនៃសេចក្ដីស្លាប់។ ហេតុនេះហើយ បានជាទឹកអាចសំដៅទៅលើគម្រោងការដ៏អស្ចារ្យនៃព្រះឈើឆ្កាង។ ដោយសារនិមិត្តរូបនេះ ពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងរួមស្លាប់ជាមួយព្រះគ្រីស្ត។

១២២១- ការឆ្លងកាត់សមុទ្រក្រហម ដែលពិតជារំដោះជនជាតិអ៊ីស្រាអែលឲ្យរួចពីទាសភាពនៅប្រទេសអេស៊ីប ប្រកាសទុកជាមុនថា អគ្គសញ្ញាជ្រមុជទឹករំដោះឲ្យរួចពីបាប៖

> ព្រះអង្គបានប្រោសពូជពង្សរបស់លោកអប្រាហាំឲ្យដើរឆ្លងកាត់សមុទ្រក្រហម ដើម្បីឲ្យប្រជាជនអ៊ីស្រាអែលដែលរួចពីកណ្ដាប់ដៃខ្មាំងសត្រូវនេះ ធ្វើជានិមិត្តរូបនៃប្រជារាស្ត្រនៃបុត្រធីតារបស់ព្រះជាម្ចាស់ (MR)។

១២២២- ទីបំផុត ការឆ្លងកាត់ទន្លេយ័រដាន់ជានិមិត្តរូបទុកជាមុននៃអគ្គសញ្ញាជ្រមុជទឹក។ ពេលនោះ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទទួលព្រះអំណោយទាននៃទឹកដី ដែលព្រះអង្គបានសន្យា ដល់ពូជពង្សរបស់លោកអប្រាហាំ ហើយដែលតំណាងជីវិតអស់កល្បជានិច្ច។ ព្រះបន្ទូលសន្យានៃមរតកដ៏ល្អប្រសើរនេះកើតជារូបរាងក្នុងសម្ព័ន្ធមេត្រីថ្មី។

## ពិធីជ្រមុជទឹករបស់ព្រះគ្រីស្ត

១២២៣- ព្រះគ្រីស្តយេស៊ូបំពេញនិមិត្តរូបទាំងប៉ុន្មាននៃសម្ពន្ធមេត្រីចាស់។ ព្រះអង្គចាប់ផ្តើមជីវិតជាសាធារណៈរបស់ព្រះអង្គ ក្រោយពីបានទទួលពិធីជ្រមុជទឹកពីសន្តៈ យ៉ូហាន បាទីស្ត ក្នុងទន្លេយ័រដាន់ (មថ ៣,១៣) ហើយក្រោយពីបានមានព្រះជន្មថ្មី ព្រះអង្គផ្តល់បេសកកម្មនេះទៅក្រុមគ្រិស្តទូត៖ "ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវបង្រៀនគេឲ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា" (មថ ២៨,១៩-២០) (មក ១៦,១៥-១៦)។

១២២៤- ព្រះអម្ចាស់នៃយើងបានស្ម័គ្រចិត្តទទួលពិធីជ្រមុជទឹកពីសន្តៈ យ៉ូហាន ដែលមានសម្រាប់អ្នកបាប ដើម្បី "ស្របតាមសេចក្តីសុចរិតដែលព្រះជាម្ចាស់បានបង្គាប់ទុក" (មថ ៣,១៥)។ កាយវិការរបស់ព្រះយេស៊ូនេះសម្តែងឲ្យយើងដឹងថា ព្រះអង្គ "បានលះបង់អ្វីៗទាំងអស់" (ភីល ២,៧)។ ព្រះវិញ្ញាណដែលរេរាលើទឹកនៃការបង្កើតដំបូងយាងចុះមកសណ្ឋិតលើព្រះគ្រីស្តដើម្បីចាប់ផ្តើមការបង្កើតថ្មី ហើយព្រះបិតាសម្តែងឲ្យយើងដឹងថាព្រះយេស៊ូជា "ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ" (មថ ៣,១៦-១៧)។

១២២៥- ព្រះគ្រីស្តបានបើកប្រភពនៃពិធីជ្រមុជទឹកឲ្យមនុស្សទាំងអស់ក្នុងបុណ្យចម្លងរបស់ព្រះអង្គ។ តាមការពិត ព្រះអង្គមានព្រះបន្ទូលអំពីទុក្ខលំបាកដែលព្រះអង្គនឹងរងនៅទីក្រុងយេរូសាឡឹម ដូចជា "ពិធីជ្រមុជ" ដែលព្រះអង្គត្រូវតែទទួល (មក ១០,៣៨) (លក ១២,៥០)។ ព្រះលោហិត និងទឹកដែលហូរចេញពីឆ្អឹង ជំនីរបស់ព្រះយេស៊ូដែលត្រូវវង្គាង (យហ ១៩,៣៤) ជានិមិត្តសញ្ញានៃពិធីជ្រមុជទឹក និងពិធីអរព្រះគុណ ដែលជាអគ្គសញ្ញានៃជីវិតថ្មី (១យហ ៥,៦-៨)៖ ហេតុនេះ យើងអាច "កើតពីទឹក និងពីព្រះវិញ្ញាណ" ដើម្បីចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ (យហ ៣,៥)។

> ចូរគិតថា តើអ្នកជ្រមុជនៅឯណា តើពិធីជ្រមុជទឹកមកពីណា ក្រៅពីព្រះឈើឆ្កាងនៃព្រះគ្រីស្ត ក្រៅពីមរណភាពរបស់ព្រះគ្រីស្ត? គម្រោងការដ៏លាក់កំបាំងទាំងមូលស្ថិតនៅទីនោះ គឺព្រះអង្គបានរងទុក្ខលំបាកសម្រាប់អ្នក។ អ្នករួចពីបាប ក្នុងអង្គព្រះអង្គ អ្នកបានទទួលការសង្គ្រោះក្នុងអង្គព្រះអង្គ (សន្តៈ អំប្រ៉ូស)។

## ពិធីជ្រមុជទឹកក្នុងព្រះសហគមន៍

១២២៦- លុះដល់ថ្ងៃព្រះវិញ្ញាណយាងមក ព្រះសហគមន៍បានប្រារព្ធ និងផ្តល់អគ្គសញ្ញាជ្រមុជទឹកដ៏វិសុទ្ធ។ សន្តៈសិលាប្រកាសចំពោះបណ្តាជនដែលរំជួលចិត្ត ដោយសារធម្មធម្មទេសនាទេសនារបស់លោកថា៖ "សូមបងប្អូនកែប្រែចិត្តគនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ដើម្បីឲ្យព្រះជាម្ចាស់លើកលែងទោសបងប្អូនឲ្យរួចពីបាប ហើយបងប្អូននឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាអំណោយទានរបស់ព្រះជាម្ចាស់" (កក ២,៣៨)។ ក្រុមគ្រីស្តទូត និងសហការីរបស់ពួកលោក ផ្តល់ពិធីជ្រមុជទឹកដល់អស់អ្នកដែលផ្ញើជីវិតលើព្រះយេស៊ូ គឺជនជាតិយូដា អស់អ្នកដែលគោរពកោតខ្លាចព្រះជាម្ចាស់ និងសាសន៍ដទៃ (កក ២,៤១ ; ៨,១២-១៣ ; ១០,៤៨ ; ១៦,១៥)។ ពិធីជ្រមុជទឹកតែងតែជាប់ទាក់ទិននឹងជំនឿ៖ សន្តៈ ប៉ូល មានប្រសាសន៍ទៅកាន់ឆ្មាំគុករបស់គាត់នៅភីលីពថា៖ "សូមជឿលើព្រះអម្ចាស់យេស៊ូទៅ នោះព្រះជាម្ចាស់នឹងសង្គ្រោះលោក ព្រមទាំងសង្គ្រោះក្រុមគ្រួសាររបស់លោកផងដែរ" ហើយ "ឆ្មាំគុក និងក្រុមគ្រួសាររបស់គាត់ក៏បានទទួលពិធីជ្រមុជទឹកភ្លាម" (កក ១៦,៣១-៣៣)។

១២២៧- តាមគ្រីស្តទូតប៉ូល ដោយសារពិធីជ្រមុជទឹក អ្នកជឿរួមស្លាប់ជាមួយព្រះគ្រីស្ត គេចូលទៅក្នុងផ្នូរ និងមានជីវិតថ្មីជាមួយព្រះអង្គ៖

យើងទាំងអស់គ្នាដែលបានទទួលពិធីជ្រមុជទឹក ដើម្បីរួមជាមួយព្រះគ្រីស្តយេស៊ូនោះ គឺយើងបានជ្រមុជរួមជាមួយព្រះអង្គដែលសោយទិវង្គត។ ហេតុនេះ ដោយពិធីជ្រមុជទឹក ដើម្បីរួមស្លាប់ជាមួយព្រះអង្គ យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ។ ដូច្នេះ ព្រះគ្រីស្តមានព្រះជន្មថ្មី ដោយសារសិរីរុងរឿងរបស់ព្រះបិតាយ៉ាងណា យើងក៏រស់នៅតាមរបៀបថ្មីយ៉ាងនោះដែរ (រម ៦,៣-៤) (កូឡ២,១២)។

អស់អ្នកដែលបានទទួលពិធីជ្រមុជទឹក "មានព្រះគ្រីស្តជាប់ជាមួយដែរ" (កាឡ ៣,២៧)។ ដោយ សារព្រះវិញ្ញាណដ៏វិសុទ្ធ ពិធីជ្រមុជទឹកបន្សុទ្ធ ធ្វើឲ្យបានវិសុទ្ធ និងធ្វើឲ្យទៅជាសុចរិត (១ករ ៦,១១ ; ១២,១៣)។

១២២៨-អ្នកទទួលពិធីជ្រមុជទឹកដូចជាមុជទឹកហើយ"ពូជដែលមិនចេះរលួយ"នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្តល់ជីវិត (១ពត្រ ១,២៣ ; អភ ៥,២៦)។ និយាយអំពីពិធីជ្រមុជទឹក សន្តៈ អូគូស្តាំងមានប្រសាសន៍ថា៖ "ព្រះបន្ទូលយាងមកជួបវត្ថុធាតុ ហើយក្លាយទៅជាអគ្គសញ្ញា"។

## ៣. តើព្រះសហគមន៍ប្រារព្ធអគ្គសញ្ញាជ្រមុជទឹកយ៉ាងដូចម្តេច?

### ការបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ

១២២៩- តាំងពីសម័យក្រុមគ្រីស្តទូតមកម្ល៉េះ យើងក្លាយទៅជាគ្រីស្តបរិស័ទដោយដើរតាមផ្លូវមួយ ដែលមានដំណាក់កាលជាច្រើន។ យើងអាចដើរតាមផ្លូវនេះ យឺតៗ ឬលឿន ក៏បានដែរ។ ផ្លូវនេះ មានចំណុចសំខាន់ៗខ្លះៗ ដូចជាការប្រកាសព្រះបន្ទូល ការទទួលដំណឹងល្អដែលនាំឲ្យកែប្រែចិត្តគំនិត ការប្រកាសជំនឿ ពិធីជ្រមុជទឹក ការចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ ការទទួលព្រះកាយព្រះគ្រីស្ត។

១២៣០- ការបង្ហាត់នេះ បានផ្លាស់ប្តូរជាច្រើនដងតាមសតវត្ស និងតាមកាលៈទេសៈ។ នៅសតវត្សដំបូងនៃព្រះសហគមន៍ ការបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទបានរីកចម្រើនច្រើន។ អ្នកស្វែងយល់ ត្រូវរៀបចំខ្លួនយ៉ាងយូរដោយមានពិធីជួយត្រៀមខ្លួនជាបន្តបន្ទាប់ ជាដំណាក់កាលខាងពិធីបុណ្យនៃផ្លូវរបស់អ្នកស្វែងយល់ រហូតដល់ពួកគេទទួលអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ។

១២៣១- នៅទីនោះពិធីជ្រមុជទឹករបស់កូនក្មេងបានទៅជាពិធីធម្មតានៃពិធីប្រារព្ធអគ្គសញ្ញានេះ ពិធីនេះ បានក្លាយទៅជាកិច្ចការតែមួយ ដែលសង្ខេបយ៉ាងខ្លីដំណាក់កាលទាំងប៉ុន្មាន មុននឹងទៅជាគ្រីស្តបរិស័ទពេញលេញ។ ពិធីជ្រមុជទឹករបស់កូនក្មេងទាមទារឲ្យមានការបង្ហាត់ក្រោយពីបានជ្រមុជទឹក គឺមិនគ្រាន់តែបង្រៀនគេក្រោយពីបានជ្រមុជទឹកប៉ុណ្ណោះទេ ថែមទាំងឲ្យការប្រោសប្រណីនៃពិធីជ្រមុជទឹករីកចម្រើនក្នុងខ្លួនអ្នកដែលបានជ្រមុជទឹកដែរ។ នេះគឺជាតួនាទីរបស់ការអប់រំជំនឿ ។

១២៣២- ចំពោះព្រះសហគមន៍ខាងបស្ចិមប្រទេស មហាសន្និបាតវ៉ាទីកង់ទីពីរបានកែឡើងវិញ "ក្បួនបង្ហាត់មនុស្សពេញវ័យឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ ដោយមានដំណាក់កាលប្លែកពីគ្នាជាច្រើន" (SC ៦៤) ដែលពិធីផ្សេងៗមាននៅក្នុង "Ordo initiationis christinae adultorum (១៩៧២)។ ម្យ៉ាងទៀត នៅក្នុងប្រទេសដែលមានមនុស្សជាច្រើនមិនស្គាល់ព្រះគ្រីស្ត "ក្រៅពីពិធីបញ្ចូលគ្រីស្តសាសនាតាមប្រពៃណីយើងនេះ មហាសន្និបាតបានអនុញ្ញាតឲ្យទទួលកត្តាខ្លះៗដកស្រង់ពីពិធីផ្សេងៗបញ្ចូលសាសនាតាមប្រពៃណីរបស់គេ ដូចមាន

ឃើញប្រជាជននីមួយៗតែងតែប្រព្រឹត្តនោះ។ យើងអាចសម្រួលពិធីទាំងនោះឲ្យបានស្របតាមពិធីគ្រីស្តសាសនាបាន។" ( SC ៦៥ ; SC ៣៧-៤០ )។

១២៣៣- ដូច្នេះហើយ បានជាសព្វថ្ងៃនេះ ក្នុងពិធីទាំងអស់ខាងបស្ចិម និងបូព៌ាប្រទេស ការបង្ហាត់មនុស្សពេញវ័យឲ្យទៅជាគ្រីស្តបរិស័ទពេញលេញចាប់ផ្តើមដោយពិធីចូលព្រះសហគមន៍ រហូតដល់ការប្រារព្ធតែម្តងគត់អគ្គសញ្ញាទាំងបី គឺអគ្គសញ្ញាជ្រមុជទឹក លាបថ្ងាស និងអរព្រះគុណ ( AG ១៤ ; CIC ៨៥១ ; ៨៦៥ ; ៨៦៦ )។ ក្នុងពិធីខាងបូព៌ាប្រទេស ការបង្ហាត់កូនក្មេងចាប់ផ្តើមនៅពេលដែលគេជ្រមុជទឹក ដែលមានអគ្គសញ្ញាលាបថ្ងាស និងអរព្រះគុណជាបន្តបន្ទាប់ភ្លាមៗនោះ ឯខាងបស្ចិមប្រទេសវិញ មានការអប់រំជំនឿអស់រយៈពេលជាច្រើនឆ្នាំ ដែលបញ្ចប់ដោយអគ្គសញ្ញាលាបថ្ងាស និងអរព្រះគុណ ដែលជាចំណុចកំពូលនៃការបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ ( CIC ៨៥១ ; ៨៦៨ )។

## ការអប់រំដោយអគ្គសញ្ញា

១២៣៤- យើងអាចយល់ឃើញយ៉ាងច្បាស់អំពីអត្ថន័យ និងព្រះអំណោយទានរបស់អគ្គសញ្ញាជ្រមុជទឹក តាមរយៈពិធីផ្សេងៗនៃពិធីបុណ្យនេះ។ដោយចូលរួមចំណែកយ៉ាងសកម្មក្នុងកាយវិការនិងពាក្យសម្តីនៃពិធីបុណ្យនេះ គ្រីស្តបរិស័ទចាប់ផ្តើមយល់អំពីលក្ខណៈសម្បត្តិដែលអគ្គសញ្ញានេះសម្តៅ និងសម្រេចចំពោះអ្នកជ្រមុជទឹកគ្រប់រូប។

១២៣៥- នៅពេលចាប់ផ្តើមពិធីបុណ្យសញ្ញាឈើឆ្កាង ជាស្លាកស្នាមរបស់ព្រះគ្រីស្តលើអ្នក ដែលនឹងទៅជាកម្មសិទ្ធិរបស់ព្រះអង្គ ហើយសម្តៅទៅលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្ត ដែលបានសង្គ្រោះយើងនៅលើឈើឆ្កាង។

១២៣៦- ការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ បំភ្លឺបេក្ខជន និងអង្គប្រជុំ អំពីសេចក្តីពិតដែលព្រះជាម្ចាស់សម្តែងឲ្យស្គាល់ ហើយជំរុញឲ្យផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ ដែលមិនអាចបំបែកពីអគ្គ សញ្ញាជ្រមុជទឹកបានឡើយ។ តាមការពិត ពិធីជ្រមុជទឹកជា "អគ្គសញ្ញានៃជំនឿ" តាមរបៀបពិសេស ដ្បិតដោយ សារអគ្គសញ្ញានេះ យើងចូលក្នុងជីវិតនៃជំនឿខាងអគ្គសញ្ញា។

១២៣៧- ដោយសារពិធីជ្រមុជទឹកមានន័យថា ព្រះជាម្ចាស់រំដោះអ្នកស្វែងយល់ឲ្យរួចពីអំពើបាប និងពីមារកំណាច យើងធ្វើពិធីបណ្តេញខ្មោចលើបេក្ខជន។ យើងចាក់ប្រេង ឬដាក់ដៃលើគេ ហើយគេលះបង់មារចោលយ៉ាងច្បាស់លាស់។ ដោយសារគេបានត្រៀមខ្លួនបែបនេះ គេអាចប្រកាសជំនឿរបស់ព្រះសហគមន៍ ដែលយើងនឹង "ប្រគល់ឲ្យ" គេដោយសារពិធីជ្រមុជទឹក ( រម ៦,១៧ )។

១២៣៨- យើងប្រសិទ្ធពរលើទឹក ដោយពាក្យអង្វរឲ្យព្រះវិញ្ញាណយាងមក ( នៅវេលាដដែល ឬនៅរាត្រីបុណ្យចម្លង )។ ព្រះសហគមន៍ទូលអង្វរព្រះជាម្ចាស់ឲ្យឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះក្នុងទឹកនេះ ដោយសារព្រះបុត្រារបស់ព្រះអង្គ ដើម្បីឲ្យអស់អ្នកដែលនឹងជ្រមុជ "កើតពីទឹក និងពីព្រះវិញ្ញាណ" ( យហ ៣,៥ )។

១២៣៩- បន្ទាប់មក មានពិធីសំខាន់បំផុត នៃអគ្គសញ្ញា គឺពីធីជ្រមុជទឹក តែម្តង ដែលសម្តែង និងសម្រេចថាអ្នកជ្រមុជទឹកបានស្លាប់នឹងអំពើបាប ហើយបានចូលក្នុងព្រះជន្មនៃព្រះត្រៃឯកដ៏វិសុទ្ធបំផុត ដោយរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្ត។ ការជ្រមុជក្នុងទឹកបីដងសម្តែងយ៉ាងច្បាស់លាស់ពិធីជ្រមុជទឹក ប៉ុន្តែ តាំងពីបុរាណកាល យើងអាចចាក់ទឹកបីដងលើក្បាលរបស់អ្នកដែលជ្រមុជទឹក។

១២៤០-ក្នុងព្រះសហគមន៍ខាងបស្ចិមប្រទេសពេលចាក់ទឹកបីដងនោះអ្នកទទួលមុខងារបម្រើព្រះសហគមន៍

មានប្រសាសន៍ថា៖ "ឈ្មោះ ខ្ញុំជ្រមុជអ្នក ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"។ ក្នុងពិធីបុណ្យខាងបូព៌ាប្រទេស ដោយអ្នកស្វែងយល់បែរមុខទៅខាងបូព៌ា លោកបូជាចារ្យមានប្រសាសន៍ថា៖ "អ្នកបម្រើរបស់ព្រះជាម្ចាស់ ឈ្មោះ ទទួលពិធីជ្រមុជទឹក ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" ហើយរាល់ពេលលោកអង្វរព្រះមួយព្រះអង្គនៃព្រះត្រៃឯក លោកជ្រមុជគេក្នុងទឹក និងលើកគេឡើងវិញ។

១២៤១- ការចាក់ប្រេងគ្រីស្មា ជាប្រេងក្រអូបដែលលោកអភិបាលបានប្រសិទ្ធពរ សម្ដែងនូវព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធចំពោះអ្នកដែលបានជ្រមុជទឹក។ គេបានក្លាយទៅជាគ្រីស្ដបរិស័ទ គឺគេ បានទទួលការ "អភិសេក" នៃព្រះវិញ្ញាណដ៏វិសុទ្ធ រួមចំណែកជាមួយព្រះគ្រីស្ដ ដែលបានទទួលការអភិសេកជាបូជាចារ្យ ជាព្យាការី និងជាព្រះមហាក្សត្រ (OBP ៦២)។

១២៤២- ក្នុងពិធីបុណ្យនៃព្រះសហគមន៍ខាងបូព៌ាប្រទេស ពិធីចាក់ប្រេងក្រោយពីបានជ្រមុជទឹកជាអគ្គសញ្ញាគ្រីស្មា (លាបថ្ងាស)។ក្នុងពិធីបុណ្យខាងបស្ចិមប្រទេសពិធីនេះប្រកាសទុកជាមុនថាលោកអភិបាលនឹងចាក់ប្រេងគ្រីស្មាម្ដងទៀត ពោលគឺអគ្គសញ្ញាលាបថ្ងាសដែលដូចជា "បញ្ជាក់" និងបង្ហើយពិធីអភិសេកពេលជ្រមុជទឹក។

១២៤៣* ពិធីបំពាក់អាវសឆើតឆាយ ជានិមិត្តរូបថា អ្នកដែលបានជ្រមុជទឹក "មានព្រះគ្រីស្ដជាប់ជាមួយ" (កាឡ ៣,២៧) គឺគេបានមានជីវិតថ្មីជាមួយព្រះគ្រីស្ដ។ ទៀន ដែលយើងអុជទៅនឹងទៀនព្រះជ័យ សម្ដែងថាព្រះគ្រីស្ដបានបំភ្លឺអ្នកពន្លកថ្មី។ ក្នុងព្រះគ្រីស្ដ អ្នកដែលបានជ្រមុជទឹកជា "ពន្លឺនៃពិភពលោក" (មថ ៥,១៤) (ភីល ២,១៥)។ អ្នកដែលបានជ្រមុជទឹកថ្មីនេះ បានទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ក្នុងអង្គព្រះបុត្រាតែមួយ។ គេអាចសូត្រធម៌សេចក្ដីអធិដ្ឋាននៃបុត្រធីតារបស់ព្រះជាម្ចាស់៖ ឱព្រះបិតានៃយើងខ្ញុំ។

១២៤៤- ពិធីទទួលព្រះកាយព្រះលោហិតជាលើកទីមួយ។ ដោយសារគេបានទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ និងបានបំពាក់អាវនៃពិធីមង្គលការ អ្នកពន្លកថ្មីអាចចូលរួមក្នុង "ពិធីមង្គលការរបស់កូនចៀម" ហើយទទួលអាហារនៃជីវិតថ្មី គឺព្រះកាយ និងព្រះលោហិតព្រះគ្រីស្ដ។ ព្រះសហគមន៍ខាងបូព៌ាប្រទេសរក្សាទុកឯកភាពនៃពិធីបង្ហាត់ឲ្យទៅជាគ្រីស្ដបរិស័ទ ដោយជូនព្រះកាយព្រះលោហិតព្រះគ្រីស្ដដល់អស់អ្នកដែលបានជ្រមុជទឹក និងបានទទួលអគ្គសញ្ញាលាបថ្ងាស សូម្បីតែដល់កូនក្មេងដែរ ដោយរំឭកអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់៖ "ទុកឲ្យក្មេងៗមករកខ្ញុំចុះ កុំឃាត់ពួកវាឡើយ" (មក ១០,១៤)។ ព្រះសហគមន៍ខាងបស្ចិមប្រទេស ដែលមានតែអ្នកចេះដឹងខ្លួនអាចទទួលព្រះកាយព្រះគ្រីស្ដ សម្ដែងថា អគ្គសញ្ញាអរព្រះគុណតាមអគ្គសញ្ញាជ្រមុជទឹក ដោយ យកកូនក្មេងដែលទើបបានជ្រមុជទឹកទៅជិតអាសនៈដើម្បីសូត្រធម៌ឱព្រះបិតានៃយើងខ្ញុំ។

១២៤៥- ពិធីប្រទានពរយ៉ាងឧឡារិក បញ្ចប់ពិធីជ្រមុជទឹក។ នៅពេលដែលមានកូនក្មេងទើបកើតបានជ្រមុជទឹក យើងប្រទានពរដល់ម្ដាយរបស់កូននេះតាមរបៀបពិសេស។

## ៤. តើអ្នកណាអាចទទួលពិធីជ្រមុជទឹកបាន?

១២៤៦- "អ្នកណាដែលមិនទាន់បានទទួលពិធីជ្រមុជទឹកអាចទទួលពិធីជ្រមុជទឹក ហើយមានតែអ្នកនោះដែលអាចទទួលបាន" (CIC ៨៦៤)។

### ពិធីជ្រមុជទឹករបស់មនុស្សពេញវ័យ

១២៤៧- តាំងពីដើមដំបូងនៃព្រះសហគមន៍ ក្នុងកន្លែងដែលយើងទើបតែប្រកាសដំណឹងល្អ ពិធីជ្រមុជទឹក

របស់មនុស្សពេញវ័យជាស្ថានភាពធម្មតា។ ដូច្នេះ ការបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ (ការត្រៀមខ្លួនទទួលពិធីជ្រមុជទឹក) មានសារៈសំខាន់។ការបង្ហាត់នេះត្រូវតែណែនាំឲ្យធ្វើជីវិតលើព្រះជាម្ចាស់ និងឲ្យមានរបៀបរស់នៅតាមគ្រីស្តសាសនា ហើយរៀបចំឲ្យទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់ ក្នុងអគ្គសញ្ញាជ្រមុជទឹក លាបថ្វាស និងអរព្រះគុណ។

១២៤៨ ការបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទ ឬការអប់រំអ្នកស្វែងយល់ មានគោលដៅឲ្យអ្នកនោះ កែប្រែចិត្តគំនិត និងធ្វើជីវិតទាំងស្រុងទៅលើព្រះអង្គ ដោយឆ្លើយតបនឹងព្រះជាម្ចាស់ និងដោយរួបរួមជាមួយនឹងសហគមន៍មួយ។ "ការអប់រំជំនឿនោះ (...) ជាការហ្វឹកហ្វឺនឲ្យគេរស់នៅបែបជាគ្រីស្តបរិស័ទក្នុងគ្រប់វិស័យប្រចាំជីវិត (...)។ សាវ័ករបស់ព្រះគ្រីស្តរួបរួមជាមួយព្រះបរមគ្រូ ដោយទទួលការអប់រំ និងហ្វឹកហ្វឺនផងដែរ។ ហេតុនេះហើយបានជាត្រូវណែនាំអ្នកទទួលការអប់រំជំនឿទាំងនោះ ឲ្យចូលក្នុងគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះយ៉ាងសមរម្យ និងត្រូវបង្ហាត់គេឲ្យរស់នៅស្របតាមបែបដំណឹងល្អទៀតផង។ ត្រូវណែនាំគេដោយពិធីផ្សេងៗតាមពេលវេលាជាលំដាប់លំដោយ ឲ្យចូលរួមក្នុងរបៀបរស់នៅតាមជំនឿ ឲ្យចូលរួមក្នុងពិធីបុណ្យនានានៃព្រះសហគមន៍ ព្រមទាំងឲ្យគេមានចិត្តស្រឡាញ់ ស្របតាមប្រជារាស្ត្ររបស់ព្រះជាម្ចាស់ផង" (AG ១៤ ; OICA ១៩ និង ៩៨)។

១២៤៩- "អ្នកស្វែងយល់ក៏នៅក្នុងព្រះដំណាក់ព្រះគ្រីស្តរួចហើយដែរ។ ជារឿយៗ គេរស់នៅដោយមានជំនឿមាំមួន មានចិត្តសង្ឃឹម និងមានចិត្តស្រឡាញ់ផង" (AG ១៤)។ "ព្រះសហគមន៍ដែលប្រៀបដូចជាម្តាយ ក៏ចាប់ផ្តើមយកចិត្តទុកដាក់នឹងគេ ថ្នាក់ថ្នមថែទាំគេក្នុងឋានៈជាកូនចៅ ដោយចិត្តស្រឡាញ់ដែរ" (LG ១៤ ; CIC ២០៦ ; ៧៨៨,៣)។

### ពិធីជ្រមុជទឹករបស់កូនក្មេង

១២៥០- សភាពជាមនុស្សត្រូវរបួសដោយសារអំពើបាប ដូច្នេះហើយ បានជាពេលកើតមក សូម្បីតែកូនក្មេងត្រូវតែកើតជាថ្មីក្នុងអគ្គសញ្ញាជ្រមុជទឹកដែរ (DS១៥១៤) ដើម្បីឲ្យរួចពីអំណាចនៃភាពងងឹតនិងចូលក្នុងសេរីភាពនៃបុត្រធីតារបស់ព្រះជាម្ចាស់ (កូឡ១,១២-១៤) ដែលព្រះអង្គត្រាស់ហៅមនុស្សទាំងអស់។ យើងអាចយល់ឃើញយ៉ាងជាក់ច្បាស់អំពីព្រះអំណោយដ៏ឥតគិតថ្លៃនៃការសង្គ្រោះ ក្នុងពិធីជ្រមុជទឹករបស់កូនក្មេង។ បើមិនផ្តល់ពិធីជ្រមុជទឹកដល់កូនក្មេងក្រោយពីបានកើតមកទេ ព្រះសហគមន៍ និងឪពុកម្តាយនឹងមិនផ្តល់ឲ្យ កូនក្មេងនេះបានទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដែលជាព្រះអំណោយទានដ៏លើសលប់ក្រៃលែង (CIC ៨៦៧ ; CCEO ៦៨១ ; ៦៨៦)។

១២៥១- ឪពុកម្តាយជាគ្រីស្តបរិស័ទត្រូវទទួលស្គាល់ថា ទំនៀមទម្លាប់នេះស្របនឹងតួនាទីរបស់គេ ដែលព្រះជាម្ចាស់បានប្រគល់ឲ្យ គឺឲ្យគេចិញ្ចឹមកូន (LG ១១ ; ៤១ ; GS ៤៨ ; CIC ៨៦៨)។

១២៥២- ទំនៀមទម្លាប់ជ្រមុជទឹកកូនក្មេងជាប្រពៃណីដ៏យូរអង្វែងរបស់ព្រះសហគមន៍។ គេបញ្ជាក់យ៉ាងច្បាស់អំពីប្រពៃណីនេះតាំងពីសតវត្សទីពីរ។ក៏ប៉ុន្តែ គេអាចផ្តល់ពិធីជ្រមុជទឹកដល់កូនក្មេង (CDF) តាំងពីសម័យក្រុមគ្រីស្តទូត គឺនៅពេល "ក្រុមគ្រួសារទាំងមូល" បានទទួលពិធីជ្រមុជទឹក (កក ១៦,១៥.៣៣ ; ១៨,៨ ; ១ករ ១,១៦) ។

### ជំនឿ និងពិធីជ្រមុជទឹក

១២៥៣- ពិធីជ្រមុជទឹកជាអគ្គសញ្ញានៃជំនឿ (មក ៦,១៦)។ ប៉ុន្តែ អ្នកជឿត្រូវការសហគមន៍របស់អ្នកជឿឯទៀតៗ។ គ្រីស្តបរិស័ទម្នាក់ៗអាចជឿតែក្នុងជំនឿរបស់ព្រះសហគមន៍ប៉ុណ្ណោះ។ មិនបាច់ឲ្យអ្នកស្វែងយល់មានជំនឿគ្រប់លក្ខណៈ និងមាំមួនទេ ឲ្យតែគេចាប់ផ្តើមមានជំនឿដែលនឹងរីកចម្រើន បានហើយ។ យើងសួរទៅអ្នកស្វែងយល់ ឬបងធម៌របស់គេថា៖ "តើអ្នកសុំអ្វីពីព្រះសហគមន៍?" ហើយគេឆ្លើយថា៖ "ជំនឿ!"។

១២៥៤- ជំនឿត្រូវតែរីកចម្រើនក្រោយពី មនុស្សបានជ្រមុជទឹក ទោះជាកូនក្មេង ឬមនុស្សពេញវ័យយ៉ាងណាក៏ដោយ។ ហេតុនេះហើយ បានជារៀងរាល់ឆ្នាំ នៅក្នុងរាត្រីបុណ្យចម្លង ព្រះសហគមន៍រំឭកពាក្យសន្យានៃពិធីជ្រមុជទឹកឡើងវិញ។ ការត្រៀមខ្លួនឲ្យជ្រមុជទឹករៀបចំតែឲ្យចូលក្នុងជីវិតថ្មីប៉ុណ្ណោះ។ ពិធីជ្រមុជទឹកជាប្រភពនៃជីវិតថ្មីក្នុងអង្គព្រះគ្រីស្ត ហើយជីវិតទាំងស្រុងរបស់គ្រីស្តបរិស័ទផុសចេញពីព្រះអង្គ។

១២៥៥ ដើម្បីឲ្យព្រះអំណោយទាននៃពិធីជ្រមុជទឹកអាចរីកចម្រើនបាន ឪពុកម្តាយត្រូវតែជួយ ដូចឪពុកម្តាយធម៌ដែរ។ ឪពុកម្តាយធម៌ត្រូវតែជាមនុស្សដែលមានជំនឿរឹងមាំ ដែលអាច និងត្រៀមខ្លួនជួយអ្នកដែលទើបជ្រមុជទឹក ទោះជាកូនក្មេង ឬមនុស្សពេញវ័យក្តី នៅតាមផ្លូវរបស់គេ ក្នុងការរស់នៅជាគ្រីស្តបរិស័ទ (CIC ៨៧២-៨៧៤)។ តួនាទីរបស់ពួកគេពិតជាមុខងារនៃព្រះសហគមន៍ (officium) (SC ៦៧)។ ព្រះសហគមន៍ទាំងមូលទទួលខុសត្រូវ ក្នុងការលាតសន្ធឹង និងការរក្សាទុកព្រះអំណោយទានដែលមកពីពិធីជ្រមុជទឹក។

## ៥. តើអ្នកណាអាចផ្តល់ពិធីជ្រមុជទឹកបាន?

១២៥៦- ជាធម្មតា អ្នកផ្តល់ពិធីជ្រមុជទឹក គឺមានលោកអភិបាល និងលោកបូជាចារ្យ ហើយនៅក្នុងព្រះសហគមន៍ខាងបស្ចិមប្រទេស លោកឧបដ្ឋាកផងដែរ (CIC ៨៦១,១ ; CCEO ៦៧៧,១)។ បើមានការចាំបាច់ ទោះជាអ្នកមិនបានទទួលពិធីជ្រមុជទឹកក៏ដោយ ក៏អាចផ្តល់ពិធីជ្រមុជទឹកបាន លុះត្រាតែគេមានបំណងផ្តល់ពិធីនេះ គឺមានបំណងចង់ធ្វើអ្វីដែលព្រះសហគមន៍ធ្វើពេលផ្តល់ពិធីជ្រមុជទឹក ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះសហគមន៍យល់ឃើញថា ព្រះជាម្ចាស់មានព្រះហឫទ័យសង្គ្រោះមនុស្សទាំងអស់ (១ធម ២,៤) ហើយពិធីជ្រមុជទឹកជាការចាំបាច់ដើម្បីទទួលការសង្គ្រោះផងដែរ (មក ១៦,១៦)។

## ៦. ចាំបាច់ត្រូវតែទទួលពិធីជ្រមុជទឹក

១២៥៧- ព្រះអម្ចាស់ផ្ទាល់អះអាងថា ចាំបាច់ត្រូវតែទទួលពិធីជ្រមុជទឹកដើម្បីទទួលការសង្គ្រោះ (យហ ៣,៥)។ ហេតុនេះ ព្រះអង្គបានបញ្ជាក្រុមសាវ័កឲ្យទៅប្រកាសដំណឹងល្អ និងផ្តល់ពិធីជ្រមុជទឹកដល់គ្រប់ជាតិសាសន៍ទាំងអស់ (មថ ២៨,២០ ; DS ១៦១៨ ; LG ១៤ ; AG ៥)។ អស់អ្នកដែលបានទទួលដំណឹងល្អ ហើយដែលអាចសុំទទួលអគ្គសញ្ញានេះ ចាំបាច់ត្រូវតែទទួលពិធីជ្រមុជទឹក ដើម្បីទទួលការសង្គ្រោះ (មក ១៦,១៦)។ ព្រះសហគមន៍មិនស្គាល់មធ្យោបាយផ្សេងទៀតក្រៅពីពិធីជ្រមុជទឹកទេ ដើម្បីធានាថា នឹងចូលក្នុងបរមសុខអស់កល្បជានិច្ច។ ហេតុនេះ ព្រះសហគមន៍ប្រុងប្រយ័ត្នមិនធ្វេសប្រហែសនឹងបេសកកម្ម ដែលខ្លួនបានទទួលពីព្រះអម្ចាស់ គឺឲ្យអស់អ្នកដែលអាចទទួលពិធីជ្រមុជទឹក "កើតពីទឹក និងពីព្រះវិញ្ញាណ"។ ព្រះជាម្ចាស់បានជាប់ចំណងការសង្គ្រោះជាមួយនឹងអគ្គសញ្ញាជ្រមុជទឹក ប៉ុន្តែព្រះអង្គផ្ទាល់មិនជាប់ចំណងនឹងអគ្គសញ្ញានានារបស់ព្រះអង្គឡើយ ។

១២៥៨- តាំងពីដើមរៀងមក ព្រះសហគមន៍ជឿជាក់យ៉ាងម៉ឺងម៉ាត់ថា អស់អ្នកដែលស្លាប់ ដោយសារជំនឿ ទោះបីមិនបានទទួលពិធីជ្រមុជទឹកក៏ដោយ ក៏ដូចជាបានទទួលជ្រមុជទឹកដោយសារពួកគេបានស្លាប់ដើម្បី និង ដោយរួបរួមជាមួយព្រះគ្រីស្ត។ ទោះជាមិនមែនជាអគ្គសញ្ញាក៏ដោយ ក៏ពិធីជ្រមុជក្នុងឈាម និងបំណងប្រថ្នាចង់ បានទទួលពិធីជ្រមុជទឹក បង្កើតផលនៃពិធីជ្រមុជទឹកដែរ ។

១២៥៩- ចំពោះអ្នកស្វែងយល់ ដែលស្លាប់មុននឹងទទួលពិធីជ្រមុជទឹក ហើយប្រាថ្នាយ៉ាងច្បាស់លាស់ ចង់ បានទទួលពិធីនេះ ដោយសោកស្តាយចំពោះអំពើបាបរបស់ខ្លួន និងព្យាយាមរស់នៅក្នុងសេចក្តីស្រឡាញ់ បំណង នេះធានាថា នឹងទទួលការសង្គ្រោះ ដែលគេមិនបានទទួលតាមអគ្គសញ្ញា។

១២៦០- "ដោយព្រះគ្រីស្តសោយទិវង្គតដើម្បីមនុស្សទាំងអស់ និងដោយព្រះជាម្ចាស់កំណត់ទីដៅតែមួយ ឲ្យ ជីវិតមនុស្សយ៉ាងពិតមែននោះ ពោលគឺឲ្យរួមរស់ជាមួយព្រះអង្គ យើងត្រូវតែយល់ថា ព្រះវិញ្ញាណដ៏វិសុទ្ធប្រោស ឲ្យមនុស្សទាំងអស់អាចរួមជាមួយព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មី តាមរបៀបដែលព្រះជាម្ចាស់ ស្គាល់" (GS ២២ ; LG ១៦ ; AG ៧)។ អ្នកណា ដែលមិនស្គាល់ដំណឹងល្អរបស់ព្រះគ្រីស្ត និងព្រះសហគមន៍ របស់ព្រះអង្គ ប៉ុន្តែដែលស្វែងរកសេចក្តីពិត និងគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ តាមអ្វីដែលគេដឹង អាចទទួល ការសង្គ្រោះបាន។ យើងអាចស្មានថា បុគ្គលបែបនោះ មានបំណងប្រាថ្នាយ៉ាងច្បាស់លាស់នឹងទទួលពិធីជ្រមុជ ទឹក បើគេបានដឹងជាមុនថា ចាំបាច់ត្រូវតែទទួលពិធីនេះ ដើម្បីទទួលការសង្គ្រោះ។

១២៦១- ឯកូនក្មេងដែលស្លាប់ដោយមិនបានទទួលពិធីជ្រមុជទឹក ព្រះសហគមន៍គ្រាន់តែអាចថ្វាយពួកវា ទៅធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដូចព្រះសហគមន៍ធ្វើក្នុងពិធីបញ្ចុះសពសម្រាប់ពួកវា។ តាមការពិត ធម៌ មេត្តាករុណាដ៏លើសលប់របស់ព្រះជាម្ចាស់ ដែលសព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ (១ធម ២,៤) និងសេចក្តីថ្នាក់ថ្នមរបស់ព្រះយេស៊ូចំពោះកូនក្មេង ដែលមានព្រះបន្ទូលថា៖ "ទុកឲ្យក្មេងៗមករកខ្ញុំចុះ កុំឃាត់ពួកវាឡើយ" (មក ១០,១៤) ធ្វើឲ្យយើងអាចសង្ឃឹមថា កូនក្មេងដែលស្លាប់ដោយមិនបាន ទទួលពិធី ជ្រមុជទឹកអាចដើរតាមផ្លូវឆ្ពោះទៅការសង្គ្រោះផងដែរ។ ហេតុនេះ ព្រះសហគមន៍រំឭកថា មិនត្រូវឃាត់ក្មេងៗ ដែលមករកព្រះគ្រីស្តតាមព្រះអំណោយទាននៃពិធីជ្រមុជទឹកដ៏វិសុទ្ធឡើយ។

## ៧. ព្រះអំណោយទានរបស់ពិធីជ្រមុជទឹក

១២៦២- ចំណុចខ្លះៗ ដែលវិញ្ញាណអាចដឹងខ្លួននៃពិធីអគ្គសញ្ញា សម្តែងនូវផលផ្សេងៗនៃពិធីជ្រមុជទឹក។ ការជ្រមុជក្នុងទឹកជានិមិត្តរូបថា អ្នកជ្រមុជស្លាប់ ត្រូវបន្សុទ្ធ និងកើតជាថ្មី។ ផលសំខាន់ៗទាំងពីរ នៃពិធីនេះ គឺ ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសអ្នកជ្រមុជឲ្យរួចពីអំពើបាប ហើយឲ្យគេកើតជាថ្មី (កក ២,៣៨ ; យហ ៣,៥)។

### ឲ្យរួចពីបាប...

១២៦៣- ដោយសារពិធីជ្រមុជទឹក ព្រះជាម្ចាស់លើកលែងទោសចំពោះអំពើបាបទាំងអស់ ទាំងអំពើបាបដើម ដំបូង ទាំងអំពើបាបដែលអ្នកជ្រមុជទឹកបានប្រព្រឹត្តផ្ទាល់ខ្លួន ទាំងទោសនៃអំពើបាបផងដែរ (DS ១៣១៦)។ តាមការពិត ចំពោះអស់អ្នកដែលកើតជាថ្មី គ្មាននៅសេសសល់អ្វី ដែលនឹងរារាំងគេមិនឲ្យចូលក្នុងព្រះរាជ្យរបស់ ព្រះជាម្ចាស់ ទោះជាអំពើបាបរបស់លោកអដាំមក្តី អំពើបាបរបស់គេផ្ទាល់ខ្លួនក្តី ឬផលនៃអំពើបាប ដែលធ្ងន់ជាង គេអាចនាំមនុស្សឲ្យឃ្លាតឆ្ងាយពីព្រះជាម្ចាស់ក្តី។

១២៦៤-ក៏ប៉ុន្តែផលវិបាកខ្លះៗនៃអំពើបាបស្ថិតនៅក្នុងអ្នកដែលជ្រមុជទឹក ដូចជាទុក្ខលំបាក ជម្ងឺ សេចក្ដីស្លាប់ ឬភាពទន់ខ្សោយដែលមកពីធម្មជាតិ (ដែលទាក់ទងនឹងចរិត...) ហើយលក្ខណៈមានចិត្តលម្អៀងចង់ប្រព្រឹត្តអំពើបាប ដែលការបញ្ញូនបន្តហៅថា កិលេសតណ្ហា ដែលប្រៀបធៀបនឹង "ប្រភពនៃបាប" (fomes peccati)៖ "ព្រះជាម្ចាស់បានទុកកិលេសតណ្ហាដើម្បីឲ្យយើងតស៊ូ ប៉ុន្តែ កិលេសតណ្ហាមិនអាចធ្វើបាបដល់អស់អ្នកដែលតស៊ូដោយចិត្តក្លាហាន ដែលមិនព្រមចុះចូលដៃជាមួយទេ និងដោយមានព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្ដជួយ"។ លើសពីនេះទៅទៀត "គេនឹងទទួលភ្នងជ័យ លុះត្រាតែគេប្រយុទ្ធត្រឹមត្រូវតាមក្បួន" (២ធម ២,៥)។ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៥១៥)។

### "កើតជាថ្មី"

១២៦៥- ពិធីជ្រមុជទឹកមិនគ្រាន់តែបន្សុទ្ធអំពីអំពើបាបទាំងអស់ប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យពន្លកថ្មី "កើតជាថ្មី" (២ករ ៥,១៧) ឲ្យទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ (កាឡ ៤,៥-៧) ដែល "រួបរួមជាមួយព្រះអង្គ" (២ពត្រ ១,៤) ជាសិរីរាង្គរបស់ព្រះគ្រីស្ដ (១ករ ៦,១៥ ; ១២,២៧) ទទួលមរតករួមជាមួយព្រះអង្គ (រម ៨,១៧) និងជា ព្រះដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ (១ករ ៦,១៩)។

១២៦៦- ព្រះត្រៃឯកដ៏វិសុទ្ធបំផុតប្រោសប្រទានអ្នកដែលជ្រមុជទឹកឲ្យបានទៅជាវិសុទ្ធ និងឲ្យបានទៅជាមនុស្សសុចរិត ៖

- ទើបគេអាចផ្ញើជីវិតលើព្រះជាម្ចាស់ សង្ឃឹមលើព្រះអង្គ និងស្រឡាញ់ព្រះអង្គ ដោយគុណធម៌ដែលព្រះជាម្ចាស់ប្រទាន
- ទើបគេអាចមានរបៀបរស់នៅ និងប្រតិបត្តិតាមព្រះវិញ្ញាណដ៏វិសុទ្ធ ដោយព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ
- ទើបគេអាចប្រព្រឹត្តអំពើល្អ ដោយគុណធម៌នៃសីលធម៌ ។

ហេតុនេះហើយ បានជារបៀបរស់នៅហួសធម្មជាតិរបស់គ្រីស្ដបរិស័ទចាក់ឫសក្នុងអគ្គសញ្ញាជ្រមុជទឹកដ៏វិសុទ្ធ។

### ព្រះជាម្ចាស់បង្រួបបង្រួមយើងក្នុងព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ដ

១២៦៧-ពិធីជ្រមុជទឹកធ្វើឲ្យយើងទៅជាសិរីរាង្គនៃព្រះកាយព្រះគ្រីស្ដ។"ហេតុនេះ (...) យើងជាសិរីរាង្គរបស់គ្នាទៅវិញទៅមក" (អភ ៤,២៥)។ ពិធីជ្រមុជទឹកធ្វើឲ្យយើងរួមជាមួយព្រះសហគមន៍ ។ ប្រជាជនតែមួយរបស់ព្រះជាម្ចាស់នៃសម្ពន្ធមេត្រីថ្មី ដែលហួសព្រំដែនខាងធម្មជាតិរបស់ប្រជាជាតិនានា វប្បធម៌ ជាតិសាសន៍ និងភេទកើតមកពីពិធីជ្រមុជទឹក៖"យើងបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណតែមួយ ដើម្បីផ្សំគ្នាឡើងជាព្រះកាយតែមួយ ហើយយើងសុទ្ធតែបានទទួលព្រះវិញ្ញាណតែមួយដែរ" (១ករ ១២,១៣)។

១២៦៨- អ្នកដែលជ្រមុជទឹកបានទៅជា "ថ្មដ៏មានជីវិត" ដើម្បី "កសាងព្រះដំណាក់របស់ព្រះវិញ្ញាណធ្វើ ជាក្រុមបូជាចារ្យដ៏វិសុទ្ធ" (១ពត្រ ២,៥)។ ដោយសារពិធីជ្រមុជទឹក ពួកគេរួបរួមជាមួយព្រះគ្រីស្ដក្នុងឋានៈជាបូជាចារ្យ ក្នុងបេសកកម្មរបស់ព្រះអង្គជាព្យាការី និងជាព្រះមហាក្សត្រ ពួកគេជា "ពូជសាសន៍ដែលព្រះជាម្ចាស់បានជ្រើសរើស ជាក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ ជាជាតិសាសន៍ដ៏វិសុទ្ធ ជាប្រជារាស្ដ្រដែលព្រះជាម្ចាស់បាន

យកមកធ្វើជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ ដើម្បីឲ្យបងប្អូនប្រកាសដំណឹងអំពីស្នាព្រះហស្ដដ៏អស្ចារ្យរបស់ព្រះអង្គ ដែលបានហៅបងប្អូនឲ្យចេញពីទីងងឹតមកកាន់ពន្លឺដ៏រុងរឿងរបស់ព្រះអង្គ"(១ពត្រ២,៩)។ដោយសារពិធីជ្រមុជទឹក អ្នកដែលជ្រមុជរួមជាមួយគ្រីស្ដបរិស័ទឯទៀតៗដែលសុទ្ធតែជាបូជាចារ្យ ។

១២៦៩- ដោយសារគេបានទៅជាសមាជិកព្រះសហគមន៍ អ្នកដែលជ្រមុជមិនមែនជាកម្មសិទ្ធិរបស់ខ្លួនឯងទៀតទេ (១ករ ៦,១៩) ប៉ុន្តែ គេជាកម្មសិទ្ធិរបស់អ្នកដែលសោយទិវង្គត និងមានព្រះជន្មថ្មី ដើម្បីយើង (២ករ ៥,១៥)។ហេតុនេះ គេត្រូវគោរពចុះចូលអ្នកដទៃ (អភ ៥,២១ ; ១ករ ១៦,១៥-១៦) បម្រើគេ (យហ ១៣,១២-១៥) ក្នុងសហភាពរបស់ព្រះសហគមន៍ "ទុកចិត្ត និងស្ដាប់បង្គាប់" អ្នកដឹកនាំព្រះសហគមន៍ (ហប ១៣,១៧) ព្រមទាំង "គោរព (ពួកលោក) ដោយចិត្តស្រឡាញ់" (១ថស ៥,១២-១៣)។ ពិធីជ្រមុជទឹកនាំឲ្យទៅជាអ្នកទទួលខុសត្រូវ និងមានភារកិច្ចយ៉ាងណា អ្នកដែលជ្រមុជទឹកក៏មានសិទ្ធិនៅក្នុងព្រះសហគមន៍យ៉ាងនោះដែរ ពោលគឺទទួលអគ្គសញ្ញា ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងឲ្យព្រះសហគមន៍ជួយគាំទ្រគេខាងវិញ្ញាណផងដែរ (LG ៣៧ ; CIC ២០៨-២២៣)។

១២៧០-"(អ្នកជ្រមុជទឹក) កើតជាថ្មីនិងទៅជាបុត្រធីតារបស់ព្រះបិតា គេត្រូវតែប្រកាសនៅចំពោះមុខមនុស្សលោកនូវជំនឿដែលគេបានទទួលពីព្រះជាម្ចាស់ ដោយសារព្រះសហគមន៍" (LG ១១) ហើយចូលរួម ចំណែកក្នុងសកម្មភាពនៃប្រជាជនរបស់ព្រះជាម្ចាស់ក្នុងការប្រកាសដំណឹងល្អ (LG ១៧ ; AG ៧,២៣)។

## ចំណងនៃអគ្គសញ្ញាចងគ្រីស្ដបរិស័ទឲ្យរួបរួមជាមួយគ្នាជាធ្លុងតែមួយ

១២៧១- ដោយសារពិធីជ្រមុជទឹកជាមូលដ្ឋានគ្រឹះ គ្រីស្ដបរិស័ទរួបរួមគ្នាជាធ្លុងតែមួយ ហើយជាមួយអស់អ្នកដែលមិនទាន់រួបរួមជាមួយព្រះសហគមន៍កាតូលិកឲ្យបានពេញលក្ខណៈដែរ៖ "អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ដ ហើយបានទទួលអគ្គសញ្ញាជ្រមុជទឹកយ៉ាងត្រឹមត្រូវ ក៏គេរួបរួមម៉្យាងជាមួយព្រះសហគមន៍កាតូលិកដែរ ទោះបីគេមិនរួបរួមយ៉ាងពេញលក្ខណៈក្ដី (...)។ ទោះជាយ៉ាងណាក៏ដោយ ក៏បងប្អូនទាំងនោះ ពិតជាមនុស្សសុចរិតដោយគេផ្ញើជីវិតលើព្រះគ្រីស្ដ គេបានទទួលជំនឿនោះនៅពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក គេចូលរួមក្នុងព្រះកាយព្រះគ្រីស្ដ គេក៏ពិតជាមានឈ្មោះថា ជាគ្រីស្ដបរិស័ទដែរ" (UR ៣)។ " ហេតុនេះ ពីធីជ្រមុជទឹកពិតជាចំណងនៃឯកភាពខាងអគ្គសញ្ញា ដែលចងអស់អ្នកដែលកើតជាថ្មីដោយសារពិធីនោះ" (UR ២២)។

## ស្លាកខាងវិញ្ញាណដែលមិនអាចលុបឡើយ...

១២៧២- ដោយសារពិធីជ្រមុជទឹក អ្នកជ្រមុជរួបរួមជាមួយព្រះគ្រីស្ដ និងមានលក្ខណៈដូចព្រះគ្រីស្ដដែរ (រម ៨,២៩)។ ពិធីជ្រមុជទឹកដូចជាវាយត្រាខាងវិញ្ញាណដែលមិនអាចលុបទេ (character) ជាសញ្ញាសម្គាល់ថា គេជាកម្មសិទ្ធិរបស់ព្រះគ្រីស្ដ។ អំពើបាបណាមួយមិនអាចលុបបំបាត់ស្នាមនេះទេ ទោះបីអំពើបាបឃាត់ពិធីជ្រមុជទឹក មិនឲ្យបង្កើតផលបានក៏ដោយ (DS ១៦០៩-១៦១៩)។ យើងផ្ដល់ពិធីជ្រមុជទឹកម្ដងជាការស្រេច យើងក៏មិនអាចផ្ដល់ពិធីនេះម្ដងទៀតបានដែរ។

១២៧៣- ដោយសារពិធីជ្រមុជទឹក អ្នកដែលជ្រមុជរួបរួមជាមួយព្រះសហគមន៍ គ្រីស្ដបរិស័ទបានទទួលសញ្ញាសម្គាល់ខាងអគ្គសញ្ញា ដែលតម្រង់ពួកគេក្នុងពិធីបុណ្យខាងគ្រីស្ដសាសនា (LG ១១)។ ពិធីជ្រមុជទឹកធ្វើឲ្យគ្រីស្ដបរិស័ទអាចបម្រើព្រះជាម្ចាស់ ដោយចូលរួមចំណែកយ៉ាងសកម្មក្នុងពិធីបុណ្យដ៏វិសុទ្ធនៃព្រះសហគមន៍ ហើយធ្វើឲ្យពួកគេទៅជាបូជាចារ្យ ដោយមានរបៀបរស់នៅដ៏វិសុទ្ធ ដោយចិត្តស្រឡាញ់យ៉ាងស័ក្ដិសិទ្ធិ (LG ១០)។

១២៧៤- "ត្រារបស់ព្រះអម្ចាស់" ("Dominicus character") (សន្តៈ អូគូស្តាំង) ជាត្រាដែលព្រះវិញ្ញាណដ៏វិសុទ្ធបានដៅចំណាំយើង "ទុកសម្រាប់ថ្ងៃដែលព្រះអង្គនឹងយាងមកលោះយើង" (អភ ៤,៣០) (អភ ១,១៣-១៤ ; ២ករ ១,២១-២២)។ "តាមការពិត ពិធីជ្រមុជទឹកជាត្រានៃជីវិតអស់កល្បជានិច្ច" (សន្តៈ អ៊ីរ៉េណេ)។ គ្រីស្តបរិស័ទម្នាក់ដែលនឹង "រក្សាទុកត្រា" រហូតដល់ទីបំផុត ពោលគឺនៅតែស្មោះត្រង់នឹងលក្ខណៈនៃពិធីជ្រមុជទឹករបស់គេនឹងអាចទៅបរមសុខ "ដោយមានសញ្ញាសម្គាល់នៃជំនឿ" ជាជំនឿនៃពិធីជ្រមុជទឹករបស់គេ ដោយរង់ចាំឃើញព្រះជាម្ចាស់យ៉ាងសប្បាយ (ដែលសម្រេចជំនឿយ៉ាងពេញលេញ) និងដោយរង់ចាំឲ្យមនុស្សមានជីវិតថ្មី។

## សង្ខេប

១២៧៥- ត្រូវតែទទួលអគ្គសញ្ញាបី ដើម្បីបានទៅជាគ្រីស្តបរិស័ទពេញសិទ្ធ គឺអគ្គសញ្ញាជ្រមុជទឹក ដែល ចាប់ផ្តើមជីវិតថ្មី អគ្គសញ្ញាលាបប្រេងឆ្លងថ្ងាស ដែលពង្រឹងជីវិតថ្មីនេះ និងអគ្គសញ្ញាអរព្រះគុណ ដែលបំប៉នសាវ័កជាមួយនឹងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ដើម្បីបានក្លាយទៅជាព្រះគ្រីស្ត។

១២៧៦- "ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យពួកគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវបង្រៀនពួកគេឲ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា" (មថ ២៨,១៩-២០)។

១២៧៧- ពិធីជ្រមុជទឹកផ្តល់ឲ្យគ្រីស្តបរិស័ទមានជីវិតថ្មីក្នុងអង្គព្រះគ្រីស្ត។ តាមព្រះហឫទ័យ របស់ព្រះអម្ចាស់ យើងត្រូវតែទទួលពិធីជ្រមុជទឹក ដើម្បីទទួលការសង្គ្រោះ ដូចជាព្រះសហគមន៍ផ្ទាល់ ដែលនាំឲ្យយើងទទួលពិធីជ្រមុជទឹក។

១២៧៨- ពិធីសំខាន់បំផុតនៃបុណ្យជ្រមុជទឹក គឺជ្រមុជបេក្ខជនក្នុងទឹក ឬចាក់ទឹកលើក្បាលគាត់ ដោយទូលអង្វរព្រះត្រៃឯកដ៏វិសុទ្ធបំផុត ពោលគឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

១២៧៩- ផលនៃពិធីជ្រមុជទឹក ឬការប្រណីសន្តោសនៃពិធីជ្រមុជទឹកមានច្រើន គឺការរំដោះឲ្យរួចពី បាបដើមដំបូង និងឲ្យរួចពីបាបផ្ទាល់ខ្លួនទាំងប៉ុន្មាន កំណើតឲ្យជីវិតថ្មី ដែលធ្វើឲ្យមនុស្សទៅជាបុត្រធីតារបស់ព្រះបិតា សិរីរាង្គរបស់ព្រះគ្រីស្ត និងព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ គ្រីស្តបរិស័ទចូលរួមក្នុងព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត ហើយចូលរួមក្នុងឋានៈរបស់ព្រះគ្រីស្តជាបូជាចារ្យផងដែរ។

១២៨០- ពិធីជ្រមុជទឹកដៅសញ្ញានៃវិញ្ញាណមួយ ដែលមិនអាចលុបបាន នៅក្នុងព្រលឹង ជាលក្ខណៈ ដែលញែកអ្នកជ្រមុជទឹកឲ្យគោរពប្រណិប័តន៍គ្រីស្តសាសនា។ ដោយសារលក្ខណៈនេះ យើងមិនអាចផ្តល់ពិធីជ្រមុជទឹកម្តងទៀតបានឡើយ។

១២៨១- អស់អ្នកដែលទទួលមរណភាពដោយសារជំនឿ គឺអ្នកស្វែងយល់ និងអស់អ្នក ដែលមានព្រះហឫទ័យប្រណីសន្តោសជំរុញ ទោះបីគេមិនស្គាល់ព្រះសហគមន៍ ប៉ុន្តែដែលស្វែងរកព្រះជាម្ចាស់ដោយមានចិត្តស្មោះ និងខិតខំធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ទទួលការសង្គ្រោះ ទោះបីគេមិនបានទទួលពិធីជ្រមុជទឹកក៏ដោយ (LG ១៦)។

១២៨២- តាំងពីដើមរៀងមក យើងផ្តល់ពិធីជ្រមុជទឹកដល់កូនក្មេង ដ្បិតពិធីនេះ ជាព្រះអំណោយទាននៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដែលមិនទាមទារឲ្យមនុស្សមានបុណ្យទេ។ កូនក្មេងជ្រមុជទឹក

ក្នុងជំនឿនៃព្រះសហគមន៍។ ពេលចូលក្នុងជីវិតជាគ្រីស្តបរិស័ទ យើងទទួលសេរីភាពយ៉ាងពិតប្រាកដ។

១២៨៣- រីឯក្មេងដែលស្លាប់ដោយមិនបានជ្រមុជទឹក ពិធីបុណ្យព្រះសហគមន៍អញ្ជើញយើង ឲ្យជឿទុកចិត្ត លើធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ និងអង្វរព្រះអង្គឲ្យគេទទួលការសង្គ្រោះ។

១២៨៤- បើមានករណីចាំបាច់ នរណាម្នាក់ក៏អាចផ្តល់ពិធីជ្រមុជទឹកបាន ឲ្យតែគេមានបំណងធ្វើអ្វី ដែលព្រះសហគមន៍ធ្វើ ហើយឲ្យគេចាក់ទឹកលើក្បាលបេក្ខជនដោយពោលថា៖ "ខ្ញុំជ្រមុជអ្នកក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"។

## ប្រការទី២៖

## អគ្គសញ្ញាលាបថ្វាស

១២៨៥ រួមជាមួយអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាអរព្រះគុណ អគ្គសញ្ញាលាបថ្វាសជា "អគ្គ សញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ"។ ត្រូវតែរក្សាទុកឯកភាពរបស់អគ្គសញ្ញាទាំងបីនោះ។ ដូច្នេះ ត្រូវពន្យល់ឲ្យគ្រីស្តបរិស័ទដឹងថា ត្រូវតែទទួលអគ្គសញ្ញានេះ ដើម្បីឲ្យព្រះអំណោយទាននៃពិធីជ្រមុជទឹកបានសម្រេច (OCf)។ តាមការពិត "ដោយសារអគ្គសញ្ញាលាបថ្វាស ចំណងរវាងគ្រីស្តបរិស័ទនិងព្រះសហគមន៍ កាន់តែប្រសើរឡើង គេក៏ទទួលកម្លាំងពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ និងទទួលភារកិច្ចផ្សព្វផ្សាយជំនឿ ព្រមទាំងការពារជំនឿនេះផង ដោយពាក្យសម្តី និងដោយការប្រតិបត្តិតាមជំនឿនេះដែរ ក្នុងឋានៈខ្លួនជាសាក្សីដ៏ពិតប្រាកដរបស់ព្រះគ្រីស្ត" (LG ១១ ; OCf)។

### ១. ការលាបថ្វាសក្នុងការចាត់ចែងនៃការសង្គ្រោះ

១២៨៦- ក្នុងសម្ព័ន្ធមេត្រីចាស់ ពួកព្យាការីបានប្រកាសថា ព្រះវិញ្ញាណរបស់ព្រះអម្ចាស់នឹងយាងមកសណ្ឋិតលើព្រះមេស្ស៊ី ដែលគេទន្ទឹងរង់ចាំ (អស ១១,២) ដើម្បីបេសកកម្មរបស់ព្រះអង្គ (លក ៤,១៦-២២ ; អស ៦១,១)។ ព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះសណ្ឋិតលើព្រះយេស៊ូ នៅពេលដែលព្រះអង្គទទួលពិធីជ្រមុជទឹកពីលោកយ៉ូហានជាសញ្ញាសម្គាល់បញ្ជាក់ថា គឺព្រះអង្គនេះហើយ ដែលយាងមក ដែលជាព្រះមេស្ស៊ី ជាព្រះបុត្រារបស់ព្រះជាម្ចាស់ (មថ ៣,១៣-១៧ ; យហ ១,៣៣-៣៤)។ ដោយបានចាប់កំណើតពីព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះយេស៊ូក៏រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះបិតាប្រទានឲ្យព្រះអង្គ "យ៉ាងបរិបូណ៌" (យហ ៣,៣៤) ឲ្យបានពេញលក្ខណៈ អស់មួយជីវិត និងក្នុងបេសកកម្មទាំងស្រុងរបស់ព្រះអង្គ។

១២៨៧- ក៏ប៉ុន្តែ ព្រះជាម្ចាស់ពុំមានព្រះបំណងប្រោសប្រទានព្រះវិញ្ញាណយ៉ាងបរិបូណ៌នេះ ឲ្យព្រះមេស្ស៊ីតែប៉ុណ្ណោះទេ គឺប្រទានឲ្យប្រជាជនទាំងមូល (អគ ៣៦,២៥-២៧ ; យហ ៣,១-២)។ ជាច្រើនលើក ច្រើនសាព្រះគ្រីស្តមានព្រះបន្ទូលសន្យានឹងចាក់បង្ហូរព្រះវិញ្ញាណ (លក ១២,១២ ; យហ ៣,៥-៨ ; ៧,៣៧-៣៩ ; ១៦,៧-១៥ ; កក ១,៨) ព្រះអង្គក៏បានបំពេញទៅតាមព្រះបន្ទូលនេះ នៅថ្ងៃបុណ្យចម្លង (យហ ២០,២២) បន្ទាប់មកតាមរបៀបច្បាស់លាស់ នៅថ្ងៃបុណ្យព្រះវិញ្ញាណយាងមក (កក ២,១-៤)។ ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធក្រុមគ្រីស្តទូតចាប់ផ្តើមប្រកាស "កិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់" (កក ២,១១) ហើយលោកសិលាប្រកាសថាការចាក់បង្ហូរនៃព្រះវិញ្ញាណនេះ ជាសញ្ញាសម្គាល់ថា ព្រះរាជ្យរបស់ព្រះជាម្ចាស់បានចាប់ផ្តើមហើយ (កក ២,១៧-១៨)។ អស់អ្នកដែលបានជឿលើធម្មទេសនារបស់ក្រុមគ្រីស្តទូត ហើយដែលបានទទួលពិធីជ្រមុជទឹក បានទទួល

ព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (កក ២,៣៨)។

១២៨៨- "ចាប់តាំងពីពេលនេះមក ក្រុមគ្រីស្តទូតផ្តល់ព្រះអំណោយទានរបស់ព្រះវិញ្ញាណឲ្យពន្លកថ្មីដោយដាក់ដៃលើពួកគេ ដើម្បីបំពេញព្រះបំណងរបស់ព្រះគ្រីស្ត។ ព្រះអំណោយទាននេះ បំពេញព្រះអំណោយទាននៃពិធីជ្រមុជទឹកឲ្យបានពេញលក្ខណៈ (កក ៨,១៥-១៧ ; ១៩,៥-៦)។ ហេតុនេះហើយ បានជាក្នុងលិខិតផ្ញើជូនគ្រីស្តបរិស័ទជាតិហេប្រឺ ចាប់ផ្តើមមានលទ្ធិអំពីពិធីជ្រមុជទឹក និងអំពីពិធីដាក់ដៃ ក្នុងការបង្ហាត់ជាលើកដំបូងឲ្យទៅជាគ្រីស្តបរិស័ទ (ហប ៦,២)។ ការបញ្ជូនបន្តនៃព្រះសហគមន៍កាតូលិកសម្គាល់យ៉ាងត្រឹមត្រូវថា ពិធីដាក់ដៃដូចជាប្រភពនៃអគ្គសញ្ញាលាបថ្ងាស ដែលបន្តព្រះអំណោយទាននៃបុណ្យព្រះវិញ្ញាណយាងមកម្យ៉ាង (សម្តេចប៉ាប ប៉ូលទី៦)។

១២៨៩- ភ្លាមៗនោះ គេចាប់ផ្តើមលាបប្រេងក្រអូប (គ្រីស្មា) រួមជាមួយពិធីដាក់ដៃ ដើម្បីសម្តែងនូវព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ពិធីលាបប្រេងនេះ សម្តែងនូវឈ្មោះថា "គ្រីស្តបរិស័ទ" ដែលមានន័យថា "អ្នកដែលបានទទួលអភិសេក" គឺព្រះគ្រីស្តផ្ទាល់ ដែល "ព្រះជាម្ចាស់បានចាក់ព្រះវិញ្ញាណដ៏វិសុទ្ធអភិសេកព្រះអង្គ" (កក ១០,៣៨)។ ពិធីលាបប្រេងមានរហូតដល់សព្វថ្ងៃ ទាំងនៅបស្ចិមប្រទេស ទាំងនៅបូព៌ាប្រទេស។ ហេតុនេះ នៅបូព៌ាប្រទេស គេហៅអគ្គសញ្ញានេះថា អគ្គសញ្ញាគ្រីស្មា ឬពិធីលាបប្រេងគ្រីស្មា ឬមីរ៉ុន បានសេចក្តីថា គ្រិស្មា។ នៅបស្ចិមប្រទេស អគ្គសញ្ញាលាបថ្ងាសបញ្ជាក់ អគ្គសញ្ញាជ្រមុជទឹក ដែលបញ្ចប់ការបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ ហើយពង្រឹងការប្រណីសន្តោសនៃពិធីជ្រមុជទឹក ដែលជាផលនៃព្រះវិញ្ញាណដ៏វិសុទ្ធ។

### ប្រពៃណីពីរ៖ បស្ចិម និងបូព៌ាប្រទេស

១២៩០- នៅសតវត្សដើម អគ្គសញ្ញាលាបថ្ងាស និងអគ្គសញ្ញាជ្រមុជទឹកធ្វើជាពិធីតែមួយ ដូចជា "អគ្គសញ្ញាពីរជាមួយ" តាមពាក្យសម្តីរបស់សន្តៈ ស៊ីព្រីយ៉ាំង។ ក្នុងចំណោមមូលហេតុផ្សេងៗ ដោយសារមានពិធីជ្រមុជទឹករបស់កូនក្មេងកាន់តែច្រើនៗគ្រប់ពេលវេលា ដោយសារមានព្រះសហគមន៍ (តាមភូមិ) កាន់តែច្រើនៗ ដែលធ្វើឲ្យភូមិភាគកាន់តែធំៗ លោកអភិបាលក៏មិនអាចដឹកនាំពិធីជ្រមុជទឹកទាំងអស់បានឡើយ។ នៅបស្ចិមប្រទេស គេចាប់ផ្តើមបំបែកអគ្គសញ្ញាទាំងពីរ ពីព្រោះគេចង់ទុកឲ្យលោកអភិបាលបង្ហើយអគ្គសញ្ញាជ្រមុជទឹក។ ព្រះសហគមន៍ខាងបូព៌ាប្រទេសបានរក្សាទុកឯកភាពនៃអគ្គសញ្ញាទាំងពីរនោះ ទើបលោកបូជាចារ្យដែលផ្តល់ពិធីជ្រមុជទឹកជាអ្នកផ្តល់អគ្គសញ្ញាលាបថ្ងាសផងដែរ។ ប៉ុន្តែ លោកត្រូវតែប្រើ "មីរ៉ុន" ដែលលោកអភិបាលបានប្រសិទ្ធពរ (CCEO ៦៩៥,១ ; ៦៩៦,១)។

១២៩១- ទំនៀមទម្លាប់មួយនៃព្រះសហគមន៍នៅទីក្រុងរ៉ូមបានជួយអភិវឌ្ឍប្រពៃណីនៃបស្ចិមប្រទេស ដោយគេបានលាបប្រេងពីរដង ក្រោយពីបានផ្តល់អគ្គសញ្ញាជ្រមុជទឹក៖ ពេលពន្លកថ្មីជ្រមុជក្នុងទឹករួចហើយ លោកបូជាចារ្យលាបប្រេងម្តង បន្ទាប់មក លោកអភិបាលលាបប្រេងម្តងទៀតលើថ្ងាសរបស់អ្នកដែលជ្រមុជទឹកថ្មីនោះ (សន្តៈ អ៊ីប៉ូលីត)។ ពិធីលាបប្រេងគ្រីស្មាដំបូង ដែលលោកបូជាចារ្យផ្តល់ឲ្យ នៅជាប់នឹងពិធីជ្រមុជទឹក សម្តែងថាអ្នកដែលជ្រមុជទឹករួមជាមួយព្រះគ្រីស្តក្នុងមុខងារជាព្យាការី ជាបូជាចារ្យ និងជាព្រះមហាក្សត្រ។ បើគេផ្តល់ពិធីជ្រមុជទឹកដល់មនុស្សពេញវ័យ មានពិធីលាបប្រេងតែម្តងក្រោយពីបានជ្រមុជទឹក គឺអគ្គសញ្ញាលាបថ្ងាស។

១២៩២- របៀបប្រតិបត្តិរបស់ព្រះសហគមន៍ខាងបូព៌ាប្រទេសបញ្ជាក់យ៉ាងច្បាស់ អំពីឯកភាពនៃការបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ។ ឯចំពោះព្រះសហគមន៍ខាងបស្ចិមប្រទេសវិញ សម្តែងយ៉ាងច្បាស់ថា គ្រីស្ត

បរិស័ទថ្មីរួបរួមជាមួយលោកអភិបាលរបស់គេ ដែលជាអ្នកជានា ហើយដែលជាអ្នកបម្រើឲ្យព្រះសហគមន៍របស់លោករួបរួមជាមួយគ្នាជាធ្លុងតែមួយ បានទៅជាកាតូលិក និងមកពីក្រុមគ្រីស្តទូត គឺជាប់ចំណងនឹងព្រះសហគមន៍របស់ព្រះគ្រីស្ត។

## ២. សញ្ញាសម្គាល់ និងពិធីនៃអគ្គសញ្ញាលាបថ្វាស

១២៩៣- ក្នុងពិធីនៃអគ្គសញ្ញានេះ ត្រូវវែកញែកសញ្ញាសម្គាល់នៃប្រេងអភិសេក អំពីអ្វីដែលអភិសេកសម្តែង និងសំដៅ គឺត្រា ខាងវិញ្ញាណ។

តាមព្រះគម្ពីរ និងពីបុរាណកាល ប្រេងអភិសេក មានអត្ថន័យជាច្រើន៖ ប្រេងជាសញ្ញានឹងជីវិតដ៏ពេញបរិបូណ៌ (ទក ១១,១៤ ល។ល) និងពោរពេញដោយអំណរសប្បាយ (ទន ២៣,៥ ; ១០៤,១៥) ប្រេងបន្សុទ្ធ (លាបប្រេងមុន និងក្រោយបានមុជទឹក) ធ្វើឲ្យទន់ភ្លន់ (ប្រេងរបស់កីឡាករ) ជាសញ្ញានៃការព្យាបាល ដ្បិតប្រេងបន្ធន់ខ្ញាំ និងដំបៅ (អស ១,៦ ; លក ១០,៣៤) ហើយនាំឲ្យមានសោភណភាពត្រចះត្រចង់ សុខភាពល្អ និងកម្លាំងមាំមួន។

១២៩៤- យើងអាចយល់ឃើញថា អត្ថន័យនៃប្រេងអភិសេកទាំងអស់នោះ មាននៅក្នុងអគ្គសញ្ញាដែរ។ យើងលាបប្រេងអ្នកស្វែងយល់មុនពិធីជ្រមុជទឹក ដើម្បីបន្សុទ្ធគេ និងពង្រឹងកម្លាំងរបស់គេ យើងលាបប្រេងអ្នកជំងឺដើម្បីព្យាបាល និងសម្រាលទុក្ខគេ។ យើងលាបប្រេងគ្រីស្មាក្រោយពីបានជ្រមុជទឹក ក្នុងអគ្គសញ្ញាលាបថ្វាស និងតែងតាំងជាសញ្ញាសម្គាល់ថា យើងទុកអ្នកទទួលអគ្គសញ្ញានោះសម្រាប់ឧទ្ទិសដល់ព្រះជាម្ចាស់។ ដោយសារអគ្គសញ្ញាលាបថ្វាស គ្រីស្តបរិស័ទ គឺអស់អ្នកដែលបានទទួលប្រេងអភិសេក ចូលរួមចំណែកច្រើនជាងមុនក្នុងបេសកកម្មរបស់ព្រះយេស៊ូគ្រីស្ត ក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធដែលសណ្ឋិតយ៉ាងបរិបូណ៌លើព្រះអង្គ ដើម្បីឲ្យជីវិតទាំងស្រុងរបស់ពួកគេភាយ "ក្លិនក្រអូបរបស់ព្រះគ្រីស្ត" (២ករ ២,១៥)។

១២៩៥- ដោយសារពិធីលាបប្រេងនេះ អ្នកដែលទទួលអគ្គសញ្ញាលាបថ្វាសក៏ទទួល "ស្នាម" ជាត្រា នៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រាជានិមិត្តរូបនៃបុគ្គលម្នាក់ (កណ ៣៨,១៨ ; បច ៨,៦) អំណាចរបស់គេ (កណ ៤១,៤២) ជានិមិត្តរូបថា បុគ្គលនេះជាម្ចាស់លើវត្ថុមួយ (ទក ៣២,៣៤) -ហេតុនេះ មេទ័ពធ្លាប់បោះត្រាលើទាហានរបស់គេ ហើយម្ចាស់វាយត្រាលើទាសកររបស់ខ្លួន-។ ត្រាបញ្ជាក់ឯកសារខាងច្បាប់ (១ពង្ស ២១,៨) ឬឯកសារផ្សេងទៀត (យរ ៣២,១០) ហើយអាចធ្វើឲ្យឯកសារនេះទៅជាឯកសារសម្ងាត់ (អស ២៩,១១)។

១២៩៦- ព្រះគ្រីស្តផ្ទាល់មានព្រះបន្ទូលថា បានទទួលត្រានៃព្រះបិតារបស់ព្រះអង្គ (យហ ៦,២៧)។ ឯ គ្រីស្តបរិស័ទ ក៏បានទទួលត្រាដែរ៖ "ព្រះជាម្ចាស់បានដៅចំណាំសញ្ញាសម្គាល់ (ត្រា) របស់ព្រះអង្គលើយើង និងប្រទានព្រះវិញ្ញាណមកបញ្ចាំចិត្តយើងផងដែរ" (២ករ ១,២២) (អភ ១,១៣ ; ៤,៣០)។ ត្រានៃព្រះវិញ្ញាណដ៏វិសុទ្ធនេះបញ្ជាក់ថា យើងជាកម្មសិទ្ធិទាំងស្រុងរបស់ព្រះគ្រីស្ត និងត្រូវបម្រើព្រះអង្គជានិច្ច ប៉ុន្តែ ត្រានេះបញ្ជាក់ដែរថា ព្រះជាម្ចាស់នឹងជួយការពារថែរក្សាយើងនៅគ្រាលំបាកចុងក្រោយបំផុត (វវ ៧,២-៣ ; ៩,៤ ; អគ ៩, ៤-៦)។

### ពិធីបុណ្យនៃអគ្គសញ្ញាលាបថ្វាស

១២៩៧- វេលាសំខាន់មួយមុននឹងប្រារព្ធពិធីអគ្គសញ្ញាលាបថ្វាស ប៉ុន្តែដែលជាផ្នែកមួយនៃពិធីនេះម្យ៉ាង គឺវេលា ដែលយើងប្រសិទ្ធពរលើប្រេងគ្រីស្មា ។ ថ្ងៃព្រហស្បតិ៍ពិសិដ្ឋ នៅក្នុងអភិបូជាគ្រីស្មា លោកអភិបាល

ប្រសិទ្ធពរលើប្រេងគ្រីស្មាសម្រាប់ភូមិភាគទាំងមូលរបស់លោក។ ក្នុងព្រះសហគមន៍ខាងបូព៌ាប្រទេស មានតែលោកព្រឹទ្ធាចារ្យដែលអាចប្រសិទ្ធពរលើប្រេង៖

> ក្នុងពិធីបុណ្យស៊ីរីយ៉ាកនៅអង់ទីអូស ពាក្យអង្វរឲ្យព្រះវិញ្ញាណយាងមកសណ្ឋិតលើប្រេងគ្រីស្មាដ៏វិសុទ្ធ (មីរ៉ូន) មានដូចតទៅ៖ "ឱព្រះបិតាអើយ! (...) សូមព្រះអង្គចាត់ព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើពួកយើង និងលើប្រេងនេះ ដែលនៅខាងមុខយើង ហើយសូមទ្រង់ប្រសិទ្ធពរលើប្រេងនេះ ដើម្បីឲ្យប្រេងនេះបានទៅជា សម្រាប់អស់អ្នកដែលនឹងត្រូវចាក់ និងត្រូវដៅចំណាំ ដូចជាមីរ៉ូនដ៏វិសុទ្ធ មីរ៉ូនរបស់បូជាចារ្យ មីរ៉ូនរបស់ព្រះមហាក្សត្រ ប្រេងអភិសេកនៃអំណរសប្បាយ សំលៀកបំពាក់នៃពន្លឺ អាវនៃការសង្គ្រោះ អំណោយខាងវិញ្ញាណ ដែលប្រោសព្រលឹង និងរូបកាយ ឲ្យបានវិសុទ្ធ សុភមង្គលដែលមិនអាចរលួយបាន ត្រាដែលមិនអាចរលុបបាន ខែលនៃជំនឿ និងមួកដ៏គួរឲ្យរន្ធត់ប្រឆាំងនឹងកលល្បិចទាំងប៉ុន្មានរបស់មារសាតាំង"។

១២៩៨- ពេលយើងប្រារព្ធអគ្គសញ្ញាលាបថ្ងាសដោយឡែកពីអគ្គសញ្ញាជ្រមុជទឹក ដូចនៅក្នុងក្បួនពិធីបុណ្យនៃទីក្រុងរ៉ូម ពិធីបុណ្យនៃអគ្គសញ្ញាចាប់ផ្តើមដោយរំឭកពាក្យសន្យានៃពិធីជ្រមុជទឹកឡើងវិញ ហើយអ្នកដែលហៀបនឹងទទួលអគ្គសញ្ញាលាបថ្ងាសប្រកាសជំនឿរបស់គេ។ ហេតុនេះហើយ បានជាយើងអាចយល់ឃើញយ៉ាងច្បាស់ថា អគ្គសញ្ញាលាបថ្ងាសបន្តអគ្គសញ្ញាជ្រមុជទឹក (SC ៧១)។ ពេលមនុស្សពេញវ័យម្នាក់ទទួលពិធីជ្រមុជទឹក គេទទួលអគ្គសញ្ញាលាបថ្ងាសភ្លាមៗ និងចូលរួមក្នុងអគ្គសញ្ញាអរព្រះគុណ (CIC ៨៦៦)។

១២៩៩- ក្នុងក្បួនពិធីបុណ្យនៃទីក្រុងរ៉ូម លោកអភិបាលលាតដៃលើអស់អ្នកដែលទទួលអគ្គសញ្ញាលាបថ្ងាសជាកាយវិការ ដែលមកពីសម័យក្រុមគ្រីស្តទូត ហើយដែលបង្ហាញព្រះអំណោយទានរបស់ព្រះវិញ្ញាណ។ បន្ទាប់មក លោកអភិបាលអង្វរព្រះវិញ្ញាណឲ្យទ្រង់យាងមក៖

> បពិត្រព្រះជាម្ចាស់ដ៏មានព្រះហឫទ័យសប្បុរសក្រៃលែង ព្រះអង្គជាព្រះបិតារបស់ព្រះយេស៊ូ ជាព្រះគ្រីស្ត និងជាព្រះអម្ចាស់នៃយើងខ្ញុំ។ សូមព្រះអង្គទតមើលបងប្អូនដែលទើបបានជ្រមុជទឹកនោះ។ ដោយសារពិធីជ្រមុជទឹក ព្រះអង្គក៏បានប្រោសបងប្អូនទាំងនោះឲ្យរួចផុតពីបាបនានា។ ព្រះអង្គបានប្រោសបងប្អូនទាំងនោះឲ្យកើតជាថ្មីដោយសារទឹក និងព្រះវិញ្ញាណផងដែរ។ សូមទ្រង់ព្រះមេត្តាចាក់បង្ហូរព្រះវិញ្ញាណរបស់ព្រះអង្គលើបងប្អូនទាំងនោះ តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ។ សូមទ្រង់ប្រទានព្រះវិញ្ញាណដែលសណ្ឋិតលើព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូ។ ព្រះវិញ្ញាណដែលផ្តល់ប្រាជ្ញាឈ្លាសវៃ ឲ្យចេះពិចារណាដឹងខុសត្រូវ ព្រះវិញ្ញាណដែលផ្តល់ឲ្យមានយោបល់ល្អ និងផ្តល់កម្លាំង ព្រះវិញ្ញាណដែលបំភ្លឺចិត្តគំនិតឲ្យស្គាល់ និងគោរពប្រណិប័តន៍ព្រះបិតា សូមឲ្យគេចេះគោរពកោតខ្លាចព្រះអង្គ។ យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់នៃយើងខ្ញុំ។

១៣០០- បន្ទាប់មក មានពិធីសំខាន់បំផុតនៃអគ្គសញ្ញា។ ក្នុងពិធីខាងបស្ចិមប្រទេស "គេទទួលអគ្គសញ្ញាលាបថ្ងាស នៅពេលដែលយើងលាបប្រេងគ្រីស្មាលើថ្ងាស ដោយដាក់ដៃ ហើយមានប្រសាសន៍ថា៖ "ខ្ញុំដៅអ្នកដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះអំណោយទានរបស់ព្រះជាម្ចាស់" (សម្តេចប៉ាប ប៉ូលទី៦)។ ក្នុងព្រះសហគមន៍ខាងបូព៌ាប្រទេស ក្រោយពីបានអង្វរព្រះវិញ្ញាណឲ្យយាងមក គេលាបប្រេងមីរ៉ូន លើផ្នែកសំខាន់ៗ នៃរូបកាយដូចជា ថ្ងាស ភ្នែក ច្រមុះ ត្រចៀក បបូរមាត់ ទ្រូង ខ្នង ដៃ និងជើង ដោយមានប្រសាសន៍ថា៖ "សញ្ញាសម្គាល់របស់ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះអំណោយទាន"។

១៣០១- គ្រីស្តបរិស័ទ និងលោកអភិបាលធ្វើកាយវិការមួយ សម្តែង និងបញ្ជាក់ថា ពួកគេរួបរួមជាមួយគ្នា ដើម្បីបញ្ចប់ពិធីនៃអគ្គសញ្ញា (សន្តៈ អ៊ីប៉ូលីត)។

## ៣- ផលនៃអគ្គសញ្ញាលាបថ្ងាស

១៣០២- តាមពិធីបុណ្យ ការចាក់បង្ហូរនៃព្រះវិញ្ញាណដ៏វិសុទ្ធឲ្យបានពេញលេញជាផលនៃអគ្គសញ្ញាលាបថ្ងាស ដូចព្រះជាម្ចាស់បានចាក់បង្ហូរព្រះវិញ្ញាណឲ្យក្រុមគ្រីស្តទូត នៅថ្ងៃបុណ្យព្រះវិញ្ញាណយាងមក។

១៣០៣- តាមការពិត អគ្គសញ្ញាលាបថ្ងាសធ្វើឲ្យរីកចម្រើន និងពង្រឹងព្រះអំណោយទានរបស់អគ្គសញ្ញាជ្រមុជទឹក។ អគ្គសញ្ញានេះ៖

- ធ្វើឲ្យយើងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ យ៉ាងជ្រាលជ្រៅ បណ្តាលឲ្យយើងអាចពោលថា៖ "អប្បា! ឱព្រះបិតាអើយ"" (រម ៨,១៥)

- ធ្វើឲ្យយើងអាចរួមរស់យ៉ាងខ្ជាប់ខ្ជួនជាមួយព្រះគ្រីស្ត

- ពង្រឹងព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ

- ធ្វើឲ្យយើងជាប់ចំណងជាមួយព្រះសហគមន៍បានល្អប្រសើរជាងមុន (LG ១១)

- ផ្តល់កម្លាំងពិសេសនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីផ្សព្វផ្សាយ និងការពារជំនឿ តាមពាក្យសម្តី និងតាមកិច្ចការ ដូចជាសាក្សីពិតប្រាកដរបស់ព្រះគ្រីស្ត និងដើម្បីប្រកាសដោយចិត្តក្លាហានព្រះនាមព្រះគ្រីស្ត កុំឲ្យយើងខ្មាសនឹងព្រះឈើឆ្កាងជាដរាបតរៀងទៅ (DS ១៣១៩ ; LG ១១ ; ១២)៖

ចូររំឭកថា អ្នកបានទទួលសញ្ញាខាងវិញ្ញាណ គឺព្រះវិញ្ញាណនៃប្រាជ្ញាឈ្លាសវៃ ដែលនាំឲ្យចេះពិចារណាដឹងខុសត្រូវ ព្រះវិញ្ញាណដែលផ្តល់ឲ្យមានយោបល់ល្អ និងផ្តល់កម្លាំង ព្រះវិញ្ញាណដែលបំភ្លឺចិត្តគំនិតឲ្យស្គាល់ និងគោរពប្រណិប័តន៍ព្រះបិតា ព្រះវិញ្ញាណដែលនាំឲ្យគោរពកោតខ្លាចព្រះអង្គ ហើយចូររក្សាទុកអ្វីដែលអ្នកបានទទួល។ ព្រះជាម្ចាស់ជាព្រះបិតាបានដៅចំណាំអ្នក ដោយសញ្ញាសម្គាល់របស់ព្រះអង្គ ព្រះគ្រីស្តជាព្រះអម្ចាស់បានអភិសេកអ្នក ហើយបានបញ្ចាំព្រះវិញ្ញាណក្នុងចិត្តរបស់អ្នក (សន្តៈ អំប្រ័រ)។

១៣០៤- ដូចអគ្គសញ្ញាជ្រមុជទឹកដែលអគ្គសញ្ញាលាបថ្ងាសបង្ហើយ យើងផ្តល់អគ្គសញ្ញាលាបថ្ងាសតែម្តងប៉ុណ្ណោះ។ អគ្គសញ្ញាលាបថ្ងាសដៅចំណាំក្នុងព្រលឹងស្នាមខាងវិញ្ញាណដែលមិនអាចលុប ជា "លក្ខណៈពិសេស" (DS ១៦០៩) ជាសញ្ញាសម្គាល់ថា ព្រះយេស៊ូគ្រីស្តបានដៅចំណាំគ្រីស្តបរិស័ទម្នាក់ពីត្រានៃព្រះវិញ្ញាណព្រះអង្គ ដោយផ្តល់ឫទ្ធានុភាពពីស្ថានលើ ដើម្បីឲ្យគេទៅជាសាក្សីរបស់ព្រះអង្គ (លក ២៤,៤៨-៤៩)។

១៣០៥- "លក្ខណៈពិសេស" ពង្រឹងឋានៈជាបូជាចារ្យរបស់គ្រីស្តបរិស័ទ ដែលសុទ្ធតែជាបូជាចារ្យតាំងពីអគ្គសញ្ញាជ្រមុជទឹក ឲ្យកាន់តែល្អប្រសើរ ហើយ "អ្នកដែលទទួលអគ្គសញ្ញាលាបថ្ងាសទទួលឫទ្ធានុភាពអាចប្រកាសជំនឿរបស់ព្រះគ្រីស្តជាសាធារណៈ ហាក់ដូចជាគេបានទទួលបន្ទុកមួយ (quasi ex officio) (សន្តៈ ថូម៉ាស នៃអាកាំង)។

## ៤- «តើនរណាអាចទទួលអគ្គសញ្ញានេះបាន»

១៣០៦- អស់អ្នកដែលបានជ្រមុជទឹកហើយ ៗមិនទាន់បានទទួលអគ្គសញ្ញាលាបថ្ងាស អាច និងត្រូវតែទទួល

អគ្គសញ្ញាលាបថ្ងាស ( CIC ៨៨៩,១ )។ ដោយសារអគ្គសញ្ញាជ្រមុជទឹក លាបថ្ងាស និងអរព្រះគុណរួម ឯកភាព ជាមួយគ្នា "គ្រីស្តបរិស័ទជាចាំបាច់ត្រូវតែទទួលអគ្គសញ្ញានេះ ក្នុងពេលសមរម្យ" ( CIC ៨៩០ ) ដ្បិតបើ គ្មានអគ្គសញ្ញាលាបថ្ងាស និងអរព្រះគុណទេ អគ្គសញ្ញាជ្រមុជទឹកពិតជាត្រឹមត្រូវ ហើយមានប្រសិទ្ធិភាព ប៉ុន្តែ អ្នកដែលបានជ្រមុជទឹកមិនទាន់ជាគ្រីស្តបរិស័ទពេញលេញនៅឡើយ។

១៣០៧- ប្រពៃណីខាងបស្ចិមប្រទេសស្នើសុំឲ្យមាន "អាយុគ្រប់គ្រាន់" ដើម្បីទទួលអគ្គសញ្ញាលាបថ្ងាស។ ក៏ប៉ុន្តែ បើមានគ្រោះថ្នាក់ដល់ជីវិត យើងត្រូវតែផ្តល់អគ្គសញ្ញាលាបថ្ងាសដល់កូនក្មេង ទោះបីពួកវាមិនទាន់គ្រប់អាយុក៏ដោយ ( CIC ៨៩១ ; ៨៨៣,៣ )។

១៣០៨- ទោះជាមានពេលខ្លះ យើងធ្លាប់និយាយអំពីអគ្គសញ្ញាលាបថ្ងាសថា ជាអគ្គសញ្ញារបស់ "គ្រីស្តបរិស័ទចាស់ទុំ" យ៉ាងណាក៏ដោយ ក៏យើងមិនត្រូវច្រឡំអាយុពេញវ័យនៃជំនឿជាមួយនឹងអាយុពេញវ័យខាងធម្មជាតិ ឬយើងមិនត្រូវភ្លេចថា ព្រះជាម្ចាស់ប្រោសប្រទានព្រះអំណោយទាននៃអគ្គសញ្ញាជ្រមុជទឹក ដោយមិនរាប់បាបបុណ្យ ហើយដែលមិនត្រូវការឲ្យយើង "បញ្ជាក់" ដើម្បីឲ្យព្រះអំណោយទាននេះមានប្រសិទ្ធិភាពទេ។ សន្តៈថូម៉ាស នៃអាកាំង រំឭកថា៖

> អាយុនៃកាយមិនអាចធ្វើឲ្យព្រលឹងខូចខាតទេ។ ហេតុនេះ ទោះជាស្ថិតនៅក្នុងកុមារភាពក៏ដោយ មនុស្សអាចទទួលអាយុខាងវិញ្ញាណឲ្យបានពេញលក្ខណៈ ដូចមានចែងទុកក្នុងកណ្ឌព្រះប្រាជ្ញាញាណ ( ៤,៨ )៖ អាយុជីវិត ដែលមានតម្លៃ មិនមែនមកពីមានអាយុវែង ហើយរស់បានយូរឆ្នាំនោះទេ"។ ហេតុនេះហើយ បានជាកុមារ កុមារីជាច្រើនបានតស៊ូដោយចិត្តក្លាហានរហូតដល់បង្ហូរឈាម ដើម្បីព្រះគ្រីស្ត ដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ( សន្តៈ ថូម៉ាស នៃអាកាំង )។

១៣០៩- ក្នុងការត្រៀមខ្លួន ទទួលអគ្គសញ្ញាលាបថ្ងាស ត្រូវតែមានគោលដៅណែនាំគ្រីស្តបរិស័ទឲ្យរួមរស់ជាមួយព្រះគ្រីស្តយ៉ាងស្និទ្ធស្នាលជាងមុន ឲ្យស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធ កិច្ចការ អំណោយទាន និងការត្រាស់ហៅរបស់ព្រះអង្គ យ៉ាងជិតស្និទ្ធជាងមុន ដើម្បីអាចទទួលការខុសត្រូវប្រកាសដំណឹងល្អ ក្នុងការរស់នៅជាគ្រីស្តបរិស័ទ។ ហេតុនេះ អ្នកណែនាំអប់រំជំនឿឲ្យបេក្ខជនទទួលអគ្គសញ្ញាលាបថ្ងាសត្រូវតែខិតខំដាស់តឿនគេឲ្យដឹងថា គេជាកម្មសិទ្ធិនៃព្រះសហគមន៍របស់ព្រះយេស៊ូគ្រីស្ត ទាំងព្រះសហគមន៍សកល ទាំងសហគមន៍តាមភូមិ។ សហគមន៍តាមភូមិនេះ ទទួលការខុសត្រូវយ៉ាងពិសេសក្នុងការរៀបចំមនុស្ស ដែលនឹងទទួលអគ្គសញ្ញាលាបថ្ងាស ( OCf )។

១៣១០- ត្រូវតែរួមរស់ជាមួយព្រះជាម្ចាស់ឲ្យបានពេញលេញ ដើម្បីទទួលអគ្គសញ្ញាលាបថ្ងាស។ គួរទទួលអគ្គសញ្ញាលើកលែងទោស ដែលបន្សុទ្ធយើង មុននឹងទទួលព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវតែអធិដ្ឋានយ៉ាងជ្រាលជ្រៅបំផុត ដើម្បីត្រៀមខ្លួន ដោយមានចិត្តសុភាពរាបសា ដើម្បីទទួលឫទ្ធានុភាព និងព្រះអំណោយទានផ្សេងៗនៃព្រះវិញ្ញាណដ៏វិសុទ្ធ ( កក ១,១៤ )។

១៣១១- បេក្ខជនគួរស្វែងរកជំនួយខាងវិញ្ញាណរបស់ឪពុកម្តាយធម៌ ដើម្បីទទួលអគ្គសញ្ញាលាបថ្ងាស ដូចចំពោះអគ្គសញ្ញាជ្រមុជទឹកផងដែរ។ ឪពុកម្តាយធម៌នៃអគ្គសញ្ញាលាបថ្ងាសគួរតែជាឪពុកម្តាយធម៌នៃអគ្គសញ្ញាជ្រមុជទឹកដែរ ដើម្បីបញ្ជាក់នូវឯកភាពនៃអគ្គសញ្ញាទាំងពីរនោះ ( OCf ; CIC ៨៩៣,១.២ )។

## ៥- អ្នកមានមុខងារផ្តល់អគ្គសញ្ញាលាបថ្ងាស

១៣១២- ជាធម្មតា អ្នកមានមុខងារ ផ្តល់អគ្គសញ្ញាលាបថ្ងាស គឺជាលោកអភិបាល (LG ២៦)។

នៅបូព៌ាប្រទេស ជាធម្មតា លោកបូជាចារ្យដែលផ្តល់ពិធីជ្រមុជទឹកជាអ្នកដែលផ្តល់អគ្គសញ្ញា លាបថ្ងាសក្នុងពិធីបុណ្យតែមួយ។ ក៏ប៉ុន្តែ លោកធ្វើដូច្នេះជាមួយនឹងប្រេងគ្រីស្មា ដែលលោកព្រឹទ្ធាចារ្យ ឬលោកអភិបាលបានប្រសិទ្ធ ដែលសម្តែងនូវឯកភាពដែលមកពីក្រុមគ្រីស្តទូតរបស់ព្រះសហគមន៍ ដែលអគ្គសញ្ញាលាប ថ្ងាសពង្រឹងចំណង។ ក្នុងព្រះសហគមន៍ខាងបស្ចិមប្រទេស យើងប្រតិបត្តិតាមវិន័យដដែលនេះ ក្នុងពិធីជ្រមុជទឹករបស់មនុស្សពេញវ័យ ឬនៅពេលដែលយើងទទួលគ្រីស្តបរិស័ទម្នាក់ឲ្យរួបរួមជាមួយព្រះសហគមន៍ឲ្យបានពេញលេញ នៅពេលដែលគេមកពីសហគមន៍គ្រីស្តបរិស័ទផ្សេង ដែលមិនបានទទួលអគ្គសញ្ញាលាបថ្ងាសតាមក្បួនច្បាប់ព្រះសហគមន៍ (CIC ៨៨៣,២)។

១៣១៣- ក្នុងពិធីខាងបស្ចិមប្រទេស ជាធម្មតា អ្នកមានមុខងារផ្តល់អគ្គសញ្ញាលាបថ្ងាសជាលោកអភិបាល (CIC ៨៨២)។ ទោះបីជាលោកអភិបាលអាចអនុញ្ញាតឲ្យលោកបូជាចារ្យផ្តល់អគ្គសញ្ញាលាបថ្ងាស (CIC ៨៨៤,២) ដោយសារមូលហេតុសំខាន់ៗយ៉ាងណាក៏ដោយ ក៏លោកអភិបាលគួរផ្តល់អគ្គសញ្ញានេះដោយ ខ្លួនលោកផ្ទាល់ ដោយសារអត្ថន័យផ្ទាល់នៃអគ្គសញ្ញានេះ និងដោយមិនភ្លេចថា យើងបានបំបែកអគ្គសញ្ញានេះពីអគ្គសញ្ញាជ្រមុជទឹក ដើម្បីឲ្យលោកអភិបាលអាចផ្តល់ជូនអស់អ្នកដែលត្រូវទទួល។ លោកអភិបាលជាអ្នក បន្តមុខងារពីក្រុមគ្រីស្តទូត ពួកលោកបានទទួលអគ្គសញ្ញាតែងតាំងឲ្យបានពេញលក្ខណៈ ហេតុនេះហើយ បានជាពេលលោកអភិបាលផ្តល់អគ្គសញ្ញានេះ លោកបញ្ជាក់ថា អស់អ្នកដែលទទួលអគ្គសញ្ញានេះរួបរួមយ៉ាងស្និទ្ធស្នាលជាងមុនជាមួយព្រះសហគមន៍ រួមជាមួយក្រុមគ្រីស្តទូត និងរួមរស់ក្នុងបេសកកម្មផ្តល់សក្ខីភាពអំពីព្រះគ្រីស្តផងដែរ។

១៣១៤- បើគ្រីស្តបរិស័ទម្នាក់ជិតស្លាប់ លោកបូជាចារ្យណាម្នាក់ត្រូវតែផ្តល់អគ្គសញ្ញាលាបថ្ងាសឲ្យគេ (CIC ៨៨៣,៣)។ ព្រះសហគមន៍គ្មានបំណងឲ្យបុត្រធីតាណាម្នាក់របស់ខ្លួនចាកចេញពីលោកនេះ បើព្រះវិញ្ញាណដ៏វិសុទ្ធមិនទាន់បានប្រោសគេឲ្យបានគ្រប់លក្ខណៈ ដោយសារព្រះអំណោយទានយ៉ាងបរិបូណ៌របស់ព្រះគ្រីស្ត។

## សង្ខេប

១៣១៥- "ក្រុមគ្រីស្តទូត នៅក្រុងយេរូសាឡឹម បានឮដំណឹងថា អ្នកស្រុកសាម៉ារីនាំគ្នាទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក៏ចាត់លោកសិលា និង លោកយ៉ូហានឲ្យទៅជួបអ្នកទាំងនោះ។ លុះទៅដល់ស្រុកសាម៉ារី គ្រីស្តទូតទាំងពីរក៏ទូលអង្វរព្រះជាម្ចាស់សុំឲ្យពួកអ្នកជឿបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដ្បិតព្រះវិញ្ញាណពុំទាន់យាងចុះមកសណ្ឋិតលើអ្នកណាម្នាក់ក្នុងចំណោមពួកគេនៅឡើយទេ គឺគេគ្រាន់តែបានទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះអម្ចាស់យេស៊ូប៉ុណ្ណោះ។ ពេលនោះលោកសិលា និងលោកយ៉ូហានបានដាក់ដៃលើគេ ហើយគេក៏បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ" (កក ៨,១៤-១៧)។

១៣១៦- ពិធីលាបថ្ងាសធ្វើឲ្យព្រះអំណោយទាននៃពិធីជ្រមុជទឹកបានពេញលក្ខណៈ គឺអគ្គសញ្ញានេះ ផ្តល់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យយើងចាក់ឫសយ៉ាងជ្រៅក្នុងពូជពង្សជាបុត្រធីតារបស់ព្រះជាម្ចាស់ ឲ្យយើងរួមជាមួយព្រះគ្រីស្តយ៉ាងស្និតស្នាល ជាប់ចំណងនឹងព្រះសហគមន៍យ៉ាងមាំមួន ចូលរួមក្នុងបេសកកម្មរបស់ព្រះសហគមន៍ច្រើនជាងមុន និងជួយឲ្យយើងផ្តល់សក្ខីភាពអំពីគ្រីស្តសាសនាតាមពាក្យសម្តីផង និងតាមកិច្ចការផងដែរ។

១៣១៧- ដូចពិធីជ្រមុជទឹកដែរ ពិធីលាបថ្ងាសដៅសញ្ញាសម្គាល់មួយនៃវិញ្ញាណ ដែលមិនអាចលុបបាន ក្នុង

ព្រលឹងគ្រីស្តបរិស័ទ ហេតុនេះ មួយជីវិតនេះ យើងអាចទទួលអគ្គសញ្ញានេះ តែម្តងប៉ុណ្ណោះ។

១៣១៨- ក្នុងបូព៌ាប្រទេស គេផ្តល់អគ្គសញ្ញានេះក្រោយពីបានជ្រមុជទឹកភ្លាមៗ ក្រោយមក គេចូលរួមក្នុងពិធីអរព្រះគុណ ជាប្រពៃណីដែលបញ្ជាក់ថា អគ្គសញ្ញាទាំងបីបង្ហាត់ឲ្យគេទៅជាគ្រីស្តបរិស័ទពេញលេញ ឯក ភាពជាមួយគ្នា។ ក្នុងព្រះសហគមន៍ខាងបស្ចិមប្រទេស យើងផ្តល់អគ្គសញ្ញានេះ នៅពេលដែលបេក្ខជនចេះទទួលខុសត្រូវ ហើយយើងទុកឲ្យលោកអភិបាលប្រារព្ធអគ្គសញ្ញានេះ ដើម្បីបង្ហាញថា អគ្គសញ្ញានេះពង្រឹងចំណងជាមួយព្រះសហគមន៍។

១៣១៩- បេក្ខជនណាម្នាក់ ដែលចង់ទទួលពិធីលាបថ្ងាស និងដែលចេះទទួលខុសត្រូវ ត្រូវប្រកាសជំនឿ ទទួលការលើកលែងទោស មានបំណងចង់ទទួលអគ្គសញ្ញា និងត្រៀមខ្លួនបំពេញតួរនាទីរបស់ខ្លួនជាសាវ័ក និងជាសាក្សីរបស់ព្រះគ្រីស្ត ក្នុងព្រះសហគមន៍ផង ក្នុងសង្គមផង។

១៣២០- ពិធីសំខាន់បំផុតនៃពិធីលាបថ្ងាស គឺការចាក់ប្រេងគ្រីស្មាលើថ្ងាសរបស់គ្រីស្តបរិស័ទ (នៅបូព៌ាប្រទេសលើវិញ្ញាណឯទៀត) ដោយមានអ្នកទទួលមុខងារបម្រើដាក់ដៃ ដោយពោលថា៖ "ខ្ញុំដៅអ្នកដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះអំណោយទានរបស់ព្រះជាម្ចាស់" ក្នុងពិធីបុណ្យនៅទីក្រុងរ៉ូម "សញ្ញាសម្គាល់របស់ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះអំណោយទាន" ក្នុងពិធីខាងបូព៌ាប្រទេស។

១៣២១- នៅពេលដែលយើងប្រារព្ធពិធីលាបថ្ងាសដាច់ឡែកពីពិធីជ្រមុជទឹក យើងបង្ហាញថា ពិធីទាំងពីរជាប់ចំណងនឹងគ្នា ដោយរំឭកអំពីពាក្យសន្យានៃពិធីជ្រមុជទឹក។ យើងប្រារព្ធពិធីលាបថ្ងាស នៅពេលដែលថ្វាយអភិបូជា បញ្ជាក់អំពីឯកភាពនៃអគ្គសញ្ញាទាំងបីបង្ហាត់គេឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ។

## ប្រការទី៣៖

## អគ្គសញ្ញាអរព្រះគុណ

១៣២២ ពិធីអរព្រះគុណដ៏វិសុទ្ធបញ្ចប់ការបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ។ អស់អ្នកដែលអគ្គសញ្ញាជ្រមុជទឹកត្រូវបានលើកឡើងឲ្យមានឋានៈជាបូជាចារ្យ ហើយដែលបានរួមរស់ជាមួយព្រះគ្រីស្ត ដោយសារអគ្គសញ្ញាលាបថ្ងាស អ្នកទាំងអស់នោះ ចូលរួមចំណែកជាមួយសហគមន៍ទាំងមូលក្នុងសក្ការបូជាផ្ទាល់របស់ព្រះអម្ចាស់ ដោយសារអគ្គសញ្ញាអរព្រះគុណ។

១៣២៣- "នៅពិធីជប់លៀងចុងក្រោយ គឺនៅពេលយប់ដែលព្រះយេស៊ូត្រូវគេបញ្ជូន ព្រះសង្គ្រោះរបស់យើងតែងតាំងសក្ការបូជាអរព្រះគុណ គឺបូជាព្រះកាយនិងព្រះលោហិតរបស់ព្រះអង្គ ដើម្បីបន្តសក្ការបូជាព្វដ៏ឈើឆ្កាងតរៀងទៅរហូតដល់ព្រះអង្គយាងមក។ ព្រះអង្គក៏ផ្ញើទុកឲ្យព្រះសហគមន៍ជាភរិយាដ៏ជាទីស្រឡាញ់នឹករឭកអំពីព្រះអង្គបូជាព្រះជន្ម និងមានព្រះជន្មថ្មីដែរ គឺព្រះអង្គផ្ញើទុកនូវអគ្គសញ្ញានៃសេចក្តីស្រឡាញ់នេះ ជាសញ្ញាសម្គាល់អំពីព្រះសហគមន៍រួបរួមគ្នាជាធ្លុងតែមួយ ជាចំណងនៃសេចក្តីស្រឡាញ់ ជាពិធីជប់លៀងនៃបុណ្យចម្លង។ ក្នុងពិធីជប់លៀងនៃបុណ្យចម្លងនោះ គ្រីស្តបរិស័ទយើងបរិភោគព្រះគ្រីស្តទុកជាអាហារ។ យើងទទួលព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់យ៉ាងពេញបរិបូណ៌ ហើយយើងក៏ទទួលព្រះអំណោយទានដើមដំបូងដែលបញ្ចាំចិត្តឲ្យដឹងថា យើងមុខជានឹងទទួលសិរីរុងរឿងនៅពេលអនាគតពុំខាន" (SC ៤៧)។

## ១- ពិធីអរព្រះគុណជាប្រភព និងជាកំពូលនៃការរស់នៅក្នុងព្រះសហគមន៍

១៣២៤- ពិធីអរព្រះគុណ "ជាប្រភព និងជាកំពូលនៃការរស់នៅទាំងស្រុងរបស់គ្រីស្តបរិស័ទ" (LG ១១)។ "អគ្គសញ្ញាឯទៀតៗ ព្រមទាំងមុខងារទាំងអស់នៃព្រះសហគមន៍ ទាក់ទង និងស្ថិតក្រោមអំណាចនៃពិធីអរព្រះគុណ ដ្បិតក្នុងពិធីអរព្រះគុណដ៏វិសុទ្ធ មានកំណប់ខាងវិញ្ញាណទាំងស្រុងរបស់ព្រះសហគមន៍ ពោលគឺព្រះគ្រីស្តផ្ទាល់ ដែលជាបុណ្យចម្លងរបស់ពួកយើង" (PO ៥)។

១៣២៥- "អគ្គសញ្ញាអរព្រះគុណសម្តែង និងសម្រេចការរួមរស់ក្នុងព្រះជន្មរបស់ព្រះជាម្ចាស់ និងឯកភាពនៃប្រជារាស្ត្ររបស់ព្រះអង្គ ដែលធ្វើឲ្យព្រះសហគមន៍មានសភាពជាព្រះសហគមន៍។ ក្នុងអគ្គសញ្ញានេះ មានកំពូលនៃកិច្ចការដែលព្រះជាម្ចាស់ប្រោសមនុស្សលោកឲ្យបានវិសុទ្ធ នៅក្នុងអង្គព្រះគ្រីស្តផង ហើយមានការគោរពប្រណិប័តន៍ នៅក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ ដែលមនុស្សលោកថ្វាយចំពោះព្រះគ្រីស្ត និងនៅក្នុងអង្គព្រះអង្គចំពោះព្រះបិតា" (CdR)។

១៣២៦- ទីបញ្ចប់ ដោយសារពិធីបុណ្យអរព្រះគុណ យើងរួបរួមជាមួយនឹងពិធីបុណ្យនៃស្ថានបរមសុខហើយ ហើយយើងប្រារព្ធទុកជាមុនជីវិតអស់កល្បជានិច្ច នៅពេលដែល "ព្រះជាម្ចាស់បានគ្រងរាជ្យលើអ្វីៗទាំងអស់គ្រប់ប្រការ" (១ករ ១៥,២៨)។

១៣២៧- និយាយឲ្យខ្លីទៅ អគ្គសញ្ញាអរព្រះគុណជាសេចក្តីសង្ខេប និងបូកសរុបជំនឿរបស់យើង៖ "របៀបគិតរបស់យើងសម្របទៅនឹងពិធីអរព្រះគុណ ហើយពិធីអរព្រះគុណវិញ បញ្ជាក់អំពីរបៀបគិតរបស់យើង" (សន្តអ៊ីរ៉េណេ)។

## ២- «តើគេហៅអគ្គសញ្ញានេះយ៉ាងដូចម្តេច»

១៣២៨- របៀបហៅផ្សេងៗ ដែលគេធ្លាប់ប្រើសម្តែងនូវលក្ខណៈសម្បត្តិដ៏ប្រសើរបំផុតនៃអគ្គសញ្ញានេះ។ របៀបហៅនីមួយៗបំភ្លឺលក្ខណៈខ្លះៗនៃអគ្គសញ្ញានេះ។ គេហៅអគ្គសញ្ញានេះថា៖

អរព្រះគុណ ដ្បិតយើងអរព្រះគុណព្រះជាម្ចាស់។ ពាក្យ **eucharistein** (លក ២២,១៩ ; ១ករ ១១,២៤) និង **eulogein** (មថ ២៦,២៦ ; មក ១៤,២២) រំឭកពិធីប្រទានពរនៃសាសនាយូដា ដែលប្រកាស -ជាពិសេសក្នុងពិធីជប់លៀង- ស្នាព្រះហស្តរបស់ព្រះជាម្ចាស់៖ ការបង្កើត ការសង្គ្រោះ និងការប្រោសឲ្យបានវិសុទ្ធ។

១៣២៩- ពិធីជប់លៀរបស់ព្រះអម្ចាស់ (១ករ ១១,២០) សំដៅទៅលើពិធីជប់លៀងចុងក្រោយ របស់ព្រះអម្ចាស់ជាមួយក្រុមសាវ័ក មុននឹងរងទុក្ខលំបាក ដែលប្រារព្ធទុកជាមុនពិធីជប់លៀងមង្គលការរបស់កូនចៀម (វវ ១៩,៩) នៅទីក្រុងយេរូសាឡឹមនៅស្ថានបរមសុខ។

ពិធីកាច់នំបុ័ង ដ្បិតព្រះយេស៊ូបានប្រើពិធីនេះ ដែលជាលក្ខណៈពិសេសនៃម្ហូបអាហាររបស់ជនជាតិយូដា នៅពេលដែលព្រះអង្គប្រទានពរ និងចែកនំបុ័ងក្នុងឋានៈជាម្ចាស់ផ្ទះ (មថ ១៤,១៩ ; ១៥,៣៦ ; មក ៨,៦.១៩) ជាពិសេសនៅពិធីជប់លៀងចុងក្រោយ (មថ ២៦,២៦ ; ១ករ ១១,២៤)។ ដោយសារកាយវិការនេះ ក្រុមសាវ័កនឹងទទួលស្គាល់ព្រះអង្គ ក្រោយពីព្រះអង្គមានព្រះជន្មថ្មី (លក ២៤,១៣-៣៥) ហើយគ្រីស្តបរិស័ទដើមនឹងហៅអភិបូជារបស់គេតាមពាក្យសម្តីនេះដែរ (កក ២,៤២.៤៦ ; ២០,៧.១១)។ ដោយសារពាក្យសម្តីនេះ គ្រីស្តបរិស័ទចង់បង្ហាញថា អស់អ្នកដែលទទួលទាននំបុ័ងតែមួយ

ដែលត្រូវកាច់ គឺព្រះគ្រីស្ត អ្នកនោះរួបរួមជាមួយព្រះអង្គ ហើយធ្វើជារូបកាយតែមួយក្នុងអង្គព្រះអង្គ (១ករ ១០,១៦-១៧)។

អង្គប្រជុំអរព្រះគុណ (synaxis) ដ្បិតអង្គប្រជុំរបស់គ្រីស្តបរិស័ទ ដែលសម្តែងព្រះសហគមន៍ឲ្យមើលឃើញ ជាអ្នកប្រារព្ធពិធីអរព្រះគុណ (១ករ ១១,១៧-៣៤)។

១៣៣០- ធម៌នឹករឭក នៃទុក្ខលំបាក និងជីវិតថ្មីរបស់ព្រះអម្ចាស់។

សក្ការបូជាដ៏វិសុទ្ធ ដ្បិតអគ្គសញ្ញានេះ ធ្វើឲ្យសក្ការបូជាតែមួយរបស់ព្រះគ្រីស្តជាព្រះ សង្គ្រោះមានវត្តមានសព្វថ្ងៃ ព្រមទាំងបង្រួបបង្រួមតង្វាយរបស់ព្រះសហគមន៍ ឬសក្ការបូជាដ៏វិសុទ្ធនៃអភិបូជា "យញ្ញបូជាសម្រាប់លើកតម្កើងព្រះជាម្ចាស់" (ហប ១៣,១៥) (ទន ១១៦,១៣.១៧) យញ្ញបូជាខាងវិញ្ញាណ (១ពត្រ ២,៥) យញ្ញបូជាដ៏បរិសុទ្ធ (មគ ១,១១) និងដ៏វិសុទ្ធ ដ្បិតយញ្ញបូជានេះ សម្រេចសព្វគ្រប់យញ្ញបូជាទាំងអស់នៃសម្ព័ន្ធមេត្រីចាស់។

ពិធីបុណ្យដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ដ្បិតពិធីបុណ្យទាំងអស់របស់ព្រះសហគមន៍បានពេញលក្ខណៈដោយសារការប្រារព្ធអគ្គសញ្ញានេះ។ តាមអត្ថន័យដដែលនេះ យើងហៅអគ្គសញ្ញានេះថា ពិធីលើកតម្កើងគម្រោងការដ៏លាក់កំបាំងដ៏វិសុទ្ធ។ យើងនិយាយអំពីអគ្គសញ្ញាដ៏វិសុទ្ធបំផុតដែរ ដ្បិតអគ្គសញ្ញានេះ ជាអគ្គសញ្ញានៃអគ្គសញ្ញាទាំងអស់។ អគ្គសញ្ញាដ៏វិសុទ្ធបំផុត សម្តៅទៅលើព្រះកាយព្រះគ្រីស្តដែលយើងទុកនៅក្នុងព្រះពន្លា។

១៣៣១- អគ្គសញ្ញាព្រះកាយព្រះគ្រីស្ត ដ្បិតដោយសារអគ្គសញ្ញានេះ យើងរួមរស់ជាមួយព្រះគ្រីស្ត ដែលប្រោសយើងឲ្យចូលរួមចំណែកក្នុងព្រះកាយ ព្រះលោហិតព្រះអង្គ ដើម្បីឲ្យទៅជារូបកាយតែមួយ (១ករ ១០,១៦-១៧)។ យើងហៅអគ្គសញ្ញានេះថា វត្ថុដ៏វិសុទ្ធ៖ ta hagia ; sancta (Const. Ap. ; ឌីដាខេ) -ដែលជាអត្ថន័យដំបូងនៃសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ដែលមាននៅក្នុងធម៌ប្រកាសជំនឿរបស់ក្រុមគ្រីស្ទទូត- នំប៉័ងនៃទេវទូត នំប៉័ងនៃស្ថានបរមសុខ ថ្នាំនៃជីវិតអមតៈ (សន្តៈ អ៊ីញ៉ាស អង់ទីអូស)...

១៣៣២- អភិបូជាដ៏វិសុទ្ធ ដ្បិតពិធីចាត់គ្រីស្តបរិស័ទឲ្យទៅ (missio) បញ្ចប់ពិធីបុណ្យ ដែលព្រះជាម្ចាស់បានសម្រេចគម្រោងការនៃការសង្គ្រោះ។ ព្រះអង្គចាត់ឲ្យគ្រីស្តបរិស័ទទៅ ដើម្បីគាប់ព្រះ ហឫទ័យរបស់ព្រះអង្គក្នុងជីវិតប្រចាំថ្ងៃ។

## ៣- អគ្គសញ្ញាអរព្រះគុណក្នុងការចាត់ចែងនៃការសង្គ្រោះ

### សញ្ញាសម្គាល់នៃនំប៉័ង និងស្រា

១៣៣៣- ដោយសារព្រះបន្ទូលរបស់ព្រះគ្រីស្ត និងដោយសារពាក្យអង្វរឲ្យព្រះវិញ្ញាណយាងមក នំប៉័ង និងស្រាក្លាយទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ នេះជាស្នូលនៃពិធីអរព្រះគុណ។ ព្រះសហគមន៍ ដែលស្មោះត្រង់នឹងព្រះបញ្ញារបស់ព្រះអម្ចាស់ នៅតែធ្វើអ្វីដែលព្រះអង្គបានធ្វើមុននឹងរងទុក្ខលំបាក ព្រះសហគមន៍ក៏ធ្វើដូច្នេះ ដើម្បីរំឭកដល់ព្រះអង្គ រហូតដល់ពេលទ្រង់នឹងយាងមកវិញពោរពេញដោយសិរីរុងរឿង៖ "ព្រះអង្គយកនំប៉័ងមកកាន់..." "ព្រះអង្គលើកពែងស្រាទំពាំងបាយជូរឡើង..."។ ដោយក្លាយទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត តាមរបៀបអាថ៌កំបាំង សញ្ញាសម្គាល់នៃនំប៉័ង និងស្រា នៅតែសម្តែងសប្បុរសធម៌នៃការ បង្កើត។

ហេតុនេះ ពេលថ្វាយតង្វាយ យើងអរព្រះគុណព្រះជាម្ចាស់ ដើម្បីនំប៉័ង និងស្រា (ទន ១០៤,១៣-១៥) ជាផលផ្លែនៃ "ការងាររបស់មនុស្សលោក" ប៉ុន្តែ មុនដំបូង "ផលផ្លែនៃទឹកដី" និង "ដើមទំពាំងបាយជូរ" ដែលជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ជាព្រះបង្កើត។ ព្រះសហគមន៍យល់ឃើញថា កាយវិការរបស់លោកមែលគីសេដែកជាព្រះមហាក្សត្រ និងជាបូជាចារ្យ ដែល "យកនំប៉័ង និងស្រា" (កណ ១៤,១៨) ជានិមិត្តរូបទុកជាមុននៃតង្វាយរបស់ខ្លួន (MR)។

១៣៣៤- ក្នុងសម្ពន្ធមេត្រីចាស់ គេថ្វាយនំប៉័ង និងស្រាធ្វើជាយញ្ញបូជា ក្នុងចំណោមផលផ្លែដំបូងនៃផែនដី ដើម្បីអរព្រះគុណព្រះជាម្ចាស់ជាព្រះបង្កើត។ ប៉ុន្តែ ក្នុងកាលៈទេសៈនៃដំណើរឆ្ពោះទៅកាន់សេរីភាព នំប៉័ង និងស្រានោះ ទទួលអត្ថន័យថ្មី៖ នំប៉័ងឥតមេ ដែលជនជាតិអ៊ីស្រាអែលបរិភោគជារៀងរាល់ឆ្នាំ រំឭកថាគេបានចាកចេញពីប្រទេសអេស៊ីបយ៉ាងប្រញាប់ប្រញាល់ នំម៉ាណាតែងតែរំឭកឲ្យជនជាតិអ៊ីស្រាអែលដឹងថាគេរស់ដោយសារអាហារនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ (ទក ៨,៣)។ ទីបញ្ចប់ នំប៉័ងប្រចាំថ្ងៃជាផលផ្លែនៃទឹកដីសន្យា ដែលធានាថា ព្រះជាម្ចាស់គោរពព្រះបន្ទូលសន្យារបស់ព្រះអង្គជានិច្ច។ "ពែងនៃព្រះពរ" (១ករ ១០,១៦) នៅទីបញ្ចប់នៃពីធីជប់លៀងនៃបុណ្យចម្លងរបស់ជនជាតិយូដា មិនគ្រាន់តែសម្ដែងនូវភាពសប្បាយរីករាយនៃស្រា ទំពាំងបាយជូទេ ថែមទាំងបង្ហាញថា ពួកគេរង់ចាំគ្រាចុងក្រោយបំផុត ជាគ្រាដែលព្រះសង្គ្រោះនឹងប្រោសទីក្រុងយេរូសាឡឹមឡើងវិញដែរ។ ព្រះយេស៊ូបានតែងតាំងអភិបូជារបស់ព្រះអង្គ ដោយផ្ដល់អត្ថន័យថ្មី និងជាស្ថាពរដល់ការប្រទានពរលើនំប៉័ង និងលើពែង ។

១៣៣៥- នៅពេលដែលព្រះយេស៊ូប្រទានព្រះពរ កាច់ និងចែកនំប៉័ងឲ្យបណ្ដាជនតាមរយៈក្រុមសាវ័ក ការអស្ចារ្យនោះជានិមិត្តរូបទុកជាមុននំប៉័ងតែមួយ និងយ៉ាងបរិបូណ៌ នៃពិធីអរព្រះគុណរបស់ព្រះអង្គ (មថ ១៤,១៣-២១ ; ១៥,៣២-៣៩)។ សញ្ញានៃទឹកប្រែជាស្រានៅភូមិកាណា (យហ ២,១១) ប្រកាសទុកជាមុនពេលកំណត់នៃសិរីរុងរឿងរបស់ព្រះយេស៊ូ ហើយសម្ដែងថា ពិធីមង្គលការបានសម្រេច នៅក្នុងព្រះរាជ្យព្រះបិតា ដែលគ្រីស្តបរិស័ទនឹងពិសាស្រាថ្មី (មក១៤,២៥) ដែលបានក្លាយទៅជាព្រះលោហិតព្រះគ្រីស្ត។

១៣៣៦- ពេលព្រះយេស៊ូនមានព្រះបន្ទូលជាលើកទីមួយអំពីអភិបូជា ក្រុមសាវ័កទាស់ចិត្ត ដូចពេលព្រះអង្គមានព្រះបន្ទូលថា នឹងរងទុក្ខលំបាកដែរ៖ "ពាក្យទាំងនេះ ទាស់ត្រចៀកណាស់! តើនរណាអាចទ្រាំស្ដាប់បាន?" (យហ ៦,៦០)។ អភិបូជា និងព្រះឈើឆ្កាងដូចជាថ្មជំពប់ចិត្ត ជាគម្រោងការដ៏អស្ចារ្យតែមួយ ដែលនៅតែបណ្ដាលឲ្យមនុស្សទាស់ទែងគ្នា។ "ចុះអ្នករាល់គ្នាវិញ តើអ្នករាល់គ្នាចង់ចេញទៅដែរ ឬ?" (យហ ៦,៦៧)៖ សំណួររបស់ព្រះអម្ចាស់នេះលាន់ឮគ្រប់សម័យ ដូចជាព្រះអង្គអញ្ជើញយើងឲ្យយល់ឃើញថា មានតែ "ព្រះបន្ទូលរបស់ព្រះអង្គ (ដែល) ផ្ដល់ជីវិតអស់កល្បជានិច្ច" (យហ ៦,៦៨) ហើយឲ្យយើងយល់ឃើញថា ពេលយើងទទួលព្រះអំណោយទាននៃអភិបូជារបស់ព្រះអង្គដោយមានជំនឿ យើងក៏ទទួលព្រះអង្គផ្ទាល់ផងដែរ។

## ការតែងតាំងពិធីអរព្រះគុណ

១៣៣៧- ដោយព្រះអម្ចាស់ស្រឡាញ់មិត្តសម្លាញ់របស់ព្រះអង្គ ទ្រង់ក៏ស្រឡាញ់ពួកគេរហូតដល់ទីបំផុត។ ព្រះអង្គជ្រាបថា ដល់ពេលកំណត់ដែលព្រះអង្គត្រូវឆ្លងពីលោកនេះឆ្ពោះទៅឯព្រះបិតាវិញ។ ពេលកំពុងបរិភោគអាហារ ព្រះអង្គលាងជើងពួកគេ ហើយទ្រង់ប្រទានវិន័យនៃសេចក្តីស្រឡាញ់ឲ្យពួកគេ (យហ ១៣,១-១៧)។ ដើម្បីបញ្ជាំសេចក្តីស្រឡាញ់នេះ ដើម្បីកុំឲ្យឃ្លាតឆ្ងាយពីមិត្តសម្លាញ់របស់ព្រះអង្គ ហើយដើម្បីឲ្យពួកគេ អាចចូលរួមចំណែកក្នុងបុណ្យចម្លងរបស់ព្រះអង្គ ទ្រង់ក៏តែងតាំងអភិបូជាជាពិធីនឹករឭកថា ព្រះអង្គសោយទិវង្គត និងមាន

ព្រះជន្មថ្មី ហើយព្រះអង្គបានបញ្ជាក្រុមគ្រីស្តទូតឲ្យពួកគេលើកតម្កើងព្រះអង្គរហូតដល់ព្រះអង្គនឹងយាងមកវិញ។ ព្រះអង្គក៏បាន "តែងតាំងពួកលោកឲ្យទៅជាបូជាចារ្យនៃសម្ព័ន្ធមេត្រីថ្មី" (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៧៤០)។

១៣៣៨- គម្ពីរសហចក្ខុ និងសន្តះប៉ូលជម្រាបឲ្យយើងដឹងថា ព្រះយេស៊ូបានតែងតាំងអភិបូជា ឯសន្តះយ៉ូហានវិញ លោករៀបរាប់នូវព្រះបន្ទូលរបស់ព្រះយេស៊ូក្នុងធម្មសាលានៃទីក្រុងកាផានុម ជាព្រះបន្ទូលដែលរៀបចំការតែងតាំងពិធីអរព្រះគុណ៖ ព្រះគ្រីស្តសម្តែងព្រះអង្គឲ្យយើងដឹងថា ព្រះអង្គជានំប៉័ងនៃជីវិត ដែលចុះពីស្ថានបរមសុខមក (យហ ៦)។

១៣៣៩- ព្រះយេស៊ូបានជ្រើសរើសវេលានៃបុណ្យចម្លង ដើម្បីបំពេញព្រះបន្ទូលរបស់ព្រះអង្គ នៅទីក្រុងកាផានុម គឺប្រទានឲ្យក្រុមសាវ័កនូវព្រះកាយ និងព្រះលោហិតព្រះអង្គ៖

> លុះដល់ថ្ងៃបុណ្យនំប៉័ងឥតមេ ជាថ្ងៃដែលគេត្រូវសម្លាប់កូនចៀមធ្វើយញ្ញបូជាសម្រាប់បុណ្យចម្លង។ ព្រះយេស៊ូបានចាត់លោកសិលានិងលោកយ៉ូហានឲ្យទៅមុន ដោយមានព្រះបន្ទូលថា៖ "ចូរទៅរៀបចំពិធីជប់លៀងសម្រាប់យើង នៅក្នុងពេលបុណ្យចម្លង" (...)។ អ្នកទាំងពីរក៏ចេញទៅ (...)។ គេរៀបចំម្ហូបអាហារសម្រាប់បុណ្យចម្លង។ លុះដល់ពេលកំណត់ហើយ ព្រះយេស៊ូក៏រួមតុជាមួយក្រុមគ្រីស្តទូត ព្រះអង្គមានព្រះបន្ទូលថា៖ "មុនពេលខ្ញុំរងទុក្ខលំបាក ខ្ញុំចង់បរិភោគម្ហូបអាហារក្នុងឱកាសបុណ្យចម្លងនេះ ជាមួយអ្នករាល់គ្នាណាស់"។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ខ្ញុំនឹងមិនបរិភោគម្ហូបអាហារបុណ្យចម្លងនេះទៀតទេ លុះត្រាតែពិធីបុណ្យនេះបានសម្រេចសព្វគ្រប់ នៅក្នុងព្រះរាជ្យព្រះជាម្ចាស់" (...)។ បន្ទាប់មកព្រះអង្គយកនំប៉័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចព្រះអង្គកាច់ប្រទានឲ្យពួកគេដោយមានព្រះបន្ទូលថា៖ "នេះជារូបកាយខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ចូរធ្វើដូច្នេះ ដើម្បីនឹករំឭកដល់ខ្ញុំ"។ លុះជប់លៀងរួចហើយ ព្រះអង្គធ្វើតាមបែបដដែល ទ្រង់យកពែងមកកាន់ ទាំងមានព្រះបន្ទូលថា៖ "នេះជាពែងនៃសម្ព័ន្ធមេត្រីថ្មី ចងឡើងដោយសារលោហិតខ្ញុំ ដែលត្រូវបង្ហូរសម្រាប់អ្នករាល់គ្នា" (លក ២២,៧-២០) (មថ ២៦,១៧-២៩ ; មក ១៤,១២-២៥ ; ១ករ ១១,២៣-២៦)។

១៣៤០- ដោយប្រារព្ធពិធីជប់លៀងចុងក្រោយជាមួយក្រុមគ្រីស្តទូតរបស់ព្រះអង្គ នៅពេលបុណ្យចម្លង ព្រះយេស៊ូបានផ្តល់អត្ថន័យជាស្ថាពរដល់បុណ្យចម្លងនៃជនជាតិយូដា។ តាមការពិត ពិធីជប់លៀងចុងក្រោយរៀបចំទុកជាមុនបុណ្យចម្លងថ្មី ជាការចម្លងរបស់ព្រះយេស៊ូឆ្ពោះទៅព្រះបិតារបស់ព្រះអង្គ ដោយសោយទីវង្គត និងមានព្រះជន្មថ្មី។ អភិបូជាលើកតម្កើងបុណ្យចម្លងនេះ សម្រេចសព្វគ្រប់បុណ្យចម្លងនៃជនជាតិយូដា និងប្រារព្ធទុកជាមុនបុណ្យចម្លងចុងក្រោយរបស់ព្រះសហគមន៍ក្នុងសិរីរុងរឿងនៃព្រះរាជ្យ។

### "ធ្វើដូច្នេះដើម្បីនឹករឭកដល់ខ្ញុំ"

១៣៤១- ព្រះយេស៊ូបញ្ជាឲ្យយកតម្រាប់តាមកាយវិការ និងព្រះបន្ទូលរបស់ព្រះអង្គ "រហូតដល់ព្រះអង្គយាងមកវិញ" មិនគ្រាន់តែដើម្បីរំឭកដល់ព្រះអង្គ និងអ្វីដែលព្រះអង្គបានប្រព្រឹត្តទេ ប៉ុន្តែ ព្រះអង្គមានព្រះបន្ទូលអំពីពិធីបុណ្យ ដោយក្រុមគ្រីស្តទូត និងអ្នកបន្តក្រុមនេះ ដែលនឹករឭក ព្រះគ្រីស្ត ជីវិតរបស់ព្រះអង្គ ហើយនឹករឭកថាព្រះអង្គបានសោយទិវង្គត មានព្រះជន្មថ្មី និងជួយអង្វរព្រះបិតា។

១៣៤២- តាំងពីដើមដំបូង ព្រះសហគមន៍ស្មោះត្រង់នឹងព្រះបញ្ញារបស់ព្រះអម្ចាស់។ មានចែងទុកអំពី

ព្រះសហគមន៍នៅទីក្រុងយេរូសាឡឹមថា៖

> សាវ័កទាំងនោះព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំប៉័ង និងព្យាយាមអធិស្ឋាន (...)។ ជារៀងរាល់ថ្ងៃ គេរួមចិត្តគំនិតគ្នាព្យាយាមចូលព្រះវិហារ ធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសផង (កក ២,៤២.២៦)។

១៣៤៣- គ្រីស្តបរិស័ទជួបជុំគ្នាធ្វើ "ពិធីកាច់នំប៉័ង" (កក ២០,៧) ជាពិសេស "ថ្ងៃទីមួយនៃសប្តាហ៍" គឺថ្ងៃអាទិត្យ ជាថ្ងៃដែលព្រះយេស៊ូមានព្រះជន្មថ្មី។ ចាប់តាំងពីពេលនោះមក រហូតដល់សព្វថ្ងៃ យើងនៅតែថ្វាយអភិបូជា ទើបមានអភិបូជាគ្រប់ព្រះសហគមន៍ ជាមួយនឹងរចនាសម្ព័ន្ធមូលដ្ឋានដដែល។ អភិបូជាជាស្នូលនៃការរស់នៅក្នុងព្រះសហគមន៍។

១៣៤៤- ហេតុនេះហើយ បានជាពីពិធីបុណ្យមួយទៅពិធីបុណ្យមួយទៀត ដោយប្រកាសថា ព្រះយេស៊ូបានសោយទិវង្គត និងមានព្រះជន្មថ្មី "រហូតដល់ព្រះអង្គយាងមកវិញ" (១ករ ១១,២៦) ប្រជារាស្ត្រ របស់ព្រះជាម្ចាស់ដែលកំពុងធ្វើបូជនីយេសចរណ៍ "ដើរទៅមុខតាមទ្វារចង្អៀតនៃឈើឆ្កាង" (AG ១) ឆ្ពោះទៅ ពិធីជប់លៀងនៃស្ថានបរមសុខ នៅពេលដែលអស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើសនឹងរួមតុនៃព្រះរាជ្យ។

## ៤- ពិធីបុណ្យនៃអគ្គសញ្ញាអរព្រះគុណ

### អភិបូជាគ្រប់សម័យកាល

១៣៤៥- តាំងពីសតវត្សទីពីរ សន្ត: យូស្តាំង ជាមរណសាក្សី ផ្តល់សក្ខីភាពអំពីកិច្ចសំខាន់ដែលគ្រីស្តបរិស័ទត្រូវប្រតិបត្តិក្នុងពិធីបុណ្យអរព្រះគុណ។ កិច្ចនោះ នៅតែមានដដែលរហូតដល់សព្វថ្ងៃ សម្រាប់ព្រះសហគមន៍សំខាន់ៗ។ នៅឆ្នាំ ១៥៥ ដើម្បីពន្យល់ឲ្យព្រះចៅអធិរាជ អង់តូនីន ជាអ្នកគោរពប្រពៃណីបំតន៍ (១៣៨-១៦១) នូវអ្វីដែលគ្រិស្តបរិស័ទធ្វើ សន្ត: យូស្តាំងសរសេរសេចក្តីនោះថា៖

> នៅថ្ងៃដែលគេហៅថា ថ្ងៃអាទិត្យ គ្រីស្តបរិស័ទទាំងអស់ ព្រមទាំងអ្នកនៅទីក្រុងក្តី អ្នកនៅស្រុកស្រែក្តីមកជួបជុំគ្នា។ ពួកគេអានសេចក្តីដែលក្រុមគ្រីស្តទូតបានសរសេរទុក និងសេចក្តីប្រៀនប្រដៅរបស់ពួកព្យាការី។ គេអានយ៉ាងយូរបំផុតតាមលទ្ធភាពរបស់ពួកគេ។ កាលណាអ្នកអាន អានចប់ អ្នកអធិបតីជំរុញនិងដាស់តឿនឲ្យយកតម្រាប់តាមសេចក្តីដ៏ប្រសើរទាំងអស់នោះ។បន្ទាប់មក យើងទាំងអស់គ្នាក្រោកឡើងហើយអធិដ្ឋានរួមគ្នា ដើម្បីខ្លួនឯង (...) និងដើម្បីអ្នកដទៃ គ្រប់ទីកន្លែងដែលពួកគេនៅ ដើម្បីឲ្យយើងទៅជាមនុស្សសុចរិត ទាំងរបៀបរស់នៅ និងកិច្ចការផងទាំងពួង ព្រមទាំងគោរពបទបញ្ញាដោយចិត្តស្មោះ ហើយដើម្បីបានទទួលការសង្គ្រោះអស់កល្បជានិច្ច។ លុះដល់អធិដ្ឋានរួច យើងធ្វើកាយវិការជាសញ្ញាថាយើងសម្រុះសម្រួលនឹងគ្នា។ បន្ទាប់មកទៀត គេយកនំប៉័ង ហើយពែងដាក់ស្រានិងទឹកលាយគ្នាឲ្យអ្នកអធិបតីរបស់បងប្អូន។ លោកទទួលយកអំណោយនោះ កោតសរសើរ និងលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតានៃសកលលោក ដោយព្រះនាមព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយលោកអរព្រះគុណ (ជាភាសាក្រិក eucharistain) យ៉ាងយូរ ដ្បិតព្រះជាម្ចាស់បានប្រោសយើងឲ្យសមនឹងអំណោយនោះ។ លុះដល់លោកអធិដ្ឋាន និងអរព្រះគុណរួច គ្រីស្តបរិស័ទអបអរសាទរ ដោយថ្លែងថា អាម៉ែន។ នៅពេលដែលអ្នកអធិបតីបានអរព្រះគុណ និងប្រជាជនបានឆ្លើយតបរួច អស់អ្នកដែលយើងហៅថា ឧបដ្ឋាកចែកនំប៉័ង

ស្រា និងទឹក "ដែលព្រះជាម្ចាស់បានប្រែ" ទៅដល់អស់អ្នកដែលកំពុងចូលរួម ហើយពួកលោកយកទៅជូនអស់អ្នកដែលមិនបានចូលរួម។

១៣៤៦- ពិធីបុណ្យអរព្រះគុណប្រារព្ធតាមកិច្ចដែលត្រូវប្រតិបត្តិដដែល ពីសតវត្សមួយទៅសតវត្សមួយរហូតដល់សព្វថ្ងៃ ដោយមានវេលាសំខាន់ៗពីរ ដែលរួមឯកភាពជាមួយគ្នា៖

- ការជួបជុំគ្នា ពិធីលើកតម្កើងព្រះបន្ទូល ជាមួយនឹងការអានអត្ថបទ ធម្មទេសនា និងសេចក្ដីអង្វរសកល

- ពិធីអរព្រះគុណដ៏វិសុទ្ធ ដោយមានការថ្វាយតង្វាយ ធម៌អរព្រះគុណ ការប្រសិទ្ធពរ និងពិធីទទួលព្រះកាយព្រះលោហិតព្រះគ្រីស្ត។

ពិធីលើកតម្កើងព្រះបន្ទូល និងពិធីអរព្រះគុណដ៏វិសុទ្ធ រួមជាមួយគ្នាធ្វើជា "កិច្ចគោរពបម្រើព្រះជាម្ចាស់តែមួយគត់" (SC ៥៦) ដ្បិតតុនៃអភិបូជាជាតុនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ផង តុនៃព្រះកាយព្រះអម្ចាស់ផងដែរ (DV ២១)។

១៣៤៧- តើចលនានេះ មិនមែនជាចលនានៃពិធីជប់លៀងនៃបុណ្យចម្លងរបស់ព្រះយេស៊ូ ដែលមានព្រះជន្មថ្មីជាមួយក្រុមសាវ័កទេឬ? នៅកំពុងធ្វើដំណើរ ព្រះអង្គពន្យល់គម្ពីរឲ្យពួកគេ បន្ទាប់មក ព្រះអង្គចូលរួមតុជាមួយពួកគេ ទ្រង់ "យកនំប៉័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចកាច់ប្រទានឲ្យគេ" (លក ២៤,១៣-៣៥)។

## ចលនានៃពិធីបុណ្យ

១៣៤៨- ទាំងអស់គ្នាជួបជុំគ្នា ។ គ្រីស្តបរិស័ទនាំគ្នាចូលក្នុងកន្លែងតែមួយដើម្បីថ្វាយអភិបូជា។ ព្រះគ្រីស្តផ្ទាល់ជាព្រះសិរសា ជាតួឯកនៃពិធីអរព្រះគុណ។ ព្រះអង្គជាមហាបូជាចារ្យនៃសម្ពន្ធមេត្រីថ្មី។ ដោយយើងមើលមិនឃើញព្រះអង្គជាអ្នកអធិបតីនៃពិធីអរព្រះគុណទាំងអស់។ លោកអភិបាល ឬលោកបូជាចារ្យ (ដែលប្រព្រឹត្តក្នុងអង្គព្រះគ្រីស្តជាព្រះសិរសា ) ជាតំណាងរបស់ព្រះអង្គ ដោយណែនាំអង្គប្រជុំ ទេសនាក្រោយពីបានអានអត្ថបទ ទទួលតង្វាយ និងសូត្រធម៌អរព្រះគុណដ៏វិសុទ្ធ។ ទាំងអស់គ្នា ចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យតាមរបៀបរៀងៗខ្លួន៖ អ្នកអាន អ្នកយកតង្វាយមកថ្វាយ អ្នកជូនព្រះកាយព្រះលោហិតព្រះគ្រីស្ត ហើយប្រជាជនទាំងមូល គេចូលរួមផងដែរ ដោយពោលពាក្យ អាម៉ែន ។

១៣៤៩- ក្នុងពិធីលើកតម្កើងព្រះបន្ទូល មាន "សេចក្ដីប្រៀនប្រដៅរបស់ពួកព្យាការី" ពោលគឺសម្ពន្ធមេត្រីចាស់ និង"សេចក្ដីដែលក្រុមគ្រីស្តទូតបានទុក" ពោលគឺលិខិតរបស់ពួកលោក និងកំណ្ឌដំណឹងល្អ។ ក្រោយពីធម៌ទេសនាដែលដាស់តឿនឲ្យចាត់ទុកថា ព្រះបន្ទូលនេះ ពិតជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ (១ថស ២,៥) ព្រមទាំងឲ្យប្រតិបត្តិតាម មានសេចក្ដីអង្វរសកលសម្រាប់មនុស្សទាំងអស់ តាមពាក្យសម្ដីរបស់គ្រីស្តទូតប៉ូលថា៖ "ជាបឋមខ្ញុំសូមផ្ដែផ្ដាំឲ្យទូលសូមព្រះជាម្ចាស់ អធិដ្ឋាន អង្វរ និងអរព្រះគុណព្រះអង្គ សម្រាប់មនុស្សទាំងអស់ផង។ សម្រាប់ស្ដេច និងអ្នកកាន់អំណាចគ្រប់ៗរូប ដើម្បីឲ្យយើងរស់នៅបានសុខក្សេមក្សាន្តគ្មានចលាចល ទាំងគោរពប្រណិប័តន៍ព្រះជាម្ចាស់ អស់ពីចិត្ត និងមានជីវិតថ្លៃថ្នូរ" (១ធម ២,១-២)។

១៣៥០- ពិធីថ្វាយតង្វាយ ៖ ពេលនោះ ជូនកាលជាក្បួនដង្ហែ យើងយកនំប៉័ង និងស្រាទៅដល់អាសនៈ ដែលលោកបូជាចារ្យនឹងថ្វាយជាសក្ការបូជា ក្នុងព្រះនាមព្រះគ្រីស្ត ហើយដែលនឹងទៅជាព្រះកាយ និងព្រះលោហិតព្រះអង្គ។ កាយវិការនេះ ជាកាយវិការផ្ទាល់របស់ព្រះគ្រីស្ត នៅពិធីជប់លៀងចុងក្រោយ ពេលព្រះអង្គ "យកនំប៉័ង និងពែងមកកាន់"។ "មានតែព្រះសហគមន៍ ដែលថ្វាយសក្ការបូជាដ៏បរិសុទ្ធនេះ ចំពោះព្រះជាម្ចាស់ជាព្រះបង្កើត

ដោយថ្វាយអ្វីដែលមកពីការបង្កើតរបស់ព្រះអង្គ ព្រមទាំងអរព្រះគុណព្រះអង្គផង" (សន្តៈ អ៊ីរ៉េណេ ; មគ ១,១១)។ ពិធីថ្វាយតង្វាយទៅដល់អាសនៈទទួលយកកាយវិការរបស់ព្រះបាទមែលគីសេដែក ហើយប្រគល់អំណោយរបស់ព្រះបង្កើតក្នុងព្រះហស្តរបស់ព្រះគ្រីស្ត។ គឺព្រះអង្គនេះហើយ ដែលប្រោសយញ្ញបូជាទាំងប៉ុន្មានដែលមនុស្សព្យាយាមថ្វាយ ឲ្យបានគ្រប់លក្ខណៈ ក្នុងសក្ការបូជារបស់ព្រះអង្គ។

១៣៥១- តាំងពីដើមដំបូង គ្រីស្តបរិស័ទយកអំណោយរបស់ពួកគេ រួមជាមួយនំប៉័ង និងស្រា ដើម្បីចែករំលែកដល់អស់អ្នក ដែលមានតម្រូវការ។ ទំនៀមទម្លាប់នៃការរៃប្រាក់ (១ករ ១៦,១) ដែលមានរហូតដល់សព្វថ្ងៃ យកតម្រាប់តាមព្រះគ្រីស្ត ដែលបានដាក់ខ្លួនមកជាអ្នកក្រ ដើម្បីឲ្យយើងបានទៅជាអ្នកមាន (២ករ ៨,៩)៖

អស់អ្នកដែលមាន ហើយដែលចង់ចែកទានតាមលទ្ធភាព ដែលខ្លួនបានកំណត់ទុកជាមុន។ យើងយកអ្វីដែលបានទទួលជូនអ្នកអធិបតី ហើយលោកជួយសង្គ្រោះក្មេងកំព្រា និងស្ត្រីមេម៉ាយ អស់អ្នកដែលមានជំងឺ ឬមូលហេតុផ្សេងៗធ្វើឲ្យគេខ្វះខាត អ្នកជាប់គុក អន្តោប្រវេសន៍ និយាយឲ្យខ្លី លោកជួយសង្គ្រោះអស់អ្នកដែលមានតម្រូវការ (សន្តៈ យូស្តាំង)។

១៣៥២- ធម៌អរព្រះគុណដ៏វិសុទ្ធ ៖ ធម៌អរព្រះគុណដ៏វិសុទ្ធ ជាធម៌ប្រសិទ្ធពរ ដែលជាស្នូល និងកំពូលនៃពិធីបុណ្យ៖

ក្នុងធម៌ប្រារព្ធ ព្រះសហគមន៍អរព្រះគុណព្រះបិតា តាមរយៈព្រះគ្រីស្ត ក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធសម្រាប់ស្នាព្រះហស្តទាំងអស់របស់ព្រះអង្គ ដោយសារព្រះអង្គបានបង្កើត សង្គ្រោះ និងប្រោសមនុស្សលោកឲ្យបានវិសុទ្ធ។ សហគមន៍ទាំងមូលរួមជាមួយសេចក្តីសរសើរឥតឈប់ឈរ ដែលព្រះសហគមន៍នៅស្ថានបរមសុខ អស់ទេវទូត និងសន្តៈបុគ្គលទាំងឡាយច្រៀងថ្វាយទៅព្រះដ៏វិសុទ្ធបំផុត។

១៣៥៣- ក្នុងពិធីអង្វរព្រះវិញ្ញាណ ព្រះសហគមន៍ទូលសូមព្រះបិតាឲ្យព្រះអង្គចាត់ព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ (ឬ ឫទ្ធានុភាពរបស់ព្រះអង្គ (MR)) ឲ្យយាងមកសណ្ឋិតលើនំប៉័ង និងស្រា ដើម្បីឲ្យនំ និងស្រានោះបានទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ត ដោយសារឫទ្ធានុភាពរបស់ព្រះអង្គ ហើយដើម្បីឲ្យអស់អ្នកដែលចូលរួមក្នុងពិធីអភិបូជាក្លាយទៅជារូបកាយ និងវិញ្ញាណតែមួយ (ប្រពៃណីពិធីបុណ្យខ្លះដាក់ពាក្យអង្វរព្រះវិញ្ញាណក្រោយពីធម៌នឹករឭក)។

ក្នុងពិធីរំឭកការតែងតាំងពិធីអរព្រះគុណឡើងវិញ ឫទ្ធានុភាពនៃព្រះបន្ទូល និងកិច្ចការរបស់ព្រះគ្រីស្ត ព្រមទាំងឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ប្រោសនំប៉័ង និងស្រាឲ្យបានទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ជាសក្ការបូជាដែលព្រះអង្គបានថ្វាយនៅលើឈើឆ្កាងម្តងជាការស្រេច។

១៣៥៤- ក្នុងធម៌នឹករឭក ដែលមានបន្ទាប់មក ព្រះសហគមន៍រំឭកថា ព្រះយេស៊ូបានរងទុក្ខលំបាក មានព្រះជន្មថ្មី ហើយនឹងយាងមកវិញពោរពេញដោយសិរីរុងរឿង។ ព្រះសហគមន៍ថ្វាយទៅព្រះបិតាសក្ការបូជារបស់ព្រះបុត្រាព្រះអង្គ ដែលសម្រុះសម្រួលយើងឲ្យជានានឹងព្រះអង្គ។

ក្នុងការជួយអង្វរសម្រាប់អ្នកដទៃ ព្រះសហគមន៍សម្តែងថា យើងថ្វាយអភិបូជារួមជាមួយព្រះសហគមន៍ ទាំងមូលនៅស្ថានបរមសុខ និងនៅលើផែនដី ទាំងអ្នករស់ ទាំងអ្នកស្លាប់ ដោយរួមជាមួយពួកគង្វាលព្រះសហគមន៍ គឺសម្តេចប៉ាប លោកអភិបាលនៃភូមិភាគនេះ ក្រុមបូជាចារ្យ និងពួកឧបដ្ឋាករបស់លោក ព្រមទាំងពួកលោកអភិបាល និងព្រះសហគមន៍របស់អស់លោក ក្នុងពិភពលោកទាំងមូល។

១៣៥៥- ពេលទទួលព្រះកាយ ព្រះលោហិតព្រះគ្រីស្ត ក្រោយពីសេចក្ដីអធិដ្ឋានរបស់ព្រះអម្ចាស់ និងពិធីកាច់នំបុ័ង គ្រីស្តបរិស័ទទទួល"នំបុ័ងនៃស្ថានបរមសុខ"និង"ពែងនៃការសង្គ្រោះ"គឺព្រះកាយនិងព្រះលោហិតព្រះគ្រីស្តដែលបានបូជាព្រះអង្គ "សម្រាប់ឲ្យមនុស្សលោកមានជីវិត" (យហ ៦,៥១)៖

> ដោយសារ "ព្រះជាម្ចាស់បានប្រែ" (eucharisted) នំបុ័ង និងស្រានេះ "យើងហៅអាហារនេះថា អរព្រះគុណ (Eucharist) ហើយគ្មាន នរណាម្នាក់អាចទទួលបានទេ បើគេមិនជឿលើសេចក្ដីពិត ដែលយើងបង្រៀន បើគេមិនបានមុជទឹក ដើម្បីរួចពីបាប ហើយបើគេមិនរស់តាមវិន័យរបស់ព្រះគ្រីស្ត" (សន្តៈយូស្ទាំង)។

## ៥- សក្ការបូជាខាងអគ្គសញ្ញាៈ អរព្រះគុណ នឹករឭក វត្តមាន

១៣៥៦- គ្រីស្តបរិស័ទថ្វាយអភិបូជាតាំងពីដើមដំបូង ហើយតាមរបៀបដែលត្រូវប្រតិបត្តិ និងដែលមិនបានផ្លាស់ប្ដូរ ទោះបីសម័យកាល និងពិធីបុណ្យផ្សេងៗ ពីព្រោះយើងដឹងថា យើងជាប់ចំណងនឹងព្រះបញ្ញារបស់ព្រះអម្ចាស់មុននឹងព្រះអង្គរងទុក្ខលំបាក៖ "ធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ" (១ករ ១១,២៤-២៥)។

១៣៥៧- យើងគោរពព្រះបញ្ញារបស់ព្រះអម្ចាស់នេះ ដោយនឹករឭកយញ្ញបូជារបស់ព្រះអង្គ។ យើងថ្វាយចំពោះព្រះបិតា អ្វីដែលព្រះអង្គផ្ទាល់បានប្រទានមកយើង គឺអំណោយនៃការបង្កើតរបស់ព្រះអង្គ នំបុ័ង និងស្រាដែលបានក្លាយទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ និងដោយសារព្រះបន្ទូលរបស់ព្រះគ្រីស្ត៖ ហេតុនេះ ព្រះគ្រីស្តពិតជាមានវត្តមាន តាមរបៀបអាថ៌កំបាំង។

១៣៥៨- ដូច្នេះ ត្រូវតែចាត់ទុកពិធីអរព្រះគុណដូចជា៖

- ពិធីអរព្រះគុណកោតសរសើរលើកតម្កើងព្រះបិតា
- ពិធីនឹករឭកយញ្ញបូជារបស់ព្រះគ្រីស្ត និងរបស់ព្រះកាយព្រះអង្គ
- វត្តមានរបស់ព្រះគ្រីស្ត ដោយសារឫទ្ធានុភាពរបស់ព្រះបន្ទូលព្រះអង្គ និងរបស់ព្រះវិញ្ញាណ ព្រះអង្គ។

### ពិធីអរព្រះគុណកោតសរសើរលើកតម្កើងព្រះបិតា

១៣៥៩- ពិធីអរព្រះគុណ ជាអគ្គសញ្ញានៃការសង្គ្រោះរបស់យើង ដែលព្រះគ្រីស្តបានសម្រេចនៅលើឈើឆ្កាង ជាយញ្ញបូជាកោតសរសើរអរព្រះគុណព្រះជាម្ចាស់ ដើម្បីស្នាព្រះហស្តនៃការបង្កើត។ ក្នុងអភិបូជា យើងថ្វាយចំពោះព្រះបិតាសត្វលោកទាំងអស់ដែលព្រះជាម្ចាស់ស្រឡាញ់ តាមរយៈព្រះយេស៊ូដែលបានសោយទីវង្គត និងមានព្រះជន្មថ្មី។ តាមរយៈព្រះគ្រីស្ត ព្រះសហគមន៍អាចថ្វាយយញ្ញបូជាកោតសរសើរអរព្រះគុណ ដើម្បីអ្វីៗទាំងអស់ដ៏សប្បុរស ស្រស់បំព្រង និងយ៉ាងត្រឹមត្រូវ ដែលព្រះជាម្ចាស់បានធ្វើក្នុងការបង្កើត និងដើម្បីមនុស្សជាតិ។

១៣៦០- ពិធីអរព្រះគុណជាយញ្ញាអរព្រះគុណព្រះបិតា ព្រះសហគមន៍ក៏ប្រទានពរ ដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់អ្វីៗដ៏ល្អ ដែលព្រះអង្គបានធ្វើ ដោយបង្កើត សង្គ្រោះ និងប្រោសមនុស្សលោកឲ្យបានវិសុទ្ធ។ អត្ថន័យដំបូងនៃអភិបូជា គឺ "អរព្រះគុណ"។

១៣៦១- ពិធីអរព្រះគុណជាយញ្ញាកោតសរសើរ ព្រះសហគមន៍ក៏ច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះ

ជាម្ចាស់ ក្នុងនាមសត្វលោកទាំងអស់។ យើងអាចសរសើរព្រះអង្គ តាមរយៈព្រះគ្រីស្តតែប៉ុណ្ណោះ៖ ព្រះអង្គបង្រួប បង្រួមគ្រីស្តបរិស័ទជាមួយព្រះអង្គ ក្នុងការលើកតម្កើង និងការជួយអង្វររបស់ព្រះអង្គ ទើបយើងកោតសរសើរ ព្រះបិតា ដោយព្រះគ្រីស្ត ជាមួយព្រះអង្គ និងនៅក្នុងព្រះអង្គ។

## ពិធីនឹករឭកសក្ការបូជារបស់ព្រះគ្រីស្ត និងរបស់ព្រះកាយព្រះអង្គជាព្រះសហគមន៍

១៣៦២- ពិធីអរព្រះគុណជាពិធីនឹករឭកបុណ្យចម្លងរបស់ព្រះគ្រីស្ត ធ្វើឲ្យសក្ការបូជាតែមួយរបស់ព្រះអង្គ មានវត្តមានសព្វថ្ងៃ និងថ្វាយសក្ការបូជានេះតាមរបៀបអគ្គសញ្ញា ក្នុងពិធីបុណ្យព្រះសហគមន៍ ដែលជាព្រះ កាយ ព្រះអង្គ។ ក្នុងធម៌អរព្រះគុណដ៏វិសុទ្ធទាំងអស់ មានសេចក្តីអធិដ្ឋានមួយ ដែលគេហៅថា ធម៌នឹករឭក ក្រោយពី ព្រះបន្ទូលអំពីការតែងតាំងអភិបូជា។

១៣៦៣- តាមអត្ថន័យនៃព្រះគម្ពីរដ៏វិសុទ្ធ ក្នុងធម៌នឹករឭក យើងមិនគ្រាន់តែនឹកគិតដល់ហេតុការណ៍ទាំង ប៉ុន្មានអំពីអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែយើងប្រកាសកិច្ចការដ៏អស្ចារ្យដែលព្រះជាម្ចាស់បានបញ្ចេញសម្រាប់ មនុស្សលោក (សរ ១៣,៣)។ ដោយលើកតម្កើងហេតុការណ៍ទាំងនោះ ហេតុការណ៍ទាំងនោះក៏មានវត្តមាន សព្វថ្ងៃម៉្យាង។ ជនជាតិអ៊ីស្រាអែលយល់ការរំដោះចេញពីប្រទេសអេស៊ីបតាមរបៀបនេះ៖ រាល់ពេលគេប្រារព្ធ បុណ្យចម្លង ហេតុការណ៍ទាំងប៉ុន្មាននៃដំណើរឆ្ពោះទៅកាន់សេរីភាពមានវត្តមានសព្វថ្ងៃ ក្នុងការចងចាំរបស់ អ្នកជឿ ដើម្បីឲ្យពួកគេប្រតិបត្តិតាម។

១៣៦៤- ធម៌នឹករឭកទទួលអត្ថន័យថ្មីក្នុងសម្ពន្ធមេត្រីថ្មី។ ពេលព្រះសហគមន៍ថ្វាយអភិបូជា ព្រះសហគមន៍ នឹករំលឹកបុណ្យចម្លងរបស់ព្រះគ្រីស្ត ហើយបុណ្យចម្លងនេះមានវត្តមានសព្វថ្ងៃ៖ សក្ការបូជាដែល ព្រះគ្រីស្តបាន ថ្វាយនៅលើឈើឆ្កាងម្តងជាការស្រេចមានវត្តមានរហូត (ហប ៧,២៥-២៥)៖ "គ្រប់ពេលព្រះសហគមន៍ថ្វាយ អភិបូជា គឺថ្វាយសក្ការបូជារបស់ព្រះយេស៊ូ ដែលបូជាព្រះជន្មនៅលើឈើឆ្កាង ព្រះអង្គលោះយើង ព្រោះនៅលើ ឈើឆ្កាងគេបានបូជាព្រះគ្រីស្តជាយញ្ញរបស់យើងក្នុងឱកាសបុណ្យចម្លង" (LG ៣)។

១៣៦៥- ដោយសារពិធីអរព្រះគុណជាពិធីនឹករឭកដល់បុណ្យចម្លងរបស់ព្រះគ្រីស្ត ពិធីអរព្រះគុណក៏ជា សក្ការបូជាផងដែរ។ ព្រះបន្ទូលដែលតែងតាំងអភិបូជាសម្តែងលក្ខណៈជាយញ្ញបូជានៃពិធីអរព្រះគុណ៖ "នេះជា រូបកាយ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា" ហើយ "នេះជាពែងនៃសម្ពន្ធមេត្រីថ្មី ចងឡើងដោយសារលោហិត របស់ខ្ញុំ ដែលត្រូវបង្ហូរសម្រាប់អ្នករាល់គ្នា" (លក ២២,១៩-២០)។ ក្នុងពិធីអរព្រះគុណ ព្រះគ្រីស្តប្រទាន ព្រះកាយនោះ ដែលព្រះអង្គបានប្រគល់សម្រាប់យើងនៅលើឈើឆ្កាង ព្រះលោហិតនោះ ដែលព្រះអង្គបាន "បង្ហូរ ដើម្បីលើកលែងទោសមនុស្សទាំងអស់ឲ្យរួចពីបាប" (មថ ២៦,២៨)។

១៣៦៦- ដូច្នេះហើយ បានជាពិធីអរព្រះគុណជាសក្ការបូជា ដ្បិតដោយសារពិធីអរព្រះគុណ សក្ការបូជានៃ ឈើឆ្កាងមានវត្តមាន ដ្បិតពិធីអរព្រះគុណនឹករឭក សក្ការបូជានេះ ហើយដ្បិតពិធីអរព្រះគុណទទួលនិងប្រតិបត្តិ តាមផលផ្លែនៃសក្ការបូជានេះ៖

> (ព្រះគ្រីស្ត) ជាព្រះ និងជាអម្ចាស់នៃយើង ថ្វាយព្រះកាយព្រះអង្គចំពោះព្រះជាម្ចាស់ជាព្រះបិតាម្តង ជាការស្រេច ដោយសោយទិវង្គតដូចជាអ្នកជួយអង្វរ លើអាសនៈនៃព្រះឈើឆ្កាង ដើម្បីឲ្យ (មនុស្សលោក) រួចពីបាបអស់កល្បជានិច្ច។ ក៏ប៉ុន្តែ សេចក្តីស្លាប់របស់ព្រះអង្គមិនបញ្ចប់មុខងាររបស់ព្រះអង្គក្នុងឋានៈ ជាបូជាចារ្យទេ (ហប ៧, ២៤.២៧)។ នៅពិធីជប់លៀងចុងក្រោយ "នៅយប់ដែល (ព្រះអង្គ) ត្រូវគេ

ចាប់បញ្ជូនទៅឆ្កាង" (១ករ ១១,២៣) ព្រះអង្គសព្វព្រះហឫទ័យផ្ញើទុកឲ្យព្រះសហគមន៍ (ជាព្រះមហេសីដ៏ជាទីស្រឡាញ់របស់ព្រះអង្គ) សក្ការបូជាដែលមើលឃើញ (តាមការទាមទាររបស់ធម្មជាតិមនុស្ស) ដែលតំណាងឲ្យសក្ការបូជាបង្ហូរឈាម ដែលនឹងកើតឡើងម្តងជាការស្រេចនៅលើឈើឆ្កាង ដែលគេនឹករឭករហូតដល់គ្រាចុងក្រោយបំផុត (១ករ ១១,២៣)។ សក្ការបូជានេះនឹងជួយសង្គ្រោះយើងឲ្យរួចពីបាប ដែលយើងប្រព្រឹត្តជារៀងរាល់ថ្ងៃ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៧៤០)។

១៣៦៧- សក្ការបូជារបស់ព្រះគ្រីស្ត និងសក្ការបូជារបស់ព្រះសហគមន៍មានតែមួយដដែល៖ "មានយញ្ញតែមួយដដែល គឺព្រះអង្គដដែលដែលប្រោសប្រទានឥឡូវនេះតាមមុខងាររបស់លោកបូជាចារ្យ ហើយដែលបានបូជាព្រះអង្គនៅលើឈើឆ្កាង។ មានតែរបៀបថ្វាយប៉ុណ្ណោះដែលផ្លាស់ប្តូរ" (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៧៤៣)។ "សក្ការបូជារបស់ព្រះជាម្ចាស់ ដែលមានក្នុងអភិបូជា ព្រះគ្រីស្តដដែលនេះ ដែលបានបូជាព្រះអង្គម្តងហើយនៅលើអាសនៈនៃឈើឆ្កាង ដោយបង្ហូរឈាម ហើយដែលគង់នៅ និងថ្វាយព្រះអង្គ ដោយមិន បង្ហូរឈាម" (សន្តៈ អ៊ីញ៉ាស)។

១៣៦៨- ពិធីអរព្រះគុណជាសក្ការបូជារបស់ព្រះសហគមន៍ដែរ ។ ព្រះសហគមន៍ ដែលជាព្រះកាយព្រះគ្រីស្តចូលរួមចំណែកក្នុងតង្វាយនៃប្រធានរបស់ខ្លួន។ ដោយរួបរួមជាមួយព្រះអង្គ ព្រះសហគមន៍ថ្វាយខ្លួនទាំងស្រុងដែរ។ ព្រះសហគមន៍រួបរួមជាមួយព្រះអង្គ ក្នុងការជួយអង្វររបស់ព្រះអង្គសម្រាប់មនុស្សទាំងអស់។ ក្នុងពិធីអរព្រះគុណ សក្ការបូជារបស់ព្រះគ្រីស្តក៏ក្លាយទៅជាយញ្ញបូជានៃសិរីរាង្គរបស់ព្រះកាយព្រះអង្គដែរ។ ការរស់នៅរបស់គ្រីស្តបរិស័ទ ពាក្យសរសើរ ទុក្ខលំបាក ការអធិដ្ឋាន និងការងាររបស់គេ រួបរួមជាមួយព្រះគ្រីស្តដែលថ្វាយខ្លួនទាំងស្រុង ហើយទទួលតម្លៃថ្មីនោះ។ សក្ការបូជារបស់ព្រះគ្រីស្តលើអាសនៈផ្តល់ឲ្យគ្រីស្តបរិស័ទគ្រប់ជំនាន់អាចរួមជាមួយតង្វាយរបស់ព្រះអង្គបាន។

ក្នុងទីបញ្ចុះសព គ្រីស្តបរិស័ទឧស្សាហ៍គូរព្រះសហគមន៍ដូចជាស្ត្រីម្នាក់ ដែលលាតត្រដាងដៃ កំពុងអធិដ្ឋាន។ ដូចព្រះគ្រីស្តបានលាតត្រដាងព្រះហស្តនៅលើឈើឆ្កាងយ៉ាងណា ដោយព្រះអង្គ ជាមួយព្រះអង្គ និងក្នុងអង្គព្រះអង្គ ព្រះសហគមន៍ក៏ថ្វាយខ្លួន និងជួយអង្វរសម្រាប់មនុស្សលោកយ៉ាងនោះដែរ។

១៣៦៩- ព្រះសហគមន៍ទាំងមូលរួបរួមជាមួយតង្វាយ និងការជួយអង្វររបស់ព្រះគ្រីស្ត។ ដោយទទួលបន្ទុករបស់លោកសិលានៅក្នុងព្រះសហគមន៍ សម្តេចប៉ាប ចូលរួមចំណែកក្នុងពិធីអរព្រះគុណទាំងអស់។ ក្នុងពិធីអរព្រះគុណទាំងអស់នោះ យើងបញ្ចេញឈ្មោះរបស់លោក ដែលជាសញ្ញាសម្គាល់ និងជាអ្នកបម្រើនៃឯកភាពរបស់ព្រះសហគមន៍សកល។ លោកអភិបាល នៃភូមិភាគដែលយើងថ្វាយអភិបូជា រមែងតែងតែជាអ្នកទទួលខុសត្រូវនៃអភិបូជា ទោះបីជាលោកបូជាចារ្យ ម្នាក់ធ្វើអ្នកអធិបតីយ៉ាងណាក៏ដោយ។ យើងបញ្ចេញនាមរបស់លោក ដើម្បីបង្ហាញថា លោកជាប្រធាននៃព្រះសហគមន៍ តាមភូមិភាគនោះ រួមជាមួយពួកលោកបូជាចារ្យ និងពួកឧបដ្ឋាកផងដែរ។ សហគមន៍ជួយអង្វរសម្រាប់អស់អ្នក ដែលមានមុខងារបម្រើព្រះសហគមន៍ ដែលថ្វាយអភិបូជាសម្រាប់ និងជាមួយសហគមន៍នេះ៖

អភិបូជាមួយដែលត្រឹមត្រូវគឺជាអភិបូជាដែលលោកអភិបាល ឬអ្នកដែលលោកអភិបាលបានជ្រើសរើសជាអ្នកអធិបតី (សន្តៈ អ៊ីញ៉ាស អង់ទូអូស)។

ដោយសារមុខងាររបស់លោកបូជាចារ្យ យញ្ញបូជាខាងវិញ្ញាណរបស់គ្រីស្តបរិស័ទបានសម្រេច ដោយរួបរួមជាមួយនឹងសក្ការបូជារបស់ព្រះគីស្ត ជាស្ពានមេត្រីតែមួយ ដែលលោកបូជាចារ្យថ្វាយក្នុងអភិបូជា

ក្នុងនាមព្រះសហគមន៍ទាំងមូល តាមរបៀបដែលមិនបង្ហូរឈាម និងតាមលក្ខណៈជាអគ្គសញ្ញា រហូតដល់ព្រះអម្ចាស់ផ្ទាល់យាងមកវិញ (PO ២)។

១៣៧០- សមាជិកដែលស្ថិតនៅលើផែនដី ព្រមទាំងសមាជិកដែលនៅក្នុងសិរីរុងរឿងនៃស្ថានបរមសុខផង ក៏រួបរួមជាមួយតង្វាយរបស់ព្រះគ្រីស្តដែរ៖ ព្រះសហគមន៍ថ្វាយអភិបូជា ដោយរួបរួមជាមួយព្រះនាងព្រហ្មចារិនីម៉ារីដ៏វិសុទ្ធបំផុត ដោយនឹកគិតដល់ព្រះនាង ព្រមទាំងសន្តៈ និងសន្តីបុគ្គលទាំងឡាយ។ ក្នុងពិធីអរព្រះគុណព្រះសហគមន៍ និងព្រះនាងម៉ារី ហាក់ដូចជានៅក្បែរឈើឆ្កាង ដោយរួបរួមជាមួយតង្វាយ និងការជួយអង្វររបស់ព្រះគ្រីស្ត។

១៣៧១- យើងថ្វាយអភិបូជាសម្រាប់គ្រីស្តបរិស័ទ "ដែលស្លាប់នៅក្នុងអង្គព្រះគ្រីស្ត ហើយដែលមិនទាន់ ត្រូវបន្សុទ្ធឲ្យពេញលេញនៅឡើយ" (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៧៤៣) ដើម្បីឲ្យពួកគេអាចចូលក្នុងពន្លឺ និងសេចក្តីសុខសាន្តរបស់ព្រះគ្រីស្ត៖

> ចូរបញ្ចុះសពនេះ នៅកន្លែងណាក៏បាន" កុំខ្វល់នឹងវាធ្វើអ្វី" អ្វីដែលខ្ញុំសុំ គឺឲ្យកូនៗនឹកគិតដល់ខ្ញុំ នៅអាសនៈរបស់ព្រះអម្ចាស់ នៅគ្រប់កន្លែង (សន្តៈ ម៉ូនីក មុនទទួលមរណភាព ចំពោះសន្តៈ អូគូស្តាំង និងប្អូនលោក)។
>
> បន្ទាប់មក យើងអធិដ្ឋាន (ក្នុងធម៌អរព្រះគុណដ៏វិសុទ្ធ) សម្រាប់បុព្វបុរសដ៏វិសុទ្ធ និងលោកអភិបាលដែល កំពុងសម្រាន្តលក់ ហើយជាទូទៅដើម្បីអស់អ្នកដែលបានចូលដំណេកមុនយើង ដោយជឿថា នឹងបានផលប្រយោជន៍ដ៏ប្រសើរសម្រាប់ព្រលឹង ដែលយើងអង្វរព្រះជាម្ចាស់ ចំពោះមុខយញ្ញបូជាដ៏វិសុទ្ធ និងគួរឲ្យគោរព កោតខ្លាច (...)។ ដោយជួយអង្វរព្រះជាម្ចាស់សម្រាប់អស់អ្នកដែលកំពុងដេកលក់ ទោះជាអ្នកបាបក្តី (...) យើងថ្វាយចំពោះព្រះគ្រីស្តដែលបូជាព្រះជន្ម ដើម្បីលោះបាបយើង សូមឲ្យព្រះជាម្ចាស់ដែលជាមិត្តសម្លាញ់របស់មនុស្សលោក សព្វព្រះហឫទ័យនឹងពួកគេ និងពួកយើងផង (សន្តៈ ស៊ីរីលនៃទីក្រុងយេរូសាឡឹម)។

១៣៧២- សន្តៈ អូគូស្តាំងសង្ខេបបានយ៉ាងអស្ចារ្យលទ្ធិនេះ ដែលជំរុញយើងឲ្យចូលរួមចំណែកកាន់ តែជ្រៅៗក្នុងសក្ការបូជានៃព្រះសង្គ្រោះយើង ដែលយើងលើកតម្កើងក្នុងពិធីអរព្រះគុណ៖

> យើងថ្វាយចំពោះព្រះជាម្ចាស់បូរី ដែលព្រះអង្គបានលោះទាំងស្រុងនេះ ពោលគឺអង្គប្រជុំ និងសហភាពរបស់ជនដ៏វិសុទ្ធ ដូចជាយញ្ញបូជាសកល ដោយមហាបូជាចារ្យ ដែលយករូបរាងជាទាសករ រហូតដល់បូជាព្រះជន្ម សម្រាប់យើង ដោយរងទុក្ខលំបាក ដើម្បីឲ្យយើងទៅជាព្រះកាយនៃប្រធានដ៏អស្ចារ្យនេះ (...)។ នេះគឺជាយញ្ញ បូជារបស់គ្រីស្តបរិស័ទ៖ "យើងមានគ្នាច្រើនរួបរួមជាមួយព្រះកាយតែមួយក្នុងអង្គព្រះគ្រីស្ត" (រម ១២,៥)។ ព្រះ សហគមន៍នៅតែបូជាយញ្ញនេះ ក្នុងអគ្គសញ្ញានៃអាសនៈ ដែលគ្រីស្តបរិស័ទស្គាល់យ៉ាងច្បាស់ ហើយដែលបង្ហាញថា ក្នុងអ្វីៗដែលព្រះសហគមន៍ថ្វាយ ព្រះសហគមន៍ក៏ថ្វាយទាំងខ្លួនឯងផង។

## វត្តមានរបស់ព្រះគ្រីស្ត ដោយសារឫទ្ធានុភាពនៃព្រះបន្ទូលព្រះអង្គ និងឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ

១៣៧៣- "ព្រះគ្រីស្តយេស៊ូបានសោយទិវង្គត ទ្រង់មានព្រះជន្មថ្មី គង់ខាងស្តាំព្រះបិតា និងទូល អង្វរឲ្យយើង"

(រម ៨,៣៤) ព្រះអង្គគង់នៅក្នុងសហគមន៍តាមរបៀបផ្សេងៗពីគ្នា (LG ៤៨)៖ ក្នុងព្រះបន្ទូលព្រះអង្គ ក្នុងការអធិដ្ឋានរបស់ព្រះសហគមន៍ "នៅទីណាមានពីរ ឬបីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ" (មថ ១៨,២០) ក្នុងជនក្រីក្រ អ្នកជំងឺ អ្នកទោស (មថ ២៥,៣១-៤៦) ក្នុងអគ្គសញ្ញាដែលព្រះអង្គជាអ្នកបង្កើត ក្នុងអភិបូជា ជាពិសេសក្នុងអ្នកអធិបតី។ ប៉ុន្តែ "ព្រះអង្គគង់នៅតាមរបៀបដ៏ល្អប្រសើរជាទីបំផុត ក្នុងព្រះកាយ និងព្រះលោហិតព្រះអង្គ" (SC ៧)។

១៣៧៤- របៀបគង់នៅរបស់ព្រះគ្រីស្តក្នុងព្រះកាយ ព្រះលោហិតព្រះគ្រីស្តមានតែមួយ។ វត្តមាននេះ លើកអភិបូជាឲ្យលើសអគ្គសញ្ញាឯទៀតៗ បណ្តាលឲ្យពិធីអរព្រះគុណក្លាយទៅជា "ភាពល្អឥតខ្ចោះនៃជីវិតខាងវិញ្ញាណ និងគោលដៅចុងក្រោយរបស់អគ្គសញ្ញាទាំងអស់" (សន្ត: ថូម៉ាស នៃអាកាំង)។ ក្នុងអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធបំផុត "សារធាតុ ព្រះកាយ និងព្រះលោហិត រួបរួមជាមួយព្រលឹង និងសភាពជាព្រះជាម្ចាស់របស់ព្រះអម្ចាស់នៃយើងព្រះយេស៊ូគ្រីស្ត ទើបព្រះគ្រីស្តទាំងស្រុងពិតជាគង់នៅ យ៉ាងពិតប្រាកដ (មហាសន្និបាតនៅទីក្រុងត្រង់ ; DS ១៦៥១)។ "យើងហៅវត្តមាននេះ "ពិតប្រាដក" ដោយមិនរាប់អំពីវត្តមានឯទៀតៗ ដែល "ពិតប្រាកដ" ដែរ គឺតាមរបៀបល្អប្រសើរ ដ្បិតវត្តមាននេះស្ថិតដោយសារធាតុ ដោយសារវត្តមាននេះ ព្រះគ្រីស្តជាព្រះជាម្ចាស់ និងជាមនុស្ស ដែលគង់នៅទាំងស្រុង" (MF ៣៩)។

១៣៧៥- ព្រះគ្រីស្តគង់នៅក្នុងអគ្គសញ្ញាដោយប្រែ នំប៉័ង និងស្រា ដោយព្រះកាយ និងព្រះលោហិតព្រះអង្គ។ គ្រូបាធ្យាយព្រះសហគមន៍បានប្រកាសយ៉ាងម៉ឺងម៉ាត់ នូវជំនឿព្រះសហគមន៍លើប្រសិទ្ធិភាពនៃព្រះបន្ទូល ព្រះគ្រីស្ត និងកិច្ចការរបស់ព្រះវិញ្ញាណ ដើម្បីបំពេញកិច្ចការនេះ។ ហេតុនេះ សន្ត: យ៉ូហាន គ្រីសូស្តូម មានប្រសាសន៍ថា៖

> មិនមែនមនុស្ស ដែលធ្វើឲ្យតង្វាយទៅជាព្រះកាយព្រះលោហិតព្រះគ្រីស្តទេ គឺព្រះគ្រីស្តផ្ទាល់ ដែលត្រូវគេឆ្កាងសម្រាប់យើង។ លោកបូជាចារ្យ ជាតំណាងរបស់ព្រះគ្រីស្ត បញ្ចេញពាក្យសម្តីនោះ ប៉ុន្តែ ព្រះជាម្ចាស់ជាអ្នកប្រទានប្រសិទ្ធិភាព និងប្រណីសន្តោស។ ព្រះគ្រីស្តមានព្រះបន្ទូលថា នេះជារូបកាយរបស់ខ្ញុំ។ ព្រះបន្ទូលនេះ ប្រែតង្វាយ។

### សន្ត: អំប្រ័រ មានប្រសាសន៍ថា៖

> សូមជឿជាក់ច្បាស់ថា ការអស្ចារ្យនេះ មិនមែនមកពីធម្មជាតិទេ ប៉ុន្តែមកពីការប្រសិទ្ធពរ ហើយឫទ្ធានុភាព នៃការប្រសិទ្ធពរខ្លាំងជាងកម្លាំងធម្មជាតិ ដ្បិតដោយសារការប្រសិទ្ធពរ ធម្មជាតិផ្ទាល់ផ្លាស់ប្តូរ (...)។ តើព្រះបន្ទូលព្រះគ្រីស្ត ដែលអាចបង្កើតដោយមិនប្រើអ្វីសោះ មិនអាចផ្លាស់ប្តូរអ្វីៗទាំងអស់ទេឬ? ដ្បិតការបង្កើតអ្វីមួយមិនងាយជាងការផ្លាស់ប្តូរវាឡើយ។

១៣៧៦- មហាសន្និបាតនៅទីក្រុងត្រង់សង្ខេបជំនឿកាតូលិកដោយប្រកាសថា៖ "ដោយសារព្រះគ្រីស្ត ជាព្រះសង្គ្រោះយើង មានព្រះបន្ទូលថា នំប៉័ងដែលព្រះអង្គថ្វាយពិតជាព្រះកាយរបស់ព្រះអង្គ ព្រះសហគមន៍ក៏ តែងតែបានជឿជាក់ថា (ដែលមហាន្និបាតដ៏វិសុទ្ធប្រកាសម្តងទៀត)៖ ដោយការប្រសិទ្ធពរលើនំប៉័ង និងស្រា សារធាតុទាំងស្រុងរបស់នំប៉័ងផ្លាស់ប្តូរទៅជាសារធាតុទាំងស្រុងនៃព្រះកាយព្រះគ្រីស្ត ជាព្រះអម្ចាស់នៃយើង ហើយសារធាតុទាំងស្រុងនៃស្រាទៅជាសារធាតុទាំងស្រុងនៃព្រះលោហិតព្រះអង្គ។ ព្រះសហគមន៍ហៅយ៉ាងត្រឹមត្រូវការផ្លាស់ប្តូរនេះថា ការផ្លាស់ប្តូរសារធាតុ (DS ១៦៤២)។

១៣៧៧- វត្តមានរបស់ព្រះគ្រីស្តក្នុងអគ្គសញ្ញាអរព្រះគុណ ចាប់ផ្តើមចាប់តាំងពីការប្រសិទ្ធពរ រហូតដល់នៅពេលសេសសល់ព្រះកាយ និងព្រះលោហិត។ ព្រះគ្រីស្តគង់នៅទាំងស្រុងក្នុងព្រះកាយ និងព្រះលោហិត និងគង់នៅទាំងស្រុងក្នុងគ្រប់ផ្នែកនៃព្រះកាយ និងព្រះលោហិតនេះ ដូច្នេះ ពិធីកាច់នំប៉័ងមិនបំបែកព្រះគ្រីស្តឡើយ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៤១)។

១៣៧៨- ការថ្វាយបង្គំព្រះកាយព្រះលោហិតព្រះគ្រីស្ត។ ក្នុងពិធីអភិបូជា យើងសម្តែងនូវជំនឿរបស់យើងថា ព្រះគ្រីស្តពិតជាគង់នៅក្នុងព្រះកាយព្រះលោហិតព្រះអង្គ ដោយ (ឧទាហរណ៍) លុតជង្គង់ ឬឱនកាយ ជាសញ្ញាសម្គាល់ថា យើងថ្វាយបង្គំព្រះអម្ចាស់។ "ព្រះសហគមន៍កាតូលិកថ្វាយបង្គំ និងនៅតែថ្វាយបង្គំអគ្គសញ្ញាអរព្រះគុណ មិនគ្រាន់តែពេលថ្វាយអភិបូជាប៉ុណ្ណោះទេ ថែមទាំងក្រៅពិធីបុណ្យផងដែរ គឺដោយរក្សាទុកយ៉ាងថ្នាក់ថ្នមជាទីបំផុតព្រះកាយព្រះគ្រីស្ត ដោយតាំងព្រះកាយឲ្យគ្រីស្តបរិស័ទគោរពយ៉ាងឧឡារិក ហើយដោយហែព្រះកាយព្រះអង្គផង" (MF ៥៦)។

១៣៧៩- ដំបូង យើងត្រូវការព្រះពន្លាដ៏វិសុទ្ធសម្រាប់រក្សាទុកព្រះកាយព្រះគ្រីស្ត ដើម្បីជូនទៅអ្នកជំងឺ និងអស់អ្នក ដែលមិនបានមកថ្វាយអភិបូជា។ ដោយជឿយ៉ាងជ្រាលជ្រៅដល់វត្តមានដ៏ពិតប្រាកដរបស់ព្រះគ្រីស្តក្នុងព្រះកាយព្រះអង្គ ព្រះសហគមន៍បានឈ្វេងយល់នូវអត្ថន័យនៃការថ្វាយបង្គំយ៉ាងស្ងៀមស្ងាត់នូវព្រះអម្ចាស់ដែលគង់នៅក្នុងព្រះកាយព្រះអង្គ។ ហេតុនេះហើយ បានជាត្រូវដាក់ព្រះបន្លានៅកន្លែងដ៏សមរម្យនៃព្រះវិហារ ត្រូវធ្វើព្រះពន្លាតាមរបៀបដែលព្រះពន្លានេះ បញ្ជាក់ និងសម្តែងសេចក្តីពិតនៃវត្តមានដ៏ពិតប្រាកដរបស់ព្រះគ្រីស្តក្នុងអគ្គសញ្ញាដ៏វិសុទ្ធ។

១៣៨០- ព្រះគ្រីស្តសព្វព្រះហឫទ័យគង់នៅក្នុងព្រះសហគមន៍តាមរបៀបតែមួយនេះ គឺជាការសមរម្យណាស់។ ដោយសារព្រះគ្រីស្តបានចាកចេញពីមិត្តសម្លាញ់របស់ព្រះអង្គដោយរូបរាងដែលមើលឃើញ ព្រះអង្គក៏សព្វព្រះហឫទ័យគង់នៅជាមួយយើង តាមអគ្គសញ្ញា។ ដោយសារព្រះគ្រីស្តបានបូជាព្រះជន្មនៅលើឈើឆ្កាងដើម្បីសង្គ្រោះយើង ព្រះអង្គក៏សព្វព្រះហឫទ័យឲ្យយើងមានការនឹករឭកនៃសេចក្តីស្រឡាញ់ ដែលព្រះអង្គបានស្រឡាញ់យើង "រហូតដល់ទីបំផុត" (យហ ១៣,១) គឺរហូតដល់បូជាព្រះជន្ម។ វត្តមានខាងអគ្គសញ្ញា ព្រះអង្គស្ថិតក្នុងចំណោមយើង តាមរបៀបអាថ៌កំបាំង ដូចជាអ្នកដែលបានស្រឡាញ់យើង និងបានបូជាព្រះជន្មសម្រាប់យើង (កាឡ ២,២០) ហើយព្រះអង្គនៅតែគង់នៅជាមួយយើងតាមសញ្ញាសម្គាល់ដែលសម្តែង និងផ្តល់សេចក្តីស្រឡាញ់នេះ៖

> ព្រះសហគមន៍ និងពិភពលោកត្រូវការពិធីថ្វាយបង្គំព្រះកាយព្រះគ្រីស្ត។ ព្រះយេស៊ូរង់ចាំយើងក្នុងអគ្គសញ្ញានៃសេចក្តីស្រឡាញ់នេះ។ កុំបដិសេធមិនព្រមចំណាយពេលវេលា ដើម្បីជួបព្រះអង្គក្នុងការថ្វាយបង្គំ ក្នុងការ ស្ញឹងស្ញាធ៏ពោរពេញដោយជំនឿ ដោយត្រៀមខ្លួននឹងព្យាបាលកំហុសធ្ងន់ និងទោសនៃពិភពលោក។ សូមកុំឲ្យយើងឈប់ថ្វាយបង្គំឡើយ (សម្តេចប៉ាប យ៉ូហាន ប៉ូល ទី២)។

១៣៨១- "សន្តៈថូម៉ាសមានប្រសាសន៍ថា "យើងមិនដឹងអំពីវត្តមាននៃព្រះកាយយ៉ាងពិតប្រាកដរបស់ព្រះគ្រីស្ត និងព្រះលោហិតយ៉ាងពិតប្រាកដរបស់ព្រះគ្រីស្តក្នុងអគ្គសញ្ញា ដោយវិញ្ញាណទេ ប៉ុន្តែដោយសារតែជំនឿ ប៉ុណ្ណោះ ដែលសំអាងលើអំណាចរបស់ព្រះជាម្ចាស់"។ ហេតុនេះ ដោយអធិប្បាយអត្ថបទរបស់សន្តៈ លូកា ២២,១៩៖ "នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា" សន្តៈ ស៊ីរីល ប្រកាសថា៖ "កុំសួរខ្លួនឯងថា តើជាការពិតឬ ប៉ុន្តែសូមទទួលដោយមានជំនឿថា ជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ដ្បិតព្រះអង្គ ដែលជាសេចក្តី

ពិតមិនចេះកុហកទេ"" (សម្ដេចប៉ាប ប៉ូលទី៦)។

ឱព្រះជាម្ចាស់ ដែលលាក់លៀមអើយ" ទូលបង្គំសូមក្រាបថ្វាយបង្គំព្រះអង្គ ដែលពិតជាគង់នៅក្នុងនំប៉័ង និងស្រា។ ចិត្តទូលបង្គំចុះចូលទាំងស្រុងក្រោមអំណាចព្រះអង្គ ដ្បិតពេលទូលបង្គំមើលឃើញព្រះអង្គ ទូលបង្គំរន្ធត់ចិត្តណាស់។ ចក្ខុវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ មិនអាចដឹងអំពីព្រះអង្គទេ អ្វីៗដែលយើងឮ ត្រូវតែជឿទុកចិត្ត ខ្ញុំម្ចាស់ជឿលើព្រះបន្ទូលទាំងអស់នៃព្រះបុត្រារបស់ព្រះជាម្ចាស់ គ្មានអ្វីពិតជាងព្រះបន្ទូលនៃសេចក្ដីពិតនេះទេ។

## ៦. ពិធីជប់លៀងនៃបុណ្យចម្លង

១៣៨២- អភិបូជាជាពិធីនឹករឭកសក្ការបូជាឥតឈប់ឈរនៃព្រះឈើឆ្កាងផង ជាពិធីជប់លៀងដ៏សក្ការៈ ដែលយើងរួបរួមជាមួយព្រះកាយ និងព្រះលោហិតព្រះអម្ចាស់ផង ដោយមិនអាចបំបែកពីគ្នាបាន។ ក៏ប៉ុន្តែ ពិធីអភិបូជាតម្រង់ឲ្យគ្រីស្តបរិស័ទរួបរួមយ៉ាងស្និទ្ធស្នាលជាមួយព្រះគ្រីស្ត ដោយទទួលព្រះកាយព្រះលោហិតព្រះអង្គ។ ពេលយើងទទួលព្រះកាយព្រះលោហិតព្រះអង្គ យើងក៏ទទួលព្រះគ្រីស្តផ្ទាល់ ដែលបានបូជាព្រះជន្មសម្រាប់យើង។

១៣៨៣- អាសនៈ ដែលអង្គប្រជុំជួបជុំគ្នាជុំវិញដើម្បីថ្វាយអភិបូជា តំណាងលក្ខណៈទាំងពីរនៃគម្រោងការណ៍ដ៏អស្ចារ្យតែមួយ គឺអាសនៈនៃយញ្ញបូជា និងតុរបស់ព្រះអម្ចាស់។ លើសពីនេះទៅទៀត អាសនៈនៃគ្រីស្តសាសនាជានិមិត្តរូបរបស់ព្រះគ្រីស្តផ្ទាល់ ដែលគង់នៅកណ្ដាលអង្គប្រជុំរបស់គ្រីស្តបរិស័ទ ដូចជាយញ្ញដែលយើងថ្វាយដើម្បីសម្រុះសម្រួលយើងផង ហើយដូចជាចំណីអាហារនៃស្ថានបរមសុខដែលប្រគល់ខ្លួនមកយើងផង។ សន្តៈ អំប្រ័រ មានប្រសាសន៍ថា "អ្វីទៅជាអាសនៈរបស់ព្រះគ្រីស្ត ក្រៅពីតំណាងនៃព្រះកាយព្រះគ្រីស្ត?" ម្យ៉ាងទៀត "អាសនៈតំណាងព្រះកាយ (ព្រះគ្រីស្ត) ហើយព្រះកាយព្រះគ្រីស្តគង់នៅលើអាសនៈ"។ ពិធីបុណ្យសម្ដែងឯកភាពនៃយញ្ញបូជា និងការទទួលព្រះកាយ ក្នុងសេចក្ដីអធិដ្ឋានជាច្រើន។ ហេតុនេះ ព្រះសហគមន៍នៅទីក្រុងរ៉ូមអង្វរនៅក្នុងធម៌អរព្រះគុណដ៏វិសុទ្ធថា៖

ឱព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ" យើងខ្ញុំសូមឱនកាយអង្វរព្រះអង្គ សូមមេត្តាឲ្យទេវទូតនាំយកសក្ការបូជានេះ ទៅថ្វាយព្រះអង្គទៅលើអាសនៈឯស្ថានបរមសុខ នៅចំពោះព្រះភ័ក្ត្រនៃព្រះដ៏ខ្ពង់ខ្ពស់បំផុត។ សូមឲ្យយើងខ្ញុំ ដែលទទួលព្រះកាយព្រះលោហិតដ៏វិសុទ្ធនៃព្រះបុត្រា ដោយរួមរស់ជាមួយតុសក្ការៈនេះ បានពោរពេញដោយព្រះហឫទ័យប្រណីសន្តោស និងព្រះពរយ៉ាងបរិបូណ៌។

### "សូមអ្នករាល់គ្នាយកពិសាចុះ"៖ ការទទួលព្រះកាយ

១៣៨៤- ព្រះអម្ចាស់ជំរុញយើងឲ្យទទួលព្រះអង្គក្នុងអគ្គសញ្ញាអរព្រះគុណ៖ "ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ប្រសិនបើអ្នករាល់គ្នាមិនពិសាសាច់ និងលោហិតរបស់បុត្រមនុស្សទេ អ្នករាល់គ្នាគ្មានជីវិតក្នុងខ្លួនឡើយ" (យហ ៦,៥៣)។

១៣៨៥- យើងក៏ត្រូវរៀបចំខ្លួន នឹងទទួលព្រះកាយព្រះលោហិតព្រះអង្គ ដើម្បីឆ្លើយតបនឹងព្រះយេស៊ូ។ សន្តៈប៉ូល ដាស់តឿនយើងឲ្យពិនិត្យចិត្តគំនិតយើង៖ "ប្រសិនបើអ្នកណាពិសានំប៉័ង និងពិសាស្រាពីពែងរបស់ព្រះអម្ចាស់ ដោយមិនសមរម្យ អ្នកនោះនឹងមានកំហុស ចំពោះព្រះកាយនិងព្រះលោហិតរបស់ព្រះអម្ចាស់។ ដូច្នេះ

ម្នាក់ៗត្រូវពិនិត្យពិច័យ មើលចិត្តគំនិតរបស់ខ្លួនឯងសិន សឹមពិសានំប៉័ង និងពិសាស្រាពីពែងនេះ ដ្បិតអ្នកណាពិសានំប៉័ង និងពិសាស្រាពីពែងនោះដោយមិនបានយល់ដល់ព្រះកាយរបស់ព្រះអម្ចាស់ទេ អ្នកនោះយកទោសមកដាក់លើខ្លួនឯងផ្ទាល់" (១ករ១១,២៧-២៩)។ អ្នកណាយល់ថា ខ្លួនបានប្រព្រឹត្តអំពើបាបធ្ងន់ អ្នកនោះត្រូវទទួលអគ្គសញ្ញាលើកលែងទោស មុននឹងទទួលព្រះកាយព្រះលោហិតព្រះគ្រីស្ត។

១៣៨៦- នៅពីមុខអគ្គសញ្ញាដ៏ខ្ពង់ខ្ពស់នេះ គ្រីស្តបរិស័ទត្រូវនិយាយដូចនាយទាហាន (មថ ៨,៨) ដោយបន្ទាបខ្លួន ព្រមទាំងមានជំនឿថា៖ **"Domine, non sum digus, ut intres sub tectum meum, sed tantum div verbum, et sanabitur anima mea"** ("ឱព្រះអម្ចាស់អើយ" ខ្ញុំមិនសមនឹងទទួលព្រះអង្គទេ តែសូមព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋមក នោះព្រលឹងខ្ញុំនឹងបានជាសះស្បើយ")។ ក្នុងពិធីបុណ្យដ៏ប្រសើររបស់សន្តះយ៉ូហាន គ្រីសូស្តូម គ្រីស្តបរិស័ទអធិដ្ឋានដោយមានចិត្តគំនិតដដែល៖

> ឱព្រះបុត្រារបស់ព្រះជាម្ចាស់ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសទូលបង្គំឲ្យរួមរស់ជាមួយព្រះអង្គ ក្នុងពិធីជប់លៀងដ៏អាថ៌កំបាំងរបស់ព្រះអង្គ ដ្បិតទូលបង្គំនឹងមិនប្រាប់ទីសម្ងាត់ដល់ខ្មាំងសត្រូវរបស់ព្រះអង្គ ហើយក៏នឹងមិនថើបព្រះអង្គដូចលោកយូដាសទេ។ ប៉ុន្តែ ដូចចោរម្នាក់ដែលជាប់ឈើឆ្កាងជាមួយព្រះអង្គ ទូលបង្គំស្រែកឡើងថា៖ ឱព្រះអម្ចាស់អើយ" ពេលព្រះអង្គយាងមកគ្រងរាជ្យ សូមកុំភ្លេចទូលបង្គំ។

១៣៨៧- គ្រីស្តបរិស័ទត្រូវតមអាហារតាមច្បាប់ព្រះសហគមន៍របស់ពួកគេ (CIC ៩១៩) ដើម្បីរៀបចំខ្លួនឲ្យទទួលអគ្គសញ្ញានេះ ដោយសមរម្យ។ ត្រូវតែមានអាកប្បកិរិយា (កាយវិការ សំលៀកបំពាក់) ត្រឹមត្រូវដែលសម្តែងថា យើងគោរពយ៉ាងឧឡារិកចំពោះព្រះគ្រីស្តដែលទៅជាភ្ញៀវយើង ពោរពេញទៅដោយអំណរសប្បាយ ។

១៣៨៨- បើពួកគេមានលក្ខណៈត្រឹមត្រូវ គ្រីស្តបរិស័ទគួរទទួលព្រះកាយព្រះលោហិតព្រះគ្រីស្តរាល់ពេលពួកគេចូលរួមអភិបូជា ស្របតាមអត្ថន័យផ្ទាល់នៃអគ្គសញ្ញាអរព្រះគុណ៖ "យើងផ្តែផ្តាំដាស់តឿនយ៉ាងខ្លាំងឲ្យគ្រីស្តបរិស័ទចូលរួមអភិបូជាតាមរបៀបដ៏ល្អប្រសើរជាងគេ គឺដោយទទួលព្រះកាយរបស់ព្រះអម្ចាស់ ក្រោយពីបូជាចារ្យបានទទួលនោះ ក្នុងសក្ការបូជានោះ" (SC ៥៥)។

១៣៨៩- តាមព្រះសហគមន៍ គ្រីស្តបរិស័ទ "ត្រូវតែចូលរួមអភិបូជារាល់ថ្ងៃអាទិត្យ និងថ្ងៃបុណ្យ" (OE ១៥) ហើយទទួលព្រះកាយព្រះលោហិតព្រះគ្រីស្ត យ៉ាងហោចណាស់មួយឆ្នាំម្តង ជាពិសេសនៅពេលរដូវបុណ្យចម្លង (CIC ៩២០) ដោយបានទទួលអគ្គសញ្ញាលើកលែងទោស។ ប៉ុន្តែ ព្រះសហគមន៍ជំរុញគ្រីស្តបរិស័ទ ឲ្យទទួលព្រះកាយព្រះលោហិតដ៏វិសុទ្ធរាល់ថ្ងៃអាទិត្យ និងថ្ងៃបុណ្យ ឬច្រើនជាងនេះទៅទៀត សូម្បីតែជារៀងរាល់ថ្ងៃក៏បានដែរ។

១៣៩០- ដោយសារវត្តមានខាងអគ្គសញ្ញារបស់ព្រះគ្រីស្តក្នុងនំប៉័ង និងស្រា ទោះបីយើងទទួលតែនំប៉័ងយ៉ាងណាក៏ដោយ ក៏យើងនឹងទទួលផលទាំងស្រុងនៃអគ្គសញ្ញាអរព្រះគុណ។ ដោយសារមូលហេតុផ្សេងៗ របៀបទទួលព្រះកាយនេះ បានទៅជាទំនៀមទម្លាប់ នៃពិធីបុណ្យខាងបស្ចិមប្រទេស។ "យើងគួរទទួលព្រះកាយនិងព្រះលោហិត ដើម្បីធ្វើជាសញ្ញាសម្គាល់យ៉ាងច្បាស់នៃពិធីជប់លៀង" (IGMR ២៤០)។ របៀបនេះ ជារបៀបធម្មតានៅពិធីបុណ្យខាងបូព៌ាប្រទេស។

### ផលនៃការទទួលព្រះកាយព្រះលោហិត

១៣៩១- ពេលយើងទទួលព្រះកាយព្រះលោហិត យើងបង្កើនការរួបរួមជាមួយព្រះគ្រីស្ត។ ពេលយើងទទួល

ព្រះកាយព្រះគ្រីស្ត យើងរួមរស់យ៉ាងស្និទ្ធស្នាលជាមួយព្រះគ្រីស្ត។ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ "អ្នក ណាពិសាសាច់ និងលោហិតរបស់ខ្ញុំ អ្នកនោះស្ថិតនៅក្នុងខ្ញុំ ហើយខ្ញុំក៏ស្ថិតនៅក្នុងអ្នកនោះដែរ" (យហ ៦,៥៦)។ ជីវិតក្នុងអង្គព្រះគ្រីស្តចាក់ឫសក្នុងពិធីជប់លៀងនៃអភិបូជា៖ "ព្រះបិតាបានចាត់ខ្ញុំឲ្យមក ទ្រង់មានព្រះជន្មរស់ ហើយខ្ញុំមានជីវិតដោយសារព្រះអង្គយ៉ាងណា អ្នកបរិភោគខ្ញុំក៏នឹងមានជីវិត ដោយសារខ្ញុំយ៉ាងនោះដែរ" (យហ ៦,៥៧)៖

> ក្នុងពិធីបុណ្យរបស់ព្រះអម្ចាស់ នៅពេលដែលគ្រីស្តបរិស័ទទទួលព្រះកាយព្រះបុត្រា ពួកគេប្រកាសចំពោះគ្នាទៅវិញទៅមកដំណឹងល្អថា ព្រះជាម្ចាស់បានប្រោសប្រទានជីវិតហើយ ដូចនៅពេលដែលទេវទូតមានប្រសាសន៍ទៅនាងម៉ារី នៃម៉ាដាឡាថា៖ "ព្រះគ្រីស្តមានព្រះជន្មថ្មី""។ ឥឡូវនេះអ្នកណាផ្ញើជីវិតលើព្រះគ្រីស្ត អ្នកនោះមានជីវិត និងមានជីវិតថ្មី (ពិធីបុណ្យនៅអង់ទីអូស)។

១៣៩២- អ្វីដែលចំណីអាហារបង្កើតក្នុងរូបកាយយើងយ៉ាងណា ព្រះកាយព្រះលោហិតបង្កើតផលក្នុងជីវិតខាងវិញ្ញាណយើងយ៉ាងនោះដែរ។ ការទទួលសាច់របស់ព្រះគ្រីស្តដែលមានព្រះជន្មថ្មី "ដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រោសឲ្យមានជីវិត ហើយដែលធ្វើឲ្យមានជីវិតរស់រវើក" (PO ៥) រក្សាទុក ពង្រឹង និងប្រោសឲ្យព្រះអំណោយទានដែលយើងបានទទួលនៅពិធីជ្រមុជទឹក មានជីវិតថ្មីឡើងវិញ។ ព្រះកាយព្រះគ្រីស្ត ដែលជានំប៉័ងនៃបូជនីយេសចរណ៍យើង ត្រូវចិញ្ចឹមជីវិតរបស់គ្រីស្តបរិស័ទ ដើម្បីឲ្យជីវិតនេះរីកចម្រើនរហូតដល់ស្លាប់។ នៅពេលនោះ យើងនឹងទទួលព្រះកាយជាលើកចុងក្រោយ។

១៣៩៣- ពេលយើងទទួលព្រះកាយ យើងឃ្លាតឆ្ងាយពីបាប ។ ព្រះកាយព្រះគ្រីស្តដែលយើងទទួលជាព្រះកាយដែល "ត្រូវបូជាសម្រាប់យើង" ហើយព្រះលោហិតដែលយើងពិសា "ត្រូវបង្ហូរសម្រាប់មនុស្សទាំងអស់ឲ្យរួចពីបាប"។ ហេតុនេះ ហើយបានជាអគ្គសញ្ញាអរព្រះគុណមិនអាចបង្រួបបង្រួមយើងជាមួយព្រះគ្រីស្ត ដោយមិនបានបន្សុទ្ធយើងឲ្យរួចពីបាបដែលយើងបានប្រព្រឹត្ត ព្រមទាំងការពាររក្សាយើងឲ្យរួចពីបាបនៅពេលអនាគតបានឡើយ៖

> "រៀងរាល់ពេលដែលបងប្អូនពិសានំប៉័ង និងពិសាស្រាពែងនេះ បងប្អូនប្រកាសអំពីព្រះអម្ចាស់សោយទិវង្គត រហូតដល់ព្រះអង្គយាងមកវិញ" (១ករ ១១,២៦)។ ពេលយើងប្រកាសថា ព្រះអម្ចាស់បានសោយទិវង្គត យើងក៏ប្រកាសថា បានរួចពីបាប។ បើរាល់ពេលព្រះលោហិតព្រះអង្គត្រូវបង្ហូរ ព្រះលោហិតនេះត្រូវបង្ហូរដើម្បីឲ្យរួចពីបាប ខ្ញុំក៏ត្រូវតែទទួលព្រះលោហិតនេះជានិច្ច ដើម្បីឲ្យព្រះលោហិតនេះប្រោសខ្ញុំឲ្យរួចពីបាបជានិច្ច។ ខ្ញុំតែង តែប្រព្រឹត្តអំពើបាបជានិច្ច ខ្ញុំក៏តែងតែត្រូវមានថ្នាំព្យាបាលជានិច្ចដែរ (សន្តអំប្រ័រ)។

១៣៩៤- ចំណីអាហារខាងផ្លូវកាយពង្រឹងកម្លាំងឡើងវិញយ៉ាងណា អគ្គសញ្ញាអរព្រះគុណពង្រឹងសេចក្តីស្រឡាញ់ ដែលក្នុងជីវិតប្រចាំថ្ងៃ កាន់តែខ្សោយទៅៗ ហើយសេចក្តីស្រឡាញ់ថ្មីនេះលុបបំបាត់អំពើបាបស្រាលៗ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS១៦៣៨)។ ដោយប្រទានព្រះអង្គមកយើង ព្រះគ្រីស្តពង្រឹងសេចក្តីស្រឡាញ់របស់យើង ហើយប្រោសយើងឲ្យអាចផ្តាច់ចំណងឥតសណ្តាប់ធ្នាប់ចំពោះសត្វលោក ព្រមទាំងឲ្យយើងអាចចាក់ឫសក្នុងអង្គព្រះអង្គ៖

> ព្រះគ្រីស្តសោយទិវង្គត ដើម្បីយើងដោយសារសេចក្តីស្រឡាញ់ នៅពេលយើងនឹករឭកដល់ព្រះអង្គសោយទិវង្គត ពេលថ្វាយសក្ការបូជា យើងទូលសូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមកប្រទានសេចក្តី

ស្រឡាញ់មកយើង។ ដោយសារសេចក្ដីស្រឡាញ់នេះ ព្រះគ្រីស្ដសព្វព្រះហឫទ័យសោយទិវង្គតដើម្បីយើងៗ អង្វរឲ្យអាចចាត់ទុកថា លោកីយ៍ត្រូវឆ្កាងដើម្បីយើង ហើយយើងក៏ត្រូវឆ្កាងដើម្បីលោកីយ៍ដែរ (...) ដោយបានទទួលព្រះអំណោយទាននៃសេចក្ដីស្រឡាញ់ ចូររម្ងាប់អំពើបាប ហើយរួមរស់ជាមួយព្រះជាម្ចាស់ (សន្ដ: ហ្វូលគង់ នៃរូស្ព) ។

១៣៩៥- ដោយសារសេចក្ដីស្រឡាញ់ដដែល ដែលអគ្គសញ្ញាអរព្រះគុណបង្កាត់ក្នុងចិត្តយើង អគ្គសញ្ញានេះការពាររក្សាយើងឲ្យរួចពីអំពើបាបធ្ងន់ នៅពេលអនាគត។ បើយើងចូលរួមចំណែកក្នុងជីវិតព្រះគ្រីស្ដកាន់តែច្រើនឡើងៗ បើយើងរីកចម្រើនក្នុងមេត្រីភាពរបស់ព្រះអង្គកាន់តែច្រើនឡើងៗ យើងក៏កាន់តែពិបាកឃ្លាតឆ្ងាយពីព្រះអង្គដោយប្រព្រឹត្តអំពើបាបធ្ងន់ដែរ។ ព្រះជាម្ចាស់មិនតម្រង់អគ្គសញ្ញាអរព្រះគុណ ដើម្បីលើកលែងទោសអំពើបាបធ្ងន់ទេ ព្រោះជាលក្ខណៈពិសេសនៃអគ្គសញ្ញាលើកលែងទោសវិញ។ អគ្គសញ្ញាអរព្រះគុណមានលក្ខណៈពិសេសថា ជាអគ្គសញ្ញារបស់អស់អ្នកដែលរួបរួមជាមួយព្រះសហគមន៍យ៉ាងពេញលេញ។

១៣៩៦- ឯកភាពនៃព្រះកាយដ៏អាថ៌កំបាំង៖ អគ្គសញ្ញាអរព្រះគុណកសាងព្រះសហគមន៍។ អស់អ្នកដែលទទួលព្រះកាយ ព្រះលោហិតព្រះគ្រីស្ដរួបរួមជាមួយព្រះអង្គយ៉ាងស្និទ្ធស្នាល ទើបព្រះអង្គបង្រួបបង្រួមគ្រីស្ដបរិស័ទទាំងអស់ក្នុងរូបកាយតែមួយ គឺព្រះសហគមន៍។ ព្រះកាយព្រះគ្រីស្ដប្រោសឲ្យជាថ្មីឡើងវិញ និងពង្រឹងការរួបរួមជាមួយព្រះសហគមន៍នេះ ដែលអគ្គសញ្ញាជ្រមុជទឹកបានសម្រេចហើយ កាន់តែជ្រៅៗ។ ក្នុងពិធីជ្រមុជទឹកព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យធ្វើជារូបកាយតែមួយ (១ករ១២,១៣)។ ពិធីអរព្រះគុណសម្រេចការត្រាស់ហៅនេះ៖ "ពេលយើងលើកពែងឡើង ដើម្បីអរព្រះគុណព្រះជាម្ចាស់ យើងរួបរួមជាមួយព្រះលោហិតរបស់ព្រះគ្រីស្ដ រីឯពេលយើងកាច់នំប៉័ង យើងរួបរួមជាមួយព្រះកាយរបស់ព្រះគ្រីស្ដដែរ។ ដោយមាននំប៉័ងតែមួយប៉ុណ្ណោះ យើងដែលមានគ្នាច្រើន ក៏រួបរួមគ្នាជារូបកាយតែមួយដែរ ព្រោះយើងទាំងអស់គ្នាទទួលចំណែកពីនំប៉័ងតែមួយនោះ" (១ករ ១០,១៦-១៧)។

បើបងប្អូនជាព្រះកាយព្រះគ្រីស្ដ និងជាសិរីរាង្គរបស់ព្រះអង្គ អគ្គសញ្ញា ដែលនៅលើតុនៃព្រះអម្ចាស់ជាអគ្គសញ្ញារបស់បងប្អូន ហើយបងប្អូនក៏ទទួលអគ្គសញ្ញារបស់បងប្អូន។ បងប្អូនឆ្លើយថា "អាម៉ែន" ("ពិតមែនហើយ"") ចំពោះអ្វីដែលបងប្អូនទទួល ហើយបងប្អូនយល់ស្របដោយឆ្លើយតប។ អ្នកឮពាក្យនេះ "ព្រះកាយព្រះគ្រីស្ដ" ហើយអ្នកឆ្លើយថា "អាម៉ែន"។ ចូរអ្នកទៅជាសិរីរាង្គនៃព្រះកាយព្រះគ្រីស្ដ ដើម្បីឲ្យចម្លើយរបស់អ្នកពិតជា ត្រឹមត្រូវមែន (សន្ដ: អូគូស្ដាំង)។

១៣៩៧- អគ្គសញ្ញាអរព្រះគុណជំរុញឲ្យជួយជនក្រីក្រ៖ យើងត្រូវតែទទួលស្គាល់ព្រះគ្រីស្ដក្នុងអ្នកក្រីក្រជាងគេជាបងប្អូនរបស់ព្រះអង្គ ដើម្បីទទួល ក្នុងសេចក្ដីពិត ព្រះកាយព្រះលោហិតព្រះគ្រីស្ដដែលត្រូវបូជាសម្រាប់យើង (មថ ២៥,៤០)៖

អ្នកបានទទួលព្រះលោហិតព្រះអម្ចាស់ ហើយអ្នកមិនចេះទទួលស្គាល់ប្អូនរបស់អ្នក។ អ្នកប្រឡាក់តុនេះដោយគិតថា មិនសមនឹងចែកម្ហូបអាហាររបស់អ្នកចំពោះអ្នកដែលព្រះជាម្ចាស់បានអញ្ជើញមករួមតុនេះ។ ព្រះជាម្ចាស់បានរំដោះអ្នកឲ្យរួចពីអំពើបាបទាំងអស់របស់អ្នក ទ្រង់ក៏បានអញ្ជើញអ្នកឲ្យរួមតុ ហើយអ្នកគ្មានចិត្តមេត្តាករុណា (សន្ដ: យ៉ូហាន គ្រីសូស្ដូម)។

១៣៩៨- អគ្គសញ្ញាអរព្រះគុណ និងឯកភាពរវាងគ្រីស្ដបរិស័ទ ។ ពីមុខអាថ៌កំបាំងដ៏ខ្ពង់ខ្ពស់នេះ សន្ដ: អូគូស្ដាំង ស្រែងឡើងថា៖ "ឱអគ្គសញ្ញានៃការគោរពប្រណិប័តន៍" ឱអគ្គសញ្ញានៃឯកភាព" ឱចំណងនៃសេចក្ដី

ស្រឡាញ់"។ ការបាក់បែកគ្នាក្នុងព្រះសហគមន៍ ដែលផ្ដាច់គ្រីស្ដបរិស័ទមិនឲ្យរួមគុនៃព្រះអម្ចាស់ជាធ្លុងតែមួយ ធ្វើឲ្យឈឺចាប់យ៉ាងណា សេចក្ដីអង្វររបស់ព្រះអម្ចាស់ជំរុញអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គឲ្យរួមជាមួយគ្នាជាធ្លុងតែមួយក៏យ៉ាងនោះដែរ។

១៣៩៩- ព្រះសហគមន៍ខាងបូព៌ាប្រទេស ដែលមិនសូវរួបរួមជាមួយព្រះសហគមន៍កាតូលិក ថ្វាយអភិបូជាដោយសេចក្ដីស្រឡាញ់យ៉ាងជ្រាលជ្រៅ។ "ទោះបីព្រះសហគមន៍ទាំងនោះបែកចេញពីយើងក្ដី ក៏ (...) ព្រះសហគមន៍ទាំងនោះមានអគ្គសញ្ញាដ៏ពិតប្រាកដ ជាពិសេសឲ្យមានអភិបាលត ៗគ្នាតាំងពីក្រុមគ្រីស្ដទូតរៀងមក -មុខងារជាបូជាចារ្យ និងពិធីអរព្រះគុណ ដែលជាកត្តាឲ្យពួកគេរួបរួមជាមួយយើងយ៉ាងជិតស្និទ្ធ" (UR ១៥)។ "យើងអាច និងគួររួបរួមធ្វើពិធីដ៏សក្ការៈជាមួយគ្នាបានខ្លះទៅ តាមកាលៈទេសៈត្រឹមត្រូវ និងដោយមានការអនុញ្ញាតអំពីអភិបាលព្រះសហគមន៍" (UR ១៥ ; CIC ៨៤៤,៣)។

១៤០០- សហគមន៍ដែលបានមកពីការកែតម្រង់ ហើយដែលបែកចេញពីព្រះសហគមន៍កាតូលិក "ជាពិសេសព្រោះគេគ្មានអគ្គសញ្ញាតែងតាំង គេមិនរក្សាទុកសភាពដើមនៃគម្រោងការដ៏អស្ចារ្យនៃពិធីអរព្រះគុណទេ" (UR ២២)។ ហេតុនេះហើយ បានជាព្រះសហគមន៍កាតូលិកមិនអាចឲ្យយើងរួមរស់ជាមួយគេក្នុងពិធីអរព្រះគុណបានឡើយ។ក៏ប៉ុន្តែ"ពេលសហគមន៍ទាំងនោះនឹករឭកទៅដល់ពីធីជប់លៀងដ៏វិសុទ្ធអំពីព្រះអម្ចាស់សោយទិវង្គត និងមានព្រះជន្មថ្មី គេប្រកាសថា ជីវិតដ៏ពិតប្រាកដមានន័យថា រួមរស់ជាមួយព្រះគ្រីស្ដ និងរង់ចាំឲ្យព្រះអង្គយាងមកវិញ ប្រកបដោយសិរីរុងរឿងផង" (UR ២២)។

១៤០១- នៅពេលដែលមានការចាំបាច់ធ្ងន់ធ្ងរ តាមអភិបាលភូមិភាគវិនិច្ឆ័យ អ្នកដែលទទួលមុខងារបម្រើព្រះសហគមន៍កាតូលិកអាចផ្ដល់អគ្គសញ្ញា (អរព្រះគុណ លើកលែងទោស លាបប្រេងអ្នកជំងឺ) ដល់គ្រីស្ដបរិស័ទឯទៀត ៗដែលមិនរួបរួមជាព្រះសហគមន៍កាតូលិកយ៉ាងពេញលេញ ប៉ុន្តែដែលសូមឲ្យទទួលអគ្គសញ្ញានោះដោយគ្មាននរណាបង្ខំ។ ពួកគេត្រូវតែសម្ដែងជំនឿនៃព្រះសហគមន៍កាតូលិក ដែលទាក់ទងនឹងអគ្គសញ្ញានោះ ហើយឲ្យគេបានត្រៀមខ្លួនទុកជាមុនផង (CIC ៨៤៤,៤)។

## ៧. ពិធីអរព្រះគុណ "បញ្ចាំសិរីរុងរឿងដែលនឹងយាងមក"

១៤០២- ក្នុងសេចក្ដីអធិដ្ឋានពីបុរាណកាល ព្រះសហគមន៍លើកតម្កើងគម្រោងការដ៏អស្ចារ្យនៃពិធីអរព្រះគុណ៖ "ឱពិធីជប់លៀងដ៏សក្ការៈ ដែលព្រះគ្រីស្ដជាចំណីអាហាររបស់យើង ដែលយើងរំឭកដល់ទុក្ខលំបាករបស់ព្រះអង្គ ដែលព្រះហឫទ័យប្រណីសន្ដោសឈានចូលក្នុងព្រលឹងយើង ហើយដែលព្រះជាម្ចាស់បញ្ចាំសិរីរុងរឿងដែលនឹងយាងមក"។ បើពិធីអរព្រះគុណជាពិធីនឹករឭកបុណ្យចម្លងរបស់ព្រះអម្ចាស់ បើយើងទទួល "ព្រះពរទាំងឡាយនៃស្ថានបរមសុខ និងព្រះហឫទ័យប្រណីសន្ដោស" (MR) ដោយទទួលព្រះកាយព្រះលោហិតព្រះគ្រីស្ដ ពិធីអរព្រះគុណក៏ជាការប្រារព្ធទុកជាមុនសិរីរុងរឿងនៃស្ថានបរមសុខដែរ។

១៤០៣- ក្នុងពិធីជប់លៀងចុងក្រោយ ព្រះអម្ចាស់ផ្ទាល់បានបំបែរមុខសាវ័ករបស់ព្រះអង្គឆ្ពោះទៅបុណ្យចម្លងដែលនឹងសម្រេចពេញលក្ខណៈក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់៖ "ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អំណើះតទៅខ្ញុំនឹងមិនពិសាស្រាទំពាំងបាយជូរទៀតឡើយ រហូតដល់ថ្ងៃដែលខ្ញុំនឹងពិសាស្រាទំពាំងបាយជូរថ្មីជាមួយអ្នករាល់គ្នា នៅក្នុងព្រះរាជ្យនៃព្រះបិតាខ្ញុំ" (មថ ២៦,២៩) (លក ២២,១៨ ; មក ១៤,២៥)។ ជារៀងរាល់ពេលដែលព្រះសហគមន៍ថ្វាយអភិបូជា ព្រះសហគមន៍ក៏រំឭកនូវព្រះបន្ទូលសន្យានេះ ហើយបែរមុខទៅរក "អ្នកដែលជិតមកដល់

ហើយ" (វវ ១,៤)។ ពេលអធិដ្ឋាន ព្រះសហគមន៍អង្វរឲ្យព្រះអង្គយាងមក "ម៉ារ៉ាណថា" (១ករ ១៦,២២) "ឱព្រះអម្ចាស់យេស៊ូអើយ" សូមយាងមក" (វវ ២២,២០) "សូមឲ្យព្រះហឫទ័យប្រណីសន្ដាសរបស់ព្រះអង្គយាងមក ហើយឲ្យលោកីយ៍នេះកន្លងផុតទៅ" (ឌីដាខេ)។

១៤០៤- ព្រះសហគមន៍ដឹងថា ចាប់ពីពេលនេះទៅ ព្រះអម្ចាស់យាងមកក្នុងពិធីអរព្រះគុណរបស់ព្រះអង្គ ហើយព្រះអង្គគង់នៅកណ្ដាលពួកយើងផង។ ក៏ប៉ុន្តែ វត្តមាននេះ ហាក់ដូចជាលាក់លៀមដែរ។ ហេតុនេះ យើងថ្វាយអភិបូជាដោយ "មានសង្ឃឹមយ៉ាងមាំថា នឹងបានបរមសុខ ហើយយើងខ្ញុំក៏រង់ចាំព្រះយេស៊ូគ្រីស្តជាព្រះសង្គ្រោះទ្រង់យាងត្រឡប់មកវិញ" (សេចក្តីអធិដ្ឋានក្រោយពីធម៌ឱព្រះបិតានៃយើងខ្ញុំ) ដោយ "សង្ឃឹមថា នឹងបានពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គជានិច្ចនិរន្តរ៍។ នៅពេលព្រះអង្គជូតទឹកភ្នែកយើងខ្ញុំ ពេលនោះ យើងខ្ញុំនឹងមើលឃើញព្រះភ័ក្ត្រព្រះជាម្ចាស់យ៉ាងជាក់ស្ដែង ហើយយើងខ្ញុំនឹងបានវិសុទ្ធ ដូចព្រះអង្គ អស់កល្បជានិច្ចដែរ។ យើងខ្ញុំលើកតម្កើងព្រះអង្គឥតឈប់ឈររួមជាមួយព្រះគ្រីស្តជាព្រះអម្ចាស់នៃយើងខ្ញុំ" (MR ធម៌អរព្រះគុណដ៏វិសុទ្ធទី៣)។

១៤០៥- មានតែអគ្គសញ្ញាអរព្រះគុណដែលបញ្ជាក់ឲ្យច្បាស់នូវសេចក្តីសង្ឃឹមយ៉ាងមាំថា នឹងបានផ្ទៃមេឃ និងផែនដីថ្មីប្រកបដោយយុត្តិធម៌ (១ពត្រ ៣,១៣)។ ជារៀងរាល់ពេលយើងថ្វាយគម្រោងការដ៏អស្ចារ្យនេះ "យើងរួចពីបាប" ហើយ "យើងកាច់នំប៉័ងតែមួយ ជាថ្នាំអមតៈ ថ្នាំព្យាបាលកុំឲ្យស្លាប់ ប៉ុន្តែឲ្យយើង រួមរស់ជាមួយព្រះយេស៊ូគ្រីស្តជាដរាបតរៀងទៅ" (សន្តៈ អ៊ីញ៉ាស នៃអង់ទីអូស)។

## សង្ខេប

១៤០៦- ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំនេះហើយជាអាហារ ដែលមានជីវិតចុះមកពីស្ថានបរមសុខ។ អ្នកណាបរិភោគអាហារនេះ នឹងរស់នៅអស់កល្បជានិច្ច (...) អ្នកណាពិសាសាច់និងលោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច (...) អ្នកនោះស្ថិតនៅក្នុងខ្ញុំ ហើយខ្ញុំក៏ស្ថិតនៅក្នុងអ្នកនោះដែរ (យហ ៦,៥១.៥៤.៥៦)។

១៤០៧- ពិធីអរព្រះគុណជាស្នូល និងជាកំពូលនៃជីវិតព្រះសហគមន៍ ដ្បិតក្នុងពិធីនេះ ព្រះគ្រីស្តប្រោស ព្រះសហគមន៍ព្រះអង្គ និងសមាជិកទាំងអស់របស់ព្រះអង្គឲ្យចូលរួមក្នុងសក្ការៈបូជាកោតសរសើរ និងអរព្រះគុណដែលព្រះអង្គបានថ្វាយម្តងជាការស្រេចនៅលើឈើឆ្កាងទៅព្រះបិតារបស់ព្រះអង្គ។ ដោយសារសក្ការៈបូជា នេះ ព្រះអង្គចាក់បង្ហូរព្រះអំណោយទាននៃការសង្គ្រោះលើព្រះកាយព្រះអង្គ គឺព្រះសហគមន៍។

១៤០៨- ពិធីបុណ្យអរព្រះគុណតែងតែមានដូចតទៅ៖ ការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពិធីអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតា ចំពោះព្រះអំណោយទានទាំងអស់របស់ព្រះអង្គ ជាពិសេសចំពោះព្រះអំណោយទាននៃព្រះបុត្រាព្រះអង្គ ពិធីប្រសិទ្ធពរលើនំប៉័ង និងស្រា និងការចូលរួមក្នុងពិធីជប់លៀងដោយទទួលព្រះកាយ និងព្រះលោហិតព្រះអម្ចាស់។ ចំណុចទាំងអស់នោះ ជាកិច្ចការតែមួយនៃពិធីបុណ្យ។

១៤០៩- ពិធីអរព្រះគុណជាការនឹករឭកបុណ្យចម្លងរបស់ព្រះគ្រីស្ត ពោលគឺព្រះរាជកិច្ចនៃការសង្គ្រោះ ដែលជីវិត សេចក្តីស្លាប់ និងព្រះជន្មថ្មីរបស់ព្រះគ្រីស្តបានសម្រេច ហើយដែលពិធីបុណ្យធ្វើឲ្យមានវត្តមានសព្វថ្ងៃ។

១៤១០- គឺព្រះគ្រីស្តផ្ទាល់ ជាមហាបូជាចារ្យអស់កល្បជានិច្ចនៃសម្ព័ន្ធមេត្រីថ្មី ដែលថ្វាយសក្ការៈបូជា ដោយប្រព្រឹត្តតាម រយៈអ្នកមានមុខងារបម្រើ។ គឺព្រះគ្រីស្តដដែលនេះ ដែលស្ថិតនៅក្នុងនំប៉័ង និងស្រា និងដែលជា

តង្វាយនៃសក្ការៈបូជា។

១៤១១- មានតែពួកបូជាចារ្យ ដែលបានទទួលពិធីតែងតាំងយ៉ាងត្រឹមត្រូវទេ ដែលអាចថ្វាយពិធីអរព្រះគុណ និងប្រសិទ្ធពរលើនំប៉័ង និងស្រា ដើម្បីឲ្យទៅជាព្រះកាយ ព្រះលោហិតព្រះអម្ចាស់បាន។

១៤១២- សញ្ញាសម្គាល់សំខាន់ជាងគេនៃអគ្គសញ្ញាអរព្រះគុណជានំប៉័ងនៃស្រូវសាលី និងស្រាទំពាំងបាយជូរ ដែលយើងអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ ហើយលោកបូជាចារ្យពោលពាក្យនៃការប្រសិទ្ធពរ ដែលព្រះយេស៊ូមានព្រះបន្ទូលនៅពិធីជប់លៀងចុងក្រោយ៖ "នេះជាព្រះកាយ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា (...) នេះជាពែងនៃព្រះលោហិតរបស់ខ្ញុំ..."។

១៤១៣- ដោយសារការប្រសិទ្ធពរ នំប៉័ង និងស្រាប្រែជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ នៅក្នុងនំប៉័ង និងស្រា ដែលត្រូវប្រសិទ្ធពរ ព្រះគ្រីស្តផ្ទាល់ ដែលមានព្រះជន្មពោរពេញដោយសិរីរុងរឿង មានវត្តមានពិតប្រាកដមែន និងដោយសារធាតុ រួមជាមួយព្រះកាយ និងព្រះលោហិតព្រះអង្គ ព្រលឹង និងសភាពជាព្រះជាម្ចាស់របស់ព្រះអង្គផងដែរ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៤០ ; ១៦៥១)។

១៤១៤- ដោយសារពិធីអរព្រះគុណជាសក្ការៈបូជា យើងថ្វាយពិធីនេះ ដើម្បីលោះអំពើបាបរបស់មនុស្សទាំងរស់ទាំងស្លាប់ ហើយដើម្បីទទួលព្រះអំណោយទានខាងវិញ្ញាណ ឬខាងលោកីយ៍អំពីព្រះជាម្ចាស់។

១៤១៥- នរណាចង់ទទួលព្រះកាយព្រះគ្រីស្តត្រូវតែបានទទួលការលើកលែងទោស។ ប្រសិនបើនរណាម្នាក់ដឹងខ្លួនថា បានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ គេមិនអាចទទួលព្រះកាយបានទេ ទាល់តែគេបានទទួលអគ្គសញ្ញាលើកលែងទោសជាមុនសិន។

១៤១៦- ការទទួលព្រះកាយ ព្រះលោហិតដ៏វិសុទ្ធរបស់ព្រះគ្រីស្តធ្វើឲ្យអ្នកទទួលរួបរួមជាមួយព្រះអម្ចាស់ស្និតស្នាលជាងមុន ប្រោសគេឲ្យរួចពីបាបស្រាលៗ និងការពារគេកុំឲ្យប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ។ ដោយសារចំណងនៃសេចក្ដីស្រឡាញ់រវាងអ្នកទទួល និងព្រះគ្រីស្តខ្លាំងជាងមុន ការទទួលអគ្គសញ្ញានេះ ពង្រឹងឯកភាពព្រះសហគមន៍ ដែលជាព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត។

១៤១៧- ព្រះសហគមន៍ជំរុញគ្រីស្តបរិស័ទឲ្យទទួលព្រះកាយ ព្រះលោហិតព្រះគ្រីស្ត រាល់ពេលគេចូលរួមអភិបូជា។ គេត្រូវទទួលព្រះកាយ ព្រះលោហិតព្រះអង្គយ៉ាងហោចណាស់មួយឆ្នាំម្ដង។

១៤១៨- ដោយសារព្រះគ្រីស្តផ្ទាល់គង់នៅក្នុងអគ្គសញ្ញានៃអាសនៈ ត្រូវតែគោរពព្រះអង្គដោយក្រាបថ្វាយបង្គំ។ "ពេលយើងសួរសុខទុក្ខអគ្គសញ្ញាដ៏វិសុទ្ធបំផុត យើងបង្ហាញភស្តុតាងថា យើងដឹងគុណព្រះអង្គ ជា សញ្ញាថាយើងស្រឡាញ់ព្រះអង្គ ហើយជាភារកិច្ចចំពោះព្រះគ្រីស្តជាព្រះអម្ចាស់យើង" (MF)។

១៤១៩-ព្រះគ្រីស្ត ដែលបានឆ្លងពីលោកនេះទៅព្រះបិតា ក្នុងពិធីអរព្រះគុណ ព្រះអង្គបញ្ចាំសិរីរុងរឿងឲ្យយើងត្រូវតែទទួលនៅក្បែរព្រះអង្គ៖ ការចូលរួមក្នុងសក្ការៈបូជាដ៏វិសុទ្ធបធ្វើឲ្យយើងមានចិត្ត ដូចព្រះហឫទ័យព្រះអង្គជួយគាំទ្រកម្លាំងយើងនៅពេលធ្វើបូជនីយេចរណ៍នៅក្នុងជីវិតនេះ ធ្វើឲ្យយើងចង់បានជីវិតអស់កល្បជានិច្ច និងធ្វើឲ្យយើងរួមជាមួយព្រះសហគមន៍នៃស្ថានបរមសុខ ព្រហ្មចារិនីម៉ារីដ៏វិសុទ្ធ និងជនដ៏វិសុទ្ធទាំងឡាយ។

# ជំពូកទីពីរៈ

# អគ្គសញ្ញានៃការព្យាបាល

១៤២០- ដោយសារអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ មនុស្សទទួលជីវិតថ្មីរបស់ព្រះគ្រីស្ត។ ប៉ុន្តែ ជីវិតនេះ នៅក្នុង "ឆ្នាំងដី" (២ករ ៤,៧)។ ឥឡូវ ជីវិតនេះ "កប់ទុកជាមួយព្រះគ្រីស្តក្នុងព្រះជា ម្ចាស់" (កូឡ ៣,៣)។ យើងស្ថិតនៅក្នុង "ជម្រកមួយដែលត្រូវរលួយសូន្យទៅ" ដដែល (២ករ ៥,១) ត្រូវរងទុក្ខលំបាក ធ្លាក់ខ្លួនឈឺ និងស្លាប់។ យើងក៏អាចបាត់បង់ជីវិតថ្មីនៃបុត្រធីតារបស់ព្រះជាម្ចាស់ដោយសារអំពើបាបដែរ។

១៤២១- ព្រះអម្ចាស់យេស៊ូគ្រីស្ត ជាគ្រូពេទ្យនៃព្រលឹង និងរូបកាយរបស់យើង ព្រះអង្គដែលបានលើកលែង ទោសឲ្យមនុស្សខ្វិនដៃខ្វិនជើង និងប្រោសឲ្យគេបានជា (មក ២,១-១២) ទ្រង់សព្វព្រះហឫទ័យ ឲ្យព្រះសហ គមន៍ព្រះអង្គបន្តព្រះរាជកិច្ចនៃការព្យាបាល និងការសង្គ្រោះរបស់ព្រះអង្គ ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ សូម្បីតែចំពោះសិរីរាង្គរបស់ព្រះអង្គផ្ទាល់។ នេះគឺជាគោលដៅរបស់អគ្គសញ្ញាទាំងពីរដើម្បីព្យាបាល ពោលគឺ អគ្គសញ្ញាលើកលែងទោស និងអគ្គសញ្ញាលាងប្រេងឲ្យអ្នកជំងឺ។

# ប្រការទី៤ៈ

# អគ្គសញ្ញាលើកលែងទោស និងសម្រុះសម្រួល

១៤២២- "អស់អ្នកដែលទទួលអគ្គសញ្ញាលើកលែងទោស គឺទទួលការលើកលែងទោសពីព្រះជាម្ចាស់ប្រកប ដោយព្រះហឫទ័យមេត្តាករុណា ចំពោះបទដែលគេបានប្រព្រឹត្តខុសនឹងព្រះហឫទ័យព្រះអង្គ។ នៅពេលជាមួយ គ្នានោះ គេស្រុះស្រួលជាមួយព្រះសហគមន៍ដែលត្រូវរបួសដោយបាបរបស់គេ។ ព្រះសហគមន៍ក៏ជួយឲ្យគេប្រែ ចិត្តគំនិត ដោយមានសេចក្តីស្រឡាញ់ ដោយធ្វើជាគំរូល្អឲ្យគេ និងដោយអធិដ្ឋានទៀតផង" (LG ១១)។

## ១. តើគេហៅអគ្គសញ្ញានេះយ៉ាងដូចម្តេច?

១៤២៣- គេហៅអគ្គសញ្ញានេះថា អគ្គសញ្ញានៃការកែប្រែចិត្តគំនិត ដ្បិតដោយសារអគ្គសញ្ញានេះ យើងក៏ ឆ្លើយតបចំពោះព្រះយេស៊ូដែលត្រាស់ហៅយើងឲ្យកែប្រែចិត្តគំនិត (មក ១,១៥) ហើយយើងត្រឡប់មករក ព្រះបិតាវិញ (លក ១៥,១៨) ដែលកាលពីមុនអំពើបាបបាននាំយើងឲ្យឃ្លាតឆ្ងាយ។

គេហៅអគ្គសញ្ញានេះថា អគ្គសញ្ញានៃការសោកស្តាយចំពោះអំពើបាបដែលខ្លួនបានប្រព្រឹត្ត ដ្បិត ដោយសារអគ្គសញ្ញានេះ គ្រីស្តបរិស័ទដែលបានប្រព្រឹត្តអំពើបាប ចាប់ផ្តើមកែប្រែចិត្តគំនិត សោកស្តាយ និងទូទាត់កំហុសរបស់ខ្លួន ដោយរួបរួមជាមួយព្រះសហគមន៍។

១៤២៤- គេហៅអគ្គសញ្ញានេះថា អគ្គសញ្ញានៃការសារភាព ដ្បិតគេចាំបាច់ត្រូវតែទទួលស្គាល់ និងសារភាព បាបចំពោះលោកបូជាចារ្យម្នាក់។ តាមអត្ថន័យជ្រៅ ដោយសារអគ្គសញ្ញានេះ យើង "ទទួលស្គាល់" លើកតម្កើង កោតសរសើរភាពដ៏វិសុទ្ធនៃព្រះជាម្ចាស់ និងធម៌មេត្តាករុណារបស់ព្រះអង្គចំពោះអ្នកបាបដែរ។

គេហៅអគ្គសញ្ញានេះថា អគ្គសញ្ញាលើកលែងទោស ដ្បិតដោយសារពិធីលើកលែងទោសរបស់ លោក បូជាចារ្យក្នុងព្រះនាមព្រះជាម្ចាស់ ព្រះអង្គក៏ប្រោសប្រទានឲ្យអ្នកបាបនូវ "ការលើកលែងទោស និងសេចក្តី

សុខសាន្ត" (PO)។

គេហៅអគ្គសញ្ញានេះថា អគ្គសញ្ញាសម្រុះសម្រួល ដ្បិតអគ្គសញ្ញានេះផ្តល់ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ឲ្យអ្នកបាប ដែលព្រះអង្គសម្រុះសម្រួល៖ "ទុកឲ្យព្រះជាម្ចាស់សម្រុះសម្រួលបងប្អូនឲ្យជានានឹងព្រះអង្គវិញទៅ" (២ករ៥,២០)។ អ្នកដែលទទួលសេចក្តីស្រឡាញ់ប្រកបដោយធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ត្រៀមខ្លួននឹងឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះអម្ចាស់៖ "ចូរទៅសម្រុះសម្រួលនឹងបងប្អូនរបស់អ្នកជាមុនសិន" (មថ ៥,២៤)។

## ២. ហេតុអ្វីបានជាមានអគ្គសញ្ញាលើកលែងទោសក្រោយពីពិធីជ្រមុជទឹក?

១៤២៥- "ព្រះជាម្ចាស់លាងសម្អាតបងប្អូន ប្រោសប្រទានឲ្យបងប្អូនបានវិសុទ្ធ ព្រមទាំងឲ្យបងប្អូន បានសុចរិត ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្ត តាមរយៈព្រះវិញ្ញាណនៃព្រះជាម្ចាស់របស់យើង រួចស្រេចទៅហើយ" (១ករ ៦,១១)។ ត្រូវដឹងខ្លួនអំពីភាពថ្កុំថ្កើងនៃព្រះអំណោយទាន ដែលព្រះជាម្ចាស់ប្រោសប្រទានក្នុងអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ ដើម្បីឈ្វេងយល់ថា អ្នកដែល "មានព្រះគ្រីស្តស្ថិតនៅជាប់ជាមួយ" (កាឡ ៣,២៧) មិនអាចប្រព្រឹត្តអំពើបាបទៀតទេ។ ប៉ុន្តែ នៅពេលជាមួយគ្នានេះ គ្រីស្តទូតសន្តៈយ៉ូហានមានប្រសាសន៍ថា៖ "ប្រសិនបើយើងពោលថា យើងគ្មានបាបសោះ នោះយើងបញ្ឆោតខ្លួនឯង ហើយសេចក្តីពិតក៏មិនស្ថិតនៅក្នុងយើងដែរ" (១យហ ១,៨) ហើយព្រះអម្ចាស់ផ្ទាល់បានប្រៀនប្រដៅយើងឲ្យអធិដ្ឋាន៖ "សូមអភ័យទោសឲ្យយើងខ្ញុំ" (លក ១១,៤) ដោយដឹងច្បាស់ថា ព្រះជាម្ចាស់នឹងអភ័យទោសឲ្យយើង លុះត្រាតែយើងលើកលែងទោសឲ្យគ្នាទៅវិញទៅមក។

១៤២៦- ដោយសារយើងបានកែប្រែចិត្តគំនិត ទៅរកព្រះគ្រីស្ត យើងបានកើតជាថ្មីក្នុងពិធីជ្រមុជទឹក យើងបានទទួលព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ និងបានទទួលព្រះកាយព្រះលោហិតព្រះគ្រីស្តធ្វើជាអាហារ យើងក៏បានទៅជា "វិសុទ្ធ និងឥតសៅហ្មងចំពោះព្រះភ័ក្ត្រព្រះអង្គ" (អភ ៥,២៧)។ ក៏ប៉ុន្តែ ជីវិតថ្មីដែលយើងបានទទួលក្នុងការបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទមិនបានលុបភាពទន់ខ្សោយនៃធម្មជាតិមនុស្ស ឬចិត្តលោភលន់ចង់ប្រព្រឹត្តអំពើបាប ដែលការបញ្ញនបន្តហៅថាកិលេសតណ្ហា ដែលស្ថិតនៅជាប់នឹងអ្នកជ្រមុជទឹក ដើម្បីឲ្យគេបង្ហាញនូវការប្រយុទ្ធក្នុងការរស់នៅជាគ្រីស្តបរិស័ទ ដោយមានព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្តជួយ (DS ១៥១៥)។ ការប្រយុទ្ធនេះ ជាការកែប្រែចិត្តគំនិតឲ្យទៅបានវិសុទ្ធ និងទទួលជីវិតអស់កល្បជានិច្ច ដែលព្រះអម្ចាស់តែងតែត្រាស់ហៅយើង (DS ១៥៤៥ ; LG ៤០)។

## ៣. ការកែប្រែចិត្តគំនិតរបស់អ្នកជ្រមុជទឹក

១៤២៧- ព្រះយេស៊ូត្រាស់ហៅឲ្យកែប្រែចិត្តគំនិត។ ការត្រាស់ហៅនេះ ជាផ្នែកដ៏ចាំបាច់នៃការប្រកាសព្រះរាជ្យ៖ "ពេលកំណត់មកដល់ហើយ រីឯព្រះរាជ្យរបស់ព្រះជាម្ចាស់ក៏មកជិតបង្កើយដែរ។ ចូរនាំគ្នាកែប្រែចិត្តគំនិត ហើយជឿដំណឹងល្អចុះ" (មក ១,១៥)។ ដំបូង តាមធម្មទេសនាព្រះសហគមន៍ ការត្រាស់ហៅនេះ សំដៅទៅលើអស់អ្នកដែលមិនទាន់ស្គាល់ព្រះគ្រីស្ត និងដំណឹងល្អរបស់ព្រះអង្គ។ ហេតុនេះ ពិធីជ្រមុជទឹកគឺជាការកែប្រែចិត្តគំនិត ដើមដំបូង និងសំខាន់ជាងគេដែរ។ ដោយសារយើងផ្ញើជីវិតទាំងស្រុងលើដំណឹងល្អ និងទទួលអគ្គសញ្ញាជ្រមុជទឹក (កក ២,៣៨) យើងលះបង់អំពើអាក្រក់ និងទទួលការសង្គ្រោះ ពោលគឺយើងរួច ពីបាបទាំងអស់

និងទទួលព្រះអំណោយទាននៃជីវិតថ្មី។

១៤២៨- ក៏ប៉ុន្តែ ការត្រាស់ហៅរបស់ព្រះគ្រីស្តនៅតែលាន់ឮក្នុងការរស់នៅរបស់គ្រីស្តបរិស័ទ។ ការកែប្រែចិត្តគំនិតជាលើកទីពីរនេះ ជាកិច្ចការដែលមិនអាចផ្អាកបាន សម្រាប់ព្រះសហគមន៍ទាំងមូល ដែល "មានអ្នកបាបនៅក្នុងផ្ទៃ" ដូច្នេះ "ព្រះសហគមន៍វិសុទ្ធផង ត្រូវបន្សុទ្ធខ្លួនឯងផង" ហើយត្រូវតែខិតខំកែប្រែឲ្យបានថ្មីជានិច្ច" (LG ៨)។ ការខិតខំកែប្រែចិត្តគំនិតមិនគ្រាន់តែជាកិច្ចការរបស់មនុស្សទេ ប៉ុន្តែជាចលនានៃ "ចិត្តសោកស្ដាយ" (ទន ៥១,១៩) ដែលព្រះហឫទ័យប្រណីសន្ដោសទាក់ទាញ និងជំរុញ (យហ ៦,៤៤ ; ១២,៣២) ឲ្យកែប្រែ ដើម្បីឆ្លើយតបនឹងសេចក្ដីស្រឡាញ់ប្រកបដោយធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលបានស្រឡាញ់យើង (១យហ ៤,១០)។

១៤២៩- ក្រោយពីបានបដិសេធបីដងមិនព្រមទទួលស្គាល់ម្ចាស់របស់ខ្លួន សន្ត:សិលា ដែលកែប្រែចិត្តគំនិតផ្ដល់សក្ខីភាពថា ការកែប្រែចិត្តគំនិតមិនគ្រាន់តែជាកិច្ចការរបស់មនុស្សទេ គឺដោយសារព្រះយេស៊ូប្រកបដោយធម៌មេត្តាករុណាឥតព្រំដែន ទតឃើញលោក ៗស្រក់ទឹកភ្នែកសោកស្ដាយបាបរបស់ខ្លួន (លក ២២,៦១) ហើយក្រោយពីព្រះយេស៊ូមានព្រះជន្មថ្មី លោកក៏បានបញ្ជាក់ជាបីដងថា ស្រឡាញ់ព្រះអង្គ (យហ ២១,១៥-១៧)។ ការកែប្រែចិត្តគំនិតជាលើកទីពីរមានលក្ខណៈរួម ដែរ ដូចជាពេលដែលព្រះអម្ចាស់ត្រាស់ហៅព្រះសហគមន៍មួយទាំងមូល៖ "ចូរកែប្រែចិត្តគំនិត"" (វវ ២,៥.១៦)។

> និយាយអំពីការកែប្រែចិត្តគំនិតទាំងពីរ សន្ត: អំប្រ័រ មានប្រសាសន៍ថា នៅក្នុងព្រះសហគមន៍ "មានទឹក និងទឹកភ្នែក គឺទឹកនៃពិធីជ្រមុជទឹក និងទឹកភ្នែកនៃការសោកស្ដាយបាប"។

## ៤. ការសោកស្ដាយយ៉ាងពិតប្រាកដ

១៤៣០- ដូចចំពោះព្យាការីកាលពីមុន ព្រះយេស៊ូត្រាស់ហៅឲ្យកែប្រែចិត្តគំនិត និងសោកស្ដាយអំពើបាប មិនមែនដោយប្រព្រឹត្តកិច្ចការខាងក្រៅ ដូចជា "បាវកាន់ទុក្ខ និងផេះ" ការតមអាហារ និងការលត់ដំខ្លួនទេ ប៉ុន្តែដោយកែប្រែដល់ទីជម្រៅនៃចិត្តគំនិត ព្រមទាំងសោកស្ដាយបាបយ៉ាងពិតប្រាកដ ។ បើមិនកែប្រែចិត្តគំនិតយ៉ាងពិតប្រាកដទេ យើងក៏នៅតែកុហក និងមិនបានផលឡើយ ផ្ទុយទៅវិញ បើយើងកែប្រែចិត្តគំនិតយ៉ាងពិតប្រាកដ យើងបញ្ជាក់អាកប្បកិរិយានេះ ដោយបញ្ចេញសញ្ញាសម្គាល់អាចមើលឃើញ និងកិច្ចការដែលបង្ហាញថា យើងសោកស្ដាយអំពើបាបរបស់ខ្លួន (យហ ២,១២-១៣ ; អស ១,១៦-១៧ ; មថ ៦,១-៦.១៦-១៨)។

១៤៣១- ពេលយើងកែប្រែចិត្តគំនិតយ៉ាងពិតប្រាកដ យើងតម្រែតម្រង់ការរស់នៅរបស់យើងឡើងវិញ ទាំងស្រុង យើងត្រឡប់ទៅរកព្រះជាម្ចាស់វិញឲ្យអស់ពីចិត្ត យើងលែងប្រព្រឹត្តអំពើបាបនោះទៀត យើងស្អប់ខ្ពើមអំពើអាក្រក់ទាំងអស់ដែលយើងបានប្រព្រឹត្ត។ នៅពេលជាមួយគ្នានេះ យើងប៉ងប្រាថ្នា និងប្ដេជ្ញាចិត្តផ្លាស់ប្ដូរជីវិតដោយសង្ឃឹមលើធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ និងជឿទុកចិត្តថា ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គនឹងយាងមកជួយយើងផងដែរ។ ការកែប្រែចិត្តគំនិតយ៉ាងពិតប្រាកដនេះ នាំមកជាមួយនូវការឈឺចាប់ និងទុក្ខព្រួយ ដែលជាកិច្ចសង្គ្រោះយើង ដែលគ្រូបាធ្យាយហៅថា animi cruiatus (ទុក្ខព្រួយនៃវិញ្ញាណ) compunctio cordis (ចិត្តសោកស្ដាយ) (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៧៦-១៦៧៨ ; ១៧០៥ ; CR ២,៥,៤)។

១៤៣២- ចិត្តមនុស្សមានះ និងរឹងរូស។ ព្រះជាម្ចាស់ត្រូវតែប្រោសប្រទានឲ្យមនុស្សមានចិត្តគំនិតថ្មី (អគ ៣៦,២៦-២៧)។ ការកែប្រែចិត្តគំនិតមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ដែលប្រោសយើង

ឲ្យត្រឡប់មករកព្រះអង្គវិញ៖ "ព្រះអម្ចាស់អើយ" សូមនាំយើងខ្ញុំឲ្យវិលត្រលប់មកវិញ នោះយើងខ្ញុំនឹងវិលត្រឡប់មកវិញ" (សណ ៥,២១)។ ព្រះជាម្ចាស់ប្រោសប្រទានកម្លាំងឲ្យចាប់ផ្ដើមសាជាថ្មី។ ពេលយើងយល់ឃើញភាពថ្កុំថ្កើងនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ចិត្តគំនិតយើងជំទាស់នឹងអំពើបាបដែលគួរឲ្យស្អប់ខ្ពើម ហើយយើងចាប់ផ្ដើមញញើតពុំហ៊ានប្រឆាំងនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយប្រព្រឹត្តអំពើបាប និងឃ្លាតឆ្ងាយពីព្រះអង្គទៀតផង។ មនុស្សកែប្រែចិត្តគំនិត នៅពេលដែលមើលឃើញ អ្នកដែលអំពើបាបយើងបានចាក់ទម្លុះ (យហ ១៩,៣៧ ; សក ១២,១០)៖

> ចូរមើលឃើញព្រះលោហិតព្រះគ្រីស្ដ ហើយឈ្វេងយល់ឲ្យច្បាស់ថា ព្រះលោហិតនេះ មានតម្លៃដ៏លើសលប់ចំពោះព្រះបិតាព្រះអង្គ ដ្បិតដោយសារព្រះលោហិតបានត្រូវបង្ហូរដើម្បីសង្គ្រោះយើង ព្រះអង្គក៏បានទុកឲ្យពិភពលោកទាំងមូលកែប្រែចិត្តគំនិត ដោយព្រះហឫទ័យប្រណីសន្ដោស (សន្ដៈ ក្លេម៉ង់ នៅទៅក្រុងរ៉ូម)។

១៤៣៣- ចាប់តាំងពីបុណ្យចម្លង ព្រះវិញ្ញាណដ៏វិសុទ្ធ "បញ្ជាក់ឲ្យមនុស្សលោកដឹងថា គេយល់ខុសអំពីបាប" (យហ ១៦,៨-៩) ពោលគឺពិភពលោកមិនបានជឿលើអ្នកដែលព្រះបិតាបានចាត់ឲ្យមក។ ប៉ុន្តែ ព្រះវិញ្ញាណដដែលនេះ ដែលសម្ដែងនូវអំពើបាប ជាព្រះលួងលោម (យហ ១៥,២៦) ដែលព្រះហឫទ័យប្រណីសន្ដោសប្រទានឲ្យមនុស្សអាចសោកស្ដាយអំពើបាប និងអាចកែប្រែចិត្តគំនិតបាន (កក ២,៣៦-៣៨ ; សម្ដេចប៉ាបយ៉ូហាន ប៉ូលទី២ ; DV ២៧-៤៨)។

## ៥. របៀបផ្សេងៗនៃការសោកស្ដាយអំពើបាបក្នុងការរស់នៅជាគ្រីស្ដបរិស័ទ

១៤៣៤-គ្រីស្ដបរិស័ទអាចសោកស្ដាយអំពើបាបរបស់ខ្លួនតាមរបៀបខុសប្លែកពីគ្នា។ព្រះគម្ពីរ និងគ្រូបាធ្យាយសង្កត់លើចំណុចបី គឺការតមអាហារ ការអធិដ្ឋាន និងការធ្វើទាន (តប ១២,៨ ; មថ ៦,១-១៨) ដែលសម្ដែងនូវការកែប្រែចិត្តគំនិត ចំពោះខ្លួនឯង ចំពោះព្រះជាម្ចាស់ និងចំពោះអ្នកដទៃ។ ព្រះជាម្ចាស់បន្សុទ្ធយើងឲ្យបានពេញលេញ ពេលយើងទទួលពិធីជ្រមុជទឹក ឬពេលយើងស្លាប់ដូចជាមរណសាក្សី ប៉ុន្តែ ព្រះគម្ពីរ និងគ្រូបាធ្យាយបន្ថែមទៀតថា យើងអាចទទួលការលើកលែងទោសពេលយើងខិតខំស្រុះស្រួលជាមួយបងប្អូន ពេលយើងស្រក់ទឹកភ្នែកសោកស្ដាយអំពើបាបរបស់ខ្លួន ពេលយើងចង់ជួយសង្គ្រោះបងប្អូន (យក ៥,២០) នៅពេលដែលសន្ដៈបុគ្គលជួយអង្វរព្រះជាម្ចាស់សម្រាប់យើង ឬពេលយើងប្រព្រឹត្តតាមសេចក្ដីស្រឡាញ់ ដែល "រមែងគ្របបាំងអំពើបាបដ៏ច្រើនលើសលប់" (១ពត្រ ៤,៨)។

១៤៣៥- យើងកែប្រែចិត្តគំនិតក្នុងជីវិតប្រចាំថ្ងៃ ដោយស្រុះស្រួលគ្នា ដោយចង់រំដោះទុក្ខអ្នកក្រីក្រ ដោយការពារច្បាប់និងយុត្តិធម៌(អម ៥,២៤;អស ១,១៧)ដោយសារភាពភាពកំហុសចំពោះបងប្អូនដោយជួយកែលំអគ្នាទៅវិញទៅមក ដោយរំឭករបៀបរស់នៅឡើងវិញ ដោយពិនិត្យមនសិការ ដោយមានអ្នកជួយណែនាំវិញ្ញាណដោយសុខចិត្តរងទុក្ខលំបាក និងដោយស៊ូទ្រាំទទួលការបៀតបៀនដោយសារយុត្តិធម៌។ ពេលយើងលីឈើឆ្កាងជារៀងរាល់ថ្ងៃ ដើរតាមព្រះយេស៊ូ យើងដើរតាមផ្លូវនៃការលើកលែងទោសជាពុំខាន (លក ៩,២៣)។

១៤៣៦- អគ្គសញ្ញាអរព្រះគុណ និងការសោកស្ដាយអំពើបាបរបស់ខ្លួន។ ការកែប្រែចិត្តគំនិត និងការសោកស្ដាយអំពើបាបមានប្រភព និងចំណីអាហារចេញមកពីពិធីអរព្រះគុណ ពីព្រោះនៅក្នុងពិធីនេះ សក្ការបូជារបស់ព្រះគ្រីស្ដ ដែលបានសម្រុះសម្រួលយើងឲ្យជានានឹងព្រះជាម្ចាស់ មានវត្តមានសព្វថ្ងៃ។ ដោយសារពិធីនេះ អស់

អ្នកដែលរួបរួមជាមួយព្រះគ្រីស្តទទួលចំណីអាហារ និងកម្លាំង។ ពិធីអរព្រះគុណជា "ថ្នាំបន្សាប ដែលរំដោះយើងឲ្យរួចពីកំហុសប្រចាំថ្ងៃ និងជួយការពារយើងឲ្យចាកផុតពីការប្រព្រឹត្តអំពើបាបធ្ងន់" (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៣៨)។

១៤៣៧- ការអានព្រះគម្ពីរដ៏វិសុទ្ធ ការអធិដ្ឋានតាមពេលកំណត់ ការសូត្រធម៌ ឱព្រះបិតានៃយើងខ្ញុំ ឬពិធីណាមួយ ដោយមានចិត្តស្មោះ ជ្រមុញយើងឲ្យកែប្រែចិត្តគំនិត សោកស្ដាយអំពើបាបរបស់ខ្លួន និងជួយយើងឲ្យទទួលការអភ័យទោសពីអំពើបាបរបស់យើង។

១៤៣៨- វេលា និងថ្ងៃនៃការសោកស្ដាយអំពើបាប នៅឆ្នាំពិធីបុណ្យ (រាល់ថ្ងៃសុក្រនៃរដូវអប់រំពិសេស ដើម្បីសញ្ជឹងគិតដល់ព្រះយេស៊ូដែលបានសោយទិវង្គត) ជាវេលាដ៏ប្រសើរ ក្នុងព្រះសហគមន៍ ដើម្បីសោកស្ដាយអំពើបាប (SC ១០៩-១១០ ; CIC ១២៤៩-១២៥៣ ; CCEO ៨៨០-៨៨៣)។ ក្នុងវេលានោះ គួរប្រព្រឹត្តលំហាត់ខាងវិញ្ញាណ ពិធីលើកលែងទោស បូជនីយចរណ៍ ដើម្បីបង្ហាញថា យើងសោកស្ដាយអំពើបាប គួរស្ម័គ្រចិត្តតមអាហារ ធ្វើទាន ចែករំលែកទ្រព្យសម្បត្តិ (ដល់ជនក្រីក្រ ឬដើម្បីជួយប្រកាសដំណឹងល្អ)។

១៤៣៩- ព្រះយេស៊ូបានរៀបរាប់យ៉ាងអស្ចារ្យនូវចលនានៃការកែប្រែចិត្តគំនិត និងការសោកស្ដាយអំពើបាប ក្នុងពាក្យប្រស្នាអំពី "កូនវង្វេង" ដែល "ឪពុកពោរពេញដោយធម៌មេត្តាករុណា" ជាតួឯក (លក ១៥,១១-២៤)៖ កូនភ្លើតភ្លើននឹងសេរីភាពក្លែងក្លាយ លះបង់ផ្ទះឪពុក ជួបប្រទះនឹងទុក្ខវេទនាដ៏ខ្លាំងខ្លាក្រោយពីបានបំផ្លាញទ្រព្យសម្បត្តិអស់ កូនខ្មាស់គេណាស់ ពេលគាត់ត្រូវថែរក្សាជ្រូក ជាពិសេសពេលគាត់ចង់ចំអែតក្រពះនឹងចំណីដែលគេដាក់ឲ្យជ្រូកស៊ីនោះ គាត់រិះគិតក្នុងចិត្តអំពីម្ហូបអាហារហូហៀរដែលគាត់ធ្លាប់បរិភោគនៅផ្ទះឪពុក គាត់សោកស្ដាយអំពើបាប និងសម្រេចចិត្តទទួលស្គាល់កំហុសរបស់ខ្លួនចំពោះឪពុក គាត់ត្រឡប់មកវិញ ឪពុករាក់ទាក់ទទួលគាត់ដោយអំណរសប្បាយ៖ អ្វីៗទាំងអស់នោះជាលក្ខណៈពិសេសនៃការកែប្រែចិត្តគំនិត។ សំលៀកបំពាក់ល្អៗបំផុត ចិញ្ចៀន និងពិធីជប់លៀងជានិមិត្តរូបនៃជីវិតថ្មី បរិសុទ្ធ ពោរពេញដោយអំណរនេះ ជាជីវិតនៃមនុស្សដែលវិលត្រឡប់មករកព្រះជាម្ចាស់ និងក្រុមគ្រួសាររបស់ព្រះអង្គ ដែលជាព្រះសហគមន៍។ មានតែព្រះគ្រីស្ត ដែលស្គាល់ទីជម្រៅនៃសេចក្ដីស្រឡាញ់នៃព្រះបិតារបស់ព្រះអង្គ ដែលអាចសម្ដែងឲ្យយើងដឹងអំពីធម៌មេត្តាករុណាដ៏ជ្រាលជ្រៅជាទីបំផុត យ៉ាងសាមញ្ញ ៗ និងប្រកបដោយសោភណភាព។

## ៦. អគ្គសញ្ញាលើកលែងទោស និងសម្រុះសម្រួល

១៤៤០- ពេលយើងប្រព្រឹត្តអំពើបាប យើងធ្វើបាបព្រះជាម្ចាស់ និងឃ្លាតឆ្ងាយពីព្រះអង្គ។ ម្យ៉ាងទៀត យើងលែងរួបរួមជាមួយព្រះសហគមន៍។ ហេតុនេះ ហើយបានជាពេលយើងកែប្រែចិត្តគំនិត យើងទទួលការលើកលែងទោសពីព្រះជាម្ចាស់ និងស្រុះស្រួលជាមួយនឹងព្រះសហគមន៍។ អគ្គសញ្ញាលើកលែងទោសសម្ដែង និងសម្រេចការទាំងពីរនោះតាមពិធីបុណ្យ។

### មានតែព្រះជាម្ចាស់ទេ ដែលលើកលែងទោសឲ្យរួចពីបាប

១៤៤១- មានតែព្រះជាម្ចាស់ទេ ដែលអាចលើកលែងទោសឲ្យរួចពីបាប (មក ២,៧)។ ដោយសារព្រះ យេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ ព្រះអង្គមានព្រះពន្ធលអំពីព្រះអង្គផ្ទាល់៖ "បុត្រមនុស្សមានអំណាចលើកលែងទោសឲ្យមនុស្សនៅលើផែនដីនេះរួចពីបាបបាន" (មក ២,១០) ហើយព្រះអង្គប្រតិបត្តិតាមអំណាចរបស់ព្រះជាម្ចាស់នេះ៖ "ខ្ញុំអភ័យទោសឲ្យអ្នកបានរួចពីបាបហើយ"" (មក ២,៥ ; លក ៧,៤៨)។ លើសពីនេះទៅទៀត

ដោយសារព្រះអង្គប្រកបដោយអំណាចរបស់ព្រះជាម្ចាស់ ទ្រង់ក៏ប្រទានអំណាចនេះឲ្យមនុស្ស ដើម្បីឲ្យគេប្រតិបត្តិតាមក្នុងព្រះនាមព្រះអង្គ (យហ ២០,២១-២៣)។

១៤៤២- ព្រះគ្រីស្តសព្វព្រះហឫទ័យឲ្យព្រះសហគមន៍ទាំងមូល ក្នុងការអធិដ្ឋាន ការរស់នៅ និងក្នុងកិច្ចការជាសញ្ញាសម្គាល់ និងជាឧបករណ៍នៃការលើកលែងទោស និងការសម្រុះសម្រួល ដែលព្រះអង្គបានទទួលដោយបង្ហូរព្រះលោហិតព្រះអង្គ។ ក៏ប៉ុន្តែ ព្រះអង្គបានប្រគល់អំណាចនៃការលើកលែងទោសឲ្យក្រុម គ្រីស្តទូត។ ក្រុមនេះមាន "មុខងារសម្រុះសម្រួលមនុស្សម្នាឲ្យជានានឹងព្រះអង្គវិញ" (២ករ ៥,១៨)។ ព្រះអង្គចាត់គ្រីស្តទូតឲ្យទៅ "ក្នុងព្រះនាមព្រះគ្រីស្ត" ហើយតាមរយៈពួកលោក "ព្រះជាម្ចាស់ផ្ទាល់" ដាស់តឿន និងអង្វរ៖ "ទុកឲ្យព្រះជាម្ចាស់សម្រុះសម្រួលបងប្អូនឲ្យជានានឹងព្រះអង្គវិញ" (២ករ ៥,២០)។

## ការសម្រុះសម្រួលជាមួយនឹងព្រះសហគមន៍

១៤៤៣- នៅក្នុងជីវិតជាសាធារណៈរបស់ព្រះអង្គ ព្រះយេស៊ូមិនគ្រាន់តែលើកលែងទោសឲ្យរួចពីបាបប៉ុណ្ណោះទេ ថែមទាំងបានសម្តែងនូវផលនៃការលើកលែងទោសនេះ គឺព្រះអង្គបានបញ្ចូលអ្នកបាប ដែលបានឃ្លាតឆ្ងាយ ឬត្រូវដេញចេញ ឲ្យចូលក្នុងសហគមន៍នៃប្រជាជនរបស់ព្រះជាម្ចាស់វិញ។ ព្រះយេស៊ូប្រទានសញ្ញាសម្គាល់យ៉ាងច្បាស់អំពីការសម្រុះសម្រួលនេះ ដោយទទួលអ្នកបាបឲ្យរួមតុជាមួយព្រះអង្គ។ លើសពីនេះទៅទៀត ព្រះអង្គយាងមករួមតុជាមួយពួកគេ ដែលជាកាយវិការសម្តែងយ៉ាងអស្ចារ្យអំពីការលើកលែងទោសនៃព្រះជាម្ចាស់ (លក ១៥) និងការត្រឡប់មកវិញក្នុងប្រជាជនរបស់ព្រះជាម្ចាស់ (លក ១៩,៩)។

១៤៤៤- ដោយប្រគល់អំណាចរបស់ព្រះអង្គផ្ទាល់ ដល់ក្រុមគ្រីស្តទូតឲ្យលើកលែងទោសរួចពីបាប ព្រះអម្ចាស់ប្រទានអំណាចសម្រុះសម្រួលអ្នកបាបជាមួយព្រះសហគមន៍ឲ្យពួកលោកផងដែរ។ ព្រះបន្ទូល យ៉ាងឧឡារិករបស់ព្រះគ្រីស្តចំពោះលោកស៊ីម៉ូនសិលា សម្តែងលក្ខណៈពិសេសនៃមុខងារនេះរបស់ពួកលោក៖ "ខ្ញុំនឹងប្រគល់កូនសោព្រះរាជ្យនៃស្ថានបរមសុខឲ្យអ្នក។ អ្វីៗដែលអ្នកចងនៅលើផែនដីនេះ ព្រះជាម្ចាស់នឹងចងនៅស្ថានបរមសុខ ហើយអ្វីៗដែលអ្នកស្រាយនៅលើផែនដី ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថានបរមសុខដែរ" (មថ ១៦,១៩)។ "ព្រះអង្គដែលប្រទានឲ្យលោកសិលាមានបន្ទុកចងនិងស្រាយ ព្រះអង្គក៏បានប្រទានបន្ទុកនេះយ៉ាងពិតប្រាកដឲ្យក្រុមគ្រីស្តទូត ដែលរួមជាមួយមេដឹកនាំរបស់គេដែរ" (មថ ១៨,១៨ ; ២៨,១៦-២០) (LG ២២)។

១៤៤៥- ពាក្យចង និងស្រាយ មានន័យថា៖ នរណាដែលអ្នករាល់គ្នានឹងដេញពីការរួបរួមរបស់អ្នករាល់គ្នា អ្នកនោះក៏នឹងត្រូវដេញពីការរួបរួមជាមួយព្រះជាម្ចាស់ដែរ ឯនរណាដែលអ្នករាល់គ្នានឹងទទួលក្នុងការរួបរួមរបស់អ្នករាល់គ្នាឡើងវិញ ព្រះជាម្ចាស់ក៏នឹងទទួលអ្នកនោះឲ្យរួបរួមជាមួយព្រះអង្គដែរ។ ការសម្រុះសម្រួលជាមួយព្រះសហគមន៍មិនអាចបំបែកចេញពីការសម្រុះសម្រួលជាមួយនឹងព្រះជាម្ចាស់បានទេ ។

## អគ្គសញ្ញានៃការលើកលែងទោស

១៤៤៦- ព្រះគ្រីស្តបានតែងតាំងអគ្គសញ្ញាលើកលែងទោស សម្រាប់អ្នកបាបទាំងអស់របស់ព្រះសហគមន៍ព្រះអង្គ ជាពិសេសអស់អ្នកដែលបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ ដែលបានជ្រមុជទឹករួចហើយៗ ដែលបានបាត់បង់ព្រះអំណោយទាននៃអគ្គសញ្ញាជ្រមុជទឹក និងបានធ្វើឲ្យការរួបរួមក្នុងព្រះសហគមន៍ត្រូវរបួស។ អគ្គសញ្ញាលើកលែងទោសផ្តល់ឲ្យពួកគេអាចកែប្រែចិត្តគំនិត និងទទួលព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដែលប្រោសឲ្យទៅជាមនុស្សសុចរិតវិញ។ គ្រូបាធ្យាយព្រះសហគមន៍ថ្លែងអំពីអគ្គសញ្ញានេះ ដូចជា "ក្តារទីពីរ (សម្រាប់

សង្គ្រោះ) ក្រោយពីការលិចលង់ ដែលជាការបាត់បង់ព្រះអំណោយទាននៃព្រះហឫទ័យប្រណីសន្ដោស" (លោក ទែរទូលីយ៉ាំង)។

១៤៤៧- ពីសតវត្សមួយទៅសតវត្សមួយ របៀបដែលព្រះសហគមន៍បានអនុវត្តអំណាចដែលព្រះអម្ចាស់បានប្រោសប្រទាននេះ បានផ្លាស់ប្ដូរជាច្រើនលើកច្រើនសា។ ក្នុងអម្លុងសតវត្សដើម ការសម្រុះសម្រួលរបស់គ្រីស្ដបរិស័ទ ដែលបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរណាស់ ក្រោយពីបានជ្រមុជទឹក (ដូចជាការគោរពព្រះក្លែងក្លាយ បទសម្លាប់មនុស្ស ឬអំពើផិតក្បត់) ទាក់ទងនឹងវិន័យយ៉ាងតឹងរ៉ឹង គឺអ្នកបាបត្រូវតែសោកស្ដាយអំពើបាបរបស់ខ្លួនជាសាធារណៈ អស់រយៈពេលជាច្រើនឆ្នាំ មុននឹងអាចទទួលការលើកលែងទោស។ គេកម្រអាចចូលក្នុង "ក្រុមអ្នកបាប" ក្នុងតំបន់ខ្លះតែម្ដង ក្នុងមួយជីវិត (ដោយទាក់ទងនឹងអំពើបាបធ្ងន់ធ្ងរខ្លះតែប៉ុណ្ណោះ)។ នៅសតវត្សទីប្រាំពីរ ដោយមានការបញ្ជូនបន្តនៃវត្តអារាមខាងបូព៌ាប្រទេសជួយបំភ្លឺសាសនទូតជនជាតិអៀរឡង់ នៅទ្វីបអឺរ៉ុប ធ្វើឲ្យអ្នកបាបមិនបាច់ប្រព្រឹត្តកិច្ចការជាច្រើន យូរអង្វែង និងជាសាធារណៈ ដែលបង្ហាញថា អ្នកនោះសោកស្ដាយអំពើបាបរបស់ខ្លួន មុននឹងសម្រុះសម្រួលជាមួយនឹងព្រះសហគមន៍ទេ។ ចាប់ពីពេលនោះមក គេផ្ដល់អគ្គសញ្ញាតាមរបៀបលាក់សម្ងាត់រវាងអ្នកបាប និងលោកបូជាចារ្យ។ តាមការអនុវត្តរបៀបថ្មីនេះ យើងអាចផ្ដល់អគ្គសញ្ញានេះម្ដងទៀត និងបើកផ្លូវឲ្យយើងទទួលអគ្គសញ្ញានេះយ៉ាងទៀងទាត់។ ម៉្យាងទៀត យើងអាចបញ្ចូលក្នុង ពិធីតែមួយការលើកលែងទោសអំពើបាបធ្ងន់ធ្ងរ និងអំពើបាបស្រាលៗផងដែរ។ ព្រះសហគមន៍អនុវត្តអគ្គសញ្ញាលើកលែងទោសតាមរបៀបនេះរហូតដល់សព្វថ្ងៃ។

១៤៤៨- តាមរយៈការផ្លាស់ប្ដូរទាំងប៉ុន្មាននៃវិន័យ និងពិធីនៃអគ្គសញ្ញានេះ ពីសតវត្សមួយទៅសតវត្សមួយ យើងពិនិត្យឃើញរចនាសម្ព័ន្ធមូលដ្ឋានដដែល។ រចនាសម្ព័ន្ធនេះ មានចំណុចពីរសំខាន់ គឺសកម្មភាពរបស់មនុស្សដែលកែប្រែចិត្តគំនិត ក្រោមកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (ការសោកស្ដាយ ការសារភាព ការទូទាត់) ម៉្យាងទៀត ជាកិច្ចការរបស់ព្រះជាម្ចាស់ តាមរយៈព្រះសហគមន៍។ តាមរយៈលោកអភិបាល និងលោកបូជាចារ្យព្រះសហគមន៍ ដែលផ្ដល់ការ លើកលែងទោសក្នុងព្រះនាមព្រះយេស៊ូគ្រីស្ដ ហើយកំណត់នូវរបៀបទូទាត់) អង្វរសម្រាប់អ្នកបាប និងសោកស្ដាយអំពើបាបរួមជាមួយគេដែរ។ ហេតុនេះហើយ បានជាអ្នក បាបបានជាសះស្បើយ និងរួបរួមក្នុងព្រះសហគមន៍ឡើងវិញ។

១៤៤៩- ពិធីលើកលែងទោស ដែលយើងធ្លាប់ប្រើក្នុងព្រះសហគមន៍ខាងបស្ចិមប្រទេស បង្ហាញចំណុចសំខាន់ៗនៃអគ្គសញ្ញានេះ គឺព្រះបិតានៃធម៌មេត្តាករុណាជាប្រភពនៃការលើកលែងទោស ព្រះអង្គសម្រុះសម្រួលអ្នកបាបដោយសារបុណ្យចម្លងរបស់ព្រះបុត្រាព្រះអង្គ និងព្រះអំណោយទាននៃព្រះវិញ្ញាណព្រះអង្គ ហើយតាមរយៈការអធិដ្ឋាន និងមុខងាររបស់ព្រះសហគមន៍៖

> សូមព្រះបិតាជាអម្ចាស់បង្ហាញធម៌មេត្តាករុណាឲ្យអ្នកបានស្គាល់។ ដោយព្រះយេស៊ូជាព្រះបុត្រាបានសោយទិវង្គត និងមានព្រះជន្មថ្មី ព្រះបិតាបានសម្រុះសម្រួលមនុស្សលោកឲ្យជានានឹងព្រះអង្គ ទ្រង់ក៏បានចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមកដែរ ដើម្បីរួចពីបាប។ តាមរយៈព្រះសហគមន៍ សូមព្រះអង្គព្រះមេត្តាលើកលែងទោសឲ្យអ្នក និងប្រទានសេចក្ដីសុខសាន្តឲ្យអ្នកផងដែរ។ រីឯខ្ញុំវិញ ខ្ញុំសូមលើកលែងទោសឲ្យអ្នក ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

## ៧. កិច្ចការរបស់អ្នកបាប

១៤៥០- "ការលើកលែងទោសដូចជាបង្ខំអ្នកបាបឲ្យសុខចិត្តប្រតិបត្តិតាមចំណុចទាំងអស់ គឺមានចិត្តសោកស្ដាយ សារភាពដោយវាចា ហើយមានអាកប្បកិរិយាចេះបន្ទាបខ្លួន និងចង់ទូទាត់អំពើបាបរបស់ខ្លួន ដោយបង្កើតផលឲ្យបានច្រើន" ( CR ២,៥,២១ ; មហាសន្និបាតនៅទីក្រុងត្រង់ ៖ DS ១៦៧៣ ) ។

### ការសោកស្ដាយអំពើបាប

១៤៥១- ក្នុងចំណោមកិច្ចការរបស់អ្នកបាប ការសោកស្ដាយបាបសំខាន់ជាងគេ។ "ព្រលឹងអ្នកសោកស្ដាយឈឺចាប់ និងស្អប់អំពើបាបដែលខ្លួនបានប្រព្រឹត្ត ព្រមទាំងប្ដេជ្ញាចិត្តមិនប្រព្រឹត្តអំពើបាប ក្នុងអនាគតទៀតទេ" ( មហាសន្និបាតនៅទីក្រុងត្រង់ ៖ DS ១៦៧៦ ) ។

១៤៥២-កាលបើការសោកស្ដាយបណ្ដាលមកពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលយើងស្រឡាញ់លើសអ្វីៗទាំងអស់ គេហៅថា "គ្រប់លក្ខណៈ" (ការសោកស្ដាយនៃសេចក្ដីស្រឡាញ់)។ ការសោកស្ដាយនេះលើកលែងទោសពីអំពើបាបស្រាលៗ ហើយអាចផ្ដល់ការលើកលែងទោសនៃអំពើបាបធ្ងន់ធ្ងរ បើយើងប្ដេជ្ញាចិត្តចង់ទទួលអគ្គសញ្ញាលើកលែងទោសយ៉ាងឆាប់រហ័ស ( មហាសន្និបាតនៅទីក្រុងត្រង់ ៖ DS ១៦៧៧ ) ។

១៤៥៣-ការសោកស្ដាយ "មិនគ្រប់លក្ខណៈ" ក៏ជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ដែរ ដោយព្រះវិញ្ញាណដ៏វិសុទ្ធជំរុញ។ ការសោកស្ដាយនេះ មកពីយើងគិតថា អំពើបាបគួរស្អប់ខ្ពើម ឬយើងខ្លាចធ្លាក់ឋាននរក ឬយើងខ្លាចទទួលបាបកម្ម (យើងសោកស្ដាយព្រោះយើងខ្លាច)។ វិបត្តិដ៏ខ្លាំងខ្លានៃមនសិការនេះ អាចផ្ដើមឲ្យមានការវិវត្តិន៍ខាងផ្លូវចិត្ត ដែលកិច្ចការនៃព្រះហឫទ័យប្រណីសន្ដោសនឹងបង្ហើយ ដោយទទួលអគ្គសញ្ញាលើកលែងទោស។ ការសោកស្ដាយមិនគ្រប់លក្ខណៈនេះ មិនអាចផ្ដល់ការលើកលែងទោសឲ្យរួចពីបាបធ្ងន់ធ្ងរទេ ប៉ុន្តែជួយឲ្យរៀបចំខ្លួនទទួលការលើកលែងទោសនេះ ក្នុងអគ្គសញ្ញា ( មហាសន្និបាតនៅទីក្រុងត្រង់ ៖ DS ១៦៧៨ ) ។

១៤៥៤-គួររៀបចំខ្លួនទទួលអគ្គសញ្ញានេះ ដោយរិះគិតពិចារណា ក្រោមពន្លឺនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ការអប់រំខាងសីលធម៌នៃដំណឹងល្អ និងលិខិតផ្សេងៗរបស់គ្រីស្ដទូត ផ្ដល់អត្ថបទជាច្រើន ដែលអាចជួយយើងបានមានដូចជា សុន្ទរកថានៅលើភ្នំ ឬការប្រៀនប្រដៅរបស់ក្រុមគ្រីស្ដទូត (រម ១២១៥-១ករ ១២-១៣; កាឡ ៥; អភ ៤-៦)។

### ការសារភាពបាប

១៤៥៥-ជាធម្មតា យើងអាចយល់ឃើញថា ការសារភាពបាបរំដោះយើង និងជួយយើងឲ្យសម្រុះស្រួលជាមួយនឹងអ្នកដទៃ។ ដោយសារភាព មនុស្សប្រឈមមុខនឹងអំពើបាប ដែលខ្លួនបានប្រព្រឹត្ត គេទទួលការខុសត្រូវ ទើបគេបើកចិត្តឲ្យព្រះជាម្ចាស់ និងការរួបរួមក្នុងព្រះសហគមន៍ឡើងវិញ ដើម្បីឲ្យមានអនាគតថ្មី។

១៤៥៦-ការសារភាពចំពោះលោកបូជាចារ្យម្នាក់ ជាចំណុចដ៏សំខាន់ នៃអគ្គសញ្ញាលើកលែងទោស ៖ "ពេលសារភាព អ្នកបាបត្រូវរៀបរាប់អំពើបាបធ្ងន់ធ្ងរទាំងអស់ ដែលគេដឹងខ្លួន ក្រោយពីបានរិះគិតពិចារណាយ៉ាងត្រឹមត្រូវ ទោះបីជាអំពើបាបនោះគ្មាននរណាដឹងសោះក៏ដោយ ហើយទោះបីគេបានប្រព្រឹត្តបាបប្រឆាំងនឹងវិន័យទាំងពីរចុងក្រោយនៃវិន័យដប់ប្រការតែប៉ុណ្ណោះក៏ដោយ ( សរ ២០,១៧; មថ ៥,២៨ ) ដ្បិតជួនកាលអំពើបាបនោះធ្វើឲ្យព្រលឹងរបួស និងគ្រោះថ្នាក់ច្រើនជាងអំពើបាបដែលយើងបានប្រព្រឹត្តចំពោះមុខអ្នកដទៃ" (មហាសន្និបាត

នៅទីក្រុងត្រង់៖ DS ១៦៨០)៖

> នៅពេលដែលគ្រីស្តបរិស័ទខិតខំសារភាពអំពើបាបទាំងអស់ ដែលពួកគេនឹកគិតដល់ យើងមិនអាចសង្ស័យថា ពួកគេយកអំពើបាបទាំងនោះទៅថ្វាយចំពោះធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ អស់អ្នកដែលប្រព្រឹត្តតាមរបៀបផ្សេង ហើយមានបំណងលាក់អំពើបាបខ្លះ ព្រះហឫទ័យដ៏សប្បុរសរបស់ព្រះជាម្ចាស់ក៏មិនអាចដកអ្វីតាមរយៈលោកបូជាចារ្យបានឡើយ ដ្បិត "បើអ្នកជំងឺអៀមខ្មាស់បង្ហាញដំបៅរបស់ខ្លួនឲ្យលោកគ្រូពេទ្យឃើញ លោកមិនអាចព្យាបាលអ្វីដែលលោកមិនដឹងទេ" (សន្តៈ យេរ៉ូម; មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៨០)។

១៤៥៧-តាមច្បាប់ព្រះសហគមន៍ "គ្រីស្តបរិស័ទណាដែលដល់អាយុចេះដឹងខ្លួនត្រូវសារភាពអំពើបាបធ្ងន់ធ្ងរដែលខ្លួនដឹង យ៉ាងហោចណាស់មួយឆ្នាំម្តង" (DS ១៦៨៣, ១៧០៨)។ អ្នកដែលដឹងខ្លួនថា បានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ មិនអាចទទួលព្រះកាយដ៏វិសុទ្ធរបស់ព្រះគ្រីស្ត ដោយមិនបានទទួលអគ្គសញ្ញាលើកលែងទោសបានទេ ទោះបីអ្នកនោះសោកស្តាយអំពើបាបខ្លាំងយ៉ាងណាក៏ដោយ លើកលែងតែមានមូលហេតុសំខាន់ៗដើម្បីទទួលព្រះកាយព្រះគ្រីស្ត ហើយគេមិនអាចជួបលោកបូជាចារ្យ (CIC ៩១៦; CCEO ៧១១)។ កូនក្មេងត្រូវទទួលអគ្គសញ្ញាលើកលែងទោស មុននឹងទទួលព្រះកាយដ៏វិសុទ្ធរបស់ព្រះគ្រីស្តជាលើកទីមួយ (CIC ៩១៤)។

១៤៥៨-ព្រះសហគមន៍ផ្តែផ្តាំឲ្យសារភាពអំពើបាបប្រចាំថ្ងៃ (អំពើបាបស្រាលៗ) ទោះបីជាការមិនចាំបាច់ក៏ដោយ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៨០; CIC ៩៨៨,២)។ តាមការពិត ការសារភាពបាបស្រាលៗយ៉ាងទៀងទាត់ជួយយើងឲ្យអប់រំមនសិការរបស់ខ្លួន ប្រយុទ្ធប្រឆាំងនឹងកិលេសតណ្ហា ទុកឲ្យព្រះគ្រីស្តព្យាបាលយើង ដើម្បីឲ្យមានការរីកចម្រើនកនៃជីវិតខាងវិញ្ញាណ។ ដោយឧស្សាហ៍ទទួលព្រះអំណោយទាននៃធម៌មេត្តាករុណារបស់ព្រះបិតាតាមរយៈអគ្គសញ្ញានេះ ព្រះអង្គក៏ជំរុញយើងឲ្យមានចិត្តមេត្តាករុណាដូចព្រះអង្គផងដែរ (លក ៦,៣៦)៖

> អ្នកដែលសារភាពអំពើបាបរបស់ខ្លួន គឺបានសហការជាមួយព្រះជាម្ចាស់រួចហើយ។ ព្រះជាម្ចាស់ចោទប្រកាន់អំពើបាបរបស់អ្នក បើអ្នកចោទប្រកាន់អំពើបាបនោះដែរ គឺអ្នកចូលរួមជាមួយព្រះជាម្ចាស់។ ដូច្នេះគេអាចនិយាយថា មនុស្ស និងអ្នកបាប ជាតថភាពពីរ ពោលគឺពេលអ្នកព្គេនិយាយអំពីមនុស្សនោះ ព្រះជាម្ចាស់ជាអ្នកធ្វើ ពេលអ្នកព្គេនិយាយអំពីអ្នកបាប នោះមនុស្សជាអ្នកធ្វើ។ ចូរបំផ្លាញអ្វីៗដែលអ្នកបានធ្វើ ដើម្បីឲ្យព្រះជាម្ចាស់សង្គ្រោះអ្វីៗដែលព្រះអង្គបានធ្វើ (...)។ ពេលអ្នកផ្តើមស្អប់អ្វីដែលអ្នកបានធ្វើ នោះកិច្ចការដ៏ល្អរបស់អ្នកចាប់ផ្តើមហើយ ដ្បិតអ្នកចោទប្រកាន់កិច្ចការដ៏អាក្រក់របស់អ្នក។ យើងចាប់ផ្តើមប្រព្រឹត្តកិច្ចការដ៏ល្អ គឺយើងសារភាពកិច្ចការដ៏អាក្រក់។ អ្នកប្រព្រឹត្តតាមសេចក្តីពិតនោះ អ្នកនឹងចូលមកក្នុងពន្លឺ (សន្តៈ អូគូស្តាំង)។

## ការទូទាត់

១៤៥៩-អំពើបាបជាច្រើនធ្វើឲ្យអ្នកដទៃខូចខាត។ ត្រូវតែព្យាយាមទូទាត់អំពើបាបនោះ (ឧទាហរណ៍ សងអ្វីដែលយើងបានលួច លើកកិត្តិយសរបស់អ្នកដែលត្រូវនិយាយបង្កាច់ឡើងវិញ ព្យាបាលមុខរបួស)។ យុត្តិធម៌ទាមទារការទូទាត់នេះ។ លើសពីនេះទៅទៀត អំពើបាបធ្វើឲ្យអ្នកបាបផ្ទាល់ត្រូវរបួស និងធ្លាក់ទន់ខ្សោយ ព្រមទាំងទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងអ្នកដទៃផងដែរ។ ការលើកលែងទោសដកអំពើបាបចេញ ប៉ុន្តែមិនអាចដោះ

ស្រាយបញ្ហាទាំងអស់ ដែលបណ្តាលមកពីអំពើបាបនោះបានទេ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៧១២)។ ពេលងើបពីអំពើបាបមកវិញ អ្នកបាបត្រូវមានសុខភាពខាងវិញ្ញាណឡើងវិញ។ ដូច្នេះ គេត្រូវធ្វើអ្វីមួយទៀត ដើម្បីជួសជុលអំពើបាបរបស់ខ្លួន គឺគេត្រូវ "ទូទាត់" តាមរបៀបត្រឹមត្រូវ ឬ "ជុសជួល" អំពើបាបរបស់ខ្លួន។ គេហៅការទូទាត់នេះថា "ការទទួលទោស" ដែរ។

១៤៦០-ពេលលោកបូជាចារ្យបង្ខំឲ្យទទួលទោស លោកត្រូវតែយកចិត្តទុកដាក់នឹងស្ថានភាពរបស់អ្នកបាប ព្រមទាំងព្យាយាមឲ្យគេរីកចម្រើនខាងវិញ្ញាណផងដែរ។ ការទទួលទោសនេះ ត្រូវសមស្របនឹងលក្ខណៈនៃបាប ដែលគេបានប្រព្រឹត្ត។ យើងអាចអធិដ្ឋាន ថ្វាយតង្វាយមួយ ជួយអ្នកក្រីក្រ ឬអ្នកជំងឺ បម្រើអ្នកដទៃ ស្ម័គ្រចិត្ត តមអាហារ ធ្វើយញ្ញបូជា ជាពិសេសសុខចិត្តលីឈើឆ្កាងដោយចិត្តអត់ធ្មត់។ ការទទួលទោសទាំងអស់បែបនេះ ជួយយើងឲ្យរួបរួមជាមួយព្រះគ្រីស្ត ពីព្រោះមានតែព្រះអង្គទេ ដែលបានទទួលទោសសម្រាប់បាបរបស់យើង (រម ៣,២៥; ១យហ ២,១-២) ម្តងជាការស្រេច។ ទោសទាំងអស់នោះធ្វើឲ្យយើងអាចទទួលមរតករួមជាមួយព្រះគ្រីស្ត ដែលមានព្រះជន្មថ្មី "ដ្បិតយើងរងទុក្ខលំបាករួមជាមួយព្រះអង្គដែរ" (រម ៨,១៧) (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៩០)៖

> ប៉ុន្តែ យើងទូទាត់អំពើបាបរបស់ខ្លួនតែតាមរយៈព្រះយេស៊ូគ្រីស្តប៉ុណ្ណោះ៖ គិតអំពីខ្លួនឯង យើងមិនអាចធ្វើអ្វីដោយខ្លួនឯងបានទេ គឺ "យើងអាចធ្វើបានទាំងអស់រួមជាមួយព្រះអង្គ ដែលជាអ្នកប្រទានកម្លាំងឲ្យយើង" (ភីល ៤,១៣)។ ហេតុនេះ មនុស្សគ្មានអ្វីដែលអាចលើកតម្កើងខ្លួនឯង ប៉ុន្តែ "សិរីរុងរឿង" ទាំងអស់របស់យើងស្ថិតនៅក្នុងអង្គព្រះគ្រីស្ត (...) យើងទូទាត់ក្នុងអង្គព្រះអង្គ ដោយ "ប្រព្រឹត្តអំពើល្អ ដើម្បីបញ្ជាក់ថា (យើង) បានកែប្រែចិត្តគំនិត" (លក ៣,៨)។ អំពើល្អទាំងនោះ មានកម្លាំងមកពីព្រះគ្រីស្ត យើងថ្វាយអំពើល្អនោះចំពោះព្រះបិតាតាមរយៈព្រះគ្រីស្ត ហើយព្រះបិតាគាប់ព្រះហឫទ័យនឹងតង្វាយនោះ ដោយសារព្រះគ្រីស្តផងដែរ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៩១)។

## ៨-អ្នកមានមុខងារផ្តល់អគ្គសញ្ញានេះ

១៤៦១-ដោយសារព្រះគ្រីស្តបានប្រគល់មុខងារសម្រុះសម្រួលឲ្យក្រុមគ្រីស្តទូត (យហ ២០,២៣; ២ករ ៥,១៨) លោកអភិបាល ជាអ្នកបន្តមុខងារនេះ ហើយពួកបូជាចារ្យ ជាសហការីរបស់លោក បន្តបម្រើមុខងារនេះតទៅទៀត។ តាមការពិត ដោយសារអគ្គសញ្ញាតែងតាំង លោកអភិបាល និងលោកបូជាចារ្យមានអំណាចលើកលែងទោសអំពើបាបទាំងអស់ "ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"។

១៤៦២-ការលើកលែងទោសស្រុះស្រួលអ្នកបាបជាមួយនឹងព្រះជាម្ចាស់ និងជាមួយព្រះសហគមន៍ផងដែរ។ តាំងពីបុរាណកាលមក គេចាត់ទុកយ៉ាងត្រឹមត្រូវលោកអភិបាល ជាប្រធានដែលអាចមើលឃើញនៃព្រះសហគមន៍ភូមិភាគថា ជាអ្នកមានអំណាច និងមុខងារសម្រុះសម្រួល៖ លោកជាអ្នកសម្រុះសម្រួលនៃវិន័យនៃការលើកលែងទោស (LG ២៦)។ បូជាចារ្យជាសហការីរបស់លោក មានអំណាចនេះ លុះត្រាតែពួកលោកបានទទួលបន្ទុកពីលោកអភិបាល (ឬពីមេក្រុមគ្រួសារបព្វជិត) ឬពីសម្តេចប៉ាប តាមច្បាប់ព្រះសហគមន៍ (CIC ៨៤៤; ៩៦៧-៩៦៩; ៩៧២; CCEO ៧២២,៣-៤)។

១៤៦៣-អំពើបាបខ្លះធ្ងន់ធ្ងរណាស់អាចនាំឲ្យមានការបណ្តេញចេញពីព្រះសហគមន៍ ដែលជាទោសធ្ងន់ជាងគេក្នុងព្រះសហគមន៍ ដែលឃាត់មិនឲ្យទទួលអគ្គសញ្ញា និងសិទ្ធិខ្លះក្នុងព្រះសហគមន៍ ហើយដែលមានតែសម្តេចប៉ាប

លោកអភិបាលភូមិភាគ និងលោកបូជាចារ្យដែលបានទទួលការអនុញ្ញាតទេ ដែលអាចផ្តល់ការលើកលែងទោសបាន (CIC ១៣៣១; ១៣៥៤-១៣៥៧; CCEO ១៤៣១; ១៤៣៤; ១៤២០)។ បើមានគ្រោះថ្នាក់ដល់ជីវិតលោកបូជាចារ្យណាម្នាក់ ទោះបីគ្មានសិទ្ធិផ្តល់អគ្គសញ្ញាលើកលែងទោសក៏ដោយ ក៏អាចលើកលែងទោសទាំងប៉ុន្មាន (CIC ៩៧៦; CCEO ៧២៥) និងទទួលយកអ្នកបាបឲ្យចូលក្នុងព្រះសហគមន៍ឡើងវិញបានដែរ។

១៤៦៤-លោកបូជាចារ្យត្រូវលើកទឹកចិត្តគ្រីស្តបរិស័ទឲ្យទទួលអគ្គសញ្ញាលើកលែងទោស ព្រមទាំងមានពេលទំនេរផ្តល់អគ្គសញ្ញានេះ រាល់ពេលគ្រីស្តបរិស័ទសូមទទួលអគ្គសញ្ញានេះ តាមរបៀបសមគួរ (CIC ៩៨៦; CCEO ៧៣៥; PO ១៣)។

១៤៦៥-ក្នុងពេលដែលផ្តល់អគ្គសញ្ញាលើកលែងទោស លោកបូជាចារ្យបំពេញមុខងារជាគង្វាលដ៏សប្បុរសដែលស្វែងរកកូនចៀមវង្វេង ឬជាជនជាតិសាម៉ារីដ៏ល្អ ដែលរុំរបួស ឬជាបិតាដែលរង់ចាំកូនវង្វេង ទទួលយ៉ាងរាក់ទាក់ ពេលកូនត្រឡប់មកវិញ ឬជាចៅក្រមដ៏សុចរិតដែលមិនកាន់ជើងនរណាម្នាក់ ហើយដែលវិនិច្ឆ័យតាមរបៀបត្រឹមត្រូវ និងប្រកបទៅដោយធម៌មេត្តាករុណាផង។ និយាយឲ្យខ្លីទៅ លោកបូជាចារ្យជាសញ្ញាសម្គាល់ និងជាឧបករណ៍នៃសេចក្តីស្រឡាញ់ពោរពេញទៅដោយធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះអ្នកបាប។

១៤៦៦-លោកបូជាចារ្យដែលផ្តល់អគ្គសញ្ញាលើកលែងទោសមិនមែនជាគ្រូទេ គឺលោកជាអ្នកបម្រើនៃការលើកលែងទោសដែលមកពីព្រះជាម្ចាស់។ អ្នកទទួលមុខងារផ្តល់អគ្គសញ្ញានេះត្រូវរួមចិត្តគំនិតនឹងគោលបំណង និងសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត (PO ១៣)។ លោកត្រូវតែស្គាល់ឲ្យច្បាស់អាកប្បកិរិយារបស់គ្រីស្តបរិស័ទមានបទពិសោធន៍ចំពោះបញ្ហារបស់មនុស្ស ចេះគោរពថ្នាក់ថ្នមអ្នកបាប លោកក៏ត្រូវស្រឡាញ់សេចក្តីពិត ស្មោះត្រង់នឹងក្រុមដឹកនាំព្រះសហគមន៍ ហើយណែនាំអ្នកបាបឲ្យជាសះស្បើយ និងឲ្យគេចាស់ទុំយ៉ាងពេញលេញ ដោយអំណត់។ លោកត្រូវអធិដ្ឋាន និងសោកស្តាយបាបចំពោះអ្នកបាប ដោយអង្វរធម៌មេត្តាករុណារបស់ព្រះអម្ចាស់។

១៤៦៧-បូជាចារ្យដែលបំពេញមុខងារដ៏ប្រសើរនេះ ត្រូវចេះថ្នាក់ថ្នម ព្រមទាំងគោរពមនុស្ស ព្រះសហគមន៍ប្រកាសថា លោកបូជាចារ្យណាម្នាក់ ដែលផ្តល់អគ្គសញ្ញាលើកលែងទោស ត្រូវតែរក្សាការសម្ងាត់ជាដាច់ខាតអំពីអំពើបាបដែលអ្នកបាបបានសារភាព បើពុំដូច្នោះទេ ត្រូវទទួលទោសដ៏ធ្ងន់ធ្ងរណាស់ (CIC ១៣៨៨,១; CCEO ១៤៥៦)។ ម្យ៉ាងទៀត លោកមិនអាចប្រើចំណេះដឹងអំពីការរស់នៅរបស់អ្នកបាបទេ។ គេហៅសម្ងាត់ ដែលគ្មានករណីលើកលែងនោះ ថាជា "ត្រានៃអគ្គសញ្ញា" ពីព្រោះអគ្គសញ្ញា "បោះត្រា" ពីលើអ្វីៗដែលអ្នកបាបបានសារភាពចំពោះលោកបូជាចារ្យ។

## ៩-ផលនៃអគ្គសញ្ញានេះ

១៤៦៨-"ការលើកលែងទោសមានប្រសិទ្ធភាពបញ្ចូលយើង ក្នុងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ឡើងវិញ និងបង្រួបបង្រួមយើងជាមួយព្រះអង្គដូចជាមិត្តសម្លាញ់ពីរនាក់" (CR ២,៥,១៨)។ អគ្គសញ្ញានេះមានគោលដៅ និងបង្កើតផលជាការសម្រុះសម្រួលជាមួយព្រះជាម្ចាស់។ ចំពោះអស់អ្នកដែលទទួលអគ្គសញ្ញាលើកលែងទោស ដោយមានចិត្តសោកស្តាយ "នឹងមានអារម្មណស្ងប់ និងមនសិការល្អ ហើយព្រះជាម្ចាស់នឹងលួងលោមចិត្តគេយ៉ាងខ្លាំង" (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៧៤)។ តាមការពិត អគ្គសញ្ញាសម្រុះសម្រួលជាមួយព្រះជាម្ចាស់ពិតជានាំឲ្យ "វិញ្ញាណមានជីវិតថ្មី" ផ្តល់សេចក្តីថ្លៃថ្នូរ និងផលដ៏ល្អនៃជីវិតរបស់បុត្រធីតាព្រះជាម្ចាស់ ជាពិសេសមេត្រីភាពជាមួយព្រះជាម្ចាស់។

១៤៦៩-អគ្គសញ្ញានេះសម្រុះសម្រួលយើងជាមួយនឹងព្រះសហគមន៍។ អំពើបាបទម្លុះ ឬបំបែកការរួបរួមគ្នាជាបងប្អូន។ អគ្គសញ្ញាលើកលែងទោសជួសជុល ឬកែលំអការរួបរួមគ្នានេះឡើងវិញ។ តាមអត្ថន័យនេះ អគ្គសញ្ញានេះមិនគ្រាន់តែព្យាបាលអ្នកដែលចូលក្នុងសហគមន៍ឡើងវិញប៉ុណ្ណោះទេ ថែមទាំងបង្កើតផលដ៏រស់រវើក លើព្រះសហគមន៍ដែលត្រូវរបួសដោយសារបាបនៃសមាជិកម្នាក់របស់ខ្លួនទៀតផង (១ករ ១២,២៦)។ អ្នកបាបដែលត្រូវបានលើកលែងទោស ហើយចូលរួបរួមក្នុងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយឡើងវិញ ដោយផ្លាស់ប្តូរសេចក្តីល្អខាងវិញ្ញាណរវាងសមាជិកទាំងអស់នៃព្រះកាយព្រះគ្រីស្ត ទោះជានៅធ្វើបូជនីយេសចរណ៍ ឬនៅក្នុងមាតុភូមិនៃស្ថានបរមសុខហើយក៏ដោយ ក៏អគ្គសញ្ញានេះពង្រឹងអ្នកបាបដែរ (LG ៤៨-៤៩)។

ត្រូវរំឭកថា ការសម្រុះសម្រួលជាមួយព្រះជាម្ចាស់បង្កើតផលម្យ៉ាងដូចជា ការសម្រុះសម្រួលផ្សេងទៀតនឹងព្យាបាលការបាក់បែកផ្សេងៗដែលមកពីអំពើបាប។ អ្នកបាបសម្រុះសម្រួលជាមួយនឹងខ្លួនឯងក្នុងជម្រៅចិត្តគេទទួលយកសេចក្តីពិតផ្នែកខាងក្នុងឡើងវិញ គេសម្រុះសម្រួលជាមួយបងប្អូនដែលគេបានប្រមាថ ឬបញ្ឈឺចិត្តគេ សម្រុះសម្រួលជាមួយព្រះសហគមន៍ គេសម្រុះសម្រួលជាមួយពិភពលោកទាំងមូល (RP ៣១)។

១៤៧០-ក្នុងអគ្គសញ្ញានេះ ដោយអ្នកបាបពឹកផ្អែកលើធម៌មេត្តាករុណាលើព្រះជាម្ចាស់ គេរៀបចំទុកជាមុនការវិនិច្ឆ័យ ម្យ៉ាងដែលគេនឹងទទួលនៅពេលចុងក្រោយបំផុត។ ដ្បិតគឺពេលនេះ ក្នុងលោកនេះហើយ ដែលយើងអាចជ្រើសរើសរវាងជីវិត និងសេចក្តីស្លាប់ ហើយមានតែដើរតាមមាគ៌ានៃការកែប្រែចិត្តគំនិតទេ ទើបយើងអាចចូលក្នុងព្រះរាជ្យបាន លើកលែងតែមានអំពើបាបធ្ងន់ធ្ងរប៉ុណ្ណោះ (១ករ ៥,១១; កាឡ ៥,១៩-២១; វវ ២២,១៥)។ ដោយកែប្រែចិត្តគំនិតធ្វើជីវិតលើព្រះគ្រីស្ត អ្នកបាបឆ្លងពីសេចក្តីស្លាប់ទៅរកជីវិត ហើយ "មិនត្រូវទទួលទោសឡើយ" (យហ ៥,២៤)។

## ១០-បុណ្យកុសលសម្រាប់អនុគ្រោះ

១៤៧១-លទ្ធិ និងការអនុវត្តន៍បុណ្យកុសលសម្រាប់អនុគ្រោះក្នុងព្រះសហគមន៍ទាក់ទងយ៉ាងស្និទ្ធស្នាលជាមួយនឹងផលនៃអគ្គសញ្ញាលើកលែងទោស។

### អ្វីទៅជាបុណ្យកុសលសម្រាប់អនុគ្រោះ?

"ដោយសារបុណ្យកុសលសម្រាប់អនុគ្រោះ ព្រះសហគមន៍លើកទោសក្នុងលោកនេះនៃអំពើបាប ដែលកំហុសបានត្រូវលុបរួចហើយ។ គ្រីស្តបរិស័ទអាចទទួលការលើកលែងទោសនេះ តាមល័ក្ខខ័ណ្ឌផ្សេងៗ ដោយសារអំណាចនៃព្រះសហគមន៍ ដែលមានឋានៈជាអ្នកផ្តល់ការលើកទោសនេះ ចែក និងអនុវត្តកំណប់នៃការទូទាត់របស់ព្រះគ្រីស្ត និងសន្តបុគ្គល"។

"បុណ្យកុសលនោះអាចរំដោះទោសនៃអំពើបាបក្នុងលោកនេះបានមួយផ្នែក ឬទាំងស្រុង"។ យើងអាចផ្តល់បុណ្យកុសលនោះសម្រាប់អ្នករស់ ឬអ្នកស្លាប់ (សម្តេចប៉ាប ប៉ូលទី៦)។

### ទោសនៃអំពើបាប

១៤៧២-ដើម្បីយល់អំពីលទ្ធិនេះ និងការអនុវត្តន៍នៃព្រះសហគមន៍ ត្រូវតែយល់ថា អំពើបាបមានផលវិបាកពីរ។ អំពើបាបធ្ងន់ធ្ងរធ្វើឲ្យយើងឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ទើបយើងមិនអាចទទួលជីវិតអស់កល្បជានិច្ចបានទេ។ គេហៅផលវិបាកនេះថាជា "ទោសអស់កល្បជានិច្ច" នៃអំពើបាប។ ម្យ៉ាងទៀត អំពើបាបណា ទោះជាស្រាលក្តី នាំយើង

ឲ្យជាប់ចំណងនឹងសត្វលោក ដែលត្រូវបន្សុទ្ធទាំងក្នុងលោកនេះ ឬនៅពេលស្លាប់ក្នុងស្ថានភាពដែលគេហៅថា កិច្ចជម្រះឲ្យបានវិសុទ្ធ។ ការបន្សុទ្ធនេះ រំដោះយើងឲ្យរួចពីអ្វីដែលគេហៅថា "ទោសក្នុងលោកនេះ" នៃអំពើបាប។ យើងមិនត្រូវគិតថា ព្រះជាម្ចាស់សងសឹកដោយដាក់ទោសទាំងពីនោះទេ ប៉ុន្តែទោសទាំងពីរនោះបណ្ដាលកើតចេញមកពីអំពើបាបផ្ទាល់តែម្ដង។ ការកែប្រែចិត្តគំនិតដោយក្ដីស្រឡាញ់យ៉ាងពិតប្រាកដអាចបន្សុទ្ធអ្នកបាបឲ្យពេញលេញ ទើបគ្មានទោសណាមួយនៅសេសសល់ទៀតទេ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៧១២-១៧១៣; ១៨២០)។

១៤៧៣-ការលើកលែងទោសឲ្យរួចពីបាប និងការរួបរួមជាមួយព្រះជាម្ចាស់ឡើងវិញ បណ្ដាលឲ្យមានការលើកទោសអស់កល្បជានិច្ចនៃអំពើបាប។ ប៉ុន្តែ ទោសក្នុងលោកនេះនៅសេសសល់។ គ្រីស្តបរិស័ទត្រូវតែខិតខំសុខចិត្តទទួលទោសក្នុងលោកនេះដែលមកពីអំពើបាប ដូចជាព្រះអំណោយទាន ដោយស៊ូទ្រាំរងទុក្ខលំបាកទាំងប៉ុន្មានដោយចិត្តអត់ធ្មត់ ដោយប្រឈមមុខនឹងសេចក្ដីស្លាប់ នៅពេលកំណត់។ គេត្រូវព្យាយាមលះបង់ចោល "កិរិយាមារយាទដែលគេធ្លាប់កាន់ពីដើម" ដើម្បីបាន "កើតជាថ្មីឡើងវិញ" (អភ ៤,២៤) ដោយប្រព្រឹត្តតាមធម៌មេត្តាករុណា និងសេចក្ដីស្រឡាញ់ ព្រមទាំងអធិដ្ឋាន និងសោកស្ដាយបាបផងដែរ។

## ក្នុងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ

១៤៧៤-គ្រីស្តបរិស័ទ ដែលខិតខំបន្សុទ្ធខ្លួនឲ្យរួចពីបាបរបស់ខ្លួន និងឲ្យបានវិសុទ្ធដោយមានព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ជួយ មិនមែនមានតែម្នាក់ឯងទេ។ "ជីវិតនៃបុត្រធីតារបស់ព្រះជាម្ចាស់ជាប់ចំណងយ៉ាងអស្ចារ្យក្នុងអង្គព្រះគ្រីស្ត និងតាមរយៈព្រះគ្រីស្ត រួមជាមួយជីវិតបងប្អូនគ្រីស្តបរិស័ទឯទៀតៗ ក្នុងឯកភាពដែលហួសធម្មជាតិនៃព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត ដូចក្នុងខ្លួនបុគ្គលដ៏អាថ៌កំបាំងម្នាក់ដែរ" (សម្ដេចប៉ាប ប៉ូលទី៦)។

១៤៧៥-ក្នុងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ "មានចំណងនៃសេចក្ដីស្រឡាញ់ដ៏ស្ថិតស្ថេរជានិច្ច និងការផ្លាស់ប្ដូរនៃសេចក្ដីល្អទាំងអស់យ៉ាងបរិបូណ៌រវាងគ្រីស្តបរិស័ទ -អស់អ្នកដែលចូលក្នុងមាតុភូមិនៃស្ថានបរមសុខ អស់អ្នកដែលត្រូវជម្រះឲ្យបានវិសុទ្ធ ឬអស់អ្នកដែលនៅតែធ្វើបូជនីយសចរណ៍នៅលើផែនដី។ ក្នុងការផ្លាស់ប្ដូរដ៏អស្ចារ្យនេះ ភាពដ៏វិសុទ្ធរបស់ម្នាក់ឆ្លងដល់អ្នកដទៃ ហួសពីការខូចខាត ដែលអំពើបាបរបស់ម្នាក់បានប្រព្រឹត្តចំពោះអ្នកដទៃទៅទៀត។ ហេតុនេះហើយបានជាសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយអាចជួយអ្នកបាបឲ្យបានវិសុទ្ធចាកផុតពីទោសនៃអំពើបាបលឿនជាង និងដោយមានប្រសិទ្ធិភាពខ្លាំងជាង។

១៤៧៦-គេហៅសេចក្ដីល្អខាងវិញ្ញាណនៃសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយថា កំណប់នៃព្រះសហគមន៍ "ដែលមិនមែនជាចំនួនបូកសរុបនៃសេចក្ដីល្អនោះ ដូចជាទ្រព្យសម្បត្តិប្រមូលបានពីមួយសតវត្សទៅមួយសតវត្សទេ ប៉ុន្តែ ជាសម្បត្តិដែលមានតម្លៃជាអនេក ចាយមិនចេះអស់ ចំពោះព្រះជាម្ចាស់ ជាបុណ្យកុសលរបស់ព្រះគ្រីស្តជាអម្ចាស់នៃយើង ដែលព្រះអង្គបានថ្វាយដើម្បីឲ្យមនុស្សជាតិរួចពីបាប និងអាចរួបរួមជាមួយព្រះបិតាបាន។ ការទូទាត់ និងបុណ្យកុសលនៃការសង្គ្រោះរបស់ព្រះអង្គស្ថិតយ៉ាងបរិបូណ៌នៅក្នុងអង្គព្រះគ្រីស្តជាព្រះសង្គ្រោះរបស់យើង" (ហប ៧,២៣-២៥; ៩,១១-២៨)។

១៤៧៧-"ពាក្យអង្វរ និងកិច្ចការដ៏ល្អរបស់ព្រះនាងព្រហ្មចារិនីម៉ារីពោរពេញទៅដោយសុភមង្គល និងរបស់សន្តបុគ្គលទាំងឡាយ ដែលព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្តបានប្រោសឲ្យបានវិសុទ្ធ ដែលបានដើរតាមព្រះអង្គ ហើយដែលបានបំពេញកិច្ចការជាទីគាប់ព្រះហឫទ័យព្រះបិតា ជាកំណប់ដ៏មានតម្លៃខ្ពង់ខ្ពស់បំផុត ដែល

មិនអាចរាប់បាន និងថ្មីជានិច្ច ចំពោះព្រះជាម្ចាស់។ ដូច្នេះ ដោយពួកគាត់បានធ្វើការដើម្បីសង្គ្រោះខ្លួនឯង ពួកគាត់បានរួមសហការក្នុងការសង្គ្រោះនៃបងប្អូនរបស់ពួកគាត់ក្នុងឯកភាពនៃព្រះកាយដ៏អាថ៌កំបាំង"(សម្ដេចប៉ាប ប៉ូលទី៦)។

### ទទួលការអនុគ្រោះពីព្រះជាម្ចាស់តាមរយៈព្រះសហគមន៍

១៤៧៨-ព្រះយេស៊ូគ្រីស្តអនុញ្ញាតឲ្យព្រះសហគមន៍មានអំណាចចង និងស្រាយ ហើយក៏អាចផ្ដល់បុណ្យកុសលសម្រាប់អនុគ្រោះចំពោះគ្រីស្តបរិស័ទម្នាក់ និងបើកកំណប់នៃបុណ្យកុសលរបស់ព្រះគ្រីស្ត និងសន្តបុគ្គល ដើម្បីឲ្យព្រះបិតាលើកលែងទោសក្នុងលោកនេះដែលគ្រីស្តបរិស័ទនោះ ជំពាក់ដោយសារអំពើបាបរបស់ខ្លួន។ ហេតុនេះហើយបានជាព្រះសហគមន៍មិនគ្រាន់តែចង់ជួយគ្រីស្តបរិស័ទម្នាក់នោះទេ ថែមទាំងចង់ជំរុញគេឲ្យអធិដ្ឋាន សោកស្ដាយបាប និងបំពេញកិច្ចការនៃសេចក្ដីស្រឡាញ់ (សម្ដេចប៉ាប ប៉ូលទី៦; មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៨៣៥)។

១៤៧៩-គ្រីស្តបរិស័ទ ដែលចែកស្ថានកំពុងតែជម្រះឲ្យបានវិសុទ្ធ ពួកគេជាសមាជិកនៃសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយដែរ ដូច្នេះ យើងអាចជួយគេ ដោយទទួលបុណ្យកុសលសម្រាប់អនុគ្រោះគេ ទើបគេអាចរួចពីទោសក្នុងលោកនេះ ដែលគេជំពាក់ដោយសារអំពើបាបរបស់ពួកគេ។

## ១១-ពិធីបុណ្យនៃអគ្គសញ្ញាលើកលែងទោស

១៤៨០-ដូចអគ្គសញ្ញាឯទៀតៗ ការលើកលែងទោសជាកិច្ចការខាងពិធីបុណ្យ។ ជាធម្មតា ចំណុចសំខាន់ៗនៃពិធីបុណ្យ មានដូចតទៅ៖ លោកបូជាចារ្យជម្រាបសួរ និងប្រទានពរ អានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីជួយបំភ្លឺចិត្តគំនិត និងជំរុញឲ្យសោកស្ដាយអំពើបាប ដោយដាស់តឿនឲ្យកែប្រែចិត្តគំនិត។ បន្ទាប់មក អ្នកបាបទទួលស្គាល់អំពើបាបរបស់ខ្លួន និងសារភាពចំពោះលោកបូជាចារ្យ លោកក៏សូមឲ្យអ្នកបាបទូទាត់អំពើបាប (អ្នកបាបត្រូវតែសុខចិត្តធ្វើតាម) ហើយលោកលើកលែងទោសអ្នកបាប។ ទីបញ្ចប់ទាំងអស់គ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយលោកប្រទានពរដោយចាត់គ្រីស្តបរិស័ទឲ្យទៅ។

១៤៨១-ពិធីបុណ្យខាងបូព៌ាប្រទេសផ្ដល់ការលើកលែងទោសដោយមានសេចក្ដីផ្សេងៗ ដែលសម្ដែងយ៉ាងអស្ចារ្យ គម្រោងការដ៏អស្ចារ្យនៃការលើកលែងទោស៖ "សូមព្រះដែលបានលើកលែងទោសឲ្យព្រះបាទដាវីឌ តាមរយៈព្យាការីណាថាន នៅពេលព្រះអង្គបានសារភាពអំពើបាបរបស់ព្រះអង្គ ព្រះដែលបានលើកលែងទោសឲ្យលោកសិលានៅពេលលោកបានស្រក់ទឹកភ្នែកយ៉ាងសែនអាម៉ាស ព្រះដែលបានលើកលែងទោសឲ្យស្ត្រីពេស្យា នៅពេលនាងបានស្រក់ទឹកភ្នែកលើព្រះបាទាព្រះអង្គ ព្រះដែលបានលើកលែងទោសឲ្យផារីស៊ីម្នាក់ និងកូនវង្វេង សូមព្រះដដែលនេះ លើកលែងទោសឲ្យអ្នក នៅក្នុងលោកនេះ និងនៅក្នុងបរមលោក តាមរយៈខ្ញុំជាអ្នកបាប ហើយសូមព្រះអង្គកោះហៅអ្នកឲ្យមកតុលាការដ៏គួរឲ្យភិតភ័យរបស់ព្រះអង្គ ដោយមិនថ្កោលទោសអ្នក ព្រះអង្គដែលទទួលព្រះពរអស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន" ។

១៤៨២-អគ្គសញ្ញាលើកលែងទោសអាចមាននៅក្នុងពិធីបុណ្យរួម។ ក្នុងពិធីនេះ យើងរៀបចំរួមជាមួយគ្នាឲ្យសារភាព និងអរព្រះគុណចំពោះការលើកលែងទោសដែលយើងបានទទួល។ ទីនេះ ការសារភាពអំពើបាបផ្ទាល់ខ្លួន និងការលើកលែងទោសម្នាក់ៗត្រូវរាប់បញ្ចូលក្នុងពិធីបុណ្យលើតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយមានការអានអត្ថបទ និងធម៌ទេសនា ការពិនិត្យមនសិការជាមួយគ្នា ការសុំរួមជាមួយគ្នាឲ្យទទួលការលើកលែងទោសរួមការសូត្រធម៌ ឱព្រះបិតានៃយើងខ្ញុំ និងការអរព្រះគុណរួម។ ពិធីបុណ្យរួមនេះ បញ្ជាក់យ៉ាងច្បាស់ថា ការលើក

លែងទោសទាក់ទងនឹងព្រះសហគមន៍។ ទោះបីយើងប្រារព្ធអគ្គសញ្ញានេះ តាមរបៀបណាក៏ដោយ ក៏អគ្គសញ្ញាលើកលែងទោសតែងតែជាកិច្ចការខាងពិធីបុណ្យដែរ ដែលជាកិច្ចការរបស់ព្រះសហគមន៍ និងកិច្ចការជាសាធារណៈផងដែរ (SC ២៦-២៧)។

១៤៨៣-បើមានការចាំបាច់ដ៏ធ្ងន់ធ្ងរ យើងអាចផ្ដល់អគ្គសញ្ញាលើកលែងទោស ក្នុងពិធីបុណ្យរួម ដោយមានគ្រីស្ដបរិស័ទទាំងអស់សារភាព និងទទួលការលើកលែងទោសរួមជាមួយគ្នា ដូចជានៅពេលដែលមានគ្រោះថ្នាក់ដល់ជីវិត ឬនៅពេលដែលលោកបូជាចារ្យគ្មានពេលទំនេរល្មមដើម្បីស្ដាប់អ្នកបាបម្នាក់ម្ដងៗ ឬនៅពេលដែលមានអ្នកបាបច្រើន គ្មានលោកបូជាចារ្យគ្រប់គ្រាន់ ដើម្បីស្ដាប់អ្នកបាបម្នាក់ៗក្នុងពេលដ៏សមរម្យ ទាល់តែអ្នកបាបដែលគ្មានកំហុសពីខ្លួនគេផ្ទាល់ នឹងមិនបានទទួលអគ្គសញ្ញា ឬព្រះកាយព្រះគ្រីស្ដជាយូរមកហើយ។ ក្នុងករណីនេះ គ្រីស្ដបរិស័ទនៅតែអាចសារភាពអំពើបាបផ្ទាល់ខ្លួន តាមបំណងរបស់គេ ដើម្បីឲ្យការលើកលែងទោសមានប្រសិទ្ធិភាព (CIC ៩៦២,១)។ លោកអភិបាលភូមិភាគជាអ្នកសម្រេចតាមល័ក្ខខ័ណ្ឌផ្សេងៗថា តើយើងអាចផ្ដល់ការលើកលែងទោសរួមជាមួយគ្នាបាន ឬទេ (CIC ៩៦១,២)។ ទោះបីមានគ្រីស្ដបរិស័ទជាច្រើនក្នុងឱកាសបុណ្យធំៗ ឬបូជនីយសចរណ៍យ៉ាងណាក៏ដោយ ក៏មិនមែនជាករណីចាំបាច់ឡើយ (CIC ៩៦១,១)។

១៤៨៤-"ការសារភាពរបស់ម្នាក់ៗចំពោះអំពើបាបទាំងអស់ ដោយមានការលើកលែងទោស ជាមធ្យោបាយធម្មតាតែមួយ ដែលគ្រីស្ដបរិស័ទអាចសម្រុះសម្រួលជាមួយនឹងព្រះជាម្ចាស់ និងព្រះសហគមន៍លើកលែងតែគេមានមូលហេតុខាងផ្លូវកាយ ឬខាងផ្លូវចិត្តមិនអាចឲ្យគេសារភាពបានឡើយ" (OP ៣១) ដ្បិតព្រះគ្រីស្ដមានសកម្មភាពក្នុងអគ្គសញ្ញានីមួយៗ ព្រះអង្គមានព្រះបន្ទូលផ្ទាល់ចំពោះអ្នកបាបម្នាក់ៗ៖ "កូនអើយ! ខ្ញុំអភ័យទោសឲ្យអ្នកបានរួចពីបាប" (មក ២,៥)។ ព្រះអង្គជាគ្រូពេទ្យ ដែលឈ្ងោកមើលអ្នកជំងឺម្នាក់ៗដែលត្រូវការព្រះអង្គ (មក ២,១៧) ដើម្បីឲ្យបានជាសះស្បើយ ព្រះអង្គក៏ប្រោសគេឲ្យក្រោកឡើង និងបញ្ចូលគេក្នុងសហគមន៍ជាបងប្អូន។ ដូច្នេះហើយបានជាការសារភាពផ្ទាល់ខ្លួនជារបៀបដ៏មានន័យជាងគេនៃការសម្រុះសម្រួលជាមួយព្រះជាម្ចាស់ និងជាមួយព្រះសហគមន៍។

## សង្ខេប

១៤៨៥-នៅល្ងាចថ្ងៃបុណ្យចម្លង ព្រះអម្ចាស់យេស៊ូបង្ហាញព្រះអង្គឲ្យក្រុមគ្រីស្ដទូតឃើញ ហើយមានព្រះបន្ទូលថា៖ "ចូរទទួលព្រះវិញ្ញាណ!។ បើអ្នករាល់គ្នាលើកលែងទោសអ្នកណាម្នាក់ឲ្យរួចពីបាបព្រះជាម្ចាស់ក៏នឹងលើកលែងទោសអ្នកនោះឲ្យរួចពីបាបដែរ។ ផ្ទុយទៅវិញ បើអ្នករាល់គ្នាប្រកាន់ទោសអ្នកណា អ្នកនោះមុខជាត្រូវជាប់ទោសមិនខាន" (យហ ២០,២២-២៣)។

១៤៨៦-អគ្គសញ្ញាផ្ទាល់ គឺជាអគ្គសញ្ញាដែលគេហៅថា អគ្គសញ្ញានៃការកែប្រែចិត្តគំនិត នៃការសារភាព នៃការទទួលទោស ឬនៃការសម្រុះសម្រួល ផ្ដល់ការលើកលែងទោសចំពោះអំពើបាប ដែលយើងប្រព្រឹត្តក្រោយពីបានជ្រមុជទឹកហើយ។

១៤៨៧-នរណាប្រព្រឹត្តអំពើបាបបង្ខូចកិត្តិយស និងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ឋានៈរបស់ខ្លួនគេផ្ទាល់ជាមនុស្ស ដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យទៅជាបុត្រធីតារបស់ព្រះអង្គ និងប្រយោជន៍ខាងវិញ្ញាណរបស់ព្រះសហគមន៍ ដែលគ្រីស្ដបរិស័ទម្នាក់ៗត្រូវតែជាថ្មដ៏មានជីវិត។

១៤៨៨-ចំពោះអ្នកជឿ គ្មានអំពើអាក្រក់ណាអាក្រក់ជាងអំពើបាប ហើយគ្មានអ្វីហុចផលអាក្រក់ជាងនោះចំពោះ

អ្នកបាបផ្ទាល់ ចំពោះព្រះសហគមន៍ និងចំពោះពិភពលោកទាំងមូលទៀតទេ។

១៤៨៩-យើងត្រឡប់ទៅរួមជាមួយព្រះជាម្ចាស់ ក្រោយពីបានឃ្លាតឆ្ងាយពីព្រះអង្គដោយសារអំពើបាប មកពីចលនានៃព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ពោរពេញដោយធម៌មេត្ដាករុណា ដែលព្រួយប្រាម្ភចំពោះការសង្គ្រោះមនុស្ស។ ត្រូវតែសុំព្រះអំណោយទានដ៏មានតម្លៃនេះសម្រាប់ខ្លួនឯង ដូចសម្រាប់អ្នកដទៃផងដែរ។

១៤៩០-ដើម្បីត្រឡប់ទៅរកព្រះជាម្ចាស់វិញ ដែលគេហៅថា ការកែប្រែចិត្តគំនិត យើងត្រូវតែឈឺចាប់ និងស្អប់ខ្ពើមចំពោះអំពើបាប ដែលយើងបានប្រព្រឹត្ត ព្រមទាំងសន្យាយ៉ាងម៉ឺងម៉ាត់ថា មិនប្រព្រឹត្តអំពើបាបទៀតទេ។ ដូច្នេះ ការកែប្រែចិត្តគំនិតប៉ះពាល់ដល់អតីតកាលផង និងអនាគតកាលផង។ អ្នកដែលកែប្រែចិត្តគំនិតសង្ឃឹមលើធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។

១៤៩១-អ្នកបាបត្រូវបង្ហាញអំពីកិច្ចការបី ហើយលោកបូជាចារ្យត្រូវលើកលែងទោស ដើម្បីឲ្យមានអគ្គសញ្ញាលើកលែងទោស។ កិច្ចការទាំងបីរបស់អ្នកបាប គឺការសោកស្ដាយ ការសារភាពចំពោះលោកបូជាចារ្យ និងពាក្យសម្ដីចង់ទូទាត់អំពើបាប។

១៤៩២-មូលហេតុដែលមកពីជំនឿត្រូវជំរុញឲ្យសោកស្តាយ។ បើយើងសោកស្ដាយ ដោយសារសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ ការសោកស្ដាយនេះ បាន "គ្រប់លក្ខណៈ"។ បើមានមូលហេតុផ្សេង ការសោកស្ដាយនេះ "មិនគ្រប់លក្ខណៈ" ទេ។

១៤៩៣-អ្នកដែលចង់សម្រុះសម្រួលជាមួយព្រះជាម្ចាស់ និងព្រះសហគមន៍ត្រូវទទួលសារភាពចំពោះលោកបូជាចារ្យអំពើបាបធ្ងន់ធ្ងរ ដែលគេមិនទាន់បានសារភាព ហើយដែលគេនឹកឃើញក្រោយពីបានរិះគិតពិចារណាច្បាស់លាស់។ ទោះបីមិនចាំបាច់ក៏ដោយ ក៏ព្រះសហគមន៍ជំរុញឲ្យសារភាពអំពើបាបស្រាលដែរ។

១៤៩៤-លោកបូជាចារ្យស្នើសុំឲ្យអ្នកបាបប្រព្រឹត្តកិច្ចការខ្លះ ដើម្បី "ទូទាត់" ការខូចខាតដែលមកពីអំពើបាប និងដើម្បីធ្វើតាមទម្លាប់ផ្ទាល់របស់សាវ័កព្រះគ្រីស្ត។

១៤៩៥-មានតែពួកបូជាចារ្យទេ ដែលបានទទួលពីអំណាចព្រះសហគមន៍ឲ្យលើកលែងទោសឲ្យរួចពីបាប។

១៤៩៦-ផលខាងវិញ្ញាណនៃអគ្គសញ្ញាលើកលែងទោសមានដូចតទៅ៖

-ការសម្រុះសម្រួលជាមួយព្រះជាម្ចាស់ ដែលនាំឲ្យអ្នកបាបទទួលការប្រោសប្រណីឡើងវិញ
-ការសម្រុះសម្រួលជាមួយព្រះសហគមន៍
-ការលើកទោសអស់កល្បជានិច្ច ដែលមកពីអំពើបាបធ្ងន់ធ្ងរ
-ការលើកទោសក្នុងលោកនេះ ដែលមកពីអំពើបាប
-សេចក្ដីសុខសាន្ត និងសេចក្ដីស្ងប់ក្នុងចិត្ត ព្រមទាំងការលួងលោមខាងវិញ្ញាណផងដែរ
-ការពង្រឹងកម្លាំងខាងវិញ្ញាណ ដើម្បីប្រយុទ្ធក្នុងនាមជាគ្រីស្ដបរិស័ទ។

១៤៩៧-ការសារភាពរៀងៗខ្លួននៃអំពើបាបធ្ងន់ធ្ងរទាំងអស់ ព្រមទាំងការទទួលការលើកលែងទោសជាមធ្យោបាយធម្មតាតែមួយ ដើម្បីសម្រុះសម្រួលជាមួយព្រះជាម្ចាស់ និងព្រះសហគមន៍។

១៤៩៨-គ្រីស្ដបរិស័ទអាចទទួលការលើកលែងទោសក្នុងលោកនេះ ដែលមកពីអំពើបាប ដោយសារបុណ្យកុសល ដែលគេអនុគ្រោះដល់ខ្លួនឯង និងដល់ព្រលឹងដែលស្ថិតនៅស្ថានជម្រះផង។

# ប្រការទី៥៖

# អគ្គសញ្ញាលាបប្រេងឲ្យអ្នកជំងឺ

១៤៩៩-"ដោយអស់លោកបូជាចារ្យលាបប្រេងឲ្យអ្នកជំងឺ និងដោយអស់លោកអធិដ្ឋានអង្វរព្រះជាម្ចាស់ ព្រះសហគមន៍ទាំងមូលផ្ញើអ្នកជំងឺទៅលើព្រះអម្ចាស់យេស៊ូដែលបានរងទុក្ខលំបាក និងដែលមានព្រះជន្មថ្មី សូមព្រះអង្គសម្រាលទុក្ខគេ និងសង្គ្រោះគេផង។ លើសពីនេះទៅទៀត ព្រះសហគមន៍ដាស់តឿនអ្នកជំងឺទាំងនោះឲ្យស្ម័គ្រចិត្តរួមជាមួយព្រះគ្រីស្តដែលរងទុក្ខលំបាក និងដែលសោយទិវង្គត ដើម្បីឲ្យគេជួយប្រជារាស្ត្ររបស់ព្រះជាម្ចាស់តាមចំណែករបស់ខ្លួន" (LG ១១)។

## ១-មូលដ្ឋានគ្រឹះនៃពិធីលាបប្រេងក្នុងការចាត់ចែងនៃការសង្គ្រោះ

### ជំងឺក្នុងជីវិតរបស់មនុស្សលោក

១៥០០-ជំងឺ និងទុក្ខលំបាកតែងតែជាបញ្ហាដ៏ធ្ងន់ធ្ងរបំផុតនៃជីវិតរបស់មនុស្សលោក។ ដោយសារជំងឺមនុស្សដកពិសោធន៍ថា គេគ្មានអំណាច ហើយគេមានកំណត់ព្រំដែន និងទីបញ្ចប់។ ជំងឺណាមួយអាចធ្វើឲ្យយើងនឹកគិតដល់សេចក្តីស្លាប់។

១៥០១-ជំងឺអាចនាំយើងឲ្យព្រួយចិត្ត គិតតែពីខ្លួនឯង ជូនកាលអស់សង្ឃឹម និងបះបោរប្រឆាំងនឹងព្រះជាម្ចាស់។ ប៉ុន្តែ ជំងឺអាចនាំបុគ្គលម្នាក់ឲ្យរីកចម្រើន ជួយឲ្យគេរិះគិតពិចារណាអំពីអ្វីដែលមិនសូវសំខាន់ក្នុងជីវិតរបស់គេ ដើម្បីបែរទៅរកអ្វីដែលសំខាន់ៗវិញ។ ជារឿយៗ ជំងឺជំរុញឲ្យស្វែងរកព្រះជាម្ចាស់ ឲ្យត្រឡប់ទៅរកព្រះអង្គវិញ។

### អ្នកជំងឺពីមុខព្រះជាម្ចាស់

១៥០២-ពេលធ្លាក់ខ្លួនឈឺ មនុស្សនៃសម្ពន្ធមេត្រីចាស់ បែរមុខទៅរកព្រះជាម្ចាស់។ គេត្អូញត្អែរអំពីជំងឺរបស់គេពីមុខព្រះជាម្ចាស់ (ទន ៣៨) ហើយគេអង្វរព្រះអង្គ ដែលជាម្ចាស់នៃជីវិត និងសេចក្តីស្លាប់ ឲ្យគេបានជាសះស្បើយ (ទន ៦,៣; អស ៣៨)។ ដោយសារគេឈឺ គេចាប់ផ្តើមដើរតាមផ្លូវនៃការកែប្រែចិត្តគំនិត (ទន ៣៨,៥; ៣៩,៩.១២) ហើយការលើកលែងទោសរបស់ព្រះជាម្ចាស់ចាប់ផ្តើមប្រោសគេឲ្យបានជា (ទន ៣២,៥; ១០៧,២០; មក ២,៥-១២)។ ជនជាតិអ៊ីស្រាអែលដកពិសោធន៍ថា ជំងឺជាប់ចំណងនឹងអំពើបាប និងអំពើអាក្រក់ តាមរបៀបអាថ៌កំបាំង ហើយបើយើងស្មោះត្រង់នឹងព្រះជាម្ចាស់ យើងក៏មានជីវិតឡើងវិញ៖ "យើងជាព្រះអម្ចាស់ដែលប្រោសអ្នករាល់គ្នាឲ្យបានជា" (សរ ១៥,២៦)។ ព្យាការីឈ្វេងយល់ថា ទុក្ខលំបាកអាចជួយសង្គ្រោះអ្នកដទៃអំពីអំពើបាបរបស់គេដែរ (អស ៥៣,១១)។ ទីបំផុត លោកអេសាយប្រកាសថា ក្នុងគ្រាណាមួយ នៅទីក្រុងស៊ីយ៉ូន ព្រះជាម្ចាស់នឹងលើកលែងទោសកំហុសទាំងឡាយ និងប្រោសអ្នកជំងឺទាំងអស់ឲ្យបានជា (អស ៣៣,២៤)។

### ព្រះគ្រីស្តជាគ្រូពេទ្យ

១៥០៣-ធម៌មេត្តាករុណារបស់ព្រះគ្រីស្តចំពោះអ្នកជំងឺ និងការព្យាបាលរបស់ព្រះអង្គចំពោះជនពិការគ្រប់ប្រភេទ (មថ ៤,២៤) ជាសញ្ញាសម្គាល់យ៉ាងច្បាស់ថា "ព្រះជាម្ចាស់យាងមករំដោះប្រជារាស្ត្ររបស់ព្រះអង្គ" (លក ៧,១៦) ហើយព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយហើយ។ ព្រះយេស៊ូមិនគ្រាន់តែមានអំណាចព្យាបាលទេ

ថែមទាំងលើកលែងទោសឲ្យរួចពីបាបដែរ (មក ២,៥-១២)។ ព្រះអង្គយាងមកព្យាបាលព្រលឹង និងរូបកាយរបស់មនុស្សទាំងស្រុង។ ព្រះអង្គជាគ្រូពេទ្យដែលអ្នកជំងឺត្រូវការ (មក ២,៧)។ ធម៌មេត្តាករុណារបស់ព្រះអង្គចំពោះអស់អ្នកដែលរងទុក្ខលំបាកធំធេងណាស់ បានជាព្រះអង្គយកគេធ្វើជាតំណាងរបស់ព្រះអង្គ៖ "កាលយើងមានជំងឺ អ្នករាល់គ្នាបានមកសួរសុខទុក្ខយើង" (មថ ២៥,៣៦)។ ពីសតវត្សមួយទៅសតវត្សមួយសេចក្ដីស្រឡាញ់ដ៏ពិសេសចំពោះ អ្នកពិការតែងតែដាស់តឿនគ្រីស្តបរិស័ទឲ្យយកចិត្តទុកដាក់ចំពោះអស់អ្នក ដែលរងទុក្ខលំបាកខាងផ្លូវចិត្ត ឬខាងផ្លូវកាយ។ សេចក្ដីស្រឡាញ់នេះ ជាប្រភពនៃការខិតខំឥតឈប់ឈរ ដើម្បីសម្រាលទុក្ខគេ។

១៥០៤-ជារឿយៗ ព្រះយេស៊ូសុំអ្នកជំងឺឲ្យជឿ (មក ៥,៣៤.៣៦; ៩,២៣)។ ព្រះអង្គប្រើសញ្ញាសម្គាល់ដើម្បីព្យាបាល ដូចជាទឹកមាត់ និងការដាក់ដៃ (មក ៧,៣២-៣៦; ៨,២២-២៥) ភក់ និងការជម្រះខ្លួន (យហ ៩,៦ត)។ អ្នកជំងឺចង់ពាល់ព្រះអង្គ (មក ១,៤១; ៣,១០; ៦,៥៦) ដ្បិត "មានឫទ្ធានុភាពចេញពីព្រះអង្គមកប្រោសគេឲ្យជាគ្រប់ៗគ្នា" (លក ៦,១៩)។ ហេតុនេះហើយបានជាក្នុងអគ្គសញ្ញា ព្រះគ្រីស្តនៅតែ "ពាល់" យើងដើម្បីប្រោសយើងឲ្យបានជា។

១៥០៥-ព្រះគ្រីស្តរំជួលព្រះហឫទ័យដោយឃើញថា មនុស្សរងទុក្ខលំបាកខ្លាំងណាស់ ទើបព្រះអង្គក៏មិនគ្រាន់តែទុកឲ្យអ្នកជំងឺពាល់ព្រះកាយតែប៉ុណ្ណោះទេ ថែមទាំងទទួលយកភាពវេទនារបស់ពួកគេ៖ "ព្រះអង្គបានទទួលយកភាពពិការរបស់យើង ហើយព្រះអង្គក៏ទទួលយកជំងឺរបស់យើងដែរ" (មថ ៨,១៧) (អស ៥៣,៤)។ ព្រះអង្គមិនបានប្រោសអ្នកជំងឺទាំងអស់ឲ្យបានជាឡើយ។ ការព្យាបាលរបស់ព្រះអង្គជាសញ្ញាសម្គាល់ថា ព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមកហើយ ហើយប្រកាសការព្យាបាលជាដាច់ខាត គឺជ័យជម្នះលើអំពើបាប និងលើសេចក្ដីស្លាប់ដោយសារបុណ្យចម្លងរបស់ព្រះអង្គ។ នៅលើឈើឆ្កាង ព្រះគ្រីស្តបានទទួលយកអំពើអាក្រក់លើខ្លួនព្រះអង្គ ហើយបាន "ដកបាបចេញពីមនុស្សលោក" (យហ ១,២៩) ដែលជំងឺគ្រាន់តែជាផលវិបាក។ ដោយសារព្រះអង្គបានរងទុក្ខលំបាក និងសោយទិវង្គតនៅលើឈើឆ្កាង ព្រះគ្រីស្តបានផ្ដល់អត្ថន័យថ្មីដល់ទុក្ខលំបាក គឺទុក្ខលំបាកអាចធ្វើឲ្យយើងរួមរស់ជាមួយព្រះអង្គ និងរួបរួមក្នុងការរងទុក្ខលំបាករបស់ព្រះអង្គ ដើម្បីសង្គ្រោះមនុស្សលោក។

### "ចូរប្រោសអ្នកជំងឺឲ្យបានជាសះស្បើយ..."

១៥០៦-ព្រះគ្រីស្តសូមឲ្យក្រុមសាវ័កដើរតាមព្រះអង្គ ដោយលីឈើឆ្កាងរបស់ខ្លួន (មថ ១០,៣៨)។ ក្នុងពេលដើរតាមព្រះអង្គ ពួកគេផ្លាស់ប្ដូរចិត្តគំនិតអំពីជំងឺ និងអំពីអ្នកជំងឺផងដែរ។ ព្រះយេស៊ូប្រោសពួកគេឲ្យរួមជាមួយព្រះអង្គ ដោយដាក់ខ្លួនជាអ្នកក្រ និងបម្រើអ្នកដទៃ។ ព្រះអង្គប្រោសពួកគេឲ្យរួមចំណែកក្នុងមុខងារនៃធម៌មេត្តាករុណា និងការព្យាបាលរបស់ព្រះអង្គ៖ "ពួកសាវ័កក៏ចេញទៅប្រកាសឲ្យមនុស្សម្នាប្រែចិត្តគំនិត។ គេបានដេញអារក្សជាច្រើនចេញពីមនុស្ស ព្រមទាំងចាក់ប្រេងលើអ្នកជំងឺជាច្រើននាក់ ដើម្បីប្រោសគេឲ្យបានជាសះស្បើយ" (មក ៦,១២-១៣)។

១៥០៧-ព្រះអម្ចាស់ដែលមានព្រះជន្មថ្មីចាត់គេឲ្យទៅម្ដងទៀត ("ក្នុងនាមយើង (...) ប្រសិនបើគេដាក់ដៃលើអ្នកជំងឺ អ្នកជំងឺនឹងបានជាសះស្បើយ"៖ មក ១៦,១៧-១៨) ហើយសញ្ញាសម្គាល់ដែលព្រះសហគមន៍ធ្វើក្នុងព្រះនាមព្រះអង្គបញ្ជាក់ថា ព្រះអង្គពិតជាបានចាត់គេឲ្យទៅ (កក ៩,៣៤; ១៤,៣)។ សញ្ញាសម្គាល់នោះសម្ដែងតាមរបៀបពិសេសថា ព្រះយេស៊ូពិតជា "ព្រះជាម្ចាស់ដែលសង្គ្រោះ" (មថ ១,២១; កក ៤,១២)។

១៥០៨-ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឲ្យអ្នកខ្លះចេះព្យាបាលតាមព្រះអំណោយទានពិសេស (១ករ ១២,៩.២៨.

៣០) ដើម្បីសម្តែងឫទ្ធានុភាពនៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្តដែលមានព្រះជន្មថ្មី។ ទោះបីយើងអធិដ្ឋានអស់ពីចិត្តក៏ដោយ ក៏ជូនកាលយើងមិនអាចព្យាបាលជំងឺទាំងអស់ដែរ។ ហេតុនេះហើយបានជាសន្តៈ ប៉ូល ត្រូវរៀនពីព្រះអម្ចាស់ថា៖ "ការប្រណីសន្តោសរបស់យើង គឺល្មមគ្រប់គ្រាន់សម្រាប់អ្នកហើយ ដ្បិតឫទ្ធានុភាពរបស់យើងនឹងលេចចេញមកយ៉ាងខ្លាំងបំផុតក្នុងមនុស្សទន់ខ្សោយ" (១ករ ១២,៩) ហើយទុក្ខលំបាកដែលត្រូវស៊ូទ្រាំអាចមានអត្ថន័យថា៖ "ខ្ញុំរងទុក្ខលំបាកក្នុងរូបកាយដូច្នេះ ដើម្បីជួយបំពេញទុក្ខលំបាករបស់ព្រះគ្រីស្តសម្រាប់ព្រះកាយរបស់ព្រះអង្គដែលជាព្រះសហគមន៍" (កូឡ ១,២៤)។

១៥០៩-"ចូរមើលអ្នកជំងឺឲ្យបានជា!" (មថ ១០,៨)។ ព្រះសហគមន៍បានទទួលបន្ទុកនេះពីព្រះអម្ចាស់ ហើយព្យាយាមបំពេញបន្ទុកនេះ ដោយថែទាំអ្នកជំងឺផង អធិដ្ឋានសម្រាប់គេផងដែរ។ ព្រះសហគមន៍ជឿលើវត្តមានដែលផ្តល់ជីវិតរបស់ព្រះគ្រីស្ត ដែលជាគ្រូពេទ្យនៃព្រលឹង និងរូបកាយ។ វត្តមាននេះមានសកម្មភាពពិសេសតាមរយៈអគ្គសញ្ញា ជាពិសេសតាមរយៈអគ្គសញ្ញាអរព្រះគុណ ជានំប៉័ងដែលផ្តល់ជីវិតអស់កល្បជានិច្ច (យហ ៦,៥៤.៥៨) ហើយដែលសន្តៈ ប៉ូល និយាយប្រាប់យើងថា ទាក់ទងនឹងសុខភាពខាងរូបកាយ (១ករ ១១,៣០)។

១៥១០-ក៏ប៉ុន្តែ ព្រះសហគមន៍នៅសម័យក្រុមគ្រីស្តទូតស្គាល់ពិធីពិសេសសម្រាប់អ្នកជំងឺ ដែល សន្តៈ យ៉ាកុប បញ្ជាក់៖ "ក្នុងចំណោមបងប្អូន បើនរណាមានជំងឺ ត្រូវអញ្ជើញព្រឹទ្ធាចារ្យរបស់ព្រះសហគមន៍មក ដើម្បីឲ្យលោកទាំងនោះអធិដ្ឋាន និងលាបប្រេងឲ្យគាត់ក្នុងព្រះនាមព្រះអម្ចាស់។ សេចក្តីអធិដ្ឋានដែលផុសចេញមកពីជំនឿនឹងសង្គ្រោះអ្នកជំងឺនេះ ហើយព្រះអម្ចាស់នឹងប្រោសគាត់ឲ្យក្រោកឡើងវិញ។ ប្រសិនបើគាត់បានប្រព្រឹត្តអំពើបាប ព្រះអង្គនឹងលើកលែងទោសឲ្យ" (យក ៥,១៤-១៥)។ ការបញ្ជូនបន្តបានទទួលស្គាល់ថា ពិធីនេះជាអគ្គសញ្ញាក្នុងចំណោមអគ្គសញ្ញាទាំងប្រាំពីរនៃព្រះសហគមន៍ (DS ២១៦; ១៣២៤-១៣២៥; ១៦៩៥-១៦៩៦; ១៧១៦-១៧១៧)។

## អគ្គសញ្ញាមួយសម្រាប់អ្នកជំងឺ

១៥១១-ព្រះសហគមន៍ជឿ និងប្រកាសថា ក្នុងចំណោមអគ្គសញ្ញាទាំងប្រាំពីរ មានអគ្គសញ្ញាពិសេសដើម្បីសម្រាលទុក្ខអស់អ្នកជំងឺ គឺការលាបប្រេងឲ្យពួកគេ៖

> ព្រះគ្រីស្តជាព្រះអម្ចាស់នៃយើងបានតែងតាំងការលាបប្រេងដ៏វិសុទ្ធឲ្យអ្នកជំងឺនេះ ដូចជាអគ្គសញ្ញានៃសម្ព័ន្ធមេត្រីថ្មីដោយមានព្រះបន្ទូលយ៉ាងពិតប្រាកដ និងយ៉ាងច្បាស់។ ក្រោយពីសន្តៈ ម៉ាកុស (មក ៦,១៣) សន្តៈ យ៉ាកុប ជាគ្រីស្តទូត និងបងប្អូនរបស់ព្រះអម្ចាស់ផ្តែផ្តាំគ្រីស្តបរិស័ទឲ្យធ្វើពិធីលាបប្រេងនេះ (យក ៥,១៤-១៥; មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៩៥)។

១៥១២-ក្នុងប្រពៃណីខាងពិធីបុណ្យ នៅបូព៌ា និងបស្ចិមប្រទេសផងដែរ តាំងពីបុរាណកាល មានផ្តល់សក្ខីភាពថា គេបានលាបប្រេងលើអ្នកជំងឺជាមួយនឹងប្រេងព្រះពរ។ ពីសតវត្សមួយទៅសតវត្សមួយ គេបានលាបប្រេងតែលើអស់អ្នកដែលហៀបនឹងស្លាប់ប៉ុណ្ណោះ។ ដោយសារមូលហេតុនេះ គេបានហៅពិធីនេះថា "ពិធីលាបប្រេងចុងក្រោយបំផុត"។ ទោះជាយ៉ាងណាក៏ដោយ ពិធីបុណ្យមិនដែលភ្លេចអង្វរព្រះអម្ចាស់ឲ្យអ្នកជំងឺបានជាសះស្បើយ បើការព្យាបាលនេះអាចសង្គ្រោះគេបាន (DS ១៦៩៦)។

១៥១៣-ធម្មនុញ្ញក្រុមគ្រីស្តទូត "Sacram unctionem infirmorum" ("ពិធីលាបប្រេងដ៏វិសុទ្ធឲ្យអ្នកជំងឺ") នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧២ ក្រោយពីមហាសន្និបាតវ៉ាទីកង់ទីពីរ (SC ៧៣) បានចាត់ចែងថា នៅក្នុង

ពិធីនៃបស្ចិមប្រទេស ចាប់ពីពេលនេះទៅ ត្រូវធ្វើដូចតទៅ៖

> ត្រូវផ្ដល់អគ្គសញ្ញាលាបប្រេងដល់អ្នកជំងឺធ្ងន់ធ្ងរ ដោយលាបប្រេងព្រះពរ (ប្រេងអូលីវ ឬប្រេងផ្សេងទៀតចេញមកពីរុក្ខជាតិ) លើថ្ងាស និងលើដៃ ដោយមានប្រសាសន៍តែម្ដងថា៖ "តាមរយៈពិធីលាបប្រេងដ៏វិសុទ្ធនេះ សូមឲ្យព្រះអម្ចាស់ប្រកបដោយធម៌មេត្តាករុណា លើកទឹកចិត្តអ្នក ដោយព្រះហឫទ័យប្រណីសន្ដោសនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ហេតុនេះ ដោយព្រះអង្គបានរំដោះអ្នកពីអំពើបាបទាំងអស់ សូមព្រះអង្គសង្គ្រោះអ្នក និងប្រោសអ្នកឲ្យក្រោកឡើង" (CIC ៨៤៧,១)។

## ២-តើនរណាទទួល និងនរណាផ្ដល់អគ្គសញ្ញានេះ?

### នៅពេលដែលមានអ្នកជំងឺធ្ងន់ធ្ងរ...

១៥១៤-ការលាបប្រេងឲ្យអ្នកជំងឺ "មិនមែនអគ្គសញ្ញាសម្រាប់គ្រីស្ដបរិស័ទ ដែលជិតនឹងស្លាប់ទេ ដូច្នេះ គ្រីស្ដបរិស័ទដែលចាប់ផ្ដើមវ័យចំណាស់ ឬចាស់ជរា ឬមានជំងឺទម្ងន់ គួរទទួលអគ្គសញ្ញានេះ" (SC ៧៣)។

១៥១៥-ប្រសិនបើអ្នកជំងឺណាម្នាក់ ដែលបានទទួលប្រេងជាសះស្បើយ ហើយបើគេធ្លាក់ខ្លួនឈឺយ៉ាងធ្ងន់ធ្ងរម្ដងទៀត គេអាចទទួលអគ្គសញ្ញានេះម្ដងទៀតបាន។ នៅពេលមានជំងឺដដែល យើងអាចផ្ដល់អគ្គសញ្ញាម្ដងទៀតបើជំងឺកាន់តែដុនដាបទៅៗ។ គួរទទួលពិធីលាបប្រេងឲ្យអ្នកជំងឺនៅពេលត្រូវវះកាត់ ឬចាស់ជរា ដែលសុខភាពកាន់តែទន់ខ្សោយ។

### "ត្រូវអញ្ជើញព្រឹទ្ធាចារ្យរបស់ព្រះសហគមន៍មក..."

១៥១៦-មានតែលោកបូជាចារ្យប៉ុណ្ណោះ (លោកអភិបាល និងលោកព្រឹទ្ធាចារ្យ) ដែលជាអ្នកទទួលមុខងារលាបប្រេងឲ្យអ្នកជំងឺបាន (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៩៧; ១៧១៩; CIC ១០០៣; CCEO ៧៣៩,១)។ គ្រូគង្វាលមានភារកិច្ចប្រៀនប្រដៅគ្រីស្ដបរិស័ទអំពីផលដ៏ល្អនៃអគ្គសញ្ញានេះ។ គ្រីស្ដបរិស័ទត្រូវតែលើកទឹកចិត្តអ្នកជំងឺឲ្យគេសូមលោកបូជាចារ្យផ្ដល់អគ្គសញ្ញានេះ។ អ្នកជំងឺត្រូវតែរៀបចំខ្លួនឲ្យទទួលអគ្គសញ្ញានេះតាមរបៀបសមគួរ និងដោយមានគង្វាល និងសហគមន៍ទាំងមូលរបស់គេ មកសួរសុខទុក្ខគេ ព្រមទាំងអធិដ្ឋាន និងយកចិត្តទុកដាក់លើគេដូចជាបងប្អូន។

## ៣-តើគេប្រារព្ធអគ្គសញ្ញានេះយ៉ាងដូចម្ដេច?

១៥១៧-ដូចអគ្គសញ្ញាឯទៀតៗដែរ ពិធីលាបប្រេងជាពិធីបុណ្យរួម (SC ២៧) ទោះជាពិធីនេះកើតមានក្នុងក្រុមគ្រួសារ នៅមន្ទីរពេទ្យ នៅព្រះសហគមន៍ សម្រាប់អ្នកជំងឺតែម្នាក់ ឬសម្រាប់ក្រុមអ្នកពិការក៏ដោយ។ គួរប្រារព្ធពិធីនេះរួមជាមួយនឹងអគ្គសញ្ញាអរព្រះគុណ ដែលជាពិធីនឹករឭកបុណ្យចម្លងរបស់ព្រះអម្ចាស់។ តាមកាលៈទេសៈយើងអាចផ្ដល់អគ្គសញ្ញាលើកលែងទោសមុនអគ្គសញ្ញាលាបប្រេងនេះ និងបន្ទាប់មកថ្វាយអភិបូជា។ ដោយសារពិធីអរព្រះគុណជាអគ្គសញ្ញានៃបុណ្យចម្លងរបស់ព្រះគ្រីស្ដ អគ្គសញ្ញាអរព្រះគុណគួរជាអគ្គសញ្ញាចុងក្រោយនៃការធ្វើដំណើរដ៏សែនឆ្ងាយនៅលើលោកនេះ ជា "ស្បៀងអាហារ" ដើម្បី "ឆ្លង" ឆ្ពោះទៅជីវិតអស់កល្បជានិច្ច។

១៥១៨-ពាក្យសម្ដី និងអគ្គសញ្ញាមិនអាចបំបែកពីគ្នាបានឡើយ។ ពិធីលើកតម្កើងព្រះបន្ទូល ដោយមានពិធីលើកលែងទោសទុកជាមុន បើកពិធីបុណ្យ។ ព្រះបន្ទូលរបស់ព្រះគ្រីស្ដ និងសក្ខីភាពរបស់ក្រុមគ្រីស្ដទូតជាស់

តឿនជំនឿរបស់អ្នកជំងឺ និងរបស់សហគមន៍ដើម្បីទូលអង្វរឫទ្ធានុភាពនៃព្រះវិញ្ញាណរបស់ព្រះអម្ចាស់។

១៥១៩-ពិធីលើកតម្កើងអគ្គសញ្ញានេះ មានចំណុចសំខាន់ៗដូចតទៅ៖ "ព្រឹទ្ធាចារ្យរបស់ព្រះសហគមន៍" (យក ៥,១៤) ដាក់ដៃយ៉ាងស្ងៀមស្ងាត់លើអ្នកជំងឺ ពួកលោកអធិដ្ឋានសម្រាប់អ្នកជំងឺតាមជំនឿរបស់ព្រះសហគមន៍ (យក ៥,១៥) គឺពិធីពិសេសនៃអគ្គសញ្ញានេះ អង្វរឲ្យព្រះវិញ្ញាណយាងមក។ បន្ទាប់មក ពួកលោកលាបប្រេង (ដែលលោកអភិបាលបានប្រទានពរ) ឲ្យអ្នកជំងឺ។

កិច្ចការខាងពិធីបុណ្យនោះបង្ហាញថា អគ្គសញ្ញានេះផ្តល់ព្រះអំណោយទានអ្វីខ្លះ។

## ៤-ផលនៃពិធីអគ្គសញ្ញានេះ

១៥២០-ព្រះអំណោយទានពិសេសពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះអំណោយទានដំបូងនៃអគ្គសញ្ញានេះ គឺព្រះវិញ្ញាណសម្រាលទុក្ខអ្នកជំងឺ ឲ្យទទួលសេចក្តីស្ងប់ និងសេចក្តីក្លាហាន ដើម្បីជម្រះលើជំងឺ ដែលមានសភាពធ្ងន់ធ្ងរ និងរោគរបស់មនុស្សចាស់ជរា។ ព្រះអំណោយទាននេះ បានមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រោសអ្នកជំងឺឲ្យផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់សាជាថ្មី និងពង្រឹងប្រឆាំងនឹងការល្បួងរបស់មារ ដែលនាំឲ្យអ្នកជំងឺបាក់ទឹកចិត្ត និងភ័យខ្លាចចំពោះសេចក្តីស្លាប់ (ហប ២,១៥)។ ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណរបស់ព្រះអង្គ ព្រះអម្ចាស់មានព្រះហឫទ័យជួយដឹកនាំព្រលឹងអ្នកជំងឺឲ្យបានជាផង ព្រមទាំងរូបកាយផងដែរ បើព្រះអង្គសព្វព្រះហឫទ័យ (មហាសន្និបាតនៅទីក្រុងហ្លូរង់៖ DS ១៣២៥)។ ម្យ៉ាងទៀត "ប្រសិនបើគាត់បានប្រព្រឹត្តអំពើបាប ព្រះអង្គនឹងលើកលែងទោសឲ្យ" (យក ៥,១៥) (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៧១៧)។

១៥២១-អ្នកជំងឺរួមរស់ជាមួយព្រះគ្រីស្តដែលរងទុក្ខលំបាក។ ដោយសារព្រះអំណោយទាននៃអគ្គសញ្ញានេះ អ្នកជំងឺទទួលកម្លាំង និងអំណោយទានឲ្យរួមរស់យ៉ាងស្និទ្ធស្នាលជាមួយព្រះគ្រីស្ត ដែលរងទុក្ខលំបាក៖ ព្រះជាម្ចាស់ប្រោសគេតាមរបៀបម្យ៉ាង ដើម្បីទុកឲ្យគេបង្កើតផល ដោយចូលរួមក្នុងទុក្ខលំបាកនៃព្រះសង្គ្រោះ។ ទុក្ខលំបាកដែលមកពីអំពើបាបដើមដំបូង ទទួលអត្ថន័យថ្មី គឺដោយសារការរងទុក្ខលំបាក អ្នកជំងឺរួមចំណែកក្នុងព្រះរាជកិច្ចនៃការសង្គ្រោះរបស់ព្រះយេស៊ូ។

១៥២២-ព្រះអំណោយទានរបស់ព្រះសហគមន៍។ អ្នកជំងឺដែលទទួលអគ្គសញ្ញានេះ "ដោយស្ម័គ្រចិត្តរួមរស់ជាមួយព្រះគ្រីស្តដែលរងទុក្ខលំបាក និងសោយទិវង្គត" "ជួយប្រជារាស្ត្ររបស់ព្រះជាម្ចាស់តាមចំណែករបស់ខ្លួន" (LG ១១)។ ដោយប្រារព្ធអគ្គសញ្ញានេះ ព្រះសហគមន៍ជួយអង្វរព្រះជាម្ចាស់សម្រាប់អ្នកជំងឺ នៅក្នុងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ចំណែកឯអ្នកជំងឺវិញ ដោយសារព្រះអំណោយទាននៃអគ្គសញ្ញានេះ គេជួយតាមចំណែករបស់ខ្លួនឲ្យព្រះសហគមន៍បានវិសុទ្ធ និងឲ្យមនុស្សលោកបានសេចក្តីសុខ ដែលព្រះសហគមន៍រងទុក្ខលំបាក និងថ្វាយខ្លួនចំពោះព្រះជាម្ចាស់ជាព្រះបិតា តាមរយៈព្រះគ្រីស្ត។

១៥២៣-អ្នកជំងឺរៀបចំខ្លួនដើម្បីឆ្លងពីលោកនេះទៅបរមលោក។ បើគេផ្តល់អគ្គសញ្ញាលាបប្រេងដល់អស់អ្នកដែលមានជំងឺ ឬភាពពិការធ្ងន់ធ្ងរយ៉ាងណា ត្រូវតែផ្តល់អគ្គសញ្ញានេះដល់អស់អ្នក ដែលហៀបនឹងចេញពីលោកនេះយ៉ាងនោះដែរ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៩៨) ទើបគេហៅអគ្គសញ្ញានេះថាជា sacramentum exeuntium (អគ្គសញ្ញានៃផ្លូវចេញ)។ ពិធីលាបប្រេងឲ្យអ្នកជំងឺជាកិច្ចដើម្បីបង្ហើយឲ្យយើងរួមជាមួយព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មី ដូចពិធីជ្រមុជទឹកបានចាប់ផ្តើម។ ពិធីនេះ បញ្ចប់ការលាបប្រេងដ៏វិសុទ្ធផ្សេងៗ ដែលជាដំណាក់កាលនៃជីវិតរបស់គ្រីស្តបរិស័ទ៖ ពិធីលាបប្រេងនៃអគ្គសញ្ញាជ្រមុជទឹកបានប្រោសយើង

ឲ្យកើតជាថ្មី ពិធីលាបប្រេងនៃអគ្គសញ្ញាលាបថ្ងាសបានផ្តល់កម្លាំង ដើម្បីច្បាំងប្រយុទ្ធក្នុងជីវិតនេះ។ ពិធីលាបប្រេងចុងក្រោយនេះ ផ្តល់កំពែងដ៏រឹងមាំ ដើម្បីការប្រយុទ្ធចុងក្រោយមុននឹងចូលក្នុងព្រះដំណាក់របស់ព្រះបិតា (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦៩៤)។

## ៥-អគ្គសញ្ញាចុងក្រោយរបស់គ្រីស្តបរិស័ទ

១៥២៤-លើសពីពិធីលាបប្រេងអ្នកជំងឺ ព្រះសហគមន៍ផ្តល់អគ្គសញ្ញាអរព្រះគុណសម្រាប់អស់អ្នកដែលនឹងលាចាកពីលោកនេះ។ ការទទួលព្រះកាយ ព្រះលោហិតព្រះគ្រីស្ត នៅពេលគេកំពុងឆ្លងឆ្ពោះទៅរកព្រះបិតាមានអត្ថន័យពិសេស។ តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ការទទួលព្រះកាយ ព្រះលោហិតព្រះគ្រីស្តជាពូជនៃជីវិតអស់កល្បជានិច្ច និងជាប្ញទ្ធានុភាពឲ្យមានជីវិតថ្មី៖ "អ្នកណាពិសាសាច់ និងលោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំក៏នឹងប្រោសគេឲ្យមានជីវិតថ្មី នៅថ្ងៃចុងក្រោយបំផុតផងដែរ" (យហ ៦,៥៤)។ អគ្គសញ្ញាអរព្រះគុណ ជាអគ្គសញ្ញារបស់ព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មី ជាអគ្គសញ្ញានៃការចម្លងពីសេចក្តីស្លាប់ដល់ជីវិត ពីលោកនេះទៅឯព្រះបិតា (យហ ១៣,១)។

១៥២៥-ហេតុនេះហើយបានជាដូចអគ្គសញ្ញាជ្រមុជទឹក លាបថ្ងាស និងអរព្រះគុណរួមជាមួយគ្នាក្នុងឯកភាពដែលគេហៅថា "អគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ" យ៉ាងណា យើងអាចនិយាយថា នៅពេលជីវិតគ្រីស្តបរិស័ទជិតបញ្ចប់ហើយ អគ្គសញ្ញាលើកលែងទោស លាបប្រេងឲ្យអ្នកជំងឺ និងអរព្រះគុណជា "អគ្គសញ្ញាដែលរៀបចំឲ្យចូលក្នុងមាតុភូមិ" ឬជាអគ្គសញ្ញាដែលបញ្ចប់ការធ្វើដំណើរ។

## សង្ខេប

១៥២៦-"ក្នុងចំណោមបងប្អូន តើនរណាមានជំងឺ ត្រូវអញ្ជើញព្រឹទ្ធាចារ្យរបស់ព្រះសហគមន៍មក ដើម្បីឲ្យលោកទាំងនោះអធិដ្ឋានឲ្យគាត់ និងលាបប្រេងឲ្យក្នុងព្រះនាមព្រះអម្ចាស់។ ពាក្យអធិដ្ឋាន ដែលផុសចេញមកពីជំនឿនឹងសង្គ្រោះអ្នកជំងឺនោះ ហើយព្រះអម្ចាស់នឹងប្រោសគាត់ឲ្យក្រោកឡើងវិញ។ ប្រសិនបើគាត់បានប្រព្រឹត្តអំពើបាប ព្រះអង្គនឹងលើងលែងទោសឲ្យគាត់" (យក ៥,១៤-១៥)។

១៥២៧-អគ្គសញ្ញាលាបប្រេងឲ្យអ្នកជំងឺមានគោលដៅផ្តល់ព្រះអំណោយទានពិសេសដល់គ្រីស្តបរិស័ទ ដែលជួបប្រទះនឹងទុក្ខលំបាកដោយសារជំងឺធ្ងន់ធ្ងរ ឬដោយជរាពាធ។

១៥២៨-វេលាសមគួរ ដើម្បីទទួលប្រេងដ៏វិសុទ្ធ គឺនៅពេលដែលគ្រីស្តបរិស័ទជិតស្លាប់ ដោយសារគេឈឺ ឬចាស់ជរា។

១៥២៩-រាល់ពេលដែលគ្រីស្តបរិស័ទមានជំងឺជាទម្ងន់ គេអាចទទួលប្រេងដ៏វិសុទ្ធ។ បើជំងឺដុនដាបទៅៗ គេអាចទទួលប្រេងម្តងទៀត ទោះបីគេបានទទួលម្តងហើយក៏ដោយ។

១៥៣០-មានតែពួកបូជាចារ្យ (និងលោកអភិបាល) ទេ ដែលអាចផ្តល់អគ្គសញ្ញាលាបបង្រេអ្នកជំងឺ។ ដើម្បីផ្តល់អគ្គសញ្ញានេះ ពួកលោកប្រើប្រេង ដែលលោកអភិបាលបានប្រទានពរ ឬក្នុងករណីចាំបាច់ ដែលលោកបូជាចារ្យផ្ទាល់បានប្រទានពរ។

១៥៣១-ពិធីសំខាន់នៃអគ្គសញ្ញានេះ គឺការលាបប្រេងលើថ្ងាស និងដៃរបស់អ្នកជំងឺ (ក្នុងក្បួនពិធីនៃទីក្រុងរ៉ូម) ឬលើផ្នែកផ្សេងនៃរូបកាយ (ក្នុងបូព៌ាប្រទេស)។ ម្យ៉ាងទៀត លោកបូជាចារ្យត្រូវអង្វរព្រះជាម្ចាស់ ដើម្បីទទួល

ព្រះអំណោយទានពិសេសនៃអគ្គសញ្ញានេះដែរ។

១៥៣២-ព្រះអំណោយទានពិសេសនៃអគ្គសញ្ញានេះមានផលដូចតទៅ៖

-អ្នកជំងឺរួបរួមជាមួយព្រះគ្រីស្តដែលរងទុក្ខលំបាក ដើម្បីផលប្រយោជន៍របស់ខ្លួនគេផ្ទាល់ និងរបស់ព្រះសហគមន៍ផង

-ការលួងលោមចិត្ត សេចក្តីសុខសាន្ត សេចក្តីក្លាហាន ដើម្បីស៊ូទ្រាំដូចជាគ្រីស្តបរិស័ទ ទុក្ខលំបាកទាំងប៉ុន្មាន ដែលមកពីគេឈឺ ឬគេជរា

-ការលើកលែងទោសឲ្យរួចពីបាប បើអ្នកជំងឺមិនបានទទួលអគ្គសញ្ញាលើកលែងទោស

-ការព្យាបាល បើអាចសង្គ្រោះគេបាន

-ឲ្យគេត្រៀមខ្លួននឹងឆ្លងទៅកាន់ជីវិតអស់កល្បជានិច្ច។

## ជំពូកទីបី៖

## អគ្គសញ្ញាបម្រើគ្រីស្តបរិស័ទឲ្យរួបរួមគ្នា

១៥៣៣-អគ្គសញ្ញាជ្រមុជទឹក លាបថ្ងាស និងអរព្រះគុណ ជាអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ។ ព្រះជាម្ចាស់ត្រាស់ហៅសាវ័កទាំងអស់របស់ព្រះគ្រីស្ត ឲ្យបានវិសុទ្ធ និងឲ្យទៅប្រកាសដំណឹងល្អ ក្នុងពិភពលោកទាំងមូល ហើយព្រះអង្គចាក់គ្រឹះនៃការត្រាស់ហៅរួមនេះ លើអគ្គសញ្ញាទាំងបីនោះ។ អគ្គសញ្ញានោះផ្តល់ព្រះអំណោយទានចាំបាច់ ដើម្បីឲ្យបូជនីយេសក៍ ដែលធ្វើដំណើរក្នុងលោកនេះឆ្ពោះទៅមាតុភូមិ មានរបៀបរស់នៅស្របតាមព្រះវិញ្ញាណ។

១៥៣៤-អគ្គសញ្ញាពីរផ្សេងទៀត គឺអគ្គសញ្ញាតែងតាំង និងអគ្គសញ្ញាអាពាហ៍ពិពាហ៍ មានគោលដៅជួយសង្គ្រោះអ្នកដទៃ។ ទោះបីអគ្គសញ្ញានោះ ជួយសង្គ្រោះខ្លួនឯងយ៉ាងណាក៏ដោយ ក៏អគ្គសញ្ញានោះជួយសង្គ្រោះខ្លួនឯងដោយបម្រើអ្នកដទៃដែរ។ អគ្គសញ្ញានោះ ផ្តល់បេសកកម្មពិសេសក្នុងព្រះសហគមន៍ និងជួយកសាងប្រជារាស្ត្ររបស់ព្រះជាម្ចាស់។

១៥៣៥-ក្នុងអគ្គសញ្ញានោះ អស់អ្នកដែលព្រះជាម្ចាស់បានញែក ដោយអគ្គសញ្ញាជ្រមុជទឹក និងលាបថ្ងាសរួចស្រេចទៅហើយ (LG ១០) ដើម្បីទៅជាបូជាចារ្យដូចគ្រីស្តបរិស័ទឯទៀតៗ សុទ្ធជាបូជាចារ្យ អ្នកនោះដែលអាចទទួលមុខងារពិសេស។ ព្រះជាម្ចាស់ញែកអស់អ្នកដែលទទួលអគ្គសញ្ញាតែងតាំង ដើម្បីទៅជា "គង្វាលរបស់ព្រះសហគមន៍ ដោយសារព្រះបន្ទូល និងដោយបានទទួលការប្រោសប្រណីផង" (LG ១១) ក្នុងព្រះនាមព្រះគ្រីស្ត។ ចំពោះ "គូស្វាមីភរិយាជាគ្រីស្តបរិស័ទ មានអគ្គសញ្ញាដ៏ពិសេសមួយផ្តល់កម្លាំងដល់ពួកគេ ដែលហាក់ដូចជាញែកពួកគេដើម្បីឲ្យគេអាចបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសមរម្យ" (GS ៤៨,២)។

## ប្រការទី៦៖

## អគ្គសញ្ញាតែងតាំង

១៥៣៦-ដោយសារអគ្គសញ្ញាតែងតាំង ព្រះសហគមន៍នៅតែប្រព្រឹត្តបេសកកម្ម ដែលព្រះគ្រីស្តបានប្រគល់ឲ្យក្រុមគ្រីស្តទូត រហូតដល់អវសានកាលនៃពិភពលោក។ ហេតុនេះ អគ្គសញ្ញានេះ ជាអគ្គសញ្ញារបស់អស់អ្នកដែល

បានទទួលមុខងារបម្រើព្រះសហគមន៍ តាំងពីក្រុមគ្រីស្តទូតមក។ អគ្គសញ្ញានេះ មានបីថ្នាក់ គឺថ្នាក់ជាអភិបាល ថ្នាក់ជាបូជាចារ្យ និងថ្នាក់ជាឧបដ្ឋាក។

(អំពីការតែងតាំង និងបេសកកម្មរបស់អ្នកដែលបានទទួលមុខងារបម្រើព្រះសហគមន៍ ដោយព្រះគ្រីស្ត សូមអានលេខ ៨៧១ត។ នៅទីនេះ យើងអធិប្បាយអំពីរបៀបបញ្ជូនមុខងារនេះតាមអគ្គសញ្ញាប៉ុណ្ណោះ។)

## ១-ហេតុអ្វីបានជាគេហៅអគ្គសញ្ញានេះថា អគ្គសញ្ញាតែងតាំង (Orders)?

១៥៣៧-នៅសម័យជនជាតិរ៉ូម៉ាំង ពាក្យក្រុម (**order**) សំដៅទៅលើក្រុមដែលសង្គមស៊ីវីលបានចាត់ចែងជាពិសេសក្រុមរបស់មេដឹកនាំ។ **Ordinatio** (តែងតាំង) មានន័យថា ការបញ្ចូលក្នុង **ordo** (ក្រុម) មួយ។ ក្នុងព្រះសហគមន៍ មានក្រុមដែលតាំងពីបុរាណកាល និងយោងតាមព្រះគម្ពីរដ៏វិសុទ្ធ (ហប ៥,៦; ៧,១១; ទន ១១០,៤) ការបញ្ជូនបន្តហៅថា **taxeis** (ជាភាសាក្រិក) **ordines** ៖ ហេតុនេះហើយបានជាមានចែងក្នុងពិធីបុណ្យថា **ordo episcoporum** (ក្រុមអភិបាល) **ordo presbyterium** (ក្រុមបូជាចារ្យ) **ordo diaconorum** (ក្រុមឧបដ្ឋាក)។ មានក្រុមផ្សេងទៀតដែលគេហៅ **ordo** ដែរ ដូចជាក្រុមអ្នកស្វែងយល់ ក្រុមព្រហ្មចារី ក្រុមស្វាមី ក្រុមស្ត្រីមេម៉ាយ ជាដើម។

១៥៣៨-គេបញ្ចូលនរណាម្នាក់ក្នុងក្រុមណាមួយនៃព្រះសហគមន៍នោះ តាមពិធីមួយ ដែលគេហៅថា **Ordinatio** ជាកិច្ចការខាងសាសនា និងខាងពិធីបុណ្យ ដែលជាការប្រសិទ្ធ ការប្រទានពរ ឬអគ្គសញ្ញាមួយ។ សព្វថ្ងៃគេទុកពាក្យ **Ordinatio** សម្រាប់កិច្ចការខាងអគ្គសញ្ញា ដែលបញ្ចូលនរណាម្នាក់ ក្នុងក្រុមអភិបាល ក្រុមបូជាចារ្យ និងក្នុងក្រុមឧបដ្ឋាក ដែលមិនគ្រាន់តែជាការបោះឆ្នោត ការតែងតាំង ការប្រគល់សិទ្ធិ ឬការចាត់ចែង ដោយសហគមន៍ប៉ុណ្ណោះទេ ដ្បិតពិធីនេះប្រគល់ព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រគល់ "អំណាចដ៏ពិសិដ្ឋ" (**sacra potestas – LG ១០**) ដែលបានមកពីតែព្រះគ្រីស្តផ្ទាល់ប៉ុណ្ណោះ តាមរយៈព្រះសហគមន៍ព្រះអង្គ។ គេហៅពិធីតែងតាំងនេះ **consecratio** (ពិធីប្រសិទ្ធពរ) ដ្បិតដោយសារពិធីនេះ ព្រះគ្រីស្តញែក និងទុកសម្រាប់ឧទ្ទិសដល់ព្រះសហគមន៍របស់ព្រះអង្គ។ ពិធីដាក់ដៃរបស់លោកអភិបាល ដោយមានធម៌ប្រសិទ្ធពរ ជាសញ្ញាសម្គាល់ដែលមើលឃើញនៃការប្រសិទ្ធពរនេះ។

## ២-អគ្គសញ្ញាតែងតាំងក្នុងការចាត់ចែងនៃការសង្គ្រោះ

### មុខងារជាបូជាចារ្យក្នុងសម្ព័ន្ធមេត្រីចាស់

១៥៣៩-ព្រះជាម្ចាស់បានចាត់ចែងប្រជារាស្ត្រ ដែលព្រះអង្គបានជ្រើសរើសឲ្យទៅជា "អាណាចក្របូជាចារ្យ និងជាប្រជាជាតិដ៏វិសុទ្ធ" (សរ ១៩,៦) (អស ៦១,៦)។ ប៉ុន្តែ នៅក្នុងប្រជារាស្ត្រអ៊ីស្រាអែល ព្រះជាម្ចាស់ជ្រើសរើសកុលសម្ព័ន្ធលេវី ក្នុងចំណោមកុលសម្ព័ន្ធទាំងដប់ពីរ ដើម្បីបម្រើពិធីបុណ្យ (ជរ ១,៤៨-៥៣)។ ព្រះជាម្ចាស់ផ្ទាល់ជាមរតករបស់ពួកគេ (យស ១៣,៣៣)។ ពិធីពិសេសមួយបានបញ្ជាក់ប្រភពនៃក្រុមបូជាចារ្យនៃសម្ព័ន្ធមេត្រីចាស់ (សរ ២៩,១-៣០; លវ ៨)។ ក្នុងពិធីនេះ ព្រះជាម្ចាស់តែងតាំងពួកបូជាចារ្យ "សម្រាប់ទាក់ទងជាមួយព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍ដល់មនុស្សលោក ក្នុងការថ្វាយតង្វាយ និងថ្វាយយញ្ញបូជារំដោះបាបមនុស្ស" (ហប ៥,១)។

១៥៤០-ទោះបីពួកបូជាចារ្យនោះ ដែលព្រះជាម្ចាស់បានតែងតាំង ដើម្បីប្រកាសព្រះបន្ទូលរបស់ព្រះអង្គ (មគ ២,៧-៩) ហើយដើម្បីឲ្យរួបរួមជាមួយព្រះអង្គឡើងវិញ ដោយយញ្ញបូជា និងការអធិដ្ឋានយ៉ាងណាក៏ដោយ ក៏

ពួកគេមិនអាចសង្គ្រោះបានទេ ពីព្រោះពួកគេតែងតែត្រូវបូជាយញ្ញ មិនអាចធ្វើឲ្យវិសុទ្ធជាស្ថាពរបានឡើយ (ហប ៥,៣; ៧,២៧; ១០,១-៤)។ មានតែយញ្ញបូជារបស់ព្រះគ្រីស្តទេ ដែលអាចសង្គ្រោះ និងប្រោសឲ្យបានវិសុទ្ធជាស្ថាពរ។

១៥៤១-ក៏ប៉ុន្តែ ពិធីបុណ្យព្រះសហគមន៍យល់ឃើញថា មុខងារជាបូជាចារ្យរបស់លោកអារ៉ូន កិច្ចបម្រើរបស់ក្រុមលេវី និងការតែងតាំង "ព្រឹទ្ធាចារ្យ" ចិតសិបនាក់ (ជរ ១១,២៤-២៥) ជានិមិត្តរូបទុកជាមុនរបស់ក្រុមបូជាចារ្យនៃសម្ពន្ធមេត្រីថ្មី។ ហេតុនេះហើយបានជាក្នុងពិធីខាងបស្ចិមប្រទេស ក្នុងធម៌ប្រារព្ធប្រសិទ្ធពរនៃពិធីតែងតាំងលោកអភិបាលព្រះសហគមន៍អង្វរ៖

ឱព្រះជាម្ចាស់ជាព្រះបិតារបស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើងខ្ញុំ (...) ក្នុងអំឡុងសម័យសម្ពន្ធមេត្រីចាស់ ព្រះអង្គចាប់ផ្តើមឲ្យព្រះសហគមន៍កើតជារូបរាង។ តាំងពីដើមរៀងមក ព្រះអង្គបានតម្រង់ប្រជាជនដែលចេញមកពីលោកអប្រាហាំ ឲ្យទៅជាប្រជាជនដ៏វិសុទ្ធ។ ព្រះអង្គបានតែងតាំងមេដឹកនាំ និងបូជាចារ្យ ហើយទ្រង់តែងតែជួយបម្រើទីសក្ការៈរបស់ព្រះអង្គជានិច្ច...

ក្នុងពិធីតែងតាំងលោកបូជាចារ្យ ព្រះសហគមន៍អង្វរ៖

ឱព្រះអម្ចាស់ជាព្រះបិតាដ៏វិសុទ្ធបំផុត (...) ដូចមានក្នុងសម្ពន្ធមេត្រីចាស់ស្រាប់ ព្រះអង្គបានតែងតាំងពួកមហាបូជាចារ្យ ដើម្បីដឹកនាំប្រជាជន ហើយព្រះអង្គក៏បានជ្រើសរើសមនុស្សផ្សេងទៀត ដើម្បីឲ្យពួកគេចូលរួមក្នុងកិច្ចបម្រើរបស់ពួកលោក និងជួយពួកលោកឲ្យបំពេញក្នុងមុខងារនោះ ហាក់ដូចជាព្រះអង្គប្រកាសទុកជាមុនអំពីអគ្គសញ្ញា។ ហេតុនេះហើយបានជាព្រះអង្គបានប្រោសប្រទានឲ្យមនុស្សប្រុសចិតសិបនាក់ពោរពេញដោយប្រាជ្ញាញាណ ព្រះវិញ្ញាណដែលព្រះអង្គបានប្រោសប្រទានឲ្យលោកម៉ូសេ ហើយទ្រង់បានធ្វើឲ្យកូនចៅរបស់លោកអារ៉ូនចូលរួមក្នុងពិធីប្រសិទ្ធពរ ដែលឪពុករបស់ពួកគេបានទទួល។

ឯក្នុងធម៌ប្រសិទ្ធពរក្នុងការតែងតាំងលោកឧបដ្ឋាក ព្រះសហគមន៍ប្រកាសថា៖

ឱព្រះបិតាដ៏វិសុទ្ធបំផុត (...) ដើម្បីកសាងព្រះវិហារថ្មីនេះ (ព្រះសហគមន៍) ព្រះអង្គបានតែងតាំងអ្នកបម្រើដែលមានថ្នាក់ផ្សេងពីគ្នា គឺលោកអភិបាល លោកបូជាចារ្យ និងលោកឧបដ្ឋាក ដែលសុទ្ធតែមានមុខងារបម្រើព្រះអង្គ ដូចកាលពីមុនក្នុងសម្ពន្ធមេត្រីចាស់ ព្រះអង្គបានញែកកូនចៅនៃកុលសម្ព័ន្ធលេវី ដែលទ្រង់ជាមរតករបស់ពួកគេ ដើម្បីបម្រើព្រះដំណាក់ព្រះអង្គ។

### ព្រះគ្រីស្តជាបូជាចារ្យតែមួយ

១៥៤៤-ព្រះគ្រីស្តយេស៊ូដែលជា "ស្ពានមេត្រីតែមួយរវាងព្រះជាម្ចាស់ និងមនុស្សលោក" (១ធម ២,៥) បំពេញនិមិត្តរូបទុកជាមុនទាំងអស់របស់ក្រុមបូជាចារ្យនៃសម្ពន្ធមេត្រីចាស់។ ការបញ្ជូនបន្តនៃគ្រីស្តសាសនាចាត់ទុកព្រះបាទមេលគីសេដែក "ជាបូជាចារ្យរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត" (កណ ១៤,១៨) ដូចជានិមិត្តរូបទុកជាមុនរបស់ព្រះគ្រីស្តជាបូជាចារ្យ ជា "មហាបូជាចារ្យតាមរបៀបព្រះបាទមេលគីសេដែក" (ហប ៥,១០; ៦,២០) "ដ៏វិសុទ្ធស្លូតត្រង់ ឥតសៅហ្មង" (ហប ៧,២៦) ដែល "ដោយសារតង្វាយតែមួយគត់ ព្រះគ្រីស្តធ្វើឲ្យអស់អ្នកដែលទ្រង់បានឲ្យវិសុទ្ធហើយនោះ បានគ្រប់លក្ខណៈរហូតទៅ" (ហប ១០,១៤) ពោលគឺដោយសារសក្ការបូជាតែមួយនៃព្រះឈើឆ្កាង។

១៥៤៥-ព្រះគ្រីស្តបានសង្គ្រោះមនុស្សលោក ដោយសារសក្ការបូជាតែមួយ ម្តងជាការស្រេច។ ក៏ប៉ុន្តែ សក្ការ

បូជានេះ មានវត្តមានក្នុងពិធីអភិបូជានៃព្រះសហគមន៍ ដូចចំពោះមុខងារជាបូជាចារ្យរបស់ព្រះគ្រីស្តផងដែរ ដែលមានវត្តមានតាមរយៈក្រុមបូជាចារ្យជាអ្នកបម្រើ។ ទោះបីមានក្រុមបូជាចារ្យនេះយ៉ាងណាក៏ដោយ ក៏ព្រះគ្រីស្តនៅតែជាបូជាចារ្យតែមួយគត់ដែរ៖ "ហេតុនេះហើយបានជាព្រះគ្រីស្តជាបូជាចារ្យដ៏ពិតប្រាកដតែមួយ ចំណែកឯបូជាចារ្យឯទៀត គ្រាន់តែជាអ្នកបម្រើព្រះអង្គប៉ុណ្ណោះ" (សន្តៈ ថូម៉ាស នៃអាកាំង)។

## យើងអាចចូលរួមចំណែកពីរយ៉ាងក្នុងមុខងារជាបូជាចារ្យរបស់ព្រះគ្រីស្ត

១៥៤៦-ព្រះគ្រីស្តជាមហាបូជាចារ្យ និងជាស្ពានមេត្រីតែមួយ ដែលបានធ្វើឲ្យព្រះសហគមន៍ទៅជា "រាជាណាចក្រ និងជាក្រុមបូជាចារ្យបម្រើព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះអង្គ" (*វវ* ១,៦) (*វវ* ៥,៩-១០; ១ពត្រ ២,៥.៩)។ សហគមន៍ទាំងមូលរបស់អ្នកជឿជាក្រុមបូជាចារ្យ។ គ្រីស្តបរិស័ទជាបូជាចារ្យដោយចូលរួមចំណែក តាមការត្រាស់ហៅរបស់ខ្លួន ក្នុងបេសកកម្មរបស់ព្រះគ្រីស្តជាបូជាចារ្យ ជាព្យាការី និងជាព្រះមហាក្សត្រ។ ដោយសារអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបថ្ងាស ព្រះជាម្ចាស់ "ប្រសិទ្ធពរឲ្យពួកគេទៅជា (...) ក្រុមបូជាចារ្យដ៏វិសុទ្ធ" (LG ១០)។

១៥៤៧-គ្រីស្តបរិស័ទទាំងអស់សុទ្ធតែជាបូជាចារ្យរួម ប៉ុន្តែមានគ្រីស្តបរិស័ទខ្លះ ជាអភិបាល ឬជាបូជាចារ្យសម្រាប់បម្រើព្រះសហគមន៍តាមលំដាប់លំដោយ។ ទោះបី "ឋានៈជាបូជាចារ្យទាំងពីរបែបនោះទទួលចំណែកពីព្រះគ្រីស្តជាបូជាចារ្យតែមួយព្រះអង្គគត់ តាមរបៀបរបស់ខ្លួន" (LG ១០) យ៉ាងណាក៏ដោយ ក៏ឋានៈជាបូជាចារ្យទាំងពីរនោះប្លែកពីគ្នាទាំងស្រុង ប៉ុន្តែ "ជាប់ទាក់ទិននឹងគ្នា" (LG ១០) ផងដែរ។ គ្រីស្តបរិស័ទទៅជាបូជាចារ្យដោយសារពិធីជ្រមុជទឹក ដោយរស់នៅក្នុងជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ និងដោយរស់នៅតាមព្រះវិញ្ញាណដ៏វិសុទ្ធ ឯអ្នកទទួលមុខងារជាបូជាចារ្យទៅជាបូជាចារ្យដោយបម្រើគ្រីស្តបរិស័ទឯទៀតៗដែលសុទ្ធតែជាបូជាចារ្យ។ ឋានៈជាបូជាចារ្យសម្រាប់បម្រើស្ថិតនៅក្រោមឋានៈជាបូជាចារ្យរបស់គ្រីស្តបរិស័ទទាំងអស់ ហើយជាមធ្យោបាយមួយ ដែលព្រះគ្រីស្តប្រើដើម្បីកសាង និងណែនាំព្រះសហគមន៍របស់ព្រះអង្គ។ ហេតុនេះហើយបានជាព្រះសហគមន៍បញ្ជូនមុខងារជាបូជាចារ្យសម្រាប់បម្រើតាមរយៈអគ្គសញ្ញាពិសេស គឺអគ្គសញ្ញាតែងតាំង។

ក្នុងអង្គព្រះគ្រីស្តជាព្រះសិរសា...

១៥៤៨-ក្នុងកិច្ចបម្រើព្រះសហគមន៍របស់អ្នកទទួលអគ្គសញ្ញាតែងតាំង ព្រះគ្រីស្តផ្ទាល់មានវត្តមានក្នុង ព្រះសហគមន៍ព្រះអង្គ ក្នុងឋានៈជាព្រះសិរសានៃព្រះកាយព្រះអង្គ គង្វាលនៃហ្វូងចៀមរបស់ព្រះអង្គ មហាបូជាចារ្យនៃសក្ការបូជាដែលសង្គ្រោះមនុស្សលោក ម្ចាស់នៃសេចក្តីពិត។ ព្រះសហគមន៍ថ្លែងថា ដោយសារអគ្គសញ្ញាតែងតាំង លោកបូជាចារ្យបំពេញកិច្ចការបម្រើ **in persona Christi Capitis** (ក្នុងអង្គព្រះគ្រីស្តជាព្រះសិរសា) (LG ១០; ២៨; SC ៣៣; CD ១១; PO ២; ៦)៖

> តាមការពិតទៅ អ្នកបម្រើទទួលមុខងាររបស់លោកបូជាចារ្យដដែល គឺព្រះគ្រីស្តយេស៊ូ។ តាមការពិតអ្នកបម្រើនេះ ហាក់ដូចជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុត ដោយសារពិធីតែងតាំងជាបូជាចារ្យ ដែលខ្លួនបានទទួល លោកទទួលអំណាចបំពេញកិច្ចការ ដោយសារឫទ្ធានុភាពរបស់ព្រះគ្រីស្ត ដែលខ្លួនលោកជាតំណាង (**virtute ac persona ipsius Christi** ) (សម្តេចប៉ាប ពីយូសទី១២)។

ព្រះគ្រីស្តជាប្រភពនៃក្រុមបូជាចារ្យទាំងអស់ ដ្បិតអស់លោកបូជាចារ្យនៃធម្មវិន័យចាស់ ជាតំណាងរបស់ព្រះគ្រីស្ត ឯអស់លោកបូជាចារ្យនៃធម្មវិន័យថ្មី បំពេញសកម្មភាពក្នុងអង្គព្រះគ្រីស្ត (សន្តៈ ថូម៉ាស នៃអាកាំង)។

១៥៤៩-ដោយសារមុខងារបម្រើព្រះសហគមន៍ ជាពិសេសរបស់លោកអភិបាល និងលោកបូជាចារ្យ យើងអាច

មើលឃើញវត្តមានរបស់ព្រះគ្រីស្ត ដែលជាមេដឹកនាំព្រះសហគមន៍ ក្នុងចំណោមសហគមន៍របស់អ្នកជឿ (LG ២១)។ តាមពាក្យសម្ដីដ៏ពិរោះរបស់សន្ត: អ៊ីញ៉ាស នៃអង់ទីអូស លោកអភិបាលជា **typos tou Patros** គឺលោកជារូបដ៏រស់រវើករបស់ព្រះជាម្ចាស់ជាព្រះបិតា។

១៥៥០-ទោះបីវត្តមានរបស់ព្រះគ្រីស្ត ស្ថិតនៅក្នុងអ្នកទទួលមុខងារបម្រើព្រះសហគមន៍យ៉ាងណាក៏ដោយ ក៏យើងមិនត្រូវយល់ថា ព្រះជាម្ចាស់ការពារអ្នកបម្រើនេះ ពីភាពទន់ខ្សោយរបស់មនុស្ស ចិត្តលោភលន់ កំហុស ឬអំពើបាបឡើយ។ ឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធមិនទទួលខុសត្រូវលើកិច្ចការទាំងអស់របស់អ្នកបម្រើនោះឡើយ។ ព្រះវិញ្ញាណធានាថា ទោះបីអ្នកបម្រើប្រព្រឹត្តបាបក៏ដោយ ក៏អគ្គសញ្ញានៅតែបង្កើតផលដែរ ប៉ុន្តែ មានកិច្ចការជាច្រើនផ្សេងទៀត ដែលភាពជាមនុស្សរបស់អ្នកបម្រើបង្កើតផលវិបាក ដែលមិនស្របនឹងដំណឹងល្អ ហើយដែលអាចព្យាបាទព្រះសហគមន៍មិនឲ្យបង្កើតផលផ្លែបានឡើយ។

១៥៥១-ក្រុមបូជាចារ្យនោះ មានមុខងារបម្រើ ។ "ព្រះអម្ចាស់បានផ្ញើបន្ទុក ដែលជាកិច្ចបម្រើ ដ៏ពិតប្រាកដនេះឲ្យគង្វាលនៃប្រជារាស្ត្ររបស់ព្រះអង្គ" (LG ២៤) សំអាងទៅលើព្រះគ្រីស្ត និងមនុស្សលោក។ កិច្ចបម្រើនេះពឹងផ្អែកទាំងស្រុងលើព្រះគ្រីស្ត ដែលជាបូជាចារ្យតែមួយ ហើយព្រះជាម្ចាស់បានតែងតាំងកិច្ចបម្រើនេះ ចំពោះមនុស្សលោក និងព្រះសហគមន៍។ អគ្គសញ្ញាតែងតាំងផ្ដល់ "អំណាចដ៏ពិសិដ្ឋ" ដែលជាអំណាចរបស់ព្រះគ្រីស្តតែម្ដង។ យើងត្រូវប្រតិបត្តិតាមអំណាចនេះ ដោយយកតម្រាប់តាមព្រះគ្រីស្ត ដែលបានទៅជាអ្នកបម្រើរបស់មនុស្សទាំងអស់ (មក ១០,៤៣-៤៥) ដោយសារសេចក្ដីស្រឡាញ់។ "ព្រះអម្ចាស់មានព្រះបន្ទូលយ៉ាងច្បាស់ថា បើយើងថែទាំហ្វូងចៀមរបស់ព្រះអង្គ យើងក៏បង្ហាញភស្តុតាងថា យើងស្រឡាញ់ព្រះអង្គដែរ" (សន្ត: យ៉ូហាន គ្រីសូស្តូម; យហ ២១,១៥-១៧)។

... "**ក្នុងនាមព្រះសហគមន៍ទាំងមូល**"

១៥៥២-អ្នកទទួលតែងតាំងជាបូជាចារ្យសម្រាប់បម្រើព្រះសហគមន៍ មិនគ្រាន់តែមានមុខងារតំណាងព្រះគ្រីស្តជាព្រះសិរសាព្រះសហគមន៍ ចំពោះអង្គប្រជុំរបស់គ្រីស្តបរិស័ទប៉ុណ្ណោះទេ គឺលោកមានសកម្មភាពក្នុងនាមព្រះសហគមន៍ទាំងមូល នៅពេលដែលលោកថ្វាយការអធិដ្ឋានរបស់ព្រះសហគមន៍ចំពោះព្រះជាម្ចាស់ ហើយជាពិសេសនៅពេលដែលលោកថ្វាយអភិបូជា (LG ១០)។

១៥៥៣-"ក្នុងនាមព្រះសហគមន៍ទាំងមូល" ពុំមានន័យថា ពួកបូជាចារ្យជាប្រតិភូនៃសហគមន៍ឡើយ។ ការអធិដ្ឋាន និងតង្វាយរបស់ព្រះសហគមន៍មិនអាចបែកចេញពីការអធិដ្ឋាន និងតង្វាយរបស់ព្រះគ្រីស្ត ដែលជាមេដឹកនាំរបស់ព្រះសហគមន៍ឡើយ គឺនៅក្នុង និងតាមរយៈព្រះសហគមន៍ យើងគោរពប្រណិប័តន៍ព្រះគ្រីស្តតែមួយអង្គ។ គឺព្រះសហគមន៍ទាំងមូល ក្នុងឋានៈជាព្រះកាយព្រះគ្រិស្ត ដែលអធិដ្ឋាន និងថ្វាយខ្លួនចំពោះព្រះជាម្ចាស់ជាព្រះបិតា "ដោយព្រះគ្រីស្តជាមួយព្រះអង្គ និងក្នុងអង្គព្រះអង្គ" រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង។ ព្រះកាយទាំងមូល **caput et membra** (ព្រះសិរសា និងអវយវៈ) អធិដ្ឋាន និងថ្វាយខ្លួន អាស្រ័យហេតុនេះហើយបានជាគេហៅអស់អ្នកដែលជាអ្នកបម្រើពិសេសក្នុងព្រះកាយនេះ ជាអ្នកបម្រើរបស់ព្រះគ្រីស្តផង របស់ព្រះសហគមន៍ផង។ ដោយសារអ្នកទទួលការតែងតាំងជាបូជាចារ្យសម្រាប់បម្រើជាតំណាងរបស់ព្រះគ្រីស្ត គេអាចធ្វើជាតំណាងរបស់ព្រះសហគមន៍ផងដែរ។

## ៣-លំដាប់ថ្នាក់ទាំងបីនៃអគ្គសញ្ញាតែងតាំង

១៥៥៤-"មានគ្រីស្តបរិស័ទខ្លះ បំពេញមុខងារបម្រើ ដែលព្រះជាម្ចាស់បានតែងតាំងក្នុងព្រះសហគមន៍ តាមលំដាប់ថ្នាក់ផ្សេងៗ ដែលគ្រីស្តបរិស័ទតាំងពីដើមរៀងមកធ្លាប់ហៅថា អភិបាល បូជាចារ្យ និង ឧបដ្ឋាក" (LG ២៨)។ លទ្ធិនៃព្រះសហគមន៍កាតូលិក ដែលមានសម្តែងក្នុងពិធីបុណ្យ ក្រុមមេដឹកនាំ និងរបៀបប្រតិបត្តិដ៏ស្ថិតស្ថេររបស់ព្រះសហគមន៍ ទទួលស្គាល់ថា យើងអាចចូលរួមចំណែកក្នុងឋានៈជាបូជាចារ្យរបស់ព្រះគ្រីស្តជាអ្នកបម្រើបានពីរថ្នាក់ គឺឋានៈជាអភិបាល ឋានៈជាបូជាចារ្យ។ ឯលោកឧបដ្ឋាក ត្រូវជួយ និងបម្រើពួកលោកវិញ។ ហេតុនេះហើយ បានជាសព្វថ្ងៃ ពាក្យ sacerdos (បូជាចារ្យ) សំដៅទៅលើលោកអភិបាល និងលោកបូជាចារ្យ ប៉ុន្តែ មិនសំដៅទៅលើលោកឧបដ្ឋាកឡើយ។ ក៏ប៉ុន្តែ លទ្ធិនៃព្រះសហគមន៍កាតូលិកបង្រៀនថា កិច្ចការខាងអគ្គសញ្ញាមួយ ដែលគេហៅថា "តែងតាំង" ពោលគឺអគ្គសញ្ញាតែងតាំង ធ្វើឲ្យលោកអភិបាល និងលោកបូជាចារ្យចូលរួមចំណែកក្នុងថ្នាក់ជាបូជាចារ្យ ហើយធ្វើឲ្យឧបដ្ឋាកចូលរួមចំណែកក្នុងថ្នាក់ជាអ្នកបម្រើ។

សូមអ្នករាល់គ្នាគោរពពួកលោកឧបដ្ឋាកដូចព្រះយេស៊ូគ្រីស្ត ដូចអ្នករាល់គ្នាគោរពលោកអភិបាលផងដែរ ដែលជារូបតំណាងរបស់ព្រះបិតា ហើយសូមគោរពពួកបូជាចារ្យដូចជាព្រឹទ្ធសភារបស់ព្រះជាម្ចាស់ និងអង្គប្រជុំរបស់ក្រុមគ្រីស្តទូត៖ បើគ្មានពួកលោកទេ យើងមិនអាចនិយាយអំពីព្រះសហគមន៍បានឡើយ (សន្តៈអ៊ីញ៉ាសនៃអង់ទីអូស)។

### ការតែងតាំងជាអភិបាលជាអគ្គសញ្ញាតែងតាំងពេញបរិបូណ៌

១៥៥៥-"តាំងពីដើមដំបូងមក ក្នុងចំណោមមុខងារបម្រើព្រះសហគមន៍ មុខងារដ៏សំខាន់ជាងគេ គឺមុខងារជាអភិបាល ដូចការបញ្ជូនបន្តធ្វើជាសាក្សីស្រាប់។ អស់លោកដែលទទួលមុខងារជាអភិបាលមានខ្សែតាំងពីដើមដំបូងរៀងមកម្ល៉េះ អស់លោកប្រៀបដូចជាខ្នែងដែលគេផ្សាំមក បន្តពូជជាគ្រីស្តទូតរហូតមក" (LG ២០)។

១៥៥៦-"ព្រះគ្រីស្តបានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ ដែលយាងមកសណ្ឋិតលើក្រុមគ្រីស្តទូតយ៉ាងពិសេស ដើម្បីឲ្យអស់លោកអាចបំពេញបន្ទុកដ៏ខ្ពង់ខ្ពស់ទាំងនេះ។ រីឯក្រុមគ្រីស្តទូតក៏បញ្ជូនបន្តព្រះអំណោទានខាងវិញ្ញាណនេះឲ្យសហការីរបស់អស់លោក ដោយពិធីដាក់ដៃលើគាត់ រហូតដល់មកយើងសព្វថ្ងៃ" (LG ២១)។

១៥៥៧-"មហាសន្និបាតដ៏វិសុទ្ធបង្រៀនថា ដោយអគ្គសញ្ញាតែងតាំងជាអភិបាល អស់លោកទទួលមុខងារជាបូជាចារ្យយ៉ាងពេញលក្ខណៈ។ ប្រពៃណីខាងពិធីបុណ្យរបស់ព្រះសហគមន៍ និងគ្រូបាធ្យាយតែងតែបញ្ជាក់ថា ពេលលោកអភិបាលទទួលអគ្គសញ្ញាតែងតាំងជាអភិបាល លោកទទួលមុខងារជាបូជាចារ្យយ៉ាងខ្ពង់ខ្ពស់បំផុត និងទទួលមុខងារជាបូជាចារ្យយ៉ាងពេញកម្រិត (summa)" (LG ២១)។

១៥៥៨-"អគ្គសញ្ញាតែងតាំងជាអភិបាលផ្តល់ឲ្យលោកមានបន្ទុកណែនាំគេឲ្យបានវិសុទ្ធ ព្រមទាំងឲ្យលោកមានបន្ទុកបង្រៀន និងត្រួតត្រាព្រះសហគមន៍ (...) ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានព្រះអំណោយទានដល់អស់លោកដោយសារពិធីដាក់ដៃ និងដោយពាក្យក្នុងពិធីប្រសិទ្ធពរ ព្រមទាំងចាក់លក្ខណៈដ៏ពិសិដ្ឋនៅក្នុងលោកទៀតផង។ ហេតុនេះហើយបានជាអស់លោកអភិបាលពិតជាតំណាងរបស់ព្រះគ្រីស្តផ្ទាល់ ដែលព្រះអង្គជាព្រះបរមគ្រូ ជាគង្វាល និងជាមហាបូជាចារ្យ។ អស់លោកក៏បំពេញមុខងាររបស់ព្រះអង្គដែរ (in Eius persona agant ) (LG ២១)។ "ហេតុនេះហើយបានជាដោយសារព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ លោកអភិបាលបានទៅជាព្រះបរមគ្រូដ៏ពិតប្រាកដនៃជំនឿ ជាមហាបូជាចារ្យ និងជាគង្វាល" (CD ២)។

១៥៥៩-"គ្រីស្តបរិស័ទម្នាក់ចូលក្នុងក្រុមអភិបាល ដោយអគ្គសញ្ញាតែងតាំងជាអភិបាល និងដោយរួបរួមជាមួយ

មេដឹកនាំនៃក្រុមអភិបាល ព្រមទាំងដោយរួបរួមជាមួយអភិបាលឯទៀតៗដែរ" (LG ២២)។ របៀបប្រតិបត្តិពីបុរាណកាលរបស់ព្រះសហគមន៍ ដែលធ្លាប់ហៅអភិបាលជាច្រើនឲ្យចូលរួមចំណែកក្នុងអគ្គសញ្ញាតែងតាំង ជាអភិបាលថ្មីសម្តែងលក្ខណៈនៃក្រុមអភិបាលដែលតែងតែរួបរួមជាមួយគ្នា (LG ២២)។ សព្វថ្ងៃ ដោយសារលោកអភិបាលនៅទីក្រុងរ៉ូមជាចំណងដ៏ខ្ពង់ខ្ពស់បំផុត ដែលអាចមើលឃើញនៃការរួបរួមគ្នារវាងព្រះសហគមន៍តាមភូមិភាគ ក្នុងព្រះសហគមន៍តែមួយ ហើយដោយសារលោកធានាសេរីភាពរបស់ព្រះសហគមន៍ទាំងអស់នោះ លោកក៏ត្រូវតែធ្វើអន្តរាគមន៍ពិសេស ដើម្បីឲ្យពិធីតែងតាំងលោកអភិបាលម្នាក់បានត្រឹមត្រូវតាមច្បាប់។

១៥៦០-លោកអភិបាលម្នាក់ៗ ក្នុងឋានៈជាតំណាងព្រះគ្រីស្ត មានបន្ទុកដឹកនាំព្រះសហគមន៍ភូមិភាគ ដែលគេបានប្រគល់ឲ្យលោក ប៉ុន្តែ នៅពេលជាមួយគ្នានេះ លោករួបរួមជាមួយបងប្អូន លោកជាអភិបាលក្នុងការយកចិត្តទុកដាក់លើព្រះសហគមន៍ទាំងឡាយ៖ "ទោះបីលោកអភិបាលម្នាក់ៗជាគង្វាលពិសេសសម្រាប់តែហ្វូងចៀមរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏ដោយសារព្រះជាម្ចាស់បានតែងតាំងលោកឲ្យបន្តមុខងាររបស់ក្រុមគ្រីស្តទូត លោករួមសាមគ្គីក្នុងការទទួលខុសត្រូវបេសកកម្មរបស់ព្រះសហគមន៍ដែរ" (សម្តេចប៉ាប ពីយូសទី១២; LG ២៣; CD ៤; ៣៦; ៣៧; AG ៥; ៦; ៣៨)។

១៥៦១-អ្វីៗទាំងអស់ដែលយើងទើបនឹងបរិយាយពន្យល់ថា ពិធីអរព្រះគុណ ដែលមានលោកអភិបាលធ្វើជាអធិបតី មានអត្ថន័យយ៉ាងពិសេស គឺសម្តែងថា ព្រះសហគមន៍រួបរួមគ្នា នៅជុំវិញអាសនៈ ក្រោមការដឹកនាំរបស់អ្នកដែលជារូបតំណាងរបស់ព្រះគ្រីស្ត ជាគង្វាលដ៏ល្អ និងព្រះសិរសានៃព្រះសហគមន៍ព្រះអង្គ (SC ៤១; LG ២៦)។

## អគ្គសញ្ញាតែងតាំងលោកបូជាចារ្យជាសហការីរបស់លោកអភិបាល

១៥៦២-"ព្រះបិតាបានប្រសិទ្ធព្រះគ្រីស្តឲ្យបានវិសុទ្ធ ហើយចាត់ព្រះអង្គឲ្យយាងមកក្នុងពិភពលោកតាមរយៈក្រុមគ្រីស្តទូត ព្រះគ្រីស្តក៏បានប្រោសឲ្យអស់លោកអភិបាលដែលបន្តមុខងារពីក្រុមគ្រីស្តទូតមក បានវិសុទ្ធរួមជាមួយព្រះអង្គ និងទទួលបេសកកម្មរួមជាមួយព្រះអង្គដែរ។ រីឯក្រុមអភិបាលវិញ អស់លោកបានបញ្ជូនបន្តយ៉ាងត្រឹមត្រូវនូវបន្ទុកនៃមុខងាររបស់អស់លោកឲ្យគ្រីស្តបរិស័ទផ្សេងៗតទៅទៀតក្នុងព្រះសហគមន៍ តាមកម្រិតផ្សេងៗ" (LG ២៨)។ "ព្រះសហគមន៍បញ្ជូនបន្តមុខងារបម្រើរបស់លោកអភិបាលទៅដល់លោកបូជាចារ្យដែរ តាមកម្រិតទាបជាង។ អស់លោកត្រូវគេតែងតាំងជាក្រុមបូជាចារ្យដូច្នេះ ដើម្បីទៅជាសហការីរបស់ក្រុមអភិបាល ក្នុងកិច្ចបំពេញបេសកកម្មជាគ្រីស្តទូត ដែលព្រះគ្រីស្តបានផ្ញើទុកឲ្យក្រុមអភិបាល" (PO ២)។

១៥៦៣-"អស់លោកបូជាចារ្យមានមុខងារភ្ជាប់ជាមួយនឹងក្រុមលោកអភិបាល។ ហេតុនេះហើយបានជាបូជាចារ្យចូលរួមចំណែកក្នុងអំណាចរួមរបស់ព្រះគ្រីស្តផ្ទាល់ ដែលព្រះអង្គសាងសង់ព្រះកាយព្រះអង្គផង ប្រោសឲ្យព្រះកាយនេះបានវិសុទ្ធ និងត្រួតត្រាព្រះកាយនេះទៀតផង។ ហេតុនេះហើយ ព្រះសហគមន៍ផ្ញើមុខងារជាបូជាចារ្យ ដោយសារអគ្គសញ្ញាដ៏ពិសេសមួយ គឺដោយអគ្គសញ្ញាតែងតាំង ថ្វីដ្បិតអស់លោកត្រូវទទួលអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញជាមុនសិនក៏ដោយ។ ដោយសារអគ្គសញ្ញាតែងតាំងនេះ ព្រះវិញ្ញាណដ៏វិសុទ្ធលាបប្រេងអភិសេក ដៅចំណាំអស់លោកឲ្យមានលក្ខណៈពិសេស គឺព្រះអង្គប្រោសឲ្យអស់លោកបានដូចព្រះគ្រីស្តជាមហាបូជាចារ្យ ដើម្បីឲ្យអស់លោកមានសមត្ថភាពអាចប្រព្រឹត្តកិច្ចក្នុងនាមព្រះគ្រីស្តផ្ទាល់ជាព្រះសិរសា" (PO ២)។

១៥៦៤-"ទោះបីបូជាចារ្យមិនទទួលបន្ទុកពេញលេញជាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុតក្តី ទោះបីបូជាចារ្យ នៅពេលប្រើអំណាចស្ថិតនៅក្រោមអភិបាលក្តី ក៏បូជាចារ្យរួបរួមជាមួយលោកអភិបាលក្នុងឋានៈលោកជាបូជាចារ្យ។ ដោយ

អស់លោកទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើឲ្យបានដូចព្រះគ្រីស្តជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់ ដែលស្ថិតនៅអស់កល្បជានិច្ច (ហប ៥,១-១០; ៧,២៤; ៩,១១-២៨) ព្រះអង្គបានប្រសិទ្ធអស់លោកបូជាចារ្យ ដើម្បីឲ្យប្រកាសដំណឹងល្អ ឲ្យទៅជាគង្វាលរបស់គ្រីស្តបរិស័ទ និងគោរពបម្រើព្រះជាម្ចាស់ក្នុងឋានៈជាបូជាចារ្យនៃសម្ពន្ធមេត្រីថ្មីយ៉ាងពិតប្រាកដ " (LG ២៨)។

១៥៦៥-ដោយសារអគ្គសញ្ញាតែងតាំង លោកបូជាចារ្យចូលរួមចំណែកក្នុងបេសកកម្មសកល ដែលព្រះគ្រីស្តបានប្រគល់ឲ្យក្រុមគ្រីស្តទូត។ ព្រះអំណោយទានខាងវិញ្ញាណ ដែលពួកលោកបានទទួលក្នុងអគ្គសញ្ញាតែងតាំងរៀបចំពួកលោក មិនគ្រាន់តែឲ្យបំពេញបេសកកម្មតូច ដែលមានកំណត់ទេ គឺបេសកកម្មសង្គ្រោះ "រហូតដល់ស្រុកដាច់ស្រយាលនៃផែនដី" (PO ១០) "ដោយត្រៀមខ្លួនអស់ពីចិត្តឲ្យទៅប្រកាសដំណឹងល្អ កន្លែងណាក៏បាន" (OT ២០)។

១៥៦៦-"អស់លោកបំពេញបន្ទុកដ៏ពិសិដ្ឋរបស់អស់លោកយ៉ាងពិសេសក្នុងពិធីអរព្រះគុណ គឺនៅពេលនោះអស់លោកប្រព្រឹត្តកិច្ចការក្នុងព្រះនាមព្រះគ្រីស្ត និងជំនួសព្រះអង្គ ហើយប្រកាសគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ។ អស់លោកប្រមូលពាក្យអង្វររបស់គ្រីស្តបរិស័ទឲ្យរួបរួមជាមួយសក្ការបូជានៃម្ចាស់របស់គេ។ អស់លោកធ្វើឲ្យសក្ការបូជាតែមួយគត់របស់ព្រះគ្រីស្ត ដែលបានបូជាព្រះជន្មទុកជាយញ្ញបូជាឥតសៅហ្មងថ្វាយទៅព្រះបិតាម្តងជាការស្រេច ស្ថិតនៅកន្លែង នៅពេលអស់លោកថ្វាយអភិបូជាផង" (LG ២៨)។ អ្នកទទួលមុខងារជាបូជាចារ្យសម្រាប់បម្រើព្រះសហគមន៍ប្រមូលកម្លាំងរបស់ខ្លួនទាំងអស់ចេញពីសក្ការបូជាតែមួយនេះ (PO ២)។

១៥៦៧-"អស់លោកបូជាចារ្យជាសហការីដ៏ឈ្លាសវៃរបស់ក្រុមអភិបាល ក្នុងឋានៈជាអ្នកជួយ និងជាឧបករណ៍។ អស់លោកបូជាចារ្យបម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយរួបរួមជាមួយអភិបាលរបស់ខ្លួន ជាក្រុមបូជាចារ្យតែមួយ ដែលមានមុខងារផ្សេងៗពីគ្នា។ នៅគ្រប់កន្លែងដែលមានសហគមន៍គ្រីស្តបរិស័ទ អស់លោកប្រៀបបីដូចជាវត្តមានរបស់លោកអភិបាល ដោយពួកលោករួមសហការជាមួយលោកអភិបាលដោយទុកចិត្ត និងដោយមានចិត្តទូលំទូលាយ ព្រមទាំងសុខចិត្តទទួលចំណែកនៃបន្ទុក និងចិត្តស្រឡាញ់របស់លោក។ ពួកលោកយកចិត្តទុកដាក់បម្រើគ្រីស្តបរិស័ទជារៀងរាល់ថ្ងៃ តាមបន្ទុក និងចិត្តស្រឡាញ់នោះ" (LG ២៨)។ ពួកបូជាចារ្យត្រូវតែប្រតិបត្តិតាមមុខងាររបស់ខ្លួន ដោយពឹងផ្អែកលើលោកអភិបាល និងដោយរួបរួមជាមួយលោក។ នៅពេលពួកលោកទទួលការតែងតាំង ពួកលោកសន្យាស្តាប់បង្គាប់លោកអភិបាល ហើយនៅទីចុងក្រោយនៃពិធីបុណ្យ ពួកលោកឱបលោកអភិបាល ជាសញ្ញាសម្គាល់បង្ហាញថា លោកអភិបាលចាត់ទុកពួកលោកដូចជាសហការី ជាកូន ជាបងប្អូន និងជាមិត្តសម្លាញ់របស់លោក ហើយពួកគេត្រូវតែស្រឡាញ់ និងស្តាប់បង្គាប់លោកវិញ។

១៥៦៨-"ដោយបូជាចារ្យទាំងអស់ទទួលអគ្គសញ្ញាតែងតាំង អស់លោកចូលក្នុងក្រុមបូជាចារ្យ ហើយក៏ភ្ជាប់ជាមួយគ្នាយ៉ាងជិតស្និទ្ធទុកជាបងប្អូន ដែលទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យតែមួយដូចគ្នាដែរ។ អស់លោកក៏រួមគ្នាយ៉ាងពិសេស ជាក្រុមបូជាចារ្យតែមួយគត់ ស្ថិតក្រោមអំណាចអភិបាលភូមិភាគដែលអស់លោកបម្រើ" (PO ៨)។ តាមទំនៀមទម្លាប់នៃពិធីបុណ្យ បន្ទាប់ពីលោកអភិបាល ពួកលោកបូជាចារ្យដាក់ដៃលើបេក្ខជន នៅក្នុងពិធីតែងតាំង ដើម្បីសម្តែងថា ពួកលោកបូជាចារ្យរួមជាមួយគ្នាជាធ្លុងតែមួយ។

### អគ្គសញ្ញាតែងតាំងជាឧបដ្ឋាក "ដើម្បីបម្រើ"

១៥៦៩-"ក្នុងរចនាសម្ពន្ធនៃមុខងារបម្រើព្រះសហគមន៍តាមលំដាប់លំដោយ ក្រុមឧបដ្ឋាកស្ថិតនៅកម្រិតទាប

ជាងគេ លោកអភិបាលដាក់ដៃលើគេ "មិនមែនដើម្បីឲ្យទៅជាបូជាចារ្យទេ តែឲ្យគេបម្រើ" (LG ២៩; CD ១៥)។ ក្នុងអគ្គសញ្ញាតែងតាំងជាឧបដ្ឋាក មានតែលោកអភិបាល ដែលធ្វើពិធីដាក់ដៃ ដើម្បីបង្ហាញថា លោក ឧបដ្ឋាកជាប់ចំណងយ៉ាងពិសេសនឹងលោកអភិបាលក្នុងកិច្ចការនៃ "កិច្ចបម្រើ" របស់លោក (សន្ត: អ៊ីប៉ូលីត)។

១៥៧០-ក្រុមឧបដ្ឋាកចូលរួមចំណែកយ៉ាងពិសេសក្នុងបេសកកម្ម និងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្ត (LG ៤១; AA ១៦)។ អគ្គសញ្ញាតែងតាំងដៅចំណាមពួកលោក ដូចជាមានស្លាកស្នាម ("លក្ខណៈ") ដែលគ្មាននរណាម្នាក់អាចលុបបំបាត់បានឡើយ ហើយដែលធ្វើឲ្យពួកលោករួមរស់ជាមួយព្រះគ្រីស្ត ដែលបានទៅជា "ឧបដ្ឋាក" គឺអ្នកបម្រើរបស់មនុស្សទាំងអស់ (មក ១០,៤៥; លក ២២,២៧; សន្ត: ប៉ូលីកាប)។ ក្រុមឧបដ្ឋាកមានមុខងារជួយលោកអភិបាល និងលោកបូជាចារ្យក្នុងការលើកតម្កើងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ជាពិសេស អភិបូជា ចែកព្រះកាយព្រះគ្រីស្ត ជួយបម្រើអគ្គសញ្ញាអាពាហ៍ពិពាហ៍ និងប្រទានពរដល់គូស្វាមីភរិយា ប្រកាសដំណឹងល្អ និងទេសនាណែនាំពិធីបញ្ចុះសព និងចូលរួមក្នុងក្រុមសង្គារៈផ្សេងៗ (LG ២៩; SC ៣៥,៤; AG ១៦)។

១៥៧១-ចាប់តាំងពីមហាសន្និបាតទីពីរនៅវ៉ាទីកង់ ព្រះសហគមន៍ខាងបស្ចិមប្រទេសបានតែងតាំងមុខងារជាឧបដ្ឋាកឡើងវិញ "តាមកម្រិតផ្ទាល់ និងទុកជាមុខងារអចិន្ត្រៃយ៍ក្នុងរចនាសម្ពន្ធ តាមលំដាប់លំដោយនៃព្រះសហគមន៍" (LG ២៩) ឯព្រះសហគមន៍ខាងបូព៌ាប្រទេសតែងតែរក្សាទុកមុខងារនេះជានិច្ច។ មុខងារជាឧបដ្ឋាកអចិន្ត្រៃយ៍នេះ ដែលយើងអាចប្រគល់ទៅមនុស្សប្រុសដែលមានភរិយាហើយ ដូចជាទ្រព្យសម្បត្តិសំខាន់សម្រាប់ព្រះសហគមន៍។ តាមការពិត អ្នកដែលបំពេញមុខងារនេះ ពិតជាអ្នកបម្រើគេ ក្នុងកិច្ចការខាងពិធីបុណ្យ ឬក្នុងការប្រកាសដំណឹងល្អ ក្នុងកិច្ចការខាងសង្គម ឬកិច្ចការដែលសម្ដែងសេចក្តីស្រឡាញ់ នៅក្នុងព្រះសហគមន៍។ គួរ "ពង្រឹងកម្លាំងបុរសទាំងនោះ ដោយធ្វើពិធីដាក់ដៃលើគេ ជាពិធីក្រុមគ្រីស្តទូតបញ្ជូនបន្តមក។ អស់លោកក៏ត្រូវរួបរួមយ៉ាងជិតស្និទ្ធនឹងអាសនៈ ពោលគឺក្នុងអភិបូជា ដើម្បីឲ្យអស់លោកអាចបំពេញមុខងារបម្រើរបស់ខ្លួនយ៉ាងសកម្មជាង តាមព្រះជាម្ចាស់ប្រណីសន្ដោសដល់អស់លោក ដោយសារអគ្គសញ្ញាតែងតាំងជាឧបដ្ឋាក" (AG ១៦)។

## ៤-ពិធីប្រារព្ធអគ្គសញ្ញានេះ

១៥៧២-ពិធីប្រារព្ធអគ្គសញ្ញាតែងតាំងលោកអភិបាល លោកបូជាចារ្យ ឬលោកឧបដ្ឋាកជាកិច្ចការសំខាន់ណាស់ សម្រាប់ព្រះសហគមន៍ភូមិភាគ គ្រីស្តបរិស័ទត្រូវតែបានចូលរួមឲ្យបានច្រើន។ គួរប្រារព្ធពិធីនេះ យ៉ាងឧឡារិក នៅថ្ងៃអាទិត្យ ក្នុងព្រះវិសាលវិហារ។ អគ្គសញ្ញាតែងតាំងទាំងបីរបស់លោកអភិបាល លោកបូជាចារ្យ និងលោកឧបដ្ឋាក មានរចនាសម្ព័ន្ធដូចគ្នា ហើយស្ថិតក្នុងពិធីអរព្រះគុណ។

១៥៧៣-ពិធីសំខាន់ៗ នៃអគ្គសញ្ញាតែងតាំងសម្រាប់ថ្នាក់ទាំងបី គឺលោកអភិបាលដាក់ដៃលើក្បាលរបស់បេក្ខជន ហើយធម៌ប្រសិទ្ធពរអង្វរព្រះជាម្ចាស់ឲ្យព្រះអង្គចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះអំណោយទានផ្សេងៗ តាមមុខងាររបស់បេក្ខជន (សម្ដេចប៉ាប ពីយូសទី១២៖ DS ៣៨៥៨)។

១៥៧៤-ដូចអគ្គសញ្ញាឯទៀតៗ មានពិធីផ្សេងៗទៀតក្នុងពិធីលើកតម្កើង។ ពិធីនោះ ផ្លាស់ប្ដូរខ្លាំងណាស់តាមប្រពៃណីនៃពិធីបុណ្យផ្សេងៗ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏នៅតែរួបរួមគ្នាក្នុងការសម្ដែងលក្ខណៈផ្សេងៗនៃព្រះអំណោយទានរបស់អគ្គសញ្ញានានាដែរ។ ហេតុនេះ ពិធីដើមដំបូងនៃពិធីបុណ្យខាងបស្ចិមប្រទេស (ការណែនាំបេក្ខជន ការត្រាស់ហៅគាត់ សេចក្តីផ្ដើមរបស់លោកអភិបាល ការសួរចម្លើយបេក្ខជន ពិធីអង្វរសន្តបុគ្គលទាំងឡាយ) បញ្ជាក់ថា យើងបានជ្រើសរើសបេក្ខជនស្របតាមទំនៀមទម្លាប់របស់ព្រះសហគមន៍ ហើយ

រៀបចំពិធីប្រសិទ្ធពរយ៉ាងឧឡារិក។ បន្ទាប់មក ពិធីផ្សេងៗទៀតសម្តែង និងបញ្ចប់តាមរបៀបជានិមិត្តរូប នូវគម្រោងការដ៏អស្ចារ្យដែលទើបនឹងកើតឡើង គឺសម្រាប់លោកអភិបាល និងលោកបូជាចារ្យ ពិធីចាក់ប្រេងគ្រីស្មា ដែលជាសញ្ញាសម្គាល់ពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យមុខងាររបស់ពួកលោកបង្កើតផល ការប្រគល់ក័ណ្ឌគម្ពីរដំណឹងល្អ ចិញ្ចៀន មួក និងដំបងឲ្យលោកអភិបាល ជាសញ្ញាសម្គាល់ថា លោកមានបេសកកម្មប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ លោកស្មោះត្រង់នឹងព្រះសហគមន៍ ដែលជាព្រះមហេសីរបស់ព្រះគ្រីស្ត លោកទទួលបន្ទុកធ្វើជាគង្វាលនៃហ្វូងចៀមរបស់ព្រះអម្ចាស់។ យើងប្រគល់ចាន និងពែងទៅលោកបូជាចារ្យ ជា "តង្វាយរបស់ប្រជារាស្ត្រដ៏វិសុទ្ធ" ដែលលោកត្រូវថ្វាយចំពោះព្រះជាម្ចាស់ ហើយយើងប្រគល់ក័ណ្ឌគម្ពីរដំណឹងល្អដល់លោកឧបដ្ឋាក ដែលទើបនឹងទទួលបេសកកម្មប្រកាសដំណឹងល្អ។

## ៥-តើអ្នកណាអាចប្រគល់អគ្គសញ្ញានេះ?

១៥៧៥-ព្រះគ្រីស្តជ្រើសរើសក្រុមគ្រីស្តទូត ហើយប្រោសពួកលោកឲ្យចូលរួមចំណែកក្នុងបេសកកម្ម និងអំណាចរបស់ព្រះអង្គ។ ដោយគង់ខាងស្តាំព្រះបិតា ព្រះអង្គមិនបោះបង់ហ្វូងចៀមរបស់ព្រះអង្គចោលទេ ប៉ុន្តែរក្សាការពារហ្វូងចៀមនេះ ដោយសារក្រុមគ្រីស្តទូត។ សព្វថ្ងៃនេះ ព្រះអង្គក៏នៅតែណែនាំហ្វូងចៀមនេះ ដោយចាត់ចែងឲ្យមានគង្វាលបន្តមុខងារពីក្រុមគ្រីស្តទូតមក (MR ធម៌ប្រារព្ធរបស់ក្រុមគ្រីស្តទូតទី១)។ ហេតុនេះហើយបានជាព្រះគ្រីស្ត "ប្រទាន" ឲ្យអ្នកខ្លះមានមុខងារជាគ្រីស្តទូត អ្នកខ្លះផ្សេងទៀតទៅជាគង្វាល (អភ ៤,១១)។ ព្រះអង្គនៅតែមានសកម្មភាពតាមរយៈលោកអភិបាល (LG ២១)។

១៥៧៦-ដោយសារអគ្គសញ្ញាតែងតាំងជាអគ្គសញ្ញារបស់អ្នក ដែលទទួលមុខងារបម្រើតាំងពីក្រុមគ្រីស្តទូត លោកអភិបាលក្នុងឋានៈជាអ្នកបន្តមុខងារក្រុមគ្រីស្តទូត ត្រូវតែបញ្ជូន "ព្រះអំណោយទានខាងវិញ្ញាណ" (LG ២១) "ពូជជាគ្រីស្តទូត" (LG ២០)។ លោកអភិបាល ដែលទទួលតែងតាំងយ៉ាងត្រឹមត្រូវ ពោលគឺដែលមានខ្សែរយៈក្នុងការបន្តតំណែងតាំងពីសម័យក្រុមគ្រីស្តទូតមក មានសិទ្ធិផ្តល់អគ្គសញ្ញាតែងតាំងទាំងបីថ្នាក់បានយ៉ាងត្រឹមត្រូវ (DS ៧៩៤ និង ៨០២; CIC ១០១២; CCEO ៧៤៤; ៧៤៧)។

## ៦-តើអ្នកណាអាចទទួលអគ្គសញ្ញានេះ?

១៥៧៧-"មានតែមនុស្សប្រុស (vir ) ម្នាក់ ដែលបានជ្រមុជទឹក ដែលអាចទទួលអគ្គសញ្ញាតែងតាំងដ៏វិសុទ្ធបានយ៉ាងត្រឹមត្រូវ" (CIC ១០២៤)។ ព្រះអម្ចាស់យេស៊ូបានជ្រើសរើសមនុស្សប្រុស (viri) ដើម្បីបង្កើតក្រុមគ្រីស្តទូតដប់ពីរនាក់ (មក ៣,១៤-១៩; លក ៦,១២-១៦) ហើយក្រុមគ្រីស្តទូតបានធ្វើតាមព្រះអង្គ នៅពេលពួកលោកបានជ្រើសរើសសហការី (១ធម ៣,៣-១៣; ២ធម ១,៦; ទត ១,៥-៩) ដើម្បីបន្តមុខងាររបស់ពួកលោក (សន្តៈ ក្លេម៉ង់ នៅរ៉ូម)។ ក្រុមអភិបាល ដោយមានពួកបូជាចារ្យរួមជាមួយក្នុងឋានៈជាបូជាចារ្យ ធ្វើឲ្យក្រុមគ្រីស្តទូតដប់ពីររូបមានវត្តមានសព្វថ្ងៃ រហូតដល់ព្រះគ្រីស្តយាងមកវិញ។ ព្រះសហគមន៍ទទួលស្គាល់ថា ខ្លួនឯងជាប់ទាក់ទិននឹងជម្រើសនេះរបស់ព្រះអម្ចាស់ផ្ទាល់។ ហេតុនេះហើយបានជាយើងមិនអាចផ្តល់អគ្គសញ្ញាតែងតាំងដល់មនុស្សស្រីបានឡើយ (MD ២៦-២៧; CDF)។

១៥៧៨-គ្មាននរណាម្នាក់មានសិទ្ធិទទួលអគ្គសញ្ញាតែងតាំងឡើយ។ តាមការពិត គ្មាននរណាម្នាក់តាំងខ្លួនឯងឲ្យបំពេញមុខងារនេះទេ គឺទាល់តែព្រះជាម្ចាស់ត្រាស់ហៅ ទើបបំពេញបាន (ហប ៥,៤)។ អ្នកដែលគិតថា ព្រះជាម្ចាស់ត្រាស់ហៅគាត់ឲ្យទទួលមុខងារជាបូជាចារ្យ ត្រូវតែបន្ទាបខ្លួនក្រោមអំណាចរបស់ព្រះសហគមន៍ ដែល

ជាអ្នកទទួលខុសត្រូវ និងដែលមានសិទ្ធិហៅនរណាម្នាក់ឲ្យទទួលអគ្គសញ្ញាតែងតាំង។ ដូចព្រះអំណោយទានផ្សេងៗទៀតដែរ អគ្គសញ្ញានេះ ជាព្រះអំណោយទានលើសអំពីកុសលកម្មរបស់ខ្លួន។

១៥៧៩-ព្រះសហគមន៍ខាងបស្ចិមប្រទេសជ្រើសរើសអស់អ្នកដែលទទួលអគ្គសញ្ញាតែងតាំង លើកលែងតែឧបដ្ឋាកអចិន្ត្រៃយ៍ ក្នុងចំណោមគ្រីស្តបរិស័ទភេទប្រុស ដែលនៅលីវ ហើយដែលមានបំណងចង់រក្សាទុកភាពនៅលីវ "ដើម្បីព្រះរាជ្យនៃស្ថានបរមសុខ" (មថ ១៩,១២)។ ព្រះជាម្ចាស់ត្រាស់ហៅពួកគេឲ្យបូជាជីវិតទាំងស្រុងចំពោះព្រះអម្ចាស់ និង "កិច្ចការរបស់ព្រះអម្ចាស់" (១ករ ៧,៣២) ពួកគេក៏ថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ និងមនុស្សលោក។ ភាពនៅលីវជាសញ្ញាសម្គាល់នៃជីវិតថ្មីនេះ ដែលអ្នកទទួលមុខងារបម្រើព្រះសហគមន៍បានថ្វាយខ្លួន។ ពេលយើងទទួលភាពនៅលីវនេះ ដោយចិត្តសប្បាយរីករាយ យើងប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់ ដូចពន្លឺព្រះអាទិត្យបំភ្លឺមនុស្សលោកដែរ (PO ១៦)។

១៥៨០-ក្នុងព្រះសហគមន៍ខាងបូព៌ាប្រទេស តាំងពីច្រើនសតវត្សមកហើយ គេអនុវត្តតាមវិន័យប្លែកពីគេមួយៈ គេជ្រើសរើសលោកអភិបាលក្នុងចំណោមមនុស្សនៅលីវតែប៉ុណ្ណោះ ប៉ុន្តែគេអាចផ្តល់អគ្គសញ្ញាតែងតាំងជាឧបដ្ឋាក និងជាបូជាចារ្យដល់មនុស្សប្រុសដែលមានភរិយារួចហើយ។ របៀបប្រតិបត្តិនេះ គេចាត់ទុកថា ត្រឹមត្រូវតាំងពីយូរហើយ ពួកបូជាចារ្យទាំងនោះ បង្កើតផលជាច្រើនចំពោះសហគមន៍របស់ពួកលោក (PO ១៦)។ ម្យ៉ាងទៀត ក្នុងព្រះសហគមន៍ខាងបូព៌ាប្រទេស លោកបូជាចារ្យនៅលីវមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ហើយមានបូជាចារ្យជាច្រើនស្ម័គ្រចិត្តនៅលីវ ដើម្បីព្រះរាជ្យរបស់ព្រះជាម្ចាស់។ នៅបូព៌ា ដូចនៅបស្ចិមប្រទេស អ្នកណាដែលបានទទួលអគ្គសញ្ញាតែងតាំងមិនអាចរៀបការទៀតទេ។

## ៧-ផលនៃអគ្គសញ្ញាតែងតាំង

### អគ្គសញ្ញាតែងតាំងមិនអាចលុបបានទេ

១៥៨១-ដោយសារព្រះអំណោយទានពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ អគ្គសញ្ញានេះធ្វើឲ្យរួមរស់ជាមួយព្រះគ្រីស្ត ដើម្បីទៅជាឧបករណ៍របស់ព្រះគ្រីស្តសម្រាប់ព្រះសហគមន៍ព្រះអង្គ។ ដោយសារពិធីតែងតាំង យើងអាចប្រតិបត្តិក្នុងឋានៈជាតំណាងព្រះគ្រីស្ត ជាព្រះសិរសាព្រះសហគមន៍ ក្នុងមុខងារទាំងបីរបស់ព្រះអង្គជាបូជាចារ្យ ជាព្យាការី និងជាព្រះមហាក្សត្រ។

១៥៨២-ដូចចំពោះអគ្គសញ្ញាជ្រមុជទឹក និងលាបប្រេងថ្វាស យើងចូលរួមចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តតែមួយដងគត់។ អគ្គសញ្ញាតែងតាំងមានលក្ខណៈខាងវិញ្ញាណដែលមិនអាចលុបបាន ហើយយើងមិនអាចផ្តល់អគ្គសញ្ញានេះម្តងទៀង ឬផ្តល់អគ្គសញ្ញានេះសម្រាប់តែមួយរយៈទេ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៧៦៧ ; LG ២១; ២៨; ២៩; PO ២)។

ដោយសារមូលហេតុត្រឹមត្រូវ យើងអាចរំដោះបន្ទុករបស់មនុស្សម្នាក់ ដែលបានទទួលអគ្គសញ្ញាតែងតាំងយ៉ាងត្រឹមត្រូវ អំពីភារកិច្ច និងកិច្ចការ ដែលទាក់ទងនឹងមុខងាររបស់គេ ឬយើងអាចហាមឃាត់គេមិនឲ្យប្រតិបត្តិតាម (CIC ២៩០-២៩៣; ១៣៣៦,១.៣.៥; ១៣៣៨,២) ប៉ុន្តែ គេមិនអាចត្រឡប់ទៅជាគ្រីស្តបរិស័ទធម្មតា (តាមន័យចំ) បានទៀតឡើយ ដ្បិតគេបានទទួលលក្ខណៈនៃអគ្គសញ្ញាជាដរាប។ ការត្រាស់ហៅ និងបេសកកម្មដែលគេបានទទួលនៅថ្ងៃពិធីតែងតាំង ធ្វើឲ្យគេមានលក្ខណៈពិសេសជាអចិន្ត្រៃយ៍។

១៥៨៤-ទីបញ្ចប់ដោយសារព្រះគ្រីស្តមានសកម្មភាព និងជួយសង្គ្រោះ តាមរយៈអ្នកទទួលអគ្គសញ្ញាបម្រើព្រះសហគមន៍ ទោះបីអ្នកនោះមិនសមនឹងឋានៈរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏ព្រះគ្រីស្តនៅតែមានសកម្មភាពដែរ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៦១២; DS ១១៥៤)។ សន្តៈ អូគូស្តាំងបញ្ជាក់យ៉ាងច្បាស់ថា៖

> ចំពោះអ្នកបម្រើក្រអឺតក្រអោង ត្រូវតែរាប់វាជាមួយនឹងមារកំណាច ប៉ុន្តែ ព្រះអំណោយទានរបស់ព្រះគ្រីស្ត មិនត្រូវខូចទេ ពីព្រោះអ្វីដែលហូរចេញមកពីព្រះអង្គរក្សាទុកភាពបរិសុទ្ធ អ្វីដែលឆ្លងកាត់តាមព្រះអង្គនៅតែថ្លាយង់ ហើយទៅដល់ដីមានជីជាតិល្អ (...)។ តាមការពិតគុណធម៌ខាងវិញ្ញាណរបស់អគ្គសញ្ញាដូចជាពន្លឺ គឺអស់អ្នកដែលត្រូវបំភ្លឺទទួលពន្លឺនេះយ៉ាងពេញលេញ ហើយទោះបីពន្លឺនេះឆ្លងកាត់មនុស្សកខ្វក់ក្តី ក៏ពន្លឺនេះមិនកខ្វក់ដែរ។

## ព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

១៥៨៥-ព្រះអំណោយទានពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធចំពោះអគ្គសញ្ញានេះ គឺអ្នកទទួលមុខងារបម្រើរួមរស់ជាមួយព្រះគ្រីស្តក្នុងឋានៈជាបូជាចារ្យ ជាព្រះបរមគ្រូ និងជាគង្វាល។

១៥៨៦-សម្រាប់លោកអភិបាល ព្រះអំណោយទាននេះ ជាព្រះអំណោយទានផ្តល់កម្លាំង (តាមធម៌ប្រសិទ្ធពរអភិបាល ក្នុងពិធីខាងបស្ចិមប្រទេស៖ "ព្រះវិញ្ញាណ ដែលប្រោសឲ្យទៅជាមេដឹកនាំ") គឺណែនាំ និងការពារដោយកម្លាំង និងដោយការប្រុងប្រយ័ត្ន ព្រះសហគមន៍របស់លោក ដូចជាឪពុក និងគង្វាលម្នាក់ ដោយស្រឡាញ់មនុស្សទាំងអស់ ជាពិសេសអ្នកក្រីក្រ អ្នកជំងឺ និងអស់អ្នកដែលមានតម្រូវការ (CD ១៣ និង ១៦)។ ព្រះអំណោយទាននេះ ជំរុញលោកឲ្យប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ ឲ្យទៅជាគំរូនៃហ្វូងចៀមរបស់លោក ឲ្យដើរមុខពួកគេនៅលើមាគ៌ាឆ្ពោះទៅភាពដ៏វិសុទ្ធ ដោយធ្វើជាតំណាងរបស់ព្រះគ្រីស្តជាបូជាចារ្យ និងយញ្ញបូជាក្នុងពិធីអរព្រះគុណ និងដោយមិនខ្លាចបូជាជីវិតសម្រាប់ចៀមរបស់ខ្លួនទេ៖

> ឱព្រះបិតាដែលស្គាល់ចិត្តគំនិតអើយ! សូមប្រទានឲ្យអ្នកបម្រើ ដែលព្រះអង្គបានជ្រើសរើសឲ្យទៅជាលោកអភិបាលឲ្យលោកណែនាំហ្វូងចៀមដ៏វិសុទ្ធរបស់ព្រះអង្គ។ សូមឲ្យលោកធ្វើជាបូជាចារ្យដ៏ខ្ពង់ខ្ពស់ឥតសៅហ្មង និងដោយបម្រើព្រះអង្គទាំងថ្ងៃទាំងយប់។ សូមឲ្យលោកគាប់ព្រះហឫទ័យព្រះអង្គ និងថ្វាយតង្វាយនៃព្រះសហគមន៍ដ៏វិសុទ្ធរបស់ព្រះអង្គ។ ដោយសារវិញ្ញាណនៃបូជាចារ្យដ៏ខ្ពង់ខ្ពស់ សូមឲ្យលោកមានអំណាចលើកលែងទោសអំពើបាប តាមការបង្គាប់របស់ព្រះអង្គ សូមឲ្យលោកចែកបន្ទុកផ្សេងៗតាមបញ្ជារបស់ព្រះអង្គ ហើយសូមឲ្យលោកស្រាយចំណងទាំងប៉ុន្មាន ដោយសារអំណាចដែលព្រះអង្គបានប្រទានឲ្យក្រុមគ្រីស្តទូត។ សូមឲ្យលោកជាទីគាប់ព្រះហឫទ័យ ដោយសារភាពថ្នាក់ថ្នម និងចិត្តបរិសុទ្ធរបស់លោក ដោយថ្វាយទឹកអប់ដ៏ក្រអូបឈ្ងុយ តាមរយៈព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត... (សន្តៈ អ៊ីប៉ូលីត)។

១៥៨៧-ពាក្យអង្វរពិសេស នៅបីសង់ សម្តែងនូវព្រះអំណោយទាននៃអគ្គសញ្ញាតែងតាំងជាបូជាចារ្យ។ ដោយដាក់ដៃ លោកអភិបាល មានប្រសាសន៍ថា៖

> ឱព្រះអម្ចាស់អើយ! សូមព្រះអង្គបំពេញព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដល់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យលើកឡើងឲ្យមានឋានៈជាបូជាចារ្យ ដើម្បីឲ្យគេសមនឹងឈរពីមុខអាសនៈ ប្រកាសដំណឹងល្អនៃព្រះរាជ្យព្រះអង្គ បំពេញមុខងារជាអ្នកបម្រើព្រះបន្ទូលរបស់ព្រះអង្គជាសេចក្តីពិត ថ្វាយតង្វាយ និងយញ្ញបូជាខាងវិញ្ញាណ ជ្រមុជទឹកប្រជារាស្ត្ររបស់ព្រះអង្គឲ្យកើតជាថ្មី ទើបប្រជារាស្ត្រនេះ អាចចូលគាល់

ព្រះជាម្ចាស់ដ៏ប្រសើរ ជាព្រះសង្គ្រោះ គឺព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាតែមួយរបស់ព្រះអង្គ នៅថ្ងៃព្រះអង្គសោយរាជ្យ។ សូមឲ្យគេទទួលរង្វាន់ពីព្រះហឫទ័យសប្បុរសឥតព្រំដែនរបស់ព្រះអង្គ ចំពោះការគ្រប់គ្រងដ៏ស្មោះត្រង់របស់គេ។

១៥៨៨-ឯឧបដ្ឋាកវិញ "តាមព្រះអំណោយទាននៃអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ គេទទួលកម្លាំងបម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដោយបម្រើក្នុងពិធីបុណ្យ ដោយប្រកាសព្រះបន្ទូល និងដោយសម្ដែងសេចក្ដីស្រឡាញ់ ទាំងរួបរួមជាមួយលោកអភិបាល និងក្រុមបូជាចារ្យរបស់លោក" (LG ២៩)។

១៥៨៩-ដោយល្វែងយល់អំពីព្រះអំណោយទាន និងបន្ទុកដ៏ប្រសើរបំផុតនៃមុខងារជាបូជាចារ្យ គ្រូបណ្ឌិតដ៏វិសុទ្ធបានយល់ឃើញឲ្យច្បាស់ថា ត្រូវកែប្រែចិត្តគំនិតជាប្រញាប់ ដើម្បីជីវិតទាំងស្រុងរបស់អស់លោកស្របតាមអ្នកដែលអគ្គសញ្ញាធ្វើឲ្យគេទៅជាអ្នកបម្រើ។ ហេតុនេះហើយបានជាកាលនៅជាបូជាចារ្យវ័យក្មេងនៅឡើយ សន្ដៈ គ្រែគ័រ នៅណាស៊ីអង់ បន្លឺសម្លេងឡើងថា៖

> ត្រូវតែបរិសុទ្ធមុននឹងចង់ឲ្យអ្នកដទៃបរិសុទ្ធ។ ត្រូវតែរៀន ដើម្បីបង្រៀន។ ត្រូវតែទៅជាពន្លឺ ដើម្បីបំភ្លឺ។ ត្រូវតែមកជិតព្រះជាម្ចាស់ ដើម្បីឲ្យគេទៅជិតព្រះអង្គ។ ត្រូវតែវិសុទ្ធ ដើម្បីឲ្យគេវិសុទ្ធ។ ត្រូវតែណែនាំដោយដឹកដៃ និងជួយផ្ដល់យោបល់ដោយប្រាជ្ញា។ ខ្ញុំដឹងថា យើងជាអ្នកបម្រើរបស់អ្នកណា យើងមានកម្រិតណា ហើយអ្នកណាជាទិសដៅរបស់យើង។ ខ្ញុំស្គាល់ភាពខ្ពង់ខ្ពស់របស់ព្រះជាម្ចាស់ និងភាពទន់ខ្សោយរបស់មនុស្ស ប៉ុន្តែ ខ្ញុំស្គាល់កម្លាំងរបស់គេដែរ។ (អ្វីទៅជាបូជាចារ្យ?) លោកជាអ្នកការពារសេចក្ដីពិត លោកឈរឡើងជាមួយទេវទូត លោកថ្វាយសិរីរុងរឿងជាមួយអគ្គទេវទូត លោកធ្វើឲ្យយញ្ញបូជាឡើងទៅលើអាសនៈនៃស្ថានបរមសុខ លោករួបរួមជាមួយព្រះគ្រីស្តជាបូជាចារ្យ លោកកែលំអមនុស្សលោកឡើងវិញ លោកធ្វើឲ្យគេទៅជាតំណាងរបស់ព្រះជាម្ចាស់ឡើងវិញ លោកបង្កើតគេម្ដងទៀត ដើម្បីបរមលោក ទីបញ្ចប់ព្រះជាម្ចាស់ប្រោសលោកឲ្យទៅជាព្រះ ហើយលោកធ្វើឲ្យគេទៅជាព្រះដែរ។

ឯលោកបូជាចារ្យដ៏វិសុទ្ធនៃភូមិអារ្សមានប្រសាសន៍ថា៖ "គឺលោកបូជាចារ្យ ដែលបន្តកិច្ចការនៃការសង្គ្រោះនៅលើផែនដី..."។ "ប្រសិនបើយើងនឹងយល់ឲ្យច្បាស់អំពីអ្វីដែលជាបូជាចារ្យនៅលើផែនដីនេះ យើងនឹងស្លាប់មិនមែនដោយសារការភ័យខ្លាចទេ ប៉ុន្តែដោយសារសេចក្ដីស្រឡាញ់..."។ "មុខងារជាបូជាចារ្យ ដូចជាសេចក្ដីស្រឡាញ់នៃព្រះហឫទ័យរបស់ព្រះយេស៊ូ"។

## សង្ខេប

១៥៩០-សន្ដៈ ប៉ូល មានប្រសាសន៍ទៅកាន់លោកធីម៉ូថេ ជាសាវ័ករបស់លោកថា៖ "ខ្ញុំសូមរំឭកដាស់តឿនអ្នកថា ចូរធ្វើឲ្យព្រះអំណោយទានរបស់ព្រះជាម្ចាស់ ដែលអ្នកបានទទួល ដោយខ្ញុំដាក់ដៃលើនោះ មានសកម្មភាពឡើងវិញ" (២ធម ១,៦) ហើយ "ប្រសិនបើបងប្អូនណាម្នាក់ចង់បានមុខងារជាអភិបាល គាត់មានបំណងបំពេញមុខងារដ៏ប្រសើរហើយ" (១ធម ៣,១)។ លោកមានប្រសាសន៍ចំពោះលោកទីតុសថា៖ "ខ្ញុំទុកប្អូនឲ្យនៅកោះក្រែត ដើម្បីចាត់ចែងកិច្ចការដែលនៅសល់ ឲ្យមានរបៀបរៀបរយ និងតែងតាំងព្រឹទ្ធាចារ្យ នៅតាមក្រុងនីមួយៗដូចខ្ញុំបានផ្ដាំរួចហើយ" (ទត ១,៥)។

១៥៩១-ព្រះសហគមន៍ទាំងមូលជាប្រជាជនសុទ្ធតែជាបូជាចារ្យ។ ដោយសារពិធីជ្រមុជទឹក គ្រីស្តបរិស័ទទាំងអស់រួមចំណែកក្នុងឋានៈជាបូជាចារ្យរបស់ព្រះគ្រីស្ត។ គេហៅការចូលរួមនេះថា "គ្រីស្តបរិស័ទសុទ្ធតែជាបូជាចារ្យ"។

ពីលើនេះ ហើយដើម្បីបម្រើគ្រីស្តបរិស័ទទាំងនោះ មានអ្នកចូលរួមក្នុងបេសកកម្មរបស់ព្រះគ្រីស្ត ដែលអគ្គសញ្ញាតែងតាំងប្រគល់ឲ្យមុខងារជាអ្នកបម្រើក្នុងព្រះនាម និងនៅក្នុងអង្គព្រះគ្រីស្ត ជាព្រះសិរសាក្នុងចំណោមសហគមន៍។

១៥៩២-មុខងារបម្រើព្រះសហគមន៍ប្លែកពីឋានៈជាបូជាចារ្យធម្មតារបស់គ្រីស្តបរិស័ទ ដ្បិតមុខងារនេះ ផ្តល់អំណាចដ៏សក្ការៈដើម្បីបម្រើគ្រីស្តបរិស័ទ។ ពួកលោកមានភារកិច្ចបម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដោយបង្រៀន (munus docendi) ប្រារព្ធពិធីបុណ្យ (munus liturgicum) និងដឹកនាំព្រះសហគមន៍ (munus regendi)។

១៥៩៣-តាំងពីដើមមក គេប្រគល់មុខងារឲ្យអ្នកបម្រើព្រះសហគមន៍តាមបីថ្នាក់ គឺៈ លោកអភិបាល លោកបូជាចារ្យ និងលោកឧបដ្ឋាក។ រចនាសម្ព័ន្ធនាំអ្នកបម្រើព្រះសហគមន៍ ដែលបានតែងតាំង ហើយមិនអាចជំនួសគ្នាបាន គឺបើពុំមានអភិបាល បូជាចារ្យ និងឧបដ្ឋាកទេ យើងមិនអាចនិយាយអំពីព្រះសហគមន៍បានឡើយ (សន្តះអ៊ីញ៉ាស នៃអង់ទីអូស)។

១៥៩៤-លោកអភិបាលទទួលអគ្គសញ្ញាតែងតាំងពេញលក្ខណៈ ដែលបញ្ចូលលោកក្នុងក្រុមលោកអភិបាល និងធ្វើឲ្យលោកទៅជាប្រធានដែលអាចមើលឃើញនៃព្រះសហគមន៍ពិសេស ដែលគេប្រគល់ឲ្យលោក។ ដោយលោកជាអ្នកបន្តមុខងារក្រុមគ្រីស្តទូត និងជាសមាជិកក្រុមលោកអភិបាល លោកត្រូវរួមចំណែកក្នុងការទទួលខុសត្រូវដែលមកពីក្រុមគ្រីស្តទូត និងក្នុងបេសកកម្មព្រះសហគមន៍ទាំងមូល ក្រោមអំណាចរបស់សម្តេចប៉ាប ជាអ្នកបន្តមុខងារអំពីលោកសិលា។

១៥៩៥-ពួកបូជាចារ្យរួមជាមួយពួកអភិបាលក្នុងឋានៈជាបូជាចារ្យ ហើយជាមួយគ្នានេះដែរ ត្រូវការពួកលោកដើម្បីបំពេញមុខងារជាបូជាចារ្យ។ ព្រះជាម្ចាស់ត្រាស់ហៅពួកលោកឲ្យជាសហការីដ៏ឈ្លាសវៃរបស់ពួកអភិបាល ពួកលោកបង្កើតក្រុមលោកបូជាចារ្យរួមជាមួយលោកអភិបាល ដោយមានបន្ទុកទទួលខុសត្រូវលើព្រះសហគមន៍ពិសេស។ ពួកលោកទទួលបន្ទុកដឹកនាំសហគមន៍មួយ ឬមុខងារពិសេសមួយពីលោកអភិបាល។

១៥៩៦-ពួកឧបដ្ឋាកជាអ្នកទទួលពិធីតែងតាំង ដើម្បីបំពេញមុខងារផ្សេងៗរបស់ព្រះសហគមន៍ក្នុងការបម្រើ។ ពួកលោកមិនទទួលឋានៈជាបូជាចារ្យទេ ប៉ុន្តែពិធីតែងតាំងប្រគល់ឲ្យពួកលោកមុខងារសំខាន់ៗក្នុងការបម្រើព្រះបន្ទូល ពិធីបុណ្យ ការដឹកនាំព្រះសហគមន៍ និងការបម្រើអ្នកដទៃដោយក្តីស្រឡាញ់ ជាមុខងារដែលពួកលោកត្រូវប្រតិបត្តិក្រោមអំណាចលោកអភិបាលរបស់ពួកលោក។

១៥៩៧-គេប្រគល់អគ្គសញ្ញាតែងតាំងដោយដាក់ដៃ និងសេចក្តីអធិដ្ឋានយ៉ាងឧឡារិក ដែលទូលសុំអង្វរព្រះជាម្ចាស់សម្រាប់បេក្ខជននូវព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលលោកត្រូវការដើម្បីបំពេញមុខងាររបស់ខ្លួន។ ពិធីតែងតាំងផ្តល់លក្ខណៈខាងអគ្គសញ្ញាដែលមិនអាចលុបបានឡើយ។

១៥៩៨-ព្រះសហគមន៍ប្រគល់អគ្គសញ្ញាតែងតាំងឲ្យតែបុរស (viris) ដែលបានជ្រមុជទឹក ហើយដែលព្រះសហគមន៍ទទួលស្គាល់ថា មានសមត្ថភាពអាចបំពេញមុខងារនេះពិតប្រាកដមែន។ ព្រះសហគមន៍មានអំណាចទទួលខុសត្រូវ និងមានសិទ្ធិត្រាស់ហៅនរណាម្នាក់ឲ្យទទួលពិធីតែងតាំង។

១៥៩៩-ក្នុងព្រះសហគមន៍ខាងបស្ចិមប្រទេស គេប្រគល់អគ្គសញ្ញាតែងតាំងធ្វើជាបូជាចារ្យឲ្យតែបេក្ខជន ដែលស្ម័គ្រចិត្តនៅលីវ ហើយដែលបង្ហាញបំណងប្រាថ្នាថា ចង់នៅលីវ ជាសាធារណៈ ដោយសារសេចក្តីស្រឡាញ់ចំពោះព្រះរាជ្យរបស់ព្រះជាម្ចាស់ និងដើម្បីបម្រើមនុស្សលោក។

១៦០០-ពួកអភិបាលមានមុខងារប្រគល់អគ្គសញ្ញាតែងតាំងទាំងបីលំដាប់ថ្នាក់។

# ប្រការទី៧៖

# អគ្គសញ្ញាអាពាហ៍ពិពាហ៍

១៦០១-"ដោយសម្ព័ន្ធមេត្រីជាគូស្វាមីភរិយា បុរស និងស្ត្រីរួមរស់ជាមួយគ្នាអស់មួយជីវិត។ លក្ខណៈផ្ទាល់នៃសហគមន៍នេះ មានគោលដៅតម្រង់ទៅរកផលប្រយោជន៍គូស្វាមីភរិយា ការបន្តពូជ និងការអប់រំកូន។ ព្រះគ្រីស្តជាព្រះអម្ចាស់បានលើកសម្ព័ន្ធមេត្រីរវាងគ្រីស្តបរិស័ទនេះឲ្យមានឋានៈជាអគ្គសញ្ញា" (CIC ១០៥៥,១)។

## ១-អាពាហ៍ពិពាហ៍ក្នុងគម្រោងការរបស់ព្រះជាម្ចាស់

១៦០២-ព្រះគម្ពីរដ៏វិសុទ្ធចាប់ផ្តើមដោយព្រះជាម្ចាស់បង្កើតមនុស្សជាបុរសជាស្ត្រីជាតំណាងរបស់ព្រះជាម្ចាស់ និងមានលក្ខណៈដូចព្រះអង្គដែរ (កណ ១,២៦-២៧) ហើយព្រះគម្ពីរបញ្ចប់លើសុបិននិមិត្តអំពី "ពិធីមង្គលការរបស់កូនចៀម" (វវ ១៩,៧.៩)។ ពីសេចក្តីផ្តើមរហូតដល់សេចក្តីបញ្ចប់ ព្រះគម្ពីរថ្លែងអំពី "គម្រោងការដ៏លាក់កំបាំង" នៃអាពាហ៍ពិពាហ៍ អំពីការតែងតាំង និងអត្ថន័យដែលព្រះជាម្ចាស់បានប្រទានឲ្យអាពាហ៍ពិពាហ៍ អំពីប្រភព និងទីដៅនៃអាពាហ៍ពិពាហ៍។ ក្នុងអំឡុងប្រវត្តិសាស្ត្រនៃការសង្គ្រោះ មានចែងទុកនៅក្នុងគម្ពីរថា គូស្វាមីភរិយាបានជួបប្រទះនឹងការលំបាកផ្សេងៗដែលមកពីអំពើបាប និងបានកើតជាថ្មី "ក្នុងអង្គព្រះអម្ចាស់" (១ករ ៧,៣៩) គឺក្នុងសម្ព័ន្ធមេត្រីថ្មីរវាងព្រះគ្រីស្ត និងព្រះសហគមន៍ (អភ ៥,៣១-៣២)។

### អាពាហ៍ពិពាហ៍ក្នុងការចាត់ចែងនៃការបង្កើត

១៦០៣-"គូស្វាមីភរិយា ពិតជាសហគមន៍ដ៏ជ្រាលជ្រៅម៉្យាង ដោយអ្នកទាំងពីររួមរស់ជាមួយគ្នា និងស្រឡាញ់គ្នា។ ព្រះជាម្ចាស់ជាអ្នកបង្កើតតែងតាំងសហគមន៍នេះ និងប្រទានឲ្យសហគមន៍នេះមានវិន័យផ្ទាល់" (GS ៤៨,១)។ លក្ខណៈផ្ទាល់របស់មនុស្សប្រុស និងមនុស្សស្រី មកពីព្រះហស្តរបស់ព្រះបង្កើត ហើយព្រះអង្គត្រាស់ហៅគេឲ្យរៀបការ។ ទោះបីមានការផ្លាស់ប្តូរជាច្រើន អស់រយៈពេលជាច្រើនសតវត្សមកហើយក្តី តាមវប្បធម៌ រចនាសម្ព័ន្ធក្នុងសង្គម និងតាមអាកប្បកិរិយាខាងវិញ្ញាណផ្សេងៗយ៉ាងណាក្តី អាពាហ៍ពិពាហ៍មិនសុទ្ធតែជាការតាក់តែងរបស់មនុស្សទេ។ ទោះបីមានលក្ខណៈផ្សេងៗពីគ្នាក៏ដោយ ក៏យើងមិនត្រូវភ្លេចលក្ខណៈរួម និងជាអចិន្ត្រៃយ៍ផងដែរ។ ទោះបីជាមនុស្សនៅគ្រប់ទីកន្លែងមិនចាប់អារម្មណ៍ចំពោះកិត្តិយសដ៏ថ្លៃថ្នូរនៃអាពាហ៍ពិពាហ៍យ៉ាងណាក៏ដោយ (GS ៤៧,២) ក៏វប្បធម៌ទាំងអស់ទទួលស្គាល់ថា អាពាហ៍ពិពាហ៍មានលក្ខណៈដ៏ប្រសើរដែរ ដ្បិត "សន្តិភាពរបស់បុគ្គលម្នាក់ៗ និងសន្តិភាពរបស់សង្គម ភ្ជាប់យ៉ាងជិតស្និទ្ធនឹងការរីកចម្រើននៃសហគមន៍គូស្វាមីភរិយា និងរបស់សហគមន៍ក្រុមគ្រួសារ" (GS ៤៧,១)។

១៦០៤-ព្រះជាម្ចាស់ដែលបានបង្កើតមនុស្សដោយសារសេចក្តីស្រឡាញ់ ទ្រង់ក៏បានត្រាស់ហៅគេឲ្យស្រឡាញ់ ដែលជាការត្រាស់ហៅមូលដ្ឋានចំពោះមនុស្សគ្រប់រូបតាំងពីកំណើតមកម្ល៉េះ ដ្បិតព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាង និងមានលក្ខណៈរបស់ព្រះអង្គ (កណ ១,២៧) ដែលមានព្រះអង្គផ្ទាល់ជាសេចក្តីស្រឡាញ់ (១យហ ៤,៨.១៦)។ ព្រះជាម្ចាស់បានបង្កើតមនុស្សជាបុរស ជាស្ត្រី សេចក្តីស្រឡាញ់របស់គេចំពោះគ្នាទៅវិញទៅមក និងដែលមិនអាចផ្តាច់បាន ក្លាយទៅជាតំណាងនៃសេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់ជាទីបំផុតរបស់ព្រះអង្គចំពោះមនុស្សលោក។ ចំពោះព្រះបង្កើត សេចក្តីស្រឡាញ់នេះ ល្អណាស់ ល្អប្រសើរបំផុត (កណ ១,៣១)។ ព្រះជាម្ចាស់ប្រទានព្រះពរដល់សេចក្តីស្រឡាញ់នេះ ក្នុងគោលដៅឲ្យបង្កើតផល និងឲ្យបានសម្រេចក្នុងការថែទាំពិភពលោក៖ "ព្រះជាម្ចាស់

បានប្រទានពរឲ្យគេ គឺព្រះអង្គមានព្រះបន្ទូលថា៖ "ចូរបង្កើតកូនចៅឲ្យបានកើនច្រើនឡើងពាសពេញលើផែនដី ហើយត្រួតត្រាផែនដី" (កណ ១,២៨)។

១៦០៥-ព្រះគម្ពីរដ៏វិសុទ្ធអះអាងថា ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងមនុស្សស្រីដើម្បីគ្នាទៅវិញទៅមក៖ "បើមនុស្សប្រុសនៅតែម្នាក់ឯងដូច្នេះ មិនស្រួលទេ"។ ព្រះជាម្ចាស់ប្រទានស្ត្រី ជា "សាច់ដែលកើតចេញមកពីសាច់" របស់គេ ពោលគឺខ្លួនគេផ្សេងម្នាក់ទៀត មនុស្សម្នាក់ដែលមានឋានៈស្មើនឹងគេ ជិតស្និទ្ធនឹងគេជាទីបំផុត ដូចជា "អ្នកជំនួយ" ជាតំណាងរបស់ "ព្រះជាម្ចាស់ដែលយាងមកជួយយើង" (ទន ១២១,២)។ "ហេតុនេះ បុរសចាកចេញពីឪពុកម្ដាយទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរក្លាយទៅជារូបកាយតែមួយ" (កណ ២,១៨-២៥)។ ព្រះអម្ចាស់ផ្ទាល់បង្ហាញថា បុរស និងស្ត្រីត្រូវរួមរស់ជាមួយគ្នា ដោយមិនអាចបំបែកពីគ្នាបានឡើយ ដោយទ្រង់រំឭកអំពីគម្រោងការដំបូងរបស់ព្រះបង្កើត៖ "គេមិនមែនជាបុគ្គលពីរនាក់ទៀតទេ គឺជារូបកាយតែមួយវិញ" (មថ ១៩,៦)។

## អាពាហ៍ពិពាហ៍ក្រោមអំណាចនៃអំពើបាប

១៦០៦-មនុស្សគ្រប់ៗរូបដកពិសោធន៍អំពីអំពើអាក្រក់ នៅជុំវិញខ្លួន និងនៅក្នុងខ្លួនឯងផង។ បទពិសោធន៍នេះ ស្ថិតនៅក្នុងទំនាក់ទំនងរវាងបុរស និងស្ត្រីដែរ។ តាំងពីដើមដំបូងបង្អស់ គូស្វាមីភរិយាឈ្លោះទាស់ទែងគ្នា ចង់ធ្វើជាម្ចាស់លើគ្នាទៅវិញទៅមក គ្មានភក្ដីភាពនឹងគ្នា ច្រណែនគ្នា និងអាចជំទាស់រហូតដល់ស្អប់គ្នា និងបែកចេញពីគ្នាទៀតផង។ ភាពច្របូកច្របល់នេះ អាចលេចឡើងខ្លាំង ឬតិច ជួនកាលអាចពុះពារបាន ឬមិនបានទៅតាមវប្បធម៌ តាមសម័យកាល ឬតាមបុគ្គល ប៉ុន្តែភាពច្របូកច្របល់នេះហាក់ដូចជាមានលក្ខណៈសកល។

១៦០៧-បើតាមជំនឿ ភាពច្របូកច្របល់នេះ ដែលយើងយល់ឃើញយ៉ាងឈឺចាប់ មិនមែនមកពីលក្ខណៈរបស់បុរស និងស្ត្រី ឬពីលក្ខណៈនៃទំនាក់ទំនងរវាងពួកគេទេ ប៉ុន្តែមកពីអំពើបាប។ អំពើបាបដើមដំបូងផ្ដាច់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ ហើយបង្កើតផលវិបាកដំបូងថា បុរស និងស្ត្រីដែលដើមដំបូងរួបរួមជាមួយគ្នា ផ្ដាច់ទំនាក់ទំនងរវាងគ្នានឹងគ្នា។ គេចោទប្រកាន់គ្នា (កណ ៣,១២) គេលែងទាក់ទាញគ្នា (ការទាក់ទាញគ្នាជាព្រះអំណោយទានដែលមកពីព្រះជាម្ចាស់ - កណ ២,២២) ដើម្បីធ្វើជាម្ចាស់លើគ្នាទៅវិញទៅមក ហើយគេមានចិត្តលោភលន់ (កណ ៣,១៦ខ)។ នៅពេលស្ត្រីមានផ្ទៃពោះ នាងសម្រាលកូនដោយឈឺចុកចាប់ ឯបុរសវិញ គេត្រូវរកស៊ីចិញ្ចឹមជីវិតដោយបង្ហូរញើស (កណ ៣,១៦-១៩)។

១៦០៨-ក៏ប៉ុន្តែ ទោះបីមានភាពច្របូកច្របល់យ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់នៅតែរក្សាសណ្ដាប់ធ្នាប់នៃការបង្កើត។ ដើម្បីព្យាបាលមុខរបួសនៃអំពើបាប បុរស និងស្ត្រីត្រូវការជំនួយនៃព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ដែលព្រះអង្គពោរពេញទៅដោយធម៌មេត្តាករុណាឥតព្រំដែន មិនដែលបដិសេធក្នុងការប្រទានទេ (កណ ៣,២១)។ បើព្រះជាម្ចាស់មិនយាងមកជួយទេ បុរស និងស្ត្រីមិនអាចរួមរស់ជាមួយគ្នា តាមគម្រោងការ "ដើមដំបូងបង្អស់" របស់ព្រះជាម្ចាស់បានឡើយ។

## អាពាហ៍ពិពាហ៍ក្រោមគរុកោសល្យនៃធម្មវិន័យ

១៦០៩-ព្រះជាម្ចាស់ប្រកបដោយធម៌មេត្តាករុណាមិនបានបោះបង់មនុស្សបាបចោល។ ទោះបីព្រះអង្គដាក់ទោសអ្នកបាប ដូចជាស្ត្រីសម្រាលកូនដោយ "ឈឺចុកចាប់" (កណ ៣,១៦) ឬបុរសរកស៊ីចិញ្ចឹមជីវិត "ដោយបង្ហូរញើស" (កណ ៣,១៩) យ៉ាងណាក៏ដោយ ក៏ទោសទាំងអស់នោះ ដូចជាថ្នាំព្យាបាលផលវិបាកនៃអំពើបាបដែរ។ ក្រោយពីមនុស្សបានធ្លាក់ខ្លួនជាអ្នកបាប អាពាហ៍ពិពាហ៍ជួយមនុស្សកុំឲ្យគិតតែពីខ្លួនឯង កុំឲ្យគេភ្លេចភ្លើន

នឹងការសប្បាយផ្ទាល់ខ្លួន ប៉ុន្តែឲ្យគេបើកចិត្តទូលាយចំពោះគូរបស់ខ្លួន ឲ្យគេចេះជួយគ្នាទៅវិញទៅមក ឲ្យគេចេះប្រគល់ខ្លួនចំពោះគ្នាទៅវិញទៅមក។

១៦១០-ក្រោមគរុកោសល្យនៃធម្មវិន័យចាស់ មនុស្សបានយល់ឃើញថា អាពាហ៍ពិពាហ៍ទាមទារឲ្យបុរសមានភរិយាតែមួយ ឬស្ត្រីមានស្វាមីតែមួយ ហើយគូស្វាមីភរិយាមិនអាចបំបែកពីគ្នាបានឡើយ។ បុព្វបុរស និងស្ដេចនៅតែអាចមានភរិយាច្រើន ក៏ប៉ុន្តែធម្មវិន័យ ដែលលោកម៉ូសេបានទទួល មានគោលដៅការពារស្ត្រីប្រឆាំងនឹងការគ្រប់គ្រងតាមអំពើចិត្តរបស់បុរស ទោះបីតាមធម្មវិន័យនេះ លោកម៉ូសេអនុញ្ញាតឲ្យបុរសលែងភរិយា ដោយសារមនុស្សមាន "ចិត្តរឹងរូស" (មថ ១៩,៨; ទក ២៤,១) យ៉ាងណាក៏ដោយ។

១៦១១-ដោយឈ្វេងយល់ថា សម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់ជាមួយជនជាតិអ៊ីស្រាអែល ដូចជាសេចក្តីស្រឡាញ់តែមួយដ៏ស្មោះភក្តីរវាងគូស្វាមីភរិយា (ហស ១-៣; អស ៥៤; ៦២; យរ ២-៣; ៣១; អគ ១៦; ២៣) ពួកព្យាការីបានរៀបចំចិត្តគំនិតរបស់ប្រជាជនដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យយល់កាន់តែស៊ីជម្រៅថា បុរសត្រូវតែមានភរិយាតែមួយ ឬស្ត្រីមានស្វាមីតែមួយ ហើយគូស្វាមីភរិយាមិនអាចបំបែកពីគ្នាបានឡើយ (មគ ២,១៣-១៧)។ កំណែគម្ពីរនាងរូថ និងលោកតូប៊ីត ផ្តល់សក្ខីភាពដ៏គួរឲ្យរំភើបអំពីអត្ថន័យដ៏ខ្ពង់ខ្ពស់នៃអាពាហ៍ពិពាហ៍ អំពីភក្តីភាព និងអំពីសេចក្តីថ្នាក់ថ្នមរបស់គូស្វាមីភរិយា។ ការបញ្ជូនបន្តតែងតែយល់ឃើញថា បទចម្រៀងព្រះបាទសាឡូម៉ូន ដែលបង្ហាញអំពីសេចក្តីស្រឡាញ់របស់មនុស្សលោក ឆ្លុះបញ្ចាំងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែល "មានកម្លាំងដូចសេចក្តីស្លាប់" និងដែល "ទន្លេទាំងប៉ុន្មានពុំអាចពន្លិច" បានឡើយ (បច ៨,៦-៧)។

## អាពាហ៍ពិពាហ៍នៅក្នុងអង្គព្រះអម្ចាស់

១៦១២-សម្ព័ន្ធមេត្រីជាគូស្វាមីភរិយារវាងព្រះជាម្ចាស់ និងប្រជារាស្ត្រអ៊ីស្រាអែលបានរៀបចំសម្ព័ន្ធមេត្រីថ្មី និងអស់កល្បជានិច្ច ដែលព្រះបុត្រារបស់ព្រះជាម្ចាស់បានរួបរួមម៉្យាងជាមួយមនុស្សជាតិទាំងស្រុង ដែលព្រះអង្គបានសង្គ្រោះ ដោយប្រសូតជាមនុស្ស និងដោយបូជាព្រះជន្ម (GS ២២) ហេតុនេះព្រះអង្គបានរៀបចំ "ពិធីមង្គលការរបស់កូនចៀម" (វវ ១៩,៧.៩)។

១៦១៣-ពេលចាប់ផ្តើមជីវិតជាសាធារណៈ ព្រះយេស៊ូធ្វើសញ្ញាសម្គាល់ដំបូងរបស់ព្រះអង្គ ដោយសារពាក្យសុំរបស់ព្រះមាតា នៅក្នុងពិធីមង្គលការមួយ (យហ ២,១-១១)។ ព្រះសហគមន៍ចាត់ទុកថា វត្តមានរបស់ព្រះយេស៊ូក្នុងពិធីមង្គលការនៅភូមិកាណាមានសារៈសំខាន់ណាស់។ ព្រះសហគមន៍យល់ឃើញថា វត្តមាននេះ បញ្ជាក់ថាអាពាហ៍ពិពាហ៍ជាកិច្ចប្រពៃណាស់ និងប្រកាសថា ចាប់ពីពេលនេះទៅ អាពាហ៍ពិពាហ៍ជាសញ្ញាសម្គាល់ដ៏មានប្រសិទ្ធភាពនៃវត្តមានរបស់ព្រះគ្រីស្ត។

១៦១៤-ក្នុងធម៌ទេសនារបស់ព្រះអង្គ ព្រះយេស៊ូបានប្រៀនប្រដៅយ៉ាងច្បាស់នូវអត្ថន័យដំបូងនៃការរួបរួមរវាងបុរស និងស្ត្រី តាមព្រះហឫទ័យដើមដំបូងរបស់ព្រះបង្កើត។ លោកម៉ូសេអនុញ្ញាតឲ្យបុរសលែងភរិយា ពីព្រោះមនុស្សមានចិត្តរឹងរូស (មថ ១៩,៨) ប៉ុន្តែ គូស្វាមីភរិយាមិនអាចបំបែកពីគ្នាបានឡើយ ដ្បិតព្រះជាម្ចាស់ផ្ទាល់បានចងសម្ព័ន្ធមេត្រីនេះ៖ "មនុស្សមិនត្រូវបំបាក់បំបែកគូស្រករ ដែលព្រះជាម្ចាស់បានផ្សំផ្គុំនោះឡើយ" (មថ ១៩,៦)។

១៦១៥-ដោយសារព្រះអង្គមានព្រះបន្ទូលយ៉ាងច្បាស់ថា គូស្វាមីភរិយាមិនអាចបំបែកពីគ្នាបាន មនុស្សខ្លះបានគិតថា ការទាមទារបែបនេះធ្វើមិនកើតឡើយ (មថ ១៩,១០)។ ក៏ប៉ុន្តែ ព្រះយេស៊ូមិនបានដាក់បន្ទុកធ្ងន់ជ្រុល

ជាងធម៌វិន័យរបស់លោកម៉ូសេ លើគូស្វាមីភរិយា (មថ ១៩,២៩-៣០)។ ដោយព្រះអង្គយាងមករៀបចំឡើងវិញសណ្ដាប់ធ្នាប់នៃការបង្កើត ដែលអំពើបាបបានធ្វើឲ្យច្របូកច្របល់ ព្រះអង្គប្រទានកម្លាំងផ្ទាល់ និងការប្រណីសន្ដោស ដើម្បីឲ្យគូស្វាមីភរិយាអាចរៀបការ តាមលក្ខណៈថ្មីនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ដោយដើរតាមព្រះគ្រីស្ដ ដោយលះបង់ផលប្រយោជន៍ផ្ទាល់ និងដោយលីឈើឆ្កាងលើខ្លួនឯង (មក ៨,៣៤) គូស្វាមីភរិយានឹងអាច "យល់" (មថ ១៩,១១) អត្ថន័យដំបូងនៃអាពាហ៍ពិពាហ៍ និងប្រតិបត្តិតាម ដោយមានជំនួយអំពីព្រះគ្រីស្ដ។ ព្រះអំណោយទាននៃអាពាហ៍ពិពាហ៍របស់គ្រីស្ដបរិស័ទនេះ ជាផលផ្លែនៃព្រះឈើឆ្កាងរបស់ព្រះគ្រីស្ដ ដែលជាប្រភពនៃជីវិតរបស់គ្រីស្ដបរិស័ទ។

១៦១៦-គ្រីស្ដទូតប៉ូលធ្វើឲ្យយើងយល់អំពីអត្ថន័យនេះ ដោយមានប្រសាសន៍ថា៖ "ចំពោះបងប្អូនដែលមានប្រពន្ធវិញ ចូរស្រឡាញ់ភរិយាដូចព្រះគ្រីស្ដបានស្រឡាញ់ព្រះសហគមន៍ដែរ ព្រះអង្គបូជាព្រះជន្មរបស់ព្រះអង្គផ្ទាល់សម្រាប់ព្រះសហគមន៍ ដើម្បីប្រោសឲ្យព្រះសហគមន៍បានទៅជាវិសុទ្ធ" (អភ ៥,២៥-២៦) ហើយលោកបន្ថែមភ្លាមថា៖ "ហេតុនេះហើយបានជាបុរសត្រូវចាកចេញពីឪពុកម្ដាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរនឹងបានទៅជារូបកាយតែមួយ គម្រោងការដ៏លាក់កំបាំងនេះ មានអត្ថន័យជ្រាលជ្រៅណាស់ ខ្ញុំនិយាយសេចក្ដីនេះសំដៅលើព្រះគ្រីស្ដ និងព្រះសហគមន៍តែប៉ុណ្ណោះ" (អភ ៥,៣១-៣២)។

១៦១៧-សេចក្ដីស្រឡាញ់ជាគូស្វាមីភរិយារវាងព្រះគ្រីស្ដ និងព្រះសហគមន៍ដៅចំណាមជីវិតទាំងស្រុងរបស់គ្រីស្ដបរិស័ទ។ ពិធីជ្រមុជទឹក ដែលបញ្ចូលក្នុងប្រជាជនរបស់ព្រះជាម្ចាស់ ជាអាថ៌កំបាំងដ៏អស្ចារ្យនៃអាពាហ៍ពិពាហ៍ស្រេចទៅហើយ ហាក់ដូចជាពិធីជម្រះឲ្យបានស្អាតបរិសុទ្ធ មុននឹងពិធីជប់លៀងនៃពិធីមង្គលការ ដែលជាពិធីអរព្រះគុណ។ ឯអាពាហ៍ពិពាហ៍របស់គ្រីស្ដបរិស័ទទៅជាសញ្ញាសម្គាល់ដ៏មានប្រសិទ្ធភាព និងទៅជាអគ្គសញ្ញានៃសម្ព័ន្ធមេត្រីរវាងព្រះគ្រីស្ដ និងព្រះសហគមន៍។ ដោយសារអាពាហ៍ពិពាហ៍រវាងគ្រីស្ដបរិស័ទសំដៅ និងផ្ដល់ការប្រណីសន្ដោស អាពាហ៍ពិពាហ៍នេះ ជាអគ្គសញ្ញាដ៏ពិតប្រាកដនៃសម្ព័ន្ធមេត្រីថ្មី (DS ១៨០០; CIC ១០៥៥,២)។

## ព្រហ្មចារិយភាពដើម្បីព្រះរាជ្យ

១៦១៨-ព្រះគ្រីស្ដជាស្នូលនៃការរស់នៅរបស់គ្រីស្ដបរិស័ទ។ ចំណងជាមួយព្រះអង្គសំខាន់ជាងចំណងឯទៀតៗ ដូចជាចំណងជាមួយក្រុមគ្រួសារ ឬចំណងនៅក្នុងសង្គម (លក ១៤,២៦; មក ១០,២៨-៣១)។ ចាប់តាំងពីព្រះសហគមន៍ដើមដំបូង មានបុរស និងស្ត្រី មិនព្រមរៀបការ ដើម្បីដើរតាមកូនចៀមនៅគ្រប់ទីកន្លែងទាំងអស់ (វវ ១៤,៤) ដើម្បីខ្វល់ខ្វាយនឹងព្រះអម្ចាស់ ដើម្បីបានគាប់ព្រះហឫទ័យព្រះអង្គ (១ករ ៧,៣២) និងដើម្បីរត់ទៅទទួលព្រះស្វាមី (មថ ២៥,៦)។ ព្រះគ្រីស្ដផ្ទាល់អញ្ជើញអ្នកខ្លះឲ្យដើរតាមព្រះអង្គ តាមរបៀបរស់នៅបែបនេះ ដែលព្រះអង្គនៅតែជាគំរូ៖

> អ្នកខ្លះមិនអាចរៀបការបាន តាំងពីកំណើតមក។ អ្នកខ្លះទៀតមិនអាចរៀបការបាន មកពីត្រូវគេក្រៀវ។ រីឯអ្នកខ្លះទៀតមិនរៀបការ មកពីយល់ដល់ព្រះរាជ្យនៃស្ថានបរមសុខ។ អ្នកណាមានប្រាជ្ញា ចូរយកពាក្យនេះទៅរិះគិតឲ្យយល់ចុះ! (មថ ១៩,១២)។

១៦១៩-ព្រហ្មចារិយភាព ដើម្បីព្រះរាជ្យនៃស្ថានបរមសុខ មកពីព្រះអំណោយទាននៃពិធីជ្រមុជទឹក ជាសញ្ញាសម្គាល់ដ៏មានឫទ្ធានុភាព ដែលបង្ហាញថា ចំណងជាមួយព្រះគ្រីស្ដសំខាន់លើសអ្វីៗទាំងអស់។ ព្រហ្មចារីទន្ទឹងរង់ចាំឲ្យព្រះអង្គយាងមកវិញ និងជាសញ្ញាសម្គាល់រំឭកថា អាពាហ៍ពិពាហ៍ក្នុងលោកនេះចេះតែកន្លងផុតទៅហើយ

(មក ១២,២៥; ១ករ ៧,៣១)។

១៦២០-ទាំងអគ្គសញ្ញាអាពាហ៍ពិពាហ៍ ទាំងព្រហ្មចារិយភាពដើម្បីព្រះរាជ្យ មកពីព្រះអម្ចាស់ផ្ទាល់។ គឺព្រះអង្គនេះហើយ ដែលផ្ដល់អត្ថន័យដល់កិច្ចការទាំងពីរនោះ និងប្រទានការប្រណីសន្ដោសជាចាំបាច់ ដើម្បីអាចប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះអង្គ (មថ ១៩,៣-១២)។ ការលើកតម្លៃនៃព្រហ្មចារិយភាពដើម្បីព្រះរាជ្យ (LG ៤២ ; PC ១២; OT ១០) និងអត្ថន័យនៃអាពាហ៍ពិពាហ៍តាមគ្រីស្តសាសនាមិនអាចបំបែកពីគ្នាបាន និងបំពេញគ្នាទៅវិញទៅមក៖

> បើយើងប្រមាថអាពាហ៍ពិពាហ៍ យើងក៏បញ្ចុះតម្លៃនៃសិរីរុងរឿងរបស់ព្រហ្មចារិយភាពដែរ។ បើយើងលើកតម្កើងអាពាហ៍ពិពាហ៍ យើងក៏លើកកិត្តិយសនៃព្រហ្មចារិយភាពដែរ (...) ដ្បិតអ្វីដែលហាក់ដូចជាល្អបើប្រៀបធៀបនឹងសេចក្ដីអាក្រក់ មិនអាចទៅជាសេចក្ដីល្អពេញលក្ខណៈឡើយ ប៉ុន្តែអ្វីដែលល្អជាងសេចក្ដីល្អដែលមិនអាចប្រកែកបាន ជាសេចក្ដីល្អតែម្ដង (សន្ត: យ៉ូហាន គ្រីសូស្តូម; FC ១៦)។

## ២-ការប្រារព្ធពិធីអាពាហ៍ពិពាហ៍

១៦២១-ក្នុងពិធីនៃបស្ចិមប្រទេស ជាធម្មតា គ្រីស្តបរិស័ទកាតូលិកពីរនាក់រៀបការក្នុងពេលថ្វាយអភិបូជាដ៏វិសុទ្ធ ដ្បិតអគ្គសញ្ញាទាំងអស់ភ្ជាប់ចំណងនឹងបុណ្យចម្លងរបស់ព្រះគ្រីស្ត (SC ៦១)។ ពិធីនឹករឭកនៃសម្ព័ន្ធមេត្រីថ្មី ដែលព្រះគ្រីស្តបានរួបរួមជាដរាបជាមួយព្រះសហគមន៍ ជាព្រះមហេសីដ៏ជាទីស្រឡាញ់របស់ព្រះអង្គសម្រេចក្នុងពិធីអរព្រះគុណ។ ព្រះអង្គក៏បានបូជាព្រះជន្មដើម្បីព្រះមហេសីនេះ (LG ៦)។ ដូច្នេះហើយបានជាគូស្វាមីភរិយាគួរចងសម្ព័ន្ធមេត្រីប្រគល់ខ្លួនចំពោះគ្នាទៅវិញទៅមក ដោយថ្វាយខ្លួនទាំងស្រុង រួមជាមួយនឹងសក្ការបូជារបស់ព្រះគ្រីស្តចំពោះព្រះសហគមន៍ព្រះអង្គ ដែលមានវត្តមានក្នុងអភិបូជា ហើយដោយទទួលព្រះកាយព្រះលោហិតព្រះគ្រីស្ត ដើម្បីឲ្យពួកគេ "ធ្វើជារូបកាយតែមួយ" ក្នុងអង្គព្រះគ្រីស្ត (១ករ ១០,១៧)។

១៦២២-"ដោយសារពិធីអាពាហ៍ពិពាហ៍ជាកិច្ចការខាងអគ្គសញ្ញា ដែលធ្វើឲ្យបានវិសុទ្ធ ពិធីនេះ (...) ត្រូវតែត្រឹមត្រូវ សមរម្យ និងត្រូវបង្កើតផល" (FC ៦៧)។ ដូច្នេះ គូដណ្ដឹងគួររៀបចំខ្លួនប្រារព្ធពិធីអាពាហ៍ពិពាហ៍ ដោយទទួលអគ្គសញ្ញាលើកលែងទោស។

១៦២៣-ក្នុងព្រះសហគមន៍ខាងបស្ចិមប្រទេស ជាធម្មតា យើងចាត់ទុកគូស្វាមីភរិយា ក្នុងឋានៈជាអ្នកបម្រើព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្ត ផ្ដល់អគ្គសញ្ញាអាពាហ៍ពិពាហ៍ឲ្យគ្នាទៅវិញទៅមក ដោយសម្ដែងចំពោះព្រះសហគមន៍ថា ពួកគេយល់ព្រមរៀបការជាមួយគ្នា។ ក្នុងពិធីបុណ្យខាងបូព៌ាប្រទេស ក្រោយពីបានទទួលពាក្យសន្យារបស់គូស្វាមីភរិយា អ្នកបម្រើនៃអគ្គសញ្ញា (ដែលគេហៅថា "ពិធីអភិសេក") ជាលោកបូជាចារ្យ ឬលោកអភិបាល អភិសេកស្វាមី និងភរិយាជាបន្តបន្ទាប់ ជាសញ្ញាសម្គាល់ថា ពួកគេបានចងសម្ព័ន្ធមេត្រី។

១៦២៤-ក្នុងពិធីបុណ្យផ្សេងៗ មានសេចក្ដីអធិដ្ឋាន និងពាក្យអង្វរជាច្រើនឲ្យព្រះជាម្ចាស់ប្រោសប្រទានព្រះហឫទ័យប្រណីសន្ដោស និងប្រទានព្រះពរដល់គូស្វាមីភរិយាថ្មី ជាពិសេសដល់ភរិយា។ ក្នុងពាក្យអង្វរនៃអគ្គសញ្ញានេះ គូស្វាមីភរិយាទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដូចជាការរួបរួមពោរពេញដោយសេចក្ដីស្រឡាញ់រវាងព្រះគ្រីស្ត និងព្រះសហគមន៍ (អភ ៥,៣២)។ ព្រះវិញ្ញាណជាត្រានៃសម្ព័ន្ធមេត្រីរបស់គេ ជាប្រភពឥតរីងស្ងួតនៃសេចក្ដីស្រឡាញ់របស់គេ ជាកម្លាំងដើម្បីឲ្យគេនៅភក្ដីនឹងគ្នាជានិច្ច។

## ៣-ការយល់ព្រមឲ្យរៀបអាពាហ៍ពិពាហ៍

១៦២៥-គូស្រករនៃអាពាហ៍ពិពាហ៍ជាបុរសម្នាក់ និងជាស្ត្រីម្នាក់ ដែលបានជ្រមុជទឹក មានសេរីភាពក្នុងការរៀបអាពាហ៍ពិពាហ៍ ហើយដែលបង្ហាញថា ពួកគេយល់ព្រមរៀបការជាមួយគ្នា។ "មានសេរីភាព" មានន័យថា៖

-គ្មានការបង្ខិតបង្ខំ

-គ្មានច្បាប់ធម្មជាតិ ឬច្បាប់របស់ព្រះសហគមន៍រារាំងគេមិនឲ្យរៀបការឡើយ។

១៦២៦-ព្រះសហគមន៍ចាត់ទុកថា គូស្វាមីភរិយាត្រូវតែយល់ព្រមរៀបការជាមួយគ្នា។ ការយល់ព្រមនេះ ជាផ្នែកដ៏ចាំបាច់ដែល "បង្កើតអាពាហ៍ពិពាហ៍" (CIC ១០៥៧,១)។ ប្រសិនបើគូស្រករមិនយល់ព្រមទេ គ្មានអាពាហ៍ពិពាហ៍ឡើយ។

១៦២៧-"ពេលគូស្វាមីភរិយាប្រគល់ខ្លួនទៅវិញទៅមក និងទទួលគ្នាទៅវិញទៅមក អ្នកទាំងពីរពិតជាប្រព្រឹត្តកិច្ចមួយ ដែលមានលក្ខណៈមនុស្សជាតិសុទ្ធសាធ" (GS ៤៨,១; CIC ១០៥៧,២)៖ "បងយកអូនធ្វើជាភរិយាបង-អូនយកបងធ្វើជាស្វាមីអូន" (OcM ៤៥)។ ពេលអ្នកទាំងពីរ "ធ្វើជារូបកាយតែមួយ" (កណ ២,២៤; មក ១០,៨; អភ ៥,៣១) ពួកគេបំពេញពាក្យសន្យានេះ ដែលចងគូស្វាមីភរិយាជាមួយគ្នា។

១៦២៨-គូស្រករម្នាក់ៗត្រូវមានបំណងរៀបការជាមួយគ្នា ដោយគ្មានអំពើហិង្សា ឬការបំភ័យធ្ងន់ធ្ងរណាមួយពីខាងក្រៅឡើយ (CIC ១១០៣)។ គ្មាននរណាម្នាក់អាចជំនួសគូស្រករបាន (CIC ១០៥៧,១)។ បើគ្មានសេរីភាពនេះទេ អាពាហ៍ពិពាហ៍មិនត្រឹមត្រូវឡើយ។

១៦២៩-ហេតុនេះហើយបានជា (ឬដោយសារមូលហេតុផ្សេងទៀត ដែលធ្វើឲ្យអាពាហ៍ពិពាហ៍ដូចជាមិនបានកើតឡើង (CIC ១០៩៥-១១០៧) ក្រោយពីតុលាការរបស់ព្រះសហគមន៍ ដែលមានសមត្ថកិច្ចបានពិនិត្យពិច័យស្ថានការណ៍ ព្រះសហគមន៍អាចសម្រេចថា អាពាហ៍ពិពាហ៍ "គ្មានតម្លៃ" ពោលគឺអាពាហ៍ពិពាហ៍មិនដែលបានកើតឡើង។ ក្នុងករណីនេះ គូស្រករមានសេរីភាពរៀបការ។ ប៉ុន្តែ បើពួកគេបានរួបរួមជាមួយគ្នា ឬជាមួយនរណាម្នាក់ផ្សេងទៀតពីមុនមក ពួកគេត្រូវគោរពភារកិច្ចដែលមកពីការរួបរួមនេះ (CIC ១០៧១)។

១៦៣០-លោកបូជាចារ្យ (ឬលោកឧបដ្ឋាក) ដែលចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ ទទួលពាក្យសន្យារបស់គូស្វាមីភរិយា ក្នុងនាមព្រះសហគមន៍ និងប្រទានព្រះពររបស់ព្រះសហគមន៍។ វត្តមានរបស់អ្នកបម្រើព្រះសហគមន៍ (និងរបស់សាក្សីផងដែរ) សម្តែងឲ្យមើលឃើញថា អាពាហ៍ពិពាហ៍ជារឿងដែលទាក់ទងនឹងព្រះសហគមន៍។

១៦៣១-ហេតុនេះហើយបានជាធម្មតា ព្រះសហគមន៍សុំឲ្យគ្រីស្តបរិស័ទរៀបការតាមពិធីបុណ្យខាងព្រះសហគមន៍ (មហាសន្និបាតនៅទៅក្រុងត្រង់៖ DS ១៨១៣-១៨១៦; CIC ១១០៨)។ មូលហេតុជាច្រើនពន្យល់ឆន្ទៈនេះ៖

-អគ្គសញ្ញាអាពាហ៍ពិពាហ៍ជាកិច្ចការនៃពិធីបុណ្យ។ ហេតុនេះហើយបានជាគួរប្រារព្ធពិធីអាពាហ៍ពិពាហ៍ក្នុងពិធីបុណ្យសាធារណៈរបស់ព្រះសហគមន៍

-អាពាហ៍ពិពាហ៍ត្រូវបញ្ចូលក្នុង ordo (ក្រុម) នៃព្រះសហគមន៍ បង្កើតសិទ្ធិ និងភារកិច្ចក្នុងព្រះសហគមន៍រវាងគូស្វាមីភរិយា និងចំពោះកូនៗផងដែរ

-ដោយសារអាពាហ៍ពិពាហ៍ជារបៀបរស់នៅក្នុងព្រះសហគមន៍ ត្រូវតែដឹងច្បាស់អំពីអាពាហ៍ពិពាហ៍ (ទើបចាំបាច់ត្រូវតែមានសាក្សី)

-លក្ខណៈជាសាធារណៈនៃការយល់ព្រមជាកិច្ចការពារនូវពាក្យសន្យានេះ ដែលគូស្វាមីភរិយាបានផ្តល់ឲ្យគ្នាទៅវិញទៅមក និងជួយគេឲ្យនៅស្មោះត្រង់នឹងពាក្យសន្យានេះដែរ។

១៦៣២-គូស្វាមីភរិយាត្រូវតែត្រៀមខ្លួនមុននឹងរៀបការ ដើម្បីឲ្យពួកគេមានសេរីភាព និងទទួលខុសត្រូវចុះកិច្ចសន្យារវាងគ្នានឹងគ្នា ហើយដើម្បីឲ្យសម្ព័ន្ធមេត្រីមានគ្រឹះដ៏រឹងមាំដែលមានលក្ខណៈជាមនុស្សសុទ្ធសាធ និងដែលមកពីគ្រីស្តសាសនាផង៖

យកតម្រាប់មាតាបិតាជាគំរូ ប្រតិបត្តិតាមការប្រៀនប្រដៅរបស់លោក និងក្រុមគ្រួសារជាផ្លូវដ៏ពិសេសនៃការត្រៀមនេះ។

តួនាទីរបស់ពួកគង្វាល និងសហគមន៍របស់គ្រីស្តបរិស័ទ ដែលជា "ក្រុមគ្រួសាររបស់ព្រះជាម្ចាស់" ចាំបាច់ត្រូវតែបញ្ជូនបន្តឧត្តមគតិអំពីអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារ ដែលមានលក្ខណៈជាមនុស្សសុទ្ធសាធ និងដែលមកពីគ្រីស្តសាសនាផង (CIC ១០៦៣) ជាពិសេសនៅសម័យបច្ចុប្បន្ននេះ យុវជនជាច្រើនមានបទពិសោធន៍ថា ក្រុមគ្រួសារបែកបាក់គ្នា មិនអាចបញ្ជូនបន្តឧត្តមគតិនោះបានឡើយ៖

ត្រូវបង្ហាត់យុវជនឲ្យទាន់ពេលវេលា និងតាមតម្រូវការ អំពីកិត្តិយសដ៏ថ្លៃថ្នូរនៃសេចក្តីស្នេហាជាគូស្វាមីភរិយា អំពីតួនាទី និងអំពីការអនុវត្តផងដែរ។ ដូច្នេះ យុវជនដែលទទួលការអប់រំអំពីព្រហ្មចរិយធម៌ដល់ពេលកំណត់ គេអាចរៀបអាពាហ៍ពិពាហ៍ រស់នៅជាគូស្វាមីភរិយា ក្រោយពីបានរស់នៅយ៉ាងថ្លៃថ្នូរតាំងពីពេលភ្ជាប់ពាក្យមក (GS ៤៩,៣)។

អាពាហ៍ពិពាហ៍រវាងគ្រីស្តបរិស័ទកាតូលិក នឹងគ្រីស្តបរិស័ទនិកាយផ្សេង -អាពាហ៍ពិពាហ៍រវាងគ្រីស្តបរិស័ទកាតូលិក និងអ្នកដែលមិនមែនជាគ្រីស្តបរិស័ទ

១៦៣៣-ក្នុងប្រទេសជាច្រើន គ្រីស្តបរិស័ទកាតូលិកច្រើនរៀបការជាមួយគ្រីស្តបរិស័ទខាងនិកាយផ្សេង។ គូស្វាមីភរិយា និងពួកគង្វាលត្រូវតែយកចិត្តទុកដាក់នឹងស្ថានភាពនេះ ជាពិសេសនៅពេលដែលគ្រីស្តបរិស័ទកាតូលិករៀបការជាមួយអ្នកដែលមិនមែនជាគ្រីស្តបរិស័ទ។

១៦៣៤-ទោះបីគូស្វាមីភរិយាកាន់និកាយផ្សេងពីគ្នាយ៉ាងណាក៏ដោយ ក៏គេអាចរៀបការបាន បើគេចែករំលែកនូវអ្វីៗដែលម្នាក់ៗបានទទួលក្នុងសហគមន៍របស់ខ្លួន ហើយបើគេរៀនពីគ្នាទៅវិញទៅមកអំពីរបៀបដែលរៀងៗខ្លួនជាគ្រីស្តបរិស័ទផងដែរ។ ប៉ុន្តែ យើងមិនត្រូវយល់ខុសអំពីការលំបាកផ្សេងៗដែលកើតឡើង នៅពេលដែលគ្រីស្តបរិស័ទកាតូលិករៀបការជាមួយគ្រីស្តបរិស័ទខាងនិកាយផ្សេងទៀតដែរ។ ការលំបាកនោះ មកពីព្រះសហគមន៍មិនទាន់បានដោះស្រាយការបាក់បែករវាងគ្រីស្តបរិស័ទនៅឡើយ។ គូស្វាមីភរិយាអាចទទួលវិបាកកម្មនៃការបាក់បែករវាងគ្រីស្តបរិស័ទក្នុងក្រុមគ្រួសាររបស់គេផ្ទាល់។ នៅពេលដែលគ្រីស្តបរិស័ទកាតូលិកម្នាក់រៀបការជាមួយអ្នកដែលមិនមែនជាគ្រីស្តបរិស័ទ ការលំបាកនោះអាចកាន់តែធុនធ្ងរទៅ។ គំនិតផ្សេងគ្នាអំពីជំនឿ អំពីអាពាហ៍ពិពាហ៍ ឬគំនិតខាងសាសនាផ្សេងគ្នា អាចបង្កើតភាពតានតឹងក្នុងការរស់នៅជាគូស្វាមីភរិយា ជាពិសេសចំពោះការអប់រំកូនៗ។ ពេលនោះ គូស្វាមីភរិយាអាចចាញ់ការល្បួង មិនខ្វល់ខ្វាយនឹងសាសនាឡើយ។

១៦៣៥-តាមច្បាប់ព្រះសហគមន៍ខាងបស្ចិមប្រទេស នៅពេលគ្រីស្តបរិស័ទកាតូលិករៀបការជាមួយគ្រីស្តបរិស័ទនិកាយផ្សេង គេត្រូវការការអនុញ្ញាតជាក់លាក់ ពីអាជ្ញាធរព្រះសហគមន៍ (CIC ១១២៤)។ នៅពេលដែលគ្រីស្តបរិស័ទកាតូលិករៀបការជាមួយអ្នកដែលមិនមែនជាគ្រីស្តបរិស័ទ គេត្រូវឲ្យមានការលើកលែងជាក់លាក់ ដើម្បីឲ្យអាពាហ៍ពិពាហ៍ត្រឹមត្រូវ (CIC ១០៨៦)។ ព្រះសហគមន៍ផ្តល់ការអនុញ្ញាត ឬការលើកលែងនោះ លុះត្រាតែ

ភាគីទាំងពីរស្គាល់ និងមិនទាត់ចោលគោលដៅ និងលក្ខណៈសំខាន់ៗនៃអាពាហ៍ពិពាហ៍ ហើយភាគីកាតូលិកសុខចិត្តទទួលភារកិច្ចផ្តល់ពិធីជ្រមុជទឹកឲ្យកូនៗ និងអប់រំពួកគេក្នុងព្រះសហគមន៍កាតូលិក (CIC ១១២៥)។

១៦៣៦-ក្នុងតំបន់ជាច្រើន ដោយសារក្រុមអន្តរនិកាយ នៅពេលគ្រីស្តបរិស័ទកាតូលិករៀបការជាមួយគ្រីស្តបរិស័ទខាងនិកាយផ្សេង សហគមន៍គ្រីស្តបរិស័ទបានចាត់ចែងឲ្យមានក្រុមរួម ដែលមានមុខងារជួយគូស្វាមីភរិយាឲ្យរស់នៅតាមស្ថានភាពពិសេសរបស់គេក្រោមពន្លឺនៃជំនឿ ហើយដើម្បីជួយពុះពារភាពតានតឹងទាំងប៉ុន្មាន ដែលកើតមកពីភារកិច្ចរបស់គូស្វាមីភរិយាចំពោះគ្នាទៅវិញទៅមក និងចំពោះសហគមន៍របស់គេ។ ក្រុមនោះក៏ត្រូវលើកទឹកចិត្តគូស្វាមីភរិយាឲ្យគោរពគ្នាទៅវិញទៅមក ទោះបីគេខុសប្លែកពីគ្នាក៏ដោយ។

១៦៣៧-ក្នុងពេលដែលគ្រីស្តបរិស័ទកាតូលិករៀបការជាមួយអ្នកដែលមិនមែនជាគ្រីស្តបរិស័ទ ស្វាមីកាតូលិកមានមុខងារពិសេស៖ "ដ្បិតព្រះជាម្ចាស់ប្រោសស្វាមីដែលមិនជឿឲ្យបានវិសុទ្ធដោយសារភរិយា ហើយព្រះអង្គក៏ប្រោសភរិយាដែលមិនជឿឲ្យបានវិសុទ្ធ ក៏ដោយសារស្វាមីដែលជាអ្នកជឿនោះដែរ" (១ករ ៧,១៤)។ បើព្រះជាម្ចាស់ ដែលប្រោសអ្នកមិនជឿឲ្យបានវិសុទ្ធ ប្រោសគេឲ្យស្ម័គ្រចិត្តកែប្រែចិត្តគំនិតជឿលើគ្រីស្តសាសនា គូស្រករដែលជឿ និងព្រះសហគមន៍ពិតជាត្រេកអរណាស់។ គូស្រករដែលស្រឡាញ់គ្នាដោយស្មោះ ដែលប្រតិបត្តិគុណធម៌ខាងក្រុមគ្រួសារ ដោយចិត្តសុភាពរាបសា និងដោយអំណត់ និងដែលអធិដ្ឋាន អាចរៀបចំគូស្រករដែលមិនជឿឲ្យទទួលព្រះហឫទ័យប្រណីសន្តោសដើម្បីកែប្រែចិត្តគំនិត។

## ៤-ផលនៃអគ្គសញ្ញាអាពាហ៍ពិពាហ៍

១៦៣៨-"ដោយសារគូស្វាមីភរិយារៀបអាពាហ៍ពិពាហ៍យ៉ាងត្រឹមត្រូវ ជាចំណងដែលចងពួកគេ ជានិច្ចនិរន្តរ៍តរៀងទៅ។ ម្យ៉ាងទៀត ក្នុងអាពាហ៍ពិពាហ៍តាមគ្រីស្តសាសនា ព្រះជាម្ចាស់ពង្រឹងកម្លាំង និងដូចជាញែកគូស្វាមីភរិយា ដោយសារអគ្គសញ្ញាពិសេស ដើម្បីបំពេញភារកិច្ច និងរបៀបរស់នៅយ៉ាងថ្លៃថ្នូរ" (CIC ១១៣៤)។

### ចំណងនៃអាពាហ៍ពិពាហ៍

១៦៣៩-ព្រះជាម្ចាស់ផ្ទាល់ចងពាក្យសន្យា ដែលគូស្វាមីភរិយាប្រគល់ខ្លួនចំពោះគ្នាទៅវិញទៅមក និងទទួលពីគ្នាទៅវិញទៅមក (មក ១០,៩)។ "ស្ថាប័នម្យ៉ាងកើតមកពីសម្ព័ន្ធមេត្រីរវាងពួកគេ គឺអាពាហ៍ពិពាហ៍ដែលធម្មវិន័យរបស់ព្រះជាម្ចាស់បញ្ជាក់ ហើយសូម្បីតែសង្គមមនុស្សក៏ទទួលស្គាល់ដែរ" (GS ៤៨,១)។ សម្ព័ន្ធមេត្រីរវាងគូស្វាមីភរិយាត្រូវរាប់បញ្ចូលក្នុងសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់ជាមួយមនុស្សលោក៖ "ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់បានលើកយកសេចក្តីស្រឡាញ់ដ៏ពិតប្រាកដរបស់គូស្វាមីភរិយាឲ្យចូលរួមជាមួយ" (GS ៤៨,២)។

១៦៤០-ព្រះជាម្ចាស់ផ្ទាល់ចាត់ចែងចំណងអាពាហ៍ពិពាហ៍ ដូច្នេះហើយ ទើបគ្រីស្តបរិស័ទដែលបានរៀបការ និងបានរួមបវេណីរួចហើយ មិនអាចបំបែកពីគ្នាបានឡើយ។ ចំណងនេះ ដែលចេញមកពីកិច្ចការដ៏សេរីរបស់គូស្វាមីភរិយា ដែលបានរួមបវេណីហើយ មិនអាចដកហូតវិញបាន ហើយបង្កើតសម្ព័ន្ធមេត្រី ដែលព្រះហឫទ័យភក្តីភាពរបស់ព្រះជាម្ចាស់ធានា។ ព្រះសហគមន៍ពុំមានអំណាចសម្រេចប្រឆាំងនឹងការចាត់ចែងនៃព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់នេះបានឡើយ (CIC ១១៤១)។

### ព្រះអំណោយទាននៃអគ្គសញ្ញាអាពាហ៍ពិពាហ៍

១៦៤១-"តាមរបៀបរស់នៅរបស់ខ្លួន និងតាមឋានៈរបស់ខ្លួន គ្រីស្តបរិស័ទជាគូស្វាមីភរិយា ទទួលព្រះអំណោយ

ទានផ្ទាល់ក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់" (LG ១១)។ ព្រះអំណោយទានពិសេសនៃអគ្គសញ្ញាអាពាហ៍ពិពាហ៍នេះ មានគោលដៅកែលំអសេចក្តីស្រឡាញ់រវាងគូស្វាមីភរិយាឲ្យកាន់តែល្អប្រសើរ និងជួយគេឲ្យរួមរស់ជាមួយគ្នាដោយមិនបំបែកពីគ្នា។ ដោយសារព្រះអំណោយទាននេះ "គូស្វាមីភរិយាជួយគ្នាទៅវិញទៅមកឲ្យទៅជាជនដ៏វិសុទ្ធតាមការរស់នៅជាគូស្វាមីភរិយា ដោយបង្កើតកូន និងអប់រំពួកវា" (LG ១១)។

១៦៤២-ព្រះគ្រីស្តជាប្រភពនៃព្រះអំណោយទាននេះ។ "កាលពីដើម ព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីប្រកបដោយព្រះហឫទ័យស្រឡាញ់ និងមានចិត្តភក្តីជាមួយប្រជារាស្ត្រព្រះអង្គយ៉ាងណា សព្វថ្ងៃព្រះសង្គ្រោះរបស់មនុស្សលោកជាព្រះស្វាមីនៃព្រះសហគមន៍ ក៏យាងមកជួបគូស្វាមីភរិយាជាគ្រីស្តបរិស័ទដោយសារអគ្គសញ្ញាអាពាហ៍ពិពាហ៍យ៉ាងនោះដែរ" (GS ៤៨,២)។ ព្រះអង្គគង់នៅជាមួយពួកគេ ប្រទានកម្លាំងឲ្យពួកគេដើរតាមព្រះអង្គ ដោយលីឈើឆ្កាងលើខ្លួនឯង ទ្រង់ឲ្យគេងើបឡើងវិញក្រោយពីបានជំពប់ដួល ឲ្យគេលើកលែងទោសឲ្យគ្នាទៅវិញទៅមកឲ្យគេជួយរំលែកទុក្ខធុរៈគ្នាទៅវិញទៅមក (កាឡ ៦,២) ឲ្យគេ "គោរពចុះចូលគ្នាទៅវិញទៅមក ដោយកោតខ្លាចព្រះគ្រីស្ត" (អភ ៥,២១) និងឲ្យគេស្រឡាញ់គ្នាទៅវិញទៅមក ដោយសេចក្តីស្រឡាញ់ហួសពីធម្មជាតិចេះថ្នាក់ថ្នមគ្នា និងបង្កើតផល។ ក្នុងក្តីអំណរដែលមកពីសេចក្តីស្រឡាញ់ និងពីជីវិតក្នុងក្រុមគ្រួសាររបស់គេ ព្រះអង្គប្រទានឲ្យគេស្គាល់រសជាតិទុកជាមុននៃពិធីមង្គលការនៃកូនចៀម នៅក្នុងលោកនេះរួចហើយ៖

> តើខ្ញុំនឹងយកកម្លាំងចេញមកពីណា ដើម្បីរៀបរាប់យ៉ាងត្រឹមត្រូវអំពីសុភមង្គលនៃអាពាហ៍ពិពាហ៍ តាមព្រះសហគមន៍ ដែលតង្វាយបញ្ជាក់ ដែលពិធីថ្វាយព្រះពរចង? ពួកទេវទូតប្រកាស ហើយព្រះបិតាដែលគង់នៅស្ថានបរមសុខបញ្ជាក់សុភមង្គលនេះ (...)។ គូស្វាមីភរិយាជាគ្រីស្តបរិស័ទ ដែលរួបរួមគ្នាក្នុងសេចក្តីសង្ឃឹមតែមួយ ក្នុងបំណងប្រាថ្នាតែមួយ ក្នុងវិន័យតែមួយ ក្នុងកិច្ចបម្រើតែមួយ ពិតជាល្អប្រសើរណាស់! ទាំងពីរនាក់ជាបុត្រធីតារបស់ព្រះបិតាតែមួយ ជាអ្នកបម្រើរបស់ម្ចាស់តែមួយ។ គ្មានអ្វីបំបែកគេ ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ ផ្ទុយទៅវិញ គេពិតជាបុគ្គលពីរនាក់ក្នុងរូបកាយតែមួយ។ នៅទីណារូបកាយមានតែមួយ នៅទីនោះមានចិត្តតែមួយដែរ (លោក ទែរទូលីយ៉ាំង; FC ១៣)។

## ៥-សិទ្ធិ និងនាទីកិច្ចនៃសេចក្តីស្រឡាញ់ជាគូស្វាមីភរិយា

១៦៤៣-"ផ្នែកទាំងអស់នៃបុគ្គលម្នាក់ -រូបកាយ និងសភាវគតិ អារម្មណ៍ និងមនោសញ្ចេតនា វិញ្ញាណ និងឆន្ទៈ -ត្រូវបាញ់ចូលគ្នាជាសេចក្តីស្រឡាញ់របស់គូស្វាមីភរិយា។ សេចក្តីស្រឡាញ់នេះ តម្រង់ឲ្យគូស្វាមីភរិយាទៅជាបុគ្គលតែម្នាក់ ដោយរួបរួមជាមួយគ្នាមិនគ្រាន់តែខាងផ្លូវកាយទេ ជាពិសេសដោយមានចិត្តគំនិតតែមួយ។ សេចក្តីស្រឡាញ់នេះ ទាមទារឲ្យគូស្វាមីភរិយាប្រគល់ខ្លួនចំពោះគ្នាទៅវិញទៅមកជានិច្ចនិរន្តរ៍ ដោយមិនអាចបំបែកពីគ្នាបានឡើយ និងដោយមានចិត្តភក្តី និងដោយបង្កើតផលផ្លែ។ សេចក្តីស្រឡាញ់នេះ មានលក្ខណៈរបស់សេចក្តីស្រឡាញ់ជាគូស្វាមីភរិយាខាងធម្មជាតិ ប៉ុន្តែ មានអត្ថន័យថ្មី ដែលមិនត្រឹមតែបន្សុទ្ធ និងពង្រឹងលក្ខណៈនោះទេ ថែមទាំងលើកលក្ខណៈនោះរហូតដល់ទៅជាឧត្តមគតិរបស់គ្រីស្តសាសនាផ្ទាល់" (FC ១៣)។

### គូស្វាមីភរិយារួមជាមួយគ្នា ដោយមិនអាចបំបែកពីគ្នាបានឡើយ

១៦៤៤-សេចក្តីស្រឡាញ់របស់គូស្វាមីភរិយាទាមទារឲ្យសហគមន៍របស់គេរួមជាមួយគ្នា ដោយមិនអាចបំបែក

ពីគ្នាបានឡើយ៖ "គេមិនមែនជាបុគ្គលពីរនាក់ទៀតទេ គឺជារូបកាយតែមួយវិញ" (មថ ១៩,៦)។ "ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យរីកចម្រើនជានិច្ច ក្នុងការរួបរួមជាមួយគ្នា ដោយគោរពពាក្យសន្យានៃអាពាហ៍ពិពាហ៍ក្នុងជីវិតប្រចាំថ្ងៃ គឺប្រគល់ខ្លួនទាំងស្រុងចំពោះគ្នាទៅវិញទៅមក" (FC ១៩)។ ការរួបរួមជាមួយព្រះយេស៊ូគ្រីស្តដែលផ្តល់អគ្គសញ្ញាអាពាហ៍ពិពាហ៍បញ្ជាក់ បន្សុទ្ធ និងបំពេញការរួបរួមនេះ ដែលមានលក្ខណៈជាមនុស្សសុទ្ធសាធ។ ការរស់នៅដោយមានជំនឿតែមួយ និងការទទួលពិធីអរព្រះគុណរួមជាមួយគ្នាពង្រឹងការរួបរួមជាមួយគ្នានេះ។

១៦៤៥-"ពេលគូស្វាមីភរិយាស្នេហាគ្នាយ៉ាងពេញលក្ខណៈ នោះបុរស និងស្ត្រីមានកិត្តិយសថ្លៃថ្នូរ និងមានឋានៈស្មើគ្នា។ សមភាពនេះ បង្ហាញយ៉ាងច្បាស់ថា ត្រូវមានគូស្រករតែមួយគត់ដូចព្រះអម្ចាស់បានបញ្ជាក់ស្រាប់ហើយ" (GS ៤៩,២)។ បើបុរសមានភរិយាច្រើន ឬស្ត្រីមានស្វាមីច្រើន គេប្រឆាំងនឹងកិត្តិយសដ៏ថ្លៃថ្នូរស្មើគ្នានេះ និងសេចក្តីស្រឡាញ់ជាគូស្វាមីភរិយាដែលមានតែមួយចំពោះគ្នា (FC ១៩)។

## ភក្តីភាពនៃសេចក្តីស្រឡាញ់ជាគូស្វាមីភរិយា

១៦៤៦-សេចក្តីស្រឡាញ់ជាគូស្វាមីភរិយាទាមទារឲ្យគូស្វាមីភរិយាមានចិត្តភក្តី ដែលមិនអាចរំលោភបានឡើយ ដ្បិតពួកគេប្រគល់ខ្លួនចំពោះគ្នាទៅវិញទៅមក។ សេចក្តីស្រឡាញ់មានជាស្ថាពរ មិនអាចបញ្ចប់បានឡើយ។ "គេដឹងខ្លួនថា គេរួបរួមគ្នាដោយចិត្តថ្លើមតែមួយ និងរួបរួមគ្នាកាន់តែជិតស្និទ្ធ ដោយប្រគល់ខ្លួនទៅវិញទៅមក ដោយរួមបវេណី និងទាមទារឲ្យគូស្វាមីភរិយា មានចិត្តភក្តីទាំងស្រុង មិនអាចបំបែកបានឡើយ" (GS ៤៨,១)។

១៦៤៧-មូលហេតុដ៏សំខាន់នៃការទាមទារនេះ ស្ថិតនៅក្នុងព្រះហឫទ័យស្មោះស្ម័គ្ររបស់ព្រះជាម្ចាស់ចំពោះសម្ព័ន្ធមេត្រីរបស់ព្រះអង្គ ឬរបស់ព្រះគ្រីស្តចំពោះព្រះសហគមន៍ព្រះអង្គ។ ដោយសារអគ្គសញ្ញាអាពាហ៍ពិពាហ៍ គូស្វាមីភរិយាអាចធ្វើជាតំណាង និងអាចផ្តល់សក្ខីភាពចំពោះភក្តីភាពនេះ។ ដោយសារអគ្គសញ្ញាអាពាហ៍ពិពាហ៍ ដែលមិនអាចរំលាយបាន ទទួលអត្ថន័យថ្មី និងស៊ីជម្រៅបំផុត។

១៦៤៨-ប្រហែលជាមានអ្នកខ្លះគិតថា យើងមិនអាចរួមរស់ជាមួយម្នាក់ផ្សេងទៀតអស់មួយជីវិតបានឡើយ។ ហេតុនេះហើយបានជាត្រូវតែប្រកាសដំណឹងល្អថា ព្រះជាម្ចាស់ស្រឡាញ់យើងដោយសេចក្តីស្រឡាញ់ជាស្ថាពរ ដែលមិនអាចដកហូតបានឡើយ។ គូស្វាមីភរិយាទទួលចំណែកក្នុងសេចក្តីស្រឡាញ់នេះ ដែលជួយទ្រទ្រង់គេ ហើយបើគេនៅភក្តីនឹងគ្នា គេអាចធ្វើជាសាក្សីនៃសេចក្តីស្រឡាញ់ដ៏ស្មោះស្ម័គ្ររបស់ព្រះជាម្ចាស់បាន។ ព្រះសហគមន៍គួរគាំទ្រ និងដឹងគុណចំពោះគូស្វាមីភរិយា ដែលផ្តល់សក្ខីភាពអំពីសេចក្តីស្រឡាញ់នេះ ជារឿយៗក្នុងស្ថានភាពដ៏លំបាក (ដោយមានព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ជួយគេផង) (FC ២០)។

១៦៤៩-ប៉ុន្តែ ទោះជាយ៉ាងណាក៏មានអ្នកខ្លះដែរ ស្ថិតនៅក្នុងស្ថានភាពដែលមិនអាចរស់នៅជាមួយគ្នា ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួច បណ្តាលមកអំពីមូលហេតុផ្សេងៗ។ ក្នុងករណីនោះ ព្រះសហគមន៍អនុញ្ញាតឲ្យស្វាមីភរិយាបែកគ្នាដោយរាងកាយ និងលែងរស់នៅជាមួយគ្នា។ ស្វាមីភរិយានៅតែជាប្តីប្រពន្ធចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ក៏ប៉ុន្តែមិនអាចរៀបការម្តងទៀតទេ។ ក្នុងស្ថានភាពដ៏លំបាកនេះ មានតែការសម្រុះសម្រួលគ្នាទេ ទើបជាដំណោះស្រាយដ៏ប្រសើរ ប្រសិនជាអាចធ្វើទៅរួច។ ព្រះជាម្ចាស់ត្រាស់ហៅព្រះសហគមន៍ឲ្យរួមចំណែកជាមួយអ្នកទាំងអស់នោះ ដើម្បីឲ្យពួកគេរស់នៅក្នុងសភាពជាគ្រីស្តបរិស័ទ មានភក្តីភាពចំពោះចំណងអាពាហ៍ពិពាហ៍ដែលមិនអាចបំបែកចេញពីគ្នា។

១៦៥០-សព្វថ្ងៃនេះ មានគ្រីស្តបរិស័ទកាតូលិកក្នុងប្រទេសជាច្រើន ដែលលែងលះគ្នា ហើយដែលរៀប

អាពាហ៍ពិពាហ៍ម្តងទៀត តាមច្បាប់រដ្ឋបវេណី។ ព្រះសហគមន៍នៅតែប្រកាន់តាមព្រះបន្ទូលរបស់ព្រះយេស៊ូគ្រីស្ត ថា៖ "ប្រសិនបើស្វាមីណាលែងភរិយា ហើយទៅរៀបការនឹងស្ត្រីម្នាក់ទៀត ស្វាមីនោះបានផិតក្បត់ភរិយារបស់ខ្លួន។ រីឯភរិយាណាដែលលែងស្វាមី ហើយទៅរៀបការនឹងបុរសម្នាក់ទៀត ស្ត្រីនោះក៏បានប្រព្រឹត្តអំពើផិតក្បត់ដែរ" (មក ១០,១១-១២) ដូច្នេះ បើអាពាហ៍ពិពាហ៍ដំបូងត្រឹមត្រូវ ព្រះសហគមន៍ក៏មិនអាចទទួលស្គាល់ចំណងអាពាហ៍ពិពាហ៍ថ្មីទេ។ ប្រសិនបើអ្នកដែលបានលែងលះគ្នា ហើយទៅរៀបការម្តងទៀតតាមច្បាប់រដ្ឋបវេណី នោះពួកគេស្ថិតនៅក្នុងស្ថានភាពដែលផ្ទុយនឹងវិន័យរបស់ព្រះជាម្ចាស់។ ហេតុនេះហើយ ពួកគេមិនអាចទទួលព្រះកាយព្រះលោហិតព្រះគ្រីស្ត ក្នុងស្ថានភាពបែបនេះទេ។ ដូចគ្រានេះដែរ ពួកគេមិនអាចទទួលភារកិច្ចណាមួយក្នុងព្រះសហគមន៍បានឡើយ។ ព្រះសហគមន៍អាចផ្តល់អគ្គសញ្ញាលើកលែងទោស ទាល់តែអ្នកទាំងអស់នោះសោកស្តាយបានរំលោភបំពានលើសញ្ញាសម្គាល់នៃសម្ព័ន្ធមេត្រី និងភក្តីភាពចំពោះព្រះគ្រីស្ត ហើយប្តេជ្ញាថា នឹងរស់នៅដោយមិនរួមរ័ក្សជាមួយគ្នាជាដាច់ខាត។

១៦៥១-ចំពោះគ្រីស្តបរិស័ទ ដែលរស់នៅក្នុងស្ថានភាពបែបនេះ ហើយនៅតែរក្សាជំនឿ និងមានបំណងអប់រំកូនៗ ទៅតាមគ្រីស្តសាសនា ពួកបូជាចារ្យ និងសហគមន៍ទាំងមូលត្រូវតែបង្ហាញនូវការយកចិត្តទុកដាក់ទៅលើពួកគេ កុំឲ្យពួកគេយល់ថា ពួកគេបែកចេញពីព្រះសហគមន៍ ដែលពួកគេអាច និងត្រូវរួមចំណែកក្នុងឋានៈជាអ្នកដែលបានជ្រមុជទឹក៖

> ត្រូវអញ្ជើញពួកគេមកស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ ចូលរួមថ្វាយអភិបូជា ព្យាយាមអធិដ្ឋានជានិច្ច ចូលរួមធ្វើវិភាគទាន និងចូលរួមក្នុងសកម្មភាពព្រះសហគមន៍ក្នុងការរកយុត្តិធម៌ អប់រំកូនៗតាមគ្រីស្តសាសនា សោកស្តាយអំពើបាបរបស់ខ្លួន និងអង្វរព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ពីមួយថ្ងៃទៅមួយថ្ងៃ (FC ៨៤)។

### ត្រូវតែយល់ព្រមបន្តពូជ (សមិទ្ធិផល)

១៦៥២-"លក្ខណៈនៃអាពាហ៍ពិពាហ៍ និងលក្ខណៈនៃសេចក្តីស្រឡាញ់របស់គូស្វាមីភរិយា តម្រង់ទិសទៅរកការបន្តពូជ និងទៅឲ្យការអប់រំកូន ដែលហាក់ដូចជាគោលដៅដ៏កំពូលនៃអាពាហ៍ពិពាហ៍ និងនៃសេចក្តីស្រឡាញ់ជាគូស្វាមីភរិយា" (GS ៤៨,១)៖

> កូនៗជាអំណោយទានដ៏ប្រសើរបំផុតនៃការរួមរស់ជាគូស្វាមីភរិយា ហើយក៏ជួយផ្តល់សេចក្តីសុខដល់ឪពុកម្តាយយ៉ាងខ្លាំងដែរ។ ព្រះជាម្ចាស់មានព្រះបន្ទូលដោយផ្ទាល់ព្រះអង្គថា "បើមនុស្សប្រុសនៅតែឯងមិនស្រួលទេ" (កណ ២,១៨)។ តាំងពីដើមរៀងមក ព្រះអង្គបង្កើតមនុស្សជាបុរស និងជាស្ត្រី (មថ ១៩,៤) ព្រះអង្គក៏សព្វព្រះហឫទ័យឲ្យមនុស្សទទួលចំណែកពិសេសក្នុងកិច្ចបង្កើតរបស់ព្រះអង្គ ហេតុនេះហើយបានជាព្រះអង្គប្រទានពរឲ្យបុរស និងស្ត្រីថា៖ "ចូរបង្កើតកូនចៅឲ្យបានកើនច្រើនឡើង" (កណ ១,២៨)។ ដូច្នេះ ស្នេហាដ៏ពិតប្រាកដ តាមការយល់ឃើញយ៉ាងត្រឹមត្រូវ ដូចរចនាសម្ពន្ធនៃក្រុមគ្រួសារដែលហូរមកពីស្នេហានោះ ក៏តម្រង់ទៅជួយឲ្យគូស្វាមីភរិយាមានចិត្តទូលាយសហការជាមួយព្រះហឫទ័យស្រឡាញ់របស់ព្រះបង្កើត និងរបស់ព្រះសង្គ្រោះ គឺព្រះអង្គមានបំណងចង់ពង្រីកមហាគ្រួសាររបស់ព្រះអង្គ និងឲ្យមហាគ្រួសារនោះកាន់តែប្រសើរឡើងៗ ដោយសារពួកគេ (GS ៥០,១)។

១៦៥៣-ផលនៃសេចក្តីស្រឡាញ់ជាគូស្វាមីភរិយាលាតសន្ធឹងដល់ផលនៃជីវិតខាងសីលធម៌ ជីវិតខាងវិញ្ញាណ

និងការស់នៅហួសធម្មជាតិ ដែលឪពុកម្ដាយបញ្ជូនបន្ដដល់កូនៗរបស់គេ ដោយសារការអប់រំ។ ឪពុកម្ដាយជាគ្រូអប់រំដំបូង និងសំខាន់ជាងគេនៃកូនៗ (GE ៣)។ តាមអត្ថន័យនេះ មុខងារសំខាន់ជាងគេរបស់គូស្វាមីភរិយា និងក្រុមគ្រួសារ គឺបម្រើជីវិត (FC ២៨)។

១៦៥៤-គូស្វាមីភរិយា ដែលព្រះជាម្ចាស់មិនបានប្រោសប្រទានឲ្យមានកូន អាចមានការរស់នៅជាគូស្វាមីភរិយាពោរពេញដោយអត្ថន័យ តាមលក្ខណៈជាមនុស្សសុទ្ធសាធផង និងតាមគ្រីស្ដសាសនាផងដែរ។ ពួកគេអាចបង្កើតផលផ្លែបានច្រើន ដោយស្រឡាញ់ និងជួយអ្នកដទៃ និងដោយសុខចិត្តលះបង់ខ្លួនឯងផងដែរ។

## ៦-ក្រុមគ្រួសារជាព្រះសហគមន៍ដ៏តូចមួយ

១៦៥៥-ព្រះគ្រីស្ដសព្វព្រះហឫទ័យប្រសូត និងចម្រើនឡើងក្នុងចំណោមក្រុមគ្រួសារដ៏វិសុទ្ធរបស់លោក យ៉ូសែប និងនាងម៉ារី។ ព្រះសហគមន៍ជា "ក្រុមគ្រួសាររបស់ព្រះជាម្ចាស់"។ តាំងពីដើមដំបូង អស់អ្នក "រួបរួមជាមួយក្រុមគ្រួសារ" របស់ពួកគេ ដែលបានទៅជាអ្នកជឿ (កក ១៨,៨) ជាស្នូលនៃព្រះសហគមន៍។ នៅពេលដែលពួកគេកែប្រែចិត្តគំនិត ពួកគេប៉ងប្រាថ្នាឲ្យ "ក្រុមគ្រួសារ" ទាំងអស់របស់ពួកគេទទួលការសង្គ្រោះផងដែរ (កក ១៦,៣១ និង ១១,១៤)។ ក្រុមគ្រួសារដែលបានទៅជាអ្នកជឿដូចជាកោះដ៏តូចៗនៃរបៀបរស់នៅជាគ្រីស្ដបរិស័ទក្នុងចំណោមមនុស្សលោកដែលមិនជឿ។

១៦៥៦-សព្វថ្ងៃនេះ ក្នុងលោកដែលមិនស្គាល់ជំនឿ ឬជួនកាលដែលប្រឆាំងនឹងជំនឿ ក្រុមគ្រួសារជាអ្នកជឿមានសារៈសំខាន់ណាស់ ដូចជាក្រុមតូចៗដែលមានជំនឿដ៏រស់រវើក និងដែលបំភ្លឺមនុស្សលោក។ ហេតុនេះហើយបានជាតាមពាក្យបុរាណមួយ មហាសន្និបាតវ៉ាទីកង់ទីពីរហៅក្រុមគ្រួសារ Ecclesia domestica (ព្រះសហគមន៍ដ៏តូច) (LG ១១; FC ២១)។ "ឪពុកម្ដាយជាអ្នកប្រកាសជំនឿមុនគេដល់កូនរបស់ខ្លួនដោយពាក្យសម្ដី និងដោយធ្វើជាគំរូដល់កូន (...)។ ឪពុកម្ដាយបម្រើព្រះជាម្ចាស់ដែលត្រាស់ហៅកូនម្នាក់ៗ ឲ្យបំពេញមុខងាររបស់ខ្លួនជាពិសេសត្រាស់ហៅឲ្យទៅជាបូជាចារ្យ" (LG ១១)។

១៦៥៧-ឪពុកម្ដាយ កូនៗ និងសមាជិកទាំងអស់របស់ក្រុមគ្រួសារបំពេញមុខងារជាបូជាចារ្យដែលមកពីអគ្គសញ្ញាជ្រមុជទឹក តាមរបៀបយ៉ាងពិសេស "ដោយទទួលអគ្គសញ្ញានានា ដោយអធិដ្ឋាន ដោយអរព្រះគុណ ដោយរស់នៅយ៉ាងវិសុទ្ធទុកជាសក្ខីភាព ដោយលះបង់ និងដោយប្រព្រឹត្តតាមសេចក្ដីស្រឡាញ់យ៉ាងសកម្មដែរ" (LG ១០)។ ដូច្នេះ ក្រុមគ្រួសារដូចជាសាលារៀនខាងគ្រីស្ដសាសនាដើមដំបូង និងដូចជា "សាលាអប់រំមនុស្សឲ្យរីកចម្រើន" (GS ៥២,១)។ នៅទីនេះ យើងរៀនឲ្យមានចិត្តព្យាយាម អំពីអំណរដែលបានមកពីការងារ អំពីសេចក្ដីស្រឡាញ់ដូចជាបងប្អូន អំពីការលើកលែងទោស ទោះជាត្រូវតែលើកលែងទោសម្ដងទៀត ហើយជាពិសេសយើងរៀនលើកតម្កើងព្រះជាម្ចាស់ ដោយអធិដ្ឋាន និងបូជាជីវិត។

១៦៥៨-ត្រូវតែនឹករឭកដល់អស់អ្នកដែលរស់នៅតែម្នាក់ឯង ដោយសារល័ក្ខខ័ណ្ឌនៃការរស់នៅរបស់គេ -ជារឿយៗផ្ទុយនឹងឆន្ទៈរបស់ខ្លួន -ដែលនៅជិតស្និទ្ធនឹងព្រះយេស៊ូ ហើយដែលព្រះសហគមន៍ ជាពិសេសពួកគង្វាលគួរយកចិត្តទុកដាក់ជាប្រញាប់។ ក្នុងចំណោមពួកគេ មនុស្សជាច្រើនគ្មានក្រុមគ្រួសារ ជួនកាលដោយសារជីវភាពក្រីក្រ។ អ្នកខ្លះរស់នៅតាមដំណឹងល្អ ដោយបម្រើព្រះជាម្ចាស់ និងអ្នកដទៃ និងគួរឲ្យយកតម្រាប់តាម។ ត្រូវតែបើកទ្វារនៃ "ព្រះសហគមន៍ដ៏តូច" និងមហាគ្រួសារដែលជាព្រះសហគមន៍ ឲ្យពួកគេទាំងអស់គ្នា។ "គ្មាននរណាម្នាក់ពុំមានក្រុមគ្រួសារនៅក្នុងលោកនេះទេ។ ព្រះសហគមន៍ជាផ្ទះ និងជាក្រុមគ្រួសាររបស់មនុស្សទាំងអស់ ពិសេសអស់អ្នកដែល "នឿយហត់ និងមានបន្ទុកធ្ងន់" (មថ ១១,២៨)" (FC ៨៥)។

# សង្ខេប

១៦៥៩-សន្តៈ ប៉ូល មានប្រសាសន៍ថា៖ "ចំពោះបងប្អូនដែលមានប្រពន្ធវិញ ចូរស្រឡាញ់ភរិយា ដូចព្រះគ្រីស្ត បានស្រឡាញ់ព្រះសហគមន៍ដែរ (...) គម្រោងការដ៏លាក់កំបាំងនេះ មានអត្ថន័យជ្រៅណាស់ ខ្ញុំនិយាយសេចក្តីនេះសំដៅលើព្រះគ្រីស្ត និងព្រះសហគមន៍តែប៉ុណ្ណោះ" (អភ ៥,២៥.៣២)។

១៦៦០-ព្រះជាម្ចាស់ជាអ្នកបង្កើតសម្ព័ន្ធមេត្រីជាគូស្វាមីភរិយា ដោយមានបុរស និងស្ត្រីធ្វើជាសហគមន៍ដ៏ជិតស្និទ្ធ ដោយអ្នកទាំងពីររួមរស់ជាមួយគ្នា និងស្រឡាញ់គ្នា ហើយទ្រង់បានប្រទានវិន័យនេះឲ្យសហគមន៍នេះផ្ទាល់។ លក្ខណៈសហគមន៍នេះ មានគោលដៅតម្រង់ទៅរកផលប្រយោជន៍គូស្វាមីភរិយា ក្នុងការបន្តពូជ និងការអប់រំកូន។ ព្រះគ្រីស្តជាព្រះអម្ចាស់បានលើកសម្ព័ន្ធមេត្រីរវាងគ្រីស្តបរិស័ទនេះឲ្យមានឋានៈជាអគ្គសញ្ញា (GS ៤៨,១; CIC ១០៥៥,១)។

១៦៦១-អគ្គសញ្ញាអាពាហ៍ពិពាហ៍សំដៅទៅលើការរួបរួមរវាងព្រះគ្រីស្ត និងព្រះសហគមន៍។ អគ្គសញ្ញានេះផ្តល់ឲ្យគូស្វាមីភរិយាអាចស្រឡាញ់គ្នា ដូចព្រះគ្រីស្តបានស្រឡាញ់ព្រះសហគមន៍ផងដែរ។ ព្រះអំណោយទាននៃអគ្គសញ្ញានេះធ្វើឲ្យសេចក្តីស្រឡាញ់រវាងគូស្វាមីភរិយាកាន់តែប្រសើរៗ ពង្រឹងឯកភាពរបស់គេ ដែលមិនអាចរលាយបាន និងធ្វើឲ្យគេទៅជាជនដ៏វិសុទ្ធនៅលើផ្លូវនៃជីវិតអស់កល្បជានិច្ច (មហាសន្និបាតនៅទៅក្រុងត្រង់៖ DS ១៧៩៩)។

១៦៦២-អាពាហ៍ពិពាហ៍កើតឡើងនៅពេលដែលគូស្រករទាំងពីរយល់ព្រមរៀបការ ពោលគឺគេមានបំណងចង់ប្រគល់គ្នាទៅវិញទៅមកជាស្ថាពរ ក្នុងគោលដៅចងសម្ព័ន្ធមេត្រីពោរពេញដោយសេចក្តីស្រឡាញ់ដ៏ស្មោះដែលបង្កើតផល។

១៦៦៣-ដោយសារអាពាហ៍ពិពាហ៍ចាត់ចែងគូស្រករឲ្យមានលក្ខណៈរស់នៅជាសាធារណៈក្នុងព្រះសហគមន៍ គួរប្រារព្ធពិធីអាពាហ៍ពិពាហ៍ជាសាធារណៈ ដូចពិធីបុណ្យ ចំពោះមុខលោកបូជាចារ្យ (ឬសាក្សីពិតប្រាកដរបស់ព្រះសហគមន៍) សាក្សី និងអង្គប្រជុំគ្រីស្តបរិស័ទ។

១៦៦៤-ដើម្បីរៀបអាពាហ៍ពិពាហ៍ គូស្រករត្រូវតែរួមឯកភាព និងយល់ព្រមឲ្យបន្តពូជ។ ម៉្យាងទៀត អាពាហ៍ពិពាហ៍មិនអាចរលាយបានដែរ។ ការមានភរិយា (ឬស្វាមី) ជាច្រើនប្រឆាំងនឹងឯកភាពនៃអាពាហ៍ពិពាហ៍ ការលែងលះបំបាក់បំបែកអ្វីដែលព្រះជាម្ចាស់បានផ្សំផ្គុំ ហើយបើគូស្រករមិនព្រមបង្កើតផល គេមិនអាចទទួល "ព្រះអំណោយទានដ៏ប្រសើរ" នៃអាពាហ៍ពិពាហ៍ គឺកូនក្មេង (GS ៥០,១)។

១៦៦៥-បើគូស្រកររៀបការជាមួយម្នាក់ផ្សេងទៀត នៅពេលដែលគូស្រករឯទៀតនៅតែមានជីវិត គេប្រឆាំងនឹងគម្រោងការ និងវិន័យរបស់ព្រះជាម្ចាស់ ដែលព្រះគ្រីស្តបានប្រៀនប្រដៅ។ គេមិនបែកចេញពីព្រះសហគមន៍ទេ ប៉ុន្តែគេមិនអាចទទួលព្រះកាយព្រះលោហិតព្រះគ្រីស្តបានឡើយ។ គេនឹងរស់នៅតាមគ្រីស្តសាសនាដោយអប់រំកូនក្នុងជំនឿ។

១៦៦៦-ក្រុមគ្រួសារជាគ្រីស្តបរិស័ទជាកន្លែង ដែលកូនក្មេងទទួលការប្រកាសជំនឿជាលើកទីមួយ។ ហេតុនេះហើយបានជាគេហៅយ៉ាងត្រឹមត្រូវក្រុមគ្រួសារនេះថា "ព្រះសហគមន៍ដ៏តូច" ជាសហគមន៍ពោរពេញដោយព្រះអំណោយទាន ដែលមានការអធិដ្ឋាន ជាសាលានៃគុណធម៌របស់មនុស្ស និងសេចក្តីស្រឡាញ់នៃគ្រីស្តសាសនា។

# ជំពូកទីបួន៖

# ពិធីលើកតម្កើងផ្សេងទៀត

## ប្រការទី១៖

## អនុសញ្ញា

១៦៦៧-"ព្រះសហគមន៍ជាមាតាដ៏វិសុទ្ធ ក៏តែងតាំងអនុសញ្ញាផ្សេងៗ ដែលជាសញ្ញាសម្គាល់ដ៏សក្ការៈស្រដៀងនឹងអគ្គសញ្ញាម៉្យាង សម្ដែងជាពិសេសអំពីផលខ្លះខាងព្រះវិញ្ញាណ ដែលគ្រីស្តបរិស័ទទទួលដោយពាក្យអង្វររបស់ព្រះសហគមន៍។ ដោយអនុសញ្ញាទាំងនោះ មនុស្សមានចិត្តចង់ទទួលផលដ៏សំខាន់ជាងគេនៃអគ្គសញ្ញា ហើយក៏បានវិសុទ្ធតាមសភាពការណ៍ផ្សេងៗប្រចាំជីវិតនៅរបស់គេ" (SC ៦០)។

### លក្ខណៈពិសេសនៃអនុសញ្ញា

១៦៦៨-ព្រះសហគមន៍តែងតាំងអនុសញ្ញា ដើម្បីឲ្យមុខងារបម្រើព្រះសហគមន៍ របៀបរស់នៅខ្លះ កាលៈទេសៈផ្សេងៗនៃជីវិតរបស់គ្រីស្តបរិស័ទ និងការប្រើប្រាស់របស់របរដែលមានប្រយោជន៍ចំពោះមនុស្សឲ្យបានវិសុទ្ធ។ តាមការសម្រេចចិត្តរបស់លោកអភិបាល អនុសញ្ញាអាចបំពេញតម្រូវការ វប្បធម៌ និងប្រវត្តិសាស្ត្រពិសេសរបស់ប្រជាជនគ្រីស្តបរិស័ទនៃតំបន់ ឬសម័យណាមួយ។ ក្នុងអនុសញ្ញានានា តែងតែមានសេចក្ដីអធិដ្ឋានជារឿយៗ មានកាយវិការមួយ ដូចជាពិធីដាក់ដៃ សញ្ញាឈើឆ្កាង ការប្រោះទឹកវិសុទ្ធ (ដែលរំឭកអំពីពិធីជ្រមុជទឹក)។

១៦៦៩-អនុសញ្ញាមកពីឋានៈជាគ្រីស្តបរិស័ទដែលបានជ្រមុជទឹក ដែលសុទ្ធតែជាបូជាចារ្យ គឺព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទឲ្យទៅជា "ព្រះពរ" (កណ ១២,២) និងឲ្យប្រទានពរ (លក ៦,២៨; រម ១២,១៤; ១ពត្រ ៣,៩)។ ហេតុនេះហើយបានជាគ្រីស្តបរិស័ទធម្មតាអាចណែនាំពិធីខ្លះ (SC ៧៩; CIC ១១៦៨)។ បើពិធីមួយទាក់ទងកាន់តែច្រើននឹងការរស់នៅក្នុងព្រះសហគមន៍ និងខាងអគ្គសញ្ញា អ្នកទទួលមុខងារបម្រើព្រះសហគមន៍ (អភិបាល បូជាចារ្យ ឬឧបដ្ឋាក) (Ben ១៦; ១៨) ត្រូវធ្វើអធិបតី។

១៦៧០-អនុសញ្ញាមិនផ្ដល់ព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធដូចអគ្គសញ្ញាទេ ប៉ុន្តែ ដោយសារការអធិដ្ឋានរបស់ព្រះសហគមន៍ អនុសញ្ញារៀបចំឲ្យទទួលការប្រណីសន្ដោស និងឲ្យរួមសហការជាមួយផង។ "ចំពោះគ្រីស្តបរិស័ទដែលរកព្រះជាម្ចាស់ដោយចិត្តទៀងត្រង់ ពិធីផ្សេងៗនៃអគ្គសញ្ញា និងអនុសញ្ញានានា នាំឲ្យស្ទើតែគ្រប់ព្រឹត្តិការណ៍ប្រចាំការរស់នៅរបស់គេបានវិសុទ្ធ ដោយព្រះហឫទ័យប្រណីសន្ដោស ដែលហូរចេញមកពីព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង ពោលគឺពីព្រះគ្រីស្តរងទុក្ខលំបាក សោយទិវង្គត និងមានព្រះជន្មថ្មី។ គឺព្រះគ្រីស្តនេះហើយ ដែលប្រោសឲ្យអគ្គសញ្ញា និងអនុសញ្ញាទាំងប៉ុន្មានមានអនុភាព។ វត្ថុស្ទើតែទាំងអស់ដែលមនុស្សប្រើប្រាស់យ៉ាងត្រឹមត្រូវ ក៏អាចតម្រង់ទៅរកគោលដៅតែមួយនេះ គឺធ្វើឲ្យមនុស្សបានវិសុទ្ធ និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់" (SC ៦១)។

### អនុសញ្ញាផ្សេងៗ

១៦៧១-ក្នុងចំណោមអនុសញ្ញា មានពិធីប្រទានព្រះពរ (ដល់មនុស្ស តុ វត្ថុ កន្លែង)។ ពិធីប្រទានពរនានា

ដូចជាការលើកតម្កើងព្រះជាម្ចាស់ និងពាក្យអង្វរឲ្យព្រះអង្គប្រោសប្រទានព្រះអំណោយទានផងដែរ។ ព្រះជាម្ចាស់ជាព្រះបិតាប្រទានព្រះពរ "គ្រប់យ៉ាងផ្នែកខាងវិញ្ញាណ" (អភ ១,៣) ដល់គ្រីស្តបរិស័ទក្នុងអង្គព្រះគ្រីស្ត។ ហេតុនេះហើយបានជាព្រះសហគមន៍ប្រទានពរ ដោយអង្វរព្រះនាមព្រះយេស៊ូ និងជាធម្មតាដោយធ្វើសញ្ញាដ៏វិសុទ្ធនៃព្រះឈើឆ្កាងរបស់ព្រះគ្រីស្ត។

១៦៧២-ព្រះពរខ្លះមានឥទ្ធិពលខ្លាំងណាស់ គឺមានគោលដៅញែក មនុស្សខ្លះចំពោះព្រះជាម្ចាស់ និងទុកវត្ថុ ឬកន្លែងខ្លះសម្រាប់ពិធីបុណ្យ។ ក្នុងចំណោមព្រះពរចំពោះមនុស្ស -ដែលមិនត្រូវច្រឡំនឹងអគ្គសញ្ញាតែងតាំង -មានព្រះពរលើប្រធានអារាម ការញែកប្រសិទ្ធព្រហ្មចារិនី ពិធីធ្វើពាក្យសច្ចាប្រណិធាន ហើយព្រះពរចំពោះមុខងារខ្លះៗក្នុងព្រះសហគមន៍ (អ្នកអានព្រះបន្ទូល អ្នកបម្រើអាសនៈ អ្នកណែនាំអប់រំជំនឿ ជាដើម)។ ឯព្រះពរដែលទាក់ទងនឹងវត្ថុ មានពិធីឧទ្ទិស ឬពិធីឆ្លងព្រះវិហារ ឬអាសនៈ ពិធីព្រះពរប្រេង ចាន ពែង និងសម្លៀកបំពាក់ដ៏សក្ការៈ ជួងជាដើម។

១៦៧៣-មានពិធីដេញខ្មោច នៅពេលដែលព្រះសហគមន៍ប្រកបដោយអំណាច សុំជាសាធារណៈ ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ឲ្យព្រះជាម្ចាស់ការពារមនុស្សម្នាក់ ឬវត្ថុណាមួយ ប្រឆាំងនឹងមារសត្រូវ ឬឲ្យចាកផុតពីអំណាចរបស់វា។ ព្រះយេស៊ូបានប្រតិបត្តិតាម (មក ១,២៥ត) ហើយព្រះអង្គបានប្រគល់អំណាច និងបន្ទុកដេញខ្មោចឲ្យព្រះសហគមន៍ (មក ៣,១៥; ៦,៧.១៣; ១៦,១៧)។ តាមរបៀបសាមញ្ញ យើងធ្វើពិធីដេញខ្មោចក្នុងអគ្គសញ្ញាជ្រមុជទឹក។ ដោយមានការអនុញ្ញាតពីលោកអភិបាល មានតែលោកបូជាចារ្យទេ ដែលអាចធ្វើពិធីដេញខ្មោចយ៉ាងឧឡារិក ដែលគេហៅថា "មហាពិធីដេញខ្មោច"។ ត្រូវប្រតិបត្តិតាមដោយប្រុងប្រយ័ត្ន និងដោយគោរពយ៉ាងតឹងរ៉ឹង វិន័យរបស់ព្រះសហគមន៍។ ពិធីនេះ មានគោលដៅដេញខ្មោច ឬរំដោះឲ្យរួចពីមារ ដោយសារអំណាចខាងវិញ្ញាណ ដែលព្រះយេស៊ូបានប្រគល់ឲ្យព្រះសហគមន៍របស់ព្រះអង្គ។ ប៉ុន្តែ យើងមិនត្រូវច្រឡំនឹងជំងឺផ្លូវចិត្តខ្លះ ដែលជាសមត្ថកិច្ចរបស់គ្រូពេទ្យ។ ដូច្នេះ មុនធ្វើពិធីដេញខ្មោច ត្រូវតែដឹងច្បាស់ថា តើករណីនោះមកពីវត្តមានរបស់មារ ឬមកពីជំងឺណាមួយ?

## ពិធីប្រជាប្រិយ

១៦៧៤-ក្រៅពីពិធីបុណ្យនៃអគ្គសញ្ញា និងអនុសញ្ញា ការអប់រំជំនឿត្រូវយកចិត្តទុកដាក់ទៅលើលក្ខណៈនៃការគោរពប្រណិប័តន៍ចំពោះព្រះជាម្ចាស់របស់គ្រីស្តបរិស័ទ និងទៅតាមជំនឿដែលមានលក្ខណៈប្រជាប្រិយ។ គ្រប់សម័យកាលទាំងអស់ ប្រជាជនគ្រីស្តបរិស័ទបានសម្តែងចេញជំនឿរបស់ខ្លួន តាមលក្ខណៈផ្សេងៗរួមជាមួយអគ្គសញ្ញានៃព្រះសហគមន៍ ដូចជាការគោរពបូជាចំពោះសរីរធាតុ ទស្សនកិច្ចទៅទីកន្លែងសក្ការៈនានា បូជនីយសចរណ៍ ក្បួនដង្ហែផ្សេងៗ ផ្លូវដើរឈើឆ្កាង របាំសាសនា ផ្កាំ បន្តោង ជាដើម (មហាសន្និបាតនៅទីក្រុងនីសេទី២៖ DS ៦០១; ៦០៣; មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៨២២)។

១៦៧៥-ការថ្វាយងបង្គំទាំងអស់នោះបន្តជីវិតនៃពិធីបុណ្យព្រះសហគមន៍ ប៉ុន្តែមិនជំនួសពិធីបុណ្យនោះទេ៖ "ត្រូវធ្វើឲ្យការថ្វាយបង្គំនោះស្របតាមរដូវនានានៃពិធីបុណ្យ ដើម្បីឲ្យសមស្របនឹងពិធីបុណ្យ ដើម្បីឲ្យហូរចេញមកពីពិធីបុណ្យ និងដើម្បីបញ្ចូលប្រជាជនក្នុងពិធីបុណ្យ ពីព្រោះជាការពិត ដោយសារខ្លឹមសាររបស់ពិធីបុណ្យល្អប្រសើរជាងការថ្វាយបង្គំនោះផងដែរ" (SC ១៣)។

១៦៧៦-ត្រូវតែរិះគិតពិចារណាក្នុងព្រះសហគមន៍ ដើម្បីគាំទ្រ និងជួយទៅដល់ពិធីប្រជាប្រិយ និងតាម

កាលៈទេសៈដើម្បីបន្សុទ្ធ និងកែតម្រូវអត្ថន័យខាងសាសនា ដែលមានក្នុងពិធីទាំងអស់នោះ ដើម្បីឲ្យអស់អ្នកដែលប្រារព្ធពិធីទាំងអស់នោះ ស្គាល់អាថ៌កំបាំងរបស់ព្រះគ្រីស្តកាន់តែច្បាស់លាស់។ ការប្រតិបត្តិពិធីប្រជាប្រិយស្ថិតនៅក្រោមការវិនិច្ឆ័យរបស់លោកអភិបាល និងទៅតាមល័ក្ខខ័ណ្ឌទូទៅរបស់ព្រះសហគមន៍។

ជាធម្មតា ពិធីប្រជាប្រិយជាសំណុំនៃគុណសម្បត្តិ ដែលរួមជាមួយការយល់ដឹងរបស់គ្រីស្តសាសនា និងដែលឆ្លើយតបនឹងសំណួរសំខាន់ៗនៃជីវិតរបស់មនុស្សលោក។ ការយល់ដឹងដ៏ត្រឹមត្រូវរបស់ប្រជាជនកាតូលិកសង្ខេបអ្វីដ៏សំខាន់ចំពោះការរស់នៅ ទើបធ្វើឲ្យព្រះជាម្ចាស់ និងមនុស្ស ព្រះគ្រីស្ត និងព្រះនាងម៉ារី វិញ្ញាណ និងរូបកាយ ព្រះអំណោយទាន និងរចនាសម្ព័ន្ធ បុគ្គល និងសហគមន៍ ជំនឿ និងមាតុភូមិ ប្រាជ្ញា និងអារម្មណ៍រួបរួមជាមួយគ្នាតាមរបៀបបង្កបង្កើត។ ការយល់ដឹងនេះ គឺជាមនុស្សនិយមរបស់គ្រីស្តបរិស័ទ ដែលអះអាងជាដាច់ខាតថា មនុស្សគ្រប់ៗរូបមានឋានៈដ៏ថ្លៃថ្នូរជាបុត្រធីតារបស់ព្រះជាម្ចាស់ ដែលធ្វើឲ្យមនុស្សរួមជាមួយគ្នាដូចជាបងប្អូន ដែលបង្រៀនឲ្យជួបធម្មជាតិ ដូចជាឲ្យយល់អំពីការងារ ហើយដែលផ្តល់មូលហេតុឲ្យរស់នៅប្រកបដោយសេចក្តីរីករាយ និងអារម្មណ៍ស្រស់ស្រាយ ទោះជាស្ថិតក្នុងការលំបាកយ៉ាងណាក៏ដោយ។ ការយល់ដឹងនេះ ក៏ជួយឲ្យប្រជាជនចេះរិះគិតពិចារណា និងចេះវិនិច្ឆ័យនៅពេលដែលព្រះសហគមន៍បម្រើដំណឹងល្អ ឬនៅពេលដែលគេប្រើដំណឹងល្អដើម្បីផលប្រយោជន៍ផ្សេង (EN ៤៨)។

## សង្ខេប

១៦៧៧-គេហៅអនុសញ្ញាសញ្ញាសម្គាល់ដ៏សក្ការៈ ដែលព្រះសហគមន៍បានចាត់ចែង ហើយដែលមានគោលដៅរៀបចំមនុស្សលោកឲ្យទទួលផលនៃអគ្គសញ្ញា និងធ្វើឲ្យកាលៈទេសៈផ្សេងៗនៃជីវិតបានទៅជាវិសុទ្ធ។

១៦៧៨-ក្នុងចំណោមអនុសញ្ញា ពិធីប្រទានពរមានសារៈសំខាន់។ ក្នុងការប្រទានពរ មានការលើកតម្កើងព្រះជាម្ចាស់ ដើម្បីកិច្ចការ និងព្រះអំណោយទានរបស់ព្រះអង្គ ហើយមានការជួយទូកអង្វររបស់ព្រះសហគមន៍ ដើម្បីឲ្យមនុស្សលោកអាចប្រើប្រាស់ព្រះអំណោយទានរបស់ព្រះជាម្ចាស់តាមលក្ខណៈនៃដំណឹងល្អ។

១៦៧៩-ជីវិតជាគ្រីស្តបរិស័ទបំប៉ុននឹងពិធីបុណ្យផង និងអស់ពិធីប្រជាប្រិយឯទៀតៗ ដែលចាក់ឫសក្នុងវប្បធម៌ផ្សេងៗ។ ដោយយកចិត្តទុកដាក់បំភ្លឺពិធីទាំងអស់នោះតាមពន្លឺនៃជំនឿ ព្រះសហគមន៍លើកទឹកចិត្តឲ្យមានពិធីប្រជាប្រិយ ដែលសម្តែងថា មនុស្សចេះរិះគិតអំពីរបៀបប្រកាសដំណឹងល្អ និងមានការយល់ដឹង ដែលបន្ថែមលក្ខណៈសម្បត្តិនៃជីវិតជាគ្រីស្តបរិស័ទ។

# ប្រការទី២៖

## ពិធីបញ្ចុះសព

១៦៨០-អគ្គសញ្ញាទាំងអស់ ជាពិសេសអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទពេញលេញ មានគោលដៅជាបុណ្យចម្លងចុងក្រោយនៃបុត្រធីតារបស់ព្រះជាម្ចាស់ គឺបុណ្យចម្លងដែលធ្វើឲ្យគេចូលទៅក្នុងជីវិតនៃព្រះរាជ្យដោយសារសេចក្តីស្លាប់។ នៅពេលនោះ អ្វីដែលគេប្រកាសដោយមានជំនឿ និងក្នុងសេចក្តីសង្ឃឹម "ខ្ញុំរង់ចាំពេលដែលមនុស្សស្លាប់នឹងទទួលជីវិតថ្មី និងជីវិតក្នុងលោកខាងមុខផង" (ធម៌ប្រកាសជំនឿនៅនិសេ/កុងស្តង់ទីណូប) បានសម្រេចរួចហើយ។

## ១-បុណ្យចម្លងចុងក្រោយរបស់គ្រីស្តបរិស័ទ

១៦៨១-គម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង គឺព្រះគ្រីស្តដែលជាទីសង្ឃឹមតែមួយរបស់យើង ទ្រង់សោយទិវង្គត និងមានព្រះជន្មថ្មី សម្តែងនូវអត្ថន័យនៃសេចក្តីស្លាប់តាមគ្រីស្តសាសនា។ គ្រីស្តបរិស័ទដែលស្លាប់នៅក្នុងអង្គព្រះគ្រីស្តយេស៊ូ "ឃ្លាតឆ្ងាយពីរូបកាយនេះ ហើយទៅនៅជិតព្រះអម្ចាស់" (២ករ ៥,៨)។

១៦៨២-ចំពោះគ្រីស្តបរិស័ទ ថ្ងៃនៃសេចក្តីស្លាប់ជាថ្ងៃចុងក្រោយនៃជីវិតខាងអគ្គសញ្ញា បង្ហើយកំណើតថ្មីរបស់គេ ដែលបានចាប់ផ្តើមនៅពិធីជ្រមុជទឹក។ ពេលនោះ គ្រីស្តបរិស័ទចាប់ផ្តើម "មានលក្ខណៈ" ជាស្ថាពរ "របស់ព្រះបុត្រា" ដែលអភិសេកនៃព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រទាន ហើយគេចូលរួមចំណែកក្នុងពិធីជប់លៀងនៃព្រះរាជ្យ ដែលពិធីអរព្រះគុណប្រារព្ធទុកជាមុន ទោះបីជាគេត្រូវជម្រះចិត្តគំនិតទៀតនៅឡើយ ដើម្បីអាចបំពាក់សម្លៀកបំពាក់នៃពិធីមង្គលការ។

១៦៨៣-ព្រះសហគមន៍ក្នុងឋានៈជាមាតា ដែលបានជួយគ្រីស្តបរិស័ទផ្នែកអគ្គសញ្ញា នៅពេលធ្វើបូជនិយេសចរណ៍នៅលើលោកនេះ កំដរគេនៅទីចុងក្រោយនៃការធ្វើដំណើរ ដើម្បីប្រគល់គេ "ក្នុងព្រះហស្តរបស់ព្រះបិតា"។ ព្រះសហគមន៍ថ្វាយបុត្រនៃការប្រោសប្រណីរបស់ព្រះអង្គទៅព្រះបិតា នៅក្នុងអង្គព្រះគ្រីស្ត បញ្ចុះពូជនៃរូបកាយទៅក្នុងដី ដោយសង្ឃឹមថា និងទទួលជីវិតថ្មីពោរពេញទៅដោយសិរីរុងរឿង (១ករ ១៥,៤២-៤៤)។ តង្វាយនេះបានពេញលក្ខណៈក្នុងពិធីអភិបូជា ពិធីព្រះពរដែលមានពីមុន និងពីខាងក្រោយជាអនុសញ្ញា។

## ២-ការប្រារព្ធពិធីបញ្ចុះសព

១៦៨៤-ពិធីបញ្ចុះសពមិនប្រគល់អគ្គសញ្ញា ឬអនុសញ្ញាឲ្យអ្នកស្លាប់ទេ ដ្បិតគេបាន "ឆ្លង" ហួសពីការចាត់ចែងនៃអគ្គសញ្ញាទៅហើយ។ ក៏ប៉ុន្តែ ពិធីនោះ នៅតែជាពិធីបុណ្យរបស់ព្រះសហគមន៍ (SC ៨១-៨២)។ មុខងាររបស់ព្រះសហគមន៍មានគោលដៅដើម្បីបង្ហាញថា យើងរួបរួមជាមួយអ្នកស្លាប់ ហើយដើម្បីឲ្យសហគមន៍ចូលរួមចំណែកក្នុងពិធីបញ្ចុះសព និងប្រកាសជីវិតអស់កល្បជានិច្ចឲ្យសហគមន៍នេះផងដែរ។

១៦៨៥-ពិធីផ្សេងៗនៃពិធីបញ្ចុះសពបង្ហាញថា ចំពោះគ្រីស្តសាសនា សេចក្តីស្លាប់ដូចជាការចម្លងមួយស្របតាមស្ថានភាព និងប្រពៃណីនៃតំបន់នីមួយៗ សូម្បីតែពណ៌នៃពិធីបុណ្យ (SC ៨១)។

១៦៨៦-Ordo exsequiarum (Oex) នៃពិធីបុណ្យនៅទីក្រុងរ៉ូមស្នើសុំឲ្យមានពិធីបីយ៉ាង តាមកន្លែងទាំងបីនៃពិធីបញ្ចុះសព (ផ្ទះ ព្រះវិហារ ទីបញ្ចុះសព) និងតាមបំណងរបស់ក្រុមគ្រួសារ ប្រពៃណីនៃតំបន់នីមួយៗ វប្បធម៌ និងប្រពៃណីប្រជាប្រិយ៍ផងដែរ។ ពិធីនេះ ដូចប្រពៃណីខាងពិធីបុណ្យឯទៀតៗ ហើយមានបួនវគ្គសំខាន់ៗ៖

> ១៦៨៧-ការទទួលនៃសហគមន៍។ ពិធីបុណ្យចាប់ផ្តើមដោយការគោរពគ្នាតាមរបៀបជំនឿ។ សម្តី "លួងលោម" (តាមអត្ថន័យរបស់សម្ព័ន្ធមេត្រីថ្មី៖ ឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធប្រកបដោយសេចក្តីសង្ឃឹម) (១ថស ៤,១៨) ទទួលញាតិមិត្តរបស់អ្នកស្លាប់។ សហគមន៍ដែលកំពុងអធិដ្ឋាន ប្រជុំគ្នា និងរង់ចាំ "ព្រះបន្ទូលនៃជីវិតអស់កល្បជានិច្ច"។ មរណភាពរបស់សមាជិកម្នាក់នៃសហគមន៍ (ឬថ្ងៃខួប ថ្ងៃទីប្រាំពីរ ឬថ្ងៃទីសែសិប) គឺជាព្រឹត្តិការណ៍មួយ ដែលត្រូវតែធ្វើឲ្យនឹកគិតដល់ហួសពី "លោកនេះ" និងទាក់ទាញគ្រីស្តបរិស័ទឲ្យផ្ញើជីវិតទៅលើព្រះគ្រីស្ត ដែលមានព្រះជន្មថ្មី។

១៦៨៨-នៅពេលពិធីបញ្ចុះសព ត្រូវតែរៀបចំដោយយកចិត្តទុកដាក់ពិធីលើកតម្កើងព្រះបន្ទូល ដ្បិតនៅក្នុងអង្គប្រជុំអាចមានអ្នកខ្លះ ឬមិត្តភ័ក្តិរបស់អ្នកស្លាប់ ដែលមិនមែនជាគ្រីស្តបរិស័ទ។ ជាពិសេសធម៌ទេសនាត្រូវតែ "ជៀសវាងកុំឲ្យសរសើរអ្នកស្លាប់" (Oex ៤១) ប៉ុន្តែ ត្រូវបំភ្លឺអាថ៌កំបាំងនៃសេចក្តីស្លាប់តាមគ្រីស្តសាសនាក្នុងពន្លឺរបស់ព្រះគ្រីស្ត ដែលមានព្រះជន្មថ្មី។

១៦៨៩-អភិបូជា។ នៅពេលប្រារព្ធពិធីក្នុងព្រះវិហារ ពិធីអរព្រះគុណសម្តែងលក្ខណៈជាការចម្លងនៃសេចក្តីស្លាប់តាមគ្រីស្តសាសនា (Oex ១)។ នៅពេលនោះ ព្រះសហគមន៍បង្ហាញថា ខ្លួនរួបរួមជាមួយអ្នកស្លាប់ គឺដោយថ្វាយទៅព្រះបិតា ក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ សក្ការបូជារបស់ព្រះគ្រីស្តដែលបានសោយទិវង្គត និងបានទទួលព្រះជន្មថ្មី ព្រះសហគមន៍ក៏ទូលសុំឲ្យបុត្ររបស់ខ្លួនរួចពីបាប និងផលវិបាករបស់បាប ហើយឲ្យគេចូលរួមតុក្នុងព្រះរាជ្យឲ្យបានពេញលក្ខណៈ (Oex ៥៧)។ តាមរយៈពិធីអរព្រះគុណនេះ សហគមន៍របស់គ្រីស្តបរិស័ទ ជាពិសេសក្រុមគ្រួសាររបស់អ្នកស្លាប់ រៀនរួមរស់ជាមួយអ្នកដែល "ដេកលក់ក្នុងអង្គព្រះអម្ចាស់" ដោយទទួលព្រះកាយព្រះគ្រីស្ត ដែលអ្នកស្លាប់ជាសិរីរាង្គដ៏រស់រវើក ហើយដោយទូលអង្វរព្រះជាម្ចាស់ដើម្បីគាត់ និងជាមួយគាត់។

១៦៩០-ព្រះសហគមន៍ "ផ្ញើផ្តាំអ្នកស្លាប់ថ្វាយទៅព្រះជាម្ចាស់" គឺ "លា សមាជិករបស់ខ្លួនម្នាក់ មុននឹងបញ្ចុះសពរបស់គេ" (Oex ១០)។ ប្រពៃណីនៅប៊ីសង់លាអ្នកស្លាប់ដោយថើបគេ៖

ដោយសារពិធីសុំលាហើយនេះ "យើងច្រៀងដោយសារគេចាកចេញពីជីវិតនេះ និងគេបែកចេញពីយើង ប៉ុន្តែយើងរួបរួមជាមួយគ្នាផងដែរ។ ទោះបីយើងស្លាប់យ៉ាងណាក៏ដោយ ក៏យើងមិនបែកពីគ្នាដែរ ដ្បិតយើងទាំងអស់គ្នា ធ្វើដំណើរតាមផ្លូវតែមួយ ហើយយើងនឹងនៅក្នុងកន្លែងតែមួយដែរ។ យើងនឹងមិនដែលបែកពីគ្នាទេ ដ្បិតយើងរស់ ដើម្បីព្រះគ្រីស្ត ហើយឥឡូវនេះយើងរួមរស់ជាមួយព្រះគ្រីស្ត ដោយដើរឆ្ពោះទៅព្រះអង្គ (...) យើងទាំងអស់គ្នានឹងនៅក្នុងអង្គព្រះគ្រីស្ត" (សន្តៈ ស៊ីម៉ូន នៃថេស្សាឡូនិក)។

# វគ្គទីបី៖

# ការរស់នៅ

# ក្នុងអង្គព្រះគ្រីស្ទ

១៦៩១- "គ្រីស្តបរិស័ទអើយ! ចូរទទួលស្គាល់ឋានៈដ៏ថ្លៃថ្នូររបស់ខ្លួន! ដោយសារអ្នកមានលក្ខណៈជាព្រះជាម្ចាស់រួមជាមួយព្រះអង្គ ចាប់ពីឥឡូវនេះទៅ កុំប្រព្រឹត្តអំពើសៅហ្មងដូចកាលពីមុនទៀតទេ។ ចូររំឭកថាអ្នកជាកម្មសិទ្ធិរបស់ប្រធានណា ហើយអ្នកជាសមាជិករបស់ព្រះកាយណា។ ចូររំឭកថា ព្រះជាម្ចាស់បានដកអ្នកចេញពីអំណាចនៃភាពងងឹត ដើម្បីផ្ទេរអ្នកឲ្យចូលក្នុងពន្លឺ និងក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់" (សន្តៈ ឡេអុងដ៏ប្រសើរ)។

១៦៩២- ធម៌ប្រកាសជំនឿបានប្រកាសតម្លៃដ៏វិសេសបំផុតនៃព្រះអំណោយទានរបស់ព្រះជាម្ចាស់ ចំពោះមនុស្ស ក្នុងស្នាព្រះហស្តនៃការបង្កើតរបស់ព្រះអង្គ ហើយលើសពីនេះទៅទៀត ដោយសារព្រះអង្គបានសង្គ្រោះ និងប្រោសមនុស្សឲ្យបានវិសុទ្ធ។ អ្វីដែលអ្នកជឿប្រកាស អគ្គសញ្ញាក៏ផ្តល់ឲ្យ គឺ "ដោយសារអគ្គសញ្ញាដែលធ្វើឲ្យគេកើតជាថ្មី" គ្រីស្តបរិស័ទបានក្លាយទៅជា "បុត្រធីតារបស់ព្រះជាម្ចាស់" (យហ ១,១២ ; ១យហ ៣,១) គេ "មានលក្ខណៈជាព្រះជាម្ចាស់រួមជាមួយព្រះអង្គ" (២ពត្រ ១,៤)។ ដោយទទួលស្គាល់ ក្នុងជំនឿ ឋានៈថ្មីរបស់គេ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទ "ឲ្យមានរបៀបរស់នៅស្របតាមដំណឹងល្អរបស់ព្រះគ្រីស្ត" (ភីល ១,២៧)។ ដោយសារអគ្គសញ្ញា និងការអធិដ្ឋាន គេទទួលព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្ត និងព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនាំគេឲ្យអាចប្រតិបត្តិតាម។

១៦៩៣- ព្រះគ្រីស្តយេស៊ូតែងតែគាប់ព្រះហឫទ័យរបស់ព្រះបិតា (យហ ៨,២៩)។ ព្រះអង្គតែងតែរួបរួមជាមួយព្រះបិតាយ៉ាងពេញលក្ខណៈ។ យ៉ាងណាមិញ ព្រះជាម្ចាស់អញ្ជើញសាវ័ករបស់ព្រះអង្គឲ្យរស់នៅដោយគោរពព្រះបិតា ដែល "ទតឃើញនៅក្នុងទីស្ងាត់កំបាំង" (មថ ៦,៦) ដើម្បីឲ្យ "បានគ្រប់លក្ខណ៍ដូចព្រះបិតាដែលគង់នៅស្ថានបរមសុខគ្រប់លក្ខណ៍យ៉ាងនោះដែរ" (មថ ៥,៤៨)។

១៦៩៤- ដោយរួមជាមួយព្រះគ្រីស្ត ដោយសារអគ្គសញ្ញាជ្រមុជទឹក (រម ៦,៥) គ្រីស្តបរិស័ទ "បានស្លាប់រួចផុតពីអំណាចបាប ហើយមានជីវិតរស់សម្រាប់ព្រះជាម្ចាស់ ក្នុងអង្គព្រះគ្រីស្តយេស៊ូ" (រម ៦,១១) ទើបគេចូលរួមចំណែកក្នុងព្រះជន្មថ្មីរបស់ព្រះអង្គ (កូឡ ២,១២)។ ដោយដើរតាមព្រះគ្រីស្ត និងដោយស្ថិតនៅជាប់នឹងព្រះអង្គ (យហ ១៥,៥) គ្រីស្តបរិស័ទអាច "យកតម្រាប់តាមព្រះជាម្ចាស់ ដូចជាបុត្រធីតាដ៏ជាទីស្រឡាញ់ ហើយរស់នៅដោយមានចិត្តស្រឡាញ់" (អភ ៥,១) ដោយមានចិត្តគំនិត ពាក្យសម្តី និងកិច្ចការ ដូច "ចិត្តគំនិតរបស់ព្រះគ្រីស្តយេស៊ូ" ដែរ (ភីល ២,៥) ហើយដោយយកតម្រាប់តាមព្រះអង្គ (យហ ១៣,១២-១៦)។

១៦៩៥- "ព្រះជាម្ចាស់បានប្រោសប្រទាន (គ្រីស្តបរិស័ទ) ឲ្យបានសុចរិត ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្ត តាមរយៈព្រះវិញ្ញាណនៃព្រះជាម្ចាស់របស់យើង" (១ករ ៦,១១) ព្រះអង្គក៏បាន "ប្រោសប្រទាន គេឲ្យបានវិសុទ្ធ និងត្រាស់ហៅគេឲ្យទៅជាសន្តៈបុគ្គល" (១ករ ១,២) គ្រីស្តបរិស័ទបានក្លាយទៅជា "ព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ " (១ករ ៦,១៩)។ "ព្រះវិញ្ញាណនៃព្រះបុត្រា" នេះ បង្រៀនគេឲ្យចេះអង្វរព្រះបិតា (កាឡ ៤,៦) ដែលទ្រង់បានទៅជាជីវិតរបស់គេ ធ្វើឲ្យគេប្រតិបត្តិតាម (កាឡ ៥,២៥) ដើម្បី "បង្កើតផលនៃព្រះវិញ្ញាណ" (កាឡ ៥,២២) គឺគេប្រព្រឹត្តកិច្ចការដោយក្តីស្រឡាញ់។ ដោយព្យាបាលមុខរបួសនៃអំពើបាប ព្រះវិញ្ញាណដ៏វិសុទ្ធ "ប្រោសយើងផ្នែកខាងក្នុងឲ្យក្លាយជាថ្មី ដើម្បីកែប្រែគំនិតប្រាជ្ញា និងវិញ្ញាណឲ្យបានថ្មីដែរ" (អភ ៤,២៣) ព្រះអង្គក៏បំភ្លឺយើង និងពង្រឹងកម្លាំងយើង ដើម្បីរស់នៅ "ដូចជាពន្លឺ" (អភ ៥,៨) ដោយសារ "សេចក្តីសប្បុរស សេចក្តីសុចរិត និងសេចក្តីពិតគ្រប់យ៉ាង" (អភ ៥,៩)។

១៦៩៦- មាគ៌ារបស់ព្រះគ្រីស្ត "នាំទៅរកជីវិត" មាគ៌ាផ្ទុយនឹងផ្លូវរបស់ព្រះអង្គ "នាំទៅរកសេចក្តីវិនាស" (មថ

៧,១៣) (ទក ៣០,១៥-២០)។ ប្រស្នានៃដំណឹងល្អអំពីមាគ៌ាទាំងពីរ តែងតែស្ថិតនៅក្នុងការអប់រំជំនឿរបស់ព្រះសហគមន៍ គឺសម្ដែងឲ្យយើងដឹងថា ការសម្រេចចិត្តខាងសីលធម៌សំខាន់ណាស់ ដើម្បីសង្គ្រោះយើង។ "មានមាគ៌ាពីរ មួយជាមាគ៌ានៃជីវិត មួយទៀតជាមាគ៌ានៃសេចក្ដីស្លាប់ ប៉ុន្តែមាគ៌ាទាំងពីរប្លែកពីគ្នាខ្លាំងណាស់" (ឌីដាខេ)។

១៦៩៧- ក្នុងការអប់រំជំនឿ ត្រូវតែបង្ហាញឲ្យច្បាស់អំណរ និងការទាមទារនៃមាគ៌ារបស់ព្រះគ្រីស្ត (CT ២៩)។ ក្នុងអង្គព្រះអង្គ ការអប់រំជំនឿនៃ "ជីវិតថ្មី" (រម ៦,៤) មានដូចតទៅ៖

- ការអប់រំជំនឿអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ជាគ្រូផ្ទៃកខាងក្នុងនៃរបៀបរស់នៅតាមព្រះគ្រីស្ត ជាភ្ញៀវដ៏ទន់ភ្លន់ និងជាមិត្តសម្លាញ់ ដែលបំភ្លឺ ណែនាំ កែលំអ និងពង្រឹងរបៀបរស់នៅនេះ
- ការអប់រំជំនឿអំពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ដ្បិតយើងទទួលការសង្គ្រោះដោយសារព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ ម្យ៉ាងទៀត កិច្ចការយើងអាចបង្កើតផលសម្រាប់ជីវិតអស់កល្បជានិច្ចក៏ដោយសារព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គដែរ
- ការអប់រំជំនឿអំពីសុភមង្គលយ៉ាងពិតប្រាកដ ដ្បិតសុភមង្គលយ៉ាងពិតប្រាកដសង្ខេបមាគ៌ារបស់ព្រះគ្រីស្ត ជាផ្លូវតែមួយឆ្ពោះទៅសុភមង្គលអស់កល្បជានិច្ច ដែលចិត្តមនុស្សលោកប្រាថ្នាចង់បាន
- ការអប់រំជំនឿអំពីអំពើបាប និងអំពីការលើកលែងទោស ពីព្រោះបើមនុស្សមិនទទួលស្គាល់ថាខ្លួនជាអ្នកបាបទេ គេមិនអាចស្គាល់សេចក្ដីពិតអំពីខ្លួនឯងបានឡើយ ដែលជាល័ក្ខខ័ណ្ឌដើម្បីប្រព្រឹត្តយ៉ាងត្រឹមត្រូវ ហើយបើព្រះជាម្ចាស់មិនប្រោសប្រទានការលើកលែងទោសទេ មនុស្សមិនអាចទ្រាំទ្រសេចក្ដីពិតនេះបានឡើយ
- ការអប់រំជំនឿអំពីគុណធម៌របស់មនុស្សលោក ដើម្បីចាប់អារម្មណ៍អំពីសោភណភាពនៃអ្វីដ៏ល្អ ដែលទាក់ទាញចិត្តគំនិត
- ការអប់រំជំនឿអំពីគុណធម៌នៃគ្រីស្តសាសនា គឺជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ ដោយយកតម្រាប់តាមគំរូរបស់សន្ដៈបុគ្គល
- ការអប់រំជំនឿនៃធម្មវិន័យនៃសេចក្ដីស្រឡាញ់ ក្នុងវិន័យដប់ប្រការ
- ការអប់រំជំនឿនៃព្រះសហគមន៍ ដ្បិតជីវិតរបស់គ្រីស្តបរិស័ទអាចរីកចម្រើន លាតសន្ធឹង និងផ្តល់ខ្លួនក្នុងការផ្លាស់ប្ដូរជាច្រើន "នៃសេចក្ដីល្អខាងវិញ្ញាណ" ក្នុង "សហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ"។

១៦៩៨- ព្រះយេស៊ូគ្រីស្តតែងតែជាគំរូដំបូង និងសំខាន់ជាងគេបំផុតនៃការអប់រំជំនឿនេះ ព្រះអង្គដែលព្រះអង្គផ្ទាល់ជា "ផ្លូវ ជាសេចក្ដីពិត និងជាជីវិត" (យហ ១៤,៦)។ ដោយសម្លឹងមើលព្រះអង្គក្នុងជំនឿ គ្រីស្តបរិស័ទអាចសង្ឃឹមថា ព្រះអង្គផ្ទាល់នឹងសម្រេចព្រះបន្ទូលសន្យារបស់ព្រះអង្គក្នុងខ្លួនគេ ហើយដោយស្រឡាញ់ព្រះអង្គដូចព្រះអង្គបានស្រឡាញ់គេដែរ គេអាចប្រព្រឹត្តកិច្ចការសមស្របនឹងឋានៈរបស់ខ្លួន៖

ខ្ញុំសូមអង្វរឲ្យចាត់ទុកថា ព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើងពិតជាប្រធានរបស់យើង ហើយអ្នករាល់គ្នាជាសមាជិករបស់ព្រះអង្គ។ ព្រះអង្គជាកម្មសិទ្ធិរបស់អ្នករាល់គ្នា ដូចប្រធានជាកម្មសិទ្ធិរបស់សមាជិក ដែរ។ អ្វីៗដែលជារបស់ព្រះអង្គក៏ជារបស់អ្នករាល់គ្នាដែរ គឺចិត្តគំនិត បេះដូង ព្រះកាយ ព្រលឹង និងសមត្ថភាពទាំងអស់របស់ព្រះអង្គ ហើយអ្នករាល់គ្នាត្រូវតែប្រើប្រាស់ដូចជារបស់អ្នកផ្ទាល់ ដើម្បីបម្រើ កោតសរសើរ ស្រឡាញ់ និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ អ្នករាល់គ្នាជាកម្មសិទ្ធិរបស់ព្រះអង្គ ដូចសមាជិកជាកម្មសិទ្ធិរបស់ប្រធាន

ដែរ។ ហេតុនេះហើយ បានជាព្រះអង្គប៉ងប្រាថ្នាខ្លាំងណាស់ក្នុងការប្រើប្រាស់អ្វីៗទាំងអស់ដែលមានក្នុងខ្លួនអ្នករាល់គ្នា ដើម្បីកិច្ចបម្រើ និងសិរីរុងរឿងនៃព្រះបិតារបស់ព្រះអង្គ ដូចរបស់របរដែលជាកម្មសិទ្ធិរបស់ព្រះអង្គដែរ (សន្តៈ យ៉ូហាន អើដ)។ ជីវិតខ្ញុំ គឺព្រះគ្រីស្ត (ភីល ១,២១)។

# ភាគទីមួយៈ

# ព្រះជាម្ចាស់ត្រាស់ហៅមនុស្សលោក

# ឲ្យរស់នៅក្នុងអង្គព្រះវិញ្ញាណ

១៦៩៩- ជីវិតរស់នៅក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធបំពេញការត្រាស់ហៅរបស់មនុស្ស (ជំពូកទីមួយ)។ ជីវិតនេះប្រកបដោយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងសាមគ្គីភាពរវាងមនុស្ស (ជំពូកទីពីរ)។ ព្រះជាម្ចាស់ប្រោសប្រទានជីវិតនេះ ដូចជាការសង្គ្រោះមួយ (ជំពូកទីបី)។

## ជំពូកទីមួយៈ

## ឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស

១៧០០- ដោយសារព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាង និងមានលក្ខណៈដូចព្រះអង្គ មនុស្សមានឋានៈដ៏ថ្លៃថ្នូរ (ប្រការទី១)។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យមានសុភមង្គលយ៉ាងពិតប្រាកដ ដើម្បីបំពេញឋានៈដ៏ថ្លៃថ្នូររបស់គេ (ប្រការទី២)។ មនុស្សក៏ត្រូវតែស្ម័គ្រចិត្តបំពេញលក្ខណៈរបស់ខ្លួន (ប្រការទី ៣)។ ដោយសារកិច្ចការដែលគេប្រព្រឹត្តដោយចេតនា (ប្រការទី៤) មនុស្សប្រតិបត្តិតាម ឬមិនប្រតិបត្តិតាមអ្វីដ៏ល្អប្រសើរដែលព្រះជាម្ចាស់មានព្រះបន្ទូលសន្យា ហើយដែលមនសិការបញ្ជាក់ (ប្រការទី៥)។ មនុស្សលោកកសាងខ្លួនឯង និងរីកចម្រើនផ្នែកខាងក្នុង គឺគេធ្វើឲ្យជីវិតខាងវិញ្ញាណទៅជាសម្ភារៈនៃការលូតលាស់របស់គេ (ប្រការទី ៦)។ ដោយមានព្រះហឫទ័យប្រណីសន្ដោសជួយឧបត្ថម្ភ គេរីកចម្រើនក្នុងគុណធម៌ (ប្រការទី៧) ចៀសវាងអំពើបាប ហើយបើគេបានប្រព្រឹត្តបាប គេថ្វាយខ្លួន ដូចកូនពៅវង្វេង (លក ១៥,១១-៣១) ចំពោះធម៌មេត្តាករុណានៃព្រះបិតារបស់យើងដែលគង់នៅស្ថានបរមសុខ (ប្រការទី៨)។ ដូច្នេះ គេឈានទៅដល់ភាពល្អឥតខ្ចោះនៃសេចក្តីស្រឡាញ់។

### ប្រការទី១ៈ

### មនុស្សលោកជារូបតំណាងរបស់ព្រះជាម្ចាស់

១៧០១- "ពេលព្រះគ្រីស្តសម្តែងអាថ៌កំបាំងដ៏អស្ចារ្យរបស់ព្រះបិតា និងអាថ៌កំបាំងនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ ទ្រង់ក៏សម្តែងឋានៈរបស់មនុស្សយ៉ាងពេញលេញ និងនាំគេឲ្យស្គាល់តម្លៃដ៏ថ្លៃថ្នូររបស់ខ្លួន តាមព្រះជាម្ចាស់បានកំណត់ទុក" (GS ២២,១)។ ក្នុងអង្គព្រះគ្រីស្ត ដែលជា "រូបតំណាងរបស់ព្រះជាម្ចាស់ដែលយើងមើលពុំឃើញ" (កូឡ ១,១៥) (២ករ ៤,៤) ព្រះជាម្ចាស់បានបង្កើតមនុស្សលោកដូចជា "តំណាង និងមានលក្ខណៈ" របស់ព្រះបង្កើត។ ក្នុងអង្គព្រះគ្រីស្ត ដែលជាព្រះសង្គ្រោះ ព្រះជាម្ចាស់បានប្រោសមនុស្ស ដែលអំពើបាប

ដើមបានបង្ខូច ឲ្យមានលក្ខណៈដូចព្រះអង្គឡើងវិញ ដោយទ្រង់បានកែលក្ខណៈនេះក្នុងសោភណភាពដើម ហើយបានបន្ថែមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គថែមទៀតផង (GS ២២,២)។

១៧០២- មនុស្សគ្រប់ៗរូបមានលក្ខណៈដូចព្រះជាម្ចាស់។ លក្ខណៈនេះ ភ្លឺចិញ្ចាចចិញ្ចែង ពេលមនុស្សរួបរួមជាមួយគ្នា ដូចព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធរួបរួមជាមួយគ្នាផងដែរ (សូមអានជំពូកទីពីរ)។

១៧០៣- ដោយមាន "ព្រលឹងវិញ្ញាណអមតៈ" (GS ១៤) មនុស្ស "ជាសត្វលោកតែមួយគត់ដែលព្រះអង្គសព្វព្រះហឫទ័យបង្កើតដើម្បីខ្លួនឯង" (GS ២៤,៣)។ តាំងពីគេនៅក្នុងផ្ទៃមកម្ល៉េះ ព្រះជាម្ចាស់មានព្រះហឫទ័យឲ្យមនុស្សលោកទទួលសុភមង្គលអស់កល្បជានិច្ច។

១៧០៤- មនុស្សទទួលចំណែកក្នុងពន្លឺ និងឫទ្ធានុភាពនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ ដោយសារប្រាជ្ញា មនុស្សអាចយល់អំពីរបៀបរៀបរយនៃអ្វីៗទាំងអស់ ដែលព្រះជាម្ចាស់បានចាត់ចែង។ ដោយសារបំណងរបស់ខ្លួន មនុស្សអាចទៅរកសុភមង្គលដ៏ពិតប្រាកដ ដោយខ្លួនឯង។ មនុស្សទៅជាបានពេញលក្ខណៈដោយ "ស្វះស្វែងរក និងស្រឡាញ់សេចក្ដីពិត និងអ្វីដែលល្អប្រសើរ" (GS ១៥,២)។

១៧០៥- ដោយសារព្រលឹង ឫទ្ធានុភាពខាងវិញ្ញាណ ឫទ្ធានុភាពនៃប្រាជ្ញា និងឫទ្ធានុភាពនៃបំណងរបស់ខ្លួន មនុស្សមានសេរីភាព "ជាសញ្ញាសម្គាល់ពិសេសបញ្ជាក់ថា មនុស្សមានលក្ខណៈដូចព្រះជាម្ចាស់" (GS ១៧)។

១៧០៦- ដោយសារប្រាជ្ញា មនុស្សស្គាល់ព្រះសូរសៀងរបស់ព្រះជាម្ចាស់ ដែលជំរុញ "ឲ្យប្រព្រឹត្តអំពើល្អ និងចៀសវាងមិនឲ្យប្រព្រឹត្តអំពើអាក្រក់" (GS ១៦)។ ម្នាក់ៗត្រូវតែធ្វើតាមក្បួនវិន័យ ដែលលាន់ឮក្នុងមនសិការ ហើយដែលបំពេញក្នុងសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងអ្នកដទៃ។ ការរស់នៅប្រកបដោយសីលធម៌បញ្ជាក់អំពីឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស។

១៧០៧- "មារដ៏មានកលល្បិចជាងគេបញ្ឆោតមនុស្ស បណ្ដាលឲ្យគេប្រើសេរីភាពរបស់ខ្លួនហួសហេតុ" (GS ១៣,១)។ មនុស្សបានចាញ់ការល្បួង និងបានប្រព្រឹត្តអំពើអាក្រក់។ មនុស្សនៅតែប្រាថ្នាចង់បានអ្វីដ៏ល្អ ប៉ុន្តែធម្មជាតិរបស់ខ្លួនត្រូវអំពើបាបដើមដំបូងធ្វើឲ្យរបួស។មនុស្សមានចិត្តលម្អៀងប្រព្រឹត្តអំពើអាក្រក់និងអាចប្រព្រឹត្តកំហុសផងដែរ៖

- ហេតុនេះ យើងយល់ឃើញថា មនុស្សបាក់បែកពីខាងក្នុង។ ការរស់នៅរបស់មនុស្សយើង ទោះជាការរស់នៅរបស់បុគ្គលម្នាក់ៗក្ដី ជាការរស់នៅរួមក្ដី ជាការប្រយុទ្ធដ៏ឃោរឃៅ គឺសេចក្ដីល្អប្រយុទ្ធនិងសេចក្ដីអាក្រក់ ពន្លឺប្រយុទ្ធនិងភាពងងឹត (GS ១៣,២)។

១៧០៨- ដោយសារព្រះអង្គបានរងទុក្ខលំបាក ព្រះគ្រីស្ដបានរំដោះយើងឲ្យរួចពីមារសាតាំង និងពីអំពើបាប។ ដោយសារបុណ្យកុសលព្រះអង្គ ៗក៏បានប្រទានជីវិតថ្មីក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គកែលំអឡើងវិញនូវអ្វីៗដែលអំពើបាបបានបំផ្លាញក្នុងខ្លួនយើង។

១៧០៩- អ្នកដែលផ្ញើជីវិតទាំងស្រុងទៅលើព្រះគ្រីស្ដក្លាយទៅជាបុត្រធិតារបស់ព្រះជាម្ចាស់ ដែលផ្លាស់ប្ដូរគេដោយប្រោសប្រទានគេឲ្យអាចយកតម្រាប់តាមព្រះគ្រីស្ដ អាចប្រព្រឹត្តកិច្ចការត្រឹមត្រូវ និងប្រតិបត្តិតាមអ្វីដែលល្អ។ ដោយរួបរួមជាមួយព្រះសង្គ្រោះរបស់ខ្លួន សាវ័កឈានទៅរកភាពល្អឥតខ្ចោះនៃសេចក្ដីស្រឡាញ់ គឺភាពដ៏វិសុទ្ធ។ ដោយព្រះហឫទ័យប្រណីសន្ដោសបានរៀបចំ ការរស់នៅតាមសីលធម៌រីកចម្រើនឲ្យពេញលក្ខណៈក្នុងជីវិតអស់កល្បជានិច្ច ក្នុងសិរីរុងរឿងនៃស្ថានបរមសុខ។

## សង្ខេប

១៧១០- "ព្រះគ្រីស្តសម្តែងឋានៈរបស់មនុស្សយ៉ាងពេញលេញ និងនាំឲ្យគេស្គាល់តម្លៃដ៏ថ្លៃថ្នូររបស់ខ្លួន តាមព្រះជាម្ចាស់បានកំណត់ទុក" (GS ២២,១)។

១៧១១- ចាប់តាំងពីផ្ទៃម្តាយមកម្ល៉េះ ព្រះជាម្ចាស់តម្រូវឲ្យមនុស្សមានព្រលឹងខាងវិញ្ញាណ ប្រាជ្ញា និងឆន្ទៈបែរទៅរកព្រះអង្គ និងឲ្យទទួលសុភមង្គលអស់កល្បជានិច្ច។ មនុស្សបានល្អឥតខ្ចោះ ដោយ "ស្វះស្វែងរកស្រឡាញ់សេចក្តីពិតនិងអ្វីដ៏ល្អប្រសើរ" (GS ១៥,២)។

១៧១២- នៅក្នុងខ្លួនមនុស្ស សេរីភាពដ៏ពិតប្រាកដ "ជាសញ្ញាសម្គាល់ពិសេសបញ្ជាក់ថាមនុស្សមានលក្ខណៈដូចព្រះជាម្ចាស់" (GS ១៧)។

១៧១៣ មនុស្សត្រូវតែធ្វើតាមវិន័យខាងសីលធម៌ ដែលជំរុញគេ "ឲ្យប្រព្រឹត្តអំពើល្អ និងជៀសវាងមិនឲ្យប្រព្រឹត្តអំពើអាក្រក់" (GS ១៦)។ វិន័យនេះ លាន់ឮក្នុងមនសិការរបស់ខ្លួន។

១៧១៤- មនុស្សដែលត្រូវរបួសដោយសារអំពើបាបដើមដំបូងអាចប្រព្រឹត្តខុស និងមានចិត្តលម្អៀងប្រព្រឹត្តអំពើអាក្រក់ ក្នុងការប្រើប្រាស់សេរីភាពរបស់ខ្លួន។

១៧១៥- នរណាផ្ញើជីវិតទៅលើព្រះគ្រីស្តមានជីវិតថ្មីក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ។ ការរស់នៅតាមសីលធម៌ ដោយមានការប្រោសប្រណីជួយឲ្យរីកចម្រើន និងបានពេញលេញ ត្រូវតែសម្រេចក្នុងសិរីរុងរឿងនៃស្ថានបរមសុខ។

# ប្រការទី២៖

# ព្រះជាម្ចាស់ត្រាស់ហៅយើងឆ្ពោះទៅរកសុភមង្គលយ៉ាងពិតប្រាកដ

## ១. សុភមង្គលយ៉ាងពិតប្រាកដ

១៧១៦- សុភមង្គលយ៉ាងពិតប្រាកដជាស្នូលនៃធម៌ទេសនារបស់ព្រះយេស៊ូ។ ពេលព្រះអង្គប្រកាសអំពីសុភមង្គលនេះ ព្រះអង្គយកព្រះបន្ទូលសន្យា ដែលព្រះជាម្ចាស់បានប្រោសប្រទានឲ្យប្រជាជនរបស់ព្រះអង្គតាំងពីលោកអប្រាហាំ មកវិញ។ ព្រះអង្គបំពេញព្រះបន្ទូលសន្យានោះ សំដៅទៅលើព្រះរាជ្យនៃស្ថានបរមសុខ គឺមិនគ្រាន់តែជាការកាន់កាប់ដីប៉ណ្ណោះទេ។

- អ្នកណាដាក់ចិត្តជាអ្នកក្រខ្សត់អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេបានទទួលព្រះរាជ្យនៃស្ថានបរមសុខ! អ្នកណាមានចិត្តស្លូតបូត អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងទទួលផែនដីទុកជាមត៌ក! អ្នកណាសោកសៅ អ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងសម្រាលទុក្ខពួកគេ! អ្នកណាស្រេកឃ្លានសេចក្តីសុចរិតអ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងប្រទានឲ្យពួកគេបានឆ្អែត! អ្នកណាមានចិត្តមេត្តាករុណា អ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងសម្តែងព្រះហឫទ័យមេត្តាករុណាដល់ពួកគេវិញ! អ្នកណាមានចិត្តបរិសុទ្ធ អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងឃើញព្រះជាម្ចាស់! អ្នកណាកសាងសន្តិភាព អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងមានឈ្មោះជាបុត្ររបស់ព្រះជាម្ចាស់! អ្នកណាត្រូវគេបៀតបៀន

ព្រោះតែបានធ្វើតាមសេចក្ដីសុចរិត អ្នកនោះមានសុភមង្គលហើយ ដ្បិតគេបានទទួលក្នុងព្រះរាជ្យនៃស្ថានបរមសុខ! ប្រសិនបើមានគេត្មះតិះដៀល បៀតបៀន និងមានគេនិយាយអាក្រក់គ្រប់យ៉ាងបង្ខូចឈ្មោះអ្នករាល់គ្នា ព្រោះតែខ្ញុំ នោះអ្នករាល់គ្នាមានសុភមង្គលហើយ! ចូរត្រេកអរសប្បាយរីករាយឡើង ព្រោះអ្នករាល់គ្នានឹងទទួលរង្វាន់យ៉ាងធំ នៅស្ថានបរមសុខ ដ្បិតពួកព្យាការីដែលទៅរស់នៅមុនអ្នករាល់គ្នា ក៏ត្រូវគេបៀតបៀនដូច្នោះដែរ (មថ ៥,៣-១២)។

១៧១៧- ព្រះបន្ទូលនេះឆ្លុះបញ្ចាំងអំពីព្រះភ័ក្ត្រព្រះយេស៊ូគ្រីស្ត និងរៀបរាប់សេចក្ដីស្រឡាញ់របស់ព្រះអង្គ។ ព្រះបន្ទូលនេះ សម្ដែងការត្រាស់ហៅរបស់គ្រីស្តបរិស័ទ ដែលរួមជាមួយព្រះអង្គក្នុងសិរីរុងរឿងនៃទុក្ខលំបាក និងការទទួលព្រះជន្មថ្មីរបស់ព្រះអង្គ។ ព្រះបន្ទូលនេះ បំភ្លឺកិច្ចការ និងអាកប្បកិរិយាពិសេសនៃការរស់នៅជាគ្រីស្តបរិស័ទ។ ព្រះបន្ទូលនេះ គាំទ្រសេចក្ដីសង្ឃឹមក្នុងពេលត្រូវគេបៀតបៀន និងប្រកាសព្រះពរ និងរង្វាន់ទាំងប៉ុន្មានដែលព្រះជាម្ចាស់បានប្រទានឲ្យសាវ័ករួចមកហើយតាមលក្ខណៈដ៏លាក់កំបាំង។ ជីវិតរបស់ព្រហ្មចារិនីម៉ារី និងសន្តៈបុគ្គលទាំងឡាយចាប់ផ្ដើមបំពេញព្រះបន្ទូលនេះ។

## ២. មនុស្សប្រាថ្នាចង់បានសុភមង្គល

១៧១៨- ព្រះបន្ទូលនេះ ឆ្លើយតបនឹងបំណងប្រាថ្នារបស់មនុស្ស ដែលតែងតែចង់បានសុភមង្គល។ បំណងប្រាថ្នានេះ មកពីព្រះជាម្ចាស់។ ព្រះជាម្ចាស់បានដាក់បំណងនេះក្នុងចិត្តមនុស្ស ដើម្បីទាក់ទាញគេទៅរកព្រះអង្គដែលមានតែព្រះអង្គទេ ដែលអាចបំពេញបំណងប្រាថ្នានេះបាន៖

- យើងទាំងអស់គ្នាប្រាកដជាចង់រស់នៅដោយសប្បាយរីករាយ ហើយជាតិជាមនុស្ស មនុស្សទាំងអស់យល់ព្រមនឹងសំណូមពរនេះ មុននឹងបានស្ដាប់សព្វគ្រប់ហើយ (សន្តៈ អូគូស្តាំង)។
- តើខ្ញុំម្ចាស់ស្វែងរកព្រះអម្ចាស់យ៉ាងដូចម្ដេច? នៅពេលដែលខ្ញុំម្ចាស់ស្វែងរកព្រះរបស់ខ្ញុំ ខ្ញុំម្ចាស់ក៏ស្វែងរកជីវិតដ៏ពេញលេញ សូមឲ្យខ្ញុំម្ចាស់ស្វែងរកព្រះអង្គ ដើម្បីឲ្យព្រលឹងខ្ញុំម្ចាស់រស់ ដ្បិតរូបកាយខ្ញុំម្ចាស់រស់ដោយសារព្រលឹង ហើយព្រលឹងខ្ញុំម្ចាស់រស់ដោយសារព្រះអង្គ (សន្តៈ អូគូស្តាំង)។
- មានតែព្រះជាម្ចាស់ទេ ដែលធ្វើឲ្យឆ្អែតស្កប់ស្កល់ (សន្តៈ ថូម៉ាស នៃអាកាំង)។

១៧១៩- សុភមង្គលយ៉ាងពិតប្រាកដសំដៅទៅលើការរស់នៅរបស់មនុស្សលោក ជាទីចុងក្រោយបំផុតនៃកិច្ចការមនុស្ស គឺព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យទទួលសុភមង្គលរបស់ព្រះអង្គផ្ទាល់។ ព្រះជាម្ចាស់ត្រាស់ហៅយើងម្នាក់ៗផង ព្រះសហគមន៍ទាំងមូលផង ជាប្រជាជនថ្មីរបស់អស់អ្នក ដែលបានទទួលព្រះបន្ទូលសន្យា និងប្រតិបត្តិតាមដោយមានជំនឿ។

## ៣. សុភមង្គលយ៉ាងពិតប្រាកដតាមគ្រីស្តសាសនា

១៧២០- សម្ពន្ធមេត្រីថ្មីប្រើពាក្យសម្ដីផ្សេងៗដើម្បីកំណត់សុភមង្គល ដែលព្រះជាម្ចាស់ត្រាស់ហៅមនុស្ស គឺនៅពេលព្រះរាជ្យរបស់ព្រះជាម្ចាស់នឹងយាងមក (មថ ៤,១៧) នៅពេលយើងនឹងឃើញព្រះជាម្ចាស់៖ "អ្នកណាមានចិត្តបរិសុទ្ធ អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងមើលឃើញព្រះជាម្ចាស់!" (មថ ៥,៨) (១យហ ៣,២;១ករ ១៣,១២) ការចូលក្នុងអំណររបស់ព្រះអម្ចាស់ (មថ ២៥,២១.២៣) ការចូលក្នុងថ្ងៃសម្រាករបស់ព្រះជាម្ចាស់ (ហប ៤,៧-១១)៖

- នៅទីនោះ យើងនឹងសម្រាក ហើយយើងនឹងឃើញ។ យើងនឹងឃើញ ហើយយើងនឹងស្រឡាញ់។ យើងនឹងស្រឡាញ់ ហើយយើងនឹងកោតសរសើរ។ នេះគឺជាទីចុងក្រោយ ដែលគ្មានទីចុងក្រោយទេហើយ តើយើងមានទីចុងក្រោយអ្វីក្រៅពីទៅដល់ព្រះរាជ្យដែលគ្មានទីចុងក្រោយ? (សន្ដ: អូគូស្ដាំង)។

១៧២១- ព្រះជាម្ចាស់បានបង្កើតយើង ដើម្បីស្គាល់ បម្រើ និងស្រឡាញ់ព្រះអង្គ រហូតទៅដល់ស្ថានបរមសុខ។ សុភមង្គលយ៉ាងពិតប្រាកដធ្វើឲ្យយើងមានលក្ខណៈជាព្រះជាម្ចាស់រួមជាមួយព្រះអង្គ (១ពត្រ ១,៤) ហើយធ្វើឲ្យយើងរួមចំណែកក្នុងជីវិតអស់កល្បជានិច្ច (យហ ១៧,៣)។ ដោយសារសុភមង្គលនេះ មនុស្សចូលក្នុងសិរីរុងរឿងរបស់ព្រះគ្រីស្ដ (រម ៨,១៨) និងក្នុងព្រះជន្មនៃព្រះត្រៃឯកផងដែរ។

១៧២២- សុភមង្គលនេះ ហួសប្រាជ្ញា និងកម្លាំងរបស់មនុស្ស ប៉ុន្តែមកពីព្រះអំណោយទានរបស់ព្រះជាម្ចាស់។ ហេតុនេះហើយ បានជាគេហៅសុភមង្គលនេះថា ហួសធម្មជាតិ ដូចព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ដែលរៀបចំមនុស្សឲ្យចូលរួមក្នុងសុភមង្គលរបស់ព្រះជាម្ចាស់។

- "អ្នកណាមានចិត្តបរិសុទ្ធ អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងឃើញព្រះជាម្ចាស់!"។ តាមការពិត ដោយសារភាពថ្កុំថ្កើង និងសិរីរុងរឿងដែលមិនអាចថ្លែងបាន "គ្មាននរណាអាចមើលឃើញព្រះជាម្ចាស់ បើគេមិនស្លាប់ទេ" ដ្បិតយើងមិនអាចយល់ព្រះបិតាបាន ប៉ុន្តែដោយសារសេចក្ដីស្រឡាញ់ និងសប្បុរសធម៌របស់ព្រះអង្គចំពោះមនុស្ស ហើយដោយសារឫទ្ធានុភាពរបស់ព្រះអង្គ ៗ ប្រោសប្រទានឲ្យអស់អ្នកដែលស្រឡាញ់ព្រះអង្គឲ្យអាចមើលឃើញព្រះអង្គបាន (...) "ដ្បិតអ្វីដែលមនុស្សធ្វើមិនកើត ព្រះជាម្ចាស់អាចធ្វើឲ្យកើតឡើង"" (សន្ដ: អ៊ីរ៉េណេ)។

១៧២៣- ដោយសារព្រះជាម្ចាស់មានព្រះបន្ទូលសន្យាប្រទានសុភមង្គលដ៏ពិតប្រាកដ យើងត្រូវធ្វើការសម្រេចចិត្តយ៉ាងសំខាន់បំផុត។ ព្រះបន្ទូលនេះ អញ្ជើញយើងឲ្យជម្រះចិត្តពីកិលេសតណ្ហា និងឲ្យស្វះស្វែងរកសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់។ ព្រះបន្ទូលនេះ បង្រៀនយើងឲ្យយល់ថា សុភមង្គលដ៏ពិតប្រាកដមិនស្ថិតនៅលើទ្រព្យសម្បត្តិ ឬលើសុខុមាលភាព លើកិត្តិនាម ឬលើអំណាច ហើយមិនស្ថិតនៅលើកិច្ចការណាមួយរបស់មនុស្ស ទោះជាមានផលប្រយោជន៍ ដូចជាវិទ្យាសាស្ត្រ បច្ចេកទេស សិល្បៈ ឬសត្វលោកណាមួយក៏ដោយ ប៉ុន្តែសុភមង្គលដ៏ពិតប្រាកដនេះ ស្ថិតនៅលើព្រះជាម្ចាស់តែមួយអង្គប៉ុណ្ណោះ ដែលជាប្រភពនៃអ្វីៗដ៏ល្អប្រសើរ និងសេចក្ដីស្រឡាញ់គ្រប់យ៉ាង៖

- សព្វថ្ងៃនេះ ទ្រព្យសម្បត្តិជាព្រះដ៏ធំ។ បណ្ដាជនទាំងអស់ថ្វាយបង្គំព្រះនេះ ដោយមិនបានគិតពិចារណាឡើយ។ គេវាស់សុភមង្គលតាមទ្រព្យសម្បត្តិ ហើយគេវិនិច្ឆ័យកិត្តិយសតាមទ្រព្យសម្បត្តិនេះដែរ (...)។ អ្វីៗទាំងអស់នោះ មកពីការជឿជាក់ថា ដោយសារទ្រព្យសម្បត្តិ យើងអាចធ្វើអ្វីៗទាំងអស់។ ដូច្នេះ សព្វថ្ងៃ ទ្រព្យសម្បត្តិជាព្រះក្លែងក្លាយមួយ ហើយកិត្តិយសជាព្រះក្លែងក្លាយមួយទៀត (...)។ កិត្តិយសធ្វើឲ្យគេស្គាល់ និងកោតសរសើរក្នុងពិភពលោក (ដូចជាតារាចម្រៀង) ថាជា អ្វីដ៏ល្អ អ្វីដ៏ល្អប្រសើរបំផុត ដែលត្រូវតែគោរពផងដែរ (លោន ន្យូម៉ាន)។

១៧២៤- វិន័យដប់ប្រការ ព្រះបន្ទូលរបស់ព្រះយេស៊ូអំពីសុភមង្គលយ៉ាងពិតប្រាកដ និងការប្រៀនប្រដៅរបស់ក្រុមគ្រីស្ដទូតរៀបរាប់ឲ្យយើងស្គាល់ផ្លូវ ដែលនាំឲ្យទៅព្រះរាជ្យនៃស្ថានបរមសុខ។ យើងដើរតាមផ្លូវនេះពីមួយជំហានទៅមួយជំហានទៀត តាមកិច្ចការប្រចាំថ្ងៃ ដោយមានព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធជួយឧបត្ថម្ភផង។ ដោយមានព្រះបន្ទូលរបស់ព្រះគ្រីស្ដ បន្តិចម្ដងៗ យើងបង្កើតផលក្នុងព្រះសហគមន៍ដើម្បីសិរីរុងរឿងរបស់ព្រះជាម្ចាស់ (មថ ១៣,៣-២៣)។

## សង្ខេប

១៧២៥- ព្រះបន្ទូលរំឭកឡើងវិញអំពីសុភមង្គលយ៉ាងពិតប្រាកដ គឺជាព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ តាំងពីលោកអប្រាហាំ ហើយព្រះអង្គនឹងបំពេញព្រះបន្ទូលសន្យានោះ នៅឯព្រះរាជ្យនៃស្ថានបរមសុខ។ សុភមង្គលយ៉ាងពិតប្រាកដបំពេញបំណងប្រាថ្នាចង់បានសុភមង្គល ដែលព្រះជាម្ចាស់បានដាក់ក្នុងចិត្តមនុស្ស។

១៧២៦- ព្រះបន្ទូលអំពីសុភមង្គលយ៉ាងពិតប្រាកដបង្រៀនឲ្យយើងដឹងថា គោលដៅចុងក្រោយបំផុត ដែលព្រះជាម្ចាស់ត្រាស់ហៅយើង គឺព្រះរាជ្យ ការមើលឃើញព្រះជាម្ចាស់ ការរួមចំណែកក្នុងសភាពជាព្រះជាម្ចាស់ ជីវិតអស់កល្បជានិច្ច ឲ្យយើងទៅជាបុត្រធីតារបស់ព្រះអង្គ ការសម្រាកក្នុងអង្គព្រះអង្គ។

១៧២៧- សុភមង្គលយ៉ាងពិតប្រាកដនៃជីវិតអស់កល្បជានិច្ចជាព្រះអំណោយទានរបស់ព្រះជាម្ចាស់។ នេះជាសុភមង្គល ដែលមានលក្ខណៈហួសធម្មជាតិ ដូចជាការប្រោសប្រណីដែលណែនាំយើងឲ្យទទួលជីវិតនេះដែរ។

១៧២៨- ព្រះបន្ទូលអំពីសុភមង្គលយ៉ាងពិតប្រាកដធ្វើឲ្យយើងត្រូវតែជ្រើសរើសជាដាច់ខាតអំពីទ្រព្យសម្បត្តិលោកីយ៍ ហើយជម្រះចិត្តគំនិតយើង ដើម្បីឲ្យយើងចេះស្រឡាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់។

១៧២៩- សុភមង្គលយ៉ាងពិតប្រាកដនៃស្ថានបរមសុខជាលក្ខណៈសម្រាប់ថ្លឹងថ្លែងក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិ លោកីយ៍ស្របតាមវិន័យរបស់ព្រះជាម្ចាស់។

# ប្រការទី៣៖

# សេរីភាពរបស់មនុស្ស

១៧៣០- ព្រះជាម្ចាស់បានបង្កើតមនុស្សដែលមានប្រាជ្ញា គឺមនុស្សមានឋានៈដ៏ថ្លៃថ្នូរអាចផ្ដើម និងគ្រប់គ្រងកិច្ចការរបស់ខ្លួនបាន។ "ព្រះជាម្ចាស់ប្រទានឲ្យមនុស្សធ្វើជាម្ចាស់លើសេចក្ដីសម្រេចរបស់ខ្លួន" (បសរ ១៥,១៤) ដើម្បីឲ្យគេអាចស្វះស្វែងរកព្រះបង្កើតរបស់ខ្លួន ដោយខ្លួនឯង ហើយដើម្បីឲ្យបានគ្រប់លក្ខណៈ ពោរពេញដោយសុភមង្គល ដោយស្ម័គ្រចិត្តភ្ជាប់នឹងព្រះអង្គ។

- មនុស្សមានប្រាជ្ញាដូច្នេះគេមានលក្ខណៈដូចព្រះជាម្ចាស់មានសេរីភាពនិងជាម្ចាស់លើអំពើរបស់ខ្លួន (សន្ដ: អ៊ីរ៉េណេ)។

## ១. សេរីភាព និងការទទួលខុសត្រូវ

១៧៣១- សេរីភាពជាអំណាច ដែលចាក់ឫសក្នុងប្រាជ្ញា និងឆន្ទៈ ឲ្យប្រព្រឹត្ត ឬមិនប្រព្រឹត្ត ធ្វើនេះ ឬធ្វើនោះ ស្ម័គ្រចិត្តបំពេញកិច្ចការដោយខ្លួនឯង។ ដោយសារសេរីភាព មនុស្សម្នាក់ៗជាម្ចាស់លើខ្លួនឯង។ សេរីភាពជាកម្លាំងរបស់មនុស្ស ដែលធ្វើឲ្យគេរីកចម្រើន ក្នុងសេចក្ដីពិត និងសប្បុរសធម៌ ឲ្យបានពេញលេញ។ មនុស្សមានសេរីភាពបានគ្រប់លក្ខណៈ នៅពេលដែលគេប្រើសេរីភាព ដើម្បីព្រះជាម្ចាស់ជាសុភមង្គលយ៉ាងពិតប្រាកដរបស់យើង។

១៧៣២- ដរាបណាមនុស្សមិនបានតម្រូវសេរីភាព ឲ្យស្ថិតនៅក្រោមអ្វីដ៏ល្អប្រសើរបំផុតរបស់ខ្លួន គឺព្រះជាម្ចាស់ ដរាបនោះមនុស្សអាចជ្រើសរើសរវាងអំពើល្អ ឬអំពើអាក្រក់ ដូច្នេះអាចរីកចម្រើនក្នុងភាពល្អឥតខ្ចោះ ឬប្រព្រឹត្ត

អំពើបាប។ សេរីភាពជាលក្ខណៈពិសេសនៃកិច្ចការមនុស្សលោក ហើយជាប្រភពនៃការកោតសរសើរ ឬការស្តីបន្ទោស អំពើបុណ្យកុសល ឬអំពើអកុសល។

១៧៣៣- បើយើងប្រព្រឹត្តអំពើល្អកាន់តែច្រើន យើងក៏មានសេរីភាពកាន់តែច្រើនដែរ។ យើងមានសេរីភាពយ៉ាងពិតប្រាកដ នៅពេលយើងបម្រើអ្វីដ៏ល្អ និងយុត្តិធម៌តែប៉ុណ្ណោះ។ ពេលយើងជ្រើសរើសការមិនស្តាប់បង្គាប់ និងការប្រព្រឹត្តអំពើអាក្រក់ យើងបំពានសេរីភាព និងទៅជា "ខ្ញុំបម្រើនៃអំពើបាប" (រម ៦,១៧)។

១៧៣៤- សេរីភាពនាំឲ្យមនុស្សទៅជាអ្នកទទួលខុសត្រូវ នៃកិច្ចការរបស់ខ្លួន លុះត្រាតែគេស្ម័គ្រចិត្តប្រព្រឹត្តកិច្ចការនោះ។ ពេលយើងរីកចម្រើនក្នុងគុណធម៌ ការស្គាល់អ្វីដែលល្អ និងការហ្វឹងហាត់ផ្លូវចិត្ត បង្កើននូវការគ្រប់គ្រងលើឆន្ទៈរបស់ខ្លួន។

១៧៣៥- អវិជ្ជា ការធ្វេសប្រហែស អំពើហិង្សា ការភ័យខ្លាច ទំនៀមទម្លាប់ កិលេសតណ្ហា និងកត្តាផ្សេងៗខាងចិត្តវិទ្យា ឬដែលមកពីសង្គម អាចបន្ថយ ឬលុបបំបាត់ ការទម្លាក់ទោស និងការទទួលខុសត្រូវលើកិច្ចការណាមួយ។

១៧៣៦- មនុស្សទទួលខុសត្រូវលើកិច្ចការណាមួយ ដែលខ្លួនបានប្រព្រឹត្តផ្ទាល់៖

ហេតុនេះហើយ បានជាព្រះអម្ចាស់សួរទៅកាន់លោកអដាំ ក្រោយពីលោកបានប្រព្រឹត្តអំពើបាប នៅសួនច្បារថា៖ "ម្តេចក៏អ្នកធ្វើដូច្នេះ?" (កណ ៣,១៣) លោកកាអ៊ីនក៏ដូច្នោះដែរ (កណ ៤,១០) ឬនៅពេលដែលព្យាការីណាថានសួរព្រះបាទដាវីឌ ក្រោយពីព្រះអង្គបានប្រព្រឹត្តអំពើផិតក្បត់ ជាមួយនឹងភរិយារបស់លោកអ៊ូរី និងបានសម្លាប់លោក (២សម ១២,៧-១៥)។

> យើងគ្មានចេតនាដោយផ្ទាល់នឹងប្រព្រឹត្តកិច្ចការមួយ ដែលខូចខាតមកពីការធ្វេសប្រហែសរបស់យើង ដែលគួរតែយកចិត្តទុកដាក់ធ្វើ។ ឧទាហរណ៍ដូចជាគ្រោះថ្នាក់មួយបណ្តាលមកពីយើងមិនស្គាល់ច្បាប់ចរាចរណ៍។

១៧៣៧- យើងអាចអធ្យាស្រ័យចំពោះអំពើមួយ ដែលគេបានប្រព្រឹត្តដោយអចេតនា ដូចស្ត្រីជាម្តាយម្នាក់អស់កម្លាំងហេវហត់ ដោយគ្មានគោលបំណង ដោយបានថែទាំជំងឺកូន។ យើងមិនអាចទម្លាក់ទោសទេ បើគេគ្មានបំណងបង្កើតផលវិបាកនេះ គោលដៅ ឬមធ្យោបាយ ដូជមនុស្សម្នាក់ស្លាប់ដោយសង្គ្រោះមនុស្សម្នាក់ទៀត។ យើងអាចទម្លាក់ទោសលើមនុស្សម្នាក់ ដែលប្រព្រឹត្តខុសដោយដឹងផលវិបាកជាមុន និងមានលទ្ធភាពអាចគេចផុតពីផលវិបាកនេះបាន ដូចអ្នកបើកបររថយន្តបុកមនុស្សម្នាក់ស្លាប់ ព្រោះស្រវឹងស្រា។

១៧៣៨- យើងប្រើសេរីភាពក្នុងទំនាក់ទំនងរវាងមនុស្ស។ មនុស្សម្នាក់ៗ ដែលព្រះជាម្ចាស់បានបង្កើតជារូបតំណាងរបស់ព្រះអង្គមានសិទ្ធិធម្មជាតិឲ្យមានសេរីភាពនិងការទទួលខុសត្រូវ។មនុស្សទាំងអស់ត្រូវតែគោរពសិទ្ធិមនុស្សគ្រប់រូប។ដោយសារមនុស្សមានឋានៈដ៏ថ្លៃថ្នូរ គេត្រូវតែមានសិទ្ធិប្រព្រឹត្តតាមសេរីភាពរបស់ខ្លួន ជាពិសេសក្នុងកិច្ចសីលធម៌ និងកិច្ចសាសនា (DH ២)។ សង្គមត្រូវតែទទួលស្គាល់ និងការពារសិទ្ធិនេះ ក្នុងគ្រប់ខ័ណ្ឌនៃផលប្រយោជន៍រួម និងរបៀបរៀបរយសាធារណៈ (DH ៧)។

## ២. សេរីភាពរបស់មនុស្សក្នុងការចាត់ចែងការសង្គ្រោះ

១៧៣៩- សេរីភាព និងអំពើបាប។ ទោះបីមនុស្សមានសេរីភាពក៏ដោយ ក៏គេមានកំណត់ព្រំដែន និងអាច

ប្រព្រឹត្តកំហុសផងដែរ។ មនុស្សបានស្ម័គ្រចិត្តប្រព្រឹត្តបាប។ ដោយបដិសេធមិនព្រមគម្រោងការពោរពេញដោយសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ មនុស្សបានយល់ច្រឡំខ្លួនឯង គេក្លាយទៅជាខ្ញុំបម្រើនៃអំពើបាប ហើយក្លាយទៅជាទាសករនៃអ្វីៗផ្សេងទៀតជាច្រើន។ តាំងពីដើមដំបូង ប្រវត្តិសាស្ត្ររបស់មនុស្សលោកផ្ដល់សក្ខីភាពថា ដោយសារគេប្រើសេរីភាពមិនត្រឹមត្រូវ មនុស្សរងទុក្ខវេទនា និងត្រូវគេសង្កត់សង្កិនជិះជាន់។

១៧៤០- ការគម្រាមកំហែងលើសេរីភាព។ ទោះបីមនុស្សយើងមានសេរីភាពក៏ដោយ ក៏យើងពុំមានសិទ្ធិនិយាយ ឬធ្វើតាមអំពើចិត្តដែរ។ ពេលយើងអះអាងថា "មនុស្ស ដែលជាប្រធាននៃសេរីភាព ពឹងផ្អែកលើខ្លួនឯងដោយមានគោលដៅបំពេញផលប្រយោជន៍ផ្ទាល់ក្នុងការគ្រប់គ្រងធនធាននៅលើផែនដី"គឺយើងនិយាយកុហក។ ម្យ៉ាងទៀត ជារឿយៗគេមិនទទួលស្គាល់ ឬគេឧស្សាហ៍បំពានលក្ខខ័ណ្ឌនៃរបៀបសេដ្ឋកិច្ច សង្គម នយោបាយ ឬវប្បធម៌ ដែលចាំបាច់ត្រូវតែប្រតិបត្តិ។ ស្ថានភាពយ៉ាងងងឹតងងល់ និងយ៉ាងអយុត្តិធម៌ទាំងនេះ រារាំងមិនឲ្យជីវិតខាងសីលធម៌ ហើយជំរុញទាំងអ្នករឹងមាំ ទាំងអ្នកទន់ខ្សោយ ឲ្យប្រព្រឹត្តអំពើបាបប្រឆាំងនឹងសេចក្ដីស្រឡាញ់។ ដោយឃ្លាតឆ្ងាយពីសីលធម៌ មនុស្សបំផ្លាញសេរីភាពរបស់ខ្លួន ទៅជាខ្ញុំបម្រើរបស់ខ្លួនឯង ផ្ដាច់មេត្រីភាពជាមួយនឹងបងប្អូន និងបះបោរប្រឆាំងនឹងសេចក្ដីពិតរបស់ព្រះជាម្ចាស់ផងដែរ។

១៧៤១- ការរំដោះ និងការសង្គ្រោះ។ ដោយសារព្រះឈើឆ្កាងដ៏រុងរឿង ព្រះគ្រីស្តបានសង្គ្រោះមនុស្សទាំងអស់។ ព្រះអង្គបានលោះគេចេញពីអំពើបាប ដែលធ្វើឲ្យគេជាខ្ញុំបម្រើ។ "ព្រះគ្រីស្តបានរំដោះយើងឲ្យមានសេរីភាពពិតប្រាកដ" (កាឡ ៥,១)។ នៅក្នុងអង្គព្រះអង្គ យើងរួបរួមជាមួយនឹង "សេចក្ដីពិត ដែលរំដោះយើងឲ្យមានសេរីភាព" (យហ ៨,៣២)។ ព្រះជាម្ចាស់បានប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ហើយដូចគ្រីស្តទូតប៉ូលប្រៀនប្រដៅថា "នៅទីណាមានព្រះវិញ្ញាណរបស់ព្រះអម្ចាស់ នៅទីនោះក៏មានសេរីភាពដែរ" (២ករ ៣,១៧)។ ចាប់តាំងពីឥឡូវនេះទៅ ដោយសារ"សេរីភាពនៃបុត្រធិតារបស់ព្រះជាម្ចាស់"(រម ៨,២១) យើងមានសិរីរុងរឿង។

១៧៤២- សេរីភាព និងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់។ ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្តមិនប្រជាំងនឹងសេរីភាពរបស់យើងទេ នៅពេលដែលសេរីភាពនេះ ស្របតាមសេចក្ដីពិត និងអ្វីដ៏ល្អដែលព្រះជាម្ចាស់បានដាក់បញ្ចូលក្នុងចិត្តមនុស្ស។ ផ្ទុយទៅវិញ ដូចបទពិសោធន៍នៃគ្រីស្តសាសនាផ្ដល់សក្ខីភាពជាពិសេសក្នុងការអធិដ្ឋាន បើយើងធ្វើតាមព្រះហឫទ័យប្រណីសន្ដោស យើងពង្រឹងសេរីភាព និងមានទំនុកចិត្តក្នុងគ្រាលំបាក ដូចជាការគាបសង្កត់ និងការបង្ខិតបង្ខំដែលមកពីខាងក្រៅ។ ដោយសារការប្រោសប្រណីសន្ដោសព្រះវិញ្ញាណដ៏វិសុទ្ធអប់រំយើងឲ្យមានសេរីភាពខាងវិញ្ញាណ ដើម្បីឲ្យយើងទៅជាសហការីនៃព្រះរាជកិច្ចរបស់ព្រះអង្គក្នុងព្រះសហគមន៍ និងក្នុងពិភពលោកផងដែរ៖

> ឱព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យសប្បុរស ហើយដែលមានឫទ្ធានុភាពសព្វប្រការ! សូមទ្រង់ព្រះមេត្តាដកឧបសគ្គទាំងប៉ុន្មាន ដែលរារាំងផ្លូវយើងខ្ញុំមិនឲ្យប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គ សូមប្រោសយើងខ្ញុំឲ្យអាចបម្រើព្រះអង្គដោយចិត្តស្មោះជានិច្ចផង (MR ពាក្យអធិដ្ឋានចូលថ្ងៃអាទិត្យទី៣២ប្រចាំឆ្នាំ)។

## សង្ខេប

១៧៤៣- "ព្រះជាម្ចាស់ប្រទានឲ្យមនុស្សធ្វើជាម្ចាស់លើសេចក្ដីសម្រេចរបស់ខ្លួន" (បសរ ១៥,១៤)។ ដើម្បីឲ្យគេអាចស្ម័គ្រចិត្តភ្ជាប់នឹងព្រះបង្កើតរបស់ខ្លួន ហើយបានទៅជាល្អឥតខ្ចោះ (GS ១៧,១)។

១៧៤៤- សេរីភាពជាអំណាច ដែលត្រូវប្រព្រឹត្ត ឬមិនត្រូវប្រព្រឹត្ត ហើយត្រូវបំពេញកិច្ចការដោយខ្លួនឯង។

មនុស្សមានសេរីភាពគ្រប់លក្ខណៈ នៅពេលដែលគេប្រើសេរីភាព ដើម្បីព្រះជាម្ចាស់ ដែលជាសុភមង្គលយ៉ាងពិតប្រាកដ។

១៧៤៥- សេរីភាពជាលក្ខណៈនៃកិច្ចការរបស់មនុស្ស។ សេរីភាពធ្វើឲ្យមនុស្សទទួលខុសត្រូវលើកិច្ចការទាំងប៉ុន្មាន ដែលខ្លួនស្ម័គ្រចិត្តប្រព្រឹត្ត។ មនុស្សជាម្ចាស់ផ្ទាល់នៃកិច្ចការ ដែលខ្លួនស្ម័គ្រចិត្តធ្វើ។

១៧៤៦- អវិជ្ជា អំពើហិង្សា ការភ័យខ្លាច និងកត្តាផ្សេងៗខាងចិត្តវិទ្យា ឬដែលមកពីសង្គម អាចបន្ថយ ឬលុបបំបាត់ ការទម្លាក់ទោស និងការទទួលខុសត្រូវលើកិច្ចការណាមួយ។

១៧៤៧- ដោយសារមនុស្សមានឋានៈដ៏ថ្លៃថ្នូរ គេត្រូវតែមានសិទ្ធិប្រព្រឹត្តតាមសេរីភាពរបស់ខ្លួន ជាពិសេសក្នុងកិច្ចសីលធម៌ និងកិច្ចសាសនា។ ក៏ប៉ុន្តែ ទោះបីមនុស្សយើងមានសេរីភាពក៏ដោយ ក៏គេពុំមានសិទ្ធិនិយាយ ឬធ្វើតាមទំនើងចិត្តដែរ។

១៧៤៨- "ព្រះគ្រីស្តបានរំដោះយើងឲ្យមានសេរីភាពពិតប្រាកដ" (កាឡ ៥,១)។

## ប្រការទី៤៖

## សីលធម៌នៃកិច្ចការរបស់មនុស្ស

១៧៤៩- ដោយសារមនុស្សមានសេរីភាព គេមានសីលធម៌ផងដែរ។ នៅពេលដែលគេប្រព្រឹត្តកិច្ចការដោយមានសេរីភាព មនុស្សដូចជាឪពុកនៃកិច្ចការរបស់ខ្លួន។ យើងអាចវិនិច្ឆ័យកិច្ចការរបស់មនុស្ស ពោលគឺកិច្ចការដែលយើងស្ម័គ្រចិត្តជ្រើសរើសក្រោយពីបានរិះគិតពិចារណា។ កិច្ចការទាំងអស់នោះ ល្អ ឬអាក្រក់។

### ១. ប្រភពនៃសីលធម៌

១៧៥០- សីលធម៌នៃកិច្ចការរបស់មនុស្សអាស្រ័យទៅលើ៖

- កម្មវត្ថុដែលយើងជ្រើសរើស
- គោលដៅ ឬគោលបំណង
- កាលៈទេសៈនៃកិច្ចការនោះ
- កម្មវត្ថុ គោលបំណង និងកាលៈទេសៈជា "ប្រភព" ឬផ្នែក របស់សីលធម៌នៃកិច្ចការមនុស្ស។

១៧៥១- កម្មវត្ថុ ដែលយើងជ្រើសរើសជាអ្វីដ៏ល្អ ដែលយើងមានបំណងប្រព្រឹត្ត ដោយចេតនា។ កម្មវត្ថុនេះ ជាគោលនៃកិច្ចការរបស់មនុស្ស។ កម្មវត្ថុដែលយើងជ្រើសរើសជាលក្ខណៈពិសេសនៃសីលធម៌របស់កិច្ចការ ដោយមិនរាប់ពីបំណង តាមអ្វីដែលប្រាជ្ញាទទួលស្គាល់ និងវិនិច្ឆ័យថា តើកម្មវត្ថុនេះ ស្រប ឬមិនស្របតាមអ្វីដ៏ល្អយ៉ាងពិតប្រាកដឬទេ។ យើងអាចស្គាល់អ្វីដ៏ល្អ ឬអ្វីដ៏អាក្រក់តាមក្បួនសីលធម៌ ដែលមនសិការបញ្ជាក់ដែរ។

១៧៥២- ប្រឈមនឹងកម្មវត្ថុ គោលបំណង ស្ថិតនៅខាងអ្នកដែលប្រព្រឹត្តកិច្ចការ។ ដោយសារគោលបំណងស្ថិតនៅក្នុងប្រភពនៃកិច្ចការដែលយើងមានបំណងប្រព្រឹត្ត ហើយកំណត់កិច្ចការតាមគោលដៅ គោលបំណងនេះជាផ្នែកដ៏សំខាន់មួយ ដើម្បីវិនិច្ឆ័យថា តើកិច្ចការនេះត្រឹមត្រូវ ឬទេ។ គោលដៅជាផ្នែកដំបូងនៃគោលបំណង ហើយសំដៅទៅលើទីដៅដែលយើងចង់ ដើម្បីបំពេញកិច្ចការនេះ។ គោលបំណងជាចលនានៃបំណងឆ្ពោះទៅ

គោលដៅ គឺតម្រូវទៅទីចុងក្រោយនៃកិច្ចការ។ គោលបំណងតម្រង់នូវអ្វីដ៏ល្អនៃកិច្ចការដែលយើងប្រព្រឹត្ត។ គោលបំណងនេះមិនគ្រាន់តែជាទីដៅនៃកិច្ចការនីមួយៗទេ ប៉ុន្តែ អាចតម្រូវកិច្ចការជាច្រើនឆ្ពោះទៅគោលដៅតែមួយ។ ឧទាហរណ៍ ពេលយើងបម្រើនរណាម្នាក់ ដើម្បីជួយគេ យើងអាចប្រព្រឹត្តកិច្ចការនេះ ដោយសារសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ ដែលជាគោលដៅចុងក្រោយនៃកិច្ចការទាំងអស់របស់យើង។ គោលបំណងជាច្រើនអាចជំរុញឲ្យប្រព្រឹត្តកិច្ចការតែមួយដែរ ដូចជានៅពេលដែលយើងជួយនរណាម្នាក់ ដើម្បីបានទទួលអ្វីមួយវិញ ឬដើម្បីអួតបំប៉ោងខ្លួនឯង។

១៧៥៣- គោលបំណងល្អ (ឧ- ជួយអ្នកដទៃ) មិនអាចធ្វើឲ្យអាក្បកិរិយាអាក្រក់ (ដូចជាការនិយាយកុហក ឬការនិយាយដើមគេ) ទៅជាល្អ ឬត្រឹមត្រូវ។ គោលដៅមិនធ្វើឲ្យមធ្យោបាយក្លាយជាត្រឹមត្រូវ។ ហេតុនេះហើយបានជាយើងមិនអាចផ្ដន្ទាទោសមនុស្សម្នាក់ ដែលគ្មានទោស ដើម្បីសង្គ្រោះប្រជាជនឡើយ។ ផ្ទុយទៅវិញ គោលបំណងអាក្រក់ (ដូចជាអួតបំប៉ោងខ្លួនឯង) ធ្វើឲ្យកិច្ចការ ដែលអាចជាកិច្ចការល្អ (ដូចជាការធ្វើទាន - មថ ៦,២-៤) ទៅជាអាក្រក់វិញ។

១៧៥៤-កាលៈទេសៈព្រមទាំងផលជាផ្នែកបន្តបន្ទាប់នៃកិច្ចការរបស់សីលធម៌។កាលៈទេសៈនោះជួយបង្កើន ឬបន្ថយលក្ខណៈល្អ ឬលក្ខណៈអាក្រក់នៃកិច្ចការរបស់មនុស្ស (ឧ- ចំនួនប្រាក់ដែលគេលួច)។ កាលៈទេសៈនោះអាចកាត់បន្ថយ ឬធ្វើឲ្យការទទួលខុសត្រូវរបស់អ្នកដែលបានប្រព្រឹត្តរឹតតែធ្ងន់ធ្ងរ (ដូចជានៅពេលដែលយើងប្រព្រឹត្តកិច្ចការណាមួយ ដោយខ្លាចស្លាប់)។ កាលៈទេសៈផ្ទាល់មិនអាចផ្លាស់ប្ដូរលក្ខណៈត្រឹមត្រូវ ឬទេ នៃកិច្ចការផ្ទាល់ ហើយមិនអាចធ្វើឲ្យកិច្ចការអាក្រក់ទៅជាល្អ ឬត្រឹមត្រូវឡើយ។

## ២. អំពើល្អ និងអំពើអាក្រក់

១៧៥៥- កម្មវត្ថុ គោលដៅ និងកាលៈទេសៈត្រូវតែល្អ ដើម្បីឲ្យកិច្ចការបានល្អតាមសីលធម៌។ បើមានគោលដៅអាក្រក់កិច្ចការក៏អាក្រក់ដែរទោះបីកម្មវត្ថុនៃកិច្ចការនេះល្អ(ដូចជាអធិដ្ឋាននិងតមអាហារ"ដើម្បីឲ្យគេសរសើរ")។

- កម្មវត្ថុដែលយើងជ្រើសរើស អាចនាំឲ្យកិច្ចការទាំងមូលទៅជាអាក្រក់។ យើងមិនអាចជ្រើសរើសអាក្បកិរិយាខ្លះ - ដូចជាអំពើប្រាសចាកសីលធម៌ - ដ្បិតអំពើនោះតែងតែជាអំពើអាក្រក់។

១៧៥៦- ដូច្នេះហើយ បានជាមិនត្រូវវិនិច្ឆ័យ តើកិច្ចការត្រឹមត្រូវ ឬទេ តាមតែគោលបំណងដែល ជំរុញឲ្យប្រព្រឹត្តកិច្ចការនោះ ឬតាមកាលៈទេសៈ (ឥទ្ធិពលនៃសង្គម ការបង្ខិតបង្ខំ ការចាំបាច់ ជាដើម)។ មានកិច្ចការខ្លះដែលតែងតែខុសច្បាប់ ដោយសារកម្មវត្ថុរបស់កិច្ចការនោះ (ដោយមិនរាប់អំពីកាលៈទេសៈ ឬគោលបំណង) ដូចជាការដាក់បណ្ដាសាលើព្រះជាម្ចាស់ ការប្រព្រឹត្តខុសនឹងសម្បថ ការសម្លាប់មនុស្ស និងការប្រព្រឹត្តអំពើផិតក្បត់។ យើងមិនអាចប្រព្រឹត្តអំពើអាក្រក់ ដើម្បីឲ្យអំពើល្អចេញមកពីអំពើអាក្រក់នេះបានឡើយ។

## សង្ខេប

១៧៥៧- កម្មវត្ថុ គោលបំណង និងកាលៈទេសៈជា "ប្រភព" ទាំងបីរបស់សីលធម៌នៃកិច្ចការមនុស្ស។

១៧៥៨- កម្មវត្ថុដែលយើងជ្រើសរើសជាលក្ខណៈពិសេសនៃសីលធម៌របស់កិច្ចការ ដោយមិនរាប់អំពីបំណងតាមអ្វីដែលប្រាជ្ញាទទួលស្គាល់ និងវិនិច្ឆ័យថា តើកម្មវត្ថុនេះ ស្រប ឬមិនស្របតាមអ្វីដ៏ល្អយ៉ាងពិតប្រាកដឡើយ។

១៧៥៩- "យើងមិនអាចដោះសារអំពើអាក្រក់ ដែលយើងបានប្រព្រឹត្តដោយមានគោលបំណងល្អបានឡើយ"

(សន្តៈ ថូម៉ាស នៃអាកាំង)។ គោលដៅមិនធ្វើឲ្យមធ្យោបាយក្លាយជាត្រឹមត្រូវបានទេ។

១៧៦០- កម្មវត្ថុ គោលដៅ និងកាលៈទេសៈត្រូវតែល្អ ដើម្បីឲ្យកិច្ចការបានល្អតាមសីលធម៌។

១៧៦១- យើងមិនអាចជ្រើសរើសអាកប្បកិរិយាខ្លះ ដ្បិតអំពើនោះតែងតែជាអំពើអាក្រក់។យើងមិនអាចប្រព្រឹត្តអំពើអាក្រក់ ដើម្បីឲ្យអំពើល្អចេញមកពីអំពើអាក្រក់នេះបានឡើយ។

# ប្រការទី៥៖

# សីលធម៌នៃតណ្ហា

១៧៦២- មនុស្សជាប់ទាក់ទងនឹងសុភមង្គលយ៉ាងពិតប្រាកដ តាមកិច្ចការ ដែលខ្លួនប្រព្រឹត្តដោយចេតនា៖ តណ្ហា និងអារម្មណ៍របស់គេអាចរៀបចំគេ និងជួយគេឲ្យទទួលសុភមង្គលនេះ។

## ១. តណ្ហា

១៧៦៣- ពាក្យ "តណ្ហា" មកពីបេតិកភ័ណ្ឌនៃគ្រីស្តសាសនា។ អារម្មណ៍ ឬតណ្ហាសំដៅទៅលើការរំជួលចិត្ត ឬចលនាខាងផ្លូវចិត្ត ដែលជំរុញឲ្យប្រព្រឹត្ត ឬមិនប្រព្រឹត្ត អ្វីដែលយើងយល់ ឬនឹកស្មានថាជាការល្អ ឬជាការអាក្រក់។

១៧៦៤- តណ្ហាជាធាតុផ្សំខាងធម្មជាតិនៃចិត្តមនុស្ស ជាទីចម្លង និងចំណងរវាងជីវិតខាងផ្លូវចិត្ត និងជីវិតខាងវិញ្ញាណ។ ព្រះអម្ចាស់នៃយើងសម្តែងថា ចលនានៃតណ្ហាផុសចេញពីចិត្តមនុស្ស (មក ៧,២១)។

១៧៦៥- តណ្ហាមានច្រើន។ តណ្ហាសំខាន់ជាងគេបំផុតជាសេចក្តីស្រឡាញ់។ អ្វីដ៏ល្អទាក់ទាញ និងជំរុញឲ្យស្រឡាញ់។ អ្នកមានចិត្តស្រឡាញ់ប្រាថ្នាចង់បានអ្វីដ៏ល្អ ដែលគេពុំទាន់មាន ហើយសង្ឃឹមថា នឹងបានទទួល។ ចលនានេះ បញ្ចប់ក្នុងការសប្បាយ និងអំណរ ដែលមកពីគេបានទទួលអ្វីដ៏ល្អនេះ។ អ្នកខ្លាចក្រែងអ្វីដ៏អាក្រក់ស្អប់ខ្ពើម និងភ័យខ្លាចអ្វីដ៏អាក្រក់ក្នុងអនាគត។ ចលនានេះ បញ្ចប់ក្នុងការព្រួយចិត្តដោយសារវត្តមាននៃអ្វីដ៏អាក្រក់ ឬក្នុងកំហឹងដែលប្រឆាំងនឹងអ្វីដ៏អាក្រក់នេះ។

១៧៦៦- "អ្នកមានចិត្តស្រឡាញ់ចង់បានអ្វីដ៏ល្អសម្រាប់នរណាម្នាក់ផ្សេងទៀត" (សន្តៈ ថូម៉ាស នៃ អាកាំង)។ តណ្ហាទាំងអស់ផ្សេងទៀតផុសចេញមកពីចលនាដំបូងនៃចិត្តមនុស្សទៅរកអ្វីដ៏ល្អ។ យើងស្រឡាញ់តែអ្វីៗដ៏ល្អទេ (សន្តៈ អូគូស្តាំង)។ "តណ្ហាអាក្រក់បើសេចក្តីស្រឡាញ់អាក្រក់ តណ្ហាល្អបើសេចក្តីស្រឡាញ់ល្អ" (សន្តៈ អូគូស្តាំង)។

## ២. តណ្ហា និងជីវិតប្រកបដោយសីលធម៌

១៧៦៧- តណ្ហាផ្ទាល់មិនល្អ ឬមិនអាក្រក់ឡើយ។ យើងអាចវិនិច្ឆ័យតណ្ហាតាមសីលធម៌ លុះត្រាតែតណ្ហាពិតជាមកពីប្រាជ្ញា និងបំណង។ តណ្ហាចេតនា "បើយើងមានបំណងធ្វើតាម ឬយើងមិនប្រឆាំងនឹងធ្វើតាម" (សន្តៈ ថូម៉ាស នៃអាកាំង)។ ប្រាជ្ញាត្រូវតែគ្រប់គ្រងលើតណ្ហា ដើម្បីឲ្យមនុស្សបានគ្រប់លក្ខណៈខាងសីលធម៌ (សន្តៈ ថូម៉ាស នៃអាកាំង)។

១៧៦៨- ភាពដ៏វិសុទ្ធ ឬសីលធម៌របស់មនុស្សមិនអាស្រ័យទៅលើអារម្មណ៍ដ៏សំខាន់ឡើយ។ [...] តណ្ហាល្អនៅពេលដែលតណ្ហានោះជួយឲ្យធ្វើកិច្ចការល្អ ផ្ទុយទៅវិញតណ្ហាអាក្រក់ នៅពេលដែលតណ្ហានោះជួយឲ្យធ្វើកិច្ចការអាក្រក់។ បំណងត្រឹមត្រូវតម្រង់ចលនាខាងផ្លូវចិត្ត (ដែលបំណងនេះទទួលយក)ឆ្ពោះទៅអ្វីដ៏ល្អ និង

សុភមង្គលដ៏ពិតប្រាកដ។ បំណងអាក្រក់ចាញ់តណ្ហាឥតសណ្ដាប់ធ្នាប់ និងធ្វើឲ្យតណ្ហានោះកាន់តែខ្លាំងឡើង ៗ។ គុណធម៌ អាចតម្រូវអារម្មណ៍ផ្សេង ៗ ឯបាបធម៌ អាចបង្ខូចអារម្មណ៍ទាំងអស់នោះ។

១៧៦៩- ក្នុងការរស់នៅជាគ្រីស្តបរិស័ទ ព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់បំពេញព្រះរាជកិច្ចរបស់ព្រះអង្គ ដោយទទួលយកមនុស្សទាំងមូល ព្រមទាំងការឈឺចាប់ ការភ័យខ្លាច ការព្រួយចិត្តរបស់គេ ដូចក្នុងពេលដែលព្រះអម្ចាស់រងទុក្ខលំបាកផងដែរ។ ក្នុងអង្គព្រះគ្រីស្ត អារម្មណ៍របស់មនុស្សអាសម្រេចឲ្យបានពេញលក្ខណៈ ក្នុងសេចក្ដីស្រឡាញ់ និងសុភមង្គលយ៉ាងពិតប្រាកដ។

១៧៧០- មនុស្សបានគ្រប់លក្ខណៈខាងសីលធម៌ នៅពេលដែលបំណងជំរុញគេឲ្យទៅរកអ្វីដ៏ល្អថែមទាំងនៅពេលដែលចិត្តថ្លើមជំរុញគេផងដែរ ដូចទំនុកតម្កើងបញ្ជាក់ថា៖ "ទូលបង្គំបន្លឺសម្លេងតម្កើងព្រះដ៏មានព្រះជន្មគង់នៅ អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត" (ទន ៨៤,៣)។

## សង្ខេប

១៧៧១- ពាក្យ "តណ្ហា" សម្ដៅទៅលើការរំជួលចិត្ត ឬអារម្មណ៍។ តាមរយៈការរំជួលចិត្ត មនុស្សអាចយល់ ឬនឹកស្មានថាជាការល្អ ឬជាការអាក្រក់។

១៧៧២- តណ្ហាសំខាន់ជាងគេ គឺសេចក្ដីស្រឡាញ់ និងការស្អប់ បំណងប្រាថ្នា និងការភ័យខ្លាច អំណរ ការព្រួយចិត្ត និងកំហឹង។

១៧៧៣- តណ្ហាជាចលនាខាងផ្លូវចិត្ត មិនល្អ ឬមិនអាក្រក់ឡើយ។ យើងអាចវិនិច្ឆ័យតណ្ហាតាមសីលធម៌លុះត្រាតែតណ្ហាពិតជាមកពីប្រាជ្ញា និងបំណង។

១៧៧៤- គុណធម៌ អាចតម្រូវអារម្មណ៍ផ្សេង ៗ ឯបាបធម៌ អាចបង្ខូចអារម្មណ៍ទាំងអស់នោះ។

១៧៧៥- មនុស្សបានគ្រប់លក្ខណៈខាងសីលធម៌ នៅពេលដែលបំណងជំរុញឲ្យរកអ្វីដ៏ល្អជាមួយនឹង "ចិត្តគំនិត" គេផងដែរ។

# ប្រការទី៦៖

# មនសិការខាងសីលធម៌

១៧៧៦- "នៅពេលមនុស្សយើងរិះគិត យើងមុខជានឹងរកឃើញក្បួនវិន័យដែលខ្លួនមិនបានកំណត់ខ្លួនឯងកប់នៅខាងជម្រៅនៃមនសិការរបស់ខ្លួន គឺជាក្បួនវិន័យដែលយើងត្រូវតែអនុវត្តតាម។ សម្លេងនេះនៅតែជំរុញយើងឲ្យមានចិត្តស្រឡាញ់ ឲ្យប្រព្រឹត្តអំពើល្អ និងចៀសវាងមិនឲ្យប្រព្រឹត្តអំពើអាក្រក់ លាន់ឮក្នុងជម្រៅចិត្តនៅពេលត្រូវការ (...)។ ព្រះជាម្ចាស់ជារក្បួនវិន័យនោះក្នុងចិត្តមនុស្ស (...)។ ក្នុងមនុស្ស មនសិការជាមណ្ឌលដ៏ស្ងាត់កំបាំងជាងគេ ជាទីកន្លែងដ៏សក្ការៈដែលមនុស្សនៅតែម្នាក់ឯងជាមួយព្រះជាម្ចាស់ ជាកន្លែងព្រះសូរសៀងរបស់ព្រះអង្គលាន់ឮឡើង" (GS ១៦)។

## ១. ការវិនិច្ឆ័យនៃមនសិការ

១៧៧៧- ដោយស្ថិតនៅក្នុងចិត្តមនុស្ស មនសិការជំរុញគេ (រម ២,១៤-១៦) នៅពេលត្រូវការ ឲ្យប្រព្រឹត្ត

អំពើល្អ និងចៀសវាងមិនឲ្យប្រព្រឹត្តអំពើអាក្រក់ឡើយ។ មនសិការវិនិច្ឆ័យជម្រើសផ្សេងៗ ដោយយល់ស្របនឹងជម្រើសល្អ និងចោទប្រកាន់ជម្រើសអាក្រក់ (រម ១,៣២)។ មនសិការបញ្ជាក់នូវអំណាចនៃសេចក្តីពិត តាមអ្វីដ៏ល្អប្រសើរបំផុត ដែលទាក់ទាញមនុស្ស និងបញ្ជាគេឲ្យប្រតិបត្តិតាម។ នៅពេលដែលគេស្តាប់មនសិការ មនុស្សដែលចេះរិះគិតពិចារណា អាចឮព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន។

១៧៧៨- ដោយសារមនសិការ ប្រាជ្ញាមនុស្សវិនិច្ឆ័យនូវសីលធម៌នៃកិច្ចការណាមួយ ដែលគេកំពុងធ្វើ ឬដែលគេបានប្រព្រឹត្តរួចហើយ។ គ្រប់កិច្ចការ និងពាក្យសម្តី មនុស្សត្រូវតែធ្វើតាមអ្វីដែលខ្លួនដឹងថា សុចរិត និងត្រឹមត្រូវ។ ដោយសារមនសិការ មនុស្សទទួល និងស្គាល់បទបញ្ញានៃធម្មវិន័យរបស់ព្រះជាម្ចាស់៖

> មនសិការជាក្បួនវិន័យនៃវិញ្ញាណយើង ប៉ុន្តែ មនសិការហួសវិញ្ញាណយើង។ មនសិការបញ្ជាយើង បានសេចក្តីថា ការទទួលខុសត្រូវ ភារកិច្ច ការភ័យខ្លាច និងសេចក្តីសង្ឃឹម (...)។ មនសិការជាអ្នកនាំសាររបស់អ្នក ដែលមានព្រះបន្ទូលមកយើងតាមរយៈស្បៃ ប្រៀនប្រដៅ និងណែនាំយើង ក្នុងពិភពនៃធម្មជាតិ ដូចក្នុងពិភពនៃការប្រណីសន្តោសផងដែរ។ មនសិការជាសហការីដំបូងនៃសហការីទាំងអស់របស់ព្រះគ្រីស្ត (លោក ន្យូម៉ាន)។

១៧៧៩- មនុស្សម្នាក់ៗត្រូវតែដឹងខ្លួនសមល្មម ដើម្បីស្តាប់ឮ និងធ្វើតាមសម្លេងនៃមនសិការរបស់ខ្លួន។ ជាចាំបាច់មនុស្សត្រូវតែរិះគិតពិចារណាក្នុងជម្រៅចិត្ត ជាពិសេសក្នុងលោកនេះដែលការរស់នៅឧស្សាហ៍ជំរុញយើងមិនឲ្យរិះគិតពិចារណាឡើងវិញអំពីខ្លួនឯងទេ៖

> ចូរទៅរកមនសិការរបស់ខ្លួន ចូរសួរមនសិការទៅ (...)។ ចូរបងប្អូនត្រឡប់ទៅក្នុងខ្លួនវិញ ហើយក្នុងអ្វីៗទាំងអស់ដែលបងប្អូនធ្វើ ចូរសម្លឹងមើលសាក្សីដ៏ប្រសើរ គឺព្រះជាម្ចាស់ (សន្តៈ អូគូស្តាំង)។

១៧៨០- ឋានៈដ៏ថ្លៃថ្នូររបស់មនុស្សទាមទារឲ្យមានមនសិការត្រឹមត្រូវ។ ដោយសារមនសិការ យើងយល់ឃើញគោលការណ៍នៃសីលធម៌ យើងអនុវត្តគោលការណ៍នោះ ក្នុងកាលៈទេសៈ ដោយបានរិះគិតពិចារណាអំពីមូលហេតុ និងសេចក្តីល្អផ្សេងៗ ទីបញ្ចប់យើងវិនិច្ឆ័យកិច្ចការដែលយើងត្រូវប្រព្រឹត្ត ឬកិច្ចការដែលយើងបានប្រព្រឹត្តរួចហើយ។ ការវិនិច្ឆ័យដោយរិះគិតពិចារណា នៃមនសិការទទួលស្គាល់សេចក្តីពិតអំពីអ្វីដ៏ល្អខាងសីលធម៌ដែលក្បួនវិន័យនៃប្រាជ្ញាបានប្រកាស។ នរណាដែលប្រតិបត្តិតាមការវិនិច្ឆ័យនេះ ជាមនុស្សម្នាក់ដែលចេះរិះគិតពិចារណា។

១៧៨១- ដោយសារមនសិការ យើងទទួលខុសត្រូវ នូវលើកិច្ចការដែលយើងប្រព្រឹត្ត។ បើមនុស្សប្រព្រឹត្តអំពើអាក្រក់ ការវិនិច្ឆ័យដ៏ត្រឹមត្រូវនៃមនសិការអាចធ្វើជាសាក្សី ក្នុងខ្លួនគេ នៃសេចក្តីពិតសកលនៃអ្វីដ៏ល្អ ហើយជាមួយគ្នានេះ មនសិការជាសាក្សីនៃលក្ខណៈអាក្រក់នៃជម្រើសរបស់គេដែរ។ ការវិនិច្ឆ័យនៃមនសិការកត់ទុកជាមុននូវសេចក្តីសង្ឃឹមលើធម៌មេត្តាករុណា គឺដោយបញ្ជាក់ថា យើងបានប្រព្រឹត្តកំហុស ការវិនិច្ឆ័យនេះរំឭកយើងថាត្រូវសូមការលើកលែងទោស ត្រូវប្រព្រឹត្តអំពើល្អ និងត្រូវប្រតិបត្តិតាមគុណធម៌តទៅទៀតជានិច្ចនិរន្តរ៍ ដោយមានព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ជួយឧបត្ថម្ភផងដែរ៖

> ចិត្តយើងមិនភ័យខ្លាចនៅចំពោះព្រះភ័ក្ត្រព្រះអង្គទេ។ ហេតុនេះ ប្រសិនបើចិត្តគំនិតយើងដាក់ទោសយើងនោះ ព្រះជាម្ចាស់ដែលធំជាងចិត្តរបស់យើង ទ្រង់ឈ្វេងយល់ទាំងអស់ (១យហ ៣,១៩-២០)។

១៧៨២- មនុស្សមានសិទ្ធិប្រព្រឹត្តតាមមនសិការ និងសេរីភាពរបស់ខ្លួន ដើម្បីសម្រេចចិត្តបំពេញកិច្ចការខាង

សីលធម៌រៀងៗខ្លួន។ "យើងមិនអាចបង្ខិតបង្ខំមនុស្សឲ្យប្រតិបត្តិប្រឆាំងនឹងមនសិការរបស់ខ្លួនទេ។ ប៉ុន្តែ យើងមិនអាចរារាំងគេមិនឲ្យប្រតិបត្តិតាមមនសិការរបស់ខ្លួនដែរ ជាពិសេសក្នុងកិច្ចការទាក់ទងនឹងសាសនា" (DH ៣)។

## ២. ការអប់រំមនសិការ

១៧៨៣- ត្រូវតែអប់រំមនសិការ និងបំភ្លឺការវិនិច្ឆ័យនៃសីលធម៌។ ពេលយើងអប់រំមនសិការឲ្យបានល្អ មនសិការនេះ ត្រឹមត្រូវ និងស្របតាមសេចក្ដីពិត។ មនសិការវិនិច្ឆ័យតាមប្រាជ្ញាស្របតាមអ្វីដ៏ល្អពិតប្រាកដ ដែលព្រះប្រាជ្ញាញាណរបស់ព្រះបង្កើតសព្វព្រះហឫទ័យ។ ដោយសារមនុស្សស្ថិតនៅក្រោមឥទ្ធិពលអវិជ្ជមាន ហើយដោយសារអំពើបាបល្បួងគេឲ្យធ្វើតាមការវិនិច្ឆ័យរបស់ខ្លួនជាជាងការប្រៀនប្រដៅដ៏ត្រឹមត្រូវ ជាចាំបាច់មនុស្សត្រូវតែអប់រំមនសិការ។

១៧៨៤- អស់មួយជីវិត មនុស្សមានមុខងារអប់រំមនសិការ។ ចាប់តាំងពីឆ្នាំដំបូង មនសិការបំភ្លឺកូនក្មេងឲ្យស្គាល់ និងអនុវត្តតាមក្បួនវិន័យដែលស្ថិតក្នុងជម្រៅចិត្ត ហើយដែលមនសិការទទួលស្គាល់។ ត្រូវតែអប់រំដោយរិះគិតពិចារណា គឺត្រូវបង្រៀនគុណធម៌ កុំឲ្យភ័យខ្លាច កុំឲ្យគិតតែអំពីខ្លួនឯង កុំឲ្យអួតបំប៉ាង កុំឲ្យអស់សង្ឃឹមពេលបានប្រព្រឹត្តអំពើបាប កុំឲ្យវក់នឹងអំពើបាប ដែលមកពីភាពទន់ខ្សោយ និងកំហុសរបស់មនុស្ស។ ការអប់រំមនសិការធានាសេរីភាព និងបង្កើតសន្តិភាពក្នុងចិត្ត។

១៧៨៥- ក្នុងការអប់រំមនសិការ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាពន្លឺនៅលើផ្លូវយើង។ ត្រូវតែទទួលព្រះបន្ទូលនេះដោយជឿ ដោយអធិដ្ឋាន និងដោយប្រតិបត្តិតាម។ ម្យ៉ាងទៀត ត្រូវតែរិះគិតពិចារណាអំពីមនសិការរបស់ខ្លួនស្របតាមព្រះឈើឆ្កាងរបស់ព្រះអម្ចាស់។ ព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដោយមានសក្ខីភាព ឬដំបូន្មានរបស់អ្នកដទៃ និងការប្រៀនប្រដៅរបស់ព្រះសហគមន៍ជួយណែនាំយើង (DH ១៤)។

## ៣. ត្រូវតែជ្រើសរើសតាមមនសិការរបស់ខ្លួន

១៧៨៦- ពេលត្រូវជ្រើសរើសធ្វើកិច្ចការប្រកបដោយសីលធម៌ មនសិការអាចវិនិច្ឆ័យត្រឹមត្រូវស្របតាមប្រាជ្ញា និងធម្មវិន័យរបស់ព្រះជាម្ចាស់ ផ្ទុយទៅវិញមនសិការអាចវិនិច្ឆ័យខុស ដែលធ្វើឲ្យឃ្លាតឆ្ងាយពីប្រាជ្ញា និងពីធម្មវិន័យរបស់ព្រះជាម្ចាស់។

១៧៨៧- ជួនកាល មនុស្សប្រឈមមុខនឹងស្ថានភាព ពិបាកវិនិច្ឆ័យ និងពិបាកសម្រេចចិត្ត។ ប៉ុន្តែ គេត្រូវស្វែងរកអ្វីដ៏ល្អ និងត្រឹមត្រូវជានិច្ច និងរិះគិតពិចារណាអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលធម្មវិន័យរបស់ព្រះអង្គសម្ដែង។

១៧៨៨- ហេតុនេះ មនុស្សខិតខំបកស្រាយបទពិសោធន៍ និងសញ្ញាសម្គាល់នៃពេលវេលា ដោយរិះគិតពិចារណា ស្ដាប់ដំបូន្មានរបស់អ្នកដទៃ និងដោយមានព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះអំណោយទានរបស់ព្រះអង្គជួយឧបត្ថម្ភផង។

១៧៨៩- មានវិន័យខ្លះត្រូវអនុវត្តក្នុងករណីទាំងអស់ៈ

- យើងមិនអាចធ្វើអំពើអាក្រក់ ដើម្បីទទួលផលល្អបានឡើយ
- "បើអ្នករាល់គ្នាចង់ឲ្យអ្នកដទៃប្រព្រឹត្តចំពោះខ្លួនបែបណា ត្រូវប្រព្រឹត្តចំពោះគេបែបនោះដែរ" (មថ ៧,១២) (លក ៦,៣១ ; តប ៤,១៥)

- ត្រូវគោរពអ្នកដទៃជានិច្ច និងគោរពមនសិការរបស់គេផងដែរ ដោយចិត្តស្រឡាញ់៖ " ដោយបងប្អូនប្រព្រឹត្តអំពើបាបបែបនេះចំពោះបងប្អូនឯទៀតៗ និងដោយធ្វើអំពើដែលនាំឲ្យទាស់នឹងស្មារតីរបស់គេនោះ បងប្អូនក៏ដូចជាបានប្រព្រឹត្តអំពើបាបចំពោះព្រះគ្រីស្តផ្ទាល់តែម្តង" (១ករ ៨,១២)។ "ប្រសិនបើយើងមិន (...) ប៉ះពាល់របស់ណាដែលធ្វើឲ្យបងប្អូនជំពប់ចិត្តបាត់ជំនឿ នោះជាការល្អប្រពៃហើយ" (រម ១៤,២១)។

## ៤. ការវិនិច្ឆ័យខុស

១៧៩០- មនុស្សត្រូវធ្វើតាមការវិនិច្ឆ័យដ៏ច្បាស់លាស់នៃមនសិការរបស់ខ្លួនជានិច្ច។ បើគេសម្រេចប្រព្រឹត្តប្រឆាំងនឹងការវិនិច្ឆ័យនេះ គេនឹងផ្តន្ទាទោសខ្លួនឯង។ ប៉ុន្តែ ជួនកាលមនុស្សមិនដឹងមិនស្គាល់ ហើយវិនិច្ឆ័យខុសកិច្ចការដែលគេបានប្រព្រឹត្ត ឬដែលគេនឹងប្រព្រឹត្ត។

១៧៩១- ជារឿយៗ ការមិនដឹងមិនស្គាល់នេះ បណ្តាលមកពីការមិនទទួលខុសត្រូវរបស់ខ្លួនឯងផ្ទាល់។ ហេតុនេះ នៅពេលដែល "មនុស្សមិនរវីរវល់ស្វែងរកសេចក្តីពិត និងអ្វីដ៏ល្អប្រសើរ ហើយមានទម្លាប់ប្រព្រឹត្តអំពើបាបយូរៗទៅ មនសិការរបស់គេហាក់ដូចជាខ្វាក់" (GS ១៦)។ ក្នុងករណីនេះ មនុស្សទទួលខុសត្រូវលើអំពើបាបដែលខ្លួនប្រព្រឹត្ត។

១៧៩២- បើយើងមិនស្គាល់ព្រះគ្រីស្ត និងដំណឹងល្អរបស់ព្រះអង្គ បើយើងយកតម្រាប់តាមគំរូដ៏អាក្រក់របស់អ្នកដទៃ បើយើងជាឈ្លើយនៃតណ្ហា បើយើងទាមទារឲ្យមនសិការពឹងលើខ្លួនឯង បើយើងបដិសេធមិនព្រមទទួលអំណាច និងការប្រៀនប្រដៅរបស់ព្រះសហគមន៍ បើយើងមិនព្រមកែប្រែចិត្តគំនិត និងប្រព្រឹត្តតាមសេចក្តីស្រឡាញ់ទេ នោះយើងអាចភ័ន្តច្រឡំក្នុងការវិនិច្ឆ័យចំពោះអាកប្បកិរិយាប្រកបដោយសីលធម៌។

១៧៩៣- ផ្ទុយទៅវិញ បើយើងមិនអាចឈ្នះអវិជ្ជាបាន ឬក៏យើងវិនិច្ឆ័យខុស ដោយគ្មានការទទួលខុសត្រូវ យើងមិនអាចផ្តន្ទាទោសអ្នកដែលបានប្រព្រឹត្តអំពើអាក្រក់បានឡើយ។ ក៏ប៉ុន្តែ អំពើនេះ នៅតែជាអំពើអាក្រក់ ជាការខ្វះខាត ឥតសណ្តាប់ធ្នាប់មួយ។ ដូច្នេះ យើងត្រូវតែខិតខំកែលំអមនសិការអំពីកំហុសរបស់ខ្លួន។

១៧៩៤- ជំនឿដ៏ពិតប្រាកដបំភ្លឺមនសិការដ៏ល្អ និងត្រឹមត្រូវ ដ្បិតសេចក្តីស្រឡាញ់ "ផុសចេញពីចិត្តបរិសុទ្ធ ពីមនសិការជ្រះថ្លា និងពីជំនឿឥតពុតត្បុត" (១ធម ១,៥) (១ធម ៣,៩ ; ២ធម ១,៣ ; ១ពត្រ ៣,២១ ; កក ២៤,១៦)៖

> មនសិការទៀងត្រង់កាន់តែខ្លាំងយ៉ាងណា បុគ្គល ឬក្រុមមនុស្សអាចសម្រេចសេចក្តីឲ្យកាន់តែច្បាស់ និងឲ្យបានស្របតាមច្បាប់សីលធម៌ ដែលមិនអាចប្រកែកបាន (GS ១៦)។

## សង្ខេប

១៧៩៥- "ក្នុងខ្លួនមនុស្ស មនសិការជាមណ្ឌលដ៏ស្ងាត់កំបាំងជាងគេ ជាទីកន្លែងដ៏សក្ការៈដែលមនុស្សនៅតែម្នាក់ឯងជាមួយព្រះជាម្ចាស់ ជាកន្លែងដែលព្រះអង្គបន្លឺព្រះសូរសៀង" (GS ១៦)។

១៧៩៦- ដោយសារមនសិការ ប្រាជ្ញាមនុស្សវិនិច្ឆ័យនូវសីលធម៌នៃកិច្ចការណាមួយ។

១៧៩៧- ចំពោះមនុស្សដែលបានប្រព្រឹត្តអំពើអាក្រក់ ការវិនិច្ឆ័យនៃមនសិការកត់ទុកជាមុនថា អាចកែប្រែចិត្ត

គំនិត ដោយមានសេចក្តីសង្ឃឹម។

១៧៩៨- ពេលយើងអប់រំមនសិការបានល្អ មនសិការនេះ ត្រឹមត្រូវ និងស្របតាមសេចក្តីពិត។ មនសិការធ្វើការវិនិច្ឆ័យតាមប្រាជ្ញា សមស្របតាមអ្វីដ៏ល្អពិតប្រាកដ ដែលព្រះប្រាជ្ញាញាណរបស់ព្រះបង្កើតសព្វព្រះហឫទ័យ។ មនុស្សម្នាក់ៗត្រូវតែរកមធ្យោបាយអប់រំមនសិការរបស់ខ្លួន។

១៧៩៩- ពេលត្រូវជ្រើសរើសធ្វើកិច្ចការប្រកបដោយសីលធម៌ មនសិការអាចវិនិច្ឆ័យត្រឹមត្រូវសមស្របតាមប្រាជ្ញា និងធម្មវិន័យរបស់ព្រះជាម្ចាស់ ផ្ទុយទៅវិញមនសិការអាចវិនិច្ឆ័យខុស ដែលធ្វើឲ្យឃ្លាតឆ្ងាយពីប្រាជ្ញា និងពីធម្មវិន័យរបស់ព្រះជាម្ចាស់។

១៨០០- មនុស្សត្រូវធ្វើតាមការវិនិច្ឆ័យដ៏ច្បាស់លាស់នៃមនសិការរបស់ខ្លួនជានិច្ច។

១៨០១- ជួនកាលមនុស្សមិនដឹងមិនស្គាល់ ហើយវិនិច្ឆ័យខុស។ ការមិនដឹងមិនស្គាល់នេះ បណ្តាលមកពីការមិនទទួលខុសត្រូវខ្លួនឯងផ្ទាល់។

១៨០២- ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាពន្លឺបំភ្លឺជំហានរបស់យើង។ យើងត្រូវតែស្វែងយល់អំពីព្រះបន្ទូលនេះដោយសារជំនឿ និងដោយការអធិដ្ឋាន ហើយត្រូវតែអនុវត្តតាមផងដែរ។ ហេតុនេះហើយ បានជាយើងត្រូវអប់រំមនសិការខាងសីលធម៌។

# ប្រការទី៧៖

# គុណធម៌

១៨០៣- "សូមបងប្អូនគិតតែអំពីអ្វីៗដែលពិត ដែលថ្លៃថ្នូរ សុចរិត បរិសុទ្ធ គួរឲ្យស្រឡាញ់ គួរឲ្យគោរព និងគំនិតណាដែលល្អឥតខ្ចោះ គួរឲ្យកោតសរសើរ" (ភីល ៤,៨)។

- គុណធម៌ ជាទម្លាប់មោះមុតឲ្យប្រព្រឹត្តអ្វីដ៏ល្អ។ ដោយសារគុណធម៌ មនុស្សមិនគ្រាន់តែប្រព្រឹត្តអំពើល្អទេ ថែមទាំងបានពេញលក្ខណៈផងដែរ។ មនុស្សដែលមានគុណធម៌តម្រង់ទៅរកអ្វីដ៏ល្អអស់ពីកម្លាំងកាយចិត្ត គេចង់បានអ្វីដ៏ល្អ និងប្រព្រឹត្តកិច្ចការដ៏ល្អផងដែរ។
- គោលដៅនៃជីវិតប្រកបដោយគុណធម៌ គឺថា មានលក្ខណៈដូចព្រះជាម្ចាស់ (សន្តៈ គ្រែគ័រ នៃនីស)។

## ១. គុណធម៌របស់មនុស្ស

១៨០៤- គុណធម៌របស់មនុស្ស ជាអាកប្បកិរិយាមោះមុត ទម្លាប់នឹងន និងភាពល្អឥតខ្ចោះនៃប្រាជ្ញាឈ្លាសវៃ និងឆន្ទៈក្នុងការចាត់ចែងកិច្ចការ និងតណ្ហារបស់យើង ហើយណែនាំរបៀបរស់នៅរបស់យើងតាមប្រាជ្ញា និងជំនឿ។ ដោយសារគុណធម៌នោះ មនុស្សងាយស្រួលទៅរករបៀបរស់នៅប្រកបដោយសីលធម៌ និងអំណរសប្បាយ។ មនុស្សដែលមានគុណធម៌ គឺជាមនុស្សដែលប្រតិបត្តិតាមអ្វីដែលល្អៗ ដោយមានសេរីភាពពេញលេញ។

មនុស្សមានគុណធម៌មកពីគេប្រតិបត្តិតាម។ គុណធម៌ជាផល និងជាពន្លកនៃអំពើល្អ ដែលមានសីលធម៌ល្អ។ គុណធម៌នោះ រៀបចំកម្លាំងទាំងអស់របស់មនុស្ស ឲ្យប្រួមក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

## គុណធម៌សំខាន់ៗ

១៨០៥- គុណធម៌បួនមានតួនាទីសំខាន់ៗ។ ហេតុនេះហើយ បានជាគេហៅគុណធម៌នោះថាជា "គុណធម៌សំខាន់ៗ" ដែលមានគុណធម៌ផ្សេងៗទៀតស្ថិតនៅជាមួយ។ មានការចេះរិះគិតពិចារណា សេចក្ដីសុចរិត សេចក្ដីក្លាហាន និងការចេះទប់ចិត្ត។ "តើមាននរណាស្រឡាញ់សេចក្ដីសុចរិតឬទេ? គុណធម៌ល្អគ្រប់យ៉ាងសុទ្ធតែជាស្នាព្រះហស្ដរបស់ព្រះប្រាជ្ញាញាណ គឺព្រះអង្គបង្រៀនឲ្យចេះស្កប់ចិត្ត ចេះរិះគិតពិចារណា មានសេចក្ដីសុចរិត និងចិត្តក្លាហាន" (ប្រាញ ៨,៧)។ អត្ថបទគម្ពីរផ្សេងទៀតសរសើរគុណធម៌នោះ ដែលគេហៅតាមរបៀបផ្សេងៗ។

១៨០៦- អ្នកចេះរិះគិតពិចារណា រៀបចំប្រាជ្ញាឲ្យរិះគិតគ្រប់កាលទេសៈអំពីអ្វីដ៏ល្អយ៉ាងពិតប្រាកដ ហើយជ្រើសរើសមធ្យោបាយត្រឹមត្រូវ ដើម្បីបំពេញអ្វីដ៏ល្អនេះ។ "មនុស្សឆ្លាតមិនធ្វើអ្វីដោយឥតគិតពិចារណាឡើយ" (សុភ ១៤,១៥)។ "ត្រូវគិតឲ្យវែងឆ្ងាយ និងភ្ញាក់ស្មារតីឡើង ទើបអធិដ្ឋានកើត" (១ពត្រ ៤,៧)។ ក្រោយពីលោកអារីសតូត សន្ដៈ ថូម៉ាសសរសេរថា៖ "អ្នកចេះរិះគិតពិចារណាចេះបំពេញកិច្ចការតាមវិន័យត្រឹមត្រូវ"។ មនុស្សចេះរិះគិតពិចារណាមិនអៀនបៀន មិនភ័យខ្លាច មិនប្រើកលល្បិច ឬមិនលាក់លៀមឡើយ។ គេហៅគុណធម៌នេះថា **auriga virtutum**៖ គុណធម៌នេះ ណែនាំគុណធម៌ផ្សេងៗទៀត ដោយប្រុងប្រយ័ត្ន។ មនុស្សដែលមិនថ្វេសប្រហែសវិនិច្ឆ័យក្រោយពីបានរិះគិតពិចារណា។ អ្នកចេះរិះគិតពិចារណាសម្រេច និងណែនាំអាកប្បកិរិយារបស់ខ្លួនតាមការវិនិច្ឆ័យនេះ។ ដោយសារគុណធម៌នេះ យើងប្រតិបត្តិតាមគោលការណ៍សីលធម៌ដោយគ្មានកំហុសចំពោះករណីពិសេស ហើយយើងលែងសង្ស័យអំពីអ្វីដ៏ល្អដែលត្រូវបំពេញ និងអ្វីដ៏អាក្រក់ដែលត្រូវចៀសវាង។

១៨០៧- អ្នកសុចរិត មានបំណងមោះមុតដ៏ស្ថិតស្ថេរ ដើម្បីថ្វាយទៅព្រះជាម្ចាស់ និងផ្ដល់ដល់អ្នកដទៃនូវអ្វីៗដែលត្រូវតែថ្វាយ និងផ្ដល់ឲ្យ។ គេហៅសេចក្ដីសុចរិតចំពោះព្រះជាម្ចាស់ថាជា "គុណធម៌នៃសាសនា"។ ចំពោះមនុស្សវិញ សេចក្ដីសុចរិតនាំឲ្យចេះគោរពសិទ្ធិរបស់មនុស្ស និងបង្កើតភាពសុខដុមក្នុងទំនាក់ទំនងរវាងគ្នានិងគ្នាដែលលើកទឹកចិត្តឲ្យមានយុត្តិធម៌ចំពោះមនុស្ស និងចំពោះផលប្រយោជន៍រួម។ ក្នុងគម្ពីរដ៏វិសុទ្ធ អ្នកសុចរិតប្លែកពីគេ ព្រោះចិត្តគំនិត និងរបៀបរស់នៅរបស់គាត់ត្រឹមត្រូវ និងទៀងត្រង់ចំពោះអ្នកដទៃ។ "ពេលវិនិច្ឆ័យទោស កុំកាត់ក្ដីដោយអយុត្តិធម៌ កុំរើសមុខនរណាឲ្យសោះ គឺកុំយោគយល់អ្នកតូច ឬ អ្នកធំ តែត្រូវវិនិច្ឆ័យឲ្យជនរួមជាតិរបស់អ្នកដោយយុត្តិធម៌" (លវ ១៩,១៥)។ "បងប្អូនដែលជាម្ចាស់ ចូរប្រព្រឹត្តអំពើណាដែលសុចរិត និងយុត្តិធម៌ដល់ទាសកររបស់ខ្លួន ដោយដឹងថា បងប្អូនផ្ទាល់ ក៏មានម្ចាស់មួយព្រះអង្គនៅស្ថានបរមសុខដែរ" (កូឡ ៤,១)។

១៨០៨- អ្នកមានចិត្តក្លាហាន មានចិត្តមោះមុតដ៏ស្ថិតស្ថេរនៅតែទៅរកអ្វីដ៏ល្អ ទោះបីមានទុក្ខលំបាកយ៉ាងណាក៏ដោយ។ សេចក្ដីចិត្តក្លាហានពង្រឹងការសម្រេចចិត្តឲ្យតស៊ូប្រឆាំងនឹងការល្បួង និងពុះពារឧបសគ្គក្នុងការរស់នៅប្រកបដោយសីលធម៌។ អ្នកមានចិត្តក្លាហានអាចជម្នះការភ័យខ្លាច សូម្បីតែសេចក្ដីស្លាប់ ហើយអាចប្រឈមមុខទល់នឹងសេចក្ដីលំបាក និងការបៀតបៀនផងដែរ។ អ្នកមានចិត្តក្លាហានអាចលះបង់ និងបូជាជីវិតដើម្បីមូលហេតុដ៏ត្រឹមត្រូវ។ "ព្រះអម្ចាស់ជាកម្លាំងរបស់ខ្ញុំ ខ្ញុំច្រៀងថ្វាយព្រះអង្គ ព្រះអង្គសង្គ្រោះខ្ញុំ" (ទន ១១៨,១៤)។ "អ្នករាល់គ្នាជួបនឹងទុក្ខវេទនានៅក្នុងលោក ប៉ុន្តែ ចូរតាំងចិត្តក្លាហានឡើង! ខ្ញុំបានឈ្នះលោកនេះ" (យហ ១៦,៣៣)។

១៨០៩- អ្នកចេះទប់ចិត្ត ចេះតមការសប្បាយ និងនាំឲ្យមានលំនឹងក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិនៃលោកនេះ។ គុណធម៌នេះ នាំឲ្យគេចេះគ្រប់គ្រងកិលេសតណ្ហា និងការប៉ងប្រាថ្នាដោយមានកំណត់ព្រំដែនតាមសេចក្ដី

ទៀងត្រង់។ អ្នកចេះទប់ចិត្តតម្រូវចិត្តថ្លើមទៅរកអ្វីដ៏ល្អ នឹងន និង "មិនបណ្ដោយតាមសន្ទុះចិត្តលោភលន់ និងតណ្ហាឡើយ" (បសរ ៥,២) (បសរ ៣៧,២៧-៣១)។ គម្ពីរសម្ពន្ធមេត្រីចាស់ឧស្សាហ៍សរសើរអ្នកចេះទប់ចិត្តថា៖ "មិនបណ្ដោយខ្លួនទៅតាមតណ្ហា ហើយមិនធ្វើតាមចិត្តប៉ងប្រាថ្នារបស់កូនឡើយ" (បសរ ១៨,៣០)។ ក្នុងសម្ព័ន្ធមេត្រីថ្មី គេហៅអ្នកចេះទប់ចិត្តនេះថាជា អ្នកមាន "ចិត្តធ្ងន់" ចេះ "ស្កប់ស្កល់"។ "ត្រូវរស់នៅក្នុងលោកនេះដោយមានចិត្តធ្ងន់ សុចរិត និងគោរពប្រណិប័តន៍ព្រះជាម្ចាស់" (តទ ២,១២)។

> យើងមានរបៀបរស់នៅត្រឹមត្រូវនៅពេលដែលយើងស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្ត អស់ពីព្រលឹង និងដោយប្រព្រឹត្តកិច្ចការទាំងអស់ចំពោះព្រះអង្គ។ យើងថ្វាយទៅព្រះអង្គសេចក្ដីស្រឡាញ់សុទ្ធសាធ (ដោយចេះស្កប់ចិត្ត) ដែលគ្មានវេទនាអាចមករញ្ជួយ (ដែលមកពីចិត្តក្លាហាន) ដែលធ្វើតាមតែព្រះអង្គ (នេះគឺជាសេចក្ដីសុចរិត) ហើយដែលប្រុងស្មារតី កុំឲ្យចាញ់កលល្បិច និងភាពកុហកឡើយ (នេះគឺជាការចេះរិះគិតពិចារណា) (សន្តៈ អូគូស្តាំង)។

## គុណធម៌ និងការប្រណីសន្ដោស

១៨១០- ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់បន្សុទ្ធ និងលើកគុណធម៌ ដែលមកពីការអប់រំ ដោយបំពេញកិច្ចការដោយចេតនា និងដោយការខិតខំព្យាយាមប្រតិបត្តិតាមជានិច្ច។ ដោយមានព្រះជាម្ចាស់ជួយ គុណធម៌ពង្រឹងចរិតឲ្យរឹងមាំ និងធ្វើឲ្យយើងប្រព្រឹត្តអ្វីដ៏ល្អដោយងាយស្រួល។ អ្នកមានគុណធម៌រីករាយនឹងប្រតិបត្តិតាម។

១៨១១- មនុស្សដែលត្រូវរបួសដោយសារអំពើបាប មិនងាយប្រព្រឹត្តតាមសីលធម៌ទេ។ ព្រះគ្រីស្ដបានប្រោសប្រទានព្រះអំណោយទានសង្គ្រោះយើងនិងព្រះហឫទ័យប្រណីសន្ដោសដែលយើងត្រូវការដើម្បីព្យាយាមស្វែងរកគុណធម៌។ ជានិច្ចកាលម្នាក់ៗត្រូវតែទូលសូមព្រះហឫទ័យប្រណីសន្ដោសនៃពន្លឺ និងកម្លាំងនេះ ទទួលអគ្គសញ្ញារួមសហការជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយធ្វើតាមព្រះអង្គដែលត្រាស់ហៅយើងឲ្យស្រឡាញ់អ្វីដ៏ល្អ និងចៀសវាងអំពើអាក្រក់។

## ២. គុណធម៌ដែលព្រះជាម្ចាស់ប្រទាន

១៨១២- គុណធម៌របស់មនុស្សចាក់ឫសក្នុងគុណធម៌ដែលព្រះជាម្ចាស់ប្រទាន ហើយដែលតម្រូវសមត្ថភាពរបស់មនុស្សឲ្យទទួលចំណែកក្នុងសភាពជាព្រះជាម្ចាស់ (២ពត្រ ១,៤) ដ្បិតមនុស្សទទួលគុណធម៌អំពីព្រះជាម្ចាស់ផ្ទាល់។ គុណធម៌នោះ រៀបចំការរស់នៅរបស់គ្រីស្ដបរិស័ទឲ្យមានទំនាក់ទំនងជាមួយនឹងព្រះត្រៃឯក មានព្រះជាម្ចាស់ជាព្រះមួយអង្គ និងជាព្រះត្រៃអង្គ ជាប្រភព មូលហេតុ និងគោលដៅ។

១៨១៣- គុណធម៌ដែលមកពីព្រះជាម្ចាស់ជាមូលដ្ឋាន ណែនាំ និងបញ្ជាក់លក្ខណៈពិសេសរបស់កិច្ចការប្រកបដោយសីលធម៌របស់គ្រីស្ដបរិស័ទ។គុណធម៌នោះ ជាប្រភពរបស់គុណធម៌ឯទៀតៗ និងធ្វើឲ្យគុណធម៌ឯទៀតៗស្ថិតនៅយូរអង្វែង។ ព្រះជាម្ចាស់ចាក់បង្ហូរគុណធម៌នោះក្នុងព្រលឹងរបស់គ្រីស្ដបរិស័ទ ដើម្បីឲ្យគេអាចប្រព្រឹត្តដូចបុត្រធីតារបស់ព្រះអង្គ ហើយឲ្យគេស័ក្ដិសមនឹងទទួលជីវិតអស់កល្បជានិច្ច។ ដោយសារគុណធម៌នោះ ព្រះជាម្ចាស់បញ្ចាំចិត្តយើងនូវវត្តមាន និងកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ទៅតាមសមត្ថភាពមនុស្ស។ គុណធម៌ដែលមកពីព្រះជាម្ចាស់មានបីយ៉ាង គឺជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ (១ករ ១៣,១៣)។

## ជំនឿ

១៨១៤- ជំនឿជាគុណធម៌ដែលមកពីព្រះជាម្ចាស់។ ដោយសារជំនឿ យើងផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ ជឿលើព្រះបន្ទូលរបស់ព្រះអង្គ និងសេចក្ដីដែលព្រះអង្គបានសម្ដែងឱ្យយើងដឹង ហើយដែលព្រះសហគមន៍ដ៏វិសុទ្ធស្នើសុំឱ្យជឿ ដ្បិតព្រះអង្គផ្ទាល់ជាសេចក្ដីពិត។ ដោយសារជំនឿ "មនុស្សស្ម័គ្រចិត្តផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់" (DV ៥)។ ហេតុនេះហើយ បានជាអ្នកជឿស្វែងរកចង់ស្គាល់ និងប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ "ព្រះជាម្ចាស់ប្រោសប្រទានឱ្យមនុស្សសុចរិតដោយសារជំនឿ និងឱ្យគេប្រតិបត្តិតាមជំនឿ" (រម ១,១៧)។ ជំនឿដ៏រស់រវើក "នាំឱ្យប្រព្រឹត្តអំពើផ្សេងៗដោយចិត្តស្រឡាញ់" (កាឡ ៥,៦)។

១៨១៥- ព្រះអំណោយទាននៃជំនឿស្ថិតនៅក្នុងខ្លួនអ្នក ដែលមិនបានប្រព្រឹត្តបាបប្រឆាំងនឹងជំនឿនេះឡើយ (មហាសន្និបាតនៅទៅក្រុងត្រង់៖ DS ១៥៤៥)។ ប៉ុន្តែ "ជំនឿដែលគ្មានការប្រព្រឹត្តអំពើល្អ គឺជាជំនឿស្លាប់" (យប ២,២៦)៖ បើគ្មានសេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ទេ ជំនឿមិនធ្វើឱ្យគ្រីស្តបរិស័ទរួបរួមជាមួយព្រះគ្រីស្តបានពេញលក្ខណៈទេ ហើយមិនធ្វើឱ្យគេទៅជាសិរីរាង្គដ៏រស់រវើកនៃព្រះកាយព្រះអង្គឡើយ។

១៨១៦- សាវ័ករបស់ព្រះគ្រីស្តមិនគ្រាន់តែត្រូវរក្សាជំនឿទុក និងរស់ដោយសារជំនឿនេះទេ ថែមទាំងគេត្រូវតែប្រកាស និងផ្ដល់សក្ខីភាពអំពីជំនឿនេះ ដោយចិត្តក្លាហាន និងផ្សព្វផ្សាយជំនឿនេះផងដែរ៖ "គ្រីស្តបរិស័ទទាំងអស់ត្រូវប្រុងខ្លួននឹងប្រកាសជំនឿលើព្រះគ្រីស្ត នៅចំពោះមុខមនុស្សលោក។ នៅពេលមានគេបៀតបៀនធ្វើបាបព្រះសហគមន៍ គ្រីស្តបរិស័ទត្រូវសុខចិត្តដើរតាមព្រះអង្គរហូតដល់ឈើឆ្កាង ព្រោះព្រះសហគមន៍នៅតែជួបការបៀតបៀនពុំខានឡើយ" (LG ៤២ ; DH ១៤)។ ត្រូវតែបម្រើគេ និងផ្ដល់សក្ខីភាពនៃជំនឿ ដើម្បីទទួលការសង្គ្រោះ៖ "អ្នកណាទទួលស្គាល់ខ្ញុំនៅចំពោះមុខមនុស្សលោក ខ្ញុំនឹងទទួលស្គាល់អ្នកនោះវិញ នៅចំពោះព្រះភ័ក្ត្រព្រះបិតារបស់ខ្ញុំ ដែលគង់នៅស្ថានបរមសុខ។ រីឯអ្នកណាបដិសេធមិនទទួលស្គាល់ខ្ញុំនៅចំពោះមុខមនុស្សលោក ខ្ញុំក៏បដិសេធមិនទទួលស្គាល់អ្នកនោះ នៅចំពោះព្រះភ័ក្ត្រព្រះបិតារបស់ខ្ញុំ ដែលគង់នៅស្ថានបរមសុខដែរ" (មថ ១០,៣២-៣៣)។

## សេចក្ដីសង្ឃឹម

១៨១៧- សេចក្ដីសង្ឃឹមជាគុណធម៌ដែលព្រះជាម្ចាស់ប្រទាន។ ដោយសារសេចក្ដីសង្ឃឹម យើងប៉ងប្រាថ្នាចង់បានព្រះរាជ្យនៃស្ថានបរមសុខ និងជីវិតអស់កល្បជានិច្ច ដូចជាសុភមង្គលរបស់យើង ដោយផ្ញើជីវិតទាំងស្រុងលើព្រះបន្ទូលសន្យារបស់ព្រះគ្រីស្ត និងដោយពឹងផ្អែកលើព្រះហឫទ័យប្រណីសន្ដោសនៃព្រះវិញ្ញាណដ៏វិសុទ្ធ មិនមែនលើកម្លាំងរបស់ខ្លួនឯងទេ។ "ត្រូវរក្សាសេចក្ដីសង្ឃឹម ដែលយើងប្រកាសនោះ ឱ្យបានខ្ជាប់ខ្ជួន កុំឱ្យរង្គើឡើយ ដ្បិតព្រះជាម្ចាស់មានព្រះបន្ទូលសន្យាយ៉ាងណា ទ្រង់នឹងធ្វើតាមយ៉ាងនោះដែរ" (ហប ១០,២៣)។ "ព្រះជាម្ចាស់ចាក់បង្ហូរព្រះវិញ្ញាណនេះមកលើយើងយ៉ាងបរិបូណ៌ ដោយសារព្រះយេស៊ូគ្រីស្ត ជាព្រះសង្គ្រោះរបស់យើង ដើម្បីឱ្យយើងបានសុចរិត ដោយសារព្រះហឫទ័យប្រោសប្រណីរបស់ព្រះអង្គ និងឱ្យយើងបានទទួលជីវិតអស់កល្បជានិច្ច ជាមត៌ក តាមសេចក្ដីសង្ឃឹមរបស់យើង" (តទ ៣,៦-៧)។

១៨១៨- សេចក្ដីសង្ឃឹមជាគុណធម៌ ដែលបំពេញបំណងប្រាថ្នាចង់បានសុភមង្គល ដែលព្រះជាម្ចាស់បានដាក់ក្នុងចិត្តមនុស្សគ្រប់ៗរូប។ គុណធម៌នេះ ទទួលយកការសង្ឃឹមទាំងប៉ុន្មាន ដែលជំរុញមនុស្សឱ្យមានសកម្មភាពបន្សុទ្ធការសង្ឃឹមនោះស្របតាមព្រះរាជ្យនៃស្ថានបរមសុខ ការពារមនុស្សកុំឱ្យបាក់ទឹកចិត្ត ជួយគាំទ្រមនុស្ស

តែលតោល និងពង្រីកចិត្តឲ្យរង់ចាំសុភមង្គលអស់កល្បជានិច្ច។ សន្ទុះនៃសេចក្តីសង្ឃឹមការពារមនុស្សមិនឲ្យគិតតែពីប្រយោជន៍ខ្លួនឯង និងនាំឲ្យស្គាល់សុភមង្គលនៃសេចក្តីស្រឡាញ់។

១៨១៩- សេចក្តីសង្ឃឹមនៃគ្រីស្តសាសនាទទួលយក និងបំពេញសេចក្តីសង្ឃឹមនៃប្រជារាស្ត្រដែលព្រះជាម្ចាស់បានជ្រើសរើស ដែលមានប្រភព និងយកតម្រាប់តាមសេចក្តីសង្ឃឹមរបស់លោកអប្រាហាំ ដែលកូនអ៊ីសាកបានបំពេញព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ហើយដែលយញ្ញបូជាបានបន្សុទ្ធ (កណ ១៧,៤-៨ ; ២២,១-១៨)។" ទោះបីគ្មានអ្វីជាទីសង្ឃឹមក៏ដោយ ក៏លោកអប្រាហាំនៅតែមានសង្ឃឹម និងមានជំនឿ ហើយលោកក៏បានទៅជាឪពុករបស់ជាតិសាសន៍ជាច្រើន" (រម ៤,១៨)។

១៨២០- សេចក្តីសង្ឃឹមនៃគ្រីស្តសាសនាលាតសន្ធឹង តាំងពីពេលដែលព្រះយេស៊ូចាប់ផ្តើមទេសនា ក្នុងការប្រកាសសុភមង្គលយ៉ាងពិតប្រាកដ។ សុភមង្គលយ៉ាងពិតប្រាកដ លើកសេចក្តីសង្ឃឹមរបស់យើងឆ្ពោះទៅលើមេឃដូចជាទឹកដីសន្យាថ្មី ហើយបង្ហាញផ្លូវតាមរយៈការលំបាកទាំងប៉ុន្មាន ដែលរង់ចាំសាវ័ករបស់ព្រះយេស៊ូ។ ប៉ុន្តែ ដោយសារគុណបុណ្យរបស់ព្រះយេស៊ូគ្រីស្ត និងទុក្ខលំបាករបស់ព្រះអង្គ ព្រះជាម្ចាស់រក្សាយើងទុកក្នុង " សេចក្តីសង្ឃឹមមិនធ្វើឲ្យយើងខកចិត្តឡើយ" (រម ៥,៥)។ សេចក្តីសង្ឃឹមជា "យុថ្កានៃព្រលឹង" ដ៏ជាប់មាំមួន "ដែលចូល (...) ឆ្ពោះទៅកាន់កន្លែងដែលព្រះយេស៊ូបានយាងចូលទៅមុន" (ហប ៦,១៩-២០)។ សេចក្តីសង្ឃឹមជាអាវុធដែលការពារយើងក្នុងការច្បាំងប្រយុទ្ធក្នុងការសង្គ្រោះ៖ "យើងត្រូវតែចេះប៉ាន់ប្រមាណដោយយកជំនឿ និងសេចក្តីស្រឡាញ់មកពាក់ធ្វើជាអាវក្រោះ ព្រមទាំងយកសេចក្តីសង្ឃឹមលើការសង្គ្រោះ មកពាក់ធ្វើជាមួកដែក" (១ថស ៥,៨)។ សេចក្តីសង្ឃឹមផ្តល់សេចក្តីរីករាយ ទោះជាលំបាកយ៉ាងណាក៏ដោយ៖ "ចូរសប្បាយរីករាយដដោយចិត្តសង្ឃឹម។ ចូរកាន់ចិត្តអត់ធ្មត់ក្នុងពេលមានទុក្ខលំបាក" (រម ១២,១២)។ ការអធិដ្ឋានសម្តែង និងបំប៉នសេចក្តីសង្ឃឹមជាពិសេសក្នុងសេចក្តីអធិដ្ឋាន"ឱព្រះបិតានៃយើងខ្ញុំ"ដែលជាសេក្តីសង្ខេបនៃអ្វីៗទាំងអស់ដែលសេចក្តីសង្ឃឹមធ្វើឲ្យយើងប៉ងប្រាថ្នា។

១៨២១- ដូច្នះហើយ បានជាយើងអាចសង្ឃឹមនឹងបានសិរីរុងរឿងនៃស្ថានបរមសុខ ដែលព្រះជាម្ចាស់មានព្រះបន្ទូលសន្យាចំពោះអស់អ្នកដែលស្រឡាញ់ (រម ៨,២៨-៣០) និងគាប់ព្រះហឫទ័យព្រះអង្គ (មថ ៧,២១)។ គ្រប់កាលៈទេសៈ ដោយមានព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ អ្នករាល់គ្នាត្រូវតែសង្ឃឹម "ស៊ូទ្រាំរហូតដល់ចុងបញ្ចប់" (មថ ១០,២២ ; មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៥៤១) និងទទួលអំណរនៃស្ថានបរមសុខដែលជារង្វាន់អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ចំពោះកិច្ចការដ៏ល្អដែលយើងបានប្រព្រឹត្តដោយមានព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្ត។ ដោយមានសេចក្តីសង្ឃឹម ព្រះសហគមន៍អង្វរព្រះជាម្ចាស់ឲ្យ "មនុស្សទាំងអស់ទទួលការសង្គ្រោះ" (១ធម ២,៤) និងមានបំណងប្រាថ្នាចង់រួបរួមជាមួយព្រះគ្រីស្ត ជាព្រះស្វាមីរបស់ខ្លួនក្នុងសិរីរុងរឿងនៃស្ថានបរមសុខ៖

> ឱព្រលឹងអើយ ចូរសង្ឃឹមទៅ! អ្នកមិនស្គាល់ពេលកំណត់ទេ។ ចូរប្រុងស្មារតីដោយយកចិត្តទុកដាក់អ្វីៗទាំងអស់ចេះតែកន្លងផុតទៅយ៉ាងលឿន ទោះបីអ្វីដែលច្បាស់លាស់ហាក់ដូចជាគួរឲ្យសង្ស័យ និងពេលវេលាដ៏ខ្លីហាក់ដូចជាយូរ ដោយសារអ្នកមិនចេះអត់ធ្មត់ក៏ដោយ។ ចូរនឹកគិតថា អ្នកកាន់តែច្បាំង នោះអ្នកនឹងកាន់តែបង្ហាញសេចក្តីស្រឡាញ់របស់អ្នកចំពោះព្រះរបស់អ្នក ហើយ នៅថ្ងៃណាមួយ អ្នកនឹងត្រេកអរសប្បាយកាន់តែខ្លាំងឡើងៗជាមួយនឹងព្រះដ៏ជាទីស្រឡាញ់របស់អ្នក ក្នុងសុភមង្គល និងអំណរសប្បាយដែលគ្មានទីបញ្ចប់ឡើយ(សន្តី ថេរេសានៃព្រះយេស៊ូ)។

## សេចក្ដីស្រឡាញ់

១៨២២- សេចក្ដីស្រឡាញ់ជាគុណធម៌ដែលជាព្រះអំណោយទាន។ ដោយសារសេចក្ដីស្រឡាញ់ យើងស្រឡាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់ ដើម្បីព្រះអង្គផ្ទាល់ ហើយយើងស្រឡាញ់អ្នកដទៃ ដូចខ្លួនឯងដោយសារសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់។

១៨២៣- ព្រះយេស៊ូបានធ្វើឲ្យសេចក្ដីស្រឡាញ់ទៅជាវិន័យថ្មី (យហ ១៣,៣៤)។ ដោយស្រឡាញ់មិត្តសម្លាញ់របស់ព្រះអង្គ "រហូតដល់ទីបំផុត" (យហ ១៣,១) ព្រះអង្គក៏សម្ដែងសេចក្ដីស្រឡាញ់របស់ព្រះបិតា ដែលព្រះអង្គទទួល។ ដោយស្រឡាញ់គ្នាទៅវិញទៅមក សាវ័កយកតម្រាប់តាមសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ ដែលពួកគេទទួលទុកក្នុងខ្លួន។ ហេតុនេះហើយ បានជាព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដូចព្រះបិតាស្រឡាញ់ខ្ញុំដែរ។ ចូរទុកសេចក្ដីស្រឡាញ់របស់ខ្ញុំឲ្យស្ថិតនៅជាប់នឹងអ្នករាល់គ្នាចុះ" (យហ ១៥,៩) ឬ៖ " វិន័យរបស់ខ្ញុំមានដូចតទៅនេះ គឺអ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" (យហ ១៥,១២)។

១៨២៤- សេចក្ដីស្រឡាញ់ ដែលជាផលនៃព្រះវិញ្ញាណ និងដែលបំពេញធម្មវិន័យឲ្យបានគ្រប់លក្ខណៈ គឺជាការប្រតិបត្តិតាមធម្មវិន័យ របស់ព្រះជាម្ចាស់ និងរបស់ព្រះគ្រីស្តព្រះអង្គ៖ "ចូរទុកសេចក្ដីស្រឡាញ់របស់ខ្ញុំឲ្យស្ថិតនៅជាប់នឹងអ្នករាល់គ្នាចុះ។ បើអ្នករាល់គ្នាប្រតិបត្តិតាមវិន័យរបស់ខ្ញុំអ្នករាល់គ្នាពិតជាទុកសេចក្ដីស្រឡាញ់របស់ខ្ញុំ (យហ ១៥,៩-១០) (មថ ២២,៤០ ; រម ១៣,៨-១០)។

១៨២៥- ព្រះគ្រីស្តបានសោយទិវង្គត ដោយសារសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះយើង ក្នុងគ្រាដែលយើងនៅជា "សត្រូវ" របស់ព្រះអង្គនៅឡើយ (រម ៥,១០)។ ព្រះអម្ចាស់សូមយើងឲ្យស្រឡាញ់ដូចព្រះអង្គ រហូតដល់ស្រឡាញ់ខ្មាំងសត្រូវ របស់យើង (មថ ៥,៤៤) ឲ្យយើងទៅជាបងប្អូនរបស់អ្នកដទៃ (លក ១០,២៧-៣៧) ស្រឡាញ់កូនក្មេង (មក ៩,៣៧) និងជនក្រីក្រដូចព្រះអង្គផ្ទាល់ (មថ ២៥,៤០.៤៥)។

> គ្រីស្តទូតប៉ូលរៀបរាប់អំពីសេចក្ដីស្រឡាញ់យ៉ាងអស្ចារ្យ៖ "អ្នកមានចិត្តស្រឡាញ់តែងតែអត់ធ្មត់ ជួយធុរៈគេ ហើយមិនចេះឈ្នានីសគេទេ។ អ្នកមានចិត្តស្រឡាញ់មិនវាយឫកខ្ពស់ មិនអួតអាងឡើយ។ អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចងគំនុំ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្ដីពិតវិញ។ អ្នកមានចិត្តស្រឡាញ់ អត់ឱនគ្រប់កាលៈទេសៈ ជឿគ្រប់កាលៈទេសៈ សង្ឃឹមគ្រប់កាលៈទេសៈ ហើយទ្រាំទ្រគ្រប់កាលៈទេសៈ" (១ករ ១៣,៤-៧)។

១៨២៦- គ្រីស្តទូតប៉ូលបន្ថែមទៀតថា៖ "បើសិនជាខ្ញុំគ្មានសេចក្ដីស្រឡាញ់ទេ ខ្ញុំជាមនុស្សឥតបានការអ្វីទាំងអស់" ហើយទោះបីខ្ញុំមានព្រះអំណោយទានពិសេស ចេះបម្រើគេ ទោះបីខ្ញុំមានគុណធម៌... "បើសិនជាខ្ញុំគ្មានសេចក្ដីស្រឡាញ់ទេនោះ ក៏គ្មានប្រយោជន៍អ្វីដល់ខ្ញុំដែរ" (១ករ ១៣,១-៤)។ សេចក្ដីស្រឡាញ់ជាគុណធម៌ដ៏ប្រសើរលើសគុណធម៌ឯទៀតៗទាំងអស់។ សេចក្ដីស្រឡាញ់ជាគុណធម៌ទីមួយនៃគុណធម៌ដែលមកពីព្រះជាម្ចាស់៖ "ឥឡូវនេះមានគុណធម៌បីយ៉ាងស្ថិតនៅ គឺជំនឿ សេចក្ដីសង្ឃឹម សេចក្ដីស្រឡាញ់។ ប៉ុន្តែក្នុងចំណោមគុណធម៌បីយ៉ាងនោះ មានតែសេចក្ដីស្រឡាញ់ទេ ដែលប្រសើរជាងគេបំផុត" (១ករ ១៣,១៣)។

១៨២៧- សេចក្ដីស្រឡាញ់ជំរុញ និងណែនាំឲ្យប្រតិបត្តិតាមគុណធម៌ទាំងអស់។ សេចក្ដីស្រឡាញ់ "ធ្វើឲ្យបងប្អូនរួបរួមគ្នាពេញលក្ខណៈ" (កូឡ ៣,១៤) ជារូបរាងនៃគុណធម៌ គឺរៀបចំគុណធម៌រវាងគ្នានិងគ្នា ជាប្រភពនិងទីចុងក្រោយនៃការប្រព្រឹត្តគុណធម៌នោះតាមគ្រីស្តសាសនា។ សេចក្ដីស្រឡាញ់ទទួលយក បន្សុទ្ធ និងលើក

កម្លាំងរបស់មនុស្សឲ្យចេះស្រឡាញ់ ដូចព្រះជាម្ចាស់ស្រឡាញ់យើងឲ្យបានពេញលក្ខណៈ និងហួសធម្មជាតិ។

១៨២៨- ការប្រតិបត្តិតាមសីលធម៌ ដោយមានសេចក្តីស្រឡាញ់ណែនាំ ផ្តល់សេរីភាពខាងវិញ្ញាណឲ្យគ្រីស្តបរិស័ទ ដែលជាបុត្រធីតារបស់ព្រះជាម្ចាស់។ គ្រីស្តបរិស័ទមិនឈរចំពោះព្រះជាម្ចាស់ដូចជាទាសករ ដែលភិតភ័យ ឬដូចជាអ្នកស៊ីឈ្នួលគេ ដោយរង់ចាំប្រាក់ឈ្នួលគេទេ ប៉ុន្តែ ដូចជាបុត្រ ដែលឆ្លើយតបនឹង "ព្រះជាម្ចាស់ដែលបានស្រឡាញ់យើងជាមុន" (១យហ ៤,១៩)៖

> យើងគេចផុតអំពីសេចក្តីអាក្រក់ ព្រោះយើងខ្លាចទទួលទោស ហើយយើងដូចជាទាសករ ឬមួយយើងចង់បានរង្វាន់ ហើយយើងដូចជាអ្នកស៊ីឈ្នួលច្បាំងឲ្យគេ ឬម៉្យាងទៀតយើងស្តាប់បង្គាប់ ដើម្បីសេចក្តីល្អផ្ទាល់ខ្លួន និងសេចក្តីស្រឡាញ់របស់អ្នកដែលបញ្ជា (...) ហើយយើងប្រៀបបីដូចជាបុត្រធីតា (សន្តៈបាស៊ីល)។

១៨២៩- អ្នកមានចិត្តស្រឡាញ់បង្កើតផល ដូចជាអំណរ សេចក្តីសុខសាន្ត និងធម៌មេត្តាករុណា អ្នកមានចិត្តស្រឡាញ់យោគយល់ និងចេះជួយកែលំអគ្នាទៅវិញទៅមកដូចជាបងប្អូន អ្នកមានចិត្តស្រឡាញ់ចេះអធ្យាស្រ័យ ធ្វើឲ្យគេស្រឡាញ់វិញ មិនគិតអំពីផលប្រយោជន៍ផ្ទាល់ មានចិត្តទូលាយ រាប់រកអ្នកដទៃ ដោយរួបរួមជាមួយគ្នា៖

> កិច្ចការទាំងអស់របស់យើងបញ្ចប់ក្នុងសេចក្តីស្រឡាញ់យ៉ាងស្មោះ។ ទីបំផុត យើងរត់សំដៅទៅរកសេចក្តីស្រឡាញ់នេះ។ ពេលជួបហើយ យើងក៏សម្រាកក្នុងសេចក្តីស្រឡាញ់នេះ (សន្តៈអូគូស្តាំង)។

## ៣. ព្រះអំណោយទាន និងផលនៃព្រះវិញ្ញាណដ៏វិសុទ្ធ

១៨៣០- ព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ជួយគាំទ្រជីវិតប្រកបដោយសីលធម៌របស់គ្រីស្តបរិស័ទ។ ព្រះអំណោយទាននោះ គឺជាលក្ខណៈអចិន្ត្រៃយ៍ ដែលធ្វើឲ្យមនុស្សស្តាប់បង្គាប់ការជំរុញរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

១៨៣១- ព្រះអំណោយទាន ទាំងប្រាំពីរនៃព្រះវិញ្ញាណដ៏វិសុទ្ធ គឺប្រាជ្ញា ការឈ្លាសវៃ ការចេះផ្តល់ដំបូន្មាន ចិត្តអង់អាច ការចេះដឹង ការគោរពប្រណិប័តន៍ និងការគោរពកោតខ្លាចព្រះជាម្ចាស់។ ព្រះគ្រីស្តជាព្រះបុត្រារបស់ព្រះបាទដាវីឌមានព្រះអំណោយទានទាំងអស់នោះពេញលក្ខណៈ (អស ១១,១- ២)។ ព្រះអំណោយទាននោះបំពេញ និងណែនាំគុណធម៌របស់អស់អ្នកដែលទទួលព្រះអំណោយទាននោះ ឲ្យបានពេញលក្ខណៈ។ ព្រះអំណោយទាននោះ ធ្វើឲ្យគ្រីស្តបរិស័ទឆាប់ស្តាប់តាមការជំរុញរបស់ព្រះជាម្ចាស់។

> សូមព្រះវិញ្ញាណដ៏សប្បុរសរបស់ព្រះអង្គ ដឹកនាំទូលបង្គំឲ្យដើរក្នុងមាគ៌ាដែលគ្មានឧបសគ្គ (ទន ១៤៣,១០)។

> អស់អ្នក ដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ណែនាំ សុទ្ធតែជាបុត្រធីតារបស់ព្រះជាម្ចាស់ (...)។ ប្រសិនបើយើងពិតជាបុត្រធីតាមែន នោះយើងមុខជាទទួលមត៌កពុំខាន។ យើងនឹងទទួលមត៌កពីព្រះជាម្ចាស់ គឺទទួលមត៌ករួមជាមួយព្រះគ្រីស្ត (រម ៨,១៤.១៧)។

១៨៣២- ផល នៃព្រះវិញ្ញាណ គឺជាភាពល្អឥតខ្ចោះដែលព្រះវិញ្ញាណបង្កើតក្នុងខ្លួនយើងដូចជាផលផ្លែដំបូងនៃសិរីរុងរឿងអស់កល្បជានិច្ច។ តាមការបញ្ជូនបន្តរបស់ព្រះសហគមន៍ មានផលដប់ប្រាំពីរ៖ "សេចក្តីស្រឡាញ់ អំណរ សេចក្តីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសន្តោសមេត្តា ចិត្តសប្បុរស ចិត្តស្លូតបូត ចេះយោគយល់ ភក្តីភាព ចេះបន្ទាបខ្លួនឯង ចេះតមការសប្បាយ ចេះទប់ចិត្តខ្លួនឯង" (កាឡ ២២-២៣ តាមគម្ពីរ៧០)។

# សង្ខេប

១៨៣៣- គុណធម៌ ជាទម្លាប់មោះមុតឲ្យប្រព្រឹត្តអ្វីដ៏ល្អ។

១៨៣៤- គុណធម៌របស់មនុស្សជាទម្លាប់នឹងននៃប្រាជ្ញាឈ្លាសវៃ និងឆន្ទៈក្នុងការចាត់ចែងកិច្ចការ និងតណ្ហារបស់យើង ហើយដឹកនាំរបៀបរស់នៅរបស់យើងតាមប្រាជ្ញា និងជំនឿ។"គុណធម៌សំខាន់ៗ" ដែលមានគុណធម៌ផ្សេងៗទៀតស្ថិតនៅជាមួយ មានការចេះរិះគិតពិចារណា សេចក្ដីសុចរិត សេចក្ដីក្លាហាន និងការចេះទប់ចិត្ត។

១៨៣៥- អ្នកចេះរិះគិតពិចារណា រៀបចំប្រាជ្ញាឲ្យរិះគិតគ្រប់កាលទេសៈអំពីអ្វីដ៏ល្អយ៉ាងពិតប្រាកដ ហើយជ្រើសរើសមធ្យោបាយត្រឹមត្រូវ ដើម្បីបំពេញអ្វីដ៏ល្អនេះ។

១៨៣៦- អ្នកសុចរិតមានបំណងមោះមុតដ៏ស្ថិតស្ថេរ ដើម្បីថ្វាយទៅព្រះជាម្ចាស់ និងផ្ដល់ដល់អ្នកដទៃនូវអ្វីៗដែលត្រូវតែថ្វាយ និងផ្ដល់ឲ្យ។

១៨៣៧- អ្នកមានចិត្តក្លាហានមានចិត្តមោះមុតដ៏ស្ថិតស្ថេរ ដើម្បីទៅរកអ្វីដ៏ល្អ ទោះបីមានទុក្ខលំបាកយ៉ាងណាក៏ដោយ។

១៨៣៨- អ្នកចេះទប់ចិត្តចេះតមការសប្បាយ និងនាំឲ្យមានលំនឹងក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិនៃលោកនេះ។

១៨៣៩- ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់បន្សុទ្ធ និងលើកគុណធម៌ ដែលមកពីការអប់រំ ដោយបំពេញកិច្ចការដោយចេតនា និងដោយការខិតខំព្យាយាមប្រតិបត្តិតាមជានិច្ច។

១៨៤០- គុណធម៌ដែលព្រះជាម្ចាស់ប្រទាន រៀបចំការរស់នៅរបស់គ្រិស្តបរិស័ទឲ្យមានទំនាក់ទំនងជាមួយនឹងព្រះត្រៃឯកដ៏វិសុទ្ធ។ គុណធម៌នោះ មានព្រះជាម្ចាស់ជាប្រភព ជាមូលហេតុ និងជាគោលដៅនិងដើម្បីព្រះអង្គដែលអ្នកជឿស្គាល់ សង្ឃឹម និងស្រឡាញ់។

១៨៤១- គុណធម៌ដែលព្រះជាម្ចាស់ប្រទានមានបីយ៉ាង គឺជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់។ គុណធម៌នោះ ជាប្រភពរបស់គុណធម៌ឯទៀតៗ និងធ្វើឲ្យគុណធម៌ឯទៀតៗស្ថិតនៅយូរអង្វែង។

១៨៤២- ដោយសារជំនឿយើងផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ ជឿលើព្រះបន្ទូលរបស់ព្រះអង្គ និងសេចក្ដីដែលព្រះអង្គបានសម្ដែងឲ្យយើងដឹង ហើយដែលព្រះសហគមន៍ដ៏វិសុទ្ធស្នើសុំឲ្យជឿ។

១៨៤៣- ដោយសារសេចក្ដីសង្ឃឹម យើងប្រាថ្នាចង់បាន និងរង់ចាំពីព្រះជាម្ចាស់ ដោយជឿទុកចិត្តលើព្រះអង្គយ៉ាងមោះមុតនូវជីវិតអស់កល្បជានិច្ច និងព្រះអំណោយទានផ្សេងៗ ដែលសមនឹងទទួលក្នុងជីវិតនេះ។

១៨៤៤- ដោយសារសេចក្ដីស្រឡាញ់ យើងស្រឡាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់ ហើយយើងស្រឡាញ់អ្នកដទៃដូចខ្លួនឯង ដោយសារសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់។សេចក្ដីស្រឡាញ់នេះ "ធ្វើឲ្យបងប្អូនរួបរួមគ្នាពេញលក្ខណៈ" (កូឡ ៣,១៤) និងជារូបរាងនៃគុណធម៌ទាំងអស់។

១៨៤៥- ព្រះអំណោយទានទាំងប្រាំពីរនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះជាម្ចាស់ប្រោសប្រទានឲ្យគ្រិស្តបរិស័ទ គឺប្រាជ្ញា ភាពឈ្លាសវៃ ការចេះផ្ដល់ដំបូន្មាន ចិត្តអង់អាច ការចេះដឹង ការគោរពប្រណិប័តន៍ និងការគោរពកោតខ្លាចព្រះជាម្ចាស់។

# ប្រការទី៨៖

# អំពើបាប

## ១. ធម៌មេត្តាករុណា និងអំពើបាប

១៨៤៦- ដំណឹងល្អ គឺជាការសម្តែង តាមរយៈព្រះយេស៊ូគ្រីស្ត នៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះអ្នកបាប (លក ១៥)។ ទេវទូតជនដំណឹងល្អនេះទៅប្រាប់លោកយ៉ូសែបថា៖ "លោកត្រូវថ្វាយព្រះនាមថា "យេស៊ូ "ដ្បិតបុត្រនេះនឹងសង្គ្រោះប្រជារាស្ត្រព្រះអង្គឲ្យរួចពីបាបរបស់គេ" (មថ ១,២១)។ យ៉ាងណាមិញ ពិធីអរព្រះគុណជាអគ្គសញ្ញានៃការសង្គ្រោះ៖ "នេះជាលោហិតរបស់ខ្ញុំ គឺលោហិតនៃសម្ពន្ធមេត្រី ដែលត្រូវបង្ហូរ ដើម្បីលើកលែងទោសមនុស្សទាំងអស់ឲ្យរួចពីបាប" (មថ ២៦,២៨)។

១៨៤៧- "ព្រះជាម្ចាស់បានបង្កើតយើងដោយយើងមិនបានចូលរួមក្នុងការបង្កើតនេះឡើយ ប៉ុន្តែ ព្រះអង្គមិនសព្វព្រះហឫទ័យសង្គ្រោះយើង បើយើងមិនចូលរួមចំណែកក្នុងការសង្គ្រោះនេះឡើយ" (សន្តៈ អូគូស្តាំង)។ ត្រូវតែសារភាពកំហុសរបស់យើង ដើម្បីបានទទួលធម៌មេត្តាករុណារបស់ព្រះអង្គ។ "ប្រសិនបើយើងពោលថា "យើងគ្មានបាបសោះ" គឺយើងបញ្ឆោតខ្លួនយើង សេចក្ដីពិតមិនស្ថិតនៅក្នុងខ្លួនយើងទេ។ ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិតទ្រង់នឹងអត់ទោសយើងឲ្យរួចពីបាប ព្រមទាំងជម្រះយើងឲ្យបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង" (១យហ ១,៨-៩)។

១៨៤៨- ដូចសន្តៈប៉ូលមានប្រសាសន៍៖ "នៅទីណាដែលមានបាបកាន់តែច្រើន នៅទីនោះព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ក៏រឹតតែមានច្រើនលើសលប់ថែមទៀត"។ ប៉ុន្តែ ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ត្រូវតែរកឃើញអំពើបាប ដើម្បីបំពេញកិច្ចការរបស់ខ្លួន គឺដើម្បីកែប្រែចិត្តគំនិតយើង និងប្រោសប្រទាន "សេចក្ដីសុចរិតដើម្បីឲ្យមនុស្សលោកមានជីវិតអស់កល្បជានិច្ចតាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើង" (រម ៥,២០-២១)។ ព្រះជាម្ចាស់ប្រៀបបីដូចជាគ្រូពេទ្យដែលស្ទាបស្ទង់ដំបៅមុនរំដំបៅនេះ គឺតាមរយៈព្រះបន្ទូល និងព្រះវិញ្ញាណព្រះអង្គ ៗក៏បំភ្លឺអំពើបាបយ៉ាងច្បាស់ៗ៖

ត្រូវតែបំភ្លឺអំពើបាប ដើម្បីកែប្រែចិត្តគំនិត។ ការវិនិច្ឆ័យនៃមនសិការស្ថិតក្នុងការកែប្រែចិត្តគំនិតនេះ។ យើងអាចយល់ឃើញថា ព្រះវិញ្ញាណនៃសេចក្ដីពិត ៗជាប្រព្រឹត្តកិច្ចការក្នុងជម្រៅចិត្តមនុស្ស ហើយនៅពេលជាមួយគ្នានេះ ព្រះអំណោយទានថ្មីនៃព្រះហឫទ័យប្រណីសន្ដោស និងសេចក្ដីស្រឡាញ់ក៏ចាប់ផ្ដើមដែរ៖ "ចូរទទួលព្រះវិញ្ញាណដ៏វិសុទ្ធ"។ ហេតុនេះ ក្នុងការបំភ្លឺអំពើបាបនេះ យើងរកឃើញព្រះអំណោយទានពីរ គឺមនសិការប្រតិបត្តិតាមសេចក្ដីពិត ហើយយើងដឹងច្បាស់ថា នឹងបានទទួលការសង្គ្រោះ។ ព្រះវិញ្ញាណនៃសេចក្ដីពិតជាព្រះដ៏ជួយការពារ (DeV ៣១)។

## ២. អ្វីទៅជាអំពើបាប?

១៨៤៩- អ្នកប្រព្រឹត្តអំពើបាបប្រព្រឹត្តកំហុសប្រឆាំងនឹងប្រាជ្ញា សេចក្ដីពិត និងមនសិការត្រឹមត្រូវ។ គេមិនចេះស្រឡាញ់យ៉ាងពិតប្រាកដ ចំពោះព្រះជាម្ចាស់ផង ចំពោះអ្នកដទៃផង ដោយសារគេជាប់ជំពាក់នឹងរបស់របរផ្សេង ៗ។ អំពើបាបធ្វើឲ្យធម្មជាតិមនុស្ស និងសាមគ្គីភាពរវាងមនុស្សត្រូវរបួស។ អំពើបាបជា "ពាក្យសម្តី កិច្ចការ

ឬសេចក្តីប្រាថ្នាប្រឆាំងនឹងវិន័យអស់កល្បជានិច្ច" (សន្តៈ អូគូស្តាំង ; សន្តៈ ថូម៉ាស នៃអាកាំង)។

១៨៥០- អ្នកប្រព្រឹត្តអំពើបាបទាស់នឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ៈ "ទូលបង្គំបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះហឫទ័យព្រះអង្គ គឺទាស់នឹងព្រះអង្គតែមួយគត់ ដ្បិតទូលបង្គំបានប្រព្រឹត្តអំពើមួយ ដែលព្រះអង្គចាត់ទុកថាជាអំពើបាប" (ទន ៥១,៦)។ អំពើបាបប្រឆាំងនឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង ហើយធ្វើឲ្យយើងឃ្លាតឆ្ងាយពីសេចក្តីស្រឡាញ់នេះ។ ដូចអំពើបាបដើម អ្នកបាបមិនស្តាប់បង្គាប់ បះបោរប្រឆាំងនឹងព្រះជាម្ចាស់ ដោយមានបំណងក្លាយទៅជា "ដូចព្រះ" ដែលស្គាល់ និងកំណត់អ្វីល្អ អ្វីអាក្រក់ (កណ ៣,៥)។ អ្នកបាប "ស្រឡាញ់ខ្លួនឯងរហូតដល់ប្រមាថព្រះជាម្ចាស់" (សន្តៈ អូគូស្តាំង)។ ដោយលើកតម្កើងអួតបំប៉ោងខ្លួនឯង អ្នកបាបផ្ទុយស្រឡះនឹងព្រះយេស៊ូដែលស្តាប់បង្គាប់ព្រះជាម្ចាស់ និងបំពេញការសង្គ្រោះ (ភីល ២,៦-៩)។

១៨៥១- ទុក្ខលំបាករបស់ព្រះគ្រីស្ត ដែលនឹងឈ្នះអំពើបាប សម្តែងយ៉ាងច្បាស់នូវអំពើហិង្សានៃអំពើបាបដែលមានគ្រប់បែបយ៉ាងៈ មេដឹកនាំ និងប្រជាជនមិនព្រមជឿ ស្អប់ព្រះអង្គជាទីបំផុត គេទាត់ចោល និងសើចចំអកឲ្យព្រះអង្គ លោកពីឡាតកំសាក ទាហានឃោរឃៅ លោកយូដាសក្បត់ព្រះយេស៊ូ លោកសិលាបដិសេធមិនស្គាល់ព្រះអង្គ ក្រុមសាវ័កបោះបង់ព្រះអង្គចោល។ ក៏ប៉ុន្តែ ពេលនោះ ជាពេលនៃភាពងងឹត និងជាពេលរបស់ចៅហ្វាយនៃលោកីយ៍ (យហ ១៤,៣០) សក្ការបូជារបស់ព្រះគ្រីស្តទៅជាប្រភពដ៏លាក់កំបាំង ដែលការលើកលែងទោសនៃអំពើបាបរបស់យើងនឹងផុសចេញមក។

## ៣. អំពើបាបផ្សេងៗទៀត

១៨៥២- អំពើបាបមានច្រើនប្រភេទ។ ព្រះគម្ពីរផ្តល់បញ្ជីជាច្រើនអំពីអំពើបាប។ ក្នុងលិខិតផ្ញើជូនគ្រីស្តបរិស័ទនៅកាឡាទី កិច្ចការរបស់លោកីយ៍ប្រឆាំងនឹងផលនៃព្រះវិញ្ញាណៈ "យើងស្គាល់ច្បាស់នូវអំពើបាបផ្សេងៗ ដែលកើតចេញមកពីលោកីយ៍ គឺមានអំពើប្រាសចាកសីលធម៌ អំពើសៅហ្មង កាមគុណថោកទាប ការថ្វាយបង្គំព្រះក្លែងក្លាយ វិជ្ជាធ្មប់ ឈ្លោះប្រកែកគ្នា បាក់បែកគ្នា ច្រណែនគ្នា កំហឹងឃោរឃៅ ប្រកួតប្រជែងគ្នាប្រឆាំងគ្នា ប្រកាន់បក្សពួក ឈ្នានីសគ្នា ស៊ីផឹកជ្រុល និងអំពើផ្សេងៗទៀត ដែលស្រដៀងគ្នា។ ខ្ញុំសូមជម្រាបឲ្យបងប្អូនដឹងជាមុន ដូចខ្ញុំបាននិយាយរួចមកហើយថា អស់អ្នកដែលប្រព្រឹត្តអំពើទាំងអស់នេះពុំអាចទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ទុកជាមត៌កបានឡើយ" (៥,១៩-២១) (រម ១,២៨-៣២ ; ១ករ ៦,៩-១០ ; អភ ៥,៣-៥ ; កូឡ ៣,៥-៨ ; ១ធម ១,៩-១០ ; ២ធម ៣,២-៥)។

១៨៥៣- យើងអាចបែងចែកអំពើបាបតាមគោលដៅ ដូចជាការប្រព្រឹត្តរបស់មនុស្ស ឬតាមគុណធម៌ ដែលអំពើបាបប្រឆាំង ឬតាមបទបញ្ញាដែលអំពើបាបជំទាស់។ យើងអាចរៀបចំអំពើបាបតាមអំពើនោះទាក់ទងនឹងព្រះជាម្ចាស់ អ្នកដទៃ ឬខ្លួនឯង។ យើងអាចបែងបែកអំពើបាបខាងវិញ្ញាណ ឬខាងផ្លូវកាយ ខាងគំនិត ខាងពាក្យសម្តី ខាងកិច្ចការ ឬដោយការខកខាន។ តាមការប្រៀនប្រដៅរបស់ព្រះអម្ចាស់ អំពើបាបចាក់ឫសក្នុងចិត្តមនុស្សក្នុងបំណងដ៏សេរីរបស់គេៈ "គំនិតអាក្រក់ ការកាប់សម្លាប់ អំពើផិតក្បត់ កាមគុណថោកទាប ការលួចប្លន់ ពាក្យកុហក ពាក្យត្មះតិះដៀល សុទ្ធតែចេញមកពីចិត្តមនុស្សទាំងអស់ ដែលធ្វើឲ្យមនុស្សសៅហ្មង" (មថ ១៥,១៩-២០)។ ចិត្តក៏ជាជំរំនៃសេចក្តីស្រឡាញ់ ជាគោលនៃអំពើដ៏ល្អ និងបរិសុទ្ធ ហើយដែលអំពើបាបធ្វើឲ្យរបួស។

## ៤. អំពើបាបធ្ងន់ (ដែលនាំឲ្យស្លាប់) និងអំពើបាបស្រាល

១៨៥៤- ត្រូវតែចាត់ទុកអំពើបាបថា តើអំពើបាបធ្ងន់ ឬស្រាល? ដូចក្នុងព្រះគម្ពីរ (១យហ ៥,១៦-១៧) ការ

បញ្ជូនបន្តនៃព្រះសហគមន៍បែងចែកអំពើបាបធ្ងន់ និងអំពើបាបស្រាល។ បទពិសោធន៍របស់មនុស្សបញ្ជាក់ការបែងចែកនេះ។

១៨៥៥- អំពើបាបធ្ងន់ បំផ្លាញសេចក្តីស្រឡាញ់ក្នុងចិត្តមនុស្ស ដោយប្រព្រឹត្តបទល្មើសធ្ងន់ប្រឆាំងនឹងធម្មវិន័យរបស់ព្រះជាម្ចាស់។ អំពើបាបនេះ ធ្វើឲ្យមនុស្សឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ដែលជាទីចុងក្រោយបំផុត និងសុភមង្គលយ៉ាងពិតប្រាកដរបស់គេ ដោយស្រឡាញ់របស់របរមួយច្រើនជាងព្រះអង្គ។

- អំពើបាបស្រាល មិនបំផ្លាញសេចក្តីស្រឡាញ់ទេ ទោះបីអំពើបាបនេះ ប្រឆាំងនឹងសេចក្តីស្រឡាញ់ និងធ្វើឲ្យសេចក្តីស្រឡាញ់របួសក៏ដោយ។

១៨៥៦- ដោយសារអំពើបាបធ្ងន់វាយលុកសេចក្តីស្រឡាញ់ជាគោលការណ៍សំខាន់ៗ អ្នកប្រព្រឹត្តអំពើបាបធ្ងន់ត្រូវការធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ និងកែប្រែចិត្តគំនិត ដោយទទួលអគ្គសញ្ញាលើកលែងទោស៖

> នៅពេលដែលបំណងស្វែងរកអ្វីមួយផ្ទុយនឹងសេចក្តីស្រឡាញ់ ដែលជាទីចុងក្រោយបំផុត គោលដៅផ្ទាល់នៃអំពើបាបនោះនាំឲ្យស្លាប់ (...) ទោះជាប្រឆាំងនឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ (ដូចជាការប្រមាថព្រះអង្គ ការក្បត់ព្រះអង្គជាដើម) ឬប្រឆាំងនឹងសេចក្តីស្រឡាញ់របស់អ្នកដទៃ (ដូចជាការសម្លាប់មនុស្ស ការប្រព្រឹត្តអំពើផិតក្បត់ ជាដើម) (...)។ ផ្ទុយទៅវិញនៅពេលដែលបំណងរបស់អ្នកបាបទៅរកអ្វីមួយដ៏អាក្រក់ ប៉ុន្តែដែលមិនប្រឆាំងនឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងអ្នកដទៃ (ដូចជាពាក្យសម្តីមិនត្រឹមត្រូវ ការសើចឥតប្រយោជន៍ជាដើម) អំពើបាបនោះ ជាអំពើបាបស្រាល (សន្ត: ថូម៉ាស នៃអាគាំង)។

១៨៥៧- បាបធ្ងន់មានល័ក្ខខ័ណ្ឌបីយ៉ាង៖ "អំពើបាបធ្ងន់ គឺជាអំពើបាប ដែលមានគោលដៅជាអំពើធ្ងន់ ហើយដែលអ្នកប្រព្រឹត្តដោយដឹងខ្លួនច្បាស់ និងដោយចេតនា" (**RP ១៧**)។

១៨៥៨- ចម្លើយរបស់ព្រះយេស៊ូចំពោះអ្នកមានម្នាក់ កំណត់និយ័យដប់ប្រការចំពោះអំពើបាបធ្ងន់៖ "កុំសម្លាប់មនុស្ស កុំប្រព្រឹត្តអំពើផិតក្បត់ កុំលួចទ្រព្យសម្បត្តិគេ កុំនិយាយកុហកធ្វើឲ្យគេមានទោស កុំកេងប្រវ័ញ្ចយកសម្បត្តិនរណាឲ្យសោះ ចូរគោរពមាតាបិតា" (មក ១០,១៩)។ ទម្ងន់នៃអំពើបាប ធ្ងន់ ឬស្រាល៖ ការសម្លាប់មនុស្សធ្ងន់ជាងការលួច។ ម្យ៉ាងទៀត អំពើបាបធ្ងន់ ឬស្រាល អាស្រ័យទៅលើអ្នក ដែលរងអំពើបាបដែរ៖ ពេលយើងប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងឪពុកម្តាយ យើងប្រព្រឹត្តអំពើបាបធ្ងន់ជាងអំពើហិង្សាប្រឆាំងនឹងនរណាម្នាក់ផ្សេងទៀត។

១៨៥៩- យើងប្រព្រឹត្តអំពើបាបធ្ងន់ ក្នុងពេលដែលមានស្មារតីភ្លឺស្វាងនិងក្នុងពេលដែលយើងយល់ស្របទាំងស្រុង ដោយដឹងច្បាស់ថា ជាអំពើអាក្រក់ ប្រឆាំងនឹងធម្មវិន័យរបស់ព្រះជាម្ចាស់។ ម្យ៉ាងទៀត ដោយយល់ព្រមប្រព្រឹត្តអំពើនេះ ដោយចេតនា ហើយជាជម្រើសខ្លួនផ្ទាល់។ បើយើងប្រព្រឹត្តអំពើនេះ ដោយធ្វើមិនដឹង ឬដោយមានចិត្តរឹងរូស យើងរឹតតែប្រព្រឹត្តអំពើបាបនេះ ដោយចេតនាទៅទៀត។

១៨៦០- បើយើងប្រព្រឹត្តអំពើបាបធ្ងន់ដោយមិនដឹងខ្លួន និងដោយអចេតនា យើងមិនអាចទទួលខុសត្រូវបានឡើយ ប៉ុន្តែ មនុស្សទាំងអស់ត្រូវតែស្គាល់គោលការណ៍នៃក្បួនវិន័យខាងសីលធម៌ ដែលព្រះជាម្ចាស់បានចារទុកក្នុងចិត្តមនុស្សគ្រប់រូប។ ចលនាខាងផ្លូវចិត្ត និងតណ្ហា ការគាបសង្កត់របស់អ្នកដទៃ ឬបញ្ហាផ្សេងៗខាងផ្លូវចិត្ត អាចនាំឲ្យមនុស្សប្រព្រឹត្តអំពើបាបដោយអចេតនា ឬដោយបង្ខិតបង្ខំ។ អំពើបាបធ្ងន់ជាងគេ គឺជាអំពើបាបដែលយើងប្រព្រឹត្ត ដោយដឹងច្បាស់ និងដោយចង់ប្រព្រឹត្តអំពើអាក្រក់។

១៨៦១- ដោយសារមនុស្សមានសេរីភាព គេអាចប្រព្រឹត្តអំពើបាបដែលនាំឲ្យស្លាប់ ឬគេអាចជ្រើសរើសសេចក្តីស្រឡាញ់ផងដែរ។ អំពើបាបបណ្តាលឲ្យបាត់បង់សេចក្តីស្រឡាញ់ និងព្រះហឫទ័យប្រណី សន្តោសរបស់ព្រះជាម្ចាស់ដែលប្រោសឲ្យបានវិសុទ្ធ។ បើយើងមិនសោកស្តាយអំពើបាបនេះ ហើយបើព្រះជាម្ចាស់មិនលើកលែងទោសឲ្យទេ យើងត្រូវបណ្តេញចេញពីព្រះរាជ្យរបស់ព្រះគ្រីស្ត និង ទទួលសេចក្តីស្លាប់នៃស្ថាននរក ដ្បិតយើងមានសេរីភាពអាចជ្រើសរើសធ្វើកិច្ចការផ្សេងៗ ជាដរាបតរៀងទៅ ដោយមិនថយក្រោយឡើយ។ ក៏ប៉ុន្តែបើយើងអាចវិនិច្ឆ័យថា កិច្ចការណាមួយធ្ងន់មែន យើងត្រូវតែទុកឲ្យសេចក្តីសុចរិត និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់វិនិច្ឆ័យមនុស្សវិញ។

១៨៦២- យើងប្រព្រឹត្តអំពើបាបស្រាល នៅពេលដែលយើងមិនធ្វើតាមក្បួនវិន័យ នៃសីលធម៌ក្នុងកិច្ចការដ៏តូចមួយ ឬនៅពេលដែលយើងមិនស្តាប់បង្គាប់ក្បួនវិន័យនៃសីលធម៌ក្នុងកិច្ចការធ្ងន់មួយ ប៉ុន្តែ ដោយមិនដឹងខ្លួន ឬដោយអចេតនា។

១៨៦៣- ពេលយើងប្រព្រឹត្តអំពើបាបស្រាល យើងលែងចេះស្រឡាញ់ឲ្យបានគ្រប់លក្ខណៈ យើងជាប់ចិត្តនឹងរបស់របរឥតសណ្តាប់ធ្នាប់ព្រលឹងយើងមិនរីកចម្រើនក្នុងការប្រព្រឹត្តគុណធម៌និងអំពើល្អប្រកបដោយសីលធម៌ទេ ហើយយើងសមនឹងទទួលទោសក្នុងលោកនេះ។ បើយើងប្រព្រឹត្តអំពើបាបស្រាល ដោយចេតនា និងដោយមិនកែប្រែចិត្តគំនិត យើងអាចប្រព្រឹត្តអំពើបាបធ្ងន់បន្តិចម្តងៗ។ ក៏ប៉ុន្តែ ទោះបីយើងប្រព្រឹត្តអំពើបាបស្រាលយ៉ាងណាក៏ដោយ ក៏យើងមិនប្រឆាំងនឹងព្រះហឫទ័យ និងមេត្រីភាពរបស់ព្រះជាម្ចាស់ គឺយើងមិនផ្តាច់សម្ព័ន្ធមេត្រីជាមួយនឹងព្រះអង្គឡើយ។ យើងអាចទូទាត់អំពើបាបស្រាល ដោយមានព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ជួយឧបត្ថម្ភផង។ "ទោះបីយើងប្រព្រឹត្តអំពើបាបស្រាលយ៉ាងណាក៏ដោយ ក៏ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់នៅតែប្រោសយើងឲ្យបានវិសុទ្ធជានិច្ច និងឲ្យទៅជាបុត្រធីតារបស់ព្រះអង្គ ហើយព្រះអង្គនៅតែស្រឡាញ់យើង និងប្រទានសុភមង្គលអស់កល្បជានិច្ចមកយើង" (**RP ១៧**)៖

> មនុស្សមិនអាចចៀសផុតពីអំពើបាបស្រាលបានទេ ទាល់តែគេនៅក្នុងលោកីយ៍នៅឡើយ។ ប៉ុន្តែ អំពើបាបនោះដែលគេហៅថា ស្រាល កុំគិតថាគ្មានផលវិបាកឲ្យសោះ៖ បើអ្នកគិតថាអំពើនោះគ្មានផលវិបាកទេ ពេលអ្នកថ្លឹងអំពើនោះ ចូរញាក់ដៃជើង ពេលអ្នករាប់អំពើនោះ។ របស់ស្រាលៗជាច្រើននឹងក្លាយជាដុំធំមួយ តំណក់ទឹកជាច្រើនបំពេញទន្លេមួយ គ្រាប់ជាច្រើនក្លាយគំនរមួយ។ បើអញ្ចឹង អ្វីទៅជាសេចក្តីសង្ឃឹមរបស់យើង? មុនដំបូង ត្រូវតែសារភាព... (សន្តៈ អូគូស្តាំង)។

១៨៦៤- "អ្នកដែលពោលពាក្យប្រមាថព្រះវិញ្ញាណដ៏វិសុទ្ធវិញ ព្រះអង្គមិនលើកលែងទោសសោះឡើយ ដ្បិតអ្នកនោះមានទោសអស់កល្បជានិច្ច" (មក ៣,២៩) (មថ ១២,៣២ ; លក ១២,១០)។ ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់គ្មានកំណត់ព្រំដែនទេ ប៉ុន្តែ អ្នកដែលបដិសេធដោយចេតនាមិនព្រមទទួលធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ មិនកែប្រែចិត្តគំនិត ហើយបោះបង់ចោលការលើកលែងទោសនៃអំពើបាបរបស់ខ្លួន និងការសង្គ្រោះដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រទាន (**DeV** ៤៦)។ ចិត្តរឹងរូសបែបនេះ នាំឲ្យធ្លាក់នរកបាន។

## ៥. អំពើបាបរាលដាល

១៨៦៥- បើយើងប្រព្រឹត្តអំពើបាប យើងនឹងរឹតតែប្រព្រឹត្តអំពើបាបតទៅទៀត។ អំពើបាបបង្កើតបាបធម៌ដោយប្រព្រឹត្តអំពើដដែលៗ។ ដូច្នេះ យើងមានចិត្តលម្អៀងមិនត្រឹមត្រូវ ដែលធ្វើឲ្យមនសិការយើងងងឹត។ យើង

លែងចេះគិតពិចារណាអំពីអ្វីដ៏ល្អ និងអ្វីដ៏អាក្រក់។ ហេតុនេះហើយ បានជាយើងចេះតែប្រព្រឹត្តអំពើបាបច្រើនឡើងៗ ប៉ុន្តែ អំពើបាបនោះមិនអាចបំផ្លាញមូលដ្ឋានគ្រឹះនៃមនសិការបានឡើយ។

១៨៦៦- យើងអាចរៀបបាបធម៌ជាក្រុមទៅតាមគុណធម៌ដែលបាបធម៌នោះប្រឆាំង ឬយោងតាមអំពើបាបមូលដ្ឋាន ដែលបទពិសោធន៍របស់គ្រីស្តបរិស័ទបានបែងចែក តាមសន្ត: យ៉ូហាន កាស៊ីអាំង និងសន្ត: គ្រេគ័រដ៏ប្រសើរ។ គេហៅអំពើបាបនោះថា ជាអំពើបាបមូលដ្ឋាន ពីព្រោះអំពើបាបនោះបង្កើតអំពើបាប និងបាបធម៌ផ្សេងៗទៀត។ មានចិត្តក្រអឺតក្រទម ចិត្តកំណាញ់ ចិត្តលោភលន់ កំហឹង ចិត្តមិនបរិសុទ្ធ ចិត្តល្មោភស៊ី សេចក្តីខ្ជិលច្រអូស ឬអារម្មណ៍រីងស្ងួត។

១៨៦៧- ការបញ្ជូនបន្តនៃការអប់រំជំនឿរំឭកយើងថា មានអំពើបាបស្រែកលាន់ឮពីដីឡើងដល់លើមេឃ ដូចជាឈាមរបស់លោកអេបិល ( កណ ៤,១០ ) អំពើបាបរបស់អ្នកក្រុងសូដុម ( កណ ១៨,២០ ; ១៩,១៣ ) ទុក្ខលំបាករបស់ប្រជាជននៅស្រុកអេស៊ីប ( សរ ៣,៧-១០ ) ពាក្យតម្អូញរបស់ជនបរទេស ស្ត្រីមេម៉ាយ និងក្មេងកំព្រា ( សរ ២២,២០-២២ ) អំពើអយុត្តិធម៌ចំពោះកម្មករ ( ទក ២៤,១៤-១៥ ; យក ៥,៤ )។

១៨៦៨- អំពើបាបជាអំពើរបស់មនុស្សម្នាក់ៗផ្ទាល់ខ្លួន។ ម្យ៉ាងទៀត យើងទទួលខុសត្រូវចំពោះអំពើបាបដែលអ្នកដទៃប្រព្រឹត្ត គឺនៅពេលដែលយើងរួមសហការជាមួយគេ ៖

- ដោយចូលរួមចំណែកជាមួយគេតែម្តង និងដោយចេតនា
- ដោយបញ្ជាគេ ទូន្មានគេ សរសើរគេ ឬយល់ស្របនឹងគេ
- ដោយមិនបាច់ឲ្យគេដឹង ឬដោយមិនរារាំងគេមិនឲ្យប្រព្រឹត្ត នៅពេលដែលយើងត្រូវតែធ្វើដូច្នេះ
- ដោយការពារពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់

១៨៦៩- ហេតុនេះហើយ បានជាអំពើបាបធ្វើឲ្យមនុស្សទៅជាដៃគូនឹងគ្នាទៅវិញទៅមក ហើយធ្វើឲ្យកិលេសតណ្ហា អំពើហិង្សា និងអយុត្តិធម៌គ្រងរាជ្យរវាងគ្នានិងគ្នា។ អំពើបាបបង្កើតស្ថានភាពក្នុងសង្គម និងស្ថានបនប្រឆាំងនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ "រចនាសម្ព័ន្ធនៃអំពើបាប" សម្តែង និងជាផលវិបាកនៃអំពើបាបរបស់មនុស្សម្នាក់ៗផ្ទាល់ ហើយជំរុញជនរងគ្រោះឲ្យប្រព្រឹត្តអំពើអាក្រក់ដែរ។ក្នុងអត្ថន័យប្រៀបធៀបរចនាសម្ព័ន្ធនោះជា "អំពើបាបនៃសង្គម" ( **RP** ១៦ )។

## សង្ខេប

១៨៧០- "ព្រះជាម្ចាស់បានបណ្តោយឲ្យមនុស្សទាំងអស់មិនស្តាប់បង្គាប់ព្រះអង្គ ដើម្បីសម្តែងព្រះហឫទ័យមេត្តាករុណាដល់មនុស្សទាំងអស់" ( រម ១១,៣២ )។

១៨៧១- អំពើបាបជា "ពាក្យ កិច្ចការ ឬសេចក្តីប្រាថ្នាផ្ទុយនឹងវិន័យអស់លក្សជានិច្ច" ( សន្ត:អូគូស្តាំង )។ អ្នកប្រព្រឹត្តអំពើបាបជំទាស់នឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ អ្នកបាបប្រឆាំងនឹងព្រះជាម្ចាស់ មិនស្តាប់បង្គាប់ព្រះអង្គ ផ្ទុយស្រឡះនឹងព្រះយេស៊ូដែលស្តាប់បង្គាប់ព្រះជាម្ចាស់។

១៨៧២- អំពើបាបជាកិច្ចការប្រឆាំងនឹងប្រាជ្ញា។ អំពើបាបធ្វើឲ្យធម្មជាតិមនុស្ស និងសាមគ្គីភាពរវាងមនុស្សត្រូវរបួស។

១៨៧៣- អំពើបាបចាក់ឫសក្នុងចិត្តមនុស្ស។ជាធម្មតា យើងបែងចែកប្រភេទនៃអំពើបាប ហើយយើងដឹងថា អំពើបាបធ្ងន់ ឬស្រាល តាមគោលដៅ។

១៨៧៤- បើយើងស្ម័គ្រចិត្ត ពោលគឺដោយដឹង និងដោយចង់ ប្រព្រឹត្តអ្វីមួយប្រឆាំងនឹងធម្មវិន័យរបស់ព្រះជាម្ចាស់ ហើយប្រឆាំងនឹងទីចុងក្រោយរបស់មនុស្ស គឺយើងប្រព្រឹត្តអំពើបាប ដែលនាំឲ្យស្លាប់។ អំពើបាបនេះបំផ្លាញសេចក្តីស្រឡាញ់ក្នុងខ្លួនយើង។ បើគ្មានសេចក្តីស្រឡាញ់នោះទេ យើងមិនអាចទទួលសុភមង្គលដ៏ពិតប្រាកដបានឡើយ។ បើយើងមិនសោកស្តាយអំពើបាបនេះ យើងអាចទទួលសេចក្តីស្លាប់អស់កល្បជានិច្ច។

១៨៧៥- អំពើបាបស្រាលបង្ខូចសីលធម៌ ប៉ុន្តែ សេចក្តីស្រឡាញ់អាចទូទាត់អំពើបាបនេះ។ អំពើបាបនេះ មិនបំផ្លាញសេចក្តីស្រឡាញ់ឡើយ។

១៨៧៦- បើយើងប្រព្រឹត្តអំពើបាប ទោះជាស្រាលក៏ដោយក៏យើងនឹងបង្កើតបាបធម៌ ដែលមានអំពើបាបមូលដ្ឋានដែរ។

# ជំពូកទីពីរៈ

# សហគមន៍មនុស្ស

១៨៧៧- ព្រះជាម្ចាស់ត្រាស់ហៅមនុស្សលោកឲ្យសម្តែងរូបតំណាងរបស់ព្រះអង្គ និងបានទៅជារូបតំណាងនៃព្រះបុត្រាតែមួយរបស់ព្រះបិតា។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សគ្រប់រូប ដ្បិតព្រះអង្គត្រាស់ហៅ មនុស្សរាល់គ្នាឲ្យទទួលសុភមង្គលរបស់ព្រះអង្គ ។ក៏ត្រាស់ហៅសហគមន៍ទាំងមូលរបស់មនុស្សផងដែរ។

## ប្រការទី១ៈ

## មនុស្ស និងសង្គម

### ១. ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យរួមរស់ជាមួយគ្នា

១៨៧៨- ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឆ្ពោះទៅទីដៅតែមួយ គឺព្រះអង្គផ្ទាល់។ ពេលមនុស្សរួបរួមគ្នាក្នុងសេចក្តីពិត និងសេចក្តីស្រឡាញ់ គឺគេរួបរួមគ្នាម្យ៉ាង ដូចព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណរួបរួមគ្នាដែរ (GS ២៤,៣)។ សេចក្តីស្រឡាញ់ចំពោះអ្នកដទៃមិនអាចបំបែកពីសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់បានឡើយ។

១៨៧៩- មនុស្សត្រូវការរស់នៅក្នុងសង្គម។ ការរស់នៅក្នុងសង្គមមិនមែនជាសេចក្តីបន្ថែមលើលក្ខណៈនៃជីវិតមនុស្សទេ ប៉ុន្តែជាការទាមទាររបស់ធម្មជាតិ។ មនុស្សរីកចម្រើនគ្រប់វិស័យ នឹងអាចឈានទៅដល់ទីដៅរបស់ខ្លួនបាន ដោយមានទំនាក់ទំនងជាមួយអ្នកដទៃ ដោយជួយបម្រើគ្នាទៅវិញទៅមក និងដោយនិយាយសន្ទនាជាមួយមនុស្សទុកជាបងប្អូន (GS ២៥,១)។

១៨៨០- សង្គម គឺជាសំណុំនៃមនុស្សជាច្រើន ដែលទាក់ទងគ្នា ដូចសរីរាង្គកាយ ដោយគោលការណ៍នៃឯកភាពមួយ ដែលលើសពីបុគ្គលម្នាក់ៗ។ សង្គមមួយជាអង្គប្រជុំដែលមើលឃើញ និងដែលមានលក្ខណៈខាងវិញ្ញាណ ហើយដែលស្ថិតស្ថេរយូរអង្វែង គឺសង្គមទទួលយកអតីតកាលផង រៀបចំអនាគតកាលផង។ ដោយសារ

សង្គម មនុស្សម្នាក់ៗទៅជា "អ្នកទទួលមរតក" ទទួល "ព្រះអំណោយទាន" ដែលធ្វើឲ្យអត្តសញ្ញាណរបស់ខ្លួនរីកចម្រើន ហើយគេត្រូវអភិវឌ្ឍន៍ផលនៃព្រះអំណោយទាននោះ (លក ១៩,១៣.១៥)។ មនុស្សម្នាក់ៗត្រូវតែបម្រើសង្គម ដែលខ្លួនជាសមាជិក និងគោរពអាជ្ញាធរ ដែលទទួលខុសត្រូវលើផលប្រយោជន៍រួម។

១៨៨១- សហគមន៍នីមួយៗមានគោលដៅរបស់ខ្លួន ហើយត្រូវគោរពតាមគោលការណ៍ ប៉ុន្តែ "មនុស្ស ពិតជា និងត្រូវជាដើមកំណើត ជាប្រធានបទ និងជាទីដៅនៃស្ថាប័នសង្គមទាំងអស់" (GS ២៥,១)។

១៨៨២- សង្គមខ្លះ ដូចជាក្រុមគ្រួសារ និងទីក្រុងដែលជាការរស់នៅជាមួយគ្នា ស្របតាមលក្ខណៈរបស់មនុស្សតែម្តង។ មនុស្សត្រូវការសង្គមនោះជាចាំបាច់។ ត្រូវតែលើកទឹកចិត្តឲ្យបង្កើតសហគមន៍ និងស្ថាប័ន "ដែលមានគោលដៅខាងសេដ្ឋកិច្ច ខាងវប្បធម៌ ខាងសង្គម ខាងកីឡា ខាងល្បែងកំសាន្ត ខាងវិជ្ជាជីវៈ ខាងនយោបាយ ក្នុងសហគមន៍ខាងនយោបាយផង ដូចក្នុងពិភពលោកទាំងមូលផងដែរ" (MM ៦០) ដើម្បីឲ្យមនុស្សជាច្រើនចូលរួមចំណែកក្នុងការរស់នៅក្នុងសង្គម។ "ការប្រមូលផ្តុំគ្នាបង្កើតសង្គម "នេះ សម្តែងចិត្តលម្អៀងរបស់មនុស្សឲ្យប្រមូលគ្នាជាសហគមន៍ ដើម្បីបំពេញគោលដៅ ដែលសមត្ថភាពរបស់ម្នាក់ៗមិនអាចធ្វើបាន។ ការប្រមូលផ្តុំគ្នាបង្កើតសង្គមនេះធ្វើឲ្យលក្ខណៈសម្បត្តិរបស់មនុស្សរីកចម្រើនជាពិសេសការផ្តើមគំនិតនិងការទទួលខុសត្រូវ។ ការប្រមូលផ្តុំគ្នាបង្កើតសង្គមនេះ ជួយធានាសិទ្ធិរបស់មនុស្សផងដែរ (GS ២៥,២ ; CA ១២)។

១៨៨៣- ក៏ប៉ុន្តែ ការប្រមូលផ្តុំគ្នាបង្កើតសង្គមអាចបង្កើតវិបត្តិខ្លះផងដែរ។ បើរដ្ឋអំណាចធ្វើអន្តរាគមន៍ច្រើនពេក សេរីភាព និងការផ្តើមគំនិតរបស់មនុស្សអាចថយក្រោយបាន។ លទ្ធិព្រះសហគមន៍បានបង្កើតគោលការណ៍មួយ ដែលគេហៅថាគោលការណ៍នៃជំនួស។ តាមគោលការណ៍នេះ "សង្គមដែលមានកម្រិតខ្ពស់មិនត្រូវធ្វើអន្តរាគមន៍ក្នុងការរស់នៅខាងក្នុងនៃសង្គមដែលមានកម្រិតទាប ដោយដកសមត្ថភាពរបស់ខ្លួនចេញបានទេ ប៉ុន្តែ សង្គមដែលមានកម្រិតខ្ពស់ត្រូវតែគាំទ្រសង្គមដែលមានកម្រិតទាប ក្នុងពេលជាចាំបាច់ និងជួយសង្គមនេះឲ្យចាត់ចែងកិច្ចការរបស់ខ្លួនជាមួយនឹងផ្នែកផ្សេងៗ ដែលមានក្នុងសង្គមនេះ ដើម្បីផលប្រយោជន៍រួម" (CA ៤៨; សម្តេចប៉ាបទី១១)។

១៨៨៤- ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យក្តោបក្តាប់អំណាចទាំងអស់ សម្រាប់តែព្រះអង្គប៉ុណ្ណោះទេ គឺព្រះអង្គប្រគល់ឲ្យសត្វលោកនីមួយៗមុខងារដែលខ្លួនអាចប្រតិបត្តិ តាមសមត្ថភាពនៃលក្ខណៈរបស់ខ្លួនផ្ទាល់។ ការរស់នៅក្នុងសង្គមត្រូវតែយកតម្រាប់តាមរបៀបគ្រប់គ្រងនេះ។ របៀបគ្រប់គ្រងពិភពលោករបស់ព្រះជាម្ចាស់ ផ្តល់សក្ខីភាពថា ព្រះអង្គពិតជាគោរពសេរីភាពរបស់មនុស្ស ដែលគួរបំភ្លឺប្រាជ្ញារបស់អស់អ្នកដែលគ្រប់គ្រងសហគមន៍មនុស្ស។ ពួកគេត្រូវតែប្រព្រឹត្តដូចអ្នកបម្រើនៃឧបការគុណរបស់ព្រះជាម្ចាស់។

១៨៨៥- គោលការណ៍នៃជំនួសប្រឆាំងនឹងសមូហភាពនិយមគ្រប់បែបយ៉ាង និងបង្ហាញកំណត់ព្រំដែននៃអន្តរាគមន៍របស់រដ្ឋអំណាច។ គោលការណ៍នេះ តម្រង់ទិសឲ្យទំនាក់ទំនងរវាងមនុស្ស និងសង្គមរួបរួមជាមួយគ្នាបានល្អប្រសើរ ហើយតម្រង់ទិសឲ្យការចាត់ចែងរបៀបរៀបរយអន្តរជាតិយ៉ាងពិតប្រាកដផងដែរ។

## ២. ការកែប្រែចិត្តគំនិត និងសង្គម

១៨៨៦- សង្គមជាចាំបាច់ ដើម្បីឲ្យការត្រាស់ហៅរបស់មនុស្សបានសម្រេច។ ដើម្បីឈានទៅដល់គោលដៅនេះ គេត្រូវតែគោរពលំដាប់លំដោយដ៏ត្រឹមត្រូវនៃគុណធម៌ ដែលធ្វើឲ្យលក្ខណៈខាងរូបកាយ និងដែលកើតពីសភាវគតិចុះចូលក្រោមលក្ខណៈខាងក្នុង និងខាងវិញ្ញាណ" (CA ៣៦)៖

ជាដំបូង ត្រូវចាត់ទុកការរស់នៅក្នុងសង្គមថា មានលក្ខណៈខាងវិញ្ញាណ។ តាមការពិត ដោយសារការរស់នៅក្នុងសង្គមនេះ យើងផ្លាស់ប្តូរចំណេះដឹងក្នុងពន្លឺនៃសេចក្តីពិត យើងគោរពសិទ្ធិ និងបំពេញភារកិច្ច យើងជំរុញគ្នាទៅវិញទៅមកទៅរកអ្វីដែលល្អ យើងរួបរួមគ្នាក្នុងការប្រើប្រាស់សោភណភាព។ ការរស់នៅក្នុងសង្គមជាលក្ខណៈអចិន្ត្រៃយ៍ ដើម្បីផ្តល់ដល់អ្នកដទៃលក្ខណៈសម្បត្តិរបស់ខ្លួនឯង ហើយជាបំណងរួមឲ្យរីកចម្រើនខាងវិញ្ញាណជានិច្ចនិរន្តរ៍ផង។ នេះគឺជាគុណសម្បត្តិដែលត្រូវតែណែនាំ និងតម្រង់សកម្មភាពខាងវប្បធម៌ ជីវិតខាងសេដ្ឋកិច្ច ការចាត់ចែងនៅក្នុងសង្គម ចលនា និងរបបខាងនយោបាយ ការតែងច្បាប់ ហើយការសម្តែងឯទៀតៗនៃការរស់នៅក្នុងសង្គម ដើម្បីឲ្យសង្គមល្អូតលាស់ជានិច្ច (PT ៣៥)។

១៨៨៧- បើយើងប្រឡំមធ្យោបាយ និងគោលដៅ (CA ៤១) ពោលគឺយើងចាត់ទុកថា មធ្យោបាយជាគោលដៅចុងក្រោយបំផុត ឬយើងចាត់ទុកថា មនុស្សគ្រាន់តែជាមធ្យោបាយសុទ្ធសាធ ដើម្បីបានគោលដៅមួយ យើងបង្កើតរចនាសម្ព័ន្ធអយុត្តិធម៌ "ដែលធ្វើឲ្យយើងមិនអាចប្រតិបត្តិតាមគ្រីស្តសាសនា ស្របតាមបទបញ្ជារបស់ព្រះជាម្ចាស់ជាអ្នកតែងច្បាប់" (សម្តេចប៉ាប ពីយូសទី១២)។

១៨៨៨- ដូច្នេះ មនុស្សត្រូវតែប្រើសមត្ថភាពខាងវិញ្ញាណ និងខាងសីលធម៌ ហើយត្រូវតែកែប្រែចិត្តគំនិតជានិច្ច ដើម្បីបានទទួលការផ្លាស់ប្តូរក្នុងសង្គម ដែលបម្រើមនុស្សពិតមែន។ ទោះបីយើងផ្តល់អាទិភាពដល់ការកែប្រែចិត្តគំនិតយ៉ាងណាក៏ដោយ ក៏យើងមិនលុបបំបាត់ទេ ផ្ទុយទៅវិញយើងចាំចាច់ត្រូវតែកែប្រែ ស្ថាប័ន និងល័ក្ខខ័ណ្ឌនៃការរស់នៅ ដែលបណ្តាលឲ្យប្រព្រឹត្តអំពើបាប ដើម្បីឲ្យស្ថាប័ន និងល័ក្ខខ័ណ្ឌ នោះ ដើម្បីឲ្យសមរម្យត្រឹមត្រូវតាមយុត្តិធម៌ និងជំរុញឲ្យប្រព្រឹត្តអ្វីដ៏ល្អ ជាជាងបង្កើតឧបសគ្គ (LG ៣៦)។

១៨៨៩- បើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់មិនជួយសង្គ្រោះទេ មនុស្សមិនអាច "រកឃើញផ្លូវចង្អៀតរវាងភាពកំសាកដែលចាញ់អំពើអាក្រក់ និងការប្រើអំពើហិង្សា ដើម្បីប្រយុទ្ធអំពើអាក្រក់។ តាមការពិត អ្នកប្រើអំពើហិង្សាពង្រឹងអំពើអាក្រក់" (CA ២៥)។ ផ្លូវនេះ ជាផ្លូវនៃសេចក្តីស្រឡាញ់ ពោលគឺសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងអ្នកដទៃ។ សេចក្តីស្រឡាញ់ជាវិន័យសំខាន់ជាងគេក្នុងសង្គម គឺអ្នកមានចិត្តស្រឡាញ់គោរពអ្នកដទៃ និងសិទ្ធិរបស់គេ ហើយទាមទារឲ្យប្រតិបត្តិតាមយុត្តិធម៌។ មានតែសេចក្តីស្រឡាញ់ទេ ដែលធ្វើឲ្យយើងអាចប្រតិបត្តិតាមយុត្តិធម៌បាន។ សេចក្តីស្រឡាញ់នាំឲ្យគេហ៊ានបូជាជីវិត៖ "អ្នកដែលខិតខំរក្សាជីវិតរបស់ខ្លួន នឹងបាត់បង់ជីវិត រីឯអ្នកដែលបាត់បង់ជីវិត នឹងបានរួចជីវិតវិញ" (លក ១៧,៣៣)។

## សង្ខេប

១៨៩០- ពេលមនុស្សរួបរួមគ្នាក្នុងសេចក្តីពិត និងសេចក្តីស្រឡាញ់ គឺគេរួបរួមគ្នាម្យ៉ាង ដូចព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណរួបរួមគ្នាដែរ។

១៨៩១- ដើម្បីគោរពលក្ខណៈធម្មជាតិរបស់ខ្លួន មនុស្សត្រូវការរស់នៅក្នុងសង្គម។ សង្គមខ្លះ ដូចជាក្រុមគ្រួសារ និងការរស់នៅក្នុងទីក្រុង ដែលសមស្របតាមលក្ខណៈធម្មជាតិរបស់មនុស្ស។

១៨៩២- "មនុស្សពិតជា និងត្រូវជាដើមកំណើត ជាប្រធានបទ និងជាទីដៅនៃស្ថាប័នសង្គមទាំងអស់" (GS២៥,១)។

១៨៩៣- ត្រូវតែលើកទឹកចិត្តឲ្យមនុស្សចូលរួមក្នុងសហគមន៍ និងស្ថាប័ននានា ដែលគេជ្រើសរើស។

១៨៩៤- តាមគោលការណ៍នៃការជំនួស រដ្ឋអំណាច ឬសង្គមដែលមានគម្រិតខ្ពស់ណាមួយ មិនត្រូវធ្វើអន្តរាគមន៍ក្នុងការផ្តើមគំនិត និងការទទួលខុសត្រូវ របស់មនុស្ស ឬសង្គមកណ្តាលឡើយ។

១៨៩៥- សង្គមត្រូវលើកទឹកចិត្តមនុស្សឲ្យប្រតិបត្តិតាមគុណធម៌ ដោយមិនរារាំងគេ។ សង្គមត្រូវតែគោរពតាមលំដាប់លំដោយដ៏ត្រឹមត្រូវនៃឧត្តមគតិ។

១៨៩៦-នៅទីណាអំពើបាបបង្ខូចបរិយាកាសក្នុងសង្គមត្រូវតែសុំឲ្យមនុស្សកែប្រែចិត្តគំនិតនិងឲ្យព្រះជាម្ចាស់ប្រោសប្រណី។ សេចក្តីស្រឡាញ់ជំរុញឲ្យកែតម្រង់សង្គមយ៉ាងត្រឹមត្រូវ។ យើងមិនអាច ដោះស្រាយបញ្ហាក្នុងសង្គម បើពុំមានដំណឹងល្អបានឡើយ (CA ៣)។

# ប្រការទី២៖

# ការរួមចំណែកក្នុងការរស់នៅក្នុងសង្គម

## ១. អំណាច

១៨៩៧- "បើគ្មានមនុស្សប្រកបដោយអំណាចតាមច្បាប់ ដែលជួយការពារស្ថាប័ន និងយកចិត្តទុកដាក់នឹងផលប្រយោជន៍រួម តាមរបៀបត្រឹមត្រូវ ការរស់នៅក្នុងសង្គមមិនអាចមានរបៀបរៀបរយ និងពហុផលបានឡើយ" (PT ៤៦)។

- គេហៅ "អាជ្ញាធរ" លក្ខណៈសម្បត្តិរបស់មនុស្ស ឬស្ថានប័ន ដែលតែងច្បាប់ និងបទបញ្ជា ដើម្បីឲ្យអ្នកដទៃស្តាប់បង្គាប់។

១៨៩៨- សហគមន៍មនុស្សនីមួយៗត្រូវការអាជ្ញាធរ ដើម្បីគ្រប់គ្រងសហគមន៍នោះ (សម្តេចប៉ាប ឡេអុងទី១៣)។ អាជ្ញាធរនេះចាក់ឫសក្នុងលក្ខណៈជាមនុស្ស ជាចាំបាច់ដើម្បីឲ្យមនុស្សរួមជាមួយគ្នាក្នុងសង្គម ហើយមានតួនាទីការពារថែរក្សាប្រយោជន៍រួមនៅក្នុងសង្គម តាមតែអាចធ្វើបាន។

១៨៩៩-របៀបរៀបរយនៃសីលធម៌ទាមទារឲ្យមានអាជ្ញាធរ។អំណាចនេះមកពីព្រះជាម្ចាស់៖"មនុស្សគ្រប់ៗរូបត្រូវស្តាប់បង្គាប់អាជ្ញាធរ ដ្បិតអំណាចទាំងឡាយសុទ្ធតែមកពីព្រះជាម្ចាស់ គឺព្រះអង្គបានតែងតាំងឲ្យមានអំណាចទាំងនោះឡើង។ ដូច្នេះ អ្នកដែលប្រឆាំងនឹងអាជ្ញាធរ ក៏ដូចជាប្រឆាំងនឹងរបៀបរៀបរយដែលព្រះជាម្ចាស់បានចាត់ចែងនោះដែរ ហើយអ្នក ដែលប្រឆាំង មុខជាធ្វើឲ្យខ្លួនមានទោសមិន ខានឡើយ (រម ១៣,១-២) (១ពត្រ ២,១៣-១៧)។

១៩០០- មនុស្សទាំងអស់ត្រូវតែស្តាប់បង្គាប់ គឺផ្តល់កិត្តិយសដ៏ត្រឹមត្រូវដល់អាជ្ញាធរ ត្រូវគោរព និងដឹងគុណដោយចិត្តសប្បុរស អស់អ្នកដែលបានទទួលបន្ទុកនេះ តាមគុណរបស់គេ។

សម្តេចប៉ាបសន្តៈក្លេម៉ងនៅទីក្រុងរ៉ូមបានសរសេរសេចក្តីអង្វរបុរាណជាងគេនៃព្រះសហគមន៍ ដើម្បីអាជ្ញាធរនយោបាយ៖

> "ឱព្រះអម្ចាស់អើយ! សូមប្រោសប្រទានឲ្យគាត់មានសុខភាព សន្តិភាព ឲ្យគាត់ចេះរួមគ្នាជាធ្លុងតែមួយ និងហើយគាត់មានស្ថិរភាព ដើម្បីឲ្យគាត់ប្រតិបត្តិតាមអំណាចដ៏ខ្ពង់ខ្ពស់ ដែលព្រះអង្គបាន បញ្ជូនឲ្យគាត់។ គឺព្រះអង្គនេះហើយ ជាអម្ចាស់ ជាព្រះមហាក្សត្រនៃស្ថានបរមសុខ ដែលប្រទានឲ្យបុត្រមនុស្សនូវសិរី

រុងរឿង កិត្តិយស និងអំណាចនៅលើផែនដី។ សូមព្រះអម្ចាស់ណែនាំការគ្រប់គ្រងរបស់គាត់ តាមអ្វីដ៏ល្អ តាមអ្វីគាប់ព្រះហឫទ័យព្រះអង្គ ដើម្បីឲ្យគាត់ប្រតិបត្តិតាមអំណាច ដែលព្រះអង្គបានប្រទាន ឲ្យគាត់ដោយគោរពប្រណិប័តន៍ព្រះអង្គ ពោរពេញដោយសេចក្តីសុខសាន្ត និងដោយមានចិត្តស្លូតបូត ហើយដើម្បីឲ្យព្រះអង្គសព្វព្រះហឫទ័យនឹងគាត់ផង។

១៩០១- ទោះបីព្រះជាម្ចាស់បានតែងតាំងអំណាច តាមរបៀបរៀបរយរបស់ព្រះអង្គ យ៉ាងណាក៏ដោយ ក៏ "ចំពោះការកំណត់របបនយោបាយ និងការជ្រើសរើសអ្នកដឹកនាំប្រទេសវិញ ត្រូវតែឲ្យប្រជាពលរដ្ឋជ្រើសរើសដោយសេរី តាមបំណងរបស់គេទៅចុះ" (GS ៧៤,៣)។

- យើងអាចមានរបបនយោបាយប្លែកៗពីគ្នាជាច្រើន លុះត្រាតែរបបទាំងអស់នោះស្វែងរកផលប្រយោជន៍ដ៏ត្រឹមត្រូវឲ្យសហគមន៍ដែលទទួលយករបបនោះ។ របបដែលមានលក្ខណៈប្រឆាំងនឹងធម្មវិន័យធម្មជាតិ របៀបរៀបរយជាសាធារណៈ និងសិទ្ធិមនុស្សជាគ្រឹះ មិនអាចសម្រេចប្រយោជន៍រួមរបស់ប្រជាជាតិ ដែលរបបនោះដឹកនាំដោយបង្ខិតបង្ខំ។

១៩០២- អាជ្ញាធរមិនត្រូវតែងច្បាប់ខាងសីលធម៌ដោយខ្លួនផ្ទាល់ទេ។ អាជ្ញាធរមិនត្រូវត្រួតត្រាបែបផ្តាច់ការទេ ប៉ុន្តែ ត្រូវប្រព្រឹត្តដើម្បីផលប្រយោជន៍រួម "ហាក់ដូចជាកម្លាំងខាងវិញ្ញាណ ដែលសំអាងលើសេរីភាព និងលើគំនិតរបស់មនុស្សទទួលខុសត្រូវ" (GS ៧៤,២)៖

ច្បាប់ទាំងមូលរបស់មនុស្សមានលក្ខណៈជាច្បាប់ លុះត្រាតែការតែងច្បាប់នេះ ស្របតាមប្រាជ្ញា ដែលយល់ថាត្រឹមត្រូវ។ ដូច្នេះ ការតែងច្បាប់យកកម្លាំងរបស់ខ្លួនចេញមកពីធម្មវិន័យអស់កល្បជានិច្ច។ ក្នុងករណីដែលច្បាប់ឃ្លាតចេញពីប្រាជ្ញា ត្រូវតែប្រកាសថា ច្បាប់នេះមិនត្រឹមត្រូវទេ ដ្បិតប្រឆាំងនឹងលក្ខណៈរបស់ធម្មវិ ន័យ។ ការតែងច្បាប់បែបនេះ ដូចជាអំពើហិង្សាម្យ៉ាង (សន្ត: ថូម៉ាស នៃអាកាំង)។

១៩០៣- អាជ្ញាធរប្រព្រឹត្តត្រឹមត្រូវ លុះត្រាតែគេស្វែងរកប្រយោជន៍រួមរបស់ក្រុម ដែលគេគ្រប់គ្រង ហើយបើគេប្រើមធ្យោបាយត្រឹមត្រូវតាមច្បាប់សីលធម៌ ដើម្បីបានផលប្រយោជន៍នេះ។ បើមេដឹកនាំអនុម័តច្បាប់អយុត្តិធម៌ ឬបើគេចាត់វិធានការប្រឆាំងនឹងរបៀបរៀបរយនៃសីលធម៌ យើងមានសិទ្ធិមិនស្តាប់បង្គាប់ឡើយ។"ក្នុងករណីនេះ អាជ្ញាធរលែងជាអាជ្ញាធរ និងធ្លាក់ខ្លួនទៅជាសង្កត់សង្កិនជិះជាន់មនុស្សទៅវិញ" (PT ៥១)។

១៩០៤- "អំណាច និងសមត្ថកិច្ចផ្សេងៗគួរប្រឆាំងនឹងអំណាចនីមួយៗ ដើម្បីឲ្យអំណាចនោះស្ថិតក្នុងកំណត់ព្រំដែនដ៏ត្រឹមត្រូវ។ ស្របតាមគោលការណ៍នៃ "នីតិរដ្ឋ" ច្បាប់ជាអ្នកកាន់អំណាច មិនមែនបំណងផ្តាច់ការរបស់មនុស្សឡើយ" (CA ៤៤)។

## ២. ផលប្រយោជន៍រួម

១៩០៥- ផលប្រយោជន៍របស់ម្នាក់ៗពិតជាទាក់ទងនឹងផលប្រយោជន៍រួម ស្របតាមលក្ខណៈរបស់មនុស្សដែលរស់នៅក្នុងសង្គម។ ត្រូវកំណត់ផលប្រយោជន៍រួមយោងតាមមនុស្សម្នាក់ៗ៖

កុំរស់នៅតែម្នាក់ឯង ដូចជាមនុស្សតែលតោល ហាក់ដូចជាព្រះជាម្ចាស់បានប្រោសអ្នករាល់គ្នាឲ្យបានសុចរិតរួចហើយ ប៉ុន្តែ ចូរប្រមូលផ្តុំគ្នា ដើម្បីស្វែងរកប្រយោជន៍រួម (លោក បាណាបាស)។

១៩០៦- ពាក្យ "ប្រយោជន៍រួម" មានន័យថា "លក្ខណៈទាំងប៉ុន្មានក្នុងសង្គម ដែលហុចឲ្យទាំងក្រុមផ្សេងៗ

ព្រមទាំងសមាជិកនីមួយៗនៃក្រុមទាំងនោះ អាចបានពេញលក្ខណៈគ្រប់គ្រាន់ និងធូរធារ" (GS ២៦,១)។ ក្នុងការរស់នៅ មនុស្សទាំងអស់ចាប់អារម្មណ៍នឹងផលប្រយោជន៍រួម។ មនុស្សម្នាក់ៗជាពិសេសអស់អ្នក កាន់អំណាចត្រូវប្រុងប្រយ័ត្ន ដើម្បីបានប្រយោជន៍រួម។ ផលប្រយោជន៍រួមមានលក្ខណៈចាំបាច់បីយ៉ាង ៖

១៩០៧- មុនដំបូង ត្រូវតែគោរពសិទ្ធិបុគ្គលនីមួយៗ។ ក្នុងនាមនៃប្រយោជន៍រួម អាជ្ញាធរត្រូវតែគោរពសិទ្ធិមនុស្សជាគ្រឹះ ដែលមិនអាចលក់ដូរបានទេ។ សង្គមត្រូវឲ្យសមាជិករបស់ខ្លួនម្នាក់ៗបំពេញការត្រាស់ហៅរបស់ខ្លួន។ ជាពិសេស ប្រយោជន៍រួមស្ថិតនៅក្នុងល័ក្ខខ័ណ្ឌគោរពសេរីភាពពីកំណើត ដែលជាចាំបាច់ ដើម្បីឲ្យការត្រាស់ហៅរបស់មនុស្សរីកចម្រើន៖ "មានសិទ្ធិធ្វើតាមមនសិការដ៏ត្រឹមត្រូវរបស់ខ្លួន មានសិទ្ធការពារជីវភាពផ្ទាល់ខ្លួន និងមានសេរីភាពត្រឹមត្រូវ មានសេរីភាពខាងសាសនាជាដើម" (GS ២៦,២)។

១៩០៨- ទីពីរ ប្រយោជន៍រួមទាមទារឲ្យមនុស្សរស់នៅក្នុងសង្គមប្រកបដោយសុខុមាលភាព ហើយឲ្យក្រុមរបស់ខ្លួនរីករចម្រើន។ ការអភិវឌ្ឍន៍ជាសេចក្ដីសង្ខេបនៃភារកិច្ចទាំងអស់នៃសង្គម។ ក្នុងនាមប្រយោជន៍រួម អាជ្ញាធរពិតជាត្រូវតែសម្រេចចិត្តរវាងប្រយោជន៍បុគ្គលផ្សេងៗ ប៉ុន្តែ ត្រូវរកមធ្យោបាយធ្វើយ៉ាងណាឲ្យមនុស្សអាចឈានទៅដល់អ្វីៗដែលខ្លួនត្រូវការ ដើម្បីរស់នៅសមរម្យនឹងឋានៈខ្លួនជាមនុស្សដ៏ពិតប្រាកដ។ ឧ-ឲ្យគេមានចំណីអាហារ សម្លៀកបំពាក់ ផ្ទះនៅ សិទ្ធិជ្រើសរើសរបៀបរស់នៅ សិទ្ធិក្នុងការបង្កើតក្រុមគ្រួសារជាដើម (GS ២៦,២)។

១៩០៩-ត្រូវឲ្យមានសន្តិភាពគឺឲ្យមានរបៀបរៀបរយដ៏ត្រឹមត្រូវយូរអង្វែង និងប្រកបដោយ សុវត្ថិភាពត្រឹមត្រូវ ដើម្បីបានប្រយោជន៍រួម។ ដូច្នេះ អាជ្ញាធរត្រូវតែធានាសន្តិសុខ នៅក្នុងសង្គម និងចំពោះសមាជិកម្នាក់ៗរបស់សង្គមនេះ ដោយប្រើមធ្យោបាយត្រឹមត្រូវ។ ម្យ៉ាងទៀត ដោយសារប្រយោជន៍រួម ម្នាក់ៗ និងទាំងអស់គ្នាមានសិទ្ធិការពារខ្លួនឯងផងដែរ។

១៩១០- បើសហគមន៍មនុស្សនីមួយៗមានផលប្រយោជន៍រួម ដែលជាអត្តសញ្ញាណរបស់ខ្លួន សហគមន៍នយោបាយ ក៏បំពេញប្រយោជន៍រួមឲ្យបានពេញលក្ខណៈ។ រដ្ឋអំណាចត្រូវតែការពារ និងពង្រឹងផលប្រយោជន៍រួមនៃសង្គមស៊ីវិល ប្រជាពលរដ្ឋ និងរបស់ក្រុមកណ្ដាល។

១៩១១- មនុស្សពឹងផ្អែកលើគ្នាទៅវិញទៅមកកាន់តែច្រើនឡើងៗរហូតដល់ផែនដីទាំងមូល។ ត្រូវតែមានប្រយោជន៍រួមសកល ដើម្បីឲ្យក្រុមគ្រួសារមនុស្ស ដែលប្រមូលផ្ដុំសត្វលោកដែលមានឋានៈខាងធម្មជាតិស្មើគ្នារួមឯកភាពជាមួយគ្នា។ ដោយសារប្រយោជន៍រួមសកលនេះ សហគមន៍ប្រជាជាតិត្រូវតែផ្គត់ផ្គង់ "នូវតម្រូវការនានារបស់មនុស្ស ក្នុងវិស័យសង្គម ពោលគឺផ្គត់ផ្គង់ស្បៀងអាហារ សុខាភិបាល ការអប់រំ... ហើយក៏ត្រូវមានសមត្ថភាពអាចប្រឈមមុខនឹងសភាពការណ៍ពិសេសដែលកើតក្នុងតំបន់ខ្លះ ឧ- ជួយសម្រាលទុក្ខជនភៀសខ្លួនដែលខ្ចាត់ខ្ចាយក្នុងពិភពលោកទាំងមូល ឬផ្ដល់ជំនួយដល់ជនអន្តោប្រវេសន៍និងក្រុមគ្រួសារគេផង" (GS ៨៤,២)។

១៩១២- ប្រយោជន៍រួមតែងតែតម្រូវឲ្យមនុស្សរីកចម្រើនជានិច្ច៖ "វត្ថុត្រូវស្ថិតនៅក្រោមចំណុះរបស់បុគ្គល បុគ្គលមិនត្រូវស្ថិតនៅក្រោមចំណុះរបស់វត្ថុទេ" (GS ២៦,៣)។ របៀបរៀបរយនេះ មានសេចក្ដីពិតជាមូលដ្ឋានដែលមានរបៀបរៀបរយយ៉ាងត្រឹមត្រូវ និងមានជីវិតដោយសារសេចក្ដីស្រឡាញ់។

## ៣. ការទទួលខុសត្រូវ និងការចូលរួមចំណែក

១៩១៣- មនុស្សចូលរួមចំណែកក្នុងសង្គម នៅពេលដែលគេស្ម័គ្រចិត្តចូលរួមដោយចិត្តសប្បុរសក្នុងការផ្លាស់ប្ដូរសង្គម។ មនុស្សទាំងអស់ចាំបាច់ត្រូវតែរួមចំណែកតាមមុខងារ និងតួនាទីរបស់ខ្លួន ដើម្បីពង្រឹងប្រយោជន៍

រួម។ ភារកិច្ចនេះ មកពីលក្ខណៈនៃឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស។

១៩១៤- ជាដំបូង មនុស្សរួមចំណែក នៅពេលដែលខ្លួនគេផ្ទាល់ទទួលខុសត្រូវ លើវិស័យផ្សេងៗ គឺដោយផ្គត់ផ្គង់អប់រំក្រុមគ្រួសាររបស់ខ្លួន ដោយសារមនសិការក្នុងការងារ មនុស្សរួមចំណែកក្នុងប្រយោជន៍អ្នកដទៃ និងរបស់សង្គម (CA ៤៣)។

១៩១៥- ប្រជាពលរដ្ឋត្រូវព្យាយាមចូលរួមយ៉ាងសកម្មក្នុងការរស់នៅជាសាធារណៈ។ របៀបនៃការចូលរួមចំណែកនេះ អាចផ្លាស់ប្ដូរពីប្រទេសមួយទៅប្រទេសមួយ ឬពីវប្បធម៌មួយទៅវប្បធម៌មួយ។ "ត្រូវសរសើរប្រជាជាតិខ្លះ ដែលដឹកនាំប្រជាពលរដ្ឋជាច្រើនឲ្យរួមចំណែកក្នុងកិច្ចការរដ្ឋ ដោយមានសេរីភាពយ៉ាងពិតប្រាកដ" (GS ៣១,៣)។

១៩១៦- ដូចភារកិច្ចខាងសីលធម៌ឯទៀតៗ ភាគីក្នុងសង្គមត្រូវតែកែប្រែចិត្តគំនិត ជានិច្ច ដើម្បីឲ្យមនុស្សទាំងអស់រួមចំណែកក្នុងការប្រព្រឹត្តប្រយោជន៍រួម។ ត្រូវតែដាក់ទោសយ៉ាងម៉ឺងម៉ាត់លើអស់អ្នកដែលបន្លំ និងប្រើកលល្បិចផ្សេងៗ ដើម្បីគេចពីច្បាប់ និងកាតព្វកិច្ចរបស់សង្គម ដែលផ្ទុយស្រឡះនឹងការទាមទាររបស់យុត្តិធម៌។ ត្រូវតែយកចិត្តទុកដាក់នឹងការលូតលាស់របស់ស្ថាប័ន ដែលធ្វើឲ្យល័ក្ខខ័ណ្ឌនៃជីវភាពរបស់មនុស្សបានប្រសើរឡើង (GS ៣០,១)។

១៩១៧- អស់អ្នក ដែលមានបន្ទុកប្រកបដោយអំណាច ត្រូវតែពង្រឹងគុណធម៌ ដែលទាក់ទាញទំនុកចិត្តរបស់សមាជិកនៃក្រុមនានា ហើយជំរុញគេឲ្យបម្រើអ្នកដទៃ។ ការចូលរួមចំណែកចាប់ផ្ដើមក្នុងការអប់រំ និងវប្បធម៌។ "គួរឲ្យនឹកយ៉ាងត្រឹមត្រូវថា អនាគតស្ថិតនៅលើអស់អ្នកដែលផ្ដល់ឲ្យមនុស្សតំណក្រោយៗ មានមូលហេតុអាចរស់នៅ និងសង្ឃឹមបាន" (GS ៣១,៣)។

## សង្ខេប

១៩១៨- "អំណាចទាំងឡាយសុទ្ធតែមកពីព្រះជាម្ចាស់ គឺព្រះអង្គបានតែងតាំងឲ្យមានអំណាចទាំងប៉ុន្មានឡើង" (រម ៣១,១)។

១៩១៩- សហគមន៍មនុស្សទាំងអស់ត្រូវការអាជ្ញាធរ ដើម្បីឲ្យសង្គមនេះបន្តតទៅទៀត និងរីកចម្រើនផង។

១៩២០- "សហគមន៍នយោបាយ និងរដ្ឋអំណាចមានគ្រឹះយ៉ាងជាក់ច្បាស់ ទៅតាមលក្ខណៈរបស់មនុស្ស។ បើដូច្នេះមែន សហគមន៍នយោបាយនិងរដ្ឋអំណាចក៏ហូរមកពីរបៀបរៀបរយ ដែលព្រះជាម្ចាស់បានតែងតាំងហើយនោះដែរ" (GS ៧៤,៣)។

១៩២១- អាជ្ញាធរប្រព្រឹត្តត្រឹមត្រូវ លុះត្រាតែគេស្វែងរកប្រយោជន៍រួមរបស់សង្គម។ អាជ្ញាធរត្រូវតែប្រើមធ្យោបាយត្រឹមត្រូវតាមសីលធម៌ ដើម្បីបានផលប្រយោជន៍នោះ។

១៩២២- យើងអាចមានរបបនយោបាយប្លែកៗពីគ្នាជាច្រើន លុះត្រាតែរបបទាំងអស់នោះស្វែងរកផលប្រយោជន៍ដ៏ត្រឹមត្រូវឲ្យសហគមន៍ដែលទទួលយករបបនោះ។

១៩២៣- រដ្ឋអំណាចត្រូវប្រតិបត្តិតាមសីលធម៌ និងធានាឲ្យអាចប្រព្រឹត្តតាមសេរីភាព។

១៩២៤-"ពាក្យ"ប្រយោជន៍រួម"មានន័យថា"លក្ខណៈទាំងប៉ុន្មានក្នុងសង្គមដែលហុចផលឲ្យទាំងក្រុមផ្សេងៗ ទាំងសមាជិកនីមួយៗនៃក្រុមទាំងនោះ អាចបានពេញលក្ខណៈកាន់តែពេញលេញនិងកាន់តែងាយស្រួល" (GS

២៦,១)។

១៩២៥- ផលប្រយោជន៍រួមមានលក្ខណៈចាំបាច់បីយ៉ាង ៖ ការគោរព និងការលើកទឹកចិត្តសិទ្ធិគ្រឹះរបស់មនុស្ស សេចក្ដីសុខសាន្ត និងការអភិវឌ្ឍន៍នៃទ្រព្យខាងវិញ្ញាណ និងខាងលោកីយ៍របស់សង្គម សន្តិភាព និងសន្តិសុខរបស់ក្រុម និងសមាជិកក្រុមនោះ។

១៩២៦- ត្រូវតែស្វែករកផលប្រយោជន៍រួមស្របតាមឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស។ ម្នាក់ៗត្រូវតែយកចិត្តទុកដាក់ជំរុញ និងគាំទ្រស្ថាប័ន ដែលធ្វើឲ្យលក្ខខ័ណ្ឌនៃការរស់នៅរបស់មនុស្សរីកចម្រើន។

១៩២៧- រដ្ឋអំណាចត្រូវតែការពារ និងពង្រឹងផលប្រយោជន៍រួមនៃសង្គមស៊ីវិល។ ត្រូវតែចាត់ចែងសង្គមអន្តរជាតិ ដើម្បីបានផលប្រយោជន៍ក្រុមគ្រួសារទាំងមូលរបស់មនុស្ស។

## ប្រការទី៣៖

## យុត្តិធម៌នៅក្នុងសង្គម

១៩២៨- មានយុត្តិធម៌នៅក្នុងសង្គម នៅពេលដែលសង្គមនេះ បំពេញល័ក្ខខ័ណ្ឌ ដែលផ្ដល់ឲ្យសហគមន៍ និងបុគ្គលម្នាក់ៗ អាចទទួលអ្វីដែលគេមានសិទ្ធិទទួល តាមលក្ខណៈ និងការត្រាស់ហៅរបស់គេរៀងៗខ្លួន។ យុត្តិធម៌ក្នុងសង្គមទាក់ទងនឹងប្រយោជន៍រួម និងការប្រព្រឹត្តអំណាច។

### ១. ការគោរពមនុស្សទុកជាបុគ្គល

១៩២៩- មានតែនៅពេលដែលសង្គមគោរពឋានៈដ៏ថ្លៃថ្នូរបំផុតរបស់មនុស្ស ទើបអាចមានយុត្តិធម៌ក្នុងសង្គមបាន។ មនុស្សជាគោលដៅចុងក្រោយបំផុតនៃសង្គម។ សង្គមចុះក្រោមមនុស្ស៖

> ព្រះបង្កើតបានប្រគល់ឲ្យយើងការពារ និងលើកកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស។ ក្នុងកាលៈទេសៈទាំងអស់នៃប្រវត្តិសាស្ត្រ បុរស និងស្ត្រីពិតជាទទួលខុសត្រូវ និងជំពាក់ចិត្តចំពោះភារកិច្ចនេះយ៉ាងមោះមុត (SRS ៤៧)។

១៩៣០- បើយើងគោរពមនុស្សទុកជាបុគ្គល យើងក៏ត្រូវតែគោរពសិទ្ធិដែលហូរចេញពីកិត្តិយសដ៏ថ្លៃថ្នូររបស់គេទុកជាសត្វលោក។ សង្គមត្រូវតែគោរពសិទ្ធិទាំងអស់នោះ ដែលកើតឡើងមុនសង្គមទៅទៀត។ សិទ្ធិនោះជាមូលដ្ឋានគ្រឹះខាងសីលធម៌នៃអំណាចនីមួយៗ គឺបើសង្គមណាមួយប្រមាថ ឬបដិសេធមិនព្រមទទួលស្គាល់សិទ្ធិទាំងអស់នោះក្នុងការតែងច្បាប់ទេ សង្គមនោះ មិនត្រូវតាមសីលធម៌សោះ (PT ៦៥)។ បើអំណាចណាមួយមិនគោរពសិទ្ធិទាំងអស់នោះ អាជ្ញាធរមិនអាចអាងលើកម្លាំង ឬអំពើហិង្សា ដើម្បីឲ្យប្រជាពលរដ្ឋស្ដាប់បង្គាប់គេបានឡើយ។ ព្រះសហគមន៍ត្រូវរំឭក ហើយវែកញែកសិទ្ធិទាំងអស់នោះចំពោះមនុស្សគ្រប់គ្នា ដែលមានឆន្ទៈល្អដើម្បីកុំឲ្យមានការទាមទារសិទ្ធិហួសហេតុ ឬក្លែងក្លាយ។

១៩៣១- ដើម្បីគោរពមនុស្សទុកជាបុគ្គល ត្រូវតែអនុវត្តតាមគោលការណ៍ "សូមឲ្យមនុស្សគ្រប់គ្នារាប់អានអ្នកដទៃ ដោយគ្មានលើកលែង ទុកដូចជា "ខ្លួនឯងម្នាក់ទៀត" គឺសូមនឹកគិតដល់ការរស់នៅរបស់គេ នឹកគិតដល់អ្វីៗដែលគេត្រូវការ ដើម្បីមានជីវភាពយ៉ាងថ្លៃថ្នូរ" (GS ២៧,១)។ គ្មានច្បាប់ណាមួយអាចលុបបំបាត់ការភ័យខ្លាច ការវិនិច្ឆ័យជាមុន ការអួតបំប៉ោង និងការគិតតែពីខ្លួនឯង ដែលជាឧបសគ្គមិនឲ្យ កសាងសង្គម ដែលមនុស្ស

រាប់អានគ្នាដូចបងប្អូនពិតៗ។ មនុស្សលែងកាន់អាកប្បកិរិយាទាំងអស់នោះ នៅពេលដែលគេស្រឡាញ់មនុស្សម្នាក់ៗទុកជា "បងប្អូន"។

១៩៣២- ត្រូវតែប្រញាប់តាំងខ្លួនជាបងប្អូនរបស់អ្នកដទៃ និងបម្រើគេយ៉ាងសកម្ម ជាពិសេសចំពោះមនុស្សកម្សត់ទុរគត ទោះជាវិស័យណាក៏ដោយ។ "គ្រប់ពេលដែលអ្នករាល់គ្នាបានប្រព្រឹត្តអំពើទាំងនោះ ចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ ដែលជាបងប្អូនរបស់យើងនេះ អ្នករាល់គ្នាក៏ដូចជាបានប្រព្រឹត្តចំពោះយើងដែរ" (មថ ២៥,៤០)។

១៩៣៣- អស់អ្នកដែលគិត ឬប្រព្រឹត្តតាមរបៀបផ្សេងពីយើងក៏មានភារកិច្ចដដែលនេះដែរ។ ព្រះគ្រីស្តប្រៀនប្រដៅយើងរហូតដល់សូមព្រះជាម្ចាស់លើកលែងទោសឲ្យគេ និងបង្ហាញវិន័យអំពីសេចក្តីស្រឡាញ់ ជាវិន័យនៃធម្មវិន័យថ្មី រហូតដល់ស្រឡាញ់ខ្មាំងសត្រូវទាំងអស់ទៀតផង (មថ ៥,៤៣-៤៤)។បើយើងស្អប់ខ្មាំងសត្រូវក្នុងឋានៈជាមនុស្ស យើងមិនអាចទទួលសេរីភាពនៃដំណឹងល្អបានទេ ប៉ុន្តែ បើយើងស្អប់អំពើអាក្រក់ដែលគេបានប្រព្រឹត្តក្នុងឋានៈជាសត្រូវ យើងអាចទទួលសេរីភាពនេះបាន។

## ២. មនុស្សស្មើគ្នាផង ខុសប្លែកគ្នាផង

១៩៣៤- មនុស្សទាំងអស់សុទ្ធតែមានវិញ្ញាណចេះគិតគូរ។ ព្រះជាម្ចាស់បង្កើតមនុស្សឲ្យមានលក្ខណៈដូចព្រះអង្គ។ គេមានសភាពតែមួយ និងដើមកំណើតតែមួយដែរ។ ដោយសារសក្ការបូជារបស់ព្រះអង្គ ព្រះគ្រីស្តបានលោះគេទាំងអស់គ្នា។ ព្រះជាម្ចាស់ក៏ត្រាស់ហៅគេឲ្យរួមចំណែកក្នុងសុភមង្គលតែមួយ គឺសុភមង្គលរបស់ព្រះជាម្ចាស់៖ ហេតុនេះហើយ បានជាមនុស្សទាំងអស់មានកិត្តិយសស្មើគ្នា។

១៩៣៥- មនុស្សទាំងអស់ស្មើគ្នា ជាពិសេសដោយសារកិត្តិយសដ៏ថ្លៃថ្នូររបស់ខ្លួន និងសិទ្ធិដែលហូរចេញមកពីកិត្តិយសនេះ៖

> ការរើសអើងទាំងអស់ ដែលទាក់ទងនឹងភេទ ពូជសាសន៍ ពណ៌សម្បុរស្បែក ឋានៈក្នុងសង្គម ភាសា ឬសាសនា ត្រូវតែបំបាត់ ពីព្រោះជាអំពើ ដែលផ្ទុយនឹងព្រះបំណងនៃព្រះជាម្ចាស់ (GS ២៩,២)។

១៩៣៦- ក្នុងលោកនេះ មនុស្សកើតមកដោយគ្មានអ្វីៗទាំងអស់ ដែលចាំបាច់អភិវឌ្ឍជីវិតរបស់ខ្លួន ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត។ គេត្រូវការអ្នកដទៃ។ មនុស្សប្លែកពីគ្នាតាមវ័យ តាមសមត្ថភាពខាងផ្លូវកាយ តាមប្រាជ្ញា តាមសីលធម៌ តាមអ្វីដែលខ្លួនបានទទួល តាមទ្រព្យសម្បត្តិ (GS ២៩,២)។ ព្រះជាម្ចាស់មិនបានចែក "ព្រះអំណោយទាន" ឲ្យមនុស្សស្មើគ្នាឡើយ (មថ ២៥,១៤-៣០ ; លក ១៩,១១-២៧)។

១៩៣៧- ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សប្លែកពីគ្នា និងឲ្យម្នាក់ៗទទួលពីអ្នកដទៃនូវអ្វីដែលខ្លួនត្រូវការ ហើយព្រះអង្គឲ្យអស់អ្នកដែលមាន "ព្រះអំណោយទាន" ផ្តល់ផលផ្លែនៃព្រះអំណោយទាននោះឲ្យអស់អ្នកដែលត្រូវការ។ ដោយសារមនុស្សប្លែកពីគ្នា មនុស្សត្រូវតែមានចិត្តសប្បុរស ចេះយោគយល់គ្នាទៅវិញទៅមក និងចែករំលែកដល់អ្នកដទៃ ហើយទទួលវប្បធម៌នានាពីគ្នាទៅវិញទៅមកផងដែរ៖

> យើងមិនប្រទានគុណធម៌ទាំងអស់ឲ្យម្នាក់ៗស្មើគ្នាឡើយ (...)។ មានគុណធម៌ជាច្រើន ដែលយើងចែកទៅឲ្យអ្នកនេះខ្លះ អ្នកនោះខ្លះ តាមរបៀបណាក៏ដោយ (...)។ ចំពោះអ្នកនេះ យើងប្រទានសេចក្តីស្រឡាញ់ ចំពោះអ្នកនោះ សេចក្តីសុចរិត ចំពោះអ្នកនេះទៀត ឲ្យគេចេះបន្ទាបខ្លួន ចំពោះអ្នកនោះទៀត ជំនឿដ៏រស់រវើក (...)។ ឯទ្រព្យសម្បត្តិលោកីយ៍ ដែលជាចាំបាច់សម្រាប់ជីវភាពមនុស្ស យើងមិនបាន

ចែកឲ្យស្មើគ្នាទេ ហើយយើងមិនសព្វព្រះហឫទ័យឲ្យម្នាក់ៗមានអ្វីដែលខ្លួនត្រូវការជាចាំបាច់ ដើម្បីឲ្យមនុស្សមានឱកាសនឹងបំពេញសប្បុរសធម៌ចំពោះគ្នាទៅវិញទៅមក (...)។ យើងសព្វព្រះហឫទ័យឲ្យមនុស្សត្រូវការគ្នាទៅវិញទៅមក ហើយឲ្យគេទៅជាអ្នកបម្រើរបស់យើង ដើម្បីចែកព្រះអំណោយទានដែលគេបានទទួលពីយើង (សន្តី កាតឺរីន នៅស៊ីយ៉ែន)។

១៩៣៨- ម្យ៉ាងទៀត មានបុរស និងស្ត្រីរាប់លាននាក់មិនស្មើគ្នាដោយសារមូលហេតុផ្សេងទៀតដ៏អាក្រក់ ហើយដែលផ្ទុយស្រឡះនឹងដំណឹងល្អ៖

មនុស្សមានកិត្តិយសដ៏ថ្លៃថ្នូរស្មើគ្នា ហេតុនេះត្រូវទាមទារឲ្យមនុស្សមានជីវភាពត្រឹមត្រូវ និងតាមលក្ខណៈរបស់ខ្លួនជាមនុស្សកាន់តែខ្លាំងឡើងៗ។ សេដ្ឋកិច្ច និងសង្គមកិច្ច មានភាពខុសគ្នាឆ្ងាយហួសហេតុពេកនៃសមាជិក ឬប្រជាជន ដែលជាក្រុមគ្រួសារតែមួយ ជាហេតុនាំឲ្យកើតរឿងអាស្រូវ។ ភាពមិនស្មើគ្នាជ្រុលហួសហេតុនេះ នាំមកនូវឧបសគ្គ ដែលរាំងស្ទះកិច្ចការសង្គម រារាំងសមភាព ជំទាស់នឹងកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស ជំទាស់នឹងសន្តិភាពក្នុងសង្គមជាតិ និងអន្តជាតិផងដែរ (GS ២៩,៣)។

## ៣. សាមគ្គីភាពរបស់មនុស្ស

១៩៣៩- ដោយសារមនុស្សរួបរួមជាមួយគ្នាដូចជាបងប្អូន ហើយដោយសារគ្រីស្តសាសនា គេត្រូវរួមសាមគ្គីនឹងគ្នាទុកជាមិត្តសម្លាញ់ និងស្រឡាញ់គ្នាក្នុងសង្គម។

សព្វថ្ងៃ មនុស្សជាច្រើនប្រព្រឹត្តកំហុស ដោយភ្លេចនិយមន័យរបស់សាមគ្គីភាព និងសេចក្តីស្រឡាញ់រវាងមនុស្ស ដែលមកពីសហគមន៍ដើម និងមានភាពស្មើគ្នាតាំងពីកំណើត ចេះគិតគូ ទោះបីជាសមាជិកនៃប្រជាជាតិណាមួយក៏ដោយ ហើយដែលមកពីព្រះយេស៊ូគ្រីស្តបានថ្វាយសក្ការបូជានៅលើឈើឆ្កាងចំពោះព្រះបិតារបស់ព្រះអង្គដែលគង់នៅស្ថានបរមសុខ ដើម្បីលោះមនុស្សលោកទាំងអស់ឲ្យរួចពីបាប (សម្តេចប៉ាប ពីយូសទី១២)។

១៩៤០- ជាដំបូង មនុស្សរួមសាមគ្គីនឹងគ្នា ក្នុងការចែកទ្រព្យសម្បត្តិ និងការផ្តល់ប្រាក់បៀវត្សនៃការងារ។ ម្យ៉ាងទៀត ដោយសារគេរួមសាមគ្គីនឹងគ្នា មនុស្សត្រូវតែខិតខំពង្រឹងរបៀបរៀបរយក្នុងសង្គមឲ្យកាន់តែប្រកបដោយយុត្តិធម៌ ដែលនឹងកាត់បន្ថយភាពតានតឹង និងដែលជាភាពងាយស្រួលក្នុងការដោះស្រាយទំនាស់។

១៩៤១- មានតែនៅពេលដែលមនុស្សរួមសាមគ្គីនឹងគ្នាគ្រប់បែបយ៉ាង ទើបអាចដោះស្រាយបញ្ហាក្នុងសង្គម និងខាងសេដ្ឋកិច្ច គឺឲ្យជនក្រីក្ររួមសាមគ្គីរវាងគ្នានឹងគ្នា ឲ្យអ្នកមាននិងអ្នកក្ររួបរួមគ្នា ឲ្យកម្មកររួមជាមួយគ្នា ឲ្យថៅកែនិងបុគ្គលិកក្នុងសហគ្រាសរួមសាមគ្គីគ្នា ឲ្យមានសាមគ្គីភាពរវាងប្រជាជាតិ និងប្រជាជននានា។ របៀបរៀបរយខាងសីលធម៌ទាមទារឲ្យមានសាមគ្គីភាពអន្តរជាតិ។ សន្តិភាពក្នុងពិភពលោកពឹងផ្អែកលើសាមគ្គីភាពនេះម្យ៉ាងដែរ។

១៩៤២- មនុស្សត្រូវរួមសាមគ្គីគ្នា មិនគ្រាន់តែដោយចែករំលែកទ្រព្យសម្បត្តិលោកីយ៍ប៉ុណ្ណោះទេ។ ដោយចែករំលែកសម្បត្តិនៃវិញ្ញាណដែលមកពីជំនឿ ព្រះសហគមន៍បានជួយអភិវឌ្ឍទ្រព្យសម្បត្តិលោកីយ៍ និងបានបើកផ្លូវថ្មីថែមទៀតផង។ ហេតុនេះហើយ បានជាពីសតវត្សមួយទៅសតវត្សមួយ ព្រះអម្ចាស់បានបញ្ជាក់ព្រះបន្ទូលរបស់ព្រះអង្គថា៖ "ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសេចក្តីសុចរិតរបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀត" (មថ ៦,៣៣)។

តាំងពីពីរពាន់ឆ្នាំមកហើយ ចិត្តគំនិតដែលបានជំរុញ និងនៅតែជំរុញឲ្យបង្កើតល័ក្ខខ័ណ្ឌក្នុងសង្គម ដើម្បីឲ្យមនុស្សទាំងអស់អាចមានជីវភាពរស់នៅសមគួរនឹងឋានៈរបស់ខ្លួន និងរបស់គ្រីស្តសាសនា នៅតែស្ថិតក្នុងព្រលឹងព្រះសហគមន៍ជានិច្ច។ ចិត្តគំនិតនេះ ជំរុញបឲ្យបព្វជិតទៅជាកសិករ ឲ្យរំដោះទាសករ ឲ្យព្យាបាលអ្នកជំងឺ ឲ្យនាំសារនៃជំនឿ នៃអារ្យធម៌ នៃវិទ្យាសាស្រ្ត សម្រាប់មនុស្សគ្រប់ជំនាន់ និងប្រជាជាតិទាំងឡាយ (សម្តេងប៉ាប ពីយូសទី១២)។

## សង្ខេប

១៩៤៣- មានយុត្តិធម៌នៅក្នុងសង្គម នៅពេលដែលសង្គមនេះ បំពេញល័ក្ខខ័ណ្ឌ ដែលផ្តល់ឲ្យសហគមន៍ និងបុគ្គលម្នាក់ៗ អាចទទួលនូវអ្វីដែលគេមានសិទ្ធិទទួល។

១៩៤៤-ការគោរពបុគ្គល គឺចាត់ទុកអ្នកដទៃដូចជា "ខ្លួនឯងម្នាក់ទៀត"។ ត្រូវតែគោរពសិទ្ធិមូលដ្ឋាន ដែលមកពីឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស។

១៩៤៥- មនុស្សទាំងអស់ស្មើគ្នា ជាពិសេសដោយសារថានៈដ៏ថ្លៃថ្នូររបស់ខ្លួន និងសិទ្ធិដែលហូរចេញមកពីកិត្តិយសនេះ។

១៩៤៦- តាមគម្រោងការរបស់ព្រះជាម្ចាស់ មនុស្សប្លែកពីគ្នា ដ្បិតព្រះអង្គសព្វព្រះហឫទ័យឲ្យយើងត្រូវការពឹងពាក់គ្នាទៅវិញទៅមក។ ដោយសារមនុស្សប្លែកពីគ្នា គេត្រូវតែស្រឡាញ់គ្នា។

១៩៤៧- មនុស្សមានថានៈដ៏ថ្លៃថ្នូរស្មើគ្នា ហេតុនេះត្រូវខិតខំកាត់បន្ថយភាពអយុត្តិធម៌ដ៏ជ្រុលហួសហេតុពេកក្នុងសង្គម និងខាងសេដ្ឋកិច្ច។ ឋានៈដ៏ថ្លៃថ្នូរនេះ ជំរុញឲ្យបំបាត់ភាពមិនស្មើគ្នាដ៏អាក្រក់។

១៩៤៨- សាមគ្គីភាពជាគុណធម៌នៃគ្រីស្តសាសនា ដែលចែករំលែកទ្រព្យសម្បត្តិខាងវិញ្ញាណច្រើនជាងទ្រព្យសម្បត្តិលោកីយ៍ទៅទៀត។

## ជំពូកទីបីៈ

## ការសង្គ្រោះរបស់ព្រះជាម្ចាស់ៈ ធម្មវិន័យ និងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ

១៩៤៩- ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យទទួលសុភមង្គលយ៉ាងពិតប្រាកដ។ ដោយសារអំពើបាបធ្វើឲ្យគេត្រូវរបួស មនុស្សត្រូវការឲ្យព្រះជាម្ចាស់សង្គ្រោះគេ។ ព្រះគ្រីស្តប្រោសប្រទានការសង្គ្រោះនេះ ដោយសារធម្មវិន័យដែលណែនាំគេ និងដោយសារព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ ដែលជួយគាំទ្រគេផងដែរ៖

សូមបងប្អូនខំប្រឹងធ្វើការ ដោយគោរពកោតខ្លាច និងញាប់ញ័របស្របតាមការសង្គ្រោះ ដែលបងប្អូនបានទទួល ដ្បិតព្រះជាម្ចាស់ទេតើ ដែលធ្វើឲ្យបងប្អូនមានទាំងបំណង មានទាំងសមត្ថភាពអាចនឹងប្រព្រឹត្តតាមព្រះបំណងដ៏សប្បុរសរបស់ព្រះអង្គ (ភីល ២,១២-១៣)។

## ប្រការទី១៖

## ធម្មវិន័យខាងសីលធម៌

១៩៥០- ធម្មវិន័យខាងសីលធម៌ ជាស្នាព្រះហស្តនៃព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។ តាមអត្ថន័យនៃព្រះគម្ពីរ ធម្មវិន័យនេះ ហាក់ដូចជាដំបូន្មានរបស់ឪពុកម្នាក់ ដូចជាគរុកោសល្យរបស់ព្រះជាម្ចាស់។ ធម្មវិន័យនេះបង្គាប់មនុស្សឲ្យដើរតាមផ្លូវ និងបទបញ្ជា ដែលនាំគេឆ្ពោះទៅសុភមង្គលយ៉ាងពិតប្រាកដ តាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់។ ធម្មវិន័យនេះ ហាមមិនឲ្យដើរតាមផ្លូវអាក្រក់ ដែលបណ្ដាលឲ្យឃ្លាតឆ្ងាយពីព្រះជាម្ចាស់ និងសេចក្ដីស្រឡាញ់របស់ព្រះអង្គ។ ធម្មវិន័យនេះ ម៉ឺងម៉ាត់ក្នុងបទបញ្ជាផង គួរ ឲ្យស្រឡាញ់ក្នុងសេចក្ដីសន្យាផង។

១៩៥១- ធម្មវិន័យជាក្បួនច្បាប់ ដែលអាជ្ញាធរត្រឹមត្រូវបានតែង ដើម្បីប្រយោជន៍រួម។ ព្រះបង្កើតប្រកបដោយឫទ្ធានុភាព ព្រះប្រាជ្ញាញាណ និងសប្បុរសធម៌ បានចាត់ចែងរបៀបរៀបរយស្របតាមប្រាជ្ញានៃសត្វលោកនានាដើម្បីជាប្រយោជន៍ និងជាទីចុងក្រោយរបស់គេ។ ធម្មវិន័យអស់កល្បជានិច្ចជាសេចក្ដីពិតដំបូង និងចុងក្រោយបំផុតនៃវិន័យឯទៀតៗទាំងអស់។ ប្រាជ្ញាប្រកាស និងតែងតាំងធម្មវិន័យដូចជាការរួមចំណែកក្នុងឧបការគុណរបស់ព្រះដ៏មានព្រះជន្មគង់នៅ ជាព្រះបង្កើត និងជាព្រះសង្គ្រោះរបស់មនុស្សទាំងអស់៖ "អ្វីទៅជាធម្មវិន័យ? គឺជាការតែងតាំងប្រាជ្ញាឲ្យមានរបៀបរៀបរយ" (សម្ដេចប៉ាប ឡេអុងទី១៣)។

> នៅក្នុងចំណោមសត្វលោកទាំងអស់ដែលមានជីវិត មានតែមនុស្សទេ ដែលអាចលើកតម្កើងខ្លួនឯងថាខ្លួនឯងសមនឹងបានទទួលធម្មវិន័យពីព្រះជាម្ចាស់៖ ព្រោះមនុស្សជាសត្វប្រកបដោយប្រាជ្ញា ដែលអាចយល់ និងចេះរិះគិតពិចារណា នឹងមានរបៀបរស់នៅដោយប្រើសេរីភាព និងប្រាជ្ញាក្រោមអំណាចរបស់ព្រះដែលបានប្រោសប្រទានអ្វីៗទាំងអស់ឲ្យគាត់ (លោក ទែរទូលីយ៉ាំង)។

១៩៥២- ធម្មវិន័យខាងសីលធម៌មានច្រើនបែប ដែលមានទំនាក់ទំនងជាមួយគ្នាដែរ៖ ធម្មវិន័យអស់កល្បជានិច្ច ដែលជាប្រភពនៃវិន័យឯទៀតៗទាំងអស់ក្នុងអង្គព្រះជាម្ចាស់ ធ្មវិន័យធម្មជាតិ ធម្មវិន័យដែលព្រះអង្គបានសម្ដែងឲ្យយើងស្គាល់ ដែលមានធម្មវិន័យចាស់ និងធម្មវិន័យថ្មី ឬធម្មវិន័យនៃដំណឹងល្អ ទីបញ្ចប់មានច្បាប់នៃសង្គម និងរបស់ព្រះសហគមន៍។

១៩៥៣- ព្រះគ្រីស្តបំពេញធម្មវិន័យខាងសីលធម៌បានពេញលក្ខណៈ។ ធម្មវិន័យនេះ មានឯកភាពក្នុងអង្គព្រះអង្គដែរ។ ព្រះយេស៊ូគ្រីស្តផ្ទាល់ជាផ្លូវឆ្ពោះទៅភាពល្អឥតខ្ចោះ។ ព្រះអង្គជាគោលដៅនៃធម្មវិន័យ ដ្បិតមានតែព្រះអង្គទេ ដែលបង្រៀន និងប្រទានសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់៖ "ព្រះគ្រីស្តជាគោលដៅរបស់វិន័យ ដើម្បីឲ្យអស់អ្នកជឿបានសុចរិត" (រម ១០,៤)។

### ១. ធម្មវិន័យខាងសីលធម៌តាមធម្មជាតិ

១៩៥៤- មនុស្សរួមចំណែកក្នុងព្រះប្រាជ្ញាញាណ និងសប្បុរសធម៌នៃព្រះបង្កើត ដែលប្រគល់ឲ្យគេចេះធ្វើជាម្ចាស់លើខ្លួនឯង និងមានសមត្ថភាពអាចគ្រប់គ្រងលើខ្លួនឯងបាន ដើម្បីទៅរកសេចក្ដីពិត និងអ្វីដ៏ល្អ។ ធម្មវិន័យធម្មជាតិសម្ដែងថា មនុស្សប្រកបដោយសីលធម៌តាំងពីដើមដំបូង ដែលនាំឲ្យគេចេះរិះគិតពិចារណាអំពីអ្វីដ៏ល្អ និងអ្វីដ៏អាក្រក់ អំពីសេចក្ដីពិត និងសេចក្ដីកុហក៖

> ព្រះជាម្ចាស់បានសរសេរ និងចារធម្មវិន័យធម្មជាតិក្នុងព្រលឹងរបស់មនុស្សទាំងអស់ និងរបស់មនុស្ស

ម្នាក់ៗ ដ្បិតវិន័យនេះ ជាប្រាជ្ញារបស់មនុស្ស ដែលបញ្ជាឲ្យធ្វើល្អ និងហាមមិនឲ្យប្រព្រឹត្តអំពើបាបឡើយ (...)។ ប៉ុន្តែ បទបញ្ជានៃប្រាជ្ញាមនុស្សនេះ មិនអាចមានអំណាចដូចធម្មវិន័យទេ បើបទបញ្ជានេះ មិនមែនជាសម្លេង និងជាអ្នកកណ្តាលរបស់ប្រាជ្ញាដ៏ខ្ពង់ខ្ពស់បំផុត ដែលវិញ្ញាណ និងសេរីភាពរបស់យើង ត្រូវស្ថិតនៅក្រោមអំណាច (សម្តេចប៉ាបឡេអុងទី១៣)។

១៩៥៥- "ធម្មវិន័យរបស់ព្រះជាម្ចាស់ និងធម្មវិន័យធម្មជាតិ" (GS ៨៩,១) បង្ហាញឲ្យមនុស្សស្គាល់ផ្លូវ ដែលគេត្រូវដើរ ដើម្បីប្រព្រឹត្តអំពើល្អ និងទៅដល់គោលដៅរបស់គេ។ ធម្មវិន័យធម្មជាតិប្រកាសបទបញ្ជាដំបូង និងសំខាន់ៗ ដែលគ្រប់គ្រងជីវិតខាងសីលធម៌ ហើយមានគោលការណ៍សំខាន់ៗថា ត្រូវតែមានបំណងប្រាថ្នាចង់បានព្រះជាម្ចាស់ និងស្ថិតនៅក្រោមអំណាចព្រះអង្គ ដែលជាប្រភព និងចៅក្រមនៃអ្វីៗទាំងអស់ដ៏ល្អ ហើយត្រូវតែរាប់អ្នកដទៃដូចខ្លួនឯងផងដែរ។ វិន័យដប់ប្រការសម្តែងបទបញ្ជាផ្សេងៗនៃធម្មវិន័យនេះ។ គេហៅធម្មវិន័យនេះថា ធម្មវិន័យធម្មជាតិ មិនមែនយោងតាមលក្ខណៈរបស់សត្វលោកដែលគ្មានប្រាជ្ញាទេ ប៉ុន្តែដោយសារប្រាជ្ញាដែលប្រកាសធម្មវិន័យនេះ ជាកម្មសិទ្ធិនៃធម្មជាតិផ្ទាល់របស់មនុស្ស។

តើគេចារវិន័យទាំងអស់នោះនៅឯណាទៅ ក្រៅពីសៀវភៅនៃពន្លឺនេះ ដែលគេហៅថាជាសេចក្តីពិត? នៅទីនោះហើយ ដែលព្រះជាម្ចាស់បានសរសេរវិន័យត្រឹមត្រូវទាំងអស់ នៅទីនោះហើយ ដែលវិន័យនេះឆ្លងក្នុងចិត្តមនុស្ស ដែលបំពេញសេចក្តីសុចរិត។ វិន័យនេះ មិនចេញពីគេទេ ប៉ុន្តែដាក់ស្នាមលើគេដូចជាត្រា ដែលឆ្លងពីចិញ្ចៀនទៅលើក្រមួន តែមិនចេញពីចិញ្ចៀនឡើយ (សន្តៈ អូគូស្តាំង)។

ធម្មវិន័យធម្មជាតិជាពន្លឺនៃប្រាជ្ញាឈ្លាសវៃ ដែលព្រះជាម្ចាស់បានដាក់ក្នុងខ្លួនយើងតែប៉ុណ្ណោះ។ ដោយសារវិន័យនេះ យើងដឹងថា ត្រូវតែធ្វើអ្វីខ្លះ ហើយត្រូវចៀសវាងអ្វីខ្លះដែរ។ ព្រះជាម្ចាស់បានប្រទានពន្លឺ ឬវិន័យនេះ ឲ្យសត្វលោក (សន្តៈ ថូម៉ាស នៃអាកាំង)។

១៩៥៦- ប្រាជ្ញាបានតែងតាំងធម្មវិន័យធម្មជាតិ ដែលស្ថិតក្នុងចិត្តមនុស្សម្នាក់ៗ ដែលជាបទបញ្ជាសកល ហើយមានអំណាចសម្រាប់មនុស្សទាំងអស់។ ធម្មវិន័យនេះ សម្តែងកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស និងជាមូលដ្ឋានរបស់សិទ្ធិ និងភារកិច្ចគ្រឹះរបស់គេ៖

មានវិន័យពិតប្រាកដមែន គឺប្រាជ្ញាដ៏ត្រឹមត្រូវ។ វិន័យនេះ ស្របតាមធម្មជាតិ ស្ថិតក្នុងមនុស្សទាំងអស់ មិនប្រែប្រួល និងអស់កល្បជានិច្ច។ បញ្ជានៃវិន័យនេះ ដូចជាភារកិច្ច ការហាមប្រាមនៃវិន័យនេះ ធ្វើឲ្យឃ្លាតឆ្ងាយពីកំហុស (...)។ បើយើងជំនួសវិន័យនេះដោយវិន័យផ្ទុយ យើងនឹងប្រព្រឹត្តអំពើសៅហ្មង។ យើងត្រូវតែអនុវត្តតាមបទបញ្ជានីមួយៗ និងគ្មាននរណាអាចលុបវិន័យនេះចោលបានឡើយ (លោក ស៊ីសេរ៉ូន)។

១៩៥៧- មានរបៀបអនុវត្តធម្មវិន័យធម្មជាតិជាច្រើន។ យើងអាចរិះគិតពិចារណាស្របតាមលក្ខខ័ណ្ឌនៃជីវភាព ទីកន្លែង សម័យ និងកាលៈទេសៈ ប៉ុន្តែទោះជាមានវប្បធម៌ជាច្រើនផ្សេងពីគ្នាយ៉ាងណាក៏ដោយ ក៏ធម្មវិន័យធម្មជាតិដូចជាក្បួន ដែលធ្វើឲ្យមនុស្សជាប់ចំណងជាមួយគ្នាដែរ ហើយទោះបីមនុស្សតែងតែប្លែកពីគ្នាក៏ដោយ ក៏ធម្មវិន័យនេះ ដូចជាបង្ខំគេឲ្យមានគោលការណ៍រួម។

១៩៥៨- ធម្មវិន័យធម្មជាតិមិនប្រែប្រួល (GS ១០) ស្ថិតនៅជាអចិន្ត្រៃយ៍ ទោះជាប្រវត្តិសាស្ត្រផ្លាស់ប្តូរជានិច្ចក៏ដោយ។ ធម្មវិន័យនេះ នៅតែស្ថិតស្ថេរក្រោមចរន្តនៃគំនិត និងរបៀបរស់នៅ ហើយជួយឲ្យគំនិត និងរបៀបរស់នៅទាំងអស់នោះរីកចម្រើន។ បទបញ្ជា ដែលសម្តែងធម្មវិន័យនេះ នៅតែមានតម្លៃជានិច្ច។ ទោះបីយើងបដិសេធមិនព្រមទទួលស្គាល់គោលការណ៍នៃធម្មវិន័យធម្មជាតិតក៏ដោយ ក៏យើងមិនអាចបំផ្លាញ ឬដកធម្មវិន័យ

នេះចេញពីចិត្តមនុស្សបានឡើយ។ ធម្មវិន័យធម្មជាតិតែងតែផុសឡើងក្នុងជីវិតរបស់មនុស្ស និងរបស់សង្គម៖

> ឱព្រះអម្ចាស់អើយ! ធម្មវិន័យរបស់ព្រះអង្គ ហើយធម្មវិន័យដែលព្រះអង្គបានដាក់ក្នុងចិត្តមនុស្ស ពិតជាដាក់ទោសលើអ្នកលួចមិនខាន។ ទោះបីយើងមានចិត្តរឹងរូសក៏ដោយ ក៏យើងមិនអាចលុបបំបាត់វិន័យនេះបានឡើយ (សន្តៈ អូគូស្តាំង)។

១៩៥៩- ធម្មវិន័យធម្មជាតិជាស្នាព្រះហស្តដ៏ល្អប្រសើរបំផុតនៃព្រះបង្កើត ហើយផ្តល់មូលដ្ឋានគ្រឹះដ៏រឹងមាំដែលមនុស្សអាចកសាងអាគ៌ានៃក្បួនវិន័យខាងសីលធម៌ ដើម្បីនឹងណែនាំគេ។ ធម្មវិន័យធម្មជាតិជាមូលដ្ឋានខាងសីលធម៌ជាចាំបាច់ ដើម្បីកសាងសហគមន៍មនុស្សផងដែរ។ ទីបំផុត ធម្មវិន័យធម្មជាតិផ្តល់មូលដ្ឋានជាចាំបាច់ ដើម្បីតែងច្បាប់សម្រាប់សង្គម។ [...]

១៩៦០- មនុស្សទាំងអស់មិនអាចយល់ភ្លាមៗ និងច្បាស់លាស់នូវបទបញ្ញានៃធម្មវិន័យធម្មជាតិឡើយ។ ក្នុងស្ថានភាពបច្ចុប្បន្ន ព្រះជាម្ចាស់ត្រូវតែប្រោសប្រទានព្រះហឫទ័យប្រណីសន្តោស និងសម្តែងព្រះអង្គ ឲ្យមនុស្សដែលជាអ្នកបាបស្គាល់ ដើម្បីឲ្យមនុស្សទាំងអស់អាចស្គាល់សេចក្តីពិតខាងសាសនា និងខាងសីលធម៌ "ដោយងាយស្រួល ដោយដឹងយ៉ាងម៉ឺងម៉ាត់ និងដោយគ្មានកំហុសឡើយ" (សម្តេចប៉ាប ពីយូទី១២៖ DS ៣៨៧៦)។

## ២. ធម្មវិន័យចាស់

១៩៦១- ព្រះជាម្ចាស់ ដែលជាព្រះបង្កើត និងជាព្រះសង្គ្រោះរបស់យើង បានជ្រើសរើសជនជាតិអ៊ីស្រាអែលធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គ ហើយបានសម្តែងធម្មវិន័យរបស់ព្រះអង្គឲ្យគេស្គាល់។ ធ្វើដូច្នេះ ព្រះអង្គបានរៀបចំឲ្យព្រះគ្រីស្តយាងមក។ ធម្មវិន័យរបស់លោកម៉ូសេសម្តែងសេចក្តីពិតជាច្រើន ដែលប្រាជ្ញាអាចឈ្វេងយល់បាន។ ព្រះជាម្ចាស់ប្រកាស និងបញ្ជាក់បន្ថែមឲ្យស្គាល់សេចក្តីពិតទាំងអស់នោះ នៅក្នុងសម្ព័ន្ធមេត្រីនៃការសង្គ្រោះ។

១៩៦២- ធម្មវិន័យចាស់ជាសភាពដំបូងនៃធម្មវិន័យ ដែលព្រះជាម្ចាស់សម្តែងឲ្យយើងស្គាល់។ វិន័យដប់ប្រការសង្ខេបបទបញ្ញាខាងសីលធម៌នៃវិន័យនេះ។ បទបញ្ញានៃវិន័យដប់ប្រការជាមូលដ្ឋានគ្រឹះនៃការត្រាស់ហៅរបស់មនុស្ស ដែលជារូបតំណាងរបស់ព្រះជាម្ចាស់ ហាមមិនឲ្យប្រព្រឹត្តអ្វីដែលប្រឆាំងនឹងសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងអ្នកដទៃ ហើយសង្កត់ធ្ងន់លើអ្វីដែលសំខាន់ៗ។ វិន័យដប់ប្រការ គឺជាពន្លឺចំពោះមនសិការរបស់មនុស្សទាំងអស់ ដើម្បីសម្តែងឲ្យគេស្គាល់ការត្រាស់ហៅ និងមាគ៌ារបស់ព្រះជាម្ចាស់ ហើយដើម្បីការពារគេអំពីអ្វីដ៏អាក្រក់៖

- ព្រះជាម្ចាស់បានចារលើបន្ទះថ្មនៃធម្មវិន័យនូវអ្វីដែលមនុស្សមិនបានអានក្នុងចិត្តគេ (សន្តៈ អូគូស្តាំង)។

១៩៦៣- តាមប្រពៃណីនៃគ្រីស្តសាសនា វិន័យដ៏វិសុទ្ធ (រម ៧,១២) ខាងវិញ្ញាណ (រម ៧,១៤) និងដ៏ល្អប្រសើរ (រម ៧,១៦) មិនទាន់គ្រប់លក្ខណ៍ទេ។ ដូចគ្រូបង្រៀនម្នាក់ (កាឡ ៣,២៤) វិន័យចាស់បង្ហាញអំពីអ្វីដែលត្រូវតែធ្វើ ប៉ុន្តែ មិនផ្តល់កម្លាំង និងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបំពេញអ្វីដែលត្រូវតែធ្វើនេះឡើយ។ ដោយសារអំពើបាប ដែលវិន័យចាស់នេះ មិនអាចដកចេញបាន វិន័យនេះ ហាក់ដូចជានាំឲ្យក្លាយទៅជាទាសករ។ តាមសន្តៈ ប៉ូល វិន័យចាស់ មានមុខងារបង្ហាញអំពើបាប ឲ្យយើងដឹងថា ចិត្តមនុស្ស "លោភលន់" (រម ៧)។ ក៏ប៉ុន្តែ វិន័យចាស់នៅតែជាដំណាក់កាលដំបូងនៅលើផ្លូវឆ្ពោះទៅព្រះរាជ្យ។ វិន័យចាស់រៀបចំប្រជារាស្ត្ររបស់ព្រះជាម្ចាស់ និងគ្រីស្តបរិស័ទម្នាក់ៗឲ្យកែប្រែចិត្តគំនិត និងឲ្យផ្ញើជីវិតទៅលើព្រះជាម្ចាស់ជាព្រះសង្គ្រោះ។ ធម្មវិន័យចាស់ផ្តល់ការប្រៀនប្រដៅ ដែលនៅស្ថិតស្ថេរជានិច្ច ដូចព្រះបន្ទូលរបស់ព្រះជាម្ចាស់ផងដែរ។

១៩៦៤- ធម្មវិន័យចាស់រៀបចំដំណឹងល្អ។ "ធម្មវិន័យដូចជាព្យាការីប្រកបដោយគរុកោសល្យ" (សន្តៈអ៊ីរ៉េណេ)។ ធម្មវិន័យដូចជាព្យាការី និងប្រផ្នូលអំពីព្រះគ្រីស្ត ដែលនឹងប្រោសឲ្យរួចពីបាប ហើយផ្ដល់រូប និងនិមិត្តរូបដល់គម្ពីរសម្ពន្ធមេត្រីថ្មី ដើម្បីសម្ដែងរបៀបរស់នៅតាមព្រះវិញ្ញាណ។ ទីបញ្ចប់ កំណ្ឌនៃគម្ពីរព្រះប្រាជ្ញាញាណ និងគម្ពីរព្យាការីបំពេញវិន័យចាស់ និងតម្រូវវិន័យនេះឆ្ពោះទៅសម្ពន្ធមេត្រីថ្មី និងព្រះរាជ្យនៃស្ថានបរមសុខ។

> ក្រោមរបបនៃសម្ពន្ធមេត្រីចាស់ មនុស្សខ្លះប្រតិបត្តិតាមសេចក្ដីស្រឡាញ់ និងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ហើយដែលប៉ងប្រាថ្នាចង់បានព្រះបន្ទូលសន្យាខាងវិញ្ញាណ និងអស់កល្បជានិច្ច។ អ្នកនោះជាប់នឹងធម្មវិន័យថ្មី។ ផ្ទុយទៅវិញ ក្រោមរបបនៃសម្ពន្ធមេត្រីថ្មី មនុស្សខ្លះនាលោកីយ៍នេះ នៅតែឃ្លាតឆ្ងាយពីភាពឥតខ្ចោះនៃធម្មវិន័យថ្មី។ ក្នុងសម្ពន្ធមេត្រីថ្មីដែរ យើងត្រូវតែបំភ័យឲ្យគេខ្លាចទទួលទោស និងសន្យាថា គេនឹងបានទទួលរង្វាន់ខាងលោកីយ៍ ដើម្បីជំរុញគេឲ្យប្រព្រឹត្តអំពើល្អ។ យ៉ាងណាក៏ដោយ ទោះបីធម្មវិន័យចាស់ទូន្មានឲ្យចេះស្រឡាញ់គ្នាយ៉ាងណាក៏ដោយ ក៏វិន័យនេះ មិនផ្ដល់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែល "ជាសេចក្ដីស្រឡាញ់ ដែលព្រះជាម្ចាស់បានចាក់បង្ហូរក្នុងចិត្តយើង" ដែរ (រម ៥,៥) (សន្តៈ ថូម៉ាស នៃអាកាំង)។

## ៣. ធម្មវិន័យថ្មី ឬធម្មវិន័យនៃដំណឹងល្អ

១៩៦៥- ធម្មវិន័យថ្មី ឬធម្មវិន័យនៃដំណឹងល្អធ្វើឲ្យធម្មវិន័យរបស់ព្រះជាម្ចាស់ ជាធម្មវិន័យធម្មជាតិ ដែលព្រះអង្គបានសម្ដែងឲ្យយើងស្គាល់ បានគ្រប់លក្ខណៈ នៅក្នុងលោកនេះ។ ធម្មវិន័យថ្មី ឬធម្មវិន័យនៃដំណឹងល្អជាស្នាព្រះហស្តរបស់ព្រះគ្រីស្ត ដែលព្រះអង្គសម្ដែង នៅពេលទ្រង់ទេសនាលើភ្នំ។ វិន័យនេះ ជាស្នាព្រះហស្តរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែរ ហើយដែលក្លាយទៅជាវិន័យនៃសេចក្ដីស្រឡាញ់នៅក្នុងចិត្ត៖ "បន្តិចទៀតយើងនឹងចងសម្ពន្ធមេត្រីមួយថ្មីជាមួយពូជពង្សរបស់អ៊ីស្រាអែល (...)។ យើងនឹងដាក់វិន័យរបស់យើងក្នុងប្រាជ្ញារបស់ពួកគេ យើងនឹងចារវិន័យទាំងនោះទុកនៅក្នុងចិត្តរបស់ពួកគេ យើងនឹងបានទៅជាព្រះរបស់ពួកគេ ហើយគេជាប្រជារាស្ត្ររបស់យើង" (ហប ៨,៨-១០) (យរ ៣១,៣១-៣៤)។

១៩៦៦- ធម្មវិន័យថ្មីជាព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះជាម្ចាស់ប្រោសប្រទានឲ្យគ្រីស្តបរិស័ទ ដោយធ្វើជីវិតលើព្រះគ្រីស្ត។ វិន័យនេះ ប្រតិបត្តិតាមសេចក្ដីស្រឡាញ់ ប្រើធម៌ទេសនារបស់ព្រះអម្ចាស់ ដើម្បីប្រៀនប្រដៅយើងអំពីអ្វីដែលត្រូវតែធ្វើ ហើយប្រើអគ្គសញ្ញាដើម្បីឲ្យយើងអាចប្រព្រឹត្តតាម៖

> អ្នកដែលចង់សញ្ជឹងគិត ដោយគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងដោយរិះគិតពិចារណាយ៉ាងច្បាស់អំពីធម៌ទេសនា ដែលព្រះអម្ចាស់នៃយើង បានប្រកាសនៅលើភ្នំ ដូចយើងអានក្នុងដំណឹងល្អ តាមសន្តៈម៉ាថាយ អ្នកនោះពិតជានឹងរកឃើញបញ្ញត្តិដ៏គ្រប់លក្ខណ៍នៃការរស់នៅជាគ្រីស្តបរិស័ទ (...)។ បទបញ្ញាទាំងអស់ ដែលអាចណែនាំយើងឲ្យរស់នៅដូចជាគ្រីស្តបរិស័ទ ស្ថិតក្នុងធម៌ទេសនានេះ (សន្តៈ អូគូស្តាំង)។

១៩៦៧- ធម្មវិន័យនៃដំណឹងល្អ "បំពេញ" (មថ ៥,១៧-១៩) លម្អិតលម្អន់ ហួសវិន័យចាស់ និងធ្វើ ឲ្យវិន័យចាស់បានគ្រប់លក្ខណៈ។ ក្នុងធម៌ទេសនាអំពីសុភមង្គលយ៉ាងពិតប្រាកដ វិន័យថ្មីបំពេញព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ដោយលើកព្រះបន្ទូលនោះឆ្ពោះទៅ "ព្រះរាជ្យនៃស្ថានបរមសុខ"។ ព្រះជាម្ចាស់ប្រទានវិន័យថ្មីឲ្យអស់អ្នកដែលសុខចិត្តទទួលសេចក្ដីសង្ឃឹមថ្មីនេះ ដោយមានជំនឿ គឺជនក្រីក្រ អស់អ្នកដែលចេះបន្ទាបខ្លួន ជនកម្សត់ទុគត អស់អ្នកដែលមានចិត្តបរិសុទ្ធ អស់អ្នកដែលត្រូវគេបៀតបៀនដោយសារព្រះគ្រីស្ត។ ធ្វើដូច្នេះ វិន័យ

ថ្មីបង្ហាញមាគ៌ាផ្សេងៗដ៏គួរឲ្យឆ្ងល់នៃព្រះរាជ្យ។

១៩៦៨- វិន័យថ្មីបំពេញបទបញ្ញា នៃធម្មវិន័យ។ ធម៌ទេសនារបស់ព្រះអម្ចាស់ មិនលុបបំបាត់ ឬបញ្ចុះតម្លៃបទបញ្ញខាងសីលធម៌នៃវិន័យចាស់ទេ ប៉ុន្តែ ស្រាយបំភ្លឺនូវសេចក្តីអាថ៌កំបាំង និងការទាមទារថ្មីៗ បន្ថែមទៀត ដែលសម្តែងប្រាប់យើងអំពីសេចក្តីពិតទាំងអស់របស់ព្រះជាម្ចាស់ និងមនុស្ស។ ធម៌ទេសនានោះ មិនបន្ថែមបញ្ញត្តិថ្មីពីក្រៅទៀតទេ ប៉ុន្តែកែតម្រង់គ្រឹះនៃកិច្ចការនានា គឺចិត្តគំនិតមនុស្ស។ នៅក្នុងចិត្តនេះហើយ ដែលមនុស្សជ្រើសរើសរវាងភាពបរិសុទ្ធ និងភាពមិនបរិសុទ្ធ (មថ ១៥,១៨-១៩) ទីនោះជាកន្លែងបង្កើតជំនឿ សេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ និងគុណធម៌ឯទៀតៗ។ ដូច្នេះ ដំណឹងល្អនាំធម្មវិន័យឲ្យបានគ្រប់លក្ខណ៍ ដោយយកតម្រាប់តាមព្រះបិតានៃស្ថានបរមសុខដែលគ្រប់លក្ខណ៍យ៉ាងនោះដែរ (មថ ៥,៤៨) ដោយលើកលែងទោសឲ្យខ្មាំងសត្រូវ និងដោយអធិដ្ឋានសម្រាប់អ្នកបៀតបៀន តាមលំនាំព្រះជាម្ចាស់ដែលពោរពេញទៅដោយសប្បុរសធម៌ដូច្នោះដែរ (មថ ៥,៤៤)។

១៩៦៩- អ្នកកាន់វិន័យថ្មីប្រតិបត្តិតាមកិច្ចការនៃសាសនា គឺធ្វើទាន អធិដ្ឋាន តមអាហារ ដោយឧទ្ទិសទៅដល់ "ព្រះបិតាដែលទតឃើញនៅក្នុងទីស្ងាត់កំបាំង" ដោយមិនចង់ឲ្យ "អ្នកដទៃឃើញ" (មថ ៦,១-៦; ១៦-១៨)។ អ្នកកាន់វិន័យថ្មីអធិដ្ឋានដោយសូត្រធម៌ ឱព្រះបិតានៃយើងខ្ញុំ (មថ ៦,៩-១៣)។

១៩៧០- វិន័យថ្មីជំរុញយើងឲ្យជ្រើសរើសចូលតាម "ទ្វារចង្អៀត" (មថ ៧,១៣-១៤) ហើយ ឲ្យយើងអនុវត្តតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ (មថ ៧,២១-២៧) ដែលមានសេចក្តីថា៖ "បើអ្នករាល់គ្នាចង់ឲ្យអ្នកដទៃប្រព្រឹត្តចំពោះខ្លួនបែបណា ត្រូវប្រព្រឹត្តចំពោះគេបែបនោះដែរ។ ធម្មវិន័យនិងគម្ពីរព្យាការីមានចែងទុកមកដូច្នេះឯង" (មថ ៧,១២) (លក ៦,៣១)។

ធម្មវិន័យនៃដំណឹងល្អទាំងមូលស្ថិតនៅក្នុង "វិន័យថ្មី" របស់ព្រះយេស៊ូ (យហ ១៣,៣៤) គឺឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះអង្គបានស្រឡាញ់យើងដែរ (យហ ១៥,១២)។

១៩៧១- ត្រូវតែបង្រួបបង្រួមការអប់រំខាងសីលធម៌របស់ក្រុមគ្រីស្តទូត ដូចជា រម ១២-១៥ ;១ករ ១២-១៣ ; កូឡ ៣-៤ ; អភ ៤-៥។ល។ ជាមួយនឹងធម៌ទេសនារបស់ព្រះអម្ចាស់។ លទ្ធិនេះ បញ្ជូនការប្រៀបប្រដៅរបស់ព្រះអម្ចាស់ក្រោមការចាត់ចែងគ្រប់គ្រងរបស់ក្រុមគ្រីស្តទូត ជាពិសេសដោយការសម្តែងគុណធម៌ ដែលហូរចេញមកពីជំនឿទៅលើព្រះគ្រីស្ត ហើយដែលសេចក្តីស្រឡាញ់ ជាព្រះអំណោយទានសំខាន់ជាងគេនៃព្រះវិញ្ញាណដ៏វិសុទ្ធណែនាំ។ "ចូរមានចិត្តស្រឡាញ់ដោយឥតលាក់ពុត (...)។ ចូរស្រឡាញ់រាប់អានគ្នាទៅវិញទៅមកទុកដូចជាបងប្អូនបង្កើត (...)។ ចូរសប្បាយរីករាយបដោយចិត្តសង្ឃឹម។ ចូរកាន់ចិត្តអត់ធ្មត់ក្នុងពេលមានទុក្ខលំបាក។ ចូរព្យាយាមអធិដ្ឋាន។ ត្រូវជួយទំនុកបំរុងប្រជាជនដ៏វិសុទ្ធ ដែលខ្វះខាតព្រមទាំងទទួលភ្ញៀវដោយរាក់ទាក់ផង" (រម ១២,៩-១៣)។ ការប្រៀនប្រដៅនេះ បង្រៀនយើងឲ្យរិះគិតពិចារណា ក្រោមពន្លឺនៃទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគ្រីស្ត និងព្រះសហគមន៍ (រម ១៤; ១ករ ៥-១០)។

១៧៩២- គេហៅវិន័យថ្មីថាជាវិន័យនៃសេចក្តីស្រឡាញ់ ដ្បិតដោយសារវិន័យនេះ យើងប្រព្រឹត្តដោយសេចក្តីស្រឡាញ់ ដែលព្រះវិញ្ញាណដ៏វិសុទ្ធចាក់បង្ហូរ ជាជាងប្រព្រឹត្តដោយភ័យខ្លាច។ គេហៅវិន័យថ្មីនេះថាជាវិន័យនៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដ្បិតវិន័យនេះ ផ្តល់ឫទ្ធានុភាពនៃព្រះហឫទ័យប្រណីសន្តោស ដើម្បីឲ្យយើងប្រព្រឹត្តតាមជំនឿ និងតាមអគ្គសញ្ញា។ គេហៅវិន័យនេះថាជាវិន័យដែលផ្តល់សេរីភាព (យក ១,២៥ ; ២,១២) ដ្បិតវិន័យនេះ រំដោះយើងឲ្យរួចពីពិធីផ្សេងៗ និងក្បួនច្បាប់នៃវិន័យចាស់ និងជំរុញយើងឲ្យ

ប្រព្រឹត្តដោយសារសេចក្ដីស្រឡាញ់ ទីបំផុតធ្វើឲ្យយើងលែងជាអ្នកបម្រើ "ដែលមិនយល់កិច្ចការដែលម្ចាស់របស់ខ្លួនប្រព្រឹត្ត" ដើម្បីទៅជាមិត្តសម្លាញ់របស់ព្រះគ្រីស្ត ដ្បិត "អ្វីៗដែលខ្ញុំបានឮពីព្រះបិតាមក ខ្ញុំក៏បានប្រាប់ឲ្យអ្នករាល់គ្នាដឹងដែរ" (យហ ១៥,១៥) ឬជាកូនដែលត្រូវទទួលមត៌កពីឪពុក (កាឡ ៤,១-៧.២១-៣១ ;រម ៨,១៥)។

១៩៧៣- វិន័យថ្មីមិនគ្រាន់តែមានបទបញ្ញាទេ ថែមទាំងមានដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ។ ជាធម្មតាយើងវែកញែកបទបញ្ញារបស់ព្រះជាម្ចាស់ជាមួយនឹងដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ តាមសេចក្ដីស្រឡាញ់ ដែលធ្វើឲ្យការរស់នៅរបស់គ្រីស្តបរិស័ទបានពេញលក្ខណៈ។ បទបញ្ញាមានគោលដៅឲ្យបោះបង់ចោលអ្វីដែលប្រឆាំងនឹងសេចក្ដីស្រឡាញ់។ ដំបូន្មានមានគោលដៅវែកញែកអ្វី ដែលអាចរាំងសេចក្ដីស្រឡាញ់មិនឲ្យរីកចម្រើន ទោះបីអ្វីៗទាំងអស់នោះមិនប្រឆាំងនឹងសេចក្ដីស្រឡាញ់ក៏ដោយ។

១៩៧៤- ដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អសម្ដែងថា អ្នកមានចិត្តស្រឡាញ់បានគ្រប់លក្ខណៈដ៏រស់រវើក។ អ្នកមានចិត្តស្រឡាញ់មិនស្កប់ចិត្តទេ បើមិនបានឲ្យថែមទៀត។ ដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អបញ្ជាក់ឫទ្ធានុភាពនៃសេចក្ដីស្រឡាញ់ ដែលដាស់តឿនយើងខាងវិញ្ញាណ។ វិន័យថ្មីបានគ្រប់លក្ខណ៍ ដោយសារបទបញ្ញាអំពីសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងអ្នកដទៃ ឯដំបូន្មានវិញ បង្ហាញផ្លូវខ្លីជាងគេ មធ្យោបាយស្រួលជាងគេដែលត្រូវអនុវត្ត តាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះមនុស្សម្នាក់ៗ៖

> (ព្រះជាម្ចាស់) មិនសព្វព្រះហឫទ័យឲ្យនរណាម្នាក់ធ្វើតាមដំបូន្មានទាំងអស់ទេ គ្រាន់តែអនុវត្តដំបូន្មានដែលស័ក្តិសមតាមលក្ខណៈពិសេសរបស់មនុស្ស តាមសម័យកាល តាមឱកាស និងតាមកម្លាំង តាមសេចក្ដីស្រឡាញ់ទាមទារ ដ្បិតសេចក្ដីស្រឡាញ់នេះ ជាព្រះមហាក្សត្រិយានីនៃគុណធម៌ទាំងអស់ផ្សេងទៀត នៃបទបញ្ញាទាំងអស់ នៃដំបូន្មានទាំងអស់ ហើយនិយាយឲ្យចំទៅ គឺវិន័យ និងកិច្ចការទាំងអស់នៃគ្រីស្តសាសនា ដែលផ្ដល់ឋានៈ កម្រិត ពេលវេលា និងតម្លៃ ឲ្យអ្វីៗទាំងអស់នោះ (សន្តៈ ហ្វ្រង់ស័រ នៅសាឡ)។

## សង្ខេប

១៩៧៥- តាមព្រះគម្ពីរធម្មវិន័យដូចជាដំបូន្មានរបស់ព្រះជាម្ចាស់ទុកជាឪពុកម្នាក់ ដែលប្រៀនប្រដៅមនុស្សឲ្យដើរតាមផ្លូវ ដែលនាំឲ្យទទួលសុភមង្គលដ៏ពិតប្រាកដ ដែលព្រះអង្គបានសន្យា និងដែលហាមប្រាមមិនឲ្យដើរតាមមាគ៌ានៃអំពើអាក្រក់។

១៩៧៦- "ដោយសារធម្មវិន័យ ប្រាជ្ញាចុះចូលក្រោមផលប្រយោជន៍រួម ដែលអ្នកមានបន្ទុកដឹកនាំសហគមន៍ជាអ្នកថ្លែង" (សន្តៈ ថូម៉ាស នៃអាកាំង)។

១៩៧៧- ព្រះគ្រីស្តជាទីចុងក្រោយនៃធម្មវិន័យ (រម ១០,៤)។ មានតែព្រះអង្គទេ ដែលបង្រៀន និងប្រទានសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់។

១៩៧៨- ដោយសារធម្មវិន័យធម្មជាតិ មនុស្សរួមចំណែកក្នុងព្រះប្រាជ្ញាញាណ និងសប្បុរសធម៌របស់ព្រះជាម្ចាស់ ហើយជារូបតំណាងរបស់ព្រះអង្គជាព្រះបង្កើតរបស់ខ្លួន។ ធម្មវិន័យនេះ សម្ដែងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស និងជាមូលដ្ឋាននៃសិទ្ធិ និងភារកិច្ចគ្រឹះរបស់គេ។

១៩៧៩- ធម្មវិន័យធម្មជាតិមិនប្រែប្រួល ស្ថិតស្ថេរជាអចិន្ត្រៃយ៍ ក្នុងប្រវត្តិសាស្ត្រ។ បទបញ្ញា ដែលសម្ដែងធម្មវិន័យនេះ នៅតែមានតម្លៃជានិច្ច។ធម្មវិន័យធម្មជាតិផ្ដល់មូលដ្ឋានជាចាំបាច់ ដើម្បីតែងក្បួនសីលធម៌ និងច្បាប់

សម្រាប់សង្គម។

១៩៨០- ធម្មវិន័យចាស់ជាសភាពដំបូងនៃធម្មវិន័យ ដែលព្រះជាម្ចាស់សម្តែងឲ្យយើងស្គាល់។ វិន័យដប់ប្រការសង្ខេបបទបញ្ញាខាងសីលធម៌នៃវិន័យនេះ។

១៩៨១- ធម្មវិន័យរបស់លោកម៉ូសេមានសេចក្តីពិត ដែលមនុស្សអាចយល់បាន។ ព្រះជាម្ចាស់បាន សម្តែងធម្មវិន័យនេះឲ្យមនុស្សស្គាល់ ដ្បិតពួកគេមិនបានអានធម្មវិន័យនេះក្នុងចិត្តគេ។

១៩៨២- ធម្មវិន័យចាស់រៀបចំដំណឹងល្អ។

១៩៨៣- ធម្មវិន័យថ្មីមកពីព្រះហឫទ័យប្រណីសន្តោសនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រតិបត្តិតាមសេចក្តីស្រឡាញ់ ហើយដែលយើងទទួលដោយផ្ញើជីវិតទាំងស្រុងទៅលើព្រះគ្រីស្ត។ ធម៌ទេសនានៅលើភ្នំសម្តែងធម្មវិន័យនេះ ដែលប្រើប្រាស់អគ្គសញ្ញា ដើម្បីផ្តល់ព្រះអំណោយទាននៃវិន័យនេះឲ្យយើង។

១៩៨៤-ធម្មវិន័យនៃដំណឹងល្អបំពេញលើសពីវិន័យចាស់ និងធ្វើឲ្យវិន័យចាស់បានគ្រប់លក្ខណៈ គឺសុភមង្គលដ៏ពិតប្រាកដអំពីព្រះរាជ្យនៃស្ថានបរមសុខបំពេញព្រះបន្ទូលសន្យា ហើយធម្មវិន័យនេះ បំពេញបទបញ្ញានៃធម្មវិន័យចាស់ ដោយកែតម្រង់ចិត្តគំនិត ជាគ្រឹះនៃកិច្ចការទាំងអស់។

១៩៨៥- ធម្មវិន័យថ្មីជាវិន័យនៃសេចក្តីស្រឡាញ់ វិន័យនៃការប្រោសប្រណី វិន័យដែលផ្តល់សេរីភាព។

១៩៨៦- វិន័យថ្មីមិនគ្រាន់តែមានបទបញ្ញាទេ ថែមទាំងមានដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ។ "តាមគម្ពីរដំណឹងល្អ ព្រះអម្ចាស់ប្រទានដំបូន្មានច្រើនឲ្យក្រុមសាវ័កកាន់។ ព្រះសហគមន៍បានវិសុទ្ធយ៉ាងពិសេសដោយគ្រីស្តបរិស័ទកាន់តាមដំបូន្មានទាំងនោះ" (LG ៤២)។

## ប្រការទី២៖

## ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្តោស

## និងប្រោសមនុស្សលោកឲ្យបានសុចរិត

### ១. ព្រះជាម្ចាស់ប្រោសមនុស្សលោកឲ្យបានសុចរិត

១៩៨៧- ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ អាចប្រោសយើងឲ្យបានសុចរិត ពោលគឺឲ្យយើងរួចពីបាប ដោយ "ផ្ញើជីវិតលើព្រះយេស៊ូគ្រីស្ត" (រម ៣,២២) និងដោយសារអគ្គសញ្ញាជ្រមុជទឹកផងដែរ (រម ៦,៣-៤)៖

> ប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រីស្ត យើងក៏ជឿថា យើងនឹងមានជីវិតរួមជាមួយព្រះអង្គដែរ ព្រោះយើងដឹងថា ព្រះគ្រីស្ត ដែលមានព្រះជន្មថ្មីនោះ ទ្រង់លែងសោយទិវង្គត ហើយមច្ចុរាជគ្មានអំណាចលើព្រះអង្គទៀតទេ ដ្បិតព្រះអង្គបានសោយទិវង្គតនោះ គឺសោយទិវង្គតឲ្យបានរួចផុតពីអំណាចបាបម្តងជាសូរេច។ ឥឡូវនេះ ព្រះអង្គមានព្រះជន្មរស់នោះ គឺរស់សម្រាប់ព្រះជាម្ចាស់។ រីឯបងប្អូនវិញក៏ដូច្នោះដែរ ចូរចាត់ទុកថាខ្លួនបានស្លាប់ រួចផុតពីអំណាចបាប ហើយបងប្អូនមានជីវិតរស់សម្រាប់ព្រះជាម្ចាស់ដោយរួមជាមួយព្រះគ្រីស្តយេស៊ូ (រម ៦,៨-១១)។

១៩៨៨- ដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ យើងរួមចំណែកក្នុងទុក្ខលំបាករបស់ព្រះគ្រីស្ត ដោយស្លាប់ឲ្យរួចផុតពីអំពើបាប ហើយយើងក៏រួមចំណែកជាមួយព្រះអង្គដែលមានព្រះជន្មថ្មី ដោយកើតជាថ្មីផងដែរ។ យើងជាសរីរាង្គនៃព្រះកាយព្រះគ្រីស្ត គឺព្រះសហគមន៍ (១ករ ១២) យើងជាមែកជាប់នឹងដើមទំពាំងបាយជូរ គឺព្រះអង្គផ្ទាល់ (យហ ១៥,១-៤)៖

យើងរួមជាមួយព្រះជាម្ចាស់ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ។ ដោយសារព្រះវិញ្ញាណរួមជាមួយផង យើងក៏រួមជាមួយព្រះជាម្ចាស់ដែរ(...)។ហេតុនេះអស់អ្នកដែលព្រះវិញ្ញាណគង់នៅជាមួយទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ (សន្តៈ អាថាណាស)។

១៩៨៩- ស្នាព្រះហស្តដំបូងនៃព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺការកែប្រែចិត្តគំនិតដែលធ្វើឲ្យយើងបានទៅជាសុចរិត ស្របតាមព្រះបន្ទូលរបស់ព្រះយេស៊ូ នៅពេលព្រះអង្គចាប់ផ្តើមប្រកាសដំណឹងល្អ៖ "ចូរប្រែចិត្តគំនិត ដ្បិតព្រះរាជ្យនៃស្ថានបរមសុខនៅជិតបង្កើយហើយ!" (មថ ៤,១៧)។ ដោយព្រះហឫទ័យប្រណីសន្ដោសជំរុញគេ មនុស្សទៅរកព្រះជាម្ចាស់ និងឃ្លាតឆ្ងាយអំពីអំពើបាប ដូច្នេះ គេទទួលការលើកលែងទោស និងទទួលសេចក្តីសុចរិតដែលមកពីស្ថានលើ។ "ព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានសុចរិត គឺព្រះអង្គលើកលែងទោសឲ្យគេ ប្រោសគេឲ្យបានវិសុទ្ធ និងកែចិត្តគំនិតរបស់គេឡើងវិញផងដែរ" (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៥២៨)។

១៩៩០- ដោយសារព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានសុចរិត មនុស្សឃ្លាតឆ្ងាយអំពីអំពើបាប ដែលប្រឆាំងនឹងសេចក្តីស្រឡាញ់របស់ព្រះអង្គ ហើយប្រោសចិត្តមនុស្សឲ្យបានបរិសុទ្ធ។ ព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានសុចរិត ក្រោយពីធម៌មេត្តាករុណារបស់ព្រះអង្គបានលើកលែងទោសឲ្យគេ។ ពេលមនុស្សទៅជាសុចរិត គេសម្រុះសម្រួលឲ្យជានានឹងព្រះជាម្ចាស់ បានរួចពីបាប និងជាសះស្បើយផង ដែរ។

១៩៩១- ជាមួយគ្នានេះដែរ ពេលមនុស្សទៅជាសុចរិត គេទទួលសេចក្តីសុចរិតរបស់ព្រះជាម្ចាស់ ដោយផ្ញើជីវិតទៅលើព្រះគ្រីស្ត។ នៅទីនេះ សេចក្តីសុចរិតសំដៅទៅលើសេចក្តីស្រឡាញ់ដ៏ត្រឹមត្រូវរបស់ព្រះជាម្ចាស់។ ដោយសារយើងទៅជាមនុស្សសុចរិត ព្រះជាម្ចាស់ចាក់បង្ហូរជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ក្នុងចិត្តយើង ហើយយើងអាចប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះអង្គបានដែរ។

១៩៩២- ព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិត ដោយសារគុណបុណ្យនៃទុក្ខលំបាករបស់ព្រះគ្រីស្ត ដែលបានបូជាព្រះជន្មនៅលើឈើឆ្កាង ដូចជាយញ្ញបូជាដ៏មានព្រះជន្មដ៏វិសុទ្ធ និងដែលជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយដែលព្រះលោហិតបានលោះអំពើបាបរបស់មនុស្សទាំងអស់។ ព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិត តាមរយៈពិធីជ្រមុជទឹក ជាអគ្គសញ្ញានៃជំនឿ។ ព្រះជាម្ចាស់ប្រោសយើង ឲ្យបានសុចរិត ដូចព្រះអង្គសុចរិតផងដែរ ដោយសារឫទ្ធានុភាពនៃធម៌មេត្តាករុណារបស់ព្រះអង្គ។ យើងទៅជាមនុស្សសុចរិត ដើម្បីសិរីរុងរឿងនៃព្រះជាម្ចាស់ និងរបស់ព្រះគ្រីស្ត និងដើម្បីទទួលព្រះអំណោយទាននៃជីវិតអស់កល្បជានិច្ច (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៥២៩)៖

ឥឡូវនេះ ព្រះជាម្ចាស់សម្តែងឲ្យយើងដឹងអំពីរបៀបព្រះអង្គប្រោសមនុស្សឲ្យបានសុចរិត គឺព្រះអង្គមិនគិតអំពីវិន័យទេ ដូចធម្មវិន័យ និងគម្ពីរព្យាការីបានបញ្ជាក់ទុកស្រាប់។ ព្រះជាម្ចាស់ប្រោសអ្នក ដែលជឿលើព្រះយេស៊ូគ្រីស្តឲ្យបានសុចរិត គឺព្រះអង្គធ្វើដូច្នេះចំពោះអស់អ្នកដែលជឿ។ មនុស្សទាំងអស់មិនខុសគ្នាត្រង់ណាឡើយ សុទ្ធតែបានប្រព្រឹត្តអំពើបាបគ្រប់គ្នា ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជា

មួយ តែព្រះជាម្ចាស់ប្រោសគេឲ្យបានសុចរិត ដោយឥតគិតពីកុសលបុណ្យដែលគេសន្សំនោះទេ គឺព្រះអង្គប្រោសគេឲ្យបានសុចរិតតាមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ ដោយព្រះយេស៊ូគ្រីស្ដលោះគេ។ ព្រះជាម្ចាស់បានតម្រូវឲ្យព្រះយេស៊ូធ្វើជាយញ្ញបូជាសម្រាប់លោះអស់អ្នក ដែលមានជំនឿឲ្យរួចពីបាប ដោយសារព្រះលោហិតរបស់ព្រះអង្គ។ ធ្វើដូច្នេះ ព្រះអង្គបង្ហាញរបៀប ដែលព្រះអង្គប្រោសមនុស្សឲ្យបានសុចរិត គឺពីដើមព្រះអង្គពុំបានដាក់ទោសមនុស្សលោក ដែលប្រព្រឹត្តអំពើបាប ក្នុងគ្រាដែលព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ដល់គេនោះទេ។ ឥឡូវនេះ ព្រះអង្គសព្វព្រះហឫទ័យបង្ហាញអំពីរបៀបដែលព្រះអង្គប្រោសមនុស្សឲ្យបានសុចរិត ដើម្បីសម្ដែងថា ព្រះអង្គសុចរិត ហើយទ្រង់ប្រោសអ្នកដែលជឿលើព្រះយេស៊ូឲ្យបានសុចរិតផងដែរ (រម ៣,២១-២៦)។

១៩៩៣- ពេលមនុស្សទៅជាសុចរិត ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ និងសេរីភាពរបស់មនុស្សរួមសហការជាមួយគ្នា។ មនុស្សសុខចិត្តជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលអញ្ជើញគេឲ្យកែប្រែចិត្តគំនិត ហើយរួមសហការ ដោយមានចិត្តស្រឡាញ់ ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលថែរក្សាការពារគេ៖

នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺចិត្តមនុស្ស មនុស្សត្រូវមានសកម្មភាព ដើម្បីទទួលការបំភ្លឺនេះ ក៏គេអាចបដិសេធមិនព្រមទទួលក៏បានដែរ ប៉ុន្តែ គេក៏មិនអាចស្ម័គ្រចិត្តទៅរកសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់ បើព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់មិនមកជួយគេផងដែរ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៥២៥)។

១៩៩៤- ពេលព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានសុចរិត ព្រះអង្គក៏បង្ហាញសេចក្ដីស្រឡាញ់របស់ព្រះអង្គយ៉ាងអស្ចារ្យជាទីបំផុត ដែលព្រះគ្រីស្ដបានសម្ដែងឲ្យយើងស្គាល់ ហើយដែលព្រះវិញ្ញាណដ៏វិសុទ្ធបានប្រោសប្រទានឲ្យ។ សន្ដ: អូគូស្ដាំង គិតថា "ពេលព្រះជាម្ចាស់ប្រោសអ្នកបាបឲ្យបានសុចរិត ព្រះអង្គក៏ប្រព្រឹត្តកិច្ចការដ៏អស្ចារ្យខ្លាំងជាងពេលព្រះអង្គបង្កើតផ្ទៃមេឃ និងផែនដីទៅទៀត" ដ្បិត "ផ្ទៃមេឃ និងផែនដីនឹងកន្លងផុតទៅ ប៉ុន្តែ ព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានសុចរិត និងសង្គ្រោះគេជាដរាបតរៀងទៅ"។ លោកគិតថា ពេលព្រះជាម្ចាស់ប្រោសអ្នកបាបឲ្យបានសុចរិត ព្រះអង្គសម្ដែងធម៌មេត្តាករុណាខ្លាំងជាងពេលព្រះអង្គបង្កើតទេវទូតទៀតផង។

១៩៩៥- ព្រះវិញ្ញាណដ៏វិសុទ្ធជាគ្រូក្នុងជម្រៅចិត្តមនុស្ស។ នៅពេលដែលព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានសុចរិត ព្រះអង្គបង្កើត "មនុស្សផ្នែកខាងក្នុងជម្រៅចិត្ត" (រម ៧,២២ ; អភ ៣,១៦) បានសេចក្ដីថា ព្រះអង្គប្រោសមនុស្សទាំងមូលឲ្យបានវិសុទ្ធ៖

ពីដើម បងប្អូនបានប្រគល់សរីរាង្គកាយរបស់បងប្អូនឲ្យធ្វើជាខ្ញុំបម្រើនៃអំពើសៅហ្មង និងអំពើទុយ៌ស ដែលនាំឲ្យប្រឆាំងនឹងព្រះជាម្ចាស់យ៉ាងណា ឥឡូវនេះ ចូរបងប្អូនប្រគល់សរីរាង្គកាយរបស់បងប្អូនធ្វើជាខ្ញុំបម្រើនៃសេចក្ដីសុចរិតដើម្បីឲ្យបងប្អូនបានវិសុទ្ធយ៉ាងនោះដែរ (...)។ ឥឡូវនេះ បងប្អូនបានរួចពីអំណាចបាបមកបម្រើព្រះជាម្ចាស់វិញ បងប្អូនទទួលផល ដែលធ្វើឲ្យបងប្អូនទៅជាវិសុទ្ធ ដើម្បីឲ្យមានជីវិតអស់កល្បជានិច្ច (រម ៦,១៩.២២)។

## ២. ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់

១៩៩៦- ព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិតមកពីព្រះអង្គប្រណីសន្ដោសយើង។ ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្ដោស បានសេចក្ដីថា ព្រះអង្គប្រទានព្រះអំណោយទានសង្គ្រោះយើង ដើម្បីឲ្យ យើងអាច

ឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះអង្គ គឺឲ្យយើងក្លាយទៅជាបុត្រធីតារបស់ព្រះអង្គ (យហ ១,១២-១៨) (រម ៨,១៤-១៧) មានលក្ខណៈជាព្រះជាម្ចាស់ (២ពត្រ ១,៣-៤) និងឲ្យយើងទទួលជីវិតអស់កល្បជានិច្ច (យហ ១៧,៣)។

១៩៩៧- ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ប្រោសយើង ឲ្យទទួលព្រះជន្មរបស់ព្រះជាម្ចាស់ ប្រោសយើង ឲ្យចូលរួមជាមួយព្រះត្រៃឯកយ៉ាងស្និទ្ធស្នាល គឺដោយសារពិធីជ្រមុជទឹក គ្រីស្ដបរិស័ទរួមចំណែកក្នុងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្ដ ជាព្រះសិរសានៃព្រះកាយព្រះអង្គ។ ដូច "បុត្រម្នាក់" យើងអាចហៅព្រះជាម្ចាស់ថា "ព្រះបិតា" រួមជាមួយព្រះបុត្រាតែមួយ។ យើងទទួលជីវិតពីព្រះវិញ្ញាណ ដែលចាក់បង្ហូរសេចក្ដីស្រឡាញ់ ហើយដែលបង្កើតព្រះសហគមន៍។

១៩៩៨- ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យទទួលជីវិតអស់កល្បជានិច្ច ជាការត្រាស់ហៅហួសធម្មជាតិ ដែលពឹងផ្អែកទាំងស្រុងលើព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដ្បិតមានតែព្រះអង្គទេ ដែលអាចសម្ដែងព្រះអង្គ និងប្រទានព្រះកាយព្រះអង្គផ្ទាល់។ ទោះបីមនុស្ស ឬសត្វលោកណាមួយមានបំណងយ៉ាងណាក៏ដោយ ក៏គេពុំមានសមត្ថភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ឆ្លើយតបនឹងព្រះជាម្ចាស់ ដែលត្រាស់ហៅគេឡើយ (១ករ ២,៧-៩)។

១៩៩៩- ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្ដជាព្រះអំណោយទាន ដែលព្រះជាម្ចាស់ប្រទានមកយើងដោយប្រោសព្រះជន្មរបស់ព្រះអង្គ ដែលព្រះវិញ្ញាណចាក់បង្ហូរក្នុងព្រលឹងយើង ដើម្បីឲ្យព្រលឹងនេះ បានរួចពីបាប និងបានវិសុទ្ធ គឺជាព្រះហឫទ័យប្រណីសន្ដោស ដែលប្រោសយើងឲ្យបានវិសុទ្ធ ឬឲ្យបានមានលក្ខណៈជាព្រះជាម្ចាស់ ដែលយើងទទួលក្នុងពិធីជ្រមុជទឹក។ ព្រះហឫទ័យប្រណីសន្ដោសនេះ ជាប្រភពក្នុងខ្លួនយើង ដែលនាំឲ្យយើងវិសុទ្ធ (យហ ៤,១៤;៧,៣៨-៣៩)៖

> ប្រសិនបើនរណាម្នាក់រួបរួមជាមួយព្រះគ្រីស្ដ អ្នកនោះនឹងបានកើតជាថ្មី អ្វីៗពីអតីតកាលបានកន្លងផុតទៅ ហើយអ្វីៗទាំងអស់បានប្រែមកជាថ្មីវិញ។ អ្វីៗទាំងនោះកើតមកពីព្រះជាម្ចាស់ ដែលសម្រុះសម្រួលយើង ឲ្យជានានឹងព្រះអង្គវិញ ដោយសារព្រះគ្រីស្ដ ហើយប្រទានឲ្យយើងមានមុខងារសម្រុះសម្រួលមនុស្សម្នា ឲ្យជានានឹងព្រះអង្គវិញដែរ (២ករ ៥,១៧-១៨)។

២០០០- ដោយព្រះជាម្ចាស់ប្រោសប្រណីយើងឲ្យបានវិសុទ្ធ ព្រះអង្គប្រទានព្រះអំណោយទាន ជាអចិន្ត្រៃយ៍ដ៏ស្ថិតស្ថេរ និងហួសធម្មជាតិ ដែលធ្វើឲ្យព្រលឹងអាចរួមជាមួយព្រះជាម្ចាស់បាន និងប្រព្រឹត្តដោយសារសេចក្ដីស្រឡាញ់របស់ព្រះអង្គ។ ត្រូវតែវែកញែកការប្រណីសន្ដោសជាអចិន្ត្រៃយ៍ដើម្បីឲ្យយើងរស់នៅ និងប្រព្រឹត្តតាមអ្វីដែលព្រះជាម្ចាស់ត្រាស់ហៅយើង ពីការប្រណីសន្ដោសដ៏អស្ចារ្យ ដែលព្រះជាម្ចាស់ប្រោសប្រទានមកយើង ដើម្បីឲ្យយើងកែប្រែចិត្តគំនិត ឬដែលព្រះអង្គប្រោសយើងឲ្យបានវិសុទ្ធ។

២០០១- នៅពេលដែលមនុស្សរៀបចំខ្លួន ទទួលព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ តាមពិតព្រះអង្គបានប្រោសប្រណីគេរួចទៅហើយ។ យើងត្រូវការព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ជាចាំបាច់ ដើម្បីជំរុញ និងទ្រទ្រង់យើងឲ្យរួមសហការជាមួយព្រះអង្គ ដែលប្រោសយើងឲ្យបានសុចរិត ដោយសារជំនឿ និងប្រោសយើងឲ្យបានវិសុទ្ធ ដោយសារសេចក្ដីស្រឡាញ់។ ព្រះជាម្ចាស់បង្ហើយកិច្ចការ ដែលព្រះអង្គចាប់ផ្ដើមនៅក្នុងខ្លួនយើង ដ្បិត "ព្រះអង្គចាប់ផ្ដើម ដោយធ្វើតាមរបៀបដែលយើងចង់ ព្រះអង្គក៏បង្ហើយកិច្ចការនោះ ដោយរួមសហការជាមួយនឹងបំណងយើង ដែលព្រះអង្គបានកែរួចហើយ" (សន្ដអូគូស្ដាំង)៖

តាមពិត យើងធ្វើការដែរ ប៉ុន្តែយើងគ្រាន់តែធ្វើការជាមួយព្រះជាម្ចាស់ ដែលទ្រង់ធ្វើការ ដ្បិតធម៌មេត្តា

> ករុណារបស់ព្រះអង្គធ្វើការមុនយើង ដើម្បីឲ្យយើងបានជាសះស្បើយ។ ធម៌មេត្តាករុណាធ្វើការពីក្រោយយើងថែមទៀត ដើម្បីឲ្យយើងបានជីវិត ក្រោយពីបានជាសះស្បើយ។ ធម៌មេត្តាករុណាធ្វើការមុនយើង ដើម្បីត្រាស់ហៅយើងនិងធ្វើការពីក្រោយយើងដើម្បីឲ្យយើងទទួលសិរីរុងរឿង។ធម៌មេត្តាករុណាធ្វើការមុន ដើម្បីឲ្យយើងគោរពប្រណិប័តន៍ព្រះអង្គ និងធ្វើការក្រោយដើម្បីឲ្យយើងរួមជាមួយព្រះជាម្ចាស់អស់កល្បជានិច្ច ដ្បិតបើព្រះអង្គមិនគង់ជាមួយយើងទេ យើងធ្វើអ្វីមិនកើតឡើយ (សន្ត: អូគូស្តាំង)។

២០០២- ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ផ្ដើមត្រាស់ហៅមនុស្ស ឲ្យស្ម័គ្រចិត្តឆ្លើយតបនឹងព្រះអង្គ ដ្បិតព្រះអង្គបានបង្កើតមនុស្សជារូបតំណាងរបស់ព្រះអង្គ ដោយប្រគល់ឲ្យគេមានសេរីភាព និងអាចស្គាល់ និងស្រឡាញ់ព្រះអង្គ។ព្រលឹងរួបរួមជាមួយសេចក្តីស្រឡាញ់ ដោយមានសេរីភាពពេញលេញតែប៉ុណ្ណោះ។ ព្រះជាម្ចាស់ប៉ះពាល់ភ្លាមៗ និងជំរុញចិត្តមនុស្សតែម្តង។ ព្រះអង្គបានដាក់បំណងប្រថ្នាចង់បានសេចក្តីពិត និងអ្វីដ៏ល្អក្នុងចិត្តមនុស្ស ហើយមានតែព្រះអង្គទេ ដែលអាចបំពេញបំណងប្រាថ្នានេះ។ ព្រះបន្ទូលសន្យាអំពី "ជីវិតអស់កល្បជានិច្ច" បំពេញបំណងប្រាថ្នានេះ លើសពីសេចក្តីសង្ឃឹមទៀតទៀត៖

> ព្រះអង្គបានសម្រាកនៅថ្ងៃទីប្រាំពីរ ក្រោយពីបានបង្កើតអ្វីៗទាំងអស់ ដែលជាស្នាព្រះហស្តដ៏ល្អប្រសើរបំផុតរបស់ព្រះអង្គ ដើម្បីមានព្រះបន្ទូលមកយើងទុកជាមុន តាមរយៈគម្ពីររបស់ព្រះអង្គថា យើងនឹងសម្រាកនៅថ្ងៃសប្ប័ទនៃជីវិតអស់កល្បជានិច្ច នៅក្នុងអង្គព្រះអង្គ ក្រោយពីបានប្រព្រឹត្តកិច្ចការ "ដ៏ល្អប្រសើរ បំផុត" (ដ្បិតមកពីព្រះអង្គផ្ទាល់) របស់យើង (សន្ត: អូគូស្តាំង)។

២០០៣- ដោយសារព្រះហឫទ័យប្រណីសន្តោស ព្រះជាម្ចាស់ប្រោសប្រទានព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រោសយើងឲ្យបានសុចរិត និងឲ្យបានវិសុទ្ធ។ ម្យ៉ាងទៀត ព្រះហឫទ័យប្រណី សន្តោសរបស់ព្រះជាម្ចាស់ប្រទានឲ្យយើងព្រះអំណោយទានផ្សេងៗ ដែលព្រះវិញ្ញាណប្រទានយើង ដើម្បីឲ្យយើងរួមជាមួយព្រះអង្គក្នុងព្រះរាជកិច្ចរបស់ព្រះអង្គ គឺដើម្បីឲ្យយើងរួមសហការក្នុងការសង្គ្រោះអ្នកដទៃ និងឲ្យព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត រីកចម្រើនផងដែរ។ ព្រះអំណោយទានទាំងអស់នោះជាព្រះអំណោយទានខាងអគ្គសញ្ញា។ ម្យ៉ាងទៀត ព្រះជាម្ចាស់ក៏ប្រណីសន្តោសយ៉ាងពិសេស ដែលសន្ត: ប៉ូលហៅជាភាសាក្រិកថា ព្រះអំណោយទាន (LG ១២)។ទោះជាព្រះអំណោយទានអស្ចារ្យ ដូចជាអាចប្រព្រឹត្តការអស្ចារ្យ ឬអាចនិយាយភាសាចម្លែកក៏ដោយ ក៏ព្រះជាម្ចាស់ប្រទានព្រះអំណោយទាន ដើម្បីជួយបម្រើព្រះហឫទ័យប្រណីសន្តោសដែលប្រោសឲ្យបានវិសុទ្ធ ហើយដើម្បីផលប្រយោជន៍រួមរបស់ព្រះសហគមន៍។ ព្រះអំណោយទានជួយបម្រើសេចក្តីស្រឡាញ់ ដែលកសាងព្រះសហគមន៍ (១ករ ១២)។

២០០៤- ក្នុងចំណោមព្រះអំណោយទានពិសេស ត្រូវតែរំឭកអំពីព្រះអំណោយទាន ដែលជួយឲ្យអាចទទួលបន្ទុក និងបំពេញមុខងារដែលមានប្រយោជន៍សម្រាប់ព្រះសហគមន៍៖

> យើងមានព្រះអំណោយទានប្លែកៗពីគ្នា ស្របតាមព្រះហឫទ័យប្រណីសន្តោស ដែលព្រះជាម្ចាស់ប្រទានមកយើង។ ប្រសិនបើបងប្អូនណាទទួលព្រះអំណោយទានខាងថ្លែងព្រះបន្ទូល ត្រូវថ្លែងឲ្យស្របតាមជំនឿ។ អ្នកណាទទួលព្រះអំណោយទានខាងបម្រើ ចូរបម្រើទៅ។ អ្នកណាទទួលព្រះអំណោយទានខាងបង្រៀន ចូរបង្រៀនទៅ។ អ្នកដែលលើកទឹកចិត្តបងប្អូន ចូរលើកទឹកចិត្តគេទៅ។ អ្នកដែលចែកទ្រព្យរបស់ខ្លួនចូរចែកដោយចិត្តស្មោះសរ។ អ្នកដែលដឹកនាំ ចូរដឹកនាំដោយចិត្តខ្នះខ្នែង។ អ្នកដែលចែកទានដល់ជនក្រីក្រ ចូរចែកឲ្យគេដោយចិត្តត្រេកអរ (រម ១២,៦-៨)។

២០០៥- ដោយសារព្រះហឫទ័យប្រណីសន្ដោសហួសធម្មជាតិ យើងមិនអាចដកបទពិសោធន៍អំពីព្រះហឫទ័យប្រណីសន្ដោសនេះបានទេ។ មានតែតាមជំនឿទេ ដែលយើងអាចស្គាល់ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់។ ដូច្នេះ យើងមិនអាចពឹងផ្អែកលើអារម្មណ៍ ឬលើកិច្ចការផ្សេងៗរបស់យើង ដើម្បីសន្និដ្ឋានថា ព្រះជាម្ចាស់បានប្រោសយើងឲ្យបានសុចរិត និងបានសង្គ្រោះយើង (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៥៣៣-១៥៣៤)។ ក៏ប៉ុន្ដែ តាមព្រះបន្ទូលរបស់ព្រះអម្ចាស់៖ "អ្នករាល់គ្នាអាចស្គាល់គេបាន តាមអំពើដែលគេប្រព្រឹត្ដ" (មថ ៧,២០) បើយើងនឹកគិតដល់កិច្ចការដ៏ល្អរបស់ព្រះជាម្ចាស់ក្នុងជីវិតយើង និងក្នុងជីវិតរបស់ជនដ៏វិសុទ្ធ ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ពិតជាមានសកម្មភាពក្នុងខ្លួនយើង ហើយជំរុញយើងឲ្យផ្ញើជីវិត និងពឹងផ្អែកលើព្រះអង្គកាន់តែច្រើនឡើងៗ។

> ហេតុនេះហើយ បានជានៅពេលដែលចៅក្រមនៃតុលាការព្រះសហគមន៍ ដែលចង់ចាប់កំហុសគាត់ ដោយសួរគាត់ថា តើគាត់ស្ថិតក្នុងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ឬទេ សន្ដី យ៉ូហាន នៃអាក ឆ្លើយតបថា៖ "បើខ្ញុំមិននៅក្នុងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ទេ សូមឲ្យព្រះអង្គប្រណីសន្ដោសខ្ញុំ ហើយបើខ្ញុំនៅក្នុងព្រះហឫទ័យប្រណីសន្ដោសមែន សូមឲ្យព្រះអង្គទុកខ្ញុំនៅជាមួយផង"។

## ៣. បុណ្យកុសល

ជនដ៏វិសុទ្ធទាំងឡាយលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។ នៅពេលព្រះអង្គលើកតម្កើងបុណ្យកុសលរបស់គេ ព្រះអង្គក៏លើកតម្កើងព្រះអំណោយទានផ្ទាល់របស់ព្រះអង្គ (MR ធម៌ប្រារព្ធសន្ដះបុគ្គល)។

២០០៦- ជាធម្មតា ពាក្យ "បុណ្យកុសល" សំដៅទៅលើរង្វាន់ ឬទោស ដែលសហគមន៍ ឬសង្គមត្រូវតែផ្ដល់ឲ្យសមាជិករបស់ខ្លួនម្នាក់ ដែលបានប្រព្រឹត្ដអំពើល្អ ឬអាក្រក់។ បុណ្យកុសលទាក់ទងនឹងគុណធម៌នៃយុត្ដិធម៌ ដែលទាមទារឲ្យមានភាពស្មើគ្នា។

២០០៧- មនុស្សគ្មានសិទ្ធិ គ្មានបុណ្យកុសលចំពោះព្រះជាម្ចាស់ឡើយ គឺព្រះជាម្ចាស់ និងយើងមិនស្មើគ្នាទាល់តែសោះ ដ្បិតយើងបានទទួលអ្វីៗទាំងអស់ពីព្រះអង្គ ដែលជាព្រះបង្កើតយើង។

២០០៨- ក្នុងជីវិតរបស់គ្រីស្ដបរិស័ទ មនុស្សមានបុណ្យកុសលចំពោះព្រះជាម្ចាស់ ដ្បិតព្រះជាម្ចាស់ស្ម័គ្រចិត្តឲ្យមនុស្សរួមជាមួយព្រះអង្គក្នុងព្រះរាជកិច្ចនៃព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ។ ព្រះជាម្ចាស់ជាព្រះបិតាជំរុញមនុស្ស បន្ទាប់មក មនុស្សស្ម័គ្រចិត្តប្រព្រឹត្ដកិច្ចការ ដោយរួមសហការជាមួយព្រះអង្គ ហេតុនេះបុណ្យកុសលនៃអំពើល្អមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់សិន មុននឹងមកពីគ្រីស្ដបរិស័ទ។ តាមពិត បុណ្យកុសលរបស់មនុស្សត្រឡប់ទៅរបស់ព្រះជាម្ចាស់ផ្ទាល់ ដ្បិតគេប្រព្រឹត្ដអំពើល្អនៅក្នុងអង្គព្រះគ្រីស្ដ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធថែទាំ និងជួយសង្គ្រោះផង។

២០០៩- ដោយសារយើងជាបុត្រធីតារបស់ព្រះជាម្ចាស់ គឺយើងមានលក្ខណៈជាព្រះជាម្ចាស់ ដោយសារព្រះអង្គប្រោសប្រណីយើង យើងបានបុណ្យកុសលយ៉ាងពិតប្រាកដ តាមសេចក្ដីសុចរិតរបស់ព្រះអង្គ។ ព្រះជាម្ចាស់ប្រណីសន្ដោសប្រទានសិទ្ធិឲ្យយើងគឺសិទ្ធិនៃសេចក្ដីស្រឡាញ់ដែលធ្វើឲ្យយើងទទួល"មរតករួមជាមួយព្រះគ្រីស្ដ" ហើយសមនឹងទទួល "មរតកនៃជីវិតអស់កល្បជានិច្ច តាមព្រះបន្ទូលសន្យា" (មហាន្និបាតនៅទីក្រុងត្រង់៖ DS ១៥៤៦)។ បុណ្យកុសលនៃអំពើល្អរបស់យើង ជាព្រះអំណោយទាននៃសប្បុរសធម៌របស់ព្រះជាម្ចាស់ (មហាន្និបាតនៅទីក្រុងត្រង់៖ DS ១៥៤៨)។ "ព្រះហឫទ័យប្រណីសន្ដោសបានប្រតិបត្តិមុនយើង ឥឡូវនេះ យើងថ្វាយ

អ្វីដែលយើងជំពាក់ (...)។ បុណ្យកុសលជាព្រះអំណោយទានរបស់ព្រះជាម្ចាស់" (សន្ត: អូគូស្តាំង)។

២០១០- ព្រះជាម្ចាស់ប្រណីសន្តោសយើងទៅតាមកម្រិត គ្មាននរណាម្នាក់ស័ក្តិសមនឹងទទួលព្រះហឫទ័យប្រណីសន្តោសដំបូង ដែលប្រោសយើងឲ្យកែប្រែចិត្តគំនិត ទទួលការលើកលែងទោស និងប្រោសយើងឲ្យបានសុចរិត។ បន្ទាប់ពីព្រះវិញ្ញាណដ៏វិសុទ្ធ និងសេចក្តីស្រឡាញ់ជួយណែនាំ យើងស័ក្តិសមនឹងទទួល ព្រះអំណោយទាន ដែលមានប្រយោជន៍ដើម្បីឲ្យយើង និងអ្នកដទៃ បានវិសុទ្ធ ដើម្បីឲ្យព្រះហឫទ័យប្រណីសន្តោស និងសេចក្តីស្រឡាញ់រីកចម្រើនក្នុងខ្លួនយើង និងដើម្បីឲ្យយើងអាចទទួលជីវិតអស់កល្បជានិច្ច។ យើងអាចទទួលព្រះអំណោយទានខាងលោកីយ៍ ដូចជាសុខភាព មេត្រីភាព តាមព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។ ការអធិដ្ឋានរបស់គ្រីស្តបរិស័ទមានគោលដៅទទួលព្រះអំណោយទានទាំងអស់នោះ ហើយការអធិដ្ឋាននេះ ផ្តល់ព្រះហឫទ័យប្រណីសន្តោស ដែលយើងត្រូវការ ដើម្បីប្រព្រឹត្តអំពើបុណ្យកុសល។

២០១១- នៅក្នុងខ្លួនយើង សេចក្តីស្រឡាញ់របស់ព្រះគ្រីស្តជាប្រភពនៃបុណ្យកុសលទាំងអស់ ចំពោះព្រះជាម្ចាស់។ ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ប្រោសយើងឲ្យរួមជាមួយព្រះគ្រីស្ត ដោយចិត្តស្រឡាញ់យ៉ាងសកម្ម ធ្វើឲ្យអំពើរបស់យើងហួសធម្មជាតិ ទើបមានបុណ្យកុសលចំពោះព្រះជាម្ចាស់ ដូចចំពោះមនុស្សផងដែរ។ ជនដ៏វិសុទ្ធតែងតែយល់ឃើញថា បុណ្យកុសលរបស់គាត់ជាព្រះអំណោយទានសុទ្ធសាធនៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។

> ក្រោយពីបាននិរទេសនៅលើផែនដីនេះ ខ្ញុំម្ចាស់សង្ឃឹមថា នឹងរួបរួមជាមួយព្រះអង្គ នៅក្នុងមាតុភូមិ ប៉ុន្តែ ខ្ញុំម្ចាស់មិនចង់បានបុណ្យកុសលសម្រាប់ស្ថានបរមសុខទេ ខ្ញុំម្ចាស់ចង់ធ្វើការសម្រាប់តែសេចក្តីស្រឡាញ់របស់ព្រះអង្គប៉ុណ្ណោះ (...)។ នៅពេលល្ងាចនៃជីវិតនេះ ខ្ញុំម្ចាស់នឹងឈរដៃទទេខាងមុខព្រះអង្គ ពីព្រោះខ្ញុំមិនស័ក្តិសូមឲ្យព្រះអង្គរាប់កិច្ចការរបស់ខ្ញុំម្ចាស់ទេ។ អំពើទាំងអស់របស់យើងសុទ្ធតែប្រឡាក់ចំពោះព្រះនេត្ររបស់ព្រះអង្គ។ ដូច្នេះ ខ្ញុំចង់ស្លៀកពាក់សេចក្តីសុចរិតរបស់ព្រះអង្គផ្ទាល់ និងទទួលព្រះអង្គផ្ទាល់ ពីសេចក្តីស្រឡាញ់ របស់ព្រះអង្គ ជាដរាបតរៀងទៅ (សន្តី ថេរេសា នៃព្រះកុមារយេស៊ូ)។

## ៤. ភាពដ៏វិសុទ្ធរបស់គ្រីស្តសាសនា

២០១២- "យើងដឹងទៀតថា អ្វីៗទាំងអស់ផ្សំគ្នាឡើង ដើម្បីឲ្យអស់អ្នកស្រឡាញ់ព្រះជាម្ចាស់បានទទួលផលល្អ (...) ដ្បិតអស់អ្នកដែលព្រះអង្គបានជ្រើសរើស ទ្រង់ក៏បានតម្រូវទុកជាមុនឲ្យគេមានលក្ខណៈដូចព្រះបុត្រារបស់ព្រះអង្គដែរ ដើម្បីឲ្យព្រះបុត្រាបានទៅជារៀមច្បង ក្នុងបណ្តាបងប្អូនជាច្រើន។ អស់អ្នកដែលព្រះអង្គបានតម្រូវទុកជាមុននោះ ទ្រង់ក៏បានត្រាស់ហៅ ហើយអ្នកដែលព្រះអង្គបានត្រាស់ហៅនោះ ទ្រង់ក៏ប្រោសគេឲ្យបានសុចរិត រីឯអស់អ្នក ដែលព្រះអង្គប្រោសឲ្យបានសុចរិតនោះ ទ្រង់ក៏ប្រទានឲ្យគេមានសិរីរុងរឿងដែរ (រម ៨,២៨-៣០)។

២០១៣- "អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ទោះជាគេរស់នៅតាមរបៀបណាក្តី ឬមានឋានៈណាក្តី ក៏ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យរស់យ៉ាងពេញលក្ខណៈជាគ្រីស្តបរិស័ទ និងឲ្យមានសេចក្តីស្រឡាញ់យ៉ាងពេញលក្ខណៈដែរ" (LG ៤០)។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យទៅជាជនដ៏វិសុទ្ធ៖ "ព្រះបិតារបស់អ្នករាល់គ្នាដ៏ខ្ពង់ខ្ពស់បំផុតគ្រប់លក្ខណ៍យ៉ាងណា សូមឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍យ៉ាងនោះដែរ" (មថ ៥,៤៨)។

គ្រីស្តបរិស័ទត្រូវយកកម្លាំង ដែលខ្លួនបានទទួលតាមកម្រិតនៃព្រះអំណោទានរបស់ព្រះគ្រីស្តមកប្រើ

ដើម្បីឲ្យបានវិសុទ្ធគ្រប់លក្ខណៈ។ (...) ដោយបំពេញព្រះហឫទ័យព្រះបិតាក្នុងគ្រប់ប្រការ និងបូជាកម្លាំងចិត្ត កម្លាំងកាយលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតា និងបម្រើអ្នកដទៃផង។ ធ្វើដូច្នេះ ទើបលក្ខណៈវិសុទ្ធនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់នឹងបង្កើតផលផ្លែជាច្រើន ដូចរបៀបរស់នៅរបស់សន្តៈបុគ្គលជាច្រើនអនេក ដែលប្រវត្តិសាស្ត្រព្រះសហគមន៍ជាសាក្សីស្រាប់ (LG ៤០)។

២០១៤- យើងរីកចម្រើនខាងវិញ្ញាណ ដោយរួមជាមួយព្រះគ្រីស្តកាន់តែជិតស្និទ្ធឡើងៗ។ គេហៅការរួបរួមជាមួយព្រះអង្គនេះថា ការរួបរួម "ដ៏អាថ៌កំបាំង" ដ្បិតយើងរួមចំណែកក្នុងអាថ៌កំបាំងរបស់ព្រះគ្រីស្ត ដោយសារអគ្គសញ្ញា - ជា "អាថ៌កំបាំងដ៏វិសុទ្ធ" - និងក្នុងអាថ៌កំបាំងនៃព្រះត្រៃឯក ដោយសារព្រះអង្គដែរ។ ព្រះជាម្ចាស់ត្រាស់ហៅយើងទាំងអស់គ្នាឲ្យរួមយ៉ាងស្និទ្ធស្នាលជាមួយព្រះអង្គ ទោះបី ព្រះអង្គប្រទានព្រះអំណោយទានពិសេស ឬសញ្ញាសម្គាល់ដ៏អស្ចារ្យនៃជីវិតដ៏អាថ៌កំបាំងនេះ ឲ្យអ្នកខ្លះតែប៉ុណ្ណោះ ដើម្បីសម្តែងព្រះអំណោយទានដែលព្រះអង្គប្រទានសម្រាប់មនុស្សទាំងអស់យ៉ាងណាក៏ដោយ។

២០១៥- យើងត្រូវតែដើរតាមផ្លូវនៃឈើឆ្កាង ដើម្បីឲ្យបានវិសុទ្ធគ្រប់លក្ខណៈ។ បើយើងមិនលះបង់ និងមិនតស៊ូខាងវិញ្ញាណទេ យើងមិនអាចទៅជាជនដ៏វិសុទ្ធបានឡើយ (២ធម ៤)។ យើងរីកចម្រើនខាងវិញ្ញាណលុះត្រាតែ យើងធ្វើទុក្ករកិរិយា និងលត់ដំខ្លួន ដើម្បីរស់នៅក្នុងសន្តិភាព និងអំណរសប្បាយនៃសុភមង្គលយ៉ាងពិតប្រាកដ៖

អ្នកដែលឡើង ទៅពីដំណាក់កាលដំបូងទៅដំណាក់កាលដំបូង ដោយមិនចេះឈប់ តាមរយៈដំណាក់កាលដំបូង ដែលគ្មានទីបញ្ចប់ឡើយ។ អ្នកណាឡើងតែងតែប្រាថ្នាចង់បានអ្វីដែលខ្លួនស្គាល់ហើយ (សន្តៈគ្រេគ័រ នៃនីស)។

២០១៦- បុត្រធីតានៃព្រះមាតារបស់យើង ជាព្រះសហគមន៍ដ៏វិសុទ្ធសង្ឃឹមថា ព្រះជាម្ចាស់ជាព្រះបិតារបស់គេនឹងប្រោសប្រណីគេឲ្យមានចិត្តព្យាយាមរហូតដល់ទីបំផុត ហើយនឹងផ្តល់រង្វាន់ ដើម្បីកិច្ចការដ៏ល្អ ដែលគេបានប្រព្រឹត្តរួមជាមួយព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ ព្រមទាំងរួមរស់ជាមួយព្រះយេស៊ូផងដែរ (មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៥៧៦)។ ដោយរក្សាទុកក្បួនជីវិតដដែល អ្នកជឿរួបរួមក្នុង "សេចក្តីសង្ឃឹមដ៏គ្មានទីបញ្ចប់" ជាមួយអស់អ្នក ដែលធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ប្រមូលផ្តុំក្នុង "ក្រុងដ៏វិសុទ្ធ ជាក្រុងយេរូសាឡឹមថ្មី ចុះពីស្ថានបរមសុខ គឺចុះមកពីព្រះជាម្ចាស់ ទាំងតុបតែងខ្លួនដូចភរិយាថ្មោងថ្មីរង់ចាំទទួលស្វាមី" (វវ ២១,២)។

## សង្ខេប

២០១៧- ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសយើងឲ្យបានសុចរិត។ ដោយផ្ញើជីវិតលើព្រះយេស៊ូគ្រីស្ត និងដោយសារអគ្គសញ្ញាជ្រមុជទឹក យើងរួមរស់ជាមួយព្រះគ្រីស្ត ដែលសោយទិវង្គត និងមានព្រះជន្មថ្មី ព្រះវិញ្ញាណប្រោសយើងឲ្យរួមចំណែកក្នុងព្រះជន្មរបស់ព្រះអង្គ។

២០១៨- នៅពេលដែលមនុស្សទៅជាសុចរិត ឬកែប្រែចិត្តគំនិត គេបានផលពីរយ៉ាង គឺដោយមានព្រះហឫទ័យប្រណីសន្តោសជំរុញគេ មនុស្សបែរទៅរកព្រះជាម្ចាស់ និងឃ្លាតឆ្ងាយពីអំពើបាប ទើបទទួលការលើកលែងទោស និងសេចក្តីសុចរិតនៃស្ថានលើ។

២០១៩- នៅពេលដែលព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានសុចរិត ព្រះអង្គលើកលែងទោសឲ្យគេ ប្រោសគេ

ឲ្យបានវិសុទ្ធ និងកែចិត្តគំនិតរបស់គេឡើងវិញ។

២០២០- ព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិត ដោយសារគុណបុណ្យនៃទុក្ខលំបាករបស់ព្រះគ្រីស្ត ដែលបានបូជាព្រះជន្មនៅលើឈើឆ្កាង។ ព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិតតាមពិធីជ្រមុជទឹក។ ព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិតដូចព្រះអង្គសុចរិតផងដែរ។យើងទៅជាមនុស្សសុចរិតដើម្បីសិរីរុងរឿងនៃព្រះជាម្ចាស់ និងរបស់ព្រះគ្រីស្ត និងដើម្បីទទួលព្រះអំណោយទាននៃជីវិតអស់កល្បជានិច្ច។ ពេលព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានសុចរិត ព្រះអង្គក៏បង្ហាញធម៌មេត្តាករុណារបស់ព្រះអង្គយ៉ាងអស្ចារ្យជាទីបំផុត។

២០២១- ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្ដោស បានសេចក្ដីថា ព្រះអង្គប្រទានព្រះអំណោយទានសង្គ្រោះយើង ដើម្បីឲ្យយើងអាចឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះអង្គ គឺឲ្យយើងទៅជាបុត្រធីតារបស់ព្រះអង្គ។ ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ប្រោសយើងឲ្យចូលរួមជាមួយព្រះត្រៃឯកយ៉ាងស្និទ្ធស្នាល។

២០២២- ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់រៀបចំ និងជំរុញមនុស្សឲ្យស្ម័គ្រចិត្តឆ្លើយតបនឹងព្រះអង្គ។ ដោយព្រះជាម្ចាស់ប្រោសប្រណី ព្រះអង្គក៏បំពេញចិត្តគំនិតមនុស្សយ៉ាងជ្រាលជ្រៅចំពោះសេរីភាព ហើយត្រាស់ហៅគេឲ្យស្ម័គ្រចិត្តរួមសហការជាមួយព្រះអង្គ ព្រមទាំងប្រោសសេរីភាពនេះឲ្យបានពេញលេញ។

២០២៣- ដោយព្រះជាម្ចាស់ប្រោសប្រណីយើងឲ្យបានវិសុទ្ធ ព្រះអង្គប្រទានព្រះជន្មផ្ទាល់របស់ព្រះ អង្គឲ្យយើង ដែលព្រះវិញ្ញាណដ៏វិសុទ្ធចាក់បង្ហូរក្នុងព្រលឹងយើង ដើម្បីប្រោសព្រលឹងនេះឲ្យបានជាសះស្បើយពីអំពើបាប និងឲ្យបានវិសុទ្ធផងដែរ។

២០២៤- ដោយព្រះជាម្ចាស់ប្រោសប្រណីយើងឲ្យបានវិសុទ្ធ យើងអាច "គាប់ព្រះហឫទ័យរបស់ព្រះ ជាម្ចាស់"។ ព្រះអំណោយទាន ដែលមកពីព្រះហឫទ័យពិសេសនៃព្រះវិញ្ញាណដ៏វិសុទ្ធ ស្ថិតនៅក្រោមព្រះហឫទ័យប្រណីសន្ដោសដែលប្រោសឲ្យបានវិសុទ្ធ ហើយមានគោលដៅ គឺផលប្រយោជន៍រួមរបស់ព្រះសហគមន៍។ ព្រះជាម្ចាស់ប្រណីសន្ដោសយ៉ាងអស្ចារ្យជាច្រើនលើកច្រើនសា តាមរបៀបប្លែកពីព្រះហឫទ័យជាអចិន្ត្រៃយ៍ ដែលស្ថិតក្នុងខ្លួនយើងជារៀងរហូត។

២០២៥- យើងមានបុណ្យកុសលចំពោះព្រះជាម្ចាស់ ព្រោះតែព្រះអង្គមានគម្រោងការឲ្យមនុស្សចូល រួមក្នុងព្រះរាជកិច្ចដ៏ប្រោសប្រណីរបស់ព្រះអង្គ។ ជាដំបូង បុណ្យកុសលមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ក្រោយមកមកពីមនុស្សរួមសហការជាមួយព្រះអង្គ។ បុណ្យកុសលរបស់មនុស្សមកពីព្រះជាម្ចាស់។

២០២៦- ដោយសារយើងជាបុត្រធីតារបស់ព្រះជាម្ចាស់ ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធអាចប្រោសប្រទានបុណ្យកុសលពិតប្រាកដឲ្យយើង តាមសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់។ ចំពោះព្រះជាម្ចាស់ក្នុងខ្លួនយើង សេចក្ដីស្រឡាញ់ជាប្រភពសំខាន់បំផុតនៃបុណ្យកុសល។

២០២៧- គ្មាននរណាម្នាក់សមនឹងទទួលព្រះហឫទ័យប្រណីសន្ដោសដើមដំបូង ដែលបានប្រោសយើង ឲ្យកែប្រែចិត្តគំនិតឡើយ។ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជួយណែនាំ យើងស័ក្តិសមនឹងទទួលព្រះអំណោយទានដែលមានប្រយោជន៍ដើម្បីឲ្យយើង និងអ្នកដទៃ អាចមានជីវិតអស់កល្បជានិច្ច ដូចទ្រព្យសម្បត្តិលោកីយ៍ចាំបាច់ផងដែរ។

២០២៨- "ព្រះជាម្ចាស់ត្រាស់ហៅអស់អ្នក ដែលផ្ញើជីវិតទៅលើព្រះគ្រីស្ត ឲ្យរស់យ៉ាងពេញលក្ខណៈជាគ្រីស្តបរិស័ទ និងឲ្យមានសេចក្ដីស្រឡាញ់យ៉ាងពេញលក្ខណៈដែរ" (LG ៤០)។ "ភាពល្អឥតខ្ចោះរបស់ គ្រីស្តសាសនា

មានព្រំដែនតែមួយគត់ គឺគ្មានកំណត់ព្រំដែនឡើយ" (សន្ត: គ្រែគ័រ នៃនីស)។

២០២៩- "បើអ្នកណាចង់ដើរតាមខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំចុះ" (មថ ១៦,២៤)។

## ប្រការទី៣៖

## ព្រះសហគមន៍ជាមាតាអប់រំយើង

២០៣០- គ្រីស្តបរិស័ទបំពេញការត្រាស់ហៅរបស់ខ្លួន ក្នុងព្រះសហគមន៍ ដោយរួបរួមជាមួយគ្រីស្តបរិស័ទទាំងអស់។ គេទទួលពីព្រះសហគមន៍ការប្រៀនប្រដៅនៃ "វិន័យរបស់ព្រះគ្រីស្ត" (កាឡ ៦,២) ដែលមានក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គេទទួលពីព្រះសហគមន៍ព្រះអំណោយទាននៃអគ្គសញ្ញា ដែលទ្រទ្រង់គេនៅតាម "ផ្លូវ"។ គេរៀនពីព្រះសហគមន៍ឲ្យយកតម្រាប់តាមជនដ៏វិសុទ្ធ ដែលព្រះនាងព្រហ្មចារិនីម៉ារីដ៏វិសុទ្ធបំផុតជារូបតំណាង និងជាប្រភព ដែលផ្តល់សក្ខីភាព ក្នុងប្រពៃណីខាងវិញ្ញាណ និងប្រវត្តិដ៏យូរអង្វែង និងដែលពិធីបុណ្យលើកតម្កើង។

២០៣១- ការរស់នៅខាងសីលធម៌ដូចជាពិធីបុណ្យខាងវិញ្ញាណ។ យើង "ថ្វាយខ្លួនទៅព្រះអង្គទុកជាយញ្ញបូជាដ៏មានជីវិត ដ៏វិសុទ្ធ ហើយជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់" (រម ១២,៣) ក្នុងព្រះកាយព្រះគ្រីស្ត ដែលយើងជាសិរីរាង្គ ដោយរួបរួមក្នុងតង្វាយនៃពិធីអរព្រះគុណរបស់ព្រះអង្គ។ ក្នុងពិធីបុណ្យ និងពិធីប្រារព្ធអគ្គសញ្ញានានា ការអធិដ្ឋាន និងការប្រៀនប្រដៅប្រមូលផ្តុំគ្នា រួមជាមួយព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្ត ដើម្បីបំភ្លឺ និងបំប៉នកិច្ចការរបស់គ្រីស្តបរិស័ទ។ ដូចការរស់នៅទាំងស្រុងរបស់គ្រីស្តបរិស័ទ ពិធីអភិបូជាជាប្រភព និងជាកំពូលនៃការរស់ប្រកបដោយសីលធម៌។

### ១. ការរស់នៅប្រកបដោយសីលធម៌ និងក្រុមមេដឹកនាំព្រះសហគមន៍

២០៣២- ព្រះសហគមន៍ ដែលជា "សសរ និងជាគ្រឹះទ្រទ្រង់សេចក្តីពិត" (១ធម ៣,១៥) "បានទទួលព្រះបញ្ញាដ៏ឧឡារិករបស់ព្រះគ្រីស្តពីក្រុមគ្រីស្តទូត ឲ្យប្រកាសសេចក្តីពិតអំពីការសង្គ្រោះ" (LG ១៧)។ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ព្រះសហគមន៍ត្រូវប្រកាសគោលការណ៍នៃសីលធម៌ សូម្បីតែគោលការណ៍ដែលទាក់ទងនឹងរបៀបរៀបរយក្នុងសង្គមផងដែរ ហើយត្រូវវិនិច្ឆ័យអ្វីៗនៅលើផែនដី ដើម្បីការពារសិទ្ធិគ្រឹះរបស់មនុស្ស និងការសង្គ្រោះរបស់ព្រលឹង" (CIC ៧៤៧)។

២០៣៣- ក្រុមគង្វាលជាអ្នកដឹកនាំព្រះសហគមន៍ បង្រៀនសីលធម៌ ក្នុងការអប់រំជំនឿ និងក្នុងធម៌ទេសនាដោយស្នាដៃរបស់ទេវវិទូ និងរបស់អ្នកនិពន្ធខាងវិញ្ញាណជួយផងដែរ។ ហេតុនេះហើយ បានជាក្រោមការណែនាំ និងការប្រុងប្រយ័ត្នរបស់ពួកគង្វាល "បញ្ញាត្តិ" នៃសីលធម៌ខាងគ្រីស្តសាសនា ពោលគឺក្បួនច្បាប់ បទបញ្ញា និងគុណធម៌ពិសេសៗជាច្រើន ដែលមកពីជំនឿលើព្រះគ្រីស្ត និងដែលសេចក្តីស្រឡាញ់ផ្តល់ជីវិត បានបញ្ជូនពីជំនាន់មួយទៅជំនាន់មួយទៀត។ តាមប្រពៃណី វិន័យដប់ប្រការ ដែលប្រកាសគោលការណ៍នៃការរស់នៅប្រកបដោយសីលធម៌សម្រាប់មនុស្សទាំងអស់ ជាមូលដ្ឋាននៃការអប់រំជំនឿនេះ រួមជាមួយធម៌ប្រកាសជំនឿ និងសេចក្តីអធិដ្ឋាន "ឱព្រះបិតានៃយើងខ្ញុំ"។

២០៣៤- សម្តេចប៉ាប និងអស់លោក ដែល "ជាគ្រូគួរឲ្យទុកចិត្ត គឺជាគ្រូដែលទទួលអំណាចរបស់ព្រះគ្រីស្ត។ អស់លោកប្រកាសជំនឿឲ្យប្រជារាស្ត្រ ដែលព្រះជាម្ចាស់បានផ្ញើទុកមកឲ្យអស់លោក គឺជំនឿដែលបំភ្លឺ និងណែនាំចិត្តគំនិត និងកិរិយាមាយាទរបស់គេ" (LG ២៥)។ ការដឹកនាំធម្មតា និងសកលរបស់សម្តេចប៉ាប និងអស់លោកអភិបាល ដែលរួបរួមជាមួយសម្តេច ប្រៀនប្រដៅសេចក្តីពិតដែលត្រូវតែជឿ សេចក្តីស្រឡាញ់ដែលត្រូវអនុវត្ត និងសុភមង្គលយ៉ាងពិតប្រាកដដែលត្រូវតែសង្ឃឹមចំពោះគ្រីស្តបរិស័ទ។

២០៣៥- ក្រុមមេដឹកនាំរួមចំណែកក្នុងអំណាចរបស់ព្រះគ្រីស្ត តាមកម្រិតខ្ពង់ខ្ពស់ជាទីបំផុត ដោយឯកសិទ្ធិមិនអាចភ័ន្តច្រឡំបាន។ ក្រុមមេដឹកនាំមិនអាចភ័ន្តច្រឡំបាន អំពីសេចក្តីទាំងប៉ុន្មាន ដែលព្រះជាម្ចាស់សម្តែងឲ្យមនុស្សលោកស្គាល់ (LG ២៥) អំពីវិស័យទាំងអស់នៃលទ្ធិ ព្រមទាំងលទ្ធិនៃសីលធម៌ ដែលជាចាំបាច់ ដើម្បីរក្សា ពន្យល់ និងអនុវត្តសេចក្តីពិតនៃជំនឿដែលជួយសង្គ្រោះ (CDF)។

២០៣៦- ម្យ៉ាងទៀត ក្រុមមេដឹកនាំមានអំណាចលើបទបញ្ញាពិសេសនៃធម្មវិន័យធម្មជាតិ ដ្បិតព្រះបង្កើតសព្វព្រះហឫទ័យឲ្យយើងត្រូវអនុវត្តតាម ដើម្បីទទួលការសង្គ្រោះ។ ដោយរំឭកវិន័យធម្មជាតិ ក្រុមមេដឹកនាំព្រះសហគមន៍បំពេញមុខងាររបស់ខ្លួនក្នុងឋានៈជាព្យាការីគឺប្រកាសឲ្យមនុស្សលោកស្គាល់ឋានៈយ៉ាងពិតប្រាកដរបស់ខ្លួន ហើយរំឭកគេអំពីភារកិច្ចរបស់ខ្លួនចំពោះព្រះជាម្ចាស់ (DH ១៤)។

២០៣៧ ក្រុមមេដឹកនាំបង្រៀនធម្មវិន័យរបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានផ្ញើទុកឲ្យព្រះសហគមន៍ ឲ្យគ្រីស្តបរិស័ទ ដូចជាមាគ៌ានៃជីវិត និងសេចក្តីពិត។ ដូច្នេះ គ្រីស្តបរិស័ទមានសិទ្ធិ (CIC ២១៣) ទទួលបទបញ្ញារបស់ព្រះជាម្ចាស់ ដែលជួយសង្គ្រោះ គឺដែលជម្រះឲ្យគិតត្រឹមត្រូវ ហើយដែលព្យាបាលប្រាជ្ញារបស់មនុស្សដែលត្រូវរបួស ដោយមានព្រះហឫទ័យប្រណីសន្តោសជួយផងដែរ។ គ្រីស្តបរិស័ទមានភារកិច្ច អនុវត្តធម្មនុញ្ញ និងក្រិត្យវិន័យនៃអាជ្ញាធរត្រឹមត្រូវរបស់ព្រះសហគមន៍។ ទោះបីមាគ៌ាទាំងអស់នោះទាក់ទងនឹងកិរិយាមាយាទយ៉ាងណាក៏ដោយ ក៏ត្រូវតែស្តាប់បង្គាប់ដោយមានចិត្តស្រឡាញ់ដែរ។

២០៣៨- ព្រះសហគមន៍ត្រូវការឲ្យពួកគង្វាលធ្វើការអស់ពីចិត្តថ្លើម ព្រះសហគមន៍ក៏ត្រូវការវិទ្យាសាស្ត្ររបស់ទេវវិទូ គ្រីស្តបរិស័ទទាំងអស់ និងមនុស្សដែលមានឆន្ទៈល្អឲ្យចូលរួម ក្នុងកិច្ចការប្រៀនប្រដៅ និងអនុវត្តសីលធម៌នៃគ្រីស្តសាសនា។ ជំនឿ និងការអនុវត្តន៍ដំណឹងល្អផ្តល់ឲ្យម្នាក់ៗបទពិសោធន៍នៃជីវិត "ក្នុងអង្គព្រះគ្រីស្ត" ដែលបំភ្លឺគេ និងនាំគេឲ្យអាចគិតពិចារណាអំពីអ្វីដែលមកពីព្រះជាម្ចាស់ និងអ្វីដែលមកពីមនុស្ស ទៅតាមព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ (១ករ ២,១០-១៥)។ ហេតុនេះហើយ បានជាព្រះវិញ្ញាណដ៏វិសុទ្ធអាចប្រើអ្នកតូចតាចជាងគេដើម្បីបំភ្លឺអ្នកប្រាជ្ញ និងអ្នកដែលមានឋានៈដ៏ខ្ពង់ខ្ពស់។

២០៣៩- អ្នកទទួលមុខងារបម្រើត្រូវតែប្រតិបត្តិតាម ដោយមានចិត្តចង់បម្រើអ្នកដទៃដូចជាបងប្អូន និងចង់បម្រើព្រះសហគមន៍អស់ពីចិត្តថ្លើម ក្នុងព្រះនាមព្រះអម្ចាស់ (រម ១២,៨.១១)។ នៅពេលជាមួយគ្នានេះ មនសិការ របស់ម្នាក់ៗ រិះគិតពិចារណាអំពីកិច្ចការរៀងៗខ្លួន ត្រូវចៀសវាងមិនឲ្យគិតតែអំពីខ្លួនឯងប៉ុណ្ណោះ គឺគេត្រូវគិតអំពីប្រយោជន៍រួមឲ្យអស់ពីសមត្ថភាព ដែលធម្មវិន័យខាងសីលធម៌សម្តែង ពោលគឺធម្មវិន័យធម្មជាតិ និងធម្មវិន័យដែលព្រះជាម្ចាស់បានសម្តែងឲ្យយើងស្គាល់ ដែលជាវិន័យរបស់ព្រះសហគមន៍ និងការប្រែនប្រដៅរបស់ក្រុមមេដឹកនាំអំពីសីលធម៌។ មនសិការរបស់រៀងៗខ្លួនមិនត្រូវប្រឆាំងនឹងប្រាជ្ញា ធម្មវិន័យខាងសីលធម៌ ឬក្រុមមេដឹកនាំព្រះសហគមន៍ឡើយ។

២០៤០-ហេតុនេះហើយ បានជាគ្រីស្តបរិស័ទអាចរាប់ខ្លួនឯងទុកជាបុត្រធីតារបស់ព្រះសហគមន៍ កាន់តែខ្លាំង

ឡើងៗ។ គំនិតនេះមកពីព្រះអំណោយទានធម្មតានៃបុណ្យជ្រមុជទឹក ដែលបានបង្កើតយើងក្នុងផ្ទៃព្រះសហគមន៍ និងបានធ្វើឲ្យយើងទៅជាសិរីរាង្គនៃព្រះកាយព្រះគ្រីស្ត។ ដោយយកចិត្តទុកដាក់លើយើងដូចជាមាតា ព្រះសហគមន៍ផ្តល់ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់មកយើង ដែលឈ្នះអំពើបាបទាំងអស់របស់យើង ហើយដែលប្រតិបត្តិយ៉ាងពិសេសក្នុងអគ្គសញ្ញាលើកលែងទោស។ ដូចមាតាម្នាក់ដែលថែទាំកូនៗរបស់ខ្លួន ព្រះសហគមន៍ផ្តល់ចំណីអាហារនៃព្រះបន្ទូល និងពិធីអរព្រះគុណព្រះអម្ចាស់ ក្នុងពិធីបុណ្យរបស់ខ្លួន ពីមួយថ្ងៃទៅមួយថ្ងៃ។

## ២. បទបញ្ញារបស់ព្រះសហគមន៍

២០៤១- បទបញ្ញាព្រះសហគមន៍ស្ថិតក្នុងការរស់នៅប្រកបដោយសីលធម៌ ដែលទាក់ទងនឹងពិធីបុណ្យ។ ពិធីបុណ្យជួយបំប៉នការរស់នៅខាងសីលធម៌នេះ។ ត្រូវតែគោរពវិន័យទាំងអស់នោះ ដែលអាជ្ញាធរព្រះសហគមន៍តាក់តែង ដើម្បីឲ្យគ្រីស្តបរិស័ទអធិដ្ឋាន មានរបៀបរស់នៅស្របតាមសីលធម៌ និងស្រឡាញ់ព្រះជាម្ចាស់ និងអ្នកដទៃកាន់តែច្រើនឡើងៗ៖

២០៤២- វិន័យទីមួយសុំឲ្យគ្រីស្តបរិស័ទចូលរួមក្នុងពិធីអរព្រះគុណនៃព្រះសហគមន៍នៅថ្ងៃរំឭកព្រះអម្ចាស់មានព្រះជន្មថ្មី (CIC ១២៤៦-១២៤៨ ; CCEO ៨៨១,១.២.៤)។

- វិន័យទីពីរសុំឲ្យគ្រីស្តបរិស័ទរៀបចំខ្លួននឹងថ្វាយអភិបូជា ដោយទទួលអគ្គសញ្ញាលើកលែងទោស ដែលបន្តកិច្ចការនៃពិធីជ្រមុជទឹក ដែលគ្រីស្តបរិស័ទបានចាប់ផ្តើមកែប្រែចិត្តគំនិត និងទទួលការលើកលែងទោស (CIC ៩៨៩ ; CCEO ៧១៩)។

វិន័យទីបីសុំឲ្យគ្រីស្តបរិស័ទទទួលព្រះកាយ ព្រះលោហិតព្រះគ្រីស្តយ៉ាងហោចណាស់មួយឆ្នាំម្តង ក្នុងឱកាសបុណ្យចម្លង ដែលជាប្រភព និងជាស្នូលនៃពិធីបុណ្យខាងគ្រីស្តសាសនា (CIC ៩២០ ; CCEO ៧០៨ ; ៨៨១,៣)។

២០៤៣- វិន័យទីបួនសុំឲ្យគ្រីស្តបរិស័ទចូលរួមក្នុងពិធីបុណ្យសំខាន់ៗ ដែលលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ព្រហ្មចារិនីម៉ារី និងសន្តះបុគ្គល (CIC ១២៤៦ ; CCEO ៨៨១,១.៤ ; ៨៨០,៣)។

- វិន័យទីប្រាំសុំឲ្យគ្រីស្តបរិស័ទតមអាហារ និងលត់ដំខ្លួន ដើម្បីរៀបចំខ្លួនថ្វាយពិធីបុណ្យផ្សេងៗ ដើម្បីជួយយើងឲ្យគ្រប់គ្រងកិលេសតណ្ហា និងឲ្យមានសេរីភាព (CIC ១២៤៩-១២៥១ ; CCEO ៨៨២)។
- ទីបញ្ចប់ គ្រីស្តបរិស័ទត្រូវតែជួយឧបត្ថម្ភព្រះសហគមន៍តាមសមត្ថភាពរបស់រៀងៗខ្លួន (CIC ២២២)។

## ៣. របៀបរស់នៅប្រកបដោយសីលធម៌ និងសក្ខីភាពសម្រាប់អ្នកដទៃ

២០៤៤- គ្រីស្តបរិស័ទត្រូវតែមានចិត្តស្មោះស ដើម្បីប្រកាសដំណឹងល្អ និងដើម្បីបេសកកម្មនៃព្រះសហគមន៍ក្នុងពិភពលោក។ សក្ខីភាពនៃរបៀបរស់នៅរបស់គ្រីស្តបរិស័ទត្រូវបញ្ជាក់សារនៃការសង្គ្រោះ និងសម្តែងឲ្យមនុស្សលោកដឹងថា សារនេះ ពោរពេញដោយកម្លាំងនៃសេចក្តីពិត និងពោរពេញដោយពន្លឺ។ "សក្ខីភាពនៃរបៀបរស់នៅរបស់គ្រីស្តបរិស័ទ និងកិច្ចការដែលគេប្រព្រឹត្ត ដោយមានចិត្តគំនិតហួសធម្មជាតិ មានឫទ្ធានុភាពអាចទាក់ទាញមនុស្សឲ្យផ្ញើជីវិតទៅលើព្រះជាម្ចាស់បាន" (AA ៦)។

២០៤៥- ដោយសារគេជាសរីរាង្គនៃព្រះកាយ ដែលព្រះគ្រីស្តជាព្រះសិរសា (អភ ១,២២) គ្រីស្តបរិស័ទជួយកសាងព្រះសហគមន៍ ដោយមានជំនឿ និងសីលធម៌យ៉ាងរឹងមាំ។ ព្រះសហគមន៍រីកចម្រើន និងលូតលាស់ដោយសារគ្រីស្តបរិស័ទវិសុទ្ធ (LG ៣៩) រហូតដល់យើង "ទៅជាមនុស្សពេញវ័យ ដល់កម្ពស់របស់ព្រះគ្រីស្តដែលបំពេញអ្វីៗទាំងអស់" (អភ ៤,១៣)។

២០៤៦- ដោយមានរបៀបរស់នៅស្របតាមព្រះគ្រីស្ត គ្រីស្តបរិស័ទធ្វើឱ្យព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមកដល់ "ជាព្រះរាជ្យនៃយុត្តិធម៌ សេចក្តីពិត និងសេចក្តីសុខសាន្ត" (MR ធម៌ប្រារព្ធនៃព្រះគ្រីស្តជាព្រះមហាក្សត្រ)។ ក៏ប៉ុន្តែ គេមិនបោះបង់ចោលភារកិច្ចរបស់គេនៅលើផែនដីនេះទេ គេបំពេញភារកិច្ចនោះដោយមានចិត្តអត់ធ្មត់ និងពោរពេញដោយសេចក្តីស្រឡាញ់ ដោយមានចិត្តស្មោះត្រង់នឹងម្ចាស់របស់គេផង។

## សង្ខេប

២០៤៧- នៅពេលដែលយើងរស់នៅតាមសីលធម៌ យើងគោរពប្រណិប័តន៍ព្រះជាម្ចាស់។ ពិធីបុណ្យ និងការប្រារព្ធអគ្គសញ្ញាបំប៉នកិច្ចការរបស់គ្រីស្តបរិស័ទ។

២០៤៨- បទបញ្ញារបស់ព្រះសហគមន៍ទាក់ទងនឹងជីវិតខាងសីលធម៌ និងជីវិតជាគ្រីស្តបរិស័ទ ដោយរួមជាមួយនឹងពិធីបុណ្យ និងយកពិធីបុណ្យនេះធ្វើជាអាហារ។

២០៤៩- ជាធម្មតា ពួកគង្វាលព្រះសហគមន៍ដឹកនាំព្រះសហគមន៍ខាងសីលធម៌ ដោយការអប់រំជំនឿ និងដោយទេសនា ដោយយកវិន័យដប់ប្រការជាគ្រឹះ ដែលចែងអំពីគោលការណ៍នៃការរស់នៅប្រកបដោយសីលធម៌សម្រាប់មនុស្សទាំងអស់។

២០៥០- សម្តេចប៉ាប និងពួកអភិបាល ដែលជាគ្រូបណ្ឌិតដ៏ពិតប្រាកដ ទេសនាចំពោះប្រជារាស្ត្ររបស់ព្រះជាម្ចាស់អំពីជំនឿ ដែលត្រូវតែជឿ និងអនុវត្តក្នុងរបៀបរស់នៅ។ ម្យ៉ាងទៀត ពួកលោកត្រូវតែជួយដោះស្រាយបញ្ហាខាងសីលធម៌ ដែលមកពីធម្មវិន័យធម្មជាតិ និងពីប្រាជ្ញា។

២០៥១- ក្រុមមេដឹកនាំមិនអាចភ័ន្តច្រឡំអំពីវិស័យទាំងអស់នៃលទ្ធិ ព្រមទាំងលទ្ធិនៃសីលធម៌ ដែលជាចាំបាច់ដើម្បីរក្សា ពន្យល់ និងអនុវត្តសេចក្តីពិតនៃជំនឿដែលជួយសង្គ្រោះបានទេ។

# វិន័យដប់ប្រការ

| សេរីភាព ២០,២-១៧ | ទុតិយកថា ៥,៦-២១ | |
|---|---|---|
| យើងព្រះអម្ចាស់ ជាព្រះរបស់អ្នក យើងបាននាំ អ្នក ចេញពីស្រុកអេស៊ីប ជាស្រុកដែលអ្នកធ្វើជាទាសករ។ | យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នក យើងបាននាំអ្នកចាកចេញពីស្រុកអេស៊ីប ជាស្រុកដែលអ្នកធ្វើជាទាសករ។ | |
| មិនត្រូវគោរពព្រះណាផ្សេង ក្រៅពីយើងឡើយ។ | មិនត្រូវគោរពព្រះណាផ្សេងក្រៅពីយើងឡើយ។ | ត្រូវក្រាបថ្វាយបង្គំ និងស្រឡាញ់ព្រះតែមួយគត់។ |
| មិនត្រូវឆ្លាក់រូបអ្វី ឬយកវត្ថុដែលជាតំណាងអ្វីមួយនៅលើមេឃ នៅលើផែនដី ឬនៅក្នុងទឹកក្រោមដីធ្វើជាព្រះឡើយ។ | | |
| មិនត្រូវក្រាបថ្វាយបង្គំ រូបព្រះទាំងនោះ ឬគោរពបម្រើរូបទាំងនោះឡើយ។ យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នក យើងមិនចង់ឲ្យអ្នកជំពាក់ចិត្តនឹងព្រះណាផ្សេង ក្រៅពីយើងឡើយ។ ប្រសិនបើនរណាក្បត់ចិត្តយើង យើងនឹងដាក់ទោសគេចាប់ពីឪពុករហូតដល់កូនចៅបីបួនតំណ ផ្ទុយទៅវិញយើងនឹងសម្តែងសេចក្តីសប្បុរស រហូតដល់មួយពាន់តំណ ចំពោះអស់អ្នកដែលស្រឡាញ់ និងប្រតិបត្តិតាមបញ្ជារបស់យើង។ | | ត្រូវគោរព ព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ មិនត្រូវប្រមាថព្រះអង្គ និងមិនត្រូវស្បថឥតបានការ។ |
| មិនត្រូវយកព្រះនាម របស់ព្រះអម្ចាស់ ជាព្រះរបស់អ្នកទៅប្រើឥតបានការនោះឡើយ ដ្បិតព្រះអម្ចាស់នឹងមិនអត់អោនឲ្យអ្នក ដែលយកព្រះនាមរបស់ព្រះអង្គ ទៅប្រើឥតបានការរបៀបនេះ ជាដាច់ខាត។ | មិនត្រូវយកព្រះនាម របស់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ទៅប្រើឥតបានការនោះឡើយ។ | ត្រូវគោរពថ្ងៃ របស់ព្រះអម្ចាស់ ដោយបម្រើព្រះជាម្ចាស់អស់ពីចិត្ត។ |

| | | |
|---|---|---|
| ចូររំឭកថ្ងៃសប្ប័ទ ហើយញែកថ្ងៃនោះជាថ្ងៃដ៏វិសុទ្ធ។ អ្នកមានពេលប្រាំមួយថ្ងៃ សម្រាប់បំពេញកិច្ចការទាំងប៉ុន្មាន ដែលអ្នកត្រូវធ្វើ តែថ្ងៃទីប្រាំពីរ ជាថ្ងៃសប្ប័ទរបស់ព្រះអម្ចាស់ជាព្រះនៃអ្នក។ ដូច្នេះ នៅថ្ងៃនោះទាំងអ្នក ទាំងកូនប្រុសកូនស្រីរបស់អ្នក ទាំងអ្នកបម្រើប្រុសស្រី ទាំងសត្វពាហនៈ និងជនបរទេស ដែលរស់នៅជាមួយអ្នក មិនត្រូវធ្វើការអ្វីឡើយ ដ្បិតក្នុងរយៈពេលប្រាំមួយថ្ងៃ ព្រះអម្ចាស់បានបង្កើតផ្ទៃមេឃ ផែនដីសមុទ្រ និងរបស់សព្វសារពើ ដែលស្ថិតនៅទីទាំងនោះ។ នៅថ្ងៃទីប្រាំពីរព្រះអង្គសម្រាកហេតុនេះហើយបាន ជាព្រះអម្ចាស់ប្រទានពរដល់ថ្ងៃសប្ប័ទ ហើយញែកថ្ងៃនោះ ជាថ្ងៃដ៏វិសុទ្ធ។ | ចូរគោរពថ្ងៃសប្ប័ទ ហើយញែកថ្ងៃនោះទុកជាថ្ងៃដ៏វិសុទ្ធ។ | ត្រូវគោរពមាតាបិតា និងប្រធានរបស់អ្នក។ |
| ចូរគោរពមាតាបិតារបស់អ្នក ដើម្បីឲ្យអ្នកមានអាយុយឺនយូរ នៅលើដីដែលព្រះអម្ចាស់ ជាព្រះនៃអ្នកប្រទានដល់អ្នក។ | ចូរគោរពមាតា បិតារបស់អ្នក។ | កុំសម្លាប់មនុស្ស កុំប្រព្រឹត្តអំពើអាក្រក់ កុំស្អប់ ឬខឹងគេឡើយ។ |
| | | ត្រូវមានចិត្តបរិសុទ្ធ និងគ្រប់គ្រងខ្លួនឯង។ |
| កុំសម្លាប់មនុស្ស។ | កុំសម្លាប់មនុស្ស។ | កុំនិយាយដើមគេ កុំកុហកគេឡើយ។ |
| កុំប្រព្រឹត្តអំពើផិតក្បត់។ | កុំប្រព្រឹត្តអំពើផិតក្បត់។ | ចូរមានចិត្តគំនិត និងប្រាថ្នាបរិសុទ្ធ។ |
| កុំលួចប្លន់គេ។ | កុំលួចប្លន់គេ។ | |
| កុំធ្វើសាក្សីក្លែងក្លាយដែលនាំ ឲ្យអ្នកដទៃមានទោស។ | កុំធ្វើសាក្សីក្លែងក្លាយនាំឲ្យអ្នកដទៃមានទោស។ | កុំលោភលន់ ចង់បានទ្រព្យគេដោយប្រើកលល្បិចឡើយ។ |

កុំលោភលន់ ចង់បានផ្ទះរបស់អ្នកដទៃ កុំលោភលន់ ចង់បានប្រពន្ធគេ ឬក៏លោភលន់ ចង់បានអ្នកបម្រើប្រុស អ្នកបម្រើស្រីគោលា ឬអ្វីផ្សេងទៀត ដែលជារបស់គេឡើយ។

កុំលោភលន់ចង់បានប្រពន្ធគេ

កុំប៉ងប្រាថ្នាចង់បាន... ឬអ្វីផ្សេងទៀតរបស់គេឡើយ។

## ភាគទីពីរ៖

## វិន័យដប់ប្រការ

### "លោកគ្រូ! តើខ្ញុំត្រូវធ្វើអ្វី...?"

២០៥២- "លោកគ្រូ! តើខ្ញុំត្រូវប្រព្រឹត្តអំពើល្អអ្វីខ្លះ ដើម្បីឲ្យមានជីវិតអស់កល្បជានិច្ច?"។ ព្រះយេស៊ូឆ្លើយតបនឹងយុវបុរសម្នាក់ ដែលសួរនឹងសំណួរនេះ ថា ត្រូវតែទទួលស្គាល់ថា មានតែព្រះជាម្ចាស់ "ល្អ សប្បុរស" ជាអ្នកដ៏ល្អប្រសើរជាទីបំផុត និងជាប្រភពនៃអ្វីៗទាំងអស់ដ៏ល្អ"។ បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ "បើអ្នកចង់ចូលទៅក្នុងជីវិត ត្រូវប្រតិបត្តិតាមវិន័យទៅ" ហើយព្រះអង្គប្រកាសវិន័យ ដែលទាក់ទងនឹងសេចក្ដីស្រឡាញ់ចំពោះអ្នកដទៃ៖ "កុំសម្លាប់មនុស្ស កុំប្រព្រឹត្តអំពើផិតក្បត់ កុំលួចទ្រព្យសម្បត្តិគេ កុំនិយាយកុហកធ្វើឲ្យគេមានទោសចូរគោរពមាតាបិតា"។ ទីបញ្ចប់ ព្រះយេស៊ូសង្ខេបវិន័យទាំងអស់នោះ តាមរបៀបវិជ្ជមាន៖ "ចូរស្រឡាញ់បងប្អូនឯទៀត ដូចអ្នកស្រឡាញ់ខ្លួនឯងដែរ" (មថ ១៩,១៦-១៩)។

២០៥៣- បន្ទាប់ពីចម្លើយទីមួយនេះ ព្រះយេស៊ូបន្ថែមចម្លើយមួយទៀតគឺ៖ "បើអ្នកចង់បានល្អឥតខ្ចោះ ចូរយកទ្រព្យសម្បត្តិរបស់អ្នកទាំងប៉ុន្មានទៅលក់ ហើយចែកឲ្យជនក្រីក្រទៅ ធ្វើដូច្នេះ ទើបអ្នកបានសម្បត្តិសួគ៌ រួចសឹមអញ្ជើញមកតាមខ្ញុំ!" (មថ ១៩,២១)។ ចម្លើយនេះ មិនលុបបំបាត់ចម្លើយទីមួយឡើយ។ ត្រូវប្រតិបត្តិតាមវិន័យ ដើម្បីដើរតាមព្រះយេស៊ូគ្រីស្ត។ ព្រះអង្គមិនលុបបំបាត់ធម្មវិន័យទេ (មថ ៥,១៧) ប៉ុន្តែ ព្រះអង្គអញ្ជើញមនុស្សឲ្យយល់ឃើញថា ព្រះគ្រូរបស់ខ្លួនបំពេញធម្មវិន័យឲ្យបានគ្រប់លក្ខណៈ។ ក្នុងដំណឹងល្អតាមសន្តៈម៉ាកុស សន្តៈម៉ាថាយ និងសន្តៈលូកា រឿងដែលព្រះយេស៊ូត្រាស់ហៅយុវបុរស ជាអ្នកមាន ឲ្យដើរតាមព្រះអង្គ ដោយស្ដាប់បង្គាប់ព្រះអង្គដូចជាសាវ័កម្នាក់ និងដោយប្រតិបត្តិតាមវិន័យ ស្ថិតនៅក្នុងការត្រាស់ហៅឲ្យដាក់ខ្លួនជាអ្នកក្រ និងឲ្យរក្សាព្រហ្មចរិយធម៌ (មថ ១៩,៦-១២.២១.២៣-២៩)។ យើងមិនអាចបំបែកដំបូន្មានដែលមានចែងក្នុងដំណឹងល្អចេញពីធម្មវិន័យបានឡើយ។

២០៥៤- ព្រះយេស៊ូបានលើកយកវិន័យដប់ប្រការឡើងវិញ ប៉ុន្តែ ព្រះអង្គបានសម្ដែងឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រតិបត្តិក្នុងវិន័យជាលាយលក្ខណ៍អក្សរ។ ព្រះអង្គបានប្រកាស "សេចក្ដីសុចរិតប្រសើរជាងសេចក្ដីសុចរិតរបស់ពួកធម្មាចារ្យ និងពួកគណៈផារីស៊ី" (មថ ៥,២០) ដូចព្រះអង្គបានប្រកាសសេចក្ដីសុចរិតរបស់សាសន៍ដទៃផងដែរ (មថ ៥,៤៦-៤៧)។ ព្រះអង្គបានលាតសន្ធឹងការទាមទារទាំងប៉ុន្មាននៃធម្មវិន័យ។ "អ្នករាល់គ្នាធ្លាប់ឮសេចក្ដី ដែលមានថ្លែងប្រាប់បុព្វបុរសថា "កុំសម្លាប់មនុស្ស" (...) រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា អ្នកណាខឹងនឹងបងប្អូន អ្នកនោះនឹងត្រូវគេផ្ដន្ទាទោសដែរ" (មថ ៥,២១-២២)។

២០៥៥- នៅពេលដែលយើងទូលសួរព្រះអង្គថា៖ "ក្នុងធម្មវិន័យ តើមានវិន័យណាសំខាន់ជាងគេ?" (មថ ២២,៣៦) ព្រះយេស៊ូឆ្លើយតបថា៖ "ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា ហ្នឹងហើយជាវិន័យទីមួយដែលសំខាន់ជាងគេបំផុត។ រីឯវិន័យទីពីរក៏សំខាន់ដូចគ្នាដែរ គឺត្រូវស្រឡាញ់បងប្អូនឯទៀត ដូចអ្នកស្រឡាញ់ខ្លួនឯង។ វិន័យទាំងពីរនេះជាឫសគល់របស់ធម្មវិន័យ និងគម្ពីរព្យាការីទាំងអស់" (មថ ២២,៣៧-៤០) (ទក ៦,៥ ; លវ ១៩,១៨)។ ត្រូវបកស្រាយវិន័យដប់ប្រការក្រោមពន្លឺនៃវិន័យទាំងពីរនោះ ជាវិន័យតែមួយនៃសេចក្ដីស្រឡាញ់ ដែលបំពេញធម្មវិន័យឲ្យបានគ្រប់លក្ខណៈ៖

វិន័យដែលចែងថា កុំប្រព្រឹត្តអំពើផិតក្បត់ កុំសម្លាប់មនុស្ស កុំលួចទ្រព្យសម្បត្តិគេ កុំមានចិត្តលោភលន់ និងវិន័យឯទៀតៗមកសង្ខេបមកជាវិន័យតែមួយនេះថា ចូរស្រឡាញ់បងប្អូនឯទៀត ដូចអ្នកស្រឡាញ់ខ្លួនឯងដែរ។ អ្នកមានចិត្តស្រឡាញ់មិនដែលប្រព្រឹត្តអាក្រក់ដល់បងប្អូនឯទៀតឡើយ ដូច្នេះ សេចក្តីស្រឡាញ់នាំឲ្យប្រតិបត្តិតាមវិន័យបានពេញលក្ខណៈ (រម ១៣,៩-១០)។

## វិន័យដប់ប្រការក្នុងព្រះគម្ពីរដ៏វិសុទ្ធ

២០៥៦- ពាក្យ "វិន័យដប់ប្រការ" មានអត្ថន័យចំថា "ព្រះបន្ទូលទាំងដប់" (សរ ៣៤,២៨ ; ទក ៤,១៣ ; ១០,៤)។ព្រះជាម្ចាស់បានសម្តែងព្រះបន្ទូលទាំងដប់នោះ ឲ្យប្រជារាស្ត្ររបស់ព្រះអង្គស្គាល់ នៅលើភ្នំដ៏វិសុទ្ធ។ ព្រះអង្គបានសរសេរព្រះបន្ទូលនោះ "ដោយព្រះអង្គុលីរបស់ព្រះអង្គផ្ទាល់" (សរ ៣១,១៨ ; ទក ៥,២២) ខុសពីបទបញ្ញាឯទៀតៗដែលលោកម៉ូសេបានសរសេរ (ទក ៣១,៩.២៤)។ ព្រះបន្ទូលនោះ ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដ៏ប្រសើរក្រៃលែង ហើយត្រូវបានគេបញ្ចូលក្នុងកណ្ឌសេរីភាព(សរ២០,១-១៧)និងក្នុងកណ្ឌទុតិយកថា (ទក ៥,៦-២២)។ ចាប់តាំងពីសម្ព័ន្ធមេត្រីចាស់ គម្ពីរដ៏វិសុទ្ធយោងទៅតាម "ព្រះបន្ទូលទាំងដប់" (ហាស ៤,២ ; យរ ៧,៩ ; អគ ១៨,៥-៩) ប៉ុន្តែ សម្ព័ន្ធមេត្រីថ្មីនៅក្នុងអង្គព្រះយេស៊ូគ្រីស្តសម្តែងអត្ថន័យដ៏ពេញលក្ខណៈរបស់ព្រះបន្ទូលនោះ។

២០៥៧- ត្រូវយល់ថា វិន័យដប់ប្រការស្ថិតក្នុងកាលៈទេសៈនៃដំណើរឆ្ពោះទៅកាន់សេរីភាព ដែលជាហេតុការណ៍ដ៏អស្ចារ្យ ជាស្នូលនៃសម្ព័ន្ធមេត្រីចាស់ គឺព្រះជាម្ចាស់រំដោះព្រះជារាស្ត្ររបស់ព្រះអង្គ។ ទោះជាគេសរសេរបទបញ្ញាអវិជ្ជមាន ការហាមប្រាម ឬបទបញ្ញាវិជ្ជមាន (ដូចជា "ចូរគោរពមាតាបិតា") ក៏ដោយ ក៏ "ព្រះបន្ទូលទាំងដប់" បង្ហាញលក្ខខ័ណ្ឌនៃជីវិត ដែលព្រះជាម្ចាស់បានរំដោះឲ្យរួចពីអំពើបាប។ វិន័យដប់ប្រការជាផ្លូវនៃជីវិត៖

> ខ្ញុំបង្គាប់អ្នកនៅថ្ងៃនេះឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ហើយដើរតាមមាគ៌ារបស់ព្រះអង្គ កាន់តាមបទបញ្ញា ក្រឹត្យវិន័យ និងច្បាប់របស់ព្រះអង្គ។ ធ្វើដូច្នេះ ទើបអ្នករស់រានមានជីវិត និងកើនចំនួនច្រើនឡើង (ទក ៣០,១៦)។

យើងអាចយល់ឃើញឫទ្ធានុភាព ដែលជួយរំដោះនៃវិន័យដប់ប្រការនេះ ក្នុងបទបញ្ញាអំពីថ្ងៃសប្ប័ទជាថ្ងៃសម្រាក ដែលមានសម្រាប់ជនបរទេស និងទាសករផងដែរ៖

> អ្នកត្រូវនឹកចាំថា អ្នកធ្លាប់ធ្វើជាទាសករ នៅស្រុកអេស៊ីប ហើយព្រះអម្ចាស់ជាព្រះរបស់អ្នកបាននាំអ្នកចាកចេញពីទីនោះ ដោយឫទ្ធិបារមី និងតេជានុភាពរបស់ព្រះអង្គ។ ហេតុនេះហើយបានជាព្រះអម្ចាស់ជាព្រះរបស់អ្នកបង្គាប់ឲ្យអ្នកគោរពថ្ងៃសប្ប័ទ (ទក ៥,១៥)។

២០៥៨- "ព្រះបន្ទូលទាំងដប់" សង្ខេប និងប្រកាសធម្មវិន័យរបស់ព្រះជាម្ចាស់៖ "នេះហើយជាព្រះបន្ទូលដែលព្រះអម្ចាស់ថ្លែងមកកាន់ក្រុមជំនុំទាំងមូល ដោយបន្លឺព្រះសូរសៀងខ្លាំងៗ នៅលើភ្នំ ពីក្នុងភ្លើង ពពកនិងអ័ព្ទ។ ព្រះអង្គពុំមានព្រះបន្ទូលអ្វីបន្ថែមពីលើនេះទៀតទេ ព្រះអង្គបានចារព្រះបន្ទូលទាំងនោះនៅលើបន្ទះថ្មពីរ រួចប្រគល់មកឲ្យខ្ញុំ" (ទក ៥,២២)។ ហេតុនេះហើយ បានជាគេហៅបន្ទះថ្មទាំងពីរនោះថា "សន្ធិសញ្ញា" (សរ ២៥,១៦)។ តាមពិត ប្រការនៃសម្ព័ន្ធមេត្រីរវាងព្រះជាម្ចាស់ និងប្រជារាស្ត្ររបស់ព្រះអង្គស្ថិតក្នុងបន្ទះថ្មទាំងពីរនោះ។ ត្រូវតែដាក់ "បន្ទះថ្មជាសន្ធិសញ្ញា" (សរ ៣១,១៨ ; ៣២,១៥ ; ៣៤,២៩) នោះ ក្នុង "ហិប" (សរ ២៥,១៦; ៤០,១-២)។

២០៥៩- ព្រះជាម្ចាស់ប្រកាស "ព្រះបន្ទូលទាំងដប់" នៅពេលដែលព្រះអង្គសម្តែងព្រះអង្គឲ្យគេឃើញ ("ព្រះអម្ចាស់មានព្រះបន្ទូលនៅចំពោះមុខអ្នករាល់គ្នា នៅលើភ្នំ ពីកណ្តាលភ្នក់ភ្លើង"៖ ទក ៥,៤)។ ព្រះជាម្ចាស់សម្តែងព្រះអង្គផ្ទាល់ សិរីរុងរឿងរបស់ព្រះអង្គ ព្រមទាំងព្រះបន្ទូលទាំងដប់នោះផងដែរ។ ក្នុងការប្រទានវិន័យទាំងដប់ប្រការនេះ ព្រះអង្គបានប្រទានព្រះអង្គផ្ទាល់ និងព្រះហឫទ័យដ៏វិសុទ្ធផងដែរ។ ដោយសម្តែងព្រះហឫទ័យរបស់ព្រះអង្គ ៗក៏សម្តែងព្រះអង្គឲ្យប្រជារាស្ត្ររបស់ព្រះអង្គស្គាល់។

២០៦០- ព្រះអំណោយទាននៃវិន័យដប់ប្រការ និងធម្មវិន័យ ជាផ្នែកនៃសម្ព័ន្ធមេត្រី ដែលព្រះជាម្ចាស់បានចងជាមួយប្រជារាស្ត្ររបស់ព្រះអង្គ។ តាមកណ្តនៃដំណើរឆ្ពោះទៅកាន់សេរីភាព ព្រះជាម្ចាស់សម្តែង "ព្រះបន្ទូលទាំងដប់" ចន្លោះពេលដែលព្រះអង្គស្នើសុំសម្ព័ន្ធមេត្រី (សរ ១៩) និងទីបញ្ចប់នៃសម្ព័ន្ធមេត្រី (សរ ២៤) ក្រោយពីប្រជារាស្ត្របានសន្យា "ប្រព្រឹត្ត" តាមព្រះបន្ទូលទាំងអស់របស់ព្រះជាម្ចាស់ ហើយ "ប្រតិបត្តិតាម" (សរ ២៤,៧)។ ព្រះជាម្ចាស់ប្រគល់វិន័យដប់ប្រការក្រោយពីបានរំឭកនូវសម្ព័ន្ធមេត្រីតែប៉ុណ្ណោះ ("ព្រះអម្ចាស់ ជាព្រះនៃយើងបានចងសម្ពន្ធមេត្រីជាមួយដូនតារបស់យើង នៅលើភ្នំហូរែប"៖ ទក ៥,២)។

២០៦១- វិន័យដប់ប្រការទទួលអត្ថន័យពេញលេញនៅក្នុងសម្ព័ន្ធមេត្រី។ តាមព្រះគម្ពីរ ការប្រតិបត្តិតាមសីលធម៌របស់មនុស្សមានអត្ថន័យពេញលេញ នៅក្នុង និងតាមរយៈសម្ព័ន្ធមេត្រី។ ព្រះបន្ទូលទីមួយនៃ "ព្រះបន្ទូលដប់ប្រការ" រំឭកថា ព្រះជាម្ចាស់ស្រឡាញ់ប្រជារាស្ត្ររបស់ព្រះអង្គ៖

> ព្រះជាម្ចាស់បានដាក់ទោសមនុស្សលោក ដែលបានប្រព្រឹត្តអំពើបាប ដោយប្រោសគេឲ្យចេញពីស្ថានបរមសុខនៃសេរីភាពទៅធ្វើជាឈ្លើយនៃលោកីយ៍នេះ ហេតុនេះ ឃ្លាទីមួយនៃវិន័យដប់ប្រការ ដែលជាព្រះបន្ទូលដំបូងនៃធម្មវិន័យរបស់ព្រះជាម្ចាស់ ស្តីអំពីសេរីភាព៖ "យើងព្រះអម្ចាស់ ជាព្រះរបស់អ្នក យើងបាននាំអ្នកចេញពីស្រុកអេស៊ីបជាស្រុកដែលអ្នកធ្វើជាទាសករ" (សរ២០,២ ; ទក ៥,៦) (លោក អូរីសែន)។

២០៦២- ព្រះជាម្ចាស់ប្រកាសធម្មវិន័យ ក្រោយពីបានរំឭកអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គ ចំពោះប្រជារាស្ត្ររបស់ព្រះអង្គ ពោលគឺដោយសារសម្ព័ន្ធមេត្រី យើងជាកម្មសិទ្ធិរបស់ព្រះអង្គ ទើបយើងត្រូវតែគោរពវិន័យរបស់ព្រះអង្គ។ ការរស់នៅតាមសីលធម៌ជាចម្លើយ ចំពោះព្រះអម្ចាស់ ដែលស្រឡាញ់យើងមុន។ ដោយរស់នៅតាមសីលធម៌ យើងតបស្នងព្រះគុណព្រះជាម្ចាស់ លើកតម្កើង និងអរព្រះគុណព្រះអង្គ ហើយយើងរួមសហការជាមួយនឹងគម្រោងការរបស់ព្រះអង្គក្នុងប្រវត្តិសាស្ត្រ។

២០៦៣- លើសពីនេះទៅទៀត ដោយសារក្នុងកាតព្វកិច្ចទាំងប៉ុន្មាន ព្រះជាម្ចាស់មានព្រះបន្ទូលផ្ទាល់ ("យើងជាព្រះអម្ចាស់") ទៅកាន់មនុស្សម្នាក់ផ្សេងទៀត ("អ្នក") ព្រះអង្គក៏បញ្ជាក់សម្ព័ន្ធមេត្រី និងការសន្ទនារវាងព្រះអង្គ និងមនុស្ស។ ក្នុងវិន័យទាំងអស់របស់ព្រះជាម្ចាស់ ព្រះអង្គមានព្រះបន្ទូលទៅកាន់តែមនុស្សម្នាក់ៗ។ ព្រះអង្គក៏សម្តែងឲ្យមនុស្សម្នាក់ៗ ដឹងអំពីព្រះហឫទ័យព្រះអង្គជាមួយគ្នានេះដែរ ព្រះអង្គមានព្រះបន្ទូលឲ្យប្រជារាស្ត្រទាំងមូល។

> ព្រះអម្ចាស់បញ្ជាឲ្យយើងស្រឡាញ់ព្រះជាម្ចាស់ និងបង្រៀនឲ្យយើងប្រព្រឹត្តតាមយុត្តិធម៌ចំពោះអ្នកដទៃ ដើម្បីឲ្យទៅជាមនុស្សសុចរិត និងសក្តិសមនឹងព្រះជាម្ចាស់។ ហេតុនេះ ដោយសារវិន័យដប់ប្រការ ព្រះជាម្ចាស់រៀបចំមនុស្សឲ្យក្លាយទៅជាមិត្តសម្លាញ់របស់ព្រះអង្គ ហើយឲ្យគេមានចិត្តគំនិតតែមួយជាមួយអ្នកដទៃ(...)។ យើងជាគ្រីស្តបរិស័ទត្រូវអនុវត្តវិន័យដប់ប្រការនោះផងដែរ។ ដោយសារព្រះអម្ចាស់ប្រសូតជាមនុស្ស ព្រះអង្គមិនបានលុបបំបាត់ទេ ប៉ុន្តែ ព្រះអង្គបានធ្វើឲ្យវិន័យដប់ប្រការនោះបានចម្រើនឡើង។

## វិន័យដប់ប្រការក្នុងការបញ្ជូនបន្តនៃព្រះសហគមន៍

២០៦៤- ស្របតាមព្រះគម្ពីរ និងដោយយកតម្រាប់តាមព្រះយេស៊ូ ការបញ្ជូនបន្តព្រះសហគមន៍បានទទួលស្គាល់ថា វិន័យដប់ប្រការមានសារៈសំខាន់ ហើយមានអត្ថន័យសំខាន់ណាស់។

២០៦៥- ចាប់តាំងពីជំនាន់សន្តៈអូគូស្តាំងមក "វិន័យដប់ប្រការ" មានសារៈសំខាន់ណាស់ក្នុងការអប់រំជំនឿរបស់អ្នកស្វែងយល់ និងគ្រីស្តបរិស័ទ។ នៅសតវត្សទី១៥ យើងចាប់ផ្តើមសម្តែងវិន័យដប់ប្រការជាពាក្យកាព្យស្រួលចាំ និងតាមរបៀបវិជ្ជមាន រហូតដល់សព្វថ្ងៃនេះ។ ជារឿយៗ សៀវភៅអំពីលទ្ធិនៃគ្រីស្តសាសនាបានស្តីអំពីសីលធម៌តាមលំដាប់លំដោយនៃ "វិន័យដប់ប្រការ"។

២០៦៦- ក្នុងប្រវត្តិសាស្ត្រ យើងបានចែក និងបានរៀបចំវិន័យដប់ប្រការតាមរបៀបផ្សេងៗ។ សៀវភៅនេះដែលធ្វើតាមការរៀបចំរបស់សន្តៈអូគូស្តាំង បានទៅជាប្រពៃណីនៃព្រះសហគមន៍កាតូលិក និងសហគមន៍ខាងលូធែរផងដែរ។ គ្រូបាធ្យាយក្រិកបានចែកវិន័យដប់ប្រការតាមរបៀបផ្សេង ដែលមានក្នុងព្រះសហគមន៍អ័រតូដុក និងសហគមន៍ដែលមកពីការកែតម្រង់។

២០៦៧- វិន័យដប់ប្រការប្រកាសថា ត្រូវស្រឡាញ់ព្រះជាម្ចាស់ និងអ្នកដទៃ។ វិន័យទាំងបីដំបូងទាក់ទងនឹងសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ ឯវិន័យប្រាំពីរទៀត ទាក់ទងនឹងសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ។

- សេចក្តីស្រឡាញ់មានវិន័យពីរ ដែលព្រះអម្ចាស់មានព្រះបន្ទូលថា បំពេញធម្មវិន័យ និងព្យាការីទាំងអស់យ៉ាងណា (...) វិន័យដប់ប្រការចែកជាតុពីរយ៉ាងនោះដែរ។ វិន័យបីប្រការត្រូវគេសរសេរលើតុមួយ វិន័យប្រាំពីរប្រការលើតុមួយទៀត (សន្តៈ អូគូស្តាំង)។

២០៦៨- មហាសន្និបាតនៅទីក្រុងត្រង់ប្រៀនប្រដៅថា គ្រីស្តបរិស័ទ និងមនុស្សសុចរិតត្រូវតែប្រតិបត្តិតាមវិន័យដប់ប្រការ (DS ១៥៦៩-១៥៧០)។ មហាសន្និបាតនៅទីក្រុងវ៉ាទីកង់អះអាងថា៖ "ព្រះជាម្ចាស់ប្រទានឲ្យអស់លោកអភិបាល ក្នុងឋានៈជាអ្នកបន្តមុខងារពីក្រុមគ្រីស្តទូតមក មានបេសកកម្មបង្រៀនមនុស្សគ្រប់ជាតិសាសន៍ និងប្រកាសដំណឹងល្អដល់សត្វលោកទាំងឡាយ ដើម្បីឲ្យមនុស្សលោកទាំងអស់ទទួលការសង្គ្រោះ ដោយផ្ញើជីវិតលើព្រះគ្រីស្ត ដោយទទួលអគ្គសញ្ញាជ្រមុជទឹក និងដោយប្រព្រឹត្តតាមវិន័យទាំងប៉ុន្មាន" (LG ២៤)។

## ឯកភាពនៃវិន័យដប់ប្រការ

២០៦៩- យើងមិនអាចបំបែកវិន័យដប់ប្រការបានឡើយ។ "ព្រះបន្ទូល" នីមួយៗពឹងទៅលើព្រះបន្ទូលផ្សេងៗទៀត និងព្រះបន្ទូលទាំងអស់ផង។ តុទាំងពីរបំភ្លឺគ្នាទៅវិញទៅមក ហើយឯកភាពជាមួយគ្នា។ បើយើងប្រព្រឹត្តល្មើសប្រការតែមួយ យើងក៏ប្រព្រឹត្តល្មើសវិន័យទាំងអស់ផងដែរ (យក ២,១០-១១)។ យើងមិនអាចសរសើរអ្នកដទៃ បើយើងមិនលើកតម្កើងព្រះជាម្ចាស់ជាអ្នកបង្កើតគេទេ។ យើងមិនអាចក្រាបថ្វាយបង្គំព្រះជាម្ចាស់ បើយើងមិនស្រឡាញ់មនុស្សទាំងអស់ជាសត្វលោករបស់ព្រះអង្គឡើយ។ វិន័យដប់ប្រការធ្វើឲ្យការរស់នៅ ដើម្បីព្រះជាម្ចាស់ និងការរស់នៅក្នុងសង្គមឯកភាពជាមួយគ្នា។

## វិន័យដប់ប្រការ និងច្បាប់ធម្មជាតិ

២០៧០- យើងស្គាល់វិន័យដប់ប្រការ ដ្បិតព្រះជាម្ចាស់បានសម្តែងព្រះអង្គឲ្យយើងស្គាល់។ វិន័យដប់ប្រការបង្រៀនយើងឲ្យស្គាល់សភាពពិតប្រាកដរបស់មនុស្សផងដែរ។ វិន័យដប់ប្រការបំភ្លឺភារកិច្ចចាំបាច់ និងសិទ្ធិគ្រឹះ

ដែលជាលក្ខណៈនៃមនុស្សជាតិ។ វិន័យដប់ប្រការមាននៅក្នុងច្បាប់ដ៏សំខាន់នៃធម្មជាតិ៖

> តាំងពីដើមរៀងមក ព្រះជាម្ចាស់បានបណ្ដុះច្បាប់ធម្មជាតិក្នុងចិត្តមនុស្ស។ វិន័យដប់ប្រការគ្រាន់តែជាសេចក្ដីរំឭកប៉ុណ្ណោះ (សន្ដ អ៊ីរ៉េណេ)។

២០៧១- ទោះជាមិនពិបាកយល់ក៏ដោយ ក៏ព្រះជាម្ចាស់បានសម្ដែងវិន័យនេះ ដើម្បីឲ្យយល់យ៉ាងច្បាស់ និងយ៉ាងពិតប្រាកដ អំពីច្បាប់ធម្មជាតិ។ មនុស្ស ដែលជាអ្នកបាប ត្រូវការឲ្យព្រះអង្គសម្ដែងវិន័យដប់ប្រការ៖

> ព្រះជាម្ចាស់ត្រូវតែពន្យល់ឲ្យបានពេញលេញវិន័យដប់ប្រការ ពីព្រោះអំពើបាបបានធ្វើ ឲ្យពន្លឺនៃប្រាជ្ញាបានងងឹតងងល់ និងធ្វើឲ្យឆន្ទៈងាករេខុសផ្លូវ (សន្ដ ប៉ូណាវង់តឿ)។

> យើងស្គាល់វិន័យរបស់ព្រះជាម្ចាស់ ដោយសារការសម្ដែងរបស់ព្រះអង្គ ដែលព្រះសហគមន៍ណែនាំឲ្យយើងស្គាល់ និងដោយសារសម្លេងនៃមនសិការ។

## ត្រូវតែប្រតិបត្តិតាមវិន័យដប់ប្រការ

២០៧២- ដោយសារវិន័យដប់ប្រការសម្ដែងឲ្យយើងស្គាល់ភារកិច្ចរបស់មនុស្ស ចំពោះព្រះជាម្ចាស់ និងអ្នកដទៃដែលជាភារកិច្ចដ៏សំខាន់គឺយើងមិនអាចផ្លាស់ប្ដូរវិន័យដប់ប្រការនោះបានទេ ហើយយើងត្រូវតែប្រតិបត្តិតាមគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ គ្មាននរណាម្នាក់អាចគេចផុតពីការប្រតិបត្តិតាមវិន័យដប់ប្រការនោះបានឡើយ។ ព្រះជាម្ចាស់បានចារវិន័យដប់ប្រការក្នុងចិត្តគំនិតមនុស្សគ្រប់រូប។

២០៧៣- បើយើងធ្វើតាមបទបញ្ជា គឺយើងមានភារកិច្ច មិនជាធ្ងន់ធ្ងរប៉ុន្មានទេ។ ឧ- វិន័យទីប្រាំហាមប្រាមមិនឲ្យជេរប្រមាថគេ ប៉ុន្ដែ អំពើនេះ ខុសធ្ងន់ អាស្រ័យទៅលើកាលៈទេសៈ និងគោលបំណងរបស់អ្នកដែលប្រព្រឹត្តអំពើនេះ។

## "បើដាច់ពីខ្ញុំ អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតឡើយ"

២០៧៤- ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំនេះហើយជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក។ អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នកនោះ ទើបអ្នកនោះបង្កើតផលបានច្រើន។ បើដាច់ពីខ្ញុំ អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតឡើយ" (យហ ១៥,៥)។ ផលក្នុងព្រះបន្ទូលនេះ សំដៅទៅលើភាពដ៏វិសុទ្ធនៃជីវិតរបស់ម្នាក់ដែលរួបរួមជាមួយព្រះគ្រីស្ដ។ នៅពេលដែលយើងធ្វើជីវិតទៅលើព្រះគ្រីស្ដ រួបរួមក្នុងព្រឹត្តការណ៍ដ៏អស្ចារ្យរបស់ព្រះអង្គ និងរក្សាទុកវិន័យរបស់ព្រះអង្គ ព្រះសង្គ្រោះផ្ទាល់យាងមកគង់នៅក្នុងខ្លួនយើង ដើម្បីស្រឡាញ់ព្រះបិតា និងបងប្អូនរបស់ព្រះអង្គ គឺព្រះបិតា និងបងប្អូនរបស់យើង។ ដោយសារព្រះវិញ្ញាណ ព្រះអង្គផ្ទាល់ក្លាយទៅជាក្បួនវិន័យដ៏រស់រវើក និងដែលស្ថិតក្នុងខ្លួនយើង នៃកិច្ចការរបស់យើង។ "វិន័យរបស់ខ្ញុំមានដូចតទៅនេះ គឺអ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" (យហ ១៥,១២)។

## សង្ខេប

២០៧៥- "តើខ្ញុំត្រូវប្រព្រឹត្តអំពើល្អអ្វីខ្លះ ដើម្បីឲ្យមានជីវិតអស់កល្បជានិច្ច?-បើអ្នកចង់ចូលទៅក្នុងជីវិត ត្រូវប្រតិបត្តិតាមវិន័យទៅ" (មថ ១៩,១៦-១៧)។

២០៧៦- ដោយប្រតិបត្តិតាម និងដោយទេសនា ព្រះយេស៊ូបានបញ្ជាក់ថា វិន័យដប់ប្រការនៅតែមានតម្លៃ

ជានិច្ច។

២០៧៧- ព្រះជាម្ចាស់ប្រោសប្រទានព្រះអំណោយទាននៃវិន័យដប់ប្រការក្នុងសម្ព័ន្ធមេត្រី ដែលព្រះអង្គចង ជាមួយប្រជារាស្ត្រព្រះអង្គ។ បទបញ្ញារបស់ព្រះជាម្ចាស់ទទួលអត្ថន័យពិតប្រាកដក្នុង និងតាមសម្ព័ន្ធមេត្រីនេះ។

២០៧៨- ស្របតាមព្រះគម្ពីរ និងស្របតាមព្រះយេស៊ូ ដែលជាគំរូ ការបញ្ជូនបន្តព្រះសហគមន៍បានទទួល ស្គាល់ថា វិន័យដប់ប្រការមានសារៈសំខាន់ណាស់ និងមានអត្ថន័យជ្រាលជ្រៅណាស់។

២០៧៩- វិន័យដប់ប្រការជាសំណុំមួយ ដែល "ព្រះបន្ទូល" នីមួយៗ ឬ "បទបញ្ញា" នីមួយៗ សំដៅទៅ លើសំណុំនោះ។ បើយើងបំពានបទបញ្ញាតែមួយ យើងបំពានធម្មវិន័យទាំងមូលដែរ (យក ២,១០-១១)។

២០៨០- វិន័យដប់បប្រការផ្ទុកទៅដោយធម្មវិន័យធម្មជាតិយ៉ាងពិសេស។ យើងស្គាល់វិន័យដប់ប្រការ មកពី ព្រះជាម្ចាស់បានសម្ដែងឲ្យយើងស្គាល់ និងមកពីប្រាជ្ញារបស់មនុស្សផងដែរ។

២០៨១- វិន័យដប់ប្រការថ្លែងអំពីភារកិច្ចដ៏សំខាន់។ ក៏ប៉ុន្តែបើយើងធ្វើតាមបទបញ្ញា គឺយើងមានភារកិច្ច មិន ជាធ្ងន់ធ្ងរប៉ុន្មានទេ។

២០៨២- អ្វីដែលព្រះជាម្ចាស់បញ្ជា ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គជួយឲ្យធ្វើបានសម្រេច។

## ជំពូកទីមួយ៖

## "ត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នក

## ឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា"

២០៨៣- ព្រះយេស៊ូបានសង្ខេបភារកិច្ចរបស់មនុស្សចំពោះព្រះជាម្ចាស់ ដោយមានព្រះបន្ទូលថា៖ "ត្រូវ ស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា" (មថ២២,៣៧) (លក ១០,២៧៖ "អស់ពីកម្លាំង")។ ព្រះបន្ទូលនេះ ស្ថិតក្រោយការត្រាស់ហៅយ៉ាងឧឡារិក៖ "អ៊ីស្រាអែលអើយ ចូរស្ដាប់! មានតែព្រះអម្ចាស់ជាព្រះរបស់យើង" (ទក ៦,៤)។

- ព្រះជាម្ចាស់បានស្រឡាញ់មនុស្សមុនគេស្រឡាញ់ព្រះអង្គ។ ព្រះបន្ទូលទីមួយនៃ "ព្រះបន្ទូលទាំង ដប់" រំឭកនូវសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ជាព្រះតែមួយអង្គគត់។ បន្ទាប់មក ធម្មវិន័យពន្យល់ ចម្លើយនៃសេចក្ដីស្រឡាញ់ ដែលព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យថ្វាយទៅព្រះអង្គវិញ។

## ប្រការទី១៖

## វិន័យទីមួយ

យើងព្រះអម្ចាស់ ជាព្រះរបស់អ្នក យើងបាននាំអ្នកចេញពីស្រុកអេស៊ីប ជាស្រុកដែលអ្នកធ្វើជាទាសករ។ មិន ត្រូវគោរពព្រះណាផ្សេងក្រៅពីយើងឡើយ។ មិនត្រូវឆ្លាក់រូបអ្វី ឬយកវត្ថុដែលជាតំណាងអ្វីមួយនៅលើមេឃនៅ លើផែនដី ឬនៅក្នុងទឹកក្រោមដីធ្វើជាព្រះឡើយ។ មិនត្រូវក្រាបថ្វាយបង្គំរូបព្រះទាំងនោះ ឬគោរពបម្រើរូប ទាំងនោះឡើយ (សរ ២០,២-៥) (ទក ៥,៦-៩)។

ក្នុងគម្ពីរមានចែងថា "អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គប៉ុណ្ណោះ" (មថ ៤,១០)។

## ១. "ចូរកោតខ្លាចព្រះអម្ចាស់ ជាព្រះរបស់អ្នក ហើយគោរពបម្រើព្រះអង្គ"

២០៨៤- ព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យគេស្គាល់ ដោយរំឭកអំពីកិច្ចការដែលពោរពេញទៅដោយឫទ្ធានុភាព ដ៏សប្បុរស និងដែលជួយរំដោះរបស់ព្រះអង្គ ក្នុងប្រវត្តិរបស់អ្នកដែលព្រះអង្គមានព្រះបន្ទូលមកថា៖ "យើងបាននាំអ្នកចេញពីស្រុកអេស៊ីប ជាស្រុកដែលអ្នកធ្វើទាសករ"។ វិន័យទីមួយស្ថិតក្នុងព្រះបន្ទូលទីមួយ៖ "ចូរកោតខ្លាចព្រះអម្ចាស់ ជាព្រះរបស់អ្នក ហើយគោរពបម្រើព្រះអង្គ (...)។ មិនត្រូវជំពាក់ចិត្តជាមួយព្រះឯទៀតៗ" (ទក ៦,១៣-១៤)។ ជាដំបូង ព្រះជាម្ចាស់ត្រាស់ហៅ និងទាមទារយ៉ាងត្រឹមត្រូវឲ្យមនុស្សទទួលស្គាល់ និងក្រាបថ្វាយបង្គំព្រះអង្គ។

២០៨៥- មុនដំបូង ព្រះជាម្ចាស់ជាព្រះតែមួយគត់ និងជាព្រះដ៏ពិតប្រាកដសម្តែងសិរីរុងរឿងរបស់ព្រះអង្គឲ្យជនជាតិអ៊ីស្រាអែលស្គាល់ (សរ ១៩,១៦-២៥ ; ២៤,១៥-១៨)។ ដោយសារព្រះជាម្ចាស់សម្តែងព្រះអង្គៗក៏សម្តែងការត្រាស់ហៅ និងសេចក្តីពិតរបស់មនុស្សឲ្យមនុស្សស្គាល់ផងដែរ។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យសម្តែងព្រះអង្គដោយបំពេញកិច្ចការស្របតាមលក្ខណៈរបស់គេគឺ"ជារូបតំណាងនិងមានលក្ខណៈដូចព្រះជាម្ចាស់"៖

> លោកទ្រីផូនអើយ! តាំងពីដើមដំបូង និងជាដរាបតរៀងទៅ គ្មានព្រះណាផ្សេងទៀតទេ ក្រៅពីព្រះដែលបានបង្កើត និងប្រតិស្ឋានសកលលោក។ យើងមិនគិតថា ព្រះរបស់យើងខុសប្លែកពីព្រះរបស់អ្នករាល់គ្នាឡើយ។ ព្រះអង្គជាព្រះដដែល ដែលបាននាំបុព្វបុរសរបស់អ្នករាល់គ្នាឲ្យចាកចេញពីស្រុកអេស៊ីប "ដោយឫទ្ធានុភាពដ៏ខ្លាំងខ្លារបស់ព្រះអង្គ"។ យើងមិនជឿសង្ឃឹមលើព្រះណាផ្សេងទេ គ្មានព្រះណាផ្សេងទេ ប៉ុន្តែ យើងជឿសង្ឃឹមលើព្រះរបស់លោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប ជាព្រះរបស់អ្នករាល់គ្នាដែរ (សន្ត: យ៉ូស្តាំង)។

២០៨៦- "ជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ ស្ថិតនៅក្នុងវិន័យទីមួយ។ បើនិយាយអំពីព្រះជាម្ចាស់ យើងយល់ថា ជាសភាវៈដ៏ស្ថិតស្ថេរ ដែលមិនប្រែប្រួល ដដែលជានិច្ច ស្មោះត្រង់ និងសុចរិត ល្អឥតខ្ចោះ។ ដូច្នេះហើយ យើងត្រូវទទួលព្រះបន្ទូលរបស់ព្រះអង្គជានិច្ច និងផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គផងដែរ។ ព្រះអង្គជាព្រះដ៏មានឫទ្ធានុភាពសព្វប្រការ ដ៏ល្អសប្បុរស ដែលប្រព្រឹត្តអំពើល្អដោយគ្មានព្រំដែន។ តើនរណាមិនជឿ និងសង្ឃឹមលើព្រះអង្គ? ដោយគិតពិចារណាអំពីសប្បុរសធម៌ និងការថ្នាក់ថ្នម ដែលព្រះអង្គបានចាក់បង្ហូរលើពួកយើង តើនរណាមិនស្រឡាញ់ព្រះអង្គ? ដូច្នេះហើយ បានជាក្នុងព្រះគម្ពីរដ៏វិសុទ្ធ ព្រះអង្គមានព្រះបន្ទូលមុន ឬក្រោយបទបញ្ញារបស់ព្រះអង្គថា "យើងជាព្រះអម្ចាស់"" (CR ៣,២,៤)។

### ជំនឿ

២០៨៧- ប្រភពនៃការរស់នៅប្រកបដោយសីលធម៌របស់យើង ស្ថិតនៅក្នុងជំនឿចំពោះព្រះជាម្ចាស់ ដែលសម្តែងឲ្យយើងដឹងអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គ។ សន្ត: ប៉ូល មានប្រសាសន៍ថា "ការស្តាប់បង្គាប់នៃជំនឿ" (រម ១,៥ ; ១៦,២៦) ជាភារកិច្ចដំបូងបង្អស់។ លោកបន្ថែមទៀតថា "ការមិនស្គាល់ព្រះជាម្ចាស់" នាំឲ្យប្រព្រឹត្តអំពើខុសសីលធម៌ (រម ១,១៨-៣២)។ យើងមានភារកិច្ចចំពោះព្រះជាម្ចាស់ គឺផ្ញើជីវិតលើព្រះអង្គ និងផ្តល់សក្ខីភាពអំពីព្រះអង្គ។

២០៨៨-វិន័យទីមួយសុំឲ្យយើងបំប៉ន និងរក្សាជំនឿរបស់យើង ដោយមិនធ្វេសប្រហែស និងដោយប្រុងស្មារតី ហើយសុំឲ្យយើងបោះបង់ចោលអ្វីៗទាំងអស់ដែលប្រឆាំងនឹងជំនឿ។ យើងអាចប្រព្រឹត្តអំពើបាបប្រឆាំងនឹងជំនឿតាមរបៀបផ្សេងៗពីគ្នាដូចជា៖

- យើងអាចសង្ស័យដោយចេតនា ដោយមិនរវីរវល់ ឬបដិសេធមិនព្រមទទួលស្គាល់ថា អ្វីដែលព្រះជាម្ចាស់បានសម្តែង និងអ្វីដែលព្រះសហគមន៍ស្នើសុំឲ្យជឿជាការពិត។យើងសង្ស័យដោយអចេតនា នៅពេលដែលយើងនៅស្ទាក់ស្ទើរក្នុងការធ្វើជីវិតលើព្រះជាម្ចាស់ មិនចេះពុះពារឧបសគ្គផ្សេងៗ ដែលទាក់ទងនឹងជំនឿ ឬនៅពេលដែលយើងមានចិត្តអន្ទះសា ដោយសារជំនឿមិនទាន់ច្បាស់លាស់នៅឡើយ។ បើយើងសង្ស័យដោយមានបំណងសង្ស័យ យើងអាចវង្វេងខាងជំនឿបានដែរ។

២០៨៩- យើងមិនព្រមជឿ នៅពេលដែលយើងមិនរវីរវល់នឹងសេចក្តីពិត ដែលព្រះជាម្ចាស់បានសម្តែងឲ្យយើងស្គាល់ ឬនៅពេលដែលយើងបដិសេធមិនព្រមទទួលសេចក្តីពិតនេះ។ "ក្រោយពីបានទទួលពិធីជ្រមុជទឹក យើងឃ្លាតចាកពីសេចក្តីពិត នៅពេលដែលយើងប្រឆាំងជាដាច់ខាតនឹងសេចក្តីពិត ដែលត្រូវតែជឿ ឬនៅពេលដែលយើងសង្ស័យជាដាច់ខាតអំពីសេចក្តីពិតនេះ។ យើងអាចក្បត់ជំនឿផងដែរ គឺយើងបោះបង់ជំនឿចោល។ យើងអាចបែកចេញពីព្រះសហគមន៍ ដោយមិនព្រមស្តាប់បង្គាប់សម្តេចប៉ាប ឬមិនព្រមរួបរួមជាមួយសមាជិកព្រះសហគមន៍ ដែលស្ថិតក្រោមអំណាចរបស់សម្តេច" (CIC ៧៥១)។

## សេចក្តីសង្ឃឹម

២០៩០- នៅពេលដែលព្រះជាម្ចាស់សម្តែងព្រះអង្គ និងត្រាស់ហៅគេ មនុស្សមិនអាចឆ្លើយនឹងសេចក្តីស្រឡាញ់របស់ព្រះអង្គឲ្យបានគ្រប់លក្ខណៈដោយពឹងលើកម្លាំងរបស់ខ្លួនឯងបានឡើយ។ គេត្រូវសង្ឃឹមថា ព្រះជាម្ចាស់នឹងប្រទានឲ្យគេអាចស្រឡាញ់ព្រះអង្គវិញ និងអាចប្រតិបត្តិតាមវិន័យនៃសេចក្តីស្រឡាញ់។ សេចក្តីសង្ឃឹម គឺជាការរង់ចាំដោយជឿទុកចិត្ត ឲ្យព្រះជាម្ចាស់ប្រទានព្រះពរ និងឲ្យយើងនឹងមើលឃើញព្រះអង្គដោយមានសុភមង្គលពេញលេញ។ ការភ័យខ្លាចប្រព្រឹត្តអំពើខុសឆ្គងចំពោះសេចក្តីស្រឡាញ់របស់ព្រះអង្គ ដែលនាំឲ្យមានទោស ក៏ជាសេចក្តីសង្ឃឹមដែរ។

២០៩១- វិន័យទីមួយក៏សំដៅលើអំពើបាបប្រឆាំងនឹងសេចក្តីសង្ឃឹម ដែលជាភាពអស់សង្ឃឹម និងការអួតបំប៉ោងផងដែរ៖

- មនុស្សអាចលែងសង្ឃឹម ថា ព្រះជាម្ចាស់នឹងជួយសង្គ្រោះគេ ឬនឹងលើកលែងទោសឲ្យគេ។ ភាពអស់សង្ឃឹមប្រឆាំងនឹងសប្បុរសធម៌ សេចក្តីសុចរិតរបស់ព្រះអង្គ - ដ្បិតព្រះអម្ចាស់គោរពព្រះបន្ទូលសន្យា - និងធម៌មេត្តាករុណារបស់ព្រះអង្គជានិច្ច។
- យើងអាចអួតបំប៉ោង តាមរបៀបពីរយ៉ាង គឺយើងអាចអួតបំប៉ោងអំពីសមត្ថភាពរបស់ខ្លួន (យើងសង្ឃឹមថា អាចសង្គ្រោះខ្លួនឯង ដោយមិនបាច់ព្រះជាម្ចាស់យាងមកជួយ) ឬយើងស្មានថា ព្រះជាម្ចាស់នឹងសង្គ្រោះយើង ដោយមិនបាច់កែប្រែចិត្តគំនិត ឬព្រះអង្គនឹងប្រទានសិរីរុងរឿងមកយើង ដោយមិនបាច់ខិតខំប្រព្រឹត្តអំពើល្អ។

### សេចក្ដីស្រឡាញ់

២០៩៣- បើយើងជឿលើសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ព្រះអង្គត្រាស់ហៅយើង ហើយយើងក៏មានភារកិច្ចត្រូវតែឆ្លើយតបនឹងសេចក្ដីស្រឡាញ់នេះ ដោយចិត្តស្រឡាញ់យ៉ាងស្មោះ។ វិន័យទីមួយបញ្ជា ឲ្យយើងស្រឡាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់ និងស្រឡាញ់សត្វលោកទាំងអស់ ដើម្បីព្រះអង្គ និងដោយសារព្រះអង្គ (ទក ៦,៤-៥)។

២០៩៤- យើងអាចប្រព្រឹត្តអំពើបាបប្រឆាំងនឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់តាមរបៀបផ្សេងៗ៖ យើងអាចមិនអើពើ គឺមិនរវីរវល់ ឬបដិសេធមិនព្រមទទួលសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ មិនទទួលស្គាល់ថាសេចក្ដីស្រឡាញ់របស់ព្រះអង្គថ្នាក់ថ្នម មិនព្រមទទួលស្គាល់ឫទ្ធានុភាពនៃសេចក្ដីស្រឡាញ់។ មិនចេះដឹងគុណនៅពេលដែលយើងភ្លេច ឬមិនព្រមទទួលស្គាល់សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ និងស្រឡាញ់ព្រះអង្គវិញដូចព្រះអង្គបានស្រឡាញ់យើង។ មិនសូវខ្វះខ្វែង នៅពេលដែលយើងស្ទាក់ស្ទើរ ឬមិនរវីរវល់ឆ្លើយតបនឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ យើងក៏អាចបដិសេធមិនព្រមថ្វាយខ្លួនចំពោះសេចក្ដីស្រឡាញ់ផងដែរ។ ខ្ជិលច្រអូសខាងវិញ្ញាណ នៅពេលដែលយើងបដិសេធមិនព្រមទទួលអំណរ ដែលមកពីព្រះជាម្ចាស់ និងស្អប់ខ្ពើមអ្វីដ៏ល្អ ដែលមកពីព្រះអង្គ។ អាចស្អប់ ព្រះជាម្ចាស់ មកពីចិត្តក្រអឺតក្រអោង គឺប្រឆាំងនឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ មិនព្រមទទួលស្គាល់សប្បុរសធម៌របស់ព្រះអង្គ និងដាក់បណ្ដាសាព្រះអង្គ ដែលហាមប្រាមមិនឲ្យប្រព្រឹត្តអំពើបាប និងដែលផ្ដន្ទាទោសផងដែរ។

## ២. "មិនត្រូវគោរពព្រះណាផ្សេងក្រៅពីព្រះជាម្ចាស់ឡើយ"

២០៩៥- គុណធម៌ដែលព្រះជាម្ចាស់ប្រទាន គឺជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ ធ្វើឲ្យគុណធម៌ខាងសីលធម៌កើតជារូបរាង និងមានជីវិត។ ហេតុនេះ សេចក្ដីស្រឡាញ់ជំរុញយើងឲ្យថ្វាយព្រះជាម្ចាស់នូវអ្វីដែលយើងជំពាក់ព្រះអង្គ ដ្បិតយើងជាសត្វលោក។ គុណធម៌នៃសាសនា រៀបចំយើងឲ្យកាន់កិរិយាមាយាទនេះ។

### ការក្រាបថ្វាយបង្គំ

២០៩៦- ការក្រាបថ្វាយបង្គំជាកិច្ចការទីមួយរបស់គុណធម៌នៃសាសនា។ ពេលយើងក្រាបថ្វាយបង្គំព្រះជាម្ចាស់ យើងទទួលស្គាល់ថាព្រះអង្គជាព្រះជាព្រះបង្កើតជាព្រះសង្គ្រោះជាព្រះអម្ចាស់និងជាអ្នកគ្រប់គ្រងលើអ្វីៗទាំងអស់ ព្រះអង្គជាសេចក្ដីស្រឡាញ់ដែលគ្មានព្រំដែន និងពោរពេញដោយធម៌មេត្តាករុណា។ ដូចមានចែងទុកក្នុងទុតិយកថា (ទក ៦,១៣) ព្រះយេស៊ូមានព្រះបន្ទូលថា៖ "អ្នកត្រូវតែថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គមួយប៉ុណ្ណោះ" (លក ៤,៨)។

២០៩៧- យើងក្រាបថ្វាយបង្គំព្រះជាម្ចាស់ ដោយគោរពកោតខ្លាចព្រះអង្គ នៅក្រោមអំណាចរបស់ព្រះអង្គ និងទទួលស្គាល់ថា បើគ្មានព្រះជាម្ចាស់ទេ សត្វលោកដូចជា "សាបសូន្យ"។ យើងក្រាបថ្វាយបង្គំព្រះជាម្ចាស់ នៅពេលដែលយើងលើកតម្កើងសរសើរព្រះអង្គ និងបន្ទាបខ្លួនឯង ដូចព្រះនាងម៉ារី ដោយទទួលស្គាល់ថា ព្រះអង្គបានប្រព្រឹត្តការអស្ចារ្យ ហើយព្រះនាមរបស់ព្រះអង្គបានវិសុទ្ធ (លក ១,៤៦-៤៩)។ ពេលយើងក្រាបថ្វាយបង្គំព្រះជាម្ចាស់ ជាព្រះតែមួយអង្គគត់ យើងលែងគិតតែអំពីប្រយោជន៍ផ្ទាល់ខ្លួន យើងរួចអំពីអំពើបាប និងអំពីអំណាចលោកីយ៍។

### ការអធិដ្ឋាន

២០៩៨- ការអធិដ្ឋានបំពេញជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ ដែលវិន័យទីមួយបញ្ជាឲ្យប្រតិបត្តិ។ ដោយវិញ្ញាណឡើងទៅឯព្រះជាម្ចាស់ យើងគោរពក្រាបថ្វាយបង្គំព្រះជាម្ចាស់ គឺយើងលើកតម្កើងកោតសរសើរ អរព្រះគុណ ជួយអង្វរ និងទូលសុំអង្វរព្រះអង្គ។ ចាំបាច់ត្រូវតែអធិដ្ឋាន ដើម្បីអាចស្តាប់បង្គាប់បទបញ្ជារបស់ព្រះជាម្ចាស់។ "ត្រូវតែអធិដ្ឋានជានិច្ច មិនត្រូវរសាយចិត្តឡើយ" (លក ១៨,១)។

### យញ្ញបូជា

២០៩៩- យើងធ្វើតាមរបៀបត្រឹមត្រូវ នៅពេលដែលយើងថ្វាយយញ្ញបូជាចំពោះព្រះជាម្ចាស់ ជាសញ្ញាសម្គាល់ថា យើងក្រាបថ្វាយបង្គំ អរព្រះគុណ ទូលអង្វរ និងរួបរួមជាមួយព្រះអង្គ៖ "កិច្ចការណា ដែលយើងប្រព្រឹត្ត ដើម្បីរួមរស់ជាមួយព្រះជាម្ចាស់ ហើយដើម្បីទទួលសុភមង្គល ជាយញ្ញបូជាដ៏ពិតប្រាកដ" (សន្តៈ អូគូស្តាំង)។

២១០០- យញ្ញបូជាត្រូវតែបង្ហាញចិត្តគំនិត ដើម្បីទៅជាការបូជាដ៏ពិតប្រាកដ៖ "យញ្ញបូជា ដែលព្រះអង្គសព្វព្រះហឫទ័យឲ្យទូលបង្គំថ្វាយ គឺចិត្តសោកស្តាយ..." (ទន ៥១,១៩)។ ជារឿយៗ ព្យាការីនៃសម្ព័ន្ធមេត្រីចាស់បានបន្ទោសអស់អ្នក ដែលធ្វើយញ្ញបូជា ដោយមិនរវីរវល់នឹងព្រះជាម្ចាស់ (អម ៥,២១-២៥) ឬដោយមិនស្រឡាញ់អ្នកដទៃ (អស ១,១០-២០)។ ព្រះយេស៊ូរំឭកពាក្យសម្តីរបស់ព្យាការីហូសេ៖ "យើងមិនចង់បានយញ្ញបូជាទេ គឺចង់បានតែសេចក្តីមេត្តាករុណាប៉ុណ្ណោះ" (មថ ៩,១៣ ; ១២,៧) (ហស ៦,៦)។ មានយញ្ញបូជាល្អឥតខ្ចោះតែមួយ គឺយញ្ញបូជា ដែលព្រះគ្រីស្តបានថ្វាយនៅលើឈើឆ្កាង ដើម្បីសេចក្តីស្រឡាញ់ចំពោះព្រះបិតា និងដើម្បីសង្គ្រោះយើង (ហប ៩,១៣-១៤)។ ដោយរួមជាមួយយញ្ញបូជារបស់ព្រះអង្គ យើងអាចធ្វើឲ្យជីវិតរបស់យើងបានក្លាយទៅជាយញ្ញបូជាចំពោះព្រះជាម្ចាស់។

### ពាក្យសន្យា និងពាក្យសច្ចា

២១០១- ក្នុងកាលៈទេសៈផ្សេងៗ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទឲ្យថ្វាយពាក្យសន្យា ចំពោះព្រះអង្គ។ មានពាក្យសន្យាក្នុងអគ្គសញ្ញាជ្រមុជទឹក លាបថ្ងាស អាពាហ៍ពិពាហ៍ និងតែងតាំង។ ដោយរៀងៗខ្លួន គ្រីស្តបរិស័ទអាចសន្យាប្រព្រឹត្តកិច្ចការណាមួយ អធិដ្ឋាន ធ្វើទាន ឬធ្វើបូជនីយសេចរណ៍ ចំពោះព្រះជាម្ចាស់។ បើយើងគោរពពាក្យសន្យាចំពោះព្រះជាម្ចាស់ យើងបង្ហាញថា យើងគោរពព្រះអង្គដូចជាព្រះដ៏ឧត្តុង្គឧត្តមបំផុត និងស្រឡាញ់ព្រះអង្គជាព្រះដ៏ស្មោះត្រង់។

២១០២- "ដោយសារគុណធម៌នៃសាសនា យើងអាចសច្ចា ពោលគឺយើងសន្យាអ្វីដ៏ល្អប្រសើរ ដែលយើងអាចធ្វើបាន ចំពោះព្រះជាម្ចាស់ ដោយចេតនា និងដោយមានសេរីភាពពេញលេញ" (CIC ១១៩១,១)។ ដោយសារពាក្យសច្ចា គ្រីស្តបរិស័ទថ្វាយខ្លួនចំពោះព្រះជាម្ចាស់ ឬសន្យាចំពោះព្រះអង្គថា នឹងប្រព្រឹត្តកិច្ចការដ៏ល្អមួយ។ ដោយបំពេញពាក្យសច្ចារបស់ខ្លួន គេតបស្នងព្រះអង្គ អ្វីដែលគេបានសន្យា និងបានញែកចំពោះព្រះអង្គ។ កំណត់កិច្ចការគ្រីស្តទូតបង្ហាញថា សន្តៈប៉ូលរវល់នឹងបំពេញបំណន់ ដែលលោកបានបន់ (កក ១៨,១៨ ; ២១,២៣-២៤)។

- ព្រះសហគមន៍ទទួលស្គាល់ថា ពាក្យសច្ចាប្រព្រឹត្តតាមដំបូន្មានថៃងក្នុងដំណឹងល្អ មានតម្លៃដ៏លើសលប់ (CIC ៦៥៤)៖

ព្រះសហគមន៍ជាព្រះមាតារបស់យើង មានអំណរដោយគ្រីស្តបរិស័ទមួយចំនួនធំ ទាំងបុរសទាំងស្ត្រី

ស្ម័គ្រចិត្តតាមព្រះអង្គកាន់តែជិតស្និទ្ធិ និងបង្ហាញឲ្យកាន់តែច្បាស់ថា ព្រះសង្គ្រោះបានលះបង់អ្វីៗទាំងអស់។ អ្នកទាំងនោះមានសេរីភាពជាបុត្រធីតារបស់ព្រះជាម្ចាស់ សុខចិត្តរស់នៅតាមរបៀបជាអ្នកក្រីក្រ និងសុខចិត្តស្តាប់បង្គាប់អ្នកណែនាំ ជាជាងធ្វើតាមបំណងរបស់ខ្លួន។ ក្នុងករណីទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ ត្រូវសុខចិត្តស្ថិតនៅក្រោមអំណាចមនុស្សដូចគ្នា ព្រោះតែព្រះជាម្ចាស់ហួសពីបញ្ញារបស់ព្រះអង្គទៅទៀត ដើម្បីឲ្យបានកាន់តែដូចព្រះគ្រីស្ត ដែលស្តាប់តាមបញ្ជាព្រះបិតា (LG ៤២)។

ក្នុងករណីខ្លះ ព្រះសហគមន៍អាចអនុញ្ញាតឲ្យរួចពីពាក្យសច្ចា និងពាក្យសន្យា ដោយមានមូលហេតុត្រឹមត្រូវ (CIC ៦៩២ ; ១១៩៦-១១៩៧)។

## សង្គមត្រូវតែគោរពសាសនា និងសិទ្ធិសេរីភាពក្នុងការកាន់សាសនាណាក៏បាន

២១០៤- "មនុស្សទាំងអស់ត្រូវតែស្វែងរកសេចក្តីពិត ជាពិសេសអំពីព្រះជាម្ចាស់ និងព្រះសហគមន៍ព្រះអង្គ ហើយនៅពេលដែលគេបានរកឃើញសេចក្តីពិតនេះ គេត្រូវតែប្រកាន់សេចក្តីពិតនេះ ដោយចិត្តស្មោះត្រង់" (DH ១)។ ភារកិច្ចនេះ ហូរចេញមកពី "លក្ខណៈផ្ទាល់របស់មនុស្ស" (DH ២)។ ទោះបីត្រូវតែបំពេញភារកិច្ចនេះក៏ដោយ ក៏យើងត្រូវតែ "គោរពយ៉ាងស្មោះ" សាសនាផ្សេងៗដែល "ឧស្សាហ៍នាំកាំរស្មីនៃសេចក្តីពិត ដែលបំភ្លឺមនុស្សទាំងអស់" ដែរ (NA ២)។ យ៉ាងណាមិញ សេចក្តីស្រឡាញ់ជំរុញគ្រីស្តបរិស័ទឲ្យ "ប្រព្រឹត្តដោយចិត្តស្រឡាញ់ ដោយរិះគិតពិចារណា ដោយចិត្តអត់ធ្មត់ ចំពោះអស់អ្នកដែលស្ថិតក្នុងភាពកំហុស និងដែលមិនស្គាល់ជំនឿ" (DH ១៤)។

២១០៥- មនុស្សគ្រប់ៗរូប និងសង្គមនីមួយៗ ត្រូវតែគោរពព្រះជាម្ចាស់តាមរបៀបពិតប្រាកដ យោងតាម "ប្រពៃណីនៃលទ្ធិកាតូលិកអំពីភារកិច្ចខាងសីលធម៌របស់មនុស្ស និងរបស់សង្គមចំពោះសាសនាដ៏ពិតប្រាកដ និងចំពោះព្រះសហគមន៍តែមួយរបស់ព្រះគ្រីស្ត" (DH ១)។ ដោយព្រះសហគមន៍តែងតែប្រកាសដំណឹងល្អដល់មនុស្សលោក ធ្វើឲ្យគ្រីស្តបរិស័ទអាច "បញ្ចូលគំនិតនៃគ្រីស្តសាសនាក្នុងចិត្តគំនិត របៀបរស់នៅ ច្បាប់ និងរចនាសម្ព័ន្ធនៃសហគមន៍ ដែលគេរស់នៅ" (AA ១៣)។ ក្នុងសង្គម គ្រីស្តបរិស័ទមានភារកិច្ចគោរព និងដាស់តឿនមនុស្សគ្រប់ៗរូបឲ្យស្រឡាញ់សេចក្តីពិត និងអ្វីដែលល្អ។ ពួកគេត្រូវធ្វើឲ្យមនុស្សស្គាល់សាសនាដ៏ពិតប្រាកដ ដែលស្ថិតក្នុងព្រះសហគមន៍កាតូលិក ដែលមកពីក្រុមគ្រីស្តទូត (DH ១)។ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទឲ្យទៅជាពន្លឺនៃពិភពលោក (AA ១៣)។ ដូច្នេះ ព្រះសហគមន៍សម្តែងថា ព្រះគ្រីស្តសោយរាជ្យលើសត្វលោកទាំងអស់ ជាពិសេសលើសង្គមរបស់មនុស្ស (សម្តេចប៉ាប ឡេអុងទី១៣ ; ពីយូសទី១១)។

២១០៦- "ក្នុងរឿងទាក់ទងនឹងសាសនា យើងមិនអាចបង្ខិតបង្ខំនរណាម្នាក់ឲ្យប្រព្រឹត្តប្រឆាំងនឹងមនសិការរបស់ខ្លួន ហើយក្នុងកំណត់ត្រឹមត្រូវ យើងមិនអាចរារាំងគេមិនឲ្យប្រព្រឹត្តតាមមនសិការរបស់ខ្លួនគេផ្ទាល់ ឬជាសាធារណៈ តែម្នាក់ឯង ឬរួមជាមួយអ្នកដទៃទេ" (DH ១)។ សិទ្ធិនេះ ចាក់ឫសក្នុងលក្ខណៈផ្ទាល់របស់មនុស្ស ដែលឋានៈដ៏ថ្លៃថ្នូរ ធ្វើឲ្យគេផ្ជាប់ខ្លួន ដោយសេរី ទៅនឹងសេចក្តីពិតដ៏ឧត្តុង្គឧត្តមក្រៃលែងលើសលោកនេះ របស់ព្រះជាម្ចាស់។ ហេតុនេះហើយ បានជា "សិទ្ធិនេះ នៅតែស្ថិតនៅក្នុងអស់អ្នក ដែលមិនស្វែងរកសេចក្តីពិត ហើយដែលមិនផ្ជាប់ខ្លួននឹងសេចក្តីពិតនេះ" (DH ២)។

២១០៧- "ប្រសិនបើច្បាប់សង្គមទទួលស្គាល់សហគមន៍ខាងសាសនាណាមួយយ៉ាងពិសេស ដោយសារប្រជាជាតិខ្លះស្ថិតក្នុងកាលៈទេសៈពិសេស ជាមួយគ្នានេះដែរ គេចាំបាច់ត្រូវតែទទួលស្គាល់ និងគោរពសិទ្ធិសេរីភាព

នៃការកាន់សាសនាណាមួយរបស់ប្រជាពលរដ្ឋទាំងអស់ និងក្រុមគ្រួសារខាងសាសនានានាផងដែរ" (DH ៦)។

២១០៨- ទោះបីយើងមានសិទ្ធិកាន់សាសនារបស់ខ្លួនយ៉ាងណាក៏ដោយ ក៏យើងមិនអាចផ្ជាប់ខ្លួននឹងអ្វីដែលខុសទេ (សម្ដេចប៉ាប ឡេអុងទី១៣) ឬយើងពុំមានសិទ្ធិប្រព្រឹត្តខុសដែរ (សម្ដេចប៉ាប ពីយូសទី១២)។ សិទ្ធិសេរីភាពកាន់សាសនាណាមួយ ជាសិទ្ធិធម្មជាតិរបស់មនុស្ស ដែលមានសេរីភាពក្នុងសង្គម ដែលបានកំណត់យ៉ាងត្រឹមត្រូវ ពោលគឺរដ្ឋអំណាចមិនអាចគាបសង្កត់ជនរណាម្នាក់ ក្នុងរឿងទាក់ទងនឹងសាសនាបានឡើយ។ ច្បាប់នៃសង្គមត្រូវតែទទួលស្គាល់សិទ្ធិខាងធម្មជាតិនេះ ដើម្បីឲ្យសិទ្ធិនេះ បានទៅជាសិទ្ធិនៅក្នុងសង្គម (DH ២)។

២១០៩- សិទ្ធិសេរីភាពខាងសាសនាមិនអាចឲ្យហួសហេតុពេក ឬគ្រាន់តែកំណត់ដោយ (សម្ដេចប៉ាប ពីយូសទី៦) "របៀបរៀបរយសាធារណៈ" ដែលបង្កើតឡើង តាមលក្ខណៈវិជ្ជមាន ឬលក្ខណៈធម្មជាតិនោះទេ (សម្ដេចប៉ាប ពីយូសទី៩)។ ត្រូវតែមាន "ព្រំដែនជាក់លាក់" នៅតាមស្ថានភាពក្នុងសង្គមនីមួយៗ ដោយប្រុងប្រយ័ត្ន តាមតម្រូវការនៃប្រយោជន៍រួម។ បន្ទាប់មក អាជ្ញាធរក្នុងសង្គមក៏ត្រូវតែបញ្ជាក់ "ព្រំដែនដ៏ត្រឹមត្រូវ"នោះ តាម "ក្បួនច្បាប់ស្របតាមរបៀបរៀបរយខាងសីលធម៌ដោយគ្មានលម្អៀង" (DH ៧)។

## ៣. "អ្នកមិនត្រូវគោរពព្រះណាផ្សេងទៀតក្រៅពីយើងបានឡើយ"

២១១០- វិន័យទីមួយហាមប្រាមមិនឲ្យគោរពព្រះណាផ្សេងទៀត ក្រៅពីព្រះអម្ចាស់ ដែលបានសម្ដែងព្រះអង្គឲ្យប្រជារាស្ត្ររបស់ខ្លួនស្គាល់។ វិន័យនេះ ប្រឆាំងនឹងអបីយជំនឿ និងការមិនចេះគោរពប្រណិប័តន៍ព្រះជាម្ចាស់។ អបីយជំនឿជាការកាន់សាសនាហួសហេតុ។ ឯការមិនចេះគោរពសាសនាវិញ ជាបាបធម៌មួយផ្ទុយនឹងគុណធម៌នៃសាសនា។

### អបីយជំនឿ

២១១១- អបីយជំនឿជាការប្រព្រឹត្តខុសនឹងរបៀបអនុវត្តន៍សាសនា។ អបីយជំនឿអាចនាំយើងឲ្យគោរពប្រណិប័តន៍ព្រះដ៏ពិតប្រាកដ តាមរបៀបមិនត្រឹមត្រូវ ឧ- នៅពេលដែលយើងគិតថា ការបំពេញកិច្ចការខ្លះ - ទោះជាត្រឹមត្រូវ ឬចាំបាច់ក៏ដោយ - ដូចជាមន្តអាគម។ យើងធ្លាក់ក្នុងអបីយជំនឿ នៅពេលដែលយើងគិតថា ការអធិដ្ឋាន ឬអគ្គសញ្ញាមានប្រសិទ្ធិភាព ទោះបីយើងពុំមានជំនឿក៏ដោយ (មថ ២៣,១៦-២២)។

### ការគោរពព្រះក្លែងក្លាយ

២១១២- វិន័យទីមួយហាមប្រាមមិនឲ្យគោរពព្រះច្រើន។ វិន័យនេះ ទាមទារមិនឲ្យមនុស្សជឿលើព្រះណាផ្សេងក្រៅពីព្រះជាម្ចាស់ មិនឲ្យគោរពកោតខ្លាចព្រះផ្សេងពីព្រះតែមួយព្រះអង្គគត់។ ព្រះគម្ពីរដ៏វិសុទ្ធតែងតែរំឭកថា ត្រូវតែបោះបង់ចោល "ព្រះក្លែងក្លាយធ្វើពីមាសពីប្រាក់ ដែលជាស្នាដៃរបស់មនុស្ស" "ព្រះទាំងនោះ មានមាត់តែមិនចេះនិយាយមានភ្នែកតែមើលមិនឃើញ"...ព្រះក្លែងក្លាយទាំងអស់នោះនាំយើងឲ្យបានទៅជាឥតបានការ៖ "អស់អ្នកដែលបានសូនធ្វើរូបព្រះក្លែងក្លាយ ហើយផ្ញើជីវិតលើព្រះទាំងនោះ និងក្លាយដូចជារូបព្រះទាំងនោះដែរ" (ទន ១១៥,៤-៥.៨) (អស ៤៤,៩-២០ ; យរ ១០,១-១៦ ; ដន ១៤,១-៣០ ; បារ ៦ ; ប្រាញ ១៣,១-១៥,១៩)។ ផ្ទុយទៅវិញ ព្រះជាម្ចាស់ជា "ព្រះដ៏មានព្រះជន្មគង់នៅ" (យស ៣,១០ ; ទន ៤២,៣ ជាដើម) ដែលធ្វើឲ្យមានជីវិត ហើយដែលបានបំពេញកិច្ចការក្នុងប្រវត្តិសាស្ត្រ។

២១១៣- ការគោរពព្រះក្លែងក្លាយមិនគ្រាន់តែសំដៅទៅលើព្រះក្លែងក្លាយនៃសាសន៍ដទៃឡើយ ប៉ុន្តែ តែងតែ

ជាការល្បួងសម្រាប់អ្នកជឿជានិច្ច គឺរាល់ពេលមនុស្សទុកសត្វលោកជាព្រះជំនួសព្រះជាម្ចាស់ ទោះជាព្រះក្លែងក្លាយក្ដី ឬអារក្សក្ដី (ឧ-ការគោរពមារសាតាំង) អំណាចក្ដី ការសប្បាយក្ដី ពូជសាសន៍ក្ដី បុព្វបុរសក្ដី រដ្ឋក្ដី ទ្រព្យសម្បត្តិក្ដី។ល។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ "អ្នករាល់គ្នាពុំអាចគោរពបម្រើព្រះជាម្ចាស់ផង និងគោរពបម្រើទ្រព្យសម្បត្តិទុកជាព្រះផងបាន" (មថ ៦,២៤)។ មរណៈសាក្សីជាច្រើនបានស្លាប់ ដើម្បីកុំឲ្យក្រាបថ្វាយបង្គំ "សត្វតិរច្ឆាន" (វវ ១៣-១៤) ហើយបដិសេធមិនព្រមទទួលស្គាល់សូម្បីតែធ្វើហាក់ដូចជាគោរពបម្រើវាក៏ដោយ។ អ្នកគោរពព្រះក្លែងក្លាយមិនព្រមទទួលស្គាល់ថា ព្រះជាម្ចាស់ជាព្រះអម្ចាស់តែមួយព្រះអង្គគត់ ទើបមិនអាចរួបរួមជាមួយព្រះអង្គបានឡើយ (កាឡ ៥,២០ ; អភ ៥,៥)។

២១១៤- នៅពេលដែលគេថ្វាយបង្គំព្រះតែមួយអង្គគត់ មនុស្សប្រមូលផ្ដុំខ្លួនឯងជាបុគ្គលតែមួយ។ វិន័យដែលបញ្ជាឲ្យក្រាបថ្វាយបង្គំព្រះអម្ចាស់តែមួយធ្វើឲ្យជីវិតមនុស្សងាយស្រួល និងសង្គ្រោះគេកុំឲ្យខ្ចាត់ខ្ចាយឥតព្រំដែន។ ការគោរពព្រះក្លែងក្លាយបង្ខូចសាសនាបុគ្គលពីកំណើតរបស់មនុស្ស។ អ្នកគោរពព្រះក្លែងក្លាយរាប់អ្វីៗទាំងអស់ទុកជាព្រះ ជាជាងព្រះជាម្ចាស់ផ្ទាល់ (លោក អូរីសែន)។

## ការទាយ និងមន្តអាគម

២១១៥- ព្រះជាម្ចាស់អាចបង្ហាញអំពីអនាគតកាលឲ្យព្យាការីរបស់ព្រះអង្គ ឬសន្ដះបុគ្គលផ្សេងទៀតស្គាល់។ ក៏ប៉ុន្តែ គ្រីស្តបរិស័ទត្រឹមត្រូវត្រូវតែផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ ដោយពុំមានចិត្តចង់ស្គាល់អនាគតជានិច្ច។ យ៉ាងណាមិញ អ្នកមិនចេះគិតគូមិនអាចទទួលខុសត្រូវបានឡើយ។

២១១៦- ត្រូវតែបោះបង់ចោលរបៀបទាយ គ្រប់ប្រភេទ៖ ការសុំឲ្យមារសាតាំង ឬអារក្សមកជួយ ការហៅរកខ្មោច ឬរបៀបទាយផ្សេងទៀត ដើម្បី "ស្គាល់" អនាគត (ទក ១៨,១០ ; យរ ២៩,៨)។ ការទស្សន៍ទាយតាមខែឆ្នាំកំណើត តាមតារាសាស្ត្រ ការទស្សន៍ទាយតាមបាតដៃ ការបកស្រាយប្រផ្នូល និងជោគ ការទស្សន៍ទាយទុកជាមុននូវព្រឹត្តិការណ៍ផ្សេងៗ និងការទៅរកគ្រូទាយ ទាំងអស់នេះ សម្ដែងថា យើងចង់គ្រប់គ្រងពេលវេលាប្រវត្តិសាស្ត្រ និងមនុស្ស ហើយនៅពេលជាមួយគ្នានេះ យើងចង់រួមចិត្តគំនិតជាមួយអំណាចដ៏លាក់កំបាំង។ ការប្រតិបត្តិទាំងអស់នោះ ប្រឆាំងនឹងកិត្តិយស និងការគោរពកោតខ្លាច ដោយចិត្តស្រឡាញ់ ដែលយើងជំពាក់ព្រះជាម្ចាស់។

២១១៧- មន្តអាគម ឬអំពើ ផ្សេងៗដែលយើងប្រើ ដើម្បីគ្រប់គ្រងអំណាចដ៏លាក់កំបាំង ដើម្បីឲ្យវាបម្រើយើង និងដើម្បីបានទទួលអំណាចហួសធម្មជាតិលើអ្នកដទៃ - ទោះជាយើងចង់ជួយគេឲ្យបានជាសះស្បើយក៏ដោយ - គឺជាទង្វើផ្ទុយនឹងគុណធម៌នៃសាសនាខ្លាំងណាស់។ ត្រូវតែដាក់ទោសធ្ងន់លើអស់អ្នកដែលប្រតិបត្តិតាមអំពើទាំងអស់នោះ ជាពិសេសនៅពេលដែលគេចង់ធ្វើបាបអ្នកដទៃ ឬនៅពេលដែលគេសុំឲ្យអារក្សមកជួយ។ យើងមិនអាចពាក់ខ្សែកាថាបានដែរ។ ជារឿយៗ ត្រូវតែប្រើរបៀបទាយ ឬអំពើមន្តអាគម ដើម្បីហៅរកខ្មោច។ ហេតុនេះព្រះសហគមន៍ហាមប្រាមគ្រីស្តបរិស័ទមិនឲ្យប្រតិបត្តិតាម។ ទោះជាយើងប្រើប្រាស់របៀបព្យាបាលតាមប្រពៃណីក៏ដោយ ក៏យើងមិនអាចហៅរកឫទ្ធិបារមីដ៏អាក្រក់ ឬឆ្លៀតថា អ្នកដទៃចាប់ជឿ បានឡើយ។

## ការមិនគោរពសាសនា

២១១៨- វិន័យទីមួយរបស់ព្រះជាម្ចាស់ហាមប្រាមមិនឲ្យប្រព្រឹត្តអំពើបាបប្រឆាំងនឹងសាសនា គឺសាកល្បងព្រះជាម្ចាស់តាមពាក្យសម្ដីឬតាមកិច្ចការការប្រមាថព្រះអង្គនិងការលក់ឬការទិញព្រះអំណោយទានរបស់ព្រះអង្គ

(ស៊ីម៉ូនី)។

២១១៩- យើងសាកល្បងព្រះជាម្ចាស់ នៅពេលដែលយើងសាកលមើល តាមពាក្យសម្ដី ឬតាមកិច្ចការសប្បុរសធម៌ និងឫទ្ធានុភាពសព្វប្រការរបស់ព្រះអង្គ។ ហេតុនេះ មារសាតាំងចង់ឲ្យព្រះយេស៊ូទម្លាក់ព្រះកាយចុះពីព្រះវិហារ ហើយបង្ខំព្រះជាម្ចាស់ឲ្យធ្វើអន្តរាគមន៍ (លក ៤,៩)។ ព្រះយេស៊ូប្រឆាំងនឹងមារដោយប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ថា៖ "កុំសាកល្បងព្រះជាម្ចាស់ជាព្រះរបស់អ្នកឡើយ" (ទក ៦,១៦)។ ពេលយើងសាកល្បងព្រះជាម្ចាស់បែបនេះ យើងមិនគោរពកោតខ្លាច និងមិនជឿទុកចិត្តព្រះជាម្ចាស់ជាព្រះបង្កើត និងជាព្រះអម្ចាស់របស់យើងទេ។ ពេលនោះ យើងសង្ស័យជានិច្ចអំពីសេចក្ដីស្រឡាញ់ ឧបការគុណ និងឫទ្ធានុភាពរបស់ព្រះអង្គ (១ករ ១០,៩ ; សរ ១៧,២-៧ ; ទន ៩៥,៩)។

២១២០- យើងប្រមាថព្រះជាម្ចាស់ នៅពេលដែលយើងប្រមាថ ឬមិនគោរពតាមរបៀបគួរសមអគ្គសញ្ញា កិច្ចការផ្សេងៗខាងពិធីបុណ្យ មនុស្ស វត្ថុ និងកន្លែងដែលត្រូវឧទ្ទិសដល់ព្រះជាម្ចាស់។ ពេលយើងប្រមាថព្រះជាម្ចាស់ យើងប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ ជាពិសេសនៅពេលដែលយើងប្រមាថពិធីអរព្រះគុណ ដ្បិតក្នុងអគ្គសញ្ញានេះ ព្រះកាយព្រះគ្រីស្ដគង់ផ្ទាល់នៅជាមួយសារធាតុ (CIC ១៣៦៧ ; ១៣៧៦)។

២១២១- គេហៅស៊ីម៉ូនី (កក ៨,៩-២៤) ការលក់ ឬការទិញព្រះអំណោយទានខាងវិញ្ញាណរបស់ព្រះជាម្ចាស់។ លោកសិលាឆ្លើយនឹងលោកស៊ីម៉ូន ដែលចង់ទិញអំណាចខាងវិញ្ញាណរបស់ក្រុមគ្រីស្ដទូត ថា៖ "ចូរឲ្យប្រាក់របស់អ្នកវិនាសអន្តរាយជាមួយអ្នកទៅ! អ្នកនឹកស្មានថា អាចយកប្រាក់មកទិញព្រះអំណោយទានរបស់ព្រះជាម្ចាស់បាន" (កក ៨,២០)។ លោកសិលាធ្វើដូច្នេះស្របតាមព្រះបន្ទូលរបស់ព្រះយេស៊ូថា៖ "អ្នករាល់គ្នាបានទទួលអំណាច ដោយឥតបង់ថ្លៃ ត្រូវជួយគេវិញ ដោយឥតគិតថ្លៃដែរ" (មថ ១០,៨) (អស ៥៥, ១)។ យើងមិនអាចយកព្រះអំណោយទានខាងវិញ្ញាណមកប្រើ ដូចជាម្ចាស់ម្នាក់បានឡើយ ដ្បិតព្រះជាម្ចាស់ជាប្រភពនៃព្រះអំណោយទានទាំងអស់នោះ។ យើងអាចទទួលព្រះអំណោយទានទាំងអស់នោះពីព្រះជាម្ចាស់ ដោយឥតបង់ថ្លៃឡើយ។

២១២២- "ក្រោយពីជំនួយ ដែលមេដឹកនាំព្រះសហគមន៍បានកំណត់ទុកជាមុន អ្នកបម្រើព្រះសហគមន៍មិនអាចសុំអ្វី ដើម្បីផ្ដល់អគ្គសញ្ញា ហើយត្រូវប្រុងប្រយ័ត្នដើម្បីឲ្យជនក្រីក្រអាចទទួលជំនួយពីអគ្គសញ្ញាបាន ទោះបីពួកគេក្រីក្រយ៉ាងណាក៏ដោយ" (CIC ៨៤៨)។ មេដឹកនាំកំណត់ "ជំនួយ" នោះតាមគោលការណ៍ថា ប្រជាជនគ្រីស្ដបរិស័ទត្រូវជួយចិញ្ចឹមជីវិតរបស់អ្នកបម្រើព្រះសហគមន៍។ "អ្នកធ្វើការត្រូវតែទទួលម្ហូបអាហារ" (មថ ១០, ១០)។ (លក ១០,៧ ; ១ករ ៩,៥-១៨ ; ១ធម ៥,១៧-១៨)។

## លទ្ធិបដិសេធថាគ្មានព្រះជាម្ចាស់

២១២៣ "មនុស្សសម័យឥឡូវមិនយល់អំពីចំណងដ៏ស្និទ្ធស្នាល យ៉ាងជ្រាលជ្រៅជាមួយព្រះជាម្ចាស់ ដែលជាចំណងផ្ដល់ជីវិតឲ្យគេទេ។ មានអ្នកខ្លះលះបង់ចំណងនេះយ៉ាងជាក់ស្ដែងថែមទៀតផង បានជាការបដិសេធថាគ្មានព្រះជាម្ចាស់ទាល់តែសោះ ជាបញ្ហានៅក្នុងចំណោមបញ្ហាដ៏ធ្ងន់ធ្ងរជាងគេនៅសម័យឥឡូវនេះ" (GS ១៩,១)។

២១២៤- ទ្រឹស្ដីហៅថា "លទ្ធិបដិសេធថាគ្មានព្រះជាម្ចាស់" មានប្រភេទផ្សេងពីគ្នាជាច្រើន។ ក្នុងចំណោមទ្រឹស្ដីទាំងអស់នោះ អ្នកកាន់លទ្ធិសម្ភារៈនិយមកំណត់តម្រូវការ និងបំណងប្រាថ្នារបស់ខ្លួន ឲ្យអាកាស និងវេលាតែប៉ុណ្ណោះ។ អ្នកកាន់លទ្ធិបដិសេធថាគ្មានព្រះជាម្ចាស់ ហើយជាមនុស្សពឹងលើខ្លួនឯងយល់ខុសថា "មនុស្សជា

ទីដៅរបស់ខ្លួនផ្ទាល់ មានតែមនុស្សទេ ដែលបង្កើត និងណែនាំប្រវត្តិសាស្ត្ររបស់ខ្លួនបាន" (GS ២០,១)។ លទ្ធិបដិសេធថា គ្មានព្រះជាម្ចាស់ មានរបៀបផ្សេងមួយទៀត ដែលរង់ចាំការរំដោះរបស់មនុស្ស ដែលជាការរំដោះខាងវិស័យសេដ្ឋកិច្ច និងសង្គម។ លទ្ធិនេះ "ជំទាស់នឹងសាសនា ដែលនាំឲ្យមនុស្សពឹងផ្អែកលើសេចក្តីសង្ឃឹម ដែលជាការបោកបញ្ឆោតថា គេនឹងមានជីវិតនៅលោកខាងមុខ បណ្តាលឲ្យមនុស្សមិនរវីរវល់នឹងសាងសង់ពិភពលោកនៅលើផែនដីនេះ" (GS ២០,២)។

២១២៥- ដោយសារអ្នកកាន់លទ្ធិនេះ លះបង់ ឬបដិសេធថាគ្មានព្រះជាម្ចាស់ ពួកគេប្រព្រឹត្តអំពើបាបប្រឆាំងនឹងគុណធម៌នៃសាសនា (រម ១,១៨)។ យើងអាចបន្ថយការផ្តន្ទាទោសនេះ តាមគោលបំណង និងតាមកាលៈទេសៈផងដែរ។ ក្នុងដើមកំណើត និងការផ្សព្វផ្សាយនៃលទ្ធិបដិសេធគ្មានព្រះជាម្ចាស់ "អ្នកជឿត្រូវទទួលកំហុសរបស់ខ្លួន។ ជួនកាលអ្នកជឿធ្វេសប្រហែសនឹងការអប់រំជំនឿរបស់ខ្លួន ឬគេពន្យល់ជំនឿរបស់ខ្លួនតាមរបៀបមិនត្រឹមត្រូវនាំឲ្យវង្វេង ឬគេកាន់សាសនាមិនត្រឹមត្រូវ កាន់តាមសីលធម៌មិនបានល្អ ឬខុសសីលធម៌ក្នុងសង្គម។ យើងអាចនិយាយថា គេលាក់ព្រះភ័ក្ត្រដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់ និងលាក់អត្ថន័យសាសនាជាជាងគេធ្វើឲ្យមនុស្សលោកស្គាល់" (GS ១៩,៣)។

២១២៦- ជារឿយៗ អ្នកកាន់លទ្ធិបដិសេធថាគ្មានព្រះជាម្ចាស់មានគំនិតខុសចង់ឲ្យមនុស្សពឹងលើខ្លួនឯងរហូតដល់បដិសេធមិនព្រមពឹងផ្អែកលើព្រះជាម្ចាស់ (GS ២០,១)។ ក៏ប៉ុន្តែ "ការទទួលស្គាល់ព្រះជាម្ចាស់មិនជំទាស់នឹងតម្លៃដ៏ថ្លៃថ្នូររបស់មនុស្សត្រង់ណាសោះឡើយ ដ្បិតតម្លៃដ៏ថ្លៃថ្នូរនេះ មកពីព្រះជាម្ចាស់ផ្ទាល់ គឺព្រះអង្គនេះហើយជាគ្រឹះនៃតម្លៃដ៏ថ្លៃថ្នូរនេះ និងធ្វើឲ្យតម្លៃដ៏ថ្លៃថ្នូរនេះបានពេញលក្ខណៈ" (GS២១,៣)។"ព្រះសហគមន៍ដឹងច្បាស់ថា សាររបស់ខ្លួនត្រូវនឹងជម្រៅចិត្តដ៏អាថ៌កំបាំងរបស់មនុស្ស" (GS ២១,៧)។

### លទ្ធិប្រកាសថាមិនអាចស្គាល់ព្រះណាសោះ

២១២៧- ទ្រឹស្តីហៅថា "លទ្ធិប្រកាសថាមិនអាចស្គាល់ព្រះណាសោះ" មានប្រភេទផ្សេងពីគ្នាជាច្រើន។ ក្នុងករណីខ្លះ អ្នកកាន់លទ្ធិនេះ មិនព្រមបដិសេធថាគ្មានព្រះជាម្ចាស់ទេ ផ្ទុយទៅវិញ គេអះអាងថា មានសភាវៈដ៏ខ្ពង់ខ្ពស់បំផុត ដែលមិនអាចសម្តែងខ្លួនឲ្យមនុស្សលោកស្គាល់ ហើយដែលគ្មាននរណាម្នាក់អាចនិយាយពន្យល់បានផងដែរ។ ក្នុងករណីផ្សេងទៀត អ្នកកាន់លទ្ធិនេះ មិនប្រកាសថា មានព្រះជាម្ចាស់ទេ ដោយអះអាងថា យើងមិនអាចបង្ហាញភស្តុតាងថាមានព្រះជាម្ចាស់ យើងមិនអាចអះអាង ឬបដិសេធថាមានព្រះជាម្ចាស់បានដែរ។

២១២៨- ជួនកាល អ្នកកាន់លទ្ធិប្រកាសថាមិនអាចស្គាល់ព្រះណាសោះអាចស្វែងរកព្រះជាម្ចាស់ម្យ៉ាង ប៉ុន្តែគេអាចមិនរវីរវល់នឹងព្រះអង្គ អាចគេចវេសពីសំណួរដ៏សំខាន់នៃដំណើរជីវិតរបស់មនុស្ស ឬអាចខ្ជិលច្រអូសក៏បានដែរ។ ជាញឹកញយ អ្នកកាន់លទ្ធិប្រកាសថាមិនអាចស្គាល់ព្រះណាសោះ ដូចជាប្រកាន់លទ្ធិបដិសេធថាគ្មានព្រះជាម្ចាស់ទុកជាទ្រឹស្តី។

## ៤. "អ្នកមិនត្រូវឆ្លាក់រូបអ្វី..."

២១២៩- ព្រះជាម្ចាស់ហាមប្រាមមិនឲ្យដៃមនុស្សឆ្លាក់រូបអ្វីអំពីព្រះអង្គ។ កណ្ឌទុតិយកថាពន្យល់ថា៖ "នៅថ្ងៃដែលព្រះអម្ចាស់មានព្រះបន្ទូលមកកាន់អ្នករាល់គ្នាពីក្នុងភ្លើង នៅភ្នំហូរែប អ្នករាល់គ្នាពុំបានឃើញព្រះអង្គមានភិនភាគបែបណាឡើយ ហេតុនេះតោងប្រយ័ត្នស្មារតី ក្រែងលោអ្នករាល់គ្នាធ្វើខ្លួនឲ្យមានបាបដោយឆ្លាក់រូបព្រះក្លែងក្លាយជារូបតំណាងព្រះណាមួយ..." (ទក ៤,១៥-១៦)។ ព្រះដែលបានសម្តែងព្រះអង្គ ឲ្យជនជាតិអ៊ីស្រា

អែលស្គាល់ជាព្រះដ៏ខ្ពង់ខ្ពស់បំផុត។ "អ្វីៗទាំងអស់សុទ្ធតែជាស្នាព្រះហស្ដរបស់ព្រះជាម្ចាស់" ប៉ុន្តែនៅពេលជាមួយគ្នានេះ "ព្រះអង្គប្រសើរលើសអ្វីៗទាំងអស់ ដែលព្រះអង្គបានបង្កើតមក" (បសរ ៤៣,២៧-២៨)។ "គឺព្រះអង្គនេះហើយ ដែលជាប្រភពនៃសម្រស់ ព្រះអង្គបានបង្កើតធម្មជាតិទាំងនោះ" (ប្រាញ ១៣,៣)។

២១៣០- ក៏ប៉ុន្តែ ចាប់តាំងពីសម្ពន្ធមេត្រីចាស់ ព្រះជាម្ចាស់បានបញ្ជា ឬអនុញ្ញាតឲ្យគេចាត់ចែងរូបភាពខ្លះ ដែលនឹងនាំឆ្ពោះទៅការសង្គ្រោះ តាមរបៀបជានិមិត្តរូប ដោយសារព្រះបន្ទូលប្រសូតជាមនុស្ស ដូចជារូបពស់ភ្លើង (ជរ ២១,៤-៩ ; ប្រាញ ១៦,៥-១៤ ; យហ ៣,១៤-១៥) ហិបនៃសម្ពន្ធមេត្រី និងខេរូប៊ីម (សរ ២៥,១០-២២ ; ១ពង្ស ៦,២៣-២៨ ; ៧,២៣-២៦)។

២១៣១- ដោយរិះគិតអំពីព្រឹត្តការណ៍ដ៏អស្ចារ្យនៃព្រះបន្ទូលប្រសូតជាមនុស្ស មហាសន្និបាតសកលទីប្រាំពីរ នៅទីក្រុងនីសេ (ឆ្នាំ៧៨៧) បានប្រកាសថា គ្រីស្តបរិស័ទអាចគោរពប្រណិប័តន៍រូបភាពដ៏វិសុទ្ធ គឺរូបរបស់ព្រះគ្រីស្តផង រូបរបស់ព្រះមាតារបស់ព្រះជាម្ចាស់ ទេវទូត និងសន្តះបុគ្គលទាំងឡាយផងដែរ។ ដោយប្រសូតជាមនុស្ស ព្រះបុត្រារបស់ព្រះជាម្ចាស់បានបង្កើត "ការចាត់ចែង" ថ្មីនៃរូបភាពផ្សេងៗ។

២១៣២- នៅពេលដែលគ្រីស្តបរិស័ទគោរពប្រណិប័តន៍រូបភាព គេមិនប្រឆាំងនឹងវិន័យទីមួយ ដែលហាមប្រាមមិនឲ្យគោរពព្រះក្លែងក្លាយឡើយ។ តាមការពិត "លើកកិត្តិយសចំពោះរូបភាពមួយ គឺផ្តល់កិត្តិយសដល់គំរូដើម" (សន្តះ បាស៊ីល) ហើយនរណាគោរពរូបមួយ គឺគោរពរូបបុគ្គលដែលគេបានគូ" (មហាសន្និបាតនៅទីក្រុងនីសេទី២៖ DS ៦០១ ; មហាសន្និបាតនៅទីក្រុងត្រង់៖ DS ១៨២១-១៨២៥ ; មហាសន្និបាតវ៉ាទីកង់ទី២៖ SC ១២៦;LG៦៧)។កិត្តិយសដែលយើងថ្លែងចំពោះរូបដ៏វិសុទ្ធជា"ការគោរពកោតខ្លាច"មិនមែនជាការថ្វាយបង្គំទេ ដែលយើងទុកសម្រាប់ព្រះជាម្ចាស់តែប៉ុណ្ណោះ៖

> ចំពោះសាសនា ការគោរពបូជាមិនសំដៅទៅលើការគោរពរូបភាពផ្ទាល់ដូចព្រះពិតទេ ប៉ុន្តែយើងទុករូបភាពទាំងនោះជាអ្នកនាំផ្លូវទៅរកព្រះជាម្ចាស់ ដែលយាងមកចាប់កំណើតជាមនុស្ស។ ដូច្នេះហើយ ចលនានេះជាការគោរពចំពោះព្រះពិត (ដែលតំណាងដោយរូបភាពទាំងនោះ) ខណៈដែលចិត្តយើងមិនសំដៅត្រឹមតែលើរូបភាពតំណាងនោះ(សន្តះ ថូម៉ាស នៃអាកាំង)។

## សង្ខេប

២១៣៣- "ត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា" (ទក ៦,៥)។

២១៣៤- វិន័យទីមួយត្រាស់ហៅមនុស្សឲ្យផ្ញើជីវិតទៅលើព្រះជាម្ចាស់ ឲ្យសង្ឃឹមទៅលើព្រះអង្គ និងឲ្យស្រឡាញ់ព្រះអង្គលើសអ្វីៗទាំងអស់។

២១៣៥- "អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក" (មថ ៤,១០)។ នៅពេលដែលយើងថ្វាយបង្គំព្រះជាម្ចាស់ អង្វរព្រះអង្គ គោរពប្រណិប័តន៍ព្រះអង្គ បំពេញពាក្យសន្យា និងពាក្យសច្ចាដែលយើងបានធ្វើចំពោះព្រះអង្គ យើងប្រព្រឹត្តកិច្ចការ ដែលជាគុណធម៌នៃសាសនា ដែលទាក់ទងនឹងការស្តាប់បង្គាប់វិន័យទីមួយ។

២១៣៦- មនុស្សម្នាក់ៗ និងសង្គមមនុស្សមានភារកិច្ចគោរពប្រណិប័តន៍ព្រះជាម្ចាស់យ៉ាងពិតប្រាកដ។

២១៣៧- មនុស្ស "មានសិទ្ធិប្រតិបត្តិតាមសាសនាជាឯកជន ឬជាសាធារណៈ" (DH ១៥)។

២១៣៨-អបិយជំនឿជាការប្រព្រឹត្តខុសពីរបៀបគោរពប្រណិប័តន៍ព្រះដ៏ពិតប្រាកដ។ការគោរពព្រះក្លែងក្លាយ ការទាយ និងមន្តអាគមក៏មកពីអបិយជំនឿដែរ។

២១៣៩- ការសាកល្បងព្រះជាម្ចាស់ ការប្រមាថព្រះអង្គ និងស៊ីម៉ូនីជាអំពើបាប ដែលវិន័យទីមួយហាមប្រព្រឹត្ត។

២១៤០- មនុស្សកាន់លទ្ធិបដិសេធថាគ្មានព្រះជាម្ចាស់ជាអ្នកប្រព្រឹត្តបាបដោយប្រឆាំងនឹងវិន័យទីមួយ។

២១៤១- ការគោរពប្រណិប័តន៍រូបភាពដ៏វិសុទ្ធចាក់ឫសលើព្រឹត្តការណ៍ដ៏អស្ចារ្យដែលថា ព្រះជាម្ចាស់ប្រសូតជាមនុស្ស។ ការគោរពរូបភាពនោះមិនប្រឆាំងនឹងវិន័យទីមួយឡើយ។

## ប្រការទី២៖

## វិន័យទីពីរ

> មិនត្រូវយកព្រះនាមរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ទៅប្រើឥតបានការនោះឡើយ (សរ ២០,៧ ; ទក៥,១១)។
>
> អ្នករាល់គ្នាធ្លាប់បានឮសេចក្ដី ដែលមានថ្លែងប្រាប់បុព្វបុរសថា៖ "កុំបំភ្លេចពាក្យសម្បថឲ្យសោះ"(...)។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា កុំស្បថឲ្យសោះ (មថ ៥,៣៣-៣៤)។

### ១. ព្រះនាមរបស់ព្រះអម្ចាស់ដ៏វិសុទ្ធ

២១៤២-វិន័យទីពីរបញ្ជាឲ្យគោរពព្រះនាមរបស់ព្រះអម្ចាស់។ ដូចវិន័យទីមួយ វិន័យនេះ ទាក់ទងនឹងគុណធម៌នៃសាសនា ហើយតម្រង់យើងឲ្យពោលតែក្នុងរឿងដ៏វិសុទ្ធប៉ុណ្ណោះ។

២១៤៣- ក្នុងចំណោមព្រះបន្ទូលទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ ដែលទ្រង់សម្ដែងព្រះអង្គឲ្យយើងស្គាល់ មានព្រះបន្ទូលដ៏ពិសេសមួយ គឺព្រះអង្គសម្ដែងព្រះនាមរបស់ព្រះអង្គ។ ព្រះជាម្ចាស់ប្រគល់ព្រះនាមរបស់ព្រះអង្គចំពោះអស់អ្នក ដែលផ្ញើជីវិតទៅលើព្រះអង្គ។ ព្រះអង្គសម្ដែងព្រះអង្គឲ្យគេស្គាល់អាថ៌កំបាំងផ្ទាល់របស់ព្រះអង្គ។ ព្រះអំណោយទាននៃព្រះនាមមកពីព្រះអង្គជឿទុកចិត្តលើមនុស្សយ៉ាងស្និទ្ធស្នាល។ "ព្រះនាមព្រះអម្ចាស់ដ៏វិសុទ្ធ"។ ហេតុនេះហើយ បានជាមនុស្សមិនអាចបំពានលើព្រះនាមព្រះអង្គបាន។ មនុស្សត្រូវចងចាំព្រះនាមព្រះអង្គដោយស្ងៀមស្ងាត់ ក្រាបថ្វាយបង្គំព្រះអង្គដោយចិត្តស្រឡាញ់ (សក ២,១៧)។ មនុស្សនឹងប្រើព្រះនាមព្រះអង្គក្នុងការនិយាយ ដើម្បីប្រទានពរ កោតសរសើរ និងលើកតម្កើងព្រះនាមព្រះអង្គតែប៉ុណ្ណោះ (ទន ២៩,២ ; ៩៦,២; ១១៣,១-២)។

២១៤៤- នៅពេលដែលយើងគោរពព្រះនាមព្រះជាម្ចាស់ យើងបង្ហាញថា ត្រូវគោរពអាថ៌កំបាំងរបស់ព្រះអង្គផ្ទាល់ និងអ្វីៗទាំងអស់ជាទីសក្ការៈដែលទាក់ទងនឹងព្រះនាមព្រះអង្គ។ ការដឹងខ្លួនអំពីអ្វីដែលជាទីសក្ការៈ មកពីគុណធម៌នៃសាសនា៖

> ការភ័យខ្លាចចំពោះអ្វីដែលជាទីសក្ការៈ តើជាអារម្មណ៍របស់គ្រីស្តបរិស័ទ ឬទេ? មិនបាច់រារែចិត្តទេ។ នោះជាអារម្មណ៍នៃយើងរាល់គ្នា ប្រសិនបើយើងនឹងឃើញព្រះដ៏ខ្ពង់ខ្ពស់បំផុត។ ទឹកចិត្តនោះ កាន់តែមានកម្រិតខ្លាំងក្លាថែមទៀត។ កាលណាយើង "ដឹងខ្លួន" និងជឿថា ព្រះអង្គគង់នៅក្បែរយើង ពេលនោះយើង

ត្រូវតែមានអារម្មណ៍នោះ តែបើយើងគ្មានអារម្មណ៍នោះទេ យើងមិនដឹងខ្លួន យើងមិនជឿថា ព្រះអង្គគង់នៅក្បែរយើង (លោក ន្យូមាន)។

២១៤៥- គ្រីស្តបរិស័ទត្រូវផ្តល់សក្ខីភាពអំពីព្រះនាមព្រះអម្ចាស់ ដោយប្រកាសជំនឿរបស់ខ្លួន និងដោយមិនភ័យខ្លាច (មថ ១០,៣២ ; ១ធម ៦,១២)។ ត្រូវតែក្រាបថ្វាយបង្គំ និងគោរពកោតខ្លាចព្រះនាមរបស់ព្រះអម្ចាស់នៃយើង គឺព្រះយេស៊ូគ្រីស្ត ក្នុងធម៌ទេសនា និងការអប់រំជំនឿ។

២១៤៦- វិន័យទីពីរហាមបំពានព្រះនាមរបស់ព្រះជាម្ចាស់ ពោលគឺមិនឲ្យប្រើប្រាស់តាមរបៀបមិនសមគួរព្រះនាមរបស់ព្រះជាម្ចាស់ របស់ព្រះយេស៊ូគ្រីស្ត របស់ព្រហ្មចារិនីម៉ារី និងនាមរបស់សន្តៈបុគ្គលទាំងអស់ផងដែរ។

២១៤៧- ពាក្យសន្យា ដែលយើងធ្វើចំពោះអ្នកដទៃក្នុងព្រះនាមព្រះជាម្ចាស់ ជាការយកកិត្តិយស ភក្តីភាព សេចក្តីពិត និងអំណាចរបស់ព្រះអង្គទៅបញ្ចាំ។ ត្រូវតែគោរពពាក្យសន្យាទាំងអស់នោះស្របតាមយុត្តិធម៌។ បើយើងមិនស្មោះត្រង់នឹងពាក្យសន្យានោះ យើងបំពានព្រះនាមរបស់ព្រះជាម្ចាស់ ហើយយើងហាក់ដូចជាធ្វើឲ្យព្រះជាម្ចាស់ជាអ្នកកុហក (១យហ ១,១០)។

២១៤៨- ការជេរប្រមាថព្រះជាម្ចាស់ ជំទាស់នឹងវិន័យទីពីរតែម្តង។ យើងជេរប្រមាថព្រះជាម្ចាស់ - នៅក្នុងចិត្ត ឬសម្តីខាងក្រៅ-ដោយស្អប់ស្តីបន្ទោសសាកល្បងនិយាយដើមមិនចេះគោរពព្រះអង្គនិងបំពានព្រះនាមព្រះអង្គ។ សន្តៈយ៉ាកុបស្តីបន្ទោសអស់អ្នក ដែល "បានប្រមាថមាក់ងាយព្រះនាមដ៏ប្រសើរបំផុត ដែលជាទីពឹងរបស់ (ពួកគេ)" (យហ ២,៧)។ យើងមិនអាចជេរប្រមាថព្រះសហគមន៍របស់ព្រះគ្រីស្ត សន្តៈបុគ្គល ព្រមទាំងវត្ថុដ៏វិសុទ្ធបានឡើយ។ ម្យ៉ាងទៀត យើងមិនអាចប្រើព្រះនាមរបស់ព្រះជាម្ចាស់ ដើម្បីលាក់បំបាំងអំពើឧក្រិដ្ឋ សង្កត់សង្កិនប្រជាជនឲ្យធ្វើជាទាសករ ធ្វើទារុណកម្ម ឬប្រហារជីវិតមនុស្សបានឡើយ។ ការបំពានព្រះនាមព្រះជាម្ចាស់ ដើម្បីប្រព្រឹត្តអំពើឧក្រិដ្ឋជាហេតុនាំឲ្យបោះបង់សាសនាចោល។

- នៅពេលដែលយើងជេរប្រមាថព្រះជាម្ចាស់ យើងមិនគោរពព្រះជាម្ចាស់ និងព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ គឺយើងប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ (CIC ១៣៦៩)។

២១៤៩- នៅពេលដែលយើងជេរគេ ដោយប្រើព្រះនាមរបស់ព្រះជាម្ចាស់ ទោះបីយើងពុំមានបំណងប្រមាថព្រះអង្គក៏ដោយ ក៏យើងមិនចេះគោរពព្រះអម្ចាស់ដែរ។ វិន័យទីពីរហាមប្រាមមិនឲ្យយើងយកព្រះនាមរបស់ព្រះជាម្ចាស់ប្រើក្នុងអំពើមន្តអាគម។

ព្រះនាមរបស់ព្រះជាម្ចាស់ប្រសើរណាស់ នៅទីណាយើងយកព្រះនាមព្រះអង្គប្រើ ដោយគោរពព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់បំផុត។ ព្រះនាមរបស់ព្រះជាម្ចាស់ដ៏វិសុទ្ធ នៅទីណាយើងយកព្រះនាមព្រះអង្គប្រើ ដោយគោរពកោតខ្លាចព្រះអង្គ និងដោយខ្លាចធ្វើបាបព្រះអង្គ (សន្តៈ អូគូស្តាំង)។

## ២. ការយកព្រះនាមព្រះអម្ចាស់ប្រើដោយឥតបានការ

២១៥០- វិន័យទីពីរហាមពោលពាក្យសម្បថក្លែងក្លាយ។ នៅពេលដែលយើងស្បថ យើងយកព្រះជាម្ចាស់ធ្វើជាសាក្សីនៃអ្វីដែលយើងអះអាង។ យើងយកសេចក្តីពិតរបស់ព្រះជាម្ចាស់មកបញ្ចាំសេចក្តីពិតរបស់ខ្លួនយើងផ្ទាល់។ ពាក្យសម្បថ គឺជាការបញ្ចាំព្រះនាមរបស់ព្រះអម្ចាស់។ "ចូរកោតខ្លាចព្រះអម្ចាស់ ជាព្រះរបស់អ្នក ហើយគោរពបម្រើព្រះអង្គ និងស្បថក្នុងព្រះនាមព្រះអង្គតែមួយប៉ុណ្ណោះ" (ទក ៦,១៣)។

២១៥១- ការហាមពោលពាក្យសម្បថជាភារកិច្ចចំពោះព្រះជាម្ចាស់។ ក្នុងឋានៈជាព្រះបង្កើត និងជាព្រះអម្ចាស់ ព្រះជាម្ចាស់ជាក្បួននៃសេចក្តីពិតទាំងអស់។ ពាក្យសម្តីរបស់មនុស្សយល់ស្រប ឬប្រឆាំងនឹងព្រះជាម្ចាស់ជាសេចក្តីពិតផ្ទាល់។ នៅពេលដែលយើងស្បថតាមសេចក្តីពិត និងយ៉ាងត្រឹមត្រូវ ពាក្យសម្បថបំភ្លឺពាក្យសម្តីរបស់មនុស្សយោងតាមសេចក្តីពិតរបស់ព្រះជាម្ចាស់។ ពេលយើងស្បថក្លែងក្លាយ យើងហាក់ដូចជាសុំឲ្យព្រះជាម្ចាស់ផ្តល់សក្ខីភាពអំពីពាក្យកុហកមួយ។

២១៥២- អ្នកណាដែលស្បថ ដោយគ្មានបំណងគោរពពាក្យសម្បថនេះ ឬដែលមិនគោរពពាក្យសម្បថរបស់ខ្លួន ក្រោយពីបានស្បថរួចហើយ អ្នកនោះ ជាអ្នកក្បត់ពាក្យសម្បថ។ អ្នកក្បត់ពាក្យសម្បថមិនគោរពព្រះអម្ចាស់យ៉ាងធ្ងន់ធ្ងរ។ បើគេស្បថ ដើម្បីប្រព្រឹត្តកិច្ចការដ៏អាក្រក់ណាមួយ គេប្រឆាំងនឹងភាពដ៏វិសុទ្ធនៃព្រះនាមរបស់ព្រះជាម្ចាស់។

២១៥៣- ព្រះយេស៊ូបានប្រកាសវិន័យទីពីរ ក្នុងធម្មទេសនា នៅលើភ្នំ៖ "អ្នករាល់គ្នាធ្លាប់បានឮសេចក្តី ដែលថ្លែងប្រាប់បុព្វបុរសថា៖ "កុំបំភ្លេចពាក្យសម្បថឲ្យសោះ។ ត្រូវតែធ្វើតាមគ្រប់ពាក្យដែលអ្នកបានស្បថនឹងព្រះអម្ចាស"។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា កុំស្បថឲ្យសោះ (...)។ ត្រូវនិយាយឲ្យទៀងទាត់ បើ "មែន" ឲ្យប្រាកដជា "មែន"បើ "ទេ" ឲ្យប្រាកដជា "ទេ"។ រីឯពាក្យពន្លើសសុទ្ធតែមកពីមារកំណាចទាំងអស់" (មថ ៥,៣៣-៣៤.៣៧)។ (យក ៥,១២)។ ព្រះយេស៊ូប្រៀនប្រដៅថា ពាក្យសម្បថណាមួយយោងតាមព្រះជាម្ចាស់ ហើយពាក្យសម្តីនីមួយៗត្រូវគោរពវត្តមានរបស់ព្រះជាម្ចាស់ និងសេចក្តីពិតរបស់ព្រះអង្គ។ យើងត្រូវប្រើព្រះជាម្ចាស់ក្នុងពាក្យសម្តី ដោយប្រុងប្រយ័ត្ន ដើម្បីគោរពដោយយកចិត្តទុកដាក់វត្តមានរបស់ព្រះអង្គ ដែលយើងបញ្ជាក់ ឬប្រមាថក្នុងការអះអាងនីមួយៗរបស់យើង។

២១៥៤- តាមសន្តៈប៉ូល (២ករ ១,២៣ ; កាឡ ១,២០) ព្រះសហគមន៍បានយល់ថា ព្រះបន្ទូលរបស់ព្រះយេស៊ូមិនជំទាស់នឹងពាក្យសម្បថ នៅពេលដែលយើងស្បថ ដើម្បីមូលហេតុសំខាន់ និងត្រឹមត្រូវ (ដូចជាពីមុខតុលាការ)។ "ត្រូវតែពោលពាក្យសម្បថ គឺការយកព្រះនាមរបស់ព្រះជាម្ចាស់ប្រើធ្វើជាសាក្សីនៃសេចក្តីពិត ដោយសេចក្តីពិត ដោយរិះគិតពិចារណា និងតាមយុត្តិធម៌" (CIC ១១៩៩,១)។

២១៥៥- ភាពដ៏វិសុទ្ធនៃព្រះនាមរបស់ព្រះជាម្ចាស់ទាមទារឲ្យយើងមិនយកព្រះនាមព្រះអង្គប្រើ ដើម្បីរឿងមិនសំខាន់ទេ។ យ៉ាងណាមិញ យើងមិនត្រូវពោលពាក្យសម្បថ ក្នុងកាលៈទេសៈ ដែលអាចនាំឲ្យគេគិតថា យើងយល់ស្របនឹងអំណាច ដែលទាមទារឲ្យយើងស្បថ ដោយអយុត្តិធម៌។ នៅពេលដែលអាជ្ញាធរមិនត្រឹមត្រូវទាមទារឲ្យយើងពោលពាក្យសម្បថ យើងអាចបដិសេធមិនព្រមស្បថ។ យើងត្រូវបដិសេធស្បថ នៅពេលដែលគេសុំឲ្យយើងស្បថ ក្នុងគោលដៅផ្ទុយនឹងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស ឬផ្ទុយនឹងការរួបរួមរបស់ព្រះសហគមន៍។

## ៣. ឈ្មោះរបស់គ្រីស្តបរិស័ទ

២១៥៦- យើងប្រគល់អគ្គសញ្ញាជ្រមុជទឹក "ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" (មថ ២៨,១៩)។ ក្នុងពិធីជ្រមុជទឹក ព្រះនាមព្រះអម្ចាស់ធ្វើឲ្យមនុស្សបានវិសុទ្ធ ហើយគ្រីស្តបរិស័ទទទួលឈ្មោះរបស់ខ្លួនក្នុងព្រះសហគមន៍។ ឈ្មោះនេះ អាចជាឈ្មោះរបស់សន្តៈបុគ្គលម្នាក់ ពោលគឺសាវ័កម្នាក់ ដែលមានភក្តីភាពគាប់ព្រះហឫទ័យរបស់ព្រះអម្ចាស់។ ការយកសន្តៈបុគ្គលម្នាក់មកជាគំរូអំពីសេចក្តីស្រឡាញ់ ធានាថា គាត់ជួយអង្វរព្រះជាម្ចាស់ដើម្បីយើង។ "ឈ្មោះនៃពិធីជ្រមុជទឹក" អាចសម្តែងគម្រោងការដ៏អស្ចារ្យ ឬគុណធម៌មួយនៃគ្រីស្ត

សាសនាផងដែរ។ "ឪពុកម្ដាយ បងធម៌ និងលោកបូជាចារ្យជាអ្នកទទួលខុសត្រូវ ត្រូវប្រុងប្រយ័ត្នកុំឲ្យគេដាក់ឈ្មោះមួយខុសនឹងអត្ថន័យនៃគ្រីស្តសាសនា" (CIC ៨៥៥)។

២១៥៧- គ្រីស្តបរិស័ទចាប់ផ្ដើមភារកិច្ចប្រចាំថ្ងៃ ដោយអធិដ្ឋាន និងកិច្ចការរបស់ខ្លួន ដោយធ្វើសញ្ញាឈើឆ្កាង "ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ អាម៉ែន"។ គ្រីស្តបរិស័ទថ្វាយកិច្ចការប្រចាំថ្ងៃទៅសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងទូលអង្វរឲ្យព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះសង្គ្រោះជួយគេឲ្យអាចប្រព្រឹត្តកិច្ចការ ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដូចជាបុត្រធីតារបស់ព្រះបិតា។ សញ្ញាឈើឆ្កាងពង្រឹងកម្លាំងរបស់យើងក្នុងការល្បួង និងក្នុងគ្រាលំបាក។

២១៥៨- ព្រះជាម្ចាស់ត្រាស់ហៅម្នាក់ៗតាមឈ្មោះរបស់ខ្លួន (អស ៤៣,១ ; យហ ១០,៣)។ ឈ្មោះរបស់មនុស្សម្នាក់ៗជាទីសក្ការៈ និងជារូបដ៏វិសុទ្ធរបស់បុគ្គលម្នាក់។ ត្រូវតែគោរពឈ្មោះរបស់គេ ជាសញ្ញាសម្គាល់នៃឋានៈដ៏ថ្លៃថ្នូររបស់គេ។

២១៥៩- ឈ្មោះដែលយើងបានទទួលជាឈ្មោះសម្រាប់ជីវិតអស់កល្បជានិច្ច។ ក្នុងព្រះរាជ្យ លក្ខណៈដ៏លាក់កំបាំង និងតែមួយរបស់មនុស្សម្នាក់ៗ ដែលបំពាក់ព្រះនាមរបស់ព្រះជាម្ចាស់ នឹងបំភ្លឺចិញ្ចាចចិញ្ចែងក្នុងពន្លឺ។ "អ្នកណាមានជ័យជំនះ (...) នៅលើដុំក្រួសនោះ មានចារឹកឈ្មោះមួយថ្មី ដែលគ្មាននរណាម្នាក់ស្គាល់ឡើយវៀរលែងតែអ្នកដែលបានទទួលនោះចេញ" (វវ ២,១៧)។ " ខ្ញុំមើលទៅ ឃើញកូនចៀមឈរនៅលើភ្នំស៊ីយ៉ូន ហើយមានមនុស្សមួយសែនបួនម៉ឺនបួនពាន់នាក់ នៅជាមួយព្រះអង្គ អ្នកទាំងនោះ មានព្រះនាមកូនចៀម និងព្រះនាមព្រះបិតារបស់ព្រះអង្គចារនៅលើថ្ងាស" (វវ ១៤,១)។

## សង្ខេប

២១៦០- "បពិត្រព្រះអម្ចាស់អើយ! ព្រះនាមរបស់ព្រះអង្គថ្កុំថ្កើងរុងរឿងពាសពេញលើផែនដីទាំងមូល" (ទន ៨,២)។

២១៦១- វិន័យទីពីរបញ្ជាឲ្យគោរពព្រះនាមព្រះអម្ចាស់ ព្រោះជាព្រះនាមដ៏វិសុទ្ធ។

២១៦២- វិន័យទីពីរហាមមិនឲ្យប្រើព្រះនាមព្រះជាម្ចាស់តាមរបៀបមិនត្រឹមត្រូវ។ ការជេរប្រមាថមានន័យថា យើងប្រើព្រះនាមរបស់ព្រះជាម្ចាស់ របស់ព្រះយេស៊ូគ្រីស្ត របស់ព្រហ្មចារិនីម៉ារី និងជនដ៏វិសុទ្ធទាំងឡាយ តាមរបៀបមិនត្រឹមត្រូវ។

២១៦៣- ពេលយើងស្បថក្លែងក្លាយយើងហាក់ដូចជា សុំឲ្យព្រះជាម្ចាស់ផ្ដល់សក្ខីភាពចំពោះពាក្យកុហកមួយ។ ក្បត់ពាក្យសម្បថ គឺមិនគោរពព្រះអម្ចាស់យ៉ាងធ្ងន់ធ្ងរ ព្រះអង្គដែលតែងតែគោរពព្រះបន្ទូលសន្យា របស់ព្រះអង្គជានិច្ច។

២១៦៤- "មិនត្រូវស្បថដោយយកព្រះបង្កើត ឬសត្វលោកជាសាក្សី លុះត្រាតែជាសេចក្ដីពិតជាចាំបាច់ និងដោយគោរពព្រះអង្គ ឬសត្វលោកនំ" (សន្តៈ អ៊ីញ៉ាស)។

២១៦៥- ក្នុងពិធីជ្រមុជទឹក គ្រីស្តបរិស័ទទទួលនាមរបស់ខ្លួនក្នុងព្រះសហគមន៍។ មាតាបិតា ឪពុកម្ដាយធម៌ និងលោកបូជាចារ្យនឹងខិតខំដាក់ឈ្មោះឲ្យតាមគ្រីស្តសាសនា។ ការយកសន្តៈបុគ្គលម្នាក់មក ជាគំរូអំពីសេចក្ដីស្រឡាញ់ ធានាថា គាត់អធិដ្ឋាន ដើម្បីយើង។

២១៦៦-គ្រីស្តបរិស័ទចាប់ផ្តើមការអធិដ្ឋាននិងកិច្ចការរបស់ខ្លួនដោយធ្វើសញ្ញាឈើឆ្កាង"ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ អាម៉ែន"។

២១៦៧- ព្រះជាម្ចាស់ត្រាស់ហៅម្នាក់ៗតាមឈ្មោះរបស់ខ្លួន (អស ៤៣,១)។

## ប្រការទី៣៖

## វិន័យទីបី

ចូររំឭកថ្ងៃសប្ប័ទហើយញែកថ្ងៃនោះ ជាថ្ងៃដ៏វិសុទ្ធ។ អ្នកមានពេលប្រាំមួយថ្ងៃ សម្រាប់បំពេញកិច្ចការទាំងប៉ុន្មានដែលអ្នកត្រូវធ្វើ តែថ្ងៃទីប្រាំពីរ ជាថ្ងៃសប្ប័ទរបស់ព្រះអម្ចាស់ ជាព្រះនៃអ្នក។ដូច្នេះ នៅថ្ងៃនោះ អ្នកមិនត្រូវធ្វើការអ្វីឡើយ (សរ ២០,៨-១០) (ទក ៥,១២-១៥)។

ព្រះជាម្ចាស់បានបង្កើតថ្ងៃសប្ប័ទ ដើម្បីជាប្រយោជន៍ដល់មនុស្ស ព្រះអង្គមិនបានបង្កើតមនុស្ស ដើម្បីឲ្យបម្រើថ្ងៃសប្ប័ទទេ។ ហេតុនេះហើយ បានជាបុត្រមនុស្សជាម្ចាស់លើថ្ងៃសប្ប័ទ (មក ២,២៧-២៨)។

### ១. ថ្ងៃសប្ប័ទ

២១៦៨- វិន័យទីបីនៃវិន័យដប់ប្រការរំឭកដល់ភាពដ៏វិសុទ្ធនៃថ្ងៃសប្ប័ទ៖ "ក្នុងរយៈពេលប្រាំមួយថ្ងៃ អ្នករាល់គ្នាអាចធ្វើការបាន ប៉ុន្តែ ថ្ងៃទីប្រាំពីរជាថ្ងៃសប្ប័ទ គឺថ្ងៃសំរាក ដែលត្រូវញែកទុកជាថ្ងៃសក្ការៈថ្វាយព្រះអម្ចាស់" (សរ ៣១,១៥)។

២១៦៩- យោងតាមសេចក្តីនេះ ព្រះគម្ពីរដ៏វិសុទ្ធរំឭកដល់ការបង្កើត ៖ "ដ្បិតក្នុងរយៈពេលប្រាំមួយថ្ងៃ ព្រះអម្ចាស់បានបង្កើតផ្ទៃមេឃផែនដីសមុទ្រ និងវត្ថុសព្វសារពើ ដែលស្ថិតនៅទីទាំងនោះ។ នៅថ្ងៃទីប្រាំពីរ ព្រះអង្គសំរាក។ ហេតុនេះហើយ បានជាព្រះអម្ចាស់ប្រទានពរដល់ថ្ងៃសប្ប័ទហើយញែកថ្ងៃនោះ ជាថ្ងៃដ៏វិសុទ្ធ" (សរ ២០,១១)។

២១៧០- ព្រះគម្ពីរសម្តែងទៀតថា ថ្ងៃរបស់ព្រះអម្ចាស់ជាថ្ងៃនឹករឭកដល់ការរំដោះរបស់ជនជាតិអ៊ីស្រាអែលឲ្យរួចផុតពីទាសភាពនៅប្រទេសអេស៊ីប៖ "អ្នកត្រូវនឹកចាំថា អ្នកធ្លាប់ធ្វើជាទាសករនៅស្រុកអេស៊ីប ហើយព្រះអម្ចាស់ ជាព្រះរបស់អ្នក បាននាំអ្នកចាកចេញពីទីនោះ ដោយឫទ្ធិបារមី និងតេជានុភាពរបស់ព្រះអង្គ។ ហេតុនេះហើយ បានជាព្រះអម្ចាស់ ជាព្រះរបស់អ្នក បង្គាប់ឲ្យអ្នកគោរពថ្ងៃសប្ប័ទ" (ទក ៥,១៥)។

២១៧១- ព្រះជាម្ចាស់បានប្រគល់ថ្ងៃសប្ប័ទឲ្យជនជាតិអ៊ីស្រាអែល ដើម្បីឲ្យគេរក្សាថ្ងៃនេះទុកជាសញ្ញាសម្គាល់នៃសម្ព័ន្ធមេត្រី ដែលមិនអាចផ្តាច់បាន (សរ ៣១,១៦)។ ថ្ងៃសប្ប័ទជាថ្ងៃសម្រាប់ព្រះអម្ចាស់ យើងត្រូវរក្សាទុកថ្ងៃដ៏វិសុទ្ធនេះ ដើម្បីលើកតម្កើងព្រះជាម្ចាស់ លើកតម្កើងស្នាព្រះហស្តរបស់ព្រះអង្គ ដែលបានបង្កើតអ្វីៗទាំងអស់ និងកិច្ចការដ៏អស្ចារ្យរបស់ព្រះអង្គ ដើម្បីជួយសង្គ្រោះជនជាតិអ៊ីស្រាអែល។

២១៧២- ព្រះជាម្ចាស់ប្រតិបត្តិយ៉ាងណា មនុស្សក៏ត្រូវប្រតិបត្តិយ៉ាងនោះដែរ។ បើព្រះជាម្ចាស់បាន "ឈប់ធ្វើការ ហើយសំរាក" ថ្ងៃទីប្រាំពីរ (សរ ៣១,៧) មនុស្សក៏ត្រូវតែ "ឈប់ធ្វើការ ហើយសំរាក" និងទុកឲ្យអ្នកដទៃជាពិសេសជនក្រីក្រ "បានសម្រាក" (សរ ២៣,១២)។ ថ្ងៃសប្ប័ទបញ្ឈប់ការងារប្រចាំថ្ងៃ និងផ្តល់ការសម្រាក។

ថ្ងៃនេះ ជាថ្ងៃប្រឆាំងនឹងការបង្ខិតបង្ខំនៃការងារ និងការទុកប្រាក់កាស់ជាធំ (ណហ ១៣,១៥-២២ ; ២របា ៣៦,២១)។

២១៧៣- តាមដំណឹងល្អ ជាញឹកញយ គេចោទប្រកាន់ព្រះយេស៊ូថា ព្រះអង្គមិនគោរពវិន័យនៃថ្ងៃសប្បទ ឡើយ។ ប៉ុន្តែ ព្រះយេស៊ូតែងតែគោរពភាពដ៏វិសុទ្ធនៃថ្ងៃនេះ (មក ១,២១ ; យហ ៩,១៦)។ ព្រះអង្គប្រកប ដោយអំណាចបកស្រាយវិន័យនេះតាមអត្ថន័យយ៉ាងពិតប្រាកដ៖ "ព្រះជាម្ចាស់បានបង្កើតថ្ងៃសប្បទ ដើម្បីជា ប្រយោជន៍ដល់មនុស្ស ព្រះអង្គមិនបានបង្កើតមនុស្ស ដើម្បីឲ្យបម្រើថ្ងៃសប្បទឡើយ" (មក ២,២៧)។ ព្រះគ្រីស្ត ប្រកបដោយធម៌មេត្តាករុណាអនុញ្ញាតខ្លួនព្រះអង្គឲ្យ "នៅថ្ងៃសប្បទ ធ្វើអំពើល្អជាជាងធ្វើអំពើអាក្រក់ សង្គ្រោះ មនុស្សជាជាងប្រហារជីវិតចោល" (មក ៣,៤)។ ថ្ងៃសប្បទជាថ្ងៃរបស់ព្រះអម្ចាស់ប្រកបដោយធម៌មេត្តាករុណា និងថ្ងៃនៃកិត្តិយសរបស់ព្រះជាម្ចាស់ (មថ ១២,៥ ; យហ ៧,២៣)។ "បុត្រមនុស្សជាម្ចាស់លើថ្ងៃសប្បទ" (មក ២,២៨)។

## ២. ថ្ងៃរបស់ព្រះអម្ចាស់

ថ្ងៃនេះជាថ្ងៃដែលព្រះអម្ចាស់បានបង្កើតមក យើងនាំគ្នាសប្បាយរីករាយនៅថ្ងៃនេះ! (ទន ១១៨, ២៤)។

### ថ្ងៃដែលព្រះគ្រីស្តមានព្រះជន្មថ្មី៖ ថ្ងៃនៃការបង្កើតថ្មី

២១៧៤- ព្រះយេស៊ូមានព្រះជន្មថ្មីពីក្នុងចំណោមមនុស្សស្លាប់ "ថ្ងៃទីមួយនៃសប្តាហ៍" (មថ ២៨,១ ; មក ១៦,២ ; លក ២៤,១ ; យហ ២០,១)។ ដោយសារថ្ងៃនេះជា "ថ្ងៃទីមួយ" ថ្ងៃដែលព្រះគ្រីស្តមានព្រះជន្មថ្មីធ្វើឲ្យ នឹកឃើញដល់ការបង្កើតទីមួយ។ ដោយសារថ្ងៃនេះ ជា "ថ្ងៃទីប្រាំបី" ក្រោយពីថ្ងៃសប្បទ (មក ១៦,១ ; មថ ២៨,១) ថ្ងៃនេះ សម្តៅទៅលើការបង្កើតថ្មី ដែលព្រះគ្រីស្តបានចាប់ផ្តើម ដោយមានព្រះជន្មថ្មី។ សម្រាប់គ្រីស្ត បរិស័ទ ថ្ងៃនេះបានក្លាយទៅជាថ្ងៃទីមួយនៃថ្ងៃឯទៀតៗ បុណ្យទីមួយនៃបុណ្យឯទៀតៗ ថ្ងៃរបស់ព្រះអម្ចាស់ (**Hè kuriakè hèmera, dies dominica**) "ថ្ងៃអាទិត្យ"៖

យើងទាំងអស់គ្នាជួបជុំគ្នានៅថ្ងៃនៃព្រះអាទិត្យ ពីព្រោះជាថ្ងៃទីមួយ [ក្រោយពីថ្ងៃសប្បទរបស់ជនជាតិយូដា ប៉ុន្តែ ជាថ្ងៃទីមួយដែរ] ដែលព្រះជាម្ចាស់ ដកទាញយករូបធាតុចេញមកពីភាពងងឹត ទ្រង់បានបង្កើតពិភពលោក ហើយនៅថ្ងៃដដែលនេះ ព្រះយេស៊ូគ្រីស្ត ជាព្រះសង្គ្រោះរបស់យើង មានព្រះជន្មថ្មីក្នុងចំណោមមនុស្សស្លាប់ (សន្តៈ យូស្តាំង)។

### ថ្ងៃអាទិត្យជាថ្ងៃបំពេញថ្ងៃសប្បទ

២១៧៥- ថ្ងៃអាទិត្យប្លែកពីថ្ងៃសប្បទ ដែលជាថ្ងៃសៅរ៍ ជារៀងរាល់សប្តាហ៍ ហើយជាថ្ងៃដែលគ្រីស្តបរិស័ទ គោរពព្រះជាម្ចាស់។ ក្នុងបុណ្យចម្លងរបស់ព្រះគ្រីស្ត ថ្ងៃអាទិត្យជាថ្ងៃបំពេញសេចក្តីពិតខាងវិញ្ញាណនៃថ្ងៃសប្បទ របស់ជនជាតិយូដា និងជាថ្ងៃដែលប្រកាសទុកជាមុនថា មនុស្សលោកនឹងសម្រាកក្នុងអង្គព្រះជាម្ចាស់អស់កល្ប ជានិច្ច។ ការគោរពធម្មវិន័យជាការត្រៀមទុកជាមុននូវព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ហើយអ្វីដែលគេ ប្រតិបត្តិក្នុងធម្មវិន័យនេះសម្តែងលក្ខណៈខ្លះរបស់ព្រះគ្រីស្ត (១ករ ១០,១១)៖

អស់អ្នកដែលរស់នៅតាមទម្លាប់ចាស់ឈានទៅរកសេចក្តីសង្ឃឹមថ្មី មិនព្រមគោរពថ្ងៃសប្បទទៀតទេ បែរទៅជាគោរពថ្ងៃរបស់ព្រះអម្ចាស់ ដែលជីវិតរបស់យើងទទួលព្រះពរ (សន្តៈ អ៊ីញ៉ាស នៃអង់ទីអូស)។

២១៧៦- ពិធីលើកតម្កើងនៅថ្ងៃអាទិត្យគោរពតាមវិន័យនៃសីលធម៌ ដែលធម្មជាតិបានចារក្នុងជម្រៅចិត្តមនុស្សគឺ"គោរពព្រះជាម្ចាស់តាមពិធីខាងក្រៅដែលមើលឃើញជាសាធារណៈ និងទៀងទាត់ ធ្វើជាសញ្ញាសម្គាល់នៃសប្បុរសធម៌សកលរបស់ព្រះអង្គចំពោះមនុស្សលោក" (សន្តៈ ថូម៉ាស នៃអាកាំង)។ ពិធីគោរពនៃថ្ងៃអាទិត្យបំពេញវិន័យខាងសីលធម៌នៃសម្ព័ន្ធមេត្រីចាស់ ទៅតាមចង្វាក់ និងគំនិតដដែល និងដោយលើកតម្កើងព្រះជាម្ចាស់ជាព្រះបង្កើត និងជាព្រះសង្គ្រោះនៃប្រជារាស្ត្ររបស់ព្រះអង្គ រៀងរាល់ថ្ងៃអាទិត្យ។

## ពិធីអរព្រះគុណនៃថ្ងៃអាទិត្យ

២១៧៧- ពិធីលើកតម្កើងព្រះជាម្ចាស់នៅថ្ងៃអាទិត្យ និងពិធីអរព្រះគុណព្រះអម្ចាស់ជាស្នូលនៃការរស់នៅរបស់ព្រះសហគមន៍។ "តាមការបញ្ជូនបន្តដែលមកពីក្រុមគ្រីស្តទូត ថ្ងៃអាទិត្យជាថ្ងៃលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង។ ព្រះសហគមន៍ទាំងមូលត្រូវតែគោរពថ្ងៃនេះទុកជាថ្ងៃបុណ្យសំខាន់ជាងគេ" (CIC ១២៤៦,១)។

"ជាមួយគ្នានេះដែរ ត្រូវតែគោរពថ្ងៃបុណ្យព្រះអម្ចាស់នៃយើងព្រះយេស៊ូគ្រីស្តប្រសូត ថ្ងៃបុណ្យព្រះគ្រីស្តសម្តែងព្រះអង្គឲ្យសាសន៍ដទៃស្គាល់ ថ្ងៃបុណ្យព្រះជាម្ចាស់លើកព្រះយេស៊ូឡើងលើ ថ្ងៃបុណ្យព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ថ្ងៃបុណ្យព្រះនាងម៉ារីដ៏វិសុទ្ធជាព្រះមាតារបស់ព្រះជាម្ចាស់ ថ្ងៃបុណ្យព្រះនាងម៉ារីមិនជំពាក់បាបតាំងពីកំណើត ថ្ងៃបុណ្យព្រះនាងម៉ារីឡើងស្ថានបរមសុខ ថ្ងៃបុណ្យសន្តៈយ៉ូសែប សន្តៈគ្រីស្តទូតសិលា និងប៉ូល និងសន្តៈបុគ្គលទាំងឡាយ" (CIC ១២៤៦,១)។

២១៧៨- អង្គប្រជុំរបស់គ្រីស្តបរិស័ទប្រតិបត្តិតាមរបៀបនេះតាំងពីសម័យក្រុមគ្រីស្តទូត (កក ២,៤២-៤៦)។ លិខិតផ្ញើទៅគ្រីស្តបរិស័ទជាតិហេប្រឺរំឭកថា៖ "មិនត្រូវលះបង់ការប្រជុំគ្នាដូចអ្នកខ្លះធ្លាប់ធ្វើនោះទេ ផ្ទុយទៅវិញ យើងត្រូវលើកទឹកចិត្តគ្នាទៅវិញទៅមកឲ្យរឹតតែខ្លាំងឡើង" (ហប ១០,២៥)។

ការបញ្ជូនបន្តចងចាំពាក្យដាស់តឿន ដែលនៅតែមានតម្លៃរហូតដល់សព្វថ្ងៃ៖ "មកទាន់ពេលនៅព្រះវិហារ មកជិតព្រះអម្ចាស់ និងសារភាពអំពើបាបរបស់ខ្លួន សម្តែងសេចក្តីសោកស្តាយក្នុងការអធិដ្ឋាន (...)។ ចូលរួមក្នុងពិធីបុណ្យដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ បញ្ចប់ការអធិដ្ឋានរបស់ខ្លួន ហើយមិនចាកចេញមុនលោកបូជាចារ្យបានប្រទានពរ (...)។ យើងធ្លាប់ប្រាប់គេជាច្រើនដងមកហើយ៖ ព្រះជាម្ចាស់បានប្រទានថ្ងៃនេះ ដើម្បីអធិដ្ឋាន និងសម្រាក។ ថ្ងៃនេះ ជាថ្ងៃដែលព្រះជាម្ចាស់បានបង្កើត។ ចូរយើងនាំគ្នាកោតសរសើរ និងសប្បាយរីករាយនៅថ្ងៃនេះ!"។

២១៧៩- "សហគមន៍ក្នុងភូមិមួយ ជាសហគមន៍របស់គ្រីស្តបរិស័ទមួយចំនួន ដែលនៅស្ថិតស្ថេរក្នុងព្រះសហគមន៍នៅតំបន់មួយ មានលោកបូជាចារ្យម្នាក់ជាអ្នកទទួលខុសត្រូវ ដែលជាគង្វាលពិសេសរបស់សហគមន៍នេះ ក្រោមអំណាចរបស់លោកអភិបាលភូមិភាគ" (CIC ៥១៥,១)។ សហគមន៍ក្នុងភូមិជាកន្លែង ដែលពិធីប្រារព្ធអភិបូជាប្រមូលគ្រីស្តបរិស័ទទាំងអស់ជារៀងរាល់ថ្ងៃអាទិត្យ។ សហគមន៍ក្នុងភូមិបង្រៀនគ្រីស្តបរិស័ទអំពីពិធីបុណ្យធម្មតា ប្រមូលប្រជាជននេះក្នុងការប្រារព្ធពិធីបុណ្យ បង្រៀនលទ្ធិនៃការសង្គ្រោះរបស់ព្រះគ្រីស្ត និងប្រតិបត្តិតាមសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ក្នុងការបំពេញកិច្ចការល្អៗ៖

អ្នកមិនអាចអធិដ្ឋាននៅផ្ទះ ដូចនៅក្នុងព្រះសហគមន៍ ដែលមានគ្រីស្តបរិស័ទមួយចំនួនដ៏ធំស្រែកអង្វរព្រះជាម្ចាស់ដោយមានចិត្តគំនិតតែមួយទេ។ មានអ្វីប្រសើរជាង វិញ្ញាណរួបរួមគ្នា ព្រលឹងយល់ចិត្តថ្លើមគ្នា ដែល

ជាចំណងនៃសេចក្តីស្រឡាញ់ និងសេចក្តីអធិដ្ឋានរបស់លោកបូជាចារ្យ (សន្តៈ យ៉ូហាន គ្រីសូស្តូម)។

### ត្រូវតែគោរពថ្ងៃអាទិត្យ

២១៨០- បទបញ្ញារបស់ព្រះសហគមន៍បញ្ជាក់យ៉ាងល្អិតល្អន់ធម្មវិន័យរបស់ព្រះអម្ចាស់៖ "គ្រីស្តបរិស័ទត្រូវតែប្រារព្ធពិធីអភិបូជានៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យសំខាន់ៗ" (CIC ១២៤៧)។ "អ្នកណាប្រារព្ធពិធីអភិបូជា គឺជាអ្នកដែលចូលរួមប្រារព្ធពិធីអភិបូជាតាមរបៀបកាតូលិក នៅថ្ងៃបុណ្យ ឬល្ងាចមុនថ្ងៃមុនបុណ្យ" (CIC ១២៤៨,១)។

២១៨១- ពិធីអរព្រះគុណនៃថ្ងៃអាទិត្យជាគ្រឹះ និងជាប្រដាប់វាស់របៀបប្រតិបត្តិរបស់គ្រីស្តបរិស័ទ។ ហេតុនេះគ្រីស្តបរិស័ទត្រូវតែចូលរួមក្នុងពិធីអរព្រះគុណនៅថ្ងៃបុណ្យសំខាន់ៗ លើកលែងតែមានមូលហេតុត្រឹមត្រូវ (ដូចជាជំងឺ ការថែទាំកូនក្មេង) ឬដោយសារគេបានទទួលការអនុញ្ញាតពីគង្វាលរបស់គេ (CIC ១២៤៥)។ អស់អ្នកដែលមិនគោរពភារកិច្ចនេះ ដោយចេតនា ប្រព្រឹត្តអំពើបាបយ៉ាងធ្ងន់ធ្ងរ។

២១៨២- ការចូលរួមក្នុងពិធីលើកតម្កើងអរព្រះគុណព្រះជាម្ចាស់នៅថ្ងៃអាទិត្យ គឺជាសក្ខីភាពថា យើងជាកម្មសិទ្ធិដ៏ភក្តីរបស់ព្រះគ្រីស្ត និងរបស់ព្រះសហគមន៍របស់ព្រះអង្គ។ ពេលនោះ គ្រីស្តបរិស័ទបញ្ជាក់ថា គេរួបរួមគ្នាក្នុងជំនឿ និងសេចក្តីស្រឡាញ់។ ពួកគេរួបរួមគ្នា ដើម្បីផ្តល់សក្ខីភាពចំពោះភាពដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ហើយបង្ហាញនូវសេចក្តីសង្ឃឹមដែលថានឹងទទួលការសង្គ្រោះ។ ពួកគេលើកទឹកចិត្តគ្នាទៅវិញទៅមកក្រោមការណែនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

២១៨៣- "ប្រសិនបើពួកគេមិនអាចចូលរួមក្នុងពិធីអរព្រះគុណ ដោយសារគ្មានអ្នកបម្រើដ៏សក្ការៈ ឬដោយសារមូលហេតុសំខាន់ផ្សេងទៀត គ្រីស្តបរិស័ទគួរចូលរួមក្នុងពិធីលើកតម្កើងព្រះបន្ទូល (បើមាន) ក្នុងព្រះវិហារតាមភូមិ ឬក្នុងកន្លែងដ៏សក្ការៈផ្សេងទៀត តាមច្បាប់ដែលលោកអភិបាលភូមិភាគបានរៀបចំទុកជាមុន ឬឲ្យពួកគេអធិដ្ឋានមួយរយៈដ៏សមគួរ តែម្នាក់ឯង ឬក្នុងក្រុមគ្រួសារ ឬតាមកាលៈទេសៈជាមួយក្រុមគ្រួសារឯទៀត" (CIC ១២៤៨,២)។

### ថ្ងៃអរព្រះគុណ និង ផ្អាកធ្វើការ

២១៨៤- "នៅថ្ងៃទីប្រាំពីរព្រះជាម្ចាស់បង្ហើយកិច្ចការដែលព្រះអង្គបានធ្វើ គឺក្រោយពីបានបញ្ចប់កិច្ចការទាំងនោះមក ព្រះអង្គក៏ឈប់សំរាកនៅថ្ងៃទីប្រាំពីរ" (កណ ២,២)។ ដូចព្រះជាម្ចាស់ដែរ ការងារ និងការសម្រាកជាចង្វាក់នៃជីវិតរបស់មនុស្ស។ ការរៀបចំឲ្យមានថ្ងៃរបស់ព្រះអម្ចាស់ជួយឲ្យមនុស្សទាំងអស់អាចមានពេលសម្រាក និងពេលលំហែអារម្មណ៍គ្រប់គ្រាន់ ដើម្បីឲ្យគេមានជីវិតរស់នៅតាមក្រុមគ្រួសារ តាមវប្បធម៌ តាមសង្គម និងតាមសាសនាទៀតផង (GS ៦៧,៣)។

២១៨៥- ថ្ងៃអាទិត្យ និងថ្ងៃបុណ្យសំខាន់ៗ គ្រីស្តបរិស័ទមិនត្រូវធ្វើការ ឬមានសកម្មភាព ដែលរារាំងមិនឲ្យគេលើកតម្កើងព្រះជាម្ចាស់ ទទួលអំណរពិសេសនៃថ្ងៃរបស់ព្រះអម្ចាស់ បំពេញកិច្ចការនៃធម៌មេត្តាករុណា លំហែវិញ្ញាណ និងរាងកាយតាមរបៀបសមរម្យ (CIC ១២៤៧)។ យើងអាចមិនបានសម្រាកនៅថ្ងៃអាទិត្យ ដោយសារមូលហេតុចាំបាច់ដែលមកពីក្រុមគ្រួសារ ឬដោយសារប្រយោជន៍រួមដ៏សំខាន់ក្នុងសង្គម។ គ្រីស្តបរិស័ទត្រូវយកចិត្តទុកដាក់កុំឲ្យមូលហេតុត្រឹមត្រូវទាំងនោះ បណ្តាលឲ្យមានទម្លាប់អាក្រក់ចំពោះសាសនា ជីវិតក្រុម

គ្រួសារ និងសុខភាព។

អ្នកស្រឡាញ់សេចក្តីពិត ត្រូវលំហែអារម្មណ៍តាមរបៀបត្រឹមត្រូវ ដោយសារសេចក្តីស្រឡាញ់វិញ ទាមទារការងារត្រឹមត្រូវ (សន្ត: អូគូស្តាំង)។

២១៨៦- គ្រីស្តបរិស័ទដែលមានពេលលំហែអារម្មណ៍ត្រូវនឹកដល់បងប្អូនរបស់គេ ដែលមានតម្រូវការ និងសិទ្ធិដូចគ្នាដែរ ហើយដែលមិនអាចឈប់សម្រាកបាន ដោយសារភាពក្រីក្រ និងភាពវេទនា។ ជាធម្មតា ថ្ងៃអាទិត្យ គ្រីស្តបរិស័ទធ្វើអំពើល្អ និងជួយបម្រើអ្នកជំងឺ ជនពិការ មនុស្សចាស់ជរា។ គ្រីស្តបរិស័ទនឹងធ្វើឲ្យថ្ងៃ អាទិត្យបានវិសុទ្ធ ដោយចំណាយពេលវេលាថែទាំក្រុមគ្រួសារ និងអ្នកជុំវិញខ្លួនគេ ដោយសារថ្ងៃផ្សេងៗទៀត គេគ្មានពេល។ ថ្ងៃអាទិត្យជាថ្ងៃសម្រាប់រិះគិតពិចារណា នៅស្ងៀមស្ងាត់ ដើម្បីពង្រឹងវប្បធម៌ និងនឹក សញ្ជឹងគិត ដើម្បីឲ្យជីវិតខាងក្នុងរបស់គ្រីស្តបរិស័ទរីកចម្រើន។

២១៨៧-ត្រូវតែខិតខំរួបរួមគ្នាដើម្បីធ្វើឲ្យថ្ងៃអាទិត្យនិងថ្ងៃបុណ្យបានវិសុទ្ធ។គ្រីស្តបរិស័ទម្នាក់ៗត្រូវចៀសវាង កុំបង្ខំអ្នកដទៃ ដោយគ្មានការចាំបាច់ ឲ្យធ្វើអ្វីមួយ ដែលរារាំងគេមិនឲ្យគោរពថ្ងៃរបស់ព្រះអម្ចាស់។ នៅពេលដែលទម្លាប់ (កីឡា ភោជនីយដ្ឋាន។ល។) និងការចាំបាច់នៅក្នុងសង្គម (សេវាកម្មសាធារណៈ។ល។) ទាមទារឲ្យអ្នកខ្លះធ្វើការនៅថ្ងៃអាទិត្យ ម្នាក់ៗទទួលខុសត្រូវរក្សាទុកពេលវេលាល្មម ដើម្បីលំហែអារម្មណ៍។ គ្រីស្តបរិស័ទត្រូវយកចិត្តទុកដាក់ ដោយចេះទប់ខ្លួន និងដោយក្តីស្រឡាញ់ ចៀសវាងអំពើហិង្សា ដែលមកពីការកម្សាន្តខ្លះ។ ទោះបីមានការចាំបាច់ខាងសេដ្ឋកិច្ច រដ្ឋអំណាចត្រូវយកចិត្តទុកដាក់ផ្តល់ពេលវេលា ដើម្បីឲ្យប្រជាពលរដ្ឋសម្រាក និងលើកតម្កើងព្រះជាម្ចាស់។ ថៅកែមានភារកិច្ចដដែលចំពោះបុគ្គលិករបស់ខ្លួនដែរ។

២១៨៨- ដោយគោរពសេរីភាពខាងសាសនា និងផលប្រយោជន៍រួម គ្រីស្តបរិស័ទត្រូវតែធ្វើឲ្យសង្គមទទួលស្គាល់ថ្ងៃអាទិត្យនិងថ្ងៃបុណ្យរបស់ព្រះសហគមន៍ដូចជាថ្ងៃសម្រាកស្រមច្បាប់។ពួកគេត្រូវតែធ្វើជាគំរូសាធារណៈ សម្រាប់មនុស្សទាំងអស់ ដោយអធិដ្ឋាន គោរព និងទទួលអំណរ ដោយការពារប្រពៃណីរបស់គេ ដែលជាការរួមចំណែកដ៏ថ្លៃថ្លាមួយ ដើម្បីឲ្យសង្គមមនុស្សបានរីកចម្រើនផ្នែកវិញ្ញាណ។ បើច្បាប់ប្រទេស ឬមូលហេតុផ្សេងៗ បង្ខំឲ្យធ្វើការថ្ងៃអាទិត្យសូមឲ្យយើងនឹកគិតថាថ្ងៃនេះជាថ្ងៃនៃការរំដោះរបស់យើងដែលធ្វើឲ្យយើងបានចូលរួមក្នុង "ពិធីជប់លៀង" ក្នុង "អង្គប្រជុំរបស់ពួករៀមច្បង ដែលមានឈ្មោះកត់ទុកនៅស្ថានបរមសុខ" (ហប ១២,២២-២៣)។

## សង្ខេប

២១៨៩- "ចូររំឭកថ្ងៃសប្ប័ទ ហើយញែកថ្ងៃនេះ ជាថ្ងៃដ៏វិសុទ្ធ" (ទក ៥,១២)។ "ថ្ងៃទីប្រាំពីរជាថ្ងៃសប្ប័ទ គឺថ្ងៃសម្រាក ដែលត្រូវញែកទុកជាថ្ងៃសក្ការៈថ្វាយព្រះអម្ចាស់" (សរ ៣១,១៥)។

២១៩០- ថ្ងៃសប្ប័ទតំណាងឲ្យថ្ងៃចុងក្រោយនៃការបង្កើតពិភពលោក ហើយជំនួសដោយថ្ងៃអាទិត្យ ដែលរំឭកនូវការបង្កើតថ្មី ចាប់ផ្តើមដោយព្រះជន្មថ្មីរបស់ព្រះគ្រីស្ត។

២១៩១- ព្រះសហគមន៍ប្រារព្ធថ្ងៃដែលព្រះគ្រីស្តមានព្រះជន្មថ្មីនៅថ្ងៃទីប្រាំបី ដែលគេហៅយ៉ាងត្រឹមត្រូវថា ថ្ងៃរបស់ព្រះអម្ចាស់ ឬថ្ងៃអាទិត្យ (SC ១០៦)។

២១៩២-"ព្រហសហគមន៍ទាំងមូលត្រូវគោរពថ្ងៃអាទិត្យដែលជាថ្ងៃបុណ្យសំខាន់បំផុត"(CIC១២៤៦,១)។

"គ្រីស្តបរិស័ទត្រូវប្រារព្ធពិធីអភិបូជានៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យសំខាន់ៗ" (CIC ១២៤៧)។

២១៩៣- "ថ្ងៃអាទិត្យ និងថ្ងៃបុណ្យសំខាន់ៗ គ្រីស្តបរិស័ទមិនត្រូវធ្វើការ ឬមានសកម្មភាព ដែលរារាំងមិនឲ្យគេលើកតម្កើងព្រះជាម្ចាស់ ទទួលអំណរពិសេសនៃថ្ងៃរបស់ព្រះអម្ចាស់ លំហែវិញ្ញាណ និងរាងកាយតាមរបៀបសមរម្យ (CIC ១២៤៧)។

២១៩៤-"ការរៀបចំឲ្យមានថ្ងៃរបស់ព្រះអម្ចាស់ជួយឲ្យមនុស្សទាំងអស់អាចមានពេលសម្រាក និងពេលលំហែអារម្មណ៍គ្រប់គ្រាន់ ដើម្បីឲ្យគេមានជីវិតរស់នៅតាមក្រុមគ្រួសារ តាមវប្បធម៌ តាមសង្គម និងតាមសាសនាទៀតផង" (GS ៦៧,៣)។

២១៩៥ បើមិនចាំបាច់ទេ គ្រីស្តបរិស័ទម្នាក់ៗត្រូវជៀសវាងបង្ខំអ្នកដទៃមិនអាចគោរពថ្ងៃព្រះអម្ចាស់។

## ជំពូកទីពីរ៖

## "ត្រូវស្រឡាញ់បងប្អូនឯទៀត

## ឲ្យបានដូចស្រឡាញ់ខ្លួនឯង"

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័កថា៖ "ចូរស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" (យហ ១៣,៣៤)។

២១៩៦- ដោយសារមានគេបានសួរអំពីវិន័យទីមួយ ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយតបថា៖ "នេះជាវិន័យទីមួយ៖"អ៊ីស្រាអែលអើយចូរស្ដាប់! មានតែព្រះអម្ចាស់ជាព្រះរបស់យើងមួយព្រះអង្គគត់ដែលពិតជាព្រះអម្ចាស់។ ត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីប្រាជ្ញា និងអស់ពីកម្លាំងកាយ"។ រីឯវិន័យទីពីរបានមានចែងថា "ត្រូវស្រឡាញ់បងប្អូនឯទៀតៗឲ្យបានដូចស្រឡាញ់ខ្លួនឯង"។ គ្មានវិន័យណាសំខាន់ជាងវិន័យទាំងពីរនេះទេ" (មក ១២,២៩-៣១)។

- គ្រីស្តទូតប៉ូលរំឭកថា៖ "មិនត្រូវជំពាក់អ្វីនរណា ក្រៅពីជំពាក់សេចក្ដីស្រឡាញ់គ្នាទៅវិញទៅមកទេ ដ្បិតអ្នកណាស្រឡាញ់អ្នកដទៃ អ្នកនោះប្រតិបត្តិតាមគម្ពីរវិន័យសព្វគ្រប់ហើយ ព្រោះវិន័យដែលចែងថា "កុំប្រព្រឹត្តអំពើផិតក្បត់ កុំសម្លាប់មនុស្ស កុំលួចទ្រព្យសម្បត្តិគេ កុំមានចិត្តលោភលន់ " និងវិន័យឯទៀតៗសសង្ខេបមកជាវិន័យតែមួយនេះថា "ចូរស្រឡាញ់បងប្អូនឯទៀតៗឲ្យបានដូចស្រឡាញ់ខ្លួនឯងដែរ"។ អ្នកមានចិត្តស្រឡាញ់មិនដែលប្រព្រឹត្តអំពើអាក្រក់ដល់បងប្អូនឯទៀតៗឡើយ។ ដូច្នេះ សេចក្ដីស្រឡាញ់នាំឲ្យប្រតិបត្តិតាមវិន័យបានពេញលក្ខណៈ" (រម ១៣,៨-១០)។

## ប្រការទី៤៖

## វិន័យទីបួន

ចូរគោរពមាតាបិតារបស់អ្នក ដើម្បីឲ្យអ្នកមានអាយុយឺនយូរនៅលើដីដែលព្រះអម្ចាស់ជាព្រះនៃអ្នកប្រទានដល់អ្នក (សរ ២០,១២)។

ព្រះអង្គធ្វើតាមឱវាទរបស់គាត់ទាំងពីរនាក់ (លក ២,៥១)។

ព្រះអម្ចាស់យេស៊ូផ្ទាល់បានរំឭកកម្លាំងនៃ "វិន័យរបស់ព្រះជាម្ចាស់" (មក ៧,៨-១៣)។ គ្រីស្តទូតប៉ូល ប្រៀនប្រដៅថាៈ "កុមារកុមារី! ចូរស្តាប់បង្គាប់មាតាបិតា ដោយយល់ដល់ព្រះអម្ចាស់ ធ្វើដូច្នេះ ទើបត្រឹមត្រូវ។ "ចូរគោរពមាតាបិតា" (នេះជាវិន័យទីមួយ ដែលមានទាំងព្រះបន្ទូលសន្យាជាប់មកជាមួយផង) ដើម្បីឱ្យបានសេចក្តីសុខ និង មានអាយុវែងនៅលើផែនដីនេះ" (អភ ៦,១-៣)។

២១៩៧- វិន័យទីបួនបើកវគ្គទីពីរ ហើយបង្ហាញអំពីសេចក្តីស្រឡាញ់។ ព្រះជាម្ចាស់សព្វព្រះហឫទ័យថា ក្រោយពីព្រះអង្គ ត្រូវគោរពមាតាបិតា ដែលយើងជំពាក់ជីវិត ហើយដែលបានអប់រំយើងឱ្យស្គាល់ព្រះជាម្ចាស់។ ត្រូវលើកកិត្តិយស និងគោរពអស់អ្នក ដែលព្រះជាម្ចាស់បានប្រគល់អំណាចរបស់ព្រះអង្គ ដើម្បីផលប្រយោជន៍យើង។

២១៩៨- បទបញ្ញានេះ សម្តែងតាមរបៀបវិជ្ជមាននូវភារកិច្ចផ្សេងៗដែលយើងត្រូវបំពេញ ហើយប្រកាសទុកជាមុនវិន័យបន្តបន្ទាប់ ដែលទាក់ទងនឹងជីវិត អាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិនៃផែនដី ពាក្យសម្តី ដែលត្រូវគោរពយ៉ាងពិសេស។ បទបញ្ញានេះ ជាគ្រឹះមួយនៃលទ្ធិសង្គមរបស់ព្រះសហគមន៍។

២១៩៩- វិន័យទីបួនសំដៅលើទំនាក់ទំនងរវាងកូន និងមាតាបិតា ពីព្រោះជាទំនាក់ទំនងរបស់មនុស្សទាំងអស់លើសកលលោក។ វិន័យនេះ ទាក់ទងនឹងញាតិសន្តានទាំងអស់ក្នុងគ្រួសារ ដែលត្រូវលើកកិត្តិយស ត្រូវស្រឡាញ់ និងដឹងគុណជីដូនជីតា និងបុព្វបុរស។ វិន័យនេះ លាតសន្ធឹងរហូតដល់ភារកិច្ចរបស់សិស្សចំពោះគ្រូ បុគ្គលិកចំពោះថៅកែ អ្នកក្រោមបង្គាប់ចំពោះចៅហ្វាយនាយ ប្រជាពលរដ្ឋចំពោះមាតុភូមិ និងចំពោះអស់អ្នកដែលគ្រប់គ្រងមាតុភូមិនេះ។

- វិន័យនេះ ទាក់ទងនឹងភារកិច្ចរបស់មាតាបិតា អាណាព្យាបាល គ្រូ ចៅហ្វាយនាយ ចៅក្រម អ្នកគ្រប់គ្រង និងអស់អ្នកប្រកបដោយអំណាចលើអ្នកដទៃ ឬលើហគមន៍របស់មនុស្សផងដែរ។

២២០០- បើយើងប្រតិបត្តិតាមវិន័យទីបួន យើងនឹងទទួលរង្វាន់ៈ " ចូរគោរពមាតាបិតារបស់អ្នក ដើម្បីឱ្យអ្នកមានអាយុយឺនយូរនៅលើដី ដែលព្រះអម្ចាស់ជាព្រះនៃអ្នក ប្រទានដល់អ្នក (សរ ២០,១២ ; ទក ៥,១៦)។ បើយើងគោរពវិន័យនេះ យើងនឹងទទួលផលនៅលើលោកនេះ ដូចជាសន្តិភាព និងភាពរុងរឿង ព្រមទាំងផលខាងវិញ្ញាណផងដែរ។ ផ្ទុយទៅវិញ ការមិនប្រតិបត្តិតាមវិន័យនេះ បណ្តាលឱ្យមានការខូចខាតជាច្រើនចំពោះសហគមន៍ និងមនុស្សផងទាំងពួង។

## ១. ក្រុមគ្រួសារតាមគម្រោងការរបស់ព្រះជាម្ចាស់

### សភាពរបស់ក្រុមគ្រួសារ

២២០១- សហគមន៍គ្រួសារកើតឡើង ដោយការព្រមព្រៀងរបស់គូស្វាមីភរិយា។ អាពាហ៍ពិពាហ៍ និងក្រុមគ្រួសារត្រូវបានរៀបចំ ដើម្បីផលប្រយោជន៍របស់គូស្វាមីភរិយា ការបន្តពូជពង្ស និងការអប់រំកូនចៅ។ សេចក្តីស្រឡាញ់រវាងគូស្វាមីភរិយា និងការបន្តពូជមានទំនាក់ទំនង និងការទទួលខុសត្រូវសំខាន់ៗរវាងសមាជិកនៃក្រុមគ្រួសារផ្ទាល់។

២២០២- បុរសនិងស្ត្រី ដែលរួបរួមគ្នាជាគូស្វាមីភរិយា និងកូនៗ បង្កើតជាគ្រួសារមួយ។ កិច្ចការនេះ រដ្ឋ

អំណាចមិនបាច់ទទួលស្គាល់ទេ។ ត្រូវតែចាត់ទុកថា ក្រុមគ្រួសារជាគំរូធម្មតា សម្រាប់របៀបផ្សេងៗក្នុងការធ្វើជាឪពុកម្តាយ។

២២០៣- ដោយបង្កើតបុរស និងស្ត្រី ព្រះជាម្ចាស់បានចាត់ចែងក្រុមគ្រួសាររបស់មនុស្ស ហើយបានប្រទានរចនាសម្ព័ន្ធជាមូលដ្ឋានគ្រឹះដល់ក្រុមគ្រួសារនេះ។ សមាជិករបស់ក្រុមគ្រួសារមានឋានៈស្មើគ្នា។ ក្រុមគ្រួសារទទួលខុសត្រូវ មានសិទ្ធិ និងភារកិច្ចផ្សេងៗ ដើម្បីជាប្រយោជន៍ដល់សមាជិករបស់ខ្លួន និងរបស់សង្គមផងដែរ។

### ក្រុមគ្រួសារគ្រីស្តបរិស័ទ

២២០៤- "ក្រុមគ្រួសារគ្រីស្តបរិស័ទបង្ហាញ និងសម្រេចយ៉ាងពិសេសការរួបរួមជាមួយគ្នាក្នុងព្រះសហគមន៍ ហេតុនេះ ត្រូវតែហៅក្រុមគ្រួសារនេះថាជាព្រះសហគមន៍ដ៏តូចមួយ" (FC ២១ ; LG ១១)។ ក្រុមគ្រួសារគ្រីស្តបរិស័ទជាសហគមន៍នៃជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់។ ដូចព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីបង្ហាញ (អភ ៥,២១-៦,៤ ; កូឡ ៣,១៨-២១ ; ១ពត្រ ៣,១-៧) ក្រុមគ្រួសារគ្រីស្តបរិស័ទមានសារៈសំខាន់ពិសេសក្នុងព្រះសហគមន៍។

២២០៥- ក្រុមគ្រួសារគ្រីស្តបរិស័ទជាការរួបរួមជាមួយមនុស្ស ជាស្លាកស្នាម និងរូបតំណាងនៃការរួបរួមរបស់ព្រះបិតា និងព្រះបុត្រាក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ។ សកម្មភាពបន្តពូជ និងអប់រំកូនរបស់ក្រុមគ្រួសារគ្រីស្តបរិស័ទឆ្លុះបញ្ចាំងស្នាព្រះហស្តរបស់ព្រះបិតាជាអ្នកបង្កើត។ ព្រះជាម្ចាស់ត្រាស់ហៅក្រុមគ្រួសារគ្រីស្តបរិស័ទឲ្យចែករំលែកការអធិដ្ឋាន និងសក្ការបូជារបស់ព្រះគ្រីស្ត។ ដោយអធិដ្ឋានជាប្រចាំថ្ងៃ និងដោយអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក្រុមគ្រួសារពង្រឹងសេចក្តីស្រឡាញ់។ ក្រុមគ្រួសារគ្រីស្តបរិស័ទប្រកាសដំណឹងល្អ ជាសាសនទូត។

២២០៦- ទំនាក់ទំនងនៅក្នុងក្រុមគ្រួសារនាំឲ្យមានមនោសញ្ចេតនា សេចក្តីស្រឡាញ់ និងប្រយោជន៍ផ្សេងៗ ដែលជាពិសេសមកពីមនុស្សគោរពគ្នាទៅវិញទៅមក។ ក្រុមគ្រួសារជាសហគមន៍ពិសេស ដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យ "គូស្វាមីភរិយាចែករំលែកគំនិតរបស់ខ្លួន ហើយឲ្យឪពុកម្តាយយកចិត្តទុកដាក់រួមសហការក្នុងកិច្ចអប់រំកូនៗផងដែរ" (GS ៥២,១)។

## ២. ក្រុមគ្រួសារ និងសង្គម

២២០៧- ក្រុមគ្រួសារជាកោសិកាដំបូងនៃការរស់នៅក្នុងសង្គម។ ក្រុមគ្រួសារជាសហគមន៍ធម្មជាតិ ដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យបុរស និងស្ត្រីប្រគល់គ្នាទៅវិញទៅមក ក្នុងសេចក្តីស្រឡាញ់ និងដោយផ្តល់ជីវិត។ អំណាច ស្ថិរភាព និងទំនាក់ទំនងក្នុងក្រុមគ្រួសារជាគ្រឹះនៃសេរីភាព សុវត្ថិភាព និងការរួមគ្នាជាបងប្អូននៅក្នុងសង្គម។ ក្រុមគ្រួសារជាសហគមន៍ ដែលចាប់តាំងពីកុមារភាពមក យើងអាចរៀនអំពីសីលធម៌ ចាប់ផ្តើមលើកតម្កើងព្រះជាម្ចាស់ និងរៀនប្រើសេរីភាពយ៉ាងត្រឹមត្រូវ។ ការរស់នៅជាក្រុមគ្រួសារបង្រៀនឲ្យចេះរស់នៅក្នុងសង្គម។

២២០៨- ក្រុមគ្រួសារត្រូវតែមានរបៀបរស់នៅ ដើម្បីឲ្យសមាជិករបស់ខ្លួនរៀនយកចិត្តទុកដាក់ទៅលើយុវជន និងចាស់ជរា អ្នកជំងឺ ឬអ្នកពិការ និងជនក្រីក្រ។ ជួនកាល មានក្រុមគ្រួសារជាច្រើន មិនអាចផ្តល់ជំនួយបែបនេះឡើយ។ នៅពេលនោះ មនុស្ស ក្រុមគ្រួសារផ្សេងទៀត និងសង្គម ត្រូវតែជួយផ្គត់ផ្គង់ទៅតាមតម្រូវការរបស់គេ៖ "រីឯសាសនាដ៏បរិសុទ្ធ ឥតខ្ចោះនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ជាព្រះបិតាវិញ គឺស្ថិតនៅលើការទៅសួរសុខទុក្ខក្មេងកំព្រា និងស្ត្រីមេម៉ាយ ដែលមានទុក្ខលំបាក ព្រមទាំងស្ថិតនៅលើការថែរក្សាខ្លួនឲ្យផុតពីអំពើ

សៅហ្មងរបស់លោកីយ៍នេះ" (យក ១,២៧)។

២២០៩- រដ្ឋអំណាចត្រូវចាត់វិធានការត្រឹមត្រូវ ដើម្បីការពារ និងគាំទ្រក្រុមគ្រួសារ។ នៅទីណាក្រុមគ្រួសារមិនអាចបំពេញមុខងាររបស់ខ្លួន ក្រុមឯទៀតនៃសង្គមត្រូវតែជួយ និងគាំទ្រក្រុមគ្រួសារនោះ។ តាមគោលការណ៍នៃជំនួស សហគមន៍ធំជាងត្រូវប្រុងប្រយ័ត្នកុំយកដណ្តើមអំណាច ឬលូកដៃចូលក្នុងការរស់នៅរបស់ក្រុមគ្រួសារនោះ។

២២១០-ក្រុមគ្រួសារសំខាន់សម្រាប់ការរស់នៅនិងសុខុមាលភាពនៃសង្គម (GS ៤៧,១) ទើបត្រូវទទួលខុសត្រូវយ៉ាងពិសេសក្នុងការគាំទ្រ និងការពង្រឹងអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារ។ សូមឲ្យរដ្ឋអំណាចចាត់ទុកថា ជាភារកិច្ចដ៏ធ្ងន់ធ្ងរមួយដែល "ត្រូវទទួលស្គាល់ និងការពារលក្ខណៈដ៏ពិតប្រាកដនៃការរស់នៅជាគូស្វាមីភរិយា និងជាក្រុមគ្រួសារ ការពារសីលធម៌សាធារណៈ និងជួយឲ្យក្រុមគ្រួសារមានជីវភាពធូរធាន" (GS ៥២,២)។

២២១១- សហគមន៍ខាងនយោបាយមានភារកិច្ចលើកកិត្តិយស និងគាំទ្រក្រុមគ្រួសា ដោយធានា៖

- សេរីភាពក្នុងការបង្កើតក្រុមគ្រួសារ មានកូន និងចិញ្ចឹមថែរក្សាគេទៅតាមសីលធម៌ និងសាសនារបស់ខ្លួន
- ការពារស្ថិរភាពនៃចំណងរវាងស្វាមីភរិយា និងស្ថាប័ននៃក្រុមគ្រួសារ
- សេរីភាពប្រកាស និងបញ្ជូនជំនឿរបស់ខ្លួន អប់រំកូនក្នុងសាសនានេះ រួមជាមួយមធ្យោបាយ និងស្ថាប័នចាំបាច់
- សិទ្ធិមានកម្មសិទ្ធិឯកជន សេរីភាពបង្កើត មានការងារ មានលំនៅដ្ឋាន មានសិទ្ធិចាកចេញពីស្រុក
- តាមស្ថាប័ននៃប្រទេសនីមួយៗ មានសិទ្ធិទទួលការព្យាបាល ទទួលការឧបត្ថម្ភសម្រាប់មនុស្សចាស់ជរា និងទទួលវិភាជន៍គ្រួសារ
- ការពារសុវត្ថិភាព ជាពិសេសប្រឆាំងនឹងគ្រោះថ្នាក់បណ្តាលមកពីគ្រឿងញៀន ការជួញដូរមនុស្ស និងរោគញៀនស្រា ជាដើម
- សេរីភាពបង្កើតសហគមន៍ជាមួយក្រុមគ្រួសារផ្សេងទៀត ហើយអាចជាតំណាងចំពោះមុខអាជ្ញាធរស៊ីវិល (FC ៤៦)។

២២១២- វិន័យទីបួនបំភ្លឺទំនាក់ទំនងឯទៀតៗនៅក្នុងសង្គម។ រវាងបងប្អូនបង្កើតយើងៗឃើញកូនរបស់ឪពុកម្តាយយើង ក្នុងបងប្អូនជីដូនមួយយើងៗឃើញកូនចៅនៃបុព្វបុរសយើង ក្នុងប្រពលរដ្ឋយើងៗឃើញកូននៃមាតុភូមិយើង ក្នុងអស់អ្នកដែលជ្រមុជទឹក យើងឃើញកូននៃមាតាយើង គឺព្រះសហគមន៍ ហើយក្នុងមនុស្សណាម្នាក់ យើងឃើញបុត្រធិតារបស់អ្នកដែលសព្វព្រះហឫទ័យឲ្យយើងហៅថា "ព្រះបិតានៃយើង"។ ដូច្នេះ ទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ ដូចជាទំនាក់ទំនងជាមួយបងប្អូន។ អ្នកដទៃមិនមែនជា "បុគ្គលណាម្នាក់" នៃសង្គមមនុស្សទេ ប៉ុន្តែជា "មនុស្សម្នាក់" ដែលគួរចាប់អារម្មណ៍ និងគោរពយ៉ាងពិសេស ដ្បិតយើងស្គាល់ដើមកំណើតរបស់គាត់។

២២១៣- មនុស្ស បង្កើតសហគមន៍មនុស្ស។ យើងគ្រប់គ្រងសហគមន៍ទាំងអស់នោះឲ្យបានល្អ មិនគ្រាន់តែនៅពេលដែលយើងធានាសិទ្ធិ និងបំពេញភារកិច្ច ព្រមទាំងគោរពកិច្ចសន្យាប៉ុណ្ណោះទេ ថែមទាំងត្រូវតែមាន

ទំនាក់ទំនងត្រឹមត្រូវរវាងចៅហ្វាយនិងបុគ្គលិក អ្នកគ្រប់គ្រងនិងប្រជាពលរដ្ឋ ដែលចេះយល់ចិត្តគ្នាទៅវិញទៅមក ស្របតាមឋានៈដ៏ថ្លៃថ្នូរបស់មនុស្ស ដែលមានបំណងប្រាថ្នាចង់បានយុត្តិធម៌ និងរស់នៅជាមួយគ្នាដូចបងប្អូន។

## ៣. ភារកិច្ចនៃសមាជិកក្រុមគ្រួសារ ភារកិច្ចរបស់កូនៗ

២២១៤- ព្រះជាម្ចាស់ជាព្រះបិតា ជាប្រភពនៃក្រុមគ្រួសារ (អភ ៣,១៤) និងជាមូលដ្ឋានគ្រឹះនៃកិត្តិយសជាឪពុកម្ដាយ។ ការគោរពរបស់កូនចំពោះឪពុកម្ដាយ ទោះជាអនិតិជន ឬជាមនុស្សពេញវ័យក៏ដោយ (សុភ ១,៨ ; តប ៤,៣-៤) កើតមកពីចំណងនៃសេចក្ដីស្រឡាញ់ខាងធម្មជាតិរវាងពួកគេ។ បទបញ្ញារបស់ព្រះជាម្ចាស់សុំឲ្យកូនៗគោរពមាតាបិតា (សរ ២០,១២)។

២២១៥- ការគោរពមាតាបិតា មកពីយើងដឹងគុណ អ្នកដែលបានបង្កើតកូនដោយផ្ដល់ជីវិត ដោយសារសេចក្ដីស្រឡាញ់ និងការងាររបស់គាត់ និងបានជួយឲ្យគេមានវ័យចម្រើនឡើង មានប្រាជ្ញាកាន់តែវាងវៃ ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់។ "ចូរលើកកិត្តិយសរបស់ឪពុក ដោយស្មោះអស់ពីចិត្ត កុំបំភ្លេចការឈឺចាប់របស់ម្ដាយនៅពេលបង្កើតអ្នកមកនោះឡើយ។ ចូរនឹកចាំថា កូនមានជីវិត ដោយសារគាត់ទាំងពីរ។ តើកូនត្រូវធ្វើយ៉ាងណាដើម្បីតបស្នងសងគុណគាត់?" (បសរ ៧,២៧-២៨)។

២២១៦- យើងបង្ហាញថា យើងគោរពមាតាបិតា ដោយធ្វើតាម និងស្ដាប់បង្គាប់ គាត់យ៉ាងពិតប្រាកដ។ "កូនអើយ! ចូរស្ដាប់ឱវាទរបស់ឪពុក កុំចោលដំបូន្មានរបស់ម្ដាយ (...) ពេលកូនទៅណាមកណា ដំបូន្មាននោះនាំផ្លូវកូន ការពារកូន ក្នុងពេលដេក ហើយសារស័ព្ទជាមួយកូន នៅពេលកូនភ្ញាក់" (សុភ ៦,២០-២២)។ "កូនមានប្រាជ្ញា តែងតែស្ដាប់ពាក្យទូន្មានរបស់ឪពុក រីឯកូនព្រហើនមិនព្រមស្ដាប់ការស្ដីប្រដៅទេ" (សុភ ១៣,១)។

២២១៧- វេលាដែលកូនរស់នៅជាមួយឪពុកម្ដាយ កូនត្រូវតែស្ដាប់បង្គាប់ឱវាទរបស់គាត់ ដែលចង់ឲ្យកូនបានល្អសម្រាប់ខ្លួនឯង ឬសម្រាប់ក្រុមគ្រួសារ។ "កុមារាកុមារី ចូរស្ដាប់បង្គាប់មាតាបិតា ក្នុងគ្រប់កិច្ចការទាំងអស់។ ធ្វើដូច្នេះ ទើបគាប់ព្រះហឫទ័យព្រះអម្ចាស់" (កូឡ ៣,២០) (អភ ៦,១)។ ក្មេងៗត្រូវតែស្ដាប់បង្គាប់ឱវាទត្រឹមត្រូវរបស់គ្រូអប់រំ និងអស់អ្នកដែលឪពុកម្ដាយបានប្រគល់ឲ្យថែមទៀតផង។ ប៉ុន្តែ ប្រសិនបើកូនយល់ឃើញថា មិនគួរស្ដាប់បង្គាប់ឱវាទដ៏អាក្រក់ សូមកុំធ្វើតាមឡើយ។

- ពេលធំពេញវ័យ កូនត្រូវតែបន្តគោរពឪពុកម្ដាយ។ ពួកគេត្រូវយកចិត្តទុកដាក់នឹងបំណងរបស់គាត់ សូមដំបូន្មានពីគាត់ និងទទួលយកការស្ដីបន្ទោសដ៏ត្រឹមត្រូវរបស់គាត់។ ពេលកូនទៅជាមនុស្សពេញវ័យ គេអាចលែង ស្ដាប់បង្គាប់ឪពុកម្ដាយ ប៉ុន្តែគេនៅតែត្រូវគោរពគាត់ជាដរាប។ តាមការពិត ការគោរពនេះ ចាក់ឫសក្នុងការគោរពកោតខ្លាចព្រះជាម្ចាស់ ដែលជាព្រះអំណោយទានមួយនៃព្រះវិញ្ញាណដ៏វិសុទ្ធ។

២២១៨- វិន័យទីបួនរំឭកឲ្យកូន ដែលក្លាយទៅជាមនុស្សពេញវ័យ ថា គេទទួលខុសត្រូវចំពោះឪពុកម្ដាយ។ តាមសមត្ថភាព ពួកគេត្រូវតែផ្ដល់ជំនួយខាងសម្ភារៈ និងខាងវិញ្ញាណ នៅពេលដែលឪពុកម្ដាយចាស់ជរា ឈឺ ឯកោ ឬពិបាកចិត្ត។ ព្រះយេស៊ូរំឭកអំពីភារកិច្ចនេះ (មក ៧,១០-១២)។

> ព្រះអម្ចាស់ប្រទានឲ្យឪពុកមានអំណាចលើកូន ព្រះអង្គក៏ប្រទានឲ្យម្ដាយមានសិទ្ធិលើកូនប្រុសដែរ។ កូនណាគោរពឪពុក កូននោះលោះបាបរបស់ខ្លួន។ កូនដែលលើកតម្កើងកិត្តិយសរបស់ម្ដាយ ដូចជាការសន្សំទ្រព្យសម្បត្តិទុក។ កូន ដែលគោរពឪពុក នឹងបានអំណរសប្បាយពីកូនរបស់ខ្លួនវិញពុំខាន ហើយនៅ

ថ្ងៃដែលគេអង្វរព្រះអម្ចាស់ ព្រះអង្គទ្រង់ព្រះសណ្ដាប់គេ។ កូនណាលើកតម្កើងកិត្តិយសរបស់ឪពុក កូននោះនឹងមានអាយុយឺនយូរ។ កូនដែលប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអម្ចាស់នឹងធ្វើឲ្យម្ដាយស្ងប់ចិត្ត (បសរ ៣,២-៦)។

កូនអើយ! ចូរផ្គត់ផ្គង់ឲ្យឪពុកអ្នកក្នុងពេលដែលគាត់ចាស់ជរា ហើយកុំធ្វើឲ្យគាត់កើតទុក្ខនៅពេលគាត់នៅមានជីវិត។ ទោះបីគាត់វង្វេងស្មារតីក្ដី ចូរអាណិតមេត្តាដល់គាត់ផង ក្នុងពេលកូនពេញកម្លាំង កុំមើលងាយគាត់ឲ្យសោះ (...)។ អ្នកណាបោះបង់ចោលឪពុករបស់ខ្លួន អ្នកនោះដូចជាប្រមាថព្រះជាម្ចាស់ ហើយអ្នកណាធ្វើឲ្យម្ដាយពិបាកចិត្ត ព្រះអម្ចាស់នឹងដាក់បណ្ដាសាអ្នកនោះ (បសរ ៣,១២-១៣.១៦)។

២២១៩- នៅពេលដែលយើងគោរពមាតាបិតា ការរស់នៅក្នុងក្រុមគ្រួសារស្រណុកសុខស្រួល។ ម្យ៉ាងទៀតយើងក៏ត្រូវគោរពបងប្អូនបង្កើត ផងដែរ។ ការគោរពមាតាបិតាបំភ្លឺក្រុមគ្រួសារទាំងមូល។ "ចៅរមែងធ្វើឲ្យជីតាមានកិត្តិយស រីឯកូនបានខ្ពស់មុខ ព្រោះតែឪពុកផងដែរ" (សុភ ១៧,៦)។ "ចូរបន្ទាបខ្លួន មានចិត្តស្លូតបូត និងចេះអត់ធ្មត់ ព្រមទាំងទ្រាំទ្រគ្នាទៅវិញទៅមក ដោយសេចក្ដីស្រឡាញ់" (អភ ៤,២)។

២២២០- ឯគ្រីស្តបរិស័ទវិញ គេដឹងគុណយ៉ាងពិសេសចំពោះអស់អ្នក ដែលបានផ្ដល់ព្រះអំណោយទាននៃជំនឿ ព្រះអំណោយទាននៃពិធីជ្រមុជទឹក និងការរស់នៅក្នុងព្រះសហគមន៍ ដូចជាឪពុកម្ដាយ សមាជិកផ្សេងនៃក្រុមគ្រួសារ លោកតា លោកយាយ ពួកគង្វាល គ្រូអប់រំជំនឿ គ្រូផ្សេងទៀត ឬមិត្តភ័ក្ដិ។ "ខ្ញុំក៏នៅនឹកចាំអំពីជំនឿឥតលាក់លៀមពុតរបស់ប្អូន គឺជាជំនឿដែលលោកយាយឡូអ៊ីសជាជីដូន និងអ្នកស្រីអឺនីសជាម្ដាយរបស់ប្អូន ធ្លាប់មានមុនប្អូន ខ្ញុំជឿជាក់ថា ប្អូនក៏មានជំនឿនេះដែរ" (២ធម ១,៥)។

## ភារកិច្ចរបស់មាតាបិតា

២២២១- សេចក្ដីស្រឡាញ់របស់គូស្វាមីភរិយាមិនគ្រាន់តែបង្កើតផល ដោយបន្តពូជប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវអប់រំកូនខាងសីលធម៌ និងខាងវិញ្ញាណផង។ "តួនាទីរបស់មាតាបិតាក្នុងការអប់រំ សំខាន់ណាស់ ដែលគេស្ទើរតែមិនអាចជំនួសគាត់បានឡើយ" (GE ៣)។ ឪពុកម្ដាយមានសិទ្ធិ និងភារកិច្ចអប់រំសំខាន់ៗ មិនអាចផ្ទេរបានឡើយ (FC ៣៦)។

២២២២- ឪពុកម្ដាយត្រូវមើលឃើញទុកកូនរបស់ខ្លួនដូចជាបុត្រធីតារបស់ព្រះជាម្ចាស់ និងគោរពគេដូចជាបុគ្គលម្នាក់។ គាត់អប់រំកូនឲ្យបំពេញធម្មវិន័យរបស់ព្រះជាម្ចាស់ ដោយខ្លួនគាត់ផ្ទាល់ស្ដាប់បង្គាប់ព្រះហឫទ័យរបស់ព្រះបិតាដែលគង់នៅស្ថានបរមសុខ។

២២២៣- មាតាបិតាជាអ្នកទទួលខុសត្រូវដំបូងនៃការអប់រំកូនរបស់គាត់។ គាត់ផ្ដល់សក្ខីភាពអំពីការទទួលខុសត្រូវនេះ ដោយបង្កើតក្រុមគ្រួសារមួយ ទៅតាមច្បាប់ក្បួនដោយការថ្នាក់ថ្នម ការលើកលែងទោស ការគោរពភក្ដីភាព និងការបម្រើគ្នាទៅវិញទៅមកដោយមិនគិតអំពីប្រយោជន៍ផ្ទាល់ខ្លួន។ ក្រុមគ្រួសារជាកន្លែង ដើម្បីអប់រំគុណធម៌ ពោលគឺត្រូវបង្រៀនឲ្យចេះលះបង់ខ្លួនឯង ឲ្យចេះរិះគិតពិចារណាត្រឹមត្រូវ ឲ្យចេះទប់ចិត្តខ្លួនឯង ដើម្បីឲ្យមានសេរីភាពយ៉ាងពិតប្រាកដ។ ឪពុកម្ដាយនឹងបង្រៀនកូនឲ្យចេះដាក់ខ្លួនទៅតាមលក្ខណៈផ្លូវកាយ លក្ខណៈដែលជាសភាវគតិនៃសភាពខាងក្នុង និងខាងវិញ្ញាណ" (CA ៣៦)។ ពួកគាត់មានភារកិច្ចយ៉ាងធ្ងន់ធ្ងរ ដើម្បីធ្វើជាគំរូដ៏ល្អដល់កូនៗ។ ពួកគាត់អាចណែនាំ និងកែលំអកូនៗឲ្យបានល្អប្រសើរ ដោយទទួលស្គាល់គុណវិបត្តិរបស់ខ្លួនគាត់ផ្ទាល់៖

"អ្នកស្រឡាញ់កូនប្រុសរបស់ខ្លួនខ្លាំង តែងតែវាយវានឹងរំពាត់ជាញឹកញាប់។ ដល់ពេលចាស់ អ្នកនោះនឹងបានសប្បាយដោយសារកូនពុំខាន" (បសរ ៣០,១)។ " រីឯអ្នកដែលជាឪពុកវិញ កុំធ្វើឲ្យកូនរបស់ខ្លួនមួម៉ៅឡើយ ប៉ុន្តែត្រូវអប់រំវាដោយពាក្យប្រៀនប្រដៅ និងដំបូន្មាន ស្របតាមព្រះអម្ចាស់" (អភ ៤,៦)។

២២២៤- ក្រុមគ្រួសារជាកន្លែងធម្មជាតិ ដើម្បីបង្ហាត់មនុស្សឲ្យចេះសាមគ្គី និងចេះទទួលខុសត្រូវក្នុងសហគមន៍។ មាតាបិតានឹងបង្រៀនកូនកុំឲ្យចូលដៃក្នុងរឿងអាស្រូវ ឬក្នុងអំពើថោកទាប ដែលគម្រាមកំហែងសហគមន៍មនុស្ស។

២២២៥- ដោយសារព្រះអំណោយទាននៃអគ្គសញ្ញាអពាហ៍ពិពាហ៍ មាតាបិតាបានទទួលខុសត្រូវ និងទទួលឯកសិទ្ធិក្នុងការប្រកាសដំណឹងល្អចំពោះកូន។ គាត់នឹងបង្ហាត់បង្រៀនគេ តាំងពីក្មេង ឲ្យស្គាល់គម្រោងការដ៏លាក់កំបាំងនៃជំនឿ។ ចំពោះកូន គាត់ជា "សាក្សីដំបូង" (LG ១១) នៃជំនឿនេះ។ គាត់នឹងដឹកនាំឲ្យគេចូលរួមចំណែកក្នុងការរស់នៅរបស់ព្រះសហគមន៍ តាំងពីក្មេងមកដែរ។ របៀបរស់នៅក្នុងក្រុមគ្រួសារអាចបំប៉នចិត្តគំនិតគេដែលនឹងជួយគាំទ្រគេអស់មួយជីវិត។

២២២៦- មាតាបិតាត្រូវតែអប់រំជំនឿ តាំងពីកូននៅតូច។ នៅពេលដែលសមាជិកក្រុមគ្រួសារជួយគ្នាឲ្យរីកចម្រើនក្នុងជំនឿ ដោយផ្តល់សក្ខីភាពជារបៀបរស់នៅស្របតាមដំណឹងល្អ។ ការអប់រំជំនឿក្នុងក្រុមគ្រួសារកើតមុន ជួយកំដរ និងធ្វើឲ្យរបៀបប្រៀនប្រដៅជំនឿផ្សេងៗទៀតរីកចម្រើន។ មាតាបិតាមានបេសកកម្មបង្រៀនកូនឲ្យចេះអធិដ្ឋាន និងឲ្យយល់អំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះគេ ជាបុត្រធីតារបស់ព្រះអង្គ (LG ១១)។ ព្រះសហគមន៍តាមភូមិជាសហគមន៍នៃពិធីអរព្រះគុណ និងជាស្នូលនៃជីវិតខាងពិធីបុណ្យរបស់ក្រុមគ្រួសារគ្រីស្តបរិស័ទ ហើយជាកន្លែងពិសេស ដើម្បីអប់រំជំនឿកូន និងឪពុកម្តាយ។

២២២៧- ឯកូនៗវិញ គេនឹងជួយឲ្យឪពុកម្តាយរីកចម្រើនក្នុងភាពដ៏វិសុទ្ធ (GS ៤៨,៤)។ ពួកគេនឹងផ្តល់ឲ្យគ្នាទៅវិញទៅមកដោយចិត្តសប្បុរសនិងដោយមិនធុញទ្រាន់ក្នុងការលើកលែងទោសដែលមកពីការឈ្លោះប្រកែក អំពើអយុត្តធម៌ និងការបោះបង់ចោលគ្នា។ សេចក្តីស្រឡាញ់រវាងបងប្អូនផ្តល់គំនិតថា គេគួរលើកលែងទោសគ្នាទៅវិញទៅមក ឯសេចក្តីស្រឡាញ់របស់ព្រះគ្រីស្តសុំឲ្យគេលើកលែងទោសគ្នាទៅវិញទៅមក (មថ ១៨,២១-២២ ; លក ១៧,៤)។

២២២៨- មាតាបិតាគោរព និងស្រឡាញ់តាំងពីកូននៅតូច ដោយយកចិត្តទុកដាក់ និងពុំធ្វេសប្រហែសក្នុងការចិញ្ចឹមកូន ហើយដោយបំពេញតម្រូវការខាងផ្លូវកាយ និងខាងវិញ្ញាណ។ នៅពេលដែលកូនកំពុងចម្រើនវ័យ មាតាបិតានៅតែគោរពកូន និងបូជាខ្លួនសម្រាប់កូនដដែល ដោយអប់រំកូនឲ្យប្រើប្រាជ្ញា និងសេរីភាពរបស់គេតាមរបៀបត្រឹមត្រូវ។

២២២៩- មាតាបិតាជាអ្នកទទួលខុសត្រូវដំបូងបង្អស់ក្នុងការអប់រំកូន គាត់មានសិទ្ធិជ្រើសរើសសាលារៀនស្របតាមជំនឿរបស់ខ្លួន។ សិទ្ធិនេះ ជាសិទ្ធិមូលដ្ឋាន។ តាមសមត្ថភាពរបស់ខ្លួន មាតាបិតាមានភារកិច្ចជ្រើសរើសសាលារៀនណា ដែលនឹងជួយគាត់ឲ្យបានល្អប្រសើរ ក្នុងមុខងារជាអ្នកអប់រំ និងជាគ្រីស្តបរិស័ទ (GE ៦)។ រដ្ឋអំណាចត្រូវតែធានាសិទ្ធិរបស់ឪពុកម្តាយនេះ និងឲ្យគេអាចប្រតិបត្តិតាមយ៉ាងពិតប្រាកដ។

២២៣០-ដោយក្លាយទៅជាមនុស្សពេញវ័យកូនមានភារកិច្ចនិងសិទ្ធិជ្រើសរើសវិជ្ជាជីវៈនិងសម្រេចចិត្តក្នុងការរស់នៅរបស់ពួកគេ។ គេនឹងទទួលយកការទទួលខុសត្រូវថ្មីនេះ ដោយជឿទុកចិត្តលើឪពុកម្តាយ ហើយដោយសុំនិងទទួលយោបល់ និងដំបូន្មានរបស់គាត់។ មាតាបិតានឹងប្រុងប្រយ័ត្នកុំបង្ខិតបង្ខំកូនឲ្យជ្រើសរើសវិជ្ជាជីវៈ ឬគូរ

ស្រករ។ ប៉ុន្តែគាត់អាចជួយផ្តល់យោបល់ដ៏ល្អត្រឹមត្រូវ ជាពិសេសនៅពេលដែលកូនគិតគូរអំពីការកសាងគ្រួសារ។

២២៣១- អ្នកខ្លះមិនរៀបការ ដើម្បីថែរក្សាឪពុកម្តាយ ឬបងប្អូនបង្កើត ឬពីព្រោះគេបូជាខ្លួនចំពោះវិជ្ជាជីវៈ ឬដើម្បីមូលហេតុត្រឹមត្រូវផ្សេងទៀត។ ពួកគេអាចជួយឲ្យក្រុមគ្រួសាររបស់មនុស្សរីកចម្រើនខ្លាំងណាស់។

## ៤. ក្រុមគ្រួសារ និងព្រះរាជ្យ

២២៣២- ទោះជាចំណងក្រុមគ្រួសារសំខាន់យ៉ាងណាក៏ដោយ ក៏មិនសំខាន់លើសអ្វីៗទាំងអស់ដែរ។ កូនចម្រើនវ័យរិះគិតពិចារណា មានឯករាជ្យជាមនុស្ស និងខាងវិញ្ញាណយ៉ាងណា គេក៏យល់ការត្រាស់ហៅពិសេសដែលមកពីព្រះជាម្ចាស់ កាន់តែច្បាស់ និងកាន់តែខ្លាំងឡើងៗយ៉ាងនោះដែរ។ មាតាបិតានឹងគោរពការត្រាស់ហៅ និងជួយកូនឲ្យឆ្លើយតបនឹងការត្រាស់ហៅនេះ។ ត្រូវតែយល់ឲ្យច្បាស់ថា ការត្រាស់ហៅដំបូងរបស់គ្រីស្តបរិស័ទ គឺដើរតាមព្រះយេស៊ូ (មថ ១៦,២៥)៖ "អ្នកណាស្រឡាញ់ឪពុកម្តាយ ខ្លាំងជាងស្រឡាញ់ខ្ញុំ អ្នកនោះមិនសមនឹងធ្វើជាសាវ័ករបស់ខ្ញុំឡើយ។ អ្នកដែលស្រឡាញ់កូនប្រុស កូនស្រីរបស់ខ្លួន ខ្លាំងជាងស្រឡាញ់ខ្ញុំ ក៏មិនសមនឹងធ្វើជាសាវ័ករបស់ខ្ញុំដែរ" (មថ ១០,៣៧)។

២២៣៣- បើយើងក្លាយទៅជាសាវ័ករបស់ព្រះយេស៊ូ គឺយើងសុខចិត្តឆ្លើយតបនឹងព្រះអង្គ ដែលអញ្ជើញយើងឲ្យទៅជាកម្មសិទ្ធិនៃក្រុមគ្រួសាររបស់ព្រះជាម្ចាស់ ឲ្យរស់នៅស្របតាមរបៀបរស់នៅរបស់ព្រះអង្គ៖ "អ្នកណាធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខអ្នកនោះហើយជាបងប្អូនប្រុសស្រី និងជាម្តាយរបស់ខ្ញុំ" (មថ ១២,៤៩-៥០)។

- ឪពុកម្តាយនឹងទទួល ហើយគោរពដោយអំណរ និងដោយអរព្រះគុណព្រះជាម្ចាស់ ចំពោះការត្រាស់ហៅរបស់ព្រះអម្ចាស់ឲ្យកូនណាម្នាក់របស់គាត់ ដើរតាមព្រះអង្គ ដោយធ្វើជាព្រហ្មចារីយ៍ ដើម្បីព្រះរាជ្យ ដោយថ្វាយខ្លួនជាបព្វជិតបព្វជិតា ឬដោយធ្វើជាបូជាចារ្យ។

## ៥. អាជ្ញាធរក្នុងសង្គមស៊ីវិល

២២៣៤- វិន័យទីបួនរបស់ព្រះជាម្ចាស់បញ្ជាឲ្យយើងលើកកិត្តិយសអស់អ្នក ដែលបានទទួលពីព្រះជាម្ចាស់នូវអំណាចនៅក្នុងសង្គម ដើម្បីផលប្រយោជន៍យើង។ វិន័យនេះ បំភ្លឺភារកិច្ចរបស់អស់អ្នកដែលកាន់អំណាច ក៏ដូចជាអស់អ្នកដែលទទួលប្រយោជន៍ពីអំណាចនេះ។

### ភារកិច្ចរបស់អាជ្ញាធរស៊ីវិល

២២៣៥- អស់អ្នកដែលកាន់អំណាច ត្រូវប្រើអំណាចដូចជាអ្នកបម្រើ៖ "បើមានអ្នកណាម្នាក់ចង់ធ្វើធំជាងគេក្នុងចំណោមអ្នករាល់គ្នា ត្រូវឲ្យអ្នកនោះបម្រើអ្នករាល់គ្នាវិញ" (មថ ២០,២៦)។ យើងដឹងថា គេកាន់អំណាចប្រកបដោយសីលធម៌ បើអំណាចនេះ មកពីព្រះជាម្ចាស់ និងមានលក្ខណៈត្រឹមត្រូវ ហើយតាមគោលដៅពិសេសរបស់អំណាចនេះ។ គ្មាននរណាម្នាក់អាចបញ្ជា ឬចាត់ចែងអ្វីដែលប្រឆាំងនឹងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស និងប្រឆាំងនឹងធម្មវិន័យធម្មជាតិបានឡើយ។

២២៣៦- ការប្រើប្រាស់អំណាចមានគោលដៅបម្រើឧត្តមគតិតាមលំដាប់លំដោយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់សេរីភាព និងការទទួលខុសត្រូវរបស់មនុស្សទាំងអស់។ មេដឹកនាំនឹងបំពេញភារកិច្ចនេះតាមយុត្តិធម៌

ប្រកបដោយប្រាជ្ញាញាណ ដោយយកចិត្តទុកដាក់តាមតម្រូវការ និងការរួមចំណែករបស់មនុស្សម្នាក់ៗ ដើម្បីឲ្យបានសេចក្តីសុខសាន្ត និងសន្តិភាព។ ពួកគេប្រុងប្រយ័ត្នកុំឲ្យក្បួនច្បាប់ និងសេចក្តីសម្រេចរបស់គេក្លាយទៅជាការល្បួង ដោយតាំងប្រយោជន៍ផ្ទាល់ខ្លួនប្រឆាំងនឹងប្រយោជន៍រួម (CA ២៥)។

២២៣៧- រដ្ឋអំណាច ត្រូវតែគោរពសិទ្ធិគ្រឹះរបស់មនុស្ស ការពារយុត្តិធម៌ ដោយគោរពសិទ្ធិរបស់មនុស្សម្នាក់ៗ ជាពិសេសសិទ្ធិរបស់ក្រុមគ្រួសារ និងជនក្រីក្រ។

- រដ្ឋអំណាចអាច និងត្រូវតែ ផ្តល់សិទ្ធិខាងនយោបាយដល់ប្រជាពលរដ្ឋ ដើម្បីប្រយោជន៍រួម។ រដ្ឋអំណាចមិនអាចផ្អាកសិទ្ធិនោះ ដោយគ្មានមូលហេតុត្រឹមត្រូវ និងមិនសមស្របតាមយុត្តិធម៌ បានឡើយ។ ការគោរពសិទ្ធិខាងនយោបាយ មានគោលដៅឲ្យបានប្រយោជន៍ដល់ជាតិ និងដល់សហគមន៍មនុស្ស។

## ភារកិច្ចរបស់ប្រជាពលរដ្ឋ

២២៣៨- អស់អ្នកដែលស្ថិតក្រោមការដឹកនាំរបស់អាជ្ញាធរ ត្រូវចាត់ទុកមេដឹកនាំដូចជារូបតំណាងរបស់ព្រះជាម្ចាស់ ដែលបានតែងតាំងគេជាអ្នកបម្រើនៃព្រះអំណោយទានរបស់ព្រះអង្គ (រម ១៣,១-២)៖ "សូមគោរពចុះចូលអំណាចនានា នៅលើផែនដីនេះ ដោយយល់ដល់ព្រះអម្ចាស់ (...) ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យបងប្អូនបំបិទមាត់ពួកមនុស្សខ្លៅ ដោយបងប្អូនប្រព្រឹត្តអំពើល្អឲ្យសមនឹងឋានៈជាមនុស្សមានសេរីភាព ក៏ប៉ុន្តែកុំប្រើសេរីភាពនេះ ដើម្បីគ្របបាំងអំពើអាក្រក់ឡើយ គឺត្រូវប្រព្រឹត្តឲ្យសមនឹងឋានៈបងប្អូនដែលជាអ្នកបម្រើរបស់ព្រះជាម្ចាស់" (១ពត្រ ២,១៣.១៦)។ ពួកអ្នកដឹកនាំមានសិទ្ធិ ជួនកាលមានភារកិច្ច ស្តីបន្ទោសយ៉ាងត្រឹមត្រូវចំពោះអ្វីដែលពួកគេគិតថា អាចបង្ខូចឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស និងផលប្រយោជន៍របស់សហគមន៍ ដើម្បីរួមសហការយ៉ាងស្មោះត្រង់ជាមួយអាជ្ញាធរ។

២២៣៩- ប្រជាពលរដ្ឋមានភារកិច្ចរួមសហការជាមួយអាជ្ញាធរស៊ីវិល ដើម្បីប្រយោជន៍របស់សង្គម តាមសេចក្តីពិតដោយយុត្តិធម៌រួមសាមគ្គីនិងប្រកបដោយសេរីភាព។សេចក្តីស្រឡាញ់ និងការចេះដឹងគុណជំរុញឲ្យស្រឡាញ់ និងបម្រើមាតុភូមិ។ ក្នុងសហគមន៍ខាងនយោបាយ ប្រជាពលរដ្ឋត្រូវមានតួនាទីបម្រើប្រយោជន៍រួម ក្រោមការដឹកនាំដ៏ត្រឹមត្រូវនៃអាជ្ញាធររបស់ខ្លួន។

២២៤០- ការចុះចូលក្រោមអាជ្ញាធរ និងការទទួលខុសត្រូវរួម ដើម្បីប្រយោជន៍រួម តម្រូវឲ្យយើងបង់ពន្ធបោះឆ្នោត និងការពារប្រទេសជាតិ៖

> ត្រូវជូនលោកទាំងនោះនូវអ្វីដែលបងប្អូនត្រូវជូន គឺបង់អាករទៅលោកណា ដែលបងប្អូនត្រូវបង់ បង់ពន្ធទៅលោកណា ដែលបងប្អូនត្រូវបង់ពន្ធ កោតខ្លាចលោកណា ដែលបងប្អូនត្រូវកោតខ្លាច គោរពលោកណា ដែលបងប្អូនត្រូវគោរព (រម ១៣,៧)។
>
> គ្រីស្តបរិស័ទស្ថិតក្នុងមាតុភូមិរបស់ខ្លួន ប៉ុន្តែគេរស់នៅដូចជាជនបរទេស។ គេបំពេញភារកិច្ចទាំងអស់របស់ប្រជាពលរដ្ឋ និងទទួលបន្ទុកទាំងអស់របស់ខ្លួន ដូចជាជនបរទេសដែរ (...)។ គេស្តាប់បង្គាប់ច្បាប់ ហើយរបៀបរស់នៅរបស់គេប្រសើរជាងច្បាប់ទាំងអស់នោះទៅទៀត (...)។ ព្រះជាម្ចាស់បានតែងតាំងគេឲ្យទទួលមុខងារដ៏ប្រសើរបំផុត បានជាគេមិនអាចរត់ចោលជួរបានឡើយ (លិខិតជនចំពោះលោកឌីអូក្នេត)។

គ្រីស្តទូតប៉ូលដាស់តឿនយើងឲ្យទូលអង្វរ និងអរព្រះគុណព្រះជាម្ចាស់ ដើម្បីព្រះរាជា និងអស់អ្នកដែលកាន់អំណាចគ្រប់ៗរូប "ដើម្បីឲ្យយើងរស់នៅបានសុខក្សេមក្សាន្ត គ្មានចលាចល ដោយគោរពប្រណិប័តន៍ព្រះជាម្ចាស់ អស់ពីចិត្ត និងមានជីវិតយ៉ាងថ្លៃថ្នូរ" (១ធម ២,២)។

២២៤១- ប្រជាជាតិជឿនលឿនត្រូវតែទទួលជនបរទេស ដែលមកជ្រកកោន ដើម្បីរស់រានមានជីវិត ដែលគេមិនអាចរកឃើញក្នុងប្រទេសរបស់ខ្លួន។ រដ្ឋអំណាចនឹងប្រុងប្រយ័ត្នក្នុងការគោរពសិទ្ធិធម្មជាតិ ដែលធ្វើឲ្យម្ចាស់ផ្ទះត្រូវការពារភ្ញៀវរបស់ខ្លួន។

ដើម្បីផលប្រយោជន៍រួម អាជ្ញាធរអាចតម្រូវឲ្យជនបរទេសគោរពតាមលក្ខ័ណ និងច្បាប់ ជាពិសេសអ្នកទាំងអស់នោះ ត្រូវគោរពភារកិច្ចរបស់ខ្លួនជាជនអន្តោប្រវេស៍ចំពោះប្រទេស ដែលគេមកជ្រកកោន ហើយដឹងគុណចំពោះបេតិកភ័ណ្ឌដែលជាសម្ភារៈ និងវិញ្ញាណ ហើយគោរពច្បាប់ និងបង់ពន្ធជូនប្រទេសនោះ។

២២៤២- ប្រជាពលរដ្ឋមិនត្រូវធ្វើតាមបទបញ្ជារបស់អាជ្ញាធរស៊ីវិលនៅពេលដែលបទបញ្ជានោះប្រឆាំងនឹងសីលធម៌ សិទ្ធិគ្រឹះរបស់មនុស្ស ឬការប្រៀនប្រដៅរបស់ដំណឹងល្អ។ យើងអាចបដិសេធមិនព្រមស្តាប់បង្គាប់អាជ្ញាធរស៊ីវិល នៅពេលដែលការទាមទាររបស់គេប្រឆាំងនឹងមនសិការត្រឹមត្រូវ ពីព្រោះយើងត្រូវជ្រើសរើសបម្រើព្រះជាម្ចាស់ ឬបម្រើសហគមន៍នយោបាយ។"អ្វីៗដែលជារបស់ព្រះចៅអធិរាជ ចូរថ្វាយទៅព្រះចៅអធិរាជវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅព្រះជាម្ចាស់វិញដែរ" (មថ ២២, ២១)។"យើងខ្ញុំត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់ជាជាងស្តាប់បង្គាប់មនុស្ស" (កក ៥,២៩)។

ប្រសិនបើរដ្ឋអំណាចបំពានសមត្ថកិច្ចរបស់ខ្លួន បែរជាជិះជាន់ប្រជាជន សូមប្រជាពលរដ្ឋ កុំរួញរាធ្វើកិច្ចការដែលប្រយោជន៍រួម ទាមទារយ៉ាងជាក់ច្បាស់។ ក៏ប៉ុន្តែ ប្រជាជនមានច្បាប់អនុញ្ញាតការពារសិទ្ធិរបស់ខ្លួន និងសិទ្ធិប្រជាពលរដ្ឋដែលត្រូវរងគ្រោះដោយរដ្ឋអំណាចជិះជាន់នោះ។ ប៉ុន្តែ ត្រូវគោរពព្រំដែននៃធម្មវិន័យធម្មជាតិ និងធម្មវិន័យនៃដំណឹងល្អផងដែរ (GS ៧៤,៥)។

២២៤៥- អ្នកតស៊ូប្រឆាំងនឹងការជិះជាន់របស់រដ្ឋអំណាច មិនអាចប្រើកម្លាំងសាស្ត្រាវុធបានឡើយ លើកលែងតែគេស្ថិតនៅក្នុងស្ថានភាពដូចល័ក្ខ័ណ្ឌខាងក្រោមនេះរួមចូលគ្នា៖

១- នៅពេលដែលមានការបំពានសិទ្ធិគ្រឹះយ៉ាងច្បាស់ ធ្ងន់ធ្ងរ និងយ៉ាងយូរ

២- អស់មធ្យោបាយក្នុងការដោះស្រាយ

៣- ដោយមិនបង្កើតភាពច្របូកច្របល់អាក្រក់ជាងមុន

៤- ដោយសង្ឃឹមយ៉ាងច្បាស់ថា អាចទទួលជ័យជំនះបាន

៥- ដោយគ្មានមធ្យោបាយណាប្រសើរជាងនេះ។

## សហគមន៍ខាងនយោបាយ និងព្រះសហគមន៍

២២៤៤- ស្ថាប័នទាំងអស់មានទស្សនវិស័យលើមនុស្ស និងដំណើរជីវិតរបស់គេ ដោយស្ថាប័នវិនិច្ឆ័យ បែងចែកតម្លៃទៅតាមលំដាប់លំដោយ និងឥរិយាបទ ដែលគេប្រកាន់យក។ សង្គមភាគច្រើនបានរៀបចំ ស្ថាប័នរបស់ខ្លួន ដោយគិតថា មនុស្សប្រសើរជាងវត្ថុនានា។ មានតែសាសនាដែលព្រះជាម្ចាស់បានសម្តែងឲ្យយើងដឹងទេ ដែលបានទទួលស្គាល់ថា ព្រះជាម្ចាស់ ដែលជាព្រះបង្កើត និងព្រះសង្គ្រោះ ជាប្រភព និងជាទីដៅរបស់មនុស្ស។

ព្រះសហគមន៍អញ្ជើញរដ្ឋអំណាចឲ្យវិនិច្ឆ័យ និងសម្រេចតាមពន្លឺនៃសេចក្តីពិតអំពីព្រះជាម្ចាស់ និងមនុស្សនេះ៖

> សង្គមដែលមិនស្គាល់ ឬបដិសេធពន្លឺនេះ ដោយគិតថា ខ្លួនមិនពឹងផ្អែកលើព្រះជាម្ចាស់ ដោយស្វែងរកគំនិត និងទីដៅរបស់ខ្លួន ដោយខ្លួនគេផ្ទាល់ ឬតាមមនោគមវិជ្ជាផ្សេងៗ មិនព្រមទទួលស្គាល់ថា មានលក្ខណៈដែលមិនចេះលម្អៀងអំពីអ្វីល្អ និងអ្វីអាក្រក់ សង្គមនោះ កាន់អំណាចផ្តាច់ការលើមនុស្ស និងដំណើរជីវិតរបស់គេ ដោយលាតត្រដាង ឬលាក់លៀម ដូចប្រវត្តិសាស្ត្រធ្លាប់បង្ហាញស្រាប់ (CA ៤៥ ; ៤៦)។

២២៤៥- ដោយសារបន្ទុក និងសមត្ថកិច្ចរបស់ខ្លួន ព្រះសហគមន៍ គឺជាសញ្ញាសម្គាល់ផង និងអ្នកការពារលក្ខណៈដ៏ខ្ពង់ខ្ពស់របស់មនុស្សផង។ មិនត្រូវច្រឡំព្រះសហគមន៍នឹងសហគមន៍នយោបាយឡើយ។ "ព្រះសហគមន៍គោរព និងលើកស្ទួយសេរីភាពខាងនយោបាយផង ហើយជួយឲ្យប្រជាពលរដ្ឋមានការទទួលខុសត្រូវផង" (GS ៧៦,៣)។

២២៤៦- ព្រះសហគមន៍មានបេសកកម្ម "វិនិច្ឆ័យតាមសីលធម៌ សូម្បីតែក្នុងវិស័យទាក់ទិននឹងនយោបាយផងដែរ នៅពេលដែលសិទ្ធិមូលដ្ឋានរបស់មនុស្ស ឬការសង្គ្រោះរបស់ព្រលឹងទាមទារ។ ព្រះសហគមន៍ត្រូវប្រើគ្រប់មធ្យោបាយស្របតាមដំណឹងល្អ និងមធ្យោបាយទាំងអស់ ដើម្បីឲ្យបានសេចក្តីសុខគ្រប់គ្នាទៅតាមស្ថានភាព និងតាមកាលៈទេសៈ" (GS ៧៦,៥)។

## សង្ខេប

២២៤៧ "ចូរគោរពមាតាបិតា" (ទក ៥,១៦ ; មក ៧,១០)។

២២៤៨- តាមវិន័យទីបួន ព្រះជាម្ចាស់សព្វព្រះហឫទ័យថា ក្រោយពីព្រះអង្គ យើងគោរពមាតាបិតា និងអស់អ្នកដែលព្រះអង្គបានប្រគល់អំណាច ដើម្បីប្រយោជន៍យើង។

២២៤៩- សហគមន៍គ្រួសារកើតឡើង ដោយសម្ព័ន្ធមេត្រី និងការព្រមព្រៀងរបស់គូស្វាមីភរិយា។ អាពាហ៍ពិពាហ៍ និងក្រុមគ្រួសារត្រូវបានរៀបចំ ដើម្បីផលប្រយោជន៍របស់គូស្វាមីភរិយា ការបន្តពូជពង្ស និងការអប់រំកូនចៅ។

២២៥០-"សន្តិភាពរបស់បុគ្គលម្នាក់ៗនិងសន្តិភាពរបស់សង្គមទាំងសង្គមមនុស្សទាំងសង្គមនៃព្រះសហគមន៍ភ្ជាប់យ៉ាងជិតស្និទ្ធនឹងការចម្រើននៃសហគមន៍គូស្វាមីភរិយា និងការចម្រើននៃសហគមន៍ក្រុមគ្រួសារ" (GS ៤៧,១)។

២២៥១-កូនៗត្រូវតែគោរពមាតាបិតាដោយចេះដឹងគុណស្តាប់បង្គាប់យ៉ាងត្រឹមត្រូវនិងជួយពួកគាត់ផងដែរ។ ការគោរពមាតាបិតានាំមកនូវភាពសុខដុមរមនានៅក្នុងក្រុមគ្រួសារ។

២២៥២- មាតាបិតាជាអ្នកទទួលខុសត្រូវដំបូងនៃការអប់រំកូន ឲ្យមានជំនឿ ឲ្យចេះអធិដ្ឋាន និងប្រតិបត្តិតាមគុណធម៌ទាំងឡាយ។ ពួកគាត់មានភារកិច្ចបំពេញតាមតែអាចធ្វើបានទៅតាមតម្រូវការខាងផ្លូវកាយ និងខាងផ្លូវចិត្តនៃកូនៗរបស់គាត់។

២២៥៣- មាតាបិតាត្រូវគោរព និងជំរុញឲ្យកូនៗបំពេញតាមការត្រាស់ហៅរបស់ពួកគេ។ ពួកគាត់នឹងនឹកឃើញឡើងវិញ និងបង្រៀនថា មុនដំបូង ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិសុទ្ធឲ្យដើរតាមព្រះយេស៊ូ។

២២៥៤- រដ្ឋអំណាចត្រូវតែគោរពសិទ្ធិគ្រឹះរបស់មនុស្ស និងលក្ខ័ណក្នុងការគោរពសេរីភាពរបស់គេ។

២២៥៥- ប្រជាពលរដ្ឋមានភារកិច្ចរួមសហការជាមួយរដ្ឋអំណាច ដើម្បីកសាងសង្គមប្រកបដោយ សេចក្ដីពិត យុត្តិធម៌ សាមគ្គីភាព និងសេរីភាព។

២២៥៦- តាមមនសិការរបស់ខ្លួន ប្រជាពលរដ្ឋមិនត្រូវធ្វើតាមបទបញ្ជារបស់អាជ្ញាធរ នៅពេលដែលបទបញ្ជានោះប្រឆាំងនឹងការទាមទារនៃសីលធម៌។ "ត្រូវស្ដាប់បង្គាប់ព្រះជាម្ចាស់ជាជាងស្ដាប់បង្គាប់មនុស្ស" (កក ៥,២៩)។

២២៥៧- ស្ថាប័នទាំងអស់ត្រូវប្រកាន់យកការវិនិច្ឆ័យ និងឥរិយាបទទៅតាមទស្សនវិស័យរបស់មនុស្ស និងដំណើរជីវិតរបស់គេ។ បើគ្មានពន្លឺនៃដំណឹងល្អអំពីព្រះ ជាម្ចាស់ និងមនុស្សទេ សង្គមទាំងនោះងាករយ៉ោងងាយទៅរកអំណាចផ្ដាច់ការ។

# ប្រការទី៥៖

# វិន័យទីប្រាំ

- កុំសម្លាប់មនុស្ស (សរ ២០,១៣)

អ្នករាល់គ្នាធ្លាប់ឮសេចក្ដី ដែលមានថ្លែងប្រាប់បុព្វបុរសថា "កុំសម្លាប់មនុស្ស" អ្នកណាសម្លាប់គេ អ្នកនោះនឹងត្រូវគេផ្ដន្ទាទោស។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា អ្នកណាខឹងនឹងបងប្អូន អ្នកនោះនឹងត្រូវគេផ្ដន្ទាទោសដែរ (មថ ៥,២១-២២)។

២២៥៨- "ជីវិតរបស់មនុស្សដ៏សក្ការៈ ដ្បិតតាំងពីកំណើតមក ជីវិតនេះ មានស្នាមនៃកិច្ចបង្កើតរបស់ព្រះជាម្ចាស់ និងស្ថិតស្ថេរជានិច្ច ក្នុងទំនាក់ទំនងពិសេសជាមួយព្រះបង្កើតរបស់ខ្លួន ដែលជាទីដៅតែមួយរបស់ខ្លួន។ មានតែព្រះជាម្ចាស់ទេ ដែលជាម្ចាស់នៃជីវិតតាំងពីកំណើតរហូតដល់ទីចុងក្រោយ ពោលគឺគ្មាននរណាអាចទាមទារដើម្បីខ្លួនឯងនូវសិទ្ធិបំផ្លាញមនុស្សដែលគ្មានទោសម្នាក់បានឡើយ" (CDF)។

## ១. ការគោរពជីវិតរបស់មនុស្ស

### សក្ខីភាពរបស់ប្រវត្តិសាស្ត្រដ៏វិសុទ្ធ

២២៥៩- ក្នុងរឿងរបស់លោកកាអ៊ីន ដែលសម្លាប់លោកអេបិលជាប្អូន (កណ ៤,៨-១២) ព្រះគម្ពីរសម្ដែងឲ្យដឹងថា តាំងពីដើមដំបូងនៃប្រវត្តិសាស្ត្ររបស់មនុស្សលោក មនុស្សមានកំហឹង និងមានចិត្តលោភលន់នៅក្នុងខ្លួន ជាផលវិបាកនៃអំពើបាបដើមដំបូង។ មនុស្សបានក្លាយទៅជាខ្មាំងសត្រូវរបស់មនុស្ស។ ព្រះជាម្ចាស់ចោទប្រកាន់ឃាតកម្មបងប្អូនឯងនេះ៖ "ម្ដេចក៏អ្នកប្រព្រឹត្តដូច្នេះ? សម្រែកឈាមប្អូនរបស់អ្នកបានលាន់ឮពីដីឡើងមកដល់យើង។ ឥឡូវនេះ អ្នកត្រូវបណ្ដាសា ហើយអ្នកត្រូវឃ្លាតឆ្ងាយពីដី ដែលបានស្រូបយកឈាមប្អូនរបស់អ្នក ជាឈាមដែលអ្នកបានបង្ហូរដោយផ្ទាល់ដៃ" (កណ ៤,១០-១១)។

២២៦០- សម្ពន្ធមេត្រីរវាងព្រះជាម្ចាស់ និងមនុស្សលោកតែងតែរំឭកថា ព្រះជាម្ចាស់បានប្រោសប្រទានជីវិតឲ្យមនុស្ស ហើយមនុស្សចេះតែប្រព្រឹត្តអំពើហិង្សា៖

(...) យើងឲ្យមនុស្សសងជីវិតនៅពេលណាដែលគេសម្លាប់មនុស្សដូចគ្នាដែរ។ អ្នកណាបង្ហូរឈាម

មនុស្ស អ្នកនោះមុខជាត្រូវមនុស្សបង្ហូរឈាមវិញមិនខាន ដ្បិតព្រះជាម្ចាស់បានបង្កើតមនុស្សលោក មកជាតំណាងរបស់ព្រះអង្គ (កណ ៩,៥-៦)។

- សម្ព័ន្ធមេត្រីចាស់ចាត់ទុកឈាមជាសញ្ញាសម្គាល់ដ៏ពិសិដ្ឋនៃជីវិត (លវ ១៧,១៤)។ ចាំបាច់ត្រូវប្រៀនប្រដៅសេចក្ដីនេះគ្រប់សម័យកាល។

២២៦១- ព្រះគម្ពីរបរិយាយយ៉ាងល្អិតល្អន់ការហាមប្រាមនៃវិន័យទីប្រាំនេះ៖ "មិនត្រូវកាត់ទោសប្រហារជីវិតជនស្លូតត្រង់ និងជនសុចរិតទេ" (សរ ២៣,៧)។ ឃាតកម្មដោយចេតនាលើមនុស្សម្នាក់ ដែលគ្មានទោស ជាអំពើប្រឆាំងនឹងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស វិន័យនៃសេចក្ដីស្រឡាញ់ និងប្រឆាំងនឹងភាពដ៏វិសុទ្ធរបស់ព្រះបង្កើតយ៉ាងធ្ងន់ធ្ងរ។វិន័យដែលហាមប្រាមឃាតកម្មនេះជាវិន័យសកល គឺមនុស្សទាំងអស់ គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែងក៏ត្រូវតែប្រតិបត្តិតាម។

២២៦២- ពេលដែលព្រះអង្គទេសនានៅលើភ្នំ ព្រះអម្ចាស់រំឭកបទបញ្ញានេះ៖ "កុំសម្លាប់មនុស្ស" (មថ ៥,២១) ហើយមានព្រះបន្ទូលបន្ថែមទៀតថា មិនត្រូវខឹង ស្អប់ និងសងសឹកគេឡើយ។ លើសពីនេះទៅទៀត ព្រះគ្រីស្តសុំឲ្យសាវ័ករបស់ព្រះអង្គបែរថ្ពាល់ម្ខាងទៀតឲ្យគេទះ (មថ ៥,២២-៣៩) និងស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួន (មថ ៥,៤៤)។ ព្រះអង្គផ្ទាល់មិនបានការពារខ្លួនឯង ហើយមានព្រះបន្ទូលមកលោកសិលា ឲ្យស៊កដាវទៅក្នុងស្រោមវិញ (មថ ២៦,៥២)។

## ការការពារខ្លួនឯងយ៉ាងត្រឹមត្រូវ

២២៦៣- ការការពារមនុស្ស និងសង្គមយ៉ាងត្រឹមត្រូវមិនមែនជាករណីលើកលែងចំពោះការហាមប្រាម មិនឲ្យប្រព្រឹត្តឃាតកម្មដោយចេតនាលើមនុស្សម្នាក់ ដែលគ្មានទោសឡើយ។ "កិច្ចការពារខ្លួនឯងអាចបង្កើតផលពីរយ៉ាង៖ មួយសម្រាប់រក្សាជីវិតខ្លួនឯង មួយទៀតការស្លាប់របស់អ្នកធ្វើបាប (...)។ យើងចង់បានផលតែមួយ ឯផលផ្សេងទៀតវិញ យើងមិនចង់បានឡើយ" (សន្តៈ ថូម៉ាស នៃអាកាំង)។

២២៦៤- សេចក្ដីស្រឡាញ់ចំពោះខ្លួនឯងជាគោលការណ៍ដ៏សំខាន់នៃសីលធម៌។ ដូច្នេះ យើងមានសិទ្ធិធ្វើឲ្យគេគោរពជីវិតយើងបាន។ អ្នកការពារជីវិតរបស់ខ្លួនគ្មានទោសប្រព្រឹត្តអំពើឃាតកម្មទេ ទោះបីគេសម្លាប់អ្នកធ្វើបាបគេក៏ដោយ៖

> ប្រសិនបើយើងប្រើអំពើហិង្សាលើសពីតម្រូវការ ដើម្បីការពារខ្លួន យើងខុសច្បាប់។ ប៉ុន្តែ ប្រសិនបើយើងប្រយុទ្ធអំពើហិង្សាតាមរបៀបត្រឹមត្រូវ យើងនឹងស្រមច្បាប់ (...)។ ទោះបីយើងប្រព្រឹត្តកិច្ចការនេះដើម្បីការពារខ្លួនយ៉ាងណាក៏ដោយ ក៏យើងអាចទទួលការសង្គ្រោះបានដែរ ដ្បិតយើងត្រូវរក្សាជីវិតរបស់ខ្លួនឯងច្រើនជាងយើងត្រូវរក្សាជីវិតអ្នកដទៃ (សន្តៈ ថូម៉ាស នៃអាកាំង)។

២២៦៥- ការការពារខ្លួនឯងមិនគ្រាន់តែជាសិទ្ធិប៉ុណ្ណោះទេ ថែមទាំងជាភារកិច្ចដ៏សំខាន់ចំពោះអ្នកដែលទទួលខុសត្រូវលើជីវិតអ្នកដទៃ លើផលប្រយោជន៍រួមរបស់ក្រុមគ្រួសារ ឬរបស់សង្គម។

២២៦៦- បើយើងចង់ការពារប្រយោជន៍រួមនៃសង្គម យើងត្រូវតែឃាត់អ្នកធ្វើបាបមិនឲ្យធ្វើបាបទៀត។ ការប្រៀនប្រដៅរបស់ព្រះសហគមន៍តាំងពីដើមដំបូងបានទទួលស្គាល់ថា រដ្ឋអំណាចត្រឹមត្រូវមានសិទ្ធិ និងភារកិច្ចផ្ដន្ទាទោសទៅតាមកំហុស ទោះជាទោសប្រហារជីវិតក៏ដោយក្នុងករណីដ៏ធ្ងន់ធ្ងរជាទីបំផុត។យ៉ាងណាមិញ អ្នកកាន់អំណាចមានសិទ្ធិប្រើកម្លាំងសាស្ត្រាវុធ ដើម្បីវាយប្រានអ្នកឈ្លានពានទឹកដី ដែលអ្នកកាន់អំណាចនោះ

បានទទួលបន្ទុក។

- ការដាក់ទោស មានផលដំបូងទូទាត់ភាពច្របូកច្របល់ដែលមកពីកំហុស។ នៅពេលដែលអ្នកទោសស្ម័គ្រចិត្តទទួលទោសនេះ គេទូទាត់ទោសរបស់ខ្លួន។ ម្យ៉ាងទៀត ការដាក់ទោសជាកិច្ចការពាររបៀបរៀបរយសាធារណៈ និងសុវត្ថិភាពរបស់មនុស្ស។ ទីបំផុត ការដាក់ទោសជាថ្នាំពេទ្យ ដែលជួយឲ្យអ្នកទោសទទួលការសង្គ្រោះ (លក ២៣,៤០-៤៣)។

២២៦៧- បើមធ្យោបាយមិនបង្ហូរឈាមល្មមគ្រប់គ្រាន់ ដើម្បីការពារជីវិតមនុស្សប្រឆាំងនឹងអ្នកធ្វើបាបក្នុងកិច្ចការពាររបៀបរៀបរយសាធារណៈ និងសុវត្ថិភាពមនុស្ស អាជ្ញាធរនឹងមិនប្រើមធ្យោបាយផ្សេងទៀតទេ ដ្បិតមធ្យោបាយនោះស្របតាមល័ក្ខខ័ណ្ឌនៃប្រយោជន៍រួម និងស្របតាមឋានៈដ៏ថ្លៃថ្នូររបស់មនុស្សហើយ។

### ឃាតកម្មដោយចេតនា

២២៦៨- វិន័យទីប្រាំហាមមិនឲ្យសម្លាប់មនុស្សដោយផ្ទាល់ខ្លួន និងដោយចេតនា។ ឃាតកម្មបែបនេះ ជាអំពើបាបធ្ងន់ធ្ងរណាស់។ ឃាតកៈ និងអស់អ្នកដែលរួមសហការដោយចេតនាក្នុងការសម្លាប់មនុស្ស ប្រព្រឹត្តអំពើបាបមួយ ដែលស្រែកអង្វរឲ្យមេឃសងសឹក (កណ ៤,១០)។

ការសម្លាប់កូនឯង (GS៥១,៣) ការសម្លាប់បងប្អូនឯង ការសម្លាប់ឪពុកឯង និងការសម្លាប់គូស្វាមីភរិយាឯងជាឃាតកម្មដ៏ធ្ងន់ធ្ងរជាទីបំផុត ដ្បិតអំពើនេះ ជាការបំបាក់បំបែកចំណងធម្មជាតិ។ ទោះបីរដ្ឋអំណាចបញ្ជា ឲ្យប្រព្រឹត្តឃាតកម្ម ដើម្បីបន្សុទ្ធពូជ ឬដើម្បីអនាម័យក៏ដោយ ក៏យើងមិនអាចសម្លាប់នរណាម្នាក់បានឡើយ។

២២៦៩- វិន័យទីប្រាំហាមមិនឲ្យធ្វើអ្វីក្នុងគោលបំណងសម្លាប់មនុស្សម្នាក់ដោយប្រយោល។ វិន័យនៃសីលធម៌ហាមប្រថុយជីវិតរបស់មនុស្សម្នាក់ ដោយគ្មានមូលហេតុសំខាន់ ព្រមទាំងហាមបដិសេធជួយមនុស្សម្នាក់ដែលរងគ្រោះថ្នាក់។

ពេលសង្គមមនុស្សសុខចិត្តឲ្យកើតទុរ្ភិក្សដោយមិនខិតខំជួយសង្គ្រោះ សង្គមនោះប្រព្រឹត្តអំពើអយុត្តិធម៌ដ៏អាស្រូវ និងកំហុសដ៏ធ្ងន់។ អ្នករកស៊ីខុសច្បាប់ ដែលអំពើរបស់គេបណ្ដាលឲ្យអ្នកដទៃ ដែលជាបងប្អូនអត់ឃ្លាន និងស្លាប់ គឺជាអ្នកប្រព្រឹត្តអំពើឃាតកម្ម មិនត្រូវអត់ឱនឡើយ (អម ៨,៤-១០)។

យើងមិនអាចផ្ដន្ទាទោសការសម្លាប់មនុស្សដោយអចេតនា បាន។ ប៉ុន្តែ យើងប្រព្រឹត្តកំហុសដ៏ធ្ងន់ធ្ងរ បើយើងបានប្រព្រឹត្តកិច្ចការជ្រុលពេក ដែលបាននាំឲ្យមានមនុស្សស្លាប់ ទោះបីយើងគ្មានបំណងចង់សម្លាប់គេយ៉ាងណាក៏ដោយ។

### ការរំលូតកូន

២២៧០- ត្រូវតែគោរព និងការពារជីវិតមនុស្សលើសពីអ្វីៗទាំងអស់តាំងពីក្នុងផ្ទៃម្ដាយមកម្ល៉េះ។ គេត្រូវទទួលស្គាល់សិទ្ធិមនុស្ស ចាប់តាំងពីគ្រាដំបូងបង្អស់នៃការរស់នៅរបស់គេ។ ក្នុងចំណោមសិទ្ធិនោះ មនុស្សដែលគ្មានទោសណាម្នាក់មានសិទ្ធិរស់រានមានជីវិត (CDF)។

យើងស្គាល់អ្នកតាំងពីមុនពេល ដែលយើងបានសូនអ្នកក្នុងផ្ទៃម្ដាយម្ល៉េះ។ យើងក៏បាញែកអ្នកទុកសម្រាប់យើងតាំងពីមុនពេល ដែលអ្នកកើតចេញពីផ្ទៃម្ដាយដែរ (យរ ១,៥)។

នៅពេលទូលបង្គំកកើតឡើងក្នុងទីលាក់កំបាំង គឺនៅក្នុងផ្ទៃមាតា រូបកាយរបស់ទូលបង្គំមិនបានលាក់បំបាំងនឹងព្រះអង្គទេ (ទន ១៣៩,១៥)។

២២៧១- តាំងពីសតវត្សទីមួយ ព្រះសហគមន៍បញ្ជាក់ថា ការរំលូតកូនដោយចេតនាជាអំពើខុសសីលធម៌។ ការប្រៀនប្រដៅនេះ មិនបានផ្លាស់ប្តូរ ហើយនៅស្ថិតស្ថេរនៅឡើយ។ ការរំលូតកូនដោយផ្ទាល់ ដើម្បីបញ្ចប់ ឬដើម្បីជាមធ្យោបាយ គឺជាអំពើខុសសីលធម៌ដ៏ធ្ងន់ធ្ងរណាស់៖

កុំរំលូតកូនក្នុងផ្ទៃ ហើយកុំសម្លាប់កូនទើបនឹងកើត (ឌីដាខេ ; លោកបាណាបាស)។

ព្រះជាម្ចាស់ ជាម្ចាស់នៃជីវិត បានប្រគល់ឲ្យមនុស្សនូវមុខងារដ៏ប្រសើរដើម្បីបម្រើជីវិត ហើយមនុស្សត្រូវតែបំពេញមុខងារនេះ តាមរបៀបសមរម្យនឹងខ្លួនគេ។ ដូច្នេះ ត្រូវរក្សាជីវិតដោយយកចិត្តទុកដាក់ជាទីបំផុត តាំងពីក្នុងផ្ទៃម្តាយមកម្ល៉េះ។ ការរំលូតកូន និងការសម្លាប់កូនជាអំពើឃាតកម្មដ៏អាក្រក់ជាទីបំផុត (លិខិតជូនចំពោះលោកឌីអូក្នេត ; លោកទែរទូលីយ៉ាំង)។

២២៧២- បើយើងរួមសហការក្នុងការរំលូតកូន យើងប្រព្រឹត្តអំពើបាបធ្ងន់។ អ្នកប្រព្រឹត្តអំពើបាបប្រឆាំងនឹងជីវិតមនុស្សនេះ ត្រូវបណ្តេញចេញពីព្រះសហគមន៍។ "នរណារំលូតកូន បើកូនស្លាប់មែន អាចត្រូវបណ្តេញចេញពីព្រះសហគមន៍ latae sententiae" (CIC ១៣៩៨) "ដោយសារតែបានប្រព្រឹត្តទោសនេះ" (CIC ១៣១៤) ហើយស្របតាមល័ក្ខខ័ណ្ឌច្បាប់ (CIC ១៣២៣-១៣២៤)។ ព្រះសហគមន៍នៅតែមានធម៌មេត្តាករុណា ប៉ុន្តែ បង្ហាញថា ឃាតកម្មនេះ ធ្ងន់ធ្ងរណាស់ ហើយបង្កើតការខូចខាតដែលមិនអាចកែបាន សម្រាប់កូនដែលត្រូវសម្លាប់ សម្រាប់ឪពុកម្តាយវា និងសម្រាប់សង្គមទាំងមូលផងដែរ។

២២៧៣- មនុស្សទាំងអស់មានសិទ្ធិរស់រានមានជីវិត ជាសិទ្ធិដែលមិនអាចទិញលក់បាន ជាផ្នែកចាំបាច់នៃសង្គមស៊ីវិល និងជាច្បាប់នៃសង្គមនេះ៖

"សង្គមស៊ីវិល និងរដ្ឋអំណាចត្រូវតែទទួលស្គាល់ និងគោរពសិទ្ធិ ដែលមិនអាចទិញលក់របស់មនុស្ស។ សិទ្ធិមនុស្សមិនពឹងផ្អែកលើមនុស្ស ឬលើមាតាបិតា ហើយមិនមែនមកពីសង្គម ឬរដ្ឋអំណាចសុខចិត្តផ្តល់ឲ្យឡើយ។ សិទ្ធិទាំងអស់នោះ ជាកម្មសិទ្ធិនៃធម្មជាតិមនុស្ស ជាផ្នែករបស់មនុស្ស ដែលមានកិច្ចបង្កើតជាប្រភព។ ក្នុងចំណោមសិទ្ធិមូលដ្ឋានទាំងអស់នោះ មានសិទ្ធិរស់រានមានជីវិត និងសិទ្ធិគោរពកាយ តាំងពីក្នុងផ្ទៃម្តាយរហូតដល់ស្លាប់" (CDF)។

"ក្នុងវេលាដែលច្បាប់វិជ្ជមានមិនឲ្យមនុស្សមួយចំនួនបានទទួលការការពារ ដែលច្បាប់ស៊ីវិលតម្រូវឲ្យរដ្ឋអំណាចចាប់ផ្តើមមិនទទួលស្គាល់ថា មនុស្សទាំងអស់ស្មើគ្នាចំពោះច្បាប់ឡើយ។ វេលាដែលរដ្ឋមិនប្រើកម្លាំង ដើម្បីបម្រើសិទ្ធិប្រជាពលរដ្ឋទាំងអស់ ជាពិសេសអ្នកទន់ខ្សោយជាងគេ មូលដ្ឋានគ្រឹះនៃរដ្ឋអំណាចត្រឹមត្រូវមួយចុះទន់ខ្សោយ (...)។ អ្នកដែលបំពានសិទ្ធិដោយចេតនាត្រូវទទួលទោសតាមច្បាប់ព្រហ្មទ័ណ្ឌ ពីព្រោះច្បាប់ត្រូវការពារកូនតាំងពីក្នុងផ្ទៃម្តាយ" (CDF)។

២២៧៤- ត្រូវចាត់ទុកថា ក្សណជាមនុស្សម្នាក់តាំងពីក្នុងផ្ទៃម្តាយមកម្ល៉េះ ហេតុនេះ ត្រូវការពារ ថែទាំ និងព្យាបាលក្សណ ដូចចំពោះមនុស្សម្នាក់ផ្សេងទៀត តាមអ្វីដែលយើងអាចធ្វើបាន។

ការវិនិច្ឆ័យរោគមុនកំណើត ត្រឹមត្រូវតាមសីលធម៌ "បើយើងគោរពជីវិតរបស់ក្សណ និងគភ៌ ហើយបើយើងវិនិច្ឆ័យ ដើម្បីការពារ ឬព្យាបាលវា (...)។ ការវិនិច្ឆ័យរោគមុនកំណើតខុសសីលធម៌ខ្លាំងណាស់ នៅ

ពេលដែលយើងគិតទុកជាមុនថាក្រោយពីបានទទួលលទ្ធផលនឹងរំលូតកូន។ការវិនិច្ឆ័យមិនអាចទៅជាការកាត់ទោសប្រហារជីវិតបាន" (CDF)។

២២៧៥- "ត្រូវចាត់ទុកថា ការធ្វើអន្តរាគមន៍លើភ្រូណត្រូវច្បាប់ លុះត្រាតែការធ្វើអន្តរាគមន៍នោះគោរពជីវិតរបស់ភ្រូណ ហើយមិនអាចនាំឲ្យភ្រូណមានគ្រោះថ្នាក់ ប៉ុន្តែមានគោលដៅព្យាបាល កែលំអសុខភាព ឬជួយឲ្យភ្រូណរស់រានមានជីវិត" (CDF)។

- "បើយើងផលិតភ្រូណ ក្នុងគោលដៅប្រើវាដូចជាថ្នាំព្យាបាល យើងខុសសីលធម៌" (CDF)។
- "ការធ្វើអន្តរាគមន៍ខ្លះ លើបេតិកភ័ណ្ឌក្រូម្សូម ឬខាងពន្ធុ ដោយគ្មានគោលដៅព្យាបាល ប៉ុន្តែ ដោយចង់ផលិតមនុស្សតាមភេទ ឬតាមគុណភាពដែលគ្រោងទុកជាមុន ការប្រើប្រាស់ទាំងអស់នោះ ផ្ទុយនឹងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស និងអត្តសញ្ញាណតែមួយ ដែលមិនអាចបង្កើតជាថ្មីបានរបស់គេ" (CDF)។

## ការជួយមនុស្សឲ្យចែកឋានយ៉ាងស្រួល

២២៧៦- ត្រូវតែគោរពយ៉ាងពិសេសដល់អស់អ្នក ដែលមានកម្លាំងចុះទន់ខ្សោយ។ ត្រូវតែជួយទ្រទ្រង់អ្នកជំងឺ ឬអ្នកពិការ ដើម្បីឲ្យគេមានរបៀបរស់នៅដូចធម្មតា តាមតែអាចធ្វើបាន។

២២៧៧- ទោះជាមានមូលហេតុ និងមធ្យោបាយយ៉ាងណាក៏ដោយ ក៏គេហៅការជួយមនុស្សឲ្យចែកឋានយ៉ាងស្រួលថា ជាការសម្លាប់អ្នកពិការ អ្នកជំងឺ ឬអ្នកជិតស្លាប់។ ការជួយមនុស្សឲ្យចែកឋានយ៉ាងស្រួលខុសនឹងសីលធម៌។

ឧ- នៅពេលដែលយើងបំពេញកិច្ចការ ឬយើងខានបំពេញកិច្ចការ ក្នុងគោលបំណងសម្លាប់គេ ដើម្បីបំបាត់ការឈឺចាប់ ជាឃាតកម្មដ៏ធ្ងន់ធ្ងរ ផ្ទុយនឹងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស និងការគោរពព្រះជាម្ចាស់ ដែលមានព្រះជន្មគង់នៅ ជាព្រះបង្កើតគេ។ ទោះបីយើងបានវិនិច្ឆ័យមិនត្រឹមត្រូវ ហើយទោះបីយើងមានបំណងល្អយ៉ាងណាក៏ដោយ កិច្ចការនេះ នៅតែជាឃាតកម្ម ដែលត្រូវតែហាមមិនឲ្យប្រព្រឹត្តជារៀងរហូត។

២២៧៨- យើងអាចឈប់ប្រើប្រាស់ថ្នាំព្យាបាលថ្លៃពេក ដែលអាចនាំឲ្យមានគ្រោះថ្នាក់ដ៏ចម្លែកខុសធម្មតា ឬដែលមិនស្របនឹងលទ្ធផលដែលយើងរង់ចាំ គឺយើងមិនព្រមនឹងព្យាបាលរោគ ដែលមិនអាចជាសះស្បើយ។ ធ្វើដូច្នោះ យើងមិនចង់សម្លាប់គេទេ ប៉ុន្តែ យើងទទួលស្គាល់ថា មិនអាចឃាត់សេចក្តីស្លាប់បានឡើយ។ បើគេមានសមត្ថកិច្ច និងសមត្ថភាព អ្នកជំងឺជាអ្នកត្រូវសម្រេច។ បើគេគ្មានសមត្ថកិច្ច និងសមត្ថភាពនោះទេ អាណាព្យាបាលត្រូវសម្រេច ដោយគោរពបំណង និងផលប្រយោជន៍ដ៏ត្រឹមត្រូវរបស់អ្នកជំងឺជានិច្ច។

២២៧៩- ទោះបីសេចក្តីស្លាប់ជិតមកដល់ហើយក៏ដោយ យើងមិនអាចឈប់ថែទាំអ្នកជំងឺដូចធម្មតាបាន។ យើងអាចប្រើថ្នាំបំបាត់ការឈឺចាប់ ដើម្បីសម្រាលទុក្ខអ្នកជំងឺ ទោះបីការប្រើថ្នាំនោះអាចសង្ខេបជីវិតគេក៏ដោយ។ ការប្រើប្រាស់ថ្នាំនោះ អាចស្របតាមឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស លុះត្រាតែយើងមិនចង់សម្លាប់គេ គឺសេចក្តីស្លាប់មិនមែនជាទីដៅ ឬមធ្យោបាយទេ គ្រាន់តែយើងដឹងទុកជាមុនថាមិនអាចគេចផុតពីសេចក្តីស្លាប់នេះបានឡើយ។ ត្រូវតែលើកទឹកចិត្តការថែទាំអ្នកជំងឺ ដោយរៀបចំគេឲ្យស្លាប់តាមស្រួលពោរពេញដោយសេចក្តីស្រឡាញ់។

## អត្តឃាតកម្ម

២២៨០- ម្នាក់ៗត្រូវទទួលខុសត្រូវលើជីវិតរបស់ខ្លួនឯងចំពោះព្រះជាម្ចាស់ជាអ្នកប្រទានឲ្យ។ គឺព្រះអង្គនេះ

ហើយដែលជាម្ចាស់ដ៏ខ្ពង់ខ្ពស់នៃជីវិតនេះ។យើងត្រូវតែទទួលជីវិតដោយចេះដឹងគុណនិងរក្សាជីវិតដើម្បីកិត្តិយសរបស់ព្រះអង្គ និងដើម្បីសង្គ្រោះព្រលឹងរបស់យើង។ យើងគ្រាន់តែជាអ្នកថែទាំជីវិតប៉ុណ្ណោះ មិនមែនជាម្ចាស់នៃជីវិត ដែលព្រះជាម្ចាស់បានប្រគល់ឲ្យយើងទេ។ ដូច្នេះ យើងមិនអាចប្រើជីវិតតាមអំពើចិត្តរបស់ខ្លួនឯងបានឡើយ។

២២៨១- អត្តឃាតកម្មប្រឆាំងនឹងទំនោរចិត្តរបស់មនុស្សដែលចង់រក្សា និងបន្តជីវិតរបស់ខ្លួន។ អ្នកសម្លាប់ខ្លួនឯងប្រឆាំងនឹងសេចក្តីស្រឡាញ់ចំពោះខ្លួនឯងធ្ងន់ធ្ងរណាស់។ គេប្រឆាំងនឹងសេចក្តីស្រឡាញ់ចំពោះអ្នកដទៃដែរ ពីព្រោះគេបំបែកចំណងសាមគ្គីភាពជាមួយនឹងក្រុមគ្រួសារ ជាតិ និងសង្គមមនុស្ស ដែលយើងនៅតែជំពាក់ចិត្ត។ អត្តឃាតកម្មប្រឆាំងនឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលមានព្រះជន្មគង់នៅ។

២២៨២- បើសម្លាប់ខ្លួនក្នុងគោលដៅធ្វើជាគំរូសម្រាប់អ្នកដទៃ ជាពិសេសយុវជន អត្តឃាតកម្មកាន់តែជាអំពើអាស្រូវយ៉ាងធ្ងន់ធ្ងរថែមទៀត។ បើយើងជួយម្នាក់ឲ្យសម្លាប់ខ្លួន យើងខុសនឹងវិន័យខាងសីលធម៌។

- អ្នកសម្លាប់ខ្លួនអាចមានជំងឺផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ អាចថប់បារម្ភ ឬខ្លាចមិនហ៊ានប្រឈមមុខនឹងទុក្ខលំបាក ឬទារុណកម្ម។ ពេលនោះ យើងមិនអាចផ្តន្ទាទោសអ្នកសម្លាប់ខ្លួនខ្លាំងពេកទេ។

២២៨៣- ទោះបីគេបានសម្លាប់ខ្លួនក៏ដោយ ក៏យើងត្រូវសង្ឃឹមថា គេអាចទទួលការសង្គ្រោះបានដែរ។ ព្រះជាម្ចាស់អាចនាំឲ្យគេសោកស្តាយអំពើរបស់គេ តាមរបៀបដែលមានតែព្រះអង្គទេ ដែលស្គាល់។ ព្រះសហគមន៍ទូលអង្វរព្រះជាម្ចាស់សម្រាប់អស់អ្នកដែលបានសម្លាប់ខ្លួន។

## ២. ការគោរពឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស

### ការគោរពព្រលឹងរបស់អ្នកដទៃ៖ អំពើអាស្រូវ

២២៨៤- យើងប្រព្រឹត្តអំពើអាស្រូវ នៅពេលដែលយើងមានអាកប្បកិរិយា ឬឥរិយាបថ ដែលនាំអ្នកដទៃឲ្យប្រព្រឹត្តអំពើអាក្រក់។ អ្នកដែលប្រព្រឹត្តអំពើអាស្រូវជាមេល្បួងអ្នកដទៃ។ គេប្រឆាំងនឹងគុណធម៌ និងភាពស្មោះត្រង់។ គេអាចនាំបងប្អូនគេឲ្យស្លាប់ខាងវិញ្ញាណ។ អ្នកប្រព្រឹត្តអំពើអាស្រូវ ប្រព្រឹត្តអំពើអាក្រក់ដ៏ធ្ងន់ធ្ងរ បើគេនាំអ្នកដទៃឲ្យប្រព្រឹត្តអំពើអាក្រក់ ដោយចេតនា ឬបើគេមិនបាននាំអ្នកដទៃឲ្យចៀសវាងប្រព្រឹត្តអំពើអាក្រក់។

២២៨៥- អំពើអាស្រូវជាអំពើបាបដ៏ធ្ងន់ធ្ងរ ដែលមកពីអំណាចរបស់អ្នកប្រព្រឹត្ត ឬភាពទន់ខ្សោយរបស់អ្នកទទួលរង។ ព្រះអម្ចាស់នៃយើងបានដាក់បណ្តាសាថា៖ "អ្នកណានាំអ្នកតូចតាចម្នាក់ ក្នុងបណ្តាអ្នកដែលជឿលើខ្ញុំនេះ ឲ្យប្រព្រឹត្តអំពើបាប ចំពោះអ្នកនោះ ប្រសិនបើគេយកត្បាល់ថ្មយ៉ាងធំមកចងកគាត់ទម្លាក់ទៅក្នុងបាតសមុទ្រឲ្យលង់ទឹក ប្រសើរជាងទុកគាត់ឲ្យនៅរស់!" (មថ ១៨,៦) (១ករ ៨,១០-១៣)។ អំពើអាស្រូវធ្ងន់ធ្ងរនៅពេលដែលអ្នកប្រព្រឹត្តជាអ្នក ដែលមានមុខងារប្រៀនប្រដៅ និងបង្រៀនអ្នកដទៃ។ ព្រះយេស៊ូស្តីបន្ទោសពួកធម្មាចារ្យ និងពួកខាងគណៈផារីស៊ី ដោយប្រៀបធៀបពួកគេនឹងចចក ដែលក្លែងខ្លួនជាចៀម (មថ ៧,១៥)។

២២៨៦- ច្បាប់ ឬស្ថាប័ននានា ការនិយម ឬគំនិតទូទៅក្នុងសង្គមអាចបង្កើតរឿងអាស្រូវ។

ឧ- អស់អ្នកដែលចាត់ចែងច្បាប់ ឬរចនាសម្ព័ន្ធក្នុងសង្គម ដែលនាំឲ្យមានទម្លាប់ ឬការប្រតិបត្តិសាសនាឲ្យទៅជាអាក្រក់ឬអស់អ្នក "ដែលចាត់ចែងល័ក្ខខ័ណ្ឌនៃការរស់នៅក្នុងសង្គម ដែលនាំឲ្យគ្រីស្តបរិស័ទមិនអាចប្រតិបត្តិតាមធម្មវិន័យ ដោយចេតនា ឬ ដោយអចេតនាក្តី" (សម្តេចប៉ាប ពីយូសទី១២) អ្នកទាំងអស់នោះប្រព្រឹត្តអំពើអាស្រូវ។ យ៉ាងណាមិញ ថៅកែដែលបង្កើតបទបញ្ជាជំរុញឲ្យមានការលួចបន្លំ គ្រូដែលធ្វើ

ឲ្យសិស្ស "មួម៉ៅ" (អភ ៦,៤ ; កូឡ ៣,២១) ឬអស់អ្នកដែលប្រើប្រាស់គំនិតទូទៅក្នុងសង្គម ដើម្បីបំបែរគេពីឧត្ដមគតិនៃសីលធម៌។

២២៨៧- អ្នកដែលប្រើអំណាចរបស់ខ្លួន ក្នុងល័ក្ខខ័ណ្ឌ ដែលនាំឲ្យប្រព្រឹត្តអំពើអាក្រក់ ឬអំពើអាស្រូវ និងទទួលខុសត្រូវលើអំពើអាក្រក់ ដែលគេបានជំរុញឲ្យគេប្រព្រឹត្ត ដោយផ្ទាល់ ឬដោយប្រយោល។ "មានមូលហេតុជាច្រើន ដែលតែងតែបណ្ដាលឲ្យមនុស្សប្រព្រឹត្តអំពើបាប។ ប៉ុន្តែ អ្នកណានាំគេឲ្យប្រព្រឹត្តអំពើបាប អ្នកនោះត្រូវវេទនាហើយ" (លក ១៧,១)។

## ការគោរពសុខភាព

២២៨៨- ជីវិត និងសុខភាពខាងផ្លូវកាយជាព្រះអំណោយទានដ៏ថ្លៃថ្នូរ ដែលព្រះជាម្ចាស់បានប្រគល់ឲ្យ។ យើងត្រូវតែថែរក្សាជីវិត និងសុខភាពយ៉ាងត្រឹមត្រូវ ដោយយកចិត្តទុកដាក់អំពីតម្រូវការរបស់អ្នកដទៃ និងប្រយោជន៍រួម។

- សង្គមត្រូវតែជួយថែទាំសុខភាព របស់ប្រជាពលរដ្ឋ ដើម្បីទទួលល័ក្ខខ័ណ្ឌនៃជីវិភាពរស់នៅ ដែលនាំឲ្យរីកចម្រើន៖ ចំណីអាហារ និងសម្លៀកបំពាក់ ទីលំនៅ ថ្នាំព្យាបាល ការរៀនសូត្រជាមូលដ្ឋាន ការងារ សង្គមកិច្ច។

២២៨៩- អ្នកប្រតិបត្តិតាមសីលធម៌ គោរពជីវិតខាងផ្លូវកាយ ប៉ុន្តែជីវិតខាងផ្លូវកាយនេះ មិនមែនលើសអ្វីៗទាំងអស់។ សីលធម៌ប្រឆាំងនឹងគំនិតរបស់សាសន៍ដទៃ ដែលថ្វាយបង្គំរូបកាយ ដោយបូជាអ្វីៗទាំងអស់ចំពោះរូបកាយ ដោយគោរពដូចជាព្រះក្លែងក្លាយរូបកាយល្អឥតខ្ចោះ និងជ័យជំនះខាងកីឡា។ ដោយសារគំនិតនេះញែកអ្នកខ្លាំងពូកែពីមនុស្សទន់ខ្សោយ គំនិតនេះអាចបង្ខូចទំនាក់ទំនងរវាងមនុស្ស។

២២៩០- គុណធម៌ចេះទប់ចិត្តខ្លួនឯងឲ្យចៀសវាងភាពជ្រុលជ្រួស ផឹកស្រា ជក់បារី និងប្រើថ្នាំព្យាបាល ជ្រុលពេក។ អស់អ្នកដែលបើកបរដោយស្រវឹងស្រា ឬដែលបើកបរលឿនពេក បណ្ដាលឲ្យអ្នកដទៃ និងខ្លួនឯងមានគ្រោះថ្នាក់ នៅលើផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស ប្រព្រឹត្តអំពើបាប។

២២៩១- ការប្រើប្រាស់គ្រឿងញៀន បំផ្លាញសុខភាព និងជីវិតមនុស្ស។ ក្រៅពីដើម្បីព្យាបាល ការប្រើប្រាស់គ្រឿងញៀនជាអំពើបាប។ ការផលិតគ្រឿងញៀនដោយលួចលាក់ និងការលក់ដូរគ្រឿងញៀនជាអំពើអាស្រូវ ហើយជំរុញឲ្យប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរណាស់ខុសនឹងសីលធម៌។

## ការគោរពមនុស្ស និងការស្រាវជ្រាវខាងវិទ្យាសាស្ត្រ

២២៩២- ការពិសោធន៍វិទ្យាសាស្ត្រ វេជសាស្ត្រ ឬខាងចិត្តសាស្ត្រលើមនុស្ស ឬក្រុមមនុស្សអាចជួយព្យាបាលអ្នកជំងឺ និងធ្វើឲ្យសុខភាពសាធារណៈរីកចម្រើន។

២២៩៣- ការស្រាវជ្រាវវិទ្យាសាស្ត្រមូលដ្ឋាន ដូចការស្រាវជ្រាវដើម្បីអនុវត្តន៍ បង្ហាញយ៉ាងច្បាស់ថា មនុស្សជាម្ចាស់នៃសត្វលោក។ វិទ្យាសាស្ត្រ និងបច្ចេកទេសជាធនធានដ៏មានតម្លៃ នៅពេលដែលយើងប្រើវិទ្យាសាស្ត្រ និងបច្ចេកទេសនោះ ដើម្បីបម្រើមនុស្ស និងធ្វើឲ្យគេចម្រើនគ្រប់លក្ខណៈ ដើម្បីជលប្រយោជន៍មនុស្សទាំងអស់។ ក៏ប៉ុន្តែ វិទ្យាសាស្ត្រ និងបច្ចេកទេសទាំងនោះ មិនអាចបង្ហាញអត្ថន័យនៃការរស់នៅនិងការរីកចម្រើនរបស់មនុស្សបានឡើយ។ វិទ្យាសាស្ត្រ និងបច្ចេកទេសស្ថិតនៅក្រោមមនុស្ស ដែលជាប្រភព និងការរីកចម្រើនរបស់វិទ្យាសាស្ត្រ

និងបច្ចេកទេសនោះ។ ហេតុនេះហើយ បានជាមនុស្ស និងឧត្តមគតិខាងសីលធម៌បង្ហាញទីដៅនៃវិទ្យាសាស្ត្រ និងបច្ចេកទេស ដោយដឹងថាវិទ្យាសាស្ត្រ និងបច្ចេកទេសនោះមានដែនកំណត់ព្រំដែនផងដែរ។

២២៩៤- យើងមិនអាចអះអាងថា ការស្រាវជ្រាវវិទ្យាសាស្ត្រ និងការអនុវត្តន៍នៃការស្រាវជ្រាវនេះមិនប៉ះពាល់ដល់សីលធម៌។ ម្យ៉ាងទៀត យើងមិនអាចតម្រូវឲ្យការស្រាវជ្រាវនោះ ទៅតាមប្រសិទ្ធិភាពនៃបច្ចេកវិទ្យា ដើម្បីបម្រើប្រយោជន៍អ្នកខ្លះច្រើនជាងអ្នកខ្លះផ្សេងទៀត ឬអាក្រក់ជាងនេះទៅទៀត ដើម្បីបម្រើមនោគមវិជ្ជា។ ដូច្នេះហើយ អត្ថន័យនៃវិទ្យាសាស្ត្រ និងបច្ចេកតិទេស ត្រូវតែគោរព ដោយគ្មានល័ក្ខខ័ណ្ឌដល់លក្ខណៈគ្រឹះនៃសីលធម៌ ត្រូវបម្រើមនុស្ស សិទ្ធិរបស់គេ និងអ្វីៗដែលល្អយ៉ាងពិតប្រាកដសម្រាប់គេ ស្របតាមគម្រោងការ និងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

២២៩៥- ទោះបីយើងស្រាវជ្រាវ និងធ្វើបទពិសោធន៍លើមនុស្សយ៉ាងណាក៏ដោយ ក៏យើងមិនអាចសម្រេចកិច្ចការ ដែលប្រឆាំងនឹងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស និងធម្មវិន័យនៃសីលធម៌បានដែរ។ ទោះជាមានការយល់ព្រមអំពីមនុស្សដែលត្រូវពិសោធក៏ដោយ ក៏យើងមិនអាចធ្វើកិច្ចការបែបនេះដែរ។ ពិសោធន៍លើមនុស្សខុសសីលធម៌ បើការពិសោធន៍នោះ នាំឲ្យមានការប្រថុយជីវិត ឬរូបកាយ និងចិត្តគំនិតរបស់មនុស្សខ្លាំងពេក ដែលមិនអាចចៀសវាងបាន។ លើសពីនេះទៅទៀត ពិសោធលើមនុស្សមិនស្របតាមឋានៈដ៏ថ្លៃថ្នូររបស់មនុស្សទេ បើសាមីខ្លួនគេ ឬអាណាព្យាបាលគេមិនយល់ព្រម។

២២៩៦- ការផ្ទេរសិរីរាង្គ ខុសសីលធម៌ បើគ្មានការយល់ព្រមពីអ្នកផ្តល់ ឬអាណាព្យាបាលគេ។ ការផ្ទេរសិរីរាង្គស្របតាមសីលធម៌ បើអ្នកផ្តល់ប្រថុយកាយ និងចិត្តស្របតាមអ្វីដែលល្អចំពោះអ្នកទទួល។ ក្នុងករណីនេះគួសរសើរអ្នកផ្តល់ដែរ។ យើងមិនអាចកាត់អវយវៈ ឬសម្លាប់មនុស្សម្នាក់ ទោះបីយើងប្រព្រឹត្តបែបនេះ ដើម្បីពន្យាសេចក្តីស្លាប់របស់មនុស្សផ្សេងទៀតក៏ដោយ។

### ការគោរពមនុស្សខាងផ្លូវកាយ

២២៩៧- ការចាប់ពង្រត់ និងការចាប់យកជាចំណាប់ខ្មាំង បណ្តាលឲ្យមានការភ័យរន្ធត់តក់ស្លុត ហើយគាបសង្កត់ជនរងគ្រោះយ៉ាងខ្លាំង ដោយគម្រាមកំហែង។ អំពើទាំងអស់នោះ ខុសសីលធម៌។ ភេរវកម្ម ដែលគម្រាមកំហែង ធ្វើឲ្យរបួស និងសម្លាប់ ដោយងងឹតងងល់ផ្ទុយនឹងច្បាប់ និងសេចក្តីស្រឡាញ់ខ្លាំងណាស់។ ការធ្វើទារុណកម្ម ដែលប្រើអំពើហិង្សាខាងផ្លូវកាយ ឬខាងផ្លូវចិត្ត ដើម្បីឲ្យគេសារភាព ដើម្បីផ្តន្ទាអ្នកទោស បំភ័យអ្នកប្រឆាំង និងដើម្បីបំពេញចិត្តស្អប់ ផ្ទុយនឹងការគោរពសិទ្ធិ និងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស។ ក្រៅពីដើម្បីព្យាបាល និងថែទាំ ការកាត់អវយវៈ ឬការធ្វើឲ្យលែងមានកូន ដោយចេតនា របស់មនុស្សដែលគ្មានទោសជាអំពើផ្ទុយនឹងធម្មវិន័យនៃសីលធម៌ (DS ៣៧២២)។

២២៩៨- ក្នុងអតីតកាល រដ្ឋាភិបាលត្រឹមត្រូវបានប្រព្រឹត្តរបៀបយ៉ាងសាហាវ ដើម្បីរក្សាវិន័យ និងរបៀបរៀបរយ។ ជារឿយៗ ពួកគង្វាលព្រះសហគមន៍មិនបានតវ៉ា ហើយបានយកបទបញ្ញានៃច្បាប់នៅទីក្រុងរ៉ូមអំពីការធ្វើទារុណកម្មមក អនុវត្តក្នុងតុលាការរបស់គេផ្ទាល់។ ទន្ទឹងនឹងទង្វើដ៏គួរសោកស្តាយទាំងអស់នោះ ព្រះសហគមន៍តែងតែប្រៀនប្រដៅថា ត្រូវតែអធ្យាស្រ័យ និងមានធម៌មេត្តាករុណា។ ព្រះសហគមន៍បានហាមប្រាមពួកមេដឹកនាំសាសនាមិនឲ្យបង្ហូរឈាម។ សព្វថ្ងៃ យើងយល់ច្បាស់ថា ការប្រព្រឹត្តអំពើសាហាវទាំងអស់នោះ ជាការមិនចាំបាច់ដើម្បីរក្សារបៀបរៀបរយសាធារណៈ ហើយមិនស្របតាមសិទ្ធិដ៏ត្រឹមត្រូវរបស់មនុស្សទេ។ ផ្ទុយទៅវិញ ការដូច្នោះ

អាចបង្ខូចអ្វីៗទាំងអស់។ ត្រូវតែធ្វើការ លុបបំបាត់ទង្វើទាំងអស់នោះចោលចេញ។ ត្រូវតែទូលអង្វរព្រះជាម្ចាស់សម្រាប់ជនរងគ្រោះ និងសម្រាប់ពេជ្ឈឃាតរបស់គេផងដែរ។

### ការគោរពអ្នកស្លាប់

២២៩៩- ត្រូវយកចិត្តទុកដាក់ និងថែទាំអ្នកជិតស្លាប់ ដើម្បីជួយគេឲ្យរស់វេលាចុងក្រោយយ៉ាងថ្លៃថ្នូរ និងយ៉ាងស្ងប់។ អ្នកជិតស្និតគួរជួយនឹងអធិដ្ឋានឲ្យ ហើយនឹងយកចិត្តទុកដាក់ ក្នុងពេលវេលាដ៏សមគួរ ឲ្យអ្នកជំងឺទទួលអគ្គសញ្ញា ដើម្បីរៀបចំឲ្យគេជួបព្រះដែលមានព្រះជន្មគង់នៅ។

២៣០០-ត្រូវគោរពសាកសពរបស់អ្នកស្លាប់ដោយចិត្តស្រឡាញ់ដោយជឿនិងសង្ឃឹមថាគេនឹងទទួលជីវិតថ្មី។ ការបញ្ចុះសពជាកិច្ចការ ដែលសម្តែងធម៌មេត្តាករុណាចំពោះរូបកាយ (តប ១,១៦-១៨) ហើយលើកកិត្តិយសនៃបុត្រធីតារបស់ព្រះជាម្ចាស់ ដែលជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

២៣០១- យើងអាចវះពិនិត្យសព ដើម្បីធ្វើការសើបអង្កេតតាមច្បាប់ ឬដើម្បីការស្រាវជ្រាវខាងវិទ្យាសាស្ត្រ។ យើងអាចផ្តល់សរីរាង្គក្រោយពីបានចែកឋាន ជាអំពើដែលគួរឲ្យកោតសរសើរ។

ព្រះសហគមន៍អនុញ្ញាតឲ្យបូជាសព បើការបូជានេះ មិននាំឲ្យសង្ស័យថា រូបកាយនឹងរស់ឡើងវិញ (CIC ១១៧៦,៣)។

## ៣. ការរក្សាសន្តិភាព

### សន្តិភាព

២៣០២- ដោយរំឭកបទបញ្ជាថា៖ "កុំសម្លាប់មនុស្ស" (មថ ៥,២១) ព្រះអម្ចាស់នៃយើងសុំឲ្យមានសន្តិភាពនៅក្នុងចិត្ត ហើយប្រឆាំងនឹងកំហឹង ដែលនាំឲ្យមានការកាប់សម្លាប់ និងសម្អប់។ កំហឹង និងសម្អប់ជាទង្វើខុសសីលធម៌៖

- កំហឹង ជាបំណងចង់សងសឹក។ "បើយើងមានបំណងចង់សងសឹក ដោយសារអំពើអាក្រក់របស់អ្នកដែលត្រូវផ្តន្ទាទោសយើងខុសច្បាប់"ប៉ុន្តែយើងអាចបង្ខំគេឲ្យទូទាត់អំពើរបស់គេ"ដើម្បីឲ្យគេកែប្រែចិត្តគំនិត និងដើម្បីគោរពយុត្តិធម៌" (សន្តៈ ថូម៉ាស នៃអាកាំង)។ បើយើងខឹងរហូតដល់ចង់សម្លាប់អ្នកដទៃ ឬធ្វើឲ្យគេរបួសធ្ងន់ យើងប្រឆាំងនឹងសេចក្តីស្រឡាញ់ដ៏ធ្ងន់ធ្ងរ គឺយើងប្រព្រឹត្តអំពើបាបដែលនាំឲ្យស្លាប់។ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ "អ្នកណាខឹងនឹងបងប្អូន អ្នកនោះនឹងត្រូវគេផ្តន្ទាទោស" (មថ ៥,២២)។

២៣០៣-ការស្អប់ដោយចេតនាប្រឆាំងនឹងសេចក្តីស្រឡាញ់។ពេលមនុស្សស្អប់អ្នកដទៃរហូតដល់ចង់ធ្វើបាបគេ គេប្រព្រឹត្តអំពើបាប។ យើងប្រព្រឹត្តអំពើបាបធ្ងន់ នៅពេលដែលយើងស្អប់អ្នកដទៃ ដោយមានបំណងចង់ធ្វើបាបយ៉ាងធ្ងន់ធ្ងរ។ "រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ព្រមទាំងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឲ្យអស់អ្នក ដែលបៀតបៀនអ្នករាល់គ្នាផង។ ធ្វើដូច្នេះ អ្នករាល់គ្នានឹងបានទៅជាបុត្រធីតារបស់ព្រះបិតាដែលគង់នៅស្ថានបរមសុខ" (មថ ៥,៤៤-៤៥)។

២៣០៤- ត្រូវតែមានសន្តិភាព ដើម្បីគោរពជីវិតមនុស្ស និងដើម្បីឲ្យជីវិតនេះរីកចម្រើន។ សន្តិភាពមិនគ្រាន់

តែមានន័យថា គ្មានសង្គ្រាមទេ ក៏មិនគ្រាន់តែឲ្យកម្លាំងអាវុធរបស់គូបដិបក្ខស្មើគ្នាទេ។ សន្តិភាពអាចកើតឡើងនៅលើផែនដីបាន លុះត្រាតែរដ្ឋអំណាចរក្សាទុកសេចក្តីសុខសាន្តរបស់មនុស្ស។ មនុស្សក៏ត្រូវតែអាចមានទំនាក់ទំនងរវាងគ្នានិងគ្នា ដោយសេរីដែរ។ ត្រូវតែគោរពឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស និងប្រជាជាតិនានា។ មនុស្សម្នាក់ៗត្រូវព្យាយាមរាប់រកអ្នកដទៃទុកជាបងប្អូនទៀតផង។ សន្តិភាពជា "សេចក្តីសុខសាន្តដោយមានរបៀបរៀបរយ" (សន្តៈ អូគូស្តាំង)។ សន្តិភាពជាកិច្ចការនៃភាពយុត្តិធម៌ (អស ៣២,១៧) និងផលនៃសេចក្តីស្រឡាញ់ (GS ៧៨,១-២)។

២៣០៥- សន្តិភាពនៅលើផែនដីជារូបតំណាង និងផលនៃសេចក្តីសុខសាន្តរបស់ព្រះគ្រីស្តជា "ព្រះអម្ចាស់នៃសេចក្តីសុខសាន្ត" (អស ៩,៥)។ ដោយសារព្រះអង្គបានសោយទិវង្គតនៅលើព្រះឈើឆ្កាង ព្រះអង្គបាន "កំចាត់សម្អប់ចោល" (អភ ២,១៦) (កូឡ ១,២០-២២) ព្រះអង្គបានសម្រុះសម្រួលមនុស្សជាមួយព្រះជាម្ចាស់ ហើយបានប្រោសព្រះសហគមន៍ព្រះអង្គឲ្យទៅជាអគ្គសញ្ញានៃឯកភាពរបស់មនុស្សលោក ដែលរួមជាមួយព្រះជាម្ចាស់ផង។ "គឺព្រះគ្រីស្តនេះហើយ ដែលជាសន្តិភាពរបស់យើង" (អភ ២,១៤)។ ព្រះអង្គមានព្រះបន្ទូលថា "អ្នកណាកសាងសន្តិភាព អ្នកនោះមានសុភមង្គលហើយ" (មថ ៥,៩)។

២៣០៦- អស់អ្នកដែលបោះបង់ចោលអំពើហិង្សាដែលបង្ហូរឈាម ហើយដែលរក្សាការពារសិទ្ធិមនុស្សដោយប្រើមធ្យោបាយការពារអ្នកទន់ខ្សោយទៅតាមលទ្ធភាពអាចធ្វើបាន ផ្តល់សក្ខីភាពដល់សេចក្តីស្រឡាញ់នៃដំណឹងល្អ លុះត្រាតែគេមិនបង្ខូចសិទ្ធិ និងភារកិច្ចរបស់អ្នកដទៃ និងរបស់សហគមន៍ផងដែរ។ គេបញ្ជាក់យ៉ាងត្រឹមត្រូវថា ការប្រើអំពើហិង្សាធ្វើឲ្យជីវិតមនុស្សទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ប្រថុយនឹងគ្រោះថ្នាក់ ព្រមទាំងកម្ទេចអ្វីៗទាំងអស់ និងសម្លាប់មនុស្សជាច្រើន (GS ៧៨,៥)។

## ត្រូវចៀសវាងសង្គ្រាម

២៣០៧- វិន័យទីប្រាំហាមប្រាមមិនឲ្យបំផ្លាញជីវិតមនុស្សដោយចេតនា។ សង្គ្រាមនាំឲ្យមានអំពើអាក្រក់ និងអំពើអយុត្តិធម៌ជាច្រើន ព្រះសហគមន៍ជំរុញគ្រីស្តបរិស័ទម្នាក់ៗឲ្យអធិដ្ឋាន និងបំពេញកិច្ចការ ដើម្បីឲ្យសប្បុរសធម៌របស់ព្រះជាម្ចាស់រំដោះយើងឲ្យរួចពីទាសភាពនៃសង្គ្រាម ដែលមានតាំងពីយូរអង្វែងមកហើយ (GS ៨១,៤)។

២៣០៨- ប្រជាពលរដ្ឋ និងអ្នកគ្រប់គ្រងម្នាក់ៗត្រូវតែធ្វើយ៉ាងណា ដើម្បីចៀសវាងឲ្យផុតពីសង្គ្រាម។

> ក៏ប៉ុន្តែ "ដរាបណាគ្មានអំណាចអន្តរជាតិដែលមានសមត្ថកិច្ច និងមានកងទ័ពគ្រប់គ្រាន់ទេ សង្គ្រាមអាចនឹងផ្ទុះឡើង។ ប៉ុន្តែ រដ្ឋាភិបាលនានាមានសិទ្ធិដ៏ត្រឹមត្រូវនឹងការពារប្រទេសរបស់ខ្លួនបាន លុះត្រាតែគេបានប្រើគ្រប់លទ្ធភាពដោះស្រាយបញ្ហាដោយសន្តិវិធីជាមុនសិន" (GS ៧៩,៤)។

២៣០៩- ត្រូវតែរិះគិតដោយយកចិត្តទុកដាក់អំពីល័ក្ខខ័ណ្ឌដ៏ត្រឹមត្រូវ ដើម្បីការពារខ្លួនដោយប្រើកម្លាំងយោធា។ ការសម្រេចចិត្តបែបនេះសំខាន់ណាស់ ត្រូវតែបញ្ចូលក្នុងល័ក្ខខ័ណ្ឌដ៏តឹងរ៉ឹង។ត្រូវតែមានល័ក្ខខ័ណ្ឌបួនយ៉ាង៖

- អ្នកឈ្លានពានចំពោះប្រទេសជាតិ ឬសហគមន៍ប្រជាជាតិ មានរយៈពេលយូរ ធ្វើឲ្យមានការខូចខាតយ៉ាងជាក់ស្តែង
- មិនអាចប្រើមធ្យោបាយណាទៀត ដើម្បីបញ្ចប់ការខូចខាតនេះ ឬមធ្យោបាយទាំងអស់នោះ គ្មានប្រសិទ្ធិភាព

- ត្រូវតែមានលក្ខខណ្ឌយ៉ាងច្បាស់ថា អាចទទួលជោគជ័យ
- ការប្រើអាវុធមិនត្រូវនាំឲ្យមានផលវិបាក និងភាពច្របូកច្របល់អាក្រក់ជាងអំពើអាក្រក់ ដែលយើងចង់បំបាត់ចោលឡើយ។ ត្រូវគិតគូរឲ្យមែនទែនដល់ការវិនាសអន្តរាយ ដែលបណ្តាលមកពីសាស្ត្រវិធីទំនើបៗ។
- ចំណុចទាំងអស់នោះ ស្របតាមលទ្ធិបុរាណអំពី "សង្គ្រាមដ៏ត្រឹមត្រូវ"។
- អស់អ្នក ដែលទទួលបន្ទុកយកចិត្តទុកដាក់នឹងប្រយោជន៍រួម ត្រូវតែវិនិច្ឆ័យលក្ខខណ្ឌទាំងអស់នោះដោយប្រុងប្រយ័ត្ន។

២៣១០- ក្នុងករណីនេះ រដ្ឋអំណាចមានសិទ្ធិ និងភារកិច្ចបង្ខិតបង្ខំឲ្យប្រជាពលរដ្ឋការពារប្រទេសជាតិ។

អស់លោកអ្នកដែលប្តេជ្ញាចិត្តបម្រើមាតុភូមិ ក្នុងឋានៈជាទាហាន សូមចាត់ខ្លួនជាអ្នកបម្រើសន្តិសុខ និងបម្រើសេរីភាពរបស់ប្រជាជាតិនានាដែរ។ ប្រសិនបើគេបំពេញកិច្ចការនេះយ៉ាងត្រឹមត្រូវ គេពិតជាបម្រើប្រយោជន៍ជាតិ និងជួយថែរក្សាសន្តិភាពមែន (GS ៧៩,៥)។

២៣១១- រដ្ឋអំណាចនឹងយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវចំពោះអស់អ្នក ដែលបដិសេធមិនព្រមកាន់អាវុធដោយសារមនសិការរបស់ខ្លួន។ ប៉ុន្តែ អ្នកទាំងអស់នោះក៏នៅតែត្រូវបម្រើសហគមន៍មនុស្សតាមរបៀបផ្សេងទៀត (GS ៧៩,៣)។

២៣១២- ព្រះសហគមន៍ និងប្រាជ្ញាមនុស្សប្រកាសថា ត្រូវតែអនុវត្ត ធម្មវិន័យនៃសីលធម៌ជានិច្ច ទោះបីមានសង្គ្រាមយ៉ាងក៏ដោយ។ "ប្រសិនបើសង្គ្រាមគួរឲ្យផ្ទុះឡើង កុំនឹកស្មានថា ពេលនោះគូបដិបក្ខអាចប្រព្រឹត្តអ្វីៗតាមអំពើចិត្តបាន" (GS ៧៩,៤)។

២៣១៣- ត្រូវតែគោរព និងយកចិត្តទុកដាក់ដោយចិត្តមនុស្សធម៌ចំពោះអស់អ្នកដែលមិនកាន់អាវុធ ទាហានដែលត្រូវរបួស និងឈ្លើយសង្គ្រាមផងដែរ។

- អ្នកធ្វើការប្រឆាំងនឹងសិទ្ធិមនុស្ស ប្រឆាំងនិងគោលការណ៍សកលអំពីសិទ្ធិនោះ ជាឧក្រិដ្ឋជន ដូចអ្នកបញ្ជាឲ្យធ្វើការទាំងនោះផងដែរ។ អ្នកស្តាប់បង្គាប់ដោយមិនរិះគិត មិនអាចលើកលែងទោសទាល់តែសោះ។ហេតុនេះ ការប្រល័យពូជសាសន៍មួយទាំងមូល ប្រល័យជាតិមួយ ឬប្រល័យជនជាតិភាគតិច ជាអំពើបាបដែលនាំឲ្យស្លាប់។ តាមសីលធម៌ យើងត្រូវតែប្រឆាំងនឹងអស់អ្នក ដែលបញ្ជាឲ្យប្រល័យពូជសាសន៍។

២៣១៤-"ប្រតិបត្តិការសឹក ដែលមានគោលដៅទៅបំផ្លាញក្រុងទាំងមូល និងតំបន់ដ៏ធំមួយ និងប្រជាជនតំបន់នោះ ពិតជាអំពើឧក្រិដ្ឋធំទាស់នឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ" (GS ៨០,៤)។ សង្គ្រាមទំនើបអាចបណ្តាលឲ្យមានគ្រោះកាចពិសេស ព្រោះសង្គ្រាមបែបនោះ ហុចឱកាសឲ្យអ្នកដែលមានអាវុធវិទ្យាសាស្ត្រទំនើបជាងគេ ជាពិសេសអាវុធបរមាណូអាវុធជីវវិទ្យាឬអាវុធគីមី ប្រព្រឹត្តអំពើឧក្រិដ្ឋទាំងនោះបាន។

២៣១៥- មនុស្សជាច្រើនយល់ឃើញថាការប្រមូលទុកអាវុធកាន់តែច្រើនឡើងៗ ជារបៀបឃាត់កុំឲ្យមានសង្គ្រាម។ គេគិតថា ជាមធ្យោបាយយ៉ាងស័ក្តិសិទ្ធិ ធានាសន្តិភាពម៉្យាងរវាងប្រជាជាតិនានា។ វិធីឃាត់សង្គ្រាមបែបនេះមិនសូវស្របតាមសីលធម៌ឡើយ។ ការប្រណាំងប្រជែងខាងសព្វាវុធ មិនធានាសន្តិភាពពិតប្រាកដឡើយ។

ការប្រណាំងប្រជែងនេះមិនអាចលុបបំបាត់មូលហេតុបណ្ដាលឲ្យកើតសង្គ្រាមទេផ្ទុយទៅវិញការប្រណាំងប្រជែងនេះ អាចបណ្ដាលឲ្យមូលហេតុទាំងនោះកាន់តែដុនដាបទៅៗ។ ប្រទេសខ្លះចាយវាយធនធានរបស់ខ្លួនយ៉ាងសម្បើមអស្ចារ្យមកបង្កើតអាវុធថ្មីៗ ប៉ុន្តែ គេមិនអាចជួយមនុស្សដែលរងទុក្ខក្នុងពិភពលោកទាំងមូលបានគ្រប់គ្រាន់ទេ (PP ៥៣)។ ការប្រណាំងប្រជែងនេះ រារាំងមិនឲ្យប្រជាជននានាអភិវឌ្ឍបានឡើយ។ការកាន់អាវុធលើសពីតម្រូវការ បង្កើនទំនាស់ និងអាចបណ្ដាលឲ្យមានការរាលដាលដល់តំបន់ផ្សេងៗទៀតក្នុងពិភពលោក។

២៣១៦- ការផលិត និងជំនួញសាស្ត្រាវុធ ប៉ះពាល់ដល់ប្រយោជន៍រួមនៃប្រជាជាតិនានា និងរបស់សហគមន៍អន្តរជាតិ។ ដូច្នេះ រដ្ឋអំណាចមានសិទ្ធិ និងភារកិច្ចត្រួតត្រាការផលិត និងជំនួញសាស្ត្រាវុធនោះ។ ការស្វែងរកប្រយោជន៍ឯកជន ឬប្រយោជន៍រួម ដោយគិតខ្លី មិនអាចដោះសាកិច្ចការ ដែលបង្កើតអំពើហិង្សា នាំឲ្យប្រជាជាតិទាស់ទែងគ្នា និងបណ្ដាលឲ្យច្បាប់អន្តរជាតិវិនាស។

២៣១៧- អំពើអយុត្តិធម៌ ស្ថានភាពសេដ្ឋកិច្ចនិងស្ថានភាពសង្គមមិនស្មើគ្នាហួសហេតុ ចិត្តច្រណែនឈ្នានីស ការមិនទុកចិត្តគ្នា ចិត្តក្រអឺតក្រអោងរវាងមនុស្ស និងប្រជាជាតិ គម្រាមកំហែងសន្តិភាពឥតឈប់ឈរ និងបង្កើតសង្គ្រាម។ អ្វីៗទាំងអស់ដែលយើងធ្វើដើម្បីយកជ័យជំនះលើភាពច្របូកច្របល់ទាំងអស់នោះ ជាការចូលរួមជួយកសាងសន្តិភាព និងចៀសវាងមិនឲ្យកើតសង្គ្រាម៖

> ដោយយើងដឹងថា មនុស្សជាអ្នកបាប គ្រោះថ្នាក់នៃសង្គ្រាមគម្រាមគំហែងយើងជានិច្ចរហូតដល់ពេលព្រះគ្រីស្តយាងមកវិញ។ ក៏ប៉ុន្តែ បើមនុស្សរួបរួមគ្នាដោយសេចក្ដីស្រឡាញ់ ហើយយកឈ្នះលើអំពើបាប មនុស្សក៏អាចឈ្នះអំពើហិង្សាបានដែរ រហូតដល់ព្រះបន្ទូលព្រះជាម្ចាស់ "ពួកគេនឹងយកដាវរបស់ខ្លួនមករំលាយធ្វើជាផាលនង្គ័ល ហើយយកលំពែងមករំលាយធ្វើជាកណ្ដៀវ។ ប្រជាជាតិមួយឈប់ច្បាំងនឹងប្រជាជាតិមួយទៀត ហើយគេក៏លែងហាត់រៀនធ្វើសង្គ្រាមទៀតដែរ" (អស ៤,២) (GS ៧៨,៦) កើតជារូបរាង។

## សង្ខេប

២៣១៨- "ព្រះជាម្ចាស់ក្ដាប់ព្រលឹងសត្វលោកទាំងអស់នៅក្នុងព្រះហស្តរបស់ព្រះអង្គ ហើយដង្ហើមជីវិតរបស់មនុស្សក៏ស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអង្គដែរ" (យប ១២,១០)។

២៣១៩- តាំងពីក្នុងផ្ទៃម្ដាយរហូតដល់ពេលស្លាប់ ជីវិតមនុស្សថ្លៃថ្នូរណាស់ ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យបង្កើតមនុស្ស ដើម្បីខ្លួនគេ ព្រះអង្គបានបង្កើតមនុស្សជារូបតំណាង និងមានលក្ខណៈរបស់ព្រះដ៏មាន ព្រះជន្មគង់នៅ ជាព្រះដ៏វិសុទ្ធ។

២៣២០- ការសម្លាប់មនុស្សម្នាក់ជាការប្រឆាំងយ៉ាងធ្ងន់ធ្ងរនឹងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស និងភាពដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ជាអ្នកបង្កើត។

២៣២១- ទោះបីជាយើងមិនអាចសម្លាប់មនុស្សយ៉ាងណាក៏ដោយ ក៏យើងអាចឃាត់អ្នកធ្វើបាបមិនឲ្យធ្វើបាបទៀតដែរ។ ការការពារខ្លួនឯងជាភារកិច្ចសំខាន់សម្រាប់អ្នកដែលទទួលខុសត្រូវលើជីវិតអ្នកដទៃ ឬលើផលប្រយោជន៍រួម។

២៣២២- តាំងពីក្នុងផ្ទៃម្ដាយមកម្ល៉េះ កូនក្មេងមានសិទ្ធិក្នុងការរស់នៅ។ ការរំលូតកូនដោយផ្ទាល់ ដើម្បី

បញ្ឈប់ ឬដើម្បីជាមធ្យាបាយ គឺជាអំពើ "គួរឱ្យស្អប់ខ្ពើម" (GS ២៧,៣) ប្រឆាំងនឹងវិន័យសីលធម៌យ៉ាងធ្ងន់ធ្ងរ។ ព្រះសហគមន៍ដាក់ទោសគ្រីស្តបរិស័ទណា ដែលប្រព្រឹត្តបទល្មើសនេះ ឱ្យដេញចេញពីព្រះសហគមន៍។

២៣២៣- ត្រូវចាត់ទុកថា ភ្រូណជាមនុស្សម្នាក់តាំងពីការរកកើតមកម៉្លេះ ហេតុនេះ ត្រូវការពារថែទាំ និងព្យាបាលភ្រូណដូចមនុស្សទៀត តាមអ្វីដែលអាចធ្វើបាន។

២៣២៤- ទោះជាមានមូលហេតុ និងមធ្យោបាយយ៉ាងណាក៏ដោយ ក៏ការជួយមនុស្សឱ្យចែកឋានយ៉ាងស្រួលជាការសម្លាប់មនុស្សដែរ។ ការជួយមនុស្សឱ្យចែកឋានយ៉ាងស្រួលប្រឆាំងយ៉ាងធ្ងន់ធ្ងរនឹងឋានៈដ៏ថ្លៃថ្នូរ របស់មនុស្ស និងមិនគោរពព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ ដែលជាព្រះបង្កើតរបស់មនុស្ស។

២៣២៥- អត្តឃាតកម្មប្រឆាំងយ៉ាងធ្ងន់ធ្ងរនឹងយុត្តិធម៌ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់។ វិន័យទីប្រាំហាមមិនឱ្យសម្លាប់ខ្លួន។

២៣២៦- អំពើអាស្រូវជាកំហុសធ្ងន់ធ្ងរ នៅពេលដែលយើងមានបំណងនាំអ្នកដទៃឱ្យប្រព្រឹត្តបាប ដោយសារកិច្ចការដែលត្រូវធ្វើ ឬដោយសារការខកខានមិនបានធ្វើ។

២៣២៧- ដោយសារសង្គ្រាមនីមួយៗនាំឱ្យមានការវិនាស និងអយុត្តិធម៌ យើងត្រូវតែព្យាយាមដោះស្រាយយ៉ាងណា តាមរបៀបត្រឹមត្រូវ កុំឱ្យមានសង្គ្រាម។ ព្រះសហគមន៍អង្វរថា៖ "សូមព្រះអម្ចាស់រំដោះយើងខ្ញុំឱ្យចាកផុតពីទុរ្ភិក្ស អន្តរាយគ្រប់បែបយ៉ាង និងសង្គ្រាម"។

២៣២៨- ព្រះសហគមន៍ និងប្រាជ្ញាមនុស្សប្រកាសថា សីលធម៌នៅតែមានតម្លៃជានិច្ចក្នុងពេលសង្គ្រាម។ ការប្រព្រឹត្តប្រឆាំងនឹងសិទ្ធិមនុស្ស ប្រឆាំងនិងគោលការណ៍សកលអំពីសិទ្ធិនោះ ជាឧក្រិដ្ឋកម្ម។

២៣២៩- ការប្រណាំងប្រជែងឱ្យបានអាវុធកាន់តែពូកែ និងកាន់តែច្រើនឡើង ពិតជាមុខរបួសយ៉ាងធ្ងន់ធ្ងរបំផុតរបស់មនុស្សជាតិ និងបណ្តាលឱ្យមានអយុត្តិធម៌ដល់អ្នកក្រីក្រ តាមរបៀបដែលទ្រាំមិនបាន។

២៣៣០- "អ្នកណាកសាងសន្តិភាពអ្នកនោះមានសុភមង្គលហើយដ្បិតពួកគេនឹងមានឈ្មោះជាបុត្ររបស់ព្រះជាម្ចាស់!" (មថ ៥,៩)។

# ប្រការទី៦៖

## វិន័យទីប្រាំមួយ

- កុំប្រព្រឹត្តអំពើផិតក្បត់ (សរ ២០,១៤ ; ទក ៥,១៨)។

អ្នករាល់គ្នាធ្លាប់ឮសេចក្តីថ្លែងទុកមកថា "កុំប្រព្រឹត្តអំពើផិតក្បត់"។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា "អ្នកណាមើលស្ត្រីម្នាក់ហើយមានចិត្តស្រើបស្រាលចង់រួមបវេណីជាមួយនាង អ្នកនោះដូចជាបានប្រព្រឹត្តអំពើផិតក្បត់ជាមួយនាង នៅក្នុងចិត្តរបស់ខ្លួន រួចស្រេចទៅហើយ" (មថ ៥,២៧-២៨)។

### ១. "ព្រះជាម្ចាស់បង្កើតមនុស្សជាបុរស ជាស្ត្រី..."

២៣៣១- "ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធរួបរួមជាមួយគ្នាដោយស្រឡាញ់គ្នាទៅវិញទៅមក យ៉ាងអាថ៌កំបាំង នៅក្នុងអង្គព្រះអង្គផ្ទាល់។ ដោយបង្កើតមនុស្សប្រុស និង

មនុស្សស្រីជាតំណាងរបស់ព្រះអង្គ ព្រះជាម្ចាស់ត្រាស់ហៅ មនុស្សលោក (ទើបព្រះអង្គប្រោសប្រទានគេឲ្យមានសមត្ថភាព និងចេះទទួលខុសត្រូវ) ឲ្យស្រឡាញ់ និងឲ្យរួបរួមជាមួយគ្នា។" (FC ១១)។

- "ព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាងរបស់ព្រះអង្គ (...) ព្រះអង្គបានបង្កើតគេជាបុរសជាស្ត្រី" (កណ ១,២៧)។ "ចូរបង្កើតកូនចៅឲ្យបានកើនច្រើនឡើង" (កណ ១,២៨)។ "នៅថ្ងៃដែលព្រះជាម្ចាស់បង្កើតមនុស្ស ព្រះអង្គបានបង្កើតគេឲ្យមានលក្ខណៈ ដូចព្រះជាម្ចាស់។ ព្រះអង្គបង្កើតគេជាបុរស ជាស្ត្រី និងប្រទានពរឲ្យគេហើយនៅថ្ងៃដែលព្រះអង្គបង្កើតគេមកនោះទ្រង់ហៅគេថា "មនុស្ស"" (កណ ៥,១-២)។

២៣៣២- ជីវិតខាងផ្លូវភេទ ប៉ះពាល់នឹងផ្នែកទាំងអស់របស់មនុស្ស ក្នុងឯកភាពនៃរូបកាយ និងព្រលឹងរបស់គេ។ ជាពិសេស ជីវិតខាងផ្លូវភេទទាក់ទងនឹងជីវិតខាងផ្លូវចិត្ត សមត្ថភាពអាចស្រឡាញ់ និងបង្កើតកូន ហើយជាទូទៅ គុណសម្បត្តិអាចរួបរួមជាមួយអ្នកដទៃ។

២៣៣៣- មនុស្សម្នាក់ៗទាំងបុរស ទាំងស្ត្រី ត្រូវតែទទួលស្គាល់ និងសុខចិត្តអត្តសញ្ញាណ ខាងផ្លូវភេទរបស់ខ្លួន។ បុរស និងស្ត្រីខុសប្លែកពីគ្នានិងបំពេញគ្នាទៅវិញទៅមកខាងផ្លូវកាយ ខាងផ្លូវចិត្ត និងខាងផ្លូវវិញ្ញាណ ដើម្បីផលប្រយោជន៍នៃការរស់នៅជាគូស្វាមីភរិយា និងឲ្យការរស់នៅក្នុងក្រុមគ្រួសាររីកចម្រើន។ សេចក្ដីសុខសាន្តរបស់គូស្វាមីភរិយា និងរបស់សង្គមអាស្រ័យទៅលើរបៀប ដែលបុរស និងស្ត្រីបំពេញគ្នា ត្រូវការគ្នា និងពឹងផ្អែកលើគ្នាទៅវិញទៅមក។

២៣៣៤- "ដោយបង្កើតមនុស្សជាបុរស ជាស្ត្រី ព្រះជាម្ចាស់ប្រោសប្រទានឲ្យពួកគេមានឋានៈដ៏ថ្លៃថ្នូរស្មើគ្នា" (FC ២២ ; GS ៤៩,២)។ "មនុស្សជាបុគ្គលម្នាក់ ទាំងបុរស ទាំងស្ត្រី ដ្បិតព្រះជាម្ចាស់បានបង្កើតទាំងពីរនាក់ជាតំណាង និងមានលក្ខណៈដូចជាបុគ្គលនៃព្រះជាម្ចាស់ផងដែរ" (MD ៦)។

២៣៣៥-ដោយបុរសនិងស្ត្រីមានឋានៈដ៏ថ្លៃថ្នូរស្មើគ្នាទោះជាខុសប្លែកពីគ្នាក៏ដោយក៏ជាតំណាងនៃឫទ្ធានុភាព និងមេត្តាករុណារបស់ព្រះជាម្ចាស់។ ការរួមរស់របស់បុរស និងស្ត្រី ជាគូស្វាមីភរិយាជារបៀបយកតម្រាប់តាមសប្បុរសធម៌នៃព្រះជាម្ចាស់ ដែលបង្កើតផលបានច្រើន៖ "ហេតុនេះ បុរសចាកចេញពីឪពុកម្ដាយទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរត្រឡប់ទៅជារូបកាយតែមួយ" (កណ ២,២៤)។ មនុស្សគ្រប់ជំនាន់ចេញមកពីការរួមរស់បែបនេះ (កណ ៤,១-២.២៥-២៦ ; ៥,១)។

២៣៣៦- ព្រះយេស៊ូយាងមក ដើម្បីកែលំអសត្វលោកឡើងវិញ ស្របតាមគម្រោងការដ៏បរិសុទ្ធដើមដំបូងរបស់ព្រះជាម្ចាស់។ ក្នុងធម្មទេសនានៅលើភ្នំ ព្រះអង្គបកស្រាយគម្រោងការរបស់ព្រះជាម្ចាស់យ៉ាងតឹងរឹង៖ "អ្នករាល់គ្នាធ្លាប់ឮសេចក្ដីថ្លែងទុកមកថា "កុំប្រព្រឹត្តអំពើផិតក្បត់"។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា "អ្នកណាមើលស្ត្រីម្នាក់ហើយមានចិត្តស្រើបស្រាលចង់រួមបវេណីជាមួយនាង អ្នកនោះដូចជាបានប្រព្រឹត្តអំពើផិតក្បត់ជាមួយនាង នៅក្នុងចិត្តរបស់ខ្លួន រួចស្រេចទៅហើយ" (មថ ៥,២៧-២៨)។ "មនុស្សមិនត្រូវបំបាក់បំបែកគូស្រករដែលព្រះជាម្ចាស់បានផ្សំផ្គុំនោះឡើយ" (មថ ១៩,៦)។

- ការបញ្ជូនបន្តព្រះសហគមន៍បានយល់ឃើញថា វិន័យទីប្រាំមួយសំដៅទៅលើជីវិតខាងផ្លូវភេទទាំងមូលរបស់មនុស្ស។

## ២. ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យចេះទប់ខ្លួន

២៣៣៧- មនុស្សដែលចេះទប់ខ្លួន គឺជាមនុស្សម្នាក់ ដែលមានជីវិតខាងផ្លូវភេទល្អប្រសើរ ទើបរូបកាយ និងវិញ្ញាណរបស់គេរួមឯកភាពជាមួយគ្នាផ្នែកខាងក្នុង។ ជីវិតខាងផ្លូវភេទ ដែលបង្ហាញថា មនុស្សជាផ្នែកនៃពិភពខាងផ្លូវកាយ និងខាងជីវសាស្ត្រ ក្លាយទៅជារបស់ខ្លួនឯងផ្ទាល់ និងមានលក្ខណៈជាមនុស្សសុទ្ធសាធ នៅពេលដែលបុរស និងស្ត្រីមានទំណាក់ទំនងពីម្នាក់ទៅម្នាក់ ប្រគល់ខ្លួនឯងទៅវិញទៅមក ទាំងស្រុង និងគ្មានកំណត់ពេលវេលា។

-គុណធម៌នៃការចេះទប់ខ្លួនទាក់ទងនឹងមនុស្សទុកជាបុគ្គលតែម្នាក់គត់ និងការផ្តល់ខ្លួនឯងទាំងស្រុង។

### មនុស្សជាបុគ្គលតែម្នាក់គត់

២៣៣៨- អ្នកដែលចេះទប់ខ្លួនរក្សាទុកឫទ្ធានុភាពទាំងស្រុងនៃជីវិត និងសេចក្តីស្រឡាញ់ ដែលព្រះជាម្ចាស់បានដាក់បញ្ចូលនៅក្នុងខ្លួនគេ ទើបមនុស្សជាបុគ្គលតែម្នាក់គត់។ អ្នកចេះទប់ខ្លួនប្រឆាំងនឹងឥរិយាបថ ដែលនឹងធ្វើឲ្យគេរបួស។ គេមិនចេះអត់អោនឲ្យនរណាម្នាក់ ដែលរស់នៅរបៀបខ្លួនមួយជីវិតពីរ ឬការនិយាយខុសពីការធ្វើ (មថ ៥,៣៧)។

២៣៣៩- អ្នកចង់ចេះទប់ខ្លួនត្រូវតែរៀនឲ្យចេះគ្រប់គ្រងលើខ្លួនឯង ដែលជាគរុកោសល្យនៃសេរីភាពរបស់មនុស្ស។ ត្រូវតែជ្រើសរើសឲ្យច្បាស់ រវាងការគ្រប់គ្រងលើតណ្ហារបស់ខ្លួន ដើម្បីបានសេចក្តីសុខ ឬការបណ្តែតបណ្តោយខ្លួនឲ្យទៅជាឈ្លើយនៃតណ្ហាទាំងអស់នោះ ហើយត្រូវវេទនា (បសរ ១,២២)។ "កិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សទាមទារឲ្យអនុវត្តតាមការជ្រើសរើសប្រកបដោយមនសិការ និងដោយសេរីភាព គឺជឿជាក់ដោយខ្លួនឯងផ្ទាល់យ៉ាងជ្រៅក្នុងចិត្ត មិនមែនដោយតណ្ហាពុះកញ្ជ្រោល ឬ ដោយការបង្ខិតបង្ខំឡើយ។ ប្រសិនបើមនុស្សរំដោះខ្លួនឲ្យរួចផុតពីទាសភាពនៃតណ្ហាទាំងអស់ គេមុខជាបានកិត្តិយសនេះ ដោយការជ្រើសរើសយកអំពើល្អដោយគ្មានការបង្ខិតបង្ខំ។ ពេលនោះគេចាប់ផ្តើមធ្វើដំណើរទៅកាន់វាសនារបស់ខ្លួន និងប្រើប្រាជ្ញាដ៏វាងវៃ ដើម្បីខិតខំយ៉ាងពិតប្រាកដរកមធ្យោបាយទៅកាន់វាសនានោះ" (GS ១៧)។

២៣៤០- អ្នកណាចង់គោរពពាក្យសន្យានៃពិធីជ្រមុជទឹករបស់ខ្លួន ហើយតស៊ូប្រឆាំងនឹងការល្បួង អ្នកនោះត្រូវប្រុងប្រយ័ត្នក្នុងការប្រើមធ្យោបាយ គឺគេត្រូវស្គាល់ខ្លួនឯង ធ្វើទុក្ករកិរិយាស្របតាមកាលៈទេសៈ ស្តាប់បង្គាប់គោរពតាមបទបញ្ញារបស់ព្រះជាម្ចាស់ ប្រតិបត្តិតាមគុណធម៌នៃសីលធម៌ និងកុំបំភ្លេចអធិដ្ឋានដោយភក្តីភាព។ "ការចេះទប់ខ្លួនរៀបចំយើងឡើងវិញ និងនាំយើងឲ្យទៅជាបុគ្គលតែម្នាក់គត់ ពីព្រោះយើងបានបាត់បង់ឯកភាពរបស់ខ្លួន ដោយមានការបែងចែក (សន្តៈ អូគូស្តាំង)។

២៣៤១- គុណធម៌នៃការចេះទប់ខ្លួនស្ថិតក្រោមគុណធម៌សំខាន់ៗនៃការចេះទប់ចិត្ត ដែលមានគោលដៅនាំឲ្យគ្រប់គ្រងតណ្ហា និងចិត្តថ្លើមមនុស្ស ដោយប្រាជ្ញា។

២៣៤២- ត្រូវតែខិតខំយ៉ាងយូរ ដើម្បីអាចគ្រប់គ្រងខ្លួនឯងបាន។ គេមិនអាចខិតខំតែម្តងហើយបានសម្រេចទេ។ ត្រូវតែខិតខំជានិច្ច អស់មួយជីវិត (ទត ២,១-៦)។ នៅក្នុងវ័យខ្លះ ត្រូវតែខិតខំយ៉ាងខ្លាំង ដើម្បីចេះទប់ខ្លួនជាពិសេសក្នុងវ័យកុមារភាព និងក្នុងវ័យជំទង់ ជាអាយុដែលត្រូវបង្កើតបុគ្គលិកលក្ខណៈរបស់ ខ្លួន។

២៣៤៣- មនុស្សត្រូវតែល្បងលាស់ ដើម្បីចេះទប់ខ្លួន ប៉ុន្តែក្នុងរយៈពេលនោះ មនុស្សត្រូវឆ្លងកាត់គុណវិបត្តិ

និងអំពើបាបជារឿយៗ។"ពីមួយថ្ងៃទៅមួយថ្ងៃ មនុស្សសុចរិតដែលចេះទប់ខ្លួន កសាងខ្លួនឯង ដោយសារជម្រើសរើសជាច្រើន ដែលគេជ្រើសដោយសេរី។ ហេតុនេះ គេស្គាល់ ស្រឡាញ់ និងបំពេញអ្វីដ៏ល្អស្របតាមសីលធម៌ទៅតាមដំណាក់កាលនៃការលូតលាស់" (FC ៣៤)។

២៣៤៤- មនុស្សគ្រប់រូបត្រូវចេះទប់ខ្លួន ដោយខិតខំសិក្សាផ្នែកវប្បធម៌ផង ដ្បិត "ការរីកចម្រើនរបស់បុគ្គលនីមួយៗ និងការអភិវឌ្ឍន៍សង្គម ជំពាក់ជំពិនគ្នាទៅវិញទៅមក" (□□ ២៥,១)។ អ្នកចេះទប់ខ្លួនត្រូវតែគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិក្នុងការទទួលព័ត៌មាន និងការអប់រំ ដែលគោរពលក្ខណៈសីលធម៌ និងវិញ្ញាណនៃជីវិតមនុស្ស។

២៣៤៥- ការចេះទប់ខ្លួនជាគុណធម៌នៃសីលធម៌។ ការចេះទប់ខ្លួនជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ដែលប្រោសប្រណីមនុស្ស ហើយជាផលនៃកិច្ចការខាងវិញ្ញាណ (កាឡ ៥,២២)។ ដោយសារទឹកនៃពិធីជ្រមុជទឹកព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឲ្យអ្នក ដែលកើតសាជាថ្មីអាចយកតម្រាប់តាមភាពបរិសុទ្ធរបស់ព្រះគ្រីស្ត (១យហ ៣,៣)។

## ត្រូវតែប្រគល់ខ្លួនឯងទាំងស្រុង

២៣៤៦- សេចក្តីស្រឡាញ់តំណាងឲ្យគុណធម៌ឯទៀតៗទាំងអស់។ ក្រោមឥទ្ធិពលនៃសេចក្តីស្រឡាញ់ ការចេះទប់ខ្លួនប្រៀបដូចជាសាលា ដែលមនុស្សរៀនប្រគល់ខ្លួនឯង។ ការគ្រប់គ្រងលើខ្លួនឯងស្ថិតនៅក្រោមការប្រគល់ខ្លួនឯង។ ការចេះទប់ខ្លួនដឹកនាំអ្នក ដែលប្រតិបត្តិតាម ឲ្យក្លាយទៅជាសាក្សីនៃភក្តីភាព និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ចំពោះអ្នកដទៃ។

២៣៤៧- គុណធម៌នៃការចេះទប់ខ្លួនរីកចម្រើនក្នុងមេត្រីភាព ហើយបង្ហាញឲ្យសាវ័កដឹងថា តើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីដើរតាម និងយកតម្រាប់តាមអ្នកដែលបានជ្រើសរើសយើង ដូចជាមិត្តសម្លាញ់ (យហ ១៥,១៥) និងដែលបានប្រគល់ខ្លួនទាំងស្រុងចំពោះយើង ហើយដែលធ្វើឲ្យយើងចូលរួមចំណែកក្នុងឋានៈជាព្រះជាម្ចាស់។ ព្រះជាម្ចាស់មានព្រះបន្ទូលសន្យានឹងប្រទានជីវិតអមតៈដល់អ្នកចេះទប់ខ្លួន។

- ការចេះទប់ខ្លួនស្តែងចេញមកអំពីចំណងមេត្រីភាពចំពោះអ្នកដទៃ។ មេត្រីភាពរវាងមនុស្សភេទដូចគ្នា ឬភេទផ្សេងពីគ្នា ជាអំពើដ៏ល្អប្រសើររបស់មនុស្សទាំងអស់ ហើយនាំឲ្យវិញ្ញាណរួបរួមគ្នា។

## របៀបផ្សេងៗនៃការចេះទប់ខ្លួន

២៣៤៨- ព្រះជាម្ចាស់ត្រាស់ហៅអស់អ្នកដែលបានជ្រមុជទឹកឲ្យចេះទប់ខ្លួន។ គ្រីស្តបរិស័ទ "មានព្រះគ្រីស្តជាប់ជាមួយ" (កាឡ ៣,៣៧)។ ព្រះអង្គជាគំរូសម្រាប់អស់អ្នកដែលចង់ចេះទប់ខ្លួន។ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទទាំងអស់ឲ្យមានរបៀបរស់នៅ ដោយចេះទប់ខ្លួន តាមស្ថានភាពពិសេសរបស់គេ។ នៅពេលដែលជ្រមុជទឹក គ្រីស្តបរិស័ទបានសន្យារស់នៅក្នុងសេចក្តីស្រឡាញ់ដោយចេះទប់ចិត្ត។

២៣៤៩- "តាមស្ថានភាពរបស់ខ្លួន មនុស្សត្រូវទប់ខ្លួន ទៅជាអ្នកខ្លះព្រហ្មចារីយ៍ ឬញែកខ្លួនឲ្យនៅលីវជានិច្ចដែលជាមធ្យោបាយដ៏ប្រសើរ ដើម្បីថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ អ្នកខ្លះទៀត រស់នៅតាមច្បាប់សីលធម៌កំណត់ ដោយរួមរស់ជាមួយគ្នាជាគូស្វាមីភរិយា ឬនៅលីវ" (CDF)។ ព្រះជាម្ចាស់ត្រាស់ហៅគូស្វាមីភរិយាឲ្យចេះទប់ខ្លួន ក្នុងការរស់នៅជាគូស្វាមីភរិយា ឯអ្នកនៅលីវវិញ ព្រះអង្គក៏ត្រាស់ហៅគេឲ្យចេះទប់ខ្លួន ដោយតម

ការរួមសង្វាស៖

គុណធម៌នាំការចេះទប់ខ្លួនមានបី គឺមួយរបស់ភរិយា មួយរបស់ស្ត្រីមេម៉ាយ ទីបី គឺព្រហ្មចារីយភាព។ យើងមិនសរសើររបៀបណាមួយ ដោយមិនសរសើររបៀបឯទៀតៗ។ ហេតុនេះវិន័យរបស់ព្រះសហគមន៍ល្អប្រសើរណាស់ (សន្តៈ អំប្រ័រ)។

២៣៥០- ព្រះជាម្ចាស់ត្រាស់ហៅគូដណ្តឹង ទាំងសងខាងឲ្យចេះទប់ខ្លួន ដោយតមការរួមបវេណី។ គេនឹងយល់ឃើញថា បើគេទប់ខ្លួន គេនឹងគោរពគ្នាទៅវិញទៅមក គេនឹងស្គាល់ភក្តីភាព ដោយសង្ឃឹមថា នឹងទទួលគ្នាទៅវិញទៅមក ដោយសារព្រះជាម្ចាស់។ គេនឹងបំរុងទុកកាយវិការទន់ភ្លន់ ដែលបង្ហាញអំពីស្នេហាពិសេសចំពោះគ្នាទៅវិញទៅមក ក្រោយពេលរៀបអាពាហ៍ពិពាហ៍។ គេនឹងជួយគ្នាទៅវិញទៅមកឲ្យរីកចម្រើនក្នុងការចេះទប់ខ្លួន។

## អំពើបាបប្រឆាំងនឹងការចេះទប់ខ្លួន

២៣៥១- មនុស្សងប់ងល់នឹងកាមគុណ នៅពេលដែលគេភ្លើតភ្លើនប្រាថ្នាចង់បានការសប្បាយខាងផ្លូវភេទដោយឥតមានរបៀបរៀបរយ។ ការសប្បាយខាងផ្លូវភេទគ្មានរបៀបរៀបរយតាមសីលធម៌ នៅពេលដែលគេស្វែងរកការសប្បាយនេះ ដើម្បីការសប្បាយផ្ទាល់ ដោយគ្មានបំណងបង្កើតកូន ឬរួបរួមជាមួយអ្នកផ្សេងឡើយ។

២៣៥២- មនុស្សលេងប្រដាប់ភេទដោយខ្លួនឯង នៅពេលដែលគេស្រើបស្រាលអារម្មណ៍ផ្លូវភេទ ដោយចេតនា ដើម្បីបានសប្បាយខាងផ្លូវភេទ។ "តាមប្រពៃណីដែលនៅស្ថិតស្ថេរជានិច្ចនិរន្តរ៍ មេដឹកនាំព្រះសហគមន៍ព្រមទាំងគ្រីស្តបរិស័ទ អះអាងដោយមិនរួញរាថា ការលេងប្រដាប់ភេទដោយខ្លួនឯងជាការប្រព្រឹត្តផ្ទាល់ខ្លួន និងគ្មានរបៀបរៀបរយ"។ "ទោះជាមូលហេតុអ្វីក៏ដោយ ក៏ការប្រើប្រាស់ប្រដាប់ភេទ ដោយចេតនា ក្រៅពីការរួមរ័កជាគូស្វាមីភរិយា ជាអំពើប្រឆាំងនឹងគោលដៅនៃការរួមរ័ក"។ គេស្វែងរកការសប្បាយខាងផ្លូវភេទ ក្រៅពី "ទំនាក់ទំនងខាងផ្លូវភេទ ប្រកបដោយសីលធម៌ ដែលជាការផ្តល់ឲ្យគ្នាទៅវិញទៅមក និងការបង្កើតកូន ដោយសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដ" (CDF)។

- ដើម្បីឲ្យការវិនិច្ឆ័យបានត្រឹមត្រូវ ចំពោះការទទួលខុសត្រូវ ផ្នែកសីលធម៌របស់មនុស្សម្នាក់ៗ និងដើម្បីស្គាល់គោលបំណងរបស់ព្រះសហគមន៍ គេត្រូវគិតថា មានអ្នកខ្លះមិនទាន់ចាស់ទុំខាងផ្លូវចិត្ត មានទម្លាប់អាក្រក់ ឬអន្ទះអន្ទែង ឬកត្តាផ្សេងៗទៀតផ្នែកចិត្ត ឬសង្គម ដែលនាំឲ្យសីលធម៌របស់គេធ្លាក់ចុះ។

២៣៥៣- ការរួមសង្វាសក្រៅពីចំណងនៃអាពាហ៍ពិពាហ៍ រវាងបុរស និងស្ត្រីដែលនៅទំនេរប្រឆាំងខ្លាំងណាស់នឹងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស និងការរួមសង្វាសរបស់មនុស្ស ដើម្បីប្រយោជន៍របស់គូស្វាមីភរិយា ការបង្កើត និងការអប់រំកូន។ ម៉្យាងទៀត ការរួមភេទក្រៅចំណងនៃអាពាហ៍ពិពាហ៍ជារឿងអាស្រូវនៅពេលដែលទាក់ទងនឹងយុវជន។

២៣៥៤- រឿងអាសអាភាស លាតត្រដាងដោយចេតនានូវការរួមរ័ក (ពិតប្រាកដ ឬក្លែងក្លាយ) របស់ដៃគូដើម្បីឲ្យអ្នកដទៃឃើញ។ រឿងអាសអាភាសប្រឆាំងនឹងការចេះទប់ខ្លួន ដែលជាការបង្ខូចលក្ខណៈនៃការរួមសង្វាសជាគូស្វាមីភរិយា ដែលជាការប្រគល់ខ្លួនយ៉ាងស្និទ្ធស្នាលរបស់គូស្វាមីភរិយាចំពោះគ្នាទៅវិញទៅមក។ រឿងអាសអាភាសបង្ខូចឋានៈដ៏ថ្លៃថ្នូររបស់អស់អ្នកដែលប្រតិបត្តិតាម (តួរ អ្នកជំនួញ អ្នកមើល) ដ្បិតម្នាក់ៗក្លាយទៅជាវត្ថុសប្បាយចំពោះអ្នកដទៃ និងនាំឲ្យមានផលចំណេញខុសច្បាប់។ អ្នកទាំងនោះហាក់ដូចជានៅក្នុងពិភពក្លែងក្លាយ។ រឿងអាសអាភាសជាអំពើបាបធ្ងន់ធ្ងរ។ រដ្ឋអំណាចត្រូវឃាត់មិនឲ្យគេផលិត និងចែកសម្ភារៈ

ទាក់ទងនឹងរឿងអាសអាភាស។

២៣៥៥- ពេស្យាចារ បង្ខូចឋានៈដ៏ថ្លៃថ្នូររបស់អ្នកដែលលក់ខ្លួន ដែលហាក់ដូចជាវត្ថុសប្បាយម្យ៉ាង។ អ្នកដែលបង់ថ្លៃប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរប្រឆាំងនឹងខ្លួនឯង គឺគេមិនចេះទប់ខ្លួន ផ្ដាច់ពាក្យសន្យានៃពិធីជ្រមុជទឹក និងបង្ខូចរូបកាយរបស់ខ្លួន ដែលជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (១ករ៦,១៥-២០)។ ពេស្យាចារជាអម្រែតនាំឲ្យសង្គមអាប់ឱន។ ជាធម្មតា ស្ដ្រីជាពេស្យា ប៉ុន្ដែ អាចមានបុរស កូនក្មេង និងក្មេងវ័យជំទង់ផងដែរ (ក្នុងករណីចុងក្រោយទាំងពីរនោះ មានអំពើបាបផង រឿងអាស្រូវផង)។ ទោះបីពេស្យាចារតែងតែជាអំពើបាបក៏ដោយ ក៏ភាពវេទនា គម្រាមកំហែង ការគាបសង្កត់របស់សង្គមអាចជួយដោះសារអ្នកប្រព្រឹត្តអំពើនេះ។

២៣៥៦- គេហៅការរំលោភ ការរួមភេទជាមួយនរណាម្នាក់ ដោយប្រើអំពើហិង្សា។ ការរំលោភប្រឆាំងនឹងយុត្តិធម៌ និងសេចក្ដីស្រឡាញ់។ ការរំលោភបង្ខូចមនុស្សគ្រប់រូប ដែលមានសិទ្ធិឲ្យត្រូវគេគោរព ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត និងសេរីភាព។ ការរំលោភអាចបង្ខូចអ្នករងគ្រោះអស់មួយជីវិត។ ការរំលោភជាអំពើបាបផ្ទាល់។ បើឪពុកម្ដាយ (សូមអានអំពីការស្មន់) ឬគ្រូអប់រំ ជាអ្នករំលោភកូនក្មេង ដែលយើងបានប្រគល់ឲ្យគេ គេធ្វើអំពើបាបធ្ងន់ធ្ងរណាស់។

## ការចេះទប់ខ្លួន និងលក្ខណៈនៃអ្នកស្រឡាញ់ភេទដូចគ្នា

២៣៥៧- លក្ខណៈនៃអ្នកស្រឡាញ់ភេទដូចគ្នាសំដៅទៅលើទំនាក់ទំនងរវាងបុរស ឬស្ដ្រី ដែលមានបំណងប្រាថ្នាចង់រួមរ័កចំពោះមនុស្សភេទដូចគ្នា។ ពួកមនុស្សប្រភេទនេះមានរបៀបខុសប្លែកពីគ្នាខ្លាំងណាស់តាមសម័យកាល និងតាមវប្បធម៌។ យើងមិនទាន់ចេះពន្យល់អំពីមូលហេតុនៃលក្ខណៈចិត្តសាស្ដ្រនេះបានឡើយ។ តាមព្រះគម្ពីរដ៏វិសុទ្ធ លក្ខណៈនេះជាអំពើសៅហ្មងដ៏ធ្ងន់ធ្ងរ (កណ១៩,១-២៩ ; រម ១,២៤-២៧ ; ១ករ ៦,៩ ; ១ធម ១,១០)។ ដោយអាងលើព្រះគម្ពីរ ការបញ្ញូនបន្ដតែងតែប្រកាសថា "ការរួមសង្វាសនឹងភេទដូចគ្នាមានលក្ខណៈផ្ទាល់ឥតរបៀបរៀបរយ" (CDF) ជាអំពើប្រឆាំងនឹងធម្មវិន័យធម្មជាតិ។ អំពើទាំងអស់នោះមិនផ្ដល់ជីវិតឡើយ។ មិនមែនជាការបំពេញគ្នាខាងផ្លូវភេទ និងខាងផ្លូវចិត្តយ៉ាងពិតប្រាកដឡើយ។ ទោះជាយ៉ាងណា ក៏យើងមិនយល់ស្របដែរ។

២៣៥៨- បុរស និងស្ដ្រីមិនតិចទេ ដែលចង់រួមរ័កជាមួយមនុស្សភេទដូចគ្នា។ ពួកគេមិនជ្រើសរើសលក្ខ័ណៈទេ ដែលនាំឲ្យគេភាគច្រើនរងទុក្ខលំបាក។ ត្រូវទទួលពួកគេដោយគោរព ដោយធម៌មេត្ដាករុណា និងដោយយកចិត្តទុកដាក់។ ត្រូវចៀសវាងកុំរើសអើងឡើយ។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់នោះឲ្យសម្រេចព្រះហឫទ័យរបស់ព្រះអង្គក្នុងជីវិតរបស់គេ ហើយប្រសិនបើអ្នកនោះជាគ្រីស្ដបរិស័ទ ព្រះអង្គក៏ត្រាស់ហៅឲ្យបង្រួបបង្រួមទុក្ខលំបាកទាំងប៉ុន្មាន ដែលគេជួបប្រទះ ដោយសារលក្ខណៈរបស់ខ្លួន ក្នុងសក្ការបូជារបស់ព្រះអម្ចាស់នៅលើឈើឆ្កាង។

២៣៥៩- ព្រះជាម្ចាស់ត្រាស់ហៅមនុស្ស ដែលស្រឡាញ់ភេទដូចគ្នានេះ ឲ្យចេះទប់ខ្លួន។ ដោយសារការគ្រប់គ្រងលើខ្លួនឯង ដោយសារសេរីភាពខាងក្នុង ជួនកាលដោយមានមិត្តភ័ក្ដជួយគាំទ្រផង ដោយអធិដ្ឋានផង ដោយព្រះអំណោយទាននៃអគ្គសញ្ញាផង និងដោយប្ដេជ្ញាចិត្ត គេអាចទៅជាមនុស្សគ្រប់លក្ខណ៍បន្ដិចម្ដងៗ។

## ៣. សេចក្ដីស្រឡាញ់របស់គូស្វាមីភរិយា

២៣៦០- ជីវិតខាងផ្លូវភេទស្ថិតក្រោមសេចក្ដីស្រឡាញ់របស់បុរស និងស្ត្រីជាគូស្វាមីភរិយា។ ក្នុងជីវិតជាគូស្រករ ការរួមបវេណីយ៉ាងស្និទ្ធស្នាលរបស់គូស្វាមីភរិយាក្លាយទៅជាសញ្ញាសម្គាល់ និងកិច្ចសន្យាបញ្ជាក់ថាគូស្វាមីភរិយាមានវិញ្ញាណរួបរួមគ្នា។ អគ្គសញ្ញាធ្វើឲ្យចំណងនៃអាពាហ៍ពិពាហ៍រវាងគ្រីស្តបរិស័ទបានវិសុទ្ធ។

២៣៦១- "ជីវិតខាងផ្លូវភេទ ដែលបុរសនិងស្ត្រីប្រគល់គ្នាទៅវិញទៅមក ដោយការរួមរ័ក មិនមែនជាសភាពជីវសាស្ត្រសុទ្ធសាធទេ ប៉ុន្តែជាសភាពស្និទ្ធស្នាលបំផុតរវាងមនុស្ស និងមនុស្ស។ ជីវិតខាងផ្លូវភេទមានលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដ លុះត្រាតែមានលក្ខណៈជាសេចក្ដីស្រឡាញ់យ៉ាងជ្រាលជ្រៅ ដែលបុរស និងស្ត្រីប្រគល់ខ្លួនទាំងស្រុងចំពោះគ្នាទៅវិញទៅមករហូតដល់ថ្ងៃស្លាប់" (FC ១១)។

> លោកតូប៊ីពោលទៅកាន់នាងសារ៉ាថា៖ "ក្រោកឡើងអូន! យើងនាំគ្នាអធិដ្ឋាន ទូលអង្វរព្រះអម្ចាស់នៃយើង សូមព្រះអង្គអាណិតមេត្តា និងសង្គ្រោះយើងផង!"។ នាងក្រោកឡើង ហើយអ្នកទាំងពីរនាំគ្នាអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គសង្គ្រោះពួកគេ។ លោកតូប៊ីយ៉ាទូលអង្វរថា៖ "បពិត្រព្រះជាម្ចាស់នៃបុព្វបុរសរបស់យើងខ្ញុំ! យើងខ្ញុំសូមលើកតម្កើងព្រះអង្គ! សូមឲ្យមនុស្សគ្រប់ជំនាន់ ក្រោយៗទៀត នាំគ្នាលើកតម្កើងព្រះនាមរបស់ព្រះអង្គ ជាដរាបតរៀងទៅ។ សូមឲ្យផ្ទៃមេឃនិងអ្វីៗសព្វសារពើនៅលើផែនដីនេះ នាំគ្នាលើកតម្កើងព្រះអង្គ អស់កល្បជាអង្វែងតរៀងទៅ! ព្រះអង្គបានបង្កើតលោកអដាំ ហើយព្រះអង្គក៏បានបង្កើតនាងអេវ៉ាជាភរិយាឲ្យជួយ និងបានជាគ្នា គឺអ្នកទាំងពីរនេះហើយ ដែលផ្ដល់កំណើតឲ្យមនុស្សជាតិ។ ព្រះអង្គមានព្រះបន្ទូលថា៖ បើមនុស្សប្រុសនៅតែឯងដូច្នេះ មិនស្រួលទេ! យើងនឹងបង្កើតម្នាក់ទៀតឲ្យជួយ និងបានជាគ្នា។ បពិត្រព្រះអម្ចាស់ ឥឡូវនេះ ខ្ញុំរៀបការជាមួយនាង មិនមែនមានបំណងបំពេញតណ្ហាទេ គឺដើម្បីឲ្យស្របតាមធម្មវិន័យ! ហេតុនេះសូមទ្រង់ព្រះមេត្តាអាណិតអាសូរដល់យើងខ្ញុំទាំងពីរនាក់! សូមឲ្យយើងខ្ញុំទាំងពីរនាក់ បានរស់នៅជាមួយគ្នារហូតដល់ចាស់ជរាផង!"។ បន្ទាប់មកអ្នកទាំងពីរឆ្លើយព្រមគ្នាថា៖ "អាម៉ែន! អាម៉ែន!" ហើយក៏រួមដំណេកជាមួយគ្នា នៅយប់នោះទៅ (តប ៨,៤-៩)។

២៣៦២- "កាយវិការទាំងប៉ុន្មាន ដែលគូស្វាមីភរិយាប្រព្រឹត្ត ដោយសេចក្ដីស្នេហាដ៏បរិសុទ្ធនោះ ពិតជាកិច្ចដ៏ល្អប្រកបដោយគុណធម៌ និងសមរម្យថ្លៃថ្នូរទៀតផង។ ប្រសិនបើគូស្វាមីភរិយាស្នេហាគ្នាតាមលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដ កាយវិការទាំងនោះ ទៅជាសញ្ញាសម្គាល់បង្ហាញអំពីការប្រគល់ខ្លួនទៅវិញទៅមក និងជួយសម្រួលការប្រគល់ខ្លួននោះទៀតផង" (GS ៤៩,២)។ ជីវិតខាងផ្លូវភេទជាប្រភពនៃអំណរសប្បាយ៖

> ព្រះបង្កើត (...) បានសម្រេចដោយផ្ទាល់ព្រះអង្គថា ក្នុងការបង្កើតកូន គូស្វាមីភរិយាបានសប្បាយទាំងផ្លូវកាយផង ផ្លូវវិញ្ញាណផង។ ដូច្នេះ គូស្វាមីភរិយាមិនធ្វើអ្វីអាក្រក់ ដោយស្វែងរកការសប្បាយនេះ និងដោយបំពេញកិច្ចការនោះ។ គេសុខចិត្តធ្វើតាមអ្វីដែលព្រះបង្កើតបានតម្រង់ទិសទុកឲ្យគេ។ ក៏ប៉ុន្តែគូស្វាមីភរិយាត្រូវតែចេះទប់ខ្លួន ដោយកំណត់ព្រំដែនត្រឹមត្រូវ (សម្ដេចប៉ាប ពីយូសទី១២)។

២៣៦៣-ដោយគូស្វាមីភរិយារួមរស់ជាមួយគ្នា ពួកគេបំពេញគោលដៅទាំងពីរនៃអាពាហ៍ពិពាហ៍ គឺប្រយោជន៍របស់គូស្វាមីភរិយាផ្ទាល់ និងការបន្តជីវិត។ យើងមិនអាចបំបែកអត្ថន័យទាំងពីរ ឬគុណសម្បត្តិនៃអាពាហ៍ពិពាហ៍នោះ ដោយមិនបង្ខូចជីវិតខាងវិញ្ញាណរបស់គូស្វាមីភរិយា ឬផលប្រយោជន៍របស់គូស្វាមីភរិយា និងអនាគតក្រុមគ្រួសារបានឡើយ។

- ហេតុនេះ សេចក្ដីស្រឡាញ់របស់បុរស និងស្ត្រីជាគូស្វាមីភរិយាទាមទារឲ្យគូស្រករមានចិត្តភក្ដី និងបង្កើតផល។

## ភក្ដីភាពរបស់គូស្វាមីភរិយា

២៣៦៤- "គូស្វាមីភរិយាពិតជាសហគមន៍ដ៏ជិតស្និទ្ធម៉្យាង ដោយអ្នកទាំងពីររួមរស់ជាមួយគ្នានិងស្រឡាញ់គ្នា។ ព្រះបង្កើតតែងតាំងសហគមន៍នេះ និងប្រទានវិន័យសម្រាប់សហគមន៍នេះផ្ទាល់ ជាសហគមន៍សង់ឡើងលើសម្ពន្ធមេត្រីរវាងគូស្វាមីភរិយា គឺអ្នកទាំងពីរសន្យាថា ម្នាក់ៗយល់ព្រមរស់នៅជាគូស្វាមីភរិយា។ ពាក្យសន្យានេះពុំអាចរលុបបានឡើយ" (GS ៤៨,១)។ អ្នកទាំងពីរប្រគល់គ្នាទាំងស្រុង និងជាស្ពានចំពោះគ្នាទៅវិញទៅមក។ គេមិនមែនជាបុគ្គលពីរនាក់ទៀតទេ គឺជារូបកាយតែមួយ។ សម្ពន្ធមេត្រី ដែលគូស្វាមីភរិយាបានចងដោយស្ម័គ្រចិត្ត ទាមទារឲ្យពួកគេរួបរួមគ្នា មិនអាចបំបែកពីគ្នាបានឡើយ (CIC ១០៥៦)។"មនុស្សមិនត្រូវបំបាក់បំបែកគូស្រករ ដែលព្រះជាម្ចាស់បានផ្សំផ្គុំនោះឡើយ" (មក ១០,៩) (មថ ១៩,១-១២ ; ១ករ ៧,១០-១១)។

២៣៦៥- អ្នកស្មោះភក្ដីសម្ដែងថា គេគោរពតាមពាក្យដែលបានសន្យា។ ព្រះជាម្ចាស់មិនដែលបំភ្លេចព្រះបន្ទូលសន្យាទេ។ អគ្គសញ្ញាអាពាហ៍ពិពាហ៍បញ្ចូលបុរស និងស្ត្រីក្នុងភក្ដីភាពរបស់ព្រះគ្រីស្ដចំពោះព្រះសហគមន៍ព្រះអង្គ។ ដោយចេះទប់ខ្លួន គូស្វាមីភរិយាផ្ដល់សក្ខីភាពអំពីគម្រោងការដ៏អស្ចារ្យនេះចំពោះពិភពលោក។

> សន្តៈ យ៉ូហាន គ្រីសូស្ដូមបញ្ចេញគំនិតថា កូនកំលោះគួរថ្លែងទៅកាន់កូនក្រមុំដោយពាក្យសម្ដីនេះ៖ "បងបានឱបអូន ហើយបងស្រឡាញ់អូន បងស្រឡាញ់អូនខ្លាំងជាងជីវិតបងទៅទៀត ដ្បិតជីវិតក្នុងលោកនេះ គ្មានតម្លៃសោះ ហើយបងស្រមៃចង់នៅជាមួយអូនអស់មួយជីវិតនេះ ទើបយើងអាចដឹងច្បាស់ថាយើងនឹងមិនបែកពីគ្នាក្នុងជីវិតខាងបរមលោកទេ (...)។ បងស្រឡាញ់អូនលើសអ្វីៗទាំងអស់ ហើយគ្មានអ្វីពិបាកជាងការមិនដឹងចិត្តអូនឡើយ"។

## សមិទ្ធិផលរបស់គូស្វាមីភរិយា

២៣៦៦- សមិទ្ធិផលជាព្រះអំណោយទាន ជាទីដៅមួយនៃអាពាហ៍ពិពាហ៍ ដ្បិតជាធម្មតា សេចក្ដីស្រឡាញ់របស់គូស្វាមីភរិយាបង្កើតផល។ កូនមិនមែនមកពីខាងក្រៅបន្ថែមខ្លួនដល់សេចក្ដីស្រឡាញ់របស់គូស្វាមីភរិយាចំពោះគ្នាទៅវិញទៅមក។ កូនផុសចេញមកពីការប្រគល់គ្នាទៅវិញទៅមកផ្ទាល់ ជាផលនៃការប្រគល់គ្នានេះ។ ហេតុនេះ ព្រះសហគមន៍ "ដែលការពារជីវិត" (FC ៣០) ប្រៀនប្រដៅថា "កិច្ចជាគូស្វាមីភរិយាត្រូវតែសុខចិត្តបន្តជីវិត" (HV ១១)។ "មេដឹកនាំព្រះសហគមន៍បានថ្លែងជាច្រើនដងហើយថា សិទ្ធិនេះ ចាក់ឫសលើចំណងរវាងអត្ថន័យទាំងពីរនៃកិច្ចជាគូស្វាមីភរិយា គឺឲ្យគូស្វាមីភរិយារួមរស់ជាមួយគ្នា និងឲ្យគេបន្តពូជ។ តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ចំណងនេះ មិនអាចបំបែកបានទេ ហើយមនុស្សមិនអាចបំបែកចំណងនេះដោយផ្ទាល់បានឡើយ" (HV ១២)។

២៣៦៧- ព្រះជាម្ចាស់ត្រាស់ហៅគូស្វាមីភរិយាឲ្យផ្ដល់ជីវិត គឺពួកគេចូលរួមចំណែកក្នុងឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ជាព្រះបង្កើត និងជាព្រះបិតាផង (អភ ៣,១៤ ; មថ ២៣,៩)។ "គូស្វាមីភរិយាមានភារកិច្ចបន្តជីវិតហើយអប់រំកូន ដោយផ្ទាល់។ ត្រូវចាត់ទុកថា ភារកិច្ចនេះជាបេសកកម្មផ្ទាល់របស់អ្នកទាំងពីរ។ គូស្វាមីភរិយាដឹងខ្លួនថា គេជាសហការីរបស់ព្រះជាម្ចាស់ ជាព្រះបង្កើត ហាក់ដូចជាបកស្រាយព្រះហឫទ័យនេះឲ្យអ្នកដទៃស្គាល់។ ហេតុនេះហើយ បានជាគេត្រូវបំពេញបន្ទុកបន្តពូជ ទាំងទទួលការខុសត្រូវក្នុងឋានៈជាមនុស្សផង និងជាគ្រីស្ត

បរិស័ទផង" (GS ៥០,២)។

២៣៦៨- ចំណុចពិសេសនៃការទទួលខុសត្រូវនេះទាក់ទងនឹងការពន្យារកំណើត។ គូស្វាមីភរិយាអាចចង់ពន្យារកំណើត ដើម្បីមូលហេតុត្រឹមត្រូវ។ ពួកគេត្រូវតែពិនិត្យថា បំណងប្រាថ្នារបស់គេ មិនមែនមកពីគេគិតតែអំពីខ្លួនឯងទេ ប៉ុន្តែ មកពីគេចង់ធ្វើជាឪពុកម្ដាយ ដោយទទួលការខុសត្រូវ និងដោយមានចិត្តទូលំទូលាយ។ ម្យ៉ាងទៀត គេនឹងមានឥរិយាបទស្របតាមទិសដៅនៃសីលធម៌៖

> ពេលគូស្វាមីភរិយាត្រូវសម្រួលស្នេហានឹងការបន្តជីវិត ក្នុងឋានៈជាអ្នកទទួលខុសត្រូវនោះ ត្រូវនឹកគិតថា ចរិយាសីលធម៌ មិនអាស្រ័យតែលើចិត្តគំនិតដ៏ស្មោះត្រង់របស់គេ ឬមិនអាស្រ័យលើការថ្លឹងថ្លែងមូលហេតុផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែត្រូវសម្រេចតាមលក្ខណៈធម្មជាតិរបស់បុគ្គល និងការប្រព្រឹត្តរបស់គេទៅវិញ ដែលជាលក្ខ័ណនៃការគោរពអត្ថន័យស្នេហារបស់គូស្វាមីភរិយា ដែលប្រគល់ខ្លួនឲ្យគ្នាទៅវិញទៅមក និងអត្ថន័យនៃកិច្ចបន្តជីវិត ស្របតាមលក្ខណៈខ្លួនគេជាមនុស្ស ក្នុងបរិយាកាសនៃសេចក្ដីស្រឡាញ់យ៉ាងពិតប្រាកដ។ ប្រសិនបើគូស្វាមីភរិយាមិនចេះទប់ខ្លួនដោយចិត្តស្មោះទេ គេមិនអាចសម្រេចផែនការនេះឡើយ (GS ៥១, ៣)។

២៣៦៩-"ដោយរក្សាលក្ខណៈសំខាន់ៗទាំងពីរនោះ គឺការរួមរស់ជាមួយគ្នា និងការបន្តពូជ កិច្ចជាគូស្វាមីភរិយានៅតែរក្សាអត្ថន័យទាំងស្រុងជាសេចក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមកយ៉ាងពិតប្រាកដ ដែលមានទីដៅដ៏ខ្ពង់ខ្ពស់បំផុតឲ្យមនុស្សទៅជាឪពុក" (HV ១២)។

២៣៧០- ការតមរួមភេទតាមរដូវ របៀបពន្យារកំណើត ដែលស្ថិតនៅលើការមើលឃើញខ្លួនឯង និងការរួមបវេណីនៅគ្រាដែលមិនអាចបង្កើតផល (HV ១៦) ស្របតាមលក្ខណៈដែលប្រកែកមិនបាននៃសីលធម៌។ វិធីសាស្ត្រទាំងនោះ គោរពរូបកាយរបស់គូស្វាមីភរិយា ជំរុញឲ្យមានភាពទន់ភ្លន់ យល់ចិត្តគ្នា និងនាំឲ្យស្គាល់សេរីភាពយ៉ាងពិតប្រកាដ។ក៏ប៉ុន្តែ"សកម្មភាពណា មានគោលដៅ ឬជាមធ្យោបាយ មិនអាចបន្តពូជ មានលក្ខណៈផ្ទាល់ជាសកម្មភាពអាក្រក់ ដែលអាចមានមុន ឬក្រោយពេលគូស្វាមីភរិយារួមបវេណី" (HV ១៤)។

ជាធម្មតាពាក្យថា គូស្វាមីភរិយាប្រគល់ខ្លួនទាំងស្រុងចំពោះគ្នាទៅវិញទៅមក ប៉ុន្តែ ការពន្យារកំណើត ដែលមានលក្ខណៈផ្ទុយ ដោយប្រកែកមិនបាន គឺនៅពេលនោះ ពួកគេមិនប្រគល់ខ្លួនទាំងស្រុងចំពោះគ្នាទៅវិញទៅមកដូចសម្ដី។ ពួកគេមិនគ្រាន់តែបដិសេធមិនព្រមផ្ដល់ជីវិតទេ ថែមទាំងកុហកសេចក្ដីពិតខាងក្នុងនៃសេចក្ដីស្រឡាញ់ជាគូស្វាមីភរិយា ដែលសម្ដែងថា មនុស្សម្នាក់ៗត្រូវប្រគល់ខ្លួនឯងទាំងស្រុង។ ការពន្យារកំណើត ដោយប្រើមធ្យោបាយធម្មជាតិប្លែកពីគ្នា បើគិតអំពីលក្ខណៈជាមនុស្ស និងអំពីសីលធម៌ ឆ្លុះបញ្ចាំងគំនិតពីរយ៉ាងអំពីមនុស្ស និងជីវិតខាងផ្លូវភេទ ដែលមិនអាចសម្រួលគ្នាបានឡើយ (FC ៣២)។

២៣៧១- "សូមឲ្យមនុស្សទាំងអស់ជ្រាបយ៉ាងច្បាស់ថា មិនត្រូវនឹកគិតអំពីជីវិតមនុស្ស និងអំពីបន្ទុកបន្តពូជនោះ ត្រឹមតែនៅលោកនេះប៉ុណ្ណោះទេ ហើយក៏គ្មានទំហំ និងអត្ថន័យយ៉ាងពេញលេញត្រឹមតែក្នុងលោកនេះដែរ។ ត្រូវរិះគិតអំពីជីវិតមនុស្ស និងបន្ទុកនៃការបន្តពូជ ដោយនឹកជានិច្ចដល់វាសនាអស់កល្បជានិច្ចរបស់មនុស្សវិញ " (GS ៥១,៤)។

២៣៧២- រដ្ឋអំណាចទទួលខុសត្រូវចំពោះសេចក្ដីសុខសាន្តរបស់ប្រជាពលរដ្ឋ។ ហេតុនេះ រដ្ឋអំណាចមានសិទ្ធិធ្វើអន្តរាគមន៍ ដើម្បីតម្រូវចំនួនរបស់មនុស្ស។ រដ្ឋអំណាចអាចធ្វើអន្តរាគមន៍ ដោយផ្ដល់ព័ត៌មាន ដែលប្រកែកមិនបាន និងដោយគោរព ប៉ុន្តែ រដ្ឋអំណាចមិនអាចធ្វើអន្តរាគមន៍តាមរបៀបផ្ដាច់ការ ឬដោយការបង្ខិតបង្ខំឡើយ។

រដ្ឋអំណាចមិនអាចជំនួសគូស្វាមីភរិយា ដែលជាអ្នកទទួលខុសត្រូវដំបូងនៃការបន្តពូជ និងការអប់រំកូនរបស់គេទេ (HV ២៣ ; PP ៣៧)។ រដ្ឋអំណាចគ្មានសិទ្ធិជំរុញឲ្យប្រើមធ្យោបាយពន្យារកំណើតខុសសីលធម៌បានឡើយ។

## កូនជាព្រះអំណោយទាន

២៣៧៣- ព្រះគម្ពីរដ៏វិសុទ្ធ និងប្រពៃណីព្រះសហគមន៍យល់ឃើញថា ក្រុមគ្រួសារដែលមានកូនច្រើន ជាសញ្ញាសម្គាល់ថា ព្រះជាម្ចាស់ប្រទានពរ ហើយឪពុកម្ដាយមានចិត្តទូលាយផងដែរ (GS ៥០,២)។

២៣៧៤- គូស្វាមីភរិយា ដែលយល់ឃើញថា មិនអាចបន្តពូជ ឈឺចាប់ខ្លាំងណាស់។ លោកអប្រាមទូលអង្វរព្រះជាម្ចាស់ថា៖ "បពិត្រព្រះជាអម្ចាស់ ទ្រង់ប្រទានអ្វីមកទូលបង្គំ ក៏ឥតប្រយោជន៍ដែរ ព្រោះទូលបង្គំនឹងលាចាកលោកនេះទៅ ទាំងគ្មានកូន" (កណ ១៥,២)។ លោកស្រីរ៉ាខែលស្រែកអង្វរលោកយ៉ាកុបជាស្វាមីថា៖ "សូមឲ្យខ្ញុំមានកូនផង បើមិនដូច្នោះទេ ខ្ញុំមុខជាស្លាប់មិនខាន" (កណ ៣០,១)។

២៣៧៥- ត្រូវតែលើកទឹកចិត្តដល់ការស្រាវជ្រាវ ដែលមានគោលដៅក្នុងការជួយព្យាបាលបុរស និងស្ត្រីអារក្នុងករណីដែលការស្រាវជ្រាវនោះ "បម្រើមនុស្ស បម្រើសិទ្ធិរបស់គេដែលមិនអាចលក់ទិញបាន ហើយបម្រើផលប្រយោជន៍ទាំងស្រុង និងយ៉ាងពិតប្រាកដរបស់គេ ស្របតាមគម្រោងការ និងព្រះហឫទ័យរបស់ព្រះជាម្ចាស់" (CDF)។

២៣៧៦- បច្ចេកទេស ដែលធ្វើឲ្យលក្ខណៈជាមាតាបិតាបែកចេញពីគ្នា ដោយសារអន្តរាគមន៍របស់អ្នកផ្សេង (ការផ្ដល់ទឹកកាម ឬការផ្ដល់បុប្ផាណ្ឌ ឬការខ្ចីស្បូន) ជាកិច្ចដែលគ្មានគុណធម៌សោះ។ បច្ចេកទេសនោះ (ការបញ្ចូល និងពហុផលសិប្បនិម្មិត ដែលមកពីអ្នកផ្សេង) បង្ខូចសិទ្ធិរបស់កូន ដែលនឹងកើតពីឪពុកម្ដាយ ដែលខ្លួនស្គាល់ និងដែលភ្ជាប់គ្នាដោយចំណងនៃអាពាហ៍ពិពាហ៍។ បច្ចេកទេសនោះក្បត់ "សិទ្ធិផ្ដាច់មុខឲ្យក្លាយទៅជាបិតាតាមរយៈមាតា និងក្លាយទៅជាមាតាតាមរយៈបិតាតែប៉ុណ្ណោះ" (CDF)។

២៣៧៧- យើងមិនអាចផ្ដន្ទាទោសគូស្វាមីភរិយាខ្លាំងពេកទេ ក្នុងពេលដែលពួកគេប្រើបច្ចេកទេសទាំងអស់នោះ (ការបញ្ចូល និងពហុផលសិប្បនិម្មិត ដែលមកពីមាតាបិតាពិតប្រាកដ) ប៉ុន្តែ បច្ចេកទេសនោះ មិនស្របតាមសីលធម៌ឡើយ។ បច្ចេកទេសនោះ បំបែកការរួមភេទ ពីការបន្តពូជ។ កិច្ចគ្រឹះនៃការរស់នៅរបស់កូន លែងទៅជាកិច្ចការ ដែលពីរនាក់ប្រគល់គ្នាទៅវិញទៅមកទៀតទេ ប៉ុន្តែ "គឺត្រូវពេទ្យ និងជីវវិទូទៅវិញទេ ដែលជាអ្នកប្រគល់ជីវិត និងអត្តសញ្ញាណនៃក្សូណ ដែលជាហេតុធ្វើឲ្យបច្ចេកទេសគ្រប់គ្រងលើប្រភព និងវាសនារបស់មនុស្ស។ ទំនាក់ទំនងនៃការគ្រប់គ្រងបែបនេះ មានលក្ខណៈប្រឆាំងផ្ទាល់នឹងកិត្តិយសដ៏ថ្លៃថ្នូរ និងស្មើគ្នារបស់ឪពុកម្ដាយ និងកូន" (CDF)។ "នៅពេលដែលយើងមិនចង់ឲ្យកិច្ចជាគូស្វាមីភរិយាបន្តពូជ ពោលគឺកាយវិការពិសេសរបស់គូស្វាមីភរិយាដែលរួមរស់ជាមួយគ្នា ការបន្តពូជនេះ គ្មានលក្ខណៈផ្ទាល់របស់ខ្លួនឡើយ (...)។ មានតែនៅពេលដែលយើងគោរពចំណងរវាងអត្ថន័យនៃកិច្ចជាគូស្វាមីភរិយា និងឯកភាពរបស់មនុស្សទេ ទើបការបន្តពូជស្របតាមកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស" (CDF)។

២៣៧៨- គូស្វាមីភរិយាគ្មានសិទ្ធិទាមទារ ឲ្យមានកូន ព្រោះកូនជាព្រះអំណោយទាន របស់ព្រះជាម្ចាស់។ "ព្រះអំណោយទានដ៏ល្អប្រសើរបំផុតរបស់អាពាហ៍ពិពាហ៍"ជាមនុស្សម្នាក់។យើងមិនអាចចាត់ទុកថាកូនដូចជាវត្ថុដែលជាកម្មសិទ្ធិមួយឡើយ។ បើគិតដូច្នោះ ត្រូវតែទទួលស្គាល់ "សិទ្ធិទាមទារឲ្យមានកូន"។ ក្នុងវិស័យនេះមានតែកូនទេ ដែលមានសិទ្ធិយ៉ាងពិតប្រាកដ គឺសិទ្ធិដែលជាផលដ៏ពិសេសនៃសេចក្ដីស្រឡាញ់ របស់ឪពុកម្ដាយវា

ព្រមទាំងសិទ្ធិ ដែលត្រូវគេគោរពដូចមនុស្សម្នាក់តាំងពីក្នុងផ្ទៃម្ដាយមកម្ល៉េះ" (CDF)។

២៣៧៩- ដំណឹងល្អបង្ហាញឲ្យយើងដឹងថា ទោះបីស្វាមីភរិយាមិនអាចបន្តពូជយ៉ាងណាក៏ដោយ ក៏គេអាចផ្ដល់អត្ថន័យថ្មីដល់ជីវិតដែរ។ ក្រោយពីបានព្យាយាមព្យាបាលខ្លួនគេ តាមរបៀបត្រឹមត្រូវ គូស្វាមីភរិយា ដែលនៅតែមិនអាចបន្តពូជ នឹងរួបរួមជាមួយព្រះអម្ចាស់នៅលើឈើឆ្កាង ដែលជាប្រភពនៃសមិទ្ធផលខាងវិញ្ញាណ។ គេអាចបង្ហាញថា គេមានចិត្តទូលាយ ដោយយកកូនកំព្រាមកចិញ្ចឹម ឬដោយជួយបម្រើអ្នកដទៃ។

## ៤. អំពើបាបប្រឆាំងនឹងកិត្តិយសនៃថ្លៃថ្នូរជាគូស្វាមីភរិយា

២៣៨០- អំពើផិតក្បត់។ ពាក្យនេះ មានន័យថា គូស្វាមីភរិយាគ្មានភក្ដីភាព។ អំពើផិតក្បត់ គឺនៅពេលដែលដៃគូទាំងពីរ ដែលយ៉ាងហោចណាស់មានម្នាក់បានរៀបការរួចហើយ រួមសង្វាសជាមួយគ្នា ទោះជារយៈពេលខ្លីក៏ដោយ។ ព្រះគ្រីស្ដផ្ដន្ទាទោសអំពើផិតក្បត់ ទោះជាការប៉ុនប៉ងក៏ដោយ (មថ ៥,២៧-២៨)។ វិន័យទីប្រាំមួយ និងសម្ពន្ធមេត្រីថ្មីហាមប្រាមអំពើផិតក្បត់ជាដាច់ខាត (មថ ៥,៣២ ; ១៩,៦ ; មក ១០,១១ ; ១ករ ៦,៩-១០)។ ពួកព្យាការីប្រកាសថា ជាអំពើបាបធ្ងន់ធ្ងរ ហើយយល់ឃើញថា អំពើផិតក្បត់មានទោសស្មើនឹងការគោរពព្រះក្លែងក្លាយ (ហស ២,៧ ; យរ ៥,៧ ; ១៣,២៧)។

២៣៨១- អំពើផិតក្បត់ជាអំពើអយុត្តិធម៌។ នរណាប្រព្រឹត្តអំពើផិតក្បត់ អ្នកនោះមិនគោរពពាក្យសន្យារបស់ខ្លួន។ គេបង្ខូចចំណងជាគូស្វាមីភរិយា ដែលជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រី បំពានសិទ្ធិរបស់គូស្រករ និងបង្ខូចអាពាហ៍ពិពាហ៍ ដោយរំលោភកិច្ចសន្យា ដែលជាគ្រឹះនៃអាពាហ៍ពិពាហ៍។ គេអាចធ្វើឲ្យកូន ដែលត្រូវការឲ្យឪពុកម្ដាយរួបរួមគ្នាយ៉ាងសុខសាន្ត ត្រូវគេរបួស។

### ការលែងលះគ្នា

២៣៨២- ព្រះអម្ចាស់យេស៊ូសង្កត់ធ្ងន់លើគម្រោងការដើមដំបូងរបស់ព្រះបង្កើត ដែលសព្វព្រះហឫទ័យឲ្យគូស្វាមីភរិយាមិនអាចបំបែកពីគ្នាបានឡើយ (មថ ៥,៣១-៣២ ; ១៩,៣-៩ ; មក ១០,៩ ; លក ១៦,១៨ ; ១ករ ៧,១០-១១)។ ព្រះអង្គលុបបំបាត់ធម្មវិន័យចាស់ ដែលអនុគ្រោះអ្នកប្រព្រឹត្តអំពើផិតក្បត់ (មថ ១៩,៧-៩)។

- "ឫទ្ធានុភាពមនុស្ស ឬមូលហេតុណាក៏បាន (លើលែងតែសេចក្ដីស្លាប់) មិនអាចបំបែកគូស្វាមីភរិយាគ្រីស្តបរិស័ទកាតូលិក ដែលបានចុះកិច្ចសន្យារៀបអាពាហ៍ពិពាហ៍ និងដែលបានរួមបវេណីរួចហើយ" (CIC ១១៤១)។

២៣៨៣- គូស្វាមីភរិយាអាចបែកពីគ្នា ដោយជាប់ចំណងនៃអាពាហ៍ពិពាហ៍ ក្នុងករណីត្រឹមត្រូវតាមច្បាប់ព្រះសហគមន៍ (CIC ១១៥១-១១៥៥)។

យើងអាចអនុគ្រោះគូស្វាមីភរិយា ដែលត្រូវតែលែងលះ ដើម្បីធានាសិទ្ធិត្រឹមត្រូវខ្លះ ដូចជាការថែទាំកូន ឬការការពារធនធាន។ ដោយធ្វើតាមច្បាប់សង្គមតែប៉ុណ្ណោះ ការលែងលះបែបនេះ មិនខុសសីលធម៌ឡើយ។

២៣៨៤- ការលែងលះ ប្រឆាំងនឹងវិន័យធម្មជាតិយ៉ាងធ្ងន់ធ្ងរ។ ពេលលែងលះ គូស្វាមីភរិយាបំបែកកិច្ចសន្យា ដែលគេបានចុះដោយស្ម័គ្រចិត្តថានឹងរួមរស់ជាមួយគ្នារហូតដល់ពេលស្លាប់។ ការលែងលះបង្ខូចសម្ពន្ធមេត្រីនៃការសង្គ្រោះ ដែលមានអគ្គសញ្ញាអាពាហ៍ពិពាហ៍ជាសញ្ញាសម្គាល់។ បើគូស្រករៀបការម្ដងទៀត ទោះជាច្បាប់សង្គមទទួលស្គាល់អាពាហ៍ពិពាហ៍ថ្មីនេះក៏ដោយ ការផ្ដាច់នេះរឹតតែធ្ងន់ធ្ងរទៅទៀត ដោយគូស្រករដែលបាន

រៀបការម្តងទៀតប្រព្រឹត្តអំពើផិតក្បត់ជាសាធារណៈនិងជាអចិន្ត្រៃយ៍៖

ក្រោយពីបានលែងលះប្រពន្ធរួចហើយ បុរសជាស្វាមីនោះទៅរួមរស់ជាមួយស្ត្រីផ្សេងទៀត បុរសនោះប្រព្រឹត្តអំពើផិតក្បត់ ដ្បិតគេធ្វើឲ្យស្ត្រីនោះប្រព្រឹត្តអំពើផិតក្បត់ ហើយស្ត្រីដែលរស់នៅជាមួយគេប្រព្រឹត្តអំពើផិតក្បត់ ដ្បិតស្ត្រីនេះ បានទាក់ទាញស្វាមីរបស់ស្ត្រីម្នាក់ផ្សេងទៀត (សន្តៈ បាស៊ីល)។

២៣៨៥- ការលែងលះជាអំពើប្រាសចាកសីលធម៌ ដ្បិតក្រុមគ្រួសារ និងសង្គមច្របូកច្របល់ ដែលជាហេតុបណ្ដាលឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរសម្រាប់គូស្រករដែលត្រូវគេបោះបង់ចោល និងចំពោះកូនដែលត្រូវរបួសចិត្ត។ ម្យ៉ាងទៀតជារឿយៗ ឪពុកម្ដាយដណ្ដើមកូនគ្នា។ ទីបំផុត ការលែងលះរាលដាលដូចជាជំងឺដំបៅក្នុងសង្គម។

២៣៨៦- គូស្រករម្នាក់អាចទៅជាជនរងគ្រោះ ដែលគ្មានទោសពៃរ៍នៃការលែងលះ ដែលច្បាប់សង្គមបានប្រកាស។ ពេលនោះ គូស្រករនេះ មិនខុសសីលធម៌ឡើយ។ គូស្រករ ដែលបានខិតខំដោយចិត្តស្មោះ ដោយមានភក្តីភាពចំពោះអគ្គសញ្ញាអាពាហ៍ពិពាហ៍ ហើយត្រូវគេបោះបង់ចោលដោយអយុត្តិធម៌ ខុសប្លែកឆ្ងាយណាស់ពីគូស្រករ ដែលបានបំផ្លាញអាពាហ៍ពិពាហ៍ស្របច្បាប់ព្រះសហគមន៍ ដោយកំហុសធ្ងន់ធ្ងររបស់ខ្លួនផ្ទាល់។

### អំពើបាបផ្សេងទៀតប្រឆាំងនឹងកិត្តិយសដ៏ថ្លៃថ្នូរជាគូស្វាមីភរិយា

២៣៨៧- យើងអាចយល់វិនាដកម្មរបស់អស់អ្នក ដែលប្រាថ្នាចង់កែប្រែចិត្តគំនិតស្របតាមដំណឹងល្អ ហើយដែលត្រូវលែងលះជាមួយនឹងស្ត្រីម្នាក់ ឬច្រើននាក់ ដែលជាគូស្រកររបស់គេអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ក៏ប៉ុន្តែ តាមច្បាប់សីលធម៌ មនុស្សប្រុសមិនអាចមានភរិយាច្រើននាក់ បានឡើយ។ ការមានភរិយាច្រើនប្រឆាំងនឹងសេចក្ដីស្រឡាញ់ជាគូស្វាមីភរិយាខ្លាំងណាស់ ដែលជាការបដិសេធនឹងគម្រោងការរបស់ព្រះជាម្ចាស់ ដែលបានសម្ដែងឲ្យយើងស្គាល់តាំងពីដើមដំបូង ហើយផ្ទុយនឹងកិត្តិយសដ៏ថ្លៃថ្នូររបស់ស្ត្រី និងបុរស ដែលស្មើគ្នា ហើយដែលបានប្រគល់ខ្លួនទាំងស្រុង ក្នុងអាពាហ៍ពិពាហ៍ ដោយមានសេចក្ដីស្រឡាញ់ចំពោះគ្នាតែមួយ" (FC ១៩ ; GS ៤៧,២)។ ដើម្បីភាពយុត្តិធម៌ គ្រីស្តបរិស័ទ ដែលធ្លាប់មានភរិយាច្រើន ត្រូវតែគោរពភារកិច្ចរបស់ខ្លួនចំពោះអតីតភរិយា និងកូន។

២៣៨៨- ការស្មន់ សំដៅទៅលើទំនាក់ទំនងផ្លូវភេទរវាងញាតិ ឬញាតិពន្ធដល់កម្រិត ដែលត្រូវហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ (លវ ១៨,៧-២០)។ សន្តៈ ប៉ូលប្រឆាំងនឹងកំហុសដ៏ធ្ងន់ធ្ងរនេះណាស់៖ " មានលេចឮនៅគ្រប់ទីកន្លែងថា ក្នុងចំណោមបងប្អូន មានកើតរឿងកាមគុណថោកទាបដ៏អាក្រក់ហួសហេតុ (...)។ គឺមានម្នាក់រួមរ័កជាមួយប្រពន្ធចុងឪពុករបស់ខ្លួន (...)។ ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ (...)ត្រូវតែបញ្ជូនជនបែបនោះទៅមារសាតាំង ក្នុងគោលបំណងធ្វើឲ្យនិស្ស័យលោកីយ៍របស់គេវិនាសបាត់បង់" (១ករ ៥,១.៤-៥)។ ការស្មន់បង្ខូចទំនាក់ទំនងក្នុងក្រុមគ្រួសារ និងធ្វើឲ្យមនុស្សអន់ថយទៅជាសត្វវិញ។

២៣៨៩- អំពើខាងផ្លូវភេទ ដែលមនុស្សពេញវ័យប្រព្រឹត្តចំពោះកូនក្មេង ឬក្មេងវ័យជំទង់ ដែលគេត្រូវថែរក្សាដូចជាការស្មន់ម្យ៉ាងផងដែរ។ ពេលនោះ ពួកគេមិនគ្រាន់តែប្រព្រឹត្តអំពើបាបប៉ុណ្ណោះទេ ថែមទាំងបំផ្លាញយ៉ាងអាស្រូវទាំងរូបកាយ ទាំងចិត្តរបស់យុវជន ដែលនឹងត្រូវរបួសអស់មួយជីវិត។ ម្យ៉ាងទៀត ពួកគេរំលោភការទទួលខុសត្រូវក្នុងការអប់រំរបស់ខ្លួនផងដែរ។

២៣៩០- មានស្នេហាដោយសេរី នៅពេលដែលបុរស និងស្ត្រីរួមរស់ជាមួយគ្នាខាងផ្លូវភេទ ដោយបដិសេធមិនព្រមឲ្យច្បាប់ទទួលស្គាល់ការរួមរស់បែបនេះជាសាធារណៈ។

តាមការពិត ពាក្យសម្ដីនេះ ជាការបោកបញ្ឆោត៖ នៅពេលដែលគូស្រករមិនព្រមរួមរស់ជាមួយគ្នាអស់មួយជីវិត ពួកគេបង្ហាញថា គេមិនទុកចិត្តលើគ្នាទៅវិញទៅមក គេមិនទុកចិត្តលើខ្លួនឯង ឬលើអនាគតឡើយ។ តើការរួមរស់របស់ពួកគេមានអត្ថន័យអ្វីខ្លះ?

- ពាក្យសម្ដីសំដៅទៅលើស្ថានភាពផ្សេងៗពីគ្នា គឺការរួមស្នេហា ការបដិសេធមិនព្រមរៀបការ ដោយគេមិនអាចភ្ជាប់ខ្លួនក្នុងកិច្ចសន្យាយូរអង្វែង (FC ៨១)។ ស្ថានភាពទាំងអស់នោះ ប្រឆាំងនឹងកិត្តិយសដ៏ថ្លៃថ្នូររបស់អាពាហ៍ពិពាហ៍ បំផ្លាញលទ្ធិផ្ទាល់អំពីក្រុមគ្រួសារ ធ្វើឲ្យភក្ដីភាពអន់ថយ។ ស្ថានភាពទាំងអស់នោះ ប្រឆាំងនឹងវិន័យនៃសីលធម៌ គឺមានតែគូស្វាមីភរិយាទេ ដែលអាចរួមបវេណីបាន។ បើយើងរួមរ័ក ក្រៅពីអាពាហ៍ពិពាហ៍ យើងប្រព្រឹត្តអំពើបាបធ្ងន់ ហើយយើងមិនអាចទទួលព្រះកាយព្រះគ្រីស្តបានឡើយ។

២៣៩១- សព្វថ្ងៃ មនុស្សជាច្រើនទាមទារឲ្យមាន "សិទ្ធិសាកល្បង" មុនរៀបការ។ ទោះបីជាអ្នកទាំងអស់នោះដែលរួមរ័កមុនពេលកំណត់ មានពាក្យសម្ដីយ៉ាងម៉ឺងម៉ាត់ក៏ដោយ ក៏ "ពាក្យសម្ដីនោះ មិនអាចធានាទំនាក់ទំនងស្មោះត្រង់ និងភក្ដីភាពរវាងបុរស និងស្ត្រី ហើយជាពិសេសមិនអាចការពារគេកុំឲ្យមានចិត្តសាវ៉ា ធ្វើតាមទំនើងចិត្តបាន" (CDF)។ ការរួមសង្វាសត្រឹមត្រូវខាងសីលធម៌ នៅពេលដែលបុរស និងស្ត្រីរួមរស់ជាមួយគ្នាជាស្ថាពរតែប៉ុណ្ណោះ។ សេចក្ដីស្រឡាញ់របស់មនុស្សទាមទារឲ្យមនុស្សប្រគល់ខ្លួនឯងទាំងស្រុង ចំពោះគ្នាទៅវិញទៅមកដោយមិន "សាកល្បង" ឡើយ។

## សង្ខេប

២៣៩២- "តាំងពីកំណើតមក ព្រះជាម្ចាស់ត្រាស់ហៅមនុស្សគ្រប់ៗរូបឲ្យស្រឡាញ់" (FC ១១)។

២៣៩៣- ដោយបង្កើតមនុស្សជាបុរស និងជាស្ត្រី ព្រះជាម្ចាស់ប្រទានឲ្យទាំងពីរនាក់មានឋានៈស្មើគ្នា។ មនុស្សម្នាក់ៗទាំងបុរស ទាំងស្ត្រី ត្រូវតែទទួលស្គាល់ និងសុខចិត្តទទួលយកអត្តសញ្ញាណខាងផ្លូវភេទរបស់ខ្លួន។

២៣៩៤- ព្រះគ្រីស្តជាគំរូឲ្យចេះទប់ខ្លួន។ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទម្នាក់ៗឲ្យចេះទប់ខ្លួន តាមស្ថានភាពពិសេសរបស់គេ។

២៣៩៥- មនុស្សដែលចេះទប់ខ្លួន គឺជាមនុស្ស ដែលមានជីវិតខាងផ្លូវភេទល្អប្រសើរ។ ដើម្បីចេះទប់ខ្លួន ត្រូវតែរៀនគ្រប់គ្រងលើខ្លួនឯង។

២៣៩៦- ក្នុងចំណោមអំពើបាបប្រឆាំងនឹងការចេះទប់ខ្លួន មានការលេងប្រដាប់ភេទដោយខ្លួនឯង ការរួមសង្វាសក្រៅពីចំណងនៃអាពាហ៍ពិពាហ៍ចូលចិត្តរឿងអាសអាភាស និងការរួមសង្វាសជាមួយមនុស្សភេទដូចគ្នា។

២៣៩៧- ដោយសារគូស្វាមីភរិយាបានចងសម្ព័ន្ធមេត្រី គេត្រូវស្រឡាញ់គ្នាដោយភក្ដីភាព។ សម្ព័ន្ធមេត្រីនេះធ្វើឲ្យអាពាហ៍ពិពាហ៍របស់ពួកគេមិនអាចរលាយបានឡើយ។

២៣៩៨- ការបន្តពូជពង្សជាអ្វីមួយដ៏ល្អ ជាព្រះអំណោយទាន និងជាទីដៅមួយនៃអាពាហ៍ពិពាហ៍។ គូស្វាមីភរិយារួមចំណែកជាមួយព្រះជាម្ចាស់ជាព្រះបិតា ដោយផ្តល់ជីវិត។

២៣៩៩- មាតាបិតាដែលជាអ្នកទទួលខុសត្រូវអាចពន្យារកំណើតបាន ប៉ុន្តែ ទោះជាមូលហេតុត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏ពួកគេមិនអាចប្រើប្រាស់មធ្យោបាយខុសសីលធម៌បានដែរ (ដូចជាការធ្វើស្ត្រី ឬបុរស ឲ្យទៅ

ជាអាវ ឬការប្រើថ្នាំពន្យារកំណើត)។

២៤០០- អំពើផិតក្បត់ការលែងលះគ្នា ការមានប្តី ឬប្រពន្ធជាច្រើន និងការរួមរ័ក្សជាមួយគ្នាដោយសេរីជាអំពើខុស យ៉ាងធ្ងន់ធ្ងរនឹងឋានៈនៃអាពាហ៍ពិពាហ៍។

## ប្រការទី៧៖

## វិន័យទីប្រាំពីរ

- កុំលួចប្លន់គេ (សរ ២០,១៥ ; ទក ៥,១៩)
- កុំលួចទ្រព្យសម្បត្តិគេ (មថ ១៩,១៨)

២៤០១- វិន័យទីប្រាំពីរហាមប្រាមមិនឲ្យយក ឬរក្សាទុកទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយអយុត្តិធម៌ ហើយមិនឲ្យប្រព្រឹត្តអំពើបាបចំពោះអ្នកដទៃទាក់ទងនឹងទ្រព្យសម្បត្តិរបស់គេ តាមរបៀបណាមួយក៏ដោយ។ វិន័យនេះផ្តែផ្តាំឲ្យមានយុត្តិធម៌ និងសេចក្តីស្រឡាញ់ ក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិនៃផែនដី និងផលផ្លែនៃការងាររបស់មនុស្ស។ ដើម្បីប្រយោជន៍រួមវិន័យនេះ សុំឲ្យគោរពទីដៅសកលនៃទ្រព្យសម្បត្តិ និងកម្មសិទ្ធិឯកជន។ គ្រីស្តបរិស័ទមានរបៀបរស់នៅដោយខិតខំប្រើប្រាស់ទ្រព្យសម្បត្តិនៃលោកនេះ តាមព្រះបន្ទូលនៃព្រះជាម្ចាស់ ដោយស្រឡាញ់អ្នកដទៃ ដូចជាបងប្អូន។

### ១. ទីដៅសកល និងកម្មសិទ្ធិឯកជននៃទ្រព្យសម្បត្តិ

២៤០២- តាំងពីដើមដំបូង ព្រះជាម្ចាស់បានប្រគល់ឲ្យមនុស្សលោកមានមុខងារត្រួតត្រា ថែរក្សាផែនដី និងភោគទ្រព្យសម្បត្តិនៃផែនដី ហើយឲ្យគេបង្កើតផលបានច្រើន (កណ ១,២៦-២៩)។ ព្រះជាម្ចាស់បានតម្រូវភោគសម្បត្តិដែលមានក្នុងពិភពលោកនេះឲ្យមនុស្សជាតិទាំងមូល។ ក៏ប៉ុន្តែ ព្រះជាម្ចាស់បានបែងចែកផែនដីរវាងមនុស្សទាំងអស់ ដើម្បីឲ្យជីវិតរបស់គេបានសុខសាន្ត ទោះជាមានការខ្វះខាត និងអំពើហិង្សាគម្រាមកំហែងក៏ដោយ។ ការយកទ្រព្យសម្បត្តិធ្វើជាកម្មសិទ្ធិរបស់ខ្លួនត្រឹមត្រូវ ដើម្បីធានាសេរីភាព និងកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស ដើម្បីជួយមនុស្សម្នាក់ៗឲ្យបំពេញតម្រូវការជាមូលដ្ឋានរបស់ខ្លួន និងតម្រូវការរបស់អស់អ្នក ដែលគេទទួលខុសត្រូវផងដែរ។ ការយកទ្រព្យសម្បត្តិនេះ ត្រូវបង្ហាញថា មនុស្សទាំងអស់សាមគ្គីគ្នា។

២៤០៣-ទោះបីមនុស្សមានសិទ្ធិឲ្យមានកម្មសិទ្ធិឯកជនដោយធ្វើការ ឬដោយបានទទួលកម្មសិទ្ធិនេះជាមរតក ឬជាអំណោយយ៉ាងណាក៏ដោយ ក៏មិនត្រូវភ្លេចថា តាំងពីដើមដំបូង ព្រះជាម្ចាស់បានប្រទានផែនដីសម្រាប់មនុស្សជាតិទាំងមូលដែរ។ ទោះបីការគាំទ្រនៃទ្រព្យសម្បត្តិរួមទាមទារឲ្យគោរពកម្មសិទ្ធិឯកជន ការគោរពសិទ្ធិនេះ និងការប្រើប្រាស់សិទ្ធិនេះយ៉ាងណាក៏ដោយ ក៏ទីដៅសកល របស់ទ្រព្យសម្បត្តិនៅតែសំខាន់ណាស់ដែរ។

២៤០៤-"ពេលមនុស្សម្នាក់ប្រើប្រាស់ភោគទ្រព្យរបស់ខ្លួនមិនត្រូវចាត់ទុកថាភោគទ្រព្យដែលខ្លួនមានត្រឹមត្រូវតាមច្បាប់នោះ ជាកម្មសិទ្ធរបស់ខ្លួនម្នាក់ឯងទេ តែត្រូវចាត់ទុកថា ភោគទ្រព្យទាំងនោះ ជាកម្មសិទ្ធរួមទៅវិញ។ ហេតុនេះ គាត់មិនគ្រាន់តែអាចប្រើប្រាស់ភោគទ្រព្យទាំងនោះបាន តែមនុស្សឯទៀតៗ ក៏អាចប្រើប្រាស់បានដែរ" (GS ៦៩,១)។ កម្មសិទ្ធិឯកជនធ្វើឲ្យម្ចាស់វាទៅជាអ្នកចាត់ចែងនៃឧបការគុណ ដើម្បីឲ្យកម្មសិទ្ធិនេះ បង្កើតផល ហើយដើម្បីផ្តល់ផលទាំងអស់នោះឲ្យអ្នកដទៃ ជាពិសេសបងប្អូនរបស់គេ។

២៤០៥- ផលិតផល - រូបី ឬអរូបីក្ដី - ដូចជាដី ឬរោងចក្រ ចំណេះជ្រៅជ្រះ ឬសិល្បៈ ទាមទារឲ្យម្ចាស់វាថែទាំវា ដើម្បីបានផលប្រយោជន៍ដល់មនុស្សភាគច្រើន។ ម្ចាស់នៃរបស់របរប្រើប្រាស់ ដើម្បីបំពេញតម្រូវការរបស់មនុស្ស ត្រូវប្រើវាដោយចេះទប់ចិត្ត និងដោយទុកផ្នែកដ៏ល្អជាងគេសម្រាប់ភ្ញៀវ អ្នកជំងឺ និងជនក្រីក្រ។

២៤០៦- អាជ្ញាធរខាងនយោបាយ មានសិទ្ធិ និងមានភារកិច្ចសម្រេចក្នុងការប្រើប្រាស់កម្មសិទ្ធិឯកជន ដើម្បីប្រយោជន៍រួម។

## ២. ការគោរពបុគ្គល និងទ្រព្យសម្បត្តិរបស់គេ

២៤០៧- ការគោរពកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស ខាងផ្នែកសេដ្ឋកិច្ច ទាមទារឲ្យចេះទប់ចិត្តខ្លួនឯង កុំឲ្យជាប់ជំពាក់នឹងទ្រព្យសម្បត្តិលោកីយ៍ ឲ្យមានភាពយុត្តិធម៌ ដើម្បីរក្សាសិទ្ធិរបស់អ្នកដទៃ និងប្រគល់ឲ្យគេអ្វីដែលគេមានសិទ្ធិទទួល ហើយឲ្យរួមសាមគ្គី តាមវិន័យនៃសេចក្ដីស្រឡាញ់ និងតាមព្រះហឫទ័យសប្បុរសរបស់ព្រះអម្ចាស់ "ដែលមានសម្បត្តិស្ដុកស្ដម្ភជាច្រើន ហើយទ្រង់បានបន្ទាបព្រះកាយ មកជាអ្នកក្រ ព្រោះតែយើង ដើម្បីឲ្យយើងបានទៅជាអ្នកមាន ដោយភាពក្រីក្ររបស់ព្រះអង្គ" (២ករ ៨,៩)។

### ការគោរពទ្រព្យសម្បត្តិអ្នកដទៃ

២៤០៨-វិន័យទីប្រាំពីរហាមប្រាមមិនឲ្យលួចគេពោលគឺការរំលោភទ្រព្យសម្បត្តិអ្នកដទៃនៅពេលដែលម្ចាស់វាមិនយល់ព្រមប្រគល់ឲ្យ ដោយមានមូលហេតុត្រឹមត្រូវ។ យើងមិនលួច បើយើងគិតថា ម្ចាស់ទ្រព្យសម្បត្តិច្បាស់យល់ព្រមប្រគល់ឲ្យ ឬបើការមិនយល់ព្រមនេះប្រឆាំងនឹងប្រាជ្ញា និងទីដៅសកលនៃទ្រព្យសម្បត្តិឡើយ។ ឧ- នៅពេលដែលត្រូវប្រើប្រាស់ទ្រព្យសម្បត្តិអ្នកដទៃ ដើម្បីបំពេញតម្រូវការជាចាំបាច់ (ចំណីអាហារ ជម្រក សម្លៀកបំពាក់ ជាដើម) (GS ៦៩,១)។

២៤០៩- របៀបយក និងរក្សាទុកទ្រព្យសម្បត្តិអ្នកដទៃ ដោយអយុត្តិធម៌ ទោះជាមិនប្រឆាំងនឹងច្បាប់សង្គមក៏ដោយ ក៏ផ្ទុយនឹងវិន័យទីប្រាំពីរដែរ។ ឧ- នៅពេលដែលយើងរក្សាទុករបស់របរដែលគេឲ្យយើងខ្ចី ឬរបស់ដែលគេបាត់ ការធ្វើជំនួញដោយលួចបន្លំគេ (ទក ២៥,១៣-១៦) ការបើកប្រាក់ខែមិនគ្រប់ចំនួន (ទក ២៤,១៤-១៥; យក ៥,៤) ការតំឡើងថ្លៃ ព្រោះគេមិនស្គាល់តម្លៃពិតប្រាកដ ឬព្រោះគេជាជនមានគ្រោះភ័យទុរគត (អម ៨,៤-៦)។

> អំពើខុសសីលធម៌មានទៀតដូចជាការកេងកម្រៃផ្លាស់ប្ដូរតម្លៃទ្រព្យសម្បត្តិ ដើម្បីកេងប្រវ័ញ្ចគេ ការសូកប៉ាន់អស់អ្នក ដែលត្រូវធ្វើការសម្រេចចិត្តតាមច្បាប់ ការប្រើប្រាស់របស់របរនៃសហគ្រាស ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ការធ្វើការមិនល្អ ការគេចពន្ធ ការធ្វើសែក និងវិក័យប័ត្រក្លែងក្លាយ ការចាយលុយឥតឧបមា ការខ្ជះខ្ជាយ។ ការបង្ខូចកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិសាធារណៈ ដោយចេតនា ខុសធម្មវិន័យនៃសីលធម៌ ហើយទាមទារឲ្យទូទាត់ការខូចខាត។

២៤១០- ត្រូវតែគោរពពាក្យសន្យា និងកិច្ចសន្យា យ៉ាងតឹងរ៉ឹង លុះត្រាតែពាក្យសន្យា និងកិច្ចសន្យាទាំងអស់នោះត្រឹមត្រូវ។ ការរស់នៅខាងសេដ្ឋកិច្ច និងក្នុងសង្គមអាស្រ័យទៅលើតម្លៃនៃកិច្ចសន្យារវាងបុគ្គល ឬនីតិបុគ្គល។ ឧ- កិច្ចសន្យាលក់ និងទិញ កិច្ចសន្យាជួល និងកិច្ចសន្យាការងារ។ ត្រូវតែចុះកិច្ចសន្យា និងប្រតិបត្តិតាមយ៉ាងត្រឹមត្រូវ។

២៤១១- កិច្ចសន្យាអាស្រ័យទៅលើភាពយុត្តិធម៌រវាងគ្នានឹងគ្នា ដែលឲ្យមានការផ្លាស់ប្ដូររវាងបុគ្គល និងបុគ្គល

ដោយគោរពសិទ្ធិគ្នាទៅវិញទៅមកយ៉ាងត្រឹមត្រូវ។ ភាពយុត្តិធម៌រវាងគ្នានិងគ្នាបង្ខំបុគ្គលឲ្យគោរពកិច្ចសន្យាយ៉ាងម៉ត់ចត់ ទាមទារឲ្យរក្សាសិទ្ធិកម្មសិទ្ធិ សងបំណុល និងបង់វិភាគទាន ដែលជាកាតព្វកិច្ចតាមកិច្ចសន្យា។

ត្រូវតែវែកញែកយុត្តិធម៌រវាងគ្នានិងគ្នានិងយុត្តិធម៌តាមច្បាប់ ដែលទាក់ទងនឹងអ្វីដែលប្រជាពលរដ្ឋក្នុងការជំពាក់ចំពោះសហគមន៍ និងយុត្តិធម៌ក្នុងការបែងចែក ដែលតម្រូវទៅតាមអ្វីដែលសហគមន៍ជំពាក់ប្រជាពលរដ្ឋទៅតាមការជួយជ្រោមជ្រែង និងតម្រូវការរបស់ពួកគេ។

២៤១២- ដើម្បីឲ្យមានយុត្តិធម៌រវាងគ្នានិងគ្នា គេត្រូវទូទាត់អំពើអយុត្តិធម៌ ដែលគេបានប្រព្រឹត្ត ហើយសងទ្រព្យសម្បត្តិដែលគេបានលួចឲ្យម្ចាស់ដើមរបស់វាវិញ៖

ព្រះយេស៊ូកោតសរសើរលោកសាខេ ដែលសន្យាថា៖ "បពិត្រព្រះអម្ចាស់! ទូលបង្គំនឹងចែកទ្រព្យសម្បត្តិរបស់ទូលបង្គំ ចំនួនពាក់កណ្ដាលដល់មនុស្សក្រីក្រ ហើយប្រសិនបើទូលបង្គំទារពន្ធពីអ្នកណាហួសកម្រិតទូលបង្គំនឹងសងអ្នកនោះវិញ មួយជាបួន" (លក ១៩,៨)។ អស់អ្នក ដែលបានយកទ្រព្យសម្បត្តិអ្នកដទៃ - តាមរបៀបណាក្ដី - ត្រូវតែឲ្យគេវិញ ឬឲ្យរបស់ដែលមានតម្លៃស្មើគ្នា ឬឲ្យប្រាក់វិញ បើទ្រព្យសម្បត្តិដែលគេបានលួចបានបាត់។ ជាមួយគ្នានេះដែរ ត្រូវសងទាំងផលកម្រៃ ដែលម្ចាស់គេត្រូវទទួលបាន បើទ្រព្យនោះមិនត្រូវលួច។ អស់អ្នក ដែលបានចូលរួមក្នុងការលួច - តាមរបៀបណាក្ដី - ហើយដែលបានទទួលផលដោយដឹងខ្លួន ត្រូវតែសងទ្រព្យសម្បត្តិនេះវិញ តាមការទទួលខុសត្រូវ និងផលចំណេញរបស់គេ។ ឧ- អស់អ្នកដែលបានបញ្ជាឲ្យគេលួច ឬបានជួយឲ្យគេលួច ឬបានលក់ទ្រព្យសម្បត្តិដែលគេលួច។

២៤១៣- ល្បែងស៊ីសង (ការលេងបៀ ជាដើម) ឬការភ្នាល់ មិនប្រឆាំងនឹងយុត្តិធម៌ ដោយផ្ទាល់ឡើយ។ ល្បែងទាំងអស់នោះ ខុសសីលធម៌នៅពេលដែលអ្នកលេងអន្តរាយអស់ទ្រព្យសម្បត្តិលុយកាក់ ដើម្បីចិញ្ចឹមខ្លួនឯង និងកូនចៅ។ ការវក់នឹងល្បែងនាំឲ្យគេក្លាយទៅជាឈ្លើយនៃល្បែងយ៉ាងធ្ងន់ធ្ងរ។ បើយើងភ្នាល់មិនត្រឹមត្រូវ ឬបើយើងលេងបន្លំគឺប្រព្រឹត្តខុសសីលធម៌ធ្ងន់ លើកលែងតែការខូចខាតស្រាលណាស់ បានជាអ្នកខាតបង់មិនអាចចាត់ទុកជាធំដុំឡើយ។

២៤១៤- វិន័យទីប្រាំពីរហាមប្រាមមិនឲ្យប្រព្រឹត្តអំពើ ឬមុខរបរ ដែលនាំឲ្យប្រើប្រាស់មនុស្សដូចជាទាសករ មិនគោរពកិត្តិយសដ៏ថ្លៃថ្នូររបស់គេ ទិញ លក់ និងផ្លាស់ប្ដូរគេដូចទំនិញ ទោះជាដើម្បីប្រយោជន៍ផ្ទាល់ មនោគមវិជ្ជា មុខជំនួញ និងមូលហេតុផ្ដាច់ការក៏ដោយ។ ការបង្អាច់បង្អោនមនុស្សឲ្យទៅជាវត្ថុប្រើប្រាស់ ឬឲ្យទៅជាប្រភពនៃការចំណេញ សុទ្ធតែជាអំពើប្រឆាំងនឹងកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស និងសិទ្ធិមូលដ្ឋានរបស់គេ។ សន្ដ:ប៉ូលបញ្ជាឲ្យគ្រីស្តបរិស័ទម្នាក់ដែលជាម្ចាស់របស់ទាសករឲ្យគិតថា ពួកគេ " មិនមែនទាសករទៀតទេ គឺជាបងប្អូនជាទីស្រឡាញ់ទៅវិញ (...) ហើយរឹតតែជាទីស្រឡាញ់ថែមទៀត ទាំងខាងលោកីយ៍ ទាំងខាងព្រះអម្ចាស់" (ភល ១៦)។

## ការគោរពពិភពលោកទាំងមូល

២៤១៥- វិន័យទីប្រាំពីរសុំឲ្យគោរពពិភពលោកទាំងមូល។ សត្វ ដូចជារុក្ខជាតិ និងរបស់របរទាំងអស់ដែលគ្មានវិញ្ញាណ មានទីដៅតម្រង់ឆ្ពោះរកប្រយោជន៍រួមនៃមនុស្សជាតិតាំងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលផងដែរ (កណ ១,២៨-៣១)។ ការប្រើប្រាស់ធនធានខនិច រុក្ខជាតិ និងសត្វនៃសកលលោកត្រូវតែគោរពសីលធម៌។ ព្រះជាម្ចាស់មិនឲ្យមនុស្សត្រួតត្រាលើរបស់របរដែលគ្មានវិញ្ញាណ និងលើសត្វលោកតាមរបៀបផ្ដាច់ការទេ ប៉ុន្តែមនុស្សត្រូវតែគិតគូរដល់គុណភាពនៃការរស់នៅរបស់អ្នកដទៃ ជាពិសេសរបស់អ្នកជំនាន់ក្រោយៗ។

ត្រូវតែគោរពពិភពលោកទាំងមូល ដូចជាគោរពព្រះជាម្ចាស់ដែរ (CA ៣៧-៣៨)។

២៤១៦- សត្វ ជាសត្វលោករបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ថែទាំវា ដោយសារឧបការគុណរបស់ព្រះអង្គប្រកបដោយធម៌មេត្តាករុណា (មថ ៦,២៦)។ ដោយសារពួកវារស់នៅ ពួកវាលើកតម្កើង និងកោតសរសើរព្រះអង្គ (ដន ៣,៥៧-៥៨)។ ហេតុនេះហើយ បានជាមនុស្សត្រូវតែថែរក្សាពួកវា។ ត្រូវរំឭកថា សន្តៈបុគ្គល ដូចជាសន្តៈប្រាង់ស័រ នៃអាស៊ីស៊ី ឬ សន្តៈភីលីព ណេរី បានថែទាំសត្វយ៉ាងថ្នាក់ថ្នម។

២៤១៧- ព្រះជាម្ចាស់បានប្រគល់ឲ្យរូបតំណាងរបស់ព្រះអង្គថែទាំសត្វ (កណ ២,១៩-២០ ; ៩,១-៤)។ ដូច្នេះ មនុស្សអាចប្រើប្រាស់សត្វ ធ្វើជាចំណីអាហារ និងធ្វើសម្លៀកបំពាក់បាន។ យើងអាចបង្ហាត់សត្វឲ្យជួយមនុស្សក្នុងការងារ និងការលំហែកំសាន្តរបស់គេបានដែរ។ មនុស្សអាចយកសត្វមកធ្វើការពិសោធន៍វេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដែលច្បាប់សីលធម៌ចាត់ទុកថា ត្រឹមត្រូវ ដ្បិតការពិសោធន៍ទាំងអស់នោះ ជួយព្យាបាល ឬសង្គ្រោះមនុស្ស។

២៤១៨- ការធ្វើឲ្យសត្វឈឺចាប់ និងការខ្ជះខ្ជាយជីវិតរបស់វាឥតប្រយោជន៍ ជាការប្រឆាំងនឹងកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស ព្រមទាំងការចាយប្រាក់កាស ដែលយើងអាចប្រើ ដើម្បីជួយសម្រាលទុក្ខវេទនារបស់មនុស្ស មិនសមរម្យផងដែរ។ យើងអាចស្រឡាញ់សត្វ ប៉ុន្តែយើងមិនត្រូវបង្វែរសេចក្តីស្រឡាញ់ចំពោះមនុស្ស ដើម្បីពួកវាបានឡើយ។

## ៣. លទ្ធិសង្គមនៃព្រះសហគមន៍

២៤១៩- "សេចក្តីដែលព្រះគ្រីស្តបានសម្តែងមក ជួយយើងយ៉ាងខ្លាំងឲ្យយល់ច្បាស់អំពីរបៀបនៃការរស់នៅក្នុងសង្គម" (GS ២៣,១)។ ដំណឹងល្អសម្តែងឲ្យព្រះសហគមន៍ស្គាល់សេចក្តីពិតរបស់មនុស្សយ៉ាងពេញលេញ។ នៅពេលដែលព្រះសហគមន៍បំពេញបេសកកម្មរបស់ខ្លួនប្រកាសដំណឹងល្អ ព្រះសហគមន៍បញ្ជាក់ឲ្យមនុស្សស្គាល់ ក្នុងព្រះនាមព្រះគ្រីស្ត នូវកិត្តិយសដ៏ថ្លៃថ្នូរ និងទីដៅរបស់ខ្លួន ឲ្យរួបរួមជាមួយអ្នកដទៃ។ ព្រះសហគមន៍បង្រៀនឲ្យមនុស្សស្គាល់ការទាមទារនៃយុត្តិធម៌ និងសន្តិភាព ស្របតាមព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។

២៤២០- ព្រះសហគមន៍វិនិច្ឆ័យខាងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ស្របតាមសីលធម៌ "ប្រសិនបើសិទ្ធិមូលដ្ឋានរបស់មនុស្ស ឬការសង្គ្រោះនៃព្រលឹងទាមទារ" (GS ៧៦,៥)។ ព្រះសហគមន៍មានបេសកកម្មប្លែកពីបេសកកម្មរបស់អាជ្ញាធរនយោបាយ ខាងផ្នែកសីលធម៌ គឺព្រះសហគមន៍គិតគូរដល់ប្រយោជន៍រួមនៃលោកនេះ ដើម្បីឲ្យការចាត់ចែងនោះបានល្អប្រសើរបំផុត ដែលជាទីដៅចុងក្រោយរបស់យើង។ ព្រះសហគមន៍ខិតខំជំរុញឲ្យកាន់ឥរិយាបទត្រឹមត្រូវក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិនៃផែនដី និងក្នុងទំនាក់ទំនងខាងសេដ្ឋកិច្ចផងនិងខាងសង្គមផង។

២៤២១- លទ្ធិសង្គមរបស់ព្រះសហគមន៍បានអភិវឌ្ឍ នៅសតវត្សទី១៩ នៅពេលដែលដំណឹងល្អបានជួបប្រទះនឹងសង្គមឧស្សាហកម្មទំនើប ព្រមទាំងរចនាសម្ព័ន្ធថ្មីដើម្បីផលិតរបស់របរប្រើប្រាស់ គំនិតនៃសង្គមថ្មី រដ្ឋ និងអំពីអំណាច របៀបថ្មីនៃការងារ និងកម្មសិទ្ធិ។ ការអភិវឌ្ឍន៍លទ្ធិសង្គមព្រះសហគមន៍ ខាងសេដ្ឋកិច្ច និងសង្គម បង្ហាញអំពីតម្លៃជាអចិន្ត្រៃយ៍នៃការប្រៀនប្រដៅរបស់ព្រះសហគមន៍ និងអត្ថន័យពិតប្រាកដនៃការបញ្ជូនបន្តដែលនៅតែរស់រវើក និងសកម្ម (CA ៣)។

២៤២២- នៅក្នុងការប្រៀនប្រដៅនេះ មានលទ្ធិ ដែលវិវត្តតាមការបកស្រាយរបស់ព្រះសហគមន៍អំពីព្រឹត្តិការណ៍ផ្សេងៗនៃប្រវត្តិសាស្ត្រ ក្រោមពន្លឺនៃព្រះបន្ទូលទាំងមូល ដែលព្រះគ្រីស្តយេស៊ូបានសម្តែងមក ដោយមាន

ព្រះវិញ្ញាណដ៏វិសុទ្ធជួយណែនាំ (SRS ១ ; ៤១)។ ការប្រៀនប្រដៅបំភ្លឺការរស់នៅរបស់គ្រីស្តបរិស័ទយ៉ាងណា មនុស្សដែលមានឆន្ទៈល្អក៏ងាយទទួលការប្រៀនប្រដៅយ៉ាងនោះដែរ។

២៤២៣- លទ្ធិសង្គមរបស់ព្រះសហគមន៍លើកយកគោលការណ៍ខ្លះ មកធ្វើការពិចារណា ដកស្រង់លក្ខណៈវិនិច្ឆ័យ និងផ្តល់ទីដៅខ្លះ ដើម្បីប្រតិបត្តិតាម៖

> ប្រព័ន្ធណា ដែលទំនាក់ទំនងក្នុងសង្គមអាស្រ័យទាំងស្រុង ទៅលើកត្តាខាងសេដ្ឋកិច្ចប្រឆាំងនឹងលក្ខណៈជាមនុស្សសុទ្ធសាធ និងកិច្ចការរបស់គេផងដែរ (CA ២៤)។

២៤២៤- តាមសីលធម៌ យើងត្រូវបដិសេធលទ្ធិមួយ ដែលទុកផលកម្រៃជាគោលដៅចុងក្រោយនៃសកម្មភាពសេដ្ឋកិច្ច។ ចិត្តលោភលន់មិនចេះស្កប់ស្កល់ចង់បានលុយតែងតែនាំមកនូវផលអាក្រក់ជានិច្ច ហើយជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងទៀត នៃទំនាស់ជាច្រើន ដែលបង្ខូចរបៀបរៀបរយក្នុងសង្គម (GS ៦៣,៣ ; LE ៧ ; CA ៣៥)។

- ប្រព័ន្ធមួយ "ដែលមិនអើពើនឹងសិទ្ធិមូលដ្ឋានរបស់មនុស្ស និងសិទ្ធិរបស់ក្រុម ហើយបែរជាមានបំណងចង់បង្កើនផលិតផលជាសមូហភាពវិញ" (GS ៦៥,២) ជាប្រពន្ធ័ដែលប្រឆាំងនឹងកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស។ របៀបប្រតិបត្តិណា ដែលចាត់ទុកមនុស្សជាមធ្យោបាយសុទ្ធសាធ ដើម្បីបានចំណេញ ជារបៀបដែលធ្វើឲ្យមនុស្សទៅជាទាសករ គោរពលុយដូចជាព្រះក្លែងក្លាយ និងជួយឲ្យទ្រឹស្តីបដិសេធថាគ្មានព្រះជាម្ចាស់រាលដាល។ "អ្នករាល់គ្នាមិនអាចគោរពបម្រើព្រះជាម្ចាស់ផង ហើយគោរពបម្រើទ្រព្យសម្បត្តិ ទុកជាព្រះផងបានឡើយ" (មថ ៦,២៤ ; លក ១៦,១៣)។

២៤២៥- ព្រះសហគមន៍បានបដិសេធមិនព្រមទទួលមនោគមវិជ្ជាផ្តាច់ការ និងមនោគមវិជ្ជាបដិសេធថាគ្មានព្រះជាម្ចាស់ ដូចជាលទ្ធិ "កុម្មុយនិស្ត" និងលទ្ធិ "សង្គមនិយម" នៅសម័យឥឡូវនេះទេ។ ម្យ៉ាងទៀត ព្រះសហគមន៍ប្រឆាំងនឹងរបៀបប្រតិបត្តិរបស់លទ្ធិមូលធននិយម ដែលគិតតែអំពីខ្លួនឯង (ឯកត្តនិយម) និងផ្តល់អាទិភាពដល់ច្បាប់នៃទីផ្សារលើសការងាររបស់មនុស្ស (CA ១០ ; ១៣ ; ៤៤)។ការគ្រប់គ្រងសេដ្ឋកិច្ច ដោយធ្វើគម្រោងប្រមូលផ្តុំបង្ខូចគ្រឹះនៃទំនាក់ទំនងក្នុងសង្គម ឯការគ្រប់គ្រងសេដ្ឋកិច្ច ដោយប្រើច្បាប់នៃទីផ្សារមិនស្របតាមយុត្តិធម៌ក្នុងសង្គម "ដ្បិតមនុស្សមានតម្រូវការជាច្រើន ដែលទីផ្សារមិនអាចបំពេញបានឡើយ" (CA ៣៤)។ ត្រូវតែផ្តល់ដំបូន្មានថា ត្រូវគ្រប់គ្រងលើទីផ្សារ និងលើការបង្កើតគំនិតថ្មីខាងសេដ្ឋកិច្ច តាមរបៀបត្រឹមត្រូវ និងតាមលំដាប់លំដោយត្រឹមត្រូវនៃឧត្តមគតិ ដើម្បីប្រយោជន៍រួម។

## ៤. សកម្មភាពខាងសេដ្ឋកិច្ច និងយុត្តិធម៌ក្នុងសង្គម

២៤២៦- ការអភិវឌ្ឍន៍សកម្មភាពខាងសេដ្ឋកិច្ច និងការបង្កើនផលិតផលមានគោលដៅបំពេញតម្រូវការរបស់មនុស្ស។ ជីវិតនៃសេដ្ឋកិច្ចមិនគ្រាន់តែមានទីដៅក្នុងការបង្កើនផលិតផល ហើយបង្កើនប្រាក់ចំណេញ និងអំណាចប៉ុណ្ណោះទេ ជីវិតនៃសេដ្ឋកិច្ចនេះ ត្រូវបម្រើបុគ្គល មនុស្សទាំងស្រុងផង និងសហគមន៍មនុស្សទាំងមូលផងដែរ។ ត្រូវដឹកនាំបំពេញសកម្មភាពខាងសេដ្ឋកិច្ច តាមវិធីសាស្រ្តរបស់វាផ្ទាល់ ដោយប្រតិបត្តិក្នុងដែនកំណត់នៃវិន័យសីលធម៌ត្រឹមត្រូវទៅតាមយុត្តធម៌នៃសង្គម ដើម្បីឆ្លើយតបនឹងគម្រោងការរបស់ព្រះជាម្ចាស់ចំពោះមនុស្ស (GS ៦៤)។

២៤២៧- ការងាររបស់មនុស្ស មកពីមនុស្ស ដែលព្រះជាម្ចាស់បានបង្កើតជារូបតំណាងរបស់ព្រះអង្គ ហើយ

ដែលព្រះអង្គត្រាស់ហៅឱ្យបន្តកិច្ចបង្កើត ដោយត្រួតត្រាលើផែនដី និងដោយរួមជាមួយគ្នា និងចំពោះគ្នាទៅវិញទៅមក (កណ ១,២៨ ; GS ៣៤ ; CA ៣១)។ ដូច្នេះ មនុស្សមានភារកិច្ចធ្វើការ៖ "អ្នកណាមិនព្រមធ្វើការ អ្នកនោះក៏មិនត្រូវបរិភោគដែរ" (២ថស ៣,១០) (១ថស ៤,១១)។ ការងារលើកតម្កើងព្រះអំណោយទានរបស់ព្រះបង្កើត និងសមត្ថភាពដែលមនុស្សបានទទួលពីព្រះអង្គ។ ការងារអាចជួយសង្គ្រោះមនុស្សផងដែរ។ ដោយធ្វើការយ៉ាងលំបាក (កណ៣,១៤-១៩) ជាមួយព្រះយេស៊ូ ជាជាងឈើនៃភូមិណាសារ៉ែត និងជាអ្នកត្រូវគេឆ្កាងលើភ្នំលលាក្បាល មនុស្សរួមសហការជាមួយព្រះបុត្រារបស់ព្រះជាម្ចាស់ ក្នុងកិច្ចសង្គ្រោះរបស់ព្រះអង្គម្យ៉ាងដែរ។ គេបង្ហាញថា គេជាសាវ័ករបស់ព្រះគ្រីស្ត ដោយលីឈើឆ្កាង ក្នុងសកម្មភាព ដែលព្រះជាម្ចាស់ត្រាស់ហៅឱ្យគេបំពេញ ជារៀងរាល់ថ្ងៃ (LE ២៧)។ ការងារអាចទៅជាមធ្យោបាយ ដើម្បីបានវិសុទ្ធ និងឲ្យតថភាពនៃផែនដីមានជីវិតរស់រវើក ក្នុងព្រះវិញ្ញាណរបស់ព្រះគ្រីស្ត។

២៤២៨- មនុស្សធ្វើការងារ និងបំពេញផ្នែកមួយនៃសមត្ថភាពរបស់លក្ខណៈជាមនុស្ស។ តម្លៃដ៏សំខាន់ៗនៃការងារស្ថិតក្នុងមនុស្សផ្ទាល់ ដែលជាប្រភព និងទីដៅនៃការងារ។ ព្រះជាម្ចាស់បានបង្កើតការងារ ដើម្បីបម្រើមនុស្ស ហើយមិនមែនបង្កើតមនុស្ស ដើម្បីបម្រើការងារឡើយ។

- មនុស្សម្នាក់ៗអាចដកស្រង់មធ្យោបាយក្នុងការងារ ដើម្បីចិញ្ចឹមជីវិតរបស់ខ្លួនឯង និងរបស់បងប្អូនផង ហើយដើម្បីជួយបម្រើសហគមន៍មនុស្សផងដែរ។

២៤២៩- មនុស្សម្នាក់ៗមានសិទ្ធិផ្ដើមគំនិតថ្មី ដើម្បីសេដ្ឋកិច្ចហើយនឹងប្រើប្រាស់ព្រះអំណោយទានរបស់ខ្លួនតាមរបៀបត្រឹមត្រូវ ដើម្បីជួយឲ្យមនុស្សទាំងអស់បានសម្បូណ៍ហូរហៀរ និងដើម្បីទទួលផលដ៏ត្រឹមត្រូវនៃការខិតខំទាំងប៉ុន្មានរបស់ខ្លួន។ គេនឹងប្រុងប្រយ័ត្នគោរពតាមបទបញ្ញា ដែលអាជ្ញាធរត្រឹមត្រូវបានតាក់តែង ដើម្បីប្រយោជន៍រួម (CA ៣២ ; ៣៤)។

២៤៣០- ការរស់នៅទាក់ទងនឹងសេដ្ឋកិច្ចជាហេតុនាំឲ្យមានផលប្រយោជន៍ផ្សេងៗពីគ្នា ដែលប្រឆាំងនឹងគ្នាជាច្រើនលើកច្រើនសា។ ហេតុនេះហើយ បានជាមានជំទាស់ជាច្រើន កើតឡើង ដែលជាលក្ខណៈពិសេសនៃការរស់នៅទាក់ទងនឹងសេដ្ឋកិច្ចនេះ (LE ១១)។ គេត្រូវខិតខំកាត់បន្ថយជំទាស់ទាំងអស់នោះ ដោយការចរចារដែលគោរពសិទ្ធិ និងកាតព្វកិច្ចរបស់ដៃគូនីមួយៗនៃសង្គម គឺអ្នកទទួលខុសត្រូវសហគ្រាស តំណាងបុគ្គលិកដូចជាក្រុមសហជីព ហើយជួនកាលរដ្ឋអំណាចផងដែរ។

២៤៣១- ការទទួលខុសត្រូវរបស់រដ្ឋាភិបាល។ "សកម្មភាពខាងសេដ្ឋកិច្ច ជាពិសេសសេដ្ឋកិច្ចនៃទីផ្សារ មិនអាចកើតមានទេ បើគ្មានស្ថានប័នច្បាប់ ឬនយោបាយ។ ត្រូវតែធានាសេរីភាពរបស់បុគ្គលនីមួយៗ និងរបស់កម្មសិទ្ធិ ដោយមិនគិតអំពីស្ថិរភាពរបស់រូបិយវត្ថុ និងសេវាកម្មសាធារណៈប្រកបដោយប្រសិទ្ធិភាព។ រដ្ឋាភិបាលមានភារកិច្ចចាំបាច់ការពារការធានាទាំងអស់នោះ ដើម្បីឲ្យអ្នកធ្វើការអាចទទួលផលនៃការងាររបស់គេ ហើយឲ្យគេយល់ថា គេត្រូវបានជំរុញឲ្យបំពេញការងារនោះ ដោយប្រសិទ្ធិភាព និងចិត្តស្មោះត្រង់ទៀតផង (...)។ រដ្ឋអំណាចមានភារកិច្ចពិនិត្យមើល និងដឹកនាំការអនុវត្តសិទ្ធិមនុស្សក្នុងវិស័យសេដ្ឋកិច្ច។ ក៏ប៉ុន្តែ ក្នុងវិស័យនេះ ស្ថានប័ន ក្រុម និងសហគមន៍ផ្សេងៗដែលមានក្នុងសង្គម ជាអ្នកទទួលខុសត្រូវមុនរដ្ឋាភិបាលទៅទៀត" (CA ៤៨)។

២៤៣២- អ្នកទទួលខុសត្រូវនៃសហគ្រាស ទទួលខុសត្រូវលើប្រតិបត្តិការ ដែលសេដ្ឋកិច្ច និងបរិស្ថានទាំងអស់នៃសហគ្រាសខ្លួនចំពោះសង្គម (CA ៣៧)។ ពួកគេត្រូវគិតអំពីប្រយោជន៍របស់មនុស្ស មិនគ្រាន់តែគិតអំពីការបង្កើនប្រាក់ចំណេញប៉ុណ្ណោះទេ។ប៉ុន្តែការចំណេញក៏ជាចាំបាច់ណាស់ដែរ។ការចំណេញអាចបង្កើតវិនិយោគ

ដែលធានាអនាគតរបស់សហគ្រាស និងបង្កើតការងារផងដែរ។

២៤៣៣- ត្រូវតែផ្តល់ការងារ និងវិជ្ជាជីវៈចំពោះមនុស្សគ្រប់រូប ដោយមិនរើសអើងអយុត្តិធម៌ ទោះជាបុរស ឬស្ត្រី មនុស្សមានសុខភាពល្អ ឬជនពិការ អ្នករស់ក្នុងស្រុកឬជនអន្តោប្រវេសន៍ក៏ដោយ (LE ១៩ ; ២២-២៣)។ សង្គមត្រូវតែជួយប្រជាពលរដ្ឋឲ្យមានការងារ និងមុខរបរ ទៅតាមកាលៈទេសៈ។

២៤៣៤- បៀវត្សត្រឹមត្រូវ ជាផលដ៏ត្រឹមត្រូវនៃការងារ។ បើយើងបដិសេធមិនព្រមឲ្យ ឬទុកមិនឲ្យបៀវត្ស យើងអាចប្រព្រឹត្តអំពើអយុត្តិធម៌ធ្ងន់ធ្ងរ (លវ ១៩,១៣ ; ទក ២៤,១៤-១៥ ; យក៥,៤)។ដើម្បីផ្តល់បានប្រាក់ខែត្រឹមត្រូវ ត្រូវតែគិតគូរអំពីតម្រូវការ និងការរួមចំណែករបស់គេ។ "ប្រាក់ឈ្នួលការងារត្រូវធានាឲ្យមនុស្សមានធនធានល្មមឲ្យសាមីខ្លួន និងក្រុមគ្រួសារ អាចរស់នៅយ៉ាងសមគួរ ក្នុងសង្គម ក្នុងវិស័យវប្បធម៌ និងក្នុងវិស័យវិញ្ញាណ ទៅតាមមុខងាររបស់គេ តាមសមត្ថភាពក្នុងការផលិតផល តាមស្ថានភាពនៃសហគ្រាស និងដល់ប្រយោជន៍រួមផង" (GS ៦៧,២)។ ការចុះកិច្ចព្រមព្រៀងលើចំនួនប្រាក់បៀវត្សទាំងសងខាងមិនគ្រប់គ្រាន់ដើម្បីដោះសាតារមសីលធម៌ឡើយ។

២៤៣៥- ការធ្វើកូដកម្ម ត្រឹមត្រូវនៅពេលដែលគេគ្មានមធ្យោបាយផ្សេងទៀត ឬជាមធ្យោបាយចាំបាច់ ដើម្បីទាមទារយកផលប្រយោជន៍សមស្របតាមការងាររបស់គេ។ ការធ្វើកូដកម្មមិនត្រឹមត្រូវ បើមានអំពើហិង្សា ឬមានគោលដៅ ដែលមិនទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ ឬប្រឆាំងនឹងប្រយោជន៍រួម។

២៤៣៦- ការមិនបង់វិភាគទានជាអំពើខុសសីលធម៌ មិនត្រឹមត្រូវទេ បើគេមិនព្រមបង់វិភាគទានចំពោះស្ថានប័ននៃសុវត្ថិភាពក្នុងសង្គម ដែលអាជ្ញាធរត្រឹមត្រូវបានកំណត់ទុក។

- ការបាត់បង់ការងារ ដោយសារគ្មានការងារធ្វើតែងតែប៉ះពាល់នឹងកិត្តិយសដ៏ថ្លៃថ្នូររបស់ជនរងគ្រោះ និងគម្រាមលំនឹងនៃជីវិត។ មនុស្សដែលបាត់បង់ការងារមិនគ្រាន់តែទទួលរងការខូចខាតផ្ទាល់ខ្លួនទេ ថែមទាំងមានការគម្រាមកំហែងជាច្រើនចំពោះក្រុមគ្រួសាររបស់គេដែរ។

## ៥. យុត្តិធម៌ និងសាមគ្គីភាពរវាងប្រជាជាតិនានា

២៤៣៧- ក្នុងសង្គមអន្តរជាតិ ដោយសារធនធាន និងមធ្យោបាយខាងសេដ្ឋកិច្ចមិនស្មើគ្នា ស្ថានភាពនេះបង្កើត "ប្រឡាយ" (SRS ១៤) ពិតប្រាកដមួយ រវាងប្រជាជាតិនានា។ ម្ខាង មានអស់អ្នក ដែលកាន់កាប់ និងអភិវឌ្ឍមធ្យោបាយនៃការលូតលាស់ ម្ខាងទៀត មានអស់អ្នក ដែលជំពាក់គេកាន់តែច្រើនឡើងៗ។

២៤៣៨- សព្វថ្ងៃ មានមូលហេតុផ្សេងៗ ខាងសាសនា ខាងនយោបាយ ខាងសេដ្ឋកិច្ច និងខាងហិរញ្ញវត្ថុ ដែលធ្វើឲ្យ "បញ្ហាសង្គមទៅជាមានលក្ខណៈអន្តរជាតិ" (SRS ៩)។ ប្រជាជាតិ ដែលនយោបាយពឹងផ្អែកលើគ្នាទៅវិញទៅមក ត្រូវតែរួមសាមគ្គីជាមួយគ្នាជាចាំបាច់។ រឹតតែចាំបាច់លើសនេះទៅទៀត គេត្រូវការសាមគ្គីភាពនេះ នៅពេលដែលត្រូវតែបង្ក្រាប "មូលហេតុអាក្រក់" ដែលរារាំងប្រទេសមិនទាន់ជឿនលឿនមិនឲ្យអភិវឌ្ឍ (SRS ១៧ ; ៤៥)។ "ដោយពិចារណាម្តងទៀតអំពីអាទិភាព និងអំពីកម្រិតនៃឧត្តមគតិ" (CA ២៨) ត្រូវតែខិតខំរួបរួមប្រមូលផ្តុំប្រើប្រាស់ធនធាន ដើម្បីអភិវឌ្ឍសីលធម៌ វប្បធម៌ និងសេដ្ឋកិច្ច ជំនួសប្រព័ន្ធហិរញ្ញវត្ថុ ដែលយកការប្រាក់ហួសប្រមាណ (CA ៣៥) ជំនួសទំនាក់ទំនងនៃពាណិជ្ជកម្មមិនស្មោះត្រង់រវាងប្រជាជាតិ និងជំនួសការប្រណាំងប្រជែងគ្រឿងសព្វាវុធ។

២៤៣៩- ប្រជាជាតិដែលមានធនធានស្តុកស្តម្ភ ទទួលខុសត្រូវខាងសីលធម៌យ៉ាងធ្ងន់ធ្ងរចំពោះប្រជាជាតិ

ដែលមិនអាចអភិវឌ្ឍដោយខ្លួនឯង ឬដោយសារព្រឹត្តការណ៍ប្រវត្តិសាស្ត្រដ៏អាក្រក់បានរារាំងប្រទេសនោះ មិនឲ្យអភិវឌ្ឍ។ ប្រជាជាតិដែលមានធនធានស្តុកស្តម្ភមានភារកិច្ចរួមសាមគ្គី និងស្រឡាញ់ប្រជាជាតិដែលមានធនធានតិចជាង។ ភារកិច្ចនេះ មានភាពយុត្តិធម៌ បើភាពសម្បូរសប្បាយរបស់ប្រជាជាតិជាអ្នកមាននោះ បានមកអំពីខ្លួនមិនបានបង់ប្រាក់ត្រឹមត្រូវតាមកម្រៃ។

២៤៤០- ជំនួយផ្តល់ការជួយ ជាចម្លើយត្រឹមត្រូវចំពោះតម្រូវការជាបន្ទាន់ ខុសពីស្ថានភាពធម្មតា ដែលបណ្តាលមកពីគ្រោះធម្មជាតិ ជំងឺរាតត្បាតជាដើម។ ប៉ុន្តែ ជំនួយនេះ មិនគ្រប់គ្រាន់ ដើម្បីជុសជួលការខូចខាតដ៏ធ្ងន់ធ្ងរ ដែលមកពីស្ថានភាពក្រីក្រ ឬដើម្បីបំពេញតម្រូវការផ្សេងៗអស់រយៈពេលយូរទេ។ លើសពីនេះទៅទៀតត្រូវតែកែលំអស្ថានប័ន អន្តរជាតិខាងសេដ្ឋកិច្ច និងខាងហិរញ្ញវត្ថុ ដើម្បីឲ្យស្ថានប័នទាំងអស់នោះលើកស្ទួយទំនាក់ទំនងត្រឹមត្រូវជាមួយប្រទេសទាំងប៉ុន្មាន ដែលមិនទាន់ជឿនលឿន (SRS ១៦)។ ត្រូវតែគាំទ្រការខិតខំរបស់ប្រទេសក្រីក្រ ដែលធ្វើការ ដើម្បីភាពរីកចម្រើន និងដើម្បីរំដោះខ្លួនឯង (CA ២៦)។ ត្រូវតែប្រតិបត្តិតាមលទ្ធិនេះតាមរបៀបពិសេសបំផុតក្នុងវិស័យកសិកម្ម។ អ្នកក្រីក្រភាគច្រើនជាកសិករ ជាពិសេសក្នុងប្រទេស ដែលមិនទាន់អភិវឌ្ឍ។

២៤៤១- ការស្គាល់ព្រះជាម្ចាស់ និងការស្គាល់ខ្លួនឯង កាន់តែច្បាស់ឡើងៗ ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍ទាំងស្រុងរបស់សហគមន៍មនុស្ស។ ការអភិវឌ្ឍន៍នេះ បង្កើនសម្ភារៈកាន់តែច្រើនឡើងៗ ដើម្បីបម្រើមនុស្ស និងសេរីភាពរបស់គេ។ ការអភិវឌ្ឍន៍នេះ បន្ថយភាពវេទនា និងការកេងប្រវ័ញ្ច ហើយជួយឲ្យមានការគោរពអត្តសញ្ញាណខាងវប្បធម៌ និងការបើកចិត្តទូលាយចំពោះអ្វីដែលខ្ពង់ខ្ពស់បំផុត (SRS ៣២)។

២៤៤២- ពួកគង្វាលព្រះសហគមន៍គ្មានមុខងារធ្វើអន្តរាគមន៍ផ្ទាល់ ក្នុងកិច្ចការនយោបាយ និងចាត់ចែងការរស់នៅក្នុងសង្គមទេ។ មុខងារនេះ ជាមុខងាររបស់គ្រីស្តបរិស័ទធម្មតា ដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យប្រតិបត្តិដោយខ្លួនឯង រួមជាមួយប្រជាពលរដ្ឋដូចគ្នាផងដែរ។ កិច្ចការសង្គមអាចមានច្រកចេញយ៉ាងច្រើន ប៉ុន្តែ ត្រូវយកប្រយោជន៍រួមជាធំ ស្របតាមសារនៃដំណឹងល្អ និងការប្រៀនប្រដៅរបស់ព្រះសហគមន៍។ គ្រីស្តបរិស័ទធម្មតាត្រូវតែ "ធ្វើឲ្យតថភាពនៅក្នុងលោកនេះ មានជីវិតរស់រវើក ដោយចិត្តខ្នះខ្នែងនៃគ្រីស្តបរិស័ទ ហើយដោយមានរបៀបរស់នៅដូចជាអ្នកកសាងសន្តិភាព និងយុត្តិធម៌" (SRS ៤៧ ; SRS ៤២)។

## ៦. សេចក្តីស្រឡាញ់ចំពោះជនក្រីក្រ

២៤៤៣- ព្រះជាម្ចាស់ប្រទានពរដល់អស់អ្នក ដែលមកជួយអ្នកក្រីក្រ ហើយស្តីបន្ទោសអស់អ្នក ដែលគេចចេញឆ្ងាយពីគេ៖ "អ្នកណាសុំអ្វីពីអ្នក ចូរឲ្យគេទៅ ហើយកុំគេចមុខចេញពីអ្នកដែលសុំខ្ចីអ្វីៗពីអ្នកដែរ" (មថ ៥,៤២)។ "អ្នករាល់គ្នាបានទទួលអំណាចដោយឥតបង់ថ្លៃ ត្រូវជួយគេវិញដោយឥតគិតថ្លៃដែរ" (មថ ១០,៨)។ ព្រះយេស៊ូគ្រីស្តនឹងទទួលស្គាល់អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើសតាមអំពើ ដែលគេបានប្រព្រឹត្តចំពោះអ្នកក្រីក្រ (មថ ២៥,៣១-៣៦)។ នៅពេលដែល "មានគេនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ" (មថ ១១,៥) (លក ៤,១៨) ជាសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះគ្រីស្ត។

២៤៤៤- "សេចក្តីស្រឡាញ់របស់ព្រះសហគមន៍ចំពោះជនក្រីក្រ (...) ជាប្រពៃណីដ៏ស្ថិតស្ថេរនៃព្រះសហគមន៍ (CA ៥៧)។ ដំណឹងល្អអំពីសុភមង្គលយ៉ាងពិតប្រាកដ (លក ៦,២០-២២) ភាពក្រីក្ររបស់ព្រះយេស៊ូ (មថ ៨,២០) និងការចាប់អារម្មណ៍របស់ព្រះអង្គចំពោះអ្នកក្រីក្រ (មក ១២,៤១-៤៤) ជួយបំភ្លឺសេចក្តីស្រឡាញ់នេះ។

សេចក្តីស្រឡាញ់ចំពោះអ្នកក្រីក្រជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងទៀតដែលថា ត្រូវតែធ្វើការ ដើម្បី "យកផលទៅជួយអ្នកដែលខ្វះខាត" (អភ ៤,២៨)។ សេចក្តីស្រឡាញ់នេះ មិនគ្រាន់តែទាក់ទងនឹងភាពក្រីក្រ ខាងសម្ភារៈប៉ុណ្ណោះទេ ថែមទាំងទាក់ទងនឹងរបៀបផ្សេងៗទៀតជាច្រើននៃភាពក្រីក្រ ដូចជាភាពក្រីក្រខាង វប្បធម៌ និងខាងសាសនា (CA ៥៧)។

២៤៤៥- សេចក្តីស្រឡាញ់ចំពោះជនក្រីក្រមិនអាចប្រដូចនឹងការស្រឡាញ់ទ្រព្យសម្បត្តិហួសហេតុ ឬការ ប្រើប្រាស់ទ្រព្យនោះ ដើម្បីតែបុគ្គលខ្លួនឯង៖

> ពួកអ្នកមានអើយ! ចូរស្រែកទ្រហោយំទៅ ព្រោះទុក្ខលំបាកនឹងកើតមានដល់អ្នករាល់គ្នាជាពុំខាន! ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នារលួយអស់ ហើយសម្លៀកបំពាក់របស់អ្នករាល់គ្នាក៏ត្រូវកណ្ដៀរស៊ីដែរ។ មាស ប្រាក់របស់អ្នករាល់គ្នាត្រូវច្រែះស៊ី ហើយច្រែះនេះ ធ្វើជាបន្ទាល់ទាស់នឹងអ្នករាល់គ្នា ព្រមទាំងស៊ីសាច់ អ្នករាល់គ្នា ដូចភ្លើងឆេះសុសដែរ។ គ្រានេះ ជាគ្រាចុងក្រោយបំផុត អ្នករាល់គ្នាបានប្រមូលទ្រព្យសម្បត្តិ ទុក ឥតបើកប្រាក់ឈ្នួលឲ្យពួកកម្មករដែលច្រូតកាត់ក្នុងស្រែរបស់អ្នករាល់គ្នាឡើយ។ មើល៍! សម្រែកអ្នក ច្រូតទាំងនោះ បានលាន់ទៅដល់ព្រះអម្ចាស់នៃពិភពទាំងមូល។ អ្នករាល់គ្នារស់នៅលើផែនដីនេះយ៉ាង សម្បូណ៌សប្បាយ ថ្កុំថ្កើង រុងរឿង ហើយអ្នករាល់គ្នាបំពេញបំណងចិត្តខ្លួនយ៉ាងឆ្អែតស្កប់ស្កល់ ដូចនៅថ្ងៃ ដែលគេសម្លាប់សត្វ។ អ្នករាល់គ្នាបានដាក់ទោស និងប្រហារជីវិតមនុស្សសុចរិត តែគេពុំបានប្រឆាំងតបត នឹងអ្នករាល់គ្នាវិញឡើយ (យក ៥,១-៦)។

២៤៤៦- សន្តៈ យ៉ូហាន គ្រីសូស្តូម ប្រមានយ៉ាងតឹងរ៉ឹងថា៖ "ពេលណាយើងមិនធ្វើឲ្យអ្នកក្រីក្រមានចំណែក ក្នុងទ្រព្យសម្បត្តិរបស់ខ្លួន ពេលនោះយើងលួចប្លន់ និងប្រហារជីវិតគេ។ យើងមិនរក្សាទុកទ្រព្យសម្បត្តិរបស់ខ្លួន ឯងទេ យើងរក្សាទុកទ្រព្យសម្បត្តិរបស់គេ"។ "ត្រូវបំពេញការទាមទារនៃយុត្តិធម៌ជាមុនសិន ក្រែងលោយើងធ្វើ ទានក្នុងនាមសេចក្តីស្រឡាញ់ ហើយគេថាទាននោះ ស្របតាមយុត្តិធម៌តែប៉ុណ្ណោះ" (AA ៨)៖

> នៅពេលដែលយើងចែកឲ្យអ្នកក្រីក្ររបស់របរចាំបាច់ យើងគ្មានចិត្តសប្បុរសទេ ប៉ុន្តែ យើងសងគេអ្វី ដែលជារបស់គេ។ យើងបំពេញភារកិច្ចនៃយុត្តិធម៌ច្រើនជាងយើងប្រព្រឹត្តកិច្ចការនៃសេចក្តីស្រឡាញ់ (សន្តៈ គ្រេគ័រដ៏ប្រសើរ)។

២៤៤៧- ដោយសារកិច្ចការនៃធម៌មេត្តាករុណា យើងជួយអ្នកដទៃ ទៅតាមតម្រូវការខាងផ្លូវកាយ និងខាង ផ្លូវចិត្តរបស់គេ (អស ៥៨,៦-៧ ; ហប ១៣,៣)។ កិច្ចការនៃធម៌មេត្តាករុណាខាងវិញ្ញាណ មានដូចជាបង្រៀន ផ្តល់ដំបូន្មាន លួងលោម លើកទឹកចិត្ត លើកលែងទោស ស៊ូទ្រាំដោយចិត្តអត់ធ្មត់។ កិច្ចការនៃធម៌មេត្តាករុណា ខាងផ្លូវកាយ មានដូចជាផ្តល់អាហារដល់អ្នកស្រេកឃ្លាន ផ្តល់ជម្រកដល់ជនអនាថា ផ្តល់សម្លៀកបំពាក់ដល់អ្នក ខ្លួនទទេ សួរសុខទុក្ខអ្នកជំងឺ និងអ្នកទោស បញ្ចុះសពអ្នកស្លាប់ (មថ ២៥,៣១-៤៦)។ ក្នុងចំណោម កិច្ចការទាំងអស់នោះ ការធ្វើទានដល់ជនក្រីក្រ (តប ៤,៥-១១ ; បសរ ១៧,២២) ផ្តល់សក្ខីភាពខ្លាំងណាស់អំពី សេចក្តីស្រឡាញ់ចំពោះអ្នកដទៃទុកជាបងប្អូន ហើយជារបៀបប្រតិបត្តិតាមយុត្តិធម៌ ដែលគាប់ព្រះហឫទ័យរបស់ ព្រះជាម្ចាស់ (មថ ៦,២-៤)៖

> អ្នកណាមានអាវពីរ ត្រូវចែកឲ្យអ្នកដែលគ្មាន ហើយអ្នកដែលមានចំណីអាហារក៏ត្រូវចែកឲ្យអ្នកគ្មាន ដែរ (លក ៣,១១)។ ចូរយកអ្វីៗនៅក្នុងចានធ្វើទានដល់ជនក្រីក្រទៅនោះ ប្រដាប់ប្រដាទាំងអស់នឹងបាន ស្អាតបរិសុទ្ធសម្រាប់ឲ្យអ្នករាល់គ្នាប្រើប្រាស់ (លក ១១,៤១)។ ប្រសិនបើបងប្អូនប្រុស ឬស្រីណាម្នាក់

គ្មានសម្លៀកបំពាក់បិទបាំងខ្លួន និងគ្មានម្ហូបអាហារបរិភោគរាល់ថ្ងៃ ហើយមានម្នាក់ ក្នុងចំណោមបងប្អូន ពោលទៅគាត់ថា៖ "សូមអញ្ជើញទៅដោយសុខសាន្ត សូមឲ្យបានកក់ក្តៅ សូមបរិភោគឲ្យបានឆ្អែត!" តែមិនឲ្យអ្វីៗដែលគេត្រូវការ តើពាក្យទាំងនេះមានប្រយោជន៍អ្វី" (យក ២,១៥-១៦) (១យហ ៣,១៧)។

២៤៤៨- "ដោយមានបែបផែនផ្សេងៗពីគ្នា ដូចជាការខ្វះខាតខាងសម្ភារៈ ការសង្កត់សង្កិនជិះជាន់ ពិការភាពខាងផ្លូវកាយ និងខាងផ្លូវចិត្ត ហើយទីបញ្ចប់មរណភាព ភាពវេទនារបស់មនុស្ស ជាសញ្ញាសម្គាល់ជាក់ច្បាស់នៃភាពទន់ខ្សោយរបស់មនុស្ស តាំងពីអំពើបាបដើមដំបូង និងអំពីតម្រូវការនៃការសង្គ្រោះ។ ហេតុនេះហើយ បានជាភាពវេទនារបស់មនុស្សនេះ បានទាក់ទាញធម៌មេត្តាករុណារបស់ព្រះគ្រីស្ត ជាព្រះសង្គ្រោះ ដែលសព្វព្រះហឫទ័យទទួលយកភាពវេទនានេះ និងឲ្យ "អ្នកតូចតាចជាងគេបំផុត" ទៅជារូបតំណាងរបស់ព្រះអង្គ។ ហេតុនេះហើយ បានជាតាំងពីដើមដំបូង ព្រះសហគមន៍ស្រឡាញ់ អស់អ្នកដែលត្រូវរងទុក្ខវេទនាច្រើនជាងគេ។ ទោះបីសមាជិកច្រើនរបស់ព្រះសហគមន៍មិនបានបំពេញភារកិច្ចរបស់ខ្លួនយ៉ាងក៏ដោយ ក៏ព្រះសហគមន៍តែងតែធ្វើការឲ្យជួយសម្រាលទុក្ខ ការពារ និងរំដោះអ្នកទាំងអស់នោះដែរ។ ព្រះសហគមន៍បានសម្រាលទុក្ខពួកគេ ដោយប្រព្រឹត្តកិច្ចការនៃសេចក្តីស្រឡាញ់ជាច្រើនអនេក ដែលនៅតែចាំបាច់គ្រប់ទីកន្លែង និងគ្រប់ពេលវេលា" (CDF)។

២៤៤៩- ក្នុងសម្ពន្ធមេត្រីចាស់ហើយ បទបញ្ញាគ្រប់ប្រភេទ (ឆ្នាំនៃធម៌មេត្តាករុណា ការហាមប្រាមមិនឲ្យខ្ចីដោយយកការប្រាក់ និងមិនឲ្យទទួលរបស់បញ្ចាំ ការបង់ពន្ធសម្រាប់ព្រះវិហារ ការបើកប្រាក់ឈ្នួលកម្មករប្រចាំថ្ងៃជារៀងរាល់ថ្ងៃ សិទ្ធិរើសសន្សំកួរស្រូវដែលជ្រុះនៅលើដី) ឆ្លើយតបនឹងពាក្យដាស់តឿននៃកណ្ឌទុតិយកថា៖ "នៅក្នុងស្រុក តែងតែមានអ្នកក្រជានិច្ច ហេតុនេះហើយ បានជាខ្ញុំបង្គាប់អ្នកឲ្យមានចិត្តទូលាយដល់បងប្អូនរបស់អ្នកដែលក្រីក្រកំសត់ទុគ៌ត នៅក្នុងស្រុក" (ទក ១៥,១១)។ ព្រះយេស៊ូយកព្រះបន្ទូលនេះទុកជាព្រះបន្ទូលរបស់ព្រះអង្គដែរ៖ "អ្នកក្រីក្រនៅជាមួយអ្នករាល់គ្នារហូត រីឯខ្ញុំវិញ ខ្ញុំមិននៅជាមួយអ្នករាល់គ្នារហូតទេ" (យហ ១២,៨)។ ព្រះអង្គមិនលុបបំបាត់ពាក្យដាស់តឿនបុរាណ៖ "អ្នករាល់គ្នាយកប្រាក់ទៅទិញជនទុគ៌ត យកស្បែកជើងមួយគូទៅដូរយកជនក្រីក្រ..." (អម ៨,៦) ប៉ុន្តែ ព្រះអង្គអញ្ជើញយើងឲ្យទទួលស្គាល់វត្តមានរបស់ព្រះអង្គក្នុងជនក្រីក្រ ដែលជាបងប្អូនរបស់ព្រះអង្គ (មថ ២៥,៤០)៖

> ថ្ងៃដែលម្តាយរបស់គាត់ស្តីបន្ទោសថាគាត់ទទួលអ្នកក្រីក្រ និងជនពិការឲ្យស្នាក់នៅក្នុងផ្ទះ សន្តី រ៉ូស នៅលីម៉ាប្រាប់ម្តាយថា៖"នៅពេលដែលយើងជួយបម្រើអ្នកក្រីក្រនិងអ្នកជំងឺយើងក៏ជួយបម្រើព្រះយេស៊ូដែរ។ យើងមិនត្រូវធុញទ្រាន់នឹងជួយអ្នកដទៃទេ ដ្បិតនៅក្នុងខ្លួនគេ យើងបម្រើព្រះយេស៊ូ"។

## សង្ខេប

២៤៥០- "កុំលួចទ្រព្យសម្បត្តិគេ" (ទក ៥,១៩)។ "ពួកចោរប្លន់ ពួកលោភលន់ចង់បានទ្រព្យគេ ពុំអាចទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ទុកជាមត៌កបានឡើយ" (១ករ ៦,១០)។

២៤៥១- វិន័យទីប្រាំពីរបញ្ញាឲ្យអនុវត្ត ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិលោកីយ៍ និងផលនៃការងារមនុស្សលោកដោយយុត្តិធម៌ និងដោយសេចក្តីស្រឡាញ់។

២៤៥២- ព្រះជាម្ចាស់ទុកទ្រព្យសម្បត្តិនៃពិភពលោកឲ្យមនុស្សជាតិទាំងមូល។ ទោះបីច្បាប់តម្រូវឲ្យមនុស្សមានកម្មសិទ្ធិឯកជនយ៉ាងណាក៏ដោយ ក៏មិនត្រូវភ្លេចថា ព្រះជាម្ចាស់ប្រទានផែនដីសម្រាប់មនុស្សជាតិទាំងមូលដែរ។

២៤៥៣- វិន័យទីប្រាំពីរហាមលួចគេ។ ការលួចជាការរំលោភទ្រព្យសម្បត្តិអ្នកដទៃ នៅពេលដែលម្ចាស់វាមិន

យល់ព្រមប្រគល់ឲ្យដោយមានមូលហេតុត្រឹមត្រូវ។

២៤៥៤- បើយើងយក ឬប្រើតាមរបៀបមិនត្រឹមត្រូវទ្រព្យសម្បត្តិរបស់គេ យើងប្រឆាំងនឹងវិន័យទីប្រាំពីរ។ ត្រូវទូទាត់អំពើអយុត្តិធម៌ ដែលបានប្រព្រឹត្ត។ ត្រូវសងទ្រព្យសម្បត្តិដែលបានលួចឲ្យម្ចាស់ដើមរបស់វាវិញ។

២៤៥៥- ច្បាប់សីលធម៌ហាមប្រាមប្រព្រឹត្តអំពើ ឬមុខរបរ ដែលនាំឲ្យប្រើប្រាស់មនុស្សដូចជាទាសករ ទិញលក់ និងផ្លាស់ប្តូរគេដូចទំនិញ ទោះជាដើម្បីប្រយោជន៍ផ្ទាល់ និងមូលហេតុផ្តាច់ការក៏ដោយ។

២៤៥៦- ការគ្រប់គ្រង ដែលព្រះជាម្ចាស់ប្រគល់ឲ្យមនុស្សលើធនធានខនិច រុក្ខជាតិ និងសត្វនៃសកលលោក ត្រូវតែគោរពសីលធម៌ ព្រមទាំងអ្នកជំនាន់ក្រោយៗដែរ។

២៤៥៧- ព្រះជាម្ចាស់ប្រគល់សត្វឲ្យមនុស្សត្រួតត្រាដោយយកចិត្តទុកដាក់។ ពួកវាអាចបំពេញតម្រូវការដ៏ត្រឹមត្រូវរបស់មនុស្សបាន។

២៤៥៨- ព្រះសហគមន៍វិនិច្ឆ័យខាងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ស្របតាមសីលធម៌ ប្រសិនបើសិទ្ធិមូលដ្ឋានរបស់មនុស្ស ឬការសង្គ្រោះនៃព្រលឹងទាមទារ។ ព្រះសហគមន៍គិតគូរដល់ប្រយោជន៍រួមនៃលោកនេះ ដើម្បីឲ្យការចាត់ចែងនោះបានល្អប្រសើរបំផុត ដែលជាទីដៅចុងក្រោយរបស់យើង។

២៤៥៩- មនុស្សខ្លួនឯងជាអ្នកបង្កើត ជាស្នូល និងជាទិសដៅនៃជីវិតខាងសេដ្ឋកិច្ច និងការរស់នៅក្នុងសង្គម។ ចំណុចសំខាន់បំផុតនៃយុត្តិធម៌ក្នុងសង្គម គឺឲ្យទ្រព្យដែលព្រះជាម្ចាស់បានបង្កើតសម្រាប់មនុស្ស ទាំងអស់ពិតជាមកដល់មនុស្សទាំងអស់មែន តាមភាពយុត្តិធម៌ និងដោយមានសេចក្តីស្រឡាញ់ជួយផងដែរ។

២៤៦០- តម្លៃដ៏ខ្ពង់ខ្ពស់នៃការងារមកពីមនុស្សខ្លួនឯង ដែលជាអ្នកបង្កើត និងជាទិសដៅនៃការងារ។ តាមការងាររបស់ខ្លួន មនុស្សរួមចំណែកក្នុងស្នាព្រះហស្តនៃការបង្កើតពិភពលោក។ ដោយរួមរស់ជាមួយព្រះគ្រិស្ត ការងារអាច ជួយសង្គ្រោះមនុស្ស។

២៤៦១- ការអភិវឌ្ឍន៍ពិតប្រាកដជាការអភិវឌ្ឍន៍របស់មនុស្សទាំងស្រុង។ គឺជាការជួយមនុស្សឲ្យមានសមត្ថភាពអាចឆ្លើយតបនឹងទិសដៅរបស់ខ្លួន ដែលជាការត្រាស់ហៅរបស់ព្រះជាម្ចាស់ (CA ២៩)។

២៤៦២- ការធ្វើទានចំពោះអ្នកក្រីក្រផ្តល់សក្ខីភាព អំពីសេចក្តីស្រឡាញ់ចំពោះអ្នកដទៃទុកជាបងប្អូន ហើយជារបៀបប្រតិបត្តិតាមយុត្តិធម៌ ដែលគាប់ព្រះឫទ័យព្រះជាម្ចាស់។

២៤៦៣- ក្នុងចំណោមមហាជនដែលគ្មានអាហារ គ្មានជម្រក គ្មានទីលំនៅ តើធ្វើដូចម្តេចកុំឲ្យស្គាល់លោកឡាសារ ជាអ្នកសុំទានក្នុងពាក្យប្រស្នា (លក ១៦,១៩-៣១) ? តើធ្វើដូចម្តេចកុំឲ្យស្តាប់ព្រះបន្ទូលព្រះយេស៊ូថា៖ "អ្នករាល់គ្នាក៏ដូចជា មិនបានប្រព្រឹត្តចំពោះយើងដែរ" (មថ ២៥,៤៥) ?។

# ប្រការទី៨៖

## វិន័យទីប្រាំបី

- កុំធ្វើសាក្សីក្លែងក្លាយដែលនាំឲ្យអ្នកដទៃមានទោស (សរ២០,១៦)។

អ្នករាល់គ្នាធ្លាប់បានឮសេចក្តី ដែលមានថ្លែងប្រាប់បុព្វបុរសថា៖ "កុំបំភ្លេចពាក្យសម្បថចោលឡើយ។ ត្រូវតែធ្វើតាមគ្រប់ពាក្យដែលអ្នកបានស្បថនឹងព្រះអម្ចាស់" (មថ៥,៣៣)។

២៤៦៤-វិន័យទីប្រាំបីហាមមិនឲ្យបង្ខូចសេចក្តីពិតក្នុងទំនាក់ទំនងជាមួយអ្នកដទៃ។ បទបញ្ញានៃសីលធម៌នេះហូរចេញមកពីលក្ខណៈនៃប្រជាជនដ៏វិសុទ្ធ ដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យទៅជាសាក្សីនៃព្រះរបស់គេ ដែលជាសេចក្តីពិត ហើយដែលសព្វព្រះហឫទ័យនឹងសេចក្តីពិត។ អំពើបាបប្រឆាំងនឹងសេចក្តីពិតបង្ហាញថា យើងមិនព្រមកាន់សីលធម៌ តាមពាក្យសម្តី ឬតាមកិច្ចការ គឺអ្នកប្រព្រឹត្តអំពើទាំងអស់នោះ ក្បត់ព្រះជាម្ចាស់យ៉ាងជាក់ច្បាស់ ទើបកម្ទេចគ្រឹះនៃសម្ព័ន្ធមេត្រី។

## ១. ការរស់នៅក្នុងសេចក្តីពិត

២៤៦៥- គម្ពីរសម្ព័ន្ធមេត្រីចាស់បញ្ជាក់ថា ព្រះជាម្ចាស់ជាប្រភពនៃសេចក្តីពិត។ ព្រះបន្ទូលព្រះអង្គជាសេចក្តីពិត (សុភ ៨,៧ ; ២សម ៧,២៨)។ ធម្មវិន័យព្រះអង្គជាសេចក្តីពិត (ទន ១១៩,១៤២)។ "ព្រះហឫទ័យស្មោះស្ម័គ្ររបស់ព្រះអង្គនៅស្ថិតស្ថេរអស់កល្បជាអង្វែងតរៀងទៅ" (ទន ១១៩,៩០) (លក ១,៥០)។ ដោយសារព្រះជាម្ចាស់ "សុចរិតឥតល្អៀងក្នុងព្រះបន្ទូលសោះឡើយ" (រម ៣,៤) ព្រះអង្គត្រាស់ហៅសមាជិកប្រជាជនព្រះអង្គឲ្យរស់នៅក្នុងសេចក្តីពិត (ទន ១១៩,៣០)។

២៤៦៦- ព្រះយេស៊ូគ្រីស្តបានសម្តែងសេចក្តីពិតទាំងស្រុងរបស់ព្រះជាម្ចាស់។ ព្រះអង្គ "ពោរពេញទៅដោយព្រះហឫទ័យប្រណីសន្តោស និងសេចក្តីពិត" (យហ ១,១៤) ព្រះអង្គ "ជាពន្លឺបំភ្លឺពិភពលោក" (យហ ៨,១២) ព្រះអង្គក៏ជាសេចក្តីពិត (យហ ១៧,១៧)។ "អស់អ្នកដែលជឿលើ (ព្រះអង្គ) មិនស្ថិតនៅក្នុងភាពងងឹតឡើយ" (យហ ១២,៤៦)។ សាវ័ករបស់ព្រះយេស៊ូ "ស្ថិតនៅជាប់នឹងព្រះបន្ទូលព្រះអង្គ" ដើម្បីស្គាល់ "សេចក្តីពិត ដែលរំដោះឲ្យមានសេរីភាព" (យហ ៨,៣២) ហើយដែលប្រោសឲ្យបានវិសុទ្ធ (យហ ១៤,៦)។ អ្នកណាដើរតាមព្រះយេស៊ូរស់នៅក្នុងអង្គ "ព្រះវិញ្ញាណនៃសេចក្តីពិត" (យហ ១៤,១៧) ដែលព្រះបិតាចាត់ឲ្យយាងមកក្នុងព្រះនាមព្រះអង្គ (យហ ១៤,២៦) ហើយដែល "នាំឲ្យស្គាល់សេចក្តីពិតគ្រប់ប្រការ" (យហ ១៦,១៣)។ ព្រះយេស៊ូបង្រៀនក្រុមសាវ័ករបស់ព្រះអង្គឲ្យស្រឡាញ់សេចក្តីពិ ដោយគ្មានល័ក្ខខ័ណ្ឌ៖ "ត្រូវនិយាយឲ្យទៀងទាត់ បើ "មែន" ឲ្យប្រាកដជា "មែន"បើ "ទេ" ឲ្យប្រាកដជា "ទេ"" (មថ ៥,៣៧)។

២៤៦៧- មនុស្សមានលក្ខណៈធម្មជាតិទៅរកសេចក្តីពិត។ គេត្រូវលើកតម្កើង និងបញ្ជាក់សេចក្តីពិត៖ "ដោយសារកិត្តិយសដ៏ថ្លៃថ្នូររបស់ខ្លួន មនុស្សទាំងអស់ (ដ្បិតពួកគេជាបុគ្គល) (...) មានលក្ខណៈធម្មជាតិរបស់ខ្លួន និងកាតព្វកិច្ចទៅតាមសីលធម៌ ក្នុងការស្វែងរកសេចក្តីពិត ជាដំបូងសេចក្តីពិតទាក់ទងនឹងសាសនា។ នៅពេលដែលគេស្គាល់សេចក្តីពិត គេក៏ជាប់ចិត្តនឹងសេចក្តីពិតនេះ និងកំណត់ការរស់នៅទាំងស្រុងរបស់គេ តាមការទាមទារនៃសេចក្តីពិត" (DH ២)។

២៤៦៨- គេហៅការប្រកាន់ភ្ជាប់នូវការពិតគឺជាភាពស្មោះត្រង់ដែលសម្តែងចេញមកតាមរយៈកិច្ចការ ឬពាក្យសម្តី។ សេចក្តីពិត ឬការប្រកាន់ភ្ជាប់នូវការពិត ជាគុណធម៌ ដែលយើងបង្ហាញចេញមកដោយប្រព្រឹត្តតែកិច្ចការពិត និងពោលតែពាក្យសម្តីពិត ដោយរក្សាខ្លួនមិនប្រើល្បិច កលល្បែងបន្លំ និងលាក់ពុតឡើយ។

២៤៦៩- "មនុស្សមិនអាចរស់នៅជាមួយគ្នា បើគេមិនទុកចិត្ត លើគ្នាទៅវិញទៅមក ពោលគឺបើគេមិនសម្តែងការពិត" (សន្តៈ ថូម៉ាស នៃអាកាំង)។ គុណធម៌នៃសេចក្តីពិតផ្តល់ឲ្យអ្នកដទៃអ្វីដែលត្រូវសងគេ។ ការប្រកាន់ភ្ជាប់នូវការពិតជាផ្លូវកណ្តាលរវាងអ្វីដែលត្រូវចេញមកប្រាប់ និងការសម្ងាត់ដែលត្រូវរក្សាទុក គឺត្រូវតែមានចិត្តស្មោះត្រង់ និងចេះលាក់រឿងសម្ងាត់។ "មនុស្សម្នាក់ត្រូវសម្តែងការពិតទៅមនុស្សម្នាក់ទៀត ដោយស្មោះត្រង់"

(សន្ត: ថូម៉ាស នៃអាកាំង)។

២៤៧០- សាវ័ករបស់ព្រះគ្រីស្តសុខចិត្ត "រស់នៅក្នុងសេចក្តីពិត" ពោលគឺដោយរស់នៅយ៉ាងសាមញ្ញ ដែលមានព្រះអម្ចាស់ជាគំរូ និងដោយស្ថិតនៅជាប់នឹងសេចក្តីពិត។ "ប្រសិនបើយើងពោលថា យើងរួមរស់ជាមួយព្រះអង្គ តែយើងបែរជារស់ក្នុងសេចក្តីងងឹតទៅវិញនោះ យើងនិយាយកុហកហើយ គឺយើងមិនប្រតិបត្តិតាមសេចក្តីពិតទេ" (១យហ ១,៦)។

## ២. "ផ្តល់សក្ខីភាពអំពីសេចក្តីពិត"

២៤៧១- ពីមុខលោកពីឡាត ព្រះយេស៊ូប្រកាសថា ព្រះអង្គយាងមក "ក្នុងលោកនេះ ដើម្បីផ្តល់សក្ខីភាពអំពីសេចក្តីពិត" (យហ ១៨,៣៧)។ គ្រីស្តបរិស័ទ "មិនត្រូវខ្មាសនឹងផ្តល់សក្ខីភាពអំពីព្រះអម្ចាស់" (២ទម ១,៨)។ ក្នុងស្ថានភាពដែលទាមទារឲ្យបញ្ជាក់ជំនឿ គ្រីស្តបរិស័ទត្រូវប្រកាសជំនឿនេះ យ៉ាងច្បាស់លាស់ ដូចសន្ត: ប៉ូលចំពោះចៅក្រមរបស់លោកផងដែរ។ គ្រីស្តបរិស័ទត្រូវតែរក្សា "ចិត្តស្អាតបរិសុទ្ធគ្រប់ជំពូក ចំពោះព្រះជាម្ចាស់ និងចំពោះមនុស្សលោក" (កក ២៤,១៦)។

២៤៧២- ភារកិច្ចរបស់គ្រីស្តបរិស័ទឲ្យចូលរួម ក្នុងការរស់នៅរបស់ព្រះសហគមន៍ ជំរុញគេឲ្យប្រព្រឹត្ត ដូចជាសាក្សីនៃដំណឹងល្អ និងសាក្សីនៃកាតព្វកិច្ចដែលហូរចេញមកពីដំណឹងល្អ។ សក្ខីភាពនេះ បញ្ជូនជំនឿតាមពាក្យសម្តីផង តាមកិច្ចការផង។ សក្ខីភាពនេះ ជាកិច្ចការស្របតាមយុត្តិធម៌ ដែលតែងតាំង ឬធ្វើឲ្យគេស្គាល់សេចក្តីពិត (មថ ១៨,១៦)៖

> ទោះជារស់នៅកន្លែងណាក៏ដោយ ក៏គ្រីស្តបរិស័ទមានភារកិច្ចបង្ហាញបញ្ជាក់ថា គេបានកើតជាថ្មីដោយរួបរួមជាមួយព្រះគ្រីស្ត។ នៅពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក គេក៏បានទទួលកម្លាំងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដោយអគ្គសញ្ញាលាបថ្វាសដែរ។ គេផ្តល់សក្ខីភាពនេះ ដោយធ្វើជាគំរូក្នុងការរស់នៅ និងពោលតែពាក្យពិត (AG ១១)។

២៤៧៣- មរណសាក្សី ផ្តល់សក្ខីភាពដ៏អស្ចារ្យជាទីបំផុតអំពីសេចក្តីពិតនៃជំនឿ គឺគាត់ផ្តល់សក្ខីភាពរហូតដល់ទទួលមរណភាព។ មរណសាក្សីផ្តល់សក្ខីភាពអំពីព្រះគ្រីស្ត ដែលបានសោយទិវង្គត និងទទួលព្រះជន្មថ្មីដោយរួបរួមជាមួយព្រះអង្គក្នុងសេចក្តីស្រឡាញ់។ គាត់ផ្តល់សក្ខីភាពអំពីសេចក្តីពិតនៃជំនឿ និងអំពីលទ្ធិនៃគ្រីស្តសាសនា។ គាត់ស៊ូស្លាប់ ដោយក្លាហាន។ "ទុកឲ្យខ្ញុំទៅជាចំណីសត្វសាហាវចុះ។ សត្វទាំងអស់នោះ នឹងជួយខ្ញុំឲ្យទៅជួបព្រះជាម្ចាស់" (សន្ត: អ៊ីញ៉ាស នៃអង់ទីអូស)។

២៤៧៤- ដោយការយកចិត្តទុកដាក់ជាទីបំផុត ព្រះសហគមន៍បានទទួលយកអនុស្សាវរីយ៍របស់អស់អ្នកដែលទៅដល់ទីបញ្ចប់ ដើម្បីបញ្ជាក់ជំនឿរបស់គេ និងដែលគេហៅថា កិច្ចការរបស់មរណសាក្សី។ អនុស្សាវរីយទាំងនោះ ជាឯកសារដើមនៃសេចក្តីពិតសរសេរដោយអក្សរឈាម៖

> តើការសប្បាយនៃលោកីយ៍នេះ នឹងអំណាចទាំងប៉ុន្មាននៅលើផែនដីនេះ មានប្រយោជន៍អ្វីសម្រាប់ខ្ញុំ? ការបាត់បង់ជីវិត ដើម្បីជួបព្រះគ្រីស្តយេស៊ូ ប្រសើរជាងគ្រប់គ្រងពិភពលោកទាំងមូល។ ខ្ញុំស្វែងរកតែព្រះគ្រីស្តប៉ុណ្ណោះទេ គឺព្រះអង្គដែលសោយទិវង្គត ព្រោះតែយើង។ ខ្ញុំចង់បានតែព្រះអង្គទេ គឺព្រះអង្គ ដែលមានជីវិតថ្មីសម្រាប់យើង។ ពេលខ្ញុំកើតសាជាថ្មីមកដល់ហើយ... (សន្ត: អ៊ីញ៉ាស នៃអង់ទីអូស)។
>
> ខ្ញុំសូមលើកតម្កើងព្រះអង្គ ដែលផ្តល់កិត្តិយសឲ្យខ្ញុំក្នុងថ្ងៃនេះ វេលានេះ សមនឹងបញ្ចូលខ្ញុំក្នុងចំណោម

មរណសាក្សីរបស់ព្រះអង្គ (...)។ ព្រះអង្គជាព្រះនៃភក្តីភាព និងសេចក្តីពិត ទ្រង់បានរក្សាព្រះបន្ទូលសន្យារបស់ព្រះអង្គ។ខ្ញុំសូមកោតសរសើរអរព្រះគុណនិងលើកតម្កើងសិរីរុងរឿងព្រះអង្គដើម្បីព្រះអំណោយទាននេះ និងអ្វីៗទាំងអស់ តាមរយៈមហាបូជាចារ្យអស់កល្បជានិច្ច ដែលគង់នៅស្ថានបរមសុខ គឺព្រះយេស៊ូគ្រីស្ត ជាបុត្រដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ដោយព្រះគ្រីស្ត ដែលគង់នៅជាមួយព្រះអង្គ រួមជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន (សន្តៈ ប៉ូលីកាប)។

## ៣. អំពើបាបប្រឆាំងនឹងសេចក្តីពិត

២៤៧៥- សាវ័ករបស់ព្រះគ្រីស្តបាន "ពាក់ជីវិតថ្មីដ៏សុចរិត និងវិសុទ្ធ មកពីសេចក្តីពិត ជាជីវិតដែលព្រះជាម្ចាស់បានបង្កើត ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ" (អភ ៤,២៤)។ ពួកគាត់បាន "ឈប់និយាយកុហក" ពួកគាត់ត្រូវ "លះបង់អំពើអាក្រក់គ្រប់យ៉ាង ល្បិចកិច្ចកលទាំងប៉ុន្មាន ការលាក់ពុត ចិត្តច្រណែនឈ្នានីស និងការនិយាយដើមគេជាដើម" (១ពត្រ ២,១)។

២៤៧៦- សក្ខីភាពក្លែងក្លាយ និងសម្បថបំពាន។ នៅពេលដែលយើងពោលពាក្យសម្តីប្រឆាំងនឹងការពិត ជាសាធារណៈ យើងប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរ។។ ពីមុខតុលាការ ពាក្យសម្តីនេះ ទៅជាសក្ខីភាពក្លែងក្លាយ (សុភ ១៩,៩)។ នៅពេលស្បថ គេហៅថា សម្បថបំពាន។ របៀបប្រព្រឹត្តទាំងអស់នោះ ធ្វើឲ្យគេដាក់ទោសមនុស្សម្នាក់ដែលគ្មានកំហុស ឬលើកលែងអ្នកមានទោស ឬធ្វើឲ្យគេដាក់ទោសលើអ្នកជាប់ចោទច្រើនជាងមុនទៅទៀត (សុភ ១៨,៥)។ សក្ខីភាពក្លែងក្លាយនោះ នាំឲ្យចៅក្រមមិនអាចកាត់ក្តីបានយុត្តិធម៌ឡើយ។

២៤៧៧- យើងមិនអាចប្រកាន់ឥរិយាបទ ឬពោលពាក្យសម្តីណាមួយ ដែលមិនគោរពកេរ្តិ៍ឈ្មោះ របស់នរណាម្នាក់បានឡើយ (CIC ២២០)៖ អ្នកប្រព្រឹត្តខុសដូចខាងក្រោមនេះ ជាអ្នកប្រព្រឹត្តអំពើបាប៖

- ជនបុរេវិនិច្ឆ័យជាអ្នក ដែលទទួលស្គាល់គុណវិបត្តិផ្លូវចិត្តរបស់អ្នកដទៃថា ជាការពិត ដោយមិនបានពិនិត្យមើលយ៉ាងល្អិតល្អន់ ទោះជាសម្ងាត់ក៏ដោយ
- អ្នកនិយាយដើមគេ ជាអ្នក ដែលលាតត្រដាងគុណវិបត្តិ និងកំហុសរបស់អ្នកដទៃ ឲ្យគេស្គាល់ដោយគ្មានមូលហេតុត្រឹមត្រូវ (បសរ ២១,២៨)
- អ្នកនិយាយបង្កាច់បង្ខោនគេ ជាអ្នក ដែលបង្ខូចកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ដោយភូតកុហក ធ្វើឲ្យគេវិនិច្ឆ័យខុសចំពោះអ្នកនេះ។

២៤៧៨- ម្នាក់ៗនឹងប្រុងប្រយ័ត្នក្នុងការបកស្រាយចិត្តគំនិត ពាក្យសម្តី និងកិច្ចការរបស់អ្នកដទៃ តាមរបៀបវិជ្ជមាន និងតាមតែអាចធ្វើបាន ដើម្បីចៀសវាងកុំឲ្យមានបុរេវិនិច្ឆ័យ៖

គ្រីស្តបរិស័ទដ៏ល្អម្នាក់ត្រូវតែប្រញាប់ទទួលសំណើររបស់អ្នកដទៃ ជាជាងដាក់ទោសគេ។ បើយើងមិនអាចទទួលសំណើរនេះបានទេ យើងត្រូវសួរគេថា តើគេយល់សំណើរនេះយ៉ាងដូចម្តេង ហើយបើគេយល់ខុស សូមឲ្យយើងជួយកែគេដោយចិត្តស្រឡាញ់។ បើមិនគ្រប់គ្រាន់ទេ សូមឲ្យរកមធ្យោបាយត្រឹមត្រូវទាំងអស់ ដើម្បីឲ្យគេទទួលការសង្គ្រោះ ដោយយល់ច្បាស់អំពីសំណើរនោះ (សន្តៈ អ៊ីញ៉ាស)។

២៤៧៩- ការនិយាយដើមគេ និងការបង្កាច់បង្ខោនគេបំផ្លាញកេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់អ្នកដទៃ។

កិត្តិយសជាសក្ខីភាពរបស់សង្គមចំពោះឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស ហើយមនុស្សគ្រប់ៗរូបមានសិទ្ធិធម្មជាតិ ឲ្យទទួលកិត្តិយស ឲ្យមានកេរ្តិ៍ឈ្មោះល្អ និងឲ្យគេគោរព។ ហេតុនេះ ការនិយាយដើមគេ និងការបង្អាប់បង្អោនគេ ជាការបង្ខូចគុណធម៌នៃយុត្តិធម៌ និងសេចក្តីស្រឡាញ់។

២៤៨០- យើងមិនអាចពោលពាក្យសម្តី ឬប្រកាន់ឥរិយាបទ ដែលលើកទឹកចិត្ត និងបញ្ជាក់អ្នកដទៃក្នុងកិច្ចការ និងអាក្បកិរិយាដ៏អាក្រក់របស់គេ ដោយបញ្ជោរ បញ្ជើចបញ្ជើ ឬផ្គាប់ចិត្តគេ បានឡើយ។ ការបញ្ជើចបញ្ជើគេជាកំហុសធ្ងន់ ធ្វើឲ្យយើងទៅជាដៃគូនៃបាបធម៌ ឬអំពើបាបធ្ងន់។ ទោះបីយើងចង់ជួយបម្រើគេ ឬទោះបីយើងជាមិត្តភក្តិគេយ៉ាងណាក៏ដោយ ក៏យើងមិនអាចប្រើពាក្យសម្តីពីរដែរ។ ការបញ្ជើចបញ្ជើគេជាអំពើស្រាលនៅពេលដែលយើងគ្រាន់តែចង់ផ្គាប់ចិត្តគេ ចៀសវាងអំពើអាក្រក់ បំពេញតម្រូវការចាំបាច់ណាមួយ ឬទទួលផលប្រយោជន៍ត្រឹមត្រូវ។

២៤៨១- អ្នកអួតបំប៉ោងខ្លួនឯង ប្រព្រឹត្តអំពើបាបប្រឆាំងនឹងសេចក្តីពិត។ យ៉ាងណាមិញ អ្នកចំអកឡកឡឺយឲ្យគេ គឺអ្នកដែលបង្អាប់បង្អោនគេ ដោយអាកប្បកិរិយាមើលងាយ ក្នុងបំណងចង់ធ្វើបាបគេ។

២៤៨២- "ពាក្យកុហកគឺការបំភ្លៃមិននិយាយការពិត ក្នុងគោលបំណងបោកបញ្ឆោតអ្នកដទៃ" (សន្តៈអូគូស្តាំង)។ ព្រះអម្ចាស់ចោទប្រកាន់ពាក្យកុហកដូចជាកិច្ចការរបស់មារសាតាំង៖ "អ្នករាល់គ្នាជាកូនចៅរបស់មារសាតាំង (...) វាមិនកាន់តាមសេចក្តីពិតទេ ព្រោះគ្មានសេចក្តីពិតនៅក្នុងខ្លួនវាសោះ។ ពេលវានិយាយកុហក នោះវានិយាយចេញពីគំនិតវាផ្ទាល់ ព្រោះវាជាមេកុហក ហើយជាឪពុកនៃអ្នកកុហក" (យហ ៨,៤៤)។

២៤៨៣- ពាក្យកុហកប្រឆាំងនឹងសេចក្តីពិតទាំងស្រុង។ ពេលយើងភូតកុហក យើងនិយាយពាក្យសម្តី ឬធ្វើសកម្មភាពប្រឆាំងនឹងសេចក្តីពិត ដើម្បីបញ្ឆោតអ្នកដែលមានសិទ្ធិស្គាល់សេចក្តីពិតនេះ។ ដោយបង្ខូចទំនាក់ទំនងរវាងមនុស្សចំពោះសេចក្តីពិត និងអ្នកដទៃ ពាក្យកុហកប្រឆាំងនឹងទំនាក់ទំនងមូលដ្ឋានរវាងមនុស្ស និងពាក្យសម្តីរបស់គេ ចំពោះព្រះអម្ចាស់។

២៤៨៤- ពាក្យកុហកធ្ងន់ ឬស្រាល អាស្រ័យទៅលើលក្ខណៈនៃសេចក្តីពិត ដែលពាក្យកុហកបង្ខូច អាស្រ័យទៅលើកាលៈទេសៈ បំណងរបស់អ្នកកុហក ការខូចខាតនៃជនរងគ្រោះ។ ការកុហកខ្លួនឯងជាអំពើបាបស្រាល ប៉ុន្តែ ពាក្យកុហកជាអំពើបាប ដែលបណ្តាលឲ្យស្លាប់ នៅពេលដែលអ្នកកុហកប្រឆាំងនឹងគុណធម៌នៃយុត្តិធម៌ និងសេចក្តីស្រឡាញ់យ៉ាងខ្លាំង។

២៤៨៥- ពាក្យកុហកទាំងអស់សុទ្ធតែជាអំពើបាប។ អ្នកកុហកបង្ខូចពាក្យសម្តី ដែលមានមុខងារផ្តល់ឲ្យអ្នកដទៃនូវសេចក្តីពិត ដែលយើងស្គាល់។ គេមានបំណងចង់បោកបញ្ឆោតអ្នកដទៃ ដោយភូតកុហកប្រឆាំងនឹងសេចក្តីពិត ហើយផ្ទុយនឹងយុត្តិធម៌ និងសេចក្តីស្រឡាញ់។ ត្រូវមានទោសខ្លាំងជាងនេះទៅទៀត នៅពេលដែលបំណងចង់បញ្ឆោតគេ បង្កើតផលវិបាក ដល់អស់អ្នក ដែលបានឃ្លាតឆ្ងាយពីការពិត។

២៤៨៦-ពាក្យកុហក(ដ្បិតពាក្យកុហកបំពានគុណធម៌នៃការប្រកាន់ភ្ជាប់នូវការពិត)ជាអំពើហិង្សាពិតប្រាកដចំពោះអ្នកដទៃ។ ពាក្យកុហកធ្វើឲ្យគេបាត់បង់សមត្ថភាព ដែលជាលក្ខខ័ណ្ឌ ដើម្បីវិនិច្ឆ័យ និងសម្រេចចិត្ត។ ពាក្យកុហកជាពូជធ្វើឲ្យមានការបាក់បែកគ្នាបណ្តាលឲ្យមានផលវិបាកបានច្រើន។ ពាក្យកុហកជារឿងអាក្រក់សម្រាប់សង្គមទាំងអស់ ធ្វើឲ្យមនុស្សលែងទុកចិត្តគ្នាទៅវិញទៅមក និងបំផ្លាញទំនាក់ទំនងក្នុងសង្គម។

២៤៨៧- នរណាប្រព្រឹត្តអំពើបាបប្រឆាំងនឹងយុត្តិធម៌ និងសេចក្តីពិត ត្រូវតែទូទាត់ ទោះជាគេបានទទួលការ

លើកលែងទោសយ៉ាងក៏ដោយ។ បើគេមិនអាចទូទាត់អំពើបាបជាសាធារណៈ ត្រូវតែទូទាត់ជាសម្ងាត់។ បើជនរងគ្រោះមិនអាចទទួលសំណងជាប្រាក់កាស ត្រូវតែទូទាត់ខាងផ្លូវចិត្ត ក្នុងនាមនៃសេចក្តីស្រឡាញ់។ ភារកិច្ចទូទាត់ទាក់ទងនឹងអំពើបាប ដែលបង្ខូចកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ។ ត្រូវតែទូទាត់ខាងផ្លូវចិត្ត ជូនកាលដោយសម្ភារៈតាមការខូចខាត។

## ៤. ការគោរពសេចក្តីពិត

២៤៨៨- ទោះបីយើងមានសិទ្ធិទទួលសេចក្តីពិត យ៉ាងណាក៏ដោយ ក៏យើងមិនអាចទាមទារទទួលសិទ្ធិនេះគ្រប់កាលៈទេសៈបាន។ ម្នាក់ៗត្រូវសម្រាប់ការរស់នៅរបស់ខ្លួន តាមវិន័យនៃដំណឹងល្អអំពីសេចក្តីស្រឡាញ់ចំពោះអ្នកដទៃទុកជាបងប្អូន។ វិន័យនេះ សុំឲ្យរិះគិតពិចារណា តាមកាលៈទេសៈ ថា តើត្រូវសម្តែងការពិតចំពោះអ្នកណា ដែលសុំទទួលការពិតនេះ ឬទេ?

២៤៨៩- ត្រូវតែឆ្លើយតបនឹងអ្នកដែលសុំទទួលព័ត៌មាន ឬគមនាគមន៍ ដោយចិត្តស្រឡាញ់ និងដោយគោរពសេចក្តីពិត។ ផលប្រយោជន៍ និងសុវត្ថិភាពរបស់អ្នកដទៃ ការគោរពជីវិតឯកជន ប្រយោជន៍រួមជាមូលហេតុល្មមដើម្បីលាក់បាំងអ្វីដែលមិនគួរដឹង ឬដើម្បីកុំបញ្ចេញឲ្យដឹងខ្លាំងពេក។ ជាញឹកញយ ត្រូវតែលាក់រឿងសម្ងាត់ កុំឲ្យកើតរឿងអាស្រូវ។ បើគេសួរ ត្រូវចេះថ្លឹងថ្លែងថា គួរប្រាប់ ឬមិនគួរប្រាប់ (បសរ ២៧,១៦ ; សុភ ២៥,៩-១០)។

២៤៩០- ការសម្ងាត់នៃអគ្គសញ្ញាលើកលែងទោស ជាការសម្ងាត់ជាទីសក្ការៈ ដែលមិនអាចក្បត់ជាដាច់ខាត។ "មិនអាចបំពានការសម្ងាត់នៃអគ្គសញ្ញាបាន ហេតុនេះហើយ បានជាលោកបូជាចារ្យមិនអាចក្បត់អ្នកសារភាពតាមពាក្យសម្តីក្តី ឬតាមរបៀបផ្សេងក្តីជាដាច់ខាត ទោះរឿងអ្វីក៏ដោយ ឬមូលហេតុអ្វីក៏ដោយ" (CIC ៩៨៣,១)។

២៤៩១- ត្រូវតែរក្សាទុកការសម្ងាត់នៃវិជ្ជាជាវៈ - ដូចជារឿងសម្ងាត់របស់អ្នកនយោបាយ ទាហាន គ្រូពេទ្យ អ្នកច្បាប់ - ឬរឿងសម្ងាត់ផ្សេងទៀត លើកលែងតែការរាំងខ្ទប់ការសម្ងាត់បណ្តាលឲ្យមានអន្តរាយយ៉ាងធ្ងន់ធ្ងរណាស់ ចំពោះអ្នកប្រគល់ ឬអ្នកទទួលការសម្ងាត់នេះ ឬអ្នកផ្សេងទៀត ហើយយើងអាចចៀសវាងការខូចខាតនោះដោយសម្តែងការពិតតែប៉ុណ្ណោះ។ ទោះបីគេមិនបានប្រគល់ព័ត៌មានជាសម្ងាត់យ៉ាងណាក៏ដោយ ក៏ព័ត៌មាន ដែលអាចធ្វើបាបនរណាម្នាក់ ដោយគ្មានមូលហេតុត្រឹមត្រូវ មិនត្រូវផ្សព្វផ្សាយឲ្យគេដឹងឡើយ។

២៤៩២- ម្នាក់ៗត្រូវតែចេះទប់ខ្លួន ក្នុងឯកជនរបស់មនុស្ស។ អ្នកទទួលខុសត្រូវលើទំនាក់ទំនងត្រូវសម្របតាមការទាមទារនៃប្រយោជន៍រួម និងការគោរពសិទ្ធិឯកជនផង។ ត្រូវតែផ្តន្ទាទោសលើការជ្រួតជ្រែងនៃព័ត៌មានក្នុងជីវិតឯកជនរបស់អ្នក ដែលមានសកម្មភាពនយោបាយ ឬសាធារណៈ លុះត្រាតែព័ត៌មាននេះ បង្ខូចការរស់នៅដ៏ស្និទ្ធស្នាល និងសេរីភាពរបស់គេ។

## ៥. ការប្រើប្រាស់មធ្យោបាយទំនាក់ទំនងក្នុងសង្គម

២៤៩៣- ក្នុងសង្គមទំនើប មធ្យោបាយទំនាក់ទំនងមានតួនាទីសំខាន់ក្នុងការផ្តល់ព័ត៌មាន និងការលើកស្ទួយវប្បធម៌ និងរបស់ការបណ្តុះបណ្តាល។ តួនាទីនេះ រីកចម្រើនតាមការអភិវឌ្ឍន៍បច្ចេកទេស មានលក្ខណៈទូលំទូលាយទៅតាមព័ត៌មានដែលត្រូវបញ្ជូន និងទៅតាមឥទ្ធិពលនៃព័ត៌មានលើមតិសាធារណៈ។

២៤៩៤- ការផ្សព្វផ្សាយព័ត៌មានត្រូវបម្រើផលប្រយោជន៍រួម (IM ១១)។ សង្គមមានសិទ្ធិទទួលព័ត៌មានដែលចាក់ឫសលើសេចក្តីពិត សេរីភាព យុត្តិធម៌ និងសាមគ្គីភាព៖

ដើម្បីគោរពសិទ្ធិនេះ តាមរបៀបត្រឹមត្រូវ ទាមទារឲ្យការផ្សព្វផ្សាយផ្ដល់ការពិតអំពីកម្មវត្ថុរបស់ខ្លួន (ដោយគោរពការទាមទារនៃយុត្តិធម៌ និងសេចក្តីស្រឡាញ់) និងពេញលេញទៅតាមរបៀបត្រឹមត្រូវ និងគួរសម ពោលគឺឲ្យមានការគោរពវិស័យសីលធម៌ទាំងអស់គោរពសិទ្ធិ និងឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស ក្នុងការយកព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មាននោះ (IM ៥)។

២៤៩៥- "សមាជិកសង្គមទាំងអស់ចាំបាច់ត្រូវតែបំពេញភារកិច្ចរបស់ខ្លួនលើវិស័យនេះ ដោយយុត្តិធម៌ និងសេចក្តីពិត។ ពួកគេនឹងប្រើមធ្យោបាយគមនាគមន៍ក្នុងសង្គម ដើម្បីជួយបង្កើត និងផ្សព្វផ្សាយយោបល់សាធារណៈដ៏ល្អ" (IM ៨)។ សាមគ្គីភាពលេចឡើងជាផលនៃទំនាក់ទំនងពិតប្រាកដ និងត្រឹមត្រូវ ហើយផលនៃការផ្សព្វផ្សាយដោយសេរីនៃគំនិតផ្សេងៗ ដែលជួយ និងគោរពអ្នកដទៃ។

២៤៩៦- មធ្យោបាយគមនាគមន៍ក្នុងសង្គម (ជាពិសេសប្រពន្ធ័ព័ត៌មាន) អាចធ្វើឲ្យអ្នកប្រើប្រាស់ទៅជាអសកម្ម គឺឲ្យគេទៅជាអ្នកប្រើប្រាស់ មិនសូវចាប់អារម្មណ៍នឹងសារ និងទស្សនីយភាពនានា។ អ្នកប្រើប្រាស់នឹងបង្ខំខ្លួនឯងឲ្យចេះទប់ខ្លួន និងកាន់វិន័យ ចំពោះប្រព័ន្ធព័ត៌មាន។ ពួកគេនឹងបំភ្លឺមនសិការយ៉ាងត្រឹមត្រូវ ដើម្បីងាយតស៊ូប្រឆាំងនឹងឥទ្ធិពលអាក្រក់។

២៤៩៧- ការទទួលខុសត្រូវក្នុងអាជីពជាអ្នកសារព័ត៌មាន គឺភារកិច្ចផ្សព្វផ្សាយបម្រើសេចក្តីពិត និងមិនប្រឆាំងនឹងសេចក្តីស្រឡាញ់។ ពួកគេនឹងខិតខំគោរពលក្ខណៈនៃទង្វើផ្សេងៗ និងកំណត់ការវិនិច្ឆ័យចំពោះជនគ្រប់រូបស្មើៗគ្នា។ ពួកគេត្រូវចៀសវាងបង្ខូចកេរ្តិ៍ឈ្មោះ។

២៤៩៨- "អាជ្ញាធរស៊ីវិល មានភារកិច្ចពិសេស ដើម្បីប្រយោជន៍រួម។ រដ្ឋអំណាចត្រូវតែការពារសេរីភាពយ៉ាងពិតប្រាកដ និងយ៉ាងត្រឹមត្រូវនៃព័ត៌មាន" (IM ១២)។ ដោយតែងច្បាប់ និងដោយពិនិត្យលើការអនុវត្តន៍ច្បាប់ រដ្ឋអំណាចនឹងធានាថា ការប្រើប្រាស់សារព័ត៌មាន តាមរបៀបមិនត្រឹមត្រូវ មិន "បង្កើតការខូចខាតធ្ងន់ធ្ងរចំពោះកិរិយាមាយាទនៃសាធារណជន និងការអភិវឌ្ឍន៍សង្គម" ទេ (IM ១២)។ ពួកគេនឹងដាក់ទោសលើការបំពានសិទ្ធិបង្ខូចកេរ្តិ៍ឈ្មោះរបស់មនុស្សម្នាក់ៗនិងអំពីការសម្ងាត់នៃជីវិតឯកជនរបស់គេ។ ពួកគេនឹងផ្ដល់ព័ត៌មាន ដែលទាក់ទងនឹងប្រយោជន៍រួម ឬនឹងឆ្លើយតបនឹងការព្រួយបារម្មណ៍ដ៏ត្រឹមត្រូវនៃប្រជាជន ទាន់ពេល និងដោយចិត្តស្មោះ។ គ្មានអ្វីអាចដោះសាឲ្យការយកព័ត៌មានក្លែងក្លាយ ដើម្បីបោកបញ្ឆោតគំនិតសាធារណជន ដោយការផ្សព្វផ្សាយ។ អន្តរាគមន៍ទាំងអស់នោះ នឹងមិនបង្ខូចសេរីភាពរបស់បុគ្គល និងក្រុមឡើយ។

២៤៩៩- សីលធម៌ដាក់ទោសលើរដ្ឋផ្ដាច់ការ ដែលមានរបៀបក្លែងសេចក្តីពិត គ្រប់គ្រងយោបល់សាធារណៈ ដោយសារព័ត៌មាន "បោកបញ្ឆោត" ជនជាប់ចោទ និងសាក្សីនៃការកាត់ក្តីជាសាធារណៈ ហើយស្មានថា អាចការពាររបៀបផ្ដាច់ការរបស់ខ្លួន ដោយបង្ក្រាបអ្វីៗទាំងអស់ ដែលគេចាត់ទុកថា ជា "គំនិតមិនត្រឹមត្រូវ"។

## ៦. សេចក្តីពិត សោភណភាព និងសិល្បៈជាទីសក្ការៈ

២៥០០- អ្នកប្រព្រឹត្តអំពើល្អត្រេកអរសប្បាយខាងវិញ្ញាណ និងសោភណភាពផ្លូវចិត្តផងដែរ។ យ៉ាងណាមិញ អ្នកប្រតិបត្តិតាមសេចក្តីពិតទទួលអំណរ និងភាពថ្កុំថ្កើងនៃសោភណភាពខាងវិញ្ញាណ។ សេចក្តីពិតផ្ទាល់ស្រស់ស្អាត។ មនុស្សប្រកបដោយប្រាជ្ញាឈ្លាសវៃចាំបាច់ត្រូវតែប្រើពាក្យសម្តីពិត ដែលបញ្ជាក់នូវប្រាជ្ញា ចំណេះដឹងអំពីសភាពការណ៍ ដែលព្រះជាម្ចាស់បានបង្កើត និងសភាពការណ៍ដែលហូរចេញមកពីព្រះអង្គ ប៉ុន្តែ មនុស្សអាចសម្តែងសេចក្តីពិត តាមរបៀបផ្សេងទៀត ដែលបំពេញគ្នាទៅវិញទៅមក ជាពិសេសនៅពេលដែលត្រូវតែនិយាយ

អំពីអ្វីដែលពិបាកនឹងនិយាយចេញមកដូចជា ជម្រៅចិត្តមនុស្ស ការលើកព្រលឹងឡើង និងអាថ៌កំបាំងរបស់ព្រះជាម្ចាស់។ មុននិងសម្តែងព្រះអង្គឲ្យមនុស្សស្គាល់តាមពាក្យសម្តីនៃសេចក្តីពិត ព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យគេស្គាល់តាមភាសាសកលនៃពិភពលោក ជាស្នាព្រះហស្តនៃព្រះបន្ទូល និងព្រះប្រាជ្ញាញាណរបស់ព្រះអង្គ៖ សណ្តាប់ធ្នាប់ និងភាពសុខដុមរមនានៃសកលលោក - ដែលកូនក្មេង និងអ្នកស្រាវជ្រាវរកឃើញ - "ភាពធំុថ្កើង និងសម្រស់របស់សត្វលោក នាំមនុស្សឲ្យសញ្ជឹងគិត ដោយការប្រៀបធៀប អំពីព្រះអង្គ ដែលបានបង្កើតសត្វលោកទាំងអស់នោះ" (ប្រាញ ១៣,៥) ដ្បិត "គឺព្រះអង្គនេះហើយ ដែលជាប្រភពនៃសម្រស់ ព្រះអង្គបានបង្កើតធម្មជាតិទាំងនោះ" (ប្រាញ ១៣,៣)។

> ព្រះប្រាជ្ញាញាណជាខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់ ប្រកបដោយឫទ្ធានុភាព និងជារស្មីដ៏វិសុទ្ធចេញមកពីសិរីរុងរឿងនៃព្រះដ៏ខ្ពង់ខ្ពស់បំផុត។ ដូច្នេះ គ្មានភាពសៅហ្មងណាអាចចូលក្នុងព្រះប្រាជ្ញាញាណបានឡើយ។ ព្រះប្រាជ្ញាញាណជារស្មីនៃពន្លឺ ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច ជាកញ្ចក់ដ៏ភ្លឺថ្លាឆ្លុះបញ្ចាំងមហិទ្ធិឫទ្ធិរបស់ព្រះជាម្ចាស់ និងជាតំណាងនៃព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ (ប្រាញ ៧,២៥-២៦)។ ព្រះប្រាជ្ញាញាណភ្លឺជាងពន្លឺព្រះអាទិត្យ និងកញ្ចុំផ្កាយទាំងឡាយទៅទៀត បើប្រៀបផ្ទឹមនឹងបន្លឺថ្ងៃ ព្រះអង្គភ្លឺហួសប្រមាណ។ យប់រមែងផ្ទេរកន្លែងទៅឲ្យថ្ងៃ ផ្ទុយទៅវិញ ព្រះប្រាជ្ញាញាណឈ្នះសេចក្តីអាក្រក់ជានិច្ច (ប្រាញ ៧,២៩-៣០)។ ខ្ញុំចាប់ចិត្តនឹងសម្រស់របស់ព្រះប្រាជ្ញាញាណ (ប្រាញ ៨,២)។

២៥០១- "ព្រះជាម្ចាស់បានបង្កើតមនុស្សជារូបតំណាងរបស់ព្រះអង្គ" (កណ១,២៦) មនុស្សក៏សម្តែងទំនាក់ទំនងយ៉ាងពិតប្រាកដរបស់ខ្លួនចំពោះព្រះជាម្ចាស់ ដោយសោភណភាពនៃស្នាដៃខាងសិល្បៈរបស់គេ។ តាមការពិត សិល្បៈ បញ្ចេញលក្ខណៈរបស់មនុស្សសុទ្ធសាធ បង្ហាញទ្រព្យសម្បត្តិផ្នែកខាងក្នុងដ៏សម្បូណ៌ហូរហៀររបស់មនុស្ស លើសពីការចង់បំពេញតម្រូវការចាំបាច់ជាលក្ខណៈរួមរបស់សត្វលោកទាំងអស់។ ដោយមកពីព្រះអំណោយទានដែលព្រះបង្កើតបានប្រោសប្រទាន និងពីការខិតខំរបស់មនុស្សផ្ទាល់ សិល្បៈដូចជាប្រាជ្ញាញាណម៉្យាង ដែលបង្រួបបង្រួមចំណេះដឹង និងជំនាញ (ប្រាញ ៧,១៧) ដើម្បីឲ្យចក្ខុវិញ្ញាណ និងសោតវិញ្ញាណអាចមើលឃើញ និងអាចស្តាប់ឮ សេចក្តីពិតអំពីសភាពការណ៍មួយ។ ដូច្នេះ សិល្បៈស្រដៀងគ្នានឹងសកម្មភាពរបស់ព្រះជាម្ចាស់ក្នុងពិភពលោក លុះត្រាតែសេចក្តីពិត និងសេចក្តីស្រឡាញ់របស់សត្វលោកបំភ្លឺសិល្បករ។ ដូចសកម្មភាពឯទៀតៗរបស់មនុស្សដែរ សិល្បៈមិនមែនជាទីចុងក្រោយរបស់មនុស្សទេ ប៉ុន្តែសិល្បៈមានគោលដៅ និងទទួលតម្លៃដោយបម្រើទីចុងក្រោយបំផុតរបស់មនុស្ស (សម្តេចប៉ាប ពីយូសទី១២)។

២៥០២- សិល្បៈជាទីសក្ការៈ ពិតប្រាកដ និងថ្លៃថ្នូរ នៅពេលដែលសិល្បៈនេះស្របតាមលក្ខណៈរបស់ខ្លួន គឺនាំឲ្យគិត និងលើកតម្កើង ក្នុងជំនឿ និងដោយក្រាបថ្វាយបង្គំ សិរីរុងរឿងនៃអាថ៌កំបាំងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះជាម្ចាស់ជាសោភណភាពដ៏ធំុថ្កើងដែលមិនអាចមើលឃើញនៃសេចក្តីពិតនិងសេចក្តីស្រឡាញ់ដែលព្រះគ្រីស្តបានសម្តែងមក ទ្រង់ក៏ "ជារស្មីនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងមានលក្ខណៈដូចព្រះអង្គបេះបិទ" (ហប ១,៣) ដែល "គ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ស្ថិតនៅយ៉ាងពេញលេញក្នុងរូបកាយព្រះអង្គ" (កូឡ ២,៩) និងជាសោភណភាពខាងវិញ្ញាណ ដែលឆ្លុះបញ្ចាំងដោយព្រះនាងព្រហ្មចារិនីម៉ារីជាព្រះមាតារបស់ព្រះជាម្ចាស់ដ៏វិសុទ្ធបំផុត ទេវទូត និងសន្តៈបុគ្គល។ សិល្បៈជាទីសក្ការៈយ៉ាងពិតប្រាកដជំរុញមនុស្សឲ្យក្រាបថ្វាយបង្គំទូលអង្វរ និងស្រឡាញ់ព្រះជាម្ចាស់ជាព្រះបង្កើត និងជាព្រះសង្គ្រោះ ជាព្រះដ៏វិសុទ្ធ ដែលប្រោសឲ្យបានវិសុទ្ធ។

២៥០៣- ហេតុនេះហើយ បានជាពួកលោកអភិបាលត្រូវតែប្រុងប្រយ័ត្នដោយខ្លួនឯងផ្ទាល់ ឬតាមរយៈអ្នក

ដទៃលើកស្ទួយសិល្បៈជាទីសក្ការៈ ទាំងថ្មី ទាំងបុរាណ ទាំងអស់ហើយយកគ្រប់លំនាំចិត្តទុកដាក់យកចេញពីពិធីបុណ្យ និងពីព្រះវិហារ អ្វីៗទាំងអស់ដែលមិនស្របតាមសេចក្តីពិតនៃជំនឿ និងសោភណភាពយ៉ាងពិតប្រាកដនៃសិល្បៈជាទីសក្ការៈ (SC ១២២-១២៧)។

## សង្ខេប

២៥០៤- "កុំធ្វើសាក្សីក្លែងក្លាយដែលនាំឲ្យអ្នកដទៃមានទោស" (សរ២០,១៦)។ សាវ័ករបស់ព្រះគ្រីស្ត បាន "ពាក់ជីវិតថ្មីដ៏សុចរិត និងវិសុទ្ធមកពីសេចក្តីពិត ជាជីវិតដែលព្រះជាម្ចាស់បានបង្កើតស្របតាមព្រះហឫទ័យ របស់ព្រះអង្គ" (អភ ៤,២៤)។

២៥០៥- សេចក្តីពិត ឬការប្រកាន់ខ្ជាប់នូវការពិត ជាគុណធម៌ ដែលយើងបង្ហាញចេញមកដោយប្រព្រឹត្តតែកិច្ចការពិត និងពោលតែពាក្យសម្តីពិត ដោយរក្សាខ្លួនមិនប្រើល្បិច កលក្លែងបន្លំ និងលាក់ពុតឡើយ។

២៥០៦- គ្រីស្តបរិស័ទ "មិនត្រូវខ្មាស់នឹងផ្តល់សក្ខីភាពអំពីព្រះអម្ចាស់" (២ធម ១,៨) តាមកិច្ចការផង ពាក្យសម្តីផង។ មរណសាក្សី ផ្តល់សក្ខីភាពដ៏អស្ចារ្យជាទីបំផុតអំពីសេចក្តីពិតនៃជំនឿ គឺគាត់ផ្តល់សក្ខីភាពរហូតដល់ទទួលមរណភាព។

២៥០៧- ដើម្បីគោរពកេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់គេ យើងមិនអាចប្រកាន់ឥរិយាបទ ឬពោលពាក្យសម្តីណាមួយ ដោយនិយាយដើមគេ ឬដោយបង្អាប់បង្អោនគេឡើយ។

២៥០៨- ពាក្យកុហក គឺការបំភ្លៃមិននិយាយការពិតក្នុងគោលបំណងបោកបញ្ឆោតអ្នកដទៃ ដែលមានសិទ្ធិនឹងទទួលសេចក្តីពិត។

២៥០៩- នរណាប្រព្រឹត្តអំពើបាបប្រឆាំងនឹងសេចក្តីពិត ត្រូវតែទូទាត់អំពើនេះ។

២៥១០- វិន័យសំខាន់បំផុតអំពីសេចក្តីស្រឡាញ់ជួយយើងឲ្យរិះគិតពិចារណាតាមកាលៈទេសៈថា តើ ត្រូវសម្តែងសេចក្តីពិត ឬទេ ចំពោះអ្នកដែលសុំទទួលសេចក្តីពិតនេះ។

២៥១១- "យើងមិនអាចរំលោភការសម្ងាត់នៃអគ្គសញ្ញាបានទាល់តែសោះ" (CIC ៩៨៣,១)។ ត្រូវតែរក្សាទុកការសម្ងាត់នៃវិជ្ជាជីវៈ។ ព័ត៌មានសម្ងាត់ដែលអាចធ្វើបាបនរណាម្នាក់ ហើយដែលគេបានប្រគល់ មិនត្រូវផ្សព្វផ្សាយឲ្យគេដឹងឡើយ។

២៥១២- សង្គមមានសិទ្ធិទទួលព័ត៌មាន ដែលចាក់ឫសលើសេចក្តីពិត សេរីភាព យុត្តិធម៌ និងសាមគ្គីភាព។ គួរបង្ខំខ្លួនឯងឲ្យចេះទប់ខ្លួន និងកាន់វិន័យ ចំពោះប្រព័ន្ធព័ត៌មាន។

២៥១៣- វិចិត្រសិល្បៈ ជាពិសេសសិល្បៈជាទីសក្ការៈ "មានទិសដៅមួយគឺខិតខំបង្ហាញតាមស្នាដៃសិល្បៈនូវសោភណភាពជាអនន្តរបស់ព្រះជាម្ចាស់។ គេកោតសរសើរព្រះជាម្ចាស់ និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គដោយជួយមនុស្ស ទៅរកព្រះជាម្ចាស់តាមសិល្បៈរបស់គេ" (SC ១២២)។

# ប្រការទី៩៖

## វិន័យទីប្រាំបួន

កុំលោភលន់ចង់បានផ្ទះរបស់អ្នកដទៃ កុំលោភលន់ចង់បានប្រពន្ធគេ ឬក៏លោភលន់ចង់បានអ្នកបម្រើប្រុស អ្នកបម្រើស្រី គោលា ឬ អ្វីផ្សេងទៀតដែលជារបស់គេឡើយ (សរ ២០,១៧)។

អ្នកណាមើលស្ត្រីម្នាក់ហើយមានចិត្តស្រើបស្រាលចង់រួមបវេណីជាមួយនាងអ្នកនោះដូចជាបានប្រព្រឹត្តអំពើផិតក្បត់ជាមួយនាង នៅក្នុងចិត្តរបស់ខ្លួន រួចស្រេចទៅហើយ (មថ ៥,២៨)។

២៥១៤- ចំពោះសន្តៈយ៉ូហាន អ្វីៗនៅក្នុងលោកីយ៍នេះ ចែកជាបំណងចិត្តលោភលន់ ឬតណ្ហាបីប្រភេទ គឺមានចិត្តលោភលន់របស់មនុស្ស ចិត្តលោភលន់ចង់បានអ្វីដែលភ្នែកមើលឃើញ និងអំនួតព្រោះទ្រព្យសម្បត្តិ (១យហ ២,១៦)។ តាមប្រពៃណីនៃការអប់រំជំនឿកាតូលិក វិន័យទីប្រាំបួនហាមប្រាមមិនឲ្យមានចិត្តលោភលន់របស់មនុស្ស ឯវិន័យទីដប់ ហាមប្រាមមិនឲ្យមានចិត្តចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ។

២៥១៥- តាមអត្ថន័យដើម "កិលេសតណ្ហា" សំដៅទៅលើបំណងប្រាថ្នារបស់មនុស្ស។ ទេវវិទ្យានៃគ្រីស្តសាសនា បានផ្តល់អត្ថន័យពិសេសដល់កិលេសតណ្ហា គឺចលនានៃចិត្តស្រើបស្រាល ដែលជំទាស់នឹងប្រាជ្ញារបស់មនុស្ស។ចំពោះគ្រីស្តទូតប៉ូល កិលេសតណ្ហាសំដៅទៅលើ"បំណងចិត្តលោភលន់របស់លោកីយ៍"ដែលជំទាស់នឹង "វិញ្ញាណ" (កាឡ ៥,១៦.១៧.២៤) ហើយដែលមកពីអំពើបាបដើមដំបូង (កណ ៣,១១)។ តណ្ហានាំមនុស្សឲ្យវង្វេងមិនដឹងខុសត្រូវ ហើយជំរុញគេឲ្យប្រព្រឹត្តអំពើបាប ទោះជាតណ្ហាផ្ទាល់មិនមែនជាអំពើបាបក៏ដោយ (មហាសន្និបាតនៅទៅក្រុងត្រង់៖ DS ១៥១៥)។

២៥១៦- ដោយមនុស្សជាសត្វលោក ដែលមានការបែងចែកជាពីរ គឺវិញ្ញាណនិងរូបកាយ ដូច្នេះ នៅក្នុងខ្លួនមនុស្សមានភាពតានតឹងម្យ៉ាង ដែលប្រឆាំងគ្នារវាង "វិញ្ញាណ" និង "បំណងចិត្តលោភលន់"។ ប៉ុន្តែ តាមការពិត ការប្រឆាំងគ្នានេះ ជាមរតក និងជាផលនៃអំពើបាប ហើយនៅពេលជាមួយគ្នានេះ បញ្ជាក់អំពើបាបនេះ។ អស់អ្នកដែលប្រយុទ្ធខាងវិញ្ញាណដកពិសោធន៍ថា បំណងចិត្តលោភលន់ប្រយុទ្ធប្រឆាំងនឹងវិញ្ញាណ៖

> គ្រីស្តទូតប៉ូលមិនប្រមាថ ឬផ្តន្ទាទោសរូបកាយ ដែលរួមជាមួយនឹងព្រលឹងវិញ្ញាណ និងជាលក្ខណៈសម្បត្តិរបស់មនុស្សទេ ផ្ទុយទៅវិញ លោកថ្លែងអំពីស្នាដៃ ឬលក្ខណៈនឹងន - គុណធម៌ និងបាបធម៌ -ល្អ ឬអាក្រក់តាមច្បាប់សីលធម៌ ដែលជាផលនៃការស្តាប់បង្គាប់ (ក្នុងករណីទីមួយ) ឬផលនៃការជំទាស់ប្រឆាំង (ក្នុងករណីទីពីរ) ចំពោះកិច្ចសង្គ្រោះនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ហេតុនេះហើយ បានជាគ្រីស្តទូតប៉ូលសរសេរថា៖ " ប្រសិនបើយើងមានជីវិតដោយសារព្រះវិញ្ញាណមែន យើងក៏ត្រូវប្រតិបត្តិតាមព្រះវិញ្ញាណដែរ" (កាឡ ៥,២៥) (សម្តេចប៉ាប យ៉ូហាន ប៉ូលទីពីរ)។

### ១. ការជម្រះចិត្តគំនិតឲ្យបានបរិសុទ្ធ

២៥១៧- ចិត្តគំនិតជាមូលដ្ឋានគ្រឹះនៃលក្ខណៈសម្បត្តិរបស់មនុស្សខាងសីលធម៌៖ "គំនិតអាក្រក់ ការកាប់សម្លាប់ អំពើផិតក្បត់ កាមគុណថោកទាប ការលួចប្លន់ ពាក្យកុហក ពាក្យត្មះតិះដៀល សុទ្ធតែចេញមកពីចិត្តមនុស្សទាំងអស់" (មថ ១៥,១៩)។ ត្រូវតែប្រយុទ្ធប្រឆាំងនឹងបំណងចិត្តលោភលន់ ដោយជម្រះចិត្តគំនិតឲ្យបានបរិសុទ្ធ និងដោយទប់ចិត្តខ្លួនឯង៖

ចូររស់នៅយ៉ាងសាមញ្ញកុំប្រព្រឹត្តអំពើបាបសោះ នោះអ្នកនឹងដូចជាកូនក្មេង ដែលមិនស្គាល់អំពើអាក្រក់ ដែលបំផ្លាញជីវិតមនុស្ស (គង្វាល ហេរម៉ាស)។

២៥១៨- ព្រះយេស៊ូមានព្រះបន្ទូលថា៖ "អ្នកណាមានចិត្តបរិសុទ្ធ អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងឃើញព្រះជាម្ចាស់" (មថ ៥,៨)។ "អ្នកណាមានចិត្តបរិសុទ្ធ" សំដៅទៅលើអស់អ្នកដែលបានថ្វាយប្រាជ្ញាឈ្លាសវៃ និងបំណងឆន្ទៈរបស់គេចំពោះព្រះជាម្ចាស់ ដែលទាមទារឲ្យមនុស្សបានវិសុទ្ធ ជាពិសេសក្នុងវិស័យបីយ៉ាង គឺសេចក្ដីស្រឡាញ់ (១ធម ៤,៣-៩ ; ២ធម ២,២២) ការចេះទប់ខ្លួនខាងផ្លូវភេទ ដោយចិត្តស្មោះត្រង់ (១ថស ៤,៧ ; កូឡ ៣,៥ ; អភ ៤,១៩) ការស្រឡាញ់រាប់អានសេចក្ដីពិត និងជំនឿត្រឹមត្រូវ (ទត ១,៥ ; ១ធម ១,៣-៤ ; ២ធម ២,២៣-២៦)។ ចិត្តបរិសុទ្ធ រូបកាយបរិសុទ្ធ និងជំនឿបរិសុទ្ធជាប់ទាក់ទិននឹងគ្នា៖

គ្រីស្តបរិស័ទត្រូវតែជឿលើប្រការទាំងប៉ុន្មាននៃធម៌ប្រកាសជំនឿ "ដោយជឿ គេស្ដាប់បង្គាប់ព្រះជាម្ចាស់ ដោយស្ដាប់បង្គាប់ព្រះអង្គ គេមានរបៀបរស់នៅត្រឹមត្រូវ ដោយមានរបៀបរស់នៅត្រឹមត្រូវ គេជម្រះចិត្តគំនិត ដោយជម្រះចិត្តគំនិត គេយល់អំពីអ្វីដែលគេជឿ" (សន្តៈ អូគូស្តាំង)។

២៥១៩- ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាចំពោះអស់អ្នក ដែលមាន "ចិត្តបរិសុទ្ធ" ថា គេនឹងឃើញព្រះអង្គទល់មុខគ្នា ហើយគេនឹងមានលក្ខណៈដូចព្រះអង្គដែរ (១ករ ១៣,២ ; ១យហ ៣,២)។ ត្រូវតែមានចិត្តបរិសុទ្ធជាមុនសិន ទើបអាចមើលឃើញព្រះជាម្ចាស់បាន។ ចាប់ពីថ្ងៃនេះទៅ បើយើងមានចិត្តបរិសុទ្ធ និងទទួលអ្នកដទៃដូចជា "បងប្អូន" យើងអាចមើលឃើញដូចព្រះជាម្ចាស់ទតឃើញដែរ។ យើងអាចយល់ឃើញថា រូបកាយមនុស្សគឺរូបកាយយើង និងរូបកាយអ្នកដទៃ ជាព្រះដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលសម្ដែងសោភណភាពរបស់ព្រះជាម្ចាស់។

## ២. ត្រូវតែតស៊ូដើម្បីមានចិត្តបរិសុទ្ធ

២៥២០- ពិធីជ្រមុជទឹកផ្ដល់ឲ្យអ្នកទទួលព្រះអំណោយទានជម្រះអំពើបាបទាំងអស់របស់ខ្លួន។ ប៉ុន្តែ អ្នកដែលបានជ្រមុជទឹកត្រូវតែបន្តទប់ទល់ប្រឆាំងនឹងកិលេសតណ្ហា និងចិត្តលោភលន់។ ដោយមានព្រះហឫទ័យរបស់ព្រះជាម្ចាស់ប្រណីសន្ដោស គេអាចធ្វើបាន៖

- ដោយសារគុណធម៌ និងអំណោយទាននៃការចេះទប់ខ្លួន ដ្បិតអ្នកចេះទប់ខ្លួនអាចស្រឡាញ់យ៉ាងស្មោះ ដោយគ្មានចិត្តលម្អៀងឡើយ
- ដោយមានបំណងបរិសុទ្ធ ដែលរកទីដៅពិតប្រាកដរបស់មនុស្ស គឺអ្នកជ្រមុជទឹកស្វែងរកព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងចង់ប្រតិបត្តិតាមគ្រប់វិស័យ (រម ១២,២ ; កូឡ ១,១០)
- ដោយមានការមើលឃើញបរិសុទ្ធ ផ្នែកខាងក្នុង និងផ្នែកខាងក្រៅផង ដោយគ្រប់គ្រងអារម្មណ៍ និងដំណើរចិត្ត ដោយមិនព្រមចូលដៃក្នុងគំនិតមិនបរិសុទ្ធ ដែលជំរុញឲ្យឃ្លាតឆ្ងាយពីបទបញ្ញារបស់ព្រះជាម្ចាស់៖ "ពេលឃើញ (...) មនុស្សឆោតល្ងង់នាំគ្នា (...) ស្រើបស្រាល" (ប្រាញ ១៥,៥)។
- ដោយអធិដ្ឋាន៖

ពីមុន ខ្ញុំនឹកស្មានថា ខ្ញុំអាចតម្រូមភេទ ដោយពឹងលើកម្លាំងរបស់ខ្លួន (...) ប៉ុន្តែ ខ្ញុំគ្មានកម្លាំងនោះទេ។ ខ្ញុំឆោតល្ងង់ណាស់ ដោយមិនដឹងថា គ្មាននរណាអាចតម្រូមភេទបាន បើព្រះអង្គមិនសព្វព្រះហឫទ័យ

ប្រោសប្រទាន ឡើយ។ ព្រះអង្គនឹងប្រោសប្រទានឲ្យខ្ញុំពិតប្រាកដមែន បើខ្ញុំបានស្រែកទូលអង្វរព្រះអង្គ ហើយបើខ្ញុំបានផ្ញើកង្វល់នេះទៅលើព្រះអង្គ ដោយមានជំនឿមាំមួន (សន្ត: អូគូស្តាំង)។

២៥២១- អ្នកមានចិត្តបរិសុទ្ធត្រូវចេះអៀនខ្មាស។ ការអៀនខ្មាសជាផ្នែកដ៏ពេញលេញនៃការទប់ចិត្តខ្លួនឯង។ ការអៀនខ្មាសការពារភាពស្និទ្ធស្នាលរបស់មនុស្ស។ អ្នកខ្មាសអៀនមិនព្រមសម្តែងអ្វីដែលត្រូវលាក់លៀម។ ការអៀនខ្មាសស្ថិតនៅក្រោមការទប់ខ្លួន និងបញ្ជាក់អំពីសេចក្តីថ្លៃថ្នូរនៃការទប់ខ្លួន។ ការអៀនខ្មាសដឹកនាំការមើលឃើញ និងកាយវិការស្របតាមកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស ដែលរួមរស់ជាមួយគ្នា។

២៥២២- អ្នកអៀនខ្មាសការពារអាថ៌កំបាំង និងស្នេហារបស់ខ្លួន ចេះអត់ធ្មត់ និងចេះទប់ខ្លួនផងដែរ។ បុរស និងស្ត្រី ដែលមានការអៀនខ្មាសចេះរង់ចាំក្នុងទំនាក់ទំនងស្នេហា មុននឹងប្រគល់គ្នាទៅវិញទៅមក។ អ្នកចេះអៀនខ្មាសបន្ទាបខ្លួន ស្លៀកពាក់សមរម្យ ចេះនៅស្ងៀម ឬចេះទប់មាត់ នៅពេលត្រូវការ។

២៥២៣- ការអៀនខ្មាស ទាក់ទងនឹងអារម្មណ៍ផង រូបកាយផង។ អ្នកអៀនខ្មាសតវ៉ានឹងការផ្សព្វផ្សាយ ដែលបើកចំហរូបកាយមនុស្សឲ្យគេមើលឃើញ ឬតវ៉ាប្រឆាំងនឹងសារព័ត៌មានខ្លះ ដែលបណ្តាលឲ្យលាតត្រដាងអ្វីៗទាំងអស់ ដែលគួរលាក់ទុក។ ការអៀនខ្មាសជំរុញឲ្យមានរបៀបរស់នៅ ដែលអាចតស៊ូប្រឆាំងនឹងការនិយមតាមការសម័យ ឬប្រឆាំងនឹងមនោគមវិជ្ជាទូទៅ។

២៥២៤- មានរបៀបខ្មាសអៀនជាច្រើនតាមវប្បធម៌នានា ប៉ុន្តែ គ្រប់កន្លែង ការអៀនខ្មាសបង្ហាញកិត្តិយសដ៏ថ្លៃថ្នូរខាងវិញ្ញាណ ដែលជាលក្ខណៈពិសេសរបស់មនុស្ស។ ការអៀនខ្មាសកើតមកជាមួយនឹងកំណើតមនសិការរបស់មនុស្ស។ បើយើងបង្រៀនកូនក្មេង និងយុវជនឲ្យចេះខ្មាសអៀន យើងក៏បង្រៀនគេឲ្យចេះគោរពមនុស្សផងដែរ។

២៥២៥- តាមគ្រីស្តសាសនា ត្រូវតែជម្រះបរិយាកាសសង្គម គឺទាមទារឲ្យមធ្យោបាយគមនាគមន៍ក្នុងសង្គមផ្តល់ព័ត៌មានដែលគោរពមនុស្ស និងដែលនាំឲ្យចេះទប់ខ្លួន។ អ្នកមានចិត្តបរិសុទ្ធចៀសវាងទស្សនកម្មវិធីស្រើបស្រាល។

២៥២៦- អស់អ្នកដែលធ្វើតាមអំពើចិត្ត យល់ខុសអំពីសេរីភាពរបស់មនុស្ស។ វិន័យនៃសីលធម៌ត្រូវតែអប់រំមនុស្ស ដើម្បីឲ្យគេកសាងសេរីភាពរបស់ខ្លួន។ ត្រូវតែសុំអ្នកទទួលខុសត្រូវក្នុងការអប់រំឲ្យបង្រៀនយុវជនដោយគោរពសេចក្តីពិត គុណសម្បត្តិនៃចិត្តគំនិត និងឋានៈដ៏ថ្លៃថ្នូរខាងសីលធម៌ និងខាងវិញ្ញាណរបស់មនុស្ស។

២៥២៧- "ដំណឹងល្អរបស់ព្រះគ្រីស្តកែលំអការរស់នៅ និងវប្បធម៌របស់មនុស្សបាបឲ្យបានថ្មីជានិច្ច។ ដំណឹងល្អនេះ តទល់ប្រឆាំងនឹងគំនិតវង្វេង ព្រមទាំងប្រការអាក្រក់គ្រប់យ៉ាង ដែលបណ្តាលមកពីកិលេសតណ្ហាបញ្ឆោតមនុស្សឥតឈប់ឈរឲ្យប្រព្រឹត្តអំពើបាប។ ដំណឹងល្អនេះ ក៏នៅតែជម្រះ និងលើកសីលធម៌ប្រជាជននានា ឲ្យកាន់តែប្រសើរឡើងថែមទៀតផង។ ដោយព្រះសហគមន៍ទទួលសម្បត្តិសួគ៌ពីព្រះជាម្ចាស់មក ព្រះសហគមន៍ហាក់ដូចជាអាចប្រោសអរិយធម៌ ពីខាងក្នុង ធ្វើឲ្យគុណសម្បត្តិខាងវិញ្ញាណ និងទេពកោសល្យផ្ទាល់របស់ប្រជាជននីមួយៗ និងការរស់នៅក្នុងសម័យនីមួយៗអាចបង្កើតផលបាន។ ព្រះសហគមន៍ពង្រឹងគុណសម្បត្តិនិងទេពកោសល្យទាំងនោះឲ្យបានរឹងប៉ឹង និងប្រោសឲ្យបានពេញលក្ខណៈ ព្រមទាំងឲ្យមានកម្លាំងថ្មីដោយរួមរស់ក្នុងអង្គព្រះគ្រីស្ត" (GS ៥៨,៤)។

## សង្ខេប

២៥២៨- "អ្នកណាមើលស្ដ្រីម្នាក់ហើយមានចិត្តស្រើបស្រាលចង់រួមបវេណីជាមួយនាង អ្នកនោះដូចជាបានប្រព្រឹត្តអំពើផិតក្បត់ជាមួយនាង នៅក្នុងចិត្តរបស់ខ្លួន រួចស្រេចទៅហើយ" (មថ ៥,២៨)។

២៥២៩- វិន័យទីប្រាំបួននាំឲ្យប្រុងប្រយ័ត្ននឹងចិត្តលោភលន់ ឬតណ្ហា។

២៥៣០- ត្រូវតែប្រយុទ្ធប្រឆាំងនឹងបំណងចិត្តលោភលន់ ដោយជម្រះចិត្តគំនិតឲ្យបានបរិសុទ្ធ និងដោយទប់ចិត្តខ្លួនឯង។

២៥៣១- អ្នកមានចិត្តបរិសុទ្ធនឹងមើលឃើញព្រះជាម្ចាស់៖ ចាប់ពីថ្ងៃនេះទៅ បើយើងមានចិត្តបរិសុទ្ធ យើងអាចមើលឃើញអ្វីៗទាំងអស់ដូចព្រះជាម្ចាស់ទតឃើញដែរ។

២៥៣២- អ្នកមានចិត្តបរិសុទ្ធត្រូវតែអធិដ្ឋាន ចេះទប់ខ្លួន មានបំណងបរិសុទ្ធ និងមើលឃើញអ្វីៗទាំងអស់ឲ្យបានបរិសុទ្ធ។

២៥៣៣- អ្នកមានចិត្តបរិសុទ្ធត្រូវចេះអៀនខ្មាស អត់ធ្មត់ មិនចេះអួតអាងខ្លួន និងនឹងនួន។ ការអៀនខ្មាស ការពារភាពស្និទ្ធស្នាលរបស់មនុស្ស។

# ប្រការទី១០៖

## វិន័យទីដប់

កុំលោភលន់ចង់បាន (...) អ្វីដែលជារបស់គេឡើយ (សរ ២០,១៧)។ កុំប៉ងប្រាថ្នាចង់បានផ្ទះរបស់អ្នកដទៃ ឬក៏ចង់បានស្រែចំការ អ្នកបម្រើប្រុស អ្នកបម្រើស្រី គោលា ឬ របស់អ្វីផ្សេងទៀតរបស់គេឡើយ (ទក ៥,២១)។

ទ្រព្យសម្បត្តិអ្នកនៅកន្លែងណា ចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ (មថ ៦,២១)។

២៥៣៤- វិន័យទីដប់បំពេញវិន័យទីប្រាំបួន ដែលទាក់ទងនឹងចិត្តលោភលន់របស់មនុស្ស។ វិន័យទីដប់ហាមប្រាមមិនឲ្យលោភលន់នឹងទ្រព្យសម្បត្តិអ្នកដទៃ ជាឫសគល់នៃការលួច ការដណ្ដើមយក និងការគៃបន្លំ ដែលវិន័យទីប្រាំពីរហាមប្រាម។ "ចិត្តលោភលន់ចង់បានអ្វីៗដែលភ្នែកមើលឃើញ" (១យហ ២,១៦) បណ្ដាលឲ្យប្រើអំពើហិង្សា និងឲ្យប្រព្រឹត្តអំពើអយុត្តធម៌ ដែលវិន័យទីប្រាំហាមឃាត់ (មីក ២,២)។ ចិត្តលោភលន់ និងអំពើថោកទាបមានប្រភពចេញមកពីចិត្តគោរពព្រះក្លែងក្លាយ ដែលបទបញ្ញាទាំងបីដំបូងនៃធម្មវិន័យមិនឲ្យប្រព្រឹត្ត (ប្រាញ ១៤,១២)។ វិន័យទីដប់សំដៅទៅលើគោលបំណងនៃចិត្តគំនិត ហើយសង្ខេបរួមបទបញ្ញាទាំងអស់នៃធម្មវិន័យជាមួយវិន័យទីប្រាំបួន។

### ១. ចិត្តលោភលន់របស់លោកីយ៍

២៥៣៥- ចិត្តស្រើបស្រាលជំរុញយើងឲ្យប្រាថ្នាចង់បានអ្វីដ៏ល្អ ដែលយើងគ្មាន។ ឧ- យើងចង់ពិសារបាយពេលឃ្លាន ឬចង់កក់ក្ដៅពេលរងា។ ការប្រាថ្នាទាំងអស់នោះ មានលក្ខណៈផ្ទាល់ដ៏ល្អ ប៉ុន្តែ ជាញឹកញយបំណងទាំងអស់នោះ មិនស្របតាមប្រាជ្ញា និងជំរុញយើងឲ្យចង់បានអ្វីដែលមិនមែនជារបស់យើង ឬអ្វីដែលជា

របស់អ្នកដទៃ។

២៥៣៦-វិន័យទីដប់ហាមប្រាមមិនឲ្យមានចិត្តលោភលន់ និងប្រាថ្នាចង់បានទ្រព្យសម្បត្តិលោកិយ៍ ដោយគ្មានដែនកំណត់។ វិន័យនេះ ហាមមិនឲ្យមានបំណងចង់ប្រព្រឹត្តអំពើទុច្ចរិតប្រឆាំងនឹងអ្នកដទៃ ដើម្បីទ្រព្យសម្បត្តិលោកីយ៍របស់គេឡើយ៖

> នៅពេលដែលធម្មវិន័យថ្លែងថា៖ "កុំលោភលន់ឡើយ" វិន័យនេះ មានន័យថា ត្រូវតែឃ្លាតឆ្ងាយពីអ្វីដែលមិនមែនជារបស់យើង ដ្បិតការស្រេកឃ្លានចង់បានទ្រព្យសម្បត្តិអ្នកដទៃធំធេងណាស់ គ្មានព្រំដែន និងមិនអាចរលត់បានឡើយ។ ហេតុនេះ មានចែងទុកមកថា៖ " អ្នកមានចិត្តកំណាញ់ចង់បានប្រាក់មិនចេះឆ្អែតឡើយ" (បសរ ៥,៩) (CR ៣,៣៧)។

៣៥៣៧- អ្នកប្រាថ្នាចង់បានរបស់របរអ្នកដទៃមិនបំពានវិន័យនេះទេ លុះត្រាតែគេប្រើមធ្យោបាយសុចរិត។ តាមប្រពៃណី ការអប់រំជំនឿបង្ហាញយ៉ាងច្បាស់លាស់ថា "អស់អ្នកដែលត្រូវតែទប់ទល់នឹងចិត្តលោភលន់ដ៏ទុច្ចរិតរបស់គេ"។ ដូច្នេះ "ត្រូវតែដាស់តឿនគេឲ្យប្រតិបត្តិតាមបទបញ្ញានេះ"៖

> មាន (...) អ្នកលក់ ដែលចង់ឲ្យមានការអត់ឃ្លាន ឬឲ្យទំនិញឡើងថ្លៃ ហើយដែលសោកស្ដាយថាមិនមែនមានតែគេម្នាក់ទេ ដើម្បីលក់ និងទិញ។ បើមានតែគេម្នាក់ គេនឹងអាចលក់បានថ្លៃជាង និងទិញបានថោកជាង។ មានអស់អ្នកដែលចង់ឲ្យអ្នកដទៃវេទនា ដើម្បីបានចំណេញ ដោយលក់ទៅគេ ឬទិញមក (...)។ មានគ្រូពេទ្យដែលចង់ឲ្យអ្នកដទៃធ្លាក់ខ្លួនឈឺ មានមេធាវីដែលទាមទារឲ្យអ្នកដទៃឈ្លោះប្រកែកគ្នា ដើម្បីឲ្យមានការកាត់ក្ដីជាច្រើន និងសំខាន់ៗ... (CR ៣,៣៧)។

២៥៣៨- វិន័យទីដប់ទាមទារឲ្យយើងកំចាត់ការច្រណែនឈ្នានីស ចេញពីក្នុងចិត្ត។ នៅពេលដែលព្យាការីណាថាន ចង់ឲ្យព្រះបាទដាវីឌសោកស្ដាយអំពីបាបរបស់ព្រះអង្គ គាត់និទានរឿងអំពីអ្នកក្រីក្រម្នាក់ ដែលមានកូនចៀមតែមួយ ដែលគេស្រឡាញ់ដូចជាកូនស្រីខ្លួនឯងនិងអ្នកមាន ដែលច្រណែនឈ្នានីសចង់បានកូនចៀមរបស់អ្នកក្រីក្រនេះ ហើយលួចកូនចៀមនេះ ទោះបីខ្លួនមានហ្វូងចៀមរាប់មិនអស់យ៉ាងក៏ដោយ (២សម ១២,១-៤)។ ចិត្តច្រណែនឈ្នានីសនាំឲ្យប្រព្រឹត្តអំពើអាក្រក់ធំជាងគេជាទីបំផុត (កណ ៤,៣-៧ ; ១ពង្ស ២១,១-២៩)។ សេចក្ដីស្លាប់ចូលមកក្នុងពិភពលោក ព្រោះតែការច្រណែនឈ្នានីសរបស់មារ (ប្រាញ ២, ២៤)៖

> យើងច្បាំងនឹងគ្នាទៅវិញទៅមក ហើយការច្រណែនឈ្នានីសបំពាក់អាវុធឲ្យយើងច្បាំងគ្នា (...)។ បើគេទាំងអស់គ្នាចេះតែបំផ្លាញព្រះកាយព្រះគ្រីស្ត តើបានប្រយោជន៍អ្វីទៅ (...)? យើងកំពុងតែធ្វើឲ្យព្រះកាយព្រះគ្រីស្តអស់កម្លាំង (...)។ យើងប្រកាសថា យើងជាអវយវៈនៃសរីរាង្គតែមួយ ហើយយើងខាំហែកស៊ីគ្នាដូចសត្វសាហាវ (សន្ដៈ យ៉ូហាន គ្រីសូស្ដូម)។

២៥៣៩- ការច្រណែនឈ្នានីសជាបាបធម៌ដ៏ធំ។ ពេលយើងមានចិត្តច្រណែនឈ្នានីស យើងព្រួយចិត្តដោយឃើញទ្រព្យសម្បត្តិអ្នកដទៃ ហើយយើងចង់បានទ្រព្យសម្បត្តិនោះមកជាកម្មសិទ្ធរបស់យើង ទោះជាតាមរបៀបទុច្ចរិតក៏ដោយ។ នៅពេលដែលយើងចង់ធ្វើបាបអ្នកដទៃយ៉ាងខ្លាំង យើងប្រព្រឹត្តអំពើបាប ដែលនាំឲ្យស្លាប់៖

> តាមសន្ដៈ អូគូស្តាំង ការច្រណែនឈ្នានីសជា "អំពើបាបរបស់មារសាតាំងផ្ទាល់"។ "ការស្អប់ ការនិយាយដើម ការបង្អាប់បង្អោន ត្រេកអរពេលអ្នកដទៃវេទនា និងការកើតទុក្ខពេលគេបានជោគជ័យ មកពីការច្រណែនឈ្នានីស" (សន្ដៈ គ្រេគ័រដ៏ប្រសើរ)។

២៥៤០- នៅពេលដែលយើងច្រណែនឈ្នានីស យើងព្រួយចិត្ត មិនព្រមទទួលសេចក្ដីស្រឡាញ់។ គ្រីស្ដបរិស័ទត្រូវតែតស៊ូប្រឆាំងនឹងចិត្តច្រណែនឈ្នានីស ដោយមានចិត្តទូលាយ។ ដោយសារចិត្តច្រណែនច្រើនកើតមកពីចិត្តអំនួតគ្រីស្ដបរិស័ទនឹងហ្វឹកហាត់ក្នុងការរស់នៅដោយបន្ទាបខ្លួន៖

> អ្នករាល់គ្នាចង់ឲ្យព្រះជាម្ចាស់ទទួលសិរីរុងរឿង ដោយសារអ្នករាល់គ្នា ឬទេ? ចូរត្រេកអរនឹងបងប្អូនរបស់អ្នករាល់គ្នាដែលរីកចម្រើន នោះព្រះជាម្ចាស់នឹងទទួលសិរីរុងរឿង ដោយសារអ្នករាល់គ្នាវិញ។ គេនឹងលើកតម្កើងព្រះជាម្ចាស់ ដ្បិតអ្នកបម្រើរបស់ព្រះអង្គបានឈ្នះការច្រណែនឈ្នានីស ដោយត្រេកអរចំពោះអំពើល្អរបស់អ្នកដទៃ (សន្ដ: យ៉ូហាន គ្រីសូស្ដូម)។

## ២. បំណងនៃព្រះវិញ្ញាណ

២៥៤១- ការចាត់ចែងនៃធម្មវិន័យ និងរបស់ការប្រោសប្រណីបង្វែរចិត្តមនុស្សពីការលោភលន់ និងការច្រណែនឈ្នានីស គឺបង្ហាត់មនុស្សឲ្យប្រាថ្នារកអ្វីដ៏ល្អជាទីបំផុត និងបង្រៀនគេឲ្យយល់អំពីបំណងនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបំពេញចិត្តមនុស្ស។

- តាំងពីដើមដំបូង ព្រះជាម្ចាស់នៃព្រះបន្ទូលសន្យាតែងតែព្រមានមនុស្សកុំឲ្យចាញ់ការល្បួងនឹងអ្វីដែល "មានរសជាតិឆ្ងាញ់ពិសា គួរឲ្យគយគន់ ហើយថែមទាំងអាចធ្វើឲ្យមានប្រាជ្ញាទៀតផង" (កណ ៣,៦)។

២៥៤២- វិន័យ ដែលព្រះជាម្ចាស់បានប្រគល់ឲ្យជនជាតិអ៊ីស្រាអែល មិនគ្រប់គ្រាន់នឹងធ្វើឲ្យអ្នកស្ដាប់បង្គាប់បានទៅជាមនុស្សសុចរិតទេ ផ្ទុយទៅវិញ វិន័យក្លាយទៅជាឧបករណ៍នៃ "ចិត្តលោភលន់" (រម ៧, ៧)។ ឆន្ទៈ និងការធ្វើ មិនស្របគ្នាទេ (រម ៧,១០) ដូចវិន័យរបស់ព្រះជាម្ចាស់ ដែលជា "វិន័យនៃគំនិតប្រាជ្ញា" និងវិន័យផ្សេងទៀត ដែល "ធ្វើឲ្យខ្ញុំជាប់ជាឈ្លើយរបស់បាប ដែលស្ថិតនៅក្នុងសរីរាង្គកាយរបស់ខ្ញុំ" (រម ៧,២៣) ប្រយុទ្ធប្រឆាំងនឹងគ្នាដែរ។

២៥៤៣- "ឥឡូវនេះ ព្រះជាម្ចាស់សម្ដែងឲ្យយើងដឹងអំពីរបៀប ដែលព្រះអង្គប្រោសមនុស្សឲ្យបានសុចរិត គឺព្រះអង្គមិនគិតអំពីវិន័យទេ ដូចធម្មវិន័យ និងគម្ពីរព្យាការីបានបញ្ជាក់ទុកស្រាប់។ ព្រះជាម្ចាស់ប្រោសអ្នកដែលមានជំនឿលើព្រះយេស៊ូគ្រីស្ដឲ្យបានសុចរិត គឺព្រះអង្គធ្វើដូច្នេះ ចំពោះអស់អ្នកដែលជឿ" (រម ៣,២១-២២)។ ហេតុនេះ អស់អ្នកដែលផ្ញើជីវិតទៅលើព្រះគ្រីស្ដ "សុទ្ធតែបានឆ្កាងតណ្ហា និងបំណងរបស់លោកីយ៍នោះចោលហើយ" (កាឡ ៥,២៤)។ ព្រះវិញ្ញាណណែនាំគេ ហើយគេក៏ដើរតាមបំណងរបស់ព្រះអង្គ (រម ៨,២៧)។

## ៣. ការដាក់ខ្លួនជាអ្នកក្រ

២៥៤៤- ព្រះយេស៊ូសុំឲ្យសាវ័ករបស់ព្រះអង្គស្រឡាញ់ព្រះអង្គលើសអ្វីៗទាំងអស់ និងលើសមនុស្សទាំងអស់ ហើយស្នើសុំឲ្យគេ "លះបង់អ្វីទាំងអស់" (លក ១៤,៣៣) ព្រោះតែព្រះអង្គ និងដំណឹងល្អ (មក ៨,៣៥)។ មុនព្រះអង្គរងទុក្ខលំបាក ព្រះយេស៊ូបានសុំឲ្យពួកគេយកតម្រាប់តាមស្ត្រីមេម៉ាយកម្សត់ម្នាក់ នៅទីក្រុងយេរូសាឡឹមដែលបានថ្វាយអ្វីៗទាំងអស់ ដែលនាងត្រូវការជាចាំបាច់សម្រាប់ចិញ្ចឹមជីវិត (លក ២១,៤)។ ចាំបាច់ត្រូវតែលះបង់ទ្រព្យសម្បត្តិ ដើម្បីចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ។

២៥៤៥- អស់អ្នកដែលផ្ញើជីវិតទៅលើព្រះគ្រីស្ដត្រូវ "យកចិត្តទុកដាក់ធ្វើជាម្ចាស់នៃតណ្ហារបស់ខ្លួន កុំឲ្យការ

ប្រើប្រាស់សម្បត្តិលោកកីយ៍ និងចិត្តលោភលន់ផ្ទុយពីចិត្តគំនិតរបស់អ្នកដាក់ខ្លួនជាអ្នកក្រីក្រ តាមដំណឹងល្អ បណ្ដាលឲ្យគេងាករេចេញអំពីការស្វែងរកសេចក្ដីស្រឡាញ់ដ៏ពេញលក្ខណៈ" (LG ៤២)។

២៥៤៦- "អ្នកណាដាក់ចិត្តជាអ្នកក្រខ្សត់ អ្នកនោះមានសុភមង្គលហើយ" (មថ ៥,៣)។ ព្រះយេស៊ូសម្ដែងសុភមង្គលយ៉ាងពិតប្រាកដ ជាពិភពពោរពេញដោយសេចក្ដីសុខសាន្ត សោភណភាព និងសន្តិភាព។ ព្រះអង្គត្រេកអរនឹងអំណរសប្បាយរបស់អ្នកក្រីក្រ ដែលជាព្រះរាជ្យរួចទៅហើយ (លក ៦,២០)៖

> ព្រះបន្ទូលហៅ "អ្នកក្រខ្សត់" អ្នកដែលស្ម័គ្រចិត្តបន្ទាបខ្លួន និងស្ម័គ្រចិត្តលះបង់ ហើយគ្រីស្តទូតប៉ូលយកភាពក្រីក្ររបស់ព្រះជាម្ចាស់ធ្វើជាគំរូ ពេលលោកមានប្រសាសន៍ថា៖ "ព្រះអង្គបានដាក់ខ្លួនជាអ្នកក្រ ព្រោះតែបងប្អូន" (២ករ ៨,៩) (សន្តៈ គ្រេគ័រ នៃនីស)។

២៥៤៧-ព្រះអម្ចាស់អាណិតអាសូរអ្នកមានដ្បិតពួកគេទទួលការសម្រាលទុក្ខក្នុងទ្រព្យសម្បត្តិសម្បូរហូរហៀរ (លក ៦,២៤)។ "អ្នកក្រអឺតក្រអោងស្វែងរកអំណាចលោកីយ៍ ឯអ្នកដែលដាក់ខ្លួនជាអ្នកក្រស្វែងរកព្រះរាជ្យនៃស្ថានបរមសុខ" (សន្តៈ អូគូស្តាំង)។ បើយើងបណ្ដោយខ្លួន ក្នុងឧបករគុណនៃព្រះបិតា ដែលគង់នៅស្ថានបរមសុខ យើងមិនបាច់ព្រួយប្រារម្ភអំពីអនាគតឡើយ (មថ ៦,២៥-៣៤)។ អ្នកជឿទុកចិត្តលើព្រះជាម្ចាស់នឹងទទួលសុភមង្គលរបស់អ្នកក្រខ្សត់ គឺគេនឹងឃើញព្រះជាម្ចាស់។

## ៤. "ខ្ញុំចង់ឃើញព្រះជាម្ចាស់"

២៥៤៨- បំណងប្រាថ្នានៃសុភមង្គលយ៉ាងពិតប្រាកដ រំដោះមនុស្សឲ្យលះបង់ទ្រព្យសម្បត្តិលោកីយ៍។ សុភមង្គលនេះ ជាសុភមង្គលពេញលក្ខណៈ នៅពេលឃើញព្រះជាម្ចាស់។ "ព្រះបន្ទូលសន្យាថានឹងបានឃើញព្រះជាម្ចាស់មានតម្លៃលើសពីសុភមង្គលណាទៅទៀត។ ព្រះគម្ពីរបានចែងថា៖មើលឃើញ គឺបានទទួល។ នរណាដែលឃើញព្រះជាម្ចាស់ អ្នកនោះមានអ្វីៗទាំងអស់ តាមបំណង" (សន្តៈ គ្រេគ័រ នៃនីស)។

២៥៤៩- ប្រជាជនដ៏វិសុទ្ធត្រូវតែតស៊ូ រួមជាមួយព្រះហឫទ័យប្រណីសន្ដោសដែលមកពីខាងលើ ដើម្បីទទួលទ្រព្យសម្បត្តិដែលព្រះជាម្ចាស់មានព្រះបន្ទូលសន្យានឹងប្រទាន។ អស់អ្នកដែលផ្ញើជីវិតទៅលើព្រះគ្រីស្តត្រូវតែរងាប់ចិត្តលោភលន់ ដើម្បីបានទទួល និងឃើញព្រះជាម្ចាស់ ហើយរួបរួមជាមួយព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ គេឈ្នះលើការល្បួងនៃការសប្បាយ និងអំណាច។

២៥៥០- នៅតាមផ្លូវឆ្ពោះទៅភាពល្អឥតខ្ចោះនេះ ព្រះវិញ្ញាណ និងព្រះមហេសីត្រាស់ហៅអស់អ្នកដែលស្ដាប់ព្រះសូរសៀងរបស់ព្រះអង្គក្នុងការរួបរួមដ៏ពេញលក្ខណៈជាមួយព្រះជាម្ចាស់ (វវ២២,១៧)៖

> នៅទីនោះ សិរីរុងរឿងដ៏ពិតប្រាកដនឹងស្ថិតនៅ។ គ្មាននរណានឹងលើកតម្កើងម្នាក់ផ្សេងទៀត ដោយបន្លំ ឬដោយបញ្ជោរទេ។ គេនឹងមិនបដិសេធកិត្តិយសដ៏ពិតប្រាកដរបស់អស់អ្នកដែលសក្ដិសមនឹងទទួល ឬមិនផ្ដល់កិត្តិយសនោះដល់អ្នកមិនសក្ដិសមទេ។ ទោះជាយ៉ាងណា អ្នកទាំងនោះ មិនហ៊ានទាមទារទេ។ នៅទីនោះ មានតែអ្នកសក្ដិសមទេ ដែលនឹងអាចចូលបាន ពីព្រោះទីនោះ ជាកន្លែងដែលសន្តិភាពដ៏ពិតប្រាកដនឹងគ្រងរាជ្យ ហើយគ្មាននរណានឹងជំទាស់នឹងខ្លួនឯង ឬនឹងអ្នកដទៃឡើយ។ ព្រះជាម្ចាស់ផ្ទាល់នឹងទៅជារង្វាន់នៃគុណធម៌។ ព្រះអង្គដែលបានប្រទានគុណធម៌ ហើយដែលមានព្រះបន្ទូលសន្យាចំពោះខ្លួនព្រះអង្គថា នឹងទៅជារង្វាន់ដ៏ល្អប្រសើរបំផុត លើសពីអ្វីៗទាំងអស់៖ "យើងនឹងធ្វើជាព្រះរបស់អ្នករាល់គ្នា ហើយឲ្យអ្នករាល់គ្នាធ្វើជាប្រជារាស្ត្ររបស់យើង" (លវ ២៦,១២)... ពាក្យរបស់គ្រីស្តទូតប៉ូលមានអត្ថន័យ

ដូចគ្នា៖ "ដើម្បីឲ្យព្រះជាម្ចាស់បានគ្រងរាជ្យលើអ្វីៗទាំងអស់គ្រប់ប្រការ" (១ករ ១៥,២៨)។ ព្រះអង្គផ្ទាល់ជាបំណងប្រាថ្នាធំបំផុតដែលយើងគយគន់ដោយស្ងើចសរសើរគ្មានទីបញ្ចប់។ព្រះអំណោយទាននេះ សេចក្តីស្រឡាញ់នេះ មុខងារនេះ មុខជានឹងទៅជារបស់មនុស្សទាំងអស់ ដូចជីវិតអស់កល្បជានិច្ចផងដែរ" (សន្ត: អូគូស្តាំង)។

## សង្ខេប

២៥៥១- "ទ្រព្យសម្បត្តិអ្នកនៅកន្លែងណា ចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ" (មថ ៦,២១)។

២៥៥២-វិន័យទីដប់ហាមមិនឲ្យមានប្រាថ្នាចង់បានទ្រព្យសម្បត្តិលោកីយ៍ដោយគ្មានដែនកំណត់ហួសហេតុ។

២៥៥៣- ពេលយើងមានចិត្តច្រណែនឈ្នានីស យើងព្រួយចិត្តដោយឃើញទ្រព្យសម្បត្តិអ្នកដទៃ ហើយយើងចង់បានទ្រព្យសម្បត្តិនោះមកជាកម្មសិទ្ធរបស់ខ្លួនយើង។ ការច្រណែនឈ្នានីសជាបាបធម៌មូលដ្ឋាន។

២៥៥៤- គ្រីស្តបរិស័ទប្រយុទ្ធប្រឆាំងនឹងចិត្តច្រណែនឈ្នានីស ដោយមានចិត្តទូលាយ ដោយចេះដាក់ខ្លួន និងដោយពឹងផ្អែកទាំងស្រុងទៅលើឧបការគុណរបស់ព្រះជាម្ចាស់។

២៥៥៥- អស់អ្នកដែលរួមជាមួយព្រះគ្រីស្ត "សុទ្ធតែបានឆ្កាងតណ្ហា និងបំណងលោភលន់ផ្សេងៗរបស់លោកីយ៍នោះចោលហើយ" (កាឡ ៥,២៤)។ ព្រះវិញ្ញាណណែនាំពួកគេ ហើយគេធ្វើតាមព្រះបំណងប្រាថ្នារបស់ព្រះអង្គ។

២៥៥៦- ត្រូវតែលះបង់ទ្រព្យសម្បត្តិ ដើម្បីចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ "អស់អ្នកដែលដាក់ខ្លួនជាអ្នកក្រក្សត់មានសុភមង្គលហើយ!"។

២៥៥៧- អ្នកមានបំណងប្រាថ្នាមានប្រសាសន៍ថា៖ "ខ្ញុំចង់ឃើញព្រះជាម្ចាស់"។ ទឹកនៃជីវិតអស់កល្បជានិច្ចបំពេញការស្រេកទឹកព្រះជាម្ចាស់ (យហ ៤,១៤)។

## វគ្គទីបួន៖

# ការអធិដ្ឋាន
# ក្នុងការរស់នៅ
# ជាគ្រីស្ទបរិស័ទ

# ភាគទីមួយ៖

# ការអធិដ្ឋានក្នុងការរស់នៅជាគ្រីស្តបរិស័ទ

២៥៥៨-ក្នុងធម៌ប្រកាសជំនឿព្រះសហគមន៍ប្រកាស "គម្រោងការដ៏លាក់កំបាំងនៃជំនឿ" (វគ្គទីមួយ) ព្រះសហគមន៍ប្រារព្ធគម្រោងការនេះក្នុងពិធីបុណ្យនៃអគ្គសញ្ញា (វគ្គទីពីរ) ដើម្បីឲ្យការរស់នៅរបស់គ្រីស្តបរិស័ទស្របតាមព្រះគ្រីស្តក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ និងដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជាព្រះបិតា (វគ្គទីបី)។ គ្រីស្តបរិស័ទត្រូវតែជឿ ប្រារព្ធ និងទទួលជីវិតពីគម្រោងការនេះដោយមានទំនាក់ទំនងដ៏រស់រវើក និងផ្ទាល់ខ្លួនជាមួយព្រះដ៏មានព្រះជន្មរស់ និងជាព្រះដ៏ពិតប្រាកដ។ ទំនាក់ទំនងនេះ គឺជាការអធិដ្ឋាន។

## អ្វីទៅជាការអធិដ្ឋាន?

ចំពោះខ្ញុំការអធិដ្ឋាន គឺជាការរំភើបចិត្តជាការនឹកគិតដល់ស្ថានលើជាការអរព្រះគុណព្រះជាម្ចាស់ដោយចិត្តស្រឡាញ់ទោះជាពេលកំពុងរងទុក្ខលំបាកក្តី ត្រេកអរសប្បាយក្តី (សន្តី ថេរេសានៃព្រះកុមារយេស៊ូ)។

## ការអធិដ្ឋានជាព្រះអំណោយទានរបស់ព្រះជាម្ចាស់

១៥៥៩-"ការអធិដ្ឋាន គឺជាការលើកព្រលឹងឡើងទៅឯព្រះជាម្ចាស់ ឬយើងអាចទូលសូមឲ្យព្រះអង្គប្រោសប្រទាននូវអ្វីសមរម្យ" (សន្តៈ យ៉ូហានដាម៉ាសែន)។ តើយើងអធិដ្ឋានយ៉ាងដូចម្ដេច? ដោយមានចិត្តអំនួត និងដោយចង់បានជានិច្ច ឬដោយមានចិត្តសុភាពរាបសា ព្រមទាំងសោកស្តាយចំពោះអំពើបាបរបស់ខ្លួន (ទន ១៣០,១)? អ្នកដែលបន្ទាបខ្លួននឹងត្រូវគេលើកតម្កើងវិញ (លក ១៨,៩-១៤)។ ត្រូវតែដាក់ខ្លួនដើម្បីចាក់គ្រឹះទៅក្នុងការអធិដ្ឋាន។ "យើងពុំដឹងអធិដ្ឋានដូចម្ដេចដើម្បីឲ្យបានសមរម្យនោះទេ" (រម ៨,២៦)។ ពេលយើងដាក់ខ្លួនយើងអាចទទួលព្រះអំណោយទានដោយឥតគិតថ្លៃនៃការអធិដ្ឋាន។ មនុស្សលោកជាអ្នកសូមទានព្រះជាម្ចាស់ (សន្តៈ អូគូស្តាំង)។

២៥៦០-"ប្រសិនបើនាងស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់!" (យហ ៤,១០)។ ព្រះជាម្ចាស់សម្ដែងនូវភាពអស្ចារ្យនៃការអធិដ្ឋាននៅជិតអណ្តូងដែលយើងមករកទឹក៖ ទីនោះព្រះគ្រីស្តយាងមកជួបមនុស្សណាម្នាក់ព្រះអង្គយាងមករកយើងមុនគេ ហើយទ្រង់ជាអ្នកសុំទឹកទទួលទាន។ ព្រះយេស៊ូស្រេកទឹក ព្រះអង្គក៏សូមទឹកពីយើងមកពីទីជម្រៅព្រះហឫទ័យព្រះជាម្ចាស់ដែលទ្រង់ប្រាថ្នាចង់បានយើង។ ទោះជាដឹង ឬមិនដឹងក្តី ពេលអធិដ្ឋានព្រះបំណងប្រាថ្នារបស់ព្រះជាម្ចាស់ និងបំណងប្រាថ្នារបស់យើងបានជួបគ្នា។ ព្រះជាម្ចាស់ត្រូវការយើង ៗត្រូវការព្រះអង្គ (សន្តៈ អូគូស្តាំង)។

២៥៦១-"នាងមុខជាសុំទឹកពីលោក ហើយលោកនឹងឲ្យទឹកដល់នាងវិញពុំខាន" (យហ ៤,១០)។ ពាក្យអង្វរយើងបែរទៅជាចម្លើយវិញជាចម្លើយដល់ពាក្យទំនួញនៃព្រះដ៏មានព្រះជន្មរស់៖ "គេបោះបង់យើងដែលជាប្រភពទឹកហូរបែរទៅជាជីកអណ្តូង ជីកស្រះដែលតែងតែប្រេះស្រាំមិនអាចទុកទឹកបានទៅវិញ" (យរ ២,៣)។ ពាក្យអង្វរយើងនេះជាចម្លើយនៃជំនឿចំពោះព្រះបន្ទូលសន្យាឥតគិតថ្លៃរបស់ព្រះសង្គ្រោះ (យហ ៧,៣៧-៣៩; អស ១២,៣; ៥១,១) ហើយជាចម្លើយនៃសេចក្តីស្រឡាញ់ចំពោះព្រះបុត្រាតែមួយដែលស្រេកទឹក (យហ ១៩,២៨; សក ១២,១០; ១៣,១)។

## ពេលអធិដ្ឋានព្រះជាម្ចាស់ និងមនុស្សយើងចងសម្ព័ន្ធមេត្រីជាមួយគ្នា

២៥៦២-តើការអធិដ្ឋានរបស់មនុស្សកើតមកពីណា? ទោះជាគេអធិដ្ឋានដោយធ្វើកាយវិការក្ដី ឬប្រើពាក្យសម្ដីក្ដី មនុស្សទាំងមូលជាអ្នកអធិដ្ឋាន។ ប៉ុន្តែ ដើម្បីដឹងថា ការអធិដ្ឋានផុសចេញពីកន្លែងណាមានពេលខ្លះព្រះគម្ពីរថ្លែងថា ការអធិដ្ឋានចេញពីព្រលឹង ឬពីវិញ្ញាណហើយជារឿយៗ ព្រះគម្ពីរថ្លែងថា ការអធិដ្ឋានកើតចេញពីចិត្ត (ជាងមួយពាន់ដង)។ ចិត្តយើងជាអ្នកអធិដ្ឋាន។ បើចិត្តយើងនៅឆ្ងាយពីព្រះជាម្ចាស់ ការអធិដ្ឋានពិតជាឥតបានការសោះឡើយ។

២៥៦៣-ចិត្តជាដំណាក់ដែលខ្ញុំនៅ (ដែលខ្ញុំ "ចុះ" តាមពាក្យសម្ដីនៃជនជាតិយូដា ឬតាមព្រះគម្ពីរ)។ ចិត្តយើងជាស្នូលដ៏លាក់កំបាំងដែលប្រាជ្ញាយើង និងអ្នកដទៃមិនអាចយល់បាន។ មានតែព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ទេដែលអាចស្ទង់ និងស្គាល់ចិត្តយើងបាន។ ចិត្តយើងជាកន្លែងសម្រាប់ការសម្រេច ដែលស្ថិតនៅក្នុងទីជម្រៅក្រៃលែងជាកន្លែងនៃសេចក្ដីពិត ជាកន្លែងដែលយើងជ្រើសរើសជីវិត ឬសេចក្ដីស្លាប់ ហើយជាកន្លែងដែលយើងជួបព្រះជាម្ចាស់ ដ្បិតដោយសារយើងជារូបតំណាងរបស់ព្រះអង្គ យើងក៏រស់នៅដោយមានទំនាក់ទំនងជាមួយព្រះអង្គ និងជាមួយអ្នកដទៃ ពោលគឺចិត្តជាកន្លែងនៃសម្ព័ន្ធមេត្រី។

២៥៦៤-ការអធិដ្ឋានតាមគ្រីស្ដសាសនាជាសម្ព័ន្ធមេត្រីរវាងព្រះជាម្ចាស់ និងមនុស្សនៅក្នុងអង្គព្រះគ្រីស្ដ។ ការអធិដ្ឋាននេះជាកិច្ចការរបស់ព្រះជាម្ចាស់ផង កិច្ចការរបស់មនុស្សផង ហើយការអធិដ្ឋានផុសចេញពីព្រះវិញ្ញាណដ៏វិសុទ្ធផង ផុសចេញពីចិត្តយើងផង បាញ់ឆ្ពោះទៅឯព្រះបិតាដោយរួមជាមួយព្រះបំណងរបស់ព្រះបុត្រាជាព្រះជាម្ចាស់ដែលប្រសូតជាមនុស្ស។

## ពេលអធិដ្ឋានព្រះជាម្ចាស់ និងមនុស្សយើងរួមរស់ជាមួយគ្នា

២៥៦៥-ក្នុងសម្ព័ន្ធមេត្រីថ្មី ពេលអធិដ្ឋានបុត្រធីតារបស់ព្រះជាម្ចាស់មានទំនាក់ទំនងដ៏រស់រវើក រួមជាមួយព្រះបិតាដែលប្រកបដោយសប្បុរសធម៌ឥតព្រំដែនរួមជាមួយព្រះបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូគ្រីស្ដ និងរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង។ ក្នុងព្រះរាជ្យព្រះអង្គព្រះជាម្ចាស់ប្រោសប្រណីឲ្យ "ព្រះត្រៃឯកដ៏វិសុទ្ធទាំងស្រុងរួបរួមជាមួយវិញ្ញាណទាំងស្រុង" (សន្ដ: គ្រេគ័រ នៃណាស៊ីអង់)។ ដូច្នេះពេលអធិដ្ឋានហាក់ដូចជាបង្កើតទំនៀមទម្លាប់ឲ្យយើងឈរពីមុខព្រះដ៏ខ្ពង់ខ្ពស់បំផុត ដោយរួមរស់ជាមួយព្រះអង្គ។ យើងអាចរួមរស់ជាមួយព្រះអង្គបែបនេះជានិច្ចបាន ដោយសារបុណ្យជ្រមុជទឹក យើងបានទៅជាបុគ្គលតែម្នាក់ជាមួយនឹងព្រះគ្រីស្ដ (រម ៦,៥)។ យើងអធិដ្ឋានតាមគ្រីស្ដសាសនា ពេលយើងរួមរស់ជាមួយព្រះគ្រីស្ដ ហើយការអធិដ្ឋាននេះលាតសន្ធឹងក្នុងព្រះសហគមន៍ ដែលជាព្រះកាយព្រះគ្រីស្ដ។ ទំហំនៃការអធិដ្ឋានជាសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ដ (អភ ៣,១៨-២១)។

# ជំពូកទីមួយ៖

# ព្រះជាម្ចាស់សម្ដែងឲ្យមនុស្សលោកដឹងអំពីការអធិដ្ឋាន

## ព្រះអង្គត្រាស់ហៅមនុស្សលោកទាំងអស់ឲ្យអធិដ្ឋាន

២៥៦៦-មនុស្សលោកស្វែងរកព្រះជាម្ចាស់។ ដោយសារព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ ព្រះអង្គក៏ត្រាស់ហៅសត្វលោកទាំងអស់ពីភាពសាបសូន្យឲ្យមានជីវិតរស់នៅ។ ដោយព្រះអង្គប្រទាន "សិរីរុងរឿង និងកិត្តិយស

ដល់គេទុកជាមកុដរាជ្យ" (ទន ៨,៦) បន្ទាប់ពីទេវទូតមនុស្សអាចទទួលស្គាល់ថា "ព្រះនាមរបស់ព្រះអង្គថ្កុំថ្កើងរុងរឿងពាសពេញលើផែនដីទាំងមូល" (ទន ៨,២)។ ទោះបីគេបានបាត់បង់លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់ដោយសារអំពើបាបរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏មនុស្សលោកនៅតែជារូបតំណាងរបស់ព្រះជាម្ចាស់ដែលជាអ្នកបង្កើតគេដែរ។ មនុស្សរក្សាទុកបំណងប្រាថ្នាចង់បានព្រះដែលត្រាស់ហៅគេ ឲ្យមានជីវិតរស់នៅ។ សាសនាទាំងឡាយផ្ដល់សក្ខីភាពថាមនុស្សលោកស្វែងរកព្រះជាម្ចាស់ជាចាំបាច់ (កក ១៧,២៧)។

២៥៦៧-ព្រះជាម្ចាស់ជាអ្នកត្រាស់ហៅមនុស្សលោកមុនគេបង្អស់។ ទោះបីមនុស្សលោកបំភ្លេចព្រះជាម្ចាស់ជាអ្នកបង្កើតគេ ឬលាក់ខ្លួនឆ្ងាយពីព្រះភ័ក្ត្រព្រះអង្គក្ដី រត់ទៅរកព្រះក្លែងក្លាយ ឬចោទប្រកាន់ព្រះអង្គថាបានបោះបង់គេចោលក្ដី ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ និងជាព្រះដ៏ពិតប្រាកដរមែងតែងតែត្រាស់ហៅមនុស្សម្នាក់ៗឲ្យជួបព្រះអង្គយ៉ាងលាក់កំបាំងក្នុងការអធិដ្ឋាន។ ក្នុងការអធិដ្ឋានព្រះដ៏ស្មោះត្រង់តែងតែស្រឡាញ់មនុស្សមុនគេ ឯមនុស្សវិញគេគ្រាន់តែឆ្លើយតបនឹងព្រះអង្គ។ ក្នុងការអធិដ្ឋានបន្តិចម្ដងៗព្រះជាម្ចាស់សម្ដែងព្រះអង្គឲ្យមនុស្សស្គាល់ និងសម្ដែងមនុស្សឲ្យគេស្គាល់ខ្លួនឯងផងដែរ ហាក់ដូចជាព្រះជាម្ចាស់ និងមនុស្សត្រាស់ហៅគ្នាទៅវិញទៅមក និងចងសម្ព័ន្ធមេត្រីជាមួយគ្នា។ តាមរយៈពាក្យសម្ដី និងកិច្ចការព្រះជាម្ចាស់សម្ដែងរឿងសម្ព័ន្ធមេត្រីនេះដែលជាប់ចិត្តមនុស្សក្នុងប្រវត្តិសាស្ត្រទាំងមូលនៃការសង្គ្រោះ។

# ប្រការទី១៖

# ក្នុងសម្ព័ន្ធមេត្រីចាស់

២៥៦៨-ក្នុងសម្ព័ន្ធមេត្រីចាស់ ព្រះជាម្ចាស់សម្ដែងឲ្យយើងដឹងអំពីការអធិដ្ឋានចាប់តាំងពីពេលដែលមនុស្សលោកធ្លាក់ខ្លួនជាអ្នកបាបរហូតដល់ពេលព្រះអង្គប្រោសគេឲ្យងើបឡើងវិញ ហើយចាប់តាំងពីពេលដែលព្រះអង្គហៅបុត្រធីតាដំបូងរបស់ព្រះអង្គដោយរំជួលព្រះហឫទ័យថា៖ "អ្នកនៅឯណា? (...) ម្ដេចក៏នាងធ្វើដូច្នេះ?" (កណ ៣,៩.១៣) រហូតដល់ពេលដែលព្រះបុត្រាតែមួយឆ្លើយតបនឹងព្រះអង្គ ដោយយាងចូលក្នុងពិភពលោក ("បពិត្រព្រះជាម្ចាស់ឥឡូវនេះទូលបង្គំមកធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គហើយ" ហប ១០,៥-៧)។ ដូច្នេះហើយ ទើបការអធិដ្ឋានត្រូវបានចងភ្ជាប់ទៅនឹងប្រវត្តិសាស្ត្ររបស់មនុស្សលោក។ ក្នុងហេតុការណ៍ទាំងឡាយនៃប្រវត្តិសាស្ត្រ ការអធិដ្ឋានជាទំនាក់ទំនងរវាងព្រះជាម្ចាស់ និងមនុស្ស។

## ស្នាព្រះហស្តនៃការបង្កើតពិភពលោកជាប្រភពនៃការអធិដ្ឋាន

២៥៦៩-ជាដំបូងការអធិដ្ឋានចេញមកពីស្នាព្រះហស្តនៃការបង្កើតភិពភលោក។ ជំពូកដំបូងទាំងប្រាំបួននៃកណ្ឌកំណើតពិភពលោករៀបរាប់អំពីទំនាក់ទំនងរបស់មនុស្សលោកជាមួយព្រះជាម្ចាស់ ពេលលោកអេបិលយកកូនសត្វដែលកើតមុនគេបង្អស់ក្នុងហ្វូងសត្វរបស់លោកមកថ្វាយព្រះអង្គ (កណ ៤,៤) ពេលលោកអេណុសគោរពថ្វាយបង្គំព្រះអង្គដោយហៅព្រះអង្គថា "ព្រះអម្ចាស់" (កណ ៤,២៦) ឬពេលជនជាតិអ៊ីស្រាអែល "ដើរតាមមាគ៌ារបស់ព្រះជាម្ចាស់" (កណ ៥,២៤)។ តង្វាយរបស់លោកណូអេ "គាប់ព្រះហឫទ័យ" ព្រះជាម្ចាស់ព្រះអង្គប្រទានព្រះពរដល់លោក ហើយប្រទានព្រះពរដល់សត្វលោកទាំងអស់តាមរយៈលោក (កណ ៨,២០-៩,១៧) ដ្បិតលោកមានចិត្តសុចរិត និងទៀងត្រង់ គឺលោក "ដើរតាមមាគ៌ារបស់ព្រះជាម្ចាស់" (កណ ៦,៩)។ ក្នុងសាសនាទាំងឡាយមនុស្សសុចរិតជាច្រើនអធិដ្ឋានតាមរបៀបដ៏ត្រឹមត្រូវនេះ។

ក្នុងសម្ព័ន្ធមេត្រីដែលមិនអាចផ្ដាច់បានជាមួយសត្វលោក (កណ ៩,៨-១៦) ព្រះជាម្ចាស់តែងតែត្រាស់ហៅមនុស្សលោកឲ្យអធិដ្ឋានដល់ព្រះអង្គ។ ប៉ុន្តែ ព្រះជាម្ចាស់សម្ដែងនូវការអធិដ្ឋានឲ្យមនុស្សលោក ជាពិសេសចាប់តាំងពីលោកអប្រាហាំដែលជាឪពុកពួកយើង។

## ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាចំពោះលោក អប្រាហាំ និងជំនឿបានក្លាយទៅជាពាក្យអធិដ្ឋាន

២៥៧០-វេលាដែលព្រះជាម្ចាស់ត្រាស់ហៅលោក អប្រាហាំ ឲ្យចាកចេញ លោកក៏ប្រតិបត្តិ "តាមព្រះបន្ទូលរបស់ព្រះអម្ចាស់" (កណ ១២,៤) គឺចិត្តលោក "គោរពតាមព្រះបន្ទូល" ស្ដាប់បង្គាប់ព្រះអង្គ។ ក្នុងការអធិដ្ឋានចាំបាច់ត្រូវតែស្ដាប់ព្រះជាម្ចាស់ និងសម្រេចតាមព្រះអង្គពីជម្រៅចិត្តរបស់ខ្លួន ពាក្យសម្ដីមិនសូវសំខាន់ទេ។ ប៉ុន្តែមុនដំបូងបង្អស់លោក អប្រាហាំ អធិដ្ឋានដោយបំពេញកិច្ចការ។ ដោយលោកជាមនុស្សម្នាក់មិនសូវចេះនិយាយស្ដី លោកតែងតែសង់អាសនៈថ្វាយចំពោះព្រះអម្ចាស់ក្នុងដំណាក់កាលនីមួយៗនៃការធ្វើដំណើរ។ ក្រោយមកលោកត្រូវតែអធិដ្ឋានដោយសម្ដីត្អូញត្អែរម្យ៉ាង ដើម្បីឲ្យព្រះជាម្ចាស់រំឭកដល់ព្រះបន្ទូលសន្យារបស់ព្រះអង្គដែលហាក់ដូចជាមិនបានគោរពឡើយ (កណ ១៥,២-៣)។ ហេតុនេះហើយបានជាតាំងពីដំបូងបង្អស់ ការអធិដ្ឋានហាក់ដូចជាវិនាដកម្មមួយដែលល្បងលមើលចិត្តមនុស្សថា តើគេជឿថាព្រះជាម្ចាស់ជាព្រះដ៏ស្មោះត្រង់ជានិច្ច ឬទេ។

២៥៧១-ក្រោយពីបានផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់ (កណ ១៥,៦) ដោយដើរតាមមាគ៌ារបស់ព្រះអង្គ និងដោយចងសម្ព័ន្ធមេត្រីជាមួយព្រះអង្គ (កណ ១៧,១-២) បុព្វបុរសយើងត្រៀមខ្លួននឹងទទួលភ្ញៀវដ៏លាក់កំបាំងក្នុងជំរំលោក គឺលោករាក់ទាក់នឹងព្រះជាម្ចាស់នៅក្រោមដើមជ្រៃ លោកតាម៉ាមរ៉េដែលសម្ដែងទុកជាមុនថាព្រះបុត្រាយ៉ាងពិតប្រាកដនៃព្រះបន្ទូលសន្យានឹងយាងមក (កណ ១៨,១-១៥; លក ១,២៦-៣៨)។ ចាប់ពីពេលនោះមកក្រោយពីបានស្គាល់គម្រោងការរបស់ព្រះអង្គ លោក អប្រាហាំ មានចិត្តគំនិតស្របនឹងព្រះហឫទ័យមេត្តាករុណានៃព្រះអម្ចាស់របស់លោកចំពោះមនុស្សលោក ហើយលោកក៏មានសេចក្ដីក្លាហានហ៊ានជួយអង្វរព្រះអង្គជំនួសពួកគេ (កណ ១៨,១៦-៣៣)។

២៥៧២-ដើម្បីបន្សុទ្ធជំនឿរបស់លោកជាលើកចុងក្រោយ ព្រះជាម្ចាស់សូមឲ្យលោកជាអ្នក "ទទួលព្រះបន្ទូលសន្យា" (ហប ១១,១៧) យកកូនដែលព្រះអង្គបានប្រោសប្រទានទៅធ្វើយញ្ញបូជា។ ជំនឿរបស់លោកមិនរវាទសោះឡើយ៖ "ព្រះជាម្ចាស់ផ្ទាល់នឹងផ្គត់ផ្គង់ចៀមសម្រាប់ធ្វើយញ្ញបូជា" (កណ ២២,៨) ដ្បិត "លោកយល់ឃើញថាព្រះជាម្ចាស់មានឫទ្ធានុភាពអាចប្រោសមនុស្សស្លាប់ឲ្យមានជីវិតថ្មីបាន" (ហប ១១,១៩)។ ហេតុនេះហើយបានជាព្រះជាម្ចាស់ប្រោសលោកឪពុករបស់អស់អ្នកជឿឲ្យមានលក្ខណៈដូចព្រះបិតា ដែលមិនបានទុកព្រះបុត្រារបស់ព្រះអង្គផ្ទាល់ គឺព្រះអង្គបានបញ្ជូនព្រះបុត្រានោះមកសម្រាប់យើងទាំងអស់គ្នា (រម ៨,៣២)។ ពេលអធិដ្ឋានព្រះជាម្ចាស់ប្រោសមនុស្សឲ្យមានលក្ខណៈដូចព្រះអង្គឡើងវិញ និងធ្វើឲ្យគេរួមចំណែកក្នុងឫទ្ធានុភាពនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដែលសង្គ្រោះប្រជាជាតិទាំងឡាយ (រម ៤,១៦-២១)។

២៥៧៣-ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាម្ដងទៀតចំពោះលោកយ៉ាកុបជាជីតារបស់កុលសម្ព័ន្ធទាំងដប់ពីរនៃជនជាតិអ៊ីស្រាអែល (កណ ២៨,១០-២២)។ មុននឹងជួបអេសាវជាបងប្រុសលោកក៏ប្រយុទ្ធប្រឆាំងអស់មួយយប់នឹង "បុរស" ដ៏អាថ៌កំបាំងម្នាក់ដែលបដិសេធមិនព្រមប្រាប់ឈ្មោះរបស់ខ្លួន តែប្រទានពរដល់លោកមុននឹងចាកចេញទៅពេលព្រឹកព្រលឹម។ ចំពោះការបញ្ជូនបន្តខាងវិញ្ញាណរបស់ព្រះសហគមន៍រឿងនេះ បង្ហាញថាអ្នកអធិដ្ឋានដូចជាអ្នកច្បាំងក្នុងជំនឿ នឹងទទួលជោគជ័យបើមានចិត្តព្យាយាម (កណ ៣២,២៥-៣១; លក ១៨,១-៨)។

## លោកម៉ូសេជាស្ពានមេត្រីជួយអង្វរព្រះជាម្ចាស់សម្រាប់អ្នកដទៃ

២៥៧៤-ពេលព្រះបន្ទូលសន្យាចាប់ផ្តើមកើតឡើង (បុណ្យចម្លងដំណើររំលោះទៅកាន់សេរីភាពព្រះអំណោយទាននៃធម្មវិន័យ និងទីបញ្ចប់នៃសម្ព័ន្ធមេត្រី) ការអធិដ្ឋានរបស់លោកម៉ូសេឆ្លុះបញ្ចាំងការអធិដ្ឋានរបស់ "ស្ពានមេត្រីតែមួយរវាងព្រះជាម្ចាស់ និងមនុស្សលោក គឺព្រះគ្រីស្តយេស៊ូ" ដែលជួយអង្វរព្រះជាម្ចាស់សម្រាប់មនុស្សលោក (១ធម ២,៥)។

២៥៧៥-នៅទីនេះដដែលព្រះជាម្ចាស់យាងមកមុនគេបង្អស់។ ព្រះអង្គត្រាស់ហៅលោកម៉ូសេពីគុម្ពោតដែលដុតតែមិនឆេះ (សរ ៣,១-១០)។ ហេតុការណ៍នេះនឹងទៅជារូបរាងនៃការអធិដ្ឋានក្នុងការបញ្ជូនបន្តខាងវិញ្ញាណរបស់ជនជាតិយូដា និងគ្រីស្តបរិស័ទផង។ បើ "ព្រះរបស់លោក អប្រាហាំ លោក អ៊ីសាក និងលោក យ៉ាកុប" ត្រាស់ហៅលោក ម៉ូសេ ជាអ្នកបម្រើរបស់ព្រះអង្គបានសេចក្តីថាព្រះអង្គជាព្រះដ៏មានព្រះជន្មរស់ដែលសព្វព្រះហឫទ័យឲ្យមនុស្សលោកមានជីវិត។ ព្រះជាម្ចាស់សម្តែងព្រះអង្គដើម្បីសង្គ្រោះគេ ប៉ុន្តែ ព្រះអង្គមិនសង្គ្រោះគេដោយខ្លួនព្រះអង្គតែប៉ុណ្ណោះទេ ហើយទ្រង់ក៏មិនបង្ខំគេផងដែរ គឺព្រះជាម្ចាស់ត្រាស់ហៅលោក ម៉ូសេ ឲ្យទៅដើម្បីឲ្យលោករួមចំណែកក្នុងព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ និងក្នុងព្រះរាជកិច្ចនៃការសង្គ្រោះរបស់ព្រះអង្គ។ ហាក់ដូចជាព្រះជាម្ចាស់អង្វរលោកម៉ូសេឲ្យចូលរួមក្នុងបេសកកម្មនេះ។ ក្រោយពីបានពិភាក្សាយ៉ាងយូរបំណងលោកម៉ូសេក៏ស្របនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាអ្នកសង្គ្រោះ។ ប៉ុន្តែ ក្នុងការសន្ទនានេះដែលព្រះជាម្ចាស់សម្តែងព្រះអង្គលោកម៉ូសេក៏រៀនអធិដ្ឋានផងដែរ គឺលោកគេចវេះប្រកែក ជាពិសេសលោកសុំហើយដោយសារលោកចេះតែសុំព្រះអម្ចាស់ក៏សម្តែងព្រះនាមដ៏ឧត្តុង្គឧត្តមមិនអាចថ្លែងបាន ព្រមទាំងកិច្ចការដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គផង។

២៥៧៦-ពេលនោះ "ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេទល់មុខគ្នាហាក់ដូចជាមនុស្សម្នាក់សន្ទនាជាមួយមិត្តសម្លាញ់របស់ខ្លួន" (សរ ៣៣,១១)។ លោកម៉ូសេអធិដ្ឋានតាមរបៀបស៊ីងស្មាធិ៍ ដែលនាំឲ្យគាត់ទៅជាអ្នកបម្រើដ៏ស្មោះត្រង់នឹងបេសកកម្មរបស់ខ្លួនជានិច្ច។ គាត់ "សន្ទនា" ជារឿយៗ និងយ៉ាងយូរជាមួយព្រះអម្ចាស់ដោយឡើងលើភ្នំដើម្បីស្តាប់ និងអង្វរព្រះអង្គដោយចុះពីលើភ្នំទៅរកប្រជាជនដើម្បីនាំព្រះបន្ទូលនៃព្រះជាម្ចាស់របស់លោក និងដើម្បីទៅណែនាំប្រជាជនទាំងនោះផង។ "ម៉ូសេមានចិត្តស្មោះត្រង់ចំពោះកិច្ចការក្នុងព្រះដំណាក់របស់យើងទាំងមូល។ យើងនិយាយទៅកាន់ម៉ូសេដោយផ្ទាល់មាត់យើងសម្តែងឲ្យម៉ូសេឃើញដោយឥតប្រើប្រស្នាហើយម៉ូសេអាចមើលយើងឃើញ" (ជរ ១២,៧-៨) ដ្បិត "លោកម៉ូសេសុភាពរាបសាជាងគេបំផុតក្នុងចំណោមមនុស្សនៅលើផែនដីនេះ" (ជរ ១២,៣)។

២៥៧៧-ក្នុងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះដ៏ស្មោះត្រង់ប្រកបដោយព្រះហឫទ័យអត់ធ្មត់ និងពោរពេញទៅដោយធម៌មេត្តាករុណានេះ (សរ ៣៤,៦) លោកម៉ូសេបានស្រង់កម្លាំងដើម្បីជួយអង្វរព្រះអង្គដោយចិត្តព្យាយាម។ លោកមិនទូលអង្វរសម្រាប់ខ្លួនលោកផ្ទាល់ទេ តែសម្រាប់ប្រជាជនដែលព្រះជាម្ចាស់បានលោះ។ លោកម៉ូសេជួយអង្វរព្រះអង្គពេលជនជាតិអ៊ីស្រាអែលប្រយុទ្ធច្បាំងនឹងជនជាតិអាម៉ាឡេក (សរ ១៧,៨-១៣) ឬដើម្បីឲ្យនាងម៉ៀរីយ៉ាមបានជាសះស្បើយ (ជរ ១២,១៣-១៤)។ ប៉ុន្តែ លោកម៉ូសេជួយទូលអង្វរព្រះជាម្ចាស់ឲ្យគេ "គ្រប់ពេលវេលា" (ទន ១០៦,៣) ដើម្បីសង្គ្រោះប្រជាជនដែលបានក្បត់ព្រះអង្គ (សរ ៣២,១-៣៤,៩)។ លោកម៉ូសេអធិដ្ឋានដោយប្រើអំណះអំណាង (ការជួយទូលអង្វរ គឺជាការប្រយុទ្ធលាក់កំបាំងមួយ) ដែលនឹងជួយអ្នកអធិដ្ឋានប្រជាជនយូដា ឬក្នុងព្រះសហគមន៍ឲ្យមានចិត្តក្លាហាន ពីព្រោះព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ដូច្នេះព្រះអង្គ

សុចរិត និងស្មោះត្រង់ ព្រះអង្គក៏មិនអាចក្បត់ខ្លួនឯងដែរ ព្រះអង្គត្រូវតែរំឭកដល់កិច្ចការដ៏អស្ចារ្យរបស់ព្រះអង្គ ដោយសារសិរីរុងរឿងរបស់ព្រះអង្គ ទ្រង់ក៏មិនអាចបោះបង់ចោលប្រជាជននេះដែលជាតំណាងរបស់ព្រះអង្គបានឡើយ។

## ព្រះបាទដាវីឌទូលអង្វរព្រះជាម្ចាស់

២៥៧៨-ការអធិដ្ឋានរបស់ប្រជាជននៃព្រះជាម្ចាស់នឹងរីកចម្រើនក្រោមម្លប់នៃព្រះដំណាក់របស់ព្រះអង្គ ពោលគឺហិបនៃសម្ពន្ធមេត្រី និងក្រោយមកព្រះវិហារ។ មុនដំបូងអ្នកណែនាំប្រជាជនដូចជាពួកគង្វាល និងពួកព្យាការីនឹងបង្រៀនគេឲ្យចេះអធិដ្ឋាន។ នាងហាណ្ណាជាម្ដាយបានបង្រៀនកុមារសាមូអែលឲ្យចេះប្រកាន់ឥរិយាបទ "ចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់" (១សម ១,៩-១៨)។ កុមារសាមូអែលបានរៀនស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ពីលោកបូជាចារ្យហេលី៖ "សូមមានព្រះបន្ទូលមកចុះទូលបង្គំជាអ្នកបម្រើរង់ចាំស្ដាប់ព្រះអង្គហើយ" (១សម ៣,៩-១០)។ ក្រោយមក លោកសាមូអែលនឹងយល់ឃើញថាត្រូវតែតស៊ូទាំងរងទុក្ខលំបាក ដើម្បីជួយទូលអង្វរព្រះជាម្ចាស់៖ "ចំពោះរូបខ្ញុំវិញ ដាច់ខាតខ្ញុំមិនប្រព្រឹត្តអំពើបាបចំពោះព្រះអម្ចាស់ដោយឈប់ទូលអង្វរឲ្យអ្នករាល់គ្នា ហើយនឹងណែនាំអ្នករាល់គ្នាឲ្យដើរតាមផ្លូវល្អ និងទៀងត្រង់មិនខានឡើយ" (១សម ១២,២៣)។

២៥៧៩-ព្រះបាទដាវីឌជាព្រះមហាក្សត្រដែល "ជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់" ជាគង្វាលដែលអធិដ្ឋានសម្រាប់ប្រជារាស្ត្ររបស់ខ្លួន និងក្នុងនាមប្រជាជននោះ។ ព្រះអង្គគោរពតាមព្រះហឫទ័យព្រះជាម្ចាស់ពោលពាក្យសរសើរ និងពោលពាក្យសោកស្ដាយ ដែលនឹងទៅជាគំរូឲ្យប្រជារាស្ត្រអធិដ្ឋានតាមផង។ ដោយសារព្រះអង្គបានទទួលប្រេងអភិសេក ព្រះអង្គអធិដ្ឋានដោយភ្ជាប់នឹងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដោយមានចិត្តស្មោះត្រង់ (១សម ៧,១៨-២៩) ជឿទុកចិត្ត និងត្រេកអរសប្បាយចំពោះព្រះជាម្ចាស់ដែលជាព្រះមហាក្សត្រ និងជាព្រះអម្ចាស់តែមួយ។ ក្នុងទំនុកតម្កើងដោយមានព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺព្រះបាទដាវីឌជាព្យាការីដើមដំបូងនៃការអធិដ្ឋានរបស់ជនជាតិយូដា និងគ្រីស្តបរិស័ទ។ ការអធិដ្ឋាននៃព្រះគ្រីស្តដែលជាព្រះមេស្ស៊ីដ៏ពិតប្រាកដ និងជាព្រះបុត្រារបស់ព្រះបាទដាវីឌនឹងសម្ដែង ហើយនឹងបំពេញអត្ថន័យនៃការអធិដ្ឋាននោះ។

២៥៨០-ព្រះវិហារនៃទីក្រុងយេរូសាឡឹមជាព្រះដំណាក់នៃការអធិដ្ឋាន កសាងដោយព្រះបាទ សាឡូម៉ូនជាព្រះបុត្រារបស់ព្រះបាទដាវីឌ។ ពេលឧទ្ទិសព្រះវិហារការអធិដ្ឋានរំឭកអំពីព្រះបន្ទូលសន្យា និងសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ វត្តមានដ៏សកម្មនៃព្រះនាមព្រះអង្គក្នុងចំណោមប្រជារាស្ត្រព្រះអង្គ និងកិច្ចការដ៏អស្ចារ្យរបស់ទ្រង់ក្នុងការធ្វើដំណើរឆ្ពោះទៅកាន់សេរីភាព។ ពេលនោះព្រះមហាក្សត្រលើកព្រះហស្តឡើងទៅលើមេឃ ហើយទូលអង្វរព្រះអម្ចាស់សម្រាប់ព្រះកាយព្រះអង្គសម្រាប់ប្រជារាស្ត្រទាំងមូល និងសម្រាប់អ្នកជំនាន់ក្រោយផងដែរ សូមឲ្យព្រះជាម្ចាស់លើកលែងទោសអំពើបាបរបស់គេ និងប្រោសប្រទានតាមតម្រូវការរបស់គេជារៀងរាល់ថ្ងៃ ដើម្បីឲ្យប្រជាជាតិទាំងឡាយដឹងថាព្រះអង្គជាព្រះតែមួយគត់ និងដើម្បីឲ្យអ្នកទាំងនោះផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ។

## លោកអេលី និងពួកព្យាការីជំរុញប្រជាជនឲ្យកែប្រែចិត្តគំនិត

២៥៨១-ចំពោះប្រជារាស្ត្ររបស់ព្រះជាម្ចាស់ព្រះវិហារជាកន្លែងអប់រំឲ្យចេះអធិដ្ឋាន ពោលគឺជាកន្លែងធ្វើបូជនីយេសចរណ៍ធ្វើបុណ្យយញ្ញបូជាថ្វាយតង្វាយធូបនំបុ័ងដែលជាសញ្ញាសម្គាល់ទាំងអស់នៃភាពដ៏វិសុទ្ធ និងសិរីរុងរឿងរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត និងយ៉ាងជិតស្និតដែលត្រាស់ហៅគេឲ្យអធិដ្ឋាន។ ប៉ុន្តែ ជារឿយៗពិធីដដែលៗបណ្ដាលឲ្យប្រជារាស្ត្រគោរពព្រះជាម្ចាស់តាមតែលើបបូរមាត់ប៉ុណ្ណោះ។ ដូច្នេះហើយបានជាមុននឹងក្រោយប្រជារាស្ត្រ

ក្លាយជាឈ្លើយនៃសឹកសង្គ្រាម ព្រះជាម្ចាស់ផ្តល់បេសកកម្មឲ្យពួកព្យាការីអប់រំគេឲ្យផ្ញើជីវិតទាំងស្រុងលើព្រះអង្គ ព្រមទាំងកែប្រែចិត្តគំនិតផង។

២៥៨២-លោកអេលីជាឪពុករបស់ពួកព្យាការីពីពូជពង្សរបស់ "អស់អ្នកដែលស្វែងរកព្រះជាម្ចាស់" អស់អ្នកដែលចង់ជួបព្រះភ័ក្ត្រព្រះអង្គ (ទន ២៤,៦)។ ឈ្មោះរបស់លោកអេលី គឺ "ព្រះអម្ចាស់ជាព្រះរបស់ខ្ញុំ" ជាចម្លើយទុកជាមុនរបស់ប្រជារាស្ត្រចំពោះការអធិដ្ឋានរបស់លោកលើភ្នំការម៉ែល (១ពង្ស ១៨,៣៩)។ លោក យ៉ាកុប ជំរុញយើងឲ្យអធិដ្ឋានដូចលោកអេលីដោយពោល "ពាក្យទូលអង្វររបស់មនុស្សសុចរិតមានប្រសិទ្ធិភាពខ្លាំងណាស់" (យប ៥,១៦ខ-១៨)។

២៥៨៣-ក្រោយពីបានរៀនពីធម៌មេត្តាករុណានៅមាត់ជ្រោះកេរីត លោកបង្រៀនស្ត្រីមេម៉ាយនៅភូមិសារិបតាឲ្យផ្ញើជីវិតទាំងស្រុងលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយលោកបញ្ជាក់ជំនឿនេះ ដោយទទូចទូលអង្វរព្រះជាម្ចាស់ដោយមានចិត្តព្យាយាម គឺព្រះអង្គប្រោសឲ្យកូនស្ត្រីនោះឲ្យរស់ឡើងវិញ (១ពង្ស ១៧,៧-២៤)។

ពេលធ្វើយញ្ញបូជាលើភ្នំការម៉ែលជាហេតុការណ៍ដែលនឹងបញ្ជាក់ជំនឿយ៉ាងពិតប្រាកដនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ នៅពេលលោកអេលីទូលអង្វរសម្រាប់ឲ្យភ្លើងរបស់ព្រះអង្គដុតយញ្ញទាំងមូលគឺ "នៅពេលដែលយើងថ្វាយតង្វាយល្ងាច"៖ "ព្រះអម្ចាស់អើយសូមមេត្តាឆ្លើយតបមកទូលបង្គំផង!"។ ពិធីបុណ្យខាងបូព៌ាប្រទេសតែងតែរំឭកយកពាក្យអធិដ្ឋានរបស់លោកអេលីនោះឡើងវិញ (១ពង្ស ១៨,២០-៣៩)។

ទីបំផុតដោយដើរតាមផ្លូវនៃវាលរហោស្ថានឆ្ពោះទៅកន្លែងដែលព្រះដ៏មានព្រះជន្មរស់ និងជាព្រះដ៏ពិតប្រាកដបានសម្តែងព្រះអង្គឲ្យប្រជារាស្ត្ររបស់ព្រះអង្គស្គាល់លោក អេលី ចូលទៅស្នាក់ក្នុងគុហាដូចលោក ម៉ូសេ រហូតដល់ព្រះជាម្ចាស់ដ៏លាក់កំបាំងយាងមក (១ពង្ស ១៩,១-១៤; សរ ៣៣,១៩-២៣)។ ប៉ុន្តែ ព្រះជាម្ចាស់នឹងសម្តែងព្រះអង្គឲ្យបានពេញលក្ខណៈដល់អស់អ្នកដែលស្វែងរកព្រះភ័ក្ត្រព្រះអង្គនៅពេលដែលព្រះយេស៊ូនឹងប្រែទ្រង់ទ្រាយ (លក ៩,៣០-៣៥)។ មនុស្សលោកស្គាល់សិរីរុងរឿងរបស់ព្រះជាម្ចាស់ វេលាដែលព្រះគ្រីស្តត្រូវគេឆ្កាង និងមានព្រះជន្មរស់ឡើងវិញ (២ករ ៤,៦)។

២៥៨៤-ដោយអស់លោកព្យាការីនៅជាមួយព្រះជាម្ចាស់ផ្ទាល់ ពួកលោកទទួលកម្លាំង និងពន្លឺអំពីព្រះអង្គ ដើម្បីបំពេញបេសកកម្ម។ គេអធិដ្ឋានមិនមែនដើម្បីគេចពីលោកដ៏មិនទៀងទាត់នេះទេ តែដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ពេលខ្លះគេពិភាក្សា ឬត្អូញត្អែរ ប៉ុន្តែ គេតែងតែជួយទូលអង្វរព្រះជាម្ចាស់ជាព្រះអម្ចាស់នៃប្រវត្តិសាស្ត្រឲ្យព្រះអង្គយាងមកសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គដោយរង់ចាំ និងរៀបចំឲ្យព្រះអង្គយាងមក (អម ៧,២.៥; អស ៦,៥.៨.១១; យរ ១,៦; ១៥,១៥-១៨; ២០,៧-១៨)។

## អង្គប្រជុំរបស់អ្នកជឿអធិដ្ឋានដោយសូត្រទំនុកតម្កើង

២៥៨៥-តាំងពីព្រះបាទដាវីឌរហូតដល់ព្រះមេស្ស៊ីយាងមក កណ្ឌគម្ពីរដ៏វិសុទ្ធមានសេចក្តីអធិដ្ឋានដែលផ្តល់សក្ខីភាពថា ប្រជារាស្ត្រអ៊ីស្រាអែលបានចូលក្នុងការអធិដ្ឋានសម្រាប់ខ្លួនឯងផង សម្រាប់អ្នកដទៃផង កាន់តែស៊ីជម្រៅទៅៗ (អរ ៩,៦-១៥; នហ ១,៤-១១; យណ ២,៣-១០; តប ៣,១១-១៦; យឌ ៩,២-១៤)។ បន្តិចម្តងៗ គេបានប្រមូលសេចក្តីអធិដ្ឋាននោះ ដែលគេហៅថាទំនុកតម្កើង (ឬ "ពាក្យសរសើរ") ហើយសរសេរចូលក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ចំនួនប្រាំកណ្ឌ ដែលជាសេចក្តីអធិដ្ឋានដ៏កំពូល។

២៥៨៦-ក្នុងឱកាសបុណ្យធំៗនៅទីក្រុងយេរូសាឡឹម ឬជារៀងរាល់ថ្ងៃសប្ប័ទក្នុងធម្មសាលាប្រជារាស្ត្ររបស់

ព្រះជាម្ចាស់ជួបជុំគ្នាសូត្រទំនុកតម្កើងដើម្បីអធិដ្ឋាន។ គេអធិដ្ឋានបែបនេះតែម្នាក់ឯង ឬជាមួយគ្នាដើម្បីអ្នកអធិដ្ឋានផង និងមនុស្សទាំងអស់គ្នាផង។ ការអធិដ្ឋានបែបនេះ កើតចេញពីទឹកដីដ៏វិសុទ្ធ និងពីសហគមន៍ជនជាតិយូដាដែលខ្ចាត់ខ្ចាយក្នុងពិភពលោករហូតដល់សត្វលោកទាំងអស់។ ពេលអធិដ្ឋានបែបនេះ គេរំឭកអំពីហេតុការណ៍របស់ព្រះសង្គ្រោះ ក្នុងអតីតកាលរហូតដល់អវសានកាលនៃប្រវត្តិសាស្ត្រ គឺគេរំឭកពីព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ដែលបានកើតចេញជារូបរាងហើយៗគេរង់ចាំព្រះមេស្ស៊ី ដែលនឹងបំពេញព្រះបន្ទូលសន្យានោះឲ្យបានពេញលក្ខណៈ។ ព្រះគ្រីស្តបានអធិដ្ឋាន និងបានបំពេញទំនុកតម្កើងដែលនៅតែជាចាំបាច់ក្នុងការអធិដ្ឋានរបស់ព្រះសហគមន៍ (IGLH ១០០-១០៩)។

២៥៨៧-ក្នុងកណ្ឌទំនុកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅជាពាក្យអង្វររបស់មនុស្សលោក។ ក្នុងកណ្ឌផ្សេងៗនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ "ពាក្យសម្ដីប្រកាសស្នាព្រះហស្ត (របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក) ហើយសម្ដែងគម្រោងការដ៏លាក់កំបាំងដែលស្ថិតនៅក្នុងស្នាព្រះហស្តនោះ" (DV ២)។ ក្នុងកណ្ឌទំនុកតម្កើងពាក្យសម្ដីរបស់អ្នកនិពន្ធសម្ដែងនូវស្នាព្រះហស្តរបស់ព្រះជាម្ចាស់ជាអ្នកសង្គ្រោះ។ ព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺស្នាព្រះហស្តរបស់ព្រះជាម្ចាស់ និងចម្លើយរបស់មនុស្សលោកដែលព្រះគ្រីស្តនឹងផ្សំផ្គុំគ្នា។ ក្នុងអង្គព្រះគ្រីស្តទំនុកតម្កើងនៅតែបង្រៀនយើងឲ្យចេះអធិដ្ឋាន។

២៥៨៨-ពិធីបុណ្យព្រះវិហារ និងចិត្តរបស់មនុស្សបង្ហាញថាមានទំនុកតម្កើងខុសប្លែកពីគ្នាជាច្រើនយ៉ាង គឺមានបទចម្រៀងលើកតម្កើងព្រះជាម្ចាស់ ពាក្យទូលអង្វរព្រះអង្គពេលរងទុក្ខលំបាក ពាក្យអរព្រះគុណព្រះអង្គ ពាក្យទូលអង្វររបស់មនុស្សម្នាក់ ឬរបស់សហគមន៍បទចម្រៀងរបស់ស្ដេច ឬបទចម្រៀងសម្រាប់ធ្វើបូជនីយសចរណ៍ ពាក្យរិះគិតពិចារណារបស់អ្នកប្រាជ្ញ។ ទំនុកតម្កើងទាំងអស់នោះដូចជាកញ្ចក់ដែលឆ្លុះភាពអស្ចារ្យរបស់ព្រះជាម្ចាស់ក្នុងប្រវត្តិសាស្ត្រនៃប្រជារាស្ត្ររបស់ព្រះអង្គ និងស្ថានភាពទាំងប៉ុន្មានដែលអ្នកនិពន្ធទំនុកតម្កើងបានឆ្លងកាត់។ ទោះបីទំនុកតម្កើងមួយអាចឆ្លុះបញ្ចាំងហេតុការណ៍ណាមួយអំពីអតីតកាលយ៉ាងណាក៏ដោយ ក៏មនុស្សគ្រប់សម័យកាលគ្រប់កាលៈទេសៈ អាចសូត្របទទំនុកតម្កើងនេះដោយសេចក្ដីពិតបានដែរ។

២៥៨៩-ទំនុកតម្កើងមានលក្ខណៈខ្លះដូចគ្នា គឺមនុស្សសូត្រទំនុកតម្កើងដោយមានចិត្តសាមញ្ញ និងដោយមិនបានគិតទុកជាមុន ព្រះបំណងប្រាថ្នារបស់ព្រះជាម្ចាស់ផ្ទាល់តាមរយៈ និងជាមួយអ្វីៗទាំងអស់ដ៏ល្អប្រសើរក្នុងការបង្កើតសត្វលោកទាំងឡាយរបស់ព្រះអង្គស្ថានភាពដ៏លំបាករបស់អ្នកជឿដែលខ្មាំងសត្រូវ និងការល្បួងជាច្រើនមកបៀតបៀនដោយសារសេចក្ដីស្រឡាញ់របស់គេចំពោះព្រះជាម្ចាស់ ហើយដែលរង់ចាំព្រះដ៏ស្មោះត្រង់ដោយជឿជាក់ថាព្រះអង្គស្រឡាញ់គេ និងដោយផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ។ ក្នុងបទទំនុកតម្កើងគេតែងតែសរសើរលើកតម្កើងព្រះជាម្ចាស់ ហេតុនេះហើយបានជាគេហៅកណ្ឌនោះយ៉ាងត្រឹមត្រូវថា៖ "ពាក្យសរសើរ"។ គេប្រើកណ្ឌនេះក្នុងពិធីបុណ្យរបស់អង្គប្រជុំដែលត្រាស់ហៅមនុស្សឲ្យអធិដ្ឋាន និងច្រៀងចម្លើយរបស់គេ៖ "Hallelou-Ya!" (អាលេលូយ៉ា) "ចូរសរសើរលើកតម្កើងព្រះអម្ចាស់!"។

អ្វីទៅដែលប្រសើរជាងទំនុកតម្កើង? ហេតុនេះហើយបានជាព្រះបាទដាវីឌមានព្រះបន្ទូលយ៉ាងត្រឹមត្រូវថា៖ "ចូរសរសើរព្រះអម្ចាស់ ដ្បិតទំនុកតម្កើងជាការល្អប្រសើរ៖ សូមឲ្យព្រះរបស់យើងទទួលពាក្យសរសើរយ៉ាងពិរោះ!"។ ត្រឹមត្រូវហើយ! ដ្បិតទំនុកតម្កើងជាពរជ័យរបស់ប្រជាជន ជាពាក្យសរសើររបស់អង្គប្រជុំចំពោះព្រះជាម្ចាស់ ជាការទះដៃរបស់មនុស្សទាំងអស់ ជាពាក្យសម្ដីរបស់សាកលលោកទាំងមូល ជាធម៌ប្រកាសជំនឿយ៉ាងពិរោះ... (សន្តៈ អំប្រ័រ)។

## សង្ខេប

២៥៩០-"ការអធិដ្ឋាន គឺជាការលើកព្រលឹងឡើងទៅឯព្រះជាម្ចាស់ ឬយើងអាចទូលសូមឲ្យព្រះអង្គប្រោសប្រទាននូវអ្វីសមរម្យ" (សន្តៈ យ៉ូហានដាម៉ាសែន)។

២៥៩១-ព្រះជាម្ចាស់ត្រាស់ហៅមនុស្សម្នាក់ៗឲ្យជួបព្រះអង្គយ៉ាងអាថ៌កំបាំងក្នុងការអធិដ្ឋាន។ ក្នុងប្រវត្តិសាស្ត្រទាំងអស់នៃការសង្គ្រោះ ហាក់ដូចជាព្រះជាម្ចាស់ និងមនុស្សត្រាស់ហៅគ្នាទៅវិញទៅមក។

២៥៩២-ការអធិដ្ឋានរបស់លោក អប្រាហាំ និងលោក យ៉ាកុប ដូចជាការប្រយុទ្ធនៃជំនឿក្នុងការជឿទុកចិត្តលើភក្ដីភាពរបស់ព្រះជាម្ចាស់ និងការដឹងច្បាស់ថា អ្នកមានចិត្តព្យាយាមនឹងយកជ័យជម្នះ។

២៥៩៣-ការអធិដ្ឋានរបស់លោក ម៉ូសេ ឆ្លើយតបនឹងព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ដើម្បីសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គ។ ការអធិដ្ឋាននេះតម្រង់ទុកជាមុននឹងការជួយអង្វររបស់ព្រះគ្រីស្តយេស៊ូ ដែលជាស្ពានមេត្រីតែមួយ។

២៥៩៤-ការអធិដ្ឋាននៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់រីកចម្រើនក្រោមម្លប់នៃព្រះដំណាក់របស់ព្រះជាម្ចាស់ ជាហិបនៃសម្ពន្ធមេត្រី និងជាព្រះវិហារ ក្រោមការដឹកនាំនៃពួកគង្វាល ជាពិសេសព្រះបាទដាវីឌ និងពួកព្យាការីផងដែរ។

២៥៩៥-ពួកព្យាការីដាស់តឿនឲ្យកែប្រែចិត្តគំនិត ហើយជួយអង្វរព្រះជាម្ចាស់ ដើម្បីប្រជារាស្ត្រ ព្រមទាំងស្វះស្វែងរកខ្នះខ្នែងព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់។

២៥៩៦-ទំនុកតម្កើងជាស្នាដៃនៃការអធិដ្ឋានក្នុងសម្ពន្ធមេត្រីចាស់ ហើយមានលក្ខណពីរដែលមិនអាចបែកពីគ្នាបានឡើយ គឺជាការអធិដ្ឋានរបស់បុគ្គលម្នាក់ៗ និងរបស់សហគមន៍ផង។ ទំនុកតម្កើងលាតសន្ធឹងដល់ប្រវត្តិសាស្ត្រទាំងមូល ដោយរំឭកឡើងវិញនូវព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ដែលបានកើតជារូបរាងរួចទៅហើយ ហើយដោយសង្ឃឹមថា ព្រះមេស្ស៊ីនឹងយាងត្រឡប់មកវិញ។

២៥៩៧-ទំនុកតម្កើងជាផ្នែកដ៏សំខាន់ និងជាអចិន្ត្រៃយ៍នៃការអធិដ្ឋានរបស់ព្រះសហគមន៍។ ត្រូវតែស្មូតទំនុកតម្កើងនៅក្នុងអង្គព្រះគ្រីស្ត ដែលជាអ្នកបំពេញទំនុកតម្កើងនោះ។ ទំនុកតម្កើងសមស្របតាមមនុស្សគ្រប់រូបនៅគ្រប់ជំនាន់។

## ប្រការទី២៖

## នៅពេលកំណត់ដ៏ពេញលក្ខណៈ

២៥៩៨-ព្រះបន្ទូលដែលប្រសូតជាមនុស្ស និងដែលគង់នៅក្នុងចំណោមយើងសម្តែងនូវការអធិដ្ឋានឲ្យបានពេញលក្ខណៈ។ ពេលយើងស្វែងយល់របៀបអធិដ្ឋានរបស់ព្រះអង្គតាមរយៈសេចក្ដីដែលសាក្សីរបស់ព្រះអង្គប្រកាសក្នុងដំណឹងល្អ គឺយើងចូលជិតព្រះអម្ចាស់ដ៏វិសុទ្ធយេស៊ូ ដូចចូលជិតគុម្ពោតដែលដុតតែមិនឆេះដែរ ពោលគឺត្រូវនឹកសញ្ជឹងគិតអំពីព្រះអង្គផ្ទាល់ ពេលទ្រង់អធិដ្ឋានហើយស្ដាប់ព្រះអង្គបង្រៀនឲ្យចេះអធិដ្ឋាន ដើម្បីដឹងថាតើព្រះអង្គទទួលពាក្យទូលអង្វររបស់យើងយ៉ាងដូចម្ដេច។

## ព្រះយេស៊ូអធិដ្ឋាន

២៥៩៩-ព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលជាបុត្រនៃព្រហ្មចារិនីបានរៀនអធិដ្ឋានក្នុងឋានៈជាមនុស្ស។ ព្រះអង្គបានរៀនអធិដ្ឋានពីព្រះមាតារបស់ព្រះអង្គ ដែលចងចាំហេតុការណ៍ដ៏អស្ចារ្យរបស់ព្រះដ៏មានឫទ្ធានុភាពសព្វប្រការព្រមទាំងត្រិះរិះពិចារណាថែមទៀត (លក ១,៤៩; ២,១៩; ២,៥១)។ ព្រះអង្គរៀនអធិដ្ឋានតាមរបៀបរបស់ប្រជារាស្ត្រព្រះអង្គនៅធម្មសាលានៃភូមិណាសារ៉ែត និងនៅព្រះវិហារទីក្រុងយេរូសាឡឹម។ ប៉ុន្តែ ការអធិដ្ឋានរបស់ព្រះអង្គផុសចេញពីប្រភពដ៏ស្ងាត់កំបាំងដូចព្រះអង្គមានព្រះបន្ទូល នៅពេលដែលទ្រង់មានព្រះជន្មដប់ពីរវស្សាថា៖ "កូនត្រូវនៅក្នុងដំណាក់ព្រះបិតារបស់កូន" (លក ២,៤៩)។ ពេលនោះព្រះជាម្ចាស់ចាប់ផ្តើមសម្តែងនូវការអធិដ្ឋានឲ្យបានពេញលក្ខណៈ គឺការអធិដ្ឋានរបស់បុត្រធីតាដែលព្រះបិតារង់ចាំពីបុត្រធីតារបស់ព្រះអង្គ ហើយដែលព្រះបុត្រាតែមួយផ្ទាល់នឹងអនុវត្តក្នុងឋានៈជាមនុស្សរួមជាមួយមនុស្សលោក និងដើម្បីពួកគេទៀតផង។

២៦០០-គម្ពីរដំណឹងល្អតាមសន្តៈ លូកា បញ្ជាក់នូវកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ និងអត្ថន័យនៃការអធិដ្ឋានរបស់ព្រះគ្រីស្តនៅលើផែនដីនេះ។ ព្រះយេស៊ូអធិដ្ឋានមុនពេលដ៏សំខាន់នៃបេសកកម្មរបស់ព្រះអង្គ គឺមុនព្រះបិតាផ្តល់សក្ខីភាពអំពីព្រះអង្គពេលព្រះអង្គជ្រមុជទឹក (លក ៣,២១) និងពេលដែលព្រះអង្គប្រែទ្រង់ទ្រាយ (លក ៩,២៨) ហើយព្រះយេស៊ូអធិដ្ឋានមុននឹងបំពេញគម្រោងការដ៏សប្បុរសរបស់ព្រះបិតាដោយរងទុក្ខលំបាក (លក ២២,៤១-៤៤)។ ព្រះយេស៊ូអធិដ្ឋានមុនពេលដ៏សំខាន់នៃបេសកកម្មរបស់ក្រុមគ្រីស្តទូត គឺមុនពេលជ្រើសរើសគ្រីស្តទូតដប់ពីររូប និងតែងតាំងពួកលោក (លក ៦,១២) មុនពេលលោកសិលាប្រកាសថាព្រះអង្គជា "ព្រះគ្រីស្តរបស់ព្រះជាម្ចាស់" (លក ៩,១៨-២០) ហើយព្រះអង្គអធិដ្ឋាន ដើម្បីកុំឲ្យប្រធានក្រុមគ្រីស្តទូតចាញ់ការល្បួង (លក ២២,៣២)។ ដោយសារព្រះយេស៊ូអធិដ្ឋានមុនហេតុការណ៍ទាំងប៉ុន្មានដែលព្រះបិតាសូមឲ្យព្រះអង្គបំពេញដើម្បីសង្គ្រោះមនុស្សលោកក្នុងឋានៈជាមនុស្ស ព្រះអង្គក៏ថ្វាយខ្លួនទាំងស្រុងដោយចិត្តសុភាពរាបសាចំពោះព្រះហឫទ័យដ៏សប្បុរសរបស់ព្រះបិតា។

២៦០១-"មានមួយថ្ងៃព្រះយេស៊ូអធិដ្ឋាននៅកន្លែងមួយ។ កាលព្រះអង្គអធិដ្ឋានរួចហើយមានសាវ័កម្នាក់ទូលព្រះអង្គថា៖ "បពិត្រព្រះអម្ចាស់សូមបង្រៀនយើងខ្ញុំឲ្យចេះអធិដ្ឋានផង" (លក ១១,១)។ មុនដំបូងសាវ័កប្រាថ្នាចង់អធិដ្ឋាន ដោយសារគេនឹកគិតដល់ម្ចាស់របស់ខ្លួនអធិដ្ឋាន។ ពេលនោះគេអាចរៀនអធិដ្ឋានពីម្ចាស់នៃការអធិដ្ឋាន។ ពេលគេនឹកសញ្ជឹងគិតដល់ព្រះបុត្រា និងស្តាប់ព្រះបន្ទូលព្រះអង្គបុត្រធីតារៀនទូលអង្វរព្រះបិតា។

២៦០២-ជារឿយៗព្រះយេស៊ូគង់នៅដាច់ឡែកពីគេតែម្នាក់ឯង ឡើងលើភ្នំដើម្បីអធិដ្ឋានពេលយប់ (មក ១,៣៥; ៦,៤៦; លក ៥,១៦)។ ដោយសារព្រះអង្គប្រសូតជាមនុស្ស ទ្រង់ក៏ទទួលយកមនុស្សលោកទាំងអស់ក្នុងការអធិដ្ឋានរបស់ព្រះអង្គ ហើយថ្វាយពួកគេចំពោះព្រះបិតាដោយថ្វាយព្រះកាយព្រះអង្គ។ ដោយសារព្រះអង្គជាព្រះបន្ទូលកើតជាមនុស្ស ព្រះអង្គអធិដ្ឋានក្នុងឋានៈជាមនុស្ស និងរួមសុខរួមទុក្ខជាមួយនឹង "បងប្អូន" របស់ព្រះអង្គ (ហប ២.១២)។ ព្រះអង្គទទួលយកភាពទន់ខ្សោយរបស់មនុស្ស ដើម្បីរំដោះគេឲ្យរួចពីភាពទន់ខ្សោយនោះ (ហប ២,១៥; ៤,១៥)។ ហេតុនេះហើយបានជាព្រះបិតាបានចាត់ព្រះអង្គឲ្យយាងមក។ ដូច្នេះព្រះបន្ទូល និងកិច្ចការរបស់ព្រះអង្គសម្តែងយ៉ាងច្បាស់នូវការអធិដ្ឋាន "ជាសម្ងាត់" របស់ព្រះអង្គ។

២៦០៣-អ្នកនិពន្ធគម្ពីរដំណឹងល្អបានរក្សាទុកពាក្យអង្វរពីរយ៉ាងរបស់ព្រះគ្រីស្ត។ ពាក្យអង្វរទាំងពីរនោះចាប់ផ្តើមដោយការអរព្រះគុណព្រះជាម្ចាស់។ ក្នុងពាក្យអង្វរទីមួយ (មថ ១១,២៥-២៧ និង លក ១០,២១-២២) ព្រះយេស៊ូប្រកាសជំនឿលើព្រះបិតាទទួលស្គាល់ និងប្រទានព្រះពរដល់ព្រះអង្គ ដ្បិតព្រះអង្គបានលាក់គម្រោងការ

ដ៏អស្ចារ្យនៃព្រះរាជ្យកុំឲ្យអ្នកដែលស្មានថាខ្លួនជាអ្នកប្រាជ្ញ និងចេះដឹងស្គាល់គម្រោងការនេះ ប៉ុន្តែទ្រង់បានសម្តែងគម្រោងការនេះឲ្យ "អ្នកតូចតាច" (អស់អ្នកដែលគ្មានទីពឹង) ស្គាល់។ ព្រះយេស៊ូវំជួលព្រះហឫទ័យ "ឱព្រះបិតាអើយ!" គឺព្រះអង្គសម្តែងនូវទីជម្រៅព្រះហឫទ័យរបស់ព្រះអង្គដែលជាប់នឹងព្រះហឫទ័យរបស់ព្រះបិតា ដូចពេលព្រះមាតាបានសម្រេចធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ នៅពេលព្រះអង្គចាប់ផ្ទៃព្រះនាង ហើយព្រះអង្គក៏សម្តែងទុកជាមុននូវព្រះបន្ទូលរបស់ព្រះអង្គ ចំពោះព្រះបិតាពេលទ្រង់នឹងរងទុក្ខលំបាក។ ព្រះយេស៊ូអធិដ្ឋានបានសេចក្តីថាក្នុងឋានៈជាមនុស្សព្រះអង្គភ្ជាប់នឹង "គម្រោងការដ៏លាក់កំបាំង" នៃព្រះហឫទ័យរបស់ព្រះបិតា (អភ ១,៩)។

២៦០៤-សន្ទៈ យ៉ូហាន ជាអ្នកថ្លែងនូវពាក្យអង្វរទីពីររបស់ព្រះអង្គ គឺមុនពេលលោកឡាសាររស់ឡើងវិញ (យហ ១១,៤១-៤២)។ នៅទីនោះដែរព្រះយេស៊ូអរព្រះគុណព្រះជាម្ចាស់មុនប្រោសលោកឲ្យរស់ឡើងវិញ៖ "បពិត្រព្រះបិតាទូលបង្គំសូមអរព្រះគុណព្រះអង្គដែលទ្រង់ព្រះសណ្តាប់ទូលបង្គំ" បានសេចក្តីថាព្រះបិតាតែងតែសណ្តាប់សំណូមពររបស់ព្រះអង្គ។ ព្រះយេស៊ូបន្ថែមទៀតថា៖ "ទូលបង្គំដឹងថាព្រះអង្គទ្រង់ព្រះសណ្តាប់ទូលបង្គំជានិច្ច" បានសេចក្តីថាចំពោះព្រះយេស៊ូវិញ ទ្រង់ក៏តែងតែសុំជានិច្ច។ ហេតុនេះដោយសារព្រះយេស៊ូអរព្រះគុណព្រះបិតា ព្រះអង្គក៏សម្តែងឲ្យយើងដឹងថា តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីសុំ គឺមុនព្រះជាម្ចាស់ប្រទានព្រះអំណោយទាន ព្រះយេស៊ូភ្ជាប់ចិត្តនឹងអ្នកដែលប្រទានព្រះអំណោយទាននោះ ជាអ្នកដែលប្រទានខ្លួនផ្ទាល់។ អ្នកប្រទានព្រះអំណោយទានមានតម្លៃជាងអំណោយ ព្រះអង្គក៏ជា "កំណប់" ហើយព្រះបុត្រាព្រះអង្គភ្ជាប់ចិត្តនឹងព្រះអង្គ។ ព្រះជាម្ចាស់ប្រទានព្រះអំណោយទាននោះ "ថែមទៀត" (មថ ៦,២១.៣៣)។

ពាក្យអង្វររបស់ព្រះយេស៊ូក្នុងឋានៈជាបូជាចារ្យ ជាសេចក្តីអធិដ្ឋានយ៉ាងពិសេសក្នុងការចាត់ចែងគម្រោងការនៃការសង្គ្រោះ។ យើងនឹងវិភាគសេចក្តីអធិដ្ឋាននេះក្នុងទីចុងក្រោយនៃភាគទីមួយ។ សេចក្តីអធិដ្ឋាននេះបង្ហាញនូវពាក្យអង្វរនៃមហាបូជាចារ្យរបស់យើងបច្ចុប្បន្នកាលនេះ ហើយជាមួយគ្នានេះដែរ ក្នុងនោះមានអ្វីៗដែលព្រះអង្គបង្រៀនឲ្យយើងស្គាល់អំពីធម៌ឱព្រះបិតាដែលយើងនឹងវិភាគក្នុងភាគទីពីរ។

២៦០៥-ពេលកំណត់មកដល់ គឺជាពេលដែលព្រះយេស៊ូបំពេញគម្រោការដ៏សប្បុរសនៃព្រះបិតាព្រះអង្គនាំយើងឲ្យយល់ពីទីជម្រៅមិនអាចស្ទង់បាននៃការអធិដ្ឋានរបស់ព្រះអង្គក្នុងឋានៈជាព្រះបុត្រា មិនគ្រាន់តែមុនពេលព្រះអង្គថ្វាយព្រះកាយព្រះអង្គទាំងស្រុងដោយស្ម័គ្រចិត្ត ("ឱព្រះបិតាអើយ! សូមកុំឲ្យសម្រេចតាមចិត្តទូលបង្គំឡើយ គឺឲ្យសម្រេចតាមព្រះហឫទ័យព្រះអង្គវិញ" លក ២២,៤២) ថែមទាំងរហូតដល់ព្រះបន្ទូលចុងក្រោយរបស់ព្រះអង្គនៅលើឈើឆ្កាងទៀតផងដែរ។ នៅទីនោះព្រះអង្គថ្វាយខ្លួនទាំងស្រុងបានសេចក្តីថា ទ្រង់អធិដ្ឋានតែម្តង ("ឱព្រះបិតាអើយ! សូមព្រះអង្គអត់ទោសឲ្យអ្នកទាំងនោះផង ដ្បិតគេមិនដឹងថាគេកំពុងធ្វើអ្វីឡើយ" លក ២៣,៣៤)។ "ខ្ញុំសូមប្រាប់ឲ្យអ្នកដឹងយ៉ាងច្បាស់ថាថ្ងៃនេះ អ្នកនឹងបានទៅនៅស្ថានបរមសុខជាមួយខ្ញុំ" (លក ២៣,៤៣) "អ្នកអើយ! នេះកូនរបស់អ្នក (...) នេះហើយម្តាយរបស់អ្នក" (យហ ១៩,២៦-២៧) "ខ្ញុំស្រេចទឹក" (យហ ១៩,២៨) "ឱព្រះនៃទូលបង្គំអើយ! ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ?" (មក ១៥,៣៤) (ទន ២២,២) "ខ្ញុំបានសម្រេចសព្វគ្រប់អស់ហើយ!" (យហ ១៩,៣០) "ព្រះបិតា! ទូលបង្គំសូមប្រគល់វិញ្ញាណរបស់ទូលបង្គំទៅក្នុងព្រះហស្តព្រះអង្គវិញ" (លក ២៣,៤៦) រហូតដល់ព្រះអង្គ "បន្លឺព្រះសូរសៀងយ៉ាងខ្លាំង" ហើយប្រគល់វិញ្ញាណទៅព្រះបិតាវិញ (មក ១៥,៣៧; យហ ១៩,៣០ខ)។

២៦០៦-ព្រះសូរសៀងយ៉ាងខ្លាំងរបស់ព្រះបន្ទូលកើតជាមនុស្ស នេះសរុបនូវទុក្ខលំបាកទាំងអស់របស់មនុស្ស

លោកគ្រប់សម័យកាលដែលជាទាសករនៃអំពើបាប និងសេចក្តីស្លាប់ ហើយសរុបសំណូមពរ និងពាក្យជួយអង្វរទាំងអស់ក្នុងប្រវត្តិសាស្ត្រនៃការសង្គ្រោះ។ ព្រះបិតាទទួលយកពាក្យអង្វរទាំងអស់នោះហើយ ព្រះអង្គក៏ធ្វើឲ្យសំណូមពរនោះបានសម្រេចលើសពីសេចក្តីសង្ឃឹមទៅទៀត ដោយប្រោសព្រះបុត្រាព្រះអង្គឲ្យមានព្រះជន្មថ្មី។ ហេតុនេះហើយបានជាព្រះជាម្ចាស់សម្រេចវិនាដកម្មនៃការអធិដ្ឋានក្នុងការចាត់ចែងគម្រោងការអំពីការបង្កើត និងការសង្គ្រោះ។ កំណ្ឌទំនុកតម្កើងផ្តល់កូនសោនៃវិនាដកម្មនេះ ក្នុងអង្គព្រះគ្រីស្ត។ ក្នុងថ្ងៃនេះជាថ្ងៃដែលព្រះយេស៊ូរស់ឡើងវិញ ព្រះបិតាមានព្រះបន្ទូលថា៖ "អ្នកជាបុត្ររបស់យើង! គឺយើងដែលបានបង្កើតអ្នកនៅថ្ងៃនេះ។ បើអ្នកសុំយើងនឹងប្រគល់ប្រជាជាតិនានាឲ្យអ្នកទុកជាមរតក ហើយយើងនឹងប្រគល់ផែនដីទាំងមូលឲ្យអ្នកទុកជាកម្មសិទ្ធិដែរ" (ទន ២,៧-៨) (កក ១៣,៣៣)។

ដោយប្រើពាក្យគួរឲ្យរំភើបលិខិតផ្ញើទៅគ្រីស្តបរិស័ទជាតិហេប្រឺបង្ហាញថា សេចក្តីអធិដ្ឋានរបស់ព្រះយេស៊ូបានសង្គ្រោះមនុស្សលោកដោយជោគជ័យ៖ "កាលព្រះគ្រីស្តរស់នៅក្នុងលោកនេះនៅឡើយ ព្រះអង្គបានបន្លឺសម្លេងយ៉ាងខ្លាំង និងបង្ហូរទឹកភ្នែកទូលអង្វរសូមព្រះជាម្ចាស់ដែលអាចសង្គ្រោះព្រះអង្គឲ្យរួចពីស្លាប់។ ដោយព្រះគ្រីស្តបានគោរពប្រណិប័តន៍ព្រះជាម្ចាស់ នោះព្រះជាម្ចាស់ក៏ប្រោសប្រទានតាមពាក្យទូលអង្វរ។ ថ្វីដ្បិតតែព្រះអង្គជាព្រះបុត្រាក៏ដោយ ព្រះអង្គក៏បានរៀនស្តាប់បង្គាប់ដោយរងទុក្ខលំបាក។ បន្ទាប់ពីព្រះអង្គបានគ្រប់លក្ខណៈហើយទ្រង់ក៏បានទៅជាប្រភពនៃការសង្គ្រោះដ៏ស្ថិតស្ថេរអស់កល្បជានិច្ច សម្រាប់អស់អ្នកដែលស្តាប់បង្គាប់ព្រះអង្គ" (ហប ៥,៧-៩)។

## ព្រះយេស៊ូបង្រៀនឲ្យចេះអធិដ្ឋាន

២៦០៧-ពេលព្រះយេស៊ូអធិដ្ឋាន ព្រះអង្គក៏បង្រៀនយើងឲ្យចេះអធិដ្ឋានដែរ។ ការអធិដ្ឋានរបស់ព្រះអង្គចំពោះព្រះបិតារបស់ព្រះអង្គនាំយើងឲ្យមានទំនាក់ទំនងជាមួយនឹងព្រះបិតាដែរ។ ប៉ុន្តែ ដំណឹងល្អផ្តល់ដំបូន្មានមួយយ៉ាងច្បាស់របស់ព្រះយេស៊ូអំពីការអធិដ្ឋាន។ បន្តិចម្តងៗ ព្រះអង្គណែនាំយើងឆ្ពោះទៅកាន់ព្រះបិតា។ ពេលព្រះអង្គមានព្រះបន្ទូលទៅកាន់បណ្តាជនដែលដើរតាមព្រះអង្គ ទ្រង់ចាប់ផ្តើមមានព្រះបន្ទូលអំពីការអធិដ្ឋានតាមសម្ព័ន្ធមេត្រីចាស់ ដែលគេស្គាល់រួចហើយ ព្រះអង្គមានព្រះបន្ទូលអំពីព្រះរាជ្យដែលកំពុងយាងមក និងដែលធ្វើឲ្យអ្វីៗទាំងអស់កើតមានសាជាថ្មី។ បន្ទាប់មកព្រះអង្គមានព្រះបន្ទូលជាពាក្យប្រស្នាអំពីភាពថ្មោងថ្មីនៃព្រះរាជ្យនោះ។ ទីបំផុតព្រះអង្គមានព្រះបន្ទូលអំពីព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធដោយមិនលាក់លៀមអ្វីសោះឲ្យក្រុមសាវ័កដែលនឹងត្រូវបង្រៀនអ្នកដទៃក្នុងព្រះសហគមន៍។

២៦០៨-លុះព្រះអង្គបង្រៀនគេនៅលើភ្នំ ព្រះយេស៊ូមានព្រះបន្ទូលសង្កត់ធ្ងន់ថាត្រូវតែកែប្រែចិត្តគំនិត គឺត្រូវសម្រុះសម្រួលជាមួយបងប្អូនមុននឹងថ្វាយតង្វាយលើអាសនៈ (មថ ៥,២៣-២៤) ស្រឡាញ់ខ្មាំងសត្រូវ និងទូលអង្វរព្រះជាម្ចាស់សម្រាប់អស់អ្នកដែលបៀតបៀនយើង (មថ ៥,៤៤-៤៥) ទូលទៅកាន់ព្រះបិតា "ក្នុងទីស្ងាត់កំបាំង" (មថ ៦,៦) មិនពោលពាក្យច្រំដែលៗឥតប្រយោជន៍ (មថ ៦,៧) អត់ទោសឲ្យអ្នកដទៃយ៉ាងពិតប្រាកដ (មថ ៦,១៤-១៥) ហើយត្រូវមានចិត្តបរិសុទ្ធ និងស្វែងរកព្រះរាជ្យរបស់ព្រះអង្គ (មថ ៦,២១.២៥.៣៣)។ ត្រូវកែប្រែចិត្តគំនិតដោយសារតែព្រះបិតា ព្រោះយើងជាបុត្រធីតារបស់ព្រះអង្គ។

២៦០៩-ពេលយើងប្តេជ្ញាកែប្រែចិត្តគំនិតយើងរៀនអធិដ្ឋានក្នុងជំនឿ។ ពេលយើងជឿ យើងជាប់ចិត្តនឹងព្រះជាម្ចាស់ដូចបុត្រធីតារបស់ព្រះអង្គលើសពីអ្វីដែលយើងអាចយល់ឃើញបាន។ យើងអាចមានជំនឿបាន ដ្បិតព្រះបុត្រាជាទីស្រឡាញ់បើកផ្លូវឲ្យយើងឆ្ពោះទៅព្រះបិតា។ ព្រះអង្គអាចសុំយើងឲ្យ "ស្វែងរក" និង "គោះទ្វារ" ដ្បិត

ព្រះអង្គផ្ទាល់ជាទ្វារ និងជាផ្លូវ (មថ ៧,៧-១១.១៣-១៤)។

២៦១០-ព្រះយេស៊ូទូលអង្វរព្រះបិតា និងអរព្រះគុណព្រះអង្គមុននឹងទទួលព្រះអំណោយទានរបស់ព្រះអង្គ យ៉ាងណាព្រះអង្គក៏បង្រៀនយើងឲ្យមានចិត្តក្លាហានដូចបុត្រធីតាយ៉ាងពិតប្រាកដរបស់ព្រះអង្គយ៉ាងនោះដែរ៖ "អ្វីក៏ដោយឲ្យតែអ្នកអធិដ្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ" (មក ១១,២៤)។ នេះជាកម្លាំងនៃការអធិដ្ឋាន "ព្រះជាម្ចាស់អាចសម្រេចកិច្ចការសព្វគ្រប់ទាំងអស់ដល់អ្នកជឿ" (មក ៩,២៣) ដែលមិនស្ទាក់ស្ទើរ (មថ ២១,២២)។ ព្រះយេស៊ូព្រួយព្រះហឫទ័យដោយឃើញថាបងប្អូនរបស់ព្រះអង្គ "គ្មានជំនឿបែបនេះ" (មក ៦,៦) និងសាវ័ករបស់ព្រះអង្គមាន "ជំនឿតិច" (មថ ៨,២៦) តែព្រះអង្គសរសើរនាយទាហានរ៉ូម៉ាំង (មថ ៨,១០) និងស្ត្រីសាសន៍កាណានម្នាក់ (មថ ១៥,២៨) ដែលមាន "ជំនឿមាំមួនណាស់"។

២៦១១-ពេលអធិដ្ឋានដោយមានជំនឿពិតប្រាកដមិនគ្រាន់តែពោលថា "ព្រះអម្ចាស់ៗអើយ" ប៉ុណ្ណោះទេ គឺត្រូវសម្រេចចិត្តប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះបិតា (មថ ៧,២១)។ ព្រះយេស៊ូត្រាស់ហៅពួកសាវ័កឲ្យអធិដ្ឋានដើម្បីរួមសហការក្នុងគម្រោងការរបស់ព្រះជាម្ចាស់ (មថ ៩,៣៨; លក ១០,២; យហ ៤,៣៤)។

២៦១២-ក្នុងអង្គព្រះយេស៊ូ "ព្រះរាជ្យព្រះជាម្ចាស់យាងមកជិតបង្កើយហើយ" ព្រះអង្គត្រាស់ហៅ ឲ្យកែប្រែចិត្តគំនិត និងឲ្យប្រុងស្មារតីផងដែរ។ ពេលអធិដ្ឋានសាវ័កប្រុងប្រៀបនឹងទទួលព្រះដ៏មានព្រះជន្មគង់នៅ ដោយនឹកទៅដល់ពេលព្រះអង្គយាងមកបន្ទាបខ្លួនជាមនុស្សព្រមទាំងសង្ឃឹមថា ព្រះអង្គនឹងយាងមកវិញពោរពេញដោយសិរីរុងរឿង (មក ១៣; លក ២១,៣៤-៣៦)។ ដោយរួមរស់ជាមួយម្ចាស់របស់ខ្លួន ក្រុមសាវ័ប្រយុទ្ធប្រឆាំងក្នុងការអធិដ្ឋានប្រុងប្រយ័ត្នកុំឲ្យចាញ់ការល្បួងឡើយ (លក ២២,៤០.៤៦)។

២៦១៣-សន្ត: លូកា បញ្ជូនពាក្យប្រស្នាសំខាន់ៗអំពីការអធិដ្ឋាន៖

ប្រាស្នាទីមួយស្តីអំពី "មិត្តសម្លាញ់ម្នាក់" (លក ១១,៥-១៣) ព្រះយេស៊ូអញ្ជើញយើងឲ្យទទូចសុំដោយមានចិត្តព្យាយាម៖ "ចូរគោះទ្វារ (...) នោះព្រះជាម្ចាស់នឹងបើកទ្វារឲ្យអ្នករាល់គ្នា"។ ចំពោះអ្នកដែលអធិដ្ឋានបែបនេះ ព្រះបិតាដែលគង់នៅស្ថានបរមសុខ "នឹងប្រទានអ្វីៗដែលអ្នកនោះត្រូវការ" ជាពិសេសព្រះវិញ្ញាណដ៏វិសុទ្ធដែលសរុបព្រះអំណោយទានទាំងអស់។

ប្រាស្នាទីពីរស្តីអំពី "ស្ត្រីមេម៉ាយម្នាក់" (លក ១៨,១-៨) ត្រូវតែអធិដ្ឋានជានិច្ចដោយមិនរសាយចិត្ត ដោយមានចិត្តអត់ធ្មត់ និងដោយមានជំនឿ។ "ប៉ុន្តែ ពេលបុត្រមនុស្សមកដល់ តើលោកឃើញមនុស្សមានជំនឿនៅលើផែនដីនេះឬទេ?"។

ក្នុងប្រស្នាទីបីអំពី "បុរសម្នាក់ខាងគណៈផារីស៊ី និងអ្នកទារពន្ធ" (លក ១៨,៩-១៤) ត្រូវតែបន្ទាបខ្លួនពេលអធិដ្ឋាន។ "ឱព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាទូលបង្គំជាអ្នកបាបផង"។ ព្រះសហគមន៍នៅតែអធិដ្ឋានដោយពាក្យដដែលនោះ៖ "Kyrie Eleison!"។

២៦១៤-ពេលព្រះយេស៊ូមានព្រះបន្ទូលយ៉ាងច្បាស់ ឲ្យក្រុមសាវ័កដឹងអំពីគម្រោងការដ៏លាក់កំបាំងនៃការអធិដ្ឋានចំពោះព្រះបិតា ព្រះអង្គសម្តែងឲ្យពួកគេនឹងយល់ថាត្រូវអធិដ្ឋានយ៉ាងដូចម្តេចនៅពេលព្រះអង្គពោរពេញដោយសិរីរុងរឿងនឹងយាងត្រឡប់ទៅឯព្រះបិតាវិញ។ ឥឡូវនេះអ្វីដែលថ្មីគឺ "ទូលសុំក្នុងព្រះនាមព្រះអង្គ" (យហ ១៤,១៣)។ បើយើងផ្ញើជីវិតទៅលើព្រះអង្គ យើងក៏នឹងស្គាល់ព្រះបិតា ដ្បិតព្រះយេស៊ូ "ជាផ្លូវ ជាសេចក្តីពិត និងជាជីវិត" (យហ ១៤,៦)។ ពេលយើងជឿ គឺយើងនឹងបង្កើតផលក្នុងសេចក្តីស្រឡាញ់ ពោលគឺរក្សាទុកព្រះបន្ទូល

និងវិន័យរបស់ព្រះអង្គស្ថិតនៅជាមួយព្រះអង្គក្នុងអង្គព្រះបិតាដែលស្រឡាញ់យើង នៅក្នុងអង្គព្រះគ្រីស្តរហូតដល់ព្រះអង្គស្ថិតនៅក្នុងយើង។ ក្នុងសម្ព័ន្ធមេត្រីថ្មីនេះយើងជឿជាក់ថាព្រះជាម្ចាស់នឹងប្រោសប្រទានតាមពាក្យសុំរបស់យើង ដ្បិតយើងទូលអង្វរព្រះអង្គដោយពឹងផ្អែកទៅលើការអធិដ្ឋានរបស់ព្រះយេស៊ូ (យហ ១៤,១៣-១៤។

២៦១៥-លើសពីនេះទៅទៀត អ្វីដែលព្រះបិតាប្រទានមកយើងនៅពេលដែលយើងអធិដ្ឋានរួមនឹងព្រះយេស៊ូ គឺ "ព្រះដ៏ជួយការពារ (...) ឲ្យទ្រង់គង់នៅជាមួយអ្នករាល់គ្នាជាដរាបតរៀងទៅ (...) ជាព្រះវិញ្ញាណនៃសេចក្តីពិត" (យហ ១៤,១៦-១៧)។ ព្រះយេស៊ូមានព្រះបន្ទូលអំពីរបៀបអធិដ្ឋានថ្មីនោះ ពេលពិធីជប់លៀងចុងក្រោយ (យហ ១៤,២៣-២៦; ១៥,៧.១៦; ១៦,១៣-១៥; ១៦,២៣-២៧)។ ក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ គ្រីស្តបរិស័ទអធិដ្ឋានរួមជាមួយព្រះបិតាដោយក្តីស្រឡាញ់ មិនគ្រាន់តែតាមរយៈព្រះគ្រីស្តប៉ុណ្ណោះទេ ថែមទាំងនៅក្នុងអង្គព្រះគ្រីស្តផងដែរ៖ "មកទល់ពេលនេះអ្នករាល់គ្នាពុំទាន់បានទូលសូមអ្វីក្នុងនាមខ្ញុំទេ ចូរទូលសូមទៅអ្នករាល់គ្នានឹងបានទទួលហើយអ្នករាល់គ្នានឹងមានអំណរពេញលក្ខណៈ" (យហ ១៦,២៤)។

## ព្រះយេស៊ូទទួលពាក្យអង្វររបស់យើង

២៦១៦-ពេលព្រះយេស៊ូគង់នៅលើផែនដីនេះ ព្រះអង្គទទួលពាក្យអង្វរតាមរយៈសញ្ញាសម្គាល់ ដែលសម្តែងទុកជាមុននូវឫទ្ធានុភាពរបស់ព្រះអង្គ ដែលសោយទិវង្គត និងមានព្រះជន្មថ្មី។ ព្រះយេស៊ូទទួលពាក្យអង្វរពីអ្នកជឿ ទោះបីគេប្រើពាក្យសម្តីក្តី (មនុស្សឃ្លង់ (មក ១,៤០-៤១) លោកយ៉ៃរ៉ូស (មក ៥,៣៦) ស្ត្រីសាសន៍កាណាន (មក ៧,២៩) អ្នកទោសដែលត្រូវគេឆ្កាង (លក ២៣,៣៩-៤៣)) ឬគេនៅស្ងៀមក្តី (បុរសបួននាក់ដែលសែងមនុស្សខ្វិន (មក ២,៥) ស្ត្រីមានជំងឺធ្លាក់ឈាម ដែលពាល់ព្រះពស្ត្ររបស់ព្រះអង្គ (មក ៥,២៨) ទឹកភ្នែក និងទឹកអប់របស់ស្ត្រីមានបាប (លក ៧,៣៧-៣៨))។ ប្រពៃណីនៃការអធិដ្ឋានចំពោះព្រះយេស៊ូ ("ព្រះរាជវង្សព្រះបាទដាវីឌអើយ! ឱព្រះយេស៊ូអើយ! សូមអាណិតមេត្តាទូលបង្គំផង!") បានយកពាក្យសុំរបស់មនុស្សខ្វាក់ឡើងវិញ៖ "ព្រះរាជវង្សព្រះបាទដាវីឌអើយ! សូមអាណិតមេត្តាយើងខ្ញុំផង!" (មថ ៩,២៧) ឬ "ឱព្រះរាជវង្សព្រះបាទដាវីឌអើយ! សូមអាណិតមេត្តាទូលបង្គំផង" (មក ១០,៤៨)។ ទោះបីព្រះអង្គប្រោសអ្នកជំងឺឲ្យបានជាសះស្បើយក្តី ឬលើកលែងទោសឲ្យអ្នកបាបក្តី ក៏ព្រះយេស៊ូតែងតែទទួលពាក្យអង្វររបស់អស់អ្នកដែលអង្វរព្រះអង្គដោយមានជំនឿ៖ "សូមទៅឲ្យបានសុខសាន្ត ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ!"។

សន្តៈ អូគូស្តាំង សង្ខេបចំណុចទាំងបីនៃការអធិដ្ឋានរបស់ព្រះយេស៊ូបានយ៉ាងអស្ចារ្យ៖ "ព្រះអង្គអង្វរព្រះជាម្ចាស់សម្រាប់យើងក្នុងឋានៈជាបូជាចារ្យ ទ្រង់អង្វរសម្រាប់យើងក្នុងឋានៈជាអ្នកដឹកនាំយើង យើងក៏អង្វរព្រះអង្គក្នុងឋានៈជាព្រះជាម្ចាស់របស់យើង។ សូមទទួលស្គាល់សម្លេងយើងក្នុងអង្គព្រះអង្គ និងសម្លេងរបស់ព្រះអង្គនៅក្នុងខ្លួនយើងផងដែរ" (IGLH ៧)។

## ការអធិដ្ឋានរបស់ព្រហ្មចារិនីម៉ារី

២៦១៧-ព្រះជាម្ចាស់សម្តែងនូវការអធិដ្ឋានរបស់នាងម៉ារីឲ្យយើងស្គាល់ នៅពេលចាប់ផ្តើមកំណត់ដ៏ពេញលក្ខណៈ។ មុនព្រះបុត្រាប្រសូតជាមនុស្ស និងមុនព្រះអង្គចាត់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ នាងម៉ារីអធិដ្ឋាន ដោយរួមសហការជាមួយនឹងគម្រោងការដ៏សប្បុរសនៃព្រះបិតា ពេលទេវទូតមកជូនដំណឹងថា ព្រះគ្រីស្តនឹងចាប់ផ្ទៃនាង (លក ១,៣៨) ពេលបុណ្យព្រះវិញ្ញាណយាងមក ដើម្បីបង្កើតព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត (កក ១,១៤)។ ដោយសារជំនឿ អ្នកបម្រើដ៏សុភាពរបស់ព្រះជាម្ចាស់ទទួលព្រះអំណោយទានរបស់ព្រះអង្គ ដែលព្រះអង្គ

ទ្រង់រង់ចាំតាំងពីពេលព្រះអង្គបានបង្កើតពិភពលោកមកម្ល៉េះ។ អ្នកដែលជា "ទីគាប់ព្រះហឫទ័យ" របស់ព្រះដ៏មានឫទ្ធានុភាពសព្វប្រការ ឆ្លើយតបនឹងព្រះអង្គ ដោយថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គ៖ "នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមឲ្យបានសម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គចុះ"។ "Fiat" ជាពាក្យអធិដ្ឋានរបស់គ្រីស្តបរិស័ទពោលគឺថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គ ដ្បិតទ្រង់ជាកម្មសិទ្ធិរបស់យើង។

២៦១៨-ដំណឹងល្អសម្តែងឲ្យយើងដឹងថា តើនាងម៉ារីអធិដ្ឋាន និងជួយអង្វរព្រះជាម្ចាស់ដោយមានជំនឿយ៉ាងដូចម្តេច។ នៅភូមិកាណា (យហ ២,១-១២) ព្រះមាតារបស់ព្រះយេស៊ូអង្វរព្រះបុត្រាព្រះនាងសម្រាប់តម្រូវការនៃពិធីមង្គលការ ជាទីសម្គាល់នៃពិធីមង្គលការផ្សេង គឺពិធីមង្គលការរបស់កូនចៀម ដែលបូជាព្រះកាយ និងព្រះលោហិតព្រះអង្គ តាមការទូលអង្វរព្រះសហគមន៍ ដែលជាព្រះមហេសីព្រះអង្គ។ នៅកាលកំណត់នៃសម្ព័ន្ធមេត្រីថ្មី នៅក្បែរឈើឆ្កាង (យហ ១៩,២៥-២៧) ព្រះយេស៊ូទទួលពាក្យអង្វររបស់នាងម៉ារី ជាស្រ្តី ជានាងអេវ៉ាថ្មីជា "មាតាយ៉ាងពិតប្រាកដរបស់អស់អ្នកដែលមានជីវិត"។

២៦១៩-ហេតុនេះហើយបានជាទំនុកតម្កើងរបស់ព្រះនាងម៉ារី (លក ១,៤៦-៥៥) (**Magnificat** ជាភាសាឡាតាំង ឬ **Mégalinaire** សម្រាប់ពិធីបុណ្យខាងបូព៌ាប្រទេស) ជាទំនុកតម្កើងនៃព្រះមាតារបស់ព្រះជាម្ចាស់ និងរបស់ព្រះសហគមន៍ផង ជាទំនុកតម្កើងរបស់បុត្រីនៃទីក្រុងស៊ីយ៉ូន និងរបស់ប្រជារាស្ត្រថ្មីនៃព្រះជាម្ចាស់ផង ដើម្បីអរព្រះគុណព្រះជាម្ចាស់ដែលប្រោសប្រទានព្រះអំណោយទានដ៏ច្រើនលើសលប់ ក្នុងការជួយសង្គ្រោះមនុស្សលោក ហើយជាទំនុកតម្កើងរបស់ "ជនក្រីក្រ" ដែលព្រះជាម្ចាស់បំពេញសេចក្តីសង្ឃឹម និងព្រះបន្ទូលសន្យាដែលព្រះអង្គបានប្រោសប្រទាន "ចំពោះលោក អប្រាហាំ និងពូជពង្សរបស់លោកជានិច្ចតរៀងទៅ"។

## សង្ខេប

២៦២០-ក្នុងសម្ព័ន្ធមេត្រីថ្មី គំរូដ៏ល្អឥតខ្ចោះអំពីការអធិដ្ឋានស្ថិតក្នុងការអធិដ្ឋានរបស់ព្រះយេស៊ូចំពោះព្រះបិតា។ ជារឿយៗ ព្រះយេស៊ូអធិដ្ឋានតែម្នាក់ឯង ក្នុងទីស្ងាត់កំបាំង ដោយភ្ជាប់សេចក្តីស្រឡាញ់ទៅនឹងព្រះហឫទ័យរបស់ព្រះបិតា រហូតដល់ព្រះឈើឆ្កាង ដោយជឿជាក់ថា ព្រះបិតានឹងទទួលពាក្យអង្វររបស់ព្រះអង្គមិនខានឡើយ។

២៦២១-ក្នុងការប្រៀនប្រដៅ ព្រះយេស៊ូបង្រៀនក្រុមសាវ័ករបស់ព្រះអង្គឲ្យអធិដ្ឋានដោយជម្រះចិត្ត ដោយមានជំនឿមាំមួន ដោយចិត្តព្យាយាម និងចិត្តក្លាហានផង។ ព្រះអង្គត្រាស់ហៅពួកគេឲ្យប្រុងស្មារតី និងអញ្ជើញគេឲ្យទូលសុំអង្វរព្រះជាម្ចាស់ក្នុងព្រះនាមព្រះអង្គ។ ព្រះយេស៊ូគ្រីស្តផ្ទាល់ទទួលពាក្យអង្វរ ដែលយើងទូលទៅព្រះអង្គ។

២៦២២-នៅពេលដែលព្រះនាងសុខចិត្តគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ (**Fiat**) និងលើកតម្កើងសរសើរព្រះអង្គ (**Magnificat**) ការអធិដ្ឋានរបស់ព្រហ្មចារិនីម៉ារីមានលក្ខណៈថា ព្រះនាងថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ ដោយផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ។

# ប្រការទី៣៖

## ក្នុងព្រះសហគមន៍

២៦២៣-ថ្ងៃបុណ្យព្រះវិញ្ញាណយាងមក ព្រះជាម្ចាស់បានចាក់បង្ហូរព្រះវិញ្ញាណនៃព្រះបន្ទូលសន្យាលើក្រុមសាវ័កដែល "រួមប្រជុំទាំងអស់គ្នា ក្នុងកន្លែងតែមួយ" (កក ២,១) និងដែលកំពុងរង់ចាំព្រះអង្គ ដោយ "រួមចិត្ត

គំនិតគ្នា ព្យាយាមអធិដ្ឋាន" (កក ១,៤)។ ព្រះវិញ្ញាណដែលប្រៀនប្រដៅ និងរំឭកព្រះសហគមន៍អំពីព្រះបន្ទូលទាំងឡាយរបស់ព្រះយេស៊ូ (យហ ១៤,២៦) នឹងបង្រៀនឲ្យចេះអធិដ្ឋានផងដែរ។

២៦២៤-ក្នុងសហគមន៍ដំបូងនៃទីក្រុងយេរូសាឡឹម អ្នកជឿ "ព្យាយាមស្តាប់ការបង្រៀនរបស់ក្រុមគ្រីស្តទូត រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំបុ័ង និងព្យាយាមអធិដ្ឋាន" (កក ២,៤២)។ ព្រះសហគមន៍ក៏អធិដ្ឋានតាមរបៀបនេះ ដោយចាក់ឫសលើជំនឿដែលបានមកពីក្រុមគ្រីស្តទូត និងបញ្ជាក់ដោយសេចក្តីស្រឡាញ់ ហើយដែលមានអភិបូជាធ្វើជាចំណីអាហារ ដើម្បីពង្រឹងការអធិដ្ឋាននេះ។

២៦២៥-គ្រីស្តបរិស័ទអធិដ្ឋានដោយស្តាប់ និងអានសេចក្តីអធិដ្ឋានក្នុងព្រះគម្ពីរ ជាពិសេសទំនុកតម្កើង ដែលព្រះគ្រីស្តបំពេញ និងផ្តល់អត្ថន័យសម្រាប់សព្វថ្ងៃ (លក ២៤,២៧.៤៤)។ ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលរំឭកឲ្យព្រះសហគមន៍នឹកគិតដល់ព្រះគ្រីស្ត ណែនាំព្រះសហគមន៍ឆ្ពោះទៅកាន់សេចក្តីពិតគ្រប់ប្រការ បណ្តាលឲ្យព្រះសហគមន៍បង្កើតសេចក្តីអធិដ្ឋានថ្មី ដែលនឹងសម្តែងគម្រោងការដ៏លាក់កំបាំង ដែលមិនអាចស្ទង់បានរបស់ព្រះគ្រីស្ត ដែលមានកិច្ចការក្នុងជីវិត អគ្គសញ្ញា និងបេសកកម្មរបស់ព្រះសហគមន៍ព្រះអង្គ។ ពាក្យសម្ដីនោះនឹងវិវឌ្ឍន៍ក្នុងប្រពៃណីសំខាន់ៗនៃពិធីបុណ្យ និងខាងវិញ្ញាណ។ របៀបអធិដ្ឋានផ្សេងៗ ដែលមានក្នុងបញ្ញត្តិនៃព្រះគម្ពីរ តាមការបញ្ជូនបន្តរបស់ក្រុមគ្រីស្តទូត នៅតែជាគំរូឲ្យគ្រីស្តបរិស័ទអធិដ្ឋាន។

## ១-ការប្រទានពរ និងការថ្វាយបង្គំ

២៦២៦-ការប្រទានពរ បង្ហាញចលនាដ៏ជ្រាលជ្រៅនៃការអធិដ្ឋានរបស់គ្រីស្តបរិស័ទ។ ក្នុងការប្រទានពរ ព្រះជាម្ចាស់ និងមនុស្សជួបជុំគ្នា គឺព្រះអំណោយទានរបស់ព្រះជាម្ចាស់ និងចម្លើយរបស់មនុស្ស ត្រាស់ហៅគ្នា និងរួមជាមួយគ្នា។ ដោយសារពិធីប្រទានពរ មនុស្សឆ្លើយតបនឹងព្រះអំណោយទានរបស់ព្រះជាម្ចាស់។ ដោយសារព្រះជាម្ចាស់ប្រទានព្រះពរដល់មនុស្ស មនុស្សអាចប្រទានពរដល់ព្រះអង្គដែលទ្រង់ជាប្រភពនៃព្រះពរទាំងឡាយវិញ។

២៦២៧-មានពេលខ្លះ យើងប្រទានពរដល់ព្រះជាម្ចាស់ដែលបានប្រទានព្រះពរដល់យើង គឺព្រះគ្រីស្តយកការប្រទានពរឡើងទៅឯព្រះបិតា ក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ (អភ ១,៣-១៤; ២ករ ១,៣-៧; ១ពត្រ ១,៣-៩) រីឯពេលខ្លះទៀត ព្រះជាម្ចាស់ប្រទានព្រះពរដល់យើង តាមរយៈព្រះគ្រីស្ត ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះពីព្រះបិតា (២ករ ១៣,១៣; រម ១៥,៥-៦; អភ ៦,២៣-២៤)។

២៦២៨-មនុស្សថ្វាយបង្គំព្រះជាម្ចាស់ ដោយទទួលស្គាល់ថា ខ្លួនឯងជាសត្វលោក ឯព្រះជាម្ចាស់ជាអ្នកបង្កើតគេ។ ពេលថ្វាយបង្គំព្រះជាម្ចាស់ យើងលើកតម្កើងភាពថ្កុំថ្កើងរុងរឿងរបស់ព្រះអម្ចាស់ដែលបានបង្កើតយើង (ទន ៩៥,១-៦) និងឫទ្ធានុភាពសព្វប្រការនៃព្រះសង្គ្រោះដែលរំដោះយើងឲ្យរួចពីបាប។ វិញ្ញាណយើងលំទោនក្រាបថ្វាយបង្គំចំពោះ "ព្រះមហាក្សត្រប្រកបដោយសិរីរុងរឿង" (ទន ២៤,៩-១០) ហើយយើងគោរពយ៉ាងស្ងៀមស្ងាត់ចំពោះព្រះដ៏ខ្ពង់ខ្ពស់ជានិច្ចនិរន្តរ៍ (សន្តៈ អូគូស្តាំង)។ ពេលយើងក្រាបថ្វាយបង្គំព្រះដ៏វិសុទ្ធបំផុត និងជាទីស្រឡាញ់ យើងបន្ទាបខ្លួន និងហ៊ានទូលអង្វរព្រះអង្គដោយចិត្តក្លាហាន។

## ២-ការអធិដ្ឋានដោយទូលអង្វរព្រះជាម្ចាស់

២៦២៩-ក្នុងសម្ពន្ធមេត្រីថ្មី មានពាក្យជាច្រើនរៀបរាប់អំពីការទូលអង្វរព្រះជាម្ចាស់ ដូចជាសូមទាមទារទទូច

អង្វរស្រែកទូល ស្រែកហៅ សូម្បីតែ "តស៊ូដោយទូលអង្វរ" (រម ១៥,៣០; កូឡ ៤,១២) ក៏មានដែរ។ ប៉ុន្តែ ជាធម្មតា យើងហៅការអធិដ្ឋានបែបនេះថា ពាក្យទូលអង្វរ។ សេចក្តីអធិដ្ឋាននេះសម្តែង ឲ្យយើងយល់ថា យើងគ្រាន់តែជាសត្វលោក យើងមិនមែនជាប្រភព ឬទីបញ្ចប់របស់ខ្លួនឯងទេ យើងមិនអាចគ្រប់គ្រងឧបសគ្គទាំងប៉ុន្មានដែលយើងជួបប្រទះ ឬយើងមិនមែនជាម្ចាស់នៃទីចុងក្រោយរបស់យើងឡើយ។ ម្យ៉ាងទៀត ចំពោះយើងជាគ្រីស្តបរិស័ទ យើងដឹងថា យើងជាអ្នកបាប ឃ្លាតឆ្ងាយពីព្រះបិតារបស់យើង។ ពេលយើងទូលអង្វរព្រះជាម្ចាស់ យើងហាក់ដូចជាត្រឡប់ទៅឯព្រះអង្គវិញ។

២៦៣០-ក្នុងសម្ពន្ធមេត្រីថ្មី ពុំសូវមានពាក្យទំនួញ ដូចនៅក្នុងសម្ពន្ធមេត្រីចាស់ទេ ដ្បិតឥឡូវនេះ ក្នុងអង្គព្រះគ្រីស្តដែលមានព្រះជន្មថ្មី ព្រះសហគមន៍សុំអង្វរព្រះជាម្ចាស់ ដោយមានសេចក្តីសង្ឃឹម ទោះបីយើងនៅតែរង់ចាំ ហើយយើងត្រូវតែកែប្រែចិត្តគំនិតជារៀងរាល់ថ្ងៃយ៉ាងណាក៏ដោយ។ ពាក្យសុំអង្វររបស់គ្រីស្តបរិស័ទផុសចេញពីប្រភពដ៏ជ្រាលជ្រៅ គឺតាមសន្តៈ ប៉ូល ពិភពលោកទាំងមូលស្រែកថ្ងូរ "ដូចជាស្ត្រីដែលហៀបនឹងសម្រាលកូន" (រម ៨,២២) យើងក៏ថ្ងូរក្នុងចិត្តដែរ ដោយទន្ទឹងរង់ចាំព្រះជាម្ចាស់ (...) លោះរូបកាយយើងទាំងស្រុង (...) ដ្បិតយើងបានទទួលការសង្គ្រោះ តែក្នុងសេចក្តីសង្ឃឹមប៉ុណ្ណោះ" (រម ៨,២៣-២៤)។ ម្យ៉ាងទៀង ព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់ក៏ស្រែកថ្ងូរ ហើយ "យាងមកជួយយើង ដែលទន់ខ្សោយនេះដែរ ដ្បិតយើងពុំដឹងអធិដ្ឋានដូចម្តេច" (រម ៨,២៦)។

២៦៣១-ពេលយើងសូមអង្វរព្រះជាម្ចាស់ឲ្យលើកលែងទោស ឲ្យយើង (ដូចអ្នកទារពន្ធ៖ "ឱព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាទូលបង្គំជាអ្នកបាបផង!" លក ១៨,១៣) យើងចាប់ផ្តើមអធិដ្ឋាន តាមរបៀបត្រឹមត្រូវ និងចិត្តបរិសុទ្ធ។ យើងបន្ទាបខ្លួនដោយជឿទុកចិត្តលើព្រះជាម្ចាស់ ទើបយើងរួមរស់ជាមួយព្រះបិតា និងព្រះបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត និងជាមួយអ្នកដទៃផងដែរ (១យហ ១,៧-២,២២)។ ហេតុនេះ "អ្វីៗក៏ដោយឲ្យតែយើងទូលសុំ យើងមុខជាទទួលពីព្រះអង្គមិនខាន" (១យហ ៣,២២)។ យើងចាប់ផ្តើមថ្វាយអភិបូជា ឬអធិដ្ឋានម្នាក់ឯង ដោយសូមអង្វរព្រះជាម្ចាស់លើកលែងទោសឲ្យយើង។

២៦៣២-តាមការប្រៀនប្រដៅរបស់ព្រះយេស៊ូ (មថ ៦,១០.៣៣; លក ១១,២.១៣) គ្រីស្តបរិស័ទអធិដ្ឋានដោយមានបំណងប្រាថ្នា និងដោយស្វែងរក ឲ្យព្រះរាជ្យព្រះជាម្ចាស់យាងមកដល់។ ត្រូវតែទូលសូមតាមលំដាប់លំដោយ ពោលគឺសូមឲ្យព្រះរាជ្យព្រះអង្គយាងមក ក្រោយមកសូមអ្វីជាចាំបាច់ដើម្បីទទួលព្រះរាជ្យនេះ និងដើម្បីរួមសហការជាមួយព្រះអង្គឲ្យព្រះរាជ្យនេះយាងមក។ សហគមន៍ដែលមកពីក្រុមគ្រីស្តទូតអធិដ្ឋានឲ្យយើងរួមសហការក្នុងបេសកកម្មរបស់ព្រះគ្រីស្ត និងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាបេសកកម្មរបស់ព្រះសហគមន៍បច្ចុប្បន្ន (រម ១០,១; អភ ១,១៦-២៣; ភីល ១,៩-១១; កូឡ ១,៣-៦; ៤,៣-៤.១២)។ ការអធិដ្ឋានរបស់សន្តៈ ប៉ូល ដែលជាគ្រីស្តទូតដ៏គ្រប់លក្ខណៈ បង្ហាញឲ្យយើងដឹងថា ត្រូវតែអធិដ្ឋានដោយនឹកគិតដល់ព្រះសហគមន៍ទាំងឡាយ។ ដោយអធិដ្ឋាន អស់អ្នកដែលបានជ្រមុជទឹកធ្វើការឲ្យព្រះរាជ្យព្រះជាម្ចាស់យាងមក។

២៦៣៣-ពេលយើងចូលរួមចំណែកក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលសង្គ្រោះមនុស្សលោក យើងអាចទូលសូមអង្វរសម្រាប់តម្រូវការណាមួយក៏បាន។ ពេលយើងទូលអង្វរព្រះជាម្ចាស់ក្នុងព្រះនាមព្រះគ្រីស្ត ព្រះអង្គដែលបានទទួលយកអ្វីៗទាំងអស់ ដើម្បីលោះអ្វីៗទាំងអស់ទទួលសិរីរុងរឿង (យហ ១៤,១៣)។ ហេតុនេះ ដោយជឿទុកចិត្តថា ព្រះជាម្ចាស់នឹងទទួលពាក្យអង្វររបស់យើង លោកយ៉ាកុប (យក ១,៥-៨) និងលោក ប៉ូល ដាស់តឿនយើងឲ្យអធិដ្ឋានគ្រប់កាលៈទេសៈ (អភ ៥,២០; ភីល ៤,៦-៧; កូឡ ៣,១៦-១៧; ១ថស ៥,១៧-១៨)។

## ៣-ការជួយអង្វរឲ្យអ្នកដទៃ

២៦៣៤-ពេលយើងជួយអង្វរព្រះជាម្ចាស់ យើងអធិដ្ឋានដូចព្រះយេស៊ូអធិដ្ឋានផងដែរ។ មានតែព្រះអង្គទេដែលជួយអង្វរព្រះបិតាចំពោះមនុស្សលោក ជាពិសេសចំពោះអ្នកបាប (រម ៨,៣៤; ១យហ ២,១; ១ធម ២,៥-៨)។ ព្រះអង្គ "អាចសង្គ្រោះអស់អ្នកដែលចូលមកជិតព្រះជាម្ចាស់ តាមរយៈព្រះអង្គ បានជាស្ថាពរ ដ្បិតព្រះអង្គមានព្រះជន្មរស់រហូត ដើម្បីទូលអង្វរព្រះជាម្ចាស់ឲ្យពួកគេ" (ហប ៨,២៥)។ ព្រះវិញ្ញាណផ្ទាល់ "ជួយទូលអង្វរឲ្យយើង (...) រីឯព្រះជាម្ចាស់ដែលឈ្វេងយល់ចិត្តមនុស្ស ទ្រង់ជ្រាបព្រះបំណងរបស់ព្រះវិញ្ញាណ ព្រោះព្រះវិញ្ញាណជួយទូលអង្វរឲ្យប្រជាជនដ៏វិសុទ្ធស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់" (រម ៨,២៦-២៧)។

២៦៣៥-តាំងពីសម័យលោក អប្រាហាំ មក អ្នកដែលមានចិត្តមេត្តាករុណាដូចព្រះជាម្ចាស់ទូលអង្វរព្រះអង្គសម្រាប់អ្នកដទៃ។ ក្នុងព្រះសហគមន៍ យើងជួយទូលអង្វរ ដោយរួមចំណែកជាមួយព្រះគ្រីស្ត គឺជាការសម្ដែងឲ្យឃើញអំពីការរួបរួមគ្នារវាងជនដ៏វិសុទ្ធទាំងឡាយ។ អ្នកដែលជួយអង្វរមិន "គិតពីប្រយោជន៍ផ្ទាល់ខ្លួនឡើយ គឺត្រូវគិតដល់ប្រយោជន៍អ្នកដទៃវិញ" (ភីល ២,៤) រហូតដល់អធិដ្ឋានសម្រាប់អស់អ្នកដែលធ្វើបាបគាត់ (កក ៧,៦០; លក ២៣,២៨.៣៤)។

២៦៣៦-សហគមន៍គ្រីស្តបរិស័ទដំបូងបានអធិដ្ឋានបែបនេះយ៉ាងជ្រាលជ្រៅជាទីបំផុត (កក ១២,៥; ២០,៣៦; ២១,៥; ២ករ ៩,១៤)។ គ្រីស្តទូតប៉ូលធ្វើឲ្យគេរួមចំណែកក្នុងមុខងាររបស់លោកអំពីដំណឹងល្អ (អភ ៦,១៨-២០; កូឡ ៤,៣-៤; ១ថស ៥,២៥) ប៉ុន្តែ លោកជួយអង្វរឲ្យគេផងដែរ (២ថស ១,១១; កូល ១,៣; ភីល ១,៣-៤)។ គ្រីស្តបរិស័ទជួយអង្វរព្រះជាម្ចាស់សម្រាប់មនុស្សទាំងអស់ ដោយឥតព្រំដែនឡើយ៖ "សម្រាប់មនុស្សទាំងអស់ (...) សម្រាប់ស្ដេច និងអ្នកកាន់អំណាចគ្រប់ៗរូប" (១ធម ២,១) សម្រាប់អ្នកបៀតបៀនគេ (រម ១២,១៤) និងដើម្បីឲ្យអស់អ្នកដែលមិនព្រមទទួលដំណឹងល្អអាចទទួលការសង្គ្រោះបានដែរ (រម ១០,១)។

## ៤-ការអធិដ្ឋានដោយអរព្រះគុណព្រះជាម្ចាស់

២៦៣៧-ព្រះសហគមន៍អធិដ្ឋានដោយអរព្រះគុណព្រះជាម្ចាស់ ជាពិសេសពេលថ្វាយអភិបូជា ព្រះសហគមន៍សម្ដែងខ្លួនឯង និងក្លាយទៅជាខ្លួនឯងកាន់តែខ្លាំងឡើងៗ។ ក្នុងព្រះរាជកិច្ចនៃការសង្គ្រោះ ព្រះគ្រីស្តរំដោះសត្វលោកឲ្យរួចពីបាប និងពីសេចក្តីស្លាប់ ដើម្បីបង្កើតគេសាជាថ្មី និងប្រោសឲ្យគេត្រឡប់ឯព្រះបិតាវិញ ដើម្បីសិរីរុងរឿងរបស់ព្រះអង្គ។ សរីរាង្គនៃព្រះកាយរួមចំណែកក្នុងកិច្ចអរព្រះគុណនៃអ្នកដឹកនាំរបស់គេ។

២៦៣៨-ដូចពេលទូលសុំអង្វរព្រះជាម្ចាស់ យើងអាចអរព្រះគុណព្រះអង្គចំពោះហេតុការណ៍ ឬតម្រូវការណាមួយដែរ។ ជារឿយៗ សន្តៈ ប៉ូល ចាប់ផ្ដើម និងបញ្ចប់លិខិតរបស់លោក ដោយអរព្រះគុណព្រះជាម្ចាស់ ហើយអរព្រះគុណព្រះអម្ចាស់យេស៊ូជានិច្ចផងដែរ។ "ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាលៈទេសៈទាំងអស់ ដ្បិតព្រះអង្គសព្វព្រះហឫទ័យឲ្យបងប្អូន ដែលរួមជាមួយព្រះគ្រីស្តយេស៊ូធ្វើដូច្នេះឯង" (១ថស ៥, ១៨)។ "ចូរព្យាយាមអធិដ្ឋានហើយប្រុងស្មារតីក្នុងការអធិដ្ឋាននេះ ព្រមទាំងអរព្រះគុណព្រះជាម្ចាស់ផង" (កូឡ ៤,២)។

## ៥-ការអធិដ្ឋានដោយសរសើរលើកតម្កើងព្រះជាម្ចាស់

២៦៣៩-ពេលយើងសរសើរលើកតម្កើងព្រះជាម្ចាស់ យើងទទួលស្គាល់ភ្លាមថា ព្រះជាម្ចាស់ជាព្រះដ៏ពិតប្រាកដមែន។ យើងច្រៀងសរសើរព្រះជាម្ចាស់ ដើម្បីព្រះអង្គ យើងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ លើសពី

អ្វីដែលព្រះអង្គធ្វើសម្រាប់យើង ដ្បិតព្រះអង្គមានព្រះជន្មគង់នៅ។ យើងចូលរួមជាមួយអស់អ្នកដ៏មានចិត្តបរិសុទ្ធ ដែលស្រឡាញ់ព្រះជាម្ចាស់ក្នុងជំនឿ មុននឹងបានឃើញព្រះអង្គប្រកបដោយសិរីរុងរឿងទៅទៀត។ ដោយសារយើងសរសើរលើកតម្កើងព្រះជាម្ចាស់ ព្រះវិញ្ញាណយាងមករួមជាមួយវិញ្ញាណយើង ដើម្បីផ្ដល់សក្ខីភាពឲ្យយើងដឹងថា យើងពិតជាបុត្រធីតារបស់ព្រះជាម្ចាស់ (រម ៨,១៦) ហើយព្រះអង្គផ្ដល់សក្ខីភាពចំពោះព្រះបុត្រាតែមួយ ដែលបានប្រោសយើងឲ្យទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ និងប្រោសយើងឲ្យលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ ពេលយើងសរសើរលើកតម្កើងព្រះជាម្ចាស់ យើងយកសេចក្ដីអធិដ្ឋានទាំងឡាយនាំទៅឯព្រះអង្គ ដែលជាប្រភព និងទីបញ្ចប់នៃការអធិដ្ឋានទាំងអស់នោះ៖ "មានព្រះជាម្ចាស់តែមួយប៉ុណ្ណោះ ព្រះអង្គជាព្រះបិតាដែលបានបង្កើតអ្វីៗសព្វសារពើមក ហើយយើងមានជីវិតរស់សម្រាប់ព្រះអង្គ" (១ករ ៨,៦)។

២៦៤០-ជារឿយៗ ក្នុងដំណឹងល្អ សន្តៈ លូកា សរសើរ និងលើកតម្កើងព្រះជាម្ចាស់ចំពោះការអស្ចារ្យរបស់ព្រះគ្រីស្ត និងចំពោះកិច្ចការគ្រីស្តទូត ដែលជាកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធផង ពោលគឺសហគមន៍នៃទីក្រុងយេរូសាឡឹម (កក ២,៤៧) អ្នកពិការដែលលោកសិលា និងលោកយ៉ូហានបានព្យាបាល (កក ៣,៩) បណ្ដាជនដែលលើកតម្កើងព្រះជាម្ចាស់ (កក ៤,២១) សាសន៍ដទៃនៅស្រុកពីស៊ីឌី ដែល "សប្បាយរីករាយជាខ្លាំង" ហើយដែល "នាំគ្នាលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់" (កក ១៣,៤៨)។

២៦៤១-"ចូរសូត្រទំនុកតម្កើងឆ្លើយឆ្លងគ្នា ដើម្បីសរសើរព្រះជាម្ចាស់ និងបទចម្រៀងមកពីព្រះវិញ្ញាណ។ ចូរច្រៀង និងលើកតម្កើងព្រះជាម្ចាស់ឲ្យអស់ពីចិត្ត" (អភ ៥,១៩; កូឡ ៣,១៦)។ ដូចអ្នកនិពន្ធគម្ពីរសម្ពន្ធមេត្រីថ្មី ដែលព្រះវិញ្ញាណបានបំភ្លឺ សហគមន៍គ្រីស្តបរិស័ទដំបូងអានកំណាព្យទំនុកតម្កើងឡើងវិញ ដោយច្រៀងគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត។ ក្នុងព្រះវិញ្ញាណដែលប្រោសអ្វីៗទាំងអស់ឲ្យទៅជាថ្មី ពួកគេថ្លែងបទចម្រៀង ដោយនឹកគិតដល់ហេតុការណ៍ដ៏អស្ចារ្យតែមួយ ដែលព្រះជាម្ចាស់បានបំពេញក្នុងអង្គព្រះបុត្រាព្រះអង្គ គឺព្រះអង្គប្រសូតជាមនុស្ស ឈ្នះសេចក្ដីស្លាប់ មានព្រះជន្មថ្មី និងយាងឡើងទៅគង់ខាងស្ដាំព្រះបិតា (ភីល ២,៦-១១; កូឡ ១,១៥-២០; អភ ៥,១៤; ១ធម ៣,១៦; ៦,១៥-១៦; ២ធម ២, ១១-១៣)។ យើងលើកតម្កើងសរសើរព្រះជាម្ចាស់ដោយសារព្រះអង្គបានសង្គ្រោះមនុស្សលោកយ៉ាងអស្ចារ្យបែបនេះ (អភ ១,៣-១៤; រម ១៦,២៥-២៧; អភ ៣,២០-២១; យដ ២៤-២៥)។

២៦៤២-បទចម្រៀងនៃពិធីបុណ្យនៅស្ថានបរមសុខ (វវ ៤,៨-១១; ៥,៩-១៤; ៧,១០-១២) និងពាក្យទូលអង្វររបស់ "ពួកសាក្សី" (មរណសាក្សី វវ ១០,៦) លើកតម្កើង "អ្វីដែលត្រូវកើតជារូបរាងក្នុងពេលឆាប់ៗ" គឺវិវរណៈ។ ពួកព្យាការី និងសន្តបុគ្គល ហើយអស់អ្នកដែលត្រូវគេកាត់ក ដើម្បីផ្ដល់សក្ខីភាពចំពោះព្រះយេស៊ូ (វវ ១៨,២៤) មហាជនដ៏ច្រើនកុះករ ដែលបានប្រឈមមុខនឹងទុក្ខលំបាក ហើយដែលចូលក្នុងព្រះរាជ្យមុនយើង ច្រៀងកោតសរសើរសិរីរុងរឿងរបស់អ្នកដែលអង្គុយលើបល្ល័ង្គ និងរបស់កូនចៀមផង (វវ ១៩,១-៨)។ ដោយរួមរស់ជាមួយពួកលោកទាំងអស់នោះ ព្រះសហគមន៍នៅលើផែនដីក៏ច្រៀងបទចម្រៀងនោះដែរ ដោយធ្វើជីវិតលើព្រះជាម្ចាស់ និងដោយរងទុក្ខលំបាកផង។ ពេលយើងអធិដ្ឋានទូលសុំអង្វរ និងជួយអង្វរព្រះជាម្ចាស់ ទោះជាយ៉ាងណា ក៏យើងសង្ឃឹមជឿជាក់ជានិច្ច ព្រមទាំងអរព្រះគុណ "ព្រះបិតាដែលបង្កើតពន្លឺ" ដែលជាប្រភពនៃ "គ្រប់អំណោយដ៏ល្អវិសេស" (យប ១,១៧)។ ជំនឿទៅជាពាក្យសរសើរដ៏វិសុទ្ធ។

២៦៤៣-អគ្គសញ្ញាអរព្រះគុណប្រមូលរបៀបអធិដ្ឋានទាំងអស់នោះ គឺជា "តង្វាយដ៏វិសុទ្ធ" នៃព្រះកាយទាំងស្រុងរបស់ព្រះគ្រីស្ត ដើម្បី "លើកតម្កើងព្រះនាមព្រះអង្គ" (មគ ១,១១) ហើយតាមប្រពៃណីនៃបស្ចិម និងបូព៌ាប្រទេសជា "យញ្ញបូជានៃពាក្យសរសើរ" ព្រះជាម្ចាស់។

## សង្ខេប

២៦៤៤-ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបង្រៀនព្រះសហគមន៍ និងរំឭកឡើងវិញនូវព្រះបន្ទូលទាំងអស់របស់ព្រះយេស៊ូ អប់រំព្រះសហគមន៍ឲ្យចេះអធិដ្ឋាន តាមរបៀបផ្សេងៗគ្នា ដោយលើកការយកពាក្យសម្ដី ដែលមាននៅក្នុងការប្រទានពរ ការទូលអង្វរ ការជួយអង្វរ ការអរព្រះគុណ និងការកោតសរសើរលើកតម្កើងព្រះជាម្ចាស់ជានិច្ច។

២៦៤៥-ដោយសារព្រះជាម្ចាស់ប្រទានពរដល់គេ ចិត្តមនុស្សអាចប្រទានពរដល់អ្នកដែលជាប្រពភពនៃព្រះពរទាំងអស់វិញ។

២៦៤៦-យើងទូលអង្វរព្រះជាម្ចាស់ ដើម្បីការលើងលែងទោស ស្វែងរកព្រះរាជ្យ ព្រមទាំងតម្រូវការដ៏ពិតប្រាកដ។

២៦៤៧-យើងអាចជួយអង្វរព្រះជាម្ចាស់ ដើម្បីអ្នកដទៃ។ ការអធិដ្ឋានបែបនេះ គ្មានព្រំដែនទេ ហើយលាតសន្ធឹងសរហូតដល់ខ្មាំងសត្រូវ។

២៦៤៨-យើងអាចអរព្រះគុណព្រះជាម្ចាស់ សម្រាប់អំណរ និងទុក្ខព្រួយណាមួយ ហេតុការណ៍ និងតម្រូវការណាមួយ ដោយរួមចំណែកជាមួយព្រះគ្រីស្ត។ ការថ្លែងអំណរគុណនេះ ត្រូវតែបំពេញអស់មួយជីវិត៖ "ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាលៈទេសៈទាំងអស់" (១ថស ៥,១៨)។

២៦៤៩-ពេលយើងកោតសរសើរលើកតម្កើងព្រះជាម្ចាស់ យើងបែរមុខទៅរកព្រះអង្គ។ យើងច្រៀងដើម្បីព្រះអង្គ យើងលើកតម្កើងសិរីរុងរឿងព្រះអង្គ លើសពីអ្វីដែលព្រះអង្គបានប្រព្រឹត្ត គឺដោយសារព្រះអង្គជាព្រះ ជាម្ចាស់។

## ជំពូកទីពីរ៖

## ការបញ្ជូនបន្តនៃការអធិដ្ឋាន

២៦៥០-យើងមិនគ្រាន់តែអធិដ្ឋាននៅគ្រាដែលចិត្តយើងជំរុញឲ្យអធិដ្ឋានទេ គឺត្រូវតែមានបំណងចង់អធិដ្ឋានដើម្បីអធិដ្ឋាន។ ម្យ៉ាងទៀត យើងមិនគ្រាន់តែត្រូវស្គាល់សេចក្ដីដែលព្រះគម្ពីរចែងទុកអំពីការអធិដ្ឋានទេ ថែមទាំងយើងត្រូវតែរៀនអធិដ្ឋានផងដែរ។ ក្នុង "ព្រះសហគមន៍ដែលជឿ និងអធិដ្ឋាន" (DV ៨) ព្រះវិញ្ញាណដ៏វិសុទ្ធបង្រៀនបុត្រធីតារបស់ព្រះជាម្ចាស់ឲ្យចេះអធិដ្ឋាន តាមរយៈការបញ្ជូនបន្តដ៏រស់រវើក (ការបញ្ជូនបន្តដ៏វិសុទ្ធ)។

២៦៥១-ការបញ្ជូនបន្តនៃការអធិដ្ឋានតាមគ្រីស្តសាសនា បង្ហាញថា ការបញ្ជូនបន្តនៃជំនឿរីកចម្រើន ជាពិសេសដោយសារអ្នកជឿធ្វើការស្មឹងស្មាធិ៍ និងសិក្សាចងចាំទុកក្នុងចិត្តគេនូវកិច្ចការ និងព្រះបន្ទូលអំពីការចាត់ចែងនៃការសង្គ្រោះ និងដោយយល់អំពីសម្បត្តិសួគ៌កាន់តែច្បាស់ (DV ៨)។

## ប្រការទី១៖

## ប្រភពនៃការអធិដ្ឋាន

២៦៥២-ព្រះវិញ្ញាណដ៏វិសុទ្ធជា "ទឹកដែលផុសឡើងផ្ដល់ជីវិតអស់កល្បជានិច្ច" (យហ ៤,១៤) ក្នុងចិត្តរបស់អ្នកអធិដ្ឋាន។ ព្រះវិញ្ញាណបង្រៀនយើងឲ្យទទួលព្រះអង្គ នៅក្នុងប្រភពផ្ទាល់តែម្ដង គឺព្រះគ្រីស្ត។ ក្នុងការរស់នៅជាគ្រីស្តបរិស័ទ ព្រះគ្រីស្តរង់ចាំយើងនៅឯប្រភពផ្សេងៗ ដើម្បីប្រទានឲ្យយើងនូវព្រះវិញ្ញាណដ៏វិសុទ្ធ៖

## ព្រះបន្ទូលរបស់ព្រះជាម្ចាស់

២៦៥៣-ព្រះសហគមន៍ "ដាស់តឿនគ្រីស្តបរិស័ទទាំងអស់យ៉ាងខ្លាំងជាទីបំផុត (...) ឲ្យរៀន "ចំណេះដ៏វិសេសវិសាលដែលនៅក្នុងព្រះគ្រីស្ត" (ភល ៣,៨) ដោយអានព្រះគម្ពីរជារឿយៗ" ប៉ុន្តែ "ត្រូវអានព្រះគម្ពីរផង និងអធិដ្ឋានផង ទើបមនុស្ស និងព្រះជាម្ចាស់អាចសន្ទនាជាមួយគ្នាបាន ដ្បិត "ពេលណាយើងអធិដ្ឋាន ពេលនោះយើងនិយាយទូលព្រះអង្គ ហើយពេលយើងអានព្រះបន្ទូល យើងស្តាប់ព្រះអង្គ (សន្ត: អំប្រ៊ែរ; DV ២៥)។

២៦៥៤-យោងតាម មថ ៧,៧ គ្រូបាធ្យាយខាងវិញ្ញាណសង្ខេបអំពីលក្ខណៈរបស់អ្នកដែលអានព្រះបន្ទូលដោយអធិដ្ឋាន៖ "ចូរស្វែងរកដោយខិតខំអាន នោះអ្នកនឹងរកឃើញដោយការស្មឹងស្មាធិ៍ ចូរគោះទ្វារដោយអធិដ្ឋាន នោះការសញ្ជឹងគិតនឹងបើកទ្វារឲ្យអ្នក" (សន្ត: គីង នៃចារត្រឺ)។

## ពិធីបុណ្យព្រះសហគមន៍

២៦៥៥-បេសកកម្មរបស់ព្រះគ្រីស្ត និងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺប្រកាស និងផ្តល់គម្រោងការដ៏លាក់កំបាំងអំពីការសង្គ្រោះ ក្នុងពិធីបុណ្យនៃអគ្គសញ្ញារបស់ព្រះសហគមន៍ ព្រមទាំងប្រោសឲ្យគម្រោងការនេះកើតជារូបរាងដូចសព្វថ្ងៃនេះផង។ គម្រោងការនេះនៅតែបន្តក្នុងចិត្តរបស់អ្នកអធិដ្ឋាន។ ជួនកាល គ្រូបាធ្យាយខាងវិញ្ញាណប្រៀបធៀបចិត្តទៅនឹងអាសនៈមួយ។ ពេលយើងអធិដ្ឋាន យើងរំឭកឡើងវិញ និងរក្សាទុកពិធីបុណ្យក្នុងទីជម្រៅចិត្តមុន និងក្រោយការប្រារព្ធពិធីបុណ្យនេះ។ ទោះបីយើងអធិដ្ឋាន "ក្នុងទីស្ងាត់កំបាំង" (មថ ៦,៦) យ៉ាងណាក៏ដោយ ក៏ការអធិដ្ឋានតែងតែជាការអធិដ្ឋានរបស់ព្រះសហគមន៍ រួមជាមួយព្រះត្រៃឯកដ៏វិសុទ្ធ (IGLH ៩)។

## គុណធម៌នៃព្រះជាម្ចាស់

២៦៥៦-យើងចូលក្នុងការអធិដ្ឋានដូចយើងចូលរួមក្នុងពិធីបុណ្យដែរ គឺតាមទ្វារចង្អៀតនៃជំនឿ។ តាមរយៈសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះអង្គ យើងស្វែងរក និងប្រាថ្នាចង់ជួបព្រះភ័ក្ត្រព្រះអម្ចាស់ យើងចង់ស្តាប់ និងរក្សាទុកព្រះបន្ទូលរបស់ព្រះអង្គ។

២៦៥៧-ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបង្រៀនយើងឲ្យប្រារព្ធពិធីបុណ្យ ដោយរង់ចាំព្រះគ្រីស្តអប់រំយើងឲ្យចេះអធិដ្ឋានដោយមានសេចក្តីសង្ឃឹមជានិច្ច។ ផ្ទុយទៅវិញ ការអធិដ្ឋានរបស់ព្រះសហគមន៍ និងការអធិដ្ឋានផ្ទាល់ខ្លួនផ្តល់សេចក្តីសង្ឃឹមដល់យើង។ ជាពិសេស ទំនុកតម្កើងដែលប្រើពាក្យជាច្រើនផ្សេងៗពីគ្នា និងយ៉ាងច្បាស់លាស់បង្រៀនឲ្យយើងសង្ឃឹមទៅលើព្រះជាម្ចាស់ជានិច្ច៖ "ខ្ញុំបានទន្ទឹងរង់ចាំព្រះអម្ចាស់ ព្រះអង្គក៏ផ្ទៀងព្រះកាណ៌ស្តាប់សម្រែកទូលអង្វររបស់ខ្ញុំ" (ទន ៤០,២)។ "សូមព្រះជាម្ចាស់ជាប្រភពនៃសេចក្តីសង្ឃឹមប្រោសបងប្អូន ដែលមានជំនឿឲ្យបានពោរពេញដោយអំណរ និងសេចក្តីសុខសាន្តគ្រប់ប្រការ ដើម្បីឲ្យបងប្អូនមានសង្ឃឹមយ៉ាងបរិបូណ៌ហូរហៀរដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ" (រម ១៥,១៣)។

២៦៥៨-"សេចក្តីសង្ឃឹមមិនអាចធ្វើឲ្យយើងខកចិត្តឡើយ ព្រោះព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គមកក្នុងចិត្តយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង" (រម ៥,៥)។ ការអធិដ្ឋានដែលមានពិធីបុណ្យហ៊ឹកហ៊ឺន ដកស្រង់អ្វីៗទាំងអស់អំពីសេចក្តីស្រឡាញ់ ដែលព្រះគ្រីស្តស្រឡាញ់យើង ហើយដែលព្រះអង្គទ្រង់ប្រោសប្រទានឲ្យយើងអាចឆ្លើយតបបាន ដោយស្រឡាញ់ដូចព្រះអង្គបានស្រឡាញ់យើងដែរ។ សេចក្តីស្រឡាញ់ជាប្រភពនៃការអធិដ្ឋាន អ្នកណាដកស្រង់ពីសេចក្តីស្រឡាញ់នេះ អ្នកនោះឡើងទៅដល់កម្រិតកំពូលនៃ

ការអធិដ្ឋាន។

ឱព្រះនៃទូលបង្គំអើយ! ទូលបង្គំស្រឡាញ់ព្រះអង្គ ហើយទូលបង្គំមានបំណងប្រាថ្នាតែមួយ គឺស្រឡាញ់ព្រះអង្គរហូតដល់ផុតដង្ហើម។ ឱព្រះជាទីស្រឡាញ់នៃទូលបង្គំអើយ! ទូលបង្គំស្រឡាញ់ព្រះអង្គ ហើយទូលបង្គំសុខចិត្តស្លាប់ដោយស្រឡាញ់ព្រះអង្គជាជាងរស់នៅដោយមិនបានស្រឡាញ់ព្រះអង្គ។ បពិត្រព្រះអម្ចាស់! ទូលបង្គំស្រឡាញ់ព្រះអង្គ ហើយទូលបង្គំសូមអង្វរឲ្យទូលបង្គំស្រឡាញ់ព្រះអង្គអស់កល្បជានិច្ច (...)។ ឱព្រះនៃទូលបង្គំ! បើអណ្ដាតនៃទូលបង្គំមិនអាចទូលព្រះអង្គគ្រប់ពេលវេលាថា ទូលបង្គំស្រឡាញ់ព្រះអង្គ នោះទូលបង្គំចង់ឲ្យចិត្តទូលបង្គំទូលព្រះអង្គថា ទូលបង្គំស្រឡាញ់ព្រះអង្គ រាល់ពេលទូលបង្គំដកដង្ហើម (សន្ត: យ៉ូហានម៉ារី វីយ៉ាណេ)។

**"នៅថ្ងៃនេះ"**

២៦៥៩-មានពេលខ្លះ យើងរៀនអធិដ្ឋាន ដោយស្ដាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ និងដោយរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មថ្មី ប៉ុន្តែ គ្រប់ពេលវេលា ក្នុងកិច្ចការនីមួយៗជារៀងរាល់ថ្ងៃ ព្រះជាម្ចាស់ប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យយើងអធិដ្ឋាន។ ការប្រៀនប្រដៅរបស់ព្រះយេស៊ូអំពីការអធិដ្ឋាន ដូចការប្រៀនប្រដៅរបស់ព្រះអង្គអំពីឧបការគុណ (មថ ៦,១១.៣៤)៖ ពេលវេលាស្ថិតនៅក្នុងព្រះហស្តរបស់ព្រះបិតា យើងជួបព្រះអង្គក្នុងបច្ចុប្បន្នកាលនេះ មិនមែនម្សិលមិញ ឬថ្ងៃស្អែកទេ គឺនៅថ្ងៃនេះ៖ "ថ្ងៃនេះ បើអ្នករាល់គ្នាឮព្រះសូរសៀងរបស់ព្រះអង្គ មិនត្រូវមានចិត្តរឹងរូសឡើយ" (ទន ៩៥,៧-៨)។

២៦៦០-ការអធិដ្ឋានក្នុងកិច្ចការទាំងឡាយនៃការរស់នៅប្រចាំថ្ងៃ និងគ្រប់ពេលវេលា ជាទីសម្ងាត់នៃព្រះរាជ្យព្រះជាម្ចាស់ ដែលព្រះអង្គសម្ដែងឲ្យអ្នក "តូចតាច" អ្នកបម្រើរបស់ព្រះគ្រីស្ដ និងអស់អ្នកដែលពឹងផ្អែកលើព្រះអង្គស្គាល់។ ជាការត្រឹមត្រូវ និងការល្អប្រសើរណាស់ បើយើងអធិដ្ឋានឲ្យព្រះរាជ្យប្រកបដោយយុត្តិធម៌ និងសេចក្ដីសុខសាន្តយាងមកណែនាំប្រវត្តិសាស្ត្រនៃពិភពលោក ប៉ុន្តែ ត្រូវតែអធិដ្ឋានក្នុងស្ថានភាពដ៏សាមញ្ញតាមការរស់នៅប្រចាំថ្ងៃផងដែរ។ របៀបអធិដ្ឋានទាំងអស់អាចទៅជាមេក្នុងម្សៅ ដែលព្រះអម្ចាស់ប្រដូចនឹងព្រះរាជ្យព្រះអង្គ (លក ១៣,២០-២១)។

## សង្ខេប

២៦៦១-ព្រះវិញ្ញាណដ៏វិសុទ្ធបង្រៀនឲ្យបុត្រធីតារបស់ព្រះជាម្ចាស់ចេះអធិដ្ឋាន ដោយសារការបញ្ជូនបន្តដ៏រស់រវើក។

២៦៦២-ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពិធីបុណ្យរបស់ព្រះសហគមន៍ គុណធម៌នៃជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ជាប្រភពនៃការអធិដ្ឋាន។

# ប្រការទី២៖

# ផ្លូវនៃការអធិដ្ឋាន

២៦៦៣-ក្នុងការបញ្ជូនបន្តដ៏រស់រវើកនៃការអធិដ្ឋាន ព្រះសហគមន៍នីមួយៗស្នើសុំឲ្យអ្នកជឿអធិដ្ឋាន តាមកាលៈទេសៈនៃប្រវត្តិសាស្ត្រ សង្គម និងវប្បធម៌ផង គឺមានពាក្យសម្ដី បទចម្រៀង កាយវិការ រូបរាង។ ក្រុមណែនាំ (DV ១០) ត្រូវតែពិចារណាថា តើផ្លូវនៃការអធិដ្ឋាននោះនៅស្មោះត្រង់នឹងការបញ្ជូនបន្តនៃជំនឿដែលមកពីក្រុម

គ្រីស្តទូត។ ពួកគង្វាល និងអ្នកណែនាំអប់រំជំនឿត្រូវតែពន្យល់អំពីអត្ថន័យនៃការអធិដ្ឋាននោះយោងតាមព្រះយេស៊ូគ្រីស្ត។

## ទូលអង្វរព្រះបិតា

២៦៦៤-ដើម្បីអធិដ្ឋានតាមលំនាំគ្រីស្តសាសនា គ្មានផ្លូវផ្សេងក្រៅពីព្រះគ្រីស្តឡើយ។ ទោះបីយើងអធិដ្ឋានតែម្នាក់ឯង ឬជាមួយគ្នាក្តី ដោយប្រើពាក្យសម្តី ឬក្នុងទីជម្រៅចិត្តក្តី យើងឡើងទៅឯព្រះបិតា លុះត្រាតែយើងអធិដ្ឋាន "ក្នុងព្រះនាម" របស់ព្រះយេស៊ូ។ ដូច្នេះ ភាពដ៏វិសុទ្ធជាមនុស្សរបស់ព្រះយេស៊ូជាផ្លូវ ដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រើ ដើម្បីបង្រៀនយើងឲ្យអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ជាព្រះបិតារបស់យើង។

## ទូលអង្វរព្រះយេស៊ូ

២៦៦៥-បំប៉នដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងពិធីបុណ្យនានា ការអធិដ្ឋានរបស់ព្រះសហគមន៍បង្រៀនឲ្យយើងចេះអធិដ្ឋានដល់ព្រះអម្ចាស់យេស៊ូ។ ទោះជាធម្មតាព្រះសហគមន៍ទូលអង្វរព្រះបិតាយ៉ាងណាក៏ដោយ ក៏ព្រះសហគមន៍ទូលអង្វរព្រះគ្រីស្ត នៅក្នុងប្រពៃណីពិធីបុណ្យខ្លះដែរ។ តាមសម័យកាលព្រះសហគមន៍ និងសម្ព័ន្ធមេត្រីថ្មី ទំនុកតម្កើងខ្លះទូលអង្វរព្រះគ្រីស្តដូចតទៅ៖ ព្រះបុត្រារបស់ព្រះជាម្ចាស់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះអម្ចាស់ ព្រះសង្គ្រោះ កូនចៀមរបស់ព្រះជាម្ចាស់ ព្រះមហាក្សត្រ ព្រះបុត្រាដ៏ជាទីស្រឡាញ់ ព្រះបុត្រារបស់ព្រហ្មចារិនី គង្វាលដ៏ល្អ ជីវិតរបស់យើង ពន្លឺរបស់យើង សេចក្តីសង្ឃឹមរបស់យើង ជីវិតដ៏រុងរឿងរបស់យើង មិត្តសម្លាញ់របស់មនុស្សលោក...

២៦៦៦-ប៉ុន្តែ ព្រះនាមដែលមានអ្វីៗទាំងអស់ គឺព្រះនាមដែលព្រះបុត្រារបស់ព្រះជាម្ចាស់ទទួល ពេលព្រះអង្គប្រសូតជាមនុស្ស គឺយេស៊ូ។ បបូរមាត់មនុស្សមិនហ៊ានពោលព្រះនាមរបស់ព្រះជាម្ចាស់ទេ (សរ ៣,១៤; ៣៣,១៩-២៣) ប៉ុន្តែ ដោយព្រះអង្គទទួលយកភាពជាមនុស្ស ព្រះបន្ទូលរបស់ព្រះជាម្ចាស់ប្រគល់ព្រះនាមព្រះអង្គមកយើង ហើយយើងអាចទូលអង្វរព្រះនាមព្រះអង្គបាន៖ "ព្រះយេស៊ូ" "YHWH សង្គ្រោះ" (មថ ១,២១)។ ព្រះនាមរបស់ព្រះយេស៊ូមានអត្ថន័យគ្រប់គ្រាន់ ពោលគឺព្រះជាម្ចាស់ផង មនុស្សលោកផង និងការចាត់ចែងក្នុងការបង្កើតផង និងការសង្គ្រោះផង។ ពេលយើងអធិដ្ឋាន "ព្រះយេស៊ូ" យើងទូលអង្វរព្រះអង្គ ហៅរកព្រះអង្គក្នុងខ្លួនយើង។ វត្តមានរបស់ព្រះអង្គស្ថិតនៅក្នុងព្រះនាមព្រះអង្គ ហើយមានតែព្រះនាមព្រះអង្គទេ ដែលសម្តែងវត្តមាននេះ។ ព្រះយេស៊ូមានព្រះជន្មថ្មី ហើយអ្នកណាអង្វរព្រះនាមព្រះអង្គ អ្នកនោះទទួលព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលបានស្រឡាញ់ព្រះអង្គ និងបានបូជាព្រះជន្មសម្រាប់ព្រះអង្គ (រម ១០,១៣; កក ២,២១; ៣,១៥-១៦; កាឡ ២,២០)។

២៦៦៧-ប្រពៃណីនៃការអធិដ្ឋាននៅបស្ចិម និងបូព៌ាប្រទេស បានអភិវឌ្ឍរបៀបអធិដ្ឋានដោយទូលអង្វរព្រះនាមរបស់ព្រះយេស៊ូ។ ជាធម្មតា តាមប្រពៃណីខាងវិញ្ញាណដែលមកពីស៊ីណៃ ស៊ីរី និងអធុស យើងទូលអង្វរព្រះអង្គដូចតទៅ៖ "ព្រះយេស៊ូជាព្រះគ្រីស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ជាព្រះអម្ចាស់ សូមអាណិតអាសូរយើងខ្ញុំជាអ្នកបាប!"។ ក្នុងការទូលអង្វរនេះ បទចម្រៀងចំពោះព្រះគ្រីស្តរបស់ ភីល ២,៦-១១ លាយឡំជាមួយនឹងពាក្យអង្វររបស់អ្នកទារពន្ធ និងពួកអ្នកសូមទានពន្លឺ (មក ១០,៤៦-៥២; លក ១៨,១៣)។ ដោយពោលពាក្យអង្វរនេះ ចិត្តមនុស្សស្របតាមទុក្ខវេទនារបស់មនុស្សលោក និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ជាព្រះសង្គ្រោះពួកគេ។

២៦៦៨-ការទូលអង្វរក្នុងព្រះនាមព្រះយេស៊ូជាមធ្យោបាយដ៏សាមញ្ញ ដើម្បីអធិដ្ឋានដោយមិនឈប់ឈរឡើយ។

ពេលយើងសូត្រធម៌ពាក្យទូលអង្វរនេះ ដោយយកចិត្តទុកដាក់ យើងមិននិយាយ "ច្រំដែលៗ" ទេ (មថ ៦,៧) តែយើង "ចងចាំទុកព្រះបន្ទូលយ៉ាងស្មោះអស់ពីចិត្តរហូតដល់បានបង្កើតផលផ្លែជាច្រើនដោយចិត្តស៊ូទ្រាំ" (លក ៨,១៣)។ យើងអាចសូត្រធម៌ពាក្យទូលអង្វរនេះ "គ្រប់ពេលវេលា" ដ្បិតពេលនោះ យើងរស់តែស្រឡាញ់ព្រះជាម្ចាស់ ដែលជាអ្នកប្រែកិច្ចការណាមួយក្នុងអង្គព្រះគ្រីស្ដយេស៊ូ។

២៦៦៩-ព្រះសហគមន៍អធិដ្ឋានដោយគោរពព្រះបេះដូងរបស់ព្រះយេស៊ូ ដូចព្រះសហគមន៍ទូលអង្វរព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គដែរ។ ព្រះសហគមន៍ថ្វាយបង្គំព្រះបន្ទូលប្រសូតជាមនុស្ស និងព្រះបេះដូងរបស់ព្រះអង្គ ដែលអំពើបាបយើងបានចាក់ទម្លុះ ដោយសារសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះមនុស្សលោក។ គ្រីស្ដបរិស័ទចូលចិត្តដើរតាមព្រះសង្គ្រោះ នៅលើផ្លូវឈើឆ្កាង តាមដំណាក់កាលនីមួយៗពីការកាត់ក្ដីព្រះយេស៊ូដល់ការបញ្ចុះសពព្រះអង្គ។ ព្រះអង្គបានសង្គ្រោះមនុស្សលោកដោយសារព្រះឈើឆ្កាងដ៏វិសុទ្ធរបស់ព្រះអង្គ។

## "ឱព្រះវិញ្ញាណដ៏វិសុទ្ធ សូមយាងមក"

២៦៧០-"បើគ្មានព្រះវិញ្ញាណដ៏វិសុទ្ធណែនាំទេនោះ ក៏គ្មាននរណាម្នាក់អាចពោលថា "ព្រះយេស៊ូជាព្រះអម្ចាស់" បានទេ" (១ករ ១២,៣)។ រាល់ពេលយើងអធិដ្ឋានព្រះយេស៊ូ ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលមានព្រះហឫទ័យប្រណីសន្ដោសយាងមកជួយណែនាំ ទាក់ទាញយើងនៅលើផ្លូវនៃការអធិដ្ឋាន។ ដោយសារព្រះអង្គបង្រៀនយើងឲ្យចេះអធិដ្ឋានដោយរំឭកយើងអំពីព្រះគ្រីស្ដ ហេតុអ្វីបានជាយើងមិនអធិដ្ឋានចំពោះព្រះអង្គផ្ទាល់? ហេតុនេះ ព្រះសហគមន៍អញ្ជើញយើងឲ្យអធិដ្ឋានព្រះវិញ្ញាណដ៏វិសុទ្ធជារៀងរាល់ថ្ងៃ ជាពិសេសពេលចាប់ផ្ដើម និងបង្ហើយកិច្ចការសំខាន់ណាមួយ។

បើយើងមិនថ្វាយបង្គំព្រះវិញ្ញាណ តើព្រះអង្គប្រោសខ្ញុំឲ្យទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ក្នុងពិធីជ្រមុជទឹកយ៉ាងដូចម្ដេច? បើយើងថ្វាយបង្គំព្រះអង្គ ហេតុអ្វីបានជាយើងមិនគោរពព្រះអង្គដាក់ដោយឡែកពីព្រះបិតា និងពីព្រះបុត្រាផង? (សន្ដ: គ្រេគ្រ័រ នៃណាស៊ីអង់)។

២៦៧១-ជាធម្មតា យើងទូលអង្វរព្រះវិញ្ញាណ ដោយទូលអង្វរព្រះបិតា តាមរយៈព្រះគ្រីស្ដជាព្រះអម្ចាស់នៃយើង ដើម្បីឲ្យព្រះអង្គប្រោសប្រទានព្រះវិញ្ញាណដែលជួយលួងលោម (លក ១១,១៣)។ ព្រះយេស៊ូទទូចសូមឲ្យយើងអធិដ្ឋានក្នុងព្រះនាមព្រះអង្គ នៅពេលដែលព្រះអង្គមានព្រះបន្ទូលសន្យានឹងប្រទានព្រះវិញ្ញាណនៃសេចក្ដីពិត (យហ ១៤,១៧; ១៥,២៦; ១៦,១៣)។ ប៉ុន្ដែ សេចក្ដីអធិដ្ឋានដ៏សាមញ្ញមកពីទំនៀមទម្លាប់បុរាណ "ឱព្រះវិញ្ញាណដ៏វិសុទ្ធ សូមយាងមក" ហើយប្រពៃណីខាងពិធីបុណ្យនីមួយៗបានអភិវឌ្ឍពាក្យអង្វរនេះក្នុងបទចម្រៀង៖

> ឱព្រះវិញ្ញាណដ៏វិសុទ្ធ សូមយាងមកបំពេញចិត្តគ្រីស្ដបរិស័ទ ហើយសូមបង្កាត់ភ្លើងនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គផង (បុណ្យព្រះវិញ្ញាណយាងមក)។
>
> ព្រះមហាក្សត្រនៃស្ថានបរមសុខ ព្រះវិញ្ញាណដែលជួយលួងលោម ព្រះវិញ្ញាណនៃសេចក្ដីពិត ដែលគង់នៅគ្រប់កន្លែង និងបំពេញអ្វីៗទាំងអស់ ជាកំណប់នៃអំពើល្អគ្រប់យ៉ាង និងប្រភពនៃជីវិត សូមយាងមកតាំងទីលំនៅក្នុងចិត្តយើងខ្ញុំ។ ឱព្រះដ៏សប្បុរសអើយ! សូមបន្សុទ្ធយើងខ្ញុំ ហើយសូមសង្គ្រោះយើងខ្ញុំផង (ពិធីបុណ្យខាងបូព៌ាប្រទេស)។

២៦៧២-ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលអភិសេកខ្លួនយើងទាំងស្រុង ជាម្ចាស់ខាងក្នុងនៃការអធិដ្ឋានរបស់គ្រីស្ដ

សាសនា។ ព្រះអង្គជាសិប្បករនៃការបញ្ជូនបន្តដ៏រស់រវើកនៃការអធិដ្ឋាន។ ទោះបីមានរបៀបអធិដ្ឋាន និងអ្នកអធិដ្ឋានច្រើនផ្សេងពីគ្នាយ៉ាងក៏ដោយ ក៏មានព្រះវិញ្ញាណតែមួយដែលយាងមកគង់នៅជាមួយអ្នកអធិដ្ឋាននីមួយៗ និងជាមួយមនុស្សទាំងអស់ផងដែរ។ គ្រីស្តបរិស័ទអធិដ្ឋានរួមគ្នាក្នុងព្រះសហគមន៍ដោយរួមរស់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។

## យើងរួមរស់ជាមួយព្រះមាតាដ៏វិសុទ្ធរបស់ព្រះជាម្ចាស់

២៦៧៣-ពេលអធិដ្ឋាន ព្រះវិញ្ញាណដ៏វិសុទ្ធបង្រួបបង្រួមយើងជាមួយព្រះបុត្រាតែមួយ ក្នុងភាពជាមនុស្សរបស់ព្រះអង្គពោរពេញដោយសិរីរុងរឿង។ តាមរយៈភាពជាមនុស្ស និងក្នុងភាពជាមនុស្សនេះ យើងអធិដ្ឋានក្នុងព្រះសហគមន៍រួមជាមួយព្រះមាតារបស់ព្រះយេស៊ូ (កក ១,១៤)។

២៦៧៤-តាំងពីពេលព្រះនាងម៉ារីបានយល់ព្រមគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺតាំងពីពេលទេវទូតជូនដំណឹងអំពីព្រះយេស៊ូ រហូតដល់ព្រះអង្គត្រូវគេឆ្កាង ព្រះនាងម៉ារីទៅជាមាតារបស់បងប្អូននៃព្រះបុត្រាព្រះនាង "ដែលមិនទាន់បង្ហើយបូជនិយេសចរណ៍នៅលើផែនដីនេះនៅឡើយ ហើយដែលប្រឈមមុខនឹងគ្រោះកាច និងទុក្ខលំបាកផ្សេងៗជាច្រើន" (LG ៦២)។ ព្រះយេស៊ូជាស្ពានមេត្រីតែមួយ ជាផ្លូវនៃការអធិដ្ឋានរបស់យើង ព្រះនាងម៉ារីជាព្រះមាតារបស់ព្រះអង្គ និងមាតារបស់យើង ឆ្លុះបញ្ចាំងព្រះអង្គ គឺព្រះនាង "បង្ហាញផ្លូវ" (Hodoghitria) ហើយតាមប្រពៃណីខាងបស្ចិម និងបូព៌ាប្រទេស ព្រះនាងជាសញ្ញាសម្គាល់របស់ព្រះអង្គ។

២៦៧៥-ដោយព្រះនាងម៉ារីរួមសហការយ៉ាងពិសេសជាមួយកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះសហគមន៍បានអភិវឌ្ឍការអធិដ្ឋានចំពោះព្រះមាតាដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ដោយសំដៅការអធិដ្ឋាននោះទៅលើព្រះគ្រីស្តដែលព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះអង្គសម្តែងព្រះអង្គ។ ក្នុងបទចម្រៀងរាប់មិនអស់ដែលសម្តែងនូវការអធិដ្ឋាននេះចលនាពីរឆ្លាស់គ្នា គឺមួយ "លើកតម្កើង" ព្រះអម្ចាស់សម្រាប់ "កិច្ចការដ៏អស្ចារ្យ" ដែលព្រះអង្គបានប្រព្រឹត្តចំពោះអ្នកបម្រើដ៏សុភាពរាបសាររបស់ព្រះអង្គ និងចំពោះមនុស្សលោកទាំងអស់ តាមរយៈនាង ហើយមួយទៀត ប្រគល់ឲ្យព្រះមាតារបស់ព្រះយេស៊ូ នូវពាក្យទូលអង្វរ និងពាក្យសរសើរនៃបុត្រធីតារបស់ព្រះជាម្ចាស់ ដ្បិតឥឡូវនេះព្រះនាងស្គាល់ភាពជាមនុស្ស ដែលព្រះបុត្រារបស់ព្រះជាម្ចាស់យកមកធ្វើជាមហេសី។

២៦៧៦-ចលនាទាំងពីរនៃការអធិដ្ឋានចំពោះព្រះនាងម៉ារីនោះ មានក្នុងសេចក្តីអធិដ្ឋាន "Ave Maria" (អាវេ ម៉ារីយ៉ា ឬបពិត្រព្រះនាងម៉ារី)៖

> "បពិត្រព្រះនាងម៉ារី (សូមព្រះនាងមានអំណរសប្បាយ)"៖ ការអធិដ្ឋានចំពោះព្រះនាងម៉ារីចាប់ផ្តើមដោយមានទេវទូតកាព្រីអែលជម្រាបសួរព្រះនាងម៉ារី ពោលគឺតាមរយៈទេវទូតរបស់ព្រះអង្គ ព្រះជាម្ចាស់ផ្ទាល់ជម្រាបសួរព្រះនាងម៉ារី។ សេចក្តីអធិដ្ឋានយើងហ៊ានយកពាក្យនេះឡើងវិញ ដោយមើលឃើញព្រះនាងម៉ារីដូចព្រះជាម្ចាស់បានទតមើលអ្នកបម្រើដ៏សុភាពរបស់ព្រះអង្គ និងដោយចិត្តរីករាយ ដូចព្រះជាម្ចាស់ត្រេកសប្បាយដោយសារព្រះនាងដែរ (លក ១,៤៨)។
>
> "ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ ព្រះអង្គគង់ជាមួយនាង"៖ ពាក្យទាំងពីររបស់ទេវទូតបំភ្លឺគ្នាទៅវិញទៅមក។ ព្រះនាងម៉ារីពោរពេញដោយព្រះហឫទ័យប្រណីសន្តោស ដ្បិតព្រះអម្ចាស់គង់ជាមួយព្រះនាង។ ព្រះជាម្ចាស់ប្រោសប្រណីព្រះនាង គឺព្រះអង្គជាប្រភពនៃសេចក្តីសុខសាន្តគ្រប់យ៉ាង គង់នៅជាមួយព្រះនាង។ "ក្រុងស៊ីយ៉ូនអើយ! ចូរបន្លឺសម្លេងដោយអំណរទៅ! (...) ព្រះអម្ចាស់ជាព្រះរបស់អ្នក ទ្រង់យាងមកគង់ជាមួយអ្នកហើយ" (សផ ៣,១៤.១៧ក)។ ព្រះនាងម៉ារី ដែលមានព្រះអម្ចាស់ផ្ទាល់តាំងទីលំនៅក្នុងខ្លួន

ព្រះនាង ជាតំណាងនៃទីក្រុងស៊ីយ៉ូន ស្ថាននៃសម្ព័ន្ធមេត្រី កន្លែងដែលសិរីរុងរឿងរបស់ព្រះអម្ចាស់ស្ថិតនៅព្រះនាងជា "ព្រះដំណាក់របស់ព្រះជាម្ចាស់ក្នុងចំណោមមនុស្សលោក" (វវ ២១,៣)។ ព្រះនាងម៉ារីជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រះនាងក៏ថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គដែលយាងមកគង់នៅក្នុងខ្លួនព្រះនាង ហើយដែលព្រះនាងនឹងផ្ដល់ដល់មនុស្សលោក។

"ព្រះអង្គបានប្រទានពរដល់ព្រះនាងលើសស្ត្រីទាំងឡាយ ហើយទ្រង់ក៏ប្រទានពរដល់បុត្រព្រះនាងដែរ"៖ ក្រោយពីពាក្យជម្រាបសួររបស់ទេវទូត សូមឲ្យយើងយកពាក្យជម្រាបសួររបស់នាងអេលីសាបិត។ "ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ" (លក ១,៤១) នាងអេលីសាបិតជាម្នាក់មុនគេ ក្នុងចំណោមអ្នកប្រកាសតៗគ្នាថា ព្រះនាងម៉ារីពោរពេញដោយសុភមង្គល (លក ១,៤៨)៖ "នាងពិតជាមានសុភមង្គលមែន" (លក ១,៤៥)។ ព្រះជាម្ចាស់ប្រទានពរដល់ព្រះនាងម៉ារី "លើសស្ត្រីទាំងឡាយ" ដ្បិតព្រះនាងបានជឿថា ព្រះបន្ទូលរបស់ព្រះអម្ចាស់នឹងកើតជារូបរាង។ ដោយសារជំនឿរបស់លោក លោកអប្រាហាំបានក្លាយទៅជាពរសម្រាប់ "ប្រជាជាតិទាំងឡាយ" (កណ ១២,៣)។ ដោយសារជំនឿរបស់ព្រះនាង ព្រះនាងម៉ារីបានក្លាយទៅជាមាតារបស់អ្នកជឿ ដោយសារព្រះនាង ប្រជាជាតិទាំងឡាយទទួលព្រះអង្គដែលជាព្រះពរផ្ទាល់របស់ព្រះជាម្ចាស់៖ "ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះព្រះនាង"។

២៦៧៧-"ឱសន្ដី ម៉ារី ជាមាតានៃព្រះអម្ចាស់ សូមជួយទូលអង្វរព្រះអង្គឲ្យយើងខ្ញុំផង"៖ យើងត្រេកអរសប្បាយរួមជាមួយនាងអេលីសាបិត៖ "តើរូបខ្ញុំមានឋានៈអ្វី បានជាមាតានៃព្រះអម្ចាស់របស់ខ្ញុំ មកសួរសុខទុក្ខខ្ញុំដូច្នេះ?" (លក ១,៤៣)។ ដោយសារព្រះនាងផ្ដល់ព្រះយេស៊ូជាបុត្ររបស់ព្រះនាងមកយើង ព្រះនាងម៉ារីជាព្រះមាតារបស់ព្រះជាម្ចាស់ និងជាមាតារបស់យើងផង។ យើងអាចប្រគល់កង្វល់ និងសំណូមពរទាំងអស់របស់យើងឲ្យព្រះនាង។ ព្រះនាងអធិដ្ឋានសម្រាប់យើង ដូចព្រះនាងបានអធិដ្ឋានសម្រាប់ខ្លួនព្រះនាងដែរ៖ "សូមឲ្យបានសម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គចុះ" (លក ១,៣៨)។ ដោយពឹងលើការអធិដ្ឋានរបស់ព្រះនាង យើងថ្វាយខ្លួនទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ រួមជាមួយព្រះនាងផងដែរ៖ "សូមឲ្យព្រះហឫទ័យព្រះអង្គបានសម្រេច"។

"សូមទូលអង្វរព្រះអង្គឲ្យយើងខ្ញុំជាអ្នកបាប ពេលនេះ និងនៅពេលស្លាប់"៖ ដោយសូមឲ្យព្រះនាងម៉ារីជួយអង្វរសម្រាប់យើង យើងទទួលស្គាល់ថា យើងជាអ្នកបាប ហើយយើងសូមទូលអង្វរ "មាតានៃសេចក្ដីមេត្តាករុណា" ដ៏វិសុទ្ធបំផុត។ យើងថ្វាយខ្លួនចំពោះព្រះនាង "ឥឡូវនេះ" នៅថ្ងៃនេះ ហើយយើងពង្រឹងទំនុកចិត្តចំពោះព្រះនាងរហូតដល់ "ពេលស្លាប់"។ សូមឲ្យព្រះនាងមកជិតយើង ដូចកាលព្រះនាងនៅជាមួយព្រះបុត្រាព្រះនាង នៅពេលព្រះអង្គត្រូវគេឆ្កាង ហើយនៅពេលយើងនឹងឆ្លងពីលោកនេះទៅបរមលោក សូមឲ្យព្រះនាងទទួលយើងដូចមាតាយើង (យហ ១៩,២៧) ដើម្បីណែនាំយើងទៅគាល់ព្រះបុត្រាព្រះនាង គឺព្រះយេស៊ូនៅស្ថានបរមសុខផង។

២៦៧៨-នៅបស្ចិមប្រទេស មជ្ឈិមសម័យបានអភិវឌ្ឍការអធិដ្ឋានដោយសូត្រផ្គុំជំនួសពិធីតាមពេលកំណត់។ នៅបូព៌ាប្រទេស របៀបសូត្រនៃអាកាធីស្ដ និងប៉ារ៉ាក្លីស៊ីស នៅតែជិតស្និទ្ធជាមួយនឹងពិធីបទចម្រៀងនៃព្រះសហគមន៍បីសង់ទីន ឯប្រពៃណីនៃព្រះសហគមន៍អារមេនីន កូប និងស៊ីរីយ៉ាកវិញ ពួកគេចូលចិត្តបទចម្រៀងប្រជាប្រិយចំពោះព្រះមាតារបស់ព្រះជាម្ចាស់។ ប៉ុន្តែ ក្នុងអាវេ ម៉ារីយ៉ា ថេអូតូគីយ៉ា គឺបទចម្រៀងរបស់សន្តៈ អេប្រ្រែម ឬរបស់សន្តៈ គ្រេគ័រ នៃណារ៉ែក គ្រឹះរបស់ប្រពៃណីនៃការអធិដ្ឋាននៅតែដដែល។

២៦៧៩-ព្រះនាងម៉ារីជាអ្នកអធិដ្ឋានដ៏គ្រប់លក្ខណៈ ជារូបតំណាងរបស់ព្រះសហគមន៍។ ពេលយើងទូលអង្វរព្រះនាង យើងជាប់ជាមួយព្រះនាងក្នុងគម្រោងការរបស់ព្រះបិតា ដែលចាត់ព្រះបុត្រាព្រះអង្គឲ្យយាងមកសង្គ្រោះ

មនុស្សលោកទាំងអស់។ យើងទទួលព្រះមាតារបស់ព្រះយេស៊ូ ដែលជាមាតារបស់អស់អ្នកដែលមានជីវិត នៅផ្ទះយើង ដូចសាវ័កដែលព្រះយេស៊ូស្រឡាញ់ (យហ ១៩,២៧)។ យើងអាចអធិដ្ឋានរួមជាមួយព្រះនាងម៉ារី និងអធិដ្ឋានព្រះនាងផងដែរ។ ការអធិដ្ឋានរបស់ព្រះនាងម៉ារីជួយគាំទ្រការអធិដ្ឋានរបស់ព្រះសហគមន៍ ដែលរួមជាមួយព្រះនាងម៉ារីក្នុងសេចក្តីសង្ឃឹម (LG ៦៨-៦៩)។

## សង្ខេប

២៦៨០-ជាធម្មតា យើងទូលអង្វរព្រះបិតា។ យ៉ាងណាមិញ យើងអាចទូលអង្វរព្រះយេស៊ូ ជាពិសេសដោយអង្វរព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ៖ "ឱព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ ឱព្រះអម្ចាស់អើយ! សូមអាណិតអាសូរយើងខ្ញុំផង!"។

២៦៨១-"បើគ្មានព្រះវិញ្ញាណដ៏វិសុទ្ធណែនាំទេនោះ គ្មាននរណាម្នាក់អាចពោលថា៖ "ព្រះយេស៊ូជាព្រះអម្ចាស់" បានដែរ (១ករ ១២,៣)។ ព្រះសហគមន៍អញ្ជើញយើងឲ្យអង្វរព្រះវិញ្ញាណដ៏វិសុទ្ធដូចជាម្ចាស់ខាងក្នុងនៃការអធិដ្ឋានតាមគ្រីស្តសាសនា។

២៦៨២-ដោយសារព្រះសហគមន៍រួមសហការយ៉ាងពិសេស ជាមួយនឹងកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះសហគមន៍ចូលចិត្តអធិដ្ឋានជាមួយព្រហ្មចារិនីម៉ារី ដើម្បីកោតសរសើរព្រឹត្តិការណ៍ដ៏អស្ចារ្យដែលព្រះជាម្ចាស់បានប្រព្រឹត្តក្នុងខ្លួនព្រះនាង ហើយដើម្បីប្រគល់ពាក្យអង្វរ និងពាក្យសរសើរទៅព្រះអង្គ រួមជាមួយព្រះនាងផងដែរ។

# ប្រការទី៣៖

# អ្នកណែនាំអធិដ្ឋាន

## សាក្សីរាប់មិនអស់

២៦៨៣-មនុស្សជាច្រើនធ្វើជាបន្ទាល់បានចូលក្នុងព្រះរាជ្យមុនយើង (ហប ១២,១) ជាពិសេសអស់អ្នកដែលព្រះសហគមន៍ទទួលស្គាល់ថា ជា "សន្តបុគ្គល" ដែលបានចូលរួមចំណែកក្នុងការបញ្ជូនបន្តដ៏រស់រវើកនៃការអធិដ្ឋានដែលជាគំរូក្នុងការរស់នៅរបស់គេ ដោយបានសរសេរសេចក្តីអធិដ្ឋានជាច្រើនទុកឲ្យយើង និងដែលមាននៅរហូតដល់សព្វថ្ងៃនេះ។ ពួកគាត់មើលឃើញព្រះជាម្ចាស់ សរសើរលើកតម្កើងព្រះអង្គ ហើយនៅតែបីបាច់ថែរក្សាអស់អ្នកដែលរស់នៅលើផែនដីនៅឡើយ។ ដោយបាន "ចូលមកសប្បាយរួមជាមួយ" ម្ចាស់របស់ពួកគាត់ ម្ចាស់នេះបាន "តាំងពួកគាត់ឲ្យមើលខុសត្រូវលើកិច្ចការធំៗ" (មថ ២៥,២១)។ ដោយសារពួកគាត់ជួយអង្វរព្រះជាម្ចាស់សម្រាប់យើង ពួកគាត់ក៏បម្រើគម្រោងការរបស់ព្រះអង្គ។ យើងអាច ហើយយើងត្រូវសូមឲ្យពួកគាត់ជួយទូលអង្វរព្រះជាម្ចាស់សម្រាប់យើង និងសម្រាប់ពិភពលោកទាំងមូលផង។

២៦៨៤-ចំណេះវិជ្ជាខាងវិញ្ញាណ ជាច្រើនបានអភិវឌ្ឍក្នុងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ក្នុងអំឡុងប្រវត្តិសាស្ត្រព្រះសហគមន៍។ ព្រះអំណោយទានផ្ទាល់របស់សាក្សីម្នាក់នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក បានត្រូវគេបញ្ជូន ដូចជា "វិញ្ញាណ" របស់លោកអេលីចំពោះលោកអេលីសេ (២ពង្ស ២,៩) និងចំពោះលោកយ៉ូហានបាទីស្ត (លក ១,១៧) ដើម្បីឲ្យសាវ័កខ្លះ អាចទទួលវិញ្ញាណនោះបានដែរ (PC ២)។ ចំណេះវិជ្ជាខាងវិញ្ញាណស្ថិតនៅក្នុងចលនាផ្សេងៗ ខាងពិធីបុណ្យ និងខាងទេវវិទ្យា ហើយផ្តល់សក្ខីភាពថា ជំនឿបានសម

ស្របនឹងវប្បធម៌ និងប្រវត្តិសាស្ត្រនៃសង្គមនីមួយៗ។ ចំណេះវិជ្ជាខាងវិញ្ញាណនៃគ្រីស្តសាសនាចូលរួមចំណែកក្នុងការបញ្ជូនបន្តដ៏រស់រវើកនៃការអធិដ្ឋាន ហើយពិតជាជួយណែនាំគ្រីស្តបរិស័ទមែន។ ដោយមានចំណេះវិជ្ជាច្រើនផ្សេងៗពីគ្នា ចំណេះវិជ្ជាទាំងអស់នោះឆ្លុះបញ្ចាំងនូវពន្លឺបរិសុទ្ធតែមួយនៃព្រះវិញ្ញាណដ៏វិសុទ្ធ។

"ព្រះវិញ្ញាណពិតជាទីលំនៅនៃសន្តបុគ្គល ហើយសន្តបុគ្គលម្នាក់ជាព្រះដំណាក់ផ្ទាល់នៃព្រះវិញ្ញាណ ដ្បិតព្រះអង្គស្នាក់នៅជាមួយព្រះជាម្ចាស់ ហើយគេហៅព្រះវិញ្ញាណនេះថា ជាព្រះវិហាររបស់ព្រះអង្គ" (សន្តៈ បាសីល)។

## អ្នកបម្រើនៃការអធិដ្ឋាន

២៦៨៥-ក្រុមគ្រួសារគ្រីស្តបរិស័ទ ជាកន្លែងដំបូង ដើម្បីជួយអប់រំឲ្យចេះអធិដ្ឋាន។ ដោយចាក់ឫសលើអគ្គសញ្ញាអាពាហ៍ពិពាហ៍ ក្រុមគ្រួសារនេះ ជា "ព្រះសហគមន៍នៅផ្ទះ" ដែលបុត្រធីតារបស់ព្រះជាម្ចាស់រៀនអធិដ្ឋាន "រួមជាមួយព្រះសហគមន៍" ហើយរៀនមានចិត្តព្យាយាមក្នុងការអធិដ្ឋាន។ ជាពិសេសក្មេងៗ ការអធិដ្ឋានប្រចាំថ្ងៃក្នុងក្រុមគ្រួសារ ផ្តល់សក្ខីភាពមុនគេបង្អស់នៃការចងចាំដ៏រស់រវើករបស់ព្រះសហគមន៍ ដែលព្រះវិញ្ញាណដ៏វិសុទ្ធបានរៀបចំបន្តិចម្តងៗ។

២៦៨៦-អ្នកទទួលមុខងារបម្រើព្រះសហគមន៍ ជាអ្នកទទួលខុសត្រូវក្នុងការអប់រំបងប្អូនរបស់គេក្នុងអង្គព្រះគ្រីស្តឲ្យចេះអធិដ្ឋានផងដែរ។ ពួកគេជាអ្នកបម្រើរបស់គង្វាលដ៏ល្អ ត្រូវបានតែងតាំងដើម្បីណែនាំប្រជាជនរបស់ព្រះជាម្ចាស់ឲ្យទៅរកប្រភពដ៏រស់រវើកនៃការអធិដ្ឋាន គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពិធីបុណ្យ ការរស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងការអនុវត្តដំណឹងល្អគ្រប់កាលៈទេសៈនៃជីវិតប្រចាំថ្ងៃ (PO ៤-៦)។

២៦៨៧-បព្វជិតជាច្រើនបានបូជាជីវិតទាំងស្រុងចំពោះការអធិដ្ឋាន។ តាំងពីវាលរហោស្ថាននៃប្រទេសអេស៊ីបមានឥសី និងលោកសង្ឃ ទាំងបុរស ទាំងស្ត្រី បានចំណាយពេលវេលា ដើម្បីកោតសរសើរព្រះជាម្ចាស់ និងជួយអង្វរព្រះអង្គដើម្បីប្រជាជនរបស់ព្រះអង្គ។ បើគេមិនអធិដ្ឋានទេ អ្នកថ្វាយខ្លួនចំពោះព្រះជាម្ចាស់ មិនអាចឈានទៅមុខ ឬរីកចម្រើនបានឡើយ។ ការអធិដ្ឋានជាប្រភពដ៏រស់រវើកនៃការស្មឹងស្មាធិ៍ និងជីវិតខាងវិញ្ញាណរបស់ព្រះសហគមន៍។

២៦៨៨-ពេលយើងអប់រំជំនឿ ក្មេងៗ យុវជន និងមនុស្សពេញវ័យ យើងចង់ឲ្យគេត្រិះរិះគិតពិចារណាអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយអធិដ្ឋានរៀងៗខ្លួន ឲ្យគេយល់អំពីអត្ថន័យបច្ចុប្បន្ននៃព្រះបន្ទូលនេះក្នុងពិធីបុណ្យ ហើយឲ្យគេទុកព្រះបន្ទូលនេះនៅក្នុងដួងចិត្ត ដើម្បីបង្កើតផលក្នុងជីវិតថ្មី។ ពេលយើងអប់រំជំនឿ យើងអាចឆ្លៀតឱកាសឈ្វេងយល់អំពីរបៀបអធិដ្ឋាននៃប្រជាជនទូទៅ និងជួយអប់រំគេដែរ (CT ៥៤)។ យើងអាចបង្រៀនគេឲ្យចេះចាំរត់មាត់ធម៌អធិដ្ឋានសំខាន់ៗ ដើម្បីជួយឲ្យគេអធិដ្ឋាន ប៉ុន្តែ យើងក៏បង្រៀនអំពីអត្ថន័យនៃធម៌អធិដ្ឋាននោះផងដែរ (CT ៥៥)។

២៦៨៩-សព្វថ្ងៃ ក្រុមអធិដ្ឋាន ឬ "សាលារៀនអធិដ្ឋាន" ជាសញ្ញាសម្គាល់បង្ហាញថា ការអធិដ្ឋានកើតសាជាថ្មីឡើងវិញនៅក្នុងព្រះសហគមន៍ ហើយជំរុញឲ្យការអធិដ្ឋានរីកចម្រើនឡើង លុះត្រាតែយើងសំអាងលើប្រភពដ៏ពិតប្រាកដនៃការអធិដ្ឋានតាមគ្រីស្តសាសនា។ កង្វល់ក្នុងការរួបរួមជាធ្លុងមួយ គឺជាសញ្ញាសម្គាល់នៃការអធិដ្ឋានយ៉ាងពិតប្រាកដនៅក្នុងព្រះសហគមន៍។

២៦៩០-ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រទានឲ្យគ្រីស្តបរិស័ទខ្លះ នូវព្រះអំណោយទានដែលជាប្រាជ្ញា ជំនឿ ហើយនឹងឲ្យគេចេះរិះគិតពិចារណា ដើម្បីផលប្រយោជន៍រួម គឺការអធិដ្ឋាន (ការជួយណែនាំខាងវិញ្ញាណ)។ បុរសស្ត្រី

ទាំងនោះ ដែលបានទទួលព្រះអំណោយទាននេះ ជាអ្នកបម្រើដ៏ពិតប្រាកដនៃការបញ្ជូនបន្តដ៏រស់រវើកនៃការអធិដ្ឋាន៖

ហេតុដូច្នេះហើយបានជាសន្តៈ យ៉ូហាន នៃព្រះឈើឆ្កាង ណែនាំថា ព្រលឹងណាដែលចង់ឈានទៅមុខក្នុងភាពល្អឥតខ្ចោះ ត្រូវតែ "ចាត់ទុកយ៉ាងច្បាស់ថា តើព្រលឹងនេះត្រូវប្រគល់ខ្លួនទៅក្នុងដៃណា ដ្បិតម្ចាស់មានលក្ខណៈយ៉ាងណា សាវ័កក៏មានលក្ខណៈយ៉ាងនោះដែរ ឪពុកមានលក្ខណៈយ៉ាងណា កូនក៏មានលក្ខណៈយ៉ាងនោះដែរ"។ ម៉្យាងទៀត៖ "អ្នកណែនាំវិញ្ញាណមិនគ្រាន់តែត្រូវមានប្រាជ្ញា និងចេះប្រុងប្រយ័ត្នប៉ុណ្ណោះទេ តែត្រូវមានបទពិសោធន៍ផងដែរ (...)។ បើអ្នកណែនាំវិញ្ញាណគ្មានបទពិសោធន៍នៃជីវិតខាងវិញ្ញាណទេ គេមិនអាចណែនាំព្រលឹង ដែលព្រះជាម្ចាស់ត្រាស់ហៅបានទេ សូម្បីតែយល់អំពីព្រលឹងនោះក៏គេមិនយល់ផង"។

## កន្លែងល្អៗដើម្បីអធិដ្ឋាន

២៦៩១-ព្រះវិហារដែលជាព្រះដំណាក់របស់ព្រះជាម្ចាស់ ជាកន្លែងផ្ទាល់នៃការអធិដ្ឋានតាមពិធីបុណ្យសម្រាប់សហគមន៍តាមភូមិ។ ព្រះវិហារជាកន្លែងពិសេស ដើម្បីគោរពក្រាបថ្វាយបង្គំព្រះកាយព្រះគ្រីស្ត ជាវត្តមានដ៏ពិតប្រាកដរបស់ព្រះអង្គ។ របៀបអធិដ្ឋានអាស្រ័យទៅលើទីកន្លែងអធិដ្ឋាន៖

-ដើម្បីអាចអធិដ្ឋានតែម្នាក់ឯង យើងអាចរៀបចំ "កន្លែងអធិដ្ឋានដ៏តូចមួយ" ដោយមានព្រះគម្ពីរដ៏វិសុទ្ធ និងរូបភាពផ្សេងៗ ដើម្បីឲ្យ "នៅក្នុងទីស្ងាត់កំបាំង" រួមជាមួយព្រះបិតារបស់យើង (មថ ៦,៦)។ ក្នុងក្រុមគ្រួសារគ្រីស្តបរិស័ទ កន្លែងដ៏តូចមួយនេះ ជំរុញឲ្យអធិដ្ឋានរួមគ្នា។

-ក្នុងតំបន់ដែលមានអារាមកាតូលិក ព្រះជាម្ចាស់ត្រាស់ហៅលោកសង្ឃទាំងអស់នោះ ឲ្យអធិដ្ឋានតាមពេលកំណត់រួមជាមួយគ្រីស្តបរិស័ទធម្មតា ហើយជួយឲ្យម្នាក់ៗអធិដ្ឋានរៀងៗខ្លួនយ៉ាងជ្រាលជ្រៅបំផុត (**PC** ៧)។

-បូជនីយចរណ៍ធ្វើឲ្យនឹកគិតដល់ការធ្វើដំណើររបស់យើងនៅលើផែនដីឆ្ពោះទៅស្ថានបរមសុខ ដែលជាទំនៀមទម្លាប់ធ្វើឲ្យការអធិដ្ឋានកើតសាជាថ្មីឡើងវិញ។ ចំពោះបូជនីយសក៏ដែលស្វែងរកប្រភពដ៏រស់រវើកនៃកម្លាំងថ្មី បូជនីយដ្ឋានជាទីលំនៅដ៏អស្ចារ្យ ដើម្បីអធិដ្ឋាន "រួមជាមួយព្រះសហគមន៍"។

## សង្ខេប

២៦៩២-ក្នុងការអធិដ្ឋាន ព្រះសហគមន៍ដែលកំពុងធ្វើដំណើររួមសហការជាមួយការអធិដ្ឋានរបស់ជនដ៏វិសុទ្ធ។ ព្រះសហគមន៍សូមឲ្យពួកគាត់ជួយអង្វរព្រះអង្គ។

២៦៩៣-ចំណេះវិជ្ជាខាងវិញ្ញាណនៃគ្រីស្តសាសនាផ្សេងៗ រួមចំណែកក្នុងការបញ្ជូនបន្តដ៏រស់រវើកនៃការអធិដ្ឋាន ហើយពិតជាជួយដឹកនាំជីវិតខាងវិញ្ញាណមែន។

២៦៩៤-ក្រុមគ្រួសារគ្រីស្តបរិស័ទជាកន្លែងដំបូង ដើម្បីជួយអប់រំឲ្យចេះអធិដ្ឋាន។

២៦៩៥-អ្នកទទួលមុខងារបម្រើព្រះសហគមន៍ អ្នកថ្វាយខ្លួន ការអប់រំជំនឿ ក្រុមអធិដ្ឋាន "ការជួយណែនាំខាងវិញ្ញាណ" ជួយគាំទ្រការអធិដ្ឋានក្នុងព្រះសហគមន៍។

២៦៩៦-ទីកន្លែងល្អៗដើម្បីអធិដ្ឋាន មានកន្លែងអធិដ្ឋានផ្ទាល់ខ្លួន ឬសម្រាប់ក្រុមគ្រួសារ អារាមបូជនីយដ្ឋាន ហើយជាពិសេសព្រះវិហារ ដែលជាកន្លែងពិសេស ដើម្បីអធិដ្ឋានខាងពិធីបុណ្យ សម្រាប់សហគមន៍គ្រីស្តបរិស័ទ និងជាកន្លែងពិសេស ដើម្បីក្រាបថ្វាយបង្គំ។

# ជំពូកទីបី៖

# ជីវិតនៃការអធិដ្ឋាន

២៦៩៧-អ្នកអធិដ្ឋានមានជីវិតថ្មី។ ត្រូវតែអធិដ្ឋានគ្រប់ពេលវេលា។ ប៉ុន្តែ យើងភ្លេចអ្នកដែលជាជីវិតរបស់យើង និងជាអ្វីៗទាំងអស់ចំពោះយើង។ ហេតុនេះ តាមប្រពៃណីនៃទុតិយកថា និងពួកព្យាការី គ្រូបាធ្យាយខាងវិញ្ញាណ សង្កត់ធ្ងន់លើការអធិដ្ឋានដូចជា "ការនឹករឭកទៅដល់ព្រះជាម្ចាស់" ដាស់តឿនឲ្យ "ចងចាំព្រះអង្គជានិច្ច ក្នុងដួងចិត្តយើង"៖ "យើងត្រូវតែនឹកគិតដល់ព្រះជាម្ចាស់ច្រើនជាងយើងដកដង្ហើមទៅទៀត" (សន្តៈ គ្រេគ័រ នៃណាស៊ីអង់)។ ប៉ុន្តែ យើងមិនអាចអធិដ្ឋាន "គ្រប់ពេលវេលា" ទេ បើយើងមិនអធិដ្ឋានទៅតាមពេលកំណត់ខ្លះ គឺជាពេលដ៏ល្អនៃការអធិដ្ឋាន។

២៦៩៨-ការបញ្ញត្តនៃព្រះសហគមន៍ស្នើសុំឲ្យគ្រីស្តបរិស័ទអធិដ្ឋានតាមពេលកំណត់ ដើម្បីឲ្យបានអធិដ្ឋានជាប្រចាំ។ កាលកំណត់ជារៀងរាល់ថ្ងៃ គឺអធិដ្ឋានពេលព្រឹក និងពេលល្ងាច មុន និងក្រោយពិសារបាយទៅតាមរយៈពេលកំណត់ទុក។ ជាពិសេស ត្រូវតែអធិដ្ឋាននៅថ្ងៃអាទិត្យ ដែលមានអភិបូជាជាស្នូល។ វគ្គនៃពិធីបុណ្យ និងបុណ្យធំៗផ្សេងៗជួយឲ្យគ្រីស្តបរិស័ទអធិដ្ឋានជារៀងរាល់ឆ្នាំ។

២៦៩៩-ព្រះអម្ចាស់ណែនាំមនុស្សគ្រប់រូបតាមផ្លូវ និងតាមរបៀបដែលគាប់ព្រះហឫទ័យព្រះអង្គ។ គ្រីស្តបរិស័ទម្នាក់ៗឆ្លើយតបនឹងព្រះអង្គតាមបេ្តជ្ញាចិត្ត និងដោយអធិដ្ឋានតាមរបៀបរៀងៗខ្លួន។ ក៏ប៉ុន្តែ ការបញ្ញត្តនៃព្រះសហគមន៍បានទុករបៀបបីយ៉ាង ដើម្បីអធិដ្ឋាន គឺអធិដ្ឋានតាមពាក្យសម្តី ការស្មឹងស្មាធិ៍ និងការធ្វើសមាធិ។ របៀបអធិដ្ឋានទាំងបីនោះ មានលក្ខណៈរួម គឺការសម្រឹងទ្រឹងគិត។ ដោយពេលអធិដ្ឋានតាមរបៀបទាំងបីនោះ យើងប្រុងស្មារតីរក្សាទុកនូវព្រះបន្ទូល និងស្ថិតនៅជាប់នឹងព្រះជាម្ចាស់ យើងក៏ទទួលបានផលល្អៗ។

## ប្រការទី១៖

## របៀបអធិដ្ឋាន

### ១-ការអធិដ្ឋានតាមពាក្យសម្តី

២៧០០-ដោយសារព្រះបន្ទូលរបស់ព្រះអង្គ ព្រះជាម្ចាស់ក៏មានព្រះបន្ទូលមកមនុស្ស។ ការអធិដ្ឋានរបស់យើងកើតជារូបរាង តាមរយៈពាក្យសម្តី ក្នុងដួងចិត្ត ឬដោយមាត់។ ប៉ុន្តែ សំខាន់ជាងគេ គឺឲ្យយើងចាប់អារម្មណ៍នឹងអ្នកដែលយើងនិយាយសន្ទនាជាមួយក្នុងការអធិដ្ឋាន។ "ព្រះជាម្ចាស់ទ្រង់ព្រះសណ្តាប់ពាក្យអង្វររបស់យើងមិនអាស្រ័យទៅលើពាក្យច្រើន ឬតិចទេ ប៉ុន្តែអាស្រ័យទៅលើការប្រឹងប្រែងរបស់យើង" (សន្តៈ យ៉ូហាន គ្រីសូស្តូម)។

២៧០១-ការអធិដ្ឋានតាមពាក្យសម្តីជាលក្ខណៈសំខាន់ៗនៃការរស់នៅជាគ្រីស្តបរិស័ទ។ ដោយសារក្រុមសាវ័កបានឃើញម្ចាស់របស់គេអធិដ្ឋាននៅស្ងៀមស្ងាត់ គេបានសុំឲ្យលោកបង្រៀនគេឲ្យចេះអធិដ្ឋាន។ ពេលនោះ ម្ចាស់បានបង្រៀនធម៌ឱព្រះបិតា ជាការអធិដ្ឋានតាមពាក្យសម្តី។ ព្រះយេស៊ូមិនគ្រាន់តែសូត្រធម៌ពិធីបុណ្យនៃធម្មសាលាទេ ដំណឹងល្អបង្ហាញឲ្យយើងដឹងថែមទៀតថា ពេលអធិដ្ឋាន ព្រះអង្គបន្លឺសម្លេង ពីពេលព្រះអង្គប្រទានពរលើកតម្កើងព្រះបិតាដោយត្រេកអរសប្បាយ (មថ ១១,២៥-២៦) រហូតដល់ពេលព្រះអង្គរងទុក្ខលំបាកនៅសួនកេតសេម៉ានី

ផងដែរ (មក ១៤,៣៦)។

២៧០២-តាមការពិត ធម្មជាតិរបស់មនុស្សយើងទាមទារឲ្យវិញ្ញាណស្របនឹងការអធិដ្ឋាននៅក្នុងដួងចិត្ត។ យើងជារូបកាយផង ជាវិញ្ញាណផង ហើយយើងត្រូវការបញ្ចេញអារម្មណ៍របស់យើងទៅខាងក្រៅ។ យើងត្រូវតែអធិដ្ឋានអស់ពីកម្លាំងកាយចិត្ត ដើម្បីឲ្យពាក្យអង្វររបស់យើងអាចមានប្រសិទ្ធភាព។

២៧០៣-ព្រះជាម្ចាស់ទាមទារឲ្យយើងអធិដ្ឋានតាមពាក្យសម្ដីដែរ។ ព្រះអង្គស្វែងរកអ្នកដែលថ្វាយបង្គំព្រះអង្គតាមវិញ្ញាណ និងតាមសេចក្ដីពិត ហេតុនេះ ត្រូវតែអធិដ្ឋានពីទីជម្រៅនៃព្រលឹង។ ព្រះអង្គមានព្រះហឫទ័យចង់ឲ្យរូបកាយ និងការអធិដ្ឋានខាងក្នុងដួងចិត្តស្របគ្នា ដ្បិតពេលយើងអធិដ្ឋានតាមបែបនេះ យើងថ្វាយអ្វីៗដែលជាទីគាប់ព្រះហឫទ័យដល់ព្រះអង្គ។

២៧០៤-ដោយសារការអធិដ្ឋានតាមពាក្យសម្ដីស្ថិតនៅខាងក្រៅចិត្ត ជាលក្ខណៈរបស់មនុស្សលោក ការអធិដ្ឋាននេះ ជាការអធិដ្ឋាននៃប្រជាជនទូទៅ ប៉ុន្តែ ទោះបីយើងអធិដ្ឋាននៅខាងក្នុងដួងចិត្តក៏ដោយ ក៏យើងមិនត្រូវបំភ្លេចការអធិដ្ឋានតាមពាក្យសម្ដីដែរ។ យើងចាប់ផ្ដើមអធិដ្ឋាននៅក្នុងចិត្ត លុះត្រាតែយើងដឹងខ្លួនថា យើងសន្ទនាជាមួយព្រះជាម្ចាស់ (សន្តី ថេរេសា នៃព្រះកុមារយេស៊ូ)។ ពេលនោះ ការអធិដ្ឋានតាមពាក្យសម្ដីក៏ក្លាយទៅជារបៀបដំបូងនៃការស្មឹងស្មាធិ៍។

## ២-ការស្មឹងស្មាធិ៍

២៧០៥-ពេលយើងស្មឹងស្មាធិ៍ គឺយើងស្វែងរក។ វិញ្ញាណចង់ឈ្វេងយល់អំពីមូលហេតុ និងរបៀបរស់នៅជាគ្រីស្តបរិស័ទ ដើម្បីភ្ជាប់នឹងព្រះជាម្ចាស់ និងគាប់ព្រះហឫទ័យព្រះអង្គ។ ត្រូវតែប្រុងស្មារតី ប៉ុន្តែ យើងពិបាកគ្រប់គ្រងខ្លួនឯង។ ធម្មតាយើងជួយខ្លួនឯង ដោយអានសៀវភៅ ហើយគ្រីស្តបរិស័ទមានសៀវភៅជាច្រើនមែនដូចជា៖ ព្រះគម្ពីរដ៏វិសុទ្ធ ជាពិសេសដំណឹងល្អ រូបភាពដ៏វិសុទ្ធ អត្ថបទព្រះគម្ពីរប្រចាំថ្ងៃ ឬអត្ថបទពេលកំណត់សៀវភៅនៃគ្រូបាធ្យាយ សៀវភៅនៃចំណេះវិជ្ជាខាងវិញ្ញាណ "សៀវភៅ" ដ៏ប្រសើរនៃពិភពលោក និងប្រវត្តិសាស្ត្រ "ទំព័រ" នៃជីវិតប្រចាំថ្ងៃ។

២៧០៦-ពេលយើងស្មឹងស្មាធិ៍ទៅដល់អ្វីដែលយើងអាន យើងទទួលយកសេចក្ដីនោះ ដោយប្រៀបធៀបនឹងខ្លួនឯង។ ពេលនោះ យើងបើកសៀវភៅផ្សេងទៀត គឺសៀវភៅនៃជីវិត។ យើងឆ្លងពីគំនិតដល់ជីវិតពិតប្រាកដ។ ដោយមានចិត្តសុភាពរាបសា និងដោយមានជំនឿ យើងរកឃើញចលនា ដែលរំជើបរំជួលចិត្ត ហើយយើងអាចរិះគិតពិចារណាអំពីចលនានោះ។ ត្រូវតែដឹងអំពីសេចក្ដីពិត ដើម្បីឈានទៅដល់ពន្លឺ៖ "ឱព្រះអម្ចាស់អើយ! តើព្រះអង្គសព្វព្រះហឫទ័យឲ្យខ្ញុំធ្វើអ្វី?"។

២៧០៧-អ្នកណែនាំខាងវិញ្ញាណមានច្រើនផ្សេងៗពីគ្នាយ៉ាងណា របៀបស្មឹងស្មាធិ៍ក៏មានច្រើនផ្សេងៗពីគ្នាយ៉ាងនោះដែរ។ ប្រសិនបើគ្រីស្តបរិស័ទម្នាក់មិនឧស្សាហ៍ស្មឹងស្មាធិ៍ទេ គេដូចជាដីទាំងបីដំបូងនៃពាក្យប្រស្នាអំពីអ្នកសាបព្រោះ (មក ៤,៤-៧.១៥-១៩)។ ប៉ុន្តែ របៀបមួយគ្រាន់តែដូចជាអ្នកណែនាំម្នាក់ អ្វីដែលសំខាន់ គឺទៅមុខ រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ នៅលើផ្លូវតែមួយនៃការអធិដ្ឋាន គឺព្រះគ្រីស្តយេស៊ូ។

២៧០៨-ដើម្បីស្មឹងស្មាធិ៍ ត្រូវតែប្រើចិត្តគំនិត យើងត្រូវស្រមើស្រមៃ រំភើបចិត្ត និងមានបំណងប្រាថ្នាផង គឺយើងត្រូវប្រមូលអ្វីៗទាំងអស់នោះ ដើម្បីពង្រឹងជំនឿ កែប្រែចិត្តគំនិត និងពង្រឹងបំណងប្រាថ្នាដើរតាមព្រះគ្រីស្ត។ គ្រីស្តបរិស័ទព្យាយាមស្មឹងស្មាធិ៍អំពី "ព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះគ្រីស្ត" ដូចក្នុងការ **Lectio divina** ឬពេល

សូត្រធម៌។ របៀបស្មឹងស្មាធិ៍បែបនេះ មានតម្លៃលើសលប់ ប៉ុន្តែ ត្រូវអធិដ្ឋានយ៉ាងជ្រាលជ្រៅតទៅទៀត គឺស្គាល់ព្រះអម្ចាស់យេស៊ូដោយក្តីស្រឡាញ់ រហូតដល់រួមរស់ជាមួយព្រះអង្គ។

## ៣-ការធ្វើសមាធិ

២៧០៩-អ្វីទៅជាការធ្វើសមាធិ? សន្តី ថេរេសាឆ្លើយថា៖ "តាមគំនិតខ្ញុំ ការធ្វើសមាធិគ្រាន់តែជាការនិយាយសន្ទនាជារឿយៗ និងយ៉ាងស្និទ្ធស្នាល ជាមួយនឹងព្រះជាម្ចាស់ដូចជាមិត្តសម្លាញ់ពីរនាក់ ដែលយើងដឹងថា ទ្រង់ស្រឡាញ់យើង"។

អ្នកធ្វើសមាធិស្វែងរក "ម្ចាស់ចិត្តរបស់ខ្លួន" (បច ១,៧) (បច ៣,១-៤) គឺព្រះយេស៊ូ ហើយនៅក្នុងព្រះអង្គគឺព្រះបិតា។ យើងស្វែងរកព្រះអង្គ ដ្បិតពេលយើងមានបំណងប្រាថ្នាចង់បានព្រះអង្គ យើងចាប់ផ្តើមស្រឡាញ់ព្រះអង្គ។ យើងស្វែងរកព្រះអង្គក្នុងជំនឿសុទ្ធសាធ ជាជំនឿដែលធ្វើឲ្យយើងកើតពីព្រះអង្គ និងរួមរស់ជាមួយព្រះអង្គផង។ ពេលធ្វើសមាធិ យើងអាចស្មឹងស្មាធិ៍បានដែរ ប៉ុន្តែ យើងទៅរកសម្លឹងព្រះអម្ចាស់។

២៧១០-បើយើងចង់ធ្វើសមាធិ ត្រូវតែជ្រើសរើសនៅពេលណា និងអស់រយៈពេលប៉ុន្មាន។ ការជ្រើសរើសនេះសម្តែងនូវឆន្ទៈ និងទីស្ងាត់កំបាំងនៃដួងចិត្តយើង។ យើងមិនធ្វើសមាធិនៅពេលទំនេរទេ គឺយើងចំណាយពេលវេលាដើម្បីព្រះអម្ចាស់ ដោយមានឆន្ទៈដ៏រឹងមាំថា មិនផ្លាស់ប្តូរចិត្តគំនិត ទោះបីមានការលំបាកផ្សេងៗក្នុងការធ្វើសមាធិយ៉ាងក៏ដោយ។ មានពេលខ្លះ យើងមិនអាចស្មឹងស្មាធិ៍បានទេ ប៉ុន្តែ យើងអាចធ្វើសមាធិគ្រប់ពេលវេលាគ្រប់កាលៈទេសៈ ដោយមិនរាប់អំពីសុខភាព ការងារ ឬអារម្មណ៍ឡើយ។ ចិត្តគំនិតជាកន្លែងជួបព្រះអម្ចាស់ដោយពឹងផ្អែក និងផ្ញើជីវិតទៅលើព្រះអង្គ។

២៧១១-យើងចូលធ្វើសមាធិ ដូចយើងចូលក្នុងពិធីបុណ្យអភិបូជាដែរ គឺយើង "ប្រមូល" អារម្មណ៍សម្រឹងទាំងកាយ ទាំងចិត្ត ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជួយណែនាំ និងយាងមកសណ្ឋិតក្នុងចិត្តយើង ដែលជាព្រះដំណាក់របស់ព្រះអម្ចាស់។ ព្រះវិញ្ញាណដាស់តឿនយើងឲ្យជឿ ដើម្បីឲ្យយើងត្រៀមខ្លួននឹងជួបព្រះអង្គ ដែលរង់ចាំយើង ដើម្បីឲ្យយើងទទួលស្គាល់សេចក្តីពិត និងវិលត្រឡប់ទៅរកព្រះអង្គវិញ ដែលស្រឡាញ់យើង ដើម្បីឲ្យយើងថ្វាយខ្លួនទាំងស្រុងទៅលើព្រះអង្គ ដូចជាតង្វាយដែលត្រូវបន្សុទ្ធ និងកែប្រែផង។

២៧១២-អ្នកធ្វើសមាធិអធិដ្ឋានដូចជាបុត្ររបស់ព្រះជាម្ចាស់ ដូចជាអ្នកបាបដែលព្រះអង្គលើកលែងទោស ហើយដែលសុខចិត្តទទួលសេចក្តីស្រឡាញ់របស់ព្រះអង្គ និងចង់ឆ្លើយតបនឹងសេចក្តីស្រឡាញ់នេះ ដោយស្រឡាញ់ច្រើនជាងមុនទៅទៀត (លក ៧,៣៦-៥០; ១៩,១-១០)។ ប៉ុន្តែ គេដឹងថា សេចក្តីស្រឡាញ់របស់គេ ជាសេចក្តីស្រឡាញ់ ដែលព្រះវិញ្ញាណចាក់បង្ហូរក្នុងចិត្តគេ ដ្បិតអ្វីៗទាំងអស់មកពីព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់។ ពេលធ្វើសមាធិ យើងថ្វាយខ្លួនដោយមានចិត្តសុភាពរាបសារ និងដោយពឹងផ្អែកលើព្រះអង្គ ឆ្ពោះទៅព្រះហឫទ័យស្រឡាញ់របស់ព្រះបិតា ដោយរួមជាមួយព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គកាន់តែជ្រៅទៅៗ។

២៧១៣-ការធ្វើសមាធិជារបៀបសាមញ្ញបំផុតក្នុងការអធិដ្ឋាន។ ការធ្វើសមាធិជាព្រះអំណោយទាន ដែលបានមកពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ យើងអាចធ្វើសមាធិ ដោយមានចិត្តសុភាពរាសា និងដោយពឹងផ្អែកទាំងស្រុងលើព្រះអង្គតែប៉ុណ្ណោះ។ ក្នុងការធ្វើសមាធិ ព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីជាមួយយើង ក្នុងជម្រៅចិត្តយើង (យរ ៣១,៣៣)។ ពេលធ្វើសមាធិ យើងរួមរស់ជាមួយព្រះអង្គ គឺព្រះគ្រីស្តដែលប្រោសមនុស្សលោក ដែលជារូបតំណាងរបស់ព្រះអង្គឲ្យ "មានលក្ខណៈដូចព្រះអង្គ" ដែរ។

២៧១៤-ការធ្វើសមាធិជាពេលដ៏ល្អៗនៃការអធិដ្ឋាន។ ពេលធ្វើសមាធិ ព្រះបិតាប្រោសយើង "ឲ្យមានកម្លាំងមាំមួនផ្នែកខាងក្នុងជម្រៅចិត្ត ដោយព្រះវិញ្ញាណរបស់ព្រះអង្គ។ ព្រះគ្រីស្តគង់នៅក្នុងចិត្តយើងដោយជំនឿ ដើម្បីឲ្យយើងបានចាក់ឫសយ៉ាងមាំមួនក្នុងសេចក្តីស្រឡាញ់" (អភ ៣,១៦-១៧)។

២៧១៥-ពេលធ្វើសមាធិ យើងសម្លឹងមើលព្រះយេស៊ូដោយផ្ញើជីវិតទៅលើព្រះអង្គ។ ដូចកសិករនៃភូមិអារស៍ម្នាក់មានប្រសាសន៍ទៅកាន់លោកបូជាចារ្យដ៏វិសុទ្ធរបស់គាត់ នៅពេលកំពុងអធិដ្ឋានពីមុខព្រះពន្លា៖ "ខ្ញុំសម្លឹងមើលព្រះអង្គ ហើយព្រះអង្គក៏សម្លឹងទតមកខ្ញុំវិញដែរ"។ យើងចាប់អារម្មណ៍នឹងព្រះអង្គ ទើបយើងលះបង់ "ខ្លួនឯង" ចោល។ ការទតឃើញរបស់ព្រះអង្គបន្សុទ្ធចិត្តគំនិតយើង។ ពន្លឺរបស់ព្រះយេស៊ូបំភ្លឺចិត្តគំនិតយើង ហើយបង្រៀនយើងឲ្យមើលឃើញអ្វីៗទាំងអស់ក្នុងពន្លឺនៃសេចក្តីពិត និងធម៌មេត្តាករុណារបស់ព្រះអង្គចំពោះមនុស្សទាំងអស់។ ពេលធ្វើសមាធិ យើងក៏សម្លឹងមើលព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះគ្រីស្តផង ទើបយើងរៀន "ស្គាល់ព្រះអម្ចាស់ពីខាងក្នុង" ដើម្បីឲ្យកាន់តែស្រឡាញ់ និងដើរតាមព្រះអង្គប្រសើរជាងមុន (សន្តៈ អ៊ីញ៉ាស)។

២៧១៦-ពេលធ្វើសមាធិ យើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងសកម្ម គឺយើងស្តាប់បង្គាប់ព្រះអង្គដោយផ្ញើជីវិតលើព្រះអង្គ យើងទទួលព្រះបន្ទូលហើយគោរពតាមដូចអ្នកបម្រើ និងភ្ជាប់ព្រះបន្ទូលព្រះអង្គដោយក្តីស្រឡាញ់ដូចជាកូនម្នាក់។ យើងក៏ចូលរួមចំណែកជាមួយព្រះបុត្រា និងព្រះនាងម៉ារី ដែលតែងតែជ្ជាប់តាមព្រះហឫទ័យព្រះបិតានឹងបានក្លាយទៅជាអ្នកបម្រើព្រះអង្គ។

២៧១៧-ពេលធ្វើសមាធិ យើងនៅស្ងៀមស្ងាត់។ ភាពស្ងៀមស្ងាត់នេះជា "និមិត្តរូបនៃពិភពលោកថ្មីដែលកំពុងយាងមក" (សន្តៈ អ៊ីសាក នៃនីនីវេ) ឬ "សេចក្តីស្រឡាញ់ដ៏ស្ងៀមស្ងាត់" (សន្តៈ យ៉ូហាន នៃព្រះឈើឆ្កាង)។ ក្នុងការធ្វើសមាធិ ពាក្យសម្តីមិនមែនជាសុន្ទរកថាទេ ប៉ុន្តែ ពាក្យសម្តីដូចជាទងស្មៅតូចៗដែលផ្គត់ផ្គង់ភ្លើងនៃសេចក្តីស្រឡាញ់។ ក្នុងភាពស្ងៀមស្ងាត់នេះ ដែលមនុស្ស "រាយមាយ" ទ្រាំមិនបាន ព្រះបិតាមានព្រះបន្ទូលមកយើងអំពីព្រះបុត្រារបស់ព្រះអង្គ ដែលប្រសូតជាមនុស្ស រងទុក្ខលំបាក សោយទិវង្គត និងមានព្រះជន្មថ្មី ហើយព្រះវិញ្ញាណនៃព្រះបិតាប្រោសយើងឲ្យចូលរួមចំណែកក្នុងការអធិដ្ឋានរបស់ព្រះយេស៊ូ។

២៧១៨-ពេលធ្វើសមាធិ យើងរួមរស់ក្នុងការអធិដ្ឋានរបស់ព្រះគ្រីស្ត លុះត្រាតែការអធិដ្ឋាននេះ ធ្វើឲ្យយើងចូលរួមចំណែកក្នុងអាថ៌កំបាំងរបស់ព្រះអង្គ។ ក្នុងអភិបូជា ព្រះសហគមន៍ប្រារព្ធអាថ៌កំបាំងរបស់ព្រះគ្រីស្ត ហើយព្រះវិញ្ញាណដ៏វិសុទ្ធធ្វើឲ្យអាថ៌កំបាំងនេះ ស្ថិតក្នុងការធ្វើសមាធិ ដើម្បីឲ្យសេចក្តីស្រឡាញ់សម្តែងចេញមកជាសកម្មភាពក្នុងការបម្រើ។

២៧១៩-ពេលធ្វើសមាធិ យើងរួមរស់ជាមួយព្រះជាម្ចាស់ ដោយក្តីស្រឡាញ់។ ការធ្វើសមាធិនាំឲ្យមនុស្សជាច្រើនទទួលជីវិត ខណៈដែលអ្នកទាំងនោះសុខចិត្តស្នាក់នៅក្នុងភាពងងឹត ដោយមានជំនឿ។ ក្នុងរាត្រីនៃបុណ្យចម្លង មានយប់នៃទុក្ខលំបាក និងទីបញ្ចុះសព។ ព្រះវិញ្ញាណរបស់ព្រះយេស៊ូ (មិនមែនជា "មនុស្សទន់ខ្សោយ" ទេ) ធ្វើឲ្យអ្នកដែលតាំងសមាធិស្គាល់ពេលកំណត់ទាំងបីនោះរបស់ព្រះយេស៊ូ។ ដូច្នេះ ត្រូវតែសុខចិត្ត "ស៊ូទ្រាំប្រុងស្មារតីរយៈពេលមួយម៉ោងជាមួយព្រះអង្គ" (មថ ២៦,៤០)។

## សង្ខេប

២៧២០-ព្រះសហគមន៍អញ្ជើញគ្រីស្តបរិស័ទឲ្យអធិដ្ឋានយ៉ាងទៀងទាត់ គឺអធិដ្ឋានប្រចាំថ្ងៃ អធិដ្ឋានតាមពេលកំណត់ អភិបូជាថ្ងៃអាទិត្យ ពិធីបុណ្យប្រចាំថ្ងៃផ្សេងៗ។

២៧២១-ការបញ្ជូនបន្តនៃគ្រីស្តសាសនាមានរបៀបអធិដ្ឋានសំខាន់ៗបីយ៉ាង គឺអធិដ្ឋានតាមពាក្យសម្តី ការស្មឹងស្មាធិ៍ និងការធ្វើសមាធិ។ របៀបអធិដ្ឋានទាំងបីនោះ មានលក្ខណៈរួម គឺការសម្រឹងទ្រឹងគិត។

២៧២២-ការអធិដ្ឋានតាមពាក្យសម្តី ចាក់ឫសលើការរួបរួមរវាងរូបកាយ និងវិញ្ញាណ តាមធម្មជាតិមនុស្ស ធ្វើឲ្យរូបកាយរួបរួមជាមួយការអធិដ្ឋានក្នុងដួងចិត្ត ដោយយកព្រះគ្រីស្តជាគំរូ ដែលអង្វរព្រះបិតារបស់ព្រះអង្គ និងដែលបង្រៀនធម៌ឱព្រះបិតាដល់សាវ័ករបស់ព្រះអង្គ។

២៧២៣-អ្នកស្មឹងស្មាធិ៍ជាអ្នកស្វែងរក គេត្រូវតែប្រើចិត្តគំនិតស្រមើស្រមៃ រំភើបចិត្ត និងមានបំណងប្រាថ្នាផង។ ការស្មឹងស្មាធិ៍មានគោលដៅឲ្យអ្នកស្មឹងស្មាធិ៍ប្រឈមមុខនឹងអ្វីដែលកើតឡើងយ៉ាងពិតប្រាកដ ក្នុងជីវិតក្រោមពន្លឺនៃជំនឿ។

២៧២៤-ការធ្វើសមាធិជារបៀបសាមញ្ញបំផុត ក្នុងការអធិដ្ឋាន។ អ្នកធ្វើសមាធិសម្លឹងមើលព្រះយេស៊ូដោយផ្ញើជីវិតទៅលើព្រះអង្គ ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ស្រឡាញ់យ៉ាងស្ងៀមស្ងាត់។ ពេលធ្វើសមាធិ យើងរួមរស់ក្នុងការអធិដ្ឋានរបស់ព្រះគ្រីស្ត លុះត្រាតែការអធិដ្ឋាននេះ ធ្វើឲ្យយើងចូលរួមចំណែកក្នុងអាថ៌កំបាំងរបស់ព្រះអង្គ។

## ប្រការទី២៖

## ត្រូវតែតស៊ូដើម្បីអធិដ្ឋាន

២៧២៥-ការអធិដ្ឋានកើតមកពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដូច្នេះយើងត្រូវតាំងចិត្តឲ្យមាំមួនខិតខំជានិច្ច ដើម្បីអធិដ្ឋាន ឬទេ។ អ្នកអធិដ្ឋានដ៏ល្បីៗក្នុងសម្ព័ន្ធមេត្រីចាស់ មុនព្រះគ្រីស្ត ដូចជាព្រះមាតារបស់ព្រះជាម្ចាស់ និងសន្តបុគ្គលទាំងអស់ រួមជាមួយព្រះអង្គ បង្រៀនឲ្យយើងចេះតស៊ូក្នុងការអធិដ្ឋាន។ តើត្រូវតស៊ូប្រឆាំងនឹងនរណាខ្លះ? គឺត្រូវប្រឆាំងនឹងខ្លួនឯងផង និងមេល្បួង ដែលប្រើកលល្បិចគ្រប់យ៉ាង មិនឲ្យមនុស្សអធិដ្ឋាន និងឲ្យគេបង្វែរចិត្តគំនិតងាកចេញឆ្ងាយពីព្រះជាម្ចាស់។ យើងអធិដ្ឋានដូចយើងរស់ ដ្បិតយើងរស់ដូចយើងអធិដ្ឋានដែរ។ ប្រសិនបើយើងមិនចង់គោរពតាមព្រះវិញ្ញាណរបស់ព្រះគ្រីស្តទេ យើងក៏មិនអាចអធិដ្ឋានក្នុងព្រះនាមព្រះអង្គដែរ។ ការ "ប្រយុទ្ធច្បាំងខាងវិញ្ញាណ" នៃជីវិតថ្មីរបស់គ្រីស្តបរិស័ទមិនអាចបំបែកចេញពីការប្រយុទ្ធច្បាំងនៃការអធិដ្ឋានបានឡើយ។

### ១-ការប្រឆាំងតបនឹងការអធិដ្ឋាន

២៧២៦-ក្នុងការប្រយុទ្ធដើម្បីអធិដ្ឋាន យើងត្រូវប្រឈមមុខនឹងគំនិតខុសអំពីការអធិដ្ឋាន ដែលមកពីខ្លួនយើង ឬពីអ្នកដទៃ។ ពេលខ្លះយើងគិតថា ការអធិដ្ឋានគ្រាន់តែជាមធ្យោបាយខាងចិត្តវិទ្យា ពេលខ្លះយើងគិតថាធ្វើការអធិដ្ឋាន ដើម្បីបានរសាយក្នុងចិត្ត ហើយពេលខ្លះទៀត យើងគិតថា ត្រូវមានអាកប្បកិរិយា ឬសម្តីសំដៅគោរពក្នុងពិធីផ្សេងៗ។ ក្នុងជម្រៅចិត្តគ្រីស្តបរិស័ទជាច្រើននាក់គិតថា គេមិនអាចអធិដ្ឋានបានទេ ព្រោះរវល់ពេក៖ គេគ្មានពេលទំនេរឡើយ។ ពួកគេបាក់ទឹកចិត្តយ៉ាងឆាប់រហ័ស ដ្បិតគេមិនដឹងថា ការអធិដ្ឋានមិនគ្រាន់តែមកពីខ្លួនគេទេ ថែមទាំងមកពីព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ។

២៧២៧-យើងត្រូវតែប្រឈមមុខនឹងការយល់ឃើញនៃ "លោកីយ៍" នេះ ដែលចូលក្នុងជម្រៅចិត្តយើង កាលណាយើងមិនបានប្រុងស្មារតី។ ឧទាហរណ៍៖

-មនុស្សទូទៅគិតថា ការពិតមកអំពីការត្រិះរិះដោយប្រាជ្ញា និងវិទ្យាសាស្ត្រ។ ប៉ុន្តែ ការអធិដ្ឋានជាអាថ៌កំបាំងលើសពីប្រាជ្ញា និងជម្រៅចិត្តយើង។

-គេគិតថា ការអធិដ្ឋានមិនបានផលិតអ្វីសោះ ដែលនាំឲ្យចំណេញ គឺគ្មានប្រយោជន៍ឡើយ។

-មានតែការសប្បាយ និងជាសុកភាពទេ ដែលជាលក្ខណៈនៃការពិត អ្វីដ៏ល្អប្រសើរ និងប្រកបដោយសោភ័ណភាព។ ក៏ប៉ុន្តែ ការអធិដ្ឋានជា "សេចក្តីស្រឡាញ់នៃសោភ័ណភាព" ជាប់ចិត្តនឹងសិរីរុងរឿងនៃព្រះដ៏មានព្រះជន្មរស់ ជាព្រះដ៏ពិតប្រាកដ។

-គេគិតថា អ្នកអធិដ្ឋានចង់ចាកចេញពីលោកនេះ។ ប៉ុន្តែ អ្នកអធិដ្ឋានតាមគ្រីស្តសាសនាមិនស្អប់ជីវិតផ្ទុយទៅវិញ គឺគេចង់ប្រែពិភពលោកនេះឲ្យបានល្អប្រសើរ។

២៧២៨-ទីបំផុត យើងត្រូវតស៊ូប្រឆាំងនឹងអ្វីដែលយើងគិតថា ជាបរាជ័យក្នុងការអធិដ្ឋានរបស់យើង៖ យើងបាក់ទឹកចិត្ត ដ្បិតយើងមានអារម្មណ៍រីងស្ងួត យើងព្រួយចិត្តថា យើងមិនបានថ្វាយអ្វីៗទាំងអស់ចំពោះព្រះអម្ចាស់ ដ្បិតយើងមាន "ទ្រព្យសម្បត្តិស្តុកស្តម្ភណាស់" (មក ១០,២២) យើងខកចិត្ត ដ្បិតព្រះជាម្ចាស់មិនឆ្លើយនឹងបំណងយើង យើងវាយឫកក្រអឺតក្រអោង ឬយើងស្មានថា យើងមានបាបច្រើនពេកដើម្បីអធិដ្ឋាន។ល។ ទីបញ្ចប់ យើងតែងតែសួរខ្លួនឯងថា៖ ហេតុអ្វីត្រូវអធិដ្ឋាន? ដើម្បីឈ្នះឧបសគ្គទាំងអស់នោះ ត្រូវតែតស៊ូដោយមានចិត្តសុភាពរាបសា ជឿទុកចិត្តលើខ្លួនឯង និងលើព្រះជាម្ចាស់ ដោយមានចិត្តព្យាយាមផង។

## ២-ត្រូវប្រុងស្មារតីដោយមានចិត្តសុភាពរាបសា

### ត្រូវប្រឈមមុខនឹងការលំបាកក្នុងការអធិដ្ឋាន

២៧២៩-ធម្មតា ពេលអធិដ្ឋាន យើងមានអារម្មណ៍រាយមាយ។ ក្នុងការអធិដ្ឋានតាមពាក្យសម្តី យើងមិនបានចាប់អារម្មណ៍អំពីពាក្យ និងអត្ថន័យនៃពាក្យនោះ។ ពេលអធិដ្ឋានក្នុងពិធីបុណ្យ ឬពេលស្មឹងស្មាធិ៍ ឬធ្វើសមាធិ យើងអាចបំភ្លេចព្រះជាម្ចាស់ផងដែរ។ ពេលនោះ យើងមិនបាច់ចាប់អារម្មណ៍អំពីគំនិតរាយមាយទេ គឺត្រូវតែប្រមូលអារម្មណ៍ឡើងវិញ។ ពេលយើងនឹកគិតដល់រឿងអ្វីមួយ យើងអាចដឹងថា យើងចាប់អារម្មណ៍នឹងរឿងនេះច្រើនជាងព្រះជាម្ចាស់។ ពេលនោះ យើងគួរភ្ញាក់ខ្លួនឡើងវិញ និងថ្វាយចិត្តគំនិតទៅព្រះជាម្ចាស់ដោយក្តីស្រឡាញ់ ដើម្បីឲ្យព្រះអង្គបន្សុទ្ធចិត្តគំនិតនេះ។ ការប្រយុទ្ធច្បាំងនៅកន្លែងណា ចិត្តរបស់យើងក៏នៅកន្លែងនោះដែរ (មថ ៦,២១.២៤)។

២៧៣០-និយាយតាមរបៀបវិជ្ជមាន ត្រូវប្រុងស្មារតី ប្រឆាំងនឹងចិត្តលោភលន់របស់យើង ដែលចង់គ្រប់គ្រងអ្វីៗទាំងអស់។ ពេលព្រះយេស៊ូមានព្រះបន្ទូលសង្កត់ធ្ងន់ថា ត្រូវប្រុងស្មារតី បានសេចក្តីថា ព្រះអង្គជិតមកដល់ហើយ ជារៀងរាល់ថ្ងៃរហូតដល់ថ្ងៃចុងក្រោយ៖ "នៅថ្ងៃនេះ"។ ព្រះស្វាមីមកពាក់កណ្តាលអធ្រាត្រ" យើងមិនត្រូវពន្លត់ពន្លឺនៃជំនឿទេ៖ "ចិត្តទូលបង្គំនឹកដល់ព្រះបន្ទូលដែលព្រះអង្គថ្លែងថា "ចូរស្វែងរកយើង" នោះទូលបង្គំឆ្លើយថា ឱព្រះអម្ចាស់អើយ! ទូលបង្គំស្វែងរកព្រះភ័ក្ត្រព្រះអង្គហើយ!" (ទន ២៧,៨)។

២៧៣១-អស់អ្នកដែលចង់អធិដ្ឋានដោយចិត្តស្មោះ អាចជួបប្រទះនឹងការលំបាកផ្សេងមួយទៀត គឺពេលអធិដ្ឋានគេអាចមានចិត្តរីងស្ងួត។ ពេលធ្វើសមាធិ យើងអាចអស់ចិត្តហើយ គ្មានអារម្មណ៍អធិដ្ឋានតទៅទៀត មិនចង់នឹកគិតដល់អ្វីសោះ សូម្បីតែរឿងនៃវិញ្ញាណក៏ដោយ គឺជាពេលនៃជំនឿបរិសុទ្ធ ស្ថិតនៅជាប់ជាមួយព្រះយេស៊ូពេលព្រះអង្គរងទុក្ខលំបាក និងសោយទិវង្គត។ "គ្រាប់ស្រូវធ្លាក់ដល់ដីហើយ បើគ្រាប់នោះងាប់ វានឹងបង្កើតផល

បានច្រើន" (យហ ១២,២៤)។ បើការរីងស្ងួតមកពីយើងមិនបានចាក់ឫស ដ្បិតព្រះបន្ទូលបានធ្លាក់លើដីមានថ្ម នោះត្រូវតស៊ូ ដើម្បីកែប្រែចិត្តគំនិត (លក ៨,៦.១៣)។

### ត្រូវប្រឈមមុខនឹងការល្បួងក្នុងការអធិដ្ឋាន

២៧៣២-ការល្បួងដែលមានជាធម្មតា ហើយដែលពិបាករកឃើញ មកពីយើងមានជំនឿតិចតួច។ ការល្បួងនេះមិនមែនមកពីយើងមិនជឿលើព្រះជាម្ចាស់ទេ តែមកពីយើងស្រឡាញ់រឿងផ្សេងៗច្រើនជាងព្រះអង្គ។ ពេលចាប់ផ្ដើមអធិដ្ឋាន យើងនឹកគិតដល់អំពីការងារ ឬរឿងផ្សេងៗជាច្រើនជំពូក ដែលត្រូវប្រញាប់ដោះស្រាយជាចាំបាច់។ ម្ដងទៀត យើងត្រូវប្រឈមមុខនឹងការពិតថា តើយើងស្រឡាញ់អ្វីខ្លះច្រើនជាងគេ? ព្រះជាម្ចាស់ ឬរឿងទាំងអស់នោះ? ពេលខ្លះយើងបែរមុខទៅរកព្រះអម្ចាស់ សូមឲ្យព្រះអង្គយាងមកជួយ ប៉ុន្តែ តើយើងជឿថាព្រះអង្គអាចជួយយើងមែនឬទេ? ពេលខ្លះទៀត យើងទុកព្រះអង្គជាសម្ព័ន្ធមិត្ត ប៉ុន្តែ យើងនៅតែពឹងលើខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ ជំនឿតិចតួចរបស់យើងបង្ហាញថា យើងមិនទាន់បានបន្ទាបខ្លួននៅឡើយទេ៖ "បើដាច់ពីខ្ញុំ អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតឡើយ " (យហ ១៥,៥)។

២៧៣៣-មានការល្បួងមួយទៀត មកពីយើងពឹងលើខ្លួនឯងខ្លាំងពេក ទើបយើងអាចបាក់ទឹកចិត្ត។ គ្រូបាធ្យាយពន្យល់ថា ពេលយើងលែងលត់ដំខ្លួន ឬប្រុងស្មារតី ឬពេលយើងលែងស្វែងយល់អំពីចិត្តខ្លួនឯង យើងក៏អាចបាក់ទឹកចិត្តបាន៖ "វិញ្ញាណរបស់មនុស្សប្រុងប្រៀបជាស្រេចមែន តែខ្លួនគេនៅខ្សោយពេក" (មថ ២៦,៤១)។ ការបាក់ទឹកចិត្តនេះ ដែលធ្វើឲ្យយើងឈឺចាប់ ផ្ទុយនឹងការអាងលើខ្លួនឯងខ្លាំងពេក។ អ្នកដែលចេះបន្ទាបខ្លួនមិនឆ្ងល់អំពីភាពវេទនារបស់ខ្លួន ផ្ទុយទៅវិញ ភាពវេទនានេះ នាំគេឲ្យជឿទុកចិត្តច្រើនជាងមុន និងចេះតស៊ូដោយមានចិត្តព្យាយាម។

## ៣-ជឿលើព្រះជាម្ចាស់ដូចជឿលើឪពុក

២៧៣៤-យើងដឹងថា យើងជឿទុកចិត្តលើព្រះជាម្ចាស់ដូចកូនម្នាក់ជឿលើឪពុក ពេលយើងរងទុក្ខវេទនា (រម ៥,៣-៥)។ ការលំបាកធំជាងគេ មកពីពេលយើងទូលអង្វរព្រះជាម្ចាស់សម្រាប់ខ្លួនឯង ឬសម្រាប់អ្នកដទៃ។ អ្នកខ្លះឈប់អធិដ្ឋាន ពីព្រោះគេស្មានថា ព្រះជាម្ចាស់មិនទទួលសំណូមពររបស់គេទេ។ ពេលនោះ ត្រូវតែសួរសំណួរពីរ៖ ហេតុអ្វីបានជាយើងគិតថា ព្រះជាម្ចាស់មិនបានទទួលពាក្យអង្វររបស់យើង? តើព្រះជាម្ចាស់ទទួលពាក្យអង្វររបស់យើងយ៉ាងដូចម្ដេច ឬតើការអធិដ្ឋានរបស់យើងមានប្រសិទ្ធភាពយ៉ាងដូចម្ដេច?

### ហេតុអ្វីបានជាយើងត្អូញត្អែរថា ព្រះជាម្ចាស់មិនទទួលពាក្យអង្វររបស់យើង?

២៧៣៥-មុនដំបូង យើងឆ្ងល់ដោយសង្កេតឃើញថា ពេលយើងលើកតម្កើង ឬអរព្រះគុណព្រះជាម្ចាស់ ដើម្បីព្រះអំណោយទានទូទៅរបស់ព្រះអង្គ យើងមិនសូវរវល់នឹងដឹងថា តើការអធិដ្ឋានរបស់យើងជាទីគាប់ព្រះហឫទ័យរបស់ព្រះអង្គឬទេ?។ ផ្ទុយទៅវិញ យើងទាមទារឲ្យបានឃើញលទ្ធផលនៃពាក្យអង្វររបស់យើង។ តើយើងគិតថាព្រះជាម្ចាស់ជានរណា ឬជាអ្វី? នៅពេលយើងអធិដ្ឋាន៖ មធ្យោបាយមួយដែលយើងគួរប្រើប្រាស់ ឬព្រះបិតានៃព្រះអម្ចាស់របស់យើង ព្រះយេស៊ូគ្រីស្ត?

២៧៣៦-តើយើងជឿជាក់ច្បាស់ថា "យើងពុំដឹងអធិដ្ឋានដូចម្ដេច ដើម្បីឲ្យបានសមនោះឡើយ" (រម ៨,២៦)? តើយើងទូលអង្វរព្រះជាម្ចាស់អំពី "អ្វីដែលល្អត្រឹមត្រូវ" ហើយឬនៅ? ព្រះបិតារបស់យើងជ្រាបនូវអ្វីៗដែលយើង

ត្រូវការ មុនយើងទូលព្រះអង្គទៅទៀត (មថ ៦,៨) ប៉ុន្តែ ព្រះអង្គរង់ចាំឲ្យយើងទូលសូមព្រះអង្គ ដ្បិតសេចក្ដីថ្លៃថ្នូរនៃបុត្រធីតារបស់ព្រះអង្គស្ថិតនៅក្នុងសេរីភាពរបស់គេ ហើយត្រូវតែអធិដ្ឋាន ដោយមានព្រះវិញ្ញាណនៃសេរីភាពរបស់ព្រះអង្គ ដើម្បីឲ្យស្គាល់ព្រះបំណងរបស់ព្រះអង្គយ៉ាងពិតប្រាកដ (រម ៨,២៧)។

២៧៣៧-"បងប្អូនមានចិត្តលោភលន់ តែមិនបានដូចបំណងប្រាថ្នាទេ (...) បងប្អូនក៏នៅតែមិនបានទទួលអ្វីដែរ ព្រោះបងប្អូនមិនទូលសូមពីព្រះជាម្ចាស់។ បងប្អូនទូលសូមដែរ តែឥតបានទទួល ព្រោះបងប្អូនទូលសូមដោយបំណងអាក្រក់ គឺបងប្អូនចង់បានសម្រាប់តែបំពេញចិត្តស្រើបស្រាលរបស់ខ្លួនប៉ុណ្ណោះ" (យក ៤,២-៣ សូមអាន យក ៤,១-១០; ១,៥-៨; ៥,១៦)។ បើយើងទូលសូមដោយមានចិត្តពីរ ដោយ "ក្បត់ចិត្ត" (យក ៤,៤) ព្រះជាម្ចាស់មិនអាចទទួលពាក្យអង្វររបស់យើងបានទេ ដ្បិតព្រះអង្គមានព្រះហឫទ័យប្រទានអ្វីដែលល្អសម្រាប់យើង ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងមានជីវិត។ "តើបងប្អូនស្មានថា សេចក្ដីដែលមានចែងទុកក្នុងគម្ពីរ ឥតបានការអ្វីទេឬ គឺថា ព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់វិញ្ញាណ ដែលព្រះអង្គប្រទានឲ្យមកគង់ក្នុងបងប្អូនរហូតដល់ប្រច័ណ្ឌ" (យក ៤,៥)។ ព្រះរបស់យើង "ប្រច័ណ្ឌ" នឹងយើងជាសញ្ញាសម្គាល់ថា ព្រះអង្គស្រឡាញ់យើងយ៉ាងពិតប្រាកដ។ សូមឲ្យយើងចូលក្នុងបំណងប្រាថ្នានៃព្រះវិញ្ញាណព្រះអង្គទៅ នោះព្រះជាម្ចាស់នឹងទទួលពាក្យអង្វររបស់យើងហើយ៖

> កុំពិបាកចិត្ត បើអ្នកទូលសុំហើយ តែអ្នកមិនបានទទួលអ្វីៗពីព្រះជាម្ចាស់ទេនោះ គឺមកពីព្រះអង្គមានព្រះហឫទ័យចង់ប្រទានឲ្យអ្នកបាននូវអ្វីៗដែលល្អប្រសើរ លើសពីបំណងប្រាថ្នារបស់អ្នកទៅទៀត ឲ្យតែអ្នកស្ថិតនៅជាមួយព្រះអង្គក្នុងការអធិដ្ឋាន ដោយចិត្តព្យាយាម (លោក អេវ្រ៉ាក)។ ព្រះអង្គមានព្រះហឫទ័យឲ្យការអធិដ្ឋានពង្រឹងបំណងប្រាថ្នារបស់យើង។ ហេតុនេះ ព្រះអង្គរៀបចំយើងឲ្យទទួលអ្វីដែលព្រះអង្គសព្វព្រះហឫទ័យប្រទានមកយើង (សន្ត: អូគូស្តាំង)។

### តើការអធិដ្ឋានរបស់យើងមានប្រសិទ្ធភាពយ៉ាងដូចម្ដេច?

២៧៣៨-ការអធិដ្ឋានក្នុងការចាត់ចែងគម្រោងការនៃការសង្គ្រោះសម្ដែងឲ្យយើងដឹងថា ជំនឿពឹងផ្អែកទៅលើសកម្មភាពរបស់ព្រះជាម្ចាស់ក្នុងប្រវត្តិសាស្ត្រ។ សកម្មភាពតែមួយរបស់ព្រះអង្គ ដែលជំរុញយើងឲ្យជឿទុកចិត្តលើព្រះអង្គដូចកូនជឿលើឪពុក គឺទុក្ខលំបាក និងការមានព្រះជន្មថ្មីរបស់ព្រះបុត្រាព្រះអង្គ។ ពេលយើងជាគ្រីស្តបរិស័ទអធិដ្ឋាន យើងរួមសហការជាមួយនឹងឧបការគុណ និងគម្រោងការដ៏សប្បុរសរបស់ព្រះអង្គចំពោះមនុស្សលោក។

២៧៣៩-សន្ត: ប៉ូល ជឿទុកចិត្តលើព្រះជាម្ចាស់យ៉ាងក្លាហាន (រម ១០,១២-១៣) ដោយចាក់ឫសលើការអធិដ្ឋាននៃព្រះវិញ្ញាណក្នុងខ្លួនយើង និងលើសេចក្ដីស្រឡាញ់របស់ព្រះបិតា ដែលបានប្រគល់ព្រះបុត្រាតែមួយរបស់ព្រះអង្គមកយើង (រម ៨,២៦-៣៩)។ មុនដំបូង ព្រះជាម្ចាស់ទទួលពាក្យអង្វររបស់យើង ដោយប្រែចិត្តគំនិតយើង។

២៧៤០-ការអធិដ្ឋានរបស់ព្រះយេស៊ូធ្វើឲ្យការអធិដ្ឋាននៃគ្រីស្តបរិស័ទមានប្រសិទ្ធភាព។ ព្រះយេស៊ូជាគំរូនៃការអធិដ្ឋាននេះ ព្រះអង្គអធិដ្ឋានក្នុងខ្លួនយើង និងជាមួយយើងផងដែរ។ ដោយសារព្រះបុត្រាតែងតែស្វែងរកអ្វីដែលជាទីគាប់ព្រះហឫទ័យរបស់ព្រះបិតា ហេតុអ្វីបានជាបុត្រធីតាជាប់ចិត្តនឹងព្រះអំណោយទានរបស់ព្រះជាម្ចាស់ច្រើនជាងព្រះអង្គផ្ទាល់?

២៧៤១-ព្រះយេស៊ូអធិដ្ឋានសម្រាប់យើង ជំនួសយើង និងដើម្បីយើងផងដែរ។ ព្រះអង្គបានប្រមូលយកពាក្យទូលអង្វរទាំងឡាយរបស់យើង នៅលើឈើឆ្កាង ហើយព្រះបិតាបានទទួលពាក្យអង្វរទាំងអស់នោះ ដោយប្រោស

ព្រះយេស៊ូឲ្យមានព្រះជន្មថ្មី។ ហេតុនេះហើយបានជាព្រះអង្គនៅតែជួយអង្វរព្រះបិតាសម្រាប់យើង (ហប ៥,៧; ៧,២៥; ៩,២៤)។ បើយើងអធិដ្ឋានរួមជាមួយព្រះយេស៊ូ ដោយជឿទុកចិត្តលើព្រះអង្គជាដាច់ខាត និងដោយមានចិត្តក្លាហានដូចកូនចំពោះឪពុក យើងអាចទទួលអ្វីៗទាំងអស់ ដែលយើងទូលសូមក្នុងព្រះនាមព្រះអង្គ ហើយលើសពីអ្វីៗទាំងអស់នោះទៅទៀត យើងក៏អាចទទួលព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់ ដែលសរុបនូវព្រះអំណោយទានទាំងអស់។

## ៤-ត្រូវព្យាយាមស្រឡាញ់

២៧៤២-"ត្រូវអធិដ្ឋានជានិច្ច" (១ថស ៥,១៧) "ត្រូវអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតាគ្រប់ពេលវេលា និងគ្រប់កិច្ចការ ក្នុងព្រះនាមព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើង" (អភ ៥,២០) "ចូរអធិដ្ឋានគ្រប់ពេលវេលា តាមការណែនាំរបស់ព្រះវិញ្ញាណ ដោយប្រើទាំងសេចក្តីអធិដ្ឋាន ទាំងពាក្យអង្វរគ្រប់យ៉ាង ហើយប្រុងស្មារតីទូលអង្វរព្រះជាម្ចាស់ ដោយចិត្តព្យាយាមបំផុត សម្រាប់ប្រជាជនដ៏វិសុទ្ធទាំងអស់" (អភ ៦,១៨)។ "ព្រះជាម្ចាស់មិនបានបញ្ជាឲ្យយើងធ្វើការឲ្យប្រុងស្មារតី និងតមអាហារជានិច្ចទេ តែត្រូវតែអធិដ្ឋានជានិច្ច" (លោក អេវ៉្រក)។ មានតែសេចក្តីស្រឡាញ់ទេ ដែលអាចជំរុញយើងឲ្យអធិដ្ឋាន ដោយមានចិត្តព្យាយាមជានិច្ច។ ត្រូវតែអធិដ្ឋានដោយស្រឡាញ់ ដោយសុភាពរាបសា ដោយជឿទុកចិត្ត និងដោយមានចិត្តព្យាយាម ហើយត្រូវប្រយុទ្ធប្រឆាំងកុំឲ្យខ្ជិលច្រអូសឡើយ។ សេចក្តីស្រឡាញ់នេះ បើកចិត្តឲ្យទូលាយអំពីសេចក្តីនៃជំនឿបីយ៉ាង ដែលជួយបំភ្លឺ និងផ្តល់ជីវិតដល់យើងគឺ៖

២៧៤៣-យើងតែងតែអាចអធិដ្ឋានបាន៖ ព្រះគ្រីស្តដែលមានព្រះជន្មថ្មី "គង់នៅ" ជាមួយគ្រីស្តបរិស័ទ "ជារៀងរាល់ថ្ងៃ" (មថ ២៨,២០) ទោះជាមានឧបសគ្គយ៉ាងណាក៏ដោយ (លក ៨,២៤)។ ពេលវេលាយើងស្ថិតក្នុងព្រះហស្តរបស់ព្រះជាម្ចាស់៖

> ទោះជាយើងនៅផ្សារក្តី ដើរលេងម្នាក់ឯងក្តី អង្គុយលក់ដូរ ឬទិញអីវ៉ាន់ក្តី សូម្បីតែកំពុងធ្វើម្ហូប ក៏យើងអាចអធិដ្ឋានយ៉ាងខ្លីៗ និងជ្រាលជ្រៅផងដែរ (សន្តៈ យ៉ូហាន គ្រីសូស្តូម)។

២៧៤៤-យើងត្រូវតែអធិដ្ឋានជាចាំបាច់។ បើយើងមិនបណ្តោយឲ្យព្រះវិញ្ញាណណែនាំយើងទេនោះ យើងនឹងធ្លាក់ទៅជាខ្ញុំបម្រើនៃអំពើបាបម្តងទៀត (កាឡ ៥,១៦-២៥)។ បើចិត្តយើងនៅឆ្ងាយពីព្រះវិញ្ញាញដ៏វិសុទ្ធ តើព្រះអង្គអាចជា "ជីវិតរបស់យើង" យ៉ាងដូចម្តេចបាន?

គ្មានអ្វីប្រសើរជាងការអធិដ្ឋានទេ៖ បើយើងអធិដ្ឋាន យើងអាចធ្វើអ្វីដែលមិនអាចធ្វើបាន។ ការអធិដ្ឋានប្រែអ្វីដែលពិបាកឲ្យបានងាយស្រួល។ អ្នកអធិដ្ឋានមិនអាចប្រព្រឹត្តអំពើបាបបានទេ (សន្តៈ យ៉ូហាន គ្រីសូស្តូម)។

អ្នកដែលអធិដ្ឋានប្រាកដជាសង្គ្រោះខ្លួនឯង អ្នកដែលមិនអធិដ្ឋានប្រាកដជាធ្លាក់នរក (សន្តៈ អាលផូស នៃលីគូរី)។

២៧៤៥-យើងមិនអាចបំបែកការអធិដ្ឋានចេញពីការរស់នៅជាគ្រីស្តបរិស័ទបានទេ ដ្បិតប្រការទាំងពីរដូចគ្នានោះ មកពីសេចក្តីស្រឡាញ់ និងការលះបង់តែមួយដដែល ដែលមកពីសេចក្តីស្រឡាញ់ គឺឲ្យយើងស្របនឹងគម្រោការដ៏សប្បុរសរបស់ព្រះបិតា ដោយក្តីស្រឡាញ់ ដូចកូនចំពោះឪពុក ឲ្យយើងរួមរស់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រោសយើងឲ្យដូចព្រះគ្រីស្តយេស៊ូ កាន់តែខ្លាំងឡើងៗ ឲ្យយើងស្រឡាញ់មនុស្សទាំងអស់ ដោយសេចក្តីស្រឡាញ់ដែលព្រះយេស៊ូបានស្រឡាញ់យើងដែរ៖ "អ្វីៗដែលអ្នករាល់គ្នាទូលសូមពីព្រះបិតាក្នុងនាមខ្ញុំ ព្រះអង្គនឹងប្រទានឲ្យអ្នករាល់គ្នាពុំខាន។ រីឯសេចក្តីបង្គាប់របស់ខ្ញុំនោះ គឺអ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក" (យហ

១៥,១៦-១៧)។

អ្នកអធិដ្ឋានជានិច្ច គឺអ្នកដែលអធិដ្ឋានផង ធ្វើអំពើល្អផង ហើយធ្វើអំពើល្អផង អធិដ្ឋានផង។ ពេលនោះ យើងអាចយល់ឃើញថា ព្រះបន្ទូលដែលថ្លែងថា "ត្រូវតែអធិដ្ឋានជានិច្ច" អាចសម្រេចបាន (លោក អូរីសែន)។

## ការអធិដ្ឋានរបស់ព្រះយេស៊ូនៅពេលកំណត់មកដល់ហើយ

២៧៤៦-លុះពេលកំណត់មកដល់ហើយ ព្រះយេស៊ូទូលអង្វរព្រះបិតា (យហ ១៧)។ ការអធិដ្ឋានរបស់ព្រះអង្គ (ជាការអធិដ្ឋានវែងជាងគេក្នុងដំណឹងល្អ) ប្រមូលការចាត់ចែងទាំងមូលនៃការបង្កើត និងការសង្គ្រោះ ដូចការសោយទិវង្គត និងជីវិតថ្មីរបស់ព្រះអង្គ។ ការអធិដ្ឋានរបស់ព្រះយេស៊ូនៅពេលកំណត់នៅតែជាការអធិដ្ឋានរបស់ព្រះអង្គ ដូចជាបុណ្យចម្លងរបស់ព្រះអង្គ ដែលបានកើត "ម្តងជាការស្រេច" ដែលនៅតែមានវត្តមានក្នុងពិធីបុណ្យនៃព្រះសហគមន៍ព្រះអង្គដែរ។

២៧៤៧-ការបញ្ជូនបន្តនៃគ្រីស្តសាសនាហៅការអធិដ្ឋាននេះថា ជាការអធិដ្ឋានរបស់ព្រះយេស៊ូ "ក្នុងឋានៈជាបូជាចារ្យ" ដែលជាមហាបូជាចារ្យរបស់យើង ដែលមិនអាចបំបែកចេញពីយញ្ញបូជារបស់ព្រះអង្គបានទេ ដែលជា "ចម្លង" (បុណ្យចម្លង) របស់ព្រះអង្គ ឆ្ពោះទៅកាន់ព្រះបិតា ដែល "ថ្វាយ" ព្រះកាយទាំងស្រុងចំពោះព្រះបិតា (យហ ១៧,១១.១៣.១៩)។

២៧៤៨-ក្នុងការអធិដ្ឋាននៃបុណ្យចម្លងនេះ ដែលជាយញ្ញបូជា ព្រះអង្គ "ប្រមូល" អ្វីៗទាំងអស់ក្នុងអង្គព្រះអង្គ (អភ ១,១០) គឺព្រះជាម្ចាស់ និងពិភពលោក ព្រះបន្ទូល និងភាពទន់ខ្សោយរបស់មនុស្ស ជីវិតអស់កល្បជានិច្ច និងពេលវេលា សេចក្តីស្រឡាញ់ដែលប្រគល់ខ្លួន និងអំពើបាបដែលក្បត់សេចក្តីស្រឡាញ់នេះ សាវ័កដែលនៅជាមួយព្រះអង្គ និងសាវ័កដែលនឹងជឿលើព្រះអង្គ ដោយសារសក្ខីភាពរបស់គេ ការបន្ទាបខ្លួន និងសិរីរុងរឿង។ ការអធិដ្ឋាននេះ ជាការអធិដ្ឋាននៃឯកភាព។

២៧៤៩-ព្រះយេស៊ូបានបំពេញអ្វីៗទាំងអស់ដែលជាព្រះរាជកិច្ចរបស់ព្រះបិតា ហើយការអធិដ្ឋាន ដូចយញ្ញបូជារបស់ព្រះអង្គ លាតសន្ធឹងរហូតដល់អវសានកាលនៃពិភពលោក។ ការអធិដ្ឋាននៃពេលកំណត់បំពេញសម័យកាលទាំងអស់ឲ្យបានសម្រេច។ ព្រះយេស៊ូ ជាព្រះបុត្រាដែលព្រះបិតាបានប្រគល់អ្វីៗទាំងអស់ ថ្វាយខ្លួនទាំងស្រុងចំពោះព្រះបិតា។ ជាមួយគ្នានេះ ព្រះអង្គសម្តែងព្រះអង្គ ដោយមានសេរីភាពដ៏ខ្ពង់ខ្ពស់បំផុត (យហ ១៧,១១. ១៣.១៩.២៤) ដោយមានអំណាច ដែលព្រះបិតាបានប្រគល់ឲ្យលើសសត្វលោកទាំងឡាយ។ ព្រះបុត្រាដែលបានបន្ទាបខ្លួនជាអ្នកបម្រើ ជាព្រះអម្ចាស់ ជា **Pantocratôr** ។ មហាបូជាចារ្យនៃយើងដែលទូលអង្វរសម្រាប់យើង ជាមហាបូជាចារ្យដែលទូលអង្វរនៅក្នុងខ្លួនយើង ហើយជាព្រះជាម្ចាស់ដែលទទួលពាក្យអង្វររបស់យើងផងដែរ។

២៧៥០-នៅពេលយើងចូលក្នុងព្រះនាមដ៏វិសុទ្ធនៃព្រះអម្ចាស់យេស៊ូ យើងអាចទទួលសេចក្តីអធិដ្ឋានពីខាងក្នុង ដែលព្រះអង្គបង្រៀនឲ្យយើងស្គាល់ គឺ "ឱព្រះបិតានៃយើងខ្ញុំ!"។ ការអធិដ្ឋានរបស់ព្រះអង្គក្នុងឋានៈជាបូជាចារ្យជួយបំភ្លឺពាក្យសូមអង្វរនៃធម៌នេះ៖ ឲ្យគេស្គាល់ព្រះនាមព្រះបិតា (យហ ១៧,៦.១១.១២.២៦) ឲ្យព្រះរាជ្យព្រះអង្គយាងមកដល់ (សិរីរុងរឿង -យហ ១៧,១.៥.១០.២៤.២៣-២៦) ឲ្យព្រះហឫទ័យ និងគម្រោងការអំពីការសង្គ្រោះរបស់ព្រះអង្គបានសម្រេច (យហ ១៧,២.៤.៦.៩.១១.១២.២៤) ហើយឲ្យយើងរួចចាកផុតពីអំពើអាក្រក់ (យហ ១៧,១៥)។

២៧៥១-ទីបំផុត ក្នុងការអធិដ្ឋាននេះ ព្រះយេស៊ូសម្តែងឲ្យយើងស្គាល់ព្រះបិតា និងព្រះបុត្រា (យហ ១៧,៣. ៦-១០.២៥) ដែលមិនអាចបំបែកចេញពីគ្នាបានឡើយ ហើយដែលជាអាថ៌កំបាំងនៃការអធិដ្ឋានផ្ទាល់។

## សង្ខេប

២៧៥២-យើងត្រូវតែខិតខំអធិដ្ឋានជានិច្ច ប្រយុទ្ធប្រឆាំងនឹងខ្លួនឯង និងកលល្បិចនៃមេល្បួងផង។ ការប្រយុទ្ធដើម្បីអធិដ្ឋានមិនអាចបំបែកចេញពីការ "ប្រយុទ្ធនៃវិញ្ញាណ" បានឡើយ ដែលជាការចាំបាច់ ដើម្បីរស់នៅជាប្រចាំតាមព្រះវិញ្ញាណរបស់ព្រះគ្រីស្ត។ យើងអធិដ្ឋានដូចយើងរស់ ដ្បិតយើងរស់ដូចយើងអធិដ្ឋានដែរ។

២៧៥៣-ក្នុងការប្រយុទ្ធដើម្បីអធិដ្ឋាន យើងត្រូវប្រឈមមុខនឹងការយល់ឃើញខុស ដែលមកពីខ្លួនយើង ឬពីអ្នកដទៃ យើងត្រូវតស៊ូប្រឆាំងនឹងអ្វីដែលយើងគិតថា ជាបរាជ័យក្នុងការអធិដ្ឋាន។ ដើម្បីជម្នះលើការសង្ស័យទាំងប៉ុន្មាន ដែលនាំឱ្យយើងគិតថា មិនចាំបាច់អធិដ្ឋាន ឬមិនអាចអធិដ្ឋាន យើងត្រូវតែតស៊ូដោយមានចិត្តសុភាពរាបសា ជឿជាក់លើខ្លួនឯង និងលើព្រះជាម្ចាស់ ដោយមានចិត្តព្យាយាមផង។

២៧៥៤-ការលំបាកខ្លាំងជាងគេក្នុងពេលអធិដ្ឋាន កើតមាននៅពេលដែលយើងមានអារម្មណ៍រាយមាយ ឬមានចិត្តរីងស្ងួត។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នោះ ត្រូវតែផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ កែប្រែចិត្តគំនិត និងប្រុងស្មារតី។

២៧៥៥-ជាធម្មតា មានការល្បួងពីរដែលគម្រាមការអធិដ្ឋាន គឺយើងមានជំនឿតិចតួច ឬយើងបាក់ទឹកចិត្តបានសេចក្ដីថា ពេលយើងលែងលត់ដំខ្លួន ឬប្រុងស្មារតី ឬពេលយើងលែងស្វែងយល់អំពីចិត្តខ្លួនឯង យើងក៏អាចបាក់ទឹកចិត្តបាន។

២៧៥៦-យើងអាចពិបាកជឿទុកចិត្តលើព្រះជាម្ចាស់ដូចកូនម្នាក់លែងជឿលើឪពុក ពេលយើងមានអារម្មណ៍ថា ព្រះអង្គមិនបានទទួលពាក្យអង្វររបស់យើង។ ដំណឹងល្អអញ្ជើញយើងឱ្យសួរខ្លួនឯងថា តើការអធិដ្ឋានរបស់យើងស្របតាមព្រះបំណងប្រាថ្នារបស់ព្រះវិញ្ញាណឬទេ?

២៧៥៧-"ត្រូវតែអធិដ្ឋានជានិច្ច" (១ថស ៥,១៧)។ យើងតែងតែអាចអធិដ្ឋានបាន។ តាមការពិត ត្រូវតែអធិដ្ឋានជាចាំបាច់។ យើងមិនអាចបំបែកការអធិដ្ឋានពីការរស់នៅជាគ្រីស្តបរិស័ទបានឡើយ។

២៧៥៨-ការអធិដ្ឋានរបស់ព្រះយេស៊ូ ដែលគេហៅយ៉ាងត្រឹមត្រូវថា "ពាក្យអធិដ្ឋានក្នុងឋានៈជាបូជាចារ្យ" (យហ ១៧) សរុបគម្រោងការដ៏អស្ចារ្យទាំងមូលអំពីការបង្កើត និងការសង្គ្រោះ ហើយជាដើមកំណើតនៃសេចក្តីសុំនៃធម៌ឱព្រះបិតានៃយើងខ្ញុំ។

## ភាគទីពីរ៖

## សេចក្តីអធិដ្ឋានរបស់ព្រះយេស៊ូជាព្រះអម្ចាស់៖ "ឱព្រះបិតានៃយើងខ្ញុំ!"

២៧៥៩-"មានមួយថ្ងៃនោះ ព្រះយេស៊ូបានអធិដ្ឋាននៅកន្លែងមួយ។ កាលព្រះអង្គអធិដ្ឋានរួចហើយ មានសាវ័កម្នាក់ទូលព្រះអង្គថា៖ បពិត្រព្រះអម្ចាស់ សូមបង្រៀនយើងខ្ញុំឱ្យចេះអធិដ្ឋាន ដូចលោកយ៉ូហានបានបង្រៀនសិស្សរបស់លោកនោះផង" (លក ១១,១)។ ព្រះអម្ចាស់មានព្រះបន្ទូលតបនឹងសំណូមពរនេះ ដោយប្រគល់ឱ្យក្រុមសាវ័ក និងព្រះសហគមន៍របស់ព្រះអង្គនូវសេចក្តីអធិដ្ឋានសំខាន់ៗជាងគេបំផុតនៃគ្រីស្តសាសនា។ សន្តៈ លូកាសង្ខេបសេចក្តីអធិដ្ឋាននេះ ក្នុងអត្ថបទដ៏ខ្លីមួយ (ប្រាំសំណូមពរ -លក ១១,២-៤) ឯសន្តៈ ម៉ាថាយផ្តល់អត្ថបទមួយដ៏វែងជាង (ប្រាំពីរសំណូមពរ -មថ ៦,៩-១៣)។ ប្រពៃណីនៃពិធីបុណ្យព្រះសហគមន៍បានរក្សាទុកអត្ថបទ

របស់សន្តៈ ម៉ាថាយ៖ (មថ ៦,៩-១៣)។

ឱព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ!

សូមសម្ដែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ

សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់

សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ

សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ

សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ

សូមកុំបណ្ដោយឲ្យយើងខ្ញុំចាញ់ការល្បួងឡើយ

តែសូមរំដោះយើងខ្ញុំឲ្យរួចពីមារកំណាច។

២៧៦០-តាំងពីដើម ទំនៀមទម្លាប់ខាងពិធីបុណ្យបានបញ្ចប់សេចក្ដីអធិដ្ឋាននៃព្រះអម្ចាស់ ដោយលើកតម្កើងព្រះអង្គ។ ក្នុងសៀវភៅដែលមានចំណងជើងថា "ឌីដាខេ" (៨,២)៖ "ដ្បិតព្រះអង្គមានឫទ្ធានុភាព និងសិរីរុងរឿងអស់កល្បជាអង្វែងតរៀងទៅ"។ ធម្មនុញ្ញដែលមកពីក្រុមគ្រីស្ដទូត (៧,២៤,១) បន្ថែម "ព្រះអង្គគ្រងរាជ្យ" ដោយចាប់ផ្ដើម ជាសេចក្ដីដែលពិធីបុណ្យគ្រប់និកាយបានរក្សាទុក។ ប្រពៃណីខាងបូព៌ាប្រទេសបន្ថែម "ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" ក្រោយពីសិរីរុងរឿង។ ក្បួនពិធីបុណ្យនៃទីក្រុងរ៉ូមលម្អិតសំណូមពរចុងក្រោយ ដោយបន្ថែម "ទន្ទឹងរង់ចាំសុភមង្គលតាមសេចក្ដីសង្ឃឹមរបស់យើង ហើយរង់ចាំព្រះយេស៊ូគ្រីស្ដ (...) យាងមកប្រកបដោយសិរីរុងរឿង" (ទត ២,១៣) បន្ទាប់មក អង្គប្រជុំលើកតម្កើងព្រះជាម្ចាស់ តាមសេចក្ដីបញ្ចប់នៃធម្មនុញ្ញដែលមកពីក្រុមគ្រីស្ដទូត។

## ប្រការទី១៖

## "សេចក្ដីសង្ខេបនៃដំណឹងល្អទាំងមូល"

២៧៦១-"សេចក្ដីអធិដ្ឋាននៃថ្ងៃអាទិត្យពិតជាសេចក្ដីសង្ខេបនៃដំណឹងល្អទាំងមូល" (លោកទែរទូលីយ៉ាំង)។ "លុះដល់ព្រះអម្ចាស់បានប្រគល់ការអធិដ្ឋាននេះ ព្រះអង្គបន្ថែមថា៖ "ចូរសូមនោះព្រះជាម្ចាស់នឹងប្រទានឲ្យ" (លក ១១,៩)។ ម្នាក់ៗអាចទូលអង្វរសេចក្ដីអធិដ្ឋានផ្សេងៗទៅស្ថានលើ តាមតម្រូវការរបស់ខ្លួនឯង ប៉ុន្តែត្រូវចាប់ផ្ដើមដោយសូត្រសេចក្ដីអធិដ្ឋានរបស់ព្រះអម្ចាស់ ដែលនៅតែជាសេចក្ដីអធិដ្ឋានគ្រឹះសំខាន់បំផុត" (លោក ទែរទូលីយ៉ាំង)។

### ១-ស្នូលនៃព្រះគម្ពីរ

២៧៦២-ក្រោយពីបានបង្ហាញថា ទំនុកតម្កើងជាចំណីអាហារសំខាន់បំផុតនៃការអធិដ្ឋានរបស់គ្រីស្ដបរិស័ទដែលប្រមូលផ្ដុំគ្នាក្នុងសំណូមពរនៃធម៌ "ឱព្រះបិតានៃយើងខ្ញុំ" សន្តៈ អូគូស្ដាំងសន្និដ្ឋានថា៖

សូមអានសេចក្ដីអធិដ្ឋានទាំងអស់ដែលមានក្នុងព្រះគម្ពីរ ខ្ញុំគិតថា បងប្អូនមិនអាចរកឃើញអ្វីមួយផ្សេងទៀត ដែលមិនស្ថិតនៅក្នុងសេចក្ដីអធិដ្ឋាននៃថ្ងៃអាទិត្យឡើយ។

២៧៦៣-ព្រះគ្រីស្ដបំពេញព្រះគម្ពីរទាំងមូល (ធម្មវិន័យ ព្យាការី និងទំនុកតម្កើង) (លក ២៤,៤៤) នេះជា "ដំណឹងល្អ"។ សន្តៈ ម៉ាថាយសង្ខេបការប្រកាសដំណឹងល្អដំបូងបង្អស់របស់ព្រះអង្គនៅលើភ្នំ (មថ ៥-៧) ហើយ

ធម៌ "ឱព្រះបិតានៃយើងខ្ញុំ" ជាស្នូលនៃការប្រកាសនេះ។ កាលៈទេសៈទាំងអស់នោះ ជួយបំភ្លឺសំណូមពរនីមួយៗ នៃសេចក្តីអធិដ្ឋានដែលព្រះអម្ចាស់បានប្រទានឲ្យ៖

> សេចក្តីអធិដ្ឋាននៃថ្ងៃអាទិត្យជាសេចក្តីអធិដ្ឋានដ៏ល្អឥតខ្ចោះ (...)។ ក្នុងសេចក្តីអធិដ្ឋាននេះ យើងមិនគ្រាន់តែសូមអ្វីដែលយើងអាចមានបំណងប្រាថ្នាតាមរបៀបត្រឹមត្រូវប៉ុណ្ណោះទេ ថែមទាំងតាមលំដាប់លំដោយសម្រាប់ទៅតាមបំណងរបស់យើងផង។ ហេតុនេះ សេចក្តីអធិដ្ឋាននេះ មិនគ្រាន់តែបង្រៀនឲ្យយើងចេះសុំទេ ថែមទាំងអប់រំយើងខាងផ្លូវចិត្តដែរ (សន្តៈ ថូម៉ាស អាកាំង)។

២៧៦៤-ធម៌ទេសនានៅលើភ្នំជាលទ្ធិនៃជីវិត សេចក្តីអធិដ្ឋាននៃថ្ងៃអាទិត្យជាការអធិដ្ឋាន ប៉ុន្តែ ព្រះវិញ្ញាណរបស់ព្រះអម្ចាស់ប្រែបំណងប្រាថ្នារបស់យើង ជាចលនាខាងក្នុងចិត្ត ដែលណែនាំជីវិតយើង។ ព្រះយេស៊ូបង្រៀនជីវិតថ្មីនេះ តាមព្រះបន្ទូលរបស់ព្រះអង្គ ហើយបង្រៀនយើងឲ្យសូមជីវិតថ្មីនេះ ដោយការអធិដ្ឋាន។ បើយើងអធិដ្ឋានតាមរបៀបត្រឹមត្រូវ ជីវិតរបស់យើងក្នុងអង្គព្រះគ្រីស្តក៏នឹងបានត្រឹមត្រូវដែរ។

## ២-"សេចក្តីអធិដ្ឋានរបស់ព្រះអម្ចាស់"

២៧៦៥-ពាក្យសម្តី "សេចក្តីអធិដ្ឋាននៃថ្ងៃអាទិត្យ" (ពោលគឺ "សេចក្តីអធិដ្ឋានរបស់ព្រះអម្ចាស់") ដែលមកពីប្រពៃណី មានន័យថា ព្រះអម្ចាស់យេស៊ូបង្រៀន និងប្រទានការអធិដ្ឋានចំពោះព្រះបិតានៃយើង គឺពិតជាការអធិដ្ឋានតែមួយគត់ "របស់ព្រះអម្ចាស់"។ តាមការពិត តាមសេចក្តីអធិដ្ឋាននេះ ព្រះបុត្រាតែមួយប្រទានឲ្យយើងនូវព្រះបន្ទូលដែលព្រះបិតាបានប្រទានឲ្យព្រះអង្គ (យហ ១៧,៧)៖ ព្រះអង្គជាគ្រូបង្រៀនឲ្យយើងចេះអធិដ្ឋាន។ ម្យ៉ាងទៀត ដោយសារព្រះអង្គជាព្រះបន្ទូលប្រសូតជាមនុស្សដូច្នេះ ព្រះអង្គឈ្វេងយល់តម្រូវការនៃបងប្អូនរបស់ព្រះអង្គដែលជាមនុស្ស ហើយសម្តែងឲ្យយើងស្គាល់៖ ព្រះអង្គជាគំរូនៃការអធិដ្ឋានរបស់យើង។

២៧៦៦-ប៉ុន្តែ ព្រះយេស៊ូមិនឲ្យយើងប្រើពាក្យចំដែលរត់មាត់ទេ (មថ ៦,៧; ១ពង្ស ១៨,២៦-២៩)។ ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះវិញ្ញាណដ៏វិសុទ្ធបង្រៀនបុត្រធីតារបស់ព្រះជាម្ចាស់ឲ្យចេះអធិដ្ឋានចំពោះព្រះបិតារបស់គេ ដោយពាក្យសម្តី។ ព្រះយេស៊ូមិនគ្រាន់តែប្រទានពាក្យសម្តីនៃការអធិដ្ឋានរបស់យើងចំពោះព្រះបិតាទេ ថែមទាំងប្រទានព្រះវិញ្ញាណរបស់ព្រះអង្គ ដែលធ្វើឲ្យពាក្យសម្តីនោះ បានទៅជា "វិញ្ញាណ និងជីវិត" (យហ ៦,៦៣)។ លើសពីនេះទៅទៀត ព្រះបិតា "បានចាត់ព្រះវិញ្ញាណនៃព្រះបុត្រារបស់ព្រះអង្គឲ្យមកសណ្ឋិតក្នុងចិត្តយើង គឺព្រះវិញ្ញាណនេះហើយ ដែលបន្លឺព្រះសូរសៀងផងឡើងថា "អប្បា! ឱព្រះបិតា!"" (កាឡ ៤,៦) បានសេចក្តីថា យើងពិតជាអាចអធិដ្ឋានដូចបុត្រធីតារបស់ព្រះជាម្ចាស់មែន។ ដោយសារការអធិដ្ឋាន យើងថ្វាយបំណងប្រាថ្នាយើងទៅព្រះជាម្ចាស់ គឺព្រះបិតាដដែល ដែល "ឈ្វេងយល់ចិត្តមនុស្ស ទ្រង់ជ្រាបព្រះបំណងរបស់ព្រះវិញ្ញាណ ព្រោះព្រះវិញ្ញាណទូលអង្វរឲ្យប្រជាជនដ៏វិសុទ្ធស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់" (រម ៨,២៧)។ ការអធិដ្ឋានចំពោះព្រះបិតាជ្រួតជ្រាបក្នុងបេសកកម្មដ៏អស្ចារ្យនៃព្រះបុត្រា និងព្រះវិញ្ញាណ។

## ៣-ការអធិដ្ឋានរបស់ព្រះសហគមន៍

២៧៦៧-តាំងពីដើមដំបូង ព្រះសហគមន៍បានទទួល និងបានរស់នៅតាមព្រះអំណោយទាននៃព្រះបន្ទូលរបស់ព្រះអម្ចាស់ និងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលមិនអាចបំបែកចេញពីគ្នាបាន ហើយដែលផ្តល់ជីវិតក្នុងចិត្តអ្នកជឿ។ សហគមន៍ដំបូងសូត្រសេចក្តីអធិដ្ឋាននៃព្រះអម្ចាស់ "មួយថ្ងៃបីដង" (ឌីដាខេ) ជំនួស "ពិធីប្រទានពរទាំងដប់ប្រាំបី" តាមទំនៀមទម្លាប់នៃពិធីបុណ្យរបស់ជនជាតិយូដា។

២៧៦៨-តាមការបញ្ជូនបន្តដែលមកពីក្រុមគ្រីស្តទូត សេចក្តីអធិដ្ឋានរបស់ព្រះអម្ចាស់ចាក់ឫសក្នុងសេចក្តីអធិដ្ឋាននៃពិធីបុណ្យ។

ព្រះអម្ចាស់បង្រៀនយើងឲ្យអធិដ្ឋានរួមគ្នាចំពោះបងប្អូនយើងទាំងអស់ ដ្បិតព្រះអង្គពុំមានព្រះបន្ទូលថា "ឱព្រះបិតានៃខ្ញុំ" ដែលគង់នៅស្ថានបរមសុខទេ ប៉ុន្តែ ព្រះអង្គមានព្រះបន្ទូលថា ឱព្រះបិតានៃ "យើងខ្ញុំ" ដើម្បីឲ្យការអធិដ្ឋានរបស់យើងមានព្រលឹងតែមួយ ចំពោះព្រះកាយទាំងមូលនៃព្រះសហគមន៍ (សន្តៈ យ៉ូហាន គ្រីសូស្តូម)។

ក្នុងប្រពៃណីខាងពិធីបុណ្យទាំងអស់ សេចក្តីអធិដ្ឋាននៃព្រះអម្ចាស់ជាផ្នែកសំខាន់បំផុតនៃការអធិដ្ឋានតាមពេលកំណត់។ អគ្គសញ្ញាទាំងបីដំបូងនៃគ្រីស្តសាសនាបង្ហាញបញ្ជាក់ថា សេចក្តីអធិដ្ឋាននៃព្រះអម្ចាស់ ពិតជាសេចក្តីអធិដ្ឋាននៃព្រះសហគមន៍មែន៖

២៧៦៩-ក្នុងអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញា លាបថ្ងាស ពីធីបញ្ជូន (traditio) ធម៌ "ឱព្រះបិតានៃយើងខ្ញុំ" មានន័យថា កំណើតថ្មីនៃជីវិតដែលជាព្រះជាម្ចាស់។ ដោយសារគ្រីស្តបរិស័ទអធិដ្ឋាន ដោយនិយាយសន្ទនាជាមួយព្រះជាម្ចាស់ ដោយព្រះបន្ទូលផ្ទាល់របស់ព្រះជាម្ចាស់ "អស់អ្នកដែលកើតជាថ្មី (...) ដោយព្រះបន្ទូលរបស់ព្រះដែលមានព្រះជន្មគង់នៅ" (១ពត្រ ១,២៣) រៀនអង្វរព្រះបិតារបស់គេ តាមតែព្រះបន្ទូល ដែលព្រះអង្គតែងតែទទួលជានិច្ច។ គេអាចអង្វរព្រះជាម្ចាស់បែបនេះ ពីព្រោះឥឡូវនេះ ប្រេងអភិសេកនៃព្រះវិញ្ញាណដ៏វិសុទ្ធគង់សណ្ឋិតនៅក្នុងចិត្ត ត្រចៀក បបូរមាត់ រូបកាយទាំងមូលរបស់គេ។ ហេតុនេះហើយបានជាអធិប្បាយភាគច្រើននៃគ្រូបាធ្យាយអំពីធម៌ "ឱព្រះបិតានៃយើងខ្ញុំ" សំដៅទៅលើអ្នកស្វែងយល់ និងពន្លកថ្មី។ ពេលព្រះសហគមន៍សូត្រធម៌សេចក្តីអធិដ្ឋាននៃព្រះអម្ចាស់ គឺប្រជាជននៃ "អស់អ្នកដែលទើបកើតមក" ដែលតែងតែអធិដ្ឋាន និងទទួលធម៌មេត្តាករុណាជានិច្ច (១ពត្រ ២,១-១០)។

២៧៧០-ក្នុងពិធីបុណ្យនៃអភិបូជា សេចក្តីអធិដ្ឋាននៃព្រះអម្ចាស់ជាការអធិដ្ឋាននៃព្រះសហគមន៍ទាំងមូល។ នៅពេលនោះ ព្រះជាម្ចាស់សម្តែងអត្ថន័យពេញលេញ និងប្រសិទ្ធភាពនៃសេចក្តីអធិដ្ឋាននេះ។ សេចក្តីអធិដ្ឋាននេះ ស្ថិតនៅរវាងធម៌អរព្រះគុណ និងពិធីទទួលព្រះកាយ ប្រមូលសំណូមពរ និងពាក្យជួយអង្វរទាំងឡាយ ដែលធម៌ "គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត ជាដើម" បានសរុប ហើយគោះទ្វារនៃពិធីជប់លៀងនៃព្រះរាជ្យ ដែលយើងប្រកាសទុកជាមុនពេលទទួលព្រះកាយព្រះគ្រីស្ត។

២៧៧១-ក្នុងអគ្គសញ្ញាអរព្រះគុណ សេចក្តីអធិដ្ឋាននៃព្រះអម្ចាស់សម្តែងថា សំណូមពរនឹងសម្រេចនៅពេលអវសានកាលនៃពិភពលោក។ សេចក្តីអធិដ្ឋាននេះ ជាសេចក្តីអធិដ្ឋាននៃ "ពេលចុងក្រោយបំផុត" ជាពេលនៃការសង្គ្រោះ ដែលបានចាប់ផ្តើម ដោយព្រះជាម្ចាស់បានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ ហើយដែលនឹងបញ្ចប់នៅពេលព្រះអម្ចាស់នឹងយាងមកវិញ។ សំណូមពរចំពោះព្រះបិតានៃយើងខ្ញុំ ផ្ទុយពីសេចក្តីអធិដ្ឋាននៃសម្ព័ន្ធមេត្រីចាស់ ពឹងផ្អែកលើគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ ដែលបានកើតជារូបរាងរួចហើយ ម្តងជាការស្រេច ក្នុងអង្គព្រះគ្រីស្ត ដែលបានសោយទិវង្គត និងមានព្រះជន្មថ្មី។

២៧៧២-សេចក្តីសង្ឃឹមផុសចេញពីជំនឿដែលមិនចេះប្រែប្រួលនេះ ហើយលើកសំណូមពរទាំងប្រាំពីរនីមួយៗ ដែលសម្តែងនូវពាក្យត្អូញត្អែរនៃបច្ចុប្បន្នកាល ជាពេលនៃភាពអត់ធ្មត់ និងការរង់ចាំ ជាពេលដែល "ព្រះជាម្ចាស់ពុំទាន់បានសម្តែងឲ្យយើងដឹងនៅឡើយ អ្វីដែលយើងនឹងទៅជាយ៉ាងណាៗនោះទេ" (១យហ ៣,២) (កូឡ ៣,៤)។ អគ្គសញ្ញាអរព្រះគុណ និងធម៌ "ឱព្រះបិតានៃយើងខ្ញុំ" មាន "រហូតដល់ព្រះអម្ចាស់យាងមកវិញ" (១ករ ១១,២៦)។

## សង្ខេប

២៧៧៣-ដើម្បីឆ្លើយតបនឹងក្រុមសាវ័ក ("បពិត្រព្រះអម្ចាស់ សូមបង្រៀនយើងខ្ញុំឲ្យចេះអធិដ្ឋាន" លក ១១, ១) ព្រះយេស៊ូប្រគល់ឲ្យគេនូវសេចក្ដីអធិដ្ឋានសំខាន់ៗជាងគេបំផុតនៃគ្រីស្ដសាសនា។

២៧៧៤-សេចក្ដីអធិដ្ឋាននៃថ្ងៃអាទិត្យពិតជាសេចក្ដីសង្ខេបនៃដំណឹងល្អទាំងមូល (លោកទែរទូលីយ៉ាំង) ជាសេចក្ដីអធិដ្ឋានដ៏ល្អឥតខ្ចោះ (សន្ដ: ថូម៉ាស នៃអាកាំង)។ សេចក្ដីអធិដ្ឋាននេះ ជាស្នូលនៃព្រះគម្ពីរ។

២៧៧៥-គេហៅសេចក្ដីអធិដ្ឋាននេះថា "សេចក្ដីអធិដ្ឋាននៃថ្ងៃអាទិត្យ" ដ្បិតសេចក្ដីអធិដ្ឋាននេះមកពីព្រះយេស៊ូជាម្ចាស់ និងគំរូឲ្យយើងអធិដ្ឋាន។

២៧៧៦-សេចក្ដីអធិដ្ឋាននៃថ្ងៃអាទិត្យជាការអធិដ្ឋានយ៉ាងពិសេសរបស់ព្រះសហគមន៍ ជាផ្នែកសំខាន់បំផុតនៃការអធិដ្ឋានតាមពេលកំណត់ និងរបស់អគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្ដបរិស័ទពេញលេញ គឺពិធីជ្រមុជទឹក ពិធីលាបថ្វាស និងពិធីអរព្រះគុណ។ ក្នុងអគ្គសញ្ញាអរព្រះគុណ សេចក្ដីអធិដ្ឋាននេះសម្ដែងថា សំណូមពរនឹងសម្រេចនៅពេលអវសានកាលនៃពិភពលោក ដោយជឿសង្ឃឹមលើព្រះអម្ចាស់ "រហូតដល់ព្រះអង្គនឹងយាងមកវិញ"(១ករ ១១,២៦)។

# ប្រការទី២៖

## "ឱព្រះបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខ"

### ១-"ត្រូវហ៊ានចូលទៅជិតព្រះជាម្ចាស់ពោរពេញដោយទំនុកចិត្ត"

២៧៧៧-ក្នុងពិធីបុណ្យអភិបូជានៃទីក្រុងរ៉ូម គេសូមឲ្យអង្គប្រជុំសូត្រធម៌ "ឱព្រះបិតានៃយើងខ្ញុំ" ដោយមានចិត្តក្លាហាន។ ពិធីបុណ្យខាងបូព៌ាប្រទេសប្រើពាក្យសម្ដីស្រដៀងគ្នា៖ "ហ៊ានដោយជឿទុកចិត្ត" "សូមព្រះអង្គប្រោសឲ្យយើងសមនឹង"។ ពីមុខគម្ពោតដែលដុតតែមិនឆេះ ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ "កុំមកជិតកន្លែងនេះ! ចូរដោះស្បែកជើងចេញ" (សរ ៣,៥)។ មានតែព្រះយេស៊ូទេ ដែលអាចឆ្លងកាត់កន្លែងដ៏វិសុទ្ធនេះ ព្រះអង្គបាន "ប្រោសមនុស្សឲ្យបានបរិសុទ្ធផុតពីអំពើបាបរួចហើយ" (ហប ១,៣) នាំយើងជួបព្រះភ័ក្ត្រព្រះបិតា៖ "ខ្ញុំនៅឯនេះ រួមជាមួយនឹងកូនចៅ ដែលព្រះជាម្ចាស់ប្រទានឲ្យខ្ញុំ" (ហប ២,១៣)៖

> ការដឹងខ្លួនថា យើងជាទាសករនឹងជំរុញយើងឲ្យខ្មាស់អៀន លក្ខណៈរបស់យើងនៅលើផែនដីនេះនឹងរលាយជាធូលីដី បើគ្មានឫទ្ធានុភាពរបស់ព្រះបិតានៃយើងផ្ទាល់ និងព្រះវិញ្ញាណនៃព្រះបុត្រាព្រះអង្គ ដែលមកជំរុញយើងឲ្យស្រែកឡើងថា៖ "អប្បា ឱព្រះបិតា!" (រម ៨,១៥)។ (...) តើយើងជាមនុស្សទន់ខ្សោយដែលត្រូវស្លាប់ ហ៊ានស្រែកហៅព្រះអង្គដូច្នេះទេ? (សន្ដ: សិលា គ្រីសូឡូង)។

២៧៧៨-ក្នុងពិធីបុណ្យខាងបស្ចិម និងបូព៌ាប្រទេស ឫទ្ធានុភាពនៃព្រះវិញ្ញាណនេះ សម្ដែងឲ្យយើងសូត្រសេចក្ដីអធិដ្ឋាននៃព្រះអម្ចាស់ ដោយប្រើពាក្យសម្ដីដ៏ល្អៗនៃគ្រីស្ដសាសនា គឺ parrhésia បានសេចក្ដីថា មានចិត្តសាមញ្ញដែលមិនចេះវៀចវេ ជឿទុកចិត្តព្រះជាម្ចាស់ដូចកូនចំពោះឪពុក មានចិត្តរឹងប៉ឹងសង្ឃឹមទៅលើព្រះអង្គដោយត្រេកអរ មានចិត្តក្លាហាន និងសុភាពរាបសា ដឹងខ្លួនដោយជឿជាក់ថា ព្រះជាម្ចាស់ស្រឡាញ់យើង (អភ ៣,១២; ហប ៣,៦; ៤,១៦; ១០,១៩; ១យហ ២,២៨; ៣,២១; ៥,១៤)។

## ២-"ឱព្រះបិតាអើយ!"

២៧៧៩-មុននឹងឈានទៅដល់សេចក្តីអធិដ្ឋាននៃព្រះអម្ចាស់ គួរបន្សុទ្ធចិត្តយើងឲ្យចេញផុតពីគំនិតក្លែងក្លាយនៃ "លោកីយ៍នេះ"។ យើងត្រូវមានចិត្តសុភាពរាបសា ទទួលស្គាល់ថា "គ្មាននរណាស្គាល់ព្រះបិតា ក្រៅពីព្រះបុត្រា និងអ្នកដែលព្រះបុត្រាសព្វព្រះហឫទ័យសម្តែងឲ្យស្គាល់នោះទេ" ពោលគឺ "អ្នកតូចតាច" (មថ ១១,២៥-២៧)។ យើងក៏ត្រូវបន្សុទ្ធចិត្តយើងឲ្យចេញផុតពីគំនិតនៃមាតាបិតា ដែលមកពីប្រវត្តិ ឬពីវប្បធម៌ផ្ទាល់ខ្លួន ដែលមានឥទ្ធិពលលើទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់។ ព្រះជាម្ចាស់ជាព្រះបិតានៃយើងហួស និងលើសគំនិតនៃពិភពលោក។ ពេលយើងដាក់ចិត្តនៅលើព្រះជាម្ចាស់ ឬប្រឆាំងនឹងព្រះអង្គ ហាក់ដូចជាយើងបង្កើតព្រះក្លែងក្លាយ ដែលយើងត្រូវក្រាបថ្វាយបង្គំ ឬត្រូវបំផ្លាញ។ ពេលយើងអធិដ្ឋានព្រះបិតា យើងចូលក្នុងអាថ៌កំបាំងរបស់ព្រះអង្គ ទៅតាមសភាពរបស់ព្រះអង្គ និងទៅតាមអ្វីៗដែលព្រះបុត្រាបានសម្តែងឲ្យយើងស្គាល់៖

> ព្រះជាម្ចាស់មិនដែលសម្តែងពាក្យសម្តី "ព្រះជាម្ចាស់ជាព្រះបិតា" ឲ្យនរណាស្គាល់ឡើយ។ ពេលលោកម៉ូសេផ្ទាល់ទូលសួរថា តើព្រះអង្គជានរណា លោកក៏បានឮព្រះនាមផ្សេងមួយទៀត។ ចំពោះយើង ព្រះបុត្រាបានសម្តែងព្រះនាមព្រះអង្គក្នុងអង្គព្រះអង្គ ដ្បិតព្រះនាមនេះ សំដៅទៅលើព្រះនាមថ្មី គឺព្រះបិតា (លោកទែរទូលីយ៉ាំង)។

២៧៨០-យើងអាចទូលអង្វរព្រះជាម្ចាស់ដូចជា "ព្រះបិតា" ដ្បិតព្រះបុត្រាកើតជាមនុស្ស និងព្រះវិញ្ញាណព្រះអង្គសម្តែងព្រះអង្គឲ្យយើងស្គាល់។ អ្វីដែលមនុស្សលោកមិនអាចនឹកគិតដល់ ឬពួកទេវទូតមិនអាចយល់ឃើញបានទេ ពោលគឺទំនាក់ទំនងរវាងព្រះបុត្រាចំពោះព្រះបិតា (យហ ១,១) ព្រះវិញ្ញាណនៃព្រះបុត្រាធ្វើឲ្យយើងអាចចូលរួមចំណែកបានដែរ ដោយជឿថា ព្រះយេស៊ូជាព្រះគ្រីស្ត ហើយយើងកើតមកពីព្រះជាម្ចាស់ (១យហ ៥,១) ។

២៧៨១-ពេលយើងអធិដ្ឋានព្រះបិតា យើងរួមរស់ជាមួយព្រះអង្គ និងជាមួយព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត (១យហ ១,៣)។ ពេលនោះ យើងស្គាល់ និងទទួលស្គាល់ព្រះអង្គ ដោយរំភើបចិត្តកាន់តែខ្លាំងទៅៗ។ តាមការពិត ពេលយើងពោលពាក្យសម្តីដំបូងនៃសេចក្តីអធិដ្ឋានរបស់ព្រះអម្ចាស់ យើងលើកតម្កើងព្រះបិតាមុននឹងអង្វរព្រះអង្គ ដ្បិតសិរីរុងរឿងរបស់ព្រះជាម្ចាស់ គឺឲ្យយើងទទួលស្គាល់ថា ព្រះអង្គជា "ព្រះបិតា" ជាព្រះដ៏ពិតប្រាកដ។ យើងអរព្រះគុណព្រះអង្គ ដែលបានសម្តែងព្រះនាមព្រះអង្គឲ្យយើងស្គាល់ ដែលបានប្រោសយើងឲ្យជឿលើព្រះអង្គ ហើយដែលគង់នៅក្នុងខ្លួនយើង។

២៧៨២-យើងអាចក្រាបថ្វាយបង្គំព្រះបិតា ពីព្រោះព្រះអង្គបានប្រោសយើងឲ្យកើតសាជាថ្មី និងឲ្យទៅជាបុត្រធីតារបស់ព្រះអង្គ នៅក្នុងអង្គព្រះបុត្រាតែមួយរបស់ព្រះអង្គ៖ ដោយសារពិធីបុណ្យជ្រមុជទឹក ព្រះអង្គប្រោសយើងឲ្យរួមក្នុងព្រះកាយព្រះគ្រីស្ត ហើយដោយសារប្រេងអភិសេកនៃព្រះវិញ្ញាណព្រះអង្គ ដែលហូរពីព្រះសិរសាដល់អវយវៈ ព្រះអង្គប្រោសយើងឲ្យទៅជា "ព្រះគ្រីស្ត"៖

តាមការពិត ព្រះជាម្ចាស់ដែលបានតម្រូវយើងទុកជាមុនឲ្យទៅជាបុត្រធីតា បានប្រោសយើងឲ្យសមស្របទៅនឹងព្រះកាយពោរពេញដោយសិរីរុងរឿងរបស់ព្រះគ្រីស្ត។ ដូច្នេះ ចាប់តាំងពីពេលនេះទៅ បងប្អូនដែលរួមចំណែកជាមួយព្រះគ្រីស្ត គេត្រូវហៅថា "ព្រះគ្រីស្ត" (សន្តៈ ស៊ីរីល នៃទីក្រុងយេរូសាឡឹម)។

មនុស្សលោកថ្មី ដែលបានកើតជាថ្មី ហើយដែលព្រះហឫទ័យប្រណីសន្តោសប្រោសឲ្យរួមជាមួយព្រះជាម្ចាស់វិញ ពោលថា "ឱព្រះបិតា!" ដ្បិតគេបានក្លាយទៅជាបុត្រធីតា (សន្តៈ ស៊ីព្រីយ៉ាំង)។

២៧៨៣-ហេតុនេះហើយបានជាដោយសារសេចក្តីអធិដ្ឋាននៃព្រះអម្ចាស់ ព្រះជាម្ចាស់សម្តែងឋានៈរបស់យើងឲ្យយើងស្គាល់ ដូចព្រះអង្គសម្តែងព្រះបិតាឲ្យយើងស្គាល់ផងដែរ (GS ២២,១)៖

ឱមនុស្សអើយ! អ្នកមិនហ៊ានលើកមុខឡើងទៅលើទេ អ្នកឈ្ងោកមើលដី ស្រាប់តែអ្នកបានទទួលការប្រោសប្រណីពីព្រះគ្រីស្ត គឺព្រះអង្គបានលើកលែងទោសឲ្យអ្នករួចពីអំពើបាបទាំងអស់។ ទៅពីអ្នកបម្រើអាក្រក់ អ្នកបានក្លាយទៅជាបុត្រដ៏ល្អ (...)។ ចូរងើបមុខមើលទៅព្រះបិតា ដែលបានលោះអ្នកដោយសារព្រះបុត្រារបស់ព្រះអង្គ ហើយចូរពោលថា៖ ឱព្រះបិតានៃយើងខ្ញុំ (...)។ ប៉ុន្តែ កុំទាមទារសិទ្ធិពិសេសណាមួយឲ្យសោះ។ ដោយឡែក ព្រះអង្គជាព្រះបិតានៃព្រះគ្រីស្តមួយអង្គគត់ ឯយើងវិញ ព្រះអង្គបានបង្កើតយើង។ ដោយមានការប្រោសប្រណីជួយឧបត្ថម្ភ ចូរអ្នកពោលថា៖ ឱព្រះបិតានៃយើងខ្ញុំ ដើម្បីបានសមជាបុត្រធីតារបស់ព្រះអង្គ (សន្តៈ អំប្រ៉ូស)។

២៧៨៤-ទោះបីព្រះជាម្ចាស់ប្រោសយើងឲ្យទៅជាបុត្រធីតា ដោយមិនគិតអំពីផលប្រយោជន៍ផ្ទាល់របស់ព្រះអង្គយ៉ាងណាក៏ដោយ ក៏យើងត្រូវតែកែប្រែចិត្តគំនិតជានិច្ច និងរស់នៅតាមរបៀបថ្មី។ ពេលយើងអធិដ្ឋានព្រះបិតារបស់យើង យើងត្រូវតែ៖

-មានបំណងប្រាថ្នាយកតម្រាប់តាមព្រះអង្គ៖ ព្រះជាម្ចាស់បានបង្កើតយើងជារូបតំណាងរបស់ព្រះអង្គ ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គប្រោសយើងឲ្យមានលក្ខណៈរបស់ព្រះអង្គវិញ យើងក៏ត្រូវតែឆ្លើយតបនឹងព្រះអង្គ។

ត្រូវតែរំឭកថា ពេលយើងហៅព្រះជាម្ចាស់ "ព្រះបិតានៃយើងខ្ញុំ" យើងក៏ត្រូវមានរបៀបរស់នៅដូចបុត្រធីតារបស់ព្រះជាម្ចាស់ (សន្តៈ ស៊ីព្រីយ៉ាំង)។

អ្នករាល់គ្នាមិនអាចហៅព្រះបិតារបស់អ្នករាល់គ្នា ជាព្រះដ៏ពោរពេញដោយសប្បុរសធម៌ បើអ្នករាល់គ្នានៅតែមានចិត្តអាក្រក់ ដ្បិតពេលនោះ អ្នករាល់គ្នាគ្មានសញ្ញាសម្គាល់នៃសប្បុរសធម៌របស់ព្រះបិតាដែលគង់នៅស្ថានបរមសុខឡើយ (សន្តៈ យ៉ូហាន គ្រីសូស្តូម)។

ត្រូវតែមើលឃើញសោភណភាពនៃព្រះបិតាជានិច្ច ហើយសោភណភាពនេះជ្រួតជ្រាបក្នុងព្រលឹងយើង (សន្តៈ គ្រេគ័រ នៃនីស)។

-មានចិត្តសុភាពរាបសាដោយជឿទុកចិត្តលើព្រះអង្គ ដែលធ្វើឲ្យយើងត្រឡប់ទៅជា "ដូចក្មេងតូចៗ" (មថ ១៨,៣) ដ្បិតព្រះបិតាសម្តែងព្រះអង្គឲ្យ "អ្នកតូចតាច" ស្គាល់ (មថ ១១,២៥)។

ត្រូវមើលឃើញព្រះជាម្ចាស់តែប៉ុណ្ណោះ ដូចជាភ្នក់ភ្លើងដ៏ធំនៃសេចក្តីស្រឡាញ់។ ព្រលឹងរលាយនៅក្នុងភ្លើងនេះ ពោរពេញទៅដោយសុភមង្គលដ៏វិសុទ្ធ ហើយនិយាយសន្ទនាជាមួយព្រះជាម្ចាស់ ដូចព្រះបិតារបស់ខ្លួនឯង យ៉ាងស្និទស្នាល និងថ្នាក់ថ្នមជាទីបំផុត (សន្តៈ យ៉ូហាន កាស៊ីយ៉ាំង)។

ព្រះបិតានៃយើងខ្ញុំ៖ ព្រះនាមនេះជំរុញយើងឲ្យអធិដ្ឋានដោយក្តីស្រឡាញ់ និងមេត្រីភាព (...) ដោយសង្ឃឹមថា យើងនឹងទទួលអ្វីដែលយើងនឹងសូម (...)។ តើព្រះអង្គអាចបដិសេធអ្វីខ្លះចំពោះពាក្យអង្វរនៃបុត្រធីតារបស់ព្រះអង្គ នៅពេលដែលព្រះអង្គបានទុកគេជាបុត្រធីតាហើយនោះ? (សន្តៈ អូគូស្តាំង)។

## ៣-ព្រះបិតា "យើងខ្ញុំ"

២៧៨៦-ព្រះបិតា "យើងខ្ញុំ" ទាក់ទងនឹងព្រះជាម្ចាស់។ គុណសព្ទនេះ មិនសម្ដែងថា ព្រះបិតាជាកម្មសិទ្ធរបស់យើងទេ ប៉ុន្តែ សម្ដែងថា យើងមានទំនាក់ទំនងថ្មីៗជាមួយនឹងព្រះជាម្ចាស់។

២៧៨៧-ពេលយើងពោលថា "ព្រះបិតានៃយើងខ្ញុំ" យើងទទួលស្គាល់ថា ព្រះបន្ទូលសន្យាប្រកបដោយសេចក្ដីស្រឡាញ់របស់ព្រះអង្គ ដែលពួកព្យាការីបានប្រកាសទុកជាមុន បានកើតជារូបរាងហើយ ក្នុងសម្ពន្ធមេត្រីថ្មី និងអស់កល្បជានិច្ច ក្នុងអង្គព្រះគ្រីស្ត គឺយើងបានទៅជាប្រជាជន "របស់" ព្រះអង្គ ហើយឥឡូវនេះ ព្រះអង្គជាព្រះ "របស់" យើង។ យើងមានទំនាក់ទំនងថ្មីជាមួយព្រះជាម្ចាស់ យើងក៏ជាកម្មសិទ្ធរវាងគ្នានឹងគ្នា ដោយមិនគិតអំពីប្រយោជន៍ផ្ទាល់៖ យើងត្រូវឆ្លើយនឹង "ព្រះហឫទ័យប្រណីសន្ដោស និងសេចក្ដីពិត" (យហ ១,១៧) ដែលព្រះជាម្ចាស់បានប្រោសប្រទានមកយើងតាមរយៈព្រះយេស៊ូគ្រីស្ត ដោយសេចក្ដីស្រឡាញ់ និងភក្ដីភាព (ហស ២,២១-២២; ៦,១-៦)។

២៧៨៨-ដោយសារសេចក្ដីអធិដ្ឋាននៃព្រះអម្ចាស់ ជាសេចក្ដីអធិដ្ឋាននៃប្រជាជនរបស់ព្រះអង្គ "នៅពេលចុងក្រោយបំផុត" ពាក្យ "យើងខ្ញុំ" សម្ដែងថា យើងជឿជាក់ និងសង្ឃឹមយ៉ាងច្បាស់លាស់ ក្នុងព្រះបន្ទូលសន្យាចុងក្រោយរបស់ព្រះជាម្ចាស់ គឺក្នុងទីក្រុងយេរូសាឡឹមថ្មី ព្រះអង្គនឹងមានព្រះបន្ទូលទៅអ្នកដែលមានជ័យជម្នះថា៖ "យើងនឹងធ្វើជាព្រះរបស់គេ ហើយគេធ្វើជាបុត្រធីតារបស់យើង" (វវ ២១,៧)។

២៧៨៩-ដោយអធិដ្ឋានព្រះបិតានៃ "យើងខ្ញុំ" យើងសំដៅទៅលើព្រះបិតារបស់ព្រះអម្ចាស់នៃយើង គឺព្រះយេស៊ូគ្រីស្ត។ យើងមិនបំបែកព្រះជាម្ចាស់ទេ ដ្បិតព្រះបិតាជា "ប្រភព និងដើមហេតុ" នៃជាតិជាព្រះជាម្ចាស់ ប៉ុន្តែយើងប្រកាសថា ព្រះបុត្រាទទួលព្រះជន្មពីព្រះអង្គ ហើយព្រះវិញ្ញាណដ៏វិសុទ្ធហូរចេញពីព្រះអង្គផងដែរ។ យើងក៏មិនច្រឡំព្រះអង្គនីមួយៗផងដែរ ដ្បិតយើងប្រកាសថា យើងរួមរស់ជាមួយព្រះបិតា និងព្រះបុត្រាព្រះអង្គព្រះយេស៊ូគ្រីស្ត ក្នុងអង្គព្រះវិញ្ញាណតែមួយរបស់អង្គទាំងពីរព្រះអង្គ។ ព្រះត្រៃឯកដ៏វិសុទ្ធរួមសភាពជាមួយគ្នា និងមិនអាចបំបែកចេញពីគ្នាបានទេ។ ពេលយើងអធិដ្ឋានព្រះបិតា យើងក្រាបថ្វាយបង្គំ និងលើកតម្កើងព្រះអង្គ រួមជាមួយព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

២៧៩០-មានព្រះជាម្ចាស់តែមួយ ហើយអស់អ្នកដែលបានកើតសាជាថ្មីពីទឹក និងពីព្រះវិញ្ញាណព្រះអង្គ (១យហ ៥,១; ១យហ ៣,៥) ដោយបានផ្ញើជីវិតទាំងស្រុងទៅលើព្រះបុត្រាតែមួយរបស់ព្រះអង្គ ទទួលស្គាល់ថាព្រះនេះជាព្រះបិតា។ ក្នុងព្រះសហគមន៍ ព្រះជាម្ចាស់ និងមនុស្សរួមរស់ជាមួយគ្នាសាជាថ្មី គឺព្រះសហគមន៍រួបរួមជាមួយព្រះបុត្រាតែមួយ ដែលបានក្លាយទៅជា "រៀមច្បងក្នុងបណ្ដាបងប្អូនជាច្រើន" (រម ៨,២៩) ព្រះសហគមន៍រួមរស់ជាមួយព្រះបិតាតែមួយ ក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធតែមួយ (អភ ៤,៤-៦)។ ពេលអធិដ្ឋានព្រះបិតា "យើងខ្ញុំ" គ្រីស្តបរិស័ទគ្រប់ៗរូបអធិដ្ឋាន ដោយរួមរស់ជាមួយព្រះជាម្ចាស់ និងដោយរួមរស់ជាមួយគ្នាផង៖ "អ្នកជឿទាំងអំបាលម៉ានមានចិត្តថ្លើមតែមួយ" (កក ៤,៣២)។

២៧៩១-ហេតុនេះហើយ ទោះជាគ្រីស្តបរិស័ទបាក់បែកគ្នាយ៉ាងណាក៏ដោយ ក៏សេចក្ដីអធិដ្ឋានចំពោះព្រះបិតានៃ "យើងខ្ញុំ" នៅតែជាសម្បត្តិរួម ហើយជាការត្រាស់ហៅចំពោះគ្រីស្តបរិស័ទគ្រប់ៗរូប គឺដោយសារគេរួមជាមួយគ្នាដោយផ្ញើជីវិតទៅលើព្រះគ្រីស្ត និងដោយទទួលពិធីជ្រមុជទឹក គេក៏ត្រូវតែចូលរួមចំណែកក្នុងការអធិដ្ឋានរបស់ព្រះយេស៊ូ ដើម្បីឲ្យសាវ័កព្រះអង្គរួមគ្នាជាធ្លុងតែមួយ (UR ៨; ២២)។

២៧៩២-ទីបំផុត បើយើងអធិដ្ឋានព្រះបិតា "យើងខ្ញុំ" ដោយសេចក្ដីពិត យើងលែងគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដ្បិតសេចក្ដីស្រឡាញ់ដែលយើងទទួល រំដោះយើងឲ្យរួចពីគិតបែបនេះ។ "យើងខ្ញុំ" ក្នុងសេចក្ដីអធិដ្ឋាននៃព្រះអម្ចាស់ មិនប្រកាន់អ្នកណាឡើយ។ ដើម្បីពោល "យើងខ្ញុំ" ដោយសេចក្ដីពិត (មថ ៥,២៣-២៤; ៦,១៤-១៦) យើងក៏ត្រូវតែលែងជំទាស់ និងបាក់បែកគ្នា។

២៧៩៣-បើគេមិននឹកគិតដល់ អស់អ្នកដែលព្រះអង្គបានប្រគល់ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ គ្រីស្តបរិស័ទមិនអាចអធិដ្ឋានព្រះបិតានៃ "យើងខ្ញុំ" ឡើយ។ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់គ្មានព្រំដែនទេ ការអធិដ្ឋានរបស់យើងក៏មិនអាចមានព្រំដែនដែរ (NA ៥)។ ពេលយើងអធិដ្ឋានព្រះបិតានៃ "យើងខ្ញុំ" យើងចូលក្នុងសេចក្ដីស្រឡាញ់ដែលព្រះគ្រីស្តបានសម្ដែងឲ្យយើងស្គាល់ គឺយើងអធិដ្ឋានរួមជាមួយ និងសម្រាប់អស់អ្នកដែលមិនទាន់ស្គាល់ព្រះអង្គ ដើម្បីឲ្យគេ "រួបរួមជាប្រជាជនតែមួយ" (យហ ១១,៥២)។ ព្រះជាម្ចាស់តែងតែណែនាំអ្នកអធិដ្ឋានដ៏ល្បីឲ្យខ្វល់ខ្វាយអំពីមនុស្សលោកទាំងអស់ និងពិភពលោកទាំងមូល គឺពេលយើងហ៊ានសូត្រធម៌ព្រះបិតានៃ "យើងខ្ញុំ" ព្រះអង្គពង្រីកការអធិដ្ឋានរបស់យើងឲ្យទូលំទូលាយ និងពោរពេញដោយសេចក្ដីស្រឡាញ់។

## ៤-"ដែលគង់នៅស្ថានបរមសុខ"

២៧៩៤-ពាក្យសម្ដីដែលមកពីព្រះគម្ពីរនេះ មិនសំដៅទៅលើកន្លែង ("ទីតាំង") ទេ ប៉ុន្តែ សំដៅទៅលើស្ថានភាពមួយ។ យ៉ាងណាមិញ ពាក្យសម្ដីនេះ មិនសម្ដែងថា ព្រះជាម្ចាស់គង់នៅឆ្ងាយពីយើងទេ ប៉ុន្តែ ព្រះអង្គពោរពេញដោយភាពថ្កុំថ្កើងដ៏ខ្ពង់ខ្ពស់ជាទីបំផុត។ ព្រះបិតារបស់យើងមិនគង់ "នៅកន្លែងផ្សេង" ទេ យើងមិនអាចយល់ឃើញដល់ភាពដ៏វិសុទ្ធដ៏លើសលប់ឥតផ្ទឹមរបស់ព្រះអង្គបានឡើយ។ ដោយសារព្រះជាម្ចាស់ជាព្រះដ៏វិសុទ្ធបំផុត ព្រះអង្គក៏គង់នៅជិតអ្នកដែលមានចិត្តសោកសង្រេង និងសុភាពរាបសា៖

> ត្រូវតែយល់ថា ពាក្យសម្ដី "ព្រះបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខ" សំដៅទៅលើចិត្តរបស់មនុស្សសុចរិត ដែលជាព្រះដំណាក់របស់ព្រះជាម្ចាស់។ យ៉ាងណាមិញ អ្នកអធិដ្ឋាននឹងប៉ងប្រាថ្នាចង់ឲ្យព្រះជាម្ចាស់យាងមកគង់នៅក្នុងចិត្តគេ (សន្ត: អូគូស្តាំង)។
>
> "ស្ថានបរមសុខ" អាចសំដៅទៅលើអស់អ្នកដែលជារូបដំណាងនៃបរមលោក ហើយដែលមានព្រះជាម្ចាស់គង់នៅ និងយាងកំសាន្ត (សន្ត: ស៊ីរីល នៃទីក្រុងយេរូសាឡឹម)។

២៧៩៥-និមិត្តរូបនៃស្ថានបរមសុខធ្វើឲ្យយើងនឹកគិតដល់គម្រោងការដ៏អស្ចារ្យនៃសម្ពន្ធមេត្រី ដែលយើងទទួលក្នុងពេលអធិដ្ឋាន។ ព្រះអង្គគង់នៅស្ថានបរមសុខ ដែលជាព្រះដំណាក់របស់ព្រះអង្គ ព្រះដំណាក់របស់ព្រះបិតាក៏ជា "មាតុភូមិ" របស់យើងដែរ។ អំពើបាបបាននិរទេសយើងចេញពីទឹកដីនៃសម្ពន្ធមេត្រី (កណ ៣) ពេលយើងកែប្រែចិត្តគំនិត ធ្វើឲ្យយើងត្រឡប់ទៅឯព្រះបិតា គឺស្ថានបរមសុខវិញ (យរ ៣,១៩.៤,១ក; លក ១៥,១៨.២១)។ ក្នុងអង្គព្រះគ្រីស្ត មេឃ និងដីសម្រុះសម្រួលនឹងគ្នា (អស ៤៥,៨; ទន ៨៥,២) ដ្បិតព្រះបុត្រា "យាងចុះពីស្ថានបរមសុខ" តែមួយព្រះអង្គ ហើយទ្រង់ក៏ប្រោសយើងឲ្យឡើងទៅស្ថានបរមសុខ រួមជាមួយព្រះអង្គវិញ ដោយសារព្រះឈើឆ្កាង ដោយព្រះអង្គមានព្រះជន្មថ្មី និងយាងឡើងស្ថានបរមសុខ (យហ ១២,៣២; ១៤,២-៣; ១៦,២៨; ២០,១៧; អភ ៤,៩-១០; ហប ១,៣; ២,១៣)។

២៧៩៦-ពេលព្រះសហគមន៍អធិដ្ឋាន "ព្រះបិតាដែលគង់នៅស្ថានបរមសុខ" ព្រះសហគមន៍ប្រកាសថា យើងជាប្រជាជនរបស់ព្រះជាម្ចាស់ ដែល "អង្គុយលើបល្ល័ង្កនៅស្ថានបរមសុខរួមជាមួយព្រះគ្រីស្តយេស៊ូ" (អភ ២,៦)

"កប់ទុកជាមួយព្រះគ្រីស្តក្នុងព្រះជាម្ចាស់" (កូឡ ៣,៣) ជាមួយគ្នានេះ "យើងតែងតែថ្ងូញថ្ងែរ សង្វាតចង់បានរូបកាយសួគ៌មកគ្របពីលើរូបកាយនេះថែមទៀត គឺឲ្យតែយើងបានរូបកាយថ្មី ប្រសើរជាជាងគ្មាន" (២ករ ៥,២) (ភីល ៣,២០; ហប ១៣,១៤)៖

គ្រីស្តបរិស័ទរស់នៅក្នុងលោកីយ៍ ប៉ុន្តែពួកគេមិនរស់នៅតាមលោកីយ៍ទេ។ ពួកគេរស់នៅលើផែនដី តែពួកគេជាប្រជារាស្ត្រនៃស្ថានបរមសុខ (លិខិតផ្ញើជូនលោកឌីយ៉ូញ៉ែត)។

## សង្ខេប

២៧៩៧-គួរមានចិត្តសាមញ្ញ និងស្មោះត្រង់ ជឿទុកចិត្ត ដោយមានចិត្តសុភាពរាបសា និងដោយត្រេកអរ ដើម្បីអធិដ្ឋានធម៌ឱព្រះបិតានៃយើងខ្ញុំ។

២៧៩៨-យើងអាចទូលអង្វរព្រះជាម្ចាស់ដូចជា "ព្រះបិតា" ដ្បិតព្រះបុត្រាកើតជាមនុស្ស បានសម្តែងព្រះអង្គឲ្យយើងស្គាល់។ ម្យ៉ាងទៀត ដោយសារពិធីជ្រមុជទឹក យើងចូលរួមក្នុងអង្គព្រះគ្រីស្ត និងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។

២៧៩៩-សេចក្តីអធិដ្ឋានរបស់ព្រះអម្ចាស់ធ្វើឲ្យយើងរួបរួមជាមួយព្រះបិតា និងព្រះបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត។ ជាមួយគ្នានេះ សេចក្តីអធិដ្ឋាននេះ សម្តែងឲ្យយើងស្គាល់ខ្លួនឯង (GS ២២,១)។

២៨០០-នៅពេលដែលយើងអធិដ្ឋានព្រះបិតាយើង យើងមានបំណងយកតម្រាប់តាមព្រះអង្គ និងមានចិត្តសុភាពរាបសាដោយជឿទុកចិត្តលើព្រះអង្គ។

២៨០១-ពេលយើងពោលថា "ព្រះបិតានៃយើងខ្ញុំ" យើងអង្វរសម្ព័ន្ធមេត្រីថ្មីក្នុងអង្គព្រះយេស៊ូគ្រីស្ត ការរួបរួមជាមួយព្រះត្រៃឯកដ៏វិសុទ្ធ និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលលាតសន្ធឹងពេញពិភពលោកទាំងមូលតាមរយៈព្រះសហគមន៍។

២៨០២-"ដែលគង់នៅស្ថានបរមសុខ" មិនសំដៅទៅលើកន្លែងទេ ប៉ុន្តែសំដៅទៅលើភាពថ្កើងថ្កុំខ្ពង់ខ្ពស់បំផុតរបស់ព្រះជាម្ចាស់ និងវត្តមានរបស់ព្រះអង្គក្នុងចិត្តមនុស្សសុចរិត។ ស្ថានបរមសុខជាព្រះដំណាក់របស់ព្រះបិតាជាមាតុភូមិយ៉ាងពិតប្រាកដ ដែលយើងតម្រង់ទៅ ហើយដែលជាកម្មសិទ្ធិរបស់យើងរួចទៅហើយ។

## ប្រការទី៣៖

## សំណូមពរទាំងប្រាំពីរ

២៨០៣-ក្រោយពីបានប្រោសយើងឲ្យជួបព្រះជាម្ចាស់ជាព្រះបិតានៃយើង ដើម្បីក្រាបថ្វាយបង្គំ ស្រឡាញ់ និងលើកតម្កើងព្រះអង្គ ព្រះវិញ្ញាណធ្វើឲ្យយើងទូលអង្វរព្រះអង្គដោយសំណូមពរទាំងប្រាំពីរ គឺសូមឲ្យព្រះអង្គប្រទានពរប្រាំពីរដង។ សំណូមពរទាំងបីដំបូង ដែលទាក់ទងនឹងព្រះជាម្ចាស់ ទាក់ទាញឲ្យយើងទៅរកសិរីរុងរឿងរបស់ព្រះបិតា រីឯសំណូមពរទាំងបួនចុងក្រោយ ហាក់ដូចជាផ្លូវឆ្ពោះទៅកាន់ព្រះអង្គ ថ្វាយភាពវេទនារបស់យើងចំពោះព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ (ទន ៤២,៨)។

២៨០៤-សំណូមពរដំបូងនាំយើងឆ្ពោះទៅព្រះជាម្ចាស់ ដើម្បីព្រះអង្គ៖ ព្រះនាមរបស់ព្រះអង្គ ព្រះរាជ្យរបស់

ព្រះអង្គ ព្រះហឫទ័យរបស់ព្រះអង្គ! ពេលយើងស្រឡាញ់យ៉ាងពិតប្រាកដ យើងនឹកគិតដល់អ្នកដែលយើងស្រឡាញ់សិន។ ក្នុងសំណូមពរទាំងបីនោះ យើងមិននិយាយអំពីខ្លួនឯងទេ តែ "បំណងប្រាថ្នាដ៏ខ្លាំង" "សេចក្តីតាន់តឹង" ផ្ទាល់របស់ព្រះបុត្រាជាទីស្រឡាញ់ចំពោះសិរីរុងរឿងនៃព្រះបិតារបស់ព្រះអង្គ ដែលប្រោសយើង (លក ២២,១៤; ១២,៥០)៖ "សូមឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ (...) សូមឲ្យព្រះរាជ្យយាងមកដល់ (...) សូមឲ្យព្រះហឫទ័យបានសម្រេច (...)៖ យញ្ញបូជារបស់ព្រះគ្រីស្តជាព្រះសង្គ្រោះបានទទួលសំណូមពរទាំងបីនោះហើយ ប៉ុន្តែ ឥឡូវនេះ យើងទូលសូមអង្វរព្រះអង្គ ដោយសង្ឃឹមថា ព្រះអង្គនឹងបំពេញសំណូមពរនោះឲ្យបានពេញលក្ខណៈ រហូតដល់ព្រះជាម្ចាស់គ្រង់រាជ្យលើអ្វីៗទាំងអស់គ្រប់ប្រការ (១ករ ១៥,២៨)។

២៨០៥-សំណូមពរទាំងបួនចុងក្រោយមានដូចក្នុងធម៌ប្រសិទ្ធព្រះកាយនៃអភិបូជា គឺយើងថ្វាយការរង់ចាំទាំងប៉ុន្មានរបស់យើង ហើយយើងទាក់ទាញព្រះបិតានៃធម៌មេត្តាករុណា។ សំណូមពរចេញមកពីយើង ហើយមានប្រយោជន៍សម្រាប់យើងចាប់តាំងពីឥឡូវនេះទៅ នៅក្នុងលោកនេះ៖ "សូមប្រទានឲ្យយើង (...) សូមលើកលែងទោសឲ្យយើង (...) កុំបណ្តោយឲ្យយើង (...) សូមរំដោះយើងខ្ញុំ"។ សំណូមពរទីបួន និងទីប្រាំទាក់ទងនឹងការរស់នៅរបស់យើង ដើម្បីឲ្យព្រះអង្គជួយចិញ្ចឹម ឬឲ្យទ្រង់ជួយព្យាបាលពីអំពើបាប។ រីឯសំណូមពរទាំងពីរចុងក្រោយទាក់ទងនឹងការប្រយុទ្ធរបស់យើង ដើម្បីឲ្យជីវិតទទួលជោគជ័យ ជាការប្រយុទ្ធនៃការអធិដ្ឋានផ្ទាល់។

២៨០៦-ដោយសារសំណូមពរទាំងបីដំបូង ព្រះជាម្ចាស់ពង្រឹងជំនឿរបស់យើង ហើយប្រទានសេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់មកយើង។ យើងជាសត្វលោក នៅតែប្រព្រឹត្តអំពើបាប យើងក៏ត្រូវតែសុំសម្រាប់យើង គឺសម្រាប់មនុស្សលោកទាំងអស់ក្នុងពិភពលោកទាំងមូលគ្រប់ជំនាន់ ដែលយើងថ្វាយចំពោះសេចក្តីស្រឡាញ់ដ៏ឥតព្រំដែននៃព្រះរបស់យើង ដ្បិតព្រះបិតារបស់យើងបំពេញគម្រោងការរបស់ព្រះអង្គសង្គ្រោះយើង និងពិភពលោកទាំងមូល តាមរយៈព្រះនាមនៃព្រះគ្រីស្តរបស់ព្រះអង្គ និងការសោយរាជ្យនៃព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ។

## ១-"សូមឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ"

២៨០៧-តាមភាសាដើម ត្រូវបកប្រែថា "សូមឲ្យព្រះនាមព្រះអង្គបានវិសុទ្ធ"។ ប្រធាននៃពាក្យ "ឲ្យបានវិសុទ្ធ" មិនមែនជាមនុស្សទេ (មានតែព្រះជាម្ចាស់ដែលប្រោសឲ្យបានវិសុទ្ធ) តែត្រូវតែយល់ថា សូមឲ្យមនុស្សទទួលស្គាល់ថា ព្រះជាម្ចាស់ជាព្រះដ៏វិសុទ្ធ ហើយសូមឲ្យគេគោរពព្រះជាម្ចាស់ដូចជាព្រះដ៏វិសុទ្ធមែន។ ហេតុនេះ ក្នុងការក្រាបថ្វាយបង្គំ យើងអាចយល់សំណូមពរនេះ ដូចជាពាក្យសរសើរ ឬពាក្យអរព្រះគុណព្រះជាម្ចាស់ (ទន ១១១,៩; លក ១,៤៩)។ ប៉ុន្តែ ព្រះយេស៊ូបង្រៀនឲ្យយើងសូត្រសំណូមពរនេះ ដូចជាការសុំបំណងប្រាថ្នា ការរង់ចាំ ដែលព្រះជាម្ចាស់ និងមនុស្សចូលរួមជាមួយគ្នា។ ចាប់តាំងពីសំណូមពរដំបូងចំពោះព្រះបិតា យើងចូលក្នុងអាថ៌កំបាំងដ៏ស្និទ្ធស្នាលនៃភាពជាព្រះជាម្ចាស់របស់ព្រះអង្គ ហើយក្នុងវិនាដកម្មនៃការសង្គ្រោះជាតិជាមនុស្សរបស់យើង។ ពេលយើងទូលសុំព្រះជាម្ចាស់ឲ្យព្រះនាមព្រះអង្គបានវិសុទ្ធ យើងចូល "ក្នុងគម្រោងការដ៏លាក់កំបាំងនៃព្រះហឫទ័យរបស់ព្រះអង្គតាមព្រះបំណងដ៏សប្បុរស ដែលទ្រង់បានសម្រេចទុកជាមុន" ដើម្បីឲ្យយើង "បានវិសុទ្ធ និងឥតសៅហ្មងនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ព្រោះព្រះអង្គមានព្រះហឫទ័យស្រឡាញ់យើង" (អភ ១,៩.៤)។

២៨០៨-នៅពេលដ៏សំខាន់ៗនៃការចាត់ចែងរបស់ព្រះជាម្ចាស់ ព្រះអង្គសម្តែងព្រះនាមព្រះអង្គឲ្យយើងស្គាល់ ប៉ុន្តែព្រះអង្គសម្តែងព្រះនាមព្រះអង្គ ដោយបំពេញព្រះរាជកិច្ចរបស់ព្រះអង្គ។ ក៏ប៉ុន្តែ ព្រះរាជកិច្ចនេះ កើតជារូបរាងនៅក្នុងខ្លួនយើង និងដើម្បីយើង ដរាបណាព្រះនាមព្រះអង្គបានវិសុទ្ធនៅក្នុងខ្លួនយើង និងតាមរយៈយើង។

២៨០៩-ភាពដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ជាកន្លែងសំខាន់ នៃអាថ៌កំបាំងអស់កល្បជានិច្ចរបស់ព្រះអង្គដែលមិនអាចឈានទៅដល់បាន។ ព្រះគម្ពីរហៅសិរីរុងរឿង គឺជារស្មីនៃភាពថ្កុំថ្កើងរបស់ព្រះអង្គ ក្នុងការបង្កើតពិភពលោក និងក្នុងប្រវត្តិសាស្រ្តមនុស្សលោក (ទន ៨; អស ៦,៣)។ ដោយព្រះជាម្ចាស់បានធ្វើឲ្យមនុស្ស "ជាតំណាង និងមានលក្ខណៈដូចព្រះអង្គ" (កណ ១,២៦) ព្រះអង្គ "ប្រទានសិរីរុងរឿងដល់គេទុកជាមកុដរាជ្យ" (ទន ៨,៦) ប៉ុន្តែ ដោយសារមនុស្សប្រព្រឹត្តអំពើបាប គេ "គ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ" (រម ៣,២៣)។ ហេតុនេះ ព្រះជាម្ចាស់នឹងសម្តែងភាពដ៏វិសុទ្ធរបស់ព្រះអង្គ ដោយសម្តែង និងប្រទានព្រះនាមព្រះអង្គ "ដើម្បីឲ្យបានដូចព្រះអង្គដែលបង្កើតមនុស្សជាថ្មី" (កូឡ ៣,១០)។

២៨១០-ព្រះជាម្ចាស់មានព្រះបន្ទូលសន្យា និងស្បថចំពោះលោក អប្រាហាំ (ហប ៦,១៣) ប៉ុន្តែ ព្រះអង្គមិនសម្តែងព្រះនាមព្រះអង្គឲ្យលោកស្គាល់ទេ។ ព្រះអង្គចាប់ផ្តើមសម្តែងព្រះនាមព្រះអង្គឲ្យលោក ម៉ូសេ ស្គាល់ (សរ ៣,១៤) ហើយទ្រង់លាតត្រដាងព្រះនាមព្រះអង្គចំពោះប្រជាជនទាំងមូលដោយសង្គ្រោះពួកគេពីជនជាតិអេស៊ីប៖ "ព្រះអង្គមានជ័យជម្នះដ៏ត្រចះត្រចង់" (សរ ១៥,១)។ តាំងពីព្រះជាម្ចាស់បានចងសម្ព័ន្ធមេត្រីលើភ្នំស៊ីណៃ ប្រជាជននេះ ជាប្រជាជន "របស់ព្រះអង្គផ្ទាល់" ហើយពួកគេត្រូវក្លាយទៅជា "ប្រជាជាតិដ៏វិសុទ្ធ" (ឬជាភាសាហេប្រឺ "ដែលបូជាជីវិត" ជាពាក្យតែមួយ -សរ១៩,៥-៦) ដ្បិតព្រះនាមរបស់ព្រះជាម្ចាស់ស្ថិតក្នុងចំណោមពួកគេ។

២៨១១-ក៏ប៉ុន្តែ ទោះបីជាព្រះជាម្ចាស់ដ៏វិសុទ្ធប្រោសប្រទានធម្មវិន័យដ៏វិសុទ្ធម្តងហើយ និងម្តងទៀត (លវ ១៩,២៖ "អ្នករាល់គ្នាត្រូវតែវិសុទ្ធ ព្រោះយើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា យើងជាព្រះដ៏វិសុទ្ធ") ហើយទោះបីជាព្រះអម្ចាស់មានព្រះហឫទ័យអត់ធ្មត់ "ដោយសារព្រះនាមព្រះអង្គ" យ៉ាងណាក៏ដោយ ក៏ប្រជាជនបង្វែរចិត្តគំនិតពីព្រះដ៏វិសុទ្ធនៃជនជាតិអ៊ីស្រាអែល ហើយ "បានបង្អាប់បង្អោននាមដ៏វិសុទ្ធរបស់ព្រះអង្គក្នុងចំណោមប្រជាជាតិទាំងឡាយ" (អគ ២០; ៣៦) ដែរ។ ហេតុនេះហើយបានជាមនុស្សសុចរិតនៃសម្ព័ន្ធមេត្រីចាស់ អ្នកក្រីក្រដែលត្រឡប់មកពីនិរទេសវិញ និងពួកព្យាការីឆេះឆួលក្នុងចិត្តចំពោះព្រះនាមព្រះអង្គ។

២៨១២-ទីបំផុត ព្រះជាម្ចាស់សម្តែង និងប្រទានឲ្យយើងស្គាល់ព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ នៅក្នុងអង្គព្រះយេស៊ូ ដែលកើតជាមនុស្ស ដើម្បីសង្គ្រោះយើង (មថ ១,២១; លក ១,៣១) គឺព្រះយេស៊ូសម្តែងព្រះនាមព្រះអង្គតាមកិច្ចការ ព្រះបន្ទូល និងយញ្ញបូជារបស់ព្រះអង្គ (យហ ៨,២៨; ១៧,៨; ១៧,១៧- ១៩)។ ព្រះនាមព្រះអង្គជាស្នូលនៃសេចក្តីអធិដ្ឋានរបស់ព្រះយេស៊ូក្នុងឋានៈជាបូជាចារ្យ៖ "បពិត្រព្រះបិតាដ៏វិសុទ្ធ (...) ទូលបង្គំបូជាជីវិតថ្វាយព្រះអង្គជាប្រយោជន៍ដល់ពួកគេ ដើម្បីឲ្យពួកគេបានវិសុទ្ធដោយសារសេចក្តីពិត" (យហ ១៧,១៩)។ ដោយសារព្រះយេស៊ូផ្ទាល់ "ប្រោសព្រះនាមព្រះអង្គឲ្យបានវិសុទ្ធ" (អគ ២០,៣៩; ៣៦,២០-២១) ព្រះអង្គ "សម្តែង" ព្រះនាមរបស់ព្រះបិតា (យហ ១៧,៦)។ លុះដល់ពេលព្រះយេស៊ូបានសោយទិវង្គត និងមានព្រះជន្មថ្មីហើយ ព្រះបិតាប្រទានឲ្យព្រះអង្គព្រះនាមប្រសើរលើសអ្វីៗទាំងអស់ គឺព្រះយេស៊ូជាព្រះអម្ចាស់ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជាព្រះបិតា (ភីល ២,៩-១១)។

២៨១៣-ក្នុងទឹកនៃពិធីបុណ្យជ្រមុជទឹក "ព្រះជាម្ចាស់លាងសម្អាតបងប្អូន ប្រោសប្រទានឲ្យបងប្អូនបានវិសុទ្ធ ព្រមទាំងឲ្យបងប្អូនបានសុចរិត ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្ត តាមរយៈព្រះវិញ្ញាណនៃព្រះជាម្ចាស់របស់យើងរួចស្រេចទៅហើយ" (១ករ ៦,១១)។ ព្រះបិតានៃយើង "ត្រាស់ហៅយើងឲ្យបានវិសុទ្ធ" (១ថស ៤,៧) ក្នុងគ្រប់កិច្ចការទាំងអស់ "គឺព្រះអង្គនេះហើយ ដែលបានប្រោសឲ្យបងប្អូនឲ្យមានតម្លៃ ដោយចូលរួមជាមួយព្រះគ្រីស្តយេស៊ូ ដែលបានវិសុទ្ធសម្រាប់យើង" (១ករ ១,៣០) ព្រះនាមរបស់ព្រះអង្គត្រូវបានវិសុទ្ធក្នុងខ្លួនយើង និងតាម

របៈយើង ដើម្បីសិរីរុងរឿងរបស់ព្រះអង្គ និងជីវិតរបស់យើងផងដែរ។ ហេតុនេះហើយបានជាសំណូមពរដំបូងរបស់យើងសំខាន់ណាស់។

តើនរណាអាចធ្វើឲ្យព្រះជាម្ចាស់បានវិសុទ្ធ ដ្បិតគឺព្រះអង្គផ្ទាល់ដែលប្រោសឲ្យបានវិសុទ្ធ? ប៉ុន្តែ ដោយទទួលយកព្រះបន្ទូលនេះ "អ្នករាល់គ្នាត្រូវតែវិសុទ្ធសម្រាប់យើង ដ្បិតយើងជាព្រះអម្ចាស់ជាព្រះដ៏វិសុទ្ធ" (លវ ២០,២៦) សូមឲ្យយើងបានវិសុទ្ធដោយពិធីជ្រមុជទឹក យើងនឹងព្យាយាមឲ្យទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ គ្រប់ពេលពីព្រោះរៀងរាល់ថ្ងៃ យើងតែងតែប្រព្រឹត្តខុស ហើយយើងត្រូវជម្រះអំពើបាបយើង ដោយបានវិសុទ្ធជារៀងរហូត (...)។ ដូច្នេះ យើងយកការអធិដ្ឋានធ្វើជាទីពឹង ដើម្បីឲ្យភាពដ៏វិសុទ្ធរបស់ព្រះអង្គស្ថិតនៅក្នុងខ្លួនយើង (សន្តៈ ស៊ីព្រីយ៉ាំង)។

២៨១៤-ព្រះនាមរបស់ព្រះជាម្ចាស់បានវិសុទ្ធនៅក្នុងចំណោមប្រជាជាតិនានា គឺអាស្រ័យទៅលើការរស់នៅ និងការអធិដ្ឋានរបស់យើង ដែលមិនអាចបំបែកចេញពីគ្នាបានឡើយ៖

យើងសូមឲ្យព្រះជាម្ចាស់ប្រោសព្រះនាមព្រះអង្គឲ្យបានវិសុទ្ធ ដ្បិតព្រះអង្គសង្គ្រោះ និងប្រោសសត្វលោកទាំងអស់ឲ្យបានវិសុទ្ធ ដោយសារភាពដ៏វិសុទ្ធ (...) គឺព្រះនាមដែលប្រទានការសង្គ្រោះដល់ពិភពលោកដែលវង្វេង ប៉ុន្តែយើងសូមឲ្យព្រះជាម្ចាស់ប្រោសព្រះនាមព្រះអង្គនេះឲ្យបានវិសុទ្ធក្នុងខ្លួនយើង ដោយសារការរស់នៅរបស់យើង ដ្បិតបើយើងមានការរស់នៅត្រឹមត្រូវ ព្រះនាមព្រះអង្គបានវិសុទ្ធ ប៉ុន្តែ បើរបៀបរស់នៅរបស់យើងមិនត្រឹមត្រូវទេ គឺយើងប្រមាថព្រះនាមព្រះអង្គ តាមពាក្យសម្តីរបស់គ្រីស្តទូតប៉ូល៖ "ព្រោះតែអ្នករាល់គ្នា បានជាសាសន៍ដទៃប្រមាថព្រះនាមរបស់ព្រះជាម្ចាស់" (រម ២,២៤; អគ ៣៦,២០-២២)។ ដូច្នេះ យើងអធិដ្ឋានឲ្យសមនឹងភាពដ៏វិសុទ្ធក្នុងព្រលឹងយើង ដូចព្រះនាមដ៏វិសុទ្ធនៃព្រះជាម្ចាស់ដូច្នេះដែរ (សន្តៈ សិលា គ្រីសូឡូង)។

ពេលយើងនិយាយថា "សូមឲ្យព្រះនាមព្រះអង្គបានវិសុទ្ធ" គឺយើងសូមឲ្យព្រះនាមព្រះអង្គបានវិសុទ្ធក្នុងខ្លួនយើង ដែលយើងនៅក្នុងអង្គព្រះអង្គ ហើយនៅក្នុងអ្នកដទៃ ដែលព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់នៅតែរង់ចាំនៅឡើយ ដើម្បីឲ្យយើងសម្របតាមវិន័យដែលបង្ខំឲ្យអធិដ្ឋានចំពោះមនុស្សទាំងអស់ សូម្បីតែខ្មាំងសត្រូវរបស់យើងដែរ។ ហេតុនេះហើយបានជាយើងមិននិយាយចំៗថា៖ សូមឲ្យព្រះនាមព្រះអង្គបានវិសុទ្ធ "នៅក្នុងខ្លួនយើង" ដ្បិតយើងសូមឲ្យព្រះនាមព្រះអង្គបានវិសុទ្ធក្នុងមនុស្សទាំងអស់ (សន្តៈ ទែរទូលីយ៉ាំង)។

២៨១៥-សំណូមពរនេះ ដែលមានសំណូមពរផ្សេងៗ ក៏ដូចជាសំណូមពរទាំងប្រាំមួយប្រការ ត្រូវបានទទួលដោយការអធិដ្ឋានរបស់ព្រះគ្រីស្ត ។ ការអធិដ្ឋានដល់ព្រះបិតាជាការអធិដ្ឋានរបស់យើង លុះត្រាតែយើងអធិដ្ឋាន "ក្នុងនាម" នៃព្រះយេស៊ូ (យហ ១៤,១៣; ១៥,១៦; ១៦,២៤.២៦)។ ក្នុងឋានៈជាបូជាចារ្យ ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ឱព្រះបិតាដ៏វិសុទ្ធអើយ! សូមថែរក្សាអ្នកទាំងនោះដោយព្រះនាមព្រះអង្គផង" (យហ ១៧,១១)។

## ២-"សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់"

២៨១៦-ក្នុងសម្ពន្ធមេត្រីថ្មី យើងអាចបកប្រែពាក្យ **Basilea** បានបីយ៉ាង គឺ "នៃព្រះមហាក្សត្រ" "ព្រះរាជាណាចក្រ" ឬ "រាជ្យ"។ ព្រះរាជ្យរបស់ព្រះជាម្ចាស់យាងដល់មុនយើង បានយាងចូលជិតក្នុងអង្គព្រះបន្ទូលប្រសូតជាមនុស្ស ដែលត្រូវគេប្រកាសតាមរយៈដំណឹងល្អទាំងមូល ហើយបានយាងមកពេលព្រះគ្រីស្តសោយទិវង្គត និងមានព្រះជន្មថ្មី។ ពិធីជប់លៀងចុងក្រោយ និងអភិបូជាជាវេលាដែលព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមក។ ព្រះ

រាជ្យព្រះអង្គស្ថិតនៅក្នុងចំណោមយើង។ ព្រះរាជ្យនឹងយាងមកប្រកបដោយសិរីរុងរឿង នៅពេលព្រះគ្រីស្តនឹងថ្វាយព្រះរាជ្យនេះ ទៅឯព្រះបិតារបស់ព្រះអង្គវិញ ៖

> ប្រហែលជាព្រះរាជ្យរបស់ព្រះជាម្ចាស់ជាព្រះគ្រីស្តផ្ទាល់ ដែលយើងទន្ទឹងរង់ចាំជារៀងរាល់ថ្ងៃ ចង់ឲ្យព្រះអង្គយាងមកគ្រងរាជ្យយ៉ាងឆាប់រហ័ស។ ព្រះអង្គជាជីវិតថ្មីរបស់យើង ដ្បិតយើងនឹងមានជីវិតថ្មីក្នុងអង្គព្រះអង្គយ៉ាងណា ព្រះអង្គអាចជាព្រះរាជ្យរបស់ព្រះជាម្ចាស់ ដ្បិតយើងនឹងគ្រងរាជ្យក្នុងអង្គព្រះអង្គយ៉ាងនោះដែរ (សន្តៈ ស៊ីព្រីយុាំង)។

២៨១៧-ការសុំនេះ គឺជា "Maranatha" (ម៉ារ៉ាណាថា) ព្រះសូរសៀងរបស់ព្រះវិញ្ញាណ និងរបស់ព្រះមហេសី ៖ "ឱព្រះអម្ចាស់យេស៊ូអើយ! សូមយាងមក" ៖

> ទោះបីជាការអធិដ្ឋាននេះ មិនបានជំរុញឲ្យយើងសុំព្រះរាជ្យនេះយាងមកដល់ក៏ដោយ ក៏យើងនៅតែទទូចទូលអង្វរព្រះអង្គបំពេញសេចក្ដីសង្ឃឹមរបស់យើង។ ក្រោមអាសនៈ ព្រលឹងនៃមរណសាក្សីទូលអង្វរព្រះអម្ចាស់យ៉ាងខ្លាំងៗថា៖ "ឱព្រះអម្ចាស់អើយ! តើពេលណាព្រះអង្គរកយុត្តិធម៌ និងសងសឹកពួកនៅលើផែនដីដែលបានបង្ហូរឈាមយើងខ្ញុំ?" (វវ ៦,១០)។ តាមការពិត ពួកគាត់ត្រូវតែទទួលយុត្តិធម៌ នៅពេលអវសានកាលនៃពិភពលោក។ ឱព្រះអម្ចាស់អើយ! សូមឲ្យព្រះរាជ្យព្រះអង្គយាងមកយ៉ាងឆាប់រហ័ស (លោកទែរទូលីយុាំង)។

២៨១៨-ក្នុងសេចក្ដីអធិដ្ឋាននៃព្រះអម្ចាស់ យើងសូមឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមក នៅពេលដែលព្រះគ្រីស្តនឹងយាងមកវិញ (ទត ២,១៣) ប៉ុន្តែបំណងប្រាថ្នានេះ មិនបង្វែរចិត្តគំនិតរបស់ព្រះសហគមន៍អំពីបេសកកម្មរបស់ខ្លួន នៅក្នុងលោកនេះទេ ផ្ទុយទៅវិញជំរុញឲ្យព្រះសហគមន៍បំពេញបេសកកម្មនេះ ដ្បិតតាំងពីបុណ្យព្រះវិញ្ញាណយាងមក ព្រះវិញ្ញាណរបស់ព្រះអម្ចាស់មានព្រះរាជកិច្ចឲ្យព្រះរាជ្យយាងមក ទ្រង់ "បន្តការសង្គ្រោះរបស់ព្រះបុត្រាក្នុងលោកនេះ និងប្រទានឲ្យមនុស្សលោកបានវិសុទ្ធយ៉ាងពេញលេញ" (MR ធម៌អរព្រះគុណទី៤)។

២៨១៩-"ព្រះរាជ្យរបស់ព្រះជាម្ចាស់អាស្រ័យនៅលើសេចក្ដីសុចរិត សេចក្ដីសុខសាន្ត និងអំណរដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធ" (រម ១៤,១៧)។ ពេលកំណត់ចុងក្រោយរបស់យើងនោះ ជាពេលនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលត្រូវបង្ហូរ។ ហេតុនេះហើយបានជា "ជីវិតខាងលោកីយ៍" និងព្រះវិញ្ញាណបានចាប់ផ្ដើមប្រយុទ្ធប្រឆាំងនឹងគ្នាជាដាច់ខាត (កាឡ ៥,១៦-២៥) ៖

> ដោយរិះគិតពិចារណាក្នុងអង្គព្រះវិញ្ញាណ គ្រីស្តបរិស័ទត្រូវតែវិភាគឲ្យល្អិតល្អន់រវាងការលូតលាស់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ និងការរីកចម្រើននៃវប្បធម៌ និងសង្គមដែលគេរស់នៅ។ ការវែកញែកនេះមិនមែនជាការបំបែកគ្នាឡើយ។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យមានជីវិតអស់កល្បជានិច្ច មិនលុបបំបាត់ប៉ុន្តែពង្រឹងភារកិច្ចរបស់គេឲ្យអនុវត្តថាមពល និងមធ្យោបាយ ដែលគេបានទទួលពីព្រះបង្កើត ដើម្បីបម្រើយុត្តិធម៌ និងសន្តិភាពក្នុងលោកនេះ (GS ២២; ៣២; ៣៩; ៤៥; EN ៣១)។

២៨២១-សំណូមពរនេះត្រូវបានលើកយកមក និងទទួលយកក្នុងសេចក្ដីអធិដ្ឋានរបស់ព្រះយេស៊ូ (យហ ១៧,១៧-២០) ហើយស្ថិតនៅក្នុងអភិបូជាដោយមានប្រសិទ្ធភាព។ សំណូមពរនេះ បង្កើតផលផ្លែក្នុងជីវិតថ្មី តាមសុភមង្គលយ៉ាងពិតប្រាកដ (មថ ៥,១៣-១៦; ៦,២៤; ៧,១២-១៣)។

## ៣-សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដីដូចនៅលើមេឃ"

២៨២២-ព្រះបិតារបស់យើងសព្វព្រះហឫទ័យឲ្យ "មនុស្សទាំងអស់បានទទួលការសង្គ្រោះ និងបានស្គាល់សេចក្តីពិតយ៉ាងច្បាស់" (១ធម ២,៣-៤)។ ព្រះអង្គ "សម្តែងព្រះហឫទ័យអត់ធ្មត់ចំពោះបងប្អូន ព្រោះព្រះអង្គមិនសព្វព្រះហឫទ័យឲ្យនរណាម្នាក់ត្រូវវិនាសឡើយ" (២ពត្រ ៣,៩) (មថ ១៨,១៤)។ វិន័យរបស់ព្រះអង្គដែលសរុបនូវវិន័យទាំងអស់ផ្សេងទៀត និងសម្តែងព្រះបំណងទាំងស្រុងរបស់ព្រះអង្គ គឺឲ្យ "យើងស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះអង្គបានស្រឡាញ់យើងដែរ" (យហ ១៣,៣៤) (១យហ ៣; ៤; លក ១០,២៥-៣៧)។

២៨២៣-"ព្រះអង្គបានប្រោសឲ្យយើង ស្គាល់គម្រោងការដ៏លាក់កំបាំងនៃព្រះហឫទ័យរបស់ព្រះអង្គ តាមព្រះបំណងដ៏សប្បុរស ដែលទ្រង់បានសម្រេចទុកជាមុន (...) គឺប្រមូលអ្វីៗទាំងអស់ (...) ឲ្យរួមគ្នានៅក្នុងអង្គព្រះគ្រីស្តជាម្ចាស់តែមួយ។ ព្រះជាម្ចាស់បានជ្រើសរើសយើងទុកដោយឡែកក្នុងអង្គព្រះគ្រីស្ត ព្រះអង្គបានតម្រូវយើងទុកជាមុនដូច្នេះ ស្របតាមផែនការណ៍របស់ព្រះអង្គ ដែលសម្រេចគ្រប់កិច្ចការទាំងអស់តាមព្រះហឫទ័យរបស់ព្រះអង្គ" (អភ ១,៩-១១)។ យើងទូលអង្វរឲ្យគម្រោងការដ៏សប្បុរសនេះបានសម្រេចនៅលើផែនដី ដូចដែលបានសម្រេចនៅលើមេឃរួចមកហើយ។

២៨២៤-បំណងរបស់ព្រះគ្រីស្ត ក្នុងឋានៈជាមនុស្ស បានបំពេញព្រះហឫទ័យរបស់ព្រះបិតាឲ្យបានគ្រប់លក្ខណៈ និងម្តងជាការស្រេច។ ពេលចូលមកដល់ក្នុងពិភពលោក ព្រះយេស៊ូមានព្រះបន្ទូលថា៖ "បពិត្រព្រះជាម្ចាស់ ឥឡូវនេះ ទូលបង្គំសូមធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ" (ហប ១០,៧; ទន ៤០,៧)។ មានតែព្រះយេស៊ូដែលអាចមានព្រះបន្ទូលថា៖ "ខ្ញុំតែងប្រព្រឹត្តកិច្ចការណាដែលគាប់ព្រះហឫទ័យព្រះអង្គជានិច្ច" (យហ ៨,២៩)។ នៅពេលជិតសោយទិវង្គត ព្រះអង្គសុខចិត្តគាប់ព្រះហឫទ័យនេះទាំងស្រុងដោយអធិដ្ឋានថា៖ "សូមកុំឲ្យសម្រេចតាមចិត្តទូលបង្គំឡើយ គឺសូមឲ្យសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គវិញ" (លក ២២,៤២) (យហ ៤,៣៤; ៥,៣០; ៦,៣៨)។ ហេតុនេះហើយបានជាព្រះយេស៊ូ "បានបូជាព្រះជន្ម ព្រោះតែបាបរបស់យើង" (កាឡ ១,៤)។ "ព្រះយេស៊ូគ្រីស្តថ្វាយព្រះកាយរបស់ព្រះអង្គ ម្តងជាការស្រេច តាមព្រះហឫទ័យព្រះជាម្ចាស់ ហេតុនេះហើយបានជាព្រះអង្គប្រោសយើងឲ្យបានសុចរិត" (ហប ១០,១០)។

២៨២៥-"ថ្វីដ្បិតតែព្រះយេស៊ូជាព្រះបុត្រាក៏ដោយ ក៏ព្រះអង្គក៏បានរៀនស្តាប់បង្គាប់ដោយរងទុក្ខលំបាក" (ហប ៥,៨)។ យ៉ាងណាមិញ យើងដែលជាសត្វលោក និងអ្នកបាប បានក្លាយទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។ យើងទូលសូមព្រះបិតារបស់យើងឲ្យបំណងយើងរួបរួមក្នុងព្រះហឫទ័យរបស់ព្រះបុត្រា ដើម្បីគាប់ព្រះហឫទ័យព្រះអង្គរួបរួមក្នុងគម្រោងការរបស់ព្រះអង្គក្នុងការសង្គ្រោះ ដើម្បីឲ្យពិភពលោកមានជីវិត។ យើងមិនអាចធ្វើបានជាដាច់ខាត ប៉ុន្តែបើយើងរួមរស់ជាមួយព្រះយេស៊ូ និងដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ យើងអាចថ្វាយបំណងរបស់យើង និងជ្រើសរើសអ្វីដែលព្រះបុត្រាតែងតែជ្រើសរើស ដើម្បីគាប់ព្រះហឫទ័យព្រះបិតា (យហ ៨,២៩)៖

> ដោយភ្ជាប់នឹងព្រះគ្រីស្ត យើងអាចទៅជាវិញ្ញាណតែមួយជាមួយព្រះអង្គ ទើបអាចបំពេញព្រះហឫទ័យព្រះអង្គបាន ហេតុនេះព្រះហឫទ័យនេះ នឹងទៅជាល្អឥតខ្ចោះនៅលើផែនដី ដូចនៅស្ថានបរមសុខ (លោកអូរីសែន)។

សូមចាត់ទុកថា តើព្រះយេស៊ូបង្រៀនយើងឲ្យបន្ទាបខ្លួន ដោយធ្វើឲ្យយើងយល់ឃើញថា សេចក្តីសុចរិតរបស់យើងមិនពឹងលើកម្លាំងរបស់យើងតែប៉ុណ្ណោះទេ តែលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់

ដែរ។ ព្រះអង្គបង្គាប់ឲ្យគ្រីស្តបរិស័ទគ្រប់ៗរូបដែលអធិដ្ឋាន ឲ្យអធិដ្ឋានសម្រាប់ផែនដីទាំងមូល ដ្បិតព្រះអង្គគ្មានព្រះបន្ទូលថា "សូមឲ្យព្រះហឫទ័យបានសម្រេច" ក្នុងខ្លួនខ្ញុំ ឬក្នុងខ្លួនយើងទេ តែ "នៅលើផែនដីទាំងមូល" ដើម្បីឲ្យកំហុសត្រូវបញ្ចៀសចេញទៅ ដើម្បីសេចក្តីពិតសោយរាជ្យ ដើម្បីអំពើអបាយមុខត្រូវបំផ្លាញ ដើម្បីគុណធម៌រីកចម្រើន ហើយដើម្បីឲ្យផែនដីមិនខុសពីស្ថានបរមសុខទៀតទេ (សន្តៈយ៉ូហាន គ្រីសូស្តូម)។

២៨២៦-បើយើងអធិដ្ឋាន យើងអាច "ពិចារណាឃើញថា ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្វីខ្លះ" (រម ១២,២; អភ ៥,១៧) និងបានទទួល "ចិត្តស៊ូទ្រាំ ដើម្បីធ្វើតាមព្រះហឫទ័យនេះ" (ហប ១០,៣៦)។ ព្រះយេស៊ូបង្រៀនយើងថា យើងចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែនតាមពាក្យសម្តីទេ តែដោយ "ធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខ" (មថ ៧,២១)។

២៨២៧-"ព្រះជាម្ចាស់ស្តាប់តែពាក្យរបស់អ្នកដែលប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គប៉ុណ្ណោះ" (យហ ៩,៣១) (១យហ ៥,១៤)។ ការអធិដ្ឋានរបស់ព្រះសហគមន៍ ក្នុងព្រះនាមព្រះអម្ចាស់របស់ខ្លួន ជាពិសេសក្នុងអភិបូជាមានឫទ្ធានុភាព ការអធិដ្ឋាននេះ គឺជាការរួបរួមគ្នាជួយអង្វរដល់ព្រះមាតាដ៏វិសុទ្ធបំផុតរបស់ព្រះជាម្ចាស់ (លក ១,៣៨.៤៩) និងដល់សន្តបុគ្គលទាំងអស់ ដែល "ជាទីគាប់ព្រះហឫទ័យ" របស់ព្រះអម្ចាស់ ព្រោះពួកគាត់តែងតែគាប់ព្រះហឫទ័យព្រះអង្គ៖

ដោយមិនបង្ខូចសេចក្តីពិត យើងអាចបកប្រែសេចក្តីអធិដ្ឋាន "សូមឲ្យព្រះហឫទ័យបានសម្រេចនៅលើផែនដីដូចនៅលើមេឃ" ដោយអធិដ្ឋានដូច្នេះថា៖ ក្នុងព្រះសហគមន៍ដូចជាក្នុងព្រះអម្ចាស់នៃយើងព្រះយេស៊ូគ្រីស្ត ក្នុងព្រះមហេសីដែលជាគូដណ្តឹងរបស់ព្រះអង្គដូចជាក្នុងព្រះស្វាមីដែលបានបំពេញព្រះហឫទ័យរបស់ព្រះបិតា (សន្តៈ អូគូស្តាំង)។

## ៤-សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ"

២៨២៨-"សូមប្រទានមកយើងខ្ញុំ"៖ ទំនុកចិត្តរបស់បុត្រធីតា ដែលរង់ចាំអ្វីៗទាំងអស់ពីព្រះបិតារបស់គេ ពិតជាល្អណាស់! "ព្រះអង្គប្រទានឲ្យព្រះអាទិត្យរបស់ព្រះអង្គរះបំភ្លឺទាំងមនុស្សអាក្រក់ ទាំងមនុស្សល្អ ហើយទ្រង់ប្រទានទឹកភ្លៀងឲ្យទាំងមនុស្សសុចរិត ទាំងមនុស្សទុច្ចរិតផងដែរ" (មថ ៥,៤៥) ហើយព្រះអង្គប្រទាន "ចំណីអាហារតាមពេលកំណត់" (ទន ១០៤,២៧) ឲ្យអស់អ្នកដែលមានជីវិត។ ព្រះយេស៊ូបង្រៀនយើងឲ្យពោលសំណូមពរនេះ ដែលលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតានៃយើង ដ្បិតយើងទទួលស្គាល់ថា ព្រះអង្គមានសប្បុរសធម៌យ៉ាងលើសលប់។

២៨២៩-"សូមប្រទានមកយើងខ្ញុំ" សម្តែងនូវសម្ព័ន្ធមេត្រី គឺយើងជាកម្មសិទ្ធរបស់ព្រះអង្គ ហើយព្រះអង្គក៏ជាកម្មសិទ្ធរបស់យើង ដើម្បីយើងផង។ ប៉ុន្តែ "យើង" នេះ ទទួលស្គាល់ថា ព្រះអង្គជាព្រះបិតារបស់មនុស្សទាំងអស់ ហើយយើងអធិដ្ឋានចំពោះព្រះអង្គដើម្បីគេទាំងអស់គ្នា ដោយរួមសាមគ្គីជាមួយនឹងតម្រូវការ និងទុក្ខលំបាករបស់គេ។

២៨៣០-"អាហារដែលយើងខ្ញុំត្រូវការ"។ ព្រះបិតាដែលប្រទានជីវិតមកយើង ត្រូវតែប្រទានអាហារជាចាំបាច់ដើម្បីជីវិត អ្វីៗសព្វសារពើ "ដ៏ល្អសមរម្យ" ខាងសម្ភារៈផង ខាងវិញ្ញាណផង។ ពេលទេសនានៅលើភ្នំ ព្រះយេស៊ូសង្កត់ធ្ងន់លើទំនុកចិត្តដែលរួមសហការជាមួយនឹងឧបការគុណនៃព្រះបិតារបស់យើង (មថ ៦,២៥-៣៤)។ ព្រះអង្គមិនសូមឲ្យយើងខ្ជិលច្រអូសទេ (២ថស ៣,៦-១៣) ប៉ុន្តែព្រះអង្គមានព្រះហឫទ័យចង់រំដោះយើងឲ្យរួចពី

កង្វល់ណាមួយ គឺឲ្យយើងជឿទុកចិត្តលើព្រះជាម្ចាស់ ដូចកូនជឿទុកចិត្តឪពុក៖

> ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាប្រទានអ្វីៗទាំងអស់ថែមទៀត ចំពោះអស់អ្នកដែលស្វែងរកព្រះរាជ្យ និងសេចក្ដីសុចរិតរបស់ព្រះអង្គ។ តាមពិត អ្វីៗទាំងអស់ជាកម្មសិទ្ធរបស់ព្រះជាម្ចាស់៖ អ្នកណាមានព្រះជាម្ចាស់ជាកម្មសិទ្ធ ហើយស្ថិតនៅក្នុងអង្គព្រះអង្គ អ្នកនោះគ្មានខ្វះខាតអ្វីឡើយ (សន្តៈ ស៊ីព្រីយ៉ាំង)។

២៨៣១-ក៏ប៉ុន្តែ ដោយសារមានអ្នកខ្លះឃ្លានដោយគ្មានចំណីអាហារគ្រប់គ្រាន់ សំណូមពរនេះ មានអត្ថន័យជ្រាលជ្រៅមួយបែបទៀត។ ដោយសារវិនាដកម្មនៃការអត់ឃ្លានក្នុងពិភពលោក ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទដែលអធិដ្ឋានតាមសេចក្ដីពិត ឲ្យទទួលខុសត្រូវយ៉ាងពិតប្រាកដចំពោះបងប្អូនគេ តាមឥរិយាបថរៀងៗខ្លួន ដោយរួមសាមគ្គីជាមួយក្រុមគ្រួសាររបស់មនុស្សលោក។ យើងមិនអាចបំបែកសំណូមពរនៃការអធិដ្ឋានរបស់ព្រះអម្ចាស់នេះ ពីពាក្យប្រស្នាអំពីជនកម្សត់ម្នាក់ឈ្មោះ ឡាសារ (លក ១៦,១៩-៣១) និងអំពីការវិនិច្ឆ័យមនុស្សលោកនៅពេលចុងក្រោយបំផុត (មថ ២៥,៣១-៤៦) បានឡើយ។

២៨៣២-ព្រះរាជ្យរបស់ព្រះជាម្ចាស់ត្រូវលើកផែនដី ដូចមេលើកម្សៅ ដោយព្រះវិញ្ញាណរបស់ព្រះគ្រីស្ត (AA ៥)។ ព្រះរាជ្យនេះ ត្រូវសម្ដែងដោយចាត់ចែងយុត្តិធម៌ក្នុងទំនាក់ទំនងរវាងគ្នានឹងគ្នា នៅក្នុងសង្គម នៅក្នុងសេដ្ឋកិច្ច ហើយនៅក្នុងទំនាក់ទំនងអន្តរជាតិ ដោយមិនភ្លេចថា គ្មានរចនាសម្ព័ន្ធត្រឹមត្រូវទេ បើគ្មានអ្នកចង់ក្លាយទៅជាមនុស្សសុចរិត។

២៨៣៣-យើងសុំឲ្យព្រះជាម្ចាស់ប្រទាន "អាហាររបស់យើង" គឺមួយសម្រាប់មនុស្សជាច្រើន។ សុភមង្គលយ៉ាងពិតប្រាកដត្រាស់ហៅឲ្យចែករំលែក គឺឲ្យយើងផ្ដល់ និងចែករំលែកសម្បត្តិលោកីយ៍ និងសម្បត្តិសួគ៌ ដោយគ្មានការបង្ខិតបង្ខំ ប៉ុន្តែដោយក្ដីស្រឡាញ់ ដើម្បីឲ្យភាពសម្បូណ៌សប្បាយរបស់អ្នកខ្លះជួយបំពេញតម្រូវការរបស់អ្នកផ្សេងទៀត ដែលខ្វះខាត (២ករ ៨,១-១៥)។

២៨៣៤-"ចូរអធិដ្ឋាន និងធ្វើការ" (សន្តៈ បេណេឌីក)។ "ចូរអធិដ្ឋានហាក់ដូចជាអ្វីៗទាំងអស់ពឹងផ្អែកលើព្រះជាម្ចាស់ ហើយធ្វើការហាក់ដូចជាអ្វីៗទាំងអស់ពឹងផ្អែកលើខ្លួនឯង"។ ដោយបានបំពេញការងាររបស់យើង ចំណីអាហារនៅតែជាព្រះអំណោយទាននៃព្រះបិតារបស់យើង។ បើយើងសុំចំណីអាហារនេះពីព្រះអង្គ ដោយអរព្រះគុណព្រះអង្គផង យើងក៏ប្រព្រឹត្តល្អដែរ។ នេះជាអត្ថន័យនៃការប្រទានពរលើតុ ក្នុងក្រុមគ្រួសារគ្រីស្តបរិស័ទ។

២៨៣៥-សំណូមពរនេះ ដែលនាំឲ្យទៅជាការទទួលខុសត្រូវដែលទាក់ទងទៅនឹងការអត់ឃ្លានមួយទៀតរបស់មនុស្សលោក គឺ "មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូល ដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ" (ទក ៨,៣; មថ ៤,៤) ពោលគឺព្រះបន្ទូល និងខ្យល់ដង្ហើមរបស់ព្រះអង្គ។ គ្រីស្តបរិស័ទត្រូវតែខិតខំអស់ពីសមត្ថភាព ដើម្បី "ប្រកាសដំណឹងល្អប្រាប់ជនក្រីក្រ"។ មានការអត់ឃ្លាននៅលើផែនដី "មិនមែនការអត់ឃ្លានខាងអាហារ ឬការស្រេកទឹកនោះទេ ផ្ទុយទៅវិញ គឺការស្រេកឃ្លានចង់ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់" (អម ៨,១១)។ ហេតុនេះហើយបានជាសំណូមពរទីបួននេះ មានអត្ថន័យពិសេសខាងគ្រីស្តសាសនា ដែលទាក់ទងនឹងនំប៉័ងនៃជីវិត គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលត្រូវទទួលដោយមានជំនឿ និងព្រះកាយព្រះគ្រីស្តដែលយើងទទួលក្នុងអភិបូជា (យហ ៦,២៦-៥៨)។

២៨៣៦-"នៅថ្ងៃនេះ" ក៏ជាពាក្យសម្ដែងនូវទំនុកចិត្តដែរ។ ដោយសារយើងពឹងផ្អែកលើខ្លួនឯងច្រើនពេក ព្រះអម្ចាស់ក៏បង្រៀនយើងឲ្យជឿទុកចិត្ត (មថ ៦,៣៤; សរ ១៦,១៩)។ ដោយសារសំណូមពរនេះ ទាក់ទងនឹងព្រះបន្ទូល និងព្រះកាយរបស់ព្រះបុត្រាព្រះអង្គ "នៅថ្ងៃនេះ" មិនគ្រាន់តែសំដៅទៅលើពេលវេលារបស់យើង ដែល

រមែងតែងតែស្លាប់ទេ គឺជាថ្ងៃនៃព្រះជាម្ចាស់៖

> បើអ្នកទទួលអាហារជារៀងរាល់ថ្ងៃសម្រាប់អ្នករាល់ថ្ងៃ គឺជាថ្ងៃនេះ។ បើព្រះគ្រីស្តជាកម្មសិទ្ធរបស់អ្នកនៅថ្ងៃនេះ ព្រះគ្រីស្តមានព្រះជន្មថ្មីសម្រាប់អ្នកជារៀងរាល់ថ្ងៃដែរ។ តើយ៉ាងដូចម្តេច? "ព្រះអង្គជាបុត្ររបស់យើង! គឺយើងបង្កើតព្រះអង្គនៅថ្ងៃនេះ" (ទន ២,៧)។ នៅថ្ងៃនេះ ពោលគឺនៅពេលដែលព្រះគ្រីស្តមានព្រះជន្មថ្មី (សន្តៈ អំប្រ័រ)។

២៨៣៧-"នៃថ្ងៃនេះ"៖ នៅក្នុងសម្ពន្ធមេត្រីថ្មី គេមិនប្រើពាក្យ épiousios នេះ ក្រៅពីក្នុងសេចក្តីអធិដ្ឋាននៃព្រះអម្ចាស់ឡើយ។ ពាក្យនេះសំដៅទៅលើ "នៅថ្ងៃនេះ" (សរ ១៦,១៩-២១) ដើម្បីលើកទឹកចិត្តយើង ឲ្យជឿទុកចិត្ត "ដោយមិនរួញរា" និងសំដៅទៅលើអ្វីដែលជាចាំបាច់ ដើម្បីចិញ្ចឹមជីវិត គឺអ្វីដែលយើងត្រូវការដើម្បីរស់ (១ធម ៦,៨)។ តាមន័យចំ (épiousios ៖ "លើសអ្វីដែលជាចាំបាច់") ពាក្យនេះសំដៅទៅលើនំប៉័ងនៃជីវិត គឺព្រះកាយព្រះគ្រីស្ត ជា "ថ្នាំផ្តល់ជីវិតអមតៈ" (សន្តៈ អ៊ីញាស់ នៃអង់ទីអូស) បើគ្មានថ្នាំសោះ យើងក៏គ្មានជីវិតក្នុងខ្លួនឡើយ (យហ ៦,៥៣-៥៦)។ ទីបញ្ចប់ តាមន័យនៃស្ថានលើពាក្យនេះ សម្តែងថា "ថ្ងៃនេះ" ជាថ្ងៃនៃព្រះអម្ចាស់ ជាថ្ងៃនៃពិធីជប់លៀងនៃព្រះរាជ្យ ដែលយើងប្រារព្ធទុកជាមុនក្នុងអភិបូជា និងដែលផ្តល់រសជាតិទុកជាមុននៃព្រះរាជ្យដែលកំពុងយាងមក។ ហេតុនេះ គួរប្រារព្ធពិធីបុណ្យអភិបូជាជា "រៀងរាល់ថ្ងៃ"។

អភិបូជាជានំប៉័ង ជាអាហារប្រចាំថ្ងៃរបស់យើង។ គុណធម៌ពិសេសនៃអាហារនេះ ជាកម្លាំងបង្រួបបង្រួម គឺអភិបូជាបង្រួបបង្រួមយើងជាមួយនឹងព្រះកាយនៃព្រះសង្គ្រោះ ហើយប្រោសឲ្យយើងទៅជាសរីរាង្គរបស់ព្រះអង្គ ដើម្បីឲ្យយើងក្លាយទៅជាអ្វីដែលយើងបានទទួល (...)។ អាហារប្រចាំថ្ងៃនេះ មាននៅក្នុងអត្ថបទដែលអ្នករាល់គ្នាស្តាប់ជារៀងរាល់ថ្ងៃនៅព្រះសហគមន៍ ហើយនៅក្នុងបទចម្រៀងដែលយើង និងអ្នករាល់គ្នាច្រៀង។ អ្វីៗទាំងអស់នោះជាការចាំបាច់ដើម្បីបូជនិយេសចរណ៍របស់យើង (សន្តៈ អូគូស្តាំង)។

ព្រះបិតាដែលគង់នៅស្ថានបរមសុខដាស់តឿនយើង ឲ្យសុំនំប៉័ងនៃស្ថានបរមសុខ ដូចបុត្រធីតានោះដែរ (យហ ៦,៥១)។ ព្រះគ្រីស្ត "ផ្ទាល់ជានំប៉័ងដែលត្រូវបានសាបព្រោះក្នុងស្ត្រីព្រហ្មចារិនី ត្រូវបានលើកក្នុងសាច់ ត្រូវបានលាយច្របាច់ក្នុងទុក្ខលំបាក ត្រូវបានដុតក្នុងភ្លើងនៃទីបញ្ចុះសព ត្រូវបានទុកបម្រុងក្នុងព្រះសហគមន៍ ត្រូវបានថ្វាយទៅដល់អាសនៈ ហើយដែលផ្តល់អាហារនៃស្ថានបរមសុខចំពោះគ្រីស្តបរិស័ទជារៀងរាល់ថ្ងៃ" (សន្តៈ សិលាគ្រីសូឡូង)។

## ៥-"សូមអត់ទោសឲ្យយើងខ្ញុំផង ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំដែរ"

២៨៣៨-សំណូមពរនេះគួរឲ្យឆ្ងល់។ បើមានតែវគ្គទីមួយនៃឃ្លានេះ -"សូមអត់ទោសឲ្យយើងខ្ញុំ" -យើងអាចបញ្ចូលសំណូមពរនេះ ក្នុងសំណូមពរទាំងបីដំបូងនៃសេចក្តីអធិដ្ឋានរបស់ព្រះអម្ចាស់ ដ្បិតយញ្ញបូជារបស់ព្រះគ្រីស្តមាន "ដើម្បីឲ្យរួចពីបាប"។ ប៉ុន្តែ តាមវគ្គទីពីរនៃឃ្លានេះ ព្រះជាម្ចាស់នឹងទទួលសំណូមពររបស់យើង លុះត្រាតែយើងបានឆ្លើយតបនឹងការទាមទារមួយ។ សំណូមពរយើងសំដៅទៅលើអនាគត យើងក៏ត្រូវឆ្លើយតបមុនពាក្យមួយម៉ាត់ដែលជាចំណងរវាងវគ្គទាំងពីរនោះ គឺ "ដូច"។

### "សូមអត់ទោសឲ្យយើងខ្ញុំផង"

២៨៣៩-យើងបានចាប់ផ្តើមអធិដ្ឋានដល់ព្រះបិតារបស់យើង ដោយជឿទុកចិត្ត និងមានចិត្តក្លាហាន។ ដោយអង្វរឲ្យព្រះនាមព្រះអង្គបានវិសុទ្ធ (ឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ) យើងបានសូមឲ្យយើងបានវិសុទ្ធកាន់តែច្រើនឡើងៗ។ ប៉ុន្តែ ទោះបីយើងពាក់អាវសឆើតឆាយនៃពិធីជ្រមុជទឹកយ៉ាងណាក៏ដោយ ក៏យើងចេះតែប្រព្រឹត្តអំពើបាប និងឃ្លាតឆ្ងាយពីព្រះជាម្ចាស់ដែរ។ ឥឡូវនេះ តាមសំណូមពរថ្មីនេះ យើងត្រឡប់មករកព្រះអង្គវិញដូចកូនវង្វេង (លក ១៥,១១-៣២) ហើយយើងទទួលស្គាល់ថា យើងជាអ្នកមានបាប ដូចអ្នកទារពន្ធ (លក ១៨,១៣)។ សំណូមពររបស់យើងចាប់ផ្តើមដោយ "សារភាព" នូវទុក្ខវេទនារបស់យើងផង និងធម៌មេត្តាករុណារបស់ព្រះអង្គផង។ យើងមានសេចក្តីសង្ឃឹមយ៉ាងមាំមួន ដ្បិត "ដោយយើងរួមក្នុងអង្គព្រះបុត្រា ព្រះអង្គបានលោះយើង និងលើកលែងទោសយើងឲ្យរួចពីបាប" (កូល ១,១៤; អភ ១,៧)។ យើងឃើញសញ្ញាសម្គាល់ដ៏ស័ក្តសិទ្ធ ដោយគ្មានទីសង្ស័យថា ព្រះអង្គបានលើកលែងទោសឲ្យយើង ក្នុងអគ្គសញ្ញានៃព្រះសហគមន៍របស់ព្រះអង្គ (មថ ២៦,២៨; យហ ២០,២៣)។

២៨៤០-ក៏ប៉ុន្តែ ធម៌មេត្តាករុណាដ៏លើសលប់នេះ មិនអាចជ្រាបចូលក្នុងចិត្តយើងបានទេ ដរាបណាយើងមិនបានលើកលែងទោសឲ្យអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងឡើយ។ គួរឲ្យភ័យខ្លាចណាស់!។ សេចក្តីស្រឡាញ់ដូចព្រះកាយព្រះគ្រីស្ត មិនអាចបំបែកបាន គឺយើងមិនអាចស្រឡាញ់ព្រះជាម្ចាស់ដែលខ្លួនមើលពុំឃើញ បើយើងមិនស្រឡាញ់បងប្អូនដែលខ្លួនមើលឃើញទេ (១យហ ៤,២០)។ ដោយមិនព្រមលើកលែងទោសឲ្យបងប្អូនយើង ចិត្តយើងបិទជិត មានះរឹងរូស ដែលសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះបិតាមិនអាចជ្រៀតចូលបានឡើយ ប៉ុន្តែ ដោយបានសារភាពអំពើបាបរបស់ខ្លួន ចិត្តយើងក៏បើកយ៉ាងទូលាយចំពោះព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ។

២៨៤១-សំណូមពរនេះសំខាន់ណាស់។ ព្រះអម្ចាស់មានព្រះបន្ទូលឡើងវិញ ដោយសារតែសំណូមពរនេះហើយដែលព្រះអង្គអធិប្បាយយ៉ាងលម្អិតក្នុងសុន្ទរកថានៅលើភ្នំ (មថ ៦,១៤-១៥; ៥,២៣-២៤; មក ១១,២៥)។ មនុស្សលោកមិនអាចបំពេញការទាមទារដ៏សំខាន់បំផុតអំពីអាថ៌កំបាំងនៃសម្ព័ន្ធមេត្រីនេះទេ ប៉ុន្តែ "គ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតឡើយ"។

### ..."ដូចយើងខ្ញុំលើកលែងទោសឲ្យអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំដែរ"

២៨៤២-"ដូច" នេះមានច្រើនក្នុងការប្រៀនប្រដៅរបស់ព្រះយេស៊ូ៖ "អ្នករាល់គ្នានឹងបានគ្រប់លក្ខណ៍ "ដូច" ព្រះបិតាដែលគង់នៅស្ថានបរមសុខបានគ្រប់លក្ខណ៍ដែរ" (មថ ៥,៤៨) "ត្រូវលើកលែងទោសឲ្យអ្នកដទៃ "ដូច" ព្រះជាម្ចាស់លើកលែងទោសឲ្យអ្នករាល់គ្នាដែរ" (លក ៦,៣៦) "ខ្ញុំឲ្យវិន័យថ្មីដល់អ្នករាល់គ្នា គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក "ដូច" ខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" (យហ ១៣,៣៤)។ បើយើងយកតម្រាប់តាមព្រះជាម្ចាស់ពីខាងក្រៅ យើងមិនអាចគោរពវិន័យរបស់ព្រះអម្ចាស់បានទេ គឺត្រូវចូលរួមចំណែកឲ្យ "អស់ពីដួងចិត្ត" ក្នុងភាពដ៏វិសុទ្ធ ធម៌មេត្តាករុណា និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នៃយើង។ មានតែព្រះវិញ្ញាណ "ជាជីវិតរបស់យើង" (កាឡ ៥,២៥) ប៉ុណ្ណោះទេ ដែលអាចនាំយើងឲ្យរួមចិត្តគំនិតជាមួយព្រះគ្រីស្តយេស៊ូ (ភីល ២,១.៥)។ ពេលនោះយើងអាច "លើកលែងទោសដល់គ្នាទៅវិញទៅមក "ដូច" ព្រះជាម្ចាស់បានលើកលែងទោសឲ្យយើងក្នុងអង្គព្រះគ្រីស្តដែរ" (អភ ៤,៣២)។

២៨៤៣-ហេតុនេះហើយបានជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីការលើកលែងទោសកើតចេញជាសេចក្តីស្រឡាញ់រហូតដល់ទីបំផុត (យហ ១៣,១)។ ព្រះបន្ទូលចុងក្រោយក្នុងពាក្យប្រស្នាអំពីអ្នកបម្រើមិនព្រមអត់ទោសឲ្យគេដែលបញ្ចប់ដោយការប្រៀនប្រដៅរបស់ព្រះអម្ចាស់ឲ្យចេះរួបរួមគ្នាក្នុងព្រះសហគមន៍ (មថ ១៨,២៣-៣៦) មានដូចតទៅ៖ "បើម្នាក់ៗមិនព្រមលើកលែងទោសឲ្យបងប្អូនដោយស្មោះអស់ពីចិត្តទេ ព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខក៏នឹងធ្វើទារុណកម្មអ្នករាល់គ្នាដូច្នោះដែរ"។ តាមការពិត អ្វីៗទាំងអស់ត្រូវចង និងស្រាយនៅក្នុង "ជម្រៅចិត្ត"។ យើងមិនអាចធ្វើជាមិនដឹងខ្លួន និងបំភ្លេចកំហុសបានទេ ប៉ុន្តែ អ្នកដែលធ្វើជីវិតទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ អាចមានចិត្តមេត្តាករុណា និងជួយទូលអង្វរព្រះជាម្ចាស់ដើម្បីអ្នកដែលបានប្រព្រឹត្តខុសនឹងខ្លួនបាន។

២៨៤៤-គ្រីស្តបរិស័ទអធិដ្ឋានរហូតដល់ "លើកលែងទោសឲ្យខ្មាំងសត្រូវ" (មថ ៥,៤៣-៤៤)។ ការអធិដ្ឋាននេះ ធ្វើឲ្យសាវ័កក្លាយទៅជាដូចម្ចាស់របស់ខ្លួន។ ការលើកលែងទោសជាគុណធម៌ដ៏ខ្ពង់ខ្ពស់បំផុតនៃការអធិដ្ឋានរបស់គ្រីស្តបរិស័ទ ហើយមានតែចិត្តដែលស្របនឹងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ទេ ដែលអាចទទួលព្រះអំណោយទាននៃការអធិដ្ឋាននេះ។ ការលើកលែងទោសផ្តល់សក្ខីភាពថា ក្នុងលោកយើងនេះ សេចក្តីស្រឡាញ់ខ្លាំងជាងអំពើបាបទៅទៀត។ មរណសាក្សីពីម្សិលមិញ និងនៅថ្ងៃនេះ ទទួលសក្ខីភាពរបស់ព្រះយេស៊ូនេះ។ ដើម្បីឲ្យបុត្រធីតារបស់ព្រះជាម្ចាស់សម្រុះសម្រួលជាមួយនឹងព្រះបិតារបស់គេ និងរវាងគ្នានឹងគ្នា (២ករ ៥,១៨-២១) ចាំបាច់ត្រូវតែមានការលើកលែងទោស (សម្តេចប៉ាប យ៉ូហាន ប៉ូលទី២ DM ១៤)។

២៨៤៥-ការលើកលែងទោសដែលមកពីព្រះជាម្ចាស់នេះ គ្មានកំណត់ គ្មានព្រំដែនឡើយ (មថ ១៨,២១-២២; លក ១៧,៣-៤)។ តាមការពិត បើនិយាយអំពីកំហុស ("បាប" តាម លក១១,៤ ឬ "ខុស" តាម មថ ៦,១២) យើងតែងតែដូចជាកូនបំណុល៖ "មិនត្រូវជំពាក់អ្វីនរណា ក្រៅពីជំពាក់សេចក្តីស្រឡាញ់គ្នាទៅវិញទៅមកនោះឡើយ" (រម ១៣,៨)។ ព្រះត្រៃឯកដ៏វិសុទ្ធ ដែលមានព្រះទាំងបីអង្គរួបរួមជាមួយគ្នាជាធ្លុងតែមួយ ជាប្រភព និងលក្ខណៈនៃសេចក្តីពិតរបស់ទំនាក់ទំនងណាមួយ (១យហ ៣,១៩-២៤)។ យើងអាចដកពិសោធន៍អំពីទំនាក់ទំនងនេះ ក្នុងពេលអធិដ្ឋាន ជាពិសេសពេលថ្វាយអភិបូជា (មថ ៥,២៣-២៤)។

ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងយញ្ញបូជារបស់អស់អ្នកដែលបំបែកអ្នកដទៃឡើយ ព្រះអង្គដេញគេចេញពីអាសនៈ ដើម្បីឲ្យគេសម្រុះសម្រួលជាមួយនឹងបងប្អូនរបស់គេសិន ព្រះអង្គមានព្រះហឫទ័យឲ្យយើងអធិដ្ឋានដើម្បីសន្តិភាព។ ព្រះជាម្ចាស់មានភារកិច្ចដ៏ល្អបំផុត គឺឲ្យប្រជាជនដ៏ស្មោះត្រង់មានសន្តិភាព ហើយចេះរួបរួមគ្នាជាធ្លុងតែមួយ ក្នុងអង្គព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ (សន្តៈ ស៊ីព្រីយ៉ាំង)។

## ៦-"សូមកុំបណ្តោយឲ្យយើងខ្ញុំចាញ់ការល្បួងឡើយ"

២៨៤៦-សំណូមពរនេះ ជាឫសគល់នៃសំណូមពរខាងដើម ដ្បិតដោយសារយើងចាញ់ការល្បួង យើងក៏ប្រព្រឹត្តអំពើបាប។ យើងសូមព្រះបិតាកុំ "បណ្តោយឲ្យ" យើងចាញ់ការល្បួងឡើយ។ ពាក្យក្រិកនេះ ពិបាកបកប្រែជាពាក្យតែមួយម៉ាត់ណាស់ គឺមានន័យថា "កុំឲ្យចូលក្នុង" (មថ ២៦,៤១) "កុំឲ្យចាញ់ការល្បួងឡើយ"។ "គ្មានអ្វីអាចល្បួងព្រះជាម្ចាស់ឲ្យធ្វើអំពើអាក្រក់បានឡើយ ហើយព្រះអង្គផ្ទាល់ក៏មិនល្បួងនរណាដែរ" (យក ១,១៣) ផ្ទុយទៅវិញ ព្រះអង្គមានព្រះហឫទ័យចង់រំដោះយើងឲ្យរួចពីការល្បួង។ យើងសូមព្រះអង្គកុំបណ្តោយឲ្យយើងដើរតាមផ្លូវដែលបណ្តាលឲ្យប្រព្រឹត្តអំពើបាប។ យើងបានចូលក្នុងការប្រយុទ្ធរវាង "សាច់ និងវិញ្ញាណ"។ យើងសូមព្រះវិញ្ញាណដែលជួយត្រិះរិះពិចារណា និងជួយផ្តល់កម្លាំងផង។

២៨៤៧-ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើឲ្យយើងចេះត្រិះរិះពិចារណា រវាងទុក្ខវេទនា ដែលជាចាំបាច់ដើម្បីឲ្យមនុស្សខាងក្នុង (លក ៨,១៣-១៥; កក ១៤,២២; ២ធម ៣,១២) អាចរីកចម្រើន និងចេះ "ស៊ូទ្រាំ" (រម ៣,៣-៥) និងការល្បួង ដែលបង្កើតអំពើបាប បណ្ដាលឲ្យស្លាប់ (យក ១,១៤-១៥)។ យើងក៏ត្រូវតែចេះបែងចែករវាង "ត្រូវមេល្បួង" និង "យល់ព្រមតាមការល្បួង"។ ទីបញ្ចប់ ពេលរិះគិតពិចារណា យើងអាចដឹងអំពីសម្ដីភូតភរនៃមេល្បួង គឺការល្បួងហាក់ដូចជា "មានរសជាតិឆ្ងាញ់ពិសា គួរឲ្យគយគន់ ថែមទាំងអាចធ្វើឲ្យមានប្រាជ្ញាទៀតផង" (កណ ៣,៦) តាមការពិត ផលផ្លែនៃការល្បួងនេះជាសេចក្ដីស្លាប់ទៅវិញ។

ព្រះជាម្ចាស់គ្មានព្រះហឫទ័យបង្ខិតបង្ខំយើងឲ្យប្រព្រឹត្តអំពើល្អទេ ព្រះអង្គមានព្រះហឫទ័យឲ្យមនុស្សមានសេរីភាព (...)។ មានពេលខ្លះ ការល្បួងល្អណាស់។ គ្រប់ៗគ្នា ព្រមទាំងយើងផងដែរ មិនបានដឹងថា ព្រលឹងយើងបានទទួលអ្វីពីព្រះអង្គទេ ប៉ុន្តែ ការល្បួងសម្ដែងឲ្យយើងស្គាល់ ដើម្បីបង្រៀនយើងឲ្យស្គាល់ខ្លួនឯង ដែលនាំឲ្យយល់អំពីភាពវេទនារបស់យើង ហេតុនេះ យើងក៏ត្រូវតែអរព្រះគុណព្រះជាម្ចាស់ ដើម្បីសេចក្ដីល្អដែលការល្បួងបានសម្ដែង (លោក អូរីសែន)។

២៨៤៨-យើងក៏ត្រូវតែសម្រេចក្នុងជម្រៅចិត្ត "កុំឲ្យចាញ់ការល្បួង"៖ "ទ្រព្យសម្បត្តិអ្នកនៅកន្លែងណា ចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ (...) គ្មានអ្នកណាម្នាក់អាចបម្រើម្ចាស់ពីរបានទេ" (មថ ៦,២១.២៤)។ "ប្រសិនបើយើងមានជីវិតដោយសារព្រះវិញ្ញាណមែន យើងក៏ត្រូវប្រតិបត្តិតាមព្រះវិញ្ញាណដែរ" (កាឡ ៥,២៥)។ ព្រះបិតាប្រទានកម្លាំងឲ្យយើង "យល់ស្របនឹង" ព្រះវិញ្ញាណដ៏វិសុទ្ធ។ "គ្មានការល្បួងណាមួយកើតមានដល់បងប្អូន ក្រៅពីការល្បួងដែលមនុស្សលោកតែងជួបប្រទះនោះឡើយ។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ ទ្រង់មិនបណ្ដោយឲ្យមារល្បួងបងប្អូនហួសពីកម្លាំងបងប្អូនទេ ប៉ុន្តែ នៅពេលបងប្អូនជួបការល្បួង ព្រះអង្គនឹងប្រទានមធ្យោបាយឲ្យបងប្អូនចេញរួច និងឲ្យបងប្អូនអាចទ្រាំទ្របាន" (១ករ ១០,១៣)។

២៨៤៩-ក៏ប៉ុន្តែ មានតែពេលអធិដ្ឋានទេ ដែលយើងអាចប្រយុទ្ធ និងទទួលជោគជ័យនេះបាន។ ដោយសារព្រះអង្គបានអធិដ្ឋាន ព្រះយេស៊ូបានឈ្នះមេល្បួង តាំងពីដើមដំបូង (មថ ៤,១-១១) និងក្នុងការប្រយុទ្ធចុងក្រោយពេលរងទុក្ខលំបាក (មថ ២៦,៣៦-៤៤)។ ព្រះគ្រីស្ដប្រោសយើងឲ្យរួមជាមួយព្រះអង្គក្នុងការប្រយុទ្ធ និងទុក្ខលំបាករបស់ព្រះអង្គ ក្នុងសំណូមពរចំពោះព្រះបិតានេះ។ ព្រះអង្គរំឭកឲ្យច្បាស់ថា ត្រូវប្រុងស្មារតី ដោយរួមរស់ជាមួយព្រះអង្គ (មក ១៣,៩.២៣.៣៣-៣៧; ១៤,៣៨; លក ១២,៣៥-៤០)។ ពេលប្រុងស្មារតី យើង "មើលចិត្តគំនិត" ហើយព្រះយេស៊ូសូមទូលអង្វរឲ្យព្រះបិតា "ថែរក្សា (យើង) ដោយព្រះនាមព្រះអង្គ" (យហ ១៧,១១)។ ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះហឫទ័យឲ្យយើងប្រុងស្មារតីជានិច្ច (១ករ ១៦,១៣; កូឡ ៤,២; ១ថស ៥,៦; ១ពត្រ ៥,៨)។ សំណូមពរនេះ មានអត្ថន័យដ៏សំខាន់ជាទីបំផុត បើនិយាយអំពីការល្បួងចុងក្រោយនៃការប្រយុទ្ធរបស់យើងនៅលើផែនដី គឺយើងសូមឲ្យមានចិត្តព្យាយាមរហូតដល់ទីចុងក្រោយ៖ "យើងនឹងមកដូចចោរចូលលួច។ អ្នកណាប្រុងស្មារតី (...) អ្នកនោះមានសុភមង្គលហើយ!" (វវ ១៦,១៥)។

## ៧-"តែសូមរំដោះយើងខ្ញុំឲ្យរួចផុតពីមារកំណាចផង"

២៨៥០-ព្រះយេស៊ូអធិដ្ឋានដោយទទួលយកសំណូមពរចុងក្រោយចំពោះព្រះបិតារបស់យើង៖ "ទូលបង្គំមិនអង្វរព្រះអង្គឲ្យយកគេចេញពីលោកនេះឡើយ គឺសូមទ្រង់មេត្តាការពារគេពីអំណាចមារកំណាចវិញ" (យហ ១៧,១៥)។ សំណូមពរនេះ ទាក់ទងនឹងយើងម្នាក់ៗ ប៉ុន្តែ គឺ "យើង" នេះហើយ ដែលអធិដ្ឋាន ដោយរួមជាមួយព្រះសហគមន៍ទាំងមូល ដើម្បីរំដោះក្រុមគ្រួសាររបស់មនុស្សលោកទាំងមូល។ សេចក្ដីអធិដ្ឋានរបស់ព្រះអម្ចាស់

តែងតែធ្វើឲ្យយើងបើកចិត្តឲ្យទូលាយ នឹកគិតដល់ការចាត់ចែងនៃការសង្គ្រោះ។ យើងពឹងផ្អែកលើគ្នាទៅវិញទៅមកក្នុងវិនាដកម្មនៃអំពើបាប និងសេចក្តីស្រឡាញ់ យើងក៏ត្រឡប់ទៅជារួមសាមគ្គី ក្នុងព្រះកាយព្រះគ្រីស្ត "ក្នុងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ" (**RP ១៦**)។

២៨៥១-តាមសំណូមពរនេះ អំពើអាក្រក់មិនមែនជារឿងអរូបីទេ តែជាបុគ្គលម្នាក់ គឺសាតាំង មារកំណាច ទេវទូតដែលប្រឆាំងនឹងព្រះជាម្ចាស់។ "មារ" (**dia-bolos**) ជាអ្នកដែល "ប្រយុទ្ធប្រឆាំងនឹង" គម្រោងការរបស់ព្រះជាម្ចាស់ និង "ព្រះរាជកិច្ចនៃការសង្គ្រោះ" ដែលព្រះគ្រីស្តបានសម្រេច។

២៨៥២-"តាំងពីដើមរៀងមក វាបានសម្លាប់មនុស្ស ហើយមិនប្រកាន់តាមសេចក្តីពិតទេ ព្រោះគ្មានសេចក្តីពិតនៅក្នុងខ្លួនវាសោះ។ ពេលវានិយាយកុហក គឺវានិយាយចេញពីគំនិតវាផ្ទាល់ ព្រោះវាជាមេកុហក ហើយជាឪពុកនៃអ្នកកុហក" (យហ ៨,៤៤) "សាតាំងដែលបាននាំមនុស្សនៅលើផែនដីទាំងមូលឲ្យវង្វេង" (វវ ១២,៩) ដោយសារវា អំពើបាប និងសេចក្តីស្លាប់បានចូលក្នុងពិភពលោក ហើយសត្វលោកទាំងអស់ "នឹងរួចចាកពីអំពើបាប និងសេចក្តីស្លាប់" ពេលវានឹងបរាជ័យ (**MR** ធម៌អរព្រះគុណទី៤)។ "យើងដឹងហើយថា អ្នកកើតមកពីព្រះជាម្ចាស់មិនប្រព្រឹត្តអំពើបាបឡើយ ដ្បិតព្រះបុត្រាដែលកើតពីព្រះជាម្ចាស់មក ការពារអ្នកនោះ ហើយមារកំណាចពុំអាចយាយីគេបានឡើយ។ យើងដឹងថា យើងកើតមកពីព្រះជាម្ចាស់ រីឯមនុស្សលោកទាំងមូលស្ថិតនៅក្រោមអំណាចរបស់មារកំណាច" (១យហ ៥,១៨-១៩)៖

> ព្រះអម្ចាស់ដែលបានដកយកអំពើបាបរបស់បងប្អូនចេញ ហើយដែលបានលើកលែងទោសកំហុសរបស់បងប្អូន ទ្រង់អាចថែរក្សាការពារបងប្អូនពីកលល្បិចរបស់មារ ដែលប្រយុទ្ធប្រឆាំងនឹងបងប្អូន ដើម្បីឲ្យខ្មាំងសត្រូវដែលធ្លាប់បង្កើតកំហុស មិនអាចបង្អើលបងប្អូនបានឡើយ។ អ្នកផ្ញើជីវិតលើព្រះជាម្ចាស់ មិនខ្លាចនឹងមារកំណាចទេ។ "ប្រសិនបើព្រះជាម្ចាស់កាន់ខាងយើងហើយ តើនរណាអាចនឹងចោទប្រកាន់យើងបាន?" (រម ៨,៣១) (សន្ទះ អំប្រ៊រ)។

២៨៥៣-នៅពេលកំណត់ព្រះយេស៊ូស្ម័គ្រចិត្តប្រគល់ព្រះកាយព្រះអង្គទៅសេចក្តីស្លាប់ ដើម្បីប្រទានព្រះជន្មព្រះអង្គមកយើង ព្រះអង្គក៏ឈ្នះ "ចៅហ្វាយរបស់លោកីយ៍" នេះ (យហ ១៤,៣១)។ ពេលនោះ ជាពេលព្រះជាម្ចាស់វិនិច្ឆ័យមនុស្សលោក ហើយចៅហ្វាយនៃលោកីយ៍នេះ "ត្រូវបណ្តេញចេញទៅក្រៅ" (យហ ១២,៣១; វវ ១២,១១)។ "វាដេញតាមស្ត្រី" (វវ ១២,១៣-១៦) ប៉ុន្តែវាមិនអាចយាយីនាងទេ៖ នាងអេវ៉ាថ្មី "ជាទីគាប់ព្រះហឫទ័យ" ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ បានរួចពីអំពើបាប និងភាពស្អុយរលួយនៃសេចក្តីស្លាប់ (ព្រះនាងម៉ារីជាព្រះមាតាដ៏វិសុទ្ធបំផុតនៃព្រះជាម្ចាស់ ដែលនៅព្រហ្មចារីយ មិនដែលជំពាក់បាបតាំងពីកំណើត ហើយដែលព្រះអង្គបានលើកឡើងទៅស្ថានបរមសុខ)។ "វាក្តៅក្រហាយនឹងស្ត្រីនោះយ៉ាងខ្លាំង វាក៏ចេញទៅធ្វើសឹកប្រឆាំងនឹងកូនចៅរបស់នាងដែលនៅសេសសល់" (វវ ១២,១៧)។ ហេតុនេះហើយបានជាព្រះវិញ្ញាណ និងព្រះសហគមន៍អង្វរថា៖ "ព្រះអម្ចាស់យេស៊ូអើយ សូមយាងមក!" (វវ ២២,១៧.២០) ដ្បិតពេលព្រះអង្គនឹងយាងមក យើងនឹងរួចពីមារកំណាច។

២៨៥៤-ដោយសូមឲ្យរួចផុតពីមារកំណាច យើងអង្វរសុំឲ្យយើងរួចពីទុក្ខវេទនាទាំងឡាយដែលមារកំណាចនេះបង្កើត ក្នុងបច្ចុប្បន្នកាល អតីតកាល និងអនាគតកាលផងដែរ។ តាមសំណូមពរចុងក្រោយនេះ ព្រះសហគមន៍ទទួលយកទុក្ខវេទនាទាំងអស់នៃពិភពលោកថ្វាយទៅឯព្រះបិតា។ ដើម្បីឲ្យចាកផុតពីទុក្ខវេទនាដែលបៀតបៀនមនុស្សលោក ព្រះសហគមន៍ទូលអង្វរសុំព្រះអំណោយទានដ៏មានតម្លៃ គឺសន្តិភាព ហើយឲ្យខ្លួនអាចរង់ចាំដល់ពេលព្រះគ្រីស្តយាងត្រឡប់មកវិញ ដោយចិត្តព្យាយាម។ ដោយអធិដ្ឋានបែបនេះ ព្រះសហគមន៍ប្រារព្ធទុកជាមុន

សូមឲ្យព្រះជាម្ចាស់សរុបមនុស្សទាំងអស់ និងអ្វីៗទាំងអស់ ក្នុងអង្គព្រះគ្រីស្ត ដែល "មានអំណាចលើសេចក្ដីស្លាប់ និងលើស្ថានមច្ចុរាជ" (វវ ១,១៨) ដែលជាម្ចាស់នៃអ្វីៗទាំងអស់ ព្រះអង្គ "ដែលមានព្រះជន្មគង់នៅសព្វថ្ងៃ គង់នៅតាំងពីដើម ហើយកំពុងតែយាងមក" (វវ ១,៨) (វវ ១,៤)៖

ឱព្រះអម្ចាស់យើងខ្ញុំអើយ សូមព្រះអង្គទ្រង់ព្រះមេត្តាជួយយើងខ្ញុំឲ្យរួចពីអន្តរាយគ្រប់បែបយ៉ាង សូមទ្រង់ប្រោសប្រទានឲ្យយើងខ្ញុំរស់នៅបានសេចក្ដីសុខសាន្ត និងរួចចាកពីអំពើបាបជានិច្ច កុំឲ្យយើងខ្ញុំជួបប្រទះនឹងទុក្ខលំបាកណាឡើយ។ យើងខ្ញុំសង្ឃឹមយ៉ាងមាំថា នឹងបានបរមសុខ ហើយយើងខ្ញុំក៏រង់ចាំព្រះយេស៊ូគ្រីស្តជាព្រះសង្គ្រោះ ទ្រង់យាងត្រឡប់មកវិញដែរ (MR)។

## សេចក្ដីចុងក្រោយសរសើរលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់

២៨៥៥-សេចក្ដីចុងក្រោយសរសើរលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ "ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព និងសិរីរុងរឿង អស់កល្បជាអង្វែងតរៀងទៅ" យកសំណូមពរទាំងបីដើមចំពោះព្រះបិតារបស់យើង គឺជាការលើកតម្កើងសិរីរុងរឿងនៃព្រះនាមព្រះអង្គ ឲ្យព្រះរាជ្យព្រះអង្គយាងមកដល់ និងឲ្យព្រះហឫទ័យពោរពេញដោយឫទ្ធានុភាពសង្គ្រោះមនុស្សលោកបានសម្រេច។ ប៉ុន្តែ ឥឡូវនេះ យើងសុំដោយក្រាបថ្វាយបង្គំ និងអរព្រះគុណព្រះជាម្ចាស់ ដូចនៅក្នុងពិធីបុណ្យនៃស្ថានបរមសុខ (វវ ១,៦; ៤,១១; ៥,១៣)។ ចៅហ្វាយលោកីយ៍នេះបានប្រើកលល្បិចយកងារទាំងបីនោះ (រាជ្យ ឫទ្ធិ និងសិរីរុងរឿង) (លក ៤,៥-៦) ឯព្រះគ្រីស្តវិញ ជាព្រះអម្ចាស់ប្រគល់ងារទាំងបីនោះ ថ្វាយព្រះបិតារបស់ព្រះអង្គ និងជាព្រះបិតារបស់យើងវិញ រហូតដល់ព្រះអង្គប្រគល់ព្រះរាជ្យថ្វាយព្រះបិតា ទម្រាំដល់ព្រះអង្គបានបំពេញការសង្គ្រោះ ហើយព្រះជាម្ចាស់បានគ្រងរាជ្យលើអ្វីៗទាំងអស់ គ្រប់ប្រការ (១ករ ១៥,២៤-២៨)។

២៨៥៦-"ពេលសូត្រធម៌រួចហើយ អ្នកពោលអាម៉ែន ដែលមានន័យថា "សូមឲ្យបានសម្រេច" (លក ១,៣៨) ដើម្បីបញ្ជាក់អំពីសេចក្ដីនៃការអធិដ្ឋាន ដែលព្រះជាម្ចាស់បានបង្រៀនមកយើង" (សន្តៈ ស៊ីរីល នៃទីក្រុងយេរូសាឡឹម)។

## សង្ខេប

២៨៥៧-ក្នុងធម៌ឱព្រះបិតា សំណូមពរទាំងបីដំបូងសំដៅទៅលើសិរីរុងរឿងរបស់ព្រះបិតា គឺឲ្យព្រះនាមបានវិសុទ្ធ ឲ្យព្រះរាជ្យយាងមកដល់ និងឲ្យបំណងប្រាថ្នារបស់ព្រះជាម្ចាស់បានសម្រេច។ តាមសំណូមពរបួនទៀត យើងបង្ហាញឲ្យព្រះអង្គដឹងអំពីបំណងប្រាថ្នាយើង គឺយើងសុំឲ្យព្រះអង្គជួយចិញ្ចឹមជីវិតរបស់យើង ឬព្យាបាលជីវិតនេះឲ្យរួចពីបាប ហើយសំណូមពរនោះ ទាក់ទងនឹងការប្រយុទ្ធរបស់យើង ដើម្បីឲ្យសេចក្ដីល្អយកជ័យជម្នះលើសេចក្ដីអាក្រក់។

២៨៥៨-ដោយទូលសុំព្រះជាម្ចាស់ឲ្យ "ព្រះនាមព្រះអង្គបានវិសុទ្ធ" យើងចូលក្នុងគម្រោងការរបស់ព្រះអង្គ គឺឲ្យព្រះនាមព្រះអង្គបានវិសុទ្ធ ដូចដែលព្រះអង្គបានសម្ដែងឲ្យលោក ម៉ូសេ ស្គាល់ ហើយបន្ទាប់មក នៅក្នុងអង្គព្រះយេស៊ូ តាមរយៈយើង និងនៅក្នុងយើង ដូចក្នុងប្រជាជាតិនានា និងមនុស្សម្នាក់ៗ។

២៨៥៩-ដោយសារសំណូមពរទីពីរ ព្រះសហគមន៍មានគោលដៅពិសេសឲ្យព្រះគ្រីស្តយាងមកវិញ និងឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមកជាស្ថាពរ។ ព្រះសហគមន៍ទូលអង្វរព្រះជាម្ចាស់ ដើម្បីឲ្យព្រះរាជ្យរីកចម្រើនក្នុងការរស់នៅ "ប្រចាំថ្ងៃ" នៃជីវិតរបស់យើង។

២៨៦០-សំណូមពរទីបី យើងទូលអង្វរព្រះបិតាសូមព្រះអង្គបង្រួបបង្រួមបំណងរបស់យើងទៅនឹងបំណងរបស់ព្រះបុត្រាព្រះអង្គ ដើម្បីបំពេញគម្រោងការរបស់ព្រះអង្គក្នុងការសង្គ្រោះពិភពលោក។

២៨៦១-សំណូមពរទីបួន រួមជាមួយបងប្អូនយើង ៗពោលថា "សូមប្រទានមកយើងខ្ញុំ" មានន័យថា យើងជឿទុកចិត្តលើព្រះបិតារបស់យើងដែលគង់នៅស្ថានបរមសុខ ដូចកូនជឿឪពុកដែរ។ "អាហារ" សំដៅទៅលើចំណីអាហារ ដែលយើងទាំងអស់គ្នាត្រូវការ ដើម្បីចិញ្ចឹមជីវិត និងសំដៅទៅលើនំបុ័ងនៃជីវិតផង គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងព្រះកាយព្រះគ្រីស្ត។ យើងទទួលអាហារនេះ ក្នុង "ថ្ងៃនេះ" របស់ព្រះជាម្ចាស់ ដូចជាចំណីអាហារជាចាំបាច់ដ៏សំខាន់ (ណាស់) នៃពិធីជប់លៀងនៃព្រះរាជ្យ ដែលពិធីអរព្រះគុណតំណាងទុកជាមុន។

២៨៦២-សំណូមពរទីប្រាំអង្វរធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ចំពោះអំពើបាបរបស់យើង។ ធម៌មេត្តាករុណានេះ អាចជ្រាបចូលក្នុងដួងចិត្តយើង លុះត្រាតែយើងបានលើកលែងទោសឲ្យខ្មាំងសត្រូវរបស់យើង ដូចព្រះគ្រីស្ត និងដោយយកព្រះអង្គជាជំនួយ។

២៨៦៣-ដោយពោលថា "សូមកុំបណ្តោយឲ្យយើងខ្ញុំចាញ់ការល្បួងឡើយ" យើងទូលសុំអង្វរព្រះជាម្ចាស់សូមព្រះអង្គជួយកុំឲ្យយើងដើរតាមផ្លូវនៃអំពើបាប។ សំណូមពរនេះ អង្វរព្រះវិញ្ញាណ ដែលចេះដឹងខុសត្រូវជាព្រះវិញ្ញាណដែលប្រទានកម្លាំង។ យើងអង្វរសុំឲ្យយើងចេះប្រុងស្មារតី មានការព្យាយាមរហូតដល់ទីបញ្ចប់។

២៨៦៤-សំណូមពរចុងក្រោយ "សូមរំដោះយើងឲ្យរួចពីមារកំណាច" គ្រីស្តបរិស័ទ រួមជាមួយព្រះសហគមន៍អង្វរព្រះជាម្ចាស់ឲ្យសម្តែងជ័យជម្នះរបស់ព្រះគ្រីស្តលើ "ចៅហ្វាយរបស់លោកីយ៍នេះ" លើមារសាតាំង ជាទេវទូតប្រឆាំងនឹងព្រះជាម្ចាស់ និងគម្រោងការរបស់ព្រះអង្គអំពីការសង្គ្រោះ។

២៨៦៥-ពាក្យចុងក្រោយ "អាម៉ែន" យើងបង្ហាញថា យើងយល់ព្រម " Fiat" ចំពោះសំណូមពរទាំងប្រាំពីរ៖ "សូមឲ្យបានសម្រេច..."។

ប្រែសម្រួលដោយលោកបូជាចារ្យ

**ហ្វ្រង់ស្វ័រ អាមេសស្សដាល** **(MEP)** និង អ្នកស្រី **ហែម ឌី**

***"AD EXPERIMENTUM"***

អនុញ្ញាតឲ្យបោះពុម្ពដោយលោក **អូលីវីយេ ឝ្មិតហាស្លេរ** (MEP)

អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ

ឆ្នាំ ២០១២

Translated by Father **François Hemeseldael**, MEP and Mrs. **Hem Dy**

**"AD EXPERIMENTUM"**

Impramatur by Bishop **OLIVIER SCHMITTHAEUSLER**, MEP

APOSTOLIC VICAR OF PHNOM PENH

CAMBODIA 2012